[26] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៧, ៣៩-៤១, ៥៧-៥៨ KH 01136707-10 ["ឆ.៣៧៖ [...] ក្នុងឆ្នាំ១៩៧៦ ខ្ញុំឃើញតាទិត្យអង្គុយនៅខាងស្តាំដៃប្រធានតំបន់ពេលប្រជុំ គឺមានន័យថាគាត់ត្រៀមឡើងហើយ [...] ស៖ ពេលលោកឃើញថា តាទិត្យ គាត់អង្គុយនៅខាងស្តាំកែ្សរ តាសោម ក្នុងកិច្ចប្រជុំថ្នាក់តំបន់។ តើលោកគិតថា គាត់អង្គុយក្នុងតួនាទីជំនួយការ ឬអនុ? ឆ.៣៩៖ តាមការយល់របស់ខ្ញុំ អ្នកអង្គុយនៅខាងស្តាំដៃ គឺជាអនុ។ ស៖ លោកធ្លាប់ឃើញ តាទិត្យ គាត់អង្គុយខាងស្តាំដៃលេខាតំបន់ប៉ុន្មានដង? នៅក្នុងឆ្នាំណា? ឆ.៤០៖ ក្នុងឆ្នាំ១៩៧៦ ពេលប្រជុំនៅខាងក្រោយសាលាស្រុកអង្គរជ័យម្តង មុខវត្តគ្រីបវ ខាងលិចផ្លូវជាតិលេខ៣ ឃុំអង្គរជ័យ។ [...] ឆ.៤១៖ ប្រហែលជាចុងឆ្នាំ១៩៧៦"]។ ឯកសារ D219/899.1.4 ម៉ឹង វេត ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង 11.04.58-11.06.38។

[27] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៧-៣៩, ៦០-៦៣ KH 01136707-08, 01136710-11។

[28] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤២, ៤៧ KH 01136707-08។

[29] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៥៨ KH 01136710, "តាទិត្យ អង្គុយនៅលើវេទិកាជាប់ តាសោម បែរមុខមកក្រោមដូចជាគេមើលកុនអ៊ីចឹង។ ចំណែកអ្នកផ្សេងទៀតអង្គុយនៅខាងក្រោមបែរមុខទៅវេទិកា"។

ទាក់ទងជាមួយពួកវៀតណាម"[30]។ អ្នកចូលរួមប្រជុំក៏ត្រូវបានដាស់តឿនផងដែរថា "ប្រសិនបើយើងធ្វើអ្វីខុស បក្សអាចធ្វើអ្វីលើយើងក៏បាន"[31]។

25. ក្រោយពីកិច្ចប្រជុំធំ ក្រុមតូចៗបានជួបជុំគ្នា សម្រាប់វគ្គសួរសំណួរ និងឆ្លងជីវទស្សន៍[32]។ ប្រធានបទនៃវគ្គទាំងនេះបង្ហាញថា តាសោម សំដៅដល់អ្នកណា ពេលនិយាយពីសេអ៊ីអា និងកាហ្សេបេ៖ ម៉ឹង វេត បាននិយាយថា ពេលគេសួរគាត់ នៅក្នុងវគ្គមួយ៖

> ខ្ញុំរាយការណ៍ពីអ្វីដែលខ្ញុំធ្លាប់បានធ្វើទាំងអស់។ ប្រសិនបើគេរកឃើញថា យើងមានបងប្អូននៅភ្នំពេញ នោះមានន័យថា យើងជាប់ខ្សែសេអ៊ីអា។ បើយើងមានសាច់ញាតិមកពីកម្ពុជាក្រោមនោះ គឺយើងជាប់ខ្សែកាហ្សេបេវៀតណាម[33]។

26. អ្នកដែលបានចូលរួមក្នុងកិច្ចប្រជុំនេះ និងវគ្គស្វ័យទិតៀននាពេលបន្ទាប់ គួរតែបានដឹងអំពីផែនការឧក្រិដ្ឋរួម ក្នុងការចាត់ទុកអ្នកទីក្រុង និងខ្មែរក្រោម ជាខ្មាំង និងជាគោលដៅសម្រាប់ការចាប់ខ្លួន ដាក់ទណ្ឌកម្ម និងសម្លាប់ក្រៅច្បាប់។ ដោយសារតែភាពលេចធ្លោ និងសិទ្ធិអំណាចរបស់ **យ៉ីម ទិត្យ** នៅសម័យនោះ វត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំនេះ និងតំណែងសំខាន់ ជាកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាល ៣ នាក់ នៅលើវេទិកា បង្ហាញថា គាត់បានចែករំលែកគោលដៅ និងធ្វើការដើម្បីជួយជំរុញផែនការឧក្រិដ្ឋនេះ។ វត្តមានរបស់គាត់នៅលើវេទិកា ដោយមិនខ្ទាស់គ្នានឹងតាសោម គឺស្មើនឹងការឯកភាពដោយប្រយោលចំពោះផែនការស្វែងរក "ខ្មាំង" និងដាក់ទណ្ឌកម្ម ដោយគ្មានដំណើរការតាមផ្លូវច្បាប់ ទៅលើអ្នកធ្វើ "ខុស"។ ដូច្នេះ **យ៉ីម ទិត្យ** បានលើកទឹកចិត្តកម្មាភិបាលនៅក្រោមបង្គាប់ដែលមានវត្តមាន ឲ្យអនុវត្តផែនការឧក្រិដ្ឋរួម។

---

[30] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤៥, ៦៤ KH 01136709, 01136711 ឯកសារ D219/899.1.4 ម៉ឹង វេត ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង 11.13.25-11.16.10។

[31] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤៩ KH 01136709 ["គាត់ផ្ញើងសន្ទរកថា ឧទ្ទេសនាមឯកសារ និងឧទ្ទេសនាមពីលទ្ធផលការងារជូនបក្ស។ គាត់ផ្ញើងចប់ហើយ ក៏ប្រគល់កម្មវិធីឲ្យអ្នកផ្សេងនិយាយ គេនិយាយអំពីទង់ទាំងបីរបស់បក្ស ទង់ទាំងបីនេះមានស្នេះត្រង់ចំពោះបក្ស ប្តេជ្ញាបម្រើបក្ស ប្រគល់ខ្លួនជូនបក្ស។ ចំណុចនេះមានន័យថា ប្រសិនបើយើងធ្វើអ្វីខុស បក្សអាចធ្វើអ្វីលើយើងក៏បាន"]។

[32] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤៥ KH 01136709។

[33] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤៥ KH 01136709។ ឯកសារ D219/899.1.4 ម៉ឹង វេត ប្រតិចារឹក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង 13.53.04-13.59.48។

<u>កិច្ចប្រជុំជាទៀងទាត់ជាមួយគណៈឃុំទាំងអស់ នៅស្រុកគីរីវង់</u>

27. រួមជាមួយសមាជិកដទៃទៀតនៃគណៈស្រុកគីរីវង់ **យ៉ីម ទិត្យ** បានចូលរួមប្រជុំទៀងទាត់ ជាមួយតំណាងមកពីឃុំទាំង ៩ នៃស្រុកគីរីវង់[34]។ ក្នុងកិច្ចប្រជុំទាំងនេះ សមាជិកទាំងបីរូបនៃគណៈស្រុកគីរីវង់ (រួមទាំង **យ៉ីម ទិត្យ**) បាននិយាយអំពីខ្មាំង រួមទាំងការបញ្ជាឲ្យសមាជិកគណៈឃុំ "រាយការណ៍ពីខ្មាំងទៅថ្នាក់ស្រុក"[35]។ ខ្មាំងប្រភេទនេះរួមមាន អ្នកដែល "ប្រកែកមិនទៅ [ធ្វើការ] ឬនិយាយថាឈឺ គឺគេចោទថាខ្មាំង"[36]។ បន្ទាប់ពីឃុំរាយការណ៍ទៅស្រុក ស្រុកផ្ញើលិខិតណែនាំថា "ខ្មាំង" ត្រូវអប់រំ ឬបញ្ជូនទៅស្រុក[37]។ គឹម ផល បានបញ្ជាក់បន្ថែមទៀតថា ក្នុងកិច្ចប្រជុំថ្នាក់ស្រុកទាំងនេះ កម្មាភិបាលថ្នាក់ឃុំត្រូវគេប្រាប់អំពីជោគវាសនាចុងក្រោយរបស់ខ្មាំងដែលគេបញ្ជូនទៅស្រុក។ គាត់បានប្រាប់ថា៖ "នៅក្នុងកិច្ចប្រជុំ គឺមាននិយាយពីការសម្លាប់៖ ឲ្យតែខ្មាំង គឺត្រូវតែសម្លាប់"[38]។ គឹម ផល ក៏បានបញ្ជាក់ផងដែរថា អ្នកដែលត្រូវគេចាប់ គឺមិនឃើញត្រឡប់មកវិញឡើយ[39]។ ដូចកិច្ចប្រជុំផ្សេងទៀតដែរ **យ៉ីម ទិត្យ** បានចូលរួមក្នុងកិច្ចប្រជុំទាំងនេះ ១) បង្ហាញថាគាត់បានចែករំលែកផែនការរួមក្នុងការកម្ទេចខ្មាំង តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្ម និង ២) បង្កើតបានជាការចូលរួមចំណែកយ៉ាងសំខាន់ដល់ការសម្រេចផែនការនេះ។

ii. អ្នកនៅក្រោមបង្គាប់ផ្ទាល់ និងមិនផ្ទាល់របស់ យ៉ីម ទិត្យ បានតាមដាន និងស្ទើបអង្កេតយ៉ាងសកម្ម ទៅលើប្រជាជន ដើម្បីកំណត់អត្តសញ្ញាណអ្នកដែលត្រូវគេចាត់ទុកជាខ្មាំង

28. ដំណើរការនៃការស្វែងរក "ខ្មាំង" ត្រូវបានអនុវត្តយ៉ាងសកម្មដោយអ្នកនៅក្រោមបង្គាប់របស់ **យ៉ីម ទិត្យ** នៅស្រុកគីរីវង់។ យូ ភ្ជុ ជាឈ្លបឃុំគោកព្រិច ស្រុកគីរីវង់ បានប្រាប់ថា គាត់ "យកការណ៍ថា តើប្រជាជនស្តាប់ការតាមផែនការ នរណាឈ្លោះគ្នា នរណាលួចអីៗជាដើម" ហើយរាយការណ៍ពីការរកឃើញរបស់គាត់ទៅមេឃុំគោកព្រិច[40] ជាអ្នកក្រោមបង្គាប់គណៈស្រុក

---

[34] ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ផល ឯ.៣៤-៣៧, ៣៩, ៤៦-៤៧, ៤៩ KH 0133416-18

[35] ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ផល ឯ.៤៣-៤៧, ៤៩ KH 01133417-18។

[36] ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ផល ឯ.៤៥ KH 01133417។

[37] ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ផល ឯ.៤៥ KH 01133417។ *សូមមើលផងដែរ* ឯកសារ D118/23 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ផល ឯ.៤២ KH 00891163។

[38] ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ផល ឯ.៦០ KH 01133419។

[39] ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គឹម ផល ឯ.៦០ KH 01133419។

[40] ឯកសារ D219/406 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ ភ្ជុ ឯ.១២-១៦ KH 01117222-23។

គិរីវង់។ ការតាមដាននេះរួមបញ្ចូលទាំងការកំណត់ថា "តើប្តីប្រពន្ធដែលរៀបការហើយព្រមចូលដំណេកជាមួយគ្នា ឬអត់ទេ"[41]។

29. ការតាមដាននេះត្រូវបានបញ្ជាឲ្យធ្វើ ពីព្រោះ "គេចង់ដឹងថា ក្នុងរបបហ្នឹង មានមនុស្សមិនត្រឹមត្រូវ មិនធ្វើស្តាប់បញ្ជា មនុស្សក្បត់ និយាយឲ្យខ្ជី មនុស្សប្រឆាំង"[42]។ អ្នកដែលត្រូវបានគេកំណត់ថាជាខ្មាំង ត្រូវចាប់ខ្លួន។ យូ ភ្ជុ បានអះអាងថា ឈ្លបឃុំបានចាប់មនុស្ស ដោយសារតែ "មិនធ្វើតាមបញ្ជាលួចអីហ្ស ប និង [...] ប្រឆាំងដោយការងារ គឺមិនព្រមធ្វើតាម"[43]។ ក្នុងហានៈជាឈ្លប យូ ភ្ជុ ក៏បានដឹងផងដែរថា "ប្រសិនបើគេដឹងថាអ្នកណាមិនស្តាប់បញ្ជា គេនឹងយកទៅសម្លាប់ចោល"[44]។

30. ស្រដៀងគ្នានេះដែរ តឹម ផល សមាជិកគណៈឃុំកំពែង ស្រុកគីរីវង់ បានបញ្ជាក់អះអាងពីព័ត៌មានថា "ចារកម្ម និងអ្នកប្រព្រឹត្តខិលខូច" ត្រូវបានបញ្ជូនពីឈ្លបឃុំ ទៅលេខាស្រុក[45]។ បន្ទាប់មក ពេលខ្លះ ថ្នាក់ស្រុកបានបញ្ជូនបញ្ជាទៅឈ្លបឃុំឲ្យចាប់ខ្លួន និងបញ្ជូនអ្នកទោសទៅថ្នាក់ស្រុក[46]។

---

[41] ឯកសារ D219/406 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ ភ្ជុ ឆ.២០ KH 01117223 ["ស៖ ពេលដែលគេឲ្យធ្វើជាអ្នករាយការណ៍ ពីប្តីប្រពន្ធដែលរៀបការថ្មី។ តើជាប្រភេទព័ត៌មានបែបណា? ហើយខុសគ្នាពីការយកការណ៍ពីប្រជាជនធម្មតាឬទេ? ឆ៖មិនខុសគ្នាប៉ុន្ថានទេ មើលថាតើប្តីប្រពន្ធដែលទើបរៀបការហើយព្រមចូលដំណេកជាមួយគ្នាឬអត់ទេ]។

[42] ឯកសារ D219/406 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ ភ្ជុ ឆ.២៥ KH 01117223 ["ស៖ តើមានផែនការ និងបញ្ជាហើយនិងទិសដៅអ្វីខ្លះ ដែលទាក់ទងនឹងការប្តេជ្ញាឲ្យរៀបការ និងការចូលដំណេករបស់គូស្រករថ្មីៗ? ឆ.២៥៖ គេចង់ដឹងថា ក្នុងរបបហ្នឹងមានមនុស្សមិនត្រឹមត្រូវ មិនធ្វើតាមបញ្ជា មនុស្សក្បត់ និយាយឲ្យខ្ជីមនុស្សប្រឆាំង]។ ណុប ង៉ីម ក៏បានលើកឡើងថា សេចក្តីណែនាំដែលគាត់បានទទួលពី តាម៉ុក គឺធ្វើការតាមដានសកម្មភាពអ្នកដែលធ្វើការនៅស្រែអំបិលណាដែលខំប្រឹងធ្វើការ និងធ្វើបានទៀងទាត់តាមពេលវេលា និងអ្នកដែលមិនសកម្មនៅពេល តាម៉ុក មកមើលស្រែអំបិលជាមួយ តាទិត្យ។ *សូមមើល*ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ីម ឆ.៥-៧ KH 01008697។

[43] ឯកសារ D219/406 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ ភ្ជុ ឆ.៥៥-៦៦ KH 01117227។

[44] ឯកសារ D219/406 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ ភ្ជុ ឆ.២៦ KH 01117224 ["ពួកគេព្យាយាមចង់ដឹងថាតើ ប្រជាជនគោរពតាមបទបញ្ជា ឬផែនការរបស់គេដែរឬអត់។ ប្រសិនបើពួកគេដឹងថា អ្នកណាមិនស្តាប់បញ្ជាគេ គេនឹងយកទៅសម្លាប់ចោល"]។

[45] ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តឹម ផល ឆ.៧-៨ KH 01133412-13។

[46] ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តឹម ផល ឆ.១៦-១៩ KH 01133414។

iii. ការចូលរួមយ៉ាងសកម្មរបស់ យ៉ីម ទិត្យ ក្នុងការចាប់ដាក់គុក សួរចម្លើយ និងសម្លាប់ខ្មាំងសង្ស័យបង្ហាញថា គាត់បានចែករំលែកផែនការឧក្រិដ្ឋកម្មរួម និងបង្កើតបានជាការចូលរួមចំណែកក្នុងផែនការឧក្រិដ្ឋរួម

31. មន្ទីរសន្តិសុខវត្តព្រះធាតុ ដែលជាកន្លែងឃុំអ្នកទោសជាប់ខ្នោះ និងខ្ទះអាហារូបត្ថម្ភ ហើយមានខ្មាំងសង្ស័យយ៉ាងហោចណាស់ ៩០០ នាក់ ត្រូវបានសម្លាប់[47] គឺជាឧបករណ៍ដ៏សំខាន់មួយរបស់ **យ៉ីម ទិត្យ** ក្នុងការអនុវត្តគោលនយោបាយស្តីពីខ្មាំងរបស់ ប.ក.ក នៅភូមិភាគនិរតី។ អ្នកជាប់ឃុំនៅវត្តព្រះធាតុ ស្ថិតនៅក្នុងប្រភេទខ្មាំងដែលត្រូវបានកំណត់នៅក្នុងកិច្ចប្រជុំ ដែល **យ៉ីម ទិត្យ** មានវត្តមាន និងបានចូលរួម។ ឆ្នាំគុកឈ្មោះ ដុក ចាន់ បាននិយាយថា "អ្នកទោសធ្ងន់ គឺអ្នកជាប់និន្នាការពីរបបមុន [...]។ អ្នកទោសធ្ងន់ភាគច្រើនគឺជាអ្នកជម្លៀស និងអ្នក ១៧ មេសា"[48]។ អ្នកទោសហោ យ៉ន បានបញ្ជាក់ថា អ្នកទោសដទៃទៀតជា "អ្នកធ្វើការនៅទីក្រុង" ហើយគាត់ត្រូវគេឃុំនៅទីនោះ ដោយសារតែគ្រួសារជាប់និន្នាការរបប លន់ នល់ និងដោយសារគាត់គ្រោងរត់ទៅវៀតណាម[49]។

32. តាមរយៈតំណែងរបស់គាត់ នៅគណៈស្រុកគិរីវង់ **យ៉ីម ទិត្យ** ជាថ្នាក់លើរបស់ ព្រីង ប្រធានមន្ទីរសន្តិសុខ ហើយ ព្រីង រាយការណ៍ទៅ **យ៉ីម ទិត្យ**[50]។ **យ៉ីម ទិត្យ** បានមកមើលមន្ទីរសន្តិសុខ

---

[47] សូមមើល V.A.1.a.iv. ឧក្រិដ្ឋកម្ម-ភូមិភាគនិរតី-តំបន់១៣-មន្ទីរសន្តិសុខវត្តប្រធាតុ-ឧក្រិដ្ឋកម្ម-មនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ)។

[48] ឯកសារ D219/87 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុក ចាន់ ឆ.១២ KH 01040112 ["ជាទូទៅ ព្រីង ជាអ្នកពិនិត្យមើលរបាយការណ៍ឡើងវិញនូវរបាយការណ៍ដែលគេបញ្ជូនពីឃុំមក ដែលរៀបរាប់អំពីប្រភេទកំហុសរបស់អ្នកទោស។ ឧទាហរណ៍ដូចជា ប្រភេទទោសស្រាល អ្នកនោះលួចរបស់របរហូបចុក ហើយអ្នកទោសធ្ងន់ គឺអ្នកជាប់និន្នាការពីរបបមុន [...]។ ខ្ញុំមិនបានដឹងរឿងអ្វីច្រើនអំពីរឿងអ្នកទោសធ្ងន់ទេ។ ដោយសារអ្នកទោសភាគច្រើនគឺជាអ្នកជម្លៀស និងអ្នក១៧មេសា]។

[49] ឯកសារ D105/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.៦២-៦៤ KH 00788835 ["ស៖ តើខ្មាំងជានរណា? ឆ.៦២៖ ខ្មាំងគឺជាខ្ញែរដែលជាអ្នកធ្វើការនៅទីក្រុង។ ស៖ ហើយមានអ្នកណាផ្សេងទៀតដែលជាខ្មាំងដែរ? ឆ.៦៣៖ អ្នកដែលលួចរបស់របរបន្តិចបន្តួចដើម្បីឲ្យកូនហូបក៏គេហៅថាជាខ្មាំងដែរ។ ស៖ តើគេចោទណោកថា ខុសអ្វីដែរ? ឆ.៦៤៖ ដោយសារខ្ញុំលួចដំឡូងឲ្យឪពុកខ្ញុំ ហើយដោយសារប្អូនថ្លៃប្រុសខ្ញុំធ្វើការខាងយន្តហោះ ហើយត្រូវបានគេចាប់នៅទីនេះ ហើយមួយយប់មកបានគេមកចាប់ខ្ញុំ]។ ឯកសារ D1.3.11.18 កិច្ចសម្ភាសន៍របស់ SOAS ជាមួយ ហូ យ៉ន EN 00217606 ["ទ័ពឈ្លបបានចាប់ខ្ញុំ ព្រោះខ្ញុំគ្រោងរត់គេចទៅវៀតណាមជាមួយមនុស្សម្នាក់ផ្សេងទៀត"]។

[50] ឯកសារ D219/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុក ចាន់ ឆ៦-៧ KH 01040104 ["ឆ.៦៖ [...] វត្តប្រធាតុគឺជាគុករបស់ស្រុក។ [...] ស៖ តើ ព្រីង គាត់រាយការណ៍ទៅឲ្យអ្នកណាគេនៅស្រុក១០៩? ឆ.៧៖ [...] បន្ទាប់ពី តាតាត់ ហើយនិង យាយ ឫ ផ្ទាស់ចេញ តាទិត្យ ក្លាយទៅជាគណៈស្រុក ហើយយាយខ្ចៀនក្លាយជាអនុរបស់គាត់"]។ ឯកសារ D1.3.11.18 កិច្ចសម្ភាសន៍

ញ៉ីកញ្ជាប់ ហើយបាននិយាយជាមួយ ព្រីង និងបុគ្គលិកផ្សេងទៀត[51]។ ពេលខ្លះ គាត់បានដើរមើលអ្នកទោស ក្នុងមន្ទីរឃុំឃាំង[52]។ **យ៉ម ទិត្យ** ក៏បានសួរចម្លើយអ្នកទោស ដោយផ្ទាល់ នៅវត្តព្រះ

របស់ SOAS ជាមួយ ហ្ស យ៉ន EN 00217606-07 ["នេះជាគុកស្រុក ក្រោមការគ្រប់គ្រងរបស់ ដុក ចាន់ ជាមួយ ព្រីង។ [...] តើត, ពុ, ឫ (ស្រី) និង ណាំ នៅលើមន្ទីរសន្តិសុខ"]។ ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុក ចន ឆ.៩៧ KH 01119214 ["តើអ្នកណាជាថ្នាក់លើរបស់មេគុក? ឆ.៩៧៖ គណៈស្រុក"]។ *សូមមើល* V.A.1.a.iii. ឧក្រិដ្ឋកម្ម-ភូមិភាគ និរតី-តំបន់១៣-មន្ទីរសន្តិសុខវត្តប្រធាតុ-រចនាសម្ព័ន្ធអំណាច និងការទំនាក់ទំនង។

[51] ឯកសារ D219/108 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ ភ្ញ ឆ.៨ KH 01045250 ["តាទិត្យ និងតាតុម មកមើលមន្ទីរសន្តិសុខវត្តប្រធាតុញ៉ីកញ្ជាប់ដែរ ប៉ុន្តែខ្ញុំមិនដឹងថា គាត់មកធ្វើអីទេ [...] ខ្ញុំធ្លាប់ឃើញពួកគាត់ជួបនិយាយជាមួយតែនឹងបុគ្គលិកមន្ទីរសន្តិសុខតែប៉ុណ្ណោះ"]។ ឯកសារ D219/406 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ ភ្ញ ឆ.១៦៦-១៦៨ KH 01117237-38 ["ស៖ តើលោកបានឃើញ តាទិត្យ ប៉ុន្ឌានដងដែរនៅគុក? ឆ.១៦៦៖ គឺឃើញតែពីរដងទេ តែពេលដែលមិទ្ធិញជាមួយប្រជាជន ខ្ញុំបានជួបច្រើនដង។ [...] ឆ.១៦៧៖ ខ្ញុំបានឃើញគាត់និយាយប៉ុណ្ណោះ។ [...] ឆ.១៦៨៖ គាត់និយាយជាមួយបុគ្គលិកនៅទីនោះ ខ្ញុំមិនហ៊ានទៅជិតផង"]។ ឯកសារ D219/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុក ចាន់ ឆ.៩-១០ KH 01040105 ["ពេលតាទិត្យ និងយាយខ្ឿនមក គេជួបតែជាមួយប្រធានមន្ទីរសន្តិសុខឈ្មោះ ព្រីង។ មិនមានពេលដែលគេមកហ្ម៊ីងជាទៀងទាត់ទេ ពេលខ្លះពីរបីខែមកម្តង ពេលខ្លះមួយឆ្នាំទើបមកម្តង។ ភាគច្រើនគេហៅព្រីងទៅជួបជាមួយគេនៅនឹងកន្លែងរបស់គេ"] [...] ពួកគេមិនចូលទៅក្នុងមន្ទីរឃុំឃាំងនិយាយជាមួយអ្នកទោសទេ តែពេលខ្លះគេនិយាយជាមួយនឹងយើងដែលជាបុគ្គលិកដែរ"។ ឯកសារ D105/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២២ KH 00788831 ["ស៖ តើលោកបានឃើញតាទិត មកគុកនេះប៉ុន្ឌានដងដែរ? ឆ.២២៖ ខ្ញុំបានឃើញគាត់មកទីនេះជាង១០ដង ព្រោះជាដំណាក់កាលសម្លាប់ច្រើន"]។ ឯកសារ D105/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៩៨-១០០ KH 00788851-52។ ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៧៥ KH 00968096។ ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៨៣-៨៧, ៨៩-៩២ KH 01110213។ ឯកសារ D118/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ុន ឆ.១៦ KH 00891155 ["តាទិត ឬតាតុម ឬយាយឫ ជាទូទៅមកត្រួតពិនិត្យមើលអ្នកទោសពេលដែលគេចាប់យកមកដល់វត្តព្រះធាតុនេះ។ ខ្ញុំដឹងរឿងនេះដោយសារ ខ្ញុំបានឮពួកឈ្លប និងតាទិត សួរចម្លើយអ្នកទោស"]។ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ុន ឆ.៤៨-៤៩ KH 01102937 ["ស៖ តើតាទិត្យមកគុកនោះប៉ុន្ឌានដងដែរ? ឆ.៤៨៖ ក្នុងរយៈពេល ៤ថ្ងៃដែលខ្ញុំនៅទីនោះ ខ្ញុំឃើញមកពីរដង។ តើពួកគេមកទាំងអស់គ្នាទាំងពីរលើកឬ? ឆ.៤៩៖ លើកទីមួយ ឃើញឫ និងទិត្យ។ លើកទីពីរ ខ្ញុំឃើញតែទិត្យទេ"]។

[52] ឯកសារ D105/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៩៩-១០០ KH 00788851-52 ["ឆ.៩៩៖ គាត់គ្រាន់តែដើរមើលអ្នកទោសហើយគាត់ចេញទៅវិញហើយ។ ស៖ គាត់ចូលទៅក្នុងមន្ទីរឃុំឃាំងមែនឬទេ? ឆ.១០០៖ បាទ កន្លែងមន្ទីរឃុំឃាំង មន្ទីរឃុំឃាំងមានបីបន្ទប់"]។ ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៦១-៦៣, ៦៦-៦៧ KH 00968094-95 ["ឆ.៦១៖ តាទិត ដើរមើលអ្នកទោសណាត្រូវសម្លាប់ អ្នកទោសណាមិនត្រូវសម្លាប់ ហើយបើអ្នកត្រូវសម្លាប់ គឺឲ្យគេទាញចេញយកមកសម្លាប់តែម្តង]។ [...] ឆ.៦២៖ តាទិត ដើរមើលអ្នកទោសតាមបន្ទប់ឃុំឃាំងអ្នកទោសតែម្តង។ [...] ឆ.៦៣៖ តាទិត មិននិយាយជាមួយនឹងអ្នកទោសនោះទេ គ្រាន់តែដើរមើលប៉ុណ្ណោះ។ [...] ស៖ នៅពេលដែល តាទិត ដើរមើលអ្នកទោសតាមបន្ទប់ឃុំឃាំង តើធ្វើយ៉ាងណាទើបគាត់ដឹងអ្នកទោសណាសម្លាប់ ហើយអ្នកទោសណាមិនសម្លាប់? ឆ.៦៦៖ តាទិត

ធាតុ[53]។ មានពេលមួយនោះ អ្នកទោសឈ្មោះ ទន់ ស៊ីន ស្ថិតនៅចម្ងាយល្មមនឹងស្តាប់ឮ **យ៉ីម ទិត្យ** សួរអ្នកទោសម្នាក់ថា "អ្នកឯងមកពីណា? មានគ្នាប៉ុន្មាននាក់នៅក្នុងក្រុមអ្នកឯង? ហើយតើហេតុអ្វីបានជាអ្នកឯងចង់រត់?"[54]។ សំណួរទាំងនេះធ្យាស់ណាស់ថាជាការខិតខំប្រឹងប្រែងកំណត់អត្តសញ្ញាណ "ខ្មាំង" ផ្សេងទៀតរបស់ ប.ក.ក និងដើម្បីជួយជំរុញគោលដៅនៃផែនការឧក្រិដ្ឋក្នុងការកំណត់អត្តសញ្ញាណ "ខ្មាំង" សំដៅឃុំឃាំង និង/ឬសម្លាប់ចោល ដោយគ្មានដំណើរការក្តីតាម

មានខ្សែរយៈរបស់គាត់ ហើយតាមខ្ញុំដឹងគេមានបញ្ជីពីតំបន់ឲ្យ តាទិត ថាអ្នកណាត្រូវសម្លាប់ អ្នកណាមិនត្រូវសម្លាប់។ តើលោកធ្លាប់បានឃើញបញ្ជីនេះដែរឬទេ? ឆ.៦៧៖ ខ្ញុំមិនធ្លាប់ឃើញទេ ព្រោះខ្ញុំជាអ្នកទោសគេមិនឲ្យដឹងនោះទេ"]។ ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៨៨ KH 01110213។

[53] ឯកសារ D118/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ីន ឆ.១៦ KH 00891155 ["តាទិត ឬតាតុម ឬយាយបូ ជាទូទៅមកត្រួតពិនិត្យមើលអ្នកទោសពេលដែលគេចាប់យកមកដល់វត្តព្រះធាតុនេះ។ ខ្ញុំដឹងរឿងនេះដោយសារ ខ្ញុំបានឮពួកឈ្លបនិងតាទិត សួរចម្លើយអ្នកទោស"]។ ឯកសារ D219/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ីន ឆ.១, ៣-៤ KH 01045262 ["ស៖ [...] តើលោកបញ្ជាក់ប្រាប់យើងបានឬទេថា លោកធ្លាប់បានឃើញ តាទិត្យ សួរចម្លើយអ្នកទោសម៉ែន ឬយ៉ាងណា? ឆ.១៖ បាទ ខ្ញុំបានឃើញ។ [...] ឆ.៣៖ ខ្ញុំធ្លាប់ឃើញ តាទិត្យ សួរចម្លើយអ្នកទោសចំនួនពីរដង។ លើកទី១ គឺគាត់សួរចម្លើយអ្នកទោសជាមួយនឹង យាយបូ ហើយលើកទី២ គឺគាត់សួរចម្លើយអ្នកទោសតែម្នាក់ឯង។ [...] ឆ.៤៖ ខ្ញុំបានឃើញតាទិត្យ និងយាយបូ ហៅអ្នកទោសម្នាក់ចេញពីកន្លែងឃុំឃាំងទៅខាងក្រោមកុដិលោកមួយដែលនៅក្បែរនោះ ហើយខ្ញុំឃើញពួកគាត់ឈរនិយាយជាមួយអ្នកទោសនោះ។ តាទិត គាត់នៅនឹងមន្ទីរសន្តិសុខនៅពេលនោះ ប្រហែលជា២០នាទីប៉ុណ្ណោះ។ ដំបូង គាត់និយាយជាមួយនឹងអ្នកទោសមួយរយៈពេលខ្លី នៅខាងក្រោមកុដិលោក បន្ទាប់មកគាត់ជួបជាមួយនឹងអ្នកយាមធ្វើការនៅមន្ទីរសន្តិសុខ ហើយនិយាយគ្នា មុនពេលគាត់ត្រឡប់ទៅវិញ។ [...] អ្នកទោសមិនត្រូវបានធ្វើបាប ឬមួយក៏រ៉ែដ៏អ៊ីទេ។ ខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងចំពោះអ្នកទោសនោះទេ ក្រោយពីការសួរចម្លើយនោះ"]។ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ីន ឆ.២៦, ៤៨-៤៩ KH 01102935, 01102937 ។

[54] ឯកសារ D219/110 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ីន ឆ.៦ KH 01045263 ["ស៖ តា ទិត្យ ពេលនោះមកតាមរទេះសេះ ជាមួយនឹងនីរសារពីរនាក់។ ពេលគាត់មកដល់ គាត់ទៅក្រោមកុដិលោកដែរ ហើយប្រាប់ឲ្យ ប៊ិន នាំយកអ្នកទោសមកជួបគាត់។ ពេលគាត់និយាយជាមួយអ្នកទោស ខ្ញុំឮមិនអស់សេចក្តីទេ ខ្ញុំគ្រាន់តែឮតិចតួចប៉ុណ្ណោះ។ គាត់សួរអ្នកទោសថា "អ្នកឯងមកពីណា? មានគ្នាប៉ុន្មាននាក់នៅក្នុងក្រុមអ្នកឯង? ហើយតើហេតុអីបានជាអ្នកចង់រត់? ហើយរត់ទៅណា?។ អ្នកទោសនោះមិនត្រូវបានវាយដំ ឬក៏ធ្វើបាបដោយ តាទិត្យ ក្នុងពេលសួរចម្លើយនោះទេ។ ការសួរចម្លើយនោះ គឺមិនលើសពី១០នាទីទេ។ បន្ទាប់មក តា ទិត្យ បានប្រាប់អ្នកយាមឲ្យយកអ្នកទោសទៅមន្ទីរឃុំឃាំងវិញ ហើយគាត់ជិះរទេះសេះចេញវិញទៅ។ ខ្ញុំមិនដឹងថា មានរឿងអ្វីកើតឡើងចំពោះអ្នកទោសទេ ក្រោយពីតា ទិត្យ ចាកចេញទៅបាត់"]។ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ីន ឆ.៥៤-៥៦ KH 01102937 ["ឆ.៥៤៖ [...] លើកដំបូង តា ទិត្យ មកជាមួយនីរសារ ហើយបានយកអ្នកទោសម្នាក់ចេញហើយបានសួរចម្លើយគាត់។ គាត់សួរចម្លើយមិនលើសពីដប់នាទីទេ។ [...] ឆ.៥៥៖ តា ទិត្យ មកជាមួយនីរសារពីរនាក់ ដើម្បីសួរចម្លើយអ្នកទោស។ [...] ឆ.៥៦៖ ខ្ញុំឮតា ទិត្យ សួរ "ថាតើគ្នាឯងប៉ុន្មាននាក់ មកពីណា!"]។

ផ្លូវតុលាការ។ មានពេលមួយទៀត **យ៉ីម ទិត្យ** បានសួរចម្លើយអ្នកទោស ៦-៨ នាក់ នៅវត្តព្រះធាតុ[55] ។

33. **យ៉ីម ទិត្យ** ក៏បានចូលរួមចំណែកផងដែរក្នុងផែនការឧក្រិដ្ឋរួម តាមរយៈការបញ្ជាឲ្យសម្លាប់ក្រៅច្បាប់ នៅវត្តព្រះធាតុ។ អ្នកទោស អោក ចន នៅចាំថា **យ៉ីម ទិត្យ** បានទាំយកបទបញ្ជាឲ្យសម្លាប់ពេលគាត់មក[56] ហើយបើតាមអ្នកទោស ហោ យ៉ន មានពេលមួយ **យ៉ីម ទិត្យ** មកមន្ទីរសន្តិសុខ

---

[55] ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ុន ឆ.៦២ KH 01102938 [“ស៖ រាល់ពេលសួរចម្លើយរបស់ តា ទិត្យ តើមានអ្នកទោសប៉ុន្មាននាក់ដែលត្រូវបានសួរចម្លើយ? ឆ.៦២៖ មានច្រើននាក់ ស្ងរមិនលើសពីដប់នាទីក្នុងមួយនាក់។ ប្រហែល ៦ ឬ៧ ឬ៨ នាក់។ តា ទិត្យ សួរចម្លើយ តែម្នាក់ឯងទេ”]។

[56] ឯកសារ D105/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៩៥-៩៧ KH 00788851["ឆ.៩៥៖ គាត់មកដូចជាថានាំយកបទបញ្ជាពីតំបន់ថា តើអ្នកទោសណាត្រូវសម្លាប់។ [...] ឆ.៩៦៖ ពេលគាត់មកគាត់មើលអ្នកទោស ហើយបើសិនជាមានផែនការពីតំបន់មកថាឲ្យសម្លាប់អ្នកទោស គឺត្រូវសម្លាប់តែម្តង។ ស៖ លោកចង់មានន័យថា តា ទិត បានយកបញ្ជីឈ្មោះអ្នកដែលត្រូវសម្លាប់មកជាមួយគាត់ តើមែនទេ? ឆ.៩៧៖ រឿងនេះជាផែនការសំងាត់របស់គេ គេមិនឲ្យយើងដឹងទេ មានតែប្រធានគុកទេទើបដឹង"]។ ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៥៨-៦០ KH 00968094 “ស៖ នៅក្នុងឯកសារសម្ភាសន៍របស់លោកកាលពីលើកមុន ដែលមានលេខ EN 00803450 លោកបាននិយាយថា “តាទិត បានទៅគុកវត្តព្រះធាតុ ហើយបានយកបញ្ជាពីថ្នាក់តំបន់ដើម្បីសម្លាប់អ្នកទោស” ហេតុអ្វីបានជាលោកដឹងថា បញ្ជានោះមកពីថ្នាក់តំបន់? ឆ.៥៨៖ ពីព្រោះច្បាប់នៅក្នុងសម័យខ្មែរក្រហមគឺតគ្នា លុះត្រាមានបញ្ជាពីថ្នាក់តំបន់ ទើបថ្នាក់ស្រុកសម្លាប់។ ស៖ តើថ្នាក់ស្រុកអាចចេញបញ្ជាសម្លាប់អ្នកទោសបានដែរ ឬទេ? ឆ.៥៩៖ ទេ មិនអាចសម្លាប់បានទេ លុះត្រាមានបញ្ជាពីខាងលើទើបមេគុកបញ្ជាឲ្យសម្លាប់អ្នកទោស”]។

ហើយអ្នកទោសមួយចំនួនត្រូវគេសម្លាប់ និងវះយកប្រមាត់[57]។ បន្ទាប់មក **យ៉ាម ទិត្យ** និងតាណាំ បានយកប្រមាត់ដាក់ឡានបើកចេញទៅ[58]។

---

[57] ឯកសារ D105/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១២-១៤ KH 00788829-30 ["ឆ.១២៖ [...] ខ្ញុំឃើញ តាទិត ដោយសារគាត់មកមន្ទីរសន្តិសុខនេះនៅពេលដែលគេមានផែនការសម្លាប់អ្នកទោស និងមកយកប្រម៉ាត់មនុស្ស។ កាលណោះ តា ទិត មកទីនោះដោយជិះឡាន។ [...] ឆ.១៣៖ តាទិត មកគុកនេះនៅពេលដែលអ្នកទោសមានចំនួនពេញគុក ហើយគេជីករណ្តៅដើម្បីសម្លាប់អ្នកទោស កាត់យកប្រម៉ាត់។ ស៖ តើរឿងនេះកើតឡើងនៅពេលណា? ឆ.១៤៖ ខ្ញុំដូចជាមិនចាំទេ តែប្រហែលជាចុងឆ្នាំ១៩៧៧ ឬ១៩៧៨ គឺមានការសម្លាប់ខ្លាំងណាស់ ព្រោះគេដឹងថា មានផែនការវាយប្រហារពីកងទ័ពវៀតណាម] ឯកសារ D118/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២២-២៦, ៣៤-៣៥ KH 00968070-71, 00968072 ["ឆ.២២៖ [...] នៅពេលដែល តាទិត និង តាណាំ មកគុក គឺពួកគេតែងតែវះពោះអ្នកទោសយកប្រម៉ាត់ ប៉ុន្តែខ្ញុំមិនដឹងថាពួកគេយកធ្វើអ្វីនោះទេ។ [...] ឆ.២៣៖ គេបានឲ្យមេគុក និងកងឈ្លបទៅធ្វើរឿងនេះ ហើយនៅពេលដែលគេវះពោះអ្នកទោស គឺគេចងអ្នកទោសបីកន្លែង ទើបពួកគេវះពោះអ្នកទោសយកប្រម៉ាត់តែម្តង។ [...] ឆ.២៤៖ តាណាំ ជាអ្នកបញ្ជាឲ្យមេគុកឈ្លោះ ព្រឹង ទៅធ្វើរឿងនេះ។ ស៖ ចំពោះតា ទិត តើលោកធ្លាប់ឮ តាទិត បញ្ជាឲ្យគេទៅវះពោះអ្នកទោសដែរឬទេ? ឆ.២៥៖ តាទិត និង តាណាំ ជាអ្នកធ្វើការជាមួយគ្នា ដូច្នេះគឺដូចគ្នាទេ។ ស៖ នៅពេល តាណាំ បញ្ជាឲ្យគេវះពោះយកប្រម៉ាត់ តើតាទិត មានវត្តមានដែរឬទេ នៅពេលនោះ? ឆ.២៦៖ បាទ តាទិត ក៏នៅទីនោះដែរ ហើយប្រម៉ាត់ត្រូវពួកគេដាក់ឡានយកចេញទៅ ប៉ុន្តែខ្ញុំមិនដឹងគេយកទៅណានោះទេ។ [...] ស៖ នៅពេលដែលគេវះពោះអ្នកទោស តើ តាទិត និង តាណាំ មានវត្តមាននៅកន្លែងនោះដែរឬទេ? ឆ.៣៤៖ តាទិត និង តាណាំ ក៏ស្ថិតនៅទីនោះដែរ គឺនៅក្បែរឡាន។ នៅពេលដែលគេវះពោះអ្នកទោសយកប្រម៉ាត់ តើគេយកប្រម៉ាត់ទាំងនោះឲ្យ តាទិត និង តាណាំ ឬក៏យ៉ាងណា? ឆ.៣៥៖ បាទ គេចងជាបាច់យកមកឲ្យ តា ទិត និង តាណាំ ដែលនៅរង់ចាំនៅឡាន]។ ឯកសារ D219/326 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.៣២-៣៦ KH 01099689 ["ស៖ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់បានទេ គេវះយកប្រម៉ាត់នៅចំពោះមុខ តាទិត តែម្តងឬ? ឆ.៣២៖ គេយកអ្នកទោសទៅវះនៅចំងាយប្រហែលជា ៥០ ម៉ែត្រពីគុក រួចហើយគេយកប្រម៉ាត់មកឲ្យ តាទិត្យ គាត់នៅក្នុងឡាន គាត់មិនបានទៅមើលទេ។ ខ្ញុំមើលពីចំងាយឃើញគេរាប់ប្រម៉ាត់នោះនៅក្នុងឡាន ហើយប្រម៉ាត់ដែលគេប្រមូលបាននោះ គេយកដាក់ក្នុងធុង។ ស៖ តើលោកគិតថា តាទិត្យ បានឃើញគេវះយកប្រមាត់នោះទេ ឬក៏គ្រាន់តែចាំនៅកន្លែង? ឆ.៣៣៖ គាត់នៅចាំនឹងកន្លែង គាត់មិនបានឃើញទេ។ ស៖ លោកគិតថា អ្នកដែលគេយកទៅសម្លាប់យកប្រមាត់នោះ តើគេបានចាប់មកជាមុន ឬក៏ពេល តាទិត្យ ទៅដល់ទីនោះទើបគេយកទៅសម្លាប់? ឆ.៣៤៖ គេមានផែនការរួចហើយ គេត្រៀមមួយយប់មុនពេលដែលអ្នកទោសថ្មីទៅ គេយកទៅសម្លាប់ចោលតែម្តង។ ស៖ លោកថា មុននឹងតាទិត្យមក នៅយប់នោះ គេមានផែនការ គេយកចាប់ដែលចាប់មកថ្មីៗ ហើយថ្ងៃស្អែកគេយកទៅសម្លាប់ ពេលតាទិត្យមក តើអ៊ីចឹងមែនទេ? ឆ.៣៥៖ បាទ។ ស៖ លោកមានដឹងថា ហេតុអ្វីបានពួកគេត្រូវចាប់ខ្លួន? ឆ.៣៦៖ តាមខ្ញុំដឹង គេយកអ្នកថ្មីមកដោយសារពួកគេមិនទាន់ស្គម ហើយមានសុខភាពល្អ ចំណែកឯអ្នកចាស់ វាស្គម"។ ឯកសារ D1.3.11.18 កិច្ចសម្ភាសន៍របស់ SOAS ជាមួយ ហ្ស យ៉ន EN 00217607 ["ប្រមាត់ត្រូវគេកាត់យកចេញពីអ្នកដែលត្រូវគេសម្លាប់។ តុំ និង ឫ មកយកប្រមាត់ដែលមានចំនួនរាប់រយ។ តែមកម្តងម្តាលប៉ុណ្ណោះ"]។

[58] ឯកសារ D118/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២២-២៦ KH 00968070-71 ["ឆ.២៦៖ [...] តា ទិត្យ ក៏នៅទីនោះដែរ ហើយប្រមាត់ត្រូវពួកគេដាក់ឡានយកចេញទៅ ប៉ុន្តែខ្ញុំមិនដឹងគេយកទៅទីណានោះទេ"]។

34. **យ៉ីម ទិញ** ក៏បានបញ្ជាឲ្យសម្លាប់ក្រៅច្បាប់ផ្សេងទៀត នៅស្រុកគីរីវង់ នៅខាងក្រៅមន្ទីរសន្តិសុខវត្តព្រះធាតុ។ ក្នុងបទសម្ភាសន៍មួយ នៅខែសីហា ឆ្នាំ១៩៨០ អតីតមេឃុំវាមអណ្តើក ស្រុកគិរីវង់ បានឆ្លើយថា **យ៉ីម ទិញ** បានបញ្ជាឲ្យគាត់សម្លាប់មនុស្ស ២០០ នាក់[59]។ មេឃុំឈ្មោះ ងោល នេះ ក៏បានបញ្ជាក់យ៉ាងច្បាស់ថា អាជ្ញាធរថ្នាក់ឃុំអាចសម្លាប់បានតែក្នុងករណីមានការឯកភាពពីស្រុកប៉ុណ្ណោះ ហើយជនរងគ្រោះភាគច្រើនត្រូវគេប្រគល់ជូនកម្លាំងសន្តិសុខស្រុក ដើម្បីសម្លាប់ បន្ទាប់ពីអាជ្ញាធរឃុំចាប់បាន[60]។ អ្នកដែលត្រូវគេសម្លាប់រួមមាន គ្រូបង្រៀន សិស្ស-និស្សិត បញ្ញវន្ត និងមនុស្សពីរនាក់ដែលគេសង្ស័យថាមានផែនការរត់ទៅវៀតណាម[61]។ ងោល បាននិយាយថា **យ៉ីម ទិញ** "មកខ្លួនឯងផ្ទាល់ដើម្បីឲ្យប្រាកដ" ថាគាត់បានសម្លាប់មនុស្សពីរនាក់ដែលគេចោទថាមានផែនការរត់ទៅវៀតណាម ហើយ **យ៉ីម ទិញ** បានចាត់ទុកថាជាអំពើ "ក្បត់"[62]។ អង្គហេតុនេះស្របនឹងការព្យាយាមរបស់ **យ៉ីម ទិញ** ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលមានផែនការ "រត់" ខណៈពេលសួរចម្លើយអ្នកទោសនៅវត្តព្រះធាតុ។ ដោយសារតែ ងោល បានស្លាប់ នៅទសវត្សរ៍ឆ្នាំ ១៩៩០ ក.ស.ច.ស មិនអាចសម្ភាសគាត់ ដើម្បីសួរបញ្ជាក់អំពីរឿងរ៉ាវរបស់គាត់ ដែលលោក

---

[59] ឯកសារ D6.1.1105 *របបប៉ុលពត* ដោយប្រវត្តិវិទូ ប៉ែន ឃៀនិន ទំព័រ ២៩០-២៩១ KH 00637653-54 ["ង៉ោល បានទទួលបញ្ជាឲ្យសម្លាប់មនុស្សពីរយនាក់។ បទបញ្ជាទាំងនេះតែងតែចេញមកពីប្រធានស្រុកឈ្មោះ ទិត ដែលណែនាំឲ្យ ង៉ោល ចាប់ប្រជាជនយកទៅឲ្យកងកំលាំងសន្តិសុខស្រុក។ អ្នកដែលត្រូវគេសម្លាប់ក្នុងឆ្នាំ១៩៧៥ មានគ្រូបង្រៀន និសិត្ស និងបញ្ញវន្ត។ ក្នុងឆ្នាំ១៩៧៦ ប្រជាជនកាន់តែច្រើនថែមទៀតត្រូវគេសម្លាប់ ក្នុងនោះរួមទាំងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជា ដែលបានហ្វឹកហ្វឺននៅហាណូយម្នាក់ដែលបានព្យាយាមអនុវត្តបទបញ្ជា "មិនឲ្យអាក្រក់ពេក"។ ង៉ោល និយាយថាការសម្លាប់ភាគច្រើន គឺជាកិច្ចការរបស់កម្លាំងសន្តិសុខស្រុកគីរីវង្ស។ "យើងខ្ញុំអាចសម្លាប់ប្រជាជនក្នុងឃុំបានប្រសិនបើថ្នាក់លើស្រុកយល់ស្រប"]។ ឯកសារ D219/726.1.1 ប្រតិចារឹកកិច្ចសម្ភាសន៍របស់ Ben Kiernan ជាមួយ ង៉ោល KH 01339958-62។

[60] ឯកសារ D6.1.1105 *របបប៉ុលពត* ដោយប្រវត្តិវិទូ ប៉ែន ឃៀនិន ទំព័រ ២៩១ KH 00637654 ["ការសម្លាប់ភាគច្រើន គឺជាកិច្ចការរបស់កម្លាំងសន្តិសុខស្រុកគីរីវង្ស។ "យើងខ្ញុំអាចសម្លាប់ប្រជាជនក្នុងឃុំបានប្រសិនបើថ្នាក់លើស្រុកយល់ស្រប"]។ សូមមើលផងដែរ ឯកសារ D219/726.1.1 ប្រតិចារឹកកិច្ចសម្ភាសន៍របស់ Ben Kiernan ជាមួយ ង៉ោល KH 01339958-62។

[61] ឯកសារ D6.1.1105 *របបប៉ុលពត* ដោយប្រវត្តិវិទូ ប៉ែន ឃៀនិន EN 00678590។ សូមមើលផងដែរ ឯកសារ D219/726.1.1 ប្រតិចារឹកកិច្ចសម្ភាសន៍របស់ Ben Kiernan ជាមួយ ង៉ោល KH 01339958-62។

[62] ឯកសារ D6.1.1105 *របបប៉ុលពត* ដោយប្រវត្តិវិទូ ប៉ែន ឃៀនិន ទំព័រ២៩១ KH 00637654 ["ង៉ោល បានសារភាពថា បានសម្លាប់មនុស្សពីរនាក់ដែលបានគ្រោងផែនការរត់ទៅប្រទេសវៀតណាម។ ទិត បានពិចារណាការក្បត់នេះ ហើយប្រាប់ ង៉ោល ឲ្យកម្ទេចប្រជាជនទាំងនេះចោល"]។ "ប្រធានស្រុកមកបញ្ជាក់ថា ខ្ញុំជាអ្នកធ្វើរឿងនេះ"។ *សូមមើលផងដែរ* ឯកសារ D219/726.1.1 ប្រតិចារឹកកិច្ចសម្ភាសន៍របស់ Ben Kiernan ជាមួយ ង៉ោល KH 01339958-62។

Ben Kiernan បានកត់ត្រាទុក[63]។ ទោះជាយ៉ាងនេះក្តី រឿងរ៉ាវនេះត្រូវបានគាំទ្រខ្លះៗដោយ ភ័ស្តុតាងរបស់កម្មាភិបាលឈ្មោះ សឹម ឈឿន ដែលនៅចាំបានថា ង៉ោល ជាមេឃុំរាមអណ្តើក[64]។

35. ក៏មានភ័ស្តុតាងផងដែរថា ក្នុងពេលគាត់បំពេញការងារ នៅតំបន់ ១៣ **យ៉ីម ទិត្យ** បានបញ្ជាឲ្យ ប្រធានសន្តិសុខស្រុកត្រាំកក់ធ្វើការចាប់ខ្លួនក្រៅច្បាប់[65]។

iv. សេចក្តីសន្និដ្ឋាន៖ យ៉ីម ទិត្យ បានចូលរួមក្នុងគ្រប់ដំណាក់កាល នៃការអនុវត្តផែនការឧក្រិដ្ឋរួម នៅភូមិភាគនិរតី

36. ភ័ស្តុតាងខាងលើបង្ហាញថា **យ៉ីម ទិត្យ** បានចូលរួមក្នុងគ្រប់ទិដ្ឋភាពទាំងអស់នៃការអនុវត្ត គោលនយោបាយស្តីពីខ្មាំងរបស់ ប.ក.ក នៅតាមទីតាំងទាំងនោះនៃភូមិភាគនិរតី ក្រោមការ គ្រប់គ្រងរបស់គាត់។ ទីមួយ គាត់បាននិយាយនៅក្នុងកិច្ចប្រជុំ (ឬចូលរួម ក្នុងតួនាទីសំខាន់ជាថ្នាក់ ដឹកនាំ និងជាអ្នកឯកភាព) ដែលនៅពេលនោះ ខ្មាំងប្រភេទផ្សេងៗត្រូវបានកំណត់ ហើយមានការ ចេញសេចក្តីណែនាំឲ្យរកទីតាំងខ្មាំង និងរាយការណ៍ តាមឋានានុក្រម ប.ក.ក។ ទីពីរ ដំណើរការនៃ ការកំណត់អត្តសញ្ញាណនេះត្រូវបានអនុវត្ត ទាំងនៅក្នុងការប្រជុំដដែលនោះ និងតាមការត្រួតពិនិត្យ ដែលធ្វើឡើងដោយអ្នកនៅក្រោមបង្គាប់មិនផ្ទាល់របស់ **យ៉ីម ទិត្យ** (ដូចជា ឈ្លបឃុំ) តាមការ ណែនាំរបស់អ្នកនៅក្រោមបង្គាប់ផ្ទាល់របស់គាត់ (ដូចជា មេឃុំ)។ ទីបី ខ្មាំង ដែលគេកំណត់ អត្តសញ្ញាណបាន ត្រូវបានចាប់ខ្លួន ដោយគ្មានដំណើរការតាមផ្លូវច្បាប់។ ទីបួន ខ្មាំងត្រូវគេកម្ទេច ដោយគេចោទថាបង្ករការគំរាមកំហែង តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ រួមមានការដាក់គុក ការធ្វើទារុណកម្ម និងការសម្លាប់ ដោយអ្នកនៅក្រោមបង្គាប់ផ្ទាល់ និងមិន ផ្ទាល់របស់ **យ៉ីម ទិត្យ** ក្រោមការគ្រប់គ្រងផ្ទាល់ និងដោយប្រយោល ពី **យ៉ីម ទិត្យ** និងតាមបញ្ជា របស់គាត់។ ភ័ស្តុតាងសម្រាប់ដំណាក់កាលនីមួយៗនៃដំណើរការនេះ បានមកពីសាក្សីផ្សេងៗដែល

---

[63] ការិយាល័យសហចៅក្រមស៊ើបអង្កេតមិនមានលទ្ធភាពធ្វើការស្តាប់ចម្លើយលោក ង៉ោល បានដោយសារគាត់បានស្លាប់នៅ អំឡុងឆ្នាំ១៩៩៣ ឬ ឆ្នាំ១៩៩៦។ ដោយសារតែលោក ង៉ោល បានស្លាប់ទៅហើយ ហើយកំណត់ហេតុរបស់លោក Ben Kiernan នៃការសន្ទនារបស់គាត់ជាមួយលោក ង៉ោល មានភាពលំអិតពិស្តាគ្រប់គ្រាន់ ដូច្នេះការសំអាងលើភស្តុតាងនេះ គឺសមហេតុផល។ សូមមើលឯកសារ D219/48 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបជំនួស KH 01365549 [បញ្ជាក់ថា លោក ង៉ោល បានស្លាប់] ។

[64] ឯកសារ D219/189 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹម ឈឿន ឆ.១៨-២០ KH 01068050។

[65] ឯកសារ D219/34 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក (អ៊ីល) ហ៊ឿន ឆ.៣៣ KH 01032071 [“តាមខ្ញុំយល់ គឺតាទិត្យ និងយាយចែម បានបញ្ជាឲ្យ តាសឿន ដែលជាប្រធានទគរបាលស្រុក ឲ្យចាប់មនុស្ស”]។

បានប្រាប់អំពីរឿងរ៉ាវស៊ីសង្វាក់គ្នាខ្លាំង។ ដូច្នេះ មានភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាថា មានគោលនយោបាយស្តីពីការកំណត់ ស្វែងរក និងកម្ទេចអ្នកដែលគេមើលឃើញថាជាខ្មាំង និងជាអ្នកប្រឆាំងនឹងរបប តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅតាមទីតាំងខ្លះនៃភូមិភាគនិរតី ក្រោមការគ្រប់គ្រងរបស់ **យ៉ីម ទិត្យ**។ ក៏មានភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាផងដែរថា **យ៉ីម ទិត្យ** បានចែករំលែកគោលបំណងឧក្រិដ្ឋនេះ និងបានចូលរួមចំណែក។

ខ. ការចូលរួមចំណែករបស់ យ៉ីម ទិត្យ ក្នុងគោលនយោបាយស្តីពីការរៀបការដោយបង្ខំ របស់ ប.ក.ក នៅភូមិភាគនិរតី

37. នៅភូមិភាគនិរតី **យ៉ីម ទិត្យ** បានណែនាំប្រជាជន ក្រោមការគ្រប់គ្រងរបស់គាត់ ឲ្យរៀបការ និងបង្កើតកូន ដើម្បីសម្រេចគោលដៅរបស់ ប.ក.ក។ ជាពិសេស គាត់ "បានប្រាប់ប្រជាជនឲ្យរៀបការ ដើម្បីឲ្យមានកូន មានគ្រួសារ និងបង្កើតយោធាថ្មីៗទៀត"[66]។ គាត់បាននិយាយបែបនេះ "ញ៉ីកញ្ជាប់ច្រើនដង [...] រៀងរាល់ឆ្នាំ"[67]។

38. សម្តីរបស់គាត់បង្ហាញថា **យ៉ីម ទិត្យ** បានដឹង និងចែករំលែកគោលនយោបាយរបស់ ប.ក.ក ស្តីពីការបង្កើនអត្រាកំណើត តាមរយៈការរៀបការដោយបង្ខំ ដើម្បីបង្កើនចំនួនកម្មករ និងទាហាន នៅក្នុងរបបនេះ។ សម្តី អំពើ និងការប្រព្រឹត្តផ្សេងទៀត របស់ **យ៉ីម ទិត្យ** បង្ហាញថា គាត់បានដឹងថាការណែនាំរបស់គាត់ ជាទូទៅ គឺជាបញ្ហាដាច់ខាត ដែលត្រូវបានអនុវត្តជាញ៉ីកញ្ជាប់ តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្មគួរឲ្យរន្ធត់។ ដូច្នេះ គាត់ត្រូវតែយល់ថា ក្នុងកាលៈទេសៈបង្ខិតបង្ខំនៃរបបកម្ពុជាប្រជាធិបតេយ្យ ការណែនាំរបស់គាត់ឲ្យប្រជាជនរៀបការ និងបង្កើតកូន ត្រូវបានយល់ថាជាបញ្ហាដាច់ខាត និងអាចបណ្តាលឲ្យរបបនេះរៀបការដោយគ្មានការយល់ព្រម ទាំងជនស៊ីវិល ទាំងកម្មាភិបាល ដែលត្រូវគេរំពឹងថានឹងរួមដំណេក ទោះបីជាមានការមិនយល់ព្រមពីដៃគូណាមួយ ឬទាំងពីរក៏ដោយ។

គ. អំពើ និងការប្រព្រឹត្តផ្សេងទៀតរបស់ យ៉ីម ទិត្យ នៅភូមិភាគនិរតី

39. តាមរយៈតំណែងផ្សេងៗរបស់គាត់ **យ៉ីម ទិត្យ** បានអនុវត្តសិទ្ធិអំណាច នៅក្នុងវិស័យមុខងារ និងបញ្ជាជាច្រើន ក្នុងរដ្ឋបាលភូមិភាគនិរតី។ គាត់មានទំនួលខុសត្រូវ ទាក់ទងនឹងនយោបាយ ភ័ស្តុភារ

---

[66] ឯកសារ D219/406 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃូ ភ្ជុ ឆ.១៨៨ KH 01117240។

[67] ឯកសារ D219/406 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃូ ភ្ជុ ឆ.១៨៨ KH 01117240។

សេដ្ឋកិច្ច ការចែកចាយម្ហូបអាហារ និងការយោសនា[68]។ គាត់បានចេញបញ្ជា ទាក់ទងនឹងការធ្វើស្រែ និងសាងសង់ប្រឡាយ ដល់ប្រធានអង្គភាពថ្នាក់ទាប និងបាននិយាយនៅក្នុងកិច្ចប្រជុំថ្នាក់ស្រុក អំពីផែនការការងារ និងការបង្កបង្កើនផលកសិកម្ម[69]។

40. មុខងារទាំងនេះមិនមានចរិតឧក្រិដ្ឋជាចាំបាច់នោះទេ ប៉ុន្តែ ឆ្លុះបញ្ចាំងអំពីកម្រិតនៃសិទ្ធិ អំណាច និងឥទ្ធិពលរបស់ **យ៉ឹម ទិត្យ**។ **យ៉ឹម ទិត្យ** ក៏ទទួលបាន និងគ្រប់គ្រងលើការផ្គត់ផ្គង់ម្ហូបអាហារដ៏សម្បូរបែបផងដែរ។ ម៉ឹង វេត ជានីរសារយោធា ដែលធ្លាប់នាំសំណើសុំម្ហូបអាហារម្តងម្កាល ទៅជូន **យ៉ឹម ទិត្យ** បាននិយាយថា "គាត់ចិញ្ចឹមជ្រូកប្រហែល ៣០-៤០ ក្បាល [នៅមន្ទីររបស់ **យ៉ឹម ទិត្យ**] ហើយមានដាំចេក ល្ហុង ជុំវិញមន្ទីរគាត់"[70]។ ម៉ឹង វេត ក៏បានគូសបញ្ជាក់ថា "គឺ **យ៉ឹម ទិត្យ** ជាអ្នកសម្រេចឲ្យ" ម្ហូបអាហារ[71]។ ក្នុងកាលៈទេសៈខ្វះខាតបែបនេះក្នុងរបបខ្មែរក្រហម ភាពសម្បូរបែបនេះគឺជាការចង្អុលបង្ហាញមួយទៀតអំពីឋានៈ និងភាពលេចធ្លោរបស់ **យ៉ឹម ទិត្យ**។

---

[68] ឯកសារ D219/358 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លួន មល់ ឆ.១០, ៥៥, ៩៤ KH 01104661, 01104667, 01104671។ ឯកសារ D219/111 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មៅ ឆោម ឆ.៤៩, ៦៩ KH 01045273, 01045275។ ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១២ KH 01136702។ ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហុក ចាន់ ឆ.៥-៧ KH 01110206។

[69] ឯកសារ D219/379 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច សម្បតិ ឆ.១៥ KH 01112269។ ឯកសារ D118/21 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិម ភី ឆ.២៧-២៨, ៣២ KH 00891149-50 ។ ឯកសារ D219/471 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពឹម ផល ឆ.៣២-៣៥, ៣៩ KH 01133416-17 ។

[70] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១៤ KH 01136702។

[71] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១២ KH 01136702 ["យ៉ឹម ទិត្យ ជាអ្នកសម្រេចឲ្យ ឧទាហរណ៍ ជ្រូកបីក្បាល បន្ថែ ចេក ល្ហុង ជាដើម។ បើគាត់ឲ្យ គឺខាងសេដ្ឋកិច្ចគាត់ជាអ្នកយក"] ។

ឃ. ការចូលរួមរបស់ យ៉ីម ទិត្យ ក្នុងផែនការឧក្រិដ្ឋរួម នៅភូមិភាគពាយ័ព្យ

41. នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ តាម៉ុក បានចាប់ផ្តើមបញ្ជូនកម្មាភិបាលនិរតីទាំងក្រុមៗ ឲ្យទៅកាន់ចំនួលខុសត្រូវផ្សេងៗ និងអនុវត្តភារកិច្ចផ្សេងៗ នៅភូមិភាគពាយ័ព្យ[72]។ ការផ្ទេរទាំងនេះនៅតែបន្ត ដោយមិនជាប់លាប់ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[73]។

42. ភ័ស្តុតាងបង្ហាញថា គោលបំណងសំខាន់នៃការផ្ទេរកម្មាភិបាលទាំងនេះ គឺដើម្បីជួយសម្រួលដល់ការអនុវត្តផែនការឧក្រិដ្ឋរួម នៅភូមិភាគពាយ័ព្យ។ មុនពេលផ្ទេរ តាម៉ុក បានប្រាប់កម្មាភិបាលភូមិភាគនិរតីថា ហេតុផលដែលពួកគេត្រូវបានបញ្ជូន គឺដើម្បី "បោសសម្អាត" កម្មាភិបាលពាយ័ព្យដែលត្រូវគេសង្ស័យថាក្បត់[74]។ ហែម មឿន ក្មួយប្រុសរបស់ តាម៉ុក បាននិយាយថា៖

> ដោយសារគេមកបោសសម្អាតភូមិភាគពាយ័ព្យ ដូច្នេះហើយទើបគេឲ្យយើងមកគ្រប់គ្រងនៅភូមិភាគពាយ័ព្យវិញម្តង។ មានតែពួកកម្មាភិបាល និងយោធានិរតីទេដែលគេបញ្ជូនមកគ្រប់គ្រងនៅពាយ័ព្យ។ ប្រជាជននៅភូមិភាគពាយ័ព្យ គឺស្អប់ភូមិភាគនិរតីណាស់ ដោយសារយើងមកត្រួតត្រាក្បាលរបស់គេ[75]។

---

[72] សូមមើលឧទាហរណ៍ ឯកសារ D219/34 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក (អ៊ីល) ហឿន ឆ.៣៦-៣៧, KH 01032072 ["តើលោកដឹងរឿងអ្វីខ្លះអំពីការបញ្ជូនកម្មាភិបាលពីភូមិភាគនិរតី ទៅកាន់ភូមិភាគពាយ័ព្យដែរ ឬទេ? ឆ.៣៦៖ គឺមានកម្មាភិបាលចំនួន៣០០នាក់ ត្រូវបានបញ្ជូនពីនិរតី ទៅពាយ័ព្យ នៅក្នុងខែមីនា ឆ្នាំ១៩៧៧។ ស៖ តើនរណាជាអ្នកសម្រេចបញ្ជូនកម្មាភិបាលទាំង៣០០នាក់ ពីខេត្តតាកែវ ទៅពាយ័ព្យ? ឆ.៣៧៖ តាម៉ុក គឺជាអ្នកសម្រេចបញ្ជូនកម្មាភិបាលទាំង៣០០នាក់ទៅពាយ័ព្យ ព្រោះតាម៉ុក គឺជាគណ:ភូមិភាគនិរតី"]។ ឯកសារ D219/654 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុក ចាន់ ឆ.៧៨ KH 01196545 ["តាម៉ុក នាំកម្មាភិបាលពីភូមិភាគនិរតីមកគ្រប់គ្រងតំបន់១"]។ *សូមមើលផងដែរ* ឧក្រិដ្ឋកម្ម-ភូមិភាគពាយ័ព្យ-ការបោសសម្អាត។

[73] សូមមើលឧទាហរណ៍ ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.១៩-២០ KH 00947290 ["ឡុច អេង ដឹងគឺមានបី ឬបួនវគ្គ នៃការបញ្ជូនប្រជាជននៅភូមិភាពនិរតី ទៅភូមិភាគពាយ័ព្យ នៅឆ្នាំ១៩៧៦"]។

[74] ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.២៣-២៤ KH 00967998។

[75] ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.២៣-២៤ KH 00967998 ["សាក្សីគឺជាក្មួយរបស់តាម៉ុក ហើយបានធ្វើដំណើរយ៉ាងច្រើនជាមួយតាម៉ុក៖ "នៅមុនពេលដែលកងពលរបស់ខ្ញុំមកបាត់ដំបង គឺគេប្រាប់យើងថាមានព្រឹត្តិការណ៍នៅពាយ័ព្យ គឺយើងទៅបោសសម្អាតពួកពាយ័ព្យ ប៉ុន្តែពេលខ្ញុំមកដល់គឺដូចតែគ្នា គ្មាននរណាក្បត់នោះទេ។ [...] តាម៉ុក គឺជាអ្នកចេញបញ្ជានេះ។ តាម៉ុក និយាយថា "សភាពការណ៍មិនស្រួលទេ ពួកពាយ័ព្យអាចក្បត់ហើយ យកទាហានទៅដាក់"] ឆ.៦០ KH 00968003 ["តាទិត បានយកកម្លាំងទាហានរបស់ខ្លួនឯងពីតាកែវមកជាមួយតាម៉ុក។ នៅបាត់ដំបងគឺមានតែតាទិត ប៉ុណ្ណោះដែលធំជាងគេបន្ទាប់ពី តាម៉ុក។ ប្រសិនបើតាម៉ុក មិននៅ គឺតាទិត ជាអ្នកទទួលបន្ទុកភូមិភាគពាយ័ព្យ។ ដោយសារគេមក

43. តាម៉ុក បានប្រាប់ ណុប ធឹម ថា អ្នកកាន់តំណែងមុន នៅភាគពាយ័ព្យ គឺ "អា" និង "ក្ឫត"[76]។ ពេជ្រ ជឹម លេខាស្រុកត្រាំកក់ ជាអ្នកនៅក្រោមបង្គាប់របស់ តាម៉ុក ដែលត្រូវបញ្ជូនទៅភូមិភាគ កណ្តាល ដោយសារហេតុផលស្រដៀងគ្នានេះ បានបញ្ជាក់អះអាងថា មូលហេតុដែលខាងភូមិភាគ និរតីទៅកាន់កាប់ភូមិភាគពាយ័ព្យនោះ គឺដោយសារគេជឿថា "ភូមិភាគពាយ័ព្យក្ឫត"[77]។ កម្មាភិបាល ថ្នាក់ទាបយល់អំពីបញ្ហានេះយ៉ាងច្បាស់។ ពេលសួរថា ហេតុអ្វីបានជា តាម៉ុក បញ្ជូន អ៊ីម ចែម ទៅ ភូមិភាគភាគពាយ័ព្យ ម៉ឹង វេត ឆ្លើយថា៖ "ខ្ញុំគ្រាន់តែឮថា មានអ្នកក្ឫត ដែលត្រូវប្តូរមុខតំណែង"[78] ។ "តាម៉ុក បានប្រាប់ក្រុមកម្មករភូមិភាគនិរតីរបស់ ឡុច អេង ថា ពួកគេត្រូវបានផ្ទេរទៅភាគពាយ័ ព្យ ពីព្រោះ "កម្មាភិបាលពាយ័ព្យមានការភ្លើតភ្លើនច្រើនរឿងស្រីញី ជិះម៉ូតូទៅធ្វើការ ហើយ ភ្លើតភ្លើននឹងសម្ភារៈប្រើប្រាស់ និងផឹកស្រា"[79]។

44. ក្នុងបរិបទនៃគម្រោងធំនេះ **យ៉ីម ទិត្យ** ត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ ឲ្យកាន់តំណែងជាច្រើន និងអនុវត្តភារកិច្ចផ្សេងៗ ដើម្បីជួយជំរុញផែនការឧក្រិដ្ឋរួម។

បោសម្អាតភូមិភាគពាយ័ព្យ ដូច្នេះហើយទើបគេឲ្យយើងមកគ្រប់គ្រងភូមិភាគពាយ័ព្យវិញម្តង។ មានតែកម្មាភិបាល និងយោធា និរតីទេ ដែលគេបញ្ជូនមកគ្រប់គ្រងនៅពាយ័ព្យ។ ប្រជាជននៅភូមិភាគពាយ័ព្យ គឺស្អប់ភូមិភាគនិរតីខ្លាំងណាស់ ដោយសារយើង មកត្ដួតត្រាកាត្តាលរបស់គេ"]។

[76] ឯកសារ D123/2/2.17a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយឈ្មោះ ណុប ធឹម KH 00733829 ["តាម៉ុកថា ស្រុកសំឡូតនឹង អាភីមៗនៅសំឡូតពីមុនមកវាក្ឫត់ៗ អត់ឲ្យប្រជាជនស៊ីបាយ ដូងវ៉ាន់ផ្ដែនៅជ្រែកៗ អត់ឲ្យប្រជាជនបេះស៊ីទេ ប្រជាជនស្រុកសំឡូត ដល់នេះផ្ដាស់ពួកខ្ញុំមក។ ស៖ តាម៉ុកនិយាយថាអីចឹង? ឆ៖ ចា"]។

[77] ឯកសារ D118/79 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.៩ KH 00934401 ["តាមខ្ញុំឮ គេថាភូមិភាគបូព៌ាក្ឫត ក្រោយមកភូមិភាគឧត្ដរក្ឫត និងបន្ទាប់មកភូមិភាគកណ្តាលក៏ក្ឫត ទើប តាម៉ុក គាត់ទៅកាន់កាប់នៅទីនោះ"]។ ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.៥៤ KH 00997030 ["ក្រោយយាយចែម និងកម្មាភិបាលផ្សេង ទៀតទៅដល់ពាយ័ព្យហើយ ទើបខ្ញុំលួចសួរគេ ហើយដឹងថា "មានរឿងហើយ ផ្ទៃក្នុងក្ឫត" ដូច្នេះទើបគេបញ្ជូនកម្មាភិបាលនិរតី ទៅពាយ័ព្យ"]។

[78] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១៣៩ KH 01136725 ["ស៖ ហេតុអ្វីបានជា តាម៉ុក បញ្ជូនយាយចែម ទៅភូមិភាគពាយ័ព្យ? ឆ.១៣៩៖ ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែឮថា មានអ្នកក្ឫត់ដែលត្រូវប្តូរមុខដំណែង"]។ *សូមមើលផងដែរ* ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.៣៧, ៤០ KH 01008702-03។ សូមមើលផងដែរ ឯកសារ D219/34 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក (អ៊ីល) ហ៊ឿន ឆ.៣៨ KH 01032072។

[79] ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាច អេង ឆ.១១-១២ KH 00947289។ ឯកសារ D219/627 ឡាច អេង ឆ.៥ KH 01184312។

១. តំណែងរបស់ យ៉ឹម ទិត្យ នៅភូមិភាគពាយ័ព្យ

ក. តំណែងផ្លូវការ

45. **យ៉ឹម ទិត្យ** បានកាន់តំណែងសំខាន់ៗមួយចំនួន នៅភូមិភាគពាយ័ព្យ។ គាត់បានបំពេញការងារជាលេខាតំបន់ ១[80] និងជាអនុលេខាភូមិភាគពាយ័ព្យផងដែរ[81] ខណៈដែល តាម៉ុក ជាលេខាភូមិភាគពា

---

[80] ឯកសារ D219/974.1.2 ណុប ងឹម ប្រតិចារ៉ឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.39.58-10.42.16 ["តំបន់១ ឈ្មោះអ៊ំទិត្យ។ ខ្ញុំស្គាល់គាត់។ [...] ចាស មកពីនិរតីដែរ"]។ ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៧ KH 01008697 ["តាមខ្ញុំដឹងតាទិត្យ ជាគណៈតំបន់១ គឺខេត្តបាត់ដំបងក្នុងឆ្នាំ១៩៧៨"។] ឆ.៦៣៖ KH 01008707 ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៩២ KH 01329398 ["គឺមកកាលភូមិភាគហ្នឹង ដឹងអ៊ំទិត្យ គណៈតំបន់១ និងតាម៉ុក គណៈភូមិភាគ"]។ ឯកសារ D219/210 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីរ ឆ.៤ KH 01074048 ["តាទិត្យ ច្បាស់ជាលេខាថ្នីរបស់តំបន់១ហើយ ក្រោយពីតាប៉ែតបាត់ខ្លួន"]។ ឯកសារ D123/2/2.17a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយឈ្មោះ ណុប ងឹម KH 00738338។ ឯកសារ D219/236 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីរ ឆ.១៨ KH 01080844 ["តាទិត្យ គឺជាគណៈតំបន់១។ ខ្ញុំមិនដឹងពីតំណែងច្បាស់រវាង តាប៉ែត និងតាទិត្យនោះទេ"]។ ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ីា ឆ.៧, ២១-២៣ KH 00960663, 00960666 ។ ឯកសារ D219/233 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ីា ឆ.៨, ២១ KH 01078133, 01078136 ["តាទិត្យ និងតា នីម បានរត់ទៅគ្រប់គ្រងនៅទីនោះ"]។ ឯកសារ D1.3.11.15 បទសម្ភាសន៍របស់ Steve Heder ជាមួយ ហៅ តាប៉ែត EN 00426119។ ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៉ាន ឆ.១១-១៥ KH 01110175 ឯកសារ D219/689 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ឆ.២០ KH 01205203 ["ឆ.២០៖ តាទិត្យហ្នឹង និយាយទៅពួកនិរតីបញ្ជូនទៅគ្រប់គ្រងសហករណ៍នៅតំបន់១"] ឆ.៨១ KH 01205217 ["តាទិត្យចូលទៅកាន់កាប់តំបន់ មុនខ្ញុំរត់ចូលព្រៃ"]។ ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.២ KH 01040093 ["ប្រធានតំបន់១ កាលនោះ គឺជាអ្នកមកភូមិភាគនិរតីដែរ គឺឈ្មោះតាទិត្យ"]។ ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.៤ KH 00990642 ["នៅថ្ងៃមួយខ្ញុំត្រូវបានគេហៅឲ្យមកប្រជុំនៅភ្នំសំពៅ នៅពេលនោះគឺជាពេលដែលខ្ញុំបានជួបប្រធានគណៈតំបន់១ ឈ្មោះទិត្យ"] ឆ.១៨ KH 00990646 ["ស៖ នៅពេលដែលប្រជុំនោះ តើតាទិត ត្រូវបានគេឧទ្ទេសនាមគាត់យ៉ាងម៉េច? ឆ.១៨៖ នៅពេលនោះគេបានឧទ្ទេសនាមគាត់ថា ជាគណៈតំបន់១"]។ ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.២៤ KH 01023877។ ឯកសារ D118/208 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក (អ៊ីុល) ហ៊ឿន ឆ.៦៤ KH 00980089 D119/70/4 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយឈ្មោះ ឯក (អ៊ីុល) ហ៊ឿន KH 00968904។ ឯកសារ D219/430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.១១៧ KH 01122418។ ការចាត់តាំងកើតឡើងក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៨។ ឯកសារ D219/430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៩៥ KH 01122413 ["តើតាទិត្យ ឡើងកាន់ជំនួសតាប៉ែតនៅពេលណា? ឆ.៩៥៖ មុន ឬក៏នៅក្នុងអំឡុងខែកក្កដា ឆ្នាំ១៩៧៨។ ដោយសារតែតាទិត្យ ធ្លាប់ទៅធ្វើជាប្រធានអង្គប្រជុំនៅខែកញ្ញា ឆ្នាំ១៩៧៨។ គាត់មកធ្វើជាប្រធានអង្គប្រជុំជាមួយកងចល័ត ហើយគាត់ជិះឡានហ្សីប"]។ ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៣៩-៤០ KH 01110179 ["ឆ.៣៩៖ ទួលអណ្តែត គឺស្ថិតនៅក្នុងឃុំចែងមានជ័យ ស្រុកបាណន់។ វាគឺជាកន្លែងការដ្ឋានដាំអំពៅ ហើយក៏ជាមូលដ្ឋានឈរជើងរបស់ តា ហេងទាវ ឬ តាប៉ែត

ផងដែរ។ [...] តាប៉ែត ត្រូវបានគេដកចេញពីតំណែងរបស់គាត់ និងជំនួសដោយ តាទិត្យ។ ស៖ តើតាទិត្យ ជំនួសតំណែង តាប៉ែត នៅពេលណា? ឆ.៤០៖ តាទិត្យ ជំនួសតំណែង តាប៉ែត នៅខែកក្កដា ឬខែសីហា ឆ្នាំ១៩៧៧"]។ ឯកសារ D219/430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៩៩ KH 01122414 ["ស៖ [...] លោកប្រាប់ខ្ញុំនៅក្នុងចម្លើយមុនរបស់លោក (ឯកសារ D219/368) ថា តាទិត្យ មកជំនួស តាប៉ែត នៅខែកក្កដា ឬសីហា ឆ្នាំ១៩៧៧ (ចម្លើយទី៤០)។ ថ្ងៃនេះលោកប្រាប់ខ្ញុំថា វាកើតឡើងនៅមុន ឬក៏ក្នុងខែកក្កដា ឆ្នាំ១៩៧៨ តើលោកអាចប្រាប់ខ្ញុំបានដែរឬទេថា មួយណាជាឆ្នាំត្រឹមត្រូវ? ឆ.៩៩៖ ឆ្នាំ១៩៧៨"] ។

[81] ឯកសារ D118/108 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទីម ឆ.១៦-១៨ KH 00951928 ["ខ្ញុំស្គាល់តាទិត្យ គាត់នៅកាន់ថាភូមិភាគពាយ័ព្យ។ [...] ខ្ញុំស្គាល់ពីឈ្មោះតាទិត ព្រោះគេឲ្យកងការពារទៅចូលរួមសន្និបាតនៅសាលាសកលបាត់ដំបងក្នុងក្រុងបាត់ដំបង ហើយគេឧទ្ទេសនាមថា តាទិត ជាប្រធានភូមិភាគពាយ័ព្យ។ ខ្ញុំដឹងថា តាទិត មកបាត់ដំបងនេះមុន តាម៉ុក តាទិត មកប្រហែលជាមួយឆ្នាំមុនវៀតណាមចូល។ [...] ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៨ [...] តាទិត ត្រូវគេឧទ្ទេសនាម ថាជាគណៈភូមិភាគពាយ័ព្យ។ [...] តា រស់ ញ៉ឹម និង តា កន គេចាប់ក្រោយគេ គឺគេចាប់ពួកគាត់ប្រហែលជា៥ទៅ៦ខែ មុនវៀតណាមចូល""]។ ឆ.២៧ KH 00951929 ["ស៖ ពេលលោកទៅសន្និបាតនៅបាត់ដំបង តើតាញ៉ឹម មានវត្តមាននៅទីនោះដែរឬទេ? ឆ.២៧៖ មិនមានទេ មានតែ តាទិត ដែលធំជាងគេ"]។ ឯកសារ D118/271 កំណត់ហេតុនៃការស្តាប់ចម្លើយ ឈាង ប៊ា ឆ.៣៤ KH 00998559 ["គេចាប់ តាញ៉ឹម មុនគេ ហើយប្រហែល៥ខែក្រោយមក គេចាប់ខ្លួនតាកឹ។ តាទិត និង តាម៉ុក ឡើងគ្រប់គ្រងជំនួស"]។ ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយ ហែម ម្ឿន ឆ.៥៩-៦១ KH 00968003 ["តាទិត និង តាប៊ិត គឺជាកូនចៅរបស់ តាម៉ុក។ [...] នៅបាត់ដំបង គឺមានតែ តាទិត ប៉ុណ្ណោះដែលធំជាងគេបន្ទាប់ពី តាម៉ុក។ ប្រសិនបើ តាម៉ុក មិននៅ គឺតាទិត ជាអ្នកទទួលខុសត្រូវភូមិភាគពាយ័ព្យ។ [...] តាម៉ុក បានប្រកាសប្រាប់យោធាថា "បើអស់ពីអញទៅ តាទិត ជាអ្នកទទួលខុសត្រូវភូមិភាគបន្ទាប់" [...] ខ្ញុំធ្លាប់ជួប តាទិត ដំបូងប្រហែងចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ នៅបាត់ដំបូង ប៉ុន្តែខ្ញុំមិនច្បាស់ទេ ព្រោះយូរឆ្នាំណាស់មកហើយ"]។ ឯកសារ D118/222 កំណត់ហេតុនៃការស្តាប់ចម្លើយ ហែម ម្ឿន ឆ.១៤ KH 00983235 ["ស៖ នៅក្នុងបទសម្ភាសន៍ពីមុននៅត្រង់សំណួរ-ចម្លើយទី៦១ លោកបាននិយាយថា៖ "តាម៉ុកប្រកាសនៅក្នុងអង្គប្រជុំមួយនៅខេត្តបាត់ដំបងថា តាទិត ជាអ្នកជំនួសគាត់នៅក្នុងភូមិភាគពាយ័ព្យ ពេលគាត់អវត្តមាន"។ តើការប្រជុំនោះធ្វើឡើងនៅពេលណា មានមនុស្សចូលរួមច្រើនទេ? ឆ.១៤៖ ខ្ញុំបានឮការប្រកាសនេះប្រហែលជាមួយអាទិត្យ បន្ទាប់ពីខ្ញុំបានទៅដល់ខេត្តបាត់ដំបង។ ខ្ញុំមិនបានយាមនៅកន្លែងប្រជុំទេ គឺខ្ញុំយាមនៅតាមផ្លូវ ហើយឃើញមានមនុស្សច្រើនទៅចូលរួមប្រជុំនោះ"]។ ឯកសារ D118/69 កំណត់ហេតុនៃការស្តាប់ចម្លើយ នួន មួន ឆ.១៤, ១៦-១៧ KH 00920212-13 ["ស៖ ឆ.១៤៖ [...] តាទិត ក្លាយជាអនុប្រធានភូមិភាគពាយ័ព្យរបស់ តាម៉ុក ទទួលបន្ទុកតំបន់១។ [...] ស៖ តើហេតុអ្វីទើបលោកដឹងថា តាទិត ជាអនុប្រធានភូមិភាគពាយ័ព្យ? ឆ.១៦៖ ព្រោះកាលណោះអ្នកដែលធំមកពីភូមិភាគនិរតីមានតែពីរនាក់ទេ គឺតាម៉ុក និង តាទិត ហើយមិនមានអ្នកណាផ្សេងទេ។ ស៖ តើគេដែលប្រកាសថា តាទិត្យ ក្លាយជាអនុប្រធានភូមិភាគដែរឬទេ? ឆ.១៧៖ គេមិនដែលប្រកាសទេ ខ្ញុំដឹងតាមរយៈប្រជាជន និងកម្មាភិបាលនិរតីដែលគ្រប់គ្រងសហករណ៍ និងសហជីព"]។ ឯកសារ D219/917 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជៃ ទូច ឆ.១១, ១៣, ១៥ KH 01388675-76 ["ឮពេលនៅដូនទាវ បាត់ដំបង ឮតែទិតៗ មិនដឹងម៉េច។ [...] ខ្ញុំឮតែគេនិយាយ ពេលប្រជុំកម្មករ។ [...] តាបូ និយាយថា តាទិត្យហ្នឹងគាត់ជាប្រធានភូមិភាគ"]។ ឯកសារ D105/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាន់ ធី ឆ.២៧ KH 00794129 ["ខ្ញុំជួបតែពីរដងទេ។ ជួបលើកទីពីរគាត់ឲ្យខ្ញុំប្រជុំប្រជាជននៅឃុំកន្ទើ២ ដើម្បីទម្លាក់ តាប៉ែត ចេញពីតំណែងភូមិភាគពាយ័ព្យ ហើយតាទិត ឡើងជាលេខាវិញ"]។ ឯកសារ D1.3.27.5 Masato Matsushita និង

Stephen Heder សម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជាព្រំដែនកម្ពុជា-ថៃ ឆ្នាំ១៩៨០ KH 00324732 [សម្ភាសន៍លើកទី១៨៖ "នៅតំបន់១ ដែលជាផ្នែកមួយរបស់ស្តៅដែរ ដែលមានលេខាឈ្មោះ តា ទិត ដែលពីមុនធ្លាប់ជាលេខាស្រុកគីរីវង្ស ក្នុងភូមិភាគនិរតី។ សមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យដែលពីមុនមកត្រូវបានចាប់ខ្លួន រួមមាន រស់ ញ៉ឹម (ជាលេខា) តាគឹ (ជាអនុលេខា) និងខ្ពង (ជាសមាជិក)។ នៅក្នុងភូមិភាគពាយ័ព្យ នៅពេលនោះហាក់ដូចជា តាទិត មានតួនាទីជាលេខាភូមិភាគ ប៉ុន្តែយូរម្តង តាម៉ុកក៏បានមកធ្វើទស្សនកិច្ចផងដែរ"]។ ឯកសារ D123/2/1.1a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ គុប ស៊ីង KH 00957635 ["កម្មាភិបាលពីនេះទៅ គាត់ទៅដល់ពាយ័ព្យហ្នឹងធ្វើជាគណៈភាគណា ប៉ុន្តែអ៊ំ ទិត ហ្នឹងសព្វថ្ងៃគាត់នៅរស់ទេ ខ្ញុំរស់នៅជាមួយគាត់តាំងពីឆ្នាំ៧៩ណោះ"]។ ឯកសារ D219/34 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក (អ៊ីល) ហ្ស៊ីន ឆ.៤៣ ["តាម៉ុក បញ្ជាឲ្យសោម ដន ជាប្រធានមន្ទីរស្រុកត្រាំកក់ ធ្វើបញ្ជីឈ្មោះកម្មាភិបាលដែលត្រូវទៅគ្រប់គ្រងភូមិភាគពាយ័ព្យ។ ខ្ញុំបានឃើញបញ្ជីឈ្មោះនោះ ដែលមាន តាទិត្យ ទៅគ្រប់គ្រងខេត្តបាត់ដំបង និងតាចាយ និងយាយចែម ចេញទៅស្រុកព្រះនេត្រព្រះ"]។ សូមមើលផងដែរ ឯកសារ D118/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាន់ ធី ឆ.២៩-៣០ KH 00920171 ["តាទិត្យ គាត់មកចូលរួមប្រជុំនៅស្វាយបីដើមនេះ កាលនោះខ្ញុំមិនដែលស្គាល់គាត់ទេ ទើបតែពេលគាត់មកដល់កន្លែងប្រជុំទើបគេប្រាប់ថា គាត់ជាតាទិត។ តាទិត គាត់ជាគណៈភូមិភាគពាយ័ព្យ។ [...] គាត់និយាយថា គាត់មកពីភូមិភាគនិរតី ហើយប្រកាសថា "គាត់មកទីនេះដើម្បីជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ"។ ក្រៅពីនេះគាត់មិនបាននិយាយអ្វីផ្សេងទៀតទេ"]។ ឯកសារ D105/4 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីយ ក្រ៉ម ឆ.២០ KH 00780625 ["តាម៉ុក និង តា ទិត្យ គេហៅថាគណៈភូមិភាគគេអញ្ជើញមក"]។ ឯកសារ D118/75 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ីយ ក្រ៉ម ឆ២៥ KH 00934369 ["ខ្ញុំដឹងរឿងនេះដោយសារ តែពួកឈ្លប ក្ងន ចៅរបស់ សុខ ដែលជាអ្នកគ្រប់គ្រងគុកនៅវត្តធម្មយុត្តិ ប្រាប់ខ្ញុំថា តាទិត ដែលជាគណៈភាគមកប្រជុំ"]។ ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ជ៉ីម ឆ.៩១ KH 01329398 ["អ៊ីម៉ុក និង អ៊ំ ទិត្យ ថ្នាក់ភូមិភាគ"]។ ឯកសារ D1.3.11.53 បទសម្ភាសន៍ជាមួយ តេន ជ៉ីម KH 00217754 ["ជ៉ីម និយាយថា គណៈភូមិភាគពាយ័ព្យចុងក្រោយ មាន តាម៉ុក ទិត និងវ៉ន"]។ ឯកសារ D118/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជ៉ីម ចាន់ធ្ងើន ឆ.២៨ KH 00920186។ ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ីា ឆ.១០ KH 00960664 ["ស៖ លោកនិយាយថា តាទិត ជាដៃស្តាំរបស់ តាម៉ុក ដែលកាន់ភូមិភាគពាយ័ព្យ តើលោកចង់មានន័យថា តាទិត ក៏មានតួនាទីនៅភូមិភាគពាយ័ព្យដែរ ឬយ៉ាងណា? បាទ! តាទិត គាត់ក៏មានតួនាទីថ្នាក់ភូមិភាគដែរ"]។ ឯកសារ D219/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុប ស៊ីង ឆ.៧៨-៧៩ KH 01046467។ ឯកសារ D219/515 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ធ៉ន ឈួយ ឆ.៣០ KH 01149403 ["តាទិត្យ បន្តកាន់តំណែងជាគណៈភូមិភាគនេះ បានរយៈពេលប្រហែល២ ឬ៣ខែ។ [...] អ្នកកាន់កម្មវិធីបានណែនាំសមាសភាព តាទិត្យ ថាជាគណៈភូមិភាគ ឬក៏ជាគណៈតំបន់ក៏មិនដឹង"] ឆ.៤៧ KH 01149406 ["តា ប៉ែត ស្រាប់តែបាត់ខ្លួន ហើយ តាទិត្យ ក៏ត្រូវបានគេណែនាំឲ្យស្គាល់ថា ជាគណៈភូមិភាគ"] ឆ.៥៧ KH 01149407 ឯកសារ D219/268 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាំ ភន ឆ.៤៣, ៤៨ KH 01088841។ ឯកសារ D219/373 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាំ ភន ឆ.៨៩-៩០ KH 01110502។ ឯកសារ D219/34 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឯក (អ៊ីល) ហ្ស៊ីន ឆ.៤៣ KH 01032073 ["តាម៉ុក បញ្ជាឲ្យសោម ដន ប្រធានមន្ទីរស្រុកត្រាំកក់ ធ្វើបញ្ជីឈ្មោះកម្មាភិបាលដែលត្រូវទៅគ្រប់គ្រងនៅភូមិភាគពាយ័ព្យ។ ខ្ញុំបានឃើញបញ្ជីឈ្មោះនោះ ដែលមានតាទិត្យ ទៅគ្រប់គ្រងខេត្តបាត់ដំបង និងតាចាយ និងយាយចែម ចេញទៅស្រុកព្រះនេត្រព្រះ"]។

យ៉ាញ[82]។ តំណែងរបស់ **យ៉ាម ទិត្យ** ជាអនុលេខាភូមិភាគ ជាតំណែងមានអំណាចៈ ហែម មឿន ក្លួយ ប្រុសរបស់ តា ម៉ុក បាននិយាយថាៈ "តាម៉ុក បានប្រកាសប្រាប់យោធាថា បើអស់ពីអញ្ញទៅ តាទិត្យ ជាអ្នកទទួលខុសត្រូវភូមិភាគបន្ទាប់" ហើយ "នៅបាត់ដំបង តាទិត្យ ជាមនុស្សទីពីរ បន្ទាប់ពី តាម៉ុក។ តាទិត្យ ជាអ្នកជំនួសគាត់នៅក្នុងភូមិភាគពាយ៉ាញ ពេលគាត់អវត្តមាន"[83]។ ភ័ស្តុតាងបង្ហាញថា តាម៉ុក នៅបន្តធ្វើជាលេខាភូមិភាគនិរតី ក្រោយពេលគាត់ត្រូវបានតែងតាំងជាលេខាភូមិភាគពាយ៉ាញ ហើយក៏មានការទទួលខុសត្រូវ នៅភូមិភាគឧត្តរ ភូមិភាគកណ្តាល ភូមិភាគបូព៌ា និងភូមិភាគបស្ចិម[84]។ ការទទួលខុសត្រូវរបស់ តាម៉ុក នៅក្រៅភូមិភាគពាយ៉ាញ (រួមទាំង ជាសមាជិកគណៈអ

---

[82] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.៦០ KH 01008707 ["តាម៉ុក គាត់គឺជាលេខាភូមិភាគពាយ៉ាញ"]។ ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.២២-២៣ KH 01110176 ["តាម៉ុក គាត់គ្រប់គ្រងភូមិភាគទាំងមូល។ គាត់គ្រប់គ្រងខេត្តចំនួនបី ដែលមានដូចជាខេត្តពោធិ៍សាត់ បាត់ដំបង និងសៀមរាប។ ស៖ តើលោកដឹងព័ត៌មាននេះដោយរបៀបណា? ឆ.២៣៖ ខ្ញុំដឹងព័ត៌មាននេះ នៅពេលដែលខ្ញុំចូលរួមកិច្ចប្រជុំមួយដែលគេបានណែនាំ តាម៉ុក ឲ្យអ្នកចូលរួមទាំងអស់បានស្គាល់ថា គាត់គឺជាអ្នកគ្រប់គ្រងភូមិភាគ"]។ ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៧ KH 00960663 ["ស៖ ពេលដែលលោករត់ចូលព្រៃ តើលោកចាំថា នរណាជាគណៈភូមិភាគពាយ៉ាញ? ឆ.៧៖ តាម៉ុក គាត់មកគ្រប់គ្រងភូមិភាគទាំងអស់ ហើយដៃស្តាំរបស់ តាម៉ុក គឺតាទិត ហើយអនុរបស់ តាទិត ឈ្មោះតានីម"]។ ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.១៨, ៣៥, ៦០ KH 00967997, 00968000, 00968003 ["តាម៉ុក ជាប្រធានភូមិភាគទាំងអស់នៅប្រទេសកម្ពុជា។ តាម៉ុក ជារងរបស់ ប៉ុល ពត។ [...] ស៖ ម្សិលមិញលោកបាននិយាយថា តាញ៉ឹម ត្រូវគេយកទៅភ្នំពេញ។ តើអ្នកណាមកជំនួសតាញ៉ឹម? ឆ.៣៥៖ តាម៉ុក ជាអ្នកជំនួស តាញ៉ឹម។ តាម៉ុក គាត់កាន់ទូទាំងប្រទេស គាត់អាចបញ្ជាអ្នកណាក៏បាន។ [...] ឆ.៦០៖ នៅបាត់ដំបងគឺមានតែតាទិត ប៉ុណ្ណោះដែលធំជាងគេបន្ទាប់ពី តាម៉ុក ប្រសិនបើ តាម៉ុក មិននៅ គឺតាទិត ជាអ្នកទទួលខុសត្រូវភូមិភាគពាយ៉ាញ"]។

[83] ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.៦០-៦១ KH 00968003-04។ ឯកសារ D118/222 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.១៤ KH 00983235។

[84] ឯកសារ D118/79 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ធឹម ឆ.៩ KH 00934401 ["តាម៉ុក គាត់នៅធ្វើជាលេខាភូមិភាគនិរតីរហូតដល់ចប់របបខ្មែរក្រហម តែដោយសារតែនៅក្នុងឆ្នាំ១៩៧៨ សភាពការណ៍ជ្រួលច្របល់ តាម៉ុក ក៏ធ្វើជាលេខាភូមិភាគពាយ៉ាញ ភូមិភាគឧត្តរ និងភូមិភាគកណ្តាល ផងដែរ"]។ ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ធឹម ឆ.៥៦ KH 00997030។ ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.៤៧ KH 009680001 ["សាក្សីនេះគឺជាក្លួយរបស់ តាម៉ុក និងធ្លាប់បានធ្វើដំណើរច្រើនដងជាមួយតាម៉ុក: ស៖ បន្ទាប់ពីតាម៉ុក មកដល់បាត់ដំបង តើតាម៉ុក នៅតែទទួលខុសត្រូវភូមិភាគនិរតីឬក៏អត់? ឆ.៤៧៖ បាទ គាត់នៅតែទទួលខុសត្រូវភូមិភាគនិរតី គឺទាំងភូមិភាគពាយ៉ាញ និងភូមិភាគនិរតី"]។ ឯកសារ D118/222 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.១០ KH 00983235។ ឯកសារ D118/103.3 កាំង ហ្គេចអ៊ាវ ហៅ ឌុច សេចក្តីសន្និដ្ឋានដែលសរសេរចុងក្រោយចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ជើងអក្សរលេខ ២៤ KH 00404797 ["គណៈអចិន្ត្រៃយ៍ គឺសំដៅលេខាភូមិភាគ។ ដោយភូមិភាគវិវត្ត សូមលំអិតដូចតទៅ៖ [...] ភូមិភាគនិរតីថ្មី ៖ ម៉ុក-បស្ចិម៖ ស៊ី (បន្ទាប់ពីចាប់ ស៊ី នៅខែមេសា ឆ្នាំ១៩៧៨ ម៉ុកឡើងជាលេខានិរតីថ្មីផង និងបស្ចិមផង)។ ពាយ៉ាញ៖ ញ៉ឹម (ត្រូវ

ចិន្ត្រៃយ៍ ប.ក.ក ប្រធានភូមិភាគនិរតី និងជាមេដឹកនាំកម្លាំងវាយជាមួយវៀតណាម និងធ្វើការបោសសម្អាតនៅផ្នែកសេសសល់នៃប្រទេស) អាចត្រូវបានតម្រូវឲ្យគាត់ធ្វើដំណើរជាញឹកញាប់។ អវត្តមានជាចាំបាច់របស់ តាម៉ុក មានន័យថា តំណែងរបស់ **យ៉ីម ទិត្យ** ជាអនុលេខា តម្រូវឲ្យគាត់ធ្វើជាលេខាភូមិភាគស្ដីទី ជារឿយៗ។

46. សាក្សីជាច្រើនក៏បានបញ្ជាក់ថា **យ៉ីម ទិត្យ** ជាលេខាតំបន់ ២[85] តំបន់ ៣[86] និងតំបន់ ៤[87]។ គាត់ក៏ត្រូវបានគេស្គាល់ថាជាសមាជិកគណៈតំបន់ ៣[88]។ ទោះជាគាត់កាន់តំណែងថ្នាក់តំបន់ជាផ្លូវការ

ចាប់ខ្លួនអំឡុងខែឧសភា ១៩៧៨ ម៉ុក ឡើងជាលេខាពាយ័ព្យមួយជាន់ទៀត) ឧត្តរថ្មី៖ សៃ (បន្ទាប់ពីចាប់ សៃ នៅថ្ងៃ ១១.១០.៧៨ ម៉ុក ជាលេខាបស្ចិម ពាយ័ព្យ ឧត្តរថ្មី) ភូមិភាគកណ្ដាល៖ ពក។

[85] ឯកសារ D219/684 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿន រ៉ុន ឆ.១៣, ២០ KH 01203936 ["ឮគេថា គណៈតំបន់។ មេកងជាអ្នកប្រាប់ថាជាគណៈតំបន់។ [...] ខ្ញុំឮមេកងគេថាគណៈតំបន់២ ខ្ញុំក៏ថាគណៈតំបន់២ទៅ"]។

[86] ឯកសារ D219/294 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ឆ.៤២-៤៣ KH 01095241-42 ["ឆ.៤២៖ យ៉ីម ទិត្យ គ្រប់គ្រងតំបន់៣។ [...] ស៖ តើលោកដឹងថា យ៉ីម ទិត ហ្នឹងគាត់ជាគណៈតំបន់ ៣ហ្នឹង ដោយសារតំណែងរបស់លោកជាគណៈស្រុកឬ? ឆ.៤៣៖ បាទ"]។ ឯកសារ D219/900.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជ្ង យ៉ន KH 00730919-90 ["មកនៅបាត់ដំបងយើងនេះ គាត់ជាគណៈតំបន់។ [...] តាទិតដូចនៅតំបន់ ៣"]។ សូមមើលឯកសារ D219/294 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី មូល អេង ឆ.១១០ KH 01095252 ["ស៖ នៅក្នុងកិច្ចបប្រជុំហ្នឹង តើគេប្រកាសថា យ៉ីម ទិត ហ្នឹងជាគណៈតំបន់ ៣ ឬយ៉ាងណាដែរ? ឆ.១១០៖ បន្ទាប់ពីដេកគិតឡើងវិញទៅ ខ្ញុំនៅមិនច្បាស់ថា តាទិត ត្រូវបានគេតែងតាំងឲ្យគ្រប់គ្រងតំបន់ ៣ ឬ តំបន់២ទេ។ តែខ្ញុំចាំច្បាស់ថា ស្រុកបាវិលត្រូវបានកាត់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ យ៉ីម ទិត"]។ *សូមមើល* ឯកសារ D118/64 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ប៉ុល សឹន KH 00920176 ["ឆ.៤៖ កាលណោះខ្ញុំធ្វើជាសេនាជនឃុំក្រពើ ស្រុកសំពៅលូន ក្នុងតំបន់ ៣"]។ ឆ.២១-២២ KH 00920178 ["ស៖ តើលោកដែលឮឈ្មោះតាទិត ដែរឬទេ? ឆ.២១៖ ខ្ញុំគ្រាន់តែឮឈ្មោះគាត់ តែខ្ញុំមិនដែលបានជួប ឬក៏ឃើញគាត់ទេ ហើយខ្ញុំមិនដឹងថា គាត់ធ្វើអ្វីដែរ។ ស៖ តើអ្នកណាជាអ្នកនិយាយប្រាប់លោកពីឈ្មោះតាទិត? ឆ.២២៖ កាលណោះខ្ញុំឮពីតារ៉ាក ជាមេឃុំគាត់និយាយ តែខ្ញុំមិនដឹងថា គាត់មានតួនាទីអ្វីទេ"]។ ឯកសារ D119/65 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទុំ ស្ងឿន ឆ.២២ង KH 00953950 ឯកសារ D219/627 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង អេង ឆ.១២ KH 01184313។

[87] ឯកសារ D105/8 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហាន់ ធី ឆ.៧ KH 00799427 ["ឆ.៧៖ តាទិត កាលណោះគឺគាត់នៅតំបន់ ៤"]។ ឯកសារ D118/63 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ហាន់ ធី ឆ.៣៤-៣៥ KH 00920171 ឯកសារ D118/96 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡុង អេង ឆ.២៩ KH 00947291 ["ឆ.២៩៖ កាលណោះតា ទិត ជាប្រធានតំបន់"]។ ឯកសារ D219/627 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆ.៤ KH 01184312 ["ប៊ីងប្រីនៅក្នុងស្រុកដូនទាវ"]។ ឯកសារ D219/884 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឡូច អេង ឆ.៤-ឆ.៨ KH 01362501-02។

[88] ឯកសារ D219/928 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ញ៉ែម ប៊ាន ឆ.៨ង KH 01394980 ["ខ្ញុំមិនស្គាល់មន្ទីរតំបន់របស់តាទិត្យ ទេ ប៉ុន្តែខ្ញុំឮថា គាត់ជាគណៈតំបន់ ៣"]។ ឯកសារ D118/85 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឆ.២៧, ២៩ KH 00945407។

ក្រៅតំបន់ ១ ឬអត់ក็ដោយ ក็การយល់ឃើញรบส่สาក្ษีផ្សេងទៀតថาคาต่ជาលេขาตำบล่ทั้งนោះ បង្ហាញអំពីภาพลเจตเจ้าหน้าที่ขอรบส่คาต่ និงสาระสำคัญของตูนาทีรบส่คาต่ชาอนุลเขาภูมิภาคพายัพ។

47. ដูจกรณีตำแหน่งรบส่คาต่ในภูมิภาคนิรตีแล้ว ยืงมีการลำบากในการกำหนดกาลบริเจ็ทแล้ว **ยืม ทิฤ** กาน่ตำแหน่งนีมูยๆ ในภูมิภาคพายัพ។ ภัสุตางขอระบุว่า ตาม็ก ได้ตั้ง **ยืม ทิฤ** ชาลเขาตำบล่ ๑ ในช่วงเดือนกุมภา ปี๑๙๗๘[89] ประเทศเขมรชาบ่ของ ตาปัต อดีตลเขาตำบล่ ๑ และ รส่ ญืม ลเขาภูมิพายัพ ดังนั้น รส่ ญืม ถูกกล่าวหาว่ามี

[89] เอกสาร D219/430 กำหนดเหตุผลการสอบสวนพยาน ญืง ปัน ส.๑๑๗ KH 01122418 ["ส: ท่านได้กล่าวว่าวันนี้ ตาทิฤ มาแทนที่ ตาปัต ในช่วงเดือนกุมภา ปี๑๙๗๘ ท่านรู้ว่าใครส่งตาปัตมาแทนที่? ส.๑๗๗: ผู้ที่ส่งมาคือตาม็ก ตา ม็ก อยู่ในตำบล่ ๑ ในเวลานั้น ตาทิฤ มาทำหน้าที่แทนตำบล่"]។ เอกสาร D219/368 กำหนดเหตุผลการสอบสวนพยาน ญืง ปัน ส.๓๙-๔๐ KH 01110179 ["ส.๓๙: ชื่อสถานที่ คือตั้งอยู่ในหมู่บ้านจีงมานชัย ตำบลปาณ์ ។ วาคือสถานที่ที่ตั้งกองบัญชาการที่เขาตั้งอยู่ ซึ่งเป็นที่ตั้งบ้านของ ตา ฮอง ทาว หรือ ตาปัต ด้วยเช่นกัน ។ [...] ตาปัต ถูกเนรเทศออกจากตำแหน่งรบส่คาต่ และแทนที่ด้วย ตาทิฤ ។ ส: เมื่อใดที่ ตาทิฤ แทนที่ตำแหน่ง ตาปัต เมื่อใด? ส.๔๐: ตาทิฤ แทนที่ตำแหน่ง ตาปัต ในเดือนกุมภา หรือเดือนมีนา ปี๑๙๗๗"]។ เอกสาร D219/430 กำหนดเหตุผลการสอบสวนพยาน ญืง ปัน ส.๙๙ KH 01122414 ["ส: [...] ท่านบอกเราว่าวาเกิดขึ้นก่อนหรือไม่ ในเดือนกุมภา ปี๑๙๗๘ ท่านสามารถบอกเราได้ไหมว่าเป็นปีที่ถูกต้องหรือไม่? ส.๙๙: ปี๑๙๗๘"]។

ទំនាក់ទំនងជាមួយវៀតណាម[90]។ (រស់ ញ៉ឹម ត្រូវបានចាប់ខ្លួន ប្រហែលនៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៩ ហើយត្រូវបានដាក់គុក នៅមន្ទីរ ស-២១[91])។

ខ. តំណែងជាមេដឹកនាំតាមព្រឹត្តន័យ មុនពេលតែងតាំងជាផ្លូវការ

48. មុនពេលត្រូវបានតែងតាំងជាផ្លូវការជាលេខាតំបន់ ១ និងជាអនុលេខាភូមិភាគពាយ័ព្យ **យ៉ឹម ទិត្យ** គឺជាមេដឹកនាំតាមព្រឹត្តន័យដ៏មានឥទ្ធិពល នៅភូមិភាគពាយ័ព្យ។ ក្នុងន័យនេះ **យ៉ឹម ទិត្យ** ស្រដៀងនឹង តាម៉ុក ជាអ្នកឧបត្ថម្ភគាំពារ គឺទោះបីជា តាម៉ុក កំពុងដឹកនាំការកាន់កាប់ភូមិភាគពាយ័ព្យដោយកម្មាភិបាលភូមិភាគនិរតីក៏ដោយ ក៏គាត់មិនមានតំណែងផ្លូវការ នៅភូមិភាគពាយ័ព្យឡើយ រហូតទាល់តែ រស់ ញ៉ឹម ត្រូវបានចាប់ខ្លួន ទើបតាម៉ុក ក្លាយជាលេខាភូមិភាគពាយ័ព្យ[92]។ ស្រដៀងគ្នានេះ

---

[90] ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ាន ឆ.៣៥-៣៧ KH 00960667 ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ែម មឿន ឆ.១៦-១៩ KH 00967997។ ឯកសារ D118/222 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ែម មឿន ឆ.១១ KH 00983234។ ឯកសារ D34.1.9 ប្រតិចារឹកបទសម្ភាសន៍ ហេង ទាវ ហៅ តាប៉ែតដោយ Steve Heder EN 01181115។ ឯកសារ D219/825.1.2 ក.ស.ច.ស-បញ្ជីឈ្មោះអ្នកទោសនៅ ស-២១ លេខរៀង ១៤២៩៨ EN 01222915 [មូល អ៊ុន ហៅ សំបាត់ ហៅ ញ៉ឹម លេខាភូមិភាគពាយ័ព្យ]។ កម្មាភិបាលល្បីៗនៃតំបន់ ១ មួយចំនួន រួមមាន តាសាយ តាណុប និងតាស្ងៃ ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលក្រោមការគ្រប់គ្រងរបស់ យ៉ឹម ទិត្យ និងតានីម។ ឯកសារ D118/271 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ាន ឆ.២៩ KH 00998558 ["នីរសារ និងកងការពារឲ្យ ហេង ទាវ ហៅ តាប៉ែត៖ "បងជីដូនមួយខ្ញុំឈ្មោះ ឆាំ លុយ ដែលរស់នៅសព្វថ្ងៃប្រាប់ថា តាសាយ តាណុប និងតាស្ងៃ សុទ្ធតែជាអ្នកពាយ័ព្យ ហើយពួកគេត្រូវបានចាប់ខ្លួនដោយពួកនិរតីដឹកនាំដោយ តាទិត និង តានីម និងបានបញ្ជូនមកទួលស្ពែងទាំងអស់"]។ ឯកសារ D219/233 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ាន ឆ.១៩ KH 00998556។ ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ាន ឆ.៣៥ KH 00960667 ["គេចាប់គាត់យកទៅដាក់នៅទួលស្ពែង ដោយចោទថា គាត់ក្បត់ និងជាប់ខ្សែយួន"]។

[91] ឯកសារ D6.1.1105 *របបប៉ុល ពត* ដោយប្រវត្តិវិទូ ប៉ែន ឃៀនិន EN 00678487, 710 ["រស់ ញ៉ឹម លេខាភូមិភាគពាយ័ព្យ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៨ ប្រាំបីថ្ងៃក្រោយ សោ ភ័ម ធ្វើអត្តឃាត។ គាត់ត្រូវបានប្រាប់ថា គាត់ត្រូវបានបញ្ជូនទៅភ្នំពេញ។ ម៉ុក ជំនួសគាត់ជាលេខាភូមិភាគ"]។ ឯកសារ D1.3.15.2 Karl D. Jackson, ed., ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨៖ *ការណាត់ជួបជាមួយការស្លាប់* "ការរៀបចំអំណាច" និពន្ធដោយ Timothy Carney EN 00105154។ ឯកសារ D1.3.18.2 ចម្លើយសារភាពនៅ ស-២១ របស់ មូល សម្ត្ត ហៅ រស់ ញ៉ឹម EN 00780859 [ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨]
។

[92] ឯកសារ D6.1.1105 Ben Kiernan *របបប៉ុល ពត* EN 00678710 ["រស់ ញ៉ឹម លេខាភូមិភាគពាយ័ព្យ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៧៨ ប្រាំបីថ្ងៃក្រោយ សោ ភ័ម ធ្វើអត្តឃាត។ គាត់ត្រូវបានប្រាប់ថា គាត់ត្រូវបានបញ្ជូនទៅភ្នំពេញ។ ម៉ុក ជំនួសគាត់ជាលេខាភូមិភាគ"]។ ឯកសារ D118/103.3 កាំង ហ្គេចអ៊ាវ ហៅ ឌុច សេចក្តីសន្និដ្ឋានដែលសរសេរចុងក្រោយចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ ជើងអក្សរលេខ២៤ KH 00404797 ["គណៈអចិន្ត្រៃយ៍ គឺសំដៅលេខាភូមិភាគ។ ដោយភូមិភាគវិវត្ត

ដែរ សូម្បីតែមុនពេលតែងតាំងជាផ្លូវការជាលេខាតំបន់ ១ និងជាអនុលេខាភូមិភាគពាយ័ព្យ **យ៉ឹម ទិត្យ** ត្រូវបានគេណែនាំជាសាធារណៈថាជាអ្នក "មកជួយដឹកនាំតំបន់ ១"[93]។

49. ភ័ស្តុតាងដំបូងបង្ហាញអំពីការអនុវត្តតួនាទីរបស់ **យ៉ឹម ទិត្យ** ជាមេដឹកនាំតាមព្រឹត្តន័យដ៏សំខាន់ នៅភូមិភាគពាយ័ព្យ គឺពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ពេលគាត់ចូលរួមក្នុងតួនាទីដ៏លេចធ្លោនៅក្នុងកិច្ចប្រជុំមួយ នៅទំនប់កង្ហត[94]។ ចាប់ពីពេលនោះមក **យ៉ឹម ទិត្យ** បានចូលរួម និងរួមចំណែកក្នុងផែនការឧក្រិដ្ឋរួម នៅតំបន់ភូមិភាគពាយ័ព្យ តាមវិធីផ្សេងៗ រួមទាំង តាមរយៈការដឹកនាំកិច្ចប្រជុំ ការត្រួតពិនិត្យការដ្ឋាន និងការបញ្ជាឲ្យសម្លាប់។

២. ការចូលរួមចំណែករបស់ យ៉ឹម ទិត្យ ក្នុងផែនការឧក្រិដ្ឋរួម នៅភូមិភាគពាយ័ព្យ

50. ការចូលរួមចំណែករបស់ **យ៉ឹម ទិត្យ** ក្នុងផែនការឧក្រិដ្ឋរួម នៅភូមិភាគពាយ័ព្យ បានឆ្លុះបញ្ចាំងអំពីការចូលរួមចំណែកពីមុនរបស់គាត់ នៅភូមិភាគនិរតី។

ក. ការចូលរួមចំណែករបស់ យ៉ឹម ទិត្យ ក្នុងការអនុវត្តគោលនយោបាយស្តីពីខ្មាំងរបស់ ប.ក.ក

i. ក្នុងកិច្ចប្រជុំធំៗ យ៉ឹម ទិត្យ ទាមទារឲ្យកម្ទេចខ្មាំង។ គាត់ក៏បានណែនាំអ្នកនៅក្រោមបង្គាប់ឲ្យតាមដានខ្មាំងសង្ស័យ និងរាយការណ៍ពីខ្មាំង តាមរយៈឋានានុក្រម ប.ក.ក

51. សាក្សីយ៉ាងហោចណាស់ ៨ នាក់ បានផ្តល់ភ័ស្តុតាងអំពីការចូលរួម និងការរួមចំណែករបស់ **យ៉ឹម ទិត្យ** ក្នុងគោលនយោបាយស្តីពីខ្មាំង ក្នុងកិច្ចប្រជុំនៅភូមិភាគពាយ័ព្យ។ គាត់បានធ្វើរបៀបនេះ តាមរយៈ (១) ការកំណត់ប្រភេទខ្មាំង (២) ការបញ្ជាឲ្យអ្នកនៅក្រោមបង្គាប់រាយការណ៍ពីខ្មាំង

សូមលំអិតដូចតទៅ៖ [...] ភូមិភាគនិរតីថ្មី៖ ម៉ុក បស្ចិម៖ ស៊ី (បន្ទាប់ពីចាប់ ស៊ី នៅខែមេសា ឆ្នាំ១៩៧៨ ម៉ុក ឡើងជាលេខានិរតីថ្មីផង និងបស្ចិមផង)។ ពាយ័ព្យ៖ ញ៉ឹម (ត្រូវចាប់ខ្លួនអំឡុងខែឧសភា ១៩៧៨ ម៉ុក ឡើងជាលេខាពាយ័ព្យមួយជាន់ទៀត)-ឧត្តរថ្មី៖ សែ (បន្ទាប់ពីចាប់ សែ ១១.១០.៧៨ ម៉ុក ជាលេខាបស្ចិម ពាយ័ព្យ ឧត្តរថ្មី)-ភូមិភាគកណ្តាល៖ ពក។

[93] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.ព KH 01040093 ["តាប៉ែត បានប្រកាសនៅក្នុងអង្គប្រជុំថា តាទិត្យ មកពីភូមិភាគនិរតីមកជួយដឹកនាំពួកយើងនៅក្នុងតំបន់១។ កាលនោះ គឺមានការប្រជុំយ៉ាងធំដែលចូលរួមដោយប្រជាជន ប្រធានភូមិ ប្រធានឃុំ ស្រុក ហើយមនុស្សទាំងអស់ប្រហែលជាង ៧០០ ទៅ៨០០នាក់។ ការប្រជុំនោះ គឺធ្វើឡើងនៅទីឯកន្លែងសាងសង់ទំបន់កង្ហត"]។

[94] *សូមមើល* ឯកសារ III.D.3.a. តួនាទី សកម្មភាព និងការប្រព្រឹត្ត ការចូលរួមរបស់ យ៉ឹម ទិត្យ នៅក្នុងផែនការឧក្រិដ្ឋកម្មរួមនៅក្នុងភូមិភាគពាយ័ព្យ សកម្មភាព និងការប្រព្រឹត្តផ្សេងទៀតរបស់ យ៉ឹម ទិត្យនៅក្នុងភូមិភាគពាយ័ព្យ ការបង្ហាញវត្តមានលើកដំបូងរបស់ យ៉ឹម ទិត្យ នៅភូមិភាគពាយ័ព្យ។

សង្ស័យតាមឋានានុក្រម ប.ក.ក (៣) ការប្រាប់កម្ទាភិបាល និងប្រជាជនសាមញ្ញថា ពួកគេត្រូវបានតាមដានចំពោះសកម្មភាពខ្មាំងសង្ស័យ (៤) ការនិយាយយ៉ាងច្បាស់ថា ខ្មាំងត្រូវតែ "កម្ទេច" ឬសម្លាប់ និង (៥) ការប្រកាសជាសាធារណៈ ពេលធ្វើការចាប់ខ្លួន និងសម្លាប់។

<u>ណុប ងឹម</u>

52. ណុប ងឹម អ្នកនៅក្រោមបង្គាប់របស់ **យ៉ីម ទិត្យ**[95] បាននឹកឃើញថា ក្នុងកិច្ចប្រជុំជាច្រើន "តាម៉ុក និងតាទិត្យ [...] បានណែនាំយើងថា យើងត្រូវកម្ទេចខ្មាំងណាដែលប្រឆាំងនឹងអង្គការ"[96]។ គាត់

[95] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៣១, ៤៤ KH 01008701, 01008704 ["នៅស្រុកសំឡូត ខ្ញុំមាននាទីជាអនុស្រុក។ [...] ជាទូទៅរបបនៃការរាយការណ៍ គឺធ្វើពីសហការណ៍ទៅឃុំ ពីឃុំទៅស្រុក ពីស្រុកទៅតំបន់ ពីតំបន់ទៅភាគ។ ហើយសេចក្តីរាយការណ៍ គឺត្រូវធ្វើតាមរបៀបនេះ។ នេះ គឺសម្រាប់ការរាយការណ៍ជាលាយលក្ខណ៍អក្សរ។ ការរាយការណ៍ផ្ទាល់មាត់ត្រូវបានធ្វើតាមរយៈអង្គប្រជុំ នីរសារជាអ្នកបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរ។ សេចក្តីណែនាំដែលសរសេរដោយដៃ គឺស្រុកបានទទួលពីថ្នាក់តំបន់ ហើយមិនមែនពីថ្នាក់ភូមិភាគទេ។ សេចក្តីណែនាំ ឬរបាយការណ៍ដែលស្រុកទទួលបានពីថ្នាក់តំបន់នៅពេលនោះ គឺមានឈ្មោះ អ៊ំទិត្យ ដែលសរសេរដោយដៃ"]។ ឯកសារ D219/298 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៤, ៦ KH 01095985 ["ខ្ញុំបានគេចាត់តាំងឲ្យធ្វើជាអនុលេខាស្រុកសំឡូតបាន៧ខែក្នុងឆ្នាំ១៩៧៨ បន្ទាប់មកយើងក៏រត់គេចពីយួន ពេលដែលរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។ [...] ស្រុកសំឡូតស្ថិតនៅតំបន់១"]។ ឯកសារ D123/2/2.17a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ងឹម KH 00733838 ["តាទិត្យ គាត់ទទួលខុសត្រូវនៅកន្លែងស្រុកសំឡូតនឹងហើយ។ ស៖ ទទួលខុសត្រូវស្រុកសំឡូតម៉េច? ឆ៖ ស្រុកសំឡូតគាត់នៅនឹង គាត់ឧស្សាហ៍ទៅស្រុកសំឡូតដែរនឹង។ ស៖ ឧស្សាហ៍ទៅ? ឆ៖ ចា! ស៖ ចឹងគាត់ធំជាងគេ គាត់មើលពីលើគេទៀត? ឆ៖ ចា! ស៖ ចឹងមានតែគាត់តំបន់? ឆ៖ អឺ! ចឹងបានថា។

[96] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៥៦ KH 01008706 ["តាម៉ុក និងតាទិត្យ បាននិយាយអំពីស្ថានភាពខ្មាំង។ ពួកគាត់ណែនាំយើងថា យើងត្រូវកម្ទេចខ្មាំងណាដែលប្រឆាំងនឹងអង្គការ។ [...] តាមខ្ញុំយល់ឃ្លាដែលថា "ខ្មាំងណាដែលក្បត់នឹងយើង យើងត្រូវកម្ទេច មានន័យថា ខ្មាំងនោះនឹងត្រូវបានសម្លាប់"]។ ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៩៩ KH 01329399 [*បញ្ជាក់ឡើងវិញ* ឆ.៥៦ ក្នុងឯកសារ D118/285]។ *សូមមើលផងដែរ* ឯកសារ D219/974.1.2 ណុប ងឹម ប្រតិចារឹក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10:56:16 ["តាម៉ុក និងទិត្យ ហ្នឹង គាត់ថា ណែនាំដូចខាងលើអ៊ីចឹង។ ណែនាំខ្មាំង វាយកម្ទេចខ្មាំង បើមានខ្មាំងណា ប្រហែលជាក្បត់អ៊ីមកនៅជាមួយយើងអ៊ីចឹងទៅ សម្លាប់យើងចោលអស់ទៅ។ ហ្នឹងអ៊ីចឹង។ ហ្នឹងសភាពថា បើខ្មាំងចូលក្នុងអង្គភាពយើង សម្លាប់យើងចោលអស់ក៏មិនដឹង យើងងាប់បាត់អស់ហើយ។ គាត់ឲ្យតាមដានអ៊ីចឹងណា"]។

បាននិយាយថា គាត់យល់ថាការប្រើពាក្យ "ក"ម្ទេច" មានន័យថា "ខ្ទាំងនោះនឹងត្រូវបានសម្លាប់"[97] ហើយ "ខ្ញុំត្រូវគេប្រាប់ឲ្យឃ្លាំមើល និងតាមដានខ្ទាំង"[98]។

53. ណុប ធឹម ក៏បានចងចាំផងដែរថា គាត់ត្រូវគេណែនាំ "ឲ្យប្រុងប្រយ័ត្នឲ្យមែនទែនអំពីខ្ទាំង ដែលអាចនឹងចូលមកណាក់ខ្លួន នៅក្នុងជួររបស់យើង" ហើយ "តាម៉ុក និងតាទិត្យ បានប្រាប់យើងថា បើយើងឃើញមានពួកនេះ យើងត្រូវព្រមានប្រាប់គេឲ្យកែប្រែ បើពុំដូច្នេះទេ យើងនឹងចាប់ពួកគេយកទៅសម្លាប់"[99]។ កម្មាភិបាលចូលរួមប្រជុំយល់ថា ពួកគេត្រូវរាយការណ៍អំពីខ្ទាំងសង្ស័យ តាមឋានានុក្រម ប.ក.ក។ ណុប ធឹម បាននិយាយ៖ "បើយើងមិនរាយការណ៍អំពីបញ្ហាសន្តិសុខនេះទៅឲ្យ [តាម៉ុក និង **យ៉ឹម ទិត្យ**] ទេ យើងនឹងមានបញ្ហាចំពោះខ្លួនយើងពុំខាន"[100]។

54. តាម៉ុក និង **យ៉ឹម ទិត្យ** បានចេញសេចក្តីណែនាំទាំងនេះ ដល់កម្មាភិបាលជាច្រើនក្រុមធំៗ។ ណុប ធឹម បានឲ្យដឹងថា កិច្ចប្រជុំខ្លះត្រូវបានចូលរួមដោយ "លេខា គណៈស្រុក និងឃុំរាប់រយនាក់"[101] ឯកិច្ចប្រជុំខ្លះទៀតត្រូវបានចូលរួមដោយ "អ្នកតំណាងមកពីស្រុក និងតំបន់ដទៃទៀត ប្រហែល ១០០ នាក់"[102]។ កិច្ចប្រជុំខ្លះធ្វើឡើងនៅផ្ទះតាម៉ុក[103]។ ព្រាប កប ប្តីរបស់ ណុប ធឹម បានបញ្ជាក់ថាប្រពន្ធគាត់បានចូលរួមប្រជុំជាទៀងទាត់ ជាមួយ **យ៉ឹម ទិត្យ**[104]។

55. តាមរយៈភ័ស្តុតាងចេញពី ណុប ធឹម ច្បាស់ណាស់ថា ខ្ទាំង ដែល **យ៉ឹម ទិត្យ** និងតាម៉ុក បានសំដៅដល់ គឺជាខ្ទាំងខាងក្នុង ជាប្រជាជនកម្ពុជាដែលគេយល់ថាមិនស្មោះត្រង់នឹង ប.ក.ក ជាជាងកម្លាំងវៀតណាមលុកលុយ។ ប្រការនេះអនុវត្តតាមវិធីសាស្ត្រដែល តាម៉ុក និង យ៉ឹម ទិត្យ បានកំណត់

---

[97] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.៥៦ KH 01008706 [តាមខ្ញុំយល់ឃ្លាដែលថា "ខ្ទាំងណាដែលក្បត់នឹងយើង យើងត្រូវកម្ទេច មានន័យថា ខ្ទាំងនោះនឹងត្រូវបានសម្លាប់"]។

[98] ឯកសារ D219/974.1.2 ណុប ធឹម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10:56:16 ។

[99] ឯកសារ D219/298 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.១៦ KH 01095988។

[100] ឯកសារ D219/298 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.១៩ KH 01095989។

[101] ឯកសារ D219/298 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.១៤ KH 01095987 ។

[102] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.៥៥ KH 01008706 ។

[103] ឯកសារ D219/298 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.១៤ KH 01095987 ។ នៅក្នុងការស្តាប់ចម្លើយលើកក្រោយ ណុប ធឹម បានអះអាងថា គាត់បានឃើញតាម៉ុក តែនៅក្នុងកិច្ចប្រជុំមួយប៉ុណ្ណោះ។ *សូមមើល* ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.១២១-១២២ KH 01329401 ។

[104] ឯកសារ D219/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ឆ.៦១-៦៣ KH 01037146, 47 ។

ចំពោះការប្រព្រឹត្តទៅលើខ្មាំងទាំងនេះ៖ "[...] ព្រមានប្រាប់ពួកគេឲ្យកែប្រែ" បន្ទាប់មក បើពួកគេមិនកែប្រែ "ចាប់ពួកគេយកទៅសម្លាប់"[105]។ ណុប ងឹម បានចាត់ទុកខ្មាំង ដែលតាម៉ុក និង **យ៉ីម ទិត្យ** បាននិយាយ ជា "ខ្មាំងបង្កប់"[106]។ ជាចុងក្រោយ ណុប ងឹម បានបង្ហាញថា ពេលគេណែនាំឲ្យរាយការណ៍អំពី "បញ្ហាសន្តិសុខ" គាត់បានរាយការណ៍អំពីអ្នកដែល "ខុសសីលធម៌" និង "បញ្ហាសន្តិសុខផ្សេងៗទៀត ដូចជាការណ្ហោះប្រកែកវ៉ៃគ្នា ហើយនិងការលួចជាដើម"[107] ដែលនេះជាការនិយាយសំដៅយ៉ាងច្បាស់ដល់ប្រជាជនសាមញ្ញ ក្រោមការគ្រប់គ្រងរបស់គាត់។

<u>**វ៉ី ផាន់**</u>

56. **វ៉ី ផាន់** អនុប្រធានភូមិ ក្នុងតំបន់ ១ ចាំថា គាត់បានចូលរួមប្រជុំនៅចំនប់កង្ហត ដែលមានមនុស្សពី ៧០០ ទៅ ៨០០ នាក់ រួមមានប្រជាជនសាមញ្ញជាច្រើននាក់ ក៏ដូចជាមេភូមិ មេឃុំ និងមេស្រុក[108]។ **យ៉ីម ទិត្យ** ត្រូវគេណែនាំនៅក្នុងកិច្ចប្រជុំនោះថាជាអ្នក "មកពីភូមិភាគនិរតី" និង "មកជួយដឹកនាំតំបន់ ១"[109]។ បន្ទាប់ពីការណែនាំរួច **យ៉ីម ទិត្យ**៖

> និយាយអំពីរឿងខ្មាំងផ្ទៃក្នុង ដែលាក់ខ្លួនស៊ីរួងផ្ទៃក្នុងរបស់ចលនាយើង ហើយក៏មានពួក សេ អ៊ីអា ការហ្សេបេយ្ហន ណាក់ខ្លួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែឃ្លាំមើលពួកទាំងនេះ ហើយបើយើងទទួលបានព័ត៌មានទាក់ទងនឹងសកម្មភាពពួកទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង[110]។

57. ក្នុងកិច្ចប្រជុំដដែលនោះ **យ៉ីម ទិត្យ** បានស្តាប់យ៉ាងស្ងៀមស្ងាត់ និងកត់ត្រា ពេលមេឃុំម្នាក់បានរាយការណ៍ថា អ្នកដែលគេចាប់បានពីបទខុសសីលធម៌ ឬមិនស្មោះត្រង់ នៅក្នុងឃុំរបស់គាត់ ត្រូវ

---

[105] ឯកសារ D219/298 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.១៦ KH 01095988។

[106] ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.១៣០ KH 01329402។

[107] ឯកសារ D219/298 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.២២, ៣៥ KH 01095989, 93។

[108] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.៣, ៩, KH 01040093, 96។

[109] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.៣ KH 01040093 ["តាប៉ែត បានប្រកាសនៅក្នុងអង្គប្រជុំថា តាទិត្យ មកពីភូមិភាគនិរតីមកជួយដឹកនាំពួកយើងនៅក្នុងតំបន់១"]។

[110] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.៥ KH 01040094។

សម្លាប់ចោល[111]។ ដូច្នេះ **យ៉ីម ទិញ្ញ** មិនបានបន្សល់ទុកនូវការសង្ស័យទេថា គោលនយោបាយដែលគាត់បានគាំទ្រ រួមបញ្ចូលទាំងការសម្លាប់ក្រៅច្បាប់។

58. ទោះបីជា វ៉ី ផាន់ ចាំថាកាលបរិច្ឆេទនៃកិច្ចប្រជុំនោះ គឺខែវិច្ឆិកា ឆ្នាំ១៩៧៨[112] ក៏ដោយ ក៏មានកត្តាជាច្រើនរ៉ាតតែទំនងទៀតថា កិច្ចប្រជុំនោះធ្វើឡើង ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧។ ទីមួយ វ៉ី ផាន់ បានបញ្ជាក់ថា តាប៉ែត មានវត្តមាននៅក្នុងកិច្ចប្រជុំ[113] ហើយ តាប៉ែត ត្រូវបានចាប់ខ្លួនរួចទៅហើយ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨[114]។ ទីពីរ វ៉ី ផាន់ បានផ្សារភ្ជាប់កិច្ចប្រជុំជាមួយនឹងការមកដល់របស់ពួកភូមិភាគនិរតី និងបាននិយាយថា កិច្ចប្រជុំធ្វើឡើង "ប្រហែលមួយឆ្នាំមុនពេលវៀតណាមមកដល់"[115]។ ជាចុងក្រោយ ទោះបីជាវាមិនច្បាស់លាស់ទាំងស្រុងក៏ដោយ ក៏ វ៉ី ផាន់ ហាក់ដូចជាផ្សារភ្ជាប់កិច្ចប្រជុំនេះជាមួយនឹងពេលបាក់ទំនប់កង្ហត[116] ដែលបានកើតឡើងប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៧[117]។

ជួន ថន

59. ជួន ថន ជាកម្មាភិបាលថ្នាក់ទាបទទួលបន្ទុកកងចល័តតូចមួយ ក៏បានឮ **យ៉ីម ទិញ្ញ** ចេញបញ្ជា នៅក្នុងកិច្ចប្រជុំមួយ ឲ្យ "កម្ទេច" អ្នកដែលគេជឿថាជាខ្មាំង។ កិច្ចប្រជុំនោះ ដែលបានធ្វើឡើងនៅក្នុងបរិវេណវត្តភ្នំសំពៅ ត្រូវបានចូលរួមដោយមនុស្សប្រមាណ ១០០ នាក់ រួមបញ្ចូលទាំងមេកងប្រធានសហករណ៍ មេឃុំ និងមេស្រុក មកពីតំបន់ ១ និងតំបន់ ៣[118]។ ក្នុងកិច្ចប្រជុំ **យ៉ីម ទិញ្ញ**ៃ

---

[111] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.៥ KH 01040094។

[112] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.៣ KH 01040093។

[113] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.៣ KH 01040093។

[114] ឯកសារ D34.1.9 ប្រតិចារ៉ឹកបទសម្ភាសន៍ ហេង ទាវ ដោយ Steve Heder EN 01181104។

[115] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.៣ KH 01040093។

[116] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ី ផាន់ ឆ.៣ KH 01040093។

[117] *សូមមើលផងដែរឧទាហរណ៍* ឯកសារ D219/374 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឃិន ឃីម ឆ.១៨៨-១៨៩ KH 01110545។ ឯកសារ D219/721 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួម ហៅ ឆ.១៩ KH 01213294។ ឯកសារ D219/430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៥៦, ៥៩ KH 01122406។ ឯកសារ D219/310 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ន្ត សាមុត ឆ.៥ KH 01097679 ។

[118] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.៤ KH 00990642 ឆ.១៦-១៩ KH 00990645-46 ["តាទិត គឺជាអ្នកដែលនិយាយអំពីរឿងរ៉ាវដែលខ្ញុំបានជម្រាបអម្បាញ់មិញនេះ។ គាត់បាននិយាយថា គាត់បានទទួលព័ត៌មានជា

> បាននិយាយថា គាត់បានទទួលព័ត៌មានជាច្រើនអំពីប្រធានសហការណ៍ ទាក់ទងនឹងអំពើចោរកម្ម ហើយនិងសកម្មភាពខ្ទាំង នៅតាមមូលដ្ឋានជាច្រើន។ គាត់បានណែនាំឲ្យយើងតាមដានសកម្មភាពទាំងនេះជាប្រចាំ។ បើយើងតាមដានឃើញសកម្មភាពទាំងនេះ គឺយើងត្រូវតែយកទៅណែនាំជាមុនសិន មុននឹងយកទៅកម្ទេច ហើយរាយការណ៍ទៅថ្នាក់លើ[119]។
>
> កិច្ចប្រជុំនេះទំនងជាធ្វើឡើងនៅដើម ឬពាក់កណ្តាលឆ្នាំ១៩៧៨[120]។

60. ឈឿង ប៊ាន បានរៀបរាប់អំពីតួនាទីរបស់ **យ៉ាម ទិត្យ** នៅក្នុងកិច្ចប្រជុំសំខាន់ពីរ។ កិច្ចប្រជុំទីមួយធ្វើឡើង នៅខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧៨ ហើយត្រូវបានចូលរួមដោយសមាជិកកងចល័តពី ៧០ ទៅ ៨០ នាក់[121]។ ក្នុងកិច្ចប្រជុំនោះ **យ៉ាម ទិត្យ** បានចាត់ទុកអ្នកលួចដំឡូង ល្ពៅ ឬចេក ជា "ខ្មាំងស៊ីរួងផ្ទៃក្នុង" ហើយបានប្រាប់អ្នកចូលរួមឲ្យរាយការណ៍អំពីកំហុសបែបនេះទាំងអស់ បើមិនដូច្នេះទេ ពួកគេក៏ត្រូវចាត់ទុកជាខ្មាំងដែរ[122]។ គាត់ក៏បានព្រមានសមាជិកកងចល័តកុំឲ្យចូលដៃចូលជើង

ច្រើនពីប្រធានសហការណ៍ ទាក់ទងនឹងចោរកម្ម ហើយនិងសកម្មភាពខ្ទាំងនៅតាមមូលដ្ឋានជាច្រើន។ គាត់បានណែនាំពួកយើងតាមដានសកម្មភាពទាំងនេះជាប្រចាំ។ បើយើងតាមដានឃើញសកម្មភាពទាំងនេះ គឺយើងត្រូវតែទៅណែនាំជាមុនសិន មុននឹងយកទៅកម្ទេច ហើយរាយការណ៍ទៅថ្នាក់លើ"]។ ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.២២ KH 01023876

[119] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៧ KH 00990645 ["តាទិត គឺជាអ្នកដែលនិយាយអំពីរឿងរ៉ាវដែលខ្ញុំបានជម្រាបអម្ចាស់ម្ចាញ់ម្ចាញ់នេះ។ គាត់បាននិយាយថា គាត់បានទទួលព័ត៌មានជាច្រើនពីប្រធានសហការណ៍ ទាក់ទងនឹងចោរកម្ម ហើយនិងសកម្មភាពខ្ទាំងនៅតាមមូលដ្ឋានជាច្រើន។ គាត់បានណែនាំពួកយើងតាមដានសកម្មភាពទាំងនេះជាប្រចាំ។ បើយើងតាមដានឃើញសកម្មភាពទាំងនេះ គឺយើងត្រូវតែទៅណែនាំជាមុនសិន មុននឹងយកទៅកម្ទេច ហើយរាយការណ៍ទៅថ្នាក់លើ"]។

[120] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.៤, ១២ KH 00990642, 44។ ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១១ KH 01023875។

[121] ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៨៧-៩០ KH 01110185-86 ឯកសារ D219/430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.១២៦-១២៧ KH 01122420 ឯកសារ D219/533 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.២ KH 01153591។

[122] ឯកសារ D219/533 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.១៣-១៤ KH 01153593 ["តាទិតនិយាយពីរឿងខ្ទាំងស៊ីរួងផ្ទៃក្នុង សូម្បីតែអ្នកលួចគាស់ដំឡូង ស្ងោល្ពៅ អាហ្ម៉ឹងចាត់ទុកថាជាខ្ទាំងស៊ីរួងផ្ទៃក្នុងទាំងអស់។ ចំពោះមានរឿងកើតឡើងត្រូវតែរាយការណ៍ទៅគាត់ បើមិនរាយការណ៍ឲ្យគាត់ គាត់ថាជាខ្ទាំងបង្កប់ស៊ីរួងផ្ទៃក្នុង។ គាត់និយាយថា បើមានរឿងកើតឡើង ឈ្លោះក ឬខ ត្រូវរាយការណ៍ឲ្យទាន់ពេលវេលាភ្លាមៗដូចជាកងត្រូវរាយការណ៍ទៅសហការណ៍"]។

ជាមួយ "ខ្មាំងស៊ីរួងផ្ទៃក្នុង" យួន ឬសេអ៊ីអា[123]។ អ្នកនៅក្រោមបង្គាប់ជាច្រើននាក់របស់ **យ៉ីម ទិត្យ** ក៏មានវត្តមាននៅឯកិច្ចប្រជុំនោះផងដែរ[124]។

61. **យ៉ីម ទិត្យ** បានធ្វើជាអធិបតី ក្នុងកិច្ចប្រជុំលើកទីពីរ នៅវត្តបាយដំរ៉ា នៅខែកញ្ញា ឬខែតុលា ឆ្នាំ ១៩៧៨[125]។ កិច្ចប្រជុំនោះ មានអ្នកចូលរួមពី ៥០ ទៅ ៧០ នាក់[126] "មានគោលបំណងសាកសួរអំពីភ្នាក់ងារសេអ៊ីអា ពួកបម្រើយួន និងខ្មាំងបង្កប់ស៊ីរួងផ្ទៃក្នុងបម្រើយួន"[127]។ **យ៉ីម ទិត្យ** "បានបំពាក់បំប៉ន់ប្រជាជនមិនឲ្យក្បត់ពីការដឹកនាំរបស់ពួកនិរតី។ អ៊ីចឹង មិនឲ្យយើងក្បត់ពីគោលការណ៍និងការដឹកនាំរបស់វា"[128]។ កិច្ចប្រជុំនេះត្រូវបានចូលរួមដោយអ្នកនៅក្រោមបង្គាប់ចំនួនរបស់ **យ៉ីម ទិត្យ** ផងដែរ[129]។

62. កម្មករធម្មតាម្នាក់ឈ្មោះ ទូច ម៉ារី បានចូលរួមកិច្ចប្រជុំធំមួយដែល **យ៉ីម ទិត្យ** ជាអ្នកឧទ្ទេសនាមនៅស្រុកមោង[130]។ ក្នុងកិច្ចប្រជុំនោះ **យ៉ីម ទិត្យ** បានប្រាប់អ្នកចូលរួមថា "មានខ្មាំងបង្កប់ខ្លួននៅក្នុងតំបន់យើង ភូមិ កងយើង"[131]។ គាត់ក៏បានគំរាមអ្នកចូលរួមថា "មានតាមដាន គេឲ្យយើងប្រយ័ត្ន

---

[123] ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៩០ KH 01110185 ["ចំណុចមួយទៀតដែល តាទិត បានលើកឡើងផងដែរនោះ គឺគាត់បានប្រាប់យើងកុំឲ្យបម្រើយួន និង សេ.អ៊ី.អា ដែលជាភ្នាក់ងារបម្រើយួន"]។ ឯកសារ D219/533 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.១១ KH 01153592។

[124] ឯកសារ D219/533 ណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៣-៧ KH 01153591-92។

[125] ឯកសារ D219/368 កំហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៩៤ KH 01110186។

[126] ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៩៤ KH 01110186។

[127] ឯកសារ D219/533 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៣៧ KH 01153596។

[128] ឯកសារ D219/533 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៣៧-៣៨ KH 01153596 ["ស៖ លោកបានប្រាប់យើងកាលពីលើកមុនថា នៅឯកិច្ចប្រជុំលើកទី២ ដែលលោកបានចូលរួមប្រជុំជាមួយ តាទិត្យ នៅវត្តបាយដំរ៉ា (ឯកសារ D219/368 ចម្លើយ៩៤) ថា តាទិត្យ ប្រាប់ប្រជាជនឲ្យ "ប្រកាន់គោលជំហររឹងមាំ"។ តើតាទិត្យ ចង់មានន័យដូចម្តេច? ឆ.៣៨៖ តាទិត្យ ចង់មានន័យបំពាក់បំប៉ន់ប្រជាជនមិនឲ្យក្បត់ពីការដឹកនាំរបស់ពួកនិរតី"]។

[129] ឯកសារ D219/533 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿន ប៊ាន ឆ.៣៦ KH 01153595។

[130] ឯកសារ D219/836 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ម៉ារី ឆ.១៥៨-១៦០, ១៦៥-១៦៦ KH 01335570-71។

[131] ឯកសារ D219/836 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ម៉ារី ឆ.១៦២ KH 01335570 ["តើគាត់បាននិយាយពីខ្មាំងទេ? ឆ.១៦២៖ គាត់និយាយ គាត់លើកឧទាហរណ៍ពីខ្មាំង គាត់ថាមានខ្មាំងបង្កប់ខ្លួននៅក្នុងតំបន់យើង ភូមិ កង យើង គាត់លើកប្រហែល១០នាទីហ្នឹងឯង"]។

ខ្លួន"[132]។ ទូច ម៉ារី បាននិយាយជាពិសេសថា អ្នកធ្វើការមិនកើតត្រូវចាត់ទុកជាខ្ទាំង និងត្រូវយកទៅសម្លាប់ចោល[133]។ ពេលស្តាប់ **យ៉ីម ទិត្យ** ទូច ម៉ារី បាននិយាយថា៖ "យើងចាស់ៗអី យើងខ្លាចហ្ន៎ង ខ្លាចតែហៅទៅ គាត់ស្លាប់ហើយ"[134]។ ទូច ម៉ារី បានដឹងអំពីការបាត់ខ្លួនមនុស្សជាច្រើន[135]។

<u>ឡុច អេង</u>

63. សាក្សី ឡុច អេង កម្មករនៅឃុំបឹងព្រៃ មានដើមកំណើតមកពីភូមិភាគនិរតី ក៏បានចូលរួមកិច្ចប្រជុំមួយ ដែល **យ៉ីម ទិត្យ** បានណែនាំអ្នកចូលរួមឲ្យតាមដាន និងរាយការណ៍ពីអ្នកធ្វើការជាមួយគ្នា។ **យ៉ីម ទិត្យ** "និយាយថា ត្រូវប្រុងប្រយ័ត្ន និងតាមដានពីសមាសភាពមិនល្អ" ហើយ "តាមភូមិ ឃុំ កុំឲ្យមានចារកិច្ច ឬគិញ ចូលមកដល់កន្លែងយើងបាន"[136]។ គាត់ក៏បានបញ្ជាឲ្យមេភូមិ និងមេឃុំ "តាមដានទាំងកម្មាភិបាល និងប្រជាជនទូទៅណា ដែលមានមានសកម្មភាពមិនប្រក្រតី ហើយត្រូវរាយការណ៍ទៅស្រុក រួចខាងស្រុកជាអ្នកសម្រេចថាតើត្រូវធ្វើយ៉ាងណាៗ"[137]។ ការបញ្ជេញពាក្យ

---

[132] ឯកសារ D219/836 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ម៉ារី ឆ.១៦៨ KH 01335571 ["គាត់និយាយពីរឿងការងារ ល្អិតល្អន់ រឿងការងារថា មានតាមដាន ឲ្យយើងប្រយ័ត្នខ្លួន"]។

[133] ឯកសារ D219/836 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ម៉ារី ឆ.១៦៨ KH 01335571 ["គាត់និយាយពីរឿងការងារ ល្អិតល្អន់ រឿងការងារថា មានតាមដាន ឲ្យយើងប្រយ័ត្នខ្លួន។ បើយើងធ្វើការ [មិន] កើត គេថាយើងខ្ទាំង គេហៅយើងទៅប្រជុំកន្លែងផ្សេង គេយកទៅសម្លាប់ហើយ"]។ *កត់សម្គាល់៖* នៅក្នុងអត្ថបទបកប្រែជាភាសាអង់គ្លេស ពាក្យ "មិន" ដែលបង្ហាញនៅក្នុងអត្ថបទភាសាខ្មែរ ត្រូវបានលុបចោល។ សហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំការបកប្រែត្រឹមត្រូវ។

[134] ឯកសារ D219/836 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ម៉ារី ឆ.១៦៨៩ KH 01335571។

[135] ឯកសារ D219/836 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទូច ម៉ារី ឆ.១៧៥-១៧៧ KH 01335572 ["ឆ.១៧៥៖ [...] ដល់យើងអង្គុយ គេហៅទៅប្រជុំ។ ដល់តែទៅប្រជុំ បាត់ហើយ ឲ្យតែទៅប្រជុំ។ ស៖ តើលោកធ្លាប់បានឃើញនរណាបាត់ខ្លួនឬទេ? ឆ.១៧៦៖ ធ្លាប់ឃើញ។ ស៖ តើលោកធ្លាប់ឃើញប៉ុន្មាននាក់? ឆ.១៧៧. ច្រើនគ្នាដែរហ្ន៎ង"]។

[136] ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៣៤ KH00 0947292។ នៅពេលដែល ឡុច អេង ផ្តល់ចម្លើយនេះកាលពីឆ្នាំ២០១៦ គាត់មិនមើលស្គាល់រូបរបស់ យ៉ីម ទិត្យ។ ប៉ុន្តែរូបថតដែលបង្ហាញឲ្យគាត់មើល គឺជារូបថតចាស់ដែលថតក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ហើយបើតាមភាពស៊ីសង្វាក់គ្នានៃភស្តុតាងរបស់ ឡុច អេង ទាក់ទងនឹងតួនាទី និងសកម្មភាពរបស់ យ៉ីម ទិត្យ សមត្ថភាពក្នុងទទួលស្គាល់រូបថតនេះ វាមិនប៉ះពាល់ភាពជឿទុកចិត្តនៃភស្តុតាងរបស់គាត់ឡើយ។ ឯកសារ D219/884 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.១៧-១៩ KH 01362503។

[137] ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៣៥ KH00 0947292។ *កត់សម្គាល់៖* ឡុច អេង ក៏បាននិយាយថា នៅជិតបញ្ចប់នៃរបបខ្មែរក្រហម គឺនៅមុនកងទ័ពវៀតណាមចូលមកដល់បន្តិច មានការលើកលែងទោស ហើយតាទិត្យ បានប្រកាសថា អ្នកធ្វើខុសនឹងត្រូវអនុគ្រោះ។ ឯកសារ D219/627 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.១៨, ២០, ៣១ KH 01184314-16។

សម្តីទាំងនេះ និងផលប៉ះពាល់ទៅលើកម្មករ ត្រូវតែយល់ ក្នុងបរិបទនៃសុន្ទរកថា ផ្ទែងដោយតាម៉ុក ទៅកាន់ពួកគេ មុនពេលពួកគេចាកចេញទៅកាន់ភូមិភាគពាយ័ព្យ។ តាម៉ុក បានគំរាមថា៖ "អញឲ្យ ហ្អែងទៅពីនេះជិះឡាន [ទៅភូមិភាគពាយ័ព្យ] តែពេលមកស្រុកវិញ ជិះចានអញមិនដឹងទេ"[138]។

<u>មូល អេន</u>

64. **យ៉ីម ទិត្យ** ក៏ចូលរួម និងរួមចំណែកផងដែរ ក្នុងការអនុវត្តគោលនយោបាយស្តីពីខ្ទាំង ក្នុងកិច្ចប្រជុំ ឯកជនជាមួយអ្នកនៅក្រោមបង្គាប់។ មូល អេន លេខាស្រុកបវេល បានឆ្លើយថា ពេល **យ៉ីម ទិត្យ** ចូលមកមើលមន្ទីរស្រុកបវេល គាត់ "បានណែនាំយើង ត្រូវការពារកុំឲ្យមានខ្ទាំង"[139]។ មូល អេន ក៏បាននិយាយផងដែរថា ពាក្យ "ខ្ទាំង [...] សំដៅទៅលើអ្នកប្រឆាំង អ្នកក្បត់ អ្នកស្រែកឡូឡា អ្នក មិនធ្វើការតាមគោលការណ៍ មិនថានរណាជានរណាទេ ឲ្យតែធ្វើការឲ្យគេមិនកើត ក៏ជាខ្ទាំងដែរ" ហើយ "ឲ្យតែធ្វើការមិនគ្រប់តាមគោលការណ៍ឲ្យគេ គឺគេនឹងសម្លាប់"[140]។ មូល អេន បានដឹងថា "អ្នកដែលជាខ្ទាំងហ្នឹង មិនដឹងយកទៅណាទេ គេយកដាក់ឡានទៅបាត់ហើយ"[141]។

<u>សឿន ម៉ត</u>

65. បន្ថែមពីលើការគំរាមកំហែងដោយបើកចំហប្រឆាំងនឹង "ខ្ទាំង" **យ៉ីម ទិត្យ** ក៏បានជំរុញយុទ្ធនាការ បំភ័យ ដើម្បីឲ្យប្រាកដថាប្រជាជនដឹងថាការគំរាមកំហែងរបស់គាត់ពិតជាត្រូវបានអនុវត្តមែន។ សឿន ម៉ត រៀបរាប់អំពីកិច្ចប្រជុំមួយនៅទំនប់កង្ហត ដែលចូលរួមដោយកម្មករកងចល័តរាប់ពាន់ នាក់ ក្រោមអធិបតីភាពរបស់ **យ៉ីម ទិត្យ** ក្នុងឆ្នាំ១៩៧៧[142]។ ក្នុងកិច្ចប្រជុំនោះ មានការប្រកាសជា សាធារណៈ (ដោយ **យ៉ីម ទិត្យ** ឬអ្នកនៅក្រោមឱវាទរបស់គាត់[143]) ថា "តាកៅ ត្រូវបានគេចាប់យក

---

[138] ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៩ KH 00947289។

[139] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៨១ KH 01095247។

[140] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៨១ KH 01095247។

[141] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៨៣ KH 01095248។

[142] ឯកសារ D219/538 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿន ម៉ត ឆ.១៧, ២១-២២, ២៤, ៣០, ៤៤, ៤៩ KH 01155823, 24, 25, 27, 28។

[143] នៅចំណុចមួយ សឿន ម៉ត និយាយនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់គាត់ថា យ៉ីម ទិត្យ បានប្រកាស។ នៅ ចំណុចផ្សេងទៀត គាត់និយាយថា គាត់ប្រាកដថា យ៉ីម ទិត្យ ដឹកនាំការប្រជុំ តែមិនដឹងនរណាគេជាអ្នកប្រកាស។ *សូមមើលឯក សារ* D219/538 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿន ម៉ត KH 01155823, 28។

ទៅសម្លាប់នៅម៉ុងចិន។ តាប៉ែត ត្រូវបានគេចាប់ខ្លួនហើយ"[144]។ ហេតុផលនៃការចាប់តាប៉ែត និងតាកៅ គឺថាពួកគេជា "ជនក្បត់"[145]។ ការប្រកាសនេះបង្ហាញឲ្យឃើញជាថ្មីម្តងទៀតថា ការគំរាមកំហែងរបស់ **យ៉ីម ទិត្យ** មិនមែនឥតប្រយោជន៍នោះទេ ហើយគាត់មានចេតនាពេញលេញចង់ឲ្យចាប់ និងសម្លាប់ "ខ្មាំង"។ សេចក្តីប្រកាសទាំងនេះក៏ជាការចូលរួមចំណែកបន្ថែមទៀតក្នុងផែនការឧក្រិដ្ឋរួម ដោយសារតែវាដើរតួជាការគំរាមកំហែង និងញុះញង់បន្ថែម ដោយប្រយោល។

<u>សេចក្តីសន្និដ្ឋានអំពីការចូលរួមរបស់ យ៉ីម ទិត្យ ក្នុងកិច្ចប្រជុំ នៅភូមិភាគពាយ័ព្យ</u>

66. វត្តមាន និងការថ្លែងរបស់ **យ៉ីម ទិត្យ** ក្នុងកិច្ចប្រជុំទាំងនេះ បង្ហាញថា គាត់បានចែករំលែកចេតនារបស់សមាជិកនៃផែនការរួម ដើម្បីកម្ទេចខ្មាំងរបស់ ប.ក.ក តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្ម រួមទាំងការសម្លាប់ក្រៅច្បាប់។ វត្តមាន និងការថ្លែងរបស់គាត់ ក៏ស្មើនឹងការណែនាំ ឬការលើកទឹកចិត្តដល់អ្នកនៅក្រោមបង្គាប់របស់គាត់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម និងជាការរួមចំណែកក្នុងផែនការឧក្រិដ្ឋរួមផងដែរ។

67. សាក្សីបានរៀបរាប់ស៊ីសង្វាក់គ្នាខ្លាំងអំពីការចូលរួមរបស់ **យ៉ីម ទិត្យ** ក្នុងការកំណត់ ស្វែងរក និងកម្ទេចខ្មាំង ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ តាំងពីដើម រហូតដល់ចប់របបខ្មែរក្រហម។ ភ័ស្តុតាងបង្ហាញថា **យ៉ីម ទិត្យ** បានចូលរួមដោយសតិសម្បជញ្ញៈ និងដោយចេតនា ក្នុងផែនការឧក្រិដ្ឋរួម តាំងពីថ្ងៃដំបូង រហូតដល់ថ្ងៃចុងក្រោយនៃរបបខ្មែរក្រហម។

ii. ការចូលរួមពាក់ព័ន្ធដោយផ្ទាល់របស់ យ៉ីម ទិត្យ ក្នុងការចាប់ ដាក់គុក និងសម្លាប់

68. ដូចនៅភូមិភាគនិរតីដែរ **យ៉ីម ទិត្យ** បានជួយជំរុញផែនការឧក្រិដ្ឋរួម ក្នុងការចាប់ខ្លួន ដាក់គុក និងសម្លាប់ខ្មាំងក្រៅច្បាប់ នៅភូមិភាគពាយ័ព្យ តាមរយៈការចេញបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ ព្រមទាំងតាមរយៈការទៅពិនិត្យមើលមន្ទីរសន្តិសុខ ក្នុងដែនទទួលខុសត្រូវរបស់គាត់។

---

[144] ឯកសារ D219/538 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឿន ម៉ត KH 01155827។

[145] ឯកសារ D219/538 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ឿន ម៉ត ១.១៧ KH 01155823។

<u>សៅ ជាប់</u>

69. សៅ ជាប់ បានឲ្យដឹងថា៖ "ក្នុងឆ្នាំ៧៦, ៧៧ ហ្នឹង តាទិត្យ បានចាត់តាំង [សមាជិកយោធាស្រុកគាស់ក្រឡ] រកខ្មាំងសេអ៊ីអា ឃ្លួន" [146]។ អ្នកដែលគេចាត់ទុកជាខ្មាំងទាំងនេះ ត្រូវបានចាប់ខ្លួន និងសម្លាប់ដោយមនុស្សមួយចំនួន រួមទាំងមេបញ្ជាការយោធាស្រុកគាស់ក្រឡ និងកម្មាភិបាលម្នាក់ឈ្មោះ អន[147]។ ក្នុងអំឡុងពេលសម្លាប់នោះ អន បានប្រាប់ សៅ ជាប់ ថា **យ៉ែម ទិត្យ** បានណែនាំគាត់ឲ្យសម្លាប់ខ្មាំងទាំងនេះ[148]។ ពេលសួរថាតើមានមនុស្សប៉ុន្មាននាក់ដែលត្រូវបាន អន សម្លាប់

---

[146] ឯកសារ D219/982 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៣៣ KH 01477629។ ឯកសារ D219/983 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១០-១១ KH 01477637។

[147] ឯកសារ D219/982 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២៦-២៧ KH 01477628 ["ស៖ ពេលក្រោយមកដែលលោកឮ អំពីពាក្យរឿងសម្លាប់ លោកឮដោយរបៀបម៉េច? ឆ.២៦៖ អាហ្នឹងដោយគាត់ចាត់តាំងគេតើ។ កាលហ្នឹងគាត់ចាត់តាំងមក ដើម្បីមកធ្វើការជាមួយបានដឹង។ [...] ខ្ញុំដឹងតាមឃាតករហ្នឹង គាត់ថាគេចាត់តាំងមកឲ្យ។ គាត់ឈ្មោះ អន"]។ ឆ.៣៣ KH 01477629 ["នៅក្នុងឆ្នាំ តាំងឆ្នាំ៧៥, ៧៦ ហ្នឹងក៏សម្លាប់ ហើយឆ្នាំ៧៧ ពួកនិរតី។ ហើយក្នុងឆ្នាំ៧៦, ៧៧ហ្នឹង តាទិត្យ ចាត់តាំងឲ្យរក សេ.អ៊ីអា ឃ្លួន" ឆ.៣១ KH 01477628 ["រាប់ពាន់នាក់ដែរ។ ខ្ញុំសួរដែរ ថាចុះមនុស្សដែលចាប់យកទៅសម្លាប់ហ្នឹង ខុសអី វាថាជា សេ.អ៊ីអា ឃ្លួន"។ ឆ.៣៤ KH 01477629 ["ដល់គេចាប់ គេថា សេ.អ៊ីអា"។ ឆ.៣៨ KH 01477630 ["អាន ជាប្រធានកងអនុសេនាធំរបស់ស្រុក"]។ ឯកសារ D219/983 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១០-១១ KH 01477637។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៤៩ KH 01425225។ ឯកសារ D219/980 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៩ KH 01477598។ ទាក់ទងនឹងតួនាទីរបស់ អន *សូមមើលផងដែរ* ឯកសារ D131/2.1.86 បញ្ជីឈ្មោះយោធាស្រុកគាស់ក្រឡតំបន់១ KH 00814636 ដាក់ឈ្មោះ អន ថាជាប្រធានកងធំ យោធាស្រុកគាស់ក្រឡតំបន់១"]។

[148] ឯកសារ D219/982 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២៨ KH 01477628 ["ស៖ អនប្រាប់លោកថាម៉េច? ឆ.២៨៖ ខ្ញុំសួរថា មិត្តឯងធ្វើឃាតករសម្លាប់ប្រជាជនហ្នឹង អ្នកណាចាត់តាំងមក។ គាត់ថាឈ្មោះ ទិត្យ ហ្នឹង"]។

តាមបញ្ជាទាំងនេះ សៅ ជាប់ បានឆ្លើយថា "រាប់ពាន់នាក់ដែរ"[149]។ សៅ ជាប់ បានឃើញដោយផ្ទាល់ភ្នែកនូវការចាប់ខ្លួន និងការសម្លាប់មួយចំនួន[150]។ ជនរងគ្រោះភាគច្រើនជាប្រជាជនថ្មី[151]។

70. ដើម្បីជួយសម្រួលដល់ការសម្លាប់ទាំងនេះ **យ៉ាម ទិត្យ** និងតាម៉ុក បានជួបជាមួយ អន និងអនុរបស់ អន ឈ្មោះ ប៉ក់ ជាញឹកញាប់[152]។ សៅ ជាប់ បានបញ្ជាក់ថា **យ៉ាម ទិត្យ** និងតាម៉ុក បានជួបជាមួយ ឃាតកទាំងពីរនេះ នៅមន្ទីរស្រុកគាស់ក្រឡ មួយខែម្តង ឬបួនប្រាំខែម្តង[153]។ ការប្រជុំទាំងនេះ "រកសេអ៊ីអា ឃួន ហ្ម៊ីងហើយ" ហើយក្នុងពេលប្រជុំ តាម៉ុក និង **យ៉ាម ទិត្យ** បានដាក់ "ផែនការការងារ

---

[149] ឯកសារ D219/982 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៣១-៣២ KH 01477628-29 ["ស៖ លោកមានចាំទេ ប្រហែលជាប៉ុន្មាននាក់ ដែល អន ចាប់សម្លាប់កាលហ្ម៊ីង? ឆ.៣១៖ រាប់ពាន់នាក់ដែរ។ [...] វាថាជា សេ.អ៊ី.អា និង ឃួន។ [... ឆ.៣២៖ វាដើរចាប់អ៊ីចឹង ហើយមិនមែនម្តងទេ គឺច្រើនដង"]។

[150] ឯកសារ D219/982 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២៩ KH 01477628 ["ចុះបើឃើញសម្លាប់ ឃើញចាប់យកទៅសម្លាប់"]។ ឯកសារ D219/983 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៣៦-៤០ KH 01477642 ["កាលហ្ម៊ីងទៅខ្ញុំឃើញគេដែលហ្ម៊ីង។ [...] ទាក់ទងនឹងការសម្លាប់ ពួកគេយកមនុស្សទៅសម្លាប់នៅកន្លែងមួយដែលគេហៅ ណ្ហារ ស្ថិតនៅភាគខាងត្បូងភ្នំធិបតី។ ទាក់ទងនឹងថាតើប្រជាជនត្រូវបានគសម្លាប់របៀបណា គេសម្លាប់ប្រជាជនដោយដំបងហើយពេលខ្លះដោយការបាញ់។ ប្រជាជនប្រហែល១០០០នាក់ត្រូវបានសម្លាប់នៅណ្ហារ"]។

[151] ឯកសារ D219/982 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៣៧ KH 01477629។

[152] ឯកសារ D219/982 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៤០-៤១, ៤៥-៤៧ KH 01477630-01477631 ["ឃើញមកប្រជុំញឹក។ [...] មានស្រុក, តាទិត្យ, ហ្ម៊ីង ហើយនិង អន, ប៉ក់, ថាច ហើយតាម៉ុក។ [...] គេមកប្រជុំនៅគាស់ក្រឡ។ អាហ្ម៊ីងគេប្រជុំរក សេ.អ៊ី.អា ឃួន ហ្ម៊ីងហើយ"]។ ចំពោះតំណែងរបស់ ប៉ក់ វិញ *សូមមើល* ឯកសារ D131/2.1.86 បញ្ជីឈ្មោះយោធាស្រុកគាស់ក្រឡ តំបន់ ១ KH 020214636 [បានចុះបញ្ជីឈ្មោះ ប៉ក់ ជា "យុទ្ធជនយោធាស្រុកគាស់ក្រឡ តំបន់ ១"]។

[153] ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៣-៤ KH 01477636 [សាក្សីជាប្រធានកងអនុសេនាតូចនៅស្រុកគាស់ក្រឡ៖ "ស៖ ពីមន្ទ្រីលមិញ [...] យើងបាននិយាយគ្នាអំពីមនុស្សបីនាក់មាន អន, ប៉ក់ និង ថាច ដែលពួកហ្ម៊ីងតែងជួបប្រជុំជាមួយ តាទិត្យ ញឹកញាប់។ តើកន្លែងដែលពួកហ្ម៊ីងប្រជុំនៅកន្លែងណា? ឆ.៣៖ នៅកន្លែងមន្ទីរស្រុកគាស់ក្រឡ។ [...] ឆ.៤ ៖ អាហ្ម៊ីងដូច១ខែអ៊ីចឹង គេមកប្រជុំម្តង"] ឆ.១៦-១៧ KH 01477638 ["ស៖ [...] តាមដែលលោកមើលឃើញ តើ តាម៉ុក តាទិត្យ និងពួក អន, ប៉ក់ និង ថាច ហ្ម៊ីងមកប្រជុំប្រហែលប៉ុន្មានដងដែរ? ឆ.១៦៖ អាហ្ម៊ីង១ខែម្តងៗ ប្រហែលបួនប្រាំដងដែរ។ ស៖ ពេលលោកចំណាំឃើញគេប្រជុំ ឃើញមកទាំងពីរនាក់ហ្ម៊ីង ឬមកតែម្នាក់ៗ ឬយ៉ាងម៉េច? ឆ.១៧៖ មានតាទិត្យ តាម៉ុក គណៈស្រុក និងគណៈសហការណ៍។ ឃើញពេលមក គឺមកទាំងពីរហ្ម៊ីងតែម្តង] ឆ.៤២ KH 01477643 ["ស៖ កាលហ្ម៊ីងអ្នកណាជាអ្នកចេញបញ្ជាឲ្យចាប់? ឆ.៤២៖ ការហ្ម៊ីងមកប្រជុំ ក្នុង១ខែមកប្រជុំម្តង ប្រជុំចប់ចាប់។ កាលហ្ម៊ីង តាម៉ុក តាទិត្យ គណៈស្រុក និងសហការណ៍"]។

[...] ឲ្យធ្វើ"[154] ដល់ អន និង ប៉ក់។ ជាលទ្ធផលនៃការសម្លាប់ **យ៉ីម ទិត្យ** និងតាម៉ុក បានដំឡើងតំណែងដល់ អន ប៉ក់ និងកម្មាភិបាលទីបី ដែលមានតួនាទីចម្បងក្នុងការសម្លាប់[155]។ សៅ ជាប់ បានលើកឡើងថា កិច្ចប្រជុំទាំងនេះ និងការចាប់ខ្លួន បានកើតឡើង "មុនពេលពួកនិរតីមកដល់"[156] ដែលបង្ហាញថាការចាប់ខ្លួនបានកើតមានឡើងភ្លាមៗ ក្រោយពី **យ៉ីម ទិត្យ** មកដល់តំបន់នោះដំបូងមុនកម្មាភិបាលភូមិភាគនិរតីក្រុមធំ[157]។ ការចងចាំរបស់គាត់ក្នុងរឿងនេះត្រូវបានបញ្ជាក់បន្ថែមដោយ

---

[154] ឯកសារ D219/982 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៤៧ KH 01477631 ["អាហ្នឹងគេប្រជុំរក សេ.អ៊ុ.អា ឃួន ហ្នឹងហើយ"]។ ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៣ KH 01477637 ["ស៖ ពេលដែលលោកនិយាយជាមួយ ប៉ក់, អន និង ថាច លោកមានបានសួរ ឬគេមានប្រាប់អំពី តាទិត្យ និង តាម៉ុក គាត់មានតួនាទី ឬថានៈជាស្អីៗទេ? ឆ.១៣ ៖ គេមេដឹកនាំ គេមកប្រជុំ មកដាក់ផែនការឲ្យធ្វើ ដើម្បីឲ្យពួកហ្នឹងធ្វើហ្នឹង អាហ្នឹងទៅលើ តាទិត្យ តាម៉ុក ហ្នឹង"]។ *សូមមើលផងដែរ* ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៤ KH 01477638 ["ស៖ លោកដឹងទេ ពេលគេប្រជុំរវាងគ្នាគេហ្នឹង រវាង តាទិត្យ និង ប៉ក់, អន, ថាច ហ្នឹង គេនិយាយពីរឿងអ្វីខ្លះ? ឆ.១៤៖ អាហ្នឹងខ្ញុំអត់ដឹងទេ។ ប៉ុន្តែពេលគេឈប់ពីប្រជុំទៅ អន, ប៉ក់, ថាច គេមានសកម្មភាពដើរចាប់ដើរអីហ្នឹង"]។

[155] ឯកសារ D219/982 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៤០-៤៤ KH 01477630-01477631 ["ឆ.៤០, ៣៩៖ ឃាតករនៅស្រុកគាស់ក្រឡមានបីនាក់ កាលហ្នឹងគឺឈ្មោះ ប៉ក់, អន និង ថាច។ [...] ប៉ក់ អង្គភាពជាមួយ អន មានមុខតំណែងកងអនុសេនាធំ។ ពីដើមជាកងអនុសេនាធំ ដល់ផុតពីហ្នឹងមកឡើងវរ:សេនាធំ។ [...] ឆ.៤១៖ ថាច ហ្នឹងអង្គភាពគេហ្នឹងដែរ។ អាហ្នឹងអនុប្រធានគេ។ ប្រធានគឺ អន ហើយ ប៉ក់ ជាអនុ ហើយនិង ថាច ជាសមាជិក។ កាលហ្នឹងអ្នកទាំងបីនាក់ហ្នឹង កាលណាសម្លាប់បានច្រើន គេតម្លើងស័ក្តិឲ្យ។ ស៖ តាមដែលលោកដឹង អ្នកណាជាអ្នកតំឡើងបុណ្យស័ក្តិឲ្យបីនាក់ហ្នឹង? ឆ.៤២៖ អាហ្នឹងតាមមើលតាទិត្យ តាម៉ុក ហ្នឹងតែម្តង ផ្ទាក់លើគេហ្នឹង។ ស៖ មានភស្តុតាងអី ដែលលោកអាចបញ្ជាក់ថាពួកហ្នឹងជាអ្នកតំឡើងស័ក្តិ? ឆ.៤៣៖ ខ្ញុំមើលទៅឃើញអ៊ីចឹង គេអ្នកចាត់តាំង មកប្រជុំពិភាក្សាគ្នា។ ស៖ អ្នកណាខស្សាហ៍មកប្រជុំហ្នឹង? ឆ.៤៤៖ ពីរនាក់ហ្នឹងគឺតាទិត្យ និងតាម៉ុក]។

[156] ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៣០-៣១ KH 01477640-41 ["ស៖ លោកនិយាយពីរឿងចាប់ៗប្រាប់យើងមកហ្នឹង ចង់និយាយថា ការចាប់នៅក្នុងរបបហ្នឹង ឬក៏មុន ឬក្រោយការមកដល់របស់ពួកនិរតី? ឆ.៣០៖ មុននិរតីមក។ ដល់ពួកនិរតីមក ទម្លាក់ពួកហ្នឹង ចាប់ពួកហ្នឹងបន្តវិញ។ ស៖ ដែលលោកនិយាយពីរឿងថា អន, ប៉ក់ និងថាច អីហ្នឹង ដែលចាប្រជុំជាមួយ តាម៉ុក តាទិត្យ ហើយទៅមានការចាប់ចងមនុស្សអីហ្នឹង។ ចង់និយាយថា ការចាប់ចងហ្នឹង ការប្រជុំចាប់ចងហ្នឹងមុនពេលដែលនិរតីមក ឬពេលនិរតីមក? ឆ.៣១៖ មុនៗ។ អាហ្នឹងបញ្ជាក់ពីរដងហើយ"] ឆ.៥៩ KH 01477645។

[157] *សូមមើល* III.ឃ.៣.ក. តំណែង អំពើ និងការប្រព្រឹត្តរបស់ យ៉ីម ទិត្យ-ការចូលរួមរបស់ យ៉ីម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្មរួមនៅភូមិភាគពាយ័ព្យ-អំពើ និងការប្រព្រឹត្តផ្សេងទៀតរបស់ យ៉ីម ទិត្យ នៅភូមិភាគពាយ័ព្យ-ការលេចមុខដំបូងរបស់ យ៉ីម ទិត្យ នៅភូមិភាគពាយ័ព្យ។

សាក្សី ឈុំ រ៉ាន់នី ដែលចាំថា ប៉ក់ ត្រូវបានចាប់ខ្លួន ក្រោយពីកម្មាភិបាលភូមិភាគនិរតីមកដល់បានមួយរយៈពេលខ្លី[158]។

ឈឿង ប៊ាន

71. សាក្សី ឈឿង ប៊ាន បានប្រាប់ថា គាត់បានឮពីសាច់ញាតិម្នាក់ដែលត្រូវគេចាប់ខ្លួនថា **យ៉ីម ទិត្យ** បានបញ្ជាកម្មាភិបាលភូមិភាគពាយ័ព្យឈ្មោះ តាសាម៉ន ឲ្យចាប់ខ្លួនមនុស្សមួយចំនួនយកទៅឃុំនៅគុកខ្នងគ្ន[159]។ គាត់ក៏បានអះអាងផងដែរថា ដោយសារកម្លាំងវៀតណាមចូលជិតមកដល់ នៅខែធ្នូ ឆ្នាំ១៩៧៨ **យ៉ីម ទិត្យ** បានបញ្ជាឲ្យសម្លាប់អ្នកទោសទាំងអស់ ដែលនៅសល់នៅមន្ទីរឃុំឃាំងវត្តបាយដំរ៉ា ហើយការសម្លាប់នេះត្រូវបានធ្វើឡើងដោយពួកឈ្លប ក្រោមការគ្រប់គ្រងរបស់តាណេន ជាអ្នកនៅក្រោមបង្គាប់របស់ **យ៉ីម ទិត្យ**[160]។

តាប៉ែត

72. តាប៉ែត ហៅ ហេង ទាវ អតីតលេខាតំបន់ ១ បាននិយាយអំពីពេលមួយដែល **យ៉ីម ទិត្យ** បានបញ្ជាទាហានរបស់គាត់ឲ្យសម្លាប់ទាហានពាយ័ព្យមួយក្រុម ដែលត្រូវគេសង្ស័យថាបះបោរប្រឆាំងនឹងអាជ្ញាធរភូមិភាគនិរតី និងសម្លាប់ជនស៊ីវិល[161]។ មុនពេលត្រូវគេសម្លាប់ ជនរងគ្រោះត្រូវគេបង្ខំឲ្យ

---

[158] ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឯ.៤៧, ៥១-៥២ KH 01029495-01029496។

[159] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.១៥៩-១៦១ KH 01153615-616 ["ឯ.១៥៩៖ [...] គាត់បានប្រាប់ថា តាទិត្យ ជាអ្នកបញ្ជាឲ្យ តាសាម៉ន ចាប់គាត់ពីរនាក់បងប្អូនទៅដាក់មន្ទីរឃុំឃាងនៅខែ៧ ឬខែ៨ ឆ្នាំ១៩៧៨។ ដោយ សារី និង សារ៉ូ ជាមនុស្សស្លូត [...] ស៖ តើនរណាជាអ្នកនិយាយថា គឺតាទិត្យ ជាអ្នកបញ្ជាឲ្យ តាម៉ន ចាប់ខ្លួន សារី និង សារ៉ូ? ឯ.១៦០ ៖ សារ៉ូ ជាអ្នកនិយាយ។ [...] ឯ.១៦១៖ [...] វាជាការសន្និដ្ឋានរបស់គាត់ខ្លួនឯងនោះទេ ព្រោះពេល តាសាម៉ន មកចាប់ពួកគាត់ តាសាម៉ន និយាយថា "ពួកអ្ហែង ពួកជាពួកក្បត់ជាតិ ក្បត់ឧត្តមគតិប្រជាជន មិនឲ្យប្រជាជនហូបអ្ហែត"]។

[160] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.១០៣-១០៤, ១០៨ KH 01153605 ["ស៖ តើនៅតែមានអ្នកទោសនៅក្នុងមន្ទីរឃុំឃាំងវត្តបាយដំរ៉ាដែរឬទេ នៅពេលដែលប្រជាជនបររទេះទៅលើ? ឯ.១០៤៖ ពេលដែលវារត់ ជូនទៅលើ ដឹកវាទៅលើហើយ អ្នកទោសទាំងនោះសុទ្ធតែវាយកទៅសម្លាប់ចោលទាំងអស់។ ពេលដែលប្រជាជនបររទេះជូនពួកវាទៅលើហើយ ពុំមានអ្នកទោសនៅក្នុងវត្តបាយដំរ៉ា ឬផ្ទះចែជ្ជ ទៀតទេ។ [...] ស៖ លោកបាននិយាយថា អ្នកទោសទាំងអស់ត្រូវបានគេសម្លាប់ តើនរណាជាអ្នកសម្លាប់អ្នកទោសទាំងអស់នោះ? ឯ.១០៨៖ អ្នកទោសទាំងអស់ដែលត្រូវបានគេសម្លាប់ គឺសម្លាប់ដោយកងឈ្លបរបស់និរតី របស់តាណេន ក្រោមការដឹកនាំរបស់ តាទិត្យ"]។

[161] ឯកសារ D34.1.10 កិច្ចសម្ភាសន៍របស់ ហេង ទាវ ហៅ តាប៉ែត ដោយ Steve Heder KH 00964055 ["ហ្ម៉ីងចាប់អ្នកដែលមកសម្លាប់នោះណ៎ា! ទិត្យ ហ្ម៉ីងវាបញ្ជា១ឲ្យកងទ័ព ក្នុងកងទ័ពហ្ម៉ីងសម្លាប់តែម្តង។ សម្លាប់ហ្ម៉ីង បើតាមនិយាយទៅ វាកងទ័ពនៅខាងពាយ័ព្យទិសហ្ម៉ីងដែរ"]។

ដើរជុំវិញ ហើយស្រែកថា៖ “កុំរយីងរយ៉ាងអ្នកស្រុកបងប្អូនទាំងអស់គ្នា ព្រោះខ្ញុំបានជាខុសរត់ចូលព្រៃ។ ដូច្នេះ ស្នើអង្គការសម្លាប់ខ្ញុំ ហើយគឺថាកុំធ្វើដូចខ្ញុំទៀត”[162]។

<u>ឯក (អ៊ីល) ហ្ជឿន</u>

73. កម្មាភិបាលឈ្មោះ ឯក ហ្ជឿន (ហៅ អ៊ីល ហ្ជឿន) បានឮពីប្អូនជីដូនមួយ ដែលបានចូលរួមក្នុងការសម្លាប់ដោយផ្ទាល់ថា **យ៉ីម ទិត្យ** បានបញ្ជាឲ្យសម្លាប់និស្សិត កម្មកររោងចក្រ ជនជាតិចិន និងវៀតណាមរាប់ពាន់នាក់ នៅជំរំតាអាន ក្នុងស្រុកព្រះនេត្រព្រះ[163]។

---

[162] ឯកសារ D34.1.10 កិច្ចសម្ភាសន៍របស់ ហេង ទាវ ហៅ តាប៉ែត ដោយ Steve Heder KH 00964055 [“ហ្ម៉ីងចាប់អ្នកដែលមកសម្លាប់នោះណ៎ា! ទិត្យ ហ្ម៉ីងវាបញ្ជា១ឲ្យកងទ័ព ក្នុងកងទ័ពហ្ម៉ីងសម្លាប់តែម្តង។ សម្លាប់ហ្ម៉ីង បើតាមនិយាយទៅ វាកងទ័ពខាងពាយ័ព្យទិសហ្ម៉ីងដែរ។ ប៉ុន្តែវាបញ្ជាឲ្យ១សម្លាប់ហ្ម៉ីង គ្នាវាទៅបីបួននាក់ទៀត។ កងទ័ពរបស់វាហ្ម៉ីង។ [...] ឲ្យបណ្តើរអាក្រោសទៀត។ ឲ្យបណ្តើរអាក្រោស ស្រែកប្រកាសថា “កុំរយីងរយ៉ាងអ្នកស្រុក បងប្អូនទាំងអស់គ្នា ព្រោះខ្ញុំបានជាខុសរត់ចូលព្រៃ។ ដូច្នេះស្នើអង្គការសម្លាប់ខ្ញុំ ហើយគឺថាកុំធ្វើដូចខ្ញុំទៀត។ ឲ្យស្រែកអ៊ីចឹង”]។

[163] ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ្ជឿន ឆ.១៣៨-១៤៩ KH 00980116-00980117 [“ឆ.១៣៨ ៖ [...] ខ្ញុំឮអ្នកសម្លាប់មនុស្សនៅភូមិភាគពាយ័ព្យនិយាយថា មានការសម្លាប់មនុស្សរាប់ពាន់នៅក្នុងភូមិភាគពាយ័ព្យ រួមមានទាំងនិស្សិតផងដែរ។ [...] ឆ.១៣៩៖ ប្អូនជីដូនមួយរបស់ខ្ញុំដែលជាអ្នកសម្លាប់មនុស្សនៅភូមិភាគពាយ័ព្យជាអ្នកប្រាប់ខ្ញុំអំពីរឿងនេះ។ [...] ឆ.១៤១៖ [...] ការសម្លាប់មនុស្សនេះគឺនៅជំរំតាអាន នៅខាងលិចទីរួមខេត្តបាត់ដំបង ដែលកន្លែងនោះនៅក្រោមការគ្រប់គ្រងរបស់ តាទិត្យ។ ស៖ តើការសម្លាប់នេះធ្វើឡើងនៅក្នុងឆ្នាំណា? ឆ.១៤២៖ នៅឆ្នាំ១៩៧៨ ហើយឆ្នាំ១៩៧៩ [...] ឆ.១៤៣ ៖ [...] គាត់និយាយថាជាបញ្ជារបស់ តាទិត្យ។ ដំបូងគេប្រមូលខ្មែរ ចិន និងវៀតណាម ទៅសម្លាប់ ដែលប្រជាជនទាំងអស់នេះនៅក្រោមការគ្រប់គ្រងរបស់ លន់ នល់។ [...] ឆ.១៤៤៖ គឺប្រមូលពីក្រុងបាត់ដំបង មានទាំងនិស្សិតផងដែរ។ ស៖ តើកន្លែងសម្លាប់មនុស្សនេះស្ថិតនៅក្នុងស្រុកណា? ឆ.១៤៥៖ នៅក្នុងស្រុកព្រះនេត្រព្រះ។ ស៖ តើប្អូនជីដូនមួយរបស់លោកបានឮដោយផ្ទាល់ ឬក៏ឃើញដោយផ្ទាល់ថា តាទិត្យ ជាអ្នកបញ្ជាឲ្យសម្លាប់មនុស្សទាំងអស់នោះដែរឬទេ? ឆ.១៤៦៖ បាទ តាទិត្យ ជាអ្នកបញ្ជាឲ្យសម្លាប់និស្សិត កម្មកររោងចក្រ ប៉ុន្តែពុំមានប្រជាជនធម្មតាត្រូវបានសម្លាប់នៅពេលនោះទេ។ [...] ឆ.១៤៨៖ ខ្ញុំដឹងរឿងនេះតែពីប្អូនជីដូនមួយរបស់ខ្ញុំប៉ុណ្ណោះ”]។

iii. ការចុះមើលរបស់ យ៉ីម ទិត្យ តាមមន្ទីរសន្តិសុខ នៅភូមិភាគពាយ័ព្យ

74. បន្ថែមលើការបញ្ជាឲ្យសម្លាប់ **យ៉ីម ទិត្យ** ក៏បានចុះមើលមន្ទីរសន្តិសុខ ក្នុងដែនទទួលខុសត្រូវរបស់គាត់ ដែលមានការដាក់គុក ការធ្វើទារុណកម្ម និងការសម្លាប់ក្រៅច្បាប់ រួមទាំងមន្ទីរសន្តិសុខនៅចកកកោះ[164] និងមន្ទីរសន្តិសុខស្រុកគាស់ក្រឡ[165]។

iv. ភ័ស្តុតាងបង្ហាញថា ល្បឿននៃការសម្លាប់ នៅភូមិភាគពាយ័ព្យ
បានកើនឡើង ក្រោយពេល យ៉ីម ទិត្យ មកដល់

75. ការអនុវត្តគោលនយោបាយស្តីពីខ្មាំង នៅភូមិភាគពាយ័ព្យ កាន់តែមានសភាពខ្លាំងក្លាឡើង ក្រោយពេល **យ៉ីម ទិត្យ** មកដល់[166]។ វាបានឈានដល់កម្រិតកំពូល នៅចុងរបបកម្ពុជាប្រជាធិបតេយ្យ មុនពេលវៀតណាមចូលលុកលុយបន្តិច[167]។ សាក្សីមួយចំនួនបានបញ្ជាក់អំពីទំនាក់ទំនងរវាងការមកដល់របស់ **យ៉ីម ទិត្យ** និងការសម្លាប់កើនឡើង។ ឧទាហរណ៍ សុខ ជាតិ ក្មួយរបស់តាប៉ែត បាននិយាយថា៖ "សម័យតាទិត្យ អត់រើសមុខទេ ឲ្យតែមនុស្សសម្លាប់ទាំងអស់ សម្លាប់ទាំងកូនង៉ាទៀត

---

[164] ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៩-២០, ២៤-២៥, ៤៧, ៤៩, ៥៣ KH 01477638-39, 43-44។

[165] ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥៦-៥៧ KH 01477645។

[166] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៥ KH 01196544 ["ពេល តាទិត្យ មក មានការសម្លាប់មនុស្សកាន់តែខ្លាំងនៅតំបន់ ១"] ឆ.៧៨ KH 01196545 ["គេល្បីថា ពេលដែល តាទិត្យ ចូលមក មនុស្សបាត់ខ្លួន"]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១០៥ KH 01205223 ["សម័យ តាទិត្យ អត់រើសមុខទេ ឲ្យតែមនុស្សសម្លាប់ទាំងអស់ សម្លាប់ទាំងកូនង៉ាទៀតផង។ ខ្ញុំឃើញលលាដ៍ក្បាលមនុស្សតូចៗប៉ុនក្បាលជង្គង់ខ្ញុំក៏មាន កូនង៉ាក៏យកទៅដែរ អត់មាននរណារួចទេ"] ឆ.១៧ KH 01205202 ["ពេលពួកនិរតីចូលមក គេចាប់ផ្តើមប្រល័យពូជសាសន៍គេខ្លាំង ព្រោះគេចាប់មនុស្សឲ្យទៅរៀនសូត្ររាល់ថ្ងៃ ពេលដែលពួកនិរតីចូលមកដល់។ កាលហ្នឹង តាទិត្យ ចូលទៅគ្រប់គ្រងនៅហ្នឹងហើយ ពេលនោះគឺរៀនសូត្ររាល់ថ្ងៃ។ ខ្ញុំចាំឆ្នាំ១៩៧៧ តែអត់ចាំខែ"] ឆ.៥២ KH 01205210។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៨៣ KH 00960673។ ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.២២-២៣ KH 01078136 ["ស៖ លោកនិយាយថា តានីម និង តាទិត្យ បានសម្លាប់មនុស្សជាច្រើននៅស្រុកសង្កែ និងស្រុកបាត់ដំបង។ តើលោកអាចប្រាប់បានទេ ថាពួកគេយកអ្នកណាទៅសម្លាប់? ឆ.២២៖ ត្រឹមត្រូវហើយ ពួកគេសម្លាប់មនុស្សជាច្រើននាក់ [...] និយាយឲ្យចំទៅ គេសម្លាប់ទាំងក្មេង ទាំងចាស់ ស្ត្រី និងកុមារ"]។

[167] ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៨៣ KH 00960673។

ផង"[168]។ ជនរងគ្រោះរួមមានទាំងអតីតកម្មាភិបាល និងអ្នកជាប់ "ខ្សែរយៈ" ព្រមទាំងជនស៊ីវិលធម្មតា និងកុមារ[169]។ បើតាម សៅ ជាប់ កម្មាភិបាលរាប់រយនាក់ត្រូវគេសម្លាប់នៅស្រុកគាស់ក្រឡមួយប៉ុណ្ណោះ[170]។

v. ចេតនាជាក់លាក់របស់ យ៉ីម ទិត្យ ក្នុងការបំផ្លិចបំផ្លាញ ក្រុមជាតិ និងពួជសាសន៍វៀតណាម និងខ្មែរក្រោម

76. ការស្អប់ និងសង្ឃ័យប្រទេសវៀតណាម ប្រជាជនវៀតណាម និងអ្វីទាំងអស់ដែលជាប់ទាក់ទងនឹងវៀតណាម គឺជាប្រធានបទខ្ជាប់ខ្ជួននៃវោហារសាស្ត្ររបស់ **យ៉ីម ទិត្យ** ពាក់ព័ន្ធនឹងខ្មាំង។ **យ៉ីម ទិត្យ** "និយាយអំពីខ្មាំងយួន" និង "ចាបងប្អូនឲ្យប្រយ័ត្នខ្មាំងយួន"[171]។ **យ៉ីម ទិត្យ** ក៏បាន "និយាយអំពីរឿងវ៉ៃជាមួយយួន" និង "និយាយអំពីរឿងខ្មាំងផ្ទៃក្នុងដែលណាក់ខ្លួនស៊ីរូងផ្ទៃក្នុងរបស់ចលនាយើង ហើយនិយាយថា យួន [...] ណាក់ខ្លួនជាមួយយើងផងដែរ"[172]។ គាត់បាននិយាយថា "មានជនបង្កប់វៀតណាមធ្វើការនៅក្នុងជួរខ្មែរក្រហម"[173] និងបានភ្ជាញ់ភ្ជែរអំពី "យួនខ្មែរ" ដែលបង្កប់នៅក្នុងជួរ ប.ក

---

[168] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១០៥ KH 01205223 ["សម័យ តាទិត្យ អត់រើសមុខទេ ឲ្យតែមនុស្សសម្លាប់ទាំងអស់ សម្លាប់ទាំងកូនង៉ាទៀតផង។ ខ្ញុំឃើញលលាដ៍ក្បាលមនុស្សតូចៗប៉ុនក្បាលជង្គង់ខ្ញុំក៏មាន កូនង៉ាក៏យកទៅដែរ អត់មាននរណារួចទេ"] ឆ.១៧ KH 01205202 ["ពេលពួកនិរតីចូលមកគេចាប់ផ្តើមប្រលប័យពូជសាសន៍គេខ្លាំង ព្រោះគេចាប់មនុស្សឲ្យទៅរៀនសូត្ររាល់ថ្ងៃ ពេលដែលពួកនិរតីចូលមកដល់។ កាលហ្នឹង តាទិត្យ ចូលទៅគ្រប់គ្រងនៅហ្នឹងហើយ ពេលនោះគឺរៀនសូត្ររាល់ថ្ងៃ។ ខ្ញុំចាំឆ្នាំ១៩៧៧ តែអត់ចាំខែ"]។

[169] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១៧, ១០៥ KH 01205202, 223។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៥, ៧៨ KH 01196544។

[170] ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១០៤-១០៦ KH 01244131-132 ["ស្រុកគាស់ក្រឡនេះ ដូចរាប់រយនាក់ឯណោះ ព្រោះតាំងពីកម្មាភិបាលតូចរហូតដល់ធំ"]។

[171] ឯកសារ D219/943 កំណត់ហេតុស្តាប់ចម្លើយ ឡម លិន ឆ.៣៧ KH 01415377។

[172] ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ ផាន់ រ៉ី ឆ.៤-៥ KH 01040094 ["ពេលនោះ តាទិត្យ [...] មាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុងដែលណាក់ខ្លួនស៊ីរូងផ្ទៃក្នុងរបស់ចលនាយើង ហើយក៏មានពួក សេ.អ៊ុ.អា កា.ហ្សេ.បេ យួន ណាក់ខ្លួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែឃ្លាំមើលពួកទាំងនេះ ហើយបើយើងបានព័ត៌មានទាក់ទងនឹងសកម្មភាពពួកទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង"]។

[173] ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃូ ភ្ជុ ឆ.១៨៤ KH 01117239។

.ក[174]។ ក្នុងពេលប្រជុំ **យ៉ាម ទិត្យ** "តែងតែនិយាយអំពីខ្មាំង ដែលគេចង់សំដៅទៅលើពួកយួន ឬវៀតណាម" និង "ចោទថាយួនហ្នឹងមានគោលបំណងលេបទឹកដីរបស់យើង"[175]។

77. អរិភាពរបស់ **យ៉ាម ទិត្យ** ចំពោះវៀតណាម បានរីករាលដាលដល់ខ្មែរក្រោមផងដែរ ពីព្រោះនៅក្នុងគោលនយោបាយរបស់ ប.ក.ក ខ្មែរក្រោម "ចាត់ទុកថាជាយួនដែរ ព្រោះរស់នៅលើទឹកដីយួន"[176]។ តា ម៉ុក បានពន្យល់ថា "ឲ្យតែអ្នករស់នៅទឹកដីយួន សុទ្ធតែយួនទាំងអស់" ហើយ "ឲ្យតែយួន គឺជាសត្រូវ"[177]។

78. ពីម ផល សមាជិកគណៈឃុំ នៅស្រុកគិរីវង់ បានឲ្យដឹងថា បញ្ហាឲ្យសម្លាប់ខ្មែរក្រោមជាច្រើននៅឃុំគោកព្រិច ស្រុកគិរីវង់ ទទួលបានពីគណៈស្រុកគិរីវង់ ក្នុងពេល **យ៉ាម ទិត្យ** ធ្វើការនៅក្នុងគណៈស្រុកនេះ[178]។

79. នៅទីបំផុត ការសង្ស័យ និងការស្អប់វៀតណាម បានក្លាយទៅជាគោលនយោបាយកម្ពុជ។ នៅក្នុងកិច្ចប្រជុំធំមួយនៅទំនប់កង្ហត ចុងសម័យកម្ពុជាប្រជាធិបតេយ្យ **យ៉ាម ទិត្យ** បាននិយាយថា

---

[174] ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ម ភ្ជុំ ឆ.១៧៥-១៧៧ KH 01117238-39 ["បាទ គឺគាត់និយាយពីរឿង "យួន" ខ្មែរ។ [...] គឺនិយាយពី "យួន" រំលោភទឹកដី។ [...] គេតាមដាន បង្កប់ផ្ទៃក្នុង ក្នុងបណ្តាញកម្មាភិបាលពីថ្នាក់ឃុំ ថ្នាក់ស្រុករហូតដល់មជ្ឈិម"]។ *សូមមើលផងដែរ* ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៣៤-១៣៥ KH 01244135។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.១៣-១៤ KH 00960664-65 ["តាទិត្យ ប្រកាសថា អ្នកដឹកនាំភូមិភាគពាយ័ព្យគឺជាជនក្បត់ ព្រោះជាប់ខ្សែរយៈយួន"]។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៣០ KH 00934389 ["គាត់និយាយថា [...] ពួកពាយ័ព្យនេះគឺ "ក្បាលយួនខ្លួនខ្មែរ" គេចោទថា ចូលដៃចូលជើងជាមួយវៀតណាម ហេតុនេះហើយទើបគេចាប់ពួកកម្មាភិបាលពាយ័ព្យសម្លាប់ចោល"]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឆ.៣០, ៣១, ៣៣-៣៤, ៤៤, ៥៥ KH 01149403-404, 406។

[175] ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៩ KH 01080844។

[176] ឯកសារ D219/900 កំណត់ហេតុស្តាប់ចម្លើយ ម្ចូល អេន ឆ.៨៣-៨៤ KH 01379795 ["[ខ្មែរក្រោម] ចាត់ទុកថាជាយួនដែរ ព្រោះរស់នៅលើទ្រលដីយួន។ [...] គេនិយាយថា ឲ្យតែអ្នករស់នៅទឹកដីយួនសុទ្ធតែយួនទាំងអស់ ហើយខ្មែរកាត់យួនដែលរស់នៅលើទឹកដីខ្មែរក៏ត្រូវគេចាត់ទុកថាជាយួនដែរ"]។

[177] ឯកសារ D219/900 កំណត់ហេតុស្តាប់ចម្លើយ ម្ចូល អេន ឆ.៨៤, ៨៧ KH 01379795 ["[តាម៉ុក] ថា ឲ្យតែយួនគឺជាសត្រូវ ហើយយោធាត្រូវធ្វើអ្វីចាំបាច់ជាមួយសត្រូវទាំងនោះ]។ *សូមមើលផងដែរ* ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.៤៥ KH 01136708 ["កា.ហ្សេ.បេ និង សេ.អ៊ីុ.អា ជាដើម។ [...] ចំណែកខ្សែ កា.ហ្សេ.បេ គឺជាប់ទាក់ទងជាមួយពួកវៀតណាម។ [...] បើយើងមានសាច់ញាតិមកពីកម្ពុជាក្រោម នោះគឺយើងជាប់ខ្សែ កា.ហ្សេ.បេ វៀតណាម"]។

[178] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ពីម ផល ឆ.១០៨-១៤៤ KH 01133426-430។ ឯកសារ D118/23 កំណត់ហេតុស្តាប់ចម្លើយ ពីម ផល ឆ.៤៣-51 KH 00891163-64។

មេដឹកនាំ ប.ក.ក "ចង់បោសសម្អាតខ្មាំងយួន [...]។ គោលដៅគេមកប្រជុំពីរឿងហ្នឹងឯង"[179]។ ពេលពិភាក្សាអំពីកិច្ចប្រជុំនេះ អ្នកចូលរួមម្នាក់បាននិយាយថា៖ "អ្នកណាជាប់ខ្សែយួន ចេះភាសាយួន បោសសម្អាតទាំងអស់"[180]។

80. បន្ថែមលើការឃោសនាសាររបស់ ប.ក.ក ស្តីពីការស្អប់ និងអរិភាពចំពោះវៀតណាម (រួមទាំងខ្សែរក្រោម) ដល់អ្នកនៅក្រោមបង្គាប់ និងប្រជាជនសាមញ្ញនៅតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ **យ៉ឹម ទិត្យ** ក៏បានចូលរួមយុទ្ធនាការប្រឆាំងនឹងវៀតណាម ដោយបញ្ជាឲ្យសម្លាប់ចោល។ បើតាម សៅ ជាប់ **យ៉ឹម ទិត្យ** បានបញ្ជាឲ្យសម្លាប់ "សេអ៊ីអា និងយួនរាប់ពាន់នាក់" ក្នុងរយៈពេលខ្លី ក្រោយពីគាត់បានមកដល់ជាលើកដំបូង ក្នុងឆ្នាំ១៩៧៦ ឬឆ្នាំ១៩៧៧[181]។ នៅឆ្នាំ១៩៧៨ ឬឆ្នាំ១៩៧៩ ជាថ្មីម្តងទៀត **យ៉ឹម ទិត្យ** បានបញ្ជាឲ្យសម្លាប់មនុស្សរាប់ពាន់នាក់ រួមទាំងវៀតណាម និងចិន[182]។

---

[179] ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.១៦, ៦២, ៦៤, ៧០-៧៥ KH 01425165, 74, 76 ["[យ៉ឹម ទិត្យ] ថា បោសម្អាតខ្មាំងយួនតែប៉ុណ្ណឹងឯង។ [...] ព្រោះគោលដៅគេមកប្រជុំពីរឿងហ្នឹងឯង។ អ្នកណាជាប់ខ្សែយួន ចេះភាសាយួនបោសសម្អាតទាំងអស់"]។ *សូមមើលផងដែរ* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ ផាន់ រ៉ី ឆ.៥ KH 01040094 ["គាត់មាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុងដែលលាក់ខ្លួនស៊ីរួងផ្ទៃក្នុងរបស់ចលនាយើង ហើយក៏មានពួក សេ.អ៊ុ.អា កា.ហ្សេ.បេ យួនលាក់ខ្លួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែប្លាំងមើលពួកទាំងនេះ ហើយបើយើងបានព័ត៌មានទាក់ទងនឹងសកម្មភាពពួកទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង"]។

[180] ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.១៦ KH 01425165 ឆ.៦២, ៦៤, ៧០-៧៥ KH 01425174, 76 ["គេថាបោសសម្អាតខ្មាំងយួនតែប៉ុណ្ណឹងឯង។ [...] ព្រោះគោលដៅគេមកប្រជុំពីរឿងហ្នឹងឯង។ អ្នកណាជាប់ខ្សែយួន ចេះភាសាយួនសម្អាតទាំងអស់។ [...] ឮថា ខ្មាំងយួនៗ"]។

[181] ឯកសារ D219/982 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៦-៣៣ KH 01477628, KH 01477629 ["អាហ្នឹងដោយគាត់ចាត់តាំងគេតើ។ [...] គាត់ឈ្មោះ អន [...] ខ្ញុំសួរថា មិត្តឯងធ្វើឃាតករសម្លាប់ប្រជាជនហ្នឹង អ្នកណាចាត់តាំងមក។ គាត់ថាឈ្មោះ ទិត្យ ហ្នឹង។ [...] ចុះបើឃើញសម្លាប់ ឃើញចាប់យកទៅសម្លាប់។ [...] អាហ្នឹងនៅគាស់ក្រឡ។ [...] រាប់ពាន់នាក់ដែរ។ ខ្ញុំសួរដែរ ថាចុះមនុស្សដែលចាប់យកទៅសម្លាប់ហ្នឹង ខុសអី វាថាជា សេ.អ៊ុ.អា យួន។ [...] នៅក្នុងឆ្នាំ តាំងពីឆ្នាំ៧៥ ហ្នឹងក៏សម្លាប់ ហើយ៧៧ ពួកនិរតីមក។ ហើយក្នុងឆ្នាំ៧៦ ហ្នឹងតាទិត្យ ចាត់តាំងរកខ្មាំង សេ.អ៊ុ.អា យួន។ អាហ្នឹងគេស្រាវជ្រាវរកចាប់រហូត។ ការចាប់ហ្នឹងទល់ពួកនិរតីចូលមក]។ ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១០-១១ KH 01477637 ["ឆ.១០៖ ខ្ញុំសួរត្រង់ថា ចាប់ហ្នឹងមានមូលហេតុអី ខុសអី។ គេថាចាប់ សេ.អ៊ុ.អា យួន ឌីបេ យួន។ ហើយខ្ញុំសួរទាំងអស់គ្នាហ្នឹង ទាំង អន, ប៉ក់ និងថាច។ ស៖ តើ ឌីបេៗ ហ្នឹងជាអី? ឆ.១១៖ ឌីបេ ដូច សេ.អ៊ុ.អា យួន ដូចតែគ្នា ពាក្យគេ"]។

[182] ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ឿន ឆ.១៣៨-១៤៤ KH 00980116 ["ខ្ញុំឮអ្នកសម្លាប់មនុស្សនៅភូមិភាគពាយ័ព្យនិយាយថា មានការសម្លាប់មនុស្សរាប់ពាន់នៅក្នុងភូមិភាគពាយ័ព្យ រួមមាននិស្សិតផងដែរ។ [...] ប្អូនជីដូនមួយរបស់ខ្ញុំដែលជាអ្នកសម្លាប់មនុស្សនៅភូមិភាគពាយ័ព្យជាអ្នកប្រាប់ខ្ញុំអំពីរឿងនេះ។ [...] ការសម្លាប់មនុស្សនេះគឺនៅជំរ

81. ភ័ស្តុតាងនៃការកំនុំរបស់ **យ៉ីម ទិត្យ** ចំពោះវៀតណាម និងខ្មែរក្រោម គួបផ្សំនឹងភ័ស្តុតាងនៃការកម្ទេចវៀតណាម និងខ្មែរក្រោម នៅតំបន់ក្រោមការគ្រប់គ្រងរបស់ **យ៉ីម ទិត្យ** បង្កើតបានជាភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាថា **យ៉ីម ទិត្យ** មានចេតនាបំផ្ទិចបំផ្លាញក្រុមជាតិវៀតណាម នៅកម្ពុជា (ជាពិសេស ខ្មែរក្រោម ដែលគាត់ និងសមាជិក JCE ដទៃទៀត យល់ឃើញថាមិនអាចទុកចិត្តបាន ដោយសារតែពួកគេមានសញ្ជាតិវៀតណាម)។

ខ. ការចូលរួមចំណែករបស់ យ៉ីម ទិត្យ ក្នុងការអនុវត្តគោលនយោបាយ ស្តីពីការរៀបការដោយបង្ខំរបស់ ប.ក.ក

82. ដូចនៅភូមិភាគនិរតីដែរ **យ៉ីម ទិត្យ** បានចូលរួមចំណែកក្នុងការអនុវត្តគោលនយោបាយស្តីពីការរៀបការដោយបង្ខំ នៅភូមិភាគពាយ័ព្យ។ **យ៉ីម ទិត្យ** បានចូលរួមក្នុងពិធីរៀបការ ក្រោមអធិបតីភាពរបស់ តាម៉ុក[183] ហើយក្នុងពេលនោះ ស្ត្រីមួយក្រុមមានគ្នាប្រហែល ៣៨ នាក់ ត្រូវគេបង្ខំឲ្យរៀបការជាមួយទាហានពិការមួយក្រុម ដែលពួកគេទើបតែបានជួបគ្នានៅថ្ងៃនោះ។ ស្ត្រីម្នាក់ ជាអនុលេខាស្រុកសំឡូតឈ្មោះ ណុប ង៉ីម បានផ្តល់សក្ខីកម្មថា មាន ៣៨ គូ ត្រូវគេបង្ខំឲ្យរៀបការនៅក្នុងពិធីតែមួយ ហើយស្ត្រីខ្លះស្រែកយំ។ គាត់បានបន្ថែមថា៖

> ខ្ញុំយំដែរហ្នឹង។ ប៉ុនអត់ចិត្ត អន់ដឹងខ្លួនសោះ អន់ចិត្តៗមាំណាស់ ព្រោះអីអត់ដែលឃើញ វាដែលឃើញ ផ្ទាប់ឃើញគ្នា កាលនៅទ័ពដូចគ្នា ប៉ុនដល់តែចាប់ដាក់អ៊ីចឹង ខ្ញុំអន់ចិត្ត ខ្ញុំចង់រត់ដែរ ប៉ុន្តែខ្លាចគេវ៉ៃចោល កុំអីរត់បាត់ហើយ។ អ៊ីចឹង ចេះតែទ្រាំ[184]។

83. ព្រាប កប ជាប្តីរបស់នាង បាននិយាយថា គាត់មិនទាំងដឹងថាក្រុមរបស់គាត់នឹងត្រូវរៀបការផងរហ្ងតទាល់តែទៅដល់មន្ទីរស្រុកសំឡូត ទើបគេប្រាប់ថា ពួកគាត់ត្រូវទៅចូលរួមប្រជុំរៀនសូត្រ

តារអន នៅខាងលិចទីរួមខេត្តបាត់ដំបង ដែលកន្លែងនោះនៅក្រោមការគ្រប់គ្រងរបស់តាទិត្យ។ [...] បាទ គាត់និយាយថាជាបញ្ជារបស់ តាទិត្យ] ឆ.១៤៥ KH 00980116 ["ស៖ តើកន្លឹងសម្លាប់មនុស្សនេះស្ថិតនៅក្នុងស្រុកណា? ឆ.១៤៥៖ នៅក្នុងស្រុកព្រះនេត្រព្រះ]។ *សូមមើលផងដែរ* ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៤០-៤៣, ៥៥ KH 00788846-47 [ភ្ជនាទីរបស់គណៈកម្មាធិការស្រុកគិរីវង្សក្នុងការចាប់ខ្លួន និងសម្លាប់ខ្មែរក្រោម]។

[183] ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៧៣ KH 01008708 ["ស៖ នៅក្នុងពិធីរៀបការនោះ តើ តាទិត្យ បានមកចូលរួមដែរឬទេ? ឆ.៧៣៖ គាត់បានមកជួប ហើយនិយាយគ្នាជាមួយ តាម៉ុក មុនពេលចាប់ផ្តើមពិធីរៀបការ ខ្ញុំមិនដឹងថាគាត់និយាយអ្វីជាមួយ តាម៉ុក ទេ"]។

[184] ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារ៉ឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.41.32-10.43.35។

នយោបាយ[185]។ ព្រាប កប បានបន្ថែមថា "គ្មាននរណាសួរខ្ញុំថា ចង់រៀបការ ឬក៏អត់ទេ។ តែយើងត្រូវធ្វើតាមបញ្ញា និងការណែនាំរបស់គេ បើមិនដូច្នេះ យើងនឹងមានបញ្ហា"[186]។

84. **យ៉ីម ទិត្យ** បានចែកគ្រែ និងអង្រឹង ដល់គូស្វាមី-ភរិយាថ្មោងថ្មី សម្រាប់គេង[187] ហើយក្រោយពីរៀបការរួច គាត់បានប្រាប់ពួកគេឲ្យ "ចេះស្រឡាញ់គ្នា"[188] ដោយបានបង្ហិតបង្ខំយ៉ាងច្បាស់ក្រឡែតឲ្យពួកគេ ដែលជាជនរងគ្រោះជាក់ស្តែងនៃការរៀបការដោយបង្ខំ ឲ្យរួមដំណេក។ **យ៉ីម ទិត្យ** បានប្រាប់គូស្វាមី-ភរិយាថ្មោងថ្មីថា៖ "មិត្តអើយធ្វើតាមអង្គការចាត់តាំង"។ ត្រង់ចំណុចនេះ ណុប ធឹម យល់ថាមានន័យថាគូស្វាមី-ភរិយាថ្មោងថ្មីត្រូវគេតម្រូវឲ្យរួមដំណេកជាមួយគ្នា[189]។

គ. ការចូលរួមចំណែករបស់ យ៉ីម ទិត្យ ក្នុងការអនុវត្តគោលនយោបាយ ស្តីពីការដាក់ឲ្យទៅជាទាសករបស់ ប.ក.ក

85. **យ៉ីម ទិត្យ** បានចូលរួមចំណែកក្នុងទិដ្ឋភាពកសិកម្ម និងសេដ្ឋកិច្ច នៃផែនការឧក្រិដ្ឋរួម ដែលស្នើនឹង និងនាំទៅដល់ការប្រព្រឹត្តអំពើដាក់ឲ្យទៅជាទាសករ និងឧក្រិដ្ឋកម្មដទៃទៀត នៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ ដោយសារតែឧក្រិដ្ឋកម្មចោទប្រកាន់ទាំងអស់ ពាក់ព័ន្ធនឹងគោលនយោបាយទាំងនេះ បានកើតឡើងនៅភូមិភាគពាយ័ព្យ ភ័ស្តុតាងទាំងអស់នៃការចូលរួមចំណែករបស់គាត់ក្នុងគោលនយោបាយទាំងនេះត្រូវបានប្រមូលផ្តុំ នៅក្នុងផ្នែកនេះ។

86. គោលនយោបាយកសិកម្ម និងសេដ្ឋកិច្ច របស់ ប.ក.ក តម្រូវឲ្យរក្សាទុកកម្លាំងពលកម្មដ៏ធំសម្បើម ក្នុងលក្ខខណ្ឌអមនុស្សធម៌ ជាមួយនឹងគោលដៅទ្វេនៃការគ្រប់គ្រងប្រជាជន (ហើយដោយហេតុនេះ

---

[185] ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៥១ KH 01037145។

[186] ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៧៥ KH 01037139។

[187] ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៤៤ KH 01037143។

[188] ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៤៦-៤៧ KH 01037144។

[189] ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ធឹម ឆ.១៤៩-១៥២ KH 01329405 ["អ៊ីទិត្យ គាត់អ្នកបង្ហូបបង្ហូម [...] គាត់ថា មិត្តអើយធ្វើតាមអង្គការចាត់តាំង។ ស៖ មានន័យថាម៉េច អង្គការចាត់តាំង? ឆ.១៥០៖ យើងត្រូវធ្វើតាមអង្គការចាត់តាំង ពីចិត្តយើង។ ស៖ ការធ្វើតាមអង្គការនោះ តើមានន័យថាពួកលោកស្រីត្រូវរួមដំណេកជាមួយបុរសជាប្តីមែនទេ? ឆ.១៥១៖ ចាស តែការហើយត្រូវដេកជាមួយគ្នាហ្ម៉ង្គហើយ។ ស៖ តើនោះជាអ្វីដែលលោកស្រីយល់ពីការណែនាំរបស់ តាទិត្យ មែនទេ? ឆ.១៥២៖ ចាស"]។ ឯកសារ D219/974.1.2 ណុប ធឹម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.06.50-11.07.54។

អាចទប់ទល់នឹងការប្រឆាំងដែលអាចកើតមានឡើង) និងការបង្កើនផលិតកម្មកសិកម្ម[190]។ ការរក្សាទុកកម្មករដែលស្ពាប់បង្ហាប់ និងមានផលិតភាព ក្នុងលក្ខខណ្ឌគួរឲ្យរន្ធត់ តម្រូវឲ្យមានការបង្កើតបរិយាកាសភ័យខ្លាច តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្ម។ កម្មករ និងកម្មាភិបាលថ្នាក់ទាប ត្រូវគេដាក់ផែនការការងារឲ្យធ្វើ និងកាលកំណត់មិនអាចសម្រេចបាន ហើយទទួលរងនូវការគំរាមកំហែងថាមានគ្រោះថ្នាក់ ឬស្លាប់ ប្រសិនបើពួកគេធ្វើមិនហើយ។ ពួកគេត្រូវបានបង្អត់អាហារ មិនឲ្យសម្រាក និងមិនទទួលបានការសម្រួលខាងអនាម័យ ក្នុងពេលដំណាលគ្នា។ ប្រការនេះអនុញ្ញាតឲ្យ ប.ក.ក ទាញយកផលិតភាពជាអតិបរមាពីកម្លាំងពលកម្មរបស់ខ្លួន ក្នុងតម្លៃអប្បបរមា ហើយទន្ទឹមនឹងនោះ លុបបំបាត់លទ្ធភាពរបស់កម្មករក្នុងការតវ៉ា ឬប្រឆាំងនឹងទិដ្ឋភាពណាមួយនៃការប្រព្រឹត្តចំពោះពួកគេ ឬប្រឆាំងនឹងរបបខ្មែរក្រហម។

87. **យ៉ាម ទិត្យ** ដើរតួយ៉ាងសំខាន់ក្នុងការបង្កើតបរិយាកាសភ័យខ្លាចដែលអាចឲ្យប្រព័ន្ធនេះដំណើរការ។ លោកបានបញ្ជាក់យ៉ាងច្បាស់ថា អ្នកដែលមិនអាចបញ្ចប់ការងារបាន ពោលគឺ អ្នក "ខ្ជិល" ត្រូវចាត់ទុកជាខ្មាំង ហើយទទួលរងទណ្ឌកម្មធ្ងន់ធ្ងរ រួមទាំងបាត់ខ្លួន និងស្លាប់។ ក្នុងកិច្ចប្រជុំមួយរបស់ កងសិប្បកម្មស្រុកគិរីវ៉ង់ គាត់បានប្រាប់កម្មករថា ពួកគេ "ត្រូវប្រយ័ត្នខ្លួន និងខំប្រឹងធ្វើការ" ហើយ "ព្រមានថាប្រយ័ត្នបាត់ខ្លួន"។ នេះជាការគំរាមកំហែង ដែលអ្នកចូលរួមប្រជុំម្នាក់យល់ថាជាការអនុវត្តចំពោះកម្មករ ដែលមិនអាចសម្រេចការងារបានតាមផែនការ[191]។ ចំពោះការផលិតកប្បាសនៅការដ្ឋានជាក់លាក់មួយ **យ៉ាម ទិត្យ** បាននិយាយថា "បើដាំកប្បាសមិនបាន ដង្ហូរស៊ីកប្បាស ដង្ហូរនឹង

---

[190] *សូមមើល* ផ្នែក VIII.ខ.១.ខ. ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល-ទម្រង់នៃការទទួលខុសត្រូវ-ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម-គោលនយោបាយស្តីពីការដាក់ឲ្យធ្វើជាទាសករ។

[191] ឯកសារ D118/33 កំណត់ហេតុស្ពាប់ចម្លើយ អ៊ំ គុណ ឆ.២៨-៣០, ៣៧-៣៨ KH 00900696-97 ["ឆ.២៨៖ [...] ខ្ញុំធ្លាប់ប្រជុំជាមួយតាទិត្យ ពេលដែលគាត់មកកន្លែងសិប្បកម្ម។ [...] ស៖ តើ តាទិត្យ ដែលនិយាយពីរឿងខ្មាំងដែរឬទេ? ឆ.៣៧៖ គាត់និយាយថា យើងត្រូវប្រយ័ត្ន ខំធ្វើការ ព្រោះមានខ្មាំងបង្ករច្រើនណាស់ ហើយគាត់និយាយថា ប្រយ័ត្នបាត់ខ្លួន។ នៅកន្លែងសិប្បកម្មនោះ ខ្ញុំមិនឃើញមានការបាត់ខ្លួនអ្វីទេ។ [...] ស៖ តាទិត្យ និយាយពីពាក្យខ្មាំងបង្ករ តើខ្មាំងនោះជាខ្មាំងប្រភេទណាដែរ? ឆ.៣៨៖ ចំពោះខ្ញុំយល់ពាក្យថា ខ្មាំងនោះគឺគេសំដៅលើកម្មករដែលធ្វើការមិនគ្រប់គ្រាន់តាមផែនការណ៍ ដូច្នេះគេចេះតែចោទថាជាខ្មាំងហើយ]។ កំណត់សម្គាល់ អ៊ំ គុណ បានកត់សម្គាល់ថា គាត់មិនបានឃើញអ្នកណាម្នាក់បាត់ខ្លួនឡើយ នៅកន្លែងការងាររបស់គាត់ ហើយថា បើគាត់មិនអាចបំពេញតាមផែនការការងារទេ គាត់"គ្រាន់តែរាយការណ៍ទៅថ្នាក់លើ ហើយបន្ទាប់មកគ្មានរឿងអ្វីកើតឡើងចំពោះ [គាត់] ទេ។ *សូមមើល* ឯកសារ D118/33 កំណត់ហេតុស្ពាប់ចម្លើយ អ៊ំ គុណ ឆ.១៥, ៣៧ KH 00900695, 97។

ស៊ីមនុស្សទៀត”[192]។ នេះជាការគំរាមកំហែងយ៉ាងច្បាស់ថា បើដំណាំមិនបានផល កម្មករ ឬអ្នកគ្រប់គ្រង អាចត្រូវគេសម្លាប់ចោល។ ក្រៅពីការគំរាមកំហែងជាចំហ ទាក់ទងនឹងការមិនអាចសម្រេចការងារតាមគោលដៅផលិតកម្ម **យឹម ទិត្យ** ក៏បានធ្វើការគំរាមកំហែងដោយប្រយោល តាមរយៈការប្រើការប្រជុំដដែល ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងការតាមដាន និង “កម្ទេច” ខ្មាំង ការកំណត់គោលដៅផលិតកម្ម និងការជំរុញឲ្យកម្មករខំប្រឹងធ្វើការជាងមុន[193]។ ឆឺន ឈ្លួយ បាននឹក

---

[192] ឯកសារ D219/64 កំណត់ហេតុស្តាប់ចម្លើយ ពៅ គឿន ឆ.៣០ KH 01037176 [“ខ្ញុំឮគេនិយាយថា តាទិត្យ បានបញ្ជាទៅតាកី ថា “បើដាំកប្បាសមិនបាន! ដង្កូវស៊ីកប្បាស ដង្កូវនឹងស៊ីមនុស្សទៀ”]។

[193] ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហែម ឈួន ឆ.១៩ KH 00905854 [“ប្រជុំនៅការដ្ឋាននោះ គាត់និយាយពីការធ្វើស្រែមួយហិកតា ៣ តោន ហើយនិយាយពីសកម្មភាពខ្មាំង។ កាលណោះសូម្បីតែភ្វាក់ ក៏ត្រូវភ្វាក់ពីពាក្យមួយហិកតា ៣តោនដែរ]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ ផាន់ វី ឆ.៣ KH 01040093-94 [“តាប៉ែត បានប្រកាសនៅក្នុងអង្គប្រជុំថា តាទិត្យ មកពីភូមិភាគនិរតីមកជួយដឹកនាំពួកយើងនៅក្នុងតំបន់ ១។ កាលនោះ គឺមានការប្រជុំមួយយ៉ាងធំ ដែលចូលរួមដោយប្រជាជន ប្រធានភូមិ ប្រធានឃុំ ស្រុក ហើយមានមនុស្សទាំងអស់ប្រហែល ៧០០ ទៅ ៨០០ នាក់។ កាលប្រជុំពេលនោះ គឺធ្វើឡើងនៅនឹងកន្លែងសាងសង់ទំនប់កង្គួត] ឆ.៤-៥ EN 01061169 [“ឆ.៤៖ គាត់បាននិយាយនៅក្នុងអង្គប្រជុំអំពីរឿងវៃជាមួយយួន [...] ស៖ តើ តាទិត្យ គាត់មានបាននិយាយអំពីខ្មាំងផ្ទៃក្នុងប្រឆាំងនឹងអង្គការដែរឬទេ? ឆ.៥៖ បាទ គាត់មាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុងដែលលាក់ខ្លួនស៊ីរូងផ្ទៃក្នុងរបស់ចលនាយើង ហើយក៏មានពួក សេ.អ៊ី.អា កា. ហ្សេ. បេឃួន លាក់ខ្លួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែឃ្លាំងមើលពួកទាំងនេះ ហើយបើយើងបានព័ត៌មានទាក់ទងនឹងសកម្មភាពពួកទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង] ឆ.៧ EN 01061170 [រៀបរាប់អំពីមេឃុំមួយរូបដែលមានឈ្មោះថា ឆេង ដែលរាយការណ៍អំពីការសម្លាប់មនុស្សដែលប្រព្រឹត្តខុសសីលធម៌ ហើយបន្ទាប់មកបញ្ជាក់ថា “ពេលដែល ឆេង កំពុងនិយាយរៀបរាប់របាយការណ៍នេះ តាទិត្យ ហើយនិង តាប៉ែត គាត់អង្គុយចាំស្តាប់ និងកត់ត្រា។ បន្ទាប់មកទៀត ប្រធានសហករណ៍/ឃុំទាំង៤ ត្រូវបានហៅឡើងរាយការណ៍អំពីដំណាំភោគផលនៅក្នុងភូមិទាំងឡាយដែលនៅក្នុងឃុំនីមួយៗ]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ឆឺន ឈ្លួយ ឆ.៣០ KH 01149403 [“បន្ថែមពីនេះទៀត គេបានលើកទឹកចិត្តឲ្យប្រជាជនខិតខំធ្វើស្រែឲ្យបាន ៥ ទៅ ៦ តោនក្នុងមួយហិកតា។ គេក៏បាននិយាយអំពីបញ្ហាគិញសម្ងាត់ និងអ្នកជាប់ខ្សែយួនផងដែរ] ឆ.៥៥ KH 01149407 [“តាទិត្យ និយាយតែម្នាក់ឯងប៉ុណ្ណោះនៅក្នុងកិច្ចប្រជុំនេះ]។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ យូ ភ្នំ ឆ.១៧៤-១៧៧ KH 01117239-40 [“ស៖ លោកបាននិយាយថា តាទិត្យ បាននិយាយនៅក្នុងកិច្ចប្រជុំ។ តើនេះជាកិច្ចប្រជុំប្រភេទអ្វីដែរ? ឆ.១៧៤៖ ប្រជុំអប់រំប្រជាជនពីការងារជីកប្រឡាយ លើកទំនប់ បង្កបង្កើនផល។ [...] ឆ.១៧៥ [...] គឺគាត់និយាយពីរឿង “យួន” ខ្មែរ។ [...] ឆ.១៧៦៖ គឺនិយាយពី “យួន” រំលោភទឹកដី។ [...] ឆ.១៧៧៖ គេតាមដាន បង្កប់ផ្ទៃក្នុង ស៊ីរូងផ្ទៃក្នុង ក្នុងបណ្តាញកម្មាភិបាលពីថ្នាក់ឃុំ ថ្នាក់ស្រុក រហូតដល់មជ្ឈិម]។ ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១៦១-១៦២, ១៦៨, ១៧០ KH 01335570-71។ ឯកសារ D219/111 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ឆោម ឆ.៥៩, ៦៣, ៦៥, ៦៧ KH 01045274 [“តាទិត្យ ធ្លាប់ហៅមនុស្សឲ្យចូលរួមប្រជុំទូទៅ [...] និយាយគឺ អ្នកនៅខាងក្រោយប្រឹងបង្កបង្កើនផល ហើយអ្នកនៅខាងមុខប្រឹងវៃខ្មាំង]។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.៩២, ៩៥, ៩៨ KH 01046468-69 [“ខ្ញុំចាំថា ខ្ញុំបានទៅរៀនសូត្រ តាទិត្យ បាននិយាយអំពីការធ្វើទំនប់ ជី

ឃើញកិច្ចប្រជុំមួយ ដែល **យ៉ាម ទិត្យ** បានលើកទឹកចិត្តឲ្យ "ប្រជាជនខិតខំធ្វើស្រែ" ខណៈពេលដែលក្រោយមកគាត់បានដាស់តឿនអ្នកចូលរួមប្រជុំអំពី "បញ្ហាគិញសម្ងាត់ និងអ្នកជាប់ខ្សែយួនផងដែរ"[194]។ ស្រដៀងគ្នានេះដែរ ក្នុងកិច្ចប្រជុំដែល ណុប ង៉ីម បានរៀបរាប់ **យ៉ាម ទិត្យ** បានប្រាប់អ្នកនៅក្រោមបង្គាប់គាត់ថាពួកគេត្រូវកសាងខ្ជាំងជាមុនសិន រួចទើបសម្លាប់ចោល ហើយគាត់ក៏បាន "ជំរុញពួកយើងឲ្យដឹកនាំឲ្យបានល្អ [...] ហើយនិងខិតខំប្រឹងប្រែងកសាងប្រទេសជាតិ និងការពារប្រទេសជាតិឲ្យបានរុងរឿងទៅមុខ[195]។ ភាពបន្តគ្នានៃការពិភាក្សាអំពីការកម្ទេចខ្ជាំង និងការពិភាក្សាអំពីការសម្រេចគោលដៅសេដ្ឋកិច្ច បញ្ជាក់យ៉ាងច្បាស់ចំពោះអ្នកទាំងអស់ដែលមានវត្តមានថា សុវត្ថិភាពរបស់ពួកគេអាស្រ័យលើការបំពេញការងារបានជោគជ័យ។ ការយល់ឃើញនេះត្រូវបានពង្រឹងដោយឧក្រិដ្ឋកម្មជាបន្តបន្ទាប់ប្រឆាំងនឹងកម្មករ[196]។ វាក៏ច្បាស់ផងដែរចំពោះកម្មាភិបាលថ្នាក់ទាបដែលចូលរួមប្រជុំ (ដូចជា ប្រធានកងចល័ត) ថា សុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគេអាស្រ័យលើផលិតកម្មជោគជ័យ ហើយពុំមានផលវិបាកអ្វីទេចំពោះការបង្ខំកម្មករ ក្រោមការគ្រប់គ្រងរបស់ពួកគេ ឲ្យសម្រេចតាមផែនការខ្ពស់របស់ថ្នាក់ដឹកនាំ។

88. ក្រៅពីការគំរាមកំហែងកម្មករ **យ៉ាម ទិត្យ** ក៏បានធ្វើឲ្យប្រាកដថា កម្មករដឹងថាពួកគេកំពុងត្រូវបានឃ្លាំមើល។ ក្នុងកិច្ចប្រជុំដែល ទូច ម៉ារី បានចូលរួម **យ៉ាម ទិត្យ** បានផ្លែងថា៖ "រឿងការងារថា មាន

ក្រប្ឡាយ ដើម្បីទប់ទឹកធ្វើស្រែ ដើម្បីឲ្យប្រទេសរីកចម្រើនបានលឿន] ឯ.១០០ EN 01079025 ["គាត់និយាយថា យើងត្រូវខំធ្វើការលើកទំនប់ ជីកប្រឡាយ ដើម្បីឲ្យប្រជាជនមានហូបចុកគ្រប់គ្រាន់ កុំឲ្យខ្ជាំងវាយប្រហារ ឬបង្ហត់បាយយើង"]។ ឯកសារ D118/245 កំណត់ហេតុស្តាប់ចម្លើយ ជួន ថន ឯ.១២ KH 00990644 ឯ.១៦-១៧ KH 00990645 ["តាមដែលខ្ញុំនឹកឃើញនៅពេលនោះ គេនិយាយអំពីការបង្កបង្កើនផល ក្នុងមួយហិកតាឲ្យបានបីទៅបួនតោន។ គេនិយាយអំពីការជ្រើសរើសពូជស្រូវឲ្យល្អសម្រាប់ដាំ ហើយឲ្យដាំដំណាំយុទ្ធសាស្ត្រខ្លះ ដូចជាដំឡូង អំពៅ ឬល្ពៅជាដើម។ [...] តាទិត្យ គឺជាអ្នកដែលនិយាយអំពីរឿងរ៉ាវដែលខ្ញុំបានជម្រាបអម្បាញ់មិញនេះ។ គាត់បាននិយាយថា គាត់បានទទួលព័ត៌មានជាច្រើនអំពីប្រធានសហករណ៍ ទាក់ទងនឹងអំពើចោរកម្ម ហើយនិងសកម្មភាពខ្ជាំងនៅតាមមូលដ្ឋានជាច្រើន។ គាត់បានណែនាំឲ្យយើងតាមដានសកម្មភាពទាំងនេះជាប្រចាំ។ បើយើងតាមដានឃើញសកម្មភាពទាំងនេះ គឺយើងត្រូវតែយកទៅណែនាំជាមុនសិន មុននឹងយកទៅកម្ទេច ហើយរាយការណ៍ទៅថ្នាក់លើ"]។

[194] ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឯ.៣០, ៥៥ KH 01149403, 07។

[195] ឯកសារ D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឯ.១៥ KH 01095988។

[196] *សូមមើល* V.ខ.២.ខ.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់ ១ – សហករណ៍ធិបតី – ឧក្រិដ្ឋកម្ម ។ V.ខ.២.គ.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់ ១ – ការដ្ឋានពលកម្មដោយបង្ខំទំនប់កង្ហត – ឧក្រិដ្ឋកម្ម ។ V.ខ.២.ឃ.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់ ១ – រោងចក្រស្ករសកំពង់គល់ – ឧក្រិដ្ឋកម្ម ។ V.ខ.៤.ខ.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់ ៤ – ឃុំកំពង់ព្រៀង – ឧក្រិដ្ឋកម្ម។

តាមដាន គេឲ្យយើងប្រយ័ត្នខ្លួន"[197]។ ទូច ម៉ារី យល់ឃើញថា នេះជាការគំរាមកំហែងថា អ្នកដែលមិនអាចសម្រេចការងារបាន អាចមានគ្រោះថ្នាក់ ឬត្រូវសម្លាប់ចោល[198] ពីព្រោះគាត់បានដឹងអំពីចំនួនអ្នកបាត់ខ្លួនច្រើន ដោយសារតែ "កំហុស" ដូចជា ឈឺ ឬអង្គុយចុះដើម្បីសម្រាក[199]។ **យ៉ីម ទិត្យ** ក៏បានធ្វើឲ្យប្រាកដក្នុងចិត្តថាអ្នកក្រោមបង្គាប់គាត់យល់ថា ពួកគេត្រូវបានតម្រូវឲ្យតាមដានផលិតភាពរបស់កម្មករ។ ណុប ងឹម ចាំបានថា **យ៉ីម ទិត្យ** និងតាម៉ុក បានណែនាំគាត់ឲ្យតាមដានកម្មករណាខំប្រឹងធ្វើការ (ពួកគេប្រើពាក្យ "សកម្ម") កម្មករណាមិនខំប្រឹងធ្វើការ[200]។

89. ការគំរាមកំហែងរបស់ **យ៉ីម ទិត្យ** មានឥទ្ធិពលដោយចេតនា ក្នុងការបង្កើតបរិយាកាសភ័យខ្លាចដែលជំរុញឲ្យកម្មករខិតខំផលិតឲ្យបានច្រើន តាមដែលអាចធ្វើទៅបាន។ ដុស ឌឿន កម្មករនៅទំនប់កង្ហត បាននិយាយថា ពេល **យ៉ីម ទិត្យ** មកដល់ការដ្ឋាន ដើម្បី "[ពិនិត្យមើល] អ្នកធ្វើការ" "បើអ្នកណាខ្ជិលច្រអូស ដឹងតែវ៉ៃចោលហើយ" [201]។ សោម វណ្ណា កម្មករនៅទំបន់កង្ហត បានរៀបរាប់អំពីឥទ្ធិពលនៃវត្តមានរបស់ **យ៉ីម ទិត្យ** ក្នុងអារម្មណ៍របស់កម្មករ និងមេកង៖ "ជាធម្មតាមុនពេល តាទិត្យ ចុះមកដល់កន្លែងកងយើង ប្រធានកងយើងតែងតែព្រមានប្រាប់យើងថា កុំឲ្យឈប់សម្រាកពីធ្វើការ។ បើសិនជាសមមិត្តទទួលខុសត្រូវគម្រោងការងារមកដល់ ហើយឃើញពួកយើងអសកម្ម ពួកយើងនឹងត្រូវបាត់ខ្លួនជាមិនខាន"[202]។ សោម វណ្ណា ក៏បាននិយាយថា មេកងប្រាប់ថា "បើឃើញ តាទិត្យ ទៅកន្លែងណា ត្រូវប្រុងប្រយ័ត្ន ព្រោះពេលដែល តាទិត្យ ទៅដល់កន្លែងណា គឺតែងតែមាននាំមនុស្សចេញទៅវិញ" ហើយគាត់បានបញ្ជាក់ថា៖ "បើឃើញ តាទិត្យ មក គឺដឹងតែ

---

[197] ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១៦៨ KH 01335571 ["និយាយពីរឿងការងារល្អិតល្អន់ រឿងការងារថា មានតាមដាន គេឲ្យយើងប្រយ័ត្នខ្លួន]។

[198] ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១៦៨ KH 01335571 ["បើយើងធ្វើការមិនកើត គេថាយើងខ្ជាំង គេហៅយើងទៅប្រជុំកន្លែងផ្សេង គេយកទៅសម្លាប់ហើយ"]។

[199] ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១៧៥-១៧៧ KH 01335572 ["ឆ.១៧៥៖ [...] អ្នកណាឈឺល្មមៗ យើងមិនហ៊ានប្រាប់គេ។ ដល់យើងអង្គុយ គេហៅទៅប្រជុំ។ ដល់តែទៅប្រជុំ បាត់ហើយ ឲ្យតែហៅទៅប្រជុំ។ ស៖ តើលោកស្រីធ្លាប់បានឃើញនរណាម្នាក់បាត់ខ្លួនឬទេ? ឆ.១៧៦៖ ធ្លាប់ឃើញ។ ស៖ តើលោកស្រីធ្លាប់ឃើញប៉ុន្មាននាក់? ឆ.១៧៧៖ ឃើញច្រើនគ្នាដែរហ្ម៏ង]។

[200] ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.៣៣ KH 01329392។

[201] ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.២១៨-២១៩ KH 01305018 ["គាត់ដើរ និងត្រួតអ្នកធ្វើការ។ [...] បើអ្នកណាខ្ជិលច្រអូស ដឹងតែវ៉ៃចោលហើយ"]។

[202] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៥ KH 01080873។

បាត់ខ្លួនមនុស្សហើយ”[203]។ ស្រដៀងគ្នានេះដែ សុខ រ៉ុ កម្មករនៅការដ្ឋានស្រុកគីរីវង់ បានរៀបរាប់ឡើងវិញអំពីការភ័យខ្លាច ក្នុងចំណោមកម្មករ ពេល **យ៉ាម ទិត្យ** មកមើលការដ្ឋាន ដោយបានបញ្ជាក់ថា៖ “ពេលកំពុងធ្វើការ សមាជិកកងបាននិយាយថា តាទិត្យ ទៅទីនោះ កុំមាត់! [យើងត្រូវ] ខំប្រឹងធ្វើការ។ ពេលថ្នាក់លើមកដល់ សមាជិកកងបានប្រាប់គ្នាកុំឲ្យមាត់។ យើងមិនហ៊ានឈប់ធ្វើការទេ ពីព្រោះយើងខ្លាចគេ” [204]។

90. បរិយាកាសភ័យខ្លាចនេះបានប៉ះពាល់ដល់កម្មាភិបាលថ្នាក់ទាប ដែលគ្រប់គ្រងកម្មករផងដែរ។ តុប សៀង អ្នកធ្វើការក្នុងកងចល័តនៅទំនប់កង្ហត ចាំបានថា ពេល **យ៉ាម ទិត្យ** មកមើលការដ្ឋានម្តងៗ ឈ្មោះ យេ ជាមេរបស់ តុប សៀង បានកោះប្រជុំ ដើម្បីជំរុញកម្មករឲ្យខំប្រឹងធ្វើការជាងមុន[205]។ ស្រដៀងគ្នានេះដែរ មេកងរបស់ សោម វណ្ណា បានព្រមានមិនឲ្យឈប់ធ្វើការ រៀងរាល់ពេល មុន **យ៉ាម ទិត្យ** មកពិនិត្យការដ្ឋាន ដោយគាត់ដឹងថា “បើសិនជាសមមិត្តទទួលខុសត្រូវគម្រោងការងារមកដល់ ហើយឃើញពួកយើងអសកម្ម ពួកយើងនឹងត្រូវបាត់ខ្លួនជាមិនខាន”[206]។

91. ភ័ស្តុតាងបង្ហាញថា សូម្បីតែកម្មករដែលមិនធ្លាប់ឃើញ **យ៉ាម ទិត្យ** ក៏ដឹងអំពីការគំរាមកំហែងដោយផ្ទាល់ និងដោយប្រយោលរបស់ **យ៉ាម ទិត្យ** ចំពោះសុវត្ថិភាពរបស់ពួកគេ។ ឃុន សាម៉ៀន នឹកឃើញថា ទោះបីជាគាត់មិនធ្លាប់ឃើញ **យ៉ាម ទិត្យ** ក៏ដោយ ក៏គាត់បានដឹងអំពីការភ័យខ្លាចដែល

---

[203] ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឯ.៣៩, ៤១, ៤៤ KH 01032223-01032224 [“ខ្ញុំពួនៅក្នុងកងចល័តរបស់ខ្ញុំគឺ យើងត្រូវប្រុងប្រយ័ត្ន បើឃើញ តាទិត្យ ទៅកន្លែងណាត្រូវប្រុងប្រយ័ត្ន ព្រោះពេលដែល តាទិត្យ ទៅដល់កន្លែងណាគឺ តែងតែមានទាំមនុស្សចេញទៅវិញ។ [...] តែបើឃើញមុខ តាទិត្យ នៅពេលថ្ងៃ ឃប់ឡើងគឺនឹងមានបាត់ខ្លួនមនុស្សហើយ [...] ព្រោះខ្ញុំបានឃើញបាត់មនុស្សមែន។ តាទិត្យ មិនបានមកការដ្ឋានធ្វើការពួកខ្ញុំទេ គាត់គ្រាន់តែដើរកាត់ការដ្ឋាន ហើយទៅកន្លឹងរបស់មេការដ្ឋាន។ បើឃើញ តាទិត្យ មកគឺដឹងតែបាត់ខ្លួនមនុស្សហើយ”]។

[204] ឯកសារ D119/108.2 កិច្ចសម្ភាសន៍របស់ សុខ រ៉ុ មជ្ឈមណ្ឌលឯកសារកម្ពុជា KH 00963273។

[205] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឿង ឯ.១៥៣ KH 01046475 [“ចាស រាល់ពេលដែល តាទិត្យ មកជួបជាមួយនឹង យេ ហើយ យេ តែងតែប្រជុំដើម្បីជំរុញឲ្យយើងធ្វើការកាន់តែខ្លាំងក្លាថែមទៀត”]។

[206] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឯ.១០ KH 01080874 [“ជាធម្មតា មុនពេល តាទិត្យចុះមកដល់កន្លែងកងយើង ប្រធានកងយើងតែងតែព្រមានប្រាប់យើងថា កុំឲ្យឈប់សម្រាកពីការងារ។ បើសិនជាសមមិត្តទទួលខុសត្រូវគម្រោងការងារមកដល់ ហើយឃើញពួកយើងអសកម្ម ពួកយើងនឹងត្រូវបាត់ខ្លួនជាមិនខាន”]។

យ៉ីម ទិត្យ បានសាបព្រោះពេញការដ្ឋាន ដោយគាត់បានបញ្ជាក់ថា កងទ័ពក្នុងកងរបស់គាត់ប្រាប់គាត់ថា៖ "បើយើងធ្វើការយឺតយ៉ាវ ឬមិនបានល្អអ្វីមួយ គឺនឹងត្រូវ តាទិត្យ យកទៅសម្លាប់"[207]។

92. ការភ័យខ្លាចនេះជាប្រេងមិនអាចខ្វះបាន ដែលធ្វើឲ្យម៉ាស៊ីនផលិតរបស់ ប.ក.ក ដើរហួសសមត្ថភាព ក្នុងលក្ខខណ្ឌប្រឹងខ្លាំង ដែល ប.ក.ក បានកំណត់។ បើគ្មានការភ័យខ្លាចនេះទេ គោលដៅទ្វេនៃផលិតកម្មអតិបរមាក្នុងតម្លៃអប្បបរមា និងការធ្វើឲ្យប្រជាជនខ្សោយ និងស្តាប់បង្គាប់ នឹងមិនអាចសម្រេចបាន។ ដូច្នេះ ការចូលរួមចំណែកយ៉ាងសំខាន់របស់ **យ៉ីម ទិត្យ** ក្នុងការបង្កើតបរិយាកាសភ័យខ្លាចនេះ បានជួយជំរុញដល់ទិដ្ឋភាពកសិកម្ម និងសេដ្ឋកិច្ច នៃផែនការឧក្រិដ្ឋរួម។ ការគំរាមកំហែងរបស់ **យ៉ីម ទិត្យ** ក៏ស្មើនឹងការណែនាំ និងការលើកទឹកចិត្តដោយប្រយោល ដល់អ្នកនៅក្រោមបង្គាប់គាត់ ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងកម្មករ ដើម្បីឈានទៅដល់គោលដៅផលិតកម្ម និងគ្រប់គ្រងប្រជាជន។ នេះគឺជាការចូលរួមចំណែកដ៏សំខាន់បន្ថែមទៀតក្នុងផែនការឧក្រិដ្ឋរួម។

93. ក្រៅពីការគំរាមកំហែង **យ៉ីម ទិត្យ** ក៏បានចូលរួមយ៉ាងសកម្ម ក្នុងការកំណត់ និងប្រកាសគោលដៅផលិតកម្ម[208] ជំរុញកម្មករគ្មានកម្លាំងកំហែងឲ្យខំប្រឹងធ្វើការកាន់តែខ្លាំង[209] និងតាមដានកម្រិតផលិតកម្ម[210]។ ទោះជាគ្មានចរិតឧក្រិដ្ឋជាប់មកជាមួយ បើពិចារណាដាច់ដោយឡែក ក្នុងបរិបទនៃបរិយាកាសភ័យខ្លាចកាន់តែខ្លាំងឡើងដោយការគំរាមកំហែងរបស់ **យ៉ីម ទិត្យ** និងបរិបទឧក្រិដ្ឋ

---

[207] ឯកសារ D219/9 កំណត់ហេតុស្តាប់ចម្លើយ ឃុន សាមឿន ឆ.២៨-២៩ KH 01025559 ["ខ្ញុំឮកងទ័ពក្នុងកងរបស់ខ្ញុំនិយាយពីឈ្មោះ តាទិត្យ។ [...] ខ្ញុំឮថា "បើយើងធ្វើការយឺតយ៉ាវ ឬមិនបានល្អអ្វីមួយ គឺនឹងត្រូវ តាទិត្យ យកទៅសម្លាប់"]។

[208] ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហែម ឈួន ឆ.១៩ KH 00905854។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.១៩-២០, ២២ KH 00967985។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឆ.៣០ KH 01149403។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ ម្ចូល អេង ឆ.១៧៤-១៧៥ KH 01095262។ ឯកសារ D118/245 កំណត់ហេតុស្តាប់ចម្លើយ ជួន ថន ឆ.១២, ១៦ KH 00990644។

[209] ឯកសារ D219/943 កំណត់ហេតុស្តាប់ចម្លើយ ឡម លិន ឆ.៣៦ KH 01415377 ["គាត់និយាយថា បងប្អូនត្រូវខំធ្វើស្រែឲ្យបានផល ដើម្បីឲ្យខាងយោធាបានហូប"]។ ឯកសារ D219/111 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ឆោម ឆ.៦៥ KH 01045274 ["តាទិត្យ និយាយគឺ អ្នកនៅខាងក្រោយប្រឹងបង្កបង្កើនផល ហើយអ្នកនៅខាងមុខប្រឹងវ៉ៃខ្លាំង"]។ ឯកសារ D219/416 កំណត់ហេតុស្តាប់ចម្លើយ លៀស គង់ ឆ.១, ១១-១២ KH 01117353, 55-56។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១០០ KH 01046469។ ឯកសារ D118/76 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្ធក ឆ.៤២-៤៣ KH 00934379។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឆ.៣០ KH 01149403 ។ ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៤៥-៤៦ KH 01037144។

[210] D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.១៦ KH 01095988។

កាន់តែរីកធំនៃរបបកម្ពុជាប្រជាធិបតេយ្យ សកម្មភាពទាំងនេះគឺជាការចូលរួមចំណែកយ៉ាងសំខាន់បន្ថែមទៀតក្នុងផែនការឧក្រិដ្ឋរួម។ ជាពិសេស នេះជាការពិត ពីព្រោះការកំណត់គោលដៅផលិតកម្ម ខ្ទះដោយ **យ៉ឹម ទិត្យ** មានលក្ខណៈហួសហេតុ លើសពីស្តង់ដាររបស់កម្ពុជាប្រជាធិបតេយ្យ[211]។

94. **យ៉ឹម ទិត្យ** ដឹងច្បាស់អំពីស្ថានភាពលំបាកលំបិន នៅការដ្ឋានក្រោមការគ្រប់គ្រងរបស់គាត់។ គាត់បានតាមដានយ៉ាងជិតដល់ទ្ធវការបង្កបង្កើនផល នៅតំបន់ក្រោមការគ្រប់គ្រងរបស់គាត់ និងបានត្រួតពិនិត្យការដ្ឋាន ជាទៀងទាត់ ទាំងនៅភូមិភាគពាយ័ព្យ ទាំងនៅភូមិភាគនិរតី រួមបញ្ចូលទាំងស្រែអំបិល កន្លែងបង្កបង្កើនផលស្រូវនៅតាមឃុំ ទំនប់ និងការដ្ឋានសាងសង់ប្រព័ន្ធស្រោចស្រព ផ្សេងទៀត និងផ្ទះដែក[212]។ បើតាម ម្ចូល អេន គោលបំណងនៃការត្រួតពិនិត្យនេះ គឺដើម្បី "មើលថា តើយើងបានធ្វើតាមផែនការរបស់ [**យ៉ឹម ទិត្យ**] ឬក៏អត់"[213]។ ក្នុងពេលត្រួតពិនិត្យ គាត់បាននិយាយទៅកាន់កម្មករទ្ធទៅ និងមេកង[214]។ លើសពីនេះទៅទៀត ក្នុងពេលត្រួតពិនិត្យ ក្នុងពេលប្រជុំ និងតាមរយៈរបាយការណ៍ណាយលក្ខណ៍អក្សរ អ្នកនៅក្រោមបង្គាប់បានរាយការណ៍ ជាទៀងទាត់ និងជា

---

[211] ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឆ.៣០ KH 01149403 ["បន្ថែមពីនេះទៀត គេបានលើកទឹកចិត្ត ឲ្យប្រជាជនខិតខំធ្វើស្រែឲ្យបាន ៥ ទៅ ៦ តោន ក្នុងមួយហិកតា"] ឆ.៥៥ KH 011494037 ["តាទិត្យ និយាយតែម្នាក់ឯងប៉ុណ្ណោះ នៅក្នុងកិច្ចប្រជុំនេះ"]។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.១៩-២០, ២២ KH 00967985 ["ស៖ នៅពេលដែលលោកទៅប្រជុំនៅមន្ទីរស្រុកជិតស្ពានកង្ហត តើអ្នកណាជាអ្នកដឹកនាំការប្រជុំនេះ? ឆ.១៩៖ ខ្ញុំឃើញ តាទិត្យ ជាអ្នកគ្រប់គ្រង និងដឹកនាំការប្រជុំនេះ។ [...] ស៖ ពេលដែលប្រជុំលើកទី១ តើគោលបំណងនៃការប្រជុំជាអ្វី? ឆ.២២៖ គេលើកអំពីបញ្ហាស្រែប្រាំង ១ហិចតាត្រូវធ្វើបានពី៣តោនទៅ៧តោនក្នុង១ឆ្នាំ]។

[212] ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.១១ KH 01394972។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៥៥-៥៦ KH 01110498។ ឯកសារ D219/268 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៥១ KH 01110497 ។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប ស៊ីង ឆ.៧២ KH 01046466។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៧ KH 00960663 ។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម រណ្ណា ឆ.៧ KH 01080874 ។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥១-៥២, ៧១, ៨១, ១៣៩, ១៤១-១៤៤, ១៤៦-១៤៧, ១៤៩ KH 01244124, 127, 128, 136, 137 ។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥០, ៥៤-៥៨, ៦១ KH 01244124-25។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ធឹម ឆ.៨, ១៧ KH 01008697-699។

[213] D219/294 កំណត់ហេតុស្តាប់ចម្លើយ ម្ចូល អេង ឆ.៧៦, ៨១ KH 01095247 ["គាត់មកមើលស្រែចំការថា តើយើងបានធ្វើតាមផែនការរបស់គាត់ឬក៏អត់"]។

[214] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប ស៊ីង ឆ.១៤៣-១៤៦ KH 01046474 ["ខ្ញុំឃើញគាត់និយាយជាមួយនឹងមេកងនៅទីនោះ ដូចជា យ៉ ជាដើម។ [...] នៅពេលដែលគាត់ជួបខ្ញុំ គាត់បានសួរសុខទុក្ខខ្ញុំ ហើយថា តើធ្វើការងារយ៉ាងម៉េចដែរ ។ [...] គាត់មិនដែលនិយាយអំពីបញ្ហាសន្តិសុខទេ គឺគាត់និយាយតែពីការងារលើកទំនប់តែប៉ុណ្ណោះ"]។

ញ៉ីកញ្ជាប់ ជូន **យ៉ីម ទិត្យ** ពាក់ព័ន្ធនឹងការរីកចម្រើននៃការបង្កបង្កើនផល និងគម្រោងសាងសង់ ក៏ដូចជាទិន្នន័យ ដូចជាចំនួនមនុស្សសរុប ចំនួនអ្នកឈឺសរុប និងថាតើប្រជាជនមានសម្លៀកបំពាក់ និងអាហារហូបចុកគ្រប់គ្រាន់ដែរឬទេ[215]។

95. ការព្រងើយកន្តើយរបស់ **យ៉ីម ទិត្យ** ចំពោះការឈឺចាប់របស់កម្មករ តាមរយៈលក្ខខណ្ឌអមនុស្សធម៌នៅតាមការដ្ឋាន នៅភូមិភាគពាយ័ព្យ ត្រូវបានបង្ហាញដោយការណ៍ដែលថា ស្ថានភាពកាន់តែអាក្រក់ទៅ១ ក្រោយពី **យ៉ីម ទិត្យ** ឡើងកាន់អំណាចនៅតំបន់នោះ។ ឧទាហរណ៍ របបអាហារនៅទំនប់កង្ហត បានថយចុះ ពេល **យ៉ីម ទិត្យ** មកគ្រប់គ្រងបន្តនៅទីនោះ[216] ហើយម៉ោងធ្វើការបានកើនឡើង[217]។

96. ជារួម ការគំរាមកំហែងដោយផ្ទាល់ និងដោយប្រយោលរបស់ **យ៉ីម ទិត្យ** ចំពោះកម្មករ និងកម្មាភិបាលថ្នាក់ទាប ការណែនាំដោយប្រយោលដល់អ្នកនៅក្រោមបង្គាប់គាត់ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដើម្បីសម្រេចគោលដៅ បរិយាកាសភ័យខ្លាចដែលគាត់បានបង្កើតឡើងដោយចេតនា ការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់គាត់ដើម្បីទទួលបានព័ត៌មានអំពីលក្ខខណ្ឌ និងហេតុការណ៍នៅតាមការដ្ឋាន ការប្រព្រឹត្តឧក្រិដ្ឋកម្មជាញឹកញាប់ នៅតាមការដ្ឋាន ក្រោមការគំរាមកំហែងជាក់លាក់ពី **យ៉ីម ទិត្យ** និងការកំណត់លក្ខខណ្ឌអមនុស្សធម៌ដោយចេតនានៅតាមការដ្ឋាន បង្កើតបានជាភ័ស្តុតាងច្បាស់លាស់

---

[215] ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.៤៤ KH 01008704។ ឯកសារ D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.១៦ KH 01008699 ["នៅក្នុងអង្គប្រជុំគេក៏បាននិយាយផងដែរ អំពីស្ថិតិនិងអត្រាមនុស្សស្លាប់និងកើតហើយនិងអំពីលទ្ធផលបង្កបង្កើនផល ដែលឃុំនីមួយ១សម្រេចបាន។ល។ នៅក្នុងអង្គប្រជុំ ជួនកាល តាម៉ុក ជួនកាល តាទិត្យ តែងតែដាក់សំណួរមកលើពួកយើងដែលជាតំណាងសង្កាត់ និងស្រុកម្នាក់ៗឲ្យរាយការណ៍ថា មានរឿងរ៉ាវអ្វីកើតឡើងនៅក្នុងសង្កាត់និងស្រុករបស់ខ្លួន"]។ ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.១៤០-១៤១ KH 01329404។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.៩៨-៩៩ KH 01095250 ។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ ផាន់ វ៉ី ឆ.៧ KH 01040094។ ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង រ៉ែត ឆ.៤៤ KH 01136708។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.៩៨, ១៦១-១៦២ KH 01095250, 60។

[216] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈៀង ប៊ាន ឆ.១១៧ KH 01110192។

[217] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៤ KH 01205215 ["ពីសម័យដែលអ៊ំគ្រប់គ្រង ពេលធ្វើការយប់ម៉ោង ១០-១១ អាចសម្រាកបាន យប់ក៏ធ្វើដែរ។ ពេលដែល តាទិត្យ ចូល យើងមិនប៉ានឈប់ទេ យើងធ្វើការរហូតដល់ម៉ោង ១ រំលងអាធ្រាត្រ គឺខុសគ្នាប៉ុណ្ណឹង។ នៅសម័យអ៊ំនៅ ឈ្លបមិនសូវខ្វាត់ខ្វែងពេលធ្វើការទេ ពេលសម័យ តាទិត្យ ពេលពលកម្ម មានឈ្លបគេតាមមើល សម័យមុនមានមេចលត មេកងតូច កងធំ គេនៅមើល អត់មានឈ្លបគេនៅមើល អត់មានឈ្លបនៅតាមទេ។ សម័យ តាទិត្យ គេមានឈ្លបនៅយាមពេលធ្វើការ មិនដឹងគេយាមការពារអ្វីទេ តែឃើញកាំភ្លើងគេយាម។ ពួកខ្ញុំគេដាក់ថាពួកសមរភូមិមុខ គឺធ្វើការទាំងយប់ទាំងថ្ងៃ"]។

និងស៊ីសង្វាក់គ្នាអំពីការទទួលខុសត្រូវរបស់ **យ៉ីម ទិត្យ** ចំពោះចំណែកនៃ JCE ដែលស្នើនឹង ឬជាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មទាំងនេះ។ **យ៉ីម ទិត្យ** បានដឹង និងចែករំលែកផែនការរួម ដើម្បីសម្រេចគោលដៅកសិកម្ម និងសេដ្ឋកិច្ចរបស់ ប.ក.ក តាមរយៈការប្រព្រឹត្តឧក្រិដ្ឋកម្ម។ គាត់មានបំណងចង់ឲ្យឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើង ហើយគាត់បានចូលរួមចំណែកដ៏សំខាន់ និងគួរឲ្យកត់សម្គាល់ ក្នុងការជំរុញ JCE ក្នុងន័យនេះ។

៣. អំពើ ឆន្ទៈការប្រព្រឹត្តរបស់ យ៉ីម ទិត្យ នៅភូមិភាគពាយ័ព្យ

ក. ការលេចមុខដំបូងរបស់ យ៉ីម ទិត្យ នៅភូមិភាគពាយ័ព្យ

97. ដំបូង **យ៉ីម ទិត្យ** មានភាពលេចធ្លោ ក្នុងឋានៈជាមេដឹកនាំតាមព្រឹត្តន័យ នៅភូមិភាគពាយ័ព្យ មុនពេលតាម៉ុក បញ្ជូនកម្មាភិបាលភូមិភាគនិរតីមួយក្រុមធំទៅភូមិភាគពាយ័ព្យទៅទៀត។ សៅ ជាប់ ប្រធានកងអនុសេនាតូចក្នុងស្រុកគាស់ក្រឡ បានពណ៌នាអំពីវគ្គរៀនសូត្រមួយមានរយៈពេលបីថ្ងៃ រៀបចំឡើងនៅទំនប់កង្ហត នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ និងដឹកនាំដោយតាវ៉ាញ លេខាតំបន់ ១ ដែលក្នុងវគ្គនោះ **យ៉ីម ទិត្យ** បានឡើងធ្វើឧទ្ទេសនាម[218]។

98. កាលវេលានៃវគ្គរៀនសូត្រនេះត្រូវបានបង្ហាញដោយហេតុការណ៍ចំនួន ៥ ដែលមានភាពស៊ីសង្វាក់គ្នា។ ដំបូង សៅ ជាប់ នៅចាំថា វគ្គរៀនសូត្រនេះរៀបចំឡើងនៅឆ្នាំ១៩៧៦[219]។ ទីពីរ សៅ ជាប់ បានរងរបួសប្រហែលនៅពាក់កណ្តាលឆ្នាំ១៩៧៦ និងបានសម្រាកនៅមន្ទីរពេទ្យនៅបាត់ដំបងរយៈពេលបីខែហើយបន្ទាប់មក គាត់បានចូលរួមវគ្គរៀនសូត្រនេះ ភ្លាមៗបន្ទាប់ពីគាត់ចេញពីមន្ទីរពេទ្យ[220] ដែលនេះសន្មតថា គឺនៅចុងឆ្នាំ១៩៧៦។ ទីបី ក្នុងពេលវគ្គរៀនសូត្រ តាវ៉ាញ នៅជាលេខា

---

[218] ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឯ.១៣-១៦, ២២ KH 01425219-20។ ឯកសារ D219/980 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឯ.២២-២៣ KH 01477600។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឯ.៣-៥, ៩ KH 01244118-19។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឯ.៦៥-៧១ KH 01244126-27។

[219] ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឯ.១៣-១៦ KH 01425219 ["ស៖ [...] លោកឃើញ ជួប តាទិត្យ ហ្នឹងដំបូងនៅឆ្នាំណា? ឯ.១៣៖ ជួបកាលពីឆ្នាំ១៩៧៦ [...] ឯ.១៤៖ កាល ៧៦ ជួបនៅកន្លែងបាត់ដំបង ហើយមកជួបនៅអាងលើកទំនប់កង្ហតនេះ"] ឯ.២២ EN 01456266 ["ស៖ តាមលោកដឹង តាម៉ុក គាត់មកដល់ភូមិភាគពាយ័ព្យ គាត់មកដល់ពេលណា ឆ្នាំណា? ឯ.២២៖ ឆ្នាំ៧៦ មករៀននៅកន្លែងនេះ កន្លែងកង្ហតនេះ ព្រោះតំបន់ទាំងអស់ គ្រប់តំបន់មករៀនជុំគ្នានៅកន្លែងកង្ហតនេះ]។

[220] ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឯ.១៥ KH 01425219 ["កាលត្រូវរបួសហ្នឹង ស្គាល់ តាទិត្យ"] ឯ.៥៥-៥៧, ៥៩-៦៣ KH 01425226-01425228 ["ស៖ លោកចាំហើយថា ខ្លួនឯងទៅផ្ការព្រៃ ហើយត្រូវគ្រាប់នៅឆ្នាំ១៩៧៦។

តំបន់ ១ នៅឡើយ[221] ហើយ តាវ៉ាញ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅ ស-២១ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧[222] មានន័យថា ការប្រជុំនេះពិតជាបានប្រព្រឹត្តទៅ មុនពេលទំនប់កង្ហតរលំ[223] ប្រហែលនៅខែកក្កដា ឆ្នាំ១៩៧៧[224]។ ចុងក្រោយ សៅ ជាប់ បានលើកឡើងថា ការប្រជុំនេះបានប្រព្រឹត្តទៅ នៅពេលដែល "យោធានិវតីមិនទាន់មកដល់" និងបាននិយាយថា **យ៉ីម ទិត្យ** បានមកដល់មុនកម្ពាភិបា

តើលោកមានចាំទេ កាលហ្នឹងនៅខែណា? ឆ.៥៥៖ ខែណាទេ ដូចអត់ចាំ។ កណ្តាលឆ្នាំ៧៦។ [...] ស៖ លោកនិយាយថា គេបញ្ជូនលោកទៅបាត់ដំបង ៣ ខែម៉េចបានលោកចាំថា ៣ ខែ? ឆ.៥៧៖ ដឹងព្រោះនៅចាំថានៅហ្នឹង ៣ ខែ។ ចេញមកវិញ គេហៅឲ្យជួយបម្រើដឹកនាំក្ដឹងៗបន្ដទៀត។ ហើយបានទៅជួបជាមួយ តាម៉ុក តាអ៊ីហ្នឹង។ [...] ស៖ បន្ទាប់ពីលោកឡើងកាន់កងយុទ្ធជនធ្វើការហ្នឹង បន្ទាប់ពីហ្នឹងមក ឃ្ងរទេបានលោកទៅជួបតាម៉ុក? ឆ.៦២៖ ជួបតាម៉ុក ជួបតាំងពីហ្នឹងមកដែរ តាំងពីចេញពីពេទ្យ។ កាលហ្នឹងទៅរៀនសូត្រ ចេញពីរបួស ដឹកនាំកងយុទ្ធជន ទៅប្រជុំ រៀនសូត្រពីសហការណ៍តាមឃុំ តាមស្រុក ថារីកចម្រើនប៉ុនណា។ ស៖ ពេលដែលលោកជួប តាទិត្យ ដំបូងនៅពេលហ្នឹង ឬពេលណា? ឆ.៦៣៖ ជួបនៅពេលហ្នឹង ជួបពេលរៀនហ្នឹង"]។

[221] ឯកសារ D219/956 កំណត់ហេតុស្ដាប់ចម្លើយ សៅ ជាប់ ឆ.៣០ KH 01425222 ["ស៖ កាលទៅរៀនសូត្រហ្នឹង កាលហ្នឹងគណៈតំបន់ លេខាតំបន់ ១ ហ្នឹងពីណាគេ? ឆ.៣០៖ គណៈតំបន់១ តាវ៉ាញ]។ ឯកសារ D219/981 កំណត់ហេតុស្ដាប់ចម្លើយ សៅ ជាប់ ឆ.៤៨ KH 01477614 ["ស៖ កាលដែលទៅរៀនសូត្រនៅកន្លែងកង្ហតហ្នឹង នៅទំនប់ហ្នឹង កាលហ្នឹងអ្នកក្ដាប់ទទួលខុសត្រូវនៅហ្នឹងអ្នកណាគេ? ឆ.៤៨៖ កាលហ្នឹងមានតាវ៉ាញ ផុតពីហ្នឹងមកមិនស្គាល់ទេ គេក្ដាប់តាមកងៗហ្នឹង ដឹកនាំប្រជាជន]។

[222] ឯកសារ D219/825.1.2 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ៩១៣ EN 01222369 [ជា ហ្ជន ហៅ វ៉ាញ លេខាតំបន់ ១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧]។

[223] ឯកសារ D219/981 កំណត់ហេតុស្ដាប់ចម្លើយ សៅ ជាប់ ឆ.១២-១៣ KH 01477608 ["ស៖ លោកមានចាំទេ បន្ទាប់រៀនសូត្រប្រជុំហ្នឹងបានប្រហែលប៉ុន្មានខែប៉ុន្មានឆ្នាំ ដែលទំនប់ហ្នឹងបាក់? ឆ.១៣៖ ដល់បាក់អត់ចាំ បាក់ក្រោយមកហើយ]។

[224] ឯកសារ D219/374 កំណត់ហេតុស្ដាប់ចម្លើយ ឃិន ឃ៉ីម ឆ.១៨៨-១៨៩ KH 01110545។ ឯកសារ D219/721 កំណត់ហេតុស្ដាប់ចម្លើយ សួម ចៅ ឆ.១៩ KH 01213294 [ទំនប់បានបាក់បែកនៅខែកក្កដា ឬសីហា ឆ្នាំ១៩៧៧]។ ឯកសារ D219/430 កំណត់ហេតុស្ដាប់ចម្លើយ ឈឿង ប៊ាន ឆ.៥៦ KH 01122406 ["ស៖ តើការបាក់ទ្វារទឹកនេះក្រោយពេល ឬមុនពេលការចាប់ខ្លួន តាវ៉ាញ នៅខែមិថុនា ឬកក្កដា ឆ្នាំ១៩៧៧? ឆ.៥៦៖ មុនពេលការចាប់ខ្លួនរបស់ តាវ៉ាញ]។ ឯកសារ D219/689 កំណត់ហេតុស្ដាប់ចម្លើយ សុខ ជាតិ ឆ.១៩ KH 01205203។ ឯកសារ D219/310 កំណត់ហេតុស្ដាប់ចម្លើយ រ៉ន្ត សាមុត ឆ.៥ KH 01097679 [ទំនប់បានរលំបាក់នៅខែកក្កដា ឆ្នាំ១៩៧៧]។ ឯកសារ D219/409 កំណត់ហេតុស្ដាប់ចម្លើយ អាង ស ឆ.៩, ២៨ KH 01117268, 70 ។ ឯកសារ D6.1.819 (ហ្ស៊ីប៊ីស) សេវាផ្សាយព័ត៌មានអន្តរជាតិ FBIS ការខិតខំប្រឹងប្រែងបង្កបង្កើនផលនៅក្នុងភូមិភាគពាយ័ព្យត្រូវបានលើកយកមកបង្ហាញ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169237 ["កសិករប្រកៀកស្មាគ្នាជួសជុលទំនប់កង្ហតដែលបានខូចខាត ដែលបានសាងសង់ឡើងនៅរដូវប្រាំងឆ្នាំ១៩៧៧]។ ឯកសារ D219/654 កំណត់ហេតុស្ដាប់ចម្លើយ សុខ ជាតិ ឆ.៦៨, ៧០ KH 01196542។ ឯកសារ D118/281 កំណត់ហេតុស្ដាប់ចម្លើយ កែវ សុខា ឆ.១១ KH 01004021។

លភូមិភាគនិរតីផ្សេងទៀត[225]។ (កាលវេលានៃការមកដល់របស់ **យ៉ីម ទិត្យ** នៅភូមិភាគពាយព្យ ក៏ស៊ីសង្វាក់គ្នាជាមួយនឹងភ័ស្តុតាងរបស់អង្គរក្សរបស់តាប៉ែត ឈ្មោះ ឈាន ប៊ីា ដែលនៅចាំថា កម្មាភិបាលនៅក្រោមបង្គាប់របស់ **យ៉ីម ទិត្យ** ជាអ្នកចាប់តាណុប និងតាសាយ កម្មាភិបាលតំបន់ ១[226]។ តាសាយ ចូល ស-២១ នៅចុងខែមិថុនា ឬដើមខែកក្កដា ឆ្នាំ១៩៧៧ រីឯតាណុប ចូល ស-២១ នៅខែកញ្ញា ឆ្នាំ១៩៧៧[227])។

99. យោងតាមចម្លើយរបស់ សៅ ជាប់ មនុស្សរាប់រយនាក់បានចូលរួមវគ្គរៀនសូត្រ[228] ក្នុងនោះមានកម្មាភិបាលមកពី "គ្រប់ស្រុក"[229] និងពី "គ្រប់តំបន់ទាំងអស់"[230]។ **យ៉ីម ទិត្យ** និងលេខាតំបន់ ១ តាវ៉ាញ ដែលកំពុងកាន់តំណែង បានបង្រៀនកម្មាភិបាលអំពីប្រធានបទផ្សេងៗ "ដូចថារឿងខាតរឿងចំណេញ រីកចម្រើន"[231]។ តាវ៉ាញ ក៏បានពិភាក្សាអំពី "ការការពារខ្មាំង មានរូបភាពអ្វីខ្លះ"[232]។

---

[225] ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៣៥ KH 01425222 ["ស៖ កាលពេលលោកជួប តាទិត្យ កាលហ្នឹងពួកនិរតី យោធានិរតីមានមកដល់នៅ? ឆ.៣៥៖ កាលហ្នឹងយោធានិរតីមិនទាន់មកដល់ទេ។ កាលហ្នឹង តាទិត្យ ហ្នឹង ឃើញចូលមកមុន]។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៤-១៥ KH 01477608 ["ស៖ យោងទៅតាមចម្លើយចុងក្រោយរបស់លោកនេះ បានន័យថា តាម៉ុក និង តាទិត្យ គឺមកនៅចូលរួមការប្រជុំរៀនសូត្រនៅកន្លែងហ្នឹងតាំងពីមុនពេលនិរតីចូលមកដល់កន្លែងទំនប់ និងតំបន់ហ្នឹងហើយ? ឆ.១៥៖ បាទ"] ឆ.២២ KH 01477610 ["ការប្រជុំនេះគឺធ្វើនៅមុនពេលពួកនិរតីមក"]។

[226] ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ីា ឆ.២៩ KH 00998558 ["បងជីដូនមួយខ្ញុំឈ្មោះ ឆាំ ផុយ ដែលរស់នៅសព្វថ្ងៃប្រាប់ថា តាសាយ តាណុប និង តាស្ងៃ សុទ្ធតែជាអ្នកពាយ័ព្យ ហើយពួកគេត្រូវបានចាប់ខ្លួនដោយពួកនិរតីដឹកនាំដោយ តាទិត្យ និងតានីម និងបានបញ្ជូនទៅគុកទួលស្ពែងទាំងអស់"]។

[227] ឯកសារ D219/825.1.2 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀង ១៣៩៤ EN 01222390 [ឌ្យ៉ីក ភាជ ហៅ ណុប សមាជិកតំបន់ ១ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧] លេខរៀង ៧៧៦៥ EN 01222640 [រស់ ម៉ៅ ហៅ ថន ឬ ពាង ឬ សាយ អតីតលេខាតំបន់ ១ ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៧៧ ឬ ថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៧]។

[228] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៣៧-៣៨ KH 01477612។

[229] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៣៧ KH 01477612 ["ដូចច្រើនដែរ [...]។ វាមកគ្រប់កន្លែងគ្រប់ស្រុក"]។

[230] ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៦ KH 01425219 ["កាលហ្នឹង គ្រប់តំបន់ទាំងអស់មកប្រជុំរៀនសូត្រនៅទំនប់កង្អត] ឆ.២២ KH 01425220 ["ឆ្នាំ៧៦ មករៀននៅកន្លែងនេះ កន្លែងកង្អតនេះ ព្រោះតំបន់ទាំងអស់ គ្រប់តំបន់មករៀនជុំគ្នានៅកន្លែងកង្អតនេះ"]។

[231] ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៤-២៥ KH 01425221។

[232] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៥, ៣០ KH 01477610-11 ["ស៖ អ្នកដែលលើកនិយាយអំពីខ្មាំង ថាអីហ្នឹង អ្នកណាគេ កាលហ្នឹង? ឆ.៣០៖ អាហ្នឹងតាវ៉ាញ"]។

យ៉ីម ទិត្យ និងតាម៉ុក បានណែនាំបង្ហាញខ្លួនដល់អ្នកចូលរួមប្រជុំទាំងអស់[233]។ សៅ ជាប់ បាន និយាយថា **យ៉ីម ទិត្យ** និងតាម៉ុក ជា "អ្នកដឹកនាំការប្រជុំរៀនសូត្រ [...] យើងធ្វើតាមគេចាត់តាំង"[234]។ តាម៉ុក និងតាវ៉ាញ "ពន្យល់ប្រាប់អ្នករៀនសូត្រ ដើម្បីដាក់បញ្ជា ហើយបញ្ជាតាមថ្នាក់ៗ អ៊ីចឹង"[235]។ ក្រោយពីវគ្គរៀនសូត្របានបញ្ចប់ អ្នកចូលរួមបានត្រឡប់ទៅអង្គភាពរបស់ពួកគេវិញ និងបានផ្សព្វផ្សាយព័ត៌មាន ដែលខ្លួនបានទទួលទៅដល់អ្នកនៅក្រោមបង្គាប់របស់ពួកគេ[236]។

100. អ្នកចូលរួមវគ្គរៀនសូត្រអាចមើលឃើញលក្ខខណ្ឌរស់នៅនៅការដ្ឋានទំនប់កង្ហត ដែលនៅទីនោះ កម្មករខំប្រឹងធ្វើការងារធ្ងន់ៗ ទោះបីពុំមានអាហារគ្រប់គ្រាន់ក្តី[237]។ ទោះបីមានលក្ខខណ្ឌធ្វើការបែបនេះក្តី តាវ៉ាញ **យ៉ីម ទិត្យ** និងអ្នកផ្សេងទៀត បានលើកទឹកចិត្តកម្មករឲ្យបន្តខំប្រឹងធ្វើការទៀត[238]។

ខ. អំពើ និងការប្រព្រឹត្តផ្សេងទៀតនៅភូមិភាគពាយ័ព្យ

101. យ៉ាងហោចណាស់ នៅពេលណាមួយក្នុងអំឡុងពេលមុនការតែងតាំងគាត់ធ្វើជាលេខាតំបន់ ១ **យ៉ីម ទិត្យ** ឈរជើងនៅទួលអណ្តែត មានទីតាំងស្ថិតនៅប្រហែលមួយគីឡូម៉ែត្រពីទ្វារទឹកទំនប់

---

[233] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៦-១៧ KH 01477609 ["ស៖ យើងនិយាយលម្អិតបន្តិចអំពីរឿងការប្រជុំរៀនសូត្រ។ ម៉េចបានលោកដឹងថា ពីរនាក់ហ្នឹងឈ្មោះ តាម៉ុក និង តាទិត្យ? [...] ឆ.១៧៖ គេខទ្មេសនាមខ្លួនគេ"]។

[234] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៦៦-៦៧ KH 01477617។

[235] ឯកសារ D219/982 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៧-៨ KH 01477624។

[236] ឯកសារ D219/980 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២០ KH 01477600។

[237] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥០-៥៧ KH 01477614-15 [សាក្សីធ្លាប់ជាប្រធានកងអនុសេនាតូចនៅឃុំគាស់ក្រឡ៖ "ស៖ កាលហ្នឹងតាម៉ុក និង តាទិត្យ ដើរមើលដែរទេ? ឆ.៥០៖ បាទ មើលទាំងអស់គ្នា។ ស៖ ថ្ងៃដែលបើករៀនសូត្រហ្នឹង អាហ្នឹងជាថ្ងៃដែលប្រជាជនធ្វើការនៅទំនប់ហ្នឹងជាធម្មតាទេ? ឆ.៥១៖ អាហ្នឹងប្រជាជននៅធ្វើការជាធម្មតា។ ស៖ កាលហ្នឹងអ្នកដែលទៅមើល ភ្ញៀវដូចលោកទៅមើលហ្នឹង កាលហ្នឹងយើងអាចមើលឃើញផ្ទាល់របៀបរស់នៅផ្ទាល់របស់ប្រជាជនហ្នឹងទេ? ឆ.៥២៖ យើងមើលឃើញតើ ប្រជាជនរស់នៅរដិបរដុបនៅតាមកំប៉ូតព្រៃហ្នឹង នៅទំនប់ហ្នឹង។ [...] ស៖ កាលហ្នឹងតាម៉ុក តាទិត្យ ឬពួកអ្នកដែលទៅមើលហ្នឹង មានបាននិយាយជាមួយប្រជាជនអ្នកធ្វើការដែរអត់ទេ? [...] ឆ.៥៥៖ មាននិយាយតើ និយាយថា មិត្តអើយប្រទេសយើងនៅក្រ ចេះតែតស៊ូទៅ ប្រទេសយើងនៅអត់ នៅក្រ។ [...] ឆ.៥៦៖ រឿងប្រជាជនមិនសប្បាយទេ ព្រោះហូបមិនអ្នែតនោះ ម្ហ៊ះហើយធ្វើទៅតាមគេបង្ខំ។ ធ្វើវាលំបាកហើយ ការហូបមិនអ្នែត មិនបានគ្រប់គ្រាន់។ [...] ឆ.៥៧៖ អាមិនសប្បាយចិត្តហ្នឹង ធ្វើការយ៉ាប់ ហូបមិនអ្នែត ម្ហ៊ះហើយធ្វើតាមអ្វីដែលគេប្រើ វាមានតែប៉ុណ្ណឹង"]។

[238] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥៨ KH 01477615 ["ស៖ កាលហ្នឹងអ្នកណាដែលនិយាយទៅប្រជាជនឲ្យខំធ្វើការ យើងនៅក្រ នៅលំបាកហ្នឹង ពីណាគេ? ឆ.៥៨៖ តាវ៉ាញ តាទិត្យ អីហ្នឹង គណៈស្រុក ហើយពួកខ្ញុំអីហ្នឹង"]។

 កង្ហត[239] ដែលនៅទីនោះ គាត់ធ្វើការជាមួយតាប៉ែត ជាលេខាតំបន់ ១ ដែលកំពុងកាន់តំណែង[240]។ **យ៉ីម ទិត្យ** កាន់កាប់អគារមួយនៅទីនោះ ដែលមានការិយាល័យមួយ និងបន្ទប់ប្រជុំមួយ[241]។ ក្នុងអំឡុងពេលនោះ តាប៉ែត បានចង្អុលប្រាប់តាទិត្យពីរចនាសម្ព័ន្ធទំនប់កង្ហត និងការងារនៅទំនប់កង្ហត[242]។ **យ៉ីម ទិត្យ** ក៏បានប្រមូលព័ត៌មានអំពីកម្មាភិបាលភូមិភាគពាយ័ព្យពីតាប៉ែតក្នុងពេលនោះផងដែរ[243]។ តាប៉ែត និង **យ៉ីម ទិត្យ** ត្រូវគេឃើញថាបានធ្វើដំណើរជុំវិញតំបន់ជាមួយគ្នា តាមរថយន្ត ហ្ស៊ីបរបស់ពួកគាត់ ហើយក្នុងពេលនោះ តាប៉ែត បានប្រគល់បញ្ជីមនុស្សដែលត្រូវចាប់ខ្លួន និងកសាង ឲ្យទៅអ្នកនៅក្រោមបង្គាប់របស់គាត់[244]។ **យ៉ីម ទិត្យ** ក៏បានជួបជាមួយ រស់ ញ៉ឹម យ៉ាងទៀងទាត់ផងដែរ នៅផ្ទះរបស់ រស់ ញ៉ឹម រយៈពេលប្រហែលមួយឆ្នាំមុនពេលចាប់ខ្លួន រស់ ញ៉ឹម[245]។

---

[239] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៨៩ KH 01122412។

[240] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៣-៣៤ KH 01110178។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៩៤ KH 01122413។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៦, ឆ.២២-២៣ KH 01196542, 33។

[241] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៨២-៨៣ KH 01110184។

[242] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៨៦-៩០ KH 01122412-13។

[243] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៩៦ KH 01122414 ["ស៊ីយ បានប្រាប់ខ្ញុំថា តាទិត្យ កំពុងយកការណ៍ពី តាប៉ែត ហើយពួកនិរតីកំពុងយកការណ៍ពីកម្មាភិបាលនៅភូមិភាគពាយ័ព្យ"]។

[244] ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៧, ១៩ KH 01095208 [សាក្សីផ្តាប់ជាប្រធានឃុំ និងអនុប្រធានឃុំ ក្នុងតំបន់ ១៖ "ឆ.១៧៖ នៅពេលដែលគេត្រូវការហៅមនុស្សណា នៅក្នុងសហករណ៍ខ្ញុំឲ្យទៅរៀនសូត្រ គេប្រាប់ខ្ញុំនូវឈ្មោះអ្នកដែលគេត្រូវការនោះ។ ខ្ញុំបានទៅប្រាប់អ្នកដែលគេត្រូវការនោះឲ្យរៀបចំរបស់របរ ដើម្បីទៅរៀនសូត្រ។ ក្រោយមកពេលដែលខ្ញុំមិនឃើញពួកគេត្រឡប់មកវិញខ្ញុំឮសូរពីអ្នកដទៃនិយាយថាអ្នកទាំងអស់នោះស្លាប់អស់ទៅហើយ។ ឈ្មោះអ្នកទាំងនោះគឺខ្ញុំទទួលពីតាប៉ែត តាផុន ហើយនិងតាណេង។ [...] ស៖ នៅក្នុងរយៈពេលដែលមានការហៅឲ្យរៀនសូត្រនោះ តើលោកដឹងឬទេ ថាតើតាទិត្យ មកធ្វើការនៅក្នុងតំបន់ហើយឬនៅ? ឆ.១៩៖ បាទ តាទិត្យ គាត់ធ្វើការនៅទីនោះហើយ។ គាត់តែងតែធ្វើដំណើរចុះឡើងជាមួយតាប៉ែត តាមរយៈឡានហ្ស៊ីប A1 និង A2"]។

[245] ឯកសារ D118/137 កំណត់ហេតុស្តាប់ចម្លើយ ឈន វន ឆ.២៧-៣០ KH 00960679 ["ខ្ញុំឮពីឈ្មោះ តាទិត្យ គាត់មកពីនិរតី។ ពេល តាទិត្យ [...] មកលេងនៅហ្នឹងផ្ទះ តាញ៉ឹម នៅរៀងរាល់ល្ងាច។ [...] ខ្ញុំមិនដឹងថាគាត់និយាយអ្វីទេ [...] តាទិត្យ មកបាត់ដំបងមិនដល់មួយឆ្នាំផង ក៏គេចាប់ តាញ៉ឹម។ [...] គាត់មានរាងខ្ពស់ មិនធាត់មិនស្គម មុខរា]។ ឯកសារ D219/237 កំណត់ហេតុស្តាប់ចម្លើយ ឈន វន ឆ.៦, ១៥ KH 00960677-78។

102. **យ៉ីម ទិត្យ** ក៏បានទទួលការតម្រង់ទិស និងការណែនាំពីកម្មាភិបាលភូមិភាគពាយ័ព្យឈ្មោះ តាសាម៉ន ដែលត្រូវគេនិយាយថាជា "អ្នកសម្លាប់"[246] និងដែលបានចូលរួមក្នុងការសម្លាប់ទ្រង់ទ្រាយធំ និងកាត់យកប្រមាត់របស់អ្នកទោស ពីពាក់កណ្តាលឆ្នាំ១៩៧៧ ដល់ចុងឆ្នាំ១៩៧៧[247]។ តាសាម៉ន បានផ្តល់ព័ត៌មានឲ្យ **យ៉ីម ទិត្យ** អំពីភូមិសាស្ត្រ និងរចនាសម្ព័ន្ធចាត់តាំងរបស់ភូមិភាគពាយ័ព្យ[248]។ ក្រោយមក **យ៉ីម ទិត្យ** បានដំឡើងតំណែងឲ្យតាសាម៉ន ដែលជាកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលភូមិភាគពាយ័ព្យពីរបីនាក់ដែលគេចផុតពីការបោសសម្អាត[249]។

103. **យ៉ីម ទិត្យ** ស្គាល់ច្បាស់ពីលក្ខខណ្ឌរស់នៅរបស់ប្រជាជនក្នុងតំបន់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់។ ក្នុងពេលប្រជុំធំៗដែលគាត់ដឹកនាំ ជាមួយកម្មាភិបាលតំបន់ ១ "តាទិត្យ គាត់និយាយអំពីស្ថានភាពទូទៅនៅក្នុងតំបន់ដែលគាត់គ្រប់គ្រង និងអំពីស្ថានភាពនៅក្នុងស្រុកនានា ក្នុងតំបន់របស់គាត់។ ហើយគាត់ក៏ផ្តល់ការណែនាំដល់អ្នកតំណាងឲ្យស្រុកនានា នៅក្នុងតំបន់របស់គាត់

---

[246] ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២៣-២៤ EN 01139585 ["ឆ.២៣៖ តាសាម៉ន គឺជាអ្នកសម្លាប់មនុស្ស។ នរណាក៏ខ្លាចគាត់ដែរ។ ស៖ តើលោកធ្លាប់បានឃើញផ្ទាល់នឹងភ្នែកអំពីហេតុការណ៍ តាសាម៉ន សម្លាប់អ្នកនាដែរឬទេ? ឆ.២៤៖ ទេ ខ្ញុំមិនដែលឃើញ តាសាម៉ន សម្លាប់នរណាម្នាក់ផ្ទាល់ភ្នែកខ្ញុំនោះទេ។ ដូចខ្ញុំបានប្រាប់លោកស្រីកាលពីកិច្ចសម្ភាសន៍របស់ខ្ញុំលើកដំបូងអ៊ីចឹងថា គេយកមនុស្សទៅសម្លាប់នៅឯស្គន់។"]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧០ KH 01205214 ["នរណាក៏ស្គាល់ តាសាម៉ន ដែរ ព្រោះគាត់ដែរនៅជាងគេ សម្លាប់មនុស្សផុតជាងអ្វីទៅទៀត នរណាៗក៏គេនិយាយដែរ ខ្ញុំគ្រាន់តែឮ តែមិនដែលឃើញទេ។ វាពិតហើយបានជាគេនិយាយតៗគ្នាបែបនេះ"]។

[247] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៧៦-៧៨ KH 01122410 ["ខ្ញុំឃើញតាសាម៉ន បណ្តើរមនុស្សយកទៅសម្លាប់ [...] នៅពេលមួយពួកគេបានយកប្រមាត់មនុស្ស ដែលគេសម្លាប់ហើយយកទៅចងព្យួរនៅលើសសរដែលខ្ញុំប្រើសម្រាប់ចងអង្រ្ពងដេក។ ព្រឹត្តិការណ៍នេះ កើតឡើងនៅក្នុងខែសីហា ឬកញ្ញា ឆ្នាំ១៩៧៧ នៅរដូវភ្លៀងធ្លាក់"]។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៨-២០ KH 01132077។

[248] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២១ KH 01122398។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣១ KH 01132080 ["ស៖ តើលោកដឹងដែរឬទេថា ហេតុអ្វីបានជាគេដំឡើងតំណែងឲ្យ តាសាម៉ន? ឆ.៣១៖ មូលហេតុដែលគេដំឡើងតំណែងឲ្យ តាសាម៉ន ព្រោះ តាទិត្យ មិនដឹងអំពីទីតាំងភូមិសាស្ត្រនៅក្នុងតំបន់នោះ ហើយ តាទិត្យ ចង់ដឹងអំពីរចនាសម្ព័ន្ធរបស់កម្មាភិបាលពីមុនដែលត្រូវបានគេដកចេញពីមុខតំណែង មុនពេលដែល តាទិត្យ មកដល់។ តាទិត្យ បានមកដល់ប្រហែលជាក្នុងខែមេសា ឆ្នាំ១៩៧៨ [...] តាសាម៉ន គ្រាន់តែជាអ្នកបង្ហាញផ្លូវឲ្យ តាទិត្យប៉ុណ្ណោះ"]។

[249] ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣១ KH 01132080 ["ស៖ តើលោកដឹងដែរឬទេថា ហេតុអ្វីបានជាគេដំឡើងតំណែងឲ្យ តាសាម៉ន? ឆ.៣១៖ មូលហេតុដែលគេដំឡើងតំណែងឲ្យ តាសាម៉ន ព្រោះ តាទិត្យ មិនដឹងអំពីទីតាំងភូមិសាស្ត្រនៅក្នុងតំបន់នោះ ហើយ តាទិត្យ ចង់ដឹងអំពីរចនាសម្ព័ន្ធរបស់កម្មាភិបាលពីមុនដែលត្រូវបានគេដកចេញពីមុខតំណែង មុនពេលដែល តាទិត្យ មកដល់។ តាទិត្យ បានមកដល់ប្រហែលជាក្នុងខែមេសា ឆ្នាំ១៩៧៨ [...] តាសាម៉ន គ្រាន់តែជាអ្នកបង្ហាញផ្លូវឲ្យ តាទិត្យ ប៉ុណ្ណោះ"] ឆ.៣៥ EN 01139588 ["ស៖ តើនរណាជាអ្នកដំឡើងហាន:ឲ្យ តាសាម៉ន? ឆ.៣៥៖ គឺ តាទិត្យ"]។

ដែរ"[250]។ នៅក្នុងការប្រជុំដែល **យ៉ីម ទិត្យ** បានចូលរួមជាមួយអ្នកនៅក្រោមបង្គាប់របស់គាត់ មានការពិភាក្សាអំពីព័ត៌មានប្រជាសាស្ត្រ និងសេដ្ឋកិច្ច ដូចជា "អំពីស្ថិតិ និងអត្រាមនុស្សស្លាប់ និងកើតហើយនិងអំពីលទ្ធផលបង្កបង្កើនផលដែលឃុំនីមួយៗសម្រេចបាន"[251] ដែលនេះបង្ហាញថា **យ៉ីម ទិត្យ** មានការយល់ដឹងល្អអំពីឥទ្ធិពលនៃគោលនយោបាយផែនការរួម ទៅលើលទ្ធភាពរបស់ប្រជាជនក្នុងការរស់នៅលើទឹកដីដែលគាត់គ្រប់គ្រង។

104. **យ៉ីម ទិត្យ** ក៏បានតម្រូវឲ្យអ្នកនៅក្រោមបង្គាប់របស់គាត់ប្រគល់របាយការណ៍ជាលាយលក្ខណ៍អក្សរជារៀងរាល់ខែទាក់ទងនឹងបញ្ហាផ្សេងៗ ដូចជា ទំហំប្រជាជននៅក្នុងស្រុករបស់ពួកគេ ចំនួនអ្នកឈឺ តើមានសម្លៀកបំពាក់ និងអាហារគ្រប់គ្រាន់ដែរឬទេ និងតើប្រជាជនមានទំនាស់នឹងគ្នាដែរឬទេ[252]។ គាត់ក៏បានផ្តល់ការណែនាំជាលាយលក្ខណ៍អក្សរយ៉ាងទៀងទាត់ផងដែរ ទៅដល់អ្នកនៅក្រោមបង្គាប់របស់គាត់ នៅស្រុកសំឡូត[253] និងត្រួតពិនិត្យមើលស្រុក ម្តង ឬពីរដងក្នុងមួយខែ[254]។

105. **យ៉ីម ទិត្យ** ក៏បានបង្ហាញ និងអនុវត្តសិទ្ធិអំណាចរបស់គាត់ជាលេខាតំបន់ ១ ដោយដឹកនាំការប្រជុំកម្មាភិបាលដែលក្នុងពេលនោះ គាត់ពិភាក្សាអំពីគោលនយោបាយបក្ស។ ឧទាហរណ៍ **យ៉ីម ទិត្យ** បានដឹកនាំការប្រជុំ ប្រហែលរៀងរាល់ ១០ ថ្ងៃម្តង សម្រាប់កម្មាភិបាលថ្នាក់សហករណ៍ទាំងអស់នៅក្នុងស្រុកគាស់ក្រឡ[255]។ គាត់បានឡើងធ្វើឧទ្ទេសនាក្នុងពេលប្រជុំមួយដែលមានកម្មាភិបាលរាប់រយនាក់ចូលរួម មកពីសហករណ៍ ស្រុក និងកងចល័ត[256] នៅបាណន់ (នៅវត្តបាណន់លើ) នៅជិតដំណាច់ឆ្នាំ១៩៧៧[257]។ **យ៉ីម ទិត្យ** បានណែនាំអ្នកចូលរួមប្រជុំឲ្យ "គោរពការចាត់តាំងរបស់អង្គ

---

[250] D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៥៥, ៨៤ KH 01008706, 710។

[251] D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.១៦ KH 01095988។ ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.១៤០-១៤១ KH 01329404។

[252] D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៤៥ KH 01008704។ *សូមមើលផងដែរ* ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.១៣២-១៣៤ KH 01329403។

[253] D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៤៤ KH 01008704 ["សេចក្តីណែនាំ ឬរបាយការណ៍ដែលថ្នាក់ស្រុកទទួលបានពីថ្នាក់តំបន់នៅពេលនោះ គឺមានឈ្មោះ អ៊ំទិត្យ ដែលសរសេរដោយដៃ"]។

[254] D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៦៥ KH 01008707។

[255] ឯកសារ D219/210 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.៤-៨ KH 01074048។

[256] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤១ KH 01205208។

[257] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៥-៧៦ KH 01196544។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៧, ៤០ KH 01205207 ["ស៖ នៅក្នុងកិច្ចសម្ភាសន៍របស់លោកកាលពីលើកមុន លោកបានប្រាប់

ការ"[258]។ **យ៉ីម ទិត្យ** ក៏បានដឹកនាំការប្រជុំនៅការដ្ឋានទំនប់កង្ហតជាប្រចាំផងដែរ។ ការប្រជុំទាំងនេះមានការចូលរួមពីអ្នកដែលមកពីស្រុកទាំងអស់ក្នុងតំបន់ ១។ នេះបង្ហាញពីសិទ្ធិអំណាចរបស់ **យ៉ីម ទិត្យ** ទៅលើតំបន់ទាំងមូល[259]។

106. ទាំងតាម៉ុក ទាំង **យ៉ីម ទិត្យ** ទាំងតាប៉ែត បានធ្វើឧទ្ទេសនាមក្នុងការប្រជុំមួយរៀបចំឡើងនៅវត្តតាមឹម ដែលក្នុងពេលប្រជុំនោះ ពួកគាត់បានគូសបញ្ជាក់ថា ប្រទេសកម្ពុជា "បានរំដោះហើយ មានឯករាជ្យម្ចាស់ការមិនបាច់ពឹងផ្អែកទៅលើប្រទេសដទៃទេ"[260]។

107. ទំនួលខុសត្រូវរបស់ **យ៉ីម ទិត្យ** ក្នុងតំបន់ ១ រួមមានការយ្លាំមើលសន្តិសុខក្នុងតំបន់ទាំងមូល ដូចដែលត្រូវបានបង្ហាញដោយការដែលថា គាត់បានណែនាំរដ្ឋអំណាចស្រុកសំឡូតឲ្យសាងសង់មន្ទីរសន្តិសុខថ្មីមួយក្នុងស្រុក នៅចុងឆ្នាំ១៩៧៨[261]។ ភ័ស្តុតាងបានបញ្ជាក់ផងដែរថា គាត់មានសិទ្ធិ

ឲ្យដឹងថា លោកបានជួប យ៉ីម ទិត្យ លើកដំបូងនៅចុងឆ្នាំ១៩៧៧ នៅក្នុងកិច្ចប្រជុំមួយ។ នៅពេលដែលលោកជួប យ៉ីម ទិត្យ លើកដំបូង តើនៅពេលនោះ តាប៉ែត ត្រូវបានគេចាប់ខ្លួនហើយឬនៅ? ឬ តាប៉ែត នៅតែបន្តធ្វើជាលេខាតំបន់១ នៃភូមិភាគពាយ័ព្យដដែល? ឆ.៣៧៖ កាលខ្ញុំទៅប្រជុំជួប តាទិត្យម្តងហ្នឹង នៅបាណន់។ ឪពុកធំរបស់ខ្ញុំ គេមិនទាន់ចាប់នៅឡើយ"]។

[258] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤៣ KH 01205208 ["ស៖ នៅក្នុងកិច្ចប្រជុំនេះ តើ តាទិត្យ មានឡើងនិយាយដែរទេ? ឆ.៤៣៖ តាទិត្យ ឡើងនិយាយថា "មិត្តយើងត្រូវគោរណការចាប់តាំងរបស់អង្គការ"] ឆ.៧៣ KH 01205215 ["ស៖ នៅក្នុងកិច្ចប្រជុំដែលលោកចូលរួម ហើយ យ៉ីម ទិត្យ បានឡើងនិយាយនៅចុងឆ្នាំ១៩៧៧ តើ យ៉ីម ទិត្យ មានបាននិយាយអំពីបញ្ហាខ្មាំងរបស់អង្គការដែរឬទេ? ឆ.៧៣៖ អត់និយាយអីដែរ ពេលខ្ញុំទៅគេគិតតែរឿងផែនការ លើកទំនប់ប្រឡាយ ទប់ស្ទឹងកង្ហតយកទឹកទៅធ្វើស្រែ។ រឿងផ្សេងអត់មានបានលើកប្រាប់ផង"]។

[259] ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.២៣-២៥ KH 01095209 ["ស៖ តើអ្នកដែលមកទទួលការណែនាំពីតាទិត្យនៅក្នុងអង្គប្រជុំ នៅនឹងទំនប់កង្ហត មកពីស្រុកនិងតំបន់ណាខ្លះ? ឆ.២៤៖ ពួកគេមកពីគ្រប់ស្រុកទាំងអស់ក្នុងតំបន់ ១។ ខ្ញុំនៅចាំថាមានមនុស្សមកពីរូង ស្រុកបាណន់ ស្រុកគាស់ក្រឡ ហើយនិងស្រុកដទៃទៀតនៅក្នុងតំបន់១។"]។ ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.១៧ KH 01080844។

[260] ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.២៨ KH 01095210។

[261] ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.៥១-៥២ KH 01008705 ["នៅពេលនោះមិនទាន់មន្ទីរសន្តិសុខនៅស្រុកសំឡូតនៅឡើយទេ ប៉ុន្តែមានផែនការកសាងមន្ទីរសន្តិសុខមួយនៅឃុំអ្ករាំងខេន។ [...] ផែនការកសាងមន្ទីរសន្តិសុខ គឺថ្នាក់ស្រុកទទួលបានមកពីថ្នាក់តំបន់ តាមរយៈលិខិតដែលមានឈ្មោះ តាទិត្យ។ នៅក្នុងលិខិតនោះ ថ្នាក់តំបន់បង្គាប់ឲ្យថ្នាក់ស្រុកសាងសង់មន្ទីរសន្តិសុខមួយទំហំ ១០ ម៉ែត្រ គុណនឹង ១០"]។ ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.១៣៧-១៣៩ KH 01329403-04។

អំណាចធ្វើការចាប់ខ្លួន និងដល់ស្រាយបញ្ហាសន្តិសុខនៅក្នុងតំបន់ ៣[262]។ គាត់ក៏ជាអ្នកគ្រប់គ្រងយោធាតំបន់ផងដែរ[263]។

108. **យ៉ីម ទិត្យ** បានមកលេងលេខាស្រុកបវេល ក្នុងតំបន់ ៣ នៅមន្ទីរស្រុក ដើម្បីត្រួតពិនិត្យស្រែ និងដំណាំផ្សេងទៀត ធានាថា ស្រុកអនុវត្តតាមផែនការរបស់ស្រុក និងផ្តល់ការណែនាំពាក់ព័ន្ធនឹងខ្ទាំង[264]។ គាត់ក៏បានទាក់ទងជាប្រចាំជាលាយលក្ខណ៍អក្សរជាមួយលេខាស្រុកបវេល តាមរយៈនីរសារៈរបស់គាត់ផងដែរ[265]។

109. សាកលវិទ្យាល័យបាត់ដំបង ត្រូវបានប្រើប្រាស់ជាកន្លែងប្រជុំសម្រាប់គណៈកម្មាធិការភូមិភាគពាយ័ព្យ ទាំងនៅមុន[266] និងក្រោយការមកដល់របស់កម្មាភិបាលភូមិភាគនិរតី។ តាម៉ុក បានកាន់កាប់ផ្ទះមួយនៅក្នុងបរិវេណសាកលវិទ្យាល័យ ពេលគាត់នៅភូមិភាគពាយ័ព្យ[267]។ **យ៉ីម ទិត្យ** អនុវត្តសិទ្ធិអំណាចរបស់ខ្លួនជាអនុលេខាភូមិភាគ ដោយកោះប្រជុំមេដឹកនាំយោធានៅសាកលវិទ្យាល័យបាត់ដំបង[268]។

---

[262] D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.១៩០-១៩១ KH 01095264។

[263] D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.១៩១ KH 01095264។

[264] D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.៧៦, ៨១ KH 01095247។

[265] D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.៩៨ KH 01095250។

[266] ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ហ៊ា ឆ.៣៣ KH 00960667។

[267] ឯកសារ D118/150 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ម៉ឿន ឆ.១១ KH 00967996 ["ផ្ទះរបស់តាម៉ុក គឺនៅក្នុងបរិវេណសាលាសកលនៅបាត់ដំបង"] ឆ.៤២-៤៣ KH 00968001 ["នៅក្នុងបរិវេណសាលាសកល"]។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ហ៊ា ឆ.៣៣ KH 00960667។

[268] ឯកសារ D118/150 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ម៉ឿន ឆ.៦១ KH 00968003 [សាក្សីជាក្មួយប្រុសតាម៉ុក ហើយធ្លាប់បានធ្វើដំណើរវែងឆ្ងាយជាមួយតាម៉ុក៖ "តាម៉ុក បានប្រកាសប្រាប់យោធាថា "បើអស់ពីអញទៅ តាទិត្យ ជាអ្នកទទួលខុសត្រូវភូមិភាគបន្ទាប់"។ តាទិត្យ ធ្លាប់បានបានហៅមេៗយោធាទៅប្រជុំនៅក្នុងបាត់ដំបងនៅបរិវេណសាលាសកល"]។ *សូមមើលផងដែរ* ឯកសារ D118/222 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ម៉ឿន ឆ.៣២ KH 00983237 [សាក្សីជាក្មួយប្រុសតាម៉ុក ហើយធ្លាប់បានធ្វើដំណើរវែងឆ្ងាយជាមួយតាម៉ុក៖ "នៅត្រង់ចំណុចមួយ នៅពេលដែលខ្ញុំឆ្លងពីខេត្តពោធិ៍សាត់មកខេត្តកំពង់ឆ្នាំង ខ្ញុំដឹងថាមានមូលដ្ឋានយោធាមួយនៅលើភ្នំត្រង់ចំណុចនោះ ហើយខ្ញុំបានឮថា តាម៉ុក ប្រចាំការនៅទីនោះ។ នៅពេលនោះ ខ្ញុំបានឃើញ តាទិត្យ ជិះឡានដែលបើកបរដោយនីរសារៈរបស់គាត់ ហើយឡានៈនោះបើកបរតាមផ្លូវទៅមូលដ្ឋានយោធានៅលើភ្នំនោះ។ ខ្ញុំដឹងថា អ្នកបើកបរជានីសារ ពីព្រោះនៅក្នុងរបបនោះមានតែនីរសារៈទេដែលអាចបើកបរឲ្យកម្មាភិបាលជាន់ខ្ពស់ និងកម្មាភិបាលផ្សេងទៀតទៅកន្លែងផ្សេងៗទៀតបាន។ ខ្ញុំមិនស្គាល់ឈ្មោះនីរសារៈរបស់គាត់ទេ។ តាទិត្យ មិនមានកងណារមមដំណើរ ឬការពារឡានៈរបស់គាត់ទេ"]។

១. សេចក្តីសន្និដ្ឋាន

110. មានភ័ស្តុតាងច្បាស់លាស់ និងស៊ីសង្វាក់គ្នាបញ្ជាក់ថា **យ៉ីម ទិព្ធ** ជាមេដឹកនាំ ប.ក.ក ដ៏សំខាន់ម្នាក់ ទាំងនៅភូមិភាគនិរតី ទាំងនៅភូមិភាគពាយ័ព្យ ហើយអំណាច និងភាពលេចធ្លោរបស់គាត់កើនឡើងឥតឈប់ឈរ ក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ទាំងមូល។ មានភ័ស្តុតាងស៊ីសង្វាក់គ្នាខ្ពស់ដែលទទួលបានពីសាក្សីឯករាជ្យ បង្ហាញថា គាត់បានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងគ្រប់ទិដ្ឋភាពនៃសហឧក្រិដ្ឋកម្មរួមដែលគ្របដណ្តប់លើភូមិភាគទាំងពីរ។

IV. រចនាសម្ព័ន្ធអំណាច និងការគ្រប់គ្រងរបស់ ប.ក.ក

111. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ **យ៉ីម ទិព្ធ** និងមេដឹកនាំតំបន់ផ្សេងទៀតបានអនុវត្តគោលនយោបាយឧក្រិដ្ឋរបស់បក្សកុម្មុយនីស្តកម្ពុជា។ ដោយប្រើប្រាស់រចនាសម្ព័ន្ធអំណាច និងវិធីសាស្ត្រទំនាក់ទំនងរបស់ ប.ក.ក គោលនយោបាយ និងបញ្ជារបស់បក្សដែលចេញពីមជ្ឈិម ត្រូវបានបញ្ជូនទៅក្រោមតាមរយៈរដ្ឋអំណាចតំបន់ ជាពិសេស អង្គការបក្សថ្នាក់ភូមិភាគ តំបន់ និងស្រុក។ **យ៉ីម ទិព្ធ** និងសមាជិកផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួម បានប្រើប្រាស់មនុស្សគ្រប់កម្រិតនៃរចនាសម្ព័ន្ធអំណាចនេះ ដែលពួកគេមានអំណាច និងឥទ្ធិពលទៅលើ ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មដែលសហព្រះរាជអាជ្ញាអន្តរជាតិធ្វើការចោទប្រកាន់។

ក. ប្រព័ន្ធថ្នាក់ជាតិ

112. លក្ខន្តិកៈរបស់ ប.ក.ក បានកំណត់ថាគណៈកម្មាធិការមជ្ឈិមជា "អង្គការរបស់បក្សមានសិទ្ធិអំណាចធំជាងគេបំផុតសម្រាប់ទូទាំងប្រទេស"[269]។ គណៈកម្មាធិការមជ្ឈិមមានសមាជិកសរុបយ៉ាងតិចណាស់ ៣០ នាក់[270]។ គណៈកម្មាធិការមជ្ឈិមមានសមាសភាពសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍ និងមេដឹកនាំយោធាថ្នាក់ភូមិភាគ និងតំបន់[271]។

---

[269] ឯកសារ D1.3.20.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា មាត្រា ៧.១ KH 00053025 ។

[270] ឯកសារ D1.3.36.1 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន EN 00539265។ ឯកសារ D1.3.27.5 Masato Matsushita និង Stephen Heder *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនថៃកម្ពុជា* KH 00324765។

[271] ឯកសារ D1.3.36.1 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន EN 00539265។ឯកសារ D6.1.93 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00242892-93។ ឯកសារ D6.1.95 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00244236។ ឯកសារ D6.1.1067 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146663។ ឯកសារ D6.1.1063

113. តាមការអនុវត្ត គណៈកម្មាធិការអចិន្ត្រៃយ៍[272] ជាអង្គភាពខ្ពស់ជាងគេបំផុត និងមានអំណាចជាងគេបំផុតនៅក្នុង ប.ក.ក និងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ[273]។ ខៀវ សំផន លើកឡើងថា "ចំពោះមាគ៌ានយោបាយ និងការចេញសេចក្តីសម្រេច [...] ត្រូវបានធ្វើ និងសម្រេចដោយគណៈកម្មាធិការអចិន្ត្រៃយ៍"[274] ហើយ ឌុច បានប្រកាសថា គណៈកម្មាធិការអចិន្ត្រៃយ៍ជា "អង្គការចាត់តាំងសំខាន់របស់បក្ស"[275]។ ទីស្នាក់ការរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នៅទីក្រុងភ្នំពេញ ត្រូវគេស្គាល់ថាជា "មន្ទីរ ៨៧០"។

114. នៅសម័យកម្ពុជាប្រជាធិបតេយ្យ គណៈកម្មាធិការអចិន្ត្រៃយ៍មានសមាជិកប្រាំពីរនាក់ ក្នុងចំណោមនោះ សមាជិកប្រាំនាក់ ជាសមាជិក "ពេញសិទ្ធិ"[276]។ លេខាភូមិភាគនិរតី តាម៉ុក បងថ្លៃរបស់ **យ៉ី**

កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00187666។ ឯកសារ D6.1.1072 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00197975។ ឯកសារ D1.3.15.2 Timothy Carney *ការដឹកនាំរបស់បក្ស* KH 00332368-69 ។ ឯកសារ D117/36.1.20 សៀវភៅរៀបរៀងដោយ Stephen Heder និង Brian Tittemore *បេក្ខជនទាំងប្រាំពីរនាក់ដែលត្រូវនាំមកកាត់ទោស* EN 00393581។ ឯកសារ D1.3.17.1 Elizabeth Becker *នៅពេលដែលសង្គ្រាមរលត់ទៅ* EN 00237887។

[272] ឯកសារ D6.1.1065 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146557។ ឯកសារ D6.1.1066 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146573។ ឯកសារ D6.1.1067 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146659។ ឯកសារ D6.1.1051 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00154926។ ឯកសារ D6.1.1056 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00178025 ។ ឯកសារ D6.1.92 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00239848។ ឯកសារ D6.1.93 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00242890។

[273] ឯកសារ D1.3.36.1 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន EN 00539264។ ឯកសារ D6.1.1065 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146557។ ឯកសារ D6.1.91 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00239832 ។ ឯកសារ D6.1.1166 កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ នៃ ប.ក.ក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ EN 00182546។ ឯកសារ D6.1.1101 កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ នៃ ប.ក.ក ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ១៩៧៦ KH 00017124-26។ ឯកសារ D1.3.29.1 បទសម្ភាសន៍ជាមួយ អ៊ៀង សារី ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00062453។ ឯកសារ D6.1.1259 កិច្ចសម្ភាសន៍របស់ SOAS ជាមួយខៀវ សំផន KH 00078213។

[274] ឯកសារ D1.3.36.1 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន EN 00539264។

[275] ឯកសារ D6.1.91 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00239832។

[276] ឯកសារ D1.3.36.1 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន EN 00539265។ ឯកសារ D1.3.29.4 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146482។ ឯកសារ D6.1.1065 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146557។ ឯកសារ D6.1.1070 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00195568-69។ ឯកសារ

ម ទិញ ជាសមាជិកម្នាក់ក្នុងចំណោមសមាជិក "ពេញសិទ្ធិ" ទាំងប្រាំនាក់នៃគណៈកម្មាធិការអចិន្ត្រៃយ៍[277]។

115. គោលការណ៍ណែនាំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ត្រូវបានបញ្ជូនទៅមន្ទីរភូមិភាគ កងពលយោធា និងក្រសួង ដែលនៅទីនោះ គោលការណ៍ណែនាំទាំងនេះត្រូវបានផ្សព្វផ្សាយទៅថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ក្រោមផ្សេងទៀត[278]។ ក្នុងគោលការណ៍ណែនាំ មានផ្តល់ការណែនាំច្បាស់លាស់អំពីថាតើពួកគេត្រូវផ្សព្វផ្សាយ និងអនុវត្តយ៉ាងដូចម្តេច[279]។

116. មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប.ក.ក បានបែងចែងប្រទេសជាតំបន់ស្នូលចំនួនប្រាំដែលមានដាក់លេខកូដសម្គាល់ៈ ភូមិភាគឦសាន (១០៨) ភូមិភាគឧត្តរ (៣០៤) ភូមិភាគពាយ័ព្យ (៥៦០) ភូមិភាគនិរតី (៤០៥) និងភូមិភាគបូព៌ា (២០៣) និង "ភូមិភាគពិសេស" ដែលរួមមានតំបន់ជុំវិញទីក្រុងភ្នំពេញ[280]។ ភ្លាមៗក្រោយថ្ងៃទី១៧ ខែមេសា ភូមិភាគបស្ចិម (៤០១) ត្រូវបានបង្កើតឡើង

D1.3.27.5 Masato Matsushita និង Stephen Heder *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនថៃកម្ពុជា* KH 00324764។

[277] ឯកសារ D1.3.36.1 កំណត់ហេតុស្តាប់ចម្លើយ ខៀវ សំផន EN 00539265។ ឯកសារ D6.1.899 កំណត់ត្រាការនិយាយរបស់ ខៀវ សំផន ដោយ អ៊ា ម៉ង់ទ្រី KH 00347037។ ឯកសារ D1.3.29.1 បទសម្ភាសជាមួយ អៀង សារី មជ្ឈមណ្ឌលឯកសារកម្ពុជា KH 00062453។ ឯកសារ D1.3.29.4 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146482។ ឯកសារ D6.1.1070 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00195568។ ឯកសារ D6.1.477 កំណត់ហេតុស្តាប់ចម្លើយ ជួន ប្រសិទ្ធិ KH 00348322 ។ ឯកសារ D6.1.1077 កំណត់ហេតុស្តាប់ចម្លើយ សូរ ហុង ហៅ សាឡុត បាន KH 00492960 ។ ឯកសារ D6.1.987 កំណត់ហេតុស្តាប់ចម្លើយ សូរ ហុង ហៅ សាឡុត បាន KH 00204102 ។ ឯកសារ D6.1.1074 កំណត់ហេតុស្តាប់ចម្លើយ ភី ភួន KH 00204072 ។ ឯកសារ D1.3.27.5 Masato Matsushita និង Stephen Heder *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនថៃកម្ពុជា* KH 00324764។

[278] ឯកសារ D6.1.503 កំណត់ហេតុស្តាប់ចម្លើយ នង សុផង់ KH 00294538-39 ។ ឯកសារ D6.1.786 កំណត់ហេតុស្តាប់ចម្លើយ អៀប ឌុច KH 00163530 ។ ឯកសារ D117/36.1.22 សេចក្តីណែនាំអំពីការប្រើពាក្យ អង្គការ និងពាក្យ បក្ស ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៩៧៧ KH 00082731 ។ ឯកសារ D6.1.473 សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកម្ពុជា ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ KH 00079282។

[279] ឯកសារ D6.1.473 សេចក្តីណែនាំអំពីការប្រើពាក្យ អង្គការ និងពាក្យ បក្ស សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកម្ពុជា ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ KH 00082731។

[280] ឯកសារ D1.3.27.5 Masato Matsushita និង Stephen Heder *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនថៃកម្ពុជា* (កំណត់ហេតុស្តាប់ចម្លើយ ចាប ឡុញ) KH 00324751។ ឯកសារ D6.1.594 Philip Short *ប៉ុល ពត៖ ប្រវត្តិនៃសុបិនអាក្រក់* EN

ចេញពីផ្នែកមួយនៃភូមិភាគនិរតី និងភូមិភាគស្វយ័តមួយចំនួន[281]។ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ភូមិភាគទីប្រាំពីរត្រូវបានបង្កើតឡើង ពេលតំបន់ស្វយ័ត ១០៣ និង ១០៦ មុនក្លាយជាភូមិភាគឧត្តរថ្មី (៨០១) ហើយភូមិភាគឧត្តរចាស់ត្រូវបានប្តូរឈ្មោះទៅជាភូមិភាគកណ្តាល[282]។

117. ភូមិភាគត្រូវបានបែងចែកជាអង្គភាពដែលគេស្គាល់ថាជាតំបន់ ដែលបន្ទាប់មកត្រូវបានបែងចែកជាស្រុក[283]។ ស្រុកមួយមានឃុំមួយចំនួនដែលមានភូមិជាច្រើន។ ការធ្វើស្រែចម្ការ និងការងារប្រពៃណីផ្សេងទៀត ត្រូវបានរៀបចំជា "សហករណ៍"[284]។

118. ភូមិភាគ តំបន់ និងស្រុកមានតួនាទីសំខាន់ក្នុងការអនុវត្តគោលការណ៍ណែនាំរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក នៅទូទាំងប្រទេស។ គណៈកម្មាធិការមួយមានសមាសភាពបីនាក់ រួមមាន លេខា អនុលេខា និងសមាជិក គ្រប់គ្រងថ្នាក់នីមួយៗក្នុងឋានានុក្រមចាត់តាំងរបស់ ប.ក.ក។

119. ឧទាហរណ៍ គណៈកម្មាធិការភូមិភាគទទួលខុសត្រូវលើការត្រួតពិនិត្យការអនុវត្តផែនការ ភារកិច្ច និងមាគ៌ាបក្សក្នុងតំបន់ ស្រុក និងឃុំ រហូតដល់អង្គភាពបក្សថ្នាក់ទាបបំផុត "រាយការណ៍អំពីស្ថានការណ៍ និងការងាររបស់ភូមិភាគជូនគណៈកម្មាធិការមជ្ឈិម"[285]។ គណៈកម្មាធិការនៅថ្នាក់តំបន់

00396426។ ឯកសារ D6.1.1085 កំណត់ហេតុស្តាប់ចម្លើយ ថា សុត KH 00204739។ ឯកសារ D6.1.521 កំណត់ហេតុស្តាប់ចម្លើយ នីម សែម KH 00357219។

លេខាស្រុក លេខាស្រុករាយការណ៍ទៅលេខាតំបន់ ១[441]។ ស្រដៀងគ្នានេះដែរ បញ្ជាត្រូវបានបញ្ជូនតាមខ្សែសង្វាក់នៃការបញ្ជា ភូមិភាគ-តំបន់-ស្រុក-សហករណ៍[442]។ បន្ទាប់ពីការបោសសម្អាតគណៈកម្មាធិការស្រុកវួច តាណេន និងតាថុន មានអំណាចបញ្ជាឲ្យប្រជាជនចូលរួមវគ្គ "កសាង" ដែលតាមពិត មានន័យថា បាត់ខ្លួន[443]។ តាណេន និងតាថុន ជាថ្នាក់លើរបស់ប្រធានសហករណ៍ តាសុន ដែលជាថ្នាក់លើរបស់ប្រធានគុកធិបតី[444]។ តាសុន ក៏មានអំណាចបញ្ជាឲ្យសម្លាប់ផងដែរ[445]។ គឹម និង ប៉ោង មានអំណាចចេញបញ្ជាឲ្យចាប់មនុស្សដល់អ្នកនៅក្រោមបង្គាប់របស់ពួកគេ ដើរមើលគុក និងកំណត់អត្តសញ្ញាណខ្មាំងដែលសង្ស័យ[446]។

---

[441] ឯកសារ D219/514 កំណត់ហេតុស្តាប់ចម្លើយ សៀន ស៊ីម ឆ.៤ KH 01149390-01149391 ["មេភូមិរាយការណ៍ទៅមេឃុំ ដែលមេឃុំនោះ ជាគណៈសហករណ៍។ [...]កាលខ្ញុំដឹកអ្នកទោស អ្នកដែលមេភូមិរាយការណ៍ជូន គឺជាមេឃុំនិរតីដែលខ្ញុំមិនចាំឈ្មោះ។"]។ ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.៤ KH 01080841 ["ខ្ញុំរាយការណ៍ឡើងទៅឲ្យបងយ៉ីន ជាលេខាប្រធានស្រុកគាស់ក្រឡ ហើយ យ៉ីន គាត់រាយការណ៍ឡើងទៅឲ្យ តាប៉ែត។"] (*សម្គាល់* សាក្សីបញ្ជាក់ថា តាប៉ែត ជាលេខាតំបន់ ១ នៅឯកសារ D219/210 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.១ KH 01074047)។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.៣២ KH 01095211។

[442] ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.១៦ KH 01095207។

[443] ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.១៦ KH 01095207 ["ខ្ញុំនៅចាំឈ្មោះអ្នកមកពីនិរតីខ្លះ ដូចជា តាថុន និងតាណេង។ [...]តាថុន និងតាណេង អ្នកហៅមនុស្សឲ្យទៅរៀនសូត្រហើយបាត់ខ្លួនរហូត។"]។

[444] ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.៩ KH 01080842 ["គាត់ (តាសុន) ធ្វើតាមបញ្ជារបស់ តាណេន និងតាថុន ដែលជាគណៈស្រុក។"]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៩៥ KH 01149428 ["តាភ្ជឿក ដែលជាមេគុកធ្វើការក្រោមបញ្ជារបស់មេសហករណ៍ គឺ តាសុន។"]។

[445] ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៧៥ KH 01149424-01149425 ["នៅភ្នំធិបតី [...]តាសុន [...]បានបញ្ជាឲ្យអ្នកចាំបាញ់ សម្លាប់ដោយទាំងតាយ៉ានផងដែរ។"]។ សាក្សី ត្ងូច ប៊ុនថី បានកំណត់ការសម្លាប់នៅវាលពិឃាតដែល "ប្រហែល កន្លះគីឡូម៉ែត្រពីជើងភ្នំធិបតី។" ដែលចម្ងាយនេះប្រហាក់ប្រហែលគ្នានឹងចម្ងាយដែលសាក្សី ឃិន ខៀន បាននិយាយថា អ្នកទោស ត្រូវបានសម្លាប់ ឲ្យទៅ តាសុន *សូមមើល* ឯកសារ D219/172 កំណត់ហេតុស្តាប់ចម្លើយ ត្ងូច ប៊ុនថី ឆ.២០-២១ KH 01065965។ ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៩៤ KH 01025662។

[446] ឯកសារ D219/624 កំណត់ហេតុស្តាប់ចម្លើយ ប៊ី ញ៉ែត ឆ.១៨ KH 01184283 ["ស៖ តើលោកស្រីមានស្គាល់ឈ្មោះ ពួកយោធាដែលចង និងនាំលោកស្រីក្នុងពេលនោះដែរឬទេ? ឆ.១៨៖ ចាស គេគឺជាពួកយោធាដែលធ្វើជាអ្នកយាមធ្វើការនៅទីនោះ ហើយគេធ្វើទៅតាមបញ្ជារបស់គឹម និងប៉ោង។ អ្នកដែលនាំពួកយើងយកទៅកន្លែងសម្លាប់នោះ ឈ្មោះ ដន។"] ឆ.១០-១១ KH 01184281 [គឹម និងប៉ោង "គេបានបើកអង្គប្រជុំចំនួន ៣ថ្ងៃ នៅវត្តដូនបា ហើយគេបានប្រកាសថា គេធ្វើការចម្រាញ់ដោយនិយាយថា គេចម្រាញ់យកតែគ្រាប់ស្រូវ គ្រាប់អង្ករដែលល្អៗ ហើយដកគ្រាប់អាក្រក់ចេញ។"]។ ឯកសារ D219/625 កំណត់ហេតុស្តាប់ចម្លើយ ប៊ី ញ៉ែត ឆ.៣១ KH 01184294 [សាក្សីត្រូវបានជាប់គុកនៅមន្ទីរសន្តិសុខគាស់ក្រឡ៖ "គឹម និងប៉ោង

152. ប្រធានភូមិចូលរួមប្រជុំនៅ "ថ្នាក់ស្រុក [...] ប្រហែលម្តងក្នុង២សប្តាហ៍" ហើយក្រោយការប្រជុំ ប្រធានភូមិបញ្ជូនបន្តផែនការការងារ និងព័ត៌មានពាក់ព័ន្ធនឹងខ្ទាំងទៅដល់កម្មករដែលខ្លួនគ្រប់គ្រង[447]។ កម្មាភិបាលថ្នាក់ស្រុកកំណត់ផែនការការងារសម្រាប់កម្មាភិបាលថ្នាក់មូលដ្ឋាននៅក្នុងភូមិ និងលើកទឹកចិត្តឲ្យពួកគេប្រឹងប្រែងធ្វើការ[448]។

153. **យ៉ីម ទិត្យ** ជាអ្នកគ្រប់គ្រងដ៏សំខាន់ និងដោយផ្ទាល់លើស្រុកគាស់ក្រឡ។ ក្រោយការបាត់ខ្លួន យ៉ីន លេខាស្រុក **យ៉ីម ទិត្យ** បានចាប់ផ្តើមរៀបចំការប្រជុំជាប្រចាំដោយខ្លួនឯងផ្ទាល់ ជាមួយប្រធានសហករណ៍ទាំងអស់នៅក្នុងស្រុកគាស់ក្រឡ ដែលពីមុនមក គឺ យ៉ីន ជាអ្នករៀបចំ[449]។ ក្នុងពេលប្រជុំទាំងនេះ **យ៉ីម ទិត្យ** បានណែនាំឲ្យប្រធានសហករណ៍ពង្រឹងស្មារតីរបស់ប្រជាជន "ឲ្យជឿជាក់ទាំងស្រុកទៅលើបក្ស"[450]។

[...]ហើយចេញចូលៗនៅទីនោះ។"] ឯ.៥ KH 01184289 ["ដោយសារពួកគាត់ជាប់សាច់ឈាមនឹងគ្រួសាររបស់ខ្ញុំ ដូចជា ឪពុកម្តាយខ្ញុំ ពេលនោះ គេចាត់ទុកពួកយើងនៅក្នុងខ្សែជាមួយគ្នា ហើយគេចោទពួកយើងថា ជាខ្សែក្បត់។ គេបានប្រើពាក្យពេចន៍ទាំងនេះ និយាយថា គេធ្វើការចម្រាញ់យកតែគ្រាប់ដែលល្អ។"]។

[447] ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឯ.២៩ KH 01022366 [សាក្សី រស់នៅភូមិធិបតី៖ "ស៖ នៅក្នុងបទសម្ភាសន៍លោកស្រីពីលើកមុន លោកស្រីនិយាយថា មេភូមិដំបូងរបស់លោកស្រីឈ្មោះ រ៉ៀន ក្រោយមក រ៉ៀន ត្រូវបានគេយកទៅសម្លាប់។ ឆន ត្រូវបានគេឲ្យមកជំនួស រ៉ៀន។ ឆន ជាកម្មាភិបាលមកពីភូមិភាគនិរតី។ តើត្រឹមត្រូវដែរឬទេ? ឯ.២៩៖ ចាស។ "] ឯ.១១៧-១២០ KH 01022376 ["ខ្ញុំគ្រាន់តែឮគេនិយាយថា ឆន ទៅចូលរួមប្រជុំនៅថ្នាក់ស្រុក។ [...]ប្រហែលម្តងក្នុង ២សប្តាហ៍ [...]ដើម្បីទទួលផែនការ។" ក្រោយមក ឆន ប្រជុំប្រាប់ប្រជាជនអំពីផែនការ និងនិយាយពីខ្ទាំងក្បត់។]។ សូមមើលផងដែរ ឯកសារ D219/549 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឯ.២១-២៤, ២៨ KH 01157577 ["ស៖ កាលពីនៅធ្វើការនៅទួលម្ទេស តើលោកស្រីមានដែលចូលរួមប្រជុំ នៅពេលពួកនិរតីកាន់កាប់ទេ? ឯ.២១៖ នៅពេលបោកស្រូវមានប្រជុំប្រាប់ឲ្យរៀបចំការងារសម្រាប់ថ្ងៃស្អែក។ [...] ឯ.២២៖ វាធ្វើឡើង ៥ថ្ងៃម្តង ឬម្តងក្នុងមួយអាទិត្យដើម្បីរៀបចំការងារ។ [...]ឯ.២៣៖ គេធ្វើនៅកន្លែងការដ្ឋានការងារ។ [...] ឯ.២៤៖ វាជាការប្រជុំនៅក្នុងកង ដូច្នេះ ម្នាក់ៗត្រូវតែទៅ គ្មានអ្នកណាមិនទៅទេ។ [...] ឯ.២៨៖ ការប្រជុំធំ គឺគេមិនធ្វើនៅការដ្ឋានទេ គឺគេធ្វើនៅការដ្ឋានទំនប់កង្គតវិញ។"]។

[448] ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឯ.៥៧, ៥៩, ៦០, ៦២ KH 01022369-01022370 [នៅភូមិមួយនៅភ្នំធិបតី៖ "ពួកគេចុះមកដាក់ផែនការឲ្យកម្មាភិបាលមូលដ្ឋាន [...] ឲ្យសម្រុកការងារ។"]។

[449] ឯកសារ D219/210 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឯ.៤, ៦-៧ KH 01074048។ សូមមើលផងដែរ ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឯ.៤, ១៧ KH 01080841, 01080844។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឯ.២១ KH 01095209។

[450] ឯកសារ D219/210 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឯ.៨ KH 01074048។

ខ. ស្រុកសង្កែ

154. ស្រុកសង្កែត្រូវបានបែងចែកយ៉ាងតិចណាស់ជាបួនឃុំ[451]។ ទីតាំងឧក្រិដ្ឋកម្មចំនួនបួនក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ស្ថិតនៅក្នុងឃុំទាំងនេះ៖ ទីតាំងពលកម្មដោយបង្ខំទំនប់កង្ហតស្ថិតនៅក្នុងឃុំកង្ហត រោងចក្រស្ករសកំពង់គល់ស្ថិតនៅក្នុងឃុំកំពង់គល់ មន្ទីរសន្តិសុខបាណន់ស្ថិតនៅក្នុងឃុំកន្ទឹ និងមន្ទីរសន្តិសុខខ្នងគ្ងស្ថិតនៅក្នុងឃុំបាយដំរ៉ាំ[452]។

155. ដូចមានបញ្ជាក់លម្អិតនៅក្នុងផ្នែកស្តីពី ការបោសសម្អាត នៃដីកាសន្និដ្ឋានស្តាពរនេះ[453] ពេលកម្មាភិបាលភូមិភាគនិរតីមកដល់ កម្មាភិបាលភូមិភាគពាយ័ព្យដែលស្ថិតក្នុងគណៈកម្មាធិការស្រុកបានបាត់ខ្លួន ឬត្រូវបានគេទម្លាក់តំណែង[454]។ ក្រោយពួកនិរតីមកដល់ ថ្នាក់ក្រោមនៅតែ

---

[451] ឃុំទាំងនេះ គឺកង្ហត កំពង់គល់ កន្ទឹ និងបាយដំរ៉ាំ។ <u>កង្ហត</u>៖ ឯកសារ D131/2.1.87 បញ្ជីឈ្មោះ កម្មាភិបាល និងប្រជាជននៅស្រុកសង្កែ តំបន់ ១ ខែកុម្ភៈ ឆ្នាំ១៩៧៨ លេខរៀង ៧៦ KH 00214644។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៨ KH 00960689។ ឯកសារ D219/268 កំណត់ហេតុស្តាប់ចម្លើយ ណាំ ផន ឆ.១០ KH 01088835។ <u>កំពង់គល់</u>៖ ឯកសារ D131/2.1.87 បញ្ជីឈ្មោះ កម្មាភិបាល និងប្រជាជននៅស្រុកសង្កែ តំបន់ ១ ខែកុម្ភៈ ឆ្នាំ១៩៧៨ លេខរៀង ៤៩ KH 00214641។ <u>កន្ទឹ</u>៖ ឯកសារ D118/146 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខតំបន់ ១ KH 01386881-01385882។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៣ KH 00967983។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៨ KH 01117283។ <u>បាយដំរ៉ាំ</u>៖ ឯកសារ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១៧ KH 01238679។ ឯកសារ D219/516 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ហាន ឆ.២ KH 01149461 ។

[452] <u>ការដ្ឋានកម្លាំងពលកម្មដោយបង្ខំកង្ហត</u>៖ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៨ KH 00960689។ <u>រោងចក្រស្ករសកំពង់គល់</u>៖ ឯកសារ D1.3.22.2 យុវជន និងយុវនារីបដិវត្ត ខែមេសា ឆ្នាំ១៩៧៦ KH 00064318-00064319។ ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហ្ជួន ជឿម ឆ.១២ KH 00951904។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លីម ទីម ឆ.២ KH 00951925។ <u>មន្ទីរស្រុកបាណន់</u>៖ ឯកសារ D118/146 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខតំបន់ ១ KH 01386881-01385882។ <u>មន្ទីរសន្តិសុខខ្នងគ្ង</u>៖ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុ ច រ៉ៃន ឆ.៥៩ KH 01040171។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១៧ KH 01238679។

[453] សូមមើល V.B.1. ឧក្រិដ្ឋកម្ម-ភូមិភាគពាយ័ព្យ-ការសម្លាប់រង្គាល។

[454] <u>លេខាវ៉ៃ/វ៉ៃ</u>៖ ឯកសារ D131/2.1.87 បញ្ជីឈ្មោះ កម្មាភិបាល និងប្រជាជននៅស្រុកសង្កែ តំបន់ ១ ខែកុម្ភៈ ឆ្នាំ១៩៧៨ លេខរៀងទី ១ KH 00214638។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៩, ១១-១២, ១៤ KH 00967984 [ឆ្នាំ១៩៧៥ "តាវ៉ៃ ជាគណៈស្រុកសង្កែ។ [...]តាវ៉ៃ [...]បាត់ខ្លួន ពេលពួកនិរតីមកដល់។ [...] ពួកនិរតីជាអ្នកមកជំនួស"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១២ KH 00960690 ["ស៖ តើតាយាន [...] គណៈស្រុកវ៉ូតឬ? ឆ.១២៖ ខ្ញុំដឹងថា គាត់នៅធ្វើជាគណៈស្រុកត្រមពេលដែលពួកនិរតីចូលមក"]។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម ឃួន ឆ.១២ KH 00960654។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧២ KH 01196543។ ឯក

សារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.៣៧ KH 01425169-01425170។ ឯកសារ D219/868 កំណត់ហេតុស្តាប់ចម្លើយ ជា ឈើយ ឆ.១៨ KH 01347431។ <u>អនុលេខា តាយ៉ាន</u>៖ ឯកសារ D131/2.1.87 បញ្ជីឈ្មោះ កម្មាភិបាល និងប្រជាជននៅស្រុកសង្កែ តំបន់ ១ ខែកុម្ភៈ ឆ្នាំ១៩៧៨ លេខរៀងទី ២ KH 00214638។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៩-១២, ១៤ KH 00967984 [នៅឆ្នាំ១៩៧៥ "នៅស្រុកសង្កែ [...]តាយ៉ាន់ អនុវរបស់តាវ៉ែ។ [...]តាយ៉ាន់ បាត់ខ្លួនពេលពួកនិរតីមកដល់ [...]ពួកនិរតីជាអ្នកមកជំនួស"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧២ KH 01196543។ ឯកសារ D219/452 កំណត់ហេតុស្តាប់ចម្លើយ ជា ធី ឆ.៧ KH 01129763។ សូមមើលឯកសារផ្ទុយ D118/135 កំណត់ហេតុស្តាប់ចម្លើយ អោម ឃួន ឆ.១២ KH 00960654 ["តាយ៉ាន់ ជាសមាជិក។"]។ <u>សមាជិក តាយាន</u>៖ ឯកសារ D131/2.1.87 បញ្ជីឈ្មោះ កម្មាភិបាល និងប្រជាជននៅស្រុកសង្កែ តំបន់ ១ ខែកុម្ភៈ ឆ្នាំ១៩៧៨ លេខរៀងទី ៨៩ KH 00214645។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១២ KH 00960690 ["ស៖ តើ [...]តាវ៉ែ ធ្វើជាគណៈស្រុករហូតឬ? ឆ.១២ ខ្ញុំដឹងថាគាត់នៅធ្វើជាគណៈស្រុកត្រឹមពេលដែលពួកនិរតីចូលមក"]។ សូមមើលឯកសារផ្ទុយ D118/135 កំណត់ហេតុស្តាប់ចម្លើយ អោម ឃួន ឆ.១២ KH 00960654 ["តាយានជា [...]អនុ"]។ ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.៣៧ KH 01425169-01425170 ["អនុប្រធាន គឺតាយាង។"]។ <u>ប្រធានយោធាស្រុក ឈ្មោះ ថាវ</u>៖ ឯកសារ D131/2.1.87 បញ្ជីឈ្មោះ កម្មាភិបាល និងប្រជាជននៅស្រុកសង្កែ តំបន់ ១ ខែកុម្ភៈ ឆ្នាំ១៩៧៨ លេខរៀងទី ៩០ KH 00214645 [ថាវ , ពីមុន៖ ប្រធានយោធាស្រុក បច្ចុប្បន្ន៖ ប្រធានសហករណ៍ឃុំកន្ទឹ ស្រុកសង្កែ តំបន់ ១]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១១ KH 00960689។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ អោម ឃួន ឆ.៣៣ KH 00960657។

"រាយការណ៍បន្តបន្ទាប់ទៅលើ"[455]។ រដ្ឋអំណាច ប.ក.ក ជារឿយៗ ទាក់ទងជាមួយថ្នាក់ក្រោម និងប្រជាជនទូទៅ តាមរយៈបញ្ជា និងនៅពេលប្រជុំ[456]។ ពួកគេពិភាក្សាអំពីការងារ និងខ្ទាំង និងចេញបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់[457]។

---

[455] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១១៨, ១២៤ KH 01046471, 01046472។ សូមមើលផងដែរ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៥-១៦ KH 01132076។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤៤ KH 01196537។

[456] <u>បញ្ជា</u>៖ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៦៤ KH 01196541 [នៅទំនប់កង្ហត "បញ្ជាការធ្វើតាមបញ្ជាពីថ្នាក់លើ។ ថ្នាក់ក្រោមធ្វើតាមថ្នាក់លើ។"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៥ KH 01040098-01040099 ["ពួកយោធានិរតី និងគណៈឃុំកន្ទឹ ២ ឈ្មោះ ផាន ដែលមកពីនិរតីដែរ [...]បញ្ជាឲ្យអ្នកធ្វើការនៅនឹងមន្ទីរឃុំឃាំងខ្ទងគ្ន"]។ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១២៧ KH 01040177 [ក្នុងឃុំបាយដំរ៉ា "ថ្នាក់លើបញ្ជា [...] ឲ្យមកចាប់។ [...]អ្នកដែលមកចាប់ គឺខាងយោធា។"]។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៤៨ KH 01046475 [នៅទំនប់កង្ហត "យើងទទួលការណែនាំពីថ្នាក់លើ"]។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងឿន ម៉ត ឆ.៥៣, ១០៣-១០៤ KH 01155829, 01155836។ <u>កិច្ចប្រជុំ</u>៖ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.៨០ KH 01394980 [នៅទំនប់កង្ហត៖ "បីថ្ងៃប្រជុំពួក មួយអាទិត្យក្រុម ។"]។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៦ KH 01132076 [នៅទំនប់កង្ហត៖ "ការប្រជុំគឺ [...]ប្រចាំសប្តាហ៍ និង [...]ប្រចាំខែ។"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៧៤ KH 01110183 [នៅទំនប់កង្ហត៖ "កិច្ចប្រជុំនៅឯផ្ទះសរសរ ៤០ ត្រូវបានធ្វើឡើងពីរដងក្នុងមួយខែជាទៀតទាត់។ ជួនកាលគេអញ្ជើញប្រធានសហករណ៍ និងប្រធានកងទាំងអស់ ឲ្យចូលរួមកិច្ចប្រជុំនៅទីនោះ ប៉ុន្តែជួនកាលទៀត គេអញ្ជើញតែប្រធានសហករណ៍ទាំងអស់ ឲ្យមកចូលរួមប៉ុណ្ណោះ។"]។ សូមមើលផងដែរ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៤៦ KH 01129725 ["កម្មាភិបាលនិរតី [...]ជួង ជាគណៈស្រុកសង្កែ ចុះមកមើលប្រឡាយទួលម្ទេស។ ខ្ញុំបានឃើញគាត់ពីរដង ពេលខ្ញុំធ្វើការនៅទីនោះរយៈពេល ១ខែ។"]។

[457] <u>ការងារបង្កបង្កើនផល</u>៖ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៥ KH 01132076 ["គណៈស្រុក [...]ផ្តល់ការចង្អុលបង្ហាញ និងការណែនាំមួយចំនួន ដើម្បីពង្រឹងជំហរ និងសតិអារម្មណ៍របស់ប្រជាជន ដើម្បីឲ្យពួកគេប្រឹងប្រែងធ្វើការបង្កបង្កើនផលឲ្យបានកាន់តែខ្លាំង។"]។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៥៣ KH 01046475 ["រាល់ពេលដែលតាទិត មកជួបជាមួយនឹង យ៉ ហើយយ៉ តែងតែប្រជុំដើម្បីជំរុញឲ្យយើងធ្វើការកាន់តែខ្លាំងក្លាថែមទៀត។"]។ <u>ខ្ទាំង</u>៖ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៥-១៦ KH 01132076 [ចូលរួមដោយគណៈស្រុក៖ "ក្នុងអង្គប្រជុំ [...]គេចាត់ឲ្យឈ្លបតាមឃ្លាំមើលអ្នកដែលត្រូវបានគេរាយការណ៍ថា បានលួចជីកដំឡូងហូបផងដែរ ដោយសារតែមនុស្សប្រភេទនេះត្រូវបានគេចោទថា ក្បត់សម្ងាហភាព។"]។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៤៨, ១៥០ KH 01046475។ <u>បញ្ជាចាប់ខ្លួន និង សម្លាប់</u>៖ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១២៧ KH 01040177 [ក្នុងឃុំបាយដំរ៉ា "ថ្នាក់លើបញ្ជា [...]ឲ្យមកចាប់។ [...]អ្នកដែលមកចាប់ គឺខាងយោធា។"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៥ KH 01040098-01040099។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងឿន ម៉ត ឆ.៥៣, ១០៣-១០៤ KH 01155829។

គ. ស្រុកសំឡូត

156. ស្រុកសំឡូតត្រូវបានបែងចែកយ៉ាងតិចណាស់ជាប្រាំបីឃុំ[458]។ ឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នៃអំពើអមនុស្សធម៌ផ្សេងទៀត (ការរៀបការដោយបង្ខំ) បានកើតមានឡើងនៅទូទាំងស្រុកនេះ។ ដូចមានរៀបរាប់លម្អិតនៅក្នុងផ្នែកស្តីពី ការបោសសម្អាត នៃដីកាសន្និដ្ឋានស្តាពរនេះ[459] កម្មាភិបាលភូមិភាគពាយ័ព្យដែលស្ថិតនៅក្នុងគណៈកម្មាធិការស្រុក ត្រូវគេចាប់ខ្លួន និងប្រសិនជាសមាជិកគណៈកម្មាធិការស្រុក ត្រូវគេបញ្ជូនទៅ ស-២១[460]។ សុខ សុផាត មេបញ្ជាការរងវរសេនាធំ ត្រូវបានចាត់តាំងឲ្យទទួលបន្ទុកលើស្រុកសំឡូតរយៈពេលពីរខែ[461] បន្ទាប់មក កម្មាភិបាលភូមិភាគនិរតីដែលមានឈ្មោះដូចតទៅនេះ បានគ្រប់គ្រងគណៈកម្មាធិការស្រុក៖ ឡេង ជាលេខា ណុប ងឹម ជាអនុលេខា និងធី ប្តីរបស់ ឡេង ជាសមាជិក[462]។

---

[458] ឃុំផ្ទះវមាស ចំលងគួយ ក្រញូង សំឡូត តាសាញ់ អូរដា អូររាំងខេន និងស្រែអណ្តូង។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.៣៦ KH 01008702។ ឯកសារ D123/2/2.17a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ងឹម KH 00733834-00733835។ ឯកសារ D131/2.1.83 បញ្ជីឈ្មោះកម្មាភិបាលស្រុកសំឡូត តំបន់ ១ លេខ ៤-៥, ៩ KH 00214615។

[459] សូមមើល V.B.1. ឧក្រិដ្ឋកម្ម-ភូមិភាគពាយ័ព្យ-ការសម្លាប់រង្គាល។

[460] លេខា ផ្ទ៖ ឯកសារ D131/2.1.83 បញ្ជីឈ្មោះកម្មាភិបាលស្រុកសំឡូត តំបន់ ១ លេខ ១ KH 00214615។ ឯកសារ D219/380 កំណត់ហេតុស្តាប់ចម្លើយ ប៉ុក សុផាត ឆ.២៨ KH 01113195 ["តាផ្ទ ជាគណៈស្រុកសំឡូតចាស់ ត្រូវបានគេចាប់ខ្លួន។ [...]។តាផ្ទ ត្រូវបាន រស់ ញ៉ឹម ហៅទៅរៀនសូត្រ។"]។ ឯកសារ D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.៩ KH 01095986។ <u>សមាជិក ឆន លុយ</u>៖ ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត លេខ ១១៥៧ EN 01222378។ ឯកសារ D131/2.1.83 បញ្ជីឈ្មោះកម្មាភិបាលស្រុកសំឡូត តំបន់ ១ លេខ ២ KH 00214615។

[461] ឯកសារ D219/380 កំណត់ហេតុស្តាប់ចម្លើយ ប៉ុក សុផាត ឆ.២៨ KH 01113195 ["ខ្ញុំទទួលខុសត្រូវ [...]ប្រហែលពីរខែ។ នៅពេលលនោះ តាផ្ទ ត្រូវបាន រស់ ញ៉ឹម ហៅទៅរៀនសូត្រ។"] ឆ.១១, ១៨-១៩, ៣០ KH 01113192, 01113193, 01113196 ។

[462] ឯកសារ D219/974.1.2 ណុប ងឹម ប្រតិចារឹកថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.38.23-10.39.58 ["ឲ្យខ្ញុំទៅនៅបានប្រាំមួយ ប្រាំពីរខែហ្នឹង ដល់គាត់ឲ្យខ្ញុំទៅនៅហ្នឹងកាន់ នៅជាមួយ បងឡេង [...]នៅជាមួយស្រុកហ្នឹង។ ខ្ញុំក្រោមគេទេ ខ្ញុំមិនចេះអក្សរទេ ស្រេចតែគេប្រើ [...]គាត់ (ឡេង) ខាងស្រុក ប្រធាន។ [...]គាត់មកពីតាកែវ។"] ម៉ោង10.38.23-10.39.58 ["ស៖ តើពេលនោះ លោកស្រីជាអនុប្រធានស្រុក ជាអនុលេខាស្រុកមែនទេ? ឆ៖ ចាស។"]។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.៣១, ៣៣ KH 01008701 ["នៅស្រុកសំឡូត ខ្ញុំមានតួនាទីជាអនុលេខាស្រុក។ [...]បងធី ជាប្តីរបស់ បងឡេង ជាសមាជិក [...]កើតនៅខេត្តតាកែវ"] ឆ.២៨-២៩, ៥៩ KH 01008700-01008701, 01008707 ។ ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៥៧-៥៨ KH 01037146 ។

157. គណៈកម្មាធិការស្រុកបានរៀបចំការប្រជុំផ្តាច់មុខក្នុងចំណោមពួកគេ និងបានចេញសេចក្តីណែនាំឲ្យទៅថ្នាក់ក្រោម រួមទាំងឈ្លបៗ[463]។ ពួកគេ "ចុះទៅតាមឃុំនានា ដើម្បីពិនិត្យការងារ" និងរៀបចំប្រជុំជាមួយ "អ្នកដែលធ្វើខុស" ដើម្បី "ព្រមានប្រាប់ពួកគាត់កុំឲ្យធ្វើអំពើដូច្នេះម្តងទៀត" បើពុំដូច្នេះទេ "គាត់នឹងត្រូវជាប់គុក"[464]។ ពេលការណែនាំត្រូវបានអនុវត្ត របាយការណ៍ស្តីពីការវិវត្តការងារត្រូវបានធ្វើ និងបញ្ជូនទៅគណៈកម្មាធិការស្រុក តាមរយៈរចនាសម្ព័ន្ធអំណាច ប.ក.ក[465]។

២. តំបន់ ២

158. តំបន់ ២ ត្រូវបានបែងចែកយ៉ាងតិចណាស់ជាបីស្រុក។ សហព្រះរាជអាជ្ញាអន្តរជាតិស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះសេចក្តី ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងស្រុកបាកាន។

---

[463] <u>ការប្រជុំ</u>៖ ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.១២១ KH 01329401 ["ប្រជុំប្រចាំខែ [...]ប្រជុំគ្នាឯងៗនៅស្រុករាល់ខែ។"]។ ឯកសារ D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.១៤ KH 01095987 [នៅក្រុងបាត់ដំបង "មួយខែម្តង [...]ប្រជុំបូកសរុបការងារ [...]ខ្ញុំបានចូលរួម"]។ <u>បញ្ជាណែនាំ</u>៖ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.៣៤ KH 01008701 ["ភារកិច្ច បងឡេង ក្នុងនាមគណៈស្រុក [...]ផ្តល់ការណែនាំរបស់គាត់តាមរយៈប្រធានកង និងប្រធានក្រុម ទាក់ទងទៅនឹងបញ្ហាសន្តិសុខគាត់មានភារកិច្ចចាត់តាំងឈ្លបឲ្យយាមកាម"]។

[464] ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.៣៦ KH 01008702 ["ការងារចម្បងរបស់ខ្ញុំ គឺចុះទៅតាមឃុំនានា ដើម្បីពិនិត្យការងារ។"]។ ឯកសារ D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.២០ KH 01095989 ["ចំពោះខ្ញុំហៅអ្នកដែលធ្វើខុសឲ្យមកជួប ហើយខ្ញុំព្រមានប្រាប់ពួកគាត់កុំឲ្យធ្វើអំពើដូច្នេះម្តងទៀត បើពុំដូច្នេះទេ គាត់នឹងត្រូវជាប់គុក។"]។

[465] <u>របាយការណ៍</u>៖ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.៤៤ KH 01008704 [ជាទូទៅ "ជាទូទៅរបបនៃការរាយការណ៍ គឺធ្វើពីសហករណ៍ទៅឃុំ ពីឃុំទៅស្រុក [...]នេះគឺសម្រាប់របាយការណ៍ជាលាយលក្ខណ៍អក្សរ។ [...]នីរសារជាអ្នកបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរ។"] ឆ.៥៤ KH 01008705 ["នៅពេលដែលខ្ញុំចុះទៅតាមឃុំនានាក្នុងស្រុកសំឡូត ខ្ញុំបានពិនិត្យឃើញស្ថានភាពដូចខាងក្រោម៖ ប្រជាជនរស់នៅតាមផ្ទះតូចៗ ពួកគេមានម្ហូបអាហារសមរម្យ ហើយពួកគេធ្វើការតាមម៉ោង និងពេលវេលា។ ស្រុកបានរាយការណ៍ស្ថានភាពបែបនេះទៅតំបន់។"]។ ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.១៣២, ១៤១ KH 01329403, 01329404 [នៅស្រុកសំឡូត របាយការណ៍ជាលាយលក្ខណ៍អក្សរ "ធ្វើក្នុងឃុំមួយខែម្តង ពីឃុំទៅស្រុក"។ រាយការណ៍ប្រចាំខែពីអត្រាកើតត្រូវធ្វើ "ពីឃុំទៅស្រុក [...]ប្រចាំឆ្នាំ"]។ <u>ប្រវត្តិរូប</u>៖ ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៥៦ KH 01037146 ["ឯកសារនានាដែលទាក់ទងនឹងប្រវត្តិរូបរបស់ខ្ញុំ ក៏ត្រូវបញ្ជូនទៅឲ្យ យាយឡេង ដឹងដែរ។"]។ ឯកសារ D219/974.1.2 ណុប ធីម ប្រតិចារឹកថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១០ ម៉ោង 14.25.04-14.26.19 ["មានប្រវត្តិរូប គេធ្វើសង្ខេបៗគ្រាន់តែថា ឈ្មោះ ក នៅឃុំនេះ នៅស្រុកនេះ មនុស្សស្រីនៅស្រុកនេះ ឃុំនេះ អ៊ីចឹងទៅ។"] (សម្គាល់៖ ឯកសារ D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឆ.២៩ KH 01095991 ។)។

159. នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តំបន់ ២ មានទីតាំងស្ថិតនៅខេត្តពោធិ៍សាត់[466] និងនៅខាងលើផ្លូវជាតិលេខ ៥ នៅប៉ែកខាងត្បូង នៅម្ខាងទៀតនឹងតំបន់ ៧[467]។ តំបន់ ២ គ្របដណ្តប់ស្រុកក្រគរមួយផ្នែក ស្រុកមោងមួយផ្នែក និងស្រុកបាកានទាំងមូល បន្ទាប់ពីបានរំលាយចូលគ្នាស្រុកបាកានក្រោមនៃតំបន់ ៧ ជាមួយស្រុកបាកានលើនៃតំបន់ ២[468]។

160. កម្មាភិបាលភូមិភាគនិរតីជាក្រុមៗ ចាប់ផ្តើមទៅដល់តំបន់ ២ នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧[469] ហើយនៅត្រឹមខែសីហា ឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគពាយ័ព្យដែលស្ថិតនៅក្នុង

---

[466] សូមមើលឧទាហរណ៍ឯកសារ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦៩ KH 01122408 ["តំបន់ ២ ស្ថិតក្នុងខេត្តពោធិសាត់។"]។

[467] ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សំរិន ឆ.១៥ KH 00979031 ["តំបន់ ៧ គឺនៅ [...]ម្ខាងផ្លូវ ពីតំបន់ ២។ តំបន់ ៧ គឺនៅខាងជើងផ្លូវជាតិលេខ ៥ ដែលតំបន់ ២ នៅភាគខាងត្បូង។ ប៉ុន្តែតាំងពីតំបន់ ២ នៅទីទួលជាងតំបន់ ៧ សាក្សីសំដៅតំបន់ ២ ថានៅខាង "លើ" តំបន់ ៧។ ភាពខុសគ្នានេះ បានឆ្លុះបញ្ចាំងនៅក្នុងឈ្មោះស្រុកថា ជាបាកានលើ ("បាកានលើ" – តំបន់ ២) ហើយបាកានក្រោម ("បាកានក្រោម" –ដើមកំណើត នៅតំបន់ ៧)។ ស្រដៀងនឹងការបែងចែកស្រុកក្រគរ។ សូមមើលឧទាហរណ៍ ឯកសារ D219/586 កំណត់ហេតុស្តាប់ចម្លើយ ឃុន ម៉ុន ឆ.៩៣ KH 01167504 ["ខាងក្រោមថ្នល់ជាតំបន់ ៧ ហើយខាងលើថ្នល់ជាតំបន់ ២។"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរឿន ឆ.១២ KH 00955680 ["ស្រុកបាកានត្រូវបែងចែកជាពីរ ខាងក្រោមផ្លូវជាតិលេខ ៥ គឺបាកានក្រោម និងខាងលើផ្លូវជាតិលេខ ៥ គឺបាកានលើ។"]។ ឯកសារ D6.1.937 Ben Kiernan *អំពើប្រល័យពូជសាសន៍ និងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា* EN 00430229 [ផែនទី ការបែងចែកតំបន់រដ្ឋបាល នៃកម្ពុជាប្រជាធិបតេយ្យ]។ ឯកសារ D219/193 កំណត់ហេតុស្តាប់ចម្លើយ រ៉ាត ផាត ឆ.១៣៨ KH 01070076។

[468] ឯកសារ D219/936 កំណត់ហេតុស្តាប់ចម្លើយ ឌុច ចន្ថា ឆ.២២-២៣ KH 01396521 [នីរសារ ខាន អនុលេខាតំបន់ ២៖ "ស ៖ តើលោកធ្លាប់បើកឡានជូនទៅកន្លែងណាខ្លះ? ឆ.២២៖ ចុះទៅស្រុកបាកាន ទៅស្រុកមោង ស្រុកក្រគរ។ ស ៖ តើលោកធ្លាប់បើកឡានជូនគាត់ទៅកន្លែងណាក្រៅតំបន់២ ដែរទេ? ឆ.២៣៖ ខ្ញុំដូចអត់មានទេ។"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.៣០ KH 01000260 ["តំបន់ ២ គ្របដណ្តប់ស្រុកក្រគរ ស្រុកមោងបូស្សី និងស្រុកបាកាន។"]។ ឯកសារ D219/921.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ចាប ពុត KH 01379964 ["ស ៖ គណ:តំបន់ នៅតំបន់ ២ មានស្រុកប៉ុន្មានទៅ? ឆ ៖ ស្រុកក្រគរអ្ហាហ្ម៊ីងតាមខ្ញុំស្គាល់។ [...]ស្រុកមោង ស្រុកបាកាន។"]។ សូមមើលផងដែរ ឯកសារ D6.1.546 ទូរលេខពីមន្ទីរ ៥៦០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ EN 00143455-56 ["តំបន់ ២៖ [...]ចំនួនទំនប់ ធំៗ ៖ ៦ (នៅមោង បាកាន និងក្រគរ)"]។ ដែលយោងក្រោយមកត្រូវកាត់ចូលជាបាកានលើ និងបាកានក្រោម។ សូមមើលកថាខណ្ឌ ១៦៨។

[469] ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.៤៣ KH 01034500 ["ស ៖ តើលោកចាំខែណាឆ្នាំណាច្បាស់ដែរទេ ពេលដែលកម្មាភិបាលនិរតីទៅដល់កន្លែងរបស់លោក? ឆ.៤៣៖ [...]គឺនៅក្នុងឆ្នាំ១៩៧៦ [...]មានបញ្ហាច្រឡូកច្របល់ ដោយកម្មាភិបាលពាយ័ព្យគេលែងទុកចិត្តទៀត បន្ទាប់មកទើបគេបញ្ជូនកម្មាភិបាលភូមិភាគនិរតី។"]។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.៣៣ KH 01075722 [សាក្សីនិយាយនៅពេលគាត់ និងអ្នកធ្វើការនៅគណ:ស្រុករបស់គាត់ បានមកដល់ខេត្តពោធិសាត់ ពីភូមិភាគនិរតី៖ "ស ៖ តើនៅពេលណាជាក់លាក់ ដែលលោកស្រីធ្វើដំណើរមកពោធិសាត់? ឆ.៣៣៖ ប្រហែលជាអំឡុងខែ ២ ឬខែ ៣ ឆ្នាំ១៩៧៧។"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ

គណៈកម្មាភិបាលតំបន់ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅ ស-២១ ទាំងអស់[470]។ បន្ទាប់មក តំបន់ ២ ផ្តួងកាត់ការគ្រប់គ្រង់ពីរដំណាក់កាល[471]។ ដំបូង បិណ កម្មាភិបាលភូមិភាគនិរតី គ្រប់គ្រងតំបន់ ២ ក្នុងឋានៈជាលេខាតំបន់ មួយរយៈពេលខ្លី[472] ហើយពីរបីខែក្រោយមក គាត់ត្រូវបានជំនួសនៅចុងឆ្នាំ ១៩៧៧ ឬដើមឆ្នាំ១៩៧៨ ដោយអតីតលេខាតំបន់ ១៣ (ភូមិភាគបស្ចិម)[473] ឈ្មោះ វ៉ាន ឯម ហៅ សារុន ដែលកាន់តំណែងនេះរហូតដល់របបកម្ពុជាប្រជាធិបតេយ្យដួលរលំ[474]។ ប្រហែលនៅឆ្នាំ

អ៊ុក សៀម ឆ.២ KH 00485643-00485644 [សាក្សី បានក្លាយជាប្រធានសហករណ៍រំលេខនៅដើមឆ្នាំ១៩៧៧ (តែងតាំងដោយ យាយរ៉ីម (សូមមើល ឆ.៣))៖ "ហៅទៅរៀនសូត្រ ហើយបានបាត់ខ្លួនរហូត នៅស្នាក់ការឃុំរំលេខ កើតឡើងនៅដើមឆ្នាំ១៩៧៧ ពេលពួកនិរតីមកកាន់កាប់ភូមិភាគពាយ័ព្យ។"]។

[470] សូមមើល V.B.1.b.ii. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ– ការបោសសម្អាត។ ការបោសសម្អាតភូមិភាគពាយ័ព្យនៅថ្នាក់ភូមិភាគ និងតំបន់ - ការបោសសម្អាតនៅថ្នក់កាតំបន់ – តំបន់ ២។

[471] *សូមមើល* ដោយសង្ខេប ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.២០ KH 00485651 ["បន្ទាប់ពីកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានគេចោទថាក្បត់ក៏មានពួកនិរតីមកគ្រប់គ្រងភូមិភាគពាយ័ព្យ។ ប្រហែលជាមួយឆ្នាំក្រោយមក ក៏មានការតាមដានថាពួកនិរតីក្បត់ ហើយក៏មានពួកបស្ចិមមកគ្រប់គ្រងលើបន្ថែមទៀតទៅ។"]។

[472] ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.២៨ KH 01075609 ["ស៖ តើអ្នកដែលមកពីតាកែវ ហើយជំនួសខាន និងគង់ សំអ៊ៀន នេះជាមនុស្សប្រុសឬក៏ជាមនុស្សស្រី? ឆ.២៨៖ [...]ខ្ញុំចាំថា ដូចជាឈ្មោះ បិណ។ បិណ មកគ្រប់គ្រងបានតែប៉ុន្ថានខែ"]។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៣១ KH 01068111 ["នៅឆ្នាំ១៩៧៧ ឈ្មោះ បិណ (ប្រុស) ជាមនុស្សមកពីនិរតីធ្វើជាគណៈតំបន់ ២។ បិណ ធ្វើជាគណៈតំបន់ ២ បានប្រហែលជា ៥ខែ ក៏ត្រូវគេចាប់ខ្លួន។"]។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ ឃង់ សុខុម ឆ.១២៤ KH 01025547 ["ស៖ អំឡុងពេលណោកស្រីនៅពោធិសាត់ តើអ្នកណាជាអ្នកលេខាតំបន់? ឆ.១២៤៖ លេខាតំបន់ ឈ្មោះ ប៊ិន។"]។ ឯកសារ D219/242 កំណត់ហេតុស្តាប់ចម្លើយ អប់ ច្រ៉ង ឆ.១៦ KH 01080919 ["បិណ មកពីភូមិភាគនិរតី"] ឆ.២៥ KH 01080920 ["ស៖ តើបិណ មកដល់ពោធិសាត់នៅឆ្នាំណា? ឆ.២៥៖ បិណ មកដល់ឆ្នាំ១៩៧៧។"]។

[473] ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ ឆ.២៤ KH 00498373 [អតីតកម្មាភិបាលភូមិភាគបស្ចិម ត្រូវបានតែងតែដោយ សារុន ជាលេខាស្រុកកណ្តៀង (សូមមើល IV.C.5. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទងរបស់ ប.ក.ក - ភូមិភាគពាយ័ព្យឆ្នាំ១៩៧៧-១៩៧៩ - តំបន់ ៧)៖"ខ្ញុំដឹងថា សារុន បានក្លាយជាគណៈតំបន់ ៣១ នៃខេត្តកំពង់ឆ្នាំង នៅក្នុងឆ្នាំ ១៩៧៦"]។ ឯកសារ D6.1.989 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ៀន ឆ.២២ KH 00486473 ["ក្នុងភូមិភាគបស្ចិមមានបីតំបន់ គឺតំបន់ ៣១ ខេត្តកំពង់ឆ្នាំង [...]តាសារុន លេខាតំបន់ ៣១។"]។ ឯកសារ D6.1.985 កំណត់ហេតុស្តាប់ចម្លើយ សៅ ផេន ឆ.១ KH 00492978។ ឯកសារ D117/36.1.1 កំណត់ហេតុស្តាប់ចម្លើយ ក៏ម សុខ KH 00195426។ ឯកសារ D6.1.349 កំណត់ហេតុស្តាប់ចម្លើយ កែវ គីន KH 00282942-00282943។

[474] សូមមើលឧទាហរណ៍ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.២៨-៣០ KH 01075609 ["ឆ.២៨៖ បិណ ត្រូវចាប់ទៅបាត់ទៀត។ [...]ឆ.២៩៖ តាសារុន ជាលេខាតំបន់ថ្មី ហើយជាមនុស្សមកពីកំពង់ឆ្នាំង។ [...]ស៖ តើតាសារុនគ្រប់គ្រងតំបន់ ២ រយៈពេលប៉ុន្ថាន? ឆ.៣០៖ [...]តាសារុនក៏មកគ្រប់គ្រងតំបន់ ២ ជំនួស បិណ ហើយគាត់នៅរហូតដល់រៀត

១៩៧៨ សារុន ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យជាមួយតាម៉ុក និង **យ៉ ម ទិត្យ**[475]។

161. ក្នុងរយៈពេលនៃការផ្លាស់ប្តូរអំណាចទាំងនេះ តាម៉ុក ជាអ្នកគ្រប់គ្រងចុងក្រោយគេលើតំបន់ ២ និងកងកម្លាំងភូមិភាគនិរតី និងភូមិភាគបស្ចិមដែលស្ថិតក្រោមបញ្ជារបស់គាត់[476]។ ម៉ុក និង សារុន

ណាមចូលមកដល់។"]។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៣១ KH 01068111 ["បន្ទាប់ពី ចិណ ត្រូវគេចាប់ខ្លួន តាសារុន ធ្វើជាគណៈតំបន់ ២ រហូតដល់បែករបបខ្មែរក្រហមឆ្នាំ១៩៧៩។ តាសារុន ជាមនុស្សមកពីកំពង់ឆ្នាំង ភូមិភាគបស្ចិម។"]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៥៧-៥៨ KH 01068133 ["ខ្ញុំទៅប្រជុំពេលដែលតាសារុន មកដល់ទីនេះបានប្រហែលជា ៣ខែ គឺប្រហែលជាឆ្នាំ១៩៧៧។ [...]គេហៅគាត់ថា គណៈតំបន់។"]។ ឯកសារ D219/921.2 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ចាប ពុត KH 01379977 ["គណៈតំបន់គេមួយ តា សារុន ហ្នឹងខ្លាំងហើយ [...]គាត់នៅរហូតដល់ឆ្នាំ១៩៧៩។"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៧៦ KH 01000275។ ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស្ងួ ណាន់ ឆ.១៩, ២៤ KH 00498372, 00498373។ ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ស្ងឿម ឆ.៦ KH 00872597។

[475] ឯកសារ D6.1.616 បទសម្ភាសន៍របស់ SOAS ជាមួយ អ៊ុក ស្ងឿម KH 00657427-00657428 ["សារុន គឺ [...]ស្ថិតនៅក្នុងគណៈភូមិភាគពាយ័ព្យផងដែរ ជំនួស កែវ។"]។ ឯកសារ D6.1.1052 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00159561។ ឯកសារ D1.3.15.2 Timothy Carney *អំណាចអង្គការ* KH 00332381។ សូមមើលកថាខណ្ឌបន្ថែម ១៤៤។

[476] យ៉ាងហោចណាស់ នៅចុងខែមីនា ដើមខែមេសា ឆ្នាំ១៩៧៨ ពេល ជ្ង ជេត ហៅ ស៊ី លេខាភូមិភាគបស្ចិម ត្រូវបានចាប់ខ្លួន តាម៉ុក បានគ្រប់គ្រងទាំងស្រុងលើភូមិភាគបស្ចិម ដោយបន្ថែមលើតួនាទីជាលេខាភូមិភាគពាយ័ព្យ។ សូមមើលឧទាហរណ៍ ឯកសារ D1.3.29.2 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146678-00146679 ["កម្ទេច ជ្ង ជេត ហៅ ស៊ី នៅបស្ចិម (ឆ្នាំមិនចាំ) នឹងខ្សែ ជ្ង ជេត ហើយយកកម្មាភិបាលរួចពីនិរតីយកទៅដាក់ តែសំខាន់ គឺតាម៉ុកទៅកាន់ជាលេខាបស្ចិមបន្ថែមពីហាន: ជាលេខានិរតីរបស់គាត់ [...]តាម៉ុក ទៅធ្វើលេខាភូមិភាគពាយ័ព្យមមួយជាន់ទៀត។ ដឹកកម្លាំងតាម៉ុក និងកម្លាំងខាងបស្ចឹមរបស់ ហ្ជត ហេត ហៅ ប៉ាល់ ទៅចាំទទួល ទទួលយកទៅពាយ័ព្យ។"]។ ឯកសារ D118/103.3 កាំង ហ្គេកអ៊ាវ ហៅ ឌុច ដីកាសន្និដ្ឋានស្តាពរជាលាយលក្ខណ៍អក្សរ ជើងទំព័រ ២៤ KH 00404797 ["ភូមិភាគបស្ចិម៖ ស៊ី (បន្ទាប់ពីចាប់ ស៊ី នៅដើមខែ ៤ ឆ្នាំ១៩៧៨ ម៉ុក ឡើងជាលេខានិរតីថ្មី ផង បស្ចិមផង។)។"] (យោងសំណុំរឿង ០០២ -ឯកសារ D427 ដីកាដំណោះស្រាយ ជើងទំព័រ ៣០២៦) ។ សូមមើលផងដែរ ឯកសារ D219/193 កំណត់ហេតុស្តាប់ចម្លើយ រ៉ាត ផាត ឆ.២១៥, ២១៧ KH 01070086-01070087 ["ស ៖ តើតាម៉ុក កាន់ភូមិភាគណាខ្លះ? ឆ.២១៥៖ ខ្ញុំដឹងតែបីទេ គឺភូមិភាគនិរតី បស្ចិម និងពាយ័ព្យ។ [...]ឆ.២១៧៖ ខ្ញុំធ្លាប់ចូលរួមប្រជុំនៅបាត់ដំបងផ្នែកយោធា ហើយនៅក្នុងការប្រជុំនេះ គេប្រកាសប្រាប់ថា តាម៉ុក កាន់បីភូមិភាគ។ ខ្ញុំមិនចាំថា ការប្រជុំនេះកើតឡើងនៅឆ្នាំណាទេ។"]។

បានជួបគ្នា[477] ហើយ ម៉ុក បានដាក់បញ្ជាឲ្យធ្វើការផ្សព្វផ្សាយនៅក្នុងតំបន់[478]។ ម៉ុក ក៏បានធ្វើទស្សនកិច្ចនៅតំបន់ជាញឹកញាប់ផងដែរ[479] រួមមាន គុកភូមិវាល[480] និងចេញបញ្ជា ក្នុងពេលប្រជុំជាមួយអ្នកដឹកនាំក្នុងតំបន់ រួមទាំងលេខាស្រុក និងប្រធានសហករណ៍[481]។

---

[477] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.១០៤, ១០៦ KH 01347279 [លេខាស្រុកបាកាន៖ "ឆ.១០៤៖ [...]ខ្ញុំដឹងថា តាសារុន ហ្នឹងទៅប្រជុំជាមួយតាម៉ុក។ [...]ស៖ តាសារុន បានប្រាប់លោកស្រីថា គាត់បានប្រជុំជាមួយ តាម៉ុក [...]តើត្រឹមត្រូវដែរឬទេ? ឆ.១០៦៖ ចាស។"]។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៨, ៤២ KH 01348857, 01348863 ["[តាម៉ុក និងតាសារុន] ទៅជួបគ្នានៅបាត់ដំបង [...]តាសារុន ណែនាំគាត់ទៅជួបថ្នាក់លើទៀត។"]។

[478] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.១០៣ KH 01347279 [" (តាម៉ុក) បញ្ជាតាមរយៈតាសារុន។"] ឆ.១០៦-១០៧ KH 01347279 ["តាសារុន ប្រាប់ថា គាត់បានចូលរួមប្រជុំជាមួយតាម៉ុក។ គាត់បន្ថែមថា តាម៉ុក បានណែនាំឲ្យយើងផ្តោតគោលដៅស្រាវជ្រាវ និងលុបបំបាត់អ្នកមានខ្សែដែលរយៈវៀតណាម។ តើត្រឹមត្រូវទេ? ឆ.១០៦ ៖ ចាស [...] ឆ.១០៧៖ (សារុន)បានទទួលផែនការ ហើយគាត់បានហៅប្រជុំទាំងអស់គ្នាឲ្យទទួលផែនការតែម្តង។"]។

[479] ឯកសារ D219/842 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ្ជន ឆ.៦២ KH 01335678 ["ស៖ នៅពេលដែល តាម៉ុក មកម្តងៗ តើ យាយរ៉ីម តែងតែអមដំណើរជាមួយគាត់ដែរឬទេ? ឆ.៦២៖ គាត់អមដំណើរចុះធ្វើដំណើរទស្សនកិច្ចតាមភូមិ តាមស្រុក តាមសមរភូមិ។"]។

[480] ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក ឃឹន ឆ.៦៥ (៦៨) KH 00955701 ["តាម៉ុកធ្លាប់ទៅមើលគុកនេះ ចំនួនពីរដង។"]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.១០៤ KH 00955739 ["ខ្ញុំធ្លាប់ឮគេនិយាយថា តាម៉ុកធ្លាប់ទៅគុកភូមិវាល។"]។

[481] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៩៣-៩៤ KH 01347277-01347278 ["ស ៖ អ៊ីចឹង ការប្រជុំជាមួយតាម៉ុក បានរៀបចំមែន តើត្រឹមត្រូវទេ? ឆ.៩៣៖ មានប្រជុំ [...]ស៖ [...]សូមលោកស្រីបញ្ជាក់ថា លោកស្រីបានប្រជុំជាមួយ តាម៉ុក ដែរ? [...]ឆ.៩៤៖ ចុះបើខ្ញុំបញ្ជាក់ថា បើប្រជុំ តែមិនដឹងប្រជុំកន្លែងណា ឆ្នាំណា ឆ្លើយបានអត់កន្លែងហ្នឹង?"]។ ឯកសារ D219/793.1 ប្រតិចារឹក *សត្រូវប្រជាជន* KH 01302793 [យាយរ៉ីម (បញ្ជាក់នៅក្នុង ឯកសារ D219/860 ឆ.២៧-៣០ KH 01347250)៖ "ខ្ញុំទទួលបញ្ជាពីថ្នាក់លើ ថ្នាក់ដូចជាថ្នាក់ខេត្ត ហើយបន្តបន្ទាប់ ពីថ្នាក់ធំទៅៗ រហូតដល់ថ្នាក់ជាតិ។"]។ ឯកសារ D219/842 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ្ជន ឆ.៦១ KH 01335678 ["ស៖ [...]តើលោកស្រីបានឃើញ តាម៉ុក ជួបប្រជុំជាមួយ យាយរ៉ីម ប៉ុន្មានដង? ឆ.៦១៖ ច្រើនដែរ។ ជួនទៅ គាត់ចុះមកសន្និបាតនៅខេត្ត ស្រុកភ្នំក្រវាញ ស្រុកបាកាន។ គាត់មកទស្សនកិច្ចច្រើនដងដែរ។"]។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ្ជន ឆ.៧៣, ៧៧ KH 01176413, 01176414 [នីរសារយាយរ៉ីម៖ "តើលោកស្រីធ្លាប់ដើរតាមយាយរ៉ីម ទៅណាទៅណីដែរឬទេ? ឆ.៧៣៖ ទៅ ទៅតាមគាត់ប្រជុំនៅមោង បាត់ដំបង ពោធិសាត់អ៊ីចឹងទៅ [...]ឆ.៧៧៖ [យាយរ៉ីម] និយាយពីការងារជាមួយអ្នកធំៗ"] ឆ.១២៦-១៣១ KH 01176418-01176419 [សាក្សីបានអមដំណើរយាយរ៉ីម ទៅមោង បាត់ដំបង ដើម្បីចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំធំៗ ដូចជា តាម៉ុក។]។ ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន់ សុខ ឆ.៧១-៨០ KH 01167525-01167526 [ពេលដែលសាក្សីរស់នៅ និងធ្វើការជាចុងភៅឲ្យយាយរ៉ីម នៅស្រុកបាកាន ឆ្នាំ១៩៧៨ (សូមមើល ឆ.២០-២១, ២៤-២៥ KH 01167520,

162. យ៉ាងហោចណាស់ មានពេលមួយនៅចន្លោះពីពាក់កណ្តាលឆ្នាំ១៩៧៨ ដល់ចុងឆ្នាំ១៩៧៨ សារុន និងលេខាស្រុកបាកាន យាយរីម បានចូលរួមប្រជុំមួយក្នុងចំណោមការប្រជុំជាប្រចាំរបស់មន្ត្រីនៃភូមិភាគពាយ័ព្យ តំបន់ និងស្រុក រួមមាន ម៉ុក និង **យ៉ីម ទិត្យ** នៅសាកលវិទ្យាល័យបាត់ដំបង[482]

01167521) គាត់បានឃើញកម្មាភិបាលខ្មែរក្រហមថ្នាក់លើ មកពីមជ្ឈិម/ភ្នំពេញមកដើម្បីនិយាយជាមួយ យាយរីម ជាច្រើនដង។"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៣,៥ KH 00485644-00485645 [អតីតប្រធានសហករណ៍រំលេចបានរៀបរាប់ ការប្រជុំជាទៀងទាត់របស់ប្រធានសហករណ៍ស្រុកបាកាន នៅតាឡូ ដែលអធិបតីដោយ តាម៉ុក តាសារុន និងយាយរីម ទាក់ទងនឹង "ពួកឯងត្រូវធ្វើតាម ផែនការដែលបក្សដាក់ឲ្យ"។ គាត់បាននិយាយផងដែរនៅក្នុងការប្រជុំនៅអតីតរោងកុននៅក្រុងពោធិសាត់ ដែលអធិបតីដោយតាម៉ុក ជាអ្នកប្រកាសអំពីជនក្បត់នៅភូមិភាគពាយ័ព្យ។]។ ឯកសារ D5/1338/3 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង14.12.51-14.19.12 [សក្ខីកម្មទាក់ទងបញ្ហាការរៀបការដោយបង្ខំ ក្នុងឃុំខ្នាទទឹង ស្រុកបាកានលើ៖ "[រ៉ីម] បាននិយាយថា គាត់បានទទួលបញ្ជាពីតាម៉ុក ហើយថា បើចង់ដឹងច្បាស់ ទៅគាស់ខ្ទោចទៅសួរតាម៉ុក។ [...]គាត់បានទទួលការណែនាំពីអ្នកផ្សេង [...]គាត់ថា បើចង់ដឹងច្បាស់លាស់ ទៅសួរខ្ទោច តាម៉ុក រឿងនៅរស់ មិនរស់ គាត់មិនដឹងទេ អាចំពោះរៀបការនេះគឺគេធ្វើអ៊ីចឹង។ [...]ព្រោះកាលដែលនាងខ្ញុំទៅដល់នោះ គាត់ឆ្លើយមកកាន់នាងខ្ញុំថា គេរៀបការមកពីថ្នាក់លើ ឲ្យទៅសួរតាម៉ុកហ្នឹង។ គាត់ថា គេឲ្យយើងរៀបការនេះ ដើម្បីយកកូនជូនអង្គការ។"] ម៉ោង 15.33.44-15.35.34។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៧៧, ១៨០ KH 01000275-01000276។

[482] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរីម ឆ.១២០, ១២២-១២៣, ១៣០-១៣១ KH 01347282, 01347283 ["ស៖ ចម្លើយនៅក្នុងកំណត់ហេតុនេះ បាននិយាយថា លោកស្រីដែលជាសាក្សីបានទៅចូលរួមប្រជុំមួយនៅកន្លែងមួយដែលសព្វថ្ងៃជាសកលវិទ្យាល័យបាត់ដំបង [...]តាទិត តាម៉ុក និង អ៊ីម ចែម ដែរ។ តើលោកស្រីចាំបានទេ ថាលោកស្រីបានទៅចូលរួមប្រជុំនៅកន្លែងមួយដែលសព្វថ្ងៃជាសកលវិទ្យាល័យខេត្តបាត់ដំបង? ឆ.១២០៖ ខ្ញុំធ្លាប់ទៅប្រជុំ។ [...]ឆ.១២២ ៖ [...]មានតែឆ្នាំ១៩៧៨ ជិតចប់ ១៩៧៨ ពេលយួនជិតរ៉ៃលុកចូលកម្ពុជា អាចម្តុំហ្នឹង។ ស៖ តើតាម៉ុកមានវត្តមានក្នុងការប្រជុំហ្នឹងទេ? ឆ.១២៣៖ តែទៅប្រជុំបាត់ដំបង មានវត្តមាន តាម៉ុកហើយ។ [...]ស៖ តើតាម៉ុក បានធ្វើជាអធិបតីក្នុងការប្រជុំហ្នឹងទេ? ឆ.១៣០៖ ចាស តែទៅប្រជុំ គាត់អ្នកនិយាយហើយ ប្រធានហ្ន៎។ តែគាត់និយាយ យើងអ្នកស្តាប់។ [...]ស៖ តើតាសារុន មានវត្តមានក្នុងការប្រជុំហ្នឹងទេ? ឆ.១៣១៖ មាន។"]។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.៥៥-៥៧, ៦៨, ១៥៣-១៥៦ KH 01095243-01095244, 01095246, 01095259 [ចៅហ្វាយស្រុកបាវិល តំបន់ ៣។ រំឭកពីការចូលរួមរបស់យាយរីម ក្នុងការប្រជុំនៅសកលវិទ្យាល័យបាត់ដំបង "រៀបចំសម្រាប់ថ្នាក់ស្រុក និងថ្នាក់តំបន់" នៅក្នុងភូមិភាគពាយ័ព្យ "ក្រោយពីចាប់ តាញ៉ឹមហើយ ប្រហែលជា ១៨ថ្ងៃ ឬយ៉ាងយូរមួយខែ" ដែល តាទិត អ៊ីម ចែម និងតាម៉ុក ក៏បានចូលរួមការប្រជុំដែរ។] ការបកស្រាយលើ ឯកសារ D219/900 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.៩០ KH 01379796 ["បន្ទាប់ពី រស់ ញ៉ឹម គេចាប់ ទៅ គេហៅយើងមកប្រជុំ ប្រហែល ២០ ទៅ ៣០នាក់ ហើយអ្នកប្រជុំត្រូវបានគេហៅឈ្មោះ ហើយខ្ញុំបានឮឈ្មោះ យាយរ៉ីម។"]។ ឯកសារ D219/842 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ូន ឆ.៤១-៤២ KH 01335675 ["ស៖ តើលោកស្រីធ្លាប់បានឮដែរឬទេថា យាយរ៉ីម បានទៅចូលរួមការប្រជុំនៅកន្លែងសកលវិទ្យាល័យខេត្តបាត់ដំបង? ឆ.៤១៖ ដែលឮ [...]ឆ.៤២៖ គាត់ទៅរហូត។"]។ សូមមើលផងដែរ ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.២៥ KH 00998557 ["ខ្ញុំជាកងការពាររបស់ តាប៉ែត ហើយតែងតែអមដំណើរ តាប៉ែត ទៅជួបជាមួយ តាទិត។ ពេលគាត់ត្រូវការប្រជុំនឹងគ្នា ប៉ុន្តែខ្ញុំមិនដែលចូលរួមក្នុងប្រជុំទាំងនោះទេ។ ខ្ញុំបានជួបគាត់ផ្ទាល់តែម្តងគត់ គឺនៅសកលវិទ្យាល័យបាត់ដំបង។"]។ ឯកសារ D219/974.1.6 សុន អ៊ែម ប្រតិ

ដែលក្នុងពេលប្រជុំនោះផែនការត្រូវបានកំណត់សម្រាប់ឆ្នាំនាពេលខាងមុខ[483]។ នៅពេលរបបដួលរលំ ម៉ុក បានកោះប្រជុំកម្មាភិបាល ដែលក្នុងពេលនោះ គាត់បានបញ្ជាឲ្យសម្លាប់ពួកភូមិភាគបូព៌ា ដែលត្រូវបានជម្លៀស[484]។

163. នៅក្នុងតំបន់ ២ លេខាតំបន់ និងលេខាស្រុកផ្សព្វផ្សាយបន្តបញ្ជាដែលទទួលបានពីថ្នាក់លើរបស់ពួកគេ និងរាយការណ៍អំពីសកម្មភាពនៅសហករណ៍[485]។ លេខាតំបន់ ២ បានរៀបចំការប្រជុំជាមួយលេខាស្រុក ផេង, រ៉ែន និង រីម និងមេដឹកនាំតំបន់ផ្សេងទៀត ដែលក្នុងពេលប្រជុំនោះ ពួកគេចេញ

ចារឹកថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៦ ម៉ោង 09.22.22-09.24.12 ["នៅមន្ទីរបក្ស សាកលវិទ្យាល័យហ្ស៊ីង [...]នៅពេលដែលភ្ញៀវជាតិកម្មាភិបាលមកពីបណ្តាខេត្ត បណ្តាស្រុកផ្សេងៗមករៀនសូត្រនៅហ្ស៊ីង ក្រោមគណៈអធិបតីរបស់គណៈភូមិភាគ ឬក៏ក្រោមអធិបតីរបស់លោក ឆ្លួន ជា អ៊ីចឹងទៅ។"]។

[483] ឯកសារ D6.1.616 បទសម្ភាសន៍របស់ SOAS ជាមួយ អ៊ុក សៀម KH 00657427-00657428 ["ខ្ញុំត្រូវបានគេកោះហៅឲ្យទៅសកលវិទ្យាល័យបាត់ដំបងពីរដងដើម្បីចូលរួមប្រជុំ ដែលនោះ [...]ការប្រជុំនេះ គឺជាការប្រជុំសម្រាប់កម្មាភិបាលចាប់ពីថ្នាក់ឃុំទាំងអស់ឡើងទៅ ដើម្បីពិនិត្យឡើងវិញនូវអ្វីដែលបានអនុវត្តរួចហើយ និងលើកផែនការសម្រាប់ឆ្នាំក្រោយ។"]។

[484] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៧៧, ១៨៤-១៨៧ KH 01000275-01000276 [មេកងនៅស្រុកបាកាន៖ "មេកងបានខ្សឹបប្រាប់ខ្ញុំអំពីផែនការមួយថា "តា៧៨ មានផែនការសម្លាប់អ្នកបូព៌ាឲ្យអស់ក្នុងរយៈពេល ៥ថ្ងៃ"។ [...]តា ៧៨ នេះ គឺសំដៅទៅលើគណៈ ៨៧០។ [...]គណៈ៨៧០ បានដាក់ផែនការមកដល់ តា១៥ [តាម៉ុក]។ តា១៥ បានយកផែនការនោះមកប្រជុំប្រាប់កម្មាភិបាលថ្នាក់ក្រោមបន្តទៀត។ មេកងដែលបានចូលរួមប្រជុំនោះ ក៏បានយកផែនការនោះមកប្រាប់ខ្ញុំ [...]នៅឆ្នាំ១៩៧៩ អំឡុងខែ ១។"]។

[485] ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.១០ KH 00485648 [ប្រធានសហករណ៍រំលេចតែងតាំងដោយយាយរីម៖ "លេខាតំបន់ និងលេខាស្រុកមានតួនាទីដើរមើលប្រជាជនធ្វើការនៅតាមមូលដ្ឋាន ហើយកោះប្រជុំអ្នកនៅក្រោមបង្គាប់ គឺប្រធានសហករណ៍ ដើម្បីផ្សព្វផ្សាយផែនការរបស់ថ្នាក់លើឲ្យប្រធានសហករណ៍យកទៅអនុវត្តជាមួយនឹងប្រជាជននៅមូលដ្ឋាន។ ការផ្សព្វផ្សាយផែនការរបស់ថ្នាក់លើនេះធ្វើឡើងតាមរយៈការកោះប្រជុំពីថ្នាក់តំបន់ ឬថ្នាក់ស្រុក ដែលប្រធានសហករណ៍ត្រូវតែចូលរួម។ ខ្ញុំដឹងថា ថ្នាក់តំបន់ និងថ្នាក់ស្រុកមកយកឯកសារ ដែលថ្នាក់សហករណ៍ទទួលបានពីស្ថានភាពប្រជាជននៅមូលដ្ឋាន ដើម្បីយកទៅប្រជុំនៅថ្នាក់លើតទៅទៀត។"]។ ឯកសារ D219/793.1 ប្រតិចារឹក *សត្រូវប្រជាជន* KH 01302794-01302795 [ស្ងួន អនុប្រធានឈ្លប នៅសហករណ៍ស្រោង ស្រុកបាកាន (បញ្ជាក់នៅក្នុង ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.២ KH 01068124) "ខ្ញុំទទួលបញ្ជាពីបងឃន ហើយបងឃន ទទួលបញ្ជាពីបងរ៉ីម។ ហើយបងរ៉ីមទទួលពីតំបន់។ តំបន់ទទួលវាពីអ្នកដឹងថាជាអ្នកណា ប្រធានធំ"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៩៤ KH 01000277 [មេកងស្រុកបាកាន៖ "គណៈ៨៧០ មកប្រជុំជាមួយនឹងថ្នាក់តំបន់ ហើយថ្នាក់តំបន់ មកប្រជុំប្រាប់ថ្នាក់ស្រុក ហើយថ្នាក់ស្រុកមកប្រជុំប្រាប់ថ្នាក់សហករណ៍។ ចុងក្រោយគណៈសហករណ៍ហៅខ្ញុំទៅប្រជុំ។"]។ ឯកសារ D5/1338/3 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.09.15-14.11.48 [សក្ខីកម្មអំពី អ្ងឿន ប្រធានកងនៅឃុំខ្ជាទទឹង ស្រុកបាកានលើ៖ "[អ្ងឿន] និយាយថាបើអ្ងែងចង់ដឹងណាស់ អ្ងែងទៅសួរចៅហ្វាយស្រុក [...]គាត់បានទទួលបញ្ជាពីថ្នាក់ស្រុក។ ហើយគាត់សំដៅទៅបងរ៉ីម [...]ដែលជាចៅហ្វាយស្រុកក្នុងអំឡុងរបបខ្មែរក្រហម។"]។

បញ្ជា និងទទួលរបាយការណ៍[486]។ បញ្ជាទាំងនោះត្រូវបានផ្សព្វផ្សាយបន្តទៅថ្នាក់ក្រោម ដោយលេខាស្រុក និងត្រូវបានអនុវត្តដោយថ្នាក់ក្រោម រួមទាំងប្រធានសហករណ៍ និងឈ្លប និងនៅការដ្ឋាន[487]។

---

[486] សូមមើលឧទាហរណ៍ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៧៧ KH 01347274 ["ស៖ តើវាជាទំនាក់ទំនងទៅវិញទៅមក មានន័យថា លោកស្រីបានទទួលបញ្ជា ឬការណែនាំមកអនុវត្ត ហើយរាយការណ៍អំពីសកម្មភាពទាំងនោះទៅ សារុន វិញ តើមែនទេ? ឆ.៧៧៖ ចាស។"]។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៧ KH 01348857 ["តាសារុន បានហៅទៅប្រជុំ។ គាត់ និងប្រជាជននៅសហករណ៍បានចូលរួមការប្រជុំ។"]។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.១២៥ KH 01075735 ["នៅពេលដែលមានផែនការ គឺ បងរ៉េន ជាអ្នកហៅពួកខ្ញុំមកប្រជុំប្រាប់។ ហើយ មានការអ្វី បងរ៉េន ជាអ្នកឡើងទៅប្រជុំនៅតំបន់។"]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៥៧-៦៣ KH 01068133 [គណៈសមរភូមិនៅស្រុកបាកាន៖ "ឆ.៥៧៖ ខ្ញុំទៅប្រជុំពេលដែល តាសារុន មកដល់ទីនេះបានប្រហែលជា ៣ខែ គឺប្រហែលជាឆ្នាំ១៩៧៧។ [...]ឆ.៥៨៖ [...]ពេលនោះ គេហៅគាត់ថា គណៈតំបន់។ [...]ឆ.៥៩៖ [...]ប្រជុំនេះ មានរយៈពេល ៣ថ្ងៃ។ [...]ឆ.៦០៖ នៅរោងកុនចាស់ ទីរួមខេត្តពោធិសាត់។ [...]មានច្រើនណាស់ គឺទូទាំងតំបន់តែម្តង មានចាប់ពីគណៈសមរភូមិ គណៈសហករណ៍ ហើយនិងគណៈស្រុក។ ស៖ តើយាយ រ៉ីម បានចូលរួមប្រជុំនេះដែរឬទេ? ឆ.៦២៖ បាទ គាត់បានចូលរួម។ [...]ឆ.៦៣៖ អ្នកចូលរួមប្រជុំនេះ គឺសុទ្ធតែជាកម្មាភិបាលទាំងអស់ មានទាំងខាងយោធាផងដែរ។"]។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន រិន ឆ.៦៤, ៦៦-៦៧ KH 01075615-01075616 ["ឆ.៦៤៖ [...]តែបើនៅពេលយប់ មានការប្រញ្ជាប់ទៅប្រជុំនៅមោង ឬក៏នៅខេត្តអ៊ីឈ្នោះ ថា ជាអ្នកឌុបម៉ូតដឹក យាយរ៉ីម ទៅប្រជុំទាំងនោះ។ [...] ស៖ ប្រជុំនៅខេត្ត តើលោកចង់សំដៅទៅលើការប្រជុំនៅតំបន់ ឬយ៉ាងណា? ឆ.៦៦ ៖ បាទ ប្រជុំនៅតំបន់ ជួនកាលប្រជុំនៅមោង ជួនកាលប្រជុំនៅទីរួមខេត្តពោធិសាត់។ ស៖ តាមលោកដឹង តើយាយរ៉ីម ចូលរួមប្រជុំថ្នាក់តំបន់ញឹកញាប់ដែរឬទេ? ឆ.៦៧៖ បាទ ញឹកញាប់ ព្រោះការងារគាត់ចុះឡើងៗញឹកញាប់ដែរ។"]។

[487] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៨៩ KH 01347277 ["ខ្ញុំទទួលបញ្ជាពីថ្នាក់លើ ហើយខ្ញុំនឹងប្រាប់ទៅថ្នាក់ក្រោម ថាថ្នាក់លើឲ្យធ្វើអ៊ីចេះ។"]។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.១៦, ១៩-២០ KH 01348859, 01348859-01348860 ["យើងបានទទួលផែនការហើយ យើងអត់ប្រជុំអត់កើត។ ដូច្នេះ យើងប្រជុំប្រាប់ គ្រាន់តែប្រជុំប្រាប់ទេណា។ [...]គេណែនាំ ប៉ុនណា យើងធ្វើតាមអ្វីដែលគេណែនាំ។ [...]យើងបានប្រជុំ គេណែនាំយើងអ៊ីចឹង។ [...]ខ្ញុំផ្តល់ការណែនាំ តាមបញ្ជារបស់តាសារុន។"]។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.១២៧ KH 01075735 ["ស៖ តើ រ៉េន បានចែករំលែកព័ត៌មានពីកិច្ចប្រជុំថ្នាក់តំបន់ដល់លោកស្រីដែរឬទេ? ឆ.១២៧៖ ចាស បាន។ គាត់បានផ្សព្វផ្សាយថា "បក្សយើងចង់ឲ្យខិតខំប្រឹងធ្វើការ" ហើយយើងក៏ដាក់ផែនការតាមកង តាមពួកអ៊ីចឹងទៅ"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.១១ KH 00485648 [ប្រធានសហករណ៍រំលេច៖ "ខ្ញុំ [...]ដឹងថា ថ្នាក់តំបន់ ឬថ្នាក់ស្រុកបានទៅប្រជុំនៅថ្នាក់លើ [...]បន្ទាប់ពីពួកគេទៅប្រជុំនៅថ្នាក់លើ ហើយ ពួកគេក៏កោះហៅថ្នាក់សហករណ៍ប្រជុំ ផ្សព្វផ្សាយផែនការដែលគេទទួលបានពីថ្នាក់លើ ដូចជាការធ្វើស្រែ ការលើកទំនប់ ការតាមដានខ្ជាំង។ល។"]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៦៩-៧២, ៧៩ KH 01068134-01068135, 01068136 [គណៈសមរភូមិ នៅសហករណ៍ស្រោង យោធាស្រុកគ្រប់គ្រងបាកាន៖ "គេប្រជុំកន្លែងរបស់ យាយរ៉ីម

164. ទាំង សារុន ទាំង រ៉ែម បានចែកចាយ និងលើកកម្ពស់ខ្លឹមសារទង់បដិវត្ត[488]។ ពួកគាត់បានផ្សព្វផ្សាយ ដល់កម្មាភិបាលតំបន់ ២ នូវគោលនយោបាយ និងមនោគមន៍វិជ្ជារបស់ ប.ក.ក រួមទាំង គោលនយោបាយកម្ទេចខ្មាំងផ្ទៃក្នុង[489]។ បញ្ហាដែលត្រូវបានបញ្ជូនទៅក្រោមតាមរចនាសម្ព័ន្ធអំណាចនៃ

នៅក្នុងមន្ទីរស្រុក។ [...]យាយរ៉ែម ជាប្រធានអង្គប្រជុំ។ [...]ប្រជុំនេះ មិនទៀតទាត់ទេ ទាល់តែមានផែនការពីលើ ទើបគេហៅទៅប្រជុំ។ [...]ខ្ញុំសំដៅទៅលើថ្នាក់ស្រុកទៅចូលរួមប្រជុំនៅថ្នាក់តំបន់។ [...]ក្រោយពេលដែលគាត់ទៅប្រជុំនៅថ្នាក់លើ ហើយពេលត្រឡប់មកវិញ គាត់ដាក់ផែនការតាមសហករណ៍។"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.៩៣-៩៦ KH 01000266 [មេកងនៅស្រុកបាកាន៖ "ឆ.៩៣៖ ដំបូងគណៈសហករណ៍ទៅទទួលមតិពីថ្នាក់លើ ហើយក៏យកមតិនោះមកប្រជុំប្រាប់ពួកខ្ញុំបន្តទៀត។ [...] ឆ.៩៤៖ ខ្ញុំឮអំឡុងឆ្នាំ១៩៧៨ ដោយសារនៅពេលនោះ ខ្ញុំជាប្រធានក្រុម ដូច្នេះ ខ្ញុំត្រូវគេហៅឲ្យចូលរួមប្រជុំជាមួយនឹងគណៈសហករណ៍ [...]ស៖ តើប្រធានសហករណ៍របស់លោកចូលរួមប្រជុំជាមួយនឹងគណៈស្រុកមែនទេ? ឆ.៩៥៖ បាទ ជាមួយនឹងថ្នាក់ស្រុក និងតំបន់។ ស៖ តើការប្រជុំកើតឡើងមុន ឬក៏ក្រោយពេលដែលកម្មាភិបាលនិរតីទៅដល់តំបន់របស់លោក? ឆ.៩៦៖ ក្រោយកម្មាភិបាលពីភូមិភាគនិរតីមកដល់កន្លែងរបស់ខ្ញុំ។"] ឆ.១២១-១២៥ KH 01000269-01000270 [រៀបរាប់ការប្រជុំដែលដឹកនាំដោយយាយ រ៉ែន យាយយ៉ាន និងយាយរ៉ែម នៅបាកាន "មន្ទីរស្រុក" ដែលនិយាយអំពី "រឿងកសាង ដកស្ទង សម្រេចផែនការ ចាត់សភាពការណ៍ខ្មាំង [...]ពួកគេនិយាយថា "ភូមិភាគពាយ័ព្យក្នុងស្រុកបាកានមានខ្មាំងច្រើនណាស់ បង្ក ប់ខ្មាំងច្រើនណាស់" គេនិយាយថា ពួកលន់នល់ ជាពួកសេ.អ៊ី.អា។ ប៉ុន្តែក្រោយមកពួកកម្មាភិបាលពាយ័ព្យទាំងអស់ គឺសម្លាប់រាល់ថ្ងៃតែម្តង។ ពាក្យខ្មាំងនេះមានន័យសំដៅទៅលើពួកខ្ញុំដែលជាអ្នកចាស់នេះហើយ។]។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ុន ឆ.៦២-៦៨ KH 01176412-01176413 [ទីរសារយាយរ៉ែម រៀបរាប់បញ្ជាយាយរ៉ែម ឲ្យចែកសំបុត្រ ទៅ "ភូមិ ស្រុក និងគណៈសហករណ៍" រៀងរាល់ពីរ ឬបីថ្ងៃ។ សំបុត្រនោះ ហៅមក "ចូលរួមប្រជុំ ឬវគ្គរៀនសូត្រ" ឬ ពេលយាយរ៉ែម "មានផែនការថ្មីណាមួយ។"] ឆ.៧៧ KH 01176414 ["[យាយរ៉ែម] និយាយពីការងារគាត់ជាមួយអ្នកទាំងនោះ [...]អំពីគណៈសហករណ៍ និងគណៈសមរភូមិ។"]។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.៣២-៣៣ KH 00955767 ["ឆ.៣២៖ នៅពេលដែលគេឲ្យយើងជីកប្រឡាយ គាត់បានបង្ហាញខ្លួននៅតាមភ្លឺស្រែ នៅតាមប្រឡាយជាដើម។ ក្នុង ១ឆ្នាំ យើងឃើញគាត់ច្រើនណាស់បានតែ បីដងប៉ុណ្ណោះ។ ស៖ តើ យាយរ៉ែម មាននិយាយផ្ទែងសុទ្ធរកថាដែរឬទេ? ឆ.៣៣៖ គាត់បាននិយាយផ្ទែងសុទ្ធរកថា ដោយនិយាយថា "ឲ្យស្នេះត្រង់ជាមួយអង្គការ សម័យនេះ ជាសម័យស្នេះត្រង់នឹងអង្គការ បើអ្នកណាក្បត់នឹងអង្គការ គឺត្រូវផ្ទាស់សមរភូមិ"។ គេមិនឲ្យប្រើពាក្យ "សម្លាប់"ទេ ពេលនោះ។"]។ សូមមើលផងដែរ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៥០-៥១ KH 00955732-00955733 ["បើ (យាយរ៉ែម) មិនបញ្ជា ម៉េចមានគេសម្លាប់។ [...] ឆ.៥១៖ [...]គាត់មានអំណាច។"]។

[488] ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សឿម ឆ.១៥ KH 00485649 ["ក្នុងឋានៈជាប្រធានសហករណ៍ ខ្ញុំធ្លាប់បានឃើញទស្សនាវដ្តីទង់បដិវត្តន៍នោះដែរ [...]មុនពេលភូមិភាគនិរតីមកគ្រប់គ្រងនៅពាយ័ព្យ តាញ៉ីម ដែលជាគណៈភូមិភាគពាយ័ព្យបានមកផ្សព្វផ្សាយពីខ្លឹមសារនៃទស្សនាវដ្តីទង់បដិវត្តន៍នេះ [...]តាសារុន និងយាយរ៉ែម ក៏បាននិយាយអំពីខ្លឹមសារនៃទស្សនាវដ្តីដូចគ្នានេះដែរ។ ខ្ញុំយល់ថា ការអានទស្សនាវដ្តីទង់បដិវត្តន៍ សម្រាប់កម្មាភិបាលខ្មែរក្រហមគឺមានប្រយោជន៍ ឲ្យមានការតស៊ូវណ្ណៈដូចមាននិយាយនៅក្នុងទស្សនាវដ្តីនោះ។"]។

[489] ឯកសារ D179/1.2.11 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារ៉ីក ថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ម៉ោង 10.04.30-10.06.33 ["ធម្មតាទេ ការអប់រំរបស់បក្ស សំខាន់លើបញ្ហាបី។ ទីមួយគោលនយោបាយរបស់បក្ស។ ទីពីរ ជំហរសតិអារម្មណ៍របស់បក្ស។ ទីបី គោល

ជំហរចាត់តាំងរបស់បក្ស"]។ ទាក់ទងនឹងការផ្សព្វផ្សាយនៃគោលនយោបាយខ្មាំងរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុង *ទង់បដិវត្តន៍* អំឡុងឆ្នាំ១៩៧៧ និង ១៩៧៨ សូមមើលឧទាហរណ៍ ឯកសារ D322/8.1.23 *ទង់បដិវត្តន៍* ខែមេសា ឆ្នាំ១៩៧៧ KH 00062986 ["ឯចំពោះខ្មាំងជាភ្នាក់ងារ "សេ.អ៊ុ.អា" "កា.ហ្សេ.បេ" និង ភ្នាក់ងារ "ឃ្លន" [...]ឲ្យវាកាន់តែខ្ទេចខ្ទីតទៅទៀត ដើបក្បាលមិនរួច។ ធ្វើយ៉ាងនេះ យើងរ៉ឹតតែបង្កើនលក្ខណៈសម្បត្តិឲ្យយើងទៅវាយខ្មាំង ឆ្នាំ១៩៧៨ នឹងឆ្នាំតទៅទៀត កាន់តែខ្លាំង និងកាន់តែបានជោគជ័យធំៗថែមទៀត។"]។ KH 00062993 ["បញ្ហាមួយដែលត្រូវយកចិត្តទុកដាក់សំខាន់ណាស់ដែរ គឺវែកមុខពួក "សេ.អ៊ុ.អា" ពួក "កា.ហ្សេ.បេ" និងភ្នាក់ងាររបស់វា ពួក "ឃ្លន" លេបទឹកដីនិងផ្តែបំរើរបស់វា"]។ ឯកសារ D6.1.542 *ទង់បដិវត្តន៍* ខែមិថុនា ឆ្នាំ១៩៧៧ KH 00062803-00062804 ["បំផុសអប់រំមហាជន គឹមហាជននៅក្នុងបក្ស [...]ឲ្យគេឃើញច្បាស់ថា ខ្មាំងបង្កប់ស៊ីរ្ងងផ្ទៃក្នុងធ្វើសកម្មភាពយ៉ាងម៉េចឲ្យគេជ្រួតជ្រាប ដើម្បីគេទៅជាកម្លាំងខ្មាំង និងវាយខ្មាំងតទៅទៀត។"]។ ឯកសារ D6.1.740 *ទង់បដិវត្ត* ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧ KH 00064758 ["នៅក្នុងមជ្ឈិម នៅក្នុងសេនាធិកា នៅក្នុងភូមិភាគ នៅក្នុងមូលដ្ឋាន សុទ្ធតែមានខ្មាំងបង្កប់នៅក្នុងជួរយើង។ បើយើងមិនមានវិធានការទាន់ពេលវេលាគឺ គ្រោះថ្នាក់។"]។ ឯកសារ D1.3.22.6 *ទង់បដិវត្ត* ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ KH 00064556 ["យើងបានឃើញ [...]សភាពពិសពុលនៃខ្មាំងខាងក្នុង [...]យើងត្រូវពង្រឹងគោលជំហរតស៊ូវណ្ណៈ [...]ដើម្បីកំចាត់ខ្មាំង ទាំងក្នុង ទាំងក្រៅ ពិសេសខ្មាំងខាងក្នុង"] EN 00185342 ["ភារកិច្ចរបស់យើង គឺវាយកំទេច [...]ខ្មាំងវិញត្រូវខ្ទេចខ្ទី ខ្ចាត់ខ្ចាយ និងរលំរលាយ។"]។

តំបន់ ២ រួមមានបញ្ជាឲ្យជម្លៀសដោយបង្ខំ ចាប់ខ្លួន និងសម្លាប់ខ្មាំង[490] ដូចជា ខ្មែរក្រោម[491] កម្មាភិបាលភូមិភាគពាយ័ព្យ[492] អតីតអ្នករដ្ឋការ លន់ នល់[493] និងពួកភូមិភាគបូព៌ាដែលត្រូវបានជម្លៀស[494]។

---

[490] ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.១២៨ KH 01075735 ["ស៖ តើ រ៉ន បានចែករំលែកព័ត៌មានប្រជុំថ្នាក់តំបន់ពីស្ថានភាពខ្មាំងដល់លោកស្រីដែរឬទេ? ឆ.១២៨៖ គាត់និយាយថា "បក្សយើងប្រឆាំងនឹងខ្មាំង កុំឲ្យអ្នកណាអូសទាញទៅណាបាន ហើយខំប្រឹងធ្វើការងារ។"]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៦៦-១៦៧ KH 01034514-01034515 ["ឆ.១៦៦៖ [...]នៅពេលដែលមានផែនការអ្វីមួយ មេគុក ត្រូវគេហៅទៅប្រជុំនៅស្រុក។ ពេលដែលមេគុកត្រឡប់មកវិញ គឺមានការសម្លាប់មនុស្សហើយ។ ស៖ លោកនិយាយថា នៅឆ្នាំ១៩៧៨ មានការសម្លាប់អ្នកទោសកើនឡើង។ តើហេតុការណ៍នេះកើតឡើងដោយស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលដែលមកពីនិរតី ឬក៏យ៉ាណា? ឆ.១៦៧៖ បាទ ជាពេលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី។"]។ ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សារ៉ៀន ឆ.៦៨-៦៩ KH 00955755 ["យាយរ៉ីម ធ្លាប់និយាយថា ពួកក្បត់ត្រូវតែបោសសម្អាតចេញពីក្រុមយើងឲ្យអស់។ [...]ខ្ញុំគ្រាន់តែឮគាត់និយាយថា ត្រូវកម្ចាត់ពួកក្បត់ផ្ទៃក្នុងឲ្យអស់ កុំទុក។"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៣ KH 00485644-00485645 [អតីតប្រធានសហករណ៍រំលេច រាយការណ៍ការប្រជុំប្រធានសហករណ៍ជាមួយនឹងតាសារុន និងយាយរ៉ីម៖ "យាយរ៉ីម បន្ថែមថា ពួកពូងង ត្រូវធ្វើតាមផែនការដែលបក្សដាក់ឲ្យ បើធ្វើមិនបានសម្រេច គឺមានន័យថាជាខ្មាំង ហើយត្រូវបាត់ខ្លួនដូចពួកមុនអ៊ីចឹង។"]។

[491] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៨៣-៨៤, ៨៦-៨៩, ១០២-១០៣, ១០៦-១០៧ KH 01347275, 01347276-01347277, 01347279 [តាម៉ុក បានចេញបញ្ជាឲ្យចាត់ចែងដោះស្រាយបញ្ហាជាមួយខ្មាំងយ្ជនតាមរយៈ តាសារុន ដែលបានកោះហៅយាយរ៉ីម និងសមាជិកសហករណ៍ ដើម្បីអនុវត្តបញ្ជានេះ។]។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.១៣-១៤, ២៧, ៤២ KH 01348858, 01348861, 01348863 ["ឆ.១៣៖ [...]មានតែតាសារុន ម្នាក់ទេ អ្នកប្រជុំប្រាប់ សហករណ៍អី។ ក្រៅពីសកម្មភាព ខ្ញុំមិនពន្លឿស ធ្វើតាមតែគេហ្នឹង។ ស៖ [...] សកម្មភាព គឺសំដៅដល់សកម្មភាពក្នុងការតាមរកកំណត់អត្តសញ្ញាណ និងលុបបំបាត់ពួកគេ តើមែនទេ? ឆ.១៤៖ ហ្នឹង គាត់ណែនាំឲ្យសហករណ៍ទាំងអស់ ឲ្យតាមដាន ហ្នឹងខ្លាចណាខ្សែរយៈយ្ជនវ៉ៃលុកអ៊ីចឹងទេ។ [...]ស៖ តើគាត់បានណែនាំ លោកស្រីឲ្យបញ្ជូនមនុស្សទៅខ្នារទទឹងឬទេ? ឆ.២៧៖ គាត់បានណែនាំ នៅអង្គប្រជុំ គាត់បានណែនាំ។ [...]ស៖ ការពិតគឺថា លោកស្រីបានបញ្ជាឲ្យមានការសម្លាប់មនុស្ស ដោយលោកស្រីទទួលបញ្ជានោះពីអ្នកដទៃទៀត ត្រឹមត្រូវទេ? [...]ឆ.៤២៖ មានតាសារុន ដដែលហ្នឹងគាត់ណែនាំ។ គាត់ទៅជួបថ្នាក់លើទៀត។"]។ ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.២០ KH 00872599 ["ខ្ញុំបានចូលរួមទៅប្រជុំមួយជាមួយប្រធានសហករណ៍ទាំងអស់នៅក្នុងស្រុកបាកាន ហើយយាយរ៉ីម បាននិយាយអំពីផែនការសម្លាប់ខ្មែរក្រោម។"] ឆ.១៧ KH 00872599 ["ប្រហែលជាចុងឆ្នាំ១៩៧៨ មានបញ្ជាពីគណៈស្រុកបាកាន [...]បានបញ្ជាឲ្យខ្ញុំប្រមូលខ្មែរក្រោមក្នុងសហករណ៍រំលេចទាំងអស់ មកដាក់នៅក្នុងសហករណ៍សខ្នារទទឹង ពីព្រោះគេចោទថា ពួកនោះជាប់និន្នាការវៀតណាម។"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៣៤-៣៥ KH 00955682-00955683 ["តើអ្នកណាជាអ្នកចេញបញ្ជាឲ្យជម្លៀសខ្មែរក្រោមចេញពីភូមិ? ឆ.៣៤៖ ចៅហ្វាយស្រុកជាអ្នកបញ្ជាមកសហករណ៍ ហើយសហករណ៍ជាអ្នកចេញបញ្ជាមកតាមក្រុមទៀត។ ស៖ នៅពេលនោះ តើអ្នកណាជាចៅហ្វាយស្រុក? ឆ.៣៥៖ យាយ

រ៉ែម។"]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១២-១១៧ KH 01068142-01068143 ជាពិសេស ឆ.១១២ ["ខ្ញុំបានចូលរួមប្រជុំនៅកោះរុន ហើយគេនិយាយអំពីផែនការបោសសម្អាតខ្មែរក្រោមនេះ។ កិច្ចប្រជុំនេះ ធ្វើឡើងនៅក្នុងឆ្នាំ១៩៧៨ ហើយមានគ្រប់មេសហាករណ៍ គណៈសមរភូមិចូលរួមប្រជុំទាំងអស់។ យាយរ៉ែម ជាប្រធានអង្គប្រជុំនៅពេលនោះ។ មុនដំបូងនៅក្នុងឆ្នាំ១៩៧៨ [...]យាយរ៉ែម ទៅចូលរួមប្រជុំនៅតំបន់។ បន្ទាប់ពីត្រឡប់មកវិញគាត់និយាយថា "ឥឡូវយើងប្រមូលខ្មែរក្រោមទាំងអស់ដាក់មួយកន្លែង ប្រមូលគ្រប់សហាករណ៍ទាំងអស់។"] ឆ.១២១, ១២៣-១៣០ KH 01068144-01068145 ឆ.១៣១ KH 01068145 ["ខ្ញុំទៅចូលរួមប្រជុំ ហើយយាយរ៉ែម ដាក់បទបញ្ជាឲ្យមកខ្ញុំធ្វើរឿងទាំងនេះ គឺដាក់បទបញ្ជាឲ្យធ្វើនៅសហាករណ៍នីមួយៗ។ យាយរ៉ែម ជាអ្នកដាក់បញ្ជាឲ្យខ្ញុំទទួលខុសត្រូវក្នុងការសម្លាប់ខ្មែរក្រោមទាំងអស់នោះ។ នេះគឺជាបទបញ្ជាតៗគ្នា។"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.៩៣-៩៤ KH 01000266 ["ឆ.៩៣៖ [...]នៅក្នុងការប្រជុំនោះ គណៈសហាករណ៍និយាយអំពីបញ្ហាបង្កបង្កើនផល ហើយក៏និយាយផងដែរថា "ខ្មែរក្រោមនេះ មិនគួរទុកទេ ព្រោះពួកគេជាពួកក្បាលយួនខ្លួនខ្មែរ។"។ ស៖ លោកឮពាក្យថា "ខ្មែរក្រោមជាក្បាលយួនខ្លួនខ្មែរ" តើលោកឮនៅពេលណា? [...]ឆ.៩៤៖ ខ្ញុំឮអំឡុងឆ្នាំ១៩៧៨។ ដោយសារនៅពេលនោះ ខ្ញុំជាប្រធានក្រុម ដូច្នេះខ្ញុំត្រូវគេហៅឲ្យចូលរួមប្រជុំជាមួយនឹងគណៈសហាករណ៍"]។ ឯកសារ D6.1.757 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន KH 00385099 ["ចំពោះបញ្ជាឲ្យសម្លាប់ ខ្ញុំដឹងថា បញ្ជាទាំងនេះ ចេញពីអង្គការថ្នាក់លើ និងពីយាយរ៉ែម។"]។

[492] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៨៨ KH 01068138 ["ពាក់ព័ន្ធនឹងកម្មាភិបាលមូលដ្ឋាននេះ តើអ្នកណាជាអ្នកមានអំណាចចេញបញ្ជាឲ្យបោសសម្អាតកម្មាភិបាលមូលដ្ឋានទាំងអស់នោះ? ឆ.៨៨៖ បញ្ជាចាប់ខ្លួននេះ គឺចេញមកពីតំបន់ ហើយនៅថ្នាក់តំបន់នោះ មានតែ តាសារុន ទេជាអ្នកចេញបញ្ជា។ តាំងពីនោះ មក តាសារុន គ្រប់គ្រងតំបន់២ រហូត។"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៣-៥ KH 00485644-00485645។

[493] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៦៨-៧២, ៧៥-៧៨ KH 01068134-01068135, 01068135-01068136 [រៀបរាប់ការប្រជុំសម្រាប់សហាករណ៍ជាផ្លូវការដែលយាយរ៉ែម ជាប្រធាន ដើម្បីពិភាក្សាពីគោលនយោបាយខ្ទាំង។ ការប្រជុំនេះគឺ "ប្រជុំហូរហែ ច្រើនដង ហើយប្រជុំរហូតដល់យួនចូលមកដល់។" បន្ទាប់ពីមន្ត្រីថ្នាក់ស្រុក បានជួបជាមួយតំបន់ ដើម្បីទំនាក់ទំនងពីបញ្ហាដែលទទួលនោះ៖ "ពេលទទួលផែនការពីថ្នាក់លើ" យាយរ៉ែម "បានណែនាំឲ្យគ្រប់សហាករណ៍ស្រាវជ្រាវរកពួកទាហាន កម្ម៉ង់ដូ និងមន្ត្រីរាជការនៅក្នុងសម័យ លន់ នល់។ [...]គាត់និយាយថា ក្រោយស្រាវជ្រាវហើយ គឺយកទៅសម្លាប់។ [...]យាយរ៉ែម និយាយថា "មិត្តទាំងអស់គ្នាហ្ន៏ង ត្រូវតែស្រាវជ្រាវឲ្យបាន ហើយយើងត្រូវបោសសម្អាតឲ្យអស់ កុំឲ្យនៅ។" យោងតាមសាក្សី រ៉ែម៖ "និយាយញ៉ីកញ្ជាប់ណាស់ ឲ្យតែប្រជុំគឺនិយាយហើយ។"]។

[494] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១៣៣ KH 01068146 ["មានបទបញ្ជានិយាយថា អ្នកបូ៉ាទាំងអស់នោះគឺជាពួកខ្ស្យួនដូចខ្ខ្មែរក្រោមដែរ។ បទបញ្ជាឲ្យសម្លាប់នេះ គឺចេញពីតំបន់ មកស្រុក ហើយស្រុកមកដល់សហាករណ៍ រួចមកដល់គណៈសមរភូមិ រួចទៅឈ្លប ហើយក៏ធ្វើការសម្លាប់អ្នកបូ៉ាតាមសហាករណ៍នីមួយៗ។"] ឆ.១៣៦-១៣៨ KH 01068146-01068147 ["ឆ.១៣៦៖ ភ្ជនាទីរបស់ខ្ញុំ គឺទទួលបន្ទុកក្នុងការសម្លាប់អ្នកបូ៉ា។ ប្រធានសហាករណ៍ឈ្មោះ ពុន (ប្រុស) ជាអ្នកបញ្ជាខ្ញុំ ហើយ ពុន ជាមនុស្សថ្មី ដែលមកគ្រប់គ្រងសហាករណ៍ជាមួយនឹង រ៉ុម។ [...]គណៈសមរភូមិ គឺនៅពីក្រោមគណៈសហាករណ៍បន្តិច ហើយប្រធានផ្នែកគឺនៅក្រោមគណៈសមរភូមិបន្តិច។ [...]ស៖ តើយាយរ៉ែម មានពាក់ព័ន្ធក្នុងដំណើរការសម្លាប់ប្រជាជនបូ៉ាដែរឬទេ? ឆ.១៣៧៖ បាទ គាត់មិនចូលរួមផ្ទាល់ទេ តែគាត់ជាអ្នកបញ្ជាមកឲ្យសម្លាប់អ្នកបូ៉ា។ យាយរ៉ែម បាននិយាយនៅក្នុងការប្រជុំ ហើយប្រាប់មេសហាករណ៍ គណៈសមរភូមិអំពីការសម្លាប់ប្រជាជនបូ៉ា។ [...]ឆ.១៣៨៖ ចុងឆ្នាំ

ក. ស្រុកបាកាន

165. ចុងក្រោយ ស្រុកបាកានត្រូវបានបែងចែកយ៉ាងតិចណាស់ជាប្រាំបួនឃុំ[495]។ ទីតាំងឧក្រិដ្ឋកម្មចំនួនប្រាំក្នុងចំណោមទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ស្ថិតនៅក្នុងឃុំចំនួនបួនក្នុងចំណោមឃុំទាំងនេះ៖ មន្ទីរសន្តិសុខភូមិវាល និងទីតាំងសម្លាប់មនុស្សព្រៃក្រហៅនៅក្នុងឃុំតាណោ មន្ទីរសន្តិសុខស្វាយជ្រុំក្នុងឃុំបឹងបាតកណ្តាល ទីតាំងសម្លាប់មនុស្សទួលសេះញ្ជ្ងីវក្នុងឃុំខ្នារទទឹង និងទីតាំង

១៩៧៨។"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៥ KH 00485645 [រៀបរាប់ការប្រជុំនៅអតីតរោងកុននៅក្រុងពោធិសាត់ដែលអធិបតីដោយ តាម៉ុក ហើយចូលរួមដោយ តាសារុន និងយាយរ៉ីម ដែលពេលនោះតាម៉ុក ប្រកាសថា "[...]អង្គការជម្លៀសប្រជាជនភូមិភាគបូព៌ាមកឲ្យមកនៅភូមិភាគពាយ័ព្យ ហើយឲ្យតាមដានប្រយ័ត្នពួកប្រជាជនបូព៌ាទាំងនោះ ប្រឆាំងមាគ៌ារបស់បក្ស ព្រោះពួកនោះ ពេលជម្លៀសពីបូព៌ាដាក់នៅរោងចក្រស្ករសនៅភ្នំពេញ គេអែកមើលឃើញមានកាំភ្លើងដែលពួកនេះមានខ្សែរយៈជាមួយយួនហើយ"] បញ្ជាក់ ឯកសារ D6.1.616 បទសម្ភាសន៍របស់ SOAS ជាមួយ អ៊ុក សៀម KH 00657428។

[676] ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈៀន ឆ.១៦ KH 01068049 ["ស៖ តើស្ថានភាពរស់នៅរបស់អ្នកជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខនោះ [វត្តព្រះធាតុ] យ៉ាងម៉េចដែរ? ឆ.១៦៖ គឺមានសភាពអាក្រក់ [...]។ មិនមានថ្នាំព្យាបាលសម្រាប់អ្នកឈឺនោះទេ"]។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.២១ KH 01047180 ["មានអ្នកទោសខ្លះឈឺ ហើយស្លាប់ [...] ដោយសារឈឺមិនមានថ្នាំព្យាបាល"]។

[677] ឯកសារ D219/86 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.១១-១៣ KH 01040105-06 ["របបហូបចុករបស់អ្នកទោស គឺមួយកំប៉ុងពីរនាក់ក្នុងមួយពេល ក្នុងមួយថ្ងៃគេឲ្យពីរពេល។ [...] អ្នកទោសមានភាពស្គមស្គាំង ពីព្រោះមិនមានអាហារហូបចុកគ្រប់គ្រាន់"]។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈៀន ឆ.១៦ KH 01068049 ["ស៖ តើស្ថានភាពរស់នៅរបស់អ្នកជាប់ឃុំនៅក្នុងមន្ទីរសន្តិសុខនោះ [វត្តព្រះធាតុ] យ៉ាងម៉េចដែរ? ឆ.១៦៖ គឺមានសភាពអាក្រក់ ពួកគេហូបតែបបរ។ [...] ពួកគេហូបអាហារមិនគ្រប់គ្រាន់"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤៨-៤៩ KH 00788833 ["អ្នកទោស [...] គេបង្អត់បាយតែម្តង"]។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.២១ KH 01047180។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូវ ឆ.៥៩-៦១ KH 01097761-62 ឆ.១០៥ KH 01097766។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៧៨ KH 00788849។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៥២ KH 00963065-66។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741590។

អាចចេញចូលបានបន្តិចបន្តួចប៉ុណ្ណោះ[678]។ អ្នកទោសបានធ្លាក់ខ្លួនឈឺ ឬស្គមកំព្រឹង ដោយសារស្ថានភាពនៅក្នុងសាលាឆាន់នេះ[679] ហើយមានអ្នកខ្លះបានស្លាប់ដោយសារជំងឺរបស់ពួកគេ[680]។

---

[678] ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៦៨-៦៩ KH 00968076 ["ស៖ លោកនិយាយថាកន្លែងឃុំខ្លួនលោក[អតីតជាសាលាឆាន់] អត់មានបង្ហួចទេ តើលោកអាចមើលឃើញរឿងរ៉ាវអ្វីកើតឡើងនៅខាងក្រៅដែរឬទេ? ឆ.៦៨៖ អត់ទេ ខ្ញុំមិនអាចមើលឃើញអ្វីនៅខាងក្រៅទេ។ ស៖ តើមានភ្លើងបំភ្លឺដែរឬទេ? ឆ.៦៩៖ អត់មានទេ"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៦៧ KH 00788835 ["ខ្ញុំនៅក្នុងគុកនោះ [វត្តព្រះធាតុ] គ្មានខ្យល់ចេញចូលទេ។ [...] អ្នកទោសជាប់តែ២ខែងាប់សរសៃក្រាកឈរមិនរួចផង"]។ ឯកសារ D219/87 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.១៥ KH 01040114 ["អគារឃុំឃាំងអ្នកទោស [...] គឺគេយកអគារសាលាឆាន់របស់លោកពីដើមមកធ្វើ។ មានបង្ហួចធ្វើពីឈើ ហើយនឹងមានទ្វារឈើពីរដែលគេចាក់សោទាំងថ្ងៃទាំងយប់។ ទ្វារនោះត្រូវបានបើកសោ នៅពេលណាដែលគេយកអាហារទៅឲ្យអ្នក ទោស"]។

[679] ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.១៦ KH 01068049។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៦៦-៦៧ KH 00788835 ["ខ្ញុំជាប់នៅទីនេះ៨ខែ ជ្រុះសក់អស់។ [...] អ្នកទោសជាប់តែ២ខែ ងាប់សរសៃក្រាកឈរមិនរួចផង"]។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៥៣ KH 00968074 ["ពេលនោះ [ពេលដែលសាក្សីរូបនេះត្រូវបានបញ្ជូនទៅ"អប់រំកែប្រែឡើងវិញ"] ខ្ញុំឈឺ ហើយស្គមស្ទាំងទៅណាមិនរួចទេ"]។ ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤៨ KH 01099690 ["[ពេលជាប់ឃុំនៅវត្តព្រះធាតុ] ខ្ញុំជ្រុះសក់អស់ ដើរមិនរួច"]។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.២៥ KH 00963061 ["ដោយសារខ្ញុំឈឺច្រើន ដែលបណ្តាលមកពីជាប់គុក [នៅវត្តព្រះធាតុ]"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣៨ KH 01083703។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741590។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714213។

[680] ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.១៦ KH 01068049 ["ស្ថានភាពរបស់ពួកគេ គឺមានសភាពអាក្រក់ [...]។ ខ្ញុំមិនអាចប្រាប់អំពីចំនួនអ្នកស្លាប់បានទេ ពីព្រោះខ្ញុំមិនដឹងថា តើពួកគេស្លាប់ដោយសារអត់ចំណីអាហារ ឬដោយសារជំងឺ។ មិនមានថ្នាំព្យាបាលសម្រាប់អ្នកឈឺនោះទេ"]។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ដេន ឆ.២១ KH 01047180 ["មានអ្នកទោសខ្លះឈឺ ហើយស្លាប់ដោយសារខ្វះម្ហូបអាហារ និងដោយសារឈឺមិនមានថ្នាំព្យាបាល"] ឆ.៣២ KH 01047182 ["ពេលដែលខ្ញុំមកដល់ ខ្ញុំបានឃើញរណ្តៅកប់ខ្មោចនៅជិតៗនោះ។ ប៉ុន្តែគេប្រាប់ខ្ញុំថា ខ្មោចដែលស្លាប់នេះគឺស្លាប់ដោយសារជំងឺ"]។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៥២ KH 00963065-66។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741589, 90។

202. អ្នកជាប់ឃុំដែលស្ថិតក្រោម "ការអប់រំឡើងវិញ" មិនជាប់ខ្នោះជើងទេ យ៉ាងហោចណាស់ក៏នៅពេលថ្ងៃដែរ[681] ហើយត្រូវបានបង្ខំឲ្យធ្វើការងារនៅក្រៅបរិវេណគុក[682]។ មានអ្នកជាប់ឃុំខ្លះត្រូវ

---

[681] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១៧-១៨ KH 00963059 ["ក្រោយពីបានជាប់ឃុំក្នុងសាលាឆាន់រយៈពេលបីខែគេដោះលែងខ្ញុំ ហើយឲ្យខ្ញុំធ្វើការនៅក្នុងបរិវេណវត្តព្រះធាតុនោះ។ [...] គេថាអាចដកជើងចេញ[ពីខ្នោះ]បានហើយ"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៧៩ KH 01083710 ឆ.១៩៦-១៩៨ KH 01083728។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូ ឆ.១២៨-១២៩ KH 01097768 ["ពេលដែលគេដាក់ខ្ញុំ៩ខែហើយ គេដូរទៅដាក់បន្ទប់ផ្សេងវិញ។ នៅក្នុងបន្ទប់ផ្សេងហ្នឹង គេអត់ដាក់ខ្នោះទេ។ ពេលថ្ងៃគេបើកទ្វារ ហើយពេលយប់បានគេបិទ"] ឆ.១៣៥-១៣៦ KH 01097768។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.៣៨ KH 01102936 ["គ្រប់អ្នកទោសទាំងអស់សុទ្ធតែជាប់ខ្នោះ មានពេលដែលចេញពីគុកប៉ុណ្ណោះដែលគេមិនដាក់ខ្នោះ"]។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741589, 90។

[682] ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ដេន ឆ.២១ KH 01047181 ["ស៖ លោកពន្យល់យើងបានទេ ថាតើមានន័យយ៉ាងម៉េច ការអប់រំ? ឆ.២៥៖ ពួកអ្នកទោសត្រូវបានគេរក្សាទុកនៅក្នុងមន្ទីរសន្តិសុខនោះ [វត្តព្រះធាតុ] រួចហើយគេបញ្ជេញឲ្យជួយធ្វើការនៅតាមស្រែ។ បន្ទាប់ពីស្ថានភាពរបស់អ្នកទោសឃើញប្រសើរឡើងវិញ អ្នកទោសនោះត្រូវបានគេបញ្ជូនត្រឡប់ទៅតាមមូលដ្ឋានដើមរបស់គេវិញ"]។ ឯកសារ D219/87 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.៤ KH 01040110 ["បន្ទាប់ពីដោះលែងមក អ្នកទោសទាំងនោះត្រូវបានឲ្យរស់នៅជាមួយនឹងក្រុមខ្ញុំមួយរយៈ រហូតដល់ថ្ងៃគេត្រូវបញ្ជូនទៅសហការណ៍ពួកគេ វិញ។ អ្នកទោសដែលគេដោះលែងហើយមកនៅធ្វើការជាមួយខ្ញុំនោះ គឺយើងចាត់តាំងឲ្យគេដាំបន្លែ និងដាំបាយឲ្យអ្នកទោសដែលជាប់នៅក្នុងមន្ទីរឃុំឃាំង [វត្តព្រះធាតុ]"]។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.២៧ KH 01034066។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូ ឆ.១៤៤-១៤៥ KH 01097769។ ឯកសារ D219/109 កំណត់ហេតុ ស្តាប់ចម្លើយ ឃូ ភ្ជុ ឆ.១១ KH 01045256។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១៧ KH 00963059។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៤០ KH 01083704 ឆ.១៩៦-១៩៨ KH 01083728។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.៤០ KH 01068054។ *សូមមើលផងដែរ* ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741572, 89។

បានបង្ខំឲ្យនាំអ្នកជាប់ឃុំផ្សេងទៀតទៅកាន់ទីតាំងសម្លាប់មនុស្ស ដើម្បីសម្លាប់ចោល[683] ឬ ត្រូវបានបង្ខំឲ្យកប់សាកសព[684]។

<u>ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរំលោភសេពសន្តវ:)</u>

203. សមាជិកគណ:ស្រុកគិរីវង់ រួមទាំង **យ៉ីម ទិត្យ** ផង ត្រូវបានបញ្ជាឲ្យសួរចម្លើយអ្នកទោសនៅវត្តព្រះធាតុ[685]។ **យ៉ីម ទិត្យ** ក៏បានចូលរួមដោយផ្ទាល់នៅក្នុងការសួរចម្លើយទាំងនោះដែរ។ ទន់ ស៊ីន ដែលធ្លាប់ជាប់ឃុំបណ្តោះអាសន្ននៅវត្តព្រះធាតុ បាននិយាយថា អ្នកស្រីបានឃើញ **យ៉ីម ទិត្យ** សួរចម្លើយអ្នកទោសដោយផ្ទាល់ចំនួនពីរដងក្នុងឆ្នាំ១៩៧៦៖"ខ្ញុំធ្លាប់ឃើញតាទិត្យ សួរចម្លើយអ្នកទោស

---

[683] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣០ KH 00963062 ["ពេលខ្លះ គេបានចាត់តាំងខ្ញុំឲ្យបណ្តើរអ្នកទោសដែលត្រូវសម្លាប់ទៅរណ្តៅទៀតផង ប្រហែលប្រាំទៅប្រាំមួយដង"] ឆ.៦១ KH 00963067 ["គេចាត់តាំងឲ្យខ្ញុំបណ្តើរអ្នកទោសបួននាក់។ ពេលទៅដល់រណ្តៅ គេឲ្យអ្នកទោសដែលជាប់ចំណង តែមិនបិតមុខទាំងនោះ អង្គុយនៅមាត់រណ្តៅ ហើយទម្លាក់ជើងចុះទៅក្នុងរណ្តៅ។ ពេលអ្នកទោសទាំង ៣០ នាក់អង្គុយជុំវិញមាត់រណ្តៅហើយ ឈឹម បានហុចកាំភ្លើងទេះមកខ្ញុំមួយ [ដើម្បីសម្លាប់អ្នកទោស] តែខ្ញុំថា ខ្ញុំមិនហ៊ានទេ។ [...] ខ្ញុំឃើញអ្នកទោសត្រូវសម្លាប់ដោយកាត់ផ្តាច់បំពង់ក ហើយឃើញឈាមពេញទីនោះ។ ពេលនោះខ្ញុំមិនហ៊ានមើលទេ គឺខ្ញុំបែរខ្នង ហើយយកចបកាយដីលុបរណ្តៅនោះ"]។

[684] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.២៦ KH 00963062 ["នៅយប់សម្លាប់នោះ [នៅវត្តព្រះធាតុ] គេឲ្យខ្ញុំយាមនៅចម្ងាយប្រហែល ១៥០ ម៉ែត្រពីគុក។ ព្រឹកឡើងគេឲ្យខ្ញុំចូលយកសពទៅកប់។ [...] [។ឈឹម]បានឲ្យខ្ញុំ និងលី ផុន [អ្នកទោសម្នាក់ទៀត] សែងខ្ទោចយកទៅកប់"] ឆ.៣០ KH 00963062 ["ពេលវៀតណាមចូលមក ខ្ទោចអ្នកទោស ៣០ គេឲ្យខ្ញុំយកទៅកប់ [អ្នកទោសនៅវត្តព្រះធាតុ]"] *ដូចបានបញ្ជាក់នៅក្នុង* ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៥២-៥៥, ៦៣ KH 01083706-07, 08។ ឯកសារ D118/111 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.២៥ KH 00953860 ["គេ[បុគ្គលិកវត្តព្រះធាតុ] កប់[សាកសពអ្នកទោសដែលគេបានសម្លាប់]ខ្លួនឯង ឬឲ្យអ្នកទោសកប់"]។

[685] ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.២៦ KH 01102934 ["ក្រោយពីតាទិត្យ តាតុំ យាយបូ ទៅដល់ [វត្តព្រះធាតុ] បញ្ជា ប៊ីន ប្រ៊ីម ព្រ៊ីង សុខ ណុល និង ខែម យកអ្នកទោសពីកន្លែងឃុំឃាំង យកមកសួរចម្លើយ។ ខ្ញុំបានឃើញ គេសួរចម្លើយអ្នកទោសទាំងនោះ។ [...] ខ្ញុំឃើញតាតុំ មកសួរចម្លើយពីរលើក។ លើកទីមួយ តាតុំ និង យាយបូ [...] បានបញ្ជា ប៊ីន, ប្រ៊ីម និងព្រ៊ីង ឲ្យគេយកអ្នកទោសមកសួរចម្លើយ។ លើកទីពីរ [...] [ខៀវ តុ] បានហៅអ្នកទោស មកសួរចម្លើយដូចលើកទីមួយដែរ"] ឆ.៤៧-៥១ KH 01102936-37 ["ឲ្យតែឃើញឈ្មោះ ទិត្យ បូ និង តុ ទៅគុកនោះ ខ្ញុំសំគាល់ឃើញថា មានបណ្តើរអ្នកទោសចេញ មកសួរចម្លើយ ហើយអ្នកទោសខ្លះបានបាត់ខ្លួន។ [...] ក្នុងរយៈពេលបួនថ្ងៃដែលខ្ញុំនៅទីនោះ [វត្តព្រះធាតុ] ខ្ញុំឃើញ [យ៉ីម ទិត្យ] មកពីរដង។ [...] លើកទីមួយ ឃើញបូ និង ទិត្យ។ លើកទីពីរ ខ្ញុំឃើញតែទិត្យទេ"]។ ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៦៥ KH 00968094 ["ស៖ តើហេតុអ្វីបានជាលោកស្គាល់ថាជា តាទិត? ឆ.៦៥៖ ព្រោះតាទិត ធ្លាប់ធ្វើការនៅស្រុកគិរីវង់ ហើយខ្ញុំក៏ធ្លាប់ធ្វើការនៅស្រុកគិរីវង់ដែរ"] ឆ.៦៨-៦៩ KH 00968095 ["ក្រោយពេល តាទិតចេញ[ពីវត្តព្រះធាតុ]ទៅ គេបានយកអ្នកទោសទៅសួរចម្លើយ"]។

ចំនួនពីរដង។ លើកទី១ គឺគាត់សួរចម្លើយអ្នកទោសជាមួយនឹងយាយ ឫ ហើយលើកទី២ គឺគាត់សួរចម្លើយអ្នកទោសតែម្នាក់ឯងទេ"[686]។

204. ការសួរចម្លើយត្រូវបានធ្វើឡើងនៅកន្លែងបើកចំហ និងក្រោមដើមឈើខាងក្រៅអគារឃុំឃាំងនៅវត្តព្រះធាតុ[687]។ ការសួរចម្លើយម្តងៗប្រើពេលប្រហែលកន្លះម៉ោង[688]។ អ្នកជាប់ឃុំត្រូវបានគេសួរ

---

[686] ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.១៦-១៧ KH 00891155 ["ខ្ញុំបានឮពួកឈ្លប និងតាទិត សួរចម្លើយអ្នកទោស។ [...] [នេះ] ប្រហែលចុងឆ្នាំ១៩៧៥ ឬដើម១៩៧៦"]។ ឯកសារ D219/110 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.៣-៧ KH 01045262-64 ["ខ្ញុំធ្លាប់ឃើញ តា ទិត្យ សួរចម្លើយអ្នកទោសចំនួនពីរលើក។ លើកទី១ គឺគាត់សួរចម្លើយអ្នកទោសជាមួយនឹងយាយឫ ហើយលើកទី២ គឺគាត់សួរចម្លើយអ្នកទោសតែម្នាក់ឯងទេ។ [...] ខ្ញុំបានឃើញ តា ទិត្យ ហើយនិង យាយ ឫ ហៅអ្នកទោសម្នាក់ចេញពីកន្លែងឃុំឃាំងទៅខាងក្រោមកុដិណោកមួយដែលនៅក្បែរនោះ ហើយខ្ញុំឃើញពួកគាត់ឈរនិយាយជាមួយអ្នកទោសនោះ។ [...] [លើកទីពីរ យីម ទិត្យ] បានប្រាប់ឲ្យ ប៊ិន នាំយកអ្នកទោសមកជួបគាត់។ ពេលគាត់និយាយជាមួយអ្នកទោស ខ្ញុំឮមិនអស់សេចក្តីទេ ខ្ញុំគ្រាន់តែឮតិចតួចប៉ុណ្ណោះ។ គាត់សួរអ្នកទោសថា៖ "អ្នកឯងមកពីណា? មានគ្នាប៉ុន្មាននាក់នៅក្នុងក្រុមអ្នកឯង? ហើយតើហេតុអីបានជាអ្នកឯងចង់រត់? ហើយរត់ទៅណា"? [...] [ការសួរចម្លើយលើកទីពីរ] កើតឡើងនៅចុងឆ្នាំ១៩៧៦"]។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.៥៤-៦២ KH 01102937-38 ["លើកដំបូងតាទិត្យមកជាមួយនឹងនីរសា ហើយបានយកអ្នកទោសម្នាក់ចេញ ហើយបានសួរចម្លើយគាត់។ [...] ខ្ញុំឮតាទិត្យសួរ៖ "ចាតើគ្នាឯងប៉ុន្មាននាក់មកពីណា!?" [...] [យីម ទិត្យ សួរចម្លើយអ្នកទោស] នៅក្រោមកុដិណោក។ [...] នៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦។ [...] មាន[អ្នកទោស]ច្រើននាក់ត្រូវបានសួរចម្លើយ [រាល់ពេលសួរចម្លើយរបស់តាទិត្យ] [...] ប្រហែល ៦ ឬ៧ ឬ៨នាក់ ត្រូវបានសួរចម្លើយ"]។

[687] ឯកសារ D3/22.3 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃវត្តព្រះធាតុ ឧបសម្ព័ន្ធ៖ ដ្យាក្រាម ក.ស.ព អំពីវត្តព្រះធាតុ EN 00223054។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.៣៥ KH 01068053 ["ការសួរចម្លើយត្រូវបានធ្វើឡើងនៅខាងក្រៅ និងពីមុខអគារឃុំអ្នកទោស"]។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.៣១ KH 01047182 ["ការសួរចម្លើយនោះ គេតែងតែធ្វើនៅក្រោមម្លប់ដើមស្វាយមួយ នៅក្បែរផ្ទះដែលពួកគេរស់នៅ [សាលាឆាន់ ឬ ចង្ក្រានបាយ/កន្លែងហូបបាយ]"]។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៨ KH 00963057 ["អ្នកទោសនៅទីនោះត្រូវគេនាំចេញម្នាក់ម្តងៗទៅសួរចម្លើយនៅក្រោមដើមអំពិលនៅប៉ែលនិរតីវត្ត[ព្រះធាតុ]"]។ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ KH 01083697-98។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៨៥ KH 00788850។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូ ឆ.៩៧ KH 01097765។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741585, 89។

[688] ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូ ឆ.៩៦ KH 01097765 ["សួរប្រហែលកន្លះម៉ោង"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣១ KH 01083702 ["ស៖ លោកនិយាយថា គេបានសួរចម្លើយ និងបានវ៉ៃលោក តើក្នុងមួយថ្ងៃគេសួរចម្លើយនិងវ៉ៃលោកយ:ពេលប៉ុន្មាន? ឆ.៣១៖ ប្រហែលជាកន្លះម៉ោងក្នុងមួយថ្ងៃ"]។

ចម្លើយអំពីបទល្មើសដែលពួកគេត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត[689] អត្តសញ្ញាណអ្នកផ្សេងទៀតដែលគេបានសន្មតថាបានប្រព្រឹត្ត"បទល្មើស"[690] និងថាតើ ពួកគេចង់ត្រឡប់ទៅសហករណ៍ពួកគេវិញដែរឬទេ[691]។ អ្នកជាប់ឃុំត្រូវបានគេប្រាប់ថា ពួកគេនឹងត្រូវបានដោះលែងឲ្យរួចខ្លួនប្រសិនបើពួកគេសារភាពថាបានប្រព្រឹត្ត "បទល្មើស" ដូចដែលគេបានចោទប្រកាន់[692]។ វិធីសាស្ត្រ

---

[689] ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.៣៥-៣៦ KH 01068053 ["អ្នកសួរចម្លើយនៅវត្តព្រះធាតុ] សួរចម្លើយដោយផ្អែកលើការចោទប្រកាន់ប្រឆាំងនឹងអ្នកជាប់ឃុំទាំងនោះ។ [...] [អ្នកជាប់ឃុំទាំងនោះ] ត្រូវបានគេចោទថាជាខ្មាំង"]។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១០ KH 00963058 ["គេសួរខ្ញុំថាតើបានបំផុសឲ្យមនុស្សរត់ទៅវៀតណាមទេ? [...] ហើយក្រោយមក គេសួរខ្ញុំទៀតថាតើមានពាក់ព័ន្ធនឹងមនុស្សដែលបានលួចកាំភ្លើង យកទៅកប់នៅជើងភ្នំទេ?"]។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូវ ឆ.៩៤ KH 01097765 ["ស៖ លោកថា គេសួរចម្លើយលោក។ តើគេសួរអ្វីខ្លះ? ឆ.៩៤៖ គេថា បើខ្ញុំថាខ្ញុំយកអង្ករ ៥០បាវមកហ្នឹង គេឲ្យរួចខ្លួនហើយ"]។ ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៩៥ KH 01110214។ *សូមមើលផងដែរ* ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគឥសាន* KH 00741585, 89។

[690] ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣៣ KH 01083702 ["ស៖ មានអ្នកទោសផ្សេងទៀតត្រូវគេយកទៅសម្លាប់ តើហេតុអ្វីបានជាគេដោះលែងលោក? ឆ.៣៣៖ ចំពោះអ្នកដែលត្រូវគេសម្លាប់នេះ ប្រហែលជាមកពីអ្នកទាំងអស់នោះឆ្លើយដាក់អ្នកដទៃ"]។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៦ KH 00963057 ["នៅពេលគេវាយសួរចម្លើយខ្ញុំ គេសួរថាតើខ្ញុំមានទាក់ទងជាមួយនឹងអ្នកណាខ្លះ? [...] គេប្រាប់ថាបើចង់ [ត្រឡប់ទៅសហករណ៍របស់សាក្សីវិញ] ប្រាប់ឈ្មោះអ្នកដែលពាក់ព័ន្ធមក"]។

[691] ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣៤ KH 01083702 ["គេបានទៅសួរអ្នកទោស[ដែលស្ថិតនៅក្រោមការសួរចម្លើយនៅវត្តព្រះធាតុ]ថា អ្នកណាមានឈ្មោះត្រូវទៅសហករណ៍ខ្លះ"] ឆ.៨៧ KH 01083712 ["ដូចខ្ញុំនិយាយមុននេះ គេ[អ្នកសួរចម្លើយនៅវត្តព្រះធាតុ]សួរថា អ្នកណាខ្លះចង់ទៅសហករណ៍វិញ"]។

[692] ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូវ ឆ.៩៤ KH 01097765 ["ស៖ លោកថា គេសួរចម្លើយលោក។ តើគេសួរអ្វីខ្លះ? ឆ.៩៤៖ គេថា បើខ្ញុំថាខ្ញុំយកអង្ករ ៥០បាវមកហ្នឹង គេឲ្យរួចខ្លួនហើយ"]។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៦ KH 00963057 ["នៅពេលគេវាយសួរចម្លើយខ្ញុំ គេសួរថាតើខ្ញុំមានទាក់ទងជាមួយនឹងអ្នកណាខ្លះ? [...] គេប្រាប់ថាបើចង់ [ត្រឡប់ទៅសហករណ៍របស់សាក្សីវិញ] ប្រាប់ឈ្មោះអ្នកដែលពាក់ព័ន្ធមក"]។

នៃការសួរចម្លើយ រួមមាន ការវាយដំ[693] ការធ្វើឲ្យថប់ដង្ហើមដោយប្រើថង់ប្លាស្ទិក[694] ការបង្ខំឲ្យអ្នកជាប់ឃុំលេបអំបិលក្នុងចំនួនដ៏ច្រើន[695] និងការគំរាមកំហែងដោយអាវុធ[696]។ ការធ្វើបាបអ្នកទោសក្នុងពេលសួរចម្លើយ ជួនកាលបណ្តាលឲ្យមានរបួសជាអចិន្ត្រៃយ៍ ឬស្លាប់[697]។

---

[693] ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈៀន ឆ.៣៥ KH 01068053 ["ប្រសិនបើអ្នកជាប់ឃុំមិនព្រមឆ្លើយ [ទៅនឹងសំណួរដែលបានសួរក្នុងពេលសួរចម្លើយនៅវត្តព្រះធាតុ] ពួកគេនឹងវាយអ្នកជាប់ឃុំដើម្បីបង្ខំឲ្យឆ្លើយ"]។ ឯកសារ D219/87 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.១២ KH 01040112 ["ចំពោះរឿងធ្វើបាបនោះមានមែន។ ឧទាហរណ៍ អ្នកទោសធ្ងន់ពេលខ្លះ គឺក៏គេមានការវ៉ៃដំដែរ។ [...] ខ្ញុំនៅចម្ងាយប្រហែលជា ១០ម៉ែត្រ ពីកន្លែងដែល ព្រីង សួរអ្នកទោស។ ខ្ញុំមិនអាចឮថា ព្រីង និយាយអ្វីខ្លះជាមួយអ្នកទោសទេ ប៉ុន្តែពេលខ្លះខ្ញុំឃើញ ព្រីង ទះកំភ្លៀង ឬទាត់អ្នកទោស"]។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៧៩ KH 00788849 ["ពេលគេយកចេញពីកន្លែងគុក[វត្តព្រះធាតុ]មក គេសួរចម្លើយ ហើយពេលណាខ្ញុំឆ្លើយមិនចំចំណុចគេ គេវាយខ្ញុំ"]។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូវ ឆ.១៣, ១០២-១០៤ KH 01097758, 65-66។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៦-៧ KH 00963057។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១២៦ KH 01083718។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741589។ *សូមមើលផងដែរ* ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លីម រ៉ែន ឆ.៣១ KH 01047182។

[694] ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៨៦ KH 00788850 ["បើកាលណាយើងមិនឆ្លើយ [ទៅនឹងការសួរចម្លើយ] គេយកថង់ប្លាស្ទិកមកឃ្លុំមុខ ហើយបើ[នៅតែ]មិនឆ្លើយ គេឃ្លុំមុខរហូតដល់ថប់ដង្ហើមស្លាប់"]។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូវ ឆ.៩៤ KH 01097765 ["គេដាក់កៅស៊ូរុំក្បាលយើង ហើយសួរ[នៅវត្តព្រះធាតុ]"] ឆ.៩៩-១០១ KH 01097765។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៧ KH 00963057 ["[បុគ្គិលវត្តព្រះធាតុ] យកថង់ប្លាស្ទិកមករុំក្បាលខ្ញុំមិនឲ្យដកដង្ហើមចំនួន ២ ដង ហើយម្តងៗរយៈពេល ២ នាទី"] ឆ.១១ KH 00963058។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.២៦ KH 01083701។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741585, 89។

[695] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៥២ KH 00963065-66 ["អ្នកទោស[នៅវត្តព្រះធាតុ]ដែលត្រូវធ្វើទារុណកម្ម គេបង្ខំឲ្យហូបអំបិលប្រហែល ១ គីឡូ។ ខ្ញុំបានឃើញដោយផ្ទាល់។ ខ្ញុំក៏ត្រូវគេបញ្ជូកអំបិលដែរ។ ការបង្ខំឲ្យ[អ្នក]ហូបអំបិលគឺជាការធ្វើទារុណកម្មពេលគេសួរចម្លើយ។ មានអ្នកទោសពីរ ដែលជាប់នៅជិតខ្ញុំ ត្រូវបានបញ្ជូកអំបិលមួយគីឡូ ម្នាក់ៗ"]។

[696] ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូវ ឆ.៩៨ KH 01097765 ["ព្រីង និង ឈីន [...] កាន់កាំភ្លើងម្នាក់មួយ ដើមៗចាំក្នុងយើង"]។

[697] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៥២ KH 00963065-66 ["ការបង្ខំឲ្យ[អ្នក]ហូបអំបិលគឺជាការធ្វើទារុណកម្មពេលគេសួរចម្លើយ។ មានអ្នកទោសពីរ ដែលជាប់នៅជិតខ្ញុំ ត្រូវបានបញ្ជូកអំបិលមួយគីឡូម្នាក់ៗ ហើយនៅពេលយប់នោះ ក្រោយពីសុំទឹកខ្ញុំផឹកហើយ ក៏ស្លាប់ទៅភ្លាម"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៦៩ KH 00788835 ["ស្លាប់ម្នាក់ហើយ [អ្នកទោសនៅវត្តព្រះធាតុនៅជំនាន់សាក្សី] ស្លាប់ដោយសារហូរឈាមច្រើនពេក"]។ ឯក

205. លទ្ធផលនៃការសួរចម្លើយត្រូវបានធ្វើឡើងជាលាយលក្ខណ៍អក្សរ និងបញ្ជូនទៅឲ្យគណៈស្រុកគិរីវង់[698]។ អ្នកជាប់ឃុំជាញឹកញាប់ត្រូវបានគេសម្លាប់ចោល បន្ទាប់ពីការសួរចម្លើយ[699]។ ឧទាហរណ៍ សាក្សី អោក ចន និង ហោ យ៉ន បានរៀបរាប់យ៉ាងលម្អិតពីរបៀបដែលសមាជិកខ្មែរក្រោមនៃក្រុម "កន្ទ្បែងស" ប្រហែល៧០នាក់ ត្រូវបានសួរចម្លើយ និងបន្ទាប់មកត្រូវបានគេយកទៅសម្លាប់ នៅវត្តព្រះធាតុ[700]។

សារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូ រ ឆ.២១ KH 01097758។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741589។ *សូមមើលជាទូទៅ* ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714213។ *សូមមើលផងដែរ* ឯកសារ D219/111 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ឆោម ឆ.៣០-៣៦ KH 01045271-72។

[698] ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈ្យ៉ាន ឆ.៣៥ KH 01068053 ["ព្រីង និងឈឹម ជាអ្នកសួរចម្លើយអ្នកទោស [នៅវត្តព្រះធាតុ]។ ពួកគេសួរសំណួរហើយកត់ត្រាចម្លើយ និងធ្វើរបាយការណ៍ទៅស្រុក[គិរីវង់]។ ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៩៦ KH 01110214 ["[ព្រីង] រាយការណ៍[ចម្លើយរបស់សាក្សីពីការសួរចម្លើយ]ទៅថ្នាក់លើ គេឲ្យចម្លើយហ្នឹងទៅថ្នាក់លើ ហើយថ្នាក់លើគេមកដោះលែង អ្នកណាដែលគួរត្រូវដោះលែង"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១២, ២៣-២៦ KH 01083698, 00-01។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៨ KH 00963057 ["នៅក្នុងគុកនោះមានអ្នកកត់ត្រាយកចម្លើយម្នាក់ គឺឈ្មោះ ឌុក ចាន់ ជាអ្នកកត់ត្រា"] ឆ.១១ KH 00963058។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.៣១ KH 01047182-83។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូ រ ឆ.៩៩ KH 01097765។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741585, 89។

[699] *សូមមើល ឧទាហរណ៍* ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៦៨-៦៩ KH 00968095 ["គេបានយកអ្នកទោសទៅសួរចម្លើយ ហើយក្រោយមកទើបគេយកអ្នកទាំងនោះទៅសម្លាប់។ [...] ខ្ញុំដឹងថា អ្នកទោសត្រូវបានយកទៅសម្លាប់ក្រោយពេលសួរចម្លើយ ពីព្រោះខ្ញុំធ្លាប់នៅក្នុងគុក ដូច្នេះហើយទើបខ្ញុំដឹងអំពីរឿងនេះ"]។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.២៨ KH 00788845 ឆ.៣៤ KH 00788845។ ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៩៦ KH 01110214។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣០ KH 00963062 ["ពួកនារីៗដែលប្តីបានរត់ទៅវៀតណាម ត្រូវគេសួរចម្លើយ ហើយក្រោយមកអ្នកទោសស្រីទាំងនោះដែលមានផ្ទៃពោះនោះ ត្រូវបានចាក់សម្លាប់ដោយលំពែង។ ខ្ញុំបានឃើញការសម្លាប់ផ្ទាល់ភ្នែក គឺមុនរថគ្រោះវៀតណាមចូលមក"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១២៨ KH 01083718 ["សួរចម្លើយហើយ គេសម្លាប់[អ្នកទោសនៅវត្តព្រះធាតុ]ចោល"]។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741585។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714215-16។

[700] ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.២៩-៣១ KH 00788845 ["ស៖ តើមានរឿងអ្វីកើតឡើង នៅពេលដែលគេយកខ្មែរក្រោមមកដាក់នៅវត្តប្រធាតុនេះ? ឆ.២៩៖ គេយកមកសួរចម្លើយ ហើយក្រោយពីសួររួច គេយកទៅសម្លាប់។ ស ៖ តើលោកដឹងថា ខ្មែរក្រោមមានចំនួនប៉ុន្មាននាក់ដែរ? ឆ.៣០៖ ៧០នាក់"]។ ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោ

206. ខណៈមានអ្នកជាប់ឃុំខ្លះមិនបានឃើញអំពើហិង្សាផ្លូវភេទបានកើតឡើង[701] ហើយបុគ្គលិកនៅវត្តព្រះធាតុបានបដិសេធក៏ដោយ[702] ក៏សាក្សី ហោ យ៉ន បាននិយាយថា ក្នុងអំឡុងនៃការជាប់ឃុំឃាំងរបស់គាត់ អ្នកទោសស្ត្រីបានប្រាប់គាត់ថា ពួកគេគឺជាជនរងគ្រោះនៃអំពើហិង្សាផ្លូវភេទ និងការរំលោភសេពសន្ថវៈដែលបានប្រព្រឹត្តដោយបុគ្គលិកវត្តព្រះធាតុ[703]។ គាត់បានធ្វើការកត់សម្គាល់ថា

ក ចន ឆ.១២៣-១៣៣ KH 01110216-17 ["ស៖ តើមានទាហានខ្មែរកម្ពុជាក្រោមប៉ុន្ថានៅនាក់ [ដែលជាប់ឃុំនៅវត្តព្រះធាតុ]? ឆ.១២៣៖ ៧០នាក់។ [...] ឆ.១២៧៖ [ខ្មែរក្រោមជាប់ឃុំ]ប្រហែលជា១អាទិត្យ បន្ទាប់ពីសួរចម្លើយហើយគេយកទៅសម្លាប់"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៨៥, ១០៨ KH 00788837, 39 ["ស៖ តើលោកបានដឹងពីបញ្ហាឈ្លោះខ្មែរក្រោមដើម្បីយកទៅសម្លាប់ដែរទេ? ឆ.១០៨៖ ខ្ញុំដឹងថា គេយកអ្នកបកប្រែវៀតណាមមកក្នុងគុកនេះ[វត្តព្រះធាតុ]ដើម្បីសួរចម្លើយខ្មែរក្រោម ហើយ១០ថ្ងៃក្រោយមក គេយកអ្នកទោសខ្មែរក្រោមទៅសម្លាប់"]។

[701] ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១៨៩-១៩០ KH 01083727 ឆ.១៩៦-២០១ KH 01083728-29។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣៦-៣៧ KH 00963063។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.១០៣ KH 00788852។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.៦៨ KH 01102939។ ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៥៤ KH 01024582។

[702] ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈៀន ឆ.៣៥ KH 01068054។ ឯកសារ D219/87 កំណត់ហេតុ ស្តាប់ចម្លើយ ដុក ចាន់ ឆ.៨ KH 01040111។ *សូមមើលផងដែរ* ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣៧ KH 00963063។

[703] ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៧០-៧៥ KH 00788835-36 ["ស៖ តើអ្នកទោសស្រី[នៅវត្តព្រះធាតុ]ត្រូវបានគេធ្វើបាប ឬរំលោភដែរឬទេ? ឆ.៧០៖ អ្នកទោសស្រីដែលស្អាតគឺគេទុកសម្រាប់រំលោភ"] ឆ.៨២-៨៣៖ KH 00788837 ["ឆ.៨៣៖ អ្នកទោសស្រីដែលស្អាតៗនកទីនេះគេមិនដាក់គុកទេ ដោយសារអ្នកយាមទុករំលោភ ដូច្នេះស្រីៗនោះ មិនតែជាមួយអ្នកយាមទេ គឺបានទ្រាំឲ្យអ្នកយាមរំលោភដើម្បីរួចខ្លួនមិនជាប់ឃុំឃាំង"]។ ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៥, ៧-៨ KH 01099686-87 ["ឆ.៥៖ ពួកគេទុក១២នាក់ដែលស្អាតៗសម្រាប់រួមភេទ។ [...] ស៖ តើលោកដឹងថា វា[ការរំលោភផ្លូវភេទដែលលោកបានលើកឡើងនៅវត្តព្រះធាតុ] បានកើតឡើងនៅពេលណា ពេលគេចាប់លោកដាក់នៅទីនោះភ្លាម ឬពេលណាមួយ? ឆ.៧៖ ខ្ញុំដឹងពេលដែលខ្ញុំចេញពីគុកហើយ [គាត់ត្រូវគេបញ្ជូនមកឲ្យធ្វើការអប់រំ]។ ខ្ញុំដឹងរឿងនេះដោយសារខ្ញុំស្តាប់ឮស្ត្រីទាំងអស់នោះជជែកគ្នា។ ស៖ ពេលនោះ លោកនៅកន្លែងណា? ឆ.៨៖ ខ្ញុំឮគេជជែកគ្នានៅក្រោមដើមអំពិល ហើយខ្ញុំបានទៅហ្ចូប និងជជែកលេងជាមួយពួកគេដែរ"] ឆ.៩-១៣ KH 01099687។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៩៧, ៩៩-១០០, ១០៧-១០៨, ១១១-១២ KH 01068080, 81, 81-82។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.២៧-២៨ KH 01034066។

ជនរងគ្រោះនៃការរំលោភសេពសន្ថវៈ ជាចុងក្រោយ "ត្រូវបាត់ខ្លួន"[704]។ ហោ យ៉ន ក៏បានរៀបរាប់ផងដែរអំពីការវះពោះអ្នកទោសដែលនៅរស់ដើម្បីយកប្រមាត់[705]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

207. អ្នកជាប់ឃុំឃាំងត្រូវបានគេសម្លាប់នៅវត្តព្រះធាតុ យ៉ាងហោចណាស់ក៏ចាប់ពីឆ្នាំ១៩៧៦[706]។ ការសម្លាប់បានកើតឡើងក្នុងទ្រង់ទ្រាយធំ ដោយមានសាក្សីជាច្រើនបានរៀបរាប់ថា មានអ្នកជាប់ឃុំចន្លោះពី៨ទៅ១៥០នាក់ ត្រូវបានគេសម្លាប់ក្នុងពេលម្តងៗ[707]។ ការណ៍នេះបានកើតឡើងញឹកញាប់

---

[704] ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១០២-១០៤ KH 01068080 ["មាន[អ្នកទោសស្រីដែលត្រូវបានគេរំលោភនៅវត្តព្រះធាតុ]តែពីរបីនាក់ប៉ុណ្ណោះ ដែលអត់មានផ្ទៃពោះ ប៉ុន្តែគេសរុបទាំងអស់យកទៅសម្លាប់តែម្តង"]។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣៤ KH 01034067 ["ខ្ញុំមិនដឹងថា គេយកពួកស្រីៗទាំងនោះ ទៅសម្លាប់ដែរណាទេ ព្រោះគេយកទៅនៅពេលយប់។ ខ្ញុំគ្រាន់តែបានឃើញគេយកពួកស្រីទាំងនោះចេញទៅដោយពួកអ្នកយាមគុកដែលជាដៃគូស្នេហារបស់ពួកស្រីៗទាំងនោះតែម្តង គឺលើកលែងតែ ព្រឹង ទេ ដែលនៅប្រចាំការនៅគុក។ ប្រហែល ២ ម៉ោងក្រោយមក ពួកអ្នកយាមគុកទាំងនោះ ត្រឡប់មកវិញ ប៉ុន្តែអត់មានស្រីៗទាំងនោះមកវិញទេ ហើយខ្ញុំក៏មិនបានឮគេនិយាយអ្វីដែរ។ ខ្ញុំមិនដែលឃើញស្រីៗទាំងនោះទៀតទេ ហើយមិនដឹងថា សាកសពពួកស្រីទាំងនោះ នៅទីណាដែរ"]។ ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១៤ KH 01099687។

[705] ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៥ KH 01034061 ["ពួកគេ [យ៉ីម ទិត្យ និង តាណាំ] គ្រាន់តែនិយាយថា "ដោយសារយើងមានខ្ទែរច្រើន ថ្ងៃនេះ វះពោះ៣០ ទៅ" និងជួនកាលទៀត គេឲ្យមកយកមនុស្ស[អ្នកទោសនៅវត្តព្រះធាតុ] ៥, ១០ ឬ ១៥នាក់ ទៅវះពោះដើម្បីយកប្រមាត់"] ឆ.៨ KH 01034062។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣០-៣៣ KH 01068071 ["ស៖ នៅពេលដែលគេវះពោះអ្នកទោស[នៅវត្តព្រះធាតុ]យកប្រមាត់ តើអ្នកទោសស្លាប់ហើយ ឬក៏នៅរស់? ឆ.៣០៖ អ្នកទោសគឺនៅរស់ មិនទាន់ស្លាប់ទេ។ [...] ឆ.៣៣៖ [...] មានអ្នកទោសខ្លះស្លាប់នៅពេលដែលវះពោះ"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១៣ KH 00788830 ["តាទិត មកគុកទីនេះដើម្បីបញ្ជាឲ្យសម្លាប់អ្នកទោស។ តាទិត មកគុកនេះ[វត្តព្រះធាតុ] នៅពេលដែលអ្នកទោសមានចំនួនពេញគុក ហើយគេដឹករណ្តៅដើម្បីសម្លាប់អ្នកទោស និងកាត់យកប្រមាត់"]។ ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១៤ KH 01099689។

[706] *សូមមើលឧទាហរណ៍* ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤៥ KH 01034069 ["ក្នុងឆ្នាំ១៩៧៦ មានពួកកន្សែងស ៦៧នាក់ [...] ត្រូវបាននាំយកមកដាក់គុកនៅវត្តព្រះធាតុ មុននឹងគេយកទៅសម្លាប់"]។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លីម ងេន ឆ.៤០ KH 01047185 ["បន្ទាប់ពីខ្ញុំមកដល់មន្ទីរសន្តិសុខវត្តព្រះធាតុ ខ្ញុំមានឮតាមមនុស្សផ្សេងៗថាមានអតីតទាហានខ្មែរកម្ពុជាក្រោមចំនួន ៦០ ដែលត្រូវបានឡើងមកជួយខ្មែរយើង ហើយក៏បាត់ខ្លួនរហូតទៅ"]។

[707] ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣១-៣៤ KH 00788831-32 ["ស៖ តើគេសម្លាប់អ្នកទោសម្តងប៉ុន្មាននាក់ដែរ? ឆ.៣១៖ នៅពេលចំនួនអ្នកទោសពេញគុក គេយកទៅសម្លាប់ម្តង ៥០ ឬ១០០ ឬ១៥០នាក់។ ស៖ ក្នុងមួយយប់? ឆ.៣២៖ បាទ។ ស៖ តើគេចែកការសម្លាប់យ៉ាងដូចម្តេចទៅចំពោះការសម្លាប់អ្នកទោស១៥០នាក់? ឆ.៣៣៖ គេប្រមូលឈ្លបឃុំ និងអ្នកយាមនៅទីនេះ ១០នាក់ ឬ២០នាក់ ឬ៣០នាក់ ដើម្បីមកសម្លាប់អ្នកទោស។ ស៖ ដូច្នេះ លោកចង់និយាយថា អ្នកទោស

រហូតដល់មួយ ឬពីរដងក្នុងមួយសប្តាហ៍[708]។ អ្នកដែលត្រូវបានគេសម្លាប់រួមមាន ខ្មែរក្រោម[709] ប្រជាជន "១៧មេសា"[710] អ្នកដែលគេចាត់ទុកថាជាប់ពាក់ព័ន្ធនឹងវៀតណាម[711] ស្ត្រី(រួមទាំងស្ត្រី

១៥០នាក់ គឺគេសម្លាប់ក្នុងពេលតែមួយ? អ.ព.៤៖ បាទ។ ចំនួនអ្នកទោសដែលត្រូវសម្លាប់គឺទៅតាមផែនការដែលគេកំណត់"]។ ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន អ.ព.៣០ KH 00968090 ["ស៖ តើលោកឃើញផ្ទាល់ភ្នែក[ទ្ទូវការសម្លាប់អ្នកជាប់ឃុំ៣០នាក់ ពីវត្តព្រះធាតុ] ដែរឬទេ? អ.ព.៣០៖ បាទ ខ្ញុំឃើញផ្ទាល់ភ្នែករបស់ខ្ញុំ"]។ ឯកសារ D118/111 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន អ.២០ KH 00953860 ["ខ្ញុំឃើញមនុស្សប្រហែល ៣០ នាក់ ត្រូវគេយកទៅសម្លាប់នៅមុខវត្តប៉ែកខាងស្តាំ"] អ.២៤ KH 00953860។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ អ.៨២-៨៤, ៨៥, ៨៧ KH 01083711, 12 ["គេមិននាំចេញទៅទាំងអស់ទេ ជួនកាលម្តង១០នាក់ ៨នាក់ ឬក៏៩នាក់។ [...] គេយកចេញម្តង១០ ទៅ១២ នាក់។ មនុស្សទាំងអស់នេះច្បាស់ជាមិនរស់ទេ"]។

[708] ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន អ.៦៧-៦៨ KH 01024583 ["ខ្ញុំបានឃើញ [ការសម្លាប់អ្នកទោសនៅវត្តព្រះធាតុ] ជាញឹកញាប់៖ គឺក្នុង១អាទិត្យខ្ញុំឃើញម្តងទៅពីរដង តែខ្ញុំមិនប៉ាន់ទៅជិតកន្លែងសម្លាប់នោះទេ"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន អ.ព.៣០ KH 00788831 ["ស៖ តើលោកឃើញ [គេយកអ្នកទោសទៅសម្លាប់] ប៉ុន្មានដងដែរ? អ.ព.៣០៖ រាប់ដងមិនឈ្នះទេ"] អ.ព.១ KH 00788832។

[709] ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោ ចន អ.១២ព-១ព.ព KH 01110216-17 ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោ ចន អ.២៨ KH 00788845 អ.ព.៤ KH 00788845។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន អ.៨៤-៨៥, ១០៨-១០៩ KH 00788837, 39។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន អ.៤៥ KH 01034070 ។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ អ.១៥១-១៥២ KH 01083721។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន អ.៤០ KH 01047185។ ឯកសារ D219/247 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ អ.៤៨ KH 01082129-30។

[710] ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន អ.៦១-៦២ KH 00968075។

[711] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ អ.៣០ KH 00963062 ["ពួកនារីៗដែលប្តីបានរត់ទៅវៀតណាមត្រូវគេសួរចម្លើយ ហើយក្រោយមកអ្នកទោស្រីទាំងនោះ ដែលមានផ្ទៃពោះផងនោះត្រូវបានចាក់សម្លាប់ដោយលំបែង។ ខ្ញុំបានឃើញការសម្លាប់ផ្ទាល់ភ្នែក គឺមុនរថក្រោះវៀតណាមចូលមក។"] អ.ព.៥ KH 00963063 ["អ្នកទោសស្ត្រីទាំងនោះ [នៅវត្តព្រះធាតុ ត្រូវចាប់ខ្លួនដោយសារប្តីរបស់គេរត់ទៅវៀតណាម] ត្រូវគេយកទៅសម្លាប់"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ អ.១៨៨ KH 01083727 ["អ្នកទោស្រីម្នាក់ដែលមានប្តីរត់ទៅវៀតណាម និងមានកូនក្នុងពោះ៦ខែត្រូវគេយកទៅវ៉ៃសម្លាប់ចោល។"]។

មានផ្ទៃពោះ)និងកុមារ[712] ហើយនឹងអ្នកជាប់ឃុំដែលព្យាយាមរត់ចេញពីវត្តព្រះធាតុផង[713]។ មានអ្នកជាប់ឃុំខ្លះត្រូវបានសម្លាប់ភ្លាមៗ បន្ទាប់ពីការមកដល់របស់ពួកគេ ដោយគ្មានការសួរចម្លើយ[714]។ មានខ្លះទៀតត្រូវបានគេជ្រើសយកទៅសួរចម្លើយរួចហើយក៏សម្លាប់ចោលតែម្តង[715]។ អ្នកជាប់ឃុំ

---

[712] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣០ KH 00963062 ["ពេលខ្ញុំទៅដល់ [វត្តព្រះធាតុ] ខ្ញុំបានឮពួកឈ្លបនិយាយអំពីការសម្លាប់ស្ត្រី និងក្មេង។ [...] ស្ត្រីទាំងនោះ ដែលមានផ្ទៃពោះផងនោះត្រូវបានចាក់សម្លាប់ដោយលំពែង។ ខ្ញុំបានឃើញការសម្លាប់ផ្ទាល់ភ្នែក គឺមុនរថក្រោះវៀតណាមចូលមក។"] ឆ.៣៥ KH 00963063 ["គេ [អ្នកទោសស្ត្រី] ត្រូវចាប់ខ្លួន [និងឃុំនៅវត្តព្រះធាតុ] ដោយសារប្តីរបស់គេរត់ទៅវៀតណាម ឬអ្នកខ្លះទៀតត្រូវចាប់ដោយសារធ្វើការយឺតយ៉ាវ ឬធ្វើឲ្យបែកចានជាដើម។ អ្នកទោសស្ត្រីទាំងនោះត្រូវគេយកទៅសម្លាប់។ [...] ក្មេងៗដែលគេចមិនធ្វើការងារ ក៏ត្រូវបានពួកវាចាប់យកមកដាក់ក្នុងគុកនេះ [នៅវត្តព្រះធាតុ] ហើយក្រោយមកត្រូវសម្លាប់ដែរ។"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១៨៨ KH 01083727 ["ចំណែក យាយទ្ងូច ម្នាក់ទៀតត្រូវគេអូសក[ពីវត្តព្រះធាតុ]រហូតដល់ស្ពាន់"]។ ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១៤ KH 01099687 ["ស៖ លោកថាស្ត្រីទាំង១២នាក់នោះ នៅពេលណាមួយនោះ គេយកទៅសម្លាប់ចោលដែរ តើអ៊ីចឹងមែនទេ? ឆ.១៤៖ បាទ ពេលស្ត្រីនោះមានផ្ទៃពោះកាន់តែធំ គេយកទៅសម្លាប់ចោលព្រោះខ្លាចគេដឹង។"] ឆ.២៦-២៧ KH 01099688 ["ខ្ញុំដឹងថាពេលស្ត្រីនោះមានផ្ទៃពោះកាន់តែធំ គេយកទៅសម្លាប់ចោល ដើម្បីកុំឲ្យអ្នកផ្សេងដឹង។ [...] ប្រហែលជាគេខ្លាចថ្នាក់លើដឹង។ ដោយសារពួកគាត់ខ្លាចថ្នាក់លើគេដឹង ហើយសម្លាប់ពួកគាត់។"] ។ *សូមមើលផ្ទុយពីនេះ* ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៦៩ KH 01024583 ["ជនរងគ្រោះដែលខ្ញុំបានឃើញគឺសុទ្ធតែប្រុស ពុំមានមនុស្សស្រីនិងកុមារនោះទេ។"]។

[713] ឯកសារ D219/87 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.១៣ KH 01040112-13។ ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៣៣ KH 00968090-91 ឆ.៣៦ KH 00968091។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៨៧ KH 00788837។ ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៣១ KH 00891156-57។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/111 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ឆោម ឆ.៣៨ KH 01045272។

[714] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១៤ KH 00963059 [អ្នកទោសខ្លះមិនទាំងបានសួរចម្លើយផង គឺត្រូវយកទៅសម្លាប់តែម្តង]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.២៨ KH 01083701។

[715] *សូមមើលឧទាហរណ៍* ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៦៨-៦៩ KH 00968095 ["គេយកអ្នកទោសទៅសួរចម្លើយ ហើយក្រោយមកទើបគេយកអ្នកទាំងនោះទៅសម្លាប់។"]។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.២៩ KH 00788845 ["[បន្ទាប់មកខ្ញែរក្រហម] យកមកសួរចម្លើយ ហើយក្រោយពីសួររួច គេយកទៅសម្លាប់។"] ឆ.៣៤ KH 00788845 ["[ខ្ញែរក្រោម] ពេលដែលគេសម្លាប់ ពេលគេសួររួចហើយ ទើបគេយកមនុស្សទាំងនោះទៅសម្លាប់។"]។ ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.១២៧ KH 01110216។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៨៥ KH 00788837 ឆ.១០៨-១០៩ KH 00788839។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣០ KH 00963062 ["ពួកនារីៗ ដែលប្តីរត់ទៅវៀតណាម ត្រូវគេសួរចម្លើយ ហើយក្រោយមកអ្នកទោស្រីទាំងនោះ ដែលមានផ្ទៃពោះផងនោះត្រូវគេចាក់សម្លាប់ដោយលំពែង។"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១២៨ KH 01083718 ["[...] សួរចម្លើយហើយ សម្លាប់ចោល [អ្នកទោសនៅវត្តព្រះធាតុ]។"]។ ឯកសារ D1.3.10.21 របាយ

ដែលហ៊ានបញ្ជេញយោបល់ថា ខ្លួនចង់ត្រឡប់ទៅសហការណ៍វិញ ឬបានចោទប្រកាន់អ្នកផ្សេងថា បានប្រព្រឹត្ត "បទល្មើស"អ្វីមួយនៅពេលកំពុងសួរចម្លើយ ជននោះនឹងត្រូវបានសម្លាប់ចោល[716]។ អ្នកជាប់ឃុំក៏ត្រូវបានគេសម្លាប់ចោលដែរ ដោយសារតែគុកពេញ[717]។

ការណ៍ Henri Locard ភូមិភាគនិរតី KH 00741585។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា សម្រាប់ខេត្តតាកែវ KH 00714214។

[716] ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.២៣-២៤, ៣៣-៣៤, ៦០, ៨៧ KH 01083700, 02, 07, 12 ។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១៥, ១៨ KH 00963059។

[717] ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៨២ KH 01083711 ["នៅពេលដែលពេញទាំងបីរនង [នៅក្នុងមន្ទីរឃុំឃាំងនៅវត្តព្រះធាតុ] គេនឹងបញ្ជេញអ្នកទោសទៅសម្លាប់"] ឆ.៨៣-៨៤ KH 01083711 ឆ.១០០ KH 01083714 ["ភ័ត ច្រើន [អ្នកទោស] គេ [ខ្មែរក្រហម] យកចេញហើយគឺយកទៅសម្លាប់"]។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៨០ KH 01102940 ["ស៖ តើលោកនៅតែរក្សាចម្លើយដែលលោកនិយាយថា ពេលដែលគុកពេញ គឺតែងតែមានមនុស្ស បាត់ខ្លួន។ ម៉ែន ទេ? ឆ.៨០៖ បាទមែន"]។

208. ការសម្លាប់ត្រូវបានធ្វើឡើងដោយបុគ្គលិកវត្តព្រះធាតុ[718] និងសមាជិកនៃកងឈ្លបស្រុកនិងឃុំ[719]។ គណៈស្រុកគិរីវង់ជាអ្នកចេញបញ្ជាសម្លាប់ទៅឲ្យបុគ្គលិកវត្តព្រះធាតុ[720]។ សាក្សី អោក ចន ធ្លាប់បានឃើញ **យ៉ីម ទិត្ស** ជ្រើសរើសអ្នកទោសយកទៅសួរចម្លើយ និងសម្លាប់ក្នុងឆ្នាំ១៩៧៧[721]។ សាក្សី ហោ យ៉ន បានរៀបរាប់យ៉ាងលម្អិតពីរបៀបដែល **យ៉ីម ទិត្ស** បានបញ្ជាឲ្យសម្លាប់អ្នកទោសនៅពេលវត្តព្រះធាតុពេញ[722]។ យោងតាម ហោ យ៉ន **យ៉ីម ទិត្ស** បានចុះមកមើលវត្តព្រះធាតុ ដើម្បីកំណត់ផែនការសម្លាប់មនុស្សដែលគេបានបំពេញយ៉ាងឆាប់រហ័ស នាពេលបន្ទាប់ពីនោះ[723]។ អតីត

---

[718] ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៧៨-៨១ KH 0088836-37 ["[បុគ្គលិកវត្តព្រះធាតុផ្សេងទៀត] ហៅគាត់ [ចន] មកតែពេលគេសម្លាប់មនុស្សប៉ុណ្ណោះ។ [...] ខ្ញុំបានជួង [ចន]។ មកតែពេលយប់នៅពេលដែលគេសម្លាប់មនុស្ស ទេ [...] គាត់ជាអ្នកសម្លាប់មនុស្សហ្នឹងហើយ។ [...] ខ្ញុំបានឃើញគាត់ [ចន] ជីករណ្តៅ និងចូលរួមក្នុងការងារសម្លាប់មនុស្ស [នៅវត្តព្រះធាតុ]។"]។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៦០ KH 00968075។ ឯកសារ D118/111 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.២១-២២ KH 00953860 ["មេគុក។ ឈ្មោះ ឈីម [នាំអ្នកទោសទៅសម្លាប់នៅខាងស្តាំមុខវត្តព្រះធាតុ] [...] ពីរបីនាក់ [ក្រៅពី ឈីម]។ ម្នាក់ទៀត [ដែលបណ្តើរមនុស្សទៅសម្លាប់] គឺ ប៊ីន។"]។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.២៦, ៣០ KH 00963062 ។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៥២, ៥៩ KH 01083706-07។ ឯកសារ D219/110 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៥ EN 01045263 ["ប៊ីន ប្រើកាំបិតក្រង៉ុកដងវែងកាត់ផ្តាច់ករបស់ ភុន។ [...] បុគ្គលិកមន្ទីរសន្តិសុខមានវត្តមានដែរ"]។ សូមមើលផងដែរ ឯកសារ D123/2/1.18 បទសម្ភាសន៍របស់មជ្ឈបណ្ឌិតឯកសារកម្ពុជាជាមួយ អ្លង ផន KH 00740391។ សូមមើលផ្ទុយពីនេះ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.៣១ KH 01068052។

[719] ឯកសារ D219/87 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.១៣ KH 01040112-13 ["មានពេលមួយ មានអ្នកទោសម្នាក់បានបំបែកគុកឃុំឃាំង [វត្តព្រះធាតុ] រត់។ [...] [យើង] ហៅយោធាស្រុកមកជួយអន្តរាគមន៍ ដោយសារបុគ្គលិកមន្ទីរសន្តិសុខមានកាំភ្លើងសេកាសេ (CKC) តែពីរដើម។"]។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១២-១៤ KH 00963058-59 ["ពេលមានការសម្លាប់ច្រើន [នៅវត្តព្រះធាតុ] ពួកគេបានបញ្ជូនទ័ពពីស្រុក [គិរីវង់] មក។ ខ្ញុំមិនស្គាល់ទ័ពទាំងនោះទេ។ ពួកគេនោះជាឈ្លបស្រុក"]។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.៣១-៣៣ KH 01068052 ។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣៣ KH 00788832។ ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៦២-៦៣ KH 01024582។

[720] ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៨ KH 01034062។ ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣៨ KH 01099690។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៥៥ KH 00788847 ឆ.៩៥-៩៧ KH 00788851។ ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៥៨-៦៦ KH 00968094-95។

[721] ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៧៣, ៩៣-៩៨ KH 00788849, 51។ ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៦១ KH 00968094 ឆ.៦៨-៦៩ KH 00968095។

[722] ឯកសារD105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១២-១៦ KH 00788829-30 ឆ.២២-២៣, ២៧ KH 00788831។

[723] ឯកសារD105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១២-១៦ KH 00788829-30 ឆ.២២-២៣, ២៧ KH 00788831។

អ្នកជាប់ឃុំម្នាក់ឈ្មោះ ទន់ ស៊ីន បានរំឭកឡើងវិញថា អ្នកទោស“បានបាត់ខ្លួន” នៅពេល **យ៉ីម ទិត្យ** ឬសមាជិកដទៃទៀតនៃគណៈស្រុកគិរីវង់ បានចុះមកមើលគុកនេះ[724]។ សាក្សីដទៃទៀតក៏បានរៀបរាប់ស្រដៀងគ្នាដែរអំពីអ្នកទោស “បាត់ខ្លួន” និងការមិនបានឃើញពួកគេវិលត្រឡប់មកវិញ[725]។

[724] ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.៤៧-៥១ KH 01102936-37 ឆ.៦៣ KH 01102938។

[725] ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.២៧ KH 010344066 ឆ.៣៤ KH 010344067 [“ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនដឹងថាគេយកពួកស្រីៗទាំងនោះ ទៅសម្លាប់បែបណាទេ ព្រោះគេយកទៅនៅពេលយប់។ ខ្ញុំគ្រាន់តែបានឃើញគេយកពួកស្រីទាំងនោះ ចេញទៅ ដោយពួកអ្នកយាមគុកដែលជាដៃគូស្នេហារបស់ពួកស្រីៗទាំងនោះតែម្តង គឺលើកលែងតែព្រឹងទេ ដែលនៅប្រចាំការនៅគុក។ ប្រហែលជាពីរម៉ោងក្រោយមក ពួកអ្នកយាមគុកទាំងនោះត្រឡប់មមកវិញ ប៉ុន្តែអត់មានស្រីៗទាំងនោះមកវិញទេ ហើយខ្ញុំក៏មិនបានឮគេនិយាយអ្វីដែរ។ ខ្ញុំមិនបានឃើញស្រីៗទាំងនោះទៀតទេ ហើយមិនដឹងថាសាកសពពួកស្រីទាំងនោះនៅទីណាដែរ។”]។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១០២-១០៤ KH 00968081។ ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១៤ KH 01099687។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លីម ដេន ឆ.៤០ KH 01047185។ *សូមមើលផងដែរ* ឯកសារ D1.3.11.33 បទសម្ភាសន៍ ក.ស.ព ជាមួយ ង៉ែត ងយ EN 00219268 ។

209. អ្នកទោសត្រូវបានសម្លាប់នៅក្នុងបរិវេណវត្តព្រះធាតុ[726] ហើយទីតាំងសម្លាប់ស្ថិតនៅក្បែរនោះ[727]។ កាំបិត ដំបង គល់ឫស្សី ភ្លៅរទេះ និងអាវុធផ្សេងទៀត ត្រូវបានគេប្រើដើម្បីសម្លាប់មនុស្ស[728]។

---

[726] ឯកសារ D219/98 កំណត់ហេតុស្តាប់ចម្លើយ ម៉ម ស្ងួរ ឆ.៣៩-៤០ KH 01043260 ["ស៖ លោកបានបញ្ជាក់ថា ឪពុកម្តាយ បងប្រុសបង្កើតពីរនាក់ ប្អូនប្រុសម្នាក់ ត្រូវគេសម្លាប់នៅវត្តព្រះធាតុ ក្នុងឃុំគោកព្រៃច។ តើត្រឹមត្រូវដែរឬទេ? ឆ.៣៩៖ បាទ ត្រឹមត្រូវ"]។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៨ KH 00968068 ["ចំណែកឯអ្នកទោសនៅក្នុងគុក គឺពួកខ្មែរក្រហមទៅចាក់សម្លាប់ទាំងអស់ ប៉ុន្តែពួកខ្មែរក្រហមសម្លាប់មិនអស់ទេ។ ពេលដែលខ្ញុំទៅមើលគុកនោះ ខ្ញុំឃើញសុទ្ធតែឈាមពេញគុកតែម្តង។"]។ ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៥២ KH 01024582 ["មានមនុស្សរាប់រយនាក់ ត្រូវបានសម្លាប់នៅវត្តព្រះធាតុ។"]។ ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៩ KH 00905848។ ឯកសារ D219/87 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.១ KH 01040110។ ឯកសារ D118/23 កំណត់ហេតុស្តាប់ចម្លើយ តិម ផល ឆ.៣៥ KH 00891162។ ឯកសារ D219/110 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៤-៥ KH 01045262-63។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៤៨ KH 01083705។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.២៦ KH 00963062។ *សូមមើលផងដែរ* ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤៥ KH 01099690។

[727] ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៦១-៦២ KH 01083708 ["អ្នកទោស១២នាក់ដំបូង ត្រូវគេយកទៅសម្លាប់នៅដីទួលមួយ ដែលឆ្លងប្រឡាយ ហើយនៅខាងក្រោយនិងខាងកើតគុក [វត្តព្រះធាតុ]។"] ឆ.១២៩-១៣៦ KH 01083718-19 ["[អ្នកទោសនៅវត្តព្រះធាតុ] ត្រូវសម្លាប់បីកន្លែង ទីមួយ ទួលគោកត្របែក ទី២ ទួលដើមក្រសាំង និងកន្លែងទី៣ មានចម្ងាយប្រហែល ១០០ ម៉ែត្រពីគុក ហើយនៅក្នុងបរិវេណគុកតែម្តង។ [...] [ទួលគោកត្របែក] នៅខាងជើងគុក ហើយមានចម្ងាយប្រហែល ២០០ម៉ែត្រ។ [...] [កន្លែងទីបីត្រូវបានកំណត់អត្តសញ្ញាណ] នៅខាងកើតគុក ដោយឆ្លងប្រឡាយ ហើយមានមានទួលមួយនៅទីនោះ។ [...] ទួលដើមក្រសាំងមានចម្ងាយប្រហែល២៥០ម៉ែត្រ ពីកន្លែងឃុំឃាំង ហើយនៅទិសខាងត្បូង។ [...] កន្លែងសម្លាប់ផ្សេងទៀតនៅឆ្ងាយពីគុក គឺនៅតាមជំរៀលភ្នំ [...] ភ្នំអណ្តូងដើមខ្ទុរ [...] ភ្នំនេះនៅភូមិព្រៃជើង ហើយនៅឆ្ងាយពីគុក នៅទិសខាងលិចគុក។ [...] [វត្តព្រះធាតុ] ប្រហែល១គីឡូម៉ែត្រ [ពីភ្នំនោះ]។"]។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៨០-៨១ KH 00788850 ["គេយកទៅសម្លាប់នៅខាងកើត និងខាងត្បូងវត្ត គឺនៅនឹងវាលស្រែតែម្តង។ [...] ដូចថាអញ្ចេះ ពេលដែលគេដោះលែងខ្ញុំហើយ ខ្ញុំបានឃើញគេយកទៅសម្លាប់ នៅកន្លែងវាលស្រែខាងត្បូងវត្ត។"] ឆ.៨២ KH 00788850 ។ ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៣១, ៤៤-៤៦ KH 00968090-92។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.២៨-២៩, ៣៦ KH 00788831-32។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១១៥ KH 00968082។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤៥ KH 01034070 ។ ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៥៧-៦០ KH 01024582 ឆ.៦៥ KH 01024583។ ឯកសារ D118/111 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.២៤-២៥ KH 00953860។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូវ ឆ.៣០ KH 01097759។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៨១ KH 01102940។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714213-14។

[728] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.២៦ KH 00963062 ["អ្នកទោសប្រហែលជា ១២នាក់ ដែលនៅសល់ ត្រូវបានសម្លាប់ក្នុងគុក [វត្តព្រះធាតុ] ដោយកាប់នឹងកាំបិតខ្វែ"] ឆ.៣០ KH 00963062 ["[អ្នកទោសស្រីនៅវត្តព្រះ

មានអ្នកជាប់ឃុំខ្លះបានស្លាប់ពេលគេកំពុងវះយកប្រមាត់[729] ឬត្រូវកាត់កបន្ទាប់ពីនោះ[730]។ ចំណែកអ្នកខ្លះទៀតត្រូវបានគេកប់ទាំងរស់[731]។

ធាតុ] ដែលមានផ្ទៃពោះផងនោះ ត្រូវបានចាក់សម្លាប់ដោយលំពែង"]។ ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៥២ KH 01083706 ["[អ្នកយាមនៅវត្តព្រះធាតុ] យកកាំបិតទៅកាប់ក [អ្នកទោស] តែម្តង។"]។ ឯកសារ D219/110 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.៤-៥ KH 01045263 ["ប៊ីន ប្រើកាំបិតក្រង៉ុកដងវ៉ែងកាត់ផ្តាច់ករបស់ ភុន [អ្នកទោសនៅវត្តព្រះធាតុ]។"]។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.២៦-២៩ KH 01102934-35 ["ប៊ីន ភ៉ីម និងព្រីង បានភ្ជាល់គ្នាកាត់ក្បាលមនុស្សម្នាក់ឈ្មោះ ភុន ឲ្យដាច់ត្រឹមមួយកាំបិត ប៊ីន និយាយថាគាត់អាចធ្វើបាន ហើយបន្ទាប់មកគាត់ក៏បានកាប់ ដាច់ដូចគាត់ថាមែន"]។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៣៥ KH 00788845 ["[ការសម្លាប់ទាំងនោះ [នៅវត្តព្រះធាតុ] មិនមែនដោយប្រើអាវុធទេ គេប្រើគល់ដំបង ឬគល់ឫស្សី"]។ ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៣០ KH 00968090 ["ស៖ នៅក្នុងឯកសារសម្ភាសន៍ [ឯកសារ D1.3.11.2] [...] លោកបាននិយាយថា 'ក្នុងម្តងៗគេយកមនុស្ស ៣០នាក់ ទៅសម្លាប់ ដោយគេវ៉ៃសម្លាប់នឹងបន្ទុះដែក។' តើលោកឃើញដោយផ្ទាល់ផ្នែកដែរឬទេ? ឆ.៣០៖ បាទ ខ្ញុំឃើញដោយផ្ទាល់ផ្នែករបស់ខ្ញុំ"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.២៨-២៩ KH 0088831 ["ឆ.២៨៖ គេប្រើតែភ្លៅរទេះ និងគល់ឫស្សីវាយ[អ្នកទោសវត្តព្រះធាតុ]សម្លាប់។"]។ ឯកសារ D118/111 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.២៥ KH 00953860 ["ខ្ញុំឃើញគេបណ្តើរទៅ និងវាយដោយភ្លៅរទេះ ដោយគ្មានក្តីមេត្តា"]។ *សូមមើលផងដែរ* ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៦៦-៦៧ KH 01024583។

[729] ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣០-៣៣ KH 00968071-72។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៥ KH 01034061 ["[ឃ៉ីម ទិត្យ និង គាណាំ] គ្រាន់តែនិយាយថា 'ដោយសារយើងមានខ្ទាំងច្រើន ថ្ងៃនេះ វះពោះ ៣០ទៅ' និងជួនកាលទៀត គេឲ្យមកយកមនុស្ស ៥, ១០ ឬ១៥នាក់ ទៅវះយកប្រម៉ាត់។"] ឆ.៨ KH 01034062។ ឯកសារ D219/326 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣២ KH 01099689 ["គេយកអ្នកទោសទៅវះនៅចម្ងាយប្រហែល ៥០ម៉ែត្រពីគុក [វត្តព្រះធាតុ]។"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១៣ KH 00788830។

[730] ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣០-៣៣ KH 00968071-72 ["ស៖ នៅពេលដែលគេវះពោះ អ្នកទោសយកប្រម៉ាត់ [នៅវត្តព្រះធាតុ] តើអ្នកទោសស្លាប់ហើយ ឬក៏នៅរស់? [...] ឆ.៣៣៖ មានអ្នកទោសខ្លះស្លាប់នៅពេលដែលវះពោះ ហើយចំពោះអ្នកណាមិនទាន់ស្លាប់ គេនឹងយកកាំបិតមកអូសកាត់កម្តងទៀត"]។

[731] ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤០ KH 00968073 ["ពួកគេមិនសម្លាប់អ្នកទោស [វត្តព្រះធាតុ] នោះទេ គឺគេរុញទម្លាក់ ហើយបន្ទាប់មកគេយកដុំថ្មទម្លាក់ចុះទៅ។"]។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.២៥ KH 01034065 ["គេកប់អ្នកទោស [វត្តព្រះធាតុ] ៤០នាក់ ទាំងនោះទាំងរស់ ដោយយកថ្មសង្កត់ពីលើមុននឹងកប់"]។

210. សាកសពជនរងគ្រោះត្រូវបានគេបោះចូលក្នុងរណ្តៅកប់សពនៅទីតាំងសម្លាប់មនុស្ស ឬនៅក្បែរ ទីតាំងនោះ[732]។ ការរៀបរាប់អំពីចំនួន និងទំហំនៃរណ្តៅកប់សព[733] ព្រមទាំងចំនួនសាកសពដែលគេ

---

[732] ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣៧-៣៨ KH 00968072 ["ឆ.៣៧៖ រណ្តៅនេះស្ថិតនៅខាងត្បូងឈរខាងកើតវត្តព្រះធាតុ ហើយរណ្តៅនេះមានទំហំធំ"]។ ឯកសារ D118/155.1 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឧបសម្ព័ន្ធ៖ ដ្យាក្រាម ក.ស.ព អំពីវត្តព្រះធាតុ EN 00968084 [ការរៀបរាប់អំពីដ្យាក្រាមបរិវេណវត្តព្រះធាតុ៖ "រណ្តៅកប់សពខាងកើតបរិវេណវត្ត។"]។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១២ KH 01034063។ ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១៦ KH 00963059 ["នៅចុង ១៩៧៩ ពេលមានការវាយប្រហារដោយរថក្រោះរបស់វៀតណាម ពេលនោះគេបានជីករណ្តៅធំៗដើម្បីកប់ខ្មោចទាំងនោះ [នៃអ្នកទោសវត្តព្រះធាតុ]។"] ឆ.២៧ KH 00963062 ["ស៖ តើលោកកប់ខ្មោចទាំង ១២ នោះទៅទីណា? ឆ.២៧៖ នៅលើខ្នងប្រឡាយខាងកើតគុក។"] ឆ.៣១ KH 00963063 ["នៅម្តុំបរិវេណវត្ត [ព្រះធាតុ] មានរណ្តៅប្រហែល ៣០រណ្តៅ"]។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៨៣-៨៤ KH 00788850 [អ្នកជាប់ឃុំនៅវត្តព្រះធាតុក្នុងឆ្នាំ១៩៧៧៖ "មុនដំបូងគេចាប់ចេញពីគុក។ ហើយ [...] គេយកទៅកន្លែងដែលគេជីកអន្លង ហើយគេសម្លាប់ [...] ដូចថាគេជីកអន្លង្គបួនជ្រុង [...] [អ្នកទោស] គេវាយនឹងគប់ឫស្សី ទម្លាក់ចូលអន្លង្គនោះតែម្តង។"]។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.៣២ KH 01047183 ["ពេលដែលខ្ញុំមកដល់ [វត្តព្រះធាតុ] ខ្ញុំបានឃើញរណ្តៅកប់ខ្មោចនៅជិតៗនោះ។"]។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូរ ឆ.១១៧ KH 01097767 ["ស៖ តើលោកមានដឹងថានៅក្បែរគុកហ្នឹង មានរណ្តៅសាកសពនៅជិតគុក [វត្តព្រះធាតុ] ហ្នឹងទេ? ឆ.១១៧៖ មាន មិនខ្វះទេ។"]។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.៤៥ KH 01068054-55 ["រណ្តៅទាំងនោះមានចម្ងាយ ៣០០ ទៅ៤០០ម៉ែត្រ ខាងកើតវត្ត [ព្រះធាតុ]។"]។ ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៥៧-៦០ KH 01024582 ["ខ្ញុំបានឃើញគេនាំអ្នកទោសចេញពីវត្តព្រះធាតុទៅទួលកុងកៅ ហើយសម្លាប់ទម្លាក់ដាក់ចូលក្នុងរណ្តៅនៅទីនោះ។"]។ ឯកសារ D219/529 កំណត់ហេតុនៃកិច្ចស៊ើបសួរ ចម្លើយរបស់ លី ឈួន KH 01443396។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៨៣-៨៤ KH 00788850។ ឯកសារ D3/22 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងវត្តព្រះធាតុ KH 00712691-93។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714214។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគនិរតី* KH 00741587-88។ *សូមមើលផងដែរ* ឯកសារ D123/2/1.18 បទសម្ភាសន៍របស់មជ្ឈបណ្ឌិតឯកសារកម្ពុជាជាមួយ អ្លង ផន KH 00740391 ។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤០-៤២ KH 00788832-33។

[733] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣១ KH 00963062-63 ["ឃើញមានរណ្តៅធំៗ ដែលមានអ្នកទោសស្លាប់យ៉ាងច្រើន។ នៅម្តុំបរិវេណវត្ត [ព្រះធាតុ] មានរណ្តៅប្រហែល ៣០រណ្តៅ។ រណ្តៅមធ្យមមានទទឹងមួយម៉ែត្រកន្លះ និងបណ្តោយ ពីរ ម៉ែត្រ។ រណ្តៅធំមានបណ្តោយ ៣ម៉ែត្រ និងទទឹង ៣ម៉ែត្រ និងជម្រៅប្រហែល ១ម៉ែត្រ។"]។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣៧-៣៨ KH 00968072 ["រណ្តៅ [ជិតវត្តព្រះធាតុ] មានទំហំធំ [...] មានទំហំប្រហែលជា ៤ទី៥ម៉ែត្រ ហើយមានជម្រៅមួយជំហរមនុស្ស។"]។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714214។ *សូមមើលផងដែរ* ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.៤៥ KH 01068054-55។

បានកប់នៅទីនោះ[734] មានភាពខុសគ្នា។ សាក្សីបានធ្វើការប៉ាន់ប្រមាណថា មានលលាដ៍ក្បាលចំនួនចន្លោះពី ៩០០ ទៅ ១,៧០០ ត្រូវបានគេជីកកាយចេញពីទីតាំងកប់សពនៅក្នុង និងជុំវិញវត្តព្រះធាតុ[735]។ ការជីកកកាយតំបន់ទាំងនេះមិនទាន់ចប់ទាំងស្រុងទេ[736]។ ដោយមានការយកចិត្តទុកដាក់

---

[734] ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.១៨៥-១៨៦ KH 01083726 ["ស៖ ចុះចំពោះអ្នកដែលជាប់ឃុំនៅ [វត្តព្រះធាតុ] មន្ទីរសន្តិសុខ តើមានរណ្តៅណាដែលគេជីកយកសាកសពអ្នកទាំងអស់នោះដែរឬទេ? ឆ.១៨៥៖ បាទគ្រប់រណ្តៅទាំងអស់ ទាំងរណ្តៅនៅវត្តព្រះធាតុផងដែរ។ [...] ឆ.១៨៦៖ ខ្ញុំមិនដឹងទេ [ថាមានអ្ហ៊ីងសាកសពជនរងគ្រោះប៉ុន្ឌានៅវត្តព្រះធាតុ]។ មានច្រើនណាស់។"]។ ឯកសារ D118/111 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.១៨-១៩ KH 00953860 ["ឆ.១៨៖ មួយរណ្តៅមានមនុស្សស្លាប់បី ឬន ឬរហូតដល់ ៣០ នាក់។ ស៖ ចុះម្តេចបានដឹងអំពីមនុស្សស្លាប់ក្នុងមួយរណ្តៅស្លាប់ ៣០នាក់? ឆ.១៩៖ ខ្ញុំមើលគោនៅទីនេះ។ ខ្ញុំឃើញគេបណ្តើរអ្នកទោសទៅសម្លាប់។"]។ ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៩-១០ KH 01024577 ["ស៖ [...] ហាក់ដូចជា[លោក] បានបញ្ជាក់ថា 'នៅជិតវត្តព្រះធាតុមានរណ្តៅកប់សាកសពមួយចំនួន និងមានជនរងគ្រោះដែលត្រូវបានគេសម្លាប់នៅក្បែរនោះប្រហែលជា ៥០០០ ទៅ ៦០០០នាក់។' តើលោកបានឆ្លើយដូច្នេះដែរឬទេ? ឆ.៩៖ បាទ ខ្ញុំបានឆ្លើយដូច្នេះ គឺមានជនរងគ្រោះច្រើនណាស់ដែលត្រូវគេសម្លាប់។ នៅក្នុងរណ្តៅនីមួយៗមានសាកសពប្រហែល៨០នាក់ ហើយសុទ្ធតែជាខ្មែរសេរី។"]។ *សូមមើលផងដែរ* ឯកសារ D123/2/1.18 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ្ហ៊ង ផន KH 00740391។ ឯកសារ D1.3.10.21 របាយការណ៍របស់ Henri Locard *ភូមិភាគឧត្តរ* KH 00741587-88។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714214។

[735] ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៣៣ KH 00891157 ["ក្រោយឆ្នាំ១៩៧៩ មេឃុំបានឲ្យអ្នកដែលជាជនដៃដល់ មានដូចជា តាប៊ិន តាព្រ៊ីម និងតាចាន់ ជាដើម ទៅគាស់រណ្តៅសាកសព ហើយកាលណោះគាស់បានប្រហែល ៩០០ លលាដ៍ក្បាល [ចម្ងាយមួយរយម៉ែត្រពីរបងវត្តព្រះធាតុ]។"]។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៧២-៧៧ KH 01102939 ["នៅពេលដែលគេជីកខ្ញុំឃើញក្បាលខ្មោចច្រើន ខ្ញុំសូមបញ្ជាក់ថា តាម៉ុក គាត់ជាមេឃុំ នៅក្នុងសម័យ ១៩៧៩ ហ្ម៊ីង តាម៉ុក បានបញ្ជា ឲ្យតាប៊ិន ព្រ៊ីម ព្រ៊ីង ជីករណ្តៅនៅទីនោះ ហើយឃើញក្បាល់ខ្មោចប្រហែល ៨០០ ទៅ ៩០០ ក្បាលខ្មោច។"]។ ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣៩ KH 00788832 ["កាលណោះខ្ញុំរាប់មានចំនួន ១៧០០ក្បាល តែរាប់មិនទាន់អស់ទេ នៅសល់ជាងពាក់កណ្តាលទៀតមិនបានរាប់ទេ ព្រោះច្រើនពេក។"]។ ឯកសារ D118/155 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.១១៣-១១៤ KH 00968082 ["ខ្ញុំរាប់ [លលាដ៍ក្បាល ១៧០០ នោះនៅវត្តព្រះធាតុ] នៅឆ្នាំ ១៩៨១។ [...] [១៧០០] គ្រាន់តែជាលលាដ៍ដែលយើងប្រមូលពីរណ្តៅមកតែប៉ុណ្ណោះ ចំពោះលលាដ៍ផ្សេងទៀតដែលនៅក្នុងព្រៃ គឺមិនបានរាប់នោះទេ។"]។ *សូមមើលផងដែរ* ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៩ KH 00905849 ឯកសារ D118/303 កំណត់ហេតុស្តាប់ចម្លើយ លី ឈួន ឆ.៥២ KH 01024581។ ឯកសារ D219/316 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ង៉ូយ ឆ.១១៧ KH 01097767។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714213-14។ ឯកសារ D123/2/1.18 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អ្ហ៊ង ផន KH 00740385-86។

[736] ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៣៣ KH 00891157["ក៏មេឃុំបញ្ឈប់ការគាស់រណ្តៅនោះទៅ"]។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៧៧ KH 01102940 ["ការជីកនេះ គឺជីកមិនអស់ទេ [ជិតវត្តព្រះធាតុ]។"]។ ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៣៣ KH 00891157។ ឯកសារ D118/112 កំណត់ហេតុ

ចំពោះការស្លាប់ដោយលក្ខខណ្ឌអមនុស្សធម៌[737] និងការសម្លាប់ គេអាចប៉ាន់ប្រមាណដោយបន្ថយចំនួនឱ្យទាបបំផុតថា យ៉ាងហោចណាស់អ្នកទោស ៩០០នាក់ ត្រូវបានសម្លាប់នៅវត្តព្រះធាតុ។

<u>ការធ្វើទុក្ខបុកម្នេញ</u>

211. ការធ្វើទុក្ខបុកម្នេញត្រូវបានប្រព្រឹត្តឡើងនៅវត្តព្រះធាតុ តាមរយៈឧក្រិដ្ឋកម្មនានាដូចបានរៀបរាប់ខាងលើប្រឆាំងនឹងខ្មែរក្រោម សមាជិកនៃអតីតរបប លន់ នល់ និងប្រជាជន "១៧មេសា"។ ខ្មែរក្រោម សមាជិកនៃអតីតរបប លន់ នល់ និងប្រជាជន "១៧មេសា" ទាំងនេះ ត្រូវបានកំណត់គោលដៅចំៗ ដោយសារតែសមាជិកភាពនៃក្រុមនយោបាយពិតប្រាកដ ឬតាមការសន្ធតរបស់ពួកគេ[738]។

v. ឧក្រិដ្ឋកម្មដែលបានស្នើឲ្យបញ្ជូនទៅជំនុំជម្រះ

212. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខវត្តព្រះធាតុ[739]ៃ អំពើប្រល័យពូជសាសន៍ក្រុមជាតិសាសន៍វៀតណាមនៅកម្ពុជា (ជាពិសេស ខ្មែរក្រោម)[740] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការ

ស្ថាប់ចម្លើយ រ៉ែន ណាត់ ឆ.៤ KH 00963057 ឆ.៣១ KH 00963063។ ឯកសារ D219/248 កំណត់ហេតុស្ថាប់ចម្លើយ រ៉ែន ណាត់ ឆ.១៨៦ KH 01083726។ ឯកសារ D105/6 កំណត់ហេតុស្ថាប់ចម្លើយ ហោ យ៉ន ឆ.៣៩ KH 00788832។ ឯកសារ D118/155 កំណត់ហេតុស្ថាប់ចម្លើយ ហោ យ៉ន ឆ.១១៣-១១៥ KH 00968082។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ខេត្តតាកែវ KH 00714215-16។

[737] *សូមមើល* V.ក.1.ក.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់ ១៣ – មន្ទីរសន្តិសុខវត្តព្រះធាតុ – ឧក្រិដ្ឋកម្ម – អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។

[738] *សូមមើល* VIII.ខ.1.ក. ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយខ្ពាំង។

[739] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ រូបគាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះមាន៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ប្រឆាំងនឹងអតីតសមាជិករដ្ឋាភិបាល លន់ នល់ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរំលោភសេពសន្ថវៈ និងការបាត់ខ្លួនដោយបង្ខំ) និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ប្រឆាំនឹងជនជាតិវៀតណាម។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះដោយ៖ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីបីរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ឯកសារ D1 ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១២-១៣។

[740] *សូមមើល* V.គ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម។

ធ្វើមនុស្សឃាត ការសម្លាប់រង្គាល[741] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹង "ប្រជាជន ១៧ មេសា" អតីតមន្ត្រី លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកនៅក្រោមបង្គាប់ ខ្មែរក្រោម និងជនជាតិវៀតណាម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរំលោភសេពសន្ថវ: ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ) ។

ខ. ទីកតាំងសម្លាប់មនុស្សវត្តអង្គុញ

i. សេចក្ដីផ្ដើម

213. ទីកន្លែងសម្លាប់មនុស្សវត្តអង្គុញ ("វត្តអង្គុញ") ស្ថិតនៅក្នុងស្រុកគីរីវង់នៃតំបន់១៣ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ កងកុមារ និងកងយុវជនស្រុក រួមមាន "ប្រជាជនថ្មី" ខ្មែរក្រោម និងក្រោយមក នៅដើមឆ្នាំ១៩៧៨ មានប្រជាជនជម្លៀសខ្មែរក្រោមមកពីវៀតណាមរស់នៅក្នុងវត្តនេះ។ សមាជិកខ្លះនៃកងទាំងនេះត្រូវបានសម្លាប់ ឬបានបាត់ខ្លួន ដោយសារមូហេតុស្ថានភាពនយោបាយខ្មែរក្រោមរបស់ពួកគេ ឬដោយសារមានលក្ខណៈជាខ្មាំងរបស់ ប.ក.ក ផ្សេងៗទៀត។ តំបន់នៅក្នុងបរិវេណវត្តនោះ ក៏ត្រូវបានប្រើជាទីកន្លែងសម្លាប់មនុស្ស ដែលជា "ប្រជាជនថ្មី" ខ្មែរក្រោម និងប្រជាជនជម្លៀស ឬ សមាជិកកង ដែលស្នាក់នៅក្នុងវត្តនោះ។

214. **យ៉ឹម ទិត្យ** បានអនុវត្តសិទ្ធិអំណាចនៅវត្តអង្គុញ ក្នុងឋានៈជាអនុលេខា និងក្រោយមក ជាលេខានៃគណៈស្រុកគីរីវង់ ហើយបន្ទាប់មកទៀត ជាសមាជិកឈានមុខនៃគណៈតំបន់១៣ (យ៉ាងហោចណាស់នៅដើមឆ្នាំ១៩៧៨) និងសមាជិកនៃ JCE។ **យ៉ឹម ទិត្យ** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅទាំងក្នុង និងក្រៅបរិវេណនៃវត្តអង្គុញ ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ។

215. ស.ច.ស.អ បានចោទប្រកាន់ **យ៉ឹម ទិត្យ** ពីឧក្រិដ្ឋកម្មនានាទាក់ទងនឹងទីតាំងសម្លាប់មនុស្សវត្តអង្គុញ ដូចតទៅ៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត

---

[741] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលចំពោះឧក្រិដ្ឋកម្មសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងសម្រាប់តែវត្តព្រះធាតុតែឯងប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលតម្រូវដើម្បីបញ្ជាក់ពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីកន្លែងសម្លាប់ទាំងអស់ និងទីតាំងការងារដោយបង្ខំ រួមទាំងវត្តព្រះធាតុផងនោះ ត្រូវលើកយកមកពិចារណាបញ្ចូលគ្នា។ ទីតាំងទាំងអស់គឺជាផ្នែកនៃប្រព័ន្ធរៀបចំមួយ ដែលបានអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង និងការសម្លាប់នៅតាមទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងនេះ ត្រូវបានជួយសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចគ្នារបស់ យ៉ឹម ទិត្យ។

ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញលើពួកខ្មែរក្រោមដោយមូលហេតុនយោបាយ និងពូជសាសន៍ អំពើបំពានរបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្ស៊ីណែវឆ្នាំ១៩៤៩ (ការសម្លាប់ដោយចេតនា) ហើយនិងឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតដោយគិតទុកជាមុន នៅក្រោមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[742]។

ii. ប្រតិបត្តិការ និងទីតាំង

216. វត្តអង្គុញត្រូវបានប្រើប្រាស់ចម្បង ជាកន្លែងសម្រាប់ស្នាក់អាស្រ័យរបស់កងយុវជន និងកងកុមារ ប.ក.ក របស់ស្រុកគីរីវង់ រហូតដល់ការរលំដួលនៃរបបកម្ពុជាប្រជាធិបតេយ្យ[743]។ ភាគច្រើននៃសមាជិកនៃកងទាំងនេះគឺជាខ្មែរក្រោម។ ខណៈដែលខ្មែរក្រោមខ្លះមានវត្តមានតាំងពីមុនយូរមកហើយ ប្រជាជនជម្លៀសខ្មែរក្រោមមួយចំនួនធំមកពីវៀតណាមបានមកដល់ស្រុកនេះ នៅក្រោយចុងឆ្នាំ១៩៧៧[744]។ កងនានាត្រូវបានបែងចែកតាមភេទ ដោយពួកវ័យជំទង់ធំៗត្រូវបានចាត់តាំងឲ្យ

---

[742] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ឹម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426545, 48-49, 58។

[743] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៦៩ KH 00993601 ["វត្តអង្គុញជាកងរបស់យុវជន"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១២៦ KH 00987241 ["ក្មេងៗស្រី (កុមារ) និងប្រុសត្រូវគេដាក់នៅក្នុងវត្តអង្គុញ"] ឆ.១២៨ KH 00987241 ["ស៖ នីវត្តអង្គុញ តើលោកស្រីស្គាល់អ្នកណាម្នាក់ ឬក៏គ្រួសារណាដែលត្រូវគេបញ្ជូនទៅវត្តអង្គុញហើយធ្វើបាប និងសម្លាប់នៅទីនោះដែរឬទេ? ឆ.១២៨៖ ខ្ញុំមិនស្គាល់ទេ។ តែខ្ញុំដឹងថា កុមារ និងមនុស្សវ័យជំទង់ដែលជាខ្មែរក្រោមត្រូវគេយកទៅដាក់នៅក្នុងវត្តអង្គុញនេះ។ គេពុំដាក់មនុស្សទាំងអស់នេះឲ្យនៅកន្លែងតែមួយនោះទេ ឧទាហរណ៍ថា មនុស្សប្រុសនៅក្នុងវិហារ មនុស្សស្រីនៅកន្លែងផ្សេង ហើយគេឲ្យអ្នកទាំងនោះធ្វើការ"]។ ឯកសារ D219/482 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែប ឆ.២៤, ៣៦ KH 01136306, 07 ["ស៖ ក្មេងៗទាំងអស់នោះ មកពីវៀតណាម ដូចលោកស្រី និងប្អូនរបស់លោកស្រីឬ? ឆ.២៤៖ ចាស់! [...] ស៖ តើលោកស្រីមានដឹងថា ក្មេងៗទាំងអស់នោះ គេទុកនៅក្នុងវត្តអង្គុញយូរប៉ុន្មានទេ? ឆ.៣៦៖ រហូតដល់ដាច់របបខ្មែរក្រហម ក្មេងខ្លះរត់ទៅរកគ្រួសារវិញ ហើយខ្លះក៏ត្រូវស្លាប់នៅទីនោះ [នៅក្នុងវត្តអង្គុន]"]។

[744] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ប្ដត្ដិ ឆ.៣០ KH 01112273 ["ក្នុងឆ្នាំ១៩៧៧ ខ្មែរក្រោម ត្រូវបានគេជម្លៀសពីវៀតណាម ឲ្យមករស់នៅក្នុងស្រុកគីរីវង្ស"] ឆ.៣៧, ៤១ KH 01112274, 75 ["ស៖ តើខ្មែរក្រោម ឬអ្នកដែលត្រូវបានសង្ស័យថាជាខ្មែរក្រោម ត្រូវបានគេយកទៅសម្លាប់នៅដីដ៏ឫកនោះដែរឬទេ? ឆ.៣៧៖ បាទ មាន។ [...] ស៖ ហេតុដូចម្តេចបានជាលោកដឹងថា អ្នកដែលបាត់ខ្លួនទាំងនោះជាខ្មែរក្រោម? ឆ.៤១៖ ពួកយើងធ្វើការនៅក្នុងកង និងស្នាក់នៅជាមួយគ្នា ដោយដេកនៅក្នុងរោងវែងជាមួយគ្នា។ ពេលខ្លះ ក្រោយពេលសម្រាកពីការងារ យើងបានសួរគ្នាទៅវិញទៅមក អំពីទីកន្លែងកំណើតរៀងៗខ្លួន។ ពួកគេបានប្រាប់ថា ពួកគេជាខ្មែរក្រោម ហើយខ្ញុំក៏ប្រាប់ថាខ្ញុំជាខ្មែរក្រោមដែរ"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១២៨ KH 00987241 ["ខ្ញុំដឹងថា កុមារ និងមនុស្សវ័យជំទង់ដែលជាខ្មែរក្រោមត្រូវគេយកទៅដាក់នៅក្នុងវត្តអង្គុញនេះ។ គេពុំដាក់មនុស្សទាំងអស់នេះឲ្យនៅកន្លែងតែមួយនោះទេ"]។ ឯកសារ D219/482 កំណត់ហេតុស្តាប់ចម្លើយ ឡាច

ទៅជួរមុខ និងសមាជិកក្មេងៗត្រូវបានដាក់ឲ្យជីកប្រឡាយ ឬឲ្យធ្វើការងារកសិកម្មនៅតាមវាលស្រែចម្ការជិតៗនោះ[745]។

217. យ៉ាងហោចណាស់ ចាប់តាំងពីចុងឆ្នាំ១៩៧៦ ពួកសមាជិកខ្មែរក្រោមនៃកងពលកម្ម ដែលមានមូលដ្ឋាននៅវត្តអង្គុញត្រូវបានសម្លាប់ចោល។ ស្រដៀងគ្នានេះដែរ ខ្មែរក្រោមនៅឃុំកំពែងត្រូវបានកំណត់គោលដៅ និងសម្លាប់ចោលចាប់ពីពេលនោះមក រួមបញ្ចូលទាំងទីកន្លែងកប់សាកសពនៅក្នុងបរិវេណវត្តអង្គុញ[746]។

218. វត្តអង្គុញ ស្ថិតនៅចំកណ្តាលវាលស្រែ នៅក្នុងឃុំកំពែង ស្រុកគីរីវង់ តំបន់១៣ នៃភូមិភាគនិរតី[747]។ វត្តអង្គុញ មើលទៅឃើញច្បាស់ចែសត្រង់ភ្លឹង និងនៅឆ្ងាយពីវត្តកំពែងប្រហែលមួយគីឡូម៉ែត្រ[748] ជាកន្លែងដែលក្រុមខ្មែរក្រោមដ៏ច្រើនត្រូវបានសម្លាប់ មុនពេលពួកប្រជាជនជម្លៀសខ្មែរក្រោមពីវៀតណាមបានមកដល់[749]។

សែប ឆ.២១ KH 01136306 [“ស៖ នៅក្នុងកិច្ចសម្ភាសលើកមុនរបស់លោកស្រី លោកស្រីថា មានកុមារ និងក្មេងៗជំទង់នៅទីនោះដែរ(វត្តអង្គុណ) តើលោកស្រីដឹងដោយរបៀបណា? ឆ.២១៖ ដោយសារតែប្អូនប្រុសរបស់ខ្ញុំត្រូវបានគេយកទៅដាក់នៅក្នុងវត្តនោះ។ ក្មេងៗជំទង់ដែលមិនទាន់មានគ្រួសារត្រូវគេប្រមូលដាក់ក្នុងវត្តនោះ”]។

[745] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១១៣ KH 00987239 [“ស៖ នៅភូមិកំពែង និងភូមិគោកព្រិច តើនៅក្នុងគ្រួសារត្រូវគេបំបែកឲ្យរស់នៅផ្សេងគ្នាដែរឬទេ? ឆ.១១៣៖ ចាស គេបំបែកឲ្យនៅផ្សេងគ្នា។ កុមារជំទង់ប្រុសៗត្រូវគេឲ្យធ្វើការនៅក្នុងក្រុមកុមារឈានមុខ ចំណែកកុមារស្រីៗគេដាក់នៅក្នុងក្រុមផ្សេងទៀត”] ឆ.១២៨៖ KH 00987241 [“ឧទាហរណ៍ថា មនុស្សប្រុសនៅក្នុងវិហារ មនុស្សស្រីនៅកន្លែងផ្សេង ហើយគេឲ្យអ្នកទាំងនោះធ្វើការ”]។ ឯកសារ D219/482 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែប ឆ.៣០ KH 01136307 [“ក្មេងធំៗគេឲ្យជញ្ជូនបាយទៅសមរភូមិមុខ ហើយក្មេងផ្សេងទៀតគេឲ្យវែកដី និង ដាំដំឡូង”]។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្បត្តិ ឆ.២៣ KH 01112271 [“យុវជនដែលត្រូវបានចាត់តាំងឲ្យជីកប្រឡាយ ត្រូវបានគេឲ្យស្នាក់នៅទីនោះ”]។

[746] *សូមមើល* V.A.1.b.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់១៣ – ទីកន្លែងសម្លាប់មនុស្សវត្តអង្គុណ – ឧក្រិដ្ឋកម្ម – ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)។

[747] ឯកសារ D3/22.1 ផែនទីបណ្តាញផ្លូវខេត្តតាកែវ។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្បត្តិ ឆ.៥ KH 01112268 [“ខ្ញុំត្រូវបានគេជម្លៀសពីភ្នំពេញ ទៅនៅឃុំកំពែង ស្រុក១០៩”]។

[748] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្បត្តិ ឆ.២៦ KH 01112272 [“ស៖ តើវត្តអង្គុញ និងវត្តកំពែង មានចម្ងាយពីគ្នាប្រហែលប៉ុន្មានដែរ? ឆ.២៦៖ ប្រហែល១គីឡូម៉ែត្រ ហើយអាចមើលឃើញដំបូលវត្តទៅវិញ ទៅមក”]។

[749] *សូមមើល* V.A.1.b.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់១៣ – ទីកន្លែងសម្លាប់មនុស្សវត្តអង្គុណ – ឧក្រិដ្ឋកម្ម – ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និង ការប្រាស្រ័យទាក់ទង

219. វត្តអង្គុញ ស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គណៈស្រុកគីរីវង់។ **យ៉ីម ទិត្យ** ជាសមាជិកមួយរូបនៃគណៈនេះ និងបានអនុវត្តគោលនយោបាយខ្ចាំង និងការធ្វើឲ្យទៅជាទាសករតាមបែប JCE នៅក្នុងស្រុកនេះ តាមរយៈការបញ្ជាឲ្យចាប់ខ្លួនក្រៅប្រព័ន្ធតុលាការ និងតាមរយៈការលើកកម្ពស់គោលនយោបាយ ដែលបានអនុវត្តអំណាចជាម្ចាស់កម្មសិទ្ធិលើប្រជាជនស៊ីវិលនៅតាមភូមិនានា និងទីកន្លែងផ្សេងៗទៀត រួមបញ្ចូលទាំង វត្តអង្គុញផងដែរ។

220. ចាប់ពីយ៉ាងហោចណាស់ ឆ្នាំ១៩៧៥ **យ៉ីម ទិត្យ** គឺជាលេខាស្រុកគីរីវង់ ឬជាអនុលេខាស្រុកនេះ[750] និងបានបន្តកាន់កាប់មុខតំណែងនេះ រហូតដល់ខែមេសា ឬខែឧសភា ឆ្នាំ១៩៧៨[751] ខណៈដែលគាត់

---

[750] ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.១០, ១៣ KH 01104662។ ឯកសារ D118/23 កំណត់ហេតុស្តាប់ចម្លើយ តិម ផល ឆ.១១-១៤ KH 00891160។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ តិម ភី ឆ.១១-១២ KH 00891148។ ឯកសារ D219/160 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.៧ EN 01059383។ ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៤-៥, ៩ KH 00905848។ ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ឈួន ឆ.៧ KH 00905853។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឆ.២៩ KH 01024599។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.១៣ KH 01047179។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.២៦, ៤០-៤១ KH 01102934, 36។ ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៤-៧ KH 00891153-54។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ប្ដត្ដិ ឆ.១៣-១៥ KH 01112269-70។ ឯកសារ D65.1.3 របាយការណ៍នៃគំរោងជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ឡេង អាន & យ៉ីម ទិត្យ EN 00704584។

[751] ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.១០, ១៣ KH 01104662។ ឯកសារ D118/23 កំណត់ហេតុស្តាប់ចម្លើយ តិម ផល ឆ.១១-១៤ KH 00891160។ ឯកសារ D219/160 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.៧ EN 01059383។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ តិម ភី ឆ.១១-១២ KH 00891148។ ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៤-៥, KH 00905848។ ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ឈួន ឆ.៧ KH 00905853។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឆ.២៩ KH 01024599។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.១៣ KH 01047179។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.២៦, ៤០-៤១ KH 01102934, 36។ ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៤-៧ KH 00891153-54។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ប្ដត្ដិ ឆ.១៣-១៥ KH 01112269-70។ ឯកសារ D65.1.3 របាយការណ៍នៃគំរោងជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ឡេង អាន & យ៉ីម ទិត្យ EN 00704584។ *សូមមើលផងដែរ* ឯកសារ D1.3.11.48 បទសម្ភាសន៍ សៀង ហោម ដោយ SOAS EN 00217750។ ឯកសារ D1.3.11.56 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ដោយ ក.ស.ព EN 00219282។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឆ.៩៩-១០១ KH 01024605-06។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤២ KH 01034069។ ឯកសារ D219/189

បានអនុវត្តគោលនយោបាយរបស់ ប.ក.ក ក្នុងពេលជាមួយគ្នានៅក្នុងភូមិភាគពាយ័ព្យ[752]។ គណៈស្រុកបានធ្វើការប្រាស្រ័យទាក់ទងយ៉ាងទៀងទាត់ជាមួយនឹងមន្ត្រីឃុំ តាមរយៈការប្រជុំផ្នាក់ស្រុកទាំងមូល[753] និងការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ[754]។ គណៈនេះបានបញ្ជាឲ្យមន្ត្រីឃុំរាយការណ៍អំពីមនុស្សដែលត្រូវបានចាត់ទុកថាជាខ្មាំង និងពិភាក្សាអំពីការចាប់ខ្លួន។ នៅក្នុងរបាយការណ៍ និងកិច្ចពិភាក្សាទាំងនេះ ពួកខ្មែរក្រោមត្រូវបានកំណត់អត្តសញ្ញាណថាជាខ្មាំង[755]។ គណៈស្រុកបានបញ្ជូនបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួនទៅកាន់គណៈឃុំ និងគណៈយោធាស្រុក[756]។

កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឯ.២៧ KH 01068052។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឯ.៩៩-១០១ KH 01024605-06។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឯ.២៧ KH 01068052។

[752] *សូមមើល* III.D.2. មុខតំណែង អំពើ និងទង្វើ របស់ យ៉ឹម ទិត្យ – ការចូលរួមរបស់ យ៉ឹម ទិត្យ នៅក្នុងផែនការឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ – ការរួមចំណែករបស់ យ៉ឹម ទិត្យ នៅក្នុងផែនការឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ។

[753] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ឹម ផល ឯ.៣៣-៣៧, ៤៣, ៤៥-៤៦, ៤៩, ៦០ KH 01133416-19។ ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ ល្ងួន មល់ ឯ.៥៨, ៩៦ KH 01104667, 71។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ តិម ភី ឯ.២២ KH 00891149។ ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឯ.៣២ KH 01110208។ ឯកសារ D219/66 កំណត់ហេតុស្តាប់ចម្លើយ គង់ ផោម ឯ.៥៧ KH 01037204។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ល ភ្ជុ ឯ.១៧៥-១៨០, ១៩៥ KH 01117238-39, 40។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឯ.៥៩ KH 01024601។ ឯកសារ D219/521 កំណត់ហេតុស្តាប់ចម្លើយ ទ៉ីម (ត៉ីប) ភី ឯ.៣៨-៤២, ៤៨ KH 01149834-35។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឯ.១៩ KH 01068050។ *សូមមើលផងដែរ* ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឯ.៤០-៤៧ KH 01136707-08។

[754] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ឹម ផល ឯ.៤៥ KH 01133417។ ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ ល្ងួន មល់ ឯ.៣១ KH 01104664។

[755] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ឹម ផល ឯ.១៣៤-៣៦ KH 01133428-29។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឯ.៤០-៤៣ KH 00788846។

[756] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ឹម ផល ឯ.៩, ១៥-១៦ KH 01133413, 14។ ឯកសារ D118/302 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន់ សារ៉ូ ឯ.៨៧ KH 01024569។ *សូមមើលផងដែរ* ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឯ.១២១ KH 01136721។ ឯកសារ D1.3.11.18 បទសម្ភាសន៍ ហោ យ៉ន ដោយ SOAS EN 00217607។

221. ឈ្លបឃុំដែលជាអ្នកសម្លាប់នៅឃុំកំពែង រួមមាន នៅវត្តអង្គុញ និងក្នុងទីបរិវេណវត្តនេះ បានរាយការណ៍ដោយផ្ទាល់ទៅកាន់គណៈស្រុក ដែលគណៈស្រុកនេះបានរាយការណ៍ដោយផ្ទាល់ទៅកាន់គណៈតំបន់១៣[757]។

222. ប៉ាន់ សារូ ជាទាហានខ្មែរក្រហមមួយរូប ឈរជើងនៅស្រុកគីរីវង់ បានឃើញ **យ៉ីម ទិត្យ** ចូលរួមប្រជុំនៅក្នុងឃុំកំពែង និងការប្រជុំនៅតាមភូមិ និងឃុំនានា នៅក្នុងស្រុកនេះ។ ការប្រជុំទាំងនេះត្រូវបានកោះហៅដោយគណៈស្រុក និងត្រូវបានចូលរួមប្រជុំដោយកងយោធា កងចល័ត និងកងពេទ្យ[758]។ ប.ក.ក ក៏បានបើកកិច្ចប្រជុំនៅវត្តអង្គុញផងដែរ ដោយមានការចូលរួមដោយមនុស្សមកពីទីកន្លែងផ្សេងៗនៅក្នុងតំបន់នោះ រួមបញ្ចូលទាំងប្រធានកងផងដែរ[759]។

---

[757] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ផត្តិ ឆ.៧១-៧៤ KH 01112280-81 ["សៈ តើលោកដឹងថា នរណាជាអ្នកសម្លាប់ខ្មែរក្រោម ដែលជាអ្នក១៧ មេសា ទាំងនោះ? ឆ.៧១៖ គឺឈ្លប ព្រោះពុំមានយោធាណាមកសម្លាប់ទេ។ យោធាមិនដឹងអ្វីនោះទេ។ សៈ តើឈ្លបឃុំ ឬឈ្លបស្រុក? ឆ.៧២៖ ឈ្លបឃុំ។ សៈ តើនរណាដែលគ្រប់គ្រងឈ្លបឃុំ? ឆ.៧៣៖ តាញ៉ៃ ដែលជាមេឃុំ គឺជាអ្នកគ្រប់គ្រងឈ្លបឃុំ។ ក្រៅពី តាញ៉ៃ គឺមាន ប៉ាល់ ដែលជាប្រធានកងយុវជន។ សៈ តើ ញ៉ៃ រាយការណ៍ទៅថ្នាក់ណាដែរ? ឆ.៧៤៖ តាញ៉ៃ រាយការណ៍ទៅគណៈស្រុក ហើយថ្នាក់ស្រុក រាយការណ៍ទៅគណៈតំបន់។ នៅពេលរាយការណ៍នោះ គឺមិនមានទូរស័ព្ទទេ គឺគេប្រើនីរសារ ដោយប្រើសេះជាយន្តជំនិះ"]។

[758] ឯកសារ D118/302 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន់ សារូ ឆ.៣៦-៣៧ KH 01024564 ["ឆ.៣៦៖ ខ្ញុំធ្លាប់ឃើញ តាទិត នៅក្នុងការប្រជុំនៅតាមភូមិឃុំជាញឹកញាប់។ សៈ តើលោកប្រជុំជាមួយ តាទិត នៅក្នុងឃុំណា? ឆ.៣៧៖ ប្រជុំក្នុងក្នុងឃុំកំពែង"]។ ឯកសារ D219/521 កំណត់ហេតុស្តាប់ចម្លើយ ទ៉ីម (ត៉ីប) ភ៉ី ឆ.៣៨-៣៩ KH 01149834 ["សៈ តើលោកស្រីបានជួបតាទិតទេ ពេលដែលលោកស្រីធ្វើការនៅស្រុក? ឆ.៣៨៖ ចាស ខ្ញុំបានជួបពេលប្រជុំពេលអ៊ីហ្ម៉ីង។ សៈ តើនោះជាការប្រជុំប្រភេទអ្វី? តើជាការប្រជុំមានមនុស្សចូលរួមច្រើន ឬក៏ជាការប្រជុំផ្ទាល់ខ្លួន? ឆ.៣៩៖ ប្រជុំពេលដែល គណៈស្រុកហៅគ្រប់គណៈឃុំ និងគ្រប់ផ្នែកមក ដូចជាកងចល័ត ផ្នែកពេទ្យ ផ្នែកទាហាន"]។ ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ុង រ៉ែត ឆ.៣៧ KH 01136707 ["ក្នុងឆ្នាំ១៩៧៦ ខ្ញុំឃើញ តាទិត្យ អង្គុយនៅខាងស្តាំដៃប្រធានតំបន់ពេលប្រជុំ គឺបានន័យថា គាត់ត្រៀមឡើងហើយ។ [...] ពេល តាសោម ត្រូវបានដក តាទិត្យ ក៏បានឡើងជំនួស តាសោម"]។

[759] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១២៦ KH 00987241 ["នៅក្នុងសម័យខ្មែរក្រហម ខ្ញុំធ្លាប់បានទៅប្រជុំនៅក្នុងវត្តអង្គុញ។ ពេលនោះគេប្រមូលមនុស្សពីកន្លែងផ្សេងៗទៀតមកប្រជុំនៅក្នុងវត្តអង្គុញនេះ"]។ ឯកសារ D219/482 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៧ EN 01136304 ["សៈ តើលោកស្រីទៅប្រជុំនៅវត្តអង្គុញប៉ុន្មានដង? ឆ.៧៖ ខ្ញុំទៅពីរដង"]។

iv. ខ្ញុំក្ដីផ្ទកម្ម

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

223. នៅដើមឆ្នាំ១៩៧៦ ពួកខ្មែរក្រោមត្រូវបានជម្លៀសពីភ្នំពេញទៅកាន់ឃុំកំពែង។ ឡាច សម្ត្ត ដែលជាខ្មែរក្រោមម្នាក់ បានរាយការណ៍ថាក្នុងរយៈពេលជាងប្រាំថ្ងៃ មានសមាជិកខ្មែរក្រោមពីបី ទៅបួននាក់ នៅក្នុងកងយុវជនរបស់គាត់ ដែលស្នាក់នៅក្នុងវត្តអង្គុញ បានបាត់ខ្លួនពីវត្តនេះក្រោមលេសថាពួកគេត្រូវបានបញ្ជូនឲ្យទៅ "រៀនសូត្រ"។ គាត់បានរៀបរាប់ពីរបៀបនៅពេលដែលមនុស្សម្នាក់ត្រូវបានដកចេញ ហើយឈ្លបស្រុកបានសួរចម្លើយគាត់នោះអំពីមុខតំណែងពីមុនរបស់អ្នកផ្សេងៗទៀតដែលជិតស្និទ្ធនឹងពួកគេ ដែលក្រោយមកត្រូវបានចាប់ខ្លួន និងមិនដែលត្រូវបានគេឃើញទៀតនោះទេ[760]។

224. ឡាច សែម បានរៀបរាប់បន្ថែមពីរបៀបដែលឈ្លបបានសម្ពុតគំរាមអ្នកធ្វើការ នៅក្នុងកងដែលស្នាក់នៅក្នុងវត្តនេះ ដោយត្រូវបានវាយរហូតដល់ស្លាប់ បើសិនជាប្រកែកមិនធ្វើការ[761]។ ឌីម ផល ដែលជាសមាជិកមួយរូបក្នុងគណៈឃុំកំពែង បានពន្យល់ថា នៅពេលដែលមនុស្សម្នាក់បាត់ខ្លួនក្នុងឃុំកំពែង នោះ "មានន័យថា គឺត្រូវបានគេយកទៅសម្លាប់"[762]ហើយ។

---

[760] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត អ.៤០ KH 01112275 ["ស៖ ហេតុដូចម្តេចបានជាលោកដឹងថា សាកសពមនុស្សទាំងនោះ គឺជាខ្មែរក្រោម? អ.៤០៖ ដោយសារពេលខ្លះ មានការបាត់ខ្លួនមនុស្សដែលស្នាក់នៅជាមួយខ្ញុំនៅក្នុងវត្តអង្គុញ ម្នាក់ ពីរនាក់ ឬបីនាក់ក្នុងមួយសប្តាហ៍។ នៅពេលដែលគេយកមនុស្សម្នាក់ទៅ គេនឹងសួរដើម្បីឲ្យដឹងអំពីសាវតារតំណែង ត្ួនាទីកាលពីមុនរបស់គ្នីគ្នាពួកគេ។ ក្រោយពេលដែលមនុស្សម្នាក់បានផ្តល់ព័ត៌មានអំពីមនុស្សម្នាក់ទៀត ពេលនោះមនុស្សម្នាក់ទៀតនោះនឹងបាត់ខ្លួនក្នុងពេលឆាប់ៗ"]។ *ប៉ុន្តែសូមមើល* ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត អ.៤២ KH 01112275 ["ស៖ តើលោកគិតថា អ្នកទាំងនោះត្រូវបានគេចាប់ខ្លួនយកទៅ ដោយសារពួកគេជាខ្មែរក្រោមឬយ៉ាងណា? អ.៤២៖ ទេ ខ្ញុំគិតថាមិនមែនដោយសារពួកគេជាខ្មែរក្រោមទេ។ ពួកគេត្រូវបានចាប់ខ្លួនយកទៅ ដោយសារជាប់និន្នាការរដ្ឋការ និងទាហានលន់ នល់ និស្សិត និងបញ្ញាវន្ត"]។

[761] ឯកសារ D219/482 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែប អ.៣២, ៣៥ KH 01136307 ["ស៖ ពេលដែលគេ[ខ្ញុំរក្រហម]ឲ្យក្មេងៗធ្វើការងារនេះ ធ្វើការងារនោះ តើពួកគេអាចប្រកែកបានដែរឬទេ? អ.៣២៖ ទេ, [បើពួកគេហ៊ានប្រកែក] ពួកគេអាចនឹងត្រូវបានគេវាយចោល។ [...] ស៖ ពេលដែលក្មេងនោះត្រូវបានគេយកទៅធ្វើការនៅកន្លែងណាមួយ តើមានអ្នកយាមទេ? អ.៣៥ ៖ មិនមានអ្នកយាមទេ ប៉ុន្តែឈ្លបជាអ្នកនាំពួកគេទៅកន្លែងធ្វើការ"]។

[762] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ឌីម ផល អ.៦០ KH 01133419 ["ស៖ នៅក្នុងកិច្ចប្រជុំថ្នាក់ស្រុក តើគេមាននិយាយពីរឿងយកមនុស្សទៅសម្លាប់ដែរ ឬទេ? អ.៦០៖ ចាស នៅក្នុងកិច្ចប្រជុំ គឺមាននិយាយពីការសម្លាប់ "ឲ្យតែខ្ទាំង គឺត្រូវតែសម្លាប់" អ្នកដែលត្រូវគេចាប់គឺមិនដែលឃើញត្រឡប់មកវិញឡើយ"] អ.១៣០-១៣១ KH 01133428 ["ស៖ ចុះអ្នកដែលបាត់

225. ក្រោយមក នៅឆ្នាំ១៩៧៦ គណៈស្រុកគីរីវង់បានណែនាំអាជ្ញាធរ ប.ក.ក នៅថ្នាក់ឃុំឲ្យផ្តោតគោលដៅលើពួកខ្មែរក្រោម។ ជាផ្នែកនៃគោលនយោបាយនោះ នៅឃុំកំពែងដែលមានវត្តអង្គុញស្ថិតនៅក្នុងនោះ ពួកគេបានបញ្ជាប្រធានឃុំឲ្យស្រាវជ្រាវពីផ្ទះមួយទៅផ្ទះមួយ ដើម្បីកំណត់អត្តសញ្ញាណខ្មែរក្រោម[763]។

226. អាជ្ញាធរឃុំនៅពេលនោះ បានស្នើឲ្យខ្មែរក្រោមដែលចង់វិលត្រឡប់ទៅវៀតណាមវិញឲ្យមកចុះឈ្មោះនៅឃុំ។ ប្រធានភូមិបានប្រាប់ម្តាយរបស់ ឡាច សម្ត្ថ្ត ថាពួកគេមានផែនការចង់សម្លាប់ពួកអ្នកដែលបានចុះឈ្មោះ។ ពេលមួយក្រោយមកទៀត អាជ្ញាធរមូលដ្ឋាន ប.ក.ក បានអញ្ជើញខ្មែរក្រោមដែលបានចុះឈ្មោះឲ្យទៅកាន់រោងបាយនៅភូមិតាពៅ ក្នុងឃុំកំពែង ហើយរថយន្តទ្រុងធំៗ

ខ្លួនទាំងអស់នោះ តើលោកស្រីមានឃើញត្រឡប់មកវិញដែរ ឬទេ? ឆ.១៣០៖ អត់ដែលឃើញត្រឡប់មកវិញទេ។ ស៖ តើលោកស្រីដឹងថាមូលហេតុអ្វីបានជាពួកគេបាត់ខ្លួនដែរ ឬទេ? ឆ.១៣១៖ ខ្ញុំមិនដឹងទេ ប៉ុន្តែការបាត់ខ្លួន មានន័យថា គឺត្រូវបានគេយកទៅសម្លាប់"]។ ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌីក ប៉ែត ឆ.៨០ KH 00979209 ["ស៖ តើលោកស្រីដឹងថា មានអ្វីកើតឡើងចំពោះអ្នកបាត់ខ្លួនទាំងនោះដែរ ឬទេ? ឆ.៨០៖ នៅពេលដែលអ្នកណាម្នាក់បាត់ខ្លួន គឺបាត់រហូតតែម្តង ដូចជាប្តីរបស់ខ្ញុំគឺលែងឃើញត្រឡប់មកវិញរហូត"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១២៧ KH 00987241 ["ស៖ តើលោកស្រីដឹងថា នៅវត្តអង្គុញមានការសម្លាប់មនុស្សដែរឬទេ? ឆ.១២៧៖ មានសម្លាប់មនុស្ស តែខ្ញុំមិនដឹងនោះទេ ព្រោះពេលដែលគេយកមនុស្សទៅសម្លាប់គេពុំឲ្យយើងដឹងនោះទេ ដោយខ្លាចបែកការណ៍។ ពេលដែលគេយកមនុស្សទៅសម្លាប់ម្តងៗគេតែងនិយាយថាយកទៅរៀនសូត្រ គេមិននិយាយថាយកទៅសម្លាប់មនុស្សនោះ ព្រោះគេខ្លាចយើងបះបោរ"]។

[763] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ថ្ត ឆ.៤៤, ៤៦ KH 01112276 ["ស៖ លោកនិយាយថា នៅក្នុងឆ្នាំ១៩៧៦ ខ្មែរក្រហម មានគោលនយោបាយកំណត់គោលដៅទៅលើខ្មែរក្រោម តើនរណាជាអ្នកកំណត់គោលនយោបាយទៅលើខ្មែរក្រោម? ឆ.៤៤៖ គោលនយោបាយនេះចេញមកពីអង្គការថ្នាក់លើ។ ខ្ញុំមិនដឹងថាគោលនយោបាយចេញមកពីអ្នកណាទេ គ្រាន់តែដឹងថា គោលនយោបាយនេះ ត្រូវបានបញ្ជូនបន្តមកឃុំ និងក្រុមយុវជន។ នៅឆ្នាំ១៩៧៧ គេបានបញ្ជូនពួកខ្ញុំដែលជាអ្នក១៧ មេសា ទៅស្រុក១០៥ (ស្រុកត្រាំកក់) ហើយបញ្ជូនពួកខ្មែរក្រោម មកពីវៀតណាម មកនៅស្រុក១០៩ (ស្រុកគីរីវង្ស) វិញ។ [...] ស៖ តើលោកដឹងអំពីគោលនយោបាយចំពោះខ្មែរក្រោម ពីថ្នាក់លើ ដោយរបៀបណា? ឆ.៤៦៖ មេឃុំ ប្រាប់ថា នេះជាផែនការរបស់អង្គការថ្នាក់លើ ដោយប្រាប់ថា "អ្នកណាដែលមានការងារពីរបបចាស់ ត្រូវប្រាប់អង្គការ ដូច្នេះគេអាចបញ្ជូនឲ្យទៅធ្វើការងារចាស់នោះវិញ"។ នៅពេលនោះ មេឃុំ បានមកប្រាប់មេភូមិតាមបញ្ជារបស់អង្គការថ្នាក់លើ ឲ្យដើរស្រង់ស្ថិតិប្រជាជនតាមផ្ទះ ថានរណាខ្លះជាខ្មែរក្រោម។ គេបាននិយាយថា នេះជាផែនការរបស់អង្គការ"]។

បានដឹកពួកគាត់ចេញទៅស្ពានស្លាគ្ងូ ក្នុងស្រុកត្រាំកក់ ជាកន្លែងដែលពួកគាត់ត្រូវបានសម្លាប់ចោល[764]។ អ្នកបើកបររថយន្តទ្រុងទាំងនោះគឺជាយោធាស្រុក[765]។

227. គោលនយោបាយស្តីពីការផ្តោតគោលដៅ និងសម្លាប់ខ្មែរក្រោម បានបន្ត នៅពេលមានប្រជាជនជម្លៀសខ្មែរក្រោមរាប់ពាន់នាក់ពីវៀតណាមបានមកដល់ ដោយចាប់ផ្តើមនៅចុងឆ្នាំ១៩៧៧។ ញ្យេប នីម បានឮថា ពួកខ្មែរក្រោមទាំងនេះត្រូវបានគេយកចេញទៅសម្លាប់[766]។ នៅភូមិអាងខ្ចៅ តែប៉ុន្តែគឺឡូម៉ែត្រពីវត្តអង្គុញប៉ុណ្ណោះ សាន់ ទូច បានឃើញប្រជាជនជម្លៀសខ្មែរក្រោម ១០នាក់ អាយុពី ២០ ទៅ ៧០ឆ្នាំត្រូវបានយោធាមូលដ្ឋានរបស់ ប.ក.ក វាយធ្វើបាបរហូតដល់ស្លាប់ តាមបញ្ជា

---

[764] ឯកសារ D118/165 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត ឆ.៩ KH 00968143 ["នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានប្រកាសថា អ្នកណានៅកម្ពុជាក្រោមគេឲ្យទៅនៅកម្ពុជាក្រោមវិញ អ្នកណាធ្វើអ្ីអង្គការឲ្យធ្វើការងារដូចមុនវិញ។ ម្តាយរបស់គាត់បានទៅចុះឈ្មោះដែរ ប៉ុន្តែមេភូមិគាត់អាណិតម្តាយខ្ុំ គាត់ប្រាប់ថាកុំឲ្យទៅចុះឈ្មោះ គេមានផែនការយកទៅសម្លាប់ចោលទេ។ ក្រោយមកគេធ្វើជុបណាង ដើម្បីរង់ចាំឡានមកទទួល ហើយគេយកទៅសម្លាប់ចោលអស់ទៅ នៅស្ពាគ្ងូ។ ផ្ទះបាយ នៅភូមិតាពៅ (ឃុំកំពែង)។ ខ្ុំមិនបានដឹងដោយផ្ទាល់ទេ ខ្ុំនៅកងយុវជន ប៉ុន្តែម្តាយខ្ុំប្រាប់។ យុវជននៅកងជាមួយខ្ុំគេហៅមកដែរ ហើយបាត់ខ្លួនទៅ"]។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត ឆ.៥១ KH 01112277 ["ស៖ តើស្ពានស្លាគ្ងូ ស្ថិតនៅកន្លែងណាដែរ? ឆ.៥១៖ [...] ស្ពានស្លាគ្ងូ ស្ថិតនៅបណ្តោយផ្លូវជាតិលេខ៣ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ"]។

[765] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត ឆ.៣០-៣១ KH 01112273 ["ស៖ លោកនិយាយថា អ្នកខ្លះមិនមែនខ្មែរក្រោមទេ ប៉ុន្តែគាត់ចុះឈ្មោះថាខ្មែរក្រោម ហើយត្រូវបានគេបញ្ជូនយកទៅសម្លាប់ចោលនៅស្ពានស្លាគ្ងូ តើលោកដឹងថា នរណាជាអ្នកយកពួកគាត់ទៅសម្លាប់? ឆ.៣០៖ ខ្ុំឃើញមនុស្សមកពីថ្នាក់ស្រុក ស្លៀកពាក់ខោអាវខ្ចៅ ជិះឡានយោធA5 មកដឹកមនុស្សយកទៅសម្លាប់ នៅក្នុងឆ្នាំ១៩៧៦។ នៅមុនដឹកមនុស្សយកទៅសម្លាប់ គេបានរៀបចំកាប់គោធ្វើម្ហូប ដើម្បីឲ្យប្រជាជនខ្មែរក្រោមហូប។ [...] ស៖ តើអ្នកដែលមកពីថ្នាក់ស្រុកនោះ គឺជាឈ្លបដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់យាយឬ ឬ? ឆ.៣១ ៖ បាទ ត្រឹមត្រូវ"]។

[766] ឯកសារ D219/524 កំណត់ហេតុស្តាប់ចម្លើយ ញ្យេប នីម ឆ.៥០-៥១ KH 01149874 ["ឆ.៥០៖ ពួកខ្មែរក្រហមកែនពួកគេ[ពួកខ្មែរក្រោម]មកភូមិកំពែងរាប់ពាន់គ្រួសារ ប្រហែលឆ្នាំ១៩៧៧ ឬ៧៨ មុនពេលពួកខ្មែរក្រហមឡើងទៅលើ។ [...] ស៖ តើលោកដឹងថាតើមានអ្ីកើតឡើងចំពោះពួកខ្មែរក្រោមទេ? ឆ.៥១៖ គេមករាប់ពាន់គ្រួសារ ជាមួយរទេះ។ ខ្ុំឮគេនិយាយថា គេយកពួកខ្មែរក្រោមទៅវ៉ៃចោល"]។

ប្រធានឃុំ ពីព្រោះគេចោទប្រកាន់ពួកគេទាំងនោះថាជាខ្មាំងវៀតណាម[767] ឬជាគិញ សេ.អ៊ុ.អា ឬ បានរៀបការប្រពន្ធវៀតណាម[768]។

228. សាន់ ទូច ក៏បានរៀបរាប់ផងដែរថា គាត់បានឃើញការសម្លាប់ខ្មែរក្រោមជាច្រើនទៀតនៅឯជើងភ្នំ អាងខ្ចៅ នៅឃុំកំពែង ក្នុងឆ្នាំ១៩៧៨។ ខណៈដែលកំពុងឃ្វាលគោនៅម្តុំនោះ គាត់បានឃើញខ្មែរ ក្រហមវាយធ្វើបាបខ្មែរក្រោម ហើយបន្ទាប់មក ពួកគេបានកប់អ្នកទាំងនោះទាំងរស់។ គាត់បាន រៀបរាប់បន្ថែមទៀតថា គាត់បានឃើញសាកសពខ្មែរក្រោមជាច្រើននៅតាមជើងភ្នំ[769]។

---

[767] ឯកសារ D118/131 កំណត់ហេតុស្តាប់ចម្លើយ សាន់ ទូច ឆ.៣២, ៣៤-៣៧, ៤០-៤៣ KH 00960602-04 ["សៈ ដោយសារ តែលោកជាអ្នកមកពីកម្ពុជាក្រោម ពេលដែលលោកនៅក្នុងភូមិអាងខ្ចៅ និងភូមិកំពែង តើមានការធ្វើទុក្ខបុកម្នេញ ឬក៏ធ្វើបាបលើ លោកដែរឬទេ? ឆ.៣២៖ បាទ មាន។ [...] សៈ ហេតុអ្វីបានជាលោកដឹងអាងខ្ចៅជាកន្លែងសម្លាប់មនុស្ស? ឆ.៣៤៖ ព្រោះមាន អ្នកផ្សេងទៀតដែលជាខ្មែរក្រោម ត្រូវបានគេបញ្ជូនទៅសម្លាប់នៅទីនោះ។ សៈ ហេតុអ្វីបានជាលោកដឹងអំពីរឿងនេះ? ឆ.៣៥៖ ប្រជាជនដែលឡើងមក(ស្រុកខ្មែរ)ជាមួយខ្ញុំ ត្រូវបានពួកគេយកទៅសម្លាប់ ហើយខ្ញុំបានឃើញដោយផ្ទាល់ភ្នែករបស់ខ្ញុំ។ នៅអាង ខ្ចៅនោះមានស្រះមួយ នៅជុំវិញស្រះមានដើមឈើ ហើយគេសម្លាប់មនុស្សនៅជុំវិញស្រះនោះ។ សៈ តើលោកបានឃើញគេ សម្លាប់មនុស្សរបៀបម៉េច? ឆ.៣៦៖ គេសម្លាប់មនុស្សដោយយកគល់ឫស្សីវ៉ៃសម្លាប់តែម្តង។ ចំណែកនៅអាងខ្ចៅវិញ គេប្រើ ដើមសង្កែវ៉ៃសម្លាប់មនុស្ស។ សៈ ហេតុអ្វីបានជាគេសម្លាប់អ្នកទាំងអស់នោះ? ឆ.៣៧៖ គេចោទថាជាខ្មាំងយួន ជាគិញ សេ.អ៊ុ. អា។ [...] សៈ តើលោកបានឃើញគេសម្លាប់តែម្តងនេះទេ ឬក៏យ៉ាងណា? ឆ.៤០៖ ខ្ញុំឃើញច្រើនដងណាស់។ សៈ តើអ្នកណា ជាអ្នកសម្លាប់អ្នកទាំងអស់នោះ? លោកស្គាល់ឈ្មោះដែរឬទេ? ពួកគេជាទាហានឬ? ឆ.៤១៖ ខ្ញុំមិនស្គាល់ទេ ដឹងតែជាខ្មែរក្រហម។ ពួកគេជាឈ្លប មិនមែនជាទាហាន។ [...] សៈ តើមានការបញ្ជាឲ្យសម្លាប់អ្នកទាំងនោះពីមេឃុំដែរឬទេ? ឆ.៤២៖ ខ្ញុំគិតថា បើមេឃុំមិនអនុញ្ញាតឲ្យសម្លាប់ អ្នកនៅក្រោមមិនហ៊ានសម្លាប់នោះទេ។ សៈ តើលោកចង់សំដៅលើមេឃុំកំពែងមែនទេ? ឆ.៤៣ ៖ បាទ"]។

[768] ឯកសារ D118/131 កំណត់ហេតុស្តាប់ចម្លើយ សាន់ ទូច ឆ.៣៧-៣៩ KH 00960603 [ឆ.៣៧៖ គេចោទថាជាខ្មាំងយួន ជា គិញ សេ.អ៊ុ.អា។ សៈ តើអ្នកដែលត្រូវបានសម្លាប់នោះ មានអាយុប្រហែលប៉ុន្មាន? ឆ.៣៨៖ មានអ្នកខ្លះអាយុចាស់ជាងខ្ញុំទៅ ទៀត អ្នកខ្លះមានអាយុ៧០ឆ្នាំខ្លះមានអាយុ២០ ខ្លះ៣០ឆ្នាំហើយមិត្តភក្តិរបស់ខ្ញុំក៏ត្រូវបានសម្លាប់ដែរ។ ឈ្មោះ ប៊ិន អាយុប្រហែល ៣០ឆ្នាំមានប្រពន្ធយួន អ៊ុក អ៊ុន ក៏មានប្រពន្ធយួន គឺត្រូវគេបានសម្លាប់ទាំងអស់ ដោយសារមានប្រពន្ធយួន។ ឈ្មោះ វ៉ា (ស្រី) ម៉ូស អាយុប្រហែល៦៨ ឬ៦៩ គាត់រស់ក្បែរផ្ទះខ្ញុំនៅកំពែង ហើយឈ្មោះ កែន និងប្រពន្ធរបស់គាត់ ក៏ត្រូវបានគេសម្លាប់ចោល។ ហើយ អ្នកទាំងអស់នោះសុទ្ធជាខ្មែរក្រោម។ កែន និង ម៉ូស ត្រូវបានសម្លាប់ក្នុងពេលតែមួយនៅកៀនក្បែរផ្ទះ។ កែន ជាអ្នកដឹកអ្នកទាំង នោះយកទៅសម្លាប់តាមរទេះសេះ ហើយក្រោយមកក៏ត្រូវបានគេសម្លាប់។ សៈ លោករៀបរាប់អំពីការសម្លាប់មនុស្ស១០នាក់ ដែលត្រូវបានគេសម្លាប់ តើត្រឹមត្រូវដែរឬទេ? ឆ.៣៩៖ បាទ"]។

[769] ឯកសារ D118/131 កំណត់ហេតុស្តាប់ចម្លើយ សាន់ ទូច ឆ.៤៦-៥៣ KH 00960604-05 ["សៈ តើទាំងអស់នេះគឺជាការ ដែលលោកបានឃើញពេលដែលលោកនៅជាប់ឃុំមែនទេ? ឆ.៤៦៖ បាទ។ សៈ តើលោកបានដឹងថា កន្លែងនោះជាកន្លែងសម្លាប់ មនុស្ស គឺមុនពេលដែលលោកត្រូវបានគេចាប់ឃុំ ឬក៏យ៉ាងណា? ឆ.៤៧៖ ខ្ញុំបានដឹងមុនពេលដែលខ្ញុំត្រូវបានគេចាប់យកទៅឃុំទៅ

229. ម៉ី សុខាន់ ជាខ្មែរក្រោមម្នាក់ដែលបានមកដល់ឃុំកំពែងក្នុងខែឧសភា ឆ្នាំ១៩៧៨ ជាមួយនឹងប្រជាជនជម្លៀសដទៃទៀត បាននិយាយថា ពួកអ្នកដែលបានរស់នៅក្នុងវត្តអង្គុញនៅពេលនោះ គឺសុទ្ធតែខ្មែរក្រោមទាំងអស់ រួមទាំង យុវជន និងកូនក្មេងផង[770]។ គង់ សំណាង បាននិយាយលម្អិតអំពីរបៀបដែល ក្នុងពេលមួយខែមុនពេលចប់របបនេះ កងយុវជនរបស់គាត់នៅវត្តអង្គុញកំពុងសម្រាកហូបអាហារថ្ងៃត្រង់ ហើយនៅពេលដែលគេបញ្ជាឲ្យពួកគាត់ច្រៀងចម្រៀងបដិវត្តន៍ មានក្មេងប្រុសម្នាក់អាយុ១២ឆ្នាំ“ដោយភ្លេចខ្លួន” ច្រៀងចម្រៀងវៀតណាម។ ប្រធានកងបានប្រាប់ទៅកងថាឲ្យទះដៃឲ្យក្មេងនោះ ហើយបន្ទាប់មក បានបញ្ជាឲ្យឈ្លូបម្នាក់សម្លាប់ក្មេងនោះចោលភ្លាមនៅនឹងមុខអ្នកវាល់គ្នា[771]។

ទៀត ព្រោះខ្ញុំទៅឃ្វាលគោ ហើយខ្ញុំធ្លាប់ឃើញគេដឹកមនុស្សតាមរទេះសេះយកទៅសម្លាប់ទីនោះ។ ស៖ តើនៅម្តុំកន្លែងសម្លាប់មនុស្សនោះ មានវត្តដែរឬទេ? ឆ.៤៨៖ អត់មានទេ ប៉ុន្តែទីតាំងនោះនៅជើងភ្នំ ហើយមានស្រះនៅទីនោះ។ ភ្នំនោះមានឈ្មោះភ្នំអាងខ្ចៅ។ ស៖ ក្រៅពីមនុស្ស១០នាក់ដែលលោកបានពិពណ៌នា តើលោកបានឃើញសាកសពផ្សេងទៀតដែរឬទេ? ឆ.៤៩៖ ខ្ញុំបានឃើញសាកសពជាច្រើនទៀតនៅក្បែរជើងភ្នំ ហើយមានអ្នកខ្លះទៀតមិនទាន់ស្លាប់ទេ គឺគេកប់ទាំងរស់តែម្តង។ ស៖ តើមានសាកសពប្រហែលប៉ុន្មានដែលលោកបានឃើញនោះ? ឆ.៥០៖ កន្លែងសម្លាប់នោះដូចជារណ្តៅគ្រាប់បេ។ ខ្ញុំបានឃើញសាកសពហើយនិងខោអាវនៅក្នុងរណាញដៅនោះ។ នៅជុំវិញកន្លែងនោះមានដើមឫស្សី និងដើមម៉ែសាក់ ហើយដើមឫស្សីនោះគឺសម្រាប់រ៉ៃសម្លាប់មនុស្ស។ ស៖ ហេតុអ្វីបានជាដឹងថាមានមនុស្សមិនទាន់ស្លាប់ ត្រូវបានគេកប់ទាំងរស់? ឆ.៥១៖ ព្រោះខ្ញុំបានឃើញរឿងនេះពេលដែលខ្ញុំទៅឃ្វាលគោ ខ្ញុំបានឃើញខ្មែរក្រហមរ៉ៃពីក្រោយ ហើយកប់សាកសពទាំងនោះ។ ស៖ តើគេសម្លាប់មនុស្សទាំងនោះនៅពេលណា? ពេលយប់ ឬពេលថ្ងៃ? ឆ.៥២៖ គឺសម្លាប់នៅពេលយប់ច្រើនជាងនៅពេលថ្ងៃ។ ស៖ តើជនរងគ្រោះដែលត្រូវបានសម្លាប់ជាខ្មែរក្រោមទាំងអស់ ឬយ៉ាងណា? ឆ.៥៣៖ ជាខ្មែរក្រោមទាំងអស់ ពួកគេចោទយើងតែពីរប៉ុណ្ណោះគឺ យកប្រពន្ធយួន និងជាគីញយួន”]។

[770] ឯកសារ D118/129 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សុខាន់ ឆ.៦២-៦៦ KH 00960576 [“ស៖ តើព្រះតេជគុណបានឃើញខ្មែរក្រោមស្នាក់នៅក្នុងវត្តនោះដែរឬទេ? ឆ.៦១៖ អាត្មាមិនបានទៅរស់នៅទីនោះទេ ប៉ុន្តែអាត្មាទៅឃ្វាលគោនៅក្បែរនោះ។ ស៖ តើមានខ្មែរក្រោមប្រហែលប៉ុន្មាននាក់ ដែលត្រូវបានដាក់នៅក្នុងវត្តអង្គុញនោះ? ឆ.៦២៖ អាត្មាមិនដឹងទេ គ្រាន់តែបានទៅឃ្វាលគោនៅក្បែរនោះប៉ុណ្ណោះ។ ភូមិប្រាសាទ ភូមិអង្គុញគ្មានប្រជាជនមូលដ្ឋានរស់នៅនោះទេ ដូច្នេះហើយនៅទីនោះគឺសុទ្ធតែជាខ្មែរក្រោម។ ស៖ ពេលដែលគេយកអ្នកទាំងនោះទៅដាក់នៅវត្តអង្គុញនោះ តើអ្នកទាំងអស់នោះនៅរស់ឬ? ឆ.៦៣៖ នៅរស់។ ស៖ តើមានកុមារ និងស្ត្រីដែរឬទេ? ឆ.៦៤៖ មានទាំងយុវជន និងកុមារ។ ស៖ តើខ្មែរក្រោមដែលគេដាក់នៅក្នុងវត្តអង្គុញរយៈពេលប៉ុន្មានទើបគេយកទៅសម្លាប់? ឆ.៦៥៖ អាត្មាមិនដឹងថា គេយកទៅសម្លាប់នៅពេលណាទេ គ្រាន់តែបានធុំក្លិនស្អុយនៅពេលដែលអាត្មាទៅឃ្វាលគោ។ ស៖ តើព្រះតេជគុណបានឮពីអ្នកដទៃ ឬក៏អ្នកដទៃប្រាប់ថា ខ្មែរក្រោមត្រូវបានគេយកទៅសម្លាប់នៅខាងក្រៅវត្តនោះ? ឆ.៦៦៖ អត់មានទេ បើទោះបីជាគេដឹងក៏គេមិនហ៊ានប្រាប់ដែរ ប៉ុន្តែគឺពិតជាខ្មែរក្រោមតែម្តង”]។

[771] ឯកសារ D219/450 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.២ KH 01129744 [“គាត់គឺជាប្រធានកងរបស់ខ្ញុំ ដែលជាអ្នកបញ្ជាឲ្យឈ្លូបយក រ៉ូ [ក្មេងប្រុសដែលបានច្រៀងចម្រៀងវៀតណាម] ទៅសម្លាប់”] ឆ.៧ KH 01129745 [“បាទ ពួកយើង

230. ឌឹក ប៉ែត បាននិយាយថា ប្តីរបស់គាត់ត្រូវបានគេយកពីវត្តកំពែងទៅកាន់វត្តអង្គុញ និងបានដាក់ក្នុងមន្ទីរឃុំឃាំង បន្ទាប់មកសម្លាប់ចោល។ មុនពេលគាត់ចាកចេញ ប្តីរបស់ ឌឹក ប៉ែត បានប្រាប់គាត់ថា៖ "ស្អែកគេនឹងបញ្ជូនខ្ញុំទៅវត្តអង្គុញ ហើយនឹងត្រូវគេសម្លាប់ពេលទៅដល់វត្តអង្គុញ"។ ឌឹក ប៉ែត ក្រោយមកបាននិយាយថា ប្តីរបស់គាត់បានស្លាប់ហើយ។ សាកសពរបស់គាត់ត្រូវបានរកឃើញនៅខាងត្បូងវត្តអង្គុញ[772]។

231. ទាំងខ្មែរក្រោម "១៧ មេសា" និងទាំងប្រជាជនជម្លៀស ស្នាក់នៅក្នុងវត្តកំពែង ប៉ុន្តែពួកខាងក្រោយនេះគ្រាន់តែស្នាក់នៅជាបណ្តោះអាសន្នប៉ុណ្ណោះ។ មុនពេលដែលប្រជាជនជម្លៀសខ្មែរក្រោមបានមកដល់នៅដើមឆ្នាំ១៩៧៨ ខ្មែរក្រោម "១៧ មេសា" ទាំងអស់នៅក្នុងឃុំវត្តកំពែងត្រូវបានសម្លាប់ចោល[773]។

អាចឃើញការសម្លាប់ រ្ង ដោយសារពេលនោះ គឺពួកយើងនៅប្រហែល ៥០ម៉ែត្រប៉ុណ្ណោះ ពីកន្លែងដែលគេសម្លាប់ រ្ង។ [...] យើងបានឃើញឈ្លបវ៉ៃ រ្ង ជាមួយនឹងត្បូងចប នៅជិតកន្លែងប្រឡាយទឹក។ យើងឃើញឈ្លបវ៉ៃ រ្ង នឹងត្បូងចបពីខាងក្រោយក្បាល"]។ ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៧៧ KH 00993602 ["ស៖ តើលោកមានសំណូមពរបន្ថែមទៀតទេ? ឆ.៖ កាលខ្ញុំសរសេរប្រវត្តិរូបដែលឆ្លើយពីមុន ខ្ញុំអត់បានសរសេរពីរឿងហ្នឹងទេ មុនពេលវៀតណាមចូលមួយខែ បានទៅនៅវត្តអង្គុញបានប្រហែលមួយខែ។ កាលណោះ មេភូមិបាននិយាយថា ខ្ញុំធំហើយល្មមទៅនៅក្នុងកងរបស់គេបានហើយ បន្ទាប់មកខ្ញុំក៏ត្រូវបានគេបញ្ជូនឲ្យទៅនៅវត្តអង្គុញ។ ស៖ តើលោកបានឃើញអ្វីកើតឡើងនៅវត្តអង្គុញនៅពេលនោះដែរទេ? ឆ.៧៧៖ នៅម៉ោង១២ថ្ងៃត្រង់ យើងសម្រាកពីការងារជីកប្រឡាយដើម្បីហូបបបរ សម្រាកប្រហែលកន្លះម៉ោង។ ក្នុងពេលសម្រាកនោះ ខ្មែរក្រហមបានអនុញ្ញាតឲ្យពួកយើងច្រៀងចម្រៀងបទបដិវត្តន៍។ ពេលនោះមានអ្នកច្រៀងបទបដិវត្តន៍ បន្ទាប់មកខ្មែរក្រហមបានហៅម្នាក់ទៀតច្រៀងមានឈ្មោះ រ្ង បានច្រៀងបទវ៉ៃតណាមដោយភ្លេចខ្លួន បន្ទាប់ពីច្រៀងចប់ខ្មែរក្រហមឲ្យយើងទះដៃហើយ វាក៏អ្ងួសដៃឈ្មោះ រ្ង នោះចេញទៅហើយក៏វ៉ៃចោលនៅមុខទាំងអស់គ្នានៅក្បែរគុម្ពរពាក់នៅក្បែរនោះ"]។

[772] ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌឹក ប៉ែត ឆ.១៣១-១៣៣ KH 00979214 ["ឆ.១៣១៖ ដំបូងគេបញ្ជូនប្តីខ្ញុំទៅវត្តកំពែង បន្ទាប់មកទើបគេបញ្ជូនទៅវត្តអង្គុញ។ ស៖ វត្តដែលគេឲ្យលោកស្រីទៅជួបប្តីរបស់លោកស្រី គឺវត្តកំពែង តើត្រឹមត្រូវដែរឬទេ? ឆ.១៣២៖ ចាស ត្រឹមត្រូវ។ ស៖ ហេតុអ្វីបានជាលោកស្រីដឹងថា ប្តីរបស់លោកស្រីត្រូវគេបញ្ជូនទៅវត្តអង្គុញ? ឆ.១៣៣៖ ប្តីរបស់ខ្ញុំប្រាប់ថា "ស្អែកគេនឹងបញ្ជូនខ្ញុំទៅវត្តអង្គុញ ហើយនឹងត្រូវគេសម្លាប់ពេលទៅដល់វត្តអង្គុញ""] ឆ.១៦៣ KH 00979217 ["គាត់គ្រាន់តែប្រាប់ខ្ញុំថា ប្តីរបស់ខ្ញុំស្លាប់នៅខាងត្បូងវត្តអង្គុញនៅក្រោមដើមឈើ ដោយមានគ្របធាងភ្នោតមួយធាងពីលើ"]។

[773] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត ឆ.៦៨-៧០, ៧៥ KH 01112280, 81 ["ស៖ តើនៅក្នុងវត្តកំពែងមានខ្មែរក្រោម ត្រូវបានគេឃុំខ្លួន និងសម្លាប់ចោល ដែរ ឬទេ? ឆ.៦៨៖ បាទ មានខ្មែរក្រោម រស់នៅ និងធ្វើការនៅទីនោះកាលជំនាន់ប៉ុល ពត។ ខ្មែរក្រោម ត្រូវបានគេយកទៅដាក់នៅគ្រប់ឃុំ ក្នុងស្រុក១០៩។ ស៖ លោកនិយាយថា នៅវត្តកំពែង មានខ្មែរក្រោម រស់នៅដែរ តើខ្មែរក្រោម ដែលនៅក្នុងវត្តនោះ គឺជាខ្មែរក្រោម ១៧មេសា ឬខ្មែរក្រោម ដែលមកពីវៀតណាម? ឆ.៦៩៖ នៅពេលដែលខ្ញុំនៅក្នុងស្រុក១០៩ គឺមានខ្មែរក្រោម ជាអ្នក១៧មេសា រស់នៅក្នុងវត្តកំពែង។ ក្រោយមក ខ្មែរក្រោមដែលជម្លៀសមក

232. នៅចុងឆ្នាំ១៩៧៨ អាជ្ញាធរមូលដ្ឋាន ប.ក.ក នៅក្នុងស្រុកគីរីវង់ មានផែនការសម្លាប់ពួកខ្មែរក្រោមដែលនៅសេសសល់។ ប៉ែន ហ៊ាង បានរៀបរាប់ថា គាត់ត្រូវបានគេកោះហៅឲ្យទៅប្រជុំនៅភូមិស្ពែង ក្នុងឃុំគោកព្រិច ដែលនៅក្នុងនោះពួកគេបានពិភាក្សាពីការឲ្យពួកខ្មែរក្រោមទាំងអស់ឲ្យហូបអាហារ បន្ទាប់ពីនោះមកពួកគេនឹងត្រូវបានសម្លាប់។ គាត់បានថ្លែងថា ការប្រជុំស្រដៀងគ្នានេះបានកើតឡើងនៅក្នុងឃុំដទៃទៀត[774]។ យ៉ាងណាក៏ដោយ ឡាច សែម បានចងចាំថា ពួកកងទ័ពវៀតណាមបានមកដល់ មុនពេលផែនការនោះត្រូវបានអនុវត្ត[775]។

233. សាកសពរបស់ខ្មែរក្រោម ដែលត្រូវបានសម្លាប់ជាច្រើនត្រូវបានកប់នៅក្បែរបរិវេណវត្តអង្គុញ។ ឡាច សម្ត្ត្ति បាននិយាយលម្អិតថា គាត់បានឃើញផ្នែកនៃសាកសពដែលបានកប់នៅក្នុងរណ្តៅដែលមានចម្ងាយពីវត្ត ៥០ ទៅ ១០០ម៉ែត្រ នៅតាមផ្លូវគាត់ទៅធ្វើការនៅពេលព្រឹក[776]។ ម៉ី សុខាន់

ពីប្រទេសវៀតណាម ក៏ត្រូវបានដាក់នៅវត្តកំពែង ផងដែរ។ ខ្ញុំសូមបញ្ជាក់ថា វត្តកំពែងមិនមែនជាកន្លែងរស់នៅជាអចិន្ត្រៃយ៍របស់ពួកគេទេ ប៉ុន្តែជាកន្លែងស្នាក់នៅបណ្តោះអាសន្នតែប៉ុណ្ណោះ ដោយសារការដ្ឋានការងារជីកប្រឡាយ នៅក្បែរនោះ។ ស៖ តើលោកដឹងថា មានរឿងអ្វីកើតឡើងចំពោះខ្មែរក្រោមដែលជាអ្នក១៧ មេសា និងខ្មែរក្រោម ដែលជម្លៀសមកពីប្រទេសវៀតណាម? ឆ.៧០៖ ខ្ញុំដឹងថាខ្មែរក្រោម ដែលជាអ្នក១៧ មេសា ត្រូវបានគេសម្លាប់ដាក់ក្នុងចេតីយ៍ ក្នុងវត្តកំពែង។ ចំណែកខ្មែរក្រោម ដែលជម្លៀសមកពីប្រទេសវៀតណាម ខ្ញុំមិនដឹងមានរឿងអ្វីកើតឡើងចំពោះពួកគេទេ ព្រោះខ្ញុំបានចេញផុត ហើយមិនបានជួបពួកគេទេ។ [...] ឆ.៧៥៖ [...] ខ្ញុំឃើញសាកសពមនុស្សនៅក្នុងវត្តកំពែង ព្រោះមុនពេលដែលចាកចេញទៅស្រុកត្រាំកក់ គឺគេឲ្យទៅប្រជុំគ្នានៅវត្តកំពែង"]។

[774] ឯកសារ D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ហ៊ាង ឆ.៤១ KH 00968135 ["បាទ កាលនោះ នៅចុងឆ្នាំ១៩៧៨ នៅភូមិស្ពែង ឃុំគោកព្រិច ខ្មែរក្រហមហៅទៅប្រជុំនិយាយពីផែនការហូបនំបញ្ចុក ហូបបង្អែម។ កាលនោះនៅឃុំណាគេប្រជុំនៅឃុំនោះ។ ខ្ញុំឮគេថា ខ្មែរក្រហមមានផែនការយកខ្មែរក្រោមទៅរៃចោលទាំងអស់ពេលហូបនំបញ្ចុករួច"]។

[775] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៩៩-១០១ KH 00987237-38 ["ឆ.៩៩៖ ពេលដែលយួនជិតចូលមកដល់ ខ្មែរក្រហមបានរៀបចំធ្វើនំបញ្ចុក នំបាញ់ច្រមៀក នំបាញ់ឆុកជាដើម ដើម្បីឲ្យខ្មែរក្រោមហូប។ ការពិតខ្មែរក្រហមមានគម្រោងចង់សម្លាប់ខ្មែរក្រោមនៅពេលនោះ ប៉ុន្តែពុំបានសម្លាប់នោះទេ វៀតណាមក៏ចូលមកដល់តែម្តង។ ស៖ តើហេតុអ្វីបានជាលោកស្រីដឹងថា ខ្មែរក្រហមមានគម្រោងយកខ្មែរក្រោមទៅសម្លាប់? ឆ.១០០៖ គឺដឹងតៗគ្នា តែនៅពេលដែលឲ្យស៊ីច្រើនអ្វីច្នេះនឹងត្រូវគេយកទៅសម្លាប់ចោល។ ដំបូងគេបានប្រជុំនៅជិតមាត់ត្រពាំងមួយ ហើយពេលដែលរៀបចំហូបចុកក៏នៅជិតត្រពាំងនោះដែរ។ ក្រោយប្រជុំនោះមកពួកខ្ញុំបានខ្សឹបខ្សៀវគ្នាថា ពួកយើងនឹងត្រូវគេសម្លាប់ហើយ។ ត្រពាំងនោះធំណាស់។ ស៖ លោកស្រីនិយាយថា នៅកន្លែងផ្សេងទៀតពេលដែលគេឲ្យហូបចុកច្រើន គឺនឹងត្រូវគេយកទៅសម្លាប់ចោល តើមានរឿងនេះកោះតឡើងនៅកន្លែងណា? ឆ.១០១៖ ដំបូងគេឲ្យប្រជុំនៅជិតត្រពាំងនៅកំពែង គោកព្រិច ហើយគេប្រាប់អំពីគម្រោងហូបនំបញ្ចុក និងនំផ្សេងទៀតនៅជិតត្រពាំងនោះ។ ប៉ុន្តែពួកខ្ញុំពុំទាន់បានហូបចុកអ្វីទេ វៀតណាមក៏ចូលមកដល់"]។

[776] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៣៤ KH 01112274 ["នៅសម័យនោះ ប្រជាជនត្រូវបានគេយកទៅសម្លាប់ចោលនៅដីដំបូក"] ឆ.៣៦-៣៧, ៣៩-៤០ KH 01112274-75 ["ស៖ តើដីដំបូកទាំងនោះ នៅក្បែរវត្តអង្គុញមែន

បានចងចាំថា នៅចុងឆ្នាំ១៩៧៨ គាត់បានឃើញរណ្តៅកប់សាកសពរួមមួយ ដែលមានសាកសពខ្មែរក្រោមរលួយភាយក្លិនចេញមកក្រៅវត្តអង្គុញ។ សុខាន់ បាននិយាយថា គាត់បានដឹងថា សាកសពទាំងនោះជារបស់ខ្មែរក្រោម ដោយសារតែពួកគេត្រូវបានគេដាក់នៅក្នុងវត្តនេះ[777]។

234. ការសម្លាប់ពួកខ្មែរក្រោមទាំងនេះនៅវត្តអង្គុញ ហើយនិយាយជាទូទៅ នៅក្នុងឃុំកំពែង គឺជាលំនាំមួយនៃការសម្លាប់ក្រៅប្រព័ន្ធតុលាការ ដោយមានចេតនាលុបបំបាត់ពួកខ្មាំងរបស់ ប.ក.ក រួម

ទេ? ឆ.៣៦៖ បាទ ដីដំបូកនោះស្ថិតនៅក្បែរវត្តអង្គុញ ចម្ងាយប្រហែល៥០ម៉ែត្រ ១០០ម៉ែត្រ និង២០០ម៉ែត្រ ពីវត្ត។ ស៖ តើខ្មែរក្រោម ឬអ្នកដែលបានសង្ស័យថាជាខ្មែរក្រោម ត្រូវបានគេយកទៅសម្លាប់នៅដីដំបូកនោះដែរឬទេ? ឆ.៣៧៖ បាទ មាន។ [...] ស៖ ហេតុដូចម្តេចបានលោកដឹងថា មានការសម្លាប់មនុស្សនៅតាមដីដំបូកនៅក្បែរវត្តអង្គុញ? ឆ.៣៩៖ ខ្ញុំដឹងអំពីការសម្លាប់មនុស្សនេះ ដោយសារខ្ញុំធ្វើការនៅក្នុងកងយុវជន ហើយខ្ញុំស្នាក់នៅក្នុងវត្តអង្គុញនោះ។ [...] នៅពេកព្រឹកពេលទៅធ្វើការ ខ្ញុំឃើញសាកសពមនុស្ស ដែលគេកប់មិនជិត ដោយចេញដៃ ជើង។ ប៉ុន្តែនៅពេលនោះ យើងមិនហ៊ាននិយាយ និងសួរនាំទេ គឺដើរទៅធ្វើការ ដោយធ្វើមិនឃើញអ្វីទាំងអស់។ [...] ឆ.៤០៖ [...] ពេលខ្លះ មានការបាត់ខ្លួនមនុស្សដែលស្នាក់នៅជាមួយខ្ញុំនៅក្នុងវត្តអង្គុញម្នាក់ ពីរនាក់ ឬបីនាក់ក្នុងមួយសប្តាហ៍"] ឆ.៧៦-៧៩ KH 01112281 ["ស៖ មុននេះលោកនិយាយថា លោកបានឃើញសាកសពមនុស្សនៅវត្តអង្គុញ តើលោកមានចាំដែរ ឬទេ? ឆ.៧៦៖ បាទ ខ្ញុំបានឃើញសាកសពមនុស្សនៅដីដំបូក ពេលដែលខ្ញុំទៅធ្វើការ និងស្នាក់នៅវត្តអង្គុញ។ ប៉ុន្តែកាលនោះ មិនមែនមុនពេលដែលខ្ញុំទៅនៅស្រុកត្រាំកក់ទេ។ កាលនោះ ខ្ញុំធ្វើការនៅការដ្ឋានមួយ ហើយខ្ញុំស្នាក់នៅវត្តអង្គុញប្រហែលជា៥ថ្ងៃប៉ុណ្ណោះ។ ស៖ តើលោកធ្វើការ និងស្នាក់នៅវត្តអង្គុញ នៅក្នុងឆ្នាំណាដែរ? ឆ.៧៧៖ នៅចុងឆ្នាំ១៩៧៦"]។

[777] ឯកសារ D118/129 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សុខាន់ ឆ.៥៥-៦០ KH 00960575-76 ["ស៖ ព្រះតេជគុណបានមានសង្ឃដីកាថា "ពីឆ្នាំ១៩៧៨, ៧៩ ព្រះតេជគុណបានឃើញសាកសពនៅក្នុងរណ្តៅសពរួមនៅវត្តអង្គុញ ភូមិអង្គុញ ឃុំកំពែង ស្រុកគីរីវង់"។ ហេតុអ្វីបានជាព្រះតេជគុណឃើញ? ឆ.៥៥៖ អាត្មាបានឃើញនៅពេលដែលនៅពេលដែលសពនោះស្អុយទៅហើយ គឺនៅពេលដែលអាត្មាបានទៅឃ្វាលគោ។ ស៖ តើទីតាំងរណ្តៅសាកសពនោះនៅក្នុងបរិវេណវត្ត ឬនៅខាងក្រៅវត្ត? ឆ.៥៦៖ នៅខាងក្រៅវត្ត។ ស៖ តើព្រះតេជគុណឃើញនៅពេលណា? ឆ.៥៧៖ អាត្មាឃើញនៅចុងឆ្នាំ១៩៧៨ អំឡុងបុណ្យភ្ជុំបិណ្ឌ។ ស៖ តើព្រះតេជគុណឃើញសាកសពនោះមានប្រហែលប៉ុន្មានសាកសព?ឆ.៥៨៖ ឃើញរណ្តៅសពតែមួយកន្លែងប៉ុណ្ណោះ ឃើញសាកសពមនុស្ស ប៉ុន្តែមិនដឹងប៉ុន្មានទេ ហើយមានធុំក្លិនស្អុយពេក ដូច្នេះទើបអាត្មាចាកចេញទៅ។ ស៖ តើរណ្តៅសាកសពនោះមានទំហំប៉ុន្មាន? ឆ.៥៩៖ មានដំបូកពីរនៅសងខាងរណ្តៅ ហើយរណ្តៅនោះមានទទឹងប្រហែល២ម៉ែត្រ បណ្តោយប្រហែល៤ម៉ែត្រ។ [...] ស៖ ព្រះតេជគុណបានមានសង្ឃដីកាថា "សាកសពទាំងអស់នោះជាខ្មែរក្រោម។ អាត្មាដឹងថាជាខ្មែរក្រោមដោយសារខ្មែរក្រោមត្រូវបានគេដាក់ឲ្យនៅដាច់ពីភូមិខ្មែរធម្មតា។ ខ្មែរក្រោមទាំងអស់នោះរស់នៅភូមិប្រាសាទ ឃុំកំពែង"។ ហើយព្រះតេជគុណមានសង្ឃដីកាទៀតថា "អាត្មាបានឃើញសាកសព ហើយធុំក្លិនស្អុយ ដូច្នេះទើបអាត្មាចាកចេញទៅ"។ តើលោកអាចពន្យល់យើងអំពីបញ្ហានេះបានដែរឬទេ? ឆ.៦០៖ ព្រោះខ្ញុំនៅក្រោមទាំងអស់ហ្នឹងត្រូវបានប្រមូលយកទៅដាក់នៅវត្តអង្គុញ"]។

> បញ្ជូលទាំង អតីតទាហាន លន់ នល់[778] "ប្រជាជន ១៧ មេសា"[779] ក្រុមជាតិពន្ធុចិន[780] និង ប្រជាជនដែលបានចោទប្រកាន់ថាបានប្រព្រឹត្ត "កំហុស"[781] នៅតាមមូលដ្ឋាន។ ការសម្លាប់ត្រូវបានធ្វើឡើងដោយឈ្លបឃុំ"[782]។

---

[778] ឯកសារ D118/302 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន់ សារ៉ូ ឆ.៧២-៧៣ KH 01024567 ["ស៖ យើងចង់ដឹងអំពីអ្នករដ្ឋការ និងអតីតទាហាន លន់ នល់ ក្រោយពេលដែលខ្មែរក្រហមរំដោះប្រទេសបានភ្លាម តើមានអ្វីកើតឡើងចំពោះអ្នកទាំងអស់នោះ? ឆ.៧២ ៖ អ្នករដ្ឋការ និងអតីតទាហាន លន់ នល់ ត្រូវគេយកចេញទៅ តែខ្ញុំមិនដឹងថាគេយកទៅកន្លែងនាទេ។ [...] ឆ.៧៣៖ ជួនកាលគេហៅអ្នករដ្ឋការ និងអតីតទាហាន លន់ នល់ ទៅដាក់នៅមន្ទីរ២០៤ (ក្នុងស្រុកត្រាំកក់) តែខ្ញុំមិនដឹងលម្អិតទៀតនោះទេ"]។ ឯកសារ D118/269 កំណត់ហេតុស្តាប់ចម្លើយ ថាន់ ធីម ឆ.៤៤ KH 00998114 ["នៅភូមិស្វាយវ៉ែ ខ្មែរក្រហមបានឃោសនាថា អ្នកណាមានបណ្ដាសក្តិអ្វី កាលនៅរបបលន់ នល់ គេនឹងឲ្យទៅកាន់តំណែងក្នុងកងទ័ពវិញ ហើយបន្ទាប់មក ត្រូវទៅវ៉ៃជាមួយយួន តែការពិតទៅ ពួកគេយកទៅសម្លាប់ចោលទាំងអស់"] ឆ.៤៩ KH 00998114 ["ស៖ តើគេយកមនុស្សទាំងនោះ ទៅសម្លាប់នៅទីណា? ឆ.៤៩៖ អ្នកទាំងនោះ ប្រហែលជាគេយកទៅសម្លាប់នៅម្តុំព្រៃរលៀក ខាងត្បូងវត្តកំពែង ពីព្រោះកាលនោះ មានក្លិនស្អុយចេញពីទីនោះ"] ឆ.៥០ KH 00998116 ["ពួកខ្មែរក្រហមបានហៅប្រជាជនមកពីភូមិស្វាយវ៉ែ ភូមិជីម្រាក់ និងមកពីភូមិផ្សេងៗទៀត មកជួបជុំគ្នា និងហូបបបរ នៅវត្តកំពែង។ ដោយមនុស្សច្រើនពេក ហើយខ្លះចូលហូបច្រើនដង ប្រធានទៅទីនោះ ឈ្មោះ តាប៉ោ ជាមេឃុំកំពែង និងតា សារ៉ូ (ប៉ាន់ សារ៉ូ) ជាអនុមេឃុំកំពែង បានបញ្ជាឲ្យឈ្លបយកអ្នកដែលចូលហូបបបរពីរដង។ [...] ព្រឹកឡើងខ្ញុំបានឃើញសាកសពប្រាំនាក់នៅក្នុងវិហារ និងប្រហែល១៥នាក់ នៅខាងលិចវិហារ"] ឆ.៥៧ KH 00998116 ["ចុងឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានប្រមូលពួកខ្ញុំមកនៅស្រុកត្រាំកក់វិញ។ គេបានប្រមូលប្រជាជនពីភូមិផ្សេងៗមកផ្ទុំគ្នានៅវត្តកំពែង ដែលខ្ញុំបានឃើញមនុស្សស្លាប់ជាង២០នាក់ ដូចរៀបរាប់ខាងលើ។ ការសម្លាប់ គេធ្វើនៅពេលយប់ ហើយព្រឹកឡើង គេមកដឹកជញ្ជូនពួកខ្ញុំឲ្យទៅរស់នៅស្រុកត្រាំកក់។ ខ្ញុំស្ថិតនៅក្នុងព្រឹត្តិការណ៍នោះដែរ"]។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ប្ដត្ដិ ឆ.ពាព KH 01112274 ["ស៖ តើ ពូ និងបងប្រុស របស់លោក ត្រូវបានគេយកទៅសម្លាប់ ដោយសារមូលហេតុជាខ្មែរក្រោម ឬក៏ពួកគាត់ជាប់និន្នាការអតីតទាហានលន់ នល់? ឆ.ពាព៖ ពូ ខ្ញុំត្រូវបានគេយកទៅសម្លាប់ដោយសារជាអតីតទ័ាហានលន់ នល់។ ចំណែកបងប្រុសខ្ញុំ គឺជានិស្សិត។ ហេតុការណ៍នេះកើតឡើងក្នុងឆ្នាំ១៩៧៧"]។

[779] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ប្ដត្ដិ ឆ.៥៥ KH 01112278 ["គេ [ខ្មែរក្រហម] បានប្រាប់ឲ្យយើងជួបជុំគ្នានៅវត្តកំពែង ដើម្បីចាំឡានមកយកទៅស្រុក១០៥។ យើងត្រូវរង់ចាំរយៈពេល២ឆប់ នៅវត្តកំពែង។ នៅអំឡុងពេលដែលខ្ញុំរង់ចាំនៅក្នុងវត្តកំពែង គឺមានការសម្លាប់អ្នក១៧ មេសា ជាច្រើននៅទីនោះ ហើយសាសកសពត្រូវបានគេយកទៅដាក់នៅក្នុងចេតីយ៍"] ឆ.៦០-៦១ KH 01112278-79 ["ខ្ញុំគិតថា របៀបសម្លាប់មនុស្ស គឺមិនខុសគ្នារវាងពួក១៧មេសា និងខ្មែរក្រោមទេ។ ពួកខ្មែរក្រោម ត្រូវបានគេយកទៅសម្លាប់ចោលនៅក្នុងព្រៃតូចៗ។ [...] ពួកវា[ខ្មែរក្រហម]យកទៅសម្លាប់នៅតាមដីដំបូក ទួលស្រែផ្សេងៗ ក្បែរកន្លែងស្នាក់នៅ។ [...] អ្នក១៧មេសា ដូចជាពួកយើង គេគ្រាន់តែយកទៅកន្លែងជិតៗនោះប៉ុណ្ណោះ"]។ ឯកសារ D118/165 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ប្ដត្ដិ ឆ.១៨-២១ KH 00968145 ["ឆ.១៨៖ ពូរបស់ខ្ញុំឈ្មោះ ចៅ ម៉ុន អតីតទាហាន លន់ នល់ ហើយនិង បងខ្ញុំឈ្មោះ ឡាច សំបូរ ជានិស្សិតត្រូវគេសម្លាប់ហើយ នៅវត្តកំពែង។ ស៖ តើនៅក្នុងឆ្នាំណាដែលគេយកមកសម្លាប់នៅវត្តកមពែងហ្នឹង? ឆ.១៩៖ នៅចុងឆ្នាំ១៩៧៧ មុនពេលដែលយកខ្មែរក្រោមមកដាក់នៅឃុំកំពែង។ ស៖ លោកជាអ្នក១៧ មេសា តើលោកធ្លាប់ទៅវត្តកំពែងជាមួយគេដែរឬ? ឆ.២០៖ បាទ ខ្ញុំទៅដែរ។ ស៖ តើលោកឃើញដោយផ្ទាល់

ភ្ជុកទេ នៅពេលដែលលោកថាគេសម្លាប់មនុស្សនោះ? ឆ.២១៖ ខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកទេ ប៉ុន្តែអ្នកនៅលើឡានជាមួយខ្ញុំ បានខ្សឹបប្រាប់ខ្ញុំថា គេវាយមនុស្សចោលនៅពេញចេតី។ យុវជននៅកងជាមួយខ្ញុំគេហៅ ដោយប្រាប់ថា អង្គការឲ្យទៅដាំបន្លែ ប៉ុន្តែតាមការពិតគេយកទៅវាយចោល ខ្ញុំឃើញដោយផ្ទាល់ភ្នែកឈ្មោះ អ៊ីង គាត់ជាអតីតទាហាន លន់ នល់។ តាប៉ាល់ ជាអ្នកសម្លាប់ ហើយគាត់ស៊ីផ្ដើមមនុស្ស"]។ ឯកសារ D219/524 កំណត់ហេតុស្ដាប់ចម្លើយ ញេប ន៏ម ឆ.៥៨-៥៩, ៦១ KH 01149875 ["ស៖ កាលនោះ មានអ្នក១៧មេសាប៉ុន្មាននាក់ដែលគេបញ្ជូនទៅត្រាំកក់? ឆ.៥៨៖ រាប់រយគ្រួសារគឺ ១០ភូមិជាងគឺ យកទៅទាំងអស់ឲ្យតែជាពួក១៧មេសា។ ស៖ អ្នកទាំងអស់ហ្នឹងមានជនជាតិអ្វីខ្លះ? ឆ.៥៩៖ មានចិនខ្លះ ខ្មែរខ្លះ ចាមខ្លះ។ មានបីសាសន៍ហ្នឹង។ គេប្រមូលទៅនៅឆ្នាំ១៩៧៦។ [...] ស៖ តើលោកមានដែលឮ ថាតើ មានអ្នកដែលគេបញ្ជូនទៅធ្វើការនោះ ត្រូវបានគេចាប់យកទៅឃុំឃាំងនៅក្រាំងតាចាន់ទេ? ឆ.៦១៖ ខ្ញុំឮថា អ្នកខ្លះត្រូវបានគេថាយកទៅមណ្ឌលកែប្រែមន្ទីរ២០៤ ដើម្បីទៅរៀនសូត្រ"]។

[780] ឯកសារ D118/165 កំណត់ហេតុស្ដាប់ចម្លើយ ឡាច សម្ផត្ដិ ឆ.៨ KH 00968143 ["ពួកគ្រួសារចិនគេឲ្យនៅភូមិអាងខ្ចៅ នៅក្នុងឃុំកំពែង ហើយបន្ទាប់មក តាញេប ដែលជាមេឃុំ [...] គាត់ចាប់បានប្ដីរបស់ជនជាតិចិនយកទៅវ៉ៃចោលនៅឆ្នាំ១៩៧៥ [ភាសាខ្មែរ៖ នៅឆ្នាំ១៩៧៦] ហើយគាត់ចាប់ប្រពន្ធរបស់គេរំលោភទាំងអស់"]។

[781] ឯកសារ D219/471 កំណត់ហេតុស្ដាប់ចម្លើយ ត៏ម ផល ឆ.១៨ KH 01133414 ["អ្នកដែលធ្វើខុសនៅក្នុងឃុំ គឺត្រូវឈ្លបឃុំជាអ្នកចាប់"] ឆ.១៣៣ KH 01133428 ["ស៖ មុននេះលោកស្រីរៀបរាប់ពីនីតិវិធីនៅក្នុងឃុំកំពែង គឺលោកស្រីត្រូវបានគេប្រាប់ឲ្យតាមដានជនខិលខូចរាយការណ៍ទៅថ្នាក់ស្រុក ហើយបន្ទាប់មកមានមនុស្សត្រូវបានគេចាប់ខ្លួន តើដូចគ្នា ឬក៏ខុសគ្នានៅក្នុងឃុំគោកព្រេច? ឆ.១៣៣៖ ចាស គឺដូចគ្នា"]។ ឯកសារ D118/269 កំណត់ហេតុស្ដាប់ចម្លើយ ថាន់ ធីម ឆ.៥៦ KH 00998116 ["ពួកខ្មែរក្រហមបានហៅប្រជាជនមកពីភូមិស្វាយវ៉ែ ភូមិជីម្រាក់ និងមកពីភូមិផ្សេងៗទៀត មកជួបជុំគ្នា និងហូបបបរ នៅវត្ត កំពែង។ ដោយមនុស្សច្រើនពេក ហើយខ្លះចូលហូបច្រើនដង ប្រធាននៅទីនោះ ឈ្មោះ តាប៉ោះ ជាមេឃុំកំពែង និងតា សារ៉ូ (ប៉ាន់ សារ៉ូ) ជាអនុមេឃុំកំពែង បានបញ្ជាឲ្យឈ្លបយកអ្នកដែលចូលហូបបបរពីរដង។ [...] ព្រឹកឡើង ខ្ញុំបានឃើញសាកសពប្រាំនាក់ នៅក្នុងវិហារ និងប្រហែល១៥នាក់ នៅខាងលិចវិហារ"]។

[782] ឯកសារ D219/471 កំណត់ហេតុស្ដាប់ចម្លើយ ត៏ម ផល ឆ.១៨ KH 01133414 ["អ្នកដែលធ្វើខុសនៅក្នុងឃុំ គឺត្រូវឈ្លបឃុំជាអ្នកចាប់"] ឆ.៦០ KH 01133419 ["ស៖ នៅក្នុងកិច្ចប្រជុំថ្នាក់ស្រុក តើមាននិយាយពីរឿងយកមនុស្សទៅសម្លាប់ដែរ ឬទេ? ឆ.៦០៖ ចាស នៅក្នុងកិច្ចប្រជុំ គឺមាននិយាយពីការសម្លាប់ "ឲ្យតែខ្ទាំង គឺត្រូវតែសម្លាប់" អ្នកដែលត្រូវគេចាប់គឺមិនដែលឃើញត្រឡប់មកវិញឡើយ"]។ ឯកសារ D118/131 កំណត់ហេតុស្ដាប់ចម្លើយ សាន់ ទូច ឆ.៤០-៤៣ KH 00960603-04 ["ស៖ តើអ្នកណា ជាអ្នកសម្លាប់អ្នកទាំងអស់នោះ? លោកស្គាល់ឈ្មោះដែរឬទេ? ពួកគេជាទាហានឬ? ឆ.៤១៖ ខ្ញុំមិនស្គាល់ទេ ដឹងតែជាខ្មែរក្រហម។ ពួកគេជាឈ្លប មិនមែនជាទាហាន។ [...] ស៖ តើមានការបញ្ជាឲ្យសម្លាប់អ្នកទាំងនោះពីមេឃុំដែរឬទេ? ឆ.៤២៖ ខ្ញុំគិតថា បើមេឃុំមិនអនុញ្ញាតឲ្យសម្លាប់ អ្នកនៅក្រោមមិនហ៊ានសម្លាប់នោះទេ។ ស៖ តើលោកចង់សំដៅលើមេឃុំកំពែងមែនទេ? ឆ.៤៣៖ បាទ"]។ ឯកសារ D219/379 កំណត់ហេតុស្ដាប់ចម្លើយ ឡាច សម្ផត្ដិ ឆ.៧៨-៧៩ KH 01112281 ["ស៖ នៅពេលដែលលោកឃើញសាកសព នៅជីដំបូកក្បែរវត្តអង្គុញ តើលោកដឹងថានរណាជាអ្នកសម្លាប់? ឆ.៧៨៖ ខ្ញុំគិតថា ប៉ាល់ និងឈ្លបឃុំ ព្រោះ ប៉ាល់ ដែលជាប្រធានកងយុវជន រាយការណ៍ទៅឈ្លបឃុំ។ ដូច្នេះ ឈ្លបឃុំអាចមកសម្លាប់មនុស្សទាំងអស់នោះ។ ស៖ តើលោកដឹងថា ថ្នាក់ស្រុកដឹងអំពីការសម្លាប់មនុស្សនេះដែរ ឬទេ? ឆ.៧៩៖ បាទ ខ្ញុំគិតថា ថ្នាក់ស្រុកដឹងអំពីរឿងនេះ"]។

ការធ្វើទុក្ខបុកម្នេញ

235. ការធ្វើទុក្ខបុកម្នេញត្រូវបានប្រព្រឹត្តឡើងតាមរយៈឧក្រិដ្ឋកម្ម ដូចបានរៀបរាប់ខាងលើប្រឆាំងនឹងខ្មែរក្រោម។ ក្រុមនេះត្រូវបានកំណត់គោលដៅយ៉ាងជាក់លាក់ ដោយសារតែសមាជិកភាពរបស់ខ្លួននៃក្រុមនយោបាយមួយដែលពិតប្រាដក ឬតាមការយល់ឃើញរបស់គេ[783]។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

236. ផ្អែកលើភស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងទីតាំងសម្លាប់មនុស្សវត្តអង្គុញ៖[784] អំពើប្រល័យពូជសាសន៍ក្រុមជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា (ជាពិសេសខ្មែរក្រោម)[785] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[786] ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងពួកខ្មែរក្រោម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)។

---

[783] *សូមមើល* V.គ.៣.ក. ឧក្រិដ្ឋកម្ម - ឧក្រិដ្ឋកម្មប្រឆាំងនឹងវៀតណាម – គោលនយោបាយរបស់ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាម – ចេតនារបស់ ប.ក.ក ចំពោះប្រជាជនវៀតណាម និងខ្មែរក្រោម។

[784] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះគឺជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងអតីតសមាជិករបប លន់ នល់ និង "ប្រជាជន១៧ មេសា" និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ និងការធ្វើបាបដោយអមនុស្សធ៌ម)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះ តាមរយៈ៖ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១៥។

[785] *សូមមើល* V.គ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងវៀតណាម។

[786] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងទាក់ទងនឹងទីតាំងសម្លាប់មនុស្សវត្តអង្គុញតែមួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងទីតាំងសម្លាប់មនុស្សវត្តអង្គុញផង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់បង្កើតបានជាផ្នែកនៃប្រព័ន្ធមួយដែលមានការរៀបចំ ក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង ហើយការសម្លាប់នៅតាមទីតាំងនិមួយៗទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ីម ទិត្យ។

គ. ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង

i. សេចក្ដីផ្ដើម

237. ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែងមានទីតាំងស្ថិតនៅក្នុងស្រុកគិរីវង់ តំបន់១៣ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ អាជ្ញាធរមូលដ្ឋានរបស់ ប.ក.ក បានសម្លាប់ខ្មែរក្រោម និងអ្នកផ្សេងទៀត ដែលពួកគេយល់ឃើញថាជា "ខ្មាំង" នៅភូមិស្ពែង និងនៅក្នុងព្រៃជាប់នោះ។ ភូមិស្ពែង ក៏ត្រូវបានប្រើជាទីកន្លែងប្រជុំសម្រាប់អាជ្ញាមូលដ្ឋានភូមិឃុំផងដែរ។ ដូចក្នុងករណីនៅទូទាំងស្រុកគិរីវង់ សមាជិក JCE បានកំណត់គោលដៅលើខ្មែរក្រោមនៅភូមិស្ពែង និងភូមិនៅជិតនោះក្នុងឃុំគោកព្រេច ដែលបានសម្លាប់មនុស្សជាច្រើននាក់។

238. ភូមិស្ពែង និងព្រៃនៅជាប់នោះស្ថិតនៅក្នុងតំបន់ភូមិសាស្ត្រនៅក្រោមការគ្រប់គ្រងផ្ទាល់របស់ **យ៉ីម ទិត្យ** ក្នុងតួនាទីរបស់គាត់ជាអនុលេខា និងក្រោយមកជាលេខាគណៈស្រុកគិរីវង់ ក៏ដូចជាសមាជិកគណៈតំបន់១៣ ផងដែរ។ **យ៉ីម ទិត្យ** គឺជាសមាជិកឈានមុខនៃ JCE និងបានចូលរួមចំណែកក្នុងឧក្រិដ្ឋកម្មនៅភូមិស្ពែង។

239. ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** អំពីឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ប្រឆាំងនឹងខ្មែរក្រោម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ) ការរំលោភយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណាវ ឆ្នាំ១៩៤៩ (អំពើមនុស្សឃាតដោយចេតនា និងការនិរទេស ឬការបញ្ជូនជនស៊ីវិលដោយខុសច្បាប់) និងឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតគិតទុកជាមុនតាមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[787]។

---

[787] ឯកសារ D350.1 សេចក្ដីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426544-45, 49, 59។

ii. ប្រតិបត្តិការ និងទីតាំង

240. ក្នុងឆ្នាំ១៩៧៨ កងកម្លាំង ប.ក.ក បានអនុវត្តការសម្លាប់ខ្មែរក្រោមក្នុងទ្រង់ទ្រាយធំនៅភូមិស្ពែង នៅព្រៃជាប់ភូមិនេះ និងនៅតាមទីកន្លែងទាំងអស់ក្នុងស្រុកគិរីវង់[788]។ ភូមិស្ពែងមានទីតាំងស្ថិតនៅក្នុងឃុំគោកព្រេច ស្រុកគិរីវង់ តំបន់១៣ នៃភូមិភាគនិរតី[789]។ វាមានវត្តមួយ ដែលមានទីតាំងស្ថិតនៅភាគខាងលិចផ្លូវកាត់តាមភូមិនេះ[790]។ វត្តស្ពែងត្រូវបានប្រើជាគុកបណ្តោះអាសន្ន មុនពេលគេ ប្តូរវាទៅកាន់វត្តព្រះធាតុក្នុងឆ្នាំ១៩៧៤[791]។ នៅភាគខាងកើត ភូមិស្ពែងមានព្រំប្រទល់ជាប់នឹងព្រៃ និងជើងភ្នំនៅក្បែរនោះ ដែលជាទីតាំងរណ្តៅសម្លាប់មនុស្ស[792]។ ភូមិស្ពែងស្ថិតនៅជិតនឹងមន្ទីរមួយក្នុង

---

[788] *សូមមើល* V.ក.១.ค.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់១៣ – ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង – ឧក្រិដ្ឋកម្ម – ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)។ V.ค.๕.ค.vi. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – ឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនវៀតណាមនៅភូមិភាគនិរតី - ការប្រព្រឹត្តលើជនជាតិវៀតណាម និងខ្មែរក្រោម នៅស្រុកគិរីវង់ ឆ្នាំ១៩៧៥-១៩៧៩ – ភូមិស្ពែង។

[789] ឯកសារ D118/169.1.19b សេចក្តីសង្ខេបពាក្យបណ្តឹង កៀន ភ័ម EN 00511538 ["បន្ទាប់ពីប្រហែលជា ១៥ថ្ងៃ អ្នកដាក់ពាក្យប្តឹង ជាមួយនឹងមនុស្ស ១០០នាក់ ត្រូវបានបញ្ជូនទៅកាន់ភូមិស្ពែង ឃុំកំពែង (ពីមុនស្ពែងស្ថិតនៅក្នុងឃុំគោកព្រេច) ស្រុកគិរីវង់ ខេត្តតាកែវ។"]។ ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.៩ KH 01104662 ["ឆ៖ តើស្រុកគិរីវង្សនៅក្នុងតំបន់ និងភូមិភាគអ្វី? ឆ.៩៖ គេហៅថាតំបន់១៣ ខេត្តតាកែវ ហើយស្ថិតនៅក្នុងភូមិភាគនិរតី។"]។

[790] ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៧៣-៧៤ KH 01110212។

[791] ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៥១ KH 01110210 ["ភូមិស្ពែងមានមន្ទីរឃុំឃាំងនៅក្នុងវត្តស្ពែង ដែលជាមន្ទីរឃុំឃាំងក្រោមដី។ ខ្ញុំស្គាល់មន្ទីរឃុំឃាំងនេះ ប៉ុន្តែខ្ញុំមិនដែលទៅទេ។"] ឆ.៦៨-៧០ KH 01110211-12 ["ឆ.៦៨៖ ដំបូងឡើងគេសង់គុកនៅវត្តស្ពែង ខ្ញុំដឹងតាមរយៈ តាតុំ គាត់ទៅទីនោះ គាត់និយាយ ហើយនៅឆ្នាំ១៩៧៤ គេរើគុកមកវត្តប្រធាតុវិញ។ ស៖ តើលោកឮនៅឯណា ពេលដែលតាតុំ គាត់និយាយនោះ? ឆ.៦៩៖ កន្លែងខ្ញុំនៅវត្តពោធិ៍រោង។ ស៖ តើកន្លែងហ្នឹងដែល តាតុំ និយាយពីរឿងគុកវត្តស្ពែង? ឆ.៧០៖ បាទ។"]។ ឯកសារ D118/156 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.១៨ KH 00968089 ["ស៖ ហេតុអ្វីបានជាលោកដឹងថា នៅឆ្នាំ១៩៧៤ ខ្មែរក្រហមយកវត្តព្រះធាតុធ្វើជាមន្ទីរឃុំឃាំង? ឆ.១៨៖ ខ្មែរក្រហមបានរើគុកពីវត្តស្ពែងនៅឃុំគោកព្រេច យកមកដាក់នៅវត្តព្រះធាតុនេះដោយសារតែវត្តព្រធាតុមានទំហំធំជាង ហើយនិងស្ងាត់ជាងនៅវត្តស្ពែង។"]។

[792] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.២៦ KH 00993596 ["នៅទីនោះមានដើមឈើធំៗ គឺជាព្រៃមួយ ព្រោះវាធំណាស់ គ្មានទណ្ឌណាដើរចូលចុះទេ ព្រោះមានដើមឈើដែលមានបន្ទាត្រើនខាងកើត និងខាងក្រោយវត្តស្ពែងនៅក្បែរជើងភ្នំ។"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សេម ឆ.១០៩-១១០ KH 00987239 ["ស៖ តើលោកស្រីឃើញលលាដ៍ក្បាលនៅកន្លែងណា? ឆ.១០៩៖ ខ្ញុំឃើញ [...] នៅខាងលិចវត្តស្ពែង។ ស៖ នៅក្បែរកន្លែងសម្លាប់មនុស្សនេះមានព្រៃដែរឬទេ? ឆ.១១០៖ ចាស នៅពេលនោះគឺសុទ្ធតែព្រៃ។"]។

ចំណោមមន្ទីរនានារបស់ស្រុកគិរីវង់ នៅក្នុងភូមិចំបក់ ដែលជាកន្លែង **យ៉ីម ទិត្យ** ធ្វើការជាមួយនឹងគណៈស្រុកនេះ[793]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និង ការប្រាស្រ័យទាក់ទង

241. ភូមិស្ពែង និងឃុំគោកព្រេចនៅក្បែរនោះ ស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គណៈស្រុកគិរីវង់។ **យ៉ីម ទិត្យ** គឺជាសមាជិកគណៈនេះ និងបានអនុវត្តគោលនយោបាយខ្ជាំង និងការធ្វើឲ្យទៅជាទាសករតាមទម្រង់ JCE នៅក្នុងស្រុកនេះ តាមរយៈបទបញ្ជាឲ្យធ្វើការចាប់ខ្លួនក្រៅប្រព័ន្ធតុលាការ និងតាមរយៈការលើកកម្ពស់គោលនយោបាយនានា ដែលបានអនុវត្តអំណាចកម្មសិទ្ធិផ្ទាល់ខ្លួនលើជនស៊ីវិលនៅក្នុងភូមិទាំងឡាយ រួមទាំងភូមិស្ពែង និងតំបន់ជិតវានេះផង។

242. ចាប់ពីយ៉ាងហោចណាស់ឆ្នាំ១៩៧៥ **យ៉ីម ទិត្យ** គឺជាលេខាស្រុកគិរីវង់ ឬជាអនុលេខា[794] និងបានបន្តកាន់មុខតំណែងនេះចាប់ពីខែមេសា រហូតដល់ខែឧសភា ឆ្នាំ១៩៧៨[795] ខណៈដែលក្នុងពេលជាមួយ

---

[793] ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.២៥-២៧ KH 01104663 ["ឆ.២៥៖ ខ្ញុំធ្វើជានិរសារឲ្យស្រុកមានដូចជា ខៀវ តុំ, តាទិត្យ, និង លីបូ ហើយខ្ញុំទទួលខុសត្រូវចែកចាយសំបុត្រទៅឃុំផ្សេងៗ។ ស៖ នៅពេលនោះតើមន្ទីរស្រុកមានទីតាំងនៅកន្លែងណា? គឺនៅភូមិចំបក់ ឃុំគោកព្រេច ស្រុកគិរីវង់ ឬស្រុក ១០៩។ ស៖ សមាជិកស្រុកទាំងបីនាក់ ដែលមានខៀវ តុំ, តាទិត្យ, និងបូ តើនៅក្នុងកន្លែងតែមួយឬ? ឆ.២៧៖ ចាស ពួកគេទាំងបីធ្វើការនៅក្នុងកន្លែងតែមួយរួមគ្នា។"]។

[794] ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.១០, ១៣ KH 01104662។ ឯកសារ D118/23 កំណត់ហេតុស្តាប់ចម្លើយ ឌីម ផល ឆ.១១-១៤ KH 00981160។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ ឌីម ភី ឆ.១១-១២ KH 00891148។ ឯកសារ D219/160 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.៧ KH 01059383។ ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៤-៥, ៩ KH 00905848។ ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ឈួន ឆ.៧ KH 00905853។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ ឥប ផាន ឆ.២៩ KH 01024599។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.១៣ KH 01047179។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.២៦, ៤០-៤១ KH 01102934, 36។ ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ីន ឆ.៤-៧ KH 00891153-54។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ប្រត្តិ ឆ.១៣-១៥ KH 01112269-70។ ឯកសារ D65.1.3 គម្រោងជម្រុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ឡេង អាន់ និង យ៉ីម ទិត្យ EN 00704584។

[795] ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.១០, ១៣ KH 01104662។ ឯកសារ D118/23 កំណត់ហេតុស្តាប់ចម្លើយ ឌីម ផល ឆ.១១-១៤ KH 00981160។ ឯកសារ D219/160 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.៧ KH 01059383។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ ឌីម ភី ឆ.១១-១២ KH 00891148។ ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៤-៥, ៩ KH 00905848។ ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ឈួន ឆ.៧ KH 00905853។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ ឥប ផាន ឆ.២៩, ៩៩-១០១ KH 01024599, 605-606។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.១៣ KH 01047179។ ឯកសារ D219/346 កំណត់ហេតុស្តាប់

គ្នានោះ រូបគាត់អនុវត្តគោលនយោបាយ ប.ក.ក ក្នុងភូមិភាគពាយ័ព្យ[796]។ គណៈស្រុកបានទំនាក់ទំនងជាប្រចាំជាមួយនឹងមន្ត្រីឃុំតាមរយៈការប្រជុំស្រុកទាំងមូល[797] និងការទំនាក់ទំនងជាលាយលក្ខណ៍អក្សរ[798]។ គណៈនេះបានបញ្ជាឲ្យមន្ត្រីឃុំរាយការណ៍អំពីប្រជាជន ដែលគេជឿជាក់ថាជាខ្មាំង និងដើម្បីពិភាក្សាអំពីការចាប់ខ្លួន។ នៅក្នុងរបាយការណ៍ និងការពិភាក្សាទាំងនេះ ខ្ញែរក្រោមត្រូវបានគេកំណត់អត្តសញ្ញាណថាជាខ្មាំង[799]។ គណៈស្រុកបានបញ្ជូនបញ្ជីឈ្មោះមនុស្សត្រូវចាប់ខ្លួន ទៅកាន់ឃុំ និងគណៈយោធាស្រុក[800]។

ចម្លើយ ទន់ ស្ងួន ឆ.២៦, ៤០-៤១ KH 01102934, 36។ ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស្ងួន ឆ.៤-៧ KH 00891153-54។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត ឆ.១៣-១៥, ២២ KH 01112269-71។ ឯកសារ D65.1.3 គម្រោងជម្រុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ឡេង អាន់ និង យ៉ីម ទិត្យ EN 00704584 ។ *សូមមើលផងដែរ* ឯកសារ D1.3.11.48 បទសម្ភាសន៍ សៀង ហោម ដោយ SOAS EN 00217750។ ឯកសារ D1.3.11.56 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស្ងួន ដោយ ក.ស.ច EN 00219282។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤២ KH 01034069។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.២៧ KH 01068052។

[796] *សូមមើល* III.ឃ.២. មុខតំណែងរបស់ យ៉ីម ទិត្យ អំពើ និង ទង្វើ – ការចូលរួមប្រព្រឹត្តរបស់ យ៉ីម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្ម រួម នៅភូមិភាគពាយ័ព្យ – ការចូលរួមចំណែករបស់ យ៉ីម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ។

[797] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ីម ផល ឆ.៣៣-៣៧, ៤៣, ៤៥-៤៦, ៤៩, ៦០ KH 01133416-19។ ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ ល្ងួន មល់ ឆ.៥៨, ៩៦ KH 01104667, 71។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ តិម ភី ឆ.២២ KH 00891149។ ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៣២ KH 01110208។ ឯកសារ D219/66 កំណត់ហេតុស្តាប់ចម្លើយ គង់ ផោម ឆ.៥៧ KH 01037204។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃូ ភ្ជុំ ឆ.១៧៥-៨០, ១៩៥ KH 01117238-40។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឆ.២៩ KH 01024599។ ឯកសារ D219/521 កំណត់ហេតុស្តាប់ចម្លើយ ទ្រីម (ត៉ីប) ភី ឆ.៣៨-៤២, ៤៨ KH 01149834-35។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.១៩ KH 01068050។ *សូមមើលផងដែរ* ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ុង វេត ឆ.៤០-៤៧ KH 01136707-08។

[798] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ីម ផល ឆ.៤៥ KH 01133417។ ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ ល្ងួន មល់ ឆ.៣១ KH 01104664។

[799] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ីម ផល ឆ.១៣៤-៣៦ KH 01133428-29។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៤០-៤៣ KH 00788846។

[800] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ីម ផល ឆ.៩, ១៥-១៦ KH 01133413-14។ ឯកសារ D118/302 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន់ សារ៉ូ ឆ.៨៧ KH 01024569។ *សូមមើលផងដែរ* ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ុង វេត ឆ.១២១ KH 01136721។ ឯកសារ D1.3.11.18 បទសម្ភាសន៍ ហោ យ៉ន ដោយ SOAS EN 00217607។

iv. ឧក្រិដ្ឋកម្ម

<u>ការនិរទេស និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ)</u>

243. នៅដើមឆ្នាំ១៩៧៨ អង្គភាពកងទ័ព ប.ក.ក បានឆ្លងកាត់ព្រំដែនទៅកាន់ប្រទេសវៀតណាម និងបានបញ្ជូនដោយបង្ខំពួកប្រជាជនខ្មែរក្រោមពីខេត្តអានយ៉ាង ប្រទេសវៀតណាម ទៅកាន់កន្លែងជាច្រើនក្នុងតំបន់១៣ រួមទាំងស្រុកគិរីវង់ផងដែរ។ ពេលមកដល់ និរទេសជនខ្មែរក្រោមត្រូវបានបង្ខំឲ្យធ្វើការ ឬឲ្យចូលរួមជាមួយអង្គភាពកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដើម្បីច្បាំងទល់នឹងវៀតណាម។ ខ្មែរក្រោមជាច្រើនក្នុងចំណោមអ្នកទាំងនេះត្រូវបានសម្លាប់។

244. នៅពេលមកដល់ឃុំគោកព្រេច និរទេសជនខ្មែរក្រោមត្រូវបានបង្ខំឲ្យនៅក្នុងភូមិដ៏ធំមួយដែលគេបោះបង់ចោល[801]។ ខ្មែរក្រហមបានផ្លាស់អ្នករស់នៅក្នុងភូមិមុនចេញអស់ អ្នកទាំងនោះជាប្រជាជនមូលដ្ឋាន និងប្រជាជនថ្មី[802]។ សាន់ ទូច បានរៀបរាប់អំពីរបៀបដែលនិរទេសជនខ្មែរក្រោម

---

[801] ឯកសារ D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ហ៊ាង ឆ.១៩ KH 00968132-33 ["ស៖ នៅភូមិច្រកដីគាំហ្ម៊ីង នៅជាមួយអ្នកមូលដ្ឋានឬ? ឆ.១៩៖ អត់ទេ សុទ្ធតែអ្នកថ្មី។ នៅក្នុងក្នុងឃុំកំពែង និងឃុំគោកព្រេច សុទ្ធតែខ្មែរក្រោមរស់នៅ។"]។ ឯកសារ D118/163 កំណត់ហេតុស្តាប់ចម្លើយ ព្រ៊ុំ សារឿន ឆ.១០ KH 00968120 ["ស៖ តើមានអ្នកភូមិប៉ុន្មានដែរ ពេលគេជម្លៀសមកនោះ? ឆ.១០៖ ប្រហែលជា ២០០ គ្រួសារ បើយើងគិតជាមធ្យមបួនទៅ៥ ក្នុងមួយគ្រួសារ ប្រហែលជា ៦០០ ទៅ៨០០នាក់។"]។ ឯកសារ D219/449 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម យោន ឆ.៤០ KH 01129737 ["ពេលដែលយើងមកដល់ភូមិស្ពែងមិនមានមនុស្សរស់នៅក្នុងភូមិនោះទេ។"]។ ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងរ ឆ.១០៤-១០៥ KH 01022435 ["ស៖ តាមលោកស្រីដឹង តើភូមិព្រាលដែលប្រជាជនរស់នៅ ស្ថិតនៅកន្លែងណា? ឆ.១០៤៖ តាមខ្ញុំយល់ប្រជាជននៅភូមិព្រាល ត្រូវបានគេបញ្ជូនទៅភូមិលើ១ទៀត។ នៅចម្ងាយប្រហែល១ ឬ២ គីឡូម៉ែត្រ ខ្ញុំបានជួបយោធាម្នាក់ឬពីរនាក់ នៅតាមផ្លូវពីភូមិព្រាលទៅភូមិស្ពែង។ ស៖ លោកស្រីនិយាយថា អ្នកភូមិព្រាលត្រូវបានគេជម្លៀសទៅនៅភូមិលើ១ហើយ។ ចុះលោកស្រីសង្កេតឃើញមានផ្ទះសម្បែងនៅក្នុងភូមិនោះទេ? ឆ.១០៥៖ ពេលឆ្លងកាត់ភូមិព្រាល ខ្ញុំមិនឃើញមានផ្ទះទេ។ នៅពេលដែលយើងទៅជិតដល់វត្តស្ពែងហើយទើបបានឃើញមានផ្ទះមួយចំនួន តែមិនឃើញមានមនុស្សរស់នៅទេ។"]។ ឯកសារ D118/203] កំណត់ហេតុស្តាប់ចម្លើយ ឌីក ប៉ែត ឆ.៥៤ KH 0979207 ["ស៖ តើមានមនុស្សមកពីកន្លែងផ្សេងធ្វើការនៅក្នុងកន្លែងរបស់លោកស្រីធ្វើការដែរឬទេ? ឆ.៥៤៖ មានតែអ្នកភូមិរបស់ខ្ញុំប៉ុណ្ណោះ ដែលធ្វើការនៅកន្លែងនោះ ហើយប្រជាជនមូលដ្ឋានត្រូវគេបញ្ជូនឲ្យទៅធ្វើការនៅកន្លែងផ្សេងមុនពេលដែលពួកខ្ញុំទៅដល់។"]។

[802] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ថិ ឆ.៤៤ KH 01112276 ["គោលនយោបាយនេះចេញមកពីអង្គការថ្នាក់លើ។ [...] គ្រាន់តែដឹងថាគោលនយោបាយនេះ ត្រូវបានបញ្ជូនបន្តមកឃុំ និងក្រុមយុវជន។ នៅឆ្នាំ១៩៧៧ គេបានបញ្ជូនពួកខ្ញុំដែលជាអ្នក១៧ មេសា ទៅនៅស្រុក១០៥ (ស្រុកត្រាំកក់) ហើយបញ្ជូនពួកខ្មែរក្រោម មកពីវៀតណាម មកនៅស្រុក១០៩ (ស្រុកគិរីវង់) វិញ។"]។ ឯកសារ D118/269 កំណត់ហេតុស្តាប់ចម្លើយ ថាន់ ធីម ឆ.៥៧ KH 00998116 ["ចុងឆ្នាំ១៩៧៧ ពួក

ប្រមាណជា ៣០០នាក់ ត្រូវបានគេបែងចែកទៅកាន់ភូមិក្បែរខាងចំនួនប្រាំក្នុងឃុំគោកព្រេច រួមទាំងភូមិស្ពែងផងដែរ[803] ដែលអ្នកតាំងលំនៅសុទ្ធតែជាខ្មែរក្រោម[804]។ និរទេសជន រួមមានកុមារ និងមនុស្សចាស់ បន្ទាប់មកត្រូវគេបង្ខំឲ្យធ្វើការក្នុងសកម្មភាពកសាងកសិកម្ម ឬនៅសមរភូមិមុខ[805]។

ខ្មែរក្រហមបានប្រមូលពួកខ្ញុំមកនៅស្រុកត្រាំកក់វិញ។ គេបានប្រមូលប្រជាជនពីភូមិផ្សេងៗមកផ្តុំគ្នានៅវត្តកំពែង ដែលខ្ញុំបានឃើញមនុស្សស្លាប់ជាង ២០នាក់ ដូចរៀបរាប់ខាងលើ។"]។

[803] D5/121 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន់ ទូច KH 00491819 ["ខ្មែរក្រោមទាំងអស់ត្រូវបានគេបញ្ជូនឲ្យទៅរស់នៅក្នុងឃុំគោកព្រិច និងបានបែងចែកឲ្យទៅរស់នៅក្នុងភូមិផ្សេងៗ ដូចជា ភូមិអង្គខ្ជូរ ភូមិកំពែង ភូមិគោកព្រិច ភូមិស្ពែង ភូមិអង្គុញ និងភូមិស្វាយវល្លិ៍ [ចំណាំ៖ ភូមិស្ពែង និងភូមិគោកព្រិច គឺជាឈ្មោះភូមិតែមួយក្នុងពេលបច្ចុប្បន្ន។ ចំណែកឈ្មោះភូមិផ្សេងៗទៀត ពុំមានការប្រែប្រួលឡើយ]។ ខ្ញុំគិតថា ភូមិនីមួយៗ មានប្រជាជនខ្មែរក្រោមប្រហែល ៣០០នាក់ ហើយភូមិទាំងអស់មានទីតាំងនៅជិតៗគ្នា។ ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួរ អ.១២៩ KH 01022438 ["ប្រជាជនដែលគេកៀរមកពីកម្ពុជាក្រោមមកប្រទេសកម្ពុជានៅពេលនោះ ត្រូវបានទាហាន៥នាក់ នាំយកទៅវត្តស្ពែង ហើយអមដំណើរដោយយោធាប្រាំនាក់។"] អ.១០៥៖ KH 01022435 ស៖ លោកស្រីនិយាយថា អ្នកភូមិព្រាលត្រូវបានគេជម្លៀសទៅនៅភូមិលើៗហើយ។ ចុះលោកស្រីសង្កេតឃើញមានផ្ទះសម្បែងនៅក្នុងភូមិនោះទេ? អ.១០៥៖ ពេលឆ្លងកាត់ភូមិព្រាល ខ្ញុំមិនឃើញមានផ្ទះទេ។ នៅពេលដែលយើងទៅជិតដល់វត្តស្ពែងហើយទើបបានឃើញមានផ្ទះមួយចំនួន តែមិនឃើញមានមនុស្សរស់នៅទេ។"]។ ឯកសារ D219/449 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម យោន អ.៣៧, ៤០ KH 01129737["ស៖ ពេលដែលលោកស្រីត្រូវបានគេបញ្ជូនទៅភូមិស្ពែង តើលោកស្រីធ្វើដំណើរដោយរបៀបណា ហើយអ្នកណាជាអ្នកប្រាប់ឲ្យលោកស្រីទៅ? អ.៣៧៖ យើងធ្វើដំណើរដោយថ្មើរជើង។ នៅពេលនោះអង្គការបានប្រាប់យើងថា យើងត្រូវតែទៅភូមិស្ពែងដើម្បីធ្វើស្រែ។ [...] អ.៤០៖ ពេលដែលយើងមកដល់ភូមិស្ពែង មិនមានមនុស្សរស់នៅក្នុងភូមិនោះទេ។"]។ ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌីក ប៉ែត អ.៤០ KH 0979205-06 ["បន្ទាប់ពីវត្តព្រាល តើគេឲ្យលោកស្រីធ្វើដំណើរទៅណាទៀត? អ.៤០៖ គេឲ្យទៅភូមិស្ពែង។"]។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ផត្តិ អ.១៣ KH 01112270 ["ខ្ញុំសូមបញ្ជាក់ថា នៅក្នុងឆ្នាំ១៩៧៧ ពួកខ្ញុំដែលជាអ្នក១៧ មេសា ត្រូវបានគេផ្ទាស់ឲ្យទៅនៅស្រុក១០៥ (ស្រុកត្រាំកក់) វិញ ហើយ បញ្ជូនពួកខ្ញុំខ្មែរក្រោម ដែលកៀរមកពីវៀតណាម មកនៅស្រុក ១០៩ (ស្រុកគិរីវង់)។"]។ ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ីម ផល អ.១២៣-១២៤ KH 01133427 ["អ.១២៣៖ មានរាប់រយនាក់។ [...] ស៖ លោកស្រីនិយាយថា ខ្មែរក្រោមរស់នៅច្រើនភូមិ តើមានភូមិណាខ្លះ? អ.១២៤៖ ខ្មែរក្រោមទាំងអស់រស់នៅភូមិត្រពាំងព្រីង ភូមិស្ពែង ភូមិគោកព្រេច និងភូមិចំបក់។"]។ ឯកសារ D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ប៊ាង អ.១៩ KH 00968132-33 ["ស៖ នៅភូមិច្រកជីគាំហ្ម៊ីង នៅជាមួយអ្នកមូលដ្ឋានឬ? អ.១៩ ៖ អត់ទេ សុទ្ធតែអ្នកថ្មី។ នៅក្នុងក្នុងឃុំកំពែង និងឃុំគោកព្រេច សុទ្ធតែខ្មែរក្រោមរស់នៅ។"]។

[804] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង អ.៤៩ KH 00993599 ["ស៖ នៅពេលដែលលោកមកដល់ស្រុកខ្មែរ តើភូមិអូរអន្សាមានប្រជាជនចាស់រស់នៅដែរឬទេ? អ.៤៩៖ នៅក្នុងភូមិអូរអន្សា និងភូមិស្ពែងគឺមានសុទ្ធតែខ្មែរកម្ពុជាក្រោមទាំងអស់ ក្រៅពីនោះមិនមាននរណាខ្ញុំស្គាល់ទេ។"]។

[805] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ អ.៣ KH 00987225 ["នៅពេលខ្មែរក្រហមកៀរគ្រួសាររបស់ខ្ញុំមកទីកដីកម្ពុជា ប្តីរបស់ខ្ញុំត្រូវគេឲ្យធ្វើការនៅក្នុងសមរភូមិមុខ។ គេបានបំបែកមនុស្សប្រុសផ្សេង មនុស្សស្រីផ្សេង។"]។ ឯកសារ D118/291

245. គណៈតំបន់១៣ និងគណៈស្រុកគិរីវង់ បានចូលរួមក្នុងការនិរទេសខ្មែរក្រោមទៅកាន់ស្រុកគិរីវង់។ ឡាច សម្ត្ត ដែលបានធ្វើការនៅក្នុងស្រុកនេះក្នុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ទាំងមូលបានផ្តែងថា គណៈតំបន់១៣ និងគណៈស្រុកគិរីវង់បានដឹងអំពីការនិរទេសទាំងអស់នេះ និងបានជួយរៀបចំការនិរទេសទាំងនេះ។ គណៈស្រុកបានផ្តល់ឡានធំៗដើម្បីដឹកជញ្ជូននិរទេសជនទាំងនេះ។ សកម្មភាពនោះជាប់ទាក់ទងនឹងការចូលរួមប្រព្រឹត្តរបស់ **យ៉ីម ទិត្យ** និង ឃាយឃូ[806]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

246. ក្នុងឆ្នាំ១៩៧៨ ការបាត់ខ្លួន និងការសម្លាប់និរទេសជនខ្មែរក្រោម ក្នុងឃុំគោកព្រេចបានកើតមានឡើង "រយៈពេលម្តងមួយៗ"[807]។ ទឹម ផល ដែលជាសមាជិកគណៈឃុំគោកព្រេច បានពន្យល់ថា វាជាការទទួលខុសត្រូវរបស់គណៈ ក្នុងការគ្រប់គ្រងនិរទេសជនខ្មែរក្រោម ដែលត្រូវបានបញ្ជូនទៅ

កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួ ឆ.១២៦ KH 01022437 ["ពេលខ្ញុំទៅដល់ភូមិស្ពែង គេឲ្យទៅដកស្ទូងច្រូតអត់ឈប់ ហើយមិនឲ្យយើងទៅណាមកណាទេ រហូតដល់រៀតណាមមករំដោះ។"]។ ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌីក ប៉ែត ឆ.៦០ KH 0979207 ["អត់ទេ គឺអាចដើរទៅផ្ទះផ្សេងទៀតបានទេ។ ដល់ម៉ោងធ្វើការគឺធ្វើការ ហើយពេលសម្រាកតែបន្តិច ប៉ុណ្ណោះគឺពុំមានឱកាសដើរទៅផ្ទះផ្សេងនោះទេ។"]។ ឯកសារ D5/121 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន ទូច KH 00491819 ["នៅក្នុងសម័យនោះ ខ្មែរក្រោម រួមទាំងខ្ញុំផងត្រូវបានគេបង្ខំឲ្យធ្វើស្រែ ឲ្យដឹកស្រូវតាមរទេះ ធ្វើស្រែ និងង់ស្ពាន។ ស្ត្រីត្រូវបានគេប្រើឲ្យធ្វើស្រែ ហើយកុមារត្រូវបានគេប្រើឲ្យរំលាយដំបូកយកដីធ្វើជីធម្មជាតិ ហើយមនុស្សផ្សេងៗទៀតត្រូវបានគេប្រើឲ្យលើកទំនប់ និងភ្ជីស្រែ និងគាស់រំលើងគល់ឈើ។ ទំនប់មានឈ្មោះថា ទំនប់គោកព្រិច។ ប្រជាជនចាស់ៗ ត្រូវបានគេបង្ខំឲ្យដាំបន្លែ។"]។

[806] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត ឆ.៨០-៨១ KH 01112282 ["ស៖ តើថ្នាក់ស្រុកដឹងអំពីការបញ្ជូន ឬក៏ការជម្លៀសខ្មែរក្រោម ពីរៀតណាមដែរ ឬទេ? ហើយថ្នាក់ស្រុកបានចូលរួមក្នុងការជម្លៀសខ្មែរក្រោមមកដែរ ឬទេ? ឆ.៨០៖ បាទ ខ្ញុំប្រាកដណាស់ ថ្នាក់ស្រុក បានដឹង និងបានចូលរួមក្នុងការជម្លៀសខ្មែរក្រោម មកពីរៀតណាមព្រោះឃុំគ្មានឡានទេ។ [*កត់សម្គាល់ថា មានកំហុសបកប្រែ ហើយអត្ថបទដើមសរសេរថា "**ភ្ជាមឡានទេ**"។ ក.ស.ច បានស្នើសុំឲ្យធ្វើការកែតម្រូវរួចហើយ*]។ សកម្មភាពប្រាកដជាមានពាក់ព័ន្ធរហូតដល់ថ្នាក់តំបន់។ មូលហេតុដែលខ្ញុំថាមានការពាក់ព័ន្ធថ្នាក់ស្រុក ព្រោះស្រុកបានរៀបចំអាហារមួយចំនួនដើម្បីទទួលខ្មែរក្រោមទាំងនោះ។ [...] ឆ.៨១៖ នៅពេលនោះ គឺមានតែយាយឃូ និងតាទិត្យ ទេ។"]។

[807] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ទឹម ផល ឆ.១២៩-១៣២ KH 01133428 ["ស៖ ចម្ងោះពេលដែលោកស្រីចូលមកកាន់ និងពេលចាកចេញពីឃុំគោកព្រេច តើលោកស្រីមានសង្កេតឃើញចំនួនខ្មែរក្រោមមានការប្រែប្រួលដែរឬទេ? ឆ.១២៩៖ មានប្រជាជនបាត់ខ្លះ។ ប៉ុន្តែខ្ញុំមិនដឹងថា តើពួកគេត្រូវបានយកទៅទីណានោះទេ។ ស៖ ចុះអ្នកដែលបាត់ខ្លួនទាំងអស់នោះ តើលោកស្រីមានឃើញត្រឡប់មកវិញដែរ ឬទេ? ឆ.១៣០៖ អត់ដែលឃើញត្រឡប់មកវិញទេ។ ស៖ តើលោកស្រីដឹងថាមូលហេតុអ្វីបានជាពួកគេបាត់ខ្លួនដែរ ឬទេ? ឆ.១៣១៖ ខ្ញុំមិនដឹងទេ ប៉ុន្តែការបាត់ខ្លួន មានន័យថា គឺត្រូវបានគេយកទៅសម្លាប់។ ស៖ តើបាត់ខ្លួននោះ បាត់រៀបណាម៉េចដែរ? បាត់ម្តងមួយ ឬបាត់ជាក្រុម? ឆ.១៣២៖ មិនមែនបាត់ជាក្រុមទេ គឺបាត់ម្តងមួយៗ។"]។ *សម្គាល់* ទឹម ផល គឺជាសមាជិកគណៈឃុំកំពែង។

កាន់ឃុំនេះក្នុងឆ្នាំ១៩៧៨[808]។ គាត់បានរៀបរាប់ជាលម្អិតអំពីរបៀបដែលគេបញ្ជូនរបាយការណ៍ទៅកាន់គណៈស្រុក ទាក់ទងនឹង "ជនខិលខូច" ខ្មែរក្រោម[809]។ បន្ទាប់មក គណៈស្រុកចេញបញ្ជាផ្តល់សិទ្ធិអំណាចឲ្យឃុំចាប់ខ្លួនខ្មែរក្រោមទាំងនោះ[810]។ ក្នុងរយៈពេលបីខែដែល ទឹម ផល ស្ថិតនៅក្នុងគណៈឃុំគោកព្រេចក្នុងឆ្នាំ១៩៧៨ នោះ រូបគាត់បានទទួលស្គាល់ថា ចំនួនខ្មែរក្រោមរស់នៅក្នុងឃុំនេះបានធ្លាក់ចុះ[811]។

247. និរទេសជនខ្មែរក្រោមបានរៀបរាប់ជាលម្អិតអំពីការបាត់ខ្លួនទាំងនេះ។ ឃិន សួរ បានរៀបរាប់ពីរបៀបដែលមេភូមិហៅប្រជុំអ្នកតាំងទីលំនៅខ្មែរក្រោម និងបានសួរថាតើ ពួកគេចង់ត្រឡប់ទៅកម្ពុជាក្រោម ឬអត់។ អ្នកដែលបាននិយាយថាចង់ទៅ ត្រូវបានគេដាក់រទេះសេះនៅល្ងាចនោះ

---

[808] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ទឹម ផល ឆ.១០៨ KH 01133425-26 ["ស៖ ឥឡូវយើងចង់និយាយពីរឿងពេលគេផ្ទេរលោកស្រីពីឃុំកំពែង ទៅឃុំគោកព្រេច។ តើលោកស្រីមានដឹងពីមូលហេតុដែលគេផ្ទេរលោកស្រីទៅគោកព្រេច ដែរឬទេ? ឆ.១០៨៖ ខ្ញុំមិនដឹងមូលហេតុទេ។ គ្រប់សមាជិកគណៈកំពែង ទាំងអស់ត្រូវផ្ទេរទៅ ឃុំគោកព្រេច។ ខ្ញុំគ្រាន់តែដឹងថា គេឲ្យពួកខ្ញុំទៅគ្រប់គ្រងខ្មែរក្រោម។"]។

[809] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ទឹម ផល ឆ.១៣៣-១៣៦ KH 01133428 ["ស៖ មុននេះលោកស្រីរៀបរាប់ពីនីតិវិធីនៅក្នុងឃុំកំពែង គឺលោកស្រីត្រូវបានគេប្រាប់ឲ្យតាមដានជនខិលខូចរាយការណ៍ទៅថ្នាក់ស្រុក ហើយបន្ទាប់មកមានមនុស្សត្រូវបានគេចាប់ខ្លួន តើដូចគ្នា ឬក៏ខុសគ្នានៅក្នុងឃុំគោកព្រេច? ឆ.១៣៣៖ ចាស គឺដូចគ្នា។ ស៖ ដើម្បីបញ្ជាក់ឲ្យច្បាស់ តើនរណាដែលជាអ្នកប្រមូលព័ត៌មានជនខិលខូចខ្មែរក្រោម នៅក្នុងឃុំគោកព្រេច? ឆ.១៣៤៖ តាប៉ស់ និងតាសារូ។ ស៖ តើពួកគេទាំងពីរនេះ ដើរប្រមូលព័ត៌មានអ្វីខ្លះពីខ្មែរក្រោម? ឆ.១៣៥៖ ខ្ញុំមិនដឹងរឿងច្រើនទេ ប៉ុន្តែពួកគេទាំងពីរ ធ្វើការជាមួយឈ្លប ដើរស្វែងរកខ្មែរក្រោមណាដែលប្រព្រឹត្តសកម្មភាពណាមួយ ដែលគេចាត់ទុកថាជាខ្មាំង។ ស៖ នៅពេលដែលគេប្រមូលព័ត៌មានបានហើយ តើពួកគេបញ្ជូនព័ត៌មានទៅណាដែរ? ឆ.១៣៦៖ បញ្ជូនទៅថ្នាក់ស្រុក។"]។

[810] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ទឹម ផល ឆ.១៣៨-១៣៩ KH 01133429 ["ស៖ នៅពេលដែលថ្នាក់ស្រុកទទួលបានរបាយការណ៍អំពីខ្មែរក្រោម ដែលគេចាត់ទុកថាជាខ្មាំង តើមានរឿងអ្វីកើតឡើងបន្ទាប់មកទៀត? ឆ.១៣៨៖ ក្រោយពេលទទួលបញ្ជាពីថ្នាក់ស្រុក គឺមនុស្សត្រូវបានគេចាប់ខ្លួន។ ស៖ ក្រោយពេលចាប់ខ្លួនរួចហើយ តើលោកស្រីដឹងថា ពួកគេត្រូវបញ្ជូនទៅណាដែរ? ឆ.១៣៩៖ ខ្ញុំមិនដឹងថា ពួកគេត្រូវបានបញ្ជូនទៅដាក់នៅវត្តព្រះធាតុ ឬក៏ត្រូវបានគេសម្លាប់ចោលនោះទេ។"]។

[811] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ទឹម ផល ឆ.១៤១-១៤៤ KH 01133429-30 ["ស៖ នៅពេលដែលលោកស្រីចាកចេញពីឃុំគោកព្រេច តើចំនួនខ្មែរក្រោមតិចជាងមុន នៅដដែល ឬក៏ច្រើនជាងមុន? ឆ.១៤១៖ ចំនួនខ្មែរក្រោមមានចំនួនតិចជាងមុន។ ស៖ នៅក្នុងរយៈពេលបីខែដែលលោកស្រីនៅក្នុងឃុំគោកព្រេច តើមានខ្មែរក្រោមថ្មីចូលមកដែរ ឬទេ? ឆ.១៤២៖ អត់ទេ គឺមានតែម្តងគត់។ ស៖ តើមកដល់ម្តងហ្នឹង គឺនៅពេលមុន ឬក្រោយពេលដែលលោកស្រីមកឃុំគោកព្រេច? ឆ.១៤៣៖ គឺខ្មែរក្រោមមកមុនខ្ញុំមកដល់ឃុំគោកព្រេច។ ស៖ តើលោកស្រីមានដឹងថា មានរណ្តៅកប់សពរួមនៅឃុំគោកព្រេចដែរ ឬទេ? ឆ.១៤៤ ៖ អត់ទេ។"]។

ហើយមិនត្រូវបានគេឃើញទៀតនោះទេ[812]។ យ៉ែម យោន ដែលជាម្តាយជនជាតិខ្មែរក្រោម បានរៀបរាប់លម្អិតអំពីរបៀបដែលបងប្រុសរបស់គាត់ និងកុមារតូចៗពីរនាក់ត្រូវបានគេនាំចេញទៅឲ្យធ្វើការចំនួនមួយខែ បន្ទាប់ពីគាត់បានមកដល់ភូមិស្ពែង ហើយមិនត្រូវបានគេឃើញទៀតនោះទេ។ គេបានប្រាប់គាត់ថា គេយកពួកគាត់ទៅសម្លាប់នៅភូមិស្ពែង[813]។

248. គង់ សំណាង បានរៀបរាប់លម្អិតអំពីរបៀបដែលក្នុងឆ្នាំ១៩៧៨ ភូមិស្ពែងត្រូវខ្មែរក្រហមប្រើធ្វើជាកន្លែងប្រជុំ និងជាទីតាំងសម្លាប់មនុស្ស។ គាត់បានរៀបរាប់ថា ខ្មែរក្រហមបានបញ្ជូនមនុស្សដែលធ្វើខុសទៅសម្លាប់ ដោយទម្លាក់ពួកគេចូលទៅក្នុងរណ្តៅនានាខាងក្រោយវត្តស្ពែង[814]។ ក្នុងឆ្នាំ១៩៧៨ សាន់ ទូច បានឃើញខ្មែរក្រហមដឹកខ្មែក្រោមតាមរទេះសេះជាច្រើនពីភូមិស្ពែង អាងខ្ចៅ កំពែង គោកព្រេច អង្គុញ និងស្វាយវល្លិ៍ យកទៅសម្លាប់នៅព្រៃក្បែរភូមិស្ពែង[815]។

---

[812] ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួរ ឆ.១៥៤ KH 010224443 ["តែមានម្តង មានការប្រជុំ ដែលមានមេភូមិជាអ្នកដឹកនាំ ហើយកាលនោះគេហៅខ្មែរក្រោមទាំងអស់ឲ្យចូលរួមប្រជុំ។ នៅពេលនោះ មេភូមិបានសួរយើងថា "តើមិត្តណាចង់ទៅស្រុកកំណើតនៅកម្ពុជាក្រោមវិញ ខ្ញុំឲ្យទៅ មិត្តណាចង់នៅហ្នឹង ខ្ញុំឲ្យនៅ"។ គេបានធ្វើបញ្ជីឈ្មោះពីរ ហើយឲ្យយើងទៅចុះឈ្មោះ ចំពោះអ្នកដែលចង់ត្រឡប់ទៅវិញ និងអ្នកដែលចង់នៅហ្នឹង។ ខ្ញុំសង្កេតឃើញថា អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីដែលចង់ត្រឡប់ទៅកម្ពុជាក្រោមវិញ គឺគេយករទេះសេះមកដឹកនៅពេលល្ងាច ហើយទៅបាត់រហូត ហើយខ្ញុំមិនដឹងថាមានរឿងអ្វីកើតឡើងនោះទេ។"]។

[813] ឯកសារ D219/449 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម យោន ឆ.១៧, ២០ KH 01129734-35 ["ស៖ តើលោកស្រីមកដល់ភូមិស្ពែងប្រហែលជារយៈពេលប៉ុន្មាន ទើបគេចាប់ពួកបងប្រុសរបស់លោកស្រី? ឆ.១៧៖ ប្រហែលជាមួយខែបន្ទាប់ពីយើងមកដល់ភូមិស្ពែង គេបានហៅបងប្រុសខ្ញុំ ហើយនិងកូនខ្ញុំពីរនាក់ គឺប្រុសម្នាក់ និងស្រីម្នាក់ ដោយប្រាប់ពួកគេថា ពួកគេត្រូវបញ្ជូនឲ្យទៅធ្វើការនៅកន្លែងផ្សេង។ ពួកគេបានបាត់ខ្លួនរហូតតាំងពីពេលនោះមក។ ខ្ញុំមិនស្គាល់ឈ្មោះ ឬមុខតំណែងអ្នកដែលមកហៅបងប្រុស និងកូនខ្ញុំទៅនោះទេ។ [...] ស៖ នៅក្នុងពាក្យបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី (ឯកសារ D5/1035/1) បាននិយាយថា បង និងកូនរបស់លោកស្រី ត្រូវបានគេយកទៅសម្លាប់នៅភូមិស្ពែង។ តើត្រឹមត្រូវឬទេ? ឆ.២០៖ ខ្ញុំឮតែប្រជាជននិយាយអំពីរឿងនេះថា បងខ្ញុំ និងកូនខ្ញុំទាំងពីរ ត្រូវបានគេយកទៅសម្លាប់នៅភូមិស្ពែង ប៉ុន្តែខ្ញុំមិនច្បាស់ទេ។"]។

[814] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.២២-២៣ KH 00993596 ["ភូមិស្ពែងជាកន្លែងទីតាំងប្រជុំរបស់ពួកខ្មែរក្រហម និងជាកន្លែងសម្លាប់មនុស្សផងដែរ។ បើមាននរណាធ្វើខុសពួកខ្មែរកប្រហមនឹងយកទៅសម្លាប់ចោលនៅក្នុងរណ្តៅដែលមានស្រាប់នៅទីនោះ។ ស៖ ហេតុអ្វីបានជាដឹងថា វត្តស្ពែងជាកន្លែងសម្លាប់មនុស្ស? ឆ.២៣៖ ខ្ញុំត្រូវពួកខ្មែរក្រហមចាត់ទៅកាត់ដើមទន្ទ្រានខែត្រនៅខាងក្រោយវត្តស្ពែង ខ្ញុំបានឃើញមានគំនរឆ្អឹងខ្មោចជាច្រើននៅទីនោះ អ៊ីចឹងខ្ញុំសន្មតថាវាជាកន្លែងសម្លាប់មនុស្ស។"]។

[815] ឯកសារ D5/121 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សាន់ ទូច KH 00491820 ["បន្ទាប់ពីត្រូវបានដោះលែង គេបានឲ្យខ្ញុំសាងសង់ស្ពានជាច្រើនកន្លែងចាប់ពីភូមិកំពែង (ក្នុងឃុំកំពែង ស្រុកព្រៃកប្បាស) រហូតដល់ភូមិពោធិ៍ ឫស្សី [...] នៅពេលខ្ញុំកំពុងសាងសង់ស្ពាន ខ្ញុំបានឃើញពួកខ្មែរក្រហមដឹកប្រជាជនខ្មែរក្រោមជាច្រើនរទេះសេះ ចេញពីភូមិទាំង៥ខាងលើ ទៅ

249. នៅក្នុងឆ្នាំដដែលនោះ គង់ សំណាង បានរកឃើញគំនរឆ្អឹងមនុស្សជាច្រើនភាយចេញក្លិនស្អុយពីខាងក្រោយវត្តស្ពែង នៅតាមជើងភ្នំខាងកើត និងខាងជើងវត្តស្ពែង[816]។ ឡាច សែម ក៏បានឃើញលលាដ៍ក្បាលមនុស្សជាច្រើននៅជិតព្រៃក្នុងស្រះទឹកខាងលិចវត្តស្ពែង។ លលាដ៍ក្បាលមួយចំនួននៅមានសាច់ជាប់នៅឡើយ[817]។

250. ខ្មែរក្រោមមកពីភូមិស្ពែងក៏ត្រូវបានគេបញ្ជូនទៅសម្លាប់នៅតាមតំបន់ផ្សេងៗទៀតផងដែរ។ ហោ យ៉ន បានរៀបរាប់លម្អិតពីរបៀបដែល មនុស្សពីវត្តស្ពែង និងកន្លែងផ្សេងទៀតក្នុងស្រុកគិរីវង់ ត្រូវ

សម្លាប់ក្នុងព្រៃក្នុងភូមិស្ពែង។"] KH 00491819 ["ខ្មែរក្រោមទាំងអស់ត្រូវបានគេបញ្ជូនឲ្យទៅរស់នៅក្នុងឃុំគោកព្រិច និងបានបែងចែកឲ្យទៅរស់នៅក្នុងភូមិផ្សេងៗ ដូចជា ភូមិអង្គខ្ជូរ ភូមិកំពែង ភូមិគោកព្រិច ភូមិស្ពែង ភូមិអង្គុញ និងភូមិស្វាយរលឿ [ចំណាំ ៖ ភូមិស្ពែង និងភូមិគោកព្រិច គឺជាឈ្មោះភូមិតែមួយក្នុងពេលបច្ចុប្បន្ន។ ចំណែកឈ្មោះភូមិផ្សេងៗទៀត ពុំមានការប្រែប្រួលឡើយ]។"]។ ឯកសារ D118/131 កំណត់ហេតុស្តាប់ចម្លើយ សាន់ ទូច ឆ.៧៨ KH 00960608 ["ស៖ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២របស់លោក [...] លោកបាននិយាយថា 'ខ្មែរក្រោមក៏ត្រូវបានសម្លាប់នៅភូមិស្ពែងនេះដែរ។' តើត្រឹមត្រូវដែរឬទេ? ឆ.៧៨៖ បាទ ខ្ញុំបាននិយាយ ប៉ុន្តែក្នុងរបបខ្មែរក្រហមខ្ញុំមិនបានដឹងរឿងនេះទេ ក្រោយបែករបបខ្មែរក្រហមយើងបានជួបជុំគ្នា ហើយនិយាយអំពីរឿងនេះ ទើបខ្ញុំបានដឹង។"]។

[816] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.២៣, ២៥-២៦ KH 00993596 ["ឆ.២៣៖ ខ្ញុំត្រូវពួកខ្មែរក្រហមចាត់ទៅកាត់ដើមទន្ទ្រានខ័ត្រនៅខាងក្រោយវត្តស្ពែង ខ្ញុំបានឃើញមានគំនរឆ្អឹងខ្ទោចជាច្រើននៅទីនោះ អ៊ីចឹងខ្ញុំសន្មតថាវាជាកន្លែងសម្លាប់មនុស្ស។ [...] ឆ.២៥៖ [...] ឃើញតែឆ្អឹងស្អុយរលួយ ក្រុមខ្ញុំដែលមានគ្នា១០នាក់ បានឃើញគំនរឆ្អឹងរលួយ ហើយនិងជះក្លិនស្អុយ ដូច្នេះយើងមិនហានៅជិតទេ។ [...] ស៖ កន្លែងដែលលោកចូលទៅឃើញមានរណ្តៅសាកសព តើវាមានទំហំប៉ុនណា? ឆ.២៦៖ នៅទីនោះមានដើមឈើធំៗ គឺជាព្រៃមួយ ព្រោះវាធំណាស់ គ្មាននរណាដើរចូលចុះទេ ព្រោះមានដើមឈើដែលមានបន្ទាច្រើនខាងកើតនិងខាងក្រោយវត្តស្ពែងនៅក្បែរជើងភ្នំ។"]។

[817] ឯកសារ D219/482 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៧០-៧២ KH 01136310-11 ["ស៖ លោកស្រីបាននិយាយនៅក្នុងឯកសារ D118/233 KH 00987234 លោកស្រីថា លោកស្រីឃើញលលាដ៍ក្បាលនៅជិត្តវត្តស្ពែង តើលោកស្រីចាំទេ? ឆ.៧០ ៖ ខ្ញុំឃើញលលាដ៍ក្បាល ប៉ុន្តែខ្ញុំមិនបានឃើញគេសម្លាប់មនុស្សឡើយ ពេលនោះ ខ្ញុំបាត់គោ ហើយដើររកទើបឃើញលលាដ៍ក្បាលនៅក្នុងរណ្តៅ។ ស៖តើលោកស្រីមានដឹងថាលលាដ៍ក្បាលនរណាទេ? ឆ.៧១៖ ខ្ញុំមិនដឹងទេ។ ស៖ តើលោកស្រីដឹងថាលលាដ៍ក្បាលហ្នឹងនៅទីនោះយូរប៉ុន្មានហើយ? ឆ.៧២៖ ខ្ញុំមិនដឹងទេ ប៉ុន្តែខ្លះមិនមានជាប់សាច់មនុស្សឡើយ លលាដ៍ក្បាលនៅស្រស់ៗ និងខ្លះទៀតស្ងួត។"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១០៨-១១០ KH 00987238-39 ["ឆ.១០៨ ៖ ខ្ញុំឃើញនៅវត្តស្ពែង។ ខ្ញុំបានឃើញនៅពេលដែលខ្ញុំទៅមើលគោ ហើយខ្ញុំក៏បានឃើញលលាដ៍ក្បាលមនុស្សពេញត្រពាំងតែម្តង។ មិនមែនតែកន្លែងវត្តស្ពែងនោះទេ សូម្បីតែកន្លែងដែលខ្ញុំរស់នៅ ឲ្យតែត្រពាំងគឺសុទ្ធតែមានលលាដ៍ក្បាលមនុស្ស។ ស៖ តើលោកស្រីឃើញលលាដ៍ក្បាលនៅកន្លែងណា? ឆ.១០៩៖ ខ្ញុំឃើញនៅបៀតនឹងវត្តស្ពែង នៅខាងលិចវត្ត។ បច្ចុប្បន្ននេះខ្ញុំមិនដឹងកន្លែងនោះគេលប់ហើយឬក៏នៅនោះទេ។ ស៖ តើលោកស្រីដឹងថា នៅក្បែរកន្លែងសម្លាប់មនុស្សនេះមានព្រៃដែរឬទេ? ឆ.១១០៖ ចាស នៅពេលនោះគឺសុទ្ធតែព្រៃ។"]។

គេបញ្ជូនទៅមន្ទីរសន្តិសុខវត្តសូបិណ និងក្រោយពីការឃុំឃាំងមួយរយៈពេលខ្លី ត្រូវគេយកទៅសម្លាប់នៅព្រៃខាងជើងភ្នំតាម៉ៅ ភ្នំថ្មជញ្ជាំង និងអាងហុងស៊ីយ[818]។

251. គង់ សំណាង បានប្រាប់អំពីការប្រជុំមួយដែលគាត់បានចូលរួមក្នុងឆ្នាំ១៩៧៨ នៅវត្តស្ពែង ដែលជាទីកន្លែងអាជ្ញាធរមូលដ្ឋាន ប.ក.ក ប្រកាស់ថា ខ្មែរក្រោមដែលរត់ទៅវៀតណាមគឺជាមនុស្សក្បាលយួនខ្លួនខ្មែរ។ នៅក្នុងការប្រជុំនោះ អាជ្ញាធរម្នាក់ក្នុងចំណោមអ្នកទាំងនោះ បានថ្លែងថា "សម្លាប់ទៅកុំទុក"[819]។ គង់ សំណាង បានរៀបរាប់អំពីកម្ទាភិបាលខ្មែរក្រហមសម្លាប់បុរសចំណាស់ខ្មែរក្រោមបីនាក់នៅវត្តស្ពែង ដោយចោទថាព្រោះតែពួកចាស់ៗទាំងនោះបានសម្លាប់គោស៊ី[820]។

252. ប៉ែន ប៊ីាង បានរំឭកអំពីការប្រជុំមួយដែលបានធ្វើឡើងនៅចុងរបបកម្ពុជាប្រជាធិបតេយ្យ នៅភូមិស្ពែង ដែលក្នុងការប្រជុំនោះអាជ្ញាធរខ្មែរក្រហមបានជួបជុំគ្នាពិភាក្សាពីផែនការសម្លាប់ខ្មែរក្រោម

---

[818] ឯកសារ D105/6 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៩០-៩៨ KH 00788838 ["សៈ ព្រឹកមិញនេះលោកក៏បង្ហាញយើងពីទីតាំងវត្តសូបិណផងដែរ តើលោកអាចប្រាប់យើងពីរឿងរ៉ាវដែលកើតឡើងនៅវត្តនោះបានឬទេ? ឆ.៩១៖ វត្តនោះគេយកមនុស្ស បញ្ជូលពេញហ្ន៏ង។ សៈ តើលោកបានទៅដល់ទីនោះដែរឬទេពេលសម័យខ្មែរក្រហម? ឆ.៩២៖ ខ្ញុំបានទៅដល់ទីនោះ គេយកអ្នកទោសមកដាក់ពេញវិហារហ្ន៏ង ហើយគេចាក់សោរ ហើយគេនៅយាមពីខាងក្រៅ។ សៈលោកនិយាយថា វត្តនោះគេប្រើសម្រាប់ដាក់អ្នកទោសរយៈពេលខ្លះទេ មែនដែរឬទេ? តើជាប្រភេទអ្នកទោសយ៉ាងណាដែរ? ឆ.៩៤៖ ជាមេ១០០ខ្នង មេ៥០ខ្នង។ សៈ តើអ្នកទោសគេយកពីឃុំណាខ្លះ? ឆ.៩៣៖ គេដាក់ (នៅវត្តសុបិណ) តែមួយអាទិត្យទេ គេយកទៅសម្លាប់អស់ហើយ។ [...] សៈ តើអ្នកទោសគេយកពីឃុំណាខ្លះ? ឆ.៩៥៖ មកពីឃុំអង្គប្រាសាទ ឃុំរាមអណ្តើក និងឃុំគោកព្រេច។ សៈ តើអ្នកទោលដែលគេដាក់នៅទីនោះមានប៉ុន្មាននាក់ដែរ? ឆ.៩៦៖ ខ្ញុំដឹងថាមាន ១០០០នាក់ គេក្រោយមកមានដាក់បន្ថែមទៀត តែខ្ញុំមិនបានទៅដល់ទីនោះទៀតទេ។ សៈ តើ១០០នាក់ នោះគេយកទៅសម្លាប់ទាំងអស់ឬ? ឆ.៩៧៖ គេចងបណ្តុរយកទៅសម្លាប់នៅជិតជើងភ្នំ។ សៈ លោកនិយាយពីវត្តស្ពែងផងដែរ មែនទេ? ឆ.៩៨៖ បាទ វត្តស្ពែងនៅក្នុងភូមិគោកព្រេច។ សៈ តើគេសម្លាប់អ្នកទោស ១០០០នាក់ កន្លែងណា? គេសម្លាប់នៅជើងភ្នំតាម៉ៅ ភ្នំថ្មជញ្ជាំង និងកន្លែងអាងហុងស៊ីយ។"]។

[819] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៨៤ KH 00993603 ["ក្នុងឆ្នាំ១៩៧៨ ពេលប្រជុំនៅវត្តស្ពែង ពួកខ្មែរក្រហមបាននិយាយពេលប្រជុំ ដោយសារមានខ្មែរក្រោមខ្លះរត់ទៅនៅវៀតណាមវិញភ្លាមៗនោះ ត្រូវបានវាចោទថា ពួកនោះជាក្បាលយួនខ្លួនខ្មែរ សម្លាប់ទៅកុំទុក គឺពួកខ្មែរក្រហមផ្សព្វផ្សាយឲ្យប្រជាជនដឹងដើម្បីកុំឲ្យរត់ទៅវៀតណាមទៀត។"]។

[820] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៤៥-៤៦ KH 00993598 ["សៈ កាលដំបូងលោកនិយាយថាខ្មែរក្រហមធ្វើទុក្ខបុកម្នេញខ្មែរក្រោមនៅស្រុកខ្មែរ សូមលោករៀបរាប់បន្ថែមបានទេ? ឆ.៤៥៖ នៅវត្តស្ពែងមានតាម្នាក់គាត់នៅឃ្វាលគោ គាត់ឃ្លានពេក គាត់មានគ្នាបីនាក់ គាត់ក៏បានលួចកាប់គោ ដោយណាក់ទុកនៅក្នុងព្រៃ។ ខ្ញុំបានហូបសាច់គោនោះដែរ ដោយសារពួកខ្ញុំឈ្មោះ សាន់ បានទៅទំនាក់ទំនងធ្វើការជាមួយតាទាំងបីនោះ ហើយពួកគាត់ក៏បានចែកសាច់គោនោះឲ្យហូបដែរ។ [...] ខ្មែរក្រហមតាមដានដឹង ក៏បានចាប់តាបីនាក់នោះ និងត្រូវពួកខ្មែរក្រហមយកទៅសម្លាប់នៅវត្តស្ពែង តែគេមិនបានសម្លាប់ពួសាន់ទេ។ សៈ តើអ្នកឃ្វាលគោទាំងបីនាក់នោះជាខ្មែរកម្ពុជាក្រោមមែនទេ? ឆ.៤៦៖ បាទ ជាខ្មែរកម្ពុជាក្រោម។"]។

ដែលនៅរស់ក្នុងតំបន់នេះ។ គេសម្រេចថាអញ្ជើញខ្មែរក្រោមទាំងអស់ឲ្យមកហូបអាហារមួយពេល ដែលក្រោយពីនោះមកគេនឹងសម្លាប់អ្នកទាំងនោះ។ ទោះជាយ៉ាងណា ផែនការនេះមិនបានធ្វើចប់នោះទេ ដោយសារវៀតណាមបានមកដល់មុនពេលខ្មែរក្រោមបានហូបអាហារទាំងនោះ[821]។

<u>ការធ្វើទុក្ខបុកម្នេញ</u>

253. ការធ្វើទុក្ខបុកម្នេញត្រូវបានធ្វើឡើងតាមរយៈឧក្រិដ្ឋកម្មនានាដែលបានរៀបរាប់ខាងលើ ប្រឆាំងនឹងខ្មែរក្រោម។ ក្រុមនេះត្រូវបានកំណត់គោលដៅយ៉ាងជាក់លាក់ ដោយសារតែសមាជិកភាពរបស់ខ្លួននៃក្រុមនយោបាយមួយដែលពិតប្រាដក ឬតាមការយល់ឃើញរបស់គេ[822]។

v. ឧក្រិដ្ឋកម្មដែលស្នើឲ្យបញ្ជូនទៅជំនុំជម្រះ

254. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យឹម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងទីតាំងសម្លាប់មនុស្សព្រៃភូមិស្ដែង[823]៖ អំពើប្រល័យពូជសាសន៍ក្រុម

[821] D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ប៉ាង ឆ.៤១ KH 00968135 ["បាទ កាលនោះ នៅចុងឆ្នាំ១៩៧៨ ឃុំគោកព្រិច ខ្មែរក្រហមហៅទៅប្រជុំនិយាយពីផែនការហូបនំបញ្ចុក ហូបបង្អែម។ កាលនោះនៅឃុំណា គេប្រជុំនៅឃុំនោះ។ ខ្ញុំឮគេថា ខ្មែរក្រហមមានផែនការយកខ្មែរក្រោមទៅវៃចោលទាំងអស់ពេលហូបនំបញ្ចុករួច។"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៩៩-១០១ KH 00987237-38 ["ឆ.៩៩៖ ពេលដែលយួនជិតចូលមកដល់ ខ្មែរក្រហមបានរៀបចំធ្វើនំបញ្ចុក នំបាញ់ច្រនៀន នំបាញ់ឌុកជាដើម ដើម្បីឲ្យខ្មែរក្រោមហូប។ ការពិតខ្មែរក្រហមមានគម្រោងចង់សម្លាប់ខ្មែរក្រោមនៅពេលនោះ ប៉ុន្តែពុំបានសម្លាប់នោះទេ វៀតណាមក៏ចូលមកដល់តែម្តង។ ស៖ តើហេតុអ្វីបានជាលោកស្រីដឹងថា ខ្មែរក្រហមមានគម្រោងយកខ្មែរក្រោមទៅសម្លាប់? ឆ.១០០៖ គឺដឹងតៗគ្នា តែនៅពេលដែលឲ្យស៊ីច្រើនដូច្នេះនឹងត្រូវយកទៅសម្លាប់ចោល។ ដំបូងគេបានប្រជុំនៅជិតមាត់ត្រពាំងមួយ ហើយពេលដែលរៀបចំហូបចុកក៏នៅជិតត្រពាំងនោះដែរ។ ក្រោយប្រជុំនោះមកពួកខ្ញុំបានខ្សឹបខ្សៀវគ្នាថា ពួកយើងនឹងត្រូវគេសម្លាប់ហើយ។ ត្រពាំងនោះធំណាស់។ ស៖ លោកស្រីនិយាយថានៅកន្លែងផ្សេងទៀត ពេលដែលគេឲ្យហូបចុកច្រើន គឺនឹងត្រូវគេយកទៅសម្លាប់ចោល តើមានរឿងនេះកើតឡើងនៅកន្លែងណា? ឆ.១០១៖ ដំបូងគេឲ្យប្រជាជននៅជិតត្រពាំងនៅកំពែង គោកព្រិច ហើយគេប្រាប់អំពីគម្រោងហូបនំបញ្ចុក និងនំផ្សេងទៀតនៅជិតត្រពាំងនោះ។ ប៉ុន្តែពួកខ្ញុំពុំទាន់បានហូបចុកអ្វីទេ វៀតណាមក៏ចូលមកដល់។"]។

[822] *សូមមើល* V.គ.៣.ក. ឧក្រិដ្ឋកម្ម - ឧក្រិដ្ឋកម្មប្រឆាំងវៀតណាម – គោលនយោបាយ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាម – ចេតនារបស់ ប.ក.ក ចំពោះប្រជាជនវៀតណាម និងខ្មែរក្រោម។

[823] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងមន្ទីរសន្តិសុខវត្តសម្តេច គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនទាន់បានចោទប្រកាន់ យឹម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះគឺ អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះតាមរយៈឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើប

ជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា (ជាពិសេស ខ្មែរក្រោម)[824] និងឧក្រិដ្ឋកម្ម ប្រឆាំងមនុស្ស ជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[825] ការនិរទេស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុ នយោបាយ ប្រឆាំងនឹងខ្មែរក្រោម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ និងការ បាត់ខ្លួនដោយបង្ខំ)។

ឃ. ទីតាំងសម្លាប់មនុស្សភូមិព្រាល

i. សេចក្ដីផ្ដើម

255. ភូមិព្រាល (“ព្រាល”) មានទីតាំងស្ថិតនៅក្នុងស្រុកគិរីវង់ តាមបណ្ដោយជាប់ព្រំដែនជាមួយប្រទេស វៀតណាម។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិនេះស្ថិតក្នុងតំបន់១៣ ហើយមានមូលដ្ឋានកង ទ័ព ប.ក.ក មួយនៅក្នុងភូមិនេះ។ ចាប់តាំងពីដើមឆ្នាំ១៩៧៨ មក ខ្មែរក្រហមបានជម្លៀសដោយបង្ខំ ទ្ធវ ខ្មែរក្រោម ដែលពួកគេចាប់បានក្នុងអំឡុងនៃការប្រយុទ្ធដោយយោធាទៅក្នុងទឹកដីវៀតណាម។ អង្គភាពកងទ័ព និងកងឈ្លបមូលដ្ឋានបានឃុំខ្លួនខ្មែរក្រោមជាបណ្ដោះអាសន្ននៅព្រាល។ ពួកគេជា ច្រើនត្រូវបានសម្លាប់ ហើយក្មេងៗខ្មែរក្រោម ត្រូវគេកេណ្ឌឲ្យចូលធ្វើទ័ពជាមួយអង្គភាពមូលដ្ឋាន ហើយអ្នកនៅសល់ត្រូវបានបញ្ជូនទៅតាមឃុំ និងការដ្ឋានផ្សេងៗនៅក្នុងស្រុកនេះ។

256. ក្នុងនាមជាអនុលេខា និងក្រោយមកជាលេខាគណៈស្រុកគិរីវង់ ហើយជាផ្នែកនៃគណៈតំបន់១៣ និងជាសមាជិកនាំមុខនៃសហឧក្រិដ្ឋកម្មរួម (JCE) **យ៉ីម ទិត្យ** បានដើរតួនាទីជាគន្លឹះមួយនៅក្នុងការ អនុវត្តឧក្រិដ្ឋកម្ម JCE នៅព្រាល។

ស្នើបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១២។

[824] *សូមមើល* V.គ. ឧក្រិដ្ឋកម្មប្រឆាំងវៀតណាម។

[825] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលនៃឧក្រិដ្ឋកម្មសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងទាក់ទងនឹងភូមិស្នែងតែ មួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាល ដែលជាលក្ខខណ្ឌតម្រូវដើម្បី បញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួម ទាំងភូមិស្នែងផង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់គឺជាផ្នែកនៃប្រព័ន្ធរៀបចំមួយ ដែលបានអនុវត្តគោល នយោបាយទុក្ខបុកម្នេញ និងសម្លាប់ខ្ទាំង ហើយការសម្លាប់នៅតាមទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងនេះ ត្រូវបានជួយ សម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ីម ទិត្យ។

257. ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** ចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងទីតាំងសម្លាប់មនុស្ស ភូមិព្រាល៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ ការធ្វើមនុស្ស ឃាត ការសម្លាប់រង្គាល ការជម្លៀស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជ សាសន៍ប្រឆាំងនឹងខ្មែរក្រោម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ) អំពើបំពារ បំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ (ការធ្វើមនុស្សឃាតដោយចេតនា និងការជម្លៀសជនស៊ីវិលដោយខុសច្បាប់) និងឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតគិតទុកជាមុន នៅ ក្រោមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[826]។

ii. ប្រតិបត្តិការ និងទីតាំង

258. កងទ័ព ប.ក.ក បានបញ្ជូនដោយបង្ខំ និងសម្លាប់ខ្មែរក្រោម នៅព្រាល ចាប់តាំងពីដើមឆ្នាំ១៩៧៨[827]។ ព្រាលមានទីតាំងស្ថិតនៅក្នុងឃុំសោម ស្រុកគិរីវង់ តំបន់១៣ នៃភូមិភាគនិរតី។ ភូមិនេះមានចម្ងាយ

---

[826] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426544, 47, 58, 59។

[827] <u>ការបញ្ជូនដោយបង្ខំ</u>៖ *ឧទាហរណ៍* ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៧, ៩-១០, ១៣ KH 00987225-26 ["ឆ.៧៖ គេបានកៀរខ្ញុំចេញពីភូមិកំណើតនៅពេលយប់ ប្រហែលជាម៉ោងប្រាំពីរ ឬក៏ប្រាំបី [...]។ ស៖ នៅពាក្យ សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី លោកស្រីបញ្ជាក់ថា លោកស្រីចេញពីទឹកដីវៀតណាមនៅខែមេសា ឆ្នាំ ១៩៧៨។ តើត្រឹមត្រូវដែរឬទេ? ឆ.៩៖ ចាស ត្រឹមត្រូវ [...]។ ឆ.១០៖ ខ្មែរក្រហមបានទៅបាញ់ប្រយុទ្ធជាមួយនឹងវៀតណាម ហើយក៏បានកៀរប្រជាជនខ្មែរក្រោមមកដាក់នៅភូមិព្រាល។ [...] ស៖ មានន័យថា លោកស្រីមកស្រុកខ្មែរ គឺពុំមែនដោយស្ម័គ្រ ចិត្តនោះទេ តើត្រឹមត្រូវដែរឬទេ? ឆ.១៣៖ ចាស"]។ ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌីក ប៉ែត ឆ.៤ KH 00979202 ["ស៖ យើងបានបង្ហាញព័ត៌មាននៅក្នុងពាក្យប្តឹងរបស់សាក្សីទៅឲ្យសាក្សីពិនិត្យ តាមរយៈអ្នកបកប្រែជាអ្នកអានឲ្យ សាក្សីស្តាប់។ ព័ត៌មានដែលទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ សូមផ្តល់ព័ត៌មានពិស្តារពីឧក្រិដ្ឋកម្ម៖ '[...] ចាប់ពីឆ្នាំ ១៩៧៨ ខ្មែរក្រហមបានវាយលុកទៅដល់ភូមិអំពាយស្វាយ ពួកវាបានកៀរក្រុមគ្រួសារខ្ញុំឡើងមកកម្ពុជា [...] មកស្នាក់នៅ១យប់ នៅវត្តព្រាល ឃុំសោម [...]'។ តើព័ត៌មានទាំងអស់នេះ ត្រឹមត្រូវដែរឬទេ? ឆ.៤៖ ចាស ត្រឹមត្រូវទាំងអស់"]។ ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួរ ឆ.១៣ KH 01022420។ ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៥៩ KH 00993600។ <u>ការសម្លាប់</u>៖ *សូមមើល* V.ក.១.ឃ.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់ ១៣ – ទីតាំងសម្លាប់ មនុស្សភូមិព្រាល – ឧក្រិដ្ឋកម្ម – ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ) ។ *សូមមើលផងដែរ* V.ค.៥.ខ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម នៅភូមិ ភាគនិរតី – ការជម្លៀសខ្មែរក្រោមពីកម្ពុជាក្រោមមកគិរីវង់ ១៩៧៧-១៩៧៨។

ប្រហែលជាប្រាំបីគីឡូម៉ែត្រពីព្រំដែនវៀតណាម[828]។ ព្រោលត្រូវបានគេប្រើធ្វើជាមូលដ្ឋានកងទ័ពដោយកងពលធំ ២៥០ ដែលធ្លាប់បានចូលរួមពាក់ព័ន្ធនៅក្នុងការប្រយុទ្ធគ្នាជាញឹកញាប់ជាមួយកងកម្លាំងវៀតណាម[829]។ វត្តនៅព្រោល ត្រូវបានគេប្រើប្រាស់ជាកន្លែងសម្រាប់ឃុំខ្លួនបណ្តោះអាសន្នចំពោះខ្មែរក្រោមដែលត្រូវបានគេជម្លៀសពីវៀតណាម មុនពេលដែលខ្មែរក្រោមខ្លះត្រូវបានសម្លាប់នៅក្នុងព្រៃកែ្ករនោះ។ ព្រៃនេះមានចម្ងាយប្រហែលជាមួយគីឡូម៉ែត្រប៉ុណ្ណោះភាគខាងជើងវត្ត[830]។ វត្តនេះមិនមានព្រះសង្ឆគង់ទេ នៅពេលនោះ ដោយសារព្រះសង្ឆត្រូវបានបង្ខំឲ្យសឹកអស់តាំងពីដើមរបបនេះ[831]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

259. ព្រោលស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គណៈស្រុកគិរីវង់។ **យ៉ីម ទិញ** គឺជាសមាជិកម្នាក់របស់គណៈកម្មាធិការនេះ ហើយបានអនុវត្តគោលនយោបាយខ្ទាំង និងការធ្វើឲ្យទៅជាទាសករនៃ JCE នៅក្នុងស្រុកនេះ តាមរយៈបញ្ជាឲ្យចាប់ខ្លួនក្រៅអំណាចតុលាការជាច្រើន និងតាមរយៈការលើកកម្ពស់គោលនយោបាយនានាដែលបានប្រើអំណាចនៃភាពជាម្ចាស់ទៅលើជនស៊ីវិលតាមបណ្តាភូមិនានា រួមទាំងភូមិព្រោលផង។ យ៉ាងហោចណាស់ក็ចាប់តាំងពីឆ្នាំ១៩៧៥ មកដែរដែល **យ៉ីម ទិញ**

---

[828] ឯកសារ D105/21 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ងួន គឹមម៉េង KH 00971227-28។ ឯកសារ D3/22.1 ផែនទីបណ្តាញផ្លូវថ្នល់ខេត្តតាកែវ។ ឯកសារ D347/2.1.55 ផែនទីភូមិភាគខ្មែរក្រហម។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៣៨-៣៩ KH 00987230 ["ស៖ ពេលគេជម្លៀសលោកស្រីពីវៀតណាមមកភូមិព្រោល តើគេប្រើមធ្យោបាយអ្វីក្នុងការធ្វើដំណើរ? ឆ.៣៨៖ គឺដើរ ពុំមានអ្វីជិះនោះទេ។ [...] ស៖ តើលោកស្រីចំណាយពេលធ្វើដំណើរយូរដែរឬទេ? ឆ.៣៩៖ ចាស ត្រូវចំណាយពេលធ្វើដំណើរមួយយប់ គឺដើររហូតទល់ភ្លឺតែម្តង"]។

[829] ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួរ ឆ.៦៥, ៦៨ KH 01022428, 29។ ឯកសារ D219/449 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម យោន ឆ.៦ KH 01129733។ ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង វេត ឆ.១៤០, ១៤៩ KH 01136725-26។ ឯកសារ D219/738.1.4, CDP កម្រងសំណួរទី១៦ ប្រតិចារឹក ឆ.១១ KH 01220836-37។ ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌីក ប៉ែត ឆ.៣៦ KH 00979205។

[830] ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួរ ឆ.៦០, ៧៧-៧៨ KH 01022428, 30។

[831] ឯកសារ D219/449 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម យោន ឆ.៦ KH 01129733 ["នៅក្នុងវត្តពុំមានលោកសង្ឆទេ។ នៅក្នុងវត្តនោះ មានតែយោធាខ្មែរក្រហមដែលស្នាក់នៅ"]។ ឯកសារ D219/49 កំណត់ហេតុស្តាប់ចម្លើយ តុប ង៉ែត ឆ.៩៩ KH 01032596 ["មិនមាន[ព្រះសង្ឆ]ទេ"] ឆ.១២១៖ KH 01032598 ["ខ្ញុំបានឃើញតែក្មួយខ្ញុំម្នាក់ឈ្មោះ ញ៉ន់ ត្រូវបានគេផ្សឹកហើយឲ្យចូលក្នុងកងទ័ពតែប៉ុណ្ណោះ"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៤៨ KH 00987231 ["គេផ្សឹក[ព្រះសង្ឆ]នៅវត្តព្រោលតែម្តង បន្ទាប់មកគេឲ្យទៅធ្វើទ័ព។ ចំពោះព្រះសង្ឆក្មេងៗគេឲ្យធ្វើទ័ព ហើយចំណែកចៅអធិការត្រូវគេបញ្ជូនទៅកំពែង គោកព្រេច"]។

បានធ្វើជាអនុលេខា ឬ លេខាស្រុកគិរីវង់[832] និងបន្តកាន់មុខនាទីទាំងនេះដល់ខែមេសា ទៅខែឧសភា ឆ្នាំ១៩៧៨[833] ខណៈដែលគាត់បានអនុវត្តគោលនយោបាយ ប.ក.ក ជាប់ជាប្រចាំរហូតមកនៅភូមិភាគពាយ័ព្យ[834]។ គណៈស្រុកនេះបានធ្វើការប្រាស្រ័យទាក់ទងយ៉ាងទៀងទាត់ជាមួយមន្ត្រី

---

[832] ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.១០, ១៣ KH 01104662។ ឯកសារ D118/23 កំណត់ហេតុស្តាប់ចម្លើយ តិម ផល ឆ.១១-១៤ KH 00891160។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ តិម ភី ឆ.១១-១២ KH 00891148។ ឯកសារ D219/160 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.៧ KH 01059383។ ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៤-៥, ៩ KH 00905848។ ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ឈួន ឆ.៧ KH 00905853។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឆ.២៩ KH 01024599។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.១៣ KH 01047179។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.២៦, ៤០-៤១ KH 01102936។ ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៤-៧ KH 00891153-54។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្បត្តិ ឆ.១៣-១៥ KH 01112269-70។ ឯកសារ D65.1.3 គម្រោងជុំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ឡេង អាន់ និង យ៉ីម ទិត្យ EN 00704584។

[833] ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.១០, ១៣ KH 01104662។ ឯកសារ D118/23 កំណត់ហេតុស្តាប់ចម្លើយ តិម ផល ឆ.១១-១៤ KH 00891160។ ឯកសារ D219/160 កំណត់ហេតុស្តាប់ចម្លើយ ដុក ចាន់ ឆ.៧ KH 01059383។ ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៤-៥, ៩ KH 00905848។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ តិម ភី ឆ.១១-១២ KH 00891148។ ឯកសារ D118/44 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ងយ ឆ.៤-៥, ៩ KH 00905848។ ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ឈួន ឆ.៧ KH 00905853 ។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឆ.២៩, ៩៩-១០១ KH 01024599, 05-06។ ឯកសារ D219/121 កំណត់ហេតុស្តាប់ចម្លើយ លឹម ងេន ឆ.១៣ KH 01047179។ ឯកសារ D219/346 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.២៦, ៤០-៤១ KH 01102936 ។ ឯកសារ D118/22 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ឆ.៤-៧ KH 00891153-54។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្បត្តិ ឆ.១៣-១៥, ២២ KH 01112269-71។ ឯកសារ D65.1.3 គម្រោងជុំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ឡេង អាន់ និងយ៉ីម ទិត្យ EN 00704584។ *សូមមើលផងដែរ* ឯកសារ D1.3.11.48 បទសម្ភាសន៍ សៀង ហោម ដោយ SOAS EN 00217750។ ឯកសារ D1.3.11.56 កំណត់ហេតុស្តាប់ចម្លើយ ទន់ ស៊ូន ដោយ ក.ស.ព EN 00219282។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៤២ KH 01034069។ ឯកសារ D219/189 កំណត់ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.២៧ KH 01068052។

[834] *សូមមើល* III.ឃ.២. មុខតំណែងរបស់ យ៉ីម ទិត្យ, អំពើ និងការប្រព្រឹត្ត – ការចូលរួមប្រព្រឹត្តរបស់ យ៉ីម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ – ការរួមចំណែករបស់ យ៉ីម ទិត្យ ចំពោះផែនការឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ។

ឃុំតាមរយៈកិច្ចប្រជុំនានាទូទាំងស្រុក[835] និងការប្រាស្រ័យទាក់ទងជាលាយលក្ខណ៍អក្សរ[836]។ គណៈកម្មាធិការបានបញ្ជាឲ្យមន្ត្រីឃុំរាយការណ៍អំពីមនុស្សដែលគេយល់ថាខ្មាំង និងឲ្យធ្វើការពិភាក្សាអំពីការចាប់ខ្លួន។ នៅក្នុងរបាយការណ៍ និងកិច្ចពិភាក្សាទាំងនេះ ខ្មែរក្រោមត្រូវបានគេកំណត់
អត្តសញ្ញាណថាខ្មាំង[837]។ គណៈស្រុកបញ្ជូនបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួនទៅឃុំ និងគណៈយោធាស្រុក[838]។

iv. ឧក្រិដ្ឋកម្ម

<u>ការជម្លៀស និងអំពើអមនុស្សធម៌ផ្សេងៗទៀត(ការបញ្ជូនដោយបង្ខំ)</u>

260. ចុងឆ្នាំ១៩៧៧ ដល់ដើមឆ្នាំ១៩៧៨ អង្គភាពយោធា ប.ក.ក បានធ្វើការវាយប្រហារឆ្លងដែនចូលទៅក្នុងប្រទេសវៀតណាម និងបានជម្លៀសដោយបង្ខំនូវខ្មែរក្រោម (ជាតិពន្ធុខ្មែរដែលមានសញ្ជាតិវៀតណាម ដែលកំពុងរស់នៅក្នុងប្រទេសវៀតណាម) រស់នៅក្នុងខេត្តអានយ៉ាង មកកាន់ទីតាំងជាច្រើនក្នុងតំបន់១៣ រួមទាំងស្រុកគិរីវង់ផង។ អ្នកដែលត្រូវគេជម្លៀសទាំងនេះភាគច្រើន មកពីភូមិអំពាយ ស្វាយ វត្តថ្មី និងនាសាគិរី ក្នុងប្រទេសវៀតណាម។ ពេលមកដល់ទិសដៅចុងក្រោយរបស់ពួកគេ

---

[835] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ម៉ីម ផល ឆ.៣៣-៣៧, ៤៣, ៤៥-៤៦, ៤៩, ៦០ KH 01133416-19។ ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ ល្ងួន មល់ ឆ.៥៨, ៩៦ KH 01104667, 71។ ឯកសារ D118/21 កំណត់ហេតុស្តាប់ចម្លើយ ម៉ីម ភី ឆ.២២ KH 00891149។ ឯកសារ D219/369 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៣២ KH 01110208។ ឯកសារ D219/66 កំណត់ហេតុស្តាប់ចម្លើយ គង់ ឆោម ឆ.៥៧ KH 01037204។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃូ ភ្ជុំ ឆ.១៧៥-១៨០, ១៩៥ KH 01117238-40។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ ឆុប ផាន ឆ.៥៩ KH 01024601។ ឯកសារ D219/521 កំណត់ហេតុស្តាប់ចម្លើយ ម៉ីម (ម៉ីប) ភី ឆ.៣៨-៤២, ៤៨ KH 01149834-35។ ឯកសារ D219/189 កំណត់ ហេតុស្តាប់ចម្លើយ សឹម ឈឿន ឆ.១៩ KH 01068050។ *សូមមើលផងដែរ* ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ុង វេត ឆ.៤០-៤៧ KH 01136707-08។

[836] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ម៉ីម ផល ឆ.៤៥ KH 01133417។ ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ ល្ងួន មល់ ឆ.៣១, ៩០ KH 01104664។

[837] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ម៉ីម ផល ឆ.១៣៤-១៣៦ KH 01133428-29។ ឯកសារ D105/5 កំណត់ហេតុស្តាប់ចម្លើយ អោក ចន ឆ.៤០-៤៣ KH 00788846។

[838] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ម៉ីម ផល ឆ.៩, ១៥-១៦ KH 01133413-14។ ឯកសារ D118/302 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន់ សារ៉ូ ឆ.៨៧ KH 01024569។ *សូមមើលផងដែរ* ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ុង វេត ឆ.១២១ KH 01136721។ ឯកសារ D1.3.11.18 បទសម្ភាសន៍ ហោ យ៉ន ដោយ SOAS EN 00217607។

នៅក្នុងស្រុកគិរីវង់ អ្នកដែលគេជម្លៀសទាំងនោះត្រូវបានបង្ខំឲ្យធ្វើការ ឬ ចូលរួមជាមួយអង្គភាពយោធា។ ពួកគេជាច្រើនត្រូវបានធ្វើទុក្ខបុកម្នេញបន្ថែមទៀតតាមរយៈការសម្លាប់ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ដោយសារតែសម្ព័ន្ធភាពជាមួយវៀតណាមតាមដែលគេយល់ឃើញ[839]។

261. កងកម្លាំងខ្មែរក្រហម មិនបានផ្តល់ជម្រើសដល់ខ្មែរក្រោមឡើយ ក្នុងការចាកចេញពីប្រទេសវៀតណាម។ ពួកគេត្រូវបាន "ក្បៀរ" "ជុំវុញ" និង "ប្រមូលផ្តុំ"[840] នៅក្រោមការគំរាមកំហែងសម្លាប់ បើពួកគេមិនព្រមចាកចេញ[841]។ ឡាច សែម បានរំឭកថា "[នៅតាមផ្លូវ] មានអ្នកខ្លះត្រូវគេទាត់ ហើយអ្នកខ្លះត្រូវគេចាក់នឹងចំពុះទុងកាំភ្លើងក៏មាន"[842]។ ខ្មែរក្រោមភាគច្រើនត្រូវបានគេយកទៅដាក់នៅភូមិព្រាលជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍[843] ជាទីកន្លែងដែលពួកគេបានជួបកងទ័ព

---

[839] *សូមមើល* V.គ.៥.ค.v. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម នៅភូមិភាគនិរតី – ការប្រព្រឹត្តចំពោះជនជាតិវៀតណាម និងខ្មែរក្រោម នៅគិរីវង់ ១៩៧៥-១៩៧៩ – ភូមិព្រាល។

[840] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡាច សែម ឆ.១០ KH 00987226 ["ខ្មែរក្រហមបានទៅបាញ់ប្រយុទ្ធជាមួយនឹងវៀតណាម ហើយក៏បានក្បៀរប្រជាជនខ្មែរក្រោមមកដាក់នៅភូមិព្រាល"] ឆ.២៥ KH 00987228 ["ស៖ នៅភូមិព្រាលតើមានមនុស្សប៉ុន្មានដែលសម្រាកនៅទីនោះជាមួយនឹងលោកស្រី? ឆ.២៦៖ មានមនុស្សច្រើន ដោយក្នុងភូមិស្រុករបស់ខ្ញុំមានតែមនុស្ស២០ទៅ៣០នាក់ប៉ុណ្ណោះដែលរត់រួចខ្លួន ចំណែកអ្នកផ្សេងទៀតត្រូវខ្មែរក្រហមក្បៀរចូលមកទីកន្លែងទាំងអស់"]។ ឯកសារ D118/163 កំណត់ហេតុស្តាប់ចម្លើយសាក្សី ព្រុំ សារឿន ឆ.៤ KH 00968119 ["តាមខ្ញុំចាំ ខ្មែរក្រហមបានវ៉ៃចូលវៀតណាម ហើយក្បៀរយកមកខ្មែរក្រោមវិញ នៅខែឧសភា ឆ្នាំ១៩៧៨"]។

[841] ឯកសារ D5/1005 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃុង យ៉ាន់ KH 00989441 ["ឆ្នាំ១៩៧៨ ទ័ពខ្មែរក្រហមបានបង្កើតសង្គ្រាមជាមួយវៀតណាម បានវាយសម្រុកចូលភូមិរបស់នាងខ្ញុំ ហើយពួកវាបានគំរាមកំហែងគ្រួសារនាងខ្ញុំ និងបងប្អូននៅភូមិថា បើនរណាម្នាក់មិនចេញ អញសម្លាប់ចោលទៅអស់"]។ ឯកសារ D5/1011 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាត់ ស្ងៀន KH 00989513 ["ឆ្នាំ១៩៧៨ ពេលនោះពួកខ្មែរក្រហមបានធ្វើសង្គ្រាមជាមួយវៀតណាម ហើយបានលុកលុយចូលទៅក្នុងភូមិនាងខ្ញុំ រួចបានស្រែកគំរាមកំហែងថា បើអ្នកណាមិនចេញ អញបាញ់សម្លាប់សម្លាប់ចោលទាំងអស់"]។

[842] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡាច សែម ឆ.៣៨ KH 00987230 [ស៖ ពេលគេជម្លៀសលោកស្រីពីវៀតណាមមកភូមិព្រាល តើគេប្រើមធ្យោបាយអ្វីក្នុងការធ្វើដំណើរ? ឆ.៣៧៖ គឺដើរ ពុំមានអ្វីជិះនោះទេ។ នៅតាមផ្លូវមានអ្នកខ្លះត្រូវគេទាត់ ហើយអ្នកខ្លះត្រូវគេចាក់នឹងចុងកាំភ្លើងក៏មាន"] ឆ.៣៧ KH 00987229 [ស៖ គេហៅថា 'វត្តព្រាល' ហើយភូមិអ្នកស្រុកនៅក្បែរនោះ ប៉ុន្តែប្រជាជនចាកចេញអស់ហើយ។ [...] ខ្ញុំមានផ្ទៃពោះ និងកូនតូចផង"]។ *សូមមើលផងដែរ* ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន សួរ ឆ.៦១ KH 01022428 ["ស៖ តើលោកស្រីដើរពីភ្នំដិន ទៅវត្តព្រាល ឬ? ឆ.៦១៖ ចាស"]។

[843] *សូមមើល ឧទាហរណ៍* ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៥៩ KH 00993600។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡាច សែម ឆ.១០, ១៣ KH 00993594-95។ ឯកសារ D219/449 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម យ៉ាន ឆ.១ KH 01129732។ ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌីក ប៉ែត ឆ.៤ KH

ខ្មែរក្រហមនៅពេលមកដល់[844]។ បន្ទាប់មក អង្គភាពកងទ័ព ប.ក.ក បានបង្ខំឲ្យអ្នកជម្លៀសខ្លះឲ្យបន្តទៅស្នែង ត្រពាំងខ្ចៅ និងកន្លែងផ្សេងទៀតនៅក្នុងតំបន់១៣[845]។

00979201-02។ *សូមមើល* V.ค.๕.ค.v. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម នៅភូមិភាគនិរតី – ការប្រព្រឹត្តចំពោះជនជាតិវៀតណាម និងខ្មែរក្រោម នៅគិរីវង់ ១៩៧៥-១៩៧៩ – ភូមិព្រាល។

[844] ឯកសារ D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ប៊ីរ៉ង អ.១៦ KH 00968132 ["សៈ តើខ្មែរក្រហមចាំទទួលខ្មែរក្រោមត្រង់ណា? អ.១៦ៈ ទាហានខ្មែរក្រហមចាំទទួលខ្មែរក្រោមនៅម្តុំវត្តព្រាល"]។ ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួរ អ.៦៥ KH 01022428 ["ពេលមកដល់វត្ត យោធាក្មេងៗពីរនាក់បានចូលទៅជួបទាហានដែលប្រចាំការនៅវត្ត។ ក្រោយមកទៀត មានវត្តមានយោធាពីរនាក់ចេញពីបរិវេណវត្តចេញមកស្វាគមន៍យើង"]។

[845] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង អ.៥៩ EN 00993600 ["ពេលវៀតណាមចូលជិតមកដល់ចុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានកៀរខ្មែរក្រោមឆ្ពងកាត់ដល់ភូមិព្រាល"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម អ.២-៣ KH 00987225 ["ខ្ញុំរស់នៅឃុំលេច្រី ស្រុកស្វាយទង ខេត្តអាងយ៉ាង ក្នុងទឹកដីវៀតណាម។ [...] ពេលដែលខ្មែរក្រហមកៀរគ្រួសាររបស់ខ្ញុំមកទឹកដីកម្ពុជា ប្តីរបស់ខ្ញុំត្រូវគេឲ្យធ្វើការនៅក្នុងសមរភូមិមុខ"] អ.៧, ៩-១០, ១៣, ២៥-២៧, ៣៤ KH 00987225-29 ["អ.៧ៈ គេបានកៀរខ្ញុំចេញពីភូមិកំណើតនៅពេលយប់ ប្រហែលជាម៉ោងប្រាំពីរ ឬក៏ប្រាំបី។ [...] សៈ នៅពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោកស្រី លោកស្រីបញ្ជាក់ថា លោកស្រីចេញពីទឹកដីវៀតណាមនៅខែមេសា ឆ្នាំ១៩៧៨។ តើត្រឹមត្រូវដែរឬទេ? អ.៩ៈ ចាស ត្រឹមត្រូវ។ [...] អ.១០ៈ ខ្មែរក្រហមបានទៅបាញ់ប្រយុទ្ធជាមួយនឹងវៀតណាម ហើយក៏បានកៀរប្រជាជនខ្មែរក្រោមមកដាក់នៅភូមិព្រាល។ [...] អ.២៥ៈ [...] ពេលដែលខ្មែរក្រហមកៀរខ្មែរក្រោមមកទឹកដីកម្ពុជា គឺពួកគេឲ្យពួកខ្ញុំសម្រាកនៅភូមិព្រាល ៣ថ្ងៃ។ សៈ នៅភូមិព្រាល តើមានមនុស្សប៉ុន្មានដែលសម្រាកនៅទីនោះជាមួយនឹងលោកស្រី? អ.២៦ៈ មានមនុស្សច្រើន ដោយក្នុងភូមិស្រុករបស់ខ្ញុំមានតែមនុស្ស២០ទៅ៣០នាក់ប៉ុណ្ណោះ ដែលរត់រួចខ្លួន ចំណែកអ្នកផ្សេងទៀតត្រូវខ្មែរក្រហមកៀរចូលមកទឹកដីខ្មែរទាំងអស់។ សៈ នៅក្នុងភូមិកំណើតរបស់លោកស្រី តើមានប្រជាជនប៉ុន្មាននាក់? អ.២៧ៈ មានប្រជាជនរាប់រយនាក់ [...]។ អ.៣៤ [...] ។ បន្ទាប់មក គេបញ្ជូនខ្ញុំទៅ [...] គោកព្រេច"]។ ឯកសារ D219/449 កំណត់ហេតុស្តាប់ចម្លើយ យ៉ែម យ៉ាន អ.១ KH 01129732 ["គេបានកៀរពួកយើងចេញពីភូមិកំណើតរបស់ខ្ញុំនៅប្រទេសវៀតណាម គឺភូមិគោកអំពិល ឃុំលេច្រី ស្រុកស្វាយទង ខេត្តអាងយ៉ាង ឲ្យឡើងមកប្រទេសកម្ពុជា។ ពេលដែលយោធាខ្មែរក្រហមទៅដល់ក្នុងភូមិ គេបានប្រាប់យើងឲ្យចេញពីផ្ទះដើម្បីទៅប្រទេសកម្ពុជា។ [...] ។ ពេលដែលខ្ញុំមកពីវៀតណាម មកដល់ប្រទេសកម្ពុជាដំបូង គេបានដាក់ពួកយើងឲ្យស្នាក់នៅក្នុងវត្តព្រាល។ យើងស្នាក់នៅក្នុងវត្តនោះបានប្រហែលជា២ថ្ងៃ ទើបគេដឹកយើងតាមឡានចេញទៅនៅឃុំកំពែងគោកព្រេច។ [...] ខ្ញុំមានផ្ទៃពោះ៦ខែពេលដែលគេជម្លៀមកប្រទេសកម្ពុជា"]។ ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌីក ប៉ែត អ.៤ EN 00985586-87 ["សៈ [...] ព័ត៌មានដែលទាក់ទងនឹងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ [នៅក្នុងព័ត៌មាននៃពាក្យបណ្តឹង] សូមផ្តល់ព័ត៌មានពិស្តារពីឧក្រិដ្ឋកម្ម៖ "ក្នុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ ខ្ញុំរស់នៅកម្ពុជាក្រោម ចាប់ពីឆ្នាំ១៩៧៨ ខ្ខ្មែរក្រហមបានវាយលុកទៅដល់ភូមិអំពាយស្វាយ ពួកវាបានកៀរក្រុមគ្រួសារខ្ញុំឡើងមកកម្ពុជាឆ្ពងកាត់តាមព្រៃក(វិញតេ) មកតាមស្រែឃ្ជូញ មកស្នាក់នៅ១យប់នៅវត្តព្រាល ឃុំសោម ស្រុកគិរីវង់ ខេត្តតាកែវ។ ស្អែកឡើងពួកវាបានបញ្ជូនឲ្យពួកខ្ញុំបន្តឡើងទៅលើទៀត ទៅដល់ភូមិស្នែង ឃុំគោកព្រេច ស្រុកគិរីវង់ ខេត្តតាកែវ [...]"។ តើព័ត៌មានទាំងអស់នេះ ត្រឹមត្រូវដែរឬទេ? អ.៤ៈ ចាស ត្រឹមត្រូវទាំងអស់"]។ ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួរ អ.១២-

១៣ KH 01022420 ["ភូមិខ្ញុំឈ្មោះ វាលប្រកែស បច្ចុប្បន្នហៅថា ភូមិយ៉ាងយ៉ាវ។ [...] ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ គ្រួសារខ្ញុំ និងប្រជាជនរស់នៅក្នុងភូមិកំណើតយ៉ាងសប្បាយរីករាយ តែនៅឆ្នាំ១៩៧៨ ពួក ប៉ុល ពត បានចូលទៅក្នុងភូមិរបស់ខ្ញុំ ហើយបញ្ចុះបញ្ចូលគ្រួសារខ្ញុំ និងគ្រួសារខ្មែរក្រោមដទៃទៀតឲ្យមករស់នៅខ្មែរលើ (កម្ពុជា) ដោយប្រាប់ថា មិនចាំច់តយករបស់របរ និងសម្លៀកបំពាក់អ្វីមកតាមទេ ព្រោះនៅស្រុកខ្មែរមានអ្វីគ្រប់យ៉ាងមិនខ្វះទេ"] ឆ.៦៣ KH 01022428 ["គឺសុទ្ធតែខ្មែរក្រោមស្នាក់ដែលធ្វើដំណើរមកនៅពេលនោះ និងយោធាក្មេងៗពីនាក់ដែលមកអមជាមួយយើង"] ឆ.១០១ KH 01022434 ["ស៖ តើការចាកចេញពីវត្តព្រាល មានន័យថាលោកស្រី និងប្រជាជនដទៃទៀតចាកចេញពីភូមិព្រាលមែនដែរឬទេ? ឆ.១០១៖ ត្រឹមត្រូវហើយ បន្ទាប់មកគេឲ្យស្នាក់នៅវត្តស្តែង ក្នុងភូមិស្តែង ប្រហែលជានៅក្នុងឃុំកំពែង។"]។ ឯកសារ D5/1007 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យិន ស្នួរ KH 00989465 ["ក្នុងឆ្នាំ១៩៧៥ ទៅដល់ ១៩៧៧ នាងខ្ញុំរស់នៅភូមិវាលប្រកែវ ឃុំយ៉ាងយ៉ាវស្រុកស្វាយទង ខេត្តអាងយ៉ាង ខ្មែរកម្ពុជាក្រោម នៅក្នុងឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហមបានចូលទៅដល់ភូមិខ្ញុំ ក៏បានបញ្ចុះបញ្ចូលគ្រួសារខ្ញុំ ក៏ដូចជាបងប្អូនក្នុងភូមិទាំងមូលឲ្យមកស្រុកខ្មែរ [...]។ ព្រឹកឡើងបន្តដំណើរមកដល់ភូមិព្រាល [...]។ ក្រោយមកពួកខ្មែរក្រហមក៏ជំរុញឲ្យទៅរស់នៅក្នុងភូមិស្តែង"]។ ឯកសារ D5/1035 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យែម យោន KH 00991294។ ឯកសារ D5/1005 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យុង យ៉ាន់ KH 00989441 ["កាលឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ រស់នៅវត្តថ្មី ឃុំស៊ិនតូ ស្រុកទិនបៀង ខេត្តមាត់ជ្រូក ប្រទេសវៀតណាម លុះដល់ឆ្នាំ១៩៧៨ ទ័ពខ្មែរក្រហមបានបង្កើតសង្គ្រាមជាមួយវៀតណាម បានវាយសម្រុកចូលភូមិរបស់នាងខ្ញុំ ហើយពួកវាបានគំរាមកំហែងគ្រួសារនាងខ្ញុំ និងបងប្អូននៅភូមិថា បើនរណាម្នាក់មិនចេញ អញសម្លាប់ចោលទាំងអស់។ [...] ធ្វើដំណើរទាំងយប់ឆ្ពោះទៅកាន់ចំណុចវត្តព្រាល [...]។ ថា [ក្រោយគំរាមកំហែង]ហើយ ពួកវាក៏នាំគ្រួសារនាងខ្ញុំ និងបងប្អូនទាំងអស់ទៅកាន់ភូមិត្រពាំងខ្ចៅ ឃុំរាមអណ្តើក"]។ ឯកសារ D5/1010 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គយ ស្តើង KH 00989501 ["ក្នុងឆ្នាំ១៩៧៥ នាងខ្ញុំរស់នៅភូមិភ្នំអន្ទង់ ឃុំយ៉ាងយ៉ាវ ស្រុកស្វាយទង ខេត្តអាងយ៉ាង ខ្មែរកម្ពុជាក្រោម។ មកដល់ឆ្នាំ១៩៧៨ កងទ័ពខ្មែរក្រហម បានវាយបុកចូលទៅដល់ភូមិនាងខ្ញុំ ពួកវាក៏បង្ខិតបង្ខំហើយកៀរគ្រួសារខ្ញុំ ប្រជាជនក្នុងភូមិទាំងអស់ឲ្យមកស្រុកខ្មែរ។ [...] ព្រឹកឡើងបន្តដំណើរមកទៀត មកដល់ភូមិព្រាលក៏សម្រាកទៀត។ [...] មកដល់ភូមិជីរះ ពួកវាក៏ឲ្យរស់នៅទីនោះ"]។ ឯកសារ D5/1011 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាត់ សឿន KH 00989513 ["ក្នុងឆ្នាំ១៩៧៥ [១៩៧៧] នាងខ្ញុំរស់នៅភូមិថ្មី ឃុំស៊ិនតូ ស្រុកស្វាយទង ខេត្តអាងយ៉ាង កម្ពុជាក្រោម។ [...] ពួកវាក៏កៀរពួកនាងខ្ញុំឲ្យឡើងមកនៅចំណុចវត្តព្រាល សម្រាកបានមួយយប់ [...]។ បន្ទាប់មក ពួកវាក៏នាំគ្រួសារនាងខ្ញុំ និងបងប្អូនទាំងអស់ឆ្ពោះទៅកាន់ភូមិអូរអន្ទ្យា ឃុំកំពែងគោកព្រេច"]។ ឯកសារ D5/1036 ព័ត៌មានបន្ថែមក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សែ សារី KH 00991310 ["កាលឆ្នាំ១៩៧៥ នាងខ្ញុំរស់នៅភូមិជើងគោ ឃុំអាងគី ស្រុកស្វាយទង ខេត្តអាងយ៉ាង [...] ខ្មែរក្រហមបានវាយចូលដល់ទឹកដីភូមិកំណើតរបស់នាងខ្ញុំនៅកម្ពុជាក្រោម។ ពួកវា [...] ឲ្យប្រជាជន]ជម្លៀសចេញ [...] តាមផ្លូវ [...] រួចសម្រាកនៅភ្នំជិន លុះដល់ពាក់កណ្តាលអធ្រាត្រម៉ោង៣.០០នាទី ចំណែកគ្រួសារនាងខ្ញុំ និងប្រជាជនជាច្រើនទៀត [...] មកស្នាក់នៅវត្តព្រាលមួយយប់។ [...] មកដល់ស្រុកត្រាំកក់"] KH 00991309 ["ជនរងគ្រោះ និងប្រជាជនដទៃទៀតត្រូវគេបញ្ជូនទៅកាន់ភូមិពកត្របែក ឃុំពកត្របែក"]។ ឯកសារ D5/1009 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ញ៉ី KH 00989489 ["នៅឆ្នាំ១៩៧១ នាងខ្ញុំរស់នៅភូមិភ្នំម្សៀង ឃុំយ៉ាងយ៉ាវ ខេត្តមាត់ជ្រូក ខ្មែរកម្ពុជាក្រោម នៅឆ្នាំ១៩៧៨ ពួក ប៉ុល ពត បានសំលៀសចេញពីមកស្រុកខ្មែរ [...] ស្នាក់នៅភូមិព្រាលមួយទៀត ពេលព្រឹកឡើងរៀបធ្វើដំណើរទៅមុខបន្តទៀត។ [...] ពេលក្រោយមក ពួកវាក៏បញ្ជូនគ្រួសារនាងខ្ញុំឲ្យមករស់នៅភូមិស្វាយសរ ឃុំព្រៃដែង ស្រុកគិរីវង់ ខេត្តតាកែវ"]។

<u>អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

262. ចំពោះប្រុសៗខ្មែរក្រោមដែលមានកម្លាំងខ្លាំងដែលនៅរស់រានមានជីវិត ហើយដែលនៅមានក្នុងភូមិព្រាល ត្រូវបានគេបង្ខំឲ្យគាំទ្រយោធា ប.ក.ក ដែលមានមូលដ្ឋានក្នុងតំបន់នោះ[846]។ នៅទីនោះ ពួកគេបានធ្វើការជាក្រុមមានគ្នាចាប់ពី ៥នាក់ ដល់ ១០០ នាក់ មានដូចជាធ្វើស្រែ ដាំបន្លែ និងធ្វើ "ចម្រូង"[847]។ លក្ខខណ្ឌការងារគឺលំបាកខ្លាំង ហើយរបបអាហារមិនគ្រប់គ្រាន់ឡើយ ដែលបណ្តាលឲ្យមានជំងឺកង្វះអាហារធ្ងន់ធ្ងរ និងស្ពាប់ចំពោះទាហ៊ានកំណែនខ្មែរក្រោម និងយុទ្ធជន/យុទ្ធនារីផ្សេងទៀត រួមទាំងមនុស្សចាស់ និងកុមារផងដែរ[848]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

263. រដ្ឋអំណាច ប.ក.ក នៅព្រាល បានកំណត់គោលដៅទៅលើខ្មែរក្រោម និងអ្នកផ្សេងទៀតដែលគេបានចោទថា ជាប់ខ្សែវៀតណាម ហើយភាគច្រើនត្រូវបានសម្លាប់[849]។ យោធានៅភូមិព្រាល បាន

---

[846] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១០, ៥២-៥៣ KH 00987226-31 ["ឆ.១០៖ [...] រួចហើយខ្មែរក្រហមបានជ្រើសរើសអ្នកមានកម្លាំងខ្លាំង ដូចជាប្រុសៗ ឲ្យធ្វើការនៅសមរភូមិមុខ។ [...] ឆ.៥២ [...] ចំណែកខ្ញុំបានចេញដំណើរពីភូមិព្រាលនៅពេលព្រឹក ហើយដើរហួតដល់តែយប់ទើបមានឡានមកដឹក។ ស៖ នៅពេលនោះ តើ តើប្តី និងកូនរបស់លោកស្រីនៅជាមួយនឹងលោកស្រីដែរឬទេ? ឆ.៥៣៖ ប្តីរបស់ខ្ញុំត្រូវគេចាប់យកទៅធ្វើទ័ព ចំណែកកូនស្រីម្នាក់ទៀតត្រូវគេសម្លាប់ដោយបោះទៅលើចុងបូស្សីរួចទៅហើយ"]។ ឯកសារ D219/49 កំណត់ហេតុស្តាប់ចម្លើយ គុប ង៉ែត ឆ.៩១, ១០១ KH 01032595-96។

[847] ឯកសារ D219/49 កំណត់ហេតុស្តាប់ចម្លើយ គុប ង៉ែត ឆ.៩៥, ១០៣-១០៤, ១០៩, ១១២ KH 01032596-97។

[848] ឯកសារ D219/49 កំណត់ហេតុស្តាប់ចម្លើយ គុប ង៉ែត ឆ.១០២, ១១៤, ១១៨ KH 01032596-98 ["ស៖ តើលោកអាចពិពណ៌នាអំពីវត្តព្រាលបានទេ? ឆ.១០២៖ ពិបាករស់នៅណាស់ទីនោះ គឺមនុស្ស ១០នាក់ គេឲ្យអង្ករដប់កំប៉ុង [ខ្ញុំ៖ ២កំប៉ុង] ជួនកាលយើងតួញថា ម្ហូបតិច គេថា ដឹកជញ្ជូនមកពិបាក។ ដូច្នេះ ជួនកាលយើងបបរទឹកវាវ១ [...]។ ស៖ ក្នុងពាក្យបណ្តឹងរបស់លោក លោកបាននិយាយថា [...] គេបង្អត់អាហារពួកលោក១០នាក់ផ្សេងទៀត។ តើហេតុការណ៍នេះកើតឡើងនៅឆ្នាំណា ហើយនៅកន្លែងណាដែរ? ឆ.១១៤៖ ព្រឹត្តិការណ៍នេះកើតឡើងនៅវត្តព្រាល [...]។ ឆ.១១៨៖ [...] ដោយសារយើងហូបមិនឆ្អែត យើងចេះតែដើរកអ្វីហូប គេចោទថា យើងខ្ជាំង បាត់ខ្លួនហើយ"]។ ឯកសារ D5/1036 ព័ត៌មានបន្ថែមក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសែ សារី KH 00991310 ["ចាស់ជរា កុមារមួយចំនួនឈឺ និងអត់អាហារ ស្ពាប់ជាបណ្តើរៗ"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៤១-៤២ KH 00987230 ["ស៖ នៅភូមិព្រាល តើគេឲ្យអាហារលោកស្រីហូបចុកគ្រប់គ្រាន់ដែរឬទេ? ឆ.៤១៖ អត់ទេ មានតែអាហារបន្តិចបន្តួចដែលខ្ញុំយកមកជាប់ខ្លួនប៉ុណ្ណោះ។ [...] ឆ.៤២៖ [...] ពេលនៅស្រុកកំណើត មានរបស់ហូបចុកគ្រប់គ្រាន់ តែពេលមកដល់ភូមិព្រាល ហូបចុកមិនគ្រប់គ្រាន់នោះទេ"]។

[849] ឯកសារ D219/746 កំណត់ហេតុស្តាប់ចម្លើយ សែស អ៊ីន ឆ.៣៦ KH 01223986 ["ស៖ ចំពោះមនុស្សជំពូកដែលជាគេគោលដៅរបស់គេក្នុងការចង់កម្ទេច ឬសម្លាប់នោះ តែអ្នកមានខ្សែរយៈជាមួយនឹងទាហាន លន់ នល់ ឬអ្នកមានបងប្អូនគ្រួសារ

សួរដេញដោលជនស៊ីវិលយ៉ាងដិតដល់ ដើម្បីកំណត់សញ្ជាតិពួកគេ។ អ្នកដែលនិយាយខ្មែរមិនច្បាស់ ឬ មានសំនៀងដែលអាចឲ្យកំណត់បានថាពួកគេមកពីវៀតណាម ពួកគេនឹងត្រូវសម្លាប់[850]។ យិន សួរ បានពន្យល់ថា ខ្មែរក្រហម "[...] គឺគេពុំចាត់ទុកយើងខ្មែរក្រោមថាជាខ្មែរទេ គឺចាត់ទុកជាយួន"[851]។ ទន្ទឹមនេះ ពួកគេនឹងត្រូវសម្លាប់ បើ "និយាយប៉ែឡាំដូចវៀតណាម"[852]។ ឆែម ញ៉ឹម បាន

ជាមួយនឹងប្រទេសយួន។ អ្នកមានបងប្អូនបណ្តាញប្រទេសយួន គេតាមដានអ្នកហ្នឹង។"]។ ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ យិន សួរ ឆ.៧១, ៩៥-៩៦ KH 01022429-30, 33 ["ឆ.៧១៖ ខ្ញុំបានឃើញព្រឹត្តិការណ៍នៃការចាប់ខ្លួន និងចោទពួកគាត់ថាជាគិញយួនដោយផ្ទាល់ភ្នែក ហើយបានជួប ពូវ៉ាង ដែលរត់រួចខ្លួន ព្រមទាំងទទួលព័ត៌មានពីការសម្លាប់បងខ្ញុំទាំងបីនាក់នោះផ្ទាល់។ [...] ឆ.៩៥៖ ពួកយើងខ្លាចពួកគេយកយើងទៅវ៉ៃចោល នៅពេលដែលយើងនិយាយប្រាប់គេថាយើងចង់វិលត្រឡប់ទៅស្រុកកំណើតវិញ។ ស៖ ហេតុអ្វីបានជាលោកស្រីគិតថាអ៊ីចឹង? ឆ.៩៦៖ ខ្ញុំបានឃើញគេចាប់បងប្រុសខ្ញុំ និង វ៉ាង ហើយបណ្តើរយកទៅសម្លាប់ផ្ទាល់ភ្នែក។ ដូច្នេះខ្ញុំគិតថា គេនឹងធ្វើមកលើខ្ញុំ និងអ្នកផ្សេងទៀត បើសិនជាយើងនិយាយថា យើងចង់ត្រឡប់ទៅស្រុកកំណើតវិញ។"]។ ឯកសារ D5/1005 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃុង យ៉ាន់ KH 00989441 ["[យើង] ធ្វើដំណើរទាំងយប់ឆ្ពោះទៅកាន់ចំណុចវត្តព្រាល ហើយពួកវាក៏យកប្តីនាងខ្ញុំ និងប្រុសម្នាក់យកទៅសម្លាប់នៅទីនោះ នាងខ្ញុំឃើញសភាពបែបនេះ ក៏ស្រែកយំយ៉ាងខ្លាំង។"]។ ឯកសារ D5/1009 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ញ៉ី KH 00989489 ["ពួកវាចាប់ខ្លួនប្តី និងឪពុកម្តាយរបស់នាងខ្ញុំទៅសម្លាប់នៅចំណុចខាងលើវត្តព្រាល។ [...] នាងខ្ញុំក៏ភ្ញាក់ខ្លួនព្រើត មិននឹកស្មានជនជាតិខ្មែរសម្លាប់ខ្មែរឯងសោះ។"]។ ឯកសារ D5/1011 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ាត់ សៀន KH 00989513 ["ព្រលឹមឡើងពួកវាក៏យកឪពុកម្តាយនាងខ្ញុំទៅសំលាប់ចោលយ៉ាងអាណោចអធមជាទីបំផុត។ ឃើញសភាពការណ៍បែបនេះ ពួកខ្ញុំក៏ស្រែកយំយ៉ាងខ្លាំង។"]។ ឯកសារ D5/1549 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សុខ ស៊ីន KH 01091760 ["រួចពួកវាក៏ចាប់ប្តីនាងខ្ញុំ ដោយគ្មានកំហុសអ្វីសោះ បណ្តើរយកទៅព្រៃបូស្សីខាងលើភូមិព្រាល បាញ់សម្លាប់ចោលតែម្តង។"]។

[850] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.២៣-២៥ KH 00987228 ["ឆ.២៣៖ ក្រុមគ្រួសាររបស់ខ្ញុំ និងខ្ញុំគឺនិយាយខ្មែរច្បាស់។ [...] ឆ.២៤៖ អ្នកដែលនិយាយមិនច្បាស់ ឬក៏និយាយប៉ែឡាំគឺត្រូវយកទៅវ៉ៃសម្លាប់ចោលនៅក្នុងព្រៃក្នុងភូមិព្រាល ហើយខ្លះសម្លាប់នៅក្នុងព្រៃបូស្សី។ ស៖ នៅពេលនោះតើហេតុអ្វីបានជាលោកស្រីដឹងថា គេនាំមនុស្សយកទៅសម្លាប់នៅភូមិព្រាល? ឆ.២៥៖ ព្រោះពេលដែលខ្មែរក្រហមកៀរខ្មែរក្រោមមកទ៍កដីកម្ពុជា គឺពួកគេឲ្យពួកខ្ញុំសម្រាកនៅភូមិព្រាល ៣ ថ្ងៃ។"] ឆ.២៩-៣០ KH 00987228 ["ឆ.២៩៖ នៅភូមិព្រាល ខ្មែរក្រហមបានធ្វើការសួរប្រជាជន ដើម្បីកំណត់សញ្ញាតិ ដោយអ្នកណាដែលនិយាយមិនច្បាស់ គឺនឹងត្រូវខ្មែរក្រហមយកទៅវ៉ៃសម្លាប់ចោល។ ស៖ ហេតុអ្វីបានជាលោកស្រីដឹងខ្មែរក្រហមយកអ្នកដែលនិយាយមិនច្បាស់ទៅវ៉ៃចោល? ឆ.៣០៖ ពេលនោះមានលក្ខណៈច្រឫកច្របល់ ហើយខ្មែរក្រហមបានឲ្យខ្មែរក្រោមនិយាយ បើអ្នកណានិយាយមិនច្បាស់ គឺខ្មែរក្រហមទាញចេញទៅភ្លាមតែម្តង គឺវ៉ៃផ្ទូសៗតែម្តង។"]។

[851] ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ យិន សួរ ឆ.៤៤ KH 01022425 ["បើតាមរបៀបដែលគេធ្វើបាបយើងឲ្យវេទនាបែបនោះ គឺគេពុំចាត់ទុកយើងខ្មែរក្រោមថាជាខ្មែរទេ គឺចាត់ទុកជាយួន"]។

[852] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡាច សែម ឆ.២២ KH 00987227 ["គឺនិយាយប៉ែឡាំដូចវៀតណាមនឹងត្រូវគេយកទៅសម្លាប់ មានមនុស្សបួនប្រាំនាក់ត្រូវគេយកទៅសម្លាប់""] ឆ.៣៣ KH 00987229 ["ស៖ [...] តើលោកស្រីស្គាល់ឈ្មោះអ្នកដែលយកខ្មែរក្រោមនិយាយមិនច្បាស់ទៅសម្លាប់ដែរឬទេ? ឆ.៣៣៖ ខ្ញុំមិនស្គាល់ទេ ពួកគេគឺជាឈ្លប និងទាហានខ្មែរក្រហម"]។

និយាយថា ឈ្លប ប.ក.ក បានសម្លាប់ឪពុកម្តាយ និងបងប្រុសគាត់បីនាក់ទៀតនៅវត្តព្រាលក្នុងរយៈពេលចន្លោះពីគ្នាតែប្រាំថ្ងៃ ដោយគេយល់ថា ពួកគេជា វៀតណាម[853]។ ឈ្លប ប.ក.ក បានសម្លាប់ខ្មែរក្រោមផ្សេងទៀតនៅភូមិព្រាល ដោយចោទពួកគេថា ជាទាហាន ឬគិញវៀតណាម[854]។

264. ខ្មែរក្រោមជាប់កំណែន និងជនស៊ីវិលជាច្រើននៅវត្តព្រាល បានបាត់ខ្លួន និងត្រូវបានសន្មតថា ត្រូវបានសម្លាប់[855]។ តុប ង៉ែត ដែលជាខ្មែរក្រោមជាប់កំណែនម្នាក់នៅពេលនោះ បាននិយាយថា៖ "គេឲ្យយើងនៅតែក្នុងវត្ត ប្រសិនបើយើងមិនស្តាប់ទេ យើងនឹងបាត់ខ្លួន"[856]។ សែស អឿន បានឮអំពី

---

[853] ឯកសារ D5/1037/1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆែម ញ៉ីម EN 00991313។

[854] ឯកសារ D5/1009 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ញ៉ី KH 00989489 ["ពួកវាចោទគាត់ [ប្តីខ្ញុំនិងឪពុកម្តាយខ្ញុំ] ថាគេញសម្ងាត់ឃ្លួន។"]។ ឯកសារ D5/1010 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គយ ស្ពើង KH 00989501 ["ព្រឹកឡើងយើងបន្តដំណើរមកទៀត មកដល់ភូមិព្រាលក៏សំរាកទៀត លុះព្រឹកឡើងឪពុករបស់នាងខ្ញុំ គាត់ឃើញកងឈ្លបគាត់ក៏ដើរគេចចេញបំរុងនឹងដឹកគោមកទឹម ពួកវាក៏ចោទថា សមមិត្តឯងហេតុអ្វីបានជារាងជាភ័យម្លេះ មិត្តឯងធ្វើទាហានឃ្លួនមែនទេ រួចពួកវាក៏នាំខ្លួនគាត់យកទៅសម្លាប់ខាងលើភូមិព្រាលតែម្តងទៅ។"]។

[855] ឯកសារ D219/49 កំណត់ហេតុស្តាប់ចម្លើយ តុប ង៉ែត ឆ.១០៩, ១១២-១១៨ KH 01032597-98 ["ឆ.១០៩៖ [...] គ្នាខ្ញុំប្រាំនាក់ មកចូលធ្វើទាហាននៅវត្តព្រាល ហើយយប់នោះ ម្នាក់បានទៅបាត់ខ្លួនទៅ។ [...] ឆ.១១២៖ [...] បើយើងធ្វើខុស គេយកទៅបាត់។ ស៖ ពេលលោកប្រចាំការ ឬក៏រស់នៅវត្តព្រាល តើលោកកត់សំគាល់ឃើញគេយកមនុស្សទៅបាត់ច្រើនទេ? ឆ.១១៣៖ ច្រើនដែរ។ នៅពេលមួយនោះ បុរសខ្មែរក្រោមបីនាក់ គេហៅទៅ ហើយបាត់រហូត ខ្ញុំមិនដឹងថា ពួកគេធ្វើអ្វីខុសទេ។ ស៖ ក្នុងពាក្យបណ្តឹងរបស់លោក លោកបាននិយាយថា គេយកក្ជួយប្រុសរបស់លោកទៅសម្លាប់ ដោយមិនធ្វើខុសអ្វីទាល់តែសោះ [...]។ តើហេតុការណ៍នេះកើតឡើងនៅឆ្នាំណា ហើយនៅកន្លែងណាដែរ? ឆ.១១៤៖ ព្រឹត្តិការណ៍នេះកើតឡើងនៅវត្តព្រាល។ ស៖ ហេតុអ្វីបានជាគេយកក្ជួយប្រុសលោកទាំងពីរនាក់យកទៅសម្លាប់? ឆ.១១៥៖ ខ្ញុំមិនដឹងពីមូលហេតុទេ។ ស៖ តើមាននរណាគេបានឃើញថា អ្នកណាគេយកទៅទេ? ឆ.១១៦៖ អត់ទេ គេយកទៅពេលយប់។ ស៖ ជាទូទៅ ពេលលោកមករស់នៅស្រុកគិរីវង់ តើលោកសង្កេតឃើញគេប្រព្រឹត្តចំពោះខ្មែរក្រោម ខុសពីខ្មែរធម្មតាដែរឬទេ? ឆ.១១៧៖ ខុសគ្នា។ គេនៅផ្សេង យើងនៅផ្សេង បើយើងធ្វើខុសគេកម្ទេចយើង។ ស៖ ក្នុងពេលលោកស្នាក់នៅស្រុកគិរីវង់ តើលោកមានដែលសង្កេតឃើញមានការបាត់ខ្លួនមនុស្សទាំងក្រុមៗភ្លាមៗដែរឬទេ? ឆ.១១៨៖ អត់ទេ ប៉ុន្តែយូរៗបាត់មួយ។ ដោយសារយើងហូបមិនឆ្អែត យើងចេះតែដើរកអ្វីហូប គេចោទថា យើងខ្ជាំង បាត់ខ្លួនហើយ"]។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៤៥ KH 00987230 ["ចាស គឺមានច្រើនណាស់។ ចំពោះខ្ញុំ ខ្ញុំបានបាត់បង ពូ និងអ៊ំ ជាដើម"]។

[856] ឯកសារ D219/49 កំណត់ហេតុស្តាប់ចម្លើយ តុប ង៉ែត ឆ.៩៣ KH 01032595។

ការចាប់ខ្លួន និងការសម្លាប់នៅភូមិព្រាលក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ និងបានរំឭកថា ការចាប់ខ្លួនត្រូវបានគេធ្វើឡើងនៅពេលយប់[857]។

265. ជាតួយ៉ាង ខ្មែរក្រោមត្រូវបានគេសម្លាប់នៅក្នុងព្រៃនៅជាប់ភូមិ[858]។ យិន ស្ងួរ បាននិយាយថា យោធា ប.ក.ក ពីរនាក់បានសម្លាប់បងប្រុសរបស់គាត់ពីរនាក់ និងបងប្អូនជីដូនមួយគាត់ម្នាក់ ក្រោយពីចោទប្រកាន់ពួកគាត់ថា ជាគិញវៀតណាម[859]។ ឡាច សែម បានរំឭកថា "ពេលដែលសម្លាប់[អ្នកដែលនិយាយមិនច្បាស់] ខ្មែរក្រហមបានយកអ្នកទាំងអស់នោះទៅក្នុងព្រៃក្បែរទីនោះដែរ គឺសម្លាប់នៅក្នុងព្រៃនោះ"[860]។ ខ្មែរក្រោមមួយក្រុមផ្សេងទៀត ដែលរួមមានទាំងកូនស្រីអាយុបី

---

[857] ឯកសារ D219/746 កំណត់ហេតុស្តាប់ចម្លើយ សែស អ៊ីន ឆ.៣៥ KH 01223986 ["កាលខ្ញុំនៅភូមិព្រាល គ្រាន់តែឮ [អំពីការចាប់ខ្លួន និងការសម្លាប់] ឃើញផ្ទាល់ភ្នែក គឺមិនដែលបានឃើញទេ។ ពេលយប់ គេចាប់មនុស្ស យើងមិនបានដើរទៅណាទេ យើងនៅតែក្នុងផ្ទះយើង។ ដល់ព្រឹកឡើង បានគេថា អ្ហ! ចាប់អ្នកនេះ ចាប់អ្នកនោះ"]។

[858] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៥៩ KH 00993600 ["[ខ្មែរក្រហម] សម្លាប់ [ខ្មែរក្រោម] ក្នុងព្រៃក្នុងភូមិព្រាល។"]។ ឯកសារ D5/1009 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ញ៉ី KH 00989489 ["ពួកវាចាប់ខ្លួនប្តី និងឪពុកម្តាយរបស់នាងខ្ញុំទៅសម្លាប់នៅចំណុចខាងលើវត្តព្រាល។"]។

[859] ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ យិន ស្ងួរ ឆ.៦០, ៦៧, ៦៩, ៧១, ៨៣, ៨៥ KH 01022428-32 ["ឆ.៦០៖ ឈ្មោះវត្តនោះគឺវត្តព្រាល ហើយគេឲ្យយើងទៅស្នាក់នៅក្នុងបរិវេនវត្តនោះ។ [...] ឆ.៦៧៖ [...] ទាហានក្មេងៗពីរនាក់ដែលអ្នកទៅយកយើងពីកម្ពុជាក្រោមបានប្រកាសប្រាប់យើងថា ពួកយើងត្រូវស្នាក់នៅក្នុងវត្ត១ថ្ងៃ [...] ឆ.៦៩៖ នៅប្រហែលម៉ោង១រសៀល ពួកយោធាក៏ដើរមកត្រួតពិនិត្យយើង និងសង្ស័យថាបងប្រុសខ្ញុំពីរនាក់ បងជីដូនមួយខ្ញុំម្នាក់ និងម្នាក់ឈ្មោះ រ៉ាង ដោយគេចោទថាជាគិញយួន។ ទាំងបួននាក់នោះត្រូវគេចាប់ចង ដោយយកខ្សែលួសដោតកដៃចងពីម្នាក់ទៅម្នាក់។ ពួកគេបណ្តើរអ្នកទាំងបួនទៅក្នុងព្រៃនៅខាងលើវត្ត។ ប្រហែលមួយម៉ោងក្រោយមក រ៉ាង បានរត់ត្រឡប់មកវិញ ដោយមានឈាមប្រលាក់ពេញដៃ ដោយព្យាយាមរត់ត្រឡប់ទៅកម្ពុជាក្រោមវិញ។ រ៉ាង រត់កាត់វត្តនោះ ហើយក៏បានជួបខ្ញុំ និងប្រាប់ថា បងប្រុសរបស់ខ្ញុំ និងបងជីដូនមួយខ្ញុំត្រូវគេបាញ់សម្លាប់បាត់ហើយ។ [...] ស៖ លោកស្រីនិយាយថា "គេចោទពួកគាត់ថាជាគិញយួន"។ តើព្រឹត្តិការណ៍នេះ កើតឡើងនៅចំពោះមុខលោកស្រី ឬមួយយ៉ាងណា? ឆ.៧១៖ ខ្ញុំបានឃើញព្រឹត្តិការណ៍នៃការចាប់ខ្លួន និងចោទពួកគាត់ថា ជាគិញយួនដោយផ្ទាល់ភ្នែក ហើយបានជួប ពូរ៉ាង ដែលរត់រួចខ្លួន ព្រមទាំងទទួលព័ត៌មានពីការសម្លាប់បងទាំងបីនាក់របស់ខ្ញុំ។ [...] ឆ.៨៣៖ មានយោធាពីរនាក់បណ្តើរបងប្រុសខ្ញុំ និង រ៉ាង ចេញទៅសម្លាប់នៅក្នុងព្រៃ ហើយខ្ញុំឃើញមានយោធា ៥នាក់ទៀត នៅជាប់នឹងប្រជាជន នៅពេលគេបណ្តើរបងប្រុសខ្ញុំទៅសម្លាប់។ [...] ស៖ តើឈ្មោះ រ៉ាង បានប្រាប់លោកស្រីថា នរណាជាអ្នកសម្លាប់បងប្រុសរបស់លោកស្រីទេ? ឆ.៨៥៖ គាត់ប្រាប់ខ្ញុំថា យោធាពីរនាក់ដែលបណ្តើរបងប្រុសខ្ញុំទៅនោះហើយ គឺជាអ្នកសម្លាប់បងប្រុសខ្ញុំ។"]។ ឯកសារ D5/1007 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យិន ស្ងួរ KH 00989465 ["ពួកវាចោទថាបងប្រុសនាងខ្ញុំ២នាក់ និងបងស្ពួនមួយ១នាក់ ថាយកការឲ្យវៀតណាម ហើយក៏ចាប់យកទៅចងជាប់ជាមួយអ្នកទោសម្នាក់ទៀតឈ្មោះ រ៉ាង យកទៅសម្លាប់ចំណុចលើភូមិព្រាល។"]។

[860] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៣២ KH 00987229។

ឆ្នាំរបស់ ឡាច សែម ផង ត្រូវបានគេយកទៅសម្លាប់ក្នុងគុម្ពឫស្សីក្បែរព្រៃ[861]។ សាន់ ទូច បាន និយាយថា សាកសពខ្មែរក្រោមមិនត្រូវបានគេកប់នោះទេ គឺគេបោះចូលក្នុងណ្ណង្ហង្ហភ្នំនៅក្បែរភូមិ ព្រៃនោះតែម្តង[862]។ ក្នុងឆ្នាំ១៩៨០ និងនៅពេលក្រោយមកទៀត អ្នករស់រានមានជីវិតខ្មែរក្រោម បានរៀបរាប់អំពីការសម្លាប់បងប្អូន និងក្រុមគ្រួសាររបស់ពួកគេដែលគេបានបញ្ជូនទៅវត្តព្រៃ[863]។

266. សាកសពខ្មែរក្រោមប្រហែលជា ១,០០០នាក់ ត្រូវបានរកឃើញនៅក្នុងរណ្តៅកប់សពរួមមួយ ក្នុង ណ្ណង្ហង្ហភ្នំដែលមានចម្ងាយប្រហែលជា ១.៥ គីឡូម៉ែត្រពីព្រៃ។ នៅពេលក្រោយមក នៅទីតាំងនេះ សាន់ ទូច បានសង្កេតឃើញមានបំណែកបែកបាក់នៃឆ្អឹងមនុស្សនិងសម្លៀកបំពាក់[864]។ នៅក្នុងឆ្នាំ

---

[861] ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១៧, ២៤, ៥៣ KH 00987227, 28, 31 ["កូនស្រីរបស់ខ្ញុំដែលមានអាយុបពាន្ធាំត្រូវគេបោះចូលទៅគុម្ពឫស្សីទាំងរស់តែម្តង។ [...] កូនស្រីរបស់ខ្ញុំបានរត់តាមប្តីខ្ញុំ ពេលនោះបានធ្វើឲ្យទាហានខ្មែរក្រហមខឹង ពួកវាក៏យកកូនស្រីខ្ញុំទៅបោះលើចុងឫស្សីស្លាប់តែម្តង។ [...] អ្នកដែលនិយាយមិនច្បាស់ ឬក៏និយាយប៉ែ្ចឡាំ គឺត្រូវគេយកទៅវ៉ៃសម្លាប់ចោលនៅក្នុងព្រៃក្នុងភូមិព្រៃ ហើយខ្លះសម្លាប់នៅក្នុងព្រៃឫស្សី។ [...] កូនស្រីម្នាក់ទៀតត្រូវគេសម្លាប់ដោយបោះទៅលើចុងឫស្សីរួចទៅហើយ។"]។

[862] ឯកសារ D118/131 កំណត់ហេតុស្តាប់ចម្លើយ សាន់ ទូច ឆ.៦០-៦២ KH 00960606 ["ស៖ [...] ក្នុងរបាយការណ៍នេះ លោកនិយាយថា "បានឃើញរណ្តៅសាកសពរួមពីរ។ មួយនៅក្នុងភូមិព្រៃ [...] តើលោកអាចបញ្ជាក់ថាលោកបាននិយាយដូច្នេះដែរឬទេ? ឆ.៦០៖ បាទ ខ្ញុំបាននិយាយដូច្នេះ។ ស៖ ហេតុអ្វីបានជាលោកដឹងថា សាកសពខ្មែរក្រោមត្រូវបានកប់នៅទីនេះ? ឆ.៦១៖ គេមិនបានកប់នោះទេ គឺគេវ៉ៃចោលហើយញាត់ចូលក្នុងណ្ណង្ហង្ហនៅលើភ្នំតែម្តង។ [...] ឆ.៦២៖ ខ្ញុំមិនបានឃើញនោះទេ ប៉ុន្តែអ្នកមូលដ្ឋានបានឲ្យការណ៍អំពីរឿងនេះ"]។

[863] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៥៩-៦០ KH 00993600 ["ឆ.៥៩៖ [...] ពេលនោះខ្មែរក្រហមតាមស្នាក់ចាប់បានខ្មែរក្រោមដែលលួចរត់ទៅវៀតណាមនោះ យកមកសម្លាប់នៅក្នុងព្រៃក្នុងភូមិព្រៃ។ ស៖ ហេតុអ្វីបានជាលោកដឹងរឿងទាំងនោះ? ឆ.៦០៖ ក្រោយមកឆ្នាំ១៩៨០ ខ្ញុំមកនៅភូមិព្រៃ ខ្ញុំដឹងរឿងនេះតាមរយៈ អ្នករត់រួចខ្លួនហើយអត់ទៅនៅវៀតណាមវិញ គឺដោយសារគាត់មានបងប្អូនដែលត្រូវបានខ្មែរក្រហមចាប់បានហើយយកទៅសម្លាប់នៅពេលនោះ បាននិយាយប្រាប់។"]។ ឯកសារ D118/163 កំណត់ហេតុស្តាប់ចម្លើយ ព្ញ៉ សារ៉ៃន ឆ.២៦-២៧, ៣០ KH 00968122 ["ស៖ តើលោកធ្លាប់បានឃើញ ឬក៏ឮថាគេចាប់ពួកខ្មែរក្រោមទេ? ឆ.២៦៖ ខ្ញុំគ្រាន់តែឌ៉ឹងថា ខ្មែរក្រោមមកពី [...] វៀតណាម ត្រូវបានគេយកសម្លាប់នៅវត្តព្រៃ ឃុំសោម ស្រុកគិរីវង់។ [...] ឆ.២៧៖ ខ្ញុំបានដឹងពីមនុស្សដែលរត់រួច ហើយមកធ្វើការនៅក្រុមជាមួយខ្ញុំ គាត់ឈ្មោះដោក ហើយម្នាក់ទៀតឈ្មោះ គុន។ [...] ឆ.៣០៖ គេប្រាប់ខ្ញុំថា ខ្មែរក្រហមបោះកូនក្មេងឡើងលើហើយចាក់នឹងជំពុះទង់ ហើយស្រីៗគេចាប់រំលោភហើយបាញ់ចោល នៅព្រៃញ្ញេញ នៅក្បែរភូមិព្រៃ។ គ្រួសារខ្មែរក្រោមប្រហែល ១០គ្រួសារហ្នឹងដែលគេយកទៅដាក់នៅវត្តព្រៃ នៅរស់ខ្លះ ស្លាប់ខ្លះ។"]។

[864] ឯកសារ D118/147.1.43 របាយការណ៍គម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ សាន់ ទូច EN 00527165 ["ខ្ញុំបានរកឃើញរណ្តៅសាកសពរួមពីរ មួយនៅភូមិព្រៃ មួយទៀតនៅភូមិសោល ក្នុងឃុំសោម ស្រុកគិរីវង់ កន្លែងដែល[ខ្មែរ]ក្រោមត្រូវបានសម្លាប់"]។ ឯកសារ D118/131 កំណត់ហេតុស្តាប់ចម្លើយ សាន់ ទូច ឆ.៦០-៦២, ៦៤-៦៥, ៦៧-៧២,

២០១២ ងួន គឹមម៉ង ជាប្រធានភូមិព្រាល បាននិយាយថា មានរណ្តៅកប់សពរួមចំនួនពីរ ឬបីរណ្តៅស្ថិតនៅក្បែរព្រៃក្បែរភូមិព្រាល ជាទីកន្លែងដែលគេជឿថា សាកសពប្រជាជនខ្មែរ និងទាហានវៀតណាម ត្រូវបានប្រមូលយកដោយអាជ្ញាធរវៀតណាម[865]។

ការធ្វើទុក្ខបុកម្នេញ

267. ការធ្វើទុក្ខបុកម្នេញ ត្រូវបានប្រព្រឹត្តតាមរយៈឧក្រិដ្ឋកម្មទាំងប៉ុន្មានដូចបានរៀបរាប់ខាងលើ ប្រឆាំងនឹងខ្មែរក្រោម។ ក្រុមនេះត្រូវបានកំណត់គោលដៅចំៗ ដោយសារតែសមាជិកភាពពិតប្រាកដ ឬតាមការសន្មតរបស់ពួកគេចំពោះក្រុមនយោបាយ[866]។

---

[865] ឯកសារ D105/21 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ងួន គឹមម៉ង KH 00971227-28 ["នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០១២ យើងបានទៅភូមិព្រាល [...]។ នៅទីនោះ យើងបានជួបជាមួយលោកស្រី ងួន គឹមម៉ង អាយុ ៥៩ឆ្នាំជាប្រធានភូមិ។ យោងតាមលោកស្រី ងួន គឹមម៉ង ឆ្អឹងមនុស្សត្រូវបានគេរកឃើញក្នុងរណ្តៅសាកសពរួមនៅក្បែរព្រៃ។ អាជ្ញាធរវៀតណាមបានមកប្រមូលអដ្ឋិធាតុទាំងនោះស្ទើរតែទាំងអស់ព្រោះគេគិតថា នោះជាអដ្ឋិធាតុរបស់ឃ្នុជនពលីវៀតណាមក្នុងអំឡុងជម្លោះជាមួយខ្មែរក្រហម។ ជាក់ស្តែង អដ្ឋិធាតុជនជាតិខ្មែរខ្លះក៏ត្រូវបានគេរកឃើញនៅទីនោះផងដែរ។ បច្ចុប្បន្ននេះយើងមិនអាចរកទីតាំងនោះឃើញ ឬចូលទៅកាន់ទីទាំងនោះបានទេ ព្រោះទីនោះក្លាយទៅធ្វើជាវាលស្រែអស់ទៅហើយ"]។

[866] *សូមមើល* V.ค.๓.ก. ឧក្រិដ្ឋកម្ម - ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – គោលនយោបាយ បកក ដើម្បីបំផ្លាញប្រជាជនវៀតណាម - ចេតនារបស់ បកក ចំពោះប្រជាជនវៀតណាម និងខ្មែរក្រោម។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

268. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងទីតាំងសម្លាប់មនុស្សភូមិព្រាល[867]៖ អំពើប្រល័យពូជសាសន៍ទៅលើក្រុមជាតិសាសន៍វៀតណាមនៅកម្ពុជា (ជាពិសេសខ្មែរក្រោម)[868] ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[869] ការជម្លៀស ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងខ្មែរក្រោម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបញ្ជូនដោយបង្ខំ ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។

ង. មន្ទីរសន្តិសុខក្រាំងតាចាន់

i. សេចក្តីផ្តើម

269. មន្ទីរអប់រំស្រុក១០៥ ដែលគេស្គាល់ថាជា មន្ទីរសន្តិសុខក្រាំងតាចាន់ (“ក្រាំងតាចាន់”) ស្ថិតនៅក្នុងមូលដ្ឋានរឹងមាំរបស់ ប.ក.ក នៃស្រុកត្រាំកក់ ដែលនៅឆ្នាំ១៩៧៧ ត្រូវបានចាត់តាំងជា “ស្រុកគំរូ” មួយ ដែលអ្នកផ្សេងៗទៀតត្រូវបានជំរុញឲ្យធ្វើការប្រណាំងប្រជែង[870]។ នៅក្រាំងតាចាន់ ពួកកម្មាភិបាលភូមិភាគនិរតី បានឃុំឃាំងអ្នកដែលគេសង្ស័យថាជាខ្មាំងនៃរបបនោះក្រៅប្រព័ន្ធតុលាការ រួមមាន “ប្រជាជន ១៧ មេសា” និងពួកខ្មែរក្រោម។ អ្នកទោសជាច្រើននាក់ត្រូវបានធ្វើទារុណកម្ម

---

[867] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីទាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះគឺអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះដោយ៖ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១២។

[868] *សូមមើល* V.ค. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម។

[869] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលចំពោះឧក្រិដ្ឋកម្មសម្លាប់រង្គាល ត្រូវបានបញ្ជាក់ដោយភ័ស្តុតាងសម្រាប់តែមន្ទីរសន្តិសុខវត្តសម្តេចតែងតែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលជាលក្ខខណ្ឌតម្រូវសម្រាប់បញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងទីតាំងសម្លាប់មនុស្សភូមិព្រាលនេះផង ត្រូវលើកយកមកពិចារណាបញ្ចូលគ្នា។ ទីតាំងទាំងអស់ គឺជាផ្នែកនៃប្រព័ន្ធរៀបចំមួយក្នុងការអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង និងការសម្លាប់នៅតាមទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងនេះ ត្រូវបានជួយសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចគ្នារបស់ យ៉ីម ទិត្យ។

[870] សំរាប់ការជាក់លាក់ *សូមមើល* កថាខណ្ឌ ១៣៨ ដើងទំព័រ ៣៧២។

ហើយទាំងអស់គ្នាបានស្លាប់ ដោយសារលក្ខខណ្ឌថោកទាប ឬក៏ត្រូវបានសម្លាប់ សល់តែពីរ-បីនាក់ប៉ុណ្ណោះ។ ពួកកម្មាភិបាលភូមិភាគនិរតីបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះនៅក្រាំងតាចាន់ នៅក្នុងការជួយជ្រោមជ្រែងដល់សហឧក្រិដ្ឋកម្មរួមដែលនៅក្នុងនោះ **យ៉ឹម ទិត្យ** គឺជាសមាជិកនាំមុខមួយរូប។

270. ទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់នេះ ស.ច.ស.អ បានចោទប្រកាន់ **យ៉ឹម ទិត្យ** ពីឧក្រិដ្ឋកម្មនានាដូចតទៅ៖ អំពើប្រល័យពូជសាសន៍លើពួកខ្មែរក្រោម[871] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ឬពូជសាសន៍ប្រឆាំងនឹងពួកខ្មែរក្រោម និងដោយមូលហេតុនយោបាយប្រឆាំងនឹង "ប្រជាជន ១៧ មេសា" ដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ និងការឃុំខ្លួននៅក្នុងលក្ខខណ្ឌអមនុស្សធម៌) និងអំពើមនុស្សឃាតដោយគិតទុកជាមុន នៅក្រោមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[872]។

---

[871] *សូមមើល* V.ค.๕.ข.i. ឧក្រិដ្ឋកម្ម-ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម- ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាមក្នុងភូមិភាគនិរតី-ការប្រព្រឹត្តលើជនជាតិវៀតណាម និងខ្មែរក្រោមក្នុងស្រុកត្រាំកក់ ឆ្នាំ១៩៧៥-១៩៧៨-មន្ទីរសន្តិសុខក្រាំងតាចាន់-សម្រាប់ការពិភាក្សាពេញលេញមួយពីឧក្រិដ្ឋកម្មនៅក្រាំងតាចាន់ ដោយសារតែ ស.ព.អ មានទស្សនៈថា ភស្តុតាងស្តីពីទង្វើរបស់ យ៉ឹម ទិត្យ សម្រាប់បទចោទទាំងនេះ គឺត្រូវបានបកស្រាយបានប្រសើរជាង នៅពេលដែលត្រូវបានពិចារណាស្របជាមួយនឹងបរិបទច្បាប់ និង ប្រវត្តិសាស្ត្រដែលបានលើកឡើងនៅក្នុងផ្នែកនោះ។

[872] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ឹម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426544, 48, 58។

ii. ប្រតិបត្តិការ និងទីតាំង

271. ដោយបានបង្កើតឡើងក្នុងឆ្នាំ១៩៧២ ឬ ឆ្នាំ១៩៧៣[873] ក្រាំងតាចាន់បានបម្រើជាគុកធំនៅស្រុកត្រាំកក់ ទាំងនៅមុន និងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។ មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងឃុំគុស នៃស្រុកត្រាំកក់ តំបន់១៣ នៃភូមិភាគនិរតី[874]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

272. ក្រាំងតាចាន់ គឺជាគុកស្រុក ដែលត្រួតត្រាដោយគណៈស្រុកត្រាំកក់ ដែលបានរាយការណ៍ទៅគណៈតំបន់១៣ ដែលនៅពេលមួយត្រូវបានដឹកនាំដោយ **យ៉ឹម ទិត្យ**[875]។ ប្រធានឈ្មោះ ផាន់ ឆេន និងអនុ របស់គាត់ឈ្មោះ តាអាន់ បានត្រួតត្រាលើគុកនេះរហូតដល់ ផាន់ ឆេន ត្រូវបានផ្លាស់ នៅពាក់

---

[873] ឯកសារ D6.1.652 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ៉ីម KH 00373464 ["មន្ទីរនោះបង្កើតឡើងតាំងពីឆ្នាំ១៩៧២ ដោយ បក្សតំបន់ និងបក្សស្រុក"]។ ឯកសារ D6.1.778 កំណត់ហេតុស្តាប់ចម្លើយ កែវ ច័ន្ទតារ៉ា KH 00163456។ ឯកសារ D219/522 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង ឆ.២២ KH 01149847។ ឯកសារ D315.1.8 ផាន់ ឆេន ប្រតិចារ៉ឹក ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.57.00-09.58.36។

[874] *សូមមើល ឧទាហរណ៍* ឯកសារ D1.3.27.6 នាង រ៉ន *ប្រវត្តិសង្ខេបរបស់មណ្ឌលប្រល័យពូជសាសន៍ឈ្មោះក្រាំងតាចាន់* KH 00079436។ ឯកសារ D315.1.9 រ៉ាន់ សឿន ប្រតិចារ៉ឹក ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ ម៉ោង 14.08.19-14.10.18 ["មន្ទីរក្រាំងតាចាន់ ស្ថិតនៅក្នុងឃុំគុស"]។ ឯកសារ D366/4.1.1 ជ៉ាង ស្រីមុំ ប្រតិចារ៉ឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ម៉ោង 09.44.46-09.47.23 ["ខ្ញុំពុកខ្ញុំដែលគេយកសម្លាប់នៅភូមិក្រាំងតាចាន់ហ្នឹង ស្ថិតនៅក្នុងឃុំគុស"]។ ឯកសារ D6.1.652 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ៉ីម KH 00373465 ["មន្ទីរសន្តិសុខនោះមានទីតាំងស្ថិតនៅក្នុងភូមិ ក្រាំងតាចាន់ ឃុំ គុស ក្នុងស្រុក១០៥ (ស្រុកត្រាំកក់) ខេត្ត តាកែវ"]។ ឯកសារ D219/40 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.៣០-៣១ KH 01032140។

[875] ឯកសារ D364/2.1.2 សយ សែន ប្រតិចារ៉ឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.27.48-15.29.36 ["គាត់មកបានធ្វើគណៈស្រុក១០៥ហ្នឹងវិញ-តាភី ចុាំងពៀច-ប៉ុន្តែកន្លែងក្រាំងតាចាន់ ចន្លោះថ្ងៃតិចណាស់ យ៉ាងហោចក្នុងមួយអាទិត្យ គាត់មកបីដង និងបួនដង អត់ខានទេ បាទ ភី ចុាំងពៀច"]។ ឯកសារ D6.1.652 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ៉ីម KH 00373464 ["ការងារមន្ទីរសន្តិសុខ [ក្រាំងតាចាន់] គឺគេធ្វើឡើងពីមន្ទីរសន្តិសុខមកស្រុក និងពីស្រុកទៅតំបន់"]។ ឯកសារ D219/40 កំណត់ ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.៤០ KH 01032141។ ឯកសារ D118/242 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម ឃ្ងៀន ឆ.១៨៧ KH 00998748 ។ សូមមើលកថាខណ្ឌ ២៨៧ និង ២៩៣។ ចំពោះសេចក្តីពិស្តារពាក់ព័ន្ធនឹងថាតើនរណាជាគណៈស្រុកត្រាំកក់ និង នៅពេលណា *សូមមើល* កថាខណ្ឌ១៣៩។ ចំពោះសេចក្តីពិស្តារពាក់ព័ន្ធនឹងតួនាទីរបស់ យ៉ឹម ទិត្យ នៅក្នុងភូមិភាគនិរតី និងនៅគណៈតំបន់១៣ ដោយឡែក *សូមមើល* III.គ.១. មុខតំណែងរបស់ យ៉ឹម ទិត្យ អ្នកពី និងទង្វើ ការចូលរួមចំណែករបស់ យ៉ឹម ទិត្យ ក្នុងផែនការ ឧក្រិដ្ឋកម្មរួមក្នុងភូមិភាគនិរតី មុខតំណែងរបស់ យ៉ឹម ទិត្យ ក្នុងភូមិភាគនិរតី។

កណ្តាលឆ្នាំ១៩៧៥[876]។ ពេលនោះ តាអាន់ បានធ្វើជាប្រធានគុកនេះរហូតដល់របបដួលរលំ[877]។ ឌុ ច ធំ បានបម្រើជាអនុរបស់ តាអាន់ រហូតដល់គាត់ត្រូវបានជំនួសដោយដោយ ពេញ[878]។

---

[876] *សូមមើល ឧទាហរណ៍* ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.29.43-14.31.28 ["តាឆេន គាត់កាន់កាប់មន្ទីរហ្នឹងមុនគេបង្អស់ ហើយពី តាឆេន បានដូរមក តាអាន់។ តាអាន់ ហ្នឹងមកនៅក្រោយខ្ទង់ឆ្នាំខ្ញុំមិនអាចចាំទេ ខ្ទង់រំដោះហើយ គាត់មកនៅរំដោះហើយ"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.58.24-10.59.35។ ឯកសារ D315.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.23.18-14.24.52។ ឯកសារ D6.1.652 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម KH 00373466 ["ឈ្មោះ ឆេន ជាប្រធានមន្ទីរ និង អាន់ ជាអនុរបស់ ឆេន"] KH 00373469 [ឆេន ត្រូវបានផ្ទាស់ឲ្យទៅធ្វើជាប្រធានមន្ទីរសន្តិសុខ ប៊ីងស្រង៉ែ [...] ប្រហែលជាពាក់ កណ្តាលឆ្នាំ១៩៧៥] ។ ឯកសារ D6.1.779 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ៅ KH 00163468 [អតីតអ្នកទោសនៅក្រាំងតាចាន់ ដែលបានចាប់ខ្លួននៅឆ្នាំ១៩៧៤៖ "មានឈ្មោះ ផាន់ ឆេន ជាមេ-អនុឈ្មោះ អាន់"]។ ឯកសារ D6.1.690 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម ឆ.ពាក្យ KH 00414435។ ឯកសារ D134/8 កំណត់ហេតុស្តាប់ចម្លើយ ស្ងួត សាំង ឆ.៤២ KH 00964483។ ឯកសារ D6.1.669 កំណត់ហេតុស្តាប់ចម្លើយ កែវ ច័ន្ទតារា ឆ.២, ១៣ KH 00402485, 87។ *ប៉ុន្តែ សូមមើល* ថានៅពេលដែលផាន់ ឆេន ផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០២ គាត់បាននៅតែអះអាងថា គាត់មិនដែលបានបំរើជាប្រធានគុកទេ ហើយថា គាត់បានចាកចេញពីកន្លែងនោះ ក្នុងឆ្នាំ១៩៧៤៖ ឯកសារ D315.1.7 ផាន់ ឆេន ប្រតិចារឹក ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.59.59-14.01.48 ["ឆ្នាំ៧៤ ខ្ញុំទៅនៅខាងខេត្តកំពង់ស្ពឺ"] ម៉ោង 14.12.09-14.18.29, 14.36.06-14.37.40 និងឯកសារ D315.1.8 ផាន់ ឆេន ប្រតិចារឹក ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.15.13-14.18.10។ *សូមមើលផងដែរ* ឯកសារ D6.1.692 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.៤០-៤១ KH 00414487-88។

[877] *សូមមើល ឧទាហរណ៍* ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.29.43-14.31.28 ។ ឯកសារ D315.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.23.18-14.24.52 ["បាទ អ្នកដឹកនាំស្គាល់ [...] ខ្ញុំចូលទៅនៅ[ក្រាំងតាចាន់]នោះ មុនដំបូងមាន តាឆេន ហ្នឹងមុនឆ្នាំ៧៥ ដល់ក្រោយឆ្នាំ៧៥ មាន តាអាន់"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.24.11-11.25.49 ["ឈ្មោះ អាន់ គឺគាត់ជាប្រធាន។ បន្ទាប់មកឈ្មោះ ឌីម ពេញ"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.15.48-11.18.04 ។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.29.19-09.30.14។ ឯកសារ D315.1.14 ឌាង អ៊ីច ហៅ តាសាន ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ម៉ោង 15.26.50។ ឯកសារ D364/2.1.5 ស្ងួត សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.33.59-09.36.57។ ឯកសារ D118/166 កំណត់ហេតុស្តាប់ចម្លើយ ទ្រឹម ហ៊ី ឆ.៤០-៤១ KH 00968159។ ឯកសារ D118/242 កំណត់ហេតុស្តាប់ចម្លើយ ខ៊ីម ប៊ឿន ឆ.១៨៩, ២០១ KH 00998749, 50។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យ៉ិន គេង ឆ.១១៨ KH 01052704។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.២៤ KH 01000019។ *ប៉ុន្តែ សូមមើល* ឯកសារ D315.1.7 ផាន់ ឆេន ប្រតិចារឹក ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.12.09-14.14.13, 15.21.22-15.23.07។ ឯកសារ D315.1.8 ផាន់ ឆេនប្រតិចារឹក ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.04.02-11.06.05, 13.45.41-13.47.02, 15.21.10-15.25.52។ ឯកសារ D118/103.1 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.ពាក្យ KH 00483939 ឆ.៥៦, ៦០ KH 00483946-47។ ឯកសារ D6.1.692 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.២២ ២៥

273. កម្មាភិបាលតំបន់១៣ និងស្រុកត្រាំកក់ បានប្រាស្រ័យទាក់ទងគ្នាជាប់ជាប្រចាំជាមួយនឹងប្រធានគុក នៅក្រាំងតាចាន់។ កម្មាភិបាលទាំងនេះបានផ្ញើសេចក្តីណែនាំសួរចម្លើយទៅ អាន់, អាន់ បានផ្ញើរបាយការណ៍សួរចម្លើយ និង "ចម្លើយសារភាព" ត្រឡប់ទៅវិញ បន្ទាប់មក ពួកគេបានចេញបញ្ជាទៅ អាន់ ដើម្បីឲ្យដោះលែង បញ្ជូន ឬ សម្លាប់ពួកអ្នកទោស ហើយ អាន់ អនុវត្តនូវបទបញ្ជារបស់ពួកគេ[879]។

iv. ឧក្រិដ្ឋកម្ម

<u>អំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ)</u>

274. ក្នុងឆ្នាំ១៩៧៦ ប្រជាជនមកពីកម្ពុជាក្រោម រួមទាំង ជនជាតិកម្ពុជាផង ដែលបានគេចខ្លួនទៅប្រទេសវៀតណាម ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បានយល់ព្រមវិលត្រឡប់ទៅកាន់កម្ពុជាប្រជាធិបតេយ្យវិញ នៅក្នុងកម្មវិធីផ្លាស់ប្តូរគ្នាមួយ ប៉ុន្តែជាជាងអនុញ្ញាតឲ្យពួកគាត់វិលត្រឡប់ទៅកាន់ភូមិដើមកំណើតរបស់ពួកគាត់វិញនោះ ពួកខ្មែរក្រហមបានផ្លាស់ប្តូរកន្លែងរបស់ពួកគាត់ដោយបង្ខំឲ្យទៅកាន់ស្រុកនានា រួមទាំងស្រុកត្រាំកក់ផង[880]។ នៅដើមឆ្នាំ១៩៧៧ មាន "ប្រជាជន ១៧

---

៣៧ ៤១ ៤៤ ៤៧ KH 00414485, 87-89។ ឯកសារ D6.1.695 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.៤ ៣០ ៣២-៣៣ ៤៧ KH 00414442, 46-48។ ឯកសារ D219/40 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.៤០ KH 01032141។ ឯកសារ D219/41 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.៧៥ ៩២-៩៣ KH 01032154, 56។

[878] ឯកសារ D315.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.23.18-14.24.52 ["ក្រោយឆ្នាំ៧៥ [ថ្នាក់ដឹកនាំគុក] មាន តាអាន់, តាពេញ-តាពេញធំ-អ៊ុ! តាឌុចធំ មិនមែន តាពេញធំ ទេ តាឌុច ធំ"]។ ឯកសារ D315.1.3 សយ សែន ប្រតិចារឹក ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ម៉ោង 14.36.10-14.37.55 ["ឌុចធំ ហ្នឹងគេអនុប្រធានហើយ"]។ ឯកសារ D315.1.17 នុត នូវ ប្រតិចារឹក ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ម៉ោង 10.37.42-10.40.10 ["អ៊ៀប ឌុច នេះ មានស្គាល់ពិតប្រាកដ។ អ៊ៀប ឌុច ហ្នឹងជាប្រធានយុវជនស្រុកត្រាំកក់ពីមុន ក្រោយមកឮថាមកនៅមន្ទីរក្រាំងតាចាន់"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.24.11-11.25.49 ["ឌុចធំ គាត់អញ្ជើញចេញពីកន្លែងក្រាំងតាចាន់ ពីឆ្នាំ៧៧ គាត់ត្រឡប់ទៅនៅភូមិភាគឧត្តរ"]។ ឯកសារ D6.1.119 កំណត់ហេតុស្តាប់ចម្លើយ សយ សែន KH 00223068។ ឯកសារ D118/133 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឆ.៣៨ KH 00960633។ ឯកសារ D6.1.709 កំណត់ហេតុស្តាប់ចម្លើយ ស្រី ថន ឆ.៤ KH 00427973។

[879] *សូមមើល* កថាខណ្ឌ ២៨៧ និង ២៩៣។

[880] ឯកសារ D315.1.4 រ៉ ពៅ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.23.46-09.25.00 ["មន្ត្រីរបស់វៀតណាមហ្នឹងរដ្ឋការរបស់វៀតណាមហ្នឹង ប្រាប់ថាបងប្អូនខ្មែរត្រូវវិលត្រឡប់ទៅភូមិកំណើតវិញ ដោយសារមានការដោះដូរ។ អ៊ីចឹង បងប្អូនដែលបានគេចអៀសខ្លួនពីខ្មែរទៅ នាំគ្នាស្រុះស្រួលមូលមតិយោបល់គ្នា បានព្រមព្រៀងវិលត្រឡប់មកភូមិកំណើតវិញ"] ម៉ោង

មេសា” រាប់ពាន់នាក់ពីម្តុំជិតស្រុកគិរីវង់ ក៏ត្រូវបានផ្លាស់ប្តូរលំនៅដ្ឋានដោយបង្ខំឲ្យទៅកាន់ស្រុកត្រាំកក់ផងដែរ ដោយសារតែការភ័យខ្លាចថា អ្នកទាំងនោះនឹងរត់គេចខ្លួនទៅវៀតណាម[881]។ កំណត់ត្រាគុកដែលនៅសេសសល់បានបញ្ជាក់ថា ពួកអ្នកផ្លាស់ប្តូរលំនៅស្ថានជាច្រើននាក់ត្រូវបានដាក់ឃុំឃាំងជាចុងក្រោយនៅក្រាំងតាចាន់[882]។

09.31.04-09.33.50 [“ពេលវាដឹកមកដាក់នៅភូមិត្នោតជុំហ្នឹង ក្រោយពីវាប្រមូលទ្រព្យសម្បត្តិអស់”] ម៉ោង 09.43.04-09.45.19 [ពួកមកពីយួន “គេចាត់ទុកដូចជាខ្ញុំកញ្ជះដាច់ផ្ទៃរបស់គេអ៊ីចឹង។ ជាឧបករណ៍មួយសម្រាប់គេវ៉ៃគេតប់។ អ៊ីចឹងការហូប ការដេក ដើរ ឈរ អង្គុយ គឈក្រឹតវិន័យគេតឹងតែងណាស់។ អត់មានយើងដើរលហេតរហូតបាន ឬមួយហូប បើសិនណាយើងចាប់ត្រីបាន ត្រូវយកទៅដាក់ក្នុងសហករណ៍”]។ ឯកសារ D5/49/3 តាក សាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ម៉ោង 13.12.57-13.15.33 [“ខ្ញុំឡើងមក ដោយដូរយួនហ្នឹង”] ម៉ោង 13.19.21-13.22.13 [“នាងខ្ញុំមិនដឹងថាទៅណាទេ ថាបានមកដល់ស្រុកភូមិហើយ ពីតតែអរ។ ដល់រួចទៅ [...] គេអត់ឲ្យនាងខ្ញុំទៅនុំងផង គេឲ្យយកខ្ញុំហួសទៅត្នោតជុំទៅ”]។ ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ឆ.៨១ KH 00960592។

[881] ឯកសារ D6.1.1105 ប៉ែន ឃៀនិន *របប ប៉ុល ពត* KH 00637647 [“ក្នុងពេលទន្ទឹមគ្នានេះដែរ ប្រជាជនថ្មីជម្លៀសមកពីភ្នំពេញដែលកំពុងស្ថិតនៅក្នុងស្រុកគិរីវង់ ត្រូវបានគេបញ្ជូនបន្តទៅទៀត ដោយបកមកក្រោយបញ្ជ្រាសទិសមកវិញ។ សារុន ដែលរៀបរាប់រំលឹកប្រាប់ថា “នៅដើមឆ្នាំ១៩៧៧ ប្រជាជនថ្មីទាំងអស់នៅស្រុកគិរីវង់ត្រូវពួកខ្មែរក្រហមបញ្ជូនទៅលត់ដំនៅស្រុកត្រាំកក់ ហើយកាលនោះគឺមានចំនួនរាប់ពាន់នាក់។ ពួកខ្មែរក្រហមទាំងនោះខ្លាចយើងខ្ញុំរត់ទៅវៀតណាម””]។

[882] *សូមមើល ឧទាហរណ៍* <u>ខ្សែរក្រោម</u>៖ ឯកសារ D347/2.1.9 បញ្ជីឈ្មោះអ្នកទោសនៅក្រាំងតាចាន់ លេខរៀងទី៣៣ KH 00068737 [ថាច់ វណ្ណា-បោសសំអាតនៅថ្ងៃទី២២ ខែឧសភា ឆ្នាំ១៩៧៧]។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271093 [ថាច់ សារ៉ែន] KH 00271118 [ថាច់ អ៊ីក] KH 00271123 [កិម ខេន] KH 00271125 [ចាន់ ដារ៉ា]។ ឯកសារ D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271155 [ខៀវ ភ័]។ ឯកសារ D6.1.214 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270823 [ថាច់ ស្ងួន]។ ឯកសារ D6.1.1220 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00068062 [ថាច់ អ៊ីងណាង] KH 00068068 [នាង អាន់] KH 00068069 [គឹម ធី សារ៉ែន] KH 00068069 [ថាច់ ធីស៊ីង] KH 00068069 [ទួន ហ៊ុន]។ ឯកសារ D6.1.275 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270861 [លី ឡេម] KH 00270878 [សុក ភៅ ហៅ ការ] EN 00270884 [គឹម អ៊ីញ] KH 00270892-93 [ណង់ ភន ហៅ ញ្ញូង]។ ឯកសារ D118/162 កំណត់ហេតុស្តាប់ចម្លើយ កែវ កន ឆ.៣៣ KH 00968112។ <u>“ប្រជាជន ១៧ មេសា” ដែលបានបញ្ជូនមកពីស្រុកគិរីវង់ (ស្រុក១០៩)</u>៖ ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271060 [នាង ម៉ៅ, ប្រាយ ប៉ាន, ហ៊ីម ហេន] KH 00271061 [ភ៉ី ផុន, គាវ ឆ្លង, ពី សុក ហេង, ស្ង ណុស] KH 00271061-62 [សៀង ធី, សៀង រ៉ៀន, អ៊ិន ឡាយ, ខៀវ ហោ] KH 00271066-67 [យ៉ែម សារ៉ន,ស្ងួន ហ៊ៀម] KH 00271068 [រដ្ឋ ម៉ុស] KH 00271068 [ចាន់ ឆក] KH 00271069 [ញ្ជ៉ែប] KH 00271072 [ម៉ាន់ សេង] KH 00271076 [សុក ជ្ង, ម៉ៅ ចាន់ផុន, សុក សយ] KH 00271077 [រស់ ឡាយ, សោម សុស៊ីន, យស់ គឹម]។ ឯកសារ D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271133-34 [ទ្រី ហេង, អ៊ីង ភ័ម, មាស អេង, សែស សរ៉ី, ធ៉ីង ភ័ម, តាក ស៊ីម, ង៉ែត ង៉ាន, ឃុន ឃន, ខៀវ សុន] KH 00271141-42 [រ៉ាត់ ថន] KH 00271146-47 [ស សារ៉ី, ចាន់ ថា] KH 00271147

ការដាក់ក្នុងមន្ទីរឃុំឃាំង

275. ក្រាំងតាចាន់ គឺជាមជ្ឈមណ្ឌលនៃប្រព័ន្ធគុកស្រុកត្រាំកក់ ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានដាក់ក្នុងមន្ទីរឃុំឃាំងនូវពួកអ្នកប្រព្រឹត្តកំហុស "ធ្ងន់ធ្ងរ"។ មិនមានអតីតអ្នកទោសណាម្នាក់ដែលបានផ្តល់នូវភ័ស្តុតាងដែលបានបញ្ជាក់ថាពួកគាត់ ឬនរណាម្នាក់ផ្សេងទៀតដែលបានជាប់ឃុំឃាំងជាមួយនឹងគាត់ ទទួលបានការចោទប្រកាន់ជាផ្លូវការពីឧក្រិដ្ឋកម្មណាមួយ នៅមុន ឬ ក្រោយពេលមកដល់ក្រាំងតាចាន់ឡើយ។ ពួកគេមិនត្រូវបានអនុញ្ញាតឲ្យទទួលបាននីតិវិធីត្រឹមត្រូវ ហើយមានអ្នកខ្លះត្រូវបានឃុំខ្លួនតាមទំនើងចិត្តអស់ជាច្រើនឆ្នាំ[883]។ ផ្ទុយទៅនឹងការទទួលបានមេធាវីការពារក្តី ឬការវិនិច្ឆ័យទោសដ៏ត្រឹមត្រូវ ពួកអ្នកទោសត្រូវទទួលរងនូវការធ្វើទារុណកម្មដើម្បីទាញយក "ចម្លើយសារភាព" ដែលបង្កើតបានជាមូលដ្ឋាននៃការចោទប្រកាន់សម្រាប់ការឃុំខ្លួនពួកគេដោយខុសច្បាប់ទៅវិញ[884]។

[ស៊ិន សុង] KH 00271148 [សាន ស៊ីង] KH 00271150 [ឡាយ គៀក] KH 00271152 [ឆេង ដាំលរ] KH 00271158 [ម៉ូ រ បន់ហៀង] KH 00271159 [ប៉ែន ឌន់] KH 00271160 [កប ហៅ ហម] KH 00271161-62 [គុយ នី, រ៉ន ហម ហៅ ពៅ មុ ន្នី] KH 00271165 [ស្ងួន ភី, ចក់ សៀប, ជ្ងុ ផល់]។ ឯកសារ D6.1.297 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271084-85 [ស្ងួ តែម] KH 00271085 [រ៉ាត់ ថន]។

[883] ឯកសារ D347/2.1.9 បញ្ជីស្នើបក្សចំពោះអ្នកទោសជាប់យូរឆ្នាំយូរខែកន្លងមកហើយ KH 00068730 [អ៊ាត ចិន, ហ៊ុន សេង [ហ៊ុន គិមសេង], មាស សារ៉ាត់, រ៉ង សានុ [រ៉ង សារ៉ុន], អ៊ីច ហាន]។ ឯកសារ D347/2.1.9 បញ្ជីអ្នកទោស ម១០៥ ពួកដែលជាប់ រាប់ឆ្នាំកន្លងមកហើយស្នើយោបល់បក្សសម្រេច KH 00068736 [យុគ ស៊ែន [សយ ស៊ែន], មើលមិនដាច់, ហ៊ុន ញ៉ូ, មាស រ៉ាត់, សំ ជ្ងុន]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារ៉ីក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.14.09-10.16.15 ["ឃុំខ្លួនរូបខ្ញុំ ជាមួយម្តាយខ្ញុំ ក្នុងក្រាំងតាចាន់ ពីឆ្នាំ១៩៧៦ រហូតទៅដល់ឆ្នាំ១៩៧៨ [...] គេយកទៅដាក់នៅត្រៀមសហករណ៍មួយ ត្រៀមធ្វើ ក្រែងដល់ថ្ងៃណាគេប្រមូលយកទៅវិញ។ គេធ្វើបណ្តោះអាសន្ន។ រយៈពេលបីឆ្នាំ[នៅក្រាំងតាចាន់]"]។ ឯកសារ D219/972.2.2 សយ ស៊ែន ប្រតិចារ៉ីក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.40.28-13.42.38 [បានបញ្ជាក់ថាគាត់ជាប់នៅក្នុងមន្ទីរឃុំឃាំងក្រាំងតាចាន់ហ្នឹងរយៈពេល៥ឆ្នាំ]។ ឯកសារ D219/899.1.3 រ៉ង សារ៉ុន ប្រតិចារ៉ីក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.42.55-09.46.07, 10.20.26-10.24.55, 11.42.57-11.47.53 [បានជាប់នៅក្នុងមន្ទីរឃុំឃាំងក្រាំងតាចាន់ជាមួយកូនតូចរបស់គាត់ ចាប់ពីខែឧសភា ឆ្នាំ១៩៧៧ រហូតដល់ពួកវៀតណាមបានមកដល់ក្នុងឆ្នាំ១៩៧៩]។ ឯកសារ D6.1.788 កំណត់ហេតុស្តាប់ចម្លើយ ឌាង ដាំ KH 00163545 [ជាប់គុកក្រាំងតាចាន់ពីឆ្នាំ១៩៧៧ ដល់ប៉ែក]។ ឯកសារ D219/522 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង ឆ.៣២ KH 01149848។

[884] *សូមមើល* V.ក.១.ង.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់ ១៣ – មន្ទីរសន្តិសុខក្រាំងតាចាន់ – ឧក្រិដ្ឋកម្ម – ទារុណកម្ម។

276. ឯកសារកម្ពុជាប្រជាធិបតេយ្យដែលនៅសេសសល់ចំនួន១២ បានផ្តល់នូវកម្រិតប្រែប្រួលនៃសេចក្តីពិស្តារ១ របស់ពួកអ្នកទោសដែលបានឃុំខ្លួននៅក្រាំងតាចាន់[885] ដូចជា មុខរបរ១ របស់ពួកគាត់នៅមុនរបបនេះ កំហុសដែលបានលើកឡើងចោទប្រកាន់ និងកាលបរិច្ឆេទដាក់គុក និង/ឬ ស្លាប់។ ស.ព.អ បានចងក្រងនូវព័ត៌មានឲ្យទៅជាបញ្ជីរួមមួយ ដើម្បីជួយបង្ហាញពីប្រភេទមនុស្សដែលត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងនៅក្រាំងតាចាន់[886]។ ក្រាហ្វិកចំនួនប្រាំបី (រូបលេខ ១.១-១.៨) ដែលបានជួយផ្តល់នូវការយល់ដឹងល្អប្រសើរជាង អំពីអ្នកជាប់ឃុំឃាំងនៅក្រាំងតាចាន់ ត្រូវបានដាក់បញ្ចូលនៅក្នុង **ឧបសម្ព័ន្ធ គ** ។

277. ការវិភាគមួយនៃបញ្ជីឈ្មោះ (**ឧបសម្ព័ន្ធ គ.១**) បង្ហាញថាមានភាគច្រើនលើសលុប (៧៥%) នៃប្រជាជនដែលបានចាប់ខ្លួន និងឃុំខ្លួននៅក្រាំងតាចាន់គឺជា "ប្រជាជន ១៧ មេសា" ឬម្យ៉ាងវិញ

---

[885] *សូមមើល* ឯកសារ D6.1.1214, D6.1.1220, D6.1.217, D347/2.1.3, D6.1.202, D6.1.218, D6.1.297, D347/2.1.9, D347/2.1.5, D6.1.275, D6.1.214, D6.1.1224។

[886] ទិន្នន័យនេះត្រូវបានកម្រិតពីព្រោះផ្នែកមួយចំនួននៃកំណត់ត្រាមើលមិនដាច់ ហើយមានព័ត៌មានខ្លះបានបាត់យ៉ាងច្បាស់លាស់។ មានភាពផ្សេងពីគ្នាផងដែរនៅក្នុងការប្រកបសរសេរអក្សរភាសាមួយនៅក្នុងឈ្មោះ តាមការបកប្រែឯកសារជាភាសាអង់គ្លេស និងបារាំង។ កាលណាមានទំនាស់នឹងគ្នា ស.ព.អ បានពិនិត្យមើលសំណៅដើមជាភាសាខ្មែរ ថាជាប្រភពអំណាចឯកសារ។ សូមកត់សម្គាល់ថា មានតែ តារាងស្ថិតិចំនួន ១១ ក្នុងចំណោម ១២ ប៉ុណ្ណោះដែលត្រូវបានដាក់បញ្ចូលទៅក្នុងការវិភាគរបស់ ក.ស.ព ធ្វើជាមូលដ្ឋានសម្រាប់តារាងស្ថិតិនេះ។ តារាងស្ថិតិទី១២ (ឯកសារ D347/2.1.3) ត្រូវបានថតចម្លងចេញពីឯកសារដើម ជាពីរកំណាត់-មួយកំណាត់ពាក់កណ្តាល មានឈ្មោះ អាយុ និង ទីកន្លែងកំណើត ដែលត្រូវតែស៊ីគ្នានឹង មួយកំណាត់ពាក់កណ្តាលទៀត ដែលមានមុខរបរ និង កាលបរិច្ឆេទនៃការការចាប់ខ្លួន/ការសម្លាប់។ ការណ៍នេះនឹងតម្រូវឲ្យមានការតម្រឹមឈ្មោះភូមិ ឃុំ និងស្រុក ឲ្យបានត្រឹមត្រូវ ដោយមានឈ្មោះខេត្តត្រូវគ្នា នៅកំណាត់ពាក់កណ្តាលម្ខាងទៀត តាមលំដាប់លំដោយដែលពួកវាមាននៅក្នុងតារាងស្ថិតិ។ យ៉ាងណាក៏ដោយ វាទំនងជាមានផ្នែកដែលស៊ីគ្នាមួយចំនួន បានបាត់ ដោយសារទីកន្លែងនានានោះមិនស៊ីគ្នាទេ។ អាស្រ័យហេតុដូច្នេះ ក.ស.ព បានរក្សាតារាងស្ថិតិនេះដាច់ដោយឡែក ហើយបានដាក់វាជា ឧបសម្ព័ន្ធ គ.៣ ដោយសារតែផ្នែកនៃតារាងស្ថិតិដែលអាចស៊ីគ្នាយ៉ាងគួរឲ្យជឿជាក់បាន។

ទៀត ត្រូវបានគេស្គាល់ថាជា "ប្រជាជនថ្មី"[887]។ "ប្រជាជនមូលដ្ឋាន"[888] និងកម្មាភិបាល ប.ក.ក[889] ក៏ដូចជា ជនជាតិចិន វៀតណាម ចាម និងខ្មែរក្រោម[890] ក៏ត្រូវបានឃុំខ្លួនផងដែរ ប៉ុន្តែស្ថិតក្នុងចំនួន

---

[887] *សូមមើល* ឧបសម្ព័ន្ធ គ.២ រូបលេខ ១.១ *ប្រជាជនថ្មី ទល់នឹង ប្រជាជនមូលដ្ឋាន នៅក្រាំងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុងឧបសម្ព័ន្ធ គ.១។ ការវិភាគបញ្ជីអ្នកទោសនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់, ពួកអ្នកទោសដែលត្រូវបានកំណត់អត្តសញ្ញាណជា "ប្រជាជនថ្មី" ដែលមានមូលដ្ឋាននៅលើព័ត៌មានជីវប្រវត្តិដែលអាចមាន បានថ្លែងពីទីកន្លែងកំណើតរបស់ពួកគេ មុខរបរពីមុន និងទីកន្លែងរស់នៅចុងក្រោយដែលបានដឹង។ ពួកអ្នកទោសដែលពុំមានព័ត៌មានជីវប្រវត្តិដែលអាចមាន ត្រូវបានធ្លុះបញ្ចាំងនៅក្នុងប្រភេទ "មិនបានកត់ត្រា" នៃ រូបលេខ ១.១។ *សូមមើលផងដែរ* ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.02.34 ["បាទ [អ្នកទោសនៅក្រាំងតាចាន់]ភាគច្រើនថ្មីហ្នឹងតែម្តង។ ភាគច្រើន ច្រើនតែ ១៧មេសាហ្នឹង"]។ ឯកសារ D6.1.782 កំណត់ហេតុស្តាប់ចម្លើយ អៀប ឌុច KH 00163493។ ឯកសារ D6.1.780 កំណត់ហេតុស្តាប់ចម្លើយ ស៊ាង សឿន KH 00163479។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.៥០ KH 01000025។

[888] *សូមមើល* ឧបសម្ព័ន្ធ គ.២ រូបលេខ ១.១ *ប្រជាជនថ្មី ទល់នឹង ប្រជាជនមូលដ្ឋាន នៅក្រាំងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុងឧបសម្ព័ន្ធ គ.១។ ការវិភាគបញ្ជីអ្នកទោសនៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់ ពួកអ្នកទោសដែលត្រូវបានកំណត់អត្តសញ្ញាណជា "ប្រជាជនមូលដ្ឋាន" ដែលមានប្រើប្រាស់ទូវព័ត៌មានជីវប្រវត្តិដែលអាចមាន បានថ្លែងពីទីកន្លែងកំណើតរបស់ពួកគេ មុខរបរពីមុន និង ទីកន្លែងរស់នៅចុងក្រោយដែលបានដឹង។ *សូមមើលផងដែរ* ឯកសារ D6.1.780 កំណត់ហេតុស្តាប់ចម្លើយ ស៊ាង សឿន KH 00163479 ["បែកពីភ្នំពេញ[អ្នកទោស] មកច្រើន [...] នៅមូលដ្ឋានក៏មាន"]។ ឯកសារ D6.1.782 កំណត់ហេតុស្តាប់ចម្លើយ អៀប ឌុច KH 00163493។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.៥០ KH 01000025។

[889] *សូមមើល* ឧបសម្ព័ន្ធ គ.២ រូបលេខ១.១ *ប្រជាជនថ្មី ទល់នឹង ប្រជាជនមូលដ្ឋាន នៅក្រាំងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុងឧបសម្ព័ន្ធ គ.១។

[890] <u>ប្រជាជនចិន</u>៖ ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271061 [លីម ឌិច ហ្ជ] KH 00271061 [ហេង ហ្ជរ] KH 00271074 [លី គន]។ ឯកសារ D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271150 [ឡាយ គ្ជៀក] KH 00271156 [ជុង គឹមឆែ] KH 00271156-57 [លីម ឈ្ជ] [ជុង ឈន]។ ឯកសារ D6.1.214 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270835-36 [គិម សាវ៉ាន់] [សុក ណាំ] KH 00270836 [អ៊ៀង ប៊ុនថន] KH 00270847 [លីប លៀប] KH 00270852 [សុខា ហៅ ស៊ុ]។ ឯកសារ D6.1.1224 បញ្ជីឈ្មោះអ្នកទោសនៅក្រាំងតាចាន់ KH 00068018 [ម៉ៅ ទុង]។ ឯកសារ D6.1.1220 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00068062-63 [សុក ទាង]។ ឯកសារ D6.1.275 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270894-95 [សំ សឿង]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163505 ["[ពួកអ្នកទោស] សុទ្ធតែមកពីស្រុក ១០៥ មានចិន ឃ្លួន ចាម, ឃ្លួនមាន២នាក់ និងអ្នក ១៧ មេសា"]។ ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រ៉ ពៅ ឆ.៥៩ KH 00960589។ <u>ប្រជាជនវៀតណាម</u>៖ ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271064 [យិន ខ៉ីង ហៅ ឡុង]។ ឯកសារ D6.1.214 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270815 [ថាច់ សឿង]។ ឯកសារ D6.1.1220 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00068056 [ដេ យ៉ឺន]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163505។ <u>ប្រជាជនចាម</u>៖ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី ៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.46.43-09.49.36 ["ច្រើនតែជនជាតិចាម បើថាក្រៅពីហ្នឹងខ្ញុំមិនសូវដែលឃើញទេ បើចាមអា

ជាភាគរយតិចមែនទែន។ ជាង ៨០% នៃអ្នកទោសគឺជាបុរស[891]។ អ្នកទោសស្ត្រី រួមមាន ស្រីក្មេងៗ ស្ត្រីមានផ្ទៃពោះ និងប្រពន្ធរបស់បុគ្គលដែលគេបានចាត់ទុកថាជាខ្ទាំង[892]។ សក្ខីកម្ម និងឯកសារ

ហ្ម្ងអាចស្គាល់ដោយសារគាត់ថាខ្ញុំអត់ហ្ងបសាច់ជ្រូកទេពីមុន"]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163505។ ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រ៉ ពៅ ឆ.៥៩ KH 00960589។ <u>ប្រជាជនខ្មែរក្រោម</u>៖ *សូមមើល* ភស្តុតាងដែលលើកឡើងខាងលើក្នុងជើងទំព័រ ៨៨២។

[891] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ១.៣ *អ្នកទោសបុរស និងស្ត្រី នៅក្រាំងតាចាន់* និងទិន្នន័យគាំទ្រនៅក្នុង ឧបសម្ពន្ធ គ.១ ក៏ដូចជាព័ត៌មានបន្ថែមដែលមាននៅក្នុង ឧបសម្ពន្ធ គ.៣។ *សូមមើលផងដែរ* ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.25.48-11.27.45 ["បាទ អ្នកទោស គេបញ្ជូនមកនោះ ភាគច្រើនជាបុរស"]។ ឯកសារ D347/2.1.34 ហង់រី ឡូកា ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង 09.46.40-09.48.41 ["យ៉ាងហោចណាស់ក៏មានអ្នកទោស ៨៦ភាគរយ[ក៏ប៉ុន្តែជាភាសាបារាំង និងអង់គ្លេស ថា ៩០ភាគរយ] ជាអ្នកទោសបុរសនៅតាមគុកទាំងអស់នៅប្រទេសកម្ពុជា"]។

[892] *សូមមើល ខ១០ហារណ៍* ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.42.55-09.46.07, 10.20.26-10.24.55, 11.42.57-11.47.53 [បានជាប់នៅក្នុងមន្ទីរឃុំឃាំងក្រាំងតាចាន់ជាមួយកូនតូចរបស់គាត់ ចាប់ពីខែឧសភា ឆ្នាំ១៩៧៧ រហូតដល់ពួកវៀតណាមបានមកដល់ក្នុងឆ្នាំ១៩៧៩]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.42.38-13.45.31 ["បានបាទ ខ្ញុំបញ្ជាក់]។ ស្ត្រី និង កុមារ"]។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.25.48-11.27.45 ["[អ្នកទោស]ស្ត្រីតិច ក្មេងក៏តិចដែរ"]។ ឯកសារ D6.1.780 កំណត់ហេតុស្តាប់ចម្លើយ ស៊ាង សៀន KH 00163479 ["ស៖ មានស្រី-កុមារទេ? ឆ.៖ មាន! អ្នកមានផ្ទៃពោះក៏មានដែរ នារីក៏មានសំណាប់ដែរ ប្តី ប្រពន្ធ កូន ១គ្រួសារ"]។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271095 [អ៊ៀង ស៊ាប] KH 00271101 [ភ្ជ្ជ សុក, ពេច សារ៉ាន] KH 00271121 [សេង ស៊ីថា] KH 00271129 [កុក ឡេ ង]។ ឯកសារ D347/2.1.9 បញ្ជីឈ្មោះអ្នកទោសនៅក្រាំងតាចាន់ KH 00068730 [ហ៊ុន សេង, មាស សារ៉ាត់, វង សានុ, អ៊ុច ហាន]។

ដែលនៅសេសសល់ ក៏បានបង្ហាញផងដែរថា មានពួកអ្នកទោសដែលស្ថិតនៅក្នុងអាយុចាប់ពី ទារក និងកូនក្មេងដែលមានអាយុពីរ-បីឆ្នាំ[893] រហូតដល់ ចាស់ជរា (៨៧ឆ្នាំ)[894]។

278. ស្ទើរតែ ៥០ភាគរយ នៃចំនួនអ្នកទោសធ្លាប់បានធ្វើការជាទាហាន មន្ត្រីរដ្ឋាភិបាល ឬ ប៉ូលិស នៅក្នុងអំឡុងពេលនៃរបប លន់ នល់[895]។ និស្សិត គ្រូបង្រៀន ព្រះសង្ឆ និង អ្នកប្រកបវិជ្ជាជីវៈ មាន

---

[893] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ១.៤ *អាយុរបស់អ្នកទោសនៅក្រោងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុង ឧបសម្ពន្ធ គ.១ ក៏ដូចជាព័ត៌មានបន្ថែមដែលមាននៅក្នុងឧបសម្ពន្ធ គ.៣។ *សូមមើលផងដែរ* ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.42.55-09.46.07 [សាក្សីរូបនេះបានជាប់នៅក្នុងមន្ទីរឃុំឃាំងក្រោងតាចាន់ជាមួយកូនតូចរបស់គាត់ ចាប់ពីខែឧសភា ឆ្នាំ១៩៧៧ រហូតដល់ពួកវៀតណាមបានមកដល់ក្នុងឆ្នាំ១៩៧៩]។ ឯកសារ D364/2.1.5 ស្ងួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.42.10-09.47.03 ["បាទ តាមខ្ញុំសង្កេតឃើញនៅក្នុងទីនោះ គឺកូនក្មេងតូចមានទៅ[ក្រោងតាចាន់]តាមឪពុកម្តាយបាទ។ [...] នៅក្នុងពេលនោះ គឺក្មេងនៅជាមួយឪពុកម្តាយមិនថាបុរស មិនថាស្ត្រីទេ គឺរស់នៅជាមួយបាទ"]។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165333 ["មានចាស់ មានក្មេង តែក្មេងៗតូចគេមិនដាក់ខ្នោះទេ"]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163507 ["ស៖ កូនង៉ាពីរនាក់[របស់អ្នក]ស្លាប់[នៅក្រោងតាចាន់]ដែរ? ឆ.៖ ស្លាប់ដោយអត់ទឹកដោះ"]។ ឯកសារ D219/522 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង ឆ.២៤-២៥ KH 01149847។ ឯកសារ D118/167 កំណត់ហេតុស្តាប់ចម្លើយ ว៉ាន់ សឿន ឆ.២១១ KH 00968194។ ឯកសារ D219/2 កំណត់ហេតុស្តាប់ចម្លើយ សែត យ៉ែម ឆ.៤០ KH 01024792។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.៥១ KH 01000025។

[894] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ ១.៤ *អាយុរបស់អ្នកទោសនៅក្រោងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុង ឧបសម្ពន្ធ គ.១ ក៏ដូចជាព័ត៌មានបន្ថែមដែលមាននៅក្នុង ឧបសម្ពន្ធ គ.៣។ *សូមមើលផងដែរ* ឯកសារ D6.1.275 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រោងតាចាន់ KH 00270881 [ណុប ឡុង ៨៧ឆ្នាំ]។ ឯកសារ D6.1.1224 បញ្ជីឈ្មោះអ្នកទោសនៅក្រោងតាចាន់ KH 00068018 [ว៉ា សៅផន ៨២ឆ្នាំ]។ ឯកសារ D6.1.1220 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រោងតាចាន់ KH 00068062 [ចៅ ទិត ៧៩ឆ្នាំ]។ ឯកសារ D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រោងតាចាន់ KH 00271147 [ម៉ក់ ហៀន ៧៥ ឆ្នាំ]។ ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រោងតាចាន់ KH 00271068 [ធ៏ល គាត ៧០ឆ្នាំ]។

[895] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ ១.៥ *អតីតមុខរបររបស់អ្នកទោសនៅក្រោងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុង ឧបសម្ពន្ធ គ.១ ក៏ដូចជាព័ត៌មានបន្ថែមដែលមាននៅក្នុង ឧបសម្ពន្ធ គ.៣។ *សូមមើលផងដែរ* ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.36.30-14.38.17 ["បាទ អាហ្ម៉ីងកើនឡើង[នៅក្រោងតាចាន់]ពីឆ្នាំរំដោះហើយបានកើន អាហ្ម៉ីង [...]គេយកពីភ្នំពេញ រំដោះពីភ្នំពេញ [...] ដូចថាទាហានលន់ នល់ អ៊ីចឹង"]។ ឯកសារ D315.1.20 ឯក ហៀន ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.08.47-11.10.37 [បញ្ជាក់ថាអតីតអ្នកមន្ត្រីរដ្ឋការស៊ីវិល និងមន្ត្រីយោធារបស់លោក លន់ នល់ត្រូវបានគេតាមដាន នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥]។ ឯកសារ D315.3.3 សៅ ប៊ីនាន ប្រតិចារឹក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.11.15-09.14.37 [បងប្រុសរបស់គាត់ដែលជាអតីតទាហាន លន់ នល់ ត្រូវបានសម្លាប់នៅក្រោងតាចាន់]។ ឯកសារ D6.1.686 កំណត់ហេតុស្តាប់ចម្លើយ សៅ ប៊ីនាន ឆ.២២ KH 00408316។ ឯកសារ D6.1.878 អ៊ា ម៉ង់ច្រី *ច្រវ៉ាក់នៃភាពភ័យខ្លាច (The Chain of Terror)* EN 00182222-23 ["ភាគច្រើននៃពួកដែលត្រូវបានចាប់ខ្លួននៅពាក់កណ្តាលឆ្នាំ១៩៧៥

១០ភាគរយផ្សេងទៀត ខណៈដែលប្រមាណជាប្រាំបីភាគរយគឺជាអតីតកម្មាភិបាល ប.ក.ក ឬ ជាយុទ្ធជន[896]។ សមាជិកគ្រួសាររបស់ប្រជាជនដែលមានជាប់ទាក់ទងនឹងរបប លន់ នល់ ក៏ត្រូវបានចាប់ខ្លួនផងដែរ[897]។

279. ក្រៅពីការជាប់ទាក់ទងនឹងបុគ្គល ឬក្រុមដែល "គួរឲ្យសង្ស័យ" ប្រជាជនក្នុងស្រុកត្រាំកក់ត្រូវបានចាប់ខ្លួនតាមទំនើងចិត្ត និងបញ្ជូនទៅកាន់ក្រាំងតាចាន់ ដោយសារគ្រាន់តែដើររកអាហារខ្លួនឯងមក

និង ឆ្នាំ១៩៧៦ គឺជាទាហាន និងប៉ូលីសរបស់លោក លន់ នល់។ [...] នៅដើមឆ្នាំ១៩៧៦ មានពួកទាហាន និងប៉ូលីសរបស់លោក លន់ នល់ ច្រើនជាងប្រភេទផ្សេងទៀត"]។

[896] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ ១.៥ *អតីតមុខរបររបស់អ្នកទោសនៅក្រាំងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុង ឧបសម្ពន្ធ គ.១ ក៏ដូចជាព័ត៌មានបន្ថែមដែលមាននៅក្នុង ឧបសម្ពន្ធ គ.៣។ *សូមមើលផងដែរ* ឯកសារ D315.1.20 ឯក ហៀន ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.08.47-11.10.37 ["ស៖ អ៊ីចឹងខ្ញុំចង់សួរពីពាក់ព័ន្ធនឹង [...] អតីត[...]គ្រូបង្រៀន [...]។ តើខ្មាំងទាំងអស់ហ្នឹងជាខ្មាំងដដែលៗមែនទេ ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ៧៥នោះ គេនៅតែបន្តស្វែងរកខ្មាំងទាំងអស់ហ្នឹងទៀតមែនទេ? ឆ.៖ បាទ ពិតណាស់"]។ ឯកសារ D6.1.686 កំណត់ហេតុស្តាប់ចម្លើយ សៅ ប៊ីន ឆ.២២ KH 00408316។

[897] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ ១.៧ *ក្រុមគ្រួសាររបស់អតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរដែលត្រូវបានឃុំខ្លួន* និង ទិន្នន័យគាំទ្រនៅក្នុង ឧបសម្ពន្ធ គ.១ ក៏ដូចជាព័ត៌មានបន្ថែមដែលមាននៅក្នុង ឧបសម្ពន្ធ គ.៣។ រូបលេខ ១.៧ ពណ៌នាពីបុគ្គលដែលត្រូវបានឃុំខ្លួននៅក្រាំងតាចាន់ ដែលខ្លួនគាត់មិនមែនជាអតីតមន្ត្រីរដ្ឋការសាធារណរដ្ឋខ្មែរ ប៉ុន្តែបានបញ្ជាក់ថា ពួកគាត់ជាសាច់ញាតិរបស់អតីតទាហាន ឬមន្ត្រីណាម្នាក់។ *សូមមើលផងដែរ ឧទាហរណ៍* ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271063 [ណុប គា ២១ឆ្នាំ៖ ឪពុករបស់នាងជាវរសេនីយ៍ទោ នៅអគ្គសេនាធិការ ភ្នំពេញ]។ ឯកសារ D347/2.1.5 បញ្ជីអ្នកទោសនៅក្រាំងតាចាន់ KH 00079337 [ឯម សម្ប័ត្ដ ២៤ឆ្នាំ៖ ឪពុករបស់គាត់ជាអនុសេនីយ៍ឯក (កំទេចរួចហើយ)]។ ឯកសារ D6.1.1220 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00068053 [ង៉ែត ណែល ១៣ឆ្នាំ៖ ឪពុករបស់គាត់ជាវរសេនីយ៍ឯក] KH 00068079 [ជា ភក្ដី ១៩ឆ្នាំ៖ ឪពុករបស់គាត់ជាអភិបាលខេត្ដកំពង់ឆ្នាំង]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.40.28-13.42.38 ["ពីរឿងខ្ញុំពីបញ្ហាវាពាក់ព័ន្ធពីឪពុកធ្វើមេស្រុកពីជំនាន់លន់នល់ -- ពីជំនាន់សីហនុៗ។ ហើយពាក់ព័ន្ធតែប៉ុណ្ណឹងរឿងខ្ញុំ អត់ដែលមានរឿងហេតុអីពីបញ្ហាណាមួយក៏អត់មានដែរ"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.18.02-09.20.07 ["ហ្ស! ខ្ញុំគេចោទពីបញ្ហាបងប្អូនខ្ញុំធ្វើស័ក្ដិ៣ ឬស័ក្ដិ៤ អីអ៊ីចឹងទៅ"] ម៉ោង 10.09.00-10.11.07 ["នេះ បើតាមខ្ញុំមើលទៅ មើលតែអ្នកណា [...] មានខ្សែបណ្ដាញនៅខាង លន់ នល់ [...] អាហ្នឹងដូចទារុណកម្មគ្រប់មនុស្សអ៊ីចឹងទាំងអស់"]។ ឯកសារ D366/4.1.1 ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.14.22-11.16.37 ["បើមានការពាក់ព័ន្ធអី មានបងប្អូនធ្វើធំធ្វើអីកាលជំនាន់ហ្នឹង [...] អ៊ីចឹង គេៗត្រូវចាប់យកទៅសម្លាប់ចោលនៅពេលហ្នឹងដែរ។ គេពាក្យមួយគេនិយាយច្រើនថា បើសម្លាប់ហើយរំលើងអស់ទាំងឫសទាំងគល់អីទាំងអស់"]។ ឯកសារ D315.2.1 មាស សុខា ប្រតិចារឹក ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.55.57-11.57.43 ["រយៈពេល ៥ថ្ងៃ[ក្រោយគេចាប់ឪពុកខ្ញុំ] បានគេមកប្រមូលម្ដាយខ្ញុំ និងបងប្អូនខ្ញុំតូចតាចយកទៅ ហើយអ្នកភូមិជាមួយគ្នាហ្នឹង"]។ ឯកសារ D6.1.998 កំណត់ហេតុស្តាប់ចម្លើយ ស្ងួត្រ សាំង KH 00165342។ ឯកសារ D219/119.1.4 កំណត់ហេតុស្តាប់ចម្លើយ អ៊ូ ដាវ ឆ.១៨៧ KH 01043307។

បរិភោគ[898] ដោយសារត្រូវបានមើលឃើញថាបានរៀនសូត្រចេះដឹង ឬដោយសារវណ្ណភាពខ្ពស់[899] ដោយសារការពោលគ្នញ្ញគ្នែរ ឬការទិតៀនដល់របប[900] ឬដោយសារការធ្វើឲ្យមាន "កំហុស" អ្វី

---

[898] *សូមមើល ឧទាហរណ៍* ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271067 [សុក ស៊ីន ៖ លួចអង្ករ] KH 00271067 [វ៉ាន់ សារុន៖ លួចដំឡូង មាន់ ពងមាន់] KH 00271069-70 [ញ្ជើប ម៉ា៖ លួចទឹកត្នោត]។ ឯកសារ D347/2.1.5 បញ្ជីអ្នកទោសនៅក្រាំងតាចាន់ KH 00079337 [ស្ងួន ភី, ចក់ អៀប និង ជុំ ថល់៖ លួចមាន់]។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271096 [ម៉ក់ ម៉ុន ហៅ មិត៖ លួចត្រសក់ និងខ្ទឹម] KH 00271108 [ចយ ញ៉ូ៖ លួចអង្ករ និងឡើងដាក់ទឹកត្នោតឲ្យកូនផឹក]។ ឯកសារ D6.1.275 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270876 [ជៀម ប៊ាវ អតីតទាហាន លន់ នល់៖ "អាក្បត់នេះវាបានសារភាពថា៖ អំពើក្បត់របស់វាមានដូចខាងក្រោមនេះ៖ ទី១. បានលួចដំឡូង។ ទី២. បានលួចដំឡូង និងស្ករ"]។ *សូមមើលផងដែរ* ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.47.12-13.49.14 [នៅក្នុងកំឡុងពេលសួរចម្លើយនៅក្រាំងតាចាន់៖ "ហើយកាលណាអ្នកណាអត់សូវឆ្លើយ អ្នកណាដែលឆ្លើយថា នៅតាមសហករណ៍ថា លួច ប្ដន់អី ឬថាលួច។ លួចហើយអត់មានលួចអីខុសពីរឿងថា លួចដូង លួចស្វាយ លួចដូចថា ជាពិសេសលួចដំឡូង ហើយដូងញ៉ីកជាងគេតែម្ដង មានតែប៉ុណ្ណឹង។ កាលណាហេវ អត់ឃ្លានចេះតែលួចហើយ [...] បើឆ្លើយថា "អត់លួចទេ" គេវ៉ៃហ្ម?ងហើយ នៅតែវ៉ៃ វ៉ៃទាល់តែឆ្លើយ"]។

[899] *សូមមើលឧទាហរណ៍* ឯកសារ D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271145-46 [ស៊ីន សារ៉ាត់ "ជាអនុធនសិស្សជាន់ខ្ពស់១រូបផង"] KH 00271155 [សុក ហួយ គឺជាថៅកែឡាន "នាយទុន" មានឡានៗ៨ហាង]។ ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271077 [ង៉ែ សារ៉ៃ៖ "ធ្វើការនៅក្រុមហ៊ុនអាកាសចរ នៅពោធិ៍ចិនតុង ភ្នំពេញ ក្នុងឋានៈ នាយទុន"]។ ឯកសារ D315.1.20 ឯក ហ៊ីន ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 13.58.50-14.00.46 ["អាវណ្ណ:កសិករលើ អានាយទុន អនុធនហ្ម?ង អត់ល្អទេ គឺត្រូវតែកង់ប្រវត្តិសាស្ត្រកិនហើយ [...]។ ហើយកង់ប្រវត្តិសាស្ត្រកិនហ្ម?ង [...] អត់ថាចាស់ អត់ថាថ្មីទេ ឲ្យតែបែងចែកទៅត្រូវកម្រិតវណ្ណភាពអ្នកមាន"]។

[900] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ១.២ *បទល្មើសដែលបានចោទប្រកាន់អ្នកទោសនៅក្រាំងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុងឧបសម្ពន្ធ គ.១។ *ឧទាហរណ៍* ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271076-77 [ឡុង ពិល៖ ពួកអាទាំងពានាក់នេះ បានជំនុំគ្នាវាថា៖ "យើងសព្វថ្ងៃរស់នៅពិបាកខ្លាំងណាស់ ដូចមនុស្សខ្ញុំគេ រកតែសម្រាកគេចវេះ បន្ដិចបន្ដួច មិនបាន បើមេកងគេតឹងរ?ងណាស់"]។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271123-24 [យ៉ាង កយ បានពោលគ្នញ្ញគ្នែរពីសម្ងួហភាព របបអាហារ និងកម្មាភិបាលជាន់ខ្ពស់អាចហ្ងួបអ្វីៗគ្រប់យ៉ាង]។ ឯកសារ D6.1.214 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270824 [ហៅ នាង៖ ការឮសូរកាំភ្លើងទ្ងរ?ៗ នៅព្រំដែន វាបាននិយាយថាបើឈ្នះសប្បាយណាស់ យ៉ាងហោចណាស់ក៏បានធ្វើប្រធានភូមិដែរ]។ *សូមមើលផងដែរ* ឯកសារ D315.1.20 ឯក ហ៊ីន ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 13.55.25-13.56.50 ["អត់មានប៊ានលាន់មាត់ [...]ទេ តែប៊ានគេថាទំនាស់សហករណ៍។ តែទំនាស់សហករណ៍ គេយកទៅព្រៃទាំងថ្ងៃហ្ម?ង អត់មានចាំយប់ទាន់ទេ។ អាហ្ម?ងពាក្យហ្ម?ង ពាក្យទំនាស់សហករណ៍"]។ ឯកសារ D315.2.1 មាស សុខា ប្រតិចារឹក ថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.39.08-11.40.22 ["ឆ្នាំ៧៦ គាត់[ខ្ញុំ]ក៏ប្រឆាំងនឹងគេរឿងហ្ងួបបាយមិនឆ្អែត ព្រោះគេថាគាត់អ្នកក្បត់នឹងសហករណ៍"]។ ឯកសារ D219/522 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ុន គឹមសេង ឆ.២៧ KH 01149847។

មួយ[901]។ ប្រជាជនដែលត្រូវបានគេគិតថាខ្ជិលច្រអូស ឬពុតធ្វើជាឈឺ ត្រូវបានចោទប្រកាន់ថាបានលួច ឬប៉ុនប៉ង (សូម្បីតែការធ្វើផែនការ) រត់គេចខ្លួនចេញពីឃុំ ក៏ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងនៅកន្លែងនោះផងដែរ[902]។

---

[901] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ១.២ *បទល្មើសដែលបានចោទប្រកាន់របស់អ្នកទោសនៅក្រាំងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុង ឧបសម្ពន្ធ គ.១។ *ឧទាហរណ៍* ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271067 [សុក ស៊ន: ដឹកគោស៊ីស្រូវ]។ ឯកសារ D347/2.1.5 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00079337-38 [នាង ដាំ: ឈ្មោះនេះ "សេរីភ្លឺតភ្លើន មិនគោរពអង្គការវិន័យ"]។ ឯកសារ D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271152 [ផេង ង៉ោល: មានគំនិតរត់ចោលប្រពន្ធកូន[...]ទៅស្រុកយួន] KH 00271164-65 [ឯម សម្ត្រិ: លួចម្ហូបអាហារ និងដឹកគោទំលាក់លើស្ពាន រួចបណ្តាលឲ្យបាក់ជើងគោមួយ]។ ឯកសារ D6.1.214 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270848 [អ៊ុង លី: ដេកយប់ណាក៏អារម្មណ៍នឹកឃើញទ្រូកអាមេរិកកាំង សប្បាយធ្លាប់ស៊ីផ្ទាញ់ "ជាអារម្មណ៍គ្រាន់តែនឹកទេ មិនដែលបញ្ជេញទៅក្រៅទេ"]។ *សូមមើលផងដែរ* ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.02.34-14.04.44 ["ឆ្នាំ៧៧ហ្នឹង [...] ឲ្យតែពួសួរថាមានខ្ទាស់អីបន្តិចបន្តួច គេបញ្ជូនមកហើយ"]។

[902] *សូមមើល* ឧបសម្ពន្ធ គ.២ រូបលេខ១.២ *បទល្មើសដែលបានចោទប្រកាន់របស់អ្នកទោសនៅក្រាំងតាចាន់* និង ទិន្នន័យគាំទ្រនៅក្នុង ឧបសម្ពន្ធ គ.១។ *ឧទាហរណ៍* <u>ការខ្ជិលច្រអូស និង/ឬ ធ្វើពុតជាឈឺ</u>: ឯកសារ D6.1.1220 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00068054 [ង៉ែត រ៉ន] KH 00068055 [ប្រាក់ អ៊ុន ហៅ រស់] KH 00068066 [អ៊ៀ លីមទូច]។ ឯកសារ D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271162-63 [ប៉ុក ប៊ុនលី]។ ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271067 [រ៉ាន់ សារុន]។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271094-95 [ប៉ុក ផៃ]។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.02.45-10.04.23 ["បាទ អ្នកទោសដែលគេបញ្ជូនទៅ[ក្រាំងតាចាន់]ហ្នឹងគឺភាគច្រើនសុទ្ធតែគេចោទថា លួចនិងពុត ហើយនិងខ្ជិលតែម្តង"]។ <u>ចោទថាលួច</u>: ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271067 [ម៉ឹង សន]។ ឯកសារ D347/2.1.5 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00079337-38 [គុយ នី] KH 00079337-38 [គង់ រ៉ែត]។ ឯកសារ D6.1.1220 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00068080 [ជា សុផល]។ ឯកសារ D219/899.1.1 ខ៉ែម ឫទ្ធី ប្រតិចារឹក ថ្ងៃទី៤ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.54.02-15.58.19 [អតីតគណៈឃុំជាងទង: "ចាស បានទទួលការអប់រំខាងលើ។ [...] បទល្មើសធ្ងន់ គឺការទំនាស់ប្រឆាំង។ ដល់ខ្លះ កប់ចានកប់ឆ្នាំងក៏មានដែរ។ [...] អាហ្នឹងជា ថាជាប្រឆាំង"]។ <u>ការប៉ុនប៉ង ឬមានផែនការរត់គេច</u>: ឯកសារ D6.1.214 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270847 [រ៉ាល់ ថន]។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271091 [លី ផៃ]។ ឯកសារ D6.1.275 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270890 [ត៉ីង ឡេន, ហាន់ ស្ងៀ]។ *សូមមើលផងដែរ* ឯកសារ D6.1.294 របាយការណ៍ពីឃុំនានាទៅមន្ទីរស្រុក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ EN 00322174 ["យុវជននេះរត់ចុះ រត់ឡើង [...] សូម អ/ក ជាទីគោរពជ្រាបជាព័ត៌មាន"]។

អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)

280. លក្ខខណ្ឌនៅក្រាំងតាចាន់គឺកាចសាហាវ និងយោរយៅ[903]។ អគារឈើមានរហូតដល់ទៅបួន មានប្រវែងប្រមាណពី បី ទៅ ប្រាំម៉ែត្រ គុណនឹង ប្រាំពីរ ទៅ ២០ម៉ែត្រ[904] ដាក់អ្នកទោសយ៉ាងតិចពី ២០ ទៅ ២០០នាក់ នៅពេលណាមួយនោះ[905]។ អ្នកទោសភាគច្រើនត្រូវបានដាក់ខ្នោះជើងទាំងយប់

---

[903] *សូមមើល ឧទាហរណ៍* ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.20.24-15.21.42 ["កាលណាអត់ទាន់ធ្វើគុកហ្នឹងបានថែមគុកថ្មីពីរទៀត ណែន ឡើងណែនគរលើគ្នាផ្ទៀងមួយប្រឡោះដែក រនុកដែកហ្នឹងវាមានគរ បានរយៈកាលដាក់ដី ទំហំក្ដារ មួយម៉ែត្រហ្នឹងដាក់បានបួននាក់ ដល់ពេលមនុស្សមកច្រើន គាត់ដាក់ក្ដារប្រឡោះជើងហ្នឹង ស៊ីក ជើងនឹងអាប្រឡោះជើងអាប្រឡោះត្រយូវខ្នោះហ្នឹងមួយម៉ែត្រៗហ្នឹងគឺអាចដាក់បានដល់ប្រាំពីរប្រាំបីនាក់"]។ ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 10.50.27-10.53.10 ["គឺយើងទាំងអស់គ្នាអត់បានដេក ក្ងន់ដ៏ត ក្ងន់ដ៏ាតូចៗ វាយ៉ាំ។ យប់នោះទាន់ហាន់ណាស់លោក ដោយមនុស្សវាពេញ វាណែនរោងពេក"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 13.56.17-13.58.20 ["ក្ងន់តូចនៅជាមួយម្ដាយ អត់មានបែកពីម្ដាយ កើតទេ។ មិនដឹងយកទៅដាក់ឯណា ក្រៅពីម្ដាយឪពុក ម្ដាយអ្នកឱ្យ ដកពីលើម្ដាយហ្នឹងអ៊ីចឹងទៅ ព្រោះកន្លែងចង្អៀត"]។ ឯកសារ D6.1.785 កំណត់ហេតុស្ដាប់ចម្លើយ សុក សុត KH 00163524។

[904] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.02.41-10.04.15 [រៀបរាប់ពីអាគារដែលគាត់ត្រូវបានឃុំខ្លួន៖ "អគារនោះមានបណ្ដោយ១២ម៉ែត្រ ទទឹង៥ម៉ែត្រ"] ម៉ោង 13.56.17-13.58.20 ["មានផ្ទះបីអាគារសម្រាប់ដាក់អ្នកទោសហ្នឹងតែម្ដង"]។ ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 10.47.18-10.50.27 ["ចាស អគារដែលគេដាក់អ្នកទោសមានបី"]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.22.45-14.24.02 ["គុកកាលឆ្នាំខ្ញុំទៅនៅដំបូង គឺមានគុកតែពីរទេ ដល់មកឆ្នាំ៧៥ ធ្វើគុកថែមពីរទៀត បានគុកបួន"] ម៉ោង 13.42.38 ["បាទ ក្នុងតួគុកមួយទាំងមូល គឺឧទាហរណ៍ថា វាទទឹងប្រាំម៉ែត្រអ៊ីចឹង បណ្ដោយវាមានជួនខ្លះវាមានដល់ពីរដណ្ដប់ ខ្លះមានប្រាំបួន ខ្លះមានដល់១៥"]។ ឯកសារ D315.1.7 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.07.07-11.10.12 ["ក្នុងអគារមួយៗមានទទឹងប្រហែលជាប្រាំម៉ែត្រ ឬក៏ប្រាំម៉ែត្រលើសបន្ដិចបន្ដួច បណ្ដោយប្រហែលជាប្រាំពីរម៉ែត្រ បាទ"]។ ឯកសារ D6.1.997 កំណត់ហេតុស្ដាប់ចម្លើយ សាំង ស៊ីម KH 00165333។ ឯកសារ D6.1.784 កំណត់ហេតុស្ដាប់ចម្លើយ មាស សុខា KH 00163513។ ឯកសារ D219/522 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ុន គឹមសេង ឆ.៣៦ KH 01149848។ ឯកសារ D6.1.149.37 ប្លង់មន្ទីរសន្ដិសុខក្រាំងតាចាន់ដែលត្រូវបានចងក្រពីព័ត៌មានដែលផ្ដល់ឲ្យដោយសាក្សីសយ សែន។

[905] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.24.25 ["ឃ្លានគុកវាអត់ឃីតបេរទេ មានគុកខ្លះ៥០ គុកខ្លះ១០០ គុកខ្លះ៧០ ២០អ៊ីចឹង"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.21.42-15.23.48 ["ពេលមនុស្សមកច្រើន [...] ពីរជួរហ្នឹងអាច ១០០ជាងក្នុងមួយគុក ១០០ជាងទៅ ២០០ តែប៉ុណ្ណឹងទេ បាទ"]។ ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 10.56.97-10.59.19 [ពាក់ព័ន្ធនឹងអាគារដែលនាងត្រូវបានឃុំខ្លួន៖ "អគារហ្នឹង បើគេដាក់យើងពេញ វាចូលខ្ទង់៤០ហើយលោកគ្រូ ប៉ុន្ដែប្រជ្រៀតគ្នា។ ដេកប្រជ្រៀតគ្នាហើយពេលហ្នឹង។ អាហ្នឹងខ្ទង់៤០ ហើយខាងរោងពីរទៀត គឺរោងហ្នឹងប៉ុនៗគ្នា តាមខ្ញុំមើល អត់មានតូចធំជាងគ្នា

ទាំងថ្ងៃ លើកលែងតែអ្នកប្រព្រឹត្តបទល្មើសស្រាលៗពីរ-បីនាក់ និងកូនក្មេងតូចៗ ពីព្រោះមិនមានខ្នោះជើងតូចៗត្រូវនឹងពួកគេនោះទេ[906]។ ការរឹតត្បិតដ៏តឹងតែងបានបណ្តាលឲ្យអ្នកទោសជាច្រើនកើតមានទ្ទូរដំបៅដ៏គួរឲ្យឈឺចាប់[907]។ ប្រសិនបើខ្នោះជើងធ្ងន់ រុងរលុង អ្នកទោសត្រូវបានវាយធ្វើបាប

ទេ"]។ ឯកសារ D315.2.6 រៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 14.37.16-1439H [នៅពេលដែលសាក្សីបានទៅកាន់គុកដើម្បីបាញ់ថ្នាំកំចាត់សត្វល្អិត៖ "ខ្ញុំបាទលួចអើតមើលតែមួយអគារ ឃើញដេកបួនជួរ។ បើតាមខ្ញុំវាយតម្លៃ មួយអគារហ្នឹងវែងជាងគេប្រហែលជាជាងមួយរយនាក់ ដេកទាំងអស់"]។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165333។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លឹម ហាច KH 00165347-48។ ឯកសារ D219/2 កំណត់ហេតុស្តាប់ចម្លើយ សែត យ៉ែម ឆ.ពត KH 01024791។

[906] ឯកសារ D6.1.931 រូបថតខ្នោះជើងដែកដែលប្រមូលបានមកវិញនៅកន្លែងមន្ទីរសន្តិសុខក្រាំងតាចាន់។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.24.35-15.26.26 [បញ្ជាក់ថារូបថតខ្នោះជើងពីរសន្ធឹកដែលបានលើកឡើងខាងលើ គឺដូចគ្នាបេះបិទទៅនឹងខ្នោះជើងដែលបានប្រើប្រាស់នៅក្រាំងតាចាន់ដើម្បីដាក់ខ្នោះជើងពួកអ្នកទោស] ម៉ោង 13.42.38-13.45.31 ["កុមារដែលតូចៗ មិនអាចដាក់ខ្នោះកើត អត់អាចដាក់ខ្នោះកើត ឲ្យនៅជាមួយឪពុកម្តាយៗ [...] ក្មេងតូចៗវាអត់មានខ្នោះដាក់ តូចៗពេក [...] វាមានច្រើនតែធំៗ កងជើងអ៊ីចឹង [...] កដៃតូចៗដាក់ម៉េចនឹងជាប់"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.11.27 ["កាលណាអ្នកទោសធ្ងន់ ក៏មិនដឹងថាធ្ងន់ ហើយក៏ស្រាល បានគេនាំមកៗដល់មុនដំបូង អ៊ីចឹងគេដាក់ជើងទាំងពីរ។ ដាក់ជើងទាំងពីរហើយ ដាក់ដៃពីលើទៀត ដាក់មានរនុកដែកដាក់ដៃលើនេះមួយទៀតបាទ"]។ ឯកសារ D315.1.7 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.10.12។ ឯកសារ D315.2.3 មាស សុខា ប្រតិចារឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.23.01-11.25.02។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.46.07-09.48.38។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លឹម ហាច KH 00165347។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165332-33។ ឯកសារ D6.1.784 កំណត់ហេតុស្តាប់ចម្លើយ មាស សុខា KH 00163513។ ឯកសារ D6.1.1000 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ស៊ាន់ KH 00165356។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីន គឹមសេង KH 00163505។ ឯកសារ D6.1.785 កំណត់ហេតុស្តាប់ចម្លើយ សុក សុត KH 00163522។ ឯកសារ D6.1.695 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.២ឆ KH 00414445។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.៣៤ឆ KH 01052727។

[907] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.26.26-15.28.11 ["បើនិយាយពី[ដំបៅខ្នោះជើង]ក្លាយ ១រហូតដំបៅអត់ងុះរោមទល់សព្វថ្ងៃហ្នឹង ក្លាយទល់សព្វថ្ងៃ។ ប៉ុន្តែសម័យនោះបានគុណទឹកដោះម្តាយផ្ទៃ រ៉ែតែកូនកង្កែប [...] យកមកបុកជាមួយអំបិល ហើយយកមកស្ទ្ម យកមកបិទ គឺបានជាទាំងក្បាលនិងជើងទល់សព្វថ្ងៃ"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.48.38-09.51.29 ["ខ្ញុំខំស្រវាងើបតតេះតតះដើរទៅអត់មានកម្លាំង ហើយជើងខ្ញុំត្រូវដែកដាក់កង ដាក់ហ្នឹងវាស្ពឹក ដើរ[ទៅដល់កន្លែងគេសួរចម្លើយខ្ញុំ]អត់ដឹងជើង។"]។

យ៉ាងយ៉ោងយ៉ៅ[908]។ ពួកអ្នកទោសដេកប្រជ្រៀតគ្នា ខ្នងលើកម្រាលឈើ និងមិនត្រូវបានអនុញ្ញាតឲ្យរំកិល ធ្វើឲ្យឮសំឡេងខ្លាំង ឬ ប្រាស្រ័យទាក់ទងគ្នាពីម្នាក់ទៅម្នាក់នោះទេ[909]។

281. ការអនុវត្តផ្នែកអនាម័យនៅក្រាំងតាចាន់គឺមិនមានទេ។ អ្នកជាប់ឃុំឃាំងមិនត្រូវបានឲ្យងូតទឹកទេ[910]។ នៅពេលយប់ពួកគេត្រូវបានបង្ខំឲ្យបន្ទោរបង់នៅតាមកន្លែងដែលពួកគេដេក[911]។ ពួកគេមិនត្រូវបានផ្តល់នូវសម្លៀកបំពាក់សម្រាប់ផ្លាស់ប្តូរទេ ដែលការណ៍នេះបានបង្ខំឲ្យ មាស សុខា លួចសម្លៀកបំពាក់ពីអ្នកទោសដែលស្លាប់[912]។ ក្លិនគឺអាក្រក់ខ្លាំងណាស់ - មិនមែនត្រឹមតែខ្លួនប្រាណដែលមិន

---

[908] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.30.02-11.31.44 ["អ្នកណាខ្ទោះណារើ ចូលមកចាប់អាដង្កាប់មួយចាប់ញ៉ីងខ្ទោះ ក្រោកក្រាកៗ តែមានរបួតខ្ទោះ រ៉ៃស្លាប់យប់ហ្ន៎ងអត់មានយកទៅណាទេ រ៉ៃមុខៗអ្នកទោសទាំងអស់គ្នាក្នុងគុកទាំងអស់ហ្ន៎ង រ៉ៃឲ្យមើល បាទ"]។

[909] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.10.44 ["បើអ្នកទោសណាដេករើបម្រាស់ក្នុងអគារ យប់ឡើង គេអ្នកយាមសួរថាអ្នកណារើ? ហើយបើអត់ឆ្លើយ គឺដំបងឫស្សីចូលមករ៉ៃទូទៅទាំងអ្នកទោសអត់រើ និងទាំងអ្នករើ។"] ម៉ោង 14.23.50 ["អ្នកទោសទាំងអស់ពេលយប់ថ្ងៃអី មានវិន័យគេ។ ដេកអត់ឲ្យរើ [...] តែហ៊ានរើគឺៗរ៉ៃអ៊ីចឹងតែម្តងយប់ឡើង"] ម៉ោង 14.25.36 ["អ្នកទោសទាំងអស់ពេលយប់ថ្ងៃអី មានវិន័យគេ។ អត់ឲ្យនិយាយគ្នា [...] តែហ៊ាន [...] គឺៗរ៉ៃអ៊ីចឹងតែបម្តង"]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.30.02-11.31.44 ["មានគាស់ក្រោកក្រាកអី គេចូលមករ៉ៃស្លាប់នៅកន្លែងក្នុងគុកហ្ន៎ង អត់ទាន់ដោះខ្ទោះចេញ រ៉ៃឲ្យតែមានឮសួរខ្ទោះក្រេកក្រោកៗហ្ន៎ងចូលមករ៉ៃទាំងយប់ហ្ន៎ង អត់ទុក។ ថ្ម្ងៃម៉ាន -- ព្រោះកងទ័ពវាយាម ដូរវេនគ្នាយាម មួយម៉ោងពីរនាក់ៗ"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៥ ម៉ោង 10.53.10-10.56.97 ["[ពីព្រោះតែខ្ញុំនិយាយទៅកាន់ម្នាក់នេះ] គេដាក់គុកសាជាថ្ម ណែងឲ្យចេញ ដាក់កងជើងសាជាថ្ម ឈប់ឲ្យខ្ញុំចេញរហូតដល់មួយអាទិត្យបានគេឲ្យខ្ញុំចេញ។ [...] គេថា "អាមាត់ហ្ន៎ងកុំពូកែដ៏ង កុំពូកែនិយាយគេ មកដល់កន្លែងនេះហើយ យើងអត់មានសិទ្ធិនិយាយជាមួយអ្នកណាទាំងអស់" ។"]។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លឹម ហាច KH 00165348 ["គេឲ្យដេកផ្ទ្ការពេលចង់ផ្ទ្ការ យើងកំរើកបន្ដិចកុំឲ្យឮសូរសំឡេង តែលើសូរគេចូលមកវាយយើងទាំងអស់នេះ។"]។

[910] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.28.11-15.29.41 [អ្នកទោសទទួលបានទឹកមួយត្រឡោក ក្រោយពេលអាហារ ហើយអ្នកដែលញ៉ាំហើយមុនគេត្រូវតែផឹកឲ្យលឿន និងលុបលាងមុខមុនពេលអ្នកយាមស្រែកស្តីឲ្យពួកគេ]។ ឯកសារ D364/2.1.5 ប្រតិចារឹក សូត្រ សាំង ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.44.22-09.47.03 ["អ្នកទោសបងប្អូនដែលជាប់ពិរុទ្ធក្នុងនោះ គឺមិនមាន [...] ដុសលាងខ្លួន សម្អាតអនាម័យខ្លួនបានត្រឹមត្រូវទេ"]។ ឯកសារ D6.1.119 កំណត់ហេតុស្តាប់ចម្លើយ សយ សែន KH 00223066 ["ការបត់ដៃបត់ជើងរបស់អ្នកទោសមិនមានទឹកលាងសំអាតទេ ហើយអ្នកទោសក៏មិនបានទទួលទឹកសម្រាប់ងូតសំអាតរាងកាយដែរ។"]។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លឹម ហាច KH 00165348។

[911] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.29.41-15.31.24។

[912] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.42.59-11.45.20។

បានលាងសំអាត ឬខោអាវដែលមិនបានបោកគក់នោះទេ ក៏ប៉ុន្តែក្លិននោះចេញមកពីរណ្តៅកប់សពដែលមានសាកសពស្អុយរលួយនៅជុំវិញបរិវេណនោះ[913]។ អគារត្រូវបានទន្ទ្រាន ដោយចៃ សង្កើច កន្ធាត និង កណ្តុរ[914]។

282. អ្នកទោសត្រូវបានធ្វើឲ្យអាម៉ាសមុខ និងបន្ទាបបន្ថោកជាប្រចាំ។ ខណៈដែលត្រូវបានដាក់ខ្នោះជើងក្នុងក្រុមចម្រុះគ្នា ពួកគេត្រូវបន្ទោរបង់ដាក់ក្នុងត្រឡោកដូង ឬឆ្នាំង ដែលបញ្ជូនបន្តគ្នាតាមជួរពីអ្នកទោសម្នាក់ទៅម្នាក់ទៀត ហើយពួកគេមិនមានអ្វីលាងសម្អាត បន្ទាប់ពីនោះឡើយ[915]។ អ្នកដែលធ្វើ

---

[913] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.29.41-15.31.24, 15.41.43-15.43.36 [*ហានបញ្ជាក់* កំណត់ហេតុស្តាប់ចម្លើយរបស់គាត់ ឯកសារ D6.1.119 ត្រង់ KH 00223063៖ "[ទ័ព] មិនចូលទៅខាងក្នុងទេ ព្រោះនៅក្នុងគុកវាមានក្លិនខស្អុយអីលាមក និងទឹកនោមជាដើម"] ម៉ោង 16.02.13-16.03.45 ["ដល់ពីរបីថ្ងៃ [បន្ទាប់ពីសម្លាប់] វាហើម ដល់ហើមវាប្រេះដី ដល់ប្រេះដីវាចេះតែស្អុយភាយចេញមក កន្លែងក្លិន កន្លែងយើងនៅខ្ពាំងទៅ១ ប្រធានមន្ទីរគាត់ហៅខ្ញុំ [...] ឲ្យទៅជាន់បង្ហាប់ខ្មោចហ្នឹងកុំឲ្យវាផ្ទុះឡើងបាន។ ជាន់ចោះដីចោះអីថែម។"]។ ឯកសារ D315.1.11 វ៉ាន់ សឿន ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.58.32-10.01.13 ["ធំក្លិនបាទ។ [...] ធំក្លិនសាកសពតែម្តងបាទ។ [...] បាទការធំក្លិន វាស្អុយអសោចពេញទាំងភូមិហ្នឹង ទឹកដីហ្នឹងតែម្តងបាទ។ [...] ក្លិនហ្នឹងមកពីរណ្តៅសាកសពហ្នឹងតែម្តងបាទ។"]។ ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៥ ម៉ោង 10.47.18-10.50.27 [នៅពេលដែលគាត់ចូលទៅកាន់អគារឃុំឃាំងដំបូង គាត់បានដឹងថា "វា១ចង់ងាប់ហើយ វាពិបាកចិត្តណាស់"]។ ឯកសារ D6.1.782 កំណត់ហេតុស្តាប់ចម្លើយ អៀប ឌុច KH 00163493 ["ពេលចូល [ក្រាំងតាចាន់] ពេលបើកទ្វាធំក្លិន ឃើញមនុស្សទាំងអស់ ខ្ញុំឲ្យគេបិទ [ទ្វា] អត់ចង់មើលតទៅទៀត។"]។

[914] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.27.35-11.30.32 ["[អ្នកទោសនៅក្រាំងតាចាន់] វេទនាហួសខ្លាំងណាស់ និយាយពីសម្រាន្តវិញ វាសង្កើចហើយចៃមិនដឹងយកទៅណាអស់ទេ ចៃសាច់យើងហ្នឹង។"]។ ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 10.47.18-10.50.27 ["សឹងតែចាកណ្តុរ កន្ធាត ក៏វាចេញមិនរួច"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.10.44-10.12.33 ["អគារអោងសម្រាប់ឃុំឃាំងមនុស្ស វាសត្វសង្កើចរាប់ *(ពុមិនច្បាស់)* ក្នុងទះមួយដៃលើក្តារហ្នឹងទៅ ប្រមូលសង្កើច សឹងតែមួយទ្ធកដៃក្នុងមួយយប់ៗ។"]។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លឹម ហាច KH 00165350។ ឯកសារ D6.1.784 កំណត់ហេតុស្តាប់ចម្លើយ មាស សុខា KH 00163515។ ឯកសារ D6.1.1000 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ស៊ាន់ KH 00165357។ រៀស សន មានម្តងនោះលេខាស្រុកបានបញ្ជូនគាត់ឲ្យទៅបាញ់ថ្នាំសម្លាប់សត្វល្អិត ពីព្រោះអ្នកទោសស្លាប់ដោយសារគ្រុនចាន់ តែគាត់បាញ់តែជុំវិញបរិវេណប៉ុណ្ណោះ មិនមែនក្នុងអោងឃុំឃាំងទេ។ *សូមមើល* ឯកសារ D315.2.6 រៀស សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 14.31.45-14.36.12, 15.49.39-15.52.44។ ឯកសារ D315.2.7 រៀស សន ប្រតិចារឹក ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ម៉ោង 10.55.40-11.01.32។

[915] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.10.44-10.12.33 ["អ្នកទោសឃុំខ្លួននៅក្នុងនោះ គេមានបីដុងមួយសម្រាប់ដាក់យកទឹកនោម និងលាមក ហើយគេមានត្រឡោកមួយសម្រាប់ឲ្យយើងងើបជុះ ទាំងជើងជាប់ខ្នោះទាំងអស់ហ្នឹង ងើបជុះផ្ទៀងខ្លួនបន្តិចទៅ ហើយហុចបន្តគ្នា យកទៅចាក់ក្នុងបីដុងដាក់ទឹកនោមហ្នឹង ហើយលាមកហ្នឹង

ឲ្យកំពប់លាមក ឬទឹកនោមក្នុងពេលនោះត្រូវពួកអ្នកយាមវាយនឹងដំបងឫស្សី[916]។ លាមក និងទឹកនោមក្នុងត្រឡោកដូងនោះត្រូវចាក់ចូលទៅក្នុងធុងមួយដែលទុកនៅក្នុងបន្ទប់ឃុំឃាំងនោះ[917]។ អ្នកទោសទទួលបានទឹកផឹកតិចតួចប៉ុណ្ណោះ[918] ហើយគេឲ្យផឹកពីត្រឡោកដូងដដែល ដែលគេប្រើសម្រាប់ដាក់ទឹកនោម និងលាមក បន្ទាប់ពីបានលាងទឹកវាហើយ[919]។

បន្តគ្នាហុចរហូតទៅដល់កន្លែងបីដុងហ្នឹង។"]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.27.35-11.30.02 ["ជើងជាប់ទាំងពីរ ផ្ទៀងខ្លួនអ៊ីចឹង ផ្ទៀងហើយយកអាត្រឡោកហូបបាយហ្នឹងដាក់ពីក្រោមទៅ ដាក់ពីក្រោមហើយបន្តគ្នាមក។ បត់ជើងហ្នឹងហើយ បន្តគ្នាជាប់ៗគុក ឥគ្នាចេះតែឥគ្នាអ៊ីចឹងទៅ ឥចាក់នីបីដុងនៅកណ្តាល ដាក់បីដុងនៅសរសរកណ្តាល។"]។ ឯកសារ D364/2.1.5 ស្ងួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.44.22-09.47.03 ["អ្នកទោសបងប្អូនដែលជាប់ពិរុទ្ធក្នុងនោះ គឺមិនមាន [...] ដុសលាងខ្លួន សម្អាតអនាម័យខ្លួនបានត្រឹមត្រូវទេ"]។ ឯកសារ D6.1.1000 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ស៊ាន់ KH 00165356។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លឹម ហាច KH 00165348។ ឯកសារ D6.1.998 កំណត់ហេតុស្តាប់ចម្លើយ ស្ងួត្រ សាំង KH 00165341។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165332។

[916] ឯកសារ D6.1.784 កំណត់ហេតុស្តាប់ចម្លើយ មាស សុខា KH 00163514។

[917] *សូមមើល* ភ័ស្តុតាងយោងក្នុងជើងទំព័រ ៩១៥។

[918] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.07.16-10.10.44 ["បែរទឹកផឹកវិញ ទឹកគេដងគ្រលុកជី ក្បែរគ្រលុកជីចម្ងាយដែល កន្លះម៉ែតពីគ្រលុកជី ហើយទឹកហ្នឹងក្រហមរបៀបចេញជីពីក្នុងគ្រលុកជីហ្នឹង។ ក្នុងមួយថ្ងៃគេឲ្យផឹកតែពីរដងទេ ផឹកពីរដងយ៉ាងច្រើនបីក្អៀកចុះ កុំឲ្យតែស្ងួតក ក្នុងមួយថ្ងៃ។"]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.28.11-15.29.41 ["ពេលហូបបាយហើយគេឲ្យខ្ញុំយួរមួយ [...] ចាំងដូចចាំងឈើអ៊ីចឹង គេធ្វើដូចចាំងឈើចាក់ទឹកក្នុងហ្នឹង ខ្ញុំយួរមួយចាំងហ្នឹងដាក់ត្រឡោកមួយ។ ពាលបាយដួសដាក់បាយហើយតាមជួរហ្នឹង យួរចាំងដើរតាម កន្លែងណាចង់បានទឹក ដងទឹកហ្នឹងដាក់មួយត្រឡោក។ ប៉ុន្តែដងទឹកដាក់មួយត្រឡោកហ្នឹងទាល់ហូបបាយហើយៗ យកត្រឡោកបាយហ្នឹងដងទឹកពីចាំងខ្ញុំអ្នកយួរទៅឲ្យ អត់មានត្រឡោកដងទុកឲ្យហ្នឹងអត់មាន យកត្រឡោកបាយហូបហើយ អ្នកណាហូបបាយមុនគេហើយមុន គេយកត្រឡោកបាយហ្នឹងដងទឹកជូតមុខជូតមាត់ [...] ឲ្យប្រញ្ជាប់ ព្រោះអ្នកយាមគេនៅយាមឈរយាមនៅមាត់ទ្វារហ្នឹងថា៖ "អ្នែងយួរម្ល៉ះ?" "ខ្ញុំថាគាត់រវល់ដងទឹក"។ អ៊ីចឹងគេសម្ពុតដាក់ ដងបានតែមួយភ្ជែតៗហ្នឹងទេ បាទ។"]។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លឹម ហាច KH 00165348 ["គេឲ្យទឹកហូបដាក់ក្នុងត្រឡោកនោះដែរ"] KH 00165350 [ឃើញអ្នកទោសត្រូវបានសម្លាប់ដោយសារឈប់ ពេលកំពុងជីរណ្តៅ ដើម្បីទៅរកទឹកផឹក]។

[919] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី ៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.27.35-11.30.02។

283. របបអាហារមិនគ្រប់គ្រាន់ទាល់តែសោះ មានតែបបរៗមួយវែក[920] ហើយអ្នកទោសបានផ្ទាក់ខ្លួនស្គមរីងរៃ[921]។ វង សារុន បានឃើញដោយផ្ទាល់ភ្នែក អ្នកទោសដ៏កម្សត់ម្នាក់ស្រែកឃ្លានខ្លាំងពេកស៊ីកណ្តុរទាំងរស់ និងចែកខ្លះទៅឲ្យកូនប្រុសអាយុមួយឆ្នាំរបស់គាត់។ បុរសនោះ និងកូនប្រុសរបស់គាត់បានស្លាប់មួយខែក្រោយមកបន្ទាប់ពីរាងកាយរបស់ពួកគេឡើងហើម[922]។ កូនក្មេងបានស្លាប់ដោយកង្វះអាហារូបត្ថម្ភ ហើយ "ក្មេងហ្នឹងវាស្គមវាស្ពាំង" ពីព្រោះម្តាយអត់ឃ្លានរបស់ពួក

---

[920] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.07.16-10.10.44 ["ក្នុងមួយពេលគេឲ្យហូបមួយវែកក្រឡូងតូច អង្ករយ៉ាងច្រើន ១០គ្រាប់ ដំឡូងបីដុំប៉ុនៗម្រាមដៃយើង ហើយព្រលឹតបីកំណាត់ហ្នឹង។ [...] គឺអាហារ វាមានហូបតែពីរពេល ប៉ុន្តែវាអត់គ្រប់គ្រាន់។ វាខ្វះខាតយ៉ាងច្រើនជាទីបំផុតក្នុងអាហារហូបចុកហ្នឹង។ វាទ្រាំហោវក្នុងមួយថ្ងៃ បានតែពីរពេលមែន ប៉ុន្តែបួកសរុបថា ក្នុងមួយថ្ងៃអង្ករយ៉ាងច្រើនប្រហែលជា២០ ទៅ ៣០គ្រាប់ចុះក្នុងមួយថ្ងៃ ហើយដំឡូងប្រាំមួយដុំចុះ។"] ឯកសារ D315.2.3 មាស សុខា ប្រតិចារឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.50.50-11.55.03 [សាក្សីទទួលបានបបរច្រើនជាងអ្នកទោសផ្សេងទៀត ដើម្បីគាត់មានកម្លាំងមើលគោ]។ ឯកសារ D364/2.1.5 សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.47.03-09.49.38 ["អ្នកទោសមិនបានអាហារគ្រប់គ្រាន់ទេបាទ។ មានបបរ មានៗបបរណាយដំឡូងដ៏មាន បបរទឹករាយក៏បាន។"]។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.36.56-13.39.20 ["បើតាមខ្ញុំឃើញគឺអ្នកទោសហូបយ៉ាងច្រើនបំផុត ម្នាក់មួយត្រឡោកទេ។ [...] ត្រឡោកនេះ សម្រាប់ដាក់បាយបបរ និងសម្ពហ្នឹងណាយជាមួយគ្នាហ្នឹងក្នុងមួយត្រឡោកហ្នឹង។"]។ ឯកសារ D219/2 កំណត់ហេតុស្តាប់ចម្លើយ សែត យ៉ែម ឆ.២២, ៣១ KH 01024790, 1024790-91។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លីម ហាច KH 00165349។ ឯកសារ D6.1.1000 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ស៊ាន់ KH 00165356។ ឯកសារ D6.1.785 កំណត់ហេតុស្តាប់ចម្លើយ សុក សុត KH 00163524 ។

[921] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.21.34-11.24.11 ["អ្នកទោស [...] គេបង្អត់បាយឲ្យស្គមស្ពាំង ហើយបានគេបញ្ជូនទៅកន្លែងរណ្តៅយកទៅសម្លាប់។"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 1034H-10.36.57 ["[អ្នកយាម] អត់មានប្រាប់ទេ គ្រាន់តែមិនឲ្យលើកបាយចូលទៅហ្នឹង [អ្នកដែលទើបតែត្រូវបានសួរចម្លើយហើយ]។"]។ ឯកសារ D5/803/3 ប៊ុន សារ៉ៀន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ម៉ោង 10.32.17-10.34.32 ["ទៅដល់ហ្នឹង [នៅក្រាំងតាចាន់] ឃើញគាត់នៅរែកទឹករែកអីស្រោចដំណាំនៅហ្នឹង។ ដល់ពេលឃើញអ៊ីចឹងទៅ ខ្ញុំក៏យំក៏ស្រែក ដែលឃោះញអ៊ីចឹង វារកអ្វីប្រៀបធៀបមិនបាន ឃើញគាត់មើលគាត់សឹងមិនស្គាល់។"]។ ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 10.50.27-10.53.10 ["អ្នកដែលនៅយួរ គេក្រយកទៅសម្លាប់ស្គមដើរអត់រួច។"]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163507។

[922] ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.03.09-11.05.26។

គេមិនមានលទ្ធភាពផ្តល់ទឹកដោះ[923]។ ទោះបីជាអ្នកទោសកំពុងអត់អាហារ ក៏ពួកគេមិនត្រូវបានអនុញ្ញាតឲ្យតវ៉ានោះដែរ[924]។

284. មិនមានអង្គភាពពេទ្យនៅក្រាំងតាចាន់ទេ ហើយអ្នកទោសដែលឈឺ ឬមានរបួសត្រូវគេទុកចោលគ្មានការព្យាបាល[925]។ អ្នកទោសបានស្លាប់ប្រចាំថ្ងៃដោយសារកង្វះអាហាររូបត្ថម្ភ ទារុណកម្ម និង

---

[923] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.05.24-10.10.44, 10.16.15-10.18.34 ["ហើយប្អូនៗខ្ញុំតូចវាបានរយៈបីខេបានវាស្លាប់ ព្រោះវាដាច់ជាតិទឹកដោះ អត់អាហារហ្នឹងតាមក្រោយរូបខ្ញុំទាំងអស់គ្នាអ្នករស់នៅ។"]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163507 ["ស៖ កូនដ៏ា [របស់អ្នក] ពីរនាក់ស្លាប់ដែរ? ឆ៖ ស្លាប់ដោយអត់ទឹកដោះ។"]។

[924] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.54.17-11.56.11 ["អ្នកទោសគេហ្ចូបតែបបរ [...] ប្រៃក៏ដោយ សាបក៏ដោយ ស្រេចអ្នកឯងធ្វើបានប្រៃក៏ដោយ អត់មាននិយាយ រឿងប្រៃសាប។"]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163505 ["វាហាមមិនឲ្យនិយាយរឿងញ៉ាំមិនឆ្អែត អីៗវាធ្វើឲ្យយើងខ្ជាធ។"]។

[925] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.12.33-10.14.09 ["រឿងឈឺព្យាបាល គ្មានមានតែទុកឲ្យដាប់នៅក្នុងកន្លែង។ អត់មានអ្នកណាជួយព្យាបាលទេ។ អត់មានពេទ្យ អត់មានគ្រូខ្មែរឯណាចូលទៅមើលបាន អត់មាន។ ឈឺដ៏ងតែដាប់នៅទីនោះ"]។ ឯកសារ D364/2.1.5 សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.44.22-09.47.03 ["អ្នកទោសបងប្អូនដែលជាប់ពិរុទ្ធក្នុងនោះ គឺមិនមានបានថ្នាំសង្ក្ដ [...] បានត្រឹមត្រូវទេ"]។ ឯកសារ D315.2.7 រ៉ៀល សន ប្រតិចារឹក ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ម៉ោង 11.01.32-11.03.15 ["ស៖ ដូច្នេះលោកមិនដែលទទួលបានសំណើថ្នាំសង្ក្ដ ឬផលិតផលផ្សេងៗពីមន្ទីរសន្តិសុខក្រាំងតាចាន់ទេមែនទេ? ឆ៖ បាទអ៊ីចឹងមែន។ មិនដែលបានទទួលការសុំទេ អត់។"]។ ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.03.09-11.05.26 [អ្នកទោស និងកូនរបស់គាត់ដែលរាងកាយបានហើម ក្រោយពីបានញ៉ាំកណ្ដុររស់នោះ មិនបានទទួលថ្នាំព្យាបាលទេ ហើយក៏ស្លាប់ទៅ]។ ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀល សន ឆ.១៣៩-១៤៣, ១៦០ KH 00975637, 00975639។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លឹម ហា KH 00165350។ ឯកសារ D6.1.1000 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ស៊ាន់ KH 00165357។

ជំងឺ[926]។ អ្នកដែលស្លាប់ក្នុងអគារឃុំឃាំងពេលខ្លះត្រូវបានគេទុកចោលនៅទីនោះជាច្រើនម៉ោង ជាមួយនឹងអ្នកទោសផ្សេងៗទៀត មុនពេលដែលគេយកសាកសពពួកគេចេញ[927]។

285. អ្នកទោសមួយក្រុមតូចត្រូវបានចាត់តាំងការងារឲ្យរក្សារដំណើរការមន្ទីរសន្តិសុខនេះ។ ពួកអ្នកទោសដែលត្រូវបានជ្រើសរើសទាំងនេះ ត្រូវបានគេដោះខ្នោះជើងរាល់ថ្ងៃឲ្យទៅធ្វើការខាងក្រៅបន្ទប់ឃុំឃាំង[928]។ ភារកិច្ចរបស់ពួកគេរួមមាន ចម្អិនម្ហូប និងចែកបបរឲ្យអ្នកទោសផ្សេងទៀត

---

[926] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.12.33-10.14.09 ["ឃើញសឹងរាល់ថ្ងៃអ្នកអត់អាហារ អ្នកឈឺងាប់ត្រូវរួចខ្លួន ហើយអត់អាហារ ស្លាប់ទៅ វាមានច្រើនដែរ។ [...] ពេលវៃស្ងរចម្លើយ ហើយដល់ដាច់អាហារអ៊ីចឹងទៅត្រូវស្លាប់ ហើយរាល់តែយប់ មួយយប់មួយ មួយយប់ពីរអ៊ីចឹងទៅ មុននឹងយកទៅសម្លាប់។"]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.27.35-11.30.32 ["គ្រាន់តែចៃ និងសង្កើចខាំស្លាប់ក្នុងមួយយប់ អត់បាត់ពីគុកមួយ បាត់ពីបួននាក់នឹងបីនាក់ទេក្នុងមួយយប់ ចៃហើយសង្កើចខាំ។ ហ្នឹងចៃហើយសង្កើចខាំ និងពីបញ្ហាអត់អាហារផង។"]។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លីម ហាច KH 00165350។ ឯកសារ D6.1.1000 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ស៊ាន់ KH 00165357។ *សូមមើលផងដែរ* ជើងទំព័រ ៩២២-៩២៣។

[927] *សូមមើល ឧទាហរណ៍* ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.33.40-15.35.44 ["ខ្ញុំអ្នកចូលដោះចេញៗពីខ្ទោចមកទៅដាក់ឲ្យៗអ្នកជាៗ អ្នករស់នៅចេះតែដាក់ អ្នកខ្ទោចដោះចេញមក។ ហើយទុកដល់ល្ងាចម៉ោងបួន [...] គេឲ្យចេញតែថ្ងៃល្ងាច ទៅបីសម្លាប់ពីយប់ក៏ដោយ ស្លាប់ពីថ្មើរម៉ាន យើងចូលពីយប់ កណ្តាលយប់ហ្នឹង ដឹងនៅហ្នឹងហើយ។ ស្អែកឡើងថ្ងៃល្ងាចម៉ោងបួន ម៉ោងបីបញ្ជូលអ្នកទោសធ្វើការ បានយកបាន។"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 15.54.48-16.01.30 [អ្នកទោសដែលត្រូវបានវៃក្នុងពេលស្ងរចម្លើយនៅថ្ងៃមុន ត្រូវបាននាំត្រឡប់ទៅកាន់កន្លែងឃុំឃាំងវិញ ហើយនៅព្រឹកឡើង នៅពេលដែលសាក្សីត្រូវបានបញ្ជាឲ្យបើកទ្វារអាគារនោះ គាត់បានឃើញអ្នកទោសនោះស្លាប់ជាប់ខ្នោះ ដេកជាមួយនឹងអ្នកទោសផ្សេងទៀត]។ ឯកសារ D6.1.878 អ៊ា ម៉េងទ្រី *ច្រវ៉ាក់នៃភាពភ័យខ្លាច* (*The Chain of Terror*) EN 00182232 ["ប្រសិនបើអ្នកទោសស្លាប់នៅពេលយប់ កម្មាភិបាលខ្មែរក្រហមមិនយកសាកសពចេញភ្លាមទេ៖ គឺគេទុកសាកសពរហូតដល់ព្រឹក ឬល្ងាចថ្ងៃក្រោយ នៅពេលដែលអ្នកទោសស្រាលត្រឡប់មកពីធ្វើការវិញទើបអាចយកទៅកប់។"]។

[928] ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.25.38-09.28.52 ["មានតែបីបួនប្រាំនាក់គេលែងឲ្យធ្វើការតែប៉ុណ្ណឹង មានតែប៉ុណ្ណឹងទេ ក្រៅពីហ្នឹងទៀត អត់មានទេ។ [...] មានកូនចៅយាយញ៉ គាត់មួយក្រុមគ្រួសារ ហ្នឹងមានកូនគាត់ អាខុម, អាខាយ, អាហាប់, យាយញ៉, ខ្ញុំ, តាចិន, អ៊ីហ៊ីន។ បាទមានតែប៉ុណ្ណឹង។"]។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 16.00.28-16.02.40 ["បាទមាន។ អ្នកទោសដែលនៅក្នុងនោះ អ្នកខ្លះ គេឲ្យចេញវាល ធ្វើការធម្មតា។ [...] មានរែកដី ដកស្ទូងអ៊ី ដល់ខែដកស្ទូង ដកស្ទូង។"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 10.53.10-10.56.97 ["មកដល់ថាគេយកអ្នកទោសមកដល់ក្រាំងតាចាន់ បើដល់ខែស្ទូង គេអត់ទាន់យកទៅវ៉ៃចោលទេ គេឲ្យទៅស្ទូតជាមួយពួកខ្ញុំប៉ុន្ឌានៅនាក់ហ្នឹង តាដាំ ពូសែម អ៊ីហាត់ (រ៉ាត់) អ៊ីផុន ក្បឿន។ អាហ្នឹងទៅស្ទូងជាមួយអ្នកទោសដូចគ្នា ប៉ុន្តែអ្នកទោសយើង គឺជាអ្នកទោសដែលគេអាចឲ្យចេញក្រៅពេលធ្វើការ។"]។ ឯកសារ D118/167 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ សឿន ឆ.១៦៩ KH 00968189។

ជីករណ្តៅកប់សពសម្រាប់ការសម្លាប់ អ្ងស និងកប់សាកសព រែកទឹក និងចាក់ផុងលាមក និងទឹកនោមចោល[929]។

[929] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.19.27-11.21.08 ["គាត់លែងឲ្យខ្ញុំធ្វើការនៅក្នុងហ្នឹងមានតែមើលក្របី ហើយមើលក្របីមកសម្រាប់ទៅកាប់រណ្តៅសម្រាប់កប់សពហ្នឹង ហើយនិងខ្ទោចស្លាប់នៅក្នុងគុក។ ហ្នឹងគេវៃស្ងរចម្លើយហ្នឹង បង្ហត់បាយដាក់ក្នុងគុកហ្នឹង គឺកាលណាស្លាប់ហើយ ហូតខ្ទោះចេញ ដល់ហូតខ្ទោះចេញហើយ ខ្ញុំយកសែងយកទៅដាក់កប់តាមៗជ្ងរបង។"] ម៉ោង 11.23.13 ["ពេលថ្ងៃ គឺខ្ញុំគេដោះលែងនៅខាងក្រៅ មើលក្របីមើលគោ។ ពេលម៉ោងបួនល្ងាចៗ គេបញ្ចូលអ្នកធ្វើការខាងក្រៅហ្នឹងជាង ១០នាក់ ពីរដណ្តប់នាក់ បីដណ្តប់នាក់ គឺអ្នកធ្វើការខាងក្រៅ ដែលធ្វើស្ទូងដក ដាំដំណាំកសិកម្មអីផ្សេងៗអ៊ីចឹងទៅ។"] ម៉ោង 11.25.30-11.27.35 ["ប៉ុន្តែនៅប្រមែប្រមូលដូចថា មានសពមានអីស្លាប់តាមគុកមួនហ្នឹងទាំងអស់ហ្នឹង យកសពអីទុកដាក់ហើយអស់បានចមកចូលខ្ជ្ជន ដាក់ខ្ជ្ជនឯងបាទ"]។ ឯកសារ D315.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14:15:02-14.20.02, 14.21.35-14.23.18 ["ខ្ញុំមានការជាអចិន្ត្រៃយ៍ខ្ញុំ មានតែភ្ជ្ជ មើលគោ មើលក្របីហើយភ្ជ្ជ ព្រោះខ្ញុំខាងក្របី។ [...] ហើយពីភ្ជ្ជរហ្នឹងគេប្រើខ្ញុំពីរនាក់ តាចិនហ្នឹង សែងលាមកតាមគុកមួយៗ លាមកនិងទឹកនោម។"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.18.34-10.20.50 ["ពេលថ្ងៃ [ម្តាយខ្ញុំ និងបងស្រីខ្ញុំ] គេនឹងឲ្យគាត់មកដាំបបរឲ្យអ្នកទោស ហើយបងស្រីខ្ញុំទៅរែកដីដំបូក។ [...] រូបខ្ញុំផ្ទាល់គេឲ្យមើលតែគោ ហើយនឹងក្របីបួន គោពីរតែប៉ុណ្ណឹងទេ"] ម៉ោង 15.54.48-15.56.14 ["គេហៅ សយ សែន, តាចិន កាប់រណ្តៅកប់"]។ ឯកសារ D219/899.1.3 វង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.18.04-11.20.23 ["គេកំ៏បញ្ជេញខ្ញុំឲ្យធ្វើការជាមួយអ្នកជាប់ទោសដូចគ្នា [...]។ គេឲ្យយើងទៅរែកដីៗដំបូក"] ម៉ោង 14.01.34-14.03.30 ["[សយ សែន] មានខ្ទោចងាប់ ខ្ទោចអ៊ីទៅ គាត់អ្ងស គាត់អ៊ីទៅចោលឯណា ស្រេចគេបញ្ជាគាត់។ ហើយគាត់ជាអ្នកយកលាមកពេលព្រឹកទៅចាក់ចោល។"] ម៉ោង 14.03.30-14.05.24 ["ចាស ពេលគេប្រើឲ្យយើងរែកអាដីលាមកហ្នឹងយកទៅដាក់ រាយយកទៅចាក់ស្រែ គឺគាត់ [សយ សែន] ធ្វើជាមួយក្រុមពួកខ្ញុំហ្នឹង។"]។ ឯកសារ D364/2.1.5 ស្ងត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 15.24.06-15.27.37 ["យាយញ៉ គាត់ដាំបាយឲ្យអ្នកទោស។"]។ ឯកសារ D315.1.10 រ៉ាន់ សឿន ប្រតិចារឹក ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 10.59.28-11.01.28។ ឯកសារ D315.1.11 រ៉ាន សឿន ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.24.10-09.25.30។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 16.00.28-16.02.40។ ឯកសារ D315.1.7 ស្រី ថន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.55.38។ ឯកសារ D5/803/3 ប៊ុន សារ៉ៀន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ម៉ោង 10.32.17-10.34.42។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165333, 35។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លីម ហាច KH 00165349។ ឯកសារ D6.1.788 កំណត់ហេតុស្តាប់ចម្លើយ នាង ដាំ KH 00163546។ ឯកសារ D118/167 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ សឿន ឆ.១៦៩ KH 00968189។ ឯកសារ D219/522 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង ឆ.៥២, ៦៨ KH 01149849, 51។

ការធ្វើទារុណកម្ម

286. ការសួរចម្លើយនៅក្រាំងតាចាន់ត្រូវបានធ្វើឡើងនៅក្នុងអគារចំហ នៅប៉ែកខាងត្បូងបរិវេណគុក[930] ប្រហែលជា ៥០ម៉ែត្រ ពីអ្នកទោសដែលត្រូវឃុំខ្លួន[931]។ ភាពជិតគ្នានេះមានន័យថា អ្នកយាម និងអ្នកទោសជាញឹកញាប់បានឮសំឡេងស្រែកឈឺចាប់របស់ជនរងគ្រោះដែលទទួលរងទារុណកម្ម[932]

---

[930] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.41.02-11.45.20 ["គេធ្វើការិយាល័យមួយម្ខាងបាំង ម្ខាងបាំងតែពីក្រោយអ៊ីចេះ វាលពីខាងត្បូង វាលពីខាងជើង វាលពីខាងកើត ចំហ គេអត់មានធ្វើក្នុងងបន្ទប់ថ្ម បន្ទប់អីទេ។ [...] មានតែដំបូលទេ អត់ជញ្ជាំងទេ។ មានតែជញ្ជាំងតឿកម្ពស់៥ឹកពីដីទេ។ អត់មានជញ្ជាំងបាំងជុំវិញទេ។"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.52.48-10.56.36 ["ដំបូលប្រក់ស្លឹក ជញ្ជាំងប្រដីសឫស្សីបាំងជាមួយស្លឹកត្នោត កន្លែងសួរចម្លើយ។ ប៉ុន្តែខាងក្រោយគេវៃជញ្ជាំងជិត ខាងមុខគេទុកវាលសម្រាប់សួរចម្លើយ ប៉ុន្តែទុកជញ្ជាំងតឿ។ [...] មើលឃើញ។ ដូចថាមើលឃើញពីខាងមុខហ្នឹង ខាងមុខគេសួរហ្នឹង គេវាយជញ្ជាំងតឿ។"]។ ឯកសារ D315.1.7 ផាន់ ឆេន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.43.51-14.45.59 ["បាទ ត្រឹមត្រូវ"] *បញ្ជាក់ដោយ* ឯកសារ D6.1.692 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.៣៥-៣៦ KH 00414486-87 ["កន្លែងសម្រាប់សួរចម្លើយក៏នៅក្នុងបរិវេណមន្ទីរដែ គឺជាកូនរោងតូចនៅជ្រុងខាងត្បូងនៃមន្ទីរ។ [...] រោងសួរចម្លើយ គឺចំហរ មានទំហំប្រហែលមួយម៉ែត្របួនជ្រុង ប្រក់ស្បូវ ហើយមិនមានជញ្ជាំងនោះទេ។"]។ ឯកសារ D315.1.11 វ៉ាន់ ស្ងឿន ប្រតិចារឹក ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.16.07-09.17.36 ["បន្ទប់សួរចម្លើយនៅ [...] ខាងត្បូងផ្លូវចម្ងាយ ៣០ម៉ែត្រ បាទ។"]។

[931] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.23.47-10.27.54 ["កន្លែងសួរចម្លើយអត់ឆ្ងាយពីអាគារគុកហ្នឹងទេ ចម្ងាយដី ៥០ម៉ែត្រ [...] [ហើយវា] ចម្ងាយពីគ្នា ៥ម៉ែត្រពីចង្ក្រានបាយគេ។"]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.13.05-15.14.24 ["ដីហ្នឹង [គឺ] [...] ប្រហែលជាជាង១០ម៉ែត្រដូចគ្នា ពីកន្លែងអ្នកយាមហើយទៅកន្លែងសួរចម្លើយ ហើយចង្ក្រានបាយកងទ័ពហ្នឹង ជាង១១០ម៉ែត្រដូចគ្នាបាទ"]។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.11.38-09.12.47 ["អ៊ៈ ចម្ងាយ ទាក់ទងនឹងចម្ងាយពីអគារ [អ្នកទោស] ទៅ [កន្លែងសួរចម្លើយ] ប្រហែល ៤០ម៉ែត្រ។"] ម៉ោង 09.12.47-09.14.54 ["បន្ទប់របស់ប្រធានមានចម្ងាយប្រហែលជា ៧០ម៉ែត្រ ឬក៏លើសពីនេះ។"]។ ឯកសារ D6.1.123 កំណត់ហេតុស្តាប់ចម្លើយ ស្រី ថន KH 00224790 ["ខ្ញុំបានឃើញគេនាំអ្នកទោសមកវាយសួរចម្លើយជារៀងរាល់ថ្ងៃ នៅបន្ទប់សួរចម្លើយដែលមានចម្ងាយប្រហែល ៥០ម៉ែត្រពីរោងខ្ញុំធ្វើការ។"]។ ឯកសារ D6.1.149.37 ប្លង់មន្ទីរសន្តិសុខក្រាំងតាចាន់ដែលត្រូវបានចងក្រងពីព័ត៌មានដែលផ្តល់ឱ្យដោយសាក្សី សយ សែន។

[932] ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.44.06-13.46.48 ["ខ្ញុំបានឮសម្រែកដែលគេស្រែកហ្នឹង ខ្ញុំឮ បើថាខ្ញុំឃើញផ្ទាល់ភ្នែកគឺខ្ញុំអត់ឃើញទេ បាទ។ [...] បាទ កន្លែងខ្ញុំយាមក៏ឮសូរដល់ដែរ បើសិនជាអ្នកទោសនោះស្រែកខ្លាំង។ ប៉ុន្តែភាគច្រើនគេមិនសូវឱ្យស្រែកឮប៉ុន្មានទេ។ ដល់នៅជិតបានឮ។"]។ ឯកសារ D364/2.1.5 ស្ងួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 14.49.02-14.52.21 ["ក្នុងសម្រែកបងប្អូនអ្នកទោស មិនមែន ខ្ញុំរស់នៅទីហ្នឹងពិតជាឮហើយ។ ឮដោយសារទី១គេវៃសួរចម្លើយនេះក៏ឮ។ អាហ្នឹងឮជាក់ស្តែងតែម្តងបាទ។"]។ ឯកសារ D6.1.784 កំណត់ហេតុស្តាប់ចម្លើយ មាស សុខា KH 00163515 ["នៅពេលដែលយកអ្នកទោសទៅនោះ ខ្ញុំដឹងហើយ ហើយតែវាយសួរចម្លើយ មានឮស្រែក

។ អតីតអ្នកទោសឈ្មោះ មាស សុខា បានរំឭកថា៖ "ស្រែកពេញកន្លែងអគារ កន្លែងសួរចម្លើយ ហ្នឹង"[933]។

287. ការសួរចម្លើយនៅក្រាំងតាចាន់ត្រូវបានបញ្ជាមកពីអាជ្ញាធរថ្នាក់តំបន់ និងថ្នាក់ស្រុក[934]។ ទារុណកម្មត្រូវបានប្រើដើម្បីទាញយក "ចម្លើយសារភាព" ចំពោះបទល្មើសដែលវាប់ចាប់ពីការជាប់ពាក់ព័ន្ធជាមួយនឹងខ្សែខ្ចាំង រហូតដល់ការលួចដំឡូង[935]។ វាល់ "ចម្លើយសារភាព" ត្រូវបានធ្វើ

ហើយ។"]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163507 ["វាយស្រែករោទ៍ដូចគោអញ្ជឹង លឺសួរគេវាយពេលសួរចម្លើយ ចម្ងាយប្រហែល 50m។"]។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន គេង ឆ.២៨១-២៨២ KH 01052700។

[933] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.23.47-10.25.38។

[934] ឯកសារ D6.1.695 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.៣២-៣៤ KH 00414446។

[935] *សូមមើល ឧទាហរណ៍* D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ ខែមីនា ឆ្នាំ១៩៧៨ KH 00271146 [រាយការណ៍ថា "ការសួរចម្លើយឈ្លិចឈ្លី" ត្រូវបានធ្វើចំពោះ ស៊ិន សារ៉ាត់ អតីតប៉ើអ៊ីមស័ក្តិបី "ដើម្បីស្រាវជ្រាវរកខ្សែរវា"]។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271118 [រាយការណ៍ថា អ្នកទោសខ្មែរក្រោម ថាង់ អ៊ីក "ខ្សែរបស់អា យ៉ាប" និង "រ៉ៃសួរចម្លើយមិនសារភាព"]។ ឯកសារ D6.1.275 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270876 [អំពីឈ្មោះ ជៀម ហ៊ីវ អតីតទាហាន លន់ នល់៖ "អាក្បត់នេះវាបានសារភាពថា៖ អំពើក្បត់របស់វាមានដូចខាងក្រោម៖ ទី១ បានលួចដំឡូង ២ បានលួចស្ករ។"] KH 00270884 [រាយការណ៍ថា បុរសពីនាក់ "អាទាំងពីរនាក់នេះជាខ្សែរយ:បក្សពួករបស់ អាប៉ាន់ លៀងជាវ និង ក្ងៀត ណេង" បានឆ្លើយដាក់មនុស្សពីរនាក់ផ្សេងទៀតក្នុងពេលសារភាពរបស់ខ្លួន]។ ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00271069 ["តាមការសួរឈ្លិចឈ្លីរកខ្សែសង្វាក់មេកើយរបស់វា"] KH 00271070 ["លុះយើងខ្ញុំសួរស្រាវជ្រាវទៅ [ពុធ] សារភាពថា វាបានទទួលការអប់រំពីមេវាម្នាក់ឈ្មោះ ទ្រៀង"]។ ឯកសារ D6.1.214 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ KH 00270842 ["ក្រោយពីបានបញ្ជាក់សួរចម្លើយរកខ្សែរយ:វាសារចុះសារឡើង វាបានសារភាព" និងបានកំណត់អត្តសញ្ញាណពួកក្បត់បីនាក់ទៀត]។ ឯកសារ D6.1.1200 សេចក្តីរាយការណ៍ពី អាន់ នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ទៅកាន់បក្ស ចុះខែកក្កដា-សីហា ឆ្នាំ១៩៧៧ KH 00082726 ["តាមការសាកសួរស្រាវជ្រាវ" ចំពោះឈ្មោះ ស៊ីន យ៉ាង រូបគាត់បានឆ្លើយដាក់អតីតមន្ត្រី លន់ នល់ ពីរនាក់ ដែលជា "មេបំផុលនិងអប់រំ"]។ ឯកសារ D6.1.239 សេចក្តីរាយការណ៍ពី ម៉ែង នៅគុកអង្ករការ ទៅកាន់អង្គការ ចុះថ្ងៃទី២៣-២៤ ខែមីនា ឆ្នាំ១៩៧៧ [អំពីការចាប់ខ្លួន សួរចម្លើយ និងការសារភាពរបស់ ក្មេងអាយុ១០ឆ្នាំ ឈ្មោះ រ៉ា ដែលទោសត្រូវបានចោទថាជាផ្នែកមួយនៃក្រុមដែលបានរត់គេចខ្លួន។ នៅថ្ងៃទី២៨ ខែមីនា លេខាស្រុក គិត បានទំនាក់ទំនងផ្ទាល់ទៅកាន់ អាន់ នៅក្រាំងតាចាន់ឲ្យ "សួរចម្លើយអាគិញនេះឲ្យបានល្អ"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.31.02-11.33.27 ["ខ្ញុំឮគេសួរចម្លើយ ឮពេញត្រចៀក គេស្រែកឮៗ។ [...] សួរកសិករថ្មីមួយ គេសួរថា "ហ្អែងនៅភ្នំពេញ ហ្អែងពាក់ស័ក្តិពអត់?" កសិករថ្មីថា "អត់ទេ ខ្ញុំអត់មានធ្វើទាហានពាក់ស័ក្តិពាក់អីទេ"។ គ្រាន់តែពាក្យប៉ុណ្ណឹងណាលោក ខ្ញុំឮសន្ធឹកវ៉ៃខ្វ៉ៃបៗៗ។ [...] សួរទៀតថា "ហ្អែងពាក់ស័ក្តិ៣ដែរអត់?" ឆ្លើយថា "អត់" រ៉ៃបន្តទៀត។ រហូតដល់អ្នកទោសវាឈឺដល់ចិត្ត ហើយ វាបងប្អូនងាប់ហើយ ឆ្លើយថា "ខ្ញុំពាក់ស័ក្តិ៣ម៉ែន" ដើម្បីឈប់ឲ្យគេវ៉ៃ។"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក

កំណត់ត្រា និងសង្ខេបក្នុងសៀវភៅកត់ត្រាមួយ[936]។ សេចក្តីសង្ខេបទាំងនេះក្រោយមកត្រូវបានវាយអង្គុលីលេខជារបាយការណ៍ ដែលចុះហត្ថលេខាដោយប្រធាន អាន់ និងបញ្ជូនទៅមន្ទីរស្រុក[937]

ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.30.15-10.31.36 ["ខ្ញុំឮគេសួរ "អ្នែងធ្វើអីជំនាន់ដែលនៅជាមួយ លន់ នល់ អ្នែងស័ក្តិបី៣ ឬស័ក្តិ៤ អ្នែងធ្វើ សេ.អ៊ុ.អា អាមេរិកាំង ឬ សេ.អ៊ុ.អា ឃ្លន?" [...] ស្បោងកៅស៊ូ គេកម្រច្រកណាស់។ ទោសអ្នកមិនធ្លើយ បានគេច្រក។ ខ្ញុំឃើញតែម្តងទេច្រកស្បោងកៅស៊ូ។"] ម៉ោង 15.31.48-15.33.47 ["ពេលគេសួរ ជួនណា អ្នែងធ្វើការអី បាក់ទង្គ័ល លួចដំឡុង លួចមាន់ លួចអ្វីៗផ្សេងទៀតទៅ អ្នែងប្រឆាំងនឹងសហការណ៍ អ៊ីចឹងទៅ។ គេសួរគ្រប់ជំពូកទាំងអស់ [...] បើគេសួរសំខាន់បំផុតរឿង សេ.អ៊ុ.អា ឃ្លន ហើយអាមេរិកាំងតែប៉ុណ្ណឹង។"] ម៉ោង 15.38.30-15.40.34 ["គេច្រកសួរ ដើម្បីសួរចម្លើយឲ្យធ្លើយ។ បុគ្គលណាបន្ត្រវេន ធ្វើអីធ្វើអីហ្នឹង គេសួររកអ្នកធ្វើរាជការ ឬមន្ត្រីតូចធំអី គេសួរបន្ត្រអ៊ីចឹងទៅ។"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.07.14-10.11.07។ ឯកសារ D6.1.119 កំណត់ហេតុស្តាប់ចម្លើយ សយ សែន KH 00223059។ ឯកសារ D6.1.782 កំណត់ហេតុស្តាប់ចម្លើយ អ្រៀប ឌុច KH 00163496។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លីម ហាច KH 00165346-47។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.៥២-៥៣ KH 01000025។

[936] *សូមមើល ឧទាហរណ៍* ឯកសារ D6.1.217 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់។ ឯកសារ D6.1.202 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ ចុះខែមីនា-ធ្នូ ឆ្នាំ១៩៧៨។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់។ ឯកសារ D6.1.275 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់។ ឯកសារ D6.1.238 សេចក្តីរាយការណ៍ស្តីពីចម្លើយសារភាពពីមន្ទីរសន្តិសុខក្រាំងតាចាន់ ទៅកាន់បក្ស ចុះខែមីនា ឆ្នាំ១៩៧៧-ខែកក្កដា ឆ្នាំ១៩៧៨។ ឯកសារ D6.1.214 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់។ ឯកសារ D6.1.297 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ និងសេចក្តីរាយការណ៍ជូនបក្ស។ ឯកសារ D6.1.1220 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់។ ឯកសារ D347/2.1.34 Henri Locard ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង 15.33.34-15.34.43 ["នៅគុកក្រាំងតាចាន់អីអ៊ីចឹង គឺថាមានឯកសារ មានអីអ៊ីចឹង មានសេចក្តីសង្ខេបនៃការសួរចម្លើយនៅក្នុងសៀវភៅ គេសរសេរហើយស្រេច។"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 15.30.05-15.31.48 [ត្រូវបានសួរចម្លើយ ខណៈដែលអនុ ពេញ កត់ត្រាចម្លើយរបស់អ្នកទោស]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.29.12-11.33.27 [ទាក់ទងនឹងការសួរចម្លើយគាត់៖ "មានគេកត់ ឈ្មោះ អាន់ អ្នកកត់។ [...] គេសរសេរនៅចុងតុម្ខាងនោះ យើងអត់បានដឹងថា -- ដឹងជាអក្សរអ្នកណាទេ។ [...] ព្រោះអ៊ីវ៉ែអាម្នាក់នោះឲ្យធ្លើយស័ក្តិពាតាមៗគោលបំណងរបស់វាហើយហ្នឹង។ អ៊ីចឹងសំណួរដែលវាសួរខ្ញុំ វាអាចសរសេរទៅជាយ៉ាងម៉េចក៏បានដែរ អាហ្នឹងខ្ញុំគិតថាអ៊ីចឹង។"]។ ឯកសារ D6.1.785 កំណត់ហេតុស្តាប់ចម្លើយ សុក សុត KH 00163523 [ទាក់ទងនឹងការសួរចម្លើយរបស់គាត់៖ "ឌុច ជាអនុប្រធាន [ធ្វើការសួរចម្លើយ]។ [...] ពេញជាអ្នកកត់ត្រា។ ចេង អ្នកវាយធ្វើទារុណកម្ម។"]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163506 [ទាក់ទងនឹងការសួរចម្លើយគាត់៖ "សន់ គ្រាន់តែអង្គុយមើល ឌុចតូចអ្នកវាយតាមបញ្ជារ ឌុចធំអ្នកកាន់បញ្ជីកត់ត្រា។"]។ ឯកសារ D6.1.695 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ណេន ឆ.៣២ KH 00414446។ ឯកសារ D6.1.782 កំណត់ហេតុស្តាប់ចម្លើយ អ្រៀប ឌុច KH 00163496។

[937] *សូមមើលឧទាហរណ៍* ឯកសារ D6.1.229 សេចក្តីរាយការណ៍ពី អាន់ ទៅកាន់បក្ស អំពីចម្លើយសារភាពរបស់អ្នកទោស ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៦ KH 00271030-31។ ឯកសារ D6.1.230 សេចក្តីរាយការណ៍ពី អាន់ ទៅកាន់បក្ស អំពីចម្លើយ

។ បន្ទាប់មក មន្ត្រីស្រុក និងតំបន់បញ្ជូនឯកសារទាំងនោះត្រឡប់មក អាន់ វិញ ដោយភ្ជាប់ជាមួយនូវសេចក្តីណែនាំឲ្យអនុវត្ត ដែលបញ្ជាក់ច្បាស់ថាពួកគេបានដឹងឮ និងបានអនុញ្ញាតឲ្យប្រើទារុណកម្មនៅក្រាំងតាចាន់[938]។

288. ការធ្វើទារុណកម្មបានកើតមានឡើងជាប្រចាំចំពោះមុខវត្តមានមន្ត្រីគុកជាន់ខ្ពស់[939]។ អ្នកទោសទទួលរងការវាយដំយ៉ាងដំណាំ ជាញឹកញាប់ដល់សន្លប់ ឬស្លាប់ក៏មាន[940]។ អ្នកសួរចម្លើយប្រើដង្កាប់

សារភាពរបស់អ្នកទោស ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ D6.1.1200 សេចក្តីរាយការណ៍ពី អាន់ ទៅកាន់បក្ស អំពីចម្លើយសារភាពរបស់អ្នកទោស ចុះខែកក្កដា-សីហា ឆ្នាំ១៩៧៧។ ឯកសារ D347/2.1.7 សេចក្តីរាយការណ៍ពី អាន់ ទៅកាន់បក្ស អំពីចម្លើយសារភាពរបស់អ្នកទោស ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ D6.1.305 សេចក្តីរាយការណ៍ពី អាន់ ទៅកាន់គណកម្មាធិការស្រុកត្រាំកក់ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៧៧ KH 00270932។ ឯកសារ D6.1.238 សេចក្តីរាយការណ៍ពី អាន់ ទៅកាន់បក្ស អំពីចម្លើយសារភាពរបស់អ្នកទោស ចុះខែមីនា ឆ្នាំ១៩៧៧-ខែកក្កដា ឆ្នាំ១៩៧៨។ ឯកសារ D6.1.205 សេចក្តីរាយការណ៍ពី អាន់ ទៅកាន់បក្ស ទាក់ទងនឹងចម្លើយសារភាពរបស់អ្នកទោស ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ១៩៧៨។ ឯកសារ D6.1.695 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ធេន ឆ.១៣, ២០-២២ KH 00414443-45។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.32.57-09.35.02, 09.45.41-09.47.58, 09.51.18-09.53.03, 09.53.03-09.54.15, 09.56.50-09.59.20។ ឯកសារ D118/167 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ស្ងឿន ឆ.៤០, ៤៨-៤៩, ៥៥-៥៦ KH 00968176-78។ ឯកសារ D6.1.652 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ័ម KH 00373464-65។

[938] *សូមមើល* ជើងទំព័រ ១៣៧។ ឯកសារ D6.1.1221 បញ្ជារបស់កម្ពុជាប្រជាធិបតេយ្យពី [លេខាស្រុកត្រាំកក់] គិត ទៅកាន់ អាន់ ចុះថ្ងៃទី១៣ ខែមិថុនា [១៩៧៧] KH 00082730 ["ជំរាបមកស/ម អាន់ ជាទីស្នាហា! ចំពោះពួកអាក្បត់ ១០នាក់ [...] បញ្ជូនមកម្សិលមិញនេះ ស្នើ ស/ម សាកសួរណ្ដ្ដិចណ្ដ្ដ សួររកខ្សែរបស់វាឲ្យអស់"]។ ឯកសារ D6.1.279 បញ្ជារបស់កម្ពុជាប្រជាធិបតេយ្យពី គិត ទៅកាន់ អាន់ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00270734 ["ស/ម អាន់ ជាទីស្នេហា! ស្នើសាកសួរចម្លើយឲ្យបានល្អិតល្អន់ ព្រោះឈ្មោះនេះខ្សែ ច/ត របស់ សេអ៊ីអា។"]។ ឯកសារ D6.1.1200 បញ្ជារបស់កម្ពុជាប្រជាធិបតេយ្យពី គិត ទៅកាន់ អាន់ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៧ KH 00082727 ["បញ្ជាអ្នកទោសទាំងអស់ដែលចាប់នៅក្នុងឃុំ ជាងទង [...] សួរចម្លើយផុតខ្សែវាឲ្យអស់ កំទេចចុះ។"]។ ឯកសារ D6.1.207 បញ្ជារបស់កម្ពុជាប្រជាធិបតេយ្យពី សាន ទៅកាន់ អាន់ KH 00079128 [សេចក្តីណែនាំឲ្យសួរចម្លើយ ហ៊ីល និង ស៊ាន ដើម្បីស្វែងរកខ្សែរបស់ពួកគេ]។ ឯកសារ D6.1.292 សេចក្តីរាយការណ៍ពី គិត នៅស្រុក១០៥ ទៅកាន់បក្ស ចុះថ្ងៃទី៦ ខែតុលា ឆ្នាំ១៩៧៧ EN 00322172 [គិត បានស្នើសុំសេចក្តីសម្រេចលើយុទ្ធនាវីម្នាក់ ដែលត្រូវបានឃុំខ្លួនដោយសារបានដើរសេរីគ្មានការអនុញ្ញាត។ លេខាតំបន់ ១៣ ឈ្មោះ ប្រាក់ បានឆ្លើយតបថា៖ "នាវីនេះខ្ទាំងហើយ។ សុំសួរចម្លើយរកខ្ទាំងវាបន្ទាន់។ [...] សួរចម្លើយជាបន្ទាន់។"]។

[939] *សូមមើល* ភ័ស្តុតាងយោងក្នុងកថាខណ្ឌ ២៨៧។

[940] *សូមមើលឧទាហរណ៍* ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.09.00-10.11.07 ["បាទ រ៉ែដំបងបូស្សី។ បូស្សីប្រហែលជាប្រវែងប្រាំពីរតឹក ឬក៏ប្រាំមួយតឹក។ បូស្សីប្រហែលប៉ុនករដៃបាទ។ គេកាត់បូស្សីនៅកន្លែងហ្នឹង មានបីកង់ បួនកង់នៅពីក្រោយសួរចម្លើយនៅហ្នឹង។"]។ ឯកសារ D364/2.1.5 ស្ងួត សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 13.39.07-13.42.42 ["គេយកដំបងវាយសួរចម្លើយ និងយកថង់ប្លាស្ទិកមកដើម្បីឲ្យថប់ដង្ហើម ឲ្យអ្នក

ដកក្រចកដៃអ្នកទោស ឬមួលរាងកាយរហូតទាល់តែពួកគេព្រមសារភាព[941]។ ពួកគេក៏បានចងអ្នកទោសព្យួរក្បាលចុះក្រោមជើងឡើងលើ ឬព្យួរកឡើងលើ និងវាយពួកគេ[942]។ អ្នកទោសផ្សេងទៀត

ទោសចេញជាចម្លើយឲ្យគេបាទ។"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.35.55-11.40.02 ["ថ្ងៃមួយគេយកកងទ័ពម្នាក់ យកទៅដេកនៅក្បែរខ្ញុំ។ [...] ពេលដែលគេទៅសួរចម្លើយ លោកដឹងម៉េចទេ? រ៉ៃខ្លាំងណាស់ លោកអើយ! ហ្នឹងអ្នកទោសដេកជាប់នឹងខ្ញុំ។ រ៉ៃៗថាគ្មានសាច់ម៉ែបង្កើត។ ពេលគេបណ្តើរមកវិញ មួយយប់ទាល់ភ្លឺ កងទ័ពនោះយំ"] ម៉ោង 10.53.10-10.56.97 [ក្រោយពីមិត្តរបស់គាត់ រ៉ុម ត្រូវបានសួរចម្លើយរួច៖ "ដល់ពេលយប់ហ្នឹងអាដេកហ្នឹងវាមានប្រលោះកណ្តាលដើរ [...] ខ្ញុំហ្នឹងក៏តកេះតតះយកដៃទៅស្ទាបវា។ លោកអើយ គួរអនិចារណាស់ ខ្ជនរួមរឹត ខ្ញុំអត់មានកន្លែងដែលសាច់ម៉ែចែកទេ កន្ទួលប៉ុនៗមេដៃ ប៉ុនៗមេជើងទាំងអស់។"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.30.15-10.31.36 ["អ្នែងឆ្លើយឲ្យត្រឹងមើល៍ បើអត់ឆ្លើយ អ្នែង រ៉ៃអ្នែងងាប់ហ្នឹងឥឡូវ។"] ម៉ោង 15.40.34-15.44.02 ["ពេលគេច្រក គេមុន--គេសួរហើយ គេវាដំ វាយទាត់ធាក់អ៊ីចឹងទៅ។ [...] គេទាត់ពាក់ស្បែកជើងទាត់។ ស្បែកជើងអាម៉ែហ្វ៉ូក អាំមេរិកាំងហ្នឹង ហើយដំបង គេសួរចម្លើយអ៊ីចឹង។"]។ ឯកសារ D6.1.784 កំណត់ហេតុស្តាប់ចម្លើយ មាស សុខា KH 00163518 ["គេសួរថា ហ្អែងធ្វើអី? ធ្វើ CIA អាមេរិកាំងឬ CIA ឃ្លួន? ជំនាន់ លន់ នល់ ហ្អែងពាក់ស័ក្តិប៉ុន្មាន? ពេលណាមិនឆ្លើយ គេវាយទាល់តែសន្ធប់ក៏មានដែរ។"]។ ឯកសារ D6.1.785 កំណត់ហេតុស្តាប់ចម្លើយ សុក សុត KH 00163525 ["ស៖ ក្រោយសួរចម្លើយមានឃើញអ្នកទោសរបួសទេ? ឆ៖ មាន មានបែកហូរឈាម ខ្ញុំឃើញរាល់ថ្ងៃ [...] ស៖ សុទ្ធតែនាក់ដែលគេវាយសួរចម្លើយ? ឆ៖ សុទ្ធតែសន្ធប់ទាំងអស់។ ស៖ គេវាយដោយអី? ឆ៖ ដោយដំបង តំបងគេតំរៀបពេញជញ្ជាំង បាក់មួយយកមួយ។ ស៖ ស្រីក៏គេវាយដែរ? ឆ៖ វាយទាំងអស់។"]។ ឯកសារ D6.1.788 កំណត់ហេតុស្តាប់ចម្លើយ នាង ដាំ KH 00163547។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165334។ ឯកសារ D6.1.123 កំណត់ហេតុស្តាប់ចម្លើយ ស្រី ថន KH 00224790។ ឯកសារ D6.1.1000 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ សឿន KH 00165354 ។ ឯកសារ D118/166 កំណត់ហេតុស្តាប់ចម្លើយ ទីម ហ៊ី KH 00968161។ ឯកសារ D6.1.1234 បទសម្ភាសន៍ ម៉ាន់ សេង ដោយគណៈកម្មការស្រាវជ្រាវឧក្រិដ្ឋកម្ម KH 00032861។

[941] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.27.54-10.30.15។ ឯកសារ D364/2.1.2 សយ ស៊ែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.11.07-10.12.52។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.៥២-៥៣ KH 01000025។

[942] ឯកសារ D315.1.10 រ៉ាន សឿន ប្រតិចារឹក ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៥ ម៉ោង 11.23.55-11.27.23 ["ម្តាយមីងខ្ញុំគាត់ [នៅក្រាំងតាចាន់] ជាប់រយៈពេលបីឆ្នាំបាទ។ ដល់កាលគាត់ជាប់ហ្នឹង គេដាក់ខ្សែរ៉ូកក នៅស្នាមទល់បច្ចុប្បន្នសព្វថ្ងៃបាទ។"]។ ឯកសារ D6.1.785 កំណត់ហេតុស្តាប់ចម្លើយ សុក សុត KH 00163522 ["គេហៅខ្ញុំទៅសួរចម្លើយទីនោះ ខ្ញុំឃើញខ្សែពួរ បើយើងឆ្លើយមិនត្រង់ គេព្យួរជើងឡើងទៅលើ។"]។ ឯកសារ D118/166 កំណត់ហេតុស្តាប់ចម្លើយ ទីម ហ៊ី KH 00968161។ ឯកសារ D6.1.999 កំណត់ហេតុស្តាប់ចម្លើយ លីម ហាច KH 00165346-47។

ត្រូវបានធ្វើឲ្យថប់ដង្ហើមដោយប្រើថង់ប្លាស្ទិកចងរុំមុខរបស់ពួកគេ ឬក៏ជ្រមុជទឹក[943]។ អ្នកទោសភាគច្រើនបានស្លាប់ក្នុងអំឡុងពេលសួរចម្លើយ ឬក្រោយពីនោះ[944]។

289. អ្នកទោសស្ត្រីត្រូវបានកំណត់គោលដៅផងដែរសម្រាប់ការរំលោភបំពាន ដែលមានតម្លៃស្មើទៅនឹងទារុណកម្ម នៅពេលដែលពួកគេត្រូវបានរំលោភសេពសន្ថវៈដោយអ្នកយាមគុក និងមន្ត្រីគុក[945]។ យ៉ាងយោចណាស់ក็ម្តងដែរដែល អ្នកយាមបានញាត់គ្រាប់រំសេវចូលក្នុងយោនីរបស់ស្ត្រី[946]។

---

[943] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.30.15-10.31.36 ["ច្រកបានប្រហែលជា ៥នាទី មិនទាន់ផង អ្នកនោះឆ្លើយ ឆ្លើយហើយគេវៃបន្តទៀត។"] ម៉ោង 11.45.20-11.47.34 ["តែសួរមិនឆ្លើយគឺគេវៃហើយ បើកាលណាវៃមិនហើយ [...] គេច្រកស្បោង"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.14.33-15.16.21 ["ឃើញតែចងស្ពាបសេក [ដៃអ្នកទោស] ហើយចងមុខជាមួយនឹងកន្សែងៗកៅស៊ូ។"]។ ឯកសារ D315.1.10 វ៉ាន់ សឿន ប្រតិចារឹក ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 11.13.40-11.15.14 ["ហើយម្យ៉ាងវិញទៀត នៃសំខាន់បំផុត គឺគេវាយច្រកថង់ប្លាស្ទិកតែម្តងបាទ។"]។ ឯកសារ D364/2.1.5 ស្ងួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.38.49-09.42.10 ["ធ្វើទារុណកម្ម សួរចម្លើយ បាទ មាន មានសួរដូចជា វៃសួរចម្លើយ ឬមួយចងកំណត់ផ្លាស្ទិកមុខបាទ។"]។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165334។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.៥២ KH 01000025។

[944] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 15.34.52-15.37.07 ["ច្រកមិនដឹងប៉ុន្មានទាទី ខ្ញុំអត់ដឹងទាទី ឬកំណត់ម៉ោងទេ ខ្ញុំអត់ដឹង ព្រោះឃើញដល់ពេលនេះគេអូសយកទៅដាក់ពន្ធនាគារវិញ ស្អែកឡើងឃើញអូសម្នាក់ហ្នឹងទៅកប់។"]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.55.14-13.58.37 ["ឆ៖ អ្នកគេដាក់គុកក្នុងហ្នឹង ដែលវៃសួរចម្លើយទារុណកម្មដាក់គុកក្នុងហ្នឹង មិនអាចរត់រួចក្នុង១ខែក្នុងម្នាក់ទេ ព្រោះគេអត់ឲ្យអីហូបទាំងអស់ អត់មានហូបអីទាំងអស់។ គេដាក់ខ្ទោះចោលតែម្តង។ ស៖ អ៊ីចឹងមានន័យថា ទោះបីក្នុងករណីណាក็ដោយ ពួកគេគង់តែស្លាប់ក្នុងរយៈពេល១ខែហ្នឹង ទោះបីមិនទាន់សម្លាប់មុនឹងក็ដោយ។ អ៊ីចឹងមែនទេ? ឆ៖ បាទ ព្រោះមុននឹងយកមកសួរចម្លើយ ហើយមុនយកមកទុកនៅកន្លែងវិញ គឺគាត់ធ្វើទារុណកម្មឡើងហ្ចត់ឡេវអស់ហើយ គ្មានសល់អី ឈាមចេញតាមមាត់តាមអណ្តាតអស់ហើយ លែងដឹងលែងអីជាមនុស្សអស់ហើយហ្នឹង បាទ។"]។ ឯកសារ D6.1.1000 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ស៊ាន់ KH 00165357។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165334។ ឯកសារ D118/166 កំណត់ហេតុស្តាប់ចម្លើយ ទីម ហ៊ី KH 00968161។ ឯកសារ D219/522 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង ឆ.៥២ KH 01149849។

[945] ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.៨៣-៨៤ KH 01000030។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.៣៤៧-៣៧២ KH 01052727-29។ *ប៉ុន្តែសូមមើល* ឯកសារ D315.1.10 វ៉ាន់ សឿន ប្រតិចារឹក ថ្ងៃទី ៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 15.13.28-15.17.56 ["តែដោយរំលោភដូចគ្មានទេបាទ។"]។

[946] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.58.37-14.00.40 [សាក្សីត្រូវបានអ្នកយាមបញ្ជូនឲ្យទៅកប់សាកសពស្ត្រីពីរនាក់ដែលអ្នកយាមនោះទើបតែបានរំលោភសេពសន្ថវៈ និងសម្លាប់ចោល។ អ្នកយាមនោះបានញ៉ុកកាំភ្លើងគ្រាប់ M-79 ទៅក្នុងយោនីរបស់ស្ត្រីទាំងនោះ]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ

290. អ្នកទោសទាំងអស់នៅក្រាំងតាចាន់ ត្រូវបានដាក់ឲ្យស្ថិតក្រោមការឈឺចាប់ផ្លូវចិត្តធ្ងន់ធ្ងរ ដោយសារតែពួកគេមានការភ័យខ្លាចជាប្រចាំ ឬអ្នកដែលពួកគេខ្វល់ខ្វាយនោះគឺជាមនុស្សបន្ទាប់ដែលត្រូវរងទារុណកម្ម ឬសម្លាប់ចោល។ អ៊ុក ហ៊ីម បានរំឭកថា គាត់ញ័រខ្លួននៅពេលបានឃើញពេជ្ឈឃាតកាន់សរីរាង្គជនរងគ្រោះដែលទើបតែត្រូវបានសម្លាប់ស្រស់ៗ[947]។ រ៉ង សារុន ដែលត្រូវបានឃុំខ្លួនជាមួយនឹងកូនស្រីអាយុមួយឆ្នាំរបស់គាត់នោះ បានផ្តល់សក្ខីកម្មថា គាត់បានឲ្យរបបបបរបស់គាត់ទៅកូនគាត់ចំនួនបីថ្ងៃ ដោយសារតែ "ដល់ពេលវាយ៉ាំ គេចូលមកវ៉ៃ ព្រោះអ៊ីវាក្មេងវាអត់ដឹង តែវាឃ្លានវាយ៉ាំហើយ បើអ៊ីចឹងគេមកវ៉ៃកូននៅនឹងចំពោះមុខខ្ញុំ ខ្ញុំជាម្តាយចង់ប្រេះទ្រូងហើយ។ ដូច្នេះ ខ្ញុំសុខត្រូវបង្អត់ខ្លួនឯង[948]"។

<u>អំពើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

291. អាជ្ញាធរកម្ពុជាប្រជាធិបតេយ្យក្នុងស្រុកត្រាំកក់ ជាញឹកញាប់បានចាប់ និងបញ្ជូនមនុស្សចេញដោយសម្ងាត់ ដោយមិនឲ្យអ្នកដែលពួកគេស្រឡាញ់ដឹងព័ត៌មានណាមួយអំពីទីកន្លែង ឬជោគវាសនារបស់អ្នកទាំងនោះឡើយ[949]។ សាក្សី ឯក ហ៊ៀន បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា

២០១៥ ម៉ោង 10.38.04-10.40.46 [កំណត់អត្តសញ្ញាណអ្នកយាមដែលបានរំលោភសេពសន្ថវ: និងសម្លាប់ស្ត្រីពីរនាក់នោះជា ឌុច តូច និង សាំង។ ពួកគេទាំងពីរមិនត្រូវបានដាក់ទណ្ឌកម្មនោះទេ]។ ឯកសារ D315.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.24.52-14.30.49។ *ប៉ុន្តែសូមមើល* ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.50.52-15.57.40 [បដិសេធភ័ស្តុតាងរបស់ សយ សែន ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវ:នេះថាជា "ចម្លើយបំភ្លាន់ និងបំភ្លៃការពិត" ពីព្រោះការរំលោភសេពសន្ថវ:ត្រូវបានហាមឃាត់ ហើយបើអ្នកណាបានប្រព្រឹត្តការរំលោភផ្លូវភេទនឹងមិនត្រូវបានអត់ឱនឡើយ]។

[947] ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.៥១ KH 01000025។

[948] ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.48.38-09.51.29។ *សូមមើលផងដែរ* ម៉ោង 10.59.19-11.01.19 [អ្នកយាមបានបង្ខំកូនស្រីរបស់គាត់ឲ្យលេងជាមួយត្រីដែលមានទ្រមុងរឹងស្រួច ដែលអាចបង្ករការឈឺចាប់យ៉ាងខ្លាំង។ ពួកគេ "ថាឲ្យវាងាប់ទៅ ឲ្យផុតពូជ អាសែត។ គេនិយាយអ៊ីចឹងនៅមុខខ្ញុំ។ ពេលហ្នឹងខ្ញុំគ្មានអៀក្រៅពីថា សូមព្រះអង្គ សូមទេវតា ជួយកូនខ្ញុំ កុំឲ្យមានសត្វអស់ហ្នឹងមុត។"]។

[949] *សូមមើល ខ១ាហារណ៍* ឯកសារ D315.1.20 ឯក (អ៊ីល) ហ៊ៀន ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 16.00.11 ["គេចាប់អត់ចំហេ យប់ឡើងគេដើរចាប់បាត់ៗទៅ យើងអត់បានដឹងដែរហ្នឹង ព្រឹកឡើងបាត់មនុស្សអស់ហើយ។"]។ ឯកសារ D6.1.650 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ៉ីម KH 00373462 ["មានប្រជាជនខ្លះមកប្តឹងឲ្យខ្ញុំដែលជាគណៈស្រុកឲ្យជួយពីរឿងបាត់បងប្អូន កូនចៅ របស់ពួកគេ ហើយខ្ញុំបានប្រាប់ទៅគេវិញថា ខ្ញុំជួយមិនបានទេ។ ប្រជាជនមកប្តឹងពីរឿងបាត់បងប្អូនកូនចៅ ដោយសារបងប្អូនកូនចៅរបស់គេនោះមានទំនាស់ពីរឿងនយោបាយដែលគេចោទគ្នាថាក្បត់។"]។ ឯកសារ D5/49/3 តាកសាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ម៉ោង 13.27.27-13.29.15 ["ពេលម៉ោងប្រាំឡើងមក ឃើញតែគោបាត់ប្តីខ្ញុំ [...]

នៅពេលដែល **យ៉ីម ទិញ្ញ** ទទួលបន្ទុកតំបន់នេះ រូបគាត់ និង អ៊ីម ចែម បានបញ្ជាប្រធានសន្តិសុខស្រុកឲ្យចាប់មនុស្ស[950]។ ការចាប់ខ្លួនជាច្រើនត្រូវបានធ្វើឡើងនៅពេលយប់ ឬក៏តាមការប្រើឧបាយក្លែងក្លាយ ដែលមានន័យថា អ្នកដែលនៅសល់ពីការចាប់ដឹងត្រឹមតែថាអ្នកជាទីស្រឡាញ់របស់ខ្លួនបានបាត់ខ្លួនប៉ុណ្ណោះ[951]។ មនុស្សបានបាត់ពីស្រុកជាប្រចាំថ្ងៃ និងមិនដែលបានត្រឡប់មកវិញនោះទេ[952]។ ប៉ុន្តែ ៤០ឆ្នាំក្រោយមក អ្នកជាទីស្រឡាញ់របស់ពួកគេនៅតែឆ្ងល់អំពីជោគវាសនារបស់ពួកនាក់ទាំងនោះ។

ហើយខ្ញុំក៏ខ្ញុំមិនហ៊ានសួរទៀត មិនហ៊ានសួរប្តីខ្ញុំថាទៅណាមកណា ខ្ញុំមិនហានសួរទេ ខ្ញុំខ្លាច។"]។ ឯកសារ D315.1.4 រ៉ី ពៅ ប្រតិចារ៉ីក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.01.34-10.03.21 ["អ៊ីចឹងការវាយចាប់ចង វាធ្វើបាបហ្នឹងជារៀងហូរហែរាល់ថ្ងៃហ្នឹង ប៉ុន្តែគេអត់ថាយកទៅវ៉ៃចោល ឬយកទៅសម្លាប់ទេ គេថាយកទៅរៀនសូត្រ ហើយសម័យនុង ខ្ញុំឃើញគេចងជាហូរហែអ៊ីចឹង ប៉ុន្តែថា គេថាយកទៅរៀនសូត្រ ហើយអ៊ីចឹងយើងក៏មិនបានសួរនាំគេដែរ គ្រាន់តែឃើញអ៊ីចឹងភ័យរកតែព្រលឹង រកតែអាយុជាវិតដូចគ្នាហ្នឹង។ មាននរណាបានទៅសួរនាំគេសម័យនោះ គេបិទសិទ្ធយើងមិនឲ្យនិយាយស្តី មិនឲ្យដឹងឮអ្វីទាំងអស់។"]។ ឯកសារ D6.1.218 សៀវភៅកត់ត្រារបស់អ្នកសួរចម្លើយនៅក្រាំងតាចាន់ ខែសីហា ឆ្នាំ១៩៧៦ KH 00271131 [បទឧក្រិដ្ឋមួយក្នុងចំណោមបទឧក្រិដ្ឋនានារបស់ ឡុង នោម ដែលបានសារភាពនោះគឺ គាត់បានបំផុស "ប្រជាជនជួយទាមទាប្តីបាត់ ប្រពន្ធបាត់កូន"]។

[950] ឯកសារ D219/34 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ីន ធ.ពាព KH 01032071។

[951] *សូមមើលឧទាហរណ៍* ឯកសារ D315.3.1 ជូ គឹមឡេង ប្រតិចារ៉ីក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ម៉ោង 14.33.44-14.34.57 ["គេចាប់យកទៅពេលយប់ យើងអត់មានឃើញទេ [...] យកទៅដោយស្ងាត់ៗ"]។ ឯកសារ D366/4.1.1 ជាំង ស្រីមុំ ប្រតិចារ៉ីក ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥ ម៉ោង 9.40.32-09.43.37 ["សាច់ញាតិរបស់ខ្ញុំច្រើនណាស់ដែលបានបាត់ខ្លួន ដែលពេលខ្មែរក្រហមយកទៅសម្លាប់ហ្នឹង ជាពិសេសឪពុករបស់ខ្ញុំ [...] នៅម៉ោងប្រាំពីរយប់ មានប្រធានភូមិ ប្រធានកង ទៅហៅឪពុកខ្ញុំចេញពីក្រោមផ្ទះ តែពេលនោះបាត់ឪពុកខ្ញុំទៅ ម្តាយខ្ញុំខំស្រែកហៅក៏គាត់អត់ដឹងថាឪពុកទៅណាមកណាដែរ។ ហើយក៏ម្តាយខ្ញុំក៏គាត់នឹកឃើញថា អំមិញឮមាត់ខ្សឹបខ្សៀវនៅក្រោមផ្ទះ មានអ្នកមកហៅ អ៊ីចឹងមានគេហៅទៅណា គាត់ -- អ៊ីចឹងបាត់មួយយប់ទៅ បានចាប់អារម្មណ៍ថាប្រហែលជាគេចាប់បាត់ហើយចាស។"]។ ឯកសារ D315.3.4 អ៊ីង សារ៉ៀន ប្រតិចារ៉ីក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ម៉ោង 10.04.25-10.06.27 [នៅវត្តចំប៉ាលើក ក្នុងស្រុកត្រាំកក់៖ "គ្រូ ប៉េអ៊ីម ប៉ូលិស ទាហាន គយ យកទៅ ថាទៅធ្វើការ បាត់រហូតទល់សព្វថ្ងៃ។"]។ ឯកសារ D5/49/3 តាក សាន់ ប្រតិចារ៉ីក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ម៉ោង 14.16.15-14.18.18 ["[ប្តីខ្ញុំ] ឲ្យគាត់ហ្នឹងទៅដឹកស្រូវពូជហ្នឹង ស្រាប់តែទៅនឹងវាឃើញតែរទេះគោមកវិញ តែបើប្តីខ្ញុំអត់ឃើញ រទេះទៅប៉ុន្ថានហ្នឹង អត់ឃើញមកទាំងអស់គ្នា បាត់ទាំងអស់ រហូតដល់ខ្ញុំបែកហ្នឹង ខ្ញុំរត់មកហ្នឹងបាត់រហូត។"]។ ឯកសារ D315.1.20 ឯក (អ៊ីល) ហ៊ីន ប្រតិចារ៉ីក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 16.00.11-16.01.24 ["ពេលដែលគេចាប់ ដល់បាត់ព្រឹកឡើង ក្នុងក្រុមយើងហ្នឹងបាត់មនុស្ស។"]។ ឯកសារ D315.3.3 សៅ ហ៊ាន ប្រតិចារ៉ីក ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.02.58-14.04.16 ["នឹកឃើញថាបាត់ទៅមិនដែលឃើញមកវិញ នឹកឃើញក្នុងចិត្តថាស្លាប់ហើយ។"]។

[952] *សូមមើលឧទាហរណ៍* ឯកសារ D315.2.6 រ៉ៀល សន ប្រតិចារ៉ីក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.24.50-09.28.50 ["ក្រោយពីបង្កើតសហករណ៍ហ្នឹង ចេះតែបាត់មនុស្សក្នុងភូមិ។"]។ ឯកសារ D315.1.20 ឯក (អ៊ីល) ហ៊ីន ប្រតិចារ៉ីក ថ្ងៃទី៧

292. ដូចបានជម្រាបតាំងពីមុន មានអ្នកទោសនៅក្រាំងតាចាន់តែពីរបីនាក់ប៉ុណ្ណោះ ដែលនៅរស់រានមានជីវិត។ អ្នកទោសខ្លះបានស្លាប់ ដោយសារលទ្ធផលនៃលក្ខខណ្ឌដោយផ្ទាល់ដែលបានដាក់មកលើពួកគេដោយអ្នកចាប់ខ្លួនរបស់កម្ពុជាប្រជាធិបតេយ្យ[953]។ ចំណែកអ្នកផ្សេងទៀតបានស្លាប់ដោយសារលទ្ធផលទទួលរងរបួសដោយផ្ទាល់ដែលបានធ្វើនៅពេលសួរចម្លើយ និងទារុណកម្មដ៏ឃោរឃៅ[954]។មនុស្សរាប់ពាន់នាក់ទៀតបានស្លាប់ក្រោមកណ្តាប់ដៃរបស់មន្ត្រីគុក នៅក្នុងការសម្លាប់ក្រៅប្រព័ន្ធតុលាការ ដែលគេបានគិតទុកជាមុន។

293. ការសម្លាប់នៅក្រាំងតាចាន់ គឺបានធ្វើឡើងក្រោមបញ្ជារបស់ថ្នាក់លើយ៉ាងច្បាស់ក្រឡែត។ បន្ទាប់ពីការសួរចម្លើយ និងធ្វើទារុណកម្មរួច មន្ត្រីគុកបានបញ្ជូនរបាយការណ៍ដែលលម្អិតពីចម្លើយសារភាពរបស់អ្នកទោសទៅស្រុក ជាគណៈកម្មាធិការដែលបានត្រួតពិនិត្យនិងបញ្ជូនបន្តទៅតំបន់[955]។ បន្ទាប់មក មន្ត្រីតំបន់១៣ បានពិនិត្យលើចម្លើយសារភាពទាំងនោះ និងបានសម្រេចថាតើ នរណា

ខែឧសភា ឆ្នាំ២០១៥ ម៉ោង 16.00.11-16.03.30 ["ស៖ តើកត្តានៃការបាត់ខ្លួននេះ វាជាកត្តាមួយដែលនាំឲ្យមានការភ័យខ្លាចដល់ស្មារតីប្រជាជននៅក្នុងស្រុកត្រាំកក់ទាំងមួលដែរទេ ឆ្លងតាមការសង្កេតរបស់លោក? ឆ៖ ប្រជាជនមិនថាមេឃុំ មិនថាចៅហ្វាយស្រុក មិនថាមេភូមិទេ យប់ឡើងខ្សឹងខ្សៀវគ្នាថាខ្លាចត្រជាក់ខ្លួនអស់ហើយ។ [...] យើងភ័យខ្លាចទាំងអស់គ្នា ត្រជាក់ខ្លួនទាំងអស់គ្នា គេចាប់នោះចាប់ពេកទៅ។"]។ ឯកសារ D315.2.3 អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ម៉ោង 14.13.51-14.16.19 ["មិនមែនមានតែ [បងស្រីផ្ទៃរបស់ខ្ញុំនោះទេដែលបាត់ខ្លួននោះ]។ មានស្ត្រីៗមួយគំនរទៀត ដែលមានប្តីជានាយទាហានជាគ្រូបង្រៀនជាអី គេយកទៅបាត់អ៊ីចឹងហើយ ហើយគេប្រមូលផ្តុំនារីៗអស់ហ្នឹង គេដាក់ថា "កងមេមាយ"។ ខ្ញុំគ្រាន់តែឮថាពាក្យ "កងមេមាយ" គឺមានន័យថាប្តី -- អត់ប្តីហើយ មេម៉ាយហ្នឹង។ គេដាក់ឈ្មោះ "កងមេម៉ាយ" អ៊ីចឹងហ្មង។ អ៊ីចឹងបានខ្ញុំសន្ទតថា ទៅហើយអត់ត្រឡប់មកវិញទេ។"]។ ឯកសារ D315.2.4 ឯម ហ៊ីង ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.44.50-10.46.27 [ពេលកំពុងធ្វើការនៅស្រុកត្រាំកក៖ "ពរ ចម្រើនពរ ឃើញបាត់អ៊ីចឹងដែរ។ ប៉ុន្តែសួរគ្នីគ្នាថា មនដឹងទៅណាថា គេថា "អង្គការគេហៅទៅរៀនសូត្របាត់ហើយ មិនដឹងទេ"។ សួរគ្នីគ្នាទៅ គេឆ្លើយតែប៉ុណ្ណឹងចប់តែម្តង។"]។ ឯកសារ D315.1.17 នុត ន្ទូរ ប្រតិចារឹក ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ ម៉ោង 13.38.35-13.39.47។ ឯកសារ D315.2.5 ភ្ជាំ យ៉ាវ ប្រតិចារឹក ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.10.01។ ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ឆ.៤២ KH 00960587 ["មានការបាត់មនុស្សរាល់ថ្ងៃ"]។ ឯកសារ D6.1.782 កំណត់ហេតុស្តាប់ចម្លើយ អៀប ឌុច KH 00163493 ["បើប្រវត្តិរូបនិយាយថាជាទាហានអ្នកនោះឯងត្រូវបាត់ខ្លួន។"] KH 00163497 ["ខ្ញុំធ្វើការភូមិ ហើយភូមិណាក៏មានរាយការណ៍ថាមានបាត់ខ្លួនដែរ។"]។ ឯកសារ D6.1.686 កំណត់ហេតុស្តាប់ចម្លើយ សៅ ប៊ាន ឆ.២២ KH 00408316។

[953] *សូមមើល* V.ក.១.ង.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់ ១៣ – មន្ទីរសន្តិសុខក្រាំងតាចាន់ – ឧក្រិដ្ឋកម្ម – អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។

[954] *សូមមើល* V.ក.១.ង.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់ ១៣ – មន្ទីរសន្តិសុខក្រាំងតាចាន់ – ឧក្រិដ្ឋកម្ម – ការធ្វើទារុណកម្មជាពិសេស ជើងទំព័រ ៩៤៤។

[955] *សូមមើល* កថាខណ្ឌ ២៨៧។

ដែលនឹងត្រូវ“បោសសម្អាត” ឬ “កម្ទេច” ហើយចម្លើយសារភាពរបស់ពួកគេក៏ត្រូវបានគេធ្វើកំណត់សម្គាល់ទៅតាមនោះ[956]។ អតីតលេខាស្រុកត្រាំកក់ នាង អ៊ីច ហៅ តាសាន បានផ្តល់សក្ខីកម្មថា បទបញ្ជាសម្លាប់ណាក៏ដោយ ត្រូវតែអនុម័តដោយភូមិភាគ[957]។ ពេលបានអនុម័តរួច បទបញ្ជាសម្លាប់ទាំងនោះត្រូវបានបញ្ជូនត្រឡប់ទៅស្រុក១០៥ វិញ ដែលមាននីរសារម្នាក់ជាអ្នកនាំបទបញ្ជានោះទៅឲ្យប្រធានគុកក្រាំងតាចាន់ ហើយបទបញ្ជានោះក៏ត្រូវបានអនុវត្តយ៉ាងឆាប់រហ័ស[958]។

---

[956] *សូមមើល* ឧទាហរណ៍ ឯកសារ D6.1.1200 សេចក្តីរាយការណ៍ពី អាន់ នៅមន្ទីរសន្តិសុខស្រុកក្រាំងតាចាន់ ជូនបក្ស កក្កដា-សីហា ១៩៧៧ KH 00082724 [ចំណារដោយដៃដែល ប្រាក់ នៃ ត.១៣(តំបន់១៣) ណែនាំ អាន់ ឲ្យ៖“សំរេចកំទេសចុះ” ថ្ងៃទី ៧/៨/៧៧។ ត.១៣។ ប្រាក់”] KH 00082725 [“សំរេចកំទេសចុះ” នៅថ្ងៃទី៧/៨/៧៧។ ត.១៣។ ប្រាក់”។ ឯកសារ D219/702.1.99 ពេជ្រ ជ័ម ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ម៉ោង 14.13.47-14.19.10 [“[សោម ជាប្រធានតំបន់] គ្រាន់តែគ្ងសទេ [ឈ្មោះលើរបាយការណ៍ចម្លើយសារភាព] អត់មានថាម៉េចៗទេ ហើយក៏បញ្ជូនឡើងទៅ ខុម។ ខុម ឃើញហើយ បន្តទៅទៀតទៅកាន់ អាន់ ទៅ។[...] រឿងនេះវាជារឿងដល់កន្លែងអ្នកទោសហ្នឹងហើយ តំបន់គ្រប់គ្រង ជារបស់តំបន់ហើយ”]។ ឯកសារ D219/702.1.103 ពេជ្រ ជ័ម ប្រតិចារឹក ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ម៉ោង 11.21.05-11.23.00 [“ស៖ ខ្ញុំសួរថា តើឈ្មោះមនុស្សដែលត្រូវគេបោសសម្អាតហ្នឹងគឺ ត្រូវគ្ងសខ្ញែងដោយបិ្ចតក្រហមមែនឬដែរទេ? ឆ៖ ទេ ព្រោះក្នុងហ្នឹងគេដាក់ចម្លើយនៅនឹងអស់ហើយៗយើងខាងលើ សម្រេចយ៉ាងម៉េចគេដោះស្រាយតាមហ្នឹង នៅខាងមន្ទីរ”]។ ឯកសារ D6.1.653 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ័ម KH 00373475-76។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165332។ សូម*កត់សំគាល់ថា* ជូនកាលបញ្ជាឲ្យកំទេចត្រូវបានប្រគល់ដោយលេខាស្រុក៖ ឯកសារ D6.1.1200 បញ្ជារបស់កម្ពុជាប្រជាធិប តេយ្យពី គិត ទៅ អាន់ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៧៧ KH 00082727 [សេចក្តីណែនាំពីលេខាស្រុក គិត ទៅប្រធានមន្ទីរសន្តិសុខ ក្រាំងតាចាន់ ឲ្យសួរចម្លើយអ្នកទោសពីឃុំជាងទង ផ្ទុតខ្ញែងឲ្យអស់, រួចហើយកំទេចចុះ]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.04.51-10.07.14 [រៀបរាប់ថា កាលណាសំបុត្រពីស្រុក នាំយកទៅឲ្យមេដឹកនាំណាម្នាក់នៃគណៈកម្មាធិការគុកក្រាំងតាចាន់ ទោះបីគាត់មិនចេះអក្សរក៏ដោយ គាត់ដឹងថាដាក់បិ្ចតក្រហម មានន័យថាអ្នកទោសត្រូវកំទេស]។

[957] ឯកសារ D315.1.14 នាង អ៊ីច ប្រតិចារឹក ថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.10.50-09.13.01 [“ដូច្នេះ ន័យថាបោសសម្អាតហ្នឹងគឺសម្លាប់។ [...] ខ្ញុំសូមបញ្ជាក់ថា ការសម្រេចទាំងអស់នេះគឺនៅលើ តារ៉ន ដែលជាតំបន់ ជាប្រធានតំបន់១៣ ដែលចុះក្បាប់ស្រុកត្រាំកក់ផ្ទាល់តែម្តង។ ស៖ តើនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ គោលនយោបាយបញ្ជាឲ្យប្រហារជីវិត ត្រូវមានការយល់ព្រមដោយថ្នាក់តំបន់មែនទេ? ឆ៖ ថ្នាក់តំបន់ស្នើទៅថ្នាក់ភាគទៀត។ [...] ។ ហើយមានការសម្រេចពីថ្នាក់ភាគ និងថ្នាក់តំបន់មក បានខាងខ្ញុំជាជំនួយការស្រុកនេះ គឺក៏សរសេរតាមការសម្រេចរបស់គាត់នេះ”]។

[958] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.07.09-14.08.54 [“មុនធ្លឹងសម្លាប់ [តា អាន់] មាននីរសាគាត់ពីរនាក់។ គាត់ធ្វើឯកសារហ្នឹងហើយ ខ្ញុំឃើញ ចុះខ្ញុំនៅផ្ទះ នៅមើលគោនៅនឹងផ្ទះ នៅរោងគោនៅផ្ទះច្រកចេញ។ កាលណានីរសាគាត់ជិះសេះទៅកន្លែងសាលា -- ទៅមន្ទីរស្រុកអ៊ីចឹងទៅ ទៅមួយសន្ទុះថ្ងៃល្ងាចមកដល់វិញឃើញបានស្រោមសំបុត្រមកវិញ ទៅបានសំបុត្រមកវិញមួយ។ ស្អែកឡើងជួនកាលមានកម្មវិធីអ៊ីផ្សេងៗក៏មានដែរ”]។ ឯកសារ

294. អ្នកទោសដែលត្រូវបានជ្រើសរើសយកទៅសម្លាប់ ត្រូវបានគេប្រាប់ថា គេយកពួកគេត្រឡប់ទៅសហករណ៍របស់ពួកគេវិញ[959]។ ផ្ទុយទៅវិញ ពួកគេត្រូវបានបណ្តើរ(ឬដាក់រទេះរុញ)ទៅកាន់កន្លែងសម្លាប់ បញ្ជាឲ្យលត់ជង្គង់ ហើយក៏បានវ៉ៃក្បាលពួកគេនឹងតួងចប ឬវត្ថុដទៃទៀត មុននឹង

D315.1.10 វ៉ាន់ សឿន ប្រតិចារឹក ថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.45.12-09.46.27 [បញ្ជាក់ថា រាល់ពេលដែលសារត្រូវបានប្រគល់ពីស្រុក ១០៥ ជូនទៅក្រាំងតាចាន់ ការសម្លាប់ក៏កើតមាននៅពេលបន្ទាប់]។ ឯកសារ D118/167 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ សឿន ឆ.៥៤-៥៥ KH 00968177។ ឯកសារ D219/702.1.99 ពេជ្រ ជ័ម ប្រតិចារឹក ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៥ ម៉ោង 14.13.47-14.17.48 ["[សោម ជាប្រធានតំបន់] គ្រាន់តែគ្ងសទេ [ឈ្មោះលើរបាយការណ៍ចម្លើយសារភាព] អត់មានថាម៉ែចៗទេ ហើយក៏បញ្ជូនឡើងទៅ[លេខាស្រុក] ខុម។ ខុម ឃើញហើយបន្តទៅទៀតទៅកាន់ អាន់ ទៅ។ ឯកសារ D6.1.653 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ័ម KH 00373475 ["ចម្លើយសារភាព និងរបាយការណ៍ [...] ត្រូវឆ្លងកាត់ស្រុកជាមុនសិន។ រួចស្រុកផ្ញើទៅតំបន់ [...]។ មួយថ្ងៃឬពីរថ្ងៃក្រោយមកទើបឃើញតំបន់ ផ្ញើសេចក្តីសម្រេច[សរសេរ]នៅក្នុងចម្លើយសារភាពនោះ ត្រឡប់មកស្រុកវិញ"]។ ឯកសារ D6.1.650 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ័ម KH 00373458។ ឯកសារ D118/166 កំណត់ហេតុស្តាប់ចម្លើយ ទ័ម ហ៊ី KH 00968159។ ឯកសារ D6.1.695 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេង ឆ.១៨, ២០-២៣ KH 00414444-45។

[959] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.52.33-13.54.10 ["មុននឹងយកមនុស្សទៅសម្លាប់ គឺទៅដល់គេបើកទ្វារ បើកទ្វារគុកហ្នឹង គេប្រាប់ថា ឥឡូវបើកទ្វារគុកហ្នឹង គេប្រាប់ថាបងប្អូនទាំងអស់បានរួចទៅតាមសហករណ៍វិញហើយ បើអ៊ីចឹងយើងត្រូវ និងគោរពនឹងផែនការនឹងអង្គការ ប៉ុន្តែមិនបានទៅអស់គ្នាទេ បានទៅមួយចំនួន"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 13.48.08-13.49.24 ["តែដល់ពេលក្រោយតែចាក់មេក្រូ ឮគេថាឲ្យអ្នកទោសហ្នឹងវិលត្រឡប់ទៅផ្ទះវិញ ព្រោះអ៊ីនៅកែខ្លួន កែប្រែខ្លួនបានហើយ"] 10.50.27-10.53.10 ["គេឲ្យទៅផ្ទះ ខ្ញុំស្មានតែទៅផ្ទះ។ [...] ដល់ពេលគេយកមនុស្សទៅបាត់អស់ អ៊ីផុន ដែលក្តិចមួលៗខ្ញុំហ្នឹង គាត់ប្រាប់ថា អ៊ីរុនឯងអត់ដឹងទេ គេឲ្យទៅផ្ទះហ្នឹង គេយកទៅវ៉ៃចោលណា"]។ ឯកសារ D6.1.119 កំណត់ហេតុស្តាប់ចម្លើយ សយ សែន KH 00223060, 65។

អារកពួកគេ[960]។ អតីតអ្នកទោស រ៉ង សារុន បានផ្តល់សក្ខីកម្មថា នាងបានឃើញគេសំលៀងកាំបិតយក មនុស្សទៅសម្លាប់ និងពួកពេជ្ឈឃាតត្រឡប់មកវិញដែលប្រឡាក់ដោយឈាម[961]។

295. កូនក្មេងជាញឹកញាប់ត្រូវបានគេសម្លាប់ជាមួយឪពុកម្តាយរបស់ពួកគេ[962]។ ជាតួយ៉ាង កូនង៉ែត និងកូនក្មេងត្រូវគេចាប់ព្យួរជើងឡើងលើ និងបោកទៅនឹងគល់ឈើដើម្បីបំបែកលលាដ៍ក្បាល រួចហើយ

---

[960] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.55.14 ["គេឲ្យអង្គុយ គាត់រ៉ែនឹងតួងចបៗពីក្រោយ គាត់ធាក់ប្រមៀល។ ធាក់ប្រមៀលហើយ [...] គេយកដាវមួយ ដាវវែងៗ ផ្តែប្រហែលជាអាចជាបួន និងប្រាំតឹកផ្តែដាវហ្នឹង។ រ៉ែពីក្រោយហើយ យកដាវកាត់បំពង់កនេះ។ កាត់បំពង់កហើយ អ្ងសទម្លាក់រណ្តៅហើយ ស្រាតខោអាវចេញទាំងអស់ ខោអាវមិនថាស្រីមិនថាប្រុស ស្រាតទុកគរមួយកន្លែងៗហ្នឹង"]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.17.21-11.20.06 ["វិធីសម្លាប់មនុស្ស គេភាគច្រើន គេអារក គេអត់មានរ៉ែនឹងគល់ឫស្សី ឬរ៉ែនឹងតួងចបអីទេ ព្រោះរ៉ែនឹងគល់ឫស្សី វាយូរណាស់។ គេប្រើវិធីអារកហ្នឹងតែម្តង។ ពីរនាក់អ្នកតោង ម្នាក់អ្នកអារ"]។ ឯកសារ D364/2.1.5 ស្ងួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង 14.02.55-14.07.36 ["ទីតាំងសម្លាប់មនុស្ស គឺនៅខាងតួងកន្លែងសួរចម្លើយ។ [...] មនុស្ស គេសម្លាប់ដោយនឹងតួងចប ឬនឹងគល់ឫស្សី។ [...] ថ្ងៃណាដែលខ្ញុំទៅឃើញ គឺខ្ញុំលួចមើលទៅ អាហ្នឹងឃើញបាន"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 10.50.27-10.53.10 ["អ្នកដែលៗនៅយូរ គេក្រយកទៅសម្លាប់ ស្ពមដើរអត់រួច គេដាក់រទេះរុញ ពេលដែលយកទៅសម្លាប់ហ្នឹង"] 14.33.38-14.36.24 ["ចំពោះអ្នកដើរអត់រួច គេយករទេះរុញហ្នឹងហ្ស"]។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163506។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165334។ ឯកសារ D118/167 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ សឿន ឆ.១៧៧ KH 00968190។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យ៉ិន គេង ឆ.២៥៥, ៣៨១ KH 01052718, 21។

[961] ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 11.10.00-11.13.44, 13.43.41-13.45.50, 15.03.28-15.06.20។

[962] D315.2.3 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.33.40-10.36.49 ["គេសម្លាប់ម្តាយហើយ គឺសម្លាប់កូនហើយ"]។ ឯកសារ D364/2.1.5 ស្ងួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ម៉ោង14.07.36-14.10.08។

បោះចូលក្នុងរណ្តៅ[963]។ នៅពេលសវនាការ អ្នកទោសនៅរស់រានមានជីវិតឈ្មោះ សយ សែន បានរំឭកពីសំឡេងដែលគាត់បានឮគេបោកកូនក្មេងឮសូរ"ភ្ងសៗ"នឹងគល់ត្នោត[964]។

296. គេចាក់ចម្រៀងឮខ្លាំងៗ ឬពុះឧស កុំឲ្យឮសូរសម្រែករបស់អ្នកដែលគេសម្លាប់ ត្រូវបានគេធ្វើឡើង[965]។ អ្នកទោសត្រូវបានគេបង្ខំឲ្យជីករណ្តៅ និងអូសសាកសពទម្លាក់ទៅក្នុងរណ្តៅទាំងនោះនៅក្រោយការសម្លាប់[966]។ អ្នកទោសខ្លះទៀតត្រូវបានបង្ខំឲ្យជីករណ្តៅសម្រាប់កប់ខ្លួនឯងផ្ទាល់

---

[963] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.21.34-11.24.11។ ឯកសារ D315.1.6 ស្រី ថន ប្រតិចារឹក ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.16.04-11.17.33។ ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163506។ ឯកសារ D6.1.119 កំណត់ហេតុស្តាប់ចម្លើយ សយ សែន KH 00223067។ ឯកសារ D6.1.785 កំណត់ហេតុស្តាប់ចម្លើយ សុក សុត KH 00163524។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.១៥៥ KH 01052707។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.៥១ KH 01000025។ ឯកសារ D134/8 កំណត់ហេតុស្តាប់ចម្លើយ សូត្រ សាំង ឆ.៩០ KH 00964488។

[964] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.35.47-13.37.33។

[965] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.20.50-10.23.47 ["ហើយមុននឹងសម្លាប់គេនឹងបានចាក់មេក្រូឡើងកងរំពងយ៉ាងទ្រហឹងអឹងកង ពុំឲ្យអ្នកណាស្តាប់ឮបន្តិចសោះ។ គេវាយនឹងស្គរ គោះជញ្ជាំង គោះប៉ោតទ្វងទាំង បន្ទាប់កុំឲ្យមនុស្សឮ"]។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.54.10-13.55.14 ["ចាក់កូនមីក្រូមួយ ហើយពុះឧសនៅជិតៗ កុំឲ្យឮសូរស្នូរអានោះមកដល់។ ហើយមីក្រូចាក់បទចម្រៀងសម័យ ប៉ុលពត ហ្ម៉ង ហើយទៅដល់នោះមួយសន្ទុះ បកមកយកវិញៗ"]។ ឯកសារ D219/899.1.3 រ៉ង សារុន ប្រតិចារឹក ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 13.48.08-13.49.24 ["ដល់ពេលបន្តិចទៀត ខ្ញុំដឹងអីចឹងមែន។ ពេលគេយកមនុស្សទៅវ៉ៃចោល គឺគេចាក់មីក្រូ។ និយាយរួមចាក់ឲ្យថ្ពង់ កុំឲ្យឮ យើងអ្នកនៅខាងក្នុងហ្ម៉ង ឮគេស្រែក ឬគេអីចឹងទៅ"]។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165334។ ឯកសារ D6.1.781 កំណត់ហេតុស្តាប់ចម្លើយ ថោង ស៊ាវ KH 00163485។ ឯកសារ D6.1.787 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ខាន់ KH 00163537។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.៣៦ KH 01052695 ឆ.១៦៨ KH 01052709។ ឯកសារ D219/522 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង ឆ.៥៩-៦០ KH 01149850។

[966] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.57.04-13.58.37 ["បើជីកខ្លាំង ហ្វ៊ីកហ្ម៉ីនខ្លាំង ដែលអាចឲ្យខ្ញុំទៅជួយកប់សពហ្ម៉ង ទុកដាក់ខ្ទោចមែនទ័ទតែម្តង ឆ្នាំ៧៧"] ម៉ោង 11.19.27-11.21.08 [សាក្សីបានជីករណ្តៅសម្រាប់កប់សាកសព និងសែងអ្នកទោសដែលស្លាប់នៅក្នុងខ្ទោះជើង យកទៅកប់"]។ ឯកសារ D315.1.3 សយ សែន ប្រតិចារឹក ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ម៉ោង 15.21.30-15.24.21 ["ខ្ញុំពីរនាក់តាមិន ហើយនឹង អាខា មួយទៀត។ បីនាក់ជីករណ្តៅ [...] ប្រហែលជាអាចជាបួនដាប់ម្ភៃរណ្តៅប៉ុណ្ណឹងទេ"]។ ឯកសារ D315.2.3 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.03.28-11.05.37 ["[សាកសព]ក្នុងរណ្តៅនេះ អ្ហែងទៅកប់ផង"]។ ឯកសារ D6.1.788 កំណត់ហេតុស្តាប់ចម្លើយ នាង ដាំ KH 00163547។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165335។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.១៥៩ KH 01052708។

នៅមុនពេលពួកគេត្រូវបានសម្លាប់[967]។ សាកសពគ្រប់វ័យត្រូវបានគេដាក់តម្រៀបពីលើគ្នា[968]។ មានករណីខ្លះ ពួកពេជ្ឈឃាតបានវះយកសរីរាង្គ ដូចជា ថ្លើមនិងប្រមាត់ ដើម្បីហូប[969]។ មន្ត្រីក្រាំងតាចាន់បានរាយការណ៍អំពីចំនួនអ្នកស្លាប់ទៅមន្ទីរស្រុក[970]។

297. គ្មាននរណាដឹងចំនួនអ្នកទោសពិតប្រាកដដែលបានស្លាប់នៅក្រាំងតាចាន់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យទេ ដោយសារកត្តាខុសគ្នាមួយចំនួន។ ទីមួយ គុកត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧២ ឬ ១៩៧៣[971] ហើយសំណល់រូបវន្តខ្លះដែលបានរកឃើញពីទីតាំងនេះ អាចទំនងជានឹងផ្តល់ដល់ការសន្ធតចំពោះការសម្លាប់ដែលបានកើតឡើង នៅមុនយុត្តាធិការពេលវេលារបស់តុលាការនេះ។ ទីពីរ សំណល់សាកសពជាច្រើន ជាពិសេសលលាដ៍ក្បាល ត្រូវបានគាស់កកាយយកដោយគ្រួសារដែលសង្ឃឹមថា នឹងរក្សាទុកជាការចងចាំជានិមិត្តរូបខ្លះៗ ចំពោះការបាត់បង់មនុស្សជាទីស្រឡាញ់របស់

---

[967] ឯកសារ D6.1.781 កំណត់ហេតុស្តាប់ចម្លើយ ថោង ស៊ាវ KH 00163486 [“គេឲ្យអ្នកត្រូវគេសម្លាប់នោះ កាប់រណ្តៅដោយខ្លួនឯង រួចហើយគេយកមនុស្សនេះវាយនឹងតួងចប និងគល់ឫស្សី”]។

[968] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.37.33-13.38.46 [“មនុស្សចាស់ គេច្រើនតែវ៉ៃផ្ទងពីក្រោយផ្ទារ កាលណាធាក់ផ្ទារអ៊ីចឹង គេយកដាវចាក់ផ្តាច់បំពង់ក។ ហើយដល់លើកនេះ អត់មានផ្តាច់ ក្មេងហ្នឹងអត់មានផ្តាច់បំពង់កទេ វ៉ៃផ្ទងអ៊ីចឹង គេអូសដាក់រណ្តៅ”] ម៉ោង 13.55.14-13.57.04 [“ហើយអូសទម្លាក់រណ្តៅ ហើយស្រាតខោអាវចេញទាំងអស់ ខោអាវមិនថាស្រីមិនថាប្រុស ស្រាតទុកគរមួយកន្លែងៗហ្នឹង”]។

[969] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.35.47-13.37.33 [“គល់ត្នោតអ៊ីចឹង ខ្ញុំងាកមើលក្រោម ចុម! បោកក្មេង។ ដល់ក្មេងអ៊ីចឹងវា ពាក់អាក្មេងព្ជរជើងឡើងលើអ៊ីចឹង វាវះយកយកប្រមាត់”]។ ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.56.11-11.59.04 [“គេយកមកហាលប្រមាត់ហ្នឹង ជាច្រើនអ៊ីចឹង [...] ហើយថ្ងៃមួយឃើញគេដាក់ស្រាផឹកគ្នាគេប៉ុន្ឌានៅនាក់ហ្នឹង មេៗហ្នឹង។ [...] តែពេលសម្លាប់មនុស្សបានគេផឹក [ស្រាដាក់ប្រមាត់]”] ម៉ោង 12.02.45-12.04.31 [“ប្រមាត់មនុស្ស ខ្ញុំដើរទៅឃ្វាលគោ គេហាលលាក់នៅកៀនរបង ខ្ញុំឃើញគេដោត ព្ជរ។ ខ្ញុំដឹងថាប្រមាត់មនុស្សហ្នឹង អត់មានក្រៅជាប្រមាត់សត្វទេ។ ទៅរកប្រមាត់សត្វឯណាមក អត់មាន ប្រមាត់គោ ប្រមាត់ក្របីទេ ព្រោះប្រមាត់ច្រើន”]។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ីក ហ៊ីម ឆ.៥១ KH 01000025។

[970] ឯកសារ D6.1.1222 សេចក្តីរាយការណ៍ជូនបក្ស ក្នុងរយៈខែ៧. ៧៧ KH 00068017 [សេចក្តីរាយការណ៍នេះបង្ហាញឃើញថា ព័ត៌មានស្រដៀងគ្នានេះត្រូវបានគេបញ្ជូនទៅមេដឹកនាំបក្សជាប្រចាំខែពីក្រាំងតាចាន់ រួមទាំងចំនួនអ្នកទោសដែលបានចូលគុកនេះ នៅក្នុងរយៈពេលនៃខែនោះ ចំនួនអ្នកទោសសរុប ចំនួនអ្នកស្លាប់ដោយជំងឺ ចំនួនអ្នកទោសដែលត្រូវបានសម្លាប់ និងចំនួនអ្នកទោសដែលនៅសល់។ សម្រាប់ខែដែលគេបានរាយការណ៍ ចំនួនទាំងនោះមាន ១៨, ៨១, ២, ៣៩ និង ៤០ រៀងគ្នានិមួយៗ]។ *សូមមើលផងដែរ* ឯកសារ D6.1.1220 សេចក្តីរាយការណ៍ជូនបក្សពី អាន់ នៅមន្ទីរអប់រំ ១០៥ KH 00068049 [សំណេរដោយដៃកត់សំគាល់ថា “ចាប់ពីថ្ងៃយើងកំទេសពួកអាខ្មាំងមកទល់សព្វថ្ងៃនេះ អស់ចំនួន ១៥,០០០នាក់។ សូមបក្សជ្រាប”។ ចុះហត្ថលេខាដោយ អាន់]។

[971] *សូមមើល* ភ័ស្តុតាងដែលបានយោងនៅក្នុងកំណត់សំគាល់ជើងទំព័រ ៨៧៣។

ពួកគេ[972]។ សំណល់ខ្លះទៀត ត្រូវបានសត្វកកាយ ឬ ត្រូវពុកផុយដោយសារពេលវេលាជាច្រើនទសវត្សរ៍ និងកង្វះការអភិរក្សឲ្យបានត្រឹមត្រូវ[973]។ ជាចុងក្រោយ ខណៈដែលយើងមានបញ្ជី និងរបាយការណ៍អ្នកទោសដែលនៅរស់រានមានជីវិតទាក់ទងនឹងសកម្មភាពនៅក្រាំងតាចាន់ក៏ដោយ ក៏គ្មានមធ្យោបាយណាមួយដែលគេអាចកំណត់បានថាតើមានកំណត់ត្រាដៃទៀតចំនួនប៉ុន្មានត្រូវបានគេរកឃើញនោះដែរ។ យ៉ាងណាមិញ ដូចបានពិភាក្សាខាងក្រោម មានភ័ស្តុតាងយ៉ាងសន្ធឹកសន្ធាប់ដែលមិនបន្សល់ទុកនូវមន្ទិលអ្វីទាំងអស់ដែលថា មានអ្នកទោសរាប់ពាន់នាក់បានស្លាប់នៅក្រាំងតាចាន់ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។

298. មនុស្សតែមួយក្តាប់តូចប៉ុណ្ណោះដែលបានជាប់គុកនៅក្រាំងតាចាន់ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនៅរស់រានមានជីវិត[974]។ ពួកគេ និងអតីតឆ្មាំគុកនេះ បានផ្តល់ភ័ស្តុតាងផ្ទាល់ភ្នែកយ៉ាងទូលំទូលាយអំពីការស្លាប់របស់អ្នកទោសផ្សេងទៀត ដោយសារលក្ខខណ្ឌអមនុស្សធម៌ និងការសម្លាប់ជាប្រចាំនៅមន្ទីរសន្តិសុខនេះ[975]។ សាក្សីជាច្រើនបានផ្តល់ភ័ស្តុតាងបន្ថែមទម្ងន់ថា ការសម្លាប់បានកើតឡើង

---

[972] ឯកសារ D219/702.1.10 កែវ ច័ន្ទតារា ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.13.50-14.15.44, 15.12.03-15.17.45។ ឯកសារ D6.1.472 របាយការណ៍ស្តីពីគម្រោងផែនទីរបស់ DC-Cam KH 01169219។

[973] ឯកសារ D219/702.1.10 កែវ ច័ន្ទតារា ប្រតិចារឹក ថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.07.13-14.12.35។ ឯកសារ D6.1.472 របាយការណ៍ស្តីពីគម្រោងផែនទីរបស់ DC-Cam KH 01169219។

[974] តុលាការនេះបានទទួលភ័ស្តុតាងពីអ្នកនៅរស់រានមានជីវិត មាស សុខា, សយ សែន, រង សារុន, កែវ ច័ន្ទតារា, ហ៊ុន គឹមសេង ហៅ យាយ ញ៉ូ, លឹម ហាច, នាង ដាំ, អ៊ុក ហ៊ីម និង កែវ ម៉ៅ។ *សូមមើលផងដែរ* ឯកសារ D219/899.1.3 រង សារុន ប្រតិចារឹក ថ្ងៃទី៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 14.19.43-14.21.07 [និយាយថា យាយញ៉ូ[ហ៊ុន គឹមសេង] ក្រុមគ្រួសារយាយញ៉ូ គេឲ្យត្រឡប់ទៅផ្ទះវិញ។ នៅខ្ញុំ នៅតាដាំ[នាង ដាំ] នៅសែន[សយ សែន] នៅអ៊ីហាន] ម៉ោង 15.14.21-15.16.22 [ហាន និងអ្នកផ្សេងទៀតបានរត់គេចខ្លួនមុន រង សារុន ត្រូវបានដោះលែង]។ ឯកសារ D315.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.39.39-09.41.26 ["គាត់ស្លាប់អស់ហើយ នៅសល់តែខ្ញុំហើយនឹងយាយញ៉ូ ហើយគ្រួសារកូនចៅយាយញ៉ូ តែប៉ុណ្ណឹង"]។ ឯកសារ D134/8 កំណត់ហេតុស្លាប់ចម្លើយ សូត្រ សាំង ឆ.១១៩ KH 00964491។ ឯកសារ D6.1.1000 កំណត់ហេតុស្លាប់ចម្លើយ វ៉ាន់ សឿន ឆ.១១៩ KH 00165358 ["[អ្នកទោស]ប្រុសៗវិញ ភាគច្រើនត្រូវឈឺស្លាប់ ឬ ត្រូវគេសម្លាប់។ រីឯប្រុសៗវិញរួចខ្លួនតិចណាស់"]។

[975] *សូមមើល* V.ក.១.ង.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់ ១៣ – មន្ទីរសន្តិសុខក្រាំងតាចាន់ – ឧក្រិដ្ឋកម្ម – អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។ V.ក.១.ង.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់ ១៣ – មន្ទីរសន្តិសុខក្រាំងតាចាន់ – ឧក្រិដ្ឋកម្ម – ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)។

យ៉ាងទៀងទាត់[976] ហើយ មាស សុខា ដែលធ្លាប់ជាប់ឃុំនៅក្រាំងតាចាន់ អស់រយៈជិតបីឆ្នាំ បានឃើញការសម្លាប់អ្នកទោស២០នាក់ ឬច្រើនជាងនេះជាប្រចាំ[977]។

299. មាស សុខា និង សយ សែន ទាំងពីរនាក់សុទ្ធតែបានផ្តល់សក្ខីកម្មអំពីកាលៈទេសៈមួយនៅពេលដែលមនុស្សជាង ១០០នាក់ មកពីឃុំស្រែរនោង និងញ្ជ្រៀងញ្ជ្រង បានមកដល់គុក ហើយត្រូវបានគេសម្លាប់ដោយគ្មានការសួរចម្លើយ ដោយសារគុកពេញ[978]។ យិន គេង ដែលបានរស់នៅជិតមន្ទីរសន្តិសុខនេះ បានរំឭកពីឧប្បត្តិហេតុមួយដែលខ្ទេរក្រោមចំនួនពីរក្រុម សរុប ១២៧នាក់ ទាំងចាស់ទាំងក្មេងបានមកដល់គុកនេះ "ដើម្បីរៀនសូត្រ" ហើយត្រូវបានគេទុកតែពីរថ្ងៃ ក៏ត្រូវបានសម្លាប់ចោលតែម្តង[979]។

---

[976] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.13.35-11.14.54 ["ស៖ [...] តើលោកអាចប្រាប់តុលាការបានទេ លោកបានឃើញប៉ុន្មានដង ដែលគេយកអ្នកទោសយកទៅដាក់នៅរណ្តៅនៅខាងក្រៅបរិវេណគុកនោះ? ឆ៖ [...] ខ្ញុំ បើនិយាយរួមទៅ វាឃើញ បើត្រួតពិនិត្យទៅ ឃើញសឹងរាល់ថ្ងៃ ប៉ុន្តែគេសម្លាប់វារំលងតែ មួយសប្តាហ៍គេសម្លាប់តែម្តងៗ"]។ *សូមមើលផងដែរ* ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.00.40-14.02.34 ["វាច្រើនដោយថ្ងៃ ដោយខ្ញុំមិនមែនថាច្រើនរាល់ថ្ងៃ អត់ទេ ក៏រៃចោលរាល់ថ្ងៃ ក៏អត់ដែរ"]។ ឯកសារ D6.1.785 កំណត់ហេតុស្តាប់ចម្លើយ សុក សុត KH 00163524 ["បាទ ច្រើនស្ទើរតែរាល់ថ្ងៃ ឲ្យតែមានចូល ស្អែកឡើងវាយចោលម្តងៗច្រើន"]។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន គេង ឆ.៣៨៥ KH 01052731។

[977] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.17.21-11.20.06 ["ស៖ នៅពេលដែលលោកបានឃើញគេសម្លាប់អ្នកទោសនោះ តើលោកអាចប្រាប់ខ្ញុំបានទេ តើគេ នៅក្នុងឱកាសម្តងៗដែលលោកបានឃើញហ្ន៎ង តើគេសម្លាប់អ្នកទោសប៉ុន្មាននាក់? ឆ៖ [អ្នកទោស] វាអត់ទៀង ជួនណា៥០នាក់ ជួនណា១០០នាក់ ជួនណា៧០នាក់ ជួនណា៨០នាក់ ជួនណា៦០នាក់ ជួនណា២០នាក់ តិចបំផុតក្នុងមួយថ្ងៃ"]។ ឯកសារ D315.2.3 មាស សុខា ប្រតិចារឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.51.26 ["ម៉ោងបីរសៀលគេចាប់ជញ្ជូនមនុស្សចេញពីក្នុងបរិវេណរបងទី១ ទៅឲ្យអ្នកឆ្នាំយាតកម្មបន្តម្តងបីម្តងបួន ម្តងពីរ ម្តងប្រាំនាក់អ៊ីចឹងទៅ។ ហើយមួយគន្លាក់ គេជញ្ជូនម្តងទៀត។ ជញ្ជូនទាល់តែអស់គ្នា១០០ជាងនាក់[ទៅរណ្តៅនោះ"]។ ឯកសារ D6.1.997 កំណត់ហេតុស្តាប់ចម្លើយ សាំង ស៊ីម KH 00165334។ ឯកសារ D219/522 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង ឆ.៣៧ KH 01149848។

[978] ឯកសារ D315.2.2 មាស សុខា ប្រតិចារឹក ថ្ងៃទី២១ ខែមករា ឆ្នាំ២០១៥ ម៉ោង 10.20.50-10.23.47, 12.00.10-12.02.45។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.44.48-09.49.36។ *សូមមើលផងដែរ* ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163505 ["ពេល[គុក]ពេញ គេយកវាយចោលម្តង"]។ ឯកសារ D6.1.709 កំណត់ហេតុស្តាប់ចម្លើយ ស្រី ថន ឆ.៦៩ KH 00427979។

[979] ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន គេង ឆ.១២៩, ១៤១-១៤៣, ១៤៧-១៥៦ KH 01052705, 06, 07-08 ។

300. អ្នកទោសពីរនាក់ដែលគេតែងតែប្រើឲ្យជីករណ្តៅជាទៀងទាត់ សយ សែន និងនាង ដាំ ទាំងពីរនាក់បានផ្តល់ភ័ស្តុតាងទាក់ទងនឹងចំនួនសាកសពដែលរណ្តៅនីមួយៗអាចដាក់បាន ចាប់ពី ២ ដល់ ៦០ នាក់[980]។ សយ សែន បានផ្តល់សក្ខីកម្មថា ក្នុងឆ្នាំ១៩៧៧ ពេលគេអស់កន្លែងសម្រាប់ជីករណ្តៅនៅកន្លែងធម្មតា គេក៏ជីករណ្តៅបន្ថែមខាងក្រៅនៃបរិវេណខាងក្នុង[981]។ ក្នុងឆ្នាំ១៩៧៧ នេះផងដែរ អ្នកទោសត្រូវបានគេបញ្ជាឲ្យជីកស្រះតូចៗដើម្បីជាកន្លែងបន្ថែមសម្រាប់កប់សាកសព[982]។

301. ចំពោះសំណល់រូបវន្ត មានរណ្តៅសាកសពយ៉ាងតិចប្រាំបីត្រូវបានជីកកកាយនៅក្រាំងតាចាន់[983]។ កែវ ច័ន្ទតារា បានផ្តល់សក្ខីកម្មថា លលាដ៍ក្បាលដែលបានរកឃើញនៅទីតាំងនេះ មានចំនួនជាង

---

[980] ឯកសារ D315.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.13.01-15.14.24 ["អត់អាចរាប់បាន [រណ្តៅសាកសព] ច្រើន [នៅបរិវេណក្រាំងតាចាន់]។ រាប់អត់បាន មានតូច មានធំ មានម្នាក់ មានពីរនាក់ មានបីនាក់ មានបួននាក់អីចឹង រាប់អត់បាន"]។ ឯកសារ D6.1.788 កំណត់ហេតុស្តាប់ចម្លើយ នាង ដាំ KH 00163547។ ឯកសារ D6.1.119 កំណត់ហេតុស្តាប់ចម្លើយ សយ សែន KH 00223064។

[981] ឯកសារ D315.1.3 សយ សែន ប្រតិចារឹក ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ម៉ោង 15.21.30-15.24.21 ["ស៖ តើលោកអាចនិយាយប្រាប់ ជូនតុលាការបានដែរឬទេថា លោកខ្លួនឯងផ្ទាល់ហ្នឹង លោកក៏ត្រូវបានជីករណ្តៅនៅខាងក្រៅរបងទី១ដែរ ដើម្បីកប់សាកសពនោះ។ អីចឹងមែនទេ? ឆ៖ បាទ ខ្ញុំបានជីក វាឲ្យទៅជីក ខ្ញុំពីរនាក់តាចិន ហើយនឹង អាខា មួយទៀត។ [...] [ខ្ញុំបានជីក រណ្តៅ] ប្រហែលជាអាចជាបួនដាប់ម្ភៃរណ្តៅប៉ុណ្ណឹងទេ។ ប៉ុន្តែមួយរណ្តៅវាមាន៣០ មាន២០ មាន១០ [សាកសពអ្នកទោសដែលបានសម្លាប់"]។

[982] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.19.12-15.20.42 ["ឆ្នាំ៧៧មក អាងពីខាងត្បូងនេះ អាងពីខាងត្បូងខ្លោងទ្វារចូលនេះ អាហ្ន៎ងមួយរណ្តៅពីខាងត្បូងហ្ន៎ង អាហ្ន៎ងកន្លែងកប់សពទាំងអស់បាទ មួយកំណត់ខាងត្បូងនេះកប់សព ពីមុនតូចមួយទេ ជីក អ្នកទោសអ្នកជីកកន្លែងហ្ន៎ង។ ស៖ តើលោកផ្ទាល់ ជីករណ្តៅហ្ន៎ងជាមួយអ្នកទោសផ្សេងទៀតទេ? ឆ៖ បាទ ខ្ញុំបាន។ បាន ប៉ុន្តែជីក ខ្ញុំជីកតែចុងក្រោយទេ ជីកពីមុនខ្ញុំអត់បានជីកទេ។ ជីកអាចុងក្រោយគេឲ្យកាប់សម្រាប់ឆ្នាំ៧៧នេះ អាចុងកំណាត់ខាងត្បូងនេះសម្រាប់កប់សពថែមពីលើហ្ន៎ង"]។

[983] ឯកសារ D6.1.778 កំណត់ហេតុស្តាប់ចម្លើយ កែវ ច័ន្ទតារា KH 00163462 ["ស៖ គាស់រណ្តៅប៉ុន្មាន? ឆ៖ ៨ រណ្តៅ"]។

១០,០០០[984]។ អតីតប្រធានយុវជនស្រុក អៀប ឌុច បានប្រាប់អ្នកស៊ើបអង្កេតថា គាត់យល់ស្របថាចំនួនអាចដល់ម៉ឺន ដោយសារគ្រប់ភូមិទាំងអស់សុទ្ធតែបានរាយការណ៍អំពីការបាត់ខ្លួន[985]។

302. កំណត់ហេតុជាណាយលក្ខណ៍អក្សរក៏បានបង្ហាញដែរថា អ្នកទោសត្រូវបានសម្លាប់ក្នុងទ្រង់ទ្រាយធំនៅក្រាំងតាចាន់។ របាយការណ៍ប្រចាំខែចំនួនពីរពីឆ្នាំ១៩៧៧ ផ្តល់ទូវទិដ្ឋភាពភ្លាមៗមួយអំពីស្ថិតិប្រចាំខែ៖ ចំនួនរួមបញ្ចូលគ្នានៃអ្នកទោស ១៣១នាក់ ត្រូវបានសម្លាប់ ហើយប្រាំបីនាក់ផ្សេងទៀតបានស្លាប់ដោយមូលហេតុផ្សេងៗ[986]។ អតីតឆ្នាំគុក ស្រី ថន បានផ្តល់សក្ខីកម្មថា ៩៩ភាគរយ នៃអ្នកទោសដែលបានជាប់ឃុំនៅគុកនេះ ត្រូវបានសម្លាប់[987]។ ប្រហែលសូចនាករណ៍ដែលល្អដាច់គេគឺរបាយការណ៍ដែលគ្មានចុះថ្ងៃខែដែលបានចុះហត្ថលេខាដោយប្រធានគុក ឈ្ឍោ អាន ដែលបានប្រាប់បក្សថា ខ្ទាំងជាង ១៥,០០០នាក់ ត្រូវបាន “កម្ទេច” នៅគុកនេះ[988]។ ទោះចំនួនពិតប្រាកដយ៉ាង

---

[984] ឯកសារ D219/972.2.2 កែវ ច័ន្ទតារា ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.07.19-10.09.02 [អតីតប្រធានឃុំមួយក្នុងចំណោមឃុំនៅកែ្ចរនោះ ដែលគាត់បានពាក់ព័ន្ធដោយផ្ទាល់នៅក្នុងសកម្មភាពជីកគាស់ក្នុងទសវត្សរ៍ឆ្នាំ១៩៨០៖ “ស៖ [...] តើលោកអាចបញ្ជាក់ថាចំនួនលលាដ៍ក្បាល ១០,០១៣ ដែលលោកបាននិយាយហ្នឹង ជាចំនួនពិតប្រាកមែនទេ? ឆ៖ បាទ លលាដ៍ក្បាលនេះដែលយើងរាប់ហើយហ្នឹង គឺពិតប្រាកដហើយ”]។ ឯកសារ D6.1.778 កំណត់ហេតុស្តាប់ចម្លើយ កែវ ច័ន្ទតារា KH 00163462 [មាន “ផ រណ្តៅ មាន ១០,០៥៥ នាក់ (រាប់ក្បាលជាក់ស្តែង) ប៉ុន្តែមានរណ្តៅច្រើនទៀតដែលមិនទាន់គាស់”]។ *សូមមើលផងដែរ* ឯកសារ D315.1.3 សយ សែន ប្រតិចារឹក ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ម៉ោង 15.19.10-15.21.30 [“បើតាមខ្ញុំមើល ដែលស្មានទិដ្ឋភាពនៅកន្លែងនោះ គឺមិនអាចលើស ១០,០០០ទេ។ ខ្ពងប្រហែលជា ១០,០០០ជាង សព្វថ្ងៃនេះអដ្ឋិធាតុគាស់រណ្តៅ រកមាសរកប្រាក់សម័យ៧៩ហ្នឹង ឡើងព្រះកេសកន្លែងក្រាំងតាចាន់ហ្នឹងវា១០,០០០នាក់ជាងទៅហើយ ចុះទម្រាំនៅភូមិខាងក្រៅ កន្លែងកប់ខាងក្រៅនេះ វាពេញភូមិទាំងអស់ អាខាងក្រៅនេះ។ អារបងទី១ខាងក្រៅ អារបង ផុតរបងទី២នេះ គឺភូមិខាងលិចនេះណែនពេញទាំងអស់ មិនទាន់គាស់ទេ។ សព្វថ្ងៃនៅសពនៅកន្លែងហ្នឹងទាំងអស់ អត់ទាន់គាស់ទេភូមិហ្នឹង”]។

[985] ឯកសារ D6.1.782 កំណត់ហេតុស្តាប់ចម្លើយ អៀប ឌុច KH 00163497។

[986] ឯកសារ D6.1.1222 សេចក្តីរាយការណ៍ជូនបក្ស ក្នុងរយៈខែ៧ ឆ្នាំ៧៧ KH 00068017 [អ្នកទោស៣៩នាក់ ពីក្នុងចំណោម ៨១នាក់ ត្រូវបាន “បោសសំអាត” និង “ឈឺស្លាប់អស់ ២នាក់។ នៅសល់ទាំងចាស់ទាំងថ្មី ៤០ នាក់”]។ ឯកសារ D6.1.1226 សេចក្តីរាយការណ៍អំពីអ្នកទោស បំណាច់ខែ១១.៧៧ KH 00068014 [អ្នកទោសចូលថ្មី ៧៥ នាក់ អ្នកទោសត្រូវបាន “បោសសំអាតអស់” ៩២ នាក់ “ឈឺស្លាប់អស់” ៦ នាក់ និង (ពាក់សក្តិ៤កន្លះ) អ.ក (អង្គការ) “ដកទៅតំបន់” ១ នាក់ សព្វថ្ងៃនៅសល់ទាំងអស់ ៨៥ នាក់]។

[987] ឯកសារ D6.1.709 កំណត់ហេតុស្តាប់ចម្លើយ ស្រី ថន ឆ.៥៣ KH 00427978។ *សូមមើលផងដែរ* ឯកសារ D6.1.783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន គឹមសេង KH 00163507។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន គេង ឆ.២៥៥, ៣៨១ KH 01052713។ ឯកសារ D6.1.1002 កំណត់ហេតុស្តាប់ចម្លើយ ជា សៀង KH 00165365។

[988] ឯកសារ D6.1.1220 សេចក្តីរាយការណ៍ជូនបក្សពី អាន់ នៅមន្ទីរអប់រំ ១០៥ គ្មានចុះកាលបរិច្ឆេទ KH 00068049។

ណាក៏ដោយ គេច្បាស់ណាស់ថា មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយគ្មានដំណើរតាមនីតិវិធីច្បាប់។

ការធ្វើទុក្ខបុកម្នេញ

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើ "ប្រជាជន ១៧ មេសា"

303. "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" នៅក្នុងស្រុកត្រាំកក់ ស្ថិតក្រោមការចាប់ខ្លួនជាប្រចាំ និងបានជាប់ក្នុងមន្ទីរឃុំឃាំងញ៉ីកញ្ជាប់ជាង "ប្រជាជនមូលដ្ឋាន"[989]។ តាមពិត កំណត់ហេតុនានាដែលនៅសស់ពីសម័យកាលកម្ពុជាប្រជាធិបតេយ្យបង្ហាញឲ្យឃើញថា អ្នកទោសបីនាក់ក្នុងចំណោមបួននាក់ដែលបានជាប់ឃុំនៅក្រាំងតាចាន់ គឺជា "ប្រជាជន ១៧ មេសា" និងរួមទាំងអ្នកដែលគេបញ្ជូនទាំងបង្ខំពីស្រុកគិរីវង់ផង[990]។ នៅពេលជាប់ឃុំ "ប្រជាជន ១៧ មេសា" ត្រូវបានគេប្រព្រឹត្តចំពោះយ៉ាងឃោរឃៅជាង ដោយសារតែឋានៈរបស់ពួកគេ[991]។

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើខ្មែរក្រោម

304. ខ្មែរក្រោមដែលគេបានបញ្ជូនពីស្រុកត្រាំកក់ ត្រូវបានអាជ្ញាធរកម្ពុជាប្រជាធិបតេយ្យចាត់ទុកថា ជាផ្នែកនៃក្រុមពួជសាសន៍វៀតណាម។ ពួកគេត្រូវបានចោទប្រកាន់ថា ជាពួកដែលមាន "ក្បាលយួន

---

[989] ឯកសារ D6.1.294 សេចក្តីរាយការណ៍ពីឃុំ មកមន្ទីរស្រុក KH 00270983 [សេចក្តីរាយការណ៍ ចុះថ្ងៃទី៤/ ១/ ៧៧ ពី ឃុន នៃឃុំ ស្រែរនោង ជូនបក្ស និយាយថា៖ "សូមបញ្ជាក់មកបក្ស ចំពោះប្រ/ជ ថ្មី នៅជាច្រើនទៀតដែលប្រឆាំង+អ/ក ប្រឆាំងនឹងបក្ស ហេតុនេះ ខ្ញុំនឹងចាប់បញ្ជូនជាបន្តបន្ទាប់"]។ ឯកសារ D315.3.1 ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ម៉ោង 14.13.42-14.15.48 [ក្នុងឃុំណាយបូ៖ "យើងពួក១៧មេសា រង់ចាំតែថ្ងៃដែលយើងមានកំហុស គេនឹងយកយើងទៅរៀនសូត្រ គឺអ្នកថ្មីយកទៅសម្លាប់ គេយកអ្នកថ្មីយកទៅសម្លាប់ចោល។ អ្នកចាស់អត់ដែលមានឃើញបាត់ម្នាក់សោះតាំងពីខ្ញុំទៅនៅហ្នឹងប្រមាណ៣ឆ្នាំ៨ខែ២០ថ្ងៃ អត់មានដែលបាត់អ្នកចាស់ទេ បាត់តែអ្នកថ្មីរហូត"] ម៉ោង 14.15.48-14.17.48 ["បើយើង [ប្រជាជនថ្មី] ប្រព្រឹត្តធ្វើមិនសកម្ម មិនខ្លាំងក្លា គឺបាត់ខ្លួនដោយងាយ"] ម៉ោង 14.36.37 [ប្រជាជនថ្មីជាទិសដៅនៃការចាប់ខ្លួន "ខ្លាំងមែនទែន""]។

[990] *សូមមើល* ភ័ស្តុតាងដែលបានយោងក្នុងកំណត់សំគាល់ជើងទំព័រ ៨៨២, ៨៨៧។

[991] ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 15.51.53-15.54.03 ["ប្រជាជនថ្មី" ត្រូវបានគេសម្លាប់លឿនជាង "ប្រជាជនមូលដ្ឋាន"]។ ឯកសារ D6.1.119 កំណត់ហេតុស្តាប់ចម្លើយ សយ សែន KH 00223067 ["អ្នកទោសបែបប្រភេទធ្ងន់ជាអ្នក១៧ មេសា ដែលកាលនោះគេហៅថា ប្រជាជនថ្មី រីឯអ្នកទោសស្រាលជាអ្នកមូលដ្ឋាន"]។

ខ្ជួនខ្មែរ" និងត្រូវបានគេហៅថា "យួន"[992]។ ភ្លាមៗបន្ទាប់ពីខ្មែរក្រោមបានមកដល់ មន្ត្រីកម្ពុជាប្រជាធិបតេយ្យបានប្រកាសនៅក្នុងអង្គប្រជុំនានានៅទូទាំងស្រុកថា គោលនយោបាយជាតិដើម្បីសម្លាប់ "យួន" គឺត្រូវអនុវត្តនៅមូលដ្ឋាន[993]។ ដើម្បីជាការត្រៀមជាមុន ប្រធានឃុំបានបង្កើតបញ្ជីគ្រួសារខ្មែរក្រោមនិងវៀតណាម នៅក្នុងតំបន់របស់ពួកគេ ហើយបន្ទាប់មកក៏បញ្ជូនបញ្ជីនោះទៅស្រុក[994]។

---

[992] ឯកសារ D315.1.4 រ៉ី ពៅ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.32.56 ["មេកង មេឃុំ មេក្រុមហ្នឹង គេចោទយើងថា យើងយួន។ គេចោទយើងថា "អាយ៉ងយួន" ជាសេ.អ៊ុ.អា របស់យួន អ៊ីចឹង"] ម៉ោង 13.38.52-13.41.13 ["ពីមុនដំបូងគេហៅថា ប្រជាជនបញ្ជើ និង ត្រៀម ដល់យូរៗទៅគេឈប់ហៅអ៊ីចឹង គេឈប់ប្រើពាក្យហ្នឹង គេហៅតែ "អាយ៉ងយួន"។ [...] គេក៏ហៅយើងថា "សេ.អ៊ុ.អា របស់យួន ឬមួយគិញយួនអ៊ីចឹងដែរ"] ម៉ោង 13.34.19-13.36.16, 13.36.16-13.41.13 ["អ៊ៈ សម្រាប់ខ្លួនខ្ញុំផ្ទាល់ ខ្ញុំមិនដែលថា ខ្ញុំខ្មែរកម្ពុជាក្រោមទេ ប៉ុន្តែសម័យប៉ុលពត ពេលខ្ញុំឡើងទៅ -- គេយកខ្ញុំទៅរស់នៅជាមួយគេៗ ហៅខ្ញុំខ្មែរកម្ពុជាក្រោម។ គេហៅខ្ញុំថាយួនអ៊ីចឹងហ្ស។ [...] វាអ្នកហៅដាក់ឈ្មោះពួកខ្ញុំអ៊ីចឹង។ ស៊ៈ នៅពេលដែលលោកនិយាយថា "យើង" លោកសំដៅលើមនុស្សទាំងអស់ដែលគេចាត់ទុកថាខ្មែរកម្ពុជាក្រោមឬក៏យ៉ាងម៉េច គឺថាអ្នកទាំងអស់ហ្នឹងហើយគេចាត់ទុកថា "ក្បាលយួនខ្ជួនខ្មែរ"។ អ៊ីចឹងមែនទេ? បាទ ជាការពិតណាស់លោកប្រធាន"]។ *សូមមើលផងដែរ* ឯកសារ D315.2.6 រៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 13.51.15-13.52.50 ["ស៊ៈ សូមលោកពន្យល់លម្អិតបន្តិចមក តើប្រជាជនណាដែលលោកសង្កេតឃើញថា ជាគោលដៅនេះ គេកំណត់នោះ? អ៊ៈ ប្រជាជនជាគោលដៅហ្នឹង គឺប្រជាជនកម្ពុជាក្រោម [...] គឺគេសំដៅថាជាគិញយួន ជាអ៊ីចឹង ហ្ស.កា.បេ"]។ ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.55.43-09.56.52 ["ប៉ុន្តែខ្ញុំអត់ដឹងថា ខ្មែរកម្ពុជាក្រោមទេ ដឹងតែយួន នៅនោះគេដឹងតែយួន បើ[នរណា]និយាយប៉ៃឡាំ គេដឹងតែ"យួន"ហើយ"]។

[993] ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រៀល សន ឆ.៤៣ KH 00975627 ["ខ្ញុំបានឮថា អ្នកដែលមកពីខ្មែរកម្ពុជាក្រោមត្រូវបានចោទប្រកាន់ថាជា កា.ហ្ស.បេ និង គិញយួន។ នៅក្នុងកិច្ចប្រជុំនោះក៏បានលើកឡើងថា ត្រូវសម្លាប់ខ្មែរក្រោមទាំងអស់នោះផងដែរ"] និងឯកសារ D315.2.6 រៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 11.13.37-11.17.12 [ការពិភាក្សាអំពីការបោសសម្អាតនេះ គឺខ្ញុំដឹងតែកន្លែងខ្ញុំប្រជុំហ្នឹងទេ"]។ ឯកសារ D315.1.20 ឯក(អ៊ីល) ហ៊ីន ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.08.41-15.10.21 ["៧៦ ខែពហ្នឹង មានផែនការបោសសម្អាតយួននៅក្នុងប្រទេសកម្ពុជាទាំងមូលដូចស្រុក១០៥អ៊ីចឹង"] ម៉ោង 15.24.11-15.26.03 ["[ខ្ញុំគ្រាន់តែបានដឹងថា] ផែនការអ៊ី[សេចក្តីណែនាំឲ្យសម្លាប់វៀតណាម] ស្រុកទទួលតែពីខេត្តហ្នឹង [...]។ មជ្ឈិមមកគេមកតែត្រឹមខេត្តហ្នឹង។ [...]អ៊ីចឹងដឹងតែប៉ុណ្ណឹងទេ អត់ដឹងវែងឆ្ងាយទេ"]។ ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក(អ៊ីល) ហ៊ីន ឆ.៣៣, ៣៧-៣៨, ៦២ KH 00980102, 03-04, 06។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យ៉ិន គេង ឆ.១៣១-១៤០ KH 01052705-06។

[994] ឯកសារ D315.2.6 រៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 11.13.37-11.17.12, 13.35.50-13.38.52 ["ស៊ៈ លោកសាក្សី ឯកសារដែលបង្ហាញជូនលោកនេះគឺជារបាយការណ៍ ចុះហត្ថលេខាដោយកម្មាភិបាលម្នាក់ឈ្មោះ ម៉ុន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧៧ មានចំណងជើងថា "បញ្ជីឈ្មោះខ្មែរកម្ពុជាក្រោមមកពីឃុំត្រពាំងធំជើង" គឺជាឃុំរបស់លោក។ គេបានកំណត់ខ្មែរក្រោមចំនួន៧ពាគ្រួសាររស់នៅក្នុងឃុំហ្នឹង មានទាំងមុខនាទីពីរបបមុន និងខានន្តរសក្តិចំពោះអ្នកដែលមានអតីតជាទាហាន។ លោកសាក្សី តើ ម៉ុន ដែលចុះហត្ថលេខាលើរបាយការណ៍នេះជានរណា? អ៊ៈ ម៉ុន នេះគឺជាមេឃុំត្រពាំងធំជើង។ ស៊ៈ តើ ម៉ុន គឺជាមេឃុំម្នាក់ដែលមានវត្តមាននៅក្នុងកិច្ចប្រជុំដែលលោករៀបរាប់ថា មានគេណែនាំអំពីប្រភេទមនុស្សដែលត្រូវបោស

អ្នកដែលមានឈ្មោះនៅក្នុងបញ្ជីនោះ រួមទាំងកូនក្មេងផង ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ និងខ្លះទៀតត្រូវបានគេបញ្ជូនទៅក្រាំងតាចាន់[995]។ អតីតអ្នកទោស សយ សែន បានរំឭកថា អ្នកដែលគេចាត់ទុកថា "យួន" ដែលបានមកដល់មន្ទីរសន្តិសុខនេះត្រូវបាន "ដាក់នៅទីនោះមួយរយៈ" បន្ទាប់មកក៏យកទៅ "កន្លែងសម្លាប់"[996]។ សាក្សីម្នាក់ទៀតបានរំឭកពីកាលៈទេសៈមួយដែលខ្មែរក្រោម ១២៧

សម្អាតនោះដែរឬទេ? ឆ៖ បាទ"]។ ឯកសារ D347/2.1.4 សេចក្តីរាយការណ៍បញ្ជាក់ពី ផន ជំរាប អ/ក ស្រុកជាទីគោរព នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ១៩៧៧ KH 00079090 ["ប្រ/ជ កម្ពុជាក្រោម និង ប្រ/ជ ដែលយួនដួរមក ៦៤ គ្រួសារមកមាន ៦៤គ្រួសារ ចំនួនមនុស្សមានចំនួន ២២៨នាក់"]។ ឯកសារ D6.1.1216 បញ្ជី ប្រ/ជ កម្ពុជាក្រោមដែលស្នាក់នៅឃុំអង្គតាសោម ស្រុកត្រាំកក់ ៣០ មេសា ១៩៧៧ KH 00079100-01។ ឯកសារ D6.1.1210 បញ្ជីដួរអ្នកទោសឃុំអង្គតាសោម KH 00068019-20។ ឯកសារ D65.1.52 បញ្ជី ប្រជាជនកម្ពុជាក្រោម នៅក្នុងឃុំពពេល KH 00068576។ ឯកសារ D6.1.470 បញ្ជីប្រជាជនកម្ពុជាក្រោមពីឃុំគុស ២៩ មេសា ១៩៧៧ KH 00270811-14។ ឯកសារ D347/2.1.3 បញ្ជី ប្រ/ជា ទើបមកពីស្រុកយួន KH 00068037 [កំណត់គ្រួសារខ្មែរក្រោមនៅក្នុងឃុំស្រែរនោង]។ ឯកសារ D6.1.262 សេចក្តីរាយការណ៍បញ្ជីឈ្មោះមកពីយួន នៅក្នុងស្រុកត្រាំកក់ ៥ មិថុនា ១៩៧៧ KH 00079112។ ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក(អ៊ីល) ហ៊ីន ឆ.៤៧ KH 00980104។

[995] ឯកសារ D315.1.4 រ៉ ពៅ ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.32.02-11.36.00 ["ពេលខ្ញុំផ្ទាស់ប្តូរទៅកន្លែងពីភូមិស្ទឹង ទៅនៅភូមិពងទ្រីកហ្នឹង ពេលខ្ញុំទៅ ខ្ញុំបានឃើញមែន [...] [ខ្មែរក្រោម] ៣០នាក់ គេចងចេញ កាលនោះអ្នកដែលនៅក្នុងឃុំសំរោងហ្នឹង អ៊ីចឹងគេបណ្តើរតាមផ្លូវ ប្រឡាយពួកខ្ញុំមកពីអ៊ីចេះ គេទៅពីអ៊ីចេះ ហើយវែកបញ្ជ្រួសមុខគ្នាអ៊ីចឹង។ អ៊ីចឹង [...] សម្លាប់កន្លែងណា ឬមួយក៏យកទៅធ្វើទារុណកម្មនៅកន្លែង [...] អាហ្នឹងខ្ញុំមិនអាចសន្និដ្ឋានបានដែរ"] *សូមអានជាមួយនឹង* ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រ៉ ពៅ ឆ.៥៦ KH 00960589 ឆ.៦០-៦៨ KH 00960590-91 [ខ្មែរក្រោមចំនួន ៣០ នាក់ ត្រូវបានបណ្តើរទៅក្រាំងតាចាន់]។ ឯកសារ D315.2.6 រ៉ៀល សន ប្រតិចារឹក ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 13.55.28-13.57.14 ["ប្រជាជនវៀតណាមទាំងអស់នោះបាត់ខ្លួននៅពេលយប់ ឬក៏ពេលកំពុងធ្វើការ ធ្វើការពលកម្មនៅតាមប្រឡាយ តាមអ៊ីហ្នឹង។ វាហៅយកទៅបាត់អស់"]។ ឯកសារ D315.1.20 ឯក(អ៊ីល) ហ៊ីន ប្រតិចារឹក ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.28.17-15.29.23 ["បាទ ឲ្យតែគេ -- ជនជាតិវៀតណាមនោះ គេនិយាយវៀតណាមតែម្តងនៅក្នុងទ្រីកដីកម្ពុជា និយាយតែជនជាតិវៀតណាម បើនិយាយខ្មែរគេអត់ចាប់ទេ។ គេចាប់តែអ្នកណាដែលចេះនិយាយភាសាគ្នាទៅវិញទៅមកហ្នឹង ភាសាយួនហ្នឹង។ [...] [មេឃុំ] គេឲ្យម្ចាស់ការរៀងខ្លួន"]។ ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក(អ៊ីល) ហ៊ីន ឆ.៤៥-៤៦, ៥៣ KH 00980104, 05។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យ៉ិន គេង ឆ.១២៩-១៣១, ១៤១-១៥៦ KH 01052705, 06-08។ ឯកសារ D118/162 កំណត់ហេតុស្តាប់ចម្លើយ កែវ កន ឆ.៣២-៣៣, KH 00968112។ *សូមមើលផងដែរ* កំណត់សំគាល់ជើងទំព័រ ៨៨២ រៀបរាប់អ្នកទោសខ្មែរក្រោមនៅក្រាំងតាចាន់។

[996] ឯកសារ D364/2.1.2 សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.56.52 ["ស៖ តើអ្នកដែលនិយាយមិនសូវច្បាស់ ឬក៏និយាយមិនសូវល្អហ្នឹង គេថា ពួកគេហ្នឹងជា "យួន" ហើយពួកគេហ្នឹងត្រូវបានសួរចម្លើយហើយបានយកទៅសម្លាប់ ឬក៏យកទៅសម្លាប់ទាំងមិនទាន់បានសួរចម្លើយបាទ ឆ្នាំ៧៧ហ្នឹង ខ្ញុំបានប្រាប់ដូចជាដដែលៗ ថាវា ជួនកាលមកច្រើនណាស់អត់ ? បានសួរចម្លើយទេក្នុងប្រទង់ប្រទាញគ្នា កើតសង្គ្រាមនៅតាមព្រំដែន អត់បានប្រទង់ប្រទាញ អត់បានសួរ អត់បានអ៊ីចេ មកដល់គឺ

នាក់ទាំងចាស់ទាំងក្មេងបានមកដល់ក្រាំងតាចាន់ "ដើម្បីរៀនសូត្រ" ហើយត្រូវបានគេទុកតែពីរថ្ងៃ ក៏ត្រូវបានសម្លាប់ចោល[997]។ យោងតាម សយ សែន៖ "អ្នកទោសខ្មែរកម្ពុជាក្រោមទាំងអស់ ត្រូវបានសម្លាប់"[998]។

v. ឧក្រិដ្ឋកម្មដែលបានស្នើឲ្យចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ

305. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សុំស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់៖[999] អំពើប្រល័យពូជសាសន៍ក្រុមជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា (ជាពិសេសខ្មែរក្រោម)[1000] ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល[1001] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយប្រឆាំងនឹង "ប្រជាជន ១៧ មេសា" ខ្មែរក្រោម និង វៀតណាម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការផ្លាស់ប្តូរទីលំនៅដោយបង្ខំ ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។

គាត់មកដល់ ជួនកាលបើច្រើនពេកបញ្ចូលគុកខ្លះ គាត់យកទៅខ្លះ បណ្តើរៗអ៊ីចឹង។"]។ ឯកសារ D118/133 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឆ៨២-៩១. KH 00960637-38។

[997] ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន គេង ឆ.១២៩-១៣១, ១៤១-១៥៦ KH 01052705, 06-08។

[998] ឯកសារ D118/133 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឆ.៨៧ KH 00960638។

[999] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មមួយដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មនេះ គឺអំពើអមនុស្សធម៌ផ្សេងៗទៀត(ការបាត់ខ្លួនដោយបង្ខំ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មនេះ តាមរយៈឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១៤។

[1000] *សូមមើល* V.គ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម។

[1001] សហព្រះរាជអាជ្ញាសន្និដ្ឋានថា ធាតុផ្សំនៃអំពើមហាប្រល័យនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់តែមួយគត់។ ម្យ៉ាងវិញទៀត សហព្រះរាជអាជ្ញារក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃអំពើមហាប្រល័យដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងមន្ទីរសន្តិសុខក្រាំងតាចាន់ផង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់បង្កើតបានជាផ្នែកនៃប្រព័ន្ធមួយដែលមានការរៀបចំ ក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង ហើយការសម្លាប់នៅលើទីតាំងនិមួយៗទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ីម ទិត្យ។

ច. មន្ទីរសន្តិសុខវត្តអង្គស្រីមុន្នី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន

i. សេចក្តីផ្តើម

306. មន្ទីរសន្តិសុខវត្តអង្គស្រីមុន្នី ("វត្តអង្គស្រី")[1002] និងទីតាំងសម្លាប់មនុស្សព្រៃសុខុន ("ព្រៃសុខុន")[1003] មានទីតាំងស្ថិតនៅក្នុងស្រុកកោះអណ្តែតនៃតំបន់១៣ នាសម័យកាលរបបកម្ពុជាប្រជាធិបតេយ្យ។ វត្តអង្គស្រី ត្រូវបានគេប្រើជាកន្លែងសម្រាប់ឃុំអ្នកទោសរាប់រយនាក់ សម្រាប់នាំយកទៅសម្លាប់នៅព្រៃសុខុន នៅពេលក្រោយមក។ អ្នកទោសភាគច្រើនដែលបានជាប់ឃុំនៅវត្តអង្គស្រី ហើយត្រូវបានសម្លាប់នៅព្រៃសុខុន គឺជាខ្មែរក្រោម។

307. ក្នុងនាមជាអនុលេខា ហើយបន្ទាប់មកបានឡើងធ្វើជាលេខាគណៈតំបន់១៣ និងជាសមាជិកនាំមុខម្នាក់នៃសហឧក្រិដ្ឋកម្មរួម (JCE) **យ៉ឹម ទិត្យ** មានការទទួលខុសត្រូវ និងមានសិទ្ធិអំណាចនៅលើព្រឹត្តិការណ៍នានានៅវត្តអង្គស្រី និងព្រៃសុខុន នៅពេញរបបកម្ពុជាប្រជាធិបតេយ្យ។

308. ស.ច.ស.អ បានចោទប្រកាន់ **យ៉ឹម ទិត្យ** ថាបានប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចខាងក្រោមទាក់ទងនឹងមន្ទីរសន្តិសុខវត្តអង្គស្រីមុន្នី និងទីកន្លែងសម្លាប់ព្រៃសុខុន៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ប្រឆាំងខ្មែរក្រោម និងឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតគិតទុកជាមុន នៅក្រោមមាត្រា៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[1004]។

[1002] មន្ទីរសន្តិសុខវត្តអង្គស្រីមុន្នី ត្រូវបានគេស្គាល់តាមរយៈឈ្មោះជាច្រើនខុសៗគ្នានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន៖ វត្តអង្គសិរីមាលី វត្តសំភ្ជ និងវត្តថ្មី។ *សូមមើល* ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ធ.១១, ៧៦ KH 01169863, 72 ។ ឯកសារ D119/82 កំណត់ហេតុស្តាប់ចម្លើយ នាង អ៊ូច ហៅ តាសាន ធ.៣០ KH 00971370-71។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ធ.៨ KH 01171491។ ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ធ.១៩ KH 00872485។

[1003] ព្រៃសុខុន ក៏ត្រូវគេស្គាល់ផងដែរថា ព្រៃណ្ណាក់ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ *សូមមើល* ឯកសារ D1.3.10.14 មជ្ឈមណ្ឌលឯកសារកម្ពុជា របាយការណ៍វិភាគខេត្តតាកែវ KH 00714207។

[1004] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ឹម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426544, 45, 47, 49, 59។

ii. ប្រតិបត្តិការ និងទីតាំង

309. វត្តអង្គស្រីមុន្នី និងព្រៃសុខុន បានធ្វើប្រតិបត្តិការចាប់ពីខែមេសា ឆ្នាំ១៩៧៥ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1005]។ វត្តអង្គស្រី ស្ថិតនៅក្នុងភូមិសំភ្ជ ឃុំព្រៃខ្ជា នៅលើផ្លូវលំឆ្ពោះទៅខាងជើងព្រៃសុខុន នៅក្នុងភូមិស៊ីស្ពា ឃុំធ្លាប្រជុំ ដែលមានចម្ងាយប្រមាណ ២.៥ គីឡូម៉ែត្រ[1006]។ វត្តអង្គស្រី រួមមានព្រះវិហារ ដែលគេដាក់ពួកទាហាន[1007] និងយ៉ាងហោចណាស់មានអគារចំនួនពីរខ្នងដែលគេប្រើសម្រាប់ឃុំមនុស្ស អគារដែលមានស្រាប់មួយខ្នង និងមន្ទីរឃុំឃាំងមួយខ្នងដែលបានកសាងឡើងដោយខ្មែរក្រហម[1008]។

310. ព្រៃសុខុន ជាតំបន់ព្រៃដែលមានទំហំប្រហែល១០ហិកតា[1009]។ មានរណ្តៅធំៗជាច្រើនត្រូវបានគេជីកនៅលើទីតាំងនេះ និងត្រូវបានប្រើជារណ្តៅកប់សាកសពរួម[1010]។ ការចូលក្នុងព្រៃសុខុនត្រូវបានហាមឃាត់ ប៉ុន្តែគេអាចដើរតាមផ្លូវដែលស្ថិតជាប់នឹងព្រៃ ភ្ជាប់ពីភូមិស៊ីស្ពាទៅភូមិសំភ្ជ[1011]។

[1005] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.៣៤ KH 00866860 ["គេសម្លាប់ដាក់រហូតចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ខែ១១ ឆ្នាំ១៩៧៨ ពេលដែលវៀតណាមចូលមកដល់ភូមិនេះ"]។ ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៤៧ KH 01169868 ["ស៖ លោកមានដឹងថា ទាហានឈរជើងនៅក្នុងរយៈពេលណាដែរ? ឆ.៤៧៖ ពី ១៩៧៥ ដល់រំដោះហ្នឹងតែម្តង"]។ ឯកសារ D119/10 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណកន្លែងនៃទីតាំងសម្លាប់មនុស្ស ព្រៃសុខុន KH 00981803។

[1006] ឯកសារ D119/9 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរឃុំឃាំងវត្តអង្គស្រីមុន្នី KH 01100828។ ឯកសារ D119/10 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃទីតាំងសម្លាប់មនុស្ស ព្រៃសុខុន KH 00981803។

[1007] ឯកសារ D119/16 កំណត់ហេតុស្តាប់ចម្លើយ កៅ ឆេង ឆ.២០ KH 00893283 ["អង្គភាពយោធាទាំងមូល មានទីតាំងនៅវត្តអង្គសេរីមាលី"]។ ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៤០ KH 01169867 ["ស៖ លោកមានដឹងពីមូលហេតុអ្វីបានជាគេយកខ្មែរក្រោមទៅដាក់នៅវត្តអង្គសេរីមាលីដែរឬទេ? ឆ.៤០៖ កន្លែងហ្នឹងជាមូលដ្ឋានទ័ពស្រុក គេដាក់នៅទីនោះ"]។ ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.១៩ KH 008772485។

[1008] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.១១ KH 00866857។

[1009] ឯកសារ D119/10 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃទីតាំងសម្លាប់មនុស្ស ព្រៃសុខុន KH 00981803។

[1010] ឯកសារ D119/16 កំណត់ហេតុស្តាប់ចម្លើយ កៅ ឆេង ឆ.១២ KH 00893282 ["ខ្ញុំសូមបញ្ជាក់បន្ថែមទៀតទេថា នៅព្រៃសុខុននេះ មានគេជីករណ្តៅធំៗជាច្រើនសម្រាប់កប់មនុស្ស"]។

[1011] ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.២៨-២៩ KH 00872486 ["តំបន់នោះជាតំបន់ហាមឃាត់ដោយខ្មែរក្រហម មិនអនុញ្ញាតឲ្យអ្នកណាចូលនោះទេ [...]។ យើងអាចដើរតាមផ្លូវដែលស្ថិតនៅជាប់នឹងព្រៃ ភ្ជាប់ពីភូមិស៊ីស្ពាទៅភូមិសំភ្ជ ប៉ុន្តែមិនអាចចូលក្នុងព្រៃនោះបានទេ"]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និង ការប្រាស្រ័យទាក់ទង

311. វត្តអង្គស្រី និងព្រៃសុខុន គឺស្ថិតនៅក្រោមសិទ្ធិអំណាចរបស់គណៈស្រុកកោះអណ្តែត[1012]។ វត្តអង្គស្រី ត្រូវបានគេប្រើជាមូលដ្ឋានយោធាស្រុក[1013] ហើយសមាជិកកងឈ្លបនៃស្រុកកោះអណ្តែត (អ្នកនៅក្រោមបង្គាប់ **យ៉ីម ទិត្យ**) គឺមានការពាក់ព័ន្ធក្នុងការចាប់ខ្លួន និងឃុំឃាំងមនុស្សនៅឯវត្តអង្គស្រីនិងការសម្លាប់មនុស្សនៅព្រៃសុខុន[1014]។ ក្នុងនាមជាអនុលេខាតំបន់១៣ ហើយក្រោយមកបានក្លាយជាលេខានោះ[1015] **យ៉ីម ទិត្យ** មានការទទួលខុសត្រូវ និងសិទ្ធិអំណាចទៅលើវត្តអង្គស្រី និងព្រៃសុខុន រួមទាំងអំណាចការបញ្ជាឲ្យប្រធានសន្តិសុខស្រុកកោះអណ្តែត តា សៀន ដើម្បីចាប់ខ្លួន

[1012] *សូមមើល* IV.ខ.១.គ. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទងរបស់ ប.ក.ក - ភូមិភាគនិរតី - តំបន់ ១៣ - ស្រុកកោះអណ្តែត។

[1013] ឯកសារ D119/16 កំណត់ហេតុស្តាប់ចម្លើយ កៅ ឆេង ឆ.២០ KH 00893283 ["ស៖ តើមន្ទីរយោធាស្រុក មានទីតាំងនៅវត្តអង្គសេរីមាលីឬ? ឆ.២០៖ អង្គភាពយោធាទាំងមូល មានទីតាំងនៅវត្តអង្គសេរីមាលី"]។ ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៤០ KH 01169867 ["ស៖ លោកមានដឹងពីមូលហេតុអ្វីបានជាគេយកខ្ញែរក្រោមទៅដាក់នៅវត្តអង្គសេរីមាលីដែរឬទេ? ឆ.៤០៖ កន្លែងហ្នឹងជាមូលដ្ឋានទ័ពស្រុក គេដាក់នៅទីនោះ"]។ ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.១៩ KH 00872485 ["បាទ ពីដំបូងឈ្លោះវត្តសំភ្ជ៌ បន្ទាប់មកទើបគេដាក់ឈ្លោះវត្តអង្គសេរីមាលី។ វត្តនេះជាទីតាំងយោធាស្រុកកោះអណ្តែត"]។ ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.២ KH 00866856 ["ពីព្រោះខ្ញែរក្រហមពុំចង់ឲ្យមានប្រជាជនណាម្នាក់រស់នៅជិតបរិវេណវត្តទេ។ ពីព្រោះពេលនោះបរិវេណវត្តនេះត្រូវបានប្រើដោយខ្ញែរក្រហមធ្វើជាមន្ទីរស្រុក"]។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.៧១ KH 01185748។

[1014] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.២៥ KH 00866859 ["នៅពេលដែលប្រជាជនទាំងនោះត្រូវបាននាំចេញពីអគារសាលារៀន គេ [...] បណ្តើរដោយកងឈ្លបពីរនាក់ដែលមានកាំភ្លើង [...]។ នៅក្នុងពេលជាមួយគ្នានោះ មានពួកឈ្លបចេញពីព្រៃក្បែរទីនោះ ចាប់ចងអ្នកទាំងនោះ ហើយនាំចេញទៅតែម្តង"]។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.៧៤ KH 01171503។ ឯកសារ D219/568 កំណត់ហេតុស្តាប់ចម្លើយ ម៉ុ ផណ្ណា ឆ.៨១ KH 01165969។ ឯកសារ D119/16 កំណត់ហេតុស្តាប់ចម្លើយ កៅ ឆេង ឆ.២២ KH 00893284។ *សូមមើលផងដែរ* ឯកសារ D219/358 កំណត់ហេតុស្តាប់ចម្លើយ លួន មល់ ឆ.៣៣-៣៦ KH 01104664-65។ ឯកសារ D1.3.11.19 កំណត់ហេតុនៃកិច្ចសម្ភាសន៍ របស់ ក.ស.ព KH 00848194។ ឯកសារ D119/18 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស រឿងរ៉ាវរបស់ ហ៊ីយ ពន KH 00901572-73។

[1015] *សូមមើល* III.គ.១. ភ្ជាប់ អំពើ និងការប្រព្រឹត្តិរបស់ យ៉ីម ទិត្យ ការចូលរួមរបស់ យ៉ីម ទិត្យ ក្នុងផែនការឧក្រិដ្ឋរួមនៅក្នុងភូមិភាគនិរតី ភ្ជាប់ទីរបស់ យ៉ីម ទិត្យ នៅក្នុងភូមិភាគនិរតី។

មនុស្ស[1016]។ បទបញ្ជាដូច្នេះ ត្រូវបានអនុវត្តដោយកម្មាភិបាលថ្នាក់ក្រោម និងរាយការណ៍ជូនថ្នាក់លើ[1017]។

312. កិច្ចប្រជុំជាច្រើនត្រូវបានធ្វើឡើងដោយកម្មាភិបាលថ្នាក់ស្រុក និងថ្នាក់តំបន់ ក្នុងស្រុកកោះអណ្តែត ដែលពិភាក្សាអំពី *ក្នុងចំណោមបញ្ហាជាអាទិ៍*៖ "ការកម្ទេច" ជនណាដែលបានប្រព្រឹត្តខុសសីលធម៌[1018] ការវាយប្រយុទ្ធ"យួន"ល្ហានពាន[1019] ការប្រុងប្រយ័ត្នខ្ពស់ប្រឆាំងកម្មករដែលអាចជា "គិញ"[1020] និងសេចក្តីណែនាំឲ្យតាមដាន "ខ្មាំងខាងក្នុង"[1021]។

[1016] ឯកសារ D193/8.2 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ីន ហៅ ឯក ហ៊ីន ឆ.ពាព KH 01032071 ["តាមខ្ញុំយល់ គឺតាទិត្យ និងយាយចែម បានបញ្ជាឲ្យប្រធានសន្តិសុខស្រុក តាសឿន ឲ្យចាប់ខ្លួនមនុស្ស"]។ ឯកសារ D219/40 កំណត់ហេតុស្តាប់ចម្លើយផាន់ ឆេន ឆ.៣៥ KH 01032140។

[1017] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.៤១ KH 01171496 ["ស៖ តើលោកដឹងថា ម៉ោង រាយការណ៍ទៅណាទេ? ឆ.៤១៖ គេថា រាយការណ៍ទៅអង្គការថ្នាក់លើៗ តែខ្ញុំមិនដឹងថារាយការណ៍ទៅអ្នកណាទេ"] ឆ.៤៤ KH 01171497 ["ស៖ តើ ម៉ោង មានធ្លាប់និយាយថា ប្រជាជនខ្មែរក្រោមជាខ្មាំង ឬក៏គោលដៅដែលត្រូវកម្ទេចចោលរបស់អង្គការទេ? ឆ.៤៤៖ គេនិយាយច្បាស់ថា អង្គការថ្នាក់លើចាត់តាំងគេធ្វើជាប្រធាននគរបាល ដើម្បីមកកម្ទេចតែម្តង"]។

[1018] ឯកសារ D6.1.688 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន KH 00368611។

[1019] ឯកសារ D119/108 សុខ រ៉ុ ឆ.៤៧-៤៨ KH 0097405។

[1020] ឯកសារ D118/274 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ឆ.៣០ KH 00999991 ឆ.៣៤ KH 00999992។ ឯកសារ D6.1.688 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន KH 00368610។

[1021] ឯកសារ D118/242 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម ហ៊ីន ឆ.៨៧, ៩១ KH 00998734។

iv. ខ្ញុំក្ដីកម្ម

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

313. មនុស្សត្រូវបានចាប់ខ្លួន ហើយយកទៅកាន់វត្តអង្គស្រីមុន្នីជារៀងរាល់ថ្ងៃ[1022]។ ហង់ សុង ដែលបានរស់នៅជិតភូមិស៊ីស្ពាកាលណោះ បានឃើញមនុស្សរវាងបួន និងដប់នាក់ ត្រូវបានចាប់ខ្លួន ចង ហើយបណ្ដើរជាជួរទៅកាន់គុកជារៀងរាល់ថ្ងៃ សម្រាប់រយៈពេល១២ខែ[1023]។

314. ពួកដែលបានឃាត់ខ្លួនគឺជាពួកខ្មែរក្រោម "ពួក១៧មេសា" អតីតមន្ត្រីរដ្ឋការ លន់ នល់ ពួកខ្មែរលើ ប្រជាជនមកពីភូមិសំភ្ជ និងភូមិផ្សេងៗទៀតនៅកោះអណ្ដែត ដែលត្រូវបានគិតថាជា "ប្រជាជន

[1022] ឯកសារ D119/5 កំណត់ហេតុស្ដាប់ចម្លើយ ហង់ សុង ឆ.២៨ KH 00872456 ["ស៖ ពេលនោះតើអ្នកស្រីធ្លាប់ឃើញផ្ទាល់ភ្នែកនូវការចាប់ចង ឬសម្លាប់ដែរឬទេ? ឆ.២៨៖ ខ្ញុំឃើញរាល់ថ្ងៃ គេចាប់ចងមនុស្សទាំងខ្សែៗ ដាក់ខ្នោះ។ គ្មានថ្ងៃណាមួយដែលមិនមានការចាប់ចងទេ។"]។ ឯកសារ D219/591 កំណត់ហេតុស្ដាប់ចម្លើយ គុណ សំ ឆ.២២-២៣ KH 01169865 ["ឆ.២២៖ ខ្ញុំមិនដឹងទេ ហើយការងារគេម៉េចៗក៏ខ្ញុំមិនដឹងដែរ ខ្ញុំគ្រាន់តែឃើញគេយកអ្នកទាំងនោះទៅទីនោះតែប៉ុណ្ណោះ។ ស៖ លោកឃើញអ្នកទាំងនោះនៅពេលណា? ឆ.២៣៖ មានថ្ងៃ មានយប់ គេយកទៅដាក់ទីនោះមិនមែនទៅដាក់ម្ដងទាំងអស់ទេ"]។

[1023] ឯកសារ D119/5 កំណត់ហេតុស្ដាប់ចម្លើយ ហង់ សុង ឆ.២៧ KH 00872456 ["ស៖ តើអ្នកស្រីនៅទួលគោកស្រុករយៈពេលប៉ុន្មាន? ឆ.២៧៖ ប្រហែល១ឆ្នាំ។"] ឆ.២៩ KH 00872457 ["ស៖ ក្នុងមួយថ្ងៃៗចាប់មនុស្សប្រហែលប៉ុន្មាននាក់? ឆ.២៩៖ ប្រហែលបួនដប់នាក់។ គេចាប់ចងដាក់ដៃទៅខាងក្រោយខ្នង"]។

ដែលធ្វើខុស”[1024] និងអ្នកផ្សេងៗទៀតដែលបានគិតថាជា “ខ្មាំង” នៃរបបកម្ពុជាប្រជាធិបតេយ្យ[1025]។ ពួកអ្នកទោស ជារួមមាន បុរស ស្ត្រី និងកុមារ[1026]។

315. ភាគច្រើននៃអ្នកទោសនៅវត្តអង្គស្រី គឺជាក្រុមគ្រួសារខ្មែរក្រោម ដែលត្រូវបានបញ្ជូនដោយ ប.ក.ក ពីភ្នំពេញ និងតាកែវ[1027]។ វង ណុប ដែលបានរស់នៅកែ្ទរវត្តអង្គស្រី បានរៀបរាប់ថា ប្រមាណជា ២០០ គ្រួសារខ្មែរក្រោមត្រូវបានបញ្ជូនពីភ្នំពេញ និង២០០គ្រួសារ ពីតាកែវ ត្រូវបានឃុំ

[1024] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.២៤ KH 00866858 [“បើសិនជាមានប្រជាជនណាធ្វើខុស [...] [វា] នឹងត្រូវរាយការណ៍ទៅប្រធានភូមិ ឃុំ និង សហការណ៍។ ហើយអ្នកដែលធ្វើខុសនោះនឹងត្រូវយកចេញទៅបាត់ ឬក៏ដាក់ក្នុងមន្ទីរឃុំឃាំង”] ឆ.៣៣ KH 00866860 [“ស៖ លោកបាននិយាយថា ក្រៅពីសាលារៀនដែលដាក់ឃុំឃាំងប្រជាជនមកពីតាកែវ និងភ្នំពេញ គឺនៅមានមន្ទីរឃុំឃាំងមួយទៀត ដែលខ្មែរក្រហមបានធ្វើសម្រាប់ឃុំឃាំងអ្នកទោសនៅជិតព្រះវិហារ។ តើអ្នកទោសទាំងនោះជាអ្នកទោសប្រភេទណា? មន្ទីរឃុំឃាំងនោះត្រូវបានបង្កើតឡើង១ឆ្នាំក្រោយពេលប្រជាជនតាកែវ និងភ្នំពេញ ត្រូវគេយកចេញទៅបាត់អស់។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរឃុំឃាំងនេះ ត្រូវបានចាប់យកមកពីភូមិផ្សេងៗនៅក្នុងស្រុកកោះអណ្តែត”]។ ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.២៦ KH 00872486 [“ស៖ លោកនិយាយថា លោកបានឃើញគេចាប់អ្នក១៧មេសា ហើយបណ្តើរចេញទៅ តើលោកដឹងទេ អ្នកដែលត្រូវចាប់ខ្លួននោះ គេយកទៅទីណា? ហើយមានជាតិសាសន៍អ្វីខ្លះ? ឆ.២៦៖ ជាជនជាតិខ្មែរ ដែលជាអ្នកជម្លៀសមកពីភ្នំពេញ រួមមានអតីតទាហាន លន់ នល់”]។ ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៣២ KH 01169866 [“ស៖ តើចំនួនតិច ឬចំនួនច្រើន? ឆ.៣២៖ តាមខ្ញុំស្តាប់ឮគេនិយាយថា មានច្រើនដែរ មិនមែនមានតែខ្មែរក្រោមទេ ក៏មានខ្មែរលើត្រូវគេចាប់ទុកនៅទីនោះដែរ”]។

[1025] ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៧៧ KH 01169872 [“ធ្លាប់ឮ តែគេចោទថាខ្មាំង គឺគេចាប់ទៅបាត់ហើយ”]។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.៧១ KH 01171502 [“កន្លែងវត្តហ្នឹងជាគុក និងសាលាស្រុក ហើយគេចាប់មនុស្សយកទៅដាក់កន្លែងហ្នឹង។ បើគេចោទថាខ្មាំង គេចាប់យកមកដាក់នៅកន្លែងហ្នឹងហើយ។”] ឆ.៧៦ KH 01171503 [“ខ្ញុំបានប្រាប់គាត់ថា [ម៉ោង កម្ចាភិបាល បកក]គ្មានអ្នកនៅរស់ទេ បើឯងដើរទំនាស់ និងចោទគេគ្រប់គ្នាថាជាខ្មាំង។ គាត់ប្រាប់ខ្ញុំវិញថា នោះគឺអង្គការ”]។

[1026] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.១៤ KH 00866857 [“ស៖ តើប្រជាជនទាំងនោះមានអតីតមុខងារជាអ្វីខ្លះ? ឆ.១៤៖ អត់មានមុខងារអ្វីច្បាស់លាស់ទេប្រជាជនទាំងនោះ។ ប្រជាជនទាំងនោះត្រូវបានគេដាក់ឲ្យនៅមួយកន្លែង។ ប្រជាជនទាំងអស់នោះគឺចំរុះ មានមនុស្សចាស់ វ័យកណ្តាល ប្រុស ស្រី ក្មេង ទារក។ អ្នកទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យដើរហើរសេរីនៅក្នុងបរិវេណវត្តនោះទេ”]។

[1027] ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.១៣ KH 01169863 [“នៅឆ្នាំ៧៥ ក្រោយពេលដែលប្រជាជនដែលបែកពីភ្នំពេញមក គេយកប្រជាជនក្រោមយកមកដាក់នៅវត្តអង្គសេរីមាលីដែលមានទាហានឈរជើងនៅទីនោះ។”]។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.៧ KH 01171491 [“ស៖ តើមានជនជាតិខ្មែរក្រោមរស់នៅទីនេះទេ? ឆ.៧៖ ទេ មិនមានទេ គឺមានតែខ្មែរក្រោមដែលគេនាំមកពីភ្នំពេញ និងតាកែវមកដាក់នៅវត្តនេះ ហើយក្រោយមក យកទៅសម្លាប់នៅព្រៃសុខុន”]។ ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៣៦ KH 00872487។

ខ្លួននៅវត្តអង្គស្រី[1028]។ ខ្មែរក្រោមទាំងពីរក្រុមនេះត្រូវបានយកទៅវត្តអង្គស្រី ក្នុងរយៈកាលមួយខែ ក្រោយការដួលរលំនៃក្រុងភ្នំពេញ[1029]។

316. អ្នកទោស ដែលបានឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងដែលបានសង់នៅឆ្នាំ១៩៧៦ នៅវត្តអង្គស្រី ត្រូវបានដាក់ខ្នោះជើងទាំងយប់ ទាំងថ្ងៃ[1030]។ ពួកដែលបានឃុំខ្លួននៅក្នុងអគារសាលារៀន មិនត្រូវបានគេដាក់ខ្នោះជើងទេ ប៉ុន្តែមិនអាចផ្លាស់ទីកន្លែងដោយសេរីបាននៅក្នុងគុកនេះទេ[1031]។ សាក្សី ហង់ សុង បានប្រាប់ថា ពួកអ្នកទោសបុរសៗត្រូវបានសួរចម្លើយមុននឹងបញ្ជូនទៅកាន់ព្រៃសុខុនដើម្បីសម្លាប់

[1028] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.៣៣ KH 01171495 ["ស៖ មានន័យថា មានប្រជាជនខ្មែរក្រោមមកពីតាកែវចំនួន២០០គ្រួសារ និងប្រជាជនខ្មែរក្រោមមកពីភ្នំពេញ២០០គ្រួសារទៀត។ តើត្រឹមត្រូវដែរទេ? ឆ.៣៣៖ បាទ"]។

[1029] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.៨ KH 00866856 ["ស៖ ក្រោយ១៧ មេសា ឆ្នាំ១៩៧៥ តើមានរយៈពេលប៉ុន្មាន ទើបមានពួកជម្លៀសមកពីទីក្រុងផ្សេងៗមកដល់ភូមិនេះ? ឆ.៨៖ បន្ទាប់ពីភ្នំពេញរលំរយៈពេល១ខែទើបមានប្រជាជនមកពីភ្នំពេញមកដល់ទីនេះ។ ប៉ុន្តែ មានប្រជាជនមកពីក្រុងតាកែវមកដល់ទីនេះមុនប្រជាជនភ្នំពេញ"]។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.២៩ KH 01171495។

[1030] ឯកសារ D119/5 កំណត់ហេតុស្តាប់ចម្លើយ ហង់ សុង ឆ.២៨ KH 00872456 ["នៅក្នុងមន្ទីរឃុំឃាំងនោះគេធ្វើជាខ្នោះដាក់ជើង ដែលមានដែកស៊ីកសម្រាប់ដាក់កជើងអ្នកទោស។"]។ ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.៣៣ KH 00866860 ["មន្ទីរឃុំឃាំងនោះត្រូវបានបង្កើតឡើង១ឆ្នាំក្រោយពេលប្រជាជនតាកែវ និងភ្នំពេញត្រូវគេយកចេញទៅបាត់អស់។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរឃុំឃាំងនេះ ត្រូវបានចាប់យកមកពីភូមិផ្សេងៗនៅក្នុងស្រុកកោះអណ្តែត។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរឃុំឃាំងនេះ ត្រូវបានចាប់យកមកពីភូមិផ្សេងៗនៅក្នុងស្រុកកោះអណ្តែត។ អ្នកទាំងអស់នោះត្រូវបានដាក់ខ្នោះជើងទាំងយប់ទាំងថ្ងៃ ហើយអ្នកដែលត្រូវយកទៅសម្លាប់ គឺយកទៅសម្លាប់នៅកន្លែងព្រៃសុខុនដែរ"]។

[1031] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.១៤ KH 00866857 ["ស៖ តើប្រជាជនទាំងនោះមានអតីតមុខងារជាអ្វីខ្លះ? ឆ.១៤៖ អត់មានមុខងារអ្វីច្បាស់លាស់ទេប្រជាជនទាំងនោះ។ ប្រជាជនទាំងនោះត្រូវបានគេដាក់ឲ្យនៅមួយកន្លែង។ ប្រជាជនទាំងអស់នោះគឺចំរុះ មានមនុស្សចាស់ វ័យកណ្តាល ប្រុស ស្រី ក្មេង ទារក។ អ្នកទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យដើរហើរសេរីនៅក្នុងបរិវេណវត្តនោះទេ។"] ឆ.២៧ KH 00866859 ["ស៖ តើប្រជាជនមកពីតាកែវ និងភ្នំពេញ ដែលដាក់នៅសាលារៀននោះ ត្រូវបានគេដាក់ខ្នោះដែរឬទេ? ឆ.២៧៖ ទេ គេពុំបានដាក់ខ្នោះអ្នកទាំងនោះទេ។ ប៉ុន្តែគេមិនអនុញ្ញាតឲ្យអ្នកទាំងនោះចេញដើររហេតរហូតទេ គឺឲ្យនៅតែមួយកន្លែង។"] ឆ.២៨ KH 00866859។

ចោល[1032]។ អ្នកស្រុកមូលដ្ឋានជឿជាក់ថា "ដូចជាគ្មាន [អ្នកណាត្រូវបានគេដោះលែង] ទេ អ្នកដែលគេយកទៅឃុំនៅទីនោះសុទ្ធតែត្រូវបានយកទៅសម្លាប់ទាំងអស់"[1033]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

317. ការធ្វើមនុស្សឃាតបានកើតឡើងនៅក្នុងវិសាលភាពមួយយ៉ាងរង្គាលនៅព្រៃសុខុន[1034]។ សាក្សីនានាបានរៀបរាប់ថា ការសម្លាប់ប្រចាំថ្ងៃ[1035] មានរហូតដល់ទៅ ១០គ្រួសារ ត្រូវបានសម្លាប់ក្នុង

[1032] ឯកសារ D119/5 កំណត់ហេតុស្តាប់ចម្លើយ ហង់ សុង ឆ.៣០ KH 00872457 ["អ្នកដែលមានទោសល្មមៗ ត្រូវបានគេចងទាំងខ្សែៗ នាំចេញទៅទិសខាងត្បូង [ទៅព្រៃសុខុន] ហើយអ្នកខ្លះទៀតគេដាក់ខ្នោះជើង។ ចំពោះនារីៗ ត្រូវគេចាប់ចងហើយបណ្តើរចេញទៅ ចំណែកបុរសត្រូវគេដាក់ខ្នោះជើង ដើម្បីស្រួចម្ហើយ"]។

[1033] ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៣៧ KH 01169867 ["ស៖ តើមានអ្នកណាត្រូវបានគេដោះលែងចេញពីវត្តអង្គសេរីមាលីដែរទេ? ឆ.៣៧៖ បើតាមអ្នកភូមិគេនិយាយ ដូចជាគ្មានទេ អ្នកដែលគេយកទៅឃុំនៅទីនោះសុទ្ធតែត្រូវបានយកទៅសម្លាប់ទាំងអស់"]។

[1034] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.៣២ KH 00866860 ["ស៖ តើលោកអាចធ្វើការប៉ាន់ស្មានបានឬទេថា តើមនុស្សដែលគេសម្លាប់នៅព្រៃសុខុននោះមានចំនួនប៉ុន្មាននាក់? ឆ.៣២៖ "យល់ទៅតាមការប៉ាន់ស្មានរបស់ខ្ញុំ មានប្រហែលជា១០០គ្រួសារដែលត្រូវបានគេសម្លាប់នៅព្រៃសុខុន។ ចំនួនជាមធ្យមគ្រួសារមួយៗមានប្រហែល ៤នាក់"]។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីផែនទីខេត្តតាកែវ បទសម្ភាសន៍លោក រ៉ង់ ប៊ីរ KH 00714212 ["សាក្សីនោះបានប៉ាន់ប្រមាណថា មានសាកសពចំនួនប្រហែល ១០ ០០០ ទៅ ១២ ០០០ សាកសព"]។

[1035] ឯកសារ D219/604 កំណត់ហេតុស្តាប់ចម្លើយ សំ ទូច ឆ.៧២ KH 01173499 ["ស៖ តើលោកស្រីឃើញហេតុការណ៍នេះនៅពេលណា? តើលោកស្រីឃើញហេតុការណ៍បែបនេះ ចំនួនប៉ុន្មានដង? ឆ.៧២៖ នៅពេលខ្ញុំទៅឃ្វាលគោ។ ខ្ញុំឃើញរាល់តែថ្ងៃ ប្រហែលជាមួយខែឃើញរាល់តែថ្ងៃ ពីរបីៗយកទៅវាយចោល"]។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.៦៥ KH 01171501 ["ស៖ ក្នុងអំឡុងរយៈពេល ២-៣ ខែដែលលោកនៅកន្លែងហ្នឹង តើជាមធ្យមលោកឃើញគេយកមនុស្សទៅវ៉ៃចោលប៉ុន្មាននាក់ក្នុងមួយថ្ងៃ? ឆ.៦៥៖ "មួយថ្ងៃៗគេយកមនុស្សទៅវ៉ៃចោលយ៉ាងតិច១០នាក់។"] ឆ.៦១ KH 01171500។

មួយលើកៗ[1036]។ ការសម្លាប់បែបដូច្នេះគឺមានរយៈពេលពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[1037] ។

318. អ្នកដែលត្រូវបានសម្លាប់នៅព្រៃសុខុន គឺជាអ្នកទោសមកពីវត្តអង្គស្រី ហេតុដូច្នេះ ជនរងគ្រោះរួមបញ្ចូលទាំងបុរស ស្ត្រី និងកុមារ[1038] ដែលមានប្រវត្តិខុសៗគ្នា រួមមានទាំង 'ប្រជាជន១៧មេសា' អតីតមន្ត្រីរដ្ឋការ លន់ នល់ និងជាពិសេសនោះគឺ ខ្មែរក្រោម[1039]។

[1036] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.៥៥ KH 01171499 [ស៖ តើអ្នកណាជាអ្នកបណ្តើរប្រជាជនចេញទៅ? ឆ.៥៥៖ ឈ្លប ហើយពួកគេធំៗនៅចាំកន្លែងនោះហើយ។ គេឲ្យឈ្លបតូចៗហ្នឹងមកហៅចេញទៅ។ គេហៅទៅម្តង៥គ្រួសារ ហើយពេលខ្លះ១០គ្រួសារ។"]។ ឯកសារ D219/568 កំណត់ហេតុស្តាប់ចម្លើយ មុំ ផល្លា ឆ.៦៩ KH 01165968 ["ស៖ តើលោកស្រីឃើញគេបណ្តើរមនុស្សប៉ុន្មាននាក់? ឆ.៦៩៖ ច្រើនណាស់ ប្រហែលជា៣០នាក់។"]។ ឯកសារ D1.3.10.14 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីផែនទីខេត្តតាកែវ រឿងរ៉ាវរបស់លោក រ៉ង់ ប៊ីង KH 00714211។

[1037] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប ឆ.៣៤ KH 00866860 ["គេសម្លាប់ដាក់រហូត [ទីកន្លែងសម្លាប់ព្រៃសុខុន] ចាប់តាំងពីថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ខែ១១ ឆ្នាំ១៩៧៨ ពេលដែលវៀតណាមចូលមកដល់ភូមិនេះ។"]។ ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៤០ KH 01169867 ["កន្លែងហ្នឹង[វត្តអង្គស្រី]ជាមូលដ្ឋានទ័ពស្រុក គេដាក់នៅទីនេះ"] ឆ.៤៧ KH 01169868 ["ស៖ លោកមានដឹងថាទាហានឈរជើងនៅក្នុងរយៈពេលណាដែរ? ឆ.៤៧៖ ពី១៩៧៥ ដល់រំដោះហ្នឹងតែម្តង"]។ ឯកសារ D119/10 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃទីកន្លែងសម្លាប់ព្រៃសុខុន KH 00981803។

[1038] ឯកសារ D219/568 កំណត់ហេតុស្តាប់ចម្លើយ មុំ ផល្លា ឆ.៦៩-៧១ KH 01165968 ["ស៖ តើលោកស្រីឃើញគេបណ្តើរមនុស្សប៉ុន្មាននាក់? ឆ.៦៩៖ ច្រើនណាស់ ប្រហែលជា ៣០នាក់។ ស៖ លោកស្រីថា មានមនុស្សដែលគេយកទៅសម្លាប់ប្រហែលជា ៣០នាក់។ តើមានក្មេងៗទេ? ឆ.៧០៖ មាន។ មានកូនក្មេងប្រហែលជាប្រាំ ឬប្រាំមួយនាក់ ទៅជាមួយម្តាយ។ ស៖ តើក្មេងៗមានអាយុប៉ុន្មាន? ឆ.៧១៖ មិនដឹងអាយុប៉ុន្មានទេ ប៉ុនគេចេះដើរហើយ។ ខ្ញុំឃើញស្ត្រីម្នាន់ពរកូន ហើយគេប្រាប់ឲ្យគាត់ទម្លាក់កូនចុះ ឲ្យកូននោះដើរខ្លួនឯង។ រីឯម្តាយគេចងដៃទៅក្រោយ"]។

[1039] ឯកសារ D219/568 កំណត់ហេតុស្តាប់ចម្លើយ មុំ ផល្លា ឆ.៦១ KH 01165967 ["នៅពេលដែលគេយកអ្នក១៧មេសា ហើយនិងខ្មែរក្រោមទៅសម្លាប់នៅព្រៃសុខុន"]។ ឯកសារ D219/604 កំណត់ហេតុស្តាប់ចម្លើយ សំ ទូច ឆ.៧០ KH 01173499 ["ស៖ ម៉េចបានលោកស្រីដឹងថា គេយកមនុស្សទៅវាយចោលនៅព្រៃសុខុន? ឆ.៧០៖ ចាស ខ្ញុំឃើញ។ ពួក១៧ គេយកទៅវាយចោល"]។ ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.២៦ KH 00872487។ ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៣៦ KH 01169867។

319. អ្នកទោសវត្តអង្គស្រី ត្រូវបានគេប្រាប់ថា ពួកគាត់នឹងត្រូវបញ្ជូនទៅផ្ទះ ឬត្រូវផ្ទេរទៅកាន់ទីកន្លែងផ្សេងទៀត ប៉ុន្តែផ្ទុយទៅវិញ ពួកគាត់ត្រូវបានបញ្ជូនមកកាន់ព្រៃសុខុនៃ ពួកឈ្លបបានចង ភ្ជង់កាំភ្លើងបណ្តើរចូលទៅក្នុងព្រៃ និងបានបង្ខំឲ្យជីករណ្តៅ[1040]។

320. បន្ទាប់មកឈ្លបបានវាយសម្លាប់អ្នកទោសទាំងនោះ មុនពេលបោះសាកសពចូលទៅក្នុងរណ្តៅ[1041]។ ជនរងគ្រោះខ្លះនៅរស់នៅឡើយ នៅពេលគេលប់រណ្តៅទាំងនោះ[1042]។ មុំ ផណ្ណា ដែលបានធ្វើការ

[1040] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ រង ណុប ឆ.២៥ KH 00866859 ["ស៖ តើរយៈប៉ុន្មានបន្ទាប់ពីប្រជាជនតាកែវ ត្រូវបានយកទៅសម្លាប់នៅកន្លែងសម្លាប់ ទើបលោកដឹងអំពីរឿងនោះ? ឆ.២៥៖ ខ្ញុំបានដឹងរឿងនោះក្នុងថ្ងៃតែមួយ។ ប្រជាជនទាំងនោះត្រូវបានយកចេញទៅពេលម៉ោង២ ឬ៣ រសៀល។ ខ្ញុំបានឃើញគេបណ្តើរពួកគេតាមផ្លូវយកចូលក្នុងព្រៃ។ ផ្ទះរបស់ខ្ញុំស្ថិតនៅម្ខាងផ្លូវពីបរិវេណវត្ត។ ពេលនោះខ្ញុំពុំទាន់បានរើផ្ទះទៅនៅកន្លែងថ្មីនៅឡើយទេ។ ដូច្នេះហើយទើបបានខ្ញុំឃើញរឿងរ៉ាវកើតឡើងក្នុងពេលនោះ។ នៅពេលដែលប្រជាជនទាំងនោះត្រូវបាននាំចេញពីអគារសាលារៀន គេពុំត្រូវបានចងទេ។ គេបណ្តើរដោយកងឈ្លបពីរនាក់ ដែលមានកាំភ្លើង។ ឈ្លបម្នាក់ដើរខាងមុខ ម្នាក់ទៀតដើរខាងក្រោយ។ ពួកគេទាំងនោះត្រូវបានបណ្តើរទៅដល់កន្លែងមួយដែលគេប្រជុំ នៅពេលនោះគេប្រាប់ពួកនោះថា គេនឹងបញ្ជូនទៅកន្លែងថ្មី ឬដីថ្មី។ នៅក្នុងពេលជាមួយគ្នានោះមានពួកឈ្លបចេញពីក្នុងព្រៃកៃ្សរទីនោះ ចាប់ចងអ្នកទាំងនោះ ហើយនាំចេញទៅតែម្តង"]។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រង ណុប ឆ.៥៣ KH 0071499 ["ស៖ ចំពោះប្រជាជនក្រុមទី១ ដែលមកពីតាកែវ តើលោកបានឃើញគេយកទៅសម្លាប់នៅព្រៃសុខុនដោយផ្ទាល់ភ្នែកទេ? ឆ.៥៣៖ ខ្ញុំឃើញ ឲ្យតែម៉ោងប្រហែលម៉ោងហ្នឹង គេយកទៅសម្លាប់ហើយ។ គេយកប្រជាជនចេញទៅពីម៉ោង ២ ឬម៉ោង៣ ដល់ម៉ោង៦ល្ងាច។ ប្រជាជនអត់មានភ័យព្រួយទេ ព្រោះត្រូវបានគេប្រាប់ថា អង្គការឲ្យទៅនៅភូមិថ្មី។"] ឆ.៥៦ KH 01171499 ["ស៖ តើប្រជាជនដែលលោកឃើញគេបណ្តើរទៅនៅនោះត្រូវបានដាក់ខ្នោះទេ? ឆ.៥៦៖ គេមិនដាក់ខ្នោះទេ តែពេលទៅដល់កន្លែងបានគេចង។ ទៅដល់កន្លែងគេឲ្យអង្គុយចុះ គេប្រជុំ ហើយឈ្លបចេញពីព្រៃមកភ្ជុង ហើយចង ហើយនាំយកទៅរណ្តៅ។ អ្នកវ៉ៃចេះតែវ៉ៃទៅ ហើយអ្នកចងចេះតែចាប់ចងទៅ"]។ ឯកសារ D219/604 កំណត់ហេតុស្តាប់ចម្លើយ សំ ទូច ឆ.៧១ KH 01173499 ["ស៖ តើលោកស្រីបានឃើញអ្វីខ្លះ? ឆ.៧១៖ ខ្ញុំឃើញគេបណ្តើរចងខ្សែរ យកទៅវាយចោល គេឲ្យកាប់ដីអន្ទង្គងកប់ខ្លួនឯង។ ពួក១៧ មានចេះកាប់ដីអន្ទង្គងអីវ៉ា មានចេះធ្វើអីវ៉ា ពួក១៧ហ្នឹង"]។ *សូមមើលផងដែរ* ឯកសារ D1.3.10.14 របាយការណ៍ផែនទីខេត្តតាកែវ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ការរៀបរាប់របស់ រ៉ង់ ហៀង KH 00714211។

[1041] ឯកសារ D219/568 កំណត់ហេតុស្តាប់ចម្លើយ មុំ ផណ្ណា ឆ.៦៨ KH 01165968 ["ខ្ញុំនៅកៃ្សរនោះ ហើយខ្ញុំអាចឮសំឡេងមនុស្សវាយ និងស្រែក ហើយខ្ញុំក៏ងើបមើល បានឃើញគេយកដំបងប្រហែល១ម៉ែត្រ វាយមនុស្សម្តងមួយ១ទម្លាក់ចូលក្នុងអន្ទង"]។ ឯកសារ D119/7 កំណត់ហេតុស្តាប់ចម្លើយ មុំ ផណ្ណា ឆ.២២ KH 00872469 ["ខ្ញុំឃើញគេវ៉ៃមនុស្ស ខ្ញុំភ័យ ខ្ញុំខ្លាច ហើយក៏ដើរចេញពីកន្លែងនោះទៅបោចនៅកន្លែងផ្សេងទៀត។ ខ្ញុំឃើញមានមនុស្សច្រើន ប៉ុន្តែខ្ញុំមិនហ៊ានមើលនោះទេ"]។ ឯកសារ D219/604 កំណត់ហេតុស្តាប់ចម្លើយ សំ ទូច ឆ.៧៤ KH 01173499។ ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.៣២ KH 00872487។

[1042] ឯកសារ D219/604 កំណត់ហេតុស្តាប់ចម្លើយ សំ ទូច ឆ.៧៤ KH 01173499 ["ខ្លះទៀតវាយហើយនៅរស់ខ្វឹកៗ ក៏កប់គរគ្នា"] ឆ.៧៩-៨០ KH 01173500 ["ឆ្នាំ៧៦។ [...] រដូវច្រូតហើយ ខែ០១ ខែ០២"]។

នៅតំបន់ព្រៃសុខុននៅពេលនោះ បានរៀបរាប់ថាបានឮសំឡេងវាយ និងសម្រែក[1043]។ សាក្សីទាំងឡាយក៏បានរៀបរាប់លម្អិតអំពីក្លិនស្អុយចេញពីរណ្តៅចំហដែលពេញទៅដោយសាកសព និងបានឃើញផ្ទុរលប់ដីបែកប្រេះចំហ ដោយសារសាកសពហើម[1044]។

321. ព្រៃសុខុនមានរណ្តៅសាកសពរួមធំៗបីទៅបួនរណ្តៅ[1045] ដែលមានទំហំវិជ្ជមាត្រចាប់ពីប្រមាណ ២០ម៉ែត្រ និងជម្រៅពីរម៉ែត្រ ទៅ១០ម៉ែត្រគុណនឹងប្រាំម៉ែត្រ និងជម្រៅពីរម៉ែត្រ[1046]។ ទោះបីជា

[1043] ឯកសារ D119/7 កំណត់ហេតុស្តាប់ចម្លើយ ម៉ុ ផណ្ណ អ.២២ KH 00872469 ["ស៖ តើអ្នកស្រីមានបាននឹកឃើញព្រឹត្តិការណ៍ណាខ្លះ ដែលកើតឡើងនៅព្រៃសុខុនដែរ ឬទេ? អ.២២៖ នៅពេលដែលខ្ញុំធ្វើការនៅកងចល័ត គេបានឲ្យខ្ញុំទៅបោចរពាក់ ខ្ញុំបានឃើញ [ខ្ម្នីរក្រហម] រ៉ែមនុស្សទម្លាក់អន្ទង់ ហើយស្រែកអ្ហយ ជួយផង!។ ខ្ញុំឮសូរគេវ៉ៃផ្ទ្ធសៗ!"]។

[1044] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ រ៉ង ណុប អ.៣៤ KH 00866860-61 ["រណ្តៅទាំងនោះ គេចំហាទុករហូតកាលពីជំនាន់ខ្ម្នីរក្រហម ហើយគេសម្លាប់មនុស្សដាក់ពីមួយថ្ងៃទៅមួយថ្ងៃជាបន្តបន្ទាប់។ គេសម្លាប់ដាក់រហូតចាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រហូតដល់ខែ១១ ឆ្នាំ១៩៧៨ ពេលដែលវៀតណាមចូលមកដល់ភូមិនេះ។ ដោយសារគេសម្លាប់មនុស្សដាក់ហើយពុំបានលុបរណ្តៅ ធ្វើឲ្យមានក្លិនស្អុយនៅទីនោះ រួចហើយមានហ្វូងរុយខ្មៅងងឹតហើរពេញព្រៃតែម្តង"]។ ឯកសារ D119/4 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ អ.៣០ KH 00872486 ["ស៖ មានសាក្សីម្នាក់ដែលយើងបានសម្ភាស គាត់បាននិយាយថា ពេលដែលដើរកាត់ទីតាំងព្រៃសុខុននោះ គឺមានក្លិនស្អុយ ហើយមានរុយពេញព្រៃតែម្តង។ តើត្រឹមត្រូវដែរទេ? អ.៣០៖ បាទ ត្រឹមត្រូវ។ ខ្ញុំឃើញជាក់ស្តែងតែម្តង ហើយគេឲ្យខ្ញុំទៅកប់អ្នកដែលគេវ៉ៃចោលនៅតាមផ្ទ្ធរទៅព្រៃសុខុន នៅខាងឆ្វេងដៃ ព្រោះគេកប់មិនជិត ហើយពេលដែលវាហើម ក៏ប្រេះផ្ទ្ធរ រួចគេឲ្យខ្ញុំទៅកប់ផ្ទ្ធរនោះវិញ។ ខ្ញោចដែលខ្ញុំទៅកប់នោះជាមនុស្សស្រីពីរនាក់ ដែលមានសក់វែង ហើយគេបានយកចេញពីទួលគោកស្រុកទៅកាន់ទីនោះ"]។

[1045] ឯកសារ D1.3.10.14 មជ្ឈមណ្ឌលឯកសារកម្ពុជា របាយការណ៍វិភាគខេត្តតាកែវ KH 00714211 ["មានរណ្តៅធំៗបួន [នៅព្រៃសុខុន]"]។ ឯកសារ D119/10 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងព្រៃសុខុន KH 00981802 ["បន្ទាប់ពីដើរ ២ គីឡូម៉ែត្រពីច្រកចូលផ្ទ្ធរដើរ ទៅដល់ទីតាំងរណ្តៅសពរួមទាំងបី [...] រណ្តៅពីរនៅខាងស្តាំផ្ទ្ធរដើរ (ខាងជើង) និងមួយទៀតនៅខាងឆ្វេង (ខាងត្បូង)។ ទីតាំងរណ្តៅសពរួមនោះមានឈ្មោះថាត្រពាំងស្វាយ"]។

[1046] ឯកសារ D119/10.2 ឧបសម្ព័ន្ធ ២ រូបថតនៃរបាយការណ៍ស្តីពីការកំណត់ទីកន្លែងរបស់ កសចស EN 00882066 ["ទីតាំង [ផ្ទ្ធរ] ទាំងអស់នេះមានរាងមូល ក្នុងនោះ ផ្ទ្ធរមួយកន្លែងមានអង្កត់ផ្ចិតប្រហែល ២០ ម៉ែត្រ ជម្រៅ +/-២ ម៉ែត្រ និងមួយទៀតមានរាងចតុកោណប្រហែលជា ១០ម៉ែត្រ x ៥ម៉ែត្រ ជម្រៅ+/-២ម៉ែត្រ"]។ ឯកសារ D1.3.10.14 មជ្ឈមណ្ឌលឯកសារកម្ពុជា របាយការណ៍វិភាគខេត្តតាកែវ KH 00714211 ["មានរណ្តៅធំៗបួន [នៅព្រៃសុខុន] [...] រណ្តៅនីមួយៗមានទំហំ ១០ម៉ែត្រ x ១០ម៉ែត្រ។ រណ្តៅនីមួយៗមានជម្រៅពីរម៉ែត្រ"]។ ឯកសារ D119/10 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងព្រៃសុខុន KH 00981802 ["បន្ទាប់ពីដើរ ២ គីឡូម៉ែត្រពីច្រកចូលផ្ទ្ធរដើរ ទៅដល់ទីតាំងរណ្តៅសពរួមទាំងបី [...] រណ្តៅពីរនៅខាងស្តាំផ្ទ្ធរដើរ (ខាងជើង) និងមួយទៀតនៅខាងឆ្វេង (ខាងត្បូង)។ ទីតាំងរណ្តៅសពរួមនោះមានឈ្មោះថាត្រពាំងស្វាយ"]។

ការប៉ាន់ប្រមាណនេះប្រែប្រួលក៏ដោយ ក៏សាក្សីបានលើកឡើងថា មានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅព្រៃសុខុន[1047]។

<u>ការធ្វើទុក្ខបុកម្នេញ</u>

322. ការធ្វើទុក្ខបុកម្នេញត្រូវបានធ្វើឡើងតាមរយៈឧក្រិដ្ឋកម្មនានាដែលបានរៀបរាប់ខាងលើ ប្រឆាំងនឹងខ្មែរក្រោម សមាជិកអតីតរបប លន់ នល់ និងប្រជាជន '១៧ មេសា' នៅវត្តអង្គស្រី និងព្រៃសុខុន។ ពួកខ្មែរក្រោម ពួកសមាជិកនៃអតីតរបប លន់ នល់ និង "ប្រជាជន ១៧ មេសា" ទាំងនេះគឺសុទ្ធតែជាគោលដៅពិសេស ដោយសារតែសមាជិកភាពរបស់ខ្លួនពិតប្រាកដ ឬត្រូវបានគេសន្មតថាជាក្រុមនយោបាយ[1048]។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

323. ផ្អែកលើភស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខវត្តអង្គស្រីមុន្នី និងទីកន្លែងសម្លាប់ព្រៃសុខុន[1049]ៃ អំពើប្រល័យពូជសាសន៍លើក្រុមជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា (ជាពិសេសគឺ ខ្មែរ

[1047] ឯកសារ D119/2 កំណត់ហេតុស្តាប់ចម្លើយ រង ណុប ឆ.៣២ KH 00866860 ["ឃល់ទៅតាមការប៉ាន់ស្មានរបស់ខ្ញុំ មានប្រហែលជា ១០០០ គ្រួសារ ដែលត្រូវបានគេសម្លាប់នៅព្រៃសុខុន។ ចំនួនជាមធ្យមគ្រួសារមួយៗមានប្រហែល ៤នាក់"]។ ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រង ណុប ឆ.២៤ KH 01171494 ["គ្រួសារខ្លះមានបីនាក់ ឬនាក់ ប្រាំនាក់ និងខ្លះមានដល់ប្រាំមួយនាក់ ទៅប្រាំពីរនាក់ឯណោះ"]។ ឯកសារ D219/604 កំណត់ហេតុស្តាប់ចម្លើយ សំ ទូច ឆ.៩២ KH 01173501 ["មិនដឹងប៉ុន្មានទេ ច្រើនពេក"]។ ឯកសារ D1.3.10.14 មជ្ឈមណ្ឌលឯកសារកម្ពុជា របាយការណ៍វិភាគខេត្តតាកែវ KH 00714211-12, 00714205។

[1048] *សូមមើល* VIII.ខ.១.ក. ការទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តិតាមរយៈសហឧក្រិដ្ឋកម្ម្ជ – គោលនយោបាយចំពោះខ្ទាំង។

[1049] ស.ព.អ សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានា ដែល សចស បានទទួលពិនិត្យ តែមិនទាន់បានដាក់ជាបទចោទលើ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះមាន៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយមកលើអតីតសមាជិករដ្ឋាភិបាល លន់ នល់ និង 'ប្រជាជន ១៧ មេសា' និងអំពើអមនុស្សធម៌ផ្សេងៗទៀតគឺការបាត់ខ្លួនដោយបង្ខំ និងការប្រព្រឹត្តិយ៉ាងអមនុស្សធម៌។ ស.ច.ស បានទទួលពិនិត្យអំពើឧក្រិដ្ឋកម្មទាំងនេះតាមរយៈ **D65** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១៥។

ក្រោម)[1050] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល[1051] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹង "ប្រជាជន១៧មេសា" អតីតមន្ត្រីរបប លន់ នល់ និងខ្មែរក្រោម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។

២. ភូមិភាគពាយ័ព្យ

១. ការបោសសម្អាត

ក. យន្តការនៃការបោសសម្អាត

*i. បរិបទពេលវេលា និងតួនាទីរបស់ **យ៉ីម ទិត្យ** និងតាម៉ុក*

324. កម្មាភិបាលភូមិភាគនិរតី យុទ្ធជន និងទាហានរាប់ពាន់នាក់ត្រូវបានតាម៉ុក និង **យ៉ីម ទិត្យ** បញ្ជូនទៅភូមិភាគពាយ័ព្យជាមួយនឹងបេសកកម្ម "បោសសម្អាតពួកពាយ័ព្យ" ទាំងស៊ីវិល ទាំងយោធា និង "គ្រប់គ្រងនៅពាយ័ព្យ"[1052]។ តាម៉ុក បានទទួលបញ្ជាផ្ទាល់ពី ប៉ុល ពត ក្នុងពេលប្រជុំមួយនៅទីក្រុង

[1050] *សូមមើល* V.ค. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មមកលើរៀតណាម។

[1051] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលចំពោះឧក្រិដ្ឋកម្មសម្លាប់រង្គាលមានភ័ស្តុតាងបញ្ជាក់សម្រាប់តែវត្តអង្គស្រី និងព្រៃសុខុន ប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ស.ព.អ មានគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលតម្រូវដើម្បីបង្ហាញពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីកន្លែងសម្លាប់ទាំងអស់ និងទីតាំងការងារដោយបង្ខំនានា រួមមានវត្តអង្គស្រី និងព្រៃសុខុនផងដែរ ត្រូវលើកយកមកពិចារណាបញ្ចូលគ្នា។ ទីតាំងទាំងអស់គឺជាផ្នែកនៃប្រព័ន្ធរៀបចំមួយ ដែលបានអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្ទាំង និងការសម្លាប់នៅតាមទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងនេះ ត្រូវបានជួយសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចគ្នារបស់ យ៉ីម ទិត្យ។

[1052] ឯកសារ D118/150 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ម៉ឿន ឆ.២៣-២៤ KH 00967998 ["ខ្ញុំធ្លាប់ឮ គឺមុនពេលដែលកម្លាំងរបស់ខ្ញុំមកបាត់ដំបង គឺគេប្រាប់យើងថា មានព្រឹត្តិការណ៍ទៅពាយ័ព្យ គឺយើងទៅបោសសម្អាតពួកពាយ័ព្យ [...] ឆ.២៤៖ តាម៉ុក ជាអ្នកនិយាយអំពីរឿងនេះ។ តាម៉ុក និយាយថា "សភាពការណ៍មិនស្រួលទេ ពួកពាយ័ព្យអាចក្បត់ហើយ យកទាហានទៅងាក់"។ ឆ.៥៨-៦០ KH 00968003 ["តាម៉ុក បានហៅកម្លាំងទៅបង្ក្រាបពួកពាយ័ព្យ]។ [...] ឆ.៦០ តាទិត បានយកកម្លាំងទាហានរបស់ខ្លួនឯងពីតាកែវមកជាមួយ តាម៉ុក។ [ដោយសារគេមកបោសសម្អាតភូមិភាគពាយ័ព្យ ដូច្នេះហើយទើបគេឲ្យយើងមកគ្រប់គ្រងនៅពាយ័ព្យវិញម្តង។ មានតែពួកកម្មាភិបាល និងយោធានិរតីទេ ដែលគេបញ្ជូនមកគ្រប់គ្រងនៅភូមិភាគពាយ័ព្យ"]។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៤០ KH 01008703 ["តាម៉ុក បាននិយាយថា មានកម្មាភិបាលពាយ័ព្យទាំងនោះក្បត់អង្គការ ដូច្នេះហើយ ទើបគាត់បញ្ជូនកម្មាភិបាលនិរតីឲ្យទៅគ្រប់គ្រងជំនួសវិញ"]។ ឯកសារ D119/124 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន ឆ.២៧ KH 00987270 [បានអះអាងថា កម្មាភិបាលភូមិភាគនិរតីដឹងថា នឹងត្រូវមានភារកិច្ចសម្រិត

ភ្នំពេញ ដើម្បីរៀបចំការផ្ទេរកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ ដើម្បី "ដោះស្រាយ" អ្នកដែលគ្រប់គ្រងភូមិភាគ និងត្រូវបានចាត់ទុកថាជាជនក្បត់ និងខ្ទាំងរបស់អង្គការ[1053]។ តាម៉ុក និង **យ៉**

សម្រាំង និងកម្មេចកម្មាភិបាលភូមិភាគពាយ័ព្យដែលក្បត់អង្គការ]។ ឯកសារ D219/900 កំណត់ហេតុស្តាប់ចម្លើយ ម្ចូល អេន ឆ.៤០, ៥៧-៥៨ KH 01379790-01379792 [ពន្យល់ថា នៅពាក់កណ្តាលឆ្នាំ១៩៧៧ តាមផ្លូវដែលពួកគេធ្វើដំណើរទៅភូមិភាគពាយ័ព្យ ប៉ុល ពត បានប្រាប់ទៅយោធាភូមិភាគនិរតីថា ពួកគេត្រូវបានបញ្ជូនទៅទីនោះដើម្បី "ការពារកុំឲ្យមានខ្ទាំងបង្កប់នៅក្នុងភូមិភាគពាយ័ព្យ"]។ ឯកសារ D118/222 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ម៉ឿន ឆ.៦ KH 00983233។ ឯកសារ D118/137 ឈន រ៉ន កំណត់ហេតុស្តាប់ចម្លើយ ឆ.១០-១១ KH 00960677។

[1053] ឯកសារ D118/259 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ័ម ឆ.៥៥-៥៨, ៦៣-៦៥, ១៤០, ១៤២, ១៤៩ KH 00997030, 00997031, 00997034 [សាក្សីពន្យល់ថា ប៉ុល ពត និង តាម៉ុក ជាអ្នកសម្រេចបញ្ជូនកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគពាយ័ព្យ ហើយថា ប៉ុល ពត បានដាក់បញ្ជាដោយផ្ទាល់ទៅកាន់ តាម៉ុក នៅក្នុងអង្គប្រជុំមួយ ឲ្យគាត់រៀបចំបញ្ជូន ត្រូវដឹកនាំកងកម្លាំងយោធាភូមិភាគនិរតី។ ដូច្នេះ តាម៉ុក មានអំណាចត្រួតត្រាទៅលើភូមិភាគពាយ័ព្យ ដែល "ក្បត់" ហើយត្រូវ "ដោះស្រាយ" ឲ្យបាន (ល្អដូចជានៅភូមិភាគបូព៌ា និងភូមិភាគពិសេសដែរ)]។ ឯកសារ D119/68 កំណត់ហេតុស្តាប់ចម្លើយ រ៉ាម គុន ហៅ ភីភ្ជួន ឆ.១០ KH 00969023 ["ប៉ុល ពត ទុកចិត្តលើ តាម៉ុក [...] តាម៉ុក ត្រូវបានចាត់តាំងឲ្យទៅគ្រប់គ្រងនៅភូមិភាគនោះ តាម៉ុក ក៏បានជ្រើសរើសមនុស្សដែលគាត់ទុកចិត្តឲ្យអមដំណើរជាមួយគាត់"] ឆ.២-៣ KH 00969022។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ធ៉ីម ឆ.៤០ KH 01008730 ["តាម៉ុក បាននិយាយថា កម្មាភិបាលបាយ័ព្យទាំងនោះក្បត់អង្គការ ដូច្នេះហើយទើបគាត់បញ្ជូនកម្មាភិបាល និរតីឲ្យទៅគ្រប់គ្រងជំនួសវិញ"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ហៅ ខុម ឆ.៧៨ KH 01196544-01196545 ["នៅពេល តាម៉ុក មកដល់ កម្មាភិបាលចាស់ៗត្រូវបានចោទថាក្បត់ជាតិ និងចោទថាជាប់ខ្សែយួន"]។

ម ទិត្យ បានដឹកនាំយុទ្ធនាការបោសសម្អាតដែលមជ្ឈិមបក្សបានបញ្ជាមក[1054]។ **យ៉ាម ទិត្យ** ខ្លួនគាត់ផ្ទាល់ បានចេញបញ្ជាឲ្យបោសសម្អាតក្រុមមនុស្សជាក់លាក់[1055]។

[1054] ឯកសារ D105/3 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន អ.ពព-ព៤ KH 00780638 ["អ.ពព៖ ឮគេថា តាម៉ុក មកពីនិរតី តាទិត មកពីនិរតី [...] ភូមិភាគពាយ័ព្យត្រូវគេចាប់ខ្លួនទាំងអស់ ចាប់តាំងពីថ្នាក់ភូមិភាគចុះមកថ្នាក់តំបន់ រហូតដល់ថ្នាក់សហករណ៍។ ស៖ តើការចាប់នោះ គឺនៅក្រោមអំណាចរបស់ តាម៉ុក និង តាទិត ឬទេ? អ.ព៤៖ បាទ"]។ ឯកសារ D119/124 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន អ.២ព KH 00987269 ["តាម៉ុក បានចាត់តាំងកម្មាភិបាលដែលស្មោះត្រង់ទឹងអង្គការ ពីភូមិភាគនិរតីឲ្យទៅគ្រប់គ្រងស្ទើរតែគ្រប់ភូមិភាគទាំងអស់ រួមទាំងភូមិភាគពាយ័ព្យផងដែរ"]។ ឯកសារ D118/150 កំណត់ហេតុស្តាប់ចម្លើយ ហែម ម្ងៀន អ.៦០ KH 00968003 ["តាទិត បានយកកម្លាំងទាហានរបស់ខ្លួនឯងពីតាកែវមកជាមួយ តាម៉ុក"]។ ឯកសារ D118/86 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹក លី អ.៤ KH 00945417 ["នៅក្នុងខែ៧ ឆ្នាំ១៩៧៨ គេចាប់ តាញ៉ឹម និងកម្មាភិបាលពាយ័ព្យមួយចំនួន ដោយ តាម៉ុក និង តាទិត ហៅ តាទិតក្បាលធំ និងពួកកម្មាភិបាលមកពីនិរតី ដោយគេចោទថា ពួកពាយ័ព្យទាំងនោះក្បត់"]។ ឯកសារ D105/8 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី អ.២០, ២២ KH 00794128 ["ស៖ តើលោកបានឮទេថា តាទិត និយាយពីការបោសសម្អាតកម្មាភិបាលណាដែលក្បត់ដែរឬទេ? អ.២០៖ ហ្ម៎ងហើយ ផែនការគេអ៊ីចឹងតែម្តង បើកុំតែវៀតណាមចូលមក កុំអីគេបោសសម្អាតអស់ហើយ។ [...] អ.២២៖ ព្រោះគេចាត់ទុកពួកខ្ញុំជាខ្មាំង ហើយគេបានសម្លាប់គ្នាខ្ញុំអស់ច្រើននាក់ហើយ"]។ ឯកសារ D118/75 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីយ ក្រ៊ីម អ.២ឥ KH 00934370 ["គាត់អាចដកពួកកម្មាភិបាលពាយ័ព្យចេញបានដោយស្រួល"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ហៅ ខុម អ.៧ឥ KH 01196544 ["គេលឺថា ពេលដែលតាទិត្យ ចូលមក មនុស្សបាត់ខ្លួន។ ថ្នាក់លើ ដូចជា តាវ៉ាញ, តាញ៉ឹម, តាប៉ែត និង តាអ៊ាំ ដែលខ្ញុំឮថា ជាថ្នាក់ភូមិភាគ និងគណៈយោធាត្រូវបានចាប់ខ្លួន"]។ ឯកសារ D219/944 កំណត់ហេតុស្តាប់ចម្លើយ រ៉ែ រួម អ.៦ KH 01415386 ["ដំបូងឡើយ នៅពេលនោះមានតែយោធាពាយ័ព្យ។ ក្រោយមកមានយោធានិរតីនៅក្រោម តាម៉ុក។ មុនដំបូងធ្វើការជាមួយគ្នា ដល់ក្រោយមកធ្វើការចាប់មនុស្ស រួមទាំងយោធាពាយ័ព្យផង"]។ ឯកសារ D20 ហាន់ ធី កំណត់ហេតុស្តាប់ចម្លើយ KH 00699642-00699643។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយឈាន ប៊ីា អ.១១ KH 00960664។ ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន អ.២៧ KH 00891133។

[1055] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿន ប៊ាន អ.១ឥ១ KH 01110197 ["មេកងរបស់ខ្ញុំបានរត់គេចខ្លួន ហើយ តាសាម៉ន បានដេញសម្លាប់ពួកគាត់ ទៅតាមបញ្ជារបស់ តាទិត្យ។ [...] បានប្រាប់ខ្ញុំថា រ៉ីម និង ប៉ុច ត្រូវបានបាញ់ស្លាប់ កាលពីជំនាន់ដែល តាទិត្យ គ្រប់គ្រង។"] អ.២ឦ-២ផ, ៣ឥ KH 01110177-01110178 ["ក្រោយពីដែល តាទិត្យ បានឡើងកាន់អំណាចរយៈពេលពីរសប្តាហ៍ តាព្រ ក៏ត្រូវបានចាប់ខ្លួន។ [" អ.២៧៖ មានយោធាចំនួនប្រាំនាក់ ដែលសុទ្ធសឹងតែមានប្រដាប់អាវុធ បានមករក តាព្រ ហើយប្រាប់គាត់ថា អង្គការថ្នាក់លើឲ្យគាត់ទៅរៀនសូត្រ។ [...] អ.២ផ៖ ប្រហែលជាក្នុងខែមករា ឬខែកុម្ភៈ ឆ្នាំ១ឥ៧ផ [...] អ.៣ឥ៖ [...] ហើយក្រោយពេលដែល តាទិត្យ បានកាន់អំណាចរយៈពេលពីរសប្តាហ៍ ទើបតាព្រ ត្រូវបានចាប់ខ្លួន"]។ ឯកសារ D219/263 កំណត់ហេតុស្តាប់ចម្លើយ អ៊ាំ លុយ អ.៣០, ពព-ព៤, ឥ១-ឥ២, ឥ៥, ឥ៧-ឥ៩, ៥ផ KH 01086094-01086097 [ពន្យល់ប្រាប់ថា យ៉ាម ទិត្យ ប្រធានតំបន់១ "បានបញ្ជាគេឲ្យសម្លាប់សនុស្ស" ដោយសារតែ ន៊ីម ជាកូនចៅរបស់ តាទិត្យ បានចាប់ចង និងវាយ ហើយបាញ់សម្លាប់មនុស្សប្រហែល ៥០ នាក់ នៅវាលស្រែក្នុងពេលយប់]។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ីា អ.៧-ផ KH 00960664 ["តានីម និង តាទិត មកស្នាក់នៅទំនប់កង្ហត ហើយ តាទិត្យ និង

325. ផែនការបោសសម្អាតភូមិភាគពាយ័ព្យ ត្រូវបានអនុវត្តជាដំណាក់កាលៗ ដើម្បីចៀសវាងការដើរ បះបោរពីសំណាក់ថ្នាក់ដឹកនាំភូមិពាយ័ព្យ។ ទោះបីជាពេលវេលានៃការបញ្ជូនពួកគេមានការប្រែ ប្រួល ទៅតាមតំបន់ទាំងប្រាំពីរនៃភូមិភាគក៏ដោយ នៅក្នុងក្រុមដំបូង កម្មាភិបាលភូមិភាគនិរតី និង ទាហានរាប់រយនាក់ត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ នៅចន្លោះពីពាក់កណ្តាលឆ្នាំ១៩៧៦ ដល់ ដើមឆ្នាំ១៩៧៧[1056]។ ក្រុមដំបូងនេះចាប់ផ្តើមធ្វើការជាមួយកម្មាភិបាលភូមិភាគពាយ័ព្យ ថ្នាក់សហ ករណ៍ ថ្នាក់ឃុំ និងថ្នាក់ស្រុក និងតាមដានកម្មាភិបាលមូលដ្ឋាន[1057]។ ការដក ការចាប់ ការឃុំឃាំង

តានីម ចាប់មនុស្សពីសហករណ៍នៅតាមស្រុកសង្កែ និងស្រុកបាត់ដំបង ទៅបាញ់ចោលមិនតិចទេ។ [...] ឆ.៨៖ ដោយសារតែ គាត់ចេញបញ្ជាឲ្យមកចាប់បងប្អូនពីសហករណ៍ ដោយគេហៅមកប្រជុំ រួចគេចាប់ដាក់ឡានយកទៅសម្លាប់ចោលតែម្តង"]។ ឯក សារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.២៣ KH 00934388 ["ប្រជាជនហៅ តាទិត តែ "អា" ទេ គេស្អប់គាត់ ណាស់ ព្រោះគាត់នោះកាច។ ពេល តាទិត ចូលមកដល់តំបន់នេះ ប្រជាជននៅពាយ័ព្យគេដកសិទ្ធិអស់ហើយ គេដកតាំងពីមេភូមិ មេឃុំ ហើយគេដកកាំភ្លើងអស់ ហើយអ្នកខ្លះក៏រត់ចូលព្រៃ។ បើកុំតែវៀតណាមចូលមកទាន់ គេសម្លាប់ប្រជាជននៅទីនេះអស់ ហើយ"] ឆ.៣០ KH 00934389 ["គាត់និយាយថា ពួកពាយ័ព្យនេះគឺ "ក្បាលយួនខ្លួនខ្មែរ" គេចោទថា ចូលដៃចូលជើងជាមួយវៀ តណាម ហេតុនេះហើយ ទើបគេចាប់ពួកកម្មាភិបាលពាយ័ព្យសម្លាប់ចោល។ នៅពេលពួកនិរតីក្តោបក្តាប់តំបន់នេះទាំងស្រុង ហើយ គេចាប់ពួកអតីតកម្មាភិបាលពាយ័ព្យ ដូចជា កងចល័ត ប្រធានសហករណ៍ យកទៅសម្លាប់នៅភូមិបាយ ឃុំបាយដំរ"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ហៅ ខុម ឆ.៧៥ KH 01196544។

[1056] ឯកសារ D118/85 កំណត់ហេតុស្តាប់ចម្លើយ ជា ជឿន ឆ.៩-១០, ១២, ១៥ KH 00945404-00945405 [ប្រាប់ថា ក្នុងខែ មិថុនា ឆ្នាំ១៩៧៦ គាត់ត្រូវបានគេចាត់តាំងឲ្យចេញពីភូមិភាគនិរតី ទៅធ្វើការនៅភូមិភាគពាយ័ព្យ តាមការស្នើសុំរបស់ តាម៉ុក ហើយវាយតម្លៃថា កម្មាភិបាល ពី ១.០០០ ទៅ ១.៥០០ នាក់ បានចាកចេញទៅកាន់ភូមិភាគពាយ័ព្យនៅ ខែមិថុនា ឆ្នាំ១៩៧៦]។ ឯកសារ D118/249 កំណត់ហេតុស្តាប់ចម្លើយ សុន ឯម ឆ.៣១-៣២ KH 00990862 ["ពួកខ្ញុំគឺជាអ្នកទទួលកម្មាភិបាលថ្មីៗ ដែលគេបញ្ជូនមកក្នុងដំណាក់កាលដំបូង ចំនួនចន្លោះពី ៥០០ ទៅ ៦០០ នាក់ មានស្រី មានប្រុស ទាំងស៊ីវិល និងយោធា នៅ ប្រហែលចុងឆ្នាំ១៩៧៦ គឺគេបញ្ជូនមកជំនួសកម្មាភិបាលថ្នាក់ក្រោមចាស់ៗ មុននឹងគេជំនួសកម្មាភិបាលថ្នាក់លើៗ។ [...] ឆ.៣២ ៖ ពួកគេមកពីភូមិភាគនិរតី ស្ត្រីភាគច្រើនមកពីអង្គភាពស្រែអំបិល"]។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៧៩-៨០ KH 01244128 ["ឆ្នាំ៧៧ និរតី បញ្ជាប្រជាពលរដ្ឋ មកដល់ដាក់ដើម្បីកសាងជាមួយពាយ័ព្យ"]។ ឯកសារ D118/107 កំណត់ហេតុស្តាប់ចម្លើយ សែត ខុន ឆ.២៩ KH 00951918 [ក្នុងឆ្នាំ១៩៧៦]។ ឯកសារ D219/861 កំណត់ហេតុ ស្តាប់ចម្លើយ សេក សំអាត ហៅ រ៉ីម ឬ យាយរ៉ីម ឆ.២៩-៣២ KH 01347266 [រំឭកពីការផ្ទេរទៅកាន់ភូមិភាគពាយ័ព្យក្នុងពេល ដំបូងនៃឆ្នាំ១៩៧៧]។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ឆ.១៦-១៨, ៣៣ KH 01075719-01075722 ។ ឯកសារ D118/250 កំណត់ហេតុស្តាប់ចម្លើយ មុត រ៉ើក ឆ.៧០ KH 00992419។ ឯកសារ D219/181 កំណត់ហេតុស្តាប់ ចម្លើយ ប៉ោ បណ្ណែត ឆ.១៩ KH 01066319។ ឯកសារ D219/242 កំណត់ហេតុស្តាប់ចម្លើយ អប់ ច្រ៉ង ហៅ រ៉ន ឆ.១៤, ២៦ KH 01080919-01080920។ ឯកសារ D118/153 កំណត់ហេតុស្តាប់ចម្លើយ ឡុង រ៉ុន ឆ.៥៤ KH 00968038។

[1057] ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.២ KH 00960662-00960663 ["កម្មាភិបាលនិរតីចូលមក ដល់ភូមិភាគនេះនៅដើមឆ្នាំ១៩៧៧ ដោយមុនដំបូង ពួកគេមិនទាន់ចូលមកដឹកនាំភូមិភាគពាយ័ព្យនៅឡើយទេ គឺគេមកពីរបីនាក់

និងការសម្លាប់កម្មាភិបាលមូលដ្ឋានពីថ្នាក់ទាបដល់ថ្នាក់កណ្តាល បានចាប់ផ្តើមប៉ុន្មានខែក្រោយមកនៅពាក់កណ្តាលឆ្នាំ១៩៧៧[1058]។ បន្ទាប់មក ពួកគេត្រូវបានជំនួសភ្លាមៗដោយ

មកធ្វើការនៅតាមមន្ទីរ ស្រុក ឃុំ ជាមួយពួកពាយ័ព្យ ហើយគេមកតាមដានពួកពាយ័ព្យ [...] ពួកនិរតី គេចាប់ផ្តើមចាប់កម្មាភិបាលពាយ័ព្យពីថ្នាក់ក្រោមទៅមុន ហើយចុងបញ្ចប់គឺចាប់តាៗតែម្តង"]។ ឯកសារ D118/86 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម លីហៅ គឹម ឆ.១៣ KH 00945419 ["ពួកនិរតីគេបញ្ជូនមកបង្កប់ឲ្យនៅធ្វើការតាមភូមិតាំងពីឆ្នាំ១៩៧៦ មកម្ល៉េះ [...] គេមិនមែនមកដឹកនាំពួកពាយ័ព្យទេ"]។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៦៤ KH 01244126 ["និរតីមកបង្កប់នៅពាយ័ព្យជិត ១ ឆ្នាំ"]។ ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហ្ជន ជ្រឿម ឆ.១២ KH 00951904 ["ពេលពួកនិរតីចូលមកភូមិភាគពាយ័ព្យដំបូង គេមកធ្វើការជាមួយពួកពាយ័ព្យដោយមិនទាន់ធ្វើការចាប់ខ្លួនអ្វីទេ គឺគេមកតាមដានពួកពាយ័ព្យ"] ឆ.៣៦ KH 00951907 ["គេថាគេមកជួយពួកពាយ័ព្យ តែតាមពិតគេមកដើម្បីស្ទើបអង្កេតពួកពាយ័ព្យ"] ឆ.៣៩ KH 00951908 ។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ស្ទឿម ឆ.៣ KH 00485644។ ឯកសារ D118/137 កំណត់ហេតុស្តាប់ចម្លើយ ឈន រ៉ន ឆ.៨ KH 00960677។ ឯកសារ D219/944 កំណត់ហេតុស្តាប់ចម្លើយ រ៉ែ រ្ជម ឆ.៦ KH 01415386។

[1058] ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហ្ជន ជ្រឿម ឆ.៣៩ KH 00951908 ["ពេលពួកនិរតីមកដំបូងគឺចុងឆ្នាំ១៩៧៦ [...] ពួកនេះហើយគឺជាអ្នកមកស្ទើបការណ៍។ ហើយបានប្រហែល ៣ ទៅ ៤ ខែគឺក្នុងពាក់កណ្តាលឆ្នាំ១៩៧៧ ទើបគេបញ្ជូនកម្មាភិបាលនិរតីមកបន្ថែមទៀត មកធ្វើការបោសសម្អាត និងកាន់ក្តាប់ភូមិភាគពាយ័ព្យ"]។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ហ៊ា ឆ.២ KH 00960663 ["ពួកនិរតី គេចាប់ផ្តើមចាប់កម្មាភិបាលពាយ័ព្យពីថ្នាក់ក្រោមទៅមុន ហើយចុងបញ្ចប់គឺចាប់តាៗតែម្តង"] ឆ.៣៩ KH 00960668 ["បន្ទាប់ពីគេតាមដានហើយ គេចាប់ផ្តើមចាប់កម្មាភិបាលពាយ័ព្យម្តងមួយៗ ដោយគេចាប់ពីត្រឹមថ្នាក់ស្រុក រហូតដល់ថ្នាក់ភូមិភាគ។ ពួកនិរតីគេមិនចាប់ប្រធានសហការណ៍ ឬក៏ប្រធានឃុំទេគ្រាន់តែក្តាប់ពីលើ"] ឆ.៨៤ KH 00960673 ["ស៖ តើលោកដឹងថា មានកម្មាភិបាលពាយ័ព្យថ្នាក់ក្រោមណានៅរស់ដែរឬទេ? ឆ.៨៤៖ មិនមាននរណានៅរស់ទេ"]។ ឯកសារ D219/974.1.6 សុន ឯម ប្រតិចារ៉ឹក ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ម៉ោង 10.57.27-11.00.02 ["គេសម្អាតនោះ គេសម្អាតចាប់ពីកម្មាភិបាលថ្នាក់ខាងក្រោមៗ ដែលយកកម្មាភិបាលផ្សេងៗពីខាងក្រៅ ដែលមានពីនិរតីយកមកជំនួស ធ្វើការងារផ្សុំនឹងកម្មាភិបាលចាស់ ដែលនៅមានស្រាប់ក្នុងខេត្តបាត់ដំបង"]។ ឯកសារ D118/249 កំណត់ហេតុស្តាប់ចម្លើយ សុន ឯម ឆ.៣០-៣១, ៣៤ KH 00990861-00990862 ["ស៖ លោកដឹងឮអំពីការផ្លាស់ប្តូរកម្មាភិបាលចាស់ៗនៅភូមិភាពពាយ័ព្យដោយខ្លួនឯងត្រឹមម៉ែមិថុនា ឬខែកក្កដា ឆ្នាំ១៩៧៧ [...] តើនេះត្រឹមត្រូវដែរឬទេ? ឆ.៣០៖ បាទ ត្រឹមត្រូវ។ [...] ឆ.៣១៖ ចំនួនចន្លោះពី ៥០០ ទៅ ៦០០ នាក់ មានស្រី មានប្រុស ទាំងស៊ីវិល និងយោធា នៅប្រហែលចុងឆ្នាំ១៩៧៦ គឺគេបញ្ជូនមកជំនួសកម្មាភិបាលថ្នាក់ក្រោមចាស់ៗ មុននឹងគេជំនួសកម្មាភិបាលថ្នាក់លើៗ។ [...] ឆ.៣៤៖ ពួកកម្មាភិបាលចាស់ៗនោះត្រូវបានគេចោទថាពួកក្បត់ជាតិ"]។ ឯកសារ D219/181 កំណត់ហេតុស្តាប់ចម្លើយ ប៉ោ បណ្ណែត ឆ.១៤-១៦, ១៩ KH 01066318-01066319 [ពន្យល់ប្រាប់ថា ពីរ ឬបីខែក្រោយមក ទើបពួកគេចាប់ពួកកម្មាភិបាលពាយ័ព្យទាំងនោះ (មុនពេលឆ្នាំខ្មែរ ក្នុងឆ្នាំ១៩៧៧) ពួកកម្មាភិបាលនិរតីចាប់ខ្លួនកម្មាភិបាលពាយ័ព្យ គឺធ្វើឡើងពីថ្នាក់លើចុះមកក្រោម គឺពីថ្នាក់ស្រុកមកថ្នាក់ឃុំ ហើយក្រោយមកទៀត អ្នកអតីតកម្មាភិបាលក្នុងជួរយោធា និងរដ្ឋបាលនៅភូមិភាគ។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ទឿន ម៉ត ឆ.១៧ KH 01155823 ["ទាំងមេកងពាយ័ព្យ និងមេសហការណ៍ ត្រូវបានគេដកចេញអស់ ដោយក្រុមពួកតាទិត្យ"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ស្ទឿម ហៅ សន ស្ទឿម ឆ.២ KH 00485643។ ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.២៧ KH 00891133។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.៥៣

កម្មាភិបាលភូមិភាគនិរតី[1059]។ ដោយសារតែយុទ្ធជន និងកម្មាភិបាលភូមិភាគនិរតី ទាំងប្រជាជនស៊ីវិល ទាំងយោធា ពីរក្រុមធំៗ ត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ នៅក្នុងរយៈពេលសេសសល់នៃឆ្នាំ

KH 01096591។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៤ KH 01132081។ ឯកសារ D219/944 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.៦ KH 01415386។ ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.១៧ KH 01078135។ ឯកសារ D219/66 គង់ ឆោម ហៅ ង៉ោ ណាំឆាយ ហៅ គង់ វិបុល ឆ.៥៤ KH 01037204។

[1059] ឯកសារ D118/250 កំណត់ហេតុស្តាប់ចម្លើយ មុត វើក ឆ.៨៨ KH 00992421 ["ពេលដែលពួកនិរតីមកដល់គឺបានរៀបចំអ្នកគ្រប់គ្រងអស់ហើយ គឺមកជាក្រុមតែម្តង ឧទាហរណ៍ថា ក្នុងឃុំរបស់ខ្ញុំមាន ៥ សហការណ៍ ដូច្នេះគេរៀបចំមនុស្សសម្រាប់គ្រប់គ្រង ៥ សហការណ៍ រួមទាំងយោធាផងដែរ ហើយនៅពេលណាដែលគេចាប់ផ្តើមចាប់ខ្លួនមនុស្ស គេចាប់តែម្តង"]។ ឯកសារ D118/87 កំណត់ហេតុស្តាប់ចម្លើយ ទេព សៀន ឆ.៤១ KH 00945431 [សាក្សីពន្យល់ពីបេសកកម្មរបស់កម្មាភិបាល ៥ នាក់ មកពីភូមិភាគនិរតី រួមទាំងខ្លួនគាត់ផង នៅពេលពួកគេមកដល់ភូមិភាគពាយ័ព្យដើម្បីកាន់កាប់គណៈឃុំ និងគណៈស្រុក]។ ឯកសារ D118/107 កំណត់ហេតុស្តាប់ចម្លើយ សែត ខុន ឆ.២, ១៤ KH 00951915-00951916។ ឯកសារ D118/137 កំណត់ហេតុស្តាប់ចម្លើយ ឈន រ៉ន ឆ.៩ KH 00960677។ ឯកសារ D118/153 កំណត់ហេតុស្តាប់ចម្លើយ ឡុង រ៉ុន ឆ.៣៨ KH 00968036។ ឯកសារ D219/15 [D219/515] កំណត់ហេតុស្តាប់ចម្លើយ ធ៉ីន ឈួយ ឆ.២៨ KH 01149402។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ុន ហៅ គង់ សារ៉ុន ឆ.៤៤ KH 01034501។

១៩៧៧[1060] និងនៅដើមឆ្នាំ១៩៧៨[1061] ចំនួននៃការចាប់ និងសម្លាប់កាន់តែកើនឡើង[1062] រហូតដល់ពេលតាម៉ុក និង **យ៉ីម ទិញ** អាច "ធ្វើការបោសសម្អាត និងកាន់ក្តាប់ភូមិភាគពាយ័ព្យ"[1063]។

[1060] ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈឿត ឯ.៣៥ KH 01425169 ["បើនិយាយទៅ វាមកពីរដំណាក់កាល ស្រីៗបញ្ជូនមកមុន។ នៅខែ ៧ ៧៧ វាមកទាំងផ្ទាំងតែម្តង។ ដើមឆ្នាំ៧៦, ៧៧ ហ្នឹងគេបញ្ជូនមកមួយសា មកក្តាប់យើងហើយសុទ្ធតែស្រីៗ ហើយឲ្យមកក្តាប់នៅតាមការដ្ឋាន។ ហើយនៅខែអាសាធមកទាំងផ្ទាំងតែម្តង"]។ ឯកសារ D118/153 កំណត់ហេតុស្តាប់ចម្លើយ ឡុង រ៉ុន ឯ.៣៨ KH 00968036 ["ពេលនោះ តាម៉ុក គាត់យកកម្មាភិបាល និងប្រជាជនមួយចំនួនពីនិរតី ហើយក៏មានមេយោធា និងកងទ័ព១ខ្លះផងដែរ"] ឯ.៥៤, ៦៤ KH 00968038, 00968040 ["គេបញ្ជូនមនុស្សពីភូមិភាគនិរតីមកភូមិភាគពាយ័ព្យបីដង។ [...] ឯ.៦៤៖ ដំបូងនៅឆ្នាំ១៩៧៧ នៅពេលនោះ យាយចែម ក៏មកដែរ។ ក្រោយមកទៀតចន្លោះ ១៩៧៧ ដល់ ១៩៧៨ ក៏មានមនុស្សមួយក្រុមតូចទៀតមកដែរ។ ចុងក្រោយ គឺក្រុមរបស់ខ្ញុំនៅឆ្នាំ១៩៧៨"]។ ឯកសារ D118/107 កំណត់ហេតុស្តាប់ចម្លើយ សែត ឌុន ឯ.២៩ KH 00951918។ ឯកសារ D219/922 កំណត់ហេតុស្តាប់ចម្លើយ ឈឹម ញ៉ាំ ឯ.៧០-៧២ KH 01391815។ ឯកសារ D118/4 កំណត់ហេតុស្តាប់ចម្លើយ កន ចឹក ឯ.១៥ KH 00882709។

[1061] *សូមមើលឧទាហរណ៍* ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឯ.៤៤ ["នៅដើមឆ្នាំ១៩៧៨ ពួកនិរតីជាច្រើនមានទាំងប្រជាជន កម្មាភិបាល និងយោធាផង ចាប់ផ្តើមចូលមកភូមិភាគពាយ័ព្យនេះ"]។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ដ៏ម ឯ.២៨-២៩, ៣១ KH 01008700-01008701 [សាក្សីត្រូវបានបញ្ជូនពីស្រែអំបិលកែប នៅដើមឆ្នាំ១៩៧៨ ទៅធ្វើជាអនុលេខាស្រុកតំបន់ ១ នៅស្រុកសំឡូត]។ ឯកសារ D118/153 កំណត់ហេតុស្តាប់ចម្លើយ ឡុង រ៉ុន ឯ.៣-៤, ៣៩ KH 00968030-68, 00968036 [សាក្សីត្រូវបានបញ្ជូននៅខែមករា ឆ្នាំ១៩៧៨ ទៅកាន់កាប់តំបន់ ៣ ទៅកាន់មន្ទីរពាណិជ្ជកម្ម តំបន់ ៣ រួមគ្នាជាមួយនឹង នយ លាវ ដែលជាប្រធានមន្ទីរតំបន់ ៣]។ ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឯ.៤, ១០-១២, ២៩ KH 01395015, 01395017 [កុមារត្រូវបានបញ្ជូននៅដើមឆ្នាំ១៩៧៨ ទៅកាន់រោងចក្រស្ករសកំពង់គល់ ជាមួយនឹងកងចល័តកុមារទាំងមូល ដែលមកពីតំបន់ ១៣]។ ឯកសារ D118/107 កំណត់ហេតុស្តាប់ចម្លើយ សែត ឌុន ឯ.២៩ KH 009519183។

[1062] *សូមមើលឧទាហរណ៍* ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឯ.២៣, ៣០ KH 00934388-00934389 ["គាត់និយាយថា ពួកពាយ័ព្យនេះគឺ "ក្បាលយួនខ្ជួនខ្ទេ" [...] ឯ.៣០៖ នៅពេលពួកនិរតីក្តោបក្តាប់តំបន់នេះទាំងស្រុងហើយ គេចាប់ពួកអតីតកម្មាភិបាលពាយ័ព្យ ដូចជា កងចល័ត ប្រធានសហករណ៍ យកទៅសម្លាប់នៅភូមិបាយដំរ៉ា ឃុំបាយដំរ៉ា"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឯ.៣៩ KH 01000261 ["ពេលដែលពួកនិរតីទៅដល់ ពួកគេបានចាប់ទាំងអស់ ទាំងកងតូច កងធំ គណៈសហករណ៍ គណៈស្រុក គណៈតំបន់ និងគណៈភូមិភាគយកទៅសម្លាប់ទាំងអស់"]។ ឯកសារ D219/263 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឯ.៤២, ៤៥, ៤៧-៤៩ KH 01086095-01086096 [និយាយលម្អិតពីរបៀបដែលថាមនុស្ស ៥០ នាក់ រួមទាំងសមាជិកសាច់ញាតិរបស់គាត់ ៤០ នាក់ ត្រូវបានចាប់ខ្ជួនដោយ ញ៉ឹម និងទាហានរបស់គាត់ ដោយវាយសម្លាប់ ឬបាញ់សម្លាប់អ្នកទាំងអស់នោះសម្លាប់នៅទីវាល នៅពេលយប់]។ ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឯ.៥០-៥៣ KH 01029495-01029496។

326. ការបោសសម្អាតនាំឲ្យមានការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ និងគ្រួកនរបស់ពួកគេក្នុងទ្រង់ទ្រាយធំ នៅចន្លោះពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៧ ដល់ចប់របប[1064]។ ផ្អែកលើមុខតំណែងរបស់ពួកគេ ភាពធ្ងន់ធ្ងរនៃបទល្មើសដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត និងទីតាំងភូមិសាស្ត្ររបស់ពួកគេ យុទ្ធជន និងកម្មាភិបាលភូមិភាគពាយ័ព្យដែលត្រូវបានចាប់ខ្លួន ត្រូវបានបញ្ជូនទៅ ស-២១[1065] ឬទៅមន្ទីរសន្តិសុខភូមិភាគពាយ័ព្យ[1066] ឬសម្លាប់នៅទីតាំងសម្លាប់មនុស្សដែលនៅជិតនោះ[1067]។ កម្មាភិបាលថ្នាក់ទាប យុទ្ធជន និងទាហាន ដែលមិនត្រូវបានចាប់ខ្លួន

[1063] D118/106 ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហ្ជួន ជឿម ឆ.ពាក់ KH 00951908 ["ពេលពួកនិរតីមកដំបូងគឺ ចុងឆ្នាំ១៩៧៦ [...] ពួកនេះហើយគឺជាអ្នកមកស៊ើបការណ៍។ ហើយបានប្រហែល ៣ ទៅ ៤ ខែគឺក្នុងពាក់កណ្តាលឆ្នាំ១៩៧៧ ទើបគេបញ្ជូនកម្មាភិបាលនិរតីមកបន្ថែមទៀត មកធ្វើការបោសសម្អាត និងកាន់ក្តាប់ភូមិភាគពាយ័ព្យ"]។

[1064] *សូមមើល* V.ខ.១.ក.ii. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – យន្តការនៃការបោសសម្អាត – ស្ថិតិ ស-២១។ ឧបសម្ព័ន្ធ ឃ.១-ឃ.១៥ (បញ្ជីឈ្មោះ និងតារាងអ្នកទោសស-២១)។ *សូមមើលផងដែរ* ឯកសារ D118/137 កំណត់ហេតុស្តាប់ចម្លើយ ឈន រ៉ន ឆ.៦១ KH 00960683 ["ពេលដែលពួកនិរតីចូលតាំងពីឆ្នាំ១៩៧៧ មកការសម្លាប់កាន់តែខ្លាំងទៅៗ ព្រោះគេចាប់កម្មាភិបាលពាយ័ព្យទាំងអស់ ហើយគេក៏ចាប់ប្រជាជនខ្លះដែរ"]។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត (ភាគ) ឆ.១៣-១៥ KH 01165911 [បញ្ជាក់ថា ឃុំតាប៉ុន មនុស្សប្រហែល ៣៥០ នាក់ត្រូវបានចាប់ខ្លួន និងសម្លាប់ចោល]។ ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈ៊ីង ឈឿត ឆ.៤៨ KH 01425272។

[1065] *សូមមើល* V.ខ.១.ក.ii. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – យន្តការនៃការបោសសម្អាត – ស្ថិតិ ស-២១។ ឧសម្ព័ន្ធ ឃ.១-ឃ.១៥ (បញ្ជីឈ្មោះ និងតារាងអ្នកទោសស-២១)។ *សូមមើលផងដែរ* ឯកសារ D118/249 កំណត់ហេតុស្តាប់ចម្លើយ សុន ឯម ឆ.ពាក់ KH 00990862 [ពន្យល់ថា បើទោសធ្ងន់គេបញ្ជូនទៅមន្ទីរស-២១ (គុកទួលស្លែង) និងព្រៃស]។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៥៥ KH 00960670។

[1066] *សូមមើលឧទាហរណ៍* មន្ទីរសន្តិសុខស្រុក<u>គាស់ក្រឡ</u> តំបន់ ១៖ ឯកសារ D118/4 កំណត់ហេតុស្តាប់ចម្លើយ កន ចឹក ឆ.១៣, ២១ KH 00882709-00882710។ មន្ទីរសន្តិសុខ<u>ជ្រាណន់</u> តំបន់ ១៖ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១, ៤ KH 00934385 ["ឆ.៤៖ កម្មាភិបាលពាយ័ព្យខ្លះគេយកទៅដាក់នៅគុកបាណន់ ហើយខ្លះគេយកទៅសម្លាប់នៅបាយដំរ"]។ មន្ទីរសន្តិសុខ<u>កកោះ</u> តំបន់ ១៖ ឯកសារ D118/137 កំណត់ហេតុស្តាប់ចម្លើយ ឈន រ៉ន ឆ.២៥ KH 00960679។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ផ្ទៀន ហៅ ហម ឆ.ពាក់-ពាក់ KH 00947583។ មន្ទីរសន្តិសុខ<u>ខ្ទុងគ្ង</u> តំបន់ ១៖ ឯកសារ D219/515 ណាត់ហេតុស្តាប់ចម្លើយ អ៊ីន ឈួយ KH 01149399-01149400។ មន្ទីរសន្តិសុខ<u>វត្តកណ្ដាល</u>៖ ឯកសារ D118/249 កំណត់ហេតុស្តាប់ចម្លើយ សុន ឯម ឆ.ពាក់ KH 00990862។ មន្ទីរសន្តិសុខ<u>វត្តគិរីរម្ស</u> តំបន់ ៣៖ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ឈួយ ឆ.២ KH 01149402។ ឯកសារ D219/458 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស ភ្ជឿង ឌី រ៉ៀងរ៉ាវរបស់ភ្ជឿង ឌី KH 01218534។

[1067] *សូមមើលឧទាហរណ៍* ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.ពាក់ KH 00934389 ["នៅពេលពួកនិរតីក្តាបក្តាប់តំបន់នេះទាំងស្រុងហើយ គេចាប់ពួកអតីតកម្មាភិបាលពាយ័ព្យ ដូចជា កងចល័ត ប្រធានសហករណ៍ យកទៅសម្លាប់នៅភូមិបាយដំរ ឃុំបាយដំរ"]។ ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈ្ម ១ ១ KH 01029496-

ឬសម្លាប់ទេ ត្រូវបានបញ្ជូនទៅការដ្ឋានលត់ដំ នៅភូមិភាគពាយ័ព្យ ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ពួកភូមិភាគនិរតី[1068] ឬមួយចំនួនតូចត្រូវបានដកចេញពីតំណែងសំខាន់ៗ និងជំនួសដោយកម្មាភិបាលភូមិភាគនិរតីវិញ[1069]។

327. ក្រោយការចាប់ខ្លួនកម្មាភិបាលថ្នាក់ទាប កម្មាភិបាលស្នើរតែគ្រប់ស្រុក និងតំបន់ទាំងអស់[1070] មេបញ្ជាការកងទ័ពភូមិភាគពាយ័ព្យ (ថ្នាក់ដឹកនាំសេនាធិការ និងមេដឹកនាំទាំងអស់ចាប់ពីកងពល

01029497 [បានអះអាងថា នៅពេលដែលកម្មាភិបាលភូមិភាគនិរតីបានមកដល់ ពួកគេបានចាប់ចងកម្មាភិបាលភូមិភាគពាយ័ព្យ តាំងពីប្រធានកង រហូតដល់ប្រធានយោធាស្រុក ហើយបញ្ជូនពួកគេយកទៅសម្លាប់នៅកែ្សរៗនោះ]។ ឯកសារ D219/263 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.៤២, ៤៥, ៤៧-៤៩ KH 01086095-01086096 [បានបញ្ជាក់លម្អិតថា តើមនុស្ស ៥០ នាក់ ព្រមទាំងសាច់ញាតិ ៤០ នាក់ទៀត ត្រូវបាន ទឹម និងទាហានរបស់គេចាប់ចង បន្ទាប់មកក៏ត្រូវបានវាយ ហើយនិងបាញ់សម្លាប់ក្នុងវាលស្រែនៅពេលយប់]។ ឯកសារ D119/66 កំណត់ហេតុស្តាប់ចម្លើយ ប៊ិន ហ៊ីយ ឆ.១៥ KH 00969016។

[1068] ឯកសារ D118/4 កំណត់ហេតុស្តាប់ចម្លើយ កន ចឹក ឆ.១៧ KH 0082710 [សាក្សីត្រូវបានផ្ទេរពីមុខនាទីជាប្រធានឃុំនៅស្រុកគាស់ក្រឡ តំបន់ ១ នៅចុងឆ្នាំ១៩៧៧ ហើយត្រូវបានចាត់តាំងឲ្យធ្វើការដោយបង្ខំ រួមទាំងដឹកជញ្ជូនអ្នកទោសផង]។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.២២, ៣៥, ៣៩ KH 01129720, 01129722-01129723 ["ពួកអតីតយោធាភូមិភាគពាយ័ព្យទាំងនោះ ត្រូវបានបញ្ជូនពីឃុំកោះ ឲ្យទៅធ្វើការនៅភ្នំជើងទេញ ដែលស្ថិតនៅខាងកើតទួលម្ទេស និងខាងជើងភ្នំធិបតី។ [...] ឆ.៣៥៖ ខ្ញុំបានឃើញអតីតយោធាភូមិភាគពាយ័ព្យ ត្រូវបានគេឲ្យធ្វើការងារធ្ងន់ធ្ងរយ៉ាងខ្លាំង និងទទួលអាហារហូបតិចតួច ហើយពួកគេបានដួលសន្លប់ នៅពេលដែលពួកគេត្រូវរែកដីឡើងលើទំនប់អាង [...] ក្បាលជង្គង់ធំជាងក្បាលរបស់ពួកគេទៅទៀត ហើយបើទោះបីជាដូច្នេះក៏ដោយ ក៏គេនៅតែបង្ខំឲ្យធ្វើការហួសកម្លាំងដដែល។ [...] ឆ.៣៩៖ អតីតយោធាភូមិភាគពាយ័ព្យ គឺមានកងការពារឃ្លាំមើលពួកគេធ្វើការ ព្រោះពួកគេត្រូវបានគេចាត់ទុកថាអ្នកទោស"]។ ឯកសារ D219/305 ងិន ធ៌ីយ ឆ.១៧ KH 01096572។

[1069] *សូមមើលឧទាហរណ៍* ឯកសារ D118/85 កំណត់ហេតុស្តាប់ចម្លើយ ជា ជឿន ឆ.៣៩ KH 00945408-00945409 ["ក្រោយពេលដែលខ្ញុំមកនៅបាត់ដំបង ឧបមាថា ពីមុនគាត់ធ្វើប្រធានភូមិ តែក្រោយមកគេមិនយកគាត់ទៅណាទេ តែគេឲ្យគាត់កាន់ការងារបន្ទាប់យើង។ [...] អាចារ្យ ឌីក គាត់ធ្វើជាមេភូមិនៅទីនោះ តែពេលដែលខ្ញុំមក គេទម្លាក់តំណែងគាត់មកធ្វើជាសមាជិកភូមិ"]។ ឯកសារ D118/87 កំណត់ហេតុស្តាប់ចម្លើយ ទេព សៀន ឆ.១៤ KH 00945429។

[1070] <u>នៅថ្នាក់តំបន់</u>៖ ឯកសារ D219/825.1.2 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ៩១៣ [ជា ហ្ជួន ហៅ រ៉ាញ លេខាតំបន់ ១ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧] លេខរៀង ៥៣៣៤ [ម៉ែ ជុន (ម៉ែន ជុន) ហៅ ហ៊ីង លេខាតំបន់៥ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧] លេខរៀង ៩៨៩០] ស៊ុន គុន ហៅ ស៊ុយ អនុលេខាតំបន់ ៤ ចុះថ្ងៃទី២៦ ខែមិថុនា/ថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៧] លេខរៀង ៦១៧៣] អ៊ីម តូយ លេខាតំបន់៧ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧] លេខរៀង ១៩៩៧] ហម ធិល ហៅ ខាន អនុលេខាតំបន់២ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៧/ថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៧] លេខរៀង ៦២៦៥] អុន សំអ៊ឿន ហៅ សារ៉ែត សមាជិកតំបន់ ២ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៧] លេខរៀង ១២៧៣៨ [តូច ម្ជូច សមាជិកនៃតំបន់ ៤ ចុះថ្ងៃទី៥/៦ ខែសីហា ឆ្នាំ១៩៧៧] លេខរៀង ៨៤៤១ [ស្រី អ៊ីម ហៅ រ៉ែន ប្រធានគណៈកម្មាធិការតំបន់ ២ មុននឹងក្លាយទៅជាលេខាតំបន់ ១ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៧] លេខរៀង ១៣៩៤ [ឌ្យ៊ីក ភាជ ហៅ ណុប សមាជិកតំបន់ ១ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧

ត្រូវបានសម្លាប់នៅថ្ងៃទី១២ ខែតុលា ឆ្នាំ១៩៧៧] លេខរៀង ៥៣៧០ [ផិន ធីម (ម៉ិញ ចឹម ឬ ធីម) ហៅ ហៀង (ប៊ីង) លេខាតំបន់ ៤ ចុះថ្ងៃទី១៨ ខែ១០/ថ្ងៃទី១៨ ខែ១២ ឆ្នាំ១៩៧៧] លេខរៀង ៧៨៧២ [រ៉ន ជេត ហៅ គូ អនុលេខាតំបន់ ៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា/ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៧ ឬ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៨] លេខរៀង ៦៨៥៧ [ភោគ ពុំ (ភោគ សារី ហៅ ពុំ) ជាលេខាតំបន់ ៣, ២៥, ចុះថ្ងៃទី២៩ ឬ ៣០ ខែមិថុនា ឆ្នាំ១៩៧៨។ បានបញ្ជាក់នៅក្នុង "ត្រង់កំណត់សម្គាល់ថា" បញ្ជីអ្នកទោសមន្ទីរស-២១ បានអះអាងថា មនុស្សនេះត្រូវបាន "កម្ទេចចោលដោយមានកំណត់ហេតុសរសេរដោយដៃ និងថតរូប"]។ លេខរៀង ៤៣៩៥ [ឡឹក សៀត ហៅ រ៉ង លេខាតំបន់ ៤ ចុះថ្ងៃទី២៦/២៧ ខែមិថុនា ឆ្នាំ១៩៧៨ ឬ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៧៨]។ <u>នៅថ្នាក់ស្រុក</u> ៖ ឯកសារ D219/825.1.2 បញ្ជីអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀង ២៤ [អន ម៉ោង លេខាស្រុកព្រះនេត្រព្រះ ក្នុងតំបន់ ៥ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧] លេខរៀង ៩៩៦៣ [ស្ងួន សន លេខាស្រុកសេរីសោភណ្ឌ ចុះថ្ងៃទី២៧/២៨ ខែមិថុនា ឆ្នាំ១៩៧៧] លេខរៀង ៤១៨២ [ឃីម ហ្ជត លេខាស្រុកថ្មពួក តំបន់ ៥ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៧] លេខរៀង ៤៨២៣ [អាំ ឆាត (សាត) អនុលេខាស្រុកពួក តំបន់៥ ចុះថ្ងៃទី២៨/២៩ ខែកក្កដា ឆ្នាំ១៩៧៧] លេខរៀង ៥៨១៣ [អ៊ូច ផុន លេខាស្រុកមោង តំបន់២ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ១៩៧៧] លេខរៀង ១៥៥៨ [អែម សឹម (អែម សុន) អនុលេខាស្រុកដូនទាវ ក្នុងតំបន់ ៤ ចុះថ្ងៃទី ៥ ខែសីហា ឆ្នាំ១៩៧៧] លេខរៀង ៥៩០៩ [ង៉ាន យ៉ែម ហៅ ហាត់ លេខាស្រុកភ្នំស្រុក តំបន់ ៥ ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៧៧ ត្រូវបានកម្ទេចនៅថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៧៨] លេខរៀង ៧២២០ [ប៉ូច ធីក ហៅ ធីក អនុលេខាស្រុកដូនទាវ ក្នុងតំបន់ ៤ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧] លេខរៀង ៦៣៣៤ [ហៀ វ៉ាន់ លេខាស្រុក ៤១ តំបន់ ៤ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៧ ត្រូវយកកម្ទេចនៅថ្ងៃទី១១/១២ ខែវិច្ឆិកា ឆ្នាំ១៩៧៧] លេខរៀង ១២៨៥៤ [ត្រ៊ីក ម៉ន ហៅ រ៉ៃ លេខាស្រុក៤១ -ស្រុកបាក់ព្រា- ក្នុងតំបន់៤ ចុះថ្ងៃទី៧/៨ ខែតុលា ឆ្នាំ១៩៧៧] លេខរៀង ៨២៩៣ [ស្ងួត ឆេល ហៅ ភ៉ី អនុលេខាស្រុកដូនទាវ តំបន់ ៤ ចុះថ្ងៃទី៧ ខែតុលា ឆ្នាំ១៩៧៧] លេខរៀង ៤៩២ [ចាន់ អ៊ីន ហៅ អ៊ីន លេខាស្រុកមង្គលបុរី ចុះថ្ងៃទី២២/២៣ ខែតុលា ឆ្នាំ១៩៧៧] លេខរៀង ៧៩០៣ [រ៉ីត ឌាល់ ហៅ ថា លេខាស្រុកអំពិល តំបន់៣ ចុះថ្ងៃទី២២/២៤ ខែតុលា ឆ្នាំ១៩៧៧] លេខរៀង ២៩៩៦ [កើត ព្ញ៉ ហៅ ប៊ា លេខាស្រុកភ្នំសំពៅ ក្នុងតំបន់ ៣ ចុះថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៧៨] លេខរៀង ៨៦៤៨ [ស្វាយ អ៊ីត លេខាស្រុកប៉ោយប៉ែត ក្នុងតំបន់ ៣ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៨] លេខរៀង ៨៩៣៩ [ជា អ៊ីន លេខាស្រុកក្រគរ ក្នុងតំបន់ ២ ចុះថ្ងៃទី២៤ ខែមីនា/ ចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៨] លេខរៀង ៩៥៦៨ [អេង រិន អនុលេខាស្រុកអំពិល ក្នុងតំបន់៣ ចុះថ្ងៃទី១៤/១៥ ខែមេសា ឆ្នាំ ១៩៧៨] លេខរៀង ៥៥៥៣ [ផិន សា ហៅ ម៉ន លេខាស្រុកមង្គលបុរី តំបន់ ៣ ចុះថ្ងៃទី១៦/១៨ ខែមិថុនា ឆ្នាំ១៩៧៨] លេខរៀង ៦១៧ [អេង ឆន ហៅ ឆាន់ ផុន លេខាស្រុកបវេល តំបន់ ៣ ចុះថ្ងៃទី១៧/១៨ ខែមិថុនា ឆ្នាំ១៩៧៨] លេខរៀង ៤៨២៥ [មើ មី ហៅ ម៉ៅ សាម៉ែ លេខាស្រុកប៉ោយប៉ែត ក្នុងតំបន់ ៣ ចុះថ្ងៃទី១៨/២៦ ខែមិថុនា ឆ្នាំ១៩៧៨] លេខរៀង ៤២៤៤ [ឡី ផ្ងយ លេខាស្រុកដូនទាវ តំបន់ ៤ ចុះថ្ងៃទី២៦/៣០ ខែមិថុនា ឆ្នាំ១៩៧៨] លេខរៀង ១១៤៨០ [ប្រាក់ ឃ្ជប ហៅ ឃ្ជន លេខាស្រុកដូនទ្រី តំបន់ ៤ ចុះថ្ងៃទី២៦/៣០ ខែមិថុនា ឆ្នាំ១៩៧៨]។ លេខរៀង ១១៤៨១ [ឃក់ ហ៊ីត លេខាស្រុកបាក់ព្រា តំបន់៤ ចុះថ្ងៃទី២៦/៣០ ខែមិថុនា ឆ្នាំ១៩៧៨] លេខរៀង ១១៤៨២ [ជ៉ីម ចន អនុលេខាស្រុកដូនទាវ ក្នុងតំបន់ ៤ ចុះថ្ងៃទី២៦/៣០ ខែមិថុនា ឆ្នាំ១៩៧៨] លេខរៀង ១១៤៨៣ [ម៉ក់ រ៉ៃ អនុលេខាស្រុកដូនទ្រី ក្នុងតំបន់ ៤ ចុះថ្ងៃទី២៦/៣០ ខែមិថុនា ឆ្នាំ១៩៧៨]។ ឯកសារ D6.1.83 David Chandler (ដេវីដ ឆេនដលរ) *សំឡេងពីមន្ទីរស-២១* ឆ្នាំ១៩៩៩ KH 00191908 ["នៅដំណាច់ឆ្នាំ១៩៧៧ លេខា និងអ្នកជំនួយការទាំងអស់នៅតំបន់ទាំងប្រាំពីរក្នុងភូមិភាគពាយ័ព្យត្រូវបានបោសសម្អាត"]។ ឯកសារ D34.1.9 កិច្ចសម្ភាសន៍របស់ ហេង ទាវ ហៅ តាប៉ែត ដោយ Steve Heder KH 00965620 ["ដល់ក្រោយទៀតយកលេខាតំបន់ ដូចជាលេខាតំបន់នៅក្នុងភូមិភាគពាយ័ព្យទិសយកមក លេខាតំបន់ ដូចជា តំបន់ ១, តំបន់ ២, តំបន់ ៣, តំបន់ ៤, តំបន់ ៥, តំបន់ ៦, តំបន់ ៧។ [...] លេខា អនុលេខា

រហូតដល់វរសេនាតូច និងអនុសេនាធំ)[1071] និងមេសំខាន់ៗនៃមន្ទីរ ៥៦០ និងក្រសួងនៃមន្ទីរនោះ[1072] ត្រូវបានចាប់ខ្លួន និងសម្លាប់ ពីពាក់កណ្តាលឆ្នាំ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨។ ការបោសសម្អាតជាប្រព័ន្ធ បានឈានទៅដល់ការចាប់ខ្លួនសមាជិកគណៈកម្មាធិការភូមិភាគ[1073] ជាពិសេសការចាប់ខ្លួន និងការជំនួសតំណែងលេខាភូមិភាគពាយ័ព្យ រស់ ញ៉ឹម[1074] នៅខែមិថុនា ឆ្នាំ១៩៧៨ និងការដក និងក្រោយមកចាប់ខ្លួនកម្មាភិបាលគណៈកម្មាធិការភូមិភាគពាយ័ព្យ គង់ សុផល ហៅ តាកឹ, ហេង ទាវ ហៅ តាប៉ែត និង ភោគ សារី ហៅ តាតុំ[1075]។

យកមក១មករៀនខាងនយោបាយហ្នឹងចាប់ទាំងអស់។ ដូចជានៅក្នុងកន្លែងហ្នឹង តាហ៊ីង នេះ, ដូចជា តាម៉ន នេះ, ដូចជា តាវ៉ាញ, តាទូ លេខាតំបន់, តាអ៊ៀង, តាសារី"]។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធ្ងៀន ឆ.១៥ KH 00947578 ["ក្រោយពេលខ្ញុំត្រឡប់មកពីប៉េកាំង ប្រទេសចិន ខ្ញុំដឹងថា ប្រធានតំបន់ ១ តំបន់ ២ តំបន់ ៣ តំបន់ ៤ តំបន់ ៥ តំបន់ ៦ តំបន់ ៧ នៃភូមិភាគពាយ័ព្យ ត្រូវបានចាប់ខ្លួនបញ្ជូនទៅភ្នំពេញ ហើយជំនួសដោយអ្នកមកពីភូមិភាគនិរតី"] ឆ.១៦-៣០ KH 00947578-00947581។ ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.២០ KH 01078135។ ឯកសារ D118/190 កំណត់ហេតុស្តាប់ចម្លើយ ម្ម៉ី ពៅ ឆ.១១៤ KH 00977056។ ឯកសារ D118/137 កំណត់ហេតុស្តាប់ចម្លើយ ឈន រ៉ន ឆ.១០-១១ KH 00960678 ឆ.៦១ KH 00960683។ ឯកសារ D219/276 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ង៉ុយ ឆ.២៤ KH 01088940 ។ *សូមមើលខាងក្រោម* V.ខ.១.ខ.ii. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតនៅភូមិភាគពាយ័ព្យ នៅថ្នាក់ភូមិភាគ និងថ្នាក់តំបន់ – ការបោសសម្អាតនៅថ្នាក់តំបន់។

[1071] *សូមមើល* V.ខ.១.ខ.i. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតនៅភូមិភាគពាយ័ព្យនៅថ្នាក់ភូមិភាគ និងថ្នាក់តំបន់ – ការបោសសម្អាតកម្មនៅថ្នាក់ភូមិភាគ – កម្មាភិបាលយោធាភូមិភាគពាយ័ព្យ។

[1072] *សូមមើល* V.ខ.១.ខ.i. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតនៅភូមិភាគពាយ័ព្យ នៅថ្នាក់ភូមិភាគ និងថ្នាក់តំបន់ – ការបោសសម្អាតនៅថ្នាក់ភូមិភាគ – មន្ទីរ៥៦០ និង "ក្រសួងនានា"។

[1073] *សូមមើល* V.ខ.១.ខ.i. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតនៅភូមិភាគពាយ័ព្យ នៅថ្នាក់ភូមិភាគ និងថ្នាក់តំបន់ – ការបោសសម្អាតនៅថ្នាក់ភូមិភាគ – គណៈកម្មាធិការភូមិភាគពាយ័ព្យ។

[1074] *សូមមើល* V.ខ.១.ខ.i. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតនៅភូមិភាគពាយ័ព្យ នៅថ្នាក់ភូមិភាគ និងថ្នាក់តំបន់ – ការបោសសម្អាតនៅថ្នាក់ភូមិភាគ – គណៈកម្មាធិការភូមិភាគពាយ័ព្យ។ សូមមើលផងដែរ ឯកសារ D24 កំណត់ហេតុស្តាប់ចម្លើយ ទេស ប៊ាញ KH 00699639 ["ខ្ញុំដឹងច្បាស់ អ្នកដែលមកជំនួស ម្ចូល សម្បត្តិ គឺ តាម៉ុក ក្នុងឋានៈជាមេដឹកនាំភូមិភាគពាយ័ព្យនេះ។ [...] ហើយខ្ញុំបានឃើញការផ្លាស់ទីរបស់ទាហានជាច្រើនមកតំបន់នោះ គេថាមកចាប់ ម្ចូលសម្បត្តិ"]។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.៤១ KH 01238685។ ឯកសារ D219/210 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ហៅ តាណង ឆ.៦ KH 01074048។ ឯកសារ D219/66 កំណត់ហេតុស្តាប់ចម្លើយ គង់ ឆោម ហៅ ដ៉ោ ណារ៉ាយ ហៅ គង់ វិបុល ឆ.៣៨-៣៩ KH 01037202។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធ្ងៀន ឆ.៣៣-៣៤, ៤១ KH 00947582, 00947585។

[1075] គង់ សុផល ហៅ តាកឹ ត្រូវបានចាប់ខ្លួននៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ហើយបញ្ជូនទៅមន្ទីរ ស-២១។ ហេង ទាវ ហៅ តាប៉ែត ត្រូវបានចាប់ខ្លួននៅខែកញ្ញា-តុលា ឆ្នាំ១៩៧៨ ហើយត្រូវបានបញ្ជូនទៅធ្វើការដោយបង្ខំនៅខេត្តកំពង់ស្ពឺ។ ភោគ សារី ហៅ

328. តាម៉ុក និង **យ៉ឹម ទិត្យ** គ្រប់គ្រងភូមិភាគពាយ័ព្យមួយផ្នែកធំ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ ហើយការគ្រប់គ្រងកាន់តែរីកធំទៅ១ នាពេលក្រោយមក។ ពួកគេប្រចាំការនៅសាលារៀនរបស់បក្ស គឺសាកលវិទ្យាល័យបាត់ដំបង[1076] ធ្វើទស្សនកិច្ចជាប្រចាំនៅការដ្ឋាន[1077] និងដាក់កម្មាភិបាលភូមិភាគ

ពុំ (ទ) បានចូលមន្ទីរស-២១ នៅចុងខែមិថុនា ឆ្នាំ១៩៧៨។ សូមមើល V.ខ.១.ខ.i. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតនៅភូមិភាគពាយ័ព្យ នៅថ្នាក់ភូមិភាគនិងថ្នាក់តំបន់ – ការបោសសម្អាតនៅថ្នាក់ភូមិភាគ – គណៈកម្មាធិការភូមិភាគពាយ័ព្យ។

[1076] ឯកសារ D105/8 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.១៣-២៣ KH 00794127-00794128 [សាក្សីបានចូលរួមក្នុងអង្គប្រជុំនៅបាត់ដំបង ដែលដឹកនាំដោយ យ៉ឹម ទិត្យ ហើយបានចូលរួមដោយ តាញ៉ឹម និង តាប៉ែត ព្រមទាំងកម្មាភិបាល ១៥០ នាក់។ ពន្យល់ថា តាញ៉ឹម, តាប៉ែត និងខ្លួនគាត់ផ្ទាល់មានការភ័យខ្លាច ដែលគេចាប់ខ្លួននៅពេលនោះ ហើយនិយាយថា បានរាយការណ៍រាល់កិច្ចការទាំងអស់ ដែលត្រូវធ្វើទៅកាន់ តាទិត្យ]។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៣៣ KH 00960667 [បានរៀបរាប់ថា តាម៉ុក រស់នៅនិងធ្វើការនៅសាលាសកលបាត់ដំបង មុន តាប៉ែត, តាញ៉ឹម និង តាកឹ ត្រូវបានចាប់ខ្លួន។] ឆ.១៤ KH 00960665 ["កម្មាភិបាលដឹកនាំពាយ័ព្យដែលចូលរួមប្រជុំនោះមានតែបីនាក់ទេ គឺតាញ៉ឹម តាកឹ និង តាប៉ែត ហើយក្រៅពីនោះគឺសុទ្ធតែកម្មាភិបាលនិរតីទាំងអស់"]។ ឯកសារ D118/150 កំណត់ហេតុស្តាប់ចម្លើយ ហែម មឿន ឆ.១១, ៤២ KH 00967996, 00968001 [ផ្ទះរបស់តាម៉ុកក្នុងបរិវេណសាលាសកលដែលនៅទល់មុខព្រលានបន្ត្រហោះ] ឆ.៦១ KH 00968003 ["តាទិត្យ ធ្លាប់បានហៅមេៗយោធាទៅប្រជុំនៅក្នុងបាត់ដំបងនៅបរិវេណសាលាសកល"]។ ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាង ប៊ា ឆ.២៥ KH 00998557 ["ខ្ញុំបានជួបគាត់ផ្ទាល់តែម្តងគត់ គឺនៅសាកលវិទ្យាល័យបាត់ដំបង ហើយកាលនោះ ខ្ញុំនៅអមការពារ តាប៉ែត ដែរ"]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៨៨, ៩៥ KH 01122412។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣១ KH 01132081។

[1077] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿន ប៊ាន ឆ.១៦, ១៧, ១៩, ២៤, ១១៤ KH 01110176, 01110191 [សាក្សីបានឃើញ តាទិត្យ ចុះត្រួតពិនិត្យទំនប់កង្ហតជាទៀងទាត់នៅខែមីនា ឬ ខែមេសា ឆ្នាំ១៩៧៧ ជួនកាលជាមួយ តាម៉ុក ដែលនៅទីនោះ តាទិត្យ បានបញ្ជូនអ្នកក្រោមបង្គាប់នៅក្នុងកងចល័តរបស់ខ្លួន ដូចជា តែម, វ៉ាត, រ៉ន (ស្រី), រ៉ុម (ស្រី) និង ឈា។ គាត់បានឃើញ តាទិត្យ ត្រួតពិនិត្យមើលការដ្ឋាន "ច្រើនលើកវាប់មិនអស់"] ឆ.១១៦ KH 01110192 ["តាទិត្យ បានគ្រប់គ្រងទៅលើទំនប់កង្ហតក្នុងខែវិច្ឆិកា ឬ ខែធ្នូ ឆ្នាំ១៩៧៧ ហើយគាត់គ្រប់គ្រងទាំងស្រុង ក្នុងឆ្នាំ១៩៧៨ ដែលនៅពេលនោះ គឺពុំមានកម្មាភិបាលពាយ័ព្យទៀតឡើយ"]។ ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៦-១៨ KH 01080844 [សាក្សីបានទៅកាន់ទំនប់កង្ហតជាទៀងទាត់ ដើម្បីទៅជួប តាប៉ែត។ ជួនកាល គាត់ឃើញ យ៉ឹម ទិត្យ ដែលនៅក្នុងគណៈតំបន់ ១ ក្នុងអំឡុងពេលប្រជុំ ដែលរៀបចំឡើងនៅទីនោះ ហើយបានឮគាត់និយាយនៅក្នុងអង្គប្រជុំបែបនោះ]។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌៀន ឆ.៤៩-៥១ KH 01210567 ["ឆ.៤៩៖ ជួនកាលគាត់នៅបាណន់ ជួនកាលនៅកង្ហត គាត់ដើរទៅ ហើយប្រជាជនជីកប្រឡាយ។ [...] ឆ.៥០៖ ឆ្នាំ៧៦ [...] ឆ.៥១៖ នៅក្នុងរបបហ្ស៊ីង"] ឆ.២១៧-២១៩ (ភាសាអង់គ្លេស) 01337081 ["ស៖ តើគាត់ទទួលខុសត្រូវអ្នកលើកទំនប់កង្ហតនោះមែនទេ? ឆ.២១៨៖ គាត់បានដើរជុំវិញ។ គាត់ពិនិត្យមើលអ្នកដែលកំពុងធ្វើការ។ ឆ.២១៩៖ ប្រសិនមាននរណាម្នាក់ខ្ជិល ពួកគេនឹងត្រូវយកទៅសម្លាប់"]។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.៥៣ KH 01096591 [សាក្សីបានឮពី តាទិត្យ នៅក្នុងពេលដែល តាទិត្យ បានចុះទៅមើលការដ្ឋានទួលម្ទេសប្រហែលជាក្នុងរដូវប្រាំង ឆ្នាំ១៩៧៧។]។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៥៣, ៥៥, ៦២ KH 00967988-

និរតីដែលស្នោះត្រង់ក្នុងមុខតំណែងសំខាន់ៗ នៅគ្រប់តំបន់ និងមន្ទីរនៃភូមិភាគពាយ័ព្យ។ នៅត្រឹមខែមិថុនា ឆ្នាំ១៩៧៨ ពួកគេគ្រប់គ្រងទាំងស្រុងលើភូមិភាគ ពីក្រោមទៅលើ[1078]។

329. ការកាន់កាប់ភូមិភាគពាយ័ព្យជាដំណើរការមួយដែលមានការវិវត្តទៅមុខ ហើយសូម្បីតែនៅមុនពេលចាប់ខ្លួន រស់ ញ៉ឹម តាម៉ុក និង **យ៉ឹម ទិត្យ** មានឥទ្ធិពល និងគ្រប់គ្រងលើ រស់ ញ៉ឹម និងអនុរបស់គាត់ទៅហើយ[1079]។ យោងតាមចម្លើយរបស់អតីតអង្គរក្សរបស់ រស់ ញ៉ឹម **យ៉ឹម ទិត្យ** បានជួប រស់ ញ៉ឹម នៅផ្ទះរបស់ រស់ ញ៉ឹម នៅបាត់ដំបង រយៈពេលប្រហែលមួយឆ្នាំរហូតដល់ការចាប់ខ្លួន រស់ ញ៉ឹម[1080]។ **យ៉ឹម ទិត្យ** ក៏ជួបប្រជុំជាញឹកញាប់ជាមួយតាប៉ែត ចូលរួមក្នុងការប្រជុំជា

00967989។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.៧២-៧៣, ៧៥, ៩១, ១៤៥ KH 01046466, 01046467, 01046474។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៦៥-៦៨, ៧១ KH 01244126។ ឯកសារ D219/551 កំណត់ហេតុស្តាប់ចម្លើយ ហេង ឃ្លី ឆ.៥៥-៥៦ KH 01157597។

[1078] ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈា ប៊ា ឆ.១៦, ២១, ៤៩ KH 01078135-01078136, 01078140-01078141 ["ខ្ញុំច្បាស់ជា តាទិត្យ ហើយ ព្រោះគេមកគ្រប់គ្រងភូមិភាគ។ [...] ឆ.២១៖ តាទិត្យ និង តានឹម កាន់កាប់ទាំងតំបន់ ១ និងភូមិភាគពាយ័ព្យទាំងមូលផង ក្រោយពីគេចាប់ខ្លួន តាប៉ែត។ [...] ស៖ ក្រោយពី តាប៉ែត បានជួបប្រជុំជាមួយ តាទិត្យ ហើយ លោកនៅស្និទ្ធហ្នឹង តាប៉ែត។ តើលោកដែលសង្កេតឃើញ តាប៉ែត មានការព្រួយបារម្ភ ឬខ្លាច តាទិត្យ ដែរឬទេ? ឆ.៤៩៖ ខ្ញុំសង្កេតឃើញថា គាត់មានការផ្លាស់ប្តូរច្រើន ទាំងទឹកមុខ និងចរិត ក្នុងនោះរួមមានទាំងការខកចិត្ត និងភ័យព្រួយផង។ [...] មុន យ៉ឹម ទិត្យ មកដល់ គាត់មានសិទ្ធិអំណាច និងដើរពិនិត្យមើលការងារនៅតាមសហករណ៍ក្នុងតំបន់ ១ តែក្រោយ យ៉ឹម ទិត្យ ទៅដល់ គាត់គ្មានអំណាចអ្វីទៀតទេ"]។ ឯកសារ D219/894 កំណត់ហេតុស្តាប់ចម្លើយ កៅ ពន ឆ.២២ KH 01379556 ["នៅពេលតាទិត្យ មកបាត់ដំបងគាត់ហៅប្រជុំ ពេលនោះ ខ្ញុំនៅធ្វើការនឹងបាត់ដំបង [...] គាត់ទទួលយកការដឹកនាំចាត់ចែង"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈៀង ប៊ាន ឆ.១១៤ KH 01110192 ["គាត់បានគ្រប់គ្រងតំបន់នោះពេញ លេញ ក្នុងឆ្នាំ ១៩៧៨"]។ ឯកសារ D119/124 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន ឆ.១០ KH 00987267 ["ការបាត់ខ្លួនរបស់កម្មាភិបាលនៅភូមិភាគទាំងអស់បង្កឡើងដោយវត្តមាន តាម៉ុក និងអ្នកនៅក្រោមបង្គាប់របស់គាត់នៅក្នុងភូមិភាគទាំងនោះ"]។ ឯកសារ D219/193 កំណត់ហេតុស្តាប់ចម្លើយ រ៉ាត ផាត ឆ.២១៧ KH 01070087។ ឯកសារ D118/259 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជ៉ីម ឆ.៥៦, ១៤២ KH 00997031, 00997042។

[1079] ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៣៣ KH 00960667 ["តាម៉ុក គាត់ស្នាក់នៅសាលាសកលនោះ [...] កាលនោះ តាប៉ែត តាញ៉ឹម និង តាកឹ មិនទាន់ចាប់ខ្លួននៅឡើយទេ"] ឆ.១៤ KH 00960665 ["នៅពេលប្រជុំនោះគឺសម្រាប់តែថ្នាក់ដឹកនាំ ហើយគ្មានប្រជាជនចូលរួមទេ សូម្បីតែអ្នកការពារក៏គេមិនឲ្យចូលដែរ។ កម្មាភិបាលដឹកនាំពាយ័ព្យដែលចូលរួមប្រជុំនោះមានតែបីនាក់ទេ គឺ តាញ៉ឹម តាកឹ និង តាប៉ែត ហើយក្រៅពីនោះ គឺសុទ្ធតែកម្មាភិបាលនិរតីទាំងអស់"]។

[1080] ឯកសារ D118/137 កំណត់ហេតុស្តាប់ចម្លើយ ឈន វ៉ន ឆ.២៧-៣០ KH 00960679 ["ឆ.២៧៖ ខ្ញុំឮពីឈ្មោះ តាទិត្យ គាត់មកពីនិរតី។ ពេល តាទិត្យ [...] គាត់មកលេងនៅហ្នឹងផ្ទះ តាញ៉ឹម នៅរៀងរាល់ល្ងាច។ [...] មកលេង តាញ៉ឹម ខ្ញុំមិនថាគាត់

សាធារណៈ និងធ្វើដំណើរនៅទូទាំងតំបន់ ១ ជាមួយគាត់ ទាំងនៅមុន និងក្រោយពេលចាប់ខ្លួន រស់ ញ៉ឹម ដែរ[1081]។ យោងតាមចម្លើយរបស់ សៅ ជាប់ ក្នុងពេលប្រជុំនៅឆ្នាំ១៩៧៧ **យ៉ាម ទិត្យ** និងតាម៉ុក វាយតម្លៃលើការវិវត្តទៅមុខនៃការបោសសម្អាត "[ខ្មាំង]ស៊ីរួងផ្ទៃក្នុង"[1082]។

ii. ស្ថិតិនៅ ស-២១

330. ការវិភាគព័ត៌មានដែលមាននៅក្នុងកំណត់ហេតុ ស-២១[1083] បញ្ជាក់ថា ពួកភូមិភាគពាយ័ព្យ ១៣៦៦ នាក់ ត្រូវបានឃុំឃាំងនៅ ស-២១ នៅចន្លោះពីចុងឆ្នាំ១៩៧៥ ដល់ខែធ្នូ ឆ្នាំ១៩៧៨។ បន្ទាប់ពីលុបឈ្មោះអ្នកទោសទាំងអស់ដែលត្រូវបានកំណត់ថា "ប្រជាជនថ្មី" និងអ្នកដែលចូល ស-២១ មុនថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៧ ចេញពីបញ្ជីនេះ នៅសល់ ១០១០ នាក់ ដែលជាជនរងគ្រោះនៃការបោសសម្អាតភូមិភាគពាយ័ព្យ។ ក្នុងក្រុមនេះ ៣១៣ នាក់ធ្វើការនៅថ្នាក់ភូមិភាគ និង ៥៧៦ នាក់ធ្វើការនៅថ្នាក់តំបន់ ឬនៅថ្នាក់ក្រោម។ ពុំមានទិន្នន័យគ្រប់គ្រាន់ដើម្បីកំណត់ថាតើពួកពាយ័ព្យ

និយាយអ្វីទេ [...] ឆ.២៨៖ តាទិត្យ មកបាត់ដំបងមិនដល់មួយឆ្នាំផង ក៏គេចាប់ តាញ៉ឹម។ [...] ឆ.៣០៖ គាត់មានរាងខ្ពស់ មិនធាត់ មិនស្គម មុខរា"]។ ឯកសារ D219/237 កំណត់ហេតុស្តាប់ចម្លើយ ឈន រ៉ន ឆ.៦, ១៥ KH 01080849-01080850។

[1081] ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ រ៉ី ផាន់ ឆ.៣ KH 01040094 ["តាប៉ែត បានប្រកាសនៅក្នុងអង្គប្រជុំថា តាទិត្យ មកពីភូមិភាគនិរតីមកជួយដឹកនាំពួកយើងនៅក្នុងតំបន់ ១"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៥, ៣៤, ៣៦ KH 01110176, 01110178 ["ឆ.១៥៖ គឺប្រហែលជាចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ [...] ឆ.៣៤៖ នៅពេលដែល តាទិត្យ មកដល់ដំបូង គាត់ស្ថិតនៅទួលអណ្តែតរយៈពេលមួយខែ [...] ឆ.៣៦៖ តាទិត្យ បានមកដល់ទួលអណ្តែត ប្រហែលជាខែមីនា ឬខែមេសា ឆ្នាំ១៩៧៧"]។ ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាង ប៊ា ឆ.២៥ KH 00998558 ["ខ្ញុំជាកងការពាររបស់ តាប៉ែត ហើយតែងតែអមដំណើរ តាប៉ែត ទៅជួបជាមួយ តាទិត្យ ពេលគាត់ត្រូវការប្រជុំនឹងគ្នា ប៉ុន្តែខ្ញុំមិនដែលចូលរួមក្នុងប្រជុំទាំងនោះទេ។ ខ្ញុំបានជួបគាត់ផ្ទាល់តែម្តងគត់ គឺនៅសាកលវិទ្យាល័យបាត់ដំបង ហើយកាលនោះខ្ញុំនៅអមការពារ តាប៉ែត ដែរ"]។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៩ KH 01095208 ["តាទិត្យ [...] គាត់តែងតែធ្វើដំណើរចុះឡើងជាមួយ តាប៉ែត តាមរយៈឡានហ្ស៊ីប"]។ ឯកសារ D219/291 [D219/292] កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.២៨ KH 01095210 ["នៅពេលប្រជុំនោះ [តាម៉ុក] ជាអ្នកនិយាយ។ ខ្ញុំមិនដឹងថាគាត់និយាយអ្វីខ្លះទេ ពេលនោះ ប៉ុន្តែខ្ញុំចាំថា តាទិត្យ និង តាប៉ែត ក៏បាននិយាយក្នុងពេលនោះដែរ"]។ ឯកសារ D20 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី KH 00699643។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ សឿន ម៉ត ឆ.៣៥-៣៦ KH 01155826។

[1082] D219/763 ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១២៦-១៣០, ១៣៣-១៣៥, ១៣៨ KH 01244134-01244136 [ពន្យល់ថា គាត់បានចូលរួមប្រជុំពីរដងនៅក្នុងឆ្នាំ១៩៧៧ ដែលដឹកនាំដោយ តាម៉ុក និង តាទិត្យ ក្នុងសាលាអនុវិទ្យាល័យចាស់នៅបាត់ដំបង ហើយថា "អង្គប្រជុំមួយដែលបានធ្វើឡើងដើម្បីដកពិសោធ និងដកស្រង់ពីមូលហេតុអារឿងស៊ីរួងខាងក្នុង" រួមមាន សេ.អ៊ុ.អា និង ខ្សែយ្ជួន ហើយនិង "វាយតម្លៃមើលថា តើមានការរីកចម្រើនប៉ុណ្ណា ឬក៏អត់"]។

[1083] *សូមមើល* ឧបសម្ព័ន្ធ ឃ.១-ឃ.១៥ (បញ្ជី និងតារាងអ្នកទោស ស-២១)។

១២១ នាក់ធ្វើការនៅថ្នាក់ណានោះទេ។ កំណត់ហេតុ ស-២១ បង្ហាញនូវរយៈពេលពីរដែលចំនួនកម្មាភិបាលជាន់ខ្ពស់ (គណៈកម្មាធិការតំបន់ ឬគណៈកម្មាធិការវរសេនាតូច និងខាងលើ) កើនឡើងខ្ពស់។ ដំបូងគឺនៅខែមិថុនា ទៅខែសីហា ឆ្នាំ១៩៧៧ ដែលនៅពេលនោះ កម្មាភិបាលជាន់ខ្ពស់ប្រហែល ៥០ នាក់ និងយុទ្ធជន និងកម្មាភិបាលប្រហែល ១៨០ នាក់ផ្សេងទៀត ត្រូវបានឃុំឃាំងនៅ ស-២១។ ការឡើងខ្ពស់លើកទីពីរ គឺនៅខែមិថុនា ឆ្នាំ១៩៧៨ នៅពេលដែល រស់ ញ៉ឹម និងកម្មាភិបាលជាន់ខ្ពស់នៃភូមិភាគពាយ័ព្យ និងគូកនដែលនៅសេសសល់ ត្រូវបានឃុំឃាំង (កម្មាភិបាលជាន់ខ្ពស់ប្រហែល ១៩ នាក់ និងអ្នកផ្សេងទៀត ៥៦ នាក់)។ នៅចន្លោះរយៈពេលទាំងពីរនេះ ចំនួនទាហាន យុទ្ធជន និងកម្មាភិបាលភូមិភាគពាយ័ព្យដែលចូល ស-២១ នៅតែស្ថិតនៅកម្រិតខ្ពស់ និងទៀងទាត់ (៨២ នាក់នៅខែកញ្ញា ឆ្នាំ១៩៧៧, ១៧៩ នាក់នៅខែតុលា ឆ្នាំ១៩៧៧, ៦០ នាក់នៅខែវិច្ឆិកា ឆ្នាំ១៩៧៧, ៤៣ នាក់នៅខែធ្នូ ឆ្នាំ១៩៧៧, ១០៩ នៅខែមករា ឆ្នាំ១៩៧៨, ១៣៤ នាក់នៅខែកុម្ភៈ ឆ្នាំ១៩៧៨, ៤១ នាក់នៅខែមីនា ឆ្នាំ១៩៧៨, ២៧ នាក់នៅខែមេសា ឆ្នាំ១៩៧៨ និង ២ នាក់នៅខែឧសភា ឆ្នាំ១៩៧៨)។

iii. តួនាទីរបស់ រស់ ញ៉ឹម ក្នុងការបោសសម្អាត

331. ទោះបីអំណាច និងឥទ្ធិពលរបស់ រស់ ញ៉ឹម លើភូមិភាគរបស់គាត់ ចេះតែថយចុះទៅ១ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ក៏ដោយ ក៏គាត់នៅតែជាលេខាភូមិភាគពាយ័ព្យមានតែឈ្មោះ រហូតដល់ពេលចាប់ខ្លួនគាត់នៅខែមិថុនា ឆ្នាំ១៩៧៨។ ក្នុងរយៈពេលនោះ រស់ ញ៉ឹម ព្យាយាមបញ្ចុះបញ្ចូលមជ្ឈិមបក្សថា គាត់នៅតែស្មោះត្រង់[1084]។ យ៉ាងណាមិញ ទាំងនៅមុន និងក្រោយថ្ងៃទី០១ ខែមិថុនា ឆ្នាំ

[1084] ទូរលេខ និងរបាយការណ៍ដែលនៅសេសសល់ដែលបញ្ជូនដោយ រស់ ញ៉ឹម ផ្ញើជូនទៅកាន់ថ្នាក់ដឹកបក្សនៅទីក្រុងភ្នំពេញ បង្ហាញថា អ្នកដឹកនាំភូមិភាគពាយ័ព្យបានធ្វើរបាយការណ៍លម្អិតជូនទៅមជ្ឈិម ស្តីអំពីស្ថានភាពខ្លាំងនៅក្នុងតំបន់របស់ខ្លួន ហើយបានប្រឹងប្រែងស្វែងរកមុខព្រួញ និងសេចក្តីណែនាំ ដើម្បីធ្វើយ៉ាងណាអនុវត្តមាគ៌ាបក្ស៖ ឯកសារ D1.3.27.3 របាយការណ៍ពីម-៥៦០ គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៧៧ KH 00008497-00008501។ ឯកសារ D6.1.966 របាយការណ៍ពីម-៥៦០ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៧៧ KH 00214271-00214273។ ឯកសារ D6.1.59 ទូរលេខពី ញ៉ឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៧៧ KH 00020913 ["ទុកឲ្យអង្គការសម្រេចទៅលើបញ្ហានេះ"]។ ឯកសារ D1.3.30.4 ទូរលេខពី ញ៉ឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៧៧ KH 00020858។ ឯកសារ D132.1.39 ទូរលេខពី ញ៉ឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៧ KH 00020873 ["ខ្ញុំស្នើមតិសំរេចអង្គការ"]។ ឯកសារ D6.1.973 ទូរលេខពី ញ៉ឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៧ KH 00020901 [អះអាងថា គាត់បានធ្វើផ្ទៃក្រូចពោធិ៍សាត់មួយឡានធំទៅជូនថ្នាក់ដឹកនាំបក្ស]។ ឯកសារ D1.3.30.8 ទូរលេខពី ញ៉ឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៧៧ KH 00001319 [ដែលសួរអំពីសេចក្តីសម្រេចអង្គការថា តើគួរវាយប្រហារទីតាំងដែលខ្លាំងកំពុងស្ថិតនៅដែរឬទេ]។

១៩៧៧ និងបន្តរហូតដល់ដើមឆ្នាំ១៩៧៨ រស់ ញ៉ឹម និងអនុរបស់គាត់ គង់ សុផល ហៅ តាកឹ (អ្នកទាំងពីរជាសមាជិកណៈកម្មាធិការមជ្ឈិមរបស់ ប.ក.ក[1085] និងសមាជិកនៃ JCE ជាមួយ **យ៉ឹម ទិព្ធ** និងតាម៉ុក) មានតួនាទីសំខាន់ក្នុងការបោសសម្អាតអ្នកនៅក្រោមបង្គាប់ផ្ទាល់របស់ពួកគាត់។ ពេលខ្លះ ពួកគាត់កោះហៅ តាមបញ្ជារបស់មជ្ឈិមបក្ស កម្មាភិបាលឲ្យទៅរៀនសូត្រនៅទីក្រុងភ្នំពេញ (ដែលនៅទីនោះពួកគាត់ត្រូវបានចាប់ខ្លួន)[1086] ឬបញ្ជា ផ្អែកលើការណែនាំរបស់ថ្នាក់លើ ឲ្យចាប់ និង/ឬសម្លាប់កម្មាភិបាលថ្នាក់ទាប និងក្រុមគ្រួសាររបស់ពួកគេ "រាប់មិនអស់"[1087]។ យ៉ាង

ឯកសារ D1.3.30.19 ទូរលេខ ២៤២ ពី ញ៉ឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ KH 00021043-00021044។ ឯកសារ D6.1.52 ទូរលេខពី ញ៉ឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី១០ ខែមីនា KH 00021443។ ឯកសារ D34.1.9 កិច្ចសម្ភាសន៍របស់ ហេង ទាវ ហៅ ប៉ែត ដោយ Steve Heder KH 00965627 ["ស៖ អ៊ីចឹងតាមដំណឹងតាំងពីជំនាន់ទុំងថា ប៉ុល ពត ហើយនិង តាញ៉ឹម ហ្នឹងអត់មានទំនាស់គ្នា--? ឆ៖ អត់មានទំនាស់អ៊ីធំដុំទេ បាទ"] KH 00965631 ["តាកឹ ក៏ចង់ជិតស្និទ្ធ តាញ៉ឹម ក៏ចង់ជិតស្និទ្ធ"]។

[1085] ឯកសារ D6.1.882 កំណត់ហេតុសួរចម្លើយ កាំង ហ្គេចអ៊ាវ ហៅ ឌុច (តុលាការយោធា) ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៩៩ KH 00320749 ["សមាជិកអចិន្ត្រៃយ៍មជ្ឈិមពេញសិទ្ធិ ដូចជា រស់ ញ៉ឹម, គង់ សុផល ហៅ កឹ"]។ ឯកសារ D179/1.2.11 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារ៉ឹក ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ម៉ោង 15.10.35-15.14.18 ["លេខា ឬក៏ហៅថាគណៈកម្មាធិការភូមិភាគគ្រប់ភូមិភាគ ដែលជាសមាជិកមជ្ឈិមដែរហ្នឹង"]។ ឯកសារ D347/2.1.11 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយលោកតាអាចារ្យ ប្រាក់ សារិន KH 00044060 ["មានមួយថ្នាក់ទៀតនៅមជ្ឈិម តាកឹ [...] តាកឹ គាត់ភូមិភាគដែរ តែគាត់មិនមែនប្រធានទេ"]។ ឯកសារ D1.3.27.5 *បទសម្ភាសន៍ជាមួយជនភៀសខ្លួនកម្ពុជានៅព្រំដែនកម្ពុជា-ថៃ* ដោយ Masato Matsushita និង Stephen Heder ឆ្នាំ១៩៨០ KH 00324764-00324766។ ឯកសារ D117/36.1.23 សៀវភៅនិពន្ធដោយ Philip Short "*ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ*" ឆ្នាំ២០០៥ KH 01169749 EN 00396673។

[1086] ឯកសារ D219/380 កំណត់ហេតុស្តាប់ចម្លើយ ប៉ុក សុផាត ឆ.២២ KH 01113193 ["កម្មាភិបាលពាយ័ព្យទាំងនោះត្រូវបានគេហៅទៅរៀនសូត្រ។ [...] គាត់ជាអ្នកហៅ ពួកកម្មាភិបាលឲ្យទៅរៀនសូត្រ"]។ *សូមមើលផងដែរ* ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធឿន ឆ.២១, ៣១-៣២ KH 00947579, 00947581-00947582 ["ឆ.២១៖ គេហៅគណៈតំបន់ទាំងនោះទៅរៀនសូត្រនៅភ្នំពេញ ហើយពួកគេក៏បាត់ខ្លួនរហូត បន្ទាប់មកឃើញមានអ្នកថ្មីមកពីភូមិភាគនិរតីទៅកាន់កាប់។ [...] ឆ.៣១៖ គេហៅទៅប្រជុំនៅភ្នំពេញ ហើយមួយអាទិត្យក្រោយមកទើបគេប្រកាសថា ចាប់ខ្លួន។ [...] ឆ.៣២៖ ពួកគេទាំងអស់ [...] បាត់ខ្លួន"]។

[1087] ឯកសារ D1.3.30.19 ទូរលេខ ២៤២ ពី ញ៉ឹម គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ KH 00021043-00021044 [ក្រោយ "ជួបអង្គការ" ញ៉ឹម បានធ្វើសេចក្តីរាយការណ៍ គោរពជូនអង្គការ ៨៧០ ថា គាត់ព្យាយាមអនុវត្តតាម "ការណែនាំរបស់អង្គការ ៨៧០" ដោយចាប់ផ្តើមមានការ "ប្រុងប្រយ័ត្នឲ្យបានខ្ពស់ថែមទៀត" ប្រឹងប្រែង "វាយកម្ទេចខ្មាំងឈ្លានពាន" ហើយនិង "បោសសម្អាតពួកសមាសភាពអន្តរាយជាបន្តទៅទៀត"]។ ឯកសារ D219/66 កំណត់ហេតុស្តាប់ចម្លើយ គង់ ឆោម ហៅ ង៉ោ ណារ៉ាយ ហៅ គង់ វិបុល ឆ.៤៣-៤៥, ៤៧-៤៨, ៥១, ៥៤ KH 01037203-01037204 ["ឆ.៤៣៖ ដំបូងគេប្រើ តាញ៉ឹម និង តាកឹ ឲ្យចាប់ខ្លួនកូនចៅរបស់ពួកគាត់នៅក្រោមៗជាមុនសិន។ [...] ឆ.៤៤៖ វាជាការបញ្ជាមកពីថ្នាក់លើ គឺ

ហោចណាស់រហូតដល់ចុងឆ្នាំ១៩៧៧ រស់ ញ៉ឹម បានទទួលចម្លើយសារភាព ស-២១ ជាប្រចាំ ហើយគាត់ប្រើប្រាស់ចម្លើយសារភាពទាំងនេះដើម្បីកំណត់អត្តសញ្ញាណ និង/ឬបញ្ជាឲ្យចាប់ខ្លួនអ្នកដែលអ្នកទោស ស-២១ ឆ្លើយដាក់[1088]។ ការចាប់ខ្លួនទាំងនេះ ពេលខ្លះ ត្រូវបានធ្វើឡើងដោយ

មកពីភ្នំពេញ។ [...] ឆ.៤៥៖ ចាប់ផ្តើមឡើងអំឡុងពីខែ៥ ឆ្នាំ១៩៧៧ ទៅ។ [...] ឆ.៤៧៖ កម្មាភិបាលដែលគេចាប់ខ្លួននៅពេលនោះមានច្រើនណាស់ រាប់មិនអស់ទេ [...] ស៖ តើគេចាប់ខ្លួនសមាជិកក្រុមគ្រួសារកម្មាភិបាលទាំងអស់នោះដែរឬទេ? ឆ.៤៨៖ បាទ ទាំងប្រពន្ធ និងកូន។ [...] ឆ.៥១៖ យោធាជាអ្នកចុះទៅចាប់ផ្ទាល់។ [...] ឆ.៥៤៖ គេបានបញ្ជាទៅ តាញ៉ឹម និង តាកី ឲ្យធ្វើការចាប់ខ្លួនកម្មាភិបាលថ្នាក់ក្រោមៗ មួយចំនួន។ រួចហើយទើបយោធានិរតីចូលមកដល់ ហើយបន្តធ្វើការចាប់ខ្លួនកម្មាភិបាលពាយ័ព្យបន្តទៀត"]។ ឯកសារ D118/249 កំណត់ហេតុស្តាប់ចម្លើយ សុន ឯម ឆ.៤៩, ៥១ KH 0990864 [ពន្យល់ថាបញ្ជាចេញមកពីមជ្ឈិមបក្ស ហើយទាំងនួន ជា និង ប៉ុល ពត បានទៅជួប រស់ ញ៉ឹម និង តាកីនៅឆ្នាំ១៩៧៦ និង ១៩៧៧ នៅភូមិភាគពាយ័ព្យមុនពេលមានការចាប់ខ្លួននៅនឹងកន្លែង]។ ឯកសារ D16 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00699627 ["ក្នុងឆ្នាំ១៩៧៦ និង៧៧ នេះហើយ ដែលគេចាប់យកមេៗភូមិភាគពាយ័ព្យ។ [...] សមាជិកគណៈភូមិភាគពាយ័ព្យអាចមានការពាក់ព័ន្ធដែរ ដោយភូមិភាគទទួលបញ្ជាផ្ទាល់ពីគណៈមជ្ឈិមនៅឯភ្នំពេញ"]។ ឯកសារ D119/29 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន ឈួង ឆ.៤-៦ [រៀបរាប់ពីការចាប់ចងកម្មាភិបាលមូលដ្ឋានដែលបញ្ជាដោយ ញ៉ឹម]។ ឯកសារ D119/33 កំណត់ហេតុស្តាប់ចម្លើយ ឈិត ឃ្យៀក ឆ.១៤ [ចាប់ខ្លួនកម្មាភិបាលដែលដឹកបញ្ជូនចេញទៅដោយជិះរថយន្តពណ៌សមកពីមន្ទីរសន្តិសុខភូមិភាគ]។

ខ្ញុំធ្វើបញ្ជីស្នាមហ្នឹង? ហ្នឹងគឺចល័តតំបន់។ [...] គេដកកម្លាំងពីទំនប់កង្ហតមួយចំនួនឲ្យទៅធ្វើប្រឡាយ។ [...] គ្រប់គ្រងដោយតំបន់ព្រោះគេប្រមូលមនុស្សមួយតំបន់តែម្តង"]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.១៥ KH 01117258 ["មនុស្សពីឃុំ៦០ និងឃុំ៤០ (បច្ចុប្បន្ននេះ ឃុំវាំងកេសី) [...] តំបន់៤ ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅទីនោះ" នៅការដ្ឋានជើងទិញ]។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.១៤ KH 01129719 ["គេបានបញ្ជូនកម្លាំងការងារពីតំបន់១ និងតំបន់៤ ឲ្យទៅធ្វើការនៅទីនោះ [ទួលម្នេស]"] ឆ.១០ KH 01129718 ["មនុស្សដែលគេបញ្ជូណមកពីសហករណ៍កំពង់គោ [ក្នុងតំបន់៤] ឲ្យទៅធ្វើការនៅការដ្ឋានទួលម្នេស។ [...] បន្ថែមពីនេះទៀត គេក៏បញ្ជូនកម្លាំងការងារពីតំបន់១ ឲ្យមកធ្វើការនៅការដ្ឋានទួលម្នេសផងដែរ"]។ ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៣៩ KH 01078139 [នៅការដ្ឋានទួលម្នេស]។ <u>កម្មាភិបាលភូមិភាគពាយ័ព្យ និងអ្នកទោស</u>៖ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៣ KH 01095207 [នៅភ្នំតាថុក]។ ឯកសារ D118/7 កំណត់ហេតុស្តាប់ចម្លើយ ជា ចន្ទី ឆ.១០ KH 00882739 ["បន្ទាប់ពីពួកនិរតីមកដល់ គេបញ្ជូនអ្នកដែលនៅសេសសល់[ក្នុងមន្ទីរសន្តិសុខធិបតី]ទៅរស់នៅ និងធ្វើការនៅតាមសហករណ៍"]។ ឯកសារ D219/313 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.១៣ KH 01097710 ["អ្នកទោស [...] គេបញ្ជូនមកធ្វើការនៅការដ្ឋាន[ជើងទិញ]វិញក្រោយពីគេ 'អប់រំ កសាង' នៅភ្នំធិបតី"]។ ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.១៥ KH 00891132 ["គេយកអ្នកទោសពីគ្រប់សហករណ៍នៃតំបន់១ យកមកធ្វើការនៅទួលម្នេស"] ឆ.៩ KH 00891131 ["អ្នកទោសជួនកាលគេយកទៅទាំងប្តី ទាំងប្រពន្ធ និងកូន"]។ ឯកសារ D1.3.11.36 កំណត់ហេតុបទសម្ភាសន៍ ន្ជួន ម្ជួន ដោយ ក.ស.ព EN 00210532។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.២៧ KH 00920214 ។ ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.៣១ KH 01113253 [នៅទួលម្នេស]។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ផ្ងើន ឆ.១២០ KH 00947599-600 [នៅការដ្ឋានទួលម្នេស]។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.២២ KH 01129720 [នៅភ្នំជើងទិញ] ឆ.១៩, ៣៥ KH 01129720, 22។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៦៦ KH 01187884។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៩២ KH 01205220 [នៅទួលម្នេស]។ <u>ខ្មែរក្រោម</u>៖ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.១៥៤ KH 01032628 ["ប្រជាជនចាស់ ដែលនៅភូមិថ្មីនោះ ភាគច្រើនគឺជាកម្ពុជាក្រោម"]។ ឯកសារ D219/313 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.១ KH 01097708 [នៅការដ្ឋានជើងទិញ]។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.១១៤ KH 01187888 ឆ.៨, ២៣ KH 01187878, 80 [កងកុមារនៅសហករណ៍ធិបតី]។ ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.៨៦, ១៥៧ KH 01029501, 10 [នៅម្តុំភ្នំធិបតី]។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.១, ២៧, ៦៥ KH 00988044, 47, 51 [នៅជើងទិញ]។ "<u>ប្រជាជន ១៧ មេសា</u>"៖ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.៣៦ KH 01095212 [នៅសហករណ៍ធិបតី]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៨ KH 01032613 [នៅភូមិថ្មី "គេបញ្ជូនប្រជាជនពីភ្នំពេញច្រើនរាប់មិនអស់ទៅនៅទីនោះ"]។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.២៩ KH 00981609 [នៅជើងទិញ ពួកអ្នកធ្វើការ "មកពីខេត្តផ្សេងៗ ខ្លះមកពីខេត្តកណ្តាល"]។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៥៨ KH 00960670 ["មានប្រជាជនគេដឹកពីខេត្តតាកែវឲ្យមកធ្វើស្រែនៅ [...] ភ្នំធិបតី"]។

418. "ពេលដែល តាទិត្យ ចូល [...] យើងធ្វើការរហូតដល់ម៉ោង១ រំលងអាធ្រាត្រ"[1448]។ នៅទីតាំងការងារដោយបង្ខំទ្ចលម្ចេស ថ្ងៃធ្វើការមានរយៈពេលយូរចាប់ពីម៉ោង៥ ព្រឹក រហូតដល់ម៉ោង១ រសៀល ដោយមានពេលសម្រាកពីរដង[1449]។ នៅទីកន្លែងផ្សេងទៀតនៅក្នុងសហករណ៍នេះ ប្រជាជនចាប់ផ្តើមធ្វើការយ៉ាងលឿនបំផុតពីម៉ោង៥ ព្រឹក រហូតដល់ម៉ោង៦ ល្ងាច ដោយមានពេលសម្រាកមួយដង ហើយនៅពេលល្ងាចពួកគេចូលរួមប្រជុំ[1450]។ "ពួកខ្ញុំត្រូវធ្វើការរហូតពេញមួយអាទិត្យ គឺពុំមានថ្ងៃណាសម្រាកទេ"[1451]។ បរិមាណការងារកំណត់ត្រូវបានដាក់កម្រិត ដែលមនុស្សត្រូវ "ធ្វើ

[1448] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៤ KH 01205215 [នៅទ្ចលម្ចេស]។ *សូមមើលផងដែរ* ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រឿង សុភាព ឆ.៦៥ KH 01113257 [នៅទ្ចលម្ចេស]។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.៣៤ KH 01095211 [ក្នុងសហករណ៍ធិបតី]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.២០ KH 01032614 [ក្នុងសហករណ៍ធិបតី] ឆ.៤៦ KH 01032617។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៨៩ KH 01149427 [នៅភូមិថ្មី]។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.២៣ KH 00981608 [នៅភូមិជើងទិញ]។

[1449] ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជន ម្ជន ឆ.៥, ៧ KH 00891130-31 ["យើងក្រោកពីម៉ោង៥ព្រឹកទៅធ្វើការ។ ពួកជីវពលបណ្តើរយើងមកហូបបបរវិញនៅម៉ោង ១១ថ្ងៃត្រង់។ [...] បន្ទាប់ពីបាយរួច គេឲ្យធ្វើការវិញនៅម៉ោង១ ហើយធ្វើរហូតដល់ម៉ោង៥។ [...] ក្រោយពីអាហារពេលល្ងាច [...] បោកស្រ្ជវរហូតដល់ម៉ោង ១យប់។"]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៧ KH 01205216។ ឯកសារ D118/196 កំណត់ហេតុស្តាប់ចម្លើយ រឿង សុភាព ឆ.១៩ KH 00978385។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ្ជឿម ឆ.៦១ KH 01157571 ។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឈឿន ឆ.១៨ KH 01129719។

[1450] ឯកសារ D219/517 កំណត់ហេតុស្តាប់សយ ឈឿន ឆ.៨៩ KH 01149427 [នៅភូមិថ្មី] ឆ.៧១ KH 01149424 ["ស៖ នៅភូមិថ្មី តើលោកត្រូវចូលរួមកិច្ចប្រជុំជាមួយនឹងកម្មាភិបាលនិរតី ប៉ុន្ជានដងក្នុងមួយសប្តាហ៍? ឆ.៧១៖ សឹងតែរាល់ថ្ងៃ នៅពេលរសៀលក្រោយម៉ោងធ្វើការ។"]។ ឯកសារ D219/313 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.៨ KH 01097709 [នៅការដ្ឋានជើងទិញ]។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.១៣ KH 00988045 [នៅជើងទិញ]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.២០, ៤៦ KH 01032614, 17 [ក្នុងសហករណ៍ធិបតី]។ ឯកសារ D118/243 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.២២-២៣ KH 00990632 [នៅភ្នំធិបតី]។ *សូមមើលផងដែរ* ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៥៦ KH 01022369 [នៅទ្ចលម្ចេស]។

[1451] ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.៩ KH 01117257 [នៅទីតាំងការងារដោយបង្ខំជើងទិញ]។ *សូមមើលផងដែរ* ឯកសារ D118/243 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.២៣ KH 00990632 [ក្នុងសហករណ៍ធិបតី]។ ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.១៥១ KH 01029509 [នៅជុំវិញភ្នំធិបតី]។ ឯកសារ D5/1097 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ចន្ធី KH 01025737 ។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.២២, ២៥ KH 00981608 [នៅភូមិជើងទិញ "គ្មានពេលសម្រាកថ្ងៃសៅរ៍ ឬថ្ងៃអាទិត្យទេ។ [...] សម្រាកមិនគ្រប់គ្រាន់"]។

ការខ្លាំងដើម្បីសម្រេចតាមផែនការ"[1452]។ ការយាមកាមប្រដាប់ដោយអាវុធត្រូវបានគេប្រើដើម្បីបង្ខំឲ្យមនុស្សធ្វើការ និងដើម្បីហាមឃាត់សេរីភាពក្នុងការដើរហើរ[1453]។ "ពេលសម័យ តាទិត្យ ពេលពលកម្ម មានឈ្លបគេតាមមើល។ [...] ទាំងយើងទាំងគេគឺចេះតែខំធ្វើការ"[1454]។ "ប្រសិនបើនរណាម្នាក់បដិសេធមិនធ្វើការងារតាមបញ្ជា នោះពួកគេនឹង [...] ត្រូវវាយនឹងរំពាត់"[1455]។

[1452] ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.១៥១ KH 01029509 [នៅជុំវិញភ្នំធិបតី "គេ [...] កម្រិតការងារឲ្យយើងធ្វើ ឧទាហរណ៍៖ មនុស្ស៣០នាក់ គេកំណត់ឲ្យកាប់ដីស្រែទំហំ១ហិកតារឲ្យហើយក្នុង១ថ្ងៃ។ ដូច្នេះ យើងត្រូវធ្វើការយ៉ាងខ្លាំងដើម្បីសម្រេចតាមផែនការដែលគេកំណត់។"]។ ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន ម្ហួន ឆ.៥ KH 00891130 [នៅទួលម្នាស]។ ឯកសារ D219/11 កំណត់ហេតុស្តាប់ចម្លើយ ប៉េញ ញ៉ាញ ឆ.៤ KH 01025474 [ក្នុងសហករណ៍ធិបតី]។ ឯកសារ D219/172 កំណត់ហេតុស្តាប់ចម្លើយ តូច ប៊ុនថី ឆ.២០, ២៥ KH 01065965, 67 ["ពេលខ្លះ ក្រុមរបស់ខ្ញុំដែលមានសមាជិក ៣០នាក់ ត្រូវបានគេស្នើឲ្យទៅជួយកប់សាកសព [...] ប្រហែលជាង ១០ដងក្នុងរយៈពេលប្រហែល ១ខែ។ [...] មានសាកសពយ៉ាងតិច ២០០នាក់។ [...] ពួកខ្ញុំ ដែលគេចាត់តាំងសម្រាប់តែកប់សាកសពនោះគឺជាប់រវល់រហូត។"]។

[1453] ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន ម្ហួន ឆ.៥ KH 00891130 [នៅទួលម្នាស៖ "គេមានកងជីវពលកាន់កាំភ្លើងបញ្ជាឲ្យយើងធ្វើការ។"]។ ឯកសារ D118/277 កំណត់ហេតុស្តាប់ចម្លើយ សែម រ៉ើង ឆ.៦៣-៦៤ KH 01000109-10 [ប្រហែលជាមួយគីឡូម៉ែត្រពីភ្នំធិបតី៖ "គេកម្រិតប្រជាជនមិនឲ្យដើរទៅណានោះទេ គឺគិតតែធ្វើការនៅកន្លែងដែលគេចាត់តាំងឲ្យធ្វើ។ [...] គេក៏ចាប់ផ្តើមដាក់យោធា ឬឈ្លបឲ្យឃ្លាំមើលប្រជាជនធ្វើការ [...] រហូតដល់ចុងរបបខ្មែរក្រហម។"]។ ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.៥៦-៥៧ KH 01113256 [នៅការដ្ឋានទួលម្នាស]។ ឯកសារ D118/196 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.២០ KH 00978385 [នៅការដ្ឋានទួលម្នាស]។ ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៤០-៤១ KH 01022368 [នៅទួលម្នាស]។ ឯកសារ D219/263 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.៩៥ KH 01086101 [នៅភ្នំធិបតី]។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃ្យ៉ាន ឆ.៣៩ KH 01129723 [នៅទួលម្នាស] ។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.២២ KH 00988046 [នៅជើងទិញ]។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.៣៨ KH 00985155 [នៅការដ្ឋានឆាយបល្ល័ង្ក អ្នកយាម "យកកាំភ្លើងមកគំរាមខ្ញុំ ព្រោះខ្ញុំខ្លាចឈ្លើងនៅពេលធ្វើស្រែ។ គេបានសម្លុតខ្ញុំឲ្យចុះទៅធ្វើស្រែវិញ"]។

[1454] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៤, ៧៨ KH 00981610 [នៅទួលម្នាស]។ *សូមមើលផងដែរ* ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.១៤៩-១៥០ KH 01029509 [នៅជុំវិញភ្នំធិបតី "គេឃ្លាំមើលយើង ថាតើយើងសកម្ម ឬមិនសកម្មនឹងការងារ។ ពួកគេគឺយោធា ហើយមានកាំភ្លាំង។"]។

[1455] ឯកសារ D118/231 កំណត់ហេតុស្តាប់ចម្លើយ ឃួយ ហ្ស៊ីយ ឆ.៤៩ KH 00985938 [នៅជិតភ្នំធិបតី]។

419. ពលករ "ត្រូវបានគេ [...] បង្ខំឲ្យធ្វើការហួសកម្លាំង"[1456]។ "មានស្ត្រីខ្លះទៅអង្គុយបទជើងតូច តែតាមពិតទៅគឺគ្មានអីចេញទេ ព្រោះមនុស្សវាអស់ប្រើហួសកម្លាំងមនុស្ស"[1457]។ អ្នកដែលមិនអាចបញ្ចប់ការងារដែលបានកំណត់ឲ្យ ទោះដោយមូលហេតុណាក៏ដោយ "ត្រូវបានគេដាក់ទណ្ឌកម្មឲ្យធ្វើការធ្ងន់ជាងមុនទ្វេដង" "[ចោទថា]ជាខ្ទាំង" "ត្រូវវាយនឹងរំពាត់" និង/ឬ "ត្រូវគេហៅទៅកសាងពីរបីដង"[1458]។ "ប្រសិនបើមិនកែប្រែ ពួកគេ [...] យកទៅសម្លាប់ចោល"[1459]។ កម្មករដែល "ធ្វើពុតជាឈឺ" ឬ "អាចអង្គុយ ឈរ ឬដើរបានតិចតួច [...] ឈឺសតិអារម្មណ៍" និងត្រូវ "កសាង"[1460]។

[1456] ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៣៥ KH 01129722 [នៅការដ្ឋានទួលម្នេស៖ "ពួកគេបានដួលសន្លប់នៅពេលដែល ពួកគេត្រូវរែកដីឡើងទំនប់អាង ដែលមានកំពស់ប្រហែល ៧ម៉ែត្រ។ [...] ទោះបីជាដូច្នេះដ៏ដោយ ក៏គេនៅតែបង្ខំឲ្យធ្វើការហួសកម្លាំងដដែល។"]។ *សូមមើលផងដែរ* ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.១៣៧ KH 01029507 [នៅភ្នំធិបតី៖ "ពួកយើង [...] អស់កម្លាំង ដើរមិនចង់រួច ព្រោះគេបង្ខំធ្វើការខ្លាំង"]។ ឯកសារ D118/231 កំណត់ហេតុស្តាប់ចម្លើយ ឃួយ ហួយ ឆ.៥៨ KH 00985939 [នៅជិតភ្នំធិបតី]។ ការកេញប្រវ័ញ្ចលើពលករបានអនុញ្ញាតឲ្យ លេខាភូមិភាគពាយ័ព្យ រស់ ញ៉ឹម រាយការណ៍ទៅមន្ទីរ ៨៧០ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ ថា នៅភូមិភាគពាយ័ព្យ "ការងារល្អផង ហើយលឿនជាងមុនដែរ [...] ប្រឡាយ [...] និងរៀបចំដាក់ជីតាមស្រែក៏យកចិត្តទុកដាក់ជាងឆ្នាំមុន។" *សូមមើល* ឯកសារ D1.3.30.19 ទូរលេខ ២៤២ ពី ញ៉ឹម ទៅកាន់អង្គការ ៨៧០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ KH 00021044។

[1457] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៨ KH 01205216 [នៅទួលម្នេស]។

[1458] ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៣៥ KH 01129722 [នៅការដ្ឋានទួលម្នេស "ខ្ញុំធ្លាប់ឮអំពីការដែលអ្នកធ្វើការងារ ត្រូវបានគេអនុវត្តវិន័យនៅពេលដែលពួកគេធ្វើការងារមិនបានតាមការកំណត់របស់គេ។ អ្នកធ្វើការទាំងនោះ ត្រូវបានគេដាក់ទណ្ឌកម្មឲ្យធ្វើការធ្ងន់ជាងមុនទ្វេដង។"]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៥៤, ៧៨ KH 01205210, 16 [នៅទួលម្នេស អ្នកដែល "ធ្វើបាក់ដងរែក ប្រហែកបង្គ៌ បាក់ដងចប អ្នកដែលធ្លាប់ឥវ៉ាអីគេបន្ថិចបន្ថូច [...] គេថាជាខ្ទាំង ហើយត្រូវគេយកទៅរៀនសូត្រហើយ គឺមិនចាំបាច់អីច្រើនទេ។" "បើយើងមិនធ្វើការ សមមិត្ត ខេន គេនឹងចោទយើងថាខ្សែសក្តិភូមិ"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៣២ KH 01032615 [ក្នុងសហករណ៍ធិបតី "ខ្ញុំធ្លាប់ឃើញមានគេឈប់សម្រាកញ៉ីកញ្ជាប់ ហើយក្រោយមក ពួកគេត្រូវបានហៅទៅកសាងពីរទៅបីដង។"] ឆ.៤៦ KH 01032617។ *សូមមើលផ្ទុយពីនេះ* ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៤៧ KH 01022368 [នៅទួលម្នេស "ពួកគេគ្រាន់តែស្តីបន្ទោសនៅពេលដែលយើងធ្វើការងារមិនល្អ។"]។

[1459] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៣២ KH 01032615 [ក្នុងសហករណ៍ធិបតី] ឆ.៤៦ KH 01032615។

[1460] ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.១៣៨-១៣៩ KH 01029507-08 [នៅជុំវិញភ្នំធិបតី]។ *សូមមើលផងដែរ* ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៥២ KH 01022369 [នៅទួលម្នេស]។ ឯកសារ D118/231 កំណត់ហេតុស្តាប់ចម្លើយ ឃួយ ហួយ ឆ.៤៣ KH 00985937 [នៅជិតភ្នំធិបតី]។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ីម ឆ.៦២ KH 01157571 [នៅទួលម្នេស]។

"តែក្នុងករណីដែលមិនកែប្រែម្តង ឬពីរដង គេនឹងយកអ្នកនោះទៅមន្ទីរឃុំឃាំង"[1461]។ កម្មករតម្រូវឲ្យចូលរួមប្រជុំជាប្រចាំ ដែលក្នុងពេលនោះកម្មករដែលបានធ្វើឲ្យបាក់ឧបករណ៍ "ឬគវ៉ាអីគេបន្តិចបន្តួច" ត្រូវគេចោទថាខ្មាំង[1462]។

420. ខណៈដែលកំពុងឈឺចាប់នឹងការងារហួសកម្លាំង ពលករទទួលបានអាហារតែមួយពេល ឬពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ ដែលការណ៍នេះ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីនិយាយថា វាមិនគ្រប់គ្រាន់នោះឡើយ[1463]។ អ្នកខ្លះដើររកអាហារស្មោកគ្រោក ដែលជាលទ្ធផលធ្វើឲ្យមនុស្សជាច្រើនកើត

[1461] ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ វ៉ាន់នី ឆ.១៤០ KH 01029508 [នៅជុំវិញភ្នំធិបតី]។

[1462] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៥០, ៥៤ KH 01205209-10 [នៅទួលម្ទេស៖ "ពេលប្រជុំជីវភាពប្រចាំថ្ងៃមានបាត់មនុស្សបួនដប់នាក់ [...] មូលហេតុដែលបញ្ជូនទៅ គឺអ្នកដែលធ្លាប់ធ្វើបាក់ដងរែក វហែកបង្គី បាក់ដងចប អ្នកដែលធ្លាប់គវ៉ាអីគេបន្តិចបន្តួចគេថា ជាខ្មាំង"]។ ឯកសារ D105/3 កំណត់ហេតុស្តាប់ចម្លើយ នួន មួន ឆ.២៥ KH 00780637 [នៅទួលម្ទេស "ពេលខ្ញុំកាប់ដីទៅវៀចចប ហើយគេចោតខ្ញុំនៅក្នុងមេទ្ទិញថា អ្នកដែលធ្វើបាក់ចបគឺជាខ្មាំង។ គេថាសូម្បីតែបាក់ស្លាបព្រាក៏ជាខ្មាំងដែរ។"] (កត់សម្គាល់៖ "ក្នុងមួយសប្តាហ៍គេមានស្វ័យទិទានម្តង" *សូមមើល* ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ នួន មួន ឆ.១១ KH 00891131)។ *សូមមើលផងដែរ* ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ វ៉ាច ឆ.៥៣-៥៤ KH 01022369 [សាក្សីបានធ្វើការនៅទួលម្ទេស៖ "ការប្រជុំស្វ័យទិទានក៏ធ្វើជាមួយកម្មាភិបាលថ្មីមកពីនិរតីផងដែរ [...] ១០ថ្ងៃម្តង" នៅក្នុងភូមិថ្មី។]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.៩ KH 01117257 [នៅការដ្ឋានជើងទិញ៖ "ពួកយើងក៏ត្រូវចូលរួមប្រជុំជារៀងរាល់យប់ ដែលមានរយៈពេល១ម៉ោង ឬ២ម៉ោង ដើម្បី 'ពង្រឹងគោលជំហរ'។"]។

[1463] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៧, ៨៩ KH 01205216, 20 [នៅទួលម្ទេស៖ "អាហារវាឲ្យយើងតិច។ [...] បានតែពីរពេល។ [...] ជំនាន់ តាទិត្យ [...] ១០នាក់ បីកំប៉ុង។"]។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីវ ឆ.KH 01095211 [ក្នុងសហករណ៍ធិបតី]។ ឯកសារ D118/196 កំណត់ហេតុស្តាប់ចម្លើយ រឿង សុភាព ឆ.២១-២២ KH 00978385 [នៅការដ្ឋានទួលម្ទេស៖ "របបអាហារគេឲ្យ បបររាវៗ មួយថ្ងៃបានមួយបោយ។" វាមិនគ្រប់គ្រាន់ទេ។]។ ឯកសារ D219/549 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អឿម ឆ.៨-១០ KH 01157576 [នៅទួលម្ទេស]។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.១៤, ៤៤ KH 00988045, 49 [នៅការដ្ឋានជើងទិញ]។ ឯកសារ D219/313 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.៨ KH 01097709 [នៅការដ្ឋានជើងទិញ "ពីរពេលក្នុងមួយថ្ងៃ [...] មួយពេលៗ គេឲ្យបបរមួយកាទឹកម្នាក់។ មិនគ្រប់គ្រាន់ហូបទេ។"]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.៨ KH 01117257។ ឯកសារ D118/277 កំណត់ហេតុស្តាប់ចម្លើយ សែម វឿង ឆ.៥១-៥២, ៥៦ KH 01000108 [ប្រហែលជាមួយគីឡូម៉ែត្រពីភ្នំធិបតី]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.២១-២២, ៣១, ១០៣ KH 01032614, 15, 23។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៧៨-៧៩ KH 01187885 [ក្នុងសហករណ៍ធិបតី]។ ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ វ៉ាច ឆ.៤៥ KH 01022368 [នៅទួលម្ទេស]។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត យឿន ឆ៣៥, ៤៤ KH 01129722, 24 [នៅការដ្ឋានទួលម្ទេស]។ ឯកសារ D118/231 កំណត់ហេតុស្តាប់ចម្លើយ បួយ ហ៊ុយ ឆ.៣៨-៣៩, ៥៧ KH 00985936-37, 39 [នៅជិតភ្នំធិបតី]។ ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ

"ជំងឺរាក"[1464]។ របបអាហារត្រូវបានគេដកហូត ឬកាត់ពាក់កណ្តាល ប្រសិនបើមនុស្សមិនបានធ្វើការ រួមទាំងអ្នកទាំងឡាយណាដែលឈឺ និងអ្នកដែល "ឆ្លងទៅឆ្លងមក"[1465]។ ប្រជាជន "មិនហ៊ាននិយាយទេ" ពីព្រោះពួកគេខ្លាច[1466]។

នាប ឆ.៤៤-៤៥ KH 01008722 [នៅភ្នំធិបតី]។ ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.១៣៥-១៣៧ KH 0102950 [នៅភ្នំធិបតី]។ ឯកសារ D118/243 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ២៣ KH 00990632 [នៅភ្នំធិបតី]។ ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន មួន ឆ.៦-៧ KH 00891131 [នៅទួលម្នេស]។ ឯកសារ D5/1097 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ចន្ធី KH 01025737។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.២៥, ៤៤-៤៥ KH 00981608, 11 [នៅភូមិជើងទិញ]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ លេខាភូមិភាគពាយ័ព្យ រស់ ញ៉ឹម បានរាយការណ៍ទៅកាន់មន្ទីរ ៨៧០ ដូចខាងក្រោម៖ "ខាងជីវភាពប្រជាជន៖ ក្នុងភ/ភ៖ ការខ្វះខាតគឺ៖ ៣ តំបន់ ១+៤+៥។ ទាំងអស់តំបន់៥ ខ្វះជាងគេ រួចមកតំបន់១ [...] តំបន់១៖ [...] ក្រោយមួយកំប៉ង់កន្លះ កន្លែងខ្លះដល់ពាក់កណ្តាលខែ៦ ខ្លះជាងខែ៦។" *សូមមើល* ឯកសារ D1.3.30.19 ទូរលេខ ២៤២ ពី ញ៉ឹម ទៅកាន់អង្គការ ៨៧០ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ KH 00021043-44។

[1464] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១០៤ KH 01205223 [នៅទួលម្នេស "សម្ងួរតែជម្ងឺរាកដោយសារតែគេឲ្យបបរតិច ហើយគាត់ដើរវើសក្តាម ខ្យងយកមកដុតស៊ីដោយមិនឆ្អិន។"]។ *សូមមើលផងដែរ* ឯកសារ D118/277 កំណត់ហេតុស្តាប់ចម្លើយ សែម រ៉ើង ឆ.៥២ KH 01000108 ["ម្ហូបអាហារគឺមិនគ្រប់គ្រាន់ទេ។ [...] ប្រជាជនត្រូវលួចលាក់ក្តាម ឬខ្យងទុកហូបផ្ទាល់ខ្លួន។"]។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.១៥ KH 00988045 [នៅការដ្ឋានជើងទិញ៖ "ពេលដែលហូបមិនអ្នែត ខ្ញុំបេះបន្លែពីក្នុងព្រៃដើម្បីដាក់ក្នុងបាយហូប។"]។ ឯកសារ D5/1097 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ចន្ធី KH 01025737 ["[ខ្ញុំ] ចាប់ក្ងានក្ងាត់ ឬកូនកង្កែប និងបេះបោចស្លឹកឈើស្លឹកព្រៃដើម្បីចំអែតក្រពះ។"]។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.៤៣ KH 00981611 [នៅភូមិជើងទិញ "ជួនកាលយើងទៅរកស្លឹកឈើបន្ថែមដើម្បីហូបមួយចំអែត។"]។

[1465] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៣១ KH 01032615 ["បើយើងសម្រាក មិនទៅធ្វើការ គឺមិនទទួលបានរបបអាហារដើម្បីហូបទេ។ [...] អ្នកឈឺ គឺទទួលបានរបបអាហារពាក់កណ្តាលនៃអ្នកជា។"] ឆ.៤៦ KH 01032617 ។ ឯកសារ D118/196 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.២១, ២៣ KH 00978385 [នៅការដ្ឋានទួលម្នេស៖ "អ្នកមិនធ្វើការគេឲ្យ [បបរ] កន្លះបោយ។ [...] [អ្នកឈឺ] អត់ទៅធ្វើការ គេឲ្យបបរតែកន្លះបោយ។"]។ ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.២៤ KH 01113252 ["បើសិនជាយើងដើរឆ្លងទៅ ហើយបើសិនជាគេចាប់បាន គេនឹងដាក់ពិន័យដោយផ្តាច់បាយ ផ្តាច់របបពួកយើង។"]។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.២៥ KH 00981608 [នៅភូមិជើងទិញ]។

[1466] ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៤៦ KH 01008722 [នៅភ្នំធិបតី "យើងខ្លាចពួកគេ ពួកគេកាចណាស់ ហើយយើងមិនហ៊ាននិយាយទេ។"]។ *សូមមើលផងដែរ* ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.៤៧-៤៩ KH 00981611 [នៅភូមិជើងទិញ "ខ្ញុំអត់ហ៊ាន [ឥវ៉ា] ទេ។ [...] អ្នកផ្សេងទៀតក៏មិនហ៊ានឥវ៉ាដែរ។ [...] ខ្ញុំខ្លាច។"]។

421. ដោយសារតែលក្ខខណ្ឌការងារ និងអាហារមិនគ្រប់គ្រាន់ ពលករ "ស្ពាន" សុខភាព ដែលបណ្តាលឲ្យពួកគេ "ឈឺច្រើន" និងស្គមស្គាំង[1467]។ សាក្សីម្នាក់បានប៉ាន់ស្មានថា រៀងរាល់សប្តាហ៍ "តិចបំផុត [...]៥០-៦០នាក់" ឈឺនៅទួលម្នេស និងនៅជុំវិញភ្នំធិបតី[1468]។ ពលករមើលទៅឃើញថា "ស្លេកស្គាំង" និង "ស្គមស្គាំង" មាន "ដៃជើងវែងៗដូចវែក" និង "ខ្សល់បក់រលំដួល"[1469]។ ទោះបីជាមាន "មន្ទីរពេទ្យ [...] ចម្ងាយប្រហែលជា១ គីឡូម៉ែត្រ ពីទួលម្នេស" ក៏ដោយ ក៏កម្មករមិនបានទទួលការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រត្រឹមត្រូវឡើយ[1470]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានឃើញមេកង

[1467] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៨ KH 01205216 [នៅទួលម្នេស៖ "បើនិយាយពីសុខភាពគឺស្ពាន មនុស្សគឺអន់បណ្តោយ។"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.២៤-២៥ KH 01032614 ["ខ្ញុំហេវហត់ ខ្សោយ និងឈឺច្រើន [...] អ្នកខ្លះធ្លាក់ខ្លួនឈឺរហូតដល់ស្លាប់"] ឆ.៤៦ KH 01032617។ ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៤៦ KH 01022368 [នៅទួលម្នេស៖ "ប្រជាជនខ្លះ [...] មានសុខភាពខ្សោយ ស្គមស្គាំងដោយសារមិនមានម្ហូបអាហារគ្រប់គ្រាន់។"]។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៨០ KH 01187885 [ក្នុងសហការណ៍ធិបតី៖ "[កុមារ] ឈឺច្រើនណាស់ ឈឺរាប់ភ្លេច"]។ ឯកសារ D219/549 កំណត់ហេតុស្តាប់ចម្លើយ ឆ.១២ KH 01157576 [នៅទួលម្នេស]។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៣៥ KH 01129722 [នៅការដ្ឋានទួលម្នេស]។ ឯកសារ D219/263 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.៩២ KH 01086101 [នៅភ្នំធិបតី]។

[1468] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៨២ KH 01205218។

[1469] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៨, ៨៨ KH 01205216, 19 [នៅទួលម្នេស៖ "ជើងវែកដៃវែក [...] អ្នកធ្វើការស្គេកស្គាំង អ្នកដែលធ្វើការចល័ត តែផ្នែកកម្មាភិបាលគេមុខឡើងក្រហម រូបរាងស្អាត គេមាំទាំ យើងដៃវែកជើងវែក។ បើខ្សល់ស្រួលមិនស្រួលបក់រលំដួលបណ្តោយ។"]។ ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ណុំ រ៉ាន់នី ឆ.១៣៧ KH 0102950 [នៅភ្នំធិបតី៖ "ពួកយើងស្គម [...] ដើរមិនចង់រួច"]។ *សូមមើលផងដែរ* ឯកសារ D5/1097 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ចន្ធី KH 01025737 ["ខ្ញុំដែលជាកុមារមានសភាពស្គមស្គាំងទៅ។ ដើរខ្សល់បក់ស្ទើररលំ។"]។

[1470] ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.៩០ KH 01113260 [នៅការដ្ឋានទួលម្នេស]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៨២, ១០៤ KH 01205218, 23 [នៅទួលម្នេស៖ "គេឲ្យថ្នាំយើងលេបជាថ្នាំអាចម៍ទន្សាយដែលលាយកន្ទក់ជាមួយស្ករក្រហមផ្អែមៗ ឈឺស្ទើក៏ថ្នាំអាចម៍ទន្សាយដែរ។ [...] មានពេទ្យឯណា"]។ ឯកសារ D118/196 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.៨០ KH 00978391 [នៅទួលម្នេស]។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.២០-២១ KH 00988046 [នៅជើងទិញ "ខ្មែរក្រហមនឹងឲ្យថ្នាំអាចម៍កណ្តុរត្រឡប់មកវិញ។ ហូបទៅជាដូចមិនជាអ៊ីចឹង។"]។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៨១ KH 01187885 ["តែបញ្ជូនទៅពេទ្យហើយ កម្រឃើញត្រឡប់មកវិញណាស់។"]។ ឯកសារ D118/277 កំណត់ហេតុស្តាប់ចម្លើយ សែម ស៊ីង ឆ.៧៣ KH 01000111 [ប្រហែលជាមួយគីឡូម៉ែត្រពីភ្នំធិបតី "បុគ្គលិកពេទ្យទាំងអស់ [នៅជិតជើងភ្នំ] សុទ្ធតែមនុស្សល្ងង់ និងគ្មានជំនាញផ្នែកពេទ្យនោះទេ។ មិនថាឈឺអ្វីនោះទេ អ្នកជំងឺត្រូវបានផ្តល់ថ្នាំអាចម៍ទន្សាយឲ្យលេប"]។ ឯកសារ D6.1.895 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៣៥ KH 00420975។ ឯកសារ D118/231 កំណត់ហេតុស្តាប់ចម្លើយ ឃួយ ហួយ ឆ.៧៥ KH 00985942 [នៅជិតភ្នំធិបតី]។ ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៥៥ KH 01008723 [នៅភ្នំធិបតី]។ ឯកសារ

ត្រូវបានគេ "វាយគាត់។ មេកងនារីនោះយកថ្នាំអាចម៍ទន្សាយទៅឲ្យនារីម្នាក់ហូប ហើយជ្រុលមាត់និយាយ [...] 'តែជាមិនជាមិនដឹងធ្វើយ៉ាងម៉េចទេ'"[1471]។

422. នៅទីតាំងការងារដោយបង្ខំទួលម្ទេស "កម្លាំងចល័តរាប់ពាន់នាក់" ដេកតាមប្រឡាយ និងត្រូវសាងសង់កន្លែងស្នាក់នៅដោយខ្លួនឯង[1472]។ អ្នកខ្លះរស់នៅក្នុង "រោងប្រក់ស្បូវនៅកំប៉ েតកំប៉ូត [...] ប្រក់មិនជិតសន្សើមផង ពេលភ្លៀងមក [...] ពិបាកណាស់" ដែលរោងនេះអាចចល័តបាន ចំណែកឯអ្នកខ្លះទៀត "ដេកកណ្តាលវាល [...] ដេកអង្រ្ពង"[1473]។ "គ្មានមុង"[1474]។ នៅកន្លែងផ្សេងទៀតក្នុងសហករណ៍នេះ សាក្សីបាននិយាយថា "គេយកពួកយើងឲ្យទៅដេកនៅតាមវាលស្រែ [...] ជុំវិញដំបូក"[1475]។

D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.៥៧ KH 00981612 [នៅភូមិជើងទិញ]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៣៧ KH 01129723 ["យោធា [...] ទាំងនោះត្រូវបានពិនិត្យ និងព្យាបាលដោយបុគ្គលិកពេទ្យ នៅក្នុងការដ្ឋាន [ទួលម្ទេស]។"]។

[1471] ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រឿង សុភាព ឆ.៩៥ KH 01113261 [នៅការដ្ឋានទួលម្ទេស]។

[1472] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១០០ KH 01205221 ["អ្នកខ្លះធ្វើរោងដេកប្រក់ស្លឹកឈើប្រក់ស្បូវ ធ្វើរោងស្នាក់នៅដេកពីរនាក់បីនាក់ ខ្លះ៥នាក់ ខ្លះ១០នាក់ [...] មានកម្លាំងចល័តរាប់ពាន់នាក់ដេកនៅតាមបណ្តោយប្រឡាយរបៀបនេះ។"]។

[1473] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៩៨-៩៩, ១០២ KH 01205221-22 ["ចល័តគេធ្វើរោងនៅតាមមាត់ប្រឡាយ ដែលគេលើកពីកង្ហតមក។ នៅ [...] ទួលម្ទេស យើងធ្វើរោងប្រក់ស្បូវនៅកំប៉ েតកំប៉ូត សម្រាប់នៅ។ [...] គ្មានជញ្ជាំងទេ ជារោងដែលយើងលើកពីនេះដាក់ទៅនោះ ប្រក់មិនជិតសន្សើមផង ពេលភ្លៀងមកយើងពិបាកណាស់។"] ឆ.១០០ KH 01205222 ["កម្លាំងចល័ត [...] ដេកកណ្តាលវាល។ [...] ខ្លះទៀតដេកអង្រ្ពង់ធ្វើពីបាវគ្មានខ្សែទេ។"]។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៦០ KH 01157571។ *សូមមើលផងដែរ* ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រឿង សុភាព ឆ.១០ KH 01113251។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.៤១ KH 01121672។

[1474] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១០៣ KH 01205222។

[1475] ឯកសារ D118/243 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.២៣ KH 00990632 [នៅភ្នំធ្រិបតី]។

423. សូម្បីតែនៅពេលដែលសម្រាកពីការងារ ពលករមិនត្រូវបានអនុញ្ញាតឲ្យផ្ទាស់ទីដោយសេរីឡើយ[1476]។ "សូម្បីតែបត់ជើងតូចក៏ត្រូវសុំគេដែរ"[1477]។ "ប្រជាជនខ្លះដើរហើរសេរី ត្រូវបានគេចាប់យកមកធ្វើបាប"[1478]។ ពេលយប់សមាជិកឈ្លបតាមដានប្រជាជន[1479]។

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

424. ក្រោយពេលដែលកម្មាភិបាលភូមិភាគនិរតីគ្រប់គ្រងមន្ទីរសន្តិសុខធិបតី ចំនួនអ្នកទោសកើនឡើង[1480]។ "មាន [...] អ្នកទោសថ្មីចេញចូលថ្មីច្រើនបន្តបន្ទាប់"[1481]។ ឃ្លាំងខាងក្រោមមានទទឹងប្រហែលប្រាំមួយទៅប្រាំពីរម៉ែត្រ និងបណ្តោយ ៤០ ម៉ែត្រ ហើយផ្ទុកអ្នកទោសប្រហែលជា ១០០ នាក់[1482]។ អតីតអ្នកជាប់ឃុំឈ្មោះ ឃិន ខៀន បាននិយាយថា មន្ទីរសន្តិសុខនេះបានដំណើរការដល់

[1476] ឯកសារ D118/196 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.៧៩ KH 00978390 [នៅការដ្ឋានទួលម្ទេស "អត់បានដើរទៅណាទេ។"]។ ឯកសារ D219/263 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.៩៧ KH 01086101 [នៅភ្នំធិបតី៖ "ពួកយើងមិនត្រូវបានអនុញ្ញាតឲ្យដើរដោយសេរីទេ។"]។ ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៣៧ KH 01008721 [នៅភ្នំធិបតី]។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.៣៥ KH 00981609 [នៅការដ្ឋានឆាយបល្ល័ង្ក]។

[1477] ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៤២ KH 01022368 [នៅទួលម្ទេស]។

[1478] ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៣៧ KH 01008721 [នៅភ្នំធិបតី]។

[1479] ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៩៨, ១០០ KH 01187887 ["យប់ឡើងគេ [ឈ្លប] មកដើរឃ្លាំមើលយើងតាមផ្ទះ។ [...] យប់ឡើងឮសំរ៉ីបជើងដើរ យើងអត់ទាន់ដេកហ្ម៏ង។"]។ ឯកសារ D118/243 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ២៣ KH 00990632 [នៅភ្នំធិបតី៖ "ពេលយប់ [...] មានយោធាកាន់កាំភ្លើងនៅយាមយើងរហូត។"]។ ឯកសារ D118/277 កំណត់ហេតុស្តាប់ចម្លើយ សែម ង៉ើង ឆ.៦១ KH 01000109 [ប្រហែលជាមួយគីឡូម៉ែត្រពីភ្នំធិបតី "ពួកគេចាំឃ្លាំមើលយើងធ្វើការជានិច្ច។ ហើយនៅពេលយប់ គឺមានពួកឈ្លបដើរល្បាតជាប្រចាំ។ [...] ម្នាក់ៗខ្លាច ហើយចូលដេកអស់ហើយនៅពេលយប់។"]។ ឯកសារ D118/231 កំណត់ហេតុស្តាប់ចម្លើយ ឃួយ ហួយ ឆ.៥៥ KH 00985939 [នៅជិតភ្នំធិបតី]។

[1480] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៥២ KH 01025658 ["នៅក្នុងឃ្លាំងទីមួយ [...] មានអ្នកទោសច្រើនពេក ទើបគេបញ្ជូនខ្ញុំទៅដាក់នៅឃ្លាំងខាងលើ"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៥ KH 01149367 ["ពេលដែលកម្មាភិបាលនិរតីមកដល់ពួកគេចេះតែបន្តចាប់មនុស្សរហូត។"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៤៩ KH 01032617 ["ខ្ញុំឃើញមានចំនួនអ្នកទោស [នៅវត្តភ្នំធិបតី] ចេះតែកើនឡើងនៅក្នុងមន្ទីរឃុំឃាំងនោះ។"]។

[1481] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៩២ KH 01032622។ *សូមមើលផងដែរ* ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៩៨ KH 01025663 ["គេសម្លាប់អ្នកទោសម្តង ២ ទៅ ៣នាក់ ហើយគេចាប់បញ្ចូលអ្នកថ្មីម្តង ២ ទៅ ៣នាក់វិញ។"]។

[1482] ឯកសារ D219/271 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខធិបតី KH 01477659 ["ឃ្លាំងក្រោម [...] អាគារឃុំខ្លួនមនុស្សនោះមានទំហំទទឹងចំនួន ៦ ទៅ ៧ ម៉ែត្រ និងបណ្តោយ ៤០ ម៉ែត្រ"]។ ឯកសារ D219/512 កំណត់ហេតុ

កម្រិតពេញ ដែលនាំឲ្យរូបគាត់ត្រូវគេបញ្ជូនទៅឃ្លាំងខាងលើ[1483]។ ឃ្លាំងខាងលើមានទំហំប្រហែល ៣០ ម៉ែត្របួនជ្រុង ហើយ ឃិន ខៀន និយាយថា វាផ្ទុកអ្នកទោសពី ៦០ ទៅ ៨០នាក់[1484]។ អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខនេះរួមមាន កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួក

ស្តាប់ចម្លើយ ឃិន ខៀន ឆ.៣៣-៣៤ KH 01149373 [អ្នកទោសប្រហែលជា ១០០នាក់ មកពីគុកក្រោមត្រូវបានសម្លាប់។]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៧៧ KH 01032620 [នៅក្នុងសាលាអាន់៖ "ប្រហែល ១០០នាក់ ត្រូវបានគេឃុំនៅទីនោះ"]។

[1483] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៥២, ១៣១ KH 01025658, 67 ["នៅក្នុងឃ្លាំងទីមួយ [...] មានអ្នកទោសច្រើនពេក ទើបគេបញ្ជូនខ្ញុំទៅដាក់នៅឃ្លាំងខាងលើ"។ ឃ្លាំងក្រោម "ពេញ។"]។

[1484] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៧២ KH 01025660 ["ប្រហែល ៨០នាក់ [អ្នកទោស]។"]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.២៥-២៦ KH 01149416 ["៦០ ទៅ ៧០ នាក់។"] KH 01149421 ["កំណត់សម្គាល់មន្ត្រីស៊ើបអង្កេត៖ [...] សាក្សីបានបញ្ជាក់ថា កន្លែងដែលរូបគាត់ត្រូវបានឃុំខ្លួន [...] ហៅថាឃ្លាំងលើ។"]។ ឯកសារ D219/271 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខធិបតី KH 01477660 ["ឃ្លាំងលើ [...] មានទំហំ ៣០ម៉ែត្រក្រឡា។"]។

គេ[1485] ស្ត្រី កុមារ[1486] "អ្នក ១៧ មេសា" រួមទាំងអ្នកដែលមកពីភ្នំពេញ និងអ្នកដែលជាខ្មែរក្រោម[1487] ប្រជាជនមូលដ្ឋាន[1488] និងប្រជាជនដែលគេចោទថាមានទោសស្រាល[1489]។

[1485] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៧ KH 01149367-68 ["មិនមែនតែកម្មាភិបាលពាយ័ព្យ [...] ត្រូវបានចាប់ដាក់គុកនៅភ្នំធិបតី គឺគ្រួសាររបស់ពួកគេទាំងមូលតែម្តង ដែលត្រូវគេចាប់ដាក់គុក។"]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឯ.២១, ៤៤ KH 01149415-16, 19 ["កម្មាភិបាលដែលមានឋានៈ [...] ពីអនុប្រធានសហករណ៍ចុះ ត្រូវបានគេចាប់យកទៅដាក់គុកវត្តភ្នំធិបតី។ [...] ពួកគេត្រូវបានឃុំជាមួយនឹងប្រពន្ធ និងកូនរបស់ពួកគេ។"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.៧៩-៨០ KH 01032621។ ឯកសារ D118/19 កំណត់ហេតុស្តាប់ចម្លើយ យ៉ីង ឃាន ឯ.៤៣ KH 00891139។

[1486] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.២៥, ៥១, ១០៨ KH 01025655, 58, 64។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.៧៨ KH 01032622។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឯ.២៥, ២៧ KH 01149416។ ឯកសារ D219/11 កំណត់ហេតុស្តាប់ចម្លើយ ប៉េញ ញ៉ាញ ឯ.១២ KH 01025475។ ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ កឹ សឹង ឯ.៧៧ KH 01024897។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.១២៧ KH 01025667 ["ស៖ [...] តើយោធាខ្មែរក្រហមមានឃុំឃាំងកុមារនៅក្នុងគុកភ្នំធិបតីដែរឬទេ? ឯ.១២៧៖ អត់មានទេ។"]។

[1487] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៣៧ KH 01149373 ["អ្នកទោស [...] ទាំងនោះគឺជាប្រជាជនធម្មតាមកពីភ្នំពេញ។"] ឯ.៩, ១១ KH 01149369 [សាក្សីគឺជាអ្នកទោស "១៧មេសា"។]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឯ.១៧, ២១-២២, ៦១ KH 01149415-16, 22 ["គេចាត់ទុកខ្ញុំជាប្រជាជន ១៧មេសា។ [...] ខ្ញុំត្រូវបានគេឃុំ [...] ប្រហែលជាខែកក្កដា ឆ្នាំ១៩៧៨។" សាក្សីមាន "[ជីដូនជីតា] មកពីខាងខេត្តព្រះត្រពាំង។"]។ ឯកសារ D118/19 កំណត់ហេតុស្តាប់ចម្លើយ យ៉ីង ឃាន ឯ.៤៣ KH 00891139។ ឯកសារ D219/11 កំណត់ហេតុស្តាប់ចម្លើយ ប៉េញ ញ៉ាញ ឯ.១២ KH 01025475។

[1488] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៦៣ KH 01025659 ["អ្នកទោសទាំងនោះ [...] ប្រជាជនមូលដ្ឋាន"]។ ឯកសារ D118/19 កំណត់ហេតុស្តាប់ចម្លើយ ឯ.៤៣ KH 00891139 ["ខ្លះជាអ្នកភូមិនៅទីនេះ"]។

[1489] ឯកសារ D219/313 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឯ.១២-១៣ KH 01097709-10 ["គុកមួយនៅភ្នំធីបតី ដែលគេយកអ្នកធ្វើការទៅដាក់ [...] សម្រាប់អ្នកទោសស្រាល។ [...] ខ្ញុំបានឃើញដោយផ្ទាល់ ទាហានបីនាក់បានបណ្តើរយកអ្នកធ្វើការម្នាក់តម្រង់ទៅភ្នំធិបតី ដើម្បីយកទៅអប់រំ។ អ្នកទោស្រាល សំដៅទៅលើអ្នកដែលធ្វើពត់ជាឈឺ ហើយមិនធ្វើការ ហើយអ្នកដែលតមាត់នឹងមេកង។"]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឯ.២៤ KH 01149416 ["ស៖ ហេតុអ្វីគេចាប់ខ្លួនលោកទៅឃុំនៅទីនោះ? ឯ.២៤៖ មកពីក្រុមីស៊ីស្រ្ទេ។"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៦ KH 01149367 ["កម្មាភិបាលនិរតីចាប់ខ្លួន [...] ប្រជាជនដែលបេះបង្ហែដែលដុះនៅតាមរបង អ្នកដែលកាប់ទាដែលខ្លួនចិញ្ចឹមដើម្បីហូប និងអ្នកដែលធ្វើដំណើរពីកងមួយ ទៅកងមួយ ហើយភាគច្រើន អ្នកដែលត្រូវបានគេចាប់ខ្លួននោះ គឺអ្នកដែលមកពីភ្នំពេញ។ ដូចជារូបខ្ញុំផ្ទាល់ ខ្ញុំត្រូវបានគេចាប់ខ្លួន ព្រោះខ្ញុំបានឲ្យអង្ករពីរកំប៉ុងទៅនាង អាង ដែលមកពីភ្នំពេញ។"]។

425. ទាំងនៅក្នុងឃ្លាំងខាងលើ និងឃ្លាំងខាងក្រោម អ្នកទោសដេកលើដីគក្រើម ដោយយក "បង្គីធ្វើជាខ្នើយ"[1490]។ នៅពេលយប់ អ្នកទោសប្រុសត្រូវដាក់ខ្នោះជើងជាជួរ[1491]។ នៅក្នុងឃ្លាំងខាងក្រោម អ្នកទោសត្រូវគេឃុំនៅក្នុងបរិស្ថានដែល "ក្តៅ ហប់" ដោយ "គ្មានអនាម័យ"[1492]។ អគារនោះគ្មានបង្ហូច ហើយ ឃិន ខៀន បានថ្លែងថា មិនមានកន្លែងគ្រប់គ្រាន់សម្រាប់ដេកទេ[1493]។ ដោយមិនមានបង្គន់ អ្នកទោស "កាយដីខ្សាច់កប់ [លាមក]" នៅឃ្លាំងខាងក្រោម ឬបន្ទោរបង់ខាងក្រៅក្នុងព្រៃ ក្រោមការយាមកាមប្រដាប់ដោយអាវុធ[1494]។

[1490] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៩ KH 01149368។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៨៩ KH 01032622 [នៅក្នុងឃ្លាំងខាងក្រោម "ដេកផ្ទាល់នៅនឹងដី"។]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.២៥ KH 01149416 ["គុកធ្វើពីដី គ្មានក្រាលស៊ីម៉ង់ ឬឱ្ដងទេ។ អ្នកជាប់ទោសត្រូវដេកលើគ្រួសក្រហមតែម្តង។"] KH 01149421 ["កំណត់សម្គាល់មន្ត្រីស៊ើបអង្កេត៖ [...] សាក្សីបានបញ្ជាក់ថា កន្លែងដែលរូបគាត់ត្រូវបានឃុំខ្លួន [...] ហៅថាឃ្លាំងលើ។"]។ ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៥៤ KH 01025658 [ឃ្លាំងទីមួយ "ឃ្លាំងនោះ [...] ផ្ទៃខាងក្រោមជាដីខ្សាច់។"]។

[1491] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.១៦ KH 01149369 [នៅឃ្លាំងក្រោម៖ "នៅពេលយប់ មានតែអ្នកទោសបុរសប៉ុណ្ណោះ ដែលគេដាក់ខ្នោះជើង ប៉ុន្តែគេពុំមានដាក់ខ្នោះដៃនោះទេ។ គេមានប្រើប្រាស់ឈើវែងមួយ ដើម្បីដាក់ខ្នោះជើងអ្នកទោស"]។ ឯកសារ D219/447 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.២៦ KH 01129710 ["គេឃុំខ្ញុំនៅក្នុងសាលាឆាន់របស់វត្តធិបតី [...] ហើយអ្នកដែលជាប់ខ្នោះជើង ត្រូវបានគេដាក់នៅកន្លែងមួយដែលរាងខ្ពស់ជាងគេបន្តិច"] ឆ.៣ KH 01129705 ["នៅពេលដែលយើងធ្វើការគឺគេពុំមានដាក់ខ្នោះជើងយើងទេ។"]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.២៥-២៦ KH 01149416 [នៅឃ្លាំងលើ៖ "អ្នកទោសត្រូវគេតំរៀបជាបួន ឬប្រាំជួរ មានដាក់ខ្នោះជើង។ [...] ពេលថ្ងៃអ្នកទោសទាំងនោះត្រូវបានគេឱ្យអ្ងរទេះដឹកថ្ម ហើយពុំជាប់ខ្នោះជើងទេ។"]។

[1492] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.១២៩ KH 01025667 ["ពេលយប់គេបិទទ្វា ហើយអាកាសធាតុក្តៅ ហប់។"] ឆ.៩០ KH 01025662 ["ស៖ នៅឃ្លាំងដែលគេឃុំឃាំងលោកស្រី តើមានអនាម័យឬទេ? ឆ.៩០៖ អត់មានអនាម័យទេ"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៨៩ KH 01032622 ["គ្មានអនាម័យទេ។"]។

[1493] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.១៣០-១៣១ KH 01025667 ["ឆ.១៣០៖ គុកនោះគ្មានបង្ហូចទេ [...] ស៖ [...] តើនៅក្នុងឃ្លាំងខាងក្រោមមានចន្លោះសម្រាប់អ្នកទោសដេកបានស្រួសដែរឬទេ? ឆ.១៣១៖ ទេ ឃ្លាំងនោះគ្មានចន្លោះទេ [...] ពេញទាំងអស់។"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៨៣ KH 01032621 ["មិនមានបង្ហូចទេ។"]។

[1494] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៥៨, ៩១ KH 01025658, 62 ["គេអនុញ្ញាតឱ្យចេញទៅបង្គន់តែពីរនាក់ម្តងដោយមានការយាមកាម។ [...] អ្នកទោសដែលត្រូវបត់ជើងនៅក្នុងឃ្លាំងនោះ រួចកាយដីកប់ទៅ។"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.១៨ KH 01149369។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៨៧-៨៨ KH 01032621 ["តើមានបន្ទប់ទឹកនៅក្នុងអាគារឃុំឃាំងនោះដែរឬទេ? ឆ.៨៧៖ ទេ មិនមានទេ [...] ឆ.៨៨៖ [...] គេនាំ [អ្នកទោស] ចេញទៅខាងក្រៅដើម្បីបត់ដៃបត់ជើង។"]។

426. នៅមន្ទីរសន្តិសុខ អ្នកទោសស្ថិតក្នុងសភាពស៊ីមិនអ្នែត និងខ្វះជាតិទឹក[1495]។ អ្នកដែលលួចត្រូវគេវាយយ៉ាងធ្ងន់ធ្ងរ – ម្នាក់បានសន្លប់ និងម្នាក់ទៀត "មានស្នាមរបួសនៅលើក្បាលរហូតដល់សព្វថ្ងៃ"[1496]។ អ្នកទោសដែលធ្លាក់ខ្លួនឈឺទទួលបានការព្យាបាលមិនគ្រប់គ្រាន់ ឬមិនបានទទួលទាល់តែសោះ[1497]។

[1495] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.២០, ២៥ KH 01149370-71 ["គេមិនបានឲ្យទឹកអ្នកទោសហូបនោះទេ។ [...] គេឲ្យតែអង្ករមួយកំប៉ុងប៉ុណ្ណោះសម្រាប់ធ្វើបបរឲ្យមនុស្ស ១០នាក់ហូប។"]។ ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៥៩-៦០ KH 01025658-59 ["ក្នុងមួយអាទិត្យម្តង គេបានផ្តល់ចេក១ផ្លែ សម្រាប់កាត់ចែកគ្នា ១០នាក់។ គេឲ្យហូប១ថ្ងៃ ២ដង"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.៩០ KH 01032622។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឯ.៣៨ KH 01149418 [អ្នកទោស "គេឲ្យបបរមួយពេល បបរមួយកា សម្រាប់មនុស្សម្នាក់ ហូបជាមួយទឹកត្រីដែលគេដាក់ក្នុងចានសម្រាប់គ្នា១០នាក់។ អ្នកទោសនៅទីនោះមានសភាពស្គមស្គាំង ស្បែកដណ្តប់ឆ្អឹង។"]។ ឯកសារ D118/280 កំណត់ហេតុស្តាប់ចម្លើយ សង់ សយ ឯ.១៩ KH 01004108 ["គេឲ្យអ្នកទោសហូបបបរវាវ១ពីដងក្នុងមួយថ្ងៃ។"]។

[1496] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៩៥ KH 01025663 ["បន្ទាប់មកអ្នកត្រូវគេវាយនោះដឹងខ្លួនឡើងវិញ គឺសួរអ្នកវាយដំវិញថា ហេតុអ្វីបានជាវាយខ្ញុំ? ខ្មែរក្រហមនិយាយថា ពួកឯងលួចដាំបាយស៊ីឯកជន លួចកាប់មាន់ធ្វើម្ហូប"] ឯ.៧៥ KH 01025660 [អ្នកយាម "វាយដំធ្វើបាបខ្ញុំ ហើយខ្ញុំមានស្នានរបួសនៅលើក្បាល រហូតដល់សព្វថ្ងៃ។"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.២៩ KH 01149372 ["កូនប្រុសរបស់ខ្ញុំបានលួចកាច់ពោតមួយចំនួន ហើយគេបម្រុងវាយកូនរបស់ខ្ញុំ [...] ខ្ញុំក៏បានប្រាប់គេឲ្យវាយខ្ញុំជំនួសវិញ"]។ ទាក់ទងនឹងទណ្ឌកម្មចំពោះការលួចអាហារនៅកន្លែងផ្សេងទៀតក្នុងសហការណ៍ធិបតី *សូមមើល* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.៧៧ KH 01122410 ["ខ្ញុំពួ [...] នៅទួលម្ទេស និង ជើងទឹង [...] អ្នកខ្លះត្រូវលួចស្រូវនៅពេលយប់ដើម្បីយកមកហូប ហើយនៅពេលដែលឈ្លបដឹងពួកគេត្រូវបានចាប់ខ្លួន។"]។

[1497] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.៩២ KH 01032622 ["អ្នកទោសខ្លះឈឺ"] ឯ.១៣៥ KH 01032626 ["ស៖ តើពួកកម្មាភិបាលខ្មែរក្រហមមានឲ្យពេទ្យមកព្យាបាលអ្នកទោសដែលឈឺនោះដែរឬទេ? ឯ.១៣៥៖ មិនមានទេ"]។ ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៩៣ KH 01025662 ["ស៖ តើខ្មែរក្រហមបានផ្តល់ថ្នាំសង្កូវដល់អ្នកទោសដែរឬទេ? ឯ.៩៣៖ ទេ"]។ ទោះបីជាអតីតអ្នកជាប់ឃុំ អ៊ុយ ចិន្តា និង ឃិន ខៀន ខ្វែងគ្នាលើការណ៍ថាតើ កម្មាភិបាលនិរតីប្រើមន្ទីរពេទ្យនៅជិតមន្ទីរសន្តិសុខ ឬយ៉ាងណានោះ នៅពេលដែលកម្មាភិបាលនិរតីគ្រប់គ្រងគុកនោះ សាក្សីទាំងពីរនេះផ្តល់ភ័ស្តុតាងអំពីកង្វះការព្យាបាលវេជ្ជសាស្ត្រនៅមន្ទីរពេទ្យនោះ។ *សូមមើល* ឯកសារ D219/447 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.៣០ KH 0112971។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.២៣-២៤ KH 01149370-71។ សាក្សីផ្សេងទៀត និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានយោងទៅលើការប្រើមន្ទីរពេទ្យក្នុងពេលគ្រប់គ្រងរបស់ភូមិភាគនិរតីនៅសហការណ៍ធិបតី *សូមមើល* ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រឿង សុភាព ឯ.៩០ KH 01113260។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឯ.៨១ KH 01187885។ ឯកសារ D118/277 កំណត់ហេតុស្តាប់ចម្លើយ សែម រ៉ើង ឯ.៧៣ KH 01000111។

427. ក្រោមការឃ្លាំមើលនៃអ្នកយាមប្រដាប់អាវុធ អ្នកទោសត្រូវបានបង្ខំឲ្យធ្វើការងារផ្សេងៗ រួមមាន "ជីករណ្តៅដោយខ្លួនឯង" និង"កប់រណ្តៅសព"[1498]។ ឃិន ខៀន និយាយថាការបំពេញការងារតាមចំនួនដែលគេបានកំណត់បានក្លាយជារឿងមួយដ៏ "ពិបាក" សម្រេចឲ្យបាន[1499]។ "បើយើងដេរឲ្យគេមិនគ្រប់តាមចំនួនកំណត់ ថ្ងៃស្អែកនឹងបង្កើនចំនួនដែលយើងត្រូវដេរបន្ថែមទៀត"[1500]។ ស្ត្រីនៅក្នុងអង្គភាពដេររបស់គាត់ មិនអាចសម្រាកបានទេ "ព្រោះយើងខ្លាចថា យើងដេរមួកគេមិនគ្រប់តាមចំនួនដែលគេកំណត់"[1501]។ សាក្សីម្នាក់ទៀតបានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា បន្ទាប់ពីអ្នកទោសត្រូវបានអប់រំរួចហើយនៅមន្ទីរសន្តិសុខ គេក៏បានបញ្ជូនអ្នកទោសទាំងនោះទៅការដ្ឋានពលកម្មដោយបង្ខំនៅជើងទិញ[1502]។ ឃិន ខៀន បាននិយាយថា កម្មាភិបាលភូមិភាគពាយ័ព្យដែលជាប់

[1498] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៩៤, ៩៩ KH 01025662-63 ["ខ្មែរក្រហម [...] ឲ្យជីករណ្តៅដោយខ្លួនឯង។ [...] នៅពេលខ្លះខ្មែរក្រហមប្រើអ្នកទោសដទៃទៀតឲ្យទៅកប់រណ្តៅសពនោះ"] ឆ.៦១-៦២ KH 01025659 ["អ្នកទោសទាំងនោះត្រូវបង្ខំឲ្យធ្វើការដែរ ដោយមានការយាមកាមពីយោធាខ្មែរក្រហមចំនួន៥ ទៅ៦នាក់ ដោយមានអាវុធ [...] មកពីភូមិភាគនិរតី"] ឆ.៥៥, ៧៩ KH 01025658, 61 ["ខ្ទោះជើងទាំងនោះ គឺអ្នកទោសធ្វើដោយខ្លួនឯង។ [...] នៅក្នុងមន្ទីរឃុំឃាំង គេឲ្យខ្ញុំដេរមួកយោធា"]។ ឯកសារ D219/447 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៦-៧, ១០-១២ KH 01129706-07 ["យើងត្រូវស្តាប់តាមបញ្ជារបស់គេ។ ប្រសិនបើគេឲ្យយើងធ្វើការ ហើយយើងប្រកែក គេប្រាកដជានឹងយកយើងទៅសម្លាប់ចោល។ គេឲ្យខ្ញុំលើកភ្ជ្ជ និងលើកផ្ទ្ជ្ជរពីភ្នំធិបតី មកឃុំគាស់ក្រឡ។ [...] យើងចាប់ផ្តើមធ្វើការនៅថ្ងៃរះ ឈប់ដើម្បីហូបអាហារនៅពេលថ្ងៃត្រង់។ [...] បន្តធ្វើការងារទៀតរហូតដល់ថ្ងៃលិច។ [...] គេឃ្លាំមើលយើងគ្រប់ពេលវេលាទាំងអស់។ [...] កងការពារមួយចំនួនមានកាំភ្លើង និងអ្នកខ្លះមានកាំបិត"]។ ឯកសារ D118/280 កំណត់ហេតុស្តាប់ចម្លើយ សង់ សយ ឆ.១៩ KH 01004108 ["គេ[អ្នកយាម]បញ្ជេញអ្នកទោសឲ្យធ្វើការ ព្រឹកម្តងពីម៉ោង៧ ដល់ម៉ោង១១ និងរសៀលម្តងទៀត ពីម៉ោង១ ដល់ម៉ោង ៥ ល្ងាច"]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.២៦, ៣៦ KH 01149416, 18 ["នៅពេលថ្ងៃ អ្នកទោសទាំងនោះ ត្រូវបានគេឲ្យអ្ងសរទេះដឹកថ្ម [...] គេឲ្យខ្ញុំទៅរែងខ្សាច់តែឯង"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៤៦ KH 01149374 ["ខ្ញុំចាប់ផ្តើមធ្វើការនៅម៉ោងប្រាំពីរព្រឹក រហូតដល់ម៉ោងដប់ពីរថ្ងៃត្រង់ [...] បន្តធ្វើរហូតដល់ម៉ោងប្រាំល្ងាច"]។

[1499] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៧៩ KH 01025661 ["ដំបូង គេឲ្យខ្ញុំដេរមួកយោធាចំនួន៥ ក្នុង១ថ្ងៃ។ ក្រោយមកគេឲ្យខ្ញុំដេរមួយយោធាចំនួន១០ ក្នុង១ថ្ងៃ"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៤៤-៤៥, ៥៦ KH 01149374, 76 ["ក្រុមរបស់យើងដែលសុទ្ធតែជាស្ត្រីមានគ្នា១២នាក់ [...] គេ[អ្នកយាម] បានកំណត់ចំនួនឲ្យយើងដេរឲ្យគ្រប់ឲ្យគេ។ [...] ប្រសិនបើគេឲ្យយើងដេរមួកត្រឹមតែ៥ក្នុង១ថ្ងៃ ទើបសមរម្យ ប៉ុន្តែបើគេឲ្យយើងដេរមួកចំនួន១០បែបនេះ គឺពិបាកខ្លះណាស់"]។

[1500] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៥០ KH 01149375។

[1501] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៤៩ KH 01149375។

[1502] ឯកសារ D219/313 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.១៣ KH 01097710 ["[អ្នកទោស] ទាំងនោះ [...] គេបញ្ជូនមកធ្វើការនៅការដ្ឋាន[ជើងទឹង]វិញ ក្រោយពីគេអប់រំ កសាង នៅភ្នំធិបតី"]។

គុក ត្រូវបានគេប្រព្រឹត្តចំពោះដូចគ្នានឹងអ្នកជាប់ឃុំឃាំងដទៃទៀតដែរ ប៉ុន្តែពួកគេ "មិនត្រូវបានគេអនុញ្ញាតឲ្យចេញទៅសហការណ៍របស់ពួកគេវិញទេ"[1503]។

428. មន្ទីរសន្តិសុខទួលម្នេស គឺជាផ្នែកនៃ "ជំរំអប់រំឡើងវិញ" សម្រាប់ "អ្នកទោសពីគ្រប់សហការណ៍នៅក្នុងតំបន់១ ទាំងអស់ៗ ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យ។[1504] ន្ជួន មួន ដែលជាលេខាសហការណ៍មួយក្នុងស្រុកបាត់ដំបង បាននិយាយថា គាត់ត្រូវបានគេចាប់ខ្លួនដោយសារគេគិតថាគាត់ "គឺជាខ្សែរបស់ សាយ/សយ ដែលជាលេខាតំបន់១"[1505]។ គាត់និយាយថា: "គេគ្រាន់តែចោទយើង កម្មាភិបាលភូមិភាគពាយ័ព្យទាំងអស់ ថាជាភ្នាក់ងារ កា.ហ្យ.បេ និងភ្នាក់ងារយួន"[1506]។ អ្នកទោសត្រូវបានឃុំនៅក្នុងអគារ "មាំខ្លាំងណាស់" ដែលមាន "ឈ្លប" យាមនៅខាងក្រៅ "ជាង២០ នាក់"[1507]។ ន្ជួន មួន បាននិយាយថា គេចែកឲ្យពួកគាត់ទូវ "បបរមួយថ្ងៃពីរពេល" ហើយគេ "មិនឲ្យអ្នកទោសទាក់ទងគ្នាទេ"[1508]។ ជាផ្នែកនៃការលត់ដំរបស់ពួកគេ កម្មាភិបាលភូមិភាគពាយ័ព្យដែលជាប់គុកត្រូវគេដាក់ក្នុងលក្ខខណ្ឌជាទាសករនៅភូមិទួលម្នេស ដោយសារ ពួកគេបានទទួលរងនូវលក្ខខណ្ឌរស់នៅ និង

[1503] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៩-១០ KH 01149368 ["កម្មាភិបាលពាយ័ព្យ [...] ទទួលរងការប្រព្រឹត្តដូចគ្នា ទៅនឹងអ្នកទោសទូទៅដែរ។ គេឲ្យរបបហូបចុកយើងដូចគ្នា ហើយពួកយើងដេកដោយយកបង្ក្ដីធ្វើជាខ្នើយដូចគ្នា ប៉ុន្តែក្នុងនាមយើងខ្ញុំជាអ្នក១៧មេសា គេអនុញ្ញាតឲ្យយើងចេញទៅក្រៅ ប៉ុន្តែកម្មាភិបាលពាយ័ព្យទាំងអស់នោះ មិនត្រូវបានគេអនុញ្ញាតឲ្យចេញក្រៅឡើយ។ ខ្ញុំចង់និយាយថា នៅពេលដែលខ្ញុំស្នើសុំត្រឡប់ទៅមើលកូនរបស់ខ្ញុំនៅសហការណ៍ គេបានអនុញ្ញាតឲ្យខ្ញុំទៅ ប៉ុន្តែគេមានយោធាពីរនាក់អមដំណើរខ្ញុំ ដោយឡែកកម្មាភិបាលពាយ័ព្យមិនត្រូវបានអនុញ្ញាតឲ្យចេញទៅសហការណ៍របស់ពួកគេវិញទេ"]។

[1504] ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន មួន ឆ.១៣-១៥ KH 00891131-32 ["ពួកនិរតី [...] ចាប់ពួកពាយ័ព្យយកទៅ [...] មណ្ឌលកសាងទួលម្នេស ដោយមានទាំងការដ្ឋាន និងមន្ទីរសន្តិសុខ។ [...] គេយកអ្នកទោសមកពីគ្រប់សហការណ៍នៃតំបន់១ យកមកធ្វើការនៅទួលម្នេស"]។ *សូមមើលផងដែរ* ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៩២ KH 01205220 ["កម្មាភិបាលពាយ័ព្យ គេយកទៅរៀនសូត្ររហូត"]។

[1505] ឯកសារ D1.3.11.36 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ន្ជួន មួន ដោយ ក.ស.ព EN 00210530 ["និរតីមកដល់ទីនេះពីខែ មករា ឆ្នាំ១៩៧៧ ដើម្បីមកចាប់កម្មាភិបាលពាយ័ព្យ។ គេចាប់មនុស្សតាមខ្សែប្រតិភូកម្មអំណាច។ អ្នកផ្តល់សម្ភាសន៍គឺជាមនុស្សក្នុងខ្សែរបស់ សយ ដែលជា[លេខា]តំបន់ [...] នៅពេលគេចាប់ សយ គេក៏ចាប់ខ្សែរបស់ សយ ទាំងអស់។ សយ ត្រូវបានចាប់ខ្លួន និងជំនួសមកវិញដោយ រ៉ាញ ដែលជាកម្មាភិបាលពាយ័ព្យដូចគ្នា"]។

[1506] ឯកសារ D1.3.11.36 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ន្ជួន មួន ដោយ ក.ស.ព EN 00210532។

[1507] ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន មួន ឆ.២០-២១ KH 00891132 ["គេមិនដាក់ខ្ទោះទេ ព្រោះជញ្ជាំងក្តានោះវាមាំខ្លាំងណាស់ តែមានឈ្លបគេយាមនៅខាងក្រៅ។ [...] មានជាង២០នាក់"]។

[1508] ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន មួន ឆ.១៧ KH 00891132។ ឯកសារ D105/3 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន មួន ឆ.២៤ KH 00780637 [អ្នកយាម "ចែកបបរមួយថ្ងៃពីរពេល ដោយគេឲ្យបបរមួយកាម្នាក់"]។

ការងារដ៏អមនុស្សធម៌ ដូចបានរៀបរាប់យ៉ាងលម្អិតនៅក្នុងអនុវាក្យខណ្ឌខាងលើ ស្តីពី*ការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)*[1509]។

429. ប្រជាជនផ្សេងទៀតដែលគេបានចាប់ខ្លួននៅសហករណ៍ធិបតី ត្រូវបានគេឃុំនៅមន្ទីរសន្តិសុខភ្នំថុក (តាថុក) និងនៅក្នុងភូមិវ៉ាដែលស្ថិតនៅនឹងកន្លែង ហើយនឹងមន្ទីរសន្តិសុខមិនស្ថិតនៅនឹងកន្លែង ដូចជា មន្ទីរសន្តិសុខចកកកោះ មន្ទីរសន្តិសុខខ្នងគ្ងូ និងមន្ទីរសន្តិសុខគាស់ក្រឡ[1510]។

[1509] V.ខ.២.ខ.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់១ – សហករណ៍ធិបតី – ឧក្រិដ្ឋកម្ម – ការធ្វើឲ្យទៅជាទាសករនិងអំពើអមនុស្សធម៌ផ្សេងៗទៀត(ការធ្វើបាបដោយអមនុស្សធម៌)។*សូមមើលផងដែរ*ឯកសារ D1.3.11.36កំណត់ហេតុនៃកិច្ចសម្ភាសន៍ ឌួន ម្ហួន ដោយ ក.ស.ច EN 00210532 ["ពួកគេបានបញ្ជូនខ្ញុំទៅទួលម្នេស ជាកន្លែងលត់ដំ។ [...] ទួលម្នេស គឺជាការដ្ឋាន មានមនុស្សបីក្រុម ពីរក្រុមក្នុងចំណោមក្រុមទាំងបី មិនមែនជាអ្នកទោសទេ។ [...] កងរបស់ខ្ញុំគឺអ្នកទោស [...] គេហៅថា "កងពិសេស""]។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ឌួន ម្ហួន ឆ.៦ KH 00920211 ["គេចាប់ខ្ញុំមកដាក់នៅកន្លែងអប់រំកែប្រែទួលម្នេស"]។

[1510] ឯកសារ D6.1.895 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៥២-៥៣ KH 00420977 ["[មាន]មន្ទីរសន្តិសុខ ស្ថិតនៅក្បែរជើងភ្នំ តា ថុក។ គេចាប់មនុស្សដែលលួចពោត ស្រូវ ត្រូវបានគេចាប់ទៅឃុំឃាំងនៅមន្ទីរនោះ"]។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម ឃាង ឆ.៤០, ៤៤-៤៥ KH 01187881 ["ក្បែរភូមិថ្មី [...] ភូមិវ៉ា [...] វ៉ាហ្ម៊ីងនៅមន្ទីរកសាងហ្ម៊ីង"។ អ្នកទោស "គេឃុំនៅទីនោះ"]។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៦, ៣៤ KH 01095207, 211 ["បន្ទាប់ពីពួកនិរតីមកដល់ ពួកគេបាននាំយកមនុស្សជាច្រើនយកទៅដាក់ក្នុងមន្ទីរសន្តិសុខកកោះ។ [...] សែង ត្រូវបាននាំយកមកពីសហករណ៍ភ្នំធិបតីមកដាក់នៅមន្ទីរសន្តិសុខកកោះ"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៤ KH 01040098 ["មួយរយៈពេលខ្លីមុនពេលដែលកងទ័ពវៀតណាមចូលមកដល់ [...] អ្នកទោស [...] ចេញពីខ្នងគ្ងូ [...] បុរសម្នាក់ [...] បានប្រាប់ខ្ញុំថា រូបគាត់ [...] មានកំណើតមកពីភូមិទួលម្នេស"]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.៦-៧ KH 01117257 ["ខ្ញុំធ្លាប់ឮគេថា អ្នកដែលមានកំហុសគេយកទៅវត្តគាស់ក្រឡ [...] ស្ថិតនៅប្រហែល ១០ ទៅ ១២ គីឡូម៉ែត្រ ខាងត្បូងពីការដ្ឋានជើងទឹង។ អ្វីដែលខ្ញុំបានឮគេនិយាយត្រូវបានឈ្មោះ សៀប បញ្ជាក់បន្ថែមថា ប្រសិនបើអ្នកណាធ្វើអ្វីខុស គេនឹងបញ្ជូនទៅវត្តគាស់ក្រឡហើយ"]។ ទាក់ទងនឹងមន្ទីរសន្តិសុខចកកកោះ នៅក្នុងស្រុកមោងឫស្សី *សូមមើលផងដែរ* ឯកសារ D1.3.11.36 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ឌួន ម្ហួន ដោយ ក.ស.ច EN 00210532 ["កន្លែងលត់ដំមួយទៀតស្ថិតនៅកកោះ ក្នុងស្រុកមោងឫស្សី"]។ ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ឌួន ម្ហួន ឆ.២៦ KH 00891133 ["មន្ទីរសន្តិសុខកកោះ នៅក្នុងស្រុកមោងឫស្សី [...] គឺជាមន្ទីរសន្តិសុខភូមិភាគ"]។ ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៩, ២១, ៤៧, ៤៩, ៥១, ៥៣ KH 01477638-39, 42-43, 44 [សាក្សីជាអ្នកគ្រប់គ្រងយោធានៅកងអនុសេនាតូចនៅស្រុកគាស់ក្រឡ ពីពាក់កណ្តាលឆ្នាំ១៩៧៦ រហូតដល់ពេលគាត់ទៅគ្រប់គ្រងពលករធ្វើប្រៃ ហើយបន្ទាប់មកគាត់រត់ចូលព្រៃនៅពាក់កណ្តាល ឬចុងឆ្នាំ១៩៧៨៖ "គេ [តាម៉ុក និង តាទិត្យ] ធ្លាប់ទៅមន្ទីរសន្តិសុខចកកកោះ"។ "យកមកស្រុកគាស់ក្រឡ ដូចថាស្តុក យកមក១ថ្ងៃ២ថ្ងៃ រួចបញ្ជូនទៅកន្លែង ចក កកោះណោះ"។ "កាលហ្ម៊ីងខ្ញុំទៅធ្វើប្រៃនៅជិតហ្ម៊ីង នៅជិតចក កកោះហ្ម៊ីង"។ កាលពីដើមគេធ្វើ[មន្ទីរសន្តិសុខ]ធំតើ។ អ្នកទោសនៅហ្ម៊ីងមានច្រើន"]។

ការធ្វើទារុណកម្ម

430. នៅមន្ទីរសន្តិសុខធិបតី អ្នកទោសមួយចំនួនត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្ម[1511]។ ពួកគេវាយដំអ្នកទោស "រាល់យប់" ធ្វើឲ្យ ឃិន ខៀន "គេចទៅកៀនជញ្ជាំង"[1512]។ "នៅពេលធ្វើទារុណកម្មពួកអ្នកយាមបានយកបាវគ្របពីលើអ្នកទោស រួចវាយដំ[...] ដើម្បីកុំឲ្យបែកឈាម"[1513]។ អតីតអ្នកជាប់ឃុំឃាំងឈ្មោះ អ៊ុយ ចិន្តា ត្រូវ "គេវាយជារៀងរាល់ថ្ងៃ ប្រហែលជាដងប់ថ្ងៃជាប់គ្នា"[1514]។ គាត់បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា គាត់ត្រូវបាន "គេធ្វើទារុណកម្ម" [...] ១០ដង ក្នុង១ថ្ងៃ។ [...] នៅពេលដែល[...] ជាប់ខ្នោះ"[1515]។ "ពួកគេវាយដំខ្ញុំ បើគេចង់វាយខ្ញុំ គឺគេវាយតែម្តង"[1516]។ "គេប្រើម្ជុលខ្ទាស់ចាក់ត្រចៀក[ខ្ញុំ]"[1517]។ គាត់និយាយថា បុគ្គលិកគុកបានធ្វើអំពើហិង្សាមកលើគាត់ដែលមើលទៅហាក់ដូចជា "គ្រាន់តែមកវាយខ្ញុំជាល្បែងកម្សាន្តប៉ុណ្ណោះ"[1518]។

[1511] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.១០២ KH 01025663 ["ស៖ តើក្នុងពេលសួរចម្លើយហ្នឹង គេមានធ្វើទារុណកម្មអ្នកទោសដែរឬទេ? ឯ.១០២៖ អ្នកខ្លះត្រូវគេវាយដំ ហើយសួរចម្លើយ។ រីឯអ្នកខ្លះគ្រាន់តែសួរចម្លើយតែប៉ុណ្ណោះ"] ឯ.៩៤-៩៥ KH 01025662-63 ["ខ្មែរក្រហមបានធ្វើទារុណកម្មនៅក្នុងគុក។ [...] នៅពេលគេវាយដំ គេសួរថា ថ្ងៃក្រោយហ្នែងឈប់ដាំបាយស៊ីខ្លួនឯងហើយឬនៅ?""]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឯ.២៨ KH 01149416 ["នៅពេលដែលពួកនិរតីចូលមកដំបូង អ្នកទោសនៅទីនោះ[ភ្នំធិបតី]លែងត្រូវបានគេធ្វើទារុណកម្មទៀតហើយ"]។

[1512] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៧៤ KH 01025660។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៣១ KH 01149372។ *សូមមើលផងដែរ* ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឯ.៧៥-៧៦ KH 01187885 [ពួរបស់សាក្សីត្រូវបាន "គេវាយ" ក្នុងពេលជាប់ឃុំនៅពេលពួកភូមិភាគនិរតីមកដល់]។

[1513] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៧៦ KH 01025660។ *សូមមើលផងដែរ* ឯកសារ D118/7 កំណត់ហេតុស្តាប់ចម្លើយ ជា ចន្ធី ឯ.៩ KH 00882739 ["បានឃើញខ្មែរក្រហមធ្វើទារុណកម្មអ្នកទោស ដោយយកចង់ផ្ការស្ទិកច្រកក្បាលអ្នកទោសឲ្យចប់ដង្ហើម រហូតដល់អ្នកទោសនោះប្រកាន់"]។

[1514] ឯកសារ D219/447 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.២២ KH 01129709។ *សូមមើលផងដែរ* ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.១២៦-១២៧ KH 01032625 ["គេប្រើដំបង។ [...] គេវាយចំខ្នងរបស់ខ្ញុំ"]។

[1515] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.១២៣ KH 01032625 ["ស៖ តើគេធ្វើទារុណកម្មណោកប៉ុន្មានដង ក្នុងមួយថ្ងៃ? ឯ.១២៣៖ ប្រហែល ៤ ទៅ ៥ដង ក្នុង១ថ្ងៃ ហើយមានពេលខ្លះ គេធ្វើទារុណកម្មខ្ញុំរហូតដល់ ១០ដង ក្នុង១ថ្ងៃ។ គេធ្វើទារុណកម្មខ្ញុំ នៅពេលដែលខ្ញុំជាប់ខ្នោះប៉ុណ្ណោះ"]។

[1516] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.១២១ KH 01032625។

[1517] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.១២៦ KH 01032625។

[1518] ឯកសារ D219/447 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឯ.២៥, ២៨ KH 01129710-11 ["គេគ្រាន់តែមកវាយខ្ញុំជាល្បែងកំសាន្តប៉ុណ្ណោះ។ [...] ទឹកមុខរបស់ពួកគេ គឺធម្មតាប៉ុណ្ណោះ។ [...] ជួនកាលពួកគេដើរសំដៅមករកខ្ញុំ ហើយយកម្ជុលមកចាក់

431. នៅក្នុងឧបត្ថម្ភហេតុមួយនៅមន្ទីរសន្តិសុខ អ្នកជាប់ឃុំឃាំង "រាប់រយនាក់" ត្រូវបានបណ្តើរដោយអ្នកយាមគុក១០ នាក់ ទៅកាន់កន្លែងសម្លាប់មនុស្សមួយ ដើម្បីទៅមើលអ្នកទោសដូចគ្នា ៣៧ ឬ ៣៨នាក់ ដែលគេកំពុងតែសម្លាប់។ អ្នកនៅរស់រានមានជីវិត ឃិន ខៀន បាននិយាយថាគាត់ "ភ័យខ្លាចយ៉ាងខ្លាំង" និង "តក់ស្លុតយ៉ាងខ្លាំង"។ គាត់និយាយថា គាត់បាត់បង់ការផ្តោតអារម្មណ៍ក្នុងការរាប់ចំនួនអ្នកទោសដែលគេកំពុងតែសម្លាប់នោះ "នៅពេលដែលគេយកស្ត្រីម្នាក់ជាមួយនឹងកូនង៉ា យកទៅដល់មាត់រណ្តៅរៀបវាយសម្លាប់"។ ខណៈដែលអ្នកទោសកំពុងតែត្រូវបានសម្លាប់ "គេបានប្រាប់ឲ្យយើងមើល និងកុំឲ្យយកគំរូតាមអ្នកទោសប្រុសទាំងនោះ"[1519]។

432. នៅកន្លែងផ្សេងទៀតនៅក្នុងសហករណ៍ សាក្សីនានាបាននិយាយថា សមាជិកកងឈ្លបបានរំលោភសេពសន្ថវៈលើស្ត្រីជាច្រើន នៅមុនពេលសម្លាប់ពួកគេ[1520]។

ស្ត្រីកត្រចៀករបស់ខ្ញុំលេង។ [...] គេមិនបានសួរខ្ញុំអ្វីនោះទេ គឺវាដូចជាល្បែងកំសាន្តរបស់ពួកគេអីចឹង។ ពួកគេមិនបានចោទខ្ញុំថាមានពាក់ព័ន្ធទៅនឹងរឿងអ្វីនោះឡើយ"]។

[1519] ឯកសារ D219/33 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៤-៧, ៩ KH 01032063-64 ["គេបាននាំយកអ្នកទោសទាំងអស់ចេញពីកន្លែងមន្ទីរឃុំឃាំង [...] ប៉ុន្តែគេពុំមានសម្លាប់ទាំងអស់ទេ នៅកន្លែងសម្លាប់នោះ។ គឺមានចំនួនរាប់រយនាក់ មានប្រុស ស្រី ក្មេង និងកូនង៉ាផងដែរ [...] ខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង។ អ្នកទោសទាំងអស់ត្រូវបានគេឲ្យអង្គុយនៅវាលស្រែ ហើយអ្នកយាមបានយកអ្នកទោសប្រុសម្តងមួយ១ យកទៅសម្លាប់ទម្លាក់នៅក្នុងរណ្តៅ។ ខ្ញុំបានយកកន្សែងបាំងមុខ រួចហើយលួចមើលអ្នកដែលគេយកចេញទៅវាយសម្លាប់។ គេចាប់ផ្តើមសម្លាប់តែពួកប្រុស១មុនប៉ុណ្ណោះ។ [...] ប្រហែល ៣៧ ទៅ ៣៨នាក់។ ប៉ុន្តែនៅពេលដែលគេយកស្ត្រីម្នាក់ជាមួយនឹងកូនង៉ា យកទៅដល់មាត់រណ្តៅរៀបវាយសម្លាប់ ខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំង ហើយខ្ញុំក៏គិតអ្វីលែងឃើញ ក៏មិនអាចរាប់តទៅទៀតកើត។ [...] គេបាននាំពួកយើងត្រឡប់មកមន្ទីរឃុំឃាំងវិញ។ [...] អ្នកយាមមានចំនួនប្រហែល១០នាក់ ដែលនាំយកអ្នកទោសចេញទៅនោះ"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៣៥ KH 01149373 ["អ្នកទោសទាំងស្រី ទាំងប្រុស ត្រូវបានគេនាំទៅវាលស្រែ។ គេបានប្រាប់ឲ្យយើងមើល និងកុំឲ្យយកគំរូតាមអ្នកទោសប្រុសទាំងនោះ។ ក្រោយមក គេបានចាប់ផ្តើមសម្លាប់អ្នកទោសប្រុសទាំងអស់នោះ និងបញ្ជូនអ្នកទោសស្ត្រីត្រឡប់ទៅគុកវិញ"]។

[1520] ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.១០៤-១០៧, ១១១, ១១៣ KH 01022374-75 ["ខ្ញុំគ្រាន់តែឮថាមានការចាប់ស្ត្រីទៅរំលោភនៅក្នុងព្រៃ ហើយក្រោយមកសម្លាប់ចោល។ [...] មានស្ត្រីម្នាក់ដែលស្នាក់នៅក្នុងភូមិរបស់ខ្ញុំ ត្រូវបានគេចាប់យកទៅរំលោភ និងសម្លាប់ចោល។ [...] ខ្ញុំដឹងថា ពួកគេ[មេភូមិ ឬប្រធានកង]ពិតជាដឹងពីករណីរំលោភនេះ ហើយបានបញ្ជាឲ្យឈ្លបចាប់យកទៅសម្លាប់ចោល។ ប៉ុន្តែឈ្លបនោះរំលោភ ហើយក៏សម្លាប់ចោល។ វាបានកើតឡើងនៅពេលក្រោយពួកនិរតីមកដល់។ [...] មេភូមិ ឆន [...] ខ្ញុំមិនដែលឃើញមានការដាក់ទោសទេ"]។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៩១-៩២ KH 01187886 [នៅអណ្តូងថែលុយ "[ខ្ញុំបាន]ដឹងតាម យុវជនក្មេងម្នាក់ដែលធ្វើការខាងដាំស្ពៃ។ [...] ឈ្លបខ្ចីការ៉ុងដាក់អង្ករមកពីអ្នកដាំស្ពៃ [...]។ ពេលដែលយុវជនទៅប្រមូលការ៉ុង ហើយឃើញខ្មោចស្ត្រីដែលគេរំលោភនោះ។ [...] ឃើញស្ត្រីទាំងនោះពុំមានសំលៀកបំពាក់ឡើយ"]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

433. ដោយសារលទ្ធផលនៃការអស់កម្លាំង ការបង្អត់អាហារ ជំងឺ និងកង្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ បានធ្វើឲ្យកម្មករ និងអ្នកទោសជាច្រើនបានស្លាប់នៅសហករណ៍ធិបតី ពីឆ្នាំ១៩៧៧ ដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ[1521]។ នៅមន្ទីរសន្តិសុខធិបតី "គឺស្ទើរតែរៀងរាល់ថ្ងៃ [...] មួយថ្ងៃស្លាប់មួយនាក់ ឬពីរនាក់"[1522]។ "មានតិចណាស់ដែលនៅរស់ ភាគច្រើនគឺស្លាប់"[1523]។ នៅទួលម្នាស មនុស្ស "ប្រមាណជា១០-២០នាក់[បានស្លាប់]ក៏មានក្នុង១ ខែ"[1524]។

[1521] ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.៣៦ KH 01095212 ["មានមនុស្សជាច្រើនដែលស្លាប់ដោយសារជីវភាពខ្វះខាត ហើយនឹងធ្វើការធ្ងន់ហួសហេតុ"]។ ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៥២, ៥៤ KH 01008723 ["គឺមានក្មេងប្រហែល១០ ទៅ២០នាក់ ស្លាប់ដោយអត់អាហារ។ [...] មានមនុស្សពេញវ័យខ្លះស្លាប់ដោយអត់អាហារ"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.១០៥ KH 01032623 [នៅក្នុងសហករណ៍ធិបតី "គឺមនុស្សភាគច្រើនស្លាប់ដោយសារអត់អាហារ"]។ ឯកសារ D219/549 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ្រឿម ឆ.១២ KH 01157576 [នៅទួលម្នាស៖ មានមនុស្សជាច្រើនដាច់បាយ ដោយសារ [...] ហើយទៅជាឈឺ"]។ ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៤៦ KH 01022368 [នៅទួលម្នាស]។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៨០ KH 01187885 [នៅក្នុងកងកុមារ]។ ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រឿង សុភាព ឆ.៧៦ KH 01113259 [នៅការដ្ឋានទួលម្នាស]។ ឯកសារ D118/277 កំណត់ហេតុស្តាប់ចម្លើយ សែម ស៊ីង ឆ.៥៨ KH 01000109។ ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់ធី ឆ.១៤៣ KH 01029508។ ឯកសារ D118/231 កំណត់ហេតុស្តាប់ចម្លើយ ប៊ួយ ហួយ ឆ.៣៧, ៧៥ KH 00985936, 42 [នៅជិតភ្នំធិបតី]។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៣០ KH 00988047 [ភាគីដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់អះអាងថា នៅជើងទឹង គាត់បានឃើញសាកសពមនុស្សជាច្រើនដែលស្លាប់ដោយសារអត់អាហារ អ្នកស្លាប់ភាគច្រើនជាអ្នកមកពីភ្នំពេញ] ឆ.១១ KH 00988045 ["ខ្ញុំឮថាមានអ្នកជម្លៀសពីភ្នំពេញច្រើនបានស្លាប់នៅទួលម្នាស ដោយសារអត់អាហារ"]។

[1522] ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.២២, ២៥ KH 01149370-71 ["ស៖ តើលោកស្រីបានឃើញអ្នកទោសស្លាប់ដោយសារជំងឺ និងដោយសារតែគេមិនយកចិត្តទុកដាក់ញ៉ីកញ្ជាប់ដោយកម្រិតណា? ឆ.២២៖ គឺស្ទើរតែរៀងរាល់ថ្ងៃ ជួនកាលមួយថ្ងៃស្លាប់មួយនាក់ ឬពីរនាក់។ [...] ស៖ អ្នកទោសដែលលោកស្រីបានឃើញដេកស្លាប់ និងអង្គុយស្លាប់ តើអ្នកទោសទាំងនោះ ស្លាប់ដោយសារជំងឺអ្វី? ឆ.២៥៖ ពួកស្លាប់ដោយសារអត់អាហារ"]។

[1523] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៩២ KH 01025662។

[1524] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៨៣, ១០៤ KH 01205218, 23 ["ប្រមាណ១០-២០នាក់ ក៏មានក្នុង១ខែអ្នកខ្លះដើរដួលងាប់លើដី អ្នកខ្លះកំពុងបត់ជើងងាប់នឹងអាចម៍ ព្រោះគ្នាអស់កម្លាំង គ្នាឈឺ ហើយប្រើខ្លាំងពេកក៏ដួលងាប់។ [...] ខ្លះរាករហូតដល់ងាប់ក៏មាន"]។

434. ក្រោមការដឹកនាំរបស់ភូមិភាគនិរតី សាក្សី និងភាគីដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើការកត់សម្គាល់អំពីកំណើននៃការសម្លាប់ក្រៅអំណាចតុលាការនៅក្នុងសហករណ៍[1525]។ មនុស្សម្នាក់បាននិយាយថា នៅពេលគាត់ទៅលេងផ្ទះនៅភូមិថ្មី គាត់បានឃើញកម្មាភិបាលភូមិភាគនិរតីបានចាប់ខ្លួនកម្មាភិបាលពាយ័ព្យ "ច្រើនណាស់" ដែលគាត់បានឃើញសាកសពពួកគេនៅពេលក្រោយ "នៅខាងលិចដង្កោកំណាប់ និងថាគាត់ក៏បាន "ឃើញក្បាល[មួយចំនួន]នៅមួយកន្លែង"ផងដែរ នៅកន្លែងដែលគេយកពួកកម្មាភិបាលទៅរៀនសូត្រ[1526]។ សាក្សីនានាក៏បានរៀបរាប់ពីប្រឡាយមួយនៅជើងភ្នំធិបតីខាងក្រោយភូមិថ្មី ដែលមានសាកសព "រាប់រយ" រួមទាំងខ្មោចកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកទោសពីមន្ទីរសន្តិសុខធិបតីផង[1527]។ ការសម្លាប់ក្នុងចំនួនដ៏ច្រើនតម្រូវ

[1525] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.៤៧ KH 01032617 [ក្រោយការមកដល់របស់ពួកនិរតី "មានការសម្លាប់មនុស្សច្រើនជាងមុនទៅទៀត"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៤ KH 01149367 [នៅមន្ទីរសន្តិសុខធិបតី]។ ឯកសារ D219/388 កំណត់ហេតុស្តាប់ចម្លើយ រឿង សុភាព ឆ.៧៦ KH 01113259 [នៅការដ្ឋានទួលម្ទេស]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៥១ KH 01149420 [នៅអណ្តូងថៃលុយ ចម្ងាយ ១៥០ម៉ែត្រពីភូមិថ្មី: "កម្មាភិបាលភូមិភាគនិរតីនៅតែបន្តសម្លាប់មនុស្សនៅទីនោះ និងបានពង្រីកការសម្លាប់មនុស្សនៅកន្លែងផ្សេងទៀត [...]។ ខ្ញុំធ្លាប់ទៅឃើញមានសាកសពជាច្រើនដែលមានរុយរោម"]។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៤៨ KH 00988049 [នៅជើងទិញ]។ ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៦៥ KH 01008724 ["ខ្ញុំធ្លាប់ឮគេនិយាយថា មានគេយកមនុស្សទៅសម្លាប់នៅភ្នំធិបតី ជារៀងរាល់យប់"]។

[1526] ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៣២-៣៣, ៣៦, ៥៣-៥៤, ៦០ KH 01187880-81, 82-83 ["និរតីសម្លាប់ពាយ័ព្យ។ ឃើញ មកលេងផ្ទះ[នៅភូមិថ្មី] ឃើញគេកាប់សម្លាប់កម្មាភិបាល។ [...] [មនុស្ស]ច្រើនណាស់[ត្រូវបានសម្លាប់]។ [...] ឃើញតែគេចាប់ទៅ ឃើញតែខ្មោចក្រោយ [...]។ នៅខាងលិចដង្កោកំណាប់ [...] ពេលនោះ អាខាងកើតកណ្តោកំណាប់ គេយកកម្មាភិបាលទៅរៀនសូត្រ ពេលដែលខ្ញុំទៅធ្វើការជិតនោះ ខ្ញុំឃើញក្បាលនៅមួយកន្លែង ហើយនឹងកន្លែងក្បែរនោះទៀត"]។

[1527] ឯកសារ D219/447 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.២៣ KH 01129709 ["ខ្ញុំឮថា កម្មាភិបាលពាយ័ព្យ និងគ្រួសាររបស់ពួកគេយកទៅសម្លាប់ចោលនៅជើងភ្នំធិបតី ឯកន្លែងមួយដែលមានឈ្មោះថា អណ្តូងចឹលុយ"] ឆ.៣៦-៣៧ KH 01129712-13 ["សាកសពទាំងនោះ គឺជាសាកសពរបស់អ្នកទោសដែលត្រូវបានគេឃុំខ្លួន និងសាកសពរបស់អតីតកម្មាភិបាលពាយ័ព្យដែលត្រូវបានចាប់ខ្លួន សម្លាប់ និងកប់នៅទីនោះ" នៅក្នុង "ប្រឡាយមួយដែលស្ថិតនៅក្បែរភ្នំធិបតី"។ ទីតាំងសម្លាប់មនុស្ស "គឺជាកន្លែងតែមួយ" ដូចគ្នានឹងកន្លែងដែលអ្នកទោសត្រូវបានគេសម្លាប់នៅក្រោយភូមិថ្មី។ "សាកសពមនុស្សរាប់រយនាក់ត្រូវបានគេកប់នៅទីនោះ"]។ ឯកសារ D219/172 កំណត់ហេតុស្តាប់ចម្លើយ តូច ប៊ុនធី ឆ.២០ KH 01065965 ["ចម្ងាយប្រហែល កន្លះគីឡូម៉ែត្រពី[...] ជើងភ្នំធិបតី។ កន្លែងសម្លាប់មនុស្សនោះគឺជាប្រឡាយ [...]។ ប្រឡាយនេះមានបាតទំហំប្រហែល ១,៥ម៉ែត្រ មាត់ប្រឡាយប្រហែល ៣ម៉ែត្រ និងជម្រៅប្រហែល ១,៦ម៉ែត្រ។ [...] ប្រឡាយនោះមានចម្ងាយប្រហែល ៤០០ម៉ែត្រ ត្រូវបានគេប្រើប្រាស់សម្រាប់កប់សាកសពរួចហើយ ដូច្នេះអាចមានអ្នកស្លាប់ដល់រាប់រយនាក់"]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៣៣ KH 01149417-18 [បងប្អូនជីដូនមួយសាក្សីបានឃើញ "ការដឹកមនុស្សទាំងឡាន១ពី

ឲ្យ តូច ប៊ុនថី និងមនុស្ស៣០នាក់ផ្សេងទៀត ដើម្បីកប់សាកសពទាំងនោះ "១០ដងក្នុងរយៈពេលប្រហែល ១ខែ" នៅក្នុងប្រឡាយដែលមានចម្ងាយប្រហែល ៤០០ ម៉ែត្រ[1528]។

435. នៅមន្ទីរសន្តិសុខធិបតី អ្នកយាមគុក "សម្លាប់អ្នកទោសម្តង២ ទៅ ៣នាក់"[1529]។ អតីតអ្នកជាប់ឃុំ ឃិន ខៀន បានកត់សម្គាល់ថា "ក្នុងរយៈពេល៤ ខែមានអ្នកទោសប្រហែល ១០០ នាក់ ត្រូវបានខ្ទ្រ ក្រហមសម្លាប់"[1530]។ គាត់ក៏បានឃើញការសម្លាប់យ៉ាងរង្គាលមួយនៃអ្នកទោសបុរសមកពីភ្នំពេញ យ៉ាងហោចណាស់ ៣៧ នាក់[1531]។ អ្នករស់រានមានជីវិតម្នាក់ទៀតបានសង្កេតឃើញថា កម្មាភិបាលភូមិភាគពាយ័ព្យដែលជាប់គុក និងប្រពន្ធរបស់ពួកគេដែលត្រូវបានឃុំជាមួយគាត់ដែរ នោះ "ពួកគេបានបាត់ខ្លួនអស់ ប្រហែលជាត្រូវបានគេសម្លាប់អស់ហើយ ដោយសារខ្ញុំមិនបានឃើញពួកគេទៀតឡើយ"[1532]។ ហៀបចូលមកដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ ពួកកម្មាភិបាលភូមិភាគនិរតីបានសម្លាប់អ្នកទោស ដែលនៅសេសសល់ទាំងអស់នៅមន្ទីរសន្តិសុខធិបតី រួមទាំងស្រី

កន្លែងផ្សេងទៀតមកសម្លាប់នៅជើងភ្នំធិបតី"] ឯ.៩៤ KH 01149428 [ប្រពន្ធរបស់កម្មាភិបាលភូមិភាគពាយ័ព្យម្នាក់ឈ្មោះ តាជេ រ ដែលជាមេគុកធិបតី"ត្រូវបានគេសម្លាប់នៅអណ្តូងថែលុយ"] ឯ.៤៩ KH 01149420[នៅអណ្តូងថែលុយ៖ មាន"[សាកសព] រាប់រយនាក់ មានទាំងក្មេង ទាំងចាស់ រួមទាំងកុមារផង ទាំងប្រុស ទាំងស្រី"]។ *សូមមើលផងដែរ* ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឯ.៩០ KH 01187886 ["[ខ្ញុំបានឃើញ]កន្លែងដែលវាយចោល ដែលខាងកើតអណ្តូងថែលុយ ប្រឡាយវែង គេវាយដាក់ប្រឡាយ មានខ្ទោចនារី និងយាយ [...]។ ហើយមានក្មេង ហើយនឹងកម្មាភិបាលដែលរត់"]។

[1528] ឯកសារ D219/172 កំណត់ហេតុស្តាប់ចម្លើយ តូច ប៊ុនថី ឯ.២០ KH 01065965 ["ក្រុមខ្ញុំដែលមានសមាជិក ៣០នាក់ ត្រូវបានគេស្នើឲ្យទៅជួយកប់សាកសពនៅប្រឡាយនោះដែរ។ ខ្ញុំបានទៅទីនោះ ប្រហែលជាង ១០ដងក្នុងរយៈពេលប្រហែល១ខែ។ [...] ប្រឡាយនោះចម្ងាយប្រហែល ៤០០ម៉ែត្រ"]។

[1529] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៩៨ KH 01025663។

[1530] ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៩៨ KH 01025663។

[1531] ឯកសារ D219/33 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៥ KH 01032063 ["អ្នកយាមបានយកអ្នកទោសប្រុសម្តង មួយៗយកទៅសម្លាប់ទម្លាក់នៅក្នុងរណ្តៅ។ ខ្ញុំបានយកកន្ទ្រែងបាំងមុខរួចហើយលួចមើលអ្នកដែលគេយកចេញទៅវាយសម្លាប់។ គេចាប់ផ្តើមសម្លាប់តែពួកប្រុសៗមុនប៉ុណ្ណោះ។ [...] ប្រហែល៣៧ ទៅ៣៨នាក់"]។ ឯកសារ D219/512 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឯ.៣៧ KH 01149373 ["អ្នកទោស[ប្រុស]ទាំងនោះ គឺជាប្រជាជនធម្មតាមកពីភ្នំពេញ"]។

[1532] ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឯ.៤៤ KH 01149419។

និងកូនដ៏ង[1533]។ សាក្សីនានាបានកំណត់អត្តសញ្ញាណទីតាំងផ្សេងទៀត ដែលអ្នកទោសត្រូវបានសម្លាប់រួមទាំងទីតាំងមួយដែលមាន "សាកសពជាច្រើនគរលើគ្នាជាច្រើន"[1534]។

436. ន្ជួន ម្ជួន ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យម្នាក់ដែលបានជាប់គុកនៅមន្ទីរសន្តិសុខទួលម្ជេស បាននិយាយថា: "ខ្ញែរក្រហមគេប្រើពាក្យមណ្ឌលកែប្រែ តែខ្ញុំមិនដែលឃើញគេកែប្រែអ្វីទេ ខ្ញុំឃើញតែគេយកទៅសម្លាប់តែម្តង" "រៀងរាល់យប់"[1535]។ គាត់ធ្វើការក្នុងអង្គភាពមួយសម្រាប់កម្មាភិបាលភូមិភាគពាយ័ព្យដែលជាប់គុកនៅការដ្ឋានពលកម្មការងារដោយបង្ខំទួលម្ជេស និងបានកត់សម្គាល់ឃើញថា "កម្មាភិបាលភូមិភាគពាយ័ព្យនៅជាមួយខ្ញុំនោះបាត់ខ្លួនពីរបីនាក់រាល់ថ្ងៃ។ កាលណោះ កម្មាភិបាលភូមិភាគពាយ័ព្យមកជាមួយខ្ញុំមានចំនួនជាង១០០ នាក់ ហើយក្រោយមកនៅសល់តែ៣០

[1533] ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ីយ ចិន្តា ឆ.១៥១ KH 01032623 ["នៅមុនពេលដែលកងទ័ពវៀតណាមចូលមកដល់ អ្នកទោសទាំងអស់នៅក្នុងមន្ទីរឃុំឃាំងត្រូវបានគេសម្លាប់ចោល"]។ ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៣៣ KH 01149417-18 ["ក្រោយពេលដែលខ្ញុំត្រូវបានគេដោះលែង [...] គេសម្លាប់អ្នកនៅក្នុងគុក[នៅភ្នំធិបតី]ទាំងអស់"]។ ឯកសារ D118/280 កំណត់ហេតុស្តាប់ចម្លើយ សង់ សយ ឆ.៥ KH 01004106 ["ខ្ញុំដឹងថា អ្នកទោសក្នុងឃ្លាំងទាំងអស់ត្រូវបានគេយកទៅសម្លាប់"]។ ឯកសារ D118/19 កំណត់ហេតុស្តាប់ចម្លើយ ឃីង ឃាន ឆ.៣៦ KH 00891138 ["បងថ្លៃស្រីខ្ញុំ និងកូនគាត់អាយុបីខែត្រូវគេយកទៅសម្លាប់នៅទីនោះ មុនវៀតណាមចូលតែ២ទៅ៣ថ្ងៃប៉ុណ្ណោះ"]។

[1534] ឯកសារ D118/19 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៣៨-៤០, ៤៣ KH 00891139 ["ខ្ញុំគ្រាន់តែឮ [...] ថា គេដឹកអ្នកទោសចេញពីគុកធិបតីយកទៅសម្លាប់។ [...] ខាងកើតភ្នំធិបតី ខាងកើតភូមិបឹងកន្ទ្ធត ខាងលិចរ៉ារថភ្លើង ជិតប្រឡាយ។ [...] ខ្ញុំបានឃើញ **[...]** មានសាកសពគេដាក់គរលើគ្នា។ [...] **[**អ្នកជាប់ឃុំ**]**ខ្លះជាអ្នកភូមិនៅទីនេះ ខ្លះជាកម្មាភិបាលភូមិភាគពាយ័ព្យ ខ្លះជាអ្នកភ្នំពេញ]។ ឯកសារ D219/14 កំណត់ហេតុស្តាប់ចម្លើយ ឃិន ខៀន ឆ.៩៤ KH 01025662 ["ខ្ញែរក្រហម [...] ឲ្យដឹករណ្តៅដោយខ្លួនឯង។ [...] រណ្តៅនោះមានចម្ងាយប្រហែលកន្លះគីឡូម៉ែត្រ ពីឃ្លានោះ"]។ ឯកសារ D219/271 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខ KH 01477659 ["ទីតាំងសម្លាប់អ្នកជាប់ឃុំរួមមួយ [...] ចម្ងាយពីរបីរយម៉ែត្រនៅទិសឦសាននៃឃ្លាំងក្រោម"]។ ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម ឃាង ឆ.៩០ KH 01187886 ["កន្លែងមួយទៀតដែលចុះពីគុកលើវត្ត ទៅខាងជើងបឹងពេជ្រចង្វារ"] (*កត់សំគាល់* ថាសាក្សីរូបនេះក្រោយមកបានបញ្ជាក់ថា កម្មាភិបាលភូមិភាគនិរតីបានសម្លាប់អ្នកជាប់ឃុំមកពីភ្នំធិបតី នៅជិតបឹងពេជ្រចង្វារ *សូមមើល* ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម ឃាង ឆ.១២១ KH 01187889)។

[1535] ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.២១ KH 00891132។ ឯកសារ D105/3 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.២០ KH 00780636។

នាក់ទេ"[1536]។ "កងជីវពលគេប្រាប់ខ្ញុំថា គេយកអ្នកទាំងនោះទៅជួបអង្គការ"[1537]។ សាក្សីផ្សេងទៀតបានប្រាប់អ្នកស្ទើបអង្កេត ក.ស.ច.ស ថា មានកម្មករធម្មតាប្រហែល២ ទៅ១០ នាក់ ត្រូវបានយកចេញពីការដ្ឋានពលកម្មការងារដោយបង្ខំទួលម្ទេស រៀងរាល់ពីរបីថ្ងៃម្តង រួមទាំងអ្នកដែលគេបញ្ជូនទៅ "រៀនសូត្រ"ផង[1538]។

437. នៅរ៉ាវថភ្លើងក្នុងភូមិវ៉ា អ្នកជាប់ឃុំត្រូវបានគេ "បញ្ជេញយកទៅសម្លាប់ដែរ"[1539]។ នៅចុងខែកញ្ញា ឬដើមខែតុលា ឆ្នាំ១៩៧៨ តូច ប៊ុនថី បានកប់ "សាកសព[ទាហាន]យ៉ាងតិច ២០០ នាក់" នៅជិតស្ពានីរថភ្លើង[1540]។

[1536] ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.២៧ KH 00920214។ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយពីដំបូងមួយ សាក្សីរូបនេះនិយាយថា៖ "ពេលដែលខ្ញុំរត់ អ្នកទោសនៅសល់ប្រហែលតែ១០នាក់ប៉ុណ្ណោះ [...] គ្រាន់តែដឹងថាបាត់ខ្លួន"។ *សូមមើល* ឯកសារ D105/3 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.២២-២៣ KH 00780637។ *សូមមើលផងដែរ* ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៩២ KH 01205220 ["កម្ទាភិបាលពាយ័ព្យ គេយកទៅរៀនសូត្ររហូត"] (*កត់សំគាល់* ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤៧ KH 01196538 ["អ្នកដែលគេយកទៅរៀនសូត្រ គឺបាត់ខ្លួនរហូត"])។

[1537] ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.២៧ KH 00920214។

[1538] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៥០-៥១, ៩២ KH 01205209-10, 20 ["ពេលប្រជុំជីវភាពប្រចាំថ្ងៃមានបាត់មនុស្សបួនដប់នាក់។ [...] វាចន្លោះពីរបីថ្ងៃគេយកទៅរៀនសូត្រ ហើយបាត់អ៊ីចឹងទៅ។ [...] ជាប្រជាជនធម្មតា"]។ ឯកសារ D118/196 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង សុភាព ឆ.៣៤, ៨៩ KH 00978386, 92 ["ខ្ញុំដឹងតែតាមមិត្តភក្តិមានបាត់ខ្លួន ហើយខ្ញុំឃើញគេ[ខ្មែរក្រហម]ចងមនុស្សយកទៅម្តង១ពីរ ឬប្រាំនាក់ រួមទាំងកុមារផងដែរ។ [...] បាត់ខ្លួនមនុស្ស [...] ទាំងថ្ងៃ ទាំងយប់"]។ ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៤៩ KH 01922369 ["ជួនកាលម្តងពីរនាក់"]។

[1539] ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៤៥ KH 01187881។

[1540] ឯកសារ D219/172 កំណត់ហេតុស្តាប់ចម្លើយ តូច ប៊ុនថី ឆ.៣, ២៥ KH 01065960-61, 67 ["ចុងខែកញ្ញា ឬដើមខែតុលា ឆ្នាំ១៩៧៨ [...] យោធា [...] [ត្រូវគេចង]ដោតខ្សែអង្រ៊ីងភ្ជាប់គ្នា ៥នាក់ ១០នាក់ ឬ២០នាក់ [...] ត្រូវបានគេយកទៅបាញ់សម្លាប់ដោយកាំភ្លើង។ [...] លុះដល់ពេលព្រឹកបានយោធាខ្មែរក្រហមគេចង្អុលបង្ហាញប្រាប់ក្រុមខ្ញុំឲ្យយកខ្ទោចនៅទីនេះ ទីនោះ ប៉ុន្ថាន នាក់ៗ យកទៅកប់។ កន្លែងដែលគេសម្លាប់មនុស្សទាំងនោះ គឺនៅខាងកើតផ្លូវរទេះភ្លើងប្រហែល ៥០ ទៅ ១០០ម៉ែត្រ។ [...] មានសាកសពយ៉ាងតិច ២០០នាក់។ ពួកខ្មែរក្រហមចំណាយពេលប្រហែលជាកន្លះខែដើម្បីសម្លាប់ទាហានទាំងនោះអស់"]។ *សូមមើលផងដែរ* ឯកសារ D219/644 កំណត់ហេតុស្តាប់ចម្លើយ យ៉ុម យាង ឆ.៤៨ KH 01187882 ["សម្លាប់ ខាងកើតរ៉ាក៏មាន ខាងត្បូងរ៉ាក៏មាន"]។

438. នៅកន្លែងផ្សេងទៀតក្នុងសហករណ៍ធិបតី ការសម្លាប់រួមមាន កម្មាភិបាលភូមិភាគពាយ័ព្យប្រាំពីនាក់ និងសមាជិកគ្រួសាររបស់ពួកគេនៅ "ខាងក្រោយភូមិភ្នំតាថុក" នៅចុងឆ្នាំ១៩៧៨[1541] "បុរសម្នាក់ដែលនិយាយ [...] ដូចវៀតណាម"[1542] ប្រជាជន"ដើរហើរសេរី"[1543] និងស្ត្រីដែលស្ថិតនៅក្នុងក្រុមរបស់សាក្ស៊ី[1544]។ មានករណីខ្លះ កម្មាភិបាលភូមិភាគនិរតីបានសម្លាប់ជនរងគ្រោះរបស់ខ្លួន ភ្លាមៗតែម្តង[1545]។ ក្រោមការដឹកនាំរបស់ខ្លួន ការស្លាប់គឺជារឿងគេចមិនផុតនៅតាមសហករណ៍ "ខ្ញុំបានឃើញនារីម្នាក់ចងកសម្លាប់[...] ដោយសារនារីនោះដឹងថា បើនៅរស់ ក៏គេចមិនរួចពីគេសម្លាប់ដែរ"[1546]។

[1541] ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.១០៤-១០៧ KH 01029503-04 ["ពួកនិរតី" "[...] សម្លាប់ពួកពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ" "ចុងឆ្នាំ១៩៧៨។ ៧នាក់ [...] គេសម្លាប់នៅក្រោយភូមិភ្នំតាថុក"]។

[1542] ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៣២ KH 01149417 ["មានបុរសម្នាក់ដែលនិយាយ[...] ដូចវៀតណាម ត្រូវបានគេយកទៅសម្លាប់ចោលដែរ [...] នៅពេលដែលមានកម្មាភិបាលនិរតីគ្រប់គ្រង [...] នៅអណ្តូងថែលុយ"]។

[1543] ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៤០ KH 01008721 ["យុវជន មានអាយុប្រហែល២០ឆ្នាំ ដើរហើរសេរីនោះ ត្រូវបានគេចាប់ខ្លួន រួចវាយធ្វើបាបនៅជិតខ្ញុំមានចម្ងាយប្រហែល១០ម៉ែត្រ។ ខ្ញុំបានឃើញឈាមហូរប្រឡាក់ពេញមុខមាត់អ្នកទាំងនោះ។ លុះស្អែកឡើង ខ្ញុំបានឃើញខ្មែរក្រហមលីចប ហើយប្រជាជនបាននិយាយប្រាប់ខ្ញុំថា យុវជនទាំងបីនាក់នោះ ត្រូវគេយកទៅសម្លាប់[...]ហើយ"]។

[1544] ឯកសារ D118/290 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ាច ឆ.៧៤-៧៦ KH 01022371 ["ក្រោយការមកដល់របស់ពួកនិរតី [...] ស្ត្រីទាំង៣នាក់នោះនៅក្នុងក្រុមរបស់ខ្ញុំ ហើយ [...] ខ្ញុំឮពីអ្នកដទៃថា ស្ត្រីទាំង៣នាក់នោះត្រូវបានគេយកទៅសម្លាប់។ ពួកគេធ្វើការនៅក្នុងភូមិ ក្បែរភ្នំធិបតី"]។

[1545] ឯកសារ D219/517 កំណត់ហេតុស្តាប់ចម្លើយ សយ ឈឿន ឆ.៦៩, ៩០ KH 01149423-24, 28-29 ["ក្រោមការគ្រប់គ្រងរបស់ពួកនិរតី [...] អ្នកដែលជាមុខព្រួយរបស់គេ នឹងត្រូវអូសចេញយកទៅសម្លាប់ភ្លាមតែម្តង"។ បើមាននរណាម្នាក់ប្រព្រឹត្តខុស "គេនឹងយកទៅសម្លាប់ភ្លាមតែម្តង ដោយមិនចាំបាច់យកទៅដាកគុកនោះទេ ជាពិសេសជនជាតិយួន"]។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.១០៧ KH 01032623 ["បើសិនជាគេចោទថាខ្លាំង គេចាប់យកទៅសម្លាប់ចោលតែម្តង"] ឆ.១៥១ KH 01032628 ["បើគេចាប់បានអ្នកទោសថ្មី គឺគេសម្លាប់ចោលតែម្តង"]។

[1546] ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៦៤ KH 01008724។

439. ជាការបន្ថែមចំពោះអ្វីដែលបានរៀបរាប់ខាងលើ កម្មាភិបាលភូមិភាគពាយ័ព្យ មនុស្សមានជំងឺ និង ប្រជាជនផ្សេងទៀត បានបាត់ខ្លួននៅក្នុងសហករណ៍[1547]។ មន្ទីរសន្តិសុខដែលមានទីតាំងស្ថិតនៅក្បែរជើងភ្នំតាចុក "មួយចំនួនធំ [...]បានបាត់ខ្លួនរហូត"[1548]។

ការធ្វើទុក្ខបុកម្នេញ

440. កម្មាភិបាលភូមិភាគនិរតីបានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនដូចបានរៀបរាប់ខាងលើ ក្នុងចេតនាដើម្បីកំណត់គោលដៅលើក្រុមជាក់លាក់ មានដូចជា កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ នៅមន្ទីរសន្តិសុខធិបតី[1549]។ ក្រុមនេះត្រូវបានកំណត់គោលដៅចំៗ ដោយសារតែសមាជិកភាពពិតប្រាកដ ឬតាមការសន្មតរបស់ពួកគេចំពោះក្រុមនយោបាយណាមួយ។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

441. ផ្អែកលើភស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យឹម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខធិបតី៖[1550] ការធ្វើមនុស្សឃាត ការ

[1547] ឯកសារ D118/286 កំណត់ហេតុស្តាប់ចម្លើយ ខៀវ នាប ឆ.៦៧ KH 01008724 ["ស៖ លោកស្រីមានកត់សំគាល់ឃើញថា តើមានមនុស្សបាត់ខ្លួនទេនៅកន្លែងលោកស្រី? ឆ.៦៧៖ ចាស"]។ ឯកសារ D219/11 កំណត់ហេតុស្តាប់ចម្លើយ ប៉េញ ញ៉ាញ ឆ.៨ KH 01025474 [កម្មាភិបាលភូមិភាគពាយ័ព្យ "ពួកគេស្រាប់តែបាត់ខ្លួនអស់តែម្តង"]។ ឯកសារ D118/231 កំណត់ហេតុស្តាប់ចម្លើយ ប៊ួយ ហួយ ឆ.៣៩ KH 00985937 [នៅជិតភ្នំធិបតី "ចំពោះអ្នកដែលឈឺត្រូវបានគេបញ្ជូនយកទៅកន្លែងផ្សេង ហើយក៏បាត់ខ្លួនរហូត"]។

[1548] ឯកសារ D6.1.895 កំណត់ហេតុស្តាប់ចម្លើយ គង់ វាច ឆ.៥៤ KH 00420977 ["មាន[អ្នកជាប់ឃុំ]មួយចំនួនត្រូវបានបាត់ខ្លួនរហូតហើយមួយចំនួនតូចក៏បានត្រឡប់មកវិញ"]។

[1549] *សូមមើលផងដែរ* ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ឹង អឿម ឆ.៤៥-៤៦, ៤៨ KH 01157569-70 ["នៅឆ្នាំ ១៩៧៨ [...] ពួកនិរតី [...]បានហៅ [...] ពួកយោធាពាយ័ព្យ [...] ឲ្យមកប្រជុំ [...] នៅទួលម្នេស។ គេនឹងរៀបចំជប់លៀងហូបនំបញ្ចុក។ [...] គេមានគម្រោងសម្លាប់អ្នកដែលទៅចូលរួមប្រជុំនៅទីនោះ។ [...] នៅពេលនោះ គេជីករណ្តៅរួចហើយ"]។ ឯកសារ D219/172 កំណត់ហេតុស្តាប់ចម្លើយ តូច ប៊ុនធី ឆ.២១ KH 01065966 ["[ប្រភេទ]ជនរងគ្រោះ [...] ដែលត្រូវបានសម្លាប់ [...] មាន ខ្សែក្បត់របស់តាវ៉ាញ និងក្រុមគ្រួសាររបស់ពួកគេ"]។

[1550] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យឹម ទិត្យ នៅឡើយ។ ទាំងនេះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះតាមរយៈ៖ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ

សម្លាប់រង្គាល[1551] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។

គ. ទីតាំងពលកម្មដោយបង្ខំទំនប់កង្គត

i. សេចក្ដីផ្ដើម

442. ទំនប់កង្គតគឺជាទីតាំងពលកម្មដោយបង្ខំថ្នាក់តំបន់ ដែលមានទីតាំងស្ថិតនៅក្នុងស្រុកសង្កែ តំបន់១ ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ កម្មាភិបាលភូមិភាគនិរតីបានចាប់ផ្ដើមរួមចំណែកក្នុងឧក្រិដ្ឋកម្មនៅទីតាំងនេះចាប់ពីប្រហែលជាពាក់កណ្ដាលឆ្នាំ១៩៧៧ ប្រហែលជានៅពេលដំណាលគ្នាដែលអតីតលេខាតំបន់១ ឈ្មោះ តាវ៉ាញ ត្រូវបានចាប់ខ្លួន និងពេលទំនប់កង្គតបាក់។ **យ៉ឹម ទិត្យ** និងអ្នកតំណាងផ្សេងៗទៀតនៃគណៈតំបន់១ បានពិនិត្យទីតាំងនេះ។

443. **យ៉ឹម ទិត្យ** បានប្រើឥទ្ធិពល និងអំណាចរបស់ខ្លួនលើមន្ត្រីទាំងឡាយនៅទីតាំងនេះ នៅមុន និងក្រោយពេលដែលគាត់ទទួលបានការតែងតាំងជាផ្លូវការជាលេខាតំបន់១។ គាត់បានធ្វើការជាមួយពួកកម្មាភិបាលភូមិភាគពាយ័ព្យនៅគណៈតំបន់១ មុនពេលពួកគេទាំងនោះត្រូវបានចាប់ខ្លួន ដាក់ក្នុងមន្ទីរឃុំឃាំង និង/ឬ សម្លាប់ចោល។ រូបគាត់ក៏បានជ្រើសរើសកម្មាភិបាលភូមិភាគពាយ័ព្យឲ្យគ្រប់គ្រងទីតាំងទំនប់នេះផងដែរ។ នៅចុងឆ្នាំ១៩៧៦ **យ៉ឹម ទិត្យ** ស្ថិតនៅទីតាំងទំនប់នេះ ដោយបានផ្ដែងទៅកាន់យោធាភូមិភាគពាយ័ព្យ និងបានដើរទស្សនាការដ្ឋានេះ ដើម្បីបង្ហាញនូវអ្វីដែលស្របតាម និងមិនស្របតាមគោលនយោបាយរបស់ ប.ក.ក។ គាត់បានណែនាំមន្ត្រីនៅទីនោះឲ្យការពារប្រឆាំងនឹងខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ និងបានលើកទឹកចិត្តឲ្យពលករខិតខំធ្វើការ ទោះបីជាពួកគេធ្វើពលកម្ម

៥៨-៥៩, ១១៨ខ។ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្សែក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៥-៨, ២២iii។

[1551] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃអំពើមហាប្រល័យនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្ដុតាងទាក់ទងនឹងមន្ទីរសន្តិសុខធិបតីតែមួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃអំពើមហាប្រល័យដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងមន្ទីរសន្តិសុខធិបតីផង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់បង្កើតបានជាផ្នែកនៃប្រព័ន្ធមួយដែលមានការរៀបចំ ក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំងទាំងអស់ ហើយការសម្លាប់នៅលើទីតាំងនិមួយៗទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ឹម ទិត្យ។

ក្នុងលក្ខខណ្ឌដ៏សែនអមនុស្សធម៌យ៉ាងណាក៏ដោយ។ ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ពលកររាប់រយនាក់ និងប្រហែលជាដល់ទៅរាប់ពាន់នាក់រស់នៅ និងធ្វើការក្នុងលក្ខខណ្ឌជាទាសករ ដោយសារតែពួកគេទ្រាំទ្រនឹងការរស់នៅ និងលក្ខខណ្ឌការងារអមនុស្សធម៌ ដែលបានបណ្តាលឲ្យមានការស្លាប់មនុស្សអស់ជាច្រើន។ ខ្ទាំង ប.ក.ក ដែលគេសន្មត ដូចជា ពលករធ្វើការមិនសម្រេចតាមការកំណត់ កម្មករ "មិនស្មោះត្រង់" និងកម្មាភិបាលភូមិភាគពាយ័ព្យដែល "ក្បត់" ត្រូវបានចាប់ខ្លួន ដាក់ក្នុងមន្ទីរឃុំឃាំង និង/ឬសម្លាប់ចោល។ ការចាប់ខ្លួន និងការបាត់ខ្លួនមនុស្សកើតឡើងស្របពេលជាមួយនឹងដំណើរទស្សនកិច្ចរបស់ **យ៉ីម ទិត្យ** ទៅកាន់ទីតាំងនេះ។

444. ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** អំពីឧក្រិដ្ឋកម្មដូចខាងក្រោមនេះ ទាក់ទងនឹងទីតាំងពលកម្មដោយបង្ខំទំនប់កង្ហត៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញលើកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ ដោយមូលហេតុនយោបាយ អំពីអមនុស្សធម៌ផ្សេងៗទៀត (ការឃុំខ្លួន/ការធ្វើការក្នុងលក្ខខណ្ឌអមនុស្សធម៌) ហើយនិងឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតដោយគិតទុកជាមុន នៅក្រោមមាត្រា ៥០១និង៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[1552]។

ii. ប្រតិបត្តិការ និងទីតាំង

445. ទីតាំងពលកម្មដោយបង្ខំទំនប់កង្ហតត្រូវបានបង្កើតឡើងនៅដើមរបបកម្ពុជាប្រជាធិបតេយ្យ មុនរដូវប្រាំងឆ្នាំ១៩៧៧[1553]។ កម្មាភិបាលភូមិភាគនិរតីបានចាប់ផ្តើមរួមចំណែកក្នុងឧក្រិដ្ឋកម្មនានានៅទីតាំងនេះចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ ប្រហែលគ្នានឹងពេលដែលលេខាតំបន់១ ឈ្មោះ តាវ៉ាញ ត្រូវ

[1552] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426545, 48-49, 58។

[1553] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៥២ KH 01122405។ ឯកសារ D219/411 កំណត់ហេតុស្តាប់ចម្លើយ ឈន ឈឿន ឆ.១ KH 01117298-99។ ឯកសារ D219/237 កំណត់ហេតុស្តាប់ចម្លើយ ឈន វន ឆ.១ KH 01080848 ។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង អ៊ឿម ឆ.៩ KH 01157563។ ឯកសារ D219/310 កំណត់ហេតុស្តាប់ចម្លើយ វ៉ន្ត សាមុត ឆ.១ KH 01097678។ ឯកសារ D219/954 កំណត់ហេតុស្តាប់ចម្លើយ ឈីង ឈឿត ឆ.២៧ KH 01425189 ។ ឯកសារ D6.1.819 FBIS *ការខិតខំប្រឹងប្រែងបង្ករបង្កើនផលរបស់កសិករនៅភូមិភាគពាយ័ព្យត្រូវបានលើកឡើង* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169237 ["'ទំបន់កង្ហត ត្រូវបានកសាងឡើងចាប់តាំងពីរដូវប្រាំង ឆ្នាំ១៩៧៧"]។

បានចាប់ខ្លួន ហើយទំនប់កង្ហតបាក់ក្នុងខែកក្កដា ឆ្នាំ១៩៧៧[1554]។ ពួកគេបានគ្រប់គ្រងទីតាំងនេះ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1555]។ ទីតាំងពលកម្មដោយបង្ខំទំនប់កង្ហតមានទីតាំងស្ថិតនៅក្នុងស្រុកសង្កែ តំបន់១ ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ[1556]។

[1554] <u>ការចាប់ខ្លួន តាវ៉ាញ</u>៖ ទោះបីជាគេមិនដឹងថា នៅពេលណា តាវ៉ាញ ត្រូវបានចាប់ខ្លួនក៏ដោយ គាត់បានចូលមកដល់មន្ទីរ ស-២១ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៨៧៧។ *សូមមើល* ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី 913 EN 01222369។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934385 [“តាវ៉ាញ [...] ដឹកនាំកងចល័តប្រឆាំងនឹងអង្គការ តែដោយសារតែពួកនិរតី ដឹងរឿងនេះ ក៏ចាប់ តាវ៉ាញ។”]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.២០ KH 01205203 [“ពេលពួកនិរតីចូលមក គឺគេចាប់ [...] គណៈតំបន់១ មុនទៅអស់ហើយ មាន [...] វ៉ាញ”]។ ឯកសារ D123/1/1.3a បទសម្ភាសន៍ ហួន ជឿម ដោយ ឯកសារ DC-Cam KH 00923711-12។ ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហួន ជឿម ឆ.២៥ KH 00951906។ <u>ការបាក់ទំនប់</u>៖ ឯកសារ D6.1.819 FBIS *ការខិតខំប្រឹងប្រែងបង្ករបង្កើនផលរបស់កសិករនៅភូមិភាគពាយ័ព្យត្រូវបានលើកឡើង* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169237 [“‘ក្នុងអំឡុងពេលរដូវវស្សាថ្មីៗនេះ ទ็กជំនន់បានជន់លិចទំនប់នេះ និងបណ្តាលឲ្យមានការខូចខាតមួយចំនួន។ [...]’”]។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.២ KH 01080872 [ដើមបណ្តឹងរដ្ឋប្បវេណីនៅទំនប់កង្ហត “ប្រហែលជាក្នុងខែ៧ ឆ្នាំ១៩៧៧ ពីព្រោះពេលនោះគឺជារដូវភ្លៀង។ ពួកយើងត្រូវគេបញ្ជូនទៅ [...] បន្ទាប់ពីទំនប់កង្ហតត្រូវបានបាក់។”]។ ឯកសារ D219/409 កំណត់ហេតុស្តាប់ចម្លើយ អាង ស ឆ.២៧-២៨ KH 01117270។ ឯកសារ D219/310 កំណត់ហេតុស្តាប់ចម្លើយ រ៉ន្ត សាមុត ឆ.៥ KH 01097679 [“[ទំនប់បាក់] នៅល្ងាចមួយ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៧។”]។ ឯកសារ D219/721 កំណត់ហេតុស្តាប់ចម្លើយ ស្ងួម ប៉ៅ ឆ.១៩ KH 01213294។ <u>ការមកដល់នៃកម្មាភិបាលនិរតី</u>៖ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.១១ KH 00920169 [“ពួកនោះមកក្រោយធ្វើទំនប់កាហតហើយ។”]។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934385 [សាក្សីធ្វើការនៅទំនប់កង្ហត និងបានរំលឹកថា “ពួកនិរតី [...] ចាប់ តាវ៉ាញ [...] ចាប់ខ្ញុំ និងម្នាក់ទៀត”] (*សូមមើលផ្ទុយពីនេះ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៥៩ KH 01122406 [“មុនពេលដែល តាវ៉ាញ ត្រូវបានចាប់ខ្លួន [។] ពុំមានកម្មាភិបាលភូមិភាគនិរតីឡើយ។”])។ ឯកសារ D118/281 កំណត់ហេតុស្តាប់ចម្លើយ កែវ សុខា ឆ.១១ KH 01004021 [“ទំនប់កង្ហតបាក់ [...] នៅពេលដែលពួកនិរតីមកដល់។”]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១៧-១៩ KH 01205202-03 [“ពួកនិរតីចូលទៅក្នុងឆ្នាំ១៩៧៧ [...] ខ្ញុំនៅកង្ហត [...] ក្រោយពេលទំនប់បាក់។”]។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀន ម៉ត ឆ.១១, ១៦, ២៥, ៣៦, ៤០ KH 01155822-23, 24-26។ ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.១ KH 01110158-60។ *សូមមើលផងដែរ* ឯកសារ D219/721 កំណត់ហេតុស្តាប់ចម្លើយ ស្ងួម ប៉ៅ ឆ.៦, ១៣ KH 01213292-93។ ឯកសារ D219/374 កំណត់ហេតុស្តាប់ចម្លើយ ឃិន ឃីម ឆ.១៨៨-១៨៩ KH 01110545។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.៣៣, ៥៦, ៦០, ៨៣-៨៤ KH 01046462, 65, 68។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.២១-២២ KH 01394973-74។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៣ KH 01040094 ។ ឯកសារ D219/411 កំណត់ហេតុស្តាប់ចម្លើយ ឈន ឈឿន ឆ.១៨, ២១ KH 01117302-03។

446. ដោយត្រូវបានគេពណ៌នាថាជាទីតាំងមួយ "ដ៏ធំ" រួមបញ្ចូលទាំងទំនប់កង្ហតដែលត្រូវបានសាងសង់ឡើងលើស្ទឹងសង្កែ យ៉ាងហោចណាស់មានវាលស្រែមួយ ទីស្នាក់អាស្រ័យសម្រាប់កម្មករនៅនឹងកន្លែង និងផ្ទះសសរ ៤០ សម្រាប់យោធាស្នាក់នៅ រក្សាសាស្ត្រាវុធ និងកន្លែងសម្រាប់ប្រជុំ[1557]។

[1555] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៥៧ KH 01046476។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ហ៊ា ឆ.៤៣ KH 00960668។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ហ៊ាន ឆ.៥៣ KH 01394977។ ឯកសារ D219/948 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ វណ្ណៈ ឆ.៤១-៤២ KH 01415453-54។ ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៣៦ KH 01121701។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៧០ KH 01122409។

[1556] *សូមមើលឧទាហរណ៍* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៨ KH 00960689។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៤ KH 01132054។ ឯកសារ D219/268 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១០, ២២, ៣០ KH 01088835-38 (*សម្គាល់* កង្ហត និងក្រហាត គឺជាទំនប់តែមួយ *សូមមើល* ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១៤-១៥ KH 01110493 និង ឯកសារ D6.1.819 FBIS *ការខិតខំប្រឹងប្រែងបង្ករបង្កើនផលរបស់កសិករនៅភូមិភាគពាយ័ព្យត្រូវបានលើកឡើង* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169237)។ ឯកសារ D219/451 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ហាន ឆ.១៣ KH 01129752 (*សូមមើលផ្ទុយពីនេះ* ឯកសារ D219/516 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ហាន ឆ.៧ KH 01149463)។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធឿន ឆ.៧១ KH 00947590 ។ ឯកសារ D219/310 កំណត់ហេតុស្តាប់ចម្លើយ រ៉ន្ត សាមុត ឆ.១-២ KH 01097678។ ឯកសារ D219/272 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង KH 01219918។

[1557] ឯកសារ D219/452 កំណត់ហេតុស្តាប់ចម្លើយ ធី ជា ឆ.២០ KH 01129765។ ឯកសារ D6.1.819 FBIS *ការខិតខំប្រឹងប្រែងបង្ករបង្កើនផលរបស់កសិករនៅភូមិភាគពាយ័ព្យត្រូវបានលើកឡើង* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169237។ ឯកសារ D219/410.1 គំនូសព្រៀងរបស់ ហ៊ីម ឆុងលី KH 01117277។ ឯកសារ D219/465.1 គំនូសព្រៀងរបស់ ឈឿង ប៊ាន KH 01132067។ <u>វាលស្រែ</u>៖ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៣២ KH 01032222។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ សឿន ម៉ត ឆ.២១, ៣០ KH 01155824-25។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ហ៊ាន ឆ.១៩ KH 01394973។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.៤ KH 01095205។ <u>កន្លែងស្នាក់នៅតាមដងស្ទឹង</u>៖ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១៩ KH 01110494។ ឯកសារ D219/943 កំណត់ហេតុស្តាប់ចម្លើយ ឡម លិន ឆ.១៩, ២១ KH 01415375។ ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.៣៩ KH 01396469។ នៅពេលដែលទំនប់កង្ហតស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលពាយ័ព្យ គេផ្តល់ឲ្យកន្លែងស្នាក់នៅស្រដៀងគ្នានេះដែរ *សូមមើល* ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥៣ KH 01477615។ <u>ផ្ទះសសរ៤០</u>៖ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ហ៊ាន ឆ.២៥ KH 01394974។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១២៧-១២៨ KH 01132064។ ឯកសារ D219/984 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥ KH 01477653។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៧៥ KH 01046478។ នៅពេលដែលទំនប់កង្ហតស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ ផ្ទះសសរ៤០ ដាក់កម្មាភិបាលជាន់ខ្ពស់ និងអាហារ។ *សូមមើល* ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០០ KH 01110188 ឆ.៧៥ KH 01110183។ ឯកសារ

សមាជិកគណៈតំបន់១ ធ្វើការ និង/ឬ រស់នៅទួលអណ្តែត ចម្ងាយប្រហែលជាមួយគីឡូម៉ែត្រពីទីតាំងពលកម្មដោយបង្ខំនេះ[1558]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និង ការប្រាស្រ័យទាក់ទង

447. កម្មាភិបាលភូមិភាគនិរតីបានបើកដំណើរការទីតាំងពលកម្ម ដោយបង្ខំទំនប់កង្ហតនៅថ្នាក់តំបន់។ សមាជិកគណៈតំបន់១ បានពិនិត្យទីតាំងនេះជាប្រចាំ មេដឹកនាំនៅទីតាំងនេះបានរាយការណ៍ទៅកាន់គណៈតំបន់ ហើយកងចល័ត នៅទីតាំងដែលពលករធ្វើការ មកពីទូទាំងតំបន់នេះទាំងមូល[1559]។

D118/281 កំណត់ហេតុស្តាប់ចម្លើយ កែវ សុខា ឆ.១១ KH 01004021។ ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ីា ឆ.១៧ KH 00998555។ ឯកសារ D219/272 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង KH 01219927។

[1558] <u>ទីតាំង</u>៖ ឯកសារ D219/272 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង KH 01219923។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាម ឆ.៤៣ KH 01110179 [ទួលអណ្តែត "វាមានចម្ងាយមិនដល់ ១,៥ (មួយគីឡូម៉ែត្រកន្លះ) គីឡូម៉ែត្រនោះទេ [ពីទ្វាទីក]។"]។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៤៦ KH 01132056 [ទួលអណ្តែត "នៅចម្ងាយប្រហែល ៥០០ម៉ែត្រ ពីទំនប់កង្ហត"]។ ឯកសារ D219/263 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.៨៥ KH 01086100 [វត្តទួលអណ្តែត "ចម្ងាយប្រហែល ៣០០ម៉ែត្រ ទៅ៤០០ម៉ែត្រ" ពីការដ្ឋានទំនប់កង្ហត។]។ *សូមមើលផងដែរ* ឯកសារ D219/410.1 គំនូសព្រៀងរបស់ ហ៊ីម ឆុងលី KH 01117277។ ឯកសារ D219/430.1 គំនូសព្រៀងរបស់ ឈឿង ប៊ាន EN 01122392។ <u>តាប៉ែត</u>៖ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០៤ KH 01122415 ["តាប៉ែត ស្នាក់នៅទីនោះ នៅទួលអណ្តែតជាមួយកូនប្រពន្ធរបស់គាត់។"]។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៤០ KH 01132083។ ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.២ KH 01110160។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.៦៧ KH 01394978។ ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៦ KH 01080844 ["ទំនប់កង្ហត [...] តាប៉ែត គាត់មានមន្ទីរនៅកន្លែងនោះ។"]។ <u>យ៉ឹម ទិត្យ</u>៖ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៣ KH 01110178 ["នៅពេលដែល តាទិត្យ មកដល់ដំបូង គាត់នៅទួលអណ្តែត"]។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៤០ KH 01132083។

[1559] *សូមមើល ខទាហារណ៍* ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២៤ KH 01110176 [យ៉ឹម ទិត្យ "បើនិយាយអំពីចំនួនដង គឺរាប់មិនអស់ទេ ព្រោះគាត់ចុះមើលការងារនៅការដ្ឋាន [...] រៀងរាល់ថ្ងៃ។"]។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.៧៥, ៨៨ KH 01046467, 68 [យ៉ឹម ទិត្យ "មក" ការដ្ឋានទំនប់កង្ហត [...] ប្រហែលជាពីរដងក្នុងមួយខែ។ [...] ទំនប់កង្ហតស្ថិតនៅក្រោមតំបន់១។"] ឆ.១៤៣, ១៤៧, ១៥៣ KH 01046474-75 ["ខ្ញុំឃើញ [តាទិត្យ] និយាយជាមួយនឹងមេកងនៅទីនោះ ដូចជា យ៉ ជាដើម។" ទាក់ទងនឹងខ្ទាំង យ៉ឹម ទិត្យ "និយាយតែជាមួយកម្មាភិបាលថ្នាក់លើរបស់ខ្ញុំទេ"។ "រាលពេលដែល តាទិត្យ មកជួបជាមួយនឹង យ៉ តែងតែប្រជុំដើម្បីជម្រុញឲ្យធ្វើការ កាន់តែខ្លាំងក្លាថែមទៀត។"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៦៤ KH 01196541 ["គណៈតំបន់គេបញ្ជាមក បញ្ជាការធ្វើតាមបញ្ជាតាមថ្នាក់លើ"]។ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.២ KH 01121734 ["មានកងចល័តដទៃៗទៀតមកពីឃុំ និងស្រុកផ្សេងៗមកធ្វើការនៅទំបន់ងួត។"]។ *សូមមើលផងដែរ* ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម

ដើម្បីសម្រេចឲ្យបាននូវគោលនយោបាយសេដ្ឋកិច្ច និងកសិកម្មរបស់ ប.ក.ក ទីតាំងនេះដំណើរការ ក្នុងគោលបំណងឲ្យទំនប់កង្ហតបង្ហូរទឹកពីស្ទឹងសង្កែ ដើម្បីយកទៅស្រោចស្រពតំបន់ទាំងមូល តាមរយៈប្រឡាយនានាដែលសន្ធឹងទៅទិសខាងកើត កាត់ទីតាំងពលកម្មដោយបង្ខំទួលម្ទេស ទៅកាន់ភ្នំធិបតីក្នុងស្រុកគាស់ក្រឡ[1560] ជាតំបន់ដែល **យ៉ីម ទិត្យ** គ្រប់គ្រង។

448. មុនពេលទទួលបានការតែងតាំងជាផ្លូវការរបស់ខ្លួនជាលេខាតំបន់១ **យ៉ីម ទិត្យ** បានប្រើឥទ្ធិពល និងអំណាចរបស់ខ្លួនលើមន្ត្រីនានានៅទីតាំងនេះ និងបានរួមចំណែកក្នុងការអនុវត្តគោលនយោបាយ ប.ក.ក នៅទីនោះ។ ដូចបានរៀបរាប់ខាងក្រោម គាត់បានធ្វើការងារជាមួយលេខាតំបន់១ ឈ្មោះ តាវ៉ាញ អនុរបស់ តាវ៉ាញ ឈ្មោះ តាព្ញុ និងអ្នកដែលជំនួស តាវ៉ាញ ឈ្មោះ តាប៉ែត មុនពេលពួកគេ

ប៉ាន ឆ.១៨, ២១ KH 01394973 [នៅទំនប់កង្ហត "ស្រូវដែលកងកុមារខ្ញុំធ្វើបានគេយកមកផ្គត់ផ្គង់មន្ទីរគណៈតំបន់។"]។ ទីតាំងនេះក៏ដំណើរការថ្នាក់តំបន់ផងដែរ ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគពាយ័ព្យ។ *សូមមើលឧទាហរណ៍* ឯកសារ D6.1.819 FBIS *ការខិតខំប្រឹងប្រែងបង្ករបង្កើនផលរបស់កសិករនៅភូមិភាគពាយ័ព្យត្រូវបានលើកឡើង* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169237។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៉ាន ឆ.៦៦-៦៧, ៧៥, ១៣២ KH 01110182-83, 95។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.៣-៤ KH 01095204-05។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៤៣ KH 01477613។ ឯកសារ D219/721 កំណត់ហេតុស្តាប់ចម្លើ ស្ងួម ហ៊ៅ ឆ.២០ KH 01213294។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន បានថ្លែងថា កម្មករមកពីទូទាំងភូមិភាគពាយ័ព្យទាំងមូល។ *សូមមើល* ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១៦, ២៥ KH 01110493-94 ["ខ្ញុំធ្វើការនៅទំនប់កង្ហតហ្នឹងរហូតដល់ឆ្នាំ១៩៧៨។ [...] នៅទំនប់កង្ហតហ្នឹងមានមនុស្សមកពីតំបន់ដល់ទៅ ៧"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៦៦ KH 01196541។ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម រណ្ណា ឆ.៩, ១៤, ២៤ KH 01032220, 21។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៥-២៨ KH 01132054។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.១២ KH 01117284។

[1560] ឯកសារ D6.1.819 FBIS *ការខិតខំប្រឹងប្រែងបង្ករបង្កើនផលរបស់កសិករនៅភូមិភាគពាយ័ព្យត្រូវបានលើកឡើង* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169237 ["ទំនប់កង្ហត [...] មានស្ទឹងសង្កែ ដែលបង្ហូរទឹកទៅក្នុងប្រឡាយ១០ គីឡូម៉ែត្រ និងនាំទឹកទៅកាន់អាងស្តុកដ៏ធំមួយនៅភ្នំធិបតី ដើម្បីស្រោចស្រពដីនៅក្នុងស្រុកទាំងបួននេះ [សង្កែ បាត់តំបង សំឡូត និងគាស់ក្រឡ]។"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៉ាន ឆ.១០០ KH 01110188។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ គុប សឹង ឆ.៧០ KH 01046466។ ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.៤ KH 01095205។ ឯកសារ D219/50 កំណត់ហេតុស្តាប់ចម្លើយ អ៊ុយ ចិន្តា ឆ.១៣ KH 01032613។ ឯកសារ D219/313 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២ KH 01097708។ ឯកសារ **D219/310** កំណត់ហេតុស្តាប់ចម្លើយ រ៉ន្ត សាមុត ឆ.៤ KH 01097678។ ឯកសារ D118/281 កំណត់ហេតុស្តាប់ចម្លើយ កែវ សុខា ឆ.២ KH 01004020។ ឯកសារ D219/409 កំណត់ហេតុស្តាប់ចម្លើយ អាង ស KH 01117268។ ឯកសារ D219/272 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង KH 01219923, 34។

ទាំងនោះត្រូវបានដកចេញពីមុខតំណែង[1561]។ កម្មករម្នាក់បានផ្តែងថា **យ៉ីម ទិត្យ** មានឋានៈធំជាង តាវ៉ាញ ដោយសារតែ **យ៉ីម ទិត្យ** ត្រូវបានគេណែនាំខ្លួនថាជាអនុលេខាភូមិភាគពាយ័ព្យ នៅក្នុងកិច្ចប្រជុំមួយដែលដឹកនាំដោយកម្មាភិបាលទាំងពីរនេះនៅជិតទំនប់កង្ហត[1562]។

449. សាក្សីនានាដែលជាកម្មាភិបាលភូមិភាគពាយ័ព្យ ឬបានធ្វើការស្និទ្ធទៅនឹងមេដឹកនាំ ប.ក.ក បានផ្តល់ភ័ស្តុតាងឲ្យអ្នកស៊ើបអង្កេត ក.ស.ច.ស ថា ក្រោយពេលដែល តាប៉ែត ជំនួស តាវ៉ាញ នៅការដ្ឋានក្នុងឆ្នាំ១៩៧៧ **យ៉ីម ទិត្យ** មានអំណាចស្រដៀងគ្នានឹង តាប៉ែត ឬធំជាងអ្នកទាំងឡាយដែលនៅទីតាំងនេះ។ សៅ ជាប់ ដែលជាប្រធានកងតូច បាននិយាយថា **យ៉ីម ទិត្យ** និង តាប៉ែត "[កាន់តាប់តំបន់នោះ] រហូតដល់និរតី ចូលមក" រួមទាំងទំនប់កង្ហតផងដែរ[1563]។ កងការពារ និង

[1561] <u>វ៉ាញ</u>៖ ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី 913 EN 01222369 [ជា ហ្ជ ន ហៅ វ៉ាញ លេខាតំបន់១]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្យឿង ប៊ាន ឆ.៥៩ KH 01122406 ["ខ្ញុំមិនដែលឃើញគាត់ [យ៉ីម ទិត្យ] ឡើយមុនពេលដែល តាវ៉ាញ ត្រូវបានចាប់ខ្លួន។ ពុំមានកម្មាភិបាលនិរតីឡើយ [មុនពេលចាប់ខ្លួន តាវ៉ាញ]។"]។ <u>ញ្ញ</u>ំ៖ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្យឿង ប៊ាន ឆ.៦ KH 01122396 ["តាព្រំ អនុគណៈតំបន់១"]។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធ្ឿន ឆ.២០ KH 00947579 ["តាព្រំ ជាអនុរបស់ តាវ៉ាញ។"]។ *សូមមើលផ្ទុយទីនេះ* ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៨ KH 01132054 ["តាព្រំ [ជា] គណៈស្រុក។"]។ <u>ប៉ែត</u>៖ ឯកសារ D118/19 កំណត់ហេតុស្តាប់ចម្លើយ យ៉ីង យាន ឆ.១៤ KH 00891136 ["តាប៉ែត គាត់ជាលេខាតំបន់១។"]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្យឿង ប៊ាន ឆ.៥០ KH 01122404 ["តាវ៉ាញ ត្រូវបានគេចាប់ [...] ហើយ តាប៉ែត ចូលមកកាន់ជំនួស។"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៣ KH 01040094 ។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.២៩ KH 00967986។

[1562] ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១១៧ KH 01110506 ["គណៈសមរភូមិឡើងអានហើយ ហើយប្រកាសឈ្មោះគណៈតំបន់ តាវ៉ាញ ហើយគេប្រកាស តាទិត ជាគណៈភូមិភាគ ហើយបានបន្ទាប់មក តាញ៉ីម ជាព្រធានភូមិភាគ។ គេដូចជាប្រកាសថា តាទិត ជាអនុលេខាភូមិភាគ។"]។ ឯកសារ D219/268 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៤៣ KH 01088840-41។ សាក្សី ពីដំបូងមានការភាន់ច្រឡំអំពី យ៉ីម ទិត្យ និង តាប៉ែត ថាជាមនុស្សតែមួយ ប៉ុន្តែ ការប្រើប្រាស់រូបថតរបស់អ្នកអង្កេត ក.ស.ច.ស បានដោះស្រាយការភាន់ច្រឡំមួយចំនួននោះ។ សាក្សីចំណាំ យ៉ីម ទិត្យ នៅក្នុងរូបថតទាំងនោះ និងបានបញ្ជាក់ថា វាគឺជាមនុស្សតែមួយ ដែលគាត់បានឃើញនៅក្នុងការប្រជុំដែលបាននិយាយក្នុងឋានៈជាអនុលេខាភូមិភាគពាយ័ព្យ។ *សូមមើល* ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៥៤, ១១៨ KH 01110498, 506។ *សូមមើលផងដែរ* ទីតាំងពលកម្មដោយបង្ខំដែលនៅជាប់នឹងទំនប់កង្ហត ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.២៣, ៤៧ KH 01205203, 09 ["ព្រោះមិត្តខេន មកប្រជុំអ៊ីចឹង ច្រើនហៅអង្គការ ហើយខ្ញុំគិតថា អង្គការមាននរណា គឺមានតែ តាទិត្យ ដែលគ្រប់គ្រងនៅពីលើ។ [...] ខ្ញុំនៅទួលម្ទេស"]។

[1563] ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥១, ៦០ KH 01244124-25។ *សូមមើលផងដែរ* ឯកសារ D219/374 កំណត់ហេតុស្តាប់ចម្លើយ ឃិន យ៉ីម ឆ.៤៨-៥០ KH 01110523 [សាក្សីគឺជាអនុប្រធានកងចល័តនៅទំនប់កង្ហត៖

នីរសារ របស់ តាប៉ែត ឈ្មោះ ឈាន ប៊ា បានផ្លែងថា "តាប៉ែត គាត់មកទទួលខុសត្រូវបានរយៈពេល ៦ ខែ" នៅទំនប់កង្ហត រហូតដល់ពេលដែលគាត់ត្រូវជំនួសដោយ **យ៉ឹម ទិត្យ**[1564]។ គាត់បានផ្លែងថា តាប៉ែត ត្រូវបានទម្លាក់តំណែងនៅពេលដែលកម្លាភិបាលភូមិភាគនិរតីបានមកដល់ក្នុងភូមិភាគពាយព័ព្យ និងបានផ្តល់ការរៀបរាប់ពិស្តារអំពីការវិតត្បិតការធ្វើដំណើររបស់ តាប៉ែត ក្នុងរយៈពេលប៉ុន្មានខែមុនពេល តាប៉ែត ត្រូវបានចាប់ខ្លួន[1565]។ គាត់ប្រាកដថា តាទិត្យ មានអំណាចធំជាង តាប៉ែត"[1566]។ ឈឿង ប៊ាន ដែលជាចុងភៅនៅផ្ទះសសរ ៤០ បានផ្លែងថា ក្នុងឆ្នាំ១៩៧៧ **យ៉ឹម ទិត្យ** "បានបញ្ជូនកូនចៅរបស់គាត់ [...] មកការដ្ឋានទំនប់នេះ"[1567]។ លើសនេះទៀត គាត់បាននិយាយ

"តាប៉ែត [...] ត្រូវបានគេចាត់តាំងឲ្យគាត់កាន់កាប់" គម្រោងទំនប់កង្ហត។ "គាត់មិនមែនតែម្នាក់ឯងទេ។" "ស៖ តើគាត់ជាមេគេឬ? ឆ.៥០៖ ខ្ញុំមិនដឹងដែរ ព្រោះគេមានអង្គភាពរបស់គេ ហើយអង្គភាពរបស់គេមានគ្នាបីនាក់។ ខ្ញុំឮប្រជាជននិយាយថា គាត់ឈ្មោះតាប៉ែត ដែលជាគណៈតំបន់។"]។

[1564] ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៤៣ KH 00960668។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៣២ KH 01078138 ["ស៖ ក្រោយពីគេដក តាប៉ែត តើនរណាជាអ្នកទទួលខុសត្រូវការសាងសង់ទំនប់កង្ហតបន្តទៀត? ឆ.៣២៖ ខ្ញុំមិនដឹងទេ។"]។ *សូមមើលផងដែរ* ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៤៩ KH 01078141 ["ក្រោយ យ៉ឹម ទិត្យ ទៅដល់ គាត់ [តាប៉ែត] គ្មានអំណាចអ្វីទាំងអស់។"]។

[1565] *សូមមើល* ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.២ KH 00960662-63 ["កម្លាភិបាលនិរតីចូលមកដល់ភូមិភាគនេះនៅដើមឆ្នាំ១៩៧៧។ [...] ពេលដែលពួកនិរតីចូលមមក [...] តាញ៉ឹម បានហៅ តាប៉ែត ឲ្យមកនៅក្រុងបាត់ដំបងវិញ នៅពេលនោះគាត់លែងមានតួនាទីអ្វីទៀតហើយ។ [...] អស់រយៈពេល ៥ខែក្រោយមក ទើប តាញ៉ឹម ឲ្យគាត់ទៅមើលការខុសត្រូវនៅចំការកប្បាសផ្ទួវមាសនោះវិញ ដោយពេលនោះគាត់ឡើងចុះ១ពីក្រុងបាត់ដំបងទៅចំការកប្បាស ព្រោះ តាញ៉ឹម គាត់ចង់ឲ្យតាប៉ែត នៅជិតគាត់។ រយៈពេលពីរខែក្រោយមក ប្រហែលជាក្នុងពាក់កណ្តាល ឆ្នាំ១៩៧៨ នៅពេលដែលពួកនិរតីមានទាំងយោធា និងកម្លាភិបាលចូលកាន់តែច្រើនមកភូមិភាគពាយ័ព្យនេះ តាញ៉ឹម ក៏ឈប់ឲ្យ តាប៉ែត ទៅចំការកប្បាសទៀតហើយ ដោយឲ្យនៅក្រុងបាត់ដំបង ជាមួយគាត់ ហើយនៅពេលនោះ តាប៉ែត មិនមានតួនាទីអ្វីទេ ដោយគេឲ្យគាត់នៅតែក្នុងផ្ទះ មិនអាចចេញទៅណាបានទាំងអស់។ ប្រហែលជា ៦ខែ ក្រោយមក ក៏មាននិរសារ១ របស់ តាម៉ុក មកប្រាប់ថា ឲ្យតា ប៉ែត រៀបចំឥវ៉ាន់ឲ្យទៅនៅកន្លែងផ្សេង ពេលខ្ញុំឮអំពីរឿងនេះ ខ្ញុំក៏រត់"] ឆ.៤២ KH 00960668 ["នៅក្នុងតំបន់១ គាត់ទៅធ្វើការ [...] ហើយគាត់ទៅទំនប់កង្ហតម្តងម្តាល។"]។ សាក្សីក្រោយមកបានផ្លែងថាជាផ្ទួវការ យ៉ឹម ទិត្យ "កាន់កាប់តំបន់១ [...] ក្រោយពេលគេចាប់ខ្លួន តាប៉ែត" *សូមមើល* ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.២១ KH 01078136។ *សូមមើលផងដែរ* ឯកសារ D219/896 កំណត់ហេតុស្តាប់ចម្លើយ ជួង លួម ឆ.១២ KH 01379582 [សាក្សីធ្វើការក្នុងកងពាណិជ្ជកម្មនៅជិតផ្ទះរបស់ យ៉ឹម ទិត្យ នៅអំពិលប្រហោង ខេត្តបាត់ដំបង និងបានដឹកទំនិញទៅទំនប់កង្ហត៖ "ពេលពួកនិរតីចូលមក គេដកគាត់ [តាប៉ែត] ទៅធ្វើទំនប់កង្ហត។"]។

[1566] ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.១៦ KH 01078135។

[1567] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១១៤ KH 01110191 ["កាលនោះគឺនៅឆ្នាំ១៩៧៧។ ខ្ញុំបានឃើញ តាទិត្យ ទៅមកៗនៅឯទំនប់កង្ហតក្នុងខែមីនា ឬខែមេសា ហើយគាត់ [...] បានបញ្ជូនកូនចៅរបស់គាត់ ដូចជា តែម, រ៉ាត,

ថា "តាប៉ែត [...] គ្មានអំណាចអ្វីឡើយ" មុនពេល "តាទិត្យ គ្រប់គ្រង [ទំនប់កង្ហត] បានទាំងស្រុង"[1568]។ មុនឆ្នាំ១៩៧៨ ប្រធានសហករណ៍ឈ្មោះ លេខ ភីរ បានចូលរួមការប្រជុំនៅទំនប់កង្ហត ដែលរូបគាត់ពេលខ្លះបានស្គាល់ **យ៉ីម ទិត្យ** និយាយ[1569]។ គាត់បានស្គាល់ **យ៉ីម ទិត្យ** "ជាគណៈតំបន់១" ប៉ុន្តែ "មិនដឹងពីតំណែងច្បាស់រវាង តាប៉ែត និង តាទិត្យ" នោះទេ[1570]។

450. សាក្សីផ្សេងៗទៀតបានសង្កេតឃើញពីកំណើននៃអំណាចរបស់ **យ៉ីម ទិត្យ** ក្រោយពេលការចាប់ខ្លួនតាវ៉ាញ[1571]។ ក្នុងឆ្នាំ១៩៧៨ តាប៉ែត បានប្រកាសជាសាធារណៈនៅទីតាំងពលកម្មដោយបង្ខំនេះថា

រ៉ន, រ៉ុម និង ឈា ព្រមទាំងកូនចៅដទៃទៀតមកការដ្ឋានទំនប់នេះ ក្នុងខែមេសា ឬខែឧសភា ឆ្នាំ១៩៧៧។"]។ នៅក្នុងការស្តាប់ចម្លើយបន្ទាប់មកទៀត សាក្សីនេះបាននិយាយថា រូបគាត់មិនបានឃើញ យ៉ីម ទិត្យ នៅទំនប់នេះទេ រហូតដល់ក្រោយពេល តាវ៉ាញ និង តាព្ញ ត្រូវបានចាប់ខ្លួន។ គាត់បាននិយាយថា គាត់បានឃើញ តាទិត្យ ដំបូងពេលទស្សនកិច្ចទំនប់នេះក្នុងខែមេសា ឬ ឧសភា ឆ្នាំ១៩៧៨ និងថា បន្ទាប់ពីទស្សនកិច្ចបានបីលើក យ៉ីម ទិត្យ ត្រូវបានតែងតាំងឲ្យកាន់តំបន់។ *សូមមើល* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្បឿង ប៊ាន ឆ.៥៩, ៨៤-៨៥, ៨៧-៨៨ KH 01122406, 12។

[1568] ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈ្បឿង ប៊ាន ឆ.៣១ KH 01132080 ["តាទិត្យ បានមកដល់ [...] តាប៉ែត [...] គ្មានអំណាចអ្វីឡើយ។ ក្រោយមក តាទិត្យ គ្រប់គ្រងតំបន់នោះបានទាំងស្រុង។"]។ *សូមមើលផងដែរ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្បឿង ប៊ាន ឆ.៦៤ KH 01122407 ["[នៅពេល តាប៉ែត គ្រប់គ្រង] [...] យើងរស់នៅបែបនេះបានតែ*ប៉ុន្មានខែប៉ុណ្ណោះ* មុនពេល តាទិត្យ ចូលមកកាន់កាប់។"] (គូសបញ្ជាក់បន្ថែម)។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈ្បឿង ប៊ាន ឆ.១១៦ KH 01110192 ["តាទិត្យ បានគ្រប់គ្រងទៅលើទំនប់កង្ហតក្នុងខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ១៩៧៧ ហើយគាត់គ្រប់គ្រងទាំងស្រុង ក្នុងឆ្នាំ១៩៧៨ ដែលនៅពេលនោះ។"] ឆ.៣៣ KH 01110178 ["តាទិត្យ [...] ជំនួសតំណែង តាព្ញ។"]។ ឯកសារ D118/137 កំណត់ហេតុស្តាប់ចម្លើយ ឈន រ៉ន ឆ.២៤ KH 00960679 [សាក្សីបើកឡានដឹក តាញ៉ឹម ទៅទំនប់កង្ហត រហូតដល់ពេល តាញ៉ឹម ត្រូវបានចាប់ខ្លួន៖ "ស៖ តើនរណាឡើងជំនួស [...] តាប៉ែត [...]? ឆ.២៤៖ មិនមាន [...] ព្រោះពួកនិរតីគេម៉ោ ក្តាប់ពេញអស់ហើយ"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្បឿង ប៊ាន ឆ.៩៤ KH 01122413 ["តាប៉ែត មានឋានៈខ្ពស់ជាង តាទិត្យ។"]។

[1569] ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៦, ១៨ KH 01080844។ ឯកសារ D219/210 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.២ KH 01074047។

[1570] ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៧-១៨ KH 01080844។ *សូមមើលផងដែរ* ឯកសារ D219/292 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.២៨ KH 01095210 ["គេពុំបានផ្សព្វផ្សាយប្រកាសពីមុខតំណែងរបស់ពួកគេទេ ប៉ុន្តែយើងដឹងថា តាទិត្យ និង តាប៉ែត ស្ថិតនៅក្នុងថ្នាក់តំបន់ ហើយតាម៉ុក ស្ថិតនៅខាងភូមិភាគ។"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៦ KH 01196531។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៣២ KH 00951930។

[1571] ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៤០ KH 01132056 ["តាវ៉ាញ ត្រូវបានចាប់ខ្លួនហើយ មុនពេលដែលតាទិត្យ ឡើងកាន់អំណាចនៅក្នុងតំបន់នោះ"]។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀន ម៉ត ឆ.៣៥, ៤០ KH 01155826-27 ["តាប៉ែត ហាក់មានអំណាចជាងពួកនិរតី ប៉ុន្តែក្រោយមក មានការប្រែប្រួល។"]។ ឯកសារ D20

"តាទិត្យ មកពីនិរតីមកជួយដឹកនាំពួកយើងនៅក្នុងតំបន់១"[1572]។ នៅត្រង់ចំណុចដែលសាក្សីគិតថា តាប៉ែត គឺជាកម្មាភិបាលតែមួយគត់ទទួលបន្ទុកទីតាំងនេះ ក្រោយពេលចាប់ខ្លួន តាវ៉ាញ នោះ ពួកគេបង្ហាញឲ្យឃើញនូវចំណេះដឹងតិចតួចបំផុត ឬមិនដឹងអំពី **យ៉ីម ទិត្យ** ទាល់តែសោះ[1573]។

451. មិនមែនរហូតទាល់តែពេលលេខាភូមិភាគពាយ័ព្យ តាញ៉ីម ត្រូវបានចាប់ខ្លួន នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨[1574] នោះទេ ដែលថា **យ៉ីម ទិត្យ** បានក្លាយ *តាមព្រឹត្តន័យ* ជាលេខាតំបន់១ ហើយ តាប៉ែត គឺជាអនុរបស់ **យ៉ីម ទិត្យ** ជាផ្លូវការនោះ[1575]។ ប៉ុន្តែ សាក្សីជាច្រើននៅទីតាំងពលកម្មដោយបង្ខំទំនប់ក

កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី KH 00699643 ["ពេលដែល តាទិត្យ មកដល់ គឺ តាប៉ែត នៅក្តាប់ការងារទាំងអស់។ តាទិត្យ និង តាប៉ែត ធ្វើការជាមួយគ្នា ប៉ុន្តែខ្ញុំគិតថា តាទិត្យ ជាប្រធាន ដោយសារ តាប៉ែត ត្រូវបានគេដក។"]។

[1572] ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៣, ៩ KH 01040094-97។ ឯកសារ D219/245 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការៀបរាប់របស់ វ៉ី ផាន់ KH 01364043។

[1573] *សូមមើលឧទាហរណ៍* ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៤ KH 01110160។ ["នៅពេលដែលខ្ញុំនៅការដ្ឋានកង្ហត គាត់ពុំមានកម្មាភិបាលនិរតីណាម្នាក់ជំនួសតំណែងគាត់នោះទេ។"] ឆ.៧-៨ KH 01110161 ["ឆ៖ តើនរណាដែលមានឋានៈខ្ពស់ជាង ហ៊ុន ទាវ ធ្លាប់បានមកចុះពិនិត្យមើលការដ្ឋានទំនប់កង្ហតនេះដែរ ឬទេ [...]? ឆ.៧៖ [...] ខ្ញុំមិនដឹងអំពីរឿងនេះទេ [...] ស៖ តើលោកស្រីធ្លាប់ឮឈ្មោះ តាទិត្យ ឬយ៉ីម ទិត្យ ដែរឬទេ? ឆ.៨៖ ទេ"]។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម ឃួន ឆ.៤ KH 00960653 ["តាប៉ែត [...] មើលការខុសត្រូវទំនប់កង្ហត។"] ឆ.៥, ២២ KH 00960653, 56 ["ស៖ តើ តាប៉ែត គាត់នៅធ្វើគណៈតំបន់រហូតដល់ចប់របបខ្មែរក្រហម ឬយ៉ាងណា? ឆ.៥៖ ដូចជាមិនប្ជូរទេ គាត់នៅធ្វើការនោះរហូតតែម្តង។ [...] ឆ.២២៖ ខ្ញុំមិនដែលឮពីឈ្មោះ តាទិត ទេ។"]។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.២៦-២៨ KH 01157567 [តាប៉ែត "ជាគណៈតំបន់ [...] ទាល់ចប់របបខ្មែរក្រហម។ ពេលនិរតីចូលមកដល់ ដំបូង [...] ខ្ញុំដឹងថា តាប៉ែត នៅតែជាគណៈតំបន់។"]។ ឯកសារ D219/549 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៥០ KH 01157580 ["ខ្ញុំមិនស្គាល់ តាទិត្យ ទេ។"]។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.៣៥ KH 01121671 ["តាប៉ែត [...] ទទួលខុសត្រូវកន្លែងការដ្ឋានធ្វើទំនប់នោះ។"] ឆ.៣៦ KH 01121671 ["ស៖ តើលោកស្រីមានធ្លាប់បានឮអំពី តាទិត្យ ដែលឬទេ នៅពេលក្រោយមកទៀត? ឆ.៣៦៖ ទេមិនដែលឮទេ។"]។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ផ្ងើន ឆ.៤៤ KH 00947585-86 ["តាប៉ែត ទទួលខាងទំបន់ប្រឡាយ នៅទំនប់កង្ហត។"] ឆ.១៨៥ KH 00947612 ["ស៖ [...] តើលោកធ្លាប់ឮឈ្មោះ តាទិត ដែរឬទេ? ឆ.១៨៥៖ ខ្ញុំធ្លាប់ឮឈ្មោះនេះ ប៉ុន្តែខ្ញុំមិនដឹងពីតួនាទីរបស់គាត់ទេ។"]។

[1574] ឯកសារ D1.3.18.2 ចម្លើយសារភាព ស-២១ របស់ មូល សំបាត់ ហៅ រស់ ញ៉ីម KH 00024651 [លេខាភូមិភាគពាយ័ព្យ ថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨]។

[1575] ឯកសារ D34.1.9 បទសម្ភាស ហេង ទាវ ហៅ ប៉ែត ដោយ Steve Heder KH 00965622 ["មុនដំបូងវាខ្ញុំ វាឲ្យមកធ្វើអនុលេខាតំបន់១ហ្ម៉ង។ វាចាប់ តាញ៉ីម [...] វាចាត់តាំងឲ្យអាឈ្មោះ អាទិតៗ នៅជាមួយ អាម៉ុក ហ្ម៉ង [...] ធ្វើលេខា វាឲ្យខ្ញុំធ្វើអនុលេខារបស់វា។"]។

ង្ហត មិនបានដឹងអំពីការតែងតាំង **យ៉ឹម ទិត្យ** នោះឡើយ រហូតទាល់តែ តាប៉ែត ត្រូវបានទម្លាក់តំណែង និងក្រោយមកត្រូវបានចាប់ខ្លួនក្រោយពេលចាប់ខ្លួន តាញ៉ឹម[1576]។

452. ចាប់ពីប្រហែលជាឆ្នាំ១៩៧៦ មក **យ៉ឹម ទិត្យ** បានដឹកនាំការប្រជុំនៅទីតាំងពលកម្មដោយបង្ខំ ឬនៅជិតវានោះ អំពីអ្នកដែល ប.ក.ក ចាត់ទុកថាជាខ្មាំង និងបានណែនាំអ្នកចូលរួមអំពីវិធានការណាត្រូវធ្វើ។ ក្នុងអំឡុងពេលនៃវគ្គសិក្សារយៈពេលបីថ្ងៃនៅផ្នែសសរ ៤០ យោធាភូមិភាគពាយ័ព្យ សៅ ជាប់ បានស្តាប់ **យ៉ឹម ទិត្យ** ពិភាក្សាអំពីសកម្មភាពខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ ដោយសង្កត់ធ្ងន់លើភាពចាំបាច់ត្រូវការពារប្រឆាំងនឹង "ខ្មាំងមានរូបភាពអ្វីខ្លះ"[1577]។ ក្នុងអំឡុងពេលការប្រជុំជាប្រចាំនៅ

[1576] *សូមមើលឧទាហរណ៍* ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ គុប សឹង អ.៦៨-៦៩, ៧៩, ៩៩ KH 01046466-67, 69 ["ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៨ [...] បន្ទាប់ពីបាត់ តាប៉ែត [...] ប្រធានកងរបស់ខ្ញុំប្រាប់ថា តាទិត្យ មកជំនួស តាប៉ែត ហើយនិង [...] ជាគណៈតំបន់១។"]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ អ.៣០, ៣៣ KH 01149403 ["ក្រោយពេលដែល តាប៉ែត បានបាត់ខ្លួន [...] អ្នកកាន់កម្មវិធីបានណែនាំអំពីសមាសភាព តាទិត្យ ថាជាគណៈភូមិភាគ ឬក៏ជាគណៈតំបន់ក៏មិនដឹង [...] សមាជិកកងទាំងអស់មកពីស្រុកសង្កែទាំងមូល ត្រូវបានគេអញ្ជើញឲ្យចូលរួមកិច្ចប្រជុំនោះ។"]។ ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ឈឿត អ.១៦, ១៩-២១, ៥៧, ៦២, ៦៦ KH 01425165-66, 73-75។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម អ.១៥, ១៧-១៨, ២១ KH 00967984-85។ យោងតាម តាប៉ែត គាត់ត្រូវគេចាប់ខ្លួន មួយខែឬ ពីរខែក្រោយការចាប់ខ្លួន តាញ៉ឹម ទោះបីជាគាត់ចាំបានថា តាញ៉ឹម ត្រូវបានចាប់ខ្លួនក្រោយពេលកាលបរិច្ឆេទចម្លើយសារភាព ស-២១ របស់ តាញ៉ឹម ក៏ដោយ *សូមមើល* ឯកសារ D34.1.9 បទសម្ភាសន៍ ហេង ទាវ ហៅ តាប៉ែត ដោយ Steve Heder KH 00965647 [នៅពេលដែល តាញ៉ឹម ត្រូវគេចាប់ខ្លួន កូនប្រុសរបស់គាត់បានហៅទូរស័ព្ទទៅភ្នំពេញ "ប្រហែលជាក្នុងខែហ្នឹងដែរ ខែ៨ហ្នឹង"។] KH 00965616 ["ប្រហែលខែ៩ ខែ១០ [ខ្ញុំត្រូវចាប់យកមកដាក់គុក]"]។ *សូមមើលផងដែរ* ឯកសារ D1.3.11.36 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ក.ស.ព EN 00210530។

[1577] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ អ.២៥ KH 01477610 ["ស៖ កាលហ្នឹងគេ [យ៉ឹម ទិត្យ និង តាម៉ុក] មានលើកនិយាយអំពីខ្មាំងផ្ទៃក្នុង ខ្មាំងខាងក្រៅទេ? អ.២៥៖ អាហ្នឹងលើកសព្វ។ ផ្នែកទ័ព លើកពីការការពារខ្មាំងមានរូបភាពអ្វីខ្លះ ធ្វើសកម្មភាពអ្វីខ្លះ មាន ឬមិនមាន។"] អ.១៨ KH 01477609 [ការប្រជុំត្រូវបានធ្វើឡើងដោយ "គណៈតំបន់ [...] តាវ៉ាញ"] អ.៥, ១១, ១៣, ២០ KH 01477606-09។ ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ អ.១៤-១៥, ២២, ៥៥, ៦១, ៦៣ KH 01425219-20, 26-28 [សាក្សីត្រូវរបួសនៅពាក់កណ្តាលឆ្នាំ១៩៧៦ និង បន្ទាប់ពីការព្យាបាលបីខែក្រោយមក គាត់បានជួប យ៉ឹម ទិត្យ នៅក្នុងវគ្គសិក្សាមួយនៅទីតាំងពលកម្មដោយបង្ខំទំនប់កង្ហត។]។ ឯកសារ D219/984 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ អ.៥ KH 01477653។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ អ.៦៥, ៦៨-៧១ KH 01244126។ ឯកសារ D219/980 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ អ.២០ KH 01477600។ *សូមមើលផងដែរ* III.**ឃ**.៣. ក. មុខតំណែងរបស់ យ៉ឹម ទិត្យ ទង្វើ និងអំពើប្រព្រឹត្ត – ការចូលរួមប្រព្រឹត្តរបស់ យ៉ឹម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្មរួមនៅភូមិភាគពាយ័ព្យ – ទង្វើ និងអំពើប្រព្រឹត្តផ្សេងៗទៀតរបស់ យ៉ឹម ទិត្យ នៅភូមិភាគពាយ័ព្យ – ការបង្ហាញខ្លួនដំបូងបង្អស់របស់ យ៉ឹម ទិត្យ នៅភូមិភាគពាយ័ព្យ។

ទំនប់កង្ហត **យ៉ីម ទិត្យ** បាន "ដឹកនាំ [និង] ចាត់តាំង" សៅ ជាប់ ឲ្យធ្វើការស៊ើបអង្កេត ដើម្បីរាយការណ៍អំពីការ "ខុសឆ្គង" និងបានប្រាប់គាត់ថា ប្រសិនបើកំហុសនោះ "ធ្ងន់ធ្ងរ [...] ឲ្យសម្លាប់"[1578]ចោលចុះ។ សៅ ជាប់ បាននិយាយថា **យ៉ីម ទិត្យ** បានប្រាប់គាត់ថា គាត់បានចាត់ឲ្យពេជ្ឌឃាតសម្លាប់មនុស្ស[1579]។ នៅក្នុងវគ្គសិក្សាមួយផ្សេងទៀត សាក្សី តុប សឹង ដែលជាប្រធានកងចល័តនៅទីតាំងពលកម្មដោយបង្ខំនេះ បានដឹងពី **យ៉ីម ទិត្យ** ថា ខ្មាំងរួមមានអ្នកទាំងឡាយណាដែល "បង្ហត់បានយើង"[1580]។ នៅក្នុងការប្រជុំមួយនៅទីតាំងពលកម្មដោយបង្ខំនេះ សាក្សីទីបីបានស្តាប់ **យ៉ីម ទិត្យ** និយាយ ហើយស្រដៀងគ្នានឹងបទពិសោធន៍របស់ សៅ ជាប់ ដែរ និងបាននិយាយថា **យ៉ីម ទិត្យ**៖

> បាននិយាយអំពីខ្មាំងផ្ទៃក្នុងដែលណាក់ខ្លួនស៊ីរ្ងងផ្ទៃក្នុងរបស់ចលនាយើង ហើយក៏មានពួក សេអ៊ីអា ការ៉ាហ្ស្ស៊ីប យ្ជួន ណាក់ខ្លួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែប្តូរមើលពួកទាំងនេះ ហើយបើយើងបានព័ត៌មានទាក់ទងនឹងសកម្មភាពពួកទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចយើង[1581]។

[1578] ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១២១ KH 01244134 [យ៉ីម ទិត្យ "ចាត់តាំងប្រជាជន ឬទ័ពចាត់តាងធ្វើការងារ និងចាត់តាំងឲ្យស៊ើបអង្កេត ឃើញខុសឆ្គងត្រូវរាយការណ៍បើប្រព្រឹត្តធ្ងន់ធ្ងរ ត្រូវសម្លាប់គឺឲ្យសម្លាប់។"] ឆ.១១៤, ១១៦, ១១៨, ១២០, ១២៣, KH 01244133-34។

[1579] ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១១៤ KH 01244133 ["ស៖ តើមាននរណាម្នាក់បានប្រាប់លោកថា តាទិត្យ បានចាត់តាំងឃាតករឲ្យសម្លាប់មនុស្ស ឬទេ? ឆ.១១៤៖ អាហ្ម៉ីងគឺដឹងថាមកពីគាត់ហ្ជងដែលប្រាប់ ចាត់តាំងអ្នកនេះ ឲ្យធ្វើនេះ។"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៦៧ KH 01477617 ["ដូចជាឲ្យធ្វើហិង្សារអ៊ីខ្ញុំមិនដឹងទេ។ [...] ខាងលើគេដឹកនាំល្អតើ គេមិនធ្វើហិង្សារអាក្រក់ទេ។"]។

[1580] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១០០ KH 01046469 [យ៉ីម ទិត្យ បាននិយាយថា "កុំឲ្យខ្មាំងវាយប្រហារ ឬបង្ហត់បាយយើង។"] ឆ.៩២-៩៤, ៩៦-៩៧, ៩៩ KH 01046468-69 [សាក្សីបានចូលរួមវគ្គសិក្សាប្រហែលជាពីរ ឬបីវគ្គ នៅអន្ទង់ជ្រៃ ក្នុងក្រុងបាត់ដំបង មុនពេលវៀតណាមចូលមកដល់ ជាមួយនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងនិរតី ពី២០ ទៅ ៣០នាក់។ ប្រធានកងរបស់គាត់បានប្រាប់គាត់ថា "តាទិត្យ គាត់ជាគណៈតំបន់១"]។

[1581] ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៣, ៥ KH 01040093-94។ ឯកសារ D219/245 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការៀបរាប់របស់ វ៉ី ផាន់ KH 01364043 ["វ៉ី ផាន់ បាននិយាយថា [...] គេហៅគាត់ទៅប្រជុំក្រុមឆ្នាំ១៩៧៨ នៅទំនប់កង្ហត"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១១ KH 01040097 [យ៉ីម ទិត្យ "មានអត្តចរិតស្ងួតបូត។"]។ យោងតាម វ៉ី ផាន់ យ៉ីម ទិត្យ បានមកដល់ទីតាំងនេះនៅប្រហែលជាខែវិច្ឆិកា ឆ្នាំ១៩៧៨។ ទោះជាយ៉ាងណា ការណ៍នេះមិនអាចត្រឹមត្រូវនោះទេ ដោយសារហេតុផលបីគឺ៖ ទីមួយ តាប៉ែត នៅក្នុងការប្រជុំមួយ ហើយគាត់ត្រូវបាន

453. ចាប់ពីប្រហែលជាឆ្នាំ១៩៧៦ **យ៉ឹម ទិត្យ** ក៏បានដឹកនាំការប្រជុំទាក់ទងនឹងការងារសំណង់ និងកសិកម្មផងដែរ ដោយបានសង្កត់ធ្ងន់ពីតម្រូវការធ្វើការឲ្យខ្លាំងក្លា និងត្រូវសហការគ្នា ដើម្បីសម្រេចឲ្យបាននូវគោលដៅរបស់ ប.ក.ក។ សៅ ជាប់ បាននិយាយថា គេបានយកគាត់ទៅទស្សនាទំនប់ កង្ហត ជាមួយនឹងមេកងយោធាភូមិភាពពាយ័ព្យផ្សេងទៀត នៅក្នុងតំបន់១ ដែលក្នុងអំឡុងពេលនោះ **យ៉ឹម ទិត្យ** បានផ្តល់ការណែនាំទៅកាន់ពួកគាត់អំពីអ្វីត្រូវធ្វើទាក់ទងនឹងទំនប់នេះ និងបានបង្ហាញពួកគាត់អំពីអ្វីកំពុងត្រូវបានធ្វើ និងអ្វីដែលមិនបានធ្វើ "តាមផែនការ"[1582]។ លើសពីនេះទៀត សៅ ជាប់

ចាប់ខ្លួនមួយខែឬពីរខែក្រោយពេលចាប់ខ្លួន តាញ៉ឹម។ ទីពីរ តាប៉ែត បានផ្លែងថា យ៉ឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់១ ក្រោយពេល តាញ៉ឹម ចាប់ខ្លួន។ ទីបី សាក្សីក៏បាននិយាយដែរថា យ៉ឹម ទិត្យ បានមកជាមួយកម្មាភិបាលនិរតីផ្សេងទៀត មកគ្រប់គ្រង និងជំនួសពួកពាយ័ព្យ មួយឆ្នាំមុនពេលវៀតណាមចូលមកដល់ និងថា យ៉ឹម ទិត្យ មិនបានជំនួស តាប៉ែត ទេ រហូតទាល់ប្រហែលជាមួយឆ្នាំមុនពេលដែល តាប៉ែត ជំនួស តាវ៉ាញ។ *សូមមើល* ឯកសារ D34.1.9 បទសម្ភាសន៍ ហេង ទាវ ហៅ តាប៉ែត ដោយ Steve Heder KH 00965647 [នៅពេលដែល តាញ៉ឹម ត្រូវគេចាប់ខ្លួន ក្មួនប្រុសរបស់គាត់បានហៅទូរស័ព្ទទៅភ្នំពេញ "ប្រហែលជាក្នុងខែហ្នឹងដែរ ខែ៨ហ្នឹង"។] KH 00965616 ["ប្រហែលខែ៩ ខែ១០ ខ្ញុំត្រូវចាប់យកមកដាក់គុក]"]។ KH 00965622 ["វាចាប់ តាញ៉ឹម [...] វាចាត់តាំងឲ្យអាឈ្មោះ អាទិត១ នៅជាមួយ អាម៉ុក ហ្នឹង [...] ធ្វើលេខា។"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៣ KH 01040094 ។ ការពិភាក្សារបស់ យ៉ឹម ទិត្យ ទាក់ទងនឹងខ្ទាំងយួន នៅទំបន់ កង្ហត ឬនៅក្បែរនោះក៏ត្រូវបានស្តាប់ឮដោយ លេខ ភីរ និង ឈឹង ឈៀត ផងដែរ។ *សូមមើល* ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៩ KH 01080844។ ឯកសារ D219/954 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.៧ KH 01425185។ ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈៀង ឈៀត ឆ.៧០-៧៣, ៨២, ៨៤ KH 01425176-78 (*សូមមើលផ្ទុយពីនេះ* ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈៀង ឈៀ ឆ.៧៨ KH 01425177)។ *សូមមើលផងដែរ* ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ្លីន ឈួយ ឆ.៣០, ៣៣ KH 01149403 ["សមាជិកកងទាំងអស់មកពីស្រុកសង្កែ ទាំងមូល ត្រូវបានគេអញ្ជើញឲ្យចូលរួមកិច្ចប្រជុំនោះ" នៅវត្តបាណន់ក្រោម រយៈពេល "មួយសប្តាហ៍ ដោយមាន តាទិត្យ ជាប្រធានអង្គប្រជុំ។" វា "និយាយអំពីបញ្ហាគិញសម្ងាត់ និងអ្នកជាប់ខ្សែយួនផងដែរ។"]។

[1582] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៦០, ៦៥ KH 01477616-17 ["មេកងចាត់តាំង ចាត់ចែង ឲ្យធ្វើបិទប្រឡាយ ត្រង់នេះតូច ឲ្យពង្រីកឲ្យធំ ត្រង់ណាធ្វើអី គ្រាន់តែចាត់ចែងអ៊ីចឹងឯង។ [...] អាហ្នឹងបើនិយាយទៅគេចង់ឲ្យមើលកន្លែងកសាង [...] តាមផែនការគេអត់។ កន្លែងណាខ្វះខាត មិនរីកចម្រើន។ ដល់យើងមកតាមស្រុកតាមកន្លែងយើងវិញ ឲ្យធ្វើអ៊ីចឹង ឲ្យដូចៗគ្នាអ៊ីចឹង។"] ឆ.៦៦ KH 01477617 ["ស៖ កាលហ្នឹងណោកបាននិយាយ តាម៉ុក និង តាទិត្យ ទេ? ឆ.៦៦៖ និយាយ តើ ពេលដើរគាត់បង្ហាញ មិត្តធ្វើចេះៗ។ ពេលហ្នឹង តាម៉ុក និង តាទិត្យ និយាយប្រាប់ថា មិត្តត្រូវធ្វើអ៊ីចេះៗ។"] ឆ.៣៦, ៣៨, ៤២ KH 01477612-13។ ឯកសារ D219/980 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២១ KH 01477600។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៣៩ KH 01244135។ *សូមមើលផងដែរ* III.**ឃ**.៣.ក. មុខតំណែងរបស់ យ៉ឹម ទិត្យ ទង្វើ និងអំពើប្រព្រឹត្ត – ការចូលរួមប្រព្រឹត្តរបស់ យ៉ឹម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្មរួមនៅភូមិភាគពាយ័ព្យ – ទង្វើ និងអំពើប្រព្រឹត្តផ្សេងៗទៀតរបស់ យ៉ឹម ទិត្យ នៅភូមិភាគពាយ័ព្យ – ការបង្ហាញខ្លួនដំបូងបង្អស់របស់ យ៉ឹម ទិត្យ នៅភូមិភាគពាយ័ព្យ។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌៀន ឆ.៤៩-៥០ KH 01210567។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ

បានឃើញ **យ៉ីម ទិត្យ** លើកទឹកចិត្តពលករនៅទំនប់នេះឲ្យខិតខំធ្វើការឲ្យខ្លាំង ទោះបីជា សៅ ជាប់ មើលឃើញនឹងភ្នែកថា "ប្រជាជនមិនសប្បាយទេ ព្រោះ [...] ធ្វើទៅតាមគេបង្ខំ [...] ហូបមិនឆ្អែត មិនបានគ្រប់គ្រាន់"[1583]។ ក្នុងអំឡុងពេលពីរខែ ក្រោយពេលដែលទំនប់កង្ហតបានបាក់ ដើមបណ្តឹង រដ្ឋប្បវេណី សោម វណ្ណា ត្រូវបានប្រធានកងរបស់គាត់ប្រាប់ជាប្រចាំ មុនពេលទស្សនកិច្ចរំពឹងទុក ណាមួយរបស់ **យ៉ីម ទិត្យ** ថា "កុំឲ្យឈប់សម្រាកពីការងារ"[1584]។ សាក្សីម្នាក់បានកត់សម្គាល់ថា "រាល់ពេលដែល តាទិត្យ មកជួបជាមួយនឹង យ៉ូ" ដែលជាប្រធានវរៈសេនាធំ នៃកងចល័តរបស់ សាក្សីនៅទីតាំងពលកម្មដោយបង្ខំនេះ "គាត់ [យ៉ូ] តែងតែប្រជុំដើម្បីជំរុញឲ្យយើងធ្វើការកាន់តែ ខ្លាំងក្លាថែមទៀត"[1585]។ នៅក្នុងវគ្គសិក្សាមួយ **យ៉ីម ទិត្យ** បានជំរុញឲ្យប្រធានកងចល័តមួយផ្សេង ទៀតមកពីទីតាំងនេះ "ត្រូវខំធ្វើការលើកទំនប់ ជីកប្រឡាយ ដើម្បីឲ្យប្រជាជនមានហូបចុកគ្រប់ គ្រាន់" និង "ដើម្បីឲ្យប្រទេសរីកចម្រើនបានលឿន"[1586]។ នៅក្នុងឱកាសមួយផ្សេងទៀត **យ៉ីម ទិត្យ** បានបញ្ជាឲ្យសមាជិកកងនៅទូទាំងស្រុកសង្កែ "ខិតខំធ្វើស្រែឲ្យបាន ៥ តោន ទៅ ៦តោន ក្នុងមួយ ហិកតា"[1587]។ នៅក្នុងការប្រជុំមួយនៅជិតទំនប់កង្ហត **យ៉ីម ទិត្យ** បានណែនាំអ្នកចូលរួមប្រជុំ "ឲ្យ រួបរួមជាមួយគ្នា" និង "កុំឲ្យប្រឆាំងជាមួយនឹងនិរតី"[1588]។ **យ៉ីម ទិត្យ** ក៏បានធ្វើការប្រជុំពិភាក្សាអំពី

ដុស ឌឿន អ.២០៦, ២១៧-២១៨ KH 01305017-18។ ទោះបីជា ដុស ឌឿន បាននិយាយថា តាទិត្យ ជាប្រធានស្រុកក៏ដោយ ក៏ គាត់បានរៀបរាប់អំពី តាទិត្យ ថា "ក្បាលទំពែក" និង "កាន់ក្តាប់អ្នកនៅកាប់ទំនប់កង្ហត" *សូមមើល* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន អ.២០១, ២០៨, ២១៧ KH 01305016-18។

[1583] ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ អ.៥៥, ៥៨ KH 01477615 ["អ.៥៥៖ មាននិយាយតើ និយាយ ថា មិត្តអ៊ើយប្រទេសយើងនៅក្រ ចេះតែខំតស៊ូទៅ។ [...] [...] ស៖ អ្នកណាដែលនិយាយទៅប្រជាជន ឲ្យខំធ្វើការ យើងនៅក្រ នៅលំបាកហ្នឹង ពីណាគេ? អ.៥៨៖ តាវ៉ាញ តាទិត្យ អីហ្នឹង គណៈស្រុក ហើយពួកខ្ញុំអីហ្នឹង។"] អ.៥៦ KH 01477615 ["ស៖ តាមដែលលោកមើលឃើញប្រជាជនធ្វើការ តើឃើញមុខមាត់ បង្ហាញអីថាស្រស់ថ្លា រីករាយដែរទេ? អ.៥៦៖ រឿងប្រជាជនមិន សប្បាយទេ ព្រោះហូបមិនឆ្អែត ម្ហូះហើយធ្វើទៅតាមគេបង្ខំ។ ធ្វើវាលំបាកហើយ ការហូបមិនឆ្អែត មិនបានគ្រប់គ្រាន់។"]។

[1584] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា អ.៥ KH 01080873។

[1585] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង អ.១៥៣ KH 01046475។

[1586] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង អ.៩៨, ១០០ KH 01046469 អ.៩២-៩៤, ៩៦-៩៧, ៩៩ KH 01046468-69 [សាក្សីបានចូលរួមវគ្គសិក្សាប្រហែលជាពីរ ឬបីវគ្គ នៅអន្ទង់វិល ក្នុងក្រុងបាត់ដំបង មុនពេលវៀតណាមចូលមក ដល់ ជាមួយនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងនិរតី ពី២០ ទៅ ៣០នាក់។ ប្រធានកងរបស់គាត់បានប្រាប់គាត់ថា "តាទិត្យ គាត់ ជាគណៈតំបន់១"]។ *សូមមើលផងដែរ* ឯកសារ D219/374 កំណត់ហេតុស្តាប់ចម្លើយ ឃិន ឃីម អ.៥៦ KH 01110524។

[1587] ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ្ងន ឈួយ អ.៣០, ៣៣ KH 01149403។

[1588] ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត អ.៨២ KH 01425177។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈៀង ឈៀត អ.៧៨ KH 01425177 ["គេនិយាយតែល្អហ្នឹងឯង។"]។

ការធ្វើចម្ការ ការសាងសង់ទំនប់ និងការជីកប្រឡាយ[1589] និងដើម្បីទទួលរបាយការណ៍អំពីទិន្នផលដំណាំ[1590]។

454. បន្ថែមលើការណែនាំនៅតាមព្រឹត្តិការណ៍សំខាន់ៗនៅនឹងទីតាំងផ្ទាល់[1591] **យ៉ីម ទិត្យ** បានពិនិត្យទីតាំងពលកម្មដោយបង្ខំច្រើនដង "រាប់មិនអស់នោះទេ" ពេលខ្លះមកជាមួយ តាម៉ុក តាប៉ែត និង តាវ៉ាញ[1592]។ គាត់បានពិនិត្យមើលការងារទំនប់ រួមមានការសាងសង់របស់វា ការបាក់ទំនប់ និងកម្ម

[1589] ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.១៧-១៩, ២៣-២៥ KH 00967984-85 [នៅមន្ទីរស្រុកសង្កែ ជិតស្ពានកង្ហត "ប្រហែលជាចុងឆ្នាំ១៩៧៨" "តាទិត្យ ជាអ្នកគ្រប់គ្រង" និង "គេនិយាយតែអំពីរឿងបង្កបង្កើនផលនេះប៉ុណ្ណោះ" និង "ជីកប្រឡាយកង្ហត"]។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៣៥, ៣៨, ៥៥ KH 01132055-57 [នៅទីតាំងពលកម្មដោយបង្ខំទំនប់កង្ហត ជាមួយ តាព្រំ យ៉ីម ទិត្យ "និយាយអំពីការលើកទំនប់ ជីកប្រឡាយ។"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៣៩ KH 00960693។

[1590] ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៧ KH 01040094-95 ["តាទិត្យ ហើយនិង តាប៉ែត [...] កត់ត្រា។ បន្ទាប់មកទៀត ប្រធានសហករណ៍/ឃុំទាំងបួន ត្រូវបានហៅឡើងរាយការណ៍អំពីដំណាំភោគផលនៅក្នុងភូមិទាំងឡាយដែលនៅក្នុងឃុំនីមួយៗ។ [...] របាយការណ៍ត្រូវបានធ្វើដោយប្រធានសហករណ៍/ឃុំប្រយុទ្ធ ដែលសព្វថ្ងៃនេះហៅថា ភូមិកង្ហត"]។

[1591] ឯកសារ D219/268 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៤៣ KH 01088840-41 ["ពេលមួយនោះ ខ្ញុំបានឃើញគាត់បានបើកអង្គមិន្ទិញមួយយ៉ាងធំនៅក្បែរទំនប់នោះ ដើម្បីបើកការដ្ឋានធ្វើទំនប់នៅក្រហាត ហើយមានគណកម្មវិធីរៀបចំអង្គមិន្ទិញនោះ បានប្រកាសពីឈ្មោះ និងតំណែងគាត់"] (*សម្គាល់* ថា ការប្រជុំនេះបានធ្វើឡើងមុនពេល តាវ៉ាញ ត្រូវគេបញ្ជូនទៅ ស-២១ *សូមមើល* ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១១៧ KH 01110506)។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៣៣, ៣៥-៣៧ KH 01132055 ["ខ្ញុំធ្លាប់ឃើញ តាទិត្យ។ [...] ប្រជុំនៅការដ្ឋានទំនប់កង្ហត។ [...] ជាកិច្ចប្រជុំបើកការដ្ឋាន ហើយ តាទិត្យ ត្រូវបានគេអញ្ជើញឲ្យឡើងធ្វើចំណាប់អារម្មណ៍។ [...] ព្រោះពេលនោះ តាវ៉ាញ ដែលជាគណៈតំបន់១ ត្រូវបានគេចាប់ហើយ។"] ឆ.២៨, ៣៨ KH 01132054-55 [គណៈស្រុកមាន តាយាន និងតាព្រំ ចូលរួមការប្រជុំនោះ។] (*សម្គាល់* តាយាន ត្រូវបានបញ្ជូនទៅ ស-២១ នៅថ្ងៃទី១២/០៩/៧៧ *សូមមើល* ឯកសារ D6.1.553 របាយការណ៍ ស-២១ ពី ម៉ម ណៃ ហៅ ចាន់ ទៅបងឌុច ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00052630 និង ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី 11667 EN 01222811។) ឆ.៥៥ KH 01132057។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៣៩ KH 00960693។

[1592] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឆ.២៤ KH 01110176 [យ៉ីម ទិត្យ "បើនិយាយអំពីចំនួនដង គឺរាប់មិនអស់ទេ ព្រោះគាត់ចុះមើលការងារនៅការដ្ឋាន [...] រៀងរាល់ថ្ងៃ។"] ឆ.១៦ KH 01110176 ["ជួនកាល គាត់ដើរត្រួតពិនិត្យការងារជាមួយ តាម៉ុក ដោយ តាម៉ុក គ្រាន់តែមកត្រួតពិនិត្យម្តងម្តាលប៉ុណ្ណោះ។"]។ *សូមមើលផងដែរ* ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.៧២, ៧៥, ៩០ KH 01046466-67, 68 [យ៉ីម ទិត្យ "មក" ការដ្ឋានទំនប់កង្ហត [...] ប្រហែលជាពីរដងក្នុងមួយខែ។ [...] ខ្ញុំឃើញ តាម៉ុក មកមើលការដ្ឋានតែម្តងទេ។ ចំណែក តាទិត្យ គាត់មកញឹកញាប់។"]។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៥៣ KH 00967988 [តាម៉ុក "មកជាមួយ តាទិត្យ មកមើលប្រឡាយកង្ហតនេះ។"]។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.១៤, ២១ KH 01394972-73 [ខណៈដែលកម្មាភិបាលភូមិភាគ

វិធីប្រពលវប្បកម្មកសិកម្ម[1593]។ គាត់បាននិយាយជាមួយពលករនៅនឹងទីតាំងផ្ទាល់ និងបានត្រួតពិនិត្យការងាររបស់ពួកគេ[1594]។ គាត់ទទួលបានជំនួយពីអ្នកគ្រប់គ្រងទំនប់កង្ហត និងប្រធានវរៈសេនាធំកងចល័តនានា[1595]។ ជាពិសេស **យ៉ីម ទិត្យ** បានចាត់ តាសាម៉ន ឲ្យទទួលបន្ទុកសេចក្តីកិច្ច ផ្គត់ផ្គង់ស្បៀង សមាជិកឈ្លប និងយោធានៅទំនប់នេះ[1596]។ **យ៉ីម ទិត្យ** បានដាក់ចេញផែនការការងារទៅកាន់ថ្នាក់ក្រោមរបស់គាត់[1597]។

និរតីគ្រប់គ្រងទំនប់កង្ហត យ៉ីម ទិត្យ "យូរៗគាត់ទៅម្តង"។]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៨៦, ៨៨ KH 01122412 [យ៉ីម ទិត្យ និង តាប៉ែត "ពួកគេមើលធ្វើទឹក [...] បីដងមុនពេលដែល តាទិត្យ ក្លាយជាគណៈតំបន់។"]។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៥៥-៥៦, ៨៨, ៩២ KH 01110498, 502 ["ស៖ [...] តើអ្នកដែលលោកបញ្ជាក់ថា យ៉ីម ទិត្យ ហ្នឹង គាត់បានទៅទំនប់កង្ហតហ្នឹងរហូតដល់ពេលដែលលោកចាកចេញពីទីនោះទេ? ឆ.៥៥៖ បាទ។ [...] ស៖ តើលោកឃើញបុគ្គលនៅក្នុងរូបភាពនេះមកជាមួយតាវ៉ាញទេ? ឆ.៨៨៖ បាទគាត់មកជាមួយគ្នា [...] ឆ.៩២៖ ខ្ញុំឃើញគាត់មកជាមួយគ្នាតែពីរដង បីដងទេ។"]។

[1593] ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.១១, ២១ KH 01394972-73។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៤៥ KH 01046474។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២៤ KH 01110176 ឆ.៥៨ KH 01110181 ["ពាក្យ 'ស្រែប្រពលវប្បកម្ម' សំដៅចំពោះស្រែគំរូ ដែលស្អាតដោយសារគេសម្អាតស្មៅចេញពីស្រែ ហើយស្រែប្រភេទនេះ ផ្តល់ទិន្នផលខ្ពស់។"]។

[1594] ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.១៥, ២១ KH 01394973 [ខណៈដែលកម្មាភិបាលភូមិភាគនិរតីគ្រប់គ្រងទំនប់កង្ហត យ៉ីម ទិត្យ "ឃើញយូរៗមកម្តង គាត់ [យ៉ីម ទិត្យ] មកមើលពួកខ្ញុំធ្វើការ។]"។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៤៤ KH 01046474 ["នៅពេលដែលគាត់ [យ៉ីម ទិត្យ] ជួបខ្ញុំ គាត់បានសួរសុខទុក្ខខ្ញុំ ហើយថា តើធ្វើការងារយ៉ាងម៉េចដែរ។"]។

[1595] *សូមមើលខ១ទាហរណ៍* <u>*អ្នកគ្រប់គ្រងទំនប់កង្ហតឈ្មោះ យ៉ូន*</u>៖ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៤៣ KH 01110198។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២១, ៤០ KH 01132077-78, 83 (*ក្នុងសម្គាល់ថា* ការប្រជុំបានធ្វើឡើងនៅចន្លោះខែមិថុនា និងខែសីហា ឆ្នាំ១៩៧៨ ភ្លាមៗមុនពេល យ៉ូន និង ឈឿង ប៊ាន ចាកចេញពីទំនប់កង្ហត *សូមមើល* ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦៥, ១៤៤ KH 01110182, 98។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៥, ៧១ KH 01122402, 09។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៧ KH 01132082)។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៤៩ KH 01122404។ <u>ប្រធានវរៈសេនាធំឈ្មោះ យ៉ូ</u>៖ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៤៣ KH 01046474 ។ <u>ប្រធានវរៈសេនាធំឈ្មោះ ខេន</u>៖ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.២១, ២៣ KH 01205203។

[1596] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៤១ KH 011101797-98។ *សូមមើលផងដែរ* ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.៤៤ KH 01394976។

[1597] ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២១, ៤០, ៤៤ KH 01132078, 83-84 ["តាយ៉ូន ជាអ្នកគ្រប់គ្រងទៅលើកាងារសាងសង់ទំនប់កង្ហត។ [...] តាយ៉ូន ក៏បានទៅចូលរួមកិច្ចប្រជុំជាមួយ តាទិត្យ និង តាប៉ែត នៅកន្លែងរបស់

455. **យ៉ីម ទិត្យ** "ជាអ្នកគ្រប់គ្រងខាងទ័ព" និងត្រូវបានគេដឹងថាជា "មេទ័ពខ្លាំង"[1598]ម្នាក់។ សោម វណ្ណា បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា នៅពេលដែលគាត់ធ្វើការនៅទំនប់កង្ហត ប្រហែលជាក្នុងឆ្នាំ១៩៧៧ "យោធាគឺជាអ្នក [...] យកមនុស្សចេញទៅ" រួមទាំងអ្នកទាំងឡាយណា "ដែលមិនស្មោះត្រង់ជាមួយនឹងអង្គការ"[1599]។ សាក្សីម្នាក់ទៀត ដែលកងរបស់ខ្លួនបានរាយការណ៍ផ្ទាល់ទៅកាន់តំបន់ បាននិយាយថា យោធា និងសមាជិកឈ្លបអនុវត្តបទបញ្ជាចាប់ខ្លួន[1600]។ **យ៉ីម ទិត្យ** បានមកទស្សនាផ្ទះសសរ ៤០ ជាទីដែលយោធាប្រចាំការ[1601] ហើយគាត់បានពិភាក្សាអំពីខ្ទាំងជាមួយនឹងកម្មាភិបាលថ្នាក់លើនៅទីតាំងពលកម្មដោយបង្ខំនេះ ដែលបន្ទាប់មកបានណែនាំកម្មករឲ្យ "ប្រុង

ពួកគាត់ទាំងពីរនាក់នេះដទ្ធលអណ្តែត ដើម្បីទទ្ធលផែនការពីពួកគាត់។ [...] តាយ៉ូន បានចាកចេញពីកិច្ចប្រជុំនោះមុន ដោយឡែកតាសាម៉ន នៅរង់ចាំទទ្ធលផែនការពី តាទិត្យ និងតាប៉ែត។"]។ ការប្រជុំនេះធ្វើឡើងនៅរវាងខែមិថុនា និងខែសីហា ឆ្នាំ១៩៧៨ ភ្លាមៗមុនពេល តាយ៉ូន និង ឈឿង ប៊ាន ចាកចេញពីទំនប់កង្ហត។ *សូមមើល* ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦៥, ១៤៤ KH 01110182, 98។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៥, ៧១ KH 01122402, 09។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៧ KH 01132082។ *សូមមើលផងដែរ* ឯកសារ D219/943 កំណត់ហេតុស្តាប់ចម្លើយ ឡូម លិន ឆ.១២, ១៤ KH 01415374។

[1598] ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស៊ឿន ម៉ត ឆ.២០, ៣៨ KH 01155823, 26 ["តាទិត្យ កាន់ខាងកងទ័ពទេ។ [...] ប្រជាជនគ្រប់គ្នាស្គាល់ឈ្មោះ តាទិត្យ ព្រោះគេល្បីថា តាទិត្យ ជាមេទ័ពខ្លាំង។"]។ *សូមមើលផងដែរ* ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស៊ឿន ម៉ត ឆ.៥៦ KH 01155829 ["មេភូមិ មេកង បាននិយាយលើកឡើងអំពីកងទ័ពរបស់ តាទិត្យ ដូច្នេះហើយទើបខ្ញុំដឹងថាគាត់ជាមេទ័ព។"]។

[1599] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៤ KH 01080872-73។ *សូមមើលផងដែរ* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៧ KH 00960689 ["យោធាស្រុកសង្កែ [...] នៅពេញទំនប់កង្ហត។ [...] តាព្រំ [...] ឲ្យយោធាបញ្ជូនខ្ញុំទៅដាក់នៅគុកបាណន់"]។

[1600] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៦៤ KH 01196541 ["គណៈតំបន់គេបញ្ជាមក បញ្ជាការធ្វើតាមបញ្ជា"] ឆ.៦៣ KH 01196541 ["បើចាប់នៅហ្នឹង គឺមេបញ្ជាការ និងអនុបញ្ជាការជាអ្នកបញ្ជាឲ្យចាប់។ គេឲ្យយោធា និងឈ្លប ចាប់មនុស្ស"]។

[1601] ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.១៥ KH 01394973 [សាក្សីស្ថិតនៅក្នុងកងការពារកុមារ និងបានជួយការពារទីតាំងពលកម្មដោយបង្ខំ ជាមួយនឹងយោធាចាស់ៗនៅផ្ទះសសរ ៤០៖ "ឃើញយូរៗមកម្តង គាត់ [យ៉ីម ទិត្យ] មកមើលពួកខ្ញុំធ្វើការ។"]។ យ៉ីម ទិត្យ ក៏បានធ្វើការប្រជុំនៅផ្ទះសសរ ៤០ ដែលបានចូលរួមដោយយោធាមកពីតំបន់១ ផងដែរ។ *សូមមើល* ឯកសារ D219/980 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២០-២១ KH 01477600។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៣៧ KH 01477612។ ឯកសារ D219/984 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥ KH 01477653។

ប្រយ័ត្នអំពីខ្មាំងនៅកន្លែងធ្វើការ"[1602]។ គាត់ក៏បានកំណត់ផងដែរថាតើ កម្មាភិបាលណាត្រូវដំឡើងតួនាទី ឬទម្លាក់តំណែងនៅទីតាំងពលកម្មដោយបង្ខំទ៉ន់ប៉ះកង្ហតនេះ។ សាក្សី ឈឿង ប៊ាន បានផ្តែងថា នៅពេលដែលអ្នកក្រោមបង្គាប់របស់ តាវ៉ាញ កំពុងត្រូវបានយកទៅសម្លាប់ គឺ "[លើកលែងតែ] តាសាម៉ន ចេញ ដែល តាទិត្យ ទុកឲ្យរស់"[1603]។ គាត់បានកត់សម្គាល់ថា តាសាម៉ន ត្រូវបានទម្លាក់តំណែងនៅពេលដែល តាវ៉ាញ ត្រូវបានចាប់ខ្លួន ប៉ុន្តែ "ពេល តាទិត្យ មកដល់ គេបានឲ្យ តាសាម៉ន ធ្វើជាបញ្ជាការសមរភូមិកង្ហត"[1604]។ ឈឿង ប៊ាន បានភ្ជាប់ការដំឡើងឋានៈរបស់ តាសាម៉ន ទៅនឹង **យ៉ីម ទិត្យ**[1605]។ គាត់បានរៀបរាប់អំពី តាសាម៉ន ថា "មានកេរ្តិ៍ឈ្មោះអាក្រក់ ធ្វើបាប រាយការណ៍អំពីកម្មាភិបាលពាយ័ព្យជាច្រើនទៅឲ្យ តាទិត្យ"[1606]។ សាក្សីនេះក៏បានដឹងពីកម្មាភិបាលម្នាក់ឈ្មោះ យ៉ូន ផងដែរថា មានពេលមួយនោះ នៅចន្លោះខែមិថុនា និងខែសីហា ឆ្នាំ១៩៧៨ នៅក្នុង

[1602] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៤៣, ១៤៧-១៥០ KH 01046474-75 ["ឆ.១៤៣៖ ខ្ញុំឃើញគាត់ [តាទិត្យ] និងយាយជាមួយនឹងមេកងនៅទីនោះ ដូចជា យ៉ ជាដើម។ [...] ស៖ តើ តាទិត្យ គាត់មានដែលនិយាយពន្យល់ឲ្យប្រយ័ត្នប្រយែងអំពីខ្មាំងនៅកន្លែងធ្វើការដែរឬទេ? ឆ.១៤៧៖ ចំពោះបញ្ហានេះ គាត់និយាយតែជាមួយថ្នាក់លើរបស់ខ្ញុំទេ [...] ឆ.១៤៨៖ [...] យើងទទួលការណែនាំពីថ្នាក់លើឲ្យមានការប្រុងប្រយ័ត្នអំពីខ្មាំងនៅកន្លែងធ្វើការ។ ស៖ តើលោកស្រីទទួលការណែនាំពីថ្នាក់ណា? ឆ.១៤៩៖ គឺពីថ្នាក់វរៈសេនាតូច។ ស៖ តើថ្នាក់វរៈសេនាតូចនោះទទួលការណែនាំពីថ្នាក់ណា? [...] ឆ.១៥០ ៖ គឺពីបងយ៉ ។"] ឆ.១១៥ KH 01046471 ["យ៉ ជាប្រធានវរៈសេនាធំ។"]។

[1603] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២១ KH 01122398។ *សូមមើលផងដែរ* ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៣២ KH 01110495 ["បាត់ខ្លួន តាវ៉ាញ ហើយ នៅតែ បងសាម៉ន [...] ហើយពេលពួកនិរតីមក គេទុកគាត់។"]។

[1604] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៤១ KH 01110197-98។ *សូមមើលផងដែរ* ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៣១ KH 01110495 ["បងសម៉ន [...] គ្រប់គ្រងនៅកង្ហតហ្នឹង។"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១១ KH 00960689 [នៅឆ្នាំ១៩៧៨ "ប្រធានយោធាតំបន់១ ឈ្មោះ តាសាម៉ន។"]។

[1605] ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៥ KH 01132081។ ឈឿង ប៊ាន ធ្វើការសន្និដ្ឋាននេះដោយផ្អែកលើមូលដ្ឋានដែលថា "តាសាម៉ន នៅរស់ [...] ក្រោយឆ្នាំ១៩៧៩ ខណៈពេលដែលអ្នកធ្លាប់ធ្វើការងារជាមួយគាត់ចាស់ៗត្រូវបានគេយកទៅសម្លាប់ចោលទាំងអស់" *សូមមើល* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២១ KH 01122398។ *សូមមើលផងដែរ* ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧២ KH 01205214 [តាសម៉ន "នៅក្រោមការគ្រប់គ្រងរបស់ តាទិត្យរហូត។"]។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២២០ KH 01153624 ["តាសាម៉ន ជាដៃជើងរបស់ តាទិត្យ [...] [គាត់] មានកេរ្តិ៍ឈ្មោះអាក្រក់ [...] រាយការណ៍ [...] ទៅឲ្យ តាទិត្យ"]។

[1606] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២២០ KH 01153624។

ការប្រជុំមួយ នៅមន្ទីររបស់ តាប៉ែត នៅទួលអណ្តែត **យ៉ីម ទិត្យ** បានប្រាប់ យ៉ូន ថា គាត់នឹងត្រូវទម្លាក់តំណែង[1607]។

456. **យ៉ីម ទិត្យ** បានចេញបញ្ជា និងបានទទួលរបាយការណ៍ពីមន្ត្រីទាំងឡាយនៅទីតាំងពលកម្មនេះ[1608]។ សាក្សី គុប សឹង ដែលបានធ្វើជាប្រធានកងចល័តនៅទីតាំងនេះរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានបញ្ជូនរបាយការណ៍ទៅកាន់ថ្នាក់លើរបស់គាត់ បាននិយាយថា នៅក្នុងកងចល័តនីមួយៗ ក្រុមត្រូវរាយការណ៍ទៅកាន់កងតូច ដែលត្រូវរាយការណ៍បន្តទៅកាន់កងធំរបស់ខ្លួន ដែលត្រូវរាយការណ៍បន្តទៅកាន់កងវរៈសេនាតូចរបស់ខ្លួន ដែលកងនេះរាយការណ៍បន្តទៅកាន់កងវរៈសេនាធំរបស់វា[1609]។ សាក្សី សុខ ជាតិ បាននិយាយថា ក្រុមទាំងឡាយនៅក្នុងកងចល័តរបស់គាត់បានរាយការណ៍មកគាត់ ហើយគាត់ផ្តល់របាយការណ៍លាកលក្ខណ៍អក្សរទៅតំបន់ ជំនួសឲ្យមេបញ្ជាការរបស់គាត់ដែលមិនចេះអក្សរ ពីរបីដងក្នុងមួយខែ[1610]។ បើមិនដូច្នោះទេ គាត់ថា

[1607] ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.២១, ៤០, ៤៤, ៤៦ KH 01132077-78, 83-85 ["តាយ៉ូន ជាអ្នកគ្រប់គ្រងទៅលើកាងារសាងសង់ទំនប់កង្ហត។ [...] តាយ៉ូន ក៏បានទៅចូលរួមកិច្ចប្រជុំជាមួយ តាទិត្យ និង តាប៉ែត នៅកន្លែងរបស់ពួកគាត់ទាំងពីរនាក់នេះឯទួលអណ្តែត"។ បន្ទាប់ពីការប្រជុំនេះ តាយ៉ូន បានប្រាប់ "ខ្ញុំថា យើងលែងមានភារកិច្ចអ្វីទៀតហើយនៅផ្ទះសសរ៤០។ [...] មានន័យថា គេបានដកតំណែងរបស់គាត់ហើយ។"] ឯ.៣៣ KH 01132081 ["តាមពិតគឺ តាយ៉ូន ទេដែលឲ្យខ្ញុំធ្វើជាដាំស្ពៃ។"]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.៤៩ KH 01122404 ["តាយ៉ូន ឡើងជាសាខា (លេខា) ស្រុកក្រោមពេល តាវ៉ាញ ត្រូវបានចាប់ខ្លួន។"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.១៤៣ KH 01110198។ ការប្រជុំនេះធ្វើឡើងនៅចន្លោះពីខែមុចុនា និងខែសីហា ឆ្នាំ១៩៧៨ ភ្លាមៗមុនពេល តាយ៉ូន និង ឈឿង ប៊ាន ចាកចេញពីទំនប់កង្ហត។ *សូមមើល*ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.៦៥, ១៤៤ KH 01110182, 98។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.៣៥, ៧១ KH 01122402, 09។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.៣៧ KH 01132082។

[1608] ប្រធានវរៈសេនាធំឈ្មោះ យ៉ូ៖ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ គុប សឹង ឯ.១១៥, ១៤៣, ១៤៧-១៥០, ១៥៣ KH 01046471, 74-75។ ប្រធានវរៈសេនាធំឈ្មោះ ខេន៖ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឯ.៦៤-៦៥ KH 01196541។ ប្រធានវរៈសេនាធំឈ្មោះ តាសាម៉ន៖ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.១, ១៤១-៤២ KH 01110173-74, 97-98។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.៤៤ KH 01132084-85។ *សូមមើលផងដែរ* ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.១៤៣ KH 01110198។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឯ.៣៨ KH 01132082។

[1609] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ គុប សឹង ឯ.១១៨, ១២០, ១២៤ KH 01046471-72។ *សូមមើល* ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឯ.២៤ KH 01110494។

[1610] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឯ.១៩, ៣១, ៤៤ KH 01196532-34, 37។

មេបញ្ជាការរបស់គាត់ជាអ្នករាយការណ៍ទៅតំបន់[1611]។ ការប្រជុំត្រូវបានធ្វើឡើងនៅកម្រិតជាច្រើនក្នុងឋានានុក្រមរបស់ ប.ក.ក នៅនឹងទីតាំងផ្ទាល់ និងនៅក្រៅទីតាំង ដើម្បីផ្សព្វផ្សាយព័ត៌មាន និងទទួលរបាយការណ៍ពីមន្ត្រីនានានៅតាមទីតាំងពលកម្មដោយបង្ខំនេះ[1612]។

iv. ឧក្រិដ្ឋកម្ម

<u>ការធ្វើឱ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

457. ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ មានជនស៊ីវិលរាប់រយនាក់ ឬ អាចដល់រាប់ពាន់នាក់ បានធ្វើការនៅទីតាំងពលកម្មដោយបង្ខំទំនប់កង្ហត។ សាក្សីពីរនាក់ដែលបានចាប់ផ្តើមធ្វើការនៅទីតាំងពេល តាវ៉ាញ ធ្វើជាគណៈតំបន់ ហើយបានធ្វើការនៅទីនោះ រហូតដល់ប្រហែលជាខែកក្កដា ឆ្នាំ១៩៧៨ នោះ បានធ្វើការប៉ាន់ស្មានថា មានកម្មករច្រើនពាន់នាក់[1613]។ តុប សឹង ដែលត្រូវបានបញ្ជូនពីភូមិភាគនិរតី ឱ្យមកធ្វើជាប្រធានកងចល័តមួយនៅទីតាំងពលកម្មដោយបង្ខំនេះរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ បានរំឭកថា មាន "ប្រជាជនប្រហែលជា ៧០០-៨០០នាក់" នៅក្នុងកងចល័តរបស់គាត់ដែលកំពុងធ្វើការងារនៅទីតាំងនេះ[1614]។ វ៉ាន់ ជា ដែលធ្លាប់ធ្វើការនៅទំនប់កង្ហតនៅចុងឆ្នាំ១៩៧៨ រហូតដល់ចុងបញ្ចប់នៃរបប

[1611] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ ឆ.៣១-៣២ KH 01196534-35។

[1612] *សូមមើល ឧទាហរណ៍* <u>ការប្រជុំថ្នាក់តំបន់</u>៖ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.៩២-៩៤, ៩៦-៩៧, ៩៩ KH 01046468-69។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៣, ៥ KH 01040093-94។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១១៤, ១១៦, ១១៨, ១២០ KH 01244133។ <u>ការប្រជុំថ្នាក់ស្រុក</u>៖ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.២៤ KH 01121738។

[1613] ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.២៩ KH 01110495 ["មួយថ្ងៃៗមានអ្នកធ្វើការច្រើនណាស់"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤២ KH 01196537 ["អ្នកធ្វើការសរុបមានចំនួន ៦០០០នាក់"]។ *សូមមើលផងដែរ* ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.៣៤ KH 01396468 ["សាក្សីធ្លាប់ធ្វើការនៅការដ្ឋានទំនប់កង្ហត នៅពេលដែល តាប៉ែត ធ្វើជាអ្នកគ្រប់គ្រងចំនួនបីខែ: "[មានមនុស្ស] រាប់ម៉ឺននាក់ ជាងម៉ឺន"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦៧, ៧០ KH 01122408, 09 ["ចំនួនអ្នកធ្វើការនៅទ្វារទឹកនិងទំនប់កង្ហត មានចំនួនតិចជាងមុន"]។ ក្រោយបញ្ចប់ការសាងសង់ទំនប់នេះ "ចំនួនអ្នកធ្វើការថយចុះ នៅប្រហែលត្រឹម២០០នាក់ ហើយក្រោយមកនៅប្រហែលជា ១០០នាក់ នៅខែឧសភា ឬមិថុនា ឆ្នាំ១៩៧៨"]។

[1614] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១១១, ១៤០ KH 01046470, 74។

កម្ពុជាប្រជាធិបតេយ្យ បានផ្តល់ការនូវការប៉ាន់ស្មានថា "ប្រហែលជា ១,០០០នាក់" ហើយបាននិយាយថា គ្រាន់តែកងចល័តរបស់គាត់តែមួយមាន "មនុស្សជាង១០០នាក់"[1615] ទៅហើយ។

458. កម្លាំងពលកម្មទំនប់កង្ហត មានទាំងបុរស ស្ត្រី កុមារ និងមនុស្សចាស់ ដែលភាគច្រើនមកពីតំបន់១ ក្នុងភូមិភាគពាយ័ព្យ[1616]។ ទីតាំងនេះក៏មានកម្មាភិបាលភូមិភាគពាយ័ព្យដែលគេបានទម្លាក់តំណែងផងដែរ[1617]។ ការងាររបស់ពួកគេរួមមាន កាប់ដី រែកដី រើសអាចម៍គោ និងរែកសំណាប[1618]។

[1615] ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.២ KH 01121734 ["ក្នុងកងចល័តរបស់ខ្ញុំ [...] មានមនុស្សជាង ១០០នាក់។ [...] ខ្ញុំមិនដឹងថាមានចំនួនប៉ុន្មានកងនោះទេ។ ខ្ញុំស្មានមើលទៅមនុស្សទាំងអស់គ្នាមានប្រហែលជាង ១០០០ ដែលធ្វើការនៅកន្លែងទំនប់ ប៉ុន្តែខ្ញុំមិនច្បាស់ប៉ុន្មានទេ"]។

[1616] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ គុប សឹង ឆ.១៤០ KH 01046474។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន យ៉ៀន ឆ.៤ KH 01121664។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.៩ KH 01394972 ។ ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៣១, ៣៥ KH 01121701។ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.២ KH 01121734។ ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៩ KH 01110161។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១៦, ២៥ KH 01110493, 94។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៦៦ KH 01196541 ។ *សូមមើលផងដែរ* ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥៩ KH 01477616។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៣៥ KH 01121701 ["មិនមានកុមារធ្វើការនៅទីនោះទេ"]។

[1617] <u>ព្រ្ចុំ អនុលេខាតំបន់១</u>៖ ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី 6273 EN 01222575 [ម៉ុល សុត ហៅ ព្រ្ចុំ សាងសង់ទ្វារទឹកនៅតំបន់១]។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៉ាង ប៊ាន ឆ.៥ KH 01132072 ["តាព្រ្ចុំ [...] បានធ្វើជាជាងសំណង់ ធ្វើទ្វារទឹក"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៉ាង ប៊ាន ឆ.៣៣ KH 01110178 [បន្ទាប់ពី "តាព្រ្ចុំ ត្រូវបានគេដកចេញពីតំណែងរបស់គាត់ហើយ ដោយគាត់មកធ្វើការជាមួយខ្ញុំ [...]"]។ *សូមមើលផងដែរ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៉ាង ប៊ាន ឆ.៦ KH 01122396 ["តាព្រ្ចុំ អនុគណៈតំបន់១"]។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធ្ងៀន ឆ.២០ KH 00947579។ យ៉ន សមាជិកគណៈស្រុក ស ង្កែ៖ ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី 11667 EN 01222811 [ទេព រ៉ុម ហៅ យ៉ន កម្មាភិបាលមើលត្រាក់ទ័រ ទប់ទំនប់ទឹកតំបន់១ (ប្រធានទំនប់ទឹកតំបន់១)]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៉ាង ប៊ាន ឆ.២០ KH 01122398 ["តាយ៉ាន់ ដែលអតីតគណៈស្រុកត្រូវបានគេទម្លាក់ពីតំណែង ហើយឲ្យមកធ្វើការនៅទ្វារទឹកជាមួយខ្ញុំ"]។

[1618] ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៩ KH 01110161។ ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៣៣ KH 01121701 ។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦២ KH 01110499។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.១៨-១៩, ២១ KH 01394973 ។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535។ ឯកសារ D219/747 កំណត់ហេតុស្តាប់ចម្លើយ សយ អ៊ែម ឆ.១៦ KH 01235342។ *សូមមើលផងដែរ* ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥៩ KH 01477616។

ឧបករណ៍គ្រឿងចក្រតែមួយប្រភេទប៉ុណ្ណោះ ដែលសាក្សីនានាបានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស គឺ ឡានចូកដី និងប្រដាប់ស្ទូច[1619]។

459. អ្នករស់រានមានជីវិតម្នាក់បានរៀបរាប់ពីលក្ខខណ្ឌការងារថា "យ៉ាងវេទនា" និងបានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា ទីតាំងនេះធ្វើការ "២៤ម៉ោងពេញមួយយប់មួយថ្ងៃ"[1620]។ សាក្សីជាច្រើន និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានធ្វើការចាប់ពីម៉ោង ៧ព្រឹក ដល់ម៉ោង ១១យប់ ដោយសម្រាកតែពីរដងប៉ុណ្ណោះ[1621]។ សាក្សីម្នាក់បាននិយាយថា៖ "ខ្ញុំចាប់ផ្តើមធ្វើការនៅម៉ោង៧ព្រឹក ពេលហូបបាយរួច ហើយធ្វើការរហូត [...] បន្ទាប់ពីសម្រាក ខ្ញុំចាប់ផ្តើមធ្វើការម្តងទៀត ពីម៉ោង៥ល្ងាច ទៅ

[1619] ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៩ KH 01110161 ["គេក៏មានអ៊ុចស្ការ៉ាទ័រ ផងដែរ"]។ ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៣៧ KH 01121702 ["គេមានសន្ទ្ធចយោងសសរ"]។ *សូមមើលផងដែរ* ឯកសារ D219/263 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.១១៥ KH 01086103។

[1620] ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.២១ KH 01396467។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃ្យៀន ឆ.១១ KH 01121666 ["អ្នកធ្វើការ គឺធ្វើការ២៤ម៉ោងពេញមួយយប់មួយថ្ងៃ"]។ *សូមមើលផងដែរ* ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.២២ KH 01396467។ ឯកសារ D118/281 កំណត់ហេតុស្តាប់ចម្លើយ កែវ សុខា ឆ.១២ KH 01004021។ ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៩ KH 01110161។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១៩ KH 01023832-33។ ឯកសារ D219/747 កំណត់ហេតុស្តាប់ចម្លើយ សយ អ៊ែម ឆ.១៦, ២៦ KH 01235342, 44។

[1621] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១២៧ KH 01046472 ["ចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១១ ឈប់ហូបបាយ [...] ហើយពីម៉ោង១ចុះទៅធ្វើម្តងទៀត រហូតដល់ម៉ោង៥សៀល [...]។ ពេលយប់យើងធ្វើការថែមទៀត ចាប់ពីម៉ោង៧.៣០ រហូតដល់ម៉ោង១០ ឬជួនកាលដល់ម៉ោង ១១យ"]។ ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៣៣ KH 01121701 ["ម៉ោងប្រាំពីរព្រឹក រហូទៅដល់ម៉ោងដប់មួយ ផ្ងើពីម៉ោងពីរទៅដល់ម៉ោងប្រាំ និងពីម៉ោងប្រាំទៅដល់ម៉ោងដប់យប់។ ខ្ញុំធ្វើការបីវេនក្នុងពេលនោះ"]។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀន ម៉ត ឆ.២៣ KH 01155824 ["នៅទំនប់កង្ហត យើងធ្វើការបីដងក្នុងមួយថ្ងៃ។ យើងធ្វើការរហូតដល់ម៉ោង១១យប់"]។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦១ KH 01110498-99។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.១៩ KH 01394973 ។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃ្យៀន ឆ.១១ KH 01121666។ *សូមមើលផងដែរ* ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៩ KH 01110161។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម រ៉ណ្ណា ឆ.៩ KH 01080874។ ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.២៤-២៥ KH 01396467។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្យៀង ប៊ាន ឆ.២០ KH 01122398។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្យៀង ប៊ាន ឆ.៦១ KH 01122407 ។ កំណត់ហេតុស្តាប់ចម្លើយ ឈ្យៀង ប៊ាន ឆ.៦១ KH 01122407 ["លក្ខខណ្ឌការងារ គឺល្អជាង ពេល តាប៉ែត មកកាន់ [ជាគណៈតំបន់១]។ [យើងធ្វើការងារ] ចាប់ផ្តើមពីម៉ោង១១ព្រឹក ហើយបញ្ចប់នៅម៉ោង១០យប់ ប៉ុន្តែមុនតាប៉ែត មកកាន់ ការងារចប់នៅម៉ោង១១យប់"]។

ដល់ម៉ោង៥ភ្លឺ គឺមួយយប់ពេញ”[1622]។ សាក្សីម្នាក់ទៀតបាននិយាយថា “នៅក្នុងករណីបន្ទាន់ [...] យើងត្រូវធ្វើការពេញមួយយប់ រហូតដល់ពេលថ្ងៃបន្ទាប់”[1623]។ កម្មករ “ពុំមានពេលដេកគ្រប់គ្រាន់ឡើយ”[1624]។ កម្មករម្នាក់មិនបានរស់នៅកន្លែងទីតាំងនេះទេ ហើយគាត់បានភ្ញាក់ពីដេកនៅម៉ោង៣ព្រឹក ដើម្បីចាប់ផ្តើមការងារវេនរបស់គាត់នៅម៉ោង៦ព្រឹក[1625]។ ដើម្បីជួយសម្រួលដល់ការងារពេញមួយថ្ងៃ គេមានម៉ាស៊ីនភ្លើងប្រើនៅពេលយប់ដើម្បីបំភ្លឺនៅកន្លែងទីតាំងពលកម្មដោយបង្ខំ ហើយកម្មករភាគច្រើនដេកនៅនឹងកន្លែងធ្វើការផ្ទាល់តែម្តង[1626]។

460. កាលវិភាគការងារដ៏តឹងរ៉ឹងត្រូវបានគេដាក់ទៅលើកម្មករ រួមទាំងពេលវេលាដែលពួកគេត្រូវក្រោកពីដេក[1627]។ ការឈប់សម្រាកនៅចន្លោះការងារមានរយៈពេលខ្លី ហើយការសម្រាកពេលប្តូរវេនការងារ រួមទាំងក្នុងរដូវវស្សាផង ត្រូវបានហាមឃាត់[1628]។

[1622] ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១៩ KH 01023832-33។ *សូមមើលផងដែរ* ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៧ KH 01205216 [“[យើងធ្វើការ] [...] ព្រឹកពីម៉ោង៧ ដល់ម៉ោង១២ [...] ពីម៉ោង១ ដល់ម៉ោង៥” យប់ចុះហ្វូបបរ “មកទល់ម៉ោង១អធ្រាត្រទៀត”]។

[1623] ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៩ KH 01110161 [“នៅក្នុងករណីបន្ទាន់ [...] ប្រសិនបើគេនិយាយថា ទំនប់នឹងត្រូវបាក់នៅពេលណាមួយ យើងត្រូវធ្វើការដោយឥតឈប់ឈរ។ យើងត្រូវធ្វើការពេញមួយយប់ រហូតដល់ពេលថ្ងៃបន្ទាប់។ ប៉ុន្តែករណីនេះ កើតឡើងយូរៗម្តងប៉ុណ្ណោះ”]។

[1624] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២០ KH 01122398។

[1625] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។

[1626] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១២៨ KH 01046472។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន យ៉ៃន ឆ.១១ KH 01121666។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១៩ KH 01023832-33។ ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៣២ KH 01121701។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១៩ KH 01110494។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៥០ KH 01196539។ ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.៣៨ KH 01396469។

[1627] ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦១ KH 01110498-99 [“ម៉ោងប្រាំព្រឹក គេវ៉ៃជ្ជងដាស់ ហើយម៉ោងប្រាំកន្លះគឺយើងទៅតម្រង់ជ្ជរ ហើយម៉ោងប្រាំមួយយើងចេញទៅ”]។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ីកាន ឆ.១៩ KH 01394973 [“ពេលព្រលឹមឡើងគេដាស់ឲ្យហាត់ប្រាណ ហើយម៉ោងប្រាំមួយកន្លះ គេចែកការងារឲ្យយើង”]។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៦ KH 01080873 [“រាល់ៗព្រឹក ពេលម៉ោង៣ទៀបភ្លឺ គេតែងតែវ៉ៃជ្ជង ដាស់អ្នកធ្វើការឲ្យក្រោកដើម្បីទៅធ្វើការនៅទំនប់កង្ហត”]។

[1628] ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៣៣ KH 01121701។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀន ម៉ត ឆ.២៣ KH 01155824។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦១, ៦៥ KH 01110498-99 [“ឆ.៦១ [...] ដល់ម៉ោងប្រាំមួយកន្លះ រៀងព្រលប់បន្តិច សម្រាកហើយចាប់ផ្តើមធ្វើការទៀត [...] ស៖ [...] បើ

461. "ម្នាក់ៗមានការងាររៀងៗខ្លួនត្រូវបំពេញ"[1629] ហើយកម្មករត្រូវបានគេតាមដាន[1630]។ បើពួកគេដើរចេញពីចំណុចការងារដែលគេដាក់ឲ្យធ្វើ មិនធ្វើការ ឬមិនខំប្រឹងធ្វើការ នោះគេនឹងនាំយកទៅបាត់ ដាក់គុក និង/ឬ សម្លាប់ចោល[1631]។ សាក្សីម្នាក់និយាយថា៖ "ពលកម្ម គេបង្ខំ រកស្ម័គ្រចិត្តមិន

ថ្ងៃមួយលោកចង់សម្រាក ឬក៏លោកកំពុងធ្វើការ ហើយចង់ទៅផ្ទះវិញ។ តើលោកអាចសុំគេបានទេ? ឆ.៦៥៖ មិនងាយសុំគេបានទេ"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧២ KH 01196543។ ឯកសារ D118/281 កំណត់ហេតុស្តាប់ចម្លើយ កែវ សុខា ឆ.១២ KH 01004021 ["គេចាក់មេក្រូហូត ហើយអំពាវនាវឲ្យប្រជាជនខិតខំធ្វើការ មិនត្រូវសម្រាក ឬខ្ជិលច្រអូសឡើយ"]។

[1629] ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាង ប៊ិា ឆ.៩ KH 00998554-55។

[1630] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន យឿន ឆ.១៣ KH 01121666 ["មិត្តនារី គា មានកាន់កាំភ្លើងអាកា៤៧ កាន់សៀវភៅសរសេរ ហើយនឹងប៊ិចជាប់ជានិច្ចសម្រាប់កត់ត្រាអ្នកណាដែលធ្វើខុស។ គាត់មានកញ្ចែ [...] សម្រាប់ផ្លុំឲ្យមនុស្សចុះទៅធ្វើការ និងឡើងពីធ្វើការ"]។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ិាន ឆ.២៥ KH 01394974 [នៅផ្ទះសសរ៤០ "គេឲ្យខ្ញុំយាមនៅពេលថ្ងៃ ហើយពួកយោធាធំៗ យាមពេលយប់"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ិាន ឆ.១៣៧ KH 01110196 [ឆ្មាំប្រដាប់អាវុធត្រួតពិនិត្យទៅលើការដើរហើររបស់យើង ខណៈដែល យឹម ទិត្យ មកគ្រប់គ្រងនៅកង្គូត]។ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.១២ KH 01121736។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណំ ភន ឆ.៦៤, ៦៩ KH 01110499, 500។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៤ KH 01080872-73។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៦៤-១៦៥ KH 01046476-77។ ឯកសារ D219/946 កំណត់ហេតុស្តាប់ចម្លើយ ឡៅ កង ឆ.២៩ KH 01415414។ *សូមមើលផ្ទុយពីនេះ* ឯកសារ D118/281 កំណត់ហេតុស្តាប់ចម្លើយ កែវ សុខា ឆ.១២ KH 01004021 ["កម្មាភិបាលដែលស្នាក់នៅផ្ទះសសរ៤០មានអាវុធ តែពុំមានអ្នកយាមតាមល្បាតមើលប្រជាជនធ្វើការនោះទេ"]។

[1631] ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.១២ KH 01121736 ["យើងមិនត្រូវបានអនុញ្ញាតឲ្យដើរចេញពីកន្លែងដែលគេចាត់តាំងឲ្យយើងនោះទេ។ បើមាននរណាម្នាក់ត្រូវបានគេឃើញឈប់ធ្វើការ ឬមួយដើរហើរសេរី អ្នកនោះនឹងត្រូវគេដាក់គុក"]។ ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.៤២-៤៣ KH 01121702-03 ["ជិតជើងទំនប់ [...] ប្រធានកងមកដល់បាននិយាយថា ពួកគេធ្វើការយឺត។ បន្ទាប់មកប្រធានកងនោះ ក៏យកដងចបវាយសំពងក្បាលយុវជនទាំងពីរនោះ [...]។ បន្ទាប់មកខ្ញុំបានឃើញគេ [...] សែងសាកសពយុវជនទាំងពីរនោះ"]។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៤ KH 01080872-73 ["អ្នកខ្ជិល [...] យោធាមកយកអ្នកទាំងនោះចេញទៅ"]។ ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.២៨ KH 01396468 [ចំពោះអ្នក[កម្មករ]ដែលខ្ជិល "មិនស្រួលៗ គេបាញ់ចោល"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៧ KH 00960689 ["ពេលដែលខ្ញុំត្អូញត្អែពីការងារនោះ ពួកឈ្លបគេស្តាប់ឮខ្ញុំនិយាយ គេរាយការណ៍ទៅ តាព្រំ។ តាព្រំ [...] និយាយថា ខ្ញុំប្រឆាំងនឹងបក្ស ហើយគាត់ឲ្យយោធាបញ្ជូនខ្ញុំទៅដាក់នៅគុកបាណន់តែម្តង"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រឿត ឆ.១៩ KH 01023832-33។ ឯកសារ D219/429 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ វ៉ាន់ ជា KH 01484975 ["នៅពេលដែលអ្នកធ្វើការ[កម្មករ]ធ្វើការមានការយឺតយ៉ាវ ឬក៏ប្រសិនបើធ្វើការដោយមិនប្តេជ្ញាស៊ូប្តូរទេនោះ គេនឹងវាយដំនឹងដំបង រហូតដល់ស្លាប់។ ព្រឹត្តិការណ៍ទាំងនេះបានកើតឡើង

ឃើញ"[1632]។ កម្មាភិបាល រួមទាំងយោធាផង ក៏ "បង្ខំ" មនុស្សឈឺឲ្យធ្វើការដែរ ដោយប្រាប់ពួកគេ "ឲ្យកែខ្លួន ហើយខិតខំប្រឹងធ្វើការឲ្យខ្លាំងក្លាឲ្យអង្គការ"[1633]។ មានការប្រជុំទិតៀន ស្ម័យទិតៀនគ្នាទៅវិញទៅមក[1634]។ "យើងធ្វើការកើតដោយសារតែការភ័យខ្លាច"[1635]។ "តែតម្លៃថ្នាអីចេះអីចុះអត់បានទេតែគេថាឲ្យធ្វើត្រូវតែធ្វើទៅចឹង"[1636]។ "ពេលខ្លះយើងដេកទាំងខោអាវសើម។ [...] ការងារធ្ងន់មែនទែន"[1637]។

462. នៅពេលដែលសាក្សីនានាធ្វើការប្រៀបធៀបលក្ខខណ្ឌការងារនៅចំនប់កង្ហត ក្នុងអំឡុងពេលនៃការដឹកនាំរបស់ **យ៉ីម ទិត្យ** ជាមួយនឹងលក្ខខណ្ឌការងារដែលធ្លាប់មានក្នុងអំឡុងពេលនៃការដឹកនាំរបស់ថ្នាក់ដឹកនាំមុនៗរបស់គាត់ ពួកគេបានរាយការណ៍ថាវា "យ៉ាប់ឃ្ងុនជាងមុន" និង "កាន់តែលំបាកឡើងៗ"[1638]។ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ រស់ ញ៉ឹម បានប្រាប់មន្ទីរ៨៧០ ថា នៅភូមិភាគ ពាយ៉ាព្យ "ឃើញថាការងារណ្ណផង ហើយលឿនជាងមុនដែរ [...] ប្រឡាយ [...] និងរៀបចំដាក់ជី តាម

ជាប្រចាំថ្ងៃ [...] ចុងឆ្នាំ១៩៧៨ នៅក្នុងរដូវប្រាំង"]។ *សូមមើលផងដែរ* ឯកសារ D219/748 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀន ឆ.៨៥, ៩០ KH 01235368, 69។

[1632] ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.២៦ KH 01396467។

[1633] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១១, ១៦ KH 01121666, 67 [បើសិនជាមិត្តនារី គា "ឃើញនរណាម្នាក់ឈឺ[...]គាត់នឹងចោទអ្នកនោះថាធ្វើពុតជាឈឺ ហើយដេញឲ្យទៅធ្វើការ។ [...] ពេលអ្នកជំងឺឈឺយូរ យោធាគេនឹងមកបង្ខំឲ្យចេញទៅធ្វើការ"]។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ គុប សឹង ឆ.១៥៤-១៥៥ KH 01046475-76 ["ស៖ បើសិនជាមានអ្នកណាម្នាក់ឈឺញ៉ីកញ្ជាប់គេចាត់ទុកជាខ្ជាំងហើយ តើគេមានវិធានការយ៉ាងដូចម្តេចចំពោះអ្នកឈឺនោះ?ឆ.១៥៤៖ គេណែនាំអ្នកទាំងនោះ ឲ្យកែខ្លួន ហើយខិតខំប្រឹងធ្វើការឲ្យខ្លាំងក្លាឲ្យអង្គការ។ [...] ឆ.១៥៥៖ ពេលខ្លះអ្នកនោះឈឺមែន។ ដូច្នេះ យើងនៅតែបន្តកសាងគេបន្តទៅទៀត"] *បញ្ជាក់ដំហរ* ឯកសារ ឯកសារ D123/2/1.1a បទសម្ភាសន៍ គុប ស៊ើង ដោយ DC-Cam KH 00957634-35។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦១ KH 01122407 ["លក្ខខណ្ឌការងារ គឺណ្ណជាង ពេល តាប៉ែត មកកាន់ [ជាគណៈតំបន់១]។ [...] ពេលគាត់[តាប៉ែត] មកកាន់ អ្នកធ្វើការអាចសុំច្បាប់សម្រាកកន្លះថ្ងៃ នៅពេលដែលពួកគេមិនសូវស្រួលខ្លួន"]។

[1634] ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.៧៨, ៨០ KH 01394979, 80។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។

[1635] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។

[1636] ឯកសារ D219/747 កំណត់ហេតុស្តាប់ចម្លើយ សយ អ៊ែម ឆ.១៦ KH 01235342។

[1637] ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦១-៦២ KH 01110498-99។ *សូមមើលផងដែរ* ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។

[1638] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៤១ KH 01110197-98។ ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាង ប៊ា ឆ.៩ KH 00998554-55។

ស្រែ ក៏យកចិត្តទុកដាក់ជាងឆ្នាំមុន”[1639]។ ការបន្តធ្វើអាជីវកម្មលើពលកម្មមនុស្សបានជួយឲ្យ **យ៉ីម ទិញ្ញ** ទទួលបានទីតាំងពលកម្មដោយបង្ខំជាឧទាហរណ៍គំរូមួយនៃគោលនយោបាយនិយមស្រែ ចម្ការរបស់ ប.ក.ក សម្រាប់ជូនភ្ញៀវបរទេសទស្សនានៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៨[1640]។

463. ខណៈកំពុងរងនូវការឈឺចាប់ដោយសារការងារលើសកំណត់រួចទៅហើយក្តី ការហូបចុកក៏មិនបានគ្រប់គ្រាន់ទៅទៀត។ ពួកគេទទួលបានតែអាហារពីរពេលក្នុងមួយថ្ងៃ ដែលជាទូទៅគឺជាបបរវ៉ាវ១

[1639] ឯកសារ D1.3.30.19 ទូរលេខ ២៤២ ពី រស់ ញ៉ឹម គោរពជូនអង្គការ ១១/៥/១៩៧៨ KH 00021044។

[1640] ឯកសារ D6.1.828 FBIS *សេចក្តីពិស្តារនៃទស្សនកិច្ចដោយសាស្ត្រាចារ្យចក្រភពអង់គ្លេស អ្នកសារពត៌មានអាមេរិក* ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៧៨ KH 01169232-33។ ទំនប់កង្ហត់ត្រូវបានប្តូរឈ្មោះថា ទំនប់ប្រាយុទ្ធ *សូមមើល* ឯកសារ D6.1.819 FBIS *ការខិតខំប្រឹងប្រែងបង្ករបង្កើនផលរបស់កសិករនៅភូមិភាគពាយ័ព្យត្រូវបានលើកឡើង* ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ១៩៧៨ EN 00169237។

ដែលសាក្សីនានានិយាយថា មិនគ្រប់គ្រាន់នោះឡើយ[1641]។ "[យើង]ម្នាក់ៗស្គមស្គាំង"[1642]។ រស់ ញ៉ឹម បានជម្រាបជូនមន្ទីរ ៨៧០ នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ១៩៧៨ ដូចខាងក្រោម៖

> ខាងជីវភាពប្រជាជន៖ ក្នុងភូមិភាគ ការខ្វះខាតគឺ ៣ តំបន់ ១+៤+៥ ទាំងអស់តំបន់ ៥ ខ្វះជាងគេ រួចមកតំបន់ ១ [...] តំបន់១៖ ក្រោយ ១.១/២ កំប៉ុង មួយថ្ងៃ កន្លែងខ្ពះដល់ពាក់កណ្តាលខែ៦ ខ្ពះជាងខែ៦ ត្រូវខ្វះ ខ្ពះដល់ដើមខែ៧[1643]។

464. សាក្សី ឈឿង ប៊ាន ដែលធ្លាប់ធ្វើការនៅទីតាំងពលកម្មដោយបង្ខំនេះពីពាក់កណ្តាលខែឧសភា ឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ នៅក្រោមមេដឹកនាំតំបន់១ ខុសៗគ្នា បានឆ្លងកាត់នូវសភាពការណ៍យ៉ាងអាក្រក់ដូចដែលបានរៀបរាប់យ៉ាងលម្អិតដោយ តាញ៉ឹម បាននិយាយថា៖

[1641] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១១៧ KH 01110192 ["តាទិត្យ[ឲ្យ]យើងហូបតែ[បាយជាមួយ]អំបិលប៉ុណ្ណោះ"]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២០ KH 01122398 ["របបអាហារ ពុំគ្រប់គ្រាន់ឡើយ។ [...] ពីរពេលក្នុងមួយថ្ងៃ ពេលព្រឹកនិងពេលល្ងាច។ នេះគឺក្រោយពេលការគ្រប់គ្រងរបស់ តាវ៉ាញ"]។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.១៩ KH 01394973 ["ជួនកាលគេឲ្យយើងហូបបាយ ឬបបរ ជួនកាលព្រឹកបបរ ល្ងាចបាយ តែបាយត្រូវបានគេវាស់ចែក"]។ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.៨-៩ KH 01121735-36។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧២ KH 01196543។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦០, ៩៧ KH 01110498, 99។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៥២ KH 01132087។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឈឿន ឆ.១១ KH 01121666។ ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.៣៥-៣៧ KH 01396468-69។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១៩ KH 01023832-33។ ឯកសារ D118/281 កំណត់ហេតុស្តាប់ចម្លើយ កែវ សុខា ឆ.១២ KH 01004021 ។ *សូមមើលផងដែរ* ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។ ឯកសារ D219/748 កំណត់ហេតុស្តាប់ចម្លើយ ស្រី សឿន ឆ.៩០ KH 01235368-69។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១២៩-១៣០ KH 01046472 [សាក្សីត្រូវបានបញ្ជូនពីភូមិភាគនិរតី មកធ្វើជាប្រធានកងចល័តមួយនៅទ័ពប៉ាកង្ហត៖ "របបអាហារនៅក្នុងការដ្ឋាន គឺមានគ្រប់គ្រាន់ តាមខ្ញុំដឹង គ្មានអ្នកណាតូចញ្ជែ្ជ ថា មិនគ្រប់គ្រាន់នោះទេ"]។ ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៩ KH 01110161 ["អ្នកដែលធ្វើការនៅទីនោះ មានអាហារហូបចុកគ្រប់គ្រាន់។ យើងទទួលបានអាហារបីពេលក្នុងមួយថ្ងៃ"]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២២ KH 01122398 ["ក្រោយការគ្រប់គ្រងរបស់តាវ៉ាញ គេឲ្យហូបបង្អែមម្តងក្នុងមួយសប្តាហ៍ដូចជា អង្ករដំណើប ឬក៏ទុរេន គេឲ្យបារីជក់ ពេលខ្ពះរៀងរាល់ពីរអាទិត្យម្តង"] ឆ.៦១ KH 01122407 ["ពេល តាប៉ែត មកកាន់ [ជាគណៈតំបន់១] [...] របបអាហារ គឺស្រដៀងគ្នានឹងកាលពីលើកមុនដែរ ប៉ុន្តែគេអាចរកត្រី ឬបេះបន្ថែមកថែមពីលើអាហាររបស់ពួកគេដែរ"]។

[1642] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។

[1643] ឯកសារ D1.3.30.19 ទូរលេខ ២៤២ ពី រស់ ញ៉ឹម គោរពជូនអង្គការ ១១/៥/១៩៧៨ KH 00021043-44។

"[របបអាហារ] គឺយ៉ាប់ឃ្ងីនជាងមុន [ពេលដែល តាទិត្យ គ្រប់គ្រង]"[1644]។ កម្មករមានសភាពហេវ ហត់ ត្រូវបានបង្អត់អាហារ និង/ឬ ឈឺ[1645]។ អ្នកដែលប៉ាន់លួចហូបអាហារ ត្រូវបានផ្តន្ទាទោស ឲ្យធ្វើការងារហត្ថកម្ម "ជេរប្រទេច និងវ៉ៃ" ឬ "យកទៅអប់រំ" ឬ "សម្លាប់ចោល"[1646]។ អ្នកឈឺមិន

[1644] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១២៣ KH 01110194។ *សូមមើលផងដែរ* ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៣១ KH 01110195 ["ខ្ញុំទទួលបានអាហារតិចជាង នៅពេលដែល តាទិត្យ គ្រប់គ្រង បើធៀបទៅនឹងពេលដែល តាវ៉ាញ ជាអ្នកគ្រប់គ្រង"]។

[1645] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឈឿន ឆ.១១ KH 01121666 ["មិនអ្នែតទេ ដូច្នេះយើងត្រូវតែបេះស្លឹក ឈើយកមកលាយជាមួយបាយហូបបន្ថែមទៀត"]។ ឯកសារ D118/221 កំណត់ហេតុស្តាប់ចម្លើយ ផាន់ យ៉ីម ឆ.៥៦ KH 00982494 ["គឺនឿយហត់ហើយព្រោះហូបមិនអ្នែត"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១២៥ KH 01110194 ["ស៖ ស្ថិតក្រោមការគ្រប់គ្រងរបស់ តាទិត្យ តើមានមនុស្សស្លាប់ដោយដាច់ពោះប៉ុន្មាននាក់? ឆ.១២៥៖ ខ្ញុំឃើញ ក្មេងបីនាក់ [...] ធ្លាក់ខ្លួនឈឺ"]។

[1646] ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦៧-៦៨, ៩៧ KH 01110499, 03 ["គេធ្លាប់ចាប់ខ្ញុំបានម្តងដែរ ពេលខ្ញុំលួចបេះក្រូច។ [...] គេភ្ជង់ខ្ញុំឲ្យដើរទៅកាប់រណ្តៅចេក៣០រណ្តៅ ហើយក្រូចហ្ម៉ង គេយកទៅបាត់ហើយ។ [...] ដូចជា មានខ្លះហើយ ព្រោះជួនកាលអ្នកធ្វើការនៅទីនោះ ហូបមិនគ្រប់មានលួចហូបបន្តិចបន្តួច ដូច្នេះ តែងតែមានការជេរប្រទេច ហើយ វ៉ៃតប់ខ្លះ តែមិនដល់ថ្នាក់វ៉ៃស្លាប់នៅហ្ម៉ងកន្លែងទេ"]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៤១, ៤៣ KH 01122403 ["តាសាម៉ន ឃើញពួកគេកាន់ផ្លែក្រូច ហើយចោទពួកគេថា ជិះជាន់ និងក្បត់សម្ងាហភាព។ ពួកគេត្រូវបានឲ្យ ត្រឡប់មកកងវិញបន្ទាប់ពីទទួលបានការអប់រំរយៈពេល១សប្តាហ៍ក្រោយមក។ [...] វា[ព្រឹត្តិការណ៍នេះ]កើតឡើងក្រោយពេល តាវ៉ាញ ត្រូវបានគេចាប់ខ្លួនប្រហែលជា ៥ ឬ ៦ខែ"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០៨ KH 01110190 ["បុរស[...]ម្នាក់ បានលួចចេកបីស្ងិត ដោយសារតែគាត់ឃ្លានខ្លាំងពេក។ [...] គាត់ត្រូវបានគេចាប់ចងបោះចូលទៅ ក្នុងចរន្តទឹកដែលកំពុងហូរ ម្តងហើយម្តងទៀត ចំនួនបីដង។ ដោយសារតែគាត់នៅតែអាចងើបចេញពីទឹកបាន គេក៏បណ្តើរគាត់ យកទៅសម្លាប់ចោល។ កាលណោះ [...] ក្នុងខែកក្កដា ឆ្នាំ១៩៧៧។ [...] តាសាម៉ន និងកូនចៅរបស់គាត់បាននាំគ្នាសើច"] (*កត់ សំគាល់* ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២៥-២៦ KH 01132078 ["ហេតុការណ៍នោះបានកើត ប្រហែលជា ១ខែក្រោយពេលដែលគេចាប់ តាវ៉ាញ។ [...] ខ្ញុំបានឃើញហេតុការណ៍នេះផ្ទាល់នឹងភ្នែក"])។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080873 [អ្នកណា "ដែលមិនស្មោះត្រង់ជាមួយនឹងអង្គការ [...] យោធាមក យកអ្នកទាំងនោះចេញទៅ"]។ *សូមមើលផងដែរ* ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២២០ KH 01153624។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦៣ KH 01122407 ["ប្រជា ជនត្រូវបានគេលើកលែងឲ្យប្រសិនបើពួកគេប្រព្រឹត្តកំហុសតូចតាច នៅពេល តាប៉ែត គ្រប់គ្រង។ ឧទាហរណ៍ នៅពេលដែលពួក គេលួចដំឡូង ឬអាហារហូបចុកជាដើម"]។

អាចធ្វើការត្រូវបានគេបន្ថយរបបអាហារពាក់កណ្តាល[1647]។ ការបន្ថយនេះ "ធ្វើឲ្យស្ថានភាពអ្នកជំងឺកាន់តែដុនដាបទៅៗ"[1648]។

465. អ្នកឈឺទទួលបានការយកចិត្តទុកដាក់ផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់ឡើយ ដោយសារ "ពុំមានពេលដែលមានបទពិសោធន៍"[1649]។ កម្មករខ្លះមិនដែលបានឃើញគេផ្តល់ថ្នាំពេទ្យនៅទីតាំងធ្វើការផ្ទាល់ឡើយ[1650]។ ចំណែកខ្លះទៀតបានរាយការណ៍ថា បានឃើញគេប្រើ "ទឹកដូងធ្វើជាស៊ីរ៉ូម" ឬ "ថ្នាំគ្រាប់ដែលធ្វើពីកន្ទក់ និងស្ករក្រហម"[1651]។ ជួនកាលថ្នាំពេទ្យគ្រាន់តែសម្រាប់ "ព្យាបាលគ្រុនក្តៅ និងឈឺក្បាល"[1652] ប៉ុណ្ណោះ ហើយសាក្សីម្នាក់បានរាយការណ៍ថា "អ្នកជំងឺឡើងកំដៅខ្លួនមួយរំពេច"[1653]។

466. កម្មករមិនត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះ ដើម្បីសួរសុខទុក្ខគ្រួសាររបស់ពួកគេឡើយ[1654]។ មានពេលម្តងនោះ ពេលដែលសំណើសុំរបស់កម្មករម្នាក់ត្រូវបានបដិសេធ គេបានប្រាប់គាត់ថា"អង្គការ

[1647] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១៤ KH 01121667។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១២៦ KH 01110194។

[1648] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១៤ KH 01121667។

[1649] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៧៥ KH 01122410។

[1650] ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.៩-១១ KH 01121736។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១២៥ KH 01110194។

[1651] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៧៥ KH 01122410។ ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។

[1652] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១៥ KH 01121667។

[1653] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៧៥ KH 01122410។

[1654] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.២១ KH 01196533 ["សម័យ ប៉ុល ពត គេមិនឲ្យទៅណាទេ គេមិនឲ្យទៅផ្ទះអីទេ គេឲ្យនៅតែមួយកន្លែង"]។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៥២ KH 01132087 ["ក្រោមការគ្រប់គ្រងរបស់ តាទិត្យ ប៉ុន្តែបើនិយាយឲ្យចំជាងនេះទៅទៀតគឺសូម្បីតែមុនពេលដែល តាទិត្យ មកដល់ ដោយត្រឹមតែពេលដែលអ្នកក្រោមឱវាទរបស់គាត់បានមកដល់ក្នុងតំបន់នេះ ការដើរហើររបស់ប្រជាជនត្រូវបានគេរឹតបណ្តឹង។ ច្បាប់របស់ពួកគេដែលកំណត់មកលើយើងគឺ ឥតរ៉ឹងខ្លាំងណាស់"] *កត់សំគាល់ថា* សាក្សីពីដំបូងនិយាយថា ពេលដែល តាប៉ែត គ្រប់គ្រង គាត់អាចទៅលេងសហការណ៍របស់គាត់បាន *សូមមើល* ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦៤ KH 01122407-08។ ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.២០ KH 01394973 ["ស៖ [...] សុំទៅលេងផ្ទះ [...] បានទ? ឆ.២០៖ សុំធ្លាប់សុំដែរ ប៉ុន្តែគេមិនឲ្យយើងទេ"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦៦ KH 01110499 [សាក្សីបានចាប់ផ្តើមធ្វើការនៅចំនប់កង្ហត នៅពេលដែល រ៉ាញ ធ្វើជា

យើងរំដោះហើយសុខសប្បាយទេ។ យើងមិនចាំបាច់ទៅលេងឪពុកម្តាយទេ គាត់សុខសប្បាយហើយ"[1655]។

467. ដោយការសង្ខេបពីបទពិសោធន៍ទូទៅរបស់គាត់ក្នុងឋានៈជាកម្មករម្នាក់នៅទំនប់កង្ហត ឈឿង ប៊ាន បានថ្លែងថា៖ "ក្រោមការគ្រប់គ្រងរបស់ តាទិត្យ ប៉ុន្តែបើនិយាយឲ្យចំជាងនេះទៅទៀតគឺសូម្បីតែមុនពេល ដែលតាទិត្យមកដល់ ដោយត្រឹមតែពេលដែលអ្នកក្រោមឱវាទរបស់គាត់បានមកដល់ក្នុងតំបន់នេះ ការដើរហើររបស់ប្រជាជនត្រូវបានគេរឹតបន្តឹង។ ច្បាប់របស់ពួកគេដែលកំណត់មកលើយើងគឺ តឹងរ៉ឹងខ្លាំងណាស់"[1656]។

468. **យ៉ីម ទិត្យ** អ្នកនៅក្រោមបង្គាប់របស់គាត់ និង ពួកអ្នកដែលគាត់បានសហការណ៍ជាមួយ បានអនុវត្តសិទ្ធិមានកម្មសិទ្ធិលើកម្លាំងពលកម្មដែលគ្មានការស្ម័គ្រចិត្ត និងគ្មានការតបស្នង។ អាជ្ញាធរបានកម្រិតសេរីភាពជាមូលដ្ឋានទាំងអស់របស់ពួកកម្មករទាំងឡាយនៅទីតាំងនេះ ហើយបានបង្ខំពួកគាត់ឲ្យធ្វើការងារនៅក្រោមលក្ខខណ្ឌដ៏តឹងតែងដើម្បីជាផលប្រយោជន៍ដល់របបនោះ។

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង</u>

469. ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ កម្មាភិបាលភូមិភាគពាយ័ព្យ និងពលករនៅទីតាំងនេះត្រូវបានចាប់ខ្លួន និងដាក់ក្នុងមន្ទីរឃុំឃាំងនៅខាងក្រៅទីតាំង។ តាវ៉ាញ អនុរបស់គាត់គឺតាព្ធុ តាយ៉ាន់ និង តាប៉ែត គឺជាពួកកម្មាភិបាលភូមិភាគពាយ័ព្យនៅក្នុងគណៈតំបន់១ ឬ ស្រុកសង្កែ ដែលបានធ្វើការនៅទំនប់កង្ហត។ សាក្សីនានាបានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា កម្មាភិបាលភូមិភាគនិរតីបានចាប់ តាវ៉ាញ នៅពេលដែលគាត់កំពុងធ្វើការ

គណៈតំបន់រហូតដល់ប្រហែលជាប្រាំមួយខែមុនចុងរបបកម្ពុជាប្រជាធិបតេយ្យ៖ "ស៖ តើលោកដែលឃើញអ្នកដែលគេលួចទៅផ្ទះទេ? ឆ.៦៦៖ មាន"]។ ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.១ KH 01110160 [សាក្សី ត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅផ្ទះដើម្បីចូលឆ្នាំថ្មីឆ្នាំខ្មែរ ក្នុងឆ្នាំ១៩៧៨]។

[1655] ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.២០ KH 01394973។

[1656] ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៥២ KH 01132087។ *សូមមើលផងដែរ* ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៣៦, ១៣៩ KH 01110196-97 ["ក្រោមការគ្រប់គ្រងរបស់ តាទិត្យ សេរីភាពក្នុងការដើរហើររបស់យើងត្រូវបានរឹតបន្តឹង ដោយសារតែគេខ្លាចថា យើងរួមគ្នារៀបចំផែនការប្រឆាំងពួកគេ"។ ក្រោមការគ្រប់គ្រងរបស់ តាវ៉ាញ "គេឲ្យយើងទៅ"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.២១ KH 01196533។

នៅទីតាំងនោះ[1657]។ រីឯ តាព្រុំ សាក្សី ឈឿង ប៊ាន បានឮថាមានទាហានប្រាំនាក់បានប្រាប់ តាព្រុំ ថា "អង្គការផ្ទាក់លើឲ្យគាត់ទៅរៀនសូត្រ" និងបានឃើញពួកគេដឹកគាត់ចេញទៅ[1658]។ តាព្រុំ ពីដំបូង ត្រូវបានទម្លាក់តំណែងឲ្យធ្វើការនៅឯទ្វារបង្ហូរទឹកជាមួយនឹង ឈឿង ប៊ាន[1659]។ ស្រដៀងគ្នាទៅនឹង តាព្រុំ ដែរ ឈឿង ប៊ាន បានថ្លែងថា តាយ៉ាន់ ដែលស្ថិតនៅក្នុងគណៈស្រុកសង្កែ ត្រូវបាន "គេទម្លាក់ពីតំណែង ហើយឲ្យមកធ្វើការនៅទ្វារទឹកជាមួយខ្ញុំ"[1660]។ ឯកសារដែលនៅសេសសល់ពីស-២១ កត់ត្រាកាលបរិច្ឆេទចូលរបស់ តាវ៉ាញ តាព្រុំ និង តាយ៉ាន់ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧ ថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៧៧ និង ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧៧ រៀងៗគ្នា[1661]។ តាប៉ែត ដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម បានថ្លែងថា៖ "ដក បញ្ឈប់ឲ្យធ្វើការងារ [...] ចាប់ដាក់គុកនៅកំពង់ស្ពឺ"[1662]។ គាត់បាននិយាយថា ប្រហែលជាមួយ ឬ ពីរខែក្រោយពីការចាប់ខ្លួនរបស់ តាញ៊ីម គឺ តាម៉ុក និង អ្នកនៅក្រោមបង្គាប់របស់គាត់ដែលបានចាប់ខ្លួន និងឃុំឃាំងគាត់ និងប្រពន្ធរបស់គាត់នៅទីនោះ រហូតដល់ពួកវៀតណាមចូលមកដល់[1663]។ សាក្សី សឿន ម៉ត បានដឹង

[1657] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934384-85 ["តាវ៉ាញ [...] ឲ្យដឹកនាំកងចល័តប្រឆាំងនឹងអង្គការ តែដោយសារតែពួកនិរតី ដឹងរឿងនេះ គេក៏ចាប់ តាវ៉ាញ"]។ ឯកសារ D123/1/1.3a បទសម្ភាសន៍ ហ្ជន ជឿម ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា KH 00923711-12។ ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហ្ជន ជឿម ឆ.២៥ KH 00951906។ *សូមមើលផងដែរ* ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.២០ KH 01205203 ["ពេលពួកនិរតីចូលមក គឺគេចាប់ [...] គណៈតំបន់១ មាន [...] [ទ្រឹង]វ៉ាញ"]។ ឯកសារ D1.3.11.55 កំណត់ហេតុនៃកិច្ចសម្ភាន៍ ហាន់ ធី ដោយ ក.ស.ព EN 00221582 ["តាប៉ែត បានចាប់ តាវ៉ាញ"]។

[1658] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២៧, ៣០ KH 01110177។

[1659] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៣ KH 01110178។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៥ KH 01132072។ ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោសស-២១ ដោយ ក.ស.ច.ស លេខរៀង 6273 EN 01222575។

[1660] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២០ KH 01122398។

[1661] ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោសស-២១ ដោយ ក.ស.ច.ស លេខរៀង 913 EN 01222369 [ជា ហ្ជន ហៅ វ៉ាញ លេខាតំបន់១ ២០-មិថុនា-៧៧] លេខរៀង 6273 EN 01222575 [ម៉ុល សុត ហៅ ព្រុំ សាងសង់ទ្វារទឹកនៅតំបន់១ ២៩-តុលា-៧៧] លេខរៀង 11667 EN 01222811 [ទេព រ៉ុម (ទេព រ៉ុ) ហៅ យ៉ន កម្មាភិបាលមើលត្រាក់ទ័រ ទំនប់ទឹកតំបន់១ (ប្រធានទំនប់ទឹកតំបន់១) ១២-កញ្ញា-៧៧]។

[1662] ឯកសារ D34.1.9 បទសម្ភាន៍ ហេង ទាវ ហៅ តាប៉ែត ដោយ ស្ទីវ ហេដឌ័រ KH 00965615-16។

[1663] ឯកសារ D34.1.9 បទសម្ភាន៍ ហេង ទាវ ហៅ តាប៉ែត ដោយ ស្ទីវ ហេដឌ័រ KH 00965622 ["អាម៉ុក ហើយនិងកងការពារ វា ហើយនិងទាហានមួយឡានទៅបង្ខំចាប់អ្ងសប្រពន្ធខ្ញុំដាក់ឡានមក ហើយទាញដៃខ្ញុំឡើងឡានវាមកអង្គុយជាមួយវា។ [...] យើងអត់កាំភ្លើង ដល់អ៊ីចឹងជិះមកជាមួយវា"] KH 00965621 ["ទាំងប្តីទាំងប្រពន្ធយកទៅដាក់ហ្នឹង។ ហើយដល់អ៊ីចឹងទៅដល់

ថា **យ៉ីម ទិត្យ** និង/ឬ អ្នកនៅក្រោមបង្គាប់របស់គាត់បានប្រកាសជាសាធារណៈនៅឯទំនប់កង្ហត នៅពាក់កណ្តាលឆ្នាំ១៩៧៨ ទៅចុងឆ្នាំ១៩៧៨ ថា តាវ៉ាញ និង តាប៉ែត គឺជា "ជនក្បត់" និងបាន និយាយថា ពួកគាត់បានពិភាក្សាគ្នាពីការចាប់ខ្លួន[1664]។

470. សុខ ជាតិ ដែលបានធ្វើការនៅទំនប់រហូតដល់វាត្រូវបានគេជួសជុល បានថ្លែងថា៖ "យ៉ាងហោចណាស់ក្នុង១ថ្ងៃមានមនុស្ស៤០នាក់ ត្រូវបានចាប់ខ្លួន"[1665]។ ការណ៍នេះរួមទាំងអ្នកប្រព្រឹត្តកំហុសស្រាល ដែលបានធ្វើឲ្យបាក់បែកឧបករណ៍ធ្វើការងារ សាក្សី ណង នី ដែលបានចូលរួមចំណែកនៅក្នុងការ "ខុសមាត់កនឹងអង្គការគេ" និងសាក្សី ទៀប ទិត្យ ដែលបាន "ប្រឆាំងនឹងបក្ស" ដោយសារតែគាត់បានពោលគ្នញ្ញែរអំពីការងារ[1666]។ ពួកអ្នកដែលត្រូវបានចាប់ខ្លួន ត្រូវបាន "ចោទថាខ្ជាំងដែរ"[1667]។ ណំ ភន ដែលបានធ្វើការនៅទីកន្លែងនោះរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ បានសង្កេត

រៀតណាមចូលមក"] KH 00965647 [នៅពេលដែល តាញ៉ឹម ត្រូវបានចាប់ខ្លួន ក្មួនប្រុសរបស់គាត់បានទូរស័ព្ទទៅភ្នំពេញ "ប្រហែលជាក្នុងខែហ្នឹងដែរ ខែ៨ហ្នឹង"] KH 00965615 ["ដល់ខែ៩ ខែ១០ ឆ្នាំប៉ែត -- ឆ្នាំ៧៨ ត្រូវចាប់យកមកដាក់គុក"] (*ក្ត់សម្គាល់ថា* តាប៉ែត នៅចាំបានថា តាញ៉ឹម ត្រូវបានចាប់ខ្លួននៅក្រោយកាលបរិច្ឆេទនៃចម្លើយសារភាពនៅស-២១ របស់ តាញ៉ឹម) ។ *សូមមើលផងដែរ* ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ីា ឆ.២ KH 00960662-63។

[1664] ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀន ម៉ត ឆ.១៧, ៤៤, ៤៩ KH 01155823, 27-28 ["ក្រុមពួកតាទិត្យ ចោទប្រកាន់ពួកតា វ៉ាញ តាប៉ែត និងតាកៅ ថាជាជនក្បត់ ដោយចោទថា ពួកគេប្រុងប្រៃក្លាយនៅក្នុងកងចល័ត ទៅជាទ័ព។ [...] ខ្ញុំដឹងរឿងនេះ ដោយសារ [...] ប្រកាសជាសាធារណៈនៅក្នុងកិច្ចប្រជុំ។ [...] ខ្ញុំគ្រាន់តែដឹងថា កិច្ចប្រជុំនោះ ត្រូវបានធ្វើឡើងនៅក្រោមការគ្រប់គ្រងរបស់ តាទិត្យ។ ហើយខ្ញុំមិនបានឃើញអ្នកប្រកាសទេ ព្រោះនៅពេលនោះ មានមនុស្សច្រើនរាប់ពាន់នាក់បានចូលរួម"] ឆ.៦៣ KH 01155830 ["គេនិយាយអំពីការចាប់ខ្លួនកម្មាភិបាលទាំងនោះ"] ឆ.២១-២២ KH 01155824។ *សូមមើលផងដែរ* ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៣០ KH 00934389។

[1665] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535។

[1666] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535 ["ខ្ញុំឃើញគេចាប់មនុស្ស សូម្បីតែខុសបន្តិចបន្តួច ដូចជាធ្វើឲ្យបាក់ដងចប ដងរ៉ែក"]។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934384-85 ["ពួកនិរតីបានចូលមកដល់ គេក៏ចោទខ្ញុំថា ខ្ញុំខុសមាត់កនឹងអង្គការគេ។ [...] ហើយគេក៏ចាប់ខ្ញុំ និងម្នាក់ទៀតនៅកងចល័តដែរ គាត់ឈ្មោះ ផាន"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៧ KH 00960689 ["ពេលដែលខ្ញុំគ្នញ្ញែរពីការងារនោះ ពួកឈ្លបគេស្តាប់ឮខ្ញុំនិយាយ។ [...] តា ព្រ [...] និយាយថា ខ្ញុំប្រឆាំងនឹងបក្ស"]។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១២, ៤១ KH 01132053, 56។ *សូមមើលផងដែរ* ឯកសារ D219/748 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ងៀន ឆ.៨៥, ៩០ KH 01235368-69។

[1667] ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535។

ឃើញថា "គេចាប់មនុស្ស មុនពេលគាត់ [**យ៉ីម ទិត្យ**] មក ឬក្រោយពេលគាត់ [**យ៉ីម ទិត្យ**] មកពីរបីថ្ងៃ"[1668]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

471. ជាលទ្ធផលនៃភាពអស់កម្លាំង ការអត់ឃ្លាន ជំងឺផ្សេងៗ និងកង្វះខាតការព្យាបាលខាងវិជ្ជសាស្ត្រ ពលករជាច្រើននាក់បានស្លាប់នៅទីតាំងពលកម្មដោយបង្ខំនៅទំនប់កង្ហតនេះ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1669]។ នៅក្នុងករណីខ្លះ ពួកអ្នកដែលត្រូវបានបញ្ជូនទៅកាន់មន្ទីរពេទ្យមិនដែលបានឃើញត្រឡប់មកវិញទេ[1670]។ ទោះបីជាចំនួនជាក់លាក់នៃការស្លាប់ មិនអាចបញ្ជាក់បានយ៉ាងណាក៏ដោយ ក៏ភ័ស្តុតាងនៅក្នុងសំណុំរឿងបានលើកឡើងថា វាមានចំនួនច្រើន។ យ៉ុន ឃឿន ដែលត្រូវបានបញ្ជូនដោយពួកកម្មាភិបាលភូមិភាគនិរតី ទៅកាន់ទីតាំងនេះ បានប៉ាន់ប្រមាណថា "មានអ្នកស្លាប់រាប់រយនាក់"[1671]។ ណាំ ភន ដែលបានធ្វើការនៅ

[1668] ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១១៥ KH 01110505 ["ស៖ តើលោកដែលឃើញគេចាប់មនុស្ស ក្រោយពេល យ៉ីម ទិត ចុះមកទេ? ឆ.១១៥៖ ដែលមាន គេចាប់មនុស្ស មុនពេលគាត់មក ឬក្រោយពេលគាត់មកពីរបីថ្ងៃ។ ខ្ញុំពិបាកនិយាយថាគាត់ជាអ្នកបញ្ជាឬក៏អត់ណាស់"]។

[1669] *សូមមើល ឧទាហរណ៍* ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១៤, ១៦ KH 01121667 ["[គេ]ឲ្យហូបតែបបរ១ រាវ ដូច្នេះស្ថានភាពអ្នកជំងឺ [...] ក៏ស្លាប់។ [...] អ្នកដែលស្លាប់ដោយសារការដាច់បាយ ឈឺ និងធ្វើការហួសកម្លាំងនៅទំនប់កង្ហត"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១២៤ KH 01110194 ["មានប្រជាជន [...] ស្លាប់ដោយសារដាច់ពោះ"] ឆ.១២៥ KH 01110194 ["ខ្ញុំឃើញក្មេងបីនាក់ ដែលក្នុងនោះរួមមានក្មេងប្រុសពីរនាក់ និងក្មេងស្រីម្នាក់ អាយុចន្លោះ១០ ទៅ១៥ឆ្នាំធ្លាក់ខ្លួនឈឺ ហើយពួកគេបានស្លាប់ដោយសារតែគ្មានថ្នាំ"]។ *សូមមើលផងដែរ* ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០៨, ១២៧-១២៨ KH 01110189-90, 94។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.១ KH 01110160 [សាក្សីរូបនេះមិនបានកត់សម្គាល់ពីការស្លាប់ដោយដាច់ពោះនៅទំនប់កង្ហតនោះទេ]។

[1670] ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៧០-៧១ KH 01110500 ["មានឈឺ [...] លក្ខណៈរាងកាយ [...] គេសែងយកទៅពេទ្យនៅឆ្ងាយពីកន្លែងខ្ញុំដែរ ហើយយកទៅពេទ្យទៅគឺមិនឃើញមកវិញទេ"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១៥ KH 01121667 ["មិនមានមន្ទីរពេទ្យទេ"]។

[1671] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១៦ KH 01121667 ["ខ្ញុំស្មានមើលទៅអ្នកដែលស្លាប់ដោយសារការដាច់បាយ ឈឺ និងធ្វើការហួសកម្លាំងនៅទំនប់កង្ហត មានស្លាប់រាប់រយនាក់"]។ ការប៉ាន់ស្មានរបស់សាក្សីរូបនេះអាចនឹងអនុវត្តនៅមួយរយៈពេលដែលគាត់នៅឯទំនប់ មុនពេលចាប់ខ្លួនតាវ៉ាញ រហូតដល់ទំនប់បាក់ភ្លាមៗ ឬក៏វាអាចនឹងអនុវត្តចំពោះរយៈពេលមួយក្រោយថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ នៅពេលដែលគាត់អាយុបាន១៨ឆ្នាំ។ *សូមមើល* ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន KH 01121663 ឆ.៤-៧, ៣៥ KH 01121664-65, 71។

ទីនោះនៅពេលដែល តាវ៉ាញ នៅជាគណៈតំបន់រហូតដល់ប្រមាណជាខែកក្កដា ឆ្នាំ១៩៧៨ បាននិយាយថា "គេសែងទៅមួយថ្ងៃ ៥ ទៅ ១០នាក់ រាល់ថ្ងៃ"[1672]។ សោម វណ្ណា ដែលបានធ្វើការនៅទំនប់កង្ហតចំនួនពីរខែចាប់តាំងពីប្រមាណជា ខែកក្កដា ឆ្នាំ១៩៧៧ បាននិយាយថា "ស្ទើរតែរាល់ថ្ងៃអ្នកដែលទទួលម្ហូបអាហារមិនបានគ្រប់គ្រាន់ ហើយប្រឹងធ្វើការធ្ងន់ តែងតែដួលស្លាប់នៅនឹងកន្លែងធ្វើការ"[1673]។ វ៉ាន់ ជា ដែលបាននៅទីតាំងនោះ ចាប់តាំងពីពាក់កណ្តាល ទៅចុងឆ្នាំ១៩៧៨ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ បាននិយាយថា កងចល័តរបស់គាត់មាន "មនុស្សជាង១០០នាក់" ហើយ "មានមនុស្សស្លាប់ដោយសារហូបចុកមិនគ្រប់គ្រាន់ នៅក្នុងកងរបស់ខ្ញុំ រៀងរាល់សប្តាហ៍គឺមានមនុស្សម្នាក់ ឬក៏ពីរនាក់ស្លាប់"[1674]។ ភ័ស្តុតាងទាំងនេះបង្ហាញថា **យ៉ីម ទិញ្ញ** បានទទួលស្គាល់ពីហានិភ័យដែលថា ការស្លាប់ទាំងនេះនឹងមានកើតឡើង។ ពីការធ្វើទស្សនកិច្ចជាញឹកញាប់របស់គាត់ទៅកាន់ទីកន្លែងនេះ វាច្បាស់ណាស់ដែលថា គាត់បានដឹងពីលក្ខខណ្ឌនានាដែលមិនមានសុខភាព និងពីភាសាដែលគាត់បានប្រើប្រាស់ដើម្បីពិពណ៌នាទីតាំងនោះ - "សមរភូមិក្តៅ" - ដែលមានន័យលាក់បាំងថា ការទទួលស្គាល់នៃចំនួនអ្នកស្លាប់ដែលជាពលីកម្មចាំបាច់មួយ[1675]។

472. ពលករដែលធ្វើការមិនបានគ្រប់ចំនួនតាមការកំណត់ ត្រូវបានសម្លាប់ចោលដោយចេតនានៅទីតាំងនេះ។ ដើមបណ្តឹងរដ្ឋប្បវេណី វ៉ាន់ ជា បាននិយាយថា គាត់បានឃើញរឿងនេះកើតឡើងជាញឹកញាប់ នៅចុងឆ្នាំ១៩៧៨ រួមមាន បុរសពីរនាក់ពីកងរបស់គាត់ដែលត្រូវបានសម្លាប់ដោយប្រធានកងនៅជើងទំនប់កង្ហត[1676]។

473. កម្មាភិបាលភូមិភាគនិរតី និងអ្នកនៅក្រោមបង្គាប់បានសម្លាប់ស្ត្រីនៅទីតាំងនោះ រួមទាំងអ្នកខ្លះមានផ្ទៃពោះផង។ នៅយប់មួយនោះ យ៉ុន ឃឿន បានឃើញស្ត្រីប្រាំបីនាក់ ពីរនាក់ក្នុងចំណោមនោះមាន

[1672] ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៧២ KH 01110500។

[1673] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។

[1674] ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.២, ៩ KH 01121734, 36។

[1675] ឯកសារ D219/747 កំណត់ហេតុស្តាប់ចម្លើយ សយ អ៊ែម ឆ.៥៩ KH 01235348។ *សូមមើលផងដែរ* ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.១៤ KH 01117284-85។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ សៀន ម៉ត ឆ.៣៥ KH 01155826។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៤១ KH 01110197-98។

[1676] ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.៤១-៤៣ KH 01121702-903។ ឯកសារ D219/429 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ វ៉ាន់ ជា KH 01484975។ *សូមមើលផងដែរ* ឯកសារ D219/933 កំណត់ហេតុស្តាប់ចម្លើយ ព្រិន អន ឆ.២៨ KH 01396468។

ផ្ទៃពោះ ត្រូវបានគេសម្លាប់ ហើយកប់នៅក្រោមសសរនៃផ្ទះសសរ ៤០[1677]។ គាត់[ស្ត្រី]បានប្រាប់អ្នកស្ទើបអង្កេតម្នាក់នៃ ក.ស.ច.ស ថា នៅក្រោមការដឹកនាំរបស់ភូមិភាគនិរតី "មានយោធា [ភូមិភាគពាយ័ព្យ] ម្នាក់ដែលស្គាល់ខ្ញុំច្បាស់ គាត់បានប្រាប់ខ្ញុំអំពីគម្រោងដែលគេសម្លាប់មនុស្សនៅក្នុងល្ហាចនោះ" ហើយមិនទៅជិតផ្ទះសសរ ៤០ នោះទេ[1678]។ វ៉ាន់ ជា បានឃើញការសម្លាប់ស្ត្រីមានផ្ទៃពោះម្នាក់ជាសាធារណៈទាំងកណ្តាលថ្ងៃ ដែលត្រូវបានរុញ ចូលទៅក្នុងរណ្តៅមួយទាំងរស់ ដោយយោធាភូមិភាគនិរតីបីនាក់ បន្ទាប់មកយកប្រដាប់ស្នូចមួយ ទម្លាក់សសរមួយដើមពីលើជនរងគ្រោះនៅចំនប់ទ្វារទឹកកង្ហត[1679]។

474. ប្រជាជនស៊ីវិលផ្សេងៗទៀតដែលត្រូវបានសម្លាប់ រួមមាន មនុស្សពីបីទៅប្រាំនាក់មកពីទួលម្ទេស និង ជើងទឹង នៅខែសីហា ឬខែកញ្ញា ឆ្នាំ១៩៧៧[1680]។ ឈឿង ប៊ាន បានឃើញ តាសាម៉ន នាំមនុស្សទាំងនេះពីផ្ទះសសរ ៤០ ទៅកាន់វាលស្ពង់ ដែលមានចម្ងាយមួយគីឡូម៉ែត្រខាងកើតចំនប់កង្ហត[1681]។ បន្ទាប់មក គាត់បានឃើញ តាសាម៉ន វិលត្រឡប់មកវិញដោយមានប្រម៉ាត់មកជាមួយ

[1677] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១៧ KH 01121667-68។

[1678] ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.១៨-១៩ KH 01121668។

[1679] ឯកសារ D219/425 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.៣៦-៣៩ KH 01121701-02 ["បាទ ខ្ញុំឃើញគេយកមនុស្សស្ត្រីមានផ្ទៃពោះយកទៅដាក់នៅពីក្រោមជើងសសរទំនប់ទ្វារទឹក [...]។ ខ្ញុំឃើញព្រឹត្តិការណ៍នេះដោយផ្ទាល់ភ្នែក វាកើតនៅវេលាម៉ោងដប់ ឬដប់មួយពេលព្រឹកនៅកន្លែងទ្វារទឹក។ ខ្ញុំឃើញស្ត្រីមានផ្ទៃពោះតែម្នាក់ទេពេលនោះ [...]។ មានយោធាបីនាក់ កាន់កាំភ្លើងអាកា ៤៧ ជាអ្នករុញស្ត្រីមានផ្ទៃពោះទាំងរស់ចូលទៅក្នុងណ្តៅ បន្ទាប់មកគេមានសន្ទូចយោងសសរទម្លាក់ទម្លាក់ចូលទៅក្នុងរណ្តៅពីលើស្ត្រីនោះ។ [...] ខ្ញុំនៅចម្ងាយប្រហែលជា ៣០ម៉ែត្រពីកន្លែងកើតហេតុ។ ពេលគេទម្លាក់ស្ត្រីទៅក្នុងរណ្តៅគេធ្វើដោយចំហរ[...] ដូច្នេះពួកចល័តដែលធ្វើការកែ្ចរនោះឃើញព្រឹត្តិការណ៍នេះទាំងអស់គ្នា។[...] ពួកយោធាទាំងនោះគឺពួកនិរតី"]។

[1680] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៧៦-៧៧ KH 01122410 ["ឆ.៧៦៖ [...] ព្រឹត្តិការណ៍នេះកើតឡើងនៅក្នុងខែសីហា ឬកញ្ញា ឆ្នាំ១៩៧៧ នៅរមូរភ្លៀងធ្លាក់។ [...] ស៖ តើលោកដឹងថា អ្នកទាំងនេះមកពីទួលម្ទេស និងជើងទឹង ដោយរបៀបណា? ឆ.៧៧៖ [...] ដោយសារតែខ្ញុំឮពីសមាជិកនៅក្នុងកងនារី"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០៨ KH 01110189-90 ["ប្រជាជនត្រូវបានគេចាប់ពីជើងទេញ និងទួលម្ទេស ហើយត្រូវបានឃុំខ្លួននៅ ឯ "ផ្ទះសសរ ៤០" [...]។ មានមនុស្សចន្លោះពីបី ទៅប្រាំនាក់ ដែលត្រូវបានគេចាប់ឃុំ [...]។ ហេតុការណ៍នេះ បានកើតឡើងនៅចុងឆ្នាំ១៩៧៧"]។

[1681] ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៧៦ KH 01122410 ["ខ្ញុំឃើញតាសាម៉ន បណ្តើរមនុស្សយកទៅសម្លាប់ មនុស្សទាំងនេះត្រូវបានឈ្លបតំបន់ចាប់យកមកឲ្យតាសាម៉ន [...] បណ្តើរ[លើស្ពាន]យកទៅសម្លាប់នៅវាល ឬក៏ចម្ការស្ពង់ [...] ស្ថិតនៅខាងកើតទំនប់កង្ហតប្រហែលជា១គីឡូម៉ែត្រ"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០៨ KH 01110189-90។ ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦២ KH 01132090 ["ពីផ្ទះសសរ ៤០ ទៅស្ពង់ត្រូវដើរប្រហែលជា ១៥នាទី"]។

ផងដែរ[1682]។ ឈឿង ប៊ាន បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា នៅពេលដែលគាត់បានទៅកាន់ វាលស្លង់ គាត់ "បានឃើញផ្នឹងមនុស្ស និងសាកសពមនុស្សដែលគេទើបបញ្ចុះថ្មីៗ"[1683]។

475. **យ៉ីម ទិត្យ** និង អ្នកនៅក្រោមបង្គាប់របស់គាត់ បានផ្តោតគោលដៅទៅលើពួកកម្មាភិបាលភូមិភាគ ពាយ័ព្យ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេដែលបានធ្វើការនៅទីតាំងនេះ ក៏ដូចជាក្រុមគ្រួសារ របស់ពួកគេ ហើយអ្នកទាំងនេះជាច្រើនត្រូវបានសម្លាប់ចោល។ តាវ៉ាញ តាព្ធុ និង តាយ៉ន ត្រូវបាន ចាប់ខ្លួន និងបញ្ជូនទៅកាន់ ស-២១ យោងតាមកំណត់ត្រាគុកដែលនៅសេសសល់ ដោយមិនមាន ភ័ស្តុតាងថា ពួកគាត់នៅរស់រានមានជីវិតនោះទេ[1684]។ អ្នកនៅក្រោមបង្គាប់របស់ តាប៉ែត នៅ ទីតាំងនេះក៏បាន "ចោសសម្អាតខ្ទេចហើយ" ផងដែរ យោងតាមព័ត៌មានដែល តាប៉ែត បានទទួលពី តាម៉ុក[1685]។ ណង នី បានថ្លែងថា "កម្មាភិបាលពាយ័ព្យខ្លះ [...] គេយកទៅសម្លាប់នៅ [ភូមិ] ចាយ ដំរ៉ាំ" បន្ទាប់ពីពួកកម្មាភិបាលភូមិភាគនិរតីកាន់កាប់តំបន់១ ទាំងស្រុង[1686]។

476. "គេរៀបចំធ្វើការចាប់ចង ដោយរបៀបស្ងាត់ល្អណាស់"[1687]។ ដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា សន្ធត ការទទួលខុសត្រូវលើ "មនុស្សជាច្រើននាក់" ដែលបានបាត់ខ្លួន[1688] ទៅលើ **យ៉ីម ទិត្យ**។ ក្នុង រយៈកាលពីរខែដែលគាត់បានធ្វើការនៅឯទីតាំងនេះ បន្ទាប់ពីទំនប់បាក់ៃ "បើឃើញ តាទិត្យ មកគឺ

[1682] ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០៨ KH 01110189-90 ["ខ្ញុំមិនដឹងថា ជា តា សាម៉ន ឬ អ្នកផ្សេងទៀតទេ ដែលជាអ្នកសម្លាប់ពួកគេ។ ខ្ញុំគ្រាន់តែឃើញ តា សាម៉ន ដើរត្រឡប់មកវិញ ដោយមានកាន់ប្រមាត់មនុស្សមក ជាមួយ"]។

[1683] ឯកសារ D219/465 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦២ KH 01132090។

[1684] ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោសស-២១ ដោយ ក.ស.ច.ស លេខរៀង 913 EN 01222369 លេខរៀង 6273 EN 01222575 លេខរៀង 11667 EN 01222811។

[1685] ឯកសារ D1.3.11.15 បទសម្ភាន៍ ហេង ទាវ ហៅ តាប៉ែត ដោយ ស្ទីវ ហេដឌ័រ KH 00388313 ["តាម៉ុក ហ្ម៊ីងប្រាប់ខ្ញុំថា អា ប៉ុន្មានទាក់ដែលនៅហ្ម៊ីង កង្ហត ម្ពុំកូនចៅបងឯងហ្ម៊ីង ឥឡូវហ្ម៊ីងចោសសម្អាតខ្ទេចហើយ។ ប្រាប់ខ្ញុំអ៊ីចឹង។ [...] ខ្ញុំថានិយាយមែន និយាយលែងហ្ម៊ីង? [...] និយាយមែនទ្រែន។ ដល់ប្រហែលស្អែកឡើងទៀត មានអាម្នាក់មករាយការណ៍ប្រាប់ខ្ញុំថា ឥឡូវអ៊ីចឹង ឥឡូវឃើញអ៊ីចឹងៗគេសម្លាប់អស់ហើយ [...] នៅដំណាក់រ៉ាងជិតប៉ៃលិន"]។

[1686] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៤, ៣០ KH 00934385, 89។

[1687] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.១៤ KH 01080875។ *សូមមើលផងដែរ* ឯកសារ D219/946 កំណត់ហេតុស្តាប់ចម្លើយ ឡៅ កង ឆ.២៨ KH 01415414។

[1688] ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៤ KH 01032219-20។

ដឹងតែបាត់ខ្លួនមនុស្សហើយ"[1689]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ និងសាក្សីម្នាក់ ដែលត្រូវបានស្តាប់ចម្លើយ នៅចងចាំបានថា សហការីដែលនៅក្នុងកងជាមួយគ្នា ត្រូវបានបាត់ខ្លួន។ វ៉ាន់ ជា បានថ្លែងថា "នៅក្នុងកងរបស់ខ្ញុំគឺមានមនុស្សពី ១០ ទៅ២០នាក់ [...] ទៅបាត់រហូត"[1690]។ រាជ្យ សារ៉ន បានស្គាល់មនុស្សម្នាក់នៅក្នុងកងចល័តរបស់គាត់ ដែលត្រូវបានចោទប្រកាន់ថាជាកូនស្រីរបស់នាយទុនមួយរូប ហើយត្រូវបានបញ្ជូន "ទៅរៀនសូត្រ" ដែលពីនោះមក មិនដែលឃើញគាត់វិលត្រឡប់វិញទេ[1691]។ កិច្ចប្រជុំស្វ័យទិតៀនត្រូវបានធ្វើឡើង ហើយយោងទៅតាម សោម វណ្ណា "បើបុគ្គលណានៅតែបន្តទម្រន់ពីការងារ ពីរឬបីដង [...] បុគ្គលនោះ បាត់ខ្លួនរហូតមិនដឹងជាទៅទីណាទេ"[1692]។

ការធ្វើទុក្ខបុកម្នេញ

477. កម្មាភិបាលភូមិភាគនិរតីបានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនដែលបានរៀបរាប់ខាងលើ ដោយមានចេតនាផ្តោតគោលដៅទៅលើក្រុមជាក់លាក់ ពោលគឺពួកកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ នៅទីតាំងពលកម្មដោយបង្ខំទំនប់កង្ហតនេះ។ ក្រុមនេះ

[1689] ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៤៤ KH 01032224។ *សូមមើលផងដែរ* ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៤១ KH 01032223 ["តែបើឃើញមុខ តាទិត្យ នៅពេលថ្ងៃ យប់ឡើងគឺនឹងមានបាត់ខ្លួនមនុស្សហើយ"]។ ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.១ KH 01110160 [គេស្នើយុវជនដែលធ្វើការងារនៅឯទំនប់កង្ហតឲ្យទៅប្រជុំ ហើយយុវជនទាំងនោះ មិនដែលវិលត្រឡប់មកវិញឡើយ]។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.៣៨ KH 01121672 ["អ្នកដែលគេចាប់នោះមិនដែលឃើញត្រឡប់មកវិញទេ"]។ ឯកសារ D219/747 កំណត់ហេតុស្តាប់ចម្លើយ សយ អ៊ែម ឆ.៥៩ KH 01235348 ["នៅកង្ហតហ្នឹង [...] គឺ[មានមនុស្ស]បាត់នៅកង្ហតហ្នឹងតែមិនដឹង មិនដឹងថាគេយកទៅទុកដាក់នៅឯណាក៏មិនដឹង"]។

[1690] ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ជា ឆ.១៥ KH 01121737 ["បាទ មានមនុស្សនៅក្នុងកងរបស់ខ្ញុំត្រូវបានចាប់ខ្លួន ហើយយកចេញទៅ។ ក្រោយមកខ្ញុំបានឃើញអ្នកខ្លះបានត្រឡប់មកវិញ អ្នកខ្លះបាត់រហូត។ ខ្ញុំមិនចាំឈ្មោះពួកគេទេ [...]។ នៅក្នុងកងរបស់ខ្ញុំគឺមានមនុស្សពី ១០ ទៅ២០នាក់ត្រូវបានចាប់ខ្លួនយកទៅបាត់រហូត"]។

[1691] ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.១ KH 01110160។ *សូមមើលផងដែរ* ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៦៣ KH 01196541។

[1692] ឯកសារ D219/239 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩ KH 01080874។ *សូមមើលផងដែរ* ឯកសារ D219/928 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ប៊ាន ឆ.៧៩ KH 01394979 ["ក្រោយពីកិច្ចប្រជុំទិតៀនស្វ័យទិតៀនរួច មិនមានរឿងអ្វីកើតឡើងនោះទេ។ ខ្ញុំដឹងថា ជួនកាលមានមនុស្សត្រូវបានគេផ្ញើរឲ្យទៅធ្វើការងារនៅកន្លែងផ្សេង ប៉ុន្តែខ្ញុំមិនដឹងថា មានរឿងអ្វីកើតឡើងចំពោះពួកគេទេ"]។

ត្រូវបានគេដាក់គោលដៅយ៉ាងជាក់លាក់ ដោយសារតែសមាជិកភាពនៃក្រុមនយោបាយមួយយ៉ាងពិតប្រាកដ ឬដោយការយល់ឃើញ។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

478. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចតទៅ ទាក់ទងនឹងទីតាំងពលកម្មដោយបង្ខំទ័ន្ទ១ និងទ័ន្ទ២ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[1694] ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងពួកកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ ព្រមទាំង អ្នកនៅក្រោមបង្គាប់របស់ពួកគេ ហើយនិង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។

ឃ. រោងចក្រស្ករសកំពង់គល់

i. សេចក្តីផ្តើម

479. ការដ្ឋានរោងចក្រស្ករសកំពង់គល់ ស្ថិតក្នុងស្រុកសង្កែ តំបន់ ១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងថិរវេលាពេញមួយរបបនេះ រោងចក្រនេះគឺជាទីតាំងថ្នាក់ភូមិភាគ ដែលបានចុះមកពិនិត្យ

[1693] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះមាន៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និង ការបាត់ខ្លួនដោយបង្ខំ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះ តាមរយៈ៖ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៩, ១១៨ខ។ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១, ២២iii។ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ១២, ១៣ខ។

[1694] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងទាក់ទងនឹងទីកន្លែងពលកម្មដោយបង្ខំទ័ន្ទ១ ទ័ន្ទ២ តែមួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំង ទ័ន្ទ១ ទ័ន្ទ២ ផង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់បង្កើតបានជាផ្នែកនៃប្រព័ន្ធមួយដែលមានការរៀបចំ ក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង ហើយការសម្លាប់នៅតាមទីតាំងនិមួយៗទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ីម ទិត្យ។

ដោយតំណាងគណៈភូមិភាគពាយ័ព្យ។ **យ៉ាម ទិត្យ** បានដឹកនាំកម្លាំងរបស់គាត់ដោយផ្ទាល់មកកាន់កាប់រោងចក្រនេះ។ ត្រឹមថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគពាយ័ព្យ ដែលមានឈ្មោះនៅក្នុងគណៈកម្មាធិការរោងចក្រ ត្រូវបានបោសសម្អាត។ បន្ទាប់មក **យ៉ាម ទិត្យ** បានតែងតាំង យ៉ាន មកពីខាងភូមិភាគនិរតីឲ្យធ្វើជាប្រធានរោងចក្រស្ករសនេះ។ តាំងពីដើមឆ្នាំរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ **យ៉ាម ទិត្យ** បានធ្វើជាអធិបតីក្នុងកិច្ចប្រជុំមួយនៅទីក្រុងបាត់ដំបង ជាមួយឆ្នាំការពាររោងចក្រស្ករសកំពង់គល់ ដែលក្នុងពេលនោះគាត់បានពិភាក្សាអំពីការការពារទីតាំងនេះ ពីការវាយប្រហារ ឬវិទ្ធង្សនារបស់វៀតណាម។ សំខាន់គឺ **យ៉ាម ទិត្យ** ត្រូវបានឧទ្ទេសនាមបង្ហាញខ្លួនគាត់ថា ជាប្រធានភូមិភាគពាយ័ព្យ ដែលជាការផ្ទុះបញ្ហាំងមួយអំពីអំណាចនយោបាយ និងការពិតដែលថា **យ៉ាម ទិត្យ** មានសិទ្ធិអំណាចកំពូលនៅក្នុងភូមិភាគនេះពេលដែល តាម៉ុក អវត្តមាន។

480. ក្នុងថិរវេលាដែល **យ៉ាម ទិត្យ** ទទួលខុសត្រូវចំពោះរោងចក្រស្ករសកំពង់គល់ យ៉ាន បានធ្វើជាអធិបតីក្នុងវិធីរៀបការដោយបង្ខំយ៉ាងហោចណាស់ចំនួនបីលើក ដែលមានគូស្រករពាក់ព័ន្ធចាប់ពី ១០ ទៅ ២០គូ ក្នុងមួយលើកៗ។ នៅចុងឆ្នាំ១៩៧៨ មានខ្មែរក្រោម និងកម្មករវៀតណាមយ៉ាងតិច ៣០នាក់ បានជាប់ឃុំឃាំងនៅរោងចក្រនេះ ហើយក្រោយមកពួកគេក៏ត្រូវបានគេដឹកយកទៅសម្លាប់ចោល ដែលនេះជាឧប្បត្តិហេតុមួយផ្ទុះបញ្ហាំងពីគោលនយោបាយនៃការសម្លាប់រង្គាល និងអំពើប្រល័យពូជសាសន៍យ៉ាងធំដែលបានអនុវត្តនៅក្នុងតំបន់នេះ[1695]។

481. ស.ច.ស.អ បានចោទប្រកាន់ **យ៉ាម ទិត្យ** ចំពោះឧក្រិដ្ឋកម្មដូចតទៅទាក់ទងនឹងរោងចក្រកំពង់គល់ៈ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ (ប្រឆាំងជនជាតិវៀតណាមនិងខ្មែរក្រោម) និងឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតគិតទុកជាមុន ក្រោមមាត្រា៥០១ និងមាត្រា៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[1696]។

[1695] ការកំណត់គោលដៅមនុស្សដែលគេចាត់ទុកថាពាក់ព័ន្ធជាមួយវៀតណាម នៅក្រោមសិទ្ធិអំណាចរបស់ យ៉ាម ទិត្យ ក៏បានកើតឡើងផងដែរនៅភូមិបុះខ្ទុរ មានចម្ងាយ ២គីឡូម៉ែត្រពីរោងចក្រស្ករស។ *សូមមើល* ឯកសារ D118/243 កំណត់ហេតុស្តាប់ចម្លើយ ឆាំ លុយ ឆ.១៤-១៥ KH 00990630-31។ ឯកសារ D219/274 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃរោងចក្រស្ករសកំពង់គល់ KH 01219955។ ឯកសារ D118/297 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH 01363588។ *សូមមើលផងដែរ* ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១១៩ KH 01304986។

[1696] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ាម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426546-47, 51, 60។

ii. ប្រតិបត្តិការ និងទីតាំង

482. រោងចក្រស្ករសកំពង់គល់ បានធ្វើប្រតិបត្តិការតាំងពីមុនការមកដល់របស់ពួកកម្មាភិបាលនិរតី។ សមាជិកម្នាក់នៃសមាជិកភូមិភាគពាយ័ព្យចុងក្រោយពីរនាក់ ក្នុងគណៈកម្មាធិការរោងចក្រនេះ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅ ស-២១ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧[1697] គឺពេលដែលកម្មាភិបាលភូមិភាគនិរតី បានចូលមកកាន់កាប់រោងចក្រស្ករសនេះរួចហើយ[1698]។ ពួកគេបានបន្តកាន់កាប់លើទី

[1697] ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី ៦៨៣៥ EN 01222597 [យ៉ា សេងហ្ម៉ៀង (យ៉ា សេងប៊ីង) *ហៅ* ណុប សមាជិករោងចក្រស្ករសភូមិភាគ នៅកំពង់គុល (សមាជិករោងចក្រស្ករស) ១១-១១-៧៧] ។ លឹម ទីម រៀបរាប់អំពីលំដាប់នៃការបោសសម្អាតគណៈកម្មាធិការដែល ណុប និងសមាជិកគណៈកម្មាធិការនេះម្នាក់ទៀត បានក្លាយជាមនុស្សចុងក្រោយដែលបានចាប់ខ្លួន។ *សូមមើល* ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨ KH 00951926-27 ។

[1698] ឯកសារ D219/656 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.៣ KH 01196559 [នៅឯរោងចក្រ "កម្មាភិបាលភូមិភាគនិរតីបានមកដល់ហើយ [...] ក្នុងឆ្នាំ១៩៧៧"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៦ KH 00951926 ["ប្រហែលជាក្នុងចុងឆ្នាំ១៩៧៧" យ៉ាន និង សារី មកពីភូមិភាគនិរតីបានក្លាយជាប្រធានរោងចក្រស្ករស]។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១១ KH 01058786 ["ពួកនិរតីមកដល់ទីនេះពីរដំណាក់កាល។ អ្នកដែលមកដំណាក់កាលទី១ គឺមាន [...] រ៉ ហៅ សារ៉ [...] និង យ៉ាន"]។ ឯកសារ D219/917 កំណត់ហេតុស្តាប់ចម្លើយ ជ ទូច ឆ.៩, ២២, ៣៤, ៤១-៤២ KH 01388675, 77, 78 [ក្នុងឆ្នាំ១៩៧៧ ១៩៧៨ កម្មករខ្លះមកពីភូមិភាគនិរតី ត្រូវបានបញ្ជូនទៅធ្វើការនៅរោងចក្រស្ករសនៅពេលដែល "ប្រធានភូមិភាគ គឺតាញ៉ីម"]។ *សូមមើលផងដែរ* ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.១៣ KH 01040120 ["ពួកវគ្គទី១ នៃពួកនិរតីមកដល់ប្រហែលជាក្នុងឆ្នាំ១៩៧៧ ឬ ៧៨ ប្រហែលជាមួយឆ្នាំក្រោយមក ទើបទី២ មកដល់"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១៧-១៨ KH 00951928 [លឹម ទិត្យ បាននិយាយទៅកាន់កងទ័ពមកពីរោងចក្រស្ករសថា "ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៨" នៅពេលដែល តាប៉ែត ក្នុងគណៈតំបន់១ ត្រូវបានចាប់ខ្លួន និងតាញ៉ីម មិនទាន់ត្រូវបានចាប់ខ្លួននៅឡើយ] *ដែលបានបញ្ជាក់បន្ថែមតាមរយៈ* ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៤០ KH 01196460 [សន្និបាតនេះ "គឺប្រហែលអំឡុងខែ៣ ឆ្នាំ១៩៧៨។ ដើមឆ្នាំ១៩៧៨"]។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.២១, ២៤-២៥ KH 01304977 ["ឆ្នាំក៏ចូល៧៧ហើយ" សារ៉ "មកពីខាងនិរតី" ជាគណៈកម្មាធិការរោងចក្រស្ករស ប្រហែល"ខែ០៧ ខែ០៨ហ្នឹង" បាទ "រដូវយើងភ្លៀង""]។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១១ KH 01058786 ["ពួកនិរតីមកដល់ទីនេះពីរដំណាក់កាល។ [...] ថ្នាក់ដឹកនាំដែលមកដំណាក់កាលទី២ គឺជាបុរសម្នាក់ឈ្មោះ អ៊ីង"]។ ឯកសារ D219/655 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៤, ៩ KH 01196550, 51 ។ ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឆ.១០, ១២ KH 01395015 [សាក្សីត្រូវបានគេរើសនៅ "ដើមឆ្នាំ៧៨" "រើសមកធ្វើការនៅរោងចក្រស្ករសកំពង់គល់"]។ ឯកសារ D118/60 កំណត់ហេតុស្តាប់ចម្លើយ ឡុង សុខឃី ឆ.៧ KH 00920147 ["ក្នុងឆ្នាំ១៩៧៨ គេឲ្យខ្ញុំមកនៅខាងបំរើភ្ញៀវនៅកំពង់គល់"]។

តាំងនេះ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1699]។ រោងចក្រមានទីតាំងស្ថិតនៅក្នុងភូមិតាមៀក ឃុំកំពង់គល់ ស្រុកសង្កែ តំបន់១ នៃភូមិភាគពាយ័ព្យ[1700]។ ទីតាំងមានចម្ងាយប្រមាណ ៣៧ គីឡូម៉ែត្រ ភាគខាងត្បូងទីក្រុងខេត្តបាត់ដំបង ស្ថិតនៅតាមបណ្តោយផ្លូវដូចគ្នាទៅកាន់មន្ទីរសន្តិសុខបាណន់ និងមន្ទីរសន្តិសុខខ្នងគ្ង និងវត្តទួលអណ្តែត ហើយផ្លូវឆ្ពងទៅកាន់ទំនប់កង្ហត[1701] ដែលទីតាំងទាំងនេះ **យ៉ីម ទិត្យ** ធ្លាប់បានទៅពិនិត្យមើលជាប្រចាំ។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

483. រោងចក្រស្ករសនេះ គឺជាផ្ទាសុបករណ៍កម្រិតភូមិភាគមួយ ស្ថិតនៅក្រោមសិទ្ធិអំណាចរបស់ តាម៉ុក និង **យ៉ីម ទិត្យ** តាមសមត្ថកិច្ចរបស់ពួកគេរៀងៗខ្លួនក្នុងឋានៈជា លេខា និង អនុលេខា នៃភូមិភាគពាយ័ព្យ[1702]។ នៅដើមឆ្នាំរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ **យ៉ីម ទិត្យ** និង តាម៉ុក បាននិយាយនៅ

[1699] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.២០-២១ KH 00951928-29។ ឯកសារ D118/60 កំណត់ហេតុស្តាប់ចម្លើយ ឡុង សុខឃី ឆ.៧, ១៥ KH 00920147-48។ *សូមមើលផងដែរ* ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.២ KH 01058783។ ឯកសារ D219/652 កំណត់ហេតុស្តាប់ចម្លើយ លួម ញ៉ាញ ឆ.៦ KH 01196507។ ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.២ KH 01040118។ ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាង ប៊ីា ឆ.៦១ KH 00998562។

[1700] ឯកសារ D1.3.22.2 *យុវជន និង យុវនារីបដិវត្ត* មេសា ១៩៧៦ KH 00064318។ ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហួន ជឿម ឆ.១២ KH 00951904។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.២ KH 00951925។ ឯកសារ D219/904 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម ឆ្ងញ ឆ.៧២ KH 01381136។ ឯកសារ D219/274 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃរោងចក្រស្ករសកំពង់គល់ KH 01219951-52។ ឯកសារ D118/271 កំណត់ហេតុស្តាប់ចម្លើយ ឈាង ប៊ីា ឆ.៦១ KH 00998562។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨ KH 01196453។ សព្វថ្ងៃទីតាំងការដ្ឋានរោងចក្រស្ករសកំពង់គល់ ស្ថិតនៅក្នុងឃុំចែងមានជ័យ ស្រុកបាណន់ ខេត្តបាត់ដំបង។ *សូមមើល* ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហួន ជឿម ឆ.១២ KH 00951904។ ឯកសារ D5/640 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សំ ឡេង KH 00529854។ ឯកសារ D219/274 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃរោងចក្រស្ករសកំពង់គល់ KH 01219951-52។ ឯកសារ D118/297 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH 01363588។ ឯកសារ D347/2.1.44 ផែនទីស្តីពីប្រព័ន្ធផ្លូវថ្នល់របស់កម្ពុជា អ៊ីពីខេត្តបាត់ដំបង EN 00327754។ ឯកសារ D347/2.1.52 ផែនទីស្រុក បាណន់ ខេត្តបាត់ដំបង របស់អ៊ីនតាក់ EN 01485874។

[1701] ឯកសារ D219/274 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃរោងចក្រស្ករសកំពង់គល់ KH 01219955។

[1702] ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហួន ជឿម ឆ.១២ KH 00951904 ["យោធាភូមិភាគប្រាប់ខ្ញុំថា តាទិត្យ នាំកម្លាំងរបស់គាត់ដោយផ្ទាល់ គាត់មកមើលស្ថានការណ៍នៅរោងចក្រស្ករសកំពង់គល់"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៧ KH 00951926 ["តាមខ្ញុំគិត រោងចក្រនេះប្រហែលជាស្ថិតនៅក្រោមខាងគ្រប់គ្រងរបស់មជ្ឈិម [...] ព្រោះពេលប្រជុំម្តងៗ មានតាម៉ុក មកពីខាងមជ្ឈិមមកប្រជុំ [នៅរោងចក្រ]។ តាសៀន ដែលមកពីខាងភូមិភាគ ក៏មកប្រជុំដែរ

ក្នុងអង្គប្រជុំនានានៅទីរួមខេត្តបាត់ដំបង ប្រាប់កម្មករ និងបុគ្គលិករោងចក្រនេះ អំពីស្ថានការណ៍សន្តិសុខនៅក្នុងតំបន់។ យោងតាមអ្នកចូលរួមម្នាក់ **យ៉ីម ទិត្យ** បានណែនាំកងការពារពីសារៈសំខាន់នៃការការពាររោងចក្រស្ករសពីវៀតណាម[1703]។ ក្នុងកិច្ចប្រជុំមួយផ្សេងទៀត សាក្សីម្នាក់បានឮតាម៉ុកពិភាក្សាជាមួយកម្មកររោងចក្រអំពី "អំពើក្បត់" របស់ពួកកម្មាភិបាលពាយ័ព្យ[1704]។ លឹម ទីម ដែលជាប្រធានកងការពារនៅរោងចក្រស្ករសនេះ បានរំឭកពីកិច្ចប្រជុំថ្នាក់ភូមិភាគដែល **យ៉ីម ទិត្យ** បាននិយាយថា គាត់ត្រូវបានឧទ្ទេសនាមថា ជាប្រធានភូមិភាគពាយ័ព្យ[1705]។

ហើយខ្ញុំមិនឃើញមានអ្នកមកពីខាងតំបន់មកប្រជុំទេ"] ឯ.១៧ KH 00951928 ["[ពេល] គេឲ្យកងការពារទៅចូលរួមសន្និបាតនៅសាលាសកលបាត់ដំបង [...] ហើយគេឧទ្ទេសនាមថា តាទិត្យ ជាប្រធានភូមិភាគពាយ័ព្យ"]។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.១៩-២០ KH 01196455 [កម្មាភិបាលភូមិភាគពាយ័ព្យម្នាក់ដែលស្ថិតក្នុងគណៈកម្មាធិការរោងចក្រស្ករស "ពេលគេហៅទៅប្រជុំ ក៏បានបាត់ខ្លួនទៅ" ដោយ "អង្គការថ្នាក់លើ ថ្នាក់ភូមិភាគ"] ឯ.១៣ KH 01196454។ ក្នុងអំឡុងនៃការដឹកនាំរបស់រោងចក្រដោយកម្មាភិបាលភូមិភាគពាយ័ព្យ រោងចក្របានធ្វើប្រតិបត្តិការនៅថ្នាក់ភូមិភាគ។ *សូមមើល* ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី ៦៨៣៥ EN 01222597។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឯ.៥៨-៥៩ KH 01304980។ *សូមមើលផងដែរ*ការចាខណ្ឌ[III.ឃ.១.ក. មុខតំណែងរបស់ យ៉ីម ទិត្យ អំពើ និង ទង្វើ – ការចូលរួមចំណែករបស់ យ៉ីម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ – មុខតំណែងរបស់ យ៉ីម ទិត្យ នៅភូមិភាគពាយ័ព្យ – មុខតំណែងផ្លូវការ "យ៉ីម ទិត្យ កាន់មុខតំណែងជាច្រើននៅក្នុងភូមិភាគពាយ័ព្យ"]។

[1703] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.១៨, ២២ KH 00951928-29 [ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៨ យ៉ីម ទិត្យ "និយាយពីរឿងឲ្យយើងជួយការពារ ខ្លាចឈ្លានមកចូលដុតរោងចក្រ"]។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.៤០, ៦៨ KH 01196460, 64 [សន្និបាតនេះ "គឺប្រហែលអំឡុងខែ៣ ឆ្នាំ១៩៧៨។ ដើមឆ្នាំ១៩៧៨"]។ យ៉ីម ទិត្យ បាននិយាយ "ប្រហែលជា១ម៉ោង""] ឯ.៦២, ៦៤, ៦៩ KH 01196463, 64។

[1704] ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឯ.១៩, ២១, ២៦-២៨ KH 01395016-17 [ដើមឆ្នាំ៧៨ "ពេលធ្វើសន្និបាត គេប្រកាសថា គណៈភូមិភាគមុន ក្បត់" ហើយតាម៉ុក "ថា កម្មាភិបាលពាយ័ព្យក្បត់ទាំងអស់ហើយ"។ [...] គាត់ក៏ថា ភូមិភាគនេះ [...] មានពួកចោរព្រៃច្រើនណាស់"]។

[1705] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.១៧-១៨, ៥៦ KH 00951928, 32 [ក្នុងឆ្នាំ១៩៧៨ "គេឲ្យកងការពារទៅចូលរួមសន្និបាតនៅសាលាសកលបាត់ដំបង [...] ហើយគេឧទ្ទេសនាមថា តាទិត្យ ជាប្រធានភូមិភាគពាយ័ព្យ។ [...] តាទិត នោះគាត់ក្បាលទំពេក មានកំពស់ទាប សម្បុរស ហើយមិនធាត់ទេ"] *បញ្ជាក់បន្ថែមតាមរយៈ*ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.៣៧, ៤០ KH 01196459, 60។ សន្និបាតថ្នាក់ភូមិភាគនេះបានចូលរួមដោយកងការពារ និងយោធាពីតំបន់ខុសៗគ្នាជាច្រើននៅក្នុងភូមិពាយ័ព្យ។ *សូមមើល* ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.៤៣ KH 01196460។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.២៤ KH 00951929។ *សូមមើលផងដែរ* ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឯ.៦៦ KH 01395021។ *សូមមើលផងដែរ* [*III.ឃ.១.ខ.* មុខតំណែងរបស់ យ៉ីម ទិត្យ អំពើ និង ទង្វើ ការចូលរួមចំណែករបស់ យ៉ីម ទិត្យ ក្នុងផែនការឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ មុខតំណែងរបស់

484. សាក្សីម្នាក់ដែលធ្លាប់ធ្វើការឲ្យយោធាភូមិភាគពាយ័ព្យ ត្រូវបានគេប្រាប់គាត់ថា **យ៉ឹម ទិត្យ** "បាននាំកម្លាំងរបស់គាត់ដោយផ្ទាល់" មកកាន់ការ៉ាងចក្រស្ករសនេះ ហើយបានចាត់តាំងកម្មាភិបាលភូមិភាគនិរតីឈ្មោះ យ៉ាន ធ្វើជាប្រធានរោងចក្រ[1706]។ លឹម ទីម, ខយ ឆ្ងយ, ប៉ុល ស៊ីត និងប្រាក់ សៀន ទាំងអស់គ្នាសុទ្ធតែបានធ្វើការនៅរោងចក្រស្ករសនេះ និងបានឃើញអ្វីដែលបានកើតចេញពីការផ្ទាស់ប្តូរថ្នាក់ដឹកនាំរោងចក្រ។ កម្មាភិបាលនិរតី យ៉ាន និង សារី *ហ៊ា*រ[1707] បានមកជំនួសកម្មាភិបាលពាយ័ព្យ ម៉ែត, ណុប និង បាវ ដែលធ្លាប់បម្រើការងារក្នុងគណៈកម្មាធិការនេះពីមុន[1708]។ ម៉ែត, ណុ

យ៉ឹម ទិត្យ នៅភូមិភាគពាយ័ព្យ មុខតំណែងជាមេដឹកនាំតាមព្រឹត្តន័យមុនពេលការតែងតាំងជាមន្ត្រីវការ (ដែលផ្តល់ភ័ស្តុតាងរួមអំពីយ៉ឹម ទិត្យ ដែលនៅពេលនោះជាលេខាភូមិភាគពាយ័ព្យ)។]។

[1706] ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហ្ជន ជឿម ឆ.១២ KH 00951904 ["យោធាភូមិភាគប្រាប់ខ្ញុំថា តាទិត្យ នាំកម្លាំងរបស់គាត់ដោយផ្ទាល់ គាត់មកមើលស្ថានការណ៍នៅរោងចក្រស្ករសកំពង់គល់"]។ [...] តាទិត្យ បានចាត់តាំងនារី យ៉ាន មកពីនិរតីឲ្យកាន់ក្តាប់កន្លែងរោងចក្រស្ករសនោះជំនួសវិញ"]។ *កំណត់សំគាល់*៖ ហ្ជន ជឿម ដែលបានឮអំពីការចាត់តាំង យ៉ាន នេះពីយោធាភូមិភាគពាយ័ព្យម្នាក់ ហើយគាត់ក៏មិនបានស្គាល់ យ៉ាន ដោយផ្ទាល់ដែរនោះ គឺគាត់ហាក់ដូចជាច្រឡំអំពីភេទរបស់ យ៉ាន។ ប៉ុន្តែ មានកម្មករមួយចំនួននៅរោងចក្រស្ករសនេះ បានកំណត់អត្តសញ្ញាណ យ៉ាន ថាជាប្រធានរោងចក្រស្ករសកំពង់គល់។ *សូមមើល* ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៥, ១០ KH 00951926, 27 [សាក្សីបានកំណត់អត្តសញ្ញាណថា យ៉ាន គឺប្រុស]។ ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.១៦ KH 01040121។ ឯកសារ D219/656 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.២០ KH 01196562 [សាក្សីបានកំណត់អត្តសញ្ញាណថា យ៉ាន គឺប្រុស]។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១១ KH 01058786។ កម្លាំង កម្មាភិបាល និងកម្មករនៅរោងចក្រស្ករសកំពង់គល់ បន្តនៅក្រោមបង្គាប់ យ៉ឹម ទិត្យ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលពួកគេត្រូវបានបញ្ជូនទៅស្រុកសំឡូត។ *សូមមើល* ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សៀន ឆ.៦៧, ៦៩-៧១ KH 01395021-22។ ឯកសារ D123/1/5.41 បទសម្ភាសន៍ជាមួយ ឡុង សុខឃី ហៅ ឡុង រង្គា ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00931544-45។ ឯកសារ D123/2/1.27a បទសម្ភាសន៍ជាមួយ ទ៉ីម ភ្ជួន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00957762។ ឯកសារ D219/844.1.4 គម្រោងលើកកំពស់គណនេយ្យភាព DC-Cam៖ យ៉ឹម ទិត្យ ហៅ តា ទិត្យ KH 01530127។ ឯកសារ D219/952 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម អេម ឆ.៨៥-៨៦, ១០១, ១០៦ KH 01420577, 79។ ឯកសារ D219/665 កំណត់ហេតុស្តាប់ចម្លើយ នង សុផង់ ឆ.១៨ KH 01200303។ ឯកសារ D219/380 កំណត់ហេតុស្តាប់ចម្លើយ ប៉ុក សុផាត ឆ.៣០ KH 01113196។ ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយ តុប សឹង ឆ.១៩៥, ១៩៧, ២០០ KH 01046480។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ ម្ជូល អេង ឆ.១០៦ KH 01095251-52។

[1707] ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១១ KH 01058786។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ប៉ុល ស៊ីត KH 01485003។

[1708] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨ KH 00951926-27 ["តាម៉ែត [...] តាណុប [...] និង តាបាវ[...] ហើយពួកគាត់ជាកម្មាភិបាលពាយ័ព្យ" ដែលមានឈ្មោះក្នុងគណៈកម្មាធិការរោងចក្រ។ "ពេល តា យ៉ាន និង ឃាយ សារី មកកាន់រោងចក្រស្ករសចុងឆ្នាំ១៩៧៧ ហើយពួកតាទាំងបីនាក់នោះ[តាម៉ែត, តាណុប និងតាបាវ] មិនទាន់ចាប់ខ្លួនទេ" តែគេដក

ប និង បាវ គឺជា "ពួកក្បត់ជាប់ខ្សែរវៀតណាម"[1709]។ សាក្សីនានានិយាយថា កម្មាភិបាលទាំងនេះ បានបាត់ខ្លួន ឬត្រូវបានចាប់ខ្លួនជាមួយក្រុមគ្រួសាររបស់ពួកគេក្នុងករណីរបស់ ណុប និង បាវ[1710]។ ឯកសារនៅសល់ពី ស-២១ បានកត់ត្រាថ្ងៃចូលរបស់ ណុប គឺថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧[1711]។ បុគ្គលិករោងចក្រដទៃទៀតក៏ត្រូវបានបោសសម្អាតផងដែរ[1712]។ យ៉ាន បានចាត់តាំង លឹម ទីម ឲ្យ

តំណែងពួកគាត់អស់ហើយ""] ឆ.៥ KH 00951926 [សាក្សី បាន "ការពារប្រធានរោងចក្រតែម្តង ឈ្មោះ តាយ៉ាន មកពីខេត្ត កំពត ហើយអនុប្រធានឈ្មោះ យាយ សារី គាត់ក៏ជាអ្នកមកពីខាងផ្ទៃស្រែអំបិល ខេត្តកំពត"]។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៣៥ KH 01196458។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១៦-១៩, ២១, ២៤-២៥ KH 01304976-77 ["[...] ឈ្មោះ ណុប និង ម៉ែត អ្នកគ្រប់គ្រងដំបូង [នៅរោងចក្រនោះ]។ [...] ខាងពាយ័ព្យហ្នឹង ហើយ [...]។ សារី មកជំនួសពីរនាក់ហ្នឹង [...] ខាងនិរតី។ [...] ឆ្នាំក៏ចូល ៧៧ ហើយ [...] ។ ចង់និយាយថា ខែ០៧ ខែ០៨ហ្នឹង បាទ រដូវយើងភ្លៀង"]។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៩ KH 01058785-86។ ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.១៦ KH 01040121 ["ផ្ទាក់ដឹកនាំរោងចក្រនៃពួកនិរតីដែលនៅខាងលើគេបំផុតមានបង យ៉ាន, បងនារី, រ៉ី ហើយនឹងម្នាក់ទៀត [...] គេកាន់តំណែងដឹកនាំជំនួសពួកពាយ័ព្យ"]។ ឯកសារ D219/656 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.២០ KH 01196562 ["អ្នកទទួលខុសត្រូវក្នុងរោងចក្រហ្នឹង ឈ្មោះគាត់ បង យ៉ាន [...] និង បងរ៉ី [...]"]។ *សូមមើលផងដែរ* ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ស្ងឿន ឆ.១៧, ២៧, ៧៦ KH 01395016, 17, 22។

[1709] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៣៧, ៤២ KH 00951930-31 ["ពេលគេចាប់ពួកគាត់ [ម៉ែត, ណុប និហ បាវ] យកទៅរួចហើយ ទើបគេប្រាប់ថា ពួកនោះក្បត់ ជាខ្សែរយៈឃ្លួន [...] និងពួកខ្ទាំង"]។

[1710] <u>ម៉ែត</u>៖ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨ KH 00951926-27 ["គេហៅ តាម៉ែត ឲ្យទៅប្រជុំនៅក្រុងបាត់ដំបង ហើយគាត់បានខ្លួនតាំងពីពេលនោះមក"] *ដែលបានបញ្ជាក់បន្ថែមតាមរយៈ* ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១៩-២០ KH 01196455។ ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.១៦ KH 01040121 ។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.២៣, ២៦ KH 01304977។ <u>យ៉ាង សេង ហ៊ាង ហៅ ណុប និង បាវ</u>៖ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨-១១ KH 00951926-27 [៣ខែក្រោយមកបន្ទាប់ពីបាត់ខ្លួន ម៉ែត សាក្សីបានឃើញ "ពួកនិរតីគេមកចាប់ តាបាវ និង តាណុប"។ កាលណោះពួកគេត្រូវបាន "គេចាប់យកទាំងគ្រួសារតែម្តង" កាលណោះអា អ៊ើង និង ភិន ជាអ្នកចាប់ និង "កងការពារគេមកពីនិរតី ប្រហែលជា២០នាក់"]។ ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.១៧ KH 01040121។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.២៣, ២៦, ៧៨ KH 01304977, 82។

[1711] ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី ៦៨៣៥ EN 01222597។

[1712] <u>យោធាការពារនៅផ្លូវចេញចូលបរិវេណ</u>៖ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៩ KH 01058785-86។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៤១ ឆ.៤៤-៤៦ KH 01304979។ ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហួន ជឿម ឆ.១២ KH 00951904។ <u>ប្រធានវរៈសេនាតូច ហ៊ីន</u>៖ ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហួន ជឿម ឆ.១២ KH 00951904។ <u>ប្រធានទីរសា រ៉ន ហៅ ហាន</u>៖ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៣៤ KH 01196458។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១៣ KH 00951927។

ធ្វើជាប្រធានកងការពារនិងនីរសារ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1713]។ តាម៉ុកក៏បានប្រើសិទ្ធិអំណាចទៅលើរោងចក្រស្ករសនេះដែរ។ គាត់បានចុះទៅញ៉ីកញ្ជាប់ បានពិនិត្យ បានជួបជាមួយកម្មាភិបាលជាន់ខ្ពស់ បានផ្តល់បញ្ជានិងការចាត់តាំងដោយផ្ទាល់ និងបានសង្កេតមើលកិច្ចប្រជុំរបស់កម្មាភិបាលមិនមែនជាន់ខ្ពស់នានា[1714]។ ការចាប់ខ្លួនមនុស្សនៅរោងចក្របានកើតឡើងក្នុងចិរវេលាយ៉ាងកៀកទៅនឹងរយៈពេលនៃដំណើរទស្សនកិច្ចរបស់ តាម៉ុក[1715]។

[1713] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៤ KH 00951926 ["ក្នុងខែ៥ ឬខែ៦ ឆ្នាំ១៩៧៨ ប្រធានរោងចក្រឈ្មោះ តាយ៉ាន គាត់ឲ្យខ្ញុំធ្វើជាយោធា [...] ដោយឲ្យខ្ញុំធ្វើជាមេក្រុមកងការពារ"] ឆ.១៣ KH 00951927។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១០ KH 01196453-54។ ការទទួលខុសត្រូវរបស់ លឹម ទីម មានទាំងការការពារ យ៉ាន និង សារី ក្នុងគណៈកម្មាធិការរោងចក្រ និងមើលការខុសត្រូវក្នុងការការពារកម្មករចិននៅរោងចក្រ។ *សូមមើល* ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៤-៥ KH 00951926។

[1714] ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១២, ១៤-១៥ KH 01196454-55 [តាម៉ុក "គ្រាន់តែមកមើល។ [...] គាត់មិនដែលមកប្រជុំ" ដែលសាក្សីបានចូលរួមនៅរោងចក្រទេ "គាត់គ្រាន់តែមកអើតមើលមួយភ្លែតៗ។ [...] គាត់មកជួបតែមេៗនិរតី" នៅរោងចក្រ] ឆ.៣០-៣១ KH 01196457-58។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៤, ៧ KH 00951926។ ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឆ.២១, ៤០-៤១ KH 01395016, 18, 19 [នៅរោងចក្រស្ករស "ដើមឆ្នាំ៧៨ [...] ខ្ញុំឃើញមុខគាត់[តាម៉ុក]រហូត។ [...] គាត់មកញ៉ីកញ្ជាប់។ គាត់មកពិនិត្យ ដាក់ផែនការ បញ្ជាផ្ទាល់តែម្តឹងជំនាន់នោះ"]។

[1715] ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១៨ KH 01196455 [ការចាប់ខ្លួនបានកើតឡើង "មុនហ្នឹងក៏មាន ក្រោយហ្នឹងក៏មាន" នៅពេល តាម៉ុក បានជួបជាមួយកម្មាភិបាលជាន់ខ្ពស់ហើយ] ឆ.១០៤ KH 01196470 [ទាក់ទងនឹងការចាប់ខ្លួនកម្មករ "[ខ្ញុំ]ឃើញគាត់[តាម៉ុក]មកមុនហ្នឹងប្រហែល១ខែមកដើរមើលលិចកើតៗ"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨ KH 00951927 ["ខ្ញុំឃើញ តាម៉ុក គាត់ចេញចូលៗរោងចក្រស្ករស ហើយពីរទៅបីថ្ងៃក្រោយមក គេក៏ចាប់ តាយ៉ាន"]។

485. ពេលមួយនៅខែឧសភា ឬ ខែមិថុនា ឆ្នាំ១៩៧៨ កម្មាភិបាលពីរនាក់ពីភូមិភាគនិរតីរបស់ តាម៉ុក គឺ អ៊ីង និង ភិន[1716] បានចាប់ យ៉ាន ដោយបានចោទប្រកាន់ថាក្បត់[1717]។ ក្រោយពេលចាប់ យ៉ាន, អ៊ីង បានមើលការខុសត្រូវលើរោងចក្រ រួមជាមួយនឹងកម្មករកងចល័តរបស់គាត់[1718] ហើយគាត់បានបន្តចាប់ខ្លួនបន្ថែមទៀត ដោយការប្រើប្រាស់យោធាប្រមាណជា ២០នាក់ នៅក្រោមបញ្ជារបស់គាត់ និង ភិន[1719]។

[1716] ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឆ.៣៨-៣៩, ៥១ KH 01395018, 20 ["អ៊ីង គឺជាជំនិតរបស់ តាម៉ុក។ [...] អ៊ីង មកពីនិរតីដែរ តាម៉ុក អ្នកបញ្ជូនមក [ភូមិភាគពាយ័ព្យ]"]។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.២៤ KH 01196456 ["ព្រោះ អ៊ីង និង ភិន មកមុន ហើយតាម៉ុក មកក្រោយ មកជួបពួកគេ។ ដូច្នេះខ្ញុំសន្និដ្ឋានថា ពួកគេច្បាស់ជាធ្វើការជាមួយតាម៉ុក ឬក៏ពួកគេនៅក្រុមតែមួយ"] ឆ.៣០ KH 01196457 ["តែ អ៊ីង ទៅមក១ជាមួយតាម៉ុក"]។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៣១, ៣៧ KH 01304978។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៣១, ៣៩ KH 01304978 ["ភ្លឹម? អត់មាន នៅហ្នឹងអត់មានទេ"]។

[1717] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨, ១០, ២១, ៥០ KH 00951926-27, 29, 32 [សាក្សីត្រូវបានចាត់តាំងជាប្រធានអ្នកយាមសន្តិសុខ និងនិរសា នៅរោងចក្រស្ករសដោយ យ៉ាន នៅខែឧសភា ឬខែមិថុនា ឆ្នាំ១៩៧៨៖ "ខ្ញុំឃើញ តា ម៉ុក គាត់ចេញចូលៗរោងចក្រស្ករស ហើយពីរទៅបីថ្ងៃក្រោយមក [...] អ៊ីង និង ភិន ក៏ចាប់ តាយ៉ាន [...] ហើយតែប៉ុន្មានខែប៉ុណ្ណោះក៏រៀតណាមចូលមកដល់" ដែលសាក្សីរូបនេះនិយាយថាបានកើតឡើង "ប្រហែលជាក្នុងខែ២ ឆ្នាំ១៩៧៩"]។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.២៦-២៧ KH 01196457 ["គ្នាគេហ្នឹងនិយាយ [...] អ៊ីង និង ភិន [...] និយាយគ្នាថា យ៉ាន ត្រូវចាប់ខ្លួន ដោយចោទថាក្បត់ជាតិ។ យាយ សារី [...] គាត់ប្រាប់ថាតាយ៉ាន ក្បត់"]។ សារី នៅរោងចក្រស្ករសកំពង់គល់នៅឡើយរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ *សូមមើល* ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.២០-២១ KH 00951928-29។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ប៉ុល ស៊ីត KH 01485003។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៣៤, ៣៦ KH 01304978។

[1718] ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៣០ KH 01196457 ["ភិន នៅជាប់ តែអ៊ីង ទៅមក១ [...]។ ពេលតាម៉ុក អត់មក អ៊ីង មកមើលរោងចក្រជំនួស តាម៉ុក។ ជួនកាល អ៊ីង មកដេកពីរបីយប់ ត្រឡប់ទៅវិញ"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.២១ KH 00951929 ["គឺ អ៊ីង និង ភិន ឡើងជំនួស តា យ៉ាន"]។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៣១-៣២ KH 01304978 ["អ៊ីង [...] មកគ្រប់គ្រងរោងចក្រ"] ឆ.៩៩ KH 01304984។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.២៧, ៣៤ KH 01304977-78 [អ្នកដឹកនាំរោងចក្រ "ក្រោយមក ដក[...]ចេញទៅ អ៊ីង នៅហ្នឹង"]។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ខយ ឆ្ងយ KH 01485000។ ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឆ.៣៨, ៥១ KH 01395018-20 ["ប្រធានរោងចក្រឈ្មោះ អ៊ីង"]។ *សូមមើលផងដែរ* ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.១៥ KH 01040121។

[1719] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៤៧, ៤៩-៥០ KH 00951931-32 ["ព្រោះខ្ញុំបានឃើញដោយផ្ទាល់ភ្នែក កងការពាររបស់ អ៊ីង និង ភិន ប្រមូលពួកខ្មែរក្រោម និងជនជាតិវៀតណាម [...] ប្រហែលជា៣ខែមុនវៀតណា

iv. ខ្ញុំក្ដីកម្ម

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង</u>

486. ដោយយោងតាមកំណត់ត្រាគុកដែលនៅសល់ យ៉ា សេងហៀង *ហៅ* ណុប ដែលជាសមាជិកគណៈរោងចក្រ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់ ស-២១ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧[1720]។ បន្ថែមលើនេះ ក្រោយពី អ៊ីង បានចាប់ខ្លួនពួកកម្មាភិបាលភូមិភាគនិរតី និងប្រធានរោងចក្រស្ករសឈ្ពោះ យ៉ាន រួចមក នៅប្រហែលជាពាក់កណ្ដាលឆ្នាំ១៩៧៨ "គេចាប់ផ្ដើមចាប់កម្មករធ្វើការនៅរោងចក្រស្ករ"[1721]។ ការចាប់ខ្លួនបានកើនឡើងយ៉ាងញឹកញាប់រៀងរាល់ "ពីរបីថ្ងៃម្ដង"[1722]។ "ពេលខ្លះដោយសារអ្នកដែលចាប់នោះមានច្រើនពេក យកទៅមិនអស់ គេក៏ចាក់សោទុកមនុស្សទាំងអស់នោះនៅក្នុងអគារ១ក្ដ្ឋបាលសិន"[1723]។ សាក្សី លឹម ទីម បានសង្កេតឃើញថា នៅចុងឆ្នាំ

មចូល"។ ពួកវៀតណាមបានមកដល់ "ប្រហែលជាក្នុងខែ២ ឆ្នាំ១៩៧៩"] *បានបរិយាយយ៉ាងល្អិតល្អន់* នៅត្រង់ ឯកសារ D219/649 កំណត់ហេតុស្ដាប់ចម្លើយ លឹម ទីម ឯ.៧៩, ៨៥ KH 01196466-67។ ឯកសារ D219/796 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.១០៤, ១០៦ KH 01304985 [កងទ័ពដែលនាំយកមកដោយ អ៊ីង "នៅក្រោមអ្នកប្រធានរោងចក្រហ្នឹងតាំងអស់"]។ *សូមមើលផងដែរ* ឯកសារ D219/157 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.៨ KH 01058785។ ឯកសារ D219/796 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.៦៩, ៧៤ KH 01304981។ ពួកយោធាដែលមកពីភូមិភាគនិរតីជាមួយ អ៊ីង និង ភិន ទៅរោងចក្រស្ករសកំពង់គល់។ *សូមមើល* ឯកសារ D219/796 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.៤១, ៤៧ KH 01304979។ ឯកសារ D118/108 កំណត់ហេតុស្ដាប់ចម្លើយ លឹម ទីម ឯ.១១ KH 00951927 *បានបរិយាយយ៉ាងល្អិតល្អន់* នៅត្រង់ឯកសារ D219/649 កំណត់ហេតុស្ដាប់ចម្លើយ លឹម ទីម ឯ.៣២-៣៣ KH 01196458។

[1720] ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោសស-២១ របស់ ក.ស.ច.ស លេខរៀងទី ៦៨៣៥ EN 01222597 [យ៉ា សេងហៀង (យ៉ា សេងប៊ាង) ហៅ ណុប សមាជិករោងចក្រស្ករសភាគ នៅកំពង់គល់ (សមាជិករោងចក្រស្ករស) ១១-វិច្ឆិកា-៧៧]។

[1721] ឯកសារ D118/108 កំណត់ហេតុស្ដាប់ចម្លើយ លឹម ទីម ឯ.១៩ KH 00951928។ *សូមមើលផងដែរ* ឯកសារ D219/157 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.៨ KH 01058785។ ឯកសារ D219/796 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.១០៧-១០៨ KH 01304985។

[1722] ឯកសារ D219/157 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.៨ KH 01058785 ["ការចាប់ចងមនុស្សនោះ [ដោយនិរសារមកពីខេត្តបាត់ដំបង] គឺមានឃ្យូរៗម្ដងប៉ុណ្ណោះមុនឆ្នាំ១៩៧៨ ប៉ុន្តែក្រោយពីឆ្នាំ១៩៧៨ ការចាប់ចងមានសន្ទុះញឹកញាប់មែនទែន [...] យើងតែងតែឃើញគេមកចាប់មនុស្ស ពីរបីថ្ងៃម្ដងៗ។"]។ *សូមមើលផ្ទុយទីនេះ* ឯកសារ D219/796 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.១១១-១១២ KH 01304985 [ការចាប់ខ្លួន "មិនញឹកញាប់ដែរទេ ខ្ញុំឃើញប្រមាណជាពីរដង ទៅបីដងប៉ុណ្ណឹងទេ។" មនុស្សត្រូវបានចាប់ខ្លួន "ជួនកាលពីរ មួយ។"]។

[1723] ឯកសារ D219/157 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឯ.៨ KH 01058785។ នៅក្នុងកំណត់ហេតុស្ដាប់ចម្លើយមួយ លឹម ទីម បានថ្លែងថា កម្មករនៅរោងចក្រស្ករសរមិនត្រូវបានឃុំឃាំងទេ និងថា មិនមានមន្ទីរសន្តិសុខឡើយ ប៉ុន្តែនៅក្នុងចម្លើយដដែលនោះ គាត់ក៏បានរៀបរាប់អំពីការឃុំឃាំងកម្មករខ្ទ្ចរក្រោម នៅក្នុងផ្ទះមួយក្នុងបរិវេណនោះ។ *សូមមើល* ឯកសារ D219/649

១៩៧៨ កម្មាភិបាលក្រោមបង្គាប់របស់ អ៊ីង និង ភិន បានឃុំឃាំងកម្មករដែលជាខ្មែរក្រោម និងវៀតណាមអស់រយៈពេលមួយយប់ ឬពីរយប់ នៅទីកន្លែង ក្រោមលេសក្លែងក្លាយ នៅមុនពេលដែលគេយកពួកអ្នកទាំងនោះទៅសម្លាប់ចោល[1724]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

487. ខណៈដែលជាទូទៅការសម្លាប់ត្រូវបានធ្វើឡើងដោយសម្ងាត់ កម្មករបានឮអំពីការសម្លាប់ទាំងនោះ និងទីកន្លែងសម្លាប់នានា[1725]។ យោងទៅតាមកំណត់ត្រាគុកដែលនៅសេសសល់ យ៉ា សេងហ៊ៀង *ហ៊ា*ណុប ដែលស្ថិតនៅក្នុងគណៈរោងចក្រនេះ ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅកាន់ ស-២១ ហើយពុំមានភ័ស្តុតាងណាមួយថាគាត់បានរួចជីវិតនោះទេ[1726]។ ជិតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ លឹម ទីម បានឃើញពួកកម្មករដែលជាខ្មែរក្រោម និងវៀតណាម ត្រូវបានដឹកដោយឡាន

កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨៩ KH 01196468 ឆ.៨៣, ៩៩ KH 01196467, 69។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៥១ KH 00951932។ ផ្ទះនោះស្ថិតនៅទល់មុខរោងចក្រ និងជាផ្ទះដែល លឹម ទីម ការពារ។ *សូមមើល* ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.២២, ៨៣ KH 01196456, 67។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៤៧ KH 00951931។

[1724] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៤៧-៥១ KH 00951931-32 ["ប្រហែលជាបីខែមុនវៀតណាមចូល" ដែល "ប្រហែលជាក្នុងខែ២ ឆ្នាំ១៩៧៩" "ខ្ញុំបានឃើញដោយផ្ទាល់ភ្នែក កងការពាររបស់ អ៊ីង និង ភិន ប្រមូលពួកខ្មែរក្រោម និងជនជាតិវៀតណាមមកដាក់នៅក្នុងរោងទំហំ ៨ X ៣០ ម៉ែត្រ ដែលមានទីតាំងដែលជាប់នឹងផ្ទះដែលខ្ញុំការពារ"។ "គេថាឲ្យពួកនោះទៅធ្វើស្រែនៅបឹងត្រាវ ហើយមួយយប់ ឬពីរយប់គេដឹកចេញយកទៅសម្លាប់អស់។"]។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៩៩-១០០ KH 01196469-70។ ចំពោះរបៀបដែល លឹម ទីម ដឹងថាអ្នកជាប់ឃុំជាវៀតណាម ឬជាខ្មែរក្រោម *សូមមើល* ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៧៦, ៨២ KH 01196466-67 ["ឆ.៧៦៖ វាជាជនជាតិស្បែកស និងភាសានិយាយគឺរបៀបខ្មែរកម្ពុជាក្រោម រដឹនៗ [...] ដោយសារពួកគេនិយាយរដឹនៗ ខ្ញុំគិតថាពួកគេជាខ្មែរក្រោម។ [...] ស៖ [...] តើលោកចង់និយាយសំដៅយ៉ាងម៉េចចំពោះជនជាតិវៀតណាមបែបនេះ? ឆ.៨២៖ ព្រោះឃើញស្បែកស និយាយមិនច្បាស់។"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៥៤ KH 00951932 ["ស៖ តើលោកធ្វើដូចម្តេចទើបដឹងថា អ្នកទាំងនោះជាខ្មែរក្រោម? ឆ.៥៤៖ ព្រោះដោយសារពួកគេនិយាយប៉ែលាំៗ ដូចពួកអ្នកមកពីខេត្តព្រះត្រពាំង ហើយពួកនោះគឺមានសាច់សរ។"]។ *សូមមើលផងដែរ* ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១៦ KH 01058787 ["បើកាលណាមានអ្នកណាដែលនិយាយសំឡេងប៉ែឡាំ ជារបៀបខ្មែរក្រោម គេនឹងចាប់យកទៅបាត់ហើយ។"]។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៨២ KH 01304982 ["ជំនាន់ខ្មែរក្រហម [...] ខ្មែរកម្ពុជាក្រោម ឲ្យតែនិយាយប៉ែឡាំ វាចាប់ហើយ។"]។

[1725] ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឆ.៤៦ KH 01395019។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨៨ KH 01196468។

[1726] D219/825.1.2 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី ៦៨៣៥ EN 01222597។

ទ្រុងចេញទៅ ហើយប្រមាណជាប្រាំម៉ោងក្រោយមក គាត់បានឃើញឡានទ្រុងទាំងនោះត្រឡប់មកវិញដោយមានតែខោអាវប៉ុណ្ណោះ[1727]។ ក្រោយមក ពួកយោធាបានប្រាប់ លឹម ទឹម ថាពួកទាំងនោះត្រូវបានគេសម្លាប់អស់ហើយ[1728]។

488. មនុស្សបន្តបាត់ខ្លួនពីរោងចក្រស្ករស[1729]។ ការណ៍នេះ រួមទាំងកម្មាភិបាលភូមិភាគពាយ័ព្យ និងប្រធានគណៈរោងចក្រស្ករសឈ្មោះ ម៉ែត ផងដែរ។ លឹម ទឹម ដែលរស់នៅជាមួយ ម៉ែត ក្នុងឋានៈជានីរសារបស់ ម៉ែត និងបានធ្វើការនៅឯរោងចក្ររហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ បានរំឭកឡើងវិញថា នៅមុនថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ម៉ែត ត្រូវបានកោះហៅឲ្យទៅចូលរួមប្រជុំថ្នាក់ភូមិភាគនៅទីក្រុងបាត់ដំបង ដែលបន្ទាប់ពីនោះមកគាត់បានបាត់ខ្លួន[1730]។

[1727] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.៤៧, ៤៩-៥០, ៥២ KH 00951931-32 ["ប្រហែលជាបីខែមុនវៀតណាមចូល" ដែល "ប្រហែលជាក្នុងខែ២ ឆ្នាំ១៩៧៩" "ខ្ញុំបានឃើញ [...] កងការពាររបស់ អ៊ីង និង ភិន ប្រមូលពួកខ្មែរក្រោម និងជនជាតិវៀតណាម [...]។ ឃប់ឡើងគេយកឡានដឹកពួកនោះចេញ ហើយពេលឡានមកវិញ ខ្ញុំឃើញមានតែខោអាវមកជាមួយទេ។" "តាមខ្ញុំស្មានក្នុងមួយឡានមានប្រហែល៣០នាក់ មានទាំងក្មេងទាំងចាស់ ហើយគេដឹកចេញពីរឡាន។ ខ្ញុំឃើញគេដឹកពួកខ្មែរក្រោមចេញនោះតែម្តងទេ គឺជិតចប់របបខ្មែរក្រហមហើយ។"] *រៀបរាប់បន្ថែមនៅ* ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.៧៩-៨០, ៨៦-៨៧, ១០២ KH 01196466-67, 70 [សាក្សីបានឃើញ "ថាច្រើន ដឹងថាដឹកពេញម៉ាឡាន សេអ៊ីមសេ។ វាប្រហែល ៥០ ឬច្រើនជាងនេះ ព្រោះពេញណែនម៉ាឡានហ្នឹង។" ឡានចេញ "ប្រហែលម៉ោង១២ ឃប់។ [...] ត្រឡប់មកវិញប្រហែលម៉ោងប្រាំព្រឹក ហើយឈប់នៅជិតផ្ទះខ្ញុំ។" "មានឡានពីរ តែឡានមួយដឹកកម្មករ និងឡានមួយទៀតដឹកយោធាគ្នាវាហ្នឹង។"]។ ចំពោះរបៀបដែល លឹម ទឹម ដឹងថាជនរងគ្រោះជាខ្មែរក្រោម ឬវៀតណាមនោះ *សូមមើល* ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.៧៦, ៨២ KH 01196466-67។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.៥៤ KH 00951932។ *សូមមើលផងដែរ* ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.១០៤ KH 01196470។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឯ.៨ KH 01058785។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឯ.៦៦, ៦៩, ៧៤ KH 01304981។

[1728] ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.១០០-១០១ KH 01196470 ["ស៖ ម៉េចបានលោកដឹងថាគេញ្ជូនអ្នកទាំងអស់នោះទៅសម្លាប់ចោល? ឯ.១០០៖ ព្រោះដឹងពីយោធា ក្រុមគេហ្នឹងក្មេងៗ [...] ឯ.១០១៖ [...] ពេលក្រោយដែលបាត់ពួកហ្នឹងហើយ គេថាពួកហ្នឹងគេយកទៅសម្លាប់ចោលអស់។"] ឯ.៩៧-៩៩ KH 01196469។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.៥១ KH 00951932។

[1729] *សូមមើល ខ១ាហរណ៍* ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឯ.១០៨-១០៩, ១១៦, ១២២ KH 01304985-87។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឯ.៨ KH 01058785។ ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សិត ឯ.៧ KH 01040119។

[1730] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.៨ KH 00951926-27។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទឹម ឯ.១៩-២១ KH 01196455។ ហេតុការណ៍នេះបានកើតឡើងបីខែមុនពេលកម្មាភិបាលនិរតីបានចាប់ខ្លួន គា

ការធ្វើទុក្ខបុកម្នេញ

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយទៅលើ វៀតណាម និងខ្មែរក្រោម

489. ជនជាតិវៀតណាម និងខ្មែរក្រោម ត្រូវបានគេធ្វើទុក្ខបុកម្នេញតាមរយៈឧក្រិដ្ឋកម្មនានាដែលបានរៀបរាប់ខាងលើ។ អរិភាពចំពោះនរណាម្នាក់ដែលគេយល់ឃើញថាមានជាប់ទាក់ទងទៅនឹងវៀតណាម បានកើតមានឡើងចាប់ពីថ្នាក់លើបំផុត រហូតដល់ថ្នាក់ក្រោមបំផុត នៃរដ្ឋបាលរោងចក្រនេះ។ ប្រធានរោងចក្រ ឈ្មោះ អ៊ីង និងជំនួយការរបស់គាត់ឈ្មោះ ភិន បាននិយាយថាប្រជាជនខ្មែរក្រោមត្រូវបានចាប់ខ្លួន ពីព្រោះពួកគាត់ "ជាប់ខ្សែរយៈយួន"[1731]។ នីរសារបស់ អ៊ីង និងពួកយោធារួមអាវុធរបស់គាត់នៅរោងចក្រនេះ បានចោទប្រកាន់មនុស្សដែលត្រូវបានចាប់ខ្លួនថាជាប់ "ខ្សែរយៈយួន"[1732]។ ដូចដែលបានពិភាក្សានៅក្នុងផ្នែក *ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម* នៃសេចក្តីសន្និដ្ឋាននេះ[1733] នរណាក៏ដោយដែលគេយល់ឃើញថាមានជាប់ទាក់ទងជាមួយនឹងវៀតណាម មិនថាវាជានយោបាយ ជាតិ ពូជសាសន៍ ឬ ជាតិពន្ធុ នោះទេ គឺត្រូវចាត់ទុកថាជាជនក្បត់។ ជាលទ្ធផល ពួកកម្មាភិបាលរោងចក្របានស្វែងរកឲ្យកំណត់អត្តសញ្ញាណ និងចាប់ខ្លួនពួកកម្មករវៀតណាម និងខ្មែរក្រោមទាំងអស់[1734]។ ពួកដែលត្រូវបានសង្ស័យដោយសារសំនៀង និង/ឬ មាន

ណុប ដែលស្ថិតក្នុងគណៈរោងចក្រ។ *សូមមើល* ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.៨ KH 00951926-27។ ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី ៦៨៣៥ EN 01222597 [យ៉ា សេង ហៀង ហៅ ណុប សមាជិករោងចក្រស្ពសរភាគនៅកំពង់គល់ (សមាជិករោងចក្រស្ពសរ) ១១-វិច្ឆិកា-៧៧។ *សូមមើលផងដែរ* ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឯ.១៧ KH 01040121 ។ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឯ.២៣, ២៦ KH 01304977 ។

[1731] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.៥៣ KH 00951932 [អ៊ីង និង ភិន "និយាយថា ពួកនោះជាប់ខ្សែរយៈយួន។"]។

[1732] ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.១២៩-១៣០, ១៣២ KH 01196474-75 ["ក្នុងឆ្នាំ១៩៧៨" និរសាររបស់ អ៊ីង និង "យោធាហ្នឹងនិយាយថាពួកហ្នឹង [ដែលត្រូវបានចាប់] ជាប់ខ្សែរយៈយួន។ ជាប់ខ្សែស្រឡាយ ខ្សែរចិនខ្សែយួន ជាប់ពូជន៍អ៊ីបូល ក្ងានកាត់។" "និរសារតាអ៊ីង យោធាគ្នាគេហ្នឹង [និយាយអំពីខ្សែរយៈយួន]" "គេនិយាយអ៊ីចឹង" "ពេលល្ងាចដើរលេងជួបខ្ញុំ។"]។

[1733] *សូមមើល* V.គ.ព.ក. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – គោលនយោបាយ ប.ក.ក ក្នុងការកម្ទេចជនជាតិវៀតណាម – *អរិភាពរបស់* ប.ក.ក ជនជាតិវៀតណាម និងខ្មែរក្រោម។

[1734] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឯ.១៩ KH 00951928 ["ក្រោយពីចាប់ តាយ៉ាន គេចាប់ផ្តើមចាប់កម្មករធ្វើការនៅរោងចក្រស្ពសរ ជាពិសេសអ្នកដែលមានសញ្ញាតិដើមជាយួន និងខ្មែរក្រោម។"]។

សម្ព្ធរស ត្រូវបានចាប់ខ្លួន[1735]។ ចាប់តាំងពីប្រមាណជាពាក់កណ្តាលឆ្នាំ១៩៧៨ មក "គេចាប់ផ្តើមចាប់កម្មករ [...] មានសញ្ញាតិដើមជាយួន និងខ្មែរក្រោម"[1736]។ យ៉ាងហោចណាស់មានកម្មករ ៣០ នាក់ ដែលគេសង្ស័យថាជាវៀតណាម ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង ត្រូវបានធ្វើមនុស្សឃាត និង ត្រូវបានសម្ងាប់រង្គាល ដោយពួកធ្វើការនៅក្រោម អ៊ីង និង ភិន។ នៅក្នុងតួយ៉ាងមួយផ្សេងទៀត បុរសម្នាក់ជាពូជពង្សវៀតណាម ត្រូវបានចាប់ខ្លួនជាមួយនឹងកូនរបស់គាត់ពីរនាក់[1737]។ គេបានយកអ្នកទាំងនោះចេញទៅដោយរថយន្តមួយមកពីក្រុងបាត់ដំបង[1738]។ បន្ទាប់ពីនោះមក ពុំមានខ្មែរក្រោម ឬ វៀតណាមណាម្នាក់មានវត្តមាននៅក្នុងរោងចក្រស្ករសនេះទៀតទេ[1739]។

[1735] ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៧៦, ៨២ KH 01196466 ["ស៖ ម៉េចបានលោកដឹងថា មនុស្ស ដែលត្រូវបានចាប់ខ្លួនជាខ្មែរកម្ពុជាក្រោម និងវៀតណាម? ឆ.៧៦៖ វាជាជនជាតិស្បែកស និងភាសានិយាយគឺរបៀបខ្មែរកម្ពុជាក្រោម រដឹនៗ។ [...] ដោយសារពួកគេនិយាយរដឹនៗ ខ្ញុំគិតថាពួកគេជាខ្មែរកម្ពុជាក្រោម។ [...] ស៖ នៅពេលដែលលោកនិយាយ ថា មនុស្សមួយចំនួនជាជនជាតិវៀតណាម តើលោកចង់និយាយសំដៅថាយ៉ាងម៉េច ចំពោះជនជាតិវៀតណាមបែបនេះ? ឆ.៨២៖ ព្រោះឃើញស្បែកស និយាយមិនច្បាស់។"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៥៤ KH 00951932 ["ស៖ តើលោកធ្វើដូចម្តេចទើបលោកអាចដឹងថា អ្នកទាំងនោះជាខ្មែរក្រោម? ឆ.៥៤៖ ព្រោះសោយសារពួកនោះនិយាយប៉ែលាំ ដូចពួកអ្នកមកពីខេត្តព្រះត្រពាំង ហើយពួកនោះគឺមានសាច់ស។"]។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៨២ KH 014304982 ["ខ្មែរកម្ពុជាក្រោម ឲ្យតែនិយាយប៉ែឡាំ វាចាប់ហើយ។"]។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១៦ KH 01058787 ["បើកាលណាមានអ្នកណាដែលនិយាយសំឡេងប៉ែឡាំ ជារបៀបខ្មែរក្រោម គេនឹងចាប់យកទៅបាត់ហើយ។"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១៨០ KH 01304992 ["ស៖ ក្រៅពីនិយាយប៉ែឡាំ តើមានលក្ខណៈសម្គាល់អ្វីផ្សេងទៀត ដែលយើងថា ម្នាក់ហ្នឹងជាខ្មែរក្រោមទេ? ឆ.១៨០៖ អត់។"]។

[1736] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១៩ KH 00951928។ លឹម ទីម ត្រូវបានតែងតាំងជាប្រធានសន្តិសុខ និងនិរសារ នៅរោងចក្រស្ករ ដោយ យ៉ាន ក្នុងខែឧសភា ឆ្នាំ១៩៧៨។

[1737] ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៦៦-៦៧, ៧០, ៧៤, ៨០, ៨៣, ៨៥, ១២៧, ១៣០, ១៧៨ KH 01304981-82, 87-88 [នៅពេលដែលរោងចក្រ "ក្រោមការគ្រប់គ្រងរបស់ សារ" "[ពី] ខាងក្នុងរោងចក្រ" សាក្សីបានឃើញនិរសារប្រដាប់ដោយអាវុធ "ប្រាំនាក់" ចាប់ "គ្រួសារតាគួន ហ្នឹងដែលជាប់ខ្សែយួន" យោងតាមអ្វីដែលគេបានប្រាប់សាក្សីនេះ។ អ្នកដែលត្រូវបានចាប់ខ្លួនមាន "ដូចជាបីនាក់ កូនពីរ ឪពុកមួយ" ដែលនៅ "កងចល័ត។"]។

[1738] ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៧២ KH 01304981 [ពួកគេត្រូវបានដឹកចេញតាមឡាន ដែល "មានតែចេញតែពីបាត់ដំបងទៅ ដែលមានឡានទៅ"]។

[1739] ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨៤ KH 01196467 ["ស៖ ក្រោយពេលដែលអ្នកទាំងនោះត្រូវបានគេដឹកចេញទៅ តើនៅមានខ្មែរក្រោម ឬជនជាតិវៀតណាមនៅក្នុងរោងចក្រទៀតទេ? ឆ.៨៤៖ ក្នុងរោងចក្រដូចមិនមាន តែនៅតាមកងចល័តអាចមាន [ខ្ញុំមិនច្បាស់ទេ] ព្រោះខ្ញុំមិនបានដើរ។"]។

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទៅលើពួកកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ ហើយនិងថ្នាក់ក្រោមរបស់ពួកគេ

490. ដោយត្រូវបានចាត់ទុកថាជាជនក្បត់ជាប់ "ខ្សែរយៈឃួន" កម្មាភិបាលភូមិភាគពាយ័ព្យឈ្មោះ យ៉ា សេងហៀង *ហៅ* ណុប ដែលស្ថិតនៅក្នុងគណៈអោងចក្រនេះ ត្រូវបានផ្តោតគោលដៅជាពិសេស និងបានបញ្ជូនទៅកាន់ ស-២១ ដោយសារតែសមាជិកភាពរបស់គាត់ពិតប្រាកដ ឬដែលត្រូវបានគេយល់ឃើញអំពីក្រុមនយោបាយណាមួយ (ពួកកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ និងថ្នាក់ក្រោមរបស់ពួកគេ)[1740]។

iv. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

491. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ឹម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងអោងចក្រស្ករសកំពង់គល់[1741]ៃ អំពើប្រល័យពូជសាសន៍ក្រុមជនជាតិវៀតណាម ក្នុងប្រទេសកម្ពុជា (ជាពិសេសខ្មែរក្រោម)[1742] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[1743] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូល

[1740] ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី ៦៨៣៥ EN 01222597។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.ព.ម, ៤២ KH 00951930-31 ["គេនិយាយថា ពួកដែលគេចាប់នោះ [រួមទាំងណុប] ជាពួកក្បត់ ជាខ្សែរយៈឃួន [...] និងជាខ្មាំង"]។

[1741] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ឹម ទិត្យ នៅឡើយ។ ទាំងនេះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងពួកកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ ហើយនិងថ្នាក់ក្រោមរបស់ពួកគេ ហើយនិងអំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ និង ការបាត់ខ្លួនដោយបង្ខំ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មនេះ តាមរយៈ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៨, ១១៨ខ។ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៤-៦, ៨, ១៣ខ។

[1742] សូមមើល V.គ. ឧក្រិដ្ឋកម្ម - ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម។

[1743] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃអំពើមហាប្រល័យនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភស្តុតាងទាក់ទងនឹងអោងចក្រស្ករសកំពង់គល់តែមួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃអំពើមហាប្រល័យដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងអោងចក្រស្ករសកំពង់គល់ផង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់

ហេតុនយោបាយប្រឆាំងនឹងពួកកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ និងថ្នាក់ក្រោមរបស់ពួកគេ និងអាពាហ៍ពិពាហ៍ដោយបង្ខំ[1744] និងការបាត់ខ្លួនដោយបង្ខំ)។

ង. មន្ទីរសន្តិសុខបាណន់

i. សេចក្ដីផ្ដើម

492. មន្ទីរសន្តិសុខបាណន់ ស្ថិតនៅក្នុងស្រុកសង្កែនៃតំបន់១ នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម។ នៅក្នុងកំឡុងពេលនេះ វាបានផ្លាស់ប្ដូរការគ្រប់គ្រងពីដោយថ្នាក់ស្រុក ទៅជាការគ្រប់គ្រងដោយកម្មាភិបាលយោធាថ្នាក់តំបន់។ នៅដើមឆ្នាំ១៩៧៧ គឺពីរខែបន្ទាប់ពី **យ៉ឹម ទិត្យ** បានទៅមើលទីកន្លែងនោះ ពួកកម្មាភិបាលភូមិភាគនិរតីបានគ្រប់គ្រងមន្ទីរសន្តិសុខនោះ។ **យ៉ឹម ទិត្យ** បានប្រជុំនៅក្បែរមន្ទីរសន្តិសុខទាំងនៅមុន និងក្រោយពេល ដែលគាត់ត្រូវបានតែងតាំងជាផ្លូវការជាលេខាតំបន់១។ គាត់ក៏បានបញ្ជាឲ្យចាប់ខ្លួនឡើងវិញផងដែរ ទ្ទេរពួកដែលត្រូវបានដោះលែងពីមន្ទីរសន្តិសុខដោយ តាប៉ែត។

493. ចាប់ពីប្រមាណជាពាក់កណ្ដាលឆ្នាំ១៩៧៧ រហូតដល់ ប្រាំមួយខែនៅមុនពេលដែលពួកវៀតណាមបានមកដល់ មន្ទីរសន្តិសុខនេះដាក់អ្នកទោសជាច្រើនប្រមាណជា ៥០០នាក់។ នៅថ្ងៃមួយ អ្នក

បង្កើតបានជាផ្នែកនៃប្រព័ន្ធមួយដែលមានការរៀបចំ ក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង ហើយការសម្លាប់នៅលើទីតាំងនិមួយៗទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ឹម ទិត្យ។

[1744] សូមមើល V.ខ.៧. ឧក្រិដ្ឋកម្ម-ភូមិភាគពាយ័ព្យ-អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ។ ស.ព.អ បានប្ដឹងទៅកាន់ ស.ច.ស ពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកសង្កែ នៅត្រង់ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងអាពាហ៍ ពិពាហ៍ដោយបង្ខំ និង អំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៤-៦។ នៅក្នុងដីកាសន្និដ្ឋាននោះ ត្រង់កថាខណ្ឌ៨ គាត់បានថ្លែងដោយមានភ័ស្តុតាងគាំទ្រថា រោងចក្រស្ករសកំពង់គល់ គឺជា "ផ្នែកមួយនៃស្រុកសង្កែ តំបន់១ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ"។ ព្រំប្រទល់ស្រុកសង្កែក៏ត្រូវបានពិភាក្សាផងដែរ នៅក្នុង៖ ឯកសារ D272/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខណ្ឌ ៤-៦។ ឯកសារ D344/1/3 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើសុំរបស់ យ៉ឹម ទិត្យ សុំធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងស្រុកសង្កែ ចុះថ្ងៃទី៦ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ ១៥-១៩។ ចៅក្រមនៃ អ.ប.ជ យល់ឃើញថា រោងចក្រស្ករសស្ថិតនៅត្រង់ព្រំប្រទល់ស្រុកសង្កែ ដែល ស.ច.ស ត្រូវបានប្ដឹង *សូមមើល* ឯកសារ D344/1/6 សេចក្ដីសម្រេចលើសំណើរបស់ យ៉ឹម ទិត្យ សុំធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងស្រុកសង្កែ (តំបន់ ១) ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ៤២។

ទោសរហូតដល់ទៅ ៤០នាក់ ត្រូវបានយកចូលទៅក្នុងមន្ទីរសន្តិសុខនេះ ហើយ អ្នកទោសពី ប្រាំ ទៅ ១០នាក់ ត្រូវបានសម្លាប់ចោលជារៀងរាល់ថ្ងៃ។ អ្នកទោសខ្លះបានស្លាប់ដោយសារអាហារហូបចុកមិនគ្រប់គ្រាន់ និង/ឬ ខ្វះការព្យាបាលផ្នែកវេជ្ជសាស្ត្រ។ ពួកអ្នកទោសត្រូវបានធ្វើទារុណកម្មក្នុងអំឡុងពេលសួរចម្លើយ។ មន្ទីរសន្តិសុខនេះបានធ្វើប្រតិបត្តិការយ៉ាងពេញទំហឹង ដែលបណ្តាលឲ្យកម្មាភិបាលភូមិភាគនិរតី ក្រោយមកបានបញ្ជូនពួកអ្នកទោសដែលនៅរស់រានមានជីវិតទាំងអស់នៅមន្ទីរសន្តិសុខបាណន់ ទៅកាន់មន្ទីរមួយទៀតដែលទូលាយជាងនេះ និងដែលនៅក្បែរនោះ ហៅថាមន្ទីរសន្តិសុខខ្នងគ្ង។

494. ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** ពីឧក្រិដ្ឋកម្មនានាទាក់ទងនឹងមន្ទីរសន្តិសុខបាណន់ ដូចតទៅ៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើពួកកម្មាភិបាលពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកនៅក្រោមបង្គាប់ អំពើអមនុស្សធម៌ផ្សេងៗទៀត (ការឃុំខ្លួននៅក្នុងលក្ខខណ្ឌអមនុស្សធម៌) និងឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតដោយគិតទុកជាមុន នៅក្រោមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[1745]។

ii. ប្រតិបត្តិការ និងទីតាំង

495. មន្ទីរសន្តិសុខបាណន់ ត្រូវបានបង្កើតឡើងដោយកម្មាភិបាលពាយ័ព្យ នៅពេលចាប់ផ្តើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ[1746]។ នៅដើមឆ្នាំ១៩៧៧ ពួកកម្មាភិបាលនិរតីបានគ្រប់គ្រងលើប្រតិបត្តិកា

[1745] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426550-51, 60។

[1746] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៣ KH 00934387។ ឯកសារ D219/68 កំណត់ហេតុស្តាប់ចម្លើយ យ៉ើន ចាន់ធូ ឆ.១០៤ KH 01037234។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.១ KH 01114646 ។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ើត ឆ.៣ KH 01023829។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១ KH 01040093។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យើន ឆ.២២ KH 01210564។ ឯកសារ D219/830 កំណត់ហេតុស្តាប់ចម្លើយ សេង រ៉ត ឆ.៩៨ KH 01327990។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៣ KH 01023838។ ឯកសារ D219/545 កំណត់ហេតុស្តាប់ចម្លើយ ផេរ ប៉ែត ឆ.២០ KH 01157538។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* EN 01002637, 33។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម ឃួន ឆ.២៨ KH 00960656។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៨៦-១៨៧ KH 01153619។ មានសាក្សីខ្លះត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងនៅមន្ទីរសន្តិសុខបាណន់ នៅដើមឆ្នាំ១៩៧៦ *សូមមើល* ឯកសារ D118/144 កំណត់ ហេតុស្តាប់ចម្លើយ កើត ជឿន ឆ.១ KH 01027349-51។ ឯកសារ D219/549 កំណត់ហេតុស្តាប់ចម្លើយ អ៊ុ

ង អ៊ីម ឆ.៣៥ KH 01157578។ ឯកសារ D219/68 កំណត់ហេតុស្តាប់ចម្លើយ យ៉ៀន ចាន់ធូ ឆ.២-៣, ១១៨ KH 01037222, 35។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ ស្ងួម ឆ.៣ KH 01114646។ ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.២៥, ២៧ KH 01300406។ នៅមុនរបបកម្ពុជាប្រជាធិបតេយ្យ ទីកន្លែងនេះជាមូលដ្ឋានយោធារបស់ លន់ នល់ *សូមមើល* ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934384-85។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៤៣ KH 00960694។ ឯកសារ D219/944 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១១ KH 01415388។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៣ KH 01023838។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១ KH 01040093។ ឯកសារ D219/545 កំណត់ហេតុស្តាប់ចម្លើយ ផេ ប៉ែត ឆ.២៩ KH 01157539។ ឯកសារ D118/144 កំណត់ហេតុស្តាប់ចម្លើយ កើត ជ្ងឿន ឆ.៤ KH 01027352។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002633។

ររបស់វា[1747]។ បន្ទាប់ពីការគ្រប់គ្រងមួយរយៈពេលមក ពួកគេបានបញ្ជូនពួកអ្នកទោសដែលនៅរស់រានមានជីវិតទាំងអស់ពីមន្ទីរសន្តិសុខបាណន់ ទៅកាន់មន្ទីរសន្តិសុខខ្នងគ្ន[1748]។ មន្ទីរសន្តិសុខបាណ

[1747] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ រ៉ែ រួម ឆ.១២-១៣ KH 01238678-79 ["ដល់ឆ្នាំ១៩៧៧ នៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី"។ "នៅក្នុងឆ្នាំ១៩៧៧ ហ្នឹងប្រហែលជាដើមឆ្នាំ"]។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.៦-៧, ៤៥ KH 00920211, 17 ["រហូតដល់ខែ១ ឆ្នាំ១៩៧៧ ទើបគេចាប់ខ្ញុំ [...] គឺនៅពេលពួកនិរតីចូលមកដល់ទីនេះហើយ ព្រោះគេយល់ថាខ្ញុំជាកម្មាភិបាល [...] ភូមិភាគពាយ័ព្យ។ កាលណោះគេចាប់កម្មាភិបាលភូមិភាគពាយ័ព្យ [...] គេយកខ្ញុំទៅឃុំឃាំងនៅមន្ទីរសន្តិសុខស្រុកបាណន់"]។ ឯកសារ D1.3.11.36 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ន្ជួន ម្ជួន ដោយ ក.ស.ព EN 00210530, 32 [សាក្សីត្រូវបានចាប់ខ្លួននៅ "ខែមករា ឆ្នាំ១៩៧៧" និង "ដាក់នៅគុកបាណន់"។ នៅពេលនោះ ពួកកម្មាភិបាលភូមិភាគនិរតីកំពុងបោសសម្អាតពួកកម្មាភិបាលភូមិភាគពាយ័ព្យ ហើយសាក្សីរូបនេះ "ជាខ្សែរបស់ តាសាយ"។ តាសាយ ជាលេខាតំបន់១ នៅមុនពេលដែល តាវ៉ាញ បានជំនួសគាត់]។ (*សូមកត់សម្គាល់* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៣ KH 01040093-94។ ឯកសារ D219/825.1.2 បញ្ជីអ្នកទោសនៅស-២១ ដោយ ក.ស.ច.ស លេខរៀងទី៩១៣ EN 01222369 [ជា ហ្ជួន ហៅ វ៉ាញ លេខាតំបន់១ ២០-មិថុនា-៧៧])។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934384-85 [នៅទំនប់កង្ហត ពួកនិរតីបានចោទប្រកាន់សាក្សីរូបនេះថាបានខុសមាត់ខុសក នៅពេលដែល តាវ៉ាញ មើលការខុសត្រូវលើទំនប់។ ពួកនេះបានចាប់ តាវ៉ាញ សាក្សីរូបនេះ និង អ្នកធ្វើការម្នាក់ទៀតឈ្មោះ ផាន់។ សាក្សីរូបនេះ និង ផាន់ ត្រូវជាប់គុកនៅបាណន់]។ (*សូមកត់សម្គាល់* សាក្សី ទ្ជៀប ទិត្យ បាននិយាយថា គេចាប់គាត់យកទៅដាក់គុកជាមួយនឹង ណង នី ហើយការចាប់ខ្លួនគាត់ត្រូវបានបញ្ជាដោយ តាព្រ៊ុ។ ដូច្នេះ ទ្ជៀប ទិត្យ ត្រូវបានចាប់ខ្លួនដោយពួកកម្មាភិបាលភូមិភាគនិរតី នៅមុនពេលដែល តាព្រ៊ុ ត្រូវបានបញ្ជុះសក្តិពីអនុលេខាតំបន់១ ទៅជាកសិករនៅតំនប់កង្ហត។ *សូមមើល* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទ្ជៀប ទិត្យ ឆ.៤, ៧ KH 00960688-89។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈ្ជឿង ប៊ាន ឆ.៦ KH 01122396។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈ្ជឿង ប៊ាន ឆ.២៧, ៣៣ KH 01110177-78។ ឯកសារ D219/825.1.2 បញ្ជីអ្នកទោសនៅស-២១ ដោយ ក.ស.ច.ស លេខរៀងទី៦២៧៣ EN 01222575 [ម៉ុល សុត ហៅ ព្ជ្ជ ជាងសំណង់ទ្វារទឹកនៅតំបន់១ ២៩-តុលា-៧៧])។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535 [នៅទំនប់កង្ហត "អនុបញ្ជាការជាអ្នកឲ្យឈ្ជួបចាប់យកទៅគុកបាណន់ [...] ក្នុង១ថ្ងៃ"] (*សូមកត់សម្គាល់* សាក្សីរូបនេះបានធ្វើការនៅទំនប់កង្ហតនៅមុន និងក្រោយពេលដែលពួកកម្មាភិបាលភូមិភាគនិរតីបានមកដល់ នៅក្រោយពេលទំនប់បាក់នៅឆ្នាំ១៩៧៧ ហើយនៅពេលដែលវាត្រូវបានជួសជុលហើយ សាក្សីរូបនេះបានចាកចេញពីទំនប់ *សូមមើល* ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១៧-១៩ KH 01205202-03។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧០ KH 01196542។ ឯកសារ D34.1.10 បទសម្ភាសន៍ ហេង ទារ ហៅ តាប៉ែត ដោយ ស្ទ្ជីវ ហេងឌ័រ KH 00964054-55។ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ ว๊ាន់ ជា ឆ.១៤ KH 01121736។ *សូមមើលផងដែរ* ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ ស្ជ្ជ ឆ.១៧ KH 01114650។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៥ KH 01196544 (*សូមកត់សម្គាល់* ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤០ KH 01205207)។ ឯកសារ D219/960 កំណត់ហេតុស្តាប់ចម្លើយ ស ជ្ជួន ឆ.៦, ៨, ១០-១២ KH 01429706។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៣៩-៤០ KH 00920172។

[1748] ទោះបីជាសាក្សីនានាប្រែប្រួលពីពេលវេលាដែលអ្នកទោសទាំងឡាយត្រូវបានបញ្ជូនឲ្យទៅនៅកន្លែងផ្សេងក៏ដោយ ក៏អ្នកទាំងនោះច្រើនបាននិយាយថា វាបានកើតឡើង ពីកណ្តាល ទៅដល់ចុងឆ្នាំ១៩៧៨ *សូមមើល* ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១១, ១៣ KH 00934386-87 ["ក្រោយពេលគេដោះលែងខ្ញុំ ខ្ញុំឮថា ប្តូរគុក [...] ដែលកាលណោះពួកកម្មាភិបាលនិរតីជាអ្នកប្តូរទីកន្លែង ហើយបានប្រហែលកន្លះឆ្នាំទើបវៀតណាមចូល"] ឆ.៤៥ KH 00934391 ["ខ្ញុំឮពីយោធាពេលដែលខ្ញុំជាប់គុកបាណន់ ថាតាទិត គាត់ជាគណៈតំបន់"]។ (*សូមកត់សម្គាល់* សាក្សី ទៀ១ ទិត្យ បាននិយាយថាគាត់ត្រូវបានចាប់ខ្លួន និងដាក់ក្នុងមន្ទីរឃុំឃាំងជាមួយនឹង ណាង នី។ ខណៈដែលនៅក្នុងមន្ទីរសន្តិសុខបាណន់ ទៀ១ ទិត្យ បានឃើញគេកំពុងសាងសង់ដំបូលគុកថ្មី។ ក្រោពេលដែលគេដោះលែងគាត់ គាត់បានឮថាគេប្តូរពួកអ្នកទោសទៅកាន់ទួលគ្រូ។ *សូមមើល* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀ១ ទិត្យ ឆ.៤, ១៦ KH 00960688, 90 ។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀ១ ទិត្យ ឆ.៦១, ៧៣ KH 0112058, 59)។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ីា ឆ.៦០ KH 00960670 [នៅខែកក្កដា ឬ ខែសីហា ឆ្នាំ១៩៧៨ "ពេលដែលខ្ញុំរត់មកសហការណ៍សាំងរ៉ាំង ទើបខ្ញុំដឹងថា គេប្តូរមន្ទីរសន្តិសុខបាណន់ទៅដាក់នៅខាងខ្នងគ្ងរវិញ"] (*សូមកត់សម្គាល់* សាក្សីរូបនេះបាននិយាយថាគាត់បានរត់ទៅកាន់សហការណ៍សាំងរ៉ាំង នៅពេលដែលនិរសារបស់ តាម៉ុក បានប្រាប់ តាប៉ែត ឲ្យវេចឥវ៉ាន់រើទៅកាន់កន្លែងមួយផ្សេងទៀត។ តាប៉ែត បាននិយាយថា គាត់ត្រូវបានយកចេញដោយ តាម៉ុក ហើយកងការពាររបស់គាត់ មួយខែឬពីរខែក្រោយការចាប់ខ្លួន តាញ៉ឹម។ តាញ៉ឹម នៅក្នុងមន្ទីរស-២១ នៅថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨។ *សូមមើល* ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ីា ឆ.២ KH 00960662-63។ ឯកសារ D34.1.9 បទសម្ភាសន៍ ហេង ទាវ ហៅ តាប៉ែត ដោយ ស្ទីវ ហេងឌ័រ KH 00965615, 22, 47។ ឯកសារ D1.3.18.2 ចម្លើយសារភាពរបស់ មូល សម្ត្ត ហៅ រស់ ញ៉ឹម នៅស-២១ KH 00024650 [លេខាភូមិភាគពាយ័ព្យ ១៤-មិថុនា-១៩៧៨])។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002642 ["គុក [...] ត្រូវបានខ្មែរក្រហមរុះរើចោលតាំងពីចុងឆ្នាំ១៩៧៨ [...] ដែលមានឈ្មោះហៅថា គុកគ្ងរ"]។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ ស្ងួម ឆ.៧, ២៧ KH 01114647, 51 ["ប្រហែលជាពីរទៅបីខែមុនរបបខ្មែរក្រហមដួល គេបានរើបញ្ជូនអ្នកទោសទាំងអស់យកទៅដាក់នៅ [...] គេហៅថា គុកខ្នងគ្ង"]។ *សូមមើលផងដែរ* ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យៀន ឆ.២៣ KH 01210565 ["នៅពេលដែល ពួកនិរតី មកដល់ គេយកមកដាក់នៅជិតខ្នងគ្ង"] (*សូមកត់សម្គាល់* សាក្សីរូបនេះបានលើកឡើងថា ការណ៍នេះបានកើតឡើងនៅចុងឆ្នាំ១៩៧៦ ឬចុងឆ្នាំ១៩៧៧ ប៉ុន្តែនៅពេលដែលអ្នកសម្ភាសន៍បានបញ្ជាក់ថាតើពួកអ្នកទោសត្រូវបានបញ្ជូនឆ្ពងស្ទឹងពីចុងឆ្នាំ១៩៧៧ ឬយ៉ាងណា សាក្សីរូបនេះបាននិយាយថា "បាទត្រូវ" *សូមមើល* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យៀន ឆ.២៦-២៧, ៦២, ៨៧-៨៨ KH 01305001, 04, 07)។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002649-50 (*សូមកត់សម្គាល់* ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ ស្ងួម ឆ.២០ KH 01114650)។ ឯកសារ D219/545 កំណត់ហេតុស្តាប់ចម្លើយ ផរ ប៉ែត ឆ.៥០KH 01157541 ។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ្ងឿម ឆ.២០-២៣, ៣៩ KH 01157565-66, 68 [បន្ទាប់ពីសាក្សីរូបនេះត្រូវបានដោះលែងពីមន្ទីរសន្តិសុខបាណន់ នៅថ្ងៃបន្ទាប់គុកនោះត្រូវបានគេផ្ទាស់កន្លែងទៅខ្នងគ្ង។ ពួកកម្មាភិបាលភូមិភាគនិរតីបានមកដល់ក្រោយ]។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៤, ៨ KH 01023838-39, 40 ["មន្ទីរសន្តិសុខខ្នងគ្ង ត្រូវបានបង្កើតឡើងនៅប្រហែលពាក់កណ្តាលឆ្នាំ១៩៧៦ ពេលដែលគេលើកមន្ទីរសន្តិសុខពីក្បែរវត្តបាណន់ [...] គឺនៅក្នុងជំនាន់គ្រប់គ្រងរបស់ពួកពាយ័ព្យ"]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ៊ីន ឈួយ ឆ.២០ KH 01149401 ["នៅចុងឆ្នាំ១៩៧៦ គេបានឃុំអ្នក

ន់ ស្ថិតនៅក្នុងភូមិបាណន់ ឃុំកន្ទឺ ស្រុកសង្កែ នៃតំបន់១ នៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[1749]។

496. មន្ទីរសន្តិសុខបាណន់ តាំងនៅខាងត្បូងបរិវេណវត្តបាណន់ក្រោម ក្បែរភ្នំបាណន់ និងខាងលិចស្ទឹងសង្កែ[1750]។ បរិវេណមន្ទីរសន្តិសុខនេះ មានបណ្តោយមិនតិចជាង ៥០ម៉ែត្រ និងទទឹងមិនតិច

ទោសនៅត្រើយខាងកើតស្ទឹង ហើយគុកនេះ នៅតែបន្តប្រើប្រាស់ទៀត នៅពេលដែលពួកនិរតីមកដល់។ កន្លែងនោះ គេនៅតែបន្តហៅថា ខ្នងគ្ងូ ដដែល"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៨ KH 01023830 ["គេរើគុកបាណន់ មកដាក់នៅកន្លែងខ្នងគ្ងូ តាំងពីជំនាន់ពួកពាយ័ព្យគ្រប់គ្រងម្ល៉េះ"]។

[1749] *សូមមើល ខ១ាហារណ៍* ឯកសារ D118/146 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខតំបន់១ KH 01385882 ["គុកបាណន់ មានទីតាំងស្ថិតនៅ [...] ក្នុងភូមិបាណន់។ នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ភូមិបាណន់បានស្ថិតនៅក្នុងឃុំកន្ទឺ ស្រុកសង្កែ តំបន់១ [...] មានចម្ងាយប្រហែលជា ២៣ គីឡូម៉ែត្រ នៅទិសនិរតីនៃក្រុងបាត់ដំបង"]។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.១ KH 01114646។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៨៦, ១៨៩ KH 01153619-20។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934384-85។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៦២ KH 00960671។ *សូមមើលផងដែរ* ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងឿន ម៉ត ឆ.៤, ៦-៧ KH 01155821។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១០២ KH 01122415។ ឯកសារ D219/452 កំណត់ហេតុស្តាប់ចម្លើយ ធី ជា ឆ.២ KH 01129761-62។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៤ KH 01117281-82។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៣ KH 00967983។ សព្វថ្ងៃនេះ ទីកន្លែងមន្ទីរសន្តិសុខបាណន់គឺ ភូមិបាណន់ ឃុំកន្ទឺ២ ស្រុកបាណន់ ខេត្តបាត់ដំបង *សូមមើល* ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៨៩ KH 01153620។ ឯកសារ D118/146 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខតំបន់១ KH 01385882។

[1750] <u>វត្តបាណន់ក្រោម</u>៖ *សូមមើល ខ១ាហារណ៍* ឯកសារ D118/146 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខតំបន់១ KH 01385882 ["គុកបាណន់ មានទីតាំងស្ថិតនៅត្រង់ផ្នែកខាងត្បូងនៃវត្តបាណន់ក្រោម [...] នៅខាងក្រៅបរិវេណវត្ត"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002637 ["នៅមុខប្រាសាទបាណន់ ចម្ងាយប្រហែល២៥០ម៉ែត្រមកធ្វើជាគុកសម្រាប់ឃុំឃាំងអ្នកទោស"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៤៥ KH 00960694 ["គុកគឺមានទីតាំងនៅចន្លោះវត្តបាណន់ក្រោម និង វត្តបាណន់លើ តែវានៅគៀកនឹងវត្តបាណន់ក្រោម"]។ ឯកសារ D219/68 កំណត់ហេតុស្តាប់ចម្លើយ ឃឿន ចាន់ធូ ឆ.៩៩, ១០៦ KH 01037233, 34។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ រ៉ែ រួម ឆ.២ KH 01238676។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៦ KH 00934385 (*សូមមើលផងដែរ* ផែនទីរបស់សាក្សីនៅត្រង់ឯកសារ D118/146 របាយកាណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខតំបន់១ KH 01385885)។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៥ KH 01114646។ ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហែម ប្រេង ឆ.៣៧ KH 01300408។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៣១ KH 01117289 (*សូមមើលផងដែរ* ផែនទីរបស់សាក្សីនៅត្រង់ឯកសារ D219/410.2 ផែនទីរបស់ ហ៊ីម ឆុងលី KH 01117278)។ ឯកសារ D219/954 កំណត់ហេតុស្តាប់ចម្លើយ ឈ៊ីង ឈឿត ឆ.៣, ២៩ KH 01425185, 89។

ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម ឃួន ឆ.២៦ KH 00960656។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/374 កំណត់ហេតុស្តាប់ចម្លើយ ឃិន ឃីម ឆ.២២០ KH 01110550 ["គេប្រើវត្តសម្រាប់ដាក់អ្នកទោស"]។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.៤៦ KH 00920217 ["គុកនោះគឺស្ថិតនៅក្នុងវត្តបាណន់តែម្តង"]។ ឯកសារ D219/946 កំណត់ហេតុស្តាប់ចម្លើយ ឡៅ កង ឆ.៤៩ KH 01415417 ["ស៖ តើម៉ៅ បានប្រាប់លោកអ្វីខ្លះ អំពីរឿងរ៉ាវដែលកើតឡើងនៅប្រាសាទបាណន់នោះ? ឆ.៤៩៖ គេប្រាប់ថា បើមានចាប់មនុស្ស [...] គេយកទៅសម្លាប់នៅហ្នឹងហើយ"]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤០ KH 01205207 ["គុកនោះនៅខាងត្បូងវត្ត[បាណន់លើ]"]។ <u>ភ្នំបាណន់</u>៖ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៨ KH 00960692 ["នៅជើងភ្នំខាងជើងប្រាសាទបាណន់ មានចម្ងាយ ៥០០ម៉ែត្រពីរោងដាក់អ្នកទោស"]។ ឯកសារ D118/144 កំណត់ហេតុស្តាប់ចម្លើយ កើត ជឿន ឆ.៤ KH 01027352 [មន្ទីរសន្តិសុខបាណន់ "មានទីតាំងនៅជើងភ្នំបាណន់"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002638 ["ភ្នំបាណន់ដែលមានចម្ងាយ២៥០ម៉ែត្រស្ថិតនៅខាងក្រោយគុកនោះ"]។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.២, ៤ KH 00920168។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៨១ KH 00967992 ។ ឯកសារ D219/68 កំណត់ហេតុស្តាប់ចម្លើយ ឃឿន ចាន់ធូ ឆ.៣២ KH 01037225 ["ប្រហែល ១ គីឡូម៉ែត្រពីមន្ទីរសន្តិសុខទៅជើងភ្នំបាណន់"]។ *សូមមើលផងដែរ* ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៣៤ KH 01157568។ ឯកសារ D219/374 កំណត់ហេតុស្តាប់ចម្លើយ ឃិន ឃីម ឆ.២២០ KH 01110550។ <u>ស្ទឹងសង្កែ</u>៖ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៀន ឆ.៥៦-៥៧ KH 01040171 [មន្ទីរសន្តិសុខបាណន់ "គឺវាមានចម្ងាយប្រហែល ៣០០ ទៅ ៤០០ ម៉ែត្រ [...] នៅខាងលិចស្ទឹងសង្កែ"]។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៥៧ KH 01132057 ["[វា] ស្ថិតនៅខាងលិចស្ទឹងសង្កែ"]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ផ្ទ ឈួយ ឆ.២២ KH 01149401 ។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ សឿន ម៉ត ឆ.៩០ KH 01155834 ។ ឯកសារ D219/410.2 ផែនទីរបស់ ហ៊ីម ផុងលី KH 01117278 ។ ឯកសារ D219/68 កំណត់ហេតុស្តាប់ចម្លើយ ឃឿន ចាន់ធូ ឆ.១០១ KH 01037233 ។

ជាង ៣០ម៉ែត្រនោះទេ[1751]។ វាត្រូវបានហ៊ុំព័ទ្ធដោយលួសបន្ទា ដោយមានផ្លូវចូលមួយនៅពីមុខ និងមួយផ្សេងទៀតនៅពីក្រោយ[1752]។ អគារចំនួនបីត្រូវបានប្រើប្រាស់ដើម្បីឃុំឃាំងអ្នកទោស[1753] ដែលស្ថិតនៅជាប់នឹងទីកន្លែងសួរចម្លើយ[1754]។

[1751] ឯកសារ D118/146 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខតំបន់១ KH 01385884 ["បរិវេណនោះ [...] មានទទឹងប្រវែងប្រហែលជា ៣០ ម៉ែត្រ និងបណ្តោយប្រវែងប្រហែលជា ៦០ ម៉ែត្រ"]។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៨ KH 01114647 ["បរិវេណគុកនោះ [...] មានទំហំប្រហែលជា៤០ម៉ែត្រទទឹង និង៥០ម៉ែត្រទៅ៦០ម៉ែត្របណ្តោយ"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* EN 01133056 ["បរិវេណគុកមានផ្ទៃដីប្រហែល២រ៉ៃ"]។

[1752] ឯកសារ D118/146 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខតំបន់១ KH 01385884 ["បរិវេណនោះត្រូវបានការពារដោយរបងនៅខាងមុខមួយ និងរបងនៅខាងក្រោយមួយ [...]។ របងនៅខាងក្រោយ រួមមានខ្សែលួសបន្ទាចំនួនបីជួរ"]។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៨ KH 01114647-48។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌៀន ឆ.២២ KH 01210564។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ រ៉ែ រួម ឆ.១១ KH 01238678 ["នៅជុំវិញកន្លែងនោះ មានដាក់ខ្សែភ្លើងឆក់ ខ្ញុំម្តងម្កាលក៏ឆក់ពីខ្សែភ្លើងនោះដែរ"]។ ឯកសារ D219/68 កំណត់ហេតុស្តាប់ចម្លើយ ឃឿន ចាន់ធូ ឆ.១០០ KH 01037233។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002644 ការរៀបរាប់របស់ សន ប៊ុន KH 01002652។

[1753] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៨ KH 00934386 (*សូមមើលផងដែរ* ផែនទីរបស់សាក្សីនៅត្រង់ឯកសារ D118/146 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងមន្ទីរសន្តិសុខតំបន់១ KH 01385885)។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២១ KH 00960691។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៥, ៨ KH 01114646-48 ។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហែម ហ៊ីង KH 01002641, ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002644, ការរៀបរាប់របស់ សន ប៊ុន KH 01002652។ ឯកសារ D219/68 កំណត់ហេតុស្តាប់ចម្លើយ ឃឿន ចាន់ធូ ឆ.៣, ១០០ KH 01037222, 33។ ឯកសារ D118/144 កំណត់ហេតុស្តាប់ចម្លើយ កើត ជឿន ឆ.៤ KH 01027352។ *សូមមើលផ្ទុយពីនេះ* ឯកសារ D118/144 កំណត់ហេតុស្តាប់ចម្លើយ កើត ជឿន ឆ.៤ KH 01027352 ["ខ្ញុំជាប់ឃុំឃាំងនៅក្នុងអាគារមានតែមួយខ្នងប៉ុណ្ណោះ[...]នៅពេលនោះ មិនមានអាគារផ្សេងទៀតទេ"]។

[1754] ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៥ KH 00960692 ["កន្លែងសួរចម្លើយមានតែមួយទេ គឺជារោងតូចមានទំហំ៣x៦ម៉ែត្រ បាំងជិតដោយសង្កសី និងប្រក់សង្កសី មានចំងាយ១០ម៉ែត្រ ពីរោងដែលគេឃុំខ្ញុំ"]។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១១ KH 00934386 ["កន្លែងសួរចម្លើយ ដែលមានចម្ងាយ៣០ម៉ែត្រពីរោងឈើដាក់អ្នកទោស"]។ ឯកសារ D219/68 កំណត់ហេតុស្តាប់ចម្លើយ ឃឿន ចាន់ធូ ឆ.១០១-១០២ KH 01037233 ["ហើយកន្លែងសួរចម្លើយ នៅឆ្ងាយ [...] ប្រហែលជា ២០០ ម៉ែត្រទៀត"] ឆ.៣, ២០ KH 01037222, 24 ["មន្ទីរសន្តិសុខនោះ មាន [...] ១ ផ្ទះ សម្រាប់សួរចម្លើយ"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002637-38, ការរៀបរាប់របស់ សន ប៊ុន KH 01002652។

iii. វចនាសម្ព័ន្ធសិទ្ធិអំណាច និង ការប្រាស្រ័យទាក់ទង

497. សាក្សី វ៉ែ រួម ដែលកាលនោះ ជាយោធាស្រុក និងជាអ្នកយាមគុកនៅទីនោះ បាននិយាយថា គាត់បានឃើញ **យ៉ីម ទិត្យ** "មុនពួកនិរតីមកដល់ប្រហែលជា២ខែគាត់ទៅមើល"[1755]។ វ៉ែ រួម បាននិយាយថា កម្មាភិបាលនិរតី "គ្រប់គ្រង" នៃមន្ទីរសន្តិសុខនោះ "នៅក្នុងឆ្នាំ១៩៧៧ ហ្នឹងប្រហែលជាដើមឆ្នាំ"[1756]។ សារ៉ាន់ ដែលជាប្រធានគុក និងជាប្រធានកងអនុសេនាធំរបស់ វ៉ែ រួម បានប្រាប់គាត់ថា "[តាទិត្យ] គណៈតំបន់ថ្មី"[1757]។ វ៉ែ រួម បានដឹងថា "តាទិត្យ មកពីនិរតី" និង "គាត់ថ្នាក់ធំ ថ្នាក់ខេត្តថ្នាក់ភូមិភាគ គាត់ធំ"[1758]។

498. ដំណើរទស្សនកិច្ចរបស់ **យ៉ីម ទិត្យ** ទៅកាន់មន្ទីរសន្តិសុខបាណន់ ក្នុងឆ្នាំ១៩៧៧ ត្រូវគ្នាទៅនឹងពេលវេលាដែល **យ៉ីម ទិត្យ** ត្រូវបានគេឃើញនៅក្នុងផ្នែកនានានៃតំបន់១។ នៅពេលជាមួយគ្នានោះ កម្មាភិបាលភូមិភាគនិរតីកំពុងចាប់មនុស្សជាច្រើននៅតំបន់១ ហើយបញ្ជូនពួកគាត់ទៅកាន់មន្ទីរសន្តិសុខបាណន់។ សៅ ជាប់ បានផ្តល់ភ័ស្តុតាងលម្អិតជូនទៅអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ស្តីពីវត្តមានយ៉ាងសកម្មរបស់ **យ៉ីម ទិត្យ** នៅទំនប់កង្ហត និងនៅក្នុងស្រុកគាស់ក្រឡ នៅឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧[1759]។ ទ្ធន មួន ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យ និងជាលេខាសហការណ៍មួយក្នុងស្រុក

[1755] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.៤៧, ៤៩ KH 01238686 ["ខ្ញុំឃើញដែរ គេបើកឡានទៅបាណន់ កន្លែងគុកហ្នឹង [...] ឃើញឡើងទៅលើមួយភ្លែតបាត់ទៅ។ [...] មុនពួកនិរតីមកដល់ប្រហែលជា២ខែគាត់ទៅមើល"]។

[1756] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១២-១៣ KH 01238678-79 ["ដល់ឆ្នាំ១៩៧៧ នៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី តែពេលនោះ ខ្ញុំចេញហើយ។ នៅក្នុងឆ្នាំ១៩៧៧ ហ្នឹងប្រហែលជាដើមឆ្នាំខ្ញុំអត់ចាំ"]។

[1757] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.៤៧, ៥១ KH 01238686 ["ឆ.៤៧៖ [...] កាលនោះ ខ្ញុំស្គាល់ព្រោះមេគាត់ប្រាប់ថា [តាទិត្យ]គណៈតំបន់ថ្មី។ ពីដើមមេភូមិភាគឈ្មោះ រស់ ញ៉ឹម [...] ស៖ [...] អ្នកណាអ្នកប្រាប់ថាបុរសនោះជាគណៈភូមិភាគថ្មី? ឆ.៥១៖ សារ៉ាន់ ជាអ្នកប្រាប់"]។

[1758] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.៤៥-៤៦ KH 01238686។

[1759] <u>វគ្គរៀនសូត្របីថ្ងៃ និងការធ្វើទស្សនៈកិច្ចទៅកាន់ទីកន្លែងទំនប់កង្ហត</u>៖ ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៤-១៥, ២២, ៥៥, ៦១, ៦៣ KH 01425219-20, 26-28 [សាក្សីរូបនេះត្រូវរបួសនៅពាក់កណ្តាលឆ្នាំ១៩៧៦ ហើយបន្ទាប់ពីព្យាបាលបានបីខែគាត់បានជួប យ៉ីម ទិត្យ នៅក្នុងវគ្គរៀនសូត្រមួយនៅទំនប់កង្ហត ជាកន្លែងពលកម្មដោយបង្ខំ]។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៤១, ៦៦ KH 01477613, 17 ["ឆ.៤១៖ មុនរៀនសូត្រហ្នឹង គេមើលទំនប់កង្ហតហ្នឹង។ [...] ស៖ កាលហ្នឹងលោកបាននិយាយគ្នាជាមួយតាម៉ុក និងទាទិត្យ ទេ? ឆ.៦៦៖ និយាយតើ ពេលដើរគាត់បង្ហាញ មិត្តធ្វើចេះ។ ពេលហ្នឹងតាម៉ុក និងតាទិត្យ និយាយប្រាប់ថា មិត្តត្រូវធ្វើអ៊ីចេះ"] ឆ.៥, ១១, ១៣, ២០, ៣៧ KH 01477606-12 ["ហើយរៀនបានរយៈ៣ថ្ងៃបែកគ្នា" "ការប្រជុំហ្នឹង ប្រជុំខែយើង ខែជេស្ឋ ខែអាសាឍ អាលើកទំនប់[កង្ហត]នេះហ្នឹង" និងនៅមុនវាបាក់។ អ្នកចូលរួម "មកគ្រប់កន្លែងគ្រប់ស្រុក" "ខាងនិរតីមិនទាន់មានមកទេ"] ឆ.១៦-១៨, ២៤ KH 01477609-10 [នៅក្នុង

> បាត់ដំបង បាននិយាយថា នៅខែមករា ឬ ខែកុម្ភៈ ឆ្នាំ១៩៧៧ គាត់ត្រូវបានចាប់ខ្លួនដោយពួកកម្មាភិបាលភូមិភាគនិរតី និងឃុំខ្លួននៅមន្ទីរសន្តិសុខនោះ "ពីព្រោះពួកគេយល់ថាខ្ញុំជា [...] កម្មាភិបាលពាយ័ព្យ"[1760]។ គាត់បានរំឭកឡើងវិញថា៖ "ពេលនោះពួកនិរតីចាប់ផ្តើមចូលមកហើយ" ហើយពួកនេះបានចាប់ខ្លួនពួកកម្មាភិបាលពាយ័ព្យ[1761]។ ណង នី និង ទៀប ទិត្យ បាននិយាយថា ពួកគាត់ត្រូវបានឃុំខ្លួននៅមន្ទីរសន្តិសុខបាណន់ នៅពេលមួយរវាងពាក់កណ្តាលឆ្នាំ១៩៧៧ និងខែវិច្ឆិកា ឆ្នាំ១៩៧៧ នៅក្រោយពួកកម្មាភិបាលភូមិភាគនិរតីបានចាប់លេខាតំបន់១ ឈ្មោះ តាវ៉ាញ នៅទំនប់កង្ហត ប៉ុន្តែនៅមុនពេលដែលពួកគាត់បានបញ្ចុះសក្តិអនុរបស់គាត់គឺ តាព្រ៊ុំ[1762]។

ការប្រជុំរៀនសូត្រហ្នឹង យ៉ីម ទិត្យ និង តាម៉ុក "គេឧទ្ទេសនាមខ្លួនគេ" និងបានធ្វើបទបង្ហាញ]។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៦៥, ៦៨-៦៩, ៧១, ១៣៩ KH 01244126-27, 36។ ឯកសារ D219/984 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៥ KH 01477653។ *សូមមើលផងដែរ* III.D.3.a. មុខតំណែង អំពើ និង ទង្វើរបស់ យ៉ីម ទិត្យ – ការចូលរួមចំណែករបស់ យ៉ីម ទិត្យ នៅក្នុងផែនការឧក្រិដ្ឋកម្មរួមនៅភូមិភាគពាយ័ព្យ – អំពើ និង ទង្វើផ្សេងៗទៀតរបស់ យ៉ីម ទិត្យ នៅភូមិភាគពាយ័ព្យ – ការលេចមុខជាលើកដំបូងរបស់ យ៉ីម ទិត្យ នៅភូមិភាគពាយ័ព្យ។ <u>ការប្រជុំជាមួយយោធាស្រុកគាស់ក្រឡ</u>៖ ឯកសារ D219/982 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៨-៣០, ៣៣, ៤៤-៤៧ KH 01477628-29, 31 ["ឃើញ[អន]ចាប់យកទៅសម្លាប់ [...] នៅគាស់ក្រឡ" "ខ្ញុំសួរថា មិត្តឯងធ្វើឃាតកសម្លាប់ប្រជាជនហ្នឹង អ្នកណាចាត់តាំងមក។ គាត់ថាឈ្មោះ ទិត្យ ហ្នឹង" "ហើយក្នុងឆ្នាំ៧៦ ៧៧ ហ្នឹង [...] អាហ្នឹងគេស្រាវជ្រាវរកចាប់រហូត។ ការចាប់ហ្នឹងទល់ពួកនិរតីចូលមក" "ពីរនាក់ហ្នឹងគឺតាទិត្យ និងតាម៉ុក [...] ឃើញមកប្រជុំញ៉ីក" ជាមួយនឹង "អន, ប៉ក់, ថាច"។ "គេមកប្រជុំនៅគាស់ក្រឡ"]។ ឯកសារ D219/983 កំណត់ ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៣-១៤, ៤២ KH 01477637-38, 43។ ឯកសារ D219/984 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១០ KH 01477654។

[1760] ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន ម្ហួន ឆ.១២-១៣ KH 00891131។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន ម្ហួន ឆ.៦-៧, ៤៥ KH 00920211, 17។ *សូមមើលផងដែរ* ឯកសារ D1.3.11.36 កំណត់ហេតុសម្ភាសន៍ ឆ្លួន ម្ហួន ដោយ ក.ស.ព EN 00210530, 32។

[1761] ឯកសារ D118/18 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន ម្ហួន ឆ.១៣ KH 00891131។ *សូមមើលផងដែរ* ឯកសារ D1.3.11.36 កំណត់ហេតុសម្ភាសន៍ ឆ្លួន ម្ហួន ដោយ ក.ស.ព EN 00210530។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន ម្ហួន ឆ.៧ KH 00920211។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ ស្ងួម ឆ.១៧ KH 01114650 ["ពួកភូមិភាគនិរតីចូលមកកាន់កាប់នៅក្នុងតំបន់នេះ ស្រុកបាណាន់ ក្នុងពាក់កណ្តាលឆ្នាំ១៩៧៧"]។

[1762] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934384-85 ["ពួកនិរតីបានចូលមកដល់ គេក៏ចោទខ្ញុំថា [...] កាលណោះ [...] ដោយសារតែពួកនិរតី [...] គេក៏ចាប់ តាវ៉ាញ យកទៅសម្លាប់ ហើយគេក៏ចាប់ខ្ញុំ និងម្នាក់ទៀតនៅកងចល័តដែរ [...] យកដាក់នៅគុកបាណាន់"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៧ KH 00960689 ["តាព្រ៊ុំ ជាអ្នកគ្រប់គ្រងនៅទំនប់កង្ហត ជាអ្នកបញ្ជាឲ្យ [...] ចាប់ខ្ញុំ [...] ហើយគាត់ឲ្យយោធាបញ្ជូនខ្ញុំទៅដាក់នៅគុកបាណាន់តែ

499. **យ៉ីម ទិត្យ** បានធ្វើការប្រជុំនៅក្នុងបរិវេណមន្ទីរសន្តិសុខនេះ និងបានប្រើអំណាចរបស់គាត់លើសិទ្ធិសេរីភាពរបស់អ្នកទោសនៅទីតាំងនេះនៅមុន និងក្រោយពេលរូបគាត់ទទួលបានការតែងតាំងជាលេខាតំបន់១ ជាផ្លូវការ[1763]។ នៅចុងឆ្នាំ១៩៧៧ និងមកទល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីនានាបានសង្កេតឃើញ **យ៉ីម ទិត្យ** ធ្វើសុន្ទរកថាទៅកាន់អ្នកចូលរួមក្នុងចំនួនដ៏ច្រើន ដែលរួមទាំងគណៈស្រុក និងយុទ្ធជនជាច្រើនរយនាក់ផងដែរ[1764]។ នៅក្នុងឱកាសមួយក្នុងចំណោមឱ

ម្តង។ នី ដែលជាមិត្តភ័ក្តរបស់ខ្ញុំនោះ [...] ក៏គេចាប់គាត់យកទៅដាក់គុកបាណន់ដែរ"]។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦ KH 01122396 ["តាព្រំ [...] អនុគណៈតំបន់១"]។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៣៣ KH 01110178 ["តាព្រំ ត្រូវបានគេដកចេញពីតំណែងរបស់គាត់ហើយ ដោយគាត់បានមកធ្វើការជាមួយខ្ញុំ ជាមេជាងទ្វារទឹក"]។ ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោសនៅស-២១ ដោយ ក.ស.ច.ស លេខរៀងទី៩១៣ EN 01222369 [ជា ហ្ជន ហៅ រ៉ាញ លេខាតំបន់១ ២០-មិថុនា-៧៧] លេខរៀងទី៦២៧៣ EN 01222575 [ម៉ុល សុត ហៅ ព្រំ ជាងសំណង់ទ្វារទឹកនៅតំបន់១ ២៩-តុលា-៧៧]។

[1763] ក្នុងអំឡុងពេលនៃការឃុំខ្លួន ណង នី នៅមន្ទីរសន្តិសុខនេះ ចាប់ពីពេលណាមួយចន្លោះពាក់កណ្តាលឆ្នាំ១៩៧៧ និងខែវិច្ឆិកា ឆ្នាំ១៩៧៧ រហូតដល់ប្រាំមួយខែមុនពេលវៀតណាមកដល់ គាត់ "បានឮយោធាថា តាទិត្យ ជាគណៈតំបន់។"។ *សូមមើល* ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៤៥ EN 00970458។

[1764] <u>១៩៧៦ ឬ ១៩៧៧</u>៖ ដុស ឌឿន បានចូលរួមការប្រជុំមួយក្នុងភូមិស្វាយបីដើម ឃុំកន្ទឺ ស្រុកបាណន់ ក្រោមអធិបតីរបស់ យ៉ីម ទិត្យ ដែល "មនុស្សរាប់រយទៅប្រជុំ"។ *សូមមើល* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.២០២-២០៦, ២២៨-២៣០ KH 01305016-17, 198-19។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៥២-៥៦ KH 01210568។ ទោះបីជា ដុស ឌឿន បាននិយាយថា តាទិត្យ គឺជាកម្មាភិបាលពាយ័ព្យ និងជាប្រធានស្រុកទទួលបន្ទុកឃុំកន្ទឺមួយ ស្រុកបាណន់ក៏ដោយ គាត់ក៏បាននិយាយផងដែរថា អ្នកដែល "ហៅប្រជាជនទៅប្រជុំ" "គាត់នៅកាន់កាប់អ្នកនៅកាប់ទំនប់កង្ហត ហ្ម៉ង" ត្រូវបានគេឃើញនៅដើមឆ្នាំ១៩៧៦ "ដើរមើលគេជីកប្រឡាយ" នៅកង្ហត និង "អត់ដក [ពីដំណែងទេ]" នៅពេលដែលកម្មាភិបាលភូមិភាគនិរតីបានមានវត្តមាន និង "នៅក្នុងរបបហ្ម៉ង រហូតដល់វៀតណាមចូល"។ គាត់បានរៀបរាប់ពី តាទិត្យ ថាមាន "រាងធំ ក្បាលទំពែកបន្ដិច ហើយខ្ចៅ។" *សូមមើលផងដែរ* ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៤៧-៥១, ៥៨ KH 01210567-68។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.២០១, ២០១៧-២០៩, ២១៣-២២០, ២២៤ KH 01305016-18។ <u>ចុងឆ្នាំ១៩៧៧</u>៖ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៥-៧៦ KH 01196544 ["តាទិត្យ ធ្លាប់មកប្រជុំដែរ គាត់មកមុនដំបូងគាត់នៅបាណន់។ [...] ប្រជុំខែច្រូតស្រូវ ចុងឆ្នាំ១៩៧៧ ជិតដាច់ហើយ។"]។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤០-៤១ KH 01205207-08 ["ប្រជុំនៅវត្តបាណន់លើ ហើយគុកនោះនៅខាងត្បូងវត្ត។ [...] ច្រើនគ្នាមានទាំងកម្មាភិបាល សហករណ៍ គណៈស្រុក តំណាងចល័ត និងតំណាងយុវជន គឺមានមនុស្សរាប់រយ។"]។ <u>ចុងឆ្នាំ១៩៧៨</u>៖ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឆ.៣០, ៣៣, ៤៤ KH 01149403, 06 ["កិច្ចប្រជុំនោះ ប្រហែលជានៅអំឡុងខែ១១ ឆ្នាំ១៩៧៨" "ក្រោយពេល តាប៉ែត បានបាត់ខ្លួន [...] ក្នុងវត្តបាណន់ក្រោម។ ការប្រជុំនោះមានរយៈពេលមួយសប្តាហ៍ ដោយមាន តាទិត្យ ជាប្រធានអង្គប្រជុំ [...] ជា [...] គណៈភូមិភាគ ឬក៏ជាគណៈតំបន់"។ "ប្រហែល បី ទៅបួនពាន់" "សាមាជិកកងទាំងអស់មកពីស្រុកសង្កែទាំងមូលត្រូវបានអញ្ជើញឲ្យចូលរួម"។]។ <u>ឆ្នាំ</u>

កាសទាំងនោះ យ៉ឹម ទិត្យ បានបញ្ជាអ្នកចូលរួមឲ្យ "គោរពតាមការចាត់តាំងរបស់អង្គការ"[1765]។ ក្នុងឱកាសមួយផ្សេងទៀតនោះ ប្រធានបទនៃកិច្ចពិភាក្សាទាំងនោះគឺ "គិញសម្ងាត់ និងអ្នកជាប់ខ្សែ ឃ្លួន"[1766]។ នៅពេលដែលកម្មាភិបាលភូមិភាគពាយ័ព្យ តា ប៉ែត ដែលជាគណៈតំបន់១ រហូតដល់ពេលរូបគាត់ត្រូវបានដកចេញពីតំណែង បានបញ្ជាឲ្យ "ទាហាន [...] របស់ខ្ញុំ" ដែលយាមគុក "តែ

<u>១៩៧៩</u>៖ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ សឿន ម៉ត ឆ.៥០, ៧២, ៧៥ KH 01155828, 32 ["កិច្ចប្រជុំនៅបាណន់ធ្វើឡើងនៅក្នុងឆ្នាំ១៩៧៩ [...] ប៉ុន្តែរបបខ្មែរក្រហមមិនទាន់ដួលរំលំនៅឡើយទេ។ [...] កិច្ចប្រជុំ [...] ធ្វើឡើងនៅក្នុង [...] វត្តបាណន់។ [...] ខ្ញុំមើលជុំវិញទៅ ឃើញថាអ្នកចូលរួមកិច្ចប្រជុំសុទ្ធតែយោធា។ ហើយមានប្រហែលជាបួន ទៅប្រាំរយនាក់ដែលសុទ្ធជាទ័ព។"]។

[1765] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤៣ KH 01205208។ *សូមមើលផងដែរ* ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.៦២, ៨២ KH 01425174-77 [នៅជិតចំនប់កង្ហត "វាមុន [វៀតណាមចូលមក] [...] [គាត់ប្រាប់] កុំឲ្យប្រឆាំងជាមួយនិរតី។"]។ ក្នុងឆ្នាំ១៩៧៧ ក្នុងស្រុកសង្កែ យ៉ឹម ទិត្យ "ចាត់តាំង" សៅ ជាប់ ឲ្យធ្វើការស៊ើបអង្កេតដើម្បីរាយការណ៍អំពីការ "ខុសឆ្គង" ណាមួយ និងបានប្រាប់គាត់ថា "បើ [ប្រជាជន] ប្រព្រឹត្តធ្ងន់ធ្ងរត្រូវសម្លាប់គឺឲ្យសម្លាប់។ សៅ ជាប់ បាននិយាយថា គឺ យ៉ឹម ទិត្យ ជាអ្នកដែល "ចាត់តាំង [ឲ្យសម្លាប់មនុស្ស]។"។ *សូមមើល* ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១២១ KH 01244134 និង ឆ.១១៤, ១១៦, ១១៨, ១២០, ១២៣ KH 01244133-34។ *សូមមើល ផ្ទុយពីនេះ* ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.៧៨ KH 01425177 ["និយាយតែល្អហ្នឹងឯង។"]។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៦៧ KH 01477617 ["ហិង្សាអីខ្ញុំមិនដឹងទេ។ [...] ខាងលើគេដឹកនាំល្អតើ គេមិនធ្វើហិង្សាអាក្រក់ទេ។"]។

[1766] D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ្ងន ឈួយ ឆ.៣០ KH 01149403 (*កត់សម្គាល់* ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ្ងន ឈួយ ឆ.៥៦ KH 01149407)។ ក្នុងឆ្នាំ១៩៧៦ ក្នុងស្រុកសង្កែ សៅ ជាប់ បានស្តាប់ យ៉ឹម ទិត្យ ពិភាក្សាពីសកម្មភាពរបស់ខ្មាំងខាងក្នុង និងខាងក្រៅ ដោយបានសង្កត់ធ្ងន់ពីតម្រូវការចាំត្រូវត្រូវការពារប្រឆាំងនឹង "ខ្មាំងមានរូបភាពអ្វីខ្លះ។" *សូមមើល* ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៥ KH 01477610 និង ឆ.៥, ១១, ១៣ KH 01477607-08. ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៧០-៧១ KH 01244127។ ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៤-១៥, ២២, ៥៥, ៦១, ៦៣ KH 01157546, 47, 50-51។ ក្នុងឆ្នាំ១៩៧៨ ក្នុងស្រុកសង្កែ រ៉ី ផាន់ បានស្តាប់ យ៉ឹម ទិត្យ និយាយ៖ គាត់ "និយាយអំពីខ្មាំងផ្ទៃក្នុងដែលណាក់ខ្ជួនស៊ីរ្ជងផ្ទៃក្នុងរបស់ចលនាយើយ ហើយក៏មានពួក សេ.អ៊ុ.អា កា.ហ្សេ.បេឃ្លួន ណាក់ខ្ជួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែប្តូរមើលពួកទាំងនេះ ហើយបើយើងមានព័ត៌មានទាក់ទងនឹងសកម្មភាពពួកនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង។" *សូមមើ*ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ រ៉ី ផាន់ ឆ.៣, ៥ KH 01040093-94។ ឯកសារ D219/245 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ រ៉ី ផាន់ KH 01364043។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ រ៉ី ផាន់ ឆ.១១ KH 01040097 [យ៉ឹម ទិត្យ "មានអត្តចរិតស្ងួតបួត។"]។

មួយ" ក្នុងស្រុកបាណន់ឲ្យដោះលែងអ្នកទោសប្រមាណជា ៤០នាក់ រួចមក ក្រោយពី "លែងបីថ្ងៃ [ពួកគេត្រូវ] ចាប់" មកវិញដោយ **យ៉ីម ទិត្យ**[1767]។

500. មន្ទីរសន្តិសុខបាណន់បានផ្លាស់ប្តូរពីការគ្រប់គ្រងដោយថ្នាក់ស្រុក ទៅមន្ត្រីយោធាថ្នាក់តំបន់[1768]។ ទៀប ទិត្យ ដែលបានជាប់ឃុំឃាំងក្នុងពេលណាមួយចន្លោះពាក់កណ្តាលឆ្នាំ១៩៧៧ និងខែវិច្ឆិកា ឆ្នាំ១៩៧៧ ដោយកម្មាភិបាលភូមិភាគនិរតី និងត្រូវបានដោះលែងក្នុងរយៈពេលប្រាំមួយខែមុនពេលដែលវៀតណាមបានមកដល់នោះ បាននិយាយថា រូបគាត់ "ដឹងពីការប្តូរនៅពេលដែល [...] ជាប់

[1767] ឯកសារ D34.1.10 បទសម្ភាសន៍ ហេង ទាវ ហៅ ប៉ែត ដោយ ស្ទីវ ហេដឌ័រ KH 00964054-55 ["ទាហានទាំងប៉ុន្ឌាន [...] របស់ខ្ញុំ [...] ខ្ញុំប្រាប់" ឲ្យដោះលែង "៤០ប្តាយនាក់" នៅគុកបាណន់ "តែមួយទេ"។ "បាទដល់លែងបីថ្ងៃ វាចាប់បណ្តោយ។" អ្នកចាប់គឺ "ទិត្យ លេខាតំបន់។"]។ *សូមមើលផងដែរ* ឯកសារ D1.3.11.15 បទសម្ភាសន៍ ហេង ទាវ ហៅ ប៉ែត ដោយ ស្ទីវ ហេដឌ័រ KH 00388312។

[1768] ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១៣, ១៥ KH 00960690 ["មុនដំបូងគុកបាណន់គ្រប់គ្រងដោយយោធាស្រុក តែក្រោយមកគុកនោះគ្រប់គ្រង [...] ដោយយោធាតំបន់។"]។ ឯកសារ D219/546 កំណត់ហេតុស្តាប់ចម្លើយ ផរ ប៉ែត ឆ.៣ KH 01157545 ["ពីដើមគុកបាណន់ស្រុកកាន់កាប់ តែក្រោយមកតំបន់កាន់កាប់វិញ។"]។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៦២ KH 00960671 ["ពីដំបូងគុកបាណន់គឺជាគុកថ្នាក់ស្រុក របស់ស្រុកសង្កែ តែក្រោយមក ទើបក្លាយជាគុករបស់តំបន់១"]។ ឯកសារ D118/146 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងតំបន់១ KH 01385882 ["ពីដំបូង វាគឺជាគុកមួយកម្រិតថ្នាក់ស្រុក ហើយនៅក្នុងពេលនៃរយៈកាលកម្ពុជាប្រជាធិបតេយ្យ វាបានក្លាយជាគុកមួយកម្រិតថ្នាក់តំបន់វិញ។"]។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ សន ប៊ុន KH 01002652។ <u>ស្រុក</u>៖ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ រ៉ែ រួម ឆ.២ KH 01238676 ["ខ្ញុំនៅយោធាស្រុកសង្កែ"។ "ថ្ងៃទី១ ខែ១ ឆ្នាំ៧៦ [...] ខ្ញុំមកយាមគុកនៅបាណន់។"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002652 [ការរៀបរាប់របស់ សន ប៊ុន៖ "ខ្ញុំ [...] ជាកងយោធាស្រុក [...] គេបញ្ជូនឲ្យមកធ្វើជាកងសន្តិសុខយាមក្នុងគុកបាណន់ នៅពាក់កណ្តាលឆ្នាំ១៩៧៧។"]។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម ឃួន ឆ.៣១ KH 00960657។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៨២ KH 00967992។ <u>តំបន់</u>៖ ឯកសារ D34.1.10 បទសម្ភាសន៍ ហេង ទាវ ហៅ ប៉ែត ដោយ ស្ទីវ ហេដឌ័រ KH 00964054-55 ["ទាហានទាំងប៉ុន្ឌានសុទ្ធតែទាហានរបស់ខ្ញុំ។ នៅចាំគុកចាំអ៊ីហ្ម៉ីង។ [...] មានតែកន្លែងមួយទេ ដាក់តែបាណន់មួយទេ កន្លែងផ្សេងមិនមានទេ។"]។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៨ KH 00934386 ["ខ្ញុំគិតថាគុកនោះជាគុកកម្រិតតំបន់ មិនមែនថ្នាក់ស្រុកទេ ព្រោះគេចាប់មនុស្ស [...] មកពីស្រុកផ្សេងៗមកដាក់នៅទីនោះ។"]។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ ស្ងួម ឆ.៩, ១៥ KH 01114648-49។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៤៦ KH 00920172។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.៤៨ KH 00920217។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៣៣ KH 01117289។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ីម ឆ.៣៨, ៤១ KH 01157568-69។

នៅគុកបាណន់"[1769]។ នៅដើមឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគពាយ័ព្យឈ្មោះ សារ៉ាន់ គឺជាប្រធានកងធំ និងជាប្រធានមន្ទីរសន្តិសុខនេះ[1770]។ គាត់បានរាយការណ៍ទៅកាន់យោធាស្រុក ដែលមានប្រធាន ឈ្មោះ ថាវ ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យ "ទទួលខុសត្រូវ" ខាងមន្ទីរសន្តិសុខ

[1769] ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១៥ KH 00960690។ ទៀប ទិត្យ ត្រូវបានចាប់ខ្លួន និងដោះលែងនៅពេលជាមួយគ្នានឹង ណង នី ដែរ។ ណង នី ត្រូវបានចាប់ខ្លួនក្រោយពេលដែលកម្មាភិបាលភូមិភាគនិរតីបានចាប់ខ្លួនលេខាតំបន់១ តាវ៉ាញ ហើយ ទៀត ទិត្យ បាននិយាយថា អនុរបស់ តាវ៉ាន ឈ្មោះ តាព្រំ បានបញ្ជាឲ្យចាប់ខ្លួនគាត់។ ដូច្នេះ ទៀប ទិត្យ ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលនិរតីមុនពេលតាព្រំត្រូវបានដកពីដំណែង ឲ្យធ្វើជាពលករនៅទំនប់កង្ហត។ គាត់ក៏បាននិយាយថា គេដោះលែងគាត់រយៈពេលប្រាំមួយខែក្រោយមកទៀត និងបានប៉ាន់ប្រមាណថាស្មើនឹង "ប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៨" និយាយថា "៦ខែក្រោយមកទើបវៀតណាមចូល។" ណង នី បានថ្លែងថា ក្រោយពីដោះលែង គាត់បានត្រឡប់ទៅភូមិកំណើតរបស់គាត់វិញរយៈពេលប្រាំមួយខែមុនពេលរត់ពេលវៀតណាមមកដល់។ សាក្សីទាំងពីរមានភាពស៊ីចង្វាក់គ្នា ការណ៍ដែលថាពួកគេត្រូវបានដោះលែងប្រាំមួយខែមុនពេលវៀតណាមកដល់។ *សូមមើល* ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934385។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២, ៤, ៧ KH 00960688-89។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦ KH 01122396។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២៧, ៣៣ KH 01110177-78។ ឯកសារ D219/825.1.2 បញ្ជីអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី ៩១៣ EN 01222369 លេខរៀងទី ៦២៧៣ EN 01222575។

[1770] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.៩, ១៤ KH 01238678-79 [សាក្សីគឺជាអ្នកយាមនៅមន្ទីរសន្តិសុខបាណន់ និងបានចាកចេញនៅពេលកម្មាភិបាលនិរតីមកគ្រប់គ្រងគុកនេះនៅដើមឆ្នាំ១៩៧៧៖ "ឆ.៩៖ ឈ្មោះ សារ៉ាន់ គាត់មកពី [ភូមិភាគពាយ័ព្យ [...] ស៖ តើលោកស្គាល់ប្រធានគុកហ្នឹងទេ? ឆ.១៤៖ ប្រធានគុកឈ្មោះសារ៉ាន់ អនុសេនាធំ។"]។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002645។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ្រឿម ឆ.១៨ KH 01157565។ ឯកសារ D219/545 កំណត់ហេតុស្តាប់ចម្លើយ ផរ ប៉ែត ឆ.២២ KH 01157538។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.២៤ KH 01210565។ ឯកសារ D1.3.11.55 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ដោយ ក.ស.ព EN 00221580។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១២-១៣, ១៥ KH 01238678-79 [បន្ទាប់ពី "នៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី [នៃគុកនេះ] [...] នៅក្នុងឆ្នាំ១៩៧៧ ហ្នឹងប្រហែលជាដើមឆ្នាំ" "សារ៉ាន់ ត្រូវគេចាប់គាត់"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៤៥ KH 00920172 ["ប្រធានសន្តិសុខឈ្មោះ រិន"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហាន់ ធី KH 01002637 ["នៅក្នុងគុកបាណន់ គ្រប់គ្រងដោយមេគុកម្នាក់ដែលមានឈ្មោះថា តាញ៉ិន។"]។

នេះ[1771]។ អ្នកយាមនៅទីកន្លែងនោះរួមមានសាក្សី វ៉ែ រួម ដែលជាយុទ្ធជនកងតូចរបស់ស្រុក[1772]។ ក៏មានយុទ្ធជនផ្សេងទៀតធ្វើការនៅមន្ទីរសន្តិសុខនេះ ក៏ដូចជាអ្នកសួរចម្លើយផងដែរ[1773]។ វ៉ែ រួម បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា ក្នុងឆ្នាំ១៩៧៧ គឺរយៈពេលពីរខែ បន្ទាប់ពីគាត់បានឃើញ **យ៉ីម ទិត្យ** មកទស្សនាមន្ទីរសន្តិសុខនេះ បុគ្គលិកនៅទីកន្លែងនោះត្រូវបានប្តូរ[1774]។ ណង នី និង ទៀ ទិត្យ បានជាប់ឃុំឃាំងនៅទីកន្លែងនេះចាប់ពីប្រហែលជាពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់រយៈពេលប្រាំមួយខែ មុនពេលវៀតណាមចូលមកដល់។ ណង នី បាននិយាយថា ក្នុងអំឡុងពេលនៃការឃុំឃាំងរូបគាត់ គាត់ "បានឮពីយោធា [...] ថាតាទិត គាត់ជាគណៈតំបន់" ហើយ ទៀ ទិត្យ

[1771] ឯកសារ D1.3.11.55 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ដោយ ក.ស.ព EN 00221580 ["តារ៉ន រាយការណ៍ទៅ យោធាស្រុក។"]។ ឯកសារ D131/2.1.87 បញ្ជីឈ្មោះមនុស្ស អ្នកទោស និងកម្មាភិបាលស្រុកសង្កែ តំបន់១ ចុះខែកុម្ភៈ ឆ្នាំ១៩៧៨ លេខរាងទី៩០ KH 00214645 [ថាវ មុនប្រធានយោធាស្រុក បច្ចុប្បន្ន ប្រធានសហករណ៍ឃុំកន្ទឹ ស្រុកសង្កែ តំបន់មួយ]។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.ព KH 01023838 ["តាមដែលខ្ញុំដឹងអំពីយោធាខ្មែរក្រហមម្នាក់ [...] ថាអ្នកទទួលខុសត្រូវមន្ទីរសន្តិសុខបាណន់ ឈ្មោះ ថាវ។"]។ *សូមមើលផងដែរ* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀ ទិត្យ ឆ.១១ KH 00960689។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម ឃួន ឆ.ពព KH 00960657។

[1772] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.២, ៦-៧ KH 01238676-77 ["ខ្ញុំនៅខាងយោធាស្រុកសង្កែ [...] ខ្ញុំមកយាមគុកនៅបាណន់ [...] នៅអនុសេនាតូច។ [...] ខ្ញុំជាយុទ្ធជនសុទ្ធសាធ។"]។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ សន ប៊ុន KH 01002652។ ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៥៥, ៦១, ៦៤ KH 01300410-12 (*សម្គាល់* ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ ស្ងួម ឆ.១៦ KH 01114650)។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៤៧ KH 00920172។

[1773] D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៦ KH 00934387 ["ខ្ញុំបានឮយោធាគេនិយាយថា គេសម្លាប់ [...] ខ្ញុំបានឃើញយោធាគេឆាផ្ទើមនុស្សហូប យោធានោះឈ្មោះ រ៉ុន និង ធីម។"]។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ីម ឆ.១៥, ១៧ KH 01157564-65 ["ខ្ញុំបានស្គាល់យោធាម្នាក់ [...] រ៉ាត់។"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀ ទិត្យ ឆ.ពព KH 00960693 ["ខ្ញុំស្គាល់តែអ្នកសួរចម្លើយខ្ញុំឈ្មោះ ម៉ែន និង ធីម។"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002644 ["គុក **[....]** មានយោធាយាមកាមយ៉ាងតឹងរ៉ឹង។ [...] យោធាដើរយាម ២០នាក់"]។

[1774] D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.៤៩, ៥២ KH 01238686 ["មុនពួកនិរតីមកដល់ប្រហែលជា២ខែគាត់ទៅមើល ក្រោយមកបានមានការផ្លាស់ប្តូរ ពួកពាយ័ព្យ ពេលពួកនិរតីមកជំនួស។ [...] ប្រហែលឆ្នាំ៧៧ ពេលដែលពួកនិរតីចូលមកដល់ គឺពីរខែមុន ការផ្លាស់ប្តូរនៅក្នុងមន្ទីរឃុំឃាំង។"]។

បានប្រាប់អ្នកស៊ើបអង្កេតថា នៅពេលដែលគាត់ជាប់ឃុំឃាំងនោះ "អ្នកយាមគុកនោះគឺគ្រប់គ្រងដោយយោធាតំបន់តែម្តង"[1775]។

501. មេឃុំនៅក្នុងស្រុកនោះបាននិយាយថា "ការងារអ្វីគឺត្រូវតែប្តូរយោបល់ជាមួយគាត់ [យឹម ទិត្យ] ទាំងអស់។ បើមិនរាយការណ៍ទេគឺមិនបានទេ"[1776]។ កម្មាភិបាលភូមិភាគនិរតីនៅថ្នាក់គណៈសហការណ៍ និងប្រធានកងបានទំនាក់ទំនងផ្ទាល់ជាមួយនឹងមន្ទីរសន្តិសុខនេះ នៅពេលដែលស្វែងរកឲ្យមានការដោះលែងអ្នកទោស[1777]។

502. ការដឹងឮរបស់ **យឹម ទិត្យ** អំពីឧក្រិដ្ឋកម្មនានានៅមន្ទីរសន្តិសុខក្រៅប្រព័ន្ធតុលាការនេះបានបង្ហាញតាមរយៈ៖ (i) ការណ៍ដែលគាត់ទៅទស្សនាទីតាំងនោះ មុនពេលកម្មាភិបាលភូមិភាគនិរតីបានគ្រប់គ្រងទីតាំងនោះនៅដើមឆ្នាំ១៩៧៧ (ii) ការទាមទាររបស់គាត់ឲ្យមានរបាយការណ៍លម្អិតនៅក្នុងភូមិនោះ (iii) ការរៀបចំធ្វើការប្រជុំនានារបស់គាត់នៅជិតទីតាំងនោះ (iv) បញ្ជារបស់គាត់ឲ្យចាប់ខ្លួនអ្នកទោសដែលបានដោះលែងនៅទីតាំងនោះមកវិញ និង (v) មុខតំណែងរបស់គាត់ជាលេខាតំបន់១ ដែលផ្តល់សិទ្ធិអំណាចឲ្យគាត់លើទីតាំងនោះ។

[1775] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៤៥ KH 00934391។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀ ប ទិត្យ ឆ.១៥ KH 00960690។

[1776] ឯកសារ D105/8 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.២៣ KH 00794128។ *សូមមើលផងដែរ* ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១៩, ៣១-៣២ KH 01196532-35 [នៅទីតាំងការងារបង្ខំទ៖ប់កង្ហត ក្នុងស្រុកសង្កែខ្ញុំ "រាយការណ៍ទៅឲ្យអង្គការគណៈតំបន់ [...] គេកំណត់ឲ្យរាយការណ៍១ខែហ្នឹងពីរបីដង។ [...] ប្រធានខ្ញុំ [...] មិត្ត ខេន ក៏រាយការណ៍ទៅគណៈតំបន់ដែរ។"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៧ KH 01040094-95 [នៅទីតាំងការងារបង្ខំទ៖ប់កង្ហត៖ "អ្នកដែលនិយាយក្នុងអង្គប្រជុំពេលនោះមាន តាទិត្យ [...] ឆេង បានរាយការណ៍អំពីសកម្មភាពនានាដែលកើតនៅក្នុងឃុំទាំង៧ ដែលគាត់គ្រប់គ្រង។ [...] តាទិត្យ [...] អង្គុយចាំស្តាប់ និងកត់ត្រា។ [...] របាយការណ៍ត្រូវបានធ្វើដោយប្រធានសហការណ៍/ឃុំកន្ទឹ១ និងកន្ទឹ២ [...] ដោយប្រធានសហការណ៍/ឃុំប្រយុទ្ធ ដែលសព្វថ្ងៃហៅថា ភូមិកង្ហត និងឃុំរួងសព្វថ្ងៃនេះគេហៅឃុំចែងមានជ័យ។"]។

[1777] ឯកសារ D219/960 កំណត់ហេតុស្តាប់ចម្លើយ ស ជួន ឆ.៦, ៨, ១០, ១២-១៤ KH 01429707 [នៅចុងឆ្នាំ១៩៧៨ សាក្សីគឺជាកម្មាភិបាលភូមិភាគនិរតី និងជាសមាជិកគណៈសហការណ៍ ដែលបានសុំឲ្យគណៈថ្នាក់លើមកពីភូមិភាគនិរតីរបស់គាត់ដោះលែងប្រជាជនសហការណ៍ ដែលជាប់គុកនៅមន្ទីរសន្តិសុខបាណ។ ទាក់ទងនឹងអ្នកទោស តាពន្ធក សាក្សីបានសរសេរលិខិតមួយទៅកាន់មន្ទីរសន្តិសុខបាណន់ដោយផ្ទាល់ ដើម្បីស្នើឲ្យដោះលែងគាត់ ដែលសំណើនោះត្រូវបានទទួលយកឯកភាព។]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ីម ប្រេង KH 01002649 ["នៅដើមឆ្នាំ១៩៧៨ មេកងខ្ញុំឈ្មោះ ម៉ម នី បានយកសំបុត្រមកឲ្យមេគុកដើម្បីសុំឲ្យដោះលែងខ្ញុំ។ គេដោះលែងខ្ញុំនៅម៉ោង ៧ព្រឹក។"]។

iv. ខ្ញុំក្ដីផ្ទកម្ម

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

503. ដោយយោងទៅលើចំនួននៃការចាប់ខ្លួនដ៏ច្រើន នៅពេលខ្លះមន្ទីរសន្តិសុខបាណន់បានឈានដល់កម្រិតពេញ[1778]។ សាក្សីមួយចំនួនរាយការណ៍ថាមានអ្នកទោសថ្មី ៣០ ទៅ៤០នាក់បានចូលមកមន្ទីរសន្តិសុខនេះនៅថ្ងៃនីមួយៗ[1779]។ សាក្សីម្នាក់បានប៉ាន់ប្រមាណថា នៅក្នុងអគារឃុំឃាំងតែមួយប៉ុណ្ណោះមានអ្នកទោសជាប់ឃុំប្រមាណ ៥០នាក់[1780]។ សាក្សីម្នាក់ទៀតឈ្មោះ ណង នី បាននិយាយថា ក្នុងអំឡុងពេលនៃការឃុំខ្លួនគាត់ដោយកម្មាភិបាលភូមិភាគនិរតី ចាប់ពីប្រហែលជាពាក់កណ្ដាលឆ្នាំ១៩៧៧ រហូតដល់ប្រាំមួយខែមុនពេលវៀតណាមមកដល់ គាត់បានឃើញអ្នកទោស

[1778] *សូមមើល* ឯកសារ D219/548 កំណត់ហេតុស្ដាប់ចម្លើយ អ៊ីង អ៊ីម ឆ.៣៧ KH 01157568 [សាក្សីត្រូវបានដោះលែងពីមន្ទីរសន្តិសុខបាណន់ មួយថ្ងៃមុនពេលគុកនេះផ្លាស់ទៅមន្ទីរសន្តិសុខខ្នងគ្ង៖ "ពេលខ្លះ កន្លែងឃុំឃាំងនោះពេញ ហើយគេយកអ្នកទោសមកមុនទៅសម្លាប់ចោល ហើយគេយកកន្លែងសម្រាប់ដាក់អ្នកទោសមកថ្មី។"]។ ឯកសារ D219/797 កំណត់ហេតុស្ដាប់ចម្លើយ ដុស ឌៀម ឆ.១៧ KH 01305000 ["ពីដើមយកទៅដាក់គុកនៅខាងលិចបាណន់ មើលទៅសម្លាប់ច្រើនពេកបានយកមកដាក់នៅខ្នងគ្ងវិញ។"]។ ឯកសារ D118/77 កំណត់ហេតុស្ដាប់ចម្លើយ ណង នី ឆ.១៦ KH 00934387 ["អ្នកទោសគេបញ្ជូលជារៀងរាល់ថ្ងៃ។"]។ ឯកសារ D219/390 កំណត់ហេតុស្ដាប់ចម្លើយ ហង់ សួម ឆ.១២ KH 01114649 ["នៅពាក់កណ្ដាលឆ្នាំ១៩៧៨ [...] ពេលខ្លះគេដឹកអ្នកទោសរាល់ៗថ្ងៃ ហើយពេលខ្លះ ពីរបីថ្ងៃ ទើបឃើញគេដឹកម្ដង។"]។

[1779] ឯកសារ D118/77 កំណត់ហេតុស្ដាប់ចម្លើយ ណង នី ឆ.១៦ KH 00934387 ["អ្នកទោសគេបញ្ជូលជារៀងរាល់ថ្ងៃ។"]។ ឯកសារ D219/654 កំណត់ហេតុស្ដាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535 ["យ៉ាងហោចណាស់ក្នុងមួយថ្ងៃមានមនុស្ស ៤០នាក់ ត្រូវបានចាប់ខ្លួនយកទៅដាក់នៅទីនោះ។"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ សន ប៊ុន KH 01002652 [" [អ្នកទោស] ប្រហែល ៣០ ទៅ ៤០ នាក់ស្ថិតនៅក្នុងបរិវេណគុកជាប្រចាំ [...] មានអ្នកទោសថ្មីៗ ដែលគេចាប់ខ្លួនមកជារៀងរាល់ថ្ងៃ។"] ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002649 ["ខ្ញុំបានឃើញអ្នកទោសជាច្រើននាក់ត្រូវគេចាប់មកដាក់គុកជារៀងរាល់ថ្ងៃ។"]។

[1780] ឯកសារ D219/390 កំណត់ហេតុស្ដាប់ចម្លើយ ហង់ សួម ឆ.៥-៦ KH 01114646-47 ["មានអ្នកទោសប្រហែល ៤០នាក់ ដែលឃុំនៅក្នុងរោងនោះ [...] ខ្ញុំស្មានទេ ចំនួនអ្នកទោសនៅតាមជួរនោះ ខ្ញុំបានឃើញអ្នកទោសទាំងនោះ ដោយសារពេលខ្លះ គេអនុញ្ញាតឲ្យខ្ញុំយកម្ហូបអាហារទៅឲ្យម្ដាយខ្ញុំនៅទីនោះ។"]។

៥០០នាក់[1781]។ សាក្សីផ្សេងៗទៀត រួមទាំងអតីតអ្នកទោស បានឃើញចំនួនអ្នកទោសតិចជាងនេះ[1782]។

504. អ្នកទោសមកពីទូទាំងស្រុក រួមទាំងទីតាំងការងារដោយបង្ខំទំនប់កង្គ្ត ដែល **យ៉ីម ទិត្យ** បានទៅទស្សនា និងត្រួតពិនិត្យ និងទីកន្លែងផ្សេងទៀតក្នុងតំបន់១[1783]។ បុរស ស្ត្រី ដែលពួកគាត់ខ្លះមាន

[1781] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៨ KH 00934386 ["ពេលខ្ញុំជាប់នៅទីនោះមានអ្នកទោស ៥០០នាក់។ ខ្ញុំឃើញមានអ្នកទោសចេញចូលៗ"]។

[1782] ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៣៩-៤០ KH 00920172 ["ខ្ញុំ [...] ដោះលែងអ្នកទោសរាប់រយនាក់។ [...] កាលនោះគឺនៅក្រោយរបបបង្ហូរ្ស់ហើយ ប្រហែល១ខែឬ២ខែមុនវៀតណាមចូល។"]។ ឯកសារ D105/8 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.២៥ KH 00794129 ["ខ្ញុំបានដោះលែងអ្នកទោសពី ៣០ ទៅ ៤០នាក់។"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១៦ KH 00960690 ["នៅពេលដែលខ្ញុំជាប់គុកនៅបាណន់នោះ មានអ្នកទោសប្រហែលជា ៥០នាក់ តែខ្ញុំគិតថាមានអ្នកទោសច្រើននៅពេលដែលគេប្ជូរគុក"]។ ឯកសារ D34.1.10 បទសម្ភាសន៍ ហេង ទាវ ហៅ តាប៉ែត ដោយ ស្ទីវ ហេដម៉ូ KH 00964054-55 ["ខ្ញុំប្រាប់" ឲ្យដោះលែង "៤០ប្ជាយនាក់" នៅគុកបាណន់ "តែមួយទេ"។ "បាទដល់ លែងបីថ្ងៃ វាចាប់បណ្តោយ។" អ្នកចាប់គឺ "ទិត្យ លេខាតំបន់។"]។ ឯកសារ D219/959 កំណត់ហេតុស្តាប់ចម្លើយ ស ជួន ឆ.៩៦-៩៨ KH 01429698-99 ["យ៉ាងយូរបំផុតបានបីខែ" មុនពេល "វៀតណាមធ្វើសង្គ្រាមរំដោះ [...] ៧៩" សាក្សីបានដោះលែងអ្នកទោសប្រហែលជា ៣១នាក់ ពីគុកបាណន់។]។ ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៥២ KH 01300410 ["[អ្នកទោស] ប្រហែល២០នាក់។"]។

[1783] <u>ស្រុក</u>៖ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934384-85។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២ KH 00960688។ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.១៤ KH 01121736 ។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535។ ឯកសារ D219/430 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.៦៣ KH 01122407។ ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.១១ KH 01300403។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៧, ១១ KH 01157563-64 (*សម្គាល់* ថាសាក្សីកំណត់ថាស្រុកបាណន់ស្ថិតនៅក្នុងតំបន់បី និងថាទួលម្ទេសស្ថិតក្នុងតំបន់៣។ *សូមមើល* ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៧ KH 01157563។ ឯកសារ D219/549 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.១៧ KH 01157576) ។ *សូមមើល* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002638។ <u>កន្លែងផ្សេងទៀតក្នុងតំបន់១</u>៖ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៨ KH 00934386។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៤៦ KH 00920172។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម អ៊ឿម ឆ.៣៨ KH 01157568។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.៣, ៦, ៤៥ KH 00920211, 17។ ឯកសារ D1.3.11.36 ចម្លើយ ន្ជួន ម្ជួន ដោយ ក.ស.ប EN 00210530, 32។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៣៣ KH 01117289-90។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌៀន ឆ.១៤ KH 01210563។

ផ្ទៃពោះ និងកុមារ បានជាប់ឃុំនៅទីកន្លែងនេះ[1784]។ កម្មាភិបាលភូមិភាគនិរតីបានចាត់ទុក "ប្រជាជនណាដែលលួច ឬក៏ក្បត់នឹងប្រទេសជាតិ" ថាជា "ខ្មាំង" និងត្រូវឃុំឃាំងនៅមន្ទីរសន្តិសុខបាណន់[1785]។ អ្នកទោស "ស្រាល" រួមមានអ្នកដែលធ្វើឲ្យបាក់ឧបករណ៍ធ្វើការ លួចអាហារដើម្បីបន្ថយភាពអត់ឃ្លាន និងអ្នកដែលមិនសកម្មការងារ[1786]។ អ្នកទោស "ធ្ងន់" រួមមានអតីតមន្ត្រីរដ្ឋការ

[1784] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១០ KH 00934386។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.១៣ KH 01114649។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៣២ KH 01157568 ។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002637។

[1785] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.២១, ៤១ KH 00934388, 90 ["ពេលខ្ញុំជាក់គុក គេហៅខ្ញុំ 'អា' ឬ 'អាខ្មាំង' [...] ពាក្យថាខ្មាំងគេសំដៅទៅលើប្រជាជនណាដែលលួច ឬក៏ក្បត់នឹងប្រទេសជាតិ។ និយាយរួមអ្នកដែលគេចាប់ គឺគេចោទថា ខ្មាំង ទាំងអស់។"]។ *សូមមើលផងដែរ* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៧, ៥៦ KH 00960689, 95 ["ពេលដែលគេចាប់ខ្ញុំ [...] តាព្រំ [...] និយាយថា ខ្ញុំប្រឆាំងនឹងបក្ស ហើយគាត់ឲ្យយោធាបញ្ជូនខ្ញុំទៅដាក់នៅគុកបាណន់តែម្តង។ [...] ឲ្យតែយើងធ្វើខុសអ្វីនឹងអង្គការរបស់គេ គេចោទយើងថាជាខ្មាំងហើយ។"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535។ ឯកសារ D219/959 កំណត់ហេតុស្តាប់ចម្លើយ ស ជួន ឆ.៩៨ KH 01429699 [នៅចុងឆ្នាំ១៩៧៨ សាក្សីគឺជាកម្មាភិបាលនិរតី ដែលបានដោះលែងមនុស្សពីគុកបាណន់៖ "ខ្ញុំក៏ស្តីរ ចុះតាពន្ធក គាត់ខុសអី គាត់មានរឿងអី? ហើយប្រជាពលរដ្ឋនោះក៏គេប្រាប់ថា ពូពន្ធក ហ្នឹងប្រឆាំងនឹងគេពីរឿងដាំស្រូវ និងព្រោះស្រូវ។"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002646 ["មូលហេតុដែលគេចាប់មនុស្សមកដាក់គុកមកពីគេចោទថាខ្មាំង។"] ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002648 ["គេចោទថា ខ្ញុំជាខ្មាំង"] ការរៀបរាប់របស់ ហាន់ ធី KH 01002637។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៩ KH 01040097 ["ខ្ញុំធ្លាប់ឮថា បើសិនជាមានអ្នកធ្វើការណាធ្វើខុសនៅនឹងកន្លែងការដ្ឋានទំនប់នោះ ខ្មែរក្រហមនឹងចាប់អ្នកមានកំហុសទាំងនោះមកដាក់នៅមន្ទីរសន្តិសុខបាណន់។"]។ ឯកសារ D1.3.11.55 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ដោយ ក.ស.ព EN 00221580 ["ប្រជាជនដែលធ្វើខុសត្រូវបានចាប់ខ្លួន [...] យកមកឃុំ [...] នៅមុខកន្លែងបោះបង់ចោលនៅបាណន់។"]។

[1786] ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៧ KH 00960692 ["អ្នកទោស ៥០នាក់ ដែលជាប់ជាមួយខ្ញុំនោះ ជាអ្នកទោស្រាល។"]។ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៣៥ KH 01196535 [សាក្សីបានធ្វើការនៅទីតាំងការងារដោយង្ខំទំនប់កង្ហតមុន និងក្រោយកម្មាភិបាលនិរតីបានមកដល់ទីនោះ៖ "អនុមេបញ្ជាការជាអ្នកឲ្យ [...] ចាប់ [មនុស្ស] យកទៅគុកបាណន់។ [...] សូម្បីតែខុសបន្តិចបន្តួច ដូចជាធ្វើបាក់ដងចប ដងរ៉ែក។"]។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.១ KH 01114645 ["ក្មួនង៉ែតយំជាខ្លាំង ហើយម្តាយរបស់ខ្ញុំបានដាច់ចិត្តលួចអង្ករ [...] ដើម្បីយកមកឲ្យក្មួនង៉ែតហូប។ ពួកឈ្លប ឬយោធា ក៏បានចោទម្តាយខ្ញុំថា លួចអង្ករ [...]។ ម្តាយរបស់ខ្ញុំត្រូវបានគេចាប់ខ្លួន ហើយយកទៅដាក់ក្នុងគុកវត្តបាណន់។"] (*សម្គាល់* ម្តាយរបស់សាក្សី ហ៊ែម ប្រេង បាននិយាយថា គាត់បានលួចអង្ករ *សូមមើល* ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៤៦-៤៧ KH 01300409)។ ឯកសារ D219/959 កំណត់ហេតុស្តាប់ចម្លើយ ស ជួន ឆ.៩៨ KH 01429698-700។ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.១៣-១៤ KH 01121736។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002637។ *សូមមើលផងដែរ* ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១១៧ KH 01040176។

របប លន់ នល់ កម្មាភិបាលពាយ័ព្យ ដែលគេចាត់ទុកថាជា "ភ្នាក់ងារ ក.ហ្ស.បេ និងគិញ រៀតណាម" និងអ្នកទាំងឡាយណាដែល "ខុសមាត់ខុសកនឹងអង្គការ"[1787]។ អ្នកទោសម្នាក់ ឈ្មោះ ហ៊ែម ប្រេង មានប្តីជាអតីតទាហាន លន់ នល់ បាននិយាយថា គាត់ត្រូវ "គេចោទ [...] ថាខ្ញុំជាខ្មាំងរបស់អង្គការមិនព្រមសារភាពប្រាប់ពីកន្លែងប្តីលាក់ខ្លួន និងប្រវត្តិរបស់បងប្អូនធ្វើអ្វីខ្លះក្នុងសម័យ លន់ ណុល"[1788]។

[1787] ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១១៧, ១២០ KH 01040176 ["អ្នកទោសធ្ងន់គឺជាអ្នកទោសដែលមានជាប់និន្នាការខ្មាំង។ [...] ពួកគេត្រូវបានបញ្ជូនទៅមន្ទីរឃុំឃាំងបាណន់"]។ ឯកសារ D219/373 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.១០៣ KH 01110503។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២១ KH 00960691។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ សន ប៊ុន KH 01002653។ <u>មន្ត្រីរដ្ឋការ លន់ នល់</u>៖ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៨ KH 00934387។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១៦ KH 00960690។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.២, ៤ KH 00920168។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002646។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002637។ <u>កម្មាភិបាលភូមិភាគពាយ័ព្យ</u>៖ ឯកសារ D1.3.11.36 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ដោយ ក.ស.ព. EN 00210530, 32 ["ខែមករា ឆ្នាំ១៩៧៧ ខ្ញុំត្រូវបានគេចាប់ខ្លួន និងឃុំឃាំង [...] ពីព្រោះ [...] កម្មាភិបាលពាយ័ព្យ [...] ត្រូវបោសសម្អាតដោយភូមិភាគនិរតី។ [...] គេឃុំខ្ញុំនៅក្នុងគុកបាណន់។ [...] គេគ្រាន់តែចោទពួកយើង គឺកម្មាភិបាលពាយ័ព្យទាំងអស់ ថាជាភ្នាក់ងារ ក.ហ្ស.បេ ឬគិញរៀតណាម។"]។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន ម្ជួន ឆ.៦, ៤៥ KH 00920211, 17។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៤ KH 00934385។ <u>ខុសមាត់ក</u>៖ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១ KH 00934385 ["ពួកនិរតី [...] ចោទខ្ញុំថា ខ្ញុំខុសមាត់ករនឹងអង្គការគេ [...] គេក៏ចាប់ខ្ញុំ [...] យកទៅដាក់នៅគុកបាណន់។"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៦-៧ KH 00960689 ["គេឲ្យខ្ញុំរែកដីទប់ទឹកស្ទឹងកង់ហត ហើយខ្ញុំនិយាយថា "គ្មាននរណាទប់ទឹកស្ទឹងបានទេ"។ [...] តាព្រំ [...] និយាយថា ខ្ញុំប្រឆាំងនឹងបក្ស ហើយគាត់ឲ្យយោធាបញ្ជូនខ្ញុំទៅដាក់នៅគុកបាណន់តែម្តង [...]។ នី [...] ហាមថា 'អាពួកម៉ាក់ អ្ហែង កុំនិយាយអញ្ចឹង ប្រយ័ត្នគេចាប់យកទៅដាក់គុក។' គ្រាន់តែ គាត់និយាយអញ្ចឹង ក៏គេចាប់គាត់យកទៅដាក់គុកបាណន់ដែរ។"]។

[1788] ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002648 ។ *សូមមើលផងដែរ* ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៤៣-៤៥ KH 01300409។

505. ជើងអ្នកទោស "ត្រូវបានគេដាក់ខ្នោះដែលធ្វើអំពីឈើ ខ្នោះនីមួយៗដាក់អ្នកទោសប្រាំមួយនាក់"[1789] ។ ពួកគេជាប់ខ្នោះជើងសូម្បីតែពេលបត់ជើងក៏ដោយ[1790]។ ជាលទ្ធផលដោយសារការប្រើប្រាស់ខ្នោះយូរពេកបានធ្វើឲ្យ "អ្នកទោសមួយចំនួនគឺមិនអាចក្រោករួចទេ វានៅលើដី" ពេលដោះលែង"[1791]។

[1789] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១០ KH 00934386។ *សូមមើលផងដែរ* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២២ KH 00960691 ["អ្នកទោសគេដាក់ខ្នោះឈើជាប់ជើង រៀបជាពីរជួរ តែគេដាក់តែជើងម្ខាងទេ"]។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៣៩-៤០ KH 00920172។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង អ៊ឿម ឆ.៣៦ KH 01157568។ ឯកសារ D219/374 កំណត់ហេតុស្តាប់ចម្លើយ ឃិន ឃីម ឆ.២២១ KH 01110550-51។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002641 ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002644 ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002648 ["គេនាំខ្ញុំទៅដាក់ខ្នោះជើងក្នុងរោងឃុំឃាំង ដោយយកខ្នោះធ្វើពីឈើមានរន្ធមូលៗ ហើយមានប្រវែងពីរម៉ែត្រចំនួនពីរបន្ទះមកផ្ទុំគ្នារួចវាយស្នៀតសងខាង។ ខ្នោះនេះគេអាចដាក់អ្នកទោសបានចំនួន៥នាក់"] (*កត់សំគាល់* ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៥ KH 01114647 ["កំណត់សំគាល់អ្នកស៊ើបអង្កេត៖ យាយ ហ៊ែម ប្រេង បានប្រាប់ថា អ្នកទោសនៅក្នុងគុកនោះគឺត្រូវបានគេដាក់ច្រវ៉ាក់ជើងជាជួរ។"])។

[1790] ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002649 ["ខ្ញុំត្រូវហុចបាតលោកបន្តគ្នាម្នាក់ម្តងឲ្យអ្នកទោសដទៃទៀត [សម្រាប់ជុះអាចម៍ ជុះនោមដាក់ក្នុងនោះ]។ នៅពេលដែលអាចម៍ពេញបាតលោកហើយ គេឲ្យអ្នកទោសណាដែលនៅដើររួចឲ្យលើកអាចម៍ទៅចាក់ចោល ដោយយោធាដោះខ្នោះជើងចេញ"]។

[1791] ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៣៩-៤០ KH 00920172។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002641 ["រាល់ម៉ោង៤ល្ងាច[រាល់ថ្ងៃ] គេបោះខ្សែ និងពួចៅចូលក្នុងឲ្យដើរវាយស្នៀតខ្នោះណាដែលរលុង"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៥៣-៥៤ KH 01300410 ["អ្នកទោសទាំងអស់ [...] ដាក់ខ្នោះប្រហែលជាបួនដប់ថ្ងៃ គេដោះ គេឈប់ដាក់។ [...] ដោះទាំងអស់"]។

506. លក្ខខណ្ឌរស់នៅគ្មានអនាម័យ[1792]។ ទៀប ទិត្យ ថាគេឲ្យគាត់"ងូតទឹកពីរអាទិត្យ ឬក៏មួយខែម្តង"[1793] ។ ណង នី និយាយថា គាត់ "ត្រូវមូសខាំ និងកើតចៃជាច្រើន"[1794]។ អ្នកទោសត្រូវជុះអាចម៍ ជុះនោមដោយប្រើធុងរួមគ្នា[1795]។

507. អ្នកទោសត្រូវធ្វើពលកម្ម ដែលរួមមានទាំងការយកធុងអាចម៍/ទឹកនោម ទៅចាក់ចោល និងសែងសាកសពទៅដាក់នៅភ្នំជិតនោះ[1796]។

[1792] *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002642 ["ខ្ញុំឃើញអ្នកទោសក្នុងគុកឈឺរាកមួល [...] ទាំងជាប់ខ្នោះជើង។ [...] [អ្នកជាប់ទោស] ត្រូវដេកនៅ និងស៊ីជុះនៅជាមួយគ្នា។ ខ្លួនប្រាណអ្នកទោសកខ្វក់ហួសនិយាយ។ [...] ពេលដេក ខ្ញុំហែកក្រណាត់ខោអាវពីខ្លោច ដែលឈឺស្ពាប់ [...]មករុំធ្វើខ្នើយកើយ ដែលក្នុងរោងគេចាក់អង្គាមធារពេញដី"]។

[1793] ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៦៥ KH 01132058។ *សូមមើលផងដែរ* ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៣៦ KH 01114653 ["ខ្ញុំបានឃើញដោយចៃដន្យ គឺគេបានបណ្តើរពួកអ្នកទោសឲ្យទៅមុជទឹកនៅក្នុងស្ទឹងសង្កែ"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002649 ["ឃប់ឡើង [...] ជ័ររកៅស៊ូមកឲ្យសម្រាប់ងុតបំភ្ជ [...]។ មួយឃប់ៗផ្សែងភ្លើងរោលមុខខ្ញុំឡើងហើម"]។

[1794] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១០ KH 00934386។

[1795] ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៥០ KH 01300410 ["បង្គន់ គឺជុះដាក់ឡាំង រួចយកទៅចាក់ដាក់ដីដែលគេជីកស្រាប់នៅកែ្សរនោះ ជម្រៅមួយសន្ទុងដៃ ហើយមានក្លិនស្អុយ។ [...] ជុះអាចម៍ដាក់ប៉ោត ដាក់តៗគ្នាទៅ ឬនដប់ម្តែនាក់អីចឹងទៅ"]។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៥ KH 01114647។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002649 ["មានបាតលោកពីរបីគេដាក់ក្នុងគុកសម្រាប់ឲ្យជុះអាចម៍ ជុះនោមដាក់ក្នុងនោះ ខ្ញុំត្រូវហុចបាតលោកបន្តគ្នាម្នាក់ម្តងឲ្យអ្នកទោសដទៃទៀត។ នៅពេលដែលអាចម៍ពេញបាតលោកហើយ គេ[ខ្ជែរក្រហម]ឲ្យអ្នកទោសណាដែលនៅដើររួចឲ្យលើកអាចម៍ទៅចាក់ចោល។ [...] ក្លិនខ្លួនខ្ញុំឡើងស្អុយផ្ទេះ"] ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002642។

[1796] ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៥២, ៥៥, ៥៧ KH 01300410-11 ["គេឲ្យធ្វើការ។ [...] គេបញ្ជេញឲ្យដកស្មៅ កាប់កូនឈើប៉ុនៗណេះ។ [...] គេឲ្យធ្វើការបន្តិចបន្ទួចនៅកសិណនៅមុខប្រាសាទ"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002649 ["នៅពេលដែលអាចម៍ពេញបាតលោកហើយ គេឲ្យអ្នកទោសណាដែលនៅដើររួចឲ្យលើកអាចម៍ទៅចាក់ចោល។ [...] គេប្រើឲ្យខ្ញុំចំអិនបបរសម្រាប់អ្នកទោស"] ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002645 ["គេឲ្យពួកយើងធ្វើការនៅក្នុងគុក និងឲ្យខ្ញុំធ្វើការងារផ្សេងៗដូចជា ទៅដងទឹកពីស្ទឹង ឲ្យខ្ញុំសែងខ្លោចពីគុកយកទៅកប់នៅជើងភ្នំមុខប្រាសាទ និងចំអិនបបរឲ្យអ្នកទោស"]។ ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002641 ["ខ្ញុំត្រូវបានគេឲ្យដើរមើលខ្នោះអ្នកទោសផ្សេងទៀត។[...]គេឲ្យខ្ញុំសែងខ្លោចទៅកប់នៅជើងភ្នំមុខប្រាសាទ"]។

508. ពួកគេត្រូវបានគេផ្តល់អាហារតិចតួច ទទួលបានតែបបរវារលាយជាមួយបន្ទែរលួយ ពីរដងក្នុងមួយថ្ងៃ និង "ទឹកផឹក[...] ក្នុងមួយថ្ងៃ គឺបានប្រហែល ៣៥០ម.ល"[1797]។ ហែម ប្រេង និយាយថា៖ "សុខភាព[របស់ខ្ញុំ]ទ្រុឌទ្រោមទៅៗ រាងកាយស្គមស្គាំងសល់តែស្បែកគ្របឆ្អឹង"[1798]។ មានម្តងនោះ ពេលគាត់កំពុងតែហូបអាហារលួចលាក់៖ "អ្នកយាម [...] ក៏បានវ៉ៃខ្ញុំ [...] រហូតដល់ខ្ញុំសន្ពប់"[1799]។ អ្នកទោសដែលឈឺទទួលបានតែ "ថ្នាំសម្រាប់លេប"[1800] ប៉ុណ្ណោះ។ អ្នកទោសមានជំងឺមិនទទួលបានការព្យាបាលនៅមន្ទីរពេទ្យនៅជិតនោះទេ[1801]។

[1797] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១០ KH 00934386 ["ចំពោះរបបហូបចុករបស់អ្នកទោសវិញ គេឲ្យហូបពីរពេលក្នុងមួយថ្ងៃ កាលណោះអ្នកទោសដែលជាប់ជាមួយខ្ញុំមានចំនួន៥០០នាក់ ហើយគេឲ្យអង្ករតែ១០កំប៉ុងទេសម្រាប់ទាំងអស់គ្នា។ មុនដំបូងគេយកអង្ករទៅដាំបានមួយខ្ទះ ហើយគេយកទៅរំលែកជា១០ខ្ទះ ដោយលាយជាមួយទឹកសៅ និងបន្ទែ្ល រលួយ។ ខ្ញុំបានគ្រាប់អង្ករតែ៧គ្រាប់ប៉ុណ្ណោះក្នុងមួយពេល គឺបានប្រហែល៣៥០ម.ល"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៦ KH 00960692 ["គេឲ្យហូបពីរពេល គឺព្រឹក និង ល្ងាច ដោយគេឲ្យបបរពីរវែក ដោយមានអង្ករតែ១០គ្រាប់ លាយជាមួយបន្ទែ្ករលួយៗនិងមានដង្កូវផង"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហែម ប្រេង KH 01002649 ["គេឲ្យខ្ញុំហូបបបរវារមួយថ្ងៃមួយចានធៀម។ [...] បបរមួយខ្ទះធំគេឲ្យដាក់អង្ករពីរបីកំប៉ុង ជួនកាលគេឲ្យដាក់អង្ករ ៥ កំប៉ុង និងដាក់លាយបន្ទែ គឺមានតែជ្រាំងខ្ទុ ហើយចាក់ទឹកពេញខ្ទះ។ ខ្ញុំសែងបបរយកទៅចែកអ្នកទោសនៅតាមរោងឃុំឃាំង"] ការរៀបរាប់របស់ ហែម ហ៊ីង KH 01002642។

[1798] ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002649។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហែម ហ៊ីង KH 01002642 ["រូបរាងកាយខ្ញុំស្គមស្គាំងមានតែស្បែកដណ្តប់ឆ្អឹង"]។

[1799] ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002649។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002646 ["ខ្ញុំតែងតែបេះបោចស្លឹកឈើ ឬវល្លិ៍ ពោលគឺស្លឹកស្អីក៏ដោយឲ្យតែហូបកើត។ ខ្ញុំផ្ទៀតបេះហូបឲ្យតែពេញក្រពះ និងលួចលាក់តាមខ្លួនយកចូលក្នុងគុក"]។

[1800] ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៥ KH 01114647 ["សម្រាប់អ្នកទោស គេឲ្យតែថ្នាំសម្រាប់លេបប៉ុណ្ណោះ។ គេមិនខ្វល់ថា អ្នកទោសស្លាប់ ឬរស់នោះទេ"]។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហែម ប្រេង KH 01002649 ["សូម្បីពេលខ្ញុំឈឺក៏ដោយ គ្មានអ្នកណាម្នាក់ប៉ានមាត់ក អ្វីឡើយ"]។

[1801] ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៥ KH 01114646-47 ["វត្តនេះ[វត្តបាណន់] ត្រូវបានគេប្រើធ្វើជាមន្ទីរ [ពេទ្យ] សម្រាប់ប្រជាជនទូទៅ។ [...] នៅក្នុងពេលនោះ នៅពេលណាដែលមានស្ត្រីណាមានបញ្ហាពិបាកក្នុងការកើតកូន ទើបគេបញ្ជូនឲ្យទៅចូលក្នុងមន្ទីរពេទ្យនោះ"]។ ឯកសារ D219/545 កំណត់ហេតុស្តាប់ចម្លើយ ផរ ប៉ែត ឆ.២៧ KH 01157539 ["គុកបាណន់មានចម្ងាយ "ប្រហែល ៥ម៉ែត្រ" ពីមន្ទីរពេទ្យបាណន់]។

509. ណង នី បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ថា "បើអ្នកទោសណាមិនព្រមធ្វើតាមគេ គេវាយ នឹងដំបងឬនឹងសោកង់"[1802]។ "ព្រោះ[...]ខ្ញុំឈឺនោមខ្លាំងពេកហើយនៅមិនស្ងៀមក៏ត្រូវគេវាយ"[1803]។ ហែម ប្រេង និយាយថា "ម្នាក់ៗគិតតែនាំគ្នាសំងំស្ងៀមទាំងអារម្មណ៍ភ័យខ្លាច"[1804]។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីម្នាក់បានសង្កេតឃើញ "មានឈាមនៅជាប់ជញ្ជាំងវត្ត"[1805]។

ការធ្វើទារុណកម្ម

510. យោធានៅមន្ទីរសន្តិសុខបាណន់ គឺជាអ្នកសួរចម្លើយអ្នកទោស ដោយចោទប្រកាន់ពួកគេថាខ្មាំង[1806]។ អ្នកទោសត្រូវបានសួរចម្លើយពេលមកដល់មន្ទីរសន្តិសុខ ហើយបន្ទាប់មក ត្រូវគេសួរពីរដងទៀត ក្នុងរយៈពេលមួយសប្តាហ៍ ឬពីរសប្តាហ៍[1807]។ អ្នកសួរចម្លើយប្រើថង់ប្លាស្ទិកគ្របក្បាលអ្នកទោស

[1802] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៩ KH 00934388។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002646 ["ខ្ញុំ] ត្រូវគេវាយតែម្តងគត់ គឺដោយសារខ្ញុំតម្រង់ជួរខុសកន្លែង យោធាយកដំបងមកវាយខ្ញុំមួយទំហឹងឡើងហើមសាច់បីបួនថ្ងៃទើបបាត់"]។

[1803] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៩ KH 00934388។

[1804] ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* KH 01002649។

[1805] ឯកសារ D219/374 កំណត់ហេតុស្តាប់ចម្លើយ ឃិន ឃីម ឆ.២២១ KH 01110550-51។

[1806] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៩ KH 00934387 ["ពួកនោះសុទ្ធតែយោធា ដែលសួរចម្លើយអ្នកទោស"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៣ KH 00960691 ["គេសួរចម្លើយខ្ញុំ ហើយគេថា ខ្ញុំជាខ្មាំង"]។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហែម ប្រេង KH 01002648 ["ពួកយោធាយាមគុកចាប់ខ្ញុំវាយធ្វើទារុណកម្មសួរចម្លើយ [...]។ [...] គេចោទខ្ញុំថា ខ្ញុំជាខ្មាំងរបស់អង្គការ"]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឆ.៣០ KH 01149403 ["ក្រោយពេលដែល តាប៉ែត បានបាត់ខ្លួន [...] កិច្ចប្រជុំ [...] ក្នុងវត្តបាណន់ក្រោម [...] តាទិត្យ ជាប្រធានអង្គប្រជុំ។ [...] នៅពេលប្រជុំ គេបានលើកឡើងអំពីបញ្ហាមួយចំនួន ក្នុងនោះរួមមាន បញ្ហាដែលទាក់ទងទៅនឹងអតីតទាហាន លន់ នល់ កុម្ម៉ង់ដូរ ហើយអ្នកដែលស្ថិតនៅក្នុងសមាសភាពបែបនេះ ត្រូវបានគេប្រាប់ឲ្យសារភាព"]។

[1807] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១១ KH 00934386 ["គេសួរចម្លើយខ្ញុំចំនួនពាងង។ ពេលខ្ញុំទៅដល់បានមួយអាទិត្យគេសួរម្តង ក្រោយមកប្រហែលជា២ទៅ៣អាទិត្យទើបគេមកសួរចម្លើយខ្ញុំទៀត"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៣-២៤ KH 00960691-92 ["ពេលទៅដល់[គុក]ភ្លាម គេសួរចម្លើយខ្ញុំ។ [...] ជាទូទៅ នៅរៀងរាល់ ៣ ទៅ៤ ថ្ងៃ គេយកអ្នកទោសទៅសួរចម្លើយម្តង គេសួរអ្នកទោសគ្រប់ពាងង ទើបគេឈប់សួរ។ គេសួរចម្លើយខ្ញុំ៣ពាងង។"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហែម ប្រេង KH 01002649 ["គេចាប់អ្នកទោសទៅសួរចម្លើយរាល់ថ្ងៃ"]។ *សូមមើលផងដែរ* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៤, ២៩ KH 00960692 ["ពេលគេសួរចម្លើយ គេចងដៃខ្ញុំទៅក្រោយជាប់រហូត ព្រោះគេខ្លាចអ្នកទោសតដៃ តែគេមិនចងជើងទេ។ [...] ។ ចំពោះការសួរចម្លើយ [...] គេធ្វើនៅម៉ោង ៧ព្រឹក ហើយចប់នៅម៉ោង ៩ព្រឹក"]។ ឯកសារ D118/77

ក្នុងពេលសួរចម្លើយ[1808] វាយពួកគេនឹងដំបង[1809] និងក្នុងករណី ហ៊ែម ប្រេង ពួកគេ បានដុតគាត់ រហូតទាល់តែគាត់សន្លប់[1810]។ ហ៊ែម ប្រេង បាននិយាយថា ការសួរចម្លើយរបស់គាត់បានបន្សល់ទុកនូវស្លាកស្នាមលើរាងកាយរបស់គាត់[1811]។ បុគ្គលិកគុកបានធ្វើទារុណកម្មស្ត្រីដែលគេបានចោទ

កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១១ KH 00934386 ["មុនពេលគេសួរចម្លើយខ្ញុំ គេចងដៃខ្ញុំទៅក្រោយ"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002641 ["ប៉ុន្មានថ្ងៃក្រោយមក របួសខ្ញុំមិនទាន់សះក្រម៉ាផង ខ្ញុំត្រូវអ្នកយាមគុកចាប់យកទៅធ្វើទារុណកម្មសួរចម្លើយដូចកាលលើកទីមួយទៀត"] EN 01002645 [ការរៀបរាប់របស់ ម៉ែ រ៉ុង៖ "គេដាក់អ្នកទោសឲ្យអង្គុយ រួចគេចងដៃចងជើង"]។

[1808] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១១ KH 00934386 ["គេយកថង់ផ្លាស្ទិកមកគ្របមុខខ្ញុំ រួចទើបគេគេចាប់ ផ្តើមសួរចម្លើយខ្ញុំ"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៣ KH 00960691 ["គេយកថង់ផ្លាស្ទិកមកបាំងមុខខ្ញុំកុំឲ្យខ្ញុំដកដង្ហើមរួច [...]។ ខ្ញុំឃើញអ្នកទោសផ្សេងទៀតក៏ត្រូវគេយកថង់ផ្លាស្ទិកមកបាំងមុខអ៊ីចឹងដែរ"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002646 ["គេធ្វើទារុណកម្មអ្នកទោសជាច្រើនយ៉ាងដូចជា [...] គេយកកៅស៊ូ ឬផ្លាស្ទិកមកគ្របក្បាល"] ការរៀបរាប់របស់ សន ប៊ុន KH 01002652 "[គេ] យកស្បោងមកច្រកក្បាលអ្នកទោស"] KH 01002652 [ការរៀបរាប់របស់ ហ៊ែម ប្រេង៖ "គេបានយកកៅស៊ូ ផ្លាស្ទិក[...] រកកលនឹងផុតដង្ហើមម្តងៗ"] ការរៀបរាប់របស់ ហ៊ែម ហ៊ីង៖ "ខ្ញុំថប់ដង្ហើមសន្លប់បីដង នៅពេលដែលគេបានយកកៅស៊ូផ្លាស្ទិកមកចងមុខខ្ញុំ"]។

[1809] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១១ KH 00934386 ["[ពេល]ខ្ញុំឆ្លើយដដែលៗ គេយកដំបងមកវាយខ្ញុំរហូតដល់សន្លប់"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៣-២៤ KH 00960691-92 ["គេធ្វើទារុណកម្មខ្ញុំ ដោយវាយខ្នងខ្ញុំនឹងចំហៀងពួកៅធ៌ ឬគល់ឫស្សី។ [...] រួច គេក៏យកគល់ឫស្សីមកវាយខ្ញុំ[ទៀត]។ [...] គេវ៉ៃខ្ញុំខ្លាំងៗណាស់"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002645 ["គេក៏យកដំបងឫស្សីវាយលើខ្លួនប្រាណអ្នកទោសនៅពេលសួរចម្លើយ"] ការរៀបរាប់របស់ សន ប៊ុន KH 01002652 "[គេវាយអ្នកទោសនឹងដំបង"] ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002648 ["ពួកគេយកដំបងឈើបង្ករង់បន្ទះប៉ុនកដៃមកវាយលើខ្លួនខ្ញុំជាច្រើន [...] (ដើម្បីធ្វើទារុណកម្មលើរូបខ្ញុំ)"] ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002641 ["គេវាយខ្ញុំមួយទំហឹងពីរបីដំបង រួចគេឲ្យខ្ញុំឆ្លើយសារភាព។ [...] លើកចុងក្រោយ គេចាប់ខ្ញុំទៅវាយនឹងដំបងឫស្សីពេញខ្លួនប្រាណ ឲ្យឆ្លើយសារភាពប្រាប់ពីបក្សពួក"]។

[1810] ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002648 ["[ពួកគេក៏] យកស្ករកណ្តាប់មកដុតរោលលើជើង និងខ្នងរបស់ខ្ញុំទាល់តែសន្លប់"]។

[1811] ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៤១-៤២ KH 01300408-09 ["[ពួកគេ] ធ្វើបាប[ខ្ញុំ]ឡើងហើមខ្នង។ រ៉ៃខ្នង នៅផ្លែខ្នង។ ថាខ្ញុំមិនរស់ទេ។ រ៉ៃម្តង នៅផ្លែ"]។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002648 ["[ពួកគេ] [...] វាយលើខ្លួនខ្ញុំ [...] រហូតបែកឈាមតាមអ្ហ៊ីងខ្នង និងអ្ហ៊ីងជំនី"] ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002645 ["ហើយគេគ្រីបនឹងដែកពីក្រោមចង្កាព័ទ្ធមកកន្ទីងក្បាលអ្នកទោស រួចគេយកអ្នកទោសសួរចម្លើយរហូតអ្នកទោសហូរឈាមតាមត្រចៀក។ នៅពេលបកផ្លាស្ទិកចេញពីក្បាល មានឈាមហូរតាមមាត់ និងផ្ទេញបាក់ធ្លាក់ពីមាត់។ ទារុណកម្មមួយទៀតគេយកក្តារងឿទទឹងមួយម៉ែត្រ មានបណ្តោយប្រហែលជិតបី

ថា ធ្លាប់ធ្វើស្រីបនពីរបបមុន ដោយចៀរអារដោះពួកគេ និងរំលោភពួកគេដោយប្រើវត្ថុផ្សេងៗ[1812]។

ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

511. ដោយសារចំនួនដ៏ច្រើននៃអ្នកទោសដែលជាប់ឃុំនៅមន្ទីរសន្តិសុខបាណន់ "[គេយក]អ្នកទោស[...] ទៅសម្លាប់ចោល ហើយគេយកកន្លែងសម្រាប់ដាក់អ្នកទោសមកថ្មី"[1813]។ ណង នី និង ទៀ<u>ប</u> ទិត្យ ដែលអ្នកទាំងធ្លាប់ជាប់គុកប្រហែលពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ប្រាំមួយខែមុនវៀតណាមមកដល់ បាននិយាយថា ពួកគាត់បានឃើញរឿងនេះជារៀងរាល់ថ្ងៃ[1814]។ "មានអ្នក

ម៉ែត្ររុំបន្ទាល្ងសជុំវិញក្ការនោះ រួចគេចាប់អ្នកទោសដាក់លើក្ការអ៊ីរុញអ្នកទោសរមៀលយ៉ាងឈឺផ្សារលើបន្ទាល្ងសដាច់សាច់ជាប់បន្ទ ឈាមហូរក្រហមពេញក្ការ"]។

[1812] ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002645 ["ចំណែកអ្នកណាដែលគេដឹងប្រវត្តិថា ធ្លាប់ជាស្រីបនសម័យលន់ នល់ យោធាចាប់យកមកចៀរអារដោះរបស់ស្រីនោះ ហើយយកដីមកញីលើដោះរួចឲ្យសើច និងគេយកវត្ថុផ្សេងៗមកបៀតបៀនកេរ្ត៍ខ្មាសព្រោះគេថា ពួកស្រីដែលធ្វើបនធ្លាប់តែសប្បាយ ត្រូវតែសើចសប្បាយ"]។

[1813] ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ីម ឆ.៣៧ KH 01157568 ["ពេលខ្លះ កន្លែងឃុំឃាំងនោះពេញ ហើយគេយកអ្នកទោសមកមុនទៅសម្លាប់ចោល ហើយគេយកកន្លែងសម្រាប់ដាក់អ្នកទោសមកថ្មី"]។ *សូមមើលណេះ* ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សេម ឆ.៧៤ KH 00967990 ["នៅពេលដែលមានអ្នកទោសត្រូវបានសម្លាប់ និងកប់ច្រើនពេក[...] ពួកគេក៏បានផ្លាស់ប្តូរ[ទីតាំងគុក]"]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ឈួយ ឆ.២១ KH 01149401 ["មូលហេតុដែលមានការផ្លាស់ប្តូរកន្លែងឃុំឃាំងអ្នកទោសយ៉ាងដូច្នេះ ព្រោះទីធ្លាដែលស្ថិតនៅខាងលិចស្ទឹងមានទំហំតូចជាង បើប្រៀបធៀបទៅនឹងទីធ្លាមួយទៀតដែលស្ថិតនៅខាងកើតស្ទឹង"]។ អ្នកទោសមួយចំនួនត្រូវបានដោះលែងដោយ តាប៉ែត និងអ្នកផ្សេងទៀត *សូមមើល* ឯកសារ D34.1.10 បទសម្ភាសន៍ ហេង ទាវ *ហៅ* តាប៉ែត ដោយ ស្ទីវ ហេដឌ័រ KH 00964054-55។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ីម ឆ.២៥ KH 01157566-67។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១១-១២, ២១ KH 00934386-87, 88 (*កត់សម្គាល់ថា* សាក្សី ទៀ<u>ប</u> ទិត្យ បានជាប់គុក និងត្រូវបានដោះលែងក្នុងពេលជាមួយគ្នានឹង ណង នី ដែរ ទោះបីគាត់បានកំណត់អត្តសញ្ញាណបុគ្គលម្នាក់ផ្សេងទៀតចំពោះការទទួលខុសត្រូវក្នុងការដោះលែងពួកគេក៏ដោយ *សូមមើល* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀ<u>ប</u> ទិត្យ ឆ.៤ KH 00960688)។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ ស្ងួម ឆ.១ KH 01114646។ ឯកសារ D219/959 កំណត់ហេតុស្តាប់ចម្លើយ ស ជួន ឆ.៩៨ KH 01429698-700)។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002642, ការរៀបរាប់របស់ ហ៊ែម ប្រេង KH 01002649។

[1814] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៦ KH 00934387 ["ខ្ញុំបានឃើញគេអូសអ្នកទោសចេញនៅពេលព្រឹក និងពេលល្ងាចជារៀងរាល់ថ្ងៃ"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀ<u>ប</u> ទិត្យ ឆ.២៩ KH 00960692 ["ខ្ញុ

ទោសខ្លះគេចាប់យកមកដាក់តែមួយយប់ រួចគេយកទៅសម្លាប់"[1815]។ ណង នី ក៏ធ្លាប់ឮ "យោធាគេនិយាយថា គេសម្លាប់អ្នកទោស ៥ ទៅ ១០នាក់ ក្នុងមួយថ្ងៃ" និងបានឃើញ "យោធាឆ្នើមមនុស្សហូប"[1816]។ "គេបញ្ជាឲ្យយោធាជីករណ្តៅទុកជាស្រេច" មុនការសម្លាប់ចាប់ផ្តើម[1817]។ ហង់ សួម ដែលធ្លាប់រស់នៅជាប់ផ្លូវទៅកាន់មន្ទីរសន្តិសុខនេះ បានកត់សម្គាល់ថា "ពាក់កណ្តាលឆ្នាំ ១៩៧៨ [...] ការកាប់សម្លាប់កើតឡើងខ្លាំង"[1818]។

512. បន្ថែមលើប្រភេទអ្នកទោសដូចបានរៀបរាប់លម្អិតខាងលើក្នុងអនុវាក្យខណ្ឌស្តីពី *ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)*[1819] ជនរងគ្រោះដែលបានស្លាប់ដោយគេសម្លាប់រួមមាន "អតីតទាហាន [...] គេដាក់តែមួយយប់ទេ" អ្នកដែលគេ "ចង

ឃើញគេយកអ្នកទោសចេញរាល់ថ្ងៃ ជួនកាលនៅម៉ោង ៧ព្រឹក ជួនកាលនៅម៉ោង ៤ ឬ ៥ ល្ងាច ហើយនរណាក៏ដឹងថា គេយកអ្នកទោសទៅសម្លាប់នៅកន្លែងនោះដែរ"]។

[1815] ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១៦ KH 00960690។

[1816] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៦ KH 00934387។ *សូមមើលផងដែរ* ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៣១ KH 00960690 ["ខ្ញុំឃើញគេយកអ្នកទោសចេញរាល់ថ្ងៃ ថ្ងៃខ្លះគេយកចេញម្នាក់ ជួនកាលគេយកចេញពីរនាក់ ទៅបីនាក់ ដូច្នេះវាមានចំនួនច្រើនណាស់"]។

[1817] ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៣៣ KH 01157568 ["ពេលគេកំពុងសួរចម្លើយអ្នកទោស គេបញ្ជាឲ្យយោធាមួយចំនួនជីករណ្តៅទុកជាស្រេចហើយ"]។

[1818] ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.១២ KH 01114649។ *សូមមើលផងដែរ* ឯកសារ D219/954 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៣ KH 01425185 ["ប្រាសាទបាណន់ គឺកន្លែងសម្លាប់ហើយ"]។

[1819] *សូមមើល* V.ខ.2.ង.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់១ – មន្ទីរសន្តិសុខបាណន់ – ឧក្រិដ្ឋកម្ម – ការដាក់ក្នុងមន្ទីរឃុំឃាំង និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។

នឹងអំបោះក្រហម [...] បន្ទាប់ពី [...] សួរចម្លើយ" និងជនជាតិវៀតណាម[1820]។ ពួកគេត្រូវបានសម្លាប់នៅជើងភ្នំបាណន់ និងអាចនៅកន្លែងផ្សេងទៀត[1821]។

[1820] ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៧ KH 00960692។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៣៣ KH 01157568។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៩, ១២ KH 01114648-49 [នៅពាក់កណ្តាលឆ្នាំ១៩៧៨ "ខ្ញុំសង្កេតឃើញគេដឹកមនុស្ស ដូចជា ពួកវៀតណាមជាដើម មកពីកន្លែងផ្សេងៗ តាម រយៈឡានទ្រុង ហើយយកមកបាញ់សម្លាប់ចោលនៅម្តុំនោះ [គុកវត្តបាណន់]។ [...] បន្តិចក្រោយមក ខ្ញុំឮសូរស្នូរគ្រាប់កាំភ្លើង រួចក្រោយមកទៀត ខ្ញុំឃើញឡានទាំងនោះ ត្រឡប់មកវិញ ទទេ។ នៅពេលនោះ គេបានចោទមនុស្សខ្លះ ថាជាខ្សែរបស់យួន"]។ *សូមមើលផងដែរ* ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002645 ["អ្នកទោសដែលគេធ្វើទារុណកម្មហើយមានរបួសដេកក្នុងគុក ត្រូវគេចាប់យកទៅទាំងខ្សែ បណ្តើរទៅវាយសម្លាប់"]។

[1821] <u>ភ្នំបាណន់</u>៖ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.២៧-២៨ KH 00960692 ["អ្នកទោសថ្មីដែលជាអតីតទាហាន [...] គេយកទៅសម្លាប់នៅជើងភ្នំខាងជើងប្រសាទបាណន់"]។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.៣៣-៣៤ KH 01157568 ["បន្ទាប់ពីការសួរចម្លើយ [...] គេយកមនុស្សទៅសម្លាប់ នៅជើងភ្នំប្រសាទបាណន់"]។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៨១ KH 00967992 ["គេសម្លាប់នៅជើងភ្នំបាណន់ [...] ឆ្អឹងឡើងសសំព្រុសតែម្តង"]។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១៧ KH 00970454។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ការរៀបរាប់របស់ សន ប៊ុន KH 01002653, ការរៀបរាប់របស់ ម៉ែ រ៉ុង KH 01002645។ ឯកសារ D219/374 កំណត់ហេតុស្តាប់ចម្លើយ ឃិន ឃីម ឆ.២២០ KH 01110550។ <u>កន្លែងផ្សេងៗទៀត</u>៖ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៩, ១២ KH 01114648-49 [នៅពាក់កណ្តាលឆ្នាំ១៩៧៨ "ខ្ញុំសង្កេតឃើញគេដឹកមនុស្ស ដូចជា ពួកវៀតណាមជាដើម មកពីកន្លែងផ្សេងៗ តាម រយៈឡានទ្រុង ហើយយកមកបាញ់សម្លាប់ចោលនៅម្តុំនោះ [គុកវត្តបាណន់]។ [...] បន្តិចក្រោយមក ខ្ញុំឮសូរស្នូរគ្រាប់កាំភ្លើង រួចក្រោយមកទៀត ខ្ញុំឃើញឡានទាំងនោះ ត្រឡប់មកវិញ ទទេ។ នៅពេលនោះ គេបានចោទមនុស្សខ្លះ ថាជាខ្សែរបស់យួន"]។ ឯកសារ D219/946 កំណត់ហេតុស្តាប់ចម្លើយ ឡៅ កង ឆ.៥២-៥៣ KH 01415417 ["ព្រោះអ៊ីចេះ ខ្ញុំដែងមក៧៩ហ្នឹង អ៊ ង៉ែ! ខ្ញុំនៅមុខវត្តបាណន់។ [...] ខ្ញុំគាស់ឃើញសុទ្ធតែឆ្អឹង [...] ជាប់ជាង១០នាក់"]។ ឯកសារ D219/545 កំណត់ហេតុស្តាប់ចម្លើយ ផរ ប៉ែត ឆ.៣៤ KH 01157540 ["ស៖ កាលដែលលោកនិយាយពីខាងដើមមក រយៈពេលដែលលោកធ្វើការនៅគុកបាណន់ និងព្រៃក្បាល លោកថា លោកឃើញមនុស្សស្លាប់រាប់រយនាក់ ហេតុអីបានលោកប៉ាន់ថា ខ្ញោចរាប់រយ? [...] ឆ.៣៤៖ កាលនោះ ខ្ញុំដើរតាមផ្លូវទៅឃើញ [...] ឆ.៣៥៖ [...] ផ្លូវទៅភ្នំគល់ [...] ឆ.៣៦៖ ឃើញមុនវៀតណាមចូល"] (*សូមកត់សម្គាល់* ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម យួន ឆ.២៦ KH 00960656 ["ភ្នំគល់ [...] ដែលមានចំងាយពី ៥ ទៅ ៦ គ.ម ពីវត្តបាណន់ក្រោម")។

513. អ្នកទោសក៏បានស្លាប់ផងដែរ ដោយសារកង្វះអាហារ ជំងឺនិងការព្យាបាលផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន់[1822]។

<u>ការធ្វើទុក្ខបុកម្នេញ</u>

514. កម្មាភិបាលភូមិភាគនិរតីបានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនដូចបានរៀបរាប់ខាងលើ ក្នុងចេតនាដើម្បីកំណត់គោលដៅជាក់លាក់ មានដូចជា កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ ហើយនិងអ្នកក្រោមបង្គាប់របស់ពួកគេ និងសមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ នៅមន្ទីរសន្តិសុខបាណន់។ ក្រុមទាំងនេះត្រូវបានកំណត់គោលដៅចំៗ ដោយសារតែសមាជិកភាពពិតប្រាកដ ឬតាមការសន្មតរបស់ពួកគេចំពោះក្រុមនយោបាយណាមួយ។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

515. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខបាណន់ៃ[1823] ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[1824] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុ

[1822] ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ីម ឆ.៣៦ KH 01157568 ["អ្នកទោសខ្លះបានស្លាប់ដោយសារអត់បាយនៅក្នុងកន្លែងឃុំឃាំងនោះ"]។ ឯកសារ D219/783 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ប្រេង ឆ.៥៨ KH 01300411 ["ខ្លះទៅជាប់បានតែមួយអាទិត្យ ដាច់បាយងាប់ទៅ"]។

[1823] ស.ព.អកត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ទាំងនេះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងសមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធ៌ម)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះ តាមរយៈ៖ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៩ (រួមទាំង កំណត់សំគាល់ជើងទំព័រ ២២៣), ១១៨ខ។ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៩, ២២iii។ ឯកសារ D196/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌ ២ឃ។

[1824] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃអំពើមហាប្រល័យនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងទាក់ទងនឹងមន្ទីរសន្តិសុខបាណន់តែមួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃអំពើមហាប្រល័យដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងមន្ទីរសន្តិសុខបាណន់ផង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់បង្កើត

នយោបាយប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ និងសមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។

ច. មន្ទីរសន្តិសុខខ្នងគ្ូ

i. សេចក្ដីផ្ដើម

516. មន្ទីរសន្តិសុខខ្នងគ្ូ ស្ថិតនៅក្នុងស្រុកសង្កែ តំបន់១ នៃភូមិភាគពាយ័ព្យ នៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៧៨ ពួកកម្មាភិបាលភូមិភាគនិរតី បានបញ្ជូនអ្នកទោសដែលនៅរស់រានមានជីវិតទាំងអស់ពីមន្ទីរសន្តិសុខបាណន់ដែលនៅក្បែរនោះ ឲ្យទៅកាន់មន្ទីរសន្តិសុខខ្នងគ្ូ ដោយសារវាមានចំណុះច្រើនជាង។ ពួកកម្មាភិបាលភូមិភាគនិរតីនៅតាមថ្នាក់តំបន់ នៅពេលនោះ បានគ្រប់គ្រងមន្ទីរសន្តិសុខខ្នងគ្ូ រហូតដល់ទីបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលមុន និងក្រោយការចាត់តាំង **យ៉ឹម ទិត្យ** ជាផ្លូវការជាលេខាតំបន់១ គាត់បានធ្វើការប្រជុំនៅក្បែរមន្ទីរសន្តិសុខនោះ និងទទួលខុសត្រូវចំពោះការអនុវត្តនូវគោលនយោបាយ ប.ក.ក នៅមន្ទីរសន្តិសុខនោះ។

517. គុកនេះបានទទួលពួកអ្នកជាប់ឃុំឃាំងមកពីកន្លែងផ្សេងៗនៅក្នុងតំបន់១។ ការណ៍នេះ រួមមានទាំងពួកកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ ព្រមទាំងថ្នាក់ក្រោមរបស់ពួកគេផង ពួកអតីតសមាជិករបបណោក លន់ នល់ ពួកវៀតណាម និង "ប្រជាជនថ្មី"។ ពួកអ្នកទោសបានស្ងៀមស្ងាត់នឹងការធ្វើបាបដោយអមនុស្សធម៌ និងត្រូវបានគេធ្វើទារុណកម្ម។ ការសម្លាប់រង្គាល រួមមាន អ្នកទោសជាអប្បបរមា ៨០នាក់ ត្រូវបានកើតឡើងភ្លាមៗ នៅមុនពេលការមកដល់របស់ពួកវៀតណាម។

518. ស.ច.ស.អ បានចោទប្រកាន់ **យ៉ឹម ទិត្យ** ពីឧក្រិដ្ឋកម្មនានាទាក់ទងនឹងមន្ទីរសន្តិសុខខ្នងគ្ូ ដូចតទៅ៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេ្ញដោយមូលហេតុនយោបាយ (លើពួកកម្មាភិបាលពាយ័ព្យ និងក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ) អំពើអមនុស្សធម៌

បានជាផ្នែកនៃប្រព័ន្ធមួយដែលមានការរៀបចំ ក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេ្ញ និងសម្លាប់ខ្មាំង ហើយការសម្លាប់នៅលើទីតាំងនិមួយៗទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ឹម ទិត្យ។

ផ្សេងៗទៀត (ការឃុំខ្លួននៅក្នុងលក្ខខណ្ឌអមនុស្សធម៌ និងឧក្រិដ្ឋកម្មនៃការធ្វើមនុស្សឃាតដោយគិតទុកជាមុន នៅក្រោមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[1825]។

ii. ប្រតិបត្តិការ និងទីតាំង

519. មន្ទីរសន្តិសុខខ្នងគ្ង អាចនឹងត្រូវបានប្រតិបត្តិនៅដើមឆ្នាំ១៩៧៦[1826]។ នៅឆ្នាំ១៩៧៨ ពួកកម្មាភិបាលនិរតីបានគ្រប់គ្រងទីកន្លែងនោះ នៅពេលដែលពួកគេបានបញ្ជូនអ្នកទោសដែលនៅរស់រានមានជីវិតទាំងអស់ពីមន្ទីរសន្តិសុខបាណន់ ឲ្យទៅកាន់មន្ទីរសន្តិសុខខ្នងគ្ង[1827]។ គេបានធ្វើប្រតិបត្តិការលើទី

[1825] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426551, 60។

[1826] ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គឹម ចាត ឆ.៤, ៦ KH 01058776-77។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.២៦ KH 01117287។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម ឃួន ឆ.២៨ KH 00960656។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៥៥ KH 01153614។ *សូមមើលផងដែរ* ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រៀន ឆ.៥២ KH 01040170។

[1827] ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.១១, ១៣ KH 00934386-87 ["ក្រោយពេលដែលគេដោះលែងខ្ញុំ [ពីមន្ទីរសន្តិសុខបាណន់] ខ្ញុំឮថា ប្ជូរគុក [...] ដែលកាលណោះពួកកម្មាភិបាលនិរតីជាអ្នកប្ជូរទីកន្លែង ហើយបានប្រហែលកន្លះឆ្នាំទើបរៀតណាមចូល"] ឆ.៤៥ KH 00934391 ["ខ្ញុំឮពីយោធាពេលដែលខ្ញុំជាប់គុកបាណន់ ថាតាទិត គាត់ជាគណៈតំបន់"]។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ឆ្នាំ២០១២ ការរៀបរាប់របស់ ហ៊ែម ហ៊ីង KH 01002642 ។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៧, ២៧ KH 01114647, 51 ["ប្រហែលជាពីរទៅបីខែមុនរបបខ្មែរក្រហមដួល គេបានរើបញ្ជូនអ្នកទោសទាំងអស់យកទៅដាក់ [...] គេហៅថា គុកខ្នងគ្ង"] ឆ.១៧ KH 01114650។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យើន ឆ.២៣ KH 01210565 ["នៅពេលដែល ពួកនិរតី មកដល់ គេយកមកដាក់នៅជិតខ្នងគ្ង"]។ សាក្សី ជា ប៊ាន ឃល់ដឹងថា មន្ទីរសន្តិសុខបាណន់បានរើរួចជាស្រេចទៅដាក់នៅខាងខ្នងគ្ង នៅពេលដែលគាត់បានរត់ទៅសហការណ៍សាំងរ៉ាំង ដែលនៅក្នុងខែកក្កដា ឬ ខែសីហា ឆ្នាំ១៩៧៨ *សូមមើល* ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៦០ KH 00960670 និង ឆ.២ KH 00960662-63។ ឯកសារ D34.1.9 បទសម្ភាសន៍ ហេង ទាវ ហៅ តាប៉ែត ដោយ ស្ទ្រីវ ហេងឌ័រ KH 00965616, 22, 47។ ឯកសារ D1.3.18.2 ចម្លើយសារភាពនៅស-២១ របស់ មូល សំបាត់ ហៅ រស់ ញ៉ីម KH 00024650 [ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ១៩៧៨]។ *សូមមើលផងដែរ* ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្ជឿក ឡាម ឆ.៣-៤ KH 01058792 (*សូមកត់សម្គាល់* ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្ជឿក ឡាម KH 01080834)។ ឯកសារ D219/428 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ជា ឆ.១, ១៣-១៤ KH 01121734, 36។ ឯកសារ D219/960 កំណត់ហេតុស្តាប់ចម្លើយ ស ជួន ឆ.៦, ៨, ១០, ១២-១៤ KH 01429706។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៣៩-៤០ KH 00920172។ ទោះបីជាសាក្សី ហ៊ីម ឆុងលី បាននិយាយថា មន្ទីរសន្តិសុខបាណន់ត្រូវបានរើទៅកាន់មន្ទីរសន្តិសុខខ្នងគ្ង "នៅប្រហែលពាក់កណ្តាលឆ្នាំ១៩៧៦" ដោយពួកកម្មាភិបាលភូមិភាគពាយ័ព្យក៏ដោយ ក៏គាត់បាននិយាយផងដែរថា៖ "ពួកនិរតីមកកាន់កាប់នៅ [...] ខ្នងគ្ង នៅប្រហែលចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ តាមខ្ញុំដឹង ពួកនិរតីនៅទីនេះ បានជាង១ឆ្នាំ

 កន្លែងនេះរហូតដល់ទីបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[1828]។ មន្ទីរសន្តិសុខនេះ ស្ថិតនៅក្នុងភូមិ ទ្ទលច្រនៀង ឃុំបាយដំរ៉ា ស្រុកសង្កែ នៃតំបន់១ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[1829]។

520. មន្ទីរសន្តិសុខខ្នងគ្ង ស្ថិតនៅប្រមាណជា ៥០ម៉ែត្រ ខាងកើតស្ទឹងសង្កែ ទល់មុខចំនឹងមន្ទីរសន្តិសុខបាណន់[1830]។ ត្រូវបានរៀបរាប់ថាជា"គុកធំ" បរិវេណគឺមានទទឹងពី ៥០ ទៅ ១០០ម៉ែត្រ និង

មុនពេលរបបខ្មែរក្រហមបានដួលរលំ"។ *សូមមើល* ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៤, ៨, ១៧ KH 01023838-39, 40, 41។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ឿម ឆ.២០-២៣, ៣៩ KH 01157565-66, 68 [មន្ទីរសន្តិសុខបាណន់ត្រូវបានរើកន្លែងទៅដាក់នៅខ្នងគ្ង ដោយពួកកម្មាភិបាលភូមិភាគពាយ័ព្យ។ ពួក ក ម្មាភិបាលភូមិភាគនិរតីបានមកដល់ពេលក្រោយ]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៨ KH 01023830 ["គេរើគុកបាណន់ មកដាក់នៅកន្លែងខ្នងគ្ង តាំងពីជំនាន់ពួកពាយ័ព្យគ្រប់គ្រងម្ល៉េះ"]។

[1828] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្ជ្ជ ឡាម ឆ.៣-៤ KH 01058792។ ឯកសារ D219/423 កំណត់ហេតុ ស្តាប់ចម្លើយ យ៉ុន ឈ្ឍ ឆ.៣២ KH 01121671។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៤ KH 01023838-39។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៧៨ KH 00967991។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្ឍ ឆ.៤៣ KH 01305003។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៤, ១៩ KH 01040098-99។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ៌ន ឈ្ឍ ឆ.៤៤-៤៥ KH 01149406។ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.៥៣ KH 01040170។

[1829] ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.៥៩ KH 01040171។ ឯកសារ D219/751 កំណត់ហេតុស្តាប់ ចម្លើយ វ៉ែ រ្ជ ឆ.១៧ KH 01238679។ ឯកសារ D219/516 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ហាន ឆ.២ KH 01149461 ["ទ្ទលច្រនៀងគឺជាភូមិមួយស្ថិតនៅឃុំបាយដំរ៉ា ស្រុកបាណន់។ កាលពីរបបខ្មែរក្រហម គេហៅថា ស្រុកសង្កែ"]។ *សូមមើលផងដែរ* ឯកសារ D219/988 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ វ៉ែ រ្ជ KH 01522023-24។

[1830] *សូមមើល ខ១ាហារណ៍* ឯកសារ D219/273 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខខ្នងគ្ង KH 01219940-41។ ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គ៉ីម ចាត ឆ.៤-៥ KH 01058776-77។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទ្ទៀប ទិត្យ ឆ.៥៣ KH 01132057។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ .២៧ KH 01114651។ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.៥៥ KH 01040171។ ឯកសារ D215/1.1.2 សៀវភៅអង្គការយុវសន្តិភាព *ស្រមោលក្នុងទីងងឹត* ឆ្នាំ២០១២ KH 01002642, 50។ ឯកសារ D219/533 កំណត់ហេតុស្តាប់ ចម្លើយ ឈ្ឍ ប៊ាន ឆ.១៥៥ KH 01153614។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១៥ KH 01023832 ។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៤ KH 01023838-39 (*សូមកត់សម្គាល់* ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.២៦ KH 01117287)។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ៌ន ឈ្ឍ ឆ .២២ KH 01149401។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម យ៉ូន ឆ.២៦ KH 00960656។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៧៤ KH 00967990។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ទ្ឍ ម៉ត ឆ .៩៥ KH 01155835។

បណ្តោយពី ១០០ ទៅ ២០០ម៉ែត្រ និងហ៊ុំព័ទ្ធជុំវិញដោយលួសបន្ទា ដោយមានទ្វាររបងចំនួនពីរ[1831]។ ខាងក្នុងបរិវេណ មានអគារមួយដែលត្រូវបានប្រើប្រាស់ជាកន្លែងឃុំឃាំង និងមួយផ្សេងទៀត សម្រាប់សួរចម្លើយ ព្រមទាំងកន្លែងស្នាក់នៅសម្រាប់ពួកអ្នកយាម និងយោធា[1832]។ ប្រាំមួយរយម៉ែត្រពីខាងកើតបរិវេណនោះ មានរណ្តៅកប់សាកសព នៅក្នុង និងនៅជុំវិញស្រះមួយ ហៅថា គូកណ្តាល និងនៅតាមបណ្តោយគូនោះ មានស្នាមផ្លូវមួយនាំឆ្ពោះទៅរកទីវាលមួយកន្លែង[1833]។

[1831] ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឆ.១៥ KH 01149399។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀន ម៉ត ឆ.៩៤ KH 01155835។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.២១-២៣ KH 01238680-81។ ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គឹម ចាត ឆ.៨ KH 01058777។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៤, ១៦ KH 01023829-30, 32។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ផុងលី ឆ.៤, ១៥ KH 01023838-39, 41។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យ៉ែន ឆ.១៥២ KH 01305012។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៧៦ KH 00967991។ ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្យ៉ីក ឡាម ឆ.៤ KH 01080835។ ឯកសារ D219/273 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខខ្នងគូ KH 01219940-41។

[1832] ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្យ៉ីក ឡាម ឆ.២ KH 01080835 និង *ថាម្ពងទៀតនៅត្រង់* ឯកសារ D219/273 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខខ្នងគូ KH 01219940-41, 43។ ឯកសារ D118/296 កំណត់ ហេតុស្តាប់ចម្លើយ ហ៊ីម ផុងលី ឆ.៤ KH 01023838-39។ ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គឹម ចាត ឆ.៨ KH 01058777។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៤ KH 01023829-30។ ឯកសារ D118/138 កំណត់ ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១៦ KH 00960690។ ឯកសារ D219/944 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.៦ KH 01415386។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.២២, ២៥ KH 01238681, 82។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យ៉ែន ឆ.១៣៥-១៣៦ KH 01305011 ["ស៖ តើលោកអាចប្រាប់បានទេថានៅមន្ទីរសន្តិសុខខ្នងគូនោះ មានអគារមានអីប៉ុន្មានទេ? ឆ.១៣៥៖ អត់មានទេ មានតែកន្លែង ពេលយប់ឡើងវាដាក់គ្នាយាមទៅ [...] ស៖ អត់មានអគារ អត់មានរោងអីទេ? ឆ.១៣៦៖ អត់មានទេ"]។

[1833] ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យ៉ែន ឆ.៥៩-៦២ KH 01210568 [ពួកអ្នកទោសនៅខ្នងគូ "គេយកទៅវាយចោលទាំងអស់ហ្នឹង នៅគូកណ្តាល [...] ប្រហែល ពីរគីឡូ" ប្រវែង។ "បឹង១ធំ ប្រហែលជាកន្លះគីឡូបួនជ្រុង។ នៅក្នុងបឹងខាងលើខ្ញុំឃើញ[សាកសព] ហើយនៅក្បែរហ្នឹង[មានសាកសព]"]។ (*សូមកត់សម្គាល់ថា* នៅក្នុងកំឡុងពេលទស្សនកិច្ចជាបន្តបន្ទាប់ទៅកាន់ទីកន្លែងនោះ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស ម្នាក់បានថ្លែងថា "គូកណ្តាល [...] ស្ថិតនៅប្រហែលជា ៦០០ ម៉ែត្រ ខាងកើតមន្ទីរសន្តិសុខខ្នងគូ។ [...] មានរណ្តៅរាងមូល អង្កត់ផ្ចិតប្រហែលជា ១០ ម៉ែត្រ"។ *សូមមើល* ឯកសារ D219/988 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH 01522022)]។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ផុងលី ឆ.៣៩KH 01117291 ["ខ្ញុំបានឃើញផ្លូវមួយដែលនៅខាងកើតមន្ទីរសន្តិសុខនោះ។ [...] ខ្ញុំក៏ដើរតាមផ្លូវនោះ បានប្រហែល ៥០០ម៉ែត្រ ខ្ញុំក៏បានឃើញ [...] សាកសពអ្នកទោសពីខ្នងគូ [...] នៅក្នុងបឹង។ [...] ប្រហែលជា២០ទៅ៥០ម៉ែត្រ មាន [...] សាកសព"]។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈៀង ប៊ាន ឆ.១៧៥-១៧៧ KH 01153618 ["សាកសពទាំងអស់នោះ គឹកប់នៅនឹង

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និង ការប្រាស្រ័យទាក់ទង

521. **យ៉ីម ទិត្យ** មានសិទ្ធិអំណាចលើមន្ទីរសន្តិសុខខ្នងគ្ូ។ គុកនោះត្រូវបានគ្រប់គ្រងដោយតំបន់១[1834] និងបានទទួលអ្នកទោសពីកន្លែងផ្សេងៗនៅក្នុងតំបន់១ រួមទាំងពួកដែលបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខបាណន់ក្បែរនោះផង[1835] - ជាកន្លែងឧក្រិដ្ឋកម្មដែល **យ៉ីម ទិត្យ** បានទៅធ្វើទស្សនកិច្ច និង

អាងគ្ូ [...] ជាវាលមួយស្ថិតនៅខ្នងគ្ូ [...]។ អាងគ្ូស្ថិតនៅចម្ងាយពីស្ទឹងប្រហែល១០០ ទៅ១៥០ម៉ែត្រនៅត្រើយខាងកើត"]។ ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៧៨-៧៩ KH 00967991 ["គេបានយកអ្នកទោសទៅសម្លាប់ចោលទាំងអស់នៅគ្ូកណ្តាល ដែលមានទីតាំងនៅខាងកើតគុកខ្នងគ្ូប្រហែលជា៦០០ម៉ែត្រ។ មាន [...] កន្លែងដែលគេយកអ្នកទោសទៅសម្លាប់ ពីរកន្លែងនៅគ្ូកណ្តាល [...] មានរណ្តៅធំមួយមានសាកសព"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុះ រ៉ៀត ឆ.៥ KH 01023830 ["ត្រពាំងមួយ [...] ២០០ម៉ែត្រខាងកើតរបងមន្ទីរសន្តិសុខ។ ខ្ញុំបានឃើញសាកសព [...] គរលើគ្នាជាពំនូកដ៏ធំ នៅក្នុងកូនត្រពាំងមួយ។ [...] នៅជិតត្រពាំងនៅតាមវាលនោះ មានគំនរសាកសពខ្លះ"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៤ KH 01040098 ["ខ្ញុំរក្រហមបានយកអ្នកទោស [...] ចេញពីខ្នងគ្ូយកទៅសម្លាប់នៅក្នុងត្រពាំងមួយក្បែរនោះ"]។ ឯកសារ D219/273 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខខ្នងគ្ូ KH 01219940-41, 47។ *សូមមើលផងដែរ* ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្ជ្ជ ឡាម ឆ.៦ KH 01058792-93។

[1834] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៦៧, ១៧០ KH 01153617 [ខ្ញុំគ្ូ "ជាគុកថ្នាក់តំបន់"។ គណៈគុក "រាយការណ៍ទៅឲ្យតំបន់"]។ ឯកសារ D219/545 កំណត់ហេតុស្តាប់ចម្លើយ ផរ ប៉ែត ឆ.៤៤ KH 01157541 ["ពួកតំបន់គេមកនៅកន្លែងហ្នឹង ហើយគេដកពួកខ្ញុំចេញអស់ ដែលជាយោធាស្រុក"]។ *សូមមើលផងដែរ* ឯកសារ D1.3.11.55 កំណត់ហេតុនៃកិច្ចសម្ភាសន៍ ហាន់ ធី ដោយ ក.ស.ព EN 00221581។

[1835] ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.២៨ KH 01114652។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ផ្ទុងលី ឆ.១២ KH 01023841។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ម៉ៀន ឆ.១៥៧-១៥៨ KH 01305013។ *សូមមើលផងដែរ* ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងឿន ម៉ត ឆ.១០៥ KH 01155836។ មន្ទីរសន្តិសុខខ្នងគ្ូទទួលយកអ្នកទោសពីមន្ទីរសន្តិសុខបាណន់ នៅពេលមួយដែលមន្ទីរសន្តិសុខបាណន់ក៏ជាគុកថ្នាក់តំបន់ដែរ *សូមមើល* ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៨ KH 00934386។ ឯកសារ D219/390 កំណត់ហេតុស្តាប់ចម្លើយ ហង់ សួម ឆ.៩, ១៥ KH 01114648-49។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៤៦ KH 00920172។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ឆ្ងន ម្ងួន ឆ.៤៨ KH 00920217។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ផ្ទុងលី ឆ.៣៣ KH 01117289-90។ ឯកសារ D219/548 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ្ងឿម ឆ.៣៨, ៤១ KH 01157568, 69។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទ្ងៀប ទិត្យ ឆ.១៣, ១៥ KH 00960690។ ឯកសារ D219/546 កំណត់ហេតុស្តាប់ចម្លើយ ផរ ប៉ែត ឆ.៣ KH 01157545។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៦២ KH 00960671។ ឯកសារ D118/146 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខតំបន់១ KH 01385881។ ឯកសារ D34.1.10 បទសម្ភាសន៍ ហេង ទាវ ហៅ តាប៉ែត ដោយ ស្ទ្ីរ ហេងឌ័រ KH 00964055។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.២៨ KH 01238682 [ខ្ញុំគ្ូ "ជាគុកស្រុក [...] អ្នកទោសដឹកមកពីជិតពីឆ្ងាយ គេ

បានគ្រប់គ្រង[1836]។ **យ៉ីម ទិត្យ** ក៏បានដឹកនាំការប្រជុំនានានៅទីកន្លែងជិតខាងគុកទាំងពីរនោះផងដែរ ទាំងនៅមុនពេល និងក្រោយពេលការចាត់តាំងជាផ្លូវការរបស់គាត់ជាលេខាតំបន់១[1837]។ នាឱកាសមួយ ក្នុងចំណោមឱកាសទាំងនេះ **យ៉ីម ទិត្យ** បានបញ្ជាអ្នកចូលរួមឲ្យ "គោរពការចាត់តាំងរបស់

យកមកដាក់នៅក្នុងហ្នឹង"]។ ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គឹម ចាត ឆ.១៤ KH 01058778 ["អ្នកទោស [...] ត្រូវគេបញ្ជូនមកពីតាមឃុំក្នុងស្រុកសង្កែ និងស្រុកបាណន់"] (*សូមកត់សម្គាល់ថា* ស្រុកបាណន់ ត្រូវបានដឹងឮថាជា ស្រុកសង្កែ នៅក្នុងកំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ)។ ឯកសារ D118/135 កំណត់ហេតុស្តាប់ចម្លើយ ឆោម ឃួន ឆ.៣១ KH 00960657។

[1836] *សូមមើល* ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១២-១៣, ៤៥-៤៧, ៤៩, ៥១ KH 01238678-79, 86 ។

[1837] <u>ឆ្នាំ១៩៧៦ ឬ ឆ្នាំ១៩៧៧ នៅឃុំកន្ទឹ</u>៖ សាក្សី ដុស ឌឿន បានចូលរួមក្នុងការប្រជុំមួយនៅភូមិស្វាយបីដើម ឃុំកន្ទឹ ស្រុកបាណន់ ដែល តាទិត្យ បានធ្វើជាអធិបតី ដែលមាន "មនុស្សរាប់រយទៅប្រជុំ"។ *សូមមើល* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.២០២-២០៦, ២២៨-៣០ KH 01305016-17, 18-19។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៥២-៥៦ KH 01210568។ ថ្វីបើ ដុស ឌឿន បាននិយាយថា តាទិត្យ ជាកម្មាភិបាលភូមិភាគពាយ័ព្យ និងជាប្រធានស្រុក ទទួលខុសត្រូវឃុំកន្ទឹ១ ស្រុកបាណន់ គាត់ក៏បានថ្លែងផងដែរថាបុគ្គលរូបនោះ "ធ្លាប់ហៅប្រជាជនទៅប្រជុំ" "កាន់ក្តាប់អ្នកនៅកាប់ទ៉ន់ប៉ះកង្ហតហ្នឹង", ត្រូវបានគេឃើញនៅដើមឆ្នាំ១៩៧៦ ថាគាត់ "ដើរមើលគេជីកប្រឡាយ" នៅកង្ហត, "បាទ អត់ដកទេ" នៅពេលដែលពួកកម្មាភិបាលភូមិភាគនិរតីមានវត្តមាន និង "[បានឃើញឬក៏បានឮឈ្មោះតាទិត្យនេះ] នៅក្នុងរបបហ្នឹង រហូតដល់រៀតណាម ចូល បានបាត់"។ គាត់បានរៀបរាប់ពី តាទិត្យ ថាមាន "រូបរាងធំ ក្បាលទំពែកបន្ដិច ហើយខ្មៅ"។ *សូមមើល* ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៤៧-៥១, ៥៨ KH 01210567, 68។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.២០១, ២០៧-២០៩, ២១៣-២២០, ២២៤ KH 01305016-18។ <u>ចុងឆ្នាំ១៩៧៧ នៅវត្តបាណន់លើ</u>៖ ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៧៥-៧៦ KH 01196544 ["តាទិត្យ ធ្លាប់មកប្រជុំដែរ [...] នៅបាណន់។ [...] ប្រជុំខែច្រូតស្រូវ ចុងឆ្នាំ១៩៧៧ ជិតដាច់ហើយ"]។ ឯកសារ D219/689 កំណត់ ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤០-៤១ KH 01205207-08 ["គេប្រជុំនៅវត្តបាណន់លើ ហើយគុកនោះនៅខាងត្បូងវត្ត [...]។ ច្រើនគ្នាមានទាំងកម្មាភិបាលសហករណ៍ គណៈស្រុក តំណាងចល័ត និងតំណាងយុវជន គឺមានមនុស្សរាប់រយដែរ ខ្ញុំមិនបានរាប់ទេ"]។ <u>ចុងឆ្នាំ១៩៧៨ នៅវត្តបាណន់ក្រោម</u>៖ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ៉ន ឈួយ ឆ.៣០, ៣៣, ៤៤, ៤៦ KH 01149403, 06 ["កិច្ចប្រជុំនោះ ប្រហែលជានៅអំឡុងខែ១១ ឆ្នាំ១៩៧៨" "ក្រោយពេលដែល តាប៉ែត បានបាត់ខ្លួន [...] ក្នុងវត្តបានណន់ក្រោម"។ "គុកខ្ញុំងគ្ងមានចម្ងាយពីសាលាធម្មសភា ប្រហែល៣០០ ទៅ៤០០ម៉ែត្រ"។ ការប្រជុំនោះ មានរយៈពេលមួយសប្ដាហ៍ ដោយមាន តាទិត្យ [...] ជា [...] គណៈភូមិភាគ ឬក៏ជាគណៈតំបន់ក៏មិនដឹង"។ "មានចំនួនប្រហែលបី ទៅបួនពាន់នាក់" "សមាជិកកងទាំងអស់មកពីស្រុកសង្កែទាំងមូល ត្រូវបានគេអញ្ជើញឲ្យចូលរួមកិច្ចប្រជុំនេះ"]។ <u>ឆ្នាំ១៩៧៩ នៅវត្តបាណន់</u>៖ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ សឿន ម៉ត ឆ.៥០, ៧២, ៧៥ KH 01155828, 32 ["កិច្ចប្រជុំនៅបាណន់ ធ្វើឡើងនៅក្នុងឆ្នាំ១៩៧៩ [...] ប៉ុន្ដែរបបខ្មែរក្រហមមិនទាន់ដួលរលំនៅឡើយទេ។ [...] កិច្ចប្រជុំ [...] គេធ្វើឡើងនៅក្នុង [...] វត្តបាណន់។ [...] ខ្ញុំមើលជុំវិញទៅ ឃើញថាអ្នកចូលរួមកិច្ចប្រជុំសុទ្ធតែយោធា។ ហើយមានប្រហែលជាបួន ទៅប្រាំរយនាក់ ដែលសុទ្ធជាទ័ព"]។

អង្គការ"[1838]។ នាឱកាសមួយផ្សេងទៀត ប្រធានបទនៃការពិភាក្សាគឺ "អតីតទាហាន លន់ នល់ កុម្ម ង់ដូរ ហើយអ្នកដែលស្ថិតនៅក្នុងសមាសភាពបែបនេះ ត្រូវបានគេប្រាប់ឲ្យសារភាព" និង "គិញសម្ងាត់ និងអ្នកជាប់ខ្សែយួនផងដែរ"[1839]។

522. **យ៉ីម ទិត្យ** បានអនុវត្តគោលនយោបាយ ប.ក.ក នៅមន្ទីរសន្តិសុខខ្នងគ្ន ដោយមានជំនួយពីយោធា និងកម្លាភិបាលនៅក្នុងស្រុក និងនៅគុកនេះ។ ភ័ស្តុតាងបង្ហាញថា កម្លាភិបាលមកពីភូមិភាគនិរតី រួមមាន យោធា ប្រធានសហករណ៍ និងប្រធានភូមិ បានចេញបញ្ជាឲ្យសម្លាប់អ្នកទោសនៅមន្ទីរ សន្តិសុខនេះ[1840]។ សាក្សីម្នាក់ដែលបានរស់នៅក្នុងឃុំបាយដំរ៉ា ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិប

[1838] ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៤៣ KH 01205208។ *សូមមើលផងដែរ* ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.៦២, ៨២ KH 01425174, 77 [ក្បែរទំនប់កង្ហត "ប្រជុំយ្ងរដែរ រៀតណាមចូលមក [...] កុំឲ្យប្រឆាំងជាមួយនិរតី"]។ នៅឆ្នាំ១៩៧៧ ក្នុងស្រុកសង្កែ យ៉ីម ទិត្យ "គាត់ដឹកនាំ គាត់ចាត់តាំង" សៅ ជាប់ ឲ្យស៊ើបអង្កេត ឲ្យរាយការណ៍ទ្ធ "ការខុសឆ្គង" និងបានប្រាប់គាត់ថា "បើប្រព្រឹត្តធ្ងន់ធ្ងរត្រូវសម្លាប់គឺឲ្យសម្លាប់"។ សៅ ជាប់ បានផ្ទែងថា គឺ យ៉ីម ទិត្យ នេះហើយដែល "បានចាត់តាំងឃាតកឲ្យសម្លាប់មនុស្ស"។ *សូមមើល* ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១២១ KH 01244134 និង ឆ.១១៤, ១១៦, ១១៨, ១២០, ១២៣ KH 01244133-34។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈៀត ឆ.៧៨ KH 01425177 ["គេនិយាយតែល្អហ្ម៊ីងឯង"]។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៦៧ KH 01477617 ["ឲ្យធ្វើហិង្សាអី ខ្ញុំមិនដឹងទេ។ [...] ខាងលើគេដឹកនាំ ល្អតើ គេមិនធ្វើហិង្សាអាក្រក់ទេ"]។

[1839] ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ឆ៊ីន ឈួយ ឆ.៣០ KH 01149403 (*សូមកត់សម្គាល់* D219/515 កំណត់ហេតុស្តាប់ចម្លើយ ឆ៊ីន ឈួយ ឆ.៥៦ KH 01149407)។ នៅឆ្នាំ១៩៧៦ ក្នុងស្រុកសង្កែ សៅ ជាប់ បានស្តាប់ យ៉ីមទិត្យ ពិភាក្សាពីសកម្មភាពខ្មាំងផ្ទៃក្នុង និងខាងក្រៅ ដោយសង្កត់ធ្ងន់ពីការចាំបាច់ត្រូវការពារប្រឆាំងនឹង "ខ្មាំងមានរូបភាពអ្វីខ្លះ"។ *សូម មើល* ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៥ KH 01477610 និង ឆ.៥, ១១, ១៣ KH 01477606, 08។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៧០-៧១ KH 01244127។ ឯកសារ D219/956 កំណត់ហេតុ ស្តាប់ចម្លើយ សៅ ជាប់ ឆ.១៤-១៥, ២២, ៥៥, ៦១, ៦៣ KH 01425219-20, 26-28។ នៅឆ្នាំ១៩៧៨ ក្នុងស្រុកសង្កែ វ៉ី ផាន់ បានស្តាប់ យ៉ីម ទិត្យ និយាយ៖ គាត់ "មាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុងដែលណាក់ខ្លួនស្ទ្ទីរួងផ្ទៃក្នុងរបស់ចលនាយើង ហើយក៏មាន ពួក សេ.អ៊ុ.អា កា.ហ្សេ.បេយ្ជន ណាក់ខ្លួនជាមួយយើងផងដែរ។ តាទិត្យ បាននិយាយប្រាប់ពួកយើងថា យើងត្រូវតែយ្ជាំមើលពួក ទាំងនេះ ហើយបើយើងបានព័ត៌មានទាក់ទងនឹងសកម្មភាពពួកទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេច ពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង"។ *សូមមើល* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៣, ៥ KH 01040093-94។ ឯកសារ D219/245 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ វ៉ី ផាន់ KH 01364043។ *សូមមើលផ្ទុយ ពីនេះ* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១១ KH 01040097 [យ៉ីម ទិត្យ "មានអត្តចរិតស្ងួតបូត"]។

[1840] ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៥ KH 01040099 ["មេកងនៅភូមិស្វាយព្រៃ ឃុំកន្ទ្ទ១ [...] បាន និយាយថា ពួកយោធានិរតី ហើយនិងគណៈឃុំកន្ទ្ទ១ណ្ណោះ ផាន ដែលមកពីនិរតីដែរ បានឆ្លងស្ទ្ទីងពីត្រើយខាងលិចទៅត្រើយខាង

តេយ្យបាននិយាយថា៖ "ថ្នាក់លើឲ្យ [...] ចាប់។ [...] អ្នកដែលមកចាប់គឺខាងយោធា" ដែលបានធ្វើការសម្លាប់ផងដែរ[1841]។ យោធាបានយាមកាមមន្ទីរសន្តិសុខខ្នងគ្នា[1842]។ អតីតអ្នកយាមគុកខ្នងគ្នាម្នាក់ ឈ្មោះ វ៉ែ រួម ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យ និងជាយោធាអនុសេនាតូចរបស់ស្រុក បាននិយាយថា "ពួកនិរតីគេគ្រប់គ្រង [...] មាននិរតីខ្លះ ពាយ័ព្យខ្លះ" ដែលបានធ្វើការនៅមន្ទីរសន្តិសុខនេះ[1843]។ ប្រធានគុក"មកពីនិរតី"[1844]។ ប្រធានមន្ទីរសន្តិសុខខ្នងគ្នា បានណែនាំអ្នកទោសឲ្យ "យើងខំប្តូរ អត់ធន់ ដើម្បីផលប្រយោជន៍បដិវត្តន៍ កុំក្បត់បដិវត្តន៍"[1845] គណៈគុក រួមមាន សួម ដែលជាសាក្សីម្នាក់បាននិយាយថាជាកម្មាភិបាលភូមិភាគពាយ័ព្យ[1846]។ សួម បានប្រាប់សាក្សីនោះថា គាត់បានទទួលបញ្ជាពី "ប្រធានគាត់បានឲ្យអ្នកទោសដែលទើបចូលថ្មី មានកម្លាំងវ៉ៃធ្វើបាបអ្នកទោសចាស់ៗដែលចាប់ពីមុន"[1847]។ សួម ជាមួយនឹងមេៗ និងអ្នកសួរចម្លើយ បានចូលរួមក្នុងការសួរចម្លើយ

ក្បាត ទៅបញ្ជាឲ្យអ្នកធ្វើការនៅនឹងមន្ទីរឃុំឃាំងខ្នងគ្នានាំអ្នកទោសក្នុងមន្ទីរនោះ ទាំងអស់យកទៅសម្លាប់។"]។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀន ម៉ត ឆ.១០៣-១០៤ KH 01155836 ["[តាចែម] ដឹកនាំក្រុមរបស់គាត់ទៅសម្លាប់មនុស្ស [...] នៅគុកខ្នងគ្នា"] ឆ.៥៣-៥៤ KH 01155829 ["តាចែម, តាផាន និងតាទិត្យ មកពីនិរតី។ តាចែម មានឋានៈជាមេភូមិ។ តាផាន ជាមេសហករណ៍។"]។

[1841] ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១២៧, ១៤៨ KH 01040177, 78។

[1842] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.២, ៦-៧, ១៨, ២៣ KH 01238676, 77, 79, 81។ ឯកសារ D219/549 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង អ៊ីម ឆ.១ KH 01157575។ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១៦៨ KH 01040180។

[1843] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.២៧ KH 01238682។ *សូមមើលផងដែរ* ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ៉ន ឈួយ ឆ.៥៤ KH 01149407 ["នៅពេលពួកនិរតីមកដល់ អតីតកម្មាភិបាលពាយ័ព្យមួយចំនួនដែលគ្រប់គ្រងការងារនៅក្នុងគុកខ្នងគ្នា ត្រូវបានពួកម្មាភិបាលនិរតីមកជំនួស។"]។ ឯកសារ D219/545 កំណត់ហេតុស្តាប់ចម្លើយ ផ ប៉ែត ឆ.៤៤-៤៥ KH 01157541 ["ឆ.៤៤៖ [...] ពួកតំបន់គេមកនៅកន្លែងហ្នឹង ហើយគេដកពួកខ្ញុំចេញអស់ ដែលជាយោធាស្រុក។ ស៖ កាលហ្នឹងលោកចង់និយាយថា ពួកយោធាតំបន់ហ្នឹងគេមកស្នាក់នៅកន្លែងគុកហ្នឹង ឬយ៉ាងម៉េច? ឆ.៤៥ បាទ គេមកស្នាក់នៅហ្នឹង"]។

[1844] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.២៧ KH 01238682។

[1845] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៦២ KH 01153616។

[1846] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៦៥-១៦៦, ២០៩ KH 01153617, 22 ["ស៊ីម ដែលជាអនុប្រធានគុក [...] ជាកម្មាភិបាលពាយ័ព្យ។ [...] គាត់ប្រាប់ខ្ញុំអំពីប្រធានរបស់គាត់"]។ ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីក ឡាម ឆ.២ KH 01058791 ["ប្រធានសន្តិសុខឈ្មោះ សួម"]។ ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីក ឡាម ឆ.១៥ KH 01080837។ *សូមមើលផងដែរ* ឯកសារ D219/214 កំណត់ហេតុនៃកិច្ចស៊ើបសួរ KH 01364039។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៥ KH 01040099។

[1847] D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២០៩ KH 01153622។

អ្នកទោស[1848]។ គណៈគុក "រាយការណ៍ទៅឲ្យតំបន់"[1849]។ ប្រធានឃុំនៅក្នុងស្រុកនេះបាននិយាយថា ការងារអ្វីគឺត្រូវតែប្តូរយោបល់ជាមួយគាត់ [យ៉ីម ទិត្យ] ទាំងអស់។ បើមិនរាយការណ៍ទេគឺមិនបានទេ"[1850]។

523. ការដឹងឮរបស់ **យ៉ីម ទិត្យ** អំពីឧក្រិដ្ឋកម្មនានានៅមន្ទីរសន្តិសុខក្រៅប្រព័ន្ធតុលាការនេះ បង្ហាញដោយ៖ (i) ការទទួលយកដោយមន្ទីរសន្តិសុខនេះនូវអ្នកទោសពីមន្ទីរសន្តិសុខបាណន់នៅជិតនេះដែល **យ៉ីម ទិត្យ** បានទៅទស្សនា និងបានអនុវត្តការគ្រប់គ្រងលើ (ii) ការទាមទាររបស់គាត់ឲ្យមានរបាយការណ៍លម្អិតនៅក្នុងស្រុកនោះ (iii) ការរៀបចំធ្វើការប្រជុំនានារបស់គាត់នៅក្នុងបរិវេណទីតាំងនេះ និង (iv) មុខតំណែងរបស់គាត់ជាលេខាតំបន់១ ដែលផ្តល់សិទ្ធិអំណាចឲ្យគាត់លើទីតាំងនេះ។

iv. ឧក្រិដ្ឋកម្ម

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

524. ក្នុងរយៈកាលដែលកម្មាភិបាលភូមិភាគនិរតីគ្រប់គ្រងខ្ជងគ្ន "អ្នកទោសថ្មីគឺត្រូវនាំចូលមកជារៀយៗ"[1851]។ អតីតអ្នកទោសម្នាក់បានប្រាប់សាក្សីថា "[អ្នកទោស] បញ្ជូលមួយថ្ងៃមានមួយ

[1848] D219/158 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីក ឡាម ឆ.២ KH 01058791 (*កត់សម្គាល់* ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៊ីង ប៊ាន ឆ.១៦៥ KH 01153617)។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.២៦ KH 01238682 ។

[1849] D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៊ីង ប៊ាន ឆ.១៦៥-១៦៦, ១៦៧, ២០៩ KH 01153617, 22។

[1850] D105/8 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.២៣ KH 00794128។ *សូមមើលផងដែរ* ឯកសារ D219/654 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.១៩, ៣១-៣២ KH 01196532, 34-35 [នៅទីតាំងការងារដោយបង្ខំទំនប់កង្គត ក្នុងស្រុកសង្កែ "[ខ្ញុំ] រាយការណ៍ទៅឲ្យអង្គការគណៈតំបន់ [...] គេកំណត់ឲ្យរាយការណ៍១ខែហ្នឹងពីរបីដង។ [...] ប្រធានខ្ញុំ [...] មិត្ត ខេន ក៏រាយការណ៍ទៅគណៈតំបន់ដែរ។"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៧ KH 01040094-95 [នៅទីតាំងការងារបង្ខំទំនប់កង្គត៖ "អ្នកនិយាយនៅក្នុងអង្គប្រជុំពេលនោះ គឺមាន តាទិត្យ [...]។ ឆេង បានរាយការណ៍អំពីសកម្មភាពនានាដែលកើតនៅក្នុងឃុំទាំងប្រាំពីរដែលគាត់គ្រប់គ្រង។ [...] តាទិត្យ [...] អង្គុយចាំស្តាប់ និងកត់ត្រា។ [...] របាយការណ៍ត្រូវបានធ្វើដោយប្រធានសហករណ៍/ឃុំកន្ទឹ១ និងកន្ទឹ២ [...] ដោយប្រធានសហករណ៍/ឃុំប្រយុទ្ធ ដែលសព្វថ្ងៃនេះហៅថា ភូមិកង្គត និងឃុំរ្ជង សព្វថ្ងៃនេះគេហៅថា ឃុំចែងមានជ័យ។"]។

[1851] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីក ឡាម ឆ.៧ KH 01058793។

មានពីរ ឬបីនាក់"[1852]។ វ៉ែ រួម ដែលបានយាមនៅមន្ទីរសន្តិសុខខ្នងគ្ងរយៈពេលមួយខែ បានសង្កេតឃើញ "[មានអ្នកទោស] ៧០០ ឬ ៨០០នាក់"[1853]។ សាក្សីផ្សេងទៀតនិយាយថា គុកនេះដាក់អ្នកទោស ១០០ នាក់ ឬច្រើនជាងនេះ[1854]។

525. ដូចបានរៀបរាប់ខាងលើនៅក្នុងអនុវាក្យខណ្ឌ *រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង*[1855] អ្នកទោសមកពីទូទាំងស្រុក និងកន្លែងផ្សេងទៀតក្នុងតំបន់១ រួមបញ្ចូលទាំងអ្នកដែលជាប់ឃុំនៅមន្ទីរសន្តិសុខបាណន់ និងអ្នកដែលជាប់ឃុំបណ្តោះអាសន្ននៅវត្តបាយដំរ៉ាំ[1856]។ បុរស ស្ត្រី រួមទាំងស្ត្រីមានផ្ទៃពោះ និងកុមារត្រូវបានឃុំឃាំង[1857]។ មាន "'អ្នកទោសធ្ងន់ [...] ដែលជាប់

[1852] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យឿង ប៊ាន ឆ.១៧១ KH 01153617។

[1853] ឯកសារ D219/944 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១៥ KH 01415389។

[1854] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្យ៉ីក ឡាម ឆ.៦ KH 01058793 ["អ្នកទោស [...] នៅក្នុងបន្ទប់ឃុំឃាំងនោះគឺមានប្រហែល១០០នាក់។"]។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យីន ឆ.១១២-១១៣ KH 01305009 ["ខ្ញុំឃើញ [...] ប្រហែលជា ១០០។"]។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៣៨ KH 01117290-91 ["តាមការប៉ាន់ស្មាន និងវាយតម្លៃទីតាំងក្នុងមន្ទីរសន្តិសុខនោះ គឺអាចដាក់មនុស្សបានចន្លោះពី ១០០ ទៅ ២០០នាក់។"]។ ឯកសារ D1.3.11.24 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៀន ដោយ ក.ស.ព EN 00210507 ["គុក គ្ង [...] ដាក់មនុស្ស ១៨០នាក់។"]។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធ្ងើន ឆ.១០៦ KH 00947597 [សារ៉ី និង សារ៉ូ "បានប្រាប់ខ្ញុំថា មានអតីតកម្មាភិបាលភូមិភាគពាយ័ព្យជាប់នៅទីនោះជាងមួយរយនាក់។"]។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យឿង ប៊ាន ឆ.១៧១ KH 01153617 [សារ៉ូ "ថា អ្នកដែលជាប់គុកនោះវាច្រើន។"]។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ ស៊ឿន ម៉ត ឆ.៩៤ KH 01155835 ["មានគុកធំមួយ ដែលអាចដាក់អ្នកទោសរាប់រយនាក់។ វាមានទីតាំងនៅខ្នងគ្ង"]។ ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គ៉ីម ចាត ឆ.៩ KH 01058777។

[1855] *សូមមើល* V.ខ.២.ច.iii. ឧក្រិដ្ឋកម្ម- ភូមិភាគពាយ័ព្យ-តំបន់១-មន្ទីរសន្តិសុខខ្នងគ្ង-រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនង។

[1856] ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទ្យ៉ៃប ទិត្យ ឆ.១០៨, ១១៧ KH 01132062-63 ["គេយកវត្តបាយដំរ៉ាំធ្វើជាកន្លែងឃុំមនុស្សបណ្តោះអាសន្ន មុននឹងបញ្ជូនទៅកន្លែងផ្សេងទៀត។ [...] គេបញ្ជូនទៅ [គុក] ខ្នងគ្ង។"]។ *សូមមើលផងដែរ* ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យឿង ប៊ាន ឆ.៦៤, ៦៧-៦៨ KH 01153599-600 [ប្រជាជននៅឃុំបាយដំរ៉ាំត្រូវបានចាប់ខ្លួនយកទៅមន្ទីរសន្តិសុខខ្នងគ្ង។]។

[1857] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្យ៉ីក ឡាម ឆ.៣, ៦ KH 01058792-93។ ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្យ៉ីក ឡាម ឆ.១៤ KH 01080837។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យឿង ប៊ាន ឆ.១៧២ KH 01153617-18។ ឯកសារ D219/944 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១៥ KH 01415389-90។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យីន ឆ.១៣៣ KH 01305011។ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៀន ឆ

និន្នាការខ្លាំង"[1858]។ ពួកអ្នកទាំងនោះរួមមាន៖ កម្មាភិបាលភូមិភាគពាយ័ព្យដែល "ពួកនិរតី [...] បានចោទថាជា សេអ៊ីអា និងបណ្តាញវៀតណាម" និងគ្រួសាររបស់ពួកគេ និងថ្នាក់ក្រោម ក៏ដូចជាលេខា និងអនុលេខាឃុំបាយដំរ៉ាំ[1859] សមាជិកអតីតរបប លន់ នល់[1860] "ប្រជាជនថ្មី" ប្រជាជនមូល

.១២៦ KH 01040177។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៤ KH 01023829-30។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យើន ឆ.១៣៣ KH 01305011 ["កុមារអត់មានទេ"]។

[1858] ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១១៧ KH 01040176។ *សូមមើលផងដែរ* ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.២៨ KH 01238682។

[1859] ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ៌ន ឈួយ ឆ.១៥ KH 01149399។ ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៧៧-៧៨ KH 01132059 ["តារិន និង តារ៉ម ជា [...] គណៈឃុំ [បាយដំរ៉ាំ]។ តារិន និង តារ៉ោះម ត្រូវបានចាប់ដាក់គុកខ្នងគ្នា"] ឆ.១១៥ KH 01132063 ["ឆ៖ ចុះកម្មាភិបាលផ្សេងទៀតគេឃុំនៅកន្លែងណា? ឆ.១១៥៖ ពួកគេត្រូវបានបញ្ជូនទៅគុកខ្នងគ្នាតែម្តង។"]។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ហ៊ីា ឆ.៦៥ KH 00960671 ["ក្មួយប្រុសរបស់តា ប៉ែត ឈ្មោះ រ៉ារិន និង រ៉ាត់ ក៏គេចាប់ដាក់គុកនៅខ្នងគ្នាដែរ"]។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.២៩ KH 01238682។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យើន ឆ.១៣៧ KH 01305011។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យើង ប៊ាន ឆ.១៥៩, ១៦១ KH 01153615-16 ["សារ៉ី និង សារ៉ូ [...] ធ្វើមេកងនៅក្រឡ្ពាស។ ពេលគេចាប់គាត់ដាក់ពន្ធនាគារខ្នងគ្នា" សារ៉ូ "បានប្រាប់ថា តាទិត្យ ជាអ្នកបញ្ជាឲ្យតា សាម៉ន ចាប់គាត់ពីរនាក់បងប្អូនទៅដាក់មន្ទីរឃុំឃាំងនៅខែ៧ ឬខែ៨ ឆ្នាំ១៩៧៨។ [...] តា សាម៉ន និយាយថា 'ពួកអ្ហែង ពួកជាពួកកម្ពត់ជាតិ ក្ពត់ឧត្តមគតិប្រជាជន មិនឲ្យប្រជាជនហូបអ្ហែត។'"] ឆ.១៧២ KH 01153617 [សារ៉ូ "ប្រាប់ [...] ថា កម្មាភិបាល [...] ត្រូវបានដាក់គុក។"]។ ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធ្ងើន ឆ.១០៤ KH 00947596 ["អ្នកដែលជាប់គុកនៅមន្ទីរសន្តិសុខខ្នងគ្នាចំនួនពីរនាក់ [...] ម្នាក់ឈ្មោះសារ៉ី និងម្នាក់ឈ្មោះ សារ៉ូ។ [...] សារ៉ី ជាអតីតប្រធានសហករណ៍បាយដំរ៉ាំ។"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១១ KH 01023831។

[1860] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.២៩ KH 01238682 [អ្នកជាប់ឃុំទាំងនោះជា "ទាហាន លន់ នល់។"]។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យើន ឆ.១១៤-១១៥, ១១៧ KH 01305009 ["ខ៉ែពុកក្មេកខ្ញុំ [...] [ទៅដល់មន្ទីរសន្តិសុខខ្នងគ្នា] មុន [ខ្ញុំ។]។ [...] [គាត់ជា] កងទ័ព លន់ នល់។"] ឆ.២២ KH 01305001 ["ដាក់គុកមនុស្ស ដូចជា [...] សក្តិ៥"]។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យើង ប៊ាន ឆ.១៧២ KH 01153617-18 [សារ៉ូ "ប្រាប់ [ខ្ញុំ] [...] អ្នកស្រុកដែលជាប់និន្នាការបន្តិចបន្ទ្ចជំនាន់ លន់ នល់ ដូចជាទាហាន ឬកម្ម៉ង់ដូ ដែលវាស៊ើបដឹង [...] ត្រូវបានចាប់ដាក់គុក [...] ខ្ញុំក៏ដឹងដោយខ្លួនឯងឃើញគេចាប់ មារ៉ូម ដាក់ពន្ធនាគារ ព្រោះគាត់មាននិន្នាការធ្វើពេទ្យទាហានជំនាន់ លន់ នល់។"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.១៦ KH 00960690 ["ខ្ញុំគិតថា មានអ្នកទោសច្រើន នៅពេលដែលគេប្ជូរគុកទៅនៅខាងកើតស្ទឹង ព្រោះគេចាប់ទាហាន លន់ នល់ មកច្រើនណាស់។"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៩ KH 01023831 ["អ្នកដែលធ្លាប់ជាប់នៅក្នុងមន្ទីរសន្តិសុខខ្នង [គ្នា] ម្នាក់ដែរ [...] គាត់នោះឈ្មោះ ជ្រៃ ដែលធ្លាប់ធ្វើពេទ្យ កាលនៅសម័យ លន់ នល់។"]។

ដ្ឋាន[1861] និងជនជាតិវៀតណាម[1862]។ ក៏មាន "'អ្នកទោសស្រាល' [...] ដែលលួច" អាហារ ឬ "ធ្វើការយឺតយ៉ាវបន្តិច" ផងដែរ[1863]។

526. អ្នកទោសរួមមាន ភ្ជីក ឡាំ ដែលមានផ្ទៃពោះ ត្រូវបានឃុំឃាំងនៅក្នុងរោងមួយមាន "លួសបន្ទាត់ទ្វារពីក្រៅ"[1864]។ ដៃ និងជើងរបស់ពួកគេជាប់ខ្នោះ[1865]។ "គេឲ្យ [អ្នកទោស] ដេកនៅលើដី" គ្មានមុងឡើយ[1866]។ នៅក្នុងរោង "ក្តៅខ្លាំង" ពួកអ្នកទោស "ដេកនៅហ្នឹង ជុះនៅហ្នឹង [លើដី]"[1867]។

[1861] ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១២៤ KH 01040176 ["អ្នកមកថ្មី ហើយក៏មានអ្នកចាស់ដែរត្រូវបានចាប់យកមកឃុំនៅខ្នងគ្នា។"]។

[1862] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្ជីក ឡាម ឆ.២ KH 01058791 ["ពេលគេនាំខ្ញុំទៅដល់មន្ទីរសន្តិសុខ ទើបគេប្រាប់ខ្ញុំអំពីហេតុផលដែលខ្ញុំត្រូវបានគេចាប់ខ្លួន ដោយគេថាខ្ញុំគឺជាកូនឃ្លួន។"] ឆ.៦ KH 01058793 ["ឃាយចាស់ជនជាតិវៀតណាមម្នាក់ ដែលពេលនោះត្រូវបានគេដាក់ខ្នោះជើងនៅជិតខ្ញុំ [...] ស្រែកថ្ងូរជាភាសាវៀតណាម"]។

[1863] ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១១៧, ១៣៧ KH 01040176, 78។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យ៉ែន ឆ.៣៩-៤០ KH 01210566។ *សូមមើលផងដែរ* ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.២៨ KH 01238682។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៉ែង ប៊ាន ឆ.៦៧, ១៧២ KH 01153600, 617-618។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យ៉ែន ឆ.១៣២, ១៣៤ KH 01305011។ ឯកសារ D219/748 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្យ៉ែន ឆ.៩០ KH 01235368-69។ ឯកសារ D219/932 កំណត់ហេតុស្តាប់ចម្លើយ ស្យ៉ែម វ៉ុត ឆ.៤២ KH 01396453-54។

[1864] ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៤ KH 01023830។

[1865] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្ជីក ឡាម ឆ.៦ KH 01058793។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៉ែង ប៊ាន ឆ.១៦២ KH 01153616។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.៣១ KH 01238683 ។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៤ KH 01023838-39។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៤ KH 01023829-30។ *សូមមើលផងដែរ* ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គឹម ចាត ឆ.៨ KH 01058777។

[1866] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៉ែង ប៊ាន ឆ.១៦២ KH 01153616។ ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្ជីក ឡាម ឆ.១៨, ២០ KH 01080837-38។ *សូមមើលផងដែរ* ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៤ KH 01023838-39។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៤ KH 01023829-30។ ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គឹម ចាត ឆ.៨ KH 01058777។

[1867] ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្ជីក ឡាម ឆ.១៨ KH 01080837។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យ៉ែង ប៊ាន ឆ.១៦២ KH 01153616។ *សូមមើលផងដែរ* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យ៉ែន ឆ.១៥៤ KH 01305013។

527. អ្នកទោសមានសភាពស្គមស្គាំងយ៉ាងខ្លាំង ដូចដែលបានកត់សម្គាល់ដោយ តាស៊ូម ដែលជាសមាជិកគណៈគុកនេះ[1868]។ អ្នកទោសទទួលបានរបបអាហារមិនគ្រប់គ្រាន់[1869]។ សាក្សីម្នាក់ "អ្នកទោសខ្លះដែលឃ្លានខ្លាំងក៏បានឱនរើសសំបកដំឡូងមី [...] ដែល [ខ្ញុំ] ចាក់ចោលនោះ យកមកហូប ហើយត្រូវបានអ្នកយាមស្រែកសម្ពុតមិនឲ្យរើស"[1870]។ សាក្សីម្នាក់ទៀតបាននិយាយថា អតីតអ្នកទោសបានប្រាប់គាត់ថា "[គាត់] ចាប់ក្ងានកង្កែបស៊ីទាំងឆៅ [...] ដើម្បីឲ្យតែគាត់រស់"[1871]។

528. អ្នកទោសត្រូវធ្វើការងារជាច្រើន ដែលរួមមាន ជីករណ្តៅកប់សព និងជញ្ជូននិងការកប់សាកសព[1872]។ ក៏មានបញ្ជាទៅកាន់ "អ្នកទោសដែលទើបចូលថ្មីមានកម្លាំងវ៉ៃធ្វើបាបអ្នកទោសចាស់ៗដែលជាប់ពីមុន"[1873]។ ភ្ជីក ឡាំ បាននិយាយថា សូម្បីតែនៅពេលដែលគាត់មានផ្ទៃពោះ រូបគាត់ និងអ្នកផ្សេងទៀត ដែលធ្វើស្រែ ធ្វើការចាប់ពីម៉ោង ៨ព្រឹក ដល់ម៉ោង ៥ល្ងាច ដោយសម្រាក

[1868] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២០៩ KH 01153622 ["សារី ថា ខ្ញុំគ្មានកម្លាំងទេ តាស៊ូម ថា [...] មនុស្សស្គមគ្មានកម្លាំងនៅតែឆ្ម៉ង"]។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៤២, ៦៨, ១៤៦ KH 01305003, 05, 12 ["អ្នកទោសនោះគឺស្គមស្គាំង [...] សុទ្ធតែឆ្ម៉ងទៅហើយ។ [...] ក្បើងខ្ញុំពេលនោះប៉ុនកដៃ"]។

[1869] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៧៨-១៧៩ KH 01153618។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.២២ KH 01238681។ ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្ជីក ឡាម ឆ.១២, ១៨ KH 01080836-37។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៣១ KH 01305011។ ឯកសារ D219/944 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១៥ KH 01415389-90។

[1870] ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្ជីក ឡាម ឆ.១៣ KH 01080837។

[1871] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៥៩ KH 01153615។

[1872] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្ជីក ឡាម ឆ.៦ KH 01058793 ["អ្នកទោសត្រូវបានគេប្រើឲ្យសែងសាកសព ដែលគេវ៉ៃសម្លាប់រួចយកទៅកន្លែងកប់"]។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៥៩ KH 01153615 [សារី និង សារ៉ូ "គេបានឲ្យគាត់ភ្ជួរស្រែ មើលគោ។ ពេលខ្លះគេយកមនុស្សទៅសម្លាប់ ហើយគេឲ្យគាត់កប់សពទាំងនោះ។"]។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១៨ KH 01238679 ["ពួកពាយ័ព្យគេដោះលែងខ្លះហើយ ឲ្យធ្វើស្រែ [...] រួមទាំងឪពុកខ្ញុំផង។"]។ ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្ជីក ឡាម ឆ.៩, ១១-១២ KH 01080836 ។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៣១, ១៤៦ KH 01305011-12។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ផុងលី ឆ.៤ KH 01023838-39។ *សូមមើលផងដែរ* ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១១ KH 01023831 ។

[1873] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២០៩ KH 01153622 ["តាស៊ូម បាននិយាយថា [...] ប្រធានរបស់គាត់ឲ្យអ្នកទោសដែលទើបចូលថ្មីមានកម្លាំងវ៉ៃធ្វើបាបអ្នកទោសចាស់ៗដែលជាប់ពីមុន"]។

ម្តងពេលអាហារថ្ងៃត្រង់[1874]។ អ្នកទោសស្គមស្គាំងតស៊ូអនុវត្តការងាររបស់ខ្លួន[1875]។ ប្រសិនបើពួកគេធ្វើខុស ពួកគេត្រូវបានវាយដំ[1876]។ ការគំរាមកំហែង និងអំពើហិង្សារូបលើរាងកាយត្រូវបានគេប្រើដើម្បីធ្វើឲ្យអ្នកទោសធ្វើការ[1877]។ អ្នកទោសរស់នៅក្នុងភាពភ័យខ្លាច "ភ័យខ្លាចតែពីរឿងស្លាប់" និងអាស្រ័យហេតុនេះ "តែងតែធ្វើតាមបញ្ជា […] រហូត"[1878]។

529. អ្នកទោសត្រូវបាន "រៃ […] ២ ទៅ៣ ថ្ងៃម្តង"[1879]។ ជនរងគ្រោះទាំងនេះមាន "ដង្ហូរវ្រុកដោយសារវាវាយបែក ហើយពេលនោះបើកម្រើកខ្នោះនឹងរឹត"[1880]។

[1874] ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.១០ KH 01080836។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ រ៉ែ រួម ឆ.២២ KH 01238681។ *សូមមើលផងដែរ* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៤៧ KH 01305011។

[1875] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២០៩ KH 01153622។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៤៦, ១៦២ KH 01305011, 13 ["ការប្រចាំថ្ងៃគេប្រើឲ្យខ្ញុំជម្រះស្មៅ យើងគឺស្គមខ្លាំងណាស់។ ក ជើងខ្ញុំ […] ប៉ុនកដៃ។ […] ដូចថាគ្នាមានដៃជើងតូចៗពេកជម្រះស្មៅមិនដាច់។"]។

[1876] ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៥១ KH 01305012 ["បើសែងទ៉ីកទៅកំពប់ គេវ៉ៃថែមទៀត។"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៦៣ KH 01305013 ["ខ្ញុំមិនដែលត្រូវរំពាត់នឹងគេទេ។"]។

[1877] ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៦២ KH 01305013។ ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.១៣ KH 01080837។

[1878] ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.៤, ៦-៧ KH 01080835-36។ *សូមមើលផងដែរ* ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.១៦ KH 01080837។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៦៨ KH 01305014។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១១ KH 01023831។ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១៦៧-១៦៨ KH 01040180។

[1879] D219/158 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.៧ KH 01058793។ *សូមមើលផងដែរ* ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.៦ KH 01058793 ["យាយចាស់ជនជាតិវៀតណាមម្នាក់ ដែលពេលនោះត្រូវបានគេដាក់ខ្នោះជើងនៅជិតខ្ញុំដែរ ហើយត្រូវបានគេវ៉ៃគាត់ជាមួយនឹងខ្នងពូថៅ"]។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.២០៩ KH 01153623 ["តាសារ៉ី និង តាសារ៉ូ […] គេឲ្យ […] យករំពាត់ទៅវ៉ៃអ្នកទោសដូចគ្នា។"] ឆ.១៦៥ KH 01153617 [សារ៉ូ "បាននិយាយប្រាប់ថា គាត់ត្រូវ […] គេវ៉ៃ គេទាត់ គេធាក់ គេដំស្នើររាប់មិនអស់រាល់ថ្ងៃនៅលើអ្នកទោសជាប់ពន្ធនាការទាំងអស់ អ្នកខ្លះវ៉ៃតិច អ្នកខ្លះវ៉ៃច្រើន"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៤ KH 01023830 ["មានដំបងនៅសល់ក្នុងនោះផង។"]។

[1880] D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៦២ KH 01153616។

530. ដោយសារតែលក្ខខណ្ឌរស់នៅអមនុស្សធម៌នៅមន្ទីរសន្តិសុខខ្មែរក្រហមនេះ អ្នកទោសធ្លាក់ខ្លួនឈឺ និងមិនទទួលបានថ្នាំសង្កូវឡើយ[1881]។

ការធ្វើទារុណកម្ម

531. អតីតអ្នកយាមគុកខ្មែរក្រហមឈ្មោះ វ៉ែ រ្ជម បានប្រាប់អ្នកស៊ើបអង្កេត ក.ស.ច.ស ពីៈ

> ការសួរចម្លើយរបស់គេមានតែអ៊ុតកៅស៊ូភ្លៀង ចង ហើយសួរចម្លើយ។ ក្រៅពីអ៊ុតកៅ ស៊ូមិនឆ្លើយហើយ គេមានដង្កាប់ដកក្រចក។ "[...] ការសួរចម្លើយរបស់គេហ្នឹង [...]គេសួរថា មនុស្សហ្នឹងមកពីណា អតីតធ្វើអ្វី។ [...] បើប្រាប់មិនច្បាស់ គេធ្វើទារុណកម្ម"[1882]។

532. សាក្សីជនជាតិវៀតណាម ឈ្មោះ ភឿ ក ឡាម បាននិយាយថា នាងត្រូវបានគេគំរាមវ៉ៃនឹងរំពាត់ ក្នុងពេលសួរចម្លើយរបស់គាត់លើកដំបូង[1883]។ ទោះបី ភឿ ក ឡាម មិនត្រូវបានគេវាយដំនឹងរំពាត់ក៏ដោយ ក៏គាត់និយាយថា សម្រាប់អ្នកទោសធ្ងន់នៅមន្ទីរសន្តិសុខនេះ ត្រូវបានគេវ៉ៃសួរចម្លើយយ៉ាងធ្ងន់ធ្ងរ[1884]។ ភឿ ក ឡាម "ឮអ្នកទោសប្រុសស្រែករកម៉ែរកឪ ឲ្យជួយ នៅពេលដែលគេធ្វើទណ្ឌកម្ម ពួកគាត់"[1885]។

[1881] D219/235 កំណត់ហេតុស្តាប់ចម្លើយ ភឿ ក ឡាម ឆ.១៨-១៩ KH 01080837-38 [ឆ.១៨ៈ [...] អ្នកទោសទាំងនោះមិនមានម្ហូបអាហារគ្រប់គ្រាន់ ឈឺ ហើយក្នុងមន្ទីរឃុំឃាំងនោះក្តៅខ្លាំង។ [...] ឆៈ នៅពេលដែល លោកស្រី និងអ្នកទោសឈឺ តើគេមានថ្នាំសម្រាប់ព្យាបាលដែរទេ? ឆ.១៩ៈ គ្មានទេ។"]។

[1882] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រ្ជម ឆ.២៥ KH 01238682។

[1883] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភឿ ក ឡាម ឆ.២ KH 01058791។ *សូមមើលផងដែរ* ឯកសារ D219/156 កំណត់ហេតុស្តាប់ចម្លើយ គ៉ឹម ចាត ឆ.១១ KH 01058778។

[1884] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភឿ ក ឡាម ឆ.៦ KH 01058792 ["សម្រាប់អ្នកទោសធ្ងន់ គេវ៉ៃសួរចម្លើយនិងវ៉ៃរហូតទាល់ស្លាប់"]។ *សូមមើលផងដែរ* ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៦៥ KH 01153617 [សារ៉ូ "បាននិយាយប្រាប់ថា ពេលគាត់ជាប់គុក គេធ្វើទារុណកម្ម គេវ៉ៃ គេទាត់ គេធាក់ គេដំ ស្ទើររាប់មិនអស់រាល់ថ្ងៃ"]។

[1885] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភឿ ក ឡាម ឆ.៦ KH 01058792។

ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

533. ដើម្បីមានកន្លែងទំនេរសម្រាប់អ្នកមកដល់ថ្មី អ្នកទោសត្រូវបានគេសម្លាប់រៀងរាល់ថ្ងៃ ឬរៀងរាល់បីថ្ងៃម្តង[1886]។ ឈឿង ប៊ាន បាននិយាយថា អ្នកទោសមុនឈ្មោះ សារ៉ូ បានប្រាប់គាត់ថា អ្នកទោសពី២ ទៅ៥នាក់ ត្រូវបានគេសម្លាប់ជារៀងរាល់ថ្ងៃ[1887]។ ភ្លាមៗមុនការមកដល់នៃកងកម្លាំងវៀតណាម ការសម្លាប់រង្គាលអ្នកទោសបានកើតឡើងនៅភាគខាងកើតនៃមន្ទីរសន្តិសុខនេះ រួមទាំងនៅស្រះទឹកមួយហៅថា គូកណ្តាល និងនៅជិតមន្ទីរសន្តិសុខ ក្រោយកងទ័ពវៀតណាមបានមកដល់[1888]។

[1886] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៧១ KH 01153617 [សារ៉ូ "គ្រាន់តែគាត់ថា [អ្នកដែលជាប់គុក] [...] យកចេញមកសម្លាប់[រាល់ថ្ងៃ] ប៉ុន្តែបញ្ជូលមួយថ្ងៃមានមួយ មានពីរ ឬបីនាក់"]។ ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.៧ KH 01058793 ["ការវ៉ៃនិងសម្លាប់កើតមាន ២ ទៅ ៣ថ្ងៃម្តង"]។ *សូមមើលផងដែរ* ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.១៧៧ KH 01305014។ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៃន ឆ.១៣៨ KH 01040178។

[1887] ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១៧១ KH 01153617 [សារ៉ូ "គ្រាន់តែគាត់ថា [...] [អ្នកដែលជាប់គុក] យកចេញទៅសម្លាប់មួយថ្ងៃពីរ ឬបី ឬប្រាំនាក់"] ឆ.១៥៩ KH 01153615។ *សូមមើលផងដែរ* ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.៧ KH 01058793 ["២ ទៅ ៣ថ្ងៃម្តង [...] ម្តងៗគឺមានអ្នកទោសម្នាក់ស្លាប់"]។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ សឿន ម៉ត ឆ.៥២ KH 01155828 ["តា ចែម ជាមនុស្សឃោរឃៅ គាត់សម្លាប់មនុស្សជាច្រើន។ អ្នកទោសនៅខាងកើតស្ទឹងក៏ក្រុមគាត់ជាអ្នកសម្លាប់ដែរ"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ រ៉ី ផាន់ ឆ.១៥ KH 01040098-99 ["ខ្ញុំបានឮអំពី តាគុយ ដែលជាមេកងនៅភូមិស្វាយព្រៃ ឃុំកន្ទឹ១ [...] និយាយថា ពួកយោធានិរតីហើយនឹងគណ:ឃុំកន្ទឹ២ ឈ្មោះ ផាន ដែលមកពីនិរតីដែរ បានឆ្លងស្ទឹងពីត្រើយខាងលិចទៅត្រើយខាងកើត ទៅបញ្ជាឲ្យអ្នកធ្វើការនៅនឹងមន្ទីរឃុំឃាំងខ្នងគូ នាំអ្នកទោសក្នុងមន្ទីរនោះទាំងអស់ យកទៅសម្លាប់"]។ ឯកសារ D219/748 កំណត់ហេតុស្តាប់ចម្លើយ ស្រី សឿន ឆ.៨៥ KH 01235368 ["គូ គេដាក់សម្រាប់[...] សម្លាប់អ្នកទោសនៅហ្នឹង"]។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៣២ KH 01210566។

[1888] ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហម សោម ឆ.៧៨-៧៩ KH 00967991 ["ពេលឮថាវៀតណាមចូលមកដល់បាត់ដំបង គេបានយកអ្នកទោសទៅសម្លាប់ចោលទាំងអស់នៅគូកណ្តាល [...]។ មានបួនកន្លែងដែលគេយកមនុស្សទៅសម្លាប់ ពីរកន្លែងនៅគូកណ្តាល [...]។ គេមិនបានកប់សាកសពទាំងនោះទេ គឺគេគរចោលតែម្តងព្រោះវាមានចំនួនច្រើនពេក។ សាកសពទាំងបួនកន្លែងនោះមានប្រហែលជា២០០នាក់។ មានរណ្តៅធំមួយមានសាកសពប្រហែល ៨០នាក់"]។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៤៣ ឆ.១៩៥ KH 01305003, 016 ["ចុង១៩៧៨ វៀតណាមមកដល់ បញ្ជេញយកទៅវ៉ៃនៅខ្នងគូកណ្តាលតែម្តង។ [...] រាប់រយដែរ គ្រាន់តែរាប់ក្បាលលើឃើញ ៨២ហើយ មាននៅក្នុងប៊ីង ហើយនៅតាមក្បែរៗនោះទៀតគេវ៉ៃបោះៗ"] (*កំណត់សំគាល់* នៅក្នុងចម្លើយពីមុនមួយនៅគូកណ្តាល សាក្សី "បានឃើញខ្ទោចខាងលើខ្ញុំ ឃើញប្រហែលជា ៦០ នាក់" ហើយ "នៅជិតក្បែរហ្នឹងប្រហែល ១០-១៥ នាក់ ។ *សូមមើល* ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.២៩, ឆ.៦២ KH 01210565, 68។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៤-៥ KH 01023838-40 [ប្រហែលជា ៦០០ ម៉ែត្រ ពីរបងមន្ទីរសន្តិសុខ [ពេល] ពួកកងទ័ពវៀតណាមជិតចូលមកដល់ [...]

ទោះបីចំនួនពិតប្រាកដមិនអាចឲ្យគេកំណត់បានក៏ដោយ តែវាចំនងជាខ្លាំងថា អ្នកទោសនៅមន្ទីរសន្តិសុខខ្នងគូនេះ អាចដល់រាប់រយអ្នកត្រូវបានសម្លាប់។ សាក្សីម្នាក់ដែលធ្លាប់ធ្វើដំណើរទៅកាន់មន្ទីរសន្តិសុខនេះបាននិយាយថា "មុនពេលរបបខ្មែរក្រហមដួលរលំ [...] ខ្ញុំបានឃើញរណ្តៅកប់ខ្មោចមួយៗប៉ុណ្ណោះ" ប៉ុន្តែក្រោយមក "ខ្ញុំបានឃើញសាកសពរាប់រយនាក់ដែលគរលើគ្នា"[1889]។ សាក្សីដដែលបានកត់សម្គាល់ថា "មានក្លិនស្អុយ" នៅគូកណ្តាល ហើយសាក្សីម្នាក់ទៀតបានឮ "សំឡេងរុយ" ដែលផ្ទើលនៅទីតាំងសម្លាប់មនុស្សមួយផ្សេងទៀត[1890]។ លើកលែងតែមនុស្សមួយ

មានរណ្តៅកប់ខ្មោចសងខាងតាមផ្លូវនោះជាច្រើន។ រណ្តៅកប់ខ្មោចនោះ គឺជារណ្តៅរាក់ ហើយក្នុងរណ្តៅមួយ១មានសាកសព២ ទៅ ៣នាក់ ឬ ៤ ទៅ ៥នាក់។ យើងឃើញដៃជើងហើមផុសចេញមកក្រៅ។ ខ្ញុំបន្តដំណើរតាមផ្លូវទៅមុខទៀត [...] ខ្ញុំបានឃើញគំនរខ្មោច បើតាមខ្ញុំស្មានគឺក្រោម ១០០នាក់។ [...] ។ ខ្ញុំដើរនៅក្នុងកន្លែងម្តុំនោះ ហើយខ្ញុំបានឃើញគំនរដទៃទៀតជាច្រើន៖ [...] មានសាកសព ៤ ទៅ ១០ នាក់។ សាកសពទាំងនេះមិនមានកប់ទេ គឺទុកចោលនៅលើវាល"]។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៣៩ KH 01117291 ["ខ្ញុំក៏បានឃើញសាកសពគឺសាកសពអ្នកទោសពីខ្នងគូចំនួនប្រហែល ៧០នាក់គរលើគ្នានៅក្នុងបឹង។ [...] នៅឆ្ងាយពីរណ្តៅនោះប្រហែលជា ២០ ទៅ ៥០ ម៉ែត្រ, [...] មានសាកសពពី ១០ ទៅ ១៥នាក់។ សរុបមានសាកសពអ្នកទោសប្រហែល ១០០នាក់ នៅកន្លែងនោះ"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៣ ឆ.៥ KH 01023829-30 ["បន្ទាប់ពីទ័ពវៀតណាមជិតចូលមកដល់ [...] ខ្ញុំបានឃើញសាកសពរាប់រយនាក់ដែលគរលើគ្នាជាពំនូកដ៏ធំ នៅក្នុងកូនត្រពាំងមួយ"]។ ឯកសារ D219/538 កំណត់ហេតុស្តាប់ចម្លើយ សឿន ម៉ត ឆ.៩៧ ឆ.១០១ KH 01155835 ["បងប្អូនជីដូនមួយរបស់ខ្ញុំម្នាក់បាននិយាយថានៅពេលវៀតណាមវ៉ៃចូលមក ពួកខ្មែរក្រហមបានយកអ្នកទោស[...]ទៅវ៉ៃចោលក្នុងអណ្តូងមួយ។ បងប្អូនជីដូនមួយរបស់ខ្ញុំបានឃើញ [...] ៨០សាកសព"]។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.៣០-៣២ KH 01121670-71 ["ប្រហែលជា៥ថ្ងៃបន្ទាប់ការសម្លាប់នោះ ពួកវៀតណាមចូលមកដល់។ ពួកយោធានិរតីបានសម្លាប់អ្នកទោសទាំងនោះមុនពេលដែលគេរត់គេចពីវៀតណាម"។ "ខ្ញុំបានឃើញដោយផ្ទាល់ពេលដែលគេយកអ្នកទោសចេញពីកន្លែងខ្នងគូ យកទៅសម្លាប់នៅវាលស្រែជិតខ្នងគូនោះ។ [...] ពីរថ្ងៃក្រោយមកខ្ញុំបានទៅកន្លែងវាលស្រែនោះទៅមើលឃើញសាកសពអ្នកទោសទាំងនោះ[...]។ មានអ្នកទោសប្រហែលជាង៣០នាក់ពេលដែលខ្ញុំឃើញ"]។ *សូមមើលផងដែរ* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៥ KH 01040098 ["មួយរយៈពេលខ្លីមុនពេលដែលកងទ័ពវៀតណាមចូលមកដល់ ខ្មែរក្រហមបានយកអ្នកទោសប្រហែលជា៦០នាក់ ចេញពីខ្នងគូយកទៅសម្លាប់នៅក្នុងត្រពាំងមួយក្បែរនោះ"] (*កំណត់សំគាល់* សាក្សីក្រោយមកបាននិយាយថា ឧប្បត្តិហេតុនេះបានកើតឡើងមួយថ្ងៃមុនឮសំឡេងផ្ទុះគ្រាប់ និងថា ការផ្ទុះគ្រាប់នេះបានកើតឡើងក្រោយពីការដួលរលំភ្នំពេញ។ *សូមមើល* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.១៧ ឆ.១៩ KH 01040099)។

[1889] ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៥ KH 01023830។

[1890] ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.៥ KH 01023830។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ឆុងលី ឆ.៥ KH 01023839។

ចំនួនតូចប៉ុណ្ណោះដែលនៅរស់រានមានជីវិត ក្រៅពីនោះគ្មាននរណាម្នាក់នៅរស់ឡើយ[1891]។ អ្នកដែលស្លាប់រួមមាន អតីតកម្មាភិបាល និងកងទ័ពខ្មែរក្រហមដែលគេបានចាប់ខ្លួននៅក្រោយការមកដល់របស់កម្មាភិបាលនិរតី[1892]។ សាក្សីម្នាក់បានរំឭកពីការរើស "ភាគច្រើនជាសម្លៀកបំពាក់យោធា" នៅទីតាំងមួយដែលមានសាកសព "ក្រោម ១០០ នាក់ [...] នៅមិនទាន់រលួយទាំងស្រុងនៅឡើយទេ"[1893]។ សាក្សីបាននិយាយថា សាកសពទាំងនេះគ្មានមកពីណាក្រៅពីមន្ទីរសន្តិសុខខ្នងគូទេ[1894]។

[1891] ឯកសារ D118/149 កំណត់ហេតុស្តាប់ចម្លើយ ហាម សោម ឆ.៧៨-៧៩ KH 00967991 ["គេបានយកអ្នកទោសទៅសម្លាប់ចោលទាំងអស់នៅគូកណ្តាល [...] ខ្ញុំបានដឹងរឿងនេះដោយសារខ្ញុំ និងអ្នកផ្សេងទៀតត្រូវបានគេឱ្យទៅដុតខោអាវរបស់អ្នកស្លាប់ទាំងអស់នោះ"]។ ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.៤២ KH 01238685 ["គ្មានអ្នកណារស់ទេ។ ពេលខ្ញុំត្រឡប់ទៅស្រុកវិញ គេប្រាប់ថា គេចាប់សម្លាប់អស់ហើយ"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ វឿត ឆ.៤ KH 01023829-30 ["ខ្ញុំមិនឃើញមានអ្នកនៅរស់ ឬសាកសពនៅក្នុងបរិវេណមន្ទីរសន្តិសុខនោះទេ។ ខ្ញុំគិតថា អ្នកទោសទាំងអស់នោះ ត្រូវបានគេយកទៅសម្លាប់រួមគ្នា នៅខាងក្រោមមន្ទីរសន្តិសុខនោះ"]។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៥៩ KH 01210568។ ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ឆុងលី ឆ.៤ KH 01023839-39។ <u>អ្នកនៅរស់</u>៖ ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភឿក ឡាម ឆ.៣ KH 01058792 [សាក្សីគឺជាអ្នកទោសម្នាក់ដែលផ្តាក់គេបញ្ជូនទៅមន្ទីរពេទ្យពេលគាត់ត្រូវសម្រាលកូន។ បន្ទាប់ពីសម្រាលកូនរួច ពេលគាត់ដើបដឹងខ្លួនស្រាប់តែ "គឺថានៅក្នុងមន្ទីរពេទ្យទាំងមូល គឺមានតែខ្ញុំម្នាក់គត់ដែលនៅសល់"។ "ពេលនោះគឺជាពេលដែលរបបខ្មែរក្រហមដួលរលំ"]។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វី ផាន់ ឆ.១៤ KH 01040098 ["មួយរយៈពេលខ្លីមុនពេលដែលកងទ័ពវៀតណាមចូលមកដល់ ខ្មែរក្រហមបានយកអ្នកទោសប្រហែល៦០នាក់ ចេញពីខ្នងគូយកទៅសម្លាប់[...] មានបុរសម្នាក់នៅរស់ [...]"]។ ឯកសារ D118/154 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធឿន ឆ.៣៩ KH 00968049 ["ធឿន ត្រូវបានគេវ៉ៃសម្លាប់ ហើយកប់ចោល ប៉ុន្តែពេលនោះគាត់មិនទាន់ស្លាប់នោះទេ គាត់ក៏ក្រោកឡើងមកវិញ"]។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ឆុងលី ឆ.៤៣ KH 01117292 ["តាមខ្ញុំដឹង មានតែតាវៀន ម្នាក់ទេ ដែលបានរួចជីវិត [...] តែខ្ញុំក៏មិនដឹងថា គាត់បានរួចជីវិតដោយរបៀបណានោះទេ"]។

[1892] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ វ៉ែ រួម ឆ.១៩ KH 01238680 ["ពេលពួកនិរតីមកដល់ អតីតកម្មាភិបាល ឬទាហានខ្មែរក្រហមទាំងអស់បញ្ជូនឱ្យទៅធ្វើស្រែ ហើយក្រោយមកគេយកទៅសម្លាប់ចោលទាំងអស់"]។ ឯកសារ D219/698 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌឿន ឆ.៧២ KH 01210569 ["ស៖ [...] តើនេះមានន័យថាពួកនិរតីសម្លាប់[...]ទាំងអស់ [...] ឆ្មាំគុករបស់ពួកគេផងមែនទេ? ឆ.៧២៖ បាទ"]។

[1893] ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ឆុងលី ឆ.៥ KH 01023839។ ឯកសារ D219/410 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ឆុងលី ឆ.៤៣ KH 01117292។

[1894] ឯកសារ D118/296 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឹម ឆុងលី ឆ.១១ KH 01023840 ["ស៖ លោកបានប្រាប់យើងថា លោកបានឃើញរណ្តៅខ្មោចនៅជិតបរិវេណខ្នងគូ តាមដែលលោកយល់ ឬដឹង តើសាកសពទាំងអស់នោះ គេយកចេញពីមន្ទីរសន្តិសុខណាផ្សេង ឬក៏យកចេញពីមន្ទីរសន្តិសុខខ្នងគូ ទៅសម្លាប់នៅទីកន្លែងដែលលោកឃើញនោះ? ឆ.១១៖ ខ្ញុំជឿថា សាកសពទាំងនោះ

534. អ្នកទោសក៏បានស្លាប់ដោយសារការធ្វើបាបដោយអមនុស្សធម៌ផងដែរ។ អ្នកទោសខ្លះ "គឺស្លាប់នៅជាប់នឹងខ្នោះជើង" ដោយសារគ្មានម្ហូបអាហារ និងការថែទាំផ្នែកវេជ្ជសាស្ត្រគ្រប់គ្រាន់[1895]។ សម្រាប់អ្នកទោសធ្ងន់ "ត្រូវគេវៃសួរចម្លើយ [...] រ៉ែរហូតទាល់ស្លាប់"[1896]។ អ្នកដែលមិនអាចធ្វើការបាន ឬមិនអាចអនុវត្តតាមការណែនាំ ក៏ត្រូវសម្លាប់ចោលដែរ[1897]។

535. សាក្សីនានាបាននិយាយថា នាក់ដែលពួកគេបានដឹងថា ត្រូវបានគេបញ្ជូនទៅមន្ទីរសន្តិសុខខ្នងគ្ន មិនដែលឃើញវិលត្រឡប់មកវិញឡើយ ហើយពួកគេបានសន្មតថា ពួកគេក៏ត្រូវបានសម្លាប់ដោយសារភាពរីករាលដាលនៃការសម្លាប់ដែលបានកើតមានជាទូទៅនៅទីនោះ[1898]។ ក្នុងចំណោមអ្នកដែល

គឺសុទ្ធយកចេញពីមន្ទីរសន្តិសុខខ្នងគ្ន ប៉ុណ្ណោះ។ [...] តាមដែលខ្ញុំដឹង ពុំមានមន្ទីរសន្តិសុខណាផ្សេងទៀតទេ ដែលនៅជិតៗនេះ"]។ ឯកសារ D118/295 កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រ៉ៃត ឆ.១២ KH 01023831 ["ស៖ លោកបានប្រាប់យើងថា លោកបានឃើញរណ្តៅកប់ខ្មោចនៅជិតកន្លែងមន្ទីរសន្តិសុខខ្នងគ្ន។ បើតាមលោកដឹង តើគេយកសាកសពទៅកប់នោះ យកចេញពីមន្ទីរសន្តិសុខណាផ្សេងទៀត ឬក៏យកចេញពីមន្ទីរសន្តិសុខខ្នងគ្ន? ឆ.១២៖ ខ្ញុំជឿថា ខ្មោចដែលគេយកទៅកប់នោះ គឺចេញពីមន្ទីរសន្តិសុខខ្នងគ្ន"]។

[1895] ឯកសារ D219/235 កំណត់ហេតុស្តាប់ចម្លើយ ភ្ជឹក ឡាម ឆ.១៨-១៩ KH 01080837-38 ["ឆ.១៨៖ មានអ្នកទោសខ្លះ គឺស្លាប់នៅជាប់នឹងខ្នោះជើងក្នុងមន្ទីរឃុំឃាំង ដោយសារអ្នកទោសទាំងនោះ មិនមានម្ហូបអាហារគ្រប់គ្រាន់ ឈឺ។ [...] ស៖ នៅពេល[...] អ្នកទោសឈឺ តើគេមានថ្នាំសម្រាប់ព្យាបាលដែរទេ? ឆ.១៩៖ គ្មានទេ"]។

[1896] ឯកសារ D219/158 កំណត់ហេតុស្តាប់ចម្លើយ ភ្ជឹក ឡាម ឆ.៦ KH 01058792-93។

[1897] ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យៀន ឆ.១៦៨ KH 01305014 ["ស៖ តើលោកដឹងទេថា មូលហេតុអ្វីបានជាគេយកសម្លាប់ចោល? ឆ.១៦៨៖ ដោយសារពួកគេស្គមៗពេក ធ្វើការមិនកើត"]។ ឯកសារ D219/533 កំណត់ហេតុស្តាប់ចម្លើយ ឈ្យៀង ប៊ាន ឆ.១៦២-១៦៣ KH 01153616 [សារ៉ូ និយាយថា "ប្រធានគុកឲ្យគាត់ [...] អប់រំអ្នកជាប់គុក [...] ថាយើងខំប្តូរ អត់ធន់ ដើម្បីផលប្រយោជន៍បដិវត្តន៍ កុំឲ្យក្បត់បដិវត្តន៍ [...] ចែមូសាលីន បានទះគូទ ហើយថានិយាយថា "តាពោកអ្នកស្ពាប់" ពេលនោះគេក៏យកចែមូសាលីន ទៅសម្លាប់ចោល"]។

[1898] ឯកសារ D219/751 កំណត់ហេតុស្តាប់ចម្លើយ រ៉ែ រ្ជម ឆ.១៨, ឆ.២០ KH 01238679, 82 ["គេចាប់យកឪពុកខ្ញុំទៅសម្លាប់ដែរ។ [...] ខ្ញុំពុះបាត់ឪពុកខ្ញុំ"]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ្ងន ឈ្ងយ ឆ.១០ KH 01149399 ["វាគឺជាការសន្និដ្ឋានរបស់ខ្ញុំថា អ្នកទាំងនោះ[កម្មាភិបាលភូមិភាគពាយ័ព្យ] ត្រូវបានគេសម្លាប់ ព្រោះគេបានបញ្ជូនទៅគុកធំហើយ ក៏បាត់ខ្លួនរហូត"]។ ឯកសារ D219/946 កំណត់ហេតុស្តាប់ចម្លើយ ឡៅ កង ឆ.៣៥ KH 01415415 ["ឮគេថាចាប់ទៅកន្លែងហ្នឹង គឺសម្លាប់ហើយ អត់មានមកវិញទេ"]។ ឯកសារ D219/90 កំណត់ហេតុស្តាប់ចម្លើយ កុច រ៉ៀន ឆ.១៣៥ KH 01040177 ["ខ្ញុំមិនដែលឃើញប្រជាជនដែលគេចាប់នោះ ត្រឡប់មកវិញទេ"]។ ឯកសារ D219/797 កំណត់ហេតុស្តាប់ចម្លើយ ដុស ឌ្យៀន ឆ.១៥៦ KH 01305013 ["មាន[មនុស្ស]ចេញទៅបាត់ខ្លះដែរ"]។

បាត់ខ្លួនក្រោយពីបានបញ្ជូនទៅមន្ទីរសន្តិសុខខ្មែងគ្ន មានលេខា និងអនុលេខាឃុំបាយដំរ៉ាផងដែរ[1899] ។

ការធ្វើទុក្ខបុកម្នេញ

536. កម្មាភិបាលភូមិភាគនិរតីបានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនដូចបានរៀបរាប់ខាងលើ ក្នុងចេតនាដើម្បីកំណត់គោលដៅជាក់លាក់ មានដូចជា កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ និងសមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និង "ប្រជាជនថ្មី"[1900] នៅមន្ទីរសន្តិសុខខ្មែងគ្ន។ ក្រុមទាំងនេះត្រូវបានកំណត់គោលដៅចំៗ ដោយសារតែសមាជិកភាពពិតប្រាកដ ឬតាមការសន្ធតរបស់ពួកគេចំពោះក្រុមនយោបាយណាមួយ។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

537. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ឹម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខខ្មែងគ្ន[1901]ៃ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[1902]

[1899] ឯកសារ D219/464 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៧៨ KH 01132059 ["តារិន និង តារ៉ម ត្រូវបានគេចាប់ដាក់គុកខ្មែងគ្ន ហើយក៏បាត់ខ្លួនរហូត"]។ ឯកសារ D118/138 កំណត់ហេតុស្តាប់ចម្លើយ ទៀប ទិត្យ ឆ.៥ KH 00960688-89 ["មេឃុំបាយដំរ៉ា ឈ្មោះ រ៉ម និង រិន ជាអនុប្រធានឃុំ [...]។ រិន និង រ៉ម [...] ស្លាប់អស់ហើយ"]។

[1900] *សូមមើល ខ១ាហារណ៍* ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៦៥ KH 00960671 ["ក្ជួយប្រុសរបស់តាប៉ែត ឈ្មោះ រ៉ារិន និង រ៉ាត់ ក៏គេចាប់ដាក់គុកនៅខ្មែងគ្នដែរ។ រ៉ារិន គេសម្លាប់នៅខ្មែងគ្ន"]។

[1901] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ឹម ទិត្យ នៅឡើយ។ ទាំងនេះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងសមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និង "ប្រជាជនថ្មី" ហើយនឹងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មនេះ តាមរយៈ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៩ (រួមទាំងកំណត់សំគាល់ជើងទំព័រ ២២៣) ១១៨ខ។ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ៩, ២២iii។ ឯកសារ D196/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ D196 ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៤ កថាខណ្ឌ ២ឃ។

[1902] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃអំពើមហាប្រល័យនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងទាក់ទងនឹងមន្ទីរសន្តិសុខខ្មែងគ្នតែមួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃអំពើមហាប្រល័យដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋាន

ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្ម និងក្រុមគ្រួសារ និងអ្នកក្រោមបង្គាប់របស់ពួកគេ និងសមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និង "ប្រជាជនថ្មី" និង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។

៣. តំបន់ ៣

ក. មន្ទីរសន្តិសុខវត្តគិរីរម្យ

i. សេចក្ដីផ្ដើម

538. មន្ទីរសន្តិសុខវត្តគិរីរម្យ ("វត្តគិរីរម្យ") ស្ថិតនៅក្នុងស្រុកភ្នំសំពៅនៃតំបន់៣ នៅក្នុងអំឡុងពេលរបបខ្មែរក្រហម។ មន្ទីរសន្តិសុខនេះ មានគុកចន្លោះក្តោង វត្តគិរីរម្យ និងណ្ឌានានានៅព័ទ្ធជុំវិញនោះ។ ខណៈដែលវត្ត និងណ្ឌានានាត្រូវបានប្រើប្រាស់ជាកន្លែងឃុំឃាំង និងជាទីកន្លែងសម្លាប់មនុស្សចាប់តាំងពីឆ្នាំ១៩៧៥ មកនោះ គុកចន្លោះក្តោងត្រូវបានសាងសង់ឡើងភ្លាមៗ ក្រោយពីការមកដល់នៃពួកកម្មាភិបាលភូមិភាគនិរតីនៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨។ នៅពេលមួយនោះ គុកចន្លោះក្តោងបានដាក់អ្នកទោសរហូតដល់ទៅ ២០០នាក់ ដែលត្រូវបានបង្ខំឲ្យធ្វើពលកម្ម មុនពេលត្រូវបានបញ្ជូនទៅកាន់វត្ត ឬណ្ឌានានានៅក្បែរនោះដើម្បីសម្លាប់ចោល។

539. **យ៉ីម ទិត្យ** តាមរយៈតួនាទីដឹកនាំរបស់គាត់នៅតំបន់៣ និងថ្នាក់ភូមិភាគ ត្រូវទទួលខុសត្រូវចំពោះវត្តគិរីរម្យ។ **យ៉ីម ទិត្យ** បានរស់នៅក្នុងផ្ទះមួយនៅក្បែរវត្តគិរីរម្យ ហើយជាញឹកញាប់ត្រូវបានគេឃើញនៅក្នុងតំបន់នោះ។

540. ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** អំពីឧក្រិដ្ឋកម្មនានាទាក់ទងនឹងមន្ទីរសន្តិសុខវត្តគិរីរម្យ ដូចតទៅ៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើពួកកម្មាភិបាល

ពលកម្មដោយបង្ខំទាំងអស់ រួមទាំងមន្ទីរសន្តិសុខខ្នងគ្ងដង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់បង្កើតបានជាផ្នែកនៃប្រព័ន្ធមួយដែលមានការរៀបចំ ក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្លាំង ហើយការសម្លាប់នៅលើទីតាំងនិមួយៗទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ីម ទិត្យ។

ពាយ័ព្យ និងក្រុមគ្រួសារ និងអ្នកនៅក្រោមបង្គាប់របស់ពួកគេ ហើយនិងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការឃុំខ្លួន/ការធ្វើការនៅក្នុងលក្ខខណ្ឌអមនុស្សធម៌)[1903]។

ii. ប្រតិបត្តិការ និងទីតាំង

541. វត្តគិរីរម្យ មានទីតាំងស្ថិតនៅក្នុងឃុំភ្នំសំពៅ ស្រុកភ្នំសំពៅ ខេត្តបាត់ដំបង តំបន់៣ នៃភូមិភាគពាយ័ព្យ[1904]។ វត្តគិរីរម្យមានទីតាំងសំខាន់ៗចំនួនបី៖ គុកចន្លោះក្តោង វត្តគិរីរម្យ និងល្អាងនានានៅក្បែរនោះ[1905]។ ភាគច្រើននៃអ្នកដែលបានជាប់ឃុំនៅមន្ទីរសន្តិសុខនោះ គឺមកពីស្រុកភ្នំសំពៅ[1906]។

[1903] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426553

[1904] ឯកសារ D118/85 កំណត់ហេតុស្តាប់ចម្លើយ ជា ជឿន ឆ.២៤ KH 00945406។ ឯកសារ D118/96 កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ឆ.២៣ EN 00947291។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212421។ *សូមមើលផងដែរ* ឯកសារ D219/535 កំណត់ហេតុស្តាប់ចម្លើយ ភីង ឌី ឆ.៣៨ KH 01153646។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឹន KH 00304360។ ឯកសារ D219/421 កំណត់ហេតុស្តាប់ចម្លើយ ទៀ ងួន ឆ.៧ KH 01118805។ ស្រុកភ្នំសំពៅ បច្ចុប្បន្ននេះត្រូវបានគេស្គាល់ថាជា ស្រុកបាណន់។ *សូមមើល* ឯកសារ D6.1.150 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃទីតាំងវត្តគិរីរម្យ KH 00365714-15។

[1905] ឯកសារ D6.1.150 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃទីតាំងវត្តគិរីរម្យ KH 00365715។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី "ការធ្វើផែនទីតំបន់វាលពិឃាតនៅកម្ពុជា ឆ្នាំ១៩៩៧៖ ខេត្តបាត់ដំបង" KH 00184648។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212421 ["សុខ បាននិយាយប្រាប់ខ្ញុំថា វត្តគីរីរម្យជាកន្លែងគុក និងកន្លែងសម្រាប់អ្នកទោស។ មានមន្ទីរនគរបាលមួយ គឺជាកន្លែងដាក់អ្នកទោស ដើម្បីលត់ដំ"] KH 00212422 ["បាទ ខ្ញុំបានឡើងទៅ វត្តគីរីរម្យប្រហែលមួយអាទិត្យក្រោយយួនចូលមកដល់។ [...] ខ្ញុំបានសាកសពមនុស្សរប៉ាត់រប៉ាយពាសពេញនៅតាមល្អាង និងមាត់ល្អាង ល្អាងល្ហេន និងល្អាងតែងខ្លួន"]។ ឯកសារ D6.1.164 កំណត់ហេតុស្តាប់ចម្លើយ គង់ គឹមលី KH 00274152 ["[ប្តីរបស់ គង់ គឹមលី] គាត់បានឃើញ ហើយបានប្រាប់ខ្ញុំថា នៅចន្លោះភ្នំក្តោង និងភ្នំសំពៅ មានកន្លែងដាក់អ្នកទោស"]។ ដោយសារទីកន្លែងភូមិសាស្ត្រនៃវត្ត និងគុកចន្លោះក្តោង សាក្សីនានាយោងទៅរកទីតាំងនោះថាមាន "កន្លែងខាងលើ" (វត្ត និង ល្អាង) និង "កន្លែងខាងក្រោម" (គុកចន្លោះក្តោង)។ *សូមមើល* ឯកសារ D118/64 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឹន ឆ.១៤ KH 00920177 ["មានពីរកន្លែង ខ្ញុំបានឃើញតែកន្លែងដែលគេដាក់អ្នកទោសនៅខាងក្រោម ហើយអានៅខាងលើខ្ញុំមិនដឹងទេ"]។ ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៦០ KH 01200322 ["គេមានការដ្ឋានមួយនៅជើងភ្នំចន្លោះក្តោង។ ម៉ោង១២យប់ទើបគេនាំមក កន្លែងនោះប្រហែលជាកន្លែងសួរចម្លើយក៏មិនដឹង ឬសួរចម្លើយ ហើយបានគេនាំទៅក៏មិនដឹង។ [...] គេមានពីរកន្លែង ក្រោមមួយ[ភ្នំចន្លោះក្តោង] លើមួយ"]។

[1906] ឯកសារ D219/535 កំណត់ហេតុស្តាប់ចម្លើយ ភីង ឌី ឆ.៣៦-៣៧ KH 01153646 ["ស៖ តើអ្នកដែកគេឃុំនោះ ពួកគេមកពីណាដែរ? ឆ.៣៦៖ ជាអ្នកនៅក្នុងភូមិសំពៅ និងភូមីគោកអំពិល។ ស៖ តើមានអ្នកណាមកពីខាងក្រៅភូមិពីរនេះទេ? ឆ.៣៧៖ មាន មកពីស្រុកបាណន់ [...]"]។

វត្តគិរីរម្យ និងណ្ណាងនានានៅក្បែរនោះ គឺស្ថិតនៅក្បែរកំពូលភ្នំសំពៅ[1907] ខណៈដែលគុកចន្លោះក្តោង គឺស្ថិតនៅក្នុងជ្រលងខាងក្រោមវត្ត ចន្លោះភ្នំសំពៅ និងភ្នំក្តោង[1908]។ វត្តនេះ និងណ្ណាងនានា ត្រូវបានប្រើប្រាស់ជាកន្លែងឃុំឃាំង និងទីតាំងសម្លាប់មនុស្ស ចាប់តាំងពីដើមឆ្នាំ១៩៧៥[1909]។ គុកចន្លោះក្តោងត្រូវបានសាងសង់ឡើងដោយពួកកម្មាភិបាលភូមិភាគនិរតីនៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ

[1907] ឯកសារ D6.1.173 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សារឿន KH 00197931 ["ខ្ញុំបានឃើញមន្ទីរចន្លោះក្តោងដែលមានរបងលួសព័ទ្ធជុំវិញ នៅខាងលិចភ្នំសំពៅ ហើយនៅជិតនោះមានជណ្តើរស សម្រាប់ឡើងទៅវត្តគីរីរម្យ"]។ ឯកសារ D118/67 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស ឆ.ពក KH 00920202 ["ស៖ តើលោកដែលដឹងថា មានមន្ទីរសន្តិសុខ ឬក៏កន្លែងសម្លាប់មនុស្សនៅក្នុងទីតាំងនេះ ដែរឬទេ? ឆ.ពក៧៖ មានមន្ទីរសន្តិសុខនៅចន្លោះក្តោងសម្រាប់ដាក់អ្នកទោសស្រាល ហើយអ្នកទោសធ្ងន់គេបញ្ជូនមកដាក់នៅវត្តគីរីរម្យ"]។ ឯកសារ D219/700 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ អ៊ុំ ឈួន និង នាង ឈឿ KH 01303257។

[1908] ឯកសារ D6.1.150 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងវត្តគិរីរម្យ KH 00365716។ ឯកសារ D219/415 កំណត់ហេតុស្តាប់ចម្លើយ ឌី ពៀច ឆ.ព KH 01117344 ["ទីកន្លែងនោះ គេហៅថា ចន្លោះក្តោង ឬប្រណោះក្តោង ដែលស្ថិតនៅចន្លោះភ្នំក្តោង និងភ្នំសំពៅ"]។ ឯកសារ D6.1.166 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន ជឿន KH 00274164 ["គេឃុំឃាំងមនុស្សនៅចន្លោះក្តោង នៅជិតភូមិសំណាញ់ ចម្ងាយ២០០ម៉ែត្រពីកន្លែងជណ្តើរឡើងភ្នំសំពៅ សម្រាប់ឡើងទៅវត្តគីរីរម្យ"]។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី "ការធ្វើផែនទីតំបន់វាលពិឃាតនៅកម្ពុជា ឆ្នាំ១៩៩៧៖ ខេត្តបាត់ដំបង" KH 00184647។ *សូមមើលផងដែរ* ឯកសារ D6.1.169 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស KH 00197903។ ឯកសារ D347/2.1.25 ព្រុំ សារុន ប្រតិចារឹក ថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 09.22.05។ ឯកសារ D219/700 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ អ៊ុំ ឈួន KH 01303257។

[1909] ឯកសារ D6.1.115 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្លក KH 00221547 ["ខ្ញុំបានដឹងនិងស្គាល់កន្លែងឃុំមនុស្សនៅវត្តគិរីរម្យលើភ្នំសំពៅ ដែលគេដាក់អ្នកទោសក្នុងវិហារវត្តតាំងពីឆ្នាំ១៩៧៥"]។ ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន លឿត KH 00242231 ["នៅក្នុងខែ៧ ឆ្នាំ១៩៧៥ ខ្ញុំបានឃើញសាកសពមនុស្សប្រហែលជា ២០នាក់ ស្ថិតនៅអតីតក្លិនបាញ់ស៊ីបរបស់ទាហាន លន់ នល់ ដែលស្ថិតនៅចន្លោះក្តោងក្នុងភូមិភ្នំសំពៅ"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/36 កំណត់ហេតុស្តាប់ចម្លើយ ឈួម សារ៉ុន ឆ.ព៥ KH 01032097។

១៩៧៨[1910]។ វត្តគិរីរម្យបានដំណើរការរហូតដល់កងទ័ពវៀតណាមបានចូលមកដល់នៅក្នុងខែមករា ឆ្នាំ១៩៧៩[1911]។

[1910] ឯកសារ D6.1.172 កំណត់ហេតុស្តាប់ចម្លើយ ផេ ស្រ៊ី KH 00197908 ["រោងនេះ [ចន្លោះក្តោង] ត្រូវបានសាងសង់ឡើងនៅពេលដែលពួកនិរតីមកដល់ ក្នុងរវាងចុងឆ្នាំ១៩៧៧ ដើមឆ្នាំ១៩៧៨។ [...] គុកវត្តគីរីរម្យ [...] កើតឡើងដំណាលគ្នានឹងពេលដែលខ្ញុំបានឃើញរោងនគរបាលត្រូវបានបង្កើតឡើង"]។ ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន សា KH 00242226 ["នៅក្នុងឆ្នាំ១៩៧៧ នៅភូមិសំណាញ់ ឃុំភ្នំសំពៅ មានកន្លែងមួយឈ្មោះ 'កន្លែងនគរបាល' [...] ជាកន្លែងដាក់អ្នកទោស"]។ ឯកសារ D6.1.170 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ភិរុណ KH 00197912 ["នៅចុងឆ្នាំ១៩៧៧ ដើមឆ្នាំ១៩៧៨ [...] ខ្ញុំបានឃើញគុកឃ្លាំង (គុកដែលមានរូបរាងដូចឃ្លាំង) កំពុងត្រូវសាងសង់ឡើង នៅទិសខាងត្បូងឈរខាងលិចវិហារគីរីរម្យ ត្រង់ចន្លោះភ្នំក្តោង និងភ្នំសំពៅ"]។ ឯកសារ D219/415 កំណត់ហេតុស្តាប់ចម្លើយ ឌី ពៀច ឆ.៤ KH 01117346 ["ខ្ញុំបានទៅដល់ទីតាំងភ្នំសំពៅក្នុងឆ្នាំ១៩៧៦ ហើយខ្ញុំពុំបានឮឈ្មោះចន្លោះក្តោងទេ [...] នៅដើមឆ្នាំ១៩៧៧ ទើបខ្ញុំចាប់ផ្តើមឮឈ្មោះទីតាំងនេះ។ តាមខ្ញុំចាំគេចាប់ផ្តើមបោសសម្អាតខ្ទាំងស៊ីរ៉ូងផ្ទៃក្នុងចាប់ពីឆ្នាំ១៩៧៧"]។ ឯកសារ D6.1.166 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន ជឿន KH 00197887។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារ៉ៃប ឆ.៧០-៧១ KH 01200324-25។ ឯកសារ D6.1.118 កំណត់ហេតុស្តាប់ចម្លើយ ឌុច ភ្ជី KH 00221591។

[1911] ឯកសារ D6.1.115 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្លក KH 00221547 ["ខ្ញុំបានដឹងនិងស្គាល់កន្លែងឃុំមនុស្សនៅវត្តគិរីរម្យលើភ្នំសំពៅ ដែលគេដាក់អ្នកទោសក្នុងវិហារវត្ត តាំងពីឆ្នាំ១៩៧៥ ហើយកន្លែងនេះមានសកម្មភាពរហូតដល់ឆ្នាំ១៩៧៩ មុនវៀតណាមចូល"]។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212421-22។ ឯកសារ D219/36 កំណត់ហេតុស្តាប់ចម្លើយ ឈួម សារ៉ឿន ឆ.៣៥ KH 01032097។ ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* KH 00233385-86។ *សូមមើលផងដែរ* ឯកសារ D219/700 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ អ៊ុំ ឈួន KH 01303257។

542. វត្តនេះ និងល្អាងនានានៅក្បែរនោះ គេអាចចូលទៅដល់បានតាមជណ្តើរដែលលាបពណ៌ស[1912]។ ល្អាងចំនួនបី៖ ល្អាងតែងខ្ជួន ល្អាងណ្ងាន និងល្អាងកង្កែប មានទីតាំងស្ថិតនៅខាងលើកំពូលភ្នំ សំពៅ[1913] ក្បែរវត្តនេះ[1914]។

[1912] ឯកសារ D6.1.173 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សារ៉ៀន KH 00197931 ["ខ្ញុំបានឃើញមន្ទីរចន្លោះក្តោងដែលមានរបងល្អសព័ទ្ធជុំវិញ នៅខាងលិចភ្នំសំពៅ ហើយនៅជិតនោះមានជណ្តើរស សម្រាប់ឡើងទៅវត្តគិរីរម្យ"]។ ឯកសារ D6.1.168 កំណត់ហេតុស្តាប់ចម្លើយ ព្រ៊ុ សារុន KH 00197917 ["(គេហៅជណ្តើរស ដោយសារសម័យនោះ គេបានលាបកំបោរស) ពួកខ្មែរក្រហមបានធ្វើជណ្តើរសក្នុងឆ្នាំ១៩៧៦ ដើម្បីឡើងទៅគុកវត្តគិរីរម្យ"]។ ឯកសារ D6.1.150 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងវត្តគិរីរម្យ KH 00365716, 00365724-27។

[1913] ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពី "ការធ្វើផែនទីតំបន់វាលពិឃាតនៅកម្ពុជា ឆ្នាំ១៩៩៧៖ ខេត្តបាត់ដំបង" KH 00184647។ ឯកសារ D219/36 កំណត់ហេតុស្តាប់ចម្លើយ ឈួម សារ៉ើន ឆ.ពេ KH 01032096 ។

[1914] ឯកសារ D6.1.150 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងវត្តគិរីរម្យ KH 00365716 ["រូងភ្នំនោះមាន [ល្អាង៖ ល្អាងតែងខ្ជួន ល្អាងណ្ងាន ល្អាងកង្កែប] ចម្ងាយ ៧០ម ពីវត្តនោះ ហើយនៅជិតកំពូល "ជណ្តើរស""]។

543. គុកចន្លោះក្តោង មានអគារមួយចំនួនដែលបានប្រើប្រាស់សម្រាប់ឃុំខ្លួនពួកអ្នកទោស និងជាផ្ទះរបស់កម្មាភិបាល និងពួកយោធា[1915] នៅខាងក្រោមកែ្បរជណ្តើរពណ៌សដែលនាំឆ្ពោះទៅកាន់វត្ត និងណ្ឌងនានាទាំងនោះ[1916]។ គុកចន្លោះក្តោង ត្រូវបានព័ទ្ធជុំវិញទៅដោយរបងលួសបន្លា[1917]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

544. កម្មាភិបាលភូមិភាគនិរតីបានជំនួសកម្មាភិបាលភូមិភាគពាយ័ព្យនៅក្នុងការទទួលខុសត្រូវវត្តគិរីរម្យ នៅចុងឆ្នាំ១៩៧៧[1918]។ តារ៉ាក់ ជាប្រធានឃុំភ្នំសំពៅរហូតដល់ពេលកម្មាភិបាលភូមិភាគនិរតីមកដល់[1919]។ បន្ទាប់ពី តារ៉ាក់ ត្រូវបានដកចេញ គេឃើញ **យ៉ីម ទិត្យ** ជារៀងរាល់ថ្ងៃនៅការដ្ឋានភូមិ

[1915] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៧៤ KH 01200325-26 ["[គុកចន្លោះក្តោង] របងគេហ៊ាំព័ទ្ធបន្ទាលួស មានអគារច្រើនធ្វើពីឈើប្រក់សង្កសី មានអគារច្រើនដែលគេសង់ទទឹងផ្ទៃ សម្រាប់កម្មាភិបាល និងយោធាស្នាក់នៅ ព្រមទាំងដាក់អ្នកទោស។ ខ្ញុំមិនដឹងថា មានអគារប៉ុន្មានខ្នង ប៉ុន្តែបានបន្ទប់ទេ ប៉ុន្តែវាធំដែរទីធ្លាគេហ្ម៉ង នៅចន្លោះក្តោង។ អគារធំវែងមាន៥ខ្នង ហើយអគារតូចៗមានច្រើនធ្វើព័ទ្ធសងខាង ដែលអគារទាំងអស់នេះ សុទ្ធតែស្ថិតនៅក្នុងបរិវេណរបងបន្ទាលួស"]។

[1916] ឯកសារ D6.1.150 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងវត្តគិរីរម្យ KH 00365726-27។ ឯកសារ D347/2.1.25 ព្រ ំ សារុន ប្រតិចារ៉ឹក ថ្ងៃទី ៩ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 09.22.05-09.23.47 ["នៅតែជណ្តើរសហ្ម៉ង វិហារហ្ម៉ងឯង គេឃុំខ្លួនមនុស្សនោះ មានខ្ទោះមានអ៊ីនៅហ្ម៉ងឯង ហើយទម្លាក់នៅណ្ឌងគីរីរម្យហ្ម៉ងឯង។ សម្លាប់ហើយទម្លាក់នៅណ្ឌងគីរីរម្យ ហ្ម៉ង ជិតគ្នាហ្ម៉ង"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៦០ KH 00951933 ["មានមន្ទីរសន្តិសុខនៅភ្នំសំពៅមួយ ព្រោះគេឃុំខ្ញុំមួយយប់នៅភ្នំសំពៅ មុនគេបញ្ជូនខ្ញុំយកទៅឃុំនៅក្រុងបាត់ដំបង តែខ្ញុំមិនដឹងថា មន្ទីរសន្តិសុខនោះឈ្មោះអ្វីទេ តែមានទីតាំងនៅកន្លែងមន្ទីរឃុំចាស់ នៅខាងជើងចំងាយ ៥០០ទៅ៦០០ម. ពីវត្តគិរីរម្យ។ មន្ទីរឃុំនោះគឺមានទំហំ ៤x១០ម. ក្នុងរោងនោះគេមានខ្ទោះឈើសម្រាប់ដាក់ខ្ទោះជើងអ្នកទោសពី២ទៅ៤នាក់ ហើយក្នុងរោងនោះគេអាចដាក់អ្នកទោសបាន ៤០ នាក់"]។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឺន KH 00304360-61។ ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* KH 00233385-86។

[1917] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៧៤ KH 01200325-26 ["[គុកចន្លោះក្តោង] របងគេហ៊ាំ ព័ទ្ធបន្ទាលួស"]។ ឯកសារ D6.1.173 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សារ៉ៀន KH 00197931។ ឯកសារ D6.1.128 កំណត់ហេតុ ស្តាប់ចម្លើយ ប៉ែន លៀត KH 00242230-31។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឺន KH 00304360-61។ *សូមមើលផងដែរ* ឯកសារ D219/700 កំណត់ហេតុនៃកិច្ចស្ទើបសួរ ការរៀបរាប់របស់ អ៊ុំ ឈួន KH 01303257។

[1918] ឯកសារ D118/245 កំណត់ហេតុស្តាប់ចម្លើយ ជួន ថន ឆ.៧ KH 00990644 ["ពួកនិរតីចូលមកដល់ភូមិភាគពាយ័ព្យ ប្រហែលចុងឆ្នាំ១៩៧៧ ឬដើម១៩៧៨"] ឆ.៩ KH 00990644 ["ក្រោយពីពួកនិរតីមកដល់ភូមិភាគពាយ័ព្យ គឺមានការផ្លាស់ប្តូរ គឺ ចាប់ពីថ្នាក់ក្រោមទៅដល់ថ្នាក់លើ"]។ ឯកសារ D6.1.127 កំណត់ហេតុស្តាប់ចម្លើយ ស៊ុន ណាត់ KH 00242236។

[1919] ឯកសារ D219/697 កំណត់ហេតុស្តាប់ចម្លើយ ណូក ឆៀត ឆ.៣០ KH 01213442 ["តារ៉ាក់ ប្រធានឃុំភ្នំសំពៅ"]។ ឯក សារ D118/66 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម អាន់ ឆ.៣ KH 00920192 ["កាលណោះ តារ៉ាក់ ជាមេឃុំជាអ្នកដកអាត្មាចេញពីតំណែង"]។ ឯកសារ D118/64 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឺន ឆ.២៣ KH 00920178។ ឯកសារ D118/76 កំណត់ហេតុ

គោកអំពិល នៅភ្នំសំពៅ និងបានរស់នៅក្នុងកន្លែងដែលពីមុនជាផ្ទះរបស់ តាវ៉ាក់[1920] ដែលស្ថិតនៅចម្ងាយពីមួយ ទៅពីរគីឡូម៉ែត្រ ពីវត្តគិរីរម្យ[1921]។ **យឹម ទិត្យ** ត្រូវបានកំណត់អត្តសញ្ញាណដោយសាក្សីជាច្រើននាក់ថាជាលេខាតំបន់៣[1922]។

ស្តាប់ចម្លើយ ជុច ពន្លក ឆ.១៣ KH 00934376។ ឯកសារ D219/415 កំណត់ហេតុស្តាប់ចម្លើយ ឌី ពៀច ឆ.១៣ KH 01117348 ។ ឯកសារ D6.1.118 កំណត់ហេតុស្តាប់ចម្លើយ ឌុច ភ្លី KH 00221592។ ឯកសារ D6.1.127 កំណត់ហេតុស្តាប់ចម្លើយ ស៊ុន ណាត់ KH 00242236។ ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន លឿត KH 00242230។ ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ៊ិន សា KH 00242225។ ឯកសារ D6.1.164 កំណត់ហេតុស្តាប់ចម្លើយ គង់ គឹមលី KH 00197895 ។ ឯកសារ D6.1.172 កំណត់ហេតុស្តាប់ចម្លើយ ផេ សឿ KH 00197908។ ឯកសារ D6.1.173 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សារឿន KH 00197930។

[1920] ឯកសារ D118/76 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្លក ឆ.៣៤ KH 00934378 ["ខ្ញុំមិនដែលបានជួបនិយាយផ្ទាល់មាត់ជាមួយតាទិត[យឹម ទិត្យ]ទេ តែគាត់មកនៅកន្លែងការដ្ឋានរបស់ខ្ញុំ [ផ្សារភូមិគោកអំពិល ឃុំភ្នំសំពៅ] នៅពេលដែលគេដកតាវ៉ាក់ចេញ ខ្ញុំជួបគាត់[យឹម ទិត្យ]នៅផ្ទះរបស់តាវ៉ាក់ ព្រោះគាត់ក៏ស្នាក់នៅកន្លែងនោះដែរ។ ខ្ញុំបានទៅដល់កន្លែងនោះ ដោយសារតែខ្ញុំត្រូវយកសម្ភារៈកសិកម្មយកទៅឲ្យតាផុន។ ខ្ញុំឃើញគាត់[យឹម ទិត្យ]ដេកសម្រាកនៅផ្ទះនោះ។ ឆ.៣៦ KH 00934378 ["តាទិតគាត់នៅផ្ទះនោះ [នៅផ្ទះតាវ៉ាក់ ដែលស្ថិតនៅភូមិគោកអំពិល ឃុំភ្នំសំពៅ] មិនដល់មួយឆ្នាំទេ ហើយខ្ញុំឃើញគាត់សឹងរាល់ថ្ងៃ"]។ ឆ.៤២ KH 00934379 ["ខ្ញុំធ្លាប់ប្រជុំជាមួយតាទិត[យឹម ទិត្យ]នៅកន្លែងការដ្ឋាននៅគោកអំពិលតែម្តង។ កាលណោះ គាត់[យឹម ទិត្យ] មិនមែនជាប្រធានអង្គប្រជុំទេ [ជាងមួយ ឬ ពីរឆ្នាំមិនវៀតណាមចូលមកដល់] ប្រធានអង្គប្រជុំគឺ ប្រធានការដ្ឋានរបស់ខ្ញុំ តែគេអញ្ជើញ តាទិត ឲ្យចូលរួម ហើយឲ្យគាត់[យឹម ទិត្យ] និយាយបន្ថែមកន្លែងណាដែលខ្វះខាត។ គាត់[យឹម ទិត្យ]និយាយថា ឲ្យយើងជួយធ្វើការបង្កបង្កើនផលសម្រាប់អង្គការ ហើយគាត់ជំរុញឲ្យប្រជាជនខំធ្វើការ។ ខ្ញុំគិតថា តាទិត គាត់អាចមានតួនាទីអ្វីផ្សេងមួយនៅកន្លែងនេះ"]។ ឯកសារ D118/64 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឺន ឆ.២២ KH 00920178 ["ស៖ តើអ្នកណាជាអ្នកនិយាយប្រាប់លោកពីឈ្មោះតាទិត? ឆ.២២៖ កាលណោះខ្ញុំឮពីតាវ៉ាក់ ជាមេឃុំគាត់និយាយ តែខ្ញុំមិនដឹងថា គាត់មានតួនាទីអ្វីទេ"]។

[1921] ឯកសារ D118/76 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្លក ឆ.៤៩ KH 00934380 ["ស៖ តើចម្ងាយពីផ្ទះតាទិត ទៅវត្តគីរីរម្យមានចំងាយប៉ុន្មានដែរ? ឆ.៤៩៖ [...] គឺមានចំងាយពី១,៥គ.ម ទៅ២គ.ម"]។

[1922] ឯកសារ D219/627 កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ឆ.១២-១៣ KH 01184313 ["បាទ គាត់[យឹម ទិត្យ]គឺជាគណ: តំបន់នៅបឹងប្រី និងភ្នំសំពៅ។ [...] ទិត្យ មកដល់ភ្នំសំពៅនេះក្រោយខ្ញុំ ខ្ញុំមិនដឹងថា មុខងាររបស់គាត់កាលនៅនិរតីនោះជាអ្វីទេ ប៉ុន្តែពេលដែលគាត់មកដល់ភ្នំសំពៅគេដាក់ទទួលត្រូវខុសតំបន់"]។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ឈួយ ឆ .៥៨ KH 01149408 ["តា ទិត្យ គ្រាន់តែគ្រប់គ្រងតែនៅតំបន់[តំបន់៣]នេះប៉ុណ្ណោះ"]។

545. អ្នកយាមប្រដាប់ដោយអាវុធមានវត្តមាននៅវត្តគិរីរម្យ[1923] និងនៅគុកចន្លោះក្តោង[1924] ហើយជាញឹកញាប់ បានយាមអ្នកជាប់ឃុំនៅម្តុំទីតាំងគុកនោះ[1925]។ ប្រធានសន្តិសុខឃុំភ្នំសំពៅឈ្មោះ អេង ត្រូវបានកំណត់អត្តសញ្ញាណថាជា "មេក្តោង" សម្លាប់មនុស្សនៅវត្តគិរីរម្យ[1926]។

[1923] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៣៩ KH 01200317 ["ឆ.៣៩៖ ពេលខ្ញុំឮសូរមាត់មនុស្ស ស្រែក[នៅភ្នំសំពៅ]អ៊ីចឹងទៅ ខ្ញុំក៏បានលួនតាមព្រៃទៅមើល តាមថ្មដាហ្នឹង រូបថតគេថតខ្ញុំជាប់ហ្នឹង ពេលទៅ អ្នកយាមនៅលើចុងឈើឯណោះ ហើយក្រោយមកគេក៏ចុះមកភ្ជង់យើងជាប់"] ឆ.៤៩ KH 01200319 ["ស៖ តើមានខ្មែរក្រហមប៉ុន្មានាក់ដែលនៅជុំវិញអ្នកទោសទាំងនោះ? ឆ.៤៩៖ ឃើញ៦នាក់។ ក្មេងៗអាយុប្រហែល១៦ ឬ១៧ឆ្នាំពួកយោធាហ្នឹង"] ឆ.៦៦ KH 01200324 ["ស៖ តើលោកស្រីអាចមើលឃើញយោធាខ្មែរក្រហមដើរចល័ត នៅឯកន្លែងខាងក្រោមដែរឬទេ ដោយសារតែសហការណ៍របស់លោកស្រីស្ថិតនៅកែ្បរកន្លែងខាងក្រោមនោះ? ឆ.៦៦៖ ឃើញគេដើរទៅមកៗក្នុងការដ្ឋានគេហ្នឹង ច្រើនដែរ ដើរចុះឡើងៗមួយក្រុមគេមាន៥-៦នាក់ ប៉ុន្តែមិនដឹងចំនួនពិតប្រាកដប៉ុន្មាននាក់ទេ"]។

[1924] ឯកសារ D6.1.166 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន ជឿន KH 00197888 ["អ្នកយាមកន្លែងឃុំឃាំង[នៅចន្លោះក្តោង]នោះ មានគ្នាប្រហែល ១០នាក់"]។

[1925] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៤៩ KH 01200319 ["ស៖ តើមានខ្មែរក្រហមប៉ុន្មានាក់ដែលនៅជុំវិញអ្នកទោសទាំងនោះ? ឆ.៤៩៖ ឃើញ៦នាក់។ ក្មេងៗអាយុប្រហែល១៦ ឬ១៧ឆ្នាំពួកយោធាហ្នឹង"] ឆ.៦៦ KH 01200324 ["ស៖ តើលោកស្រីអាចមើលឃើញយោធាខ្មែរក្រហមដើរចល័ត នៅឯកន្លែងខាងក្រោមដែរឬទេ ដោយសារតែសហការណ៍របស់លោកស្រីស្ថិតនៅកែ្បរកន្លែងខាងក្រោមនោះ? ឆ.៦៦៖ ឃើញគេដើរទៅមកៗក្នុងការដ្ឋានគេហ្នឹង ច្រើនដែរ ដើរចុះឡើងៗមួយក្រុមគេមាន៥-៦នាក់ ប៉ុន្តែមិនដឹងចំនួនពិតប្រាកដប៉ុន្មាននាក់ទេ"]។ ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* KH 00233385-86។

[1926] ឯកសារ D219/535 កំណត់ហេតុស្តាប់ចម្លើយ ភ័ង ឌី ឆ.៨៩ KH 01153650 ["[អេង] នេះជាឈ្មោះរបស់មេក្តោងសម្លាប់មនុស្ស"]។ ឯកសារ D219/697 កំណត់ហេតុស្តាប់ចម្លើយ ណូក ឆៀត ឆ.១៨ KH 01210556 ["ដឹងរឿងគេយកមនុស្សទៅវាយចោល។ ប្រធានគរបាលនៅហ្នឹងឈ្មោះ អេង អ្នកសម្លាប់"] ឆ.៣៦ KH 01210558 ["ដល់ក្រោយមក មានយោធាគេមក ហើយគេបានប្រាប់ ថា តាអេងហ្នឹង ជាមេប៉ូលិសនៅលើភ្នំ[សំពៅ] ហើយជាអ្នកសម្លាប់មនុស្សនៅទីនោះ"]។

iv. ខ្ញុំក្ដីកម្ម

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង</u>

546. អ្នកទោសត្រូវបានគេដឹកពីភូមិជិតខាងនៅក្នុងស្រុកនេះដោយរថយន្តទ្រុងជាប្រចាំ[1927] ទៅកាន់វត្ត គិរីរម្យ[1928]។ អ្នកដែលត្រូវបានចាប់ខ្លួនរួមមាន កម្មាភិបាលថ្នាក់ខ្ពស់ និងមន្ត្រីមកពីរបបមុខ[1929]

[1927] ឯកសារ D219/666 កំណត់ហេតុស្ដាប់ចម្លើយ យ៉ង់ សារៀប ឆ.៦០, ៦២-៦៤ KH 01200322-23 ["ឆ.៦០៖ យប់ឡើងបានគេដឹកមក ម៉ោង១២យប់។ ប៉ុន្តែមិនដឹងថា មកពីខេត្តណាទេ។ [...] ម៉ោង១២យប់ទើបគេនាំមក។ [...] ឆ.៦២៖ ដោយសារកន្លែងជិតគ្នា អ៊ីចឹងបានខ្ញុំដឹង និងឃើញគេដឹកមនុស្សតាមឡានដំរីចឹកចូលមក ប៉ុន្តែខ្ញុំមិនដឹងចំនួនពិតប្រាកដប៉ុន្មានទេ។ ជួនកាលឃើញឡើងថ្ងៃល្ងាច ជួនកាលឃើញឡើងយប់។ ស៖ តើលោកស្រីបានឃើញឡានធំដឹកមនុស្សចូលមកកន្លែងខាងក្រោមនោះ ញ៉ីកញ្ជាប់កម្រិតណា? ឆ.៦៣៖ រាល់យប់គេដឹលមក តែមួយឡានប៉ុន្មាននាក់ យើងមិនដឹងទេ។ [...] ឆ.៦៤៖ កន្លែងកំប៉ូវថ្មី ខ្ញុំបាននៅតែជាងមួយខែទេ បន្ទាប់មកគេបញ្ជូនទៅលន្លែងផ្សេង ប៉ុន្តែក្នុងរយៈពេលជាងមួយខែនោះ ខ្ញុំឃើញគេដឹកមករាល់យប់។"]។ ឯកសារ D6.1.132 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ុន សា KH 00242226 ["ខ្ញុំបានឃើញពួកខ្មែរក្រហមដឹកមនុស្សពេញចំនួន ២ឡាន យកឡើងលើភ្នំសំពៅ ហើយពេលឡានមកវិញមិនឃើញមានមនុស្សវិលត្រឡប់មកវិញ ឃើញតែខោអាង និងភួយចោលតាមផ្លូវ"]។ ឯកសារ D6.1.165 កំណត់ហេតុស្ដាប់ចម្លើយ អ៊ីម អាន់ KH 00197884។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់ DC-Cam ស្ដីពី "ការធ្វើផែនទីវាលពិឃាតនៅកម្ពុជា ១៩៩៧៖ ខែត្តបាត់ដំបង" KH 00184648។ ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្ដាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* KH 00233385-86។

[1928] ឯកសារ D219/535 កំណត់ហេតុស្ដាប់ចម្លើយ ភ័ង ឌី ឆ.៣៦-៣៧ KH 01153646 ["ស៖ តើអ្នកដែលគេឃុំនោះពួកគេមកពីណាដែរ? ឆ.៣៦៖ ជាអ្នកនៅភូមិសំពៅ និងភូមិគោកអំពិល។ [...] ស៖ តើមានអ្នកណាមកពីខាងក្រៅភូមិនេះទេ? ឆ.៣៧៖ មាន មកពីស្រុកបាណន់។"]។ *សូមមើលផងដែរ* D219/697 កំណត់ហេតុស្ដាប់ចម្លើយ ណូក ផៃត ឆ.៤៨ KH 01210559។

[1929] ឯកសារ D6.1.118 កំណត់ហេតុស្ដាប់ចម្លើយ ឌុច ភ្ជឿ KH 00221591-92 ["ស៖ តើលោកដឹងទេ ហេតុអ្វីបានជាគេ [កម្មាភិបាលភូមិភាគនិរតី] យកមនុស្សទៅសម្លាប់? ឆ៖ គេយកអ្នករាជការរបស់របប លន់ នល់ ទៅសម្លាប់តាមរយៈការរាយការណ៍ ហើយបន្ទាប់ពីរកឃើញហើយ ក៏ឃើញមានការចាប់ខ្លួនមនុស្សជាបន្តបន្ទាប់។"]។ ឯកសារ D219/515 កំណត់ហេតុស្ដាប់ចម្លើយ ធីន ឈួយ ឆ.២៣៖ KH 01149402 ["កម្មាភិបាលនិរតី គេចាប់ខ្លួនមេភូមិមុនគេ បន្ទាប់មកគឺគេចាប់មេកង។ អតីតកម្មាភិបាលពាយ័ព្យមួយចំនួនបានរត់គេខ្លួន ដោយសារតែពួកគេដឹងអំពីការចាប់ខ្លួននេះ។"]។ ឯកសារ D6.1.168 កំណត់ហេតុស្ដាប់ចម្លើយ ព្រំ សារុន KH 00197917។ *សូមមើលផងដែរ* ឯកសារ D219/700 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ អ៊ុំ ឈួន KH 01303256-57។

កម្មាភិបាលភូមិភាគពាយ័ព្យ[1930] និងអ្នកទាំងឡាយណាដែលគេជឿជាក់ថាជា "ខ្មាំង"[1931]។ អ្នកទាំងនោះរួមមាន បុរស ស្ត្រី កុមារ និងមនុស្សចាស់[1932]។

547. យ៉ង់ សារៀប បានឃើញអ្នកដែលត្រូវបានចាប់ខ្លួនមកដល់ជារៀងរាល់យប់ នៅពេលដែលគាត់រស់នៅជិតវត្តគិរីរម្យនេះ[1933]។ នៅពេលមកដល់ អ្នកដែលត្រូវបានចាប់ខ្លួនត្រូវគេបែងចែកជាអ្នកទោស "ស្រាល" និងអ្នកទោស "ធ្ងន់"[1934]។ អ្នកដែលគេហៅថាអ្នកទោស "ស្រាល" ត្រូវគេដាក់នៅក្នុងគុក

[1930] ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធីន ឈួយ ឆ.២៣៖ KH 01149402។ ឯកសារ D219/458 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ភ័ង ឌី KH 01218534។

[1931] D6.1.168 កំណត់ហេតុស្តាប់ចម្លើយ ព្រំ សារុន KH 00197917 ["ក្រច បាននិយាយថាបើអ្នកណាមិនគោរពអង្គការគឺ ជាខ្មាំង ហើយត្រូវចាប់បញ្ជូនតាមជណ្តើរសទៅវត្តគីរីរម្យ ហើយគាត់ [ក្រច ប្រធានវរ:សេនាតូចលេខ១] បាននិយាយគំរាមទៀតថា 'កាលណាទៅដល់វត្តគីរីរម្យនោះស្រួល គឺមិនត្រូវធ្វើការងារអ្វីទៀតទេ'។ កាលដែលខ្ញុំធ្វើស្រែនៅជិតនោះនៅពាក់កណ្តាលឆ្នាំ ១៩៧៦ ខ្ញុំបានឃើញយោធាពីរនាក់ បណ្តើរមនុស្សឡើងទៅវត្តគីរីរម្យ ចំនួន ៥ដង ដែលម្តងៗមានអ្នកទោសពី១ ទៅ៣នាក់។"]។ ឯកសារ D6.1.115 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្ធក KH 00221547-48។ ឯកសារ D118/76 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្ធក ឆ.៥ KH 00934375។

[1932] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៤២ KH 01200318 ["ដែលគេព្យួរកហ្នឹង សុទ្ធតែមនុស្សប្រុស។ នៅសល់តែខោខ្លីទេ សម្លៀកបំពាក់ខោអាវវែងគ្មានទេ។ ដល់ពេលខ្ញុំទៅដល់ឃើញគេហ្នឹង នៅខាងក្រោមមានអ្នកជាប់ខ្នោះប្រហែល ៣០ ទៅ៤០នាក់ទៀត មានស្រី មានប្រុស មានចាស់ មានក្មេង។"]។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឹន KH 00304360 ["កន្លែងឃុំឃាំងនោះ មានអ្នកទោសប្រហែល៥០ ទៅ៦០នាក់ ទាំងស្រី ប្រុស ក្មេង ចាស់។"]។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212422។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់ DC-Cam ស្តីពី "ការធ្វើផែនទីវាលពិឃាតនៅកម្ពុជា ១៩៩៧៖ ខែត្តបាត់ដំបង" KH 00184648។

[1933] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៦៣ KH 01200323 ["ស៖ តើលោកស្រីបានឃើញឡានធំដឹកមនុស្សចូលមកកន្លែងខាងក្រោមនោះ ញឹកញាប់កម្រិតណា? ឆ.៦៣៖ រាល់យប់គេដឹលមក តែមួយឡានប៉ុន្មាននាក់ យើងមិនដឹងទេ។"]។

[1934] ឯកសារ D6.1.173 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សារឿន KH 00197932 ["អ្នកភូមិបាននិយាយថា អ្នកដែលគេយកមកលើកដំបូង គេដាក់នៅមន្ទីរឃុំឃាំងចន្លោះក្តោង បន្ទាប់ពីមានការស្រាវជ្រាវឃើញថាជាអ្នកទោសធ្ងន់ហើយ គេយកទៅដាក់ក្នុងវត្តគិរីរម្ម។"]។

ចន្លោះក្តោង[1935]។ សាក្សីបានរៀបរាប់ថាមានអ្នកទោសចន្លោះពី២០ ទៅ២០០ នាក់បានជាប់ឃុំនៅទីនោះ[1936]។ អ្នកទោស "ធ្ងន់" ត្រូវបានគេយកមកកាន់វត្តនេះ[1937]។

[1935] ឯកសារ D118/67 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស ឆ.ពាក ៧ KH 00920202 ["មានមន្ទីរសន្តិសុខនៅចន្លោះក្តោងសម្រាប់ដាក់អ្នកទោសស្រាល ហើយអ្នកទោសធ្ងន់គេបញ្ជូនមកដាក់នៅវត្តគិរីរម្យ។"]។

[1936] ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន សា KH 00242226 ["នៅក្នុងឆ្នាំ១៩៧៧ នៅភូមិសំណាញ់ ឃុំភ្នំសំពៅ មានកន្លែងមួយឈ្មោះ 'កន្លែងនគរបាល' មានទំហំ ២០០ម៉ែត្រ x ៥០០ម៉ែត្រ ជាកន្លែងដាក់អ្នកទោស។ មានអ្នកទោសប្រហែលជា ២០០នាក់ ត្រូវបានគេដាក់ឃុំនៅទីនោះ។"]។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឹន KH 00304360 ["នៅដើមឆ្នាំ១៩៧៨ ខ្ញុំបានឃើញផ្ទាល់ភ្នែក គេធ្វើរបង និងធ្វើរោងប្រក់សង្កសី នៅចន្លោះក្តោង។ ប្រហែលមួយសប្តាហ៍ក្រោយមក [...] បានឃើញគេឃុំឃាំងមនុស្សនៅកន្លែងរោងនោះ។ កន្លែងឃុំឃាំងនោះ ដែលមានអ្នកទោសប្រហែល ៥០ ទៅ ៦០នាក់។"]។ ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លីម ទីម ឆ.៦០ KH 00951933 ["មានមន្ទីរសន្តិសុខនៅភ្នំសំពៅមួយ។ [...] មានខ្នោះឈើសម្រាប់ដាក់ខ្នោះជើងអ្នកទោសពី២ ទៅ ៤នាក់ ហើយក្នុងរោងនោះគេអាចដាក់អ្នកទោសបាន ៤០នាក់។"]។

[1937] ឯកសារ D6.1.173 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សារ៉ៀន KH 00197932 ["បន្ទាប់ពី [...] ឃើញថាជាអ្នកទោសធ្ងន់ហើយ គេយកទៅដាក់ក្នុងវត្តគិរីរម្ម។"]។ ឯកសារ D6.1.170 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ភិរុណ KH 00197912 ["ចំណែកនៅខាងក្នុងគុកបិទជិត ខ្ញុំមើលមិនឃើញទេ។ ខ្ញុំក៏បានឃើញអ្នកទោស ត្រូវបានគេបណ្តើរចុះមកពីលើភ្នំ មានជាប់ចំណងស្ពាបសេកដោតខ្សែជាជួរ។ [...] ខ្ញុំយល់ថាអ្នកទោសនេះ ជាអ្នកទោសធ្ងន់ ដោយមានជាប់ចំណង។"]។ ឯកសារ D118/67 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស ឆ.ពាក ៧ KH 00920202។

548. អ្នកទោសដែលគេឃុំនៅគុកចន្លោះក្តោងត្រូវបានបញ្ជូនមកសម្លាប់នៅវត្តនេះ[1938]។ អ្នកយាមប្រដាប់ដោយអាវុធបានបញ្ជូនអ្នកទោសពីគុកចន្លោះក្តោងឡើងតាមជណ្តើរពណ៌សមកកាន់វត្តនេះ[1939]។ អ្នកទោសត្រូវបានគេចងដៃទៅក្រោយ ហើយជាញឹកញាប់ត្រូវបានគេវាយដំ និងធ្វើបាប[1940]។

[1938] ឯកសារ D118/67 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស ឆ.៤៣ KH 00920203 ["ដោយសារអ្នកទោសគេទុកនៅខាងក្រោមភ្នំ ហើយឲ្យតែអ្នកទោសណាដែលគេបញ្ជូនទៅលើវត្តគិរីរម្យ គឺមិនដែលឃើញមានអ្នកណាមកវិញទ។"]។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឺន KH 00304361 ["នៅដើមឆ្នាំ១៩៧៨ នោះដែរ ខ្ញុំបានឃើញ កម្មាភិបាលខ្មែរក្រហមបណ្តើរមនុស្សដែលជាប់ចំណងស្ពាបសេក ចំនួន ២ ឬ៣នាក់ ឡើងទៅលើវត្តគិរីរម្យ។ [...] [ខ្ញុំ] គ្រាន់តែដឹងថាអ្នកទាំងនោះមិនអាចរស់បានទេ។"]។ ឯកសារ D6.1.150 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តគិរីរម្យ KH 00365715។

[1939] ឯកសារ D6.1.166 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន ជឿន KH 00197887-88 ["ខ្ញុំបានឃើញយោធាពីរនាក់បណ្តើរអ្នកទោសចេញពីមន្ទីរឃុំឃាំងតាមជណ្តើរឡើងទៅវត្តគិរីរម្យ មួយនាក់នៅខាងមុខ និងម្នាក់ទៀតនៅខាងក្រោយអ្នកទោស ខ្ញុំបានឃើញចំនួន ៦ដង ហើយម្តងៗមានអ្នកទោសពី ៣ ទៅ ៤នាក់ ដោយមានចំណងស្ពាបសេកទៀតផង។ [...] អ្នកយាមកន្លែងឃុំឃាំងនោះមានគ្នាប្រហែល១០នាក់ ប៉ុន្តែមិនដឹងថាពួកនោះមកពីស្រុកណាទេ។"]។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ូ ម សាត KH 00212421 ["ខ្ញុំបានឃើញម្តងគត់ គឺប្រហែលជាចុងឆ្នាំ១៩៧៨ ពេលរលៀល (ម៉ោង ៤កន្លះ)។ ខ្ញុំបានឃើញយោធាបណ្តើរអ្នកទោសមួយជួរប្រហែល១០នាក់ ដោយមានអ្នកយាមម្នាក់នៅខាងមុខ និងម្នាក់នៅពីក្រោយ។ ក្នុងចំណោមអ្នកទោសទាំងនេះ មានប្រុស ស្រី តែខ្ញុំមិនដឹងថា គេនាំយកមកពីណាទេ។ ខ្ញុំបានដឹងថា គេយកអ្នកទោសទាំងនោះទៅលើវត្តគិរីរម្យ ដើម្បីសម្លាប់។"]។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឺន KH 00304360។ ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* KH 00233385-86។

[1940] ឯកសារ D6.1.115 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្ធក KH 00221547 ["បន្ទាប់មកខ្ញុំបានឃើញពួកវានាំមនុស្សទាំង១៤នាក់នោះឡើងលើភ្នំសំពៅនៅវិហារវត្តគីរីរម្យ។ ពេលមនុស្សទាំងនោះឡើងដល់ពាក់កណ្តាលភ្នំ វាក៏ធាក់អ្នកដែលឡើងមិនរួចម្នាក់ធ្លាក់តាមជណ្តើរពីលើភ្នំ រួចវាក៏អូសអ្នកនោះឡើងទៅលើភ្នំវិញ។"]។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឺន KH 00304361 ["ខ្ញុំបានឃើញឈ្លបក្មេងៗបណ្តើរអ្នកទោសទៅមុជទឹកនៅប្រឡាយក្បែរគុកនោះ ដោយពេលខ្លះឈ្លបទាំងនោះយកដំបងវាយក្បាលអ្នកទោសដែលដើរយឺត។ នៅដើមឆ្នាំ១៩៧៨ នោះដែរ ខ្ញុំបានឃើញ កម្មាភិបាលខ្មែរក្រហមបណ្តើរមនុស្សដែលជាប់ចំណងស្ពាបសេក ចំនួន ២ ឬ៣នាក់ ឡើងទៅលើវត្តគិរីរម្យ។ ខ្ញុំឃើញហេតុការណ៍នេះតែម្តងទេ។ មិនមានអ្នកណាត្រូវបានអនុញ្ញាតឲ្យឡើងទៅលើវត្តគិរីរម្យនោះឡើយ ហើយខ្ញុំក៏មិនដឹងអំពីហេតុការណ៍ ឬវាសនាអ្នកដែលត្រូវគេបញ្ជូនឡើងទៅវត្តគិរីរម្យនោះឡើងយ គ្រាន់តែដឹងថាអ្នកទាំងនោះមិនអាចរស់បានទេ។"]។ ឯកសារ D6.1.169 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស KH 00197903។

<u>ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

549. អ្នកទោសនៅវត្តគិរីរម្យត្រូវគេបង្ខំឲ្យធ្វើការងារពលកម្ម ដូចជាវាយបំបែកថ្ម[1941] សែងកំបោរ[1942] កាត់ស្មៅ និងកាប់ឈើ[1943] ជីកប្រឡាយ និងធ្វើរបង[1944]។ អ្នកទោសក៏ត្រូវបានគេបង្ខំឲ្យធ្វើការងារកសិកម្មផងដែរ ដូចជាចិញ្ចឹមជ្រូក និងគោក្របី ធ្វើបង្គ្រឹ កាប់ដី និងដាំបន្លែ[1945]។ សាក្សី ញ៉ឹម ហ្ស ដែលបានធ្វើការនៅក្នុងសហករណ៍មូលដ្ឋាន រៀបរាប់ថា គាត់បានឃើញអ្នកទោសធ្វើការទាំងជាប់ខ្នោះ

[1941] ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប ប៉ែន លៀត KH 00242230-31 ["ពេលនោះពួកវាបណ្តើរអ្នកគោសចុះក្រោម [ភ្នំសំពៅ] គឺឲ្យទៅមុជទឹកនៅប្រឡាយក្បែររបងគុក ស្ថិតនៅភូមិសំណាញ់ [...]។ គេបង្ខំឲ្យវាយថ្ម និងធ្វើសំណង់ផ្សេងៗ។ ខ្ញុំឃើញពួកខ្មែរក្រហមពីរនាក់បណ្តើរមនុស្សជាប់ច្រវ៉ាក់ឡើងតាមជណ្តើរតំរង់ឆ្ពោះទៅវត្តគិរីរម្យ ចំនួនពីរដង និងឃើញពួកវាបណ្តើរចុះក្រោមតាមជណ្តើរដដែលនោះចំនួន ៤ ដង។"]។

[1942] ឯកសារ D6.1.169 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស KH 00197903-4 ["ខ្ញុំបានដឹង [អំពីគុកវត្តគិរីរម្យ] តាំងពីមុនឆ្នាំ ១៩៧៩។ [...] នៅពេលនោះឯង ដែលខ្ញុំបានឃើញអ្នកទោសភេទប្រុសពីរនាក់ ពាក់ខោអាវពណ៌ កំពុងសែងកំបោរថ្មនៅម្តុំចន្ទោះក្តោង និងភ្នំសំពៅ។ អ្នកទោសនោះមានសភាពស្គមស្គាំង ហើយមានជាប់ខ្នោះដៃ និងច្រវ៉ាក់ភ្ជាប់ពីមួយទៅមួយ។ ទាហានដែលបណ្តើរអ្នកទោសនោះជាកុមារអាយុប្រហែល ១២ឆ្នាំមានស្លាយកាំភ្លើង។"]។ *សូមមើលផងដែរ* ឯកសារ D6.1.170 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ភិរុណ KH 00197912។

[1943] ឯកសារ D6.1.115 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្ធក KH 00221547 ["ខ្ញុំបានដឹង និងស្គាល់កន្លែងឃុំមនុស្សនៅវត្តគិរីរម្យ [...]។ កន្លែងនោះមានសកម្មភាពរហូតដល់ឆ្នាំ១៩៧៩ មុនវៀតណាមចូល។ ខ្ញុំឃើញអ្នកទោសធ្វើការនៅលើភ្នំដូចជាកាត់ស្មៅ កាប់ឈើ។"]។

[1944] ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន សា KH 00242226 ["នៅក្នុងឆ្នាំ១៩៧៧ [...] ខ្ញុំបានឃើញអ្នកទោសធ្វើការជីកប្រឡាយ ធ្វើរបង ចិញ្ចឹមជ្រូក ចិញ្ចឹមគោ នៅពេលខ្ញុំទៅឃ្វាលគោក្បែរនោះ។"]។

[1945] ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន សា KH 00242226 ["នៅក្នុងឆ្នាំ១៩៧៧ នៅភូមិសំណាញ់ ឃុំភ្នំសំពៅ មានកន្លែងមួយឈ្មោះ 'កន្លែងនគរបាល' មានទំហំ ២០០ម៉ែត្រ x ៥០០ម៉ែត្រ ជាកន្លែងដាក់អ្នកទោស។ មានអ្នកទោសប្រហែលជា ២០០នាក់ ត្រូវបានគេដាក់ឃុំនៅទីនោះ។ ខ្ញុំបានឃើញអ្នកទោសធ្វើការជីកប្រឡាយ ធ្វើរបង ចិញ្ចឹមជ្រូក ចិញ្ចឹមគោ"]។ ឯកសារ D6.1.170 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ភិរុណ KH 00197912 ["ខ្ញុំបានឃើញគុកឃ្លាង (គុកដែលមានរាងដូចឃ្លាំង) កំពុងត្រូវសាងសង់ឡើងនៅទិសខាងត្បូងឈរខាងលិចវិហារគិរីរម្យ ត្រង់ចន្ទោះក្តោង និងភ្នំសំពៅ។ ក្រោយពេលសង់ហើយ ខ្ញុំត្រូវបានហាមមិនឲ្យចូល។ ក្រោយមកខ្ញុំត្រូវចាត់តាំងឲ្យឡើងភ្នោត ចម្ងាយប្រហែល ១០០ម៉ែត្រ ពីឃ្លាំងគុក។ ខ្ញុំបានឃើញអ្នកទោសចេញ [ក្រៅគុក] មកដាំបន្លែ។"]។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់ DC-Cam ស្តីពី "ការធ្វើផែនទីវាលពិឃាតនៅកម្ពុជា ១៩៩៧៖ ខែតុលាត់ដំបង" KH 00184648។ *សូមមើលផងដែរ* ឯកសារ D6.1.172 កំណត់ហេតុស្តាប់ចម្លើយ ផែ សឿ KH 00197908។

និងដាក់ច្រវ៉ាក់ជាប់គ្នា[1946]។ ហ៊ុន សា ដែលជាមេកងចល័ត បានឃើញអ្នកទោសត្រូវគេទាត់ និងវាយដោយស្វាយកាំភ្លើង នៅពេលកំពុងធ្វើការនៅគុកចន្លោះក្តោង[1947]។

550. ខណៈដែលអ្នកទោសនៅវត្តនេះត្រូវគេដាក់ខ្នោះជើង[1948] អ្នកទោសនៅគុកចន្លោះក្តោងជាទូទៅមិនត្រូវបានគេដាក់ខ្នោះជើងនោះទេ[1949]។ ប៉ុល សឹន ដែលឃ្វាលគោនៅលើភ្នំសំពៅ បានឃើញអ្នកទោសត្រូវគេវាយក្បាលដោយដំបង នៅពេលដែលពួកគេត្រូវបានគេនាំពីគុកចន្លោះក្តោងឲ្យទៅមុជទឹកនៅក្នុងប្រឡាយជិតនោះ[1950]។ សាក្សីជាច្រើនបានរៀបរាប់ថា ពួកគាត់បានឃើញអ្នកជាប់ឃុំឈឺ ហើយស្គមស្គាំងនៅវត្តនេះ និងនៅគុកចន្លោះក្តោង[1951]។

[1946] ឯកសារ D6.1.169 កំណត់ហេតុស្តាប់ចម្លើយ ញ៊ីម ហ្ស KH 00197903-4 ["ខ្ញុំបានឃើញអ្នកទោសភេទប្រុសពីរនាក់ ពាក់ខោអាវពណ៌ កំពុងសែងកំបោរថ្មនៅម្តុំចន្លោះក្តោង និងភ្នំសំពៅ។ អ្នកទោសនោះមានសភាពស្គមស្គាំង ហើយមានជាប់ខ្នោះដៃ និងច្រវ៉ាក់ភ្ជាប់ពីមួយទៅមួយ។ ទាហានដែលបណ្តើរអ្នកទោសនោះជាកុមារអាយុប្រហែល ១២ឆ្នាំមានស្តាយកាំភ្លើង។"]។

[1947] ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន សា KH 00242226 ["ខ្ញុំបានឃើញអ្នកទោសធ្វើការជីកប្រឡាយ ធ្វើរបង ចិញ្ចឹមជ្រូក ចិញ្ចឹមគោ។ ខ្ញុំក៏បានឃើញកូនៗយោធា ដែលជាអ្នកយាមគុកនោះ ទាត់ក្បាលអ្នកទោស និងឃើញគេវាយអ្នកទោសនឹងស្វាយកាំភ្លើង។"]។

[1948] ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប ប៉ែន លឿត KH 00242230 ["នៅដើមឆ្នាំ១៩៧៧ ខ្ញុំបានឃើញពួកទាហានខ្មែរក្រហម បណ្តើរមនុស្សដែលមានជាប់ច្រវ៉ាក់ជើងឡើងនិងចុះភ្នំសំពៅ [...] ចំនួនប្រហែលពី ១៥ ទៅ២០ នាក់។"]។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212422 ["ខ្ញុំបានឡើងទៅវត្តគិរីរម្យប្រហែលមួយអាទិត្យ ក្រោយនៃចូលមកដល់។ [...] នៅខាងក្នុងវិហារខ្ញុំបានឃើញខ្នោះឈើពីរជួរ"]។ *សូមមើលផងដែរ* ឯកសារ D219/666.1 *នាវិបដិវត្តន៍* ចម្លើយរបស់ យ៉ង សារៀប KH 01238097-99។

[1949] ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឹន KH 00304360-61 ["អ្នកទោសទាំងនោះ ស្ថិតក្នុងសភាពស្គមស្គាំងវេទនា ត្រូវបានគេឃុំក្នុងរោងដោយមិនមានដាក់ច្រវ៉ាក់។"]។ ឯកសារ D6.1.170 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ភិរុណ KH 00197912 ["ខ្ញុំបានឃើញអ្នកទោសចេញមកដាំបន្លែ មានសភាពស្គម ដោយមិនមានចងចំណង។"]។

[1950] ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឹន KH 00304361 ["ខ្ញុំបានឃើញឈ្លបក្មេងៗបណ្តើរអ្នកទោសទៅមុជទឹកនៅប្រឡាយក្បែរគុកនោះ ដោយពេលខ្លះឈ្លបទាំងនោះយកដំបងវាយក្បាលអ្នកទោសដែលដើរយឺត។"]។ ឯកសារ D118/64 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឹន ឆ.១៥ KH 00920177 ["ខ្ញុំបានឃើញគេធ្វើដូចនេះ២ ទៅ ៣ដង នៅពេលដែលគេ [ទាហានក្មេងៗ] បណ្តើរអ្នកទោសមកងូតទឹក ហើយអ្នកទោសណាដែលដើរយឺត គេ [ទាហានក្មេងៗ] វ៉ៃក្បាលហើយ"]។

[1951] ឯកសារ D6.1.170 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ភិរុណ KH 00197912 ["ខ្ញុំបានឃើញអ្នកទោសចេញមកដាំបន្លែ មានសភាពស្គម ដោយមិនមានចងចំណង។ [...] ខ្ញុំក៏បានឃើញអ្នកទោស ត្រូវបានបណ្តើរចុះមកពីលើភ្នំ មានជាប់ចំណងស្ពាបសេកដោយខ្សែជាជួរ។ [...] មានពេលខ្លះ ពេលដែលខ្ញុំឡើងត្នោត ខ្ញុំអាចចូលបាននោះ អ្នកទោសនៅក្រោម ដេលមានជំងឺ បានសុំទឹកត្នោតខ្ញុំផឹក ហើយពួកគេបានឲ្យថ្នាំបារាំងមកខ្ញុំ។"]។ ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប ប៉ែន លឿត KH 00242230 ["ស៖ តើលោកបានដឹងឮអ្វីខ្លះអំពីគុកវត្តគិរីរម្យ លើភ្នំសំពៅនាពេលនោះ? ឆ៖ [...] [នៅដើមឆ្នាំ១៩៧៧] ពេល [ទាហានខ្ម

551. ការសួរចម្លើយត្រូវបានធ្វើឡើងនៅវត្តគិរីរម្យ[1952]។ ឧបករណ៍ដែលបានរកឃើញនៅវត្តនេះ រួមមានដំបងឈើ ខ្នោះដៃ និងខ្សែពួរ[1953] ដែកស្បែង[1954] ខ្សែលួស[1955] កាំបិត និងពូថៅដែលមានប្រឡាក់ឈាមនៅឡើយ[1956]។ យ៉ង់ សារៀប ដែលជាប្រធានកងកុមារមូលដ្ឋាន បានឃើញអ្នកទោសប្រុសៗគេពួរកផុតជើងពីដីប្រហែលមួយចំអាម ហើយអ្នកទោសដទៃទៀតត្រូវគេដាក់ខ្នោះជើងនិងដៃជាជួរៗនៅក្នុងវត្ត[1957]។ យ៉ង់ សារៀប មានវត្តមាននៅក្នុងវត្ត នៅពេលគេចាក់ខ្នងរះយកថ្ពើមពីអ្នក

ក្រហម] បណ្តើរ [អ្នកជាប់ឃុំ] ម្តងៗមានមនុស្សជាប់ច្រវ៉ាក់ជើង ចំនួនប្រហែល ១៥ ទៅ ២០នាក់ ដែលសុទ្ធតែជាមនុស្សប្រុសមានរូបរាងស្គមស្គាំង ត្រូវគេបណ្តើរជាជួរ។"]។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល សឺន KH 00304360-61។ ឯកសារ D6.1.167 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន លាប KH 00197924។ ឯកសារ D6.1.150 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តគិរីរម្យ KH 00365726-27។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់ DC-Cam ស្តីពី "ការធ្វើផែនទីវាលពិឃាតនៅកម្ពុជា ១៩៩៧៖ ខេត្តបាត់ដំបង" KH 00184648។

[1952] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៨៣ KH 01200327-28 ["ខ្ញុំមានលិខិត ប្រធានវរៈគេធ្វើលិខិតឲ្យដើរ [...]។ ខ្ញុំទៅបារអាចម៍ប្រចៀវ ពេលគេសួរចម្លើយខ្ញុំក៏ដកលិខិតឲ្យគេមើល ទើបគេជឿថា យើងមិនមែនមកស៊ើបការណ៍ទេ។ បើអត់លិខិត ខ្ញុំច្បាស់ជាត្រូវគេសម្លាប់នៅឯកន្លែងនោះដែរហើយ"] ឆ.៦០ KH 01200322។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់ DC-Cam ស្តីពី "ការធ្វើផែនទីវាលពិឃាតនៅកម្ពុជា ១៩៩៧៖ ខេត្តបាត់ដំបង" KH 00184647 ["ព្រះវិហារ [វត្តគិរីរម្យ] កន្លែងសួរចម្លើយ និងអារកបង្ហូរឈាមតាមទ បង្ហូរទម្លាក់ឈាមចុះក្រោម ភ័ស្តុតាងទនៅជាប់ជញ្ជាំងព្រះវិហារ"] KH 00184648។ *សូមមើលផងដែរ* ឯកសារ D219/666.1 *នាវិបជិវ*ត្ត ការរៀបរាប់របស់ យ៉ង់ សារៀប KH 01238097-99។

[1953] ឯកសារ D6.1.166 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន ជឿន KH 00197890 ["ក្នុងវត្តគិរីរម្យពេលនោះ ខ្ញុំបានឃើញមានដំបងឈើ ខ្នោះដៃ មានខ្សែពួរ នៅក្នុងបរិវេណវត្តនោះ"]។

[1954] ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន លៀត KH 00242231 ["នៅឆ្នាំ១៩៨២ ខ្ញុំបានឡើងទៅវត្តគិរីរម្យ លើភ្នំសំពៅ ខ្ញុំបានឃើញខ្នោះឈើជាច្រើន ដែកស្បែងមូលៗប្រវែងប្រហែល ៦០-៧០ សង់ទីម៉ែត្រ"]។

[1955] ឯកសារ D6.1.165 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម អាន់ KH 00197884 ["មានមនុស្សគ្រប់គ្នានៅក្នុងភូមិបានដឹងថា មានគេយកមនុស្សមកសម្លាប់នៅលើភ្នំសំពៅ គឺសម្លាប់នៅណ្ណងនៃគិរីរម្យ។ [...] អាត្មាបានឃើញសាកសពមនុស្សនៅក្នុងណ្ណង ខ្នោះដាក់ជើង សាកសពមនុស្សស្រីពួរកនឹងខ្សែលួសចងជាប់នឹងថ្ម និងបានឃើញខ្សែលួសចងមនុស្សផង"]។

[1956] ឯកសារ D6.1.115 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្ធក KH 00221547 ["បន្ទាប់ពី ខ្ញែរក្រហមដួលរលំនៅឆ្នាំ១៩៧៩ ខ្ញុំបានឡើងនៅលើភ្នំសំពៅ ខ្ញុំបានឃើញសាកសពមនុស្សជាច្រើន ដែលមានក្លិនស្អុយចេញពីណ្ណងណ្ងានលើភ្នំសំពៅ។ ខ្ញុំបានឃើញកាំបិត ពូថៅ ដែកវែង ជាឧបករណ៍សម្លាប់មនុស្ស ដែលមានប្រឡាក់ឈាមនៅឡើយ"]។

[1957] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៣៨ KH 01200317 ឆ.៤១-៤២ KH 01200317-18 ["ស៖ តើលោកស្រីបានឃើញសាកសពចំនួនប៉ុន្មាននាក់? តើមនុស្សបានស្លាប់ហើយឬនៅ ឬមនុស្សទាំងនោះនៅរស់ ពេលដែលខ្ញែរក្រហមវះពោះយកថ្ពើមរបស់ពួកគេ? ឆ.៤១៖ មនុស្សរស់ គេចងខ្សែពួរ ប៉ុនៗកដៃ ហើយគេពួរកផុតជើងពីដីប្រហែលមួយចំអាម មួយខ្សែរបស់គេមានមនុស្ស៨នាក់។ ទាំងអស់មាន៤ខ្សែ។ [...] ដែលគេពួរកហ្នឹង សុទ្ធតែមនុស្សប្រុស។ នៅសល់តែខោ

ទោសម្នាក់ទាំងរស់ ហើយគេបង្ហូរឈាមតាមទ បង្ហូរទម្លាក់ឈាមចុះក្រោមទៅក្នុងបាសាំងមួយ[1958]។ គាត់ក៏បានឃើញផ្ដើមមួយចានដែកនៅក្នុងបរិវេណវត្ត[1959]។ ប្រជាជនរស់នៅក្បែរភូមិសំពៅ បានឮសម្រែកជាញឹកញាប់ចេញពីអ្នកទោសនៅវត្តគិរីរម្យ នៅពេលយប់[1960]។

ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

552. យោងតាមសំណល់សាកសពមនុស្សដែលបានរកឃើញនៅទីតាំងនេះ និងអ្វីដែលសាក្សីបានប្រាប់ឬបានសង្កេតឃើញ យ៉ាងហោចណាស់មានអ្នកទោសរាប់រយនាក់ ត្រូវបានសម្លាប់នៅវត្តគិរីរម្យ[1961]។

ខ្ជីទេ សម្លៀកបំពាក់ខោអាវវែងគ្មានទេ។ ដល់ពេលខ្ញុំទៅដល់ឃើញគេហ្នឹង នៅខាងក្រោមមានអ្នកជាប់ខ្នោះប្រហែល ៣០ ទៅ ៤០ នាក់ទៀត មានស្រី មានប្រុស មានចាស់ មានក្មេង ខាងក្រោមមានគេជាប់ខ្នោះបួនជួរ ទល់ខ្នងគ្នា និងទល់ជើងគ្នា ហើយគេដាក់ខ្នោះជើង និងដៃចងស្ពាបសេកទៅក្រោយ"] ឯ.៤៣ KH 01200318។

[1958] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឯ.៤៤ KH 01200318 ["ខ្មែរក្រហមបានយកកាំបិតចាក់ខ្នងហើយរុះទាញផ្ដើមមកកាត់ បន្ទាប់មកទើបបិទខ្នងនោះទៅវិញ ហើយគេយកក្រណាត់មកបិទមុខកន្លែងដែលគេរុះ។ ភ្នែករបស់បុរសដែលគេរុះយកផ្ដើមនោះ នៅមើលយើងនៅឡើយ ទឹកភ្នែកគាត់ហូរ គាត់មិនទាន់ស្លាប់ទេ ព្រោះបេះដូងគាត់នៅដើរ។ ខ្ញុំភ័យញ័រដៃ។ គេបានធ្វើទម្លាយសម្រាប់ត្រងបង្ហូរឈាមទៅក្នុងបាសាំងធំមួយ"]។

[1959] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឯ.៤៤ KH 01200318 ["ខ្ញុំ[...] ឃើញផ្ដើមមួយចានដែក មិនដឹងថា ផ្ដើមមនុស្ស ឬផ្ដើមអ្វីទេ។ [...] ពេលនោះ គេបានទាញកាំបិតទាហានមួយ ហើយប្រាប់ឲ្យខ្ញុំកាន់ចានដែកទៅជាមួយគេទៅវិហារគិរីរម្យ ដែលជាកន្លែងឧក្រិដ្ឋកម្ម"]។

[1960] ឯកសារ D6.1.170 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ភិរុណ KH 00197912 ["ប្រហែលជាមួយខែមុនវៀតណាមចូលមកដល់ នៅពេលយប់ៗ ខ្ញុំបានឮសំឡេងស្រែកចេញមកពីលើខ្នងភ្នំ"]។ ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឯ.៣៨ KH 01200317 ["ស៖ ត្រង់ទំព័រ៦៨ និង ៦៩ នៃសៀវភៅដែលមានចំណងជើងថា "នារីបដិវត្តន៍" លោកស្រីបាននិយាយអំពីហេតុការណ៍មួយនៅពេលដែលលោកស្រីទៅរកអាចម៍ប្រចៀវនៅភ្នំសំពៅ ហើយលោកស្រីបានឮសំឡេងស្រែកឲ្យ ជួយ។ តើហេតុការណ៍នេះ កើតឡើងនៅពេលណា? ឯ.៣៨៖ ក្នុងឆ្នាំ៧៨ហ្នឹង"]។

[1961] ឯកសារ D6.1.116 កំណត់ហេតុស្តាប់ចម្លើយ ទេស ប៊ីញ KH 00221600 ["ខ្ញុំបានដឹងដំណឹងថា អ្នកនៅចន្លោះក្តោងត្រូវបានគេសម្លាប់ចោល។ គេបាននិយាយថា អ្នកនៅចន្លោះក្តោងចំនួនប្រហែល ២០០នាក់ត្រូវបានក្រុមខ្មែរក្រហមនាំឡើងណ្ហង ណ្ហូនៅវត្តគិរីរម្យលើភ្នំសំពៅ រួចសម្លាប់ចោល មុនវៀតណាមចូលដល់ភ្នំសំពៅ ប្រហែល ២ ឬ ៣ថ្ងៃ ប៉ុណ្ណោះ"]។ ឯកសារ D219/784 កំណត់ហេតុស្តាប់ចម្លើយ ម៉ុ ក្រាត ឯ.៦០ KH 01300427 ["ស៖ តើក្បាលខ្ទោចត្រូវបានរាប់ជាចំនួនឬទេ? ឯ.៦០៖ ពេលនោះខ្ញុំមិនបានរាប់ទេ គ្រាន់តែបានស្ពាន ប្រហាក់ប្រហែ។ សពនៅក្នុងណ្ហណ្ហូននេះ[ណ្ហងណ្ហូន និងណ្ហងគិរីរម្យ] មិនតិចជាង៣០០ទេ ព្រោះវានៅគរលើគ្នា ហើយវាធុំក្លិនស្អុយ ដូច្នេះពិបាកទៅរាប់។ ឯនៅក្នុងណ្ហងគិរីរម្យមិនមានសពទេ មិនដឹងជាគេយកសពទៅណា ប៉ុន្តែមានទបង្ហូរឈាម កាំបិត ពួចៅនៅហ្នឹង តែមិនមានសពទេ។ នៅណ្ហងគិរីរម្យនេះ ពេលដែលខ្ញុំឡើងនៅឆ្នាំ ៧៩នេះ ឆ្អាបណាស់ ឆ្អាបឈាម ព្រោះទើបនឹងសម្លាប់ហើយថ្មីៗ ខ្ញុំទៅមិនបានយូរទេ"]។ ឯកសារ D118/66 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម អាន់ ឯ.២៦ KH 00920195 ["ក្រោយឆ្នាំ១៩៧៩ មេឃុំគេឲ្យអាត្មាទៅប្រមូលក្បាលខ្ទោចនៅវត្តគិរីរម្យ យកមកទុក

ឧទាហរណ៍ បងប្អូនបង្កើត ម្តាយមីង ម្តាយក្មេក និងយាយសាច់ផ្ទៃរបស់ ធ្ងន ឈួយ ត្រូវបានចោទថាមានជាប់ពាក់ព័ន្ធជាមួយវៀតណាម និងត្រូវបានបញ្ជូនទៅវត្តគិរីរម្យ នៅដើមឆ្នាំ១៩៧៨ ដើម្បីសម្លាប់[1962]។ អ៊ីម អាន់ ជាប្រធានភូមិ បានឮអ្នកភូមិនិយាយថា មានការកាត់បំពង់កអ្នកទោសនៅវត្តគិរីរម្យ[1963]។ ប្រហោងតាមជញ្ជាំងវត្ត និងអាងដែកត្រូវបានគេប្រើដើម្បីប្រមូល និងរក្សាឈាមពីសាកសពអ្នកជាប់ឃុំ[1964]។

នៅភ្នំសំពៅ។ នៅណ្ហងមួយកន្លែង អាត្មារាប់ឃើញថា មានចំនួនពី ២០ ទៅ ៣០ លលាដ៍ តែមានសាកសពនៅតាមណ្ហងផ្សេងទៀត"]។ ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៥៧ KH 01200322។ *សូមមើលផងដែរ* ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212421-22។ ឯកសារ D118/67 កំណត់ហេតុស្តាប់ចម្លើយ ញ៉ីម ហូ ឆ.៤០ KH 00920203។ ឯកសារ D6.1.166 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន ជឿន KH 00197889-90។ ឯកសារ D6.1.163 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សួម KH 00197935។

[1962] ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ្ងន ឈួយ ឆ.១៩ KH 01149400 ["ភ្នំសំពៅ ហាក់បីដូចជាកន្លែងដែលគេយកមនុស្សទៅវ៉ៃចោលច្រើនជាង។ ការដែលខ្ញុំដឹងថា ភ្នំសំពៅជាកន្លែងសម្លាប់មនុស្ស ដោយសារគេបានយកយាយក្មេក ម្តាយក្មេក មីង បងប្អូនខ្ញុំ យកទៅសម្លាប់នៅទីនោះ ប្រហែលដើមឆ្នាំ១៩៧៨។ បងប្អូនរបស់ខ្ញុំទាំងអស់នោះ ត្រូវបានគេចោទថា ជាប់ខ្សែ វៀតណាម។ យាយក្មេករបស់ខ្ញុំ គឺជាមនុស្សជំនាន់ក្រោយដែលជាប់ខ្សែស្រឡាយវៀតណាម"]។

[1963] ឯកសារ D118/66 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម អាន់ ឆ.២៦ KH 00920195 ["ពេលដែលអាត្មាបានទៅដល់ព្រះវិហារ អាត្មានៅឃើញមានបន្ទប់ឃុំឃាំងតូចៗ ហើយឃើញមានស្នាមឈាមជាច្រើននៅកន្លែងនោះ។ អាត្មាឮពីអ្នកភូមិនៅជិតៗនោះ ប្រាប់អាត្មាថា គេអារកអ្នកទោស ហើយគេយកសាកសពទៅបោះចោលនៅណ្ហងចម្ងាយ ២០ ទៅ ៣០ម៉ែត្រ ពីវិហារនោះ"]។ *សូមមើលផងដែរ* ឯកសារ D219/415 កំណត់ហេតុស្តាប់ចម្លើយ ឌី ពៀច ឆ.១០ KH 01117347 ["ខ្ញុំបានឮពីគេថា ក្រោយពួកនិរតីចូលមកដល់ ពួកគេបានអារកមនុស្ស ហើយទម្លាក់សាកសពចូលទៅក្នុងណ្ហងនៅលើភ្នំសំពៅ"]។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212422។ ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន លឿត KH 00242230-31។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់ DC-Cam ស្តីពី "ការធ្វើផែនទីវាលពិឃាតនៅកម្ពុជា ១៩៩៧៖ ខេត្តបាត់ដំបង" KH 00184647។ ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* KH 00233383។

[1964] ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212422 ["បាទ ខ្ញុំបានឡើងទៅវត្តគិរីរម្យ ប្រហែលមួយអាទិត្យក្រោយយួនចូលមកដល់។ ខ្ញុំបានឃើញគេចោះជញ្ជាំងព្រះវិហារ កំពស់ប្រមាណមនុស្សលត់ជង្គង់ ដាក់ទមចេញមកក្រៅ នាំឲ្យខ្ញុំគិតថា ជាកន្លែងសម្រាប់អារកអ្នកទោស បង្ហូរឈាមចេញទៅខាងក្រៅ"]។ ឯកសារ D6.1.163 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សួម KH 00197935 ["ពេលនោះខ្ញុំក៏បានឃើញផងដែរនូវរន្ធ ដែលមានស្នាមចោះជញ្ជាំងវិហារខាងត្បូង (វិហារវត្តគិរីរម្យ) មួយកន្លែង មានស្នាមបង្ហូរឈាម"]។ ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន លឿត KH 00242231 ["[ខ្ញុំ] ឃើញចានដែកមួយដែលមានតទុយោបង្ហូរទៅខាងក្រៅ ដែលខ្ញុំសន្និដ្ឋានថា ជាចានសម្រាប់ត្រងឈាមមនុស្សដែលត្រូវបានគេអារក ស្ថិតនៅក្នុងវិហារនៃវត្តនោះ"]។ ឯកសារ D6.1.164 កំណត់ហេតុស្តាប់ចម្លើយ គង់ គឹមលី KH 00197895។ ឯកសារ D6.1.169 កំណត់ហេតុស្តាប់ចម្លើយ ញ៉ីម ហូ KH 00197904។ ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៥៧ KH

553. អ្នកជាប់ឃុំឃាំងផ្សេងទៀតពីវត្តនេះ និងគុកចន្លោះក្តោង ត្រូវបានគេវ៉ែកាាល ហើយទម្លាក់ទៅក្នុងណ្ណងតែម្តង[1965]។ យ៉ង់ សារៀប បានឃើញកុមារពីរនាក់ត្រូវគេបោះចូលក្នុងណ្ណងនេះ ដើម្បីសម្លាប់ពួកគេ ហើយសាកសពពួកគេទើលើមេយឈើ[1966]។ សាកសពដែលបានរកឃើញក្នុងណ្ណង គឺដៃ

01200318។ *សូមមើលផងដែរ* ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* KH 00233385-86។

[1965] ឯកសារ D347/2.1.25 ព្រ៊ុ សារុន ប្រតិចារ៊ីក ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 09.22.05-09.23.47 ["នៅជណ្តើរសហ្ម៊ីងវិហារហ្ម៊ីងឯង គេឃុំខ្លួនមនុស្សនោះ មានខ្ទោះមានអ៊ីនៅហ្ម៊ីងឯង ហើយទម្លាក់នៅណ្ណងគិរីរម្យហ្ម៊ីងឯង។ សម្លាប់ហើយទម្លាក់នៅណ្ណងគិរីរម្យហ្ម៊ីង ជិតគ្នាហ្ម៊ីង"]។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម សាត KH 00212422 ["ខ្ញុំបានឃើញសាកសពមនុស្សរប៉ាត់រប៉ាយពាសពេញនៅតាមណ្ណង និងមាត់ណ្ណង ណ្ណងណ្ងេន និងណ្ណងតែងខ្លួន។ ខ្ញុំគិតថា សាកសពទាំងនេះមួយចំនួនទើបត្រូវបានគេសម្លាប់ក្នុងពេលមិនយូរប៉ុន្ថានទេ។ ដោយមានសាកសពខ្លះកំពុងហើម ហើយសាកសពខ្លះទ្រោមពីហើមទៅវិញហើយ។ ក្នុងចំណោមសាកសពទាំងអស់នេះមានប្រុស ស្រី ក្មេង ក្នុងសម្លៀកបំពាក់ស៊ីវិល ពណ៌ខ្មៅ និងចម្រុះណាយឡំគ្នាដែលមានចំនួនប្រហែលរាប់រយនាក់"]។ ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៥៦-៥៨ KH 01200321-22 ["គេនាំយើងទៅណ្ណងតែងខ្លួន និងណ្ណងណ្ងេន ទៅគេវ៉ែមនុស្សទម្លាក់]។ ឯកសារ D6.1.167 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន លាប KH 00197923-24។ ឯកសារ D219/916 កំណត់ហេតុស្តាប់ចម្លើយ ដិប អ៊ី ឆ.៥៤ KH 01388671។ ឯកសារ D219/415 កំណត់ហេតុស្តាប់ចម្លើយ ឌី ពៀច ឆ.១០ KH 01117347។

[1966] ឯកសារ D219/666 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សារៀប ឆ.៥៧ KH 01200322 ["តែក្មេងៗពីរនាក់នោះ គេសម្លាប់ប្រៀបផ្សេង គេចាប់បោះពីលើប្រហោង ឲ្យធ្លាក់ចូលទៅក្នុងណ្ណង តែវាអត់ធ្លាក់ចូលក្នុងណ្ណង វាទើនៅលើប្រកៀបឈើ"]។ *សូមមើលផងដែរ* ឯកសារ D6.1.169 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស KH 00197904 ["នៅក្នុងណ្ណងណ្ងេន និងណ្ណងតែងខ្លួន ខ្ញុំឃើញសាកសពដែលមានសភាពស្វិតៗស្បែកជាប់ឆ្អឹងនៅឡើយ។ នៅតាមផ្លូវទៅណ្ណង ខ្ញុំក៏បានឃើញសាកក្មេងម្នាក់នៅជាប់នឹងវល្ជ៌លើដើមឈើ"]។ ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន សា KH 00242226-27។ ឯកសារ D6.1.163 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សួម KH 00197935។

ត្រូវបានគេចងទៅក្រោយ[1967]។ អ៊ីម អាន់ បានឃើញសាកសពស្ត្រីដែលគេរុំនឹងលួសបន្ទ្លា ហើយចងទៅនឹងដុំថ្ម ហើយសាកសពផ្សេងទៀតមានជាប់ខ្នោះជើង[1968]។

554. ការសម្លាប់នៅវត្តគិរីរម្យ មានសន្ទុះកាន់តែខ្លាំងមុនពេលវៀតណាមចូល[1969]។ ក្រោយការដួលរលំនៃកម្ពុជាប្រជាធិបតេយ្យ អ្នកភូមិបានរកឃើញសាកសពមនុស្សរាប់រយនាក់នៅវត្តគិរីរម្យ និង

[1967] ឯកសារ D6.1.163 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សួម KH 00197935-36 ["ខ្ញុំបានឃើញសពអ្នកទោសម្នាក់នៅអង្គុយផ្អែកជញ្ជាំងខាងជើងនៃល្អាងណ្ងោន ដៃនៅជាប់ចំណងស្ពាបសេក ហើយស្បែកនៅជាប់ឆ្អឹងនៅឡើយ។ ខ្ញុំមិនបានដឹងអំពីគុកអ្វីផ្សេងទៀតទេ"]។ ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន សា KH 00242226-27 ["ខ្ញុំបានឃើញឈាមជាច្រើនកកនៅល្អាងណ្ងោន។ ខ្ញុំបានឃើញសាកសពទាំងអស់មានចំណងជាប់នៅនឹងដៃ"]។ ឯកសារ D6.1.169 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស KH 00197903។ ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* KH 00233385-86។

[1968] ឯកសារ D6.1.165 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម អាន់ KH 00197884 ["មានមនុស្សគ្រប់គ្នានៅក្នុងភូមិបានដឹងថា មានគេយកមនុស្សមកសម្លាប់នៅលើភ្នំសំពៅ គឺសម្លាប់នៅល្អាងនៃគិរីរម្យ។ [...] អាត្មាបានឃើញសាកសពមនុស្សនៅក្នុងល្អាង ខ្នោះដាក់ជើង សាកសពមនុស្សស្រីព្យួរកនឹងខ្សែលួសចងជាប់នឹងថ្ម និងបានឃើញខ្សែលួសចងមនុស្សផង"]។

[1969] ឯកសារ D6.1.116 កំណត់ហេតុស្តាប់ចម្លើយ ទេស ប៊ីញ KH 00221600 ["ឆ្នាំ១៩៧៩ ខ្ញុំបានដឹងដំណឹងថា អ្នកនៅចន្លោះក្តោងត្រូវបានគេសម្លាប់ចោល។ គេបាននិយាយថា អ្នកនៅចន្លោះក្តោងចំនួនប្រហែល ២០០នាក់ត្រូវបានក្រុមខ្មែរក្រហម នាំឡើងល្អាងណ្ងោននៅវត្តគិរីរម្យលើភ្នំសំពៅ រួចសម្លាប់ចោល មុនវៀតណាមចូលដល់ភ្នំសំពៅ ប្រហែល ២ ឬ ៣ថ្ងៃ ប៉ុណ្ណោះ"]។ ឯកសារ D118/67 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ហ្ស ឆ.៤១-៤២ KH 00920203 ["ស៖ តើលោកដឹងទេ ក្នុងឆ្នាំណាដែលការកាប់សម្លាប់ខ្លាំងក្លាជាងគេ? ឆ.៤១៖ ដែលសម្លាប់ខ្លាំងជាងគេគឺក្នុងឆ្នាំចុងក្រោយ ឧទាហរណ៍ បើខ្ញុំរត់ចូលព្រៃ គេនឹងចាប់សម្លាប់ទាំងគ្រួសារតែម្តង។ ស៖ តើឆ្នាំចុងក្រោយដែលលោកនិយាយនោះ គឺក្នុងឆ្នាំដែលនិរតីចូលមក ឬក៏មិនទាន់មកទេ? ឆ.៤២៖ គឺក្រោយពេលដែលពួកនិរតីចូលមកហើយ គឺនៅជិតចុងរបប។ កាលពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ គេមិនដែលយកមនុស្សទៅសម្លាប់នៅលើវត្តគិរីរម្យទេ គឺគេយកទៅសម្លាប់នៅចន្លោះក្តោង"]។ ឯកសារ D219/36 កំណត់ហេតុស្តាប់ចម្លើយ ឈួម សារ៉ឿន ឆ.៣៥ KH 01032097 ["នៅក្រោយឆ្នាំ១៩៧៩ [...] ខ្ញុំបានឃើញឆ្អឹងខ្ចោចនៅពាសពេញក្នុងល្អាងនោះ។ [...] នៅពេលដែលរបបខ្មែរក្រហមជិតដួលរលំ ពួកខ្មែរក្រហមបានរត់គេចខ្លួន នៅពេលនោះពួកខ្មែរក្រហមបានបង្ខំប្រជាជនឲ្យទៅជាមួយផងដែរ។ នៅពេលនោះ មានប្រជាជនមួយចំនួនបានបដិសេធមិនព្រមទៅជាមួយពួកខ្មែរក្រហម ដូច្នេះអ្នកទាំងនោះ ត្រូវបានពួកខ្មែរក្រហមសម្លាប់នៅនឹងកន្លែង។ តាមខ្ញុំស្មាន គឺមានមនុស្សរាប់ពាន់នាក់ ត្រូវបានគេបាញ់សម្លាប់ចោល"]។ ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ៉ើម សាត KH 00212421-22។ ឯកសារ D1.3.27.7 របាយការណ៍វិភាគរបស់ DC-Cam ស្តីពី "ការធ្វើផែនទីវាលពិឃាតនៅកម្ពុជា ១៩៩៧៖ ខេត្តបាត់ដំបង" KH 00184647-48។ *សូមមើលផងដែរ* ឯកសារ D219/700 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ អ៊ុំ ឈួន KH 01303256-57។

ណ្ណាងនៅកែ្ស្ករនោះ[1970]។ សាកសពភាគច្រើនមិនទាន់រលួយទេ ហើយនៅមានខោអាវជាប់នឹងខ្លួនផង[1971]។ សាក្សីនានាបានឲ្យដឹងថា គ្មានអ្នកទោសនៅរស់ឡើយនៅវត្តគិរីរម្យ[1972]។

ការធ្វើទុក្ខបុកម្នេញ

555. ការធ្វើទុក្ខបុកម្នេញ ត្រូវបានប្រព្រឹត្តពាសពេញក្នុងឧក្រិដ្ឋកម្មទាំងប៉ុន្មាន ដូចបានរៀបរាប់ខាងលើ ប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ ក្រុមគ្រួសាររបស់ពួកគេ និងអ្នកនៅក្រោមបង្គាប់ នៅវត្តគិរីរម្យ។ ក្រុមនេះត្រូវបានកំណត់គោលដៅចំ១ ដោយសារតែសមាជិកភាពពិតប្រាកដ ឬ តាមការសន្មតរបស់ពួកគេចំពោះក្រុមនយោបាយ។

[1970] ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប ែ ន លឿត KH 00242231 ["នៅឆ្នាំ១៩៨២ [...]។ នៅណ្ណាងទាំងបី គឺណ្ណាងណ្ងោន ណ្ណាងតែងខ្លួន និងណ្ណាងមួយទៀត មានបន្សល់ទ្ធវសាកសពជាច្រើនរយនាក់ដែលមានខោអាវជាប់ខ្លួននៅឡើយ។ សាកសពមិនទាន់រលួយទេ ហើយមានក្លិនស្អុយជាខ្លាំង"]។ ឯកសារ D219/784 កំណត់ហេតុស្តាប់ចម្លើយ ម ុ ំ ក្រាត ឆ.៦០ KH 01300427 ["ស៖ តើក្បាលខ្ទោចត្រូវបានរាប់ជាចំនួនឬទេ? ឆ.៦០៖ ពេលនោះខ្ញុំមិនបានរាប់ទេ គ្រាន់តែបានស្ទាន ប្រហាក់ប្រហែ។ សពនៅក្នុងណ្ណាណ្ងោននេះ[ណ្ណាងណ្ងោន និងណ្ណាងគិរីរម្យ] មិនតិចជាង៣០០ទេ ព្រោះវានៅគរលើគ្នា ហើយវាអ ុ ំ ក្លិនស្អុយ ដូច្នេះពិបាកទៅរាប់"]។ ឯកសារ D6.1.163 កំណត់ហេតុស្តាប់ចម្លើយ អ ុ ំ សួម KH 00197935។ ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ ុ ន សា KH 00242226-27។ ឯកសារ D6.1.165 កំណត់ហេតុស្តាប់ចម្លើយ អ ុ ំ ម អាន់ KH 00197884។ ឯកសារ D118/67 កំណត់ហេតុស្តាប់ចម្លើយ ញ ឹ ម ហ ូ ឆ.៤០ KH 00920203 ["កាលពីក្នុងឆ្នាំ១៩៧៩ ខ្ញុំបានឃើញក្នុងណ្ណាងគិរីរម្យនៅលើភ្នំ គឺមានសាកសពពេញដល់លើតែម្តង។ ខ្ញុំបានឃើញមានកន្លែងបង្ហូរឈាមអ្នកទោសនៅក្នុងវិហារគិរីរម្យផងដែរ"]។ ឯកសារ D6.1.115 កំណត់ហេតុស្តាប់ចម្លើយ ជ ុ ច ពន្ធក KH 00221547 ["នៅឆ្នាំ១៩៧៩ ខ្ញុំបានឡើងនៅលើភ្នំសំពៅ ខ្ញុំបានឃើញសាកសពមនុស្សជាច្រើន [...]។ ខ្ញុំក៏បានឃើញសាកសពកូនក្មេងទើរលើដើមឈើ លើភ្នំសំពៅក្នុងវត្តគិរីរម្យដែរ"]។

[1971] ឯកសារ D6.1.163 កំណត់ហេតុស្តាប់ចម្លើយ អ ុ ំ សួម KH 00197935។ ឯកសារ D6.1.128 កំណត់ហេតុស្តាប់ចម្លើយ ប ែ ន លឿត KH 00242231។ ឯកសារ D6.1.167 កំណត់ហេតុស្តាប់ចម្លើយ ប ែ ន លាប KH 00197923-24។

[1972] ឯកសារ D6.1.186 កំណត់ហេតុស្តាប់ចម្លើយ ញ ៉ ែ ម សាត KH 00212421-22 ["ស៖ តើលោកមានបានដឹងថា មានអ្នកនៅសល់ពីស្លាប់ពីវត្តគិរីរម្យ ឬមន្ទីរនគរបាល ដែរឬទេ? ឆ៖ ខ្ញុំគិតថា ពុំមានអ្នកនៅសល់ពីស្លាប់ពីវត្តគិរីរម្យទេ ពីព្រោះ ៥-៦ថ្ងៃមុនយួនចូលមកដល់ ខ្ញុំបានឃើញអ្នកយាមពីរនាក់ ចុះមកពីវត្តគិរីរម្យ ក្នុងនោះម្នាក់បានចូលមកផ្ទះខ្ញុំ លាងដៃដែលប្រឡាក់ឈាម។ ខ្ញុំគិតថា អ្នកពីនាក់នេះ ទើបតែបានសម្លាប់មនុស្សមុននឹងចុះមកពីវត្តគិរីរម្យ"]។ ឯកសារ D6.1.166 កំណត់ហេតុស្តាប់ចម្លើយ អ ុ ិ ន ជឿន KH 00197888 ["[ខ្ញុំ]មិនដែលបានឃើញអ្នកទោសណាម្នាក់បានរួចរស់ជីវិតពីមន្ទីរឃុំឃាំងចន្លោះក្តោង និងវត្តគិរីរម្យនោះទេ"]។ ឯកសារ D118/67 កំណត់ហេតុស្តាប់ចម្លើយ ញ ឹ ម ហ ូ ឆ.៣៩ KH 00920203 ["ចំពោះអ្នកទោសនៅកន្លែងទាំងពីរនោះ ដូចជាគ្មានរណានៅរស់ទេ"] ឆ.៤៣ KH 00920203 ["អ្នកទោសណាដែលគេបញ្ជូនទៅលើវត្តគិរីរម្យ គឺមិនឃើញមានអ្នកណាមកវិញទេ"]។ ឯកសារ D6.1.362 កំណត់ហេតុស្តាប់ចម្លើយ ប ុ ល សឹន KH 00304360។ ឯកសារ D6.1.132 កំណត់ហេតុស្តាប់ចម្លើយ ហ ុ ន សា KH 00242226-27។ ឯកសារ D219/697 កំណត់ហេតុស្តាប់ចម្លើយ ណ ូ ក ផ្ងៀត ឆ.៤៨ KH 01210559។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

556. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខវត្តគិរីរម្យ[1973]ៃ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[1974] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងកម្ជាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ ព្រមទាំងអ្នកនៅក្រោមបង្គាប់ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។

៤. តំបន់ ៤

ក. ឃុំវ៉ាំងកេសី

i. សេចក្ដីផ្ដើម

557. តំបន់ភូមិសាស្ត្រដែលបច្ចុប្បន្នត្រូវបានស្គាល់ថាជាឃុំវ៉ាំងកេសី ស្ថិតនៅក្នុងស្រុកដូនទ្រី ៤២ តំបន់ ៤ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ នៅពេលដាក់បន្ថែមអំពើនៃសហឧក្រិដ្ឋកម្មរួម ដែលក្នុងនោះ **យ៉ីម ទិត្យ** ជាថ្នាក់ដឹកនាំម្នាក់ កម្ជាភិបាលភូមិភាគនិរតី បានបើកយុទ្ធនាការឧក្រិដ្ឋកម្មនៅក្នុងទីតាំងនេះពីចុងឆ្នាំ១៩៧៧។ កម្ជាភិបាលភូមិភាគនិរតីបានចូលជំនួសប្រធានឃុំ/សហការណ៍មូលដ្ឋាន ក្នុងនោះរួមទាំង តាកុន ដែលជាលេខា ឃុំវ៉ាំងកេសី និងត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរ ស-២១ នៅថ្ងៃទី ១ ខែកុម្ភៈ ឆ្នាំ១៩៧៨។ ពួកគេបានរៀបចំឲ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំ និងចូលរួមពិធីរៀបការជាច្រើនគូក្នុងពេលតែមួយ ដែលមានរហូតដល់ ៨០ គូស្វាមីភរិយា នៅតាមទីតាំងច្រើន ដូចជានៅ

[1973] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីទាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្ម ដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនទាន់បានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះតាម រយៈ៖ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៩-៦០, ១១៨ កំណត់សំគាល់ជើងទំព័រ ២២ពា។

[1974] ស.ព.អ សន្និដ្ឋានថាធាតុផ្សំនៃភាពរង្គាលចំពោះឧក្រិដ្ឋកម្មសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងសម្រាប់តែមន្ទីរសន្តិសុខវត្តគិរីរម្យតែឯងប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលជាលក្ខខណ្ឌតម្រូវសម្រាប់បញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងមន្ទីរសន្តិសុខវត្តគិរីរម្យនេះផង ត្រូវលើកយកមកពិចារណាបញ្ចូលគ្នា។ ទីតាំងទាំងអស់ គឺជាផ្នែកនៃប្រព័ន្ធរៀបចំមួយក្នុងការអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្ទាំង ហើយការសម្លាប់នៅតាមទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងនេះ ត្រូវបានជួយសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចគ្នារបស់ យ៉ីម ទិត្យ។

វត្តវ៉ាងកេសី។ ពួកគេក៏បានបង្ហាញពីអារម្មណ៍ស្អប់ខ្ពើមប្រឆាំងនឹងជនជាតិភាគតិចវៀតណាម និងដោយមានជំនួយពីកងយោធា បានបញ្ជា និងសម្លាប់ក្រៅច្បាប់ជាច្រើនដងនូវកម្មាភិបាល និងប្រជាជនស៊ីវិល ដោយតម្រង់ទិសដៅជាពិសេស ទៅលើខ្មែរក្រោម អតីតទាហាន លន់ នល់ និងកម្មភិបាលភូមិភាគពាយ័ព្យ។

558. ស.ច.ស.អ បានចោទ **យ៉ីម ទិត្យ** ពីបទឧក្រិដ្ឋកម្មនានាដូចខាងក្រោមទាក់ទងនឹងឃុំវ៉ាងកេសី៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍លើខ្មែរក្រោម អំពើអនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ) និងឧក្រិដ្ឋកម្មនៃមនុស្សឃាត ដោយគិតទុកជាមុន អនុលោមតាមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[1975]។

ii. ប្រតិបត្តិការ និងទីតាំង

559. ចាប់ពីចុងឆ្នាំ១៩៧៧ កម្មាភិបាលភូមិនិរតីមានតួនាទីយ៉ាងសំខាន់ក្នុងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ភូមិសាស្ត្រនេះដែលបច្ចុប្បន្នជាឃុំវ៉ាងកេសី[1976]។ ពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ ដល់ពេលចុងបញ្ចប់

[1975] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ EN 01426069, 75, 78 ។

[1976] ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៨៦ KH 01032175 [កម្មាភិបាលនិរតី "បានមកដល់នៅចុងឆ្នាំ១៩៧៧ ជិតចូលឆ្នាំ១៩៧៨។"]។ ឯកសារ D219/830 កំណត់ហេតុស្តាប់ចម្លើយ សេង រើត ឆ.៣៤-៣៥ KH 01327984 ["នៅខែតុលា ឆ្នាំ១៩៧៧ [...] នៅស្វាយជាតិ [...] ពួកនិរតីមកកាន់កាប់"]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ាញ រ៉ណ្ណា ឆ.៥៩ ឆ.៦២ KH 01328005-01328006 [កម្មាភិបាលភូមិភាគនិរតីបានមកដល់ភូមិបឹងវ៉ែង ក្នុងខែធ្នូ ឆ្នាំ១៩៧៧]។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៣ KH 01097670។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.១ ឆ.៩-១០ KH 01085170 KH 01085172 ["នៅភូមិបឹងវ៉ែង [...] យាយចាន់ គឺជាកម្មាភិបាលនិរតី [...] មកដល់នៅខែមករា ឆ្នាំ១៩៧៨។"]។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.៧ KH 01096583 ["នៅភូមិវត្តកណ្តាល [...] ពួកនិរតីចូលមកនៅរដូវច្រូតកាត់ហើយ [...] ប្រហែលខែកុម្ភៈ ឬខែមីនា ឆ្នាំ១៩៧៨។"]។ ឯកសារ D219/137 កំណត់ហេតុស្តាប់ចម្លើយ ឃៀម សោន ឆ.៤៩ ឆ.៥១ KH 01053280 [កម្មាភិបាល "ត្រូវបានជំនួសដោយ យាយចាន់ និងតាឡ៊ីក [...] នៅពាក់កណ្តាលឆ្នាំ១៩៧៨។"]។ ឯកសារ D219/779 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.៤៦-៤៧ KH 01299977-01299978។ ឯកសារ D219/866 កំណត់ហេតុស្តាប់ចម្លើយ ម្ហ៊ីយ ម៉ុន ឆ.៤៦ KH 01347410 [តាឡ៊ីក និងយាយចាន់ បានមកដល់ "ជិតចប់ដែរហើយ។ គាត់មកបានប្រហែលប៉ុន្មានខែទេ បានយួនចូលមក"]។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត ឆ.៤៥ ឆ.៤៨ KH 01403887-0143888 [កម្មាភិបាលនិរតីបានមកដល់ "ប្រហែលខែធ្នូ ឆ្នាំ១៩៧៨។ [...] [វៀតណាមចូលនៅ]

នៃរបបកម្ពុជាប្រជាធិបតេយ្យ កម្មាភិបាលទាំងនោះបានគ្រប់គ្រងតំបន់នេះ[1977]។ ភូមិទាំងឡាយនៅក្នុងតំបន់នេះមានភូមិវាំងកេសីដែលមានវត្តវាំងកេសី វាំងក្រោល ព្រៃស្វាយ ស្វាយជាតិ បឹងវែង វត្តកណ្តាលដែលមានអាងទឹកកំពង់គោ ទួលស្ពួល បឹងវែង និងដំណាក់ដង្កោ[1978]។

ប្រហែល១០ថ្ងៃ ក្រោយ [កម្មាភិបាលនិរតី] បានមកដល់។ រៀតណាមចូលនៅខែ១ ថ្ងៃទី១៥ ហ្នឹងបានរៀតណាមចូលមកដល់បាត់ដំបង។"]។

[1977] សុំ ភុន (សំ ភុន) កម្មាភិបាលពាយ័ព្យ គ្រប់គ្រងវាំងកេសី រហូតដល់ពេលដែលគេបញ្ជូនគាត់ទៅ ស-២១ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ ហើយឡើងជំនួសដោយយាយចាន់ និងតាឡឹក។ *សូមមើល* ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ រៀបចំឡើងដោយ ក.ស.ច.ស, លេខរៀង៩៦៤៦ EN 01222726 [សុំ ភុន (សំ ភុន) ប្រធានវាំងកេសី តំបន់៤ នាំចូលថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨]។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.២៧ ឆ.៣៩ KH 01403883 KH 01403886 ។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៣ KH 01117259។ *សូមមើលផងដែរ* ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.៨ KH 01097697 ["កម្មាភិបាលនិរតី [...] តាឡឹក និងយាយចាន់ ឡើងធ្វើជាមេឃុំ៦០ [...] មិនបានមួយឆ្នាំផង រៀតណាមក៏ចូលមកដល់។"] (*កំណត់សម្គាល់* ឃុំ៦០ ក្រោយមកបានក្លាយជាផ្នែករបស់ឃុំវាំងកេសី*សូមមើល* ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២២ KH 01117259។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១១ KH 01117335។ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លីម សាលឿន ឆ.៦ KH 01213310។)។

[1978] <u>វាំងកេសី</u>៖ *សូមមើលខាងលើ* ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ កឹ សឹង ឆ.១២៥ KH 01024901 ["សព្វថ្ងៃ [...] ភូមិវាំងកេសី ឃុំវាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង។"]។ <u>វាំងក្រោល</u>៖ *សូមមើលខាងលើ* ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង KH 01080854 ["បច្ចុប្បន្ន [...] ភូមិវាំងក្រោល ឃុំវាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង"] ។ *សូមមើលផ្ទុយ* ឯកសារ D219/339 កំណត់ហេតុស្តាប់ចម្លើយ ប៊ុម សេវ ឆ.១ KH 01102846។ <u>ព្រៃស្វាយ</u>៖ *សូមមើលខាងលើ* ឯកសារ D219/416 កំណត់ហេតុស្តាប់ចម្លើយ លៀស គង់ ឆ.២២ KH 01117358 ["ភូមិព្រៃស្វាយ [...] ក្នុងឃុំវាំងកេសី។"]។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ វាស្ថិតនៅក្នុងឃុំវាំងកេសី ស្រុកសង្កែ *សូមមើល* ឯកសារ D131/2.1.87 បញ្ជីឈ្មោះកម្មាភិបាល និងប្រជាជន នៅស្រុកសង្កែ តំបន់១ ខែកុម្ភៈ ឆ្នាំ១៩៧៨ KH 00214638។ <u>ស្វាយជាតិ</u>៖ *សូមមើលខាងលើ* ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត យឿន ឆ.២២ KH 01129774 ["បច្ចុប្បន្នភូមិស្វាយជាតិ ស្ថិតនៅក្នុងឃុំវាំងកសី ស្រុកសង្កែ ខេត្តបាត់ដំបង។"]។ អំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិស្វាយជាតិ ស្ថិតនៅក្នុងសហករណ៍កំពង់គោ ស្រុកសង្កែ តំបន់១។ *សូមមើល* ឯកសារ D131/2.1.87 បញ្ជីឈ្មោះកម្មាភិបាល និងប្រជាជន នៅស្រុកសង្កែ តំបន់១ ខែកុម្ភៈ ឆ្នាំ១៩៧៨, លេខរៀង១០២ KH 00214646។ ឯកសារ D219/638 កំណត់ហេតុស្តាប់ចម្លើយ ខ្ញែត ម៉ៅ ឆ.២៣ KH 01186814។ <u>វត្តកណ្តាល</u>៖ *សូមមើលខាងលើ* ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត យឿន ឆ.២៥ KH 01129775 ["បច្ចុប្បន្នរស់នៅក្នុងភូមិវត្តកណ្តាល ឃុំវាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង។"]។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត យឿន ឆ.៣ KH 01129716 ["នៅភូមិវត្តកណ្តាល [...] គឺ [...] អាងកំពង់គោ។"]។ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិវត្តកណ្តាល គឺស្ថិតនៅក្នុងសហករណ៍កំពង់គោ ឃុំ៦០ ដែលក្រោយមកក្លាយជាផ្នែកនៃឃុំវាំងកេសី សូមមើលឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.២-៣ KH 01117188។ ឯកសារ D219/306 កំណត់ហេតុស្តាប់

ចម្លើយ សិន បាន ឆ.៧ KH 01096583 ។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឈឿន ឆ.១២ KH 01129771 ។ ឯកសារ D219/420 កំណត់ហេតុនៃកិច្ចស្ទើបសួរ គង់ ជ្ជ KH 01303426 ។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២២ KH 01117259 ។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១១ KH 01117335 ។ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.៦ KH 01213310 ។ ទ្ធលស្ទ្ធល៖ សូមមើលឧទាហរណ៍ ឯកសារ D219/409 កំណត់ហេតុស្តាប់ចម្លើយ អាង ស ឆ.៦ KH 01117267 [“បច្ចុប្បន្ន [...] ភូមិទ្ធលស្ទ្ធល ឃុំរ៉ាំងកេសី ស្រុកសង្កែ ខេត្ត បាត់ដំបង ។”] ។ ប៊ីងវ៉ែង៖ សូមមើលឧទាហរណ៍ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត KH 01085168 [“២០១៥ [...] នៅភូមិបីងវ៉ែង ឃុំរ៉ាំងកេសី ស្រុកសង្កែ ខេត្តបាត់ដំបង”] ។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ឆ៊ីន ឈួយ ឆ.៣ KH 01149398 ។ ដំណាក់ដង្កោ៖ សូមមើលឧទាហរណ៍ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៧១ KH 01032227 [“សព្វថ្ងៃរស់នៅភូមិដំណាក់ដង្កោ ឃុំរ៉ាំងកេសី ។”] ។

560. ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ភូមិទាំងនេះស្ថិតនៅតាមឃុំខុសៗគ្នា ដែលភូមិខ្លះត្រូវបានដាក់បញ្ចូលគ្នាបន្ទាប់ពីការមកដល់នៃកម្មាភិបាលភូមិភាគនិរតី[1979]។ ភូមិទាំងនេះមានទីតាំងស្ថិតក្នុងស្រុកដូនទ្រី ហៅស្រុក៤២ តំបន់ ៤[1980]។

[1979] សូមមើលឧទាហរណ៍ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប ង់ ថៃ ឆ.៤ KH 01097696 [នៅឃុំ៦០ "ខ្ញុំមិនច្បាស់ដែរទេ គឺអាចមាន [...] ភូមិរាំងក្រោល និងរាំងកេសី រីឯភូមិដំណាក់ដង្កោ និងបឹងវែងនៅខាងជើងផ្លូវ ដូច្នេះស្ថិតនៅក្នុងឃុំ៥។"] ។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៣ KH 01097670 ["ឃុំ៥ គឺគ្របដណ្ដប់ភូមិនានាដែលនៅខាងជើងផ្ទះ ដែលឆ្ពោះទៅកាន់សាលាឃុំរាំងកេសីបច្ចុប្បន្ន។ ចំពោះភូមិឋានដែលស្ថិតនៅខាងត្បូងផ្លូវនេះ គឺស្ថិតនៅក្នុងឃុំ៦០។ [...] ភូមិដែលស្ថិតនៅខាងជើងផ្ទះ និងភូមិនានាដែលស្ថិតនៅខាងត្បូងផ្ទះ មិនត្រូវបានអនុញ្ញាតឲ្យឆ្លងទៅលេងគ្នាបានទេ។ [...] ក្រោយពីកម្មាភិបាលនិរតីចូលមកដល់ គេហាក់ដូចជាបញ្ចូលកន្លែងនេះឲ្យទៅជាកន្លែងតែមួយ ហើយប្រជាជនអាចឆ្លងទៅឆ្លងមករកគ្នាបាន។"] (សូមមើលផងដែរ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៨១ KH 01403896)។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២២ KH 01117259 ["ក្រោយកម្មាភិបាលនិរតីមកដល់ឃុំ៦០ និងឃុំ៤០ ត្រូវបានគេបញ្ចូលគ្នាទៅជាឃុំមួយហៅឈ្មោះថា ឃុំរាំងកេសី។"]។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១១ KH 01117335។ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.៦ KH 01213310។ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប ង់ ថៃ ឆ.២២ KH 01097701 ។ កំណត់សម្គាល់ សហករណ៍កំពង់គោ ស្ថិតនៅក្នុងឃុំ៦០ ហើយរួមទាំងភូមិវត្តកណ្ដាល និងរាំងក្រោល។ សូមមើល ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហៀង សំបូរ ឆ.២-៣ KH 01117188។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.៧ KH 01096583 ។ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.១២ KH 01129771 ។ ឯកសារ D219/420 កំណត់ហេតុនៃកិច្ចស្ទើបសួរ គង់ ជ្ជ KH 01303426 ។ សូមមើលផ្ទុយ ឯកសារ D219/499 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ញ៉ើ ឆ.១ ឆ.១៤ KH 01141584-01141586 ["ឃុំ៤, [...] មានភូមិរាំងកេសី, រាំងក្រោល"]។ ឯកសារ D219/310 កំណត់ហេតុស្តាប់ចម្លើយ វន្ត សាមុត ឆ.១២ KH 01097681 ["ស៖ តើលោកដឹងថា ឃុំរាំងកេសី មានភូមិអ្វីខ្លះដែរឬទេ នៅក្នុងសម័យខ្មែរក្រហម? ឆ.១២៖ តាមពិត ខ្ញុំមិនដែលរស់នៅទីនោះទេ ហើយក៏មិនមានឈ្មោះឃុំនេះដែរ។ នៅក្នុងសម័យខ្មែរក្រហម គឺគេបង្កើតនៅក្រោយសម័យខ្មែរក្រហម។"]។

[1980] <u>ស្រុក៤២ តំបន់៤</u>៖ ឯកសារ D6.1.557 សារទូលេខកម្ពុជាប្រជាធិបតេយ្យផ្ញើពីចាន់ ជ្ជន ឌុច ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ១៩៧៧, លេខរៀង៤០ KH 00052663 ["សហករណ៍ព្រៃស្វាយ ស្រុក៤២ តំបន់៤"]។ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.៦ KH 01213310 ["ឃុំរាំងកេសី [...] ស្រុក៤២ តំបន់៤។"]។ ឯកសារ D219/895 កំណត់ហេតុស្តាប់ចម្លើយ ឃឹម លំទោន ឆ.៣១-៣២ KH 01379574 ["ភូមិដំណាក់ដង្កោ ភូមិរាំងកេសី ភូមិរាំងក្រោល [...] ស្រុក៤២។ "]។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៥ KH 01085176 ["វត្តរាំងកេសីស្ថិតនៅក្នុងស្រុក៤២ តំបន់៤។"]។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៣១ KH 01403884 ["ស៖ តើស្រុក៤២ គ្របដណ្ដប់ឃុំអ្វីខ្លះ? ឆ.៣១ ៖ [...] ឃុំរាំងកេសី។"]។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.៧ KH 01121678 ["ស្រុកដូនទ្រី ហៅថា 'ស្រុក៤២'។"]។ ឯកសារ D6.1.620 កិច្ចសម្ភាសន៍ SOAS ជាមួយ រៀម ឌី KH 00789290 ["ស្រុក៤២ គឺមកពីស្រុកដូនទ្រី។"] ។ *សូមមើល ផ្ទុយ* ឯកសារ D219/499 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ញ៉ើ ឆ.១ KH 01141584 ["ភូមិរាំងកេសី [...] ស្រុក៤១ តំបន់៤។"]។

iii. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទង

561. ដើម្បីពង្រឹងការគ្រប់គ្រងជាអតិបរមា កម្មាភិបាលភូមិភាគនិរតី ក្នុងនោះរួមមាន យាយចាន់ និងប្តី របស់គាត់ តាឡឹក[1981] បានជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ នៅតាមគណៈឃុំ/សហករណ៍មួយចំនួន នៅក្នុងតំបន់ភូមិសាស្ត្រនេះ ដែលបច្ចុប្បន្ននេះហៅថាជាឃុំវាំងកេសី[1982]។ សាក្សីម្នាក់ដែល

[1981] *សូមមើលខ១ទាហរណ៍* ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១២៩ KH 01335567 ["យាយចាន់ [...] និង [...] ប្តី [...] ពួកហ្ម៊ីងនៅខេត្តតាកែវ។"]។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៨០-៨១ KH 01032175។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃ្យៀន ឆ.៣៨ KH 01129778។ ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ កឹ សឹង ឆ.៤០ KH 010248922។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.៩ ឆ.១១ KH 01085172-01085173។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.២៥ ឆ.៤៧ KH 014038882 KH 01403888។

[1982] <u>តាភុន កម្មាភិបាលពាយ័ព្យ</u>៖ សុំ ភុន (សំ ភុន) ដែលអនុរបស់គាត់ គឺនិន ទទួលខុសត្រូវសហករណ៍ រាំងកេសី និងរាំងក្រោល។ គាត់ត្រូវគេបញ្ជូនចូល ស-២១ និងត្រូវជំនួស ដោយយាយចាន់ និងតាឡឹក។ *សូមមើល* ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ រៀបចំឡើងដោយ ក.ស.ច.ស, លេខរៀង១៦៤៦ EN 01222726។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.២៧ ឆ.៣៩ KH 01403883 KH 01403886។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២២-២៣ KH 01117259 (*កំណត់សម្គាល់* ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៨ KH 01085176)។ ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង ឆ.២៧ ឆ.៣៤ KH 01080860-01080861។ ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ កឹ សឹង ឆ.៤០ KH 01024892។ ឯកសារ D219/866 កំណត់ហេតុស្តាប់ចម្លើយ ឡើយ ម៉ុន ឆ.១២ KH 01347405។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក ម្ឿន ឆ.៦២ ឆ.៦៦ KH 01327972។ <u>កម្មាភិបាលពាយ័ព្យឈ្មោះ តាសួម</u>៖ តាសួម គ្រប់គ្រងឃុំ៦០ និងក្រោយមកត្រូវជំនួសដោយ តាភ៉ីង មុនពេលដែលយាយចាន់ និងតាឡឹក មកជំនួសតំណែងគាត់។ *សូមមើល* ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.៦-៨ KH 01097697 (*កំណត់សម្គាល់* ឯកសារ D219/779 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.៤៦ KH 01299977)។ ឯកសារ D219/375 កំណត់ហេតុស្តាប់នៃកិច្ចសើបសួរជាមួយ រាជ្យ សារ៉ន KH 01442894។ *សូមមើលផងដែរ* ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.៥ KH 01414384 ["តាឡឹក និងយាយចាន់ [...] ដេញពួកពាយ័ព្យ ហើយគេកាន់កាប់ខ្លួនគេ។"]។ ឯកសារ D219/137 កំណត់ហេតុស្តាប់ចម្លើយ ឃៀម សោន ឆ.៤៩ ឆ.៥២-៥៤ KH 01053280 [សាក្សីរស់នៅវត្តកំពង់គោ៖ "មានការផ្លាស់ប្តូរពីតាពោ និងតាឆន មកយាយចាន់ និងតាឡឹក [...] នៅផ្នាក់សហករណ៍។"]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២២ KH 01117259 ["ក្រោយ [...] ឃុំ៦០ និងឃុំ៤០ ត្រូវបានគេបញ្ចូលគ្នា [...], តាឡឹក និងយាយចាន់ ជាអ្នកគ្រប់គ្រង។ "]។ ចំពោះភូមិស្វាយជាតិ *សូមមើល* ឯកសារ D219/638 កំណត់ហេតុស្តាប់ចម្លើយ ខ្ម្ញុត ម៉ៅ ឆ.២៩ KH 01186815 ["ពេលនិរតីមក អ្នកគ្រប់គ្រងឃុំស្វាយជាតិ គឺតាមាស។"]។ ឯកសារ D219/830 កំណត់ហេតុស្តាប់ចម្លើយ សេង រើត ឆ.៣៥-៣៦ KH 01327984។ ឯកសារ D219/310 កំណត់ហេតុស្តាប់ចម្លើយ វ៉ន្ត សាមុត ឆ.៦ KH 01097679។ ចំពោះសហករណ៍កំពង់គោ *សូមមើល* ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៣២ KH 01151001 [នៅសហករណ៍កំពង់គោ កម្មាភិបាលពាយ័ព្យ តារ៉យ និងផន ត្រូវជំនួសដោយកម្មាភិបាលនិរតី ប្រធានឈ្មោះ តាញ៉ន។]។ ឯកសារ D119/109

បានចូលរួមប្រជុំមួយដែលនៅពេលនោះ យាយចាន់ និង តាឡឹក បានប្រកាសពីការដាក់បញ្ចូលគ្នានៃឃុំមួយចំនួនដែលក្រោយមកស្ថិតក្រោមការគ្រប់គ្រងរបស់កម្មាភិបាលទាំងនេះ[1983]។ សាក្សីម្នាក់ទៀតដែលបានរស់នៅក្នុងតំបន់នេះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ បានបញ្ជាក់ថា យាយចាន់ និង តាឡឹក គឺជា "កម្មាភិបាលជាន់ខ្ពស់" ដែលបាន "គ្រប់គ្រង" សហករណ៍ជាច្រើន ហើយអាស្រ័យហេតុនេះ ពួកគេ "អាចមានមុខតំណែងស្នើនឹងប្រធានឃុំ"[1984] ។

កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឡូវ អ.ពា៩ អ.៦៧ KH 00980133 KH 00980137 [សាក្សីរស់នៅក្នុងភូមិវត្តកណ្តាលហើយ "តាញ៉ន (ឌិរតី) គឺជាប្រធានសហករណ៍។"]។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន អ.១៩ KH 01129773 ។

[1983] D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត អ.២៣-២៤ KH 01117259 ["ប្រជុំធំមួយនៅក្នុងវត្តរ៉ាំងកេសី ដឹកនាំដោយតាឡឹក និងយាយចាន់ ហើយមានប្រជាជនរាប់រយនាក់មកពីតាមភូមិនានាក្នុងឃុំ ៤០ និងឃុំ ៦០" អំឡុងពេលនោះ "ពួកគេប្រជុំ ហើយប្រាប់ថា ឃុំទាំងពីរត្រូវបានគេបញ្ចូលគ្នា។"]។ *សូមមើលផងដែរ* ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា អ.៥៧ KH 01403890 ។

[1984] ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ អ.៧ អ.១៩ KH 01414385-01414386 ["យាយចាន់ និងតាឡឹក [...] ធំជាងគេនៅក្នុងឃុំ។ [...] គេជាគណ:សហករណ៍ [...]។ គេគ្រប់គ្រងទាំងអស់ បើសព្វថ្ងៃបែបគេហៅថា គណ:ឃុំមើលទៅ។"]។ *សូមមើលផងដែរ* ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត អ.៩ KH 01085172 ["យាយចាន់ គ្រប់គ្រងសហករណ៍នានានៅតំបន់នេះ។"]។ ឯកសារ D219/779 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ អ.៤៦ KH 01299977 ។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា អ.៨០ KH 01403895 ។ ឯកសារ D219/413 កំណត់ហេតុស្តាប់ចម្លើយ សុខ ន្ធូ អ.១៧ KH 01117326 ។ ឯកសារ D219/499 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ញ៉ៅ អ.៥៥ KH 01141590 ។ ដោយសារទំហំតំបន់ប្រជាសាស្ត្រដែលយាយចាន់ និងតាឡឹក គ្រប់គ្រង និងការច្របាច់ប្រញ្ចូលគ្នានៃឃុំ និងសហករណ៍មួយចំនួន គឺមានសាក្សីមួយចំនួនយល់ឃើញថា យាយចាន់ និងតាឡឹក កាន់តំណែងនៅក្នុងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា គឺខ្ពស់ជាងថ្នាក់ឃុំ។ *សូមមើល* ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង អ.៣៤ KH 01080861 ["តាឡឹក និងយាយចាន់ [...] គ្រប់គ្រងខេត្តទាំងមូល មិនមែនគ្រប់គ្រងតែសហករណ៍ទេ។"]។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា អ.៨១ KH 01032175 ["តាឡឹក និងយាយចាន់ កាន់ក្តាប់តំបន់នេះ។"]។ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន អ.១១-១២ KH 01213311 [យាយចាន់ "មិនរាយការណ៍ទៅឲ្យអ្នកណាទៀតទេ គាត់មេធំនៅហ្នឹងហើយ ព្រោះគាត់ជាមេធំនៅទីនេះ។ [...] ចាន់ គាត់កាន់ ១ ចំហៀងស្រុក ៣ ៤ ឃុំតែម្តង។"]។ សាក្សីមួយចំនួន និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ បាននិយាយថា យាយចាន់ មានអំណាចជាងតាឡឹក *សូមមើល* ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា អ.៨១ KH 01032175 ។ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន អ.៧ KH 01213310 ។ ឯកសារ D219/413 កំណត់ហេតុស្តាប់ចម្លើយ សុខ ន្ធូ អ.១ KH 01117323 ។

562. ជាញឹកញាប់ក្នុងអំឡុងពេលនៃកិច្ចប្រជុំជាច្រើនដែលមាន យាយចាន់ និង តាឡឹកជាប្រធានអង្គប្រជុំ ពួកគេទាំងពីរបានចេញបញ្ជា និងសម្លាប់មនុស្សដោយផ្ទាល់ដោយមានជំនួយពីកងទ័ព[1985] បានតម្រង់ទិសដៅលើប្រជាជនដែលពួកគេយល់ថាជាខ្មាំង ក្នុងនោះរួមទាំងប្រជាជនវៀងណាម និង

[1985] <u>បញ្ជា</u>៖ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប ង់ ថៃ ឆ.១២ KH 01097698 ["នៅវត្តរ៉ាំងកេសី [...] ដោយមានបញ្ជាពីតាឡឹក និងយាយចាន់ កូនចៅរបស់គាត់បានបាញ់រះទៅលើអ្នកទាំងនោះ។ [...] ពួកគេបានយកមនុស្ស៧នាក់ ពីកន្លែងប្រជុំនោះយកទៅសម្លាប់។"]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.១០០ KH 01328010 ["ពួកយោធាហ្ម៊ីង [...] គឺតាឡឹក និងយាយចាន់ ជាអ្នកបញ្ជា។"]។ ឯកសារ D5/85 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សោយ យ៉ែន KH 00562463 ["ឆ្នាំ១៩៧៨, [...] តាឡឹក និងយាយចាន់ [...] បានបញ្ជាឲ្យកូនចៅរបស់គាត់ដើរចាប់ប្រជាពលរដ្ឋយកទៅសម្លាប់ចោល"]។ ឯកសារ D219/314 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ,ឆ.៧-៨ KH 01097721 ["នៅពាក់កណ្តាលឆ្នាំ១៩៧៨ [...] តាឡឹក និងយាយចាន់ [...] ចាប់ផ្តើមសម្លាប់រង្គាល"]។ <u>សម្លាប់ដោយផ្ទាល់</u>៖ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៥៣-៥៤ KH 01032225 ["នៅវត្តរ៉ាំងកេសី [...] តាឡឹក និងយាយចាន់ បានបាញ់រះប្រជាជនតែម្តង ហើយក៏បាញ់ត្រូវ តាស្ទើង ស្លាប់។ ពេលនោះមានជនរងគ្រោះដែលរបួសមានច្រើន។ [...] តាឡឹក និងយាយចាន់ ជាអ្នកប្រមូលយកទៅសម្លាប់ចោល។"]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.១០៨ KH 01328010។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.២៥ KH 01403882។ ឯកសារ D219/866 កំណត់ហេតុស្តាប់ចម្លើយ ឡើយ ម៉ុន ឆ.៤១ ឆ.៤៧-៤៨ KH 01347409-01347410 ["យាយចាន់ [...] សម្លាប់ផ្ទាល់ៗដៃ។ [...] ខ្ញុំធ្លាប់ឃើញគាត់ចងគេ [...] ហើយក៏នាំយកទៅបាញ់ចោលនៅរ៉ាំងទេះភ្លើង។"] ឆ.៤៩ KH 01347410 ["គាត់នឹងសម្លាប់អ្នកណាដែលគាត់សង្ស័យលួចម្ហូប។"]។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.៧ KH 01085172 ["យាយចាន់ គឺជាអ្នកដេញខ្ញុំ និងបាញ់ខ្ញុំ [...] នៅពេលជិតចប់របបខ្មែរក្រហម។"]។

ខ្មែរក្រោម[1986] បានរៀបចំ និងចូលរួមក្នុងអាពាហ៍ពិពាហ៍រួមដោយបង្ខំ[1987] និងបានឲ្យពលករ "ខិតខំបង្កើនផលិតផលឲ្យបានច្រើន" ដើម្បីបញ្ចៀស "ការយកទៅលត់ដំ"[1988]។ ពួកគេត្រូវរៀបរាប់ថាជាមនុស្ស "សាហាវបំផុត"[1989] និង "ពូកែខាងបោសសម្អាត"[1990]។

[1986] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.១៥ KH 01097673 ["ការប្រជុំដែលដឹកនាំដោយតាឡឹក និងយាយចាន់ ប៊ីលើក [...] នៅតាមការដ្ឋានហូបបាយរួម ក្នុងភូមិរាំងក្រោល [...] បាននិយាយ [...] ការស្អប់យួន ហើយប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីជីកបូសយួនឲ្យអស់។ កាលនោះ គេតែងនិយាយពាក្យថា នៅពេលកាប់ដើម ត្រូវជីកទាំងបូសឲ្យអស់។ ពួកគេចាត់ទុកពួកយើងដែលជាខ្មែរក្រោមថាជាយួនដែរ។ [...] ដូចជាការរេងអង្ករ ហើយសល់បានប៉ុណ្ណា គឺទុកប៉ុណ្ណឹង។ គេនិយាយបែបនេះ ចង់សំដៅទៅលើការបោសសម្អាត គឺទុកតែល្អៗទេ។"]។ ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង ឆ.៤២ KH 01080863 ["តាឡឹក និងយាយចាន់ [...] អ្នកដែលត្រូវគេចោទ [ប្រជាជន] ថាជាវៀតណាម ឬខ្មែរក្រោម នៅភូមិរបស់ខ្ញុំ [រាំងក្រោល]។ [...] ខ្ញុំដឹងថា ពួកគេសម្លាប់ប្រជាជនដែលត្រូវបានគេចោទថាជាវៀតណាម មានសំនៀងវៀតណាមនៅក្នុងភូមិដទៃទៀត"]។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន មឿន ឆ.៥៨ KH 01425209។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៥១ KH 01403889 [តាឡឹក និងយាយចាន់ "ប្រមូលជនជាតិ ដូចជា [...] វៀតណាមអ៊ីយកទៅបាត់។ កម្មាភិបាលពាយ័ព្យ វាប្រមូលយកទៅបាត់ៗ។"]។ ឯកសារ D219/314 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៧-៨ KH 01097721 [ដើមបណ្តឹងរដ្ឋប្បវេណី បានឃើញទាហាន លន់ នល់ ៣០ ឬ៤០នាក់ ត្រូវបានសម្លាប់នៅក្នុងភូមិរាំងក្រោល ដោយ "កម្មាភិបាលនិរតី ឈ្មោះ តាឡឹក និងយាយចាន់។"] (*កំណត់សម្គាល់* ជនរងគ្រោះក៏មានខ្មែរក្រោមផងដែរ *សូមមើល* ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១ KH 01213301) ឆ.១៣ KH 01092722-01097723 ["នៅក្នុងបរិវេណវត្តរាំងកេសី [...] តាឡឹក និងយាយចាន់ បានប្រកាសដល់អ្នកចូលរួមទាំងអស់ថា ប្តីខ្ញុំគឺជាខ្មាំង។ "]។ ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១៣៨-១៣៩ KH 01335568 [យាយចាន់ "និយាយថា ខ្មាំងហ្នឹង ពេលយើងធ្វើការមិនពេញដៃអ៊ីចឹង។"] (*កំណត់សម្គាល់* រឿងហ្នឹងកើតឡើងនៅរាំងកេសី *សូមមើល* ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.៧៦ KH 01352095)។ ឯកសារ D219/866 កំណត់ហេតុស្តាប់ចម្លើយ ឡើយ ម៉ុន ឆ.៤៧ KH 01347410 ។ ដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ យាយចាន់ និងតាឡឹក ក៏ជាប់ពាក់ព័ន្ធក្នុងការប៉ុនប៉ងបំពុលខ្ទ្រេក្រោម នៅពេលហូបនំបញ្ចុករួមនៅរោងបាយសហករណ៍ក្នុងភូមិរាំងក្រោល *សូមមើល* ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៥៧-៥៨ KH 01032225។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៥-៦ ឆ.៨ KH 01097670-01097671 ។ ឯកសារ D219/137 កំណត់ហេតុស្តាប់ចម្លើយ ឃៀម សោន ឆ.៥៧ KH 01053281។ ឯកសារ D219/311 កំណត់ហេតុស្តាប់ចម្លើយ ពែង សាន្ត ឆ.៧ KH 01097690។ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.១៤ KH 01097699 ។

[1987] ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.១៨-១៩ KH 01213312 ["គេប្រជុំប្រាប់យើង [...] បើយើងរៀបការម្តង១គូ គឺខាតពេលវេលាកម្មាភិបាលគេធ្វើការងារ។ [...] អ្នកដែលឡើងប្រកាសពីរឿងនេះគឺយាយចាន់ តាឡឹក។"] ។ ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.៧៤ ឆ.៩០ ឆ.៩៩ KH 01352095 KH 01352097 [យាយចាន់ រៀបចំ "ប្រជុំ [...] រៀបគ្រួសារ។ [...] គាត់ឲ្យប្រាប់ប្រជាជនរៀបគ្រួសារ។"]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.៧១-៧២ ឆ.៨១ KH 01328006-01328007 [តាឡឹក និងយាយចាន់ "ជាអ្នកផ្សំផ្គុំ" រៀបការឲ្យសាក្សីនៅវត្តរាំងកេ

563. យាយចាន់ និង តាឡឹក បានទទួលព័ត៌មានអំពីគូស្វាមីភរិយាដែលទទួលរងការបង្ខំឲ្យរៀបការ[1991] ហើយសាក្សីបាននិយាយថា គាត់បានធ្វើការសង្ខេបអំពីរបាយការណ៍កសិកម្មពីការដ្ឋានទានាដែល

សី។ "តាឡឹក និងយាយចាន់ហ្នឹងឯង [...] ទ្ធន្ធានអប់រំយើងថាចាប់ដៃគ្នា ប្តេជ្ញាមិនឲ្យលែងលះគ្នាទេ ឲ្យស្រឡាញ់គ្នារហូត។"]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៥ KH 01117259។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក មឿន ឆ.៦២ ឆ.៦៦ KH 01327972។ ឯកសារ D219/413 កំណត់ហេតុស្តាប់ចម្លើយ សុខ ន្ធូ ឆ.៧ KH 01117324 ។ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈេន ឆ.៥៨ ឆ.៦២ ឆ.៦៧ KH 01327961។ ឯកសារ D219/371 របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស KH 01310907។

[1988] ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.១០២-១០៣ KH 01328010 [តាឡឹក និងយាយចាន់ "គាត់ចុះមក [...] ប្រជុំធំអ៊ីចឹង។ ឲ្យយើងខិតខំបង្កបង្កើនផលឲ្យបានច្រើន [...] ហើយឲ្យយើងចេះសាមគ្គីគ្នា។"]។ ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១៣៧ KH 01335568 [យាយចាន់ "ប្រាប់យើងធ្វើការ តែអ្នកណាធ្វើការមិនល្អ ដឹងតែគេយកលត់ដំ គាត់ថាអ៊ីចឹង។"] (*កំណត់សម្គាល់* រឿងហ្នឹងកើតឡើងនៅរ៉ាងកេសី *សូមមើល* ឯកសារ ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.៧៦ KH 01352095)។ *សូមមើលផងដែរ* ឯកសារ D219/832 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.៥៤ KH 01328025។

[1989] ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៣៨ KH 01129778។ ឯកសារ D219/779 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.៤៦ KH 01299977។ ឯកសារ D219/832 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.៨១-៨២ KH 01328027។ ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.៣៤ KH 01352091។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.២៥ KH 01403882។ ឯកសារ D219/339 កំណត់ហេតុស្តាប់ចម្លើយ ប៊ុម សេរ ឆ.១៦ KH 01102850។ ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ កឹ សឹង ឆ.៤០ KH 01024892។ ឯកសារ D219/333 កំណត់ហេតុស្តាប់ចម្លើយ ទៀ រ៉ៀង ឆ.២៨ KH 01102770។ ឯកសារ D219/499 កំណត់ហេតុស្តាប់ចម្លើយ អ៊ិន ញ៉ើ ឆ.៥៥ KH 01141590។ ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង ឆ.២៩ KH 01080860។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.៥៣ KH 01096591។ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.៨ KH 01213310។ *សូមមើលផ្ទុយ* ឯកសារ D219/339 កំណត់ហេតុស្តាប់ចម្លើយ ប៊ុម សេរ ឆ.១៦ KH 01102850 ["តាឡឹក [...] តែងតែព្យាយាមឃាត់ប្រពន្ធមិនឲ្យធ្វើបាបប្រជាជន។"]។ ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១២៩ KH 01335567 [ប្តីយាយចាន់ សុភាព ហើយចិត្តល្អ"]។

[1990] ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៨០ KH 01032175។

[1991] ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក មឿន ឆ.៧៦ KH 01327974 ["តាឡឹក និងយាយចាន់ [...] នៅពេលយប់ គេដើរមកស្តាប់យកការណ៍ប្រជាជនអ៊ីម"]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.៨៨-៨៩ ឆ.១០០ KH 01328008 KH 01328010។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហ៊ៀង ឆ.១៥ KH 01117336។

គាត់ "បានដឹងច្បាស់ [...] ដែលបានធ្លាក់ដល់ដៃយាយចាន់" ដោយសាក្សីនេះជឿជាក់ថា របាយការណ៍ទាំងនោះក្រោយមកត្រូវបានប្រើប្រាស់នៅឯកិច្ចប្រជុំថ្នាក់តំបន់[1992]។

iv. ឧក្រិដ្ឋកម្ម

<u>ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល</u>

564. ដើមបណ្តឹងរដ្ឋប្បវេណីដែលជាខ្មែរក្រោមម្នាក់បានអះអាងថា "នៅពេលកម្មាភិបាលភូមិភាគនិរតីបានមកដល់ [...] [យើង] បានរស់នៅដោយការភ័យខ្លាចពីការកាប់សម្លាប់ជាប្រចាំ នៅគ្រប់ពេលទាំងអស់។ [...] យើងបានឃើញគេចាប់ខ្លួនមនុស្ស និងសម្លាប់ចោល"[1993] ។ សាក្សី សេក មុនថា បានរស់នៅក្នុងតំបន់នេះក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយបាននិយាយថា "កម្មាភិបាលភូមិភាគនិរតី [...] បានចាប់ច្រើនជាង សម្លាប់ច្រើនជាងពួកពាយ័ព្យ"[1994]។ ដើមបណ្តឹងរដ្ឋប្បវេណីដែលខ្មែរក្រោមម្នាក់ទៀតបានរំឭកពីព្រឹត្តិការណ៍មួយចំនួន ដែលនៅពេលនោះ

[1992] ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១៤ KH 01117336 ["ពួកឈ្លបជាអ្នកយករបាយការណ៍ពីការដ្ឋានផ្សេងៗរួមមាន រ៉ាងកេសី [...] មកឲ្យខ្ញុំបូកសរុប។ [...] របាយការណ៍ដែលខ្ញុំត្រូវសរសេរ គឺជាការបូកសរុបលទ្ធផលការងារទាំងអស់ នៅក្នុងការដ្ឋានការងារដែលខ្ញុំបានរៀបរាប់មុននេះ គឺតួលេខសរុបនៃចំនួនហិកតានៃសន្ទូង ពង្រោះ (ដំណាំ ពោត ដំឡូង...។ល។ និងស្រែដែលបានភ្ជួរ។ [...] លុះក្រោយពីការមកដល់របស់ពួកនិរតី ពិសេសក្នុងពេលយាយចាន់ គ្រប់គ្រងបានជួនកាលគេប្រើឲ្យខ្ញុំធ្វើការងារនេះ"] ឆ.១៦ KH 01117337 ["ខ្ញុំច្បាស់ថា របាយការណ៍ដែលខ្ញុំបានធ្វើនោះ គឺនឹងធ្លាក់ក្នុងដៃយាយចាន់។ ជាទូទៅ ពេលពួកឈ្លបមកដឹក ខ្ញុំឲ្យទៅធ្វើរបាយការណ៍នោះ គេប្រាប់ខ្ញុំច្បាស់ៗថា គេត្រូវការរបាយការណ៍នោះ នៅម៉ោងប្រាំបី ឬប្រាំបួនព្រឹក នៅថ្ងៃបន្ទាប់សម្រាប់ប្រជុំ គឺជាការប្រជុំនៅថ្នាក់តំបន់"]។

[1993] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.១០ KH 01097672 ["ក្នុងពេលដែលពួកពាយ័ព្យគ្រប់គ្រង [...] ពួកយើងរស់នៅដោយមិនមានការភ័យខ្លាច គេយកទៅសម្លាប់នោះទេ។ យ៉ាងណាមិញ ក្នុងពេលពួកនិរតីគ្រប់គ្រង [នៅឃុំ ៦០] ការរស់នៅក៏កាន់តែលំបាក ហើយបន្ថែមទៀតនោះ គឺរស់នៅភ័យខ្លាចគេយកទៅសម្លាប់គ្រប់ពេលទាំងអស់។ ភ្លាមៗក្រោយពួកនិរតីមកដល់ ពួកគេតែងតែចាប់កំហុសយើងពីបញ្ហានេះ ពីបញ្ហានោះ ហើយពួកខ្ញុំផ្ទាល់ឃើញគេយកមនុស្សទៅសម្លាប់។"]។ *សូមមើលផ្ទុយ* ឯកសារ D119/109 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឡូវ ឆ.៧៤ KH 00980138 [ដើមបណ្តឹងរដ្ឋប្បវេណីរស់នៅក្នុងភូមិវត្តកណ្តាល នៅក្នុងរបបកម្ពុជាប្រជាធិបតេ្យ៖ "ការសម្លាប់ត្រូវបានថយចុះជាងការគ្រប់គ្រងដោយពួកពាយ័ព្យ"]។

[1994] ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.២៥ KH 01403882។

ប្រជាជនខ្មែរក្រោម[1995] អតីតទាហាន លន់ នល់ ចំនួន ៣០ ឬ ៤០ នាក់ ដែលជាខ្មែរក្រោម[1996] និងដែលត្រូវបានចាត់ទុកថាជាគិញ សេអ៊ីអា ត្រូវបានសម្លាប់[1997]។ សាក្សីខ្មែរក្រោមម្នាក់បានបញ្ជាក់ថា "ពីរ ឬបីថ្ងៃម្តង គ្រួសារដែលមានទំនាក់ទំនងជាមួយនឹងយួនត្រូវដឹកចេញ" ពីឃុំរ៉ាំងកេសីទៅសម្លាប់ចោល[1998]។

[1995] ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៩១ ឆ.៩៥ ឆ.៩៧ KH 01032176 ["ខ្ញុំដឹងដោយសារមានសាច់ញាតិរបស់ខ្ញុំ [...] មានមនុស្សជាច្រើនបានរត់ឡើងឡាន។ តាមពិតគេយកទៅសម្លាប់ចោលសោះ។ [...] វាកើតឡើងជិតពេលវៀតណាមចូលមកដល់។ [...] មានឡានប្រហែល២ ហើយមនុស្សឡើងពេញឡានតែម្តង។ [...] អ្នកដែលឡើងឡានោះ គឺសុទ្ធតែជាខ្មែរក្រោម។ "]។

[1996] ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១ ឆ.៣ KH 01213301 [នៅភូមិរ៉ាំងក្រោល "អ្នកដែលគេយកទៅសម្លាប់ទាំង៣០ ៤០នាក់នោះ គឺខ្មែរក្រោមទាំងអស់។ [...] ព្រោះអ្នកទាំងនោះកាលពីសម័យ លន់ នល់ គេឲ្យពួកគាត់ធ្វើទាហានៅសម័យ លន់ នល់ [...] ទាំងអ៊ីំ និងមា។"]។ ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយថា នៅពាក់កណ្តាលឆ្នាំ១៩៧៨ តាឡឹក និងយាយចាន់ ពាក់ព័ន្ធនឹងហេតុការណ៍ពេលប្រព្រឹត្តដោយយោធានិរតី ហើយបងប្អូនជីដូនមួយរបស់គាត់ក៏ស្ថិតនៅក្នុងក្រុមជនរងគ្រោះនោះផងដែរ។ *សូមមើល* ឯកសារ D219/314 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៧-៨ KH 01097721 ។ ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.២ KH 01213301)។ *សូមមើលផងដែរ* ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.៦៦ KH 01414393 ["ខ្មែរក្រោមនៅរ៉ាំងកេសីនេះ [...] ដូចថាពីដើមធ្វើទាហាន ធ្វើកុម៉ង់ដូ អ៊ីហ្ម៉ីង គេសម្លាប់"]។

[1997] ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៦ ឆ.៨-៩ KH 01213302-01213303 ["ស៖ លោកស្រីបានប្រាប់យើងផងដែរនៅក្នុងកិច្ចសម្ភាសន៍លើកដំបូងរបស់លោកស្រី (D219/42) ចម្លើយទី៥០ថា នៅពេលដែលលោកស្រីបានឃើញគេកំពុងសម្លាប់ប្តីរបស់លោកស្រី លោកស្រីក៏បានឃើញខ្មែរក្រហមសម្លាប់មនុស្ស៦នាក់ទៀតផងដែរ ក្នុងនោះរួមមានស្ត្រីមានផ្ទៃពោះម្នាក់ និងកុមារម្នាក់? ឆ.៦៖ [...] ចាស គឺគេហៅខ្មែរក្រោមទាំងអស់។ [...] ស៖ តើលោកស្រីដឹងទេថា ហេតុអ្វីបានជាអ្នកទាំងនោះត្រូវគេសម្លាប់? ឆ.៨៖ វាចោទយើងថាជាក្រុម សេ.អ៊ី.អា។ [...] ឆ.៩៖ វានិយាយនៅហ្ម៉ីងមុខខ្ញុំ។"]។ ហេតុការណ៍នេះកើតឡើងនៅក្នុងឆ្នាំ១៩៧៨ ក្បែររ៉ាំងកេសី *សូមមើល* ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៥០-៥១ KH 01032171 ។

[1998] ឯកសារ D219/866 កំណត់ហេតុស្តាប់ចម្លើយ ឡើយ ម៉ុន ឆ.២៤ ឆ.២៧ ឆ.២៩ KH 01347406-01347407 ["ឆ្នាំជិតវៀតណាមចូល" "ពីរបីថ្ងៃ ឃ្លានប្រាំគ្រួសារទៀតទៅ ឲ្យតែជាប់ប្រវត្តិខ្សែយួន" "យប់ឡើងគេមាន" អារ៉ៃ្រសិន (រទេះភ្លើងខ្ជីៗ)។ "កាលសេរីម្តាយក្មេកខ្ញុំ គេបញ្ជេញពីរ៉ាំងកេសី ទៅរ៉ាំងក្រោល ទៅភូមិថ្មី [...] មុនសម្លាប់ "]។

565. កម្មាភិបាលភូមិភាគនិរតី ក៏បានសម្លាប់ប្រជាជន ដោយសារពួកគេមិនគោរពតាមបទបញ្ជាផងដែរ ដូចជា ការមិនចូលរួមប្រជុំ[1999] ការប៉ុនប៉ងរត់គេច[2000] ឬ មានទង្វើដែលត្រូវបានចោទថា "ខុសសីលធម៌"[2001]។ កម្មាភិបាលភូមិភាគពាយ័ព្យ គា ផុន គឺជាលេខាយុំរ៉ាងកេសីរហូតដល់កម្មភិបាលភូមិភាគនិរតីបានចាប់ខ្លួន និងដាក់ពន្ធនាគារនៅ ស-២១។ ឯកសារដែលសេសសល់ពី ស-២១ កត់ត្រាកាលបរិច្ឆេទចូលរបស់ គាផុន នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ ហើយគាត់ត្រូវបានសម្លាប់នៅថ្ងៃ

[1999] ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៥៣-៥៥ KH 01032225 ["នៅវត្តរ៉ាងកេសី។ [...] អ្នកខ្លះមិនព្រមទៅប្រជុំទេ។ បន្ទាប់មកតាឡឹក និងយាយចាន់ បានបាញ់រះប្រជាជនតែម្តង [...] ពេលនោះមានជនរងគ្រោះ ដែលមានរបួសច្រើន [...] តាឡឹក និងយាយចាន់ ជាអ្នកប្រមូលអ្នករបួសទៅសម្លាប់ចោល។"]។ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.១២ KH 01097698 ["ប្រជុំ [...] នៅវត្តរ៉ាងកេសី ដោយមានវត្តមានតាឡឹក និងយាយចាន់។ [...] អ្នកខ្លះស្ទាក់ស្ទើរមិនចង់ទៅចូលរួមប្រជុំ។ ដោយមានបញ្ជាពី តាឡឹក និងយាយចាន់ កូនចៅរបស់គាត់បានបាញ់រះទៅលើអ្នកទាំងនោះ។ [...] ខ្ញុំបានឮរឿងនេះពីអ្នកភូមិមកវិញ។ ពួកគេបានយកមនុស្ស៧នាក់ពីកន្លែងប្រជុំនោះ យកទៅសម្លាប់។"]។ បើទោះបីជា ដើមបណ្តឹងរដ្ឋប្បវេណី ចិច សុផា បាននិយាយថា ប្តីរបស់គាត់ឈ្មោះ កាន ស្ទើន ត្រូវបានគេសម្លាប់ ដោយគេចោទគាត់ថាជាគិញ សេ.អ៊ី.អា ខ្មែរក្រោម ក៏មានសាក្សីពីររូប បាននិយាយថា ប្តីរបស់គាត់ត្រូវបានសម្លាប់ ដោយសារគាត់ទៅចូលរួមប្រជុំមួយ មិនទាន់ពេលវេលា។ *សូមមើល* ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៦ ឆ.៨ KH 01213302។ ឯកសារ D219/313 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៦ KH 01097713។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ាញ វណ្ណា ឆ.១០៨ KH 01328010។

[2000] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.១៦ KH 01097673 ["ខ្ញុំបានឃើញមួយគ្រួសារដែលមានឪពុកម្តាយ និងកូនពីរនាក់ បានរត់មកពីភូមិផ្សេង មកភូមិរ៉ាងក្រោល។ ពួកគេត្រូវ [...] សម្លាប់" ដោយកម្មាភិបាលភូមិភាគនិរតី។]។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១៧ KH 01096586 ["ខែកុម្ភៈ ឆ្នាំ១៩៧៨ [...] ប្រជាជនពីភូមិផ្សេងរត់មកកាត់ភូមិរបស់ខ្ញុំ គឺភូមិវត្តកណ្តាល នៅអាងកំពង់គោ។ ពួកកម្មាភិបាលនិរតី [...] សម្លាប់ពួកគេ។ [...] ៣០ ទៅ ៤០នាក់។"]។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត ឆ.៧០ KH 01403893 [នៅ រ៉ាងកើ ភូមិស្វាយជាតិ "គេអត់ឲ្យឲ្យផ្លងពីតំបន់មួយ ទៅតំបន់មួយទេ ពីសហករណ៍មួយទៅមួយទេ។ ហើយដល់ពេលមនុស្សចូលពីសហករណ៍ផ្សេងមក គេដឹងតែចាប់។ ជួនកាលចាប់ទៅបាត់ដំណឹងរហូតទៅ ហើយមានតែគ្រួសារហ្នឹងទេ ដែលខ្ញុំទៅចងគោឲ្យស៊ីស្មៅហ្នឹង ខ្ញុំបានឃើញសកម្មភាពនៅហ្នឹង"]។

[2001] ឯកសារ D219/310 កំណត់ហេតុស្តាប់ចម្លើយ វ៉ន្ត សាមុត ឆ.១០ KH 01097681 ["ខ្ញុំបានឃើញហេតុការណ៍មួយដែលប្រុស និងស្ត្រី ហើយ [...] គេចោទគាត់ថាខុសសីលធម៌នឹងគ្នា។ [...] នៅខែឧសភា ឬខែមិថុនា ឆ្នាំ១៩៧៨ [...] ភូមិស្វាយជាតិ យកទៅវាលស្រែនៅទួលស្ងួតនៅពេលយប់។ ខ្ញុំបានឮស្នូរកាំភ្លើងក្រោយមកទៀត ហើយព្រឹកឡើង ខ្ញុំបានទៅឃើញសាកសពអ្នកទាំងពីរនោះ។"] ឆ.៦ KH 01097679 ["តាមាស បានអនុវត្តការសម្លាប់ជាច្រើន [...] ក្នុងពេលដែលគាត់គ្រប់គ្រងអ្នកភូមិម្នាក់ ឬ ក៏ពីរនាក់ ត្រូវបានយកទៅសម្លាប់រាល់យប់ ដោយចោទថាធ្វើនេះខុស ធ្វើនោះខុស។"]។

ទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៨[2002]។ សាក្សីម្នាក់បានបញ្ជាក់ថា បន្ទាប់ពី តាឡឹក និងយាយចាន់ បានមកដល់ "កម្មាភិបាលភូមិភាគពាព័ឃ្យ ត្រូវបាន [...] ព័ទ្ធចាប់ និងយកទៅសម្លាប់"[2003]។

566. កម្មាភិបាលភូមិភាគនិរតីមានជំនឿថា ជនរងគ្រោះរបស់គេត្រូវបានចាប់ខ្លួន ដោយយល់ឃើញថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"[2004]។ ជនរងគ្រោះទាំងនោះត្រូវបានសម្លាប់ជាក្រុម[2005]។

[2002] ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោស ស-២១ រៀបចំឡើងដោយ ក.ស.ច.ស, លេខរៀង ៩៦៤៦ EN 01222726។ *សូមមើលផងដែរ* ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៣ KH 01117259 ["តាឡឹក និងយាយចាន់ មានអំណាចលើតាភុន និងតានិន ហើយក្រោយមកទៀត ពួកគេបានយកកម្មាភិបាលចាស់ៗទៅបាត់ ក្រោយពីពួកគាត់មកដល់។"] (*កំណត់សម្គាល់* ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៨ KH 01085176 ["តាភុន ប្រធានសហករណ៍រាំងក្រោល ដែលត្រូវចាប់ខ្លួន។"]។ ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង ឆ.៣៤ KH 01080861 ["តាភុន គាត់មកកាន់ [សហករណ៍រាំងក្រោល] [...] ពួកគេក៏បានប្តូរ ហើយដាក់តាឡឹក និងយាយចាន់មកវិញ។"]។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត ឆ.២៧ ឆ.៣៩ KH 01403883 KH 01403886 ["សហករណ៍រាំងកេសី [...] ប្រធានគឺ ភុន [...] អនុឈ្មោះ តានិន [...] អាហ្ម៊ីងសម័យពាយ័ព្យ។ [...] ពេលពួកនិរតីមក [...] ឃើញចាប់កម្មាភិបាល ដូចភុនដាក់ឡានហ្ស៊ីពយកទៅ"]។

[2003] ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត ឆ.៥១ KH 01403889។ *សូមមើលផងដែរ* ឯកសារ D5/85 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សោយ យ៉ែន KH 00562463 ["ឆ្នាំ១៩៧៨ [...] ពីព្រោះពួកនិរតីចូលមក [...] ពួកខ្មែរក្រហមដូចគ្នា ក៏វាចាប់យកទៅសម្លាប់ចោលដែរ។"]។

[2004] ឯកសារ D119/109 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឡូវ ឆ.៧៦ KH 00980138 ["កាលណា គេចាប់ខ្លួនហើយ គឺចប់ហើយ។ ដោយគេនិយាយថា 'ទុកក៏មិនចំណេញ ដកចេញក៏មិនខាត។'"]។

[2005] ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៩១ ឆ.៩៥ ឆ.៩៧ KH 01032176 ["ខ្ញុំដឹងដោយសារមានសាច់ញាតិរបស់ខ្ញុំ [...] មានមនុស្សជាច្រើនបានរត់ឡើងឡាន។ តាមពិតគេយកទៅសម្លាប់ចោលសោះ។ [...] វាកើតឡើងជិតពេលវៀតណាមចូលមកដល់។ [...] មានឡានប្រហែល២ ហើយមនុស្សឡើងពេញឡានតែម្តង។"] ឆ.៥០-៥១ KH 01032171 [នៅស្ថានីយ៍រថភ្លើងរាំងកេសី៖ "ខ្ញុំបានឃើញខ្មែរក្រហមសម្លាប់មនុស្សប្រាំមួយនាក់ផ្សេងទៀត [...] [នៅឆ្នាំ] ១៩៧៨។"]។ ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១ ឆ.៣ KH 01213301 [នៅភូមិរាំងក្រោល "គេយកទៅសម្លាប់ទាំង៣០ ៤០ នាក់"]។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១៧ KH 01096586 [នៅភូមិវត្តកណ្តាល៖ "ខែកុម្ភៈ ឆ្នាំ១៩៧៨ [...] ពួកកម្មាភិបាលនិរតី [...] សម្លាប់ [...] ៣០ ទៅ៤០នាក់"]។ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.១២ KH 01097698 ["នៅវត្តរាំងកេសី ដោយមានវត្តមានតាឡឹក និងយាយចាន់ [...] ខ្ញុំបានឮ [...] ពីអ្នកភូមិ [...] គេយកមនុស្ស៧នាក់ពីកន្លែងប្រជុំនោះ យកទៅសម្លាប់"]។

ជនរងគ្រោះខ្លះត្រូវបានកប់ទាំងរស់[2006]។ សាកសពគ្មានសម្លៀកបំពាក់ត្រូវបានដាក់គរលើគ្នានៅទីតាំងសម្លាប់មនុស្សក្នុងភូមិនានា ដូចជា ភូមិវត្តកណ្តាល ភូមិស្វាយជាតិ និងភូមិរាំងក្រៅ[2007]។

<u>ការធ្វើទុក្ខបុកម្នេញ</u>

ការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោមដោយសារមូលហេតុនយោបាយ

567. កម្មាភិបាលភូមិភាគនិរតីដែលបានគ្រប់គ្រងទីតាំងឃុំរាំងកេសី បានតម្រង់ទិសដៅទៅលើខ្មែរក្រោម ពីព្រោះពួកគេត្រូវបានចាត់ទុកដោយបក្សពួកម្ចុយនីស្តកម្ពុជាថាមានទំនាក់ទំនងជាមួយវៀតណាម[2008]

[2006] ឯកសារ D219/314 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១២-១៣ KH 01097721-01097723 ["ចុងឆ្នាំ១៩៧៨ [...] ខ្ញុំបានឃើញពួកគេយកចបកាយដីលប់រណ្តៅនោះ ដោយកប់អ្នកទាំងនោះទាំងរស់តែម្តង។"]។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៥០-៥១ KH 01032171 [នៅឆ្នាំ១៩៧៨ "គេបានកប់ប្តីរបស់ខ្ញុំទាំងរស់។"]។ ពាក់ព័ន្ធថាតើប្តីរបស់ ចិច សុផា ឈ្មោះ កាន់ ស្ទើន ត្រូវបានគេសម្លាប់របៀបម៉េច *សូមមើល ផ្ទុយ* ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៥៣ ឆ.៥៥ KH 01032225។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក មឿន ឆ.៧៥ KH 01327974។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត ឆ.៦ KH 01403877។

[2007] ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១៧ ឆ.២០ KH 01096586 ["ខែកុម្ភៈ ឆ្នាំ១៩៧៨ [...] បន្ទាប់ពីកម្មាភិបាលនិរតីសម្លាប់ពួកគេហើយ កម្មាភិបាលនោះដោះសម្លៀកបំពាក់គេចេញ ហើយរុញចូលរណ្តៅ។ រណ្តៅនោះ នៅភូមិវត្តកណ្តាល ជិតផ្លូវវត្តកណ្តាល។ [...] ខ្ញុំមិនដែលឃើញ [...] ដោយផ្ទាល់ភ្នែកទេ។ ប៉ុន្តែខ្ញុំឃើញសាកសព [...] នៅពេលដែលពួកកម្មាភិបាលចេញទៅបាត់។"]។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃ្យៀន ឆ.២៩ ឆ.៣១ KH 01129776-01129777 ["ខ្ញុំបានឃើញសាកសពទាំងនោះ នៅឯព្រំប្រទល់ភូមិស្វាជាតិ និងភូមិវត្តកណ្តាល។ ខ្ញុំបានឃើញសាកសពមនុស្ស ជាង១០នាក់នៅទីនោះ។ [...] ក្នុងចំណោមសាកសពស្ត្រីទាំងអស់នោះ សាកសពខ្លះអាក្រាត ហើយសាកសពខ្លះទៀតក៏មានសម្លៀកបំពាក់។ [...] ខ្ញុំគិតថាពួកគេត្រូវបានគេសម្លាប់ប្រហែលជា៣ខែ មុនពេលដែលកងទ័ពវៀតណាមរំដោះតំបន់នោះ។"]។ ឯកសារ D219/314 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៧ KH 01097721 ["ខ្ញែក្រហម យកអ្នកទាំងនោះទៅសម្លាប់នៅតាមព្រៃ និងវាលស្រែ ក្នុងភូមិរាំងក្រោល។ ការសម្លាប់នោះ គឺអនុវត្តដោយទាហាននិរតី។ [...] ខ្ញុំបានទៅទីនោះ និងបានឃើញសាកសពដោយផ្ទាល់ [...] សាកសពខ្លះនៅក្នុងរណ្តៅ ខ្លះនៅក្រៅរណ្តៅ ពុំមានសម្លៀកបំពាក់ទេ មានតែខាងក្នុងប៉ុណ្ណោះ។"] ឆ.១២-១៣ KH 01097721-01097723 [ក្បែររ៉ាវទោះហ្ពឹងភូមិស្វាយជាតិ "ចុងឆ្នាំ១៩៧៨ [...] រណ្តៅនោះមានជម្រៅប្រហែល២ម៉ែត្រ ទទឹង៧ម៉ែត្រ និងបណ្តោយ៧ម៉ែត្រ។ ខ្ញុំបានឃើញពួកគេយកចបកាយដីលប់រណ្តៅនោះ ដោយកប់អ្នកទាំងនោះ"]។

[2008] *សូមមើលផ្ទុយ* ឯកសារ D219/867 កំណត់ហេតុស្តាប់ចម្លើយ ស ហ្ស៊ីន ឆ.២៨ KH 01347423 [សាក្សី គឺជាខ្មែរក្រោម៖ នៅរាំងកេសី "ពួកខ្ញុំអត់មានធ្វើបាបទេ" ដោយកម្មាភិបាលនិរតី។]។ ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ ក៏ សឹង ឆ.៦០ KH 01024895 [ដើមបណ្តឹងរដ្ឋប្បវេណី រស់នៅភូមិរាំងក្រោល រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ៖ "ខ្ញុំមិនធ្លាប់ឮនោះទេ គោលនយោបាយ [ប្រឆាំងនឹងខ្មែរក្រោម] ពេលកម្មាភិបាលនិរតីទៅដល់កន្លែងរបស់ខ្ញុំ។ គេបានដឹកខ្មែរក្រោមទៅសម្លាប់មុនពួកនិរតីទៅដល់។"]។ ឯកសារ D119/109 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឡូ ឆ.៧២ KH 00980138 [ដើមបណ្តឹងរដ្ឋប្បវេណីរស់នៅក្នុងវត្តកណ្តាល រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ៖ "ស៖ នៅពេលដែលពួកនិរតីមកដល់ តើគេមានចាប់ខ្មែរក្រោមដែរ

។ ខ្មែរក្រោមបានរស់នៅក្នុងតំបន់ឃុំរ៉ាំងកេសី តាំងពីរបបសីហនុ[2009]។ ដើមបណ្តឹងរដ្ឋប្បវេណី សោយ យ៉ែន បានចូលរួមក្នុងកិច្ចប្រជុំចំនួនបីដងក្នុងភូមិរ៉ាំងក្រោល ដែលក្នុងអំឡុងពេលមាន ឃាយ ចាន់ និង តាឡ៊ីក ជាមេឃុំ៖

> បាននិយាយ [...] ពីការស្អប់ឃ្លួន។ ពួកគេបាននិយាយថា គេប្រើគ្រប់មធ្យោបាយទាំងអស់ ដើម្បីជីកបូសឃ្លួនឲ្យអស់។ ពួកគេតែងតែនិយាយថា នៅពេលកាប់ដើម ត្រូវជីកបូសឲ្យអស់។ ពួកគេក៏ចាត់ទុកពួកយើងដែលជាខ្មែរក្រោមថាជាឃ្លួនដែរ[2010]។

ឬទេ? ឆ.៧២៖ មិនមានទេ។"]។ ឯកសារ D219/499 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ញ៉ើ ឆ.៥៨ KH 01141591 [ក្នុងតំបន់៤ ខ្មែរក្រោមទទួលបាន "ការប្រតិបត្តិដូចគ្នា" ទៅនឹងខ្មែរធម្មតាដែរ។]។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក មឿន ឆ.៩១ KH 01327975 ["ស៖ ដូច្នេះភូមិភាគនិរតីពុំបានធ្វើអ្វីដល់ប្រជាជនខ្មែរក្រោមទេ មែនទេ? ឆ.៩១៖ បាទ។ ព្រោះពួកវាចូលមកមានរយៈពេលខ្លី។"]។ ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.៦៦ KH 01414393 ["ខ្មែរក្រោមនៅខាងរ៉ាំងកេសីនេះ គេមិនសូវសម្លាប់ទេ។"]។

[2009] ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៨៨ KH 01032175 ["ក្នុងឃុំរ៉ាំងកេសី នេះគឺសុទ្ធតែខ្មែរក្រោម ហើយពួកគាត់រស់នៅតាំងពីសម័យសម្តេច សីហនុ ម្ល៉េះ។"]។ ឯកសារ D219/409 កំណត់ហេតុស្តាប់ចម្លើយ អាង ស ឆ.៥៧ KH 01117274 [នៅភូមិស្វាយជាតិ "គ្រួសារភាគច្រើន គឺជាខ្មែរក្រោម។ [...] ពួកគេមករស់នៅតាំងពីមុនសម័យ លន់ នល់។"] ។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត ឆ.១២ KH 01403879 [មុនរបបខ្មែរក្រហម "នៅក្នុងឃុំរ៉ាំងកេសី ទាំងមូលមានខ្មែរក្រោមរាប់ពាន់គ្រួសារ យ៉ាងហោចណាស់ក៏ប្រាំពីរប្រាំបីរយគ្រួសារដែរ។ ហើយបើថាភូមិរ៉ាំងកេសី និងភូមិបឹងវែងហ្នឹងសុទ្ធតែខ្មែរក្រោម។ [...] ភូមិបឹងវែង មានប្រហែល១៥០គ្រួសារ ហៅនៅភូមិរ៉ាំងកេសីមានចំនួនប្រហែល១ៗគ្នាហ្នឹង"]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៦ KH 01117260 ["ស៖ លោកបានប្រាប់យើងពីមុនៗថា មានខ្មែរក្រោមជាច្រើនរស់នៅក្នុងឃុំរ៉ាំងកេសី ក្នុងសម័យខ្មែរក្រហម។ តើលោកអាចប៉ាន់ស្មានថា មានចំនួនខ្មែរក្រោមប៉ុន្មាននាក់ដែរ? ឆ.២៦៖ [...] តាមខ្ញុំស្មាន គឺមានប្រហែលជា១ពាន់គ្រួសារ ហើយគ្រួសារនីមួយៗមានគ្នា ៤ ទៅ៥នាក់ ជាមធ្យម។ រស់នៅក្នុងឃុំនេះ គ្រួសារភាគច្រើនគឺជាខ្មែរក្រោម។"]។ ឯកសារ D219/416 កំណត់ហេតុស្តាប់ចម្លើយ លៀស គង់ ឆ.២២ KH 01117358 ["គ្រួសារខ្មែរក្រោមភាគច្រើន គឺរស់នៅចាប់ពីភូមិព្រៃស្វាយ រហូតដល់ភូមិរ៉ាំងកេសី ក្នុងឃុំរ៉ាំងកេសី។"]។ *សូមមើលផងដែរ* ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន មឿន ឆ.៥២ KH 01425207។ ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.៧៤ KH 01414395។ *សូមមើលផ្ទុយ* ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ ក៏ សឹង ឆ.៥៥ KH 01024894។ ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង ឆ.៤២ KH 01080863។ ឯកសារ D219/499 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ញ៉ើ ឆ.៥៨ KH 01141591។ ឯកសារ D219/638 កំណត់ហេតុស្តាប់ចម្លើយ ខ្ញែត ម៉ៅ ឆ.៣៥-៣៦ KH 01186815។ ឯកសារ D219/830 កំណត់ហេតុស្តាប់ចម្លើយ សេង រ៉ែត ឆ.៩៥, KH 01327990។

[2010] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.១៥ KH 01097673។ *សូមមើលផងដែរ* ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង ឆ.៤២ KH 01080863 ["តាឡ៊ីក និងឃាយចាន់ [...]អ្នកដែលត្រូវបានគេចោទ

568. ដូចបានពិភាក្សាក្នុងផ្នែកនៃដីកាសន្និដ្ឋានស្តាពរអំពី *ឧក្រិដ្ឋកម្មលើជនជាតិវៀតណាម*[2011] ជនណាដែលត្រូវបានចាត់ទុកថាមានទំនាក់ទំនងណាមួយជាមួយនឹងវៀតណាម ទោះបីជាទំនាក់ទំនងនយោបាយ ជាតិសាសន៍ សញ្ជាតិ ឬពន្ធុ ត្រូវបានសន្មតថាជាជនក្បត់។ នៅក្នុងឃុំរ៉ាំងកេសី កម្មភិបាលភូមិភាគនិរតីបានចោទប្រកាន់ខ្មែរក្រោម ដែលមានកំណើតស្ថិតក្នុងទឹកដី ដែលនៅពេលបច្ចុប្បន្នក្នុងប្រទេសវៀតណាមថាជាវៀតណាម។ ពួកគេបានធ្វើការកត់សម្គាល់ពីសំឡេងនិយាយរបស់ខ្មែរក្រោម និងស្បែកស និងបានហៅពួកនេះថាជា "ឃ្លន" ដែលជាពាក្យខ្មែរប្រើសំដៅលើវៀតណាម[2012]។ ខ្មែរក្រោម ដូចជាដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា ត្រូវបានលាតត្រដាងពីដើមកំណើតរបស់ខ្លួន[2013]។ ជាលទ្ធផល ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀតបានទទួលព័ត៌មានថាកម្មាភិបាលភូមិភាគនិរតីបានប្រើល្បិចដើម្បីកុហកខ្មែរក្រោមក្នុងគោលបំណងកំណត់អត្តសញ្ញាណ

[ប្រជាជន] ថាជាវៀតណាម ឬខ្មែរក្រោម នៅក្នុងភូមិរបស់ខ្ញុំ [រ៉ាំងក្រាល]។ [...] ខ្ញុំដឹងថា ពួកគាត់សម្គាប់ប្រជាជនដែលត្រូវបានគេចោទថាជាវៀតណាម មានសំនៀងវៀតណាមនៅក្នុងភូមិដទៃទៀត"]។

[2011] *សូមមើល* V.គ.ព.ក. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងវៀតណាម – គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការកំចាត់វៀតណាម – ចលនារបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងវៀតណាម និងខ្មែរក្រោម។

[2012] ឯកសារ D219/137 កំណត់ហេតុស្តាប់ចម្លើយ ឃៀម សោន ឆ.៥៧ KH 01053281 [ដើមបណ្តឹងរដ្ឋប្បវេណី គឺជាខ្មែរក្រោមរស់នៅក្នុងសហគមន៍កំពង់គោ៖ "បន្ទាប់ពី [យាយចាន់ និងតាឡឹក] មកដល់ ពួកគេចោទប្រជាជនក្នុងភូមិ ដែលនិយាយដូចខ្ញុំថាជាឃ្លន"]។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៥ KH 01097670 [កម្មាភិបាលភូមិភាគនិរតីនៅក្នុង "ឃុំ១០ [...] ចាប់កំហុសពួកយើង [...] គឺដោយសារតែសំនៀងរបស់ពួកយើង ហើយគេចោទថា ពួកយើងជាឃ្លន ដែលតាមពិត ពួកយើងពុំមែនជាឃ្លនទេ គឺខ្មែរក្រោម។"]។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន មឿន ឆ.២៩ KH 01425202 ["កាលហ្នឹងពួកនិរតីចូលមក [...] យើងខ្មែរកម្ពុជាក្រោមនិយាយដូចឃ្លនអ៊ីចឹង វាថាឃ្លន"]។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៨៩ KH 01032176 ["ខ្មែរក្រហមបានចោទ [ខ្មែរក្រោម]ថាជាឃ្លន ជាពិសេសអ្នកដែលមានសម្បុរស។"]។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៥២ KH 01403889 ["ខ្មែរក្រោម គេចោទថាវៀតណាម។"]។ *សូមមើលផងដែរ* ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៦ ឆ.២៣ KH 01403877 KH 01403882។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.៤ ឆ.៦ KH 01117333-01117334 ["អ្នកដែលគេចោទថា មានមុខមាត់ដូចវៀតណាម ហើយនិយាយខ្មែរសំនៀងវៀតណាមត្រូវបានគេកោះហៅ។ [...] ពួកអ្នកទាំងនោះ ត្រូវបានតាមដាន និងចាប់ខ្លួនដោយពួកឈ្លបក្នុងឃុំរ៉ាំងកេសី។ [...] ខ្ញុំច្បាស់ថា ហេតុការណ៍កើតឡើងក្រោយពួកកម្មាភិបាលនិរតីចូលមកដល់។"]។

[2013] ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៧៨ KH 01032228 ["ខ្ញុំបានលាក់ ដើមកំណើតរបស់ខ្ញុំ។ ពេលដែលឪពុកម្តាយរបស់ខ្ញុំមកដល់រ៉ាំងកេសី ខ្ញុំមិនអាចលាក់បានទៀតទេ។"] ឆ.៣ KH 01032219 ["ស៖ តើលោកអាចពន្យល់បានទេ ថាហេតុអ្វីបានជាមានភាពខុសគ្នារវាងទីកន្លែងកំណើតក្នុងអត្តសញ្ញាណប័ណ្ណ និងទីកន្លែងកំណើតពិតប្រាកដរបស់លោក? ឆ.៣៖ ព្រោះខ្ញុំមានការភ័យខ្លាច ដោយសារខ្ញុំធ្លាប់រងគ្រោះនៅក្នុងសម័យខ្មែរក្រហម ម្យ៉ាងវិញទៀត ខ្ញុំខ្លាចរឿងនេះកើតឡើងម្តងទៀត។"]។

ពួកគេតាមរយៈការសន្យាបোកប្រាស់[2014]។ ខ្មែរក្រោម រួមទាំងប្រជាពលរដ្ឋដែលជាសមាជិកនៃអតីតទាហានក្នុងរបប លន់ នល់ ត្រូវបានសម្លាប់[2015]។ ដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ និងសាក្សីម្នាក់បានបញ្ជាក់ថា យាយចាន់ និងតាឡឹកក៏បានរៀបចំផែនការដាក់ថ្នាំបំពុលខ្មែរក្រោមដែលបានរស់រានមានជីវិតចំនួន ៣០០ ទៅ ៤០០ នាក់ នៅចុងរបបកម្ពុជាប្រជាធិបតេយ្យ[2016]។

[2014] ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៩១ ឆ.៩៧ KH 01032176 ["ខ្ញុំដឹងដោយសារមានសាច់ញាតិរបស់ខ្ញុំ [...] ដំបូងខ្មែរក្រហមបានកុហកថា បើអ្នកណាទៅសមរភូមិមុខ នឹងបានបាយហូបពីរពេល។ ពេលនោះមានមនុស្សជាច្រើនបានរត់ឡើងឡាន។ [...] អ្នកដែលឡើងឡានៗនោះគឺសុទ្ធតែជាខ្មែរក្រោម។ "]។

[2015] ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១ ឆ.៣ KH 01213301 [នៅភូមិរាំងក្រោល "អ្នកដែលគេយកទៅសម្លាប់ទាំង៣០ ៤០នាក់នោះ គឺខ្មែរក្រោមទាំងអស់។ [...] ព្រោះអ្នកទាំងនោះកាលពីសម័យ លន់ នល់ គេឲ្យពួកគាត់ធ្វើទាហាននៅសម័យ លន់ នល់ [...] ទាំងអ៊ំ និងមា។"]។ (*កំណត់សម្គាល់* ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយថា នៅពាក់កណ្តាលឆ្នាំ១៩៧៨ តាឡឹក និងយាយចាន់ ពាក់ព័ន្ធនឹងហេតុការណ៍ពេលប្រព្រឹត្តដោយយោធានិរតី *សូមមើល* ឯកសារ D219/314 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៧-៨ KH 01097721 និង ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១ KH 01213301។) ឆ.៦ KH 01213302 ["ស៖ លោកស្រីបានប្រាប់យើងផងដែរនៅក្នុងកិច្ចសម្ភាសន៍លើកដំបូងរបស់លោកស្រី (ឯកសារ D219/42) ចម្លើយទី៥០ថា នៅពេលដែលលោកស្រីបានឃើញគេកំពុងសម្លាប់ប្តីរបស់លោកស្រី លោកស្រីក៏បានឃើញខ្មែរក្រហមសម្លាប់មនុស្ស៦នាក់ទៀតផងដែរ ក្នុងនោះរួមមានស្ត្រីមានផ្ទៃពោះម្នាក់ និងកុមារម្នាក់? ឆ.៦៖ [...] ចាស គឺគេហៅខ្មែរក្រោមទាំងអស់។"] (*កំណត់សម្គាល់* ហេតុការណ៍នេះកើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៨ ក្បែរ៉ារទេះភ្លើងរាំងកេសី *សូមមើល* ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៥០-៥១ KH 01032171។)។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៩១ ឆ.៩៥ ឆ.៩៧ KH 01032176 ["ខ្ញុំដឹងដោយសារមានសាច់ញាតិរបស់ខ្ញុំ [...] មានមនុស្សជាច្រើនបានរត់ឡើងឡាន។ តាមពិតគេយកទៅសម្លាប់ចោលសោះ។ [...] វាកើតឡើងជិតពេលវៀតណាមចូលមកដល់។ [...] មានឡានប្រហែល២ ហើយមនុស្សឡើងពេញឡានតែម្តង។ [...] អ្នកដែលឡើងឡានៗនោះ គឺសុទ្ធតែជាខ្មែរក្រោម។"]។*សូមមើលផងដែរ* ឯកសារ D219/866 កំណត់ហេតុស្តាប់ចម្លើយ ឡើយ ម៉ុន ឆ.២៤ ឆ.២៧ ឆ.២៩ KH 01347406-01347407 ["ឆ្នាំជិតវៀតណាមចូល", "ពីរបីថ្ងៃ ឬនប្រាំគ្រួសារទៀតទៅ ឲ្យតែជាប់ប្រវត្តិខ្សែយួន" "យប់ឡើងគេមាន" អារ៉ាត្រៃសិន (រទេះភ្លើងខ្ពីៗ)។ "កាលសេរីម្តាយក្មេកខ្ញុំ គេបញ្ជេញពីរាំងកេសី ទៅរាំងក្រោល ទៅភូមិថ្មី [...] មុនសម្លាប់"]។

[2016] ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម រណ្ណា ឆ.៥៧-៥៨ KH 01032225 ["តាឡឹក យាយចាន់ និងយោធាខ្មែរក្រហម [...] បានប្រាប់ថាឲ្យប្រជាជនទៅហូបនំបញ្ចុកនៅការដ្ឋានបាយក្នុងវត្តរាំងកេសី។ [...] មានមនុស្សច្រើន ប្រហែលជា ៣០០ ទៅ៤០០នាក់។" បានចូលរួមប្រជុំ។]។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៥-៦ ឆ.៨ KH 01097670-01097671 ["គឺថ្ងៃទី២៥ [...] ពីរថ្ងៃក្រោយមកទៀត វៀតណាមក៏ចូលមករំដោះ [...] យោធាខ្មែរក្រហម [...] បានបញ្ជា " "[គ្រប់គ្នា] ទាំងអស់នៅក្នុងភូមិរាំងក្រោល" "ហូបនំបញ្ចុកនៅថ្ងៃនោះ។ ពួកយើងដឹងច្បាស់ណាស់ថា បើសិនជាពួកវៀតណាមចូលមកតែយឺតបន្តិច យើងច្បាស់ជាស្លាប់អស់ហើយ។" "ទាំងអស់គ្នាសុទ្ធតែនិយាយសំនៀងដូចគ្នា ដោយសារតែពួកយើងភាគច្រើនសុទ្ធសឹងតែជាខ្មែរក្រោម។" "តាឡឹក និងយាយចាន់" រៀបចំផែនការឲ្យមានការហូបនំបញ្ចុក។]។ ឯកសារ D219/137 កំណត់ហេតុស្តាប់ចម្លើយ ឃៀម សោន ឆ.៥៧ KH 01053281។ ឯកសារ D219/311 កំណត់ហេតុស្តាប់ចម្លើយ ពែង សាន្ត ឆ

ការធ្វើទុក្ខបុកម្នេញផ្នែកនយោបាយលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសាររបស់គេ និងថ្នាក់ក្រោមរបស់គេ និងសមាជិកនៃអតីតរបប លន់ នល់ និងគ្រួសាររបស់គេ

569. កម្មាភិបាលភូមិភាគនិរតីបានប្រព្រឹត្តឧក្រិដ្ឋកម្មនានាដូចបានរៀបរាប់ខាងលើ ក្នុងគោលបំណងតម្រង់ទិសដៅលើក្រុមជាក់លាក់ ពោលគឺកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសារ និងថ្នាក់ក្រោមរបស់គេ និងសមាជិកនៃអតីតរបប លន់ នល់ និងគ្រួសាររបស់គេ នៅក្នុងឃុំរ៉ាំងកេសី។ ក្រុមទាំងនេះត្រូវបានតម្រង់ទិសដៅជាពិសេស ដោយសារតែពួកគេត្រូវបានគេចាត់ទុកថាជាសមាជិកនៃក្រុមនយោបាយមួយ ឬពួកគេជាសមាជិកពិតប្រាកដនៃក្រុមនយោបាយមួយ។

v. ឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់នៅក្នុងដីការចោទប្រកាន់

570. ដោយផ្អែកលើភ័ស្តុតាងដែលបានបញ្ជាក់ខាងលើ ស.ព.អ ស្នើឲ្យមានការចោទប្រកាន់ **យ៉ីម ទិព្ធ** ពីបទឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងតំបន់ភូមិសាស្ត្រដែលត្រូវស្គាល់នាពេលបច្ចុប្បន្នថាជាឃុំរ៉ាំងកេសី[2017] ជាអាទិ៍ អំពើប្រល័យពូជសាសន៍ក្រុមជនជាតិវៀតណាម ក្នុងប្រទេសកម្ពុជា (ជាពិសេសខ្មែរក្រោម[2018]) និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់មនុស្ស ការសម្លាប់រង្គាល[2019] ការធ្វើទុក្ខបុកម្នេញដោយសារនយោបាយលើកម្មាភិបាលភូមិភាគពាយ័ព្យ និងគ្រួសារ

.៧ KH 01097690។ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប ង់ ថៃ ឆ.១៤ KH 01097699។ *សូមមើលផងដែរ* ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ ក ឹ សឹង ឆ.៦៦ KH 01024895។

[2017] សហព្រះរាជអាជ្ញាអន្តរជាតិបានកត់សម្គាល់ពាក់ព័ន្ធទៅនឹងឃុំកំពង់ព្រៀង គាត់បានស្វែងរកការចោទប្រកាន់ចំពោះបទឧក្រិដ្ឋកម្មដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលយក ប៉ុន្តែមិនទាន់ចោទប្រកាន់ យ៉ីម ទិព្ធ នៅឡើយ។ បទឧក្រិដ្ឋទាំងអស់នោះ គឺបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ធ្វើទុក្ខបុកម្នេញទៅលើគោលនយោបាយប្រឆាំងនឹងកម្មាភិបាលពាយ័ព្យ គ្រួសាររបស់ពួកគេ ថ្នាក់ក្រោម និងអតីតអ្នករដ្ឋការសម័យ លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ, និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរំលោភសេពសន្ថវ:)។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលយកបទឧក្រិដ្ឋទាំងអស់នោះ នៅក្នុងឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ៥៤, ៥៧-៥៩ (រួមទាំងជើងទំព័រ ២២៣) ១១៨.ង។ ឯកសារ D191 សារណាបន្ថែមរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ៤-៦, ១៣។

[2018] *សូមមើល* V.គ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងវៀតណាម។

[2019] សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បង្ហាញធាតុផ្សំយ៉ាងច្រើននៃឧក្រិដ្ឋកម្មសម្លាប់រង្គាល ជាភស្តុតាងដែលកើតឡើងនៅឃុំរ៉ាំងកេសីតែឯងប៉ុណ្ណោះ។ ជាផ្ទុយមកវិញ សហព្រះរាជអាជ្ញាអន្តរជាតិ ឈរលើជំហរថា ក្នុងពេលពិចារណាលើធាតុផ្សំយ៉ាងច្រើន គឺត្រូវបង្ហាញឲ្យឃើញការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខទាំងអស់ នៅទីកន្លែងសម្លាប់មនុស្ស និងការដ្ឋានការងារដោយបង្ខំ រួមទាំងឃុំរ៉ាំងកេសី គឺគួរតែដាក់សរុបបញ្ចូលគ្នា។ រាល់ទីតាំងទាំងអស់ គឺបង្កើតបានជាទម្រង់មួយ រៀបចំឡើង

របស់គេ និងថ្នាក់ក្រោមនៃអតីតរបប លន់ លន់ និងគ្រួសាររបស់គេ និងខ្មែរក្រោម និងអំពីអមនុស្ស ធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ និងរំលោភសេពសន្តវ:)[2020]។

ខ. ឃុំកំពង់ព្រៀង

i. សេចក្តីផ្តើម

571. តំបន់ភូមិសាស្ត្រនេះដែលបច្ចុប្បន្នត្រូវបានស្គាល់ថាជាឃុំកំពង់ព្រៀង ស្ថិតក្នុងស្រុកដូនទ្រី ហៅ ស្រុក ៤២ ក្នុងតំបន់ ៤ នៃភូមិភាគពាយ័ព្យក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឃុំនេះ មានមន្ទីរសន្តិសុខចំនួន ៣ កន្លែង។ នៅពេលដាក់បន្ថែមអំពើនៃសហឧក្រិដ្ឋកម្មរួម ដែលក្នុងនោះ **យ៉ីម ទិត្យ** ជាថ្នាក់ដឹកនាំម្នាក់ កម្មាភិបាលភូមិភាគនិរតី បានបើកយុទ្ធនាការឧក្រិដ្ឋកម្មនៅក្នុងទីតាំង នេះនៅដើមឆ្នាំ១៩៧៧។ យុវជនត្រូវបានបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ និងរួមដំណេកជាមួយគ្នា ដោយគ្មានការយល់ព្រម។ កម្មាភិបាលភូមិភាគនិរតីបានតម្រង់ទិសដៅលើបុគ្គលណាដែលខ្លួនចាត់ ទុកជាខ្មាំងផ្ទៃក្នុង នៅក្នុងយុទ្ធនាការធ្វើទុក្ខបុកម្នេញមួយ។ ពួកគេបានដាក់ទណ្ឌកម្មលើអតីត កម្មាភិបាលភូមិភាគពាយ័ព្យរាប់ពាន់នាក់ដោយទម្លាក់មុខតំណែង និងបានបង្ខំឲ្យពួកគេធ្វើការងារ ធ្ងន់ធ្ងរ និងបង្អត់អាហារ ដែលជាផ្នែកមួយនៃ "ការរៀនសូត្រ/អប់រំឡើងវិញ"។ កម្មាភិបាលភូមិ ភាគនិរតីបានចាប់ខ្លួន និងដាក់ពន្ធនាគារមនុស្សរាប់ពាន់នាក់នៅក្នុងក្រុមគោលដៅរបស់គេ ក្នុងនោះ រួមមានកម្មាភិបាលភូមិភាគពាយ័ព្យ ប្រជាជនវៀតណាម និងខ្មែរក្រោម។ គ្មានអ្នកទោសណាម្នាក់ បានឆ្លងកាត់ដំណើរការផ្លូវច្បាប់នោះឡើយ ហើយអ្នកទោសយ៉ាងច្រើនបានស្លាប់ ដោយសារកង្វះ ម្ហូបអាហារ ការធ្វើទារុណកម្ម និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ។ អ្នកទោសផ្សេងៗទៀតបាត់ខ្លួន ដោយគ្មានហេតុផល។

572. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានចោទ **យ៉ីម ទិត្យ** ពីអំពីឧក្រិដ្ឋកម្ម ទាក់ទងនឹងឃុំកំពង់ព្រៀង មានជាអាទិ៍: អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការធ្វើមនុស្ស ឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការធ្វើទុក្ខ បុកម្នេញដោយសារមូលហេតុនយោបាយ និងជាតិសាសន៍ប្រឆាំងនឹងខ្មែរក្រោម និងអំពើអមនុស្ស ធម៌ផ្សេងៗទៀត (ការបង្ខាំងខ្លួន/ការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌ និងអាពាហ៍ពិពាហ៍

ជាប្រព័ន្ធក្នុងការអនុវត្តគោលនយោបាយក្នុងការធ្វើទុក្ខបុកម្នេញ និងសម្លាប់សត្រូវ និងរាល់ការសម្លាប់នៅតាមទីតាំងទាំងអស់ ត្រូវតែធ្វើឡើងតាមការសម្របសម្រួលនៃការបញ្ជារបស់ យ៉ីម ទិត្យ។

[2020] *សូមមើល* V.ខ.៧. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការរៀបការដោយបង្ខំ និងរំលោភផ្លូវភេទ។

ដោយបង្ខំ) និងឧក្រិដ្ឋកម្មនៃការធ្វើឃាតគិតទុកជាមុន អនុលោមតាមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦[2021]។

ii. ប្រតិបត្តិការ និងទីតាំង

573. ចាប់ពីឆ្នាំ១៩៧៧ កម្មាភិបាលភូមិភាគនិរតីមានតួនាទីយ៉ាងសំខាន់ក្នុងឧក្រិដ្ឋកម្មនានាក្នុងតំបន់ភូមិសាស្ត្រនេះ ដែលត្រូវបានស្គាល់នាពេលបច្ចុប្បន្នថាជាឃុំកំពង់ព្រៀង[2022]។ កម្មាភិបាលទាំងនេះបានគ្រប់គ្រងតំបន់នេះរហូតដល់ពេលចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[2023]។ ភូមិដែលស្ថិត

[2021] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ EN 01426069, 74-75, 78។

[2022] ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៤៣ KH 01300000 [កម្មាភិបាលនិរតីចូលមកភូមិកាច់រទេះ "[ក្នុងឆ្នាំ១៩៧៧។"]។ ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បៀង ឆ.៧៩ KH 01335622 ["ពួកនិរតីមកក្នុងឆ្នាំ [...] ១៩៧៧" ភូមិកាច់រទេះ។]។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.១៨ KH 01114658 ["ពួកនិរតីចូលមកដល់ភូមិខ្ញុំ [កាច់រទេះ] នៅពាក់កណ្តាលឆ្នាំ១៩៧៧ ប្រហែលក្នុងខែមេសា។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៥១ KH 01047387 ["ពួកនិរតីទៅដល់តំបន់របស់ខ្ញុំ [ភូមិអូរសទ្ទក] នៅចុងឆ្នាំ១៩៧៧"]។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.១០ KH 01117189 ["ពួកនិរតីមកដល់តំបន់យើង [ភូមិថ្មី] នៅចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨។"]។ ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៣០ KH 01151000។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៤៦ ឆ.៤៨ KH 01037159។ ឯកសារ D219/333 កំណត់ហេតុស្តាប់ចម្លើយ ទៀ រ៉ៀង ឆ.១៧ KH 01102768។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ដុះ ឆ.១៨ KH 01121680។ ឯកសារ D219/394 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ឌី ឆ.៦ KH 01114690 (*កំណត់សម្គាល់* ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ឌី ឆ.២ KH 01102809)។ ឯកសារ D219/261 កំណត់ហេតុស្តាប់ចម្លើយ ឃ្យ៉ាន ស្ងឿន ឆ.១០ KH 01085796។ ឯកសារ D219/304 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ប៊ុនឈ្យ៉ាន ឆ.១១ KH 01096564។ ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀ ហេង ឆ.៣ KH 01114700។ ឯកសារ D219/305 កំណត់ហេតុស្តាប់ចម្លើយ ងិន ធ៌ីយ ឆ.៦ KH 01096570។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.១៤ KH 01037127។ ឃុំកំពង់ព្រៀង ពុំមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ *សូមមើល* ឯកសារ D219/392 កំណត់ហេតុស្តាប់ចម្លើយ ឌិត ស៊ីម, ឆ.១១ KH 01114673។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.១-២ KH 01114658។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ដុះ ឆ.៨ KH 01121678។

[2023] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៥១ KH 01047387 [នៅភូមិសាលាត្រាវ៖ "ពួកនិរតី [...] គ្រប់គ្រងរហូតដល់រ៉ៀតណាមចូលមកដល់។"]។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ឌី ឆ.២៣ KH 01102815 ["កម្មាភិបាលនិរតី គ្រប់គ្រងនៅភូមិក្បាលថ្នល់ [...] រហូតដល់កងទ័ពរ៉ៀតណាមចូលមក។"]។

ក្នុងតំបន់នេះភូមិអូសទ្ធក កាច់រទេះ និងសាលាត្រាវ (ដែលភូមិទាំងនេះស្ថិតនៅក្នុងឃុំ ៣០)[2024] និងភូមិថ្មី សំបុកអក និងក្បាលផ្ទ្ធល់ដែលពីមុនហៅថាភូមិបឹងឈូក (ដែលភូមិទាំងនេះស្ថិតក្នុងឃុំ

[2024] <u>អូសទ្ធក</u>៖ *សូមមើលខ១ទាហរណ៍* ឯកសារ D193/21.2.1 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម, ឆ.១៦ KH 01047382 [ភូមិអូសទ្ធក ស្ថិតនៅក្នុងឃុំកំពង់ព្រៀង។]។ ឯកសារ D219/341 កំណត់ហេតុស្តាប់ចម្លើយ នក់ សាង៉ាវ ឆ.៣ KH 01102869 ["ភូមិអូសទ្ធក ស្ថិតនៅក្នុងឃុំ៣០"]។ *សូមមើលផ្ទ្ធយ* ឯកសារ D219/343 កំណត់ហេតុស្តាប់ចម្លើយ រស់ ម៉ោង ឆ.៣ KH 01102893 ["ភូមិអូសទ្ធក ស្ថិតនៅក្នុងឃុំកំពង់ព្រះ។"]។ <u>កាច់រទេះ</u>៖ *សូមមើលខ១ទាហរណ៍* ឯកសារ D219/307 កំណត់ហេតុស្តាប់ចម្លើយ ប៉ាល់ យ៉ុង ឆ.២៤ ឆ.២៨ KH 01096598-01096599 ["ខ្ញុំកំពុងតែធ្វើការនៅភូមិកាច់រទេះ [...] ក្នុងឃុំ៣០"]។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.៧ KH 01121678។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.១២៧ KH 01104633។ ឯកសារ D219/261 កំណត់ហេតុស្តាប់ចម្លើយ ឃ្យៀន ស្ងៀន ឆ.៣ KH 01085793។ ឯកសារ D219/445 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.៦ KH 01129688។ ឯកសារ D219/341 កំណត់ហេតុស្តាប់ចម្លើយ នក់ សាង៉ាវ ឆ.៤ KH 01102869។ ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀ ហេង ឆ.២ KH 01114700។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.១០ KH 01037126។ <u>សាលាត្រាវ</u>៖ *សូមមើលខ១ទាហរណ៍* ឯកសារ D219/426 កំណត់ហេតុស្តាប់ចម្លើយ កែវ ឃួង ឆ.៣ KH 01121708 ["ភូមិសាលាត្រាវ ស្ថិតនៅក្នុងឃុំ៣០"]។ ឯកសារ D219/445 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.៦ KH 01129688។ សាក្សី រៀម ដុះ បាននិយាយថា ភូមិទាំងបីនោះ ស្ថិតនៅក្នុងសហការណ៍កាច់រទេះ ក្នុងឃុំ៣០ *សូមមើល* ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.១០ KH 01121678 ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់នៅក្នុងភូមិទាំងអស់នោះ នៅក្នុងសហការណ៍ផ្សេង *សូមមើល* ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៣០ KH 01151000 ["ពួកនិរតី [...] គេឲ្យខ្ញុំ [...] ទៅគ្រប់គ្រងនៅសហការណ៍កំពង់គោ នៅកាច់រទេះ"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៣០ KH 01047384 ["ក្នុងសហការណ៍ក្ងន្ធ្ងុង៖ [...] ភូមិអូសទ្ធក [...] និងភូមិសាលាត្រាវ។"]។

៦០)[2025]។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឃុំ៣០ និងឃុំ៦០ មានទីតាំងស្ថិតក្នុងស្រុកដូនទ្រី ហៅ ស្រុក៤០ តំបន់ ៤[2026]។

574. ឃុំកំពង់ព្រៀងយ៉ាងតិចមានមន្ទីរសន្តិសុខចំនួនបី។ បន្ទាប់ពីកម្ចាភិបាលភូមិភាគនិរតីបានមកដល់ ឃុំនេះភ្លាម ពួកគេបានធ្វើការផ្លាស់ប្តូរពន្ធនាគារក្នុងពេលនោះទៅកាន់វត្តកាច់រទេះ (ដែលពីមុនមានឈ្មោះថាវត្តលង្កា និងវត្តដំណាក់រទេះ) ក្នុងភូមិកាច់រទេះ[2027]។ ពួកគេបានប្រតិបត្តិការមន្ទីរសន្តិសុខ

[2025] ថ្នី៖ *សូមមើលខាងលើ* ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៧ EN 01096522 ["ភូមិថ្មី ឃុំ ៦០ (ឃុំកំពង់ព្រៀង)"]។ ឯកសារ D219/841 កំណត់ហេតុស្តាប់ចម្លើយ ហេង គុយឡាង ឆ.២២ KH 01335654។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.១៤ KH 01121679។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.៣ KH 01117188។ <u>សំបុកអក</u>៖ *សូមមើលខាងលើ* ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.១៤ KH 01121679 ["ឃុំ៦០៖ [...] ភូមិសំបុកអក "]។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.៣ KH 01117188។ <u>ក្ពាលថ្នល់</u>៖ *សូមមើលខាងលើ* ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប ង់ ថៃ ឆ.២ KH 01097696 ["ភូមិក្ពាលថ្នល់ ឃុំ៦០"]។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.៣ KH 01117188។ *សូមមើលផងដែរ* ឯកសារD219/375 កំណត់ហេតុស្តាប់នៃកិច្ចស៊ើបសួរ ជាមួយ ហេង ហ៊ៀង KH 01442898 ["នៅក្នុងអំឡុងពេលនៃរបបខ្មែរក្រហម វត្តប៊ីងឈ្មក គឺជាផ្នែកមួយនៃឃុំ៦០ តំបន់៤។ [...] ឥឡូវនេះ វាជាផ្នែកមួយនៃភូមិក្ពាលថ្នល់"]។ ឯកសារ D219/782 របាយការណ៍នៃការស៊ើបអង្កេត KH 01485171-01485172។ សាក្សី រៀម ដុះ បាននិយាយថា ភូមិថ្មី និងភូមិសំបុកអក ជាផ្នែកនៃសហការណ៍កំពង់គោ ដែលសាក្សី ឡូញ លន់ បាននិយាយថា សព្វថ្ងៃគឺឃុំកំពង់ព្រៀង *សូមមើល* ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.១៤ KH 01121679។ ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៥១ KH 01151004។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ នៅភូមិថ្មី និងភូមិសំបុកអក ក្នុងឃុំ៦០ *សូមមើល* ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្ឿង ឆ.៨ KH 01335615។ ឯកសារ D5/98 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃៀម ប៊ូ KH 00562687។

[2026] ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៣ KH 01114658 ["ឃុំ៣០ ស្ថិតនៅក្នុងស្រុក៤២ តំបន់ ៤។"]។ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប ង់ ថៃ ឆ.២ KH 01097696 ["ឃុំ៦០ ស្រុក៤២ តំបន់៤។"]។ ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀវ ហេង ឆ.២ KH 01114700។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.២ KH 01117188 [សហការណ៍កំពង់គោ "ស្ថិតនៅក្នុងឃុំ៦០ ស្រុក៤២ តំបន់"]។

[2027] ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.៤ KH 01037124 ["ក្នុងពេលពួកនិរតីគ្រប់គ្រង គេប្តូរគុកទៅដាក់នៅវត្តវិញ ដែលស្ថិតនៅខាងជើងភូមិ"]។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៣២ ឆ.៣៥ KH 01167596។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.១២ KH 01102812 ["បន្ទាប់ពីពួកនិរតីមកដល់ ពួកគេបានផ្លាស់ប្តូរគុកពីទីតាំងចាស់ ទៅក្នុងវត្តកាច់រទេះ។"]។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៣៩ KH 01114664។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៩ ឆ.៤៣ KH 01129770 KH 01129779។ ឯកសារ D219/261 កំណត់ហេតុស្តាប់ចម្លើយ ឃឿន ស្ឿន ឆ.២៤ KH 01085798។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៣៣ KH 01167596។ ឯកសារ D219/392 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.៣១ KH 01114677

នេះរហូតដល់ពេលចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[2028]។ នៅក្នុងបរិវេណនៃមន្ទីរសន្តិសុខនេះ អ្នកទោសត្រូវបានដាក់ឃុំក្នុងវិហារ ស្តូប និងរោងពេទ្យ[2029]។ អគារមួយទៀតត្រូវបានប្រើសម្រាប់សួរចម្លើយ[2030]។ កម្មាភិបាលភូមិភាគនិរតីបានប្រតិបត្តិមន្ទីរសន្តិសុខទីពីរ នៅក្នុងវិហារក្នុងវត្តបឹងឈូក ក្នុងភូមិក្បាលថ្នល់[2031]។ មន្ទីរសន្តិសុខទីបីដែលបានដំណើរការផងដែរនៅពេលនេះស្ថិត

["ស៖ តើមានគុកតែមួយទេ ឬយ៉ាងណា កាលពីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកពាយ័ព្យ? ឆ.៣១៖ ខ្ញុំដឹងតែគុកមួយ [...]។ ក្រោយមកទៀត ទើបខ្ញុំឮសួរថាមានគុកមួយទៀតនៅក្នុងវត្តកាច់រទេះ។"]។ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៣៦ ឆ.៩៩ KH 01299999 KH 01300006។ *សូមមើលផ្ទុយ* ឯកសារ D219/302 កំណត់ហេតុស្តាប់ចម្លើយ ខ្ឿន ចឹម ឆ.៨ KH 01096544 ["ពួកពាយ័ព្យបានយកវិហារ [វត្តកាច់រទេះ] ធ្វើជាគុក ហើយពួកនិរតីក៏ដូចគ្នាដែរ។"]។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់ថា វត្តកាច់រទេះ នៅក្នុងភូមិកាច់រទេះ ពីមុនគឺជាវត្តពោធិ៍លង្កា និងវត្តដំណាក់រទេះ *សូមមើល* ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.១៣ KH 01102813។ ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.៣៨ KH 01023858។ ឯកសារ D219/261 កំណត់ហេតុស្តាប់ចម្លើយ ឃ្ឿន ស្ឿន ឆ.១៧ KH 01085795។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.២១-២២ KH 01037156-01037157។ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៤០ KH 01299999។ ឯកសារ D219/333 កំណត់ហេតុស្តាប់ចម្លើយ ទៀ រ៉ៀង ឆ.១៣ ឆ.១៥ KH 01102767។ ឯកសារ D219/304 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៨ KH 01096563។

[2028] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ឿម ឆ.៥១ ឆ.១៩១ KH 01047387 KH 01047405 ["ពួកនិរតី [...] គ្រប់គ្រងរហូតដល់វៀតណាមចូលមកដល់។ [...] ពេលវៀតណាមចូលរំដោះ ហើយពួកគេបានបំបែកទ្វារមន្ទីរឃុំឃាំង [កាច់រទេះ] ដើម្បីដោះលែងអ្នកទោស។"]។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.១២ KH 01102812។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.៣ KH 01037124។

[2029] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៤២ ឆ.៧០ KH 01167597 KH 01167601 ["វាមានរោងនៅខាងនោះ ហ្នឹងសាលាមួយវ៉ែងជិតវិហារ។ នៅរោងហ្នឹងគេដាក់អ្នកទោសស្រាល [...] អ្នកទោសធ្ងន់ គេដាក់នៅក្នុងវិហារ [...] អ្នកទោសធ្ងន់បំផុតគឺនៅក្នុងចេតីយ៍ហ្នឹង"]។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២០ KH 01037128-01037129 ["មានអគារបួន ដែលគេប្រើប្រាស់កាលនោះ ក្នុងនោះរួមមានស្តូប ព្រះវិហារ រោងពេទ្យ"។ "អ្នកទោស [...] ក្នុងព្រះវិហារ។ [...] ស្ថិតនៅខាងឆ្វេងវិហារ [...] រោងពេទ្យនោះមានដាក់ [...] អ្នកទោស"]។ ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.២២ KH 00794113។ ឯកសារ D105/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តពោធិ៍លង្កា KH 00790580-00790581។

[2030] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៧០ KH 01167601 ["គេសួរនៅកែ្សរវិហារមានតូបមួយនៅខាងលិច តូបហ្នឹងកុដណោក។"]។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២២ KH 01037129 ["ផ្ទះឈើ [...] សម្រាប់សួរចម្លើយ។"]។

[2031] ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ប៉ៀង ឆ.១ KH 01117332 [វត្តបឹងឈូក ស្ថិតនៅភូមិក្បាលថ្នល់។ មុនពួកកម្មាភិបាលនិរតីមកដល់ វត្តបឹងឈូកពុំត្រូវបានប្រើប្រាស់ធ្វើអ្វីទេ។] ឆ.១១ KH 01117335 [វត្តបឹងឈូក "ស្ថិតនៅក្នុងភូមិបឹងឈូក។""]។ ឯកសារ D219/339 កំណត់ហេតុស្តាប់ចម្លើយ ប៊ុម សេរ ឆ.១៤ ឆ.១៨ KH 01102849-01102850។ ឯកសារ D219/413 កំណត់ហេតុស្តាប់ចម្លើយ សុខ នូ ឆ.២០ KH 01117326 [កម្មាភិបាលនិរតី "បានប្រើប្រាស់វត្តនោះធ្វើជាមន្ទីរឃុំឃាំ

ក្នុងភូមិសាលាត្រាវ។ សាក្សីម្នាក់បានប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា មន្ទីរសន្តិសុខនេះបានដំណើរការរហូតដល់ចុងឆ្នាំ១៩៧៨ ដែលក្នុងមន្ទីរសន្តិសុខនេះមានរោងសម្រាប់ឃុំខ្លួនអ្នកទោស ផ្ទះសម្រាប់សួរចម្លើយ និងកន្លែងកសាង ដែល "ជាសរុប មានទំហំមួយគីឡូម៉ែត្របួនជ្រុង"[2032]។ គាត់បានបញ្ជាក់ថា មានទីតាំងសម្លាប់មនុស្សនៅ ជិតៗមន្ទីរសន្តិសុខនេះ[2033]។

ង។"]។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន ម៉ៀន ឆ.៥៤-៥៥ KH 01425207-01425208 ["គេលត់ដំ កន្លែងគេហ្នឹង [...] ក្នុងវត្តបឹងឈ្វូកហ្នឹង គេដាក់ក្នុងវិហារហ្នឹង។"]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.១៩ KH 01117259 ["វត្តបឹងឈ្វូង គឺ [...] ត្រូវបានស្គាល់ថា ជាមន្ទីរអប់រំដែលប្រជាជនមានកំហុសតិចតួចត្រូវបានគេយកទៅដាក់នៅទីនោះ។"]។ ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្បៀម ឆ.៣៥ KH 01327947។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៩ KH 01097672។

[2032] ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៦៤-៦៥ KH 01347377 [សាក្សីត្រូវបានគេយកទៅ "ដាក់គុកសាលាត្រាវ [...] ដល់ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៨ "] ឆ.១០៥ KH 01347382-01347382 ["រោងនេះ សម្រាប់ដាក់អ្នកទោសដែលមិនទាន់សម្លាប់ [...] ផ្ទះមួយ [...] ជាកន្លែងសួរចម្លើយ [...] ពីផ្ទះសួរចម្លើយមកខាងត្បូង ជាកន្លែងកសាង។ ចុះពីកន្លែងកសាងទៅ មានរោងប្រវែងពីរបីទៀត ដែលសម្រាប់ដាក់អ្នកទោសមុននឹងយកទៅសម្លាប់។"] (*កំណត់សម្គាល់* ឯកសារ D219/864.1 គំនូសបង្ហាញអំពីគុកសាលាត្រាវ KH 01347367)។ ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១០៦ KH 01335606 ["អ៊ីចឹងបួកសរុបទាំងកន្លែងចាប់ដំបូងផង កសាងផង រោងចោលហ្នឹង គឺ១គីឡូដ៏។"]។ *សូមមើលផងដែរ* ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ៊ៀង សំបូរ ឆ.២៧ KH 01117193 ["ពួកយោធា [...] បានចាប់យើង [...] ហើយបញ្ជូនទៅមន្ទីរសន្តិសុខ ក្នុងភូមិសាលាត្រាវ [...] ប្រហែលជាខែវិច្ឆិកា ឆ្នាំ១៩៧៨។"]។ *សូមមើលផ្ទុយ* ឯកសារ D219/865 កំណត់ហេតុស្តាប់ចម្លើយ ពុត ហេង ឆ.២៩ KH 01347393 ["ស៖ តើលោកអាចពណ៌នាពីកន្លែងនៃមន្ទីរឃុំឃាំងសាលាត្រាវបានទេ មានរោងប៉ុន្មាន? [...] មានផ្ទះក្បឿងមួយ។"]។

[2033] ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១០៥ KH 01347382-01347383 ["ផុតពីហ្នឹងមកដល់ប្រឡាយ ជាភូមិមួយចំនួន ជាស្រែមួយចំនួន។ តំបន់នេះ គេសម្លាប់កប់អ្នកកម្ពុជាក្រោម ខ្ញែរក្រោម។"]។

iii. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទង

575. យានចាន់ និងប្ពីរបស់គាត់ តាឡឹក "ជាមេធំនៅឃុំកំពង់ព្រៀង"[2034]។ ពួកគេគឺជាកម្មាភិបាលភូមិភាគនិរតី ហើយអនុវត្តសហឧក្រិដ្ឋកម្មរួម តាមរយៈការគ្រប់គ្រងឃុំ ៦០[2035]។ ដោយសហការជាមួយ តាកែម ពួកគេក៏ទទួលខុសត្រូវផងដែរលើឃុំ ៣០"[2036]។ យាយចាន់ និងតាឡឹក បានរស់នៅ

[2034] ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៤៣ KH 01037159 ["យាយចាន់ [...] និងតាឡឹក [...] ជាមេធំនៅឃុំកំពង់ព្រៀង។"]។ ឯកសារ D219/339 កំណត់ហេតុស្តាប់ចម្លើយ ប៊ុម សេវ ឆ.១៦ KH 01102850 [ប្ពីយាយចាន់ គឺតាឡឹក"]។ ឯកសារ D219/782 របាយការណ៍នៃការស៊ើបអង្កេត កៅ ធឿន KH 01485172 ["តាឡឹក (និរតី) ប្ពីយាយចាន់ (និរតី)"]។ ដោយសារទំហំប្រជាសាស្ត្រតំបន់ដែលយាយចាន់ និង តាឡឹក គ្រប់គ្រង ហើយការបញ្ជូលគ្នានៃឃុំ និងសហករណ៍មួយចំនួន គឺមានសាក្សីមួយចំនួន ដឹងថាយាយចាន់ និងតាឡឹក កាន់តួនាទីនៅក្នុងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា គឺកម្រិតលើថ្នាក់ឃុំ។ *សូមមើល* ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៥៧ KH 01403890 ["ពេលដែលតាឡឹក និងយាយចាន់ មកហ្នឹង គេបង្រួមអាស្រុក៤១ ស្រុក៤២ បញ្ចូលគ្នាហើយកាលហ្នឹង។ ព្រោះតាឡឹក យាយចាន់ គ្រប់គ្រងស្រុក៤១ និងស្រុក៤២"]។ ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង ឆ.៣៤ KH 01080861 ["តាឡឹក និងយាយចាន់ [...] គ្រប់គ្រងខេត្ត ទាំងមូល មិនមែនគ្រប់គ្រងតែសហករណ៍ទេ។ តាឡឹក និងយាយចាន់ គ្រប់គ្រងរាប់ម៉ឺនគ្រួសារ។"]។ សាក្សី រៀម ឌី បាននិយាយថា យាយចាន់ មានអំណាចជាងតាឡឹក *សូមមើល* ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.២៣ KH 01102815។

[2035] ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ថៃ ឆ.៨ KH 01097697 ["កម្មាភិបាលនិរតី ឈ្មោះ តាឡឹក និងយាយចាន់ ឡើងធ្វើជាមេឃុំ៦០។"]។ ឯកសារ D219/341 កំណត់ហេតុស្តាប់ចម្លើយ នក់ សាង៉ាវ ឆ.៥ KH 01102869 ["តាឡឹក និងយាយចាន់ បានមកដល់មូលដ្ឋាននេះប្រហែលក្នុងឆ្នាំ១៩៧៨ [...] គ្រប់គ្រងឃុំ៦០"]។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.១១៩ KH 01104632 ["យាយចាន់ និងតាឡឹក [...] គ្រប់គ្រងនៅឃុំ៦០។"]។ ឯកសារ D219/339 កំណត់ហេតុស្តាប់ចម្លើយ ប៊ុម សេវ ឆ.១៤-១៦ KH 01102849-01102850។ ឯកសារ D219/396 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១៣ KH 01114717។ ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្ឿង ឆ.១២៨-១២៩ KH 01335627។ ឯកសារ D219/782 របាយការណ៍នៃការស៊ើបអង្កេត កៅ ធឿន KH 01485172 ["សហករណ៍នៅវត្តបឹងឈ្ងុក ឥឡូវកាន់កាប់ដោយ តាឡឹក (និរតី)"]។ ឯកសារ D219/137 កំណត់ហេតុស្តាប់ចម្លើយ ឃៀម សោន ឆ.៥១, ៥៣-៥៤ KH 01053280 ["នៅពាក់កណ្តាលឆ្នាំ១៩៧៨ [...] ពួកគាត់ [យាយចាន់ និងតាឡឹក] ឡើងជាគណៈសហករណ៍ថ្មី [...] [នៅ] សហករណ៍កំពង់គោ"]។ *សូមមើលផងដែរ* ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២២-២៣ KH 01117259 ["ក្រោយពេលពួកកម្មាភិបាលនិរតីមកដល់ឃុំ៦០ និងឃុំ៤០ ត្រូវបានបញ្ចូលគ្នាទៅជាឃុំមួយហៅឈ្មោះឃុំរ៉ាំងកេសី។ [...] តាឡឹក និងយាយចាន់ [...] ប្រជុំ ហើយប្រាប់ថា ឃុំទាំងពីរត្រូវបានគេបញ្ចូលគ្នា"]។

[2036] <u>យាយចាន់ និងតាឡឹក</u>៖ ឯកសារ D219/334 កំណត់ហេតុស្តាប់ចម្លើយ សំ ង៉ក់ ឆ.២ KH 01102778 [នៅ "ឃុំ៣០ [...] តាឡឹក និងយាយចាន់ ជាកម្មាភិបាលនិរតី [...] គ្រប់គ្រងនៅទីនោះ។"]។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ឿង សំ ឫទ្ធ ឆ.៣៩-៤០ KH 01117195 ["ក្នុងភូមិអូរសទ្ធក [...] យាយចាន់ និង [...] តាឡឹក គឺជាប្រធានសហករណ៍"]។ ឯកសារ D219/305 កំណត់ហេតុស្តាប់ចម្លើយ ងិន ធ្ងីយ ឆ.៦ ឆ.៨ KH 01096570 ["នៅភូមិអូរសទ្ធក [...] តាឡឹក និងយាយចាន់ [...] គឺ

ជាកម្មាភិបាលនិរតី"]។ ឯកសារ D219/662 កំណត់ហេតុស្តាប់ចម្លើយនៃកិច្ចសើបសួរ អ៊ីម ឌួង KH 01236412 [នៅឃុំ៣០៖ "ស៖ តើការសម្លាប់ប្តី ឬប្រពន្ធ ដែលជាជនជាតិវៀតណាម ត្រូវបានធ្វើឡើងនៅពេលដែលភូមិភាគពាយ័ព្យគ្រប់គ្រង ឬនៅពេលដែលភូមិភាគនិរតីគ្រប់គ្រង? ឆ.ខ៖ នៅពេលនោះ វាស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិនិរតី ពីព្រោះពេលនោះយាយចាន់ បានមកដល់ហើយ។"]។ <u>តាកែម</u>៖ *សូមមើលខ១ទាហរណ៍* ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៥៥ KH 01114667 [តាកែម ដែលជាកម្មាភិបាលនិរតី [...] កាន់ការ [...] ឃុំ៣០។"]។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.៩ KH 01102812 ["ក្រោយពេលពួកនិរតីមកដល់ តាកែម ជាអ្នកគ្រប់គ្រងសហករណ៍កាច់រទេះ។"]។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.២៤ KH 01121682 ["និរតី [...] ខ្ញុំនឹកឃើញឈ្មោះ ប្រធានសហករណ៍កាច់រទេះ ឈ្មោះ តាកែម។"]។ *សូមមើលផងដែរ* ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.១១៩ KH 01104632 ["ប្រសិនបើគាត់ [យាយចាន់ និងតាឡឹក] គ្រប់គ្រងឃុំ៣០ ខ្ញុំប្រហែលជាត្រូវគាត់សម្លាប់ចោលបាត់ទៅហើយ។"]។ *កំណត់សម្គាល់* សាក្សីមួយចំនួនសំដៅទៅលើកម្មាភិបាលពាយ័ព្យម្នាក់ឈ្មោះ "ទិត្យ" ដែលមិនមែនជា យ៉ីម ទិត្យ។ បុគ្គលនេះ មានអំណាចនៅក្នុងឃុំ៣០ ក្នុងកំពង់ព្រៀង គឺដូចជានៅថ្នាក់សហករណ៍។ គាត់ត្រូវបានចាប់ខ្លួននិងសម្លាប់ដោយកម្មាភិបាលនិរតី និងជំនួសដោយកម្មាភិបាលនិរតីឈ្មោះ ហេង និងកែម។ *សូមមើល* ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.៣ KH 01102809 ["តាទិត្យ ជាមេសហករណ៍ឃុំ៣០។ តាគុន ជាមេឃុំ៣០។"]។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.២៣ KH 01121682 [តាទិត្យ ជាអនុប្រធានរបស់ តាគុន ជាប្រធានសហករណ៍កាច់រទេះ។]។ *សូមមើលផងដែរ* ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១៣៥ KH 01167610 ["តាទិត្យ [...] គឺជាប្រធានសហករណ៍កាច់រទេះ។"]។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.១១៣ KH 01037166 [តាទិត្យ "ទទួលខុសត្រូវនៅការដ្ឋានទានានៅទីនោះ"]។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៥៣ KH 01114667 ["តាទិត្យ [...] ទទួលខុសត្រូវ [...] សហករណ៍ឃុំ៣០។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៧៨ KH 01047390 ["តាទិត្យ [...] ដែលជាគណៈសហករណ៍របស់ខ្ញុំ"]។ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ សៀង ចាន់ថេន ឆ.៣២ KH 01096537 ["តាទិត្យ [...] ដែលគ្រប់គ្រងនៅខាងកើតថ្នល់ជាតិ។ "]។ ឯកសារ D219/343 កំណត់ហេតុស្តាប់ចម្លើយ រស់ ម៉ោង ឆ.២៦ KH 01102898 [តាទិត្យ "និងក្រុមគ្រួសារគាត់ទាំងអស់ត្រូវបានគេយកទៅសម្លាប់នៅវត្តប៊ីងឈ្ងុក"]។ ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀវ ហេង ឆ.១០ KH 01114701 ["តាហេង និងតាកែម មកពីភូមិភាគនិរតី ឡើងជំនួសតាទិត្យ។"]។ *ប៉ុន្តែ សូមមើល* ឯកសារ D219/343 កំណត់ហេតុស្តាប់ចម្លើយ រស់ ម៉ោង ឆ.៥ KH 01102894 [នៅអូសទ្លុក "តាទិត្យ [...] គណៈសហករណ៍"]។

ក្នុងភូមិក្បាលថ្នល់[2037] និងគ្រប់គ្រងមន្ទីរសន្តិសុខ នៅក្នុងភូមិនេះ[2038]។ ពួកគេបានទទួលជំនួយបន្ថែមពីកម្មាភិបាលភូមិភាគនិរតី ដែលបានជំនួសកម្មាភិបាលភូមិភាគពាយ័ព្យ[2039]។ តាចាន់ និងតាឡឹក "មានសកម្មភាព "ខ្លាំង" និង "ចេញបញ្ជាឲ្យអ្វីៗទាំងអស់"[2040]។

[2037] ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បៀង ឆ.១២៩ KH 01335627 ["តាឡឹក និងយាយចាន់ គាត់នៅខាងភូមិក្បាលថ្នល់ គាត់នៅហ្នឹង។"]។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន មឿន ឆ.៣៦ KH 01425204 ["បឹងឈូកកន្លែងដែល [តាឡឹក និងយាយចាន់] នៅប្រចាំ"]។ ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្បើយ ឆ.២០ KH 01062687។

[2038] ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១ KH 01117332 ["ស៖ [...] លោកបានប្រាប់យើងថា យាយចាន់ គឺជាអ្នកគ្រប់គ្រងវត្តបឹងឈូក ពេលកម្មាភិបាលនិរតីចូលមកដល់ [...] តើនេះជាសេចក្តីសង្ខេប ត្រឹមត្រូវ [...]? ឆ.១៖ ត្រឹមត្រូវហើយ"]។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន មឿន ឆ.៥៤ KH 01425207 ["អ្នកណាធ្វើអីខុសបន្តិច យាយចាន់ និងតាឡឹក យកទៅដាក់នៅវត្តបឹងឈូក"]។ ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្បើម ឆ.៣៥ KH 01327947 ["ប្រហែល ៥០ម៉ែត្រ ពីខាងត្បូងវត្តបឹងឈូក [...] ដាក់ខ្ញុះខ្ញុំ បម្រុងយកខ្ញុំទៅបាញ់ចោល គឺយាយចាន់ ហ្នឹងឯង"]។ *សូមមើលផងដែរ* ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.២៣ KH 01102815 ["តាឡឹក និងយាយចាន់ [...] គ្រប់គ្រងនៅភូមិក្បាលថ្នល់ [...] រហូតដល់កងទ័ពវៀតណាមចូលមក។"]។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៩ KH 01097672 ["ពួកគាត់ស្នាក់នៅវត្តបឹងឈូក [តាឡឹក និងយាយចាន់]"]។ ឯកសារ D219/782 របាយការណ៍នៃការស៊ើបអង្កេត កៅ ផ្ទើន KH 01485171-01485172។

[2039] <u>កម្មាភិបាលនិរតីឈ្មោះ ផៃ</u>៖ ឯកសារ D219/312 កំណត់ហេតុស្តាប់ចម្លើយ ប៉ង់ ផៃ ឆ.១២ KH 01097698 ["ផៃ [...] ដែលជាកម្មាភិបាលនិរតី និងអនុរបស់តាឡឹក និងយាយចាន់។"]។ ឯកសារ D219/408 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២៩ KH 01117260 ["កម្មាភិបាលនិរតីម្នាក់ឈ្មោះ តាផៃ ដែលគ្រប់គ្រងសហករណ៍ទឹកល្អក់ ស្ថិតនៅក្នុងឃុំដែលតាឡឹក និងយាយចាន់ គ្រប់គ្រង។"]។ <u>កម្មាភិបាលនិរតី តាហេង និងតាកែម ឃុំ៣០</u>៖ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.១៨ KH 01114661 ["ពួកនិរតីមកដល់គេបានចាប់ [...] តាយិន ដែលជាប្រធានសហករណ៍ឃុំ៣០"] ឆ.២១ KH 01114661 ["តាហេង ឡើងមកធ្វើប្រធានសហករណ៍ជំនួសកម្មាភិបាលពាយ័ព្យឈ្មោះ យិន។"]។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៦ KH 01167592 ["នៅឃុំ៣០ (ឃុំ៣០) [...] តាយិន ជាគណៈសហករណ៍ [...] រហូតដល់ឆ្នាំ១៩៧៨។ នៅចុងឆ្នាំ១៩៧៨ ឬដើមឆ្នាំ១៩៧៩ មានប្រធានសហករណ៍ផ្សេងទៀត ឈ្មោះ តាកែម មកជំនួស តាយិន។ តាកែម មកពីនិរតី។ បានសម្លាប់ យិន ហ្នឹងចោលហើយ។ តាកែម តាគន់ និងតាសែ មានអង្គភាពគេច្រើន។ តាកែម និងតាគុន ជាគណៈសហករណ៍ គេក្រោយមានទៀត ផ្សេងទៀត តាហេង ជាគណៈសហករណ៍។"]។ *សូមមើលផ្ទុយ* ឯកសារ D193/21.2.1 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២២ ឆ.២៨ KH 01047383-01047384 ["យិន (ប្រុស) និង ទី (ប្រុស) ជាអ្នកគ្រប់គ្រងនៅភូមិអ្ងសទ្ធ។" [...] កម្មាភិបាលនិរតី "ស ជាគណៈសហករណ៍។"]។ <u>កម្មាភិបាលនិរតី តាញ៉ន នៅឃុំ១០</u>៖ ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៣២ KH 01151001 [នៅសហករណ៍កំពង់គោ កម្មាភិបាលពាយ័ព្យ តារ៉ុយ និងផន ត្រូវជំនួសដោយកម្មាភិបាលនិរតី ប្រធានឈ្មោះ តាញ៉ន។]។ ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បៀង ឆ.៧៨ KH 01335622 [នៅតំបន់ដំណាក់រទេះ៖ "ស៖ តើមានរឿងអ្វីកើតឡើងចំពោះ រ៉ុយ និងផយ? ឆ.៧៨៖ ពេលដែលនិរតីចូលមក [...] ញ៉ន គេជា

576. យាយចាន់ និងតាឡឹក បានធ្វើជាប្រធានអង្គប្រជុំ និងវគ្គសិក្សាជាច្រើនស្តីពីផលិតកម្ម[2041] បានចាត់ចែង និងចូលរួមក្នុងអាពាហ៍ពិពាហ៍ជាក្រុមដោយបង្ខំ[2042] បានតម្រង់ទិសដៅលើប្រជាជនដែលពួកគាត់ចាត់ទុកជាខ្មាំង ដូចជា "បញ្ញវន្ត ឬសេអ៊ីអាអាមេរិកាំង"[2043]។ ពួកគេបានបញ្ជាក់ថា អ្នក "ដែលក្បត់អង្គការ [...] ត្រូវតែវាយខ្ទោះ និងវាយចោល"[2044] ហើយ "បញ្ជាឲ្យយកមនុស្សទៅ

មេឃុំ ហើយដែលថាមកពីកំពង់ឆ្នាំង។"]។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.១៨-១៩ KH 01129772-01129773 [នៅសហការណ៍កំពង់គោ៖ "តារ៉ុយ គឺជាគណៈឃុំ [...] តារ៉ុយ ត្រូវបានកម្ទាភិបាលនិរតី តាមប្រមាញ់នៅពេលដែលពួកគេមកដល់ ហើយតារ៉ុយ ត្រូវបានគេបាញ់ស្លាប់នៅក្នុងភូមិកាច់រទេះ។ [...] តាញ៉ន គឺជាកម្ទាភិបាលនិរតី។ តាញ៉ន គឺជាគណៈសហការណ៍"]។

[2040] ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៨០ KH 01403895។

[2041] ឯកសារ D219/311 កំណត់ហេតុស្តាប់ចម្លើយ ពែង សាន្ត ឆ.៩ KH 01097691 ["នៅវត្តបឹងឈ្ងុក [...] [វគ្គរៀនសូត្រ] មានតាឡឹក និងយាយចាន់ ជាអ្នកដឹកនាំ។ គេនិយាយតែអំពីការបង្កបង្កើនផលប៉ុណ្ណោះ។"]។ ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បៀង ឆ.១៣៨-១៣៩ KH 01335628 ["នៅសហការណ៍ភូមិថ្មី [...] ពួកគេ [យាយចាន់ និងតាឡឹក] និយាយអំពីការបង្កបង្កើនផល"]។

[2042] ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្បៀម ឆ.៤៨ ឆ.៥០ ឆ.៥៨ KH 01327949-01327950 ["រៀបម្តង១០គូរ ហើយរៀបក្រោយម្តងទៀត១៥គូរ។ [...] រៀបនៅបឹងឈ្ងុក រៀបពីខាងត្បូងវត្តហ្នឹងឯង។ [...] មានតែតាឡឹក យាយចាន់ ហ្នឹងឯង ដែលប្រកាសរៀបគូរណាគូរណានោះ។"]។ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈេន ឆ.៤៤ ឆ.៦៦ ឆ.៧១ KH 01327959 KH 01327961-01327962 ["ប្រធានសហការណ៍ គេបានហៅប្រមូលផ្តុំ គឺយាយចាន់ និងតាឡឹក" ហើយពួកគេបានចូលរួមពិធីរៀបការ។ "នៅបឹងឈ្ងុក លើកទី១ គឺ១០គូរ លើកទី២ គឺ៨-៩គូរ។"]។

[2043] ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បៀង ឆ.១៤៣ KH 01335629 ["ប្រជាជនអ្នកចេះដឹង [...] គេ [យាយចាន់ និងតាឡឹក] ចោទថា បញ្ញាវន្ត ឬសេ.អ៊ី.អា ជាអាមេរិកកាំងអ៊ីចឹងទៅ។"]។

[2044] ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បៀង ឆ.១៤៨ KH 01335629 ["ផលវិបាក ដែលគាត់និយាយ ឲ្យស្មោះត្រង់នឹងអង្គការ កុំឲ្យក្បត់អង្គការ ការងារអ៊ីក៏ដោយ យើងបម្រើសមូហភាពឲ្យបានត្រឹមត្រូវ ហើយអ្នកណាក្បត់ ហូបចុកលួចលាក់អ៊ី គឺត្រូវតែវាយចោល។"]។

សម្លាប់ចោល"[2045]។ តាឡឹកបានចូលរួមក្នុងការសួរចម្លើយយ៉ាងហោចណាស់សាក្សីម្នាក់ នៅមន្ទីរសន្តិសុខកាច់រទេះ ហើយយាយចាន់បានចូលរួមដោយផ្ទាល់ក្នុងការសម្លាប់មនុស្ស[2046]។

577. យានចាន់ និងតាឡឹក បានទទួលព័ត៌មានតាមរយៈនីរសារ និងរបាយការណ៍[2047]។ សាក្សីម្នាក់បាននិយាយថា គាត់បានសង្ខេបរបាយការណ៍អំពីកសិកម្មពីការដ្ឋានផ្សេងៗថា គាត់ "បានដឹងយ៉ាង

[2045] ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ហ្ស៊ីម ឆ.៣៦ KH 01327947 ["តា [ឡឹក] [...] ហៅខ្ញុំយកទៅដាក់ខ្ទោះហ្នឹង គឺពេលព្រឹកឡើងប្រុងយកទៅបាញ់ចោល។ តាមបញ្ជារបស់តាឡឹក និងយាយចាន់ គឺយកមនុស្សទៅសម្លាប់ច្រើនគ្នាណាស់។"]។ *សូមមើលផងដែរ*ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៩ KH 01167593 ["តាឡឹក និងយាយចាន់ ក៏សម្លាប់សាហាវដែរ។ គាត់កាចណាស់។"]។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ រណ្ណ ណាក់ ឆ.១១៩ KH 01104632។ ឯកសារ D219/863 កំណត់ហេតុស្តាប់ចម្លើយ ឡៃ លឿម ឆ.៧៨ KH 01347364 [តាឡឹក និងយាយចាន់ "អ្នកគ្រប់គ្រងហ្នឹង គឺយោរយៅបណ្តោយ។ ចរឹកគេហ្នឹង សាហាវយោរយៅ។"]។ ឯកសារ D219/299 កំណត់ហេតុស្តាប់ចម្លើយ ម៉ក់ ម៉ែត ឆ.១៣ KH 01096513។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ឌី ឆ.២៣ KH 01102815។ ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ហ្ស៊ីង ឆ.១២៩ KH 01335627។ ឯកសារ D219/304 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ប៊ុនឈឿន ឆ.១៩ KH 01096565។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.៤២ KH 01117196 ["យាយចាន់ គឺជាមនុស្សសាហាវណាស់ គាត់ជាស្ត្រីម្នាក់ដែលសាហាវដូចខ្លាអ៊ីចឹង។"]។

[2046] <u>តាឡឹក</u>៖ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៦៨ ឆ.៧៣ ឆ.៧៥ ឆ.៧៧ KH 01167601-01167603 [សាក្សី ត្រូវបានសួរចម្លើយដោយ "អាខន, អាប៊ីាង, អាហាន, តាឡឹក និងអាឡាំ។ [...] បើនិយាយសំខាន់ជាងគេតែម្តង គឺតាឡឹកតែម្តង។ [...] តាឡឹក មកដល់ គាត់ធាក់ខ្ញុំកណ្តាលមុខ។ [...] ដល់អ៊ីចឹង ខ្ញុំនឹកឃើញពួកហ្នឹងនិយាយ ហើយគេសួរខ្ញុំថា មែនឬអត់? ខ្ញុំក៏ឆ្លើយថា មែន។"។ តាឡឹក បានយកកន្ទុយបារីដុតសាក្សី។]។ <u>យាយចាន់</u>៖ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.៣៩-៤១, ៤៣-៤៤ KH 01117195-01117196 ["ចុងឆ្នាំ១៩៧៨ [...] នៅជិតកន្លែងរោងបាយរួមក្នុងភូមិអូរសទ្ធក។ [...] ខ្ញុំបានឃើញអ្នករងគ្រោះដែលគេសម្លាប់ប្រហែលជា១៦ ទៅ១៧នាក់។ [...] ខ្ញុំអាចស្គាល់អ្នកដែលសម្លាប់នៅពេលនោះ គឺគេជាពួកនិរតីឈ្មោះគាត់ យាយចាន់ ជាមួយនឹងកងការពាររបស់គាត់។ [...] គេប្រើកាំបិត ហើយនិងពូថៅសម្លាប់អ្នកទាំងនោះ គេកាត់ជនរងគ្រោះឲ្យស្លាប់ ហើយគេកាត់បំពង់កថែមទៀត។ [...] [យាយចាន់] កាន់កាំបិត។ [...] កន្លែងនេះនៅប្រហែល១គីឡូម៉ែត្រខាងជើងវត្តកាច់រទេះ ហើយនៅខាងកើតផ្លូវជាតិលេខ៥។"]។ ឯកសារ D219/413 កំណត់ហេតុស្តាប់ចម្លើយ សុខ ឌូ ឆ.១ KH 01117323 ["ស៖ [...] លោកស្រីមានវត្តមាននៅវត្តបឹងឈូក និងបានឃើញការសម្លាប់កូនប្រសាស្រីរបស់លោកស្រីឈ្មោះ ប៊ីាង គឺត្រូវបានសម្លាប់ដោយយាយចាន់ នៅមុខដើមពោធិ៍។ [...] សូមលោកស្រីគូសបញ្ជាក់ [...] ព័ត៌មានសង្ខេបខាងលើពិតជាផ្ទុះបញ្ចាំងពីអ្វីដែលលោកស្រីបានប្រាប់យើង [...]? ឆ.១៖ ចាស ត្រឹមត្រូវ"]។ ឯកសារ D219/339 កំណត់ហេតុស្តាប់ចម្លើយ ប៊ុម សេរ ឆ.១៤ KH 01102849 ["ក្នុងពេលដែលរស់នៅក្នុងភូមិបឹងឈូក ខ្ញុំបានឃើញនារីម្នាក់ត្រូវបានយាយចាន់ បាញ់សម្លាប់នៅក្នុងវត្តបឹងឈូក។"]។

[2047] ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហ៊ៀង ឆ.១ KH 01117332 ["ស៖ [...] លោកបាននិយាយថា យាយចាន់ ធ្លាប់ប្រើនីរសារគាត់ឲ្យទៅយកលោក [...] ដើម្បីធ្វើរបាយការណ៍ពីសមិទ្ធិផលការងារឲ្យគាត់ ព្រោះលោកចេះអក្សរ។ [...] តើនេះជាសេចក្តីសង្ខេប ត្រឹមត្រូវ [...]? ឆ.១៖ ត្រឹមត្រូវ"]។ ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៤១-

ច្បាស់ […] ស្ថិតក្នុងដៃរបស់យាយចាន់" ដែលសាក្សីរូបនេះជឿថា របាយការណ៍ទាំងនេះក្រោយមកត្រូវបានប្រើប្រាស់នៅក្នុងកិច្ចប្រជុំថ្នាក់តំបន់[2048]។ អតីតសមាជិកគណៈសហការណ៍ម្នាក់នៅក្នុងឃុំនេះ ដែលបានធ្វើការស្ថិតក្រោមការដឹកនាំរបស់កម្មភិបាលភូមិភាគនិរតីបាននិយាយថា "បុគ្គលគ្រប់រូបត្រូវតែរាយការណ៍ […] អំពីការងាររបស់ខ្លួន"[2049]។

578. ជារួម ប្រធានបទអំពី "ខ្មាំង" ផ្ទៃក្នុង ត្រូវបានពិភាក្សា នៅក្នុងកិច្ចប្រជុំ និងមានលើកឡើងនៅក្នុងរបាយការណ៍។ ការរំឭកជាច្រើនដងត្រូវបានធ្វើឡើង "អំពីការស្វែងរកខ្មាំងណាក់ខ្លួន"។ "ភាសាគំរាមកំហែង […] ទាក់ទងនឹងការលុបបំបាត់ខ្មាំងស៊ីរួងផ្ទៃក្នុង" ត្រូវបានប្រើប្រាស់ ហើយការប្រកាសនានាត្រូវបានធ្វើឡើងអំពី "ការចាប់ខ្លួនខ្មាំងផ្ទៃក្នុងដែលបានណាក់ខ្លួននៅក្នុងជួررបក្សررបស់យើង"[2050]។

---

[42] KH 01115003 [ជាសមាជិកគណៈសហការណ៍៖ "ខ្ញុំរាយការណ៍តាមភារកិច្ច […] អ្នកកាន់កាប់ប្រជាជនផ្ទាល់រឿងធ្វើស្រែចម្ការ។ ខ្ញុំត្រូវរាយការណ៍ទៅថ្នាក់លើពាក់ព័ន្ធរឿងធ្វើស្រែចម្ការ ដឹកប្រឡាយជាដើម។ […] ខ្ញុំធ្លាប់រាយការណ៍ ឧទាហរណ៍អ្វីជាការងាររបស់ខ្ញុំដែលដាក់ឲ្យប្រជាជនធ្វើតាមផែនការ ឬក៏មិនបានជាដើម។"]។

[2048] ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១៤-១៥ KH 01117336 ["ពួកណ្ណាបជាអ្នកយកررបាយការណ៍ពីការដ្ឋានផ្សេងៗរួមមាន អ្ងសទ្ធក ក្បាលផ្ទល់ កំពង់គោ […] មកឲ្យខ្ញុំបូកសរុប។ […] ررបាយការណ៍ដែលខ្ញុំត្រូវសررសេរ គឺជាការបូកសរុបលទ្ធផលការងារទាំងអស់ នៅក្នុងការដ្ឋានការងារដែលខ្ញុំបានរៀបរាប់មុននេះ គឺតួលេខសរុបនៃចំនួនហិកតានៃសន្ធូងពង្រោះ (ដំណាំ ពោត ដំឡូង...។ល។ និងស្រែដែលបានភ្ជួរ។ […] លុះក្រោយពីការមកដល់ررបស់ពួកនិរតី ពិសេសក្នុងពេលយាយចាន់ គ្រប់គ្រងបាន ជួនកាលគេប្រើឲ្យខ្ញុំធ្វើការងារនេះ"] ឆ.១៦ KH 01117337 ["ខ្ញុំច្បាស់ថា ررបាយការណ៍ដែលខ្ញុំបានធ្វើនោះ គឺនឹងធ្លាក់ក្នុងដៃយាយចាន់។ ជាទូទៅ ពេលពួកណ្ណាបមកដឹក ខ្ញុំឲ្យទៅធ្វើررបាយការណ៍នោះ គេប្រាប់ខ្ញុំច្បាស់ៗថា គេត្រូវការررបាយការណ៍នោះ នៅម៉ោងប្រាំបី ឬប្រាំបួនព្រឹក នៅថ្ងៃបន្ទាប់សម្រាប់ប្រជុំ គឺជាការប្រជុំនៅថ្នាក់តំបន់"]។

[2049] ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៤២ KH 01151003។

[2050] ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ឌី ឆ.១៧ KH 01102814 [នៅកាច់ررទេះ "ខ្ញុំបានចូលررួមប្រជុំ ៤ ទៅ ៥ ដងដែរ […] ដឹកនាំដោយ តាកែម និងតាហេង […] ក្នុងសហការណ៍។ ពួកគេ […] ក៏បានរំឭកពួកយើងផងដែរអំពីការស្រាវជ្រាវរកខ្មាំងបង្កប់ស៊ីរួងផ្ទៃក្នុង។ នេះគឺពួកគេចង់សំដៅទៅលើអ្នកភូមិ ឬសមាជិកសហការណ៍ ដែលប្រឆាំងនឹងពួកគេ។ ពួកគេក៏បានឲ្យប្រជាជនឡើងប្តេជ្ញាថានឹងដើរតាមមាគ៌ាអង្គការជារៀងរហូត។"]។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃ្យៀន ឆ.៤៧-៤៨ KH 01129725 ["តាញ៉ូន ជាប្រធានគណៈសហការណ៍កំពង់គោ ដឹកនាំអង្គប្រជុំ […] កិច្ចប្រជុំទាំងបីលើកនោះ ផ្តោត […] និយាយអំពី […] បញ្ហាខ្មាំងស៊ីរួងផ្ទៃក្នុង។ នេះគឺជាភាសាគំរាមកំហែង […] ទាក់ទងទៅនឹងការកំចាត់ខ្មាំងស៊ីរួងផ្ទៃក្នុង"]។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហៀង សំបូរ ឆ.១ ឆ.១២ ឆ.១៤ KH 01117188 KH 01117190 ["នៅភូមិថ្មី […] ការប្រជុំគេរៀបចំឡើង […] ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧។ […] គេ [កម្មាភិបាលនិរតី] បានប្រកាសតាមមីក្រូថា […] គេធ្វើការចាប់ចងតែពួកខ្មាំងផ្ទៃក្នុង ដែលកំពុងណាក់ខ្លួននៅក្នុងជួررបស់យើង។ គេបានប្រាប់យើងថា […] គេចាប់តែខ្មាំងដែលបង្កប់ស៊ីរួងផ្ទៃក្នុងតែប៉ុណ្ណោះ។ គេបាននិយាយផងដែរថា គេសំដៅررកចាប់អ្នកដែលបានចាប់មនុស្សខុសពីមុនមក។"]។

579. ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តក្នុងតំបន់ឃុំកំពង់ព្រៀងគឺអនុលោមតាម និងស្ថិតក្នុងសកម្មភាពបន្ថែមនៃគោលនយោបាយសហឧក្រិដ្ឋកម្មរួម។ តាម៉ុកដែលជាសមាជិកដឹកនាំនៃសហឧក្រិដ្ឋកម្មរួមបានចូលរួមធ្វើជាប្រធាននៃកិច្ចប្រជុំក្នុងភូមិសាលាគ្រាវ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ដល់ចុងឆ្នាំ១៩៧៨ ដែលក្នុងនោះ គាត់បានព្រមានអ្នកចូលរួមចំនួន ៣០០ ទៅ ៤០០ នាក់ "កុំឲ្យចាញ់បោកខ្មាំងពីព្រោះប្រសិនបើខ្មាំងទាំងនោះរត់គេចខ្លួន ពួកគេអាចមានគ្រោះថ្នាក់"[2051]។ សាក្សីម្នាក់បាននិយាយថា គាត់បានឃើញសមាជិកគណៈកម្មាធិការភូមិភាគ និងតំបន់ជាច្រើននាក់បានទៅធ្វើទស្សនកិច្ចមន្ទីរសន្តិសុខសាលាគ្រាវ និងបានជួបជាមួយនឹង "ប្រធានផ្នែកសម្លាប់មនុស្ស" ហើយជាលទ្ធផល បានចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យចំនួនពីរនាក់"[2052]។

iv. ឧក្រិដ្ឋកម្ម

<u>ការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការប្រព្រឹត្តដោយអមនុស្សធម៌)</u>

580. នៅក្នុងតំបន់ឃុំកំពង់ព្រៀង ពលករដែលខ្វះរបបអាហារត្រូវបានបង្ខំឲ្យ "ធ្វើការធ្ងន់ធ្ងរ" "មិនឈប់មិនឈរឡើយ"[2053]។ ការងារទាំងនេះរួមមានធ្វើស្រែ លើកទំនប់ និងជីកប្រឡាយ និងប្រមូល

[2051] ឯកសារ D219/446 កំណត់ហេតុស្តាប់ចម្លើយ ពិក ស៊ីម ឆ.៣-៥ ឆ.៨ KH 01129695-01129696។ *សូមមើលផងដែរ* ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.២២ ឆ.៤៩ KH 01347373 KH 01347376 ["មីទ្ធិញនោះ ធ្វើនៅតំបន់ ៤ កងចល័តតំបន់៤ នៅភូមិសាលាគ្រាវ ក្រោមអធិបតីប្រធានភូមិភាគ [...] នៅឆ្នាំ១៩៧៨ [...] ប្រហែលខែ៨ យ៉ាងយូរបំផុតខែ ៩។"]។

[2052] ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៧៥ ឆ.៧៧ KH 013247379 [សាក្សីបានឃើញសមាជិកគណៈភូមិភាគ "កំពុងទស្សនៈកិច្ច [គុកសាលាគ្រាវ] ២ដង [...] ពួកគណៈតំបន់មកជួបប្រជុំជាមួយប្រធានផ្នែកសម្លាប់ នៅក្រោមដើមឈើមួយ។ ដល់ឃើញអ៊ីចឹង ពីរថ្ងៃបីថ្ងៃ ឃើញគេចាប់តាធំ ជាប្រធានគណៈកងចល័តតំបន់ ក្រោយមកហៅតាវ៉ន។ តាវ៉ន ហ្ម៊ីង ក៏គណៈតំបន់ក្តាប់ចល័តហ្ម៊ីងដែរ គេចាប់។"]។ ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៩៦ KH 01335604 ["មកច្រើន គឺគណៈតំបន់ និងគណៈភូមិភាគ។ ប៉ុន្តែអ្នកមកជួបតែមេអ្នកសម្លាប់នៅផ្ទះតែប៉ុណ្ណឹងទេ មិនបានទៅមើលអ្នកទោសទេ។"]។

[2053] <u>លក្ខខណ្ឌការងារ</u>៖ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន ម៉ៀន ឆ.៥៣-៥៤ KH 01425207 ["ឲ្យយើងធ្វើមិនសូវឈប់ មិនសូវអី [...] ឲ្យយើងធ្វើមិនឈប់មិនឈរអ៊ីចឹងណា។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.១១២ KH 01047394 ["គេ [...] ឲ្យធ្វើពលកម្មខ្លាំង។"] ឆ.៥៦ KH 01047387 ["គេមិនឲ្យសម្រាកទេពេលធ្វើការ។"]។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៥២ KH 01037159 ["ធ្វើការពីម៉ោង៥ព្រឹក ដល់ម៉ោង១១។ ហើយ [...] ពីម៉ោង១ រហូតដល់ម៉ោង៥។"]។ ឯកសារ D219/25 កំណត់ហេតុស្តាប់ចម្លើយ ស សម័យ ឆ.៤៩ KH 01029977 ["ខ្ញុំធ្វើការចាប់ពីម៉ោងប្រាំមួយព្រឹក រហូតដល់ម៉ោងដប់ពីរ។ [...]។ បន្ទាប់ពីសម្រាកកន្លះម៉ោង យើងចាប់ផ្តើមធ្វើការរហូតដល់ម៉ោង

លាមក និងអាចម៍សត្វសម្រាប់ផលិតជី[2054]។ សាក្សីម្នាក់បានបញ្ជាក់ថា ពលករពុំមានសេរីភាពក្នុងការដើរហើរឡើយ ហើយដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បាននិយាយថា កម្មាភិបាលបានត្រួតពិនិត្យពលករ ក្នុងពេលពួកគេកំពុងធ្វើការងារ[2055]។ "នៅពេលពលករមិនបានបំពេញការងារឲ្យបានល្អ ពួកគេត្រូវបានហៅឲ្យទៅប្រជុំដើម្បីកសាង"[2056]។

581. កម្មាភិបាលភូមិភាគពាយ័ព្យ "រាប់ពាន់នាក់" ត្រូវបានដកអាវុធ ទម្លាក់មុខតំណែង និងបញ្ជូនទៅភូមិកាច់រទេះ សាលាត្រាវ និងអ្ងសទ្ធុកដើម្បីធ្វើការងារដោយបង្ខំ ដែលក្នុងករណីជាច្រើន ដើម្បី "លត់ដំ/អប់រំឡើងវិញ"[2057]។ អតីតកម្មាភិបាលភូមិភាគពាយ័ព្យ ឌីក ស៊ីម បាននិយាយថា ពួកគេ "បាន

ប្រាំមួយល្ងាច។"]។ <u>កង្វះអាហារូបត្ថម្ភ</u>៖ ឯកសារ D219/305 កំណត់ហេតុស្តាប់ចម្លើយ ងិន ធីយ ឆ.១៧ KH 01096572 ["នៅពេលដែលពួកនិរតីចូលមកភូមិ [អ្ងសទ្ធុក] គេ [...] ឲ្យអាហារកម្មាភិបាលពាយ័ព្យតិចតួច"]។ ឯកសារ D219/393 កំណត់ហេតុស្តាប់ចម្លើយ ឌិក ស៊ីម ឆ.៥-ខ KH 01114682-0114683 ["ពួកយើង [អតីតពួកពាយ័ព្យ] ស្លាប់រាល់ថ្ងៃៗ ដោយារខ្វះម្ហូបអាហារនេះ។"]។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន ម៉ឿន ឆ.៥៣ KH 01425207 ["រាជិតយួនចូល [...] ប្រជាជនវាលត់ដំដល់កម្រិត ដូចឲ្យយើងហូបបបរវារ ហើយបន្ថយរបបយើង។ [...] មិនឲ្យយើងហូបគ្រប់គ្រាន់"]។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៤៩-៥០ KH 01114666 ["មនុស្សដាច់បាយ [...] ជំនាន់ពួកនិរតី។ [...] មនុស្ស [...] គឺមានតែស្បែក និងឆ្អឹង ហើយទន់ខ្សោយណាស់។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.១១២ KH 01047394 ["ខ្ញុំហូបចុកមិនគ្រប់គ្រាន់ រហូតដល់ខ្ញុំមានរូបរាងស្គមស្គាំង។"]។ ឯកសារ D219/25 កំណត់ហេតុស្តាប់ចម្លើយ ស សម័យ ឆ.៧៣ KH 01029980។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៥២ KH 01037159។

[2054] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.២ KH 01097669។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៥១ KH 01037159។ ឯកសារ D219/840 Khim Det កំណត់ហេតុស្តាប់ចម្លើយ , A58 EN 01492888 ។ ឯកសារ D219/25 កំណត់ហេតុស្តាប់ចម្លើយ ស សម័យ ឆ.៤៨ KH 01029977។ ឯកសារ D219/307 កំណត់ហេតុស្តាប់ចម្លើយ ប៉ាល់ យ៉ុង ឆ.២៤-២៥ KH 01096598។ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀង ចាន់ថេន ឆ.ខ KH 01096530។ ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.៤០ KH 01023859។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន ម៉ឿន ឆ.៤១ KH 01425205។

[2055] ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១០ KH 01117335។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៥៥ KH 01037160។ *សូមមើលផងដែរ* ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀវ ហេង ឆ.៧ KH 01114701។

[2056] ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.២ KH 01117333។ *សូមមើលផងដែរ* ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៤៣ KH 01151003។

[2057] ឯកសារ D219/446 កំណត់ហេតុស្តាប់ចម្លើយ ឌិក ស៊ីម ឆ.៣ ឆ.១៤ KH 01129695 KH 01129698 [សាក្សី គឺ "គេបានដកអាវុធ ប្រហែលជាអំឡុងខែមិថុនា ឆ្នាំ១៩៧៨" ហើយ "បន្ទាប់មកគេបញ្ជូនខ្ញុំទៅមន្ទីរកសាង នៅភូមិសាលាត្រាវ។" "គេបញ្ជូនខ្ញុំទៅធ្វើស្រែ [...] និងលើកទំនប់ នៅភូមិសាលាត្រាវ។ ខ្ញុំមិនដឹងថាអ្នកដទៃទៀត ត្រូវបានគេបញ្ជូនទៅទីកន្លែងណានោះទេ។"]

ធ្វើការពីម៉ោង ៤ ព្រឹករហូតដល់ម៉ោង ១១ យប់"។ ពួកគេ "ទទួលបានបញ្ជាឲ្យធ្វើការដោយគ្មានឈប់សម្រាក" និងពួកគេ "ត្រូវធ្វើការឲ្យបានខ្លាំងក្លាជាងពលករនៅក្នុងកងចល័តផ្សេងៗទៀត"[2058]។

582. ដោយសារតែលក្ខខណ្ឌការងារ និងកង្វះអាហារទើបពលករមាន "ការហត់នឿយហួសហេតុ" ហើយពួកគេ "បន្តធ្វើការងាររហូតដល់ឈឺ"[2059]។ ពលករហេវហត់ដែលយក ឬរកអាហារ ដោយគ្មានការអនុញ្ញាត ត្រូវបានវាយដំ ឬចាប់ខ្លួន[2060]។

(*កំណត់សម្គាល់* ឯកសារ D219/392 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម, ឆ.២០ KH 01114675 ["គេដាក់ពួកយើងជាមួយនឹងអតីតយោធារាប់ពាន់នាក់ទៀត។"])។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៣២ KH 01104619 [នៅភូមិកាច់រទេះ "ពួកគេបានដកកម្មាភិបាលពាយ័ព្យចេញ។ [...] បង្ខំឲ្យធ្វើស្រែ"]។ ឯកសារ D219/305 កំណត់ហេតុស្តាប់ចម្លើយ ងិន ធីយ ឆ.១៧ KH 01096572 [នៅភូមិអូសទូក "កម្មាភិបាលនិរតី [...] បានចាប់ខ្លួន និងដាក់គុកកម្មាភិបាលពាយ័ព្យ។ គេ [...] បង្ខំឲ្យធ្វើការ។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៣៥ KH 01047385 [នៅភូមិអូសទូក៖ "អ្នកខ្លះ [ពួកពាយ័ព្យ] ត្រូវគេទម្លាក់តំណែងមកជាប្រជាជនធម្មតា"]។

[2058] ឯកសារ D219/393 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.៤ KH 01114682។ ឯកសារ D219/392 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម, ឆ.២០ KH 01114675។ ឯកសារ D219/446 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.១៥ KH 01129698។ *សូមមើលផងដែរ* ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.១០២ KH 01151012 ["ការងារធ្ងន់ គឺដើម្បីកសាងប្រទេស។"]។

[2059] ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.១០២ KH 01104629 ["អ្នកទោសដែលមានរូបរាងស្គមស្គាំងម្នាក់មិនអាចកាប់ដីទៅមុខបាន។"]។ ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.៤៥ KH 01023859 [ក្រោយពីពួកកម្មាភិបាលនិរតីមកដល់ [...] ដោយសារតែរបបអាហារ និងលក្ខខណ្ឌការងារដូចមុនដដែល ប្រជាជននៅតែបន្តឈឺ"]។

[2060] <u>មន្ទីរសន្តិសុខកាច់រទេះ</u>៖ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ឌី ឆ.៧ KH 01102811 ["ក្នុងអំឡុងពេលផ្ទេរអ្នកទោសទៅទីតាំងថ្មី អ្នកទោសខ្លះត្រូវបានគេវៃ ដោយសារតែបេះបោច ឬរើសអ្វីម្យ៉ាងហូបតាមផ្លូវ។"]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.១១៨ KH 01328012 ["កំហុសយើងដូចថាវាឃ្លានពេកទៅ វាមានចិត្តលួចកាច់ដំឡូងលួចបូតស្រូវយកមកហូបទៅ គេចាប់កំហុសយើងត្រង់ហ្នឹងឯង។"]។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ផោម សុដា ឆ.២៥ KH 01037130 ["អ្នកទោសភាគច្រើនគេចោទថា លួចរបស់ហូប។"]។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៤០ KH 01104620 ["បងស្រីជីដូនមួយរបស់ខ្ញុំ និងប្តីគាត់ បានលួចដំឡូង ឬត្រាវ។ ដូច្នេះហើយ បានជាគេចាប់ពួកគាត់ដាក់គុក។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២៣០ KH 01047409 [រ៉ត ត្រូវគេឃុំឃាំង "ប្រហែលពា ទៅ៤ខែ [...] រ៉ត គាត់បានលួចរបស់ហូប ដោយសារគាត់ឃ្លានពេក។"]។ <u>មន្ទីរសន្តិសុខសាណាត្រាវ</u>៖ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឿង សំបូរ ឆ.២៧ KH 01117193 ["ពួកយោធាបានឃើញយើងហូបបាយ ពេលដែលយើងកំពុងមានភារកិច្ចយាមស្រូវ គេក៏បានចាប់យើង [...] ហើយបញ្ជូនយកទៅដាក់ឃុំឃាំងនៅមន្ទីរសន្តិសុខក្នុងភូមិសាណាត្រាវ [...]។ គេចាប់ខ្ញុំប្រហែលជាខែវិច្ឆិកា ឆ្នាំ១៩៧៨។"]។

<u>ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការប្រព្រឹត្តដោយអមនុស្សធម៌)</u>

583. នៅក្នុងតំបន់ឃុំកំពង់ព្រៀង កម្មាភិបាលភូមិភាគនិរតីបានចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យ នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងជួរបក្សកុម្មុយនីស្ត[2061]។

[2061] ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.២៥ KH 01114662 ["ស៖ [...] ចំនួនកម្មាភិបាលពួកពាយ័ព្យប៉ុន្មាននាក់ ដែលត្រូវបានពួកនិរតីចាប់ខ្លួន [...]? ឆ.២៥៖ [...] វាមានចំនួនរាប់រយនាក់ ដោយសារពេលនោះ ប្រធាន និងអនុប្រធាន និងសមាជិកគណៈសហករណ៍ទាំងអស់ត្រូវបានគេចាប់ខ្លួន។"]។ ឯកសារ D6.1.625 កិច្ចសម្ភាសន៍ SOAS ជាមួយ តិក ស៊ីម EN 00352051 ["ការចាប់ខ្លួនគឺចុះថ្នាក់កងអនុសេនាតូច។"] (*កំណត់សម្គាល់* ឯកសារ D219/446 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.២៧ KH 01129699 ["នៅពេលដែលពួកនិរតីមកដល់ ពួកគេ ចាប់កម្មាភិបាលពាយ័ព្យ ដែលស្ថិតនៅក្នុងតួនាទីគ្រប់គ្រង យកចេញទៅបាត់។"])។ ឯកសារ D219/305 កំណត់ហេតុស្តាប់ចម្លើយ ងិន ធ្ងីយ ឆ.១៧ KH 01096572 [នៅភូមិអ្ងសទ្ងក "កម្មាភិបាលនិរតី [...] បានចាប់ខ្លួន និងដាក់គុកកម្មាភិបាលពាយ័ព្យ។"]។ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈេន ឆ.៣៤ KH 01327958 ["ដឹងតែថាពួកពាយ័ព្យដឹងតែវាចាប់ទាំងអស់។"]។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.២២ KH 01121681។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៣៥ KH 01047385 *សូមមើលផងដែរ* ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.១៥ KH 01117190។ ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.៣៨ KH 01023858។ ឯកសារ D6.1.620 កិច្ចសម្ភាស SOAS ជាមួយ រៀម ឌី KH 00789292 ["នៅពេលពួកនិរតីមកដល់ទីនេះ ពួកគេបានចាប់កម្មាភិបាលតំបន់៤ នៃភូមិភាគពាយ័ព្យ កម្មាភិបាលស្រុក៤២ និងកម្មាភិបាលសហករណ៍ខ្ពះ។"]។ ឯកសារ D219/841 កំណត់ហេតុស្តាប់ចម្លើយ ហេង គុយឡាង ឆ.៤០ KH 01335656 ["តាដែលគាត់ឡើងបញ្ជី ខ្ញុំភ្លេច ដែលឡើងបញ្ជីសរុប ពេលដែលពួកនិរតីចូលមកដល់ពាយ័ព្យ។"]។ ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.ពាព KH 01151001 ["កាលនោះ គេឲ្យខ្ញុំជួនទៅចាប់ តារ៉ាយ។ គេទុកខ្ញុំដើម្បីឲ្យជួនទៅចាប់មនុស្ស។"]។

584. មន្ទីរសន្តិសុខកាច់រទេះ "ពេញ [...] ទៅដោយអ្នកទោស ប្រហែលជា ៣០០ នាក់"[2062]។ "នៅពេលយកអ្នកទោសចាស់ចេញទៅ គេយកអ្នកទោសថ្មីចូលមក"[2063]។ វិហារជាកន្លែងដាក់ "អ្នកទោសធ្ងន់" ហើយរោងពេទ្យប្រើសម្រាប់ដាក់ "អ្នកទោសស្រាល"[2064]។ អ្នកទោស "ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត" ត្រូវបានដាក់ឃុំនៅក្នុងស្ពូប ហើយអ្នកទោសទាំងនោះ "មិនបានឃើញពន្លឺ

[2062] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១៣៩ KH 01167611។ *សូមមើលផងដែរ* ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១០៤ KH 01167606 ["គ្មានបាយ គ្មានអ៊ីទេ សម្រាប់អ្នកទោសជាង៣០០ នាក់។"]។ ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្បៀយ ឆ.៨ KH 01062685 ["ស៖ នៅក្នុងវត្តពោធិ៍លង្កា តើមានមនុស្សប៉ុន្មាននាក់នៅទីនោះ? [...] ឆ.៨៖ មានមនុស្សប្រហែល៣០០នាក់នៅទីនោះ"]។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២០ KH 01037128-01037129 ["កាលនោះ គេដាក់អ្នកទោស៦០នាក់ ក្នុងព្រះវិហារ។ ចំណែកឯអគារដែលមានបណ្តោយប្រហែល១០០ម៉ែត្រ [...] រោងពេទ្យនោះមានដាក់អ្នកទោសដែលមិនជាប់ខ្ទោះចន្លោះពី ២០ ទៅ៤០ នាក់"]។ ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.៣២ KH 00794115 ["អ្នកទោសមានប្រហែល៤០ ទៅ៥០ នាក់នៅក្នុងព្រះវិហារ"]។ ឯកសារ D105/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខវត្តពោធិ៍លង្កា KH 00790580-00790581 ["វត្តនេះមានប្រវែងប្រហែល១៥ x ៩ ម៉ែត្រ ហើយអាចដាក់អ្នកទោសចំនួនប្រហែល ៥០ ទៅ៦០នាក់ នៅពេលតែមួយ។"]។

[2063] ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.៣២ KH 00794115។ បើទោះបីជាសាក្សីបានប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា គាត់ត្រូវបានចាប់ខ្លួននៅក្នុងឆ្នាំ១៩៧៧ ហើយជាប់គុកអស់រយៈពេល៣ខែ ហើយកម្មាភិបាលនិរតីបានជំនួសកម្មាភិបាលពាយ័ព្យ គឺ២ខែមុនពេលវៀតណាមចូលមកដល់ប្រទេសកម្ពុជា។ គាត់បាននិយាយថា គេដាក់ឃុំឃាំងគាត់នៅក្នុងវិហារនៃមន្ទីរសន្តិសុខវត្តពោធិ៍លង្កា (បង្កើតឡើងដោយកម្មាភិបាលនិរតី)។ *សូមមើល* ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.១៧, ២១, ៣៨ KH 00794113-0079415។

[2064] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៤២ KH 01167597 ["វាមានរោងនៅខាងនោះ ហ្នឹងសាលាមួយវែង ជិតវិហារ។ នៅរោងហ្នឹង គេដាក់អ្នកទោសស្រាល [...] អ្នកទោសធ្ងន់ គេដាក់នៅក្នុងវិហារ [...] អ្នកស្រាលហ្នឹង គឺអត់មានស្អីទេ គឺលួចដំឡូងលួចអ៊ី។ ឯទោសធ្ងន់គេចោទយើងថាជាប់ចលនា ឬបំផុសបំផុលអ៊ី គេដាក់ក្នុងវិហារ។"] (*កំណត់សម្គាល់* ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២០ KH 01037128-01037129 ["មានអគារបួន ដែលគេប្រើប្រាស់កាលនោះ ក្នុងនោះរួមមាន [...] រោងពេទ្យ"។ "រោងពេទ្យនោះមានដាក់ [...] អ្នកទោស"])។ ជនរងគ្រោះ ត្រូវបានគេដាក់គុក ដោយសារតែយកអាហារហូបពុំមានការអនុញ្ញាត ហើយចោទប្រកាន់ "បំផ្លាញសេដ្ឋកិច្ច" បើសិនពួកគេលួច ឬធ្វើឲ្យបាក់ស្ពាបព្រា។ *សូមមើល* ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.១២, ២៥ KH 01037127, 01037130។ ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.១៧ KH 00794113។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៤៣ KH 01114665។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.១១៨ KH 01328012។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៤០ KH 01104620។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២៣០ KH 01047409។ ឯកសារ D219/302 កំណត់ហេតុស្តាប់ចម្លើយ ខ្ឿន ចឹម ឆ.១០ KH 01096545។

ថ្ងៃទេ"[2065]។ អ្នកទោសភាគច្រើនគឺជាកម្មាភិបាលភូមិភាគពាយ័ព្យ ក្នុងនោះរួមទាំងអតីតសមាជិកនៃគណៈសហករណ៍ផងដែរ[2066]។ ការដាក់ឃុំឃាំងក្នុងមន្ទីរសន្តិសុខនេះក៏មានអតីតគ្រួសារខ្មែរក្រោមដែល "ត្រូវបានចោទប្រកាន់ [...] ថាជាវៀតណាម" "អតីតអ្នករដ្ឋការ និងទាហាន លន់ នល់" និង "ប្រជាជនថ្មី"[2067]។ អ្នកទោសត្រូវបានប្រមូលមកពីគ្រប់កន្លែងទាំងអស់ក្នុងតំបន់ ៤ ក្នុងនោះរួមទាំងពន្ធនាគារចាស់ដែលកម្មាភិបាលភូមិភាគពាយ័ព្យប្រតិបត្តិ រហូតដល់កម្មាភិបាលភូមិ

[2065] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៧០ KH 01167601។

[2066] ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៣២ KH 01104619 [នៅ "វត្តកាច់រទេះ [...] កម្មាភិបាលពាយ័ព្យជាច្រើនត្រូវបានគេដាក់គុក។ អ្នកទោសនៅក្នុងគុក ភាគច្រើនគឺជាកម្មាភិបាលពាយ័ព្យ"]។ <u>យិន</u>៖ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.១៨ KH 01114661 ["តាយិន [...] ជាប្រធានសហករណ៍ឃុំ៣០ [...] ខ្ញុំឮអំពីអ្នកជិតខាងនិយាយថា យិន ត្រូវបានពួកនិរតីចាប់ពីយប់ ហើយនាំយកទៅដាក់នៅក្នុងវត្តពោធិ៍លង្កា។"]។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៤១ KH 01104620។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.២៦ KH 01167595 ["យិន គណៈសហករណ៍ [...] ជាប់គុកជាមួយខ្ញុំ។"]។ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៨១, ១២៤ KH 01300004, 01300009 [យិន ត្រូវបាន "ចាប់ខ្លួន និងឃុំ" "នៅកន្លែងវត្ត។"]។ ឯកសារ D219/341 កំណត់ហេតុស្តាប់ចម្លើយ នក់ សាវ៉ាវ ឆ.២៣ KH 01102872។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២៦, ៣៦ KH 01047384, 01047385។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៨៧ KH 01037164។ <u>រ៉ូយ</u>៖ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ប៊ុនឈឿន ឆ.១២ KH 01096523 ["តារ៉យ ដែលជាសមាជិកគណៈឃុំ [កំពង់គោ]" ត្រូវបានយកទៅ "វត្តពោធិ៍លង្កា"]។ <u>កម្មាភិបាលពាយ័ព្យផ្សេងទៀត</u>៖ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.៤ KH 01037124។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.២២ KH 01121681។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៤៣ KH 01129779។ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៧៥ KH 01300003។ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈេន ឆ.៣៤ KH 01327958។ ឯកសារ D219/399 កំណត់ហេតុនៃកិច្ចស៊ើបសួរ រស់ ឃឿន KH 01366513។ ឯកសារ D6.1.621 កិច្ចសម្ភាសន៍ SOAS ជាមួយ រ៉ែន ដឹម EN 00352109។

[2067] ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៥៦, ៥៩-៦០ KH 00988050 ["ម្តាយមីង និងពួកចំនួនបីគ្រួសារ ប្ជុនខ្ញុំពីរគ្រួសារ ហើយនិងគ្រួសាររបស់ម្តាយខ្ញុំមួយគ្រួសារទៀតដូច្នេះមានប្រាំមួយគ្រួសារ ដែលត្រូវគេឃុំខ្លួន។ [...] គេចោទពួកគាត់ថាជាយួន។ [...] ពួកគាត់ជាខ្មែរក្រោម ហើយម្តាយរបស់ខ្ញុំចេះនិយាយភាសាវៀតណាម តែគាត់មិនមែនជាវៀតណាមទេ។"]។ ឯកសារ D219/339 កំណត់ហេតុស្តាប់ចម្លើយ ប៊ុម សេវ ឆ.១៩ KH 01102851 ["ឪពុកក្មេកខ្ញុំ [...] រស់នៅចម្ងាយ៥០ម៉ែត្រ ពីវត្តកាច់រទេះ។ គាត់បានប្រាប់ខ្ញុំថា អតីតរដ្ឋការ និងទាហានលន់ នល់ ត្រូវបានគេឃុំឃាំងក្នុងព្រះវិហារ។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.197 KH 01047405 ["អ្នកដែលត្រូវគេឃុំខ្លួននេះគឺសុទ្ធតែជាប្រជាជនថ្មី ពុំមានប្រជាជនចាស់ទេ។"]។

ភាគនិរតីបានផ្លាស់ប្តូរមន្ទីរនេះទៅកាន់វត្តកាច់រទេះ[2068]។ អ្នកទោសនៅក្នុងវិហារត្រូវបានដាក់ខ្នោះជើង[2069] និង "អ្នកទោសខ្លះមិនអាចដេកបានឡើយ ពីព្រោះកន្លែងនោះមានទំហំតូចចង្អៀតពេក ហើយមានអ្នកទោសច្រើនពេក"[2070]។ មន្ទីរសន្តិសុខមានចែនៅគ្រប់ទីកន្លែង" ហើយអ្នកទោសត្រូវតែប្រើកន្ទោរបត់ជើងរួមគ្នា[2071]។ អ្នកទោសទោសពុំមានអាហារហូបឡើយ[2072]។ "អ្នកទោសខ្លះ

[2068] <u>ពីតំបន់៤</u>៖ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៥៧ KH 01403890 ["ពេលដែលតាឡឹក និងយាយ ចាន់ [...] គ្រប់គ្រងស្រុក៤១ និងស្រុក៤២ [...] មានការចាប់មានអី គឺយកទៅដាក់នៅវត្តកាច់រទេះ។"]។ ឯកសារ D1.3.11.23 កិច្ចសម្ភាសន៍របស់ ក.ស.ព ជាមួយ គីម ហេង KH 00845888 ["ប្រជាជនមកពីតំបន់ទាំងមូល មកពីស្រុកខុសគ្នា ក្នុងតំបន់៤ [...] នៅក្នុងវិហារ"]។ ឯកសារ D219/304 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៦ KH 01096562 ["គុកវត្តពោធ៍លង្ការ គឺជាមន្ទីរសន្តិសុខយោធាតំបន់៤។ មិនមានគុកនៅតាមឃុំទេ។"]។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.១២ KH 01102812 ["វាគឺជាគុកថ្នាក់តំបន់"]។ ឯកសារ D219/333 កំណត់ហេតុស្តាប់ចម្លើយ ទៀ រ៉ៀង ឆ.១៣ KH 01102767 [វត្តកាច់រទេះ "យកធ្វើជាគុកតំបន់៤"]។ ក្នុងសម័យកម្មាភិបាលពាយ័ព្យគ្រប់គ្រងគុកនេះ *សូមមើល* ឯកសារ D6.1.620 កិច្ចសម្ភាស SOAS ជាមួយ រៀម ឌី KH 00789291 ["កាច់រទេះ [...] មន្ទីរសន្តិសុខ [...] ខ្ញុំគិតថាវាជាមន្ទីរសន្តិសុខតំបន់៤។ វាហាក់ដូចជាថា ស្រុកទាំងអស់បានបញ្ជូលអ្នកទោសមកទីនេះ។"]។ ឯកសារ D219/362 កំណត់ហេតុនៃការស៊ើបសួរ ទៀ រ៉ៀង KH 01378687 ["គុកតំបន់៤ (វត្តកាច់រទេះ)។"]។ <u>មកពីគុកចាស់</u>៖ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.៦ KH 01102810-01102811 ["គ្រប់គ្នាបានឃើញគេ [យោធាភូមិភាគនិរតី] បណ្តើរអ្នកទោសពីទីតាំងគុកចាស់ ទៅទីតាំងវត្តកាច់រទេះ...]។ ខ្ញុំបានឃើញដោយផ្ទាល់ គឺមានអ្នកទោសប្រហែល៣០នាក់"]។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៤១ KH 01114665 ["ខ្ញុំបានឃើញ [...] គេយកអ្នកទោសចេញពីរោងនោះយកទៅដាក់នៅក្នុងវត្ត។ [...] គេបណ្តើរអ្នកទោសទាំងនោះកាត់ភូមិមុខប្រជាជន។"]។

[2069] ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.២២ KH 00794113។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២០ KH 01037128-01037129។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៤០ KH 01167597។ ឯកសារ D219/304 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៥ KH 01096562។ ឯកសារ D219/399 កំណត់ហេតុនៃកិច្ចស៊ើបសួរ រស់ ឃឿន KH 01366512។

[2070] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១៣៩ KH 01167611។

[2071] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១០៨ KH 01167607។

[2072] ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៣៧ KH 01104619-01104620។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១០៤ KH 01167606 ឆ.១០៦, ១១៤ KH 01167606, 01167608 ["គ្មានអី [...] ខ្ញុំរស់ដោយសារដើមល្ហុងទេ។ ហើយបើទៅរក [...] ឃើញខ្សែង គឺទំពារគ្រឹបៗទាំងឆៅតែម្តង។ [...] បើថានៅក្នុងគុក គឺ១០០% គឺងាប់តែម្តង។ [...] អ្នកទោសខ្លះ [...] គឺនៅសល់តែអ្ហឹង គ្មានសាច់។ បើនិយាយរួមទៅ ដូចយើងទៅផឹកទឹកទទេ ទឹកថ្លាដូចទឹកអណ្តូងអ៊ីចឹង បបរគ្មានកាក គ្មានអីទេ។"]។ ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្បាយ ឆ.៦ KH 01062684 ។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២៤ KH 01037130 ["អ្នកទោសដែលគេដោះលែងឲ្យធ្វើការនៅខាងក្រៅ ទទួលបានបបរមួយកាម្នាក់ [...] មានអង្ករពី ១០ ទៅ២០គ្រាប់ និងអំបិល២គ្រាប់។ ហើយសម្រាប់អ្នកជាប់ខ្នោះគឺទទួល

[…] បានវើសយក […] លាមកមកហូប" ពីព្រោះលាមកនោះត្រូវបានលាយជាមួយសំបកដំបូង ដែលត្រូវលាយជាមួយគ្នាដើម្បីធ្វើជី"[2073]។ នៅពេលអ្នកទោសឈឺ ពួកគេ "ពុំមានថ្នាំពេទ្យដើម្បីព្យាបាលទេ" ហើយ "ពុំមានបុគ្គលិកពេទ្យ"[2074] ដែរ។ កម្មាភិបាលភូមិភាគពាយ័ព្យមួយចំនួនបានទទួលរងការវាយបំបាក់ជើង[2075]។ អ្នកទោសផ្សេងៗទៀតត្រូវបានបង្ខំឲ្យធ្វើការងារ ក្រោមការឃ្លាំមើលពីអ្នកយាមប្រដាប់អាវុធ ចាប់ពី "ម៉ោង ៦ ឬ ៧ ព្រឹក […] រហូតដល់ម៉ោង ៥ ល្ងាច" ដោយត្រូវបានអនុញ្ញាតឲ្យសម្រាកម្តង ដើម្បីបំពេញការងារទៅតាមការកំណត់ក្នុងការផលិតជី[2076]។ "ប្រសិនយើងមិនធ្វើមិនគ្រប់ការងារដែលបានផ្តល់ឲ្យទេ គេមិនឲ្យយើងឈប់ឡើយ"[2077]។ កម្មាភិបាល "មិនឲ្យពលករសម្រាកទេ ក្នុងម៉ោងធ្វើការ ហើយប្រសិនបើនរណាធ្វើការងារមិនបានល្អ ពួកគេដាក់ទណ្ឌកម្មពលករនោះ ដោយការវាយដំ"[2078]។ សាក្សីម្នាក់បានស្តាប់ឮ កម្មាភិបាលជេរជនរងគ្រោះថាខ្ជិលច្រអូស ហើយក៏បានវាយដំគាត់"[2079]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បាននិយាយថា អ្នកដើរឆ្ពងកាត់មន្ទីរសន្តិសុខ បានឮ "សំឡេងមនុស្សដែលត្រូវបានវាយនឹងដំបង" នៅពេលគាត់ដើរជិត

បានបបរវារមួយវែកដែលមានអង្ករ២ ទៅ៣គ្រាប់តែប៉ុណ្ណោះ។ ជួនកាលអ្នកដែលគេដោះលែងឲ្យធ្វើការនៅក្រៅ មានសម្ពត្រកួនហើយនិងព្រលិតខ្លះដែរ។"]។ ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គ៉ម ហេង ឆ.២៤ KH 00794114។

[2073] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១០៦ KH 01167606។

[2074] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១១០, ១១៣ KH 01167607។

[2075] ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.៣៨ KH 01023858 ["កម្មាភិបាលនិរតីបានចាប់កម្មាភិបាលពាយ័ព្យ៣នាក់ និងបានវ៉ៃបំបាក់ដៃជើងពួកគេ"]។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ដុះ ឆ.៣៥ KH 01121684 ["គេបានរកឃើញតាយិន […] ចាប់គាត់កាត់ម្រាមដៃ ម្រាមជើងអស់។"]។ ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀ រ ហេង ឆ.១៣ KH 01114702 ["ពេលដែលពួកនិរតីចាប់គាត់ [យិន] គេកាត់ម្រាមដៃរបស់គាត់។ […] ខ្ញុំឃើញដៃរបស់ យិន មានរុំរបួស។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៣៨ KH 01047385 ["ខ្ញុំបានឃើញពួកគាត់ [យិន និងទី] ត្រូវគេចាប់ចាប់ខ្លួន និងបណ្តើរទៅដាក់មន្ទីរឃុំឃាំង។ យិន និងទី ត្រូវគេកាត់ម្រាមដៃ និងស្ត្រីកត្រចៀក។"]។

[2076] ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២៤ KH 01037130។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១៥, ៧៤, ១៤០ KH 01167594, 01167602, 01167611។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២១១, ២២២ KH 01047407-01047408។ *សូមមើលផងដែរ* ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀ រ ហេង ឆ.១៥-១៦ KH 01114703។

[2077] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១៤៤ KH 01167611។

[2078] ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២៤ KH 01037130។

[2079] ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.១០២ KH 01104629 ["ដោយសារតែយើងរស់នៅ និងធ្វើការនៅកែ្សរវត្តកាច់រទេះ។ ថ្ងៃមួយនោះ […] ខ្ញុំបានឃើញកម្មាភិបាលនិរតី […] បានយកបន្ទះបូស្សីមកវាយគាត់ ហើយនៅពេលដែលកំពុងវាយនោះ ក៏បានជេរគាត់ថា គាត់ខ្ជិល"]។

មន្ទីរសន្តិសុខនេះ[2080]។ អ្នកទោសដែលត្រូវបានចាប់ខ្លួនថ្មីៗ និងត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខនេះមើលទៅមានសុខភាពធម្មតា។ ប៉ុន្តែនៅទីបញ្ចប់ ពួកគេមានសភាពស្គមស្គាំង[2081]។

585. នៅវត្តបឹងឈូក អ្នកទោសដែលត្រូវបានចងស្ពាបសេក "ទាំងខ្សែៗ" ត្រូវបាននាំចូលវត្តនេះ[2082]។ ទីតាំងនេះគឺជា "កន្លែងឃុំ" ដែលប្រជាពលរដ្ឋដែលបានបញ្ជូនទៅទីនោះ "ត្រូវបានចោទប្រកាន់ពីកំហុសស្រាល ត្រូវបានដោះលែង ក្នុងពេលអ្នកដែលត្រូវបានចោទប្រកាន់ពីកំហុសធ្ងន់ធ្ងរត្រូវបានបញ្ជូនទៅសម្លាប់នៅវត្តកាច់រទេះ"[2083]។ អ្នកទោសត្រូវបានដាក់ខ្នោះជើង ហើយបានទទួល "របបអាហារតិចតួចបំផុត"[2084]។

586. នៅមន្ទីរសន្តិសុខវត្តសាលាត្រាវ អ្នកទោសនៅទីនោះមាន "ប្រជាជន ១៧ មេសា" ប្រជាជនវៀតណាម និងខ្មែរក្រោម[2085]។ "អ្នកទោសរហូតដល់ ២០ នាក់ ត្រូវបានបញ្ជូនទៅដាក់ពន្ធនាគារ ជារៀងរាល់ថ្ងៃ"[2086]។ សាក្សីម្នាក់ដែលបានជាប់ឃុំអស់រយៈពេលមួយឆ្នាំហើយត្រូវបានដោះលែងនៅ

[2080] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២២៤ KH 01047407 ["អ្នកខ្លះដើរកែ្ជរមន្ទីរសន្តិសុខនោះ [ពោធ៍លង្ការ] គាត់ក៏បានឮសំឡេងគេវ៉ៃមនុស្សនឹងដំបង។"]។ *សូមមើលផងដែរ* ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៣៤ KH 01104619 ["នៅពេលយប់ យើងបានឮសំឡេងមនុស្សស្រែកយំខាងក្នុងវិហារ។"]។

[2081] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១១៤ KH 01167608។

[2082] ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្បើម ឆ.៤៦ KH 01327948 ["ខ្ញុំ [ឃើញ] ចងទាំងខ្សែៗ ទៅវត្តបឹងឈូកហ្នឹង។"]។

[2083] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៩ KH 01097672។

[2084] ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន ម្ឿន ឆ.៥៤, ៥៦ KH 01425207-01425208។ ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្បើម ឆ.៣៥ KH 01327947។

[2085] ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ម៊ីង សំបូរ ឆ.៣១ KH 01117193 ["គេបានប្រាប់ខ្ញុំថាគេត្រូវចាប់ខ្លួននៅក្រុងបាត់ដំបង ហើយត្រូវបានបញ្ជូនមកឃុំនៅទីនេះ ហើយពួកគេជាប្រជាជន១៧ មេសា។"]។ ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១២០ KH 01335608 ["នៅក្នុងគុក ឮពួកហ្នឹងនិយាយសម្លាប់ឃ្លួន។ [...] សម្លាប់ខ្មែរក្រោម វាថាពួកហ្នឹងឃ្លួន [...]។ ពេលហ្នឹងសម្លាប់ច្រើន ច្រើនមែនទេ។"] ឆ.១២២ KH 01335608 ["ស៖ [...] តើណោកគិតថា ខ្មែរក្រោមប៉ុន្មាននាក់ ត្រូវបានគេសម្លាប់នៅគុកសាលាត្រាវ? ឆ.១២២៖ ខ្ញុំគិតថា រាប់ពាន់នាក់ តែមិនដឹងប៉ុន្មាន។"]។ ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៦៨, ៧០ KH 01347378 ["នៅកន្លែងជីនោះ ខ្មែរក្រោម គេបណ្តើរមករាល់ល្ងាច។ [...] ខ្ញុំបានឃើញកម្ពុជាក្រោមដើរចូលទៅ"]។

[2086] ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៦៩ KH 01347378 ["ខ្ញុំគិតថា ចូល ដែលគេចាប់ចូលកងហ្នឹងគឺចូលរាល់ថ្ងៃ ចូល៤នាក់ ៥នាក់ ២០នាក់ ជាប្រចាំ។"]។ *សូមមើលផងដែរ* ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៦៧ KH 01347378 ["ពេលយប់ឡើង គ្រប់យប់ គឺមានមនុស្សចូលរាល់យប់។"]។ ឯកសារ D219/838 កំណត់ហេតុ

ថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៧៨ បានសង្កេតឃើញថា "ប្រជាជនប្រមាណជា ១.០០០ និង ២.០០០ នាក់" បានជាប់ពន្ធនាគារនៅទីនោះ[2087]។ អតីតអ្នកទោសម្នាក់ទៀតបាននិយាយថា "បន្ទាប់ពីការមកដល់របស់ក្រុមមនុស្សពីភូមិភាគនិរតី ពួកគេបានចាប់ខ្លួនខ្មែរក្រោមកាន់តែច្រើនទៅៗ"[2088]។ អ្នកទោសត្រូវបានដាក់ខ្នោះជើង"[2089] ហើយ "ឲ្យដេកលើដី"[2090]។ "កន្លែងដេកមានសភាពតូចចង្អៀត ហើយមានអ្នកទោសច្រើនកុះករ"[2091]។ អ្នកដែលបានតវ៉ា ឬត្អូញត្អែរ ត្រូវរងការធ្វើបាបបួន ឬប្រាំ ថ្ងៃ"[2092]។ អ្នកទោសដែលត្រូវធ្វើការលត់ដំឡើងវិញ "បានទទួលរបបបបរវាវមួយចាន"[2093]។

<u>ការធ្វើទារុណកម្ម</u>

587. នៅមន្ទីរសន្តិសុខកាច់រទេះ មានយ៉ាងតិច "អ្នកទោសពី ២០ ទៅ ៣០ នាក់ [...] បានរងការធ្វើទារុណកម្ម និងសួរចម្លើយ"[2094]។ ការសួរចម្លើយត្រូវបានធ្វើឡើងដោយយកកៅស៊ូភ្ជៀងរុំមុខ ដុត

ស្ពាប់ចម្លើយ ឡុង ខេន ឆ.៧៤ KH 01335602 ["គុកទី១ មានប្រវែងប្រហែលជា៥០ម៉ែត្រ ទទឹងប្រហែល៦ ទៅ៧ម៉ែត្រ។"]។ ឯកសារ D219/404 កំណត់ហេតុស្ពាប់ចម្លើយ ហ្ជឿង សំបូរ ឆ.៣០ KH 01117193 ["នៅក្នុងរោងវែងមួយ [...] មានបួនជួរ [...] ក្នុងមួយជួរ១មានអ្នកទោសមិនតិចជាង២០នាក់ទេ។"]។

[2087] ឯកសារ D219/864 កំណត់ហេតុស្ពាប់ចម្លើយ ឡុង ខេន ឆ.៦៤-៦៥, ៦៩, ៧១ KH 01347377-01347378 ["គេយកទៅដាក់គុកសាលាត្រាវ។ ខ្ញុំជាប់ឃុំនៅទីនោះដល់ថ្ងៃទី២៣ ខែ១០ ឆ្នាំ១៩៧៨"។ [...] "មកគុកនោះ វាមិនក្រោម១០០០នាក់ទេ វាអាចពី១០០០នាក់ ទៅ២០០០នាក់នោះ"។ "ជាចំនួនសរុប " ដែលសាក្សីបានឃើញ។]។ *សូមមើលផងដែរ* ឯកសារ D219/838 កំណត់ហេតុស្ពាប់ចម្លើយ ឡុង ខេន ឆ.៨១ KH 01335603 ["អ្នកទោសនៅហ្នឹង មានជាង២០០នាក់"]។

[2088] ឯកសារ D219/125 កំណត់ហេតុស្ពាប់ចម្លើយ ស្រី សៀម ឆ.៧០ KH 01047389។

[2089] ឯកសារ D219/838 កំណត់ហេតុស្ពាប់ចម្លើយ ឡុង ខេន ឆ.៧៤ KH 01335602។ ឯកសារ D219/404 កំណត់ហេតុស្ពាប់ចម្លើយ ហ្ជឿង សំបូរ ឆ.២៩ KH 01117193។

[2090] ឯកសារ D219/404 កំណត់ហេតុស្ពាប់ចម្លើយ ហ្ជឿង សំបូរ ឆ.២៩ KH 01117193។

[2091] ឯកសារ D219/838 កំណត់ហេតុស្ពាប់ចម្លើយ ឡុង ខេន ឆ.១០៨ KH 01335606។

[2092] ឯកសារ D219/838 កំណត់ហេតុស្ពាប់ចម្លើយ ឡុង ខេន ឆ.១០៧ KH 01335606។

[2093] ឯកសារ D219/838 កំណត់ហេតុស្ពាប់ចម្លើយ ឡុង ខេន ឆ.៧៣, ៩៩, ១០៥ KH 01335601, 01335605-01335606 ["គេយកទៅកន្លែងកសាង [...] ឲ្យធ្វើជីធម្មជាតិ ដើម្បីដាក់ស្រែ។ [...] គេឲ្យតែទៅកាប់ដីដំបូក [...]។ រែកដីណាយជាមួយអាចម៍អ្នកទោស ច្រចាច់បល់ ហើយដឹកយកទៅបាចនៅស្រែ។ [...] នៅកន្លែងកសាងហ្នឹង គេឲ្យហូបបបរបានមួយក្ដិតចាន។"] ឆ.៨០ KH 01335602 ["ស៖ តើមានអ្នកទោសប៉ុន្មាននាក់ ដែលគេយកកសាងខ្លួនជាមួយលោក? ឆ.៨០៖ ចេញទៅហ្នឹង មានតែ៤នាក់ទេ ប៉ុន្តែនៅកន្លែងហ្នឹង មានអ្នកចាស់ មានប្រហែល៧ ឬ៨នាក់ទៀត។"]។ ឯកសារ D219/404 កំណត់ហេតុស្ពាប់ចម្លើយ ហ្ជឿង សំបូរ ឆ.២៩ KH 01117193 ["គេ [...] នាំខ្ញុំទៅធ្វើការក្នុងពេលថ្ងៃ។"]។

[2094] ឯកសារ D219/61 កំណត់ហេតុស្ពាប់ចម្លើយ ឆោម សុដា ឆ.២៦ KH 01037130។ *សូមមើលផងដែរ* ឯកសារ D219/356 កំណត់ហេតុស្ពាប់ចម្លើយ វណ្ណ ណាក់ ឆ.៣៧ KH 01104619-01104620 ["នៅពេលដែលខ្ញុំដើរទៅធ្វើការនៅក្បែរវត្តកាច់រទេះ

នឹងកន្ទុយបារី និងវាយដំ[2095]។ សាក្សីម្នាក់បាននិយាយថា ក្នុងខណៈពេលគាត់កំពុងត្រូវបានសួរចម្លើយ មនុស្សប្រាំនាក់ "វាយដំខ្ញុំពីម៉ោង ៧ ព្រឹក រហូតដល់ម៉ោង ៣ រសៀល"។ ផ្នែមុខរបស់គាត់ត្រូវបានវាយដំ។ គាត់ "សន្ធប់បីដង"។ គាត់ត្រូវបានគេទាត់ធាក់ "ហាក់បីដូចជាពួកគេទាត់ធាក់ជញ្ជាំង" រហូតដល់គាត់ដួល ហើយគាត់មានស្នាមរណាកនៅលើដៃរបស់គាត់។ គាត់បាននិយាយថា "ខ្ញុំមិនបានដឹងថាតើខ្ញុំបានប្រព្រឹត្តខុសអ្វីនោះទេ ដូច្នេះខ្ញុំមិនដឹងថាត្រូវផ្តល់ចម្លើយអ្វីនោះឡើយ។ [...] ដោយសារពួកគេវាយដំខ្ញុំខ្លាំងពេក ខ្ញុំក៏សម្រេចថា ខ្ញុំត្រូវតែឆ្លើយ។ [...] ខ្ញុំបានឆ្លើយថា នោះជារឿងពិត។ [...] ហើយពួកគេក៏ឈប់វាយដំខ្ញុំ"[2096]។

588. នៅមន្ទីរសន្តិសុខសាលាគ្រាវ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានឃើញអ្នកទោស "ណេតដូចកង្កែប" មុនពេលគាត់សន្ធប់លែងដឹងខ្លួន ដោយសារគេយកថង់ប្លាស្ទិករុំលើក្បាលជិត[2097]។ សាក្សីម្នាក់បាននិយាយថា "ប្រមាត់អ្នកទោសត្រូវបានវះដោយកាំបិត" ដែលជា "ទារុណកម្មក្នុងពន្ធនាគារ"[2098]។

ខ្ញុំបានឃើញអ្នកទោស ត្រូវកម្មាភិបាលនិរតីធ្វើទារុណកម្ម និងវាយដំ។"]។ ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.២៥ KH 00794114 ["ខ្ញុំបានឃើញមានការវាយដំលើអ្នកទោស ដោយប្រើដែកវាយទៅលើអ្នកទោសនោះ។"]។

[2095] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៤៤-៤៥, ៧២, ៧៤ KH 01167597-01167598, 011675601-01167602 ["គេវ៉ៃខ្ញុំនឹងដំបងឈើមួយដំបង។ [...] គេយកបារីដុតដៃខ្ញុំ [...] គេសួរទៀត ខ្ញុំថាខ្ញុំអត់មាននិយាយអីទេ ហើយគេសួរខ្ញុំទៀតថា អត់មែនទេ និយាយអ្វីខ្លះ? [...] គេវ៉ៃហើយ វ៉ៃទៀតនឹងដំបង។ [...] គេយកកៅស៊ូភ្លៀងបត់ប្រហែលជាពីរកំណាត់មករុំខ្ញុំ [...] ខ្ញុំទ្រាំមិនបានទេ។ គ្រាន់តែរុំមក ខ្ញុំង៉ក់ក្បាល។ [...] ដល់ពេល គេវ៉ៃខ្ញុំខ្លាំងពេក ខ្ញុំគិតថា ឆ្លើយទៅ បើស្លាប់ក៏អាប់ស្លាប់ដែរ។ រួចហើយ ខ្ញុំឆ្លើយថាមែន។"]។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ណោម សុដា ឆ.២៤ KH 01037130 ["គេសួរចម្លើយដោយយកកៅស៊ូភ្លៀងគ្របក្បាលខ្ញុំ។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២២៩ KH 01047409 [បងប្អូនជីដូនមួយដើមបណ្តឹងរដ្ឋប្បវេណី "ប្រាប់ខ្ញុំអំពីការធ្វើទារុណកម្មលើខ្លួនគាត់ផងដែរ។ គេបានយកថង់ប្លាស្ទិករុំក្បាលគាត់ ដើម្បីឲ្យគាត់ថប់ដង្ហើម។"]។

[2096] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៤៤-៤៥, ៧២, ៧៤ KH 01167597-01167598, 011675601-01167602។

[2097] ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.៣២ KH 01117193 ["មានរោងតូចមួយនៅមិនឆ្ងាយពីកន្លែងឃុំឃាំងនោះទេ ពួកយោធាតែងតែនាំយកអ្នកទោសទៅធ្វើទារុណកម្មនៅទីនោះ។ [...] ពេលខ្ញុំ ឃើញយោធាធ្វើទារុណកម្មអ្នកទោសដោយយកថង់ប្លាស្ទិករុំពីលើក្បាលជិត រហូតដល់អ្នកទោសសន្ធប់។ មុននឹងអ្នកទោសសន្ធប់ អ្នកទោសថប់ដង្ហើម ហើយណេតដូចសត្វកង្កែប។ [...] ខ្ញុំឃើញថា ពេលដែលអ្នកទោសដួលសន្ធប់ យោធាគេដោះថង់ប្លាស្ទិកចេញ រួចចាក់ទឹកទៅលើមុខជនរងគ្រោះ រហូតដល់ជនរងគ្រោះដឹងខ្លួនវិញ។"]។ *សូមមើលផងដែរ* ឯកសារ ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៩១ KH 01335604។

[2098] ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១៤២ KH 01335610។

<u>ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

589. នៅក្នុងតំបន់ឃុំកំពង់ព្រៀងដែលស្ថិតក្នុងការដឹកនាំរបស់កម្មាភិបាលភូមិភាគនិរតី ការស្លាប់បានកើតឡើងដោយសារតែកង្វះអាហារ[2099]។ កម្មាភិបាលភូមិភាគពាយ័ព្យដែលជាប់ឃុំឃាំងបានស្លាប់ "ជារៀងរាល់ថ្ងៃ ដោយសារតែកង្វះសៀងអាហារ"[2100] ហើយនៅមន្ទីរសន្តិសុខកាច់រទេះ ក្នុងអំឡុងពេលប្រាំមួយខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ "អ្នកទោសពីប្រាំមួយទៅប្រាំពីរនាក់បានស្លាប់ជារៀងរាល់ថ្ងៃដោយសារតែគ្មានអាហារបរិភោគ"[2101]។ កម្មាភិបាលមានជំងឺដែល "ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យជិតនោះ [...] មិនធ្លាប់បានវិលវិញទេ" ហើយអ្នកទោសមួយចំនួននៅមន្ទីរសន្តិសុខកាច់រទេះ "បានធ្លាក់ខ្លួនឈឺ ហើយស្លាប់"[2102]។

590. ក្រៅពីនេះ ប្រជាជនត្រូវបានសម្លាប់ ពីព្រោះតែ (១) "និន្នាការ និងមុខរបររបស់គេក្នុងអំឡុងពេលនៃរបប លន់ នល់"[2103] (២) ពួកគេជា "ប្រជាជន ១៧ មេសា" (*ឧទាហរណ៍* មន្ទីរសន្តិសុខសាលា

[2099] ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.២៩ KH 01037157 [នៅភូមិកាច់រទេះ បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី "ស្លាប់ដោយសារហូបមិនឆ្អែត"]។ ឯកសារ D219/865 កំណត់ហេតុស្តាប់ចម្លើយ ពុត ហេង ឆ.៥៩ KH 01347396 [នៅភូមិសាលាត្រាវ៉ៃ "ស្លាប់ ដោយស្គមបាក់កម្លាំង"]។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៤៩-៥០ KH 01114666 ["មនុស្សដាច់បាយស្លាប់ជាច្រើន ពីព្រោះរបបហូបក្នុងពេលនោះ គឺអង្ករបីកំប៉ុងទឹកដោះគោសម្រាប់បបរឲ្យមនុស្ស១០០នាក់ហូប។ [...] ហើយជំនាន់ពួកនិរតីក៏ស្ថានភាពនៅដដែល ពុំមានការផ្លាស់ប្តូរទេ។ [...] ខ្ញុំបានឃើញផ្ទាល់នឹងភ្នែកនឹងមនុស្សស្លាប់ ហើយគេសែងយកទៅកប់។"]។

[2100] ឯកសារ D219/393 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.៥ KH 01114682។

[2101] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១០៦ KH 01167606។ *សូមមើលផងដែរ* ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្បើយ ឆ.៦ KH 01062684 ["មនុស្សមួយចំនួនស្លាប់ដោយសារជម្ងឺ និងពុំមានអាហារហូបចុកគ្រប់គ្រាន់។"]។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ផោម សុដា ឆ.២៤ KH 01037130 ["ក្នុងពេលគ្រប់គ្រងដោយពួកនិរតី [...] អ្នកទោស៥០ ទៅ៦០នាក់ស្លាប់ដោយដាច់ពោះនៅពេលខ្ញុំជាប់គុកនៅទីនោះ។"]។

[2102] ឯកសារ D219/393 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.៦ KH 01114683។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១១០ KH 01167607។

[2103] ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.៦ KH 01102810-01102811 ["ក្នុងពេលពួកពាយ័ព្យគ្រប់គ្រង ពួកគេស្រាវជ្រាវពីនិន្នាការរបស់ប្រជាជន និងមុខរបរពីអតីតកាលក្នុងសម័យ លន់ នល់ មុននឹងគេយកទៅសម្លាប់។]។ *សូមមើលផងដែរ* ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.៥៦ KH 01023861-01023862 ["កូនប្រុសរបស់ខ្ញុំអាយុ ១៥ឆ្នាំ។ វាប្រហែលជាបាននិយាយអ្វីខុស ឬគេដឹងថា ជាកូនរបស់ទាហាន លន់ នល់ សក្តិ៥ (ប្តីខ្ញុំ) ហើយ។ ប្តីខ្ញុំគេចាប់យកទៅសម្លាប់ដោយចោទថា ជាទាហានសក្តិ៥។ កូនខ្ញុំត្រូវបានចាប់យកទៅសម្លាប់ដោយពួកកម្មាភិបាលពាយ័ព្យ។ កាលនោះ កម្មាភិបា

ត្រាវ)[2104] (៣) ពួកគេជាជនជាតិវៀតណាម ឬប្រជាជនដែលត្រូវបានចាត់ទុកថាជាវៀតណាម ដូចជាខ្មែរក្រោម (*ខ១ទាហរណ៍* មន្ទីរសន្តិសុខកាច់រទេះ និងសាលាត្រាវ)[2105] ឬ (៤) ពួកគេគឺជាកម្មាភិបាលភូមិភាគពាយ័ព្យ ឬសមាជិកគ្រួសារដែលពាក់ព័ន្ធ[2106] (*ខ១ទាហរណ៍*ភូមិកាច់រទេះ និងមន្ទីរសន្តិ

លនិរតីបានចូលមកដល់ឃុំខ្ញុំហើយ ប៉ុន្តែមិនទាន់មកដល់ភូមិខ្ញុំទេ។ គេចាប់កូនប្រុសខ្ញុំទៅសម្លាប់ប្រហែលពីរខែក្រោយពីការចាប់ខ្លួនប្តីខ្ញុំ។"]។

[2104] ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១៣៥ KH 01335609 ["នៅគុក [សាលាត្រាវ] នោះ គេសម្លាប់តែពួក១៧មេសា"]។

[2105] <u>មន្ទីរសន្តិសុខកាច់រទេះ</u>៖ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៤៩, ៥៦, ៥៨-៦០, ៧០ KH 00988049-00988050, 00988052 [សមាជិកគ្រួសារ និងសាច់ញាតិចំនួន៥៥នាក់ ត្រូវបានឃុំនៅក្នុងភូមិកាច់រទេះ។ "ខ្មែរក្រហមបានប្រាប់ពួកគាត់ថា គេបញ្ជូនឲ្យទៅធ្វើការនៅកន្លែងផ្សេង តាមពិតគេបញ្ជូនពួកគាត់ទៅសម្លាប់ចោលនៅក្នុងរណ្តៅធំមួយនៅក្នុងភូមិកាច់រទេះ។ [...] ខ្មែរក្រហម ចោទពួកគាត់ថាជាយួន។ [...] ពួកគាត់ជាខ្មែរក្រោម។"]។ ឯកសារ D219/25 កំណត់ហេតុស្តាប់ចម្លើយ ស សម័យ ឆ.៧៤ KH 01029980 [នៅភូមិថ្មី៖ "តាសួម មានប្រពន្ធសម្បុរស ហើយជាកម្ពុជាក្រោម។ [...] ភូមិភាគនិរតី [...] កម្មាភិបាលបានចាប់ប្រពន្ធតាសួម យកទៅ។ នៅពេលយប់ ខ្ញុំបានឮសំឡេងប្រពន្ធតាសួម ស្រែក ដែលពួកនិរតីវាយ ដែលមានចម្ងាយប្រហែល៣០០ម៉ែត្រពីផ្ទះខ្ញុំ។ [...] ខ្ញុំបានឃើញប្រពន្ធតាសួម ដែលគេសម្លាប់ ហើយបានកប់នៅសល់ម្រាមជើងចេញមកក្រៅ។ ដល់ពេលព្រឹកឡើង ប្រជាជនបាននាំគ្នានិយាយថា កាលពីយប់ គេចាប់ប្រពន្ធតាសួម និងកូនស្រីបង យកទៅសម្លាប់ហើយ។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៦៤ KH 01047389 [នៅភូមិសាលាត្រាវ៖ "ខ្មែរក្រហម បានធ្វើការស្រាវជ្រាវ និងចាប់ខ្លួនរហូតជាបន្តបន្ទាប់ [...] បានកុហកខ្មែរក្រោម [...] ប្រាប់ខ្មែរក្រោមថាឲ្យទៅទន្លេ។ [...] បន្ទាប់មកខ្មែរក្រហម ក៏បរទេះដោយមានខោអាវរបស់ខ្មែរក្រោមត្រឡប់មកវិញ។"]។ ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្ងៀង ឆ.៩៩ KH 01335624 [នៅកាច់រទេះ៖ "ប្រជាជនយកទៅសម្លាប់ គឺថាវាមានច្រើនណាស់ ដែលត្រូវយកទៅសម្លាប់។ គេថា [...] ចោទថាយួន ដូចគ្រួសារខ្ញុំ (សំដៅលើប្រពន្ធរបស់សាក្សី) គេចោទថាយួន មានក្នុងបញ្ជីស្រាប់ហើយ។"]។ <u>មន្ទីរសន្តិសុខសាលាត្រាវ</u>៖ ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១២០ KH 01335608 ["នៅក្នុងគុកហ្នឹង ឮពួកហ្នឹងនិយាយសម្លាប់យួន។ [...] សម្លាប់ខ្មែរកម្ពុជាក្រោម វាថាពួកហ្នឹងយួន [...]។ ពេលហ្នឹងសម្លាប់ច្រើន ច្រើនមែនទែន។"]។

[2106] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៩ KH 01167593 [នៅសហករណ៍កាច់រទេះ៖ "កម្មាភិបាល [...] មកពីនិរតី [...] មកសម្លាប់អ្នកពាយ័ព្យ។"]។ ឯកសារ D219/343 កំណត់ហេតុស្តាប់ចម្លើយ រស់ ម៉ោង ឆ.២៦ KH 01102898 ["ក្រោយពួកនិរតីមកដល់ គាត់ [តាទិត្យ] និងក្រុមគ្រួសារគាត់ទាំងអស់ត្រូវបានគេយកទៅសម្លាប់នៅវត្តប៊ីងឈ្លូក"]។ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ សៀង ចាន់ថេន ឆ.២៩ KH 01096537 [នៅភូមិថ្មី៖ "កម្មាភិបាលនិរតីបានសម្លាប់កម្មាភិបាលពាយ័ព្យ"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៣៥ KH 01047385 [នៅភូមិអូសទ្ធុក៖ "ស៖ ពេលដែលពួកនិរតីចូលមកគ្រប់គ្រងជំនួសពួកពាយ័ព្យ តើមានអ្វីកើតឡើងចំពោះពួកពាយ័ព្យដែលត្រូវពួកនិរតីជំនួស? ឆ.៣៥៖ អ្នកខ្លះ [...] ត្រូវគេសម្លាប់ចោល។"]។ ឯកសារ D5/98 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឃៀម ប៊ូ KH 00562687 ["ដើមឆ្នាំ១៩៧៨ [...] នៅសំបុកអក [...] ពួកនិរតី [...] បានសម្លាប់កម្មាភិបាលចាស់ទាំងអស់។"]។ ឯកសារឯក

សារ D219/420 កំណត់ហេតុនៃកិច្ចស៊ើបសួរ គង់ ជូ KH 01303425 [នៅក្នុងឃុំ១០៖ "គាត់បានឮពីអ្នកជិតខាងថា នៅពេលដែលពួកនិរតីមកដល់ ពួកគេបានសម្លាប់កម្មាភិបាលភូមិភាគពាយ័ព្យ។"]។

សុខក្នុងភូមិនេះ[2107])។ សមាជិកគ្រួសារត្រូវបានសម្លាប់ ក៏ដូចជាមនុស្សដែលព្យាយាមរត់គេចពីតំបន់ឃុំកំពង់ព្រៀង[2108]។ "អ្នកទោសមួយចំនួនមកពីខេត្តកំពត នៅពេលអ្នកទោសមួយចំនួនទៀតមកពីខេត្តបាត់ដំបង"[2109]។

[2107] <u>មន្ទីរសន្តិសុខកាច់រទេះ</u>៖ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៧៥ KH 01300003 ["ពួកនិរតី [...] ចាប់ពួកកម្មាភិបាលពាយ័ព្យយកទៅ [...] មន្ទីរឃុំឃាំងកាច់រទេះ។ បន្ទាប់មកគេយកកម្មាភិបាលពាយ័ព្យទៅសម្លាប់"]។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.៥ ឆ.២៦ KH 01037125 KH 01037130 ["ពេលពួកនិរតីគ្រប់គ្រង [...] អ្នកដែលមានតួនាទីធំៗ ក្នុងពេលពួកពាយ័ព្យគ្រប់គ្រង។ [...] អ្នកទោសដែលជាអតីតយុទ្ធជនពាយ័ព្យ ព្យាយាមរត់ចេញពីគុក តែត្រូវបានបាញ់សម្លាប់ដោយយោធាដែលជាអ្នកយាមគុកនៅទីនោះ។"]។ <u>យិន</u>៖ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.២២ KH 01114662 ["ក្រោយមកទៀត យិន បានរត់ចេញពីកន្លែងឃុំឃាំងនៅវត្តពោធិ៍លង្កា ប៉ុន្តែគាត់ត្រូវបានពួកយោធាដេញតាម ហើយចាប់បានវិញ នៅជិតភូមិកាច់រទេះ។ បន្ទាប់ពីគេចាប់គាត់បាន គេកាប់គាត់នឹងពូថៅ ហើយនាំគាត់ត្រឡប់ទៅវត្តពោធិ៍លង្កាវិញ។ បានប្រហែលជាបីថ្ងៃក្រោយមក គាត់ក៏ស្លាប់ទៅ ដោយសាររបួស។"]។ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៨១, ១២៧ KH 01300004, 01300010។ ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀវ ហេង ឆ.១៣ KH 01114702។ ឯកសារ D219/333 កំណត់ហេតុស្តាប់ចម្លើយ ទៀ រ៉ៀង ឆ.១៣ KH 01102767 ។ *សូមមើលផងដែរ* ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៤២ KH 01104620។ ឯកសារ D219/302 កំណត់ហេតុស្តាប់ចម្លើយ ខ្ចឿន ចឹម ឆ.៨ KH 01096544។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ដុះ ឆ.៣៥ KH 01121684។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ងៀម ឆ.៣៨-៣៩ KH 01047385។ <u>កន្លែងផ្សេងនៅក្នុងភូមិកាច់រទេះ</u>៖ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ប៊ុនឈឿន ឆ.១៤ KH 01096524 ["ពេលដែលពួកនិរតីមកដល់ គេចាប់ [...] ពួកកម្មាភិបាលពាយ័ព្យយកទៅសម្លាប់។"]។ ឯកសារ D219/307 កំណត់ហេតុស្តាប់ចម្លើយ ប៉ាល់ យ៉ុង ឆ.៣២ KH 01096599។ ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្ងៀង ឆ.៦១ KH 01335620 ["ស៖ តើពួកកម្មាភិបាលនិរតី បានសម្លាប់ពួកកម្មាភិបាលពាយ័ព្យនៅកន្លែងណា? ឆ.៦១៖ បាទ នៅក្នុងភូមិដំណាក់រទេះហ្នឹងឯង បាទ ចាប់យកមកវាយនៅភូមិហ្នឹង។"]។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.១៨ KH 01114661។ <u>រ៉ាយ</u>៖ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឈឿន ឆ.១៨-១៩ KH 01129772-01129773 ["តារ៉ាយ គឺជាគណ:ឃុំ [កំពង់គោ] [...] តារ៉ាយ ត្រូវបានកម្មាភិបាលនិរតី តាមប្រមាញ់នៅពេលដែលពួកគេមកដល់ ហើយតារ៉ាយ ត្រូវបានគេបាញ់ស្លាប់នៅក្នុងភូមិកាច់រទេះ។"]។ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ប៊ុនឈឿន ឆ.១២ KH 01096523។

[2108] ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ឌី ឆ.៦ KH 01102810-01102811 ["ខ្ញុំបានឃើញដោយផ្ទាល់គេ [កម្មាភិបាលនិរតី] យកពីរ ឬបីគ្រួសារ ជាអ្នកជិតខាងខ្ញុំនៅភូមិកាច់រទេះ យកទៅបាត់ទាំងយប់។ ដោយមិនឃើញត្រឡប់មកវិញទេ។"]។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៥១ KH 01114666 [នៅឃុំ៦០៖ "នៅក្នុងឆ្នាំ១៩៧៨ ក្នុងពេលដែលពួកនិរតីកាន់កាប់ គាត់ [ពូរបស់ដើមបណ្តឹងរដ្ឋប្បវេណី] ហើយនិងប្រជាជនរាប់ពាន់នាក់បាននាំគ្នារត់ចូលទៅក្នុងព្រៃ។ ពេលនោះ ពួកយោធាបានដេញបាញ់សម្លាប់ពួកប្រជាជនទាំងនោះអស់ លើកលែងតែមនុស្សបីនាក់ប៉ុណ្ណោះដែលនៅរស់។"]។ ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ កឹ សឹង ឆ.៧១ KH 01024896 ["កិច្ចប្រជុំមួយនៅកំពង់ព្រៀង ហើយខ្ញែរក្រហមបានប្រកាសថា អ្នកដែលរត់គេចនោះ ត្រូវសម្លាប់នៅខាងត្បូងភ្នំធិបតី។"]។

591. "មនុស្សម្នាដឹងគ្រប់គ្នាថា [ភូមិ] កាច់រទេះគឺជាកន្លែងសម្លាប់មនុស្ស"[2110]។ សាក្សីម្នាក់បានសង្កេតឃើញថា ក្នុងរយៈពេលបីថ្ងៃជាប់គ្នា មនុស្សជាច្រើនត្រូវបានសម្លាប់ [...] ធ្វើឃាតរាប់ពាន់នាក់"[2111]។ សាក្សីម្នាក់បានប្រាប់អ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា "ប្រជាជនមិនត្រឹមតែមកពីភូមិនានាក្នុងតំបន់ ៤ ប៉ុណ្ណោះទេ ដែលពួកគេត្រូវបានប្រមូល ប៉ុន្តែបានមកពី [...] គ្រប់តំបន់ទាំងអស់ ដែលត្រូវបានយកវាយនៅកន្លែងនេះ"[2112]។ តាមការប៉ាន់ស្មានមើលរបស់ខ្ញុំ មានមនុស្សច្រើនណាស់ [...] ដែលត្រូវបានសម្លាប់ ប្រហែលរាប់ម៉ឺននាក់"[2113]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានលើកឡើងថា "ប្រជាជនរាប់ពាន់នាក់ត្រូវបានយកចេញទៅសម្លាប់នៅសាលាត្រាវ"[2114]។ គាត់ក៏បាននិយាយថា សមាជិកគ្រួសារខ្មែរក្រោមនៃគ្រួសារ និងសាច់ញាតិរបស់គាត់ចំនួន ៥៥ នាក់ ត្រូវបានសម្លាប់ក្នុងភូមិនេះ[2115]។

592. នៅក្នុងមន្ទីរសន្តិសុខកាច់រទេះក្នុងអំឡុងពេល ៦ ខែចុងក្រោយនៃរបបកម្ពុជាប្រជាធិតេយ្យ អតីតអ្នកទោសម្នាក់បានសង្កេតឃើញថា "ការស្លាប់មនុស្ស [...] មានចំនួនប្រាំមួយ ឬប្រាំពីរនាក់ ជារៀងរាល់ថ្ងៃ"[2116]។ អ្នកដែលត្រូវបានសួរចម្លើយ ហើយរកឃើញថាមានទោសត្រូវបានយកទៅ

[2109] ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៦៣ KH 00988051។

[2110] ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.២៨ KH 01023856។ *សូមមើលផងដែរ* ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បាង ឆ.៩៩ KH 01335624 ["ប្រជាជនយកទៅសម្លាប់ គឺថាវាមានច្រើនណាស់ ដែលគេយកទៅសម្លាប់។"]។

[2111] ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.៣២-៣៣ KH 01114663 ["ខ្ញុំឃើញ [...] ក្នុងមួយថ្ងៃៗ គេសម្លាប់មនុស្សរាប់រយ ហើយគេដាក់សាកសពចូលទៅក្នុងត្រពាំងទឹកតូចៗ រហូតដល់ពេញ [...] នៅក្នុងភូមិកាច់រទេះ។ [...] ក្នុងរយៈពេលបីថ្ងៃនោះ ចំនួនដែលគេសម្លាប់អាចចូលរាប់ពាន់នាក់។"]។

[2112] ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បាង ឆ.៦៤-៦៥ KH 01335620។

[2113] ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បាង ឆ.៦៧ KH 01335621។

[2114] ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៦៣ KH 00988051។

[2115] ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៤៩, ៥៦, ៥៨-៦០, ៧០ KH 00988049-00988050, 00988052 [សមាជិកគ្រួសារ និងសាច់ញាតិចំនួន៥៥នាក់ ត្រូវបានឃុំនៅក្នុងភូមិកាច់រទេះ បន្ទាប់មក "បញ្ជូន [...] ទៅសម្លាប់ចោលនៅក្នុងរណ្តៅធំមួយនៅក្នុងភូមិកាច់រទេះ។ [...] ខ្មែរក្រហម ចោទពួកគាត់ថាជាយួន។ [...] ពួកគាត់ជាខ្មែរក្រោម។"]។

[2116] ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.១៤ KH 01167594។ *សូមមើលផងដែរ* ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.២៨ KH 00794114 ["អ្នកទោសមានម្តង៤ ទៅ៥នាក់ នៅពេលដែលគេយកទៅសម្លាប់នោះ។"]។ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៣៦ KH 01299999 ["គេចាប់មនុស្ស [...] ដាក់ក្នុងវិហារនោះ។ ហើយពេលដែលវាប្រមូលបានច្រើនវាយកទៅសម្លាប់នៅខាងក្រោយមន្ទីរយោធា សម្លាប់នៅឯវាលស្រែ។"]។ ឯក

សម្លាប់ចោល។ [...] អ្នកទោសប្រហែល ២០ ទៅ ៣០ នាក់ បានស្លាប់ក្នុងអំឡុងពេលការធ្វើទារុណកម្ម និងការសួរចម្លើយ។ អ្នកទោសខ្លះ [...] បានស្លាប់ ក្នុងរយៈពេលមួយថ្ងៃ ឬពីរថ្ងៃ បន្ទាប់ពីពួកគេត្រូវបានសួរចម្លើយ"[2117]។ នៅជិតវាលស្រែខាងក្រោយមន្ទីរសន្តិសុខនេះ សាក្សីម្នាក់បានឃើញទាហាននាំយកអ្នកទោស ៣៥ ទៅ ៥០ នាក់ទៅសម្លាប់ ហើយកប់ ហើយពេលខ្លះទៀត មានអ្នកទោសចំនួន ១០ នាក់[2118]។ បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ រណ្តៅសាកសពរួមមានទីតាំងស្ថិតក្នុង និងនៅជុំវិញភូមិកាច់រទេះ និងមន្ទីរសន្តិសុខក្នុងភូមិនេះ។ រណ្តៅសាកសពមួយចំនួនមានកប់សាកសពចំនួន ២០០ នាក់[2119]។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលបានចូលទៅ

សារ D219/311 កំណត់ហេតុស្តាប់ចម្លើយ ពែង សាន្ត ឆ.១៤ KH 01097691 ["វត្តកាច់រទេះ [...] មានកន្លែងសម្លាប់មនុស្ស។"]។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៥៨ KH 01037160 [ពាក់ព័ន្ធនឹងពួរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖ "គេ [...] យកទៅវត្តកាច់រទេះ។ មានគេប្រាប់សាច់ញាតិគាត់ថាគេសម្លាប់គាត់នៅយប់នោះហើយ។"]។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៤៤ KH 01129779 ["មិត្តភក្តិរបស់ខ្ញុំដែលធ្វើការនៅក្នុងកងចល័តយោធា ប្រាប់ថា រថយន្តដឹកអ្នកទោសមកដល់វត្តកាច់រទេះ នៅពេលយប់ ហើយអ្នកទោសក៏ត្រូវបានគេសម្លាប់នៅពេលយប់ផងដែរ។"]។

[2117] ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២៤, ២៦ KH 01037130។ *សូមមើលផងដែរ* ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.២៦ KH 00794114 ["អ្នកទោសខ្លះស្លាប់ដោយសារការធ្វើទារុណកម្មធ្ងន់"]។ ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២៤ KH 01037130។

[2118] ឯកសារ D219/426 កំណត់ហេតុស្តាប់ចម្លើយ កែវ ឃួង ឆ.២២-២៤, ២៩-៣០ KH 01121711-01121713 [នៅក្នុងបរិវេណវត្តពោធិ៍លង្ការ៖ "ខ្ញុំគិតថា អ្នកទោសទាំងនោះគឺគេនាំចេញពីន្លែងផ្ទះពួកយោធា យកទៅសម្លាប់នៅនឹងរណ្តៅមួយ [...] មានចម្ងាយប្រហែល ៥០ម៉ែត្រ ពីស្រែដែលខ្ញុំធ្វើការ។ [...] ពួកអ្នកទោសត្រូវបានគេចងជាប់គ្នាជាខ្សែ ដែលមួយខ្សែមានអ្នកទោស ៥នាក់ ទៅ១០នាក់ ហើយមានយោធាម្នាក់ជាអ្នកដឹក។ [...] ខ្ញុំបានឃើញពួកយោធាចាក់ដីទៅក្នុងរណ្តៅដើម្បីកប់សាកសពនោះ។ [...] ការសម្លាប់នោះកើតឡើងនៅក្នុងរដូវភ្លៀងចុងឆ្នាំ១៩៧៧។ នៅក្នុងពេលនោះ រៀត ដែលជាកម្មាភិបាលនិរតីបានមកដល់កន្លែងនេះតាំងពីមុនការសម្លាប់នេះកើតឡើងមកម្ល៉ះ។" មាន "អ្នកទោសប្រាំខ្សែ "។] ឆ.៣០-៣១ KH 01121713 ["ប្រហែលជាប្រាំ ទៅប្រាំមួយខែក្រោយ ក្នុងរដូវច្រូតកាត់ [...] នៅវាលស្រែដដែល។ [...] អ្នកទោសដែលខ្ញុំឃើញនៅពេលនោះ គឺមានចំនួន១០នាក់។ ការសម្លាប់គឺធ្វើឡើងដូចកាលពីលើកមុន។"]។ *សូមមើលផងដែរ* ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.៨៥-៨៦ KH 01023867-01023868 ["ខ្ញុំដឹងពីគេថា កន្លែងសម្លាប់មនុស្ស គឺនៅតាមវាលស្រែ ខាងក្រោយគុកនោះតែម្តង។ ប៉ុន្តែខ្ញុំមិនដែលទៅទីនោះផ្ទាល់ទេ។ [...] ដោយសារខ្ញុំរស់នៅជិតផ្ទះយោធាម្នាក់ ខ្ញុំក៏សួរប្រពន្ធយោធានោះ ដែលឈ្មោះ រ៉ុយ [...] គេយកមនុស្សទៅណា។ គាត់ឆ្លើយថា គេយកមនុស្សទៅសម្លាប់នៅតាមវាលស្រែ ក្រោយគុកនោះ។"]។

[2119] ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្បៀង ឆ.៦៣-៦៤ KH 01335620 ["ក្នុងមួយរណ្តៅ មាន៣០នាក់ ក៏មានដែរ ច្រើនណាស់ភូមិខ្ញុំ។ [...] ក្នុងមួយរណ្តៅមាន១០០ ទៅ២០០ ក៏មានដែរ។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២៣៣-២៣៤ KH 01047410 ["ពេលដែលយួនចូលមកដល់ឆ្នាំ១៩៧៩ ខ្ញុំបានទៅមើលទីនោះ ហើយនៅខាងត្បូងវត្តក្នុងភូមិកាច់រទេះ គឺសុទ្ធតែរណ្តៅសាកសព។ [...] មានសាកសពច្រើនណាស់ ព្រោះក្នុងរណ្តៅនីមួយៗមានសាកសពរាប់រយ។"]។ ឯកសារ D219/394 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.១៩ KH 01114693 ["នៅលើផ្ទៃដីដែលពួកនិរតីសម្លាប់នេះ

ក្នុងមន្ទីរសន្តិសុខនេះនៅឆ្នាំ១៩៧៩ បានឃើញ "ស្នាមឈាម" និង "សាកសពប្រមាណ [...] ៣០ នាក់"[2120]។

593. ក្នុងភូមិអូសទ្ទូក ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់បានឃើញ ឃានចាន់ និងអង្គរក្សរបស់គាត់បានសម្លាប់ជនរងគ្រោះ ១៦ ឬ ១៧ នាក់ ដោយក្នុងនោះ "ស្ត្រីមួយចំនួន [...] ត្រូវបានសម្លាប់ ក្នុងពេលពួកគេកំពុងបីកូន"[2121]។

594. នៅឯមន្ទីរសន្តិសុខសាលាគ្រាវ អតីតអ្នកទោសឈ្មោះ ខេន ឡុង បានសង្កេតឃើញថា មនុស្សត្រូវបានសម្លាប់ "ម្តងក្នុងរយៈពេលពីរថ្ងៃ ឬយ៉ាងយូរបីថ្ងៃ"[2122]។ "នៅពេលយើងទៅដល់សាលាគ្រាវ [...] ខ្ញុំបានឃើញមនុស្សប្រហែល ២០០ នាក់ត្រូវបានសម្លាប់។ [...] ពីរបីថ្ងៃក្រោយទៀត ខ្ញុំបានឃើញគេសម្លាប់មនុស្សច្រើនទៀត ហើយការសម្លាប់នេះបន្តជារៀងរហូត"[2123]។ ទាក់ទងនឹងខ្ទ្ទ

យើងឃើញមានរណ្តៅប្រហែលជា២០ [...] ស្ថិតនៅខាងកើតផ្លូវជាតិលេខ៥។"]។ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈេន ឆ.៤១ KH 01327959 ["វិហារដែលខ្ញុំឃើញដែលវាអស់និរតីទៅ [...] ឃើញរណ្តៅកប់ខ្មោច"]។ ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៦៣ KH 01037161 ["ចម្ងាយប្រហែលកន្លះគីឡូម៉ែត្រពីវត្តកាច់រទេះ [...] ក្រោយឆ្នាំ១៩៧៩ គេឃើញមានផ្នូរខ្មោច និងសាកសពជាច្រើននៅទីនោះ។"] ឆ.៧១-៧២ KH 01037162 ["ខ្ញុំមិនបានឃើញដោយផ្ទាល់ភ្នែកទេ ប៉ុន្តែពួកអ្នកទៅរកមាសនៅទីនោះ បានទៅឃើញមានសាកសពនៅពេញអណ្តូង [...] នៅក្នុងភូមិកាច់រទេះ។"]។ *សូមមើលផងដែរ* ឯកសារ D1.3.11.23 កិច្ចសម្ភាសន៍របស់ ក.ស.ច ជាមួយ គីម ហេង KH 00845887 ["ជនជាប់ចោទ [...] ត្រូវគេបញ្ជូនទៅសម្លាប់នៅមុខវិហារ។"]។

[2120] ឯកសារ D219/304 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៥ KH 01096562 ["នៅក្នុងឆ្នាំ១៩៧៩ [...] យើងបានទៅវិហារនោះជាមួយគ្នា។ យើងបានឃើញ [...] ស្នាមឈាមនៅទីនោះ។ កាលនោះមានសាកសពប្រហែលជា៣០សាកសពរួមមានស្រី និងប្រុស។"]។ *សូមមើលផងដែរ* ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.២៤៨ KH 01047412។

[2121] ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ៊ឿង សំបូរ ឆ.៣៩-៤១ KH 01117195 ["នៅចុងឆ្នាំ១៩៧៨ [...] ខ្ញុំបានឃើញការសម្លាប់នោះនៅជិតកន្លែងរោងបាយរួមក្នុងភូមិអូសទ្ទូក [...] ខ្ញុំបានឃើញជនរងគ្រោះដែលគេសម្លាប់ប្រហែលជា១៦ ទៅ១៧នាក់។ មានស្ត្រីខ្លះត្រូវបានសម្លាប់ជាមួយនឹងកូនង៉ាដែលបីនឹងដៃ។ [...] ខ្ញុំអាចស្គាល់អ្នកដែលសម្លាប់នៅពេលនោះ គឺគេជាពួកនិរតីឈ្មោះគាត់យាយចាន់ ជាមួយនឹងកងការពាររបស់គាត់។ [...] គេប្រើកាំបិតហើយនិងពូថៅសម្លាប់អ្នកទាំងនោះ គេកាប់ជនរងគ្រោះឲ្យស្លាប់ហើយ គេកាត់បំពង់កថែមទៀត។ [...] ទីតាំងនេះនៅប្រហែលមួយគីឡូម៉ែត្រខាងជើងវត្តកាច់រទេះ និងខាងកើតផ្លូវជាតិ"។]។

[2122] ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៦៧ KH 01347377 ["ស៖ នៅក្នុងពេលដែលណាកគេឃុំនៅគុកសាលាគ្រាវនោះ តើណាកធ្លាប់ឃើញគេនាំមនុស្សចូលមន្ទីរនោះប៉ុន្មានដងដែរ? ហើយណាកឃើញគេយកមនុស្សទៅសម្លាប់ប៉ុន្មានដងដែរ នៅក្នុងអំឡុងឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨? ឆ.៦៧៖ [...] ពីរថ្ងៃ យ៉ាងយូរបំផុតបីថ្ងៃ គេចាប់យកទៅសម្លាប់ម្តង។"]។

[2123] ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៦២ KH 01335600។

ក្រោម អតីតអ្នកទោសឈ្មោះ ស្រី សៀម បាននិយាយថា "ពួកគេសម្លាប់មនុស្សនៅសាលាគ្រាវ [...] ស្ទើរតែរៀងរាល់ថ្ងៃ"[2124]។ ក្នុងរយៈពេលជាង ១០ ថ្ងៃ ឡុង ខេន បានឃើញខ្មែរក្រោមពី ១.000 ទៅ ២.000 នាក់ត្រូវបានគេយកចេញពីពន្ធនាគារទៅសម្លាប់[2125]។ គាត់បាននិយាយថា "ការសម្លាប់នេះត្រូវបានធ្វើឡើងពីរ ឬបីដង ដូច្នេះគ្មានប្រជាជនរៀតណាមនៅសល់ទៀតទេ"[2126]។ គាត់បានប៉ាន់ស្មានថា ខ្មែរក្រោម "រាប់ពាន់" នាក់ នៅមន្ទីរសន្តិសុខសាលាគ្រាវ ត្រូវបានសម្លាប់[2127] ។ ដោយសារការសម្លាប់មានចំនួនច្រើនជាទូទៅនៅមន្ទីរសន្តិសុខនេះ អ្នកសម្លាប់ "បានដឹកវណ្ណៅជារៀងរាល់ថ្ងៃ"[2128]។

595. "ក្រោមការគ្រប់គ្រងរបស់កម្មាភិបាលភូមិភាគនិរតី មនុស្សជាច្រើនបានបាត់ខ្លួន"[2129]។ ចំនួននេះរាប់បញ្ចូលទាំងកម្មាភិបាលភូមិភាគពាយ័ព្យផង[2130]។ នៅឯមន្ទីរសន្តិសុខកាច់រទេះ អ្នកទោសមួយ

[2124] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៦៦, ១៩ KH 01047389។

[2125] ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៦៧, ១៩ KH 01347378 ["ដល់ខ្ញុំមកនៅ ចេញពី [...] មកធ្វើដី [...] យកខ្មែរយើងកម្ពុជាក្រោម និងខ្មែរមួយចំនួនដែលគេចាត់ទុកថាជាខ្មែរក្រោមនោះ គឺនាំយកទៅសម្លាប់ [...] ប្រហែល១០ថ្ងៃអីទេ។ [...] ពេលមកដល់កន្លែងធ្វើដី មកគុកនោះ [...] ពី១000 ទៅ២000នាក់ [...] យកទៅសម្លាប់។ "]។

[2126] ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១២០ KH 01335608។ *សូមមើលផងដែរ* ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១២០ KH 01335608 ["សម្លាប់ខ្មែរកម្ពុជាក្រោម វាថាពួកហ្ម៊ីងយួន មិនមែនកម្ពុជាក្រោមទេ។"]។

[2127] ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១២២ KH 01335608។

[2128] ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៩៥ KH 01335604 ["ដឹករាល់ថ្ងៃ ពេលវាយអស់ហើយ គេចាប់ដឹក ស្អែកឡើងដឹកទៀត។"]។

[2129] ឯកសារ D219/426 កំណត់ហេតុស្តាប់ចម្លើយ កែវ ឃួង ឆ.៣៤ KH 01121714។ *សូមមើលផងដែរ* ឯកសារ D118/298 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ឫ ឆ.៤៦ KH 01023860 [នៅភូមិអ្ងសទ្ធកៃ "ក្រោយពីការមកដល់របស់កម្មាភិបាលនិរតី ពួកគេបាត់ខ្លួនទាំងគ្រួសារតែម្តង មិនដឹងថាពួកគេត្រូវបានយកទៅសម្លាប់ ឬរត់ភៀសខ្លួនដោយខ្លួនឯងនោះទេ។"]។

[2130] ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ីង សំបូរ ឆ.១៥ KH 01117190 ["ប្រធានកងពុកម៉ែចាស់ៗម្នាក់នៅក្នុងភូមិថ្មី ឈ្មោះយ៉ុម។ [...] ខ្ញុំបានឮអ្នកនៅក្នុងកងនិយាយថា យ៉ុម ត្រូវបានគេចាប់ខ្លួនពីពេលព្រឹក។ [...] ខ្ញុំមិនដែលបានឃើញ យ៉ុម ទៀតទេ។"]។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហ្ស៊ីង ឆ.១ KH 01117332 ["ស៖ [...] លោកបានកត់សម្គាល់អំពីការបាត់ខ្លួនរបស់កម្មាភិបាលភូមិភាគពាយ័ព្យ ដែលក្រោយមកត្រូវបានជំនួសដោយកម្មាភិបាលនិរតីវិញ។ [...] តើនេះជាសេចក្តីសង្ខេបត្រឹមត្រូវ [...]? ឆ.១៖ ត្រឹមត្រូវ"]។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀម ឌី ឆ.៥-៦ KH 01102810-0102811 ["ក្រោយពីពួកនិរតីចូលមកដល់ គឺពួកវាយកកម្មាភិបាលពាយ័ព្យធំៗទៅបាត់ទាំងអស់។ [...] ខ្ញុំក៏ឮគេនិយាយដែរថាកម្មាភិបាលពាយ័ព្យថ្នាក់តំបន់ គេយកទៅរៀនសូត្រនៅភ្នំពេញ ប៉ុន្តែមិនដឹងថាមានរឿងអ្វីកើតឡើងទេ។ [...] ខ្ញុំសង្កេតឃើញមានការបាត់ខ្លួនរបស់កម្មាភិបាលពាយ័ព្យចាប់ពីថ្នាក់សហករណ៍ ដល់ថ្នាក់តំបន់។"]។ ឯកសារ D219/394

ចំនួន "បានបាត់ខ្លួនជារៀងរហូត"[2131]។ សាក្សីម្នាក់បាននិយាយថា ប្រជាជនខ្មែរក្រោមដែលត្រូវបានចាត់ទុកថាជាវៀតណាមត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខនេះ ហើយគាត់ "មិនបានឃើញប្រជាជនទាំងនេះវិលត្រឡប់ទៅកាន់ភូមិវិញទេ"[2132]។ សាក្សីម្នាក់ទៀតជឿជាក់ថា អ្នកទោសដែលបានបាត់ខ្លួន "ត្រូវបានយកទៅសម្លាប់ចោល"[2133]។ សមាជិកនៃគណៈសហករណ៍កំពង់គោ បានឃើញ "គ្រួសារទាំងមូល" នៃខ្មែរក្រោមដែលមានមនុស្សប្រមាណពី ៥០ ទៅ ៦០ នាក់ "ត្រូវបានឃុំទុកបណ្តោះអាសន្ន" នៅរោងបាយឃុំ [កាច់រទេះ] ហើយពីរបីថ្ងៃក្រោយមក ពួកគេបានយកឡានដឹកប្រជាជនទាំងនោះចេញទៅសម្លាប់ចោល"[2134]។

កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.៤ KH 01114689 ["បន្ទាប់ពីពួកនិរតីមកដល់ ពួកកម្មាភិបាលពាយ័ព្យគេហៅឲ្យទៅប្រជុំ ឬរៀនសូត្រ ហើយមិនដែលឃើញត្រឡប់មកវិញទេ។"]។

[2131] ឯកសារ D219/61 កំណត់ហេតុស្តាប់ចម្លើយ ឆោម សុដា ឆ.២៦ KH 01037130 [នៅវត្តកាច់រទេះ៖ "អ្នកទោសខ្លះទៀតពេលគេយកទៅស្សរចម្លើយក៏បាត់រហូតតែម្តង។]។ ឯកសារ D219/310 កំណត់ហេតុស្តាប់ចម្លើយ រ៉ន្ត សាមុត ឆ.១៣ KH 01097681 [ពាក់ព័ន្ធនឹងបងប្រុសរបស់សាក្សី៖ "កាលនោះម៉ោងប្រហែល ៧ ឬ៨ព្រឹក គេបានចាប់ខ្លួនគាត់ [...] គេដឹកគាត់តាមរទេះគោយកទៅវត្តកាច់រទេះ។ បងប្រុសខ្ញុំក៏បាត់ខ្លួនតាំងពីពេលនោះមក។"]។ ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.៣៤ KH 00794115 ["ស៖ ហើយអ្នកទោសដែលគេយកចេញនោះបាត់ខ្លួនរហូតឬទេ? ឆ.៣៤៖ បាទ។"]។

[2132] ឯកសារ D219/303 កំណត់ហេតុស្តាប់ចម្លើយ ខ្ឿន ច័ម ឆ.១៩ KH 01096555 ["ខ្ញុំគ្រាន់តែឃើញគេដឹកខ្មែរក្រោមពីសាលាតាអន មកដាក់នៅក្នុងគុកវត្តកាច់រទេះ ហើយកម្មាភិបាលប្រាប់ថា ពួកគេជាយួន។ គេមិនបានប្រាប់អំពីមូលហេតុនៃការដឹកអ្នកទាំងនោះមកកាន់គុកវត្តកាច់រទេះទេ។ ខ្ញុំមិនដែលបានឃើញអ្នកដែលគេដឹកទៅគុកវត្តកាច់រទេះនេះ ចេញមកវិញទេ។"]។

[2133] ឯកសារ D105/7 កំណត់ហេតុស្តាប់ចម្លើយ គឹម ហេង ឆ.៣៤ KH 00794115។

[2134] ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៥៦, ៦៣, ៩៦ KH 01151005-01151006, 01151010 ["ប្រជាជនដែលគេចាប់មកទាំងនោះមកទាំងគ្រួសារ ភាគច្រើនស្ត្រី។ [...] គេដាក់នៅកាច់រទេះ ឬក៏ភូមិថ្មី នៅតាមផ្លូវជាតិលេខ ៥។ [...] គេនាំយកអ្នកទាំងនោះមកផ្ញើទុកមួយរយៈ នៅហ្ម៊ីងផ្ទះបាយ ហើយពីរបីថ្ងៃក្រោយមក គេត្រឡប់មកយកមនុស្សទាំងនោះឲ្យឡើងឡានចេញទៅ។ [...] ប្រហែល ៥០-៦០នាក់ ព្រោះមនុស្សពេញរោងបាយនោះ ដែលមានបណ្តោយប្រហែល ៣០ ម៉ែត្រ ទទឹងប្រហែលប្រាំពីរប្រាំបីម៉ែត្រ។"] (កំណត់សម្គាល់ សាក្សីបាននិយាយថា ភូមិកាច់រទេះ និងភូមិថ្មី គឺភូមិតែមួយ *សូមមើល* ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៦២ KH 01151006។)។ *សូមមើលផងដែរ* ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៥៦, ៩៥ KH 01151005, 01151010 ["ខ្ញុំបានស្ស ញ៉ន [ប្រធានសហករណ៍ភូមិភាគនិរតី], 'តើប្រជាជនទាំងនេះ ចាប់មកពីណា? ញ៉ន ប្រាប់ខ្ញុំថាពួកគេគឺយួន ព្រោះពួកគេនិយាយរដ៏ន។ ខ្ញុំថាអ្នកទាំងនោះមិនមែនជាយួនទេ គឺខ្មែរក្រោម។ [...] ដោយសារគេនិយាយរដ៏ន ដូចអ្នកកាច់រទេះ ព្រោះអ្នកកាច់រទេះក៏ខ្មែរក្រោមដែរ តែពួកគេរស់នៅទីនោះយូរហើយ។"] ឆ.៩៧ KH 01151010-01151011 ["គេឲ្យខ្ញុំជួនដើរចាប់ខ្ញែរក្រោមដែលបានរស់នៅកាច់រទេះនោះ អស់មួយជីវិតនោះផងដែរ។ [...] តាមខ្ញុំចាំមានមនុស្សប្រាំនាក់ [...] ដែលត្រូវបានចាប់ខ្លួនយកមកទុកនៅផ្ទះខ្ញុំ។ មានមនុស្ស

ការធ្វើទុក្ខបុកម្នេញ

ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនវៀតណាម និងខ្មែរក្រោម

596. ប្រជាជនវៀតណាម និងខ្មែរក្រោមត្រូវរងការធ្វើទុក្ខបុកម្នេញ ដោយផ្អែកលើឧក្រិដ្ឋកម្មមួយចំនួន ដូចបានរៀបរាប់ខាងលើ។ អរិភាពទៅលើជនណាដែលត្រូវបានចាត់ទុកថាមានទំនាក់ទំនងជាមួយវៀតណាម បានកើតមាននៅក្នុងតំបន់ឃុំកំពង់ព្រៀង ជាពិសេសនៅក្នុងភូមិកាច់រទេះ និងមន្ទីរសន្តិសុខសាលាត្រាវ។ សាក្សីម្នាក់ដែលបានចូលរួមក្នុងកិច្ចប្រជុំមួយដែលក្នុងពេលនោះ កម្មាភិបាលភូមិភាគនិរតីបានប្រកាសថា "មានគិញយួនក្នុងចំណោមប្រជាជន ហើយថាប្រសិនបើនរណាស្គាល់ ត្រូវតែរាយការណ៍ប្រាប់អង្គការ"[2135]។ សាក្សីម្នាក់ទៀតបានចូលរួមក្នុងកិច្ចប្រជុំមួយដែលក្នុងនោះ តាម៉ុក បានលើកឡើងពីវត្តមាននៃ "គិញយួន" ក្នុងចំណោមប្រជាជន[2136]។ ដូចបានពិភាក្សាក្នុងផ្នែកនៃដីកាសន្និដ្ឋានស្តាពរនេះអំពី *ឧក្រិដ្ឋកម្មប្រឆាំងនឹងវៀតណាម* [2137] ជនណាដែលត្រូវបានចាត់ទុកថាមានទំនាក់ទំនងជាមួយនឹងវៀតណាម ទោះបីជាផ្នែកនយោបាយ ជាតិសាសន៍ សញ្ជាតិ ឬពន្ធុក៏ដោយ ត្រូវបានកំណត់ថាជាជនក្បត់[2138]។ នៅក្នុងតំបន់ឃុំកំពង់ព្រៀង "ខ្មែរក្រោម […] បានរស់នៅទីនេះអស់រយៈពេលយ៉ាងយូរ"[2139]។ កម្មាភិបាលភូមិភាគនិរតីបានចោទប្រកាន់

ប្រហែល៤០នាក់ទៀត តែចំនួននេះខ្ញុំមិនសូវច្បាស់ទេ។ […] ពេលខ្លះគេទុកមនុស្សនៅទីនោះតែមួយយប់ រួចស្អែកឡើងគេយកឡានដឹកចេញទៅ។ បើសិនគេដឹកមួយឡានមិនអស់ គេទុកអ្នកដែលនៅសល់នៅទីនោះសិន រួចស្អែកឡើងគេមកដឹកទៀត។"]។

[2135] ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.១៩ KH 01102814។

[2136] ឯកសារ D219/343 កំណត់ហេតុស្តាប់ចម្លើយ រស់ ម៉ោង ឆ.៩ KH 01102894-01002895 [នៅភូមិអ្ងសទ្ធក៖ "ស៖ […] តាមុក និយាយថា […] គាត់ស្មាន យ៉ាងច្រើនមានគិញយួន ចំនួន៣០០នាក់ប៉ុណ្ណោះ ក្នុងចំណោមប្រជាជនទាំងនោះ។ […] តើការសង្ខេបនេះត្រឹមត្រូវដែរ ឬទេ? ឆ.៩៖ បាទ ត្រឹមត្រូវ។"]។

[2137] *សូមមើល* V.ค.๓.ก. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងវៀតណាម – គោលនយោបាយបក្សកុម្មុយនីស្តកម្ពុជាក្នុងការកម្ចាត់វៀតណាម – ចលនារបស់បក្សកុម្មុយនីស្តកម្ពុជាប្រឆាំងនឹងវៀតណាម និងខ្មែរក្រោម។

[2138] *សូមមើលផ្ទុយ* ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.១០០ KH 01151011 ["ខ្ញុំឮពាក្យប្រជាជនខ្លះគេនិយាយ តែខ្ញុំមិនដឹងថាគេដឹងមកពីណាទេថា ពួកពាយ័ព្យមិនថាជាកម្ពុជាក្រោម ឬកម្ពុជាលើទេ គេត្រូវកម្ទេចចោលទាំងអស់។"]។

[2139] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៦៣ KH 01047388។ *សូមមើលផងដែរ*ឯកសារ D219/394 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.១០ KH 01114690 [មុនរបបខ្មែរក្រហម៖ "មានគ្រួសារខ្មែរក្រោមប្រហែល១០០គ្រួសាររស់នៅក្នុងភូមិកាច់រទេះនេះ។ ប្រជាជនភាគច្រើននៅក្នុងភូមិកាច់រទេះនេះ ខ្ញុំអាចថាមានប្រហែល ៩០ភាគរយនៅពេលនោះ គឺជាខ្មែរក្រោម។"]។ ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៩៧ KH 01151010-01151011 ["ខ្មែរក្រោម […] បានរស់នៅកាច់រទេះនោះអស់មួយជីវិតនោះផងដែរ"]។ ឯកសារ D219/341 កំណត់ហេតុស្តាប់ចម្លើយ នក់ សាវ៉ាវ ឆ.២២ KH

ខ្មែរក្រោមដែលមានដើមកំណើតស្ថិតក្នុងទឹកដី ដែលក្នុងពេលនេះក្នុងប្រទេសវៀតណាមថាជាប្រជាជនវៀតណាម[2140]។ កម្មាភិបាលទាំងនេះបានធ្វើការកត់សម្គាល់លើសំឡេងនិយាយរបស់ខ្មែរក្រោម និងស្បែកសរបស់គេ ហើយបានហៅពួកគេថា "យួន" ដែលជាពាក្យខ្មែរសំដៅលើប្រជាជនវៀតណាម[2141]។ នៅពេលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចោទសួរថាតើខ្មែរក្រហមមានគោល

01102872 [នៅភូមិកាច់រទេះ៖ "ប្រជាជននៅក្នុងមូលដ្ឋាននេះទាំងអស់ សុទ្ធតែជាខ្មែរក្រោម"]។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១ KH 01117332 [នៅភូមិបឹងឈូក៖ "ស៖ [...] លោកក៏បានប្រាប់យើងដែរថា ៨០-៩០ ភាគរយនៃប្រជាជននៅមូលដ្ឋាននេះ ក្នុងសម័យខ្មែរក្រហម គឺជាគ្រួសារខ្មែរក្រោម។ តើនេះជាសេចក្តីសង្ខេប ត្រឹមត្រូវ [...]? ឆ.១៖ ត្រឹមត្រូវហើយ"]។

[2140] *សូមមើលឧទាហរណ៍* ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហៀង សំបូរ ឆ.១៨ KH 01117191 [នៅភូមិសាលាត្រាវ "ពួកនិរតីនៅពេលនោះមានគោលនយោបាយសម្លាប់បំបាត់ពូជខ្មែរក្រោម ដែលមកពីប្រទេសវៀតណាម ដោយសារគេចាត់ទុកពួកខ្មែរក្រោមនោះថាជាយួន។"]។ ឯកសារ D219/394 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.៦ KH 01114690 [នៅភូមិកាច់រទេះ "ខ្មែរក្រហម សំដៅទៅលើខ្មែរក្រោម ដោយគេចាត់ទុកពួកខ្មែរក្រោម ថាជាខ្សែយួន។"]។

[2141] ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៥៦, ៩៥ KH 01151005, 01151010 ["ខ្ញុំបានសួរ ញ៉ន [ប្រធានសហការណ៍ភូមិភាគនិរតី], 'តើប្រជាជនទាំងនេះ ចាប់មកពីណា? ញ៉ន ប្រាប់ខ្ញុំថាពួកគេគឺយួន ព្រោះពួកគេនិយាយរដីន។ ខ្ញុំថាអ្នកទាំងនោះមិនមែនជាយួនទេ គឺខ្មែរក្រោម។ [...] ដោយសារគេនិយាយរដីន ដូចអ្នកកាច់រទេះ។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៦៣ KH 01047388 [នៅភូមិអូរសទ្ធុកៈ "នៅពេលនោះខ្មែរក្រហម បានចាប់ខ្មែរក្រោម ដែលមានសម្បុរស ដោយគេចោទថាជាយួន។"]។ <u>សំនៀង</u>៖ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៥ KH 01097670។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហៀង សំបូរ ឆ.១៨ KH 01117191។ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.៥៣ KH 01300001។ ឯកសារ D219/343 កំណត់ហេតុស្តាប់ចម្លើយ រស់ ម៉ាង ឆ.១៤ KH 01102895។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.២០ KH 01102814។ ឯកសារ D219/396 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.៣៤ KH 01114719។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.១៧២ KH 01047403។ *សូមមើលផងដែរ* ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៥៩-៦០ ឆ.៧០ KH 00988050, 00988052។ <u>ពណ៌សម្បុរ</u>៖ ឯកសារ D219/25 កំណត់ហេតុស្តាប់ចម្លើយ ស សម័យ ឆ.៧៦ KH 01029981។ <u>យួន</u>៖ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហៀង សំបូរ ឆ.១៨ KH 01117191។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.៥ KH 01117333។

នយោបាយតម្រង់ទិសដៅលើខ្មែរក្រោម ឬទេ គាត់បានឆ្លើយថា "ពួកគេបាននិយាយថា ប្រជាជនខ្មែរក្រោមគឺជាខ្មាំងរបស់ពួកគេ"[2142]។ "ពួកគេបាននិយាយថា យើងមានក្បាលយួនខ្លួនខ្មែរ"[2143]។

ការធ្វើទុកបុកម្នេញដោយសារនយោបាយលើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសារ និងថ្នាក់ក្រោមរបស់គេ

597. កម្មាភិបាលភូមិភាគនិរតីបានប្រព្រឹត្តឧក្រិដ្ឋកម្មមួយ ចំនួនដូចបានរៀបរាប់ខាងលើក្នុងគោលបំណងតម្រង់ទិសដៅលើក្រុមជាក់លាក់ ពោលគឺកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសារ និងថ្នាក់ក្រោមរបស់គេក្នុងតំបន់ឃុំកំពង់ព្រៀង។ ក្រុមនេះត្រូវបានតម្រង់ទិសដៅជាពិសេស ពីព្រោះសមាជិកនៃសហឧក្រិដ្ឋកម្មរួមរបស់កម្មាភិបាលភូមិភាគនិរតី ចាត់ទុកកម្មាភិបាលភូមិភាគពាយ័ព្យជាសមាជិកនៃក្រុមនយោបាយ ដែលប្រឆាំងនឹងការដឹកនាំរបស់របបកម្ពុជាប្រជាធិបតេយ្យ។ នៅដើមឆ្នាំ១៩៧៨ កម្មាភិបាលស៊ីវិលភូមិភាគពាយ័ព្យម្នាក់បានចូលរួមក្នុងកិច្ចប្រជុំមួយជាមួយនឹង "កម្មាភិបាលដែលនៅសល់គ្រប់កម្រិតទាំងអស់" ពីសហករណ៍ក្បាលផ្ទះ និងកំពង់គោ ដែលមិនទាន់ត្រូវបានដាក់ពន្ធនាគារ ឬត្រូវបានសម្លាប់ដើម្បីស្តាប់ការបញ្ជាក់ពីតាម៉ុក លេខាភូមិភាគពាយ័ព្យដែលថា "ក្រុមទាំងអស់នៅក្នុងភូមិភាគពាយ័ព្យគឺជាជនក្បត់"[2144]។ នៅក្នុងភូមិអូសទូក ដើមបណ្តឹងរដ្ឋបាលវេណីម្នាក់បានឮកម្មាភិបាលភូមិនិរតីនិយាយថា "ជនក្បត់ទាំងអស់ត្រូវតែកម្ទេចចោល"[2145]។ កម្មាភិបា

[2142] ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីយ សាន្ត ឆ.៧៤ KH 00988053។ *សូមមើលផងដែរ* ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៦៦ KH 01151007 ["ស៖ តើអ្នកដែលត្រូវបានគេចោទថាជាយួន នឹងក្លាយជាគោលដៅសម្រាប់គេចាប់ខ្លួនដែរ ឬទេ បើទោះបីជាក់ស្តែងគេមិនមែនជាយួនក្តី? ឆ.៦៦៖ បាទ។"]។ ឯកសារ D219/341 កំណត់ហេតុស្តាប់ចម្លើយ នក់ សាង៉ាវ ឆ.២០ KH 01102872 [នៅភូមិកាច់រទេះ៖ "ខ្ញុំគ្រាន់តែដឹងថាគេ [កម្មាភិបាលនិរតី] ចង់សម្លាប់ខ្មែរក្រោមចោលទាំងអស់។ ខ្ញុំឮគេនិយាយថា អញស្មានតែយកទៅអស់ហើយ នៅមានទៀត។"]។ ឯកសារ D219/343 កំណត់ហេតុស្តាប់ចម្លើយ រស់ ម៉ោង ឆ.៦ KH 01102894 [សាក្សី គឺជាខ្មែរក្រោមម្នាក់ ដែលរស់នៅក្នុងភូមិអូសទូក នៅពេលដែលកម្មាភិបាលនិរតីបានមកដល់៖ "ស៖ [...] លោកបានប្រាប់ថា ពួកខ្មែរក្រហមចាត់ទុកខ្មែរក្រោមជាយួនទាំងអស់ ហើយចង់បោសសម្អាតពួកយើងចោលទាំងអស់។ [...] តើត្រឹមត្រូវដែរ ឬទេ? ឆ.៦៖ បាទ ត្រឹមត្រូវហើយ។"]។ ឯកសារ D219/396 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.៣៣ KH 01114719 [នៅភូមិកាច់រទេះ៖ "ខ្ញុំដឹងថា គេស្វែងសំដៅរកខ្មែរក្រោម។"]។

[2143] ឯកសារ D219/343 កំណត់ហេតុស្តាប់ចម្លើយ រស់ ម៉ោង ឆ.១៤ KH 01102895។

[2144] ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៧៥-៧៨, ៨១ KH 01151008។ *សូមមើលផងដែរ* ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៤៦ KH 01047386។ ឯកសារ D219/25 កំណត់ហេតុស្តាប់ចម្លើយ ស សម័យ ឆ.៦៩ KH 01029979។ ឯកសារ D219/839 កំណត់ហេតុស្តាប់ចម្លើយ ជា ក្ងៀង ឆ.៥៦ KH 01335619។

[2145] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៤៦ KH 01047386។

លភូមិភាគពាយ័ព្យត្រូវបានចោទប្រកាន់ថាមាន "សម្ព័ន្ធភាពជាមួយយួន"[2146]។ ឧទាហរណ៍គួរឲ្យកត់សម្គាល់មួយនៃការស្វែងរកមិនឈប់ឈរនូវកម្មាភិបាលភូមិភាគពាយ័ព្យគឺការឃុំខ្លួន ការចាប់ខ្លួនឡើងវិញ និងការសម្លាប់លេខាសហករណ៍ក្នុងឃុំ ៣០ ឈ្មោះ យិន[2147]។

v. ឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់នៅក្នុងដីការចោទប្រកាន់

598. ដោយផ្អែកលើភ័ស្តុតាងដែលបានបញ្ជាក់ខាងលើ ស.ព.អ ស្នើឲ្យធ្វើការចោទប្រកាន់ **យ៉ីម ទិត្យ** ពីបទឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងតំបន់ភូមិសាស្ត្រដែលត្រូវស្គាល់នាពេលបច្ចុប្បន្នថាជាឃុំកំពង់ព្រៀង[2148] ជាអាទិ៍ អំពើប្រល័យពូជសាសន៍ក្រុមជនជាតិវៀតណាម ក្នុងប្រទេសកម្ពុជា (ជាពិសេសខ្មែរក្រោម[2149]) និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់មនុស្ស ការសម្លាប់រង្គាល[2150] ការធ្វើឲ្យទៅជាទាសករ ការដាក់ពន្ធនាគារ ការធ្វើទុក្ខបុកម្នេញដោយសារនយោបាយ

[2146] ឯកសារ D6.1.625 កិច្ចសម្ភាស SOAS ជាមួយ ติก ស៊ីម EN 00352051។

[2147] ឯកសារ D219/63 កំណត់ហេតុស្តាប់ចម្លើយ សៅ សុខ ឆ.៨៧ KH 01037164 ["ចំពោះកម្មាភិបាល យិន នោះគេឃុំនៅក្នុងវិហារ។"]។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៤២ KH 01104620 ["កម្មាភិបាលនិរតី បានបណ្តើរពួកគេនៅតាមភូមិ ឈ្មោះយិន បានព្យាយាមរត់គេ ប៉ុន្តែត្រូវបានកម្មាភិបាលនិរតីចាប់បាន ហើយកាត់ម្រាមដៃរបស់គាត់ ហើយសម្លាប់គាត់ចោល។"]។ ឯកសារ D219/781 កំណត់ហេតុស្តាប់ចម្លើយ យ៉ាន ប្រាក់ ឆ.១២៧ KH 01300010 ["ពួកម៉ាកខ្ញុំថា [យិន] [...] លួចគាស់ទ្វាររត់ តែគេចាប់បាន គេកាត់ដៃ កាត់ជើង រួចគេយកទៅសម្លាប់នៅក្រោយវត្ត។"]។ ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀវ ហេង ឆ.១៣ KH 01114702។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ែត ឆ.៦ KH 01167592។ ឯកសារ D219/302 កំណត់ហេតុស្តាប់ចម្លើយ ខឿន ចឹម ឆ.៨ KH 01096544។ ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ឆ.២២ KH 01114662។ ឯកសារ D219/424 កំណត់ហេតុស្តាប់ចម្លើយ រៀម ដុះ ឆ.៣៥ KH 01121684។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សឿម ឆ.៣៨-៣៩ KH 01047385។

[2148] សហព្រះរាជអាជ្ញាអន្តរជាតិបានកត់សម្គាល់ពាក់ព័ន្ធទៅនឹងឃុំកំពង់ព្រៀង គាត់បានស្វែងរកការចោទប្រកាន់ចំពោះបទឧក្រិដ្ឋកម្មដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលយក ប៉ុន្តែមិនទាន់ចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ បទឧក្រិដ្ឋទាំងអស់នោះ គឺអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម និងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ធ្វើទុក្ខបុកម្នេញទៅលើគោលនយោបាយប្រឆាំងនឹងជនជាតិវៀតណាម និងអំពើអមនុស្សធម៌ផ្សេងៗទៀត (អំពើអមនុស្សធម៌ ការបាត់ខ្លួនដោយបង្ខំ និងការរំលោភសេពសន្តវ:)។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលយកបទឧក្រិដ្ឋទាំងអស់នោះ នៅក្នុងឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី២០ ខែ វិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៨-៥៩, ១១៨b។ ឯកសារ D191 សារណាបន្ថែមរបស់សហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ និងអំពើហិង្សាផ្លូវភេទ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ៤-៦, ៨, ១៣។

[2149] *សូមមើល* V.គ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងវៀតណាម។

[2150] សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បង្ហាញធាតុផ្សំយ៉ាងច្រើននៃឧក្រិដ្ឋកម្មសម្លាប់រង្គាល ជាភស្តុតាងដែលកើតឡើងនៅឃុំកំពង់ព្រៀងតែឯងប៉ុណ្ណោះ។ ជាផ្ទុយមកវិញ សហព្រះរាជអាជ្ញាអន្តរជាតិ ឈរលើជំហរថា ក្នុងពេលពិចារណាលើធាតុផ្សំយ៉ាង

លើកម្មាភិបាលភូមិភាគពាយ័ព្យ គ្រួសារ និងថ្នាក់ក្រោមរបស់ពួកគេ ខ្មែរក្រោម និងប្រជាជនវៀតណាម និងអំពីអមនុស្សធម៌ផ្សេងៗទៀត (ការប្រព្រឹត្តដោយអមនុស្សធម៌ អាពាហ៍ពិពាហ៍ដោយបង្ខំ[2151] ការរំលោភសេពសន្ថវៈ និងការបាត់ខ្លួនដោយបង្ខំ) ។

គ. មន្ទីរសន្តិសុខវត្តសម្ពេច

i. សេចក្តីផ្តើម

599. មន្ទីរសន្តិសុខវត្តសម្ពេច និងទីតាំងសម្លាប់មនុស្ស ហើយនឹងទីតាំងកប់សពនៅជាប់គ្នានោះគឺស្ថិតនៅស្រុកបាក់ព្រាស្រុក៤១ តំបន់៤ នៃភូមិភាគពាយ័ព្យនៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ដោយបានដើរតួនាទីក្នុងការជួយពន្លឿនបន្ថែមនៅក្នុងសហឧក្រិដ្ឋកម្មរួមដែលមាន **យ៉ឹម ទិត្យ** ជាសមាជិកនាំមុខនោះ ពួកកម្មាភិបាលភូមិភាគនិរតីក៏បានឡើងត្រួតត្រាលើតំបន់នេះ ត្រឹមដើមឆ្នាំ១៩៧៨ ដោយបានប្រើប្រាស់វត្តសម្ពេចធ្វើជាមន្ទីរសន្តិសុខ និងបានអនុវត្តការសម្លាប់ក្រៅអំណាចតុលាការនៅលើទីតាំងនេះ។ ជនរងគ្រោះរួមមាន ជនជាតិវៀតណាម ខ្មែរក្រោម កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ សមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ ហើយនឹង "ប្រជាជនថ្មី"។

600. ស.ច.ស.អ បានចោទប្រកាន់ **យ៉ឹម ទិត្យ** ថាបានប្រព្រឹត្តឧក្រិដ្ឋកម្មដូចខាងក្រោមទាក់ទងនឹងមន្ទីរសន្តិសុខវត្តសម្ពេច៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកនៅក្រោមបង្គាប់ ហើយនឹងឧក្រិដ្ឋកម្មនៃអំពើមនុស្សឃាតគិតទុកជាមុន នៅក្រោមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[2152]។

ច្រើន គឺត្រូវបង្ហាញឲ្យឃើញការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខទាំងអស់ នៅទីកន្លែងសម្លាប់មនុស្ស និងការដ្ឋានការងារដោយបង្ខំ រួមទាំងឃុំកំពង់ព្រៀង គឺគួរតែដាក់សរុបបញ្ចូលគ្នា។ រាល់ទីតាំងទាំងអស់ គឺបង្កើតបានជាទម្រង់មួយ រៀបចំឡើងជាប្រព័ន្ធក្នុងការអនុវត្តគោលនយោបាយក្នុងការធ្វើទុក្ខបុកម្នេញ និងសម្លាប់សត្រូវ និងរាល់ការសម្លាប់នៅតាមទីតាំងទាំងអស់ ត្រូវតែធ្វើឡើងតាមការសម្របសម្រួលនៃការបញ្ជារបស់ យ៉ឹម ទិត្យ។

[2151] *សូមមើល* V.ខ.៧. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទ។

[2152] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ឹម ទិត្យ ដែលបានកែប្រែ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ EN 01426074, 78។

ii. ប្រតិបត្តិការ និងទីតាំង

601. កម្មាភិបាលភូមិភាគនិរតី គឺជាអ្នកគ្រប់គ្រងអំណាចនៅភូមិសម្តេច ត្រឹមដើមឆ្នាំ១៩៧៨[2153]។ ពួកគេបានយកព្រះវិហារវត្តសម្តេចធ្វើជាមន្ទីរសន្តិសុខ[2154] ហើយបានធ្វើប្រតិបត្តិនៅលើគុកនេះរហូតដល់

[2153] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៦ KH 01165924 [សាក្សីត្រូវបានជម្លៀសដោយកម្មាភិបាលភូមិភាគនិរតីនៅ "ចុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨"។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.១៧, ២៦ KH 01213253, 55 [កម្មាភិបាលភូមិភាគនិរតីបានចាប់ផ្តើមចាប់ខ្លួនកម្មាភិបាលភូមិភាគពាយ័ព្យក្នុងឆ្នាំ"១៩៧៧"]។ ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន រ៉ើន ឆ.១០ KH 01203948 ["ដូចចុងឆ្នាំ៧៧ ដែលនិរតីមក"]។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៧ KH 01203884 ["ចុងឆ្នាំ៧៧ហើយ [...] និរតីមក"]។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីន ណុន ឆ.១៦ KH 01203916 ["[កម្មាភិបាលភូមិភាគនិរតីមកដល់] នៅក្នុងឆ្នាំ៧៧ដែរ ប៉ុន្តែចុងឆ្នាំ វាជិតចូល៧៨"]។ ឯកសារ D219/719 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង មាន ឆ.១១, ១២ KH 01213268 ["និរតីចូលមក ១៩៧៨"]។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ឆ.១៧ KH 01165911 ["កម្មាភិបាលភូមិភាគនិរតីចូលមក "គឺនៅឆ្នាំ១៩៧៨"]។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ស្ងួន ហេង ឆ.២ KH 01485007 [កម្មាភិបាលភូមិភាគនិរតីបានមកដល់ "នៅដើមឆ្នាំ១៩៧៨"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៦១ KH 00780650 ["ស៖ [...] លោកចង់កែតម្រូវឆ្នាំដែលកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានផ្លាស់ដោយពួកនិរតី? ឆ.៦១ បាទ ឆ្នាំនោះគឺឆ្នាំ១៩៧៦"]។

[2154] ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន រ៉ើន ឆ.៣ KH 01203945។ ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.១២ KH 00780645។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ១៩៩៨៖ ខេត្តបាត់ដំបង KH 00722401។ មុនកម្មាភិបាលភូមិភាគនិរតីប្រើប្រាស់វត្តសម្តេចធ្វើជាមន្ទីរសន្តិសុខ កម្មាភិបាលភូមិភាគពាយ័ព្យបានប្រើប្រាស់វត្តនេះសម្រាប់គោលបំណងក្រៅពីមន្ទីរសន្តិសុខ។ *សូមមើល* ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីន ណុន ឆ.៤០-៤១ KH 01203920។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត *ហៅ* ភោគ ឆ.១៧ KH 01165914 ។ ឯកសារ D219/719 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង មាន ឆ.៦, ឆ.៨ KH 01213267។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.២១, ៥៤ KH 01213254, 61។ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៧ KH 01165924 ។ ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន រ៉ើន ឆ.៣ KH 01203945។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៧ KH 01203885។ ឯកសារ D219/688 កំណត់ហេតុនៃកិច្ចស៊ើបសួរ, ការរៀបរាប់របស់ ឈាន ទុំ ឆ.២ KH 01226366-67។

ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[2155]។ មន្ទីរសន្តិសុខវត្តសម្ពេច មានទីតាំងស្ថិតនៅក្នុងភូមិសម្ពេច ឃុំតាប៉ុន ស្រុកបាក់ព្រាស្រុក៤១ នៃតំបន់៤ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2156]។

602. វត្តសម្ពេច មានអគារមួយចំនួនដែលរួមមាន ព្រះវិហារ (មានទំហំប្រហែល ២០ x ៨ ម៉ែត្រ) ដែលស្ថិតនៅចម្ងាយប្រមាណជា ២០ម៉ែត្រ ពីច្រកចូល និងកុដិលោកនៅដាច់ដោយឡែក ដែលពួកកម្មាភិបាលភូមិភាគនិរតី បានប្រើប្រាស់ធ្វើជាមន្ទីរពេទ្យ[2157]។ វត្តសម្ពេច តភ្ជាប់ពីផ្លូវដោយស្ពានមួយ[2158] និងមានស្រះទឹកមួយនៅក្បែរនោះ[2159]។ ទីតាំងសម្លាប់មនុស្សមួយកន្លែងត្រូវបានបង្កើតឡើងនៅខាងកើតមន្ទីរសន្តិសុខនេះ ហើយសាកសពត្រូវបានគេកប់នៅក្នុងរណ្តៅកប់សពរួមនៅជុំវិញទីតាំង

[2155] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៥៩-៦០ KH 01165934។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ សួន ហេង ឆ.២៨ KH 01203889។ *សូមមើលផងដែរ* ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.២១, ៥៤ KH 01213255។

[2156] ឯកសារ D105/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខវត្តសម្ពេច, KH 00790591។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ១៩៩៨៖ ខេត្តបាត់ដំបង KH 00722401។ ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ សួន ហេង ឆ.១១ KH 00780666។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត *ហៅ* ភោគ ឆ.៥០ KH 01165916។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.៤៧ KH 01213260។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ សួន ហេង ឆ.១១ KH 01203885។ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ រ៉ៃត ឆ.២៦ KH 01213284។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.២៨ KH 01203918។ ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ស្រុកសង្កែ ក្នុងតំបន់៤ ត្រូវបានគេស្គាល់ថា ស្រុកបាក់ព្រា (ស្រុក៤១) *សូមមើល* ឯកសារ D219/719 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង មាន ឆ.៤, ឆ.៨ KH 01213266, 67។ ឯកសារ D219/392 កំណត់ហេតុស្តាប់ចម្លើយ តិក ស៊ីម ឆ.១៨ KH 01114674។ ឯកសារ D219/891 កំណត់ហេតុស្តាប់ចម្លើយ ផុន សុវត្ថិ ឆ.១៨ KH 01379527។ ឯកសារ D6.1.339 ចម្លើយសារភាពស-២១ របស់ ម៉ាក ម៉ន ហៅ រ៉ៃ ["ស្រុកសង្កែ (ហៅបាក់ព្រា)"]។

[2157] ឯកសារ D105/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខវត្តសម្ពេច KH 00790593។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.១៧ KH 01203917 ["គេឃុំពេទ្យលើកុដិលោក"] ឆ.៦៥ KH 0120392។ ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ន រ៉ើន ឆ.២០ KH 01203949។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត *ហៅ* ភោគ ឆ.១៩ KH 01165911។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.២១ KH 01213254។ ឯកសារ D219/719 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង មាន ឆ.៦ KH 01213267។

[2158] ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ សួន ហេង ឆ.៥, ១៩ KH 01203883, 01203887។

[2159] ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.១៧ KH 01203917 ឆ.២៤ KH 01203918។

នេះ[2160]។ ការចេញចូលវត្តនេះ ត្រូវបានហាមឃាត់ ពេលដែលវត្តនេះបានក្លាយជាមន្ទីរសន្តិសុខ[2161] ។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

603. នៅពេលលកម្មាភិបាលភូមិភាគនិរតីបានមកដល់តំបន់នេះ កម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានសម្លាប់ ឬបានបាត់ខ្លួន[2162]។ ក្រោយមកគណៈសហការណ៍ រួមមានកម្មាភិបាលភូមិភាគនិរតីដូចខាង

[2160] ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ១៩៩៨៖ ខេត្តបាត់ដំបង KH 00722401, 08 ["ទីពិឃាតនេះ មានទីតាំងស្ថិតនៅភាគខាងលិចវត្ត។"] KH 00722385-86 ["វត្តសម្តេច [...] ឫជនីយដ្ឋានរណ្តៅសាកសពរួម ៦"] KH 00722410-11។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៥ KH 01203883 ["មានរណ្តៅសាកសពរួមចំនួនបួនកន្លែង"]។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.៦៣ KH 01203924 ["មិនមែនមួយរណ្តៅទេ បីរណ្តៅ"]។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត *ហៅ* ភោគ ឆ.២៤-២៥ KH 01165912។ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ រ៉ៃត ឆ.៣៤ KH 01213285 ["ទាល់តែក្រោយពេលវៀតណាមចូល ទើបខ្ញុំបានឃើញរណ្តៅ៣"]។ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៦២ KH 01165934 ["ខ្ញុំបានឃើញមានរណ្តៅធំៗ ចំនួន២"]។ ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៣៦ KH 00780647 ["ស៖ លោកនិយាយថា លោកបានឃើញរណ្តៅចំនួន២ ដែលមានសុទ្ធតែសាកសពនៅពេញ [...] ឆ.៣៦៖ ពេលខ្ញុំមកដល់រណ្តៅទាំងនោះ ត្រូវគេកាយហើយ"]។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.២៧ KH 01213256 ["មុនពេលសម្លាប់ គេបានជីករណ្តៅធំណាស់"]។ ឯកសារ D105/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខវត្តសម្តេច KH 00790593 ["មានរណ្តៅសាកសពរួមពីរកន្លែងត្រូវបានរកឃើញភ្លាមនៅក្នុងបរិវេណវត្ត បន្ទាប់ពីកងទ័ពវៀតណាមបានរំដោះប្រទេសកម្ពុជានៅឆ្នាំ១៩៧៩"]។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ឯក ជី KH 01485006 ["មានរណ្តៅសាកសពរួមចំនួន ៨ រណ្តៅ នៅខាងក្នុងបរិវេណនោះ [នៃវត្តសម្តេច]"]។

[2161] ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៥ KH 01203883 ["ផ្ទះដែលស្ថិតនៅមុខវត្តនេះ [វត្តសម្តេច [...] ពុំមានអនុញ្ញាតឲ្យអ្នកណាម្នាក់ប្រើប្រាស់ឡើយ"]។ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៣៦ KH 01165930 ["គេ [...] ប្រាប់ថា មិនឲ្យឆ្លងស្ពានទេ"]។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត *ហៅ* ភោគ ឆ.៥៥ KH 01165916 ["បន្ទាប់ពីការជីករណ្តៅត្រូវបានជីកហើយ គឺបរិវេណវត្តគឺបិទទាំងស្រុងមិនអនុញ្ញាតឲ្យមានការចេញចូលឡើយ"]។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.៦៥ KH 01203925 ["គេមិនឲ្យដើរទៅណារហេតរហូតទេ។ គ្រាន់តែសុំច្បាប់ ប្រាប់មេកង គេឲ្យចូលពេទ្យដែលនៅក្នុងវត្ត"]។ *សូមមើលផងដែរ* ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ, ការរៀបរាប់របស់ ស្ងួន ហេង KH 01485008។

[2162] *សូមមើលឧទាហរណ៍* <u>រ៉ែម</u>៖ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១០ KH 01165925។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.១៦ KH 01213253។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ឆ.៦៣-៦៤ KH 01165917។ <u>ខ្មែ</u>៖ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១០, ១៣, ១៦ KH

ក្រោម៖ ប្រធាន កឹក ដែលបានចេញបញ្ជាឲ្យចាប់ខ្លួនមនុស្ស អនុរបស់គាត់ឈ្មោះ សៀ និងសមាជិកឈ្មោះ នុយ និង ជៀ[2163]។ ងួន ដែល "កាន់ខាងភស្តុភារ និងសេដ្ឋកិច្ច [ក្នុងភូមិសម្តេច] [...] បានរាយការណ៍ទៅកាន់លើ [...] នៅកន្លែងស្រុក"[2164]។

604. កម្មាភិបាលភូមិភាគនិរតី តាធ៌ីល, តានឹង និង តាវ៉ាត់ ទទួលខុសត្រូវភូមិសម្តេច[2165]។ សាក្សីម្នាក់ដែលបានរស់នៅជាមួយ តាធ៌ីល បាននិយាយថា "គាត់ជាប្រធានភូមិ" ហើយ "ចូលរួមសម្លាប់ប្រជាជន"[2166]។ គាត់ក៏បានថ្លែងផងដែរថា "តានឹង អនុប្រធានភូមិ" និង "ទទួលបន្ទុកខាងយោធា" និងថា "តាវ៉ាត់ ជាសមាជិកនៃគណៈភូមិ"[2167]។

01165925-26។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ឆោម ប៉ោង ឆ.២ KH 01485015។ <u>ម៉ៅ</u>៖ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៤៨ KH 01165933។

[2163] <u>កឹក</u>៖ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ រ៉ៃត ឆ.៦, ១៥ KH 01213279-82 ["កឹកជាប្រធានសហការណ៍ពួកនិរតី។ [...] កឹក ជាអ្នកបញ្ជាឲ្យចាប់។"]។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.២៤ KH 01203888 ។ ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ន រ៉ុន ឆ.២១ KH 01203950។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ឆោម ប៉ោង ឆ.៤ KH 01485015 ការរៀបរាប់របស់ ចេន ជេត ឆ.៤ KH 01485020។ *សូមមើលផ្ទុយពីនេះ* ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ១៩៩៨៖ ខេត្តបាត់ដំបង KH 00722411 ["តាសែម ប្រធានសហការណ៍"]។ <u>សៀ, នុយ និង ជៀ</u>៖ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ រ៉ៃត ឆ.៦ KH 01213279។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ឆោម ប៉ោង ឆ.៤ KH 01485015។ *សូមមើលផងដែរ* ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.១១, ២៩ KH 01203915, 19។

[2164] ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.១៩, ៤២ KH 01213254, 59។

[2165] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.២១ KH 01165927 ["ឆ៖ តើលោកស្រីបានស្គាល់ឈ្មោះកម្មាភិបាលនិរតីដែលនៅក្តាប់ភូមិសម្តេចដែរឬទេ? [...] ឆ.២១៖ តាធ៌ីល [...] តានឹង និង តាវ៉ាត់។"]។

[2166] D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.២១-២២ KH 01165927 ["តាធ៌ីល ជាអ្នកដែលខ្ញុំនៅជាមួយ [...] គាត់ជាប្រធានភូមិ។ គាត់ [...] បញ្ជូនពីនិរតី"] ឆ.៣, ៣៥ KH 01165922-24, 30 ["ស៖ [...] លោកស្រីបានប្រាប់យើងថា [...] ប្រធានយោធា [តាធ៌ីល] ចូលរួមសម្លាប់ប្រជាជននៅយប់ដែលគេធ្វើការសម្លាប់នោះ [...] ឆ.៣៖ ចាស ត្រឹមត្រូវហើយ [...] ឆ.៣៥៖ [...] តាធ៌ីល និងអ្នកដទៃទៀតបានប្រាប់ខ្ញុំថា [...] គេនឹងធ្វើការកម្ទេចឆ្នាំងនៅពេលល្ងាច។"] *បញ្ជាក់ឡើងវិញ* D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ រុន ឡាយ ឆ.១, ៣ KH 01485013-14។ សូមមើល *ផ្ទុយពីនេះ* D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.២៤ KH 01165928 [តានឹង "ទទួលបន្ទុកខាងយោធា។"]។

[2167] <u>ន្ធីង</u>៖ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.២៤ KH 01165928។ <u>រ៉ាត់</u>៖ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.២៥ KH 01165928។ មុនពេលមកដល់នៃពួកកម្មាភិបាលនិរតីក្នុងភូមិវត្តសម្តេច សាក្សីខ្លះយល់ថា តាវ៉ាត់ មានមុខតំណែងសិទ្ធិអំណាចផ្សេងទៀតក្រៅពីជាសមាជិកគណៈភូមិ។ *សូមមើល* ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.២៤ KH 01203888។ ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ន រ៉ុន ឆ.១១ KH 01203948។

605. កម្មាភិបាលភូមិភាគនិរតី ក៏ ជាប្រធានសន្តិសុខគុកនេះ[2168]។ មានកម្មាភិបាលផ្សេងៗទៀតមានវត្តមាននៅមន្ទីរសន្តិសុខនេះផងដែរ[2169]។

iv. ឧក្រិដ្ឋកម្ម

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង</u>

606. ភ្លាមៗ ក្រោយពេលដែលកម្មាភិបាលភូមិភាគនិរតីបានមកដល់ភូមិសម្តេច មានជនរងគ្រោះជាច្រើនត្រូវបានចាប់ខ្លួន និងឃុំខ្លួននៅវត្តសម្តេច[2170]។ ពួកគេបានចាប់កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសារ ព្រមទាំងក្រុម"ខ្មាំង"ដទៃទៀតដូចជាអតីតសមាជិករបប លន់ នល់ ពួកសក្តិភូមិ បញ្ញវន្ត

ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.១៧, ២២, ៣១ KH 00780645-00780646 ។ *សូមមើលផងដែរ* ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ចេន ជេត ឆ.៤ KH 01485020។

[2168] ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.១៩ KH 00780645 [សាក្សីបានរាយឈ្មោះប្រជាជនភូមិភាគនិរតី ៖ "ស៖ លោកក៏និយាយពីប្រធានមន្ទីរសន្តិសុខវត្តសម្តេច ឈ្មោះ ក៏ តើមែនទេ? ឆ.១៩៖ បាទ"]។

[2169] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១៥, ៣៦ KH 01165926, 30 ["មានប្រហែលជា៣ ឬ៤គ្រួសារ ប៉ុន្តែក៏មានយោធាពួកនិរតីប្រហែលជា១០ ទៅ២០នាក់។"]។ ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ិន រ៉ើន ឆ.៤ KH 01203946។ ឯកសារ D219/688 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ឈាន ទុំ ឆ.៤ KH 01226367-68 ["អ្នកដែលមើលការខុសត្រូវមន្ទីរពេទ្យនៅវត្តសម្តេច ក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី ឈ្មោះ ពេទ្យ មាន។"]។ ចំពោះពេជ្ឌឃាត *សូមមើល* ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឌមណ្ឌលឯកសារកម្ពុជា ១៩៩៨៖ ខេត្តបាត់ដំបង KH 00722410-11។ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ រ៉ៃត ឆ.៩ KH 01213280-81។

[2170] ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាភ ឆ.២៧ KH 01213256 ឆ.៣១ KH 01213256 ["រាប់មិនត្រូវទេ គឺប្រហែលជា៤០០ ទៅ៥០០នាក់។ ដោយសារតែពួកវាជញ្ជូន៣ថ្ងៃឯណោះ។ ហើយពួកវា សម្លាប់១ឃប់ ១ថ្ងៃទើបអស់"]។ ឯកសារ D219/566 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភាគ ឆ.១-២ KH 01165938 ["នៅពេលនោះ កម្មាភិបាលនិរតីគឺគ្រប់គ្រងពេញតំបន់ទីនេះទៅហើយ ហើយពួកគេបានចាប់មនុស្សចំនួន៣៥០នាក់ ដែលជាមនុស្សធម្មតា។ [...] គឺពួកគេនាំអ្នកទាំងនោះចូលទៅក្នុងព្រះវិហារ"]។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីន ណុន ឆ.៥-៦ KH 01203914។ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១៩ KH 01165927 ["ខ្ញុំបានដឹងតែ២ដងទេ ពេលដែលការចាប់ខ្លួនបានកើតឡើង។ លើកទី១ កើតឡើងនៅពេលដែលឪពុករបស់ខ្ញុំត្រូវបានចាប់ខ្លួន គឺមានមនុស្សប្រហែលជាចំនួន១០៥នាក់។ ហើយលើកទី២គឺមានប្រហែលជាមនុស្ស១០០នាក់ ត្រូវបានចាប់ខ្លួន"] ឆ.៣២ KH 01165929។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការៀបរាប់របស់ ហ៊ីន ណុន ឆ.១ KH 01485004។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភាគ ឆ.៤១-៤២, ៥៣ KH 01165914, 16។ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ រ៉ៃត ឆ.៩ KH 01213280-81។

និង "ប្រជាជនថ្មី" ពីភូមិ និងពីសហការណ៍ផ្សេងៗ នៅក្នុងតំបន់នោះ[2171]។ ជាញឹកញាប់ ជនរងគ្រោះត្រូវបានកោះហៅឲ្យទៅប្រជុំ ឬ ឈ្លួងឲ្យទៅកាន់កន្លែងផ្សេងទៀតហើយបន្ទាប់មកក៏ចាប់ខ្លួនតែម្តង[2172]។

ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

607. អ្នកទោសរាប់ពាន់នាក់ត្រូវបានសម្លាប់ចោលនៅមន្ទីរសន្តិសុខវត្តសម្តេច ដោយមិនមានដំណើរការតាមយុត្តិធម៌ទេ[2173]។ សាក្សី ហេង ផាត បានរំឭកឡើងវិញថា៖ "កាលណាតែគេនាំមនុស្សចូលហើយព្រះវិហារពេញ គឺគេបញ្ចេញមនុស្សយកទៅសម្លាប់ហើយ"[2174]។ មនុស្សត្រូវបាន "សម្លាប់

[2171] <u>កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ</u>៖ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ឆ.៧-៩ KH 01165910។ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១៣ KH 01165925។ *សូមមើលផងដែរ* ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ រ៉ៃត ឆ.២៥ KH 01213284។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ រុន ឡាយ ឆ.៣ KH 01485013-14, ការរៀបរាប់របស់ ឆោម ប៉ោង ឆ.២ KH 01485015 ["ពួកគេបាននិយាយថា ពួកអង្គការបានចាត់តាំងពួកគេឲ្យគ្រប់គ្រងទៅលើតំបន់នោះ។ បន្ទាប់មក ពួកគេបានចាប់ផ្តើមចាប់ខ្លួនពួកកម្មាភិបាលភូមិភាគពាយ័ព្យទាំងអស់នៅទីនេះ"]។ <u>អតីតសមាជិកនៃរបប លន់ នល់</u>៖ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១៧, ៣០ KH 01165926-27, 30-31។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ រុន ម៉ៅ ឆ.១-២ KH 01485011-12។ <u>ពួកសក្តិភូមិ បញ្ញវន្ត និង "ប្រជាជនថ្មី"</u>៖ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៣, ១៧ KH 01165924, 26-27។ ឯកសារ D122/2.1.40 កាសែតភ្នំពេញប៉ុស្ត៍ *ជនសង្ស័យខក្រិត្តកម្មសង្គ្រាមដែលទន់ខ្សោយ "មិនខ្លាច" ការប្រឈមមុខជាមួយនឹងតុលាការទេ* EN 00895645។ <u>ក្រុម "ខ្ជាំង" ដទៃទៀត</u>៖ ឯកសារ D219/566 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ឆ.១-២ KH 01165938។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.៣៧ KH 01213258។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ រុន ម៉ៅ ឆ.២ KH 01485012។

[2172] ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ន រ៉ើន ឆ.៤ KH 01203946។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ រុន ម៉ៅ ឆ.២ KH 01485011-12។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង KH 00722408-09។

[2173] ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង KH 00722411 ["មានការប៉ាន់ស្មានថា ជនរងគ្រោះមានចំនួនពី ៥.០០០ ទៅ ៦.០០០ នាក់"]។ ឯកសារ D6.1.524 របាយការណ៍បញ្ជុះអដ្ឋិធាតុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា KH 01353579 ["ជនរងគ្រោះ ៥០០០-៦០០០ នាក់"]។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៥ KH 01203883។ ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ន រ៉ើន ឆ.៣-៤, ២៧ KH 01203945-46, 01203951។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.៦ KH 01203914។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.២៧ KH 01213256។ *សូមមើលផងដែរ* ឯកសារ D219/566 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.១១ KH 01165939។

[2174] ឯកសារ D219/566 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.៨ KH 01165939។

ដូចជាកង្កែប”[2175]។ ពួកគេ “ត្រូវបានគេនាំចូលមកទាំងខ្សែ១ជារៀងរាល់ថ្ងៃ [...] ទៅសម្លាប់”[2176]។ ការសម្លាប់មនុស្ស “កើតមានទាំងថ្ងៃទាំងយប់”[2177]។ សាក្សីនានាបានរំឭកឡើងវិញថាបានឃើញមនុស្សរាប់រយនាក់ត្រូវបានសម្លាប់នៅពេលនោះ[2178]។ ទោះបីជាកម្រមានរឿងរ៉ាវជោគជ័យក្នុងការគេចចេញពីមន្ទីរសន្តិសុខវត្តសម្ពេច[2179] ក៏ការអនុវត្តនោះគឺថា “មិនមានអ្នកណាម្នាក់ត្រូវបានគេដោះលែងចេញពីវត្តនោះទេ។ កាលណាគេនាំអ្នកណាម្នាក់យកទៅក្នុងវត្តនោះ គឺជាចុងបញ្ចប់នៃជីវិតរបស់ពួកគេហើយ”[2180]។ សាក្សីនានាដែលបានទៅកាន់វត្តសម្ពេចក្រោយពេលការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យបានឃើញឈាមនៅលើជញ្ជាំងផ្នែកខាងក្នុងនៃព្រះវិហារ និងខោអាវប្រឡាក់ទៅដោយឈាមនៅលើឥដ្ឋ[2181]។ សាក្សីមួយរូបបានសង្កេតឃើញការសរសេរនៅលើជញ្ជាំងដោយអ្នករងគ្រោះម្នាក់ដែលគេបានស្គាល់[2182]។ ឆ្លាម រ៉ាន់ *ហ៊ីរ* បានកោសសរសេរ

[2175] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.១៣ KH 01165911។

[2176] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.៥២-៥៣ KH 01165916។ *សូមមើលផងដែរ* ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ឯក ជី ឆ.៣ KH 01485005-06។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង KH 00722410។

[2177] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.២១ KH 01165912។

[2178] ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.៦ KH 01213251 ឆ.៣៤ KH 01213257 [“ចំណែកការសម្លាប់មនុស្ស ៤០០-៥០០នាក់នៅវត្តសម្ពេចគឺខ្ញុំបានឃើញ [...] ប្រហែលជានៅខែតុលា ឆ្នាំ១៩៧៧”]។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.១៥ KH 01165911 [“មានមនុស្ស [ភូមិភាគពាយ័ព្យ] ប្រហែលជា៣៥០នាក់ដែលត្រូវបានចាប់ខ្លួន និងសម្លាប់ចោល”]។ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ រ៉ៀត ឆ.៨ KH 01213280 [“ខ្ញុំបានឮកម្មាភិបាលនិរតីនិយាយគ្នាថាមានជនរងគ្រោះប្រហែល១០០នាក់ ត្រូវបានសម្លាប់[នៅវត្តសម្ពេច] ក្នុងនោះមានកុមារផងដែរ”]។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ចេន ជេត ឆ.៣ KH 01485020 [“បន្ទាប់ពីការមកដល់នៃពួកវៀតណាម។ [...] មានសាកសពចំនួនប្រហែលជា ៣០០ ទៅ ៤០០ នាក់”]។ ឯកសារ D219/688 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ហេង លាប ឆ.៣-៥ KH 01226365។

[2179] ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ហ៊ុន ណុន ឆ.១ KH 01485004។

[2180] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.៤៣ KH 01165915។

[2181] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៦០ KH 01165934។ *សូមមើលផងដែរ* ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៥៥ KH 00780649។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.២៨ KH 00203889។

[2182] ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៤៥-៤៧, ៥៣, ៥៥ KH 00780648, 00780649។

ពាក្យចុងក្រោយទាំងនេះនៅលើថ្នាំណាបទុកឲ្យប្រពន្ធគាត់ថា៖ "ប្តីដែលគេយកមកទីនេះគឺគេយកមកសម្លាប់ហើយ"[2183]។

608. ពួកកម្មាភិបាលភូមិភាគនិរតីបានចាប់ផ្តើមសម្លាប់ជនរងគ្រោះពីភូមិសម្ភេច និងតំបន់ជុំវិញវត្តសម្ភេច យ៉ាងហោចណាស់នៅចុងឆ្នាំ១៩៧៧ ហើយពួកគេ "សម្លាប់ជាបណ្តើរៗរហូតដល់ឆ្នាំ១៩៧៩"[2184]។ ជនរងគ្រោះនៃយុទ្ធនាការសម្លាប់ រួមមាន កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ[2185] "ពួកវៀតណាម ចាម និង ខ្មែរក្រោម"[2186] "ពួក ១៧ មេសា" ឬ "ប្រជាជន

[2183] ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៤៨, ៥០ KH 00780648។ *សូមមើលផងដែរ* ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.២៨ KH 01203889។

[2184] ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.២៣ KH 01213255។ *សូមមើលផងដែរ* ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភាគ ឆ.៣ KH 01165910។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង KH 00722410 ["លោក ហ្ស៊ីម បានអះអាងថា ការសម្លាប់កើតមានឡើងក្នុងចន្លោះឆ្នាំ១៩៧៧-១៩៧៨ ប៉ុន្តែការសម្លាប់ដ៏ច្រើន កើតមានឡើងនៅចុងឆ្នាំ១៩៧៨"]។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.១៨ KH 01203917។ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ រ៉ៃត ឆ.៣១ KH 01213285។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.២៦, ៤១ KH 01213255, 58-59។

[2185] ឯកសារ D219/566 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភាគ ឆ.១១ KH 01165939 ["កម្មាភិបាល [ភូមិភាគ] ពាយ័ព្យត្រូវបានបាត់ខ្លួនទាំងអស់ ខ្ញុំអាចប៉ាន់ស្មានបានថាប្រហែលជាចំនួនរាប់ពាន់នាក់"]។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.៣១-៣២ KH 01203919។ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១០, ១៣, ៤៨ KH 01165925, 32។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.៨, ១៥, ២៣ KH 01213252, 01213253, 01213255 ["ពេលវា [ពួកកម្មាភិបាលភូមិភាគនិរតី] ចូលមកដល់បាន២ខែវាបានបោសម្អាតពួកពាយ័ព្យទាំងអស់ឲ្យតែជាកម្មាភិបាល"]។ ឯកសារ D219/719 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀង មាន ឆ.១៣ KH 01213268។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភាគ ឆ.៧-១០ KH 01165910។ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ រ៉ៃត ឆ.៤ KH 01213279។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការៀបរាប់របស់ ឆោម ប៉ោង ឆ.២ KH 01485015។

[2186] ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.៥៤-៦០ KH 01203923-24។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការៀបរាប់របស់ រុន ឡាយ ឆ.២ KH 01485013។

ថ្មី"[2187] "ជាទាហាន ឬជាគ្រូបង្រៀន ឬជាពេទ្យ ឲ្យតែមានធ្វើការពីសង្គម"[2188] និង "ពួកមូលធន អ្នករៀនសូត្រ ឬបញ្ញវន្ត ហើយគេបានចាត់ទុកពួកទាំងនេះជាខ្មាំង"[2189]។ ពួកក្មេងៗក៏ត្រូវបានសម្លាប់ចោលដែរ[2190]។

609. មានមនុស្សជាច្រើនបានឮពីអ្នកផ្សេងៗទៀតថា ពួកដែលត្រូវបានយកទៅវត្តសម្តេចត្រូវបានសម្លាប់ចោលភ្លាមតែម្តង[2191]។ សាក្សីម្នាក់ត្រូវបានប្រាប់ដោយដោយពួកពេទ្យថា តាមបង្ហួចមន្ទីរពេទ្យអ្នកទាំងនោះអាចឃើញ "គេសម្លាប់មនុស្សនៅខាងកើតកុដិណោក"[2192]។ ហេង ផាត និង ហេង លាភ បានប្រាប់អ្នកស៊ើបអង្កេតក.ស.ច.ស ថាពួកគាត់បានឃើញការសម្លាប់នោះផ្ទាល់[2193]។ "ពេលខ្លះនៅពេលដែលខ្ញុំឈរមើល ខ្ញុំបានឃើញការវ៉ៃសម្លាប់មនុស្ស និងបានឮសម្រែកស្រែកយំ

[2187] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១៧ KH 01165926-27 ["ពេលគេសម្លាប់ជនរងគ្រោះ ពួកគេបានយកខោអាវជនរងគ្រោះទាំងនោះត្រឡប់មកភូមិវិញ។ ពេលនោះគេបានឲ្យពួកនិរតីបានឲ្យកម្មាភិបាលពាយ័ព្យ ដែលជាប្រធានកងជួយចង្អុលប្រាប់មើលថាតើនរណា [...] ជាខ្មាំង។ [...] ក្រុមមួយបានរួមរស់ជាមួយខ្ញែរក្រហម ហើយក្រុមមួយទៀតរស់នៅទីក្រុង ហើយពេលអ្នកនៅទីក្រុងចូលមករស់នៅក្នុងភូមិគេបានធ្វើការរាយការណ៍"]។ *សូមមើលផងដែរ* ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ចាន់ ធម៌ ឆ.៥ KH 01485009។

[2188] ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.៣៧ KH 01213258។ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១៦-១៧ KH 01165926-27។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ រុន ម៉ៅ KH 01485011-12។

[2189] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.១៧ KH 01165926-27។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.៣២ KH 01213257។

[2190] ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.៧ KH 01213252។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ចេន ជេត ឆ.៥ KH 01485020។

[2191] ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.៥ KH 01203914។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ឯក ជី ឆ.៤ KH 01485005-06 ការរៀបរាប់របស់ ឆោម ប៉ោង ឆ.១ KH 01485014-15។

[2192] ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.១៧ KH 01203917។

[2193] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.១២ KH 01165911 ["ផ្ទះខ្ញុំនៅទល់មុខវត្ត[វត្តសម្តេច] ដូច្នេះខ្ញុំបានឈរមើលគេវ៉ៃសម្លាប់មនុស្ស"]។ ឯកសារ D219/566 ហេង ផាត ហៅ ភោគ ឆ.៥-៦ KH 01165938-39 ។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.៧, ៣៤ KH 01213252, 57 ["ព្រោះកាលនោះ ខ្ញុំនៅទីនោះឯង ហើយមនុស្សត្រូវបានគេចងជាខ្សែៗនាំយកទៅសម្លាប់។ [...] ចំណែកការសម្លាប់មនុស្ស ៤០០-៥០០ នាក់នៅវត្តសម្តេច គឺខ្ញុំបានឃើញ"] ឆ.៨ KH 01213252។

ទ្រហឹងអឹងកងពេញវត្ត"[2194]។ រាងកាយអ្នកទោសត្រូវបានអូសទម្លាក់ក្នុងរណ្តៅ ហើយពួកដែលមិនទាន់ស្លាប់នៅឡើយ "ត្រូវបានគេកប់ទាំងរស់"[2195]។ រាងកាយទាំងឡាយក៏ត្រូវបានទម្លាក់នៅក្នុងស្រះមួយក្បែរនោះដែល "ពេញស្រះ"[2196]។ បន្ទាប់ពីសម្លាប់រួចហើយ ពួកកម្មាភិបាលបានយកខោអាវរបស់ជនរងគ្រោះនោះត្រឡប់វិញ[2197]។

610. ខណៈដែលការសម្លាប់កំពុងប្រព្រឹត្តទៅ កម្មាភិបាលនិរតីបានកម្រិតការចូលទៅក្នុងកន្លែងនោះដោយការបង្កើតកន្លែងឆែកឆេរនៅតាមផ្លូវ[2198]។ សាក្សីនានាបានឮកម្មាភិបាលនិរតីពិភាក្សាពីការសម្លាប់។ សាក្សីម្នាក់បានរំឭកឡើងវិញ "ថា តាធ៌ីល និងអ្នកដទៃទៀតបានប្រាប់ខ្ញុំថា ខ្ញុំត្រូវដាំបាយឲ្យពួកគេហូបឲ្យបានពីព្រឹកដើម្បីគេនឹងធ្វើការកម្ទេចខ្ទាំងនៅពេលល្ងាច"[2199]។ ម្នាក់ផ្សេងទៀតបានចូលទៅក្នុងវត្តសម្តេច ហើយ "បានឮកម្មាភិបាលនិរតីនិយាយគ្នាថាមានជនរងគ្រោះប្រហែល ១០០នាក់ ត្រូវបានសម្លាប់ […]"[2200]។

611. ខណៈដែលរាងកាយខ្លះត្រូវបានបញ្ចុះ (ទំនងជានៅក្រោយពេលបូជារួចហើយ) នៅក្នុងវត្តសម្តេចនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ គឺពុំមានរណ្តៅកប់សាកសពរួមទេ នៅមុនសម័យខ្មែរក្រហម[2201]។ ភ្លាមៗ បន្ទាប់ពីកម្មាភិបាលនិរតីផ្តាស់ប្តូរវត្តសម្តេចឲ្យទៅជាមន្ទីរសន្តិសុខ ពួកគេបានបង្គាប់ឲ្យអ្នកស្រុកជីករណ្តៅចំនួនបីនៅក្នុងទីធ្លានោះ[2202]។ "បន្ទាប់ពីជីករណ្តៅបានហើយ គឺគេចាប់ផ្តើមចាប់ខ្លួន

[2194] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.១៩ KH 01165911។ *សូមមើលផងដែរ* ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ រ៉ៃត ឆ.៨ KH 01213280។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង KH 00722409-10។

[2195] ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង ណាប ឆ.៨ KH 01213252។ *សូមមើលផងដែរ* ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.៤២ KH 01165914។

[2196] ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.២៤ KH 01203918។

[2197] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រ៉ុន ឡាយ ឆ.៥៤ KH 01165933។ *សូមមើលផងដែរ* ឯកសារ D219/564 ហេង ផាត ហៅ ភោគ ឆ.៥២ KH 01165916។

[2198] ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ រ៉ៃត ឆ.៨ KH 01213280 ["ក្រោយពេលគេសម្លាប់មនុស្សរួច គេនឹងរុះរើប៉ុស្តិ៍ត្រួតពិនិត្យចេញ"]។

[2199] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រ៉ុន ឡាយ ឆ.៣៥ KH 01165930។

[2200] ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ រ៉ៃត ឆ.៨ KH 01213280។

[2201] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.៣២ KH 01165913។

[2202] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.២៤-២៥ KH 01165912។

មនុស្សនៅពេលយប់នោះតែម្តង"[2203]។ រួមទាំងបីរណ្តៅនេះផង មានរណ្តៅសាកសពរួមរហូតដល់ទៅប្រាំបីរណ្តៅ ដែលមានទំហំផ្សេងៗគ្នា នៅក្នុងនិងនៅជុំវិញទីធ្លាវត្តសម្តេច ខ្ពះធំរហូតដល់ទៅ ១០ x ១០ ម៉ែត្រ[2204]។

612. ផ្នឹងត្រូវបានកាយចេញពីរណ្តៅនានានៅក្នុងវត្តសម្តេច បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ[2205]។ សាក្សីម្នាក់ដែលបានចូលរួមនៅក្នុងកំណាយសាកសពមនុស្សចេញពីរណ្តៅ បានប៉ាន់ប្រមាណថា "មានសាកសពប្រហែលពីរពាន់ ទៅបីពាន់នាក់ នៅក្នុងរណ្តៅសាកសពដ៏ធំនោះ" និង "សាកសពជាង ៥០" នៅក្នុងរណ្តៅនីមួយៗនៃរណ្តៅផ្សេងទាំងបី[2206]។ រណ្តៅផ្សេងមួយចំនួននៅ

[2203] ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត ហៅ ភោគ ឆ.២៨ KH 01165913។

[2204] ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីន ណុន ឆ.៦៣ KH 01203924-25 ["មិនមែនមួយរណ្តៅទេ បីរណ្តៅ"]។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត *ហៅ* ភោគ ឆ.២៤-២៥ KH 01165912 ["គេចាត់តាំងឲ្យខ្ញុំដឹកនណ្តៅចំនួន៣"]។ ឯកសារ D219/720 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ រ៉ៃត ឆ.៣៤ KH 01213285 ឆ.៣៦ KH 01213286 ["គឺ១ប្រហែលជា៥ម៉ែត្របួនជ្រុង"]។ ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៦២ KH 01165934 ["ខ្ញុំបានឃើញមានរណ្តៅធំៗចំនួន២។ ដែល រណ្តៅនីមួយៗមានទំហំប្រហែលទទឹង៦ម៉ែត្រ និងបណ្តោយប្រហែល១០ម៉ែត្រ"]។ ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៣៦-៣៨ KH 00780647 ឆ.៤២ KH 00780648។ ឯកសារ D219/718 កំណត់ហេតុស្តាប់ចម្លើយ ហេង លាប ឆ.២៧ KH 01213256 ["រណ្តៅនោះមានបណ្តោយប្រហែលជា៥ម៉ែត្រ ទទឹងប្រហែល ៣ម៉ែត្រ"]។ ឯកសារ D105/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខវត្តសម្តេច KH 00790593 ["មានរណ្តៅសាកសពរួមពីរកន្លែងត្រូវបានរកឃើញភ្លាមនៅក្នុងបរិវេណវត្ត បន្ទាប់ពីកងទ័ពវៀតណាមបានរំដោះប្រទេសកម្ពុជានៅឆ្នាំ១៩៧៩។ រណ្តៅសាកសពមួយ មានប្រវែង ១០ x ១០ ម៉ែត្រ [...] និង ៥ x ៥ ម៉ែត្រ [...]។ រណ្តៅសាកសពទាំងពីរមានជម្រៅតិចជាងពីរម៉ែត្រ"]។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង KH 00722385-86 ["វត្តសម្តេច [...] ឫជនីយដ្ឋានរណ្តៅសាកសពរួម ៦"] KH 00722410-11 ["រណ្តៅនីមួយៗ មានបណ្តោយប្រហែល ៤ ឬ ៥ម៉ែត្រ និងទទឹង ២ម៉ែត្រ ជម្រៅ ៣ម៉ែត្រ"]។ ឯកសារ D219/681 កំណត់ ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៥-៦ KH 01203883-84 ["មានរណ្តៅសាកសពរួមចំនួនបួនកន្លែង។ រណ្តៅសាកសពដែលធំជាងគេបំផុតមានទំហំ ៨ម៉ែត្រ គុណនឹង១០ម៉ែត្រ [...]។ មានសាកសពប្រហែលពីរពាន់ ទៅបីពាន់នាក់ នៅក្នុងរណ្តៅសាកសពដ៏ធំនោះ។ រណ្តៅសាកសពដទៃទៀតដែលតូចជាងនេះ មានទំហំ៥ម៉ែត្របួនជ្រុង និងមានជម្រៅមួយម៉ែត្រកន្លះ ហើយរណ្តៅនីមួយមានសាកសពជាង៥០។ [...] ត្រង់ជម្រៅរណ្តៅសាកសពខាងលើ គឺជម្រៅពីរម៉ែត្រ"] *ប៉ុន្តែសូមមើល* ឆ.២៧ KH 01203889 ["ទេ ត្រង់ហ្នឹងមិនដឹងដែរ។ មិនដឹងថា រណ្តៅហ្នឹងកើតពីពាយ័ព្យមក ឬពីនិរតីទេ មិនដឹងដែរ"]។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ, ការរៀបរាប់របស់ ឯក ជី ឆ.៤ KH 01485006 ["មានរណ្តៅសាកសពរួមចំនួន ៨ រណ្តៅ នៅខាងក្នុងបរិវេណនោះ [នៃវត្តសម្តេច]"]។ ឯកសារ D219/688 កំណត់ហេតុនៃកិច្ចស៊ើបសួរ, ការរៀបរាប់របស់ ស្ងួន រ៉ីង ឆ.៥-៦ KH 01226364។

[2205] D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត *ហៅ* ភោគ ឆ.៤៤ KH 01165915។

[2206] ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៥ KH 01203883។

ក្នុង និងនៅជុំវិញវត្ត ក៏ត្រូវបានជីកកកាយផងដែរ បន្ទាប់ពីរបបកម្ពុជាប្រជាធិបតេយ្យ[2207]។ រណ្តៅនានា និងស្រះមួយនៅក្បែរនោះដែលត្រូវបានប្រើជាកន្លែងកប់សព គឺពោរពេញទៅដោយសាកសពមនុស្ស[2208]។ ចេតិយមួយដែលពោរពេញទៅដោយផ្ទឹង និងលលាដ៍ក្បាលរបស់អ្នកដែលត្រូវបានគាស់កកាយ ត្រូវបានសាងសង់នៅក្បែរស្រះនោះ[2209]។

ការធ្វើទុក្ខបុកម្នេញ

613. កម្មាភិបាលភូមិភាគនិរតីបានប្រព្រឹត្តឧក្រិដ្ឋកម្មជាច្រើនដូចបានរៀបរាប់នៅខាងលើស្រាប់ ដោយមានចេតនាផ្តោតទៅលើក្រុមគោលដៅជាក់លាក់ គឺ ពួកវៀតណាម ខ្មែរក្រោម កម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ ពួកសមាជិកអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និង "ប្រជាជនថ្មី"។ ក្រុមទាំងនេះត្រូវផ្តោតគោលដៅជាក់លាក់ ដោយសារតែសមាជិកភាពនៃក្រុមនយោបាយមួយយ៉ាងជាក់ស្តែង ឬត្រូវបានមើលឃើញ។ ពួកកម្មាភិបាលនិរតីបានរៀបចំបញ្ជីឈ្មោះ ហើយពួកគេបានប្រើប្រាស់កម្មាភិបាលភូមិភាគពាយ័ព្យឲ្យជួយដល់ពួកគេ ក្នុងការកំណត់អត្តសញ្ញាណបុគ្គលដែលជាប់នៅក្នុងក្រុមដែលគេបានមើលឃើញថាជាខ្ទាំង[2210]។ សាក្សីម្នាក់បានឮពី

[2207] ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ន រ៉ើន ឆ.៤០ KH 01203953។ ឯកសារ D219/564 កំណត់ហេតុស្តាប់ចម្លើយ ហេង ផាត *ហៅ* ភោគ ឆ.៤៤-៤៧ KH 01165915។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង KH 00722410-11។ *សូមមើលផងដែរ* ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៣៨, ៤៣ KH 00780647-48។

[2208] ឯកសារ D105/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខវត្តសម្តេច KH 00790593 ["រណ្តៅទាំងនេះពោរពេញទៅដោយលលាដ៍ក្បាល ផ្ទឹង សំណល់សម្លៀកបំពាក់ និងសាកសព"]។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៦ KH 01203882។ ឯកសារ D105/2 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៣៨ KH 00780647។ ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ិន ណុន ឆ.១៧, ២៤ KH 01203917, 01203918។ ឯកសារ D122/2.1.40 កាសែតភ្នំពេញប៉ុស្ត៍ *ជនសង្ស័យឧក្រិដ្ឋកម្មសង្គ្រាមទន់ខ្សោយ 'មិនខ្លាច' ការប្រឈមមុខជាមួយនឹងតុលាការទេ*។

[2209] ឯកសារ D105/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខវត្តសម្តេច KH 00790593។ ឯកសារ D122/2.1.40 កាសែតភ្នំពេញប៉ុស្ត៍ *ជនសង្ស័យឧក្រិដ្ឋកម្មសង្គ្រាមទន់ខ្សោយ 'មិនខ្លាច' ការប្រឈមមុខជាមួយនឹងតុលាការទេ*។ កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.៥៩-៦០ KH 00780649។

[2210] ឯកសារ D219/685 កំណត់ហេតុស្តាប់ចម្លើយ ស៊ន រ៉ើន ឆ.២០ KH 01203946 ["ប្រពន្ធប្រធានសហករណ៍[ភូមិភាគ]និរតី[ក៏ក] ជួយជីវិតខ្ញុំ [...]។ ហើយគាត់ក៏បានទៅមើលបញ្ជីលុបឈ្មោះខ្ញុំចោល"]។

ពួកកម្មាភិបាលភូមិភាគនិរតីថាមាន "ខ្ទាំងនៅក្នុងវត្ត" នៅមន្ទីរសន្តិសុខវត្តសម្តេច ហើយថា "គេនឹងធ្វើការកម្ទេចខ្ទាំងនៅពេលល្ងាច"[2211]។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

614. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខវត្តព្រះធាតុ[2212]ៃ អំពើប្រល័យពូជសាសន៍ទៅលើក្រុមជាតិសាសន៍វៀតណាមនៅកម្ពុជា(ជាពិសេសខ្មែរក្រោម)[2213] ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[2214] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ អតីតសមាជិករបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ "ប្រជាជនថ្មី" ខ្មែរក្រោម និងជនជាតិវៀតណាម។

[2211] ឯកសារ D219/565 កំណត់ហេតុស្តាប់ចម្លើយ រុន ឡាយ ឆ.៣៥-៣៦ KH 01165930។ *សូមមើលផងដែរ* ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស៊ើបសួរ ការរៀបរាប់របស់ ឯក ជី ឆ.៤ KH 01485006។

[2212] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងមន្ទីរសន្តិសុខវត្តសម្តេច គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ទាំងនេះគឺ អំពើប្រល័យពូជសាសន៍ប្រឆាំងនឹងវៀតណាម និងខ្មែរក្រោម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិស្តីពីការដាក់ក្នុងមន្ទីរឃុំឃាំង និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងវៀតណាម ខ្មែរក្រោម សមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ ហើយនិង ប្រជាជនថ្មី។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះដោយ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៩ (រួមទាំង កំណត់សម្គាល់ជើងទំព័រលេខ ២២៣), ៦៧, ១១៨.ង។ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពីហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៨។

[2213] *សូមមើល* V.គ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម

[2214] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលចំពោះឧក្រិដ្ឋកម្មសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភស្តុតាងសម្រាប់តែមន្ទីរសន្តិសុខវត្តសម្តេចតែឯងប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលតម្រូវដើម្បីបញ្ជាក់ពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីកន្លែងសម្លាប់ទាំងអស់ និងទីតាំងការងារដោយបង្ខំ រួមទាំងមន្ទីរសន្តិសុខវត្តសម្តេចផងនោះ ត្រូវលើកយកមកពិចារណាបញ្ចូលគ្នា។ ទីតាំងទាំងអស់គឺជាផ្នែកនៃប្រព័ន្ធរៀបចំមួយ ដែលបានអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្ទាំង និងការសម្លាប់នៅតាមទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងនេះ ត្រូវបានជួយសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចគ្នារបស់ យ៉ីម ទិត្យ។

៥. តំបន់ ២

ក. មន្ទីរសន្តិសុខភូមិវាល

i. សេចក្តីផ្តើម

615. មន្ទីរសន្តិសុខភូមិវាល (“ភូមិវាល”) ក្នុងស្រុកបាកានត្រូវបានប្រើប្រាស់សម្រាប់ដាក់ជនស៊ីវិលក្នុងមន្ទីរឃុំឃាំងក្រៅប្រព័ន្ធតុលាការ ដែលត្រូវបានសង្ស័យថាជាខ្មាំងនៃរបបកម្ពុជាប្រជាធិបតេយ្យ រួមមាន ខ្មែរក្រោម និងប្រជាជនជម្លៀសមកពីភូមិភាគបូព៌ា។ អ្នកទោសត្រូវបានឃុំឃាំងនៅក្នុងលក្ខខណ្ឌដ៏គួរឲ្យខ្ពាច។ អ្នកយាមវាយធ្វើបាប រុំ ក និងក្បាលជាមួយថង់ប្លាស្ទិកហើយចាក់ទឹកចូលដើម្បីឲ្យថប់ដង្ហើម និង/ឬ ឆក់ខ្សែភ្លើងអ្នកទោសនៅអំឡុងពេលសួរចម្លើយ ហើយជាយថាហេតុបានសម្លាប់ខ្លះ តែមិនទាំងអស់គ្នាទេ។ កម្មាភិបាលនិរតី និងកម្មាភិបាលបស្ចិមបានប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះនៅក្នុងលំអាននៃសហឧក្រិដ្ឋកម្មរួមដែល **យឹម ទិត្យ** ជាសមាជិកឈានមុខម្នាក់។

616. ស.ច.ស.អ បានចោទប្រកាន់ **យឹម ទិត្យ** ពីឧក្រិដ្ឋកម្មនានាដូចខាងក្រោម ទាក់ទងនឹងមន្ទីរសន្តិសុខភូមិវាល៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនិងពូជសាសន៍ប្រឆាំងនឹងពួកខ្មែរក្រោម អំពើអមនុស្សធម៌ផ្សេងៗទៀត (ការឃុំខ្លួនក្នុងលក្ខខណ្ឌអមនុស្សធម៌) និងអំពើមនុស្សឃាតគិតទុកជាមុន នៅក្រោមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[2215]។

[2215] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426546, 52, 60។

ii. ប្រតិបត្តិការ និងទីតាំង

617. ភូមិវាល ក៏ត្រូវបានគេស្គាល់ផងដែរថាជា គុកភូមិវាល[2216] ត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខមួយ តាំងពីដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ រហូតដល់ពួកវៀតណាមបានមកដល់នៅឆ្នាំ១៩៧៩[2217]។ វាស្ថិតនៅក្នុងភូមិរហាលទិល ឃុំតាណោ ស្រុកបាកាន ខេត្តពោធិ៍សាត់ នៅក្នុងតំបន់ ២ ភូមិភាគពាយ័ព្យ[2218]។

618. មន្ទីរសន្តិសុខនេះស្ថិតនៅលើដីទំហំ ពាក់កណ្តាលមួយកន្លែង ដែលហ៊ុំព័ទ្ធទៅដោយរបងលួសបន្លា[2219]។ ទីព្រៃដែលការសម្លាប់ត្រូវបានប្រព្រឹត្តឡើង បានធ្វើជាខែលពីខាងលិច និងពីខាងត្បូង បរិវេណ

[2216] វាជាការសំខាន់ដែលបានកត់សម្គាល់ពាក្យថា "ភូមិ" មានន័យថា "village" ជាភាសាអង់គ្លេស ដូច្នេះ "ភូមិវាល" បកប្រែតាមន័យរបស់ពាក្យថា "Village Veal" ឬជាទូទៅថា "Veal Village"។ ដូច្នេះ ខណៈដែលសេចក្តីសន្និដ្ឋានៃនេះនឹងយោងទៅដល់កន្លែងថាជា មន្ទីរសន្តិសុខភូមិវាល នោះភ័ស្តុតាងជាមូលដ្ឋានៅក្នុងសំណុំរឿងយោងទៅដល់ គុកភូមិវាល គឺជាកន្លែងតែមួយដូចគ្នា។ *សូមមើល ឧទាហរណ៍* ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ (ក៏បានយោងទៅដល់ គឹម សួរ, សុង គឹម សួរ, គឹម សួរ និង ស៊ុង គឹមសួរ ផងដែរ។ ប៉ុន្តែនៅទីនេះគឺបានយោងទៅដល់ "គឹម សូរ") ឯ.១០៨ KH 00955720។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឯ.៩៧ KH 00955738។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឯ.១៣៨ KH 01000271។ ឯកសារ D219/89 កំណត់ហេតុស្តាប់ចម្លើយ សំ ឡេង ឯ.២៩ KH 01040135។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឯ.១៦០ KH 01068151 ["នៅក្នុងស្រុកបាកានមានតែមន្ទីរសន្តិសុខមួយកន្លែងទេ គឺនៅភូមិវាល"]។ ឯកសារ D5/1325 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជុន ណារី KH 01038130 ["ដល់ថ្ងៃទី ២៣-១២-១៩៧៨ ពួកវាមកចាប់ចងពីភូមិតាឡូ យកទៅសម្លាប់នៅគុកភូមិវាល ឃុំតាឡូ ស្រុកបាកាន ខេត្តពោធិ៍សាត់"]។ ឯកសារ D5/1413 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សន ឡេង KH 01100850 [សាច់ញាតិរបស់អ្នកពាក្យសុំត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងនៅក្នុង "មន្ទីរសន្តិសុខ គុកភូមិវាល ដែលស្ថិតនៅក្នុង ស្រុកបាកាន ខេត្តពោធិ៍សាត់"]។

[2217] *សូមមើល ឧទាហរណ៍* ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឯ.៣៤-៣៥ KH 01034499 [ជួនកាល សាក្សីរូបនេះធ្លាប់ធ្វើការនៅភូមិវាល (សូមមើល ឯ.៣៧, ៨៦)៖ "ប្រហែលជាចូលឆ្នាំ១៩៧៦ ទើបមានមន្ទីរសន្តិសុខ។ [...] មន្ទីរសន្តិសុខនេះឈ្មោះ "មន្ទីរសន្តិសុខភូមិវាល" ហើយយោធាជាអ្នកទទួលខុសត្រូវនៅទីនេះ"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឯ.១៤៥ KH 01000272 ["[គុកភូមិវាល]ចាប់ដំណើរការតាំងពីឆ្នាំ១៩៧៤ និង១៩៧៥"]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385138 ["ខ្ញុំបានរត់គេចពីមន្ទីរឃុំឃាំង នៅពេលដែលកងទ័ពវៀតណាមបានចូលមកក្នុងឆ្នាំ១៩៧៩"]។ ឯកសារ D5/115 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចឹក ប៊ុនរ៉ឿន EN 00426903 ["នៅឆ្នាំ១៩៧៦ ឪពុកខ្ញុំត្រូវកម្មាភិបាលខ្មែរក្រហមចាប់ខ្លួន ហើយឃុំខ្លួនរហូតដល់ឆ្នាំ១៩៧៩ នៅក្នុងគុកមួយនៅភូមិវាល"]។

[2218] ឯកសារ D118/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខភូមិវាល KH 00893187-88។

[2219] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឯ.១០៩ KH 00955720 ["តំបន់គុកនោះមានទំហំប្រហែលជាបីហិចតា។ គុកនោះគេធ្វើរបងព័ទ្ធបន្លាលួសបីជាន់"]។ ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ឿន ឯ.៩៣-៩៤ KH

នោះ[2220]។ នៅពីខាងត្បូង ក៏មានផ្លូវមួយដែលអាចប្រើប្រាស់បាននៅពេលដែលពួកអ្នកទោសត្រូវបាននាំចូលទៅកាន់កន្លែងនោះផងដែរ[2221]។ ពីខាងក្នុងបរិវេណនោះ មានអគារធ្វើពីឈើប្រក់ស្លឹកដែលជាផ្ទះរបស់អ្នកស្រុកកាលពីមុន[2222]។ ពួកយោធាគុកបានរស់នៅក្នុងអគារកែ្សរច្រកចូលខាងត្បូង ខណៈដែលពួកអ្នកទោសត្រូវបានឃុំខ្លួននៅក្នុងអគារនានានៅចំកណ្តាលបរិវេណនោះ[2223]។ ច្រកចូលពីខាងកើតគុក ភ្ជាប់ទៅផ្លូវទៅកាន់តាណោ និងទៅកាន់វាលស្រែមួយដែលបានប្រើប្រាស់

00990658។ ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីន្ធន ឆ.១៧ KH 01067988។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ម៉ោ: ម៉ុន EN 00527085 ["គុកមន្ទីរភូមិវាល [...] ត្រូវបានហ៊ុំព័ទ្ធដោយលួសបន្ទា"]។

[2220] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១០៩ KH 00955720។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក យ៉ីន ឆ.៥៧ KH 00955700។

[2221] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៩៨ KH 00955738-39 [និង KH 00955742 [ផែនទីបង្ហាញពីផ្លូវចូលខាងត្បូង]។

[2222] ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091 ["នៅក្នុងគុកធំមានអគារធ្វើពីឈើប្រក់ស្បូវ មានចំនួន១៣ អគារ។ អគារនីមួយៗមានទទឹង ៤ ឬ ៥ម៉ែត្រ និងបណ្តោយ ៣០ម៉ែត្រ"]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136 ["ពួកខ្មែរក្រហមបានយកផ្ទះប្រជាជនធ្វើជាមន្ទីរឃុំឃាំង"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១០៩-១១០ KH 00955720-21។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក យ៉ីន ឆ.៥៤ KH 00955700។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៩៨ KH 00955738-39។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091 ["នៅក្នុងគុកធំមានអគារធ្វើពីឈើប្រក់ស្បូវ មានចំនួន១៣ អគារ។ អគារនីមួយៗមានទទឹង ៤ ឬ ៥ម៉ែត្រ និងបណ្តោយ ៣០ម៉ែត្រ"]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136 ["ពួកខ្មែរក្រហមបានយកផ្ទះប្រជាជនធ្វើជាមន្ទីរឃុំឃាំង"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១០៩-១១០ KH 00955720-21។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក យ៉ីន ឆ.៥៤ KH 00955700។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៩៨ KH 00955738-39។

[2223] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១០៩ KH 00955720-21។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៩៨ KH 00955738-39។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក យ៉ីន ឆ.៥៣ KH 00955700។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១១០ KH 01034508 ឆ.១១២ KH 01034508។ ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ៀន ឆ.៩៤ KH 00990658។ *សូមមើលផងដែរ* ឯកសារ D219/57/1 ផែនទីគូសវាសដោយដៃរបស់ គង់ រុន ហៅ គង់ សារុន [ផែនទីបង្ហាញពីមន្ទីរសន្តិសុខភូមិ]។

សម្រាប់ការសម្លាប់[2224]។ សព្វថ្ងៃ មានសាលាបឋមសិក្សាមួយដែលបានសាងសង់នៅនឹងកន្លែងនោះ ហើយពុំមានស្នាមសែសសល់ដែលអាចមើលឃើញថាជាអតីតគុកនោះទេ[2225]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

619. គណៈស្រុកបាកានជាអ្នកទទួលខុសត្រូវលើភូមិវាល និងត្រួតពិនិត្យលើពួកយោធាស្រុក ដែលធ្វើប្រតិបត្តិការរាល់ថ្ងៃលើគុក[2226]។ ទោះបីជាមានភ័ស្តុតាងខ្ទាស់គ្នាអំពីថាតើនរណាជាប្រធានគុក និង

[2224] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជួង ឆ.៧១ KH 00955735 ["ជួនកាលយប់ឡើងអ្នកជាប់ខ្ទោះជាមួយគ្នា គេដោះយក៥នាក់ចេញទៅ ហើយយកទៅសម្លាប់នៅវាលស្រែ"] ឆ.៩៨ KH 00955738-39។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១១៣-១១៤ KH 01034508-09។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យឹន ឆ.៥៧ KH 00955700 ["ខ្ញុំមិនអាចរាប់បានទេ ច្រើនណាស់ គេសម្លាប់ដាក់ក្នុងព្រៃមួយពេញហើយ គេសម្លាប់ដាក់ក្នុងវាលស្រែទៀត"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៦៣ KH 00955716។

[2225] ឯកសារ D118/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខភូមិវាល KH 00893187-88។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យឹន ឆ.៦៩ KH 00955701។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជួង ឆ.៩៩ KH 00955739។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១១៥ KH 01034509។

[2226] សេចក្តីពិស្តារពាក់ព័ន្ធនឹងនរណាជាសមាជិកគណៈស្រុកបាកានក្នុងរយៈពេលពាក់ព័ន្ធ *សូមមើល* IV.គ.២.ក. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទងរបស់ ប.ក.ក – ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧-១៩៧៩ – តំបន់ ២ – ស្រុកបាកាន។ *សូមមើលផងដែរ* ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ ឃាយរ៉ីម ឆ.៩៩-១០០ KH 01348874 ["ឯការៀបចំគុក និងសន្តិសុខ គឺបងស្រីទាំងពីរ។ [...] បងស្រីទាំងពីរ ពីមុនមាន រ៉ន និង យ៉ាន"] (*កត់សម្គាល់ថា* ទោះបីជា ឃាយរ៉ីម បានកាត់បន្ថយតួនាទីរបស់គាត់ ក៏គាត់នៅតែជាអនុលេខា ហើយបន្ទាប់មក ជាលេខាគណៈស្រុក ទទួលខុសត្រូវលើគុក។ *សូមមើល* V.ខ.១. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១៦៣ KH 01068151 ["ឃាយរ៉ីម ក្តាប់រួមពីលើមន្ទីរសន្តិសុខនេះ គឺលើទាំងខាងយោធា និងប្រជាជន។ ឃាយរ៉ីម ក្តាប់ពីលើជាមួយនឹងតាផែង"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៥១ KH 01000273 ["ពួកគេទាំងបីនាក់ [រ៉ន, រ៉ីម និង យ៉ាន] គឺជាអ្នកទទួលខុសត្រូវនៅគុកភូមិវាលហើយ"]។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ឆ្លូ រិន ឆ.៦០ KH 01075614 ["ចៅ ហ្វាយស្រុកគឺនៅពីលើប្រធានមន្ទីរសន្តិសុខភូមិវាល"]។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ូន ឆ.១១៧ KH 01176418។ ឯកសារ D219/758 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម លន់ ឆ.៧១-៧២ KH 01240856។ ឯកសារ D219/921 កំណត់ហេតុស្តាប់ចម្លើយ ចាប ពុធ ឆ.១១៩ KH 01391803 ["ខ្ញុំដឹងថាកន្លែង[មន្ទីរសន្តិសុខនៅភូមិវាល]ជាកន្លែងគុក ហើយមានយោធានៅកាន់កាប់នៅទីនោះ"]។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ហៅ ត្រូហ៊ុ ន ឆ.៣២ KH 00979033 ["ភូមិវាល [...] គឺគ្រប់គ្រងដោយស្រុក និងតំបន់"]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១២០-១២២ KH 01034509។ *សូមមើលផងដែរ* ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.២៣-២៤ KH 01068110។

នៅពេលណាក็ដោយ ក็អតីតអ្នកទោស និងយោធាម្នាក់ដែលធ្លាប់ធ្វើការនៅគុកនោះបានបញ្ជាក់ថា កន, អ្ងន, កាន និង តាឈិន ទាំងអស់គ្នាបានបម្រើការងារជាប្រធានគុក ឬជាអនុប្រធានគុក នៅក្នុងអំឡុងពេលដែលនៅក្រោមការត្រួតត្រារបស់ពួកនិរតី[2227]។

620. យាយយ៉ាន យាយរ៉ឹម និង តាម៉ុក ទាំងអស់គ្នាបានទៅធ្វើទស្សនកិច្ចនៅភូមិវាលដោយផ្ទាល់។ យាយយ៉ាន ដែលបានបម្រើជាសមាជិកគណៈស្រុកបាកានមួយរយៈពេលខ្លី បានប្រាប់ទៅអ្នកស៊ើបអង្កេតថា គាត់បានទៅធ្វើទស្សនកិច្ចម្តងដែរ បានឃើញអ្នកទោស "រស់នៅយ៉ាងវេទនា" បានចែកចាយអង្ករពីឃ្លាំង ពីព្រោះពួកអ្នកទោស "ពុំមានអ្វីហូបនោះទេ" ហើយក្រោយមក បានដោះលែងពួកគេ បន្ទាប់ពីបានពិភាក្សាជាមួយ រ៉ន ដែលបានប្រាប់គាត់ថាឲ្យធ្វើដូច្នេះបើគាត់គិតថាវាជាការ "សមគួរ"[2228]។ យាយយ៉ាន បានលើកឡើងចោទប្រកាន់ថា នៅពេលនោះ គាត់បានយកពួកអ្នកទោសដែលបានដោះលែងទាំងអស់ឲ្យដាំដំណាំជាមួយនឹងគាត់ ហើយក្រោយទៀត នៅក្នុងអំឡុងពេលនៃ

[2227] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៥៣-៥៥ KH 00955714 ["បាទ ប្រធានគុកមានបីដំណាក់កាលដំបូងឈ្មោះ កន ក្រោយមកទៀត ឈ្មោះ មិត្តអ្ងន បន្ទាប់មកឈ្មោះ មិត្តកាន ។ [...] ក្នុងជំនាន់ មិត្តកាន គឺមានការសម្ពាប់បងប្អូនមកពីស្វាយរៀង។ [...] គាត់ជាប្រធានគុកភូមិវាលចុងឆ្នាំ១៩៧៨ ដល់ ១៩៧៩។"] ឆ.៣៧-៣៨ KH 00955711-12 [អ៊ីឈិន ជាអនុប្រធានគុកភូមិវាល]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.៩០ KH 01034505។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091 ["ប្រធានគុកនៅទីនេះមានឈ្មោះ កាន, អ៊ុន អ្ងន និង តាឈិន។ តាឈិន នេះមកពីភូមិភាគនិរតី។ អ្ងន និង កាន ទទួលបន្ទុកលើកិច្ចការទូទៅ"]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៥៤ KH 00955733 ["ប្រធានគុកភូមិវាលមុនដំបូងឈ្មោះ ឈិន ហើយមានអនុប្រធានបីនាក់ឈ្មោះទី១ តាកាន, ទី២ តាពង់ និងទី៣ កន។ ដល់ឆ្នាំ១៩៧៧ តាឈិន និង តាកាន ត្រូវបានគេដកចេញ [...] អ៊ុន អ្ងន (ប្រុស) ជាអ្នកនិរតីមកជំនួសវិញ"]។ *សូមមើលផងដែរ* ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ឌួន រិន ឆ.៥៨ KH 01075614 ["ដំបូងឡើយឈ្មោះ នៅ ជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខនៅភូមិវាលនេះ តែក្រោយមកទៀតក็ត្រូវគេចាប់យកបាត់។ បន្ទាប់មកឈ្មោះ កាន មកពីនិរតី ก็មកគ្រប់គ្រងបន្ត តែ កាន ត្រូវគេផ្ទាស់ចេញទៅបាត់ទៀត។ ហើយចុងក្រោយមនុស្សម្នាក់ទៀតមកពីកំពង់ឆ្នាំងមកគ្រប់គ្រងមន្ទីរសន្តិសុខនេះ តែខ្ញុំមិនចាំឈ្មោះទេ"]។ *សូមមើលផ្ទុយពីនេះ* ឯកសារ D219/556 កំណត់ហេតុស្តាប់ចម្លើយ កែប ពៅ ឆ.២៦-២៨, ៣០-៣១ KH 01158658 [អ្នកមេម៉ាយ ពីឈ្មោះ ស្ងួន អ្ងល ដែលអះអាងថាប្តីរបស់គាត់បានគ្រប់គ្រងមន្ទីរសន្តិសុខភូមិវាល "ដូចមិនដល់មួយឆ្នាំទេ តាមនេះ" ហើយនៅទីនោះនៅឡើយ នៅពេលដែលវៀតណាមបានចូលមកដល់]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១៦១ KH 01068151 ["ស៖ តើអ្នកណាជាអ្នកទទួលខុសត្រូវមន្ទីរសន្តិសុខភូមិវាល? ឆ.១៦១៖ យោធាជាអ្នកទទួលខុសត្រូវគឺឈ្មោះ អ្ងល។ មានឈ្មោះ កន និង សន ពីរនាក់ទៀតដែលអ្នកទទួលខុសត្រូវផ្ទាល់នៅមន្ទីរសន្តិសុខភូមិវាល។ ចំណែក អ្ងល គឺក្តាប់រួមពីលើ"]។

[2228] ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅយាយយ៉ាន ឆ.១៥៩-១៦១, ១៧១-១៧៤ KH 01075740-44 ។

វគ្គរៀនសូត្រ គាត់ត្រូវបានគេសួរថាតើហេតុអ្វីបានជាគាត់ដោះលែងពួកអ្នកទោស[2229]។ គួរឱ្យកត់សម្គាល់ថា គ្មានអ្នកទោសណាម្នាក់ក្នុងចំណោមអ្នកទោសដែលនៅរស់រានមានជីវិតដែលត្រូវបានជាប់ឃុំនៅភូមិវាល ត្រូវបានដោះលែងនៅពេលនោះទេ ហើយពួកគេក៏មិនបានពោលដល់ព្រឹត្តិការណ៍ដ៏គួរឱ្យចងចាំបែបនេះទៅកាន់អ្នកស៊ើបអង្កេតដែរ[2230]។

621. អតីតអ្នកទោស ចាប ខ្ជង នៅចងចាំថា លេខាស្រុក យាយរ៉ឹម បានទៅធ្វើទស្សនកិច្ចភូមិវាល "ពីរដងក្នុងមួយខែ" ដែលការណ៍នេះត្រូវគ្នានឹងអតីតអ្នកនាំសាររបស់ យាយរ៉ឹម គឺ ឡម សារ៉ូន[2231]។ ក្នុងអំឡុងពេលធ្វើទស្សនកិច្ច យាយរ៉ឹម បានចូលរួមប្រជុំជាមួយនឹងពួកយោធា និងពួកអ្នកទោស។ ជួនកាល គាត់បានណែនាំឱ្យពួកយោធាបញ្ជូនអ្នកទោសខ្លះឱ្យវិលត្រឡប់ទៅកាន់ភូមិ ឬ សហការណ៍របស់ពួកគេវិញ ប៉ុន្តែអ្នកទាំងនោះត្រូវបានបញ្ជូននៅពេលយប់ ហើយ ចាប ខ្ជង បានសន្និដ្ឋានថា "តែយកសហការណ៍វិញ គឺមានន័យថាសម្លាប់ហើយ" ពីព្រោះថាពួកអ្នកទោសបានបាត់ខ្លួនបន្ទាប់ពីនោះមក[2232]។ ក្នុងអំឡុងពេលនោះ យាយរ៉ឹម បានប្រាប់រឿងរ៉ាវខុសគ្នាមួយ ដែលជាថ្មីម្តងទៀត បានប៉ុនប៉ងកាត់បន្ថយតួនាទីរបស់គាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2233]។ គាត់បានរក្សាយ៉ាងខ្ជាប់ខ្ជួនថាគាត់ *មិនធ្លាប់ដែល* ទៅកាន់គុកនោះទេ បន្ទាប់មកទៀត គាត់បាននិយាយថាគាត់ធ្លាប់បានទៅកាន់ទីនោះ *ម្តងដែរ* ខណៈដែលរត់គេចពីវៀតណាម "ទៅមើលម៉ូចវិញ" បន្ទាប់មកទៀតគាត់វិលត្រឡប់ក្រោយវិញដោយបានអះអាងថាគាត់ *មិនធ្លាប់ដែល* ទៅកាន់ទីនោះម្តងណា

[2229] ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.១៦២, ១៦៥ KH 01075741-42។

[2230] *សូមមើល* ការរៀបរាប់របស់អ្នកទោសដែលនៅរស់រានមានជីវិត ចាប ខ្ជង (ឯកសារ D5/161, D6.1.758, D118/125) ចឹក យ៉ឹន (ឯកសារ D5/61, D118/123) និង គ ឹម ស្ងួ (ឯកសារ D5/147, D6.1.749, D18, D118/124)។

[2231] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.១០៥ KH 00955739 ["ពេលដែល តាឈិន និង តាកាន គ្រប់គ្រងគាត់[យាយរ៉ឹម]មិនដែលទៅទេ ប៉ុន្តែពេលដែល អ៊ុន អ្ងួន គ្រប់គ្រងគឺគាត់ទៅពីរដងក្នុងមួយខែ"]។ ឯកសារ D219/611 កំណត់ ហេតុស្តាប់ចម្លើយ ឡម សារ៉ូន ឆ.១១៨ KH 01176418 ["ខ្ញុំដែលទៅ[គុកនៅភូមិវាល] ទៅជាមួយគាត់[យាយរ៉ឹម] ប្រហែលកន្លះខែមួយអាទិត្យ គាត់ទៅទស្សនកិច្ច អ្នកជាប់ទោស"]។ ឯកសារ D219/842 កំណត់ ហេតុស្តាប់ចម្លើយ ឡម សារ៉ូន ឆ.៨២-៨៣ KH 01335681។

[2232] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៩២-៩៦ KH 00955737-38 ឆ.១០៦-១០៩ KH 00955739-40 ។

[2233] *សូមមើល ឧទាហរណ៍* ភ័ស្តុតាងគាំទ្រនៅក្នុងកថាខណ្ឌ ៣៥៩, ៦៦២។

ទេ[2234]។ អតីតអ្នកទោស ចឹក យឹន និង ចាប ខ្ជង ទាំងពីរនាក់នេះបានផ្តល់ភ័ស្តុតាងថា តាម៉ុក ក៏ធ្លាប់ទៅធ្វើទស្សនកិច្ចនៅមន្ទីរសន្តិសុខនោះដែរ[2235]។

iv. ឧក្រិដ្ឋកម្ម

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង</u>

622. ប្រជាជនស៊ីវិលត្រូវបានចាប់ខ្លួនតាមអំពើចិត្ត និងត្រូវឃុំខ្លួននៅភូមិវាល ខណៈដែលមន្ទីរសន្តិសុខនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី។ ពួកអ្នកជាប់ឃុំ រួមមាន ប្រជាជនដែលត្រូវបានចោទប្រកាន់ពីកំហុសសីលធម៌ ពីការលួចម្ហូបអាហារ ពីការចូលដៃជាមួយនឹងរបប លន់ នល់ ពីគិញវៀតណាម ឬ ពីជនក្បត់ទៅនឹងរបបនេះ[2236]។ ប្រជាជនជម្លៀសខ្មែរក្រោម និងពីភូមិភាគបូព៌ា ក៏

[2234] ឯកសារ D118/170 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.១២៦ KH 00969597។ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥៧ KH 01347270។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.១០០-១០២ KH 01348874 ឆ.១០៧ KH 01348875។

[2235] ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យឹន ឆ.៦៥ KH 00955701 ["តាម៉ុក ធ្លាប់ទៅមើលគុក[ភូមិវាល]នេះចំនួនពីរដង"]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.១០៤ KH 00955739 ["ខ្ញុំធ្លាប់ឮគេនិយាយថា តាម៉ុក ធ្លាប់ទៅគុកភូមិវាល ប៉ុន្តែខ្ញុំមិនដែលបានឃើញនោះទេ"]។ *កត់សម្គាល់ផងដែរ* ថា ចឹក យឹន បាននិយាយថា នៅពេលទស្សនកិច្ចទៅកាន់ភូមិវាលនៅចុងបញ្ចប់នៃរបបនោះ តាម៉ុក បានឃាត់ការសម្លាប់ពួកអ្នកទោសដែលនៅសែសសល់ ដោះលែងពួកនោះ ហើយបានបញ្ជាឲ្យគេដុតគុកនោះចោល។ ចឹក យឹន បាននិយាយថា យាយយ៉ាន បានបញ្ជាឲ្យសម្លាប់ក្រុមនោះ ប៉ុន្តែ យាយយ៉ាន ត្រូវបានជាប់ឃុំឃាំងចាប់តាំងពីឆ្នាំ១៩៧៧ ហើយក៏បានប្រកែកផងដែរថាគាត់មិនដែលបានបញ្ជាឲ្យសម្លាប់ទេ។ *សូមមើល* ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យឹន ឆ.២៣-២៤ KH 00955696-97 និង ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចឹក យឹន EN 00427010-11។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.៩០ KH 01075729 ឆ.១៧០ KH 01075743។

[2236] ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួរ KH 00385136 [អតីតអ្នកទោស៖ "តាមខ្ញុំដឹងអ្នកទោសខ្លះត្រូវបានគេចោទប្រកាន់ថា បានធ្វើខុសសីលធម៌ ជាជនក្បត់ ឬជាខ្សែពួកក្បត់ ឬជាពួកមូលធន"]។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យឹន ឆ.៥៩ KH 00955700 ["បើរឿងខ្ញុំ គេចោទថាជាខ្សែរបស់ តាវ៉ាញ។ ប្រជាជនទាំងអស់នោះប្រហែលជាគេចាប់ដោយចោទថា ជាខ្សែរបស់ តាវ៉ាញ ដែរ។ អ្នកខ្លះដែលគេជម្លៀសមកពីភ្នំពេញ ហើយគេសួរថាធ្លាប់ធ្វើអ្វី ពួកគេប្រាប់តាមត្រង់ថា ពួកគេជាទាហាន[នៃរបបមុន] ដូច្នេះពួកគេក៏ត្រូវបានយកទៅសម្លាប់ដែរ"]។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.១៦១ KH 01075741 [អតីតសមាជិកគណៈស្រុកបាកាន៖ "ខ្ញុំបានសួរអ្នកដែលជាប់ខ្នោះទាំងអស់នោះថា "ពួអ៊ំធ្វើអីខុសបានគេដាក់ខ្នោះដូច្នេះ?" ពួកគាត់ឆ្លើយថា "[...] គ្រាន់តែលួចបូតស្រូវហូបបន្តិចបន្តួចប៉ុណ្ណោះ ដោយសារឃ្លានពេក""]។ ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៤៦, ៤៨ KH 00982177-78 [ត្រូវបានចាប់ខ្លួននៅពាក់កណ្តាលឆ្នាំ១៩៧៧ "ដោយសារខ្ញុំបានលួចផ្លែខ្ទុរ" និងគេដាក់នៅគុកភូមិវាល គឺ១ខែ] ឆ.៥៧ KH 00982179។

ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងនៅភូមិវាលផងដែរ ទោះបីជាពេលខ្លះតែមួយរយៈខ្លីប៉ុណ្ណោះ[2237]។ "ពួកអ្នកធ្វើខុស" បែបដូច្នេះ មិនត្រូវបានចាប់ខ្លួនតែឯងទេ៖ "មនុស្សដែលគេយកទៅដាក់ក្នុងគុក គឺ

ឯកសារ D219/842 កំណត់ហេតុស្តាប់ចម្លើយ ឡម សាវួន ឆ.៨៣ KH 01335681 [និវសាររបស់ យាយរីម ដែលបានទៅមើលភូមិវាលជាមួយ យាយរីម៖ "គុកធម្មតា [...] អ្នកខូចសីលធម៌ អ្នកលួចរបស់ហូបរបស់អី អ៊ីចឹង"]។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត វុត ឆ.៣២ KH 00985417។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១១៩, ១២៣ KH 01034509-10។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១៦៦ KH 01068151-52។ ឯកសារ D219/676 កំណត់ហេតុស្តាប់ចម្លើយ ហុក សារិន ហៅ តាកូរ៉េ ឆ.៧៧ KH 01202404។ ឯកសារ D5/640 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សំ ឡេង KH 00529856 ["នៅចុងខែវស្សា ខ្ញុំបាទនិងក្រុមគ្រួសារ ព្រមទាំងប្រជាជនប្រមាណ ១០ គ្រួសារទៀតត្រូវបានអង្គការបញ្ជូនឱ្យទៅនៅគុកភូមិវាល [...] អង្គការចោទថាអ្នក ១១ គ្រួសារនេះលួចអង្ករយកឱ្យប្រពន្ធកូន"]។ ឯកសារ D5/115 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចឹក ប៊ុនរឿន EN 00426903 ["នៅឆ្នាំ១៩៧៦ ឪពុកខ្ញុំត្រូវបានចាប់ខ្លួនដោយកម្មាភិបាលខ្មែរក្រហម និងត្រូវបានឃុំខ្លួនរហូតដល់ឆ្នាំ១៩៧៩ នៅក្នុងគុកនៅភូមិវាល [...] គាត់ត្រូវបានចោទប្រកាន់ថាជាខ្សែរបស់ តាវ៉ាញ [...] ដែលគេចោទថាជាខ្មែរក្រោម ឬជាគិញរបស់វៀតណាម ដែលចង់បះបោរប្រឆាំងនឹងខ្មែរក្រហម"]។

[2237] *សូមមើលផងដែរ* ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គីម សួរ KH 00385135 ["នៅពេលនោះ ពួកខ្មែរក្រហមបានចាប់ផ្តើមចម្រាញ់ប្រជាជន ដើម្បីស្វែងរកខ្មែរកម្ពុជាក្រោម ដែលពួកគេចោទប្រកាន់ថាជា "ខ្សែយួន"។ ខ្ញុំត្រូវបានគេចាប់ចង និងបញ្ជូនទៅកាន់មន្ទីរឃុំឃាំង នៅភូមិវាល"] EN 00385137 ["មានប្រជាជនជាច្រើនត្រូវបានជម្លៀសពីខេត្តស្វាយរៀងមកខេត្តពោធិ៍សាត់។ ភាគច្រើននៃអ្នកទាំងនោះត្រូវបាននាំមកមន្ទីរឃុំឃាំងនៅភូមិវាល"]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខួង ឆ.៧៧-៧៩ KH 00955736 [អតីតអ្នកទោស៖ "ស៖ នៅគុកភូមិវាល តើមានអ្នកទោសខ្មែរក្រោមដែរឬទេ? ឆ.៧៧៖ បាទ មាន ប៉ុន្តែដល់ឆ្នាំ១៩៧៧ គឺគេបញ្ជូនមកដាក់នៅទួលព្រៃក្របៅអស់ហើយ។ [...] ឆ.៧៨៖ គេបញ្ជូនមកដើម្បីវ៉ៃ ចោល។ [...] ឆ.៧៩៖ [...] [ខ្មែរក្រោមដែលជាប់ឃុំ]នៅគុកភូមិវាល គឺមានចំនួនច្រើនដែរ ប្រហែលជា៥០ ទៅ៦០នាក់"]។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខួង KH 00385092 ["ខ្ញុំចាំថា គ្រួសារខ្មែរកម្ពុជាក្រោមនេះ ត្រូវបានយោធាខ្មែរក្រហមចាប់យកមកពីភូមិប្រឡាយរំដេង។ ក្នុងគ្រួសារដែលបានចាប់យកមកនេះ សមាជិកប្រហែល៦ ទៅ ៧នាក់"]។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.៥៥-៥៦ KH 00979036។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ឈុំ មាន EN 00527089 ["នៅចុងឆ្នាំ១៩៧៦ គ្រួសាររបស់គាត់ (ជាមួយនឹង១២គ្រួសារផ្សេងទៀត) ត្រូវបានជម្លៀសឱ្យទៅធ្វើការនៅភូមិវាល ដាំបន្លែសម្រាប់ពួកអ្នកទោសនៅគុកភូមិវាល [...]។ នៅពេលធ្វើការនៅទីនោះ គាត់បានឃើញខ្មែរក្រោមជាប់គុកជាច្រើននាក់ ហើយបង្ខំឱ្យធ្វើការជាទម្ងន់"] ការរៀបរាប់របស់ គីម សួរ EN 00527101 ["មានខ្មែរក្រោមជាច្រើននាក់[នៅគុកភូមិវាល] ដែលទាំងអស់គ្នា រួមទាំងខ្ញុំផង ត្រូវបានគេចោទប្រកាន់ថាជាគិញវៀតណាម។ [...] ខ្ញុំបានជួបខ្មែរក្រោមជាច្រើននាក់នៅក្នុងកងចល័តរបស់ខ្ញុំ ក៏ដូចជាអ្នកផ្សេងទៀតដែលរស់នៅតាមឃុំ និងតាមភូមិ ដែលខ្ញុំបានលើកឡើងផងដែរ។ ភាគច្រើនត្រូវបានឃុំខ្លួននៅក្នុងគុកតែពីរ-បីថ្ងៃ មុននឹងពួកគាត់ត្រូវបានដោះលែងឱ្យទៅកាន់អ្វីដែលខ្មែរក្រហមបានហៅថា "អប់រំសារជាថ្មី"។ ពួកគាត់មិនដែលត្រឡប់វិញទេ"] ការរៀបរាប់របស់ គីម សួរ EN 00527104 ["ខ្ញុំបានជួបខ្មែរក្រោមមកពីភូមិភាគបូព៌ាដែលកំពុងត្រូវបានកប់នៅក្នុងគុកវាល ហើយពួកគាត់បានប្រាប់ខ្ញុំថា ពួកគាត់ត្រូវបានបង្ខំឱ្យរត់ចេញពីភូមិភាគបូព៌ា ហើយត្រូវបានដឹកជញ្ជូនយកទៅពោធិ៍សាត់ ហើយបន្ទាប់មក ត្រូវបានបញ្ជូនទៅ

គេចាប់តាំងគ្រួសារតែម្តង រួមទាំងប្រពន្ធ ទាំងកូន ទាំងប្តីតែម្តង"[2238]។ ពួកអ្នកទោស ជាញឹកញាប់ មិនបានដឹងថាហេតុអ្វីបានជាពួកគាត់ត្រូវបានចាប់ខ្លួននោះទេ[2239]។ មិនមានភ័ស្តុតាងណាមួយ បញ្ជាក់ថាអ្នកទោសមួយណាត្រូវចាប់ខ្លួន ដោយអនុលោមតាមដីកាតុលាការណាមួយ ត្រូវបានប្រាប់ពីបទចោទប្រកាន់ ត្រូវបានផ្តល់មេធាវីការពារក្តី ត្រូវបានដាក់ឲ្យជំនុំជម្រះក្តី ឬ ត្រូវបានផ្តល់នូវកិច្ចដំណើរការនីតិវិធីតុលាការតាមបែបណាមួយ ក៏ទេដែរ។

623. កំណត់ហេតុស្តាប់ចម្លើយនៅក្នុងសំណុំរឿងប្រៃប្រួលយ៉ាងខ្លាំងទាក់ទងនឹងចំនួនអ្នកទោសដែលបានឃាត់ខ្លួននៅភូមិវាល ប៉ុន្តែពួកវាបានរាយការណ៍យ៉ាងជាប់លាប់ពីចំនួនអ្នកទោសថ្មី ដែលបានចូល

កាន់គុកវាល។ ពួកគាត់បានដឹងថាពួកគាត់នឹងត្រូវស្លាប់"] ការរៀបរាប់របស់ ម៉ីក(ថាត) ឃីន EN 00527112 ["អ្នកទោសថ្មីត្រូវបានគេប្រមូលឲ្យមកជួបជុំគ្នាពីឃុំផ្សេងៗ និងនាំយកទៅកាន់គុកភូមិវាល ដោយសង្ស័យថាជាគិញ្ជរបស់វៀតណាម ឬអ្នកយល់ចិត្តថ្លើម លន់ នល់។ ភាគច្រើននៃអ្នកទោសគឺជាខ្មែរក្រោម"]។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ីក ឃីន EN 00427009 ["អ្នកទោសខ្មែរក្រោមដែលខ្ញុំបានជួបនៅគុកភូមិវាលបានប្រាប់ខ្ញុំថា [...] ពួកគាត់ត្រូវបានគេចោទប្រកាន់ថាជាជនក្បត់ ដោយគេហៅថាពួក "ក្បាលយួនខ្ជួនខ្មែរ""]។ ឯកសារ D5/161 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចាប ខ្ជង KH 00358252 ["ក្នុងឆ្នាំ១៩៧៨ ពួកនេះ [...] សំណប់ក្រុមគ្រួសារខ្មែរកម្ពុជាក្រោមចំនួន ១០គ្រួសារ បន្ទាប់មកពួកវាបានសំណប់បងប្អូនខាងឫស្សីដែលដឹកមកពីខេត្តស្វាយរៀង យកមកសំណប់ជារៀងរាល់ថ្ងៃ"]។ *សូមមើលផងដែរ* ភ័ស្តុតាងដែលបានលើកយោងខាងក្រោមក្នុងកំណត់សម្គាល់ជើងទំព័រ ២២៩៥។

[2238] *សូមមើល ឧទាហរណ៍* ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤៥ KH 00955713។ *សូមមើលផងដែរ* ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385092 ["ខ្ញុំចាំថា គ្រួសារខ្មែរកម្ពុជាក្រោមនេះ ត្រូវបានយោធាខ្មែរក្រហមចាប់យកមកពីភូមិប្រឡាយរំដេង។ ក្នុងគ្រួសារដែលបានចាប់យកមកនេះ សមាជិកប្រហែល៦ ទៅ ៧នាក់"]។ឯកសារ D5/640 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សំ ឡេង EN 00529856 ["នៅចុងខែវស្សា[ក្នុងឆ្នាំ១៩៧៨] ខ្ញុំបាទនិងក្រុមគ្រួសារ ព្រមទាំងប្រជាជនប្រមាណជា ១០ គ្រួសារទៀតត្រូវបានអង្គការបញ្ជូនឲ្យទៅនៅគុកភូមិវាលតំបន់ ២ ឃុំតាណោ ស្រុកបាកាន ខេត្តពោធិ៍សាត់"]។ ឯកសារ D5/1339 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ីម ចយ KH 01049471 [អ្នកជម្ងៀសម្នាក់នៅភូមិភាគឫស្សីដែលរស់នៅក្នុងស្រុកបាកាន៖ "ដល់ថ្ងៃទី12-12-1978 ពួកវាមកចាប់ប្អូនខ្ញុំទាំងពីរនាក់យកទៅសម្លាប់នៅគុកភូមិវាល [...]។ ខ្ញុំបានឃើញពួកវាចាប់ប្រជាជន ចងបណ្តើរយកទៅសម្លាប់ ជាច្រើនរយនាក់ ក្នុងនោះមានកុមារានិងកុមារីជាច្រើននាក់ ខ្លះទៀតមានបីកូនខ្ជីទៅជាមួយផង"]។

[2239] ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក ឃីន ឆ.១១ KH 00955694 [ដោយបានបញ្ជាក់លើការរៀបរាប់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន (D5/61) ថាជាការពិត ដែលថា៖ "គេដាក់គុកខ្ញុំជាមួយនឹងមនុស្ស៤០នាក់ទៀត ដោយពុំប្រាប់ពីមូលហេតុនៃការដាក់គុកនោះទេ"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤១ KH 00955712។

មកជំនួសពួកជនដែលត្រូវបានសម្លាប់[2240]។ ជាការបន្ថែមទៅនឹងលំហូរធម្មតារបស់អ្នកទោស ក្រុមអ្នកជម្លៀសដ៏ច្រើនពីភូមិភាគបូព៌ា ត្រូវបានឃុំខ្លួនមួយរយៈពេលខ្លីនៅភូមិវាលនៅឆ្នាំ១៩៧៨ នៅមុនពេលដែលពួកគេត្រូវបានសម្លាប់ចោល។ គឹម សូរ នៅចាំបានថា នៅពេលមួយមានអ្នកជម្លៀសថ្មីមកពីភូមិភាគបូព៌ាជាង៤០០នាក់ ត្រូវបាននាំយកទៅកាន់គុកនោះ ហើយត្រូវបានសម្លាប់ចោល ក្នុងមួយរយៈពេលខ្លីបន្ទាប់ពីនោះមក[2241] ខណៈដែល ចាប ខ្ជង បានរៀបរាប់ពីព្រឹត្តិការណ៍មួយដែលមាន អ្នកទោសភូមិភាគបូព៌ាចំនួន ១.៧០០នាក់ ត្រូវបាននាំទៅសម្លាប់[2242]។ សរុបគ្រប់ភ័ស្តុតាង

[2240] ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៥៣ KH 00982178 [នៅពាក់កណ្តាលឆ្នាំ១៩៧៧ (*សូមមើល* ឆ.៦៦ [សំនួរ/ចម្លើយទីពីរ] KH 00982179)៖ "ស៖ តើមានអ្នកទោសផ្សេងទៀតប្រហែលប៉ុន្មាននៅគុកភូមិវាល? ឆ.៥៣៖ មានប្រហែលរាប់រយនាក់ឯណោះ"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤៣ KH 00955712 ["តាមការខ្ញុំសង្កេតមើល គឺចេញច្រើនជាងចូល។ ដំបូងឡើយគឺមានមនុស្សច្រើនណាស់ រកតែកន្លែងឲ្យមនុស្សនៅមិនទាំងបានផង មានអ្នកខ្លះដេកក្រោមដើមឈើទៀតផង"] ឆ.៤៥ KH 00955713 ["ស៖ តើលោកអាចស្មានមើលបានដែរឬទេ មានមនុស្សប្រហែលប៉ុន្មានដែលចេញចូលក្នុងគុកភូមិវាលនោះ? ឆ.៤៥៖ ខ្ញុំពិបាកស្មានណាស់ ព្រោះមានអ្នកចេញ និងអ្នកចូល។ ប៉ុន្តែពេលដែលខ្ញុំចូលដំបូង [នៅខែ៧ ឆ្នាំ១៩៧៧, *សូមមើល* ឆ.៤០] មានមនុស្សប្រហែល៧០០នាក់"]។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091 ["ក្នុងឆ្នាំ១៩៧៧ ពួកយើងត្រូវបានគេបញ្ជូនមកកាន់គុកធំនៅភូមិវាល [...]។ តាឈួម និងកូនចៅរបស់គាត់ក៏ត្រូវបានចាប់ខ្លួននិងបញ្ជូនមកកាន់ទីនោះដែរ។ នៅក្នុងគុកធំនេះ មានអ្នកទោសប្រហែល ២០០០នាក់"]។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក ឃីន ឆ.៥៥ KH 00955700 ["ប្រហែលជា១០០ ឬក៏២០០នាក់ ហើយគេយកទៅសម្លាប់រាល់ថ្ងៃ និងដាក់បញ្ចូលអ្នកទោសថ្មីមកវិញ"] *ត្រូវអានគ្រប់ផ្សំជាមួយនឹង* ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចឹក ឃីន EN 00427010 ["មនុស្ស ៣០នាក់ ភ្ជួរដីស្រែមួយហិកតារ ហើយពួកយើងទាំងអស់គ្នាសង្កេតឃើញរឿងនេះដូចគ្នា។ យើងសន្និដ្ឋានថា មនុស្សប្រហែល ៧ ទៅ ៨ នាក់ ត្រូវបានសម្លាប់រៀងរាល់យប់ ចាប់តាំងពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ ពួកគេសម្លាប់មនុស្សនៅពេលយប់ ហើយជារៀងរាល់ថ្ងៃផងដែរ ពួកអ្នកទោសថ្មីត្រូវបានប្រមូលផ្តុំយកមកពីឃុំផ្សេងៗ ហើយនាំយកទៅកាន់គុកភូមិវាល"]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.៩៧, ១០១-១០២ KH 01034506-07។

[2241] ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385137 ["ក្នុងខែមករា ឬ កុម្ភៈ ឆ្នាំ១៩៧៨ មានប្រជាជនជាច្រើនត្រូវបានជម្លៀសបីខេត្តស្វាយរៀងមកខេត្តពិធីសាត់។ ភាគច្រើននៃអ្នកទាំងនោះត្រូវបាននាំមកមន្ទីរឃុំឃាំងនៅភូមិវាល។ ពួកគេត្រូវបានបញ្ជូនមកជាពីរដំណាក់កាល ក្រុមទីមួយមានគ្នាប្រហែល ២៥០នាក់ ជាបុរស និងក្រុមទីពីរមានគ្នាប្រហែល ៥០០នាក់ ដែលមាន បុរស ស្ត្រី និងកុមារ។ ប្រជាជនទាំង ៥០០នាក់ ត្រូវបានសម្លាប់នៅពេលថ្ងៃ ចំណែកបុរស ២៥០នាក់ ត្រូវបានសម្លាប់នៅពេលយប់។ បន្ទាប់ពីសម្លាប់អ្នកទាំង ២៥០នាក់នេះ សាកសពរបស់ពួកគេត្រូវបានកប់។ ខ្ញុំបានដឹងហេតុការណ៍នេះដោយផ្ទាល់"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៦១ KH 00955715 ["ប្រហែលជា១២០នាក់ នៅយប់នោះ ប៉ុន្តែនៅពេលថ្ងៃក៏មានការសម្លាប់មនុស្សស្រី និងកូនក្មេងដែប្រហែលជាង៣០០នាក់ដែរ"]។

[2242] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៦១, ៦៨ KH 00955734-35។

ទាំងអស់ វាច្បាស់ណាស់ដែលថា មានមនុស្សរាប់ពាន់នាក់ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំងតាមអំពើចិត្ត នៅភូមិវាល។

<u>អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

624. ពួកអ្នកទោសនៅភូមិវាលត្រូវស្ថិតនៅក្នុងលក្ខខណ្ឌអមនុស្សធម៌។ អ្នកទោសភាគច្រើនត្រូវបានដាក់ខ្នោះជើង[2243]។ អតីតអ្នកទោស ហង់ ង៉ែត ត្រូវបានដាក់ខ្នោះមួយខែពេញក្នុងពេលឃុំខ្លួនគាត់នោះ គាត់ត្រូវបានដោះលែងតែរយៈពេលខ្លីប៉ុណ្ណោះដើម្បីទៅបន្ទោរបង់[2244]។ ចំពោះអាហារវិញ របបអាហារនៅគុកនោះពិតជាមិនគ្រប់គ្រាន់ទាល់តែសោះ[2245]។ ចឹក យឹន ដែលបានជាប់ឃុំនៅភូមិវាល

[2243] ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.១៦១ KH 01075741 [នៅក្នុងដំណើរទៅមើលភូមិវាល ពេលដែលគាត់ជាសមាជិកគណៈស្រុកបាកាន៖ "ខ្ញុំឃើញប្រជាជនត្រូវគេដាក់ខ្នោះដៃនិងជើង រស់នៅយ៉ាងវេទនា"] ឆ.១៧៤ KH 01075744។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៧០ KH 00955735។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091 ["អ្នកទោសប្រុសត្រូវបានគេដាក់ខ្នោះ"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១១០ KH 00955721។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យឹន ឆ.៦៤ KH 00955701។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១១០ KH 01034508។ ឯកសារ D219/842 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ្ជន ឆ.៨៣ KH 01335681។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ម៉ោ ម៉ុន EN 00527085 ["អ្នកទោសត្រូវបានឃុំជាក្រុមបីនាក់ នៅក្នុងខ្នោះជើងធ្វើពីឈើ (ពួកគេមានខ្នោះជើងវែងធ្វើពីឈើដែលមានបន្ទប់សម្រាប់មនុស្សបីនាក់ក្នុងខ្នោះនីមួយៗ) និងខ្នោះដៃ។"]។ ការរៀបរាប់របស់ គឹម សូរ EN 00527101 ["ក្រោយពី [ធ្វើទារុណកម្មរួច] យើងត្រូវបានគេដាក់ក្នុងបន្ទប់គុកក្ស្ម ដែលអ្នកទោស ២០០នាក់ ត្រូវបានដាក់ខ្នោះដៃ និងខ្នោះជើងដោយខ្នោះដែកជុំវិញកជើងរបស់យើង ភ្ជាប់ទៅនឹងបង្គោលឈើ។ [...] នៅពេលណាដែលគេចង់សម្លាប់នណាម្នាក់ គេបំបែកម្នាក់នោះចេញពីគេ ហើយនៅពេលដែលគេយកមនុស្សនោះចេញ គេដោះខ្នោះជើងយើងចេញបណ្តោះអាសន្ន។ ពេលដែលគេយកមនកមនុស្សនោះចេញទៅភ្លាម គេដាក់ខ្នោះជើងវិញ។"] ការរៀបរាប់របស់ ចឹក (ថាត) យឹន EN 00527113 ["ខ្ញុំក៏ត្រូវរបួសត្រង់ស្នងជើង និងកជើងរបស់ខ្ញុំដែរ ដោយសារនៅក្នុងគុកនោះ គេដាក់ខ្នោះយើងដោយច្រវ៉ាក់ដែក។"]។ ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គឹម សូរ KH 00358227 ["វាដាក់ខ្នោះជើងខ្ញុំទាំងយប់ទាំងថ្ងៃរយៈ១០ថ្ងៃ"]។

[2244] ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៤៧, ៤៩ KH 00982178។

[2245] ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៥៥ KH 00982178 [អ្នកទោសនៅពាក់កណ្តាលឆ្នាំ១៩៧៧៖ "គេឲ្យហូប [នៅភូមិវាល] គឺឲ្យតែបបរបន្តិចប៉ុណ្ណោះ គឺសឹងតែគ្មានគ្រាប់អង្ករង។"]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៨៤ KH 01034516 ["នៅរដូវប្រាំងអ្នកទោសទទួលបានបាយហូប តែបើនៅរដូវវស្សាគឺហូបបរ។"]។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.១៦១ KH 01075741 [នៅក្នុងដំណើរទៅមើលភូមិវាល ពេលដែលគាត់ជាសមាជិកគណៈស្រុកបាកាន៖ "ខ្ញុំឃើញប្រជាជន [...] រស់នៅយ៉ាងវេទនា ពុំមានអ្វីហូបនោះទេ។"]។ ឯកសារ D5/640 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សំ ឡេង KH 00529856 ["ម្នាក់ៗមានរូបរាង

ពីឆ្នាំ១៩៧៧ ដល់ ១៩៧៩ បានចាំថាមាន "អង្ករមួយកំប៉ុងសម្រាប់មនុស្ស ៤០នាក់"[2246]។ គឹម ស្ងួរ បានរំឭកថាពួកគាត់ទទួលបាន "មួយពេលតែបបរមួយវែកប៉ុណ្ណោះ[សម្រាប់អ្នកទោសម្នាក់]"[2247] ។ អ្នកជាប់ឃុំភាគច្រើនបានធ្លាក់ខ្លួនឈឺ និងភាគច្រើនបានស្លាប់ដោយសាររបបអាហារមិនគ្រប់គ្រាន់ កង្វះខាតការថែរទាំវេជ្ជសាស្ត្រ និងលក្ខខណ្ឌអនាម័យទាប[2248]។

625. អ្នកជាប់ឃុំជារឿយៗទទួលរងអំពើហិង្សាលើរូបរាងកាយ មានសាក្សីជាច្រើនបានរំឭកអំពីការវាយដោយរំពាត់ និងដំបង[2249]។ ការគំរាមកំហែង និងការប្រើប្រាស់អំពើហិង្សាកើតមានជាទូទៅជា

ស្ពាំងស្គមដោយហូបបបរវាវមានអង្ករមួយគ្រាប់ៗ។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម ស្ងួរ EN 00527101 ["នៅពេលខ្ញុំមកដល់ [គុកភូមិវាល] ខ្ញុំត្រូវបានគេដាក់ខ្នោះដៃប្រាំពីរថ្ងៃ ហើយគេឲ្យហូបអាហារខាប់ៗ (បាយជ្រូក)។ បន្ទាប់ពីរយៈពេលប្រាំពីរថ្ងៃដំបូងមក គេឲ្យខ្ញុំហូបតែបបរមួយវែកដាក់អំបិលមួយចិបប៉ុណ្ណោះក្នុងមួយថ្ងៃ។ គេឲ្យយើងហូងអាហារពីរពេលក្នុងមួយថ្ងៃ ម្តងនៅម៉ោង ១១ព្រឹក និងបន្ទាប់មកទៀតនៅម៉ោង ៦ល្ងាច។ គេមិនអនុញ្ញាតឲ្យមានអាហារណាផ្សេងទៀតទេ។"] EN 00527103 ["នៅពេលអាហារថ្ងៃត្រង់ គេឲ្យយើងតម្រង់ជួរដើរទៅកាន់កន្លែងហូបបាយ។ គេឲ្យយើងហូបផ្កាឈូក និងត្រកួន (បន្លែស្លឹកខៀវ) ដោយមិនមានគ្រឿងផ្សំណាផ្សេងទៀតឡើយ"]។

[2246] ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក យ៉ីន ឆ.៦៣ KH 00955701 *សូមមើលផងដែរ* ឆ.១១ និង ឆ.៥៦ អំពីពេលនៃការឃុំខ្លួនគាត់។

[2247] ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឹម ស្ងួរ KH 00358227។

[2248] *សូមមើល* ភ័ស្តុតាងលើកយោងខាងក្រោមក្នុងកំណត់សម្គាល់ជើងទំព័រ ២២៤៥-២២៤៧។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៨៤ KH 01034516 ["មានពេទ្យខ្លះដែរ ហើយថ្នាំគឺមានតែអាចម៍ទន្សាយប៉ុណ្ណោះ។"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួរ ឆ.៤៣ KH 00955712 ["ដំបូងឡើយគឺមានមនុស្សច្រើនណាស់ រកតែកន្លែងឲ្យមនុស្សនៅមិនទាំងបានផង មានអ្នកខ្លះដេកក្រោមដើមឈើទៀតផង។"] ឆ.៥២ KH 00955714 ["វាន [...] ស្លាប់ក្នុងគុកដោយសារជំងឺ។"]។ ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីន្ធន ឆ.១៧-១៨ KH 01067988-89 ["គេបង្ខំបងប្រុសរបស់ខ្ញុំឲ្យគាស់គល់ឈើ ជីករណ្តៅ គាត់មានរូបរាងស្គមស្គាំង។ នៅទីនោះគុកមានព័ទ្ធបន្ទាជុំវិញ។ មានមនុស្សរាប់រយរាប់ពាន់ត្រូវគេបង្ខំឲ្យធ្វើការនៅទីនោះ បើអ្នកណាមិនស្លាប់ដោយសារអត់បាយ ឬក៏ការងារទេ គេនឹងវៃសម្លាប់ចោលដាក់ក្នុងរណ្តៅ។ [...] គាត់បាននិយាយរឿងនេះប្រាប់ខ្ញុំទាំងអស់។ ពួកគាត់និយាយថា នៅទីនោះលំបាកណាស់ គ្មានអ្វីហូបទេ គាត់ដើរបេះស្លឹកឈើស្ងោហូបទេ។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់ គឹម ស្ងួរ EN 00527103 ["អ្នកទោសជាមួយខ្ញុំជាច្រើនអ្នកធ្លាក់ខ្លួនឈឺដោយសារកង្វះអាហារ ហើយបានស្លាប់។"] EN 00527105 ["គេឲ្យយើងដេកផ្ទាល់ដីនៅក្នុងគុកនោះលើថង់ផ្ទាស្ទិចដោយមិនមានក្រណាត់នោះទេ។ សូម្បីតែផ្ទៃក៏ខ្ញុំមិនធ្វើដាក់វាដូច្នេះដែរ"]។

[2249] ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក យ៉ីន ឆ.៦៣ KH 00955701 ["គេ [ខ្មែរក្រហម] វៃព្រឹកវៃល្ងាច។"]។ ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៥៦-៥៩ KH 00982178-79 ["ស៖ ពេលលោកស្រីត្រូវគេឃុំខ្លួន តើគេបានវៃលោកស្រីដែរឬទេ? ឆ.៥៦៖ ចាស គឺគេវៃខ្ញុំតែពីរដំបងប៉ុណ្ណោះ។ ស៖ តើលោកស្រីបានឃើញដោយអ្នកទោសផ្សេងទៀតត្រូវគេវៃដែរឬទេ? ឆ.៥៧៖ ចាស ខ្ញុំបានឃើញ អ្នកទោសធ្ងន់ធ្ងរត្រូវគេវៃ ដូចជាខុសសីលធម៌ ឬអ្នកលួចជាដើម។ តើលោក

ពិសេសចំពោះអ្នកទោស "ស្រាល" ដែលត្រូវបានគេបង្ខំឲ្យធ្វើការនៅក្រៅបន្ទប់ឃុំឃាំង។ កម្មករទាំងនោះស្ថិតក្រោមការឃ្លាំមើលជាប្រចាំ ហើយ "ប្រសិនបើនរណាម្នាក់មិនសកម្ម ឬសម្រាក [...]ពួកគេត្រូវបានគេស្រែកដាក់ និងគំរាមកំហែង។ ប្រសិនបើគេនៅតែមិនសកម្មទៀត គេនឹងបាញ់ចោល"[2250]។ ដើមបណ្តឹងរដ្ឋប្បវេណី សំ ឡេង បានរំឭកថា អ្នកទោសវ័យចំណាស់ពីរនាក់ត្រូវបានវាយរហូតទាល់តែពួកគាត់សន្លប់ ដោយសារតែមិនអាចបំពេញបរិមាណការងារកំណត់បាន[2251]។ អ្នកទោសត្រូវបានគេបង្ខំឲ្យធ្វើពលកម្មធ្ងន់ធ្ងរ ដូចជា ធ្វើស្រែ គាស់គល់ឈើ ជីករណ្តៅ

ស្រីបានឃើញរឿងនេះដោយផ្ទាល់ភ្នែកឬទេ? ឆ.៥៨៖ ចាស។ ស៖ តើគេវ៉ៃអ្នកទោសនឹងអ្វី? ឆ.៥៩៖ គេវ៉ៃនឹងខ្សែតីយ៍។"]។ ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គឹម សូរ KH 00358227 ["នៅក្នុងគុកខ្ញុំបានទទួលនូវការធ្វើបាបវាយដំច្រើនធាក់ ស្ទើគ្រប់ពេល។ ជាងនេះទៅទៀត ខ្ញុំបានឃើញផ្ទាល់ភ្នែកពួកធ្វើទារុណកម្មមកលើអ្នកទោសផ្សេងៗទៀត គឺវាវាយធ្វើបាបពុំមានត្រាប្រណីឡើយ។ វាវាយនឹងដំបង លើក្បាល ខ្នង ជើងដៃ។"]។ ឯកសារ D5/161 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចាប ខ្ជង KH 00358253 ["ពេលហ្ងូបបបរ វាយកវ៉ែកដ្ឋសបបរមកវាយក្បាលខ្ញុំគ្រប់ពេល កាលពីខ្ញុំរស់នៅក្នុងគុកភ្ជូមិវាល។"]។

[2250] ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527103 ["គេឲ្យខ្ញុំធ្វើស្រែ និងធ្វើការយូរម៉ោង ក្នុងអំពេលនោះគេសង្កេតខ្ញុំ និងបញ្ជាក់ថាខ្ញុំពិតជាអ្នកស្រែមែន។ [...] នៅពេលដែលយើងខិតខំធ្វើការយ៉ាងលំបាកនៅក្នុងវាលស្រែ មន្ត្រីខ្មែរក្រហមអង្គុយនៅលើទីទួល ហើយបើសិនជានរណាម្នាក់មិនសកម្មការងារ ឬសំរាកពីការងារនោះ គេស្រែកដាក់ និងគំរាម។ ប្រសិនបើគេនៅតែមិនសកម្មទៀត គេនឹងបាញ់ចោល។ រឿងនេះបង្ខំឲ្យយើងធ្វើការកាន់តែខ្លាំងឡើងថែមទៀត។ អ្នកដែលត្រូវបានគេបាញ់សម្លាប់ត្រូវបានបោះចោលក្នុងព្រៃដោយមិនមានពិធីបញ្ចុះសពត្រឹមត្រូវនោះទេ។"]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136 ["នៅពេលថ្ងៃ យើងត្រូវទៅធ្វើស្រែ នៅក្រោមការយាមកាមដោយឈ្លបខ្មែរក្រហមមានកាន់កាំភ្លើង។"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៥១ KH 00955714។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.៨៥-៨៦ KH 01034504-05។ ឯកសារ D5/640 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សំ ឡេង KH 00529856 ["ជាប់នៅទីនោះរយៈពេលបីខែពួកយើងត្រូវឈ្លបវាយធ្វើបាប និងបង្ខំឲ្យធ្វើការជារាងរាល់ថ្ងៃ។"]។

[2251] ឯកសារ D5/640 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សំ ឡេង KH 00529856 ["តាម៉ើ និង តាសាន់ លើកដីមិនបានពីរគីបត្រូវឈ្លបឈ្នោះ វ៉ន វាយនឹងដំបងប៉ុនកំភួនដៃសន្លប់មួយថ្ងៃពីរដង។"]។

កប់សព កប់សាកសព រែកទឹក និងជីកដី[2252]។ សូម្បីតែអ្នកទោសជាកូនក្មេងក៏ត្រូវធ្វើការមិនឈប់ដែរ និងត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកតែមួយភ្លែតប៉ុណ្ណោះដើម្បីហូបបបរ[2253]។

ការធ្វើទារុណកម្ម

626. ភូមិវាលគឺជា "កន្លែងធ្វើទារុណកម្មខ្លាំង"[2254]។ អ្នកទោសដែលនៅរស់រានមានជីវិតបានរៀបរាប់ជាលម្អិតអំពីរបៀបដែលពួកគេត្រូវបានដាក់ដោយចេតនាឲ្យស្ថិតក្រោមការឈឺចាប់ និងទុក្ខវេទនា

[2252] ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីន្ធន ឆ.១៧ KH 01067988 ["គេបង្ខំបងប្រុសរបស់ខ្ញុំឲ្យគាស់គល់ឈើ ជីករណ្តៅ គាត់មានរូបរាងស្គមស្គាំង។ [...] មានមនុស្សរាប់រយរាប់ពាន់ត្រូវគេបង្ខំឲ្យធ្វើការនៅទីនោះ"]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ EN 00388621 ["ខ្ញុំខ្លួនឯងត្រូវបានចាត់តាំងឲ្យជីករណ្តៅ ដើម្បីកប់អ្នកទោសទាំងអស់ដែលត្រូវបានសម្លាប់។ [...] ខ្ញុំត្រូវរង់ចាំនៅចម្ងាយ ២០ ទៅ ៣០ ម៉ែត ពីកន្លែងសម្លាប់ រួចបន្ទាប់មក ទើបគេហៅខ្ញុំឲ្យទៅលុបរណ្តៅ [សពទាំងនោះ]។"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១០៩ EN 00955720។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយចឹក យ៉ីន ឆ.១១ KH 00955694 [*បានបញ្ជាក់លើពាក្យសុំតាំងខ្លួនរបស់គាត់* ឯកសារ D5/61 ថាពួកគេត្រូវបានបង្ខំឲ្យធ្វើម្ហូប សម្អាត លាងចាន និងធ្វើស្រែ នៅពេលគាត់ជាអ្នកទោសនៅគុកភូមិវាល]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៥៥ KH 00955733។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់ របស់ គឹម សូរ EN 00527102 ["គេបង្ខំ [យើង] ឲ្យសម្អាត និងចំអិនម្ហូប"] EN 00527103 ["ក្នុងខែសីហា ឆ្នាំ១៩៧៨ គេឲ្យខ្ញុំធ្វើការសាកល្បងមួយ។ ដោយសារតែខ្ញុំចេះតែប្រាប់ពួកគេថាខ្ញុំជាកសិករធម្មតានោះ គេបានឲ្យខ្ញុំទៅវាលស្រែដើម្បីបង្ហាញថាខ្ញុំអាចដាំស្រូវបាន។ គេឲ្យខ្ញុំស្ទូងស្រូវ និងធ្វើការយូរម៉ោង"] EN 00527103 ["នៅពេលគេឲ្យពួកយើងទាំងអស់គ្នាដែលនៅបន្ទប់ឃុំឃាំងចេញទៅធ្វើការនោះ យើងត្រូវដើរជាជួរត្រង់ ហើយបើសិនជាយើងចេញក្រៅជួរ យើងនឹងត្រូវគេសម្លាប់ចោល។ បើសិនជានរណាម្នាក់នៅក្នុងជួរដួល ឬត្រូវគេគិតថាខ្ជិលនោះ គេនឹងបាញ់សម្លាប់យើងចោល។"] ការរៀបរាប់របស់ ឈុន មាន EN 00527089 ["ខ្ញែរក្រោមជាច្រើន [ត្រូវគេ] ដាក់ក្នុងគុក និងបង្ខំឲ្យធ្វើការជាទម្ងន់"]។ ឯកសារ D5/640 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សំ ឡេង KH 00529856 ["ឈ្មោះ ហៀ ប ជ ានប្រើឲ្យរែកទឹកក្នុងមួយនាក់បីពាង សល់ពីរែកទឹកជីកដី ១នាក់ ២គីប។"]។

[2253] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៣៤ KH 00985417 ["ខ្ញុំឃើញមានកូនក្មេងខ្លះត្រូវគេឃុំនៅមន្ទីរសន្តិសុខនៅភូមិវាល។ គេឲ្យកាប់ពើក អូសកំណ្ចោកយកមកធ្វើជីវជាដើម។ ហើយគេឲ្យកូនក្មេងទាំងនោះធ្វើការរហូត ដោយសម្រាកតែបន្តិចដើម្បីហូបបបរប៉ុណ្ណោះ។"]។ *សូមមើលផងដែរ* ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.៨៨ KH 01034505 ["កានបានឲ្យខ្ញុំទៅបង្រៀនកុមារដែលជាកូនរបស់យោធា និងកុមារដែលរួចពីមន្ទីរភូមិវាលនេះ។ គេឲ្យខ្ញុំបង្រៀននៅពេលព្រឹក ហើយពេលថ្ងៃដឹកនាំក្មេងទាំងអស់នោះធ្វើជីវ។ ខ្ញុំបង្រៀនក្មេង១នេះនៅអំឡុងឆ្នាំ១៩៧៨។"]។ *ក៥ សម្គាល់ថា* ការអះអាងរបស់គាត់ថា ក្មេង១ទាំងនេះអាយុពី៦ ទៅ១២ ឆ្នាំ"រួចពីទោសហើយ" (*សូមមើល* ឆ.៩៥-៩៦ KH 01034506)។

[2254] ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ហៅ ត្រូហ៊ីន ឆ.៣២ KH 00979033។

ធ្ងន់ធ្ងរនៅក្នុងគុកនោះ[2255]។ ក្នុងអំឡុងពេលវគ្គសួរចម្លើយជាលក្ខណៈបុគ្គល[2256] អំពើទារុណកម្ម ត្រូវបានប្រើប្រាស់ដើម្បីទាញយកព័ត៌មានអំពី "ខ្សែខ្មាំង"[2257]។ គឹម សូរ បានរំឭកឡើងវិញពីការដែលគាត់ត្រូវបានគេសួរចម្លើយ និងធ្វើទារុណកម្មជាងបីសប្តាហ៍ នៅពេលគាត់បានជាប់ឃុំជាលើកដំបូង ហើយពេលខ្លះគាត់ក៏ត្រូវបានគេវាយដំនឹងដំបងរហូតដល់គាត់ដួលសន្លប់ ឬមិនអាចដើររួច និងជួនកាលទៀតក៏ត្រូវគេធ្វើតាមទម្រង់"រុំ ក និង ក្បាលជាមួយថង់ប្លាស្ទិកហើយចាក់ទឹកចូលដើម្បីឲ្យថប់ដង្ហើម" និងជួនកាលទៀតត្រូវគេឆក់នឹងខ្សែភ្លើង[2258]។ គាត់ឲ្យតម្លៃនៃការរស់រានមានជីវិត

[2255] ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៥៦-៥៩KH 00955733។ ឯកសារ D5/161 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចាប ខ្ជង KH 00358253 ["ពួកខ្មែរក្រហមធ្វើឲ្យខ្ញុំមានរបួសជើង និងក្បាល ជាច្រើនកន្លែងពេលដែលវាធ្វើទារុណកម្មម្តងៗ។"]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136 ["នៅពេលដែលខ្ញុំមកដល់មន្ទីរឃុំឃាំងនេះ ខ្ញុំត្រូវបានសួរចម្លើយ ៣ដង ដោយមិត្តកាន និងមិត្តកន និងត្រូវធ្វើ ទារុណកម្មដោយមិត្តថុល និងមិត្តតន។"]។ *សូមមើលផងដែរ* ឯកសារ D5/1443 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នេត ផង់ EN 01135411 ["ពួកវា [ខ្មែរក្រហម] បានចាប់ អ្នកយន ទៅដាក់គុកនៅភូមិវាល ឃុំតាណោ។ ក្នុងពន្ធនាគារពួកវាធ្វើទារុណកម្មគ្រប់យ៉ាង"]។

[2256] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤៨ KH 00955713 ["សួរចម្លើយគឺសួរខុសៗគ្នា។"]។

[2257] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៥៦-៥៧ KH 00955733 ["គេសួរចម្លើយខ្ញុំក្នុងមួយថ្ងៃពីរដងក៏មាន។ គេវៃ ហើយឆក់ខ្សែភ្លើងមកលើខ្ញុំ។ គេសួរខ្ញុំថា ចង់បះបោរ ឬក៏ជាប់ខ្សែរបស់តាវ៉ាញ។ [...] គេវៃខ្ញុំរាល់ថ្ងៃ។ ប្រសិនបើប្រជាជនធ្មតាទៅជាប់គុកនៅទីនោះមិនអីទេ ប៉ុន្តែដោយសារខ្ញុំលួចរត់ ហើយគេចោទខ្ញុំថាជាប់ខ្សែ តាវ៉ាញ។"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤៧ KH 00955713 ["ស៖ តាមអ្វីដែលលោកបានឆ្លើយពីមុន [D118/147.1.43] លោកបានឆ្លើយថា 'ភាគច្រើនគឺគេសួរបួនសំណួរ ទី១ តើលោកនៅឯណាមុនរបបខ្មែរក្រហម? ទី២ ហេតុអ្វីបានជាលោកនិយាយរដឹន? ទី៣ បើសិនជាលោកជាខ្មែរក្រោម តើមានទំនាក់ទំនងជាមួយវៀតណាមដែរឬទេ? ទី៤ តើមានមនុស្ស ប៉ុន្មាននាក់នៅក្នុងក្រុមគិញនេះ?។ តើលោកទទួលស្គាល់នូវពាក្យសំដីទាំងអស់នេះ ឬទេ? ឆ.៤៧៖ បាទ គឺខ្ញុំបាននិយាយតាំងពីដំបូង។"]។

[2258] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤៦ KH 00955713 ["គេសួរចម្លើយច្រើនដង។ ដំបូងគេសួររបៀបផ្ទេមណ្ណេមជាមួយយើង នៅពេលដែលយើងមិនធ្លើយតាមការចង់បានរបស់គេ គឺគេនឹងធ្វើទារុណកម្មយើង។ ទារុណកម្មដែលខ្ញុំមិនអាចបំភ្លេចបានគឺមានបី វាយនឹងដំបង រុំក និងក្បាលជាមួយថង់ផ្លាស្ទិកហើយចាក់ទឹកចូលដើម្បីឲ្យថប់ដង្ហើម និងទីបីគឺឆក់ខ្សែភ្លើង។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527101 ["មុនពេលសួរចម្លើយខ្ញុំ គេវៃខ្ញុំដោយដំបងធំមួយ ខណៈដែលដៃទាំងពីរបស់ខ្ញុំត្រូវចងទៅក្រោយ។ គេក៏វៃកែងដៃរបស់ខ្ញុំដែរ។ ខ្ញុំនៅមានស្នាមលើកែងដៃដោយសារការវៃនេះ។ ខ្ញុំបានឆ្លើយថា 'ទេ' ទៅកាន់សំណួរទាំងអស់របស់ពួកគេ ហើយពួកគេបានវាយខ្ញុំទៀតនៅកន្លែងដដែលទាំងនោះ។ ថ្ងៃធម្មតានោះគឺនៅពេលព្រឹក ក្រោយពេលអាហារពេលព្រឹក ពួកគេនឹងវៃខ្ញុំ ក្រោយមកទៀត គេនឹងសួរសំណួរខ្ញុំ។ បើសិនជាគ្មានចម្លើយទេនោះ គេនឹងវៃខ្ញុំទៀត បន្ទាប់មកគេក៏ឈប់វៃខ្ញុំបីថ្ងៃ ហើយគេដាក់ខ្ញុំឃុំដាច់ពីគេ។ ក្រោយមកទៀត ពួកគេត្រឡប់មកវិញ ហើយរុំក និងក្បាលខ្ញុំដោយថង់ផ្លាស្ទិកហើយដាក់ទឹកចូល

របស់គាត់ដោយសារការមិន"សារភាព" ចំពោះការសួរសំណួរដដែលៗរបស់អ្នកសួរចម្លើយអំពីខ្មែរក្រោម និងអ្នកជាប់ "ខ្សែបណ្តាញ"របស់គាត់ - អ្នកទោសណាដែល "បានធ្លើយសារភាព" នឹងត្រូវគេយកទៅសម្លាប់ចោលនៅពេលក្រោយមក[2259]។ ចាប ខ្ជង បានរៀបរាប់អំពីខ្លួនគាត់ដែលត្រូវបានសួរចម្លើយពីរដងក្នុងមួយថ្ងៃ អស់រយៈពេល១០ថ្ងៃ សួរដោយមន្ត្រីគុកអំពីខ្សែតាវ៉ាញ ដែលគាត់ត្រូវបានយោធាកូនក្មេងតូចៗវ៉ៃ និងឆក់នឹងខ្សែភ្លើង[2260]។ គាត់ក៏មិនបានធ្លើយសារភាពដែរ។ ផ្ទុយទៅវិញ "ខ្ញុំធ្វើពុតជាមនុស្សគ គេវ៉ៃខ្ញុំយ៉ាងម៉េចក៏ខ្ញុំមិននិយាយ ហើយបើខ្ញុំហ៊ានស្រែកអូយតែមួយមាត់ ធ្លាស់ជាងាប់មិនខាន"[2261]។

627. អ្នកទោសស្រីខ្លះនៅភូមិវាល ក៏បានជួបនូវទម្រង់នៃការធ្វើទារុណកម្មប្រភេទមួយផ្សេងទៀតដែរ - គឺការរំលោភសេពសន្ថវៈដោយអ្នកចាប់ពួកគេ[2262]។ ប្រធានគុកឈ្មោះ កន តែងតែបង្ខំមនុស្សស្រី

ដើម្បីឲ្យថប់ដង្ហើមរហូតទាល់តែខ្ញុំសន្លប់។ បន្ទាប់មកគេនឹងចាក់ទឹកលើខ្ញុំនៅពេលដែលគេសួរចម្លើយខ្ញុំ។ គេចោទខ្ញុំថាជាគិញវៀតណាម។ ខ្ញុំប្រាប់គេថាខ្ញុំមិនដែលបានជួបជនជាតិវៀតណាមទេ ក្នុងមួយជីវិតខ្ញុំនេះពីមុនមក ហើយមិនបានដឹងអំពីសកម្មភាពរបស់ពួកគេឡើយ។ [...] គេប្រើវិធីដដែលនេះទៅលើអ្នកទោសខ្មែរក្រោមទាំងអស់ មិនមែនតែចំពោះខ្ញុំនោះទេ។ ដំណាក់កាលចុងក្រោយ ក្រោយពីរុំក និងក្បាលដោយថង់ផ្លាស្ទិកហើយដាក់ទឹកចូលដើម្បីឲ្យថប់ដង្ហើម នៅពេលដែលអ្នកសន្លប់ហើយដឹងខ្លួនឡើងវិញនោះ ខណៈដែលរាងកាយរបស់អ្នកទទឹកនោះ គេឆក់ខ្សែភ្លើងខ្ញុំ។"]។ ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គឹម សូរ EN 00384366 ["ខ្ញុំបានឃើញផ្ទាល់ភ្នែក ពួកវាធ្វើទារុណកម្មមកលើអ្នកទោសផ្សេងទៀត គឺវាវាយធ្វើបាបពុំមានត្រាប្រណីឡើយ។ វាវាយនឹងដំបងលើក្បាល ខ្នង ដើងដៃ តាមតែវាចង់វាយ។ វាឆក់ខ្សែភ្លើង និងរុំកសំពត់ភ្លៀង ឲ្យធ្លើយនូវចម្លើយដែលពួកវាចង់បាន។"]។

[2259] ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527101 ["ខ្ញុំត្រូវបានសង្គ្រោះដោយអ្នកទោសចំណាស់ម្នាក់ទៀត នៅក្នុងគុកនោះ ដែលបានប្រាប់ខ្ញុំថា៖ កុំផ្តល់ចម្លើយខុស។ ប្រសិនបើអ្នកផ្តល់ចម្លើយខុស គេនឹងចោទអ្នក ឲ្យអ្នកចុះហត្ថលេខាលើវា ហើយក្រោយមកគេនឹងសម្លាប់អ្នក។ ដូច្នេះអត់ទ្រាំវាឲ្យអស់លទ្ធភាព អត់ទ្រាំ ហើយនៅតែធ្លើយថាទេទៅកាន់សំណួរទាំងអស់របស់គេ។ កុំឲ្យចម្លើយក្លែងបន្លំទៅគេឲ្យសោះ។ នេះគឺជាវិធីតែមួយគត់ដែលខ្ញុំអាចរួចជីវិតបាន។ ខ្ញុំនៅតែធ្លើយថា 'ទេ។'"]។

[2260] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៥៦-៥៨ KH 00955733។

[2261] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៨០ KH 00955736។ *សូមមើលផងដែរ* ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៨២-៨៣ KH 00955736។ ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ៀន ឆ.៩១ KH 00990658។

[2262] ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385137 ["អ្នកទោសស្រីក៏ត្រូវបានធ្វើទារុណកម្មមុនទីងសម្លាប់។ ខ្លះទៀតត្រូវបានគេរំលោភ។ សម្លៀកបំពាក់របស់ពួកគេត្រូវបានដោះចេញពីខ្លួន មុនពេលពួកគេត្រូវបានសម្លាប់។ [...] ខ្ញុំបានឃើញនារីពីរនាក់ត្រូវបានរំលោភដោយឈ្មោះ កន និង តន នៅពេលយប់ ដោយផ្ទាល់ភ្នែក។ ព្រឹត្តិការណ៍នេះបានកើតឡើងនៅក្រៅមន្ទីរឃុំឃាំងជិតកន្លែងសម្លាប់មនុស្ស ពេលនោះខ្ញុំនៅទីនោះ ពីព្រោះខ្ញុំត្រូវរង់ចាំកប់សាកសព។"]។

ក្មេងពីរនាក់ឲ្យងូតទឹកជាមួយគាត់ ហើយបានរំលោភពួកគេ "ជាច្រើនដង"[2263]។ ចុងបញ្ចប់គាត់ក៏បានយកពួកនាងៗទាំងនោះទៅសម្លាប់ចោលពេលដែលបែកការណ៍ ប៉ុន្តែមិនដែលមានភ័ស្តុតាងណាមួយបង្ហាញថា គាត់ត្រូវបានផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មរបស់គាត់ឡើយ គេគ្រាន់តែឲ្យ "តាមដាន" ប៉ុណ្ណោះ[2264]។ កម្មាភិបាលផ្សេងទៀតនៅភូមិវាល បានយកបូស្សី ឬម្រាមជើងទៅបុកទ្វារមាសរបស់អ្នកទោសស្រីមុននឹងសម្លាប់ពួកគេ[2265]។ គឹម សូរ បានរំឭកពីរបៀបដែលអ្នកទោសនៅភូមវាលពីរនាក់ត្រូវបានរំលោភដោយអ្នកចាប់ពួកនាង និងការយំអង្វរករយ៉ាងខ្លាំងរហូតដល់ពេលពួកគេត្រូវបានសម្លាប់[2266]។

[2263] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឯ.១១៣-១១៥ KH 00955721។

[2264] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឯ.១១៣-១១៥ KH 00955721 ["មានមនុស្សស្រីពីរនាក់ជាអ្នកដាំបាយនៅក្នុងគុកនោះ ហើយប្រធានគុក មិត្តកន ជាអ្នកចាប់រំលោភ ដល់ពេលដែលបែកការណ៍ ក៏យកទោសសម្លាប់។ [...] ខ្ញុំក៏បានសួរទៅមិត្ត ខួង ហេតុអ្វីបានជាមិត្តកន យកស្ត្រីទាំងពីរនាក់នោះទៅសម្លាប់ ហើយមិត្តខួង បានប្រាប់ខ្ញុំអំពីរឿង មិត្តកន ចាប់រំលោភស្ត្រីទាំងពីរនាក់នោះ។ ក្រោយមកទៀត សំអុល ប្រធានយោធាស្រុកជាអ្នកបញ្ជាឲ្យខ្ញុំតាមដាន មិត្តកន។"]។ *សូមមើលផងដែរ* ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខួង KH 00385092 ["ថ្ងៃមួយ ខ្ញុំមានឱកាសបាននិយាយជាមួយនឹងនារី [ខ្មែរក្រោម] ចុងភៅនោះ។ នាងមានឈ្មោះថា វេញ។ នាងបានប្រាប់ខ្ញុំថា នាងត្រូវបានទាហានខ្មែរក្រហមរំលោភ។ ក្រោយមកនាងបានបាត់ខ្លួន ហើយខ្ញុំបានឃើញសាកសពរបស់នាងនៅក្នុងចម្ការដំឡូង ដែលមានចម្ងាយ ៥០ម៉ែត្រពីគុក។"]។

[2265] ឯកសារ D5/1443 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នេត ផង់ KH 01039852 ["ពួកវាបានចាប់ អ្នកយន ទៅដាក់គុកនៅភូមិវាលឃុំតាណេ។ ក្នុងពន្ធនាគាពួកវាធ្វើអទារុណកម្មគ្រប់យ៉ាង ក្រោយមកជនដៃដល់យកបូស្សីដោតតាមប្រដាប់ភេទ ធ្វើទារុណកម្មរហូតដល់ស្លាប់។"]។ ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឹម សូរ KH 00358227 [មុនពេលខ្មែរក្រហមសម្លាប់អ្នកទោស្រីម្នាក់នៅគុកភូមិវាល "ពួកវាយកម្រាមជើងទៅរុកទ្វាមាសរបស់នារី។ [...] ពួកវាលេងសើចអស់ហើយ ពួកវាក៏ទាញកាំបិតអារករម្តងបន្តិចៗ លុះតែដាច់ខ្យល់ស្លាប់។"]។

[2266] ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឹម សូរ KH 00358227-28 ["មិត្តនារីម្នាក់មិនដឹងមានកំហុសអ្វីទេ ពួកវារំលោភម្តងម្នាក់។ ពួកវាចងដៃ ហើយវាចាប់ផ្ទួលមិត្តនារីឲ្យដេកផ្ងារលើមាត់រណ្តៅដែលត្រូវពួកវាសម្លាប់ ពួកវាយកការសម្លាប់ទៅលេងសើចជាល្បែងរបស់វា ពួកវាយកម្រាមជើងទៅរុកទ្វាមាសរបស់នារី ធ្វើឲ្យនាងស្រែកយំ និងអង្វរករយ៉ាងខ្លាំង តែពួកវាពុំបានយកសំណូមពររបស់យើងឡើយ ពួកវាលេងសើចអស់ហើយ ពួកវាក៏ទាញកាំបិតអារករម្តងបន្តិចៗ លុះតែដាច់ខ្យល់ស្លាប់។ រឿងមួយទៀតដែលធ្វើឲ្យរូបខ្ញុំកាន់តែភ័យខ្លាចទៀតនោះ គឺវាចាប់នារីម្នាក់មកពីរោងចក្រ ពួកវាធ្វើទារុណកម្មដូចគ្នានេះដែរ ពេលគេធ្វើបាបខ្លាំង នាងបានស្រែកហៅរកតែព្រះបិតា ព្រះមាតាអើយជួយបុត្រផង ក្នុងពេលនេះមានតែព្រះបិតាទេដែលជួយកូនបាន។ ពាក្យដង្ហើយហៅមិនទាន់ចប់ពីមាត់ផង ពួកវាបានចាប់ដេកផ្ងារអារករសម្លាប់ពុំមានត្រាប្រណីឡើយ។"]។ *សូមមើលផងដែរ* ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385137 [ទាក់ទងនឹងការសម្លាប់អ្នកទោសស្រីពីរនាក់ ក្នុងឆ្នាំ១៩៧៨-នារីម្នាក់មកពីស្រុកកណ្តៀង និងម្នាក់ទៀតជាកម្មករមកពីរោងចក្រ សំសាន ក្នុងស្រុកបាកាន។]។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

628. មានអ្នកទោសតែមួយចំនួនតូចប៉ុណ្ណោះដែលនៅរស់រានមានជីវិតពីភូមិវាល - ចំណែកអ្នកផ្សេងទៀតត្រូវបានសម្លាប់ ឬ បាត់ខ្លួនក្នុងកាលៈទេសៈផ្សេងៗដែលបង្ហាញថា ពួកគេក៏ត្រូវបានសម្លាប់ផងដែរ។ គឹម សូរ បានពិភាក្សាពីរបៀបដែលក្រុមអ្នកទោសជារឿយៗត្រូវបានគេយកនាំចូលមក ហើយពីរបីថ្ងៃក្រោយមកក៏បាត់ខ្លួន[2267] ហើយគាត់បានធ្វើការកត់សម្គាល់ផងដែរថា អ្នកទោសដែលគេចោទ "ធ្វើវិទ្ធង្សនា [...] តែងតែបាត់ខ្លួនក្រោយការសួរចម្លើយចប់"[2268]។ ចាប ខ្ជង បានរៀបរាប់ពីរបៀបដែល យាយរ៉ីម បានបញ្ជូនក្រុមអ្នកជាប់ឃុំនៅភូមិវាល "ត្រឡប់ទៅសហករណ៍របស់គេវិញ" ប៉ុន្តែបានសន្និដ្ឋានថា ពួកគេត្រូវបានសម្លាប់ចោល ដោយសារពួកគេត្រូវបានគេបញ្ជូននៅពេលយប់ ហើយមិនដែលឃើញត្រឡប់មកភូមិរបស់ពួកគេវិញឡើយ[2269]។

629. អ្នកទោសនៅភូមិវាលជាច្រើនបានស្លាប់ដោយសារជំងឺ ឬការបង្អត់អាហារ ដែលបណ្តាលមកពីលក្ខខណ្ឌអមនុស្សធម៌ផ្សេងៗដែលពួកគេត្រូវបានបង្ខំឲ្យទទួលយកនៅក្នុងគុក[2270]។ ប៉ុន្តែ អ្នកទោសមួយចំនួនធំ គឺដាច់ខាតត្រូវតែសម្លាប់ចោលតាមគោលបំណងរបស់គេ។ ការសម្លាប់ដូច្នេះបានកើតមានឡើងជាប្រចាំ រហូតដល់រៀងរាល់ថ្ងៃ នៅក្រោយពួកកម្មាភិបាលនិរតីបានមកកាន់កាប់នៅស្រុកបាកាន[2271]។ អតីតអ្នកទោស គឹម សូរ, ម៉ីក ឃីន និង ចាប ខ្ជង បានផ្តល់ភ័ស្តុតាងយ៉ាងទូលំទូលាយអំពីឧក្រិដ្ឋកម្មទាំងនេះ និងបានបញ្ជាក់បន្ថែមដោយសាក្សីដទៃទៀត។

[2267] ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527101។

[2268] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤៩ KH 00955714។

[2269] ឯកសារD118/125 កំណត់ហេតុស្តាប់ចម្លើយចាប ខ្ជង ឆ.៩២-៩៦ KH 00955737-38 ឆ.១០៦-១០៨ KH 00955739-40 ។

[2270] *សូមមើល* ភ័ស្តុតាងគាំទ្រខាងលើក្នុង V.ខ.៥.ក.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – មន្ទីរសន្តិសុខភូមិវាល – ឧក្រិដ្ឋកម្ម – អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)។

[2271] D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក ឃីន ឆ.២០ KH 00955695 [បញ្ជាក់ថា ក្នុងឆ្នាំ១៩៧៨ មានអ្នកទោសប្រហែលប្រាំពីរទៅប្រាំបីនាក់ ដែលគេយកមកពីមន្ទីរសន្តិសុខភូមិវាល យកមកសម្លាប់រាល់ថ្ងៃ]។ ឆ.៥៥ KH 00955700 ["គេយកអ្នកទោសទៅសម្លាប់រាល់ថ្ងៃ និងដាក់បញ្ចូលអ្នកទោសថ្មីមកវិញ"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤៤ KH 00955712 ["មានអ្នកទោសប្រហែល១០ ទៅ២០នាក់ត្រូវគេយកចេញក្នុងមួយថ្ងៃៗ។"]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៧៣ KH 00955735 ["យ៉ាងហោចណាស់ក៏ប្រាំនាក់ដែរ។"]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់សារុន ឆ.១៦៧ KH 01034515។

630. ជាតួយ៉ាង អ្នកទោសត្រូវបានគេយកទៅសម្លាប់ នៅពេលយប់នៅក្នុងព្រៃជិតមន្ទីរសន្តិសុខនោះ ឬនៅវាលស្រែប៉ែកខាងកើតបរិវេណនោះ[2272]។ រណ្តៅនានាត្រូវបានគេត្រៀមឡើងសម្រាប់វគ្គនៃការសម្លាប់ និងការពិឃាតដែលគេបានធ្វើឡើងនៅតាមគែមមាត់រណ្តៅទាំងនោះដើម្បីឲ្យសាកសពធ្លាក់ចូល ឬអាចរុញទម្លាក់ទៅក្នុងរណ្តៅទាំងនោះ[2273]។ ជាធម្មតា អ្នកទោសត្រូវបានសម្លាប់ដោយដៃ ពួកគេត្រូវបានចងទៅក្រោយ[2274]។ ពេជ្ឈឃាតខ្លះបានប្រើព្រនង់ ដំបង ឬត្បូងចប វាយក្បាលនិង

[2272] ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385137 ["ការសម្លាប់ប្រជាជនទាំង ៥០០នាក់ [...] បានកើតឡើងនៅក្នុងព្រៃមានចម្ងាយប្រហែល ៧០០ម៉ែត្រខាងត្បូងភូមិវាល។"]។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091 ["ខ្ញុំបានឃើញដោយផ្ទាល់ភ្នែកនូវការសម្លាប់ខ្លះ ពីព្រោះយោធាខ្មែរក្រហមបានបង្ខំឲ្យខ្ញុំឈរកាន់ចន្លុះបំភ្លឺឲ្យពួកគេ នៅពេលដែលពួកគេកំពុងសម្លាប់មនុស្សនៅពេលយប់។"]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៧១ KH 00955735 ["ជួនកាលយប់ឡើងអ្នកជាប់ខ្នោះជាមួយគ្នា គេដោះយក ៥ នាក់ចេញទៅ ហើយយកទៅសម្លាប់នៅវាលស្រែ។"] ឆ.៩៨ KH 00955738 ["កន្លែងសម្លាប់អ្នកទោសគឺស្ថិតនៅខាងកើតនៃគុកភូមិវាល។"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៤៤ KH 00955712 ឆ.៦០-៦៣ KH 00955715-16។ ឆ.១០៩ KH 00955720។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក ឃីន ឆ.១៦ KH 00955695 ឆ.៥៧ KH 00955700។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១១៣-១១៤, ១១៧ KH 01034508-09 ឆ.១៤៣ KH 01034512។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ម៉ោះ ម៉ុន EN 00527085 ["មានផ្ទះរាប់រយនៅភូមិវាល (ក្នុងបរិវាណ ៣ x ២ គីឡូម៉ែត្រ) មានទាំងប្រជាជនខ្មែរក្រោម និងប្រជាជនខ្មែរ។ ខ្មែរក្រហមបានប្រើសាកសពជនរងគ្រោះធ្វើជាជីដាក់ស្រែ។"] ការរៀបរាប់របស់ គឹម សូរ EN 00527104 [បានរៀបរាប់អំពីការសម្លាប់អ្នកទោសភូមិភាគបូព៌ាពី ១០០ ទៅ ៣០០នាក់ នៅក្នុងវាលស្រែចំនេរមួយនៅជិតភូមិវាល]។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចឹក ឃីន EN 00427010 ["រណ្តៅកប់សពរួមត្រូវបានបង្កើតឡើងនៅក្នុងភូមិវាល នៅចំកណ្តាលវាលស្រែ។ អ្នកទោសខ្មែរក្រោមត្រូវបានសម្លាប់ជាពិសេសនៅពេលយប់ និងទម្លាក់ចូលទៅក្នុងរណ្តៅនោះ។"]។

[2273] ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៣៦ KH 01034511 ["គេបណ្តើរអ្នកទោសទៅដល់រណ្តៅ រួចហើយក៏រៃសម្លាប់ចោលតែម្តង។"]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136-37 ["បន្ទាប់ពីជីករណ្តៅរួច ខ្ញុំត្រូវរង់ចាំនៅចម្ងាយ ២០ ទៅ ៣០ ម៉ែត្រពីកន្លែងសម្លាប់ រួចបន្ទាប់មក ទើបគេហៅខ្ញុំឲ្យទៅលុបរណ្តៅ [សាកសព]។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527104 [រៀបរាប់អំពីការសម្លាប់អ្នកទោសភូមិភាគបូព៌ាចំនួន ១០០ ទៅ ៣០០នាក់ នៅក្នុងវាលស្រែជិតភូមិវាល៖ "អ្នកយាមខ្មែរក្រហមបានប្រើជំពុះទុងអារបំពង់ករពួកគេ ហើយធាក់ពួកគេទម្លាក់ទៅក្នុងរណ្តៅចំហរទាំងនោះ។"]។

[2274] ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៣៦ KH 01034511។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136-37 ["ខ្ញុំត្រូវរង់ចាំនៅចម្ងាយ ២០ ទៅ ៣០ ម៉ែត្រពីកន្លែងសម្លាប់ រួចបន្ទាប់មក ទើបគេហៅខ្ញុំឲ្យទៅលុបរណ្តៅ [សាកសព]។ ដូច្នេះ ខ្ញុំអាចមើលឃើញសាកសពទាំងអស់នោះដែលត្រូវគេចងដៃទៅក្រោយ។"]។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចឹក ឃីន EN 00427010-11 [ក្នុងឆ្នាំ១៩៧៨៖ "មានមនុស្ស នៅសល់តែ ៤០ ទៅ ៥០ នាក់ ប៉ុណ្ណោះ នៅភូមិវាល ហើយខ្ញុំដឹងច្បាស់ថាវាដល់វេនរបស់ខ្ញុំត្រូវស្លាប់ហើយ។ យើងទាំងអស់គ្នា

> កញ្ជ្រឹងកជនរងគ្រោះ ខណៈដែលពួកពេជ្ឈឃាដខ្លះទៀតប្រើកាំបិត ឬចំពុះទុង ដើម្បីចាក់កជនរងគ្រោះ[2275]។ កុមារក៏ត្រូវបានគេសម្លាប់យ៉ាងឃោរឃៅផងដែរ ជាញឹកញាប់ត្រូវបានគេធ្វើឡើងជាមួយនឹងឪពុកម្តាយរបស់ពួកគេ[2276]។

ត្រូវគេចងភ្ជាប់គ្នានៅក្នុងបន្ទប់ឃុំឃាំងធំមួយ ហើយគេយកយើងទៅកាន់ផ្នែកខាងកើតគុកវាល គឺនៅជិតព្រៃ។ មនុស្ស៤០នាក់ក្នុងចំណោមអ្នកទាំង៥០នាក់ទោះ ភាគច្រើនត្រូវគេវៃពីក្រោយដោយដៃទាំងពីចងទៅក្រោយ។ ពួកគេត្រូវគេវាយត្រង់ក្បាល និងកញ្ជ្រឹងករដោយដំបងឫស្សី ហើយងន្ទាប់មកចាក់ដោយជំពុះទង់កាំភ្លើង M16។"]។ សូមមើលផងដែរ ឯកសារ D5/1647 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ិច គៀត KH 01094108-09 ["ចុងឆ្នាំ១៩៧៨ [...] ពួកខ្មែរក្រហមនៅមន្ទីរឧក្រិដ្ឋកម្មភូមិវាលបានចាប់ចងនាងខ្ញុំ និងពួកនាងខ្ញុំសុទ្ធតែកុមារចងដៃទៅក្រោយ រុញទម្លាក់រណ្តៅទាំងរស់។ ចំណែកនាងខ្ញុំពួកខ្មែរក្រហមបានវាយសម្លាប់មិនចំក្បាល និង ក ត្រូវស្នាយ៉ាងខ្លាំង នាងខ្ញុំក៏ធ្លាក់ក្នុងរណ្តៅទៅ។"]។

[2275] ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385137 ["ជាដំបូង អ្នកទោសទាំងអស់នោះត្រូវបានវៃដោយដំបង រួចត្រូវបានអា ក បន្ដិចម្តងៗរហូតដល់ស្លាប់។"]។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00387496 ["អ្នកទោសខ្លះបន្ទាប់ពីត្រូវបានសួរចម្លើយតែនៅដើររួច ត្រូវបានបញ្ជូនយកទៅសម្លាប់នៅព្រៃយុគ ដែលមានចម្ងាយ ១គីឡូម៉ែត្រពីភូមិវាល។ [...] ខ្ញុំបានឃើញដោយផ្ទាល់នូវការសម្លាប់ខ្លះ ពីព្រោះយោធាខ្មែរក្រហមបានបង្ខំឲ្យខ្ញុំឈរកាន់ចន្លុះបំភ្លឺឲ្យពួកគេ នៅពេលដែលពួកគេកំពុងសម្លាប់មនុស្សនៅពេលយប់។ អ្នកទោសទាំងអស់នោះត្រូវបានគេសម្លាប់ដោយគល់ឫស្សី ឬដោយកាំបិតផ្ដាក់។"]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៣៦ KH 01034511។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៥៨-៥៩ KH 00955715។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន ឆ.២៣ KH 00955696។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហមការរៀបរាប់របស់ គឹម សូរ EN 00527102 ["តន និងក្រុមរបស់គាត់គឺជាអ្នកសម្លាប់មនុស្ស។ [...] ពួកគេជាអ្នកវៃមនុស្សសម្លាប់។ ពួកគេវាយក្បាលអ្នកទោសពីក្រោយ តែមួយដងប៉ុណ្ណោះ។ មានអ្នកយាមពីរប្រភេទ អ្នកមានខ្សែ និងអ្នកមានកាំបិតធំ។ គេវាយអ្នកទោសពីក្រោយ ដៃរបស់គេជាប់ចំណង។ ពួកគេដួលទៅលើដី។ អ្នកខ្លះមិនទាន់ស្លាប់នៅឡើយទេ។ បន្ទាប់មកអ្នកយាមដែលកាន់កាំបិតធំ មកកាត់បំពង់កពួកគេ។"] EN 00527104 ["បន្ទាប់មក តន និង ផុល ប្រើដំបងទាលវាយក្បាល និងកញ្ជ្រឹងកពួកគេ។ បន្ទាប់មកខ្មែរក្រោមបានដួល។ អ្នកយាមសន្ដិសុខខ្មែរក្រហមមួយក្រុមទៀត ប្រើជំពុះទុងអា ក និងធាក់ពួកគេទម្លាក់ចូលទៅក្នុងរណ្តៅចំហរ។"]។ ឯកសារ D5/1323 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អេន អេត KH 01038096 ["មនុស្សចាស់វាវាយត្ងុងចប និងគល់។"]។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចឹក យ៉ីន EN 00427010-11 [ក្នុងឆ្នាំ១៩៧៨៖ "មានមនុស្សនៅសល់តែ ៤០ ទៅ ៥០ នាក់ ប៉ុណ្ណោះ នៅភូមិវាល ហើយខ្ញុំដឹងច្បាស់ថាវាដល់វេនរបស់ខ្ញុំត្រូវស្លាប់ហើយ។ យើងទាំងអស់គ្នាត្រូវគេចងភ្ជាប់គ្នានៅក្នុងបន្ទប់ឃុំឃាំងធំមួយ ហើយគេយកយើងទៅកាន់ផ្នែកខាងកើតគុកវាល គឺនៅជិតព្រៃ។ មនុស្ស៤០នាក់ ក្នុងចំណោមអ្នកទាំង៥០នាក់ទោះ ភាគច្រើនត្រូវគេវៃពីក្រោយដោយដៃទាំងពីចងទៅក្រោយ។ ពួកគេត្រូវគេវាយត្រង់ក្បាល និងកញ្ជ្រឹងករដោយដំបងឫស្សី ហើយងន្ទាប់មកចាក់ដោយជំពុះទង់កាំភ្លើង M16។"]។

[2276] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៦២ KH 00955716 ["ខ្ញុំគ្រាន់តែឮសំឡេងក្មេងៗដែលគេយកទៅសម្លាប់ ហើយប្រែកតែប៉ុណ្ណោះ។ ខ្ញុំបានឮអ្នកដែលសម្លាប់និយាយថា 'អ្ហូអ្ហា! ពិបាកណាស់ក្មេងៗ តាមចាប់ហាត់ណាស់ ចាប់បានត្រង់ណា ចោកត្រង់ហ្នឹង'"]។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន ឆ.៦៥ KH 00955701។ ឯកសារ

631. ក្រោយពីការសម្លាប់រួច អ្នកទោសនិងយោធាត្រូវកប់សាកសព[2277]។ ដោយសារមានសាកសពច្រើន ត្រូវបានគេកប់នៅឯវាលស្រែខាងក្រៅគុក ពលករដែលត្រូវបានគេបង្ខំឲ្យធ្វើស្រែ ក៏ត្រូវធ្វើការងារនៅក្នុងស្ថានភាពដ៏តក់ស្លុតដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី មាស រឿន បានរំឭកថា៖ "គេកប់សាកសពពេញទីនោះ ហើយពេលដែលស្ទូងក៏ជាន់សាកសពទាំងអស់នោះ"[2278]។ ចឹក យឹន ត្រូវបានគេចាត់តាំងឲ្យទៅភ្ជួរស្រែ ហើយនៅពេលព្រឹកបន្ទាប់ពីការសម្លាប់ដែលគេបានធ្វើនៅពេលយប់៖ "ខ្ញុំសង្កេតឃើញទឹកពណ៌ក្រហម ហើយសាកសពក៏អណ្តែតឡើងមកលើ ហើយសាកសពនោះឡើងពណ៌ខៀវ"[2279]។

632. ចំនួនមនុស្សដែលត្រូវបានសម្លាប់នៅភូមិវាល មិនអាចគណនាឲ្យបានច្បាស់លាស់ទេ។ គ្មានកំណត់ត្រាគុកត្រូវបានគេរកឃើញឡើយ ឬសូម្បីតែថាវាធ្លាប់មានក៏គ្មាននរណាដឹងដែរ ចំណែករណ្តៅកប់សាកសព និងសំណល់សាកសពវិញក៏ត្រូវបានធ្វើឲ្យខូចទ្រង់ទ្រាយដើមនៅក្នុងរយៈជាង ៤០ឆ្នាំមក

D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៤៤-១៤៥ KH 01038097។ ឯកសារ D5/1323 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អេន អេត KH 01191233-34 ["បើកូនក្មេងតូចៗ វាចាប់ជើងហើយបោកនឹងដើមឈើ ហើយបៅទៅក្នុងរណ្តៅ ខ្លះស្លាប់ ខ្លះទៀតប្រកាច់ពេញរណ្តៅ។"]។ ឯកសារ D5/1326 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស៊ីន អ៊ីម KH 01038147។ ឯកសារ D5/1327 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ុង ពៀន KH 01038165។ ឯកសារ D5/1339 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សឹម ចយ KH 01049471។ ឯកសារ D5/1346 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុល វ៉ាន់ EN 01049583។ ឯកសារ D5/1647 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ុច គៀត KH 01094108-09។

[2277] ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136-37 [អតីតអ្នកទោស៖ " បន្ទាប់ពីជីករណ្តៅរួច ខ្ញុំត្រូវរង់ចាំនៅចម្ងាយ ២០ ទៅ ៣០ ម៉ែត្រពីកន្លែងសម្លាប់ រួចបន្ទាប់មក ទើបគេហៅខ្ញុំឲ្យទៅលុបរណ្តៅ [សាកសព]។"]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៦៤, ៦៨ KH 00955734-35។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៣៧-១៤១ KH 01034511-12។ ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឹម សូរ KH 00358228 ["រូបខ្ញុំ និងក្រុមអ្នកផ្សេងទៀត វាឲ្យជីករណ្តៅឲ្យពួកវា ពេលសំលាប់ ឲ្យពួកខ្ញុំកប់ទៀត។ ពួកខ្មែរក្រហមវាបានគំរាមថា បើអ្នកណាហានិយាយចេញទៅខាងក្រៅ អញ្ចឹងនឹងសំលាប់ពួកឯងចោលទាំងអស់។ រយៈពេលខ្ញុំរស់នៅមន្ទីរឃុំ ឃាំងភូមិវាល ឃុំតាលោ រូបខ្ញុំពុំបានដឹងអ្វីទាំងអស់ ក្រៅពីការកាប់រណ្តៅ ជាប់ខ្នោះតែប៉ុណ្ណោះ។"]។

[2278] ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រឿន ឆ.៩៦-៩៧ KH 00990658។ *សូមកត់សំគាល់ថា* នេះទំនងជាបានកើតឡើងនៅចុងឆ្នាំ១៩៧៨ (សូមមើល ឆ.៧៣-៧៤ ដែលបង្ហាញថា ពេលនោះគឺគាត់កំពុងស្ទូងស្រូវ ១ខែមុនពេលដែលវៀតណាមចូលមកដល់)។

[2279] ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម, ការរៀបរាប់របស់ ចឹក យឹន EN 00527112 *ដែលបានបញ្ជាក់តាមរយៈ* ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យឹន ឆ.១៨ KH 00955695 *សូមមើលផងដែរ* ឆ.១៩ KH 00955695[*ដែលបញ្ជាក់ថា* មនុស្ស៣០នាក់ភ្ជួរស្រែមួយហ៊ីកតាហើយយើងសង្កេតឃើញដូចគ្នា]។

នេះ[2280]។ យ៉ាងណាមិញ ភ័ស្តុតាងនៅលើសំណុំរឿងបង្ហាញឲ្យឃើញថា ការសម្លាប់បានកើតឡើងនៅគុកនេះយ៉ាងទៀងទាត់ក្នុងពេលដែលពួកកម្មាភិបាលភូមិភាគនិរតី និងភូមិភាគពាយ័ព្យ បានកាន់កាប់ស្រុកបាកាន[2281]។ អតីតអ្នកទោស ចាប ខ្ជង បានប៉ាន់ប្រមាណថា អ្នកទោសប្រាំនាក់ត្រូវបានគេសម្លាប់ជារៀងរាល់ថ្ងៃ ខណៈដែល ចឹក យឹន បានដាក់ការប៉ាន់ប្រមាណអំពីការស្លាប់នៅពេលយប់សរុបចន្លោះពីប្រាំពីរឬប្រាំបីនាក់ ចំណែក គឹម សូរ បានប៉ាន់ស្មានពី ១០ ទៅ២០នាក់[2282]។ ការគណនាតាមការប៉ាន់ស្មានកម្រិតទាបរបស់ ចាប ខ្ជង និងក្របខណ្ឌពេលវេលាបែបអភិរក្សពីពាក់កណ្តាលឆ្នាំ១៩៧៧ រហូតដល់ចុងរបប (១៨ខែ) បង្ហាញឲ្យឃើញថា អ្នកទោសជាង ២,៧០០នាក់ ត្រូវបានគេសម្លាប់[2283]។ ការសម្លាប់រង្គាលក៏បានកើតឡើងផងដែរនៅភូមិវាល និយាយឲ្យចំគឺក្នុងឆ្នាំ១៩៧៨ ពេលដែលអ្នកជម្លៀសភូមិភាគបូព៌ា ត្រូវបានគេបញ្ជូនមកកាន់មន្ទីរសន្តិសុខនេះ[2284] ធ្វើឲ្យចំនួនអ្នកស្លាប់ដែលថាមានចំនួន ២,៧០០នាក់ ឬច្រើនជាងនេះទៀត។ ដោយរួមបញ្ចូលតាមការរៀបរាប់ទាំងអស់នេះសឲ្យឃើញថា មានអ្នកទោសតែ១០ ទៅ២០នាក់ ប៉ុណ្ណោះដែលគេដឹងថានៅ

[2280] ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៥៩ KH 01034513 [សាក្សីបានធ្វើការនៅភូមិវាលក្នុងឆ្នាំ១៩៧៨៖ "ស៖ តើលោកធ្លាប់ឃើញកំណត់ហេតុស្សរចម្លើយអ្នកទោសដែរឬទេ? ឆ.១៥៩៖ អត់ទេ។"]។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ដារ៉ា ហៅ រ៉ា ឆ.៩០-៩១ KH 00973955 ["ខ្ញុំទៅ [ភូមិវាល] ក្រោយរបបខ្មែរក្រហមដើម្បីកាប់ឈើ។ [...] ខ្ញុំបានឃើញផ្ទ្រ ខោអាវ ប៉ុន្តែពុំឃើញមានរណ្តៅនោះទេ ព្រោះទីនោះជាវាល។"]។ ឯកសារ D118/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខភូមិវាល KH 00893187-88 ["អ្នកភូមិម្នាក់បានបញ្ជាក់ថា នៅពេលគាត់បានមកដល់ភូមិនេះក្នុងឆ្នា១៩៨៩ គាត់មិនបានឃើញអគារគេដាក់អ្នកទោសទេ។ គាត់បានឃើញរណ្តៅសាកសពនៅខាងក្រោបរិវេណសាលារៀន ដេលនៅមានសាកសពនៅឡើយ។ អ្នកភូមិរូបនេះមិនអាចបញ្ជាក់ពីចំនួនសាកសពដែលបានរកឃើញនៅក្នុងរណ្តៅនេះ ហើយក៏មិនអាចបញ្ជាក់ពីទំហំនៃរណ្តៅនេះបានដែរ ដោយសារតែដីបានហូរលុបរណ្តៅនេះបាត់អស់ទៅហើយ។"]។

[2281] *សូមមើល* កថាខណ្ឌ ៦២៧-៦៣១ ខាងលើ។

[2282] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៧១-៧២ KH 00955735។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យឹន ឆ.២០ KH 00955695 [*បានបញ្ជាក់* ចម្លើយនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ឯកសារ D5/61]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ ក៏ម សូរ ឆ.៤៤ KH 00955712។

[2283] អ្នកទោស ៥នាក់ ត្រូវបានសម្លាប់ក្នុងមួយយប់ x (១៨០ + ៣៧០) យប់ = ២.៧៥០ អ្នកទោសដែលបានសម្លាប់។

[2284] ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ៀន ឆ.៧៩ KH 00990656 [ទំនងជានៅចុងឆ្នាំ១៩៧៨ (សូមមើល ឆ.៧១-៧៣)៖ "បុរសម្នាក់នៅតាំងក្រសាំងត្រូវគេហៅទៅសម្លាប់មនុស្ស [គុកភូមិវាល] ហើយពេលត្រឡប់មកវិញ គាត់និយាយថា 'យប់មិញសម្លាប់មនុស្ស១០០នាក់ ពេញមួយយប់។' ខ្ញុំបានឃើញគាត់យកប្រម៉ាត់យកមកដាក់ហាលពេញលើការ៉ូដែលមានទំហំមួយម៉ែត្រប្លែនជ្រុង។"] ឆ.៨១ KH 00990656។ *សូមមើលផងដែរ* កថាខណ្ឌ ២២៩៥។

រស់រានមានជីវិតពីគុកនេះ[2285] និងសាក្សីជាច្រើនដែលបង្ហាញពីចំណុចមានប្រៀបខុសៗគ្នាជាច្រើនបានរៀបរាប់អំពីរណ្តៅកប់សពជាច្រើនដែលមានសាកសពពេញ[2286]។ តាមស្មារតីនៃភ័ស្តុតាងទាំងអស់នេះ ជាការសមហេតុផលក្នុងការសន្និដ្ឋានថា មានមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅភូមិវាល ក្នុងការពន្លឿនសហឧក្រដ្ឋិកម្មរួមរបស់ភូមិភាគនិរតីដែលមាន **យ៉ីម ទិព្ធ** ជាអ្នកចូលរួមច្រើនជាងគេ។

[2285] ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៦១-១៦២ KH 01034514 ["ឆ.១៦១៖ [...] អ្នកទោសភាគច្រើនត្រូវស្លាប់។ ស៖ តាមលោកដឹង អ្នកដែលរួចរស់ពីមន្ទីរសន្តិសុខភូមិវាលមានតិចតួចណាស់ តើត្រឹមត្រូវដែរឬទេ? ឆ.១៦២៖ បាទ ត្រឹមត្រូវ។ លុះត្រាតែអ្នកនោះមានសុខភាពល្អណាស់ ហើយអាចធ្វើការងារបាន ទើបអាចនៅរស់។"]។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចឹក យ៉ីន EN 00427011 ["មានតែពួកយើងប្រហែលជា ២០នាក់ ប៉ុណ្ណោះនៅសល់ (ក្នុងចំណោមអ្នកទោសគុកភូមិវាល) ដែលមិនត្រូវបានសម្លាប់។ ក្នុងក្រុមនេះ ១៨នាក់ជាខ្មែរ និង ២នាក់ប៉ុណ្ណោះជាខ្មែរក្រោម។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527105 ["មានតែ ១០នាក់ ប៉ុណ្ណោះរួចជីវិតពីគុកភូមិវាល"]។

[2286] *សូមមើល ឧទាហរណ៍* ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន ឆ.៥៧-៥៨ KH 00955700 ["ស៖ តើលោកអាចស្មានបានដែរឬទេ មានអ្នកទោសយកទៅសម្លាប់ប៉ុន្មាន? ហើយដាក់ថ្មីចូលប៉ុន្មាន? ឆ.៥៧៖ ខ្ញុំមិនអាចរាប់បានទេ ច្រើនណាស់ គេសម្លាប់ដាក់ក្នុងព្រៃមួយពេញហើយ គេសម្លាប់ដាក់ក្នុងវាលស្រែទៀត។ ស៖តើលោកអាចស្មានបានដែរឬទេ? ឆ.៥៨៖ ច្រើនណាស់ប្រហែលជារាប់ពាន់។"] ឆ.១៦ KH 00955695 ["[រណ្តៅសពរួមនៅក្នុងភូមិវាល] នៅក្នុងវាលស្រែមួយដែលមានក្បាលដី ៣០០ម៉ែត្រ បណ្តោយ ៥០០ម៉ែត្រ ហើយគេជីករណ្តៅ ១០ម៉ែត្រមួយៗ ដោយក្នុងមួយរណ្តៅគេកប់មនុស្សម្នាក់។ [...] នៅក្នុងព្រៃទើបមានមនុស្សច្រើនត្រូវគេសម្លាប់ដាក់ចូល។"] ឆ.១៨-១៩ KH 00955695។ ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ៀន ឆ.៩៦-៩៧ KH 00990658។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៦៧-៦៨ KH 00955734-35 ["ឆ.៦៧៖ [...] អ្នកបូព៌ាត្រូវបានបញ្ជូនមកដល់គុកភូមិវាល [...] ពួកគេយកអ្នកទាំងនោះទៅសម្លាប់ ទើបមានសាកសពពាសពេញអាងតែម្តង។ ស៖ តើហេតុអ្វីបានជាលោកដឹងថាមានចំនួន ១៧០០នាក់? ឆ.៦៨៖ ខ្ញុំអង្គុយរាប់"]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១៣៦-១៤១ KH 01034511-12។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចឹក យ៉ីន EN 00427010 ["រណ្តៅកប់សពរួមត្រូវបានបង្កើតឡើងនៅក្នុងភូមិវាលនៅចំកណ្តាលវាលស្រែ។ អ្នកទោសខ្មែរក្រោម ត្រូវបានសម្លាប់ជាពិសេសនៅពេលយប់ និងទម្លាក់ចូលទៅក្នុងរណ្តៅនោះ។"]។ ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឹម សូរ KH 00358228 ["រូបខ្ញុំ និងក្រុមអ្នកផ្សេងទៀត វាឲ្យជីករណ្តៅឲ្យពួកវា ពេលសំលាប់ ឲ្យពួកខ្ញុំកប់ទៀត។ [...] រយៈពេលខ្ញុំរស់នៅមន្ទីរឃុំឃាំងភូមិវាល [...] រូបខ្ញុំពុំបានដឹងអ្វីទាំងអស់ ក្រៅពីការកាប់រណ្តៅ ជាប់ខ្នោះតែប៉ុណ្ណោះ។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ម៉ោ ម៉ុន EN 00527085 ["មានរណ្តៅកប់សពរាប់រយរណ្តៅ នៅភូមិវាល (ក្នុងបរិវេណ ៣ x ២ គីឡូម៉ែត្រ) មានទាំងខ្មែរក្រោម និងប្រជាជនខ្មែរ។ ខ្មែរក្រហមបានប្រើសាកសពជនរងគ្រោះធ្វើជាជីដាក់ស្រែ។"]។

ការធ្វើទុក្ខបុកម្នេញ

ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះខ្មែរក្រោម

633. ក្រោយពួកកម្មាភិបាលភូមិភាគនិរតីបានចូលមកត្រួតត្រាស្រុកបាកាន ពួកគេបានកំណត់គោលដៅ និងចាប់ខ្លួនខ្មែរក្រោមជាប្រព័ន្ធនៅក្នុងតំបន់នោះ ដោយសារតែគោលគំនិតរបស់ ប.ក.ក ដែលថា ខ្មែរក្រោម មានសម្ព័ន្ធភាពជាមួយវៀតណាម[2287]។ ភាគច្រើននៃអ្នកដែលគេបានចាប់ខ្លួនទាំងនោះ ត្រូវបានគេដាក់ក្នុងមន្ទីរឃុំឃាំងក្រៅប្រព័ន្ធតុលាការនៅភូមិវាល ដែលជាតួយ៉ាងពួកគេត្រូវបានគេ

[2287] *សូមមើលឧទាហរណ៍* ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅយាយរ៉ីម ឆ.៨៣ KH 01347276 ។ ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ហៅ សន សៀម ឆ.២០ KH 00872599។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១២-១១៧ KH 01068142-42 ឆ.១២១, ១២៣-១៣១ KH 01068144-45។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៨៦-៨៧ KH 00955737 ["ស៖ ក្នុងរបបខ្មែរក្រហម តើគេសម្រាំងរកខ្មែរក្រោមមែនទេ? ឆ.៨៦៖ បាទ គេគិតថាជាយួន។ ស៖ តើគេធ្វើដូចម្តេចដើម្បីដឹងថាជាខ្មែរក្រោម? ឆ៖៨៧៖ គេដឹងតាមរយៈ:ឪពុកម្តាយថាអ្នកណាជាខ្មែរក្រោម ឬក៏ខ្មែរលើ ព្រោះអ្នកក្នុងភូមិគឺស្គាល់គ្នា។"]។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385092 ["ខ្មែរកម្ពុជាក្រោមជាគោលដៅនៃការចាប់ខ្លួន ព្រោះពួកគេត្រូវបានចោទថាជា "យួន" [វៀតណាម]។"]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385135 ["ពួកខ្មែរក្រហមបានចាប់ផ្តើមចម្រាញ់ប្រជាជន ដើម្បីស្វែងរកខ្មែរកម្ពុជាក្រោម ដែលគេចោទប្រកាន់ថាជា 'ខ្សែយួន'"។]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១២៣ KH 01034510។ ឯកសារ D240R វីដេអូ *សត្រូវរបស់ប្រជាជន ខ្សែវីដេអូខ្លីបង្ហែម៖ ឃួន រៀបរាប់អំពីផែនការ ឆ្នាំ២០១០ ម៉ោង* ១០:០០-៣:៥៨ [ផាន ឃន និយាយថា គាត់បានទៅចូលរួមក្នុងការប្រជុំមួយនៅមន្ទីរស្រុក ដែលតាផែង "បានប្រាប់យើងថាមានផែនការពីថ្នាក់លើមក ឲ្យបោសម្អាតអ្នកកម្ពុជាក្រោម" ហើយពួកគេមានពេលមួយសប្តាហ៍ដើម្បីសម្លាប់ខ្មែរក្រោមទាំងអស់]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527101 ["មានខ្មែរក្រោមជាច្រើន [នៅគុកភូមិវាល] អ្នកទាំងនោះ រួមទាំងខ្ញុំ ត្រូវបានគេចោទថាជាគិញវៀតណាម។ [...] ខ្ញុំបានជួបខ្មែរក្រោមជាច្រើនមកពីកងចលនទផ្ទាល់របស់ខ្ញុំ ក៏ដូចជាខ្មែរក្រោមផ្សេងមកពីឃុំ និងភូមិដែលខ្ញុំបានរៀបរាប់។"] EN 00527103 ["យោធានៅក្នុងគុកបានប្រាប់ខ្ញុំថា ខ្មែរក្រោមទាំងអស់នៅក្នុងភូមិ ដែលខ្ញុំបានរៀបរាប់ខាងដើមត្រូវបានសម្លាប់ ឬបញ្ជូនទៅគុកភូមិវាល។"] ការរៀបរាប់របស់ ចឹក យ៉ីន EN 00527112 ["អ្នកទោសថ្មីត្រូវបានប្រមូល និងចាប់មកពីឃុំផ្សេងៗឃុំផ្សេងៗ និងយកមកកាន់គុកភូមិវាល ដោយសង្ស័យថាជាគិញវៀតណាម ឬអ្នកគាំទ្ររបប លន់ នល់។ ភាគច្រើននៃអ្នកទោសទាំងនេះគឺជាខ្មែរក្រោម។"] ការរៀបរាប់របស់ ចឹក ប៊ុនរ៉ឿន EN 00527113 ["ឪពុករបស់ខ្ញុំត្រូវបានចាប់ខ្លួនដោយយោធាខ្មែរក្រម និងត្រូវបានឃុំខ្លួនរហូតដល់ឆ្នាំ១៩៧៩ នៅក្នុងគុកភូមិវាល ឃុំវាល ស្រុកបាកាន ខេត្តពោធិ៍សាត់។ [...] ទោះបីជាឪពុករបស់ខ្ញុំមិនមែនជាខ្មែរក្រោម ឬវៀតណាមក្តី គេសង្ស័យគាត់មានទំនាក់ទំនងជាមួយពួកគេ"]។ *សូមមើលផងដែរ* V.គ.៦.ខ . ឧក្រិដ្ឋកម្ម– ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម នៅភូមិភាគពាយ័ព្យ – ការប្រព្រឹត្ត ចំពោះជនជាតិវៀតណាម និងខ្មែរក្រោម ក្នុងតំបន់ ២ ១៩៧៧-១០៧៩។ V.គ.៣.ក. ឧក្រិដ្ឋកម្ម– ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – គោលនយោបាយ បកក ដើម្បីកម្ទេចជនជាតិវៀតណាម – អរិភាពរបស់ បកក ចំពោះវៀតណាម និង ខ្មែរក្រោម។

សួរចម្លើយរកព័ត៌មានអំពីខ្សែរៀតណាមតាមដែលគេយល់ឃើញ ហើយបន្ទាប់មកក៏សម្លាប់ចោល[2288]។ គឹម សូរ ដែលធ្លាប់ទទួលរងការធ្វើទារុណកម្មយ៉ាងឃោរឃៅនៅក្នុងពេលសួរចម្លើយ ដោយសារពួកមន្ត្រីមានការសង្ស័យទៅលើរូបគាត់ថាជាខ្មែរក្រោមនិងជាផ្នែកនៃខ្សែក្បត់[2289] បានរាយការណ៍ថា "កលល្បិចដូចគ្នាត្រូវបានគេប្រើប្រឆាំងគ្រប់ខ្មែរក្រោមទាំងអស់ មិនមែនតែខ្ញុំម្នាក់ទេ"[2290]។ ការធ្វើដូច្នេះបណ្តាលឲ្យមានគ្រោះថ្នាក់ដល់រូបរាងកាយ និងផ្លូវចិត្ត។ អ្នកទោសខ្មែរក្រោមពីរបីនាក់ដែលអាចគេចផុតពីសេចក្ដីស្លាប់បាន គឺដោយសារតែពួកគេបានលាក់សាវតារ

[2288] *សូមមើល ខ១ាហារណ៍* ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385135 ["ពួកខ្មែរក្រហមបានចាប់ផ្តើមចម្រាញ់ប្រជាជន ដើម្បីស្វែងរកខ្មែរកម្ពុជាក្រោម ដែលពួកគេចោទប្រកាន់ថាជា "ខ្សែយួន"។ ខ្ញុំត្រូវបានគេចាប់ចង និងបញ្ជូនទៅកាន់មន្ទីរឃុំឃាំង នៅភូមិវាល"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៣៧ KH 00955711-12 [ខណៈដែលគាត់នៅក្នុងគុក នៅភូមិវាល៖ "នៅក្នុងឆ្នាំ១៩៧៧ គេធ្វើប្រវត្តិក្នុងកង ជួនកាលក្នុងមួយថ្ងៃពីរដង។ ខ្ញុំមិនដឹងថាហេតុអ្វីបានជាគេធ្វើដូច្នោះនោះទេ ប៉ុន្តែខ្ញុំគិតថាប្រហែលជាដើម្បីរកមើលខ្មែរក្រោមហើយ"]។ ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ៀន ឆ.១០៥ KH 00990659 ["ខ្មែរក្រោមត្រូវគេសម្លាប់ទាំងនៅភូមិវាល"]។ ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីន្ធន ឆ.១៣-១៨ KH 01067988-89 [បងប្រុសរបស់សាក្សីរូបនេះដែលមានឈ្មោះថា យ៉ាន និងប្រពន្ធរបស់គាត់ និងកូនៗ ៥នាក់ ត្រូវបានសម្លាប់នៅគុកភូមិវាល ក្នុងឆ្នាំ១៩៧៧ ដោយគេចោទថាជាខ្មែរក្រោម]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគំរោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527101 ["នៅក្នុងគុកនោះ គេបង្ខំឲ្យខ្ញុំឆ្លើយនឹងសំនួរអំពីថាតើខ្ញុំជាគិញយួន ឬយ៉ាងណា។ គេបានសួរខ្ញុំ ៤សំនួរ៖ ១. តើអ្នករស់នៅឯណាមុនសម័យខ្មែរក្រហម? ២. ហេតុអ្វីបានជាអ្នកនិយាយដោយសម្តេងរដឹន? ៣. ដោយសារអ្នកជាខ្មែរក្រោម តើអ្នកមានបានប្រាស្រ័យទាក់ទងជាមួយនឹងរៀតណាមដែរឬទេ? ៤. តើនៅក្នុងក្រុមគិញរបស់អ្នកមានគ្នាប៉ុន្មាននាក់? [...] មធ្យោបាយស្រដៀងគ្នានេះត្រូវបានគេប្រើប្រាស់ប្រឆាំងនឹងខ្មែរក្រោមគ្រប់ៗគ្នា មិនមែនចំពោះតែរូបខ្ញុំនោះទេ។ នៅដំណាក់កាលចុងក្រោយ គឺបន្ទាប់ពីរ៉ាក និងថង់ផ្ការស្ទិកហើយ ដាក់ទឹកចូលដើម្បីឲ្យថប់ដង្ហើមមក នៅពេលដែលអ្នកបាត់បង់ស្មារតី និងដឹងខ្លួនឡើងវិញ ខណៈដែលរាងកាយរបស់អ្នកទទឹកជោគ ខ្ញុំត្រូវបានគេឆក់ខ្សែភ្លើង"] EN 00527103 ["ពួកយោធានៅក្នុងគុកបានប្រាប់ខ្ញុំថា ពួកខ្មែរក្រោមទាំងអស់ដែលខ្ញុំបាននិយាយពីមុនត្រូវបានសម្លាប់ចោល ឬបញ្ជូនទៅកាន់គុកភូមិវាល។ ដោយសារពួកគាត់មិននៅក្នុងគុក ខ្ញុំដឹងថាពួកគាត់ត្រូវបានគេសម្លាប់ចោល។ ខ្ញុំដឹងថាពួកខ្មែរក្រោមត្រូវបានសម្លាប់ចោល ពីព្រោះពួកនេះត្រូវបានគេប្រមូលមកពីគ្រប់ទីកន្លែងនៃស្រុកបាកាន យកមកសម្លាប់ពីព្រោះពួកគេជាខ្មែរក្រោម"]។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចឹក ឃីន EN 00427010 ["រណ្តៅសាកសពរួមត្រូវបានបង្កើតឡើងនៅភូមិវាល នៅចំកណ្តាលវាលស្រែ។ ពួកអ្នកទោសខ្មែរក្រោមត្រូវបានសម្លាប់ជាពិសេសនៅពេលយប់ និងកប់នៅក្នុងរណ្តៅសាកសព"]។ ឯកសារ D5/161 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់លោក ចាប ខ្ជង EN 00379339 ["ថ្ងៃមួយខ្ញុំឃើញគេចាប់បងប្អូនខ្មែរកម្ពុជាក្រោមមយយគ្រួសារដឹកចូលគឺ អ៊ំនី យាយបេ និងកូនៗចំនួន៨នាក់ទៀត គេដាក់បញ្ចូលក្នុងមន្ទីរភូមិ រាយសួរចម្លើយ និងកាប់សំលាប់ទាំងអស់នៅថ្ងៃបន្ទាប់"]។

[2289] *សូមមើល* V.ខ.៥.ក.iv. ឧក្រិដ្ឋកម្ម - ភូមិភាគពាយ័ព្យ - តំបន់ ២ - មន្ទីរសន្តិសុខភូមិវាល - ឧក្រិដ្ឋកម្ម - ការធ្វើទារុណកម្ម។

[2290] D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ គឹម សូរ EN 00527101។

របស់ខ្លួន[2291]។ គឹម សូរ អាចលាក់អត្តសញ្ញាណរបស់គាត់ថាជាខ្មែរក្រោមបាន ដោយសារមានជំនួយពីមន្ត្រីគុកម្នាក់ឈ្មោះ តាឈិន ដោយសារតែ តាឈិន ជឿថា បងប្អូនប្រុសរបស់ គឹម សូរ បានជួយជីវិតគាត់[2292]។ ចាប ខ្ជង បានធ្វើពុតជាមនុស្សគក្នុងពេលនៃការដាក់ក្នុងមន្ទីរឃុំឃាំងទាំងមូលរបស់គាត់និងការលាក់សំនៀងខ្មែរក្រោមរបស់គាត់បានយ៉ាងជោគជ័យ[2293]។ ខ្មែរក្រោមដែលនៅសេសសល់នៅភូមិវាល ត្រូវបានសម្លាប់នៅក្នុងគុក ឬត្រូវបានបញ្ជូនទៅកន្លែងផ្សេងដើម្បីសម្លាប់ចោល[2294]។

[2291] ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក ឃីន ឆ.៦០ KH 00955700 ["ស៖ តើមានខ្មែរក្រោមច្រើនដែរឬទេ នៅក្នុងគុកភូមិវាល? ឆ.៦០៖ មានតែពីរនាក់ប៉ុណ្ណោះ ហើយពួកគេនៅរស់រានមានជីវិត ព្រោះខ្មែរក្រោមគឺគេយកទៅសម្លាប់ចោលទាំងអស់ គេមិនដាក់គុកនោះទេ"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងការស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម, ការរៀបរាប់របស់ គឹម សូរ EN 00527105 ["មានតែ១០នាក់ប៉ុណ្ណោះដែលនៅរស់រានមានជីវិតពីគុកភូមិវាល។ [...] មានគ្នាយើងបីនាក់ជាខ្មែរក្រោម និងលោក ថាត[ធ្ងៀក] ឃ្យៀន ដែលគេគិតថាជាខ្មែរក្រោម ទោះបីជាមិនមែនក៏ដោយ"]។

[2292] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៣៧-៣៩ KH 00955711-12។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងការស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម, ការរៀបរាប់របស់ គឹម សូរ EN 00527101 ["ខ្ញុំត្រូវបានជួយ សង្គ្រោះដោយអ្នកទោសចាស់ម្នាក់ផ្សេងទៀតនៅក្នុងគុកនោះ"]។

[2293] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៨០-៨៥ KH 00955736-37។ ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ៀន ឆ.៩១ KH 00990657។

[2294] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៧៧-៧៩ KH 00955736 ["ដល់ឆ្នាំ១៩៧៧ គឺគេបញ្ជូនមកដាក់នៅទួលព្រៃក្របៅអស់ហើយ។ [...] គេបញ្ជូនមកដើម្បីវ៉ៃចោល គឺវ៉ៃសម្លាប់ចោលនៅទីនោះជាមួយនឹងខ្មែរក្រោមផ្សេងទៀតដែលបញ្ជូនពីខ្ទាទទឹង។ [...] នៅគុកភូមិវាល គឺមានចំនួនច្រើនដែរ ប្រហែលជា៥០ ទៅ៦០នាក់"] ឆ.៩២-៩៦ KH 00955737 [ខ្មែរក្រោម១០គ្រួសារ (មានប្រហែលជា៦០នាក់) ត្រូវបានគេបញ្ជូនត្រឡប់មកភូមិវាល មកកាន់សហការណ៍វិញ តាមបញ្ជារបស់ យាយ រ៉ុម ប៉ុន្តែមិនឃើញត្រឡប់ទៅភូមិវិញដែរ]។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក ឃីន ឆ.៦០ KH 00955700 ["ព្រោះខ្មែរក្រោមគឺគេយកទៅសម្លាប់ចោលទាំងអស់ គេមិនដាក់គុកនោះទេ"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម, ការរៀបរាប់របស់ ឈុំ មាន EN 00527089 ["ខណៈដែលកំពុងធ្វើការ [នៅក្នុងភូមិវាល] គាត់បានឃើញខ្មែរក្រោមជាប់គុកជាច្រើននាក់ ហើយបង្ខំឲ្យធ្វើការជាទម្ងន់។ តែពីរ-បីខែក្រោយមក ប៉ុណ្ណោះ កាន បានបញ្ជាឲ្យគេសម្លាប់ខ្មែរក្រោមទាំងអស់នៅតាណោ (ភូមិវាល)"]។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ម៉ីក ឃីន EN 00427010 ["រណ្តៅសាកសពរួមត្រូវបានបង្កើតឡើងនៅភូមិវាល នៅចំកណ្តាលវាលស្រែ។ ពួកអ្នកទោសខ្មែរក្រោមត្រូវបានសម្លាប់ជាពិសេសនៅពេលយប់ និងកប់នៅក្នុងរណ្តៅសាកសព"]។ *សូមមើលផងដែរ* ភ័ស្តុតាងបន្ថែមទៀតនៃការសម្លាប់ពួកខ្មែរក្រោម នៅភូមិវាល នៅក្នុង V.ខ.៥.ក.iv ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់ ២-មន្ទីរសន្តិសុខភូមិវាល-ឧក្រិដ្ឋកម្ម-ការធ្វើទុក្ខបុកម្នេញ-ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះខ្មែរក្រោម។

ការផ្ញើទុក្ខបុកម្នេញដោយមូលហេតុនយោបាយចំពោះប្រជាជនភូមិភាគបូព៌ា

634. យ៉ាងហោចណាស់ មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន១២ នៅក្នុងសំណុំរឿង បានបង្ហាញថា នៅចុងឆ្នាំ១៩៧៨ អ្នកជម្លៀសនៅភូមិភាគបូព៌ាពីខេត្តព្រៃវែង ត្រូវបានគេបញ្ជូនជាប្រព័ន្ធទៅកាន់បណ្តាភូមិនានានៅក្នុងឃុំតាណោ សម្រាប់មួយរយៈពេលខ្លី បន្ទាប់មកក៏ត្រូវបានចាប់ខ្លួន និងយកទៅភូមិវាល ជាទីកន្លែងដែលពួកគេត្រូវបានសម្លាប់[2295]។ អ្នកដាក់ពាក្យសុំមួយចំនួនបាននិយាយអំពីរបៀបដែលក្រុមអ្នកជម្លៀសភូមិភាគបូព៌ាដ៏ធំត្រូវបានគេចាប់ខ្លួន រួមទាំងសមាជិក

[2295] ឯកសារ D5/1315 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទិត្យ ទូច KH 01037963-64 [សមាជិកគ្រួសារដូចមានឈ្មោះបួននាក់ ត្រូវបានជម្លៀសទៅនៅភូមិតាណោ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៧៨]។ ឯកសារ D5/1320 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ីន សុន KH 01038046-47 [សមាជិកគ្រួសារដូចមានឈ្មោះប្រាំបួននាក់ ត្រូវបានជម្លៀសទៅនៅភូមិតំណាក់ត្រប់ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៧៨]។ ឯកសារ D5/1323 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អេន អេត KH 01038096-97 [សមាជិកគ្រួសារដូចមានឈ្មោះដប់នាក់ ត្រូវបានជម្លៀសទៅនៅភូមិតាណោ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D5/1325 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជុន ណារី KH 01038130-31 [សមាជិកគ្រួសារដូចមានឈ្មោះប្រាំពីរនាក់ ត្រូវបានជម្លៀសទៅនៅភូមិតាណោ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី២៣ ខែធ្នូ ១៩៧៨]។ ឯកសារ D5/1326 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ិន អ៊ីម KH 01038142 [ទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់មានឈ្មោះថា "គុកភូមិវាល""] KH 01038147-48 [សមាជិកគ្រួសារដូចមានឈ្មោះបួននាក់ ត្រូវបានជម្លៀសទៅនៅភូមិតាណោ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D5/1327 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៊ុង ពៀន KH 01038164-65 [សមាជិកគ្រួសារដូចមានឈ្មោះដប់នាក់ ត្រូវបានជម្លៀសទៅនៅភូមិតាណោ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D5/1339 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ីម ចយ KH 01049471-72 [សមាជិកគ្រួសារដូចមានឈ្មោះពីរនាក់ ត្រូវបានជម្លៀសទៅនៅភូមិតំណាក់ត្រប់ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D5/1340 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ សន ម៉ុន KH 01049487-88 [សមាជិកគ្រួសារដូចមានឈ្មោះពីរនាក់ ត្រូវបានជម្លៀសទៅនៅភូមិតាណោ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី២៣ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D5/1342 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ អ៊ីន KH 01049519-20 [សមាជិកគ្រួសារដូចមានឈ្មោះប្រាំពីរនាក់ ត្រូវបានជម្លៀសទៅនៅភូមិតំណាក់ត្រប់ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៨] KH 01049515 [ទីតាំង៖ ភូមិវាល]។ ឯកសារ D5/1343 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ អ៊ីញ អ៊ាន KH 01049535-36 [សមាជិកគ្រួសារដូចមានឈ្មោះប្រាំមួយនាក់ ត្រូវបានជម្លៀសទៅនៅភូមិតាណោ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D5/1346 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ុល វ៉ាន់ KH 01049583-84 [សមាជិកគ្រួសារដូចមានឈ្មោះបួននាក់ ត្រូវបានជម្លៀសទៅនៅភូមិតំណាក់ត្រប់ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៧៨]។ ឯកសារ D5/1347 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចឹក អ៊ាត KH 01049599-600 [សមាជិកគ្រួសារដូចមានឈ្មោះពីរនាក់ ត្រូវបានជម្លៀសទៅនៅភូមិតាណោ ដែលគេបានចាប់ខ្លួនកាលពីថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៧៨]។

គ្រួសាររបស់ពួកគេផង[2296]។ ការកំណត់គោលដៅ ការចាប់ខ្លួនទ្រង់ទ្រាយធំ និងការសម្លាប់ប្រជាជនភូមិភាគពូព៉ាដូច្នេះ ត្រូវបានធ្វើលើកឡើងដោយសាក្សីផ្សេងទៀត[2297]។ គឹម សូរ បានឮសម្រែកថ្ងូररបស់អ្នកជម្លៀសមកពីស្វាយរៀងដែលគេកំពុងតែសម្លាប់នៅពេលថ្ងៃ និងបានកាន់ពិលនៅយប់នោះខណៈដែលពេជ្ឈឃាដបានបញ្ចប់ការសម្លាប់ក្រុមមនុស្សជាង៤០០នាក់[2298]។ ចាប ខ្ជង បានឃើញគេនាំអ្នកទោសភូមិភាគបូព៌ា ១,៧០០នាក់ ទៅកាន់កន្លែងសម្លាប់នៅកន្លែងអាងមួយ ហើយក្រោយមកគាត់ជាអ្នកជួយកប់សាកសពទាំងនោះ[2299]។ នៅក្នុងសេចក្តីរៀបរាប់ទាំងពីរ គឺគ្មានការសួរចម្លើយទេ[2300]។ នេះបង្ហាញឲ្យឃើញបន្ថែមថា ជនរងគ្រោះត្រូវបានគេសម្លាប់ដោយសារតែពួក

[2296] ឯកសារ D5/1315 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទិត្យ ទូច KH 01037963-64។ ឯកសារ D5/1327 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៊ុង ពៀន KH 01038164-65។ ឯកសារ D5/1339 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស៊ីម ចយ KH 01049471-72។ ឯកសារ D5/1342 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គង់ អ៊ឿន KH 01049519-20។ ឯកសារ D5/1346 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ុល រ៉ាន់, KH 01049583-84។ ឯកសារ D5/1347 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចឹក អាត KH 01049599-600។

[2297] ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងការស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ផ្ងៀក (ថាត) ឃ្យ៉ាន EN 00527104 ["ចាប់ពីខែឧសភា ឬ មិថុនា ឆ្នាំ១៩៧៨ ពេលចូលដល់ចុងបញ្ចប់នៃគ្រប់គ្រងរបស់របបខ្មែរក្រហម ពួកគេបានចាប់ផ្តើមប្រមូលមនុស្សពីស្វាយរៀង ដើម្បីយកពួកគេទៅសម្លាប់ចោល។ ដំបូង ពួកគេប្រមូលខ្មែរក្រោម។ ក្រោយមកទៀត ពួកគេក៏បានកំណត់គោលដៅទៅលើអ្នកស្វាយរៀង"]។ ឯកសារ D5/161 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ចាប ខ្ជង ឆ.៦១-៦៩ KH 00358252 ["ក្នុងឆ្នាំ១៩៧៨ [...] ពួកវាបានសម្លាប់បងប្អូនខាងបូព៌ាដែលដឹកមកពីខេត្តស្វាយរៀង យកមកសម្លាប់ជារៀងរាល់ថ្ងៃ"]។

[2298] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ៥៨-៦៧ KH 00955715-16 [*កត់សំគាល់* ជាពិសេសនៅក្នុង ឆ.៦៤ ដែលគាត់បានបំភ្លឺថា នេះគឺជាការសម្លាប់អ្នកបូព៌ា មិនមែនខ្មែរក្រោមទេ]។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136-38 [កត់សំគាល់ថា ឆ្នាំសម្លាប់បានកើតឡើងក្នុងឆ្នាំ១៩៧៨ ប៉ុន្តែមានភ័ស្តុតាងដទៃទៀតដែលស៊ីសង្វាក់គ្នាជាមួយភ័ស្តុតាងនេះក្នុងឯកសារ D118/124 គឺគាត់និយាយថា ព្រឹត្តិការណ៍បានកើតឡើងក្នុងឆ្នាំ១៩៧៩]។

[2299] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៦១-៦៩ KH 00955734-35។

[2300] ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385136-38 [ពេលអ្នកទោសស្វាយរៀងមកដល់ភូមិវាល ពួកគេត្រូវបានប្រាប់ថា ពួកគេនឹងទទួលបានទ្ធូវបាញ់អាវហូប។ នៅពេលពួកគេចូលមកជាក្រុមតូចៗដើម្បីមកទទួលយកអាហារ ពួកគេត្រូវបានចាប់ចងយកទៅសម្លាប់ចោល]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៦៧ KH 00955734 [ទាក់ទងនឹងក្រុមមនុស្ស ១.៧០០ នាក់៖ អ្នកបូព៌ាត្រូវបានបញ្ជូនមកដល់គុកភូមិវាលនៅប្រហែលម៉ោង ២រសៀល។ [...] ពេលមកដល់ភ្លាមគេបានបញ្ជាឲ្យអ្នកទាំងនោះម្តង១០នាក់ ចូលតាមទ្វារខាងលិចនៃគុក ហើយចេញតាមទ្វារខាងកើតនៃគុក ដោយធ្វើរបៀបនេះម្តង១០ៗ។ គឺពួកគេយកអ្នកទាំងអស់នោះទៅសម្លាប់]។

គេត្រូវបានគេគិតថា មានជាប់ពាក់ព័ន្ធជាមួយវៀតណាម អាស្រ័យដោយទីកន្លែងដែលពួកគេរស់នៅតែមួយប៉ុណ្ណោះ។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

635. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខភូមិវាល[2301]៖ អំពើប្រល័យពូជសាសន៍ទៅលើក្រុមជាតិសាសន៍វៀតណាមនៅកម្ពុជា (ជាពិសេសខ្មែរក្រោម)[2302] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម[2303] ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងប្រជាជនភូមិភាគបូព៌ា និងខ្មែរក្រោម ព្រមទាំង អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។

[2301] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ រូបគាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះមាន៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះតាមរយៈ៖ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមលើកទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៩, ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១៦, ១៩។

[2302] *សូមមើល* V.គ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម។

[2303] ស.ព.អ សន្និដ្ឋានថា អំពើមហាប្រល័យនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងទាក់ទងនឹងមន្ទីរសន្តិសុខភូមិវាលតែមួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំមហាប្រល័យដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់ពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងមន្ទីរសន្តិសុខភូមិវាលផង គួរត្រូវបានប្រមូលបញ្ចូលគ្នា។ ទីតាំងទាំងអស់បង្កើតបានជាផ្នែកនៃប្រព័ន្ធមួយក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេញនិងសម្លាប់ខ្មាំង ហើយការសម្លាប់នៅលើទីតាំងទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ីម ទិត្យ។

ខ. មន្ទីរសន្តិសុខស្វាយជ្រុំ

i. សេចក្តីផ្តើម

636. មន្ទីរសន្តិសុខស្វាយជ្រុំ នៅក្នុងស្រុកបាកានត្រូវបានគេស្គាល់តាមរយៈឈ្មោះជាច្រើន រួមមានដូចជា៖ ផ្ទះ[2304] មន្ទីរ[2305] មន្ទីរអប់រំផ្ទះ[2306] មន្ទីរតាឃិន[2307] ឬមន្ទីរកសាងខ្ពស់ត្រពាំងជង[2308]។ ខ្មែរក្រហមប្រើទីតាំងនេះដើម្បីឃុំឃាំងដោយគ្មានដំណើរការតុលាការ ចំពោះជនទាំងឡាយណាដែលគេសង្ស័យថាជាខ្មាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ រួមបទាំងខ្មែរក្រោមផងដែរ។ អ្នកទោសត្រូវបានគេឃុំខ្លួនក្នុងលក្ខខណ្ឌយ៉ាងអមនុស្សធម៌ ត្រូវបានគេធ្វើទារុណកម្ម ហើយមនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីតាំងសម្លាប់មនុស្សព្រៃភាគ ដែលនៅក្បែរនោះ។ កម្មាភិបាលភូមិភាគនិរតី និងភូមិភាគបស្ចិមបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះតាមបែបសហឧក្រិដ្ឋកម្មរួម ដែល **យ៉ីម ទិត្យ** គឺជាសមាជិកនាំមុខ។

637. ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** អំពីឧក្រិដ្ឋកម្មនានាទាក់ទងនឹងមន្ទីរសន្តិសុខស្វាយជ្រុំ ដូចតទៅ៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញលើពួកខ្មែរក្រោមដោយមូលហេតុនយោបាយ និងពូជសាសន៍ អំពើអមនុស្សធម៌ផ្សេងៗទៀត (ការឃុំខ្លួនក្នុងលក្ខខណ្ឌអមនុស្សធម៌) និងឧក្រិដ្ឋកម្មនៃការ

[2304] ការប្រកបម្យ៉ាងទៀតគឺ ផ្ទះ (*ឧទាហរណ៍* ឯកសារ D118/194) ផ្ទះ (*ឧទាហរណ៍* ឯកសារ D134/3) តាគោល (*ឧទាហរណ៍*ឯកសារ D219/336) ផ្ទោល (*ឧទាហរណ៍*ឯកសារ D267.1.42)។

[2305] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["មន្ទីរផ្ទះ ហៅថា [...] មន្ទីរស្វាយជ្រុំ (បច្ចុប្បន្ន ហៅដូចនេះ)។"]។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខ្ញុក ចន ឆ.២៨-២៩ KH 00987991-92។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុន ឆ.៧៨, ៨២ KH 01080905។ ឯកសារ D1.3.10.6 របាយការណ៍ DC-Cam ៖ *របាយការណ៍ស្តីពីអំពើប្រល័យពូជសាសន៍នៅខេត្តពោសាត់* EN 00217583 ["គុកឈ្មោះស្វាយជ្រុំ ឬភូមិផ្ទះ"]។

[2306] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.១៨ KH 00947329 ["ហៅមន្ទីរអប់រំផ្ទះ។"]។

[2307] ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខ្ញុក ចន ឆ.៥៨ KH 00987995។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["មន្ទីរផ្ទះ ហៅថាមន្ទីរតាឃិន"]។ ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារ៉ីន ឆ.៧០ KH 00977112។

[2308] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ ឡាយ ប៊ូនី (ឧបសម្ពន្ធ) KH 00359371 ["មន្ទីរកសាងខ្ពស់ត្រពាំងជង ដល់ពេលក្រោយមកគេក៏ដូរឈ្មោះថាជាមន្ទីរផ្ទោលវិញ"] *ត្រូវបានបញ្ជាក់នៅក្នុង* ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ប៊ូនី ឆ.២២ KH 01022019។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.១៨ KH 00947329។

ធ្វើមនុស្សឃាតដោយគិតទុកជាមុន នៅក្រោមមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[2309]។

ii. ប្រតិបត្តិការ និងទីតាំង

638. មន្ទីរសន្តិសុខស្វាយជ្រុំ ("ស្វាយជ្រុំ") និងទីតាំងសម្លាប់មនុស្សព្រៃភាគ បានដំណើរការចាប់ពីឆ្នាំ ១៩៧៧[2310] រហូតដល់ចុងឆ្នាំ១៩៧៨[2311]។ ទោះបីជាមានអ្នកទោសខ្លះត្រូវបានគេដោះលែង[2312] ក៏អ្នកទោសជាច្រើនត្រូវបានគេបញ្ជូនទៅកាន់គុកផ្សេងៗទៀត រួមមានគុកបឹងគល់ និង/ឬ គុកគ្រាចក្រោល[2313]។ បរិវេណនេះមានទីតាំងស្ថិតនៅជិតអ្វីដែលសព្វថ្ងៃនេះជាភូមិស្វាយ និងស្វាយជ្រុំ ឃុំ

[2309] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យឹម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426545, 48-49, 58។

[2310] ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុន ឆ.៧៨ KH 01080905។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423-24 ["ប្រហែលជាខែ៩ ឆ្នាំ១៩៧៦ ខ្ញុំត្រូវពួកយោធាស្រុកចាប់ខ្ញុំទៅដាក់គុកនៅមន្ទីរថ្ពាល [...] មន្ទីរថ្ពាលប្រហែលជាបង្កើតនៅឆ្នាំ១៩៧៦"]។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឆ.៣ KH 01022016។

[2311] ឯកសារ D6.1.685 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.១១ KH 00407763 ["ខ្ញុំបានចាកចេញពីមន្ទីរសន្តិសុខថ្ពាលវិញ នៅចុងឆ្នាំ១៩៧៨ មុនពេលវៀតណាមចូលមកដល់ប្រហែល ២ខែ។"]។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី ឆ.៦, ៨ KH 01022017 ["ឆ.៦៖ ខ្ញុំនៅក្នុងគុកថ្ពាលរហូតដល់រដូវវស្សា ឆ្នាំ១៩៧៨ ពីព្រោះគេបានរំលាយគុកថ្ពាល ហើយប្រគល់ឲ្យទៅខាងសហការណ៍ [...] ស៖ តើគេប្រគល់គុកថ្ពាលឲ្យទៅខាងសហការណ៍នៅខែឆ្នាំណា? ឆ.៨៖ នៅចុងឆ្នាំ១៩៧៨ គឺពេលដែលគេបញ្ជូនខ្ញុំទៅកន្លែងផ្សេងទៀត។"]។ ឯកសារ D118/237 កំណត់ហេតុស្តាប់ចម្លើយ ទិត កះ ឆ.៦០, ៧០, ៧៣ KH 00988019-20 [បានរំលឹកថា ម្តាយរបស់គាត់ត្រូវបានសម្លាប់នៅក្នុងឆ្នាំ១៩៧៨ និងថា ពូរបស់គាត់ត្រូវបានសម្លាប់នៅមន្ទីរថ្ពាល "ប្រហែល១ឆ្នាំក្រោយម្តាយរបស់ខ្ញុំត្រូវគេសម្លាប់។"]។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.២១ KH 00947330។

[2312] *សូមមើល ខ១ទាហរណ៍* ឯកសារ D6.1.685 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.១១ KH 00407763។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី របស់ ឡាយ ឫទ្ធី (ឧបសម្ពន្ធ) KH 00359371 ["លុះនៅចុងឆ្នាំ១៩៧៨ គេនាំយកអ្នកទោសទាំងអស់ ខ្លះបានទៅរស់នៅសហការណ៍វិញ"]។

[2313] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424 ["[ក្នុងឆ្នាំ១៩៧៨] ផ្ទេរអ្នកទោសទៅនៅមន្ទីរគ្រាចក្រោលវិញ"]។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី ឆ.៦-៧ KH 01022017 ["ខ្ញុំត្រូវ [បន្ទាប់មក] គេដឹកទៅដាក់នៅមន្ទីរសន្តិសុខបឹងគល់ [...] ១ខែ។ [...] ខ្ញុំនៅក្នុងមន្ទីរសន្តិសុខគ្រាចក្រោលក្នុងឆ្នាំ១៩៧៨"]។ ឯកសារ D118/234 កំណត់ហេតុស្តាប់ចម្លើយ ទុំ ង៉ា ឆ.៣៥ KH 00987978។ ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជ១ ឆ.២៩ KH 01102798-99។

បឹងបត់កណ្ដាល ស្រុកបាកាន ខេត្តពោធិ៍សាត់[2314]។ ក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ ភូមិដែលនៅជិតជាងគេបំផុតគឺភូមិថ្ពល និងភូមិត្រាំសេះ ក្នុងសហករណ៍ត្រាំសេះ[2315]។ រហូតដល់ប្រហែលជាដើមឆ្នាំ១៩៧៨ តំបន់នេះបានស្ថិតក្រោមដែនសមត្ថកិច្ចយុត្តាធិការរបស់ស្រុកបាកាន (គេហៅ *ជាអាទិ៍* ថាស្រុកក្ដាត ផងដែរ)[2316] តំបន់៧ នៃភូមិភាគពាយ័ព្យ[2317]។ ក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ សារុន លើតំបន់២ និង តំបន់៧[2318] គាត់បានបញ្ចូលស្រុកបាកានក្រោម ទៅក្នុងស្រុកបាកានលើ (តំបន់២) ដើម្បីបង្កើតបានជាស្រុកបាកានតែមួយ ស្ថិតក្រោមសិទ្ធិអំណាចរបស់គាត់[2319]។

[2314] ឯកសារ D118/15 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ស្វាយជ្រុំ KH 00894715, 16, 17។ ចំពោះសេចក្ដីណែនាំ *សូមមើល* ឯកសារ D347/2.1.46 ផែនទីប្រទេសកម្ពុជា ផ្ទាំងលេខ ៥៧៣៤ EN 01045009 [បង្ហាញថាភូមិស្វាយជ្រុំ ស្វាយ និងត្រាំសេះ ស្ថិតនៅក្នុងឃុំបត់កណ្ដាល ខាងជើងក្រុងបាកាន]។

[2315] *សូមមើល ឧទាហរណ៍* ឯកសារ D118/237 កំណត់ហេតុស្តាប់ចម្លើយ ទិត កះ ឆ.៧០ KH 00988020។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.១៨ KH 00947329។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខែក ចន ឆ.២៨ KH 00987991។ ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.៧៦ KH 00973999។

[2316] ឯកសារ D219/6 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ប៊ាង ឆ.១១២ KH 01025505 ["ស្រុកក្ដាត (បាកានក្រោម)"]។

[2317] ឯកសារ D118/15 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ស្វាយជ្រុំ KH 00894717 [បានកំណត់ទីតាំងឧក្រិដ្ឋកម្មខាងជើងផ្លូវជាតិលេខ៥]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ៀន ឆ.១២ KH 00955680 ["ស្រុកបាកានត្រូវបានបែងចែកជាពីរ ខាងក្រោម [ខាងជើង] ផ្លូវជាតិលេខ៥ គឺជាបាកានក្រោម"]។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយ យ៉ាន ឆ.១៩៥, ១៩៧ KH 01075747 ["តំបន់៧ ជាតំបន់ខាងក្រោម។ [...] គឺត្រឹមផ្លូវជាតិលេខ៥ ចុះទៅខាងជើង មានដូចជាខាងកណ្ដៀង"]។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុម ឆ.៨៨ KH 01080906 ["មន្ទីរសន្តិសុខថ្ពលនេះស្ថិតនៅក្រោមតំបន់៧"]។ ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.២៤ KH 00973993 ["[សហករណ៍ត្រាំសេះ] ស្ថិតនៅក្នុង [...] ស្រុកក្ដាត តំបន់៧។"]។

[2318] *សូមមើលខាងក្រោម* កថាខណ្ឌ ៦៤២។

[2319] ឯកសារ D219/6 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ប៊ាង ឆ.១១២ KH 01025505។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៤១ KH 01068113 ["ពេលដែល សារុន មកដល់គាត់បានច្រចាច់បាកានបញ្ចូលគ្នាតែមួយ។"]។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ឌួន រិន ឆ.៤០, ៥៣ KH 01075611, 13។ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៧២-៧៣ KH 013347273-74។ សម្រាប់ព័ត៌មានលម្អិតបន្ថែម *សូមមើល* IV.ค.២. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនងរបស់ ប.ก.ก – ភូមិភាគពាយ័ព្យ ១៩៧៧-១៩៧៩ – តំបន់២។

639. មន្ទីរសន្តិសុខនេះមានទីតាំងស្ថិតនៅក្នុងបរិវេណដ៏ធំមួយ[2320] ដែលរួមបញ្ចូលទាំងវាលស្រែ ចំនប់ និងប្រឡាយ ដែលជាទីកន្លែងអ្នកទោសត្រូវគេបង្ខំឲ្យធ្វើការ[2321]។ វាមានកន្លែងស្នាក់អាស្រ័យពីរ ផ្នែកដាច់ដោយឡែកពីគ្នា៖ មួយផ្នែកដាក់អ្នកជាប់ "ទោសស្រាល" ខណៈដែលអ្នកជាប់ "ទោសធ្ងន់" ត្រូវគេដាក់នៅផ្នែកផ្សេងទៀត[2322]។ អាគារគុកមិនមានវត្តមានទៀតទេ ហើយតំបន់នេះបច្ចុប្បន្នជាវាលធំៗ[2323]។ ទីតាំងសម្លាប់មនុស្ស ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណនេះ ភាគខាងត្បូងនៃមន្ទីរនេះ ត្រូវបានគេហៅថា ព្រៃភាគ[2324]។

[2320] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["មានទំហំប្រហែលជា ៥ម៉ែត្របួនជ្រុង ដោយខាងត្បូងជាប់ផ្លូវជាតិលេខ៥ ខាងលិចនិងខាងកើត ជាប់ប្រឡាយ ១៧មេសា និងខាងជើងជាប់ចឹងសំរោង។"]។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុន ឆ.៨៦ KH 01080906។

[2321] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424 [បានរៀបរាប់អំពីការងារនៅក្នុងគុក រួមមានការជីកប្រឡាយ លើកភ្លឺស្រែ និងជីកអាងទឹក "នៅក្បែរមន្ទីរ"។]។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ ឬនី (ឧបសម្ពន្ធ) KH 00359371 ["[អ្នកទោស] ចេញទៅធ្វើការ [...] លើកចំនប់ ជីកប្រឡាយ ស្ទូងដកនៅខាងក្រៅ ទៅតាមដីស្រែដែលជាទីកដីរបស់មន្ទីរ [...] ផ្ទោល"]។

[2322] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["មន្ទីរចូលបែងចែកជាពីរ [...] អ្នកទោសធ្ងន់ដាក់នៅខាងត្បូងមន្ទីរ [...] ចំពោះអ្នកទោសស្រាល [...] ដាក់នៅខាងជើងមន្ទីរ។"]។ ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជ៉ះ ឆ.២៩ KH 01102798-99។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឬនី ឆ.២១ KH 01022019 ។ *សូមមើលផងដែរ* ឯកសារ D118/15 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ស្វាយជ្រុំ KH 00894716។

[2323] D118/237 កំណត់ហេតុស្តាប់ចម្លើយ ទិត កះ ឆ.៧១ KH 00988020។

[2324] ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឬនី KH 00373252-54 ["ភាគត្រូវបានគេដឹងថាជាកន្លែងសម្លាប់មនុស្ស [...] នៅគុកផ្ទោល [...] [មនុស្ស] ត្រូវបានគេយកទៅសម្លាប់នៅភាគ។ [...] ទាហានខ្មែរក្រហមបីបួននាក់ដែលចូលរួមក្នុងការសម្លាប់មនុស្សនោះបានក្លាយជាអ្នកទោស ហើយពួកគេបានប្រាប់ខ្ញុំថាអ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់នៅ ភាគ នៅខាងត្បូងគុកផ្ទោល។"]។ ឯកសារ D118/15 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ស្វាយជ្រុំ KH 00894717 [18] ["[លឹម សាត] បានបង្ហាញយើងបរិវេណដែលជាកន្លែងសម្លាប់មនុស្ស។ [...] បរិវេណនេះមានឈ្មោះថា ព្រៃភាគ និងស្ថិតនៅ [...] ចម្ងាយប្រហែលពីរបីរយម៉ែត្រពីកន្លែងគុកស្វាយជ្រុំ"]។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["រណ្តៅទាំងនោះនៅព្រៃភាគ។ [...] ពួកឈ្លបយកអ្នកទោសទៅសម្លាប់នៅឆ្ងាយពីមន្ទីរ ក្នុងទីកដីមន្ទីរដដែល។"]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនង

640. ចាប់តាំងពីបើកគុកនេះមក ប្រធានគុកស្វាយជ្រុំគឺឈ្មោះ ឃិន អនុឈ្មោះ គឹម និងសមាជិកឈ្មោះ ចឹក[2325]។ ឃិន និង ចឹក ទាំងពីរនាក់នេះគឺជាសមាជិកគណៈសហករណ៍មូលដ្ឋាន[2326]។ ពេលមួយនោះក្នុងឆ្នាំ១៩៧៨ ឃិន, គឹម និង ចឹក ទាំងអស់គ្នាត្រូវបានចាប់ខ្លួន និងសម្លាប់ចោល[2327]។ ភ័ស្តុតាងមិនបានបង្ហាញថាអ្នកណាគេ ប្រសិនបើមាន បានជំនួសពួកគេនោះទេ។ ប្រធានគុកនេះបានរាយការណ៍ទៅកាន់គណៈស្រុកបាកានក្រោម (ក្រោយមកជាស្រុកបាកាន) និងទទួលបញ្ជាពី

[2325] ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.១៤ KH 00947340 ["[ប្រធានមន្ទីរសន្តិសុខផ្ទៃ] ឈ្មោះ ឃិន។ អនុប្រធានឈ្មោះ គឹម និងសមាជិកឈ្មោះចឹក។"]។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខ្ចែក ចន ឆ.៥៨ KH 00987995។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុន ឆ.៧៨ KH 01080905។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឃូនី ឆ.២៣ KH 01022019។ ឯកសារ D219/844.1.1 *ស្វែងរកការពិត* ការរៀបរាប់របស់ នៅ សន ចុះខែកក្កដា ឆ្នាំ២០០២ EN 00081233 ["'តា ឃិន' គឺជាប្រធានមន្ទីរនៅបឹងបត់កណ្តាល"]។ ឯកសារ D118/147.1.3 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាំ ជ: (ទម ចាស់) KH 00557659 ["មន្ទីរស្រាលនៅខាងជើង (មន្ទីរតាចឹក) មន្ទីរធ្ងន់នៅខាងត្បូងគ្រប់គ្រងដោយ តាឃិន។"]។

[2326] ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជ: ឆ.២១ KH 01102798 ["មន្ទីរតាគោល ដែលជាគុក ដែលតាខ្ចិន ជាអ្នកកាន់កាប់។ គាត់ជាគណៈសហករណ៍"]។ ឯកសារ D118/147.1.3 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាំ ជ: (ទម ចាស់) KH 00557659 ["គណៈសហករណ៍ តាចឹក"]។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខ្ចែក ចន ឆ.៥៨ KH 01057671 ["មន្ទីរថ្ពូលនេះគឺគ្រប់គ្រងដោយ តាឃិន។"]។ *សូមមើលផងដែរ* ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារ៉ីន ឆ.៦៧-៧១, ៧៣ KH 00977112 ["មន្ទីរតាឃិននៅក្នុងឃុំរបស់ខ្ញុំនេះ [...] តាឃិនគឺជាគុករបស់ឃុំ"]។

[2327] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424 ["ប្រហែលជានៅចុងឆ្នាំ១៩៧៨ ឈ្មោះ ឃិន, តា គឹម និងឈ្មោះ ចឹក ត្រូវអង្គការយកទៅសម្លាប់។"] *ត្រូវបានបញ្ជាក់ដោយ*ឯកសារ D219/702.1.4 លឹម សាត ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង15.21.00-15.22.32។ ឯកសារ D5/799/1 របាយការណ៍នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សៀ នី EN 00918383 [ប្រហែលជាដើមឆ្នាំ១៩៧៨ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបញ្ជូនទៅកាន់មន្ទីរឃុំឃាំងយោធាស្វាយអាត់ នៅភូមិស្វាយអាត់ "ដែលជាកន្លែងគាត់បានឃើញកម្មាភិបាលខ្មែរក្រហមមួយចំនួនត្រូវបានគេសម្លាប់ដោយពួកកម្មាភិបាលគ្នាឯង ឧទាហរណ៍ តាឃិន ដែលជាប្រធានមន្ទីរឃុំឃាំងនៅសហករណ៍ថ្ពូល [...] ត្រូវបានឃុំខ្លួន និងក្រោយមកត្រូវគេសម្លាប់នៅទីនោះ។"]។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឃូនី ឆ.២៣ KH 01022019។

គណៈស្រុកនេះ[2328] ដែលទទួលខុសត្រូវលើមន្ទីរសន្តិសុខនានាក្នុងស្រុកទាំងមូល[2329]។ ការចាប់ខ្លួនបានធ្វើឡើងដោយយោធាស្រុក ឬសមាជិកឈ្លប ដែលធ្វើការចាប់មនុស្សតាមបញ្ជា ឬដោយមានការឯកភាពពីគណៈស្រុកបាកានក្រោម និងក្រោយមកជាគណៈស្រុកបាកាន[2330]។

641. ក្រោយពីកម្មាភិបាលភូមិភាគពាយ័ព្យថ្នាក់ស្រុកបានធ្វើការបោសសម្អាតនៅបាកានក្រោម ពីដើមឆ្នាំ១៩៧៧ ទៅពាក់កណ្តាលឆ្នាំ១៩៧៧[2331] រួចមក ឈ្លោះផល មកពីភូមិភាគនិរតីបានក្លាយជាលេខាស្រុកនេះ[2332] រហូតដល់ពេលរូបគាត់ត្រូវបានចាប់ខ្លួនផងដែរ និងត្រូវបានជំនួសនៅដើមឆ្នាំ១៩៧៨ ដោយ

[2328] នៅស្រុកបាកានក្រោម និងស្រុកបាកានដែលបានបញ្ចូលគ្នាតែមួយ គណៈសហការណ៍បានរាយការណ៍ជូន និងទទួលបញ្ជាពីគណៈស្រុក ស្របតាមលក្ខខន្តិកៈរបស់ ប.ក.ក។ *សូមមើលឧទាហរណ៍* ឯកសារ D219/586 កំណត់ហេតុស្តាប់ចម្លើយ ឃុន ម៉ុន ឆ.៨៣, ៨៧-៨៨ KH 01167503-04 [ស្រុកបាកានក្រោម (ក្រោយមកស្រុកបាកាន)៖"[ប្រធានសហការណ៍] ធ្វើការក្រោមស្រុក។ មានការងារអី គណៈសហការណ៍រាយការណ៍ទៅស្រុកទៅ។ [...] គណៈស្រុកចុងក្រោយឈ្លោះ តាផែង។ [...] មកដល់នៅឆ្នាំ៧៨។"]។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សុខុម ឆ.១៥៣ KH 01025550 [ស្រុកបាកាន៖ "ស៖ មានន័យថា រ៉ីម និងតាផែង បញ្ជាទៅគណៈសហការណ៍ តើត្រឹមត្រូវឬទេ? ឆ.១៥៣៖ ចាស ត្រឹមត្រូវ។"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ីក សៀម ឆ.៣, ៥ KH 00485644-46 [អតីតប្រធានសហការណ៍រំលេច (ដែលត្រូវបានតែងតាំងដោយគណៈស្រុកបាកាន *សូមមើល* ឆ.៣) បានរៀបរាប់ពីការប្រជុំជាប្រចាំរបស់ប្រធានសហការណ៍ស្រុកបាកាន ដែលដឹកនាំប្រជុំដោយ តាម៉ុក តាសារុន (លេខាតំបន់២ និងតំបន់៧) និង ឃាយរ៉ីម (លេខាស្រុកបាកាន)។]។ ឯកសារ D1.3.20.1 លក្ខន្តិកៈ ប.ក.ក មាត្រា ៦(៥), ១៣។ *សូមមើលផងដែរ* ឯកសារ D118/103.3 សេចក្តីសន្និដ្ឋានចុងក្រោយរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៧៦ KH 00404809 ["មន្ទីរសន្តិបាលគ្មានសិទ្ធិសម្រេចម្ទេចទេ។ និយាយឲ្យចំ គឺប្រធានមន្ទីរសន្តិបាលណាក៏ដោយ ក៏គ្មានអំណាចចេញបញ្ជាអត្តនោម័តឲ្យចាប់មនុស្សដែរ។"]។

[2329] *សូមមើលឧទាហរណ៍* ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុម ឆ.៥០-៥១ KH 01080901 [ប្រធានគុកនៅមន្ទីរសន្តិសុខត្រាចក្រោលនៅបាកានក្រោម បានបញ្ជាក់ថា អ្នកគ្រប់គ្រងផ្ទាល់របស់គាត់គឺលេខាស្រុក ឈ្លោះ ផល និង ផែង]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១៦៣ KH 01068151 [កម្មាភិបាលយោធាបញ្ជាក់ថា លេខាស្រុកឈ្លោះ រ៉ីម និង ផែង ក្តាប់រួមលើគុកភូមិវាល ស្រុកបាកាន។]។

[2330] *សូមមើល ឧទាហរណ៍* ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423-24 ["ខ្ញុំត្រូវពួកយោធាស្រុកចាប់ខ្ញុំទៅដាក់គុកនៅមន្ទីរថ្ពូល [...] ពេលអ្នកទោសចូលដំបូង គឺឈ្លបជាអ្នកនាំមក។"]។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុម ឆ.៣០, ៣៨, ៨១-៨២ KH 01080898-99, 906 [ឈ្លបដែលយកពួកអ្នកដែលគេចាប់ខ្លួនទៅកាន់មន្ទីរសន្តិសុខស្វាយជ្រុំ (ថ្ពូល) បញ្ជាក់ថា គាត់ធ្វើការផ្ទាល់ក្រោមស្រុក និងត្រូវរាយការណ៍ទៅស្រុកប្រសិនបើគាត់ចាប់បាននរណាម្នាក់លួចចំណីអាហារ។]។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សុខុម ឆ.១១០, ១១៤ KH 01025546។

[2331] *សូមមើល* V.ខ.១.ខ.ii. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតភូមិភាគពាយ័ព្យនៅថ្នាក់ភូមិភាគ និងថ្នាក់តំបន់ – ការបោសសម្អាតនៅថ្នាក់តំបន់ – តំបន់៧។

[2332] ឯកសារ D219/276 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ង៉ុយ ឆ.២៤KH 01088940។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុម ឆ.១៨ KH 01080896។

ឈ្មោះ ផែង មកពីភូមិភាគបស្ចឹម[2333]។ ក្រោយពីការបញ្ចូលគ្នារវាងបាកានលើ និងបាកានក្រោម ដោយលេខាតំបន់ឈ្មោះ សារុន រួចមក មានភ័ស្តុតាងផ្ទុយគ្នាចំពោះថាតើ ផែង លេខាស្រុកបាកានក្រោម ឬ យាយរ៉ីម លេខាស្រុកបាកានលើ[2334] ជាលេខាស្រុកបាកានថ្មី។ ទោះជាយ៉ាងណា ភ័ស្តុតាងបង្ហាញច្បាស់ថា ពួកគេធ្វើការជាមួយគ្នាគ្រប់គ្រងស្រុកបាកានរហូតដល់ចុងបញ្ចប់នៃរបបនេះ[2335] រួមទាំង "ការបោសសម្អាតខ្មាំង"[2336]។

642. នៅថ្នាក់តំបន់ លេខាតំបន់៧ ដំបូងគេក្រោយពេលដែលគណៈតំបន់នេះត្រូវបានបោសសម្អាត ពីដើមឆ្នាំ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧[2337] គឺជាកម្មាភិបាលភូមិភាគនិរតីឈ្មោះ គង់ ដែលទទួល

[2333] ឯកសារ D219/825.1.2 បញ្ជីរឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី 13263 EN 01222871 [អ្លង ជិន ហៅ ផល ជំនួយការស្រុកក្តាត តំបន់២ ០១-មេសា-៧៨ ឬ ២៣-មីនា-៧៨] *ប៉ុន្តែសូមមើល* ឯកសារ D6.1.13 S-21 បញ្ជីរឈ្មោះអ្នកទោសស្ទូរថ្ងៃទី២-៣ មេសា ១៩៧៨ KH 00088624 [បង្ហាញថា កាលបរិច្ឆេទចាប់ខ្លួន អ្លង ជិន នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៨]។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុម ឆ.១៨-២១ KH 01080896-97។ *សូមមើលបន្ថែមទៀត* IV.គ.៥. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនងរបស់ ប.ក.ក – ភូមិភាគពាយ័ព្យ ១៩៧៧-១៩៧៩ – តំបន់៧។

[2334] *សូមមើលឧទាហរណ៍* ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយ ទូច សេង ហៅ យាយយ៉ាន ឆ.១២០ KH 01075734 ។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សុខុម ឆ.៦៣, ៦០-៦៧ KH 01025541។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.៥២ KH 01075613។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.២០ KH 00485651 ។ *សូមមើលបន្ថែមទៀត* IV.ឆ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនងរបស់ ប.ក.ក – ភូមិភាគពាយ័ព្យ ១៩៧៧-១៩៧៩ – តំបន់២។

[2335] *សូមមើលឧទាហរណ៍* ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យ៉ង់ សុខុម ឆ.៦៦, ៨១, ១៥៣ KH 01025541, 01025543, 01025550 [បានបញ្ជាក់ថា រ៉ីម និង តាផែង បានចេញបញ្ជាទៅកាន់គណៈសហករណ៍]។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៤៣ KH 01068113។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៨០ KH 01068136។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.៤០, ៤២, ៥៣-៥៤ KH 01075611-13។ ឯកសារ D219/590 កំណត់ហេតុស្តាប់ចម្លើយ ឡុង ឃ្លោក ឆ.៦០ KH 01178805។ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥៩-៦០ KH 01347271 *ប៉ុន្តែសូមមើល* ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៩៩ KH 01348874។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ន ឆ.៣៨ KH 01176410។ ឯកសារ D6.1.616 បទសម្ភាសន៍ អ៊ុក សៀម ដោយ SOAS KH 00657427 ។ *សូមមើលបន្ថែមទៀត* IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនងរបស់ ប.ក.ក – ភូមិភាគពាយ័ព្យ ១៩៧៧-១៩៧៩ – តំបន់២។

[2336] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៨០ KH 01068136។

[2337] *សូមមើល* V.ខ.១.ខ.ii. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតភូមិភាគពាយ័ព្យនៅថ្នាក់ភូមិភាគ និងថ្នាក់តំបន់ – ការបោសសម្អាតនៅថ្នាក់តំបន់ – តំបន់៧។

បានការជួយជ្រោមជ្រែងពីលេខាស្រុកកណ្តៀងថ្មីឈ្មោះ ទ្រី[2338]។ នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ រៀន អែម *ហ៣*សារុន មកពីភូមិភាគបស្ចឹមបានគ្រប់គ្រងតំបន់២ និង តំបន់៧[2339]។ សារុនបានជួប បានរាយការណ៍ និងបានទទួល និងអនុវត្តបញ្ជាពី តាម៉ុក[2340] ហើយនៅប្រហែលជាខែមិថុនា ឆ្នាំ១៩៧៨ គាត់ទទួលបានការតែងតាំងក្នុងគណៈភូមិភាគពាយ័ព្យជាមួយ តាម៉ុក និង **យ៉ឹម ទិត្យ**[2341]។

[2338] ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហួត ម៉ឹង ហៅ សាត សុខុម ឆ.៨, ១៥ KH 00947346-47។ ឯកសារ D6.1.617 បទសម្ភាសន៍ សាត សុខុម ដោយ SOAS KH 00590218។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.២៨, ៣១ KH 00947341-42។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លីម សាត ឆ.៣២ KH 00947342។ ឯកសារ D219/825.1.2 បញ្ជីរឈ្មោះអ្នកទោស ស-២១ របស់ ក.ស.ច.ស លេខរៀងទី 8936 EN 01222694 [មុយ ទ្រី ជំនួយការស្រុករំដៀង តំបន់៧ មុនកងពល ៧០៣ (គណៈស្រុកកណ្តៀង តំបន់២ មុននៅកងពល៧០៣) ០១-មេសា-៧៨]។ *សូមមើលបន្ថែមទៀត* IV.គ.៥. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនងរបស់ ប.ក.ក – ភូមិភាគពាយ័ព្យ ១៩៧៧-១៩៧៩ – តំបន់៧។

[2339] ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៣១ KH 01068111។ ឯកសារ D6.1.616 បទសម្ភាសន៍ អ៊ុក សៀម ដោយ SOAS KH 00657427 ["សារុន ទទួលបន្ទុកតំបន់២ និងតំបន់៧។"]។ ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ សូ ណាន់ ហៅ យ៉ាយណាន់ ឆ.១៩, ២៤ KH 00498372-73។ ឯកសារ D1.3.15.2 Timothy Carney, *The Organization of Power* KH 00332381។ ចំពោះការពន្យល់លម្អិតអំពីតួនាទីរបស់ សារុន ជាលេខាតំបន់៧ *សូមមើល* IV.គ.៥. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនងរបស់ ប.ក.ក – ភូមិភាគពាយ័ព្យ ១៩៧៧-១៩៧៩ – តំបន់៧។

[2340] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យ៉ាយរ៉ីម ឆ.១០៣-១០៤, ១០៦-១០៧ KH 01347279 ។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យ៉ាយរ៉ីម ឆ.៨, ៤២ KH 01348857, 63។ *សូមមើលផងដែរ* ឯកសារ D1.3.29.2 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146678 [ដោយការបញ្ជាក់ថា តាម៉ុក បានក្លាយទៅជាលេខាភូមិភាគបស្ចឹម នៅក្រោយពីលេខាមុនឈ្មោះ ជូ ជេត ហៅ ស៊ី ត្រូវបានបោសម្អាត។ "ដឹកកម្លាំង តាម៉ុក និងកម្លាំងខាងបស្ចឹមរបស់ ហួត ហេង ហៅ ប៉ាល់ទៅទាំងឡានៗ យកទៅពាយ័ព្យ"]។ ឯកសារ D118/103.3 សេចក្តីសន្និដ្ឋានចុងក្រោយរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ កំណត់សម្គាល់ជើងទំព័រលេខ២៤ KH 00404797។ ឯកសារ D219/193 កំណត់ហេតុស្តាប់ចម្លើយ រ៉ាត ផាត ឆ.២១៥, ២១៧ KH 01070086-87។ *សូមមើលបន្ថែមទៀត* ឯកសារ IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនងរបស់ ប.ក.ក – ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧-១៩៧៩-តំបន់២។

[2341] ឯកសារ D6.1.616 បទសម្ភាសន៍របស់ SOAS ជាមួយ អ៊ុក សៀម KH 00657427 ["សារុន [...] ស្ថិតនៅក្នុងគណៈភូមិភាគពាយ័ព្យផងដែរ ជំនួស កែវ [ក៊ី]"]។ ឯកសារ D6.1.1052 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00159561-62។ ឯកសារ D1.3.15.2 Timothy Carney, *The Organization of Power* KH 00332382។ *សូមមើលបន្ថែមទៀត* ឯកសារ IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទំនាក់ទំនងរបស់ ប.ក.ក – ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧-១៩៧៩-តំបន់២។ ទាក់ទងទៅនឹងសមាជិកភាពរបស់ យ៉ឹម ទិត្យ ទៅនឹងគណៈភូមិភាគពាយ័ព្យ *សូមមើល* កថាខណ្ឌ១៤៤។ III.ឃ.១. មុខតំណែង អំពើ និង ទង្វើប្រព្រឹត្តរបស់ យ៉ឹម ទិត្យ– ការចូលរួមចំណែករបស់ យ៉ឹម ទិត្យ នៅក្នុងផែនការឧក្រិដ្ឋកម្មរួមនៅភូមិភាគពាយ័ព្យ – មុខតំណែងរបស់ យ៉ឹម ទិត្យ នៅភូមិភាគពាយ័ព្យ។

iv. ខ្ញុំក្រិដ្ឋកម្ម

<u>ការដាក់ក្នុងមន្ទីរឃុំឃាំង</u>

643. ប្រជាជនស៊ីវិលរាប់ពាន់នាក់ និងកម្មាភិបាលភូមិភាគពាយ័ព្យជាច្រើនត្រូវបានឃុំឃាំងនៅស្វាយជ្រុំ ដោយមិនមានដំណើរការត្រឹមត្រូវ ខណៈដែលកម្មាភិបាលភូមិភាគនិរតី និងបស្ចឹមបានគ្រប់គ្រងតំបន់២ និងតំបន់៧។ មិនមានភ័ស្តុតាងណាបង្ហាញថា អ្នកទោសណាម្នាក់ត្រូវបានចាប់ខ្លួនស្របតាមបញ្ញាតុលាការណាមួយឡើយ ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់ ទទួលបានមេធាវី ទទួលបានការជំនុំជម្រះ ឬត្រូវបានគេផ្តល់ឱ្យនូវដំណើរការត្រឹមត្រូវបែបណាមួយឡើយ។ ជាក់ស្តែងនោះ មិនមានប្រព័ន្ធតុលាការដំណើរការទាល់តែសោះ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2342]។

644. មន្ទីរនេះ "ដាក់ឃុំឃាំងមិនរើសមុខទេ"[2343]។ អ្នកទោសនៅស្វាយជ្រុំមានក្រុមខុសគ្នាជាច្រើន រួមមាន "ប្រជាជន ១៧ មេសា"[2344] ប្រជាជនមូលដ្ឋាន[2345] អតីតទាហាន លន់ នល់ និងក្រុមគ្រួសារ

[2342] ឯកសារ D6.1.1057 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00177581 ["ខ្ញុំទទួលស្គាល់ចំនុចនេះ។ រាល់សេចក្តីសម្រេចសំខាន់ៗ ត្រូវបានធ្វើដោយបក្ស ដែលដឹកនាំប្រទេស ផ្តាច់មុខ និងតាមរបៀបផ្តាច់ការ [...] គោលការណ៍នេះ គឺមានវិសមិតភាពជាមួយនឹងអត្ថិភាពនៃតុលាការ និង ការធានាផ្នែកនីតិវិធី"]។ ឯកសារ D1.3.29.7 បទសម្ភាសន៍របស់ UNHCR ជាមួយ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី៤-៦ ខែឧសភា ឆ្នាំ១៩៩៩ EN 00160903 ["នៅកម្ពុជាប្រជាធិបតេយ្យ គ្មានតុលាការ"]។

[2343] ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.៧២ KH 00973999។

[2344] ឯកសារ D219/702.1.4 លឹម សាត ប្រតិចារ៉ឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 13.55.31-13.58.18 [ដោយការពន្យល់ថាពួកអ្នកទោសនៅមន្ទីរសន្តិសុខ១ ១ រួមមាន ពួកអ្នកដែលបានជម្លៀសមក *ជាអាទិ៍* ពីទីក្រុងភ្នំពេញ រហូតដល់ឆ្នាំ១៩៧៨។ ពួកគេពីដំបូងត្រូវបានដាក់តាមសហករណ៍នានា ហើយបន្ទាប់មកបញ្ជូនទៅគាន់គុកថ្ម១] *បញ្ជាក់ដោយ* ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242425 ["មានប្រជាជន ១៧ [...] ប្រជាជន១៧ ជាប្រជាជនក្រោយរំដោះ"]។ ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.៧៨ KH 00974000។

[2345] ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.៧៣ KH 00973999 ["ទាំងប្រជាជន ១៨មេសា"]។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242425 ["មានប្រជាជន [...] ១៨ (ប្រជាជន១៨ ជាប្រជាជនចាស់ [...])"]។

របស់ពួកគេ[2346] កម្មាភិបាលភូមិភាគពាយ័ព្យ[2347] ជនជាតិចាម[2348] ខ្មែរក្រោម[2349] និងប្រជាជនជម្លៀសមកពីភូមិភាគបូព៌ា[2350]។ អ្នកទោសត្រូវបានចាប់មកពីសហករណ៍នានាក្នុងតំបន់ទាំងមូល[2351]។ ពួកគេរួមមានអ្នកទាំងឡាយណាដែលត្រូវបានគេចោទប្រកាន់អំពី "ទោសកំហុស"[2352]

[2346] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242425 ["មាន [...] ពួកយោធា"]។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខ្ញុក ចន ឆ.៣១-៣២ KH 00987992។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ បូនី (ឧបសម្ព័ន្ធ) KH 00359370, 71 [ពួកអ្នកទោស រួមមាន "ទាហាន អ្នកធ្វើការគ្រប់ប្រភេទ។ [...] ក្នុងរយៈពេលមួយដែលពួកនិរតី ចូលមកកាន់កាប់នៅមន្ទីរថ្មោលនេះវិញ ពួកវាក៏ចាប់យោធាចាស់ខ្លះដាក់គុកវិញ"]។ ឯកសារ D6.1.159 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សារុធ KH 001968[02], 04 ["ឪពុកខ្ញុំស្លាប់នៅក្នុងឆ្នាំ១៩៧៧ [...] ដោយសារម្តាយខ្ញុំជាប្រពន្ធរបស់នាយទាហាន [លន់ នល់] [...] ឯម្តាយខ្ញុំ និងប្អូនស្រីពៅអាយុ ៥ឆ្នាំត្រូវបានគេយកទីដាក់នៅមន្ទីរឃុំឃាំង ដែលស្ថិតនៅភូមិត្រពាំងជង ស្រុកបាកាន"]។ ប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី គឺជាអតីតទាហាន លន់ នល់ ដែលបានជាប់ឃុំឃាំង និងបានសម្លាប់ចោលនៅស្វាយជ្រុំ ក្នុងឆ្នាំ១៩៧៦ (*សូមមើល* ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373245, 53) ហើយគាត់ត្រូវបានជាប់ឃុំក្នុងពេលជាមួយគ្នានោះ នៅលើមូលដ្ឋានដែលថាគាត់ត្រូវជាប្រពន្ធ (*សូមមើល* ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373252 ["គេយកខ្ញុំមកទីនោះដោយសារតែខ្ញុំទៅតាមប្តីរបស់ខ្ញុំ"]) ។ ទោះបីជាមានការឃុំខ្លួនប្តីរបស់គាត់ និងការស្លាប់ទំនងជាមានកើតឡើង នៅមុនពេលពួកនិរតីកាន់ក្តាប់នៅតំបន់៧ ក៏ដោយ ក៏មានការបន្តឃុំខ្លួនរបស់ ឡាយ បូនី ដោយមិនមានន៖ីតិវិធីត្រឹមត្រូវតាមច្បាប់ រហូតដល់ឆ្នាំ១៩៧៨ (*សូមមើល* ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី ឆ.៦ KH 01022017) ស្ថិតនៅក្រោមយុត្តាធិការផ្ទាល់របស់ពួកគេ។

[2347] ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373254 ["ក្រោយមកទៀតទាហានខ្មែរក្រហម បីបួននាក់ដែលចូលរួមនៅក្នុងការសម្លាប់មនុស្ស [នៅស្វាយជ្រុំ] នោះបានក្លាយជាអ្នកទោស"]។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242425 ["មាន [...] ពួកកម្មាភិបាល"]។

[2348] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242425 ["ហើយអ្នកទោសមានជនជាតិចាមផងដែរ។"] ។

[2349] ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី ឆ.១៣ KH 01022018។

[2350] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242425 ["មាន [...] ប្រជាជនមកពីស្វាយរៀង កំពង់ស្ពឺ"] ។

[2351] ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.15.03-11.17.00 ["រាល់ថ្ងៃដែលបញ្ជាពីតំបន់នានា ពីសហករណ៍នានាឡើងមក អ៊ូអ ចេចចាចចុះឡើង"]។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាច បូនី (ឧបសម្ព័ន្ធ) KH 00359370 ["ដឹកមកពីសហករណ៍នានា តាមស្រុក តាមតំបន់ទន្លេ និង តាមតំបន់ភ្នំ គ្រប់កន្លែងយកមកអប់រំនៅទីនោះ"]។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242425 ["មាន [...] សហករណ៍ [ប្រជាជន]"]។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុន ឆ.៨១-៨២ KH 01080905។

[2352] ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារីន ឆ.៦៨ KH 00977112។ ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.៧៣ KH 00973999។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ បូនី (ឧបសម្ព័ន្ធ) KH 00359370 [អ្នកទោស រួមមាន "អ្នកធ្វើស្រែ ត្រូវគេចោទប្រកាន់ពីទោសកំហុសគ្រប់បែបយ៉ាង"]។

ណាមួយ ថាជា "ខ្មាំង"[2353] ឬថាជា "ឃ្លួន"[2354]។ បទមជ្ឈិមដែលបានចោទប្រកាន់ទាំងនោះរួមមាន ការលួចម្ហូបអាហារ[2355] ការប្រព្រឹត្តខុសសីលធម៌[2356] ការបដិសេធអាពាហ៍ពិពាហ៍ដែលរៀបចំដោយបក្ស[2357] ជា "នាយទុន [ឬ] ពួកសក្តិភូមិ"[2358] ការនិយាយប្រឆាំងនឹងរបបនោះ ឬការលើកទឹកចិត្តអ្នកផ្សេងមិនឲ្យធ្វើការ[2359]។ នៅពេលមកដល់ អ្នកទោសត្រូវបានចាត់ថ្នាក់ជាក្រុមអ្នកជាប់ "ទោសស្រាល" និង "ទោសធ្ងន់" អាស្រ័យលើ "កំហុស" ដែលពួកគេត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត[2360]។ ប្រសិនបើអ្នកទោសស្រាលត្រូវបានគេយល់ថាបានប្រព្រឹត្តកំហុសបន្ថែមទៀតនោះ រូបគេអាចនឹងត្រូវចាត់ថ្នាក់ឡើងវិញ[2361]។

[2353] ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខែក ចន ឆ.៥៨ KH 00987995។

[2354] ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខែក ចន ឆ.៣១ KH 00987992។

[2355] ឯកសារ D118/237 កំណត់ហេតុស្តាប់ចម្លើយ ទិត កះ ឆ.៦៩-៧០ KH 00988020។ *សូមមើលផងដែរ* ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.៨០-៨១ KH 00974000។ ឯកសារ D5/748 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ មូល រ៉ាន់ KH 00914937-38 [រៀបរាប់ពីការបានឃើញមិត្តភក្តិពីរនាក់ត្រូវបានឈ្លបនៅសហការណ៍ត្រាំសะចាប់ខ្លួន ហើយយកទៅកាន់មន្ទីរឃុំខ្លួននៅថ្ពល ទំនងជានៅឆ្នាំ១៩៧៦ ដោយសារភាពអត់ឃ្លាន ពួកគេបានរកជីកដំឡូងព្រៃ]។

[2356] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["ដោយចោទខ្ញុំថា ខុសសីលធម៌ជាមួយនារី ១៧ មេសា ប៉ុន្តែខ្ញុំមិនបានធ្វើខុសសីលធម៌អ្វីទេ"]។

[2357] ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារ៉ីន ឆ.៥៤ KH 00977110 [ដោយការបញ្ជាក់ពីសេចក្តីថ្លែងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ (ឯកសារ D5/794 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រស់ ណារ៉ិន KH 00918334) ដែលថា នៅឆ្នាំ១៩៧៧ មិត្តភក្តិម្នាក់ឈ្មោះ សុន សុផល បានប្រកែកមិនព្រមរៀបការនឹងបុរសម្នាក់ ដែលនាងមិនដែលស្គាល់ ហើយត្រូវបានបញ្ជូនទៅកាន់មន្ទីរផ្ទោល ឬមន្ទីរតាយិន ដោយបានចោទប្រកាន់ថាជាអ្នកក្បត់]។

[2358] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370 [ពួកអ្នកទោសរួមមានពួកអ្នកដែល "ដែលគេចោទថាជានាយទុន ពួកសក្តិភូមិ"]។

[2359] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["ចំពោះអ្នកទោសខាងផ្នែកនយោបាយ ដូចជាអ្នកនោះនិយាយប្រឆាំងខ្មែរក្រហម ឬនិយាយកុំឲ្យប្រជាជនធ្វើការ គឺដាក់នៅកន្លែងធ្ងន់។"]។

[2360] ឯកសារ D219/702.1.4 លឹម សាត ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 13.58.18-14.00.14 [ដោយការពន្យល់ពីប្រភេទទោស "ត្រូវគេដាក់ថាទោសធ្ងន់ គឺទោសធ្ងន់ដែរ អ៊ីចេះ"]។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី ឆ.២១ KH 01022019។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423។ ឯកសារ D118/147.1.3 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទាំ ជះ KH 00557659។

[2361] D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["ចំពោះអ្នកទោសស្រាល [...] បើនៅតែធ្វើខុសទៀតនឹងត្រូវដាក់ក្នុងទោសធ្ងន់។"]។

645. លីម សាត ដែលបានជាប់ឃុំនៅស្វាយជ្រុំពីចុងឆ្នាំ១៩៧៦ ដល់ចុងឆ្នាំ១៩៧៨[2362] បានប៉ាន់ប្រមាណថាមានអ្នកទោសជាង ១០០នាក់ នៅក្នុងផ្នែកទោសធ្ងន់ ហើយអ្នកទោសស្រាល និងក្រុមគ្រួសាររបស់ពួកគេមានប្រហែលជា ២០០០នាក់[2363]។ ទោះបីជារូបគាត់មិនបានរំឭកអំពីអ្នកទោសចូលថ្មីក៏ដោយ[2364] ក៏អ្នកផ្សេងៗ រួមទាំងអតីតអ្នកទោសឈ្មោះ ឡាយ បូនី បានផ្តល់ភ័ស្តុតាងអំពីក្រុមអ្នកទោសដែលមានដល់ទៅរាប់រយនាក់នៅពេលមួយនោះ បានចូលមកដល់មន្ទីរនេះ[2365]។ វាមានសភាព "អ៊ូអ៊ែរចេចចាចចុះឡើង"[2366] និងមាន "ច្រើនណាស់ខ្ញុំមិនអាចរាប់បានទេ"[2367]។ សូម្បីតែការធ្វើការពិចារណាថា ទាំង លីម សាត និង ឡាយ បូនី ទំនងជាបានមកដល់ស្វាយជ្រុំភ្លាមៗ មុនពេលកងកម្លាំងភូមិភាគនិរតីបានគ្រប់គ្រងតំបន់៧នោះក៏ដោយ ក៏វាច្បាស់លាស់ណាស់តាមរយៈចំនួនសរុបនៃភ័ស្តុតាងបង្ហាញថា មានមនុស្សរាប់ពាក់នាក់ត្រូវបានឃុំឃាំងក្រៅប្រព័ន្ធតុលាការក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី និងបស្ចឹម។

<u>អំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌)</u>

646. អ្នកទោសដែលខ្មែរក្រហមបានចាត់ថ្នាក់ថា "ទោសធ្ងន់" នោះ ត្រូវបានបង្ហត់ពន្លឺអស់រយៈពេលយ៉ាងយូរ ខណៈដែលត្រូវគេចាក់សោរ ក្រោមការយាមកាមដោយអ្នកយាមប្រដាប់ដោយអាវុធ នៅក្នុង

[2362] ឯកសារ D6.1.685 កំណត់ហេតុស្តាប់ចម្លើយ លីម សាត ឆ.១១ KH 00407763។

[2363] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លីម សាត KH 00242423 ["សរុបអ្នកទោសប្រហែលជាង១០០នាក់ [នៅក្នុងផ្នែកទោសធ្ងន់] [...] អ្នកទោសស្រាលមានប្រហែល ២០០០នាក់ ដោយពួកខ្មែរក្រហមចាប់ទាំងគ្រួសារៗ"]។ *សូមមើលផងដែរ* ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជះ ឆ.២៩ KH 01102798 ["គេ [ខ្មែរក្រហម] យកទៅទាំងប្តីទាំងកូនខ្ញុំ ទៅទាំងអស់"]។

[2364] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លីម សាត KH 00242424-25។

[2365] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ បូនី (ឧបសម្ព័ន្ធ) KH 00359370-71 [បានជាប់ឃុំនៅស្វាយជ្រុំ ចាប់តាំងពីពាក់កណ្តាលឆ្នាំ១៩៧៦ រហូតដល់ ចុងឆ្នាំ១៩៧៨ (*សូមមើល* ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី ឆ.៣-៤, ៦, ៨ KH 01022016-17) "ដឹកមកពីសហការណ៍នានា [...] ឃើញមនុស្សច្រើន [...] គាប់ជួនព្រឹកនោះគេដឹកអ្នកទោសមកទំលាក់ចោលជាច្រើនមិនដឹងជាប៉ុន្មានរយនាក់ទេ"]។ ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.13.49-11.15.03 ["អ៊ីចឹង អត់ពីរថ្ងៃ មួយថ្ងៃសម្លាប់ៗ យកទៅម្តងពី ២០០នាក់ជាង ៣០០នាក់ ១០០នាក់ ជាង១០០នាក់។ ចាស យកទៅសម្លាប់"]។ ឯកសារ D118/147.1.3 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទាំ ជះ KH 00557659 ["ពេលមនុស្សឡើងឡានពេញហើយ ឡានក៏បើកចេញបរដឹកយកមកដាក់នៅមន្ទីរផ្ទោល"]។ ឯកសារ D219/241 កំណត់ហេតុស្តាប់ចម្លើយ អម សុខុន ឆ.៨១-៨២ KH 01080905។

[2366] ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.13.49-11.15.03។

[2367] ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី ឆ.១៤ KH 01022018។

អគារមួយដែលគេស្គាល់ថាជា "គុកងងឹត" គេហៅដូច្នោះដោយសារវាមិនមានបង្អួច[2368]។ ដោយសារអ្នកទោសមួយចំនួននៅក្នុងក្រុមនេះ មិនត្រូវបានគេបញ្ជេញទៅក្រៅឲ្យទៅធ្វើការនោះ[2369] ពួកគេត្រូវបានគេទុកចោលនៅក្នុងបន្ទប់ឃុំងងឹត និងគ្មានខ្យល់ទាំងថ្ងៃទាំងយប់[2370]។ អ្នកជាប់ឃុំទាំងអស់នេះត្រូវបានគេដាក់ច្រវ៉ាក់ ពេលដែលដឹកទៅកាន់ស្វាយជ្រុំ[2371] និងត្រូវដាក់ខ្នោះបន្ត ទៀតនៅក្នុងកន្លែងឃុំឃាំងពេលដេក ធ្វើការ បន្ទោរបង់ និងហូបអាហារ[2372]។ នៅក្នុងបន្ទប់ស្ត្រី

[2368] ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី ឆ.៥ KH 01022016 ["គុកថ្ម្លលនេះគេហៅថា គុកងងឹត"] ឆ.១០ KH 01022018 ["ចំណែកអ្នកទោសមួយប្រភេទទៀត [ប្រភេទធ្ងន់] គឺត្រូវគេឃុំឃាំងនៅក្នុងគុកងងឹតរហូត"]។ ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 09.44.38-09.47.48។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242423 ["អោងសម្រាប់ដាក់អ្នកទោសធ្ងន់មានតែមួយទេ ហើយបិទជិតមិនមានបង្អួចទេ គឺមានតែទ្វាសម្រាប់ចូលតែប៉ុណ្ណោះ។ ពេលយប់ចាក់សោរនៅក្នុងអោង ដោយមានឈ្លបយាម"]។

[2369] ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373252 ["ប្តីរបស់ខ្ញុំ[ជាអ្នកទោសធ្ងន់]មិនបានចេញក្រៅធ្វើការទេ"]។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខែក ចន ឆ.៣១ KH 00987992 ["អ្នកទោសធ្ងន់ គេពុំបញ្ជេញមកធ្វើការនោះទេ"]។ *ប៉ុន្តែសូមមើល* ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424 ["ចំពោះអ្នកទោសធ្ងន់ ក៏ឲ្យចេញមកធ្វើការដែរ"]។ ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373252 ["អ្នកទោសប្រុសដែលនៅជាប់ខ្នោះជើង ត្រូវបានគេឲ្យធ្វើការនៅក្នុងទីធ្លាគុក"]។

[2370] ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373252-53 ["ប្តីរបស់ខ្ញុំ [...] ត្រូវបានគេចាក់សោនៅក្នុងគុក។ [...] ខ្ញុំបានផ្តល់ចំណីអាហារដល់គាត់ ដោយហុចតាមប្រហោងតូចមួយនៅក្នុងគុកនោះ [...] ប៉ុន្តែមើលគាត់អត់ឃើញទេ"]។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី ឆ.១០ KH 01022018 ["ចំណែកអ្នកទោសមួយប្រភេទទៀត គឺត្រូវគេឃុំឃាំងនៅក្នុងគុកងងឹតរហូត ទោះបីពេលហូបចុក ឬក៏បន្ទោរបង់ក៏ដោយ"]។

[2371] ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373252 ["ប្តីរបស់ខ្ញុំ[ជាអ្នកទោសធ្ងន់]ត្រូវបានគេចងស្ពាយសេក"]។ ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជ១ ឆ.២៩ KH 01102798-99 ["ពេលខ្ញុំទៅដល់ ខ្ញុំឃើញទាហានស្ទេ។ ពេលទៅដល់ហ្ម៉ង អ្នកដែលគេចងបីនាក់នៅខាងលើឡាន គេយកទៅវាយចោល។ [...] ហើយអ្នកត្រូវបានគេចងផ្សេងទៀត គេយកទៅដាក់មន្ទីរតួ្ម"]។ ឯកសារ D118/147.1.3 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទាំ ជ១ KH 00557659 ["អ្នកទោសធ្ងន់ត្រូវគេដាក់ច្រវ៉ាក់ ពេលមនុស្សឡើងឡានពេញហើយ ឡានក៏បើកចេញបរដឹកយកមកដាក់នៅមន្ទីរផ្ទោល"]។

[2372] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 0024242។ ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373252។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី ឆ.១០ KH 01022018។ *សូមមើលផងដែរ* ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ* ការរៀបរាប់របស់ អ៊ីម ស៊ីថា KH 00233426 ["មន្ទីរសន្តិសុខនៃតំបន់ប្រាំពីរមានទីតាំងនៅជិតការិយាល័យស្រុកបាកាន នៅថ្ងល [...] អ៊ីម ស៊ីថា បានឃើញច្រវ៉ាក់ និងខ្នោះដែកប្តូរពីកន្លែងមួយ ទៅកន្លែងមួយទៀត"]។

ដាច់ដោយឡែកមួយ[2373] អ្នកទោសត្រូវស្ថិតក្រោមភាពអាម៉ាស់ដោយការបន្ទោរបង់ និង នោម នៅខាងក្នុងបន្ទប់ឃុំឃាំង ដាក់ចូលក្នុងចានដែលគេប្រើសម្រាប់ដាក់បាយផងដែរនោះ។ ចាននោះត្រូវបានគេផ្ទៀងចាក់ចូលទៅក្នុងប្រអប់ឈើ ដែលត្រូវគេយកទៅចាក់ចោលរាងរាល់ពីរបីថ្ងៃម្តងប៉ុណ្ណោះ ដែលបង្កើតឲ្យមានក្លិនមិនអាចទ្រាំបាន[2374] និងស្ថិតក្នុងសភាពគ្មានអនាម័យបំផុត។ បន្ទប់នោះចង្អៀតយ៉ាងខ្លាំង ដែលអ្នកជាប់ឃុំត្រូវបង្ខំឲ្យដេកអង្គុយ[2375] ពេលខ្លះពេលសម្លៀកបំពាក់របស់ពួកគេនៅសើមនៅឡើយបន្ទាប់ពីធ្វើការខាងក្រៅរួច[2376]។ ក្នុងគុកទាំងមូល អ្នកជាប់ឃុំត្រូវបានគេវាយដំយ៉ាងព្រៃផ្សៃ ជាញឹកញាប់ដោយដំបង និងខ្សែតី[2377]។

[2373] ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី ឆ.១០ KH 01022018។

[2374] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359368-69 ["នាងខ្ញុំគេនាំបង្ហួសទៅបន្ទប់មួយផ្សេងទៀតសំរាប់ដាក់អ្នកទោសស្ត្រី។ ក្នុងកន្លែងនោះមិនគួរឲ្យជឿទេប្រសិនបើមិនបានឃើញផ្ទាល់ភ្នែក បើកទ្វារភ្លាមធំអសោចក្លិនលាមក និងទឹកនោម។ [...] ក្លិនស្អុយចានក្បានសំរាប់ហូបបាយ បែរជាគេយកមកប្រើសំរាប់ត្រងលាមកពេលបត់ជើងទៅវិញ រួចទើបកាន់យកទៅចាក់ចោលនៅកណ្តាលបន្ទប់ដែលមានធុងធ្វើពីឈើរាងបួនជ្រុង រយៈពេលមួយថ្ងៃមួយយប់ទើបគេយកលាមកនោះចេញទៅចាក់ទុកធ្វើជីនៅកន្លែងផ្សេងទៀត"]។ ឯកសារ D267.1.99 ឡាយ ឫទ្ធី ប្រតិចារឹកថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 09.47.48-09.49.35 ["ហើយខ្ញុំ ដល់ពេលវាស្អុយពេក [...] ខ្ញុំខំយកច្រមុះមកផ្ទឹបនឹងប្រហោងទ្វារដកដង្ហើមឲ្យស្រួល"]។

[2375] ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី KH 00373252 ["នៅក្នុងបន្ទប់នោះពេលយប់ មានមនុស្សកកកុញគ្មានកន្លែងសម្រាប់ទម្រេតខ្លួនទេ ខ្ញុំអាចត្រឹមតែអង្គុយតែប៉ុណ្ណោះ"]។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359369 ["ចូលក្នុងបន្ទប់វិញយ៉ាងកុះករកកន្លែងសំរាកដេកគ្មានព្រោះចង្អៀត ត្រូវតែដេកអង្គុយទាំងអស់គ្នា"]។

[2376] ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី ឆ.៥ KH 01022016-17។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359369 ["ជារដូវវស្សា [...] ខ្ញុំមានតែខោអាវមួយចង្កេះជាប់នឹងខ្លួន ចូលកន្លែងដេកទាំងខោអាវទទឹក ភ្ជឿងចុះទៅធ្វើការទាំងខោអាវសើមដដែល"]។

[2377] D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424 ["ពួកខ្មែរក្រហមធ្វើបាបអ្នកទោសដូចជា [...] រ៉ែ។ ខ្ញុំឃើញវ៉ែធ្វើបាបដោយផ្ទាល់ភ្នែក ដោយវ៉ែនឹងព្រនង់ ឬខ្សែតី។ ហើយក្រោយមកពួកឈ្លបបានយកអ្នកទោសទៅសម្លាប់ចោល [...] ខ្ញុំឃើញមានការវ៉ែធ្វើបាបអ្នកទោសជាញឹកញាប់"]។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370 ["ដោយអំណាចអង្គការ វាចង់វាយទាត់អ្នកទោសណាក៏បានមិនថាចាស់ រឺក្មេងស្រីប្រុស ស្រេចតែចិត្តវាចង់"]។ *សូមមើលផងដែរ* ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី KH 00373252 ["យើងទៅដល់កន្លែងមួយដែលគេហៅថា មន្ទីរកែប្រែផ្លូវ [...] ទាហានទាំងនោះបានឲ្យសំបុត្រមួយទៅអ្នកយាម ហើយនៅពេលដែលអ្នកយាមបានអានសំបុត្រនោះរួចភ្លាម គេវាយដំប្តីរបស់ខ្ញុំរហូតដល់ហូរឈាមស្រោចខ្លួន"]។

647. របបអាហារមិនគ្រប់គ្រាន់ទាល់តែសោះ។ លឹម សាត ដែលជាអ្នកទោសស្រាល បានរំឭកថា គាត់បានទទួលតែ "ទឹកបបរ ដោយក្នុងមួយខ្ទះមានអង្ករ ៤កំប៉ុងសម្រាប់គ្នា ៣០ នាក់"[2378]។ សូម្បីតែបរិមាណដ៏ស្តួចស្តើងនោះក៏អាចត្រូវបានគេដកហូតតាមអំពើចិត្តដែរ។ អ្នកទោសដែលមិនអាចធ្វើការបានដោយសារតែឈឺនោះ ត្រូវបានគេដាក់ទណ្ឌកម្មដោយកាត់បន្ថយរបបអាហារ ឬដោយការវាយដំ ហេតុដូច្នេះអ្នកដែលឈឺខំប្រឹងប្រែងធ្វើការដើម្បីចៀសវាងភាពអត់ឃ្លាន[2379]។ ប្រសិនបើពួកគេខកខានមិនបានធ្វើដូច្នោះទេ ឈ្លបសម្លាប់ពួកគេចោលនៅក្នុងព្រៃ[2380]។ ឡាយ ឫទ្ធី ស្រែកឃ្លានចង់ហូបអាហារយ៉ាងខ្លាំង ដូច្នេះជាច្រើនដងគាត់ស្ម័គ្រចិត្តទៅកាន់ "ភាគ" ដែលជាកន្លែងអ្នកទោសត្រូវបានគេសន្យាថាទទួលបានអាហារឆ្ងាញ់ៗជាច្រើន។ ក្រោយមកទើបគាត់ដឹងថា ការណ៍ដែលទៅ "ភាគ" នេះ មានន័យថាសម្លាប់ចោល[2381]។ អ្នកជាប់ឃុំបានធ្លាក់ខ្លួនអស់កម្លាំង ស្គមស្គាំង និងឈឺ ដោយសារតែលក្ខខណ្ឌអនាម័យទាប និងរបបអាហារមិនគ្រប់គ្រាន់[2382]។

648. អ្នកទោសជាច្រើនក៏ត្រូវគេតម្រូវឲ្យធ្វើការផងដែរ។ បន្ទាប់ពីដំណើរការជ្រើសរើសនៅពេលព្រឹក ដើម្បីកំណត់ថាអ្នកណាមួយក្នុងចំណោមពួកគេត្រូវធ្វើជា "ទាសករ" និងអ្នកណាត្រូវសម្លាប់ចោល

[2378] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424។ *សូមមើលផងដែរ* ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី KH 00373252។ ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជ៉ះ ឆ.២៩ KH 01102798-99។

[2379] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424 ["ពួកខ្មែរក្រហមធ្វើបាបអ្នកទោសជូចជាការបង្អត់បាយ ឬបបរ"]។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359369 ["ឈឺទៅអត់រួច បានហូបតែបបរមួយវែក និងអំបិលមួយគ្រាប់ទេ ដូចនេះអ្នកឈឺល្មមៗក៏ប្រឹងប្រែងចេញទៅធ្វើការនៅខាងក្រៅជាមួយគេដែរ"]។ ឯកសារ D267.1.99 ឡាយ ឫទ្ធី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.59.08-12.01.51។

[2380] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359369 ["អ្នកខ្លះហត់ពេកត្រូវឈឺ ត្រឡប់មកផ្ទះវិញមិនរួចគ្មានទីណាជួយគ្រាមកវិញត្រូវកងឈ្លបដែលនាំទៅធ្វើការ សម្លាប់ចោលនៅកណ្តាលព្រៃនោះតែម្តង"]។

[2381] ឯកសារ D267.1.99 ឡាយ ឫទ្ធី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 09.49.35-09.52.54។

[2382] ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជ៉ះ ឆ.២៩ KH 01102799 ["ម្នាក់ៗចង់ចេះដើង ព្រោះយើងធ្លាប់តែហូបបាយ"]។ ឯកសារ D5/249.1 ក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359368 ["ខ្ញុំក្រឡេកមើលជុំវិញឃើញមានអ្នកទោសបីបួននាក់ដែកឈឺអត់បានចេញទៅធ្វើការទេ"] KH 00359370 ["ខ្ញុំស្គមមានតែស្បែកដណ្តប់ឆ្អឹង"]។ ឯកសារ D267.1.99 ឡាយ ឫទ្ធី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.59.08-12.01.51។

នៅថ្ងៃនោះ[2383] អ្នកដែលរួចជីវិតត្រូវធ្វើការនៅខាងក្រៅក្រោមការយាមកាមរបស់ឈ្លប ធ្វើការជីកប្រឡាយ ឬអាងទឹក លើកភ្ជីស្រែ និងធ្វើស្រែ[2384]។ អ្នកទោសធ្ងន់ធ្វើទាំងជើងជាប់ច្រវ៉ាក់[2385]។

ការធ្វើទារុណកម្ម

649. អំពើទារុណកម្មត្រូវបានប្រើលើអ្នកទោសក្នុងពេលសួរចម្លើយនៅស្វាយជ្រុំ ក្នុងគោលបំណងទាញយកព័ត៌មាន និងចម្លើយសារភាព[2386]។ វិធីសាស្ត្ររួមមាន ការវាយដំ ជាញឹកញាប់ដោយដំបងឫស្សី និងខ្សែតី ជ្រមុជទឹក និងចាក់ទឹកលើក្បាល និងការដកក្រចកអ្នកទោស[2387]។

[2383] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទី (ឧបសម្ព័ន្ធ) KH 00359370 ["រាល់ពេលព្រឹកចេញទៅធ្វើការ គេឲ្យតម្រង់ជួរៗហើយមេកងតាមកងនិមួយៗត្រូវដើរចង្អុលមុខទាសករ ដកចេញយកមកឈរជួរផ្សេងទៀត ត្រប់កងតាមតម្រូវការរបស់គេ។ [...] ។ លុះដកមនុស្សដូរចុះឡើងហើយ មេកងនោះក៏បញ្ជាឲ្យចេញទៅធ្វើការខាងក្រៅ"]។

[2384] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424 ["ពួកឈ្លបយាមកាមពេលកំពុងធ្វើការ។ [...] ការងាររបស់អ្នកទោសស្រាលគឺជីកប្រឡាយ និងលើកភ្ជី ចំណែកអ្នកទោសធ្ងន់ គឺជីកអាងទឹកនៅកែ្សរមន្ទីរ។"]។ ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទី KH 00373252-53 ["យើងធ្វើស្រែ ស្ទូងស្រូវ។ [...] ក្រោយមកទៀត ខ្ញុំបានចូលរួមក្នុងកងស្រូច (កងប្រយុទ្ធ) ដែលត្រូវធ្វើការងារធ្ងន់"]។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទី (ឧបសម្ព័ន្ធ) KH 00359371 ["[ពួកគេ] គឺចេញទៅធ្វើការនៅសមរភូមិមុខ លើកទំនប់ ជីកប្រឡាយ ស្ទូងដកនៅខាងក្រៅ ទៅតាមដីស្រែ"]។

[2385] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424។ ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទី KH 00373252-53។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខែក ចន ឆ.៣០-៣១ KH 00987992។

[2386] ឯកសារ D267.1.99 ឡាយ ឫទី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.59.08-12.01.51។ ឯកសារ D118/147.1.3 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទាំ ជះ KH 00557659 ["ប្តីខ្ញុំត្រូវគេហៅទៅសួរចម្លើយបីព្រឹកជាប់គ្នា គឺសួរតែសំណួរដដែលៗ"]។ ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារ៉ីន ឆ.៥៤, ៦០ KH 00977110-11។

[2387] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទី ឆ.១៣, ១៦, ១៩ KH 01022020។ ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារ៉ីន ឆ.៥៤, ៦០ KH 00977110-11។ ឯកសារ D267.1.99 ឡាយ ឫទី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.59.08-12.01.51 *បញ្ជាក់* ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទី KH 00373252-53។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខែក ចន ឆ.៣១ KH 00987992។

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

650. មានអ្នកទោសខ្លះពិតជាបានរួចជីវិតពីគុកស្វាយជ្រុំ[2388]។ ទោះជាយ៉ាងណា អ្នកទោសភាគច្រើនត្រូវបានសម្លាប់ ឬបាត់ខ្លួនក្នុងកាលៈទេសៈនានាដែលបញ្ជាក់ថា ពួកគេត្រូវបានសម្លាប់[2389]។ ការសម្លាប់អ្នកទោស ជាពិសេស នៅព្រៃភាគ បានកើតមានឡើងក្នុងទ្រង់ទ្រាយធំក្នុងរយៈពេលប្រតិបត្តិការរបស់គុកស្វាយជ្រុំទាំងមូល[2390] ជាពិសេសនោះក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់ភូមិភាគនិរតី និងបស្ចិម។

651. អ្នកទោសបានបាត់ខ្លួនពីគុក "ជាបន្តបន្ទាប់"[2391]។ ឡាយ បូនី បានរៀបរាប់អំពីការផ្តាស់ប្តូរអ្នកទោស និងលំនាំជាប្រព័ន្ធនៃការសម្លាប់ក្នុងចំនួនដ៏ច្រើន រហូតដល់ចុងឆ្នាំ១៩៧៧[2392]។ បន្ទាប់ពីអ្នក

[2388] ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខ្ចែក ចន ឆ.៤០ KH 00987993។ ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លីម សាត KH 00242425 [សាក្សីខ្លួនឯងផ្ទាល់ជាអ្នករួចជីវិតពីគុកស្វាយជ្រុំ។ គាត់បានរាយការណ៍ថា "មានអ្នកទោសនៅរស់ប្រហែល ៤០០ ទៅ ៥០០នាក់ ក្រោយឆ្នាំ១៩៧៨"។ *កត់សម្គាល់* ទោះជាយ៉ាងណា ថាគាត់ពេលក្រោយមកទៀតបានបញ្ជាក់ថាពួកគេត្រូវបានបញ្ជូនទៅកាន់ត្រាចក្រោល ដែលជាកន្លែងគាត់ជឿថាពួកគេត្រូវបានសម្លាប់ចោល។ *សូមមើល* ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លីម សាត ឆ.៨ KH 00947339។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី (ឧបសម្ព័ន្ធ) KH 00359371 [អតីតអ្នកទោសដែលបានពន្យល់ថា គាត់បានរស់ជីវិតដោយសារគាត់ខំប្រឹងធ្វើការ និងត្រូវបានការពារដោយប្រធានកងរបស់គាត់]។

[2389] *សូមមើល ឧទាហរណ៍* ឯកសារ D118/237 កំណត់ហេតុស្តាប់ចម្លើយ ទិត កះ ឆ.៧០, ៧២ KH 00988020។ ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខ្ចែក ចន ឆ.៥៨, ៦០ KH 00987995។ ឯកសារ D5/748 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មូល រ៉ាន់ KH 00914938 ["មិត្តទាំងពីរនាក់នេះ តាំងពីជាប់ក្នុងមន្ទីរឃុំឃាំងផ្ទោលមកគឺបាត់ខ្លួនរហូត"]។ *សូមមើលផងដែរ* ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.៨៥-៨៧ KH 00974000-01។

[2390] ទាក់ទងនឹងការសម្លាប់ជាក់លាក់នានាដែលបានកើតឡើងនៅស្វាយជ្រុំ ទំនងជាបានកើតមុនពេលកម្ម្ចាភិបាលនិរតីបានមកគ្រប់គ្រង, *សូមមើល* ឧទាហរណ៍ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.១៧-១៨, ២៣ KH 00947329-30។ ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373252។

[2391] D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លីម សាត KH 00242424. *សូមមើល* ឧទាហរណ៍ ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.15.03-11.17.00 ["បានមកតែពីរថ្ងៃ [អ្នកទោសថ្មី] បានមមកតែបីថ្ងៃ ឬមួយយប់ គឺយកទៅឡើងស្លាត់អស់ហើយ"]។

[2392] ទោះបីជា ឡាយ បូនី យោងទៅរក "ចុងឆ្នាំ១៩៧៦" នៅក្នុងកំណត់ហេតុស្តាប់ចម្លើយមួយ (*សូមមើល* ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ បូនី KH 00373254) ក៏ដោយ ក៏សក្ខីកម្មសំណុំរឿង ០០២/០១ របស់គាត់ (*សូមមើល* ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 09.49.35-09.54.12 ["ចុងឆ្នាំ-- ពាក់កណ្តាលឆ្នាំ៧៧ ប្រហែលជា ១០ម៉ឺននាក់ អ្នកដែលត្រូវសម្លាប់ហ្ម៊ីងចាស"]) បញ្ជាក់សេចក្តីផ្ទែងនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ ដែលថា អត្រាដ៏ខ្ពស់នៃការសម្លាប់ចោលនេះបានកើតឡើងរហូតដល់ចុងឆ្នាំ១៩៧៧ (*សូមមើល* ឯកសារ D5/249.1

ទោសថ្មីបានមកដល់ស្វាយជ្រុំ "ឃើញមនុស្សច្រើនតែ ២-៣ថ្ងៃ ក៏ត្រូវស្លាប់អស់"[2393]។ អ្នកទោសខ្លះត្រូវបានសម្លាប់ចោលស្ទើតែភ្លាមៗតែម្តង[2394] ប៉ុន្តែយ៉ាងហោចណាស់រាល់បីថ្ងៃម្តង ទាហានទឹងជ្រើសរើសយ៉ាងហោចណាស់អ្នកទោសពី ២០ ទៅ ៣០នាក់ ពេលខ្លះច្រើនរហូតដល់ ២០០នាក់ តាមអំពើចិត្ត (ប្រុស ស្រី និងសូម្បីតែកុមារ) យកទៅសម្លាប់ ខណៈដែលអ្នកទោសនៅសល់ត្រូវបញ្ជូនទៅធ្វើការ[2395]។ មានតែអ្នកដែលមានសម្បទារ និងមានប្រយោជន៍បំផុតប៉ុណ្ណោះដែលរួចជីវិត[2396]។ ក្នុងការប្រៀបធៀបគួរឲ្យរន្ធត់មួយ មេកងម្នាក់នៅមន្ទីរនេះបានយោងទៅកាន់ដំណើរការនេះថាជា "ចំរ៉ាញ់យកអង្ករដើម" ដែលមានន័យថា "សម្លាប់មនុស្សអាក្រក់ និងទុកមនុស្សល្អរបស់អង្គការ"[2397]។ មានថ្ងៃមួយ អ្នកទោសរាប់រយនាក់ត្រូវបាននាំមកកាន់ស្វាយជ្រុំ ហើយនៅពេលថ្ងៃត្រង់ ភាគច្រើននៃអ្នកទាំងនោះ បើមិនទាំងអស់ទេ ត្រូវបានសម្លាប់ចោល[2398]។ តាមពិត

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ), KH 00359370 [[គេ] ធ្វើបែបនេះជារៀងរាល់ពាក់ថ្ងៃម្តង រហូតដល់ចុងឆ្នាំ១៩៧៧ (ជាផែនការសម្លាប់របស់ ប៉ុល ពត)"])។

[2393] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370។

[2394] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370 ["ខ្លះបានតែមួយយប់ត្រូវបញ្ជូនទៅភាគអស់ (មានន័យថា យកទៅសម្លាប់ចោលនៅជុំវិញមន្ទីរនេះតែម្តង"]។ ឯកសារ D5/748 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មូល រ៉ាន់ KH 00914938 ["ប្រជាជន ១៧ ដែលបានដើរកត្រី ឫតស្រូវ គាស់ដំឡូង បើឈ្លបឃើញ គឺឈ្លបចាប់ប្រមូលយកទៅសម្លាប់នៅម្តុំព្រៃផ្ទោលទាំងអស់"]។

[2395] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370 [ជាទម្លាប់រៀងរាល់ពាក់ថ្ងៃ ដែលគេហៅថាថ្ងៃធ្វើការ គឺកងវ័យកណ្តាល បុរស និងស្ត្រី កងកុមារា និងកុមារី ត្រូវនៅសម្រាកនៅនឹងកន្លែងអត់ឲ្យចេញទៅធ្វើការនៅខាងក្រៅទេ ពេលថ្ងៃនោះគេហៅថា ថ្ងៃយោធាធ្វើការ គឺមានយោធា ២ទៅ៣នាក់ ដើរមកប្រាប់តាមកន្លែងសម្រាកគ្រប់គ្នាថា សុំអ្នកវ័យកណ្តាល ២០នាក់ កុមារា កុមារី ៣០នាក់ ឬកសរុបប្រហែលជិត១០០នាក់ ឬជាង១០០នាក់ ដោយគេចង្អុលយកស្រេចចិត្ត ដើម្បីយកទៅភាគ ធ្វើបែបនេះជារៀងរាល់ពាក់ថ្ងៃម្តង រហូតដល់ចុងឆ្នាំ១៩៧៧។ [...] ផ្ទុយទៅវិញពាក្យដែលហៅថាភាគនោះគឺ មិនមែនភាគពិតប្រាកដដូចខ្ញុំបាននិយាយខាងលើទេ "យកទៅភាគ"គឺគេយកទៅសម្លាប់។[...] មេកងតាមកងនិមួយៗត្រូវដើរចង្អុលមុខទាសករ ដកចេញយកមកឈរជួរផ្សេងទៀត [...] លុះដកមនុស្សដូរចុះឡើងហើយ មេកងនោះក៏បញ្ជាឲ្យចេញទៅធ្វើការខាងក្រៅ"]។ ឯកសារ D267.1.99 ឡាយ ឫទ្ធី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 11.13.49-11.15.03 ["អត់ពីរថ្ងៃមួយថ្ងៃសម្លាប់ៗ យកទៅម្តងពី ២០០នាក់ជាង ៣០០នាក់ ១០០នាក់ ជាង១០០នាក់។ ចាស យកទៅសម្លាប់។"]។

[2396] ឯកសារ D5/748 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មូល រ៉ាន់ KH 00914938 ["ចំណែកអ្នកទោសស្រាល ពួកវាប្រើលុះអស់កម្លាំង យកទៅសម្លាប់ដូចគ្នា"]។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370-71 ["តែកម្លាំង[ខ្ញុំ]មាន [...] ដូច្នោះ មេកងបានកត់សំគាល់នាងខ្ញុំទុក"]។

[2397] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370-71។

[2398] ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370-71។

នោះ អ្នកទោសធ្ងន់ភាគច្រើនត្រូវបានសម្លាប់[2399]។ ឡាយ ឃូនី បានធ្លាក់ក្លិនសាកសពស្អុយសាយភាយពេញគុកនេះ និងបានឃើញសម្លៀកបំពាក់ប្រឡាក់ឈាមជាច្រើនរបស់ពួកអ្នកដែលស្លាប់ទាំងនោះ[2400]។

652. មានសាក្សីផ្ទាល់ភ្នែកជាច្រើនបានឃើញការសម្លាប់នៅស្វាយជ្រុំ។ លីម សាត បានឃើញឈ្លបបង្ខំជនរងគ្រោះឲ្យជីវណ្ណៅកប់សពខ្លួនឯង មុនពេលសម្លាប់នៅព្រៃភាគ និងបានឃើញការសម្លាប់មនុស្សប្រាំគ្រួសារ[2401]។ អ្នកភូមិមូលដ្ឋានក៏បានឃើញការសម្លាប់ផងដែរ[2402]។ ពេជ្ឈឃាតខ្មែរក្រហមនៅស្វាយជ្រុំ ដែលខ្លួនឯងផ្ទាល់ក្រោយមកត្រូវបានឃុំខ្លួន និងសម្លាប់នៅទីតាំងនេះផងដែរ នោះ បានរៀបរាប់ទៅកាន់អតីតអ្នកទោស ឡាយ ឃូនី អំពីអត្រានៃការសម្លាប់ដ៏ច្រើននៅព្រៃភាគ ចាប់តាំងពីគុកនេះបានបើកដំណើរការ ដោយបានប៉ាន់ប្រមាណថា នៅចុងឆ្នាំ១៩៧៧ មានមនុស្ស

[2399] ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជ១ ឆ.២៩ KH 01102798-99 ["អ្នកដែលគេចាប់ដាក់មន្ទីរត្បូង ច្រើនតែគេយកទៅវាយចោល"]។ ឯកសារ D5/748 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មូល រ៉ាន់ KH 00914938 ["អ្នកដែលជាប់ក្នុងមន្ទីរនេះ អ្នកណាដែលគេចោទថា មានទោសធ្ងន់ គឺសម្លាប់ចោលភ្លាមនៅព្រៃខាងត្បូងមន្ទីរផ្ទោល"]។

[2400] ឯកសារ D267.1.99 ឡាយ ឃូនី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 09.49.35-09.52.54 ["អ៊ីវ៉ែអ៊ីវ៉ាន់ខោអាវ អ្នកដែលនៅជាមួយគ្នានឹងខ្ញុំហ្ម៉ឹង គឺត្រឡប់មកឲ្យយើងប្រើវិញទាំងអស់។"] ម៉ោង 11.15.03-11.17.00។ ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឃូនី KH 00373254 ["ខ្ញុំជឿថា តួលេខនេះ[១០០,០០០]ត្រឹមត្រូវ។ ខ្ញុំបានឃើញសម្លៀកបំពាក់អ្នកទោសដែលគេយកទៅសម្លាប់នោះ ត្រូវបានគេយកមកគុកវិញចែកឲ្យអ្នកទោសប្រើ ដូច្នេះខ្ញុំអាចប៉ាន់ស្មានចំនួនប្រជាជនដែលត្រូវបានគេសម្លាប់បាន"]។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឃូនី (ឧបសម្ព័ន្ធ) KH 00359370 ["ជះក្លិនអសោចនៃសាកសពអ្នកទោសដែលគេបានសម្លាប់ដោយភ្ជួតកុហកថាយកទៅភាគ ហើយខ្ញុំបានឃើញមានខោអាវអ្នកទោសប្រឡាក់ឈាមរាយប៉ាយនិងធ្លាក់ក្លិនស្អុយ"]។

[2401] D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លីម សាត KH 00242424។ ឯកសារ D118/15 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងស្វាយជ្រុំ KH 00894716។

[2402] ឯកសារ D118/235 កំណត់ហេតុស្តាប់ចម្លើយ ខែក ចន ឆ.៣៣-៣៤, ៥៤ KH 00987992, 94-95។

១០០.០០០ នាក់ ត្រូវបានសម្លាប់[2403]។ លឹម សាត បានរាយការណ៍អំពីការសម្លាប់បន្ថែមទៀតនៅចុងឆ្នាំ១៩៧៨[2404]។

653. អាយុកាលរបស់អ្នកទោសខ្មែរក្រោមកាន់តែទាបជាងអ្នកទោសភាគច្រើនទៅទៀត។ ភ្លាមៗបន្ទាប់ពីមន្ត្រីគុកបានកំណត់អត្តសញ្ញាណខ្មែរក្រោមតាមយរៈសំនៀងរបស់ពួកគេរួចមក ពួកគេត្រូវបានយកទៅសម្លាប់ភ្លាមៗដូចដែលអាចធ្វើទៅបាន[2405]។ នៅក្នុងក្រុមអ្នកទោសរបស់ ឡាយ ឫទ្ធី រាល់សមាជិកខ្មែរក្រោមទាំងអស់ត្រូវបានសម្លាប់[2406]។

654. ចំនួនមនុស្សសរុបដែលត្រូវបានសម្លាប់នៅស្វាយជ្រុំ នៅពេលស្ថិតក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី និងបស្ចិមមិនអាចគណនាត្រឹមត្រូវបានទេ ជាពិសេស ដោយសារតែរណ្តៅ និងសាកសពទាំងនោះត្រូវបានខូចខាតនៅក្នុងឆ្នាំកន្លងទៅនោះ[2407]។ ទោះជាយ៉ាងណា លឹម សាត បានរំឭកថា ព្រៃភាគ មានរណ្តៅកប់សពចំនួនដប់ រណ្តៅនីមួយៗមានទំហំ ១០ម៉ែត្របួនជ្រុង[2408] និងបានគណនាថា ក្នុងចំណោមអ្នកទោស ២០០០នាក់ នៅទីនោះ នៅពេលគាត់មកដល់ មាន៤០០ ទៅ ៥០០នាក់ នៅរស់នៅចុងឆ្នាំ១៩៧៨[2409]។ មូល រ៉ាន់ ដែលបានទៅមើលទីតាំងនេះនៅឆ្នាំ១៩៧៩ បានរៀបរាប់អំពីរណ្តៅកប់សពនៅព្រៃភាគថា "ធំៗណាស់" និងថា "មានផ្ទុំងមនុស្សច្រើនណាស់"[2410]។ ដូចបានពិភាក្សាខាងលើ អតីតពេជ្ឈឃាតបានប្រាប់ ឡាយ ឫទ្ធី ថា មនុស្សជាង ១០០.០០០នាក់

[2403] ឯកសារ D267.1.99 ឡាយ ឫទ្ធី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 09.49.35-09.52.54។ ឯកសារ D267.1.42 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី KH 00373253-54។ ឯកសារ D5/249.1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាយ ឫទ្ធី (ឧបសម្ព័ន្ធ) KH 00359370 ["រហូតដល់ចុងឆ្នាំ១៩៧៧ [...] សរុប [...] អ្នកទោសត្រូវគេយកទៅសម្លាប់មានប្រហែល១០ម៉ឺននាក់"]។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី ឆ.១៣, ១៦, ១៩ KH 01022018។

[2404] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242425 ["មានការសម្លាប់អ្នកទោសច្រើននៅចុងឆ្នាំ១៩៧៨។"]។ *សូមមើល* ឧទាហរណ៍ ឯកសារ D267.1.99 ឡាយ ឫទ្ធី ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 12.03.44-12.05.38 ["ពេលដែលបណ្តើរទៅនោះ ពីគុកថ្មូល ទៅកន្លែងមន្ទីរកសាងខ្លួនបឹងគុលហ្ម៉ីង គឺថាបាត់មនុស្សច្រើនទៀត ចាស [...] អ៊ូ! បាត់អ្នកនេះ បាត់អ្នកនោះ។ [...] សម្លាប់ហ្ម៉ីងពាយចាស។

[2405] ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី ឆ.១៣, ១៦, ១៩ KH 01022018-19។

[2406] ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫទ្ធី ឆ.១៩ KH 01022019។

[2407] ឯកសារ D118/237 កំណត់ហេតុស្តាប់ចម្លើយ ទិត កះ ឆ.៧១ KH 00988020។

[2408] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424 ["ក្នុងមន្ទីរថ្ពូលមានរណ្តៅសាកសពប្រហែលជា ១០រណ្តៅ មានទំហំ ១០ម៉ែត្របួនជ្រុង។"]។

[2409] ឯកសារ D6.1.137 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត KH 00242424។

[2410] ឯកសារ D118/178 កំណត់ហេតុស្តាប់ចម្លើយ មូល រ៉ាន់ ឆ.៧៨-៨០ KH 00974000។

ត្រូវបានសម្លាប់មុនចុងឆ្នាំ១៩៧៧[2411] ហើយរូបគាត់បានសង្កេតឃើញដោយផ្ទាល់នូវចំនួនមនុស្ស ចន្លោះពី ២០ ទៅ ២០០នាក់ ត្រូវបានគេយកទៅសម្លាប់រៀងរាល់បីថ្ងៃម្តង[2412]។ សូម្បីតែទទួលយកចំនួនតិចបំផុតក្នុងលំដាប់ចំនួននៃការប៉ាន់ប្រមាណរបស់គាត់ក៏ដោយ ក៏ការសម្លាប់មនុស្ស ២០នាក់ រៀងរាល់បីថ្ងៃម្តង បានបង្ហាញថា មានមនុស្សជាង ១២០០នាក់ ត្រូវបានសម្លាប់នៅពាក់កណ្តាលឆ្នាំ ១៩៧៧ តែឯង[2413]។ ដោយពិចារណាភ័ស្តុតាងទាំងអស់នេះរួមគ្នា វាមានភាពសមហេតុផលក្នុងការសន្និដ្ឋានថា មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់នៅស្វាយជ្រុំ អនុលោមតាមទម្រង់ JCE នៃភូមិភាគនិរតី ដែល **យ៉ីម ទិញ** គឺជាអ្នកចូលរួមប្រព្រឹត្តនាំមុខគេ។

<u>ការធ្វើទុក្ខបុកម្នេញ</u>

ការធ្វើទុក្ខបុកម្នេញលើខ្មែរក្រោម

655. ខណៈដែលកម្មាភិបាលភូមិភាគនិរតី និងភូមិភាគបស្ចឹមគ្រប់គ្រងស្រុកបាកាន ពួកគេបានចាប់ខ្លួន និងសម្លាប់ខ្មែរក្រោមជាលក្ខណៈប្រព័ន្ធ ដោយសារតែទស្សនៈរបស់ ប.ក.ក ដែលថាពួកគេទាំងនោះជាប់ទាក់ទងទៅនឹងវៀតណាម[2414]។ នៅទូទាំងតំបន់៧ ទាំងមូល ខ្មែរក្រហមបានប្រមូលខ្មែរក្រោមនិងបានលុបបំបាត់ពួកគេ[2415]។ ខ្មែរក្រោមនៅស្វាយជ្រុំត្រូវបានកំណត់អត្តសញ្ញាណតាមរ

[2411] *សូមមើល* កថាខណ្ឌ ៦៥២។

[2412] *សូមមើល* កថាខណ្ឌ ៦៥១។

[2413] អ្នកទោស២០នាក់ ត្រូវបានសម្លាប់រៀងរាល់បីថ្ងៃម្តង ដូច្នេះក្នុងរយៈពេល ១៨៣ ថ្ងៃ គឺស្មើនឹង ១,២២០នាក់ (៦១ x ២០)។

[2414] *សូមមើល* ឧទាហរណ៍ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាង ហៅ យាយរ៉ីម ឆ.៨៣-៨៤, ៨៦-៨៩, ១០២-១០៣, ១០៦-១០៧ KH 01347275-79 [តាម៉ុក បានចេញបញ្ជាឲ្យដោះស្រាយទៅលើខ្សែរយៈវៀតណាម តាមរយៈ សារុន ដែលបានកោះហៅ យាយរ៉ីម និងសមាជិកសហការណ៍ ឲ្យអនុវត្តបញ្ជាទាំងនោះ]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១២-១១៧, ១២១, ១២៣-១៣១ KH 01068142-45។ ឯកសារ D240R វីដេអូ *សត្រូវរបស់ប្រជាជន វគ្គ ខ្សែវីដេអូបន្ថែម៖ ឃួន រៀបរាប់អំពីផែនការ* ២០១០ ម៉ោង 1:00-3:58 [ផាន ឃន និយាយថា គាត់បានទៅប្រជុំនៅមន្ទីរស្រុក ហើយ តាផែង "គេប្រាប់យើងថា មានផែនការពីថ្នាក់លើម៉ោ គឺគេឲ្យបោសសម្អាតអ្នកកម្ពុជាក្រោម" ហើយគេទុកពេលឲ្យមួយអាទិត្យដើម្បីសម្លាប់ខ្មែរក្រោមទាំងអស់]។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៤០, ៤២, ៤៤ KH 00996457។ *សូមមើល* ឧទាហរណ៍ V.ค.២. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – ជនជាតិវៀតណាម និងខ្មែរក្រោម ក្នុងនាមជាក្រុមខុសគ្នាមួយ។ V.ค.៦.ខ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម នៅភូមិភាគពាយ័ព្យ – ការប្រព្រឹត្តចំពោះជនជាតិវៀតណាម និងខ្មែរក្រោម ក្នុងតំបន់២ ឆ្នាំ១៩៧៧-១៩៧៩។

[2415] ឯកសារ D118/225 កំណត់ហេតុស្តាប់ចម្លើយ ជា ព្រេន ឆ.៥០, ៦២ KH 00985406, 08។

យ:សំនៀងរបស់ពួកគេ និងបានទទួលរងការឈឺចាប់ឆាប់រហ័សជាងគេ និងទទួលរងការស្លាប់ជាក់លាក់ជាងអ្នកទោសផ្សេងទៀតនៅទីនោះ[2416]។

ការធ្វើទុក្ខបុកម្នេញលើក្រុមផ្សេងៗទៀត

656. ការធ្វើទុក្ខបុកម្នេញនៅស្វាយជ្រុំក៏ត្រូវបានធ្វើឡើងតាមរយ:ឧក្រិដ្ឋកម្ម ដែលបានរៀបរាប់ខាងលើ ប្រឆាំងនឹង "ប្រជាជន ១៧ មេសា" កម្មាភិបាលភូមិភាគពាយ័ព្យ និងសមាជិកអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេផងដែរ។ ក្រុមទាំងនេះត្រូវបានកំណត់គោលដៅយ៉ាងជាក់លាក់ ដោយសារតែសមាជិកភាពរបស់ខ្លួននៃក្រុមនយោបាយមួយដែលពិតប្រាដក ឬតាមការយល់ឃើញរបស់គេ[2417]។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

657. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងមន្ទីរសន្តិសុខស្វាយជ្រុំ:[2418] អំពើប្រល័យពូជសាសន៍ក្រុមជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា (ជាពិសេសខ្មែរក្រោម)[2419] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[2420] ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខ

[2416] ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫនី ឆ.១៣, ១៦, ១៩ KH 01022018-19។

[2417] *សូមមើល* VIII.ខ.១.ក. ការទទួលខុសត្រូវផ្ទែកព្រហ្មទណ្ឌជាបុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយ: សហឧក្រិដ្ឋកម្មរួម – គោលនយោបាយខ្ពាំង។

[2418] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីតាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានាដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះមាន: ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹងអតីតសមាជិករបប លន់ នល់ កម្មាភិបាលភូមិភាគនិរតី និង "ប្រជាជន១៧ មេសា" ការធ្វើទារុណកម្ម និងការសម្លាប់រង្គាល។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះ តាមរយ:៖ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៤-៥៩ និង ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម កថាខណ្ឌ ១៦។

[2419] *សូមមើល* V.គ. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងវៀតណាម។

[2420] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលនៃឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានបញ្ជាក់ដោយភ័ស្តុតាងទាក់ទងនឹងស្វាយជ្រុំតែមួយគត់។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលជាលក្ខខណ្ឌតម្រូវដើម្បីបញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ ទីតាំងសម្លាប់មនុស្ស និងការដ្ឋានពលកម្មដោយបង្ខំទាំងអស់ រួមទាំងទីតាំងទាំងឡាយនៅស្វាយជ្រុំផង គួរត្រូវបានពិចារណារួមបញ្ចូលគ្នា។ ទីតាំងទាំងអស់បង្កើតបានជាផ្ទែកនៃប្រព័ន្ធមួយ

បុកម្នេញដោយមូលហេតុនយោបាយប្រឆាំងនឹង "ប្រជាជន ១៧ មេសា" កម្មាភិបាលភូមិភាគពាយ័ព្យ សមាជិកនៃអតីតរបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និងខ្មែរក្រោម និងអំពើអមនុស្ស ធម៌ផ្សេងៗទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)។

គ. ទីតាំងសម្លាប់មនុស្សទួលសេះញ្ជ៉ូ និងព្រៃក្របៅ

i. សេចក្ដីផ្ដើម

658. ទីតាំងសម្លាប់មនុស្សទួលសេះញ្ជ៉ូ[2421] និងព្រៃក្របៅ[2422] ស្ថិតនៅក្នុងស្រុកបាកានលើ (ក្រោយមក ស្រុកបាកាន) នៃតំបន់ ២ នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ។ កម្មាភិបាលភូមិភាគនិរតី និងភូមិភាគបស្ចិម គឺជាអ្នកធ្វើសកម្មភាពដើម្បីបង្កើតសហឧក្រិដ្ឋកម្មរួម (JCE) ដែលមាន **យ៉ីម ទិត្យ** ជាសមាជិកនាំមុខម្នាក់ ដែលបានចេញបញ្ជាឲ្យសម្លាប់ខ្មែរក្រោម និងអ្នកជម្លៀសមកពីភូមិភាគ ឫព័ាវាប់ពាន់នាក់ នៅលើទីតាំងទាំងនេះ។

659. ទាក់ទងនឹងទីតាំងសម្លាប់មនុស្សទាំងពីរ ទួលសេះញ្ជ៉ូ និងព្រៃក្របៅ ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** ចំពោះឧក្រិដ្ឋកម្មដូចតទៅ៖ អំពើប្រល័យពូជសាសន៍ខ្មែរក្រោម ឧក្រិដ្ឋកម្មប្រឆាំងមនុស្ស ជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និង

ដែលមានការរៀបចំ ក្នុងការអនុវត្តគោលនយោបាយដើម្បីធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង ហើយការសម្លាប់នៅតាមទីតាំងនិមួយៗទាំងអស់នេះ គឺសុទ្ធតែត្រូវបានសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចៗគ្នារបស់ យ៉ីម ទិត្យ។

[2421] ការសរសេរប្រកបជាភាសាខ្មែរនិងអង់គ្លេស អាចខុសគ្នាដូចតទៅនូវឈ្មោះ សេះញ្ជ៉ូ (Ses Nhov) (*សូមមើលឧទាហរណ៍* ឯកសារ D118/147.1.43 EN 00527091-92) Ses Nhoeuv (*សូមមើលឧទាហរណ៍* ឯកសារ D118/147.1.43 EN 00527099-100) សេះញ្ជ៉ូ (Ses Nho) (*សូមមើលឧទាហរណ៍* ឯកសារ D6.1.615) ទួលស្វាយ (Tuol Svay) (*សូមមើលឧទាហរណ៍*ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.ពាម) សេះញ្ជៅ (Seh Nheou) (*សូមមើលឧទាហរណ៍* ឯកសារ D347/2.1.11) Toul Sa Nhov (*សូមមើលឧទាហរណ៍* ឯកសារ D118/147.1.43 EN 00527127) សេះញ្ជ៉ូ (Ses Nhov) (*សូមមើលឧទាហរណ៍*ឯកសារ D118/223)។

[2422] ការសរសេរប្រកបជាភាសាខ្មែរនិងអង់គ្លេស អាចខុសគ្នាដូចតទៅនូវឈ្មោះ ព្រៃក្របៅ (Prey Krabao) (*ឧទាហរណ៍* ឯកសារ D219/345) ព្រៃក្រាបាវ (Prey Kabav) (*ឧទាហរណ៍* ឯកសារ D6.1.758) Prey Kra Baov (*ឧទាហរណ៍* ឯកសារ D118/147.1.43 EN 00527091-92) ព្រៃកក្របៅ (Preaek Krabau) (*ឧទាហរណ៍* ឯកសារ D5/202/4) ព្រៃកាបៅ (Prey Kabao) (*ឧទាហរណ៍*ឯកសារ D347/2.1.11) ព្រៃក្របៅ (Prey Kra Baou) (*ឧទាហរណ៍*ឯកសារ D219/639)។ ដោយសារពាក្យថា "ព្រៃ" ក្នុងភាសាខ្មែរ មានន័យថា "forest" ជាភាសាអង់គ្លេស ទើបជួនកាលទីតាំងនេះយើងឃើញមានពាក្យថា Krabao forest ផងដែរ (*ឧទាហរណ៍*ឯកសារ D219/225)។

ពួជសាសន៍ប្រឆាំងនឹងខ្មែរក្រោម និងអំពើមនុស្សឃាតគិតទុកជាមុន នៅក្រោមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[2423]។

ii. ប្រតិបត្តិការ និងទីតាំង

660. ទីតាំងសម្លាប់មនុស្សទួលសេះញ្ជ្ញ (“ទួលសេះញ្ជ្ញ”) រួមមាន រណ្តៅកប់សពមួយចំនួនដែលមាន ទីតាំងស្ថិតនៅក្នុងឃុំខ្ជារទទឹង ស្រុកបាកាន នៃតំបន់ ២ ក្នុងកន្លែងមួយដ៏ធំនៅលើភ្នំ ក្រៅអ្វីដែលសព្វថ្ងៃមានឈ្មោះថា ភូមិបាក់មែក ដែលពីមុនជាភូមិសេះញ្ជ្ញ[2424]។ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ (“ព្រៃក្របៅ”) ស្ថិតនៅក្នុងឃុំតាណោ ស្រុកបាកាន តំបន់ ២[2425] នៅជិតអ្វីដែលគេស្គាល់ថា មន្ទីរ ៤២ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[2426]។ ក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ ភូមិដែល

[2423] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426544, 47, 58, 59។

[2424] *សូមមើលឧទាហរណ៍* ឯកសារ D118/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរណ្តៅសាកសព ទួលសេះញ្ជ្ញ KH 00893190-93។ ឯកសារ D219/639 កំណត់ហេតុនៃការស្តាប់ចម្លើយ កែវ ម៉ើ ឆ.១១០ KH 01186833 [“ទួលសេះញ្ជ្ញដឹងប៉ុន្តែមិនបានឃើញរណ្តៅទេ ប៉ុន្តែដឹងថាទួលសេះញ្ជ្ញនៅបាក់មែន ឃុំខ្ជារទទឹង”]។ ឯកសារ D118/175 កំណត់ហេតុនៃការស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.៦៧ KH 00973952។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម EN 00527091, 99-100 [យោងទៅរក “ភូមិនានាក្នុងឃុំខ្ជារទទឹង[រួមទាំង] បាក់មែក ដែលធ្លាប់ហៅថា សេះញ្ជ្ញ”]។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.១០៣, ១០៥ KH 01198096 [“ទួលសេះញ្ជ្ញហ្នឹង [...] កន្លែងនោះគឺជាទួល ហើយគេជីករណ្តៅទីនោះ។ [...] គ្រាន់តែដីវាល”]។ ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយសាក្សី ថាច់ សុខ ឆ.១០៣, ១០៥ KH 00267774 [“ទួលសេះញ្ជ្ញមានទំហំ ៤០០ទៅ ៥០០ម៉ែត្របួនជ្រុង”]។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែន ដារ៉ា ឆ.៦២ KH 00973952 [“ប្រហែលជា ២ហិកតាបួនជ្រុង”]។

[2425] *សូមមើលឧទាហរណ៍* ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយសាក្សី រ៉ាន់ ចូក ឆ.៧២ KH 00973927 [“ព្រៃក្របៅ (ឃុំតាណោ)”]។ឯកសារ D6.1.758កំណត់ហេតុស្តាប់ចម្លើយសាក្សី ថាប ខ្ជង KH 00385092 [“ព្រៃកាបាវស្ថិតនៅក្នុងឃុំតាណោ”]។ ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ប៉ាន់ ឆ.២៣ KH 01167521 [“តាណោនៅក្នុងស្រុកបាកាន”]។ ឯកសារ D118/13 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងទីតាំងសម្លាប់មនុស្ស ព្រៃក្របៅ KH 00901540-41, 42 [“ ទិន្និន័យ GPS៖ N 12 30 22.1 E 103 40 51.7 [...] តំបន់ ២ – ភូមិភាគពាយ័ព្យ [...] ដើម្បីស្វែងរកទីកន្លែងសម្លាប់មនុស្ស ព្រៃក្របៅ [...] បត់ឆ្វេងក្នុងឃុំតាណោ និងបន្តទៅមុខប្រហែល ៦០០ម៉ែត្រ ទើបទៅដល់ភូមិព្រៃក្របៅ”]។ ឯកសារ D5/1559 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ន្ជ ចាន់ណា KH 01091913-14។

[2426] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែន ដារ៉ា ឆ.៧៣, ៨៤-៨៥ KH 00973953, 55 [“[មន្ទីរ ៤២] ស្ថិតនៅក្នុងសហករណ៍តាណោ [...] ខ្ញុំធ្លាប់ឮកន្លែងសម្លាប់មនុស្សផ្សេងទៀតដូចជា ព្រៃក្របៅ ដែលនៅជាប់នឹងមន្ទីរ ៤២។ [...] ការពិតគឺជាកន្លែងតែមួយ មានអ្នកខ្លះហៅថា ព្រៃក្របៅ អ្នកខ្លះហៅថា មន្ទីរ ៤២”]។ ឯកសារ D5/1559 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ន្ជ ចាន់ណា KH 01091913-14 [“ខ្មែរក្រហមបានយកម្តាយខ្ញុំទៅសម្លាប់នៅព្រៃក្របៅ មន្ទីរ ៤២”]។ ឯកសារ

ស្ថិតនៅជិតបំផុតគឺភូមិកោះអណ្តែត ភូមិព្រៃក្របៅ និងភូមិទួលថ្ម ក្នុងសហករណ៍ស្រែង[2427]។ ខ្មែរក្រហមបានប្រើកន្លែងទាំងពីរនេះធ្វើជាទីតាំងសម្លាប់មនុស្ស ប្រហែលចាប់តាំងពីពាក់កណ្តាលឆ្នាំ ១៩៧៧ រហូតដល់ដាច់របបកម្ពុជាប្រជាធិបតេយ្ស[2428] ហើយពួកគេបានធ្វើក្រោលគោ បណ្តោះអាសន្ន ឬដើម្បីឃុំខ្លួនជនរងគ្រោះមុនយកទៅសម្លាប់[2429]។

D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ សេត មាស EN 00527092 ["ខ្មែរក្រហមបានយកឪពុកគាត់ [...] ជាមួយប្រជាជនខ្មែរក្រោម២០នាក់ទៀត ទៅសម្លាប់នៅមន្ទីរ ៤២ នៅព្រៃក្របៅ សម្ទូហភាព តាណោ"]។

[2427] *សូមមើលឧទាហរណ៍*ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.១១៧ KH 01068143 ["ព្រៃក្របៅ នៅក្នុងសហករណ៍ស្រែង"]។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទីម លន ឆ.៥៧ KH 01102922។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហេង សៀង ឆ.១២ KH 01075699 ["ស៖ តើមានចម្ងាយប៉ុន្មានពីភូមិកោះអណ្តែត ទៅព្រៃក្របៅ? ឆ.១២៖ មានចម្ងាយពីគ្នាប្រហែលជា១៥០ ទៅ១៦០ម៉ែត្រ"]។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ភេ ឆ.៥៧, ៨២-៨៣ KH 01102906, 09 ["ព្រៃក្របៅ នៅភូមិទួលថ្ម។ [...] កោះអណ្តែតនៅខាងកើត ព្រៃក្របៅ ប្រហែលជា ៥០០ ម៉ែត្រពីគ្នា"]។

[2428] *សូមមើលឧទាហរណ៍*ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ ស៊ីន្ធន ឆ.៥៣ KH 00955770។ ឯកសារ D118/223 កំណត់ហេតុស្តាប់ចម្លើយសាក្សី គឹម ហួយ ឆ.៣៥ KH 00985380។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយសាក្សី វ៉ាន់ ចូក ឆ.៧២ KH 00973927។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនរឿន ឆ.៤៨ KH 00955685។

[2429] <u>ទួលសេះញ្ជ្ញ</u>៖ ឯកសារ D118/241 កំណត់ហេតុស្តាប់ចម្លើយសាក្សី ថាច់ សុខ ឆ.៥៤-៥៦ KH 00988067 ["ហើយនៅក្នុងឆ្នាំ១៩៧៩ ខ្ញុំបានមកភូមិបាក់ម្ដែក ខ្ញុំឃើញគេស្រុះបន្ទាក្រោលគោសម្រាប់ឃុំខ្លួនមនុស្សមុនយកទៅសម្លាប់។ [...] ចំហំប្រហែល ១០០ម៉ែត្រការ៉េបួនជ្រុង។ គេអាចដាក់មនុស្សបានរាប់ពាន់នាក់។ [...] ក្រោលគោស្ថិតនៅខាងជើងរៀងខាងកើតពីទួលសេះញ្ជ្ញ ចម្ងាយប្រហែលជា៥០០ ទៅ ៦០០ម៉ែត្រពីគ្នា"]។ ឯកសារ D118/197 កំណត់ហេតុស្តាប់ចម្លើយសាក្សី យាន ផាន ឆ.៥៦-៦៣ KH 00978971-72។ ឯកសារ D6.1.615 បទសម្ភាសន៍ ប្រាក់ សារិន ដោយ SOAS, KH 00722424-25។ <u>ព្រៃក្របៅ</u>៖ ឯកសារ D118/213 កំណត់ហេតុស្តាប់ចម្លើយសាក្សី យឹម ខុន ឆ.១០២ KH 00982139 ["ក្រោយចប់របបខ្មែរក្រហម ទើបខ្ញុំបានឃើញក្រោល និងក្រមាពណ៌ខៀវនៅព្រៃក្របៅ [...]"]។ ឯកសារ D5/115 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចឹក ប៊ុនរឿន EN 00426904 ["ប្រហែលជា ៣៥០គ្រួសារ ដែលគេយកមក ហើយ [...] គេដាក់នៅក្រោលគោ [នៅព្រៃក្របៅ]]"] *ដែលបញ្ជាក់នៅក្នុង* ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនរឿន ឆ.៤៨ KH 00955685។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទីម លន ឆ.៧៧ KH 01102924។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ភេ ឆ.៩៤ KH 01102910។ ឯកសារ D6.1.615 បទសម្ភាសន៍ ប្រាក់ សារិន ដោយ SOAS KH 00722424-25។ ឯកសារ D347.3 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា *ឃុំរំលេច៖ ខ្មែរក្រោម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្ស* ការរៀបរាប់របស់ វ៉ាន់ មុត KH 01413645-46។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច

661. បិណ ជាកម្មាភិបាលនិវតី បានក្លាយជាលេខាតំបន់ ២[2430] បន្ទាប់ពីសមាជិកគណៈតំបន់មុន ត្រូវបានគេបោសសម្អាត ប្រហែលជានៅពាក់កណ្តាលឆ្នាំ១៩៧៧[2431]។ ចុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨ រៀន អែម *ហៅ*សារុន មកពីភូមិភាគបស្ចិម បានមកគ្រប់គ្រងតំបន់ ២[2432]។ តាសារុន បានជួប និងបានរាយការណ៍ទៅ តាម៉ុក និងជាអ្នកដែលបានអនុវត្តបញ្ជារបស់ តាម៉ុក[2433]។ ក្នុងនាមជាអ្នកនៅក្រោមបង្គាប់ដ៏ស្មោះរបស់ តាម៉ុក គាត់គឺជាសមាជិកគន្លឹះម្នាក់នៃ JCE។ ប្រហែលជានៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ សារុន ត្រូវបានតែងតាំងជាគណៈភូមិភាគពាយ័ព្យ ជាមួយ តាម៉ុក និង **យ៉ីម ទិត្យ**[2434]។

[2430] ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.២៨ KH 01075609។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៣១ KH 01068111។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម *ហៅ*យង់ ហាន ឆ.១២៤ KH 01025547។ ឯកសារ D219/242 កំណត់ហេតុស្តាប់ចម្លើយ អប់ ច្រ៊ីង *ហៅ*រ៉ន ឆ.១៦, ២៥ KH 01080919-20។

[2431] *សូមមើល* V.ខ.១.ខ.ii. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតនៅពាយ័ព្យថ្នាក់ភូមិភាគ និងតំបន់ – ការបោសសម្អាតថ្នាក់តំបន់ – តំបន់ ២។

[2432] ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ *ហៅ* យាយណាន់ ឆ.១៩, ២៤ KH 00498372-73។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.២៨-៣០ KH 01075609។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.២៨-៣០ KH 01068111។ *សូមមើលបន្ថែម* IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច បកក និងការប្រាស្រ័យទំនាក់ទំនង – ភូមិភាគពាយ័ព្យ ១៩៧៧ – ១៩៧៩ – តំបន់ ២។

[2433] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឆ.១០២-១០៤, ១០៦-១០៧ KH 01347279 ។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឆ.៨, ៤២ KH 01348857, 63។ *សូមមើលផងដែរ* ឯកសារ D1.3.29.2 កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146678 [បញ្ជាក់ថា តាម៉ុក បានក្លាយជាលេខាភូមភាគបស្ចិម បន្ទាប់អតីតលេខា ជ្ជ ជេត ហៅ ស៊ី ត្រូវបានបោសសម្អាត។ "ដឹកកម្លាំងតាម៉ុក និងកម្លាំងខាងបស្ចិមរបស់ ហ្ជូត ហេង ហៅ ប៉ាល់ ទៅទាំងឡានៗយកទៅពាយ័ព្យ"]។ ឯកសារ D118/103.3 កាំង ហ្គេកអ៊ាវ ហៅ ឌុច ការសន្ទនាដ្ឋានចុងក្រោយជាលាយលក្ខណ៍អក្សរ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ KH 00404797, កំណត់សំគាល់ជើងទំព័រ ២៤។ ឯកសារ D219/193 កំណត់ហេតុស្តាប់ចម្លើយ រ៉ាត ផាត ឆ.២១៥, ២១៧ KH 01070086-87។ *សូមមើលបន្ថែម* IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច បកក និងការប្រាស្រ័យទំនាក់ទំនង – ភូមិភាគពាយ័ព្យ ១៩៧៧ – ១៩៧៩ – តំបន់ ២។

[2434] ឯកសារ D6.1.616 បទសម្ភាសន៍ ម៉ុក ស្ទ្រីម ដោយ SOAS, KH 00657427 ["សារុន ទទួលបន្ទុក [...] ស្ថិតនៅក្នុងគណៈភូមិភាគពាយ័ព្យផងដែរ ជំនួស កែវ"]។ ឯកសារ D6.1.1052 កំណត់ហេតុសួរចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00159561-62។ ឯកសារ D1.3.15.2 Timothy Carney *ការរៀបចំអំណាច* KH 00332381-83។ *សូមមើលបន្ថែម* IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច បកក និងការប្រាស្រ័យទំនាក់ទំនង – ភូមិភាគពាយ័ព្យ ១៩៧៧ – ១៩៧៩ – តំបន់ ២។ ទាក់ទងនឹងសមាជិកភាពរបស់ យ៉ីម ទិត្យ នៅក្នុង គណៈភូមិភាគពាយ័ព្យ *សូមមើល* IV.គ.២. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទងរបស់ ប.ក.ក

662. ត្រឹមដើមឆ្នាំ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧ កម្មាភិបាលពាយ័ព្យ ដែលជាអ្នកបង្កើតគណៈស្រុកបាកានលើ ត្រូវបានគេបោសសម្អាត ហើយស្ត្រីបីនាក់មកពីភូមិភាគនិរតី គឺយាយ រ៉ន (លេខា) សេក សំអាត *ហៅ*យាយ រីម (អនុលេខា) និង យាយ យ៉ាន (សមាជិក) បានមកជំនួសពួកគេ[2435]។ ក្រោយពីនោះបានបន្តិច គឺទំនងជាពេលដែលកម្មាភិបាលបស្ចិមបានមកដល់ រ៉ន និង យ៉ាន ត្រូវបានគេដកចេញពីគណៈស្រុក ហើយ យាយ រីម ក៏បានក្លាយជាលេខា[2436]។ ក្នុងអំឡុងពេលស្ថិតក្រោមការគ្រប់គ្រងរដ្ឋបាលរបស់កម្មាភិបាលភូមិភាគបស្ចិម សារុន និង ផេង (ដែលកាលណោះជាលេខាស្រុកបាកានក្រោម[2437]) បាកានលើ ត្រូវបានច្រចាច់បញ្ចូលគ្នាជាមួយស្រុកបាកានក្រោម ដើម្បីបង្កើតស្រុកមួយថ្មី ដែលមានឈ្មោះថាស្រុកបាកាន ដែលបានដាក់ឲ្យធ្វើប្រតិបត្តិការនៅក្រោមសិទ្ធិអំណាចរបស់ សារុន[2438]។ ខណៈភ័ស្តុតាងមិនស្របគ្នាថាតើ ផេង ឬ រីម ជាលេខាស្រុកបាកាន នៅ

– ភូមិភាគពាយ័ព្យឆ្នាំ១៩៧៧-១៩៧៩។ III.ឃ.១. មុខតំណែង ទង្វើ និងអំពើប្រព្រឹត្តរបស់ យ៉ីម ទិត្យ – ការចូលរួមប្រព្រឹត្តរបស់ យ៉ីម ទិត្យ នៅក្នុងផែនការឧក្រិដ្ឋកម្មរួម នៅភូមិភាគពាយ័ព្យ – មុខតំណែងរបស់ យ៉ីម ទិត្យ នៅភូមិភាគពាយ័ព្យ។

[2435] *សូមមើលឧទាហរណ៍* ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទូច សេង ឆ.ពាព, ១១៩ KH 01075722, 34 ។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទីម លន ឆ.២៥ KH 01102918។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡម សារ៉ន ឆ.២៨-២៩ KH 01176408។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.ពាព KH 01068112។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១១២, ១១៩ KH 01000268-69។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម *ហៅ* យង់ ហាន ឆ.៥ព, ៦៥ KH 01025540, 41 ។ *សូមមើលបន្ថែម* IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច បកក និងការប្រាស្រ័យទំនាក់ទំនង – ភូមិភាគពាយ័ព្យ ១៩៧៧ – ១៩៧៩ – តំបន់ ២។

[2436] *សូមមើលឧទាហរណ៍* ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទីម លន ឆ.២៦ KH 01102918។ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រីម ឆ.៤៤-៤៥ KH 01347268។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រីម ឆ.៩៩-១០០ KH 01348874។ ឯកសារ D219/222 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទូច សេង ឆ.១១០, ១២០ KH 01075733-34។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម *ហៅ* យង់ ហាន ឆ.៦ព, ៦៦-៦៧ KH 01025541។ *សូមមើលបន្ថែម* IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច បកក និងការប្រាស្រ័យទំនាក់ទំនង – ភូមិភាគពាយ័ព្យ ១៩៧៧ – ១៩៧៩ – តំបន់ ២។

[2437] ដូចបានកំណត់យ៉ាងលម្អិតនៅក្នុង IV.គ.២. រចនាសម្ព័ន្ធសិទ្ធិអំណាច បកក និងការប្រាស្រ័យទំនាក់ទំនង – ភូមិភាគពាយ័ព្យ ១៩៧៧ – ១៩៧៩ – តំបន់ ៧ ក្រោយពេលកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានបោសសម្អាតនៅបាកានក្រោម ផល ដែលមកពីភូមិភាគនិរតី បានក្លាយជាលេខាស្រុក រហូតដល់ពេលគាត់ត្រូវបានចាប់ខ្លួននៅដើមឆ្នាំ១៩៧៨ និងត្រូវបានជំនួសដោយ តាផេង មកពីភូមិភាគបស្ចិម។

[2438] ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៤១ KH 01068113 ["ពេលដែល តាសារ៉ុន មកដល់ គាត់បានច្រចាច់បាកានបញ្ចូលគ្នាតែមួយ"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ីក សៀម ឆ.១៩ KH 00485651 ។ ឯកសារ D219/6 កំណត់ហេតុស្តាប់ចម្លើយ អ៊ីក ប៊ីង ឆ.១១២ KH 01025505 ។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.២៨ KH 01075611, 13 ។ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រីម ឆ.៧២-៧៤ KH

ពេលគេច្រចាច់បញ្ជូលគ្នាក៏ដោយ ក៏ភ័ស្តុតាងដែលច្បាស់លាស់នោះគឺថា មេដឹកនាំទាំងពីរនេះបានធ្វើការងារជាមួយគ្នារហូតដល់ដាច់របប ដើម្បីត្រួតត្រាស្រុកនេះ[2439] រួមទាំង "ការបោសសម្អាតខ្មាំង"[2440]។

663. ដូចបានរៀបរាប់យ៉ាងលម្អិតបន្ថែមទៀតនៅខាងក្រោម លេខាស្រុក និងតំបន់ទាំងនេះ បានទទួលនិងអនុវត្តបញ្ជាពី តាម៉ុក ដើម្បីប្រព្រឹត្តបទល្មើសផ្សេងៗ នៅទីតាំងសម្ជាប់មនុស្សទួលសេះញ៉ូ និងព្រៃក្របៅ ប្រឆាំងខ្មែរក្រោម និងអ្នកជម្លៀសមកពីភូមិភាគបូព៌ា។

01347273-74។ *សម្រាប់សេចក្តីពិស្តារបន្ថែម សូមមើល* IV.ค.២. រចនាសម្ព័ន្ធសិទ្ធិអំណាច បកក និងការប្រាស្រ័យទំនាក់ទំនង – ភូមិភាគពាយ័ព្យ ១៩៧៧ – ១៩៧៩ – តំបន់ ២។

[2439] *សូមមើលឧទាហរណ៍* ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម *ហៅ* យង់ ហាន ឆ.៦៦, ៨១, ១៥៣ KH 01025541, 43, 50 [បញ្ជាក់ថា រ៉ែម និង តាផែង បញ្ជាទៅឲ្យគណៈសហករណ៍]។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៤៣ KH 01068113។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.៨០ KH 01068136។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ឌួន រិន ឆ.៤០, ៤២ KH 01075611 ឆ.៥៣-៥៤ KH 01075613។ ឯកសារ D219/590 កំណត់ហេតុស្តាប់ចម្លើយ ឡុង ឃ្លោក ឆ.៦០ KH 01167620។ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ ឃាយ រ៉ែម ឆ.៥៩-៦០ KH 01347271 *ប៉ុន្តែសូមមើល* ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ ឃាយ រ៉ែម ឆ.៩៩ KH 01348874។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឡម សារ៉ូន ឆ.៣៨ KH 01176410។ ឯកសារ D6.1.616 បទសម្ភាសន៍ អ៊ីក សៀម ដោយ SOAS KH 00657427។ *សូមមើលបន្ថែម* IV.ค. ២. រចនាសម្ព័ន្ធសិទ្ធិអំណាច បកក និងការប្រាស្រ័យទំនាក់ទំនង – ភូមិភាគពាយ័ព្យ ១៩៧៧ – ១៩៧៩ – តំបន់ ២។

[2440] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.៨០ KH 01068136។

iv. ខ្ញុំក្ដីកម្ម

<u>ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)</u>

ផែនការដើម្បីកម្ទេចខ្មែរក្រោមក្នុងស្រុកបាកាន

664. ក្រោយពួកកម្មាភិបាលនិរតីបានចូលត្រួតត្រានៅក្នុងស្រុកបាកាន តាម៉ុក បានចេញបញ្ជាឲ្យកម្ទេចសហគមន៍ខ្មែរក្រោមនៅទីនោះ[2441]។ ផែនការគឺដើម្បី "បោសសម្អាតប្រជាជនខ្មែរក្រោម"[2442]។ មន្ត្រីតំបន់ និងស្រុក រួមទាំង សារុន និង រ៉ែម ផង គឺជាអ្នកដែលបានធានាចំពោះការបោសសម្អាតនេះ "ការប្រមូល" និងការបញ្ជូនខ្មែរក្រោម អ្នកដែលបានរៀបការជាមួយខ្មែរក្រោម និងកូនរបស់ពួកគេទាំងអស់ពីគ្រប់ទិសទីក្នុងស្រុកបាកាន រហូតដល់បណ្ដាភូមិនានាក្នុងសហករណ៍ខ្នារទទឹង រួមទាំង

[2441] ឯកសារ D219/861 កំណត់ហេតុស្ដាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ែម ឆ.៨៣-៨៤, ៨៦-៨៩, ១០២-១០៣, ១០៦-១០៧ KH 01347275-79 [លេខាស្រុកបាកាន (លើ) យាយរ៉ែម: តាម៉ុក ចេញបញ្ជាឲ្យផ្ដាតគោលដៅ ស្រាវជ្រាវ និងលុបបំបាត់អ្នកមានខ្សែរយៈវៀតណាម តាមរយៈ តាសារុន ដែលបន្ទាប់មកបានកោះហៅ យាយរ៉ែម និងសមាជិកសហករណ៍ឲ្យអនុវត្តបញ្ជាទាំងនោះ]។ *សូមមើលផងដែរ* ឯកសារ D118/278 កំណត់ហេតុស្ដាប់ចម្លើយ ណម អ៊ីម ឆ.១២៨ KH 01000270 [ការសម្លាប់ខ្មែរក្រោម គេមានផែនការនៅក្រោយការមកដល់របស់ពួកកម្មាភិបាលនិរតី នៅបាកាន]។

[2442] ឯកសារ D219/188 កំណត់ហេតុស្ដាប់ចម្លើយសាក្សី ផាន ឃន ឆ.១១២ KH 01068142 [ផាន ឃន គណៈសមរភូមិនៅក្នុងសហករណ៍ស្រែង (*សូមមើល* ឯកសារ D219/187 ឆ.៦-៨ KH 01068103) បានចូលរួមប្រជុំប្រធានសហករណ៍ និងគណៈសមរភូមិក្នុងឆ្នាំ១៩៧៨ ដែលយាមរ៉ែម ជាប្រធានអង្គប្រជុំដែល "គេនិយាយអំពីផែនការបោសសម្អាតខ្មែរក្រោមនេះ"]។

ភូមិកំប្រាក់ក្ងន ខ្ទារទទឹង និងបាក់មែក (សេះញ្ជ៉ូ)[2443]។ គោលបំណង គឺដើម្បីត្រៀមរៀបចំសម្រាប់ការសម្លាប់យ៉ាងរង្គាលនៃប្រជាជនទាំងអស់នេះ[2444]។

[2443] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឆ.៨៦-៨៩ KH 01347271 និងឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឆ.១៣-១៤, ១៦, ៦០-៦១ KH 01348858-59, 66 [យាយ រ៉ីម បញ្ជាក់ថា គាត់បានទទួលការណែនាំពី សារុន ឲ្យកំណត់អត្តសញ្ញាណ និងស្រាវជ្រាវរកមនុស្សជាប់ខ្សែរវៀតណាម ដែលគាត់បានបញ្ជូនទៅសហករណ៍] ឆ.២៥-២៨, KH 01348860-61 [យាយរ៉ីម បញ្ជាក់អះអាងថា សារុន បានបញ្ជាឲ្យគាត់បញ្ជូនមនុស្ស ទៅខ្ទារទទឹង]។ ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុក សៀម ឆ.១៧ KH 00872599 [ប្រធានសហករណ៍រំលេច: "ប្រហែលជាចុង៧៨ មានបញ្ជាពីគណ:ស្រុកបាកាន [...]។ [គេ] បានបញ្ជាឲ្យខ្ញុំប្រមូលខ្ទែរក្រោមក្នុងសហករណ៍រំលេចទាំងអស់ មកដាក់នៅក្នុងសហករណ៍ខ្ទារទទឹង ពីព្រោះគេចោទថា ពួកនោះជាប់និន្នាការវៀតណាម"]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.១១១-១១២ KH 01068142 [រៀបរាប់ពីកិច្ចប្រជុំឆ្នាំ១៩៧៨មួយ សម្រាប់មេសហករណ៍ និងគណ:សមរភូមិ ដែល យាយរ៉ីម ជាប្រធានអង្គប្រជុំ: "យាយរ៉ីម បានទៅចូលរួមប្រជុំនៅតំបន់។ បន្ទាប់ពីគាត់ត្រឡប់មកវិញ គាត់និយាយថា៖ "ឥឡូវយើងប្រមូលខ្ទែរក្រោមទាំងអស់ដាក់មួយកន្លែង ប្រមូលគ្រប់សហករណ៍ទាំងអស់"។ ក្រោយប្រមូលដាក់មួយកន្លែងហើយ ទើបគាត់មានផែនការបោសសម្អាត។ គេប្រមូលខ្ទែរក្រោមពីគ្រប់សហករណ៍ទាំងអស់ទៅដាក់នៅសហករណ៍ខ្ទារទទឹង ក្នុងភូមិកំប្រាក់ក្ងន"]។ ឯកសារ D118/189 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន់ សារ៉ាយ ឆ.៧០-៧១, ៧៣, ៧៥, ៨០, ៩៨ KH 00977033-36 [បានចូលរួមប្រជុំជាមួយ យាយរ៉ីម និងមន្ត្រីស្រុកផ្សេងទៀត ហើយនឹងមេកង ដែលពេលនោះគេបានប្រាប់ថា "មានខ្ទែរក្រោមពីរលានន្ទាក់គឺសុទ្ធតែគិញយួន"។ គេតម្រូវឲ្យប្រធានកងធ្វើប្រវត្តិរូបខ្ទែរក្រោម "ឲ្យអង្គការ"។ ជាលទ្ធផល មេកងបានធ្វើប្រវត្តិរូបប្រជាជន ៣០០នាក់ក្នុងមួយថ្ងៃ។ នៅក្នុងកិច្ចប្រជុំមួយនាពេលក្រោយមក ខ្ទែរក្រហមបានប្រកាសអំពីការបង្កើតសហករណ៍មួយនៅខ្ទារទទឹងសម្រាប់ដាក់ខ្ទែរក្រោម]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនរ៉ឿន ឆ.៣៤-៣៥ KH 00955682-83។ សាក្សី និងអ្នកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានរៀបរាប់អំពីការអនុវត្តនៃការសម្រិតសម្រាំងនេះ និងការផ្លាស់ប្តូរទីលំនៅដោយបង្ខំនៃខ្ទែរក្រោម និងគ្រួសាររបស់ពួកគេ ទៅកាន់ខ្ទារទទឹង ពីទូទាំងស្រុកបាកាន។ *សូមមើលឧទាហរណ៍* ឯកសារ D219/676 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហុក សារិន ឆ.៦២-៦៣, ៦៥-៦៦ KH 01202401-02។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយសាក្សី រ៉ាន់ ចូក ឆ.៤១ KH 00973924 ។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត រ៉ុធ ឆ.៥៣, ៥៥-៥៦, ៦០-៦១ KH 00985419-20។ ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយសាក្សី លន ហេង ឆ.៣៨-៣៩ KH 00973980។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ ស៊ីធួន ឆ.២២ KH 00955775-76។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឆាត់ ផាន់ ឆ.៥១-៥២, ៧៥, ១០៣, ១០៧ KH 00996458, 60, 63, 64។ ឯកសារ D118/199 កំណត់ហេតុស្តាប់ចម្លើយសាក្សី អ្លង សារ ឆ.៤១ KH 00978997។ ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែន រ៉ន ឆ.៨១ KH 00977088។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង អេង ឆ.៥៧-៥៩, ៦៤ KH 00996446-47។ ឯកសារ D118/223 កំណត់ហេតុស្តាប់ចម្លើយសាក្សី គឹម ហ្ជួយ ឆ.៣៥ KH 00985380។ *សូមមើលបន្ថែម* V.ค.๖.๒.ii ឧក្រិដ្ឋកម្ម - ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាមនៅភូមិភាគពាយ័ព្យ – ការប្រព្រឹត្តចំពោះជនជាតិវៀតណាម និងខ្ទែរក្រោម នៅតំបន់ ២ ឆ្នាំ១៩៧៧ – ១៩៧៩ – ការជម្លៀសដោយបង្ខំនូវខ្ទែរក្រោមទៅខ្ទារទទឹង និងការសម្លាប់ពួកគេ។

665. ខ្មែរក្រោមក្នុងស្រុកបាកាន ត្រូវបានគេកំណត់គោលដៅដោយសារតែផ្ទុត់គំនិតរបស់ ប.ក.ក គិតថា ពួកគេជាប់ពាក់ព័ន្ធជាមួយវៀតណាម[2445] ហើយពួកគេខ្លាចថា ខ្មែរក្រោមអាចបង្កើតទាហានគាំទ្រមួយ បើសិនជាវៀតណាមឈ្លានពានកម្ពុជាប្រជាធិបតេយ្យ[2446]។ នៅទូទាំងស្រុកបាកាន កម្មាភិបាលខ្មែរក្រហមបានហៅខ្មែរក្រោមថា "គិញយួន" ហើយបានចោទពួកគេថា ក្បត់បក្ស[2447]។ ពួកគេបាន

[2444] *សូមមើលឧទាហរណ៍* ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន អ.១១២ KH 01068142 ["[យាយ រ៉ីម]ប្រមូលខ្មែរក្រោមពីគ្រប់សហករណ៍ទាំងអស់ទៅដាក់នៅសហករណ៍ខ្នារទទឹង ក្នុងភូមិកំប្រាក់ក្ងន។ ក្រោយមកទៀតនៅពេលបោសសម្អាតខ្មែរក្រោម គេបានចែកឲ្យសហករណ៍ខ្នារទទឹងសម្លាប់មួយចំនួន និងមួយចំនួនទៀតឲ្យទៅសហករណ៍ស្រោងជាអ្នកសម្លាប់"]។ ឯកសារ D219/639 កំណត់ហេតុនៃការស្តាប់ចម្លើយ កែវ ម៉ើ អ.៩៤ KH 01186832 ["យាយ រ៉ីម [...] ជម្លៀសមនុស្សទៅសម្លាប់"]។ ឯកសារ D118/197 កំណត់ហេតុស្តាប់ចម្លើយសាក្សី យាន ផាន អ.៦៥ KH 00978972។ ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទិត សុផារី អ.៤៧ KH 00977014។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត រ៉ុធ អ.៦០-៦១ KH 00985420។ ឯកសារ D6.1.757 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ ស៊ីន្ធន អ.៦០-៦១ KH 00385097-98។ ខណៈដែលចេតនាចុងក្រោយគឺដើម្បីសម្លាប់ខ្មែរក្រោមក៏ដោយ ក៏មានអ្នកខ្លះត្រូវបានគេបង្ខំឲ្យធ្វើការជាមុន សិននៅក្នុងសហករណ៍ខ្នារទទឹង មុននឹងពួកគេត្រូវបានសម្លាប់។ *សូមមើលឧទាហរណ៍* ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ អ.១០៣, ១០៧ KH 00996463-64 ["ជនរងគ្រោះត្រូវគេប្រមូលផ្តុំដាក់នៅខ្នារទទឹង បាក់ម៉ែក ហើយបន្ទាប់មកទើបបញ្ជូនទៅសម្លាប់ជាក្រុមៗ។ [...] គេបានប្រើឲ្យខ្មែរក្រោមស្ទ្ងរួចហើយទើបគេយកទៅសម្លាប់"]។

[2445] *សូមមើលឧទាហរណ៍* ឯកសារ D219/342 កំណត់ហេតុស្តាប់ចម្លើយសាក្សី សើន ធឿន អ.៩១, ៩៣, ៩៦ KH 01102887 [ប្រធានសហករណ៍រំលេច អ៊ុំ សៀម បានប្រាប់សាក្សីថា បងប្រុស និងឪពុកម្តាយរបស់គាត់ដែលជាខ្មែរក្រោម ត្រូវបានគេសម្លាប់នៅទួលសេះញ៉ូ "គាត់ប្រាប់ថា គេចោទឪពុកម្តាយខ្ញុំថាជាយួន យើយគេយកទៅវ៉ៃចោលអស់"]។ ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយសាក្សី ថាច់ សុខ អ.១០៣, ១០៥ KH 00267775 ["ខ្ញុំដឹងថាមានសាច់ញាតិខ្ញុំត្រូវសម្លាប់ ដោយសារមានអ្នកនៅរស់ក្នុងភូមិប្រាប់ខ្ញុំ។ [...] គាត់ប្រាប់ថាខ្មែរកម្ពុជាក្រោមត្រូវបានពួកខ្មែរក្រហមចោទថាជាប់ខ្សែយួន រួចពួកវាយកទៅសម្លាប់"]។ *សូមមើលបន្ថែម* V.គ.៣.ក. ឧក្រិដ្ឋកម្ម-ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – គោលនយោបាយរបស់ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាម – ចេតនារបស់ ប.ក.ក ចំពោះប្រជាជនវៀតណាម និងខ្មែរក្រោម។

[2446] ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហ៊ីម ស៊ីន្ធន អ.៨២, ៨៩-៩១ KH 01067999, 8000 [ភ្លាមៗមុននឹងវៀតណាមចូលក្នុងស្រុកបាកាន នៅចុងរបបកម្ពុជាប្រជាធិបតេយ្យ ហ៊ីម ស៊ីន្ធន បានអានឯកសារវាយអង្គុលីលេខមួយដែលផ្ញើជូនប្រធានអង្គភាពមួយ ដែលសរសេរថា: "យើងត្រូវវ៉ៃខ្មែរកម្ពុជាក្រោមចោល ត្រូវសម្លាប់ខ្មែរកម្ពុជាក្រោមចោល យួនមករំដោះវាឥឡូវហើយ"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនធឿន អ.៤៥ KH 00955684 គេ[នីរសារបស់យាយ រ៉ីម]បានប្រាប់យើងថា"នៅពេលដែលពួកយួនចូលមកដល់ ពួកហ្នឹង[ខ្មែរក្រោមនិងអ្នកជម្លៀសមកពីភូមិភាគបូព៌ា]នឹងចូលជាមួយយួនដើម្បីវ៉ៃយើងវិញ"]។ *សូមមើលផងដែរ* ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត រ៉ុធ អ.៩០ KH 00985424 ["តាមខ្ញុំយល់គឺគេ[ខ្មែរក្រហម]គិតថា ខ្មែរក្រោមមានទំនាក់ទំនងជាមួយនឹងយួន ហើយគេខ្លាចយួនវ៉ៃចូលស្រុក"]។

[2447] ឯកសារ D118/215 កំណត់ហេតុស្តាប់ចម្លើយសាក្សី ជា អ្ងួន អ.២៨, ៣៦ KH 00982160, 61 [អ្នកនៅរស់ខ្មែរក្រោម៖ "ខ្ញុំត្រូវគេចោទថា ជាខ្សែយួន។ [...] នេះជាមូលហេតុដែលគេចង់សម្លាប់ខ្ញុំ"]។ ឯកសារ D118/197 កំណត់ហេតុស្តាប់ចម្លើយសាក្សី យាន ផាន អ.៦៦ KH 00978972 ["គេចោទខ្ញែរក្រោមថា ជាគិញសម្ងាត់យួន ជាខ្សែរបស់យួន"]។ ឯកសារ D219/664

និយាយយោងដល់ពួកគេថា "ក្បាលយួន ខ្ជួនខ្មែរ"[2448] ជាឃ្លាដែលគេបានប្រើដដែលៗនៅក្នុងអង្គប្រជុំនានាធ្វើឡើងដោយ សារុន និង យាយ រីម[2449]។ សារុន បានប្រាប់ រីម ថា "គិញយួន មកបង្កប់[នៅក្នុងចំណោមពួកយើងទាំងអស់គ្នា ហើយបាន]រៃយកទឹកដី[យើង]"[2450] ហើយនៅក្នុងអង្គប្រជុំមួយនៅសហករណ៍ខ្ជាវទទឹង រីម បានប្រកាសថា "ខ្មែរកម្ពុជាក្រោមជាប់ខ្សែយួន ហើយខ្មែរកម្ពុជាក្រោមបើកចំហឲ្យយួនចូលក្នុងស្រុកខ្មែរ"[2451]។

កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.១១៦-១១៨, ១២០ KH 01198097-98 [រៀបរាប់អំពីកិច្ចប្រជុំមួយដែលមានមេកងម្នាក់ "ឡើងនិយាយ គេនិយាយថា កម្ពុជាក្រោម ស្វាយរៀង ព្រៃវែង អត់ទុកទេ" អង្គការ "[ចោទ]ថា អ្នកទាំងនោះ យួន។ គេថាយួន មិនទុកនៅលើដីខ្មែរ គេថាអីចឹង"]។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយសាក្សី វ៉ើន ដារ៉ា ឆ.៩៩ KH 00973956 ["បើនិយាយរួមគឺវាចោទថា "ក្បត់បក្ស" ទាំងអ្នកមកពីបូព៌ា និងខ្មែរក្រោម""]។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចាប ខ្ជង KH 00385092 ["ខ្មែរកម្ពុជាក្រោមជាគោលដៅនៃការចាប់ខ្ជួន ព្រោះពួកគេត្រូវបានចោទថាជា "យួន""]។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៤០, ៤២, ៤៤ KH 00996457។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយសាក្សី នឹម លន ឆ.៨៧ KH 01102925។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ចាត ឆ.១០១ KH 00977073។ ឯកសារ D118/214 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹង ភី ឆ.៣៨ KH 00982150។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយសាក្សី រ៉ាន់ ចូក ឆ.៤២ KH 00973924។ ឯកសារ D118/258 កំណត់ហេតុស្តាប់ចម្លើយសាក្សី រស់ ហ៊ីម ឆ.៥៨ KH 00996478។ ឯកសារ D5/113 ពាក្យសុំតាំងខ្ជួនជាដើមបណ្តឹងរដ្ឋប្បវេណី ទិត សុផារី EN 00426992 ["ខ្មែរក្រហមបានសម្លាប់ប្រជាជនខ្មែរក្រោម ដោយសារពួកគេសន្មតថា ខ្មែរក្រោមជាប់ខ្សែវៀតណាម"]។

[2448] *សូមមើលឧទាហរណ៍* ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.៩៣-៩៤, ៩៦ KH 01000266 [ប្រធានក្រុមក្នុងស្រុកបាកានដែលបានចូលរួមប្រជុំរៀបចំដោយគណៈសហករណ៍ក្នុងឆ្នាំ១៩៧៨ ត្រូវបានគេប្រាប់ថា "ពួកខ្មែរក្រោមនេះ មិនគួរទុកទេ ព្រោះពួកគេជាពួកក្បាលយួនខ្ជួនខ្មែរ"។ គាត់បានបញ្ជាក់អះអាងថា ការសម្លាប់ខ្មែរក្រោម គឺគេមានផែនការក្រោយការមកដល់របស់ក្រុមនិរតី នៅបាកាន]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនរ៉ឿន ឆ.៣៤-៣៥ KH 00955684។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.៦៣ KH 01198092។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយសាក្សី វ៉ើន ដារ៉ា ឆ.៩៩-១០១ KH 00973956-57។ ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហ៊ីម ស៊ីន្ធន ឆ.៨២ KH 01067999។

[2449] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រីម ឆ.៣១-៣២ KH 01348861។

[2450] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រីម ឆ.៨៦ KH 01347276។

[2451] ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៧១ KH 00996460។ *សូមមើលផងដែរ* ឆ.៦៥-៧១ KH 00996459-60។

666. ខ្មែរក្រោមរាប់ពាន់នាក់ត្រូវបានបញ្ជូនទាំងបង្ខំទៅខ្នារទទឹង[2452] រួមមានមនុស្សជាង ១០០ គ្រួសារ មកពីភូមិមួយ[2453]។ ក្នុងរយៈពេលពីពាក់កណ្តាល ដល់ចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨[2454] មន្ត្រីខ្មែរក្រហមរួមទាំង លេខាស្រុក រ៉ែម និង ផេង ហើយនឹងលេខាតំបន់ សារុន ផង បានកោះប្រជុំប្រធានសហករណ៍ និង"គណៈសមរភូម"(ប្រធានឈ្លប)នៅទូទាំងស្រុកបាកាន ដើម្បីចេញបញ្ជាសម្លាប់[2455]។ បន្ទាប់មក បញ្ជាទាំងនេះត្រូវបានគេផ្សព្វផ្សាយដល់អ្នកក្រោមឱវាទរបស់ពួកគេ ឈ្លប

[2452] ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយ លន ហេង ឆ.៣៩ KH 00973980។ ឯកសារ D6.1.757 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ ស៊ីន្ធន ឆ.៦០-៦១ KH 00385097-98។

[2453] ឯកសារ D118/189 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ាយ ឆ.៩៦ KH 00977036។ *សូមមើលផងដែរ* ឯកសារ D219/639 កំណត់ហេតុនៃការស្តាប់ចម្លើយ កែវ ម៉ើ ឆ.[៨៦] KH 01186831។

[2454] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែន ដារ៉ា ឆ.២៤ KH 00973947 ["ចាប់ពីពាក់កណ្តាលឆ្នាំ១៩៧៧ទៅ ខ្មែរក្រហមចាប់ផ្តើមសម្លាប់ខ្មែរក្រោម"]។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយសាក្សី គង់ រុន ឆ.១៤៦ KH 01034512 ["ខ្មែរក្រោមគេសម្លាប់នៅចុងឆ្នាំ១៩៧៨"]។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.៣៧-៣៨ KH 01198089-90។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ភេ ឆ.៦៧, ៧៣ KH 01102907, 08។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចាប ខ្ជង KH 00385092។ ឯកសារ D118/199 កំណត់ហេតុស្តាប់ចម្លើយសាក្សី អ្ជង សារ ឆ.៣០ KH 00978995។

[2455] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ែម ឆ.១៣-១៤, ១៦, ១៩, ៤២ KH 01348858-59, 63 [សារុន បានប្រជុំជាមួយមន្ត្រីសហករណ៍ ដោយបានកំណត់ផែនការដើម្បីកម្ទេចខ្មាំងដែលជាប់ខ្សែវៀតណាម ហើយបានបញ្ជាបន្តទៅ យាយរ៉ែម ដើម្បីសម្លាប់ចោលដែលគាត់បានផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំដល់អ្នកក្រោមបង្គាប់របស់គាត់]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.១១២ KH 01068142 [គណៈសមរភូមិនៅសហករណ៍ស្រោង: "ក្រោយ [ពេលដែល យាយរ៉ែម បានប្រមូលផ្តុំខ្មែរក្រោមរួចហើយ] គេបានចែកឱ្យសហករណ៍ខ្នារទទឹងសម្លាប់មួយចំនួន និងមួយចំនួនទៀតទៅសហករណ៍ស្រោងជាអ្នកសម្លាប់] ឆ.១៣១ KH 01068145 ["ខ្ញុំទៅចូលរួមប្រជុំ ហើយ យាយរ៉ែម ដាក់បទបញ្ជាឱ្យមកខ្ញុំធ្វើរឿងទាំងអស់នេះ គឺដាក់បទបញ្ជាឱ្យធ្វើនៅតាមសហករណ៍នីមួយៗ។ យាយរ៉ែម ជាអ្នកដាក់បញ្ជាឱ្យខ្ញុំទទួលខុសត្រូវក្នុងការសម្លាប់ខ្មែរក្រោមទាំងអស់នោះ។ នេះគឺជាបទបញ្ជាតៗគ្នា""]។ ឯកសារ D240R វីដេអូ *សត្រូវរបស់ប្រជាជន កំណាត់ខ្សែវីដេអូបន្ថែម៖ ឃួន រៀបរាប់អំពីផែនការ* ២០១០ ម៉ោង 1:00-3:58 [ផាន ឃន និយាយថា គាត់ទៅចូលរួមប្រជុំនៅមន្ទីរស្រុក ហើយ តាផេង "បានប្រាប់យើងថា បញ្ជាពីថ្នាក់លើឱ្យបោសសម្អាតសហគមន៍ខ្មែរក្រោម" ហើយគេទុកពេលឱ្យមួយអាទិត្យ ដើម្បីសម្លាប់ខ្មែរក្រោមទាំងអស់]។ ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ីក សៀម ឆ.១៩-២២, ២៤-២៦ KH 00872599-600 [អតីតប្រធានសហករណ៍រំលេច បានរៀបរាប់អំពីការប្រជុំមួយដែលគាត់បានចូលរួម នៅមន្ទីរស្រុកកោះរុន ក្នុងឃុំស្រោង នៅឆ្នាំ១៩៧៨ ជាមួយនឹងប្រធានសហករណ៍ប្រហែលជា ២០-៣០នាក់ទៀតក្នុងស្រុកបាកាន។ យាយរ៉ែម បានត្រឡប់ពីប្រជុំជាមួយលេខាតំបន់ សារុន ហើយបាន "និយាយអំពីផែនការសម្លាប់ខ្មែរក្រោម"]។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ី សំ ឆ.៤៣ KH 00982192។ ឯកសារ D6.1.757 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ ស៊ីន្ធន ឆ.៦០-៦១ KH

មូលដ្ឋាន និងឈ្លបដទៃទៀត[2456] ដែលជាអ្នកដែលបានអនុវត្តការសម្លាប់ទាំងនោះ រួមទាំងនៅទួលសេះញ្ជ្ញ និងនៅព្រៃក្របៅផង[2457]។

667. ខ្មែរក្រហមបានចាត់ចែងចំពោះការជ្រើសរើស និងការដើរហើររបស់ខ្មែរក្រោមពីខ្នារទទឹង ទៅទួលសេះញ្ជ្ញ និងព្រៃក្របៅ។ សាក្សីជាច្រើនបានរៀបរាប់អំពីការប្រជុំនៅខ្នារទទឹង ដែលពួកកម្មាភិបាលខ្មែរក្រហម រួមទាំង ឃារ៉ែម ខ្លួនឯងផ្ទាល់ផង បានលួងខ្មែរក្រោមឲ្យចេញទៅទីតាំងសម្លាប់មនុស្ស

00385098 ["ចំពោះបញ្ជាឲ្យសម្លាប់[ខ្មែរក្រោម] ខ្ញុំដឹងថា បញ្ជាទាំងនេះចេញពីអង្គការថ្នាក់លើ និងពីឃាយ រ៉ែម"]។ *សូមមើលផងដែរ* ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយសាក្សី វ៉ាន់ ម៉ុច ឆ.៦២ KH 00977098។

[2456] ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.២៤-២៥, ២៨ KH 01068110-11 ["សហការណ៍ជាអ្នករៀបចំឈ្លបតាមសហការណ៍។ [...] [សហការណ៍និមួយៗ]មានកងឈ្លបផ្សេងគ្នា។ [...] [អ្នកដែលទទួលខុសត្រូវកងឈ្លប] រាយការណ៍ទៅមេសហការណ៍"]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.១២៥ KH 01068145 [បទបញ្ជាទៅឈ្លប មកពីគណៈសហការណ៍]។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ភេ ឆ.៤៩ KH 01102906 ។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ថឹក ប៊ុនរ៉ឿន ឆ.៣៤ KH 00955682។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.១២៩ KH 01198099។ *សូមមើលផងដែរ* ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហ៊ីម ស៊ីន្ធន ឆ.៨២, ៩០-៩១ KH 01067999, 8000 *បញ្ជាក់* ឯកសារ D219/793.1 ប្រតិចារ៉ឹករបស់រ៉ឿង សត្រូវរបស់ប្រជាជន KH 01302792-93។

[2457] ភ័ស្តុតាងបង្ហាញថា ជនរងគ្រោះដែលគេបានយកទៅទួលសេះញ្ជ្ញ(ស្ថិតនៅក្នុងសហការណ៍ខ្នារទទឹង) ជារួមត្រូវបានសម្លាប់ដោយឈ្លបសហការណ៍ខ្នារទទឹង ខណៈនៅព្រៃក្របៅ(ស្ថិតនៅសហការណ៍ស្រោង)ត្រូវបានសម្លាប់ដោយឈ្លបសហការណ៍ស្រោង ។ *សូមមើល* ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.១១២ KH 01068142 ["គេបានចែកឲ្យសហការណ៍ខ្នារទទឹងសម្លាប់មួយចំនួន និងមួយចំនួនទៀតឲ្យទៅសហការណ៍ស្រោងជាអ្នកសម្លាប់"]។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.៥០ KH 01198091 ["គេបំបែកជាពីរក្រុម [...] [មួយក្រុម] បញ្ជូនទៅទួលសេះញ្ជ្ញ [...] មួយក្រុមទៀត គេយកទៅសម្លាប់នៅព្រៃក្របៅ"]។ ទាក់ទងនឹងជនដែលរស់នៅទីតាំងនិមួយៗ *សូមមើលឧទាហរណ៍* <u>ទួលសេះញ្ជ្ញ</u>៖ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.៥២, ៥៩ KH 01198091, 92។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ចាត ឆ.៧៦, ៧៨, ៨១ KH 00977069-70។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត រ៉ុធ ឆ.៦០-៦១ KH 00985420។ ឯកសារ D118/197 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឃាន ផាន ឆ.៣៩-៤០, ៥៤ KH 00978970, 71។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវ ជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ចិន សុខុម EN 00527090-91។ <u>ព្រៃក្រូបៅ</u>៖ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.១១៦-១១៨ KH 01068143-44។ ឯកសារ D219/187 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៦០ KH 01068116។ ឯកសារ D118/238 កំណត់ហេតុស្តាប់ចម្លើយ កុល សែត ឆ.៩៣ KH 00988034។

ទួលសេះញ៉ូ ដោយប្រាប់ពួកគេថា ទៅដកដំឡូង កាច់ពោត[2458] ឬថា ដូរទីកន្លែង/សមរភូមិ ជាដើម[2459]។

ផែនការសម្លាប់អ្នកជម្លៀសមកពីភូមិភាគបូព៌ានៅក្នុងស្រុកបាកាន

668. ការផ្តោតជាបន្ទាប់នៃគោលនយោបាយខ្មាំងរបស់សមាជិកសហឧក្រិដ្ឋកម្មរួម (JCE) គឺអ្នកជម្លៀសមកពីភូមិភាគបូព៌ា ដែលកំពុងរស់នៅក្នុងភូមិភាគពាយ័ព្យ[2460]។ នៅចន្លោះពីចុងឆ្នាំ១៩៧៧ និងដើម

[2458] ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទិត សុផារី ឆ.៥៨, ៦០ KH 00977016 ["[យាយរ៉ីម] បាននិយាយថា កម្លាំងនេះទៅកាច់ពោត ដកដំបូងជាដើម។[...]គឺត្រូវគេបញ្ជូនទៅសម្លាប់នៅព្រៃក្របៅ"]។ ឯកសារ D118/254 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ឡូយ ឆ.២៣-២៤, ២៩ KH 00996424-25 [ខ្មែរក្រហមបានចាប់ខ្លួនខ្មែរក្រោមហើយយកពួកគេទៅសម្លាប់នៅទួលសេះញ៉ូ និងព្រៃក្របៅ ដោយកុហកពួកគេថា ទៅកាច់ពោត]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនរឿន ឆ.៤៨ KH 00955685។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយសាក្សី វ៉ាន់ ឆ្ងក ឆ.៧០ KH 00973927។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ចិន សុខុម EN 00527090-91។ ឯកសារ D347.3 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជា ដោយ គឹម កែវកន្ទ្ធិដ្ឋា *ឃុំរំលេខ៖ ខ្មែរក្រោម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ការរៀបរាប់របស់ វ៉ាន់ មុត KH 01413645-46 ["ការប្រមូលប្រជាជនទៅសម្លាប់នៅទីតាំងពិឃាតទួលសេះញ៉ូ ដោយប្រាប់ថាយកទៅជីកដំឡូងនៅព្រៃធំមានរយៈពេលបីថ្ងៃជាបន្តបន្ទាប់។ នៅថ្ងៃទី៣ នៃការប្រមូលខ្មែរក្រោមទៅព្រៃធំ វ៉ាន់ មុត បានឮសូរសំឡេងផ្ទុះកាំភ្លើងនៅទួលសេះញ៉ូ"]។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត ចាត ឆ.៧១, ៧៣-៧៥ KH 00977069។ ឯកសារ D118/215 កំណត់ហេតុស្តាប់ចម្លើយសាក្សី ជា អ្ងួន ឆ.២៨ KH 00982160។ ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយសាក្សី លន ហេង ឆ.៥៣, ៥៥, ៥៧ KH 00973982។ ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយសាក្សី រ៉ែន រ៉ន ឆ.៨១ KH 00977086។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង អេង ឆ.៧៩ KH 00996449។

[2459] ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.៤០ KH 01198090 [យោងសំដៅខ្មែរក្រោមដែលគេបានសម្លាប់នៅទួលសេះញ៉ូ និងព្រៃក្របៅ ថា៖ "ក្រុមទី១ អង្គការត្រូវការផ្លាស់កន្លែង តាមតែពិត យកទៅសម្លាប់ចោល"]។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៤៥-៤៦ KH 00996458 ["ខ្មែរក្រហមប្រាប់ថា ឲ្យផ្លាស់ទីលំនៅទៅកន្លែងផ្សេង។ តាមពិត គេបញ្ជូននារីទាំងអស់នោះទៅសម្លាប់ចោល។ [...] [នារីទាំងនោះ] គេសម្លាប់នៅច្រើនកន្លែង អ្នកខ្លះត្រូវគេសម្លាប់នៅទួលសេះញ៉ូ"]។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែត រ៉ុធ ឆ.៦០-៦១ KH 00985420។ ឯកសារ D219/676 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហុក សារិន ឆ.៦៨ KH 01202402។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ីន ដារ៉ា ឆ.៥៥ KH 00973951។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ ស៊ីន្ធន ឆ.៣២, ៤៣ KH 00955767, 69។ ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយសាក្សី វ៉ាន់ ម៉ុច ឆ.១៤ KH 00977094។

[2460] *សូមមើលឧទាហរណ៍* ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនរឿន ឆ.៤៥-៤៦ KH 00955684 [គេ[នីរសារបស់យាយរ៉ីម]បានប្រាប់យើងថា 'គេសម្លាប់ខ្មែរក្រោមអស់សិន ទើបគេសម្លាប់ខ្មែរដែលនៅស្វាយរៀង និងព្រៃវែងតាមក្រោយ']។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយសាក្សី នឹម លន ឆ.៦០ KH 01102922 ["ដំបូង គេយកខ្មែរកម្ពុជា

ឆ្នាំ១៩៧៩ កងកម្លាំងភូមិភាគនិរតីបានបញ្ជូនដោយបង្ខំនូវប្រជាជនពីបណ្តាខេត្តនៅភូមិភាគបូព៌ា មកកាន់ខេត្តពោធិ៍សាត់[2461] រួមមានគ្រួសារទាំងមូល ស្ត្រី កុមារ និងមនុស្សចាស់[2462]។ អាជ្ញាធរខ្មែរក្រហមបានបញ្ជាឲ្យពាក់ក្រមាខៀវចំពោះអ្នកជម្លៀសមកពីភូមិភាគបូព៌ា ដើម្បីឲ្យកម្មាភិបាលងាយស្រួលចំណាំប្រភពដើមរបស់ពួកគេ[2463]។

ក្រោមទៅសម្លាប់ ហើយក្រោយមកបានគេយកអ្នកស្វាយរៀងទៅសម្លាប់"]។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.៦៩ KH 01198093["ពេលគេយកខ្ញែរក្រោមសម្លាប់អស់ គេយកអ្នកស្វាយរៀង ព្រៃវែងមកនៅ[ខ្នារទទឹង]។ ហ្នឹង គេចាប់ផ្តើមជម្រុះអ្នកស្វាយរៀង អ្នកព្រៃវែងវិញម្តង"] ឆ១២៣ KH 01198098 ["ពេលហ្នឹង គេសម្លាប់ខ្ញែរក្រោមជិតអស់ហើយ ពេលដែលគេយកអ្នកស្វាយរៀង ព្រៃវែង មកនៅបណ្តើរៗ"]។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយសាក្សី សេង អេង ឆ.៧៩ KH 00996447។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយសាក្សី ស៊ីន ដារ៉ា ឆ.៩៤ KH 00973956។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.១១៩ KH 00996465។

[2461] *សូមមើលឧទាហរណ៍* ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន រិន ឆ.៧៧, ៩៣ KH 01075617, 20 ["នៅឆ្នាំ១៩៧៨ គេសម្រុកដឹកមកដាក់ស្រុកបាកានច្រើនណាស់ កន្លែងណាក៏មានប្រជាជនបូព៌ាដែរ។ [...] ចុងឆ្នាំ១៩៧៧ ក៏មានប្រជាជនបូព៌ាមកដល់ដែរ ហើយរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ក៏មានប្រជាជនបូព៌ាមកដល់ដែរ"]។ ឯកសារ D219/702.1.4 លីម សាត ប្រតិចារឹក ថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 11.10.10-11.12.20, 13.46.53-13.48.58។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ៊ីន ឆ.១៧, ៦៣ KH 01089497, 504។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លីម សាត ឆ.៣-៤, ១១ KH 00947338-39, 40។ ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277335-37។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.៣៩-៤០ KH 00947317។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្លួន ហ៊ៀ ឆ.៧១ KH 01067959។ ឯកសារ D5/450/3 ប្រតិចារឹក យ៉ីម សុវណ្ណ ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង 16.01.20-16.03.33។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គ៉ីម ស្ងួ ឆ.៦៥-៦៦ KH 00955716។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៉ឹង ឆ.៦, ១០, ២៨-២៩ KH 00947346, 49។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៤៨, ៩២, ៩៩ KH 01149900, 905-906។ ឯកសារ D6.1.129 កំណត់ហេតុស្តាប់ចម្លើយ ម៉ែន ភ្លួន KH 00242428-29។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៩៩-២០០, ២៨៦ KH 01000277-78, 88។ ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្ហី KH 00273428-29។ ឯកសារ D65.1.56 កំណត់ហេតុស្តាប់ចម្លើយ នីម សាម៉ុន KH 00250705-07។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយសាក្សី ម៉ី សំ ឆ.១៨, ២១, ៣១ KH 00982190-91។

[2462] ឯកសារ D6.1.417 កំណត់ហេតុស្តាប់ចម្លើយ ឌួង អ៊ីន KH 00249891-02។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៤៦ KH 00947333។

[2463] *សូមមើលឧទាហរណ៍* ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយសាក្សី ខៀវ ផន ឆ.៧៧-៧៨ KH 01198094 ["អ្វីដែលស្ងៀកពាក់ហ្នឹងខ្ចៅដូចគ្នា តែខុសពាក់ក្រមាខៀវ ដើម្បីងាយស្រួលចំណាំអ្នកដែលគេបញ្ជូនមកហ្នឹង។ [...] តាមខ្ញុំគិត គេចំណាំ ពេលគេយកទៅសម្លាប់ហ្នឹង អ្នកដែលពាក់ក្រមាហ្នឹងគឺមកពីហ្នឹងតែម្តង"]។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ ស៊ីន្ធួន ឆ.៥១ KH 00955770។ ឯកសារ D118/213 កំណត់ហេតុស្តាប់ចម្លើយសាក្សី យ៉ីម ខុន ឆ.១០២ KH 00982139។ ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយសាក្សី លន ហេង ឆ.៨២-៨៣ KH 00973985។ ឯកសារ

669. ខ្មែរក្រហមបានរៀបរាប់អំពីអ្នកជម្លៀសមកពីភូមិភាគបូព៌ា ដូចខ្មែរក្រោមជាដើម ថាជាពួក "ក្បាលយួនខ្លួនខ្មែរ"[2464]។ ផ្នត់គំនិតរបស់ ប.ក.ក គឺថា ខ្លួនឯងក៏ធ្លាប់រួមដៃ ធ្លាប់ឈ្លបយកការណ៍ ឬយ៉ាងហោចណាស់ ក៏ធ្លាប់អាណិតអាសូរដល់វៀតណាមដែរ ដូច្នេះហើយទើបមានការក្បត់បក្ស[2465]។ ការភ័យខ្លាចចំពោះឧទ្ទាមកម្មពីអ្នកជម្លៀសមកពីភូមិភាគបូព៌ា ប្រសិនបើវៀតណាមឈ្លានពាន ក៏ជាចំណុចចម្បងនៃកង្វល់របស់ខ្មែរក្រហមផងដែរ[2466]។

D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.៩១ KH 01075620។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជូត ម៉ឹង ឆ.៣០ KH 00947349។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួរ ឆ.៦៥-៦៦ KH 00955716។

[2464] ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៤៣ KH 01102859។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនរ៉ឿន ឆ.៤៥ KH 00955684។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយសាក្សី គី ប៉េងលី ឆ.៧៣ KH 01158599។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយសាក្សី ឃីម សារុន ឆ.៦៤ KH 01088799។

[2465] *សូមមើលឧទាហរណ៍* ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហេង សៀង ឆ.១២ KH 01075712 ["ពួកឈ្លបដែលបានចូលរួមប្រជុំ ហើយបានដឹងព័ត៌មាននេះ ក៏បានមកប្រាប់ខ្ញុំបន្តថា គេត្រូវសម្លាប់ពួកស្វាយរៀង ព្រោះពួកស្វាយរៀងជា គិញ សេ.អ៊ុ.អា"]។ ឯកសារ D5/197 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារ៉ឿន KH 00571256 [អ្នកបូព៌ាដែលនៅរស់រានមានជីវិត: "ក្រោយហើយគេចាប់ខ្ញុំ ដែលយោធា៤នាក់ ដោយគេចោទខ្ញុំ ខ្ជាំងយួនមកពីភូមិភាគបូព៌ា"]។ ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយសាក្សី រស់ ណារ៉ីន ឆ.៨២-៨៣ KH 00977114 ["ខ្ញុំបានឮថា អ្នកស្វាយរៀង [...] ជាខ្ជាំងផ្ទៃក្នុង។ ខ្ញុំឮថា អ្នកស្វាយរៀងទាំងនោះបានរត់ចូលទៅស្រុកយួន ដូច្នេះទើបពួកខ្មែរក្រហមចាប់អ្នកទាំងអស់នោះ ហើយជម្លៀសមកដល់កន្លែងរបស់ខ្ញុំ ដោយចោទថាខ្ជាំងបង្ក"]។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយសាក្សី ង៉ែន ដារ៉ា ឆ.៩៩ KH 00973956 ["បើនិយាយរួមគឺវា[កម្មាភិបាលខ្មែរក្រហម]ចោទថា "ក្បត់បក្ស" ទាំងអ្នកមកពីបូព៌ា [...]""]។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ ឃង់ សុខុម *ហៅ* ឃង់ ហាន ឆ.១៤៧ KH 01025550 ["គេ[កម្មាភិបាលខ្មែរក្រហម] និយាយថា "ប្រជាជនស្វាយរៀង និងព្រៃវែងជាពួកក្បត់""]។

[2466] ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៧ KH 00485646 ["តាម៉ុក បាននិយាយអំពីការជម្លៀសប្រជាជនមកពីភូមិភាគបូព៌ា អំពីមូលហេតុនៃការជម្លៀសនេះ គឺដោយសារតែនៅតាមបណ្តាយព្រំដែនកម្ពុជា-វៀតណាម គឺមានការលំបាកដោយសារតែកងទ័ពវៀតណាមបានលុកលុយចូលកម្ពុជា ហើយមេភូមិភាគបូព៌ាឈ្មោះ សោ ភ័ម បានក្បត់"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយសាក្សី ចឹក ប៊ុនរ៉ឿន ឆ.៤៥ KH 00955684។

670. នៅចុងឆ្នាំ១៩៧៨ អ្នកជម្លៀសមកពីភូមិភាគបូព៌ាទាំងនេះ ត្រូវបានគេបញ្ជូនទៅកាន់ស្រុកបាកាន ដើម្បីសម្លាប់ចោល[2467]។ មន្ទីរ ៨៧០ បានចេញបញ្ជាឲ្យសម្លាប់ទាំងនោះ[2468]។ បញ្ជាត្រូវគេទម្លាក់ទៅឲ្យកម្មាភិបាលថ្នាក់ក្រោមនៅក្នុងស្រុកយ៉ាងប្រុងប្រយ័ត្នដោយ តាម៉ុក[2469]។ សារុន ជាលេខាតំបន់ និង រ៉ែម ជាលេខាស្រុកបាកាន ជាអ្នកធានាដល់ការអនុវត្តផែនការទាំងនេះ តាមរយៈការចេញបញ្ជាឲ្យសម្លាប់អ្នកជម្លៀសមកពីភូមិភាគបូព៌ា[2470] ដែលបានអនុវត្តនៅតាមទីតាំងនានានៅទូទាំងស្រុកបាកាន រួមទាំង ទួលសេះញ៉ូ និងព្រៃក្រហៅ។

[2467] *សូមមើលឧទាហរណ៍* ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហង្ស ង៉ែត ឆ.៧៥-៧៦ KH 00982180 ["ក្នុងរំលេច [...]។ នៅចុងឆ្នាំ១៩៧៨ ពេលដែលខ្ញុំត្រូវគេជម្លៀសមកនៅទីនេះ គឺមានការសម្លាប់ពេញទំហឹងតែម្តងទៅលើអ្នកស្វាយរៀង"]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.១៣៣-១៣៤ KH 01068146 ["ដំបូងគេជម្លៀសអ្នកបូព៌ាមកដល់ទីនេះ ហើយបែងចែកឲ្យនៅតាមគ្រប់សហករណ៍។ [...] គេជម្លៀសអ្នកបូព៌ាមកដល់តំបន់នេះប្រហែលជាខែ១០ ចុងឆ្នាំ១៩៧៨។ ក្រោយអ្នកបូព៌ាមកដល់ប្រហែលជាកន្លះខែក៏មានការសម្រេចសម្លាប់អ្នកបូព៌ាចោល"។ ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទិត សុផារី ឆ.៤៧ KH 00977018។

[2468] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៨៤-១៨៦ KH 01000276។

[2469] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៧១, ១៨៦, ១៩៤ KH 01000275-76, 77 [ប្រធានក្រុមក្នុងស្រុកបាកាន (*សូមមើល* ឆ.៩៤)៖ "តាម៉ុក [...] គេហៅថា តា១៥ [...] មកប្រជុំប្រាប់កម្មាភិបាលថ្នាក់ក្រោមបន្តទៀត។ មេកងដែលបានចូលរួមប្រជុំនោះក៏បានយកផែនការនោះមកប្រាប់ខ្ញុំ។ [...] គណៈ៨៧០មកប្រជុំជាមួយនឹងថ្នាក់តំបន់ ហើយថ្នាក់តំបន់មកប្រជុំប្រាប់ថ្នាក់ស្រុក ហើយថ្នាក់ស្រុកមកប្រជុំប្រាប់ថ្នាក់សហករណ៍។ ចុងក្រោយគណៈសហករណ៍ហៅខ្ញុំទៅប្រជុំ"]។ *សូមមើលផងដែរ* ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សឿម ឆ.៥ KH 00485645-46។

[2470] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ែម ឆ.៩-១១, ១៣-១៤ KH 01348857-58 [យាយរ៉ែម បានបញ្ជាក់ថា ពេលដែលវៀតណាមវាយប្រហារមកលើព្រំដែនកម្ពុជាប្រជាធិបតេយ្យ ម៉ុក និង សារុន បានជួបគ្នា។ ភ្លាមៗបន្ទាប់ពីនោះ ប្រជាជនមកពីស្វាយរៀង និងព្រៃវែង ត្រូវបានសម្លាប់នៅក្រោមបញ្ជារបស់គាត់[យាយរ៉ែម]។ សារុន ក៏បានប្រជុំប្រាប់ដល់សហករណ៍នានាផងដែរ]។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយសាក្សី ផាន ឃន ឆ.១៣៣-១៣៤ KH 01068146 ["មានបទបញ្ជានិយាយថា អ្នកបូព៌ាទាំងអស់នោះគឺជាខ្សែយួនដូចខ្មែរក្រោមដែរ។ បទបញ្ជាឲ្យសម្លាប់នេះគឺចេញពីតំបន់មកដល់ស្រុក ហើយស្រុកមកដល់សហករណ៍ រួចមកដល់គណៈសមរភូមិ រួចទៅឈ្លប ហើយក៏ធ្វើការសម្លាប់អ្នកបូព៌ាតាមសហករណ៍នីមួយៗ"] ឆ.១៣៦-១៣៨ KH 01068146-47 [គណៈសមរភូមិនៅសហករណ៍ស្រោងដែលគាត់ "ទទួលបន្ទុកក្នុងការសម្លាប់អ្នកបូព៌ា" និងថា ចុងឆ្នាំ១៩៧៨ យាយរ៉ែម "ជាអ្នកចេញបញ្ជាមកឲ្យសម្លាប់អ្នកបូព៌ា" នៅក្នុងអង្គប្រជុំមួយជាមួយប្រធានសហករណ៍ និងគណៈសមរភូមិ]។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយសាក្សី ហេង សៀង ឆ.៨៦-៨៩, ៩៥ KH 01075711-13 [ពួកឈ្លបក្នុងសហករណ៍ស្រោង បានប្រាប់អំពីផែនការសម្លាប់អ្នកជម្លៀសមកពីភូមិភាគបូព៌ាដោយកងឈ្លបដែលបានចូលរួមប្រជុំនៅមន្ទីរស្រុកនៅរំលេច។ ពួកគេត្រូវបានគេប្រាប់ថា "គេត្រូវសម្លាប់ពួកស្វាយរៀង ព្រោះពួកស្វាយរៀងជាគិញ សេ.អ៊ី.អា"]។ ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយសាក្សី សុខ ប៉ាន់ ឆ.១១១-១១៤ KH 01167528-29

ការសម្លាប់នៅទួលសេះញ៉ូ និងព្រៃក្របៅ

671. គេឮល្បីថានៅស្រុកបាកានទាំងមូល ខ្មែរក្រោមរាប់ពាន់នាក់ត្រូវបានសម្លាប់នៅតាមទីតាំងមួយចំនួននៅកន្លែងនោះ រួមទាំងកន្លែងដែលគេដឹងឮគ្រប់គ្នា ទួលសេះញ៉ូ និងព្រៃក្របៅ[2471] ផង។ មានសាក្សីជាច្រើនបាននិយាយអំពីការសម្លាប់នេះ បានកើតឡើងនៅក្នុងបីដំណាក់កាល[2472] ដោយមានខ្មែរក្រោមរាប់រយនាក់ត្រូវបានសម្លាប់ជារៀងរាល់លើក[2473]។ ខណៈដែលការចងចាំរបស់សាក្សីនានា ខុសគ្នាពីពេលវេលាជាក់លាក់ ទីតាំងសម្លាប់មនុស្ស និងក្រុមជនរងគ្រោះនៅក្នុងដំណាក់ការទាំងនេះ គេច្បាស់ថា ការសម្លាប់ទាំងនេះបានកើតឡើងនៅក្នុងដំណាក់កាលចាប់ពីពាក់កណ្តាលទៅចុងឆ្នាំ១៩៧៧ និង ឆ្នាំ១៩៧៨[2474] ហើយថា ពួកខ្មែរក្រហមបានផ្តោតគោលដៅជាដំបូងទៅលើ

[សាក្សីធ្លាប់ធ្វើជាអ្នកដាំស្ពឲ្យយាយ រ៉ែម មួយឆ្នាំ។ គាត់ធ្លាប់ឮ យាយរ៉ែម និយាយអំពីអ្នកជម្លៀសមកពីភូមិភាគបូព៌ា។ យាយរ៉ែមចេញបញ្ជាឲ្យ "ប្រមូលយកទៅដាក់ក្រោល"]។

[2471] *សូមមើលឧទាហរណ៍* ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង ផេង ឆ.១៦-១៧ KH 00996447 ["ខ្ញុំដឹងថាគេបានបញ្ជូនខ្មែរក្រោមជាច្រើនទៅសម្លាប់នៅព្រៃក្របៅ និងទួលសេះញ៉ូ។ មិនមែនមានខ្មែរក្រោម៤០០នាក់ដែលត្រូវគេសម្លាប់នោះទេ គឺមានរហូតដល់រាប់ពាន់នាក់ឯណោះ។ [...] មានខ្មែរក្រោមរាប់ពាន់។ [...] ខ្ញុំមិនបានរាប់ចំនួនថាប៉ុន្មានថា មានប៉ុន្មានទេ ប៉ុន្តែប្រហែលជាច្រើនជាងរាប់ពាន់នាក់ អាចរហូតទៅដល់រាប់ម៉ឺននាក់ឯណោះ"]។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385092 ["ក្នុងឆ្នាំ១៩៧៨ មានខ្មែរកម្ពុជាក្រោមជាច្រើនក៏ត្រូវបានសម្លាប់ផងដែរ នៅក្នុងទីកន្លែងពីរខុសគ្នា គឺនៅទួលសេះញ៉ូវមួយ និងព្រៃកាបាវ"]។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សំ ឆ.៥៨ KH 00982194 ["គេសម្លាប់ [ខ្មែរក្រោម] ច្រើនកន្លែងដូចជា នៅខ្នារទទឹង នៅសេះញ៉ូវជាដើម"]។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.៨៨ KH 00979042។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ្ជន ឆ.១១២-១១៣ KH 01176417។ ឯកសារ D347/2.1.11 បទសម្ភាសន៍ជាមួយ ប្រាក់ សារិន ដោយមជ្ឈមណ្ឌលឯកសារកម្ពុជា KH 00044066។

[2472] *សូមមើល ឧទាហរណ៍* ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ចូក ឆ.៧១ KH 00973927 ["ការសម្លាប់ខ្មែរក្រោមនេះចែកជាបីដំណាក់កាលគឺ ដំណាក់កាលទី១ ដំណាក់កាលទី២ និងទី៣"]។ ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយ ទិត សុផារី ឆ.៤៨ KH 00977014 ["គេចែកចេញជាបីវគ្គក្នុងការសម្លាប់ខ្មែរក្រោម"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក ប៊ុនរ៉ឿន ឆ.៣៨, ៤៨ KH 00955683, 85។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រ៉ុធ ឆ.៧៧-៧៩, ៨៤ KH 00985422-23។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.១៦ KH 00977068។

[2473] *សូមមើល ឧទាហរណ៍* ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ចូក ឆ.៧១-៧២ KH 00973927 [ដោយទៅកាន់បីដំណាក់កាល៖ "ការសម្លាប់ទាំងបីលើកនេះ គឺមានខ្មែរក្រោមរាប់រយនាក់ដូចគ្នា"]។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រ៉ុធ ឆ.១១-១២ KH 00985420 ["នៅល្ងាចថ្ងៃដដែលនោះគេបានបញ្ជូនខ្មែរក្រោមទៅសម្លាប់នៅទួលសេះញ៉ូវ។ [...] ប្រហែលជាង២០០នាក់"]។

[2474] *សូមមើល ឧទាហរណ៍* ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ចូក ឆ.៧១-៧២ KH 00973927 [ការសម្លាប់ទាំងបីដំណាក់កាល កើតឡើងនៅចុងឆ្នាំ១៩៧៧]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ម៉ីក ប៊ុនរ៉ឿន ឆ.៣៨ KH

ខ្មែរក្រោមដែលមានកម្លាំងខ្លាំងជាងគេបំផុត មុននឹងបន្តទៅកាន់ពួកជនរងគ្រោះ ដែលខ្សោយជាង ដូចជា មនុស្សចាស់ជាដើម[2475]។ ជនរងគ្រោះខ្លះមិនអាចសូម្បីតែដើរបានផង[2476]។ ឈ្លបម្នាក់ពីសហករណ៍ស្រែាង បានពន្យល់ថា ពួកខ្មែរក្រហមបានខិតទៅរកការសម្លាប់តាមរបៀបនេះ ពីព្រោះពួកគេខ្លាចខ្មែរក្រោមបះបោរ និងចង់ឲ្យប្រាកដថា អ្នកមានកម្លាំងខ្លាំងបំផុតត្រូវបានកម្ចាត់ចោលជាមុន[2477]។

672. អ្នកភូមិនៅសហករណ៍ខ្នារទទឹង បានឃើញក្រុមខ្មែរក្រោមនានាត្រូវបានយកចេញ ហើយសម្លៀកបំពាក់ និងរបស់របររបស់ពួកគេត្រូវបានវិលមកវិញ នេះមានន័យថា ពួកគេត្រូវបានសម្លាប់ហើយ[2478]។ នៅដើមឆ្នាំ១៩៧៨ ខៀវ ផន បានឃើញគ្រួសារខ្មែរក្រោមប្រមាណពី៣០ ទៅ៤០ គ្រួសារ ត្រូវបានបំបែកជាក្រុមតូចៗប្រមាណជា ៦០ នាក់ យកចេញទៅសម្លាប់អស់រយៈពេលប្រហែលជា "កន្លះខែ"។ គាត់ត្រូវបានប្រាប់ដោយ ម៉ី "គណៈសមរភូមិ" ពីសហករណ៍ខ្នារទទឹង[2479] ថា ពួកគេត្រូវបានបំបែកជាពីរក្រុម៖ ក្រុមមួយឆ្ពោះទៅកាន់ទួលសេះញ៉ូ (ដែលគាត់បានប៉ាន់

00955683 ["នៅចុងឆ្នាំ១៩៧៨ គេ [ខ្មែរក្រហម] យកខ្មែរក្រោមទៅសម្លាប់"]។ ឯកសារ D118/223 កំណត់ហេតុស្តាប់ចម្លើយ គឹម ហួយ ឆ.៣៥ KH 00985380។

[2475] *សូមមើល ឧទាហរណ៍* ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ថឹក ប៊ុនរ៉ឿន ឆ.៣៨ KH 00955683 ["វគ្គទី១ គេយកអ្នកដែលមានកម្លាំងធំទៅសម្លាប់ បន្ទាប់មកទៀតគេយកអ្នកដែលខ្សោយទៅសម្លាប់ចោលបន្ទាប់។ ហើយចុងក្រោយចាប់ផ្តើមសម្រាំងមើលអ្នកដែលរៀបការជាមួយខ្មែរក្រោម]។ ឯកសារ D5/113 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទិត សុផារី EN 00426992 ["នៅឆ្នាំ១៩៧៧ ខ្មែរក្រហមបានចូលដល់ឃុំខ្នារទទឹង និងបានចាប់ផ្តើមសម្រាំងប្រជាជន យោងទៅតាមកម្លាំងរបស់ពួកគេ (ទីមួយពួកបុរស បន្ទាប់មកពួកស្ត្រី និងចុងក្រោយ អ្នកឈឺ និងអ្នករៀបការជាមួយអ្នកខ្មែរក្រោម)។ អ្នកទាំងនេះត្រូវបានបញ្ជូនទៅកាន់ភូមិព្រៃក្របៅ"]។ ឯកសារ D5/114 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្ងួង ឌឿ EN 00426887 ["មានបីដំណាក់កាលដែលត្រូវបានធ្វើដោយខ្មែរក្រហម ដើម្បីសម្លាប់ខ្មែរក្រោម។ ទីមួយ ពួកបុរសដែលមានកម្លាំងធំទាំងអស់ត្រូវបានសម្លាប់។ ទីពីរ ពួកស្ត្រីទាំងអស់ត្រូវបានសម្លាប់។ ទីបី មនុស្សចាស់ៗ កូនក្មេង និង មនុស្សឈឺទាំងអស់ ក៏ត្រូវសម្លាប់ចោលផងដែរ"]។ ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយ ទិត សុផារី ឆ.៤៨ KH 00977014។ ឯកសារ D219/221 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២៥, ៦៤-៦៥, ៧៥ KH 01075676, 82, 84។

[2476] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៧៧, ៨៤ KH 00985422-23។

[2477] ឯកសារ D219/221 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២៥, ៦៤-៦៥, ៧៥ KH 01075676, 82, 84។

[2478] *សូមមើល ឧទាហរណ៍* ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន រ៉ន ឆ.៦៥-៦៨ KH 00977086 [ដោយផ្លែងថា នៅព្រឹកមួយនោះ ក្នុងខែកញ្ញា ឬខែតុលា ឆ្នាំ១៩៧៨ ក្រុមគ្រួសារខ្មែរក្រោមប្រហែល ២០០ ទៅ ៣០០គ្រួសារ ពីភូមិកំប្រាក់ កូនត្រូវបានគេប្រាប់ថាឲ្យទៅកាច់ពោត និងកាប់ព្រៃ។ ប្រហែលជាម៉ោង ៤រសៀល ថ្ងៃដដែល គាត់បានឃើញខ្មែរក្រហមដឹកខោអាវ និងរបស់របរអ្នកទាំងនោះត្រឡប់វិញ មានន័យថាពួកគេត្រូវបានយកទៅសម្លាប់ចោល]។

[2479] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៦០ KH 00985420។

ប្រមាណថា មានប្រមាណជា ១០០ នាក់) និងក្រុមមួយទៀតទៅព្រៃក្របៅ[2480]។ កន្លែងស្លាប់ចុងក្រោយរបស់អ្នកដែលត្រូវបានសម្លាប់ចោលមួយចំនួន គឺមិនច្បាស់លាស់ទេ ដោយហេតុថា ខ្មែរក្រហមមិនដែលផ្តល់ទូវព័ត៌មានពីវាសនារបស់ពួកជនរងគ្រោះទេ។ សមាជិកគ្រួសារដែលនៅរស់រានមានជីវិត គ្រាន់តែអាចឆ្ងល់ថា តើហេតុអ្វីបានជាសាច់ញាតិរបស់ពួកគេបានបាត់ខ្លួន និងតើពួកគេទៅកាន់ទីណា[2481]។

673. នៅក្រោយការសម្លាប់នៅទួលសេះញ៉ូ និងព្រៃក្របៅ ពួកខ្មែរក្រហមបានធ្វើការប្រជុំមួយ ដែលនៅក្នុងការប្រជុំនោះពួកគេបានប្រកាសប្រាប់ថា ពួកគេបានសម្លាប់ពួកខ្មាំងយួន ៣.០០០នាក់[2482]។

<u>ទួលសេះញ៉ូ</u>

[2480] ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.៣៥-៥៩ KH 01198089-92។ [*សូមកត់សម្គាល់ថា*៖ ការប៉ាន់ប្រមាណរបស់គាត់គឺមានមូលដ្ឋាននៅលើ មួយគ្រួសារមានប្រហែល ៥ ទៅ៦នាក់ (*សូមមើល* ឆ.៥៧)]។

[2481] *សូមមើលឧទាហរណ៍* ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ុច ឆ.១៤, ៥៩-៦០ KH 00977094, 98 ["ឆ.១៤៖ នៅពេលនោះខ្ញុំបានឮថា ខ្មែរក្រហមបានផ្ទាស់សមរភូមិ (ការដ្ឋាន) ធ្វើការប្រពន្ធរបស់ខ្ញុំទៅព្រៃធំ ហើយក្រោយរបបខ្មែរក្រហមទើបខ្ញុំដឹងថា ប្រពន្ធនិងកូនរបស់ខ្ញុំត្រូវគេយកទៅសម្លាប់នៅព្រៃក្របៅ។ (ការបកប្រែភាសារបស់ ក.ស.ព) [...] ឆ.៥៩៖ ខ្ញុំមិនដឹងថាគេសម្លាប់ប្រពន្ធរបស់ខ្ញុំនៅត្រង់ណានោះទេ គឺខ្ញុំលែងឃើញពួកគេត្រឡប់មកវិញតែម្តង។ ស៖ ហេតុអ្វីបានជាលោកដឹងថា ប្រពន្ធ និងកូនរបស់លោកត្រូវបានគេយកទៅសម្លាប់នៅព្រៃក្របៅ? ឆ.៦០៖ ខ្ញុំបានឮគេនិយាយ"]។ ឯកសារ D118/223 កំណត់ហេតុស្តាប់ចម្លើយ គឹម ហ្ស ឆ.៣៥ KH 00985380។

[2482] ឯកសារ D118/254 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ឡូយ ឆ.២៩-៣៤ KH 00996425។ ភាគច្រើននៃអ្នកដែលបានចូលរួមប្រជុំ ដូចជា ង៉ែត ឡូយ ជាដើម គឺសុទ្ធតែជាប្រពន្ធ ឬប្តីរបស់ជនរងគ្រោះខ្មែរក្រោមទាំងនោះ (*សូមមើល* ឆ.៣៤)។

674. ទួលសេះញ៉ូ គឺជាកន្លែងសម្លាប់មនុស្សដ៏ឃោរឃៅមួយនៅក្នុងស្រុកបាកាន[2483] ដែលខ្មែរក្រហមបានបង្ខំកូនក្មេង និងខ្មែរក្រោមឲ្យដឹករណ្តៅកប់សាកសព[2484]។ ខៀវ ផន និង ចាប ខ្ជង ដែលបានធ្វើដំណើរជុំវិញស្រុកបាកាន ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ នៅចងចាំបានថា គាត់បានឃើញសាកសពនៅទីនោះ[2485]។ ង៉ែត រុធ ត្រូវបានបញ្ជូនឲ្យទៅឃ្វាលគោក្របីក្បែរទួលសេះញ៉ូវក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ និងបានរៀបរាប់ថា គាត់បានឃើញរណ្តៅទាំងនោះ រួមទាំង "រណ្តៅបួនធំៗ ហើយគឺជារណ្តៅដែលថ្មីៗ" ផងដែលពេញទៅដោយសាកសពស្រាតដែលកប់មិនជិ

[2483] *សូមមើលឧទាហរណ៍* ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយ លន ហេង ឆ.៦១-៦៥, ៦៧ KH 00973983 [នៅចុងឆ្នាំ១៩៧៧ លន ហេង បានដាស់តឿនមនុស្សម្នាក់កុំឲ្យទៅទួលសេះញ៉ូវ ជាមួយនឹងខ្មែរក្រោមផ្សេងទៀត ពីព្រោះគាត់បានឮពីប្រជាជនដែលធ្លាប់ដើរទៅក្បែរកន្លែងនោះថា វាគឺជាកន្លែងសម្លាប់មនុស្ស]។ ឯកសារ D118/213 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម ខុន ឆ.១០៦ KH 00982139 ["ខ្ញុំបានដឹងរឿងនេះនៅឆ្នាំ១៩៧៨ គឺមានការសម្លាប់ខ្មែរក្រោមនៅស្នាមព្រះ ហើយចំណែកខ្មែរក្រោមដែលនៅទីនេះត្រូវបានគេយកទៅសម្លាប់នៅទួលសេះញ៉ូវ"]។ឯកសារ D118/189 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ាយ ឆ.៩៥ KH 00977036 ["ខ្ញុំឮថាមានការសម្លាប់ខ្មែរក្រោមនៅទួលសេះញ៉ូវដែរ"]។ ឯកសារ D118/241 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ ឆ.៤៤-៤៥ KH 00988065 [ថាច់ សុខ បានវិលត្រឡប់មកភូមិរំលេច និង បាក់មែក ក្នុងឆ្នាំ១៩៧៩។ "ខ្ញុំបានសួរប្រជាជនអ្នកភូមិរស់នៅជិតៗនោះក្នុងសម័យខ្មែរក្រហមថាក្នុងភូមិរំលេចគេបានយកខ្មែរកម្ពុជាក្រោម ត្រូវបានគេយកទៅសម្លាប់នៅទួលសេះញ៉ូវ"]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ ឆ.១១០-១១១ KH 01186833។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.៥២-៥៤ KH 00955770។

[2484] ឯកសារ D118/255 កំណត់ហេតុស្តាប់ចម្លើយ សេន ស៊ីណាត ឆ.៣៧ KH 00996437 ["ថ្ងៃមួយគេបានឲ្យបងឈ្មោះ ម៉ៅ ដឹករណ្តៅនៅទួលសេះញ៉ូវ ហើយម្តាយខ្ញុំបានស្រែកហៅបងប្រុសរបស់ខ្ញុំឲ្យជួយគាត់ រួចហើយបងប្រុសរបស់ខ្ញុំក៏រត់តែម្តង"]។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.៤៣-៤៥ KH 00955769។ ឯកសារ D118/191 កំណត់ហេតុ ស្តាប់ចម្លើយ ង៉ែត ចាត ឆ.៦៦, ៧០ KH 00977068 ["ឆ.៦៦៖ [...] គេឲ្យខ្មែរក្រោម និងរួមទាំងខ្ញុំផងទៅដឹករណ្តៅនៅទួលសេះញ៉ូវ [...] ស៖ តើមានមនុស្សប៉ុន្មាននាក់ដែលដឹករណ្តៅនៅពេលនោះ? ឆ.៧០៖ ប្រហែលជារាប់រយនាក់ គឺសុទ្ធតែជាខ្មែរក្រោម"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគំរោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ចិន សុខុម EN 00527091 ["[ខ្មែរក្រោម] ត្រូវបានគេយកទៅសម្លាប់នៅសេះញ៉ូវ ក្នុងភូមិបាក់មែក [...] លោក ផៀម [...] បានបញ្ជាគាត់ និងពួកក្មេងៗពីរបីនាក់ទៀតនៅកងកុមារឲ្យដឹករណ្តៅ"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគំរោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម EN 00527127 ["នៅទួលសេះញ៉ូវ [...] រណ្តៅទាំងបួនសុទ្ធតែត្រូវបានដឹកដោយកងកុមារ"]។

[2485] ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.៤៧-៤៨, ១០៣-១០៥ KH 01198091, 96។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091។

ត។ ដំបងធំៗត្រូវបានទុកចោលនៅកន្លែងកប់សាកសពនានា[2486]។ អ្នកផ្សេងទៀតបានដឹងថា មានរបាយការណ៍សាកសពនៅទីនោះ ពីអ្នកដែលបានដើរនៅម្តុំនោះ[2487]។

675. សាក្សីនានារៀបរាប់ថាបានឃើញខ្មែរក្រោមត្រូវបានគេដឹកចេញទៅទួលសេះញ៉ូវពីភូមិខ្នារទទឹង រួមទាំង បាក់មែក (ឥឡូវនេះ សេះញ៉ូវ) និងកំប្រាក់កូន[2488] ហើយកម្មាភិបាលខ្មែរក្រហមវិលត្រឡប់មកវិញនៅថ្ងៃដដែល ដោយមានខោអាវរបស់ជនរងគ្រោះយកមកចែកគ្នាទៀតផង[2489]។ នៅខែ

[2486] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៦៣, ៦៥, ៧០, ៧៣ KH 00985420-22។

[2487] ឯកសារ D118/254 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ឡូយ ឆ.៤០ KH 00996426 ["ខ្ញុំចេះតែខ្សឹបខ្សៀវជាមួយនឹងអ្នកផ្សេង ហើយអ្នកដែលធ្លាប់ទៅទីនោះ [ទៅទួលសេះញ៉ូវ] ហើយត្រឡប់មកវិញ គាត់បាននិយាយថា គាត់ឃើញសាកសពមនុស្សនៅទីនោះ"]។

[2488] ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ចូក ឆ.១០, ២៥, ៤១, ៥២, ៦៥, ៧០, ៧៤-៧៧, ៨០-៨១, ៨៤, ៩៦-៩៨ KH 00973921-22, 24-30 [រ៉ាន់ ចូក ជាខ្មែរម្នាក់ដែលបានរៀបការប្រពន្ធជាខ្មែរក្រោម នៅចងចាំបានថា នៅថ្ងៃមួយក្រោយពេលដែលខ្មែរក្រហមបានបញ្ជូនគាត់ទៅភូមិបាក់មែកក្នុងសហករណ៍ខ្នារទទឹង គណៈសហករណ៍បានធ្វើការប្រជុំខ្មែរក្រោម និងប្តី ឬប្រពន្ធរបស់ពួកគេទាំងអស់ ដោយយកលេសថាទៅកាច់ពោតនៅព្រៃធំ។ "គេប្រមូលខ្មែរក្រោមទាំងភូមិតែម្តង" មុននឹងត្រូវបានយកទៅទួលសេះញ៉ូវដើម្បីសម្លាប់ចោល។ ប្រពន្ធ កូន និង ម្តាយក្មេករបស់គាត់គឺនៅក្នុងចំណោមជនរងគ្រោះទាំងនោះ។ គាត់នៅរស់រានមានជីវិតដោយសារប្រធានកងម្នាក់នៅក្នុងសហករណ៍បានធ្វើការប្រជុំមួយ ដែលនៅក្នុងនោះគាត់បានប្រាប់ថា ប្រជាជនទាំងអស់ត្រូវបានយកទៅសម្លាប់ចោលនៅទួលសេះញ៉ូវ ហើយបានរំលឹកគាត់កុំឲ្យជូនប្រពន្ធនោះទៅ។ បន្ទាប់មក ពួកខ្មែរក្រហមបានបង្ខំគាត់ឲ្យរៀបការជាមួយស្ត្រីម្នាក់ដែលប្តីរបស់គាត់ក៏ត្រូវបានសម្លាប់ចោលនៅទួលសេះញ៉ូវនេះដែរ]។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៤២-៥៣ KH 00996457-58 [ឆាត់ ផាន់ "បានឃើញខ្មែរក្រហមចាប់ខ្មែរក្រោមចង ហើយបណ្តើរចេញទៅសម្លាប់"។ សាក្សីរូបនេះនៅចងចាំបានថា ឈ្លបបានចាប់ក្រុមនារីខ្មែរក្រោមម្តងៗពី ១០-២០ នាក់ ពីកងចល័តរបស់នាងនៅកំប្រាក់កូន ឃុំខ្នារទទឹង ដើម្បីយកទៅសម្លាប់ចោលនៅទីកន្លែងសម្លាប់មនុស្សនានា រួមទាំងទួលសេះញ៉ូវ នេះជាដើម]។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៦០-៦២ KH 00985420។ ឯកសារ D118/216 កំណត់ ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៦១-៦៧ KH 00982179។ ឯកសារ D5/114 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្ងួង ត្រឿ EN 00426887 ["ខែកក្កដា ឆ្នាំ១៩៧៨៖ ខ្ញុំបានឃើញខ្មែរក្រហមយកខ្មែរក្រោមប្រមាណជា ២.០០០នាក់ ពីខ្នារទទឹង ទៅ សេះញ៉ូវ (ភូមិបាក់មែក ក្នុងឃុំខ្នារទទឹង) ដោយរទេះសេះ"]។

[2489] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ើន ដារ៉ា ឆ.៥៥-៥៨ KH 00973951 [បីថ្ងៃបន្ទាប់ពី ង៉ើន ដារ៉ា និងសាច់ញាតិឆ្លាយរបស់គាត់ខាងខ្មែរក្រោមបានមកដល់កំប្រាក់កូន ពួ១ និងមីង១ៗរបស់គាត់-សរុប ៤២នាក់ (ប្រាំមួយគ្រួសារ) – ត្រូវបានប្រាប់ដោយខ្មែរក្រហមថា ពួកគាត់ត្រូវទៅធ្វើការនៅកន្លែងមួយផ្សេងទៀត។ គាត់ពុំបានឃើញពួកគាត់ត្រឡប់មកវិញទេចាប់តាំងពីពេលនោះមក។ ពីរ ឬបីម៉ោងក្រោយពីការចាកចេញរបស់ពួកគាត់ទៅ គាត់បានឃើញរទេះគោត្រឡប់មកវិញជាមួយនឹងខោអាវរបស់ពួមីង ដូច្នេះហើយ គាត់បានដឹងថាពួកគាត់ត្រូវគេយកទៅសម្លាប់ហើយ។ ក្រោយមកទើបគាត់សដឹងថា ខ្មែរក្រោមត្រូវបានគេយកទៅសម្លាប់នៅទួលសេះញ៉ូវ]។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៦៥ KH 00985421 ["ខោអាវទាំងអស់នោះត្រូវគេយកមកចែកឲ្យប្រជាជនវិញ ហើយខ្ញុំក៏បានខោខ្លីមួយផងដែរ"]។ ឯកសារ D118/191 កំណត់ហេតុស្តាប់

សីហា ឬ ខែកញ្ញា ឆ្នាំ១៩៧៨ ពីលើដើមឈើមួយដែលមានចម្ងាយ ៣០០ ម៉ែត្រ ខាងកើតទួលសេះ ញ៉ូ វ រ៉ែន រ៉ន បានមើលឃើញយ៉ាងច្បាស់ថាមានគេបណ្តើរខ្មែរក្រោម ២០ នាក់ ជាពីរខ្សែ។ នៅពេលដែលគាត់ត្រឡប់មកវាងបាយវិញនៅយប់នោះ គេបានប្រាប់គាត់ថា អ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់ចោល[2490]។ នៅឆ្នាំ១៩៧៨ ពៅ ស៊ីន្ធន បានឃើញគេយកមនុស្សទៅកាន់ទួលសេះ ញ៉ូ វ ហើយបានឮស្នូរកាំភ្លើង និងសំឡេងស្រែករបស់មនុស្សធំ និងកូនក្មេង[2491]។ វ៉ាន់ ម៉ុច និង ទិត សុផារី ដែលបានធ្វើការ និងរស់នៅក្បែរទួលសេះ ញ៉ូ វ ក៏បានផ្តល់នូវការរៀបរាប់យ៉ាងពិស្តារពីការឮស្នូរកាំភ្លើង និងសំឡេងស្រែកចេញមកពីទីកន្លែងនោះ នៅពេលដែលខ្មែរក្រោម រួមមាន ពួកចាស់ៗ និងកូនក្មេង ត្រូវបានសម្លាប់យ៉ាងរង្គាលដោយឈ្លបខ្មែរក្រហម[2492]។

676. ក្រោយការសម្លាប់ នៅក្នុងវាងបាយឃុំបាក់មែក ង៉ែត រុធ បានឮអ្នកសម្លាប់មកពីទួលសេះ ញ៉ូ វ ពិភាក្សាគ្នាពីការចាក់ និងវាយសម្លាប់ពួកជនរងគ្រោះ។ ពួកគេនិយាយចំអន់គ្នាទៅវិញទៅមកពីការរំលោភសេពសន្ថវៈលើពួកស្ត្រី មុននឹងមានការធ្វើមនុស្សឃាត[2493]។ ង៉ែត ចាត បានឃើញឈ្លប

ចម្លើយ ង៉ែត ចាត ឆ.២០-២២, ៧៥-៧៦ KH 00977063, 69-70 [បងស្រីរបស់ ង៉ែត ចាត ឈ្មោះ ផែន ត្រូវបានគេសម្លាប់នៅទួលសេះ ញ៉ូ វ ជាមួយប្តីរបស់គាត់ដែលជាខ្មែរក្រោម។ គាត់នៅចងចាំបានថា "បន្ទាប់មកអ្នកដែលសម្លាប់ ផែន ក៏បានយកខោអាវ និងនាឡិកាមកបង្ហាញខ្ញុំ ហើយសួរថា 'មិត្តចាត ស្គាល់ខោអាវនេះទេ?' ខ្ញុំថា 'ខ្ញុំស្គាល់ជារបស់ មិត្តផែន'។ 'ចុះស្គាល់នាឡិកានេះ មិត្តស្គាល់ទេ?' ខ្ញុំថា 'ខ្ញុំស្គាល់ជារបស់ មិត្តផែន'"]។

[2490] ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន រ៉ន ឆ.៦៩-៧៥ KH 00977086-87 *ដោយបានបញ្ជាក់ពី* ឯកសារ D5/111 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ រ៉ែន រ៉ន KH 00486902។

[2491] ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.៥៥-៥៦ KH 00955770។

[2492] ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ុច ឆ.៦៥-៦៨, ៧១ KH 00977098-99។ ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយ ទិត សុផារី ឆ.៤៨-៥០ KH 00977014-15។ *សូមមើលផងដែរ* ឯកសារ D347.3 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា *ឃុំរំលេច៖ ខ្មែរក្រោម នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ* ការរៀបរាប់របស់ វ៉ាន់ មុត KH 01413645-46 ["ការប្រមូលប្រជាជន[ខ្មែរក្រោម]ទៅសម្លាប់នៅទីតាំងពិឃាតទួលសេះ ញ៉ូ វ ដោយប្រាប់ថាយកទៅ "ជីកដំឡូងនៅព្រៃធំ" មានរយៈពេល៣ស្ងៃជាបន្តបន្ទាប់។ នៅថ្ងៃទី៣ នៃការប្រមូលខ្មែរក្រោម ទៅព្រៃធំ វ៉ាន់ មុត បានឮសូរសម្លេងផ្ទុះកាំភ្លើងនៅទួលសេះ ញ៉ូ វ"]។ ឯកសារ D5/114 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ស្ងួង ឦ EN 00426888 ["បងស្រី របស់ខ្ញុំ ឈ្មោះ ស្ងឿង ញ៉ី បានឃើញខ្មែរក្រហមសម្លាប់ពួកខ្មែរក្រោម។ គាត់បានឃើញខ្មែរក្រហមចងដៃពួកគាត់ទៅក្រោយ និងវាយក្បាលពួកជនរងគ្រោះ មុននឹងរុញពួកគាត់ចូលទៅក្នុងរណ្តៅសាកសពរួមនៅភូមិសេះ ញ៉ូ វ"]។

[2493] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៦៧-៦៨, ៧២, ៧៤ KH 00985421-22។

សំលៀងកាំបិតនៅផ្ទះរបស់នាងនៅថ្ងៃដដែល នៅពេលដែលគេយកប្តីរបស់នាងចេញទៅសម្លាប់នៅទួលសេះញ្ជ្ញ[2494]។

677. សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើននាក់ បានរៀបរាប់ពីសមាជិកក្រុមគ្រួសារខ្មែរក្រោមដែលត្រូវបានគេសម្លាប់នៅទួលសេះញ្ជ្ញ[2495]។ ពួកជនរងគ្រោះក៏បានរាប់បញ្ចូលផងដែរនូវខ្មែរ ដែលបានរៀបការជាមួយនឹងខ្មែរក្រោម ក៏ដូចជាពួកកុមារដែលបានជ្រើសរើសទៅតាមឪពុកម្តាយខ្មែរក្រោមរបស់ពួកគេ[2496]។

[2494] ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.៧៧-៧៨, ៨០-៨១ KH 00977070។ *សូមមើលបន្ថែមទៀត ឯកសារ* D219/888.1.8 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦។

[2495] *សូមមើលឧទាហរណ៍* ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីនួន ឆ.១៤-១៦, ២៦-២៧ KH 01067988, 90 [ឪពុករបស់សាក្សីរូបនេះគឺជាខ្មែរក្រោម។ នាងបានរៀបរាប់ពីការសម្លាប់ឪពុករបស់នាងនៅក្នុងឆ្នាំ១៩៧៧ ហើយបន្ទាប់មកទៀត ពីរបីខែក្រោយ បងស្រី បងថ្លៃប្រុស និងកូនៗពួកគាត់ នៅទួលសេះញ្ជ្ញ]។ ឯកសារ D219/342 កំណត់ហេតុស្តាប់ចម្លើយ សើន ធឿន ឆ.៩១, ៩៣, ៩៦ KH 01102887 [ប្រធានសហករណ៍រំលេច ឈ្មោះ អ៊ុំ ស្ងៀម បានប្រាប់ សើន ធឿន ថា បងប្រុសនិងឪពុកម្តាយរបស់គាត់ដែលជាខ្មែរក្រោម ត្រូវបានគេសម្លាប់នៅទួលសេះញ្ជ្ញ។ "គាត់ប្រាប់ថា គេចោទឪពុកម្តាយខ្ញុំថាជាយួន ហើយគេយកទៅវ៉ៃចោលអស់"]។ ឯកសារ D118/214 កំណត់ហេតុស្តាប់ចម្លើយ ចឹង ភី ឆ.៣៥-៣៧ KH 00982150 [នៅក្រោយឆ្នាំ១៩៧៩ ចឹង ភី ត្រូវបានប្រាប់ដោយ មាស ចាន់ថន ដែលជាសាច់ញាតិ និងជាប្រធានឃុំរំលេច ថា ឪពុកម្តាយរបស់នាង បងប្អូនប្រុសប្រាំមួយនាក់ ឪពុកមាពីរនាក់ និងក្រុមគ្រួសារទាំងមូល (សរុបយ៉ាងតិច ៣០នាក់) សុទ្ធតែត្រូវគេយកទៅសម្លាប់នៅទួលសេះញ្ជ្ញ]។ ឯកសារ D118/254 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ឡូយ ឆ.៣៥, ៣៩-៤១ KH 00996426-27 [ង៉ែត ឡូយ នៅចងចាំបានថា ពួកកម្មាភិបាលយកប្តីរបស់គាត់ទៅសម្លាប់នៅទួលសេះញ្ជ្ញ "យូរហើយមុនពេលដែលវៀតណាមចូលមកដល់" ។ ក្រោយមកមានគេម្នាក់ដែលបានទៅមើលទួលសេះញ្ជ្ញបានប្រាប់គាត់ថា មានសាកសពមនុស្សនៅទីនោះ]។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.២០-២២, ៧៥-៨១ KH 00977063, 69-70។ ឯកសារ D219/342 កំណត់ហេតុស្តាប់ចម្លើយ សើន ធឿន ឆ.៩៦ KH 01102887។ *សូមមើលផងដែរ* ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគំរោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ ឡី ហ្ស៊ីន EN 00527078-79 ["សមាជិក ១៥នាក់ នៃគ្រួសាររបស់គាត់ត្រូវបានគេសម្លាប់ [...] រួមទាំងឪពុកម្តាយ និងបងប្អូនរបស់គាត់ផង ដែលត្រូវបានគេចោទថាជាវៀតណាម ហើយដូច្នេះក៏ជាខ្មាំង។ ពួកគេត្រូវបានសម្លាប់នៅព្រៃក្រហ៊ៅ និង សេះញ្ជ្ញ នៅចុងឆ្នាំ១៩៧៨"]។

[2496] ឯកសារ D118/255 កំណត់ហេតុស្តាប់ចម្លើយ សេន ស៊ីណាត ឆ.៨, ២១-២២, ៣៤-៣៨ KH 00996434, 36-37 [ឪពុករបស់ សេន ស៊ីណាត ជាខ្មែរក្រោម។ ម្តាយរបស់គាត់ជាខ្មែរ។ បងប្រុសរបស់គាត់បានប្រាប់គាត់ថា ក្រោយពេលដែលឪពុក និងបងប្រុសស្រីរបស់គាត់ត្រូវបានគេយកទៅសម្លាប់ ម្តាយរបស់គាត់ត្រូវបានគេសម្លាប់នៅទួលសេះញ្ជ្ញ។ ពួកខ្មែរក្រហមបានបង្ខំបងប្រុសរបស់គាត់ឲ្យជីករណ្តៅនៅទួលសេះញ្ជ្ញ ហើយគាត់បានឃើញម្តាយរបស់គាត់នៅទីនោះស្រែកហៅគាត់ឲ្យជួយ]។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រ៉ុធ ឆ.៩៣-៩៥ KH 00985424-25។ កូនកាត់ខ្មែរក្រោម និងខ្មែរ ជាញឹកញាប់ត្រូវបានគេផ្តល់ជម្រើសឲ្យ ថាតើត្រូវទៅតាមឪពុក ឬម្តាយ ដែលជាខ្មែរក្រោម។ ពួកអ្នកដែលបានជ្រើសរើសឪពុក ឬម្តាយ ជា

678. ពួកខ្មែរក្រហមក៏បានប្រើប្រាស់ទួលសេះញ៉ូ៎ រ សម្រាប់សម្លាប់ពួកអ្នកជម្លៀសមកពីភូមិភាគបូព៌ាផងដែរ[2497]។ យាន ផាន បានរៀបរាប់ថា ខ្លួនត្រូ៎វបានគេច្រឡំថាជាអ្នកស្វាយរៀង (ពីព្រោះគាត់បានបង់ក្រមាខៀវ) និងត្រូ៎វបានគេយកទៅកាន់ទួលសេះញ៉ូ៎ រដើម្បីសម្លាប់ចោល ជាមួយនឹងអ្នកជម្លៀសមកពីភូមិភាគបូព៌ា ២០ នាក់ ផ្សេងទៀត។ គាត់នៅរស់រានមានជីវិត នៅពេលដែលការភាន់ច្រឡំនោះត្រូ៎វបានគេដឹង ក៏ប៉ុន្តែ គាត់បានឃើញការសម្លាប់អ្នកទាំងអស់គ្នាផ្សេងៗទៀត[2498]។

679. គំនរសាកសពដែលហើម ត្រូ៎វបានគេឃើញនៅទួលសេះញ៉ូ៎ រ នៅក្រោយពេលភ្លាមៗនៃការរំដោះក្នុងខែមករា ឆ្នាំ ១៩៧៩[2499]។ ពួកអ្នកស្រុកដែលបានទៅមើលកន្លែងនោះ នៅប៉ុន្មានឆ្នាំដំបូងៗ នៅក្រោយការរលំដួលនៃរបបកម្ពុជាប្រជាធិបតេយ្យ បានរាយការណ៍ថា បានឃើញរណ្តៅសាកសពជាច្រើនទំហំខុសៗគ្នា ពេញទៅដោយសាកសព[2500]។ លលាដ៍ក្បាលត្រូ៎វបានគេពិនិត្យមើលឃើញ

ខ្មែរក្រោម ត្រូ៎វបានគេគិតថាជាខ្មែរក្រោម និងត្រូ៎វបានសម្លាប់ចោល។ *សូមមើល ឧទាហរណ៍* ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយ ទិត សុផារី ឆ.៥៩ KH 00977016។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៣៨ KH 00955683។

[2497] ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ KH 00267778 [បន្ទាប់ពី ថាច់ សុខ បានវិលត្រឡប់ទៅភូមិបាក់មែកវិញក្នុងឆ្នាំ១៩៧៩ គាត់ត្រូ៎វបានពួកអ្នកស្រុកប្រាប់ថា ពួកខ្មែរក្រហមបានយកអ្នកជម្លៀសភូមិភាគបូព៌ា ដាក់នៅក្នុងក្រោលមួយ ក្បែរទួលសេះញ៉ូ៎ រ ហើយសម្លាប់ពួកគាត់ចោល]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគំរោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ សូ ផ្ទ្រ EN 00527071 ["ក្នុងកំឡុងពេលនៃរបបខ្មែរក្រហម លោក សូ ផ្ទ្រ ក៏បានរស់នៅភូមិបាក់មែកផងដែរ ដែលជាភូមិមួយនៅខេត្តពោធិ៍សាត់។ [...] លោក សូ ផ្ទ្រ នៅចងចាំបានថា នៅពេលព្រលឹមថ្ងៃមួយ ពួកខ្មែរក្រហមបានបង្ខំប្រជាជនប្រមាណជា ៨.០០០នាក់ (ដែលត្រូ៎វបានចង) បណ្តើ រចេញពីរំលេច ទៅកាន់រណ្តៅសាកសពរួមនៅទួលសេះញ៉ូ៎ រ។ មេខ្មែរក្រហមម្នាក់ ជាប្រធានសហករណ៍ បានទៅខ្នារទទឹងដើម្បីដឹកនាំការកាប់សម្លាប់ពួកជនរងគ្រោះ។ ភាគច្រើននៃអ្នករងគ្រោះ ត្រូ៎វបានបញ្ជូនមកពីភូមិភាគបូព៌ានៃប្រទេស គឺ "ខេត្តស្វាយរៀង និងខេត្តព្រៃវែង"]។

[2498] ឯកសារ D118/197 កំណត់ហេតុស្តាប់ចម្លើយ យាន ផាន ឆ.២៥-៣៩ KH 00978968-70។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.៩៩-១០០ KH 00977072-73 [ង៉ែត ចាត សព្វថ្ងៃនេះជាប្តីរបស់ យាន ផាន (*សូមមើល* ឯកសារ D118/191 KH 00977060) ហើយបានរាយការណ៍ពីព្រឹត្តិការណ៍ដូចគ្នា]។

[2499] ឯកសារ D118/241 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ ឆ.១០, ៤៤-៤៥, ៤៨-៤៩, ៥២-៥៤ KH 00988060, 65-67 [ថាច់ សុខ បានវិលត្រឡប់ទៅភូមិបាក់មែក(សេះញ៉ូ៎ រ)វិញ បន្ទាប់ពីរំដោះនៅឆ្នាំ១៩៧៩។ នៅពេលនោះ គាត់បានទៅមើលទួលសេះ ញ៉ូ៎ រ ជាកន្លែងដែលគាត់ "បានឃើញគំនរសាកសពហើមនៅឡើយ" រួមមាន "ទាំងអស់គ្នាមានប្រុស មានស្រី មានចាស់ មានក្មេង" និងមានរណ្តៅពី ៤ ទៅ ១០រណ្តៅ មានមុខប្រហែល១០ម៉ែត្រការ៉េ។ ក្លិនស្អុយអសោចផងដែរ។ សាកសពខ្លះស្លៀកពាក់ជា "ស៊ីវិល គឺពាក់ខោអាវខ្មៅ" ហើយគាត់បានកត់សម្គាល់ឃើញថា អ្នកខ្លះមានស្នាមរបួសបានន័យថាពួកគាត់ត្រូ៎វបានគេវ៉ៃ]។

[2500] ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ KH 00267774 ["ខ្ញុំឃើញសុទ្ធតែសាកសពខ្ចោចរាប់ពាន់នាក់នៅតាមរណ្តៅ ។ [...] មានប្រហែលពី ៧ ទៅ ៨ រណ្តៅ។ [...] រណ្តៅមានធំមានតូច។ រណ្តៅធំមួយមានទទឹងប្រហែលពី ៤ ទៅ ៥

ថា មានស្នាមប្រេះនៅខាងក្រោយ ហើយសាកសពខ្លះទៀតមានដៃរបស់ពួកគេចងទៅក្រោយ[2501]។ នៅប៉ុន្មានឆ្នាំក្រោយមក បន្ទាប់ពីឆ្នាំ១៩៧៩ សាកសពរាប់ពាន់នាក់ត្រូវបានគេគាស់ចេញពីក្នុងដីនៅទួលសេះញ្ជ្ញ និងត្រូវបានដាក់នៅវត្តរំលេច (វត្តចន្ទរង្សី) ជាផ្នែកនៃគំរោងការណ៍មួយដែលគ្រប់គ្រងដោយ មាស ចាន់ថន ជាប្រធានឃុំរំលេច កាលពីជំនាន់នោះ[2502]។ មានសំណាល់ជាច្រើន

ម៉ែត្រ ហើយបណ្តោយប្រហែល ១០ម៉ែត្រ។ រណ្តៅតូចមានប្រហែល ៦រណ្តៅ ហើយរណ្តៅនីមួយៗមានទំហំ ៤ ទៅ ៥ម៉ែត្រ ជួនជ្រុង។ [...] ខ្ញុំឃើញសាកសពគរលើគ្នាពេញរណ្តៅ"]។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.៥៩-៦៦ KH 00973951-52 [ង៉ែន ដារ៉ា បានឃើញរណ្តៅសាកសពចំនួន៥ នៅទួលសេះញ្ជ្ញ ដោយមានទំហំដូចតទៅ៖ (i) ៤x៣0m^2, (ii) ៣x៤0m^2, (iii) ៤x៤m^2, (iv) ៨x៨ m^2 និង (v) ២x២m^2។ គាត់បានប៉ាន់ប្រមាណថារណ្តៅទាំងនោះមានជម្រៅពី ២ ទៅ៣ម៉ែត្រ។ មាន "សាកសពពេញរណ្តៅទាំងអស់ ហើយថែមទាំងមានសាកសព និងឆ្អឹងផ្សេងទៀតនៅពាសពេញវាលទៀតផង"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគំរោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម EN 00527127 [ដំណើរទស្សនកិច្ចទីកន្លែងនេះដែលត្រូវបានដឹកនាំដោយ រាម សាញ បានកំណត់អត្តសញ្ញាណរណ្តៅសាកសពចំនួន៤ នៅទួលសេះញ្ជ្ញ។ របាយការណ៍ មានរូបថតនានាស្តីពីរណ្តៅទាំង៤ រួមទាំងកំណត់ត្រាអំពីទំហំផង។ រណ្តៅចំនួន២ "មានបណ្តោយ ២០ម និងទទឹង ៥ម" រណ្តៅចំនួន១ មាន "បណ្តោយ ១០ម និងទទឹង ៧ម" និងរណ្តៅចុងក្រោយមាន "បណ្តោយ ១០ម និងទទឹង ១០ម"។ រណ្តៅសាកសពទាំងនេះ "ពេញទៅដោយសាកសពជនរងគ្រោះ មិនបានកប់ និង មិនមានខោអាវ"]។ ឯកសារ D118/12 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរណ្តៅសាកសពនៅទួលសេះញ្ជ្ញ KH 00893191-92 [រៀបរាប់ពីទីតាំងបីកន្លែង ដែលបានកំណត់អត្តសញ្ញាណដោយ អ៊ុន ង៉ៀន ដែលបានចូលរួមពិនិត្យរណ្តៅនៅឆ្នាំ១៩៨0៖ (i) រណ្តៅមួយដែលមានទំហំ ៦x៦x១m^3 ដែលមានពី ៣0 ទៅ ៤0 សាកសពប្រុស-ស្រី (ii) រណ្តៅមួយដែលមានទំហំ ១x៣m^2 ដែលមានប្រហែល ២0 សាកសពប្រុស-ស្រីផងដែរ ដែលបានកប់ជម្រៅតិចជាងមួយម៉ែត្រ និង (iii) ទីកន្លែងមួយដែលមានប្រមាណជា ៥0 សាកសព ក៏ប៉ុន្តែប្រភពលែងអាចបញ្ជាក់ទីតាំងបានហើយ]។ *សូមមើលផងដែរ* ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ុច ឆ.៦៩-៧0 KH 00977099 [ដោយបានពន្យល់ថា គាត់បានទៅមើលទួលសេះញ្ជ្ញ ដែលគាត់បានឃើញរណ្តៅសាកសពរួមលុបដីបន្តិចបន្តួចពេញទៅដោយទឹក]។ *សូមមើលបន្ថែមទៀត* ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ដ៏ត ចាត ឆ.៦៦, ៧0 KH 00977068។ [ដោយបានពន្យល់ថា គាត់បានជីករណ្តៅដែលមានទំហំ "ប្រហែល១៥ម៉ែត្របួនជ្រុង ហើយ [...] ជ្រៅ"]។

[2501] ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ KH 00267777 ["ខ្ញុំឃើញមានស្នាមប្រេះពីខាងក្រោយលលាដ៍ក្បាល ប្រហែលជាត្រូវពួកខ្មែរក្រហមវាយ។ [...] ខ្ញុំឃើញមានខ្សែចំណងចងដៃពាត់ទៅក្រោយ ប៉ុន្តែរំមុខអត់ឃើញមានទេ"]។

[2502] ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ KH 00267775-77។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.៥៩-៦៦ KH 00973951-52។ ឯកសារ D347/2.1.11 បទសម្ភាសន៍ ប្រាក់ សារិន ដោយមជ្ឈមណ្ឌលកម្ពុជា KH 00044065-66 [ដោយបានរៀបរាប់ពីការប្រមូលឆ្អឹងជាមួយប្រធានឃុំ ឈ្មោះ មាស ចាន់ថន នៅក្នុងឆ្នាំ១៩៨0 ហើយបានយកវាទៅដាក់នៅវត្តរំលេច] *ត្រូវបានបញ្ជាក់ដោយ* ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.១១ KH 00979030។ *សូមមើលផងដែរ* ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ចូក ឆ.៨៥ KH 00973929។ ឯកសារ D219/184 កំណត់ ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីនួន ឆ.២៦ KH 01067990។

ដែលក្រុមការងារត្រូវជញ្ជូនចេញ ហើយតម្រូវឲ្យមានត្រាក់ទ័រ និងឡានសម្រាប់ដឹកជញ្ជូន[2503] ហើយមានអ្នកចូលរួមម្នាក់បានប៉ាន់ប្រមាណថា ពួកគេប្រមូលលលាដ៍ក្បាលបានពី ៦.០០០ ទៅ ៨.០០០ លលាដ៍ក្បាល[2504]។

ព្រៃក្របៅ

680. ព្រៃក្របៅក៏មានកេរ្តិ៍ឈ្មោះមិនល្អដូចគ្នានេះដែរ ក្នុងឋានៈជាទីកន្លែងសម្លាប់មនុស្ស និងជាគោលដៅចុងក្រោយរបស់ខ្មែរក្រោម ដែលត្រូវបានគេនាំយកមកពីខ្នារទទឹង[2505]។ ចឹក ប៊ុនរឿន បានប៉ាន់ស្មានថា មានគ្រួសារខ្មែរក្រោមជាង ៣០០ គ្រួសារត្រូវបានសម្លាប់នៅទីនោះ[2506]។ សាក្សី និងដើមបណ្តឹង

[2503] ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ចូក ឆ.៨៥ KH 00973929។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង្រើន ដារ៉ា ឆ.៦១ KH 00973952។ ឯកសារ D347/2.1.11 បទសម្ភាសន៍ ប្រាក់ សារិន ដោយមជ្ឈមណ្ឌលកម្ពុជា KH 00044066 [ដោយបញ្ជាក់ថា ផ្ទឹងដែលគាត់បានគាស់ជាផ្នែកនៃគំរោងនោះគឺ៖ "ផ្ទឹងច្រើនណាស់ពីរឡានត្រាក់ទ័រដាក់ពេញ"]។

[2504] ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ KH 00267777 ["ឆ.៖ បាទខ្ញុំបានរាប់[លលាដ៍ក្បាល]ដែរ ប៉ុន្តែមិនចាំច្បាស់ តែមានលោក មាស ចាន់ថន ជាអ្នកកត់ត្រាប្រហែលចាំច្បាស់ជាង។ ស៖ តើលោកអាចប៉ាន់ស្មានបានទេថាមានចំនួនលលាដ៍ក្បាលប៉ុន្មាននាក់នៅក្នុងរណ្តៅទាំងអស់? ឆ.៖ មានប្រហែល ៦.០០០ ទៅ ៧.០០០ នាក់។ លោក មាស ចាន់ថន ទើបមានតួលេខច្បាស់"]។ *សូមមើលផងដែរ* ឯកសារ D347/2.1.11 បទសម្ភាសន៍ ប្រាក់ សារិន ដោយមជ្ឈមណ្ឌលកម្ពុជា KH 00044053 ["ច្រើនដល់មែនទែនរណ្តៅមួយៗ ដើរជិតមិនបានផងចាប់ពីសេះញ្ជៅរហូតដល់ទៅលើ"]។ ឯកសារ D118/14 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងសម្លាប់មនុស្សវត្តច័ន្ទរង្សី KH 00901546 [ដោយបានកត់ត្រារណ្តៅមួយនៅវត្តច័ន្ទរង្សីដែលមានអដ្ឋិធាតុមនុស្សចំនួន ៣០០ ទៅ ៤០០ ជនរងគ្រោះខ្មែរក្រោម ដែលត្រូវបានសម្លាប់នៅតាមតំបន់ផ្សេងៗគ្នានៅក្នុងសហការណ៍ខ្នារទទឹង រួមមានរណ្តៅទួលសៃ]។

[2505] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១០៦ KH 00955720 ["ខ្ញុំធ្លាប់ឮគេនិយាយថា ព្រៃក្របៅមានការសម្លាប់មនុស្សខ្លាំងជាងភូមិវាលទៅទៀត។ ខ្ញុំបានឮថា ខ្មែរក្រោមត្រូវបានគេយកទៅសម្លាប់នៅទីនោះដែរ។"]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម្ញើ ឆ.១០៥ KH 01186833 ["គ្រាន់តែឮគេថាសុទ្ធតែរណ្តៅខ្មោច [នៅព្រៃក្របៅ]"]។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ នឹម លន ឆ.៦៥ KH 01102923 ["ខ្ញុំដឹងតែថា អ្នកត្រូវគេយកទៅសម្លាប់ [នៅព្រៃក្របៅ] នោះមកពីខាងខ្នារទទឹង។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រោម ការរៀបរាប់របស់ រ៉ែន រ៉ុន EN 00527117-18 ["ខ្ញុំក៏បានឮថា មនុស្ស១០០០នាក់ នៅភូមិកំប្រាក់ក្ងន ឃុំខ្នារទទឹង ស្រុកបាកាន ខេត្តពោសាត់ ត្រូវបានគេបញ្ជូនទៅក្រោលគោនៅព្រៃក្របៅ ហើយក្រោយមកត្រូវបានសម្លាប់ចោលនៅទីនោះ។"]។

[2506] ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរឿន ឆ.៤៨ KH 00955683 *បញ្ជាក់ដោយ* ឯកសារ D5/115 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចឹក ប៊ុនរឿន EN 00426904។

រដ្ឋប្បវេណីជាច្រើនបានផ្តល់ភ័ស្តុតាងអំពីសមាជិកគ្រួសាររបស់ពួកគេ ដែលត្រូវបានសម្លាប់នៅព្រៃក្របៅ[2507]។ ជនរងគ្រោះរួមមាន កុមារ និងជនជាតិខ្មែរដែលបានរៀបការជាមួយខ្មែរក្រោម[2508]។

681. ក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ ផាន់ សារ៉ាយ បានដឹងតាមរយៈប្រពន្ធរបស់ពេជ្ជឃាតម្នាក់នៅព្រៃក្របៅថា មានខ្មែរក្រោមជាច្រើនត្រូវបានគេយកទៅសម្លាប់នៅទីនោះ[2509]។ កុល សែត

[2507] *សូមមើល ខ១ជាឧទាហរណ៍* ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយ លន ហេង ឯ.៦៧-៧៣ KH 00973983-84 [ប្រពន្ធរបស់ លន ហេង គឺជាខ្មែរក្រោម។ ពីរ ឬបីថ្ងៃបន្ទាប់ពីពួកគេត្រូវបាន "បញ្ជូនទៅស្រុក" គាត់បានទទួលដំណឹងពីអ្នកទទួលបន្ទុកភូមិកំប្រាក់កូន ឈ្មោះ ថៃ ថា ប្រពន្ធរបស់គាត់និងកូនៗត្រូវបានសម្លាប់នៅព្រៃក្របៅ។]។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឯ.៤៦ KH 00955769 ["ឪពុកមាខ្ញុំ អ៊ំស្រីខ្ញុំត្រូវបានគេបញ្ជូនទៅ [ព្រៃក្របៅ]។ ពេលដែលខ្ញុំត្រឡប់មកពីរកត្រីនៅទន្លេសាបវិញ ខ្ញុំបានទៅសួរកឪពុកធំរបស់ខ្ញុំ ហើយមេឈ្លបបានប្រាប់ថា គេបញ្ជូនគាត់ទៅសមរភូមិព្រៃក្របៅហើយ។"]។ ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយ ទិត សុផារី ឯ.២៦-៣០ KH 00977012 [នៅចុងឆ្នាំ១៩៧៨ បងប្រុសរបស់ ទិត សុផារី ត្រូវបានយកទៅសម្លាប់។ ក្រោយមកគាត់បានឮពីអ្នកភូមិដែលដឹកអង្ករថា គាត់ត្រូវបានសម្លាប់នៅក្នុងព្រៃនៅព្រៃក្របៅ។ គេបានប្រាប់គាត់ថា ខ្មែរក្រោមទាំងអស់ត្រូវបានគេសម្លាប់។] ឯ.៦០-៦២, ៦៦-៦៩ KH 00977016-17 [នៅចុងឆ្នាំ១៩៧៨ ឪពុករបស់ ទិត សុផារី ត្រូវបានយកទៅសម្លាប់នៅព្រៃក្របៅ ជាមួយនឹងខ្មែរក្រោមជា "ច្រើន" ផ្សេងទៀត។ រូបគាត់បានឃើញ "មានមនុស្សរាប់រយនាក់ដើរតាមផ្លូវ។"]។ ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ុច ឯ.៥, ៨-១៤, ៥៧, ៥៩-៦០ KH 00977093-94, 98 [ប្រពន្ធរបស់ វ៉ាន់ ម៉ុច គឺជាខ្មែរក្រោមដែលរស់នៅរំលិចពេញមួយជីវិតរបស់គាត់។ គាត់ត្រូវបានយកទៅដោយខ្មែរក្រហមក្រោមលេសដែលថាឲ្យមួយរសមរភូមិទៅព្រៃធំ ប៉ុន្តែមិនដែលបានត្រឡប់មកវិញទេ។ ក្រោយរបបខ្មែរក្រហមទើបគាត់បានឮថា នាងត្រូវបានសម្លាប់នៅព្រៃក្របៅ]។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឯ.៨១, ៨៤ KH 00985423 [ជីដូនជីតារបស់ ង៉ែត រុធ និងឪពុកមារបស់គាត់ ត្រូវបានសម្លាប់នៅព្រៃក្របៅ។]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឯ.១០៧ KH 00955720 ["ខ្ញុំឮថា ម្តាយឪពុករបស់ខ្ញុំត្រូវបានគេយកទៅសម្លាប់[នៅព្រៃក្របៅ] ដែរ។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រោម ការរៀបរាប់របស់ ឡី ហ្ស៊ីន EN 00527078-79 ["សមាជិកគ្រួសាររបស់គាត់ ១៥នាក់ ត្រូវបានសម្លាប់ [...] រួមទាំងឪពុកម្តាយរបស់គាត់ និងបងប្អូនគាត់ ដែលត្រូវបានគេចោទថាជាវៀតណាម ហើយដូច្នោះគឺជាខ្មាំង។ ពួកគេត្រូវបានសម្លាប់នៅព្រៃក្របៅ និងសេះញ៉ូ នៅចុងឆ្នាំ១៩៧៨។"]។

[2508] ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយ ទិត សុផារី ឯ.៦០ KH 00977016 ["ស៖ ចុះចំពោះអ្នកផ្សេងទៀត ដែលជ្រើសរើសយកឪពុក ឬម្តាយជាកម្ពុជាក្រោម តើមានអ្វីកើតឡើងចំពោះពួកគេ? ឯ.៦០៖ គឺត្រូវគេបញ្ជូនទៅសម្លាប់នៅព្រៃក្របៅ។"]។ ឯកសារ D118/199 កំណត់ហេតុស្តាប់ចម្លើយ អ្លង សារ ឯ.៤៣ KH 00978997-98 ["[បងប្អូនជីដូនមួយរបស់ខ្ញុំ] ត្រូវគេយកសម្លាប់នៅព្រៃក្របៅ។ [...] នៅពេលនោះគេបានយកប្រពន្ធ ឬប្តីដែលជាខ្មែរក្រោមទៅសម្លាប់ ចំណែកបងជីដូនមួយរបស់ខ្ញុំគាត់មានប្រពន្ធជាខ្មែរក្រោម។ នៅពេលនោះគាត់មិនសុខចិត្តចំពោះរឿងនេះ ដូច្នេះហើយគាត់ក៏សុខចិត្តទៅស្លាប់ជាមួយនឹងប្រពន្ធរបស់គាត់តែម្តង។"]។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ នឹម លន ឯ.៦០ KH 01102922។

[2509] ឯកសារ D118/189 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ាយ ឯ.៩៣ KH 00977036។

និង ខៀវ ផន បានដឹងអំពីការសម្លាប់ទាំងនោះពីពេជ្ឈឃាតទាំងនោះផ្ទាល់[2510]។ ខណៈដែល សុខ ភា ដែលជាប្រធានក្រុមនៅសហករណ៍ស្រែង[2511] កំពុងធ្វើការនៅចម្ងាយប្រហែលជាបីគីឡូម៉ែត្រពីព្រៃក្របៅ រូបគាត់បានឃើញឈ្លបប្រដាប់ដោយអាវុធបណ្តើរខ្មែរក្រោមពី ២០ ទៅ ៣០នាក់ រួមទាំងកុមារ និងមនុស្សចាស ប្រុស ស្រី និងជួនកាលទាំងគ្រួសារផង ពីតំបន់រំលេច ទៅកាន់ព្រៃក្របៅចំនួនពីរដង។ គាត់កត់សម្គាល់ថា មួយរយៈក្រោយមក រំលេច ប្រែជា "ស្ងាត់"[2512]។ គណៈសមរភូមិស្រែង ឈ្លោះ ផាន ឃន បានប្រាប់គាត់ថា ខ្មែរក្រោមទាំងអស់ត្រូវបានសម្លាប់[2513]។

682. ជាក់ស្តែង ឃន ត្រូវបានចាត់តាំងដោយ ឃាយ រ៉ីម ឲ្យធ្វើការសម្លាប់ទាំងខ្មែរក្រោម ទាំងប្រជនជម្លៀសមកពីភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨[2514]។ ឃន បានរៀបរាប់ថា គាត់បានមើលអ្នកក្រោមបង្គាប់របស់គាត់ធ្វើការសម្លាប់មនុស្សនៅទីនោះ៖ "ដំបូងវ៉ៃនឹងដំបងដែលមានប្រវែងប្រហែល ១ ម៉ែត្រ រួចហើយអារ-កទម្លាក់រណ្តៅ"[2515]។ គាត់បានរាយការណ៍ថា មនុស្ស "ប្រហែលជាជាង ១០០នាក់" រួមមានមនុស្សចាស់ កុមារ និងទារក ត្រូវបានបញ្ជូនទៅសហករណ៍ស្រែងដើម្បីសម្លាប់នៅព្រៃក្របៅ[2516]។

683. សមាជិកម្នាក់នៃឈ្លបសហករណ៍ស្រែងដែល ឃន ហៅថាជាពេជ្ឈឃាត[2517] បានបដិសេធថា គាត់មិនបានធ្វើការសម្លាប់មនុស្សដោយផ្ទាល់នោះទេ ប៉ុន្តែបានរៀបរាប់ថា គាត់បានឃើញមនុស្សពី

[2510] ឯកសារ D118/238 កំណត់ហេតុស្តាប់ចម្លើយ កុល សែត ឆ.៩០, ៩២-៩៤, ៩៦ KH 00989034-35។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.១១១-១១៣ KH 01198097។

[2511] ឯកសារ D219/221 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.៩៦ KH 01075686។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.៨០ KH 01075710។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភា ឆ.៤១ KH 01102905 ។

[2512] ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភា ឆ.៥១-៦០, ៦៤, ៦៦ KH 01102906-07។

[2513] ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភា ឆ.៧០-៧១, ៧៣, ៧៦ KH 01102907-08។

[2514] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១៣១, ១៣៦, ១៤៣ KH 01068145-48។

[2515] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១៧ KH 01068143 ["នៅពេលនោះគឺសម្លាប់ [ខ្មែរក្រោម] នៅខាងលិចព្រៃក្របៅនៅក្នុងសហករណ៍ស្រែង មានទាំងអស់ ២០នាក់។ ចំពោះអ្នកសម្លាប់មានតែ១០នាក់ទេ ចំណែក១០នាក់ទៀតជាអ្នកយាមការពារក្នុងពេលសម្លាប់។"] ឆ.១២០-១២១ KH 01068144 ["គេសម្លាប់ [ខ្មែរក្រោម] [...] ដំបូងវ៉ៃនឹងដំបងដែលមានប្រវែងប្រហែល១ម៉ែត្រ រួចហើយអារ-កទម្លាប់រណ្តៅ [...] ខ្ញុំមើលគេសម្លាប់។"]។

[2516] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១៥-១១៧ KH 010681443។

[2517] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១៨ KH 01068144។

២០០ ទៅ៣០០នាក់ រួមមានឪពុកម្តាយ និងកុមារតូចៗ ត្រូវបានគេបណ្តើរជាជួរពីខ្នារទទឹង ទៅកាន់ទីតាំងព្រៃក្របៅនៅពេលល្ងាចមួយ។ ក្រោយមកនៅពេលល្ងាចនោះដែរ រូបគាត់បានទទួលបញ្ជាឲ្យប្រមូលសម្ភៀកបំពាក់ និងកាបូបរបស់ជនរងគ្រោះ និងបានឃើញសាកសពជាច្រើនពេញរណ្តៅ មិនទាន់បានកប់នៅឡើយ[2518]។

684. ប្រជាជនជម្លៀសមកពីភូមិភាគបូព៌ាជាច្រើនត្រូវបានសម្លាប់នៅព្រៃក្របៅ[2519]។ នៅក្នុងហេតុការណ៍ដ៏ឃោរឃៅមួយនៅចុងឆ្នាំ១៩៧៨ ឬដើមដំបូងនៃមករា ឆ្នាំ១៩៧៩[2520] ប្រជនជម្លៀសមកពីភូមិភាគបូព៌ារាប់រយនាក់ ឬអាចដល់រាប់ពាន់នាក់ផង រួមទាំងកុមារ[2521] ត្រូវបានគេកៀងបញ្ជូលទៅក្នុងក្រោលមួយនៅជិតព្រៃក្របៅ[2522] និងត្រូវបានដាក់ឲ្យស្ថិតក្រោមការយាមកាមប្រដាប់ដោយអាវុធ

[2518] ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ នឹម លន ឆ.៦២-៧៣ KH 01102922-23។

[2519] ឯកសារ D219/221 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.៥៩ KH 01075681 [ឈ្លបសហការណ៍ស្រោង ដែលបានបញ្ជាក់ថាជនរងគ្រោះនៅព្រៃក្របៅរួមមាន មនុស្សមកពីស្វាយរៀង និង ខ្មែរក្រោម។]។ ឯកសារ D118/213 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម ឌុន ឆ.១០០-១០១ KH 00982139 ["ក្រោយរបបខ្មែរក្រហមខ្ញុំបានដឹងថា គេបានធ្វើក្រោលដែលមានបន្ទាត់ទ្ធជុំវិញ សម្រាប់ដាក់អ្នកបូព៌ា បន្ទាប់មកទើបគេបញ្ជេញទៅសម្លាប់នៅ [...] ព្រៃក្របៅ។"]។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រោម ការរៀបរាប់របស់ ស៊ុន ញ៉ៃស EN 00527076 ["ចាប់ពីឆ្នាំ១៩៧៦ ទៅ គាត់បានរស់នៅព្រៃក្របៅ ជាមួយកូនៗរបស់គាត់។ គាត់ត្រូវគេបង្ខំឲ្យភ្ជួរស្រែ [...] នៅព្រៃក្របៅ។ [...] ខណៈដែលគាត់កំពុងភ្ជួរស្រែ គាត់បានឃើញខ្មែក្រហមនាំខ្មែរក្រោម និងអ្នកមកពីស្វាយរៀងត្រូវគេសម្លាប់ (គាត់និយាយថា គេចោទពួកគេថាជាវៀតណាម)។"]។

[2520] ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សារឿន ឆ.៤៩, ៥៧ KH 00955753-54 [អ្នកជម្លៀសមកពីបូព៌ាដែលរួចជីវិតពីហេតុការណ៍នៅក្រោលនោះ៖ "[វាកើត] ចុងឆ្នាំ១៩៧៨ ឬក៏ដើមឆ្នាំ១៩៧៩"] *បញ្ជាក់ដោយ* ឯកសារ D5/197 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន KH 00571256។ ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៉ាន់ ឆ.១១៨ KH 01167529 [បានបញ្ជាក់ថា ការសម្លាប់អ្នកស្វាយរៀងនៅក្រោលនោះកើតឡើង "ប្រហែលជា ១, ២ ខែមុនពេលវៀតណាមចូលមកដល់។"]។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.១៣-១៥ KH 01075699 [ឈ្លបសហការណ៍ស្រោងដែលបានបញ្ជាក់ថា ការសម្លាប់នៅក្រោលនោះបានកើតឡើង "មួយខែ" មុនពេលគាត់រត់គេចពីវៀតណាម។]។ *សូមមើលផងដែរ* ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ នឹម លន ឆ.៧៧ KH 01102924។ *សូមមើលផងដែរ* ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ៩១ KH 01102910។

[2521] ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.៦៥ KH 01075707។

[2522] ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២, ១២ KH 01075697-99 ["ឆ.២៖ ក្រោលនោះគឺនៅភូមិកោះអណ្តែត។ [...] ស៖ តើចម្ងាយបន្ទាន់ពីភូមិកោះអណ្តែតទៅព្រៃក្របៅ? ឆ.១២៖ មានចម្ងាយពីគ្នាប្រហែលជា ១៥០ ទៅ ១៦០ម៉ែត្រប៉ុណ្ណោះ។"]។ ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សារឿន ឆ.៥១-៥២, ៥៦ KH 00955753-54 [ទោះបីជា ម៉ី សារឿន កំណត់ថាក្រោលនោះស្ថិតនៅភូមិកោះស្វាយជាជាងកោះអណ្តែតក៏ដោយ ក៏ការរៀបរាប់លំអិតនៃហេតុ

ក្នុងការរៀបចំត្រៀមសម្លាប់ពួកគេ[2523]។ មនុស្សជាច្រើនបានព្យាយាមរត់គេច និងភៀសខ្លួនទៅព្រៃក្រចៅ[2524]។ ពួកអ្នកយាមក្រោលនោះបានចាប់ផ្តើមសម្លាប់រង្គាលអ្នកជាប់ឃុំទាំងនោះដោយកាំភ្លើង និងកាំបិតផ្ទាក់[2525]។ ហេង សៀង ដែលជាឈ្លបម្នាក់យាមក្រោលនោះ បានរត់ចូលទៅក្នុងព្រៃក្រចៅតាមបញ្ជា ដើម្បីស្វែងរក និងសម្លាប់ចោលអ្នកដែលរត់គេចខ្លួនទាំងនោះ និងបានដុតព្រៃនោះ[2526]។ ឈ្លបខ្មែរក្រហមបានបញ្ចប់ជីវិតអ្នកដែលពួកគេរកឃើញថា នៅរស់នៅឡើយ[2527]។ មានមនុស្សតែពីរបីនាក់ប៉ុណ្ណោះបានរត់គេចខ្លួន[2528]។ មនុស្សរាប់រយនាក់ បើមិនមែនរាប់ពាន់នោះ

ការណ៍នេះស្រដៀងគ្នាយ៉ាងខ្លាំង ដែលវាសមហេតុផលក្នុងការសន្និដ្ឋានថា រូបគាត់កំពុងពិភាក្សាអំពីហេតុការណ៍តែមួយ។ ជាងនេះទៀត ដូចដែល យ៉ឹម ឌុន បានពន្យល់ ខ្មែរក្រហមបានង់ក្រោលនៅកោះស្វាយ ដែលគេប្រើវាសម្រាប់ដាក់ជនរងគ្រោះត្រៀមសម្រាប់សម្លាប់នៅព្រៃក្រចៅ។ *សូមមើល* ឯកសារ D118/213 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម ឌុន ឆ.១០០-១០១ KH 00982139។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ.៨៥, ៩៤ KH 01102909-10។

[2523] ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សារឿន ឆ.៥២-៥៤ KH 00955753-54។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ ទ៉ីម លន ឆ.៧៧-៧៩ KH 01102924។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២, ២៤, ៤០ KH 01075697-703។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ.៨៨, ៩៤, ៩៨ KH 01102909-11។

[2524] ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សារឿន ឆ.៥៥ KH 00955754។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ.១០១-១០២ KH 01102911។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រហម ការរៀបរាប់របស់ អ៊ីក អឿន EN 00527072។

[2525] ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សារឿន ឆ.៥៥ KH 00955754។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ ទ៉ីម លន ឆ.៧៨-៨០ KH 01102624។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២, ២៤, ៣៧, ៤៣, ៤៥, ៤៧, ៨៤ KH 01075697-705, 711។

[2526] ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២, ៥១ KH 01075697, 706។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ.១០១-១០២ KH 01102911។

[2527] ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.៧៥ KH 01075709។

[2528] ឯកសារ D5/197 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន KH 00571256 ["ខ្ញុំបានរត់ជាមួយអ្នកទោស ៣០ នាក់ ផ្សេងទៀត"]។ ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៉ាន់ ឆ.១១៩ KH 01167529 ["ស៖ ម៉េចបានលោកស្រីដឹងអំពីផែនការដាក់អ្នកស្វាយរៀងទាំងអស់នោះនៅក្នុងក្រោលសម្លាប់ចោល? ឆ.១១៩៖ ដឹងពេលឃើញអ្នករស់រត់ចេញមក មានស្នាមអារនៅនឹងក។ គាត់មកដល់ [មន្ទីរ] ២២ ហើយគាត់បាននិយាយថា 'ក្មួយអើយ ឲ្យមីងសុំបាយហូបបន្តិចមក មីងទើបរត់ចេញពីក្រោល។ គេសម្លាប់អស់រាប់ពាន់នាក់។'"]។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.៦២-៦៤ KH 01075707។

ត្រូវបានសម្លាប់[2529]។ ពេជ្ឈឃាតគឺជាឈ្លបមកពីសហករណ៍ស្រោង ដែលដឹកនាំដោយ ផាន ឃន[2530]។

685. ទាំងជនស៊ីវិល និងកម្មាភិបាលខ្មែរក្រហមបានរៀបរាប់ថា បានឃើញសាកសពនៅព្រៃក្របៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[2531]។ ស្នាមកាំបិតត្រូវបានគេឃើញនៅលើសាកសព[2532]។ ភ្លាមៗ បន្ទាប់ពីរបបនោះដួលរលំ ក្លិនសាកសពស្អុយរលួយនៅមានខ្លាំងនៅឡើយ[2533]។ ទោះបីជា

[2529] ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សាវឿន ឆ.៥៣-៥៤ KH 00955754 ["មានប្រហែលរាប់ពាន់នាក់ [ត្រូវបានសម្លាប់នៅទីនោះ]។ [...] អ្នកទាំងអស់គ្នាសុទ្ធតែអ្នកបូព៌ា"]។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ នឹម លន ឆ.៨៥-៨៦ KH 01102925 [បានកំណត់ថា "ប្រហែលខ្ទង ២០០នាក់ នៅពេលនោះ ទាំងកុមារ ទាំងក្មេង ទាំងចាស់ [សម្លាប់លើកនោះ]។ [...] ងាប់កន្លែងណាកប់ត្រង់ហ្នឹង។ កប់នៅតាមភ្លឺស្រែ ខ្ញុំមិនដឹងថាមានផ្នូរប៉ុន្មានទេ។"]។ ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៉ាន់ ឆ.១១៩ KH 01167529។ ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រោម ការរៀបរាប់របស់ អ៊ុក អឿន EN 00527072។

[2530] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១៤៣ KH 01068148 ["ខ្ញុំទទួលបន្ទុកសម្លាប់អ្នកបូព៌ានៅខាងត្បូងភូមិកោះអណ្តែត។"]។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ នឹម លន ឆ.៨១-៨២ KH 01102924 [រូបគាត់ត្រូវបានបញ្ជាឲ្យប្រមូលសម្លៀកបំពាក់ ដោយ "គណៈសហករណ៍ឈ្មោះ ឃន"]។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២៩-៣០, ៣២ KH 01075702។

[2531] ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីនួន ឆ.៤៦-៤៧ KH 00955769 [នៅចុងឆ្នាំ១៩៧៨ សាក្សីត្រូវបានគេបញ្ជូនទៅជីកប្រឡាយ និងលើកទំនប់នៅជិតព្រៃក្របៅ ដែលជាទីដែលគាត់បានឃើញ "សាកសពជាច្រើន"។]។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២ KH 01075697 [ឈ្លបមកពីសហករណ៍ស្រោងដែលបានរកឃើញសាកសព "រាប់រយ" ភាគច្រើនគឺជាស្ត្រី ដាក់គរលើគ្នានៅព្រៃក្របៅនៅចុងឆ្នាំ១៩៧៨។ ពួកគេមើលទៅ "គួរឲ្យសង្វេកណាស់។"]។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខួង KH 00385092 [រំលឹកថាបានឃើញសាកសពមនុស្សនៅព្រៃក្របៅក្នុងឆ្នាំ១៩៧៨ ខណៈពេលដែលគាត់កំពុងដឹកដួង និងបន្លែនៅជិតតំបន់នោះ។]។ ឯកសារ D5/202/4 ព័ត៌មានបន្ថែមរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្តេះ ឯល KH 01133736 ["គាត់ធ្លាប់បានដឹងថាពួកឈ្លបយកមនុស្សច្រើនណាស់ទៅសម្លាប់នៅព្រៃកក្របៅ [...] គាត់ដឹងដោយសារគាត់ធ្លាប់ត្រូវបានឈ្លបប្រើឲ្យទៅលប់រណ្តៅសាកសពនៅទីនោះម្តង គាត់បានឃើញសាកសពពេញរណ្តៅ។ កន្លែងនោះជាកន្លែងសម្លាប់មនុស្ស។"]។

[2532] ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២ KH 01075697។

[2533] ឯកសារ D118/147.1.43 របាយការណ៍ស្តីពីគម្រោងស្រាវជ្រាវសម្រាប់សាលាក្តីខ្មែរក្រោម ការរៀបរាប់របស់ មុំ ឈន EN 00527080 ["ក្រោយពេលដែលរបបនេះបានដួលរលំ ពួកគេបានត្រឡប់ទៅរស់នៅព្រៃក្របៅវិញ។ នៅពេលដែលគាត់បានទៅដល់ គាត់បានឃើញរណ្តៅសាកសពជាច្រើនពេញទៅដោយសាកសពមនុស្សពីព្រៃក្របៅ ដល់ក្រាំសសរ ហើយគាត់នៅធំក្លិនស្អុយសាកសពរលួយនៅឡើយ។"]។

ពេលនេះតំបន់នោះគ្របដណ្ដប់ដោយវាលស្រែក៏ដោយ[2534] ក៏មានសាក្សីជាច្រើនបានឃើញរណ្ដៅកប់សព ឆ្អឹង និងលលាដ៍ក្បាលនៅព្រៃក្រចៅក្នុងរយៈពេលប៉ុន្មានឆ្នាំក្រោយឆ្នាំ១៩៧៩។ លន ហេង និង ឆ្លួន រិន ទាំងពីរនាក់នេះបានរៀបរាប់ថាបានរកឃើញឆ្អឹង និងលលាដ៍ក្បាលនៅវាយប៉ាយលើដីនៅពេលដែលពួកគេបានទៅមើលទីតាំងនេះ[2535]។ ខៀវ ផន បានរកឃើញរណ្ដៅកប់សពជាច្រើនដែលមានវង្វាស់រហូតដល់ទៅ ១០ ម៉ែត្របួនជ្រុង[2536]។ ដូចគ្នាទៅនឹងនៅទួលសេះញ៉ូវដែរ មានឆ្អឹងជាច្រើនដែលពួកវាត្រូវបានជីកគាស់ និងដឹកតាមត្រាក់ទ័រជាច្រើនគ្រឿង[2537]។ សាកសពទាំងនោះតាំងពីពេលនោះមកត្រូវបានគេតម្កល់ក្នុងចេតិយ[2538]។ គេក៏បានរកឃើញសាកសពមនុស្សមានក្រមាខៀវនៅព្រៃក្រចៅផងដែរ ដែលជាប្រភេទក្រមាពាក់ដោយអ្នកជម្លៀសមកពីភូមិភាគបូព៌ា[2539]។

[2534] ឯកសារ D118/13 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ព្រៃក្រចៅ KH 00901541-42។ ឯកសារ D219/223 កំណត់ហេតុស្ដាប់ចម្លើយ ឆ្លួន រិន ឆ.៧៥ KH 01075617។ ឯកសារ D219/188 កំណត់ហេតុស្ដាប់ចម្លើយ ផាន ឃន ឆ.១១៧ KH 01068143។

[2535] ឯកសារ D118/177 កំណត់ហេតុស្ដាប់ចម្លើយ លន ហេង ឆ.៧៤-៧៥ KH 00973984 ["ក្រោយរបបខ្មែរក្រហម ខ្ញុំធ្លាប់ទៅម្ដងនៅដែលខ្ញុំទៅដឹកអុស។ [...] ខ្ញុំឃើញមានលលាដ៍ក្បាល ឆ្អឹង និងខោអាវរបស់មនុស្សនៅវាយប៉ាយពាសពេញដី។"]។ ឯកសារ D219/223 កំណត់ហេតុស្ដាប់ចម្លើយ ឆ្លួន រិន ឆ.៧៥ KH 01075617 ["ខ្ញុំបានឃើញឆ្អឹងមនុស្សនៅទីនោះ។ សាកសពមិនត្រូវបានគេកប់នោះទេ គឺនៅពាសវាល និងក្នុងរណ្ដៅទាំងនោះ។"]។ ឯកសារ D118/13 របាយការណ៍ស្ដីពីការកំណត់អត្តសញ្ញាណទីកន្លែង ព្រៃក្រចៅ KH 00901541-42។

[2536] ឯកសារ D219/664 កំណត់ហេតុស្ដាប់ចម្លើយ ខៀវ ផន ឆ.១០៦, ១០៨ KH 01198096-97 ["គេជីករណ្ដៅ៥ម៉ែត្របួនជ្រុងជាប់ៗគ្នា ឬ១០ម៉ែត្របួនជ្រុង។ [...] អត់មានក្រោមពី ១០រណ្ដៅទេ។"]។

[2537] ឯកសារ D219/664 កំណត់ហេតុស្ដាប់ចម្លើយ ខៀវ ផន ឆ.៤៩, ៦៨ KH 01198091, 93។ ឯកសារ D118/188 កំណត់ហេតុស្ដាប់ចម្លើយ ទិត សុផារី ឆ.៣១-៣២ KH 00977012 ["ឆ.៣១៖ នៅឆ្នាំ១៩៧៩ ពួរបស់ខ្ញុំឈ្មោះ ចាន់ថន បានទៅដឹកឆ្អឹងនៅកន្លែងនោះបានប្រហែលជាបីបួនឡានត្រាក់ទ័រ។ ស៖ តើលោកស្រីចង់សំដៅទៅលើឆ្អឹងនៅព្រៃក្រចៅមែនទេ? ឆ.៣២៖ ចាស គឺនៅព្រៃក្រចៅ ហើយខ្ញុំក៏បានទៅទីនោះផងដែរ។"]។

[2538] ឯកសារ D219/664 កំណត់ហេតុស្ដាប់ចម្លើយ ខៀវ ផន ឆ.៤៩ KH 01198091 ["ពេលដែលស្រុកសន្តិភាព ហើយពេលដែលយើងដើរវើសឆ្អឹង[នៅព្រៃក្រចៅ] យកមកដាក់ស្ពបសង់ពីឈើ។"]។ ឯកសារ D118/124 កំណត់ហេតុស្ដាប់ចម្លើយ គឹម សូរ ឆ.១០៧ KH 00955720 ["ខ្ញុំទៅ [ព្រៃក្រចៅ] បានពីរដងក្រោយរបបខ្មែរក្រហម។ ខ្ញុំទៅទីនោះដើម្បីប្រមូលឆ្អឹងមនុស្សយកទៅទុកនៅក្នុងវត្ត។"]។

[2539] ឯកសារ D118/213 កំណត់ហេតុស្ដាប់ចម្លើយ យ៉ីម ឌុន ឆ.១០២ 00982139។ ឯកសារ D118/127 កំណត់ហេតុស្ដាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.៤៧-៥១ KH 00955769-70។

v. ឧក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

686. ផ្អែកលើភ័ស្តុតាងដែលកំពុងតែដំណើរការ ស.ព.អ សូមស្នើឲ្យបញ្ជូន **យ៉ីម ទិត្យ** ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដូចតទៅ ទាក់ទងនឹងទីតាំងសម្លាប់មនុស្សទាំងព្រៃក្របៅ ទាំងទួលសេះញ៉ូ[2540]ៃ អំពើប្រល័យពូជសាសន៍ក្រុមជនជាតិវៀតណាមក្នុងប្រទេសកម្ពុជា (ជាពិសេសខ្មែរក្រោម)[2541] ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[2542] ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងខ្មែរក្រោម និងប្រជាជនជម្លៀសមកពីភូមិភាគបូព៌ា និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ)។

[2540] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងទីទាំងនេះ គាត់ស្នើសុំឲ្យបញ្ជូនរឿងទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនានា ដែលបានប្តឹងទៅកាន់ ស.ច.ស តែមិនត្រូវបានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ ឧក្រិដ្ឋកម្មទាំងនេះមាន៖ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រឆាំងប្រជាជនជម្លៀសមកពីភូមិភាគបូព៌ា និងអំពើអមនុស្សធម៌ផ្សេងទៀត (ការបាត់ខ្លួនដោយបង្ខំ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មទាំងនេះដោយ៖ ឯកសារ D1 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទីបីរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥៩ ["ជនរងគ្រោះនៅក្នុងអំឡុងពេលនោះរួមមាន [...] ប្រជាជនទាំងឡានៗដែលត្រូវបាននាំមកពីរភូមិភាគបូព៌ាទៅកាន់ទីនោះ។"]។ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ ១៩ ["នៅចុងឆ្នាំ១៩៧៨ គឺក្នុងរយៈដ៏ខ្លីមុនការមកដល់របស់កងទ័ពវៀតណាម ប្រជាជនជម្លៀសមកពីភូមិភាគបូព៌ា ត្រូវបានគេប្រមូលផ្តុំនៅតាមកន្លែងមួយចំនួននៅក្នុងភូមិភាគពាយ័ព្យ និងបានសម្លាប់ចោលយ៉ាងរង្គាល។"]។

[2541] *សូមមើលផងដែរ* V.គ.៣.ក. ឧក្រិដ្ឋកម្ម - ឧក្រិដ្ឋកម្មប្រឆាំងវៀតណាម – គោលនយោបាយរបស់ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាម – ចេតនារបស់ ប.ក.ក ចំពោះប្រជាជនវៀតណាម និងខ្មែរក្រោម។

[2542] ស.ព.អ សន្និដ្ឋានថា ធាតុផ្សំនៃភាពរង្គាលចំពោះឧក្រិដ្ឋកម្មសម្លាប់រង្គាល ត្រូវបានបញ្ជាក់ដោយភ័ស្តុតាងសម្រាប់តែទីតាំងសម្លាប់មនុស្សទួលសេះញ៉ូ និងព្រៃក្របៅដោយឡែកពីគ្នា និងដោយរួមគ្នា។ ម្យ៉ាងវិញទៀត ស.ព.អ រក្សាគោលជំហរថា នៅពេលពិចារណាអំពីធាតុផ្សំនៃភាពរង្គាលដែលជាលក្ខខណ្ឌតម្រូវសម្រាប់បញ្ជាក់អំពីការសម្លាប់រង្គាល ការសម្លាប់នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស និងទីតាំងពលកម្មដោយបង្ខំទាំងអស់ រួមទាំងទីតាំងសម្លាប់នៅទួលសេះញ៉ូ និងព្រៃក្របៅនេះផង ត្រូវលើកយកមកពិចារណាបញ្ចូលគ្នា។ ទីតាំងទាំងអស់ គឺជាផ្នែកនៃប្រព័ន្ធរៀបចំមួយក្នុងការអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង និងការសម្លាប់នៅតាមទីតាំងនីមួយៗក្នុងចំណោមទីតាំងទាំងនេះ ត្រូវបានជួយសម្រួលដោយពាក្យពេចន៍ និងសកម្មភាពដូចគ្នារបស់ យ៉ីម ទិត្យ។

ឃ. ទីតាំងសម្លាប់មនុស្សវត្តច័ន្ទរង្សី

i. សេចក្តីផ្តើម

687. ទីតាំងសម្លាប់មនុស្សវត្តច័ន្ទរង្សី ("វត្តច័ន្ទរង្សី") មានទីតាំងស្ថិតក្នុងស្រុកបាកាន តំបន់ ២ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ វត្តច័ន្ទរង្សីត្រូវបានប្រើប្រាស់ជាកន្លែងឃុំខ្លួនបណ្តោះអាសន្ន និងជាទីតាំងសម្លាប់មនុស្សនៃប្រជាជនជម្លៀសពីភូមិភាគបូព៌ា។ ពួកគេដែលត្រូវបានសម្លាប់ទាំងនោះ ត្រូវបានកប់នៅតំបន់ជិត១ភូមិកូនត្នោត។

688. ក្នុងឋានៈជាលេខាវង និងជាអ្នកដឹកនាំ*ភាគព្រឹត្តន័យ* ក្នុងភូមិភាគពាយ័ព្យ និងជាសមាជិកដឹកនាំនៃសហឧក្រិដ្ឋកម្មរួម **យ៉ីម ទ៍ត្យ** ទទួលខុសត្រូវ និងមានសិទ្ធិអំណាចលើព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងនៅវត្តច័ន្ទរង្សី។

689. ស.ច.ស.អ បានចោទ **យ៉ីម ទ៍ត្យ** លើឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងទីតាំងសម្លាប់មនុស្សវត្តច័ន្ទរង្សី ជាអាទិ៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា និងឧក្រិដ្ឋកម្មនៃការធ្វើឃាតមនុស្សដោយគិតទុកជាមុន អនុលោមតាមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[2543]។

ii. ប្រតិបត្តិការ និងទីតាំង

690. ប្រជាជនជម្លៀសពីភូមិភាគបូព៌ាត្រូវបានសម្លាប់នៅវត្តច័ន្ទរង្សី និងទីតាំងសម្លាប់មនុស្សនៅជិត១វត្តនេះ ក្នុងអំឡុងពេលរវាងចុងឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩[2544]។ វត្តច័ន្ទរង្សីមានទីតាំងប្រមាណមួយ

[2543] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទ៍ត្យ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426552 – 01426553, 01426560–0142656។

[2544] ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារីន ឆ.១០២ KH 00977116 ["នៅពេលដែលមានការជម្លៀសប្រជាជនស្វាយរៀងមកដល់ទីនេះ គឺប្រហែលជានៅចុងឆ្នាំ១៩៧៨។"]។ ឯកសារ D65.1.56 កំណត់ហេតុស្តាប់ចម្លើយ ខ៉ឹម សាម៉ុន KH 00250707 ["នៅរដូវច្រូតចុងឆ្នាំ១៩៧៨ ទើបខ្ញុំត្រូវបានជម្លៀស"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៥១ KH 00955685 ["ស. ឥឡូវនិយាយពីការជម្លៀសពួកបូព៌ាវិញម្តង តើអ្នកទាំងអស់នោះត្រូវបានជម្លៀសមកបាកានៅឆ្នាំណា? ឆ.៥១៖ នៅចុងឆ្នាំ១៩៧៨"]។ ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៧៥-៧៦ KH 00982180 ["ឆ.៧៥៖ អ្នកស្វាយរៀង ត្រូវគេសម្លាប់នៅ [...] ឃុំរំលេច។ ស៖ តើរឿងនេះកើតឡើងនៅពេលណា? ឆ.៧៦៖ នៅចុងឆ្នាំ១៩៧៨ [...] មានការសម្លាប់ពេញទំហឹងតែម្តងទៅលើអ្នកស្វាយរៀង។"]។ ឯកសារ D118/175 កំណត់ហេតុស្តាប់

គីឡូម៉ែត្រពីភូមិរំលេច ឃុំរំលេច ស្រុកបាកាន តំបន់ ២ នៃភូមិភាគពាយ័ព្យ[2545]។ វត្តនេះគឺជាកន្លែងឃុំឃាំងបណ្តោះអាសន្ន[2546]។ ប្រជាជនជម្លៀសពីភូមិភាគបូព៌ាត្រូវបានសម្លាប់នៅទីតាំងនេះ ឬនៅកន្លែងនៅជិតៗនោះ រួមទាំងសាលារៀនមធ្យមសិក្សានៅជិតនោះផង[2547]។

ចម្លើយ រ៉ើន ដារ៉ា ឆ.៩៦ KH 00973956 ["ស៖ តើខ្មែរក្រហមសម្លាប់ប្រជាជនស្វាយរៀង និងព្រៃវែង? ឆ.៩៦៖ ប្រហែលជានៅចុងឆ្នាំ១៩៧៨"]។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.១០១, KH 01198096 ["ស៖ តើការសម្លាប់នៅទល់មុខវត្តរំលេចហ្នឹង នៅឆ្នាំ៧៨ឬក៏ ៧៩? ឆ.១០១៖ នៅចុង៧៨។"]។ ឯកសារ D118/14 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តចន្ទ័រង្សី KH 00901545 ["យោងតាមសាក្សីរបស់ ក.ស.ច.ស មួយរូប ចុងឆ្នាំ១៩៧៨ ដើមឆ្នាំ១៩៧៩ មុនរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម)បានដួលរលំ [...] ប្រជាជនជម្លៀសនៅភូមិភាគបូព៌ាចំនួនប្រមាណ ៦៤០ នាក់ ត្រូវបានសម្លាប់នៅវត្តចន្ទ័រង្សី។"]។ ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ["នៅខែតុលា ឆ្នាំ១៩៧៨ ទាហានខ្មែរក្រហម បានយកប្រជាជនភូមិភាគបូព៌ា [...] ប្រមាណ ២០០០ នាក់ បានមកដល់រំលេច បាកាន [...]។ នៅរសៀលល្ងាចម៉ោងប្រហែល ៦ គាត់ឮសូរស្នូរសម្លេងកាំភ្លើង [។] នៅយប់ម៉ោង ៨ ទាហានខ្មែរក្រហម បានបង្ខំគាត់ និង ក្រុមរទេះដែលមានទាហានចំនួន៦០នាក់ យកសាកសពជនរងគ្រោះមកពីបូព៌ាចំនួន ២០០០ នាក់ ទៅកប់ [...] នៅភូមិកូនត្នោត"]។

[2545] ឯកសារ D118/14 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តចន្ទ័រង្សី KH 00901545 ["វត្តចន្ទ័រង្សីដែលត្រូវបានស្គាល់ផងដែរថា ឈ្មោះវត្តរំលេច ដែលមានទីតាំងនៅក្នុងភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៣ KH 00485644 ["នៅក្នុងរបបខ្មែរក្រហម ស្រុកបាកាន ស្ថិតនៅក្នុងតំបន់ ២ នៃភូមិភាគពាយ័ព្យ"]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ ឆ.៥៧ KH 01156827 ["វត្តហ្នឹងនៅប្រទ្ធោះកណ្តាល ភូមិរំលេច និង ភូមិប្រឡាយរំដេង [...] ប្រហែល១គីឡូពីភូមិរំលេច"]។ ឯកសារ D1.3.10.11 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការគូសផែនទីវាលពិឃាតកម្ពុជា KH 00292770 ["វត្តចាន់រង្សីរស្មីរំលេច ស្ថិតនៅភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់។ កន្លែងសម្លាប់នេះ មានចម្ងាយប្រមាណ១៥គីឡូម៉ែត្រ ពីមន្ទីរស្រុកបាកាន"]។

[2546] ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.១៥ KH 00872598 ["ស៖ អ្នកភូមិភាគបូព៌ាប្រមាណជា ៣០០ នាក់ ដែលគេយកមកដាក់នៅវត្តរំលេចហ្នឹង តើពួកគេនៅទីនោះរយៈពេលប៉ុន្មានថ្ងៃ មុននឹងគេបាញ់សម្លាប់? ឆ.១៥៖ ពួកគេនៅទីនោះ ១ យប់ ហើយថ្ងៃបន្ទាប់ ទើបពួកត្រូវយោធាខ្មែរក្រហមសម្លាប់ពួកគេ។"]។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សំ ឆ.៥៤ KH 00982194 ["ពេលមកដល់ភ្លាម គេឲ្យធ្វើការ ហើយចាប់ផ្តើមសម្លាប់ពួកខ្ញុំតែម្តង។ មកដល់ភ្លាម [...] យកទៅសម្លាប់ចោល។"]។ ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្ហី KH 00273433 ["ខ្មែរក្រហមបានប្រមូលប្រជាជនបូព៌ា [...] ដាក់នៅក្នុងវត្តរំលេចមួយកន្លែង ក្រោមការគ្រប់ គ្រងរបស់ខ្មែរក្រហមដោយផ្ទាល់។ ក្រោយមក រយៈ ២ទៅ៣ថ្ងៃ យប់ឡើង ខ្មែរក្រហមបានបាញ់សម្លាប់ទាំងអស់គ្មានសល់នោះទេ"]។

[2547] ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៧៥ KH 00982180 ["អ្នកស្វាយរៀង ត្រូវគេសម្លាប់នៅខាងមុខអនុវិទ្យាល័យក្នុងឃុំរំលេចនេះ។"]។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.៩៤ KH 01198095 ["ស៖ [...] តើលោកមានដឹងថា គេយកអ្នកស្វាយរៀង ព្រៃវែង ទៅសម្លាប់នៅកន្លែងណាទេ? ឆ.៩៤ [...] ខ្ញុំបានដឹងមួយកន្លែងនៅមុខអនុវិទ្យាល័យជិតវត្តរំលេច។"]។ ឯកសារ D6.1.757 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន KH 00385099 ["ប្រជាជន[ភូមិភាគ

691. សាកសពប្រជាជនដែលបានសម្លាប់នោះ ត្រូវបានកប់ក្នុងរណ្តៅកប់សាកសពរួមនៅក្នុងភូមិកូនត្នោតដែលមានទីតាំងពីរបីគីឡូម៉ែត្រពីវត្តច័ន្ទរង្សី[2548]។ រណ្តៅកបសាកសពពីពីរទៅបីរណ្តៅដែលមានទំហំទទឹង ២០ ម៉ែត្រ បណ្តោយ ៣០ ម៉ែត្រ ហើយមានជម្រៅ ៥ ម៉ែត្រ អាចមើលឃើញនឹង

ឫ[ជ]ទាំងនោះ ត្រូវបានសម្លាប់នៅតាមផ្លូវនៅខាងមុខសាលារៀន។ [...] សាកសពអ្នកទាំងនោះ ត្រូវបានដឹកយកទៅកប់នៅខាងក្រោយសាលារៀន ដែលស្ថិតនៅចំពីមុខវត្តច័ន្ទរង្សីរំលេច"]។ ឯកសារ D6.1.134 កំណត់ហេតុស្តាប់ចម្លើយ ដួង សូ KH 00242404 ["មានចំនួន [...] រណ្តៅធំៗ៖ មួយនៅភូមិរំលេច (ខាងត្បូងវត្តរំលេច)"]។ ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ KH 00267775 ["ប្រជាជនដែលនៅរស់នៅទីនោះក្រោយឆ្នាំ១៩៧៩ ប្រាប់ខ្ញុំថា ពួកខ្មែរក្រហមយកប្រជាជនដែលជម្លៀសពីខាងបូព៌ាមកបាញ់សម្លាប់ នៅជិតសាលារៀនខាងត្បូងវត្តរំលេច"]។ ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ["ថ្ងៃមួយ គាត់និងមនុស្សពីរបីនាក់ បានដឹកប៉ះចំរណ្តៅសាកសពចំនួន៣ នៅខាងត្បូងសាលារៀនរំលេច"]។ ឯកសារ D1.3.10.11 របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការគូសផែនទីវាលពិឃាតកម្ពុជា KH 00292770 ["វត្តចាន់រង្សីរស្មីរំលេច [...] កន្លែងសម្លាប់នៅខាងលិចសាលារៀន ក្នុងភូមិរំលេច ឃុំរំលេច។"]។

[2548] ឯកសារ D118/14 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តចន្ទ័រង្សី KH 00901546 ["ភូមិកូនត្នោត ឬភូមិចាម [...]នៅក្នុង [...] ភូមិកូនត្នោត ឬភូមិចាម ឃុំរំលេច ស្រុកបាកាន ខេត្តពោធិសាត់] KH 00901546 ["ភូមិកូនត្នោត ឬភូមិចាម ស្ថិតនៅចម្ងាយប្រមាណ១គីឡូម៉ែត្រកន្លះ ពីទីតាំងសម្លាប់មនុស្សនៅវត្តច័ន្ទរង្សី។"]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ ឆ.៥៧ KH 01186827 ["ស៖ តើវត្តនេះមានចម្ងាយប៉ុន្មានពី [...] ភូមិកូនត្នោត? ឆ.៥៧៖ ចម្ងាយតែ៥គីឡូទេ ពីភូមិកូនត្នោត។"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៥៧, ឆ.៥៩ KH 00955686 ["ភូមិកូនត្នោតគឺជាភូមិចាម។ [...] ហើយនៅពេលដែលមានការបាញ់សម្លាប់មនុស្សអ្នកនេះ ទើបគេឲ្យយកទៅដាក់នៅរណ្តៅនោះ។"]។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ដារ៉ា ឆ.៩៦ KH 00973956 ["កូនត្នោត (ភូមិចាម)ក្នុងឃុំរំលេច។"]។ ឯកសារ D6.1.134 កំណត់ហេតុស្តាប់ចម្លើយ ដួង សូ KH 00242404 ["មានចំនួន [...] រណ្តៅធំៗ៖ មួយនៅ [...] ភូមិកូនត្នោត"]។

ភ្ជុកនៅឡើយនាពេលបច្ចុប្បន្ន[2549]។ រណ្តៅសាកសពទាំងនេះគឺជារណ្តៅដីខ្សាច់នៅមុនរបបខ្មែរក្រហម[2550]។

iii. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទង

692. វត្តច័ន្ទរង្សី និងឃុំរំលេចស្ថិតក្រោមការគ្រប់គ្រងគណៈស្រុកបាកាន ក្នុងអំឡុងពេលនៃការសម្លាប់ប្រជាជនជម្លៀសពីភូមិភាគបូព៌ា[2551]។ គណៈកម្មាធិការនេះមាន រ៉ែម ជាអ្នកដឹកនាំ ដែលជាអតីត កម្មាភិបាលភូមិភាគនិរតី និង ផេង អតីតកម្មាភិបាលភូមិភាគនិរតី[2552]។ គណៈកម្មាធិការនេះស្ថិតក្រោមអំណាចជារួមនៃលេខាតំបន់ ២ ឈ្មោះ តាសារុន[2553]។

[2549] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន ដារ៉ា ឆ.៩៦ KH 00973956 ["នៅភូមិកូនតោ្នត មានរណ្តៅសាកសពធំបី"]។ ឯកសារ D118/14 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង វត្តចន្ទ័រង្សី KH 00901546 ["នៅភូមិកូនតោ្នត [...] រណ្តៅសាកសពចំនួន ២ ត្រូវបានប្រទះឃើញ [...] រណ្តៅសពនីមួយៗមានទំហំ ២០ គុណនឹង ៣០ ម៉ែត្រ និង ជម្រៅ ៤ ទៅ ៥ ម៉ែត្រ"]។ ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្ហី KH 00273433 ["នៅភូមិចាមមានរណ្តៅធំណាស់ ទំហំ១០ម៉ែត្របួនជ្រុង ជម្រៅ៣ម៉ែត្រ។"]។ ឯកសារ D6.1.134 កំណត់ហេតុស្តាប់ចម្លើយ ដួង ស្ង KH 00242404 ["ខ្មែរក្រហមដឹកសាកសព [...] ទៅកប់នៅរណ្តៅ [...] មានទំហំ១០ម៉ែត្របួនជ្រុង ជម្រៅ២ម៉ែត្រ ដែលស្ថិតនៅភូមិកូនតោ្នត [...] រណ្តៅសាកសពនៅភូមិកូនតោ្នតនោះ បានបន្សល់ទុករហូតដល់សព្វថ្ងៃ មិនទាន់បានបាត់ដានទេ។"]។ ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយ ទិត សុផារី ឆ.៧៦ KH 00977018 ["មាន [...] ភូមិកូនតោ្នត [...] បច្ចុប្បន្ននេះ នៅមាន រណ្តៅនៅឡើយ"]។

[2550] ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៥៩ KH 00955686 ["រណ្តៅនោះក៏មិនមែនសម្រាប់ដាក់សាកសពដែរ គឺគេជីកដើម្បីយកខ្សាច់។"]។ ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ["រណ្តៅសាកសព (រណ្តៅត្រូវបានជីកមុនការឡើងកាន់អំណាចរបស់ខ្មែរក្រហម) នៅភូមិកូនតោ្នត"]។

[2551] សូមមើល IV.គ.២.ក. រចនាសម្ព័ន្ធ និងការទំនាក់ទំនង អំណាចរបស់គណៈកម្មាធិការអចិន្ត្រៃបក្សកុម្មុយនីសកម្ពុជា – ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧ – ១៩៧៩ តំបន់២ – ស្រុកបាកាន។

[2552] សូមមើល ឧទាហរណ៍ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម ហៅ យង់ ហាន ឆ.៦៦, ៨១, ១៥៣ KH 01025541, 01025543, 01025550។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រ៉ិន ឆ.៤០, ៤២, ៥៣-៥៤ KH 01075611, 01075613។ ឯកសារ D219/590 កំណត់ហេតុស្តាប់ចម្លើយ ឡុង ឃ្លោក ឆ.៦០ KH 01167620។ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ែម ឆ.៥៩-៦០ KH 01347271។ ប៉ុន្តែ សូមមើល ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ែម ឆ.៩៩ KH 01348874។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡូម សារ៉ូន ឆ.៣៨ KH 01176410។ ឯកសារ D6.1.616 បទសម្ភាសន៍ SOAS ជាមួយ អ៊ីក ស្ងៀម KH 0065727-0065728។

[2553] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ែម ឆ.៧២-៧៤ KH 01347273-01347274។

693. តាម៉ុកបានផ្សព្វផ្សាយបទបញ្ជាឲ្យសម្លាប់ប្រជាជនជម្លៀសពីភូមិភាគបូព៌ា នៅក្នុងកិច្ចប្រជុំនានានៅថ្នាក់តំបន់ និងស្រុក[2554]។ បទបញ្ជាឲ្យសម្លាប់ទាំងនេះត្រូវបានចេញពីដំបូងពីមន្ទីរ ៨៧០[2555]។ យាយរ៉ីម ផ្ទាល់បានចេញបញ្ជាឲ្យសម្លាប់ខ្មាំងនៅក្នុងស្រុក ដើម្បីអនុវត្តគោលនយោបាយសហឧក្រិដ្ឋកម្មរួមនៅក្នុងស្រុកបាកាន[2556]។

iv. ឧក្រិដ្ឋកម្ម

<u>ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល</u>

694. នៅរវាងចុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៩ កងទ័ពភូមិភាគនិរតីនៃ ប.ក.ក បានជម្លៀសប្រជាជនដោយបង្ខំពីខេត្តនានានៅភូមិភាគបូព៌ា ដូចជាខេត្តស្វាយរៀង ខេត្តព្រៃវែង និងខេត្តកំពង់ចាម ទៅកាន់ខេត្តពោធិ៍សាត់ក្នុងភូមិភាគពាយ័ព្យ[2557]។ អង្គភាពកងទ័ពនៃ ប.ក.ក បានបង្ខំប្រជាជនពីភូមិភាគបូព៌ាឲ្យចាកចេញពីលំនៅឋាន ពីព្រោះពួកគេយល់ថា ប្រជាជនទាំងនោះបានចូលដៃជាមួយ ឬមានសមានចិត្តជាមួយវៀតណាម ហើយដូច្នេះ បាន "ក្បត់បក្ស" និងជា "ខ្មាំង" និង "ជនក្បត់" នៃ ប.ក.ក[2558]។

[2554] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៧១, ១៨០, ១៩៤ KH 01000275, 01000276, 01000277 ["តាម៉ុក [...] ហៅថា តា១៥ [...] ប្រជុំប្រាប់កម្មាភិបាលថ្នាក់ក្រោមបន្តទៀត [...] គណៈ៨៧០ មកប្រជុំជាមួយនឹងថ្នាក់តំបន់ ហើយថ្នាក់តំបន់មកប្រជុំប្រាប់ថ្នាក់ស្រុក ហើយថ្នាក់ស្រុកមកប្រជុំប្រាប់ថ្នាក់សហករណ៍"]។

[2555] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៨៤, ១៨៥ KH 01000276 [បញ្ជាពីតា ៧៨ ត្រូវបានស្គាល់ផងដែរថាជា គណៈ៨៧០ "មេកងបានឱ្យីបប្រាប់ខ្ញុំអំពីផែនការមួយ [...] សម្លាប់អ្នកបូព៌ាឲ្យអស់ក្នុងរយៈពេល ៥ថ្ងៃ។"]។

[2556] ឯកសារ D6.1.757 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន KH 00385099 ["ចំពោះបញ្ជាឲ្យសម្លាប់ ខ្ញុំដឹងថា បញ្ជាទាំងនេះចេញពីអង្គការថ្នាក់លើ និងពី យាយរ៉ីម។"]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ ឆ.៩៤ KH 01186832 ["យាយរ៉ីម គឺគណៈស្រុក ហើយគេថា [...] គាត់ជម្លៀសមនុស្សទៅសម្លាប់។"]។

[2557] សូមមើល V.B.6.b.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់៧ – ទីតាំងសម្លាប់ វាលបាក់ចិញ្ជៀន – ឧក្រិដ្ឋកម្ម –មនុស្សឃាត និង ការសម្លាប់រង្គាល។

[2558] ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៧ KH 00485646 ["តាម៉ុក បានបញ្ជាក់អំពីមូលហេតុនៃការជម្លៀសនេះ គឺដោយសារតែនៅតាមបណ្តាយព្រំដែនកម្ពុជា វៀតណាម គឺមានការលំបាកដោយសារកងទ័ពវៀតណាមបានលុកលុយចូលកម្ពុជា ហើយមេភូមិភាគបូព៌ាឈ្មោះ សោ ភ័ម បានក្បត់។"]។ ឯកសារ D118/194 កំណត់នៃការស្តាប់ចម្លើយ រស់ ណារ៉ីន ឆ.៨២-៨៣ KH 00977114 ["ឆ.៨២៖ ខ្ញុំបានឮថា អ្នកស្វាយរៀង [...] ដោយគេចោទថា ជាខ្មាំងផ្ទៃក្នុង។ ស៖ តើលោកស្រីបានឮអ្វីខ្លះទៀត អំពីប្រជាជនស្វាយរៀង? ឆ.៨៣៖ ខ្ញុំឮថា ប្រជាជនស្វាយរៀងទាំងនោះបានរត់ចូលស្រុកយួន ដូច្នេះ ទើបពួកខ្មែរក្រហមចាប់អ្នកទាំងអស់នោះ ហើយជម្លៀសមកដល់កន្លែងរបស់ខ្ញុំ ដោយចោទថាខ្មាំងបង្ក់ប់។"]។ ឯកសារ D118/175

695. នៅក្នុងចំណោមប្រជាជនជម្លៀសពីភូមិភាគបូព៌ាទាំងនេះ ប្រជាជនប្រមាណជា ២.០០០ នាក់ ត្រូវបានជម្លៀសទៅកាន់រំលេច ក្នុងស្រុកបាកាន និងត្រូវបានសម្លាប់នៅទីនោះ[2559]។ ប្រជាជនជម្លៀសពីភូមិភាគបូព៌ាត្រូវបានដាក់ឃុំ នៅវត្តច័ន្ទរង្សីពីមួយយប់ទៅបីយប់ នៅពេលពួកគេបានទៅដល់រំលេច ហើយបន្ទាប់មកប្រជាជនទាំងនោះត្រូវបានយកទៅសម្លាប់ចោល[2560]។ ពួកគេត្រូវបានយក

កំណត់ហេតុស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.៩៩ KH 00973956 ["បើនិយាយរួមគឺវា[ខ្មែរក្រហម] ចោទថា "ក្បត់បក្ស" ទាំងអ្នកមកពីបូព៌ា និងខ្មែរក្រោម។"]។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម ហៅ យង់ ហាន ឆ.១៤៧ KH 01025550 ["គេ [ខ្មែរក្រហម] និយាយថា 'ប្រជាជបស្វាយរៀង និងព្រៃវែង ជាពួកក្បត់'"]។

[2559] ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៧៥-៧៦ KH 00982180 ["នៅឃុំរំលេច [...] នៅចុងឆ្នាំ ១៩៧៨ ពេលដែលខ្ញុំត្រូវគេជម្លៀសមកនៅទីនេះ គឺមានការសម្លាប់ពេញទំហឹងតែម្តងទៅលើអ្នកស្វាយរៀង"]។ ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្លី KH 00273428 ["ប្រជាជនមកពីកំពង់ចាម ស្វាយរៀង និងព្រៃវែង មកខេត្តពោធិសាត់។ ជាពិសេសដែលបានរស់នៅឃុំរំលេចនេះ ច្រើនជាប្រជាជនមកពីខេត្តស្វាយរៀង"]។ ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ["ទាហានខ្មែរក្រហម បានយកប្រជាជនបូព៌ា [...] ប្រមាណ ២០០០ នាក់ មកដល់រំលេច [...] ជនរងគ្រោះទាំងអស់ ត្រូវបានបាញ់សម្លាប់"]។

[2560] ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.១៤, ១៥ KH 00872598 ["ស៖ តើក្នុងពេលលោកជាប្រធានសហករណ៍ តើវត្តរំលេចហ្នឹង គឺជាគុកមែនដែរឬទេ? ឆ.១៤៖ មិនមានមែនជាគុកទេ [...] ឆ.១៥៖ ពួកគេ[ប្រជាជនភូមិភាគបូព៌ា] នៅទីនោះ ១ យប់ ហើយថ្ងៃបន្ទាប់ ទើបពួកត្រូវយោធាខ្មែរក្រហមសម្លាប់ពួកគេ។]។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សំ ឆ.៥៤ KH 00982194 ["ពេលមកដល់ភ្លាម គេឲ្យធ្វើការ ហើយចាប់ផ្តើមសម្លាប់ពួកខ្ញុំតែម្តង។ មកដល់ភ្លាម [...] យកទៅសម្លាប់ចោល។"]។ ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្លី KH 00273433 ["ខ្មែរក្រហមបានប្រមូលប្រជាជនបូព៌ា [...] ដាក់នៅក្នុងវត្តរំលេចមួយកន្លែង ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមដោយផ្ទាល់តែម្តង។ ក្រោយមករយៈ២ ទៅ៣ថ្ងៃ យប់ឡើងខ្មែរក្រហម បានបាញ់សម្លាប់ទាំងអស់គ្មានសល់នោះទេ។"]។

ទៅសម្លាប់ នៅតាមទីតាំងជាច្រើន នៅជិតៗវត្ត[2561] នៅក្បែរសាលាមធ្យមសិក្សា[2562] និងនៅក្នុងភូមិកូនត្នោត[2563]។

[2561] ឯកសារ D118/194 កំណត់នៃការស្តាប់ចម្លើយ រស់ ណារីន ឆ.៨៨, ៩១ KH 00977114 ["សៈ ក្រោយមកទៀត តើគេបានសម្លាប់អ្នកបួតាទាំងអស់នោះដែរឬទេ? ឆ.88 ចាស គេបានសម្លាប់អ្នកបួតាទាំងអស់នោះនៅរំលេច។ [...] ឆ.៩១៖ នៅខាងលិចវត្តរំលេចប្រហែលជា១គីឡូម៉ែត្រពីវត្ត។"]។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សំ ឆ.៥៩-៦១ KH 00982195 ["ខ្មែរក្រហមបានចាប់ផ្តើមសម្លាប់ [...] អ្នកបួតា [...] ខាងលិចវត្តរំលេច"]។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែ ន ដារ៉ា ឆ.៩៦, ៩៧ KH 00973956 ["ពេលនោះខ្មែរក្រហមបានធ្វើការបាញ់រះសម្លាប់អ្នកទាំងនោះ [ប្រជាជនមកពីស្វាយរៀង និង ព្រៃវែង] [...] នៅតាមច្នល់ចូលភូមិរំលេចតែម្តង។ សៈ តើការបាញ់រះសម្លាប់ប្រជាជនស្វាយរៀង និងព្រៃវែងកើតឡើងនៅមុខវត្តរំលេចមែនទេ? ឆ.៩៧៖ បាទ។"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៥៦ EN 00955686 ["គឺសម្លាប់នៅមុខវត្តតែម្តង។"]។ ឯកសារ D118/188 កំណត់ហេតុស្តាប់ចម្លើយ ទិត សុផារី ឆ.៧៥ KH 00977018 ["ហើយក៏មានការបាញ់សម្លាប់អ្នកស្វាយរៀង នៅខាងមុខវត្តរំលេចផងដែរ"]។ ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ["ជនរងគ្រោះទាំងអស់ ត្រូវបានដុតសម្លាប់ នៅតាមបណ្តោយផ្លូវទល់មុខវត្តរំលេច"]។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម ហៅ យង់ ហាន ឆ.១៤១ KH 01025545 ["សៈ តើគេ [ខ្មែរក្រហម] សម្លាប់អ្នកស្វាយរៀង និងព្រៃវែង នៅកន្លែងណា នៅសហករណ៍រំលេច? ឆ.១៤១៖ គេសម្លាប់នៅជិតភូមិរំលេចនៅតាមផ្លូវដែលក្រាលគ្រួសក្រហម។"]។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.៩០ EN 00979042 ["ប្រជាជនបួតាត្រូវគេបណ្តើរជាខ្សែ ដែលមានប្រហែលជា ២០០ម៉ែត្រ ពីវត្តរំលេចនេះ។ ពួកគេសម្លាប់ទាំងកូនក្មេងផងដែរ។"]។ ឯកសារ D6.1.134 កំណត់ហេតុស្តាប់ចម្លើយ ដួង សូ KH 00242403 ["នៅតាមផ្លូវច្នល់ក្បែរវត្តរំលេច ជាកន្លែងសម្លាប់"]។ ឯកសារ D118/147.1.44 របាយការណ៍ស្តីពីការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស រឿងរ៉ាវរបស់ ដួង សូ KH 00267897 ["នៅតាមផ្លូវច្នល់ក្បែរវត្តរំលេច [...] ខ្មែរក្រហមដឹក [...] ជម្លៀសមកពីខេត្តស្វាយរៀង និងព្រៃវែង [...] មកបាញ់សម្លាប់នៅខាងលិចវត្តរំលេច។"]។

[2562] ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៧៥ KH 00982180 ["អ្នកស្វាយរៀង ត្រូវគេសម្លាប់នៅខាងមុខអនុវិទ្យាល័យក្នុងនៅឃុំរំលេច។"]។ ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ KH 00267775 ["ពួកខ្មែរក្រហមយកប្រជាជនដែលជម្លៀសពីខាងបួតាមកបាញ់សម្លាប់នៅជិតសាលារៀនខាងត្បូងវត្តរំលេច"]។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.៩៦ KH 01198095 ["សៈ តើលោកដឹងដោយរបៀបណា ថាអ្នកមកពីស្វាយរៀង ព្រៃវែងគេយកទៅសម្លាប់នៅមុខអនុវិទ្យាល័យជិតវត្តរំលេច? ឆ.៩៦៖ ខ្ញុំដឹងតាមអ្នកនៅក្នុងកងរទេះ ដែលដឹកខ្ទោចពីកន្លែងនោះ ទៅកប់នៅកន្លែងមួយទៀត ដែលមានឈ្មោះថា កូនត្នោត"]។

[2563] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែ ន ដារ៉ា ឆ.៩៦ KH 00973956 ["ខ្មែរក្រហមបានយកប្រជាជនស្វាយរៀង និង ព្រៃវែង [...] ខ្លះទៀតសម្លាប់នៅភូមិកូនត្នោត(ភូមិចាម)"]។ ឯកសារ D118/241 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ ឆ.៨៨ KH 00988071 ["សៈ លោកបាននិយាយថា ភូមិចាម [...] ហេតុអ្វីបានលោកដឹង? ឆ.៨៨៖ ភូមិចាមហ្នឹង គឺជាកន្លែងដែលគេ[កម្មាភិបាលខ្មែរក្រហម] សម្លាប់ពួកភូមិភាគបួតា"]។

696. ការសម្លាប់ជាច្រើនត្រូវបានធ្វើឡើងជារៀងរាល់ថ្ងៃ ពោលគឺនៅពេលយប់[2564]។ ប្រជាជនជម្លៀស ប្រមាណ ១០០ ទៅ ៧០០ នាក់ ត្រូវបានបាញ់សម្លាប់ម្តងៗ[2565] ក្នុងនោះរួមទាំងបុរស ស្ត្រី និង កុមារ[2566]។ ប្រជាជនជាច្រើនត្រូវបានសម្លាប់ដោយមានដៃចងស្លាបសេក[2567]។ អ្នកដែលត្រូវបាន

[2564] ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្លី KH 00273433 ["រយៈ២ទៅ៣ថ្ងៃ យប់ឡើងខ្មែរក្រហម បានបាញ់សម្លាប់ទាំងអស់គ្មានសល់នោះទេ។"]។ ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម, រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ["នៅពេលយប់ម៉ោង៨ ទាហានខ្មែរក្រហម [...] យកសាកសព"]។

[2565] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ វ៉ើន ដារ៉ា ឆ.៩៤-៩៦, ៩៨ KH 00973956 ["ឆ.៩៤៖ [...] ខ្មែរក្រហមចាប់ផ្តើមសម្លាប់ប្រជាជនដែលមកពី ស្វាយរៀង និង ព្រៃវែង [...] ស៖ ហេតុអ្វីបានជាលោកដឹងថា ខ្មែរក្រហមសម្លាប់ប្រជាជនស្វាយរៀង និងព្រៃវែង? ឆ.៩៥៖ ខ្ញុំបានឃើញដោយផ្ទាល់ភ្នែកតែម្តង ព្រោះខ្មែរក្រហមបានបណ្តើរអ្នកទាំងនោះយកទៅសម្លាប់ទាំងខ្សែៗ។ [...] ឆ.៩៦៖ [...] ខ្មែរក្រហមបានធ្វើការបាញ់រះ [...] ប្រហែលជា៣០០នាក់"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរឿន ឆ.៥៥ KH 00955686 ["ស. តើមានមនុស្សស្លាប់ប្រហែលប៉ុន្មាននាក់? ឆ.៥៥៖ ប្រហែលជា២០០នាក់។"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សឿម ឆ.៨ KH 00485647 ["ប្រជាជនបូព៌ាប្រហែល ៣០០នាក់ [...] ពួកយោធាក៏បាញ់សម្លាប់ពួកប្រជាជនបូព៌ាទាំង៣០០នាក់នោះទៅ"]។ ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សឿម ឆ.១៥ KH 00872598។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សំ ឆ.៥៩ KH 00982195 ["ខ្មែរក្រហមបានចាប់ផ្តើមសម្លាប់អ្នកបូព៌ាប្រហែលជា៥០០នាក់"]។ ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្លី KH 00273433 ["ប្រជាជនបូព៌ាដែលត្រូវប្រមូលមកនៅឯវត្តរំលេចនេះ មានប្រមាណ៦៤០នាក់ ត្រូវបានសម្លាប់ចោលទាំងអស់"]។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.៨៩-៩០ KH 00979042 ["ស៖ តើមានប្រជាជនបូព៌ាប៉ុន្មាន ដែលត្រូវខ្មែរក្រហមសម្លាប់នៅពេលនោះ? ឆ.៨៩៖ ខ្ញុំមិនដឹងថាមានចំនួនប៉ុន្មានទេ [...] ឆ.៩០៖ [...]៖ បើតាមពេលដែលខ្ញុំនៅប្រមូលអ្ជីងជនងរងគ្រោះ គឺមានមិនតិចជាង១០០នាក់នោះទេ។"]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ ឆ.៦៩ KH 01186829 ["ស៖ តើលោកដឹងថា មានមនុស្សប៉ុន្មាននាក់ត្រូវបានគេសម្លាប់នៅលើផ្លូវជាប់វត្តទេ? ឆ.៦៩៖ ការដឹងនេះអីចេះដោយសារតែយកទៅកប់នៅរណ្តៅហ្នឹង គេនិយាយប្រាប់ថា ប្រហែល៧០០នាក់ណោះ បាញ់ម្សិលមិញ។"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរឿន ឆ.៥៥ KH 00955686 ["ស៖ តើមានមនុស្សស្លាប់ប្រហែលប៉ុន្មាននាក់? ឆ.៥៥៖ ប្រហែលជា២០០នាក់។"]។ ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សឿម ឆ.៨ KH 00485647 ["ក្រោយមក [...] ពួកយោធាក៏បាញ់សម្លាប់ពួកប្រជាជន។"]។ ឯកសារ D6.1.134 កំណត់ហេតុស្តាប់ចម្លើយ ដួង សូ KH 00242403 ["ជម្លៀសមកពីខេត្តស្វាយរៀង និងព្រៃវែង ប្រមាណជាង៣០០នាក់ [...] ឲ្យរៀបជាជួរ ដោយមានចងដៃ។ ហើយពួកខ្មែរក្រហម បានបាញ់សម្លាប់ប្រជាជនទាំងនោះ"]។

[2566] ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សឿម ឆ.៨ KH 00485647 ["ពួកយោធាក៏បាញ់សម្លាប់ [...] មានស្រីប្រុស ចាស់ ក្មេង ព្រមទាំងកុមារ។"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សួរ ឆ.៧១ EN 00975894 ["ដំបូងគេ[កម្មាភិបាលមកពីភូមិភាគនិរតី] ចាប់អ្នកមានកម្លាំងខ្លាំង រួចទើបចាប់ក្មេងៗ និងស្ត្រីតាមក្រោយ"]។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.៩០ KH 00955717 ["ពួកគេសម្លាប់ទាំងកូនក្មេងផងដែរ។"]។

[2567] ឯកសារ D6.1.134 កំណត់ហេតុស្តាប់ចម្លើយ ដួង សូ KH 00242403 ["ពួកខ្មែរក្រហម [...] ឲ្យរៀបជាជួរ ដោយមានចងដៃ [ប្រជាជនមកពីខេត្តស្វាយរៀង និងព្រៃវែង]"]។

បាញ់ ប៉ុន្តែនៅរស់ ត្រូវបានបាញ់ម្តងទៀតក្នុងរណ្តៅ[2568] ឬបានគេយកឡានបើកជាន់ពីលើរហូតដល់ស្លាប់[2569]។ ប្រជាជនជម្លៀសផ្សេងៗទៀតត្រូវបានសម្លាប់ដោយការវាយដំ ឬរុះយកប្រមាត់ និងអារក ឬវាយបំបែកក្បាល[2570]។

697. បន្ទាប់ពីសម្លាប់រួច កម្មាភិបាលខ្មែរក្រហមបានបង្ខំអ្នកភូមិនៅក្នុងតំបន់នោះឲ្យយករទេះគោដឹកសាកសពទៅកប់ក្នុងរណ្តៅកប់សាកសពរួមក្នុងភូមិកូនត្នោត[2571]។ ឈួន ហុក ត្រូវបានបង្ខំរួមជាមួយនឹងក្រុមរទេះគោផ្សេងទៀតរបស់ទាហានចំនួន ៦០ នាក់ឲ្យដឹកសាកសពចំនួន ២.០០០ នាក់

[2568] ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ["បើសិនជនរងគ្រោះ មិនទាន់ស្លាប់ ពួកខ្មែរក្រហមបានប្រមូល និងសម្លាប់ចោលនៅក្នុងរណ្តៅ"]។

[2569] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ើន ដារ៉ា ឆ.៩៦ KH 00973956 ["ក្រោយពីពេលបាញ់សម្លាប់ មានអ្នកខ្លះមិនទាន់ស្លាប់ទេ ខ្មែរក្រហមបានបើកឡានកិនសម្លាប់បន្ថែមតែម្តង"]។

[2570] ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ["សាកសពមួយចំនួន ត្រូវបានបាញ់សម្លាប់ សាកសពខ្លះ ត្រូវរុះពោះ ហើយសាកសពខ្លះត្រូវបានកាប់ដោយពូថៅ។ [...] ប្រជាជនស្វាយរៀងចំនួន៣០នាក់ ត្រូវគេសម្លាប់ដោយប្រើពូថៅវាយចំក្បាល ហើយប្រើកាំបិតកាត់ត្រង់បំពង់ករបស់ជនរងគ្រោះ។"]។ ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៧៧ KH 00982180 ["ក្រោយពេលគេវ៉ៃសម្លាប់"]។ ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារីន ឆ.៨៩ ឆ.៩១ KH 00977114 ["ខ្ញុំបានជួយដាំបាយឲ្យយោធា [...] ខ្ញុំបានឮសម្លេងគេវ៉ៃសម្លាប់មនុស្ស ផ្ទួសៗ"]។

[2571] ឯកសារ D6.1.991 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៨ KH 00485647 ["ខ្ញុំប្រាប់ឲ្យប្រជាជនក្នុងភូមិ [...] ដឹកតាមរទេះយកទៅទម្លាក់ [...] និងកប់នៅភូមិកូនត្នោត ឃុំរំលេច។"]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ ឆ.៦១, ៦៩ KH 01186828-00186829 ["កងទ័ពគេបាញ់ប្រជាពលរដ្ឋនៅហ្នឹង[វត្តរំលេច] [...] ហើយគេយកទៅដាក់នៅរណ្តៅ [...] ជិត[ភូមិ]កូនត្នោត។ [...] ការដឹងនេះអីចេះ ដោយសារយកទៅកប់នៅរណ្តៅហ្នឹង គេនិយាយប្រាប់"]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ៃន ឆ.៥៤ KH 00955685-00955686 ["ទាហានខ្មែរក្រហម [...] គេឲ្យអ្នកភូមិដឹកសពអ្នកទាំងនោះយកទៅដាក់រណ្តៅរួម"]។ ឯកសារ D6.1.134 កំណត់ហេតុស្តាប់ចម្លើយ ដួង ស្ង KH 00242404 ["ស៖ តើបានឃើញរណ្តៅសាកសព និងសាកសពយ៉ាងដូចម្តេចខ្លះ ក្រោយឆ្នាំ១៩៧៩? ឆ៖ ខ្ញុំបានឃើញសាកសពដោយផ្ទាល់ភ្នែកនៅក្នុងរណ្តៅសាកសពពីរនៅក្នុងភូមិកូនត្នោត [...] សាកសពទាំងនោះ ខ្ញុំបានដឹកប្រហែលជាពារទេះ។"]។ ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៧៧ KH 00982180 ["គេសម្លាប់អ្នកស្វាយរៀង ហើយនៅពេលយប់ គេបានដឹកសពយកទៅដាក់នៅភូមិកូនត្នោត។"]។ ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្ហី KH 00273433 ["នៅពេលព្រឹកឡើង ត្រូវហៅអ្នកដឹកជញ្ជូនតាមរទេះ [...] យកទៅកប់នៅភូមិចាម។"]។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.៨៧ KH 00979042 ["ពួកគេ [កម្មាភិបាលខ្មែរក្រហម] ក៏បានឲ្យប្រជាជនដឹកជញ្ជូនសាកសពទាំងអស់នោះទៅដាក់ភូមិចាម"]។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.៩៦ KH 01198095 ["ស. តើលោកដឹងដោយរបៀបណា ថាអ្នកមកពីស្វាយរៀង ព្រៃវែង គេយកទៅសម្លាប់[...]? ឆ.៩៦៖ ខ្ញុំដឹងតាមអ្នកនៅក្នុងកងរទេះ ដែលដឹកខ្មោចពីកន្លែងនោះ ទៅកប់នៅកន្លែងមួយទៀត ដែលមានឈ្មោះថា កូនត្នោត។"]។

ទៅកប់ក្នុងភូមិកូនត្នោត[2572]។ នៅពេលប្រជាជនមូលដ្ឋានបានវិលត្រឡប់ចូលភូមិកូនត្នោតវិញ ពួកគេបានឃើញសាកសព និងផ្នូរមនុស្សជាច្រើនក្នុងភូមិ[2573]។

<u>ការធ្វើទុកបុកម្នេញ</u>

698. ការធ្វើទុក្ខបុកម្នេញត្រូវបានធ្វើឡើងតាមរយៈឧក្រិដ្ឋកម្ម ដែលបានរៀបរាប់ខាងលើប្រឆាំងនឹងប្រជាជនជម្លៀស នៅវត្តច័ន្ទរង្សី និងទីតាំងសម្លាប់មនុស្សនៅជិតៗវត្តនេះ។ ក្រុមនេះត្រូវបានគេតម្រង់ទិសដៅជាពិសេស ពីព្រោះពួកគេគឺជាសមាជិកភាពជាក់ស្តែងរបស់ក្រុមនយោបាយមួយ ឬគឺជាប្រជាជនដែលត្រូវបានចាត់ទុកថាជាសមាជិកភាពនៃក្រុមនយោបាយមួយ[2574]។

v. ឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់នៅក្នុងដីកាចោទប្រកាន់

699. ដោយផ្អែកលើភ័ស្តុតាងដែលបានបញ្ជាក់ខាងលើ ស.ព.អ ស្នើឲ្យធ្វើការចោទប្រកាន់ **យ៉ីម ទិញ** ពីបទឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងវត្តច័ន្ទរង្សី និងទីតាំងសម្លាប់មនុស្សនៅជិតៗវត្តនេះ ជាអាទិ៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់មនុស្ស ការសម្លាប់រង្គាល[2575] និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា។

[2572] ឯកសារ D118/147.1.43 របាយការណ៍នៃគម្រោងស្រាវជ្រាវតុលាការខ្មែរក្រហម រឿងរ៉ាវរបស់ ឈួន ហុក EN 00527087 ។

[2573] ឯកសារ D118/216 កំណត់ហេតុស្តាប់ចម្លើយ ហង្ស ង៉ែត ឆ.៧៧ KH 00982181 ["ក៏បានឃើញខ្លួរមនុស្ស និង សក់"]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ ឆ.២០ KH 00186824 ["ពេលដែលមកវិញ ឃើញសាកសពច្រើន មានផ្នូរច្រើន [...] នៅជិតភូមិកូនត្នោត"]។

[2574] សូមមើល V.ខ.៥.ឃ.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់២ – ទីតាំងសម្លាប់មនុស្សវត្តច័ន្ទរង្សី – ឧក្រិដ្ឋកម្ម – មនុស្សឃាត និង ការសម្លាប់រង្គាល។ សូមមើល VIII.ខ.១.ក ការទទួលខុសត្រូវឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមសហឧក្រិដ្ឋកម្មរួម – គោលនយោបាយខ្ពាំង។ V.ខ.៦.ខ.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់៧ – ទីតាំងសម្លាប់មនុស្សវាលបាក់ចិញ្ចៀន – ឧក្រិដ្ឋកម្ម – មនុស្សឃាត និង ការសម្លាប់រង្គាល។ V.ខ.៦.ក.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់៧ –មន្ទីរសន្តិសុខលេខ៨ – ឧក្រិដ្ឋកម្ម – ការធ្វើទុកបុក្ខម្នេញ។

[2575] សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា ធាតុផ្សំនៃភាពជាទ្រង់ទ្រាយធំចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានគាំទ្រដោយផ្អែកលើភស្តុតាងនៅវត្តច័ន្ទរង្សីតែមួយគត់។ ជាជម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញាអន្តរជាតិប្រកាន់ជំហរថា នៅពេលពិចារណាទៅលើធាតុផ្សំនៃភាពជាទ្រង់ទ្រាយធំ ដែលតម្រូវឲ្យបង្ហាញការសម្លាប់រង្គាល គេគួរផ្តល់ស្ថានទម្ងន់ដល់ការសម្លាប់នៅតាមបណ្តាមន្ទីរសន្តិសុខ ទីកន្លែងសម្លាប់មនុស្ស និងការដ្ឋានការងារដោយបង្ខំទាំងអស់ រួមទាំងទីកន្លែងសម្លាប់មនុស្សវត្តច័ន្ទរង្សី។ រាល់ទីតាំងទាំងអស់ដែលបានបង្កើតជាផ្នែកនៃប្រព័ន្ធរៀបចំតែមួយ ដើម្បីអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ

ង. អំពើហិង្សាផ្លូវភេទក្នុងស្រុកបាកាន

i. សេចក្ដីផ្ដើម

700. នៅក្នុងឆ្នាំ១៩៦៨ ប.ក.ក បានបង្កើតសីលធម៌ ១២ ប្រការ ដែលគេបានប្រកាន់យកជា "ក្រឹត្យវិន័យរបស់បក្ស" ដែលណែនាំឲ្យ "ជនបដិវត្តគ្រប់រូប ត្រូវតែគោរព អនុវត្តតាមគ្រប់ ខ" ដើម្បីកសាងខ្លួនឲ្យទៅជា "ជនបដិវត្តល្អបរិសុទ្ធ"[2576]។ សីលធម៌ទាំងនេះ បានកើតមានជាយូរមកហើយតាំងពីមុនកើតបក្ស និងបានបន្តចូលមកក្នុងថិរវេលារបស់កម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថា ក្រមសីលធម៌ទាំង១២ សម្រាប់យុទ្ធជន[2577]។ ក្នុងចំណោមទាំង១២ប្រការ មានក្រម # ៦ ដែលត្រូវបានគេលើកយោងញឹកញាប់ជាងគេ ថាជា "វិធានប្រឆាំងកំហុសសីលធម៌"។ ប្រការលេខ ៦ នេះ បង្ហាប់ថា៖

> **ពុំប្រព្រឹត្តអ្វីដែលឈ្មើសនឹងស្ត្រីភេទឲ្យសោះ**
>
> និយាយរួម គឺកុំប៉ះពាល់សីលធម៌នារីបុរសឲ្យសោះ។ ព្រោះបញ្ហានេះ វានាំឲ្យប៉ះពាល់កិត្តិយសយើង ឥទ្ធិពលយើងជាជនបដិវត្ត នាំឲ្យប៉ះពាល់ដល់ប្រពៃណីស្អាតស្អំ ផ្ទៃផ្ទ្ធរបស់ប្រជាជនយើង។ [...] តែសំខាន់ម្យ៉ាងទៀត គឺបើយើងប៉ះពាល់សីលធម៌នារីបុរស ដែលជាធាតុពិតពុករលួយស្អុយគគ្រុករបស់ខ្មាំងសត្រូវគ្រប់ប្រភេទនោះ និងនាំឲ្យខ្មាំងអូសទាញយើងបាន។ ដូច្នេះ គ្រោះថ្នាក់ដល់ខ្លួន គ្រោះថ្នាក់ដល់ចលនាបដិវត្ត។
>
> ចំពោះ បញ្ហារៀបចំគ្រួសារបច្ចុប្បន្ននេះ គ្មានអ្វីជាឧបសគ្គទេ ឲ្យតែឈរលើគោលការណ៍របស់បក្សទាំងពីរយ៉ាងគឺ៖
>
> ទី១ . សាមីខ្លួនទាំងសងខាង យល់ព្រម

និងសម្ងាប់ខ្មាំង ហើយនឹងការសម្ងាប់នៅតាមទីតាំងនីមួយៗ ត្រូវបានសម្រួលដោយពាក្យសំដី និងសកម្មភាពដដែលៗរបស់ យ៉ីម ទិត្យ។

[2576] ឯកសារ D219/370.1.15 *យុវជន និង យុវនារី បដិវត្ត* ចុះខែតុលា ឆ្នាំ១៩៧៨ KH 00376487។

[2577] ឯកសារ D219/370.1.15 *យុវជន និង យុវនារី បដិវត្ត* ចុះខែតុលា ឆ្នាំ១៩៧៨ KH 00376488-89។

ទី២ . សមូហភាព យល់ព្រម ក៏ជាការស្រេចទៅហើយ។ តើមានហេតុផលអី នាំឲ្យយើងប៉ះពាល់ សីលធម៌នារីបុរស[2578]។

701. ស.ព.អ សន្និដ្ឋានថា គោលដៅនៃសីលធម៌ក្នុងការរក្សាកម្មាភិបាលបដិវត្តឲ្យ "បរិសុទ្ធ" កុំឲ្យចាញ់បញ្ឆោត "ខ្ទាំង" និងលក្ខខណ្ឌតម្រូវឲ្យសមូហភាពត្រូវតែយល់ព្រមជាមុន មុនពេលត្រូវរៀបចំឲ្យនរណាម្នាក់មានគ្រួសារនោះ នេះជាការបង្ហាញឲ្យឃើញថា មុខនាទីដ៏ចម្បងនៃ ក្រម # ៦ គឺដើម្បីហាមឃាត់ទំនាក់ទំនងផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ដែលរដ្ឋបានដាក់ទណ្ឌទណ្ឌ។ គោលដៅនេះ គឺដើម្បីរៀបចំកម្មាភិបាលដែលមានចិត្តស្មោះ ឲ្យមានគូស្រករជាមួយដៃគូដែលមានចិត្តគំនិតស្រដៀងគ្នា ដើម្បីធ្វើឲ្យក្រឹត្យវិន័យ ប.ក.ក កាន់តែជ្រួតជ្រាប។ សម្ព័ន្ធភាពក្រៅពីបក្សបានអនុមតិ គឺ "គ្រោះថ្នាក់សម្រាប់ចលនាបដិវត្ត" ដូច្នេះ វិន័យនេះមិនត្រូវបានអនុវត្តចំពោះតែកម្មាភិបាលប៉ុណ្ណោះទេ ប៉ុន្តែក៏អនុវត្តចំពោះជនស៊ីវិលផងដែរ។ មានឧទាហរណ៍ជាច្រើននៅក្នុងសំណុំរឿងបង្ហាញថា បុរសស្រី ត្រូវបានគេធ្វើទណ្ឌកម្មចំពោះការប្រព្រឹត្ត "កំហុសសីលធម៌" ដោយសារការរួមភេទ ឬទំនាក់ទំនងស្នេហាក្រៅអាពាហ៍ពិពាហ៍។ ម្យ៉ាងវិញទៀត នៅស្រុកបាកាន មានការអនុវត្តរបបពីរ - ក្រម # ៦ ត្រូវបានអនុវត្តយ៉ាងតឹងរ៉ឹងប្រឆាំងនឹងប្រជាជនស៊ីវិល ប៉ុន្តែចំពោះកម្មាភិបាលរបស់បក្សខ្លួនឯងវិញ ការរំលោភស្ត្រីតាមរយៈអំពើរំលោភសេពសន្តវ: និងអំពើហិង្សាផ្លូវភេទ ភាគច្រើនមិនត្រូវបានគេផ្តន្ទាទោសឡើយ។

702. ការរកឃើញដោយការសិក្សាមួយ ដែលបានបោះពុម្ពផ្សាយដោយក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជាក្នុងឆ្នាំ២០១១ បង្ហាញថា អំពើរំលោភសេពសន្តវ:ដោយកម្មាភិបាលខ្មែរក្រហម គឺជានិន្នាការដ៏រីករាលដាលមួយនៅក្នុងអំឡុងនៃសម័យកាលកម្ពុជាប្រជាធិបតេយ្យ ជាពិសេសក្នុងតំបន់ដូចជា ខេត្តពោធិ៍សាត់ជាដើម ដែលការសម្លាប់រង្គាលបានកើតឡើងនៅជិតចុងបញ្ចប់នៃរបប។ អ្នកឆ្លើយក្នុងការសិក្សានេះស្ទើរតែពីរភាគបី "បានដឹងពីអំពើរំលោភសេពសន្តវ: ដែលបានប្រព្រឹត្តដោយភ្នាក់ងារខ្មែរក្រហម" និង ២៨.៨ ភាគរយ បានឃើញអំពើរំលោភសេពសន្តវ:នៅក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ[2579]។ នៅក្នុងព្រឹត្តិការណ៍ទាំងអស់នោះ មានករណីនៃអំពើហិង្សាផ្លូវភេទមួយត្រូវបានគេរាយការណ៍នៅក្នុងការសិក្សានោះ ដែលជនប្រព្រឹត្តត្រូវបានគេកំណត់អត្តសញ្ញាណថាជា

[2578] ឯកសារ D219/370.1.15 *យុវជន និង យុវនារី បដិវត្ត* ចុះខែតុលា ឆ្នាំ១៩៧៨ KH 00376493-94។

[2579] ឯកសារ D310/1.1.5 Katrina Natale *ខ្ញុំអាចមានអារម្មណ៍ថា ព្រលឹងខ្ញុំកំពុងតែហោះចេញពីខ្លួនខ្ញុំ* EN 00992119, 44-45 ។

ភ្នាក់ងារខ្មែរក្រហម ប៉ុន្តែជនប្រព្រឹត្តកម្រនឹងត្រូវបានគេផ្តន្ទាទោសណាស់[2580]។ សំខាន់ជាងនេះទៀតការសិក្សាបានរកឃើញថា អំពើរំលោភសេពសន្តវ:យ៉ាងរង្គាលបានកើតឡើងនាពេលក្រោយមកនៅក្នុងរបបនេះក្នុងពេលនៃការបោសសម្អាតប្រជាជននៅក្នុងខេត្តពោធិ៍សាត់ ខេត្តស្វាយរៀង និង ខេត្តព្រៃវែង ដែលនេះបានឲ្យដឹង "ថាទីតាំងប្រជាសាស្ត្រមួយចំនួន ស្ថានភាពនយោបាយ និងថ្នាក់ដឹកនាំនៅតំបន់នោះ អាចមានឥទ្ធិពលយ៉ាងសំខាន់ចំពោះអ្វីដែលអំពើហិង្សាផ្លូវភេទ បានកើតឡើង" និងបង្ហាញឲ្យឃើញ "ថា អំពើហិង្សាផ្លូវភេទត្រូវ<u>បានគេដឹងឮ</u> និង<u>ត្រូវបានអត់ឱន</u> យ៉ាងហោចណាស់ក៏នៅក្នុងផ្នែកខ្លះរបស់ប្រទេស និងក្នុងកាល:ទេស:ជាក់លាក់ណាមួយដែរ"[2581]។

703. ជាការពិតណាស់ថា នេះគឺជាករណីដែលបានកើតមាននៅក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់។ ក្នុងអំឡុងពេលដែល **យ៉ីម ទិព្ធ** ជាសមាជិកដឹកនាំម្នាក់នៃសហឧក្រិដ្ឋកម្មរួម (JCE) នៅភូមិភាគពាយ័ព្យអំពើរំលោភសេពសន្តវ: និងអំពើហិង្សាផ្លូវភេទប្រឆាំងស្ត្រីភេទនៅក្នុងស្រុកបាកាន គឺជារឿងដ៏រីករាលដាល។ កម្មាភិបាលប្រុសក្មេងៗដែលគ្មានដៃគូផ្លូវភេទ ត្រូវបានគេប្រាប់ថា មនុស្សគ្រប់ប្រភេទទាំងអស់គ្មានសិទ្ធិអ្វីទាំងអស់ និងសមតែទទួលបានការធ្វើបាបដោយអមនុស្សធម៌។ ខណៈពេលដែលពួកគេបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ JCE ពួកកម្មាភិបាលទាំងនោះបានឆក់យកឱកាសជាគុណសម្បត្តិចំពោះមុខនាទីនៃអំណាចរបស់ខ្លួនលើស្ត្រីភេទ និងបានរំលោភសេពសន្តវ:ស្ត្រីទាំងនោះដោយនិទណ្ឌភាព។ អ្វីដែលជាវិនាសកម្មបំផុតនោះ គឺឧក្រិដ្ឋកម្មនៃអំពើបៀតបៀនផ្លូវភេទ និងអំពើរំលោភសេពសន្តវ:ដែលជាទូទៅ គឺជាកត្តាកំណត់មុនដល់ការស្លាប់សម្រាប់ជនរងគ្រោះភាគច្រើន ជាការធានាចំពោះអនាមិកភាពសម្រាប់ជនប្រព្រឹត្ត។ ខណៈដែលមិនមែនគ្រប់ស្ត្រីទាំងអស់ដែលគេបានរំលោភ សុទ្ធតែត្រូវបានសម្លាប់ក៏ពិតមែន តែនេះគឺជានិន្នាការមួយដែលបានកើតឡើងផ្ទួនៗ។

704. ភ័ស្តុតាងនៅក្នុងសំណុំរឿងចង្អុលបង្ហាញថា អាជ្ញាធរក្នុងស្រុកបាកាន ដែលជាអ្នករួមចំណែកដល់ JCE ជាមួយនឹង **យ៉ីម ទិព្ធ** បានដឹងថា អំពើរំលោភសេពសន្តវ:កំពុងតែកើតឡើង ប៉ុន្តែខ្លួនខកខានមិនបានការពារស្ត្រីងាយរងគ្រោះទាំងនោះ ឬក៏ផ្តន្ទាទោសចំពោះកម្មាភិបាលដែលបានប្រព្រឹត្តអំពើរំលោភសេពសន្តវ:នោះ។ ក្នុងអំឡុងពេលនោះ ពេលដែលមនុស្សភាគច្រើនមានការប្រុងប្រយ័ត្ន

[2580] ឯកសារ D310/1.1.5 Katrina Natale *ខ្ញុំអាចមានអារម្មណ៍ថា ព្រលឹងខ្ញុំកំពុងតែហោះចេញពីខ្លួនខ្ញុំ* EN 00992121, 61-63 ។

[2581] ឯកសារ D310/1.1.5 Katrina Natale *ខ្ញុំអាចមានអារម្មណ៍ថា ព្រលឹងខ្ញុំកំពុងតែហោះចេញពីខ្លួនខ្ញុំ* EN 00992121 (គូសបញ្ជាក់បន្ថែម) EN 00992147-48, 63-64 ។

ចំពោះអ្វីៗគ្រប់យ៉ាងដែលគេបាននិយាយដើម្បីកុំឲ្យមាន"កំហុស"រហូតដល់មានការផ្តន្ទាទោសនោះ ជនប្រព្រឹត្តនៅក្នុងស្រុកបាកាន កំពុងតែចំអកឡកឡឺយចំពោះក្រម # ៦ និងអួតក្អេងក្អាងជាចំហពីឧក្រិដ្ឋកម្មផ្ទួរភេទរបស់ខ្លួនទៅវិញ[2582]។ មានមេដឹកនាំជាច្រើនដែលស្ថិតនៅក្នុងតួនាទីនៃសិទ្ធិ

[2582] ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ី ឆ.៩៩-១០២ KH 01186832 [សាក្សីរស់នៅក្នុងភូមិខ្នារទទឹង និងឃុំរំលេច (*សូមមើល ឆ.៣៦-៣៧*) ក្នុងស្រុកបាកាន នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ៖ "ខ្មែរក្រហមហ្នឹងគឺពួកថា មុននឹងយកទៅសម្លាប់គឺគេយកទៅសម្រាត យកទៅរំលោភ ប៉ុន្តែយើងមិនបានឃើញផ្ទាល់ភ្នែកអីទេ ប៉ុន្តែឮសុះសាយតែម្តង "អំពីរំលោភមុនសម្លាប់ហ្នឹង"។ [...] បញ្ហារឿងនេះ គឺឮសុះសាយតែម្តង ក្នុងសហករណ៍ពេញហ្នឹង ភាគច្រើនគេនិយាយ។ [...] ជំនាន់ប៉ុល ពត ហ្នឹងគេដឹង តែអត់មានវិធានការទប់ស្កាត់អីទេ។ អ្នកដឹកនាំគេហ្នឹងដឹង ព្រោះឮតែទាំងអស់គ្នាអីចឹងទៅហើយ។ [...] ។ ដឹងហ្នឹងគឺច្រើន ដោយសារអ្នករំលោភគេហើយហ្នឹងដើរអួត ដើម្បីគម្រាមអ្នកនៅសេសសល់"]។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង អេង ឆ.៨១, ៨៣-៨៤, ៨៨ KH 00996449-50 [សាក្សីត្រូវបានគេបញ្ជូនទៅភូមិកំប្រាក់ក្ងន ក្នុងស្រុកបាកាន ជាមួយខ្មែរក្រោមដទៃទៀត នៅក្នុងខែកក្កដា ឬ សីហា ឆ្នាំ១៩៧៨ ហើយការសម្លាប់បានចាប់ផ្តើមនៅខែបន្ទាប់ (*សូមមើល* ឆ.៥៧-៦៥, ៧៦)៖ "ខ្ញុំឮអ្នកសម្លាប់មនុស្សជជែកគ្នា។ [...] ។ ខ្ញុំឮពួកគេនិយាយថា មនុស្សស្រីស្អាត និងក្រមុំត្រូវគេរំលោភរហូត ទាល់តែអស់ចិត្ត ហើយទើបសម្លាប់ដាក់ក្នុងរណ្តៅជាក្រោយ។ [...] ខ្ញុំនៅកន្លែងដែលពួកគេជជែកគ្នានោះតែម្តង តែខ្ញុំធ្វើតែមិនដឹង មិនឮពេលដែលពួកគេជជែកគ្នា។ [...] ខ្ញុំបានឮពួកគេជជែកគ្នាច្រើនដងអំពីការរំលោភសម្លាប់នេះ"]។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៦៧-៦៨, ៧០-៧២, ៧៤-៧៥ KH 00985421-22 [នៅភូមិបាក់ម៉ែក ជាកន្លែងដែលអ្នកដាក់ពាក្យធ្វើការ គាត់បានឮអ្នកដែលវ៉ៃសម្លាប់ខ្មែរក្រោមនៅទួលសេះញ៉ូ៖ "ពួកគេនិយាយចំអន់គ្នាថា "អ្នែងធ្វើខ្ញោចងាប់"។ តាមពិតគឺពួកគេរំលោភនារីរងគ្រោះហើយ ទើបសម្លាប់។ [...] ពួកគេបាននិយាយចំអន់គ្នាដូច្នេះ"]។ ឯកសារ D118/234 កំណត់ហេតុស្តាប់ចម្លើយ ទុំ ង៉ា ឆ.៦០-៦១ KH 00987981 [ក្នុងឆ្នាំ១៩៧៧-១៩៧៨ (*សូមមើល* ឆ.៥៧)៖ "ខ្ញុំធ្លាប់ឮតែអ្នកខុសសីលធម៌ត្រូវគេដាក់នៅគុកត្រាចក្រោល។ ខ្ញុំឮអ្នកដែលសម្លាប់មនុស្សនិយាយថា មុននឹងសម្លាប់មនុស្ស ពួកគេរំលោភមនុស្សស្រីហើយទើបសម្លាប់។ ពួកគេនិយាយលេងនិយាយសើចសប្បាយជាមួយនឹងគ្នាថា "អញធ្វើវាហើយ ទើបអញវ៉ៃវា មីណាស្អាតៗ ធ្វើវាចាំយកទៅសម្លាប់"។ [...] ។ ពួកគេគឺជាឈ្លូប"]។ ឯកសារ D118/198 កំណត់ហេតុស្តាប់ចម្លើយ ឈឹម ស្រ៊ិន ឆ.៤៥-៤៦, ៤៩ KH 00978983-84 [ពេលដែលសាក្សីកំពុងតែធ្វើការនៅអង្គភាពដឹកជញ្ជូននៅភូមិស្ទឹងកំបុត ឃុំត្រពាំងជង ស្រុកបាកាន (*សូមមើល* ឆ.២០, ៥៤)៖ "ឈ្លូបពីរនាក់ជិះបរទេះខ្ញុំ ហើយពួកគេក៏បានជជែកគ្នាអំពីនារីបួព៉ាស្អាតម្នាក់ត្រូវពួកគេចាប់រំលោភ ហើយក៏សម្លាប់ចោល។ រឿងនេះកើតឡើងប្រហែលជាចុងឆ្នាំ១៩៧៨។ [...] ខ្ញុំគ្រាន់តែឮពួកឈ្លូបជជែកគ្នាប៉ុណ្ណោះ។ [...] ។ ពួកគេនិយាយថា "យប់មិញបានយកពួកបួព៉ាទៅសម្លាប់នៅពេលទៀបភ្លឺ ហើយបានរំលោភនារីស្អាត""]។ ឯកសារ D118/228 កំណត់ហេតុស្តាប់ចម្លើយ ម៉ង ឆុន ឆ.៥០-៥៤, KH 00985449-50 [តាសឹប បានប្រាប់ដើមបណ្តឹងរដ្ឋប្បវេណីថា៖ "មីមួយនោះ ស្អាតណាស់អ្ហា! អញយកបូស្សីបុកទ្វារមាសវាហើយនៅតែស្អាតទៀត' [...] តាសឹប បន្តថា ពេលដែលគាត់រះយកប្រមាត់បី [ពីមនុស្សបីនាក់] [រួមទាំងរបស់ស្រីស្អាតម្នាក់នោះផង] ជងរងគ្រោះពុំទាន់ស្លាប់នោះទេ។ [...] ខ្ញុំមិនស្គាល់ទេ តែខ្ញុំដឹងថាគាត់ជាអ្នកមកពីស្វាយរៀង។ [...] [វាកើតឡើង] ប្រហែលជាខែ១១ ឆ្នាំ១៩៧៨។ [...] ពេលនោះខ្ញុំធ្វើការនៅកន្លែងចង្ក្រានបាយ ហើយពួកគេនិយាយគ្នាឮៗតែម្តង។ ពួកខ្លះពួកគេបានយកកាំបិតមកជន្ទខ្ញុំទៀតផង ហើយពេលខ្លះទៀតពួកគេនិយាយថា"បើមិនយកប្តីទេ ប្រយ័ត្នណា! មើលកាំបិតនេះ!' [...] តាសឹប ជាគណៈសហករណ៍អ្នកតាទ្វារ"]។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.៦៧-៧០ KH 00955771-72។

អំណាចបានកំពុងតែប្រព្រឹត្តអំពើរំលោភសេពសន្ធ:ដោយខ្លួនឯង ហើយសូម្បីតែអ្នកមិនបានរំលោភ (ដូចជាលេខាស្រុកស្រី ឈ្នោះយាយ រីម) ក៏មិនបានចាត់វិធានការនោះដែរ[2583]។ នេះគឺជាការបង្ហាញសញ្ញាដល់ជនប្រព្រឹត្តដោយផ្ទាល់ថា ឧក្រិដ្ឋកម្មដូច្នេះនឹងត្រូវបានអត់ឱន។ ដូច្នេះ នៅថ្ងៃក្រោយមកនៃរបបពេលដែលក្រុមជនស៊ីវិលជាច្រើនត្រូវបានសម្លាប់ ដែលជាផ្នែកនៃផែនការកម្ទេចជនណាដែលគេយល់ថា ខ្មាំងនោះ កម្មាភិបាលជាច្រើនក្នុងស្រុកបាកាន បានជ្រើសរើសយកតែស្ត្រីស្អាតៗប៉ុណ្ណោះសម្រាប់អំពើហិង្សាផ្លូវភេទ មុននឹងសម្លាប់ពួកគេ។ ញ្ជ្រីកញ្ជាប់ជាងគេនោះគឺស្ត្រីខ្មែរក្រោម និងស្ត្រីភូមិភាគ ឬព័ាបានក្លាយជាជនរងគ្រោះនៃអំពើរំលោភសេពសន្ធ: ប៉ុន្តែអ្នកទោសស្ត្រីតាមមន្ទីរសន្តិសុខនានានិងស្ត្រីផ្សេងទៀតដែលត្រូវបានចាត់ទុកថាជាខ្មាំង ឬដែលគេយល់ថា មានជាប់ពាក់ព័ន្ធជាមួយខ្មាំងក៏ត្រូវបានគេរំលោភផងដែរ។

705. ក.ស.ច.ស បានទទួលបណ្តឹងអំពីបទចោទនៃអំពើហិង្សាផ្លូវភេទ រួមទាំង អំពើរំលោភសេពសន្ធ: ប្រឆាំងខ្មែរក្រោម អ្នកជម្លៀសមកពីភូមិភាគឫព័ា និង "ខ្មាំង បកក ឬ ក្រុមគោលដៅផ្សេងទៀត"

[2583] *សូមមើលឧទាហរណ៍* ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ូន ឆ.១៥០-១៥៤ KH 01176420-21 [សាក្សី ធ្លាប់ធ្វើការឲ្យយាយ រីម ពេលយាយរីម ធ្វើជាលេខាស្រុក (*សូមមើល* ឯកសារ D219/842 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ូន ឆ.៣១, ៣៦-៣៨ KH 01335673-74) ហើយបាននិយាយថា យាយរីម បានឮគេប្រាប់ថា អ្នកណាស្អាតៗត្រូវបានពួកឈ្លបវាំរំលោភ។ យាយរីម ក៏បានប្រាប់គាត់ដែរថា "អ្នកណាស្អាតៗវាំរំលោភហើយបានសម្លាប់ បើមិនអីចឹងស្តាយ"។ *សូមមើល* ជាពិសេស៖ "ស៖ នៅពេលដែលឈ្លបប្រាប់យាយរីម អំពីរឿនេះ តើពេលនោះ លោកស្រីមានវត្តមានដែរឬទេ? ឆ.១៥៤៖ ខ្ញុំនៅ គាត់ចេះតែអឺអើៗទៅ គាត់អត់មានថាអីផង"] *ប៉ុន្តែ សូមមើល* ឆ.១៥៨ KH 01176421 និង ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ឆ.៧២-៧៧ KH 01348868-69 [យាយរីម បដិសេធការដឹងអំពីការកើតឡើងនៃការរំលោភសេពសន្ធ:ស្រីស្អាតៗពីខេត្តស្វាយរៀង និងព្រៃវែង]។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ ឆ.១០១-១០២ KH 01186832 [សាក្សី រស់នៅក្នុងភូមិខ្ទារទទឹង និងឃុំរំលេច (*សូមមើល* ឆ.៣៦-៣៧) ក្នុងស្រុកបាកាន នៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ៖ "ជំនាន់ប៉ុល ពតហ្នឹងគេ[អាជ្ញាធរ]ដឹង[អំពីអំពើហិង្សាប្រឆាំងស្ត្រី និងកុមារ] តែអត់មានវិធានការទប់ស្កាត់អីទេ។ អ្នកដឹកនាំគេហ្នឹងដឹង ព្រោះពួកគេទាំងអស់គ្នាអីចឹងទៅហើយ។ [...] ឆ.១០២៖ ដឹងហ្នឹងគឺច្រើនដោយសារអ្នករំលោភគេហើយហ្នឹងដើរអ្ហត"]។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួរ ឆ.១១៣, ១១៦ KH 00955721។ ឯកសារ D118/228 កំណត់ហេតុស្តាប់ចម្លើយ ម៉ង ឆុន ឆ.៥០-៥៤ KH 00985449-50 [តាសឹប ដែលជាគណ:សហការណ៍អ្នកតាទ្វារ បានប្រាប់អ្នកដាក់ពាក្យសុំ និងអ្នកផ្សេងទៀតជាចំហរអំពីការយកឫស្សីបុកទ្វារមាសស្រីស្អាតម្នាក់មកពីស្វាយរៀង និងការកាត់យកប្រមាត់នាង និងមនុស្សពីរនាក់ផ្សេងទៀតក្នុងខណ:ដែលជនរងគ្រោះនៅរស់នៅឡើយ]។ *សូមមើលផងដែរ* ឯកសារ D219/676 កំណត់ហេតុស្តាប់ចម្លើយ ហុក សារិន ឆ.១២៨-១៤០ KH 01202413-15 [នៅក្នុងសហការណ៍ត្រពាំងជងក្នុងឆ្នាំ១៩៧៨ ឬ ពាក់កណ្តាលឆ្នាំ១៩៧៨ (*សូមមើល* ឆ.១១២, ១១៥) កម្មាភិបាលជាន់ខ្ពស់ខ្មែរក្រហមបានបំបែកស្ត្រីស្អាតៗមកពីឫព័ាចេញ ហើយទុកពួកគេសម្រាប់រំលោភ]។

នៅក្នុងស្រុកបាកាន[2584] ប៉ុន្តែ ក.ស.ច.ស មិនទាន់បានចោទប្រកាន់ **យ៉ីម ទិព្យ** ចំពោះឧក្រិដ្ឋកម្មនេះ នៅឡើយ[2585]។

ii. ឧក្រិដ្ឋកម្ម

<u>អំពើហិង្សាផ្លូវភេទប្រឆាំងស្ត្រីខ្មែរក្រោម និងស្ត្រីភូមិភាគបូព៌ា</u>

706. ក្នុងអំឡុងពេលដែល **យ៉ីម ទិព្យ** ជាសមាជិកដឹកនាំម្នាក់នៃសហឧក្រិដ្ឋកម្មរួម (JCE) នៅភូមិភាគពាយ័ព្យ ស្ត្រីខ្មែរក្រោមនៅក្នុងស្រុកបាកាន ជាញឹកញាប់បានទទួលរងនូវអំពើហោរយៅផ្លូវភេទ មុនពេលពួកគេត្រូវបានសម្លាប់[2586]។ កម្មាភិបាលខ្មែរក្រហម ក៏បានរំលោភសេពសន្ថវៈស្ត្រីស្អាតៗ និង

[2584] ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៧, ១០។

[2585] ស.ច.ស.អ បានផ្តែងអំពីចេតនាមិនចង់ធ្វើកិច្ចស៊ើបសួរបន្ថែមទៀតចំពោះបទចោទទាំងនេះទេ ប៉ុន្តែបន្ទាប់មក បានយល់ស្របដើម្បីបន្ត (*សូមមើល* ឯកសារ D302 សំណើសុំមតិយោបល់ទាក់ទងនឹងការចោទអំពីអង្គហេតុដែលនឹងមិនស៊ើបអង្កេតថែមទៀតទេ ចុះថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦ KH 01212445-50 និងឯកសារ D302/3 សេចក្តីជូនដំណឹងអំពីការផ្អាកកិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់នីមួយៗ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ១, ១៤(គ), ៣២-៣៤)។ *សូមមើលផងដែរ* ឯកសារ D365/3 ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងគុកលេខ៨ និង អំពើហិង្សាផ្លូវភេទនៅក្នុងស្រុកបាកាន ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ៣០, ៥០ និងសំអាងហេតុនៅក្នុងកថាខណ្ឌ ៤០។

[2586] *សូមមើលឧទាហរណ៍* ឯកសារ D6.1.757 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន KH 00385098-99 ["ក្នុងខែកក្កដា ឆ្នាំ១៩៧៨ ប្រធានសហករណ៍បានបញ្ជូនខ្ញុំត្រលប់មកស្ពុកខ្ជា [ក្នុងស្រុកបាកាន] ដើម្បីធ្វើស្រែម្តងទៀត។ [...] នៅក្នុងសហករណ៍ស្ពុកខ្ជា ខ្ញុំបានឮឈ្លបខ្មែរក្រហមនិយាយអំពីការរំលោភនារីខ្មែរកម្ពុជាក្រោមម្នាក់ ហើយខ្ញុំបានឃើញសាកសពរបស់នាងនៅលើភ្លឺស្រែ ចម្ងាយប្រហែល៧០០ម៉ែត្រពីសហករណ៍ស្ពុកខ្ជា"]។ *អានភ្ជាប់ជាមួយ* ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.ខ៧-៧០ KH 00955771-72 ["ខ្ញុំធ្លាប់ឃើញ[ករណីរំលោភសេពសន្ថវៈ]ម្តងនៅស្ពុកខ្ជា។ [...] ខ្ញុំបានឮតែសម្រែកប៉ុណ្ណោះ ដោយនារីម្នាក់នោះស្រែកថា "ជួយផង! កុំរំលោភអញ! កុំរំលោភអញ បើសម្លាប់ក៏សម្លាប់ទៅ"។ បន្ទាប់មកព្រឹកឡើងខ្ញុំបានទៅទីនោះ ខ្ញុំក៏បានឃើញនារីម្នាក់នោះស្លាប់។ ឯកសារ D5/60 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ង៉ែត រុធ KH 00562351 ["នៅឆ្នាំ១៩៧៧ ចុងឆ្នាំវាបានប្រមូលបងប្អូនដូនតា ជាខ្មែរកម្ពុជាក្រោមទាំងអស់ពីសហករណ៍រំលេចឲ្យទៅ រស់នៅប្រមូលផ្តុំនៅក្នុងសហករណ៍ខ្នារទទឹង [ក្នុងស្រុកបាកាន]"] *អានភ្ជាប់ជាមួយ* ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៥៣-៥៧ KH 00985419-20 ឆ.៥៩-៦១ KH 00985420 [បីខែបន្ទាប់ពីត្រូវបានបញ្ជូនទៅកាន់សហករណ៍ខ្នារទទឹង ពួកខ្មែរក្រោមត្រូវបានប្រមូលយកទៅសម្លាប់ លើកលែងតែ អ្នកដាក់ពាក្យសុំរូបនេះ ម្តាយ និងបង-ប្អូនរបស់គាត់ ត្រូវបានអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់សហករណ៍វិញ ពីព្រោះម្តាយរបស់គាត់ជាខ្មែរ។ ឪពុករបស់គាត់ និងសមាជិកក្រុមគ្រួសារខ្មែរក្រោមដទៃទៀតត្រូវតែស្នាក់នៅ និងត្រូវបានសម្លាប់នៅទួលសេះញ៉ូ] ឆ.ខ៧-ខ៨, ៧០-៧២, ៧៤-៧៥ KH 00985422 [ពួកអ្នកសម្លាប់បានទៅហូបបាយនៅរោងបាយរួម ជាទីកន្លែងដែលអ្នកដាក់ពាក្យសុំកំពុងធ្វើការ និងកំពុងនិយាយជជែកគ្នាអំពីការសម្លាប់ពួកខ្មែរ

ស្រីក្រមុំពីភូមិភាគបូព៌ាផងដែរ មុនសម្លាប់ពួកគេ[2587]។ ជាអ្នកបញ្ជាឲ្យសម្លាប់ស្ត្រីក្មេងៗទាំងនេះ ពួកពេជ្ឈឃាតកម្រគិតថា ផ្ទាក់លើរបស់ខ្លួនបានយកចិត្តទុកដាក់ចំពោះស្ត្រីដែលត្រូវបានគេរំលោភ ផ្ទួរភេទណាស់។

ក្រោម៖ "ពួកគេនិយាយចំអន់គ្នាថា 'អ្នែងធ្វើខ្ទោចងាប់'។ តាមពិតគឺពួកគេរំលោភនារីរងគ្រោះហើយ ទើបសម្លាប់"]។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង អេង ឆ.៥៧-៦២, ៦៧, ៧៦ KH 00996446-47, 48 [សាក្សីរូបនេះត្រូវបានបញ្ជូនទៅកាន់ភូមិកំប្រាក់ក្ងន ក្នុងស្រុកបាកាន ជាមួយនឹងខ្មែរក្រោមដទៃទៀត ក្នុងខែកក្កដា ឬខែសីហា ឆ្នាំ១៩៧៨ ហើយការសម្លាប់បានចាប់ផ្តើមនៅខែបន្ទាប់ទៀត] ឆ.៨០-៨៤ KH 00996449 [សាក្សីរូបនេះបានឮពួកអ្នកសម្លាប់មនុស្សនិយាយគ្នាអំពីការឲ្យគេសម្រាតខោអាវពួកជនរងគ្រោះ មុននឹងសម្លាប់ពួកគេ ហើយ "ខ្ញុំឮពួកគេនិយាយថា មនុស្សស្រីស្អាត និងក្រមុំត្រូវគេរំលោភរហូតទាល់តែអស់ចិត្ត ហើយទើបសម្លាប់ដាក់ក្នុងរណ្តៅជាក្រោយ។ [...] ខ្ញុំនៅកន្លែងដែលពួកគេជជែកគ្នានោះតែម្តង តែខ្ញុំធ្វើតែមិនដឹង មិនឮពេលដែលពួកគេជជែកគ្នា"] ឆ.៨៧-៨៨ KH 00996450។ ឯកសារ D118/262 កំណត់ហេតុស្តាប់ចម្លើយ ទេព ផុន ឆ.៥២ KH 00997944 [*បញ្ជាក់អះអាងចំពោះពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់* (*សូមមើល* ឯកសារ D191.1.108 ជាសេចក្តីសង្ខេបជាភាសាខ្មែរ ឬ អង់គ្លេស ឯកសារ D191.1.109) ឆ្លើយថា "នៅចុងខែកក្កដា ឆ្នាំ១៩៧៨ មានខ្មែរកម្ពុជាក្រោមរាប់ពាន់នាក់ ដោយរាប់បញ្ចូលនឹងអ្នកជម្លៀសពីស្វាយរៀង ព្រៃវែង និងក្រុមគ្រួសាររបស់[អ្នកពាក្យសុំ] [...] ត្រូវគេយកទៅសម្លាប់នៅស្រះរំដេង"] ឆ.៦១ KH 00997945 [ដោយបញ្ជាក់ថា ស្រះរំដេងស្ថិតនៅក្នុងឃុំតាណោ [ស្រុកបាកាន]] ឆ.៧០-៧២, ៧៤ KH 00997946-47 ["ឆ.៧០៖ [...] ខ្ញុំបានឮរឿងនេះពីអ្នកដែលរត់ចេញពីកន្លែងសម្លាប់មនុស្សនិយាយថា ស្រីៗស្អាតត្រូវគេទុកដើម្បីរំលោភសិន ទើបសម្លាប់។ ស៖ តើអ្នកណាជាអ្នកនិយាយរឿងនេះប្រាប់លោកស្រី? ឆ.៧១ [គាត់][...] ជាមេក្រុមដែលមានកូនក្រុម១០នាក់។ ឆ.៧២៖ [ជនរងគ្រោះនៃអំពើរំលោភសេពសន្ថវ:] ជាខ្មែរក្រោមខ្លះ និងជាអ្នកមកពីស្វាយរៀងខ្លះ។ [...] ឆ.៧៤៖ អ្នកសម្លាប់មនុស្ស គឺជាអ្នករំលោភមនុស្សស្រីទាំងអស់នោះ ហើយប្រហែលជាពួកឈ្លប"]។ ឯកសារ D118/223 កំណត់ហេតុស្តាប់ចម្លើយ គឹម ហួយ ឆ.៤០-៤៣ KH 00985381-82 [ប្អូនជីដូនមួយជាខ្មែរក្រោមរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺជាស្រីស្អាតម្នាក់ក្នុងចំណាមស្រីស្អាតដែលត្រូវបានគេរំលោភ មុនសម្លាប់ នៅក្នុងឆ្នាំ១៩៧៧] *សូមអានអមជាមួយនឹង* ឯកសារ D5/143 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឹម ហួយ KH 00521809 [និយាយថា "ប្អូនស្រី" ត្រូវបានគេបញ្ជូនទៅសហការណ៍ស្ពុកខ្ជា ជាកន្លែងដែល "ពេលមុនសម្លាប់ វារំលោភយ៉ាងព្រៃផ្សៃបំផុត វាកាត់ដោះនិងយោនី ហើយវះពោះរួងយកផ្ទើមមកអារស៊ីទៀតផង"]។

[2587] ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៨៦,៩០, ៩៤ KH 01089007-09 [ក្នុងឃុំតាណោ ស្រុកបាកាន ឆ្នាំ១៩៧៨៖ "អ្នកស្វាយរៀងដែលគេឲ្យទៅធ្វើការនៅសំសាន្ត ត្រូវគេយកទៅសម្លាប់ចោលទាំងអស់។ [...] តាមខ្ញុំស្មានមានប្រហែលពី៣០ ទៅ៤០នាក់ [ត្រូវគេសម្លាប់]។ [...] ភាគច្រើនសុទ្ធតែជាមនុស្សស្រី។ [...] ខ្ញុំឮពីបងៗនៅក្នុងកងផលិតនិយាយថា អ្នកស្វាយរៀងដែលស្អាតៗត្រូវគេចាប់រំលោភជាមុនទើបសម្លាប់ជាក្រោយ [...]។ គេចាប់រំលោភតែអ្នកដែលស្អាតៗទេ។"]។ ឯកសារ D219/243 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ សង ឆ.៣៩-៤០, ៤៦-៤៨, ៥៣-៥៨ KH 01080946-50 [នៅក្នុងការសម្លាប់ក្នុងឆ្នាំ១៩៧៨ ទ្ធូវអ្នកជម្លៀសមកពីភូមិភាគបូព៌ាជាង២០០នាក់ នៅទួលប្រាហូត (ហៅ ទួលបង្ហូត) ក្នុងស្រុកបាកាន៖ "ឆ.៥៣៖ [...] អ្នកសម្លាប់គឺពួកវាសប្បាយអស់ចិត្តជាមួយនឹងនារីក្មេងៗស្អាតៗហើយ ទើបយកទៅសម្លាប់។ ស៖ ពាក្យថា 'សប្បាយអស់ចិត្ត' តើលោកចង់មានន័យដូចម្តេច? ឆ.៥៤៖ មានន័យថា ពួកគេយកក្មេងៗស្ត្រីក្រមុំយកទៅរំលោភលេងម្នាក់ម្ន

ឃ១ៗអ៊ីចឹងទៅ ហើយរំលោភអស់ចិត្ត ទើបគេយកទៅវ៉ៃចោល។ [...] ឆ.៥៥៖ [...] ឈ្មោះ គង់ (ស្លាប់) ជាអ្នកនិយាយប្រាប់ខ្ញុំ។ ពេលដែលធ្វើការជាសេនាជនជាមួយខ្ញុំនៅឆ្នាំ១៩៧៩ ក្រោយរបបខ្មែរក្រហម។ [...] [គាត់] បណ្តើរមនុស្សទៅជាមួយនឹងគេដែរ ហើយគេឲ្យ [គាត់នារីម្នាក់] ដែរយកទៅរំលោភ។ [...] ឆ.៥៦៖ [...] គឺរំលោភម្នាក់មួយ១ៗ។ [...] ឆ.៥៨៖ គេចាប់ផ្តើមរំលោភ នៅប្រហែលម៉ោង៧ ឬម៉ោង៨ ហើយរំលោភអស់ចិត្តទើបយកទៅវ៉ៃចោល។"]។ ឯកសារ D118/248 កំណត់ហេតុស្តាប់ចម្លើយ លី លន់ ឆ.៦៦-៧០, ៧៨ KH 00990692-93 [នៅចុងឆ្នាំ១៩៧៨ ឬដើមឆ្នាំ១៩៧៩ សាក្សីបានឃើញសាកសពមនុស្សមកពីភូមិភាគបូព៌ា "រាប់មិនអស់" នៅទួលពង្រ ដែលពេលនោះស្ថិតនៅក្នុងស្រុកបាកាន] ឆ.៩០-៩១, ៩៤-៩៥ KH 00990695 ["ស៖ តើលោកដឹងអំពីករណីចាប់រំលោភលើមនុស្សស្រីមុននឹងសម្លាប់ដែរឬទេ? ឆ.៩០៖ ខ្ញុំឮគេនិយាយប្រាប់ខ្ញុំអំពីរឿងនេះដែរ។ ដំបូងគេរំលោភមនុស្សស្រីហើយ ទើបគេសម្លាប់។ [...] ឆ.៩១៖ ខ្ញុំឃើញនៅទួលពង្រ។ [...] ឆ.៩៤៖ ខ្ញុំឃើញដោយផ្ទាល់ភ្នែករបស់ខ្ញុំ។ [...] ឆ.៩៥៖ [...] ខ្ញុំ [ឃើញ] សាកសពមនុស្សស្រីដែលត្រូវគេរំលោភផ្សេងទៀត ជួនកាលខ្ញុំឃើញសាកសពមនុស្សស្រីត្រូវបានគេសម្រាតខោស្លីបមកដាក់ត្រឹមកជើង ហើយដោះខោអាវចេញទាំងអស់ ហើយមានស្នាមអារកទៀតផង។"]។ ឯកសារ D118/262 កំណត់ហេតុស្តាប់ចម្លើយ ទេព ផុន ឆ.៥២៖ KH 00997944 [*បញ្ជាក់*ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរបស់គាត់ (*សូមមើល* សេចក្តីសង្ខេបពាក្យបណ្តឹងជាភាសាអង់គ្លេស ឯកសារ D191.1.109) បានឆ្លើយថា នៅចុងខែកក្កដា ឆ្នាំ១៩៧៨ អ្នកជម្លៀសមកពីស្វាយរៀង និង ព្រៃវែងត្រូវបានសម្លាប់នៅស្រះរំដេង] ឆ.៦១ KH 00997945 ["គេយកទៅក្រោលគោនៅស្រះរំដេងក្នុងឃុំតាណេ [ស្រុកបាកាន]។"] ឆ.៧០-៧២, ៧៤ KH 00997946-47 [នារីស្អាតៗត្រូវបានគេរំលោភមុននឹងសម្លាប់]។ ឯកសារ D65.1.56 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម សាម៉ុន KH 00250706-09 [សាក្សី ដែលត្រូវបានជម្លៀសទៅកាន់ខេត្តពោសាត់ ខាងកើតផ្សារតាណេ នៅចុងឆ្នាំ១៩៧៨ បាននិយាយអំពីការរំលោភសេពសន្តវ:លើ សារី ជាស្រីក្រមុំមកពីខេត្តព្រៃវែង ដែលបានកើតឡើងក្រោយពេលដែលពួកគេត្រូវបានជម្លៀសទៅកាន់ស្រុកបាកាន] *សូមអានភ្ជាប់ជាមួយនឹង* ឯកសារ D219/605 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម សាម៉ុនឆ.៤-៥, ៦៥-៦៩, ៧២ KH 01173509, 16-17 [សាក្សីត្រូវបានជម្លៀសទៅកាន់ខេត្តពោសាត់នៅចុងឆ្នាំ១៩៧៨។ សារី ជាក្មេងស្រីមកពីភូមិជាមួយនឹងសាក្សី ដែលបានរស់ក្នុងសហករណ៍តាណេក្រោយពេលជម្លៀសនោះ ត្រូវបានសម្លាប់ចោលភ្លាម បន្ទាប់ពីនាងត្រូវបានគេរំលោភរួច]។ ឯកសារ D118/228 កំណត់ហេតុស្តាប់ចម្លើយ ម៉ង ផុន ឆ.៤០-៥៤ KH 00985448-50 [បានរៀបរាប់អំពីការសម្លាប់អ្នកស្វាយរៀងប្រហែលជា ២០០នាក់ នៅសហករណ៍អ្នកតាទ្វា ឃុំអ្ករតាប៉ោង ស្រុកបាកាន ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ដោយរួមទាំងការរំលោភសេពសន្តវ:ក្មេងស្រីម្នាក់ផងដែរ]។ ឯកសារ D6.1.845 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង ហាន KH 00391878-79 [អ្នកដាក់ពាក្យសុំត្រូវបានជម្លៀសនៅចុងឆ្នាំ១៩៧៨ ពីខេត្តស្វាយរៀងទៅកាន់ស្រុកបាកាន ជាទីដែលរូបគាត់បានឃើញការរំលោភសេពសន្តវ:លើមីងរបស់គាត់ និងអ្នកផ្សេងទៀត៖ "ស្រីដែលមានរូបស្អាតរងការរំលោភ នេះមានន័យថា ជាធម្មតាឪពុកម្តាយរបស់ក្មេងស្រីទាំងនោះ ត្រូវបានគេសម្លាប់ជាមុន មុនពេលកូនស្រីរបស់គេរងការរំលោភ ហើយសម្លាប់។ [...] ស៖ តើអ្នកស្រីបានឃើញការរំលោភនោះប៉ុន្មានដង? ឆ៖ ខ្ញុំបានឃើញពីរឬបីដង។ [...] កងឈ្លបជាអ្នករំលោភ និងសម្លាប់ស្ត្រី។"]។ ឯកសារ D118/198 កំណត់ហេតុស្តាប់ចម្លើយ ឈឹម ស្រ៊ិន ឆ.២០, ៤៥-៤៦-៤៩ KH 00978980, 83។ ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ូន ឆ.១៥០-១៥៤ KH 01176420-21។ ឯកសារ D219/691 កំណត់ហេតុស្តាប់ចម្លើយ ម៉ៀន ម៉ៅ ឆ.៩៣, ៩៦, ១០០-១០២, ១០៦-១០៩ KH 01205242-44។ ឯកសារ D219/676 កំណត់ហេតុស្តាប់ចម្លើយ ហុក សារិន ឆ.១២៨-១៤០ KH 01202413-15។ ឯកសារ D5/1346 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៉ុល រ៉ាត់ KH 01049583 [ភូមិវាល ក្នុងឃុំតាណេ ស្រុកបាកាន ខេត្តពោធិ៍សាត់ អ្នកជម្លៀសមកពីព្រៃ

707. ខ៉ែម សាម៉ុន បានរំឭកថា នៅរុកពែក នាចុងឆ្នាំ១៩៧៨ ពួកនារីភូមិភាគពាយ័ព្យដែលនៅលីវ ក្នុងកងចល័តរបស់គាត់ត្រូវបានពួកកម្មាភិបាលកោះហៅទំនងជាឲ្យ "ទៅធ្វើប្រវត្តិរូប" ប៉ុន្តែមិនឃើញមានយកសៀវភៅទៅជាមួយដើម្បីធ្វើកំណត់ត្រានោះទេ ផ្ទុយទៅវិញនារីទាំងនោះត្រូវបានគេរំលោភសេពសន្តវ:[2588]។ ប្រជាជនជម្លៀសមកពីភូមិភាគបូព៌ាឈ្មោះ ប៉ាង ហាន បានរៀបរាប់ពីរបៀបដែលរូបគាត់បានឃើញពួកឈ្លបភូមិហៅមីងទាំងបីរបស់គាត់ចូលទៅក្នុងព្រៃ ដូច្នេះរូបគាត់បានតាមមើលពីចម្ងាយ និងបានឃើញពួកគេកាប់សម្លាប់មីងរបស់គាត់ពីរនាក់ក្នុងចំណោមបីនាក់នោះ ហើយបន្ទាប់មករំលោភ និងសម្លាប់មីងរបស់គាត់ដែលក្មេងជាងគេ មាន "អាយុ២២ ឆ្នាំហើយគាត់ស្អាត"[2589]។ សាក្សីផ្សេងទៀតបានរៀបរាប់អំពីហេតុការណ៍នានាដែលនារីខ្មែរក្រោម និងនារីភូមិភាគបូព៌ាត្រូវបានរំលោភដោយការប្រើដំបងឫស្សី ឬវត្ថុផ្សេងៗទៀត មុនពេលពួកគេត្រូវបានសម្លាប់ ហើយពេលខ្លះ ពួកកម្មាភិបាលបានវះពោះពួកគេទាំងរស់ដើម្បីយកប្រមាត់របស់អ្នកទាំងនោះ[2590]។

រ៉ែង ត្រូវបានសម្លាប់ ហើយ "ស្រីៗក្រមុំ វាចាប់រំលោភផ្ទួរភេទ ហើយបានសម្លាប់ចោល"]។ ឯកសារ D5/946 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នេត សារ៉ឿន KH 00981397, 99, 04-05។

[2588] ឯកសារ D65.1.56 កំណត់ហេតុស្តាប់ចម្លើយ ខ៉ែម សាម៉ុន KH 00250708 ["នារីៗដែលនៅក្រមុំច្រើនតែត្រូវបានគេហៅទៅធ្វើប្រវត្តិរូបហើយ ចាប់រំលោភនៅតាមដីដំបូកនៅពេលយប់ៗ។ មាននារីម្នាក់ឈ្មោះ សារី ជាឧទាហរណ៍ និងជាអ្នកមកពីខេត្តព្រៃរ៉ែង"] *អានភ្ជាប់ជាមួយ* ឯកសារ D219/605 កំណត់ហេតុស្តាប់ចម្លើយ ខ៉ែម សាម៉ុន ឯ.៣-៤, ១២-១៧, ២០ KH 01173508-09, 10 [លក្ខណៈជាក់ស្តែងទាក់ទងនឹងពេលវេលា និងទីកន្លែងជម្លៀសរបស់សាក្សីទៅកាន់ស្រុកបាកាន នៅចុងឆ្នាំ១៩៧៨ រួមមានទាំង រុកពែក នៅក្នុងស្រុកបាកានហ្នឹង] ឯ.៤១-៥៦ KH 01173513-15 [លក្ខណៈជាក់ស្តែងទាក់ទងនឹងការរំលោភនារីៗបួននាក់នៅ រុកពែក ដែលត្រូវបានហៅឲ្យ "ទៅធ្វើប្រវត្តិរូប"] ឯ.៦៥-៦៩, ៧២ KH 01173516-17, 18 [ការរំលោភ សារី បានកើតឡើងនៅសហករណ៍តាណោ (ស្រុកបាកាន)]។

[2589] ឯកសារ D6.1.845 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង ហាន KH 00391878-79 *អានភ្ជាប់ជាមួយ* ឯកសារ D5/1742 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាង ហាន KH 01176237 [ដោយផ្ទែងថាទីកន្លែងកំណើតរបស់អ្នកដាក់ពាក្យសុំ គឺនៅខេត្តស្វាយរៀង] KH 01176243 [ដោយបញ្ជាក់ថាគ្រួសាររបស់នាងត្រូវបានជម្លៀសទៅកាន់ខេត្តកណ្តាល នៅដើមឆ្នាំ១៩៧៨ និងបន្ទាប់មក នៅចុងឆ្នាំ១៩៧៨ ទៅកាន់ស្រុកបាកាន] និងឯកសារ D5/1742/2.1 របាយការណ៍បន្ថែមស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ប៉ាង ហាន EN 01379805។

[2590] <u>នារីខ្មែរក្រោម</u>៖ ឯកសារ D6.1.757 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន KH 00385098-99 ["ក្នុងខែកក្កដា ឆ្នាំ១៩៧៨ ប្រធានសហករណ៍បានបញ្ជូនខ្ញុំត្រលប់មកស្ពុកខ្ជា [ក្នុងស្រុកបាកាន] ដើម្បីធ្វើស្រែម្តងទៀត។ [...] នៅក្នុងសហករណ៍ស្ពុកខ្ជា ខ្ញុំបានឮឈ្លបខ្មែរក្រហមនិយាយអំពីការរំលោភនារីខ្មែរកម្ពុជាក្រោមម្នាក់ ហើយខ្ញុំបានឃើញសាកសពរបស់នាងនៅលើភ្លឺស្រែចម្ងាយប្រហែល៧០០ម៉ែត្រពីសហករណ៍ស្ពុកខ្ជា"]។ *អានភ្ជាប់ជាមួយ* ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឯ.៦៧-៧០ KH 00955771-72 ["ខ្ញុំធ្លាប់ឃើញ[ករណីរំលោភសេពសន្តវ:]ម្តងនៅស្ពុកខ្ជា។ [...] ខ្ញុំបានឮតែសម្រែកប៉ុណ្ណោះ

<u>អំពើហិង្សាផ្លូវភេទប្រឆាំងនឹង "ខ្មាំង ឬ ក្រុមគោលដៅផ្សេងទៀតរបស់ ប.ក.ក"</u>

708. ពួកស្ត្រីដែលគេជឿជាក់ថាជា "ខ្មាំង" ហើយត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខក្នុងស្រុកបាកាន ក៏ត្រូវបានគេរំលោភសេពសន្តវៈដោយពួកកម្មាភិបាលខ្មែរក្រហមផងដែរ មុនពេលដែលពួកអ្នកទាំងនោះត្រូវបានគេសម្លាប់ចោល។ នៅមន្ទីរសន្តិសុខភូមិវាល ក្នុងឃុំតាណោ[2591] ប្រធានគុកជារឿយៗបានបង្ខំនារីក្មេងៗពីនាក់ឲ្យងូតទឹកជាមួយខ្លួន និងបានរំលោភសេពសន្តវៈពួកគេជា "ច្រើនដង" មុនពេលអំពើរបស់គាត់ត្រូវបែកការណ៍។ ក្រោយមកគាត់បានសម្លាប់នារីក្មេងៗដែលគាត់បានរំលោភបំពានទាំងនោះ[2592]។ ទណ្ឌកម្មតែមួយគត់ដែលប្រធានគុក/អ្នករំលោភសេពសន្តវៈ ទទួលរងនោះគឺថា ប្រធានយោធាស្រុកបានបញ្ជាឲ្យអ្នកទោសម្នាក់ក្នុងចំណោមអ្នកទោសរបស់គាត់ទាំងឡាយ

ដោយនារីម្នាក់នោះស្រែកថា "ជួយផង! កុំរំលោភអញ! កុំរំលោភអញ បើសម្លាប់ក៏សម្លាប់ទៅ"។ បន្ទាប់មកព្រឹកឡើងខ្ញុំបានទៅទីនោះ ខ្ញុំក៏បានឃើញនារីម្នាក់នោះស្លាប់។ [...] នៅពេលដែលស្ត្រីនោះខឹងក៏ខាំស្មារបស់ឈ្លូបម្នាក់នោះ ដល់ពេលដែលឈ្លូបនោះខឹងក៏យកពីងពង់បុកធ្លាយពីគូទចេញទៅតាមក្បាល។ ខ្ញុំដឹងរឿងនេះដោយសារឈ្លូបនោះជាអ្នកធ្វើការជាមួយខ្ញុំ ហើយបាននិយាយថា "មីមួយនេះឆ្ងាស់ណាស់អ្ហើយ! ឃើសងែងខាំអញ! មើលអញបុកពីគូទដល់ក្បាលមើល!"។ [...] ចាស ខ្ញុំបានឮពីឈ្លូប គាត់ឈ្មោះ សារ៉ុ"]។ <u>នារីភូមិភាគឫ[illegible]</u>៖ ឯកសារ D118/248 កំណត់ហេតុស្តាប់ចម្លើយ លី លន់ ឆ.៦៦-៧០, ៧៨ KH 00990692-93 [នៅចុងឆ្នាំ១៩៧៨ ឬដើមឆ្នាំ១៩៧៩ សាក្សីរូបនេះបានឃើញសាកសព"រាប់មិនអស់" មកពីភូមិភាគឫ[illegible] នៅត្រង់ទួលពង្រ ស្រុកបាកាន] ឆ.៩០-៩១, ៩៤-៩៥ KH 00990695 [ទាក់ទងនឹងការឃើញសាកសពស្ត្រីម្នាក់នៅទួលពង្រ "ដោយគេបានសម្រាតខោខ្លីមនុស្សស្រីនោះដាក់នៅចុងជើង ហើយយកបូស្សីបុកចូលតាមទ្វារមាសរបស់មនុស្សស្រីម្នាក់នោះទៀត"]។ ឯកសារ D118/228 កំណត់ហេតុស្តាប់ចម្លើយ ម៉ង ឆុន ឆ.៤០-៥៤ KH 00985448-50 [ដោយពិភាក្សាពីការសម្លាប់អ្នកស្វាយរៀងប្រមាណជា២០០នាក់ នៅសហករណ៍អ្នកតាទ្វារ ឃុំអូរតាប៉ោង ស្រុកបាកាន នៅខែវិច្ឆិកា ឆ្នាំ១៩៧៨] ជាពិសេសនៅត្រង់ ឆ.៥០-៥១ KH 00985449-50 [តាសឹប និយាយអួតក្អេងក្អាងថា គាត់បានយកបូស្សីបុកទ្វារមាសនារីស្អាតម្នាក់នោះហើយ និងបានយកប្រម៉ាត់មីមួយហ្ម៉ីងមកដែរ ខណៈដែលនារីនោះមិនទាន់ស្លាប់នោះទេ។ នារីនោះមកពីស្វាយរៀង។ ឯកសារ D5/946 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នេត សារឿន KH 00981397 [អ្នកដាក់ពាក្យសុំមកពីស្វាយរៀង និងត្រូវបានបញ្ជូនទៅកាន់ភូមិព្រៃកជីក ឃុំដូនកែវ ស្រុកបាកាន] KH 00981399, 04-05 [នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ អ្នកដាក់ពាក្យសុំរូបនេះ គឺជានារីម្នាក់ក្នុងចំណោមនារីប្រមាណជា ៣០នាក់ ដែលមានអាយុប្រមាណជា ១៩ឆ្នាំដែលត្រូវបានចង ហើយបណ្តើរចូលទៅក្នុងព្រៃក្បែរព្រៃកជីក ដោយពួកយោធាដែលមានអាយុត្រឹម ១៣ ទៅ ១៤ឆ្នាំប៉ុណ្ណោះ។ ពួកស្រីៗត្រូវបានបង្ខំឲ្យស្រាតសំលៀកបំពាក់ចេញទាំងអស់គ្នា ត្រូវបានសួរពីប្រដាប់ភេទ ត្រូវបានរំលោភ ហើយក្រោយមក ពួកវាបានយកវត្ថុដូចជា ដងពួរ[illegible] ឬឈើមកបុកប្រដាប់ភេទ នៅពេលដែលពួកកម្មាភិបាលនាំគ្នា "សើចយ៉ាងសប្បាយហាក់ដូចជាល្បែងកំសាន្តដ៏ល្អទៅវិញ"។ អ្នកដាក់ពាក្យសុំរូបនេះត្រូវបានវាយក្បាលចំនួន ៥ពួរ[illegible] ហើយត្រូវបានទុកចោលឲ្យស្លាប់ជាមួយនឹងស្រីៗដទៃទៀត ប៉ុន្តែក្រោយមកទើបដឹងខ្លួនវិញ។ នាងជាអ្នករស់រានមានជីវិតតែម្នាក់គត់ប៉ុណ្ណោះ]។

[2591] ឯកសារ D118/11 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងនៃមន្ទីរសន្តិសុខភូមិវាល KH 00893187-88។

[2592] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួរ ឆ.១១៣-១១៥ KH 00955721។

"តាមដានគាត់"[2593]។ ពួកកម្មាភិបាលផ្សេងទៀតនៅក្នុងភូមិវាលបានរំលោភសេពសន្ថវៈអ្នកទោសនារី ទាំងតាមរយៈការស៊ីកបញ្ចូលលិង្គ និងដោយការស៊ីកដំបងឫស្សី ឬមេជើងរបស់ពួកគេយ៉ាងឃោរឃៅទៅក្នុងប្រដាប់ភេទរបស់ស្ត្រីទាំងនោះមុនពេលសម្លាប់ពួកគេ[2594]។ អតីតអ្នកទោស ចាប ខ្ជង បានរំឭកថា ក្នុងឆ្នាំ១៩៧៨ ពួកកម្មាភិបាលធ្វើការនៅភូមិវាល "[បានរំលោភ] បងប្អូននារីដែលមានរូបសម្បត្តិស្អាត [...] លេងសើច ទើបវាសម្លាប់ចោល"[2595]។ ចាប ខ្ជង ក៏បានរៀបរាប់ផងដែរពីរបៀបដែលគ្រួសារខ្មែរក្រោមមួយត្រូវបានចាប់ខ្លួន និងនាំមកកាន់គុកនេះ ដែលជាទីដែលពួកគេទទួលរងការវាយដំ និងសម្លាប់ចោល ក្រោយពេលដែលពួកកម្មាភិបាលបានរំលោភសេពសន្ថវៈកូន

[2593] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១១៣, ១១៦ KH 00955721។

[2594] ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ KH 00385137 [ទាក់ទងនឹងការសម្លាប់នៅឆ្នាំ១៩៧៨ លើអ្នកទោសនារីពីរនាក់-នារីម្នាក់មកពីស្រុកកណ្តៀង និងនារីម្នាក់ទៀតជាកម្មករមកពីរោងចក្រ សំ សាន ក្នុងស្រុកបាកាន] KH 00385137 ["អ្នកទោសស្រីក៏ត្រូវបានធ្វើទារុណកម្មមុននឹងសម្លាប់។ ខ្លះទៀតត្រូវបានគេរំលោភ។ [...] ខ្ញុំបានឃើញនារីពីរនាក់ត្រូវបានរំលោភដោយឈ្មោះ កន និង តន នៅពេលយប់ ដោយផ្ទាល់ភ្នែក។ ព្រឹត្តិការណ៍នេះបានកើតឡើងនៅក្រៅមន្ទីរឃុំឃាំងជិតកន្លែងសម្លាប់មនុស្ស ពេលនោះខ្ញុំនៅទីនោះ ពីព្រោះខ្ញុំត្រូវរង់ចាំកប់សាកសព"]។ *អានភ្ជាប់ជាមួយ* ឯកសារ D5/147 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ គឹម សូរ KH 00358227-28 ["មិត្តនារីម្នាក់ មិនដឹងមានកំហុសអ្វីទេ ពួកវាយករំលោភ ម្តងម្នាក់ៗ ពួកវាចងដៃ ហើយវាចាប់ផ្ទួលមិត្តនារីឲ្យដេកផ្ងារលើមាត់រណ្តៅដែលត្រូវពួកសំលាប់ ពួកវាយកទៅសម្លាប់ ទៅលេងសើច ជាល្បែងរបស់វា ពួកវាយកម្រាមជើងទៅរុកទ្វារមាសរបស់នារី ធ្វើឲ្យនាងស្រែកយំ និងអង្វរករយ៉ាងខ្លាំង តែពួកវាពុំបានយកសំណូមពររបស់យើងឡើយ ពួកវាលេងសើចអស់ហើយ ពួកវាក៏ទាញកាំបិត អារករម្ជង់បន្ដិចៗ លុះតែដាច់ខ្យល់ស្លាប់ រឿងមួយទៀត ដែលធ្វើឲ្យរូបខ្ញុំកាន់តែភ័យខ្លាចទៀតនោះគឺ វាចាប់នារីម្នាក់មកពីរោងចក្រ ពួកវាធ្វើទារុណកម្មដូចគ្នានេះដែរ ពេលគេធ្វើបាបខ្លាំង នាងបានស្រែកហៅរកតែ៖ "ព្រះបីតា ព្រះមាតាអើយ ជួយបុត្រផង ក្នុងលោកនេះមានតែព្រះបីតាទេដែលជួយកូនបាន" ពាក្យដង្ហោយហៅ មិនទាន់ចប់ពីមាត់ផង ពួកវាបានចាប់ដេកផ្ងារអារករសំលាប់ពុំមានត្រាប្រណីឡើយ"]។ ឯកសារ D5/1443 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ នេត ផង់ KH 01039852 ["ពួកវា[ខ្មែរក្រហម]បានចាប់ អ្នកយន ទៅដាក់គុកនៅភូមិវាល ឃុំតាលោ។ ក្នុងពន្ធនាគារ ពួកវាធ្វើទារុណកម្មគ្រប់យ៉ាង ក្រោយមក ជនដៃដល់យកឫស្សីដោតតាមប្រដាប់ភេទ ធ្វើទារុណកម្មរហូតដល់ស្លាប់"] KH 01039846 [*កត់សម្គាល់* ថាឧក្រិដ្ឋកម្មដែលបានលើកឡើងចោទប្រកាន់ប្រឆាំងនឹង នាក់ យន នេះ ត្រូវបានប្រព្រឹត្តឡើងនៅក្នុងឆ្នាំ១៩៧៧]។

[2595] ឯកសារ D5/161 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាប ខ្ជង KH 00358252។ *សូមមើលផងដែរ* ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385092 ["ថ្ងៃមួយខ្ញុំមានឱកាសបាននិយាយជាមួយនឹងនារីជាចុងភៅនោះ។ នាងមានឈ្មោះ វេញ។ នាងបានប្រាប់ខ្ញុំថា នាងត្រូវបានទាហានខ្មែរក្រហមរំលោភ។ ក្រោយមកនាងបានបាត់ខ្លួន ហើយខ្ញុំបានឃើញសាកសពរបស់នាងនៅក្នុងចម្ការដំឡុង ដេលមានចម្ងាយ ៥០ម៉ែត្រពីគុក។"]។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៨៨-៩១ KH 00955737។

ស្រីបីនាក់ក្នុងចំណោមកូនស្រីទាំងនោះ[2596]។ នៅមន្ទីរសន្តិសុខត្រាចក្រោល ក្នុងឃុំបឹងខ្នារ[2597] អតីតអ្នកទោស ម៉ើ ពៅ បានឃើញពួកយោធា ដែលធ្វើការនៅគុកនោះរំលោភសេពសន្ថវ:អ្នកទោសនារីពីរនាក់មកពីភូមិភាគបូព៌ាក្នុងបរិវេណគុកនោះ មុនពេលសម្លាប់ពួកគេចោល[2598]។

709. "ខ្ទាំង" ផ្សេងៗទៀតក៏ស្ថិតនៅក្រោមអំពើហិង្សាផ្លូវភេទផងដែរ នៅពេលណាដែលឱកាសផ្តល់ឲ្យ។ ក្នុងឆ្នាំ១៩៧៨ ប្រជាជនជម្លៀសពីភូមិភាគបូព៌ាម្នាក់ឈ្មោះ អ៊ុំ និត ត្រូវបានបញ្ជូនទៅកាន់ស្រុកបាកាន ជាទីដែល "មាននារីច្រើន" មកពីកងចល័តរបស់គាត់ ត្រូវបានយកទៅសម្លាប់ដោយមិនដឹងមូលហេតុ ប៉ុន្តែជាដំបូងពួកគេត្រូវបានរំលោភសេពសន្ថវ:ជាមុនសិន[2599]។ ក្នុងភូមិផ្សារអណ្តែត ក្នុងឆ្នាំ១៩៧៨ ឯក រ៉ា: បានឃើញឈ្លបបីនាក់រំលោភសេពសន្ថវ: និងសម្លាប់នារីបីនាក់[2600]។ នារីទីបី "បានជំទាស់យ៉ាងខ្លាំង" និងបានជេរអ្នករំលោភនោះ ដូច្នេះគេបានចាក់ជំពុះទង់របស់ខ្លួនទៅលើប្រដាប់ភេទរបស់នាង ក្រោយពេលដែលពួកគេបានរំលោភសេពសន្ថវ:នាងរួចហើយ[2601]។

[2596] ឯកសារ D5/161 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាប ខ្ជង KH 00358251។ *សូមមើលផងដែរ* ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង KH 00385091 ["ក្នុងឆ្នាំ១៩៧៧ ពួកយើងត្រូវបានគេបញ្ជូនមកកាន់គុកធំនៅភូមិវាល"] KH 00385092 [ទាក់ទងនឹងគ្រួសារ] KH 00385092 ["ខ្មែរកម្ពុជាក្រោមជាគោលដៅនៃការចាប់ខ្លួន ព្រោះពួកគេត្រូវបានចោទថាជា 'ឃ្លួន' [វៀតណាម]។"]។

[2597] ឯកសារ D118/16 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខត្រាចក្រោល KH 00893715-16។ ឯកសារ D118/174 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ពុំ ឆ.២៤ KH 00973936។

[2598] ឯកសារ D118/190 កំណត់ហេតុស្តាប់ចម្លើយ ម៉ើ ពៅ ឆ.៩២-១០២ KH 00977053-54។ *សូមមើលផងដែរ* ឯកសារ D118/147.1.7 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ម៉ើ ពៅ KH 00518528 [សាក្សីត្រូវជាប់ឃុំនៅត្រាចក្រោល ក្នុងខែតុលា ឆ្នាំ១៩៧៨ និងបាននិយាយថា អ្នកទោសនារី "ត្រូវពួកឈ្លបរំលោភ រួចយកទៅសម្លាប់យ៉ាងព្រៃផ្សៃនៅក្បែរមន្ទីរនោះ។"]។ ឯកសារ D191.1.54 ទម្រង់បែបបទសុំព័ត៌មានបន្ថែម ម៉ើ ពៅ KH 00578275។

[2599] ទោះបីជា អ៊ុំ និត មកពីភូមិភាគបូព៌ាក៏ដោយ វាមិនច្បាស់ទេថាកងចល័តរបស់គាត់មានសុទ្ធតែនារីពីភូមិភាគបូព៌ានោះ។ *សូមមើល* ឯកសារ D219/170 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ និត ឆ.៥៧-៦០, ៨០-៨២ KH 01063919-20, 23។

[2600] ឯកសារ D118/289 កំណត់ហេតុស្តាប់ចម្លើយ ឯក រ៉ា: ឆ.៤៦ KH 01022355-56 [បានរៀបរាប់ហេតុការណ៍នេះ និងបាននិយាយថា វាបានកើតឡើងនៅភូមិផ្សារអណ្តែត បីខែមុនពេលគាត់ (ឯក រ៉ា:) ត្រូវយកទៅសម្លាប់] *សូមអានភ្ជាប់ជាមួយនឹង* ឯកសារ D5/10 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឯក រ៉ា: KH 00552010 [បានបញ្ជាក់ថា ភូមិផ្សារអណ្តែតស្ថិតនៅក្នុងឃុំអូរតាប៉ោង ស្រុកបាកាន តំបន់៧ ខេត្តពោសាត់ និងបានបញ្ជាក់ថា ការបរិច្ឆេទដែលគេយកគាត់ទៅសម្លាប់គឺនៅពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៧៨ និងថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៧៨]។

[2601] ឯកសារ D118/289 កំណត់ហេតុស្តាប់ចម្លើយ ឯក រ៉ា: ឆ.៤៦ KH 01022355។

710. ចាន់ ផាយ ត្រូវបានហៅថាជាជនក្បត់ នៅពេលដែលគាត់បានបដិសេធរៀបការជាមួយប្រធានយោធានៅការដ្ឋានស្រុកបាកានរបស់គាត់ នៅចុងឆ្នាំ១៩៧៧ ហើយរូបគាត់ត្រូវបានរំលោភសេពសន្តវ:ជាក្រុមជាការដាក់ទណ្ឌកម្ម[2602]។ នៅក្នុងសវនាការឆ្នាំ២០១៣ របស់ស្ត្រី ស្តីពីអំពើហិង្សាខាងយ៉េនឌ័រ ចាន់ ផាយ បានរំឭកថា:

> ដោយសារតែខ្ញុំមិនរៀបការជាមួយប្រធាន។ អញ្ចឹងហើយ ខ្ញុំត្រូវបានគេដាក់ច្រវ៉ាក់។ វាបានបញ្ជាឲ្យកូនចៅវាផ្សេងទៀតចូលមកលេងដោះខ្ញុំ លេងប្រដាប់ភេទខ្ញុំ ក្បៀបដោះខ្ញុំ។ រួចមក ពួកវាបានប្រើរបស់មួយ ដើម្បីធ្វើបាបប្រដាប់ភេទរបស់ខ្ញុំ។ ជើងរបស់ខ្ញុំត្រូវបានហែកចេញពីគ្នា។ ហើយខ្ញុំបានសន្ធប់ផងដែរ។ ខ្ញុំបាននិយាយថា ខ្ញុំនឹងខាំលិង្គរបស់ពួកវា បន្ទាប់មកពួកគេបានដាក់លិង្គពួកគេចូលទៅក្នុងមាត់របស់ខ្ញុំ។ ខ្ញុំបានព្យាយាមគេចពីវា។ ខ្ញុំគ្រាន់តែបន់ស្រន់ឲ្យព្រះជួយ។[2603]

711. ហុង សារ៉ាត គឺជា "ប្រជាជន១៧ មេសា" ដែលមានគ្រួសាររស់នៅភ្នំពេញ និងចុងក្រោយត្រូវបានជម្លៀសទៅកាន់ស្រុកបាកានក្នុងឆ្នាំ១៩៧៨[2604]។ នៅទីនោះ ប្អូនស្រីរបស់ ហុង សារ៉ាត បានស្លាប់ដោយកង្វះអាហារ និងត្រូវបានទុកចោលឲ្យស្អុយរលួយក្នុងវាលស្រែ ហើយបងប្អូនរបស់គាត់ផ្សេង

[2602] ឯកសារD310/1.1.8 ប៊ែនី ឃី *របាយការណ៍ស្តីពីដំណើរការនៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយស្តីពីអំពើហិង្សាយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម* ការរៀបរាប់របស់ ចាន់ ផាយ KH 01506127។ ឯកសារ D5/660/1 របាយការណ៍ស្តីពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាន់ ផាយ EN 00911290 [ទោះបីជារបាយការណ៍នេះមិនមាននិយាយអំពីហេតុការស្តីពីអំពើហិង្សាផ្លូវភេទក៏ដោយ ក៏វាបាននិយាយថា "នៅចុងឆ្នាំ១៩៧៧ អ្នកដាក់ពាក្យសុំត្រូវបានបង្ខំឲ្យរៀបការដោយប្រធានកងនៅម៉ោង ៨យប់ ឲ្យរៀបការនៅម៉ោង ៩យប់។ អ្នកដាក់ពាក្យបានបដិសេធទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនេះ"។"] EN 00911289 ["ក្រោយពីត្រូវបានចោទប្រកាន់ថាជាជនក្បត់ អ្នកដាក់ពាក្យខ្លួនគាត់ផ្ទាល់ត្រូវបានចាប់ខ្លួន និងក្រោយមកត្រូវបានបញ្ជូនទៅកាន់មន្ទីរសន្តិសុខវត្តពោធ៍រង្ស ក្នុងស្រុកកណ្តៀង ខេត្តពោសាត់"]។

[2603] ឯកសារ D310/1.1.8 ប៊ែនី ឃី *របាយការណ៍ស្តីពីដំណើរការនៃការស្តាប់សំឡេងស្ត្រីជាមួយមនុស្សជំនាន់ក្រោយស្តីពីអំពើហិង្សាយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម* ការរៀបរាប់របស់ ចាន់ ផាយ KH 01506127។

[2604] ឯកសារ D191.1.15 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហុង សារ៉ាត KH 00279752។ ឯកសារ D310/1.1.13 របាយការណ៍ពី *ការស្តាប់សំឡេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីអំពើហិង្សាយេនឌ័រពេលមានជម្លោះ* ឆ្នាំ២០១២ KH 01506155 EN 00992082។ *កត់សម្គាល់*ថា ក.ស.ច.ស បានស្តាប់ចម្លើយ ហុង សារ៉ាត ជាផ្លូវការប៉ុន្តែ កំណត់ហេតុស្តាប់ចម្លើយនោះមានតែនៅក្នុងសំណុំរឿង ០០២ (*សូមមើល* ឯកសារ E3/5591) ប៉ុណ្ណោះ មិនមាននៅក្នុងសំណុំរឿង០០៤ ទេ។

ទៀតត្រូវបានសម្លាប់ដោយមូលហេតុ "កំហុស" ផ្សេងៗ[2605]។ ឪពុកម្តាយរបស់គាត់ត្រូវបានសម្លាប់នៅនឹងមុខរបស់ ហុង សាវ៉ាត[2606] ហើយពួកឈ្លបទាំងបីនាក់ដែលបានសម្លាប់ឪពុកម្តាយរបស់គាត់នោះ ក្រោយមកបានចាប់ទាញ ហុង សាវ៉ាត ចូលទៅក្នុងព្រៃ សម្រាតខោអាវរបស់គាត់ និងបានរំលោភសេពសន្តវ:រូបគាត់ម្នាក់ម្តងៗ រហូតរូបគាត់សន្លប់បាត់ស្មារតី[2607]។ នៅក្នុងសវនាការស្តីពីស្ត្រីតំបន់អាស៊ីបាស៊ីហ្វិក ក្នុងឆ្នាំ២០១២ ហុង សាវ៉ាត បានរៀបរាប់ពីរបៀបដែលដំបូងឡើយ រូបគាត់បានតស៊ូប្រឆាំងនឹងពួកដែលចាប់ខ្លួនគាត់ ប៉ុន្តែរូបគាត់បានចុះខ្សោយនៅពេលដែលកម្ទាភិបាលទីពីរបានចាប់ផ្តើមរំលោភសេពសន្តវ:លើរូបគាត់[2608]។ ខណ:នោះ ជនចាប់រំលោភដំបូងបានកាត់ច្រៀកដំបងឫស្សី ដោតដៃរបស់គាត់ភ្ជាប់ទៅនឹងដី ដោយទាញជើងគាត់កន្ទ្រែកចងភ្ជាប់ទៅនឹងដើមឈើនោះ រូបគាត់មិនអាចកម្រើកបានឡើយ។ គាត់បានប្រាប់អ្នកចូលរួមស្តាប់ថា: "[វាដូចត្រូវបានគេ]ឆ្កាងអ៊ីចឹង"[2609]។

iii. ខក្រិដ្ឋកម្មដែលស្នើសុំឲ្យបញ្ជូនទៅជំនុំជម្រះ

712. ដូចបានពិភាក្សាក្នុងផ្នែក ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល នៃសេចក្តីសន្និដ្ឋាននេះ *ចេតនាដោយមិនចំពោះ*បំពេញ*ធាតុផ្សំអត្តនោម័ត*ដើម្បីបង្ហាញថា **យ៉ីម ទិញ្ញ** និងសមាជិកផ្សេងទៀតនៃ JCE ទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការរំលោភសេពសន្តវ: ដែលបានកើតមានឡើងនៅក្នុងស្រុក

[2605] ឯកសារ D191.1.15 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហុង សាវ៉ាត KH 00279752។ ឯកសារ D310/1.1.13 របាយការណ៍ពី *ការស្តាប់សំឡេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីអំពើហិង្សាយេនឌ័រពេលមានជម្លោះ* ឆ្នាំ២០១២ KH 01506155 EN 00992082។

[2606] ឯកសារ D191.1.15 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហុង សាវ៉ាត KH 00279752។ ឯកសារ D310/1.1.13 របាយការណ៍ពី *ការស្តាប់សំឡេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីអំពើហិង្សាយេនឌ័រពេលមានជម្លោះ* ឆ្នាំ២០១២ KH 01506155 EN 00992082-83។

[2607] ឯកសារ D191.1.15 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហុង សាវ៉ាត KH 00279753។ ឯកសារ D310/1.1.13 របាយការណ៍ពី *ការស្តាប់សំឡេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីអំពើហិង្សាយេនឌ័រពេលមានជម្លោះ* ឆ្នាំ២០១២ KH 01506155 EN 00992083។

[2608] ឯកសារ D310/1.1.14R ខ្សែវីដេអូ *ការស្តាប់សំឡេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីអំពើហិង្សាយេនឌ័រពេលមានជម្លោះ* ម៉ោង 11:22-11:53។ ផ្នែករបស់គាត់មានទាំងស្រុងចាប់ពីម៉ោង 10:56-12:13។

[2609] ឯកសារ D310/1.1.14R ខ្សែវីដេអូ *ការស្តាប់សំឡេងស្ត្រីក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ស្តីពីអំពើហិង្សាយេនឌ័រពេលមានជម្លោះ* ម៉ោង 11:54-12:13។

បាកាន[2610]។ ស.ព.អ សន្និដ្ឋានថា នៅក្នុងកាលៈទេសៈនានាដែលកើតមានឡើងនៅពេលនោះ ការរំលោភសេពសន្តវៈតាមពិតគឺជាលទ្ធផលមិនអាចជៀសបាននៃគោលនយោបាយ JCE ដែលបានចាត់ថ្នាក់ក្រុមមនុស្សទាំងមូលថាជាខ្មាំង ដោយមិនមានសិទ្ធិ និងការការពារផ្នែកច្បាប់ឡើយ ហើយដែលពួកកម្មាភិបាលត្រូវបានលើកទឹកចិត្តឲ្យ "កម្ទេច" ចោល។ **យ៉ីម ទិត្យ** និងសមាជិកផ្សេងទៀតនៃ JCE ពិតជាបានដឹងអំពីលទ្ធភាពដែលថា ជនទាំងឡាយដែលពួកគេបានកំណត់ថាជា "ខ្មាំង" នឹងត្រូវគេរំលោភសេពសន្តវៈ ប៉ុន្តែបែរជាផ្សាភ្ជាប់ខ្លួនឯងទៅនឹងលទ្ធផលនោះ ហើយបន្តប្រព្រឹត្តស្របតាមផែនការឧក្រិដ្ឋនោះទៅវិញ។ ដូច្នេះ ស.ព.អ សន្និដ្ឋានថា **យ៉ីម ទិត្យ** គួរត្រូវបានចោទប្រកាន់ និងបញ្ជូនទៅជំនុំជម្រះចំពោះអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរំលោភសេពសន្តវៈ) ក្នុងស្រុកបាកាន[2611]។

៦. តំបន់ ៧

ក. គុកលេខ ៨

i. សេចក្តីផ្តើម

713. គុកលេខ ៨ មានទីតាំងស្ថិតក្នុងស្រុកកណ្តៀង តំបន់ ៧ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយត្រូវបានប្រើប្រាស់ជាមន្ទីរសន្តិសុខសម្រាប់តំបន់នេះ។ ប្រជាជនជាច្រើនពាន់នាក់ត្រូវបានជាប់ឃុំឃាំងនៅគុកលេខ ៨ នេះ ក្នុងអំឡុងពេលដែលមន្ទីរសន្តិសុខនេះដំណើរការ។ អ្នកទោសយ៉ាងតិចណាស់ ១.000 នាក់ ដែលត្រូវបានចាត់ទុកថាជា "ខ្មាំង" របស់ ប.ក.ក ក្នុងនោះមានទាំងប្រជាជនជម្លៀសពីភូមិភាគបូព៌ាយ៉ាងច្រើននោះ ត្រូវបានសម្លាប់នៅឯ ឬនៅជិតគុកនេះ។

[2610] *សូមមើល* VIII.B.1.d. ការទទួលខុសត្រូវព្រហ្មទណ្ឌជាបុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហកម្ម ឧក្រិដ្ឋកម្មរួម – ការរំលោភសេពសន្តវៈ និងអំពើហិង្សាខាងផ្លូវភេទនៅក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ។

[2611] ស.ព.អ កត់សម្គាល់ថា ទាក់ទងនឹងស្រុកបាកាន រូបគាត់ស្វែងរកឲ្យមានការបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មដែល ស.ច.ស ត្រូវបានប្តឹងទៅកាន់ ប៉ុន្តែមិនទាន់បានចោទប្រកាន់ យ៉ីម ទិត្យ នៅឡើយ។ នេះគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរំលោភសេពសន្តវៈ)។ ស.ច.ស ត្រូវបានប្តឹងអំពីឧក្រិដ្ឋកម្មនេះ ដោយឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៧, ១០។

714. ក្នុងនាមជាអនុលេខានៃភូមិភាគពាយ័ព្យពីខែកក្កដា ឆ្នាំ១៩៧៨ និងជាសមាជិកដឹកនាំនៃសហឧក្រិដ្ឋកម្ម រួម **យ៉ឹម ទិត្យ** ទទួលខុសត្រូវលើព្រឹត្តិការណ៍ដែលបានកើតឡើងនៅគុកលេខ ៨ នេះ។

715. ស.ច.ស.អ បានចោទ **យ៉ឹម ទិត្យ** លើឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងគុកលេខ ៨ មានជាអាទិ៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃការសម្លាប់មនុស្ស ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការធ្វើទុកបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា អំពើអមនុស្សធម៌ផ្សេងៗទៀត (ការបង្ខាំងមនុស្ស/ការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌) និងការសម្លាប់មនុស្សគិតទុកជាមុនដោយរំលោភលើមាត្រា ៥០១ និង ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦[2612]។

ii. ប្រតិបត្តិការ និងទីតាំង

716. គុកលេខ ៨ បានដាក់ឲ្យដំណើរការយ៉ាងតិចចាប់ពីឆ្នាំ១៩៧៧ រហូតដល់ពេលចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[2613]។ គុកនេះមានទីតាំងស្ថិតក្នុងភូមិក្បាលឈើពុក ឃុំស្សា សហករណ៍ក្បាលឈើពុក[2614] (ហៅថា បឹងចាក) ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ក្នុងតំបន់ ៧ នៃភូមិភាគពាយ័ព្យ[2615]។

[2612] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ឹម ទិត្យ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426557 – 01426558, 01426561–01426563។

[2613] ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម សារុន ឆ.៤០, ៥១, ៦០ KH 01088796-01088798។ ឯកសារ D105/9 កំណត់ហេតុស្តាប់ចម្លើយ ប៊ីង ភឿន ឆ.១១-១២, ២១ KH 00794119, 00794120។ ឯកសារ D5/450/3 ប្រតិចារឹក យ៉ឹម សុវណ្ណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង16.01.24-16.03.31។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉ែងលី ឆ.១១០-១១១ KH 01158605។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.២៣-២៤ KH 01088998។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ីុ ឆ.៥០, ៥២, ៥៨ KH 01102860, 01102861។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៥១ KH 01149900។ ឯកសារ D5/834/3 ព័ត៌មានបន្ថែមលើពាក្យតាំងសុំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទេព ហ៊ីន KH 01048942-01048943។

[2614] ឯកសារ D105/9 កំណត់ហេតុស្តាប់ចម្លើយ ប៊ីង ភឿន ឆ.២២ KH 00794120។ ឯកសារ D2.1.78b សេចក្តីសង្ខេបពាក្យបណ្តឹង ទូច ប៊ុនស៊ាន EN 00522286។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម សារុន ឆ.១២, ៤១ KH 01088794, 01088796។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.៦៩ KH 01158640។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៦២ KH 01089004។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉ែងលី ឆ.៧៦ KH 01158599។

[2615] ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉ែងលី ឆ.៣៤-៣៦, ៥៧ KH 01158593, 01158596 ["សហករណ៍ប៊ីងចក [...] ក្នុងឃុំស្សា ភូមិប៊ីងចក។"]។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.២៤-២៧ KH 01158635។

គុកនេះមានចម្ងាយមួយគីឡូម៉ែត្រ ភាគឦសាននៃចំណុចកណ្តាលភូមិ[2616]។ គុកនេះជាអតីតបន្ទាយទាហានក្នុងរបប លន់ នល់ ហើយមានទំហំប្រមាណជាមួយទៅពីរហិកតា[2617]។ នៅក្នុងបរិវេណគុកនេះ មានអគារចំនួនបីដែលត្រូវបានប្រើប្រាស់សម្រាប់ឃុំឃាំងអ្នកទោស[2618]។ នៅក្នុងបរិវេណ

ឯកសារ D2.1.82b សេចក្តីសង្ខេបពាក្យបណ្តឹង ប៊ីង ភឿន EN 00522328។ ឯកសារ D219/554 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត គួន ឆ.៣២, ៣៤, ៣៦-៣៨ KH 01158617-01158618។ ឯកសារ D105/20 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខលេខ ៨ KH 01397276 ["មន្ទីរសន្តិសុខគុកលេខ ៨ [...] ការបញ្ជាក់អំពី [...] ភូមិភាគរបស់ខ្មែរក្រហម៖ [...] ភូមិភាគពាយ័ព្យ។"]។ ឯកសារ D6.1.618 ការសម្គាសន៍របស់ SOAS ជាមួយសាត ឆាង KH 00721704 ["ស្រុក ២២ [...] ភូមិភាគពាយ័ព្យ [។] ស្រុកកណ្តៀង គឺជាស្រុក២២។"]។

[2616] ឯកសារ D105/20 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខលេខ ៨ KH 01397280-01397281។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.៧០ KH 01158640។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃីម សារុន ឆ.៤១-៤២ KH 01088796។

[2617] ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.១០៨, ១១៥ KH 01158645, 01158646។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉េងលី ឆ.៧៥ KH 01158599 ["សម័យ លន់ នល់ គេដាក់បន្ទាយទាហាន ដល់សម័យខ្មែរក្រហម គេយកកន្លែងហ្នឹងដាក់គុក០៨។"]។ ឯកសារ D5/831/3 ព័ត៌មានបន្ថែមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត គួន KH 01048940។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហឿន ឆ.៤២ KH 01149899។

[2618] ឯកសារ D105/9 កំណត់ហេតុស្តាប់ចម្លើយ ប៊ីង ភឿន ឆ.២០-២១, ២៣-២៤ KH 00794120 ["ឆ.២០៖ [...] ខ្ញុំជាប់គុកពីរឆ្នាំ បីខែ។ [...] ឆ.២១៖ នៅពេលវៀតណាមចូល ឆ្នាំ១៩៧៩ ខ្ញុំរត់ចេញ [...]។ ឆ.២៣៖ ផ្ទះឈើតូចតែវែង [...] ផ្ទះនោះមានចំនួនពីរកន្លែង។ [...] ស៖ តើគេដាក់អ្នកទោសនៅផ្ទះទាំងពីរនោះមែនឬទេ? ឆ.២៤៖ ចាស។"]។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៦០, ៦៣ KH 01089003-01089004 ["នៅល្ងាចមួយ ដោយសារតែនឹកម្តាយពេក ខ្ញុំក៏ទៅឈានមើលម្តាយខ្ញុំនៅមន្ទីរ ០៨ នេះ។ [...] គុក ០៨ នេះ មានផ្ទះដែលដូចជាខ្ទមតូច [...] សម្រាប់ដាក់អ្នកទោស។ ខ្ទមនេះមានប្រវែងវែង ហើយប្រហែលជា ៣ ទៅ ៤ ខ្ទម។"]។ ឯកសារ D105/20 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខលេខ ៨ KH 01397277 ["អ្នកទោសត្រូវបានរក្សាទុកនៅក្នុងក្រោលចំនួន៣"]។ ឯកសារ D1.3.27.11 កំណត់ហេតុស្រាវជ្រាវអំពីបណ្តាញពន្ធនាគារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគពាយ័ព្យរបស់ ហេនរី ឡូការ រឿងរ៉ាវរបស់ ចាវ គិម ទិត KH 00233420 ["គុកលេខ ៨ [...] [សាក្សី] បានបញ្ជាក់ថា នៅក្នុងគុករហូតដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ គុកនោះមានអគារធំ៤ខ្នង៖ មួយខ្នងសម្រាប់កុមារ ពីរសម្រាប់អ្នកទោសភេទប្រុស និងមួយសម្រាប់អ្នកទោសភេទស្រី។"]។ ឯកសារ D5/834/3 ព័ត៌មានបន្ថែមលើពាក្យតាំងសុំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទេព ហឿន KH 01048943 ["ពេលមកហើយ ខ្ញុំបានចូលនៅក្នុងគុក ឃើញ [...] ជង្រុកស្រូវ [...] ចំនួន៣។ ជង្រុកនេះ ជាកន្លែងសម្រាប់ដាក់អ្នកទោស។"]។ ឯកសារ D5/831/3 ព័ត៌មានបន្ថែមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត គួន KH 01048941 ["នៅក្នុងគុក មានជង្រុកស្រូវ សម្រាប់ដាក់អ្នកទោស"]។ ឯកសារ D5/807/3 ព័ត៌មានបន្ថែមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត អ៊ាម KH 01048936-01048937 ["គុកលេខ ០៨ [...] ខ្ញុំបានដឹងពីស្ថានភាពគុកនេះ តាមការរៀបរាប់របស់ម្តាយខ្ញុំ ដែលគាត់ធ្លាប់ជាប់គុកនៅទីនោះ។ [...] ។ ក្នុងគុក មានខ្ទម ៤ ទៅ ៥ ខ្នង [...] សម្រាប់ឲ្យអ្នកទោសដេក។"]។

គុកនេះ មានរោងបាយឈើមួយដោយមានដំបូលប្រកស្សូវ ផ្ទះសម្រាប់កម្មាភិបាល និងកងឈ្លប គុកពិសេស ត្រពាំងទឹក និងរណ្តៅសាកសព[2619]។

717. បន្ទាប់ពីអ្នកទោសត្រូវបានសម្លាប់រួចហើយ សាកសពរបស់ពួកគេត្រូវបានយកទៅកប់នៅទីកន្លែងផ្សេងៗស្ថិតនៅខាងក្រៅជិតនឹងបរិវេណគុក។ ទីកន្លែងទាំងនេះរួមមានទីតាំងបឹងត្រឡែង ស្រះត្រឡាច និងភូមិតាម៉ៅ[2620]។ រណ្តៅកប់សាកសពទាំងនេះមានទំហំខុសៗគ្នាសម្រាប់កប់សាកសពពីបីសាកសពរហូតដល់ជាង ២០០ សាកសព[2621]។

[2619] ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃីម សារុន ឆ.៤១, ៤៣, ៤៦ KH 01088796-01088797។ ឯកសារ D1.3.27.11 កំណត់ហេតុស្រាវជ្រាវអំពីបណ្តាញពន្ធនាគារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគពាយ័ព្យរបស់ ហេនរី ឡូការ រឿងរ៉ាវរបស់ ចាវ គិម ទិត KH 00233420។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃីម សារុន ឆ.៤៧ KH 01088797។ ឯកសារ D105/9 កំណត់ហេតុស្តាប់ចម្លើយ ប៊ីង អ៊ីន ឆ.៥៨ KH 00794124។

[2620] ឯកសារ D105/20 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខលេខ ៨ KH 01397278។ ឯកសារ D1.3.10.6 របាយការណ៍ប្រលប្ធីជសាសន៍ ខេត្តពោធិសាត់ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា EN 00217581 ["គុកនោះ ត្រូវបានហៅថា 'ស' គុកលេខ ៨ [...] ហើយមានសាកសព ត្រូវបានកប់ក្នុងរណ្តៅជាច្រើន"។]។ *សូមមើលផងដែរ* V.B.6.a.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់ ៧ – មន្ទីរសន្តិសុខលេខ ៨ – ឧក្រិដ្ឋកម្ម – ឃាតកម្ម ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងទៀត (ការបាត់ខ្លួន ដោយបង្ខំ)។

[2621] ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៥១-៨២ KH 01149900 ["មានតែរណ្តៅនៅកូនភ្នំតូចមួយ នៅមានចម្ងាយប្រហែលជា ៥០០ ទៅ ៦០០ ម៉ែត្រ ទៅគុកលេខ៨។ [...] មានមួយជួរដប់ៗ ហើយសរុបប្រហែលជា២០០នាក់។ ជួរខ្លះ មានដប់ ជួរខ្លះមានប្រាំសាកសព។ [...] ខ្ញុំឃើញដោយផ្ទាល់ ព្រោះ [...] ខ្ញុំដើរកាត់កន្លែងនោះរាល់ថ្ងៃ [...] ក្នុងរបបខ្មែរក្រហមគ្រប់គ្រង។"]។ ឆ.៧៩, ៩០ KH 01149903-01149904 ["មានសាកសពប្រហែល ៣០០ សាកសព នៅខាងជើងគុកលេខ ៨ ដែលមានចម្ងាយប្រហែលជា ៤០០ ម៉ែត្រ ពីគុក។ [...] ប្រហែលជា ១០ ម៉ែត្របួនជ្រុង ហើយជម្រៅមួយម៉ែត្រកន្លះ។"]។ ឯកសារ D5/834/3 ព័ត៌មានបន្ថែមលើពាក្យតាំងសុំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទេព ហ៊ីន KH 01048942-01048943។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉ែងលី ឆ.៨៩-៩០ KH 01158601។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.១២២, ១២៥ KH 01158640 ["មួយរណ្តៅស្រះត្រឡាចហ្ម៉ង មានចំនួនជាង ៧០០។ [...] ខ្ញុំបានឃើញ មុនពេលវៀតណាមចូលមកចំនួន២អាទិត្យ។"]។ ឯកសារ D6.1.161 កំណត់ហេតុស្តាប់ចម្លើយ ស៊ីយ សេងឈន KH 00196818 ["ឈ្មោះ ម៉ុក នី បានរួចខ្លួន [ពីការសម្លាប់] នៅចុងឆ្នាំ១៩៧៨ [...]។ គាត់បានប្រាប់ខ្ញុំថា គេយកប្រជាជនដែលជាប់នៅមន្ទីរ ក្បាលឈើពុក នេះទៅវាយសម្លាប់ចោលនៅក្នុងស្រះ ក្បែរមន្ទីរ ក្បាលឈើ ពុក ប្រហែលជាខ្នង់២០០០នាក់។"]។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ីុ ឆ.៤៩, ៥៨, ៦០ KH 01102860, 01102861។ ឯកសារ D219/55[5] កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.១២២ KH 01158646-01158647។ ឯកសារ D1.3.10.6 របាយការណ៍ប្រលប្ធីជសាសន៍ ខេត្តពោធិសាត់ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា EN 00217581 ["សាកសព ត្រូវបានកប់ក្នុងរណ្តៅនីមួយៗ មានទំហំ ១០ ម៉ែត្រ គុណនឹង ១០ ម៉ែត្រ ហើយមានជម្រៅប្រវែង ២,៥ ម៉ែត្រ និង ៣ ម៉ែត្រ។"]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

718. គុកលេខ ៨ នេះស្ថិតក្រោមសិទ្ធិអំណាចរបស់គណៈស្រុកកណ្តៀង។ បន្ទាប់ពីមានការបោសសម្អាតកម្មាភិបាលភូមិភាគពាយ័ព្យក្នុងស្រុកកណ្តៀង នៅអំឡុងពេលពីដើមឆ្នាំ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧[2622] កម្មាភិបាលភូមិភាគនិរតី ឈ្នោះ ទ្រី បានដឹកនាំគណៈស្រុកកណ្តៀងនេះបានរយៈពេលពីរបីខែប៉ុណ្ណោះ[2623] មុនពេលគាត់ត្រូវបានចាប់ខ្លួន និងបញ្ជូនទៅមន្ទីរ ស-២១ ហើយត្រូវបានសម្លាប់។ ឈ្នោះ ទ្រីនេះត្រូវបានជំនួសដោយកម្មាភិបាលភូមិភាគបស្ចឹម ឈ្នោះ យាយណាន់[2624] ដែលបន្តដឹកនាំរហូតដល់ពេលចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[2625]។

719. ស្រុកកណ្តៀងស្ថិតក្នុងក្រោមការគ្រប់គ្រងតំបន់ ៧ ហើយតាសារុនមានតួនាទីជាលេខាតំបន់ ៧។ តាសារុនបានចូលរួមក្នុងកិច្ចប្រជុំជាមួយតាម៉ុក ដែលក្នុងពេលប្រជុំនោះ តាសារុនបានទទួលបញ្ជា

[2622] *សូមមើល* V.B.1.b.ii ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – វិសុទ្ធកម្ម – វិសុទ្ធកម្មរបស់ភូមិភាគពាយ័ព្យ ពីថ្នាក់ភូមិភាគ ទៅថ្នាក់តំបន់ – វិសុទ្ធកម្មពីថ្នាក់តំបន់ – តំបន់៧។

[2623] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.២៨, ៣១ KH 00947331។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៉ឹង ហៅ សាត សុខុម ឆ.៧-៨ KH 00947346។ ឯកសារ D6.1.617 កិច្ចសម្ភាសន៍របស់SOASជាមួយ សាត សុខុម KH 00590218។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.៣២ KH 00947342។ ឯកសារ D219/825.1.2 បញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៩៣៦ KH 01222694 [មុយ ទ្រី ជំនួយការស្រុករំដៀង តំបន់ ៧ មុនកងពល ៧០៣ (គណៈស្រុករំដៀង តំបន់ ២ មុនកងពល ៧០៣) ចាប់ខ្លួននៅមន្ទីរស-២១ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨]។

[2624] ឯកសារ D219/825.1.2 បញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៩៣៦ KH 01222694 [មុយ ទ្រី ជំនួយការស្រុករំដៀង តំបន់ ៧ មុនកងពល ៧០៣ (គណៈស្រុករំដៀង តំបន់ ២ មុនកងពល ៧០៣) ចាប់ខ្លួននៅមន្ទីរស ២១ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨]។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.២៨ KH 00947331។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៉ឹង ហៅ សាត សុខុម ឆ.១៩-២០ KH 00947347-00947348។ ឯកសារ D219/849 កំណត់ហេតុស្តាប់ចម្លើយ ស្ងួ ណាន់ ហៅ យាយណាន់ ឆ.២១-២២ KH 01339988-01339989។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥១-៥៣ KH 01348864-01348865។ ឯកសារ D6.1.643 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង ឆាត់ KH 00369244។ ឯកសារ D6.1.617 កិច្ចសម្ភាសន៍របស់ SOAS ជាមួយ សាត សុខុម KH 00590218។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៩៥ KH 01089009។

[2625] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.២៨, ៤៣ KH 00947331-00947333។ ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស្ងួ ណាន់ ហៅ យាយណាន់ ឆ.១៥, ២០ KH 00498371-00498373។ ឯកសារ D219/849 កំណត់ហេតុស្តាប់ចម្លើយ ស្ងួ ណាន់ ហៅ យាយណាន់ ឆ.២១-២២ KH 01339988-01339989។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥៥, ៥៧ KH 01348865។

ឲ្យផ្សព្វផ្សាយនៅក្នុងតំបន់របស់គាត់។ បញ្ហានេះដែលរួមមានខ្លឹមសារថាតើប្រជាជនណាត្រូវផ្តោតជាគោលដៅស្មើបអង្កេត និងសម្លាប់អ្នកមានខ្សែរយៈវៀតណាម[2626]។ តាសារុន បានចាត់តាំង ណាន់ ឲ្យធ្វើជាលេខាស្រុក[2627]។

720. បន្ទាប់ពីណាន់បានឡើងកាន់អំណាចស្រុករួចមក ការសម្លាប់មនុស្សមានការកើនឡើង។ យានណាន់បានចេញបញ្ជាទៅកម្មាភិបាលនៅថ្នាក់ឃុំ និងសហករណ៍ឲ្យសម្លាប់ប្រជាជនមកពីភូមិភាគបូព៌ា និង "ប្រជាជន ១៧ មេសា" ក្នុងនោះរួមទាំងស្ត្រី កុមារ និងមនុស្សចាស់[2628]។ គាត់ក៏ជាវាគ្មិន និងប្រធានអង្គប្រជុំនានា នៅក្នុងស្រុក និងទីកន្លែងជាច្រើននៅក្នុងខេត្ត ដែលក្នុងពេលនោះ គាត់បានបញ្ជាដល់អ្នកចូលរួមប្រជុំប្រមាណពី ១០០ ទៅ ៣០០ នាក់ "ឲ្យខិតខំធ្វើការដើម្បីសម្រេចតាមផែនការ"[2629]។ ប្រធានសហករណ៍ និងប្រធានកងបានរៀបចំឲ្យមានកិច្ចប្រជុំស្វ័យទិតៀនយ៉ាង

[2626] ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.១០៣, ១០៤, ១០៦-១០៧ KH 01347279 [លេខាស្រុកបាកាន៖ "ឆ.១០៣៖ [តាម៉ុក] តាមរយៈលោក សារុន។ [...] ឆ.១០៤៖ [...] បានដឹងថា តាសារុន ហ្នឹងទៅប្រជុំជាមួយគាត់ [តាម៉ុក] [...] ស៖ [...] ស៖ តាសារុន បានប្រាប់លោកស្រីថា គាត់បានប្រជុំជាមួយតាម៉ុក ហើយ តាសារុន ថាប្រាប់លោកស្រីថា តាម៉ុក បានណែនាំឲ្យយើងផ្តោតគោលដៅស្រាវជ្រាវ និងលុបបំបាត់អ្នកមានខ្សែដែលរយៈវៀតណាម។ តើត្រឹមត្រូវឬទេ? ឆ.១០៦៖ ចាស។ [...] ឆ.១០៧៖ [សារុន] គាត់បានទទួលផែនការ ហើយគាត់បានហៅប្រជុំទាំងអស់គ្នាឲ្យទទួលផែនការតែម្តង។"]។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៨, ៤២ KH 01348857 KH 01348863 ["[តាម៉ុក និង សារុន] ទៅជួបគ្នានៅបាត់ដំបង។ [...] តាសារុន ដដែលហ្នឹង គាត់ណែនាំ គាត់ទៅជួបថ្នាក់លើទៀត។"]។ ឆ.៦១ KH 01348866។

[2627] ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស្ងៃ ណាន់ ហៅ យាយណាន់ ឆ.២០, ២២-៣៣ KH 00498372 KH 00498373-00498376 [ស្ងៃ ណាន់ បានអះអាងថា គាត់ត្រូវបានតែងតាំងជាគណៈស្រុកកណ្តៀង ដោយ សារុន។ ប៉ុន្តែ គាត់បានបដិសេធមិនទទួលតំណែងនោះទេ]។ សូមមើលផងដែរ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥១ KH 01348864 ["យាយណាន់ [...] មកស្រែករជាមួយ ពូសារុន។"]។

[2628] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៣៤, ៣៨-៣៩, ៤៦ KH 00947332-00947333។ ឯកសារ D6.1.618 ការសម្ភាសន៍របស់ SOAS ជាមួយសាត ឆាង KH 00721704។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៥០, ៥៤, ៥៦ KH 01067973-01067974។

[2629] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥៥ KH 01348865។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៉ឹង ហៅ សាត សុខុម ឆ.២៥-២៧ KH 00947348។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.២៩, ៣១ KH 00947316។

ទៀងទាត់[2630] ដែលក្នុងអំឡុងពេលប្រជុំទាំងនោះ ពួកគេបាននិយាយអំពីការបោសសម្អាតផ្ទៃក្នុង[2631]។

721. នៅក្នុងចំណោមសហករណ៍ដែលស្ថិតក្រោមសិទ្ធិអំណាចរបស់ណាន់ មានសហករណ៍ភូមិស្ទឹងដឹកនាំដោយសឿន[2632] បងប្អូនស្រីរបស់ណាន់មកពីកំពង់ឆ្នាំង[2633] និងសហករណ៍ស្បៃដឹកនាំដោយមេទ័ពណាត[2634] ដែលជាបងប្អូនស្រីរបស់ណាន់[2635]។ បងប្អូនស្រីទាំងពីររបស់ណាន់បានបញ្ជាឲ្យចាប់ខ្លួនមនុស្ស និងសម្លាប់មនុស្ស ក្នុងនោះរួមទាំងប្រជាជនជម្លៀសពីភូមិភាគបូព៌ាផងដែរ[2636]។

722. នៅក្នុងសហករណ៍ដែលជាទីតាំងនៃគុកលេខ ៨ ប្រធានសហករណ៍ក្បាលឈើពុកបានបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់មនុស្ស[2637]។ ដូចគ្នានេះដែរ ប្រធានកងក្នុងតំបន់នេះបានបញ្ជាឲ្យចាប់ខ្លួនប្រជា

[2630] ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សុវណ្ណ ឆ.៤៩-៥០ KH 01036511។ ឯកសារ D6.1.761 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សុវណ្ណ KH 00373424-00373426។ ឯកសារ D6.1.161 កំណត់ហេតុស្តាប់ចម្លើយ ស៊ីយ សេងឈន KH 00196820។

[2631] ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សុវណ្ណ ឆ.៤៩, ៥០-៥៤ KH 01036511។

[2632] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៣៧, ៤៣ KH 00947332-00947333។ ឯកសារ D6.1.618 ការសម្ភាសន៍របស់ SOAS ជាមួយសាត ឆាង KH 00721704។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៉ឹង ហៅ សាត សុខុម KH 00947349-00947350។

[2633] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៣៧ KH 00947332។ *សូមមើលបន្ថែម* ឯកសារ D118/179 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ហ៊ីន ឆ.៤, ២២ KH 00974862 KH 00974864។ ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ ហៅ យាយណាន់ ឆ.៤ KH 00498369។ *ចំណាំ* បងប្អូនស្រីទាំងពីរ ស៊ូ ណាន់ និង ស៊ូ ហ៊ីន បានបដិសេធរឿងទាំងនេះ។ *សូមមើល* ឯកសារ D118/179 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ហ៊ីន ឆ.៤៩, ៥១-៥៣ KH 00974866-00974867។ ឯកសារ D134/2 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ ហៅ យាយណាន់ ឆ.៣៦ KH 00947325។

[2634] ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៥០, ៥៤, ៥៦ KH 01067973។

[2635] ឯកសារ D134/2 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ ហៅ យាយណាន់ ឆ.៣៦ KH 00947324។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៥០ KH 01067973។

[2636] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៣៨-៣៩, ៤៨-៤៩ KH 00947332-00947334។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៥០ ឆ.៥៤ ឆ.៥៦ KH 01067973-01067974។

[2637] ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៥១-៥២ KH 01089002 ["តាំងពី អាភ៌ម ចូលមកកាន់ក្តាប់សហករណ៍ក្បាលឈើពុក វាយកមនុស្សទៅសម្លាប់ចោលផ្ទើយពាយ។ នៅក្នុងកងរបស់ខ្ញុំ វាយកមនុស្សចាស់ៗទៅសម្លាប់ចោលទាំងអស់ ហើយឪពុកខ្ញុំក៏ត្រូវវាយកទៅសម្លាប់ផងដែរ។ [...] ក្នុងកងរបស់ខ្ញុំ មានមនុស្ស ៦ នាក់ ត្រូវគេយកទៅសម្លាប់រួមមាន ៖ ឪពុកមា ៥នាក់ (សាច់ឆ្ងាយ) និង ឪពុករបស់ខ្ញុំ។ គេសម្លាប់ពួកគាត់នៅចុងឆ្នាំ១៩៧៧។"]។

ជន ហើយយកទៅដាក់ឃុំឃាំងក្នុងគុកនេះ[2638]។ មកដល់ត្រឹមពាក់កណ្តាលឆ្នាំ១៩៧៨ និងបន្ទាប់ពីការមកដល់នៃប្រធានថ្មីនៅកម្រិតភូមិ ឃុំ និងស្រុក ក្នុងនោះរួមទាំងសហករណ៍ភូមិក្បាលឈើពុកផង អ្នកទោសទាំងអស់ក្នុងគុកលេខ ៨ ត្រូវបានសម្លាប់[2639]។

723. នៅដើមឆ្នាំ១៩៧៨ ប៉ុល ពត តាម៉ុក ន្ជួន ជា និងសុន សេន រួមទាំងមេបញ្ជាការយោធាផ្សេងៗទៀត បានសម្រេចធ្វើការបោសសម្អាតភូមិភាគបូព៌ា[2640]។ នៅដើមឆ្នាំ១៩៧៩ កម្មាភិបាលខ្មែរក្រហមបានធ្វើការសម្លាប់មនុស្សចុងក្រោយ ដោយផ្អែកលើផែនការចុងក្រោយក្នុងការលុប បំបាត់ប្រជាជនជម្លៀសទាំងអស់ពីភូមិភាគបូព៌ា តាមការបញ្ជាពីមន្ទីរ ៨៧០ និងតាម៉ុក លេខាភូមិភាគពាយ័ព្យ[2641]។

[2638] ឯកសារ D5/796 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ុច ហាច KH 00530392 ["ឈ្លប រាយការណ៍ឲ្យមេកងឈ្មោះ ២ៀន ក៏បញ្ជាឲ្យចាប់ប្រពន្ធទៅដាក់មន្ទីរនោះទៀត មន្ទីរឈើពុក"]។ KH 00530391 ["នៅភូមិក្បាលឈើពុក [...]មេកងឈ្មោះ ២ៀន"]។ ឯកសារ D2.1.82b សេចក្តីសង្ខេបពាក្យបណ្តឹង ប៉ាង ភឿន EN 00522328។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉ែងលី ឆ.១០៤-១០៥ KH 01158604។ ឯកសារ D1.3.27.11 កំណត់ហេតុស្រាវជ្រាវអំពីបណ្តាញពន្ធនាគារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគពាយ័ព្យរបស់ ហេនរី ឡូការ រឿងរ៉ាវរបស់ ចាវ គិម ទិត KH 00233420។

[2639] ឯកសារ D5/796 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ុច ហាច KH 00530393 ["នៅពាក់កណ្តាលឆ្នាំ១៩៧៨ មានការផ្ទាស់ឈ្លបញ៉ីកញ្ជាប់ [...] អ្នកទោសនៅមន្ទីរក្បាលឈើពុកទាំងអស់ ហើយក៏មានគណៈសហករណ៍ថ្មី មកគ្រប់គ្រងគណៈសហករណ៍ឈើពុក"]។

[2640] ឯកសារ D6.1.98 កំណត់ហេតុស្តាប់ចម្លើយ ឈូក រ៉ីន KH 00194467 ["[...]សេចក្តីសម្រេចធ្វើការបោសសំអាត ធ្វើឡើងក្រោយពីមហាសន្និបាតប្រចាំឆ្នាំរបស់បក្ស នៅដើមឆ្នាំ១៩៧៨ ដោយ ប៉ុល ពត ន្ជួន ជា តាម៉ុក សុន សេន បានធ្វើការប្រជុំពិសេសមួយ ជាមួយមេបញ្ជាការយោធា រួមទាំងរូបខ្ញុំផងដែរ នៅទីក្រុងភ្នំពេញ។"]។

[2641] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៤៧-៤៩ KH 00947333-00947334 ["ស៖ នៅក្នុងកំណត់ហេតុរបស់អង្គការសិទ្ធិមនុស្ស យើងពិនិត្យឃើញថា គេបែងចែកប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ា [...] នៅចុងឆ្នាំ១៩៧៨ [...] បានប្រមូលផ្តុំ និងបញ្ជូនពួកគេទៅសម្លាប់ចោល។ បន្ទាប់មក នៅពេលវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ ការកាប់សម្លាប់ប្រជាជនភូមិភាគបូព៌ាកាន់តែមានកម្រិតខ្លាំងក្លាឡើង។ តើលោកពិតជាបានឆ្លើយខ្ជឹមសារនេះ ប្រាប់ទៅអង្គការសិទ្ធិមនុស្ស ដែរឬទេ? ឆ.៤៧៖ បាទ ពិតប្រាកដមែនហើយ។ ពួកខ្មែរក្រហម គេចង់សម្លាប់បង្អើយឲ្យអស់តាមផែនការចុងក្រោយរបស់ពួកគេ។ [...] ស៖ នៅក្នុងកំណត់ហេតុដែលនេះផងដែរ លោកនិយាយថា លោកបានដឹងពីរឿងនេះ ពីព្រោះ ២ៀន ដែលគាត់ចូលចិត្តខ្ញុំ ហើយចង់សម្លាប់ប្រពន្ធខ្ញុំចោល ដើម្បីយកខ្ញុំធ្វើជាប្តីរបស់គាត់ ហើយគាត់ប្រាប់ខ្ញុំអំពីផែនការលុបបំបាត់ចោលពួកអ្នកជម្លៀសមកពីភូមិភាគបូព៌ា។ តើខ្ជឹមសារនេះ ត្រឹមត្រូវដែរឬទេ? ឆ.៤៨៖ បាទ [...] ឆ.៤៩៖ ខ្ញុំបានដឹងរឿងនេះ ដោយសារខ្ញុំដើរជាប់ជាមួយ ២ៀន រហូត។ ខ្ញុំបានឮ ២ៀន បញ្ជាទៅប្រធានឈ្លបឲ្យចាប់ប្រមូលប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ា ដើម្បីបញ្ជូនទៅសម្លាប់ចោលឲ្យអស់។"]។ ឯកសារ D6.1.618 ការសម្ភាសន៍របស់ SOAS ជាមួយសាត ឆាង KH 00721704។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៨៤-១៨៨ KH 01000276 ["មេកងបានឱ្យីបប្រាប់ខ្ញុំអំពីផែនការមួយ

ថា ‘តា៧៨ មានផែនការសម្លាប់អ្នកបូ៉ា៖ឲ្យអស់ក្នុងរយៈពេល៥ថ្ងៃ។’ [...] តា៧៨នេះ គឺសំដៅទៅលើគណៈ៨៧០។ [...] គណៈ ៨៧០ បានដាក់ផែនការមកដល់តា១៥។ តា១៥ បានយកផែនការនោះមកប្រជុំប្រាប់កម្មាភិបាលថ្នាក់ក្រោមបន្តទៀត។ [...] មេកង [...] ជា បានខ្សឹបប្រាប់ខ្ញុំអំពីរឿងនេះ នៅឆ្នាំ១៩៧៩ អំឡុងខែ១ ព្រោះពេលនោះវៀតណាមចូលមកដល់ក្រុងពោធិសាត់រួចទៅហើយ។ [...] ជា ជាមនុស្សនៅបាក់ចិញ្ចៀនដែរ។”]។ (ចំណាំ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៧១ KH 01000275 [“តាម៉ុក [...] ហៅតា១៥។”])។ ឆ.២១២-២១៣, ២១៦, ២១៩-២២០ KH 01000279 KH 01000280 [“ឆ.២១២៖ គណៈសហាករណ៍បានទៅចូលរួមប្រជុំ ហើយពេលគេត្រឡប់មកវិញ គេប្រជុំប្រាប់ខ្ញុំថា ‘គណៈ៨៧០ ដាក់ផែនការឲ្យសម្លាប់អ្នកបូ៉ា៥ថ្ងៃឲ្យអស់។’ ស៖ តើផែនការនេះកើតឡើងដែរឬទេ? ឆ.២១៣៖ បាទ [...] កងទ័ពបានចេញមក ហើយចាប់មនុស្សទាំងខ្សែៗតែម្តង។ ពេលនោះ លែងណាក់ការណ៍ទៀតហើយ គេសម្លាប់អ្នកបូ៉ានៅគ្រប់កន្លែងទាំងអស់។ [...] ឆ.២១៦៖ ឲ្យតែនៅសហាករណ៍បាក់ចិញ្ចៀន គឺគេសម្លាប់គ្រប់កន្លែងទាំងអស់ [...] ក្នុងមួយថ្ងៃ១ មានមនុស្សត្រូវសម្លាប់ក្នុងសហាករណ៍របស់ខ្ញុំប្រហែល៥០នាក់។ ៥ថ្ងៃក្រោយមក ទើបគេសម្រេចឲ្យឈប់សម្លាប់អ្នកបូ៉ា។ [...] ស៖ តើលោកមានស្គាល់ឈ្មោះអ្នកសម្លាប់អ្នកបូ៉ា [...]? ឆ.២១៩៖ ពួកគេជាទ័ពតំបន់ និងស្រុក។ [...] ឆ.២២០៖ ឈ្លបក៏ចូលរួមដែរ”]។

724. រហូតដល់រយៈពេលចុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងមន្ទីរសន្តិសុខនេះ ផ្នាក់ដឹកនាំមន្ទីររួមមាន តាសឿន[2642] ឈាង ប៉ោង និងម៉ោង[2643]។ ឈាងបានជំនួសជាប្រធានគុកដំបូងគេឈ្មោះ ហេង[2644]។ កម្មាភិបាលគុកទាំងនេះបានចេញបញ្ជាឲ្យសម្លាប់អ្នកទោស ដែលត្រូវបានបញ្ជូនពីកម្រិតភូមិ

[2642] ឯកសារ D105/9 កំណត់ហេតុស្តាប់ចម្លើយ ប៊ីង ភឿន ឆ.ពាព KH 00794121 ["តាមី ប្រធានធំ តាជាង ជាអនុ ហើយ តាសឿន អនុប្រធានបន្ទាប់។"]។ ឯកសារ D2.1.82b សេចក្តីសង្ខេបពាក្យបណ្តឹង ប៊ីង ភឿន EN 00522328 ["ជាង ជាប្រធានមន្ទីរសន្តិសុខ"]។

[2643] ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.៥១ KH 01158638 ["[ឈាង] មកពីខាងស្រែស្ពុក"] ឆ.៤៧ EN 01178634 ["ស៖ នៅក្នុងស្រុកបាកាន? ឆ.៤៧៖ បាទ"]។ ឆ.៧ព-៧៤ KH 01158640-01158641 ["ស៖ តើលោកដឹងទេ អ្នកណាជាមេគុក ០៨? ឆ.៧ព៖ [...] ឈាង [...] ឆ.៧៤៖ ជាប្រធានមន្ទីរ។"]។ ឆ.៨១-៨២ KH 01158641-01158642 ["ស៖ [...] តើលោកដឹងថា នៅគុក០៨ហ្នឹង មានឆ្នាំដែដល់ឬ? ឆ.៨២៖ [...] ប៉ោង។"]។ ឯកសារ D5/811/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កែ ទិន KH 01175290 ["ឈ្លបចំនួន ២ នាក់ ឈ្មោះ ជាង និង ប៉ោង បណ្តើរមនុស្ស [...] យកទៅសម្លាប់នៅភូមិតាម៉ៅ ជិតមន្ទីរ ០៨។"]។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៦៤, ៨៤ KH 01089004 KH 01089007 ["ឆ.៦៤៖ ឈ្មោះ អាប៉ោង ជាមេគុក ០៨។"]។ ឆ.ពាៜ KH 01089000- 01089001 ["ស៖ ចុះចំពោះឈ្លបនៅសហករណ៍ ក្បាលឈើពុក តើអ្នកណាជាអ្នកទទួលសុខត្រូវឈ្លប? ឆ.ពាៜ៖ មេឈ្លបក្នុងសហករណ៍ខ្ញុំឈ្មោះ អាឈាង។"]។ ឯកសារ D1.3.10.6 របាយការណ៍ប្រលប័យពូជសាសន៍ ខេត្តពោធិសាត់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា EN 00217581 ["សាក្សីពីរនាក់បានរាយការណ៍ថាឃាតករដ៏ឃោរឃៅនៃគុកលេខ ៨ គឺ ១. ឈ្មោះ ឈៀង [...] ២. ឈ្មោះ ប៉ោង (ស្លាប់) ជាឃាតករដ៏សាហាវ"]។ ឯកសារ D5/1132 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជឿ គឹមសិ KH 01026718។ ឯកសារ D5/835/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វ៉ន អ៊ីន KH 01153217។ ឯកសារ D5/835/1 របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី វ៉ន អ៊ីន EN 00951569។ ឯកសារ D5/834/3 ព័ត៌មានបន្ថែមលើពាក្យតាំងសុំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទេព ហ៊ីន KH 01048942-01048943 ["គុកលេខ ០៨ [...] ប្រធានក្តាប់រួមនៅទីនោះឈ្មោះ អាច ប៉ាង មកពីភាគខាងលិច"]។ ឯកសារ D2.1.86b សេចក្តីសង្ខេបពាក្យបណ្តឹង ហាម ឈ EN 00461318 ["មន្ទីរសន្តិសុខ ក្បាលឈើពុក [...] ប៉ោង ជាប្រធានមន្ទីរសន្តិសុខ។"]។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៦៤-៦៥ KH 01089004 ["ឆ.៦៤៖ ឈ្មោះ អាប៉ោង ជាមេគុក ០៨។ ស៖ តើ អាប៉ោងជាមនុស្សមកពីស្រុកណា? ឆ.៦៥៖ [...] តែភាគច្រើន ច្រើនតែមកពីខាងលិចមកវិញ។"]។ ឯកសារ D5/834/3 ព័ត៌មានបន្ថែមលើពាក្យតាំងសុំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទេព ហ៊ីន KH 01048942-01048943 ["គុកលេខ ០៨ [...] អាច ប៉ាង មកពីភាគខាងលិច"]។

[2644] ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.ពាព KH 01158640-01158641។

ភាគ[2645]។ ប្រធានគុកត្រូវបានគេប្រទះឃើញថាបានចូលរួមក្នុងការសម្លាប់មនុស្ស[2646]។ កងឈ្លប ដែលមានបំពាក់អាវុធ រួមទាំងក្មេងប្រុសផង ជាអ្នកយាមមន្ទីរសន្តិសុខនេះ[2647]។

iv. ឧក្រិដ្ឋកម្ម

<u>ការដាក់ពន្ធនាគារ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការប្រព្រឹត្តដោយអមនុស្សធម៌)</u>

725. បុគ្គលទាំងឡាយត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅគុកលេខ ៨ ដោយគ្រាន់តែពួកគេជាសមាជិកក្រុមដែល ប.ក.ក យល់ថាជា "ខ្មាំង"។ អ្នកទោសមានទាំងចាស់ទាំងក្មេង[2648] និងមានទាំងអតីត

[2645] ឯកសារ D105/9 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាង ភឿន ឆ.៣៣-៣៤ KH 00794121 ["អ្នកទាំង៣នេះ មិនមែនជាអ្នកសម្លាប់ទេ តែទទួលបញ្ជាពីថ្នាក់លើមកឲ្យសម្លាប់។ ស៖ តើលោកស្រីគិតថា អ្នកណាជាអ្នកចេញបញ្ជាឲ្យអ្នកទាំង៣នាក់នេះ? ឆ.៣៤៖ ពីកន្លែងខេត្តមក"]។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៦០ KH 01102861 ["ឈ្លប [...] បើគេឲ្យសម្លាប់ ទើបពួកវាសម្លាប់។"]។

[2646] ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.៨៥-៨៦ KH 01158642 ["ខ្ញុំឃើញ [ប៉ោង] ចំនួន៣ដង"]។ ឆ.៩៩ KH 01158644 ["ស៖ តើប្រជាជនទាំងអស់នោះ ត្រូវបានគេបណ្តើរចេញពីគុកឬ? ឆ.៩៩៖ បាទ។"]។ ឯកសារ D5/811/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កែ ទិន KH 01175290-01175291 ["ឈ្លបចំនួន ២ នាក់ ឈ្មោះ ជាង និង ប៉ោង [...] គាត់បានដឹងថា អ្នកដែលយកមនុស្សទៅសម្លាប់នៅមន្ទីរ ០៨ ឬនៅក្បែរមន្ទីរ ០៨ មានឈ្មោះ ជាង និង ប៉ោង ព្រោះពីរនាក់នេះ គឺតែងតែឃើញបណ្តើរមនុស្សយកទៅសម្លាប់"]។ ឯកសារ D5/1132/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជ្រើ គឹមធិ KH 01327024 ["មន្ទីរ ០៨ [...] អ្នកដែលតែងតែយកមនុស្សទៅសម្លាប់មានឈ្មោះ អាប៉ោង [...] គ្រាន់តែបានទៅក្បែរទីនោះ នៅពេលដែលទៅធ្វើការ"]។ ឯកសារ D5/835/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វ៉ន អ៊ិន KH 01153217។

[2647] ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្ងួន ហៀ ឆ.៤៧ KH 01067955-01067956។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.៩៤ KH 01158643។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៧៣, ៧៦, ៨០ KH 01067977-01067978។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉ែងលី ឆ.៤៤-៤៥ KH 01158594-01158595។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៦០ KH 01089004។ ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម សុវណ្ណ ឆ.២២, ២៥, ៣១ KH 01036506-01036507។ ឯកសារ D5/834/3 ព័ត៌មានបន្ថែមលើពាក្យតាំងសុំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទេព ហ្ជឿន KH 01048942-01048943។ ឯកសារ D5/807/3 ព័ត៌មានបន្ថែមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត អ៊ាម KH 01048936។ ឯកសារ D219/554 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត គួន ឆ.៥៤ KH 01158620។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉ែងលី ឆ.៤៤-៤៥ KH 01158594-0115895 ["ឈ្លបវាតូចៗ ស្លាយកាំភ្លើង។ [...] វាត្រឹម២នាក់ [...] ឈ្លបវា តូចៗ [...] ប្រហែលខ្ពះ១៥ ខ្ពះ១៦ អាខ្ពះស្លាយកាំភ្លើងអ្ងួសដី"]។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៦០ KH 01089004។

[2648] ឯកសារ D5/450/3 ប្រតិចារឹក យ៉ឹម សុវណ្ណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង16.01.24-16.03.31។ ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម សុវណ្ណ ឆ.៧ KH 01036503-01036504 ឆ.៤៦-៤៧ KH 01036510-01036511។ ឯកសារ

ទាហាន លន់ នល់ និងគ្រួសាររបស់ពួកគេ[2649] ប្រជាជនជម្លៀសពីភ្នំពេញ[2650] "ពួកសក្តិភូមិ"[2651] "ពួកចក្រពត្តិ"[2652] និងប្រជាជនដែលរងការចោទប្រកាន់ថាជាគិញសេអ៊ីអា[2653] ឬខ្មាំងរបស់អង្គការ[2654]។ អ្នកទោសទាំងនេះក៏មាន "ប្រជាជនសាមញ្ញ"[2655] ពីភូមិ សហករណ៍ និងស្រុកក្នុងតំបន់ ៧[2656] ផង ដែរ។ ប្រជាជនទាំងនេះត្រូវបានចាប់ខ្លួនដោយសារមូលហេតុផ្សេងៗ ក្នុងនោះរួមមាន

D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.៨៥ ឆ.៩៩ KH 01158642 KH 01158644។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃីម សារុន ឆ.៧២ KH 01088799។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉េងលី ឆ.១៤, ៦៩, ៨០-៨២ KH 01158589 – 0115890 KH 01158598 KH 01158600។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៤៨ KH 01149900។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៧៧ KH 01067977។ ឯកសារ D219/554 កំណត់ហេតុនៃការស្តាប់ចម្លើយ ង៉ែត គួន ឆ.៦១, ៦៤ KH 01158621។ ឯកសារ D1.3.27.11 កំណត់ហេតុស្រាវជ្រាវអំពីបណ្តាញពន្ធនាគារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគពាយ័ព្យរបស់ ហេនរី ឡូការ រឿងរ៉ាវរបស់ ចាវ គិម ទិត KH 00233420-00233421។ ឯកសារ D2.1.85a ពាក្យបណ្តឹងរបស់ ក្ង ម៉ុលលី KH 00461290-00461291។

[2649] ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៥៣, ៥៧ KH 01149900-01149901។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៧៧ KH 01067977។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃីម សារុន ឆ.៦០ KH 01088798។ ឯកសារ D5/831/3 ព័ត៌មានបន្ថែមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត គួន KH 01048940-01048941 ។ ឯកសារ D2.1.86b សេចក្តីសង្ខេបពាក្យបណ្តឹង ហម ឈុយ EN 00461318។ ឯកសារ D2.1.79b សេចក្តីសង្ខេបពាក្យបណ្តឹង ជ្ជូប កែប EN 00461271។

[2650] ឯកសារ D219/554 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត គួន ឆ.៦១, ៦៤ KH 01158621។ ឯកសារ D5/831/3 ព័ត៌មានបន្ថែមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត គួន KH 01048941។

[2651] ឯកសារ D5/835/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វន អ៊ិន KH 01153217។ ឯកសារ D5/787/1 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គី ប៉ោ EN 00915833។

[2652] ឯកសារ D5/835/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វន អ៊ិន KH 01153217។

[2653] ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ ឆ្ង ម៉ុលលី ឆ.២៤, ២៦ KH 01088998-01088999។ ឯកសារ D2.1.85a ពាក្យបណ្តឹងរបស់ ក្ង ម៉ុលលី KH 00461289-00461291។ ឯកសារ D5/835/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វន អ៊ិន KH 01153217។

[2654] ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ ឆ្ង ម៉ុលលី ឆ.៦៦ KH 01089004-01089005។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ីរ ឆ.៥៩ KH 01102861។ ឯកសារ D2.1.81b សេចក្តីសង្ខេបពាក្យបណ្តឹង កែ អ៊ីរ EN 00461282 ។ ឯកសារ D2.1.83b សេចក្តីសង្ខេបពាក្យបណ្តឹង អ៊ីយ ឡុក EN 00522347។

[2655] ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៥៣ KH 01149900។

[2656] ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ ឃីម សុវណ្ណ ឆ.១៥-១៦ KH 01036505។

ការប្រព្រឹត្ត "ខុសសីលធ៌ម"[2657] ប៉ុនប៉ងរត់គេចខ្លួន[2658] គេចចេញពីការងារ[2659] លួចអាហារ[2660] និងខកខានមិនបានគោរពគោលនយោបាយបរិភោគរួម[2661]។ អ្នកទោសពីគុកលេខ ៧ ដែលត្រូវបានពិនិត្យមើលឃើញថាបានរំលោភយ៉ាងធ្ងន់ធ្ងរលើគោលនយោបាយ ប.ក.ក ជាងកំហុសគ្ពងទាំងនេះ ត្រូវបានបញ្ជូនទៅគុកលេខ ៨[2662]។

[2657] ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃឹម សារុន ឆ.៦០ KH 01088798។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ្ជឿន ឆ.៥៧ KH 01149901។ ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ ឃឹម សុវណ្ណ ឆ.៨៩ KH 01036515។ ឯកសារ D6.1.761 កំណត់ហេតុស្តាប់ចម្លើយ ឃឹម សុវណ្ណ KH 00373427-0037328។ ឯកសារ D2.1.74b សេចក្តីសង្ខេបពាក្យបណ្តឹង ស៊ីម សុខេង EN 00522211 (*ចំណាំ* ថ្វីបើដើមបណ្តឹងរដ្ឋប្បវេណីយោងទៅលើមន្ទីរ ជាមន្ទីរសន្តិសុខលេខ ០៩ ក៏ដោយ ក៏គាត់កំណត់ទីតាំងនៅក្នុងភូមិក្បាលឈើពុក។ *សូមមើល* EN 00522211)។

[2658] ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្ជន ហ្ជៀ ឆ.៦៣ KH 01067958 ឆ.៤០, ៤២–៤៣ KH 01067954-01067955។ ឯកសារ D2.1.77b សេចក្តីសង្ខេបពាក្យបណ្តឹង អ្ជន ហ្ជៀ EN 00522273។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៥២ KH 01102860។ ឯកសារ D5/1132 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជ្ជឿ គ៉ីមស៊ី KH 01026719។ ឯកសារ D5/807/3 ព័ត៌មានបន្ថែមលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត អ៊ាម KH 01048936-01048937។ (*ចំណាំ* ឯកសារ D5/807/1 សេចក្តីសង្ខេបពាក្យបណ្តឹង ង៉ែត អ៊ាម EN 00918472-00918473)។ ឯកសារ D219/979.1.9 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សុខ ខន KH 00555600-00555601។ ឯកសារ D5/812/1 សេចក្តីសង្ខេបពាក្យបណ្តឹង ប៊ិន ឈា EN 00918558។

[2659] ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃឹម សារុន ឆ.៦០ KH 01088798។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ្ជឿន ឆ.៥៧ KH 01149901។

[2660] ឯកសារ D5/450/3 ប្រតិចារ៉ឹក ឃឹម សុវណ្ណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង 15.46.38-15.51.18។ (*ចំណាំ* ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ ឃឹម សុវណ្ណ ឆ.៤៧ KH 01036511)។ ឯកសារ D6.1.761 កំណត់ហេតុស្តាប់ចម្លើយ ឃឹម សុវណ្ណ KH 00373425-00373426។ ឯកសារ D6.1.161 កំណត់ហេតុស្តាប់ចម្លើយ ស៊ីយ សេងឈន KH 00196817-00196818។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ្ជឿន ឆ.៤៧ KH 01149900។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃឹម សារុន ឆ.៨-៩, ៤០, ៦០ KH 01088794, 01088796, 01088798។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៦៦ KH 01089004-01089005។ ឯកសារ D2.1.73b សេចក្តីសង្ខេបពាក្យបណ្តឹង ទី រ៉ុន EN 00522193។ ឯកសារ D5/796 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ុច ហាច KH 00530392។

[2661] ឯកសារ D105/9 កំណត់ហេតុស្តាប់ចម្លើយ ប៉ាង ហ្ជឿន ឆ.១៤, ១៧-២១ KH 00794119, 00794120។

[2662] ឯកសារ D5/450/3 ប្រតិចារ៉ឹក ឃឹម សុវណ្ណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង 15.58.55-16.01.20។ ឯកសារ D6.1.761 កំណត់ហេតុស្តាប់ចម្លើយ ឃឹម សុវណ្ណ KH 00373424-00373426។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៥២ KH 01102860។

726. កងកម្លាំង ប.ក.ក ក៏បានឃុំឃាំងប្រជាជនជម្លៀសពីភូមិភាគបូព៌ាយ៉ាងច្រើន នៅក្នុងគុកលេខ ៨[2663] ។ ប្រជាជនជម្លៀសទាំងនេះត្រូវបានតម្រង់ទិសដៅជាពិសេសដើម្បីយកទៅសម្លាប់ចោល[2664] ។ យ៉ា

[2713] ឯកសារ D5/834 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទេព ហ៊ីន KH 00951565 ["ឆ្នាំ១៩៧៧-១៩៧៨ ខ្ញុំបាទបានឃើញពួកឃ្លាំ ត្រូវគេដឹកតាមរទេះភ្លើង មកដាក់នៅខេត្តពោធិសាត់ ហើយពួកវាចងបណ្តើរទាំងខ្សែ មកចូលក្នុងមន្ទីរ ០៨។ ហើយវាបញ្ចេញវិញ នៅពេលជិតព្រលប់"]។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៦១-៦២, ៧៩-៨០, ៨៣ KH 01149901, 01149903 ["មានតែរណ្តៅ[...]មួយ [...] គឺមានសាកសពប្រហែល ៣០០ សាកសព មានចម្ងាយប្រហែក ៥០០ ទៅ ៦០០ ម៉ែត្រ ទៅគុក ៨។ [...] នៅខាងជើងគុកលេខ៨ ដែលមានចម្ងាយប្រហែល ៤០០ ម៉ែត្រ ពីគុក។"]។ ឯកសារ D5/830 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គី ប៉េងលី KH 00951501 ["ពេលយប់ ខ្ញុំឮសូរសម្រែកវាយបណ្តើរ ប្រមូលយកទៅមានចាស់ មានក្មេង បណ្តើរទៅមន្ទីរ ០៨។។"]។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ុ ឆ.៥១ KH 01102860 ["ស៖ តើលោកស្រីមានបានឃើញផ្ទាល់ភ្នែក [...] ការដឹកមនុស្សទៅគុកក្បាលឈើពុកហ្នឹងទេ? ឆ.៥១៖ ឃើញ។ ព្រលប់ៗឡើង ឃើញហើយ។ ខ្ញុំនៅជិតហ្នឹង។"]។ ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សុវណ្ណ ឆ.១៨-១៩ KH 01036505-01036506 ["ខ្ញុំឃើញមនុស្សគេបណ្តើរច្រើនដង [...] ដូច្នេះ ហើយគេចាប់មនុស្ស [...] ទៅសម្លាប់។"]។ ឯកសារ D5/1132 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជ្ងឿ គឹមសិ KH 01026719 ["នៅ [...] នៅឆ្នាំ១៩៧៨ [...] បណ្តើរ [...] ចំនួន ៤២ នាក់ យកពីមន្ទីរសន្តិសុខ ០៨ យកទៅសម្លាប់នៅឃុំតាម៉ៅ។"]។ (*ចំណាំ* ឯកសារ D5/1132/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជ្ងឿ គឹមធិ KH 01327024 ["គាត់ធ្លាប់ឃើញគេ បណ្តើរមនុស្សយកទៅសម្លាប់ជាច្រើនដងដែរ នៅពេលដែលគាត់ទៅធ្វើស្រែនៅជិតទួលតាឡែង"])។ ឯកសារ D5/1132 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជ្ងឿ គឹមសិ KH 01026719 ["នៅឆ្នាំ១៩៧៧-១៩៧៨ ខ្ញុំបានឃើញគេបណ្តើរមនុស្សទាំងខ្សែៗ ប្រហែល ២០ ទៅ ៣០ នាក់ [...] យកទៅសម្លាប់នៅទួលតាឡែង [...] នៅឆ្នាំ១៩៧៨ [...] បណ្តើរមនុស្សពីបន្ទាយ ចងខ្សែ [...] ចំនួន ១០ ទៅ ២០ នាក់ [...] យកទៅវាយនៅទួលតាឡែង។"] ហើយ ["ចំនួន ៤២ នាក់ យកពីមន្ទីរសន្តិសុខ ០៨ យកទៅសម្លាប់នៅឃុំតាម៉ៅ។"]។ (*ចំណាំ* ឯកសារ D5/1132/3 ព័ត៌មានបន្ថែមទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជ្ងឿ គឹមធិ KH 01327023-01327024 ["ក្នុងសម័យខ្មែរក្រហម [...] គឺរស់នៅភូមិក្បាលឈើពុក [...] គាត់ធ្លាប់ឃើញគេបណ្តើរមនុស្សយកទៅសម្លាប់ជាច្រើនដងដែរ នៅពេលដែលគាត់ទៅធ្វើស្រែនៅជិតទួលតាឡែង"])។

ពាន់នាក់ ត្រូវបានសម្លាប់" នៅគុកលេខ ៨ នេះ[2714] ដោយចំនួននៃការសម្លាប់មនុស្សក្នុងមួយថ្ងៃៗ បានកើនឡើងដល់កម្រិតអតិបរមា នៅពេលទ័ពវៀតណាមបានចូលជិតដល់គុកនេះ[2715]។

[2714] ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៥៩ KH 01149901 ["ស៖ តើលោកមានដឹងចំនួនមនុស្សនៅគុកលេខ ៨ ដែលត្រូវបានសម្លាប់ទេ? ឆ.៥៩៖ មានរាប់ពាន់ សម្លាប់បណ្តើរៗ។ ពេលយួនចូលហ្នឹង គឺសម្លាប់ប្រហែលជា ៣០០ នាក់ទៀត។"]។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៥០, ៥២-៥៣ KH 01102860 ["បើតាមពួកស្វាយរៀងនិយាយមកថា [...] គេ [ខ្ញែរក្រហម [...] ដឹកទៅមន្ទីរក្បាលឈើពុក ហើយសម្លាប់។ [...] ចាប់ពីឆ្នាំ៧៧ ដល់បែករបប ប៉ុល ពតតែម្តង។ [...] យ៉ាងតិចក៏ ៥០០០ នាក់ដែរ ដែលបាត់ខ្លួន។"]។ ឆ.៥១-៥២ KH 01102860 ["ខ្ញុំនៅជិតហ្នឹង [...]០ផ"]។ ឯកសារ D5/450/3 ប្រតិចារឹក យ៉ឹម សុវណ្ណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង 16.01.24-16.03.31 KH 00855249-00855250 ។ ឯកសារ D6.1.761 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម សុវណ្ណ KH 00373425-00373426។ ហើយដែលបានកើតឡើង នៅចុងឆ្នាំ១៩៧៨ (*សូមមើល* ឯកសារ D219/979.1.6 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យ៉ឹម សុវណ្ណ KH 00359337)។ ឯកសារ D2.1.87b សេចក្តីសង្ខេបពាក្យបណ្តឹង សំ តន EN 00522358 ["នៅសហករណ៍ក្បាលឈើពុក នៅក្នុងភូមិក្បាលឈើពុក [...] បានឃើញប្រជាជនជាច្រើនត្រូវ [...] សម្លាប់នៅមន្ទីរសន្តិសុខ និង [...] ក្បែរនោះ។ គាត់និយាយថា មនុស្សប្រហែល ៧៧០ នាក់ ត្រូវបានសម្លាប់នៅទីនោះ។"]។

[2715] ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.១២២, ១២៥ KH 01158647 ["មួយរណ្តៅស្រះតាឡាចហ្នឹង មានចំនួនជាង ៧០០។ [...] ខ្ញុំបានឃើញមុនពេលវៀតណាម ចូលមកចំនួន ២ អាទិត្យ"]។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៥១ KH 01149900 ["អ្នកមកពីស្វាយរៀង ត្រូវបានសម្លាប់ [...] នៅគុកលេខ៨ មានការសម្លាប់មនុស្សប្រហែលជា១០ថ្ងៃ ឬកន្លះខែ មុនពេលកងទ័ពវៀតណាមចូលមកដល់។"]។ ឆ.១០៣, ១០៦, ១១២-១១៣ KH 01149905-01149906 ["នៅពេលយប់ [...]។ ព្រឹកឡើង អ្នកទាំងនោះ[អ្នកមកពីស្វាយរៀង] បាត់ខ្លួនអស់តែម្តង។"]។ ឯកសារ D1.3.27.11 កំណត់ហេតុស្រាវជ្រាវអំពីបណ្តាញពន្ធនាគារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគពាយ័ព្យរបស់ ហេនរី ឡូការ រឿងរ៉ាវរបស់ ចាវ គិម ទិត KH 00233422 ["នៅពេលយប់នៃថ្ងៃចុងក្រោយបង្អស់ [...] មុនកងទ័ពវៀតណាមមកដល់ អ្នកទោសប្រមាណ ១៥០០ នាក់ [...] ត្រូវសម្លាប់។"]។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉េងលី ឆ.១១០–១១១ KH 01158605 ["ពេលមួយយប់ ហ្នឹង វាយកមួយមន្ទីរហ្នឹង ទៅសម្លាប់ទាំងអស់ ដាក់ក្នុងស្រះត្រឡាច រួចវាកប់។ [...] ខ្ញុំក៏ឃើញឈាមនឹងស្រះទើបលុបដីថ្មីៗ។ [...] វៀតណាមចូលមកដល់ជិតហើយ [...] រួចវារត់ខ្ចាតខ្ចាយអស់។"]។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៤៩, ៥៨ KH 01102860-01102861 ["ពេលវៀតណាមជិតចូលមកដល់ គេយកពួកនៅ ០ផ ហ្នឹង ទៅសម្លាប់"]។ ឯកសារ D219/554 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត គួន ឆ.៧៣-៧៤ KH 01158623 ["ឮសូរថា យៀកណាមចូលមក វាសម្លាប់អ្នកទោសបង្ហើយ។"]។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ ឃ្លីម សារុន ឆ.៥១, ៥៥ KH 01088797-01088798 ["នៅពេលយួនជិតចូល [...] ទាំងអស់ [...] អ្នកទោស [...] សម្លាប់នៅមន្ទីរសន្តិសុខហ្នឹងតែម្តង។ [...] មនុស្សស្លាប់ហើមពេញស្រះនេះ"]។ ឯកសារ D5/834/3 ព័ត៌មានបន្ថែមលើពាក្យតាំងសុំខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទេព ហ៊ីន KH 01048942-01048943។ ឯកសារ D1.3.27.11 កំណត់ហេតុស្រាវជ្រាវអំពីបណ្តាញពន្ធនាគារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគពាយ័ព្យរបស់ ហេនរី ឡូការ រឿងរ៉ាវរបស់ ចាវ គិម ទិត KH 00233421 ["រណ្តៅមានច្រើនណាស់។"]។

738. វាមានហេតុផលក្នុងការសន្និដ្ឋានពីភស្តុតាងថា យ៉ាងតិចណាស់ប្រជាជន ១.០០០ នាក់ ត្រូវបានសម្លាប់នៅក្នុងគុកលេខ ៨ នេះ។ ទោះជាយ៉ាងនេះក្តី លទ្ធភាពអាចថា ចំនួនជាក់ស្តែងអាចមានរហូតដល់រាប់ពាន់នាក់ដែលតាមការប៉ាន់ស្មានចំនួនខ្ពស់បំផុត អ្នកទោសចំនួន ១០.០០០ នាក់ត្រូវបានសម្លាប់នៅទីនេះ[2716]។ រណ្តៅសាកសពរួមនៃអតីតអ្នកទោសក្នុងតំបន់នេះគាំទ្រដល់តួលេខអ្នកទោសស្លាប់យ៉ាងតិចបំផុតជាង ១.០០០ នាក់[2717]។

ការធ្វើទុក្ខបុកម្នេញ

739. ការធ្វើទុក្ខបុកម្នេញនៅគុកលេខ ៨ ត្រូវបានធ្វើឡើងតាមរយៈឧក្រិដ្ឋកម្មនានាដូចបានរៀបរាប់ខាងលើប្រឆាំងនឹង "ប្រជាជន ១៧ មេសា" សមាជិកអតីតនៃរបប លន់ នល់ និងគ្រួសាររបស់គេ "ពួកសក្តិភូមិ" "ពួកចក្រពត្តិ" និងប្រជាជនជម្លៀសពីភូមិភាគបូព៌ា។ ក្រុមនេះត្រូវបានតម្រង់ទិសដៅជាពិសេស ដោយសារពួកគេគឺជាសមាជិកជាក់ស្តែងនៃក្រុមនយោបាយមួយ ឬត្រូវបានចាត់ទុកថាជាសមាជិកនៃក្រុមនយោបាយមួយ[2718]។

[2716] ឯកសារ D1.3.27.11 កំណត់ហេតុស្រាវជ្រាវអំពីបណ្តាញពន្ធនាគារ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ភូមិភាគពាយ័ព្យ របស់ ហេនរី ឡូការ រឿងរ៉ាវរបស់ ចាវ គិម ទិត KH 00233421 ["មនុស្សប្រហែល ៣០ [៥០] នាក់ ត្រូវបានសម្លាប់ជារៀងរាល់អាទិត្យ។ មនុស្សរាប់ពាន់ រហូតដល់ ១០.០០០ នាក់ ត្រូវបានសម្លាប់។ បើនិយាយកុំឱ្យជ្រុលហួសហេតុ យ៉ាងហោចណាស់ក៏មានចំនួន ៣.០០០ ទៅ ៤.០០០ នាក់ដែរ។"]។ ឯកសារ D1.3.10.6 របាយការណ៍ប្រល័យពូជសាសន៍ ខេត្តពោធិសាត់ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា EN 00217581 ["'ស' គុកលេខ ៨។ នៅក្នុងគុកនេះ មានអ្នកទោសប្រហែល ៨០០ នាក់ ត្រូវបានសម្លាប់ដោយខ្មែរក្រហម"]។

[2717] ឯកសារ D105/20 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខលេខ ៨ KH 01397278-01397280។ ឯកសារ D1.3.10.6 របាយការណ៍ប្រល័យពូជសាសន៍ ខេត្តពោធិសាត់ របស់មជ្ឈមណ្ឌលឯកសារកម្ពុជា EN 00217581 ["'ស' គុកលេខ ៨ [...] សាកសព ត្រូវបានកប់នៅក្នុងរណ្តៅជាច្រើន"]។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហឿន ឆ.៧៩-៨០ KH 01149903 ["មានតែរណ្តៅ[...]មួយ [...]មានចម្ងាយប្រហែក ៥០០ ទៅ ៦០០ ម៉ែត្រ ទៅគុក ៨។ [...] សរុបប្រហែល ២០០ នាក់។"]។ ឆ.៧៩ KH 01149903 ["ខាងជើងគុកលេខ ៨ [...] រណ្តៅធំមួយទៀត គឺមានសាកសពប្រហែលជា ៣០០ សាកសព"]។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.១២២, ១២៥ KH 01158647 ["មួយរណ្តៅស្រះតាឡាចហ្នឹង មានចំនួនជាង ៧០០។"]។

[2718] *សូមមើល* VIII.B.1.a. ការទទួលខុសត្រូវឧក្រិដ្ឋកម្មជាលក្ខណៈបុគ្គល – របៀបនៃការទទួលខុសត្រូវ – សហកឧក្រិដ្ឋកម្មរួម – នយោបាយសត្រូវ។ V.B.6.b.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់ ៧ – ទីតាំងសម្លាប់ វាលបាក់ជញ្ជីង – ឧក្រិដ្ឋកម្ម – មនុស្សឃាត និងការសម្លាប់រង្គាល។

740. ជាពិសេស ប្រជាជនជម្លៀសពីភូមិភាគបូព៌ាត្រូវបានចាត់ថាជា "ខ្សែរយៈខ្មាំង" និងដូច្នេះ ពួកគេជាខ្មាំងរបស់ ប.ក.ក[2719]។ ពួកខ្មែរក្រហមស្អប់ប្រជាជនពីភូមិភាគបូព៌ា និងបានចាត់ទុកប្រជាជនទាំងនេះថាមាន "ក្បាលយួន ខ្លួនខ្មែរ"[2720]។

v. ឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់នៅក្នុងដីការចោទប្រកាន់

741. ដោយផ្អែកលើភ័ស្តុតាងដែលបានបញ្ជាក់ខាងលើ ស.ព.អ ស្នើឲ្យធ្វើការចោទប្រកាន់ **យ៉ីម ទិត្យ** ពីបទឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិ ទាក់ទងនឹងគុកលេខ ៨[2721] ជាអាទិ៍ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល[2722] ការធ្វើឲ្យទៅជាទាសករ ការឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញ ដោយសារមូលហេតុនយោបាយលើ "ប្រជាជន ១៧ មេសា" អតីតសមាជិកនៃ របប លន់ នល់ និងគ្រួសាររបស់គេ "ពួកសក្តិភូមិ" "ពួកចក្រពត្តិ" និងប្រជាជនជម្លៀសពីភូមិភាគបូព៌ា និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការប្រព្រឹត្តិដោយអមនុស្សធម៌ ការរំលោភសេពសន្តវៈ និងការបាត់ខ្លួនដោយបង្ខំ)។

[2719] ឯកសារ D219/266 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សិទ្ធ ឆ.៦៣ KH 01088812។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ីរ ឆ.៥០ KH 01102860។

[2720] ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉េងលី ឆ.៧៣ KH 01158599។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សារុន ឆ.៦៤ KH 01088799។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ីរ ឆ.៤៣ KH 01102859។

[2721] សហព្រះរាជអាជ្ញាអន្តរជាតិ កត់សម្គាល់ថា ពាក់ព័ន្ធនឹងទីតាំងនេះ គាត់ស្នើសុំឲ្យធ្វើការចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មនានាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានទទួលយកមកពិនិត្យ ប៉ុន្តែមិនទាន់មានការចោទប្រកាន់ទៅលើ យ៉ីម ទិត្យ។ ឧក្រិដ្ឋកម្មទាំងនេះ គឺការធ្វើទុក្ខបុកម្នេញទៅលើគោលនយោបាយប្រឆាំងនឹងអតីតសមាជិករបប លន់ នល់ "ប្រជាជន ១៧ មេសា" "ពួកសក្តិភូមិ" និង "ពួកចក្រពត្តិ" ហើយនិងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការរំលោភសេពសន្តវៈ និងការបាត់ខ្លួនដោយបង្ខំ)។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលយកឧក្រិដ្ឋកម្មទាំងនេះមកពិនិត្យ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា ឯកសារ D1 ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៧២។

[2722] សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា ធាតុផ្សំនៃភាពជាទ្រង់ទ្រាយធំចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានគាំទ្រដោយផ្អែកលើភស្តុតាងនៅពន្ធនាគារលេខ ៨ តែមួយគត់។ ជាជម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញាអន្តរជាតិប្រកាន់ជំហរថា នៅពេលពិចារណាទៅលើធាតុផ្សំនៃភាពជាទ្រង់ទ្រាយធំ ដែលតម្រូវឲ្យបង្ហាញការសម្លាប់រង្គាល គេគួរផ្តល់ស្ថានទម្ងន់ដល់ការសម្លាប់នៅតាមបណ្តាមន្ទីរសន្តិសុខ ទីកន្លែងសម្លាប់មនុស្ស និងការដ្ឋានការងារដោយបង្ខំទាំងអស់ រួមទាំងការសម្លាប់នៅពន្ធនាគារលេខ ៨។ រាល់ទីតាំងទាំងអស់ដែលបានបង្កើតជាផ្នែកនៃប្រព័ន្ធរៀបចំតែមួយ ដើម្បីអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្មាំង ហើយនឹងការសម្លាប់នៅតាមទីតាំងនីមួយៗ ត្រូវបានសម្រួលដោយពាក្យសំដី និងសកម្មភាពដដែលៗរបស់ យ៉ីម ទិត្យ។

ខ. ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជើង

i. សេចក្តីផ្តើម

742. ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជើង (“វាលបាក់”) មានទីតាំងស្ថិតក្នុងស្រុកកណ្តៀង តំបន់ ៧ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ទីតាំងនេះត្រូវបានប្រើប្រាស់សម្លាប់ប្រជាជនជម្លៀសពីភូមិភាគបូព៌ាមនុស្សយ៉ាងតិច ១.000 នាក់ ដែលពួកគេត្រូវបានចាប់ពីឃុំស្ថិតនៅជិតទីតាំងសម្លាប់មនុស្សនេះ។

743. ក្នុងឋានៈជាអនុលេខានៃគណៈភូមិភាគពាយ័ព្យ និងសមាជិកដឹកនាំម្នាក់នៃសហឧក្រិដ្ឋកម្មរួម **យ៉ីម ទិត្យ** ទទួលខុសត្រូវ និងមានសិទ្ធិអំណាចលើព្រឹត្តិការណ៍នានាដែលបានកើតឡើងនៅវាលបាក់ បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីបានមកដល់ភូមិភាគពាយ័ព្យ ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

744. ស.ច.ស.អ បានចោទ **យ៉ីម ទិត្យ** លើឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជើង ជាអាទិ៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា និងឧក្រិដ្ឋកម្មនៃការធ្វើឃាតមនុស្សដោយគិតទុកជាមុន អនុលោមតាមមាត្រា ៥០១ និងមាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦[2723]។

ii. ប្រតិបត្តិការ និងទីតាំង

745. ការសម្លាប់មនុស្សនៅទីតាំងវាលបាក់ត្រូវបានធ្វើឡើងនៅឆ្នាំ១៩៧៨ និងដើមឆ្នាំ១៩៧៩[2724]។ ទីតាំងសម្លាប់មនុស្សនេះស្ថិតនៅក្នុងឃុំស្រែស្ពុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ក្នុងតំបន់ ៧ នៃ

[2723] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426557-01426558, 01426561-01426563។

[2724] ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336 [“ស៖ សូមលោករៀបរាប់អំពីប្រជាជន បូព៌ា [...] ជម្លៀសមកខេត្តពោធិ៍សាត់? ឆ៖ [...] អ្នកទាំងនោះមកដល់ប្រហែលជានៅក្នុងខែ ១២ ឆ្នាំ១៩៧៧ ហើយប្រហែលជាបីខែក្រោយមក ទើបមានការប្រមូលយកអ្នកទាំងនោះទៅសម្លាប់នៅវាលបាក់ជញ្ជើង។ ខ្ញុំដឹងរឿងនេះដោយផ្ទាល់ ដោយសារខ្ញុំនៅក្នុងកងរទេះគោដឹកជញ្ជូន។”]។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.៣៩ KH 00947317 [“ស៖ តើលោកចាំថា ពួកបូព៌ាគេជម្លៀសមកដល់នៅឆ្នាំណា? ឆ.៣៩៖ ពួកបូព៌ាមកដល់នៅខែ មករា ឆ្នាំ១៩៧៨ និងនៅទីនេះបានបីខែ រួចគេយកទៅសម្លា

ភូមិភាគពាយ័ព្យ[2725]។ ទីតាំងនេះមានចម្ងាយប្រមាណជា ១៧ គីឡូម៉ែត្រ ស្ថិតនៅទិសឦសានៃភូមិឥន្ទធ្យា និងមានចម្ងាយប្រហែលជា ៦ គីឡូម៉ែត្រ នៅទិសអាគ្នេយ៍នៃទួលពោធិ៍ជ្រៃ[2726]។ ទីតាំងនេះមានទទឹងប្រមាណជា ១០០ ម៉ែត្រ និងបណ្តោយប្រមាណ ២០០ ម៉ែត្រ[2727]។ ទីតាំងនេះរួមមានរណ្តៅសាកសពមួយ និងបឹងទំហំ ៨ ហិកតា ដែលហ៊ុំព័ទ្ធដោយដើមឈើ និងដំណាំយ៉ាងច្រើន[2728]។

ប់។"]។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៥៦ KH 00947335 ["ខ្ញុំដឹងថា មានការកាប់សម្លាប់ប្រជាជនភូមិភាគបូព៌ានៅវាលបឹងបាក់ជញ្ជើង ចាប់ផ្តើមនៅក្នុង ១៩៧៨ ហើយបន្តរហូតមក ប៉ុន្តែ ការកាប់សម្លាប់បង្ហើយនៅក្នុងឆ្នាំ ១៩៧៩។"]។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្លួន ហៀ ឆ.៧១ KH 01067959 ["ស៖ [...] ស.៦៩៖ តើលោកស្រីធ្លាប់ឃើញគេដឹកអ្នកស្វាយរៀងទៅសម្លាប់នៅវាលបាក់ជញ្ជើងដែរឬទេ? [...] ឆ.៧១៖ នៅពាក់កណ្តាលរបបខ្មែរក្រហម។"]
។

[2725] ឯកសារ D134/6 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងសម្លាប់ វាលបាក់ជញ្ជើង KH 01045574 ["វាលបាក់ចិញ្ចៀន ឃុំស្រែស្ពុក ស្រុកកណ្តៀង ខេត្តពោធិសាត់"]។ KH 01045575 ["តំបន់ ៧-ភូមិភាគពាយ័ព្យ"]។ KH 01045576 ["ផ្នូរសាកសពមានទីតាំងស្ថិតនៅស្រុកកណ្តៀង ឃុំស្រែស្ពុក នៅនឹងកន្លែងមួយដែលអ្នករស់នៅទីនោះស្គាល់ថា ជាវាលបាក់ចិញ្ចៀន។"]។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.៤ KH 00947313 ["ស៖ តើលោកអាចប្រាប់ពីទីតាំងវាលបឹងបាក់ជញ្ជើងហ្នឹង ស្ថិតនៅភូមិឃុំ[...]? ឆ.៤៖ ទីកន្លែងហ្នឹង មិនបានដាក់នៅក្នុងភូមិណាមួយទេ ប៉ុន្តែស្ថិតនៅក្នុងឃុំស្រែស្ពុក។"]។

[2726] ឯកសារ D134/7 របាយការណ៍នៃការអនុវត្តន៍ដីកាចាត់ឲ្យស៊ើបសួរជំនួស KH 01003266 ["វាលបាក់ជញ្ជើង [...] មានចម្ងាយ ១៦.៩ គីឡូម៉ែត្រ ស្ថិតនៅទិសឥសានៃភូមិឥន្ទធ្យា និងមានចម្ងាយប្រហែល ៦ គីឡូម៉ែត្រនាទិសអាគ្នេយ៍នៃទួលពោធិ៍ជ្រៃ។"]។

[2727] ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.២១ KH 00947315 ["ស៖ លោកអាចប្រាប់យើងបានទេ តើកន្លែងសម្លាប់មនុស្សហ្នឹង មានទំហំប៉ុន្ឋានដែរ? ឆ.២១៖ [...] ទីតាំងនោះ មានទទឹង ១០០ ម៉ែត្រ និងបណ្តោយ ២០០ ម៉ែត្រ"]។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៩៣ KH 01067979-01067980 ["វាលបាក់ជញ្ជើងនេះ គឺជាវាល ហើយគ្មានផ្ទះនោះទេ"]។

[2728] ឯកសារ D134/6 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងសម្លាប់ វាលបាក់ជញ្ជើង KH 01045576-01045577 ["នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បឹងនៅវាលបាក់ចិញ្ចៀន ត្រូវបានហ៊ុំព័ទ្ធទៅដោយវាលស្រែ [...] បឹងនោះមានទំហំ ៨ហិចតានៅពេលគេវាស់នៅឆ្នាំ២០០៦"]។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.២២ KH 00947315 ["អ្នកស៊ើបអង្កេតបានឲ្យសាក្សីគ្ងសបញ្ជាក់អំពីទំហំវាលបឹងបាក់ជញ្ជើង [...]។ ស៖ តើទីតាំងហ្នឹង មានទ្រង់ទ្រាយដូចម្តេចបច្ចុប្បន្ននេះ? ឆ.២២៖ [...] មិនមានព្រៃត្រែង ព្រៃឈើទៀតទេ។"]។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៩៣ KH 01067979-01067980 ["វាលបាក់ជញ្ជើងនេះ គឺជាវាល ហើយគ្មានផ្ទះនោះទេ។ ស៖ តើនៅវាលបាក់ជញ្ជើងមានបឹងដែរឬទេ? ឆ.ចាស"]។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.២៨៥ KH 01000288 ["ស៖ តើលោកធ្លាប់ឮវាលបាក់ជញ្ជើង[ចិញ្ចៀន] ដែរឬទេ? ឆ.២៨៥៖ បាទ! វាលបាក់ជញ្ជើង[ចិញ្ចៀន] នៅទីនោះមានបឹងមួយ។"]។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្លួន ហៀ ឆ.៦៦ KH 01067958 ["វាលបាក់ជញ្ជើង [...] កន្លែងនេះ មានរណ្តៅមួយដែលមានទំហំប្រហែល ៥០ ម៉ែត្របួនជ្រុង។"]។

iii. រចនាសម្ព័ន្ធសិទ្ធិអំណាច និងការប្រាស្រ័យទាក់ទង

746. ស្រុកកណ្តៀងស្ថិតក្រោមការគ្រប់គ្រងដោយតាសារុន លេខាតំបន់ ៧[2729]។ តាសារុនបានចូលរួមក្នុងកិច្ចប្រជុំនានាជាមួយតាម៉ុក ដែលក្នុងពេលនោះគាត់បានទទួលបញ្ជាដើម្បីផ្សព្វផ្សាយក្នុងតំបន់របស់គាត់។ បទបញ្ជាទាំងនេះរួមមានថាតើត្រូវតម្រង់ទិសដៅ ស្ទើបអង្កេត និងសម្លាប់ប្រជាជនណា ដែលមានខ្សែរវរយៈជាមួយវៀតណាម[2730]។

747. បន្ទាប់ពីកម្មាភិបាលភូមិភាគពាយ័ព្យត្រូវបានបោសសម្អាត ក្នុងស្រុកកណ្តៀង នៅដើមឆ្នាំ១៩៧៧ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧[2731] កម្មាភិបាលភូមិភាគនិរតី ឈ្នោះទ្រី បានដឹកនាំគណៈស្រុកអស់រយៈពេលពីរបីខែ[2732] មុនពេលគាត់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរ ស-២១ ដើម្បីសម្លាប់ ហើយគាត់ត្រូវបានជំនួសដោយកម្មាភិបាលភូមិភាគនិរតី យាយណាន់ នៅដើមឆ្នាំ១៩៧៨[2733] ដែល

[2729] *សូមមើល* IV.គ.៥.ក. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទងរបស់ ប.ក.ក - ភូមិភាគពាយ័ព្យឆ្នាំ១៩៧៧-១៩៧៩ – តំបន់ ៧ – ស្រុកកណ្តៀង។

[2730] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៨ ឆ.៤២ KH 01348857 KH 01348863 ["[តាម៉ុក និង តាសារុន] ជួបគ្នានៅបាត់ដំបង។ [...] តាសារុន ដដែលហ្ម៉ង គាត់ណែនាំ គាត់ទៅជួបថ្នាក់លើទៀត។"]។ ឯកសារ D219/861 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.១០៣ KH 01347279 [លេខាស្រុកបាកាន៖ "ឆ.១០៣៖ [តាម៉ុក] តាមរយៈលោក សារុន។"]។ ឆ.១០៦-១០៧ KH 01347279 ["ស៖ តាសារុន បានប្រាប់លោកស្រីថា គាត់បានប្រជុំជាមួយតាម៉ុក ហើយ តាសារុន ថា ប្រាប់លោកស្រីថា តាម៉ុក បានណែនាំឲ្យយើងផ្តោតគោលដៅស្រាវជ្រាវ និងលុបបំបាត់អ្នកមានខ្សែដែលរយៈវៀតណាម។ តើត្រឹមត្រូវឬទេ? ឆ.១០៦៖ ចាស។ [...] ឆ.107៖ [សារុន] គាត់បានទទួលផែនការ ហើយគាត់បានហៅប្រជុំទាំងអស់គ្នាឲ្យទទួលផែនការតែម្តង។"]។

[2731] *សូមមើល* V.B.1.b.ii. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការបោសសម្អាត – ការបោសសម្អាតនៅថ្នាក់ភូមិភាគ និង តំបន់ នៃភូមិភាគពាយ័ព្យ – ការបោសសម្អាតនៅថ្នាក់តំបន់ – តំបន់ ៧។

[2732] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.២៨, ៣១ KH 00947331។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ហ ម៉ឹង ហៅ សាត សុខុម ឆ.៧-៨ KH 00947346។ ឯកសារ D6.1.617 កិច្ចសម្ភាសន៍របស់SOASជាមួយ សាត សុខុម KH 00590218។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.៣២ KH 00947342។ ឯកសារ D219/825.1.2 បញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៩៣៦ KH 01222694 [មុយ ទ្រី ជំនួយការស្រុករំដៀង តំបន់ ៧ មុនកងពល ៧០៣ (គណៈស្រុករំដៀង តំបន់ ២ មុនកងពល ៧០៣) ចាប់ខ្លួននៅមន្ទីរស ២១ ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៨]។

[2733] ឯកសារ D219/825.1.2 បញ្ជីអ្នកទោសមន្ទីរ ស-២១ របស់ ក.ស.ច.ស លេខរៀង ៨៩៣៦ KH 01222694។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.២៨ KH 00947331។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ហ ម៉ឹង ហៅ សាត សុខុម ឆ.១៩-២០ KH 00947347-00947348។ ឯកសារ D219/849 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ ហៅ យាយណាន់ ឆ.២១-២២ KH 01339988-01339989។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ

បានបន្តគ្រប់គ្រងស្រុកនេះរហូតដល់ពេលចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ[2734]។ គាសារុន បានចាត់តាំង ណាន់ ឲ្យទទួលមុខតំណែងនេះ[2735]។

748. បន្ទាប់ពីណាន់បានឡើងកាន់អំណាចក្នុងស្រុកនេះ ការសម្លាប់មានការកើនឡើង។ ណាន់បានចេញបញ្ជាទៅកម្មាភិបាលនៅថ្នាក់ឃុំ និងសហករណ៍ដើម្បីសម្លាប់ប្រជាជនពីភូមិភាគបូព៌ា និង "ប្រជាជន ១៧ មេសា" ក្នុងនោះរួមមានស្ត្រី កុមារ និងមនុស្សចាស់[2736]។ គាត់ក៏ធ្វើជាវាគ្មិន និងប្រធានអង្គប្រជុំ នៅក្នុងស្រុក និងកន្លែងផ្សេងៗទៀត នៅក្នុងខេត្តដែលនៅក្នុងកិច្ចប្រជុំទាំងនោះ គាត់បានបញ្ជាឲ្យអ្នកចូលរួមចំនួនពី ១០០ ទៅ ៣០០ នាក់ "ឲ្យខិតខំធ្វើការដើម្បីសម្រេចផែនការ"[2737]។ ប្រធានសហករណ៍ និងកងបានរៀបចំឲ្យមានកិច្ចប្រជុំស្វ័យទិតៀន[2738] ដែលក្នុងកិច្ចប្រជុំនោះ ពួកគេលើកឡើងអំពីការបោសសម្អាតខ្មាំងផ្ទៃក្នុង[2739]។

យាយរ៉ីម ឆ.៥១-៥៣ KH 01348864-01348865។ឯកសារ D6.1.643 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង ឆាត់ KH 00369244។ ឯកសារ D6.1.617 កិច្ចសម្ភាសន៍របស់SOASជាមួយ សាត សុខុម KH 00590218។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៩៥ KH 01089009។

[2734] កសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.២៨, ៤៣ KH 00947331-00947333។ ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស្ងួ ណាន់ ហៅ យាយណាន់ ឆ.១៥, ២០ KH 00498371-00498372។ ឯកសារ D219/849 កំណត់ហេតុស្តាប់ចម្លើយ ស្ងួ ណាន់ ហៅ យាយណាន់ ឆ.២១-២២ KH 01339988-01339989។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥៥, ៥៧ KH 01348865។

[2735] ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស្ងួ ណាន់ ហៅ យាយណាន់ ឆ.២០, ២២-៣៣ KH 00498372-00498376 [ស្ងួ ណាន់ បានទទួលស្គាល់ថាត្រូវបាន សារុន តែងតាំងជាគណៈស្រុកកណ្តៀង ប៉ុន្តែ អះអាងថា គាត់បានបដិសេធ តំណែងនេះ] ។ សូមមើល ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥១ KH 01348864 ["យាយណាន់ [...] មកស្រែករជាមួយ ពួសារុន។"]។

[2736] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៣៤, ៣៨-៣៩, ៤៦ KH 00947332-00947333។ ឯកសារ D6.1.618 ការសម្ភាសន៍របស់ SOAS ជាមួយសាត ឆាង KH 00721704។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៥០, ៥៤, ៥៦ KH 01067973-01067974។

[2737] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៥៥ KH 01348865។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៉ីង ហៅ សាត សុខុម ឆ.២៥-២៧ KH 00947348។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង ឆាត់ ឆ.២៩ KH 00947316។

[2738] ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សុវណ្ណ ឆ.៤៩-៥០ KH 01036511។ ឯកសារ D6.1.761 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សុវណ្ណ KH 00373424-00373426។ ឯកសារ D6.1.161 កំណត់ហេតុស្តាប់ចម្លើយ ស៊ីយ សេងឈន KH 00196820។

[2739] ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សុវណ្ណ ឆ.៤៩, ៥១-៥៤ KH 01036511។

749. នៅក្នុងចំណោមសហករណ៍ទាំងអស់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ណាន់ មានសហករណ៍ភូមិស្ទឹងដឹកនាំដោយសឿន[2740] បងប្អូនស្រីរបស់ណាន់មកពីកំពង់ឆ្នាំង[2741] និងសហករណ៍ស្បាដឹកនាំដោយប្រធានយោធាឈ្មោះ ណាត[2742] ដែលជាបងប្អូនស្រីរបស់ណាន់ផងដែរ[2743]។ បងប្អូនស្រីទាំងពីររបស់ណាន់បានបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់មនុស្ស ក្នុងនោះរួមទាំងប្រជាជនជម្លៀងពីភូមិភាគបូព៌ាផង[2744]។

iv. ឧក្រិដ្ឋកម្ម

<u>ការសម្លាប់មនុស្ស និងការសម្លាប់រង្គាល</u>

750. ចាប់ពីចុងឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៩[2745] កងទ័ពភូមិភាគនិរតីនៃ ប.ក.ក បានជម្លៀសប្រជាជនដោយបង្ខំពីខេត្តនានានៅភូមិភាគបូព៌ា ដូចជាខេត្តស្វាយរៀង ព្រៃវែង និងកំពង់ចាម ទៅកាន់ខេត្ត

[2740] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៣៧, ៤៣ KH 00947332-00947333។ ឯកសារ D6.1.618 ការសម្ភាសន៍របស់ SOAS ជាមួយសាត ឆាង KH 00721704។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៉ុង ហៅ សាត សុខុម KH 00947349-00947350។

[2741] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៣៧ KH 00947332។ *សូមមើលបន្ថែម* ឯកសារ D118/179 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ហ៊ីន ឆ.៤, ២២ KH 00974862, 00974864។ ឯកសារ D6.1.988 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ ហៅ យាយណាន់ ឆ.៤ KH 00498369។ *ចំណាំ* ទោះជាយ៉ាងណាក៏ដោយ បងប្អូនស្រីទាំងពីរនាក់ ស៊ូ ណាន់ និង ស៊ូ ហ៊ីន បានបដិសេធរឿងទាំងនេះ។ *សូមមើល* ឯកសារ D118/179 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ហ៊ីន ឆ.៤៩, ៥១-៥៣ KH 00974866-00974867។ ឯកសារ D134/2 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ ហៅ យាយណាន់ ឆ.៣៦ KH 00947324។

[2742] ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៥២, ៥៤-៥៥ KH 01067973។

[2743] ឯកសារ D134/2 កំណត់ហេតុស្តាប់ចម្លើយ ស៊ូ ណាន់ ហៅ យាយណាន់ ឆ.៣៦ KH 00947324។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៥០ KH 01067973។

[2744] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៣៨-៣៩, ៤៨-៤៩ KH 00947332-00947334។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៥០, ៥៤, ៥៦ KH 01067973-01067974។

[2745] ឯកសារ D219/702.1.4 ប្រតិចារឹក លឹម សាត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 13.45.35-13.50.03។ ឯកសារ D219/266 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សិទ្ធ ឆ.៦១ KH 01088812។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ៊ីន ឆ.១៧ KH 01089497។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៤៣ KH 00947333។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.៣ KH 00947338។ ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.៣៩ KH 00947317។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្ជន ហ៊ៀ ឆ.៧១ KH 01067959។ ឯកសារ D5/450/3 ប្រតិចារឹក យ៉ីម សុវណ្ណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង 16.01.24-16.03.31 KH 00855249-00855250។ ឯកសារ D6.1.759 កំណត់ហេតុស្តាប់ចម្លើយ គ៉ីម សូរ

ពោធិ៍សាត់ក្នុងភូមិភាគពាយ័ព្យ[2746]។ កងយោធាទាំងនេះបានបង្ខំឲ្យប្រជាជនរាប់ពាន់នាក់ពីភូមិភាគបូព៌ាចាកចេញពីលំនៅឋានរបស់ពួកគេចំនួនពីរ ទៅបីដង[2747]។ គ្រួសារទាំងមូលរបស់គេ ក្នុងនៅរួមទាំងស្ត្រី កុមារ និងមនុស្សចាស់[2748] ត្រូវបានបញ្ជូនទៅកាន់ខេត្តពោធិ៍តាមរថភ្លើង[2749]។ ប្រជាជនជម្លៀសត្រូវបានគេជូនក្រម៉ា ឬកន្សែងពណ៌ខៀវ[2750]ដើម្បីឲ្យកម្មាភិបាល ប.ក.ក ងាយស្រួល

KH 00385136-00385137។ ឯកសារ D6.1.129 កំណត់ហេតុស្តាប់ចម្លើយ ម៉ែន ភ្លួន KH 00242428-00242429។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៊ីង ហៅ សាត សុខុម ឆ.៦, ១០, ២៨-២៩ KH 00947346-00947349។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៩៩ KH 01000277។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ្ជឿន ឆ.៩២ KH 01149904។ *ផ្ទុយមកវិញ សូមមើល* ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉ែងលី ឆ.៦៨-៧០ KH 01158598។

[2746] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៤៤ KH 00947333។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.៤ KH 00947338-00947339។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ៊ីន ឆ.៦៣ KH 01089504។ ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336។ ឯកសារ D6.1.129 កំណត់ហេតុស្តាប់ចម្លើយ ម៉ែន ភ្លួន KH 00242428-00242429។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៩៩, ២៨៦ KH 01000277, 01000288។ ឯកសារ D6.1.143 កំណត់ហេតុស្តាប់ចម្លើយ ចក់ មល្ហី KH 00273428-00273429។ ឯកសារ D65.1.56 កំណត់ហេតុស្តាប់ចម្លើយ ខ៊ីម សាម៉ុន KH 00250706-00250707។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយ ម៊ី សំ ឆ.១៨, ២១, ៣១ KH 00982190-00982191។

[2747] ឯកសារ D6.1.417 កំណត់ហេតុស្តាប់ចម្លើយ ឌួង អ៊ីន KH 0249890-00249892។ ឯកសារ D118/217 កំណត់ ហេតុស្តាប់ចម្លើយ ម៊ី សំ ឆ.១៨, ៣១ KH 00982190-00982191។ ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម សុវណ្ណ ឆ.១៤ KH 01036505។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ្ជឿន ឆ.៩៧ KH 01149905។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ៊ីន ឆ.៣៧, ៦២ KH 01089500, 010894504។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.២០១-២០២ KH 01000278។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.៦៤ KH 01158639។

[2748] ឯកសារ D6.1.417 កំណត់ហេតុស្តាប់ចម្លើយ ឌួង អ៊ីន KH 00249892។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៤៦ KH 00947333។

[2749] ឯកសារ D219/702.1.4 ប្រតិចារឹក លឹម សាត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 11.09.15-11.13.38។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ្ជឿន ឆ.៤៨, ៩២, ៩៩ KH 01149900, 01149904-01149905។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.៤០ KH 00947317។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គ៉ឹម សូរ ឆ.៦២ KH 00955716។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ៊ីន ឆ.៤៧, ៦២ KH 01089502, 010894504 ។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៩៩-២០០ KH 01000277-01000278។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.១១ KH 00947340។

[2750] ឯកសារ D219/702.1.4 ប្រតិចារឹក លឹម សាត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 13.45.35-13.50.03។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.១១ KH 00947340។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៊ីង

កំណត់អត្តសញ្ញាណពួកគេថាជាប្រជាជនមកពីភូមិភាគបូព៌ា[2751]។ ប្រជាជនជម្លៀសទាំងនេះត្រូវបានចាត់ទុកថាមាន "ខ្សែរយៈខ្ទាំង"[2752] ហើយអាស្រ័យហេតុនេះគឺជាខ្ទាំងរបស់ ប.ក.ក។ ពួកខ្មែរក្រហមបានរៀបរាប់ថា ប្រជាជនភូមិភាគបូព៌ាមាន "ក្បាលយួន ខ្លួនខ្មែរ"[2753]។

751. ប្រជាជនជម្លៀសភូមិភាគបូព៌ាទាំងនេះរាប់ពាន់នាក់បានមកដល់ស្រុកកណ្តៀង[2754] ដែលនៅទីនោះពួកគេត្រូវបានចាត់បញ្ជូនឲ្យទៅសហករណ៍ ក្នុងនោះរួមទាំងសហករណ៍ក្បាលឈើពុក និងបឹង

ហៅ សាត សុខុម ឆ.៣០ KH 00947349។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ៊ីន ឆ.៣៦-៣៨ KH 01089500។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៥៧ KH 00947335។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១៦ KH 00947314។ ឯកសារ D6.1.643 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00369243។ ឯកសារ D219/58 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សុវណ្ណ ឆ.១៣ KH 01036505។ ឯកសារ D6.1.159 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សារ៉ុធ KH 00196805-00196806។ *ផ្ទុយមកវិញ សូមមើល* ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.២០៦-២០៨ KH 01000278។

[2751] ឯកសារ D219/702.1.4 ប្រតិចារឹក លឹម សាត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 13.47.46-13.50.03។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ៊ីន ឆ.៣៨, ៦៦ KH 01089500, 01089505។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៦៥ KH 00955716។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៉ឹង ហៅ សាត សុខុម ឆ.៣០ KH 00947349។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៨៨ KH 01089008។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៧៥ KH 01102863។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ៊ីន ឆ.៤៨ KH 01149900។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉េងលី ឆ.៦៨ KH 01158598។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.៦៧-៦៨ KH 01158640។ ឯកសារ D219/553 កំណត់ហេតុស្តាប់ចម្លើយ គី ប៉េងលី ឆ.២០៧ KH 01158598។

[2752] ឯកសារ D219/266 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សិទ្ធ ឆ.៦៣ KH 01088812។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៥០ KH 01102860។

[2753] ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៧៣ KH 01089006។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម សារុន ឆ.៦៤ KH 01088799។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.៤៣ KH 01102859។

[2754] ឯកសារ D6.1.643 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00369243។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.២១៧ KH 01000279។

ចាក[2755] និងត្រូវបានទទួលបញ្ជាឲ្យធ្វើស្រែ ឬច្រូតស្រូវ[2756]។ ពួកគេក្រោយមកត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ជាក្រុមៗ ដែលមានប្រជាជនពី ១០ ទៅ ២០០ នាក់[2757]។ មនុស្សស្រីក្មេងៗ ត្រូវបានរំលោភ មុនពេលយកទៅសម្លាប់[2758]។ នៅដើមឆ្នាំ១៩៧៩ កម្មាភិបាលខ្មែរក្រហមបានធ្វើការ

[2755] ឯកសារ D219/702.1.4 ប្រតិចារឹក លឹម សាត ចុះថ្ងៃទី០២ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 13.45.35-13.50.03។ ឯកសារ D5/450/3 ប្រតិចារឹក យ៉ឹម សុវណ្ណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង 16.01.24-16.03.31 KH 00855249-00855250។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហួត ម៉ឹង ហៅ សាត សុខុម ឆ.៣០ KH 00947349។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ្ជឿន ឆ.៩៣-៩៤ KH 01149905។ ឯកសារ D6.1.643 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00369243។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ្ជីន ឆ.៥២-៥៣ KH 01089502-01089503។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.២០១-២០២, ២១០ KH 01000278។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៨៥ KH 01089007 ឆ.៣៧ KH 01089000។ ឯកសារ D219/265 កំណត់ហេតុស្តាប់ចម្លើយ យ៉ឹម សារុន ឆ.៥, ២៣, ៦២ KH 01088793, 01088795, 01088799។ ឯកសារ D219/340 កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ី ឆ.១៨-១៩, ៤២ KH 01102586-01102587, 01102859។ ឯកសារ D219/555 កំណត់ហេតុស្តាប់ចម្លើយ កែ ទិន ឆ.២៤, ៦៤ KH 01158635, 01158639។ ឯកសារ D6.1.618 ការសម្ភាសន៍របស់ SOAS ជាមួយសាត ឆាង KH 00721704។

[2756] ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្ជួន ហ្ជៀ ឆ.៦៨-៧០ KH 01067958-01067959។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ្ជីន ឆ.៥៣ KH 01089503។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.២១០ KH 01000278។

[2757] [757] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៤៦ KH 00947333។ ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ្ជីន ឆ.៦៥, ៦៨, ៧០-៧១ KH 01089504-01089505។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហួត ម៉ឹង ហៅ សាត សុខុម ឆ.២៨-២៩, ៣១-៣២ KH 00947348-00947349។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្ជួន ហ្ជៀ ឆ.២៣-២៤, ៦៨–៧០ KH 01067952, 01067958-01067959។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៨៦-៨៧, ៩០ KH 01089007-01089008។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១៥ KH 00947314។ *សូមបញ្ជាក់ម្តងទៀតថា* ឯកសារ D6.1.643 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00369243។ ឯកសារ D219/183 កំណត់ហេតុស្តាប់ចម្លើយ សុខ ខន ឆ.៨៣-៨៧ KH 01067978-01067979។ ឯកសារ D219/266 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន សិទ្ធ ឆ.៦២-៦៣, ៦៨-៧១ KH 01088812-01088813។ ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.១៦-១៧, ១៩, ២២ KH 00947340-00947341។ ឯកសារ D6.1.685 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.១២ KH 00407763។ ឯកសារ D6.1.159 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សារ៉ុត KH 00196804-00196806។ ឯកសារ D219/526 កំណត់ហេតុស្តាប់ចម្លើយ ទេព ហ្ជឿន ឆ.១០២-១០៤, ១០៦ KH 01149905-01149906។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៧២ KH 01089006។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្ជួន ហ្ជៀ ឆ.៦៦ KH 01067958។ ឯកសារ D5/821/1 របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ផ្ទាង ផន EN 00951347។

[2758] ឯកសារ D219/282 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីល អ្ជីន ឆ.៧៥ KH 01089506។ ឯកសារ D219/279 កំណត់ហេតុស្តាប់ចម្លើយ គូ ម៉ុលលី ឆ.៨៦-៨៧, ៩០ KH 01089007-01089008។ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.២៣២-២៣៤, ២៣៧ KH 01000281។

សម្លាប់ចុងក្រោយ ដោយផ្អែកតាមផែនការកម្ទេចប្រជាជនជម្លៀសភូមិភាគបូព៌ាទាំងអស់ តាមបញ្ជារបស់មន្ទីរ ៨៧០ និងតាម៉ុក[2759]។

752. នៅឆ្នាំ១៩៧៨ ក្នុងស្រុកកណ្តៀងក្នុងសហករណ៍ធ្លាអំពិល ប្រធានសហករណ៍បានបើកកិច្ចប្រជុំមួយដែលក្នុងពេលនោះគាត់បានបញ្ជាឲ្យសម្លាប់ប្រជាជនជម្លៀសភូមិភាគបូព៌ា។ បន្ទាប់ពីកិច្ចប្រជុំនោះ អ្នកបររទេះគោមកពីកងដឹកជញ្ជូនទទួលបានការណែនាំឲ្យដឹកប្រជាជនជម្លៀសភូមិភាគបូព៌ាទាំងអស់ទៅកាន់វាលបាក់[2760]។ ការណែនាំដូចគ្នានេះក៏ត្រូវបានផ្តល់ឲ្យអ្នកបររទេះគោនៅតាម

[2759] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៨៤-១៨៨ KH 01000276 ["មេកងបានខ្សឹបប្រាប់ខ្ញុំអំពីផែនការមួយថា 'តា៧៨ មានផែនការសម្លាប់អ្នកបូព៌ាឲ្យអស់ក្នុងរយៈពេល ៥ថ្ងៃ។' [...] តា៧៨នេះ គឺសំដៅទៅលើគណៈ៨៧០។ [...] គណៈ៨៧០ បានដាក់ផែនការមកដល់តា១៥។ តា១៥ បានយកផែនការនោះមកប្រជុំប្រាប់កម្មាភិបាលថ្នាក់ក្រោមបន្តទៀត។ [...] មេកង [...] ជា បានខ្សឹបប្រាប់ខ្ញុំអំពីរឿងនេះ នៅឆ្នាំ១៩៧៩ អំឡុងខែ១ ព្រោះពេលនោះវៀតណាមចូលមកដល់ក្រុងពោធិសាត់រួចទៅហើយ។ [...] ជា ជាមនុស្សនៅបាក់ចិញ្ចៀនដែរ។"]។ (ចំណាំ ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៧១ KH 01000275 ["តាម៉ុក [...] ហៅតា១៥."])។ ឆ.២១២-២១៣, ២១៦, ២១៩-២២០ KH 01000279, 01000280 ["ឆ.២១២៖ គណៈសហករណ៍បានទៅចូលរួមប្រជុំ ហើយពេលគេត្រឡប់មកវិញ គេប្រជុំប្រាប់ខ្ញុំថា 'គណៈ៨៧០ ដាក់ផែនការឲ្យសម្លាប់អ្នកបូព៌ា ៥ថ្ងៃឲ្យអស់។' ស៖ តើផែនការនេះកើតឡើងដែរឬទេ? ឆ.២១៣៖ បាទ [...] កងទ័ពបានចេញមក ហើយចាប់មនុស្សទាំងខ្សែៗតែម្តង។ ពេលនោះ លែងណាក់ការណ៍ទៀតហើយ គេសម្លាប់អ្នកបូព៌ានៅគ្រប់កន្លែងទាំងអស់។ [...] ឆ.២១៦៖ ឲ្យតែនៅសហករណ៍បាក់ចិញ្ចៀន គឺគេសម្លាប់គ្រប់កន្លែងទាំងអស់ [...] ក្នុងមួយថ្ងៃៗ មានមនុស្សត្រូវសម្លាប់ក្នុងសហករណ៍របស់ខ្ញុំប្រហែល ៥០នាក់។ ៤ថ្ងៃក្រោយមក ទើបគេសម្រេចឲ្យឈប់សម្លាប់អ្នកបូព៌ា។ [...] ស៖ តើលោកមានស្គាល់ឈ្មោះអ្នកសម្លាប់អ្នកបូព៌ា [...]? ឆ.២១៩៖ ពួកគេជាទ័ពតំបន់ និងស្រុក។ [...] ឆ.២២០៖ ឈ្លបក៏ចូលរួមដែរ"]។

[2760] ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង ឆាត់ ឆ.៣៣, ៤២ KH 00947316-00947317 ["ស៖ តើប្រធានសហករណ៍របស់លោកមានឈ្មោះអ្វី? ឆ.៣៣៖ ឈ្មោះ មិត្ត ណុម។ ខ្ញុំមិនដឹងថា គាត់នៅរស់ ឬក៏ស្លាប់ទេ។ ខ្ញុំឮថា គាត់មកពីកំពង់ឆ្នាំង។"]។ ឆ.៤២ KH 00947317 ["ស៖ តើគេប្រជុំនៅកន្លែងណា? ឆ.៤២៖ [...] នៅក្នុងសហករណ៍ខ្ញុំ មិត្ត ណុម ជាអ្នកកោះប្រជុំ ដើម្បីបញ្ជូនអ្នកទាំងនោះទៅវាលបឹងបាក់ជញ្ជីង។"]។ ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ីង ឆាត់ KH 00277336 ["សហករណ៍ដែលខ្ញុំរស់នៅគឺ សហករណ៍ធ្លាអំពិល [...] អ្នកទាំងនោះមកដល់ប្រហែលជានៅក្នុងខែ ១២ ឆ្នាំ១៩៧៧ ហើយប្រហែលជាបីខែក្រោយមក ទើបមានការប្រមូលយកអ្នកទាំងនោះទៅសម្លាប់នៅវាលបាក់ជញ្ជីង។ ខ្ញុំដឹងរឿងនេះដោយផ្ទាល់ ដោយសារខ្ញុំនៅក្នុងកងរទេះគោដឹកជញ្ជូន។ [...] ស៖ តើអ្នកណាជាអ្នកបញ្ជាឲ្យដឹកប្រជាជនបូព៌ាទៅ? ឆ៖ ខ្ញុំមិនដឹងទេ គ្រាន់តែឃើញសហករណ៍ និងយោធាស្រុកប្រជុំគ្នា ហើយគណៈសហករណ៍បានប្រាប់ឲ្យប្រមូលកងរទេះទៅដឹកប្រជាជនមកពីស្វាយរៀង យកទៅច្រូតស្រូវនៅវាលបាក់ជញ្ជីង។"]។

សហករណ៍ផ្សេងៗទៀតក្នុងស្រុកនេះ[2761]។ នៅក្នុងកិច្ចប្រជុំមួយក្នុងសហករណ៍ភូមិស្ទឹង មេភូមិក៏បានចេញបញ្ជាដូចគ្នាឲ្យសម្លាប់ប្រជាជនជម្លៀសភូមិភាគបូព៌ាដែរ[2762]។

[2761] ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១៨ KH 00947315 ["ស៖ កាលនោះ គេឲ្យក្រុមដឹកជញ្ជូនរបស់លោក ពីភូមិធ្លាអំពិល តើលោកមានដឹងថា មានក្រុមណាផ្សេង ដែលគេឲ្យដឹកអ្នកបូព៌ាហ្នឹងទេ? ឆ.១៨៖ [...] គ្រាន់តែឮគេថា មានក្រុមមកពីសហករណ៍កោះប្រទាល ទួលគ្ង នៅក្នុងស្រុកកណ្តៀងហ្នឹងដែរ។ ឆ.៤២ KH 00947317 ["តើគេប្រជុំនៅកន្លែងណា? ឆ.៤២៖ គេប្រជុំនៅតាមសហករណ៍នីមួយៗ។ [...] បញ្ជូនអ្នកទាំងនោះទៅវាលបឹងបាក់ជញ្ជឹង។"]។ ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336-00277337 ["ស៖ តើអ្នកណាជាអ្នកបញ្ជាឲ្យដឹកប្រជាជនបូព៌ាទៅ? ឆ៖ [...] ប្រជាជនទាំងនោះ ត្រូវបានខ្មែរក្រហមដឹកមកពីគ្រប់សហករណ៍ទាំងអស់ យកទៅសម្លាប់នៅបឹងបាក់ជញ្ជឹងនោះ។"]។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហួត ម៊ីង ហៅ សាត សុខុម ឆ.៤, ៦, ៣១-៣២ KH 00947346, 00947349 ["ឆ.៤៖ ខ្ញុំធ្វើការនៅ [...] សហករណ៍ភូមិស្ទឹង [...] ឆ.៦៖ [...] នៅក្នុងស្រុកកណ្តៀង។ [...] ស៖ តើលោកស្រីដឹងដោយរបៀបណាថា ពួកខ្មែរក្រហមយកពួកបូព៌ាទៅសម្លាប់នៅវាលបឹងបាក់ជញ្ជឹង? ឆ.៣១៖ [...] តាមរយៈពួកកងរទេះដែលជាអ្នកដឹកទៅ ដោយពួកគេនិយាយថា យប់មិញពួកគេដឹកពួកបូព៌ាទៅសម្លាប់នៅវាលបឹងបាក់ជញ្ជឹង។ [...] នៅចុងឆ្នាំ១៩៧៨ [...] ឆ.៣២៖ [...] ដូចជាយកមួយចំនួនពីសហករណ៍នេះម្តង និងសហករណ៍ផ្សេងទៀតម្តង"]។

[2762] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៤៧-៤៩ KH 00947333-00947334 ["ស៖ នៅក្នុងកំណត់ហេតុរបស់អង្គការសិទ្ធិមនុស្ស យើងពិនិត្យឃើញថា គេបែងចែកប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ា [...] នៅចុងឆ្នាំ១៩៧៨ [...] បានប្រមូលផ្តុំ និងបញ្ជូនពួកគេទៅសម្លាប់ចោល។ បន្ទាប់មក នៅពេលវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ ការកាប់សម្លាប់ប្រជាជនភូមិភាគបូព៌ាកាន់តែមានកម្រិតខ្លាំងក្លាឡើង។ តើលោកពិតជាបានឆ្លើយខ្លឹមសារនេះ ប្រាប់ទៅអង្គការសិទ្ធិមនុស្ស ដែរឬទេ? ឆ.៤៧៖ បាទ ពិតប្រាកដមែនហើយ។ ពួកខ្មែរក្រហម គេចង់សម្លាប់បង្ហើយឲ្យអស់តាមផែនការចុងក្រោយរបស់ពួកគេ។ [...] ស៖ នៅក្នុងកំណត់ហេតុដែលនេះផងដែរ លោកនិយាយថា លោកបានដឹងពីរឿងនេះ ពីព្រោះ សឿន ដែលគាត់ចូលចិត្តខ្ញុំ ហើយចង់សម្លាប់ប្រពន្ធខ្ញុំចោល ដើម្បីយកខ្ញុំធ្វើជាប្តីរបស់គាត់ ហើយគាត់ប្រាប់ខ្ញុំអំពីផែនការលុបបំបាត់ចោលពួកអ្នកជម្លៀសមកពីភូមិភាគបូព៌ា។ តើខ្លឹមសារនេះ ត្រឹមត្រូវដែរឬទេ? ឆ.៤៨៖ បាទ [...] ឆ.៤៩៖ ខ្ញុំបានដឹងរឿងនេះ ដោយសារខ្ញុំដើរជាប់ជាមួយ សឿន រហូត។ ខ្ញុំបានឮ សឿន បញ្ជាទៅប្រធានឈ្លបឲ្យចាប់ប្រមូលប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ា ដើម្បីបញ្ជូនទៅសម្លាប់ចោលឲ្យអស់។"]។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៤៧-៤៩ KH 00947333-00947334 ["ស៖ នៅក្នុងកំណត់ហេតុរបស់អង្គការសិទ្ធិមនុស្ស យើងពិនិត្យឃើញថា គេបែងចែកប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ា [...] នៅចុងឆ្នាំ១៩៧៨ [...] បានប្រមូលផ្តុំ និងបញ្ជូនពួកគេទៅសម្លាប់ចោល។ បន្ទាប់មក នៅពេលវៀតណាមចូលមកដល់ទីក្រុងភ្នំពេញ ការកាប់សម្លាប់ប្រជាជនភូមិភាគបូព៌ាកាន់តែមានកម្រិតខ្លាំងក្លាឡើង។ តើលោកពិតជាបានឆ្លើយខ្លឹមសារនេះ ប្រាប់ទៅអង្គការសិទ្ធិមនុស្សដែរឬទេ? ឆ.៤៧៖ បាទ ពិតប្រាកដមែនហើយ។ ពួកខ្មែរក្រហម គេចង់សម្លាប់បង្ហើយឲ្យអស់តាមផែនការចុងក្រោយរបស់ពួកគេ។ [...] ស៖ នៅក្នុងកំណត់ហេតុដែលនេះផងដែរ លោកនិយាយថា លោកបានដឹងពីរឿងនេះ ពីព្រោះ សឿន ដែលគាត់ចូលចិត្តខ្ញុំ ហើយចង់សម្លាប់ប្រពន្ធខ្ញុំចោល ដើម្បីយកខ្ញុំធ្វើជាប្តីរបស់គាត់ ហើយគាត់ប្រាប់ខ្ញុំអំពីផែនការលុបបំបាត់ចោលពួកអ្នកជម្លៀសមកពីភូមិភាគបូព៌ា។ តើខ្លឹមសារនេះ ត្រឹមត្រូវដែរឬទេ? ឆ.៤៨៖ បាទ [...] ឆ.៤៩៖ ខ្ញុំបានដឹងរឿងនេះ ដោយសារខ្ញុំដើរជាប់ជាមួយ សឿន រហូត។ ខ្ញុំបានឮ សឿន បញ្ជាទៅប្រធានឈ្លបឲ្យចាប់ប្រមូលប្រជាជនដែលជម្លៀស

753. អ៊ុង ឆាត់ អ្នកបរ១ទេះគោម្នាក់មកពីធ្លាអំពិល បានបញ្ជាក់ថា កងដឹកជញ្ជូនរបស់គាត់មិនបានដឹងពីផែនការសម្លាប់ប្រជាជនជម្លៀសទាំងនោះទេ[2763]។ ប្រជាជនភូមិភាគបូព៌ាជឿថា ពួកគេត្រូវបានបញ្ជូនទៅវាលបាក់ដើម្បីច្រូតស្រូវ[2764]។

មកពីភូមិភាគបូព៌ា ដើម្បីបញ្ជូនទៅសម្លាប់ចោលឲ្យអស់។"]។ ឯកសារ D6.1.618 ការសម្ភាសន៍របស់ SOAS ជាមួយសាត ឆាង KH 00721704។

[2763] ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336 ["គណៈសហការណ៍បានប្រាប់ឲ្យប្រមូលកងរ១ទេះទៅដឹកប្រជាជនមកពីស្វាយរៀង យកទៅច្រូតស្រូវនៅវាលបាក់ជញ្ជើង។ [...] ពេលនោះទាំងខ្ញុំ និងប្រជាជន មិនបានដឹងថា គេដឹកយកទៅសម្លាប់ទេ ព្រោះប្រជាជនមានទឹកមុខ និងនិយាយលេខធម្មតានៅលើរ១ទេះ"]។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១១, ៤៣ KH 00947313-00947314, 00947317 ["គេថាឲ្យទៅច្រូតស្រូវទៅទីនោះ ដែលការប្រាប់នោះ[វាលបាក់ជញ្ជើង] ជាការកុហកទេ។ [...] ។ ប្រធានសហការណ៍បានប្រាប់ថា មានស្រែច្រើនទីនោះ ដែលត្រូវការកម្លាំងច្រូតកាត់។ [...] ខ្ញុំក៏មិនដឹងពីផែនការ១បស់អង្គការដែ១។ ខ្ញុំគ្រាន់តែដឹកអ្នកទាំងនោះ ទឹកន្លែងនោះ តាមតែគេប្រាប់"]។ ឆ.១៩, ៤៦ KH 00947315, 00947318 ["ឲ្យទៅច្រូតស្រូវនៅទីនោះ។ ខ្ញុំក៏មិនដឹងថា គេយកពួកហ្នឹងទៅធ្វើអីដែ១។ [...] ខ្ញុំមិនដឹងពីមូលហេតុ គេយកពួកបូព៌ាទៅសម្លាប់ទេ។"]។ *សូមមើលផងដែ១* ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៦៣ KH 00947335-00947336 ["ស៖ តើលោកដឹងថា ពួកបូព៌ាមានការប្រកែកទៅវាលបឹងបាក់ជញ្ជើងទេ? ឆ.៦៣៖ ពួកគេមិនបានប្រកែកទេ ពីព្រោះពួកគេមិនបានដឹងពីផែនការ ហើយក៏មិនដឹងពីភូមិសាស្ត្រដែ១។ ជាពិសេស ពួកខ្មែ១ក្រហមបានកុហកពួកគេថា ឲ្យទៅច្រូតស្រូវនៅទីនោះ។"]។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្លន ហៀ១ ឆ.៦៨ KH 01067958 ["នៅវាលបាក់ជញ្ជើង [...] ដំបូងគេប្រាប់ថាឲ្យទៅធ្វើចម្ការ តែតាមពិតគេយកអ្នកស្វាយរៀងទៅសម្លាប់នៅទីនោះ"]។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៊ីង ហៅ សាត សុខុម ឆ.៣២ KH 00947349 ["ពួកគេយកទៅសម្លាប់ម្តងបន្តិចៗ [...] ដោយកុហកថា ឲ្យទៅធ្វើការ ឬច្រូតស្រូវនៅទីនោះ"]។

[2764] ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336 ["គណៈសហការណ៍បានប្រាប់ឲ្យប្រមូលកងរ១ទេះទៅដឹកប្រជាជនមកពីស្វាយរៀង យកទៅច្រូតស្រូវនៅវាលបាក់ជញ្ជើង។ [...] ពេលនោះទាំងខ្ញុំ និងប្រជាជន មិនបានដឹងថា គេដឹកយកទៅសម្លាប់ទេ ព្រោះប្រជាជនមានទឹកមុខ និងនិយាយលេខធម្មតានៅលើរ១ទេះ។"]។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១១, ៤៣ KH 00947313-00947314, 00947317 ["គេថាឲ្យទៅច្រូតស្រូវទៅទីនោះ ដែលការប្រាប់នោះ[វាលបាក់ជញ្ជើង] ជាការកុហកទេ។ [...] ។ ប្រធានសហការណ៍បានប្រាប់ថា មានស្រែច្រើនទីនោះ ដែលត្រូវការកម្លាំងច្រូតកាត់។"]។ ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៦៣ KH 00947335-00947336 ["ស៖ តើលោកដឹងថា ពួកបូព៌ាមានការប្រកែកទៅវាលបឹងបាក់ជញ្ជើងទេ? ឆ.៦៣៖ ពួកគេមិនបានប្រកែកទេ ពីព្រោះពួកគេមិនបានដឹងពីផែនការ ហើយក៏មិនដឹងពីភូមិសាស្ត្រដែ១។ ជាពិសេស ពួកខ្មែ១ក្រហមបានកុហកពួកគេថា ឲ្យទៅច្រូតស្រូវនៅទីនោះ។"]។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្លន ហៀ១ ឆ.៦៨ KH 01067958 ["នៅវាលបាក់ជញ្ជើង [...] ដំបូងគេប្រាប់ថាឲ្យទៅធ្វើចម្ការ តែតាមពិតគេយកអ្នកស្វាយរៀងទៅសម្លាប់នៅទីនោះ។"]។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហ្ជត ម៊ីង ហៅ សាត សុខុម ឆ.៣២ KH 00947349 ["ពួកគេយកទៅសម្លាប់ម្តងបន្តិចៗ [...] ដោយកុហកថា ឲ្យទៅធ្វើការ ឬច្រូតស្រូវនៅទីនោះ"]។

754. ក្នុងរយៈពេលពីបីទៅបួនថ្ងៃក្រោយមក រទេះគោប្រមាណជា ៣០ ក្នុងមួយយប់បានដឹកប្រជាជនជម្លៀសភូមិភាគបូព៌ាពីសហករណ៍នានាក្នុងស្រុកទៅកាន់វាលបាក់[2765]។ នៅពេលពួកគេមកដល់ អ្នកបរទេះគោត្រូវបានបញ្ជាឲ្យដាក់ចុះប្រជាជនជម្លៀស ហើយបន្ទាប់មកចាកចេញពីកន្លែងនោះ[2766]។ អ៊ុង ឆាត់ បាននិយាយថា ក្នុងមួយយប់ នៅពេលគាត់ចាកចេញពីទីតាំងនោះ គាត់បានឃើញសមាជិកកងឈ្លបកំពុងលាក់ខ្លួននៅក្នុងព្រៃជិតៗនោះ ហើយមួយសន្ទុះក្រោយមក គាត់បានឮសំឡេងកាំភ្លើង[2767]។ អ្នកបរទេះម្នាក់ទៀត ឈ្ឃោះ ឈាង ម៉ី បានឃើញទាហានខ្មែរក្រហមបណ្តើរប្រជាជនពីរក្រុមផ្សេងគ្នាទៅកាន់វាលបាក់ ខណៈគាត់កំពុងបរទេះគោ និងធ្វើការនៅក្នុងស្រែ[2768]។

[2765] ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.២២ KH 00947341 ["ខ្ញុំដឹង ពីព្រោះខ្មែរក្រហមបានប្រមូលពួកបូព៌ាទាំងនោះចេញពីសហករណ៍នានា [...] សហករណ៍ទាំងនោះមានដូចជា សហករណ៍ស្បូរ សហករណ៍កញ្ជោ សហករណ៍ភូមិស្ទឹង និងសហករណ៍ប៊ីងឈ្ងូក។"]។ ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្លួន ហៀ ឆ.១៣, ១៧, ៦៩-៧០ KH 01067950-01067951, 01067959 ["ឆ.១៣៖ ខ្មែរក្រហមបានជម្លៀសខ្ញុំឲ្យទៅនៅស្តាំជ្រុំ [...] ឆ.១៧៖ [...] សហករណ៍ [...] ស៖ [...] តើលោកស្រីធ្លាប់ឃើញគេដឹកអ្នកស្វាយរៀងទៅសម្លាប់នៅវាលបាក់ជញ្ជឹងដែរឬទេ? ឆ.៦៩៖ ចាស [...] គេប្រាប់ថា គេដឹកអ្នកស្វាយរៀងទាំងឡានៗតែម្តងពីស្វាយរៀង មកដាក់នៅក្រុងពោធិសាត់។ បន្ទាប់មក ឲ្យអ្នកស្វាយរៀងទាំងអស់នោះ [...] សម្រាកនៅទីនេះមួយយប់។ [...] ឆ.៧០៖ [...] អ្នកស្វាយរៀងធ្វើដំណើរបន្តបន្ទុយគ្នារហូត។"]។

[2766] ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១១, ១៩ KH 00947313-00947315, 00947317 ["ខ្ញុំបានដឹក [...] អ្នកជម្លៀសមកពីភូមិភាគបូព៌ានៅទីកន្លែងនោះ ហើយខ្មែរក្រហមបានប្រាប់ពួកខ្ញុំចាកចេញពីកន្លែងនោះវិញ។ [...] លុះទៅដល់ទីនោះ ខ្ញុំបានឃើញយោធាខ្មែរក្រហមពីរបីនាក់ ហើយគេប្រាប់ [...] មនុស្សនៅទីនោះ រួចគេប្រាប់ឲ្យពួកខ្ញុំត្រឡប់មកវិញ។"]។

[2767] ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336-0027737 ["ពេលដឹកនោះ មិនមានឈ្លប ឬក៏យោធាខ្មែរក្រហមអ្នកមរទេះទេ ប៉ុន្តែពេលទៅដល់វាលបាក់ជញ្ជឹងទើបឃើញមានយោធាខ្មែរក្រហមពួនជាស្រេចនៅក្នុងព្រៃត្រែងកែ្ករនោះ។ [...] រួចខ្ញុំឃើញពួកខ្មែរក្រហមបណ្តើរប្រជាជនទៅបាញ់សម្លាប់ចម្ងាយប្រហែល ១០០ ម៉ែត្រ ពីកន្លែងដែលខ្ញុំឈប់រទេះ។"]។ *សូមអានភ្ជាប់មកជាមួយ* ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១១-១២, ១៥ KH 00947313-00947314 ["ឆ.១១៖ [...] គថាឲ្យ [...] ទៅទីនោះ [វាលបីងបាក់ជញ្ជឹង] [...] ខ្ញុំបានដឹក [...] អ្នកជម្លៀសមកពីភូមិភាគបូព៌ានៅទីកន្លែងនោះ [...] ខ្ញុំចាកចេញមកវិញនោះ ខ្ញុំបានឮស្នូរកាំភ្លើងចេញពីកន្លែងដាក់ [...]។ ស៖ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក [...] លោកបាននិយាយថា លោកបានឃើញទាហានខ្មែរក្រហម បាញ់សម្លាប់អ្នកជម្លៀសមកពីភូមិភាគបូព៌ា តើត្រឹមត្រូវ? ឆ.១២៖ ទេ មិនត្រឹមត្រូវទេ។ ខ្ញុំមិនបានឃើញការបាញ់សម្លាប់ដោយផ្ទាល់ភ្នែកទេ។ ដូចដែលខ្ញុំបញ្ជាក់នៅក្នុងកំណត់ហេតុនេះ គឺខ្ញុំបានឮស្នូរកាំភ្លើង ក្រោយពេលដែលខ្ញុំចាកចេញប្រហែល ៥០០ ម៉ែត្រ។ [...] ស.១៥៖ តើលោកដឹងថា សាកសពទាំងនោះស្លាប់ដោយសារអ្វីទេ? ឆ.១៥៖ ខ្ញុំឃើញច្បាស់ថា អ្នកទាំងនោះស្លាប់ដោយគ្រាប់កាំភ្លើង"]។

[2768] ឯកសារ D5/1056 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈាង ម៉ែ KH 00993121-00993122 ["បន្ទាប់មក ខ្ញុំត្រូវផ្ទាស់មកនៅកងចល័ត ភ្ជួរស្រែ ដកស្ទូង នៅវាលបាក់ចិញ្ចៀន ឃុំស្រែស្ពុក ស្រុកបាកាន ខេត្តពោធិសាត់។ [...] ពេលខ្ញុំកំពុងបរទេះគោទៅភ្ជួរស្រែ ស្រាប់តែខ្ញុំឃើញពួកយោធា ប៉ុល ពត អាវខ្មៅ ខោខ្មៅ បណ្តើរមនុស្សចងទាំងខ្សែៗ រួមទាំងវាយបណ្តើរផង

755. បន្ទាប់ពីសម្លាប់រួច សមាជិកកងឈ្លបមួយចំនួនដែលបានចូលរួមសម្លាប់មនុស្សនៅវាលបាក់បាន និយាយទាំងអំនួតអំពើរបៀបដែលគេបំភ័យជនរងគ្រោះ មុនបាញ់សម្លាប់ ពីព្រោះពួកគេបានលាក់ខ្លួននៅជិតទីតាំងនោះ។ កងឈ្លបទាំងនេះក៏បាននាំមកជាមួយខ្លួនទ្ងវក្រម៉ាពណ៌ខៀងដែលត្រូវបានជូនទៅប្រជាជនជម្លៀស មុនពេលពួកគេត្រូវបានជម្លៀងទៅពោធិ៍សាត់[2769]។

756. មួយខែក្រោយមកបន្ទាប់ពី អ៊ុង ឆាត់ បានដឹកប្រជាជនជម្លៀសទៅកាន់វាលបាក់ គាត់បានវិលត្រឡប់ទៅទីតាំងនោះ ហើយបានឃើញសាកសពបុរស ស្ត្រី និងកុមារដោយមានស្នាមរបួសដោយគ្រាប់កាំភ្លើង និងមានពាក់ក្រមាពណ៌ខៀវ[2770]។ លឹម សាត បានទៅវាលបាក់ដើម្បីច្រូតស្រូវនៅចុងឆ្នាំ១៩៧៨ និងបានប្រទះឃើញសាកសពស្ងួយរលួយប្រមាណជា ៦០ សាកសព ក្នុងនោះរួមទាំងទារក ដោយមានខោអាវ កាតាបស្ពាយ និងក្រមាពណ៌ខៀវ។ គាត់ជឿថា ជនរងគ្រោះត្រូវបានវាយ

ជេរផង សំដៅទៅព្រៃវាលបាក់ចិញ្ចៀន [...] ក្រោយមក ពេលកំពុងតែធ្វើការ ខ្ញុំឃើញឈ្លបស្រីស្រឡាញ់ឈ្លបប្រុស ប្រហែលមានផ្ទៃពោះហើយ ត្រូវអង្គការ ប៉ុល ពត ចាប់ចងស្ពាបទាំងពីរនាក់ បណ្តើរយកទៅសម្លាប់ នៅវាលបាក់ចិញ្ចៀននោះតែម្តង ដោយចោទថា ខុសសីលធម៌"]។

[2769] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៥៧ KH 00947335 ["ខ្ញុំបានឮពួក តាទួន និងអ្នកផ្សេងទៀតដែលបានទៅនោះ និយាយអួតអាងគ្នានៅជិតខ្ញុំថា គេបានទៅពួកស្នាក់ដើម្បីបាញ់សម្លាប់ប្រជាជនទាំងនោះ នៅវាលបាក់ជញ្ជឹង ដោយត្រឡប់មកវិញ យកទាំងក្រមាពណ៌ខៀវមកផង។ ពួកប្រជាជនជម្លៀសមកពីបូព៌ានោះ បានប្រាប់ខ្ញុំថា មុនមកពោធិ៍សាត់ អង្គការបានចែកក្រមាពណ៌ខៀវឲ្យពួកគេគ្រប់ៗគ្នា"]។

[2770] ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១៣, ១៥ KH 00947314 ["ស៖ នៅពេលដែលលោកបានទៅទីនោះ តើលោកបានឃើញសាកសពដោយផ្ទាល់ភ្នែកទេ? ឆ.១៣៖ ខ្ញុំបានឃើញសាកសពហ្នឹងដោយផ្ទាល់ភ្នែក។ ស៖ នៅពេលលោកឃើញសាកសពមួយខែ [...] តើលោកដឹងថា សាកសពទាំងនោះស្លាប់ដោយសារអ្វីទេ? ឆ.១៥៖ ខ្ញុំឃើញច្បាស់ថា អ្នកទាំងនោះស្លាប់ដោយគ្រាប់កាំភ្លើង ហើយមានខោអាវស៊ីវិលនៅជាប់នឹងខ្លួនមានទាំងប្រុសទាំងស្រី និងកុមារផងដែរ ហើយមានកន្សែងខៀវគ្រប់ៗគ្នា។"]។ ឆ.២០-២១ KH 00947315 ["មនុស្សភាគច្រើននៅក្នុងភូមិនេះ បានឃើញសាកសព[អ្នកភូមិភាគបូព៌]នៅទីនោះ [...] នៅលើដីនៅខាងត្បូង ខាងលិច និងខាងជើងបឹង"]។ ឯកសារ D6.1.643 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00369243 ["ខ្ញុំមិនបានឃើញគ្រប់ទីកន្លែងទេ មានគេឃើញផង និងខ្ញុំឃើញផង នៅក្នុងចុងឆ្នាំ១៩៧៨ ក្រោយពីការសម្លាប់ប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ានៅវាលបាក់ជញ្ជឹងរួចមក"]។

រហូតដល់ស្លាប់[2771]។ សាត ឆាង បានស្ថិតនៅទីតាំងនេះ នៅដើមឆ្នាំ១៩៧៩ និងបានរៀបរាប់ពីការមើលឃើញសាកសពស្អុយរលួយស្ថិតនៅវាយប៉ាយក្នុងតំបន់នោះ[2772]។

757. សាកសពផ្សេងៗទៀតរបស់ប្រជាជនជម្លៀសត្រូវបានកប់នៅក្នុងរណ្តៅក្នុងតំបន់នេះ[2773]។ ជារួមតាមការប៉ាន់ស្មាន ប្រជាជនជម្លៀសពីភូមិភាគបូព៌ាមិនតិចជាង ១.០០០ នាក់ឡើយត្រូវបានសម្លាប់

[2771] ឯកសារ D134/4 កំណត់ហេតុស្តាប់ចម្លើយ លឹម សាត ឆ.១៨-២១, ២៤-២៥ KH 00947340-00947341 ["ស៖ តើលោកដឹងអ្វីខ្លះអំពីការកាប់សម្លាប់ប្រជាជននៅវាលបឹងបាក់ជញ្ជើងទេ? ឆ.១៨៖ ខ្ញុំដឹងថា មានការសម្លាប់មនុស្សនៅវាលបឹងបាក់ជញ្ជើង [...] ឆ.១៩៖ [...] នៅពេលដែលទៅរកច្រូតស្រូវក្នុងខែ ១០ ឆ្នាំ១៩៧៨ [...] ខ្ញុំបានឃើញសាកសពជាច្រើន។ [...] ឆ.២០៖ ខ្ញុំបានឃើញសាកសពជាច្រើន ដោយមានខោអាវ សាកកាដូ និងក្រមាពណ៌ខៀវ ក្រហម និងខ្មៅផងដែរ។ [...] ឆ.២១៖ [...] ខ្ញុំ [...] បានឃើញសាកសពក្រៀមស្វិតដោយកំដៅថ្ងៃ មិនទាន់រលួយសាច់អស់ទេ ហើយក៏មានក្លិនស្អុយខ្លះដែរ។ [...]ឆ.២៤៖ ខ្ញុំគិតថា គេបានប្រើដំបងដើម្បីវាយសម្លាប់អ្នកទាំងនោះ ពីព្រោះមិនមានអ្នកណាប្រាប់ខ្ញុំថា គេបានព្ញស្នូរកាំភ្លើងទេ។ ស៖ នៅក្នុងសាកសពចំនួន ៦០ នាក់ហ្នឹង តើលោកឃើញមានសាកសពកុមារទេ? ឆ.២៥៖ ខ្ញុំបានឃើញមានកុមារតូចធំ រួមទាំងកូនង៉ាផងដែរ។"]។

[2772] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៥៩-៦០ KH 00947335 ["ស៖ តើលោកធ្លាប់ទៅវាលបឹងបាក់ជញ្ជើងទេ? ឆ.៥៩៖ [...] ពេលក្រោយរំដោះខេត្តពោធិសាត់ទាំងស្រុង ប្រហែលនៅខែ ៣ ឬ ខែ៤ ខ្ញុំបានទៅទីនោះ [...] ហើយបានឃើញសាកសពរលួយជាច្រើននៅទីនោះ។ [...] ឆ.៦០៖[...]ខ្ញុំមើលតែពីចម្ងាយដោយសារធុំក្លិនហុយ[ស្អុយ]។"]។

[2773] ឯកសារ D219/182 កំណត់ហេតុស្តាប់ចម្លើយ អ្ងួន ហៀ ឆ.៦៦, ៦៨ KH 01067958 ["វាលបាក់ជញ្ជើងនេះ នៅជិតទន្លេ ហើយកន្លែងនេះមានរណ្តៅមួយ ដែលមានទំហំប្រហែលជា ៥០ ម៉ែត្របួនជ្រុង មនុស្សជាច្រើនត្រូវគេសម្លាប់ដាក់ចូលរណ្តៅនេះ។ [...] ស៖ តើមនុស្សប្រភេទណា ដែលត្រូវគេសម្លាប់នៅវាលបាក់ជញ្ជើងដែរឬទេ? ឆ.៦៨៖ ពួកស្វាយរៀង ត្រូវគេសម្លាប់នៅវាលបាក់ជញ្ជើង"]។

នៅវាលបាក់[2774]។ ប្រជាជនដែលត្រូវបានសម្លាប់ទាំងនោះមានស្ត្រី និងកុមារចាប់ពីអាយុ ១ ឆ្នាំ រហូតដល់ ១៥ ឆ្នាំ[2775]។

ការធ្វើទុក្ខបុកម្នេញ

758. ការធ្វើទុក្ខបុកម្នេញត្រូវបានធ្វើឡើងតាមរយៈឧក្រិដ្ឋកម្មនានា ដែលបានរៀបរាប់ខាងលើប្រឆាំងនឹងប្រជាជនជម្លៀសពីភូមិភាគបូព៌ា។ ក្រុមនេះត្រូវបានកំណត់ជាគោលដៅជាពិសេស ព្រោះតែពួកគេ

[2774] ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336 ["តាមការប៉ាន់ស្មានរបស់ខ្ញុំ ប្រជាជនទាំងនោះមានច្រើនណាស់ រហូតដល់រាប់ពាន់។"]។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១១, ១៥, ១៧ KH 00947314-00947315 ["មួយខែក្រោយមក [...] ខ្ញុំបានទៅដល់កន្លែងនោះ ហើយបានឃើញសាកសពជាច្រើននៅពាសពេញកន្លែងនោះ។ តាមពិត ក្រោយដែលវៀតណាមរំដោះឆ្នាំ១៩៧៩ [...] សាកសពជាច្រើននៅពាសពេញទីកន្លែងនោះ [...] មានកន្សែងខៀវគ្រប់ៗគ្នា។ [...] ប្រហែលជាមិនក្រោម ១០០០ ទេ។"]។ ឯកសារ D6.1.643 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00369243 ["ឃើញខ្មោចនៅកន្លែងផ្សេងទៀតជាច្រើន នៅពេលទៅហ្វាលគោ [...] នៅក្នុងចុងឆ្នាំ១៩៧៨ ក្រោយពីការសម្លាប់ប្រជាជនដែលជម្លៀសមកពីភូមិភាគបូព៌ានៅវាលបាក់ជញ្ជើងរួចមក"]។

[2774] ឯកសារ D134/3 កំណត់ហេតុស្តាប់ចម្លើយ សាត ឆាង ឆ.៦២ KH 00947335 ["ស៖ តើលោកដឹងពីចំនួនជនរងគ្រោះ ដែលគេសម្លាប់នៅវាលបឹងបាក់ជញ្ជើងទេ? ឆ.៦២៖ [...] ប្រហែលជាមានចំនួនច្រើន ចន្លោះខ្នង់រយ ទៅដល់ខ្នង់មួយពាន់"]។ ឯកសារ D6.1.685 កំណត់ហេតុស្តាប់ចម្លើយ លីម សាត KH 00407762 ["នៅវាលបាក់ជញ្ជើង មានសម្លាប់ប្រជាជនជម្លៀសយ៉ាងច្រើន"]។ ឯកសារ D134/5 កំណត់ហេតុស្តាប់ចម្លើយ ហួត ម៉ឹង ហៅ សាត សុខុម ឆ.ពាព KH 00947349 ["ស៖ តើលោកស្រីដឹងថា ពួកបូព៌ាដែលគេយកទៅសម្លាប់មានចំនួនប៉ុន្មាននាក់ទេ? ឆ.ពាព៖ ខ្ញុំគ្រាន់តែដឹងថា មានចំនួនច្រើន"]។ ឯកសារ D134/6 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងសម្លាប់ វាលបាក់ជញ្ជើង KH 01045576 ["បើតាសម្ដីសាក្សី មានប្រជាជនដែលត្រូវគេជម្លៀសពីភូមិភាគបូព៌ាចំនួនប្រហែល ១០០០ នាក់ ត្រូវគេដឹកយកទៅវាលបាក់ចិញ្ជៀននៅខែមិនា ឬនៅរដូវប្រាំងក្នុងឆ្នាំ ១៩៧៨"]។

[2775] ឯកសារ D6.1.145 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ KH 00277336-00277337 ["ស៖ តើអ្នកណាជាអ្នកបញ្ជាឲ្យដឹកប្រជាជនបូព៌ាទៅ? ឆ៖ [...] ខ្ញុំឃើញពួកខ្មែរក្រហមបាញ់ដោយផ្ទាល់ ខ្លះស្លាប់នៅក្នុងបឹង និងវាលបាក់ជញ្ជើងនោះ។ ប្រជាជនទាំងនោះ ត្រូវបានខ្មែរក្រហមដឹកមកពីគ្រប់សហករណ៍ទាំងអស់ យកទៅសម្លាប់នៅបឹងបាក់ជញ្ជើង។ ប្រជាជនទាំងនោះមានទាំងក្មេង ទាំងចាស់ ទាំងស្រីទាំងប្រុស។"]។ ឯកសារ D134/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុង ឆាត់ ឆ.១៣, ១៥, ៤៤ KH 00947314, 00947317 ["ស៖ [...] ទីនោះ [វាលបឹងបាក់ជញ្ជើង] តើលោកបានឃើញសាកសព [...]? ឆ.១៣៖ ខ្ញុំបានឃើញ [...] ឆ.១៥៖ មានទាំងប្រុសទាំងស្រី និងកុមារផងដែរ [...] ឆ.៤៤៖ មានកុមារអាយុ ១ ឆ្នាំដល់ ១៥ ឆ្នាំគឺតាមឃើញសាកសពគេសម្លាប់មនុស្សទាំងគ្រួសារៗតែម្ដង"]។ ឯកសារ D134/6 របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីតាំងសម្លាប់ វាលបាក់ជញ្ជើង KH 01045576-01045577 ["កុមារ និងស្ត្រីជាច្រើន ត្រូវបានសម្លាប់នៅ [...] វាលបាក់ចិញ្ជៀន"]។

គឺជាសមាជិកជាក់ស្តែងនៃក្រុមនយោបាយមួយ ឬត្រូវបានចាត់ទុកថាជាសមាជិកនៃក្រុមនយោបាយមួយ[2776]។

v. ឧក្រិដ្ឋកម្មដែលត្រូវចោទប្រកាន់ក្នុងដីកាចោទប្រកាន់

759. ដោយផ្អែកលើភ័ស្តុតាងដែលបានបញ្ជាក់ខាងលើ ស.ព.អ ស្នើឲ្យធ្វើការចោទប្រកាន់ **យ៉ីម ទិត្យ** ពីបទឧក្រិដ្ឋកម្មដូចខាងក្រោម ទាក់ទងនឹងទីតាំងសម្លាប់វាលបាក់ជញ្ជីង ជាអាទិ៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃមនុស្សឃាត ការសម្លាប់រង្គាល[2777] និងការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយលើប្រជាជនជម្លៀសពីភូមិភាគបូព៌ា។

៧. អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ

ក. សេចក្ដីផ្ដើម

760. ភ័ស្តុតាងនៅក្នុងសំណុំរឿងបង្ហាញថា **យ៉ីម ទិត្យ** និងសមាជិកផ្សេងៗទៀតនៃសហឧក្រិដ្ឋកម្មរួមបានអនុវត្តគោលនយោបាយ ប.ក.ក ក្នុងការបង្ខំគូស្វាមីភរិយាឲ្យរៀបការ និងរួមភេទដោយគ្មានការយល់ព្រម។ អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានធ្វើឡើងយ៉ាងច្រើន នៅក្នុងតំបន់ ១ ក្នុងស្រុកសំឡូត និងរោងចក្រស្ករកំពង់គល់ក្នុងស្រុកសង្កែ និងក្នុងតំបន់ ៤ ក្នុងឃុំកំពង់ព្រៀង និងឃុំវ៉ាងកេសី។ **យ៉ីម ទិត្យ** និងសមាជិកផ្សេងៗនៃសហឧក្រិដ្ឋកម្មរួមបានចូលរួមចំណែកដល់ការរៀបចំ និងការជូនដំណឹងអំពីអាពាហ៍ពិពាហ៍ដែលនឹងត្រូវធ្វើឡើង ចូលរួមក្នុងពិធីរៀបអាហាហ៍ពិពាហ៍ដោយផ្ទាល់ និងបញ្ជាឲ្យតាមដានគូស្វាមីភរិយាដែលទើបរៀបការថ្មីៗ ដើម្បីធានាថាមានការរួមភេទនៅ

[2776] *សូមមើល* VIII.B.1.a. ការទទួលខុសត្រូវឧក្រិដ្ឋកម្មលក្ខណៈបុគ្គល – របៀបនៃការទទួលខុសត្រូវ – ការប្រព្រឹត្តសហឧក្រិដ្ឋកម្មរួម – គោលនយោបាយសត្រូវ។ V.B.6.a.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់ ៧ – ពន្ធនាគារលេខ ៨ – ឧក្រិដ្ឋកម្ម – ការធ្វើទុក្ខបុកម្នេញ។

[2777] សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា ធាតុផ្សំនៃភាពជាទ្រង់ទ្រាយធំចំពោះឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវបានគាំទ្រដោយផ្អែកលើភស្តុតាងនៅវាលបាក់ជញ្ជីងតែមួយគត់។ ជាជម្រើសម្យ៉ាងទៀត សហព្រះរាជអាជ្ញាអន្តរជាតិប្រកាន់ជំហរថានៅពេលពិចារណាទៅលើធាតុផ្សំនៃភាពជាទ្រង់ទ្រាយធំ ដែលតម្រូវឲ្យបង្ហាញការសម្លាប់រង្គាល គេគួរផ្ដល់ស្ថានទម្ងន់ដល់ការសម្លាប់នៅតាមបណ្ដាមន្ទីរសន្តិសុខ ទីកន្លែងសម្លាប់មនុស្ស និងការដ្ឋានការងារដោយបង្ខំទាំងអស់ រួមទាំងការសម្លាប់នៅវាលបាក់ជញ្ជីង។ រាល់ទីតាំងទាំងអស់ដែលបានបង្កើតជាផ្នែកនៃប្រព័ន្ធរៀបចំតែមួយ ដើម្បីអនុវត្តគោលនយោបាយធ្វើទុក្ខបុកម្នេញ និងសម្លាប់ខ្លាំង ហើយនឹងការសម្លាប់នៅតាមទីតាំងនីមួយៗ ត្រូវបានសម្រួលដោយពាក្យសំដី និងសកម្មភាពដដែលៗរបស់ យ៉ីម ទិត្យ។

ក្នុងអាពាហ៍ពិពាហ៍។ វិសាលភាព និងភាពញឹកញាប់នៃអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនេះ និងសកម្មភាពស្រដៀងគ្នានេះលើអាពាហ៍ពិពាហ៍នៅទូទាំងកម្ពុជាប្រជាធិបតេយ្យបង្ហាញថា អាពាហ៍ពិពាហ៍ដោយបង្ខំ និងការបង្ខំឲ្យរួមភេទបន្ទាប់ពីអាពាហ៍ពិពាហ៍ (ការរំលោភផ្លូវភេទ) គឺជាផ្នែកមួយនៃគោលនយោបាយដែលត្រូវបានរៀបចំឡើងយ៉ាងមានប្រសិទ្ធភាពដែលជាផ្នែកមួយនៃការវាយប្រហារយ៉ាងទូលំទូលាយ និងលក្ខណៈប្រព័ន្ធលើប្រជាជនស៊ីវិលកម្ពុជា។

761. ស.ច.ស.អ បានចោទ **យ៉ឹម ទិត្យ** លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ) ក្នុងស្រុកសំឡូត ឃុំកំពង់ព្រៀង និងឃុំវ៉ាំងកេសី[2778]។

ខ. សាវតារនយោបាយ

i. ទស្សនទានអំពីគ្រួសារ

762. ប.ក.ក បានបោះពុម្ពលើដំបូងអំពីទស្សនាទានរបស់ខ្លួនស្តីពីបញ្ហាកសាងគ្រួសារ នៅក្នុងចុងខែកុម្ភៈ ឆ្នាំ១៩៧៤ នៃទស្សនាវដ្តីឃោសនាការ *យុវជន និងយុវនារីបដិវត្តន៍*។ មិនដល់ ៦ សប្តាហ៍ផងបន្ទាប់ពីបានចូលកាន់កាប់ទីក្រុងភ្នំពេញ បក្សបានបោះពុម្ពឡើងវិញនូវឯកសារនេះដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយ ដោយឆ្លុះបញ្ចាំងពីភាពចាំបាច់ដែលថា បក្សបានយកចិត្តទុកលើបញ្ហានេះ និងមានគោលបំណងដើម្បីធានាថា គោលនយោបាយទាំងអស់ដែលបានរៀបរាប់លម្អិតនៅក្នុងឯកសារត្រូវតែយកទៅអនុវត្តឲ្យបានពេញលេញ នៅគ្រប់កន្លែងទាំងអស់ក្នុងប្រទេសកម្ពុជា[2779]។

763. ខ្លឹមសារសំខាន់នៃឯកសារនេះ និងសេចក្តីប្រកាសជាញឹកញាប់ពីគោលជំហររបស់បក្សគឺទស្សនាទានដែលទម្រង់គ្រួសារថ្មី ឬហៅថាគ្រួសារបដិវត្ត ត្រូវជំនួសគ្រួសារដែលមានលក្ខណៈជាប្រពៃណី។ គ្រួសារបដិវត្តចាំបាច់ត្រូវមានភាពស្មោះត្រង់នឹងអង្គការ ដែលត្រូវបានចាត់ទុកជា "ឪពុកម្តាយ" ថ្មីរបស់ប្រជាពលរដ្ឋ ក្នុងពេលដែលទំនាក់ទំនងគ្រួសារផ្សេងៗទៀតត្រូវបានចាត់ទុកថាពុំមានភាព

[2778] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ឹម ទិត្យ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426550-01426552, 01426553-01426555, 01426555-01426557។

[2779] ឯកសារ D310/1.1.1 ការបោះពុម្ពផ្សាយរបស់របបកម្ពុជាប្រជាធិបតេយ្យ លោកទស្សនៈបដិវត្ត និង មិនបដិវត្ត ចំពោះបញ្ហាកសាងគ្រួសារ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៧៤ បោះពុម្ពឡើងវិញ ចុះថ្ងៃទី០២ ខែមិថុនា ឆ្នាំ១៩៧៥ ("ឯកសារនយោបាយកសាងគ្រួសារ")។

ចាំបាច់[2780]។ គោលបំណងតែមួយនៃគ្រួសារបដិវត្តគឺត្រូវធ្វើឲ្យសម្រេចគោលដៅបដិវត្តក្នុងប្រទេស[2781]។ ក្នុងការបំពេញបេសកកម្មដើម្បីកសាងប្រទេសឡើងវិញ គ្រួសារមិនចាំបាច់រស់នៅ

[2780] ឯកសារ D179/1.2.8 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ម៉ោង 11.14.33-11.16.23 ["លេចចេញចម្រៀងមួយ [...] ម៉ែឪរំដោះមនុស្ស-- អ៊ីង បង្កើតមនុស្សបានតែម្នាក់ទេ អង្គការបដិវត្តន៍រំដោះមនុស្សបានមួយនគរ។ ដូច្នេះ ម៉ែឪអត់មានតួនាទីទេ អង្គការជាម៉ែឪ។ ហ្នឹងក្រុមគ្រួសារ គេចែករបៀបហ្នឹង"]។ ឯកសារ D219/702.1.140 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ម៉ោង 14.26.46-14.30.24 ["កូនខ្ញុំក៏ដោយ កូនកម្មាភិបាលផ្សេងទៀតក៏ដោយ តែកើតមកគឺជាកុមារ គឺកូនរបស់បក្ស ជាកូនរបស់អង្គការ ដែលគេយកចិត្តទុកដាក់ដូចគ្នា"]។ ឯកសារ D5/1334/3 ប្រតិចារឹក ជា ឌៀប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.13.39-15.16.20 [នៅឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមប្រជុំនៅទីក្រុងភ្នំពេញ ដែលពេលនោះ ខៀវ សំផន ណែនាំ "ចាកុំអាល័យតែគិតម៉ែឪ នឹកម៉ែឪ គិតតែខំប្រឹងធ្វើការជូនបក្ស ជូនរដ្ឋទៅ រឿងម៉ែឪទុកមួយម្ខែក។"]។ ម៉ោង 15.16.20-15.22.01 ["រឿងឪម៉ែ គឺកាត់ផ្តាច់ឪពុកម្តាយ បងប្អូនមិនដែលឲ្យជួបគ្នាទេ។ [...] អង្គការនិយាយថា [...] ក្រោមការគ្រប់គ្រងរបស់អង្គការ មិនមែនទៅចាំម៉ែឪ អាល័យតែទៅរកម៉ែឪទៀតទេ គឺអង្គការជាម៉ែឪហើយ។"]។ ឯកសារ D219/883.1.83 ប្រតិចារឹក ហ៊ីម ហ៊ីយ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៦ ម៉ោង 09.21.10-09.25.48 [សាក្សីជាអ្នកយាមនៅ មន្ទីរ ស-២១៖ "គេបង្រៀនសូត្រនេះ [មន្ទីរ ស-២១] ក៏បង្រៀនតែខ្ញុំមួយដែរ គឺបង្រៀនទាំងអស់គ្នា។ ម្នាក់ៗជាកូនអង្គការ មិនមែនកូនម៉ែឪយើងទេ ម៉ែឪយើងគឺថាគ្រាន់តែបានបង្កើតយើងប៉ុណ្ណឹង តែគុណគឺមានតែអង្គការទេ ជាគុណយើង។ អីចឹងយើងត្រូវគោរព អង្គការជាម៉ែឪយើង អង្គការឲ្យធ្វើអី គឺយើងត្រូវធ្វើហ្នឹង។"]។ ឯកសារ D219/370.1.5 សៀវភៅ ហង់រី លោកា មានចំណងជើងថា កូនសៀវភៅក្រហមរបស់ ប៉ុល ពត KH 0081075-00810756 ["នៅក្នុងសង្គមបដិវត្តន៍នេះ ធម្មជាតិពិតប្រាកដនៃគ្រួសារតូច ត្រូវបានផ្លាស់ប្តូរ។ [...] ទំនាក់ទំនងសង្គមតែមួយប៉ុណ្ណោះ ស្នើនឹងទំនាក់ទំនងផ្លូវចិត្ត ដែលត្រូវរាប់បញ្ចូល គឺជាទំនាក់ទំនងខ្សែបណ្តាយនៃការស្រឡាញ់របស់កូនចំពោះ (តាមពិតវាគឺជាការគោរពចំពោះ) អង្គការ។ ក្នុងពេលនោះដែរ ខ្មែរក្រហមបានរក្សាទុកពាក្យផ្សេងទៀតនៃភាពសាច់ញាតិ ("ពូ" "មីង" "បង" ។ល។) ដើម្បីឲ្យកុមារមើលឃើញថា សង្គមបដិវត្តន៍ គឺជា 'ក្រុមគ្រួសារដ៏ធំមួយ" ដោយមានអង្គការជាមេគ្រួសារ ជាគ្រូបង្រៀន និងជាឪពុកម្តាយរបស់ប្រជាជនទាំងមូល ហើយថា ពួកគេជាកូនចៅរបស់អង្គការ។ សេចក្តីស្រឡាញ់ និងសេចក្តីស្នេហាដែលកូនមានចំពោះម្តាយ ឬឪពុករបស់ពួកគេ និងសេចក្តីស្រឡាញ់ និងសេចក្តីស្នេហាដែលឪពុកម្តាយមានចំពោះកូនរបស់ពួកគេ ត្រូវតែផ្ទេរទៅឲ្យអង្គការ។"]។ ឯកសារ D1.3.17.1 សៀវភៅ អេលីហ្សាបេត បេកយ៉ែ មានចំណងជើងថា នៅពេលដែលសង្គ្រាមរលត់ទៅ KH 00232300 ["តាមលក្ខណៈវិនិច្ឆ័យរបស់ជនជាតិអាស៊ី ជនជាតិខ្មែរជាមនុស្សដែលជំពាក់ចិត្តនឹងគ្រួសារខ្លាំងជាទីបំផុត។ ប្រាដកណាស់ ការជំពាក់ចិត្តនេះ ជាធាតុផ្សំបង្កជាគំរាមកំហែងយ៉ាងធ្ងន់ធ្ងរចំពោះ អង្គការ ហើយមតិណែនាំស្នើរតែទាំងអស់របស់ពួកកុម្មុយនីស បានតម្រង់ទៅរកការរំលាយគ្រួសារចោលតាមមធ្យោបាយគ្រប់បែបយ៉ាង។"]។ ឯកសារ D117/36.1.23 សៀវភៅ Philip Short មានចំណងជើងថា ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ EN 00396533។ ឯកសារ D310/1.1.6 សៀវភៅ កាស្ទ្រូ មិ ណាហ្គ្រាវ៉ា មានចំណងជើងថា អំពើហិង្សាលើយ៉ោនឌ័រក្នុងអំឡុងរបបខ្មែរក្រហម EN 00421891។ ឯកសារ D6.1.595 សៀវភៅ ម៉ែខ្លីល ទ្រីកខ្លីរ៉ី មានចំណងជើងថា កម្ពុជាឆ្នាំ១៩៧៥-១៩៨២ EN 00397102។

[2781] ឯកសារ D310/1.1.1 ឯកសារនយោបាយកសាងគ្រួសារ KH 00407100 ["យើងទុកបញ្ហាគ្រួសារ ជាផ្នែកមួយបោះមិនដាច់ពីបញ្ហាប្រទេសជាតិ និងប្រជាជនទាំងមូល។ [...] ដូច្នេះ ការកសាងគ្រួសារបដិវត្តយើង គឺ [...] តែសំខាន់គឺដើម្បីធ្វើបដិវត្តសម្រេចភារកិច្ច ដ៏ឧត្តុង្គឧត្តម រំដោះប្រទេសជាតិ ប្រជាជននឹងវណ្ណៈក្រីក្រ ហើយឈានទៅកសាងសង្គម សង្គមនិយម និងកុម្មុយ

ជាមួយគ្នាទៀតឡើយ ហើយសមាជិកគ្រួសារជាធម្មតាត្រូវបានបំបែក និងត្រូវបានបញ្ជូនទៅកាន់ការដ្ឋានផ្សេងៗគ្នា ហើយពេលខ្លះទៅកាន់ការដ្ឋានដ៏ឆ្ងាយទៀតផង[2782]។ ទារកត្រូវបានបំបែកចេញពីម្តាយរបស់គេដើម្បីឲ្យម្តាយអាចផ្តោតការយកចិត្តទុកដាក់លើការងារ ក្នុងពេលដែលទារកទាំង

នីសនិយម ដែលជាសង្គមគ្មានមនុស្សជិះជាន់មនុស្សទៀត"]។ ឯកសារ D347/2.1.19 ប្រតិចារឹក អេលីហ្សាបេត ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.35.33-13.38.05 ["ខ្ញុំមិនបានឃើញ <គ្រួសាររស់នៅរួមគ្នា> ទេ លើកលែងតែសហការណ៍គំរូ <។> ហើយក៏មិនមានការ <ណាក់ចាំងពីការបាក់ទឹកចិត្តនោះទេ ដូច្នេះហើយ> គេ < >បន្តធ្វើការជានិច្ចកាលគឺគ្មានការឈប់សម្រាកនោះឡើយ <ហើយគេនិយាយថា ការងារគឺជាធនធានសំខាន់របស់ពួកគេ> ។ "]។ ឯកសារ D219/370.1.5 សៀវភៅ ហង់រី ណេកា មានចំណងជើងថា កូនសៀវភៅក្រហមរបស់ ប៉ុល ពត KH 00810755 ["អង្គការចង់ឲ្យចំណងគ្រួសារទាំងអស់ ត្រូវគិតពីផលប្រយោជន៍រួមឲ្យបានច្រើនជាងមុន"]។ ឯកសារ D117/36.1.23 សៀវភៅ Philip Short មានចំណងជើងថា ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ EN 00396533 ["ការរៀបអាពាហ៍ពិពាហ៍ មិនមែនត្រឹមតែរវាងសមាជិកបក្សប៉ុណ្ណោះទេ [...] គឺរវាងមនុស្សពីរនាក់ មិនមែនជារឿងបុគ្គលទេ ប៉ុន្តែជារឿងរបស់បក្ស។"]។

[2782] ឯកសារ D347/2.1.19 ប្រតិចារឹក អេលីហ្សាបេត បេកឃ័រ ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 13.35.33-13.38.05 ["កុមារទាំងអស់ គេបានបំបែកពីឪពុកម្តាយ ពីគ្រួសាររបស់គេ [...]។ ហើយនៅទីកន្លែងមួយ ខ្ញុំបានឃើញ< > កុមារជាច្រើន < >ប្រមូលឧស < ហើយគេហៅកុមារទាំងនោះថា កងកកុមារ។> < នៅពេលមួយទៀត> ខ្ញុំបានឃើញ < >ឡាន < ដឹកក្មេងជំទង់ៗ បើនិយាយពីភេទវិញ គឺមានក្មេងស្រី ឬក្មេងប្រុស ហើយពួកគេអានៅក្នុងកងកុមារ។"]។ ឯកសារ D315.1.4 ប្រតិចារឹក រី ពៅ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.28.25-11.30.25 [នៅស្រុកត្រាំកក់ ខេត្តតាកែវ ភូមិភាគនិរតី៖"ពេលសម័យនោះ ប្រុសនៅដោយប្រុស ស្រីនៅដោយស្រី ហ្នឹងការរស់នៅតាមវ័យ។ អ៊ីចឹង វ័យយុវជននៅកន្លែងយុវជន វ័យកុមារនៅតាមកងកុមារ វ័យចាស់នៅតាមចាស់ វ័យកសិករនៅតាមកសិករអ៊ីចឹងបាទ។ នៅរៀងៗគ្នា"]។ ឯកសារ D347/2.1.38 ប្រតិចារឹក មុំ រ៉ុន ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.24.37-14.29.12 [នៅខេត្តសៀមរាប ភូមិភាគឧត្តរ៖ "នៅរបបខ្មែរក្រហមគេបំបែកតើ ប្តីផ្សេង ប្រពន្ធទៅផ្សេង កូនទៅផ្សេង អត់មាននៅជុំគ្នាទេ។ កូនៅកងចល័តផ្សេងទៅ ម៉ែនៅខាងចល័តផ្សេង ឪពុកខាងចល័តផ្សេង។ អាតូចៗនៅជាមួយយាយៗ [...] បំបែកនោះ មិនមែន កូនៗក៏បំបែក អត់បានវិលមកផ្ទះវិញទេ ទៅសម្រាកនៅការដ្ឋាន"]។ ឯកសារ D310/1.1.6 សៀវភៅ កាស៊ូមិ ណាហ្គាវ៉ា មានចំណងជើងថា ការរំលោភផ្លូវភេទជាអំពើហិង្សាលើយ៉ូនដ៏ក្នុងអំឡុងរបបខ្មែរក្រហម KH 00738344 ["សមាជិកគ្រួសារនីមួយៗ ត្រូវបានបំបែកចេញពីគ្នា ដើម្បីជាការជួយដល់មូលហេតុបដិវត្តន៍។ ក្មេងៗត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ពួកគេ ដើម្បីធ្វើការនៅក្នុងក្រុមចល័ត ឬ ក្នុងនាមជាទាហានកុមារ។"]។ ឯកសារ D219/882.1.21 សៀវភៅ កាស៊ូមិ ណាហ្គាវ៉ា មានចំណងជើងថា ភាពជាអ្នកម្តាយនៅក្នុងសង្គ្រាម KH 01506057 ["បន្ទាប់ពីពិធីមង្គលការ គូស្វាមីភរិយាភាគច្រើនត្រូវបែកគ្នាដោយសារត្រូវធ្វើការងារដោយបង្ខំ នៅតំបន់ខុសៗគ្នា ហើយពួកគេមិនត្រូវបានអនុញ្ញាតិឲ្យរស់នៅជាមួយគ្នានោះទេ។ [...] ក្នុងករណីភាគច្រើន ប្រពន្ធត្រូវគេអនុញ្ញាតិឲ្យនៅក្នុងភូមិរបស់ខ្លួន រីឯប្តីត្រូវគេបញ្ជូនឲ្យទៅឆ្ងាយពីប្រពន្ធ និងកូន។ [...] ហេតុនេះ ពួកគេមិនអាចមានជីវិតអាពាហ៍ពិពាហ៍ដោយខ្លួនឯងបានឡើយ។"]។ ឯកសារ D310/1.1.5 សៀវភៅ Katrina Natale មានចំណងជើងថា ខ្ញុំមានអារម្មណ៍ថាព្រលឹងខ្ញុំហោះចេញពីខ្លួន EN 00992134។

នោះត្រូវបានលើកទឹកឲ្យទៅជួបអង្គការ មិនមែនឪពុកម្តាយរបស់គេទេ ដោយចាត់ទុកអង្គការថាជាបុគ្គលមានសិទ្ធិអំណាចជាពិសេសរបស់ពួកគេ[2783]។

764. ទំនាក់ទំនងជាមួយមនុស្ស ដែលមានភេទផ្ទុយគ្នាក៏ត្រូវបានចាត់ទុកជាឧបសគ្គដល់គោលដៅដ៏ចាំបាច់នៃការកសាងជាតិឡើងវិញដែរ[2784]។ ការរកផលប្រយោជន៍ ឬភាពរីករាយសម្រាប់តែប្រពន្ធ

[2783] ឯកសារ D219/888.1.3 ប្រតិចារឹក កាស៊ូមិ ណាហ្ការ៉ា ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 09.42.07-09.46.54 ["នៅពេលម្តាយឈប់បំបៅដោះកូនហើយ គេមិនឲ្យជួបកូនទេ ទោះបីជួបនៅពេលបាយថ្ងៃត្រង់ក៏ដោយ។"]។ ឯកសារ D347/2.1.20 ប្រតិចារឹក អេលីហ្សាបេត បេកយ៉ែ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 10.43.55-10.46.21 ["កូន <តូចៗ> ត្រូវបំបែកចេញពីឪពុកម្តាយ ហើយ <ចំពោះ> កូន <ទាំងនោះ> គេមិនឲ្យនិយាយថា ឪពុកម្តាយជាឪពុកម្តាយបង្កើតនោះទេ ឲ្យនិយាយថា ខ្មែរក្រហម ឬក៏ <កម្មាភិបាល> ជាឪពុកម្តាយរបស់ពួកគេ។"]។ ឯកសារ D347/2.1.38 ប្រតិចារឹក ម៉ុំ រ៉ុន ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង14.08.33-14.09.58 [នៅខេត្តសៀមរាប ភូមិភាគឧត្តរ៖ "ក្រោយពីពេលសម្រាលកូនហើយ នាងខ្ញុំបាននៅជិតកូនតែក្នុងមួយខែកន្លះទេ តែមួយខែកន្លះនោះ ក៏អត់មែននៅថែទាំកូននឹងផ្ទះទេ ទៅនៅសហការណ៍កិនស្រូវ។"]។ ម៉ោង 15.10.14-15.14.44 ["កូនៗរបស់ខ្ញុំទាំងអស់នោះក៏អត់មែនកូនខ្ញុំដែរ ព្រោះវាបែកចេញទៅអស់ហើយ មានតែអង្គការអ្នកកាន់កាប់។ ម្ល៉ោះហើយ ដែលកូនតូចៗនៅពីរ បីឆ្នាំ អានោះវានៅជុំនឹងយាយៗ ហើយខ្ញុំក៏អត់មានកូនទៀតដែរ"]។ ឯកសារ D310/1.1.6 សៀវភៅ កាស៊ូមិ ណាហ្ការ៉ា មានចំណងជើងថា ការរំលោភផ្លូវភេទជាអំពើហិង្សាលើយ៉ោនឌ័រក្នុងអំឡុងរបបខ្មែរក្រហម KH 00738344 ["ក្មេងៗត្រូវបានបំបែកចេញពីឪពុកម្តាយរបស់ពួកគេ ដើម្បីធ្វើការនៅក្នុងក្រុមចល័ត ឬ ក្នុងនាមជាទាហានកុមារ។ អង្គការ បានអប់រំទាហានកុមារ ដើម្បីស៊ើបការណ៍ពីអ្វីដែលឪពុកម្តាយរបស់ពួកគេបាននិយាយប្រឆាំងនឹងអង្គការ ដើម្បីរំលាយចំនងរវាងកូននិងឪពុកម្តាយ។"]។ ឯកសារ D219/882.1.21 សៀវភៅ កាស៊ូមិ ណាហ្ការ៉ា មានចំណងជើងថា ភាពជាអ្នកម្តាយនៅក្នុងសង្គ្រាម KH 01506078 EN 01322878។ ឯកសារ D310/1.1.5 សៀវភៅ Katrina Natale មានចំណងជើងថា ខ្ញុំមានអារម្មណ៍ថាព្រលឹងខ្ញុំហោះចេញពីខ្លួន EN 00992134។ *សូមមើលផងដែរ* ឯកសារ D1.3.31.1 សៀវភៅ David Chandler និងអ្នកផ្សេងទៀត ប៉ុល ពត រៀបចំអនាគត EN 00104076 [ប៉ុល ពត បានចេញនៅចំពោះមុខមជ្ឈិមបក្ស នូវការពន្យល់អំពីផែនការរបស់បក្សសម្រាប់ឆ្នាំ១៩៧៧-១៩៨០ ដែលបញ្ជាក់ ក្នុងចំណោមនោះ ថា៖ "ម្តាយមិនត្រូវទាក់ទងជាមួយកូនរបស់ខ្លួនច្រើនពេកទេ គួរតែមានពេលវេលា (សម្រាប់ម្តាយ) ទៅធ្វើការ"]។

[2784] ឯកសារ D1.3.17.1 សៀវភៅ អេលីហ្សាបេត បេកយ៉ែ មានចំណងជើងថា នៅពេលដែលសង្គ្រាមរលត់ទៅ KH 00232298 ["គេត្រូវតែរឹតត្បិតការទាក់ទងគ្នាខាងផ្លូវភេទនេះ ពីព្រោះវាធ្វើឲ្យខាតពេលវេលាច្រើនណាស់ នាំឲ្យមនុស្សបោះបង់ពីភារកិច្ចការងារដែលត្រូវបំពេញទៀតផង-ការធ្វើឲ្យប្រទេសមានលក្ខណៈឧស្សាហកម្មឆាប់រហ័ស ការលើកតម្លើសជាតិមាតុភូមិ។ [...] ពួកយុវជនត្រូវរស់នៅដោយឡែកពីពួកយុវនារី។ គេសង្ឃឹមលើពួកនេះថា នឹងខិតខំធ្វើការ រៀនហាត់ពត់លត់ដំ ដើម្បីបញ្ជេញឲ្យឃើញការធ្វើពលកម្មទាំងស្រុងមួយចំពោះ អង្គការ និងបំភ្លេចចោលភេទមួយទៀត។"]។ ឯកសារ D310/1.1.4 Bridgette Toy-Cronin "ខ្ញុំចង់និយាយប្រាប់អ្នក" KH 00721382 ["ការស្រឡាញ់គ្នា និងទំនាក់ទំនងក្នុងគ្រួសារ [...] ត្រូវបានចាត់ទុកថាជាការរំខានដល់គោលដៅបដិវត្តន៍"]។

ឬប្តី ត្រូវបានចាត់ទុកថា "ជាកម្មសិទ្ធិឯកជន" ដែលផ្ទុយនឹងផលប្រយោជន៍រួមរបស់ប្រទេស[2785] ហើយអ្នកដែលផ្តល់តម្លៃដល់ផលប្រយោជន៍រួម ត្រូវបានសន្មតថាជាអ្នកលះបង់ដល់បដិវត្តន៍[2786]។ អ្នកសារព័ត៌មាន Elizabeth Becker បានពន្យល់ថា "ពួកខ្មែរក្រហមបានទទួលការគម្រាមកំហែង មិនឲ្យបង្ហាញពីអារម្មណ៍គ្រប់ប្រភេទនៃក្តីស្រឡាញ់រវាងប្តី និងប្រពន្ធ ឪពុកម្តាយ និងកូន សហការី និងសហការី។ មនុស្សគ្រប់រូបត្រូវតែលះបង់ភាពស្និទ្ធស្នាលជាលក្ខណៈបុគ្គល[2787]។

[2785] ឯកសារ D6.1.753 ទង់បដិវត្ត ខែកញ្ញា-តុលា ឆ្នាំ១៩៧៦ KH 00063104 ["បាតុភាព [នៃកម្មសិទ្ធិឯកជន]៖ [...] ចាត់តាំងតាមមនោសញ្ចេតនារបស់ខ្លួន គ្រួសាររបស់ខ្លួន បក្សពួករបស់ខ្លួន មិនឈរលើមាគ៌ានយោបាយ សតិអារម្មណ៍ចាត់តាំងរបស់បក្ស។ ដូច្នេះ ខុសហើយ។"]។ ឯកសារ D310/1.1.1 ឯកសារនយោបាយកសាងគ្រួសារ KH 00407098-00407099 ["យុវជន យុវនារី យើងជាច្រើន ដែលជ្រួតជ្រាបនូវលោកទស្សនៈ វណ្ណៈជិះជាន់នេះ គេរើសរកគ្រួសារ ឬកសាងគ្រួសារ សុទ្ធតែដើម្បីបានលាភសក្តារៈផ្ទាល់ខ្លួន។ ពោលគឺ គេស្វែងរកផលប្រយោជន៍ ឬសុភមង្គលគ្រួសារ ដោយផ្តាច់ចេញស្រឡះពីផលប្រយោជន៍ពីជោគវាសនានៃប្រទេសជាតិ និង ប្រជាជនទាំងមូល"]។ ឯកសារ D322/8.1.14 ការបោះពុម្ពផ្សាយរបស់មជ្ឈិមបក្សកុម្មុយនីសកម្ពុជាការមានចំណងជើងថា សតិអារម្មណ៍នៃវណ្ណៈអធនឲ្យមុតស្រួច KH 00442457 ["តាំងពីដំណើរការតស៊ូរបស់យើង ជាបន្តបន្ទាប់មក ពេលតស៊ូនយោបាយក៏ដោយ ពេលសង្គ្រាមក៏ដោយ កម្មសិទ្ធិឯកជនវាប៉ះពាល់ដល់ផលប្រយោជន៍បដិវត្តន៍។ ឧទាហរណ៍ អ្នកណាគិតគូផលប្រយោជន៍គ្រួសារច្រើន តែងតែប្រាសចាកបដិវត្តន៍។ លះបង់បដិវត្តន៍រស់នៅដោយឡែក រកសុភមង្គលក្នុងគ្រួសារវិញ មិនរកសុភមង្គលក្នុងបក្សទេ។ មួយរយៈណាមួយ វាប្រែប្រួលជាគុណភាពទំនាស់ជាមួយបក្ស។ ឯកសារ D1.3.22.1 យុវជន និងយុវនារី បដិវត្ត ខែតុលា ឆ្នាំ១៩៧៥ KH 00063410 ["នៅមានសតិអារម្មណ៍ កម្មសិទ្ធិបុគ្គលសួនតួ មើលឃើញ នឹងគិតគូតែជុំវិញអាត្មាខ្លួន ជុំវិញក្រុមគ្រួសារខ្លួន និងបក្សពួកខ្លួនប៉ុណ្ណោះ មិនទាន់សម្លឹងមើលឆ្ងាយ ធំទូលាយទូទាំងប្រទេស [...] ហើយមិនសូវគិតគូដល់ផលប្រយោជន៍រួមរបស់ប្រទេសជាតិទាំងមូល។"]។ ឯកសារ D117/36.1.23 សៀវភៅ Philip Short មានចំណងជើងថា ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ EN 00396533 ["ស្រមៀងគ្នានេះដែរ ប្រសិនបើបុរសម្នាក់ មានអារម្មណ៍ស្និតស្នាលជាមួយនារីម្នាក់ បុរសនោះគួរតែ 'យកគោលជំហរសម្ងួហភាព និងដោះស្រាយវា...។ បើត្រូវផ្សេងពីនេះ ត្រូវមានគោលជំហរឯកជនរឹងមាំ"]។ ឯកសារ D219/370.1.5 សៀវភៅ ហង់រី លោកា មានចំណងជើងថា កូនសៀវភៅក្រហមរបស់ ប៉ុល ពត KH 00810755 ["'រស់នៅក្នុងមហាគ្រួសារថ្មីតែមួយ ហើយគិតតែប្រយោជន៍សម្ងួហភាព។ លះបង់កម្មសិទ្ធិស្ងួនតួ ឪពុកម្តាយញាតិសន្តាន"។ នេះគឺជាបទបញ្ញាមួយក្នុងចំណោមបទបញ្ញា ជាមូលដ្ឋាននៃសង្គមដែលបានបង្កើតដោយខ្មែរក្រហម ទោះបីវាផ្ទុយទៅនឹងប្រពៃណីរបស់ប្រទេសក៏ដោយ"]។

[2786] ឯកសារ D6.1.753 ទង់បដិវត្ត ខែកញ្ញា-តុលា ឆ្នាំ១៩៧៦ KH 00063104 ["កម្មសិទ្ធិឯកជន មិនដែលឲ្យបច្ច័យល្អទេ។ [...] កម្មសិទ្ធិឯកជនវាប៉ះពាល់ដល់ផលប្រយោជន៍បដិវត្តន៍។ ឧទាហរណ៍: អ្នកណាគិតគូផលប្រយោជន៍គ្រួសារច្រើន តែងតែប្រាសចាកបដិវត្តន៍។ លះបង់បដិវត្តន៍ រស់នៅដោយឡែក រកសុភមង្គលក្នុងគ្រួសារវិញ មិនរកសុភមង្គលក្នុងបក្សទេ។"]។

[2787] ឯកសារ D1.3.17.1 សៀវភៅ អេលីហ្សាបេត បេកយ៉ែ មានចំណងជើងថា នៅពេលដែលសង្គ្រាមរលត់ទៅ KH 00232298 ។ *សូមមើលផងដែរ* ឯកសារ D310/1.1.6 សៀវភៅ កាស៊ូមិ ណាហ្ការ៉ា មានចំណងជើងថា អំពើហិង្សាលើយ៉ោនឌ័រក្នុងអំឡុងរបបខ្មែរក្រហម EN 00421891 ។

765. ដូច្នេះ ប.ក.ក បានគ្រប់គ្រងយ៉ាងតឹងរ៉ឹងលើ "ការកសាងគ្រួសារ"។ ប.ក.ក បានអនុវត្តគោលនយោបាយ ដើម្បីគ្រប់គ្រងអាពាហ៍យ៉ាងតឹងរ៉ឹង និងបានហាមឃាត់គ្រប់ទំនាក់ទំនងទាំងអស់ដែលគ្មានការអនុញ្ញាតច្បាស់លាស់ពីអង្គការ[2788]។ ឯកសារគោលនយោបាយសំខាន់នេះបានប្រកាសថា៖

[2788] *សូមមើលឧទាហរណ៍* ឯកសារ D5/1704/3 ប្រតិចារឹក យស ផល ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 15.33.47-15.40.23 [នៅខេត្តតាកែវ ភូមិភាគនិរតី៖ "គូដណ្តឹងរបស់ខ្ញុំហ្នឹង ជាគីដណ្តឹងដែលខ្ញុំយលើចិត្តគ្នាហើយ និងសម្រេចថា នៅតែពេលរៀបការទេ។ [...]ដូច្នេះ ប្រធានកងគេប្រាប់ថា បើមានបងប្រុសរបស់ខាងស្រីហ្នឹងត្រូវអង្គការកម្ទេច គេមិនឲ្យរៀបការទេ"]។ ឯកសារ D219/888.1.8 ប្រតិចារឹក កុល ណែម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.20.50-14.27.45 [នៅខេត្តមណ្ឌលគិរី ភូមិភាគឥសាន ឆ្នាំ១៩៧៧៖ "ខ្ញុំ មានគូដណ្តឹង[រួចហើយ]នៅស្រុកខ្ញុំ។ [...] ខ្ញុំក៏ឯកភាព[ទាំងខុសប្លែក] ការក៏ការទៅម៉េចទេ។"]។ ឯកសារ D347/2.1.37 ប្រតិចារឹក សេង សឿន ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.06.43-15.08.30 [ដើមបណ្តឹងរដ្ឋប្បវេណីជាអ្នកទទួលបន្ទុកក្នុងការរៀបចំពិធីរៀបការនៅស្រុកស្អាង ខេត្តកណ្តាល ភូមិភាគនិរតី៖ "ខ្ញុំជួបផ្ទាល់អារឿងយុវនារី នៅទ័ពជាមួយខ្ញុំ ហើយវាស្រឡាញ់គ្នា [...] ហើយវាសម្លាប់វាដែរហ្នឹង។"]។ ឯកសារ D6.1.688 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ផៀន KH 00368612 [នៅក្នុងកិច្ចប្រជុំថ្នាក់តំបន់នៅភ្នំពេញ ឆ្នាំ១៩៧៧៖ "គេនិយាយពីប្តីមួយប្រពន្ធមួយ បើអ្នកណាប្រព្រឹត្តិខុស ត្រូវតែកម្ទេច។"]។ ឯកសារ D6.1.591 កំណត់ហេតុស្តាប់ចម្លើយ មួរ សេដ្ឋា KH 00365596-00365597។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.២២២-២២៤ KH 01095268។ ឯកសារ D219/36 កំណត់ហេតុស្តាប់ចម្លើយ ឈួម សាវ៉ឺន ឆ.១៨-១៩ KH 01032093។ ឯកសារ D119/131 កំណត់ហេតុស្តាប់ចម្លើយ ថង ធឿយ ឆ.៥៤-៥៧ KH 00996499។ ឯកសារ D5/1050/3 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.១៥៩-១៦១ KH 01058286។ ឯកសារ D1.3.17.1 សៀវភៅ អេលីហ្សាបេត បេកយ៉ា មានចំណងជើងថា នៅពេលដែលសង្គ្រាមរលត់ទៅ KH 00232202 ["ការសប្បាយរីករាយបានក្លាយទៅជារឿងដែលត្រូវគេសង្ស័យ ការទាក់ទងគ្នាខាងផ្លូវស្នេហា ត្រូវគេផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរបំផុត ដូចជាការលេងល្បែងស៊ីសងដែរ។"]។ KH 00232298 ["ក្នុងសហករណ៍ និងភូមិភាគជាច្រើន ទំនាក់ទំនងខាងផ្លូវស្នេហា មុនពេលរៀបអាពាហ៍ពិពាហ៍ អាចទទួលរងនូវការផ្តន្ទាទោសដល់ប្រហារជីវិត"]។ KH 00232339 ["ក្នុងកម្ពុជាប្រជាធិបតេយ្យ គេអាចរៀបអាពាហ៍ពិពាហ៍បាន លុះណាតែមានការយល់ព្រមពី ពួកអ្នកចាស់ នៅក្នុងសហករណ៍ប៉ុណ្ណោះ បានន័យថា គ្រប់អាពាហ៍ពិពាហ៍គឺបក្សជាអ្នករៀបចំទុកដាក់ឲ្យ។"]។ ឯកសារ D6.1.595 សៀវភៅ ម៉ៃខិល វិកខឺរី មានចំណងជើងថា កម្ពុជាឆ្នាំ១៩៧៥-១៩៨២ EN 00397102 ["អាពាហ៍ពិពាហ៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាចជាកិច្ចសន្យាតែមួយគត់ ក្រោយពីមានការអះអាងយល់ព្រមពីអាជ្ញាធរ"]។ EN 00397104 ["ទំនាក់ទំនងគ្រួសារ គឺជាកម្មវត្ថុនៃការគាបសង្កត់ពីអាជ្ញាធរដូចគ្នាទៅនឹងទិដ្ឋភាពផ្សេងទៀតនៃជីវិត។"]។ ឯកសារ D219/370.1.7 សៀវភៅ Gina Chon និង ថេត សម្បត្តិ មានចំណងជើងថា នៅខាងក្រោយវាលពិឃាត EN 00757496។ ឯកសារ D310/1.1.6 សៀវភៅ កាស៊ូមិ ណាកាវ៉ា មានចំណងជើងថា អំពើហិង្សាលើយ៉េនឌ័រក្នុងអំឡុងរបបខ្មែរក្រហម EN 00421891-00421893។ ឯកសារ D310/1.1.4 Bridgette Toy-Cronin "ខ្ញុំចង់និយាយប្រាប់អ្នក" KH 00721359-00721360។ ឯកសារ D117/36.1.23 សៀវភៅ Philip Short មានចំណងជើងថា ប៉ុល ពត ប្រវត្តិនៃសុបិន្តអាក្រក់មួយ EN 00396533 ["'ការជ្រើសរើសគូស្រករដោយសេរី' ត្រូវបានផ្តន្ទាទោសយ៉ាងច្បាស់ក្រឡែត។"]។

ក្នុងបញ្ហាកសាងគ្រួសារនេះ បើអង្គការ សម្ងាត់ភាពពិនិត្យឃើញយ៉ាងណា សម្រេចយ៉ាងណា ត្រូវគោរពតាមដាច់ខាត កុំទោមនស្ស កុំផ្ទាំងផ្ទាក់ ព្រោះមានតែអង្គការ មានតែសម្ងាត់ភាពទេ ដែលអាចពិនិត្យមើលបានហ្មត់ចត់ និងគ្រប់ជ្រុងជ្រោយបាន[2789]។

ii. តម្រូវការឲ្យមានកំណើនចំនួនប្រជាជន

766. ដោយចំនួនប្រជាជនដែលបានធ្លាក់ចុះយ៉ាងលឿន ដោយសារការសម្លាប់ និងការស្លាប់ និងដោយទំនាក់ទំនាក់ទំនងជាមួយវៀតណាមកាន់តែមានសភាពអាក្រក់ទៅ១ ថ្នាក់ដឹកនាំកំពូល ប.ក.ក បានសម្រេចអនុវត្តគោលនយោបាយដើម្បីបង្កើនចំនួនប្រជាជនឲ្យបានលឿន ពីព្រោះពួកគេគិតថា ប្រទេសចាំបាច់ត្រូវការកងទ័ពបន្ថែមដើម្បីការពារទឹកដី និងពលករច្រើនទៀតដើម្បីកសាងប្រទេសឡើងវិញ[2790]។

[2789] ឯកសារ D310/1.1.1 ឯកសារនយោបាយកសាងគ្រួសារ KH 00407100-00407101។ *សូមមើលផងដែរ* ឯកសារ D5/1334/3 ប្រតិចារឹក ជា ឌៀប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.18.25-15.24.04 [យោងទៅលើការអនុម័ត ឯកសារនយោបាយកសាងគ្រួសារ ខាងលើ៖ "ចំណុចនេះ អង្គការដូចដែលថាក្នុងឯកសារហ្នឹងក៏ដូចគ្នានឹងការពិតដែរ។ ចំពោះខ្ញុំផ្ទាល់ក៏ឮដែរ។ ឮមានតែគោរពអង្គការវិន័យ និងសម្ងាត់ភាពហ្នឹង។ តែសម្ងាត់ភាពថាម៉េចទៅអីចឹងហើយ អត់មានកែប្រែបានទេ តែប៉ុណ្ណឹង។"]។ ឯកសារ D310/1.1.1 ឯកសារនយោបាយកសាងគ្រួសារ KH 00407104 ["មានតែការប្រគល់គ្រួសារជូនអង្គការ ជូនសម្ងាត់ភាពជួយអប់រំកសាង និងឲ្យចុះប្រឡូកក្នុងចលនាមហាជនទេ ទើបអាចកសាងគ្រួសារយើងបានល្អ បានចម្រើនទៅតាមទិសរបស់បក្ស។"]។

[2790] ឯកសារ D6.1.739 ទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៧ KH 00063184 ["យើងខំពុះពារថែបំប៉ន លើកស្ទួយជីវភាពប្រជាជន [...] ហើយប្រជាជនកម្ពុជាជារួម បានលើកឡើងជាលំដាប់យ៉ាងឆាប់រហ័ស ដើម្បីការពារ និងកសាងកម្ពុជាឲ្យយើងឲ្យរីកលូតលាស់ ចំរុងចំរើន លោតផ្លោះ"]។ ឯកសារ D5/1334/3 ប្រតិចារឹក ជា ឌៀប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.48.32-13.51.50 [ឆ្នាំ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី បានចូលរួមប្រជុំមួយនៅទីក្រុងភ្នំពេញ ដែលពេលនោះ ខៀវ សំផន ជាអ្នកបង្រៀន បាននិយាយថា "ស៖ ដែលគាត់ [ខៀវ សំផន] និយាយអំពីពាក្យថា យុវជន យុវនារី ដែលចាស់ៗ ហើយរៀបការ។ អីចឹង គាត់មានដែល មានពន្យល់ប្រាប់ នៅពេលដែលកំពុងតែនិយាយថា យុវជន យុវនារី រៀបការ១ក្នុងគោលបំណងអ្វី ដែរអ្នកស្រី? ឆ៖ គាត់ថា រៀបការទៅ ដើម្បីបង្កើតកូន កើតចៅឲ្យបានគ្នា បានកូនចៅច្រើនទៅ ដើម្បីជាកម្លាំងការពារប្រទេសជាតិ។"]។ ឯកសារ D347/2.1.42 ប្រតិចារឹក សយ ណារ៉ៃ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 11.04.44-11.09.48 [នៅពេលដើមបណ្តឹងរដ្ឋប្បវេណីរៀបការ នៅស្រុកចំការលើ តំបន់ ៤២ ភូមិភាគឧត្តរ ឆ្នាំ១៩៧៥៖ "ប្រកាសឲ្យថា ឲ្យខ្ញុំប្តេជ្ញាចិត្តថា តាមគាត់ គឺបង្ក បង្កើតមនុស្សឲ្យបានច្រើន បង្ករ បង្កើតកូនឲ្យបានច្រើន ដើម្បីអង្គការត្រូវការមនុស្ស ដើម្បីការពារទឹកដី។"]។ ឯកសារ D117/36.1.3 កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.៤ KH 00485622-00485623។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ម ភ្ន ឆ.១៨៨ KH 01117240។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ជោចប្តូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037041 ["គោលបំណងសំខាន់នៃការ

767. មេដឹកនាំ ប.ក.ក បានប្រកាសថា កម្ពុជាប្រជាធិបតេយ្យត្រូវការចំនួនប្រជាជនពី ១៥ ទៅ ២០ លាននាក់ក្នុងរយៈពេល ៥ ទៅ ១០ ឆ្នាំទៀតដើម្បី "បំពេញតម្រូវការរបស់ប្រទេស"[2791]។ ប៉ុល ពត ផ្ទាល់បានពន្យល់ថា គោលដៅនេះគឺត្រូវតែសម្រេចឲ្យបាន តាមរយៈការរៀបចំអាពាហ៍ពិពាហ៍ ហើយសេចក្តីណែនាំពាក់ព័ន្ធត្រូវបានចេញទៅឲ្យកម្មាភិបាលដើម្បីអនុវត្ត[2792]។ ដោយសារតែអវិភាពជាមួយ

រៀបការ គឺមិនមែនដើម្បីបង្កើតក្រុមគ្រួសារឯកជន ដូចនៅក្នុងបរិបទប្រពៃណីទេ ប៉ុន្តែទៅ "ជាការបង្កើតកុមារ ដើម្បីបម្រើបដិវត្តន៍"']។

[2791] ឯកសារ D6.1.755 ទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧ KH 00063054 ["ដូច្នោះ សារៈសំខាន់នៃបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយម មានទិសដៅកសាងប្រទេសបានល្អ ការពារប្រទេសបានល្អ និងដោះស្រាយជីវភាពប្រជាជនបានឆាប់រហ័ស។ យើងត្រូវការប្រជាជនពី ១៥ ទៅ ២០ លាន់នាក់ ទើបគ្រប់គ្រាន់និងដីយើង។"]។ *សូមមើលផងដែរ* ឯកសារ D6.1.739 ទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៧ KH 00063183-00063184 ["យើងត្រូវការឲ្យមានប្រជាជនកម្ពុជាចំនួនពី ១៥ លាន ទៅ ២០ លាននាក់ ក្នុងអំឡុងជាង ១០ ឆ្នាំខាងមុខនេះ។ [...] សព្វថ្ងៃចំនួនប្រជាជនយើងជិត ៨ លាននាក់ នៅឆ្ងាយណាស់ពីលទ្ធភាពរបស់ប្រទេសយើង ដែលត្រូវមានជនកម្ពុជាជាង ២០ លាននាក់។ ដូចនេះ ទិសដៅរបស់យើង គឺបង្កើនចំនួនប្រជាជនឲ្យបានឆាប់រហ័សបំផុត"]។ ឯកសារ D6.1.1257 សេចក្តីថ្លែងការណ៍របស់ អៀង សារី នៅក្នុង សម័យប្រជុំពេញអង្គរបស់អង្គការសហប្រជាជាតិ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ KH 00291028 កថាខណ្ឌលេខ ៦០ កថាខណ្ឌលេខ ៦៣ ["យើងកំពុងខិតខំព្យាយាមធ្វើឲ្យប្រសើរឡើងយ៉ាងឆាប់រហ័សនូវស្ថានភាពរស់នៅ និងសុខភាពរបស់ប្រជាជនយើង ពីព្រោះយើងត្រូវការប្រជាជនចំនួន ១៥ ទៅ ២០ លាននាក់ ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ។"]។ ឯកសារ D257/1/3.11 សេចក្តីថ្លែងការណ៍របស់ ប៉ុល ពត នៅក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីសកម្ពុជា ក្នុងជំនួបពិភាក្សាជាមួយគណៈប្រតិភូមកពីសមាគមប៉ែលហ្ស៊ីក-កម្ពុជាចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៧៨ EN 00574566 ["បក្សកុម្មុយនីស្តកម្ពុជា និង រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ គ្រោងបង្កើនចំនួនប្រជាពលជនពី ១៥ ទៅ ២០ [លាននាក់] ក្នុងរយៈពេលពី ១០ ទៅ ១៥ឆ្នាំ"]។ ឯកសារ D310/1.1.11R វីដេអូអាពាហ៍ពិពាហ៍ក្រហម ឆ្នាំ២០១១ ម៉ោង 51:24-52:28 [សម្លេងវីដេអូរបស់ ប៉ុល ពត]។ ឯកសារ D6.1.745 ទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៨ KH 00064617-00064618។ ឯកសារ D219/370.1.10 កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ន្ជួន ជាចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ KH 00148677។ ឯកសារ D219/370.1.11 សេចក្តីសង្ខេបនៃ World Broadcasts បទសម្ភាសន៍ជាមួយមេដឹកនាំកម្ពុជាប្រជាធិបតេយ្យ (ន្ជួន ជា) ស្តីពីគោលនយោបាយប្រជាជន និងការតស៊ូប្រឆាំងនឹងវៀតណាម ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៨១ EN S00030349។ ឯកសារ D6.1.532 សៀវភៅ ខៀវ សំផន មានចំណងជើងថា ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា KH 00380466។

[2792] ឯកសារ D117/36.1.3 កំណត់ហេតុស្តាប់ចម្លើយ ជួន ធី ឆ.៤ EN 00513314 [សាក្សីបានចូលរួមការប្រជុំមួយរបស់មេដឹកនាំ និង កម្មាភិបាល នៅខេត្តកំពង់ឆ្នាំង ភូមិភាគបស្ចិម ខែមិថុនា ឆ្នាំ១៩៧៨៖ "ប៉ុល ពត ក៏បានបន្ថែមថា "យើងត្រូវបង្កើនចំនួនប្រជាជនក្នុងរយៈពេល ១០ ទៅ ២០ ឆ្នាំឲ្យបានពី ២០ ទៅ ៣០ លាននាក់ ដើម្បីការពារប្រទេស"។ ក្នុងន័យនេះ ប៉ុល ពត បានបញ្ជាក់ថា "គាត់តម្រូវឲ្យមានការរៀបចំឲ្យមានអាពាហ៍ពិពាហ៍ ដើម្បីបង្កើនចំនួនប្រជាជន ដោយឲ្យថ្នាក់ក្រោមបង្គាប់ជាអ្នករៀបចំអាពាហ៍ពិពាហ៍របស់ប្រជាជន"]។ *សូមមើលផងដែរ* ឯកសារ D5/1334/3 ប្រតិចារឹក ជា ខៀប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.47.02-13.51.50 [នៅឆ្នាំ១៩៧៥ ក្នុងទីក្រុងភ្នំពេញ៖ "[អំឡុងពេលប្រជុំនៅវត្ត ឧណ្ណាលោម ខៀវ សំផន] សូមស្នើសមមិត្តនារី យុទ្ធជន ទាំងអស់ ប្រឹងធ្វើការជូនរដ្ឋ ហើយយុទ្ធជនដែលយុទ្ធនារី ដែលមានអាយុពី ១៩ឆ្នាំឡើងទៅ ឲ្យតាមកម្ម

រៀតណាម មានសភាពតឹងតែង បញ្ហាបង្កើនចំនួនប្រជាជនបានក្លាយជាការងារបន្ទាន់ ហើយចំនួននៃពិធីរៀបអាពាហ៍ពិពាហ៍នៅទូទាំងប្រទេសក៏មានកំណើនទៅតាមនោះដែរ[2793]។ ដើម្បីឲ្យសម្រេចគោលដៅនៃការបង្កើនចំនួនប្រជាជននេះ គូស្វាមីភរិយាជាធម្មតាត្រូវបានតាមដានបន្ទាប់ពីរៀបការ រួចភ្លាមដើម្បីធានាថា ពួកគេបានរួមភេទ[2794]។

ភិបាល តាមមុខក្រសួងទាំងអស់ ឲ្យរៀបចំមានគ្រួសារទៅ [...] ស្នើតាមក្រសួងមន្ទីរទាំងអស់ឲ្យគិតគូរៀបការយុទ្ធជននារីឲ្យអស់ទៅ គាត់គ្រាន់--ទុកតែងក្មេងៗសិនទៅបានហើយ។ [...] [រៀប]ការពី -- ក្រោយពីគាត់និយាយរួច មិនទាន់បានប៉ុន្មានផង ពួកយើងខ្ញុំក៏ត្រូវរៀបការជំនាន់ខ្ទេរក្រហមនោះដែរ។"]។ ម៉ោង 15.02.15-15.08.00 ["ស៖ [...] បើតាមសម្តីរបស់លោកខៀវ សំផន ហ្នឹង ការដែលគេឲ្យរៀបការហ្នឹង គោលដៅសំខាន់ហ្នឹង គេចង់បង្កើតកូនមែនទេ? ឆ៖ ហើយក៏និយាយមិនថាត្រឹមតែគាត់មួយទេ ប្រជុំរៀនសូត្រកន្លែងណា ក៏លើកតែអ៊ីចឹងដែរ មិនថាតែគាត់មួយទេ គឺអ៊ីចឹងតែម្តង។ កម្មាភិបាលណាក៏លើតអ៊ីចឹង ឲ្យតែពេលប្រជុំ ពេលរៀនសូត្រ។"]។ ឯកសារ D219/398 កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ីយ ឆ.៨៧-៨៨ KH 01115764-01115765 [សាក្សីគឺជាកម្មាភិបាលម្នាក់នៃក្រសួងឃ្លាំងរដ្ឋ នៅភ្នំពេញ (*សូមមើល* ឆ.២៣-២៤, ៣០-៣១)៖ គាត់បានរំលឹកឡើងវិញថា ថ្នាក់ដឹកនាំ ២ រូបរបស់ក្រសួង បាននិយាយអំពីការបង្កើនចំនួនប្រជាជន តាមរយៈការរៀបចំអាពាហ៍ពិពាហ៍]។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ង ភ្ន ឆ.១៨៨, ១៩១-១៩២, ១៩៥ KH 01117240។ ឯកសារ D219/370.1.7 សៀវភៅ Gina Chon និង ថេត សម្បត្តិ មានចំណងជើងថា នៅខាងក្រោយវាលពិឃាត EN 00757496 ["ពីព្រោះពួកគេចង់បង្កើនចំនួនប្រជាជនទ្វេរដងខ្ទេរក្រហមបានបង្កើនចំនួននៃការរៀបការ។ [...] ការរៀបការក្លាយជានយោបាយរបស់រដ្ឋ"]។

[2793] ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ទោចប្ជូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្ទេរក្រហម EN 01037079 ["ករណីសិក្សាបានបង្ហាញពីការកើនឡើងនៃការរៀបការដោយបង្ខំនៅពាក់កណ្តាលឆ្នាំ១៩៧៨។"]។ *សូមមើលផងដែរ* ឯកសារ D219/243 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ សង ឆ.៦៤ KH 01080951 [នៅស្រុកបាកាន ខេត្តពោធិសាត់ ភូមិភាគពាយ័ព្យ (សូមមើល ឆ.៣-៤)៖ "ការរៀបការដោយបង្ខំនេះ កើតឡើងនៅចុងឆ្នាំ១៩៧៧ និងចុងឆ្នាំ១៩៧៨។ [...] ចុងឆ្នាំ១៩៧៨ គេចាប់រៀបការម្តងទៀត តែច្រើនជាងចុងឆ្នាំ១៩៧៧។"]។ ឯកសារ D118/212 កំណត់ហេតុស្តាប់ចម្លើយ មាស ណាគ្រី ឆ.១១៣ KH 00981618 [នៅតំបន់ ១ ភូមិភាគពាយ័ព្យ៖ "[ការបង្ខំឲ្យរៀបការ] កើតឡើងអំឡុងពីឆ្នាំ១៩៧៧ ដល់ ១៩៧៨ ដោយអង្គការប្រាប់ថា ត្រូវការបន្តពូជ"]។ ឯកសារ D219/398 កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ីយ ឆ.៧៧-៧៨, ៨៤, ៩០-៩១ KH 01115763-01115765។ ឯកសារ D219/882.1.24 សៀវភៅ Peggy Levine មានចំណងជើងថា បរិបទសិក្សាអំពីពិធីអាពាហ៍ពិពាហ៍ និងការចាប់កំណើតក្រោមរបបខ្ទេរក្រហម៖ *បដិវត្តន៍ទំនៀមទម្លាប់* EN 00482541 ["នៅក្នុងឆ្នាំ១៩៧៨ ការរក្សាទុកនូវអ្វីដែលកម្ពុជាប្រជាធិបតេយ្យផ្តាស់ប្តូរ ទៅរកភាពប្រាកដប្រជាក់នៃពិធីអាពាហ៍ពិពាហ៍របស់ខ្ទេរក្រហម-ពិធីសារក្រោយពីអាពាហ៍ពិពាហ៍។ ខ្ទេរក្រហមបានឆ្លើយតបនឹងពិធីសារនោះ ដោយការរៀបចំកសាងខ្ទមជាច្រើន សម្រាប់រាត្រីផ្សំដំណេក"]។

[2794] ឯកសារ D219/888.1.2 ប្រតិចារឹក កាស៊ូមិ ណាហ្គាវ៉ា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.23.16-14.28.11 ["ស៖ គូស្រករដែលត្រូវបានគេបង្ខំឲ្យរៀបការ តើលោកស្រីបានឮរឿងរ៉ាវពីសាក្សីថា គេនឹងតាមដានជាពិសេសដោយអាជ្ញាធរមូលដ្ឋានដើម្បីតាមដានមើលថា តើប្តីប្រពន្ធហ្នឹង រួមដំណេកដែរឬអត់ ក្រោយពីរៀបការហ្នឹង? ឆ៖ ចាស ខ្ញុំមានរឿងរ៉ាវបែបនោះ។ ជាពិសេសគឺមនុស្សដែលត្រូវបានគេបង្ខំឲ្យរៀបការប្រឆាំងនឹងឆន្ទៈរបស់គេ។"]។ ឯកសារ D310/1.1.4 Bridgette Toy-Cronin

768. ជាការផ្ទុយទៅគោលដៅនៃការបង្កើនចំនួនប្រជាជន គឺការបញ្ជូនប្តី ឬប្រពន្ធទៅកាន់ការដ្ឋានផ្សេងៗគ្នា ដើម្បីកសាងប្រទេសឡើងវិញ។ ដើម្បីធ្វើឲ្យសម្រេចគោលបំណងទាំងពីរ គូស្វាមីភរិយាដែលត្រូវបានបំបែកចេញពីគ្នា ត្រូវបានអនុញ្ញាតឲ្យជួបគ្នាវិញម្តងម្កាល[2795]។ Elizabeth Becker បានពន្យល់ថា៖

"ខ្ញុំចង់និយាយប្រាប់អ្នក" KH 00721384 ["ការបង្ខិតបង្ខំ មិនត្រឹមកំហិតត្រឹមតែការបង្ខំមនុស្សឲ្យរៀបការប៉ុណ្ណោះទេ តែបានបន្តក្រោយពេលពិធីរៀបការទៀតផង។ គូស្រករថ្មីថ្មោង តម្រូវឲ្យរួមរស់នៅជាមួយគ្នានៅរាត្រីដំបូង និងបី-បួនរាត្រីបន្ទាប់មកទៀត។ ចំពោះគូស្រករណាដែលមិនធ្លាប់ស្គាល់គ្នាពីមុនមកទេ រាត្រីដំបូងនោះមានការលំបាកណាស់។ ស្ទើរតែ អ្នកផ្តល់បទសម្ភាសន៍ទាំងអស់ បានរាយការណ៍ថា ពួកគេជឿថា អង្គការតម្រូវថា គូស្រករថ្មីថ្មោងត្រូវតែរួមភេទគ្នា។ អង្គការបានរៀបចំឲ្យមានឈ្លបនៅចាំយកការណ៍នៅក្រោមផ្ទះ 'អ្នកក្រេបទឹកឃ្មុំ" ដើម្បីស៊ើបការណ៍មើលថា តើគូស្រករថ្មីថ្មោងទាំងនេះកំពុងឈ្លោះគ្នា ឬកំពុងរួមភេទ។"]។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ទោចប្តូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037041 ["គូស្វាមីភរិយាថ្មោងថ្មី បានរស់នៅជាមួយគ្នារយៈពេលពីរ-បីថ្ងៃ បន្ទាប់ពីពិធីរៀបការ ដែលជារឿយៗមានពួកចារកម្មខ្មែរក្រហម ឬឈ្លប ត្រូវប្រាកដថា ពួកគេបានរៀបការរួចហើយនឹងមានការរួមដំណេក"]។ ឯកសារ D219/115.1 សៀវភៅ Rochelle Braaf មានចំណងជើងថា អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម KH 01045758 ["អ្នកដែលរៀបការដោយបង្ខំ ក៏ត្រូវបានពួកខ្មែរក្រហមបង្ខំឲ្យរួមដំណេកជាមួយគ្នាផងដែរ។ អ្នកផ្តល់បទសម្ភាសន៍ជនជាតិភាគតិចស្ទើរតែទាំងអស់ ដែលត្រូវបានបង្ខំឲ្យរៀបការ បានរៀបរាប់ថា ពួកខ្មែរក្រហមតាមដានពួកគេនៅពេលយប់ ដើម្បីធានាថាពួកខ្លួនរួមដំណេកជាមួយគ្នា។"]។ KH 01045813 ["ដោយសារគោលបំណងនៃការរៀបការដោយបង្ខំ គឺដើម្បីបង្កើតកូនសម្រាប់អង្គការ ប្តី-ប្រពន្ធដែលទើបរៀបការ ភាគច្រើនត្រូវបានបង្ខំឲ្យរួមភេទ ដោយមានការឃ្លាំងមើលពីខ្មែរក្រហម។"]។ ឯកសារ D310/1.1.6 សៀវភៅ កាស៊ូមិ ណាហ្គាវ៉ា មានចំណងជើងថា ការរំលោភផ្លូវភេទជាអំពើហិង្សាលើយ៉ូនម៉ារក្នុងអំឡុងរបបខ្មែរក្រហម EN 00421896 [អ្នកផ្តល់បទសម្ភាសន៍ម្នាក់ បានបញ្ជាក់ថា៖ " 'បន្ទាប់ពីរៀបការរួច ទាហានខ្មែរក្រហមបានតាមដានពួកយើង ដើម្បីឲ្យប្រាដកថា យើងបានស្រឡាញ់គ្នាទៅវិញទៅមក និងបានរួមដំណេកជាមួយគ្នា ប្រសិនបើអត់មានទេ ពួកខ្មែរក្រហមនឹងសម្លាប់ពួកគេ។ [...] ប្តីរបស់ខ្ញុំបានសួរខ្ញុំពេលជួបគ្នាដំបូងថា តើខ្ញុំស្រឡាញ់គាត់ឬទេ? ខ្ញុំបានប្រាប់ថា ស្រឡាញ់ ឬមិនស្រឡាញ់ ខ្ញុំធ្វើតាមអង្គការ ឬក៏យើងនឹងត្រូវគេសម្លាប់។ គាត់ក៏គិតដូច្នេះដែរ""]។

[2795] ឯកសារ D219/888.1.2 ប្រតិចារឹក កាស៊ូមិ ណាហ្គាវ៉ា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.53.35-13.55.11 ["ហើយប្រហែលជា៣ខែ ហើយបើថាសំណាងល្អហ្នឹងគឺថា ១ខែ អាចមកជួបប្រពន្ធបានម្តង"]។ ឯកសារ D219/115.1 សៀវភៅ Rochelle Braaf មានចំណងជើងថា អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម KH 01045814 ["បន្ទាប់មក [ដំណាក់កាលដំបូងនៃការរៀបការ] ប្តីប្រពន្ធមួយចំនួនរស់នៅបែកពីគ្នា និងអនុញ្ញាតិឲ្យជួបគ្នាជារៀងរាល់២ខែម្តង"]។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ទោចប្តូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037041 ["បន្ទាប់មកគូទាំងនោះ នឹងត្រូវត្រឡប់មកធ្វើការនៅតាមការដ្ឋានរបស់ខ្លួនវិញ ដោយជួបគ្នា រៀងរាល់ ៧ថ្ងៃ ទៅ ១០ថ្ងៃ ឬដាច់ឆ្ងាយពីគ្នាអស់រយៈពេលជាច្រើនខែ"]។ ឯកសារ D1.3.17.1 សៀវភៅ អេលីហ្សាបេត បេកយ៉ែ មានចំណងជើងថា នៅពេលដែលសង្គ្រាមរលត់ទៅ KH 00232339 ["ការប្រកាន់ច្បាប់តឹងរ៉ឹងហួសរបស់របបនេះ បាន

ម្យ៉ាងវិញទៀត ពួកគេគិតថា ការរួមភេទគួរត្រូវបានរឹតត្បិត ពីព្រោះវាត្រូវការពេលវេលាច្រើនពេក ហើយវាជាឧបសគ្គដល់ការងារដែលកំពុងធ្វើ ដល់ការងារពេល និងការធ្វើឲ្យប្រទេសមានភាពល្បីល្បាញ។ ទោះជាយ៉ាងនេះក្តី ពួកគេក៏បានសម្រេចថា ប្រទេសគួរតែមានប្រជាជនឲ្យបានច្រើនដើម្បីអនុវត្តកម្មវិធី ហើយបញ្ជាថាត្រូវបង្កើនចំនួនប្រជាជនឲ្យបានចំនួនពីរដង។ ដំណោះស្រាយគឺគ្មានការរួមភេទ គ្មានមនោសញ្ចេតនា ប៉ុន្តែអនុញ្ញាតឲ្យមានសិទ្ធិជួបគ្នាក្នុងឋានៈជាប្តី និងប្រពន្ធ[2796]។

គ. អាពាហ៍ពិពាហ៍មុនរបបកម្ពុជាប្រជាធិបតេយ្យ

769. មុនពេល ប.ក.ក ឡើងគ្រប់គ្រងប្រទេស អាពាហ៍ពិពាហ៍ក្នុងសង្គមកម្ពុជាបានចាក់ឫសលើប្រពៃណីសម្បូរបែបដោយបានរៀបចំពិធីដ៏ប្រណីត មានការចូលរួមពីសមាជិកគ្រួសារនៃគូស្វាមីភរិយា និងជាពិសេសនោះមានការយល់ព្រមពីកូនកំលោះ និងកូនក្រមុំ។

770. ចាប់តាំងពីដើមដំបូង គ្រួសារនៃគូស្វាមីភរិយាដែលត្រូវរៀបការបានរៀបចំដំណើរការរៀបអាពាហ៍ពិពាហ៍ ដោយធ្វើការវាយតម្លៃយ៉ាងល្អិតល្អន់លើកត្តាជាច្រើនក្នុងនោះរួមទាំងស្ថានភាពសេដ្ឋកិច្ច និងភាពសមរម្យនឹងគ្នានៃ[2797]កូនប្រុស និងកូនស្រី។ ជាប្រពៃណី កូនកំលោះ ឬឪពុកម្តាយ

រាវាំងមិនឲ្យគូស្វាមីភរិយាជាច្រើនរស់នៅជួបជុំគ្នាឡើយ ហើយបានអនុញ្ញាតិសិទ្ធិឲ្យមករួមដំណេកតែពីរ-បីដងប៉ុណ្ណោះក្នុងមួយខែ"]។

[2796] ឯកសារ D1.3.17.1 សៀវភៅ អេលីហ្សាបេត បេកយ៉ែ មានចំណងជើងថា នៅពេលដែលសង្គ្រាមរលត់ទៅ KH 00232298 ។

[2797] ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ញោចប្តូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037039 [ដកស្រង់ពីនិក្ខេបបទឆ្នាំ១៩៦៨ របស់ Ebihara (ស្វាយ ជាភូមិខ្មែរមួយ នៅប្រទេសកម្ពុជា)៖ "ភាគច្រើន អាពាហ៍ពិពាហ៍ត្រូវបានរៀបចំឡើងដោយឪពុកម្តាយដែលជាចាស់ទុំដំបូង។ ហើយ 'ក្នុងករណីភាគច្រើន ការយល់ឃើញ និងបំណងប្រាថ្នារបស់កូន ត្រូវបានយកមកពិចារណា។ ហើយពួកគាត់ មិន[ត្រូវ] បានបង្ខំឱ្យធ្វើអ្វីមួយដែលគួរឱ្យស្អប់ខ្ពើមទេ។' ត្រឡប់មកវិញ ឪពុកម្តាយជាទូទៅត្រូវទទួលបាន 'ការស្តាប់បង្គាប់ ការគោរព និងការលះបង់ពីកូនរបស់ពួកគាត់។' ទំនាក់ទំនងអាពាហ៍ពិពាហ៍មានចាប់ពីភាពចាំបាច់ឬភាពងាយស្រួល រហូតដល់ការយល់ឃើញនិងការគោរពគ្នាទៅវិញទៅមកយ៉ាងជ្រាលជ្រៅហើយត្រូវបានគេចាត់ទុកថាជាសម្ព័ន្ធភាពរវាងគ្រួសារទាំងមូលជាជាងកិច្ចសន្យារវាងបុគ្គល"] ។ ឯកសារ D219/882.1.21 សៀវភៅ កាស៊ូមិ ណាហ្គាវ៉ា មានចំណងជើងថា ភាពជាអ្នកម្តាយនៅក្នុងសង្គ្រាម KH 01506051 ["អាពាហ៍ពិពាហ៍ដោយបង្ខំដែលគេរកឃើញនៅក្នុងការសិក្សានេះ អាចត្រូវគេសម្គាល់ថាខុសពីអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរដោយសារតែគ្មានការចូលរួមពីឪពុកម្តាយនៅក្នុងដំណើរការនោះ"]។ ឯកសារ A259.1.5 សៀវភៅ Heuveline & Poch មានចំណងជើងថា "តើអាពាហ៍ពិពាហ៍បំភ្លេចអតីតកាលខ្លួនបានដែរឬទេ? ស្តេរភាពអាពាហ៍ពិពាហ៍នៅក្រោយរបបខ្មែរក្រហម"

កូនកំលោះពេលខ្ពះពីងពាក់ "អ្នកផ្សំផ្គុំ" ឲ្យធ្វើជាអន្តរការី ហើយឲ្យចូលទៅទំនាក់ទំនងជាមួយអនាគតកូនក្រមុំ[2798]។ បន្ទាប់មក គ្រួសារខាងស្រីធ្វើការស៊ើបអង្កេតពីសាវតារខាងប្រុស និងពិគ្រោះយោបល់ជាមួយ*អាចារ* (ហោរាសាស្ត្រសាសនា) ឲ្យទាយរកពេលវេលាល្អដើម្បីរៀបការ[2799]។

ប្រជាសាស្ត្រ ខែកុម្ភៈ ឆ្នាំ២០០៦ EN 01051848។ ឯកសារ D257/1/3.1.41 Annuska Derks ការឆ្ពោះទៅមុខរបស់ស្ត្រីខ្មែរ EN 01151585 ["តាមគំនិត ការរៀបចំអាពាហ៍ពិពាហ៍ទាក់ទងនឹងគ្រួសាររបស់ទាំងខាងក្មេងស្រី និងក្មេងប្រុស ដែលមានកេរ្តិ៍ឈ្មោះ និងផ្នែកសេដ្ឋកិច្ច ក៏ដើរតួនាទីយ៉ាងសំខាន់ផងដែរ"]។

[2798] ឯកសារ D219/882.1.21 សៀវភៅ កាស៊ូមិ ណាហ្ការ៉ា មានចំណងជើងថា ភាពជាអ្នកម្តាយនៅក្នុងសង្គ្រាម KH 01506035 ["ជាទូទៅ ម្តាយខាងកូនប្រុសជាអ្នកទាក់ទងម្តាយខាងកូនស្រី ដើម្បីសាកសួរអំពីសំណើរសុំរៀបអាពាហ៍ពពាហ៍។ វាអាចជាំណើរដែលធ្វើឡើងដោយកូនប្រុសខ្លួនឯង ឬឪពុកម្តាយជាអ្នកជ្រើសរើសកូនក្រមុំដែលសក្តិសមសម្រាប់កូនរបស់ខ្លួន។"]។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្មោចប្ដូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037040 [ដកស្រង់ពីនិក្ខេបបទរបស់ Ebihara នៅខែ ឧសភា ឆ្នាំ១៩៦៨ (ស្វាយ ជាភូមិខ្មែរមួយ នៅប្រទេសកម្ពុជា)]។ ឯកសារ A259.1.5 សៀវភៅ Heuveline & Poch មានចំណងជើងថា "តើអាពាហ៍ពិពាហ៍បំភ្លេចអតីតកាលខ្លួនបានដែរឬទេ? ស្ថេរភាពអាពាហ៍ពិពាហ៍នៅក្រោយរបបខ្មែរក្រហម" *ប្រជាសាស្ត្រ* ខែកុម្ភៈ ឆ្នាំ២០០៦ EN 01051849 ["កូនកំលោះ ឬឪពុកម្តាយរបស់ខ្លួន អាចផ្តួចផ្តើមទំនាក់ទំនងជាមួយគ្រួសារកូនក្រមុំដែលអាចក្លាយជាគូអនាគត ប៉ុន្តែជារឿយៗ មេអណ្តើកក៏ជាប់ទាក់ទងក្នុងធានាអះអាងទទួលយកគូដ៏សាកសមផងដែរ"]។ ឯកសារ D257/1/3.1.41 Annuska Derks *ការឆ្ពោះទៅមុខរបស់ស្ត្រីខ្មែរ* EN 01151585 ["វិធីសាស្ត្រភ្ជាប់ចំណងអាពាហ៍ពិពាហ៍មិនធ្វើដោយផ្ទាល់រវាងគ្រួសារទាំងសងខាងនោះទេ។ ប៉ុន្តែតាមរយៈនរណាម្នាក់ក្នុងនាមជាឪពុកម្តាយខាងក្មេងប្រុស ហើយមានទំនាក់ទំនងជាមួយឪពុកម្តាយខាងក្មេងស្រី ក៏ដូចជាចាស់ទុំផងដែរ ដើម្បីធានាឲ្យមានការទទួលយកនូវទំនាក់ទំនងថ្មីទៀត"]។

[2799] ឯកសារ D219/882.1.24 សៀវភៅ Peggy Levine មានចំណងជើងថា បរិបទសិក្សាអំពីពិធីអាពាហ៍ពិពាហ៍ និងការចាប់កំណើតក្រោមរបបខ្មែរក្រហម៖ *បដិវត្តន៍ទំនៀមទម្លាប់*EN 00482484 ["យោងតាមប្រពៃណី អាចារ្យ ជាអ្នករៀបចំពេលាមង្គលការ។ [...] ថ្ងៃអាពាហ៍ពិពាហ៍ បានកំណត់ដោយទៅតាមការទស្សន៍ទាញដែលខាងកូនស្រី (ទៅតាមទម្លាប់ខាងស្រី) ដែលស្វែងរកថ្ងៃល្អ និងចៀសពីថ្ងៃមានគ្រោះ"]។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្មោចប្ដូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037039 ["Ebihara ផ្អែកលើការចង្អុលបង្ហាញពី "សារៈសំខាន់ដ៏ធំធេង" នៃទំនាយហោរាសាស្ត្ររបស់គូប្ដីប្រពន្ធ ដែលធ្វើការទស្សន៍ទាយខែឆ្នាំ ពីសំណាក់ អាចារ្យ [គ្រហស្ថដែលយល់ដឹងផ្នែកសាសនា] ដើម្បីដឹងពីគូព្រេងដែលសាកសមនឹងគ្នា ហើយកំណត់កាលបរិច្ឆេទថ្ងៃអាពាហ៍ពិពាហ៍ដ៏ល្អ"]។ ឯកសារ A259.1.5 សៀវភៅ Heuveline & Poch មានចំណងជើងថា "តើអាពាហ៍ពិពាហ៍បំភ្លេចអតីតកាលខ្លួនបានដែរឬទេ? ស្ថេរភាពអាពាហ៍ពិពាហ៍នៅក្រោយរបបខ្មែរក្រហម" *ប្រជាសាស្ត្រ* ខែកុម្ភៈ ឆ្នាំ២០០៦ EN 01051848។

771. បន្ទាប់ពីមានការយល់ព្រមពីភាគីទាំងពីរ ក្មួនកំណេះជូនចំណងដៃ ឬប្រាក់ទៅគ្រួសារក្មួនក្រមុំដើម្បីភ្ជាប់ចំណងអាពាហ៍ពិពាហ៍[2800]។ បន្ទាប់មកពិធីរៀបអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងជាច្រើនថ្ងៃ[2801] ដែលក្នុងនោះរួមទាំងពិធីសាសនា និងប្រពៃណីមួយចំនួន និងការបញ្ជាក់ពីចំណងគ្រួសារនៃគូស្វាមីភរិយា និងគ្រួសារទាំងពីរនៅចំពោះមុខញាតិមិត្តជិតឆ្ងាយរបស់គេ[2802]។

[2800] ឯកសារ A259.1.5 សៀវភៅ Heuveline & Poch មានចំណងជើងថា "តើអាពាហ៍ពិពាហ៍បំភ្លេចអតីតកាលខ្លួនបានដែរឬទេ? ស្ថេរភាពអាពាហ៍ពិពាហ៍នៅក្រោយរបបខ្មែរក្រហម" *ប្រជាសាស្ត្រ* ខែកុម្ភៈ ឆ្នាំ២០០៦ EN 01051849 ["នៅពេលភ្ជាប់ពាក្យរួច បុរសដែលជាអនាគតកូនកម្លោះ ត្រូវបានគេរំពឹងនឹងធ្វើការ (ធ្វើបម្រើ ជាភាសាខ្មែរ) ឲ្យសាច់ផ្ទៃក្នុងកិច្ចព្រមព្រៀងមួយដែលមានរយៈពេលជិតមួយឆ្នាំឬលើសពីនេះ។ ការរៀបចំទាំងនេះ ជាទម្រង់នៃបណ្ណាការតែវាក៏មានគោលបំណង ដើម្បីពិសោធន៍លក្ខណៈសម្បត្តិរបស់កូនកំម្លោះផងដែរ។ អាពាហ៍ពិពាហ៍ត្រូវបានផ្សារភ្ជាប់ជាប្រពៃណី ដោយការទទួលយកអំណោយពីខាងបុរសជាអនាគតកូនកម្លោះ ផ្តល់ជូនឪពុកម្តាយសាច់ផ្ទៃ នាពេលអនាគត"]។ ឯកសារ D257/1/3.1.41 Annuska Derks ការឆ្ពោះទៅមុខរបស់ស្ត្រីខ្មែរ EN 01151585 ["ដំណើរការភ្ជាប់ចំណងអាពាហ៍ពិពាហ៍ទាំងនេះ រួមមានទាំងការចរចាទាក់ទងនឹងបណ្តាការកូនក្រមុំដែលត្រូវបានគេហៅថា ជំនួន (អំណោយ) ផ្ទៃទឹកដោះ (តម្លៃនៃទឹកដោះម្តាយ) ឬ ផ្ទៃផ្ទះ (តម្លៃនៃផ្ទះ) ឬក៏ខាន់ស្លា (ការចំណាយនៅក្នុងពិធីរៀបការ ដោយមានដាវ និងស្ពឺកម្ជូ)"]។ ឯកសារ D219/882.1.21 សៀវភៅ កាស្ទ្រីមិ ណាហ្គាវ៉ា មានចំណងជើងថា ភាពជាអ្នកម្តាយនៅក្នុងសង្គ្រាម KH 01506038 [លោកស្រី មួយ គា បានរំលឹកថា៖ "ឪពុកខ្ញុំបានរៀបការម្តងទៀត នៅពេលខ្ញុំមានអាយុ ៩ ឆ្នាំ។ មង្គលការរបស់គាត់ ធ្វើឡើងធំដុំណាស់ ព្រោះគាត់ជាអ្នកមាន។ ប្រពន្ធទីពីរ ត្រូវជាម្តាយចុងរបស់ខ្ញុំ ត្រូវការប្រាក់ច្រើនណាស់ពីឪពុកខ្ញុំ សម្រាប់ពិធីមង្គលការនេះ ព្រោះវាជាពិធីមង្គលការដំបូងរបស់គាត់។"]។

[2801] ឯកសារ D219/115.1 សៀវភៅ Rochelle Braaf មានចំណងជើងថា អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម KH 01045812 ["ប្រពៃណីរៀបការរបស់ខ្មែរ [...] ធម្មតាមានរយៈពេលពីរទៅបីថ្ងៃ"]។ ឯកសារ D219/882.1.24 សៀវភៅ Peggy Levine មានចំណងជើងថា បរិបទសិក្សាអំពីពិធីអាពាហ៍ពិពាហ៍ និងការចាប់កំណើតក្រោមរបបខ្មែរក្រហម៖ *បដិវត្តន៍ទំនៀមទម្លាប់* EN 00482484 ["ឯកសារពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងការរៀបចំពិធីមង្គលការ ត្រូវបានរៀបចំជាស្រេច សម្រាប់ពិធីមួយ ដែលអាចមានរយៈពេលពីមួយទៅបីថ្ងៃ។"]។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ទោចប្តូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037039 ["និក្ខេបបទឆ្នាំ១៩៦៨ ដែលមានពីរភាគ របស់ Ebihara ផ្តល់នូវការស្ទង់មតិផ្នែកនរវិទ្យាយ៉ាងលម្អិតមួយ ទាក់ទងនឹងជីវិតរស់នៅក្នុងភូមិ មុនសម័យខ្មែរក្រហម រួមមានការរៀបអាពាហ៍ពិពាហ៍ និងជីវិតរៀបអាពាហ៍ពិពាហ៍។ គាត់បានរៀបរាប់ ពីពិធីមង្គលការ គឺជាថ្ងៃដែលមានពិធីជាច្រើនយ៉ាងល្អិតល្អន់ ប្រកបដោយអត្ថន័យវប្បធម៌យ៉ាងជ្រៅ"]។ ឯកសារ D310/1.1.4 Bridgette Toy-Cronin "ខ្ញុំចង់និយាយប្រាប់អ្នក" KH 00721380-00721381។

[2802] ឯកសារ D5/1334/3 ប្រតិចារឹក ជា ឌៀប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 14.12.59-14.18.02 [នៅក្នុងការអនុវត្តន៍នៃការរៀបការ សម័យមុននិងក្រោយរបបខ្មែរក្រហម៖ "គេរៀបការតែម្តងមួយគូៗ ហើយមានភ្លេងមានភ្ជាត់ មានយាយតា ជីដូនជីតា បងប្អូន ហើយមានហែលជំនួន ហែលផ្ការ៉ា បាចផ្ការ៉ា"]។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ទោចប្តូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037033 EN 01037039។ ឯកសារ D219/882.1.24 សៀវភៅ Peggy Levine មានចំណងជើងថា បរិបទសិក្សាអំពីពិធីអាពាហ៍ពិពាហ៍

772. បើទោះបីជាអាពាហ៍ពិពាហ៍ទាំងនេះជាញឹកញាប់ត្រូវបានរៀបចំផ្សំផ្គុំឡើងដោយឪពុកម្តាយរបស់គូស្វាមីភរិយា និងផ្អែកលើការស្វែងយល់ជាក់ស្តែងក៏ដោយ ក៏ឪពុកម្តាយទាំងសងខាងចាំ បាច់ត្រូវមានការឯកភាពយល់ព្រមពីកូនកំលោះ និងកូនក្រមុំដែរ[2803]។ បទប្បញ្ញត្តិក្នុងក្រមស៊ីវិលកម្ពុជាដែលស្ថិតជាធរមាន នៅមុនរបបកម្ពុជាប្រជាធិបតេយ្យបានអនុញ្ញាតឲ្យបុរស ឬស្ត្រីផ្តាច់ការភ្ជាប់ពាក្យ ហើយបុរស ឬស្ត្រី ដែលបានរៀបការរួចហើយធ្វើការលែងលះគ្នា ប្រសិនបើការយល់ព្រមត្រូវបានរំលោភបំពានដោយការបង្ខិតបង្ខំ[2804]។

និងការចាប់កំណើតក្រោមរបបខ្មែរក្រហម៖ *បដិវត្តន៍ទំនៀមទម្លាប់* EN 00482489 [“ព្រះសង្ឆ ជាតួអង្គសំខាន់ចំពោះសេចក្តីសុខសប្បាយរបស់គ្រួសារ និងសហគមន៍ តាំងពីដើមដល់ចប់នៃពិធីរៀបអាពាហ៍ពិពាហ៍។ ព្រះសង្ឆ ផ្តល់ឱវាទដល់គូស្វាមីភរិយា ហើយភ្ជាប់ទំនាក់ទំនងជាមួយដូនតាដែលបានចែកឋានទៅ ឲ្យអញ្ជើញមកចូលរួមក្នុងពិធីមង្គលការរបស់កូនប្រុសស្រី”] EN 00482490-00482491។ ឯកសារ D219/115.1 សៀវភៅ Rochelle Braaf មានចំណងជើងថា អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម KH 01045812-0104514 ។ ឯកសារ D310/1.1.4 Bridgette Toy-Cronin “ខ្ញុំចង់និយាយប្រាប់អ្នក” KH 00721380-00721381 ។

[2803] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.១៤០-១៤២ KH 01047397-01047398។ ឯកសារ D219/289 កំណត់ហេតុស្តាប់ចម្លើយ ពេញ រ៉ា ឆ.១-២ KH 01091439-01091440។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃូ ភ្ជុំ ឆ.៥១-៥២ KH 01117226។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឃីម ឆ.១៣ KH 01039252។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ញោចប្តូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037039 EN 01037040។ ឯកសារ A259.1.5 សៀវភៅ Heuveline & Poch មានចំណងជើងថា “តើអាពាហ៍ពិពាហ៍បំភ្លេចអតីតកាលខ្លួនបានដែរឬទេ? ស្ថេរភាពអាពាហ៍ពិពាហ៍នៅក្រោយរបបខ្មែរក្រហម” *ប្រជាសាស្ត្រ* ខែកុម្ភៈ ឆ្នាំ២០០៦ EN 01051849 [“ឪពុកម្តាយមិនត្រូវបានលើកទឹកចិត្ត [...] ពីការរៀបការជាមួយកូនស្រីខ្លួនផ្ទុយពីឆន្ទៈរបស់នាង”]។ ឯកសារ D257/1/3.1.41 Annuska Derks ការឆ្ពោះទៅមុខរបស់ស្ត្រីខ្មែរ EN 01151585 [“ដំណើរការភ្ជាប់ចំណងអាពាហ៍ពិពាហ៍ទាំងនេះ រួមបញ្ចូលទាំងការចរចាទាក់ទងនឹងបណ្តាការខាងកូនស្រី [...] ទោះជាយ៉ាងណាក៏ដោយ ការរៀបចំអាពាហ៍ពិពាហ៍ មិនអាចធ្វើបានឡើង ដោយគ្មានការយល់ព្រមពីគូស្វាមីភរិយាឡើយ។”]។

[2804] ឯកសារ D257/1/3.1.5 ក្រមរដ្ឋប្បវេណី និង នីតិវិធីក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩២០ FR 01151445 មាត្រា ១៦៣ [“អាពាហ៍ពិពាហ៍ត្រូវបានលុបចោល នៅពេលដែលកិច្ចព្រមព្រៀងពីស្វាមី ឬភរិយាមួយគូ ប្រព្រឹត្តិកំហុស ឬដោយការបង្ខិតបង្ខំ។”]។

ឃ. អាពាហ៍ពិពាហ៍ក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

i. ការអនុវត្តគោលនយោបាយថ្នាក់ជាតិ

ការរៀបចំ និងការជួនដំណឹង

773. ទម្លាប់ប្រពៃណីលើអាពាហ៍ពិពាហ៍ក្នុងប្រទេសកម្ពុជាបានផ្លាស់ប្តូរទាំងស្រុង បន្ទាប់ពី ប.ក.ក បានឡើងកាន់អំណាច។ ជនរងគ្រោះពីអាពាហ៍ពិពាហ៍ដោយបង្ខំ បានផ្តល់សក្ខីកម្មថា "ប្រសិនបើប្រៀបធៀបការរៀបការនៅជំនាន់ខ្មែរក្រហម និងសម័យមុនៗខ្មែរក្រហម គឺថាខុសគ្នាដាច់"[2805]។

774. តាមប្រពៃណី ខណៈគ្រួសារទាំងសងខាងមានជាប់ពាក់ព័ន្ធយ៉ាងច្រើននៅគ្រប់ដំណាក់កាលនៃដំណើរការអាពាហ៍ពិពាហ៍ ប៉ុន្តែក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ រដ្ឋគ្រប់គ្រងអាពាហ៍ពិពាហ៍ទាំងស្រុង[2806]។ ការអនុវត្តសិទ្ធិអំណាចនេះត្រូវបានធ្វើឡើងដោយផ្អែកលើសេណារីយ៉ូចំនួនពីរ។ សេណារីយ៉ូដែលអនុវត្តញឹកញាប់បំផុតគឺ កម្មាភិបាលខ្មែរក្រហម មិនបានអនុញ្ញាតឲ្យគ្រួសារចូលរួមក្នុងការជ្រើសរើសអនាគតកូនប្រសារប្រុស ឬស្រីទេ[2807] ហើយពួកគេបានផ្សំផ្គុំគូ

[2805] ឯកសារ D5/1334/3 ប្រតិចារឹក ជា ឌៀប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 14.12.59-14.18.02 [ដើមបណ្តឹងរដ្ឋប្តីវេណ ត្រូវបានបង្ខំឲ្យរៀបការជាមួយយោធា នៅទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥]។

[2806] ឯកសារ D219/115.1 សៀវភៅ Rochelle Braaf មានចំណងជើងថា អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម KH 01045806 ["ដើម្បីគ្រប់គ្រងតួនាទីសាសនា និងគ្រួសារក្នុងជីវិតប្រជាជន របបនេះបានគ្រប់គ្រងទាំងស្រុងលើការជ្រើសរើសគូប្តីប្រពន្ធសម្រាប់ការការរៀបការ ការរៀបចំពិធីរៀបការ ទីកន្លែងដែលប្តីប្រពន្ធរស់នៅ និងការរួមដំណេករបស់ប្តីប្រពន្ធ"]។ *សូមមើលផងដែរ* ឯកសារ D219/888.1.2 ប្រតិចារឹក កាស៊ូមិ ណាហ្ការ៉ា ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.27.00-11.29.43 ម៉ោង 13.29.44-13.32.33។ ឯកសារ D310/1.1.6 សៀវភៅ កាស៊ូមិ ណាហ្ការ៉ា មានចំណងជើងថា ការរំលោភផ្លូវភេទជាអំពើហិង្សាលើយ៉ោនឌ័រក្នុងអំឡុងរបបខ្មែរក្រហម KH 00738346 ["គ្មានអាពាហ៍ពិពាហ៍មួយ ត្រូវបានធ្វើឡើងដោយគ្មានសេចក្តីបង្គាប់ដោយ អង្គការ ឡើយ។ ពាក្យស្លោកមួយរបស់អង្គការពោលថា 'អង្គការចាត់តាំងដៃគូ (ដៃគូរបស់អ្នក)។ បើសិនជាអ្នកមិនគោរពតាមអង្គការចាត់តាំងទេ ត្រូវបញ្ជូនទៅរៀនសូត្រមួយរយៈ"។ អាពាហ៍ពិពាហ៍ មិនមែនជាបញ្ហាបុគ្គលទេ ប៉ុន្តែវាត្រូវបានចាត់ទុកថាជាពិធីដ៏សំខាន់ចំពោះការធ្វើសម្បថចំពោះអង្គការ។ ដូច្នេះ វាត្រូវបានត្រួតពិនិត្យយ៉ាងហ្មត់ចត់ដោយ អង្គការ នៅថ្នាក់ភូមិ"]។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ទោចបួរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037041។ ឯកសារ D310/1.1.4 សៀវភៅ Bridgette Toy-Cronin មានចំណងជើងថា "ខ្ញុំចង់និយាយប្រាប់អ្នក" EN 00449488។

[2807] ឯកសារ D5/1334/3 ប្រតិចារឹក ជា ឌៀប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.54.56-13.56.31 [នៅទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥៖ "ខ្ញុំមិនដែលបានពិភាក្សាជាមួយម៉ែឪបងប្អូនទេ ព្រោះនៅឆ្ងាយ។ ទោះបីសុំគេទៅ ក៏គេមិនទៅ ក៏គេមិនឲ្យទៅដែរ គឺស្រេចតែអង្គការតែហ្ម្ចងហ្ម្ចឹង។"]។ ឯកសារ D219/888.1.8 ប្រតិចារឹក កុល ណែម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង

ស្វាមីភរិយា ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យមួយចំនួន ដូចជា វណ្ណៈនយោបាយ ជាតិពន្ធ និងសាវតារ[2808]។ ទោះបីជាកម្មាភិបាលខ្មែរក្រហម និងអតីតទាហានក៏ត្រូវបានផ្សំគ្នុំ ដោយប្រើប្រាស់

10.33.16-10.36.55 [បន្ទាប់ពីការបង្ខំឲ្យរៀបការ នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "ខ្ញុំអត់ចង់បានគ្រួសារ គ្មានអារម្មណ៍ចង់បានគ្រួសារ ហើយក្នុងនាមខ្ញុំជាស្ត្រីខ្មែរមួយ ខ្ញុំអត់ចង់បានប្តីដែលឪម៉ែអត់រៀបចំឲ្យ។"]។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.២២ KH 01045651 [នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "ជាធម្មតានៅកម្ពុជា មុនពួកខ្មែរក្រហមចូលមកដល់ គូស្រករភាគច្រើនត្រូវបានរៀបចំដោយឪពុកម្តាយ តែក្នុងរបបនោះ ខ្មែរក្រហមជាអ្នកសម្រេចលើអ្វីៗទាំងអស់។"]។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ទោចប្តូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037041 ["សមាជិកគ្រួសារ [...] មិនត្រូវបានពិគ្រោះយោបល់ក្នុងការរៀបចំអាពាហ៍ពិពាហ៍ ឬគូស្រករ"]។ ឯកសារ D219/882.1.21 សៀវភៅ កាស៊ូមិ ណាហ្គាវ៉ា មានចំណងជើងថា ភាពជាអ្នកម្តាយនៅក្នុងសង្គ្រាម KH 01506025 ["អាពាហ៍ពិពាហ៍ដោយបង្ខំនេះ គឺខុសគ្នាពីអាពាហ៍ពិពាហ៍ផ្សំគ្នុំតាមប្រពៃណី ព្រោះឪពុកម្តាយគ្មានអំណាចក្នុងដំណើរការសម្រេចចិត្តលើអាពាហ៍ពិពាហ៍របស់កូន ប៉ុន្តែជំនួសមកវិញ ពួកខ្មែរក្រហមបានក្លាយជា 'ឪពុកម្តាយ" ដល់អ្នកដែលត្រូវរៀបការ"]។

[2808] ឯកសារ D347/2.1.37 ប្រតិចារឹក សេង សឿន ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉ោង 09.53.16-09.56.58 ដើមបណ្តឹងរដ្ឋប្តឹងវេណី ជាអ្នកទទួលបន្ទុកក្នុងការរៀបចំពិធីរៀបការនៅ ស្រុកស្អាង ខេត្តកណ្តាល ភូមិភាគនិរតី៖ "ខ្ញុំមិនដឹងថាយ៉ាងម៉េចទេ ព្រោះនេះជាផែនការរបស់គណៈស្រុក [...] ព្រោះយកប្រវត្តិរូបទាំងសងខាង គឺខាងនារី ខាងយុវជនហ្នឹង ឲ្យប្រធានកងចល័ត គេជ្រើសរើសមក អាយុណាដែលត្រូវរៀបការ ទាំងស្រីទាំងប្រុស។ អីចឹងខ្ញុំធ្វើតាមផែនការរបស់បញ្ញាសាលាស្រុក អ៊ីនែក! គណៈស្រុក"]។ ម៉ោង 09.59.48-10.03.22 ["ពិតជារបស់ផែនការរបស់គណៈស្រុក ដែលណែនាំប្រាប់ខ្ញុំថា អាថ្មីដាក់ដោយថ្មី មូលដ្ឋានចាត់តាមមូលដ្ឋាន។"]។ ឯកសារ D5/1334/3 ប្រតិចារឹក សេង សឿន ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង11.11.05-11.15.25, 11.17.37-11.19.30 [នៅស្រុកស្អាង ខេត្តកណ្តាល ភូមិភាគនិរតី ពាក់កណ្តាលឆ្នាំ១៩៧៨ (*សូមមើល* ឯកសារ D 6.1.679 កំណត់ហេតុស្តាប់ចម្លើយ សេង សឿន ឆ.៧០ KH 00402515)៖ "កងចល័តទាំងពីរផ្នែក ចល័តខាងនារី ខាងនបុរសហ្នឹង តាមផែនការគណៈស្រុកឲ្យជ្រើសរើសការហ្នឹងយកប៉ុន្ថានថា ២០ ឬ ៣០ គូ ឲ្យប្រាកដ [...] អីចឹងកងចល័តទាំងសងខាងហ្នឹង គេយកចំនួនរៀងខ្លួន យកមកប្រាប់មកឲ្យ ផុន បង ផុន ប្រាប់មកខ្ញុំថា អ្ហែងធ្វើអីចេះ ផ្គុំផ្ទួទៅក្នុងឃុំជាមួយគ្នា ហើយអាយុបងប្រុសនុំងបង ៣ ឆ្នាំឬ ៥ ឆ្នាំទៅតាមអញ្ចាទៅ។"]។ ឯកសារ D219/702.1.87 ប្រតិចារឹក ឃូ រ៉ាន់ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ម៉ោង 15.35.15-15.38.41 *សូមអានភ្ជាប់ជាមួយ* ឯកសារ D219/138 កំណត់ហេតុស្តាប់ចម្លើយ ឃូ រ៉ាន់ ឆ.៨១ KH 01056057។ ឯកសារ D219/702.1.94 ប្រតិចារឹក ឃូ រ៉ាន់ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៦ ម៉ោង 10.52.20-10.55.54 ["[លេខាស្រុកកំពង់សៀម] ប្រាក់ ឃុត គាត់ប្រកាសមីក្រូថា ឲ្យរៀបចំសាសន៍ដូចគ្នា បានគាត់រៀបចំឲ្យ បើសាសន៍មិនដូចគ្នា គាត់អត់រៀបទេ"]។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.៧៨, ៨០ KH 01045659 [នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "អ្នកចាស់រៀបការជាមួយអ្នកចាស់ អ្នកថ្មីរៀបការជាមួយអ្នកថ្មី។ [...] បើបុរសម្នាក់ចង់រៀបការជាមួយស្ត្រីម្នាក់ គេអាចស្នើទៅអង្គការបាន។ តែគេអាចរៀបការជាមួយស្ត្រីដែលនៅប្រភេទប្រជាជនដូចគ្នាប៉ុណ្ណោះ។"]។ ឯកសារ D118/242 កំណត់ហេតុស្តាប់ចម្លើយ ខឹម ហ្ជឿន ឆ.១១២, ១២០ KH 00998738-00998739។ ឯកសារ D117/68 កំណត់ហេតុស្តាប់ចម្លើយ រ៉ា លីមហ៊ាន់ ឆ.២៣-២៤ KH 001025625។ ឯកសារ D219/171 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុលហ៊ៅ សាយ ឆ.៣៩ KH 001065954។ ឯកសារ D219/293 កំណត់ហេតុស្តាប់ចម្លើយ ជាម ពៅ ឆ.៣០ KH 01095226។ ឯក

វិធីសាស្ត្រនេះដែរ[2809] ខណៈដែលទាហានពិការជាញឹកញាប់ត្រូវបានបង្ខំឲ្យរៀបការដែលការរៀបការនេះត្រូវបានចាត់ទុកថាជា "រង្វាន់លើកទឹកចិត្ត" ចំពោះពលិកម្មដល់ប្រទេសជាតិ[2810]។

សារ D219/882.1.24 សៀវភៅ Peggy Levine មានចំណងជើងថា បរិបទសិក្សាអំពីពិធីអាពាហ៍ពិពាហ៍ និងការចាប់កំណើត ក្រោមរបបខ្មែរក្រហម៖ *បដិវត្តន៍ទំនៀមទម្លាប់* EN 00482531។ ឯកសារ D310/1.1.4 Bridgette Toy-Cronin "ខ្ញុំចង់និយាយប្រាប់អ្នក" KH 00721380-00721381។

[2809] *សូមមើល ខទាហរណ៍* ឯកសារ D219/702.1.139 ប្រតិចារឹក កាំង ហ្គេចអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០០៩ ម៉ោង 09.05.19-09.12.18 ["ខ្ញុំជាកម្មាភិបាលមួយរូបរបស់បក្សកុម្មុយនីស្តកម្ពុជា ខ្ញុំគ្មានសិទ្ធិរៀបការជាមួយនឹងជនជម្លៀសទេ។ ខ្ញុំគ្មានសិទ្ធិរៀបការជាមួយនឹងអ្នកដែលទៅពីភ្នំពេញ ប្រជាជន ១៧ មេសា ទេ។ សូមជម្រាបបញ្ជាក់ជូនលោកចៅក្រមថា ប្រពន្ធដែលខ្ញុំរៀបការនេះជាបេក្ខជនរបស់បក្សកុម្មុយនីស្តកម្ពុជា"]។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.២២២-២២៣ KH 01095268 [សាក្សីជាយោធានៅស្រុកកោះអណ្តែត ខេត្តតាកែវ ភូមិភាគនិរតី៖ "ខ្ញុំក៏មិនអាចរៀបការអ្នកដែលខ្ញុំស្រឡាញ់បានផង។ ស៖ តើលោកស្រឡាញ់អ្នកដែលមានសមាសភាពពាក់ព័ន្ធជាមួយនឹងទាហាន លន់ នល់ ឬ? ឆ៖ ហ្នឹងហើយ។"]។

[2810] ឯកសារ D5/1334/3 ប្រតិចារឹក ជា ឌៀប ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.56.31-14.04.01 [នៅពេលរៀបការដោយបង្ខំរបស់គាត់ ក្នុងទីក្រុងភ្នំពេញ នៅឆ្នាំ១៩៧៥៖ "ក្នុងគ្រួសារទាំង ១២ គូរៀបហ្នឹង គឺចាផ្ទែកនារីកងស្នែង ក៏សុទ្ធតែនារីកងស្នែង និងយោធាដែរ។ ចំណែក ឃុទ្ធជនសុទ្ធតែយោធាទាំងអស់។ ប៉ុនពួកឃុទ្ធជនទាំងអស់ហ្នឹង សុទ្ធតែឃុទ្ធជនពិការ ព្រោះពិការវ៉ៃខ្លាំងមិនកើត គេយកមកដាក់មួយកន្លែង។ ដាក់កន្លែង ដល់ពេលរៀបការហ្នឹង គេយកសុទ្ធជនពិការហ្នឹងមករៀប។ ប៉ុនពិការ មិនពិការខ្លាំងទេ ខ្លះក៏កំបុតដៃមួយចំហៀង ខ្លះខ្វះ ខ្លះខ្វាក់ភ្នែកមួយចំហៀង ខ្លះទៀតគ្រាន់តែដូចថា ខូចដៃបន្តិច ជើងបន្តិចអីទៅ គ្រាន់ថា ដើរកើតប៉ើលប៉ាលអីបន្តិចៗអីចឹងៗទៅ សុទ្ធតែអ្នកពិការទាំងអស់ រៀបមួយសាខ្ញុំហ្នឹង។"]។ ឯកសារ 219/888.1.7 ប្រតិចារឹក ព្រាប សុឃៀន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.38.59-15.41.47 [នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "ខ្ញុំធ្លាប់ឮដែរ ឮគេនិយាយតៗគ្នាថា គេនឹងយកជនពិការមករៀបការឲ្យ ដើម្បីលើកទឹកចិត្តដែលខំតស៊ូ ដូចថារំដោះប្រទេសជាតិហ្នឹង បានមកគ្រប់គ្រងសព្វថ្ងៃហ្នឹង។ អីចឹង គេនឹងរៀបឲ្យនារីស្អាតៗទៅជនពិការ។"]។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុខឿន ឆ.១២ KH 01029954 ឆ.២៤ KH 01029957 ["នៅពេលនោះ អ្នកដែលពិការគឺអ្នកដែលបានធ្វើការលះបង់នៅក្នុងសមរភូមិ ដូច្នេះហើយអ្នកដែលបានលញ្ជបង់នោះត្រូវបានគេជ្រើសរើសនារីឲ្យរៀបការ ដូចជារង្វាន់លើកទឹកចិត្តឲ្យយោធាពិការទាំងនោះ។"]។ ឯកសារ D219/504 កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.១៤៦-១៤៨ KH 01146395។ ឯកសារ D267.1.1 កំណត់ហេតុស្តាប់ចម្លើយ សេង អ៊ុល ឆ.២០, ២៧ KH 00408324-00408325។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃូ ភ្ន ឆ.១៣៦-១៣៧ KH 01117235។ ឯកសារ D219/171 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល ហៅ សាយ ឆ.៣៥ KH 01065953។ ឯកសារ D219/293 កំណត់ហេតុស្តាប់ចម្លើយ ជាម ពៅ ឆ.៣១ KH 01095226-01095227។ ឯកសារ D219/582 កំណត់ហេតុស្តាប់ចម្លើយ ឆ្លូយ ម៉ៀច ឆ.១២៩ KH 01166944។ ឯកសារ D301/2.1.21 សៀវភៅ Theresa De Langis មានចំណងជើងថា ដូចខ្ទោចប្ជូរកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំ ក្រោមរបបខ្មែរក្រហម EN 01037041 ["ព័ត៌មានលម្អិត និងបម្រែបម្រួលផ្សេងទៀត ដែលអ្នកស្រាវជ្រាវបានលើកឡើង គឺ

775. ជាធម្មតា នៅថ្ងៃរៀបអាពាហ៍ពិពាហ៍ ឬនៅមុនពេលរៀបអាពាហ៍ពិពាហ៍បន្តិច កម្មាភិបាលមូលដ្ឋានបានប្រាប់បុរស ស្ត្រីដែលត្រូវរៀបការថា ពួកគេនឹងរៀបការ ហើយបានបញ្ជាឲ្យពួកបង្ហាញខ្លួនក្នុងពិធីរៀបរៀបអាពាហ៍ពិពាហ៍[2811]។ ប្រជាជនខ្លះមិនបានទទួលការជូនដំណឹងជាមុនសោះឡើយ

ការរៀបអាពាហ៍ពិពាហ៍របស់នារីវ័យក្មេងស្រស់ស្អាត ជាមួយទាហានខ្មែរក្រហមពិការ"]។ ឯកសារ D219/370.1.8 សៀវភៅ ព្រះបាទ នរោត្តម សីហនុ មានចំណងជើងថា *អ្នកទោសខ្មែរក្រហម* EN 00632939។

[2811] ឯកសារ D219/888.1.2 កាស្ទ្រីមិ ណាកាហ្ការ៉ា ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.59.38-14.01.59 ["គឺមានគំរូផ្សេងៗ ប៉ុន្តែពិធីដ៏ទូទៅជាងគេហ្នឹងគឺថា បុរស និងស្ត្រីត្រូវបានទទួលដំណឹងថា គេនឹងរៀបការឲ្យពួកគាត់ គឺថា ដូចជា គេប្រាប់ពីព្រឹក ល្ងាចគេរៀបការ។ ឬក៏គេអាចប្រាប់មួយថ្ងៃមុន។ ពិធីរៀបការនោះ ត្រូវបានរៀបចំឡើង គឺជាពិសេសនៅពេលល្ងាច នៅថ្ងៃនោះឯង គឺជាការជូនដំណឹងខ្លីណាស់ គឺថាក្នុងរយៈពេល ២៤ តែប៉ុណ្ណឹងទេ។"]។ ឯកសារ D347/2.1.37 សេង សឿន ប្រតិចារឹក ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉ោង 09.56.58-09.59.48 [ដើមបណ្តឹងរដ្ឋប្បវេណីជាអ្នករៀបចំការរៀបការក្នុងស្រុកស្អាង ខេត្តកណ្តាល ភូមិភាគនិរតី៖ "ខ្ញុំគ្រាន់គិតក្នុងចិត្តទេ សាមីខ្លួនដែលត្រូវរៀបការ យុវជន យុវនារីទាំងអស់ហ្នឹង គ្មានដឹងខ្លួនអីទេ ស្រេចទៅលើប្រធានទេ គេជិតដល់ថ្ងៃហ្នឹងហើយ គេហៅទៅ ឈ្មោះនេះឈ្មោះនោះមកនៅជួបជុំនៅមន្ទីរស្រុក។ រហូតដល់ -- អាហ្នឹងបើនិយាយអ៊ីចឹងថា គ្មានដឹងខ្លួនទេ ទាំងប្រុសទាំងស្រី ស្រាប់តែដល់ថ្ងៃហ្នឹង គេហៅ ក្រែងទៅរៀនសូត្រ អីក៏ប្រជុំ ក៏មិនដឹងអីទេ ស្រាប់តែទៅដល់ឈ្មួម។ នេះតាមខ្ញុំដឹង។"]។ ឯកសារ D219/702.1.110 ឃិន រ៉ាត ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 09.36.48-09.39.40 [ក្នុងខេត្តកំពង់ឆ្នាំង ភូមិភាគបស្ចិម ឆ្នាំ១៩៧៧៖ "ព្រឹកនេះម៉ោងប្រាំ មិនឯងចាប់រៀបចំខ្លួនទៅ [ខេត្តកំពង់ឆ្នាំង ដើម្បីរៀបការ]។ គាត់និយាយប្រាប់ខ្ញុំអ៊ីចឹង។"]។ ឯកសារ D219/702.1.105 កង អ៊ុត ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 10.55.19-10.59.56។ ឯកសារ D219/136 កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់ ឆ.២៤, ២៦ KH 01053262។ ឯកសារ D219/323 កំណត់ហេតុស្តាប់ចម្លើយ មុត សុផុន ឆ.២៨ KH 01099668។ ឯកសារ D219/405 កំណត់ហេតុស្តាប់ចម្លើយ ឈឹន ប៊ុនសេរ៉ី ឆ.៥៨ KH 01117215។ ឯកសារ D5/1168 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ពៅ KH 01030538 [ស្រុកចំការលើ ខេត្តកំពង់ចាម តំបន់ ៤២ ភូមិភាគកណ្តាល ឆ្នាំ១៩៧៨៖ "សូម្បីតែខ្ញុំផ្ទាល់ក៏មិនបានដឹងពីការរៀបការនេះដែរ ទាល់តែដល់ថ្ងៃត្រូវឡើងប្តេជ្ញាចិត្ត ទើបខ្ញុំបានដឹង។"]។ ឯកសារ D191.1.23 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កៅ សន KH 00411877-00411878។ ឯកសារ D219/882.1.21 កាស្ទ្រីមិ ណាកាហ្ការ៉ា *ភាពជាម្តាយក្នុងសម័យសង្គ្រាម* KH 01506048 ["ស្ត្រីដែលត្រូវគេបញ្ជាឲ្យរៀបការ គឺគ្រាន់តែបានទទួលដំណឹងពីខ្មែរក្រហម ហើយបន្ទាប់មកត្រូវបញ្ជាឲ្យទៅចូលរួមក្នុងពិធីមង្គលការនោះតែម្តង។ យោងតាមការសិក្សានេះ ក្នុងករណីភាគច្រើននៃអាពាហ៍ពិពាហ៍ដោយបង្ខំ ស្ត្រីត្រូវគេបញ្ជាឲ្យចូលរួមប្រជុំ ឬពិធីរៀបអាពាហ៍ពិពាហ៍នៅពេលព្រឹក ហើយបន្ទាប់មក ក៏បានរៀបការរួចនៅត្រឹមពេលត្រលប់។ ដូច្នេះ ការជួបនឹងគូអនាគតរបស់ខ្លួនដំបូង និងការរៀបមង្គលការបានកើតមានឡើងនៅថ្ងៃដដែលនោះតែម្តង។"] KH 01506049 [លោកស្រី ទូច អ្ងួន និយាយថា៖ "មង្គលការរបស់ខ្ញុំកើតមានភ្លាមៗ និងធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលណាស់។ ថ្ងៃមួយ ខ្មែរក្រហមបានហៅខ្ញុំ ហើយពួកគេបញ្ជាឲ្យខ្ញុំរៀបការ។ ពួកគេបានប្រាប់ខ្ញុំនៅថ្ងៃរៀបការនោះ។"]។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045806-01045807, 01045810-01045811។

ដោយខ្លួនគេគិតថាមកចូលរួមប្រជុំ ហើយបានត្រឡប់ទៅវិញជាមួយនឹងប្តី ឬប្រពន្ធថ្មី[2812] ដែលជាញ៉ីកញ្ជាប់គឺជាមនុស្សដែលមិនធ្លាប់ស្គាល់គ្នាទាល់តែសោះ[2813]។

[2812] ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.48.28-13.50.45 ["ពិធីរៀបការហ្នឹងគឺខុសគ្នាពីពិធីរៀបការនៅមុនខ្មែរក្រហម។ និយាយឲ្យងាយយល់ទៅ គឺថាដូចអង្គប្រជុំមួយអ៊ីចឹង។ គឺថាគេប្រមូលមនុស្សមកប្រជុំមក ហើយបុរស និងស្ត្រីហ្នឹង គេហៅមកឲ្យចូលរួមជួបជុំគ្នាប្រជុំទៅ ហ្នឹងគឺជាការរៀបការហើយ។"]។ D219/702.1.10 ជាំង ស្រីមុំ ប្រតិចារឹក ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.23.36-09.27.21 ["អ្នករៀបចំហើយ គឺដល់តែពេលថ្ងៃរៀបការ គឺ១ហៅមកគឺក៏ឥតមានបញ្ជាក់ថាថ្ងៃនេះរៀបការដែរ ដល់ទៅហើយប្រាប់ថា កម្មវិធីរៀបការ ប្រកាសឈ្មោះតែម្តង។"]។ ឯកសារ D219/888.1.1 អ៊ុំ ឃឿន ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.39.45-15.46.58។ ឯកសារ D219/888.1.7 ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.24.04-14.31.14។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃឿន ឆ.៣៤ KH 01029960។ ឯកសារ D6.1.648 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ភាន KH 00368662 [ក្នុងស្រុកអង្គរជ័យ ខេត្តកំពត ភូមិភាគនិរតី ឆ្នាំ១៩៧៥៖ "ដំបូងអង្គការបានហៅខ្ញុំថា ទៅប្រជុំ ពេលទៅដល់ គេបានរៀបចំឲ្យខ្ញុំប្តេជ្ញា។"]។ ឯកសារ D219/234.1.7 កំណត់ហេតុស្តាប់ចម្លើយ តើ រ៉ី ឆ.១១៧ KH 01069930។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារ៉ី ឆ.២៦, ២៨ KH 01045651-01045652។ ឯកសារ D219/687 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ សារ៉ឿន ឆ.៧១ KH 01203964។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ផ្ទុយខ្ពោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037053 ["អ្នកឆ្លើយសំណួរ ១៥ [១៦%] នាក់មិនបានដឹងមុនពេលពិធីរៀបការទេថា ពួកគេនឹងត្រូវរៀបការ។"]។

[2813] *សូមមើលឧទាហរណ៍* ឯកសារ D219/702.1.110 ឃិន រ៉ាត ប្រតិចារឹក ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 09.36.48-09.39.40 [ក្នុងខេត្តកំពង់ឆ្នាំង ភូមិភាគបស្ចិម ឆ្នាំ១៩៧៧៖ "គេហ្នឹងគឺឈ្មោះ ខ្ញុំអត់ទាន់ស្គាល់គាត់ទេ។ ទាល់តែថ្ងៃគេរៀបការ ពេលល្ងាចរៀបការហ្នឹង បានខ្ញុំស្គាល់គាត់ ស្គាល់ឈ្មោះគាត់។ ពេលនោះ ខ្ញុំទាំងពីរ គឺអត់ដែលឃើញគ្នាទេ។"]។ ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.54.56-13.56.31 [ក្នុងទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥៖ "មិនដែលស្គាល់ មិនដែលឃើញមុខម៉េចទេ ទល់តែថ្ងៃរៀបការហ្នឹងបានជួបគ្នាហ្នឹង មិនដែលស្គាល់ប្រវត្តិ ស្គាល់អី ត្រង់ណា ត្រង់ណីអត់បន្តិចសោះ។"]។ ឯកសារ D219/888.1.1 អ៊ុំ ឃឿន ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.41.22-15.49.10, 15.53.54-15.57.57។ ឯកសារ D219/888.1.7 ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.24.40-14.28.40 [ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "យើងអត់បានឃើញគ្នាស្គាល់គ្នាទេ។"] ម៉ោង 15.05.34-15.08.15 ["ខ្ញុំចង់ភ្លេចប្តីបាត់ទៅហើយ បានគេឲ្យជួបម្តងទៀត។ ដល់ពេលទៅជួបហ្នឹង វាភ្លេចមុខភ្លេចមាត់អស់ ដល់អ៊ីចឹងទៅគេសួរថា អ្ហ! គ្រួសារមកហើយ ប៉ុន្តែវាមិនចាំថាមុខហ្នឹងជាគ្រួសាររបស់ខ្ញុំ។"]។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃឿន ឆ.៣៤ KH 01029960។ ឯកសារ D219/511.1.2 កំណត់ហេតុស្តាប់ចម្លើយ ឈូក រ៉ីន ឆ.៧១ KH 01110670។ ឯកសារ D118/304 កំណត់ហេតុស្តាប់ចម្លើយ ផុស ឈាន ឆ.៥៦ KH 01024592។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារ៉ី ឆ.២៧ KH 01045652។ ឯកសារ D219/323 កំណត់ហេតុស្តាប់ចម្លើយ មុត សុផុន ឆ.២៨ KH 01099668។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន យ៉ីម ឆ.៨ KH 01039251។ ឯកសារ D219/582 កំណត់ហេតុស្តាប់ចម្លើយ តូយ ម៉ៀច ឆ.១១៣ KH 01166942។ ឯកសារ D219/405 កំណត់ហេតុស្តាប់ចម្លើយ ឈីន ប៊ុនសេរ៉ី

776. នៅក្នុងសេណារីយ៉ូទីពីរដែលមិនសូវអនុវត្តគឺថា បុរស ជាពិសេសទាហាន កម្មាភិបាលខ្មែរក្រហម ឬបុគ្គលផ្សេងៗទៀត ដែលទទួលការគាំទ្រពីជនណាម្នាក់ ក្នុងជួរគណៈកម្មាធិការបានស្នើទៅកម្មាភិបាលមូលដ្ឋានសុំការអនុញ្ញាតរៀបការជាមួយស្ត្រីណាម្នាក់[2814]។ ប៉ុន្តែ អ្នកដែលស្នើសុំរៀបអាពាហ៍ពិពាហ៍ចាំបាច់ត្រូវរង់ចាំការអនុញ្ញាតពីរដ្ឋ ហើយសំណើជាច្រើនត្រូវបានច្រានចោល ទោះបីសំណើនេះត្រូវធ្វើឡើង តាមបំណងប្រាថ្នារបស់បុរស ឬស្ត្រី ឬរបស់បុរស និងស្ត្រីក៏ដោយ[2815] ។

ឆ.៥៣-៥៤ KH 01117215។ ឯកសារ D219/47 កំណត់ហេតុស្តាប់ចម្លើយ ខូវ ណេត ឆ.១៨, ២៣ KH 01032245-01032246 ។ ឯកសារ D5/1168 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ពៅ KH01030538 [ក្នុងស្រុកចំការលើ ខេត្តកំពង់ចាម តំបន់ ៤២ ភូមិភាគកណ្តាល ឆ្នាំ១៩៧៨៖ "ពួកយើងមិនដែលបានស្គាល់គ្នា ហើយមិនដែលស្រឡាញ់គ្នាដែរ តែយើងគ្មានសិទ្ធិជំទាស់ចំពោះការរៀបចំរបស់អង្គការទេ។"]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដួចខ្ចោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037041។ ឯកសារ D219/882.1.21 កាស៊ូមិ ណាកាហ្ការ៉ា *ភាពជាម្តាយក្នុងសម័យសង្គ្រាម* KH 01506050-01506053។ ឯកសារ D310/1.1.11R វីដេអូ *អាពាហ៍ពិពាហ៍ក្រហម* ឆ្នាំ២០១១ ម៉ោង 7:49-8:13 [ប៉ែន សុចាន់ ត្រូវបានបង្ខំឲ្យរៀបការក្នុងភូមិដើមរកា ឃុំថ្នល់ទទឹង ស្រុកបាកាន ខេត្តពោធិ៍សាត់ ក្នុងឆ្នាំ១៩៧៨ (*សូមមើល* ឯកសារ D5/1338 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី EN 01049449-01049450)៖ "យើងមិនស្គាល់គ្នាទេ។ ខ្ញុំមិនដឹងថាគាត់រស់នៅឯណា។ ខ្ញុំមិនដឹងថា គាត់មកពីណាទេ។"]។

[2814] ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃូ ភ្ជុ ឆ.១៤៦ KH 01117236 [សាក្សីជាយោធាឃុំម្នាក់ ក្នុងឃុំគោកព្រិច ស្រុកគិរីវង់ ខេត្តតាកែវ ភូមិភាគនិរតី ចាប់ពីឆ្នាំ១៩៧៧៖ "ការរៀបការមានពីរ គឺវាមានសេចក្តីស្នើ និងការចាត់តាំង។"]។ D219/234.1.7 កំណត់ហេតុស្តាប់ចម្លើយ តើ រ៉ ឆ.៩៧, ១០៧-១១៤ KH 01069928-01069930។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដួចខ្ចោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037033 ["ការសម្គាសករណីសិក្សាបញ្ជាក់ថា បុរសជាច្រើនមានឱកាសស្នើសុំគូស្រករក្នុងសម័យខ្មែរក្រហម ចំណុចនេះត្រូវបានរាយការណ៍នៅក្នុងចម្លើយតបពាក់កណ្តាល"]។ ឯកសារ D310/1.1.6 កាស៊ូមិ ណាកាហ្ការ៉ា *អំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម* KH 00738349-00738350 ["មានតែករណីមួយចំនួនប៉ុណ្ណោះ ដែលត្រូវបានរាយការណ៍ថា កងទ័ពខ្មែរក្រហម/មន្ត្រីខ្មែរក្រហម ត្រូវបានផ្តល់អាទិភាព ដើម្បីជ្រើសរើសប្រពន្ធ [...] អង្គការបានផ្តល់នូវរង្វាន់ពិសេសចំពោះកងទ័ព[ពិការ]ទាំងនោះ៖ ជ្រើសរើសនារីម្នាក់ដែលពួកគេចង់រៀបការជាមួយ។"]។ ឯកសារ D219/882.1.24 Peggy Levine *ការសិក្សាលើបរិបទអំពីវិធីរៀបអាពាហ៍ពិពាហ៍ និងការចាប់កំណើតក្រោមរបបខ្មែរក្រហម៖ បដិវត្តន៍ទំនៀមទម្លាប់* EN 00482531 ["យោងលើចម្លើយតបរបស់កងទ័ព ប្រសិនបើកងទ័ពមានទំនាក់ទំនងមុនរួចហើយជាមួយនឹងអ្នកមូលដ្ឋាន ប្រជាជនថ្មី ឬចាប់អារម្មណ៍លើអ្នកណាម្នាក់ គាត់ត្រូវធ្វើសំណើទៅថ្នាក់លើ ដែលជាទូទៅសំណើនេះត្រូវបានយល់ព្រម។"]។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045839-01045840។

[2815] ឯកសារ D5/1704/3 ឃស ផល ប្រតិចារឹក ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ម៉ោង 15.36.40-15.40.23 [ក្នុងស្រុកទ្រាំង ខេត្តតាកែវ ភូមិភាគនិរតី៖ "ប្រធានកងគេប្រាប់ថា [...] អង្គការមិនឲ្យរៀបការទេ អ្នកឯងស្រឡាញ់គ្នា[គ្រូដណ្តឹងមុនរបបខ្មែរក្រហម] យ៉ាងក៏ដោយ។ ត្រូវតែធ្វើជាកូនអង្គការ ឲ្យអង្គការរៀបចំឲ្យ។"]។ ឯកសារ D5/1166/3.1 អ៊ុំ ឃឿន ប្រតិចារឹក ចុះថ្ងៃទី

ពិធីរៀបអាពាហ៍ពិពាហ៍

777. ចំពោះពិធីរៀបអាពាហ៍ពិពាហ៍ផ្ទាល់ ទំនៀមទម្លាប់ប្រពៃណី និងពិធីសាសនាដ៏ពិសិដ្ឋដែលបានបង្កើតឡើងដើម្បីរៀបចំ អបអរសាទរ និងជូនពរចំណងអាពាហ៍ពិពាហ៍នៃគ្រួសារទាំងពីរ ត្រូវបានលុបបំបាត់[2816]។ សមាជិកគ្រួសារទាំងពីរជាទូទៅមិនត្រូវបានអនុញ្ញាតឲ្យពាក់ព័ន្ធ ឬក៏ចូលរួមក្នុង

---

២៣ ខែសីហា ឆ្នាំ២០១៦ ម៉ោង 09.06.45-09.08.11 [ក្នុងស្រុកចំការលើ ខេត្តកំពង់ចាម តំបន់ ៤២ ភូមិភាគកណ្តាល ក្នុងចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨៖ "មុន១ថ្ងៃដំបូង ខ្ញុំបានទទួលដំណឹងថា ដែលគេអាចទំនាក់ទំនងពីខ្ញុំម្នាក់ហ្នឹងថា ពេលគេរៀបការ គេស្នើឲ្យរៀបការ។ [...] គាត់ឈ្មោះពីជំនាន់ទុង គេហៅ អ៊ំផន១ ដល់តែពេលគាត់ទៅលេងនឹងនាងខ្ញុំអ៊ីចឹងទៅ គាត់សួរសុខទុកអ៊ីចឹងទៅ គាត់អាចស្នើទៅ ដល់តែពេល១មករៀបការមិនមែនឈ្មោះ អ៊ំផន ហ្នឹងទេ។ អ្នកផ្សេងទេ។"]។ ឯកសារ D219/488 កំណត់ហេតុស្តាប់ចម្លើយ ម៉ឹង រ៉ែត ឆ.១៦៤-១៦៥ KH 01136729 [សាក្សីគឺជាកងទ័ពក្នុងតំបន់ ៥០៥ ខេត្តក្រចេះ ឆ្នាំ១៩៧៧-១៩៧៨៖ "ចំណែកខាងបុរស ពេលខ្លះស្នើរៀបការជាមួយនារី "ក" តែដល់ពេលរៀបការត្រូវរៀបការជាមួយនារី "ឃ" ក៏មានដែរ។ មានករណីខ្លះ ពេលគេហៅឈ្មោះឡើងមកឈរមិនត្រូវជួរគ្នា ត្រូវចាប់ដៃជាមួយអ្នកផ្សេងវិញក៏មាន។ ហើយគូទាំងនោះ មិនអាចប្រកែកបានឡើយ។ [...] ខ្ញុំមិនដែលឃើញមាននរណាគេហ៊ានប្រកែកទេ ព្រោះពួកគេគោរពតាមគោលការណ៍បក្ស។"]។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.៨០, ៨៥ KH 01045659-01045660។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃៀន ឆ.៣៤ KH 01029960។ ឯកសារ D310/1.1.5 Katrina Natale *"ខ្ញុំដឹងថាព្រលឹងខ្ញុំចេញពីខ្លួន"៖ ការសិក្សាអំពីអំពើហិង្សាផ្លូវភេទក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងខេត្តបាត់ដំបង និងខេត្តស្វាយរៀង* EN 00992156 [អ្នកឆ្លើយតបជាស្ត្រីម្នាក់ទៀតនៅខេត្តស្វាយរៀង បានរាយការណ៍ថា ទោះជាកម្មាភិបាលខ្មែរក្រហមស្នើសុំកូនក្រមុំណាមួយ សំណើទាំងនេះមិនមែនទទួលបានយល់ព្រមរហូតនោះទេ។"]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្មោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037065។

[2816] ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.48.28-13.50.45 ["ស៖ តើមានពិធីសាសនាដូចជាព្រះពុទ្ធសាសនា ពិធីសាសនាអ្វីមួយ រួមទាំងព្រះពុទ្ធសាសនាផងដែរ ដូចនៅសម័យមុនកម្ពុជាប្រជាធិបតេយ្យនោះទេ? ឆ៖ ខ្មែរក្រហមលុបបំបាត់សាសនាហើយ អ៊ីចឹងមិនមានពិធីសាសនាអ្វីទាំងអស់ មិនមានលោកសង្ឆអ្វីនៅក្នុងពិធីរៀបការនេះទេ។"]។ ឯកសារ D5/1334/3 ជា ម៉ៀប ប្រតិចារឹក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 14.14.40-14.16.14 ["ដែលពេលរៀបការហ្នឹង ដូចខ្ញុំបាននិយាយអ៊ីចឹង ថាគ្មានផ្ទឹម គ្មានអីបាចផ្ការ៉ាអីទេ។ មានគ្រាន់តែហៅទៅ ហៅឈ្មោះដាក់គូណា១អ៊ីចឹងទៅ បញ្ជូលតាមគូទៅ ហើយអង្គការណែនាំបន្តិចបន្តួចអ៊ីចឹងទៅ ក៏គោរពទង់បក្សអ៊ីចឹងទៅ គឺរួចជាស្រេចទៅហើយ។ ហើយឡើងប្តេជ្ញាចិត្តគោរពទង់បក្សអ៊ីចឹងទៅ។ ធ្វើមិនបានមួយម៉ោងផងហ្នឹង។"]។ ឯកសារ D219/702.1.105 កង អ៊ីត ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 11.06.29-11.14.24។ ឯកសារ D219/702.1.106 មាស ឡៃហ្ស ប្រតិចារឹក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.21.10-15.23.42។ ឯកសារ D219/888.1.1 អ៊ុំ ឃៀន ប្រតិចារឹក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.49.10-15.55.58។ ឯកសារ D347/2.1.38 ម៉ុំ រ៉ុន ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.21.29-14.24.37, 14.24.37-14.29.12។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ីក ហ៊ីម ឆ.៣៤ KH 01000021 [ក្នុងខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៥៖ "ពេលដែលគេបង្ខំឲ្យខ្ញុំរៀបការជាមួយនឹងប្តីក្រោយនេះ ខ្ញុំនិយាយថា ឲ្យខ្ញុំទៅទៅរៀបការ និងរស់នៅជាមួយគ្នាដូចម្តេច បើពុំមានខាន់ស្លាអ្វីតាមប្រពៃណីផង ខ្ញុំខ្ជាចចាស់ទុំកាច់។"]។ ឯកសារ D267.1.126 កំណត់ហេតុស្តាប់

ចម្លើយ ព្រំ កែម ឆ.៣ KH 01023172។ ឯកសារ D219/293 កំណត់ហេតុស្តាប់ចម្លើយ ជាម ពៅ ឆ.៣៨-៣៩ KH 01095229 ។ ឯកសារ D219/99 កំណត់ហេតុស្តាប់ចម្លើយ ខ៏ត សុខន ឆ.៨៣ KH 01043278។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃៀន ឆ.១៣ KH 01029954-01029955។ ឯកសារ D219/159 កំណត់ហេតុស្តាប់ចម្លើយ នី ហ្ជន ឆ.១១៨ KH 01059365។ ឯកសារ D219/882.1.21 កាស៊ូមិ ណាកាហ្ការ៉ា *ភាពជាម្តាយក្នុងសម័យសង្គ្រាម* KH 01506055 [“ពិធីអាពាហ៍ពិពាហ៍ភាគច្រើនក្នុងរបបខ្មែរក្រហម គឺដូចជាការប្រជុំ ដែលរៀបចំឡើងដោយថ្នាក់ដឹកនាំខ្មែរក្រហម ឬប្រធានភូមិដូចនោះដែរ។ ភាគស្រដៀងគ្នា ត្រូវគេមើលឃើញដោយមិនគិតពីទីតាំងនៃការរៀបអាពាហ៍ពិពាហ៍។ ភាគច្រើនគ្មានអាហារពិសេស គ្មានតន្ត្រី និងគ្មានសមាជិកគ្រួសារមកចូលរួមទេ។”]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្ទោចប្រៃកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037033, 01037041។ ឯកសារ D219/882.1.24 Peggy Levine *ការសិក្សាបរិបទអំពីវិធីរៀបអាពាហ៍ពិពាហ៍ និងការចាប់កំណើតក្រោមរបបខ្មែរក្រហម៖ បដិវត្តន៍ទំនៀមទម្លាប់* EN 00482478, 00482491-00482492។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045811-01045814។

ពិធីរៀបអាពាហ៍ពិពាហ៍ឡើយ[2817]។ កម្មាភិបាល និងកងឈ្លបជាអ្នកជំនួសសមាជិកគ្រួសាររបស់កូនកំលោះ កូនក្រមុំ[2818] ក្នុងពេលដែលកម្មាភិបាល ប.ក.ក ពីគ្រប់ស្រទាប់ទាំងអស់រៀបចំ និងធ្វើជាអធិបតីក្នុងពិធីរៀបអាពាហ៍ពិពាហ៍[2819]។

[2817] ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.48.28-13.50.45 ["អត់មានភ្ញៀវមកពីខាងគ្រួសារទាំងសងខាង អត់មានភ្ញៀវដែលជាមិត្តភក្តិ ជាអ្វីនោះទេ។ គឺមានវត្តមានតែគូស្រករ ដែលត្រូវរៀបការនេះទេ ដោយសារថា វាមាន ជាពិធីរៀបការរួម។"]។ ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារឹក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.59.01-14.02.33។ ឯកសារ D219/888.1.7 ព្រាប សុឃឿន ប្រតិចារឹក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.26.32-14.31.14 [ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិភាគកណ្ដាល ឆ្នាំ១៩៧៧៖ "គិតតែយំ សោលសង្រេង ស្ដាយខ្លួន ស្ដាយម៉ែឪដែលគាត់អត់បានដឹង [...] កាលការនុំង ញាតិសន្ដាន ម៉ែឪមិនបានចូលរួមទេ។"]។ ឯកសារ D219/888.1.1 អ៊ុំ យឿន ប្រតិចារឹក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.49.10-15.53.54។ ឯកសារ D5/1166/3.1 អ៊ុំ យឿន ប្រតិចារឹក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ម៉ោង 10.59.49-11.03.00។ ឯកសារ D219/702.1.105 កង អ៊ិត ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 11.06.29-11.14.24។ ឯកសារ D219/702.1.96 ឱ ហូ ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 14.34.50-14.41.47។ ឯកសារ D219/24 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប សុឃឿន ឆ.២២ KH 01029957។ ឯកសារ D219/136 កំណត់ហេតុស្ដាប់ចម្លើយ ថន យ៉ង់ ឆ.៣២ KH 01053263។ ឯកសារ D219/83 កំណត់ហេតុស្ដាប់ចម្លើយ សួន យឹម ឆ.១២ KH 01039252។ ឯកសារ D219/47 កំណត់ហេតុស្ដាប់ចម្លើយ ខូវ ណេត ឆ.១៧ KH 01032244-01032245។ ឯកសារ D219/234.1.7 កំណត់ហេតុស្ដាប់ចម្លើយ តើ វី ឆ.១១៨ KH 01069930។ ឯកសារ D219/55 កំណត់ហេតុស្ដាប់ចម្លើយ ហោ យ៉ន ឆ.៣៨ KH 01034068។ ឯកសារ D5/1168 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី អោម ពៅ KH 01030538-39។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្មោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037041 ["សមាជិកគ្រួសារទាំងអស់មិនត្រូវបានអនុញ្ញាតឲ្យចូលរួមពិធីរៀបការទេ។"]។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045811 ["ក្នុងគ្រប់ករណីរៀបការទាំងអស់ មិនមានគ្រួសារចូលរួមឡើយ ឬគ្រាន់តែមានអាហារធម្មតាប៉ុណ្ណោះ។ អ្នកផ្ដល់បទសម្ភាសន៍ជាច្រើនមានការអាក់អន់ចិត្តជាខ្លាំង។"]។ ឯកសារ D219/882.1.21 កាស៊ូមិ ណាកាហ្គាវ៉ា *ភាពជាម្ដាយក្នុងសម័យសង្គ្រាម* KH 01506053 ["ពិធីរៀបអាពាហ៍ពិពាហ៍ស្ទើតែទាំងអស់ ត្រូវបានរៀបចំដោយខ្មែរក្រហម។ ឪពុកម្ដាយ និងសាច់ញាតិមិនត្រូវបានអនុញ្ញាតឲ្យចូលរួមឡើយ។"]។ ឯកសារ D310/1.1.4 Bridgette Toy-Cronin *"ខ្ញុំចង់និយាយប្រាប់អ្នក"* KH 00721380-00721381 [អង្គការមិនបានជូនដំណឹង ឬក៏អញ្ជើញគ្រួសាររបស់អ្នកត្រូវរៀបការឡើយ]។

[2818] ឯកសារ D347/2.1.38 មុំ វុន ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.38.10-13.40.35 [នៅឯពិធីរៀបអាពាហ៍ពិពាហ៍របស់នាង ក្នុងខេត្តសៀមរាប ចុងឆ្នាំ១៩៧៥៖ "ជាគណៈអធិបតី គឺមានកម្មាភិបាល មានមិត្តរ៉ុម មិត្តសន មិត្តស៊ាប៊ី ខុសពីនោះ សុទ្ធតែក្រុមកងការពារកេទាំងអស់។ ពួកមិត្តៗ គេនៅអង្គុយនៅទីនោះទាំងអស់គ្នា។ ហើយខុសពីនោះគឺសុទ្ធតែគូដែលរៀបការនោះឯង ៦០គូ មានតែប៉ុណ្ណឹងទេ អត់មានម៉ែមានឪអីទៅចូលរួមទេ។"]។ ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារឹក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.54.56-13.56.31 [ក្នុងទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥៖ "ម្ដាយឪពុក បងប្អូនរបស់ខ្ញុំ អត់បានចូលរួមទេ។ មានតែអង្គការទេ ដែលចូលរួម។"]។ ឯកសារ D219/702.1.87 យូ វ៉ាន់ ប្រតិចារឹក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦

ម៉ោង 15.32.19-15.35.15 [ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ភូមិភាគកណ្តាល៖ "ភូមិណាដែលមានគូស្វាមីយកមករៀបទៅ ភូមិនោះនាំគ្នាមកៗ ក៏ [លេខាស្រុក] ប្រាក់ ឃុត ហ្នឹងរៀបឲ្យទៅ។"]។ ឯកសារ D219/888.1.7 ព្រាប សុឃៀន ប្រតិចារឹក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.24.04-14.28.40, 15.41.47-15.44.01។ ឯកសារ D219/702.1.96 ឌ ហ្ស ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 14.34.50-14.41.47។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ស ភ្ជ ឆ.៦៣-៦៤ KH 01117228។ ឯកសារ D219/687 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ សារ៉ៀន ឆ.៨៥ KH 01203966។ ឯកសារ D219/405 កំណត់ហេតុស្តាប់ចម្លើយ ឈឹន ប៊ុនសេរ៉ី ឆ.៦១ KH 01117216។ ឯកសារ D219/136 កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់ ឆ.៣០ KH 01053263។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.២៨ KH 01045652។ ឯកសារ D219/47 កំណត់ហេតុស្តាប់ចម្លើយ ខ្ចូ ណេត ឆ.១៦ KH 01032244។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045811-01045812 ["ជាញឹកញាប់ កម្មាភិបាលចូលរួមក្នុងការរៀបការ និងពេលខ្លះមានកម្មាភិបាលច្រើននាក់ចូលរួម។"]។

[2819] ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដួចខ្ពោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037064 ["នីតិវិធីមង្គលការទាំងអស់ត្រូវបានរៀបចំ និងមានការចូលរួមជាអធិបតីភាពដោយភ្នាក់ងារសំខាន់ៗរបស់ពួកខ្មែរក្រហមនៅគ្រប់ជាន់ថ្នាក់ រួមទាំងថ្នាក់ដឹកនាំផងដែរ។"]។ <u>មជ្ឈិមបក្ស ក្រសួង និងអាជ្ញាធរកម្មិតភូមិភាគ</u>៖ ឯកសារ D219/702.1.5 ខៀ រ នៅ ប្រតិចារឹក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 14.01.20-14.05.27 [សាក្សីគឺក្ជយប្រុសតាម៉ុក ដែលបានរៀបការនៅខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៧៖ "តាម៉ុក គាត់ផ្ទុំដាក់តែម្តង។"]។ ឯកសារ D219/268 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៦៩ KH 01088844 [នៅឯពិធីរៀបការដោយបង្ខំនៅក្នុងខេត្តបាត់ដំបង ភូមិភាគបស្ចិម៖ "គឺតាម៉ុក គឺគាត់រៀបឲ្យកូនចៅគាត់ ពួកនិរតីដឹកកូនចៅគាត់ទៅរៀបការនៅបាត់ដំបង ដើម្បីរៀបការនៅទីនោះ។"]។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ មួល អេង ឆ.២០ KH 01095239 [ក្នុងខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៨៖ "តាម៉ុករៀបចំរៀបការនៅខេត្តតាកែវ។"]។ ឯកសារ D219/504 កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.៣៣ KH 01146375 [សាក្សីធ្វើការនៅឯមន្ទីរតំបន់ពាណិជ្ជកម្ម និងត្រូវបានបង្ខំឲ្យរៀបការក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៨៖ "ខ្ញុំបានឃើញ [តាពក]ពីរដង។ ម្តងក្នុងកិច្ចប្រជុំ ហើយម្តងទៀត នៅក្នុងពិធីរៀបការរបស់ខ្ញុំ។"] ឆ.១៤០ KH 01146394 ["ស៖ លោកបានលើកឡើងថា កែ ពក មកធ្វើជាអធិបតីក្នុងពិធីរៀបការរបស់លោក។ តើពេលនោះ គាត់និយាយអ្វីខ្លះ? ឆ.១៤០៖ គាត់ប្រាប់យើងឲ្យចេះស្រឡាញ់គ្នា និងរស់នៅដោយផ្ទៃកសាមគ្គីគ្នា។"] (*សម្គាល់* ថា កែ ពក ជាលេខាភូមិភាគកណ្តាលនៅពេលនោះ។ *សូមមើលឧទាហរណ៍* ឯកសារ D117/66 កំណត់ហេតុស្តាប់ចម្លើយ អ៊ីន គឹមអេង ឆ.១-២ KH 01023132 [នៅដើមឆ្នាំ១៩៧៧៖ "ខ្ញុំជាយោធារបស់ភូមិភាគ ហើយកងអនុសេនាធំរបស់ខ្ញុំប្រចាំការនៅភ្នំប្រុស។ [...] កែ ពក ជាលេខាភូមិភាគ ហើយគាត់ក៏ក្តាប់យោធាភូមិភាគផងដែរ។"])។ ឯកសារ D219/315 កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.៦២ KH 01097739។ ឯកសារ D219/454 កំណត់ហេតុស្តាប់ចម្លើយ ជុំ នៅ ឆ.៤ KH 01129784។ ឯកសារ D123/1/2.7a កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង ម៉ា ឈឿន KH 00926329 [ក្នុងខេត្តកំពង់សោម ប្រហែលអំឡុងឆ្នាំ១៩៧៧-១៩៧៨៖ "ស៖ កាលហ្នឹងមានពីណាគេណែនាំ មានមតិណែនាំឲ្យការ? ឆ៖ (ដោយឈ្មោះ ភាត, ប្រពន្ធរបស់ ឈឿន)៖ តាមុត។"]។ <u>អាជ្ញាធរកម្មិតស្រុក និងតំបន់</u>៖ ឯកសារ D219/702.1.95 ប្រាក់ ឃុត ប្រតិចារឹក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ម៉ោង 13.37.40-13.41.13 [សាក្សីគឺជាលេខាស្រុកកំពង់សៀម ហើយនិងជាសមាជិកគណៈតំបន់ ៤១៖ "ស៖ [...] តើត្រឹមត្រូវដែរទេ ដែលថា តាអាន នឹងធ្វើជាអធិបតីភាព បើសិនណាជាមានការៀបការពីប្រាំ ទៅ១០គូ? ឆ.[...] ខ្ញុំក៏ទទួលស្គាល់ ហើយពួអាន គាត់បានចូលរួម។

778. គូស្វាមីភរិយាត្រូវបានផ្សំផ្គុំគ្នា *ក្នុងចំនួនច្រើនគូ* ក្នុងពិធីចាប់ដៃគ្នាដ៏តឹងរ៉ឹងដែលពិធីទាំងនោះមានលក្ខណៈជាកិច្ចប្រជុំ មិនដូចជាព្រឹត្តិការណ៍ចាំបាច់ក្នុងជីវិតទេ[2820]។ ពិធីទាំងនេះត្រូវបានធ្វើឡើងជា

អ៊ីចឹង ខ្ញុំទទួលស្គាល់ទាំងពីរហ្នឹង គឺថានាងខ្ញុំជាអាង គឺចូលរួមក្នុងការរៀបចំអាពាហ៍ពិពាហ៍ឲ្យចាមនេះ ចំនួន ១០គូហ្នឹង គឺខ្ញុំទទួលថាខ្ញុំធ្វើទៅចុះ។"]។ ឯកសារ D219/702.1.87 ឃូ រ៉ាន់ ប្រតិចារឹក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ម៉ោង 15.32.19-15.35.15 [សាក្សីធ្វើជានីរសាររបស់ ប្រាក់ ឃុត ដែលជាលេខាស្រុកកំពស់សៀម និងក្រោយមកធ្វើជាគណៈឃុំរអាង៖ "ស៖ [...] កាលណាគេយល់ព្រមឲ្យរៀបការ ចាតើអ្នកណាជាអ្នកធ្វើអធិបតីនៅក្នុងពិធីរៀបការទាំងនោះ? ឆ៖ គឺ ប្រាក់ ឃុត ហើយនិងប្រធានភូមិ។ ភូមិណាដែលមានគូស្វាមីយកមករៀបទៅ។ [...] កាលណាតិចតួចទៅ គាត់[តារអាន]មិនបានទៅទេ គាត់រវល់។ គាត់មិនបានទៅទេ ឲ្យ ប្រាក់ ឃុត ហ្នឹងរៀបទៅ។"]។ ឯកសារ D219/138 កំណត់ហេតុស្តាប់ចម្លើយ ឃូ រ៉ាន់ ឆ.៣១ KH 01056045។ ឯកសារ D219/435 កំណត់ហេតុស្តាប់ចម្លើយ ទូច ចំរើន ឆ.៣៩-៤០ KH 01124166។ ឯកសារ D219/582 កំណត់ហេតុស្តាប់ចម្លើយ តូយ ម៉ៀច ឆ.១១៦-១២៦ KH 01166943។ ឯកសារ D219/837 កំណត់ហេតុស្តាប់ចម្លើយ ស្ង សារ៉ែន ឆ.១៣១ KH 01335590 (*កត់សម្គាល់* ថា បងអ្នន ជាប្រធានមន្ទីរតំបន់ ៤១។ *សូមមើលឧទាហរណ៍* ឯកសារ D219/776.1.1 កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង ស្ង សារ៉ែន KH 01249865 ["ហើយប្រធានតំបន់ហ្នឹងឈ្មោះ បងអ្នន។ [...] ហើយបន្ទាប់មានឈ្មោះ អ្នន ហ្នឹងទទួលបន្ទុកខាងមន្ទីរ។"])។ ឯកសារ D219/762 កំណត់ហេតុស្តាប់ចម្លើយ សារ៉ាយ ហៀន ឆ.១២៩ KH 01242633។ ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ ត៉ីម ផល ឆ.៧១ KH 01133421។ ឯកសារ D219/191 កំណត់ហេតុស្តាប់ចម្លើយ កែវ រ៉ៀន ឆ.១០-១១ KH 01068072។ ឯកសារ D117/42 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម នារី ឆ.១៦ KH 00987136។ ឯកសារ D219/323 កំណត់ហេតុស្តាប់ចម្លើយ មុត សុផុន ឆ.២៨ KH 01099668។ ឯកសារ D5/678 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថន យ៉ង់ KH 00911634។ <u>អាជ្ញាធរកម្រិតឃុំ និងសហការណ៍</u>៖ ឯកសារ D219/323 កំណត់ហេតុស្តាប់ចម្លើយ មុត សុផុន ឆ.២៨ KH 01099668 [ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៧ ៖ "[លេខាស្រុក] យាយឃុត ផ្ទាប់ឲ្យគណៈឃុំរកប្រពន្ធឲ្យខ្ញុំ។"]។ ឯកសារ D219/138 កំណត់ហេតុស្តាប់ចម្លើយ ឃូ រ៉ាន់ ឆ.២ KH 01056។ ឯកសារ D117/42 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម នារី ឆ.១៦ KH 00987136។ ឯកសារ D219/171 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល ហៅ សាយ ឆ.៣៥-៣៧ KH 01065953-01065954។ ឯកសារ D219/405 កំណត់ហេតុស្តាប់ចម្លើយ ឈឹន ប៊ុនសេរ៉ី ឆ.៥២, ៥៨ KH 01117214-01117215។ ឯកសារ D219/609 កំណត់ហេតុស្តាប់ចម្លើយ សំ រិទ្ធ អន ឆ.៤១ KH 01175127។ ឯកសារ D5/1168 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អោម ពៅ KH 01030538-39។ ឯកសារ D5/1498 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី កាក់ ហ៊ុន KH 01044361។ <u>អាជ្ញាធរភូមិ និងប្រធានកងការងារ</u>៖ ឯកសារ D219/888.1.7 ព្រាប សុឃ្ឍឿន ប្រតិចារឹក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.24.04-14.28.40 [ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "ប្រធានសហជីពហ្នឹងគេអង្គុយធំខ្ពស់អ៊ីចឹងទៅ។"]។ ឯកសារ D219/702.1.105 កង អ៊ីត ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 10.54.02-10.57.48។ ឯកសារ D117/68 កំណត់ហេតុស្តាប់ចម្លើយ រ៉ាំ លឹមហ៊ីន ឆ.២៧ KH 01025626។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃ្ឍឿន ឆ.២៣, ៣៤ KH 01029957, 01029960។ ឯកសារ D219/687 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ សារ៉ឿន ឆ.៧២ KH 01203955។

[2820] ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.48.28-13.50.45 ["ពិធីរៀបការហ្នឹងគឺខុសពីពិធីរៀបការនៅមុនសម័យខ្មែរក្រហម។ និយាយឲ្យងាយយល់ទៅ គឺថាដូចអង្គប្រជុំមួយអ៊ីចឹង។"]។ ឯកសារ D347/2.1.38 ម៉ុ រ៉ុន ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.21.29-14.24.37 [ខ០គូ ខេត្តសៀមរាប នៅចុងឆ្នាំ

១៩៧៥]។ ឯកសារ D219/888.1.7 ព្រាប សុឃឿន ប្រតិចារ៉ីក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.45.18-15.47.01 [១៥ គ្ង ស្រុកព្រៃឈរ ឆ្នាំ១៩៧៧]។ ឯកសារ D219/888.1.1 អ៊ុំ ឃឿន ប្រតិចារ៉ីក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.49.10-15.53.54 [១២ គ្ង ស្រុកចំការលើ ចុងឆ្នាំ១៩៧៨]។ ឯកសារ D219/702.1.105 កង អ៊ុត ប្រតិចារ៉ីក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 10.54.02-10.57.48 [២៥ គ្ង ទំនប់ ១មករា ឆ្នាំ១៩៧៧]។ ឯកសារ D219/702.1.96 ឱ ហ្ង ប្រតិចារ៉ីក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 13.52.35-13.54.20 [សាក្សីគឺជាមេភូមិព្រៃស្រែងៃ ស្រុកបារាយ ខេត្តកំពង់ធំ ភូមិភាគកណ្តាល ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨ ហើយបានបញ្ជាក់ថា គាត់បានរៀបចំការរៀបការម្តងពី ៣០ ទៅ ៤០គ្ង]។ ឯកសារ D6.1.688 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ផៀន KH 00368611 [ក្នុងខេត្តតាកែវ ភូមិភាគនិរតី៖ ពិធីរៀបការត្រូវបាន "ធ្វើឡើងដូចជាពិធីប្រជុំមួយ។"]។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន ឆ.៣៨ KH 01034068។ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាវៀន ឆ.១៧ KH 01213312។ ឯកសារ D6.1.410 កំណត់ហេតុស្តាប់ចម្លើយ មាស ឡៃហ្ង KH 00239931-00239932 ["... ឱកាស"]។ ឯកសារ D219/323 កំណត់ហេតុស្តាប់ចម្លើយ មុត សុផុន ឆ.២៨ KH 01099668 [៦៥ គ្ង ស្រុកកំពង់សៀម ខែ មេសា ឆ្នាំ១៩៧៧]។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.២០ KH 01045650 [៥៧ គ្ង ស្រុកកំពង់សៀម ឆ្នាំ១៩៧៧]។ ឯកសារ D117/42 កំណត់ហេតុស្តាប់ចម្លើយ ខឹម នារី ឆ.១៦ KH 00987136 [៧២គ្ង ស្រុកកំពង់សៀម ឆ្នាំ១៩៧៨]។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃឿន ឆ.៣២ KH 01029959-01029960។ ឯកសារ D219/234.1.7 កំណត់ហេតុស្តាប់ចម្លើយ តើ រ៉ី ឆ.៨៧ KH 01069927 [១៧ គ្ង ប៊ីងស្រី កំពង់សោម ឆ្នាំ១៩៧៥]។ ឯកសារ D267.1.126 កំណត់ហេតុស្តាប់ចម្លើយ ព្រ ំ កែម ឆ.៣ KH 01023172-01023173 [កំពង់សោម (មិនបានបញ្ជាក់ពេលវេលាច្បាស់លាស់ "ឆ.៣៖ ក្នុងជំនាន់នោះ")៖ "រៀបការជាក្រុម ឬការជាសហករណ៍ប៉ុណ្ណោះ ដែលជួនកាលមាន ១០ គ្ង និងជួនកាល ១៥គ្ង។"]។ ឯកសារ D219/136 កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់ ឆ.២៤ KH 01053262 [១៥០គ្ង ស្រុកកំពង់សៀម ៣ខែ មុនពេលវៀតណាមចូលមកដល់]។ ឯកសារ D219/171 កំណត់ហេតុស្តាប់ចម្លើយ ញ៊ឹម កុល ហៅ សាយ ឆ.៣៥ KH 01065953 [១៧គ្ង (ពាក្ងត្រូវបានបង្ខំ) ស្រុកកំពង់សៀម ចុងឆ្នាំ១៩៧៨]។ ឯកសារ D117/60 កំណត់ហេតុស្តាប់ចម្លើយ សុ ំ ប៉ែត ឆ.៣ KH 01007611 [១០គ្ង ស្រុកកំពង់សៀម ឆ្នាំ១៩៧៧]។ ឯកសារ D219/463 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ផុល ឆ.២៣ KH 01130707 [ពិធីអាពាហ៍ពិពាហ៍ចំនួនពីរ គឺ ២គ្ង និង ៦០គ្ង ក្នុងស្រុកកំពង់សៀម នៅជិតចុងបញ្ចប់នៃរបបខ្មែរក្រហម ដែលគ្រប់គ្រងដោយកម្មាភិបាលនិរតី]។ ឯកសារ D219/138 កំណត់ហេតុស្តាប់ចម្លើយ ឃ្ង រ៉ាន់ ឆ.៣២-៣៣ KH 01056046 [ពិធីរៀបការចំនួនពីរនៅស្រុកព្រៃឈរ ដែល តារ៉ាន ធ្វើជាអធិបតីភាព៖ ៧គ្ង និង ១១គ្ង (អ្នកមូលដ្ឋានទាំងអស់ ពួកគេ "ស្គាល់" បានស្គាល់គ្ងស្រករបស់ពួកគេពីមុន)]។ ឯកសារ D219/502 កំណត់ហេតុស្តាប់ចម្លើយ ម្ហូក សេងលី ឆ.៣៤-៣៦ KH 01142495 [ពិធីរៀបអាពាហ៍ពិពាហ៍ចំនួនពីរ ដែលមាន២០គ្ង ក្នុងស្រុកកំពង់សៀម, បន្ទាប់ពីការមកដល់របស់កម្មាភិបាលនិរតី]។ ឯកសារ D219/405 កំណត់ហេតុស្តាប់ចម្លើយ ឈីន ប៊ុនសេរ៉ី ឆ.៥០-៥២ KH 01117214 [១២ គ្ង ស្រុកព្រៃឈរ បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីមកដល់]។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045811 ["ប្រជាជនចាប់ពីបី ឬបួនគ្ង រហូតដល់រាប់រយគ្ងមកពីគ្រប់ទីកន្លែងបានរៀបការជាមួយគ្នាក្នុងពេលតែមួយ។"]។ ឯកសារ D219/370.1.5 Henri Locard *ក្ងនសៀវភៅពណ៌ក្រហមរបស់ប៉ុល ពត* EN 00810752 [អាពាហ៍ពិពាហ៍ ត្រូវបានជំនួសដោយពិធីរៀបការ ដែលធ្វើឡើងជារួម និងសាមញ្ញជាទីបំផុត]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដួចខ្ចោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037064។

លក្ខណៈសម្ងាត់ ប្រើប្រាស់រយៈពេលខ្លី និងរៀបចំឡើង បន្ទាប់ពីបានបំពេញការងារក្នុងរយៈពេលមួយថ្ងៃពេញដើម្បីកុំឲ្យខាតម៉ោងពេលធ្វើការងារ[2821]។ ជាញឹកញាប់បំផុត គូស្វាមីភរិយាថ្មីត្រូវបានប្រកាសថាត្រូវរៀបការតាមរយៈការហៅឈ្មោះ ឬបុរស និងស្ត្រីត្រូវបានបង្គាប់ឲ្យឈរជាជួរទល់មុខគ្នា និងណែនាំឲ្យចាប់ដៃគ្នាជាមួយនឹងមនុស្សឈរទល់ខ្លួនដើម្បីកំណត់ពីការរៀបការ[2822]។ ពេលខ្លះទៀត ដោយសារតែគូស្វាមីភរិយាមានចំនួនច្រើន ពិធីត្រូវបានធ្វើឡើងយ៉ាងប្រញាប់

[2821] ឯកសារ D219/293 កំណត់ហេតុស្តាប់ចម្លើយ ជាម ពៅ ឆ.៣៥ KH 01095228-01095229 [ក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិភាគកណ្តាល បន្ទាប់ពីការមកដល់កម្មាភិបាលភូមិភាគនិរតី (*សូមមើល* ឆ.៣១)៖ "កម្មវិធីរៀបការក្នុងសម័យខ្មែរក្រហមគឺគេរៀបចំនៅប្រហែលម៉ោង ៦ល្ងាច ដើម្បីសន្សំសំចៃពេលវេលា ហើយការរៀបចំកម្មវិធីទៀតសោតមានរយៈពេលប្រហែលមួយម៉ោងប៉ុណ្ណោះ។"]។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.២៩ KH 01045652 [ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ឆ្នាំ១៩៧៧៖ "ស៖ ក្រោយពីពិធីរៀបការចប់ តើមានអ្វីកើតឡើងទៀត? ឆ.២៩៖ យើងទទួលទានបានថ្ងៃត្រង់ រួចហើយបន្តធ្វើការដល់ល្ងាច"]។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ម ភ្ន ឆ.៥៤ KH 01117227 [សាក្សីគឺជាយោធាឃុំម្នាក់ ឃុំគោលព្រិច ស្រុកគិរីវង់ ខេត្តតាកែវ ភូមិភាគនិរតី ចាប់ពីឆ្នាំ១៩៧៧៖ "[ខ្មែរក្រហម] ចង់ឲ្យការរៀបការហ្នឹង ឆាប់ព្រោះគេមានការងារច្រើនត្រូវធ្វើ គឺគេមិនចង់ខ្ជះខ្ជាយពេលវេលា និងទ្រព្យធនក្នុងការរៀបចំពិធីរៀបការ។"]។ ឯកសារ D219/55 កំណត់ហេតុស្តាប់ចម្លើយ ហេ យ៉ន ឆ.៣៨ KH 01034068 [ក្នុងស្រុកគិរីវង់ ខេត្តតាកែវ ភូមិភាគនិរតី ចន្លោះឆ្នាំ១៩៧៦ និង ១៩៧៨៖ "ភាគច្រើន គេរៀបនៅពេលយប់។"]។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045810-12។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដួចខ្ចោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037064។

[2822] ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្ការ៉ា ប្រតិចារឹក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.05.50-14.08.46 ["នៅពេលដែលគេធ្វើដំណើរទៅដល់កន្លែងរៀបការនោះ គេឲ្យអង្គុយមួយជួរ ស្រីមួយជួរ បុរសមួយជួរ។ ជាទូទៅ គឺថា បុរសដែលនៅចំ អង្គុយចំមុខនារីនោះឯង ជាប្តីដែលគេត្រូវរៀបការ។ គេរៀបចំទុកជាមុន ឬក៏គេផ្តល់លេខសម្គាល់រួចហើយ។"]។ ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារឹក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.59.01-14.2.33។ ឯកសារ D219/888.1.7 ព្រាប សុឃៀន ប្រតិចារឹក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.24.04-14.28.40។ ឯកសារ D219/47 កំណត់ហេតុស្តាប់ចម្លើយ ខូវ ណេត ឆ.១៧ KH 01032244។ ឯកសារ D219/315 កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.៤៤ KH 01097736។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.២៨ KH 01045652។ ឯកសារ D219/405 កំណត់ហេតុស្តាប់ចម្លើយ ឈឹន ប៊ុនសេរី ឆ.៥២ KH 01117214។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ ម្ហូ អេង ឆ.២០ KH 01095239។ ឯកសារ D219/454 កំណត់ហេតុស្តាប់ចម្លើយ ជុំ នៅ ឆ.៤ KH 01129784។ ឯកសារ D219/234.1.7 កំណត់ហេតុស្តាប់ចម្លើយ តើ រ៉ ឆ.៩៦ KH 01069928។ ឯកសារ D5/1337 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខូវ ណេត KH 01049433-01049434។ ឯកសារ D310/1.1.4 Bridgette Toy-Cronin *"ខ្ញុំចង់និយាយប្រាប់អ្នក"* KH 00721380-00721381។

ប្រញ្ជាល់ និងល្ងាចមានភាពងងឹតផង បុរស ឬស្ត្រីខ្លះបានវង្វេងមិនដឹងថាតើខ្លួនត្រូវបានរៀបការជាមួយនរណាម្នាក់ឡើយ[2823]។

779. គូស្វាមីភរិយាដែលបានផ្សំគ្នារួចត្រូវធ្វើ "ការប្តេជ្ញាចិត្ត" ថា (១) បម្រើអង្គការ ដោយធ្វើការសន្សាជាច្រើនដូចជា ខិតខំធ្វើការងារ ធ្វើស្រែឲ្យបានផលតាមផែនការ និងគោរពអង្គការ និង (២) ប្តេជ្ញារួមរស់ជាមួយប្រពន្ធ ឬប្តីជារៀងរហូត[2824]។ ចំពោះចំណុចទីពីរនៃការប្តេជ្ញាចិត្ត កម្មាភិបាលបាន

[2823] *សូមមើលឧទាហរណ៍* ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្ការ៉ា ប្រតិចារឹក ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.05.50-13.08.46 ["នៅពេលដែលគេធ្វើដំណើរទៅដល់កន្លែងរៀបការនោះ [...] ដូច្នេះបើមានមនុស្សច្រើន នោះគេមិនដឹងថាអ្នកណាជាប្តីនោះទេ។"]។ ឯកសារ D219/494.1.14 មាន លឿយ ប្រតិចារឹក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង 14.13.46-14.17.45 [ក្នុងភូមិថ្នល់ដាច់ ខេត្តបន្ទាយមានជ័យ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "មានអ្នកខ្លះមិនដែលស្គាល់មុខគ្នា រៀបការឃើញមុខគ្នាពេលចាប់ដៃ ដល់ពេលចេញមកវិញបាត់គ្នាក៏មានដែរ។"]។ ឯកសារ D219/494.1.3 ម៉ម សៀម ប្រតិចារឹក ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 10.00.24-10.03.19 [នៅចំនប់ត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "រហូតដល់ខ្ញុំថា ពេលរៀបការហើយ ខ្លះដល់ពេលវាអត់មានភ្លើងមានអីផង ចុះមកងងឹត គ្នាអាខ្លះមិនទាន់ស្គាល់គ្នាច្បាស់ផង ទៅច្រឡំគូគ្នាក៏មាន។"] ម៉ោង 10.06.32-10.08.40។ ឯកសារ D6.1.359 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ស្ងួ KH 00295939 [ពេលរៀបអាពាហ៍ពិពាហ៍ម្តងមានចំនួនប្រហែល ១០០គូ នៅអាងត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ ភូមិភាគពាយ័ព្យ "មានអ្នកខ្លះវង្វេងគូគ្នាដោយសារច្រើនគូពេក។"]។ D118/304 កំណត់ហេតុស្តាប់ចម្លើយ ផុស ឈាន ឆ.៥៦ KH 01024592។ ឯកសារ D310/1.1.11R វីដេអូ *អាពាហ៍ពិពាហ៍ក្រហម* ឆ្នាំ២០១១ ម៉ោង 7:49-8:13 [គីម ឈានឡាយ៖ "នៅពេលដែលគេបង្ខំអ្នកឲ្យរៀបការ តើអ្នកមិនបានឃើញមុខគ្នាទៅវិញទៅមកទេឬ?" ប៉ែន សំចាន់៖ "វាងងឹតដូចពេលហ្នឹងអ៊ីចឹង។ យើងមិនអាចឃើញគ្នាច្បាស់ទេ នៅពេលដែលចូលទៅដល់កន្លែងហូបបាយ។"។ (*កំណត់សម្គាល់* ការរៀបការ គឺនៅស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ក្នុងឆ្នាំ១៩៧៨។)]។

[2824] ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារឹក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.59.01-14.02.33 [ក្នុងទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥៖ "ដល់ពេលចូលទៅដល់អ៊ីចឹងទៅ ក៏អង្គការគេផ្តែផ្ត ដូចថាឲ្យគោរពអង្គការវិន័យអីបន្តិចបន្តួចអ៊ីចឹងទៅ ក៏គេឲ្យសាមីខ្លួនហ្នឹងប្តេជ្ញាចិត្ត១ ហើយកន្លែងប្តេជ្ញាចិត្តហ្នឹង គ្មានស្អីទេ មានតែកណ្តៀរ ហើយនិងកម្រងកួរស្រូវ កន្លែងប្តេជ្ញាហ្នឹង។ [...] អង្គការគ្រាន់តែណែនាំថា ឲ្យគោរពអង្គការវិន័យ [...] ខំប្រឹងធ្វើការងារ កសាងប្រទេសជាតិឲ្យរីកចម្រើន។"]។ ឯកសារ D347/2.1.38 ម៉ុំ រ៉ុន ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.38.10-13.40.35 [ក្នុងខេត្តសៀមរាប ភូមិភាគឧត្តរ នៅចុងឆ្នាំ១៩៧៥៖ "ចាស កម្មាភិបាលដែលគេរៀបការឲ្យទាំង ៦០គូហ្នឹង គេមានភារកិច្ចគេឡើងប្រកាសប្រាប់ថា គូស្រករដែលរៀបថ្មីជាប្តីប្រពន្ធហើយនេះ ត្រូវចេះ [...] មើលថែរក្សាគ្នា ហើយខំបង្កបង្កើនផលឲ្យបានច្រើន ដើម្បីយើងយកសេដ្ឋកិច្ចនេះ ដើម្បីកម្ទេចខ្ទាំងកុំឲ្យមានសល់ [...] ប្តីប្រពន្ធដែលរៀបហ្នឹង ឲ្យឡើងមានការចាប់អារម្មណ៍ឲ្យគេស្គាល់។"]។ ឯកសារ D219/702.1.96 ឌ ហ្ស ប្រតិចារឹក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 14.38.34-14.44.10 [សាក្សីគឺជាមេភូមិប្រៃស្រង៉ែ ស្រុកបារាយ តំបន់ ៤៣ ខេត្តកំពង់ធំ ភូមិភាគកណ្តាល ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៨៖ "គេឧទ្ទេសនាមប្រាប់ទៅ។ ប៉ុណ្ណឹងចាប់ទៅបាត់ហើយ។ តែប្តេជ្ញាចិត្តទៅ ថាខ្ញុំដើរតាមអង្គការអ៊ីចុះទៅ។"]។ ឯកសារ D267.1.1 កំណត់ហេតុស្តាប់ចម្លើយ សេង អុល ឆ.៣៤ KH 00408326។ ឯកសារ D6.1.688 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ផៀន KH 00368611-00368612។ ឯកសារ D117/60 កំណត់ហេតុស្តាប់

ណែនាំគូស្វាមីភរិយាជាប្រចាំឲ្យ "ស្រឡាញ់ទៅវិញទៅមក" ចេះយោគយល់គ្នា និង "ឲ្យមានកូនជូនអង្គការ"[2825]។ ទោះបីជាមានការប្រើប្រាស់ពាក្យពេចន៍ខុសៗគ្នាក៏ដោយ ក៏សារប្តេជ្ញាចិត្តមានភាពច្បាស់លាស់៖ គូស្វាមីភរិយាថ្មីត្រូវបានរំពឹងថានឹងស្រុះស្រួលគ្នាលើអាពាហ៍ពិពាហ៍របស់គេ ដើម្បីបង្កើនចំនួនប្រជាជន"[2826]។

ចម្លើយ សុំ ប៉ែត ឆ.២៥ KH 01007617។ ឯកសារ D219/511.1.2 កំណត់ហេតុស្តាប់ចម្លើយ ឈ្លក រ៉ីន ឆ.៨៤ KH 01110671 ។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.២៨ KH 01045652។ ឯកសារ D117/68 កំណត់ហេតុស្តាប់ចម្លើយ វ៉ា លីមហ៊ុន ឆ.២៦ KH 01025625-01025626។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន យ៉ីម ឆ.៨ KH 01039251។ ឯកសារ D219/405 កំណត់ហេតុស្តាប់ចម្លើយ ឈឹន ប៊ុនសេរ៉ី ឆ.៥២ KH 01117214។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045811-01045812។ ឯកសារ D310/1.1.4 Bridgette Toy-Cronin *"ខ្ញុំចង់និយាយប្រាប់អ្នក"* KH 00721380-00721381។

[2825] *សូមមើលទាហរណ៍* ឯកសារ D347/2.1.38 ម៉ុ រ៉ុន ប្រតិចារ៉ីក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 13.38.10-13.40.35 [ក្នុងខេត្តសៀមរាប ភូមិភាគឧត្តរ នៅចុងឆ្នាំ១៩៧៥៖ "ចាស កម្មភិបាលដែលគេរៀបការឲ្យទាំង៦០គូ គេមានភារកិច្ចគេឡើងប្រកាសប្រាប់ថា គូស្រករដែលរៀបថ្មីជាប្តីប្រពន្ធហើយនេះ ត្រូវចេះស្រឡាញ់គ្នា មើលថែរក្សាគ្នា។ [...] ខិតខំបង្កបង្កើតផលកូនឲ្យបានច្រើនឲ្យអង្គការ។"]។ ឯកសារ D219/702.1.87 ឃ្ល ว๊ាន់ ប្រតិចារ៉ីក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៦ ម៉ោង 14.38.41-15.42.01 [ក្នុងស្រុកកំពង់សៀម ខេត្តកំពង់ចាម ភូមិភាគកណ្តាល៖ "ស៖ [...] តើលោកស្រីនៅចាំទេថា ប្រាក់ ឃុទ្ធ បានប្រាប់លោកស្រីរឿងនេះ ហើយថា គាត់បានឮពី តារ៉ាន ថាឲ្យរួមដំណេកជាមួយគ្នានោះ គឺដើម្បីកសាងជាតិ? ឆ៖ ចាស បានឮអ៊ីចឹងមែន កសាងជាតិ ឲ្យវាចម្រើនទៀត វាអ៊ីចឹង។"]។ ឯកសារ D219/888.1.8 ពុល ណែម ប្រតិចារ៉ីក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.12.03-15.14.19 [ក្នុងខេត្តមណ្ឌលគិរី ភូមិភាគឦសាន ឆ្នាំ១៩៧៧៖ "បើសិនមិនបង្កើតកូនឲ្យអង្គការបានទេ គឺអ្នកឯងត្រូវខុសច្បាប់។"]។ ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារ៉ីក ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 13.59.01-14.02.33។ ឯកសារ D219/504 កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.១៣៩ KH 01146394។ ឯកសារ D219/582 កំណត់ហេតុស្តាប់ចម្លើយ តូយ ម៉ៀច ឆ.១៣៣ KH 01166944។ ឯកសារ D219/138 កំណត់ហេតុស្តាប់ចម្លើយ ឃ្ល ว๊ាន់ ឆ.៣៤ KH 01056046។ ឯកសារ D219/159 កំណត់ហេតុស្តាប់ចម្លើយ នី ហ្ជន ឆ.១៤៩ KH 01059368។ ឯកសារ D5/1337 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខ្ជ ណេត KH 01049433-01049434។ ឯកសារ D5/1663 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សុខ ផា KH 01094419 [ក្នុងខេត្តកំពត ភូមិភាគនិរតី ឆ្នាំ១៩៧៧៖ "បងប្រុស រ៉ិត រ៉ៀន ប្រាប់ថា គាត់រៀបការពេលយប់ ខែវស្សា ឆ្នាំ១៩៧៧ រៀបការម្តង ១០គូ នៅសាលាស្រុកព្រៃនប់។ [...] ដោយឲ្យប្តេជ្ញាស្រឡាញ់គ្នាអស់មួយជីវិត បង្កើតកូនឲ្យអង្គការ។"]។

[2826] ឯកសារ D347/2.1.42 សយ សារ៉ៀន ប្រតិចារ៉ីក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 10.48.25-10.51.06 [រៀបការដោយបង្ខំ ក្នុងឆ្នាំ ១៩៧៥ និងបងប្អូនរបស់នាង ក្នុងឆ្នាំ១៩៧៨ ក្នុងស្រុកចំការលើ តំបន់ ៤២ ភូមិភាគកណ្តាល៖ "[ការប្តេជ្ញាចិត្តក្នុងពិធីរៀបការ អង្គការណែនាំគូស្រករថា]" ឲ្យស្រឡាញ់គ្នាចាប់ពីពេលនេះតទៅ [...] ឲ្យបង្កបង្កើមនុស្សឲ្យបានច្រើនដោយតម្រូវទៅតាមអង្គការត្រូវការ មនុស្សច្រើន ដើម្បីការពារទឹកដី។ [...] និយាយឲ្យដូចគេថាអ៊ីចឹង។" ម៉ោង 10.53.06-10.55.14 ["ខ្ញុំមានកូនគឺមិនមែនតាមចិត្តខ្ញុំចង់ថាឲ្យមានទេ តែនេះជាទិសដៅរបស់គេ គេថាត្រូវតែមានកូន ត្រូវតែបង្កើតកូនឲ្យអង្គការ។"] ម៉ោង 11.07.26-11.09.48 ["ស៖ ពេលដែលលោកស្រីឮគេប្រាប់ថា ត្រូវបង្កបង្កើតកូនឲ្យបានច្រើនហ្នឹង តើលោកស្រីគិតថា ពេលហ្នឹង

ក្បួនការយល់ព្រម

780. នៅក្នុងបរិយាកាសបង្ហិតបង្ហំដែលកើតមានជាទូទៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការព្រមព្រៀងរៀបការពិតប្រាកដដែលត្រូវបានរៀបចំឡើងដោយកម្មាភិបាលខ្មែរក្រហម គឺគ្មានឡើយ។ អ្នកដែលទទួលបានការណែនាំឲ្យរៀបការ មានការភ័យខ្លាចថា ការបដិសេធមិនរៀបការត្រូវបានគេកត់សម្គាល់ថាជា "ខ្ទាំង"[2827] ហើយជាលទ្ធផលអាចត្រូវបានយកទៅអប់រំឡើងវិញ សម្លាប់ចោល និងនាំគ្រោះថ្នាក់ដល់គ្រួសាររបស់ខ្លួន[2828]។ អាស្រ័យហេតុនេះ គូស្វាមីភរិយាលជាច្រើននាក់ទទួល

គឺថាលោកស្រីត្រូវតែរួមដំណេកជាមួយប្តី មែនទេ ដើម្បីឲ្យបានបង្កបង្កើតកូនឲ្យបានច្រើននោះ? ឆ៖ នាងខ្ញុំគិតថា បើសិនជាខ្ញុំមិនរួមរស់ជាមួយប្តី គឺនាងខ្ញុំមិនដឹងជាទៅដល់ដំណាក់កាលណាទេ គេយកនាងខ្ញុំទៅសម្លាប់ចោលក៏មិនដឹងទេ។"]។ ឯកសារ D219/888.1.7 ព្រាប សុយៀន ប្រតិចារឹក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.32.08-15.37.06។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុយៀន ឆ.៣៥, ៤០ KH 01029961, 01029962។ ឯកសារ D219/504 កំណត់ហេតុស្តាប់ចម្លើយ សាត ភាព ឆ.២៧-២៨ KH 01146374។ ឯកសារ D219/171 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល ហៅ សាយ ឆ.៤៤ KH 01065955។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.៣២, ៣៦ KH 01045653។ ឯកសារ D219/47 កំណត់ហេតុស្តាប់ចម្លើយ ខ្ចូ ណេត ឆ.៣០ KH 01032247។ ឯកសារ D219/502 កំណត់ហេតុស្តាប់ចម្លើយ ម្ហូ សេងលី ឆ.៣៧ KH 01142495។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ម ភ្ជុ ឆ.៤៦ KH 01117226។

[2827] ឯកសារ D219/702.1.105 កង អ៊ីត ប្រតិចារឹក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 10.57.48-11.01.52 [នៅចំនប់ ១មករា តំបន់ ៤២ ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "ស៖ តើនៅពេលនេះ លោកស្រីមានអារម្មណ៍ថា លោកស្រីមានសិទ្ធិសេរីភាពក្នុងការជំទាស់មិនរៀបការដែរឬទេ? ឆ៖ ចាស ខ្ញុំមិនហ៊ានជំទាស់ទេ។ បើយើងជំទាស់ គេថាយើងប្រឆាំង។ ប្រឆាំងនឹងអង្គការ ម្ហ្នោះហើយខ្ញុំមិនជំទាស់ទេ ក៏តាមគេទៅ។"]។ ឯកសារ D219/899.1.5 ម៉ឹង វេត ប្រតិចារឹក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង 10.08.19-10.10.18 [ក្នុងស្រុកគិរីវង់ ខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៥-១៩៧៧៖ "តាមដែលច្បាប់ បើយើងរៀនច្បាប់បក្ស បើយើងមិនគោរពតាមការចាត់ចែង បានន័យថា យើងហ្នឹងវាប្រឆាំងហើយ។ [...] បើសិនណាជាចាប់ ដូចជា ឥឡូវខ្ញុំអង្គភាព អ៊ ! ឲ្យយកអ្នកនេះ ឬក៏ចាត់តាំងទៅនេះ បើអត់ទៅ មានន័យថា អ្នកនុ៎ងប្រឆាំងហើយ។ អ៊ីចឹង រឿងហ្នឹងដែលយកអាច្បាប់ហ្នឹង មកនិយាយនេះ បានម្នាក់ៗខ្លាច ហើយមិនហ៊ានៗនោះទេ។"]។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ ម្ហូ អេងឆ.២០៩ KH 01095266 [ក្នុងស្រុកកោះអណ្តែត ខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៨ (*សូមមើល* ឆ.៩)៖ "គេថា បើយើងមិនគោរពអង្គការទេ យើងគិតខ្លួនឯងទៅ។"]។ ឯកសារ D6.1.846 កំណត់ហេតុស្តាប់ចម្លើយ ហេង ឡៃហ៊ាង ឆ.២៦ KH 00405490។ ឯកសារ D117/60 កំណត់ហេតុស្តាប់ចម្លើយ សុំ ប៉េត ឆ.៣០ KH 01007617។ ឯកសារ D310/1.1.4 Bridgette Toy-Cronin *"ខ្ញុំចង់និយាយប្រាប់អ្នក"* KH 00721380-81។

[2828] *សូមមើលឧទាហរណ៍* ឯកសារ D347/2.1.38 ម៉ុ រ៉ុន ប្រតិចារឹក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.28.09-13.31.04 [ក្នុងខេត្តសៀមរាប ភូមិភាគឧត្តរ ឆ្នាំ១៩៧៥៖ "មិនហ៊ានប្រកែក មិនហ៊ានតវ៉ា គឺខ្លាចតែរឿងមួយហ្នឹង គឺខ្លាចរឿងសម្លាប់ហ្នឹងតែម្តង។"]។ ឯកសារ D347/2.1.37 សេង សឿន ប្រតិចារឹក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ម៉ោង 10.03.22-10.06.00 [ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបចំការរៀបការក្នុងនាមជាប្រធានមន្ទីរស្រុកស្អាង ខេត្តកណ្តាល ភូមិភាគនិរតី ប្រហែលឆ្នាំ១៩៧៨ "តែហ៊ានតែប្រកែក ដឹងតែបាត់ខ្លួនតែប៉ុណ្ណឹងឯង។"] ម៉ោង 10.12.47-10.16.00 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ខំមឲ្យរៀបការ

"អារឿងសម័យនោះ ខ្ញុំវាពិបាកនឹងជម្រាបថា ខ្លាចអី រឿងអី ព្រោះមួយ ក្រោមការដឹកនាំរបស់គេ ហើយសម័យនោះ ពិបាកណាស់ ស្រួលមិនស្រួលហ្នឹងងាប់ បាត់ខ្លួន មិនដឹងជាស្លាប់ អាហ្នឹងមិនថា ហាន:អីថ្នាក់អីទេ តែមិនស្រួលបាត់។ ហើយអ៊ីចឹងចេះតែគិតអ៊ីចឹង អ៉! ថាឲ្យយកក៏យកទៅ អាហ្នឹង។ ខ្ញុំបានគិតឃើញទេអ៊ីចឹងទេ សម័យនោះ។"]។ ឯកសារ D219/888.1.8 ពុល ណែម ប្រតិចារឹក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.27.45-14.30.00 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ខំឲ្យរៀបការនៅស្រុកកោះញ្ជែក ខេត្តមណ្ឌលគិរី ភូមិភាគឦសាន ឆ្នាំ១៩៧៧៖ "ខ្ញុំនេះអត់ហ៊ានដែរ ត្រូវខ្លាចគេ [...] បើអ្នកមិនខ្លាច ត្រូវស្លាប់ហើយជំនាន់ហ្នឹង។"] ម៉ោង 15.20.00-15.23.10, 15.23.10-15.26.50។ ឯកសារ D219/888.1.7 ព្រាប សុឃឿន ប្រតិចារឹក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.03.36-15.05.34 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ខំឲ្យរៀបការនៅស្រុកព្រៃឈរ ខេត្តកំពង់ចាម ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "កាលក្នុងរបបហ្នឹង គ្មានមនុស្សណាហ៊ានប្រឆាំងនឹងអង្គការបក្សទេ បើគេថាឲ្យធ្វើអី យើងធ្វើហើយ ទោះបីជាយើងត្រូវគ្នា មិនត្រូវគ្នា យើងណាក់លួចនៅក្នុងអារម្មណ៍ទៅ។ បើសិនជាយើងហ៊ានបញ្ចេញ មានតែសេចក្តីស្លាប់។ [...] មិនគោរពតាមអង្គការវិន័យ គេនឹងសម្លាប់មិនឲ្យយើងឃើញម៉ែខ៏ទៀត សម្លាប់ចោលដូចសត្វដូចធាតុអ៊ីចឹង។"] ម៉ោង 15.20.22-15.23.05 ["ខ្ញុំមានតែភ័យតក់ស្លុត ភ័យខ្លាច [...] ព្រោះត្បិតអីវាមានតែការកាប់សម្លាប់ គឺថាវិលៗឃើញ វិលៗឮ ការសម្លាប់ហ្នឹងជារៀងរាល់ថ្ងៃ។ ដល់អ៊ីចឹងគឺការភ័យតក់ស្លុតរបស់ខ្ញុំនៅជាប់ៗក្នុងអារម្មណ៍ អត់មានស្រាកស្រាន្តទេ។"]។ ឯកសារ D5/1166/3.1 ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទីចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.12.56-15.17.12។ ឯកសារ D219/702.1.105 កង អ៊ុត ប្រតិចារឹក ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 10.57.48-11.01.52។ ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្ការ៉ា ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.05.50-14.12.53។ ឯកសារ D6.1.846 កំណត់ហេតុស្តាប់ចម្លើយ ហេង ឡៃប៊ីង ឆ.៣០ KH 00405490-00405491។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ ម្ជុល អេង ឆ.២១០ KH 01095266។ ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ជ ភ្ជុ ឆ.៤០ KH 01117225។ ឯកសារ D5/1050/3 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.១៥៤ EN 01069373។ ឯកសារ D219/435 កំណត់ហេតុស្តាប់ចម្លើយ ទូច ចំរើន ឆ.៧៧-៧៩, ២២៦-២២៧ KH 01124170, 01124184។ ឯកសារ D219/234.1.7 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.៨៧-៨៩, ៩៥ KH 010627។ ឯកសារ D219/323 កំណត់ហេតុស្តាប់ចម្លើយ មុត សុផុន ឆ.២៨ KH 01099668។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន យ៉ីម ឆ.៦-៧ KH 01039250។ ឯកសារ D219/136 កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់ ឆ.៣៥ KH 01053264។ ឯកសារ D117/60 កំណត់ហេតុស្តាប់ចម្លើយ សុំ ប៉ែត ឆ.៣០ KH 01007617។ ឯកសារ D219/159 កំណត់ហេតុស្តាប់ចម្លើយ នី ហួន ឆ.១១១-១១២, ១១៥-១១៦ KH 01059364។ ឯកសារ D219/47 កំណត់ហេតុស្តាប់ចម្លើយ ខ្ជ្ជ ណេត ឆ.១៦, ២៦ KH 01032244, 01032246។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* ២០១៤ KH 01045808 ["មួយភាគបីនៃអ្នកផ្តល់បទសម្ភាសន៍ទាំងនេះ ទទួលសំណើរៀបការនេះ នៅពេលត្រូវបានប្រាប់អំពីការរៀបការ។ អ្នកផ្តល់បទសម្ភាសន៍ទាំងនេះយល់ស្របដូចគ្នាថា ពួកគេភ័យខ្លាច ឬសមាជិករបស់ខ្លួនត្រូវបានសម្លាប់ ឬពួកគេត្រូវចាត់តាំងឲ្យបំពេញការងារលំបាក ឬឲ្យផ្លាស់ប្តូរទីលំនៅប្រសិនបើពួកគេបដិសេធមិនរៀបការ។"]។

យល់ព្រមតាមការណែនាំរបស់អង្គការដើម្បីរៀបការ ដោយគ្មានជំទាស់ឥវ៉ា ឡើយ[2829]។ កុល ណែម ជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងភូមិភាគពាយ័ព្យ បានផ្តល់សក្ខីកម្មថា "ខ្ញុំបានយល់ព្រមរៀបការ ក្រែងបានរស់ ហើយបានឃើញមេយឃើញផ្កាយនឹងគេ"[2830]។

[2829] សូមមើលឧទាហរណ៍ ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.19.08-14.20.55 ["ជីវិតរបស់ប្រជាជនហ្នឹង គឺស្ថិតនៅក្នុងការភ័យរន្ធត់។ អ៊ីចឹងហើយ គឺគេដឹង គឺថា គេថា គេពិបាកនឹងបដិសេធនឹងឆ្លើយថា "ទេ"។"]។ ឯកសារ D219/888.1.1 អ៊ុំ ឃឿន ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.46.58-15.51.22 [ក្នុងស្រុកចំការលើ ចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨៖ "យើងខ្ញុំអត់ហ៊ាននិយាយទេ ព្រោះកន្លងមក ខ្ញុំមានការខ្លាច ព្រោះនៅទុំងតែប្រកែក អត់បាន ដឹងតែបាត់ខ្លួន [...] ភាគច្រើន គេប្រាប់ថា ទៅបាត់ខ្លួនហ្នឹង គេហៅទៅ ជួនកាលគេហៅទៅបែកចាន អ៊ីចឹងទៅ គេហៅទៅ ៤១អ៊ីចឹងទៅ ទៅបាត់រហូតដល់សព្វថ្ងៃ [...] នាងខ្ញុំបានប្រាប់ថា ពីអង្គាល់គេការ គេនេះហ្នឹង ព្រោះកន្លងមក នាងខ្ញុំឃើញអ្នកច្រើនគ្នាហើយ ដែលប្រកែកៗហ្នឹងបាត់ខ្លួន។"]។ ឯកសារ D219/888.1.8 កុល ណែម ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.20.50-14.27.45, 14.27.45-14.32.50។ ឯកសារ D219/398 កំណត់ហេតុស្តាប់ចម្លើយ រស់ ស៊ីយ ឆ.៨៣ KH 01115764។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃឿន ឆ.១៩-២១ KH 01029956-01029957 ។ ឯកសារ D219/47 កំណត់ហេតុស្តាប់ចម្លើយ ខ្ចូ ណេត ឆ.១៦-១៧ KH 01032244-01032245។ ឯកសារ D5/172 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ញ៉ិប ទ្រី KH 00564599។ ឯកសារ D310/1.1.4 Bridgette Toy-Cronin *"ខ្ញុំចង់និយាយប្រាប់អ្នក"* KH 00721380-00721381 ។

[2830] ឯកសារ D219/888.1.8 កុល ណែម ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.20.50-14.27.45 ។

781. អ្នកដែលស្នាក់ស្នើ រ ឬបដិសេធបញ្ជាឲ្យរៀបការជាញឹកញាប់ត្រូវបានគម្រាមកំហែង[2831] ឬត្រូវបានដាក់ទណ្ឌកម្មដោយការអប់រំរៀនសូត្រ[2832] ការរំលោភបំពានផ្លូវកាយ[2833] ការរំលោភផ្លូវភេទ[2834]

[2831] ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្ការ៉ា ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.12.53-14.14.21 ["មានគំរូពីរ។ មួយ គឺចាស្នែរក្រហម ឬក៏មេភូមិនិយាយច្បាស់ៗបែបនោះថា គឺនឹងសម្លាប់អ្នកដែលគេបង្ខំ ឬសមាជិកក្រុមគ្រួសារហ្នឹង ត្រូវគេសម្លាប់ បើសិនជាពួកគេបដិសេធ។"]។ ឯកសារ D219/702.1.104 ជុំ សាម៉ៀន ប្រតិចារឹក ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 14.25.09-14.27.54 [ក្នុងស្រុកឈូក ខេត្តកំពត ភូមិភាគនិរតី ឆ្នាំ១៩៧៨៖ "ពេលគេបង្ខំឲ្យរៀបការ ខ្ញុំប្រកែកគេ។ គេប្រាប់ថា [...] បើញញឹមដាក់បុរសណាគេឃើញ នោះអ្នកនឹងត្រូវ ប្រយ័ត្នងាប់។"]។ ឯកសារ D5/1166/3.1 ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ម៉ោង 14.32.42-14.36.41 [ក្នុងស្រុកបាទី ខេត្តកំពង់ស្ពឺ ភូមិភាគនិរតី ឆ្នាំ១៩៧៨៖ "គ្មានអ្នកណាក្រៅពីប្រធានកងទេ បង្ខំរៀបការ គំរាមកំហែងសម្លាប់ផង គំរាមកំហែងយកទៅរៀនសូត្រផង [...] បើនិយាយទៅ វាអ្ជលដើមក និយាយវាមិនកើត។ គ្រាន់តែថា ពាក្យសម្តីចេញមក គឺសុទ្ធសម្តីអសុរោះទាំងអស់ យកទៅសម្លាប់ យកទៅវ៉ៃចោល អ្នកឯងមិនព្រមរៀបការ។"]។ ឯកសារ D219/888.1.7 ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.25.14-15.27.02។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃឿន ឆ.១២ KH 01029954។ ឯកសារ D219/113 កំណត់ហេតុស្តាប់ចម្លើយ កែវ ធារី ឆ.៣០ KH 01045652។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន យ៉ីម ឆ.៨ KH 01039251។ ឯកសារ D117/68 កំណត់ហេតុស្តាប់ចម្លើយ វ៉ា លីមហ៊ុន ឆ.២៧ KH 01025626។ ឯកសារ D219/294 កំណត់ហេតុស្តាប់ចម្លើយ ម្ជុល អេង ឆ.២០៩-២១០ KH 01095266។ ឯកសារ D5/172 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ញ៉ាប ទ្រី KH 00564599។ ឯកសារ D5/1675 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ប៊ិត សុក KH 01094628-01094629។ ឯកសារ D310/1.1.6 កាស៊ូមិ ណាកាហ្ការ៉ា *អំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម* KH 00738353 [រឿងរ៉ាវពីអ្នកឆ្លើយចម្លើយជាស្ត្រីម្នាក់ ដែលត្រូវបានបង្ខំឲ្យរៀបការនៅអាយុ ១៧ ឆ្នាំ៖ "[ប្តីរបស់ខ្ញុំបច្ចុប្បន្ន] មានទំនាក់ទំនងជាមួយប្រធានឃុំ ហើយវាពិបាកណាស់សម្រាប់ខ្ញុំក្នុងការប្រកែកមិនរៀបអាពាហ៍ពិពាហ៍។ ខ្ញុំមិនបានស្រឡាញ់ប្តីខ្ញុំទេ ខ្ញុំបាននិយាយថា ខ្ញុំនឹងស្លាប់ជំនួសការរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែពួកគេមិនអនុញ្ញាតឲ្យខ្ញុំស្លាប់ទេ។ ពួកគេបាននិយាយថា ការស្លាប់មិនទាន់គ្រប់គ្រាន់ទេ ប៉ុន្តែពួកគេនឹងធ្វើឲ្យខ្ញុំខ្ជាស់គេ មុននឹងពួកគេសម្លាប់ខ្ញុំ។ ពួកគេនិយាយថា ពួកគេនឹងដោះសម្លៀកបំពាក់ខ្ញុំនៅចំពោះមុខមនុស្សប្រុសទូទាំងភូមិ ហើយបន្ទាប់មក ពួកគេនឹងសម្លាប់ខ្ញុំ។ ដូច្នេះខ្ញុំគ្មានជម្រើសទេ ក្រៅពីយល់ព្រមធ្វើជាប្រពន្ធគាត់។"] KH 00738354-00738356 [រឿងរ៉ាវរបស់ ថាង-បានគំរាមកំហែងដាក់ទណ្ឌកម្ម ប្រសិនបើនាងបដិសេធមិនរៀបអាពាហ៍ពិពាហ៍]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្ចោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037033 ["ការដាក់ពិន័យសម្រាប់អ្នកបដិសេធមិនព្រមរៀបការ [...] រួមមាន ការគំរាមកំហែងដោយពាក្យសម្តី។"] EN 01037038 ["ប្រព័ន្ធនេះត្រូវបានអនុវត្តដោយបង្ខំ តាមរយៈការផ្តន្ទាទោសពិតប្រាកដ ឬគំរាមកំហែង-"យកទៅអប់រំកែប្រែ" ការដាក់គុក អំពើហិង្សាផ្លូវភេទ និងការធ្វើទារុណកម្ម ឬសម្លាប់។"] EN 01037052 ["អ្នកឆ្លើយសំណួរ ៦៩,១% ត្រូវបានគេគំរាមកំហែងដោយពាក្យសម្តី សម្រាប់ការបដិសេធមិនព្រមរៀបការក្នុងសម័យខ្មែរក្រហម។"] EN 01037053 ["អ្នកឆ្លើយសំណួរ ៧២នាក់ (៧៥%) បានរាយការណ៍ថា ត្រូវបានបង្ខំឲ្យរៀបការ ទោះបីជាវាមិនមែនជាជម្រើសរបស់ពួកគេ តែដោយសារការគំរាមកំហែងដោយពាក្យសម្តី។"]។ ឯកសារ D219/115.1 Rochelle Braaf *អំពើហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម* KH 01045758 ["ក្នុងចំណោមអ្នកផ្តល់បទសម្ភាសន៍ចំនួន ៤២នាក់ ដែលបដិសេធមិនរៀបការក្នុងពេលដំបូង មាន ៣៥នាក់ ត្រូវបានគំរាមកំហែង ឬដាក់ទណ្ឌកម្មតាមរូបភាពមួយចំនួន។"] KH 01045809 ["ប្រជាជនត្រូវបានគំរាមកំហែងផ្លាស់ប្តូរទៅរស់នៅ

ក្នុងទីកន្លែងមានគ្រោះថ្នាក់ជាងមុន ឲ្យបំពេញការងារលំបាកជាងមុន យកទៅកសាង ឬសម្លាប់ពួកគេ និង/ឬសមាជិកគ្រួសារពួកគេ។"] KH 01045811 ["ស្រីពីរនាក់បានរៀបរាប់អំពីការរៀបការដោយបង្ខំ ក្រោមការភ្ជង់កាណុងកាំភ្លើង និងភាពភ័យខ្លាចរបស់ពួកគេ។"]។ ឯកសារ D219/882.1.21 កាស្ទ្រីមិ ណាកាហ្ការ៉ា *ភាពជាម្តាយក្នុងសម័យសង្គ្រាម* KH 01506047-01506049 ។ ឯកសារ D310/1.1.4 Bridgette Toy-Cronin *"ខ្ញុំចង់និយាយប្រាប់អ្នក"* KH 00721381 ["អ្នកដែលប្រកែកមិនព្រមរៀបការតាមការរៀបចំ នឹងត្រូវគេគំរាមកំហែងថានឹងប្រើអំពើហិង្សា ឬប្រើអំពើហិង្សាជាក់ស្តែងតែម្តង។"]។

[2832] ឯកសារ D219/888.1.2 កាស្ទ្រីមិ ណាកាហ្ការ៉ា ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.17.20-14.19.08 ["ចាស ខ្ញុំបានស្តាប់រឿងជាច្រើនអំពីការដាក់ទណ្ឌកម្ម ការដាក់ទោសចំពោះអ្នកដែលបដិសេធមិនព្រមរៀបការនោះ។ ករណីមួយ គឺខ្ញុំមានារីម្នាក់នៅរតនគិរី គាត់នៅក្នុងកងកុមារ គឺគាត់អាយុ ១៥ឆ្នាំ គេបង្ខំឲ្យគាត់រៀបការ គឺនៅចុងឆ្នាំ១៩៧៨ គឺក្នុងរវាងឆ្នាំ១៩៧៨។ នាងនៅតូចពេក គឺអាយុតែ ១៥ឆ្នាំ នាងបដិសេធ។ ហើយគេក៏បានបញ្ជូននាងទៅមន្ទីរអប់រំពាខែ បន្ទាប់មក រៀតណាមក៏បានចូលស្រុកចូលកម្ពុជា។ ហើយអ៊ីចឹងគឺថា សៀវភៅមួយទៀតនៅក្នុង -- ដែលមានចំណងជើងថា "ភាពជាម្តាយនៅក្នុងសម័យសង្គ្រាម" ហ្នឹង ខ្ញុំនឹកឃើញនារីម្នាក់នៅសៀមរាប ដែលប្រាប់ខ្ញុំថា គេបញ្ជូនគាត់ទៅ១មន្ទីរអប់រំកែប្រែ ដោយសារគាត់បដិសេធមិនព្រមរៀបការ។"]។ ឯកសារ D6.1.408 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ស៊ន KH 00239952 [នៅទំនប់ ១មករា តំបន់ ៤២ ភូមិភាគកណ្តាល ឆ្នាំ ១៩៧៨៖ "ក្នុងករណីដែលយើងប្រកែកមិនព្រមតាមគេ គេយកយើងទៅកសាង។"]។ ឯកសារ D219/234.1.7 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.៩៧, ១០០-១០១ KH 01069928។ ឯកសារ D219/24 កំណត់ហេតុស្តាប់ចម្លើយ ព្រាប សុឃៀន ឆ.១២ KH 01029954។ ឯកសារ D5/1050/3 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.១៤១ KH 01058284។ ឯកសារ D219/134 កំណត់ហេតុស្តាប់ចម្លើយ នេត សារឿន ឆ.៥៣, ៥៥ KH 01052657។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដួចខ្មោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037038 ["ក្នុងករណីទាំងអស់ ប្រព័ន្ធនេះត្រូវបានអនុវត្តដោយបង្ខំ តាមរយៈការផ្តន្ទាទោសពិតប្រាកដ ឬគំរាមកំហែង-"យកទៅអប់រំកែប្រែ" ការដាក់គុក អំពើហិង្សាផ្លូវភេទ និងការធ្វើទារុណកម្ម ឬសម្លាប់។"] ឯកសារ D310/1.1.6 កាស្ទ្រីមិ ណាកាហ្ការ៉ា *អំពើហិង្សាលើយេនឌ័ក្នុងអំឡុងរបបខ្មែរក្រហម* KH 00738346 [អតីតយោធាខ្មែរក្រហមបាននិយាយថា៖ "ខ្ញុំបាននិយាយទៅកាន់អង្គការ ពីព្រោះខ្ញុំមិនយល់ព្រមជាមួយរឿងនេះ (អាពាហ៍ពិពាហ៍) ដូច្នេះអង្គការចាប់ខ្ញុំដាក់ពន្ធនាគារ។"]។

[2833] ឯកសារ D219/234.1.7 កំណត់ហេតុស្តាប់ចម្លើយ តើ រី ឆ.៩៧-១០៧ KH 01069928-01069929 [នៅបឹងស្រី ខេត្តកំពង់សោម ឆ្នាំ១៩៧៥៖ ដើមបណ្តឹងរដ្ឋប្បវេណីប្រាប់ប្រធានកងរបស់នាងថា នាងមិនរៀបការជាមួយកងទ័ព ដែលស្នើនាងរៀបការនោះទេ។ នៅយប់នោះ នាងត្រូវបានភ្ជង់កាំភ្លើងទៅកន្លែងស្ងាត់មួយជិតការដ្ឋានធ្វើការ នៅទីនោះ ប្រធានកងបានប្រាប់ទៅកងទ័ពពីរនាក់ធ្វើអ្វីក៏បានលើរូបនាង ពីព្រោះនាងគឺជា "មនុស្សក្បាលរឹង"។ កងទ័ពវាយនាងរហូតដល់ជិតភ្លឺ ហើយប្រាប់នាងថា បើស្តាប់តាមបញ្ជាមេកង នោះនឹងមិនត្រូវបានវាយឡើយ។ បន្ទាប់មក កងទ័ពនោះប្រាប់នាងឲ្យត្រលប់ទៅធ្វើការវិញ ហើយការរៀបការគឺធ្វើឡើងមួយសប្តាហ៍ក្រោយមក]។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ីក ហ៊ីម ឆ.២២ KH 01000019 [ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៥៖ "ខ្ញុំបានបដិសេធពុំព្រមរៀបការនោះទេ។ រួចហើយខ្មែរក្រហមបានបណ្តេីរខ្ញុំ ព័ទ្ធជុំវិញភូមិពាក្ងៃ ដោយពេលនោះ គេបានវ៉ៃខ្ញុំនឹងគល់ឫស្សីបីដំបង។"]។ ឯកសារ D5/1050/3 កំណត់ហេតុស្តាប់ចម្លើយ ណាប់ សុម៉ាលី ឆ.១៤១ KH 01058284 [ក្នុងស្រុកកំពង់ត្រឡាច ភូមិភាគបស្ចិម ខែវិច្ឆិកា ឆ្នាំ១៩៧៨៖ "មានស្រីស្អាតម្នាក់ ខ្ញុំគិតថា គាត់ធ្លាប់ធ្វើជាសិស្សសាលា គាត់ត្រូវបានគេឲ្យរៀបការជាមួយនឹងឈ្លបម្នាក់ ដែលជាជនពិការ គាត់បដិសេធ ហើយត្រូវបានគេទះកំផ្លៀង ៤-៥ដៃ រហូតដល់ហូរឈាម ហើយគាត់ត្រូវបានគេយកទៅអប់រំ។"]។ ឯកសារ D219/115.1 Rochelle Braaf *អំពើ*

ហិង្សាផ្លូវភេទលើជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម KH 01045809 [“ក្នុង ១០ ករណី អ្នកផ្តល់បទសម្ភាសន៍ត្រូវបានគេធ្វើទារុណកម្មដោយសារការបដិសេធមិនរៀបការ។ ក្នុងករណីខាងក្រោម ប្តីរបស់ស្ត្រីម្នាក់ ដែលខ្មែរក្រហមទើបបង្ខំឲ្យរៀបការ ត្រូវបានសម្លាប់ចោល។ នៅពេលនាងបដិសេធមិនរៀបការ នាងត្រូវបានឃុំឃាំង និងធ្វើទារុណកម្ម។”]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត*ដូចខ្មោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037033, 01037038។ ឯកសារ D310/1.1.6 កាស៊ូមិ ណាកាហ្គាវ៉ា *អំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម* KH 00738354 [អ្នកឆ្លើយតបសម្ភាសម្នាក់និយាយថា៖ “ខ្ញុំគឺជាប្រជាជនថ្មីនៅខេត្តបាត់ដំបង ហើយប្តីរបស់ខ្ញុំត្រូវបានសម្លាប់ បន្ទាប់ពីខ្មែរក្រហមបានកាន់អំណាច។ [...] ខ្ញុំត្រូវបានចាប់បង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ជាមួយកងទ័ពម្នាក់ រួមនឹងស្វាមីភរិយាជិត ៣០គូទៀត។ ខ្ញុំប្រកែកមិនព្រមធ្វើតាមបញ្ជា ហើយបន្ទាប់មក អង្គការបានចាប់ខ្ញុំទៅវាលស្រែ ហើយវ៉ៃជើងទាំងពីររបស់ខ្ញុំរហូតដល់ជើងទាំងពីរនេះបាក់។ អង្គការបានដកក្រចករបស់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែប្រកែកមិនរៀបអាពាហ៍ពិពាហ៍។”]។ ឯកសារ D310/1.1.4 Bridgette Toy-Cronin *“ខ្ញុំចង់និយាយប្រាប់អ្នក”* KH 00721380-00721381។

[2834] ឯកសារ D347/2.1.38 ម៉ុ រ៉ុន ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.15.28-11.24.41 [ក្នុងខេត្តសៀមរាប ភូមិភាគឧត្តរ ឆ្នាំ១៩៧៥៖ “ដើមបណ្តឹងរដ្ឋប្បវេណីបដិសេធមមិនព្រមរៀបការ ហើយត្រូវបានចាប់រំលោភដោយភ្ជង់កាំភ្លើង ជាមួយនឹងកម្មាភិបាលខ្មែរក្រហម ៥នាក់។ ២ថ្ងៃក្រោយមក នាងព្រមរៀបការ។”]។ ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្គាវ៉ា ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.12.53-14.14.21 [“ស៖ នៅក្នុងរបាយការណ៍របស់លោកស្រីនេះ គឺថាស្ត្រីត្រូវបានគេរំលោភដោយហេតុថា ពួកគេបដិសេធមិនព្រមរៀបការ។ តើត្រឹមត្រូវដែរឬទេ? ឆ៖ នៅក្នុងការសិក្សាដំបូងរបស់ខ្ញុំ ខ្ញុំបានឮរឿងបែបនេះ ហើយខ្ញុំក៏មានស្ត្រីម្នាក់ ដែលត្រូវធ្វើ គេបង្គាប់ឲ្យទៅមើលការរំលោភស្រីម្នាក់ទៀត ដែលគេបង្ខំឲ្យរៀបការហើយ គាត់បដិសេធ។”]។ ឯកសារ D310/1.1.6 កាស៊ូមិ ណាកាហ្គាវ៉ា *អំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម* KH 00738347-00738348 [អ្នកឆ្លើយតបជាស្ត្រីម្នាក់៖ គេប្រាប់ខ្ញុំថា ខ្ញុំត្រូវរៀបអាពាហ៍ពិពាហ៍ ប៉ុន្តែខ្ញុំប្រកែក។ ពួកគេបានយកខ្ញុំទៅក្នុងព្រៃ ហើយបានរំលោភខ្ញុំ។ បន្ទាប់ពីពួកគេរំលោភខ្ញុំ ខ្ញុំបាននិយាយទៅកាន់ពួកគេថា “សម្លាប់ខ្ញុំមក” ... ខ្ញុំនិយាយថា “កូនទាំងប្រាំមួយនាក់របស់ខ្ញុំត្រូវបានសម្លាប់រួចហើយ ដូច្នេះសូមដឹកណ្តៅ ហើយកប់ខ្ញុំជាមួយកូនដែលនៅរស់ទាំងបួននាក់របស់ខ្ញុំ ប៉ុន្តែខ្ញុំមិនព្រមរៀបអាពាហ៍ពិពាហ៍ឡើយ ... ពេលនេះ ខ្ញុំដូចជាជិតឆ្កួតហើយ។”]។ ឯកសារ D310/1.1.4 Bridgette Toy-Cronin *“ខ្ញុំចង់និយាយប្រាប់អ្នក”* KH 00721382-00721383។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្មោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់ពីការរៀបការដោយបង្ខំក្រោមរបបខ្មែរក្រហម* EN 01037033, 01037038។

និង/ឬសម្លាប់[2835]។ ក្នុងពេលខ្លះ ជនរងគ្រោះត្រូវបានបង្ខំឲ្យរៀបការម្តងទៀត បន្ទាប់ពីគូស្វាមីភរិយាដើមរបស់គេត្រូវបានសម្លាប់ ហើយពួកគេមិនបានបដិសេធឡើយ ពីព្រោះពួកគេបានដឹងពីដំបូងពីផលវិបាកដែលអាចកើតមាន[2836]។

782. នៅក្នុងបរិយាកាសប្រកបដោយការភ័យខ្លាច ដែលកើតមានជាទូទៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ បុរស និងស្ត្រីភាគច្រើនដែលបានតវ៉ាពីដំបូងបានយល់ព្រមទទួលយកអាពាហ៍

[2866] *សូមមើលឧទាហរណ៍* <u>ឃុំរ៉ាំងកេសី</u>៖ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឯ.១២ KH 01117335-01117336 ["មានប្រហែល ៦០គូ គឺធ្វើនៅឃុំរ៉ាំងកេសី និងក្នុងអំឡុងពួកនិរតីគ្រប់គ្រង។ [...] តាមខ្ញុំដឹងខាងប្រុសជាអ្នកស្នើទៅអង្គការ មុននឹងអង្គការរៀបឲ្យមានគ្រួសារ គឺពុំមែនអង្គការជាអ្នកចាប់គូឲ្យនោះទេ។ យ៉ាងណាមិញ ប្រសិនបើខាងនារីមិនពេញចិត្ត ក៏អាចមានការបញ្ជុះបញ្ចូលខ្លះដែរ ដើម្បីឲ្យព្រមព្រៀងគ្នា។"]។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេត ជោត ឯ.២, ៤-៦ KH 01085170-01085172។ សូមមើលឯកសារផ្ទុយ ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឯ.១៤-១៦ KH 01213311។ ឃុំកំពង់ព្រៀង៖ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឯ.១២៣ KH 01047395 [ក្នុងភូមិកាច់រទេះ សហករណ៍កាច់រទេះ ឆ្នាំ១៩៧៨ (សូមមើល ឯ.៩០, ១១៤)៖ "បើសិនជាខាងប្រុសស្នើសុំរៀបការជាមួយនឹងខាងនារី ប៉ុន្តែខាងនារីមិនស្រឡាញ់ខាងបុរសទេ តើអង្គការនឹងសម្រេចឲ្យពួកគេរៀបការជាមួយគ្នាដែរឬទេ? ឯ.១២៣ ៖ ចាស គឺអ្នកការនឹងបង្ខំឲ្យខាងស្រីរៀបការជាមួយនឹងបុរសនោះ។"]។ ឯកសារ D219/207 កំណត់ហេតុស្តាប់ចម្លើយ ឡុង ឈៀម ឯ.៨ KH 01074026 [ក្នុងឃុំកំពង់ព្រៀង ខែតុលា ឆ្នាំ១៩៧៨ (សូមមើល ឯ.៥, ៦)៖ "ភាគច្រើន បុរសជាអ្នកស្នើទៅអង្គការថា ពួកគេចង់រៀបការជាមួយស្ត្រីនេះ ស្ត្រីនោះ ចំណែកឯខាងនារីវិញ គឺពុំដឹងរឿងការស្នើនោះ ឬ បានឯកភាពអ្វីនោះទេ។ កម្មាភិបាលមូលដ្ឋាន ជាអ្នកសម្រេច ហើយរៀបចំការរៀបការនោះ។"]។ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀង ចាន់ ថន ឯ.១៦, ១៨ KH 01096533 [ក្នុងភូមិថ្មី សហគមន៍កំពង់គោ ខែសីហា ឆ្នាំ១៩៧៨ (សូមមើល ឯ.១៣, ១៥)៖ "ខ្ញុំមិនចង់រៀបការទេ តែមេកងរបស់ខ្ញុំប្រាប់ថា អ្នកឯងត្រូវតែរៀបការ ព្រោះអ្នកឯងជាកូនរបស់អង្គការ។ [...] ខ្ញុំត្រូវរៀបការ។ [...] ទេ មិនមានសិទ្ធិ ជ្រើសរើសគូស្រករទេ។ បុរសគេមានសិទ្ធិខ្លះក្នុងការជ្រើសរើសគូស្រករ ចំណែកស្ត្រីវិញ គគគឺគ្មានសិទ្ធិជ្រើសរើសទេ។"]។ សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ៖ ឯកសារ D119/131 កំណត់ហេតុស្តាប់ចម្លើយ ផង ផ្ងើយ ឯ.៦៥,

តាំងពីការផ្សំផ្គុំដែលស្នើឡើងដោយភាគីតែម្នាង ឬទាំងសងខាងដើម្បីរៀបការនោះ កម្មាភិបាលជាន់ទាបចាំបាច់ត្រូវសុំការអនុញ្ញាតពីថ្នាក់លើ[2867]។

ពិធីរៀបអាពាហ៍ពិពាហ៍

792. សាក្សីជាច្រើនដែលបានរស់នៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **យ៉ីម ទិញ្ញ** បានរំឭកឡើងវិញពីភាពខុសគ្នាស្រលះរវាងពិធីអាពាហ៍មុន និងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងរួមទាំងការលុបបំបាត់ពិធីជាប្រពៃណី និងវប្បធម៌ និងការចូលរួមពីសមាជិកគ្រួសារ[2868]។

---

៦៨ KH 00996500 [ក្នុងខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៧៧៖ "គេបានបង្ខំឲ្យខ្ញុំរៀបការជាមួយនឹងប្តីរបស់ខ្ញុំ។ [...] ប្តីខ្ញុំបានស្នើទៅប្រធានកង ឬប្រធានក្រុម ហើយប្រធានកង ប្រធានក្រុមបានធ្វើសំណើទៅថ្នាក់លើបន្តទៅទៀត។"]។

[2867] *សូមមើលខ១ទាហរណ៍* ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.១៦ KH 01414386 [ក្នុងឃុំរ៉ាំងកេសី ក្រោមការគ្រប់គ្រងរបស់ពួកនិរតី (*សូមមើល* ឆ.៩, ១៤) "បើយើងរៀបការដោយគ្មានការអនុញ្ញាតហ្នឹង តែមិនស្រួលងាប់ព្រោះកម្មាភិបាលគេមិនទទួលស្គាល់។"]។ ឯកសារ D119/90 កំណត់ហេតុស្តាប់ចម្លើយ ជួន ភាព ឆ.៦ KH 00976139 [ក្នុងខេត្តបន្ទាយមានជ័យ៖ "នៅពេលនោះ ខ្មែរក្រហមបានឲ្យខ្ញុំជ្រើសរើសស្ត្រីមូលដ្ឋានមកធ្វើជាប្រពន្ធ។ ពេលខ្ញុំពេញចិត្តនឹងប្រពន្ធរបស់ខ្ញុំហើយ ខ្ញុំបានស្នើទៅប្រធានកង ដើម្បីឲ្យប្រធានកងសួរទៅខាងប្រធានកងនារី។ គេមិនឲ្យយើងជ្រើសរើសស្ត្រីអ្នក ១៧មេសា ដែលមកពីភ្នំពេញទេ បើពុំដូច្នោះ គេនឹងសម្លាប់យើងចោល។"]។ ឯកសារ D219/895 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម លំទោន ឆ.១៨ KH 01379572 [ក្នុងស្រុកសង្កែ ឆ្នាំ១៩៧៨៖ "មុនដំបូង ខ្ញុំបានដាក់ពាក្យស្នើសុំរៀបការជាមួយមិត្តនារី ហាង ហេន ហើយសំណើនោះតាំងក្នុងឆ្នាំ១៩៧៧ មិនបានរៀបចំទេ រហូតដល់ឆ្នាំ១៩៧៨ ទើបគេរៀបការឲ្យ។"]។

[2868] <u>ស្រុកសំឡូត</u>៖ ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារ៉ីក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.24.14-11.26.55 ["គឺខ្ញុំអត់មានអារម្មណ៍អ៊ីនីកឃើញអារម្មណ៍ថាអន់ចិត្ត ថាគាត់ការឲ្យហ្នឹងតែម្តង អត់មានបងប្អូន អ៊ីជំនាក់ហ្នឹងយើងជ្រះស្រឡះ។"] ម៉ោង 11.22.10-11.24.14 ["គោរពអង្គការចាត់តាំង។ អ៊ីចឹង ម្នាក់ៗថាអ៊ីចឹងឯង [...] ខោខ្ចៅ អាវខ្ចៅ អាវដៃវែង មានអ៊ី សម្លៀកបំពាក់អ៊ីណ្ណ អត់ទេ។ ដូចៗគ្នាហ្នឹង ប្រុសក៏អ៊ីចឹង ស្រីក៏អ៊ីចឹងដែរ។ ខោខ្ចៅ អាវខ្ចៅហ្នឹង។ [...] មួយណាក៏អត់មានបងប្អូន អត់មានម៉ែឪ មានតែញាតិអ្នកស្គាល់គ្នាទៅធ្វើនារី កងនារីស្រែអំបិលជាមួយគ្នាហ្នឹង។ បងប្អូនណា អត់ផង មានតែគ្នាឯងហ្នឹងឯង។"] *សូមមើលផងដែរ* ម៉ោង 11.22.10-11.28.00។ ឃុំរ៉ាំងកេសី៖ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១០០, ១០៥ KH 01032177 ["ស៖ តើព្រឹត្តិការណ៍រៀបការដោយបង្ខំនេះ កើតឡើងនៅខែ៩ ឆ្នាំណា? ឆ.១០០៖ ១៩៧៨។ [...] ស៖ តើឪពុកម្តាយក៏ស្ថិតនៅទីនោះដែរ ឬក៏យ៉ាងណា? ឆ.១០៥៖ អត់ទេ តែឪពុកក្មេករបស់ខ្ញុំម្នាក់ប៉ុណ្ណោះ ដែលត្រូវគេឲ្យទៅ ឲ្យពរកូន។"] ឆ.១១៣ KH 01032178 ["ថ្ងៃមួយ [...] និយាយជាមួយថា "ម៉េចដែរ រៀបការអត់មានពិធី អត់មានភ្លេងខ្មែរដូច្នេះ?" ខ្ញុំថា "អត់មានអារម្មណ៍អ៊ីទេ ដូចឆ្គួតអ៊ីចឹង។"]។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១១-១២, ៣០, ៣២ KH 01096585, 01096588។ ឯកសារ D219/867 កំណត់ហេតុស្តាប់ចម្លើយ ស ហ្ជឿន ឆ.១១, ១៦ KH 01347421-22 (*សូមមើល* ឆ.៧ សម្រាប់ក្របខ័ណ្ឌពេលវេលា)។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ាញ រ៉ណ្ណា ឆ.៧៨, ៨០ KH 01328007។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក ម៉ឿន ឆ.៦២, ៦៦, ៦៩ KH 01327972-01327973។ ឯកសារ D219/413 កំណត់ហេតុស្តាប់ចម្លើយ សុខ ន្ធូ ឆ.៧ KH 01117324។ ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទ្ធូច ម៉ារ៉ី ឆ.១០៥ KH

ខឿន ចឹម ដែលត្រូវបង្ខំឲ្យរៀបការនៅក្នុងខែ តុលា ឆ្នាំ១៩៧៨ នៅភូមិកាច់រទេះ ឃុំកំពង់ព្រាង បានប្រាប់អ្នកស្ទើបអង្កេតថា "ប្រើសិនបើខ្ញុំចង់ឲ្យឪពុកម្តាយខ្ញុំចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់ខ្ញុំ គេនឹងយកខ្ញុំទៅកសាង"[2869]។

793. របៀបរបបនៃពិធីរៀបអាពាហ៍ពិពាហ៍មានលក្ខណៈសាមញ្ញ។ កម្មាភិបាលខ្មែរក្រហម និងកងឈ្លបបានចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ចំណែកឯសមាជិកគ្រួសាររបស់ពួកគេមិនត្រូវបាន

01352098 (*សម្គាល់* ថាពិធីរៀបការត្រូវបានរៀបចំដោយ យាយចាន់ និងធ្វើនៅបរិវេណខាងក្រៅវត្តវ៉ាងកេសី *សូមមើល* ឯ.៧៤, ៩០, ១២៧ KH 01352095, 01352097, 01352100)។ ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឯ.២៦-២៧ KH 01414387។ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈេន ឯ.៦៨, ៧០ KH 01327961-01327962។ <u>ឃុំកំពង់ព្រៀង</u>៖ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ងើម ឯ.១១៨ KH 01047395 [ក្នុងភូមិកាច់រទេះ ឃុំកំពង់ព្រៀង ខែតុលា ឆ្នាំ១៩៧៨ (*សូមមើល* ឯ.៩០-៩១, ១១៤)៖ "ខ្ញុំបានសុំគណៈសហការណ៍ថា "ខ្ញុំអាចទៅប្រាប់ឪពុកម្តាយរបស់ខ្ញុំបានដែរឬទេ?" គេឆ្លើយថា "មិនបាច់ទេ! កូនអង្គការគឺអង្គការជាអ្នករៀបចំឲ្យ"។"] ឯ.១៥៦ KH 01047400 ["ឪពុកម្តាយរបស់ខ្ញុំមិនគិតថា ការរៀបការរបស់ខ្ញុំត្រឹមត្រូវតាមផ្លូវច្បាប់នោះទេ ព្រោះពួកគាត់មិនបានចូលរួមក្នុងពិធីនេះទេ។"] ឯ.១៦៨ KH 01047402 ["គ្មានអាចារ្យ គ្មានញាតិមិត្តចូលរួម រៀបការពេលនោះ គ្រាន់តែចាប់ដៃហើយចប់។"]។ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ ស្ងើង ចាន់ថន ឯ.១៦, ២០ KH 01096533-01096534 [ក្នុងភូមិថ្មី សហការណ៍កំពង់គូ ឃុំកំពង់ព្រៀង ខែសីហា ឆ្នាំ១៩៧៨ (*សូមមើល* ឯ.១៣, ១៥)]។ ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្ងើម ឯ.៦២ KH 01327950។ ឯកសារ D219/261 កំណត់ហេតុស្តាប់ចម្លើយ ឃឿន ស្ងឿន ឯ.៥៨ KH 01085805។ <u>រោងចក្រសុរសកំពង់គល់</u>៖ ឯកសារ D219/655 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឯ.៧ KH 01196551។ <u>*សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ*</u>៖ ឯកសារ D347/2.1.42 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.11.08-09.15.24 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ខែសីហា ឆ្នាំ១៩៧៨៖ "បងខ្ញុំនៅខ្ជាទទឹងនុងដែរ ប៉ុន្តែគាត់អត់ទៅផង ទៅតែខ្ញុំម្នាក់ឯង អត់មានដឹងថា ទៅរៀបគ្រួសារផង។ សមរភូមិរៀងៗខ្លួន អត់មានបងណាស្គាល់ ម៉ែណាស្គាល់ថា កូនរៀបការអីអត់ទេ អត់ដឹងផង។"]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 13.55.20-13.58.02 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "ត្រង់ហ្នឹងហើយបានខ្ញុំឈឺចាប់។ ការរៀបការនោះ គ្មានបងគ្មានប្អូន គ្មានសាច់ញាតិណោហិតណា ដែលដឹងថាយើងរៀបការយ៉ាងម៉េចទេ គ្មានទេ។ [...] បាយក៏អត់បានហូបដែរ។"]។ ឯកសារ D219/413 កំណត់ហេតុស្តាប់ចម្លើយ សុខ ទូ ឯ.៧ KH 01117324 [នៅក្នុងពិធីរៀបការធំៗចំនួនពីរ នៅស្រុកសង្កែ ខេត្តបាត់ដំបង៖ "ខ្ញុំមិនចាំថា ហេតុការណ៍នេះកើតឡើងនៅក្នុងឆ្នាំណាទេ គ្រាន់តែដឹងថា ក្រោមការគ្រប់គ្រងរបស់ពួកនិរតី។ តាឡឹក គឺជាកម្មាភិបាលម្នាក់ក្នុងចំណោមកម្មាភិបាលផ្សេងៗទៀតដែលមានវត្តមាននៅក្នុងហេតុការណ៍នោះ។"]។ ឯកសារ D219/895 កំណត់ហេតុស្តាប់ចម្លើយ ឃីម លំទោន ឯ.២៥-២៦ KH 01379573-01379574 [ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ឆ្នាំ១៩៧៨]។

[2869] ឯកសារ D219/302 កំណត់ហេតុស្តាប់ចម្លើយ ខឿន ចឹម ឯ.២៥ KH 01096548 (*សូមមើល* ឯ.១៤, ២១ សម្រាប់ទីតាំង និងក្របខ័ណ្ឌពេលវេលា)។

អនុញ្ញាតឲ្យចូលរួមឡើយ[2870]។ កម្មាភិបាលពីថ្នាក់លើច្រើនថ្នាក់បានធ្វើជាអធិបតីក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ក្នុងនោះរួមទាំងប្រធានកង ប្រធានសហករណ៍ និងប្រធានភូមិ ប្រធានឃុំ សមាជិកគណៈស្រុក និងតំបន់ និងតាម៉ុក លេខាភូមិភាគពាយ័ព្យ[2871]។

[2870] *សូមមើលឧទាហរណ៍* <u>ស្រុកសំឡូត</u>៖ ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.២៩ KH 01037141 [ក្នុងស្រុកសំឡូត ឆ្នាំ១៩៧៨៖ "ភរិយារបស់ខ្ញុំប្រាប់ខ្ញុំថា តាទិត្យ និងតាម៉ុក ក៏បានចូលរួមពិធីនោះដែរ។"]។ ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.25.44-11.28.00 [ការ ព្រាប កប នៅស្រុកសំឡូត ឆ្នាំ១៩៧៨៖ "ម៉ែ ឪក៏អត់ដឹង បងប្អូនក៏អត់ដឹង អត់ដឹងខ្ញុំមានគ្រួសារផងហ្នឹង។"]។ ឃុំរ៉ាំងកេសី៖ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេត ជោត ឆ.២, ៦ KH 01085170-01085172 ["ពិធីចាប់ដៃនោះ គឺនៅវត្តរ៉ាំងកេសី [...] គឺនៅចុងឆ្នាំ១៩៧៨ ពេលជិតបែករបបខ្មែរក្រហម។"]។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក មឿន ឆ.៦៥ KH 01327972 [ក្នុងឃុំរ៉ាំងកេសី ខែកញ្ញា ឆ្នាំ១៩៧៧ (*សូមមើល* ឆ.៦១-៦២)៖ "ស៖ តើមនុស្សទាំងអស់ ៧ពាគ្ន នោះ សុទ្ធតែឪពុកម្តាយរៀបចំឲ្យ ឬក៏ជាការផ្សំគ្នុំ្ន របស់អង្គការ? ឆ.៦៥៖ ភាគច្រើនគឺពួកអង្គការចាប់គូ។"]។ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈេន ឆ.៤៤, ៥៨-៦០, ៧០ KH 01327959-01327962 [ការរៀបការ គាត់បានចូលរួមនៅវត្តរ៉ាំងកេសី និងវត្តប៊ីងឈ្លក ដែលបានរៀបចំដោយ យាយចាន់ និងតាឡ៊ីក។ សាច់ញាតិមិនត្រូវបានហៅឲ្យមកចូលរួមទេ]។ ឯកសារ D219/413 កំណត់ហេតុស្តាប់ចម្លើយ សុខ ទូ ឆ.៧ KH 01117324 [ក្នុងវត្តរ៉ាំងកេសី រ៉ាំងកេសី ស្រុកសង្កែ ក្រោមការគ្រប់គ្រងរបស់ពួកភូមិភាគនិរតី (*សូមមើល* ឆ.៧)]។ <u>ឃុំកំពង់ព្រៀង</u>៖ ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្ងៀម ឆ.៥៨-៥៩ KH 01327950 [ប៊ីងឈ្លក សហករណ៍កំពង់គោ ឃុំកំពង់ព្រៀង ក្រោមតាឡ៊ីក និងយាយចាន់ (*សូមមើល* ឆ.៤៧, ៥០, ៥៨)៖ "ឆ.៥៨៖ មានតែតាឡ៊ីក និងយាយចាន់ ហ្នឹងឯង ដែលប្រកាសរៀបឲ្យគូណាគូណីនោះ។ ស៖ តើលោកស្រីឃើញតាឡ៊ីក និងយាយចាន់ នៅក្នុងការរៀបការទាំងពីរលើកនោះដែរ ទេ? ឆ.៥៩៖ ទាំងពីរលើកនោះឯង។"] ឆ.៦២ KH 01327950 ["ស៖ តើអ្នកដែលត្រូវរៀបការទាំងនោះ មានសាច់ញាតិគេចូលរួមដែរឬទេ? ឆ.៦២៖ ដូចមិនឃើញមានផង ឃើញតែតួសាមីៗហ្នឹងឯង។"]។ <u>រោងចក្រស្ករសកំពង់គល់</u>៖ ឯកសារ D219/656 កំណត់ហេតុស្តាប់ចម្លើយ ប៊ុល ស៊ីត ឆ.១៥ KH 01196561 ["គ្រាន់តែដល់ពេលរៀបការ គេហៅយើងជាភ្ញៀវ អង្គុយស្តាប់គេទៅណ៎ា"] ឆ.២៥, ២៧ KH 01196563 [មានតែគណៈរោងចក្រនៅហ្នឹងបណ្តោយ [...] មាន យ៉ាន និង រ៉ី និងអ្នកក្រោមៗទៀត។"]។ ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.២៥ KH 01040122។ <u>*សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម*</u> *<u>សូមមើលផងដែរ</u>*៖ ឯកសារ D219/895 កំណត់ហេតុស្តាប់ចម្លើយ ឃីម លំទោន ឆ.១៧, ១៩ KH 01379572 [ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ឆ្នាំ១៩៧៨ (*សូមមើល* ឆ.១៨, ៣១)៖ "ស៖ កាលនោះ អ្នកណាជាអ្នករៀបចំពិធីរៀបការរបស់លោក? ឆ.១៧៖ មានកម្មាភិបាលភូមិឈ្មោះ ជា។ [...] ស៖ កាលនោះ លោកស្គាល់ឈ្មោះកម្មាភិបាលឡើងប្រកាសនៅក្នុងពេលពិធីចាប់ដៃនោះទេ? ឆ.១៩៖ កម្មាភិបាលប្រកាសនោះឈ្មោះ ជា [...] ហើយកម្មាភិបាលពីរនាក់ទៀតឈ្មោះ តាប៉ោ និងតាភ៉ីង។"] ឆ.២៧-២៨ KH 01379574 ["ស៖ អ្នកដែលជាគណៈអធិបតីនៅក្នុងពិធីរៀបការចាប់ដៃហ្នឹង ជាអ្នកណាគេ? ឆ.២៧៖ ខ្ញុំចាំថា មានតាជា តាតយ តាភ៉ីង និងកម្មាភិបាលនារីម្នាក់ទៀតឈ្មោះ សារ៉ែម និងខ្ញុំនឹកឃើញ តាស្ងួន ម្នាក់ទៀត។ [...] ឆ.២៨៖ អ្នកទាំងប្រាំនាក់ហ្នឹងមានឋានៈស្មើៗគ្នា ជាអ្នកគ្រប់គ្រងភូមិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាឡ៊ីក និងយាយចាន់។"]។ ឯកសារ D219/3 កំណត់ហេតុស្តាប់ចម្លើយ កឹ សឹង ឆ.១១២ KH 01024900 [ក្នុងពិធីរៀបការធំមួយ នៅស្រុកសង្កែ ខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ បន្ទាប់ពីការមកដល់របស់កម្មាភិបាលភូមិភាគពាយ័ព្យ (*សូមមើល* ឆ.១០៧)៖ "ខ្ញុំឃើញមានកម្មាភិបាលថ្នាក់ឃុំ និងថ្នាក់ភូមិចូលរួម។"]។

794. គូស្វាមីភរិយាក្នុងភូមិភាគពាយ័ព្យជាញឹកញាប់ត្រូវបានរៀបការ *ម្តងៗច្រើនគូ* ក្នុងពិធីរួមគ្នា[2872]។ សាក្សីចំនួន ១០ នាក់ បានរំឭកពីពិធីរៀបអាពាហ៍ពិពាហ៍ក្នុងឃុំវ៉ាំងកេសី ដែលក្នុងពេលនៃការ

ឯកសារ D347/2.1.42 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.11.08-09.13.19 [ក្នុងស្រុកបាកាន ខេត្ត ពោធិ៍សាត់ ខែសីហា ឆ្នាំ១៩៧៨៖ "អត់មានបងប្អូនណាស្គាល់ ម៉ែណាស្គាល់ថា កូនរៀបគ្រួសារអីអត់ទេ អត់ដឹងផង។ [...] អង្គការ កំណត់ឲ្យយកអ៊ីចឹ។"]។ ឯកសារ D219/917 កំណត់ហេតុស្តាប់ចម្លើយ ដៃ ទូច ឆ.៦៥ KH 01388681 [ក្នុងខេត្តបាត់ដំបង ឆ្នាំ ១៩៧៨៖ "ដំបូង ខ្ញុំមិនព្រម ខ្ញុំថា ម៉ែឪនៅស្រុកឯណោះ តែគេមិនព្រម គេថា ខ្ញុំត្រូវតែយក។"]។

[2871] <u>ស្រុកសំឡូត</u>៖ ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.05.53-11.07.45 [ក្នុង ស្រុកសំឡូត ខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "កាលហ្នឹងអ៊ីម៉ុកៗ អ្នកចាប់រៀបការតែម្តង។"]។ ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៤៧ KH 01037144 [ក្នុងស្រុកសំឡូត ខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "ការ ប្រកាសឈ្មោះគូស្រករដែលត្រូវរៀបការ ដោយតាម៉ុក។ [...] តាទិត្យ ដែលជាតំណាងតំបន់ ១ ឡើងផ្តល់មតិណែនាំដល់គូស្រករ ដែលរៀបការថ្មី។"]។ <u>ឃុំវ៉ាំងកេសី</u>៖ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈេន ឆ.៤៤ KH 01327959 ["មេ ដឹកនាំ គឺប្រធានសហករណ៍ គេហៅប្រមូលផ្តុំ គឺយាយចាន់ និងតាឡឹក ដែលជាប្រធានសហករណ៍នោះឯង។"]។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេត ជោត ឆ.២, ៦ KH 01085170-72 ["គេធ្វើពិធីចាប់ដៃនោះ គឺនៅវត្តវ៉ាំងកេសី [...] គឺ នៅចុងឆ្នាំ១៩៧៨ ពេលជិតបែករបបខ្មែរក្រហម"] ឆ.១២ KH 01085173 ["អ្នកចូលរួមជាអធិបតីពិធីរៀបការនោះមានឈ្មោះ តា ស ជាមេកង។"]។ ឯកសារ D219/867 កំណត់ហេតុស្តាប់ចម្លើយ ស ហ៊ៀន ឆ.៧, ១១, ៣៤, ៤០ KH 01347421, 01347423-01347424។ ឯកសារ D219/920 របាយការណ៍នៃសកម្មភាពស៊ើបអង្កេត ទូច សា KH 01397344 ["ពួកអង្គការ បានរៀបចំការរៀបការជាក្រុមនោះ។ ឈ្មោះ តាទុយ និងតាង៉ែត បានធ្វើជាគណៈអធិបតីនៅក្នុងពិធីរៀបការនោះ។"]។ តាហេង ជំនួសតាយិន ដែលជាប្រធានសហករណ៍។ *សូមមើល* ឯកសារ D219/391 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៊ុនរ៉ាន ហៅ សុខ ប៊ុ នរ៉ា ឆ.២១ KH 01114661។ <u>ឃុំកំពង់ព្រៀង</u>៖ ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្បាម ឆ.៥៨-៥៩ KH 01327950 [ប៊ីងឈ្លក សហករណ៍កំពង់គោ ឃុំកំពង់ព្រៀង ស្រុកសង្កែ ក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី (*សូមមើល*ឆ.៥០, ៥៨)៖ "ឆ.៥៨៖ មានតែតាឡឹក និងយាយចាន់ ហ្នឹងឯង ដែលប្រកាសរៀបឲ្យគូណាគូណីនោះ។ ស៖ តើលោកស្រីឃើញតាឡឹក និងយាយចាន់ នៅក្នុងការរៀបការទាំងពីរលើកនោះដែរទេ? ឆ.៥៩៖ ទាំងពីរលើកនោះឯង។"]។ ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្បាយ ឆ.២៤ KH 01062688 ["ពិធីនោះ មានប្រធានការដ្ឋាន ធ្វើជាអធិបតី។ ប្រធានការដ្ឋាន នោះឈ្មោះ ពោល គាត់ជាមេកដឹកនាំតែម្នាក់ប៉ុណ្ណោះ ដែលមានវត្តមាននៅទីនោះ។"]។ <u>សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ</u>៖ ឯកសារ D219/18 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឈៀន ឆ.៤៣-៤៤, ៤៦ KH 01029032-01029033 ["ប្រធានកង។ [...] ឈ្មោះ ស៊ុន ដែលជាប្រធានកង ធ្វើជាអធិបតីក្នុងពិធីនោះ។ [...] គាត់មកពីភូមិភាគនិរតី។"]។ ឯកសារ D119/131 កំណត់ហេតុស្តាប់ចម្លើយ ថង ផ្ការ ឆ.៧០ KH 00996500 [ក្នុងខេត្តបន្ទាយមានជ័យ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧ ៖ "[លេខាស្រុកព្រះនេត្រព្រះ] យាយចែម គឺជាអ្នកគ្រប់គ្រងនៅក្នុងពិធីរៀបការនោះទាំងមូល ដោយពេលនោះ គាត់បានស្រែកឲ្យ យើងចាប់ដៃគ្នា។"]។

[2872] <u>ស្រុកសំឡូត</u>៖ ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.39.58-10.43.40 ["ចាស ខ្ញុំគាត់ការនៅសំឡូត ការ៤០គូ។"] ម៉ោង 11.05.53-11.09.05 ["កាលហ្នឹង អ៊ីម៉ុកៗ អ្នកចាប់រៀបការតែម្តង។ ហើយការបានពីរ បីថ្ងៃបាន អ៊ីទិត្យ គាត់មក គាត់មកសួរណែនាំអ៊ីចឹងទៅណា គាត់មកសួរនាំអ៊ីចឹងមានអាណារត់ចោលគ្នាអ៊ីចឹងទៅណា។ ហើយអត់

មានអ្នកណារត់ចោលអ៊ីចឹងក៏គាត់ចេះតែណែនាំទៅអ៊ីចឹង។"]។ ឃុំរ៉ាំងកេសី៖ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១១-១២, ២៨ KH 01096585, 01096587 [អាពាហ៍ពិពាហ៍ដោយបង្ខំបីគូនៅនៅអាងកំពង់គោ ខែកុម្ភ: ឆ្នាំ១៩៧៨]។ ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហៀង ឆ.១២ KH 01117335 [យ៉ាងហោចណាស់មានការរៀបការមួយលើក ត្រូវបានធ្វើឡើងក្រោមការគ្រប់គ្រងរបស់ពួកភូមិភាគនិរតី៖ "មានប្រហែល ៦០គូ គឺធ្វើនៅឃុំរ៉ាំងកេសី និងក្នុងពេលពួកនិរតីគ្រប់គ្រង។ ប្អូនថ្លៃស្រីខ្ញុំម្នាក់ [...] ក៏បានរៀបការក្នុងពេលនោះដែរ។"]។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន ម្ឿន ឆ.៩, ១៩ KH 01425197-01425199 [ពាពាហ៍ពិពាហ៍ដោយបង្ខំបីគូនៅក្បាលថ្នល់ ឃុំរ៉ាំងកេសី នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧]។ ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.៩ KH 01414385 [ក្នុងវត្តរ៉ាំងកេសី ឆ្នាំ១៩៧៨ (សូមមើល ឆ.១០, ១៤)៖ ៨០គូ]។ ឯកសារ D219/828 កំណត់ហេតុស្តាប់ចម្លើយ ឈុំ ឈន ឆ.៤២, ៤៤ KH 01327959 ["រៀបមួយជំនាន់នោះ [...] ម្តង៤០ ៥០គូ។ [...] មេដឹកនាំគឺប្រធានសហករណ៍ គេហៅប្រមូលផ្តុំ។"] ឆ.៧១ KH 01327962 ["រ៉ាំងកេសី ២៥គូ។ នៅបឹងឈ្ងុក លើកទី១ គឺ១០គូ លើកទី២ គឺ៨-៩គូ។"]។ ឃុំកំពង់ព្រៀង៖ ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្ឿម ឆ.៤៨ KH 01327949 [១០-១៥គូ] ឆ.៣២ KH 01327946 ["តាឡឹក ហ្ម៊ីងគាត់ជាអ្នកនិរតី។"] ឆ.៥៨ KH 01327950 ["មានតែតាឡឹក យាយចាន់ហ្ម៊ីងឯង ដែលប្រកាសរៀបការឲ្យគូណាគូណីនោះ"]។ ឯកសារ D219/307 កំណត់ហេតុស្តាប់ចម្លើយ ប៉ាល់ យ៉ុង ឆ.៤៥ KH 01096601 [នៅកំពង់គោ ឆ្នាំ១៩៧៨ (សូមមើល ឆ.៣៧, ៤០)៖ "ចំពោះខ្ញុំ ខ្ញុំមិនចាត់ទុកថា នេះជាការរៀបការទេ គេគ្រាន់តែបញ្ជាយើងឲ្យចាប់ដៃគ្នាប៉ុណ្ណោះ ហើយរៀបចំដោយគ្មានអ្វីទេ។"] ឆ.៥០ KH 01096601 [បីគូ]។ ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្ឿយ ឆ.២៣ KH 01062687 ["ខ្ញុំបានដឹងថាមានការរៀបការ១ម្តង ៥, ៧ ឬ១០ គូ។ ការរៀបការបែបនេះកើតឡើងនៅក្នុងពេលដែលពួកនិរតីកាន់អំណាចនៅពាក់កណ្តាលរបបខ្មែរក្រហម ក្រោយពេលដែល តាឡឹក និង យាយចាន់ ឡើងកាន់អំណាច។"] ឆ.២៤ KH 01062688 [ភូមិកំពង់គោ ឃុំកំពង់ព្រៀង ១១គូ]។ ឯកសារ D65.1.29a ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្ងៀង ចាន់ថន KH 00571762-00571763 [ក្នុងឆ្នាំ១៩៧៨ ឃុំកំពង់ព្រៀង ៥គូ]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ងៀ ឆ.១២៦ KH 01047396 [ក្នុងភូមិកាច់រទេះ ឆ្នាំ១៩៧៨ (សូមមើល ឆ.៩១, ១២៥)៖ ការរៀបការពីរលើក មួយលើក ៤០គូ មួយលើកទៀត ២០គូ]។ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈ្ឿន ឆ.៦ KH 01096521 [ក្រោមការគ្រប់គ្រងរបស់ពួកភូមិភាគនិរតី ឆ្នាំ១៩៧៨ (សូមមើល ឆ.៥)៖ ៦គូ]។ ឯកសារ D219/303 កំណត់ហេតុស្តាប់ចម្លើយ ខ្ឿន ច័ម ឆ.២៥ KH 01096556 [ក្រោមការគ្រប់គ្រងរបស់ពួកភូមិភាគនិរតី ឆ្នាំ១៩៧៨ (សូមមើល ឆ.២០)៖ ១៨គូ]។ រោងចក្រស្ករកំពង់គល់៖ ឯកសារ D219/655 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.៨-៩, ១២-១៣, ១៦, ១៨ KH 01196551-01196553 [ក្រោមការគ្រប់គ្រងរបស់ពួកនិរតី (សូមមើល ឆ.៤)]។ ឯកសារ D219/656 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.៦, ១៣, ២៦, ២៨, ២៩ KH 01196560-01196561, 01196563 [ក្រោមការគ្រប់គ្រងរបស់ពួកភូមិភាគនិរតី (សូមមើល ឆ.៣)]។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១១ KH 01058786 [ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី (សូមមើល ឆ.១០)]។ សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ ៖ ឯកសារ D219/895 កំណត់ហេតុស្តាប់ចម្លើយ ឃីម លំទោន ឆ.៦, ១៧ KH 01379570-01379572 [នៅស្រុកសង្កែ ខេត្តបាត់ដំបង ស្ថិតក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី ក្នុងឆ្នាំ១៩៧៨ (សូមមើល ឆ.៨)៖ "នៅឆ្នាំ១៩៧៨ ខ្ញុំក៏ត្រូវបានរៀបចំឲ្យមានគ្រួសារ។ [...] ក្នុងថ្ងៃរៀបការនោះ គេរៀបការ៧៥គូ ក្នុងពេលជាមួយគ្នា។"]។ ឯកសារ D219/914 កំណត់ហេតុស្តាប់ចម្លើយ ផ្ងៀម ឫបៀប ឆ.៤៨-៤៩ KH 01388655-01388656 [នៅបាត់ដំបង ឆ្នាំ១៩៧៨ ស្ថិតក្រោមការគ្រប់គ្រងភូមិភាគនិរតី (សូមមើល ឆ.៥២)៖ "កាលនោះជិតចប់របបខ្មែរក្រហមហើយ។ [...] នៅចំនប់កំពឹងពួយមានរៀបការ៣០គូដែរ ហើយមានឈ្មោះខ្ញុំដែរ តែខ្ញុំ

ដឹកនាំរបស់ **យ៉ីម ទិត្យ** ហើយក្នុងពិធីនោះ គូស្វាមីភរិយាជាង ៧០ នាក់ បានរៀបការក្នុងពេលជាមួយគ្នា ហើយសាក្សីជាច្រើនបាននិយាយថា យាយចាន់ និងតាឡឹកបានចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍នោះ[2873]។ ជាធម្មតា ពិធីរៀបអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើង នៅក្រៅម៉ោងធ្វើការប្រចាំថ្ងៃ និងគូស្វាមីភរិយាត្រូវបានរៀបការក្នុងពេលតែមួយដើម្បីសន្សំពេលវេលា[2874]។ នៅក្នុងពិធី

រត់ទាំងយប់។ [...] មួយខែ ឬពីរខែឲ្យរៀបម្តង ៣០គូ១។"]។ ឯកសារ D118/228 កំណត់ហេតុស្តាប់ចម្លើយ ម៉ង ឆុន ឆ.៥៨ KH 00985450-00985451 [នៅស្រុកបាកាន៖ "ខ្ញុំត្រូវបានគេបង្ខំឲ្យរៀបការនៅឆ្នាំ១៩៧៨។ គេបង្ខំឲ្យរៀបការម្តងមាន៣០គូ។"]។ ឯកសារ D119/90 កំណត់ហេតុស្តាប់ចម្លើយ ជួន ភាព ឆ.៥ KH 00976139 [នៅខេត្តបន្ទាយមានជ័យ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី (សូមមើល ឆ.៦-៧៖ "ប្រហែល១ខែមុនរៀតណាមចូល ពួកខ្មែរក្រហមបានរៀបចំឲ្យខ្ញុំយកប្រពន្ធនៅពិធីមួយដែលមាន៤៥គូ"]។ ឯកសារ D219/254 កំណត់ហេតុស្តាប់ចម្លើយ រី រ៉ង ហៅ រី សារ៉ង ឆ.១៨ KH 01085145 [នៅមោងឫស្សី ឆ្នាំ១៩៧៨៖ "មានការរៀបការចំនួន៥គូ។"]។ ឯកសារ D219/681 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ហេង ឆ.២៩-៣០ KH 01203890 [នៅសង្កែ ឆ្នាំ១៩៧៨ (សូមមើល ឆ.៣៣)៖ "និរតីគេចាប់ផ្សំផ្ទុំម្តង១០គូ ៦០គូអី ចាប់ផ្តើមរៀប។ [...] ឃើញដែលគេរៀបនោះ ១៥គូ។"]។ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.៤៦-៤៧ KH 01135133 [ទំនប់ ក ង្ហត ស្រុកសង្កែ (សូមមើល ឆ.៤៩)៖ "ខ្ញុំធ្លាប់ឃើញគេរៀបការម្តង២០គូ ក្នុងពេលតែមួយ។ [...] ថ្នាក់ដឹកនាំយោធារបស់ពួកនិរតីដែលរៀបចំពិធីនោះ។"]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារ៉ឹក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 13.41.45-13.49.18 [នៅស្រុកបាកាន ឆ្នាំ១៩៧៨ (សូមមើល ម៉ោង 09.56.29-09.58.56)៖ "១២គូ។"]។ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ សៀង ចាន់ថន ឆ.២០ KH 01096534 [នៅភូមិថ្មី ឃុំធិបតី ស្រុកគាស់ក្រឡ ខែសីហា ឆ្នាំ១៩៧៨ (សូមមើល ឆ.១៣, ១៥)៖ "ឪពុកម្តាយរបស់ខ្ញុំមិនបានចូលរួមទេ [...] ៥គូ"]។

[2873] ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.១៤, ១៦, ២៣ KH 01213311-01213313 [៨០គូ]។ ឯកសារ D219/314 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១៨ KH 01097724 [៧៣គូ]។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.២, ១៤ KH 01085170-01085174 [៧៤គូ]។ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៨១, ៨៣ KH 01032228 [៧០ ទៅ ៨០គូ]។ ឯកសារ D219/867 កំណត់ហេតុស្តាប់ចម្លើយ ស ហ៊ីន ឆ.១១, ១៦ KH 0134721-01347422 [៧៣គូ] ឆ.៧ KH 0134721 ["ខ្ញុំរៀបការបានមួយឆ្នាំ ឃ្លួនរំដោះបាន។"]។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក មឿន ឆ.៦២, ៦៤, ៦៦ KH 01327972 [៧៣គូ]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.៧០-៧២ KH 01328006 [៧០គូ] ឆ.១២៦ KH 01328012 ["ស៖ តើលោកស្រីនៅចាំថាអ្នកណាខ្លះទៀតក្នុងពេលលោកស្រីរៀបការ៧០គូ [...]? ឆ.១២៦៖ នៅក្នុងភូមិហ្នឹងប្រហែល១០គ្រួសារ ហើយនៅព្រៃស្វាយ រាំងក្រោល ស្វាយជាតិ អ៊ីវាច្រើនភូមិណាស់។"]។ ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.៧៤, ៩០, ១០០, ១២៧ KH 01352095 ឆ.៦៤, ៦៦ [៧០ គូ]។ ឯកសារ D219/371 កំណត់ហេតុនៃកិច្ចស៊ើបសួរ រឿងរ៉ាវរបស់ រាជ សារ៉ន KH 01310907-01310908។ ដោយសារ យ៉ីម ទិត្យ ដឹកនាំនៅតំបន់ ៤ សូមមើល៖ III. ឯកសារ D.1. ត្ជនាទី សកម្មភាព និងការអនុវត្ត របស់ យ៉ីម ទិត្យ-យ៉ីម ទិត្យ ចូលរួមក្នុងផែនការព្រហ្មទណ្ឌទូទៅ ក្នុងភូមិភាគពាយ័ព្យ-យ៉ីម ទិត្យ មានត្ជនាទីនៅភូមិភាគពាយ័ព្យ។

[2874] <u>ឃុំកំពង់ព្រៀង</u>៖ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៨៨ KH 01047391 [ក្នុងភូមិកាច់រទេះ ឃុំកំពង់ព្រៀង ឆ្នាំ១៩៧៨ (*សូមមើល* ឆ.១៦, ៩១, ១១៤, ១៣៨)៖ "គេហៅប្រជាជនមកចាប់ដៃគ្នានៅពេលយប់ ព្រោះមិនចង់ឲ្យខាតពេលវេលាធ្វើការ ដូច្នេះគេធ្វើការរៀបការនៅពេលយប់។"]។ ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ

> មួយក្នុងចំណោមពិធីរៀបអាពាហ៍ពិពាហ៍នានា ដែលបានរៀបចំដោយយាយចាន់ និង តាឡឹក ពួកគេបានបង្ហាញពីការពេញចិត្តលើពិធីរៀបអាពាហ៍ពិពាហ៍យ៉ាងមានប្រសិទ្ធភាពទាំងនេះពីព្រោះថា ពិធីទាំងនោះបានកាត់បន្ថយជាអតិបរមាក្នុងការរំខានដល់បង្ករបង្កើនផលដោយអះអាងថា "បើយើងរៀបការម្តងមួយគូ គឺខាតពេលវេលាកម្មាភិបាល។ ការងារ ដូចជាស្ងួងស្រូវ និងវែកដីនឹងមិនស្ទះ ដោយសារតែពិធីរៀបអាពាហ៍ពិពាហ៍ទាំងនេះឡើយ"[2875]។

795. ដើម្បីញ៉ាំងឲ្យពិធីរៀបអាពាហ៍ពីពាហ៍ផ្សេងទៀតបន្តរៀបចំឡើង នៅគ្រប់កន្លែងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ[2876] នៅឯពិធីរៀបអាពាហ៍ពិពាហ៍ក្នុងភូមិភាគពាយ័ព្យ គូស្វាមីភរិយាថ្មី

.១១៣ KH 01151013 [ភូមិសំបុកអក ឃុំកំពង់ព្រៀង] ឆ្នាំ១៩៧៨ (*សូមមើល* ឆ.៣០, ៥៥១-៥៥២, ១០៤-១០៦)៖ "គេរៀបចំធ្វើនៅឃ្លាំងដាក់សម្ភារ: ជិតឃ្លាំងស្រូវ នៅក្នុងភូមិសំបុកអក នៅសហករណ៍កំពង់គោ នៅថ្ងៃល្ងាចប្រហែលជាម៉ោងបួន-ប្រាំ។"]។ ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្បើយ ឆ.២៤ KH 01062688 [ភូមិកំពង់គោ ឃុំកំពង់ព្រៀង បន្ទាប់ពីក្រុមនិរតីកាន់អំណាច (*សូមមើល* ឆ.២៣-២៤) នៅម៉ោង ៦ល្ងាច]។ ឯកសារ D219/302 កំណត់ហេតុស្តាប់ចម្លើយ ខ្ចឿន ចឹម ឆ.១៨ KH 01096547 [ក្នុងភូមិកាច់រទេះ ឃុំកំពង់ព្រៀង ខែតុលា ឆ្នាំ១៩៧៨ (*សូមមើល* ឆ.១២, ២១)៖ "គេឲ្យយើងរៀបការនៅម៉ោង ១០យប់ ជួនកាលព្រឹកឡើងយើងច្រឡំគូគ្នា ដោយសារតែនៅពេលយប់ងងឹតពេក យើងមើលមិនច្បាស់។"]។ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៦ KH 01096521-01096522 [ភូមិថ្មី ឃុំកំពង់ព្រៀង ឆ្នាំ១៩៧៨ (សូមមើល ឆ.៥-៧)៖ "ពិធីរៀបការច្រើនតែរៀបចំនៅពេលយប់។ [...] ពេលនោះ មានអ្នកខ្លះមិនបានចាំមុខគូរបស់ខ្លួនទេ ព្រោះយប់ងងឹត យើងមិនអាចមើលមុខគ្នាច្បាស់។"]។ <u>សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម *សូមមើល ផងដែរ*</u>៖ ឯកសារ D219/423 កំណត់ហេតុស្តាប់ចម្លើយ យ៉ុន ឃឿន ឆ.៤៦, ៤៨ KH 01121673 [នៅទំនប់កង្ហត ភូមិកង្ហត ឆ្នាំ១៩៧៨ (*សូមមើល* ឆ.៥)៖ "ធ្លាប់មាន[ការរៀបការដោយបង្ខំ]នៅទំនប់កង្ហត។ [...] ការរៀបការនោះ គឺធ្វើនៅទីធ្លានៅវេលាប្រហែលជាម៉ោង ៥ ល្ងាច។"]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 13.55.20-13.58.02 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "អង្កាល់នោះ ឡើងមកពីធ្វើការទៅអង្គុយជួរ គ្មានអ្នកណាមួយមុខស្រស់ និងពេញចិត្ត [...] ព្រោះហេវផង ហត់ផង មកដល់គេចាប់ញ្ជាត់ៗ គ្នាគ្មានបាននិយាយគ្នា ហើយក៏គ្មានឃើញមុខគ្នា ដែលស្គាល់ច្បាស់លាស់ថា បងណាជាមិត្តណា គឺខ្ញុំអត់បានឃើញ។"]។ ឯកសារ D347/2.1.42 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទីចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.08.51-09.11.08 [ក្នុងស្រុកបាកាន ឆ្នាំ១៩៧៨៖ "ស៖ តើរៀបការហ្នឹង នៅពេលម្ទើរណាដែរ? ឆ៖ រៀបការហ្នឹងពេលយប់ហើយ។"]។ ឯកសារ D219/494.1.2 ម៉ម សៀម ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 15.50.46-15.53.23 [នៅទំនប់ត្រពាំងថ្ម ខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៧៧៖ "រៀបការនៅពេលយប់"]។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ រណ្ណ ណាក់ ឆ.៦០ KH 01104623 [ក្នុងភូមិអ្ងសទ្ធក ឃុំ៣០ ខេត្តបាត់ដំបង ខែកក្កដា ឆ្នាំ១៩៧៨ (សូមមើល ឆ.២៨-២៩, ៦១)៖ "នៅម៉ោង១១យប់ ថ្ងៃដដែល គេក៏បានរៀបការឲ្យយើង។"]។

[2875] ឯកសារ D219/723 កំណត់ហេតុស្តាប់ចម្លើយ លឹម សាលឿន ឆ.១៨-១៩ KH 01213312។

[2876] *សូមមើល* V.B.7.d.i. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – ការរៀបការដោយបង្ខំ និងការរំលោភ – ការរៀបការក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ – ការអនុវត្តគោលនយោបាយជាតិ – ពិធីរៀបការ។

ត្រូវបានប្រកាសថាត្រូវរៀបការតាមរយៈ ការហៅឈ្មោះ ឬបុរស និងស្ត្រីត្រូវបានបង្គាប់ឲ្យឈរជាជួរទល់មុខគ្នា ហើយណែនាំឲ្យចាប់ដៃគ្នាជាមួយនឹងមនុស្សឈរទល់ខ្លួនដើម្បីកំណត់ពីការរៀបការ[2877]។ បន្ទាប់មក គូស្វាមីភរិយាត្រូវបានណែនាំឲ្យធ្វើការប្តេជ្ញាចិត្ត ដែលក្នុងនោះធ្វើការសន្យាថាខិតខំធ្វើការជូនអង្គការ និងប្តេជ្ញាស្រឡាញ់ប្តី ឬប្រពន្ធថ្មីរបស់ខ្លួន។[2878]

[2877] <u>ស្រុកសំឡូត</u>៖ ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.43.40-10.50.02 [ក្នុងឆ្នាំ១៩៧៨៖ "ឲ្យអង្គុយ យុវជនមួយចំហៀង ប្រុសៗមួយចំហៀង ស្រីៗមួយចំហៀងអ៊ីចឹង ឲ្យចាប់ឡើងចាប់ដៃគ្នា។"]។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៦៨ KH 01008708។ <u>ឃុំរាំងកេសី</u>៖ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.២៥ KH 01414387 [ខាងមុខវត្តរាំងកេសី ក្នុងឆ្នាំ១៩៧៨ (*សូមមើល* ឆ.១០, ១២, ១៤)៖ "ខាងនេះមិត្តៗនារី ខាងនេះមិត្តៗបុរស ហើយគេឲ្យអង្គុយជាជួរអ៊ីចឹង បន្ទាប់មក គេឲ្យឡើងប្តេជ្ញា ហើយគេផ្ទែងការណ៍ហើយ គេឲ្យហូបបបរម្នាក់ បីវែក ហើយគេឲ្យទៅផ្ទះរៀងៗខ្លួនវិញទៅ។"]។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៩៨ KH 01032176-01032177 [នៅឃុំរាំងកេសី ឆ្នាំ១៩៧៨ (*សូមមើល* ឆ.២៦, ១០០)៖ "បន្ទាប់មក គេឲ្យអង្គុយជាជួរទល់មុខនឹងខាងបុរស បើអង្គុយចំមុខបុរសណា ត្រូវរៀបការជាមួយនឹងបុរសម្នាក់នោះ។"]។ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៨១ KH 01032228 [នៅកែ្សត្រវត្តរាំងកេសី ឃុំរាំងកេសី ឆ្នាំ១៩៧៨ (*សូមមើល* ឆ.៨៣)៖ "គេមិនបានប្រាប់ខ្ញុំថាត្រូវរៀបការទេ គេបានជ្រើសរើសមនុស្សចេញពីកងចល័ត ហើយឲ្យមកអង្គុយជាពីរជួរ ដោយម្ខាងបុរស ម្ខាងនារី។"]។ <u>ឃុំកំពង់ព្រៀង</u>៖ ឯកសារ D219/827 កំណត់ហេតុស្តាប់ចម្លើយ ទុយ ក្ងឹម ឆ.៥២ KH 01327949។ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀង ចាន់ថន ឆ.២២ KH 01096534 [ក្នុងភូមិថ្មី សហគមន៍កំពង់គោ ខែសីហា ឆ្នាំ១៩៧៨ (*សូមមើល* ឆ.១៣, ១៥)៖ "នៅក្នុងពិធីរៀបការនោះ ប្រុសអង្គុយមួយជួរ ស្រីអង្គុយមួយជួរ។"]។ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៦ KH 01096521-01096522 [ភូមិថ្មី ឃុំកំពង់ព្រៀង ឆ្នាំ១៩៧៨ (*សូមមើល* ឆ.៥, ៧)៖ "គេឲ្យយុវជន យុវនារីអង្គុយជាជួរ ម្ខាងម្នាក់។"]។ ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្ងើយ ឆ.២៤ KH 01062688។ <u>រោងចក្រសុរសកំពង់គល់</u>៖ ឯកសារ D219/88 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.២៥ KH 01040122។ ឯកសារ D219/656 កំណត់ហេតុស្តាប់ចម្លើយ ប៊ុល ស៊ីត ឆ.២៤ KH 01196563។ <u>សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម *សូមមើលផងដែរ*</u>៖ ឯកសារ D219/895 កំណត់ហេតុស្តាប់ចម្លើយ ឃីម លំទោន ឆ.៦, ១៧-១៨ KH 01379570-01379572 [ក្នុងស្រុកសង្កែ ខេត្តបាត់ដំបង ឆ្នាំ១៩៧៨]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 13.43.49-13.49.18 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "ខ្ញុំដើរទៅ ឃើញគេអង្គុយតម្រង់ជួរ ប្រុសមួយជួរ ស្រីមួយជួរទៅហើយ។"]។

[2878] <u>ស្រុកសំឡូត</u>៖ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៦៨ KH 01008708។ *សូមមើលផងដែរ* ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.43.40-10.50.02, 11.07.45-11.12.25, 11.22.10-11.24.11។ <u>ឃុំរាំងកេសី</u>៖ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១១-១២, ២៦ KH 01096585, 01096587 [ក្នុងភូមិវត្តកណ្តាល ឃុំរាំងកេសី ខេត្តបាត់ដំបង៖ "ខ្ញុំត្រូវបានគេប្រាប់ឲ្យរៀបការ [...]។ ខ្ញុំរៀបការនៅខែកុម្ភៈ ឆ្នាំ១៩៧៨ នៅម៉ោងប្រាំពីរល្ងាច។ [...] ខ្ញុំត្រូវបានកម្មាភិបាលនិរតីបញ្ជាឲ្យរៀបការនៅអាងកំពង់គោ។ [...] គេ [...] ឲ្យយើងចាប់ដៃគ្នា ហើយធ្វើតាមអង្គការ។"]។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក មឿន ឆ.៦២, ៦៦-៦៧ KH 01327972-01327973 [ក្នុងឃុំរាំងកេសី ឆ្នាំ១៩៧៧៖ "ស៖ តើលោករៀបការនៅទីណាដែរ? ឆ.៦២៖ នៅមុខវិហារវត្តរាំងកេសី។ [...] ស៖

ក្នុងការយល់ព្រម

796. ដូចគ្នានឹងជនរងគ្រោះរាប់ពាន់នាក់ផ្សេងៗទៀតនៅទូទាំងប្រទេស បុរស និងស្ត្រីដែលត្រូវបានគេបង្ខំឲ្យរៀបអាពាហ៍ពិពាហ៍ក្នុងស្រុកសំឡូត ឃុំកំពង់ព្រាង និងឃុំវ៉ាំងកេសី និងនៅរៀងចក្រកំពង់គល់ មិនបានឯកភាពពិតប្រាកដជាមួយនឹងអាពាហ៍ពិពាហ៍របស់ពួកគេនោះទេ។ ណុប ង៉ីម អនុលេខាស្រុកសំឡូត មានអារម្មណ៍ថា គាត់គ្មានជម្រើសឡើយ ក្រៅពីស្តាប់ការការណែនាំឲ្យរៀបការ

តើអ្នកណាជាអ្នកដឹកនាំកម្មវិធីរៀបការនោះ? ឆ.៦៦៖ [...] យាយចាន់ និងតាឡឹក។ [...] ឆ.៦៧៖ គេណែនាំខ្លះដែរ គឺប្រឹងគោលជំហរឲ្យល្អ ធ្វើការជូនអង្គការតែប៉ុណ្ណោះ។"]។ ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.២៤-២៦ KH 01414387 [ខាងមុខវត្តវ៉ាំងកេសី ក្នុងឆ្នាំ១៩៧៨ (សូមមើល ឆ.១០, ១២, ១៤)៖ "ស៖ ពេលរៀបការណោកហ្ម៊ីង តើអ្នកណាគេជាគណៈអធិបតី? ឆ.២៤៖ [...] គេក៏ពួកនិរតីដែរ គេប្រាប់ថា យើងត្រូវចេះស្រឡាញ់គ្នា សាមគ្គីគ្នា ហើយធ្វើការឲ្យអង្គការផង [...] ឆ.២៥៖ ខាងនេះមិត្ត១នារី ខាងនេះមិត្តបុរស ហើយគេឲ្យអង្គុយជាជួរអ៊ីចឹង បន្ទាប់មក គេឲ្យឡើងប្តេជ្ញា [...] ឆ.២៦៖ គេផ្ទែងការណ៍ឲ្យយើងចេះស្រឡាញ់គ្នា។"]។ <u>ឃុំកំពង់ព្រៀង</u>៖ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀង ចាន់ថន ឆ.២២ KH 01096534 [ក្នុងភូមិថ្មី សហគមន៍កំពង់គោ ខ៉ែ សីហា ឆ្នាំ១៩៧៨ (*សូមមើល* ឆ.១៣, ១៥)៖ "គេប្រជុំណែនាំឲ្យគោរពតាមការចាត់តាំងរបស់អង្គការ ដែលឲ្យយើងរៀបការជាប្តីប្រពន្ធ ហើយត្រូវតែខិតខំធ្វើការតាមការណែនាំរបស់អង្គការ។"]។ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ប៊ុនឈឿន ឆ.៦ KH 01096521-22 [ភូមិថ្មី សហករណ៍កំពង់គោ ក្រោមការគ្រប់គ្រងរបស់ពួកនិរតី៖ "ពួកខ្មែរក្រហម [...] ឲ្យយើងដែលត្រូវរៀបការនោះ ឡើងប្តេជ្ញាចិត្ត យកគ្នាជាប្តីប្រពន្ធ ហើយគោរពតាមបទបញ្ជារបស់អង្គការ។"]។ ឯកសារ D219/303 កំណត់ហេតុស្តាប់ចម្លើយ ខ្ឿន ចឹម ឆ.២ KH 01096552។ ឯកសារ D219/167 កំណត់ហេតុស្តាប់ចម្លើយ ឃៀម ក្បាយ ឆ.២៤ KH 01062688 [ភូមិកំពង់គោ ក្រោមការគ្រប់គ្រងរបស់និរតី (*សូមមើល* ឆ.២៣-២៤)៖ "មានប្រជាជនចំនួន ១១គូ ត្រូវបានដាក់ឲ្យអង្គុយជាជួរទល់មុខគ្នា ហើយនិងចាប់ដៃគ្នា ហើយប្រកាសប្តេជ្ញាថានឹងយកគ្នាជាគូ។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ងៀម ឆ.៩៧ KH 01047392 [ក្នុងភូមិកាច់រទេះ ឃុំកំពង់ព្រៀង ឆ្នាំ១៩៧៨ (*សូមមើល* ឆ.១៦, ៩១, ១១៤, ១៣៨)៖ "នៅពេលនោះ គេនិយាយថា [...] "ឲ្យនារី និងបុរសដែលនៅលីវចាប់គ្នាបង្កើតកូន ដើម្បីកសាងជាតិ"។"]។ <u>សម្រាប់គោលបំណងសហឧក្រិដ្ឋកម្ម*រួម* *សូមមើលផងដែរ*</u>៖ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 13.55.20-13.58.02 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "គ្រាន់តែឈោងចាប់ដៃគ្នា។"] ម៉ោង 14.02.07-14.04.56 ["ឡើងប្តេជ្ញាចិត្តថា ខាងប្រុសអ្នកស្រែកទទួលប្តេជ្ញាចិត្ត ទទួលមិត្តនារីនេះអត់សម្លាប់ជីវិត។"]។ ឯកសារ D219/494.1.14 មាន លឿយ ប្រតិចារឹក ថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៥ ម៉ោង 14.13.46-14.17.45 [ក្នុងភូមិថ្នាក់ដាច់ ខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៧៧៖ "គេប្រកាសឲ្យអ្នកទាំងអស់គ្នាហ្ម៊ីងដឹងថា ថ្ងៃនេះអង្គការរៀបការឲ្យអ្នកទាំងអស់គ្នាហើយ ទាំងអស់មាន ៦ពាគូ តែអ្នកត្រូវប្រព្រឹត្តទៅតាមមាគ៌ារបស់អង្គការ ទោះបីជាអង្គការឲ្យអ្នកប្តេជ្ញាយ៉ាងណា គឺឲ្យបានយ៉ាងនោះ។ ប៉ុណ្ណ៏ងទៅ គេឲ្យយើងចាប់ដៃគ្នា បាទ ចាប់ដៃគញ្ញានាមួយគូ១ទៅ បានគេឲ្យអ្នកកណ្តាលហ្ម៊ីង គេឡើងប្តេជ្ញាដើម្បីអនុវត្តទៅតាមមាគ៌ារបស់អង្គការ ធ្វើយ៉ាងណាមួយហ៊ីកតា ឲ្យបានបីតោនទៅបួនតោន។"]។ ឯកសារ D6.1.343 កំណត់ហេតុស្តាប់ចម្លើយ យី ឡៃស្ងូ KH 00279135 [ស្រុកព្រះនេត្រព្រះ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "គេឲ្យយើងឡើងប្តេជ្ញាចិត្ត។ គេប្រាប់យើងថា ឲ្យយើងយកមួយនឹងមួយ ហើយប្តេជ្ញាបម្រើអង្គការ។"]។

បើទោះបីគាត់ជាកម្មាភិបាលដែលគួរឲ្យទុកចិត្តម្នាក់កាន់មុខតំណែងសំខាន់ក្នុងស្រុកក៏ដោយ។ គាត់បានផ្តល់សក្ខីកម្មថា៖

> ខ្ញុំបានយំ។ ខ្ញុំមានការខកចិត្ត ខកចិត្តយ៉ាងខ្លាំង ពីព្រោះខ្ញុំពុំធ្លាប់បានឃើញអនាគតប្តីរបស់ខ្ញុំ មុនថ្ងៃរៀបការឡើយ បើទោះយើងជាកងទ័ពក៏ដោយ។ ប៉ុន្តែ ប្រសិបើខ្ញុំបាន [...] បដិសេធ ខ្ញុំអាចត្រូវបានគេសម្លាប់។ ដូច្នេះ ខ្ញុំក៏យល់ព្រមទទួលយកស្ថានភាពនោះទៅ[2879]។

797. បើទោះបីក្នុងករណីខ្លះ បុរស និងស្ត្រីមិនត្រូវគម្រាមកំហែងយ៉ាងច្បាស់លាស់ក៏ដោយ ក៏ បរិយាកាសទូទៅអំពីភាពភ័យខ្លាចបានធ្វើឲ្យពួកគេជាច្រើននាក់មានជំនឿថា អង្គការអាចនឹងដាក់ទណ្ឌកម្មពួកគេ ដោយសារ "មិនគោរពតាមអង្គការ" ប្រសិនបើពួកគេបដិសេធ ហើយថា ពួកគេ គ្មានជម្រើសអ្វីផ្សេងឡើយ ក្រៅពីទទួលយកការរៀបអាពាហ៍ពិពាហ៍នោះ[2880]។ អ្នកខ្លះ "យល់ព្រម

[2879] ឯកសារ D219/974.1.2 ណុប ធ็ម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.39.58-10.43.40។ *សូមមើលផងដែរ* ឯកសារ D219/974.1.2 ណុប ធ็ម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.59.55-11.03.38 [ក្នុងស្រុកសំឡូត ខេត្ត បាត់ដំបង ឆ្នាំ១៩៧៨៖ "ស៖ អ៊ីចឹងគេក៏បានបង្ខំ ឡេង ឲ្យរៀបការជាមួយយោធាពិការដែរ។ តើអ៊ីចឹង ឬដូចម្តេច? ឆ៖ គេបង្ខំ ឲ្យគាត់រៀបការដែរ គាត់អត់មាត់ទេ ចេះតែការទៅ ទាំងគេទាំងខ្ញុំ ចេះតែទៅ។ ក្រុមគេចាត់តាំងហើយ។"] ម៉ោង 11.12.25-11.17.05 ["ខ្ញុំមិនមានជម្រើស ប៉ុន្តែត្រូវតែធ្វើតាមផែនការរបស់អង្គការ។"]។ ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៧៥ KH 01037149 ["គ្មានឧរណាសួរខ្ញុំថា ចង់រៀបការ ឬក៏អត់ទេ។ តែយើងត្រូវធ្វើតាមបញ្ញា និងការណែនាំរបស់គេ បើមិនដូច្នេះ យើងនឹងមានបញ្ហា។"]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 13.43.49-13.49.18 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "បក្សកំណត់មកហើយ ត្រូវតែរៀបការ។"] ម៉ោង 13.53.26-13.55.20 ["អ្នកឯងមិនរៀបការ ប្រយ័ត្នគេចាប់ទៅកសាង។ ដល់ពេលខ្ញុំសួរសំឡេងកសាង ក៏ខ្ញុំចូលខ្ជួនទៅឲ្យគេស្លៀកសំពត់ចង ចង្វាចេក ទៅអង្គុយជួរនឹងគេ។"]។

[2880] <u>ឃុំរ៉ាំងកេសី</u>៖ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩០ KH 01032229 [នៅកែ្សរវត្តរ៉ាំងកេសី ឆ្នាំ ១៩៧៨ (សូមមើល ឆ.៨៣)៖ "អត់មានអ្នកណាហ៊ានប្រកែកទេ បើហ៊ានប្រកែកគេនឹងយកទៅសម្លាប់ចោល។"]។ ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១១២ KH 01352098-01352100 (កំណត់សំគាល់៖ ការៀបការត្រូវបានរៀបចំ ដោយយាយចាន់ ហើយធ្វើនៅខាងក្រៅវត្តរ៉ាំងកេសី សូមមើល ឆ.៧៤, ៩០, ១២៧ KH 01352094 ឆ.៦៤, ៦៦)។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១០៤ KH 01032177 [នៅរ៉ាំងកេសី ឆ្នាំ១៩៧៨ (សូមមើល ឆ.២៦, ១០០)៖ "ទាំងអស់គ្នានៅពេលនោះពុំមានប្រកែកអ្វីទេ ព្រោះឪពុកម្តាយម្ខាងៗបានប្រាប់ថា កុំប្រកែកអី ខ្លាចគេយកទៅវ៉ៃចោល ចាំពេលក្រោយទៀតទៅ។"] ឆ.១១៤ KH 01032178 ["គឺអង្គការបានកំណត់ថា មិនអាចប្រកែកបានទេ ត្រូវតែរៀបការ។"]។ ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.៣២ KH 01414388 [នៅមុខវត្តរ៉ាំងកេសី ក្នុងឆ្នាំ១៩៧៨ (សូមមើល ឆ.១០, ១២, ១៤)៖ "អង្គាល់នោះ គ្នាខ្លាចចេះតែយកទៅ បើមិនរៀបការទេ គេឲ្យយើងទៅជីកប្រឡាយ ជីកព្រែក អានុ៎ងហាត់ណាស់ ហាត់ជាងច្រូតស្រូវ។"]។ រោងចក្រស្ករសកំពង់គល់៖ ឯកសារ D219/656 កំណត់ហេតុស្តាប់ចម្លើយ ប៉ុល ស៊ីត ឆ.១១-១២, ២៦-២៩ KH 01196561, 01196563។ ឯកសារ D219/655 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១២-១៣ KH 01196552។ ឃុំ

" ទទួលយកការរៀបអាពាហ៍ពិពាហ៍ ពីព្រោះពួកគេបានឃើញ ឬបានស្តាប់ឮ រឿងរ៉ាវអំពីការធ្វើទារុណកម្មលើអ្នកជំទាស់[2881]។ អ្នកខ្លះទៀត "យល់ព្រម" ទទួលយក បន្ទាប់ពីពួកគេទទួលរងការ

កំពង់ព្រៀង៖ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ ស្ងៀង ចាន់ថន ឆ.១៦, ១៨ KH 01096533 ។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ងឿម ឆ.១២៣ KH 01047395 ។ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៨ KH 01096522 ["អ្នកដែលមិនព្រមការ គេបញ្ជូនទៅភ្ជុំត្រជាក់ចិត្ត [...] ខ្ញុំឮថា គេថាតំបន់នោះជាកន្លែងដែលពោរពេញទៅដោយជំងឺគ្រុនចាញ់។ [...] អ្នកខ្លះក៏ឈឺគ្រុនចាញ់ស្លាប់នៅទីនោះ។"] ។ សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ ៖ ឯកសារ D219/494.1.11 ឃី ឡៃស្វូ ប្រតិចារឹក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ម៉ោង 14.00.33-14.03.44 [នៅស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "អត់ចង់ទេ ប៉ុន្តែខ្លាចគេ ទៅ។"] ។ ឯកសារ D219/888.1.8 ង៉ែត ចាត ប្រតិចារឹក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 16.02.04-16.04.09 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ខែសីហា ឆ្នាំ១៩៧៨៖ "ខ្ញុំងាកទៅមើល ហ្ស! អ៊ីក៏ចាស់មាំម្ល៉ះ ហើយយកខ្ញុំមកអាយុទើប២០ជាង គាត់៤០ជាងហើយ បងខ្ញុំឡើង១៨ឆ្នាំ។ ខ្ញុំថាប្រកែកក៏មិនដឹងប្រកែកថាម៉េច និយាយក៏មិនដឹងនិយាយថាម៉េច"] ។ ឯកសារ D219/147 កំណត់ហេតុស្តាប់ចម្លើយ ម៉ាន់ ជួន ឆ.២៤៣-២៤៥ KH 01056180 [នៅមោងឫស្សីស្ថិតក្រោមការគ្រប់គ្រងរបស់ភូមិភាគនិរតី (សូមមើល ឆ.២៣២, ២៣៩)៖ "ខ្ញុំមិនហ៊ាន [ជំទាស់] ទេ។ [...] ដោយសារយើងខ្លាចពួកគេ ហើយពួកគេមានអំណាច។"] ។ ឯកសារ D219/254 កំណត់ហេតុស្តាប់ចម្លើយ រី រ៉ង ហៅ រី សារ៉ង ឆ.១៧ KH 01085145 [នៅភ្នំបាសាក់ មោងឫស្សី ចុងឆ្នាំ១៩៧៨ (សូមមើល ឆ.១៦)៖ "បើមានអ្នកណាហ៊ានបដិសេធ ក៏មិនអាចបដិសេធបានដែរ។ គេសម្ពុតយើងថាឲ្យយើងធ្វើតាមបញ្ជារបស់គេ បើយើងចង់បដិសេធ គេនឹងសួរយើងថា តើហេតុអីបានជាអ្នកឯងហ៊ានបដិសេធ អ្នកឯងចង់ឈ្នះយើងឬ បានជាហ៊ានបដិសេធនឹងបញ្ជាយើង។"] ។ ឯកសារ D347/2.1.42 ង៉ែត ចាត ប្រតិចារឹក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.51.50-09.53.34 [នៅស្រុកបាកាន ឆ្នាំ១៩៧៨៖ "បានតែណាក់កំបាំងដែរ ខ្ញុំអត់ហ៊ានពេញមុខ ខ្ញុំខ្លាចដែរ ព្រោះអ៊ីខ្ញុំតែប្រកែកអ៊ីចឹង ក៏ចេះតែថាប្រកែកអ៊ីចឹងទៅ ប៉ុន្តែទៅចេះតែនៅតែទៅ អ៊ីចឹង។ បើថា ឲ្យប្រកែកពេញធ្ងន ខ្ញុំអត់ហ៊ានប្រកែកទេ ព្រោះអ៊ីមួយជំនាន់ហ្នឹង ដឹងស្រាប់ហើយ តែប្រកែកអត់បានអ៊ីចឹងតែម្តង។"] ។ ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម ឆ.១៦៣ KH 01025551-01025552 [សាក្សីគឺជាសមាជិកម្នាក់នៃគណៈសហការណ៍សំរោង ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៧-១៩៧៩ (សូមមើល ឆ.៤៣, ៥១)៖ "ស៖ បើអ្នកណាបដិសេធមិនព្រមរៀបការ គេនឹងចោទថាជា "ខ្ជាំង" តើត្រឹមត្រូវដែរឬទេ? ឆ៖ ចាស ត្រឹមត្រូវ។"] ។

[2881] <u>ឃុំរ៉ាំងកេសី</u>៖ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៩៧-៩៨, ១០១-១០២ KH 01032230 ["ស៖ នៅក្នុងឆ្នាំ១៩៧៨ គេបានបង្ខំឲ្យរៀបការមនុស្សប្រហែល៧៥គូ ហើយមានបុរសម្នាក់បានប្រកែក រួចគេយកទៅសម្លាប់ចោល តើលោកបានឃើញហេតុការណ៍នេះដោយផ្ទាល់ភ្នែកដែរឬទេ? ឆ.៩៧៖ ខ្ញុំមិនបានឃើញ [...] តែបុរសម្នាក់នោះបាត់ខ្លួនរហូតដល់សព្វថ្ងៃនេះ។ ឆ.៩៨៖ រៀបការនៅកន្លែងជាមួយនឹងខ្ញុំដែរ អំឡុងឆ្នាំ១៩៧៨។ [...] ឆ.១០១៖ គេបានលើកករណីរបស់គាត់ឡើងនៅក្នុងអង្គប្រជុំ ដោយគេនិយាយថា "មិត្តនេះប្រកែក មិនត្រូវធ្វើតាមនោះទេ"។ បន្ទាប់មកគេក៏នាំបុរសម្នាក់នោះចេញទៅ។ [...] ឆ.១០២៖ ហេតុការណ៍នេះកើតឡើងពេលដែលគេបង្ខំឲ្យខ្ញុំរៀបការនៅក្នុងវត្តរ៉ាំងកេសី។ មិនមែនតែខាងបុរសម្នាក់នោះទេ សូម្បីតែខាងនារីក៏ត្រូវគេនាំចេញទៅដែរ។"] ។ ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.១១២, ឆ.១១៤-១១៥ KH 01352098-01352099 ["ស៖ តើមានអ្នកណាបដិសេធមិនរៀបការទេ? ឆ.១១២៖ មិនហ៊ានទេ។ [...] ស៖ ធ្វើម៉េចបានលោកស្រីដឹងថា អត់ព្រមរៀបការត្រូវគេយកទៅសម្លាប់? ឆ.១១៤៖ ព្រោះមានគេបាត់ខ្លួន។ [...] ឆ.១១៥៖ ស្រី ប្រុស។"] (កំណត់សំគាល់ ៖ ការរៀបការត្រូវបានរៀបចំដោយយាយចាន់ ហើយធ្វើនៅខាងក្រៅវត្តរ៉ាំងកេសី សូមមើល ឆ.៧៤, ៩០, ១២៧ KH

01352094 ឯ.៦៤, ៦៦)។ ឯកសារ D219/311 កំណត់ហេតុស្តាប់ចម្លើយ ពែង សាន្ត ឯ.២០ KH 01097692 [ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ (សូមមើល ឯ.១)៖ "ខ្ញុំដឹងអំពីការរៀបការរបស់បងប្រុសខ្ញុំ គេគំរាមគាត់ថា បើមិនព្រមរៀបការ គឺត្រូវស្លាប់។ [...] គេរៀបចំនៅវត្តរ៉ាំងកេសី ហើយអាចថាមាន៨ ទៅ៩គូនៅពេលនោះ។"]។ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឯ.៩០, ៩៧-១០២ KH 01032229-01032230 [សាក្សីបានរៀបរាប់ពីរបៀបដែលបុរសម្នាក់ប្រកែកមិនរៀបការត្រូវបានគេប្រើជារឿងព្រមានដល់កម្មករផ្សេងទៀត៖ "ស៖ តើលោកដឹងដោយរបៀបណាថា បុរសម្នាក់នោះបានប្រកែក? ឯ.១០១៖ ព្រោះគេបានលើកករណីរបស់គាត់ឡើងនៅក្នុងអង្គប្រជុំ ដោយគេនិយាយថា "មិត្តនេះប្រកែក មិនត្រូវធ្វើតាមនោះទេ"។ បន្ទាប់មកគេក៏នាំបុរសម្នាក់នោះចេញទៅ។ [...] ឯ.១០២៖ មិនមែនតែខាងបុរសម្នាក់នោះទេ សូម្បីតែខាងនារីក៏ត្រូវគេនាំចេញទៅដែរ។"]។ ឃុំកំពង់ព្រៀង៖ ឯកសារ D219/798 កំណត់ហេតុស្តាប់ចម្លើយ ងិន ធ៌ីយ ឯ.១៩ KH 01306568 [ការដ្ឋានទី៦ អ្ងសទ្ធក (សូមមើល ឯ.១៨)៖ "ខ្ញុំប្រកែកថា មិនយក តែគេក៏អត់ព្រម ខ្ញុំអត់ហ៊ានប្រកែកទៀត ព្រោះឃើញអ្នកដែលប្រកែកច្រើនតែទៅភ្ជុ ខ្ជៀ ហើយមិនដែលឃើញត្រឡប់មកវិញទេ។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ងៀម ឯ.១០៧-១០៩, ១១១ KH 01047393-01047394។ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ប៊ុនឈឿន ឯ.៨ KH 01096522។ ឯកសារ D219/307 កំណត់ហេតុស្តាប់ចម្លើយ ប៉ាល់ យ៉ុង ឯ.៤៤ KH 01096601 [នៅកំពង់គោ ឆ្នាំ១៩៧៨ (សូមមើល ឯ.៣៧, ៤០)៖ "បើយើងមិនរៀបការ គេយកយើងទៅសម្លាប់ចោល ដូច្នេះខ្ញុំត្រូវតែធ្វើតាមបញ្ជារបស់គេ។"]។ សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ៖ ឯកសារ D219/268 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឯ.៧២ KH 01088845 [នៅស្រុកសង្កែ ខេត្តបាត់ដំបង៖ "ខ្ញុំឮថា តាម៉ុកគំរាមស្ត្រីវ័យក្មេង២នាក់មកពីនិរតីថា បើមិនព្រមរៀបការជាមួយកម្មាភិបាលពិការដែលមានវ័យចំណាស់នោះទេ ពួកគេនឹងត្រូវបញ្ជូនទៅសមរភូមិ។"]។ ឯកសារ D219/18 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឈៀន ឯ.៤០-៥០ KH 01029032-01029033 [នៅខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ៖ ដើមបណ្តឹងរដ្ឋប្បវេណី "ដឹងអំពីករណី" អ្នកដែលត្រូវបានគេយកទៅសម្លាប់ក្រោយពីពួកគេប្រកែកមិនព្រមរៀបការ។ ឯកសារ D219/221 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឯ.១០១ KH 01075687 [សាក្សីគឺជាកងឈ្លបរបស់កម្ពុជាប្រជាធិបតេយ្យ នៅស្រុកបាកាន ខេត្តពោធិ៍សាត់៖ អ្នកណាដែលប្រកែកមិនព្រមរៀបការម្តងហើយម្តងទៀត ពេលខ្លះត្រូវបានគេបញ្ជូនទៅការដ្ឋានធ្វើការ ហើយ "បាត់ខ្លួន"។]។

គម្រាមកំហែងថានឹងយកទៅកសាង គម្រាមកំហែងពីសេចក្ដីស្លាប់ ឬការសម្លាប់សមាជិកគ្រួសារបស់គេ[2882]។ អ្នកដែលមិនយល់ព្រមជាញឹកញាប់ត្រូវទទួលរងទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ[2883]។

[2882] ឃុំរាំងកេសី៖ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណ ឆ.៨១, ៨៣, ៩០-៩២ KH 01032228-01032229 ["នៅពេលនោះគេរៀបការប្រហែលជា៧០ ទៅ៨០គូ។ [...] កើតឡើងឆ្នាំ១៩៧៨ នៅក្បែរវិហារវត្តរាំងកេសី។ [...] អត់មានអ្នកណាហ៊ានប្រកែកទេ បើហ៊ានប្រកែកគេនឹងយកទៅសម្លាប់ចោល។ គេប្រកាសថា "ត្រូវដើរតាមមាគ៌ារបស់បក្ស មិនមានអ្នកណាអាចប្រកែកបានទេ"។ គេនិយាយអំឡុងពេលរៀបការនោះ ដោយគេប្រើមីក្រូនិយាយ។"]។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១១-១២, ១៦ KH 01096585 ["ឲ្យរៀបការ [...] នៅខែកុម្ភៈ ឆ្នាំ១៩៧៨ [...] ខ្ញុំត្រូវបានកម្មាភិបាលនិរតីបញ្ជាឲ្យរៀបការនៅអាងកំពង់គោ។ [...] បើខ្ញុំមិនធ្វើតាមគេ ខ្ញុំខ្លាចគេយកយើងទៅសម្លាប់ចោល។"] ឆ.២៦ KH 01096587 ["បើយើងមិនធ្វើតាមអង្គការទេ គេនឹងយកយើងទៅកសាង។"] ឆ.៣៤ KH 01096588 ["គ្មានអ្នកណាម្នាក់ហ៊ានបដិសេធ។"]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ិញ វណ្ណា ឆ.៧១, ៧៤ KH 01328006-01328007។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១០០, ១០៤, ១១៥ KH 01032177-01032178។ ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.៥៧ KH 01110169 ["ខ្ញុំត្រូវតែរៀបការ ដោយសារតែខ្ញុំខ្លាច ព្រោះខ្ញុំបានប្រកែកជាច្រើនលើកច្រើនសាមកហើយ។ ខ្ញុំខ្លាចគេបញ្ជូនខ្ញុំទៅនេះ ឬទៅនោះ និងបាត់ខ្លួន។"]។ កំណត់សំគាល់៖ ឯកសារ D219/371 កំណត់ហេតុនៃកិច្ចស្ទើបសួរ, រឿងរ៉ាវរបស់ រាជ្យ សារ៉ាន KH 01310907 ["គាត់ [រាជ្យ សារ៉ាន] ត្រូវបានបង្ខំឲ្យរៀបការនៅ [វត្ត] រាំងកេសី បន្ទាប់ពីពួកភូមិភាគនិរតីមកដល់។ [...] ប្រសិនបើគាត់មិនយល់ព្រមរៀបការ គាត់នឹងត្រូវបានគេយកទៅសម្លាប់។ អ្នករាល់គ្នាសង្កេតឃើញយ៉ាងដូច្នេះ។"]។ ឯកសារ D219/867 កំណត់ហេតុស្តាប់ចម្លើយ ស ហ៊ីន ឆ.១១, ១៦ KH 01347421-01347422 ["គេយកខ្ញុំទៅរៀប នៅវត្តរាំងកេសី។ [...] កាលនោះ យើងនៅក្រោមជំនាន់គេ បើយើងមិនព្រមរៀបការ គេនឹងសម្លាប់យើង។"] ឆ.៧ KH 01347421 ["ខ្ញុំរៀបការបានមួយឆ្នាំ ឃ្លួនរំដោះបាន។"]។ ឃុំកំពង់ព្រៀង៖ ឯកសារ D219/261 កំណត់ហេតុស្តាប់ចម្លើយ ឃ្យ៉ាន ស្ស៊ីន ឆ.៥១ KH 01085804។ ឯកសារ D219/307 កំណត់ហេតុស្តាប់ចម្លើយ ប៉ាល់ យ៉ុង ឆ.៤៤, ៥១-៥២ KH 01096601-01096602។ សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ៖ ឯកសារ D219/888.1.8 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 16.02.04-16.04.09 [ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានគេបង្ខំឲ្យរៀបការនៅស្រុកបាកាន ខេត្តពោធិ៍សាត់ ខែសីហា ឆ្នាំ១៩៧៨៖ "និយាយទៅខ្ញុំខ្លាចគេបញ្ជូនទៅលើ គេថាអ៊ីចឹង។ [...] ខ្ញុំខ្លាចដាប់ចោលកូនរបស់ខ្ញុំ [...] វារកអីនឹកមិនឃើញ និយាយក៏មិនរួច ថាក៏មិនចេញ ខ្លាច។ និយាយទៅថា ខ្លាចគេអ៊ីចឹងហ្ម៎ង ដូចបាក់រលាក់ ដូចថាឃើញគេហ្នឹងខ្លាចបណ្ដោយ។"] ម៉ោង 16.06.49 ["ថាទៅលើហ្នឹងមានទៅណា មានទៅងាប់ទៀតហ្នឹងឯង។"]។ ឯកសារ D219/494.1.11 ឃី ឡៃសូរ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ម៉ោង 14.06.08-14.10.00 [នៅស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ ១៩៧៨៖"អត់ទៅទេ គេថា មិត្តឯងប្រយ័ត្នគេយកទៅវ៉ៃចោល។ [...] គេថា បើខ្ញុំអត់ទៅ ប្រយ័ត្នគេយកទៅវ៉ៃចោលទាំងគ្រួសារ។"]។ ឯកសារ D219/268 កំណត់ហេតុស្តាប់ចម្លើយ ណាំ ភន ឆ.៧២ KH 01088845។ ឯកសារ D118/234 កំណត់ហេតុស្តាប់ចម្លើយ ទុំ ង៉ា ឆ.៦៧ KH 00987981។

[2883] ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម ឆ.១៦៤ KH 01025552 [សាក្សីគឺជាសមាជិកម្នាក់នៃគណៈសហការណ៍សំរោង ក្នុងខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៧-១៩៧៩៖ "អ្នកដែលមិនព្រមរៀបការនឹងត្រូវគេយកទៅរៀនសូត្រ។"]។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.១៣២-១៣៤ KH 00996466 [នៅខេត្តពោធិ៍សាត់ (មិនដឹងថ្ងៃខែឆ្នាំ)៖ សាក្សី

798. ស្ត្រីខ្លះបានជ្រើសរើសសេចក្ដីស្លាប់ ជាជាងការទទួលយកអាពាហ៍ដោយបង្ខំ។ សាក្សី ខយ ឆ្ងយ បានប្រាប់ថា នៅរោងចក្រស្ករកំពង់គល់ ប្រធានកងចល័ត យ៉ាន និងស្ត្រីពីរនាក់ផ្សេងទៀតដែលត្រូវបានបង្ខំឲ្យរៀបការជាមួយនឹងជនពិការ បានធ្វើអត្តឃាត បន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍របស់ពួកគេ[2884]។

<u>ការផ្សំដំណេកដោយបង្ខំ (អំពើរំលោភសេពសន្ថវៈ)</u>

799. គោលនយោបាយនៃការបង្ខំជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ឲ្យផ្សំដំណេកដោយគ្មានការព្រមព្រៀងដោយសេរីរបស់ពួកគាត់ (អំពើរំលោភសេពសន្ថវៈ) ត្រូវបានអនុវត្តយ៉ាងល្អិតល្អន់ក្នុងតំបន់នានាក្រោមការគ្រប់គ្រងរបស់ **យ៉ឹម ទិត្យ**។ **យ៉ឹម ទិត្យ** បាននិយាយនៅឯពិធីអាពាហ៍ពិពាហ៍មួយក្នុងស្រុកសំឡូត ក្នុងឆ្នាំ១៩៧៨ ដោយបានបញ្ជាថា "ប្ដីប្រពន្ធត្រូវស្រឡាញ់គ្នា"[2885] និងបានណែនាំពួកគាត់ឲ្យ "ធ្វើតាមអង្គការចាត់តាំង"[2886]។ យោងតាម ណុប ង៉ឹម បទបញ្ជានេះមានន័យថា "នៅពេលរៀបការរួច ត្រូវតែគេងនៅទីនោះជាមួយគ្នា"[2887]។ មន្ត្រីមូលដ្ឋានទទួលបន្ទុកការរៀបការ

ស្គាល់នារីពីនាក់ដែលបដិសេធមិនព្រមរៀបការ ត្រូវបានគេកសាងម្ដងជាពីរដង ប៉ុន្តែត្រូវបានសម្លាប់ នៅពេលដែលពួកគេនៅតែបដិសេធ។ ឯកសារ D118/194 កំណត់ហេតុស្ដាប់ចម្លើយ រស់ ណារ៉ីន ឆ.៥៤ KH 00977110 [នៅខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៧ ៖ ដើមបណ្ដឹងរដ្ឋប្បវេណី បានរៀបរាប់បញ្ជាក់ពីសម្រង់មួយរបស់គាត់នៅសម័យបក្សកុម្មុយនីស្ដកម្ពុជា អំពីមិត្តរបស់គាត់បដិសេធមិនព្រមរៀបការ ហើយបន្ទាប់មកគេបានបញ្ជូនទៅគុកត្រាចក្រោល និងបានវៃ និងធ្វើទារុណកម្ម]។ ឯកសារ D118/191 កំណត់ហេតុស្ដាប់ចម្លើយ ង៉ែត ចាត ឆ.៩២-៩៣ KH 00977071-00977072 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ខ៉ែ សីហា ឆ្នាំ១៩៧៨៖ ដើមបណ្ដឹងរដ្ឋប្បវេណី និងស្ត្រីផ្សេងទៀត និងមិត្ត រ៉ីន បានបដិសេធមិនព្រមរៀបការ។ ឈ្លបបាននាំពួកយើងទៅក្នុងព្រៃ ហើយបានរំលោភមិត្ត រ៉ីន។ សាក្សីមិនត្រូវបានរំលោភទេ ដោយសារតែគាត់បានសុំអង្វរ។]។

[2884] <u>រោងចក្រស្ករកំពង់គល់</u>៖ ឯកសារ D219/655 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឆ.១១-១៤ KH 01196552 [ខេត្តបាត់ដំបង ១៩៧៨៖ សាក្សីបានឃើញពីរនាក់ដែល "ចងកសម្លាប់ខ្លួន ដោយគេមិនពេញចិត្តនឹងប្ដីកំបុតជើង។ [...] ពីរនាក់ហ្នឹងទៅចងកនៅដើមឈើតែមួយទន្ទឹមគ្នា" ក្រោយពីពិធីរៀបការរួច។]។ ឯកសារ D219/157 កំណត់ហេតុស្ដាប់ចម្លើយ ខយ ឆ្ងយ ឆ.១១ KH 01058786 [កម្មាភិបាលនិរតី "យ៉ាង ដែលមកដឹកនាំកងចល័ត [...] បានចងកសម្លាប់ខ្លួន បន្ទាប់ពីគាត់ត្រូវបានគេបង្ខំឲ្យរៀបការជាមួយនឹងបុរសដែលគាត់មិនស្រឡាញ់។"]។

[2885] ឯកសារ D219/62 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប កប ឆ.៤៦ KH 01037144។ សូមមើលឯកសារផ្ទុយ ឯកសារ D219/62 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប កប ឆ.២៩ EN 01037141 ["ភរិយាខ្ញុំប្រាប់ថា តាទិត្យ [...] ក៏បានចូលរួមពិធីនោះដែរ។"]។

[2886] ឯកសារ D219/835 កំណត់ហេតុស្ដាប់ចម្លើយ ណុប ង៉ឹម ឆ.១៤៩ KH 01329405។

[2887] ឯកសារ D219/835 កំណត់ហេតុស្ដាប់ចម្លើយ ណុប ង៉ឹម ឆ.១៥១ KH 01329405។ សូមមើលផងដែរ ឯកសារ D219/835 កំណត់ហេតុស្ដាប់ចម្លើយ ណុប ង៉ឹម ឆ.១៥៥ KH 01329405។ ឯកសារ D219/62 កំណត់ហេតុស្ដាប់ចម្លើយ ព្រាប កប ឆ.៤៦

បានអនុវត្តតាមគំរូរបស់ **យ៉ីម ទិត្យ** ដោយបានបញ្ជាឲ្យប្តីប្រពន្ធរៀបការថ្មោងថ្មី "ចុះសម្រុង" ជាមួយដៃគូថ្មីរបស់ពួកគាត់ "រស់នៅជាមួយគ្នាជាប្តីប្រពន្ធ" ឬបង្កើតកូន[2888]។ ទោះជាមានការប្រើប្រាស់ពាក្យពេចន៍ខុសគ្នាក៏ដោយ ក៏សារមានភាពជាក់ច្បាស់៖ ប្តីប្រពន្ធដែលទើបរៀបការថ្មោងថ្មីត្រូវធ្វើតាមបំណងរដ្ឋអំណាចដែលថា ពួកគាត់ត្រូវរួមភេទដើម្បីបង្កើនចំនួនប្រជាជន[2889]។

800. **យ៉ីម ទិត្យ** និងមនុស្សក្រោមបង្គាប់របស់គាត់បានអនុវត្តវិធានការជាច្រើនដើម្បីបង្ខំឲ្យប្តីប្រពន្ធដែលទើបរៀបការថ្មោងថ្មី ផ្សំដំណេក ដោយរួមបញ្ចូលការតម្រូវឲ្យពួកគាត់ស្នាក់នៅជាមួយគ្នានៅពេលយប់ក្នុងខ្ទម ឬបន្ទប់ដែលត្រូវបានរៀបចំដាច់ដោយឡែកសម្រាប់គោលបំណងនោះ និងដាក់ឈ្លបនៅខាងក្រៅខ្ទមដើម្បីឃ្លាំមើលសកម្មភាពរបស់ពួកគាត់[2890]។ ក្រោយពិធីរៀបអាពាហ៍ពិពាហ៍ក្នុង

KH 01037144 ["តាទិត្យ បានមានប្រសាសន៍ថា ពួកយើងដែលទើបរៀបការថ្មីៗ ត្រូវចេះស្រឡាញ់គ្នា ត្រូវមានសាមគ្គីភាព"]។ ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារឹកចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.05.53-11.07.45 ["ការបានពីរបីថ្ងៃបានអ៊ំទិត្យ [...] អត់មានណារត់ចោលអ៊ីចឹងក៏គាត់ចេះតែណែនាំទៅអ៊ីចឹង ណែនាំឲ្យធ្វើល្អកុំឲ្យធ្វើអាក្រក់អ៊ីចឹងទៅណា"]។

[2888] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៩៧ KH 01047392 [នៅភូមិកាច់រទេះ ឃុំកំពង់ព្រៀង ខែតុលា ឆ្នាំ១៩៧៨ (សូមមើល ឆ.៩១ ឆ.១១៤)៖ "មេកង និងមេក្រុមជាអ្នកជ្រើសរើសគូស្រករឲ្យរៀបការជាមួយគ្នា។ នៅពេលនោះ គេនិយាយថា "ឲ្យនារី និងបុរស ដែលនៅលីវចាប់គ្នាបង្កើតកូន ដើម្បីកសាងជាតិ"។"]។

[2889] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៩៧ KH 01047392 [នៅភូមិកាច់រទេះ ឃុំកំពង់ព្រៀង, ១៩៧៨ (សូមមើល ឆ.៩០, ១១៤)៖ "នៅពេលនោះ គេនិយាយថា [...] "ឲ្យនារី និងបុរស ដែលនៅលីវចាប់គ្នាបង្កើតកូន ដើម្បីកសាងជាតិ"។"]។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឆ.១៧ KH 01085174 [បង្ខំឲ្យរៀបការនៅវត្តរ៉ាំងកេសី ចុងឆ្នាំ១៩៧៨ (សូមមើល ឆ.២, ៦)៖ "ស៖ ពាក្យថា "ត្រូវរ៉ូវគ្នានេះ" មានន័យថាជាការរួមភេទជាមួយគ្នាឬយ៉ាងណា? ឆ.១៧៖ បាទ មានន័យថា ការរួមភេទជាមួយគ្នា។"]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.30.51-14.32.02 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "ឃ្លាសម័យនុង [...] "បើមិនស្រឡាញ់ គឺមិនដក គេសម្លាប់ក្នុងពេលហ្នឹង គេធ្វើបាបទារុណកម្ម។]។

[2890] <u>ស្រុកសំឡូត</u>៖ ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារឹក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.13.17-14.15.24 ["ចេះតែខ្ជាចទៅ ខ្ជាចក្រែងលោគេលបស្តាប់អ៊ីទៅ យើងចេះតែ -- ចេះតែណែនាំគ្នាឲ្យបានល្អទៅ។"] ម៉ោង 11.09.05-11.14.36 ["គឺការហើយបានពីរបីយប់ គឺចេះតែតាមដានដែរ។"] ម៉ោង 13.29.59-13.33.58 ["ហ្នឹងព្រោះអ៊ីដ៏ង ដ៏ងឈ្លបមកតាមដាន ព្រោះអ៊ីមើលឃើញទាំងយប់។ [...] អត់មានដែលចាប់ទេ គ្រាន់តែទៅអង្កេតមើលយើងចេះរួមដំណេកគ្នាអត់ សាមគ្គីគ្នាអត់ តែប៉ុណ្ណឹងហ្នឹង។"]។ ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.១៤៧ KH 01329405 [ឈ្លប "គេតាមដានខ្ជាចយើងអត់ស្រឡាញ់គ្នា អត់រួមដំណេកគ្នាហ្នឹងណា"]។ ឃុំកំពង់ព្រៀង៖ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឆ.៦, ១០ KH 01096521-01096523 [នៅភូមិថ្មី សហករណ៍កំពង់គោស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី (សូមមើល ឆ.៦-៧)៖ "យើងបានប្តេជ្ញាចិត្តជាមួយគ្នាទៅកាន់កន្លែងដែលយើងសម្រាកតាមខ្ទម ដែលពួកគេបានរៀបចំឲ្យយើងរួចហើយ។ ឈ្លបដែលមានអាវុធបានតាមដានយើងនៅពេលយប់។ [...] ប្រសិនបើពួកគេឮថា យើងមិនចុះសម្រុងនឹងគ្នា គេនឹងរាយ

ស្រុកសំឡូត ប្តីប្រពន្ធរៀបការថ្មោងថ្មីបានត្រឡប់ទៅផ្ទះរបស់ពួកគាត់វិញដើម្បីស្វែងរកគ្រែ អង្រ្ក៏ង និងមុងដែល **យ៉ីម ទិត្យ** បានរៀបចំតាមឱវាទរបស់ តា ម៉ុក[2891]។ ជាលទ្ធផលនៃការរៀបចំទាំងនេះ និងការភ័យខ្លាចអំពីផលវិបាកនៃការប្រកែក ប្តីប្រពន្ធរៀបការថ្មោងថ្មីត្រូវបានបង្ខំឲ្យរួមភេទជាមួយដៃគូថ្មីរបស់ពួកគាត់[2892]។

ការណ៍ទៅមេរបស់គេ។"]។ សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ៖ ឯកសារ D219/888.1.8 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 16.04.09-16.05.00 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ខែសីហា ឆ្នាំ១៩៧៨៖ "ស ៖ ចាតើនៅពេលដែលអ្នកស្រីបានរៀបការរួចហ្ម៏ង គេមានរៀបចំកន្លែងឲ្យផ្សំដំណេកទេ? ឆ៖ ពេលរៀបការហើយហ្ម៏ងក៏នាំគ្នាដើរមកទាំងយប់ អ៊ីចឹង។ ខ្ញុំដើរមកមួយគូ ខ្ញុំទៅកំប្រាក់ក្ងានមកវិញ ទៅសមរភូមិកំប្រាក់ក្ងានមកវិញ។ គេធ្វើផ្ទះគេខ្ទមគេតូចៗដូចចាល្មមតែឲ្យយើងដេកមួយគ្រួសារៗអ៊ីចឹងទៅ ចេះតែនៅអ៊ីចឹងទៅ ដល់ពេលចេះតែដេកស្ងួតទៅ។"]។ ឯកសារ D219/888.1.6 ប ប៉ែន សុ ចាន់ ប្រតិចារឹក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.38.06-15.02.44 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "[ឈ្លូប] ប្រចាំការនៅតាមកងអ៊ីចឹងគេចល័ត កងនេះ កងនោះ មួយថ្ងៃកងនេះ មួយថ្ងៃកងនោះ គេចល័តយប់ឡើងគេចល័តតាមដាន។ គឺៗជាល្បែងលេងសើចរបស់គេ ដើរលប ដើរស្តាប់តែអ្នកដេកនៅជាមួយគ្នាអ៊ីចឹងឯងជាទូទៅ ជារឿងរបស់គាត់។"]។ ឯកសារ D219/12 កំណត់ហេតុស្តាប់ចម្លើយ មុយ រ្ជ្ជ ចណាង ឆ.៤០ KH 01025683 [នៅខេត្តបាត់ដំបង ឆ្នាំ១៩៧៧ (សូមមើល ឆ.៥, ៣៥)៖ "មានឈ្លូបតាមស្តាប់នៅក្រោមផ្ទះ។"]។ ឯកសារ D219/356 កំណត់ហេតុស្តាប់ចម្លើយ វណ្ណ ណាក់ ឆ.៣៤ KH 01104619 [នៅស្រុកសង្កែ ខេត្តបាត់ដំបង ឆ្នាំ១៩៧៨ (សូមមើល ឆ.២៩)៖ "គេបានសង់ខ្ទមឲ្យប្តីប្រពន្ធដែលទើបរៀបការថ្មីៗ រួមទាំងប្តីប្រពន្ធខ្ញុំផងដែរ។ គេឲ្យរស់នៅ២គូ ក្នុង១ខ្ទម។"] ឆ.៧០ KH 01104624 ["គេមិនឲ្យចិញ្ចឹមអ្នកចាំផ្ទះទេ ដោយសារតែឈ្លូបមកលបស្តាប់នៅក្រោមផ្ទះ។"]។ ឯកសារ D118/248 កំណត់ហេតុស្តាប់ចម្លើយ លី លន់ ឆ.១១៨ KH 00990698-00990699 [នៅស្រុកបាកាន ឆ្នាំ១៩៧៨ (សូមមើល ឆ.១១១)៖ "គេបានឲ្យភ្នាក់ងារនៅចាំស្តាប់ខ្ញុំ និងប្រពន្ធរបស់ខ្ញុំ ហើយភ្នាក់ងារនេះគេមិនអនុញ្ញាតឲ្យដេកនោះទេ។"]។ ឯកសារ D118/258 កំណត់ហេតុស្តាប់ចម្លើយ រស់ ហ៊ីម ឆ.៨៩ KH 00996482 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់ (សូមមើល ឆ.៩០)៖ "ក្រោយរៀបការហើយខ្មែរក្រហមបានឲ្យគេលបស្តាប់នៅក្រោមផ្ទះរបស់ប្តីប្រពន្ធថ្មីនោះ ដោយមានថតសំឡេង ដើម្បីយកសំឡេងនោះទៅឲ្យមេរបស់វា។"]។

[2891] ឯកសារ D219/62 កំណត់ហេតុស្តាប់ចម្លើយ ព្រាប កប ឆ.៤៤ KH 01037143 ["តាម៉ុក [...] ប្រាប់តាទិត្យឲ្យដឹកជញ្ជូនគ្រែមុង អង្រ្ក៏ងមកចែកអ្នកពិការដែលទើបរៀបការ។ [...] តាទិត្យ ទោះបីគាត់មិនបានដឹកជញ្ជូនមកដោយផ្ទាល់ក៏ដោយ។ [...] ប្រពន្ធខ្ញុំ [...] បានឃើញស្រោមសំបុត្រមួយមកជាមួយនឹងសម្ភារៈទាំងនោះ ដែលមាននិយាយរៀបរាប់របស់របរទាំងនោះ។ [...] អក្សរនោះសរសេរថា "ពីគណៈតំបន់១ ទិត្យ" ដោយមានហត្ថលេខានៅខាងក្រោម"។] ឆ.៣១ KH 01037141 ["ខ្ញុំបានរៀបការនៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨ នៅស្រុកសំឡូត។"]។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៦៨ KH 01008708 ["ខ្ញុំត្រូវបានគេបង្ខំឲ្យរៀបការជាមួយ [...] កប នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨។"]។

[2892] <u>ស្រុកសំឡូត</u>៖ ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារឹក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.13.17-14.15.24 ["យើងការហើយមិនចុះដំណេកគ្នា មិនរួមដំណេកគ្នាអ៊ីចឹង គឺចំពោះអារម្មណ៍ខ្លួនខ្ញុំខ្លាចអ៊ីចឹងឯង មានអារម្មណ៍មួយខ្លាចអ៊ីចឹង។"] ម៉ោង 15.35.56-15.39.16 ["ស៖ [...] តើហានៈនេះមិនធ្វើឲ្យលោកស្រីមានសិទ្ធិអំណាចអីទៅលើឈ្លូបទាំងអស់ហ្ម៏ងទេ មែនទេ? ឆ៖ ចាស អត់មែន អត់ហ៊ានជាមួយគេទេ។ ហើយសិទ្ធិប្រហែលប៉ុនខ្ញុំៗអី ទៅធ្វើអីគេ កើត។"]។ ឯកសារ D219/835

កំណត់ហេតុស្តាប់ចម្លើយ ណុប ធីម ឯ.១៤៦ KH 01329404 ["ពួកខ្ញុំធ្វើអាតូងអាតាំងដែរ ខ្លាចគេចេះតែទៅហើយ។"] ឯ.១៥៧ KH 01329406 ["ក្មេងស្រីៗ [...] ប្រាប់គ្នាថា "បើមិនត្រូវគ្នា ប្រយ័ត្នឈ្លបគេឃើញ" ហើយពេលយប់ឃើញអ៊ីចឹងមែន។"]។ កំណត់សំគាល់៖ សាក្សីបង្ហាញពីភាពខុសគ្នារវាងការដែលមិនត្រូវបានប្តីបង្ខំឲ្យរួមដំណេក ប៉ុន្តែបង្ខំរួមដំណេកដើម្បីគោរពតាមវិន័យរបស់អង្គការ។ សូមមើល ឯកសារ D219/974.1.2 ណុប ធីម ប្រតិចារឹក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១០ ម៉ោង 14.18.30-14.21.38 14.18.35-14.20.55 ["ស៖ [...] តើលោកស្រីរួមដំណេកដោយមានការបង្ខិតបង្ខំពីប្តីរបស់លោកស្រី ឬក៏ដោយសារការព្រមព្រៀងគ្នា? ឯ៖ គឺចំពោះខ្លួនខ្ញុំ អត់មានបង្ខំ ខាងនោះក៏មិនបង្ខំដែរ សំខាន់គឺចិត្ត។ ដូចខ្ញុំថា ថាគោរពវិន័យចាត់តាំង គឺយើងនៅក្រោមគេដឹកនាំ។ [...] អត់មានអ្នកណាបង្ខំណា អត់ទេ។"] (គ្មានសេចក្តីប្រកាន់ខ្ជាប់)។ ឃុំរាំងកេសី៖ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឯ.១១៦, ១១៩ KH 01032178-01032179 [ក្នុងឃុំរាំងកេសី ១៩៧៨ (សូមមើល ឯ.២៦, ១០០)៖ "គេឲ្យពួកខ្ញុំទៅដេកជាមួយគ្នានៅឯស្រែ [...] ពួកឈ្លបជាអ្នកតាមដាន។"] ឯ.១២៥ KH 01032179 ["ស៖ តើមានអ្វីកើតឡើងចំពោះអ្នកដែលមិនព្រមរួមរក្សាជាមួយគ្នា? ឯ.១២៥៖ គេដាក់ទោសគឺ យកបុរសនោះទៅកសាង តែមិនដែលឃើញត្រឡប់មកវិញនោះទេ។"]។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឯ.៣៥-៣៦, ៣៨-៣៩ KH 01096588-01096589 [នៅអាងកំពង់គោ វត្តកណ្តាល ឃុំរាំងកេសី ខែកុម្ភៈ ឆ្នាំ១៩៧៨ (សូមមើល ឯ.១១-១២)៖ "ពេលរៀបការរួច [...] នៅពេលយប់មានកងឈ្លបលួចតាមដានយើង។ [...] ប្រសិនបើប្តីប្រពន្ធខ្ជិះណ្លោះគ្នាពេលយប់ គេនឹងយកទៅកសាង។ [...] ខ្ញុំចំណាយពេលពីរបីយប់ បន្ទាប់ពីយើងដឹងថា មានស្ថានការណ៍មិនល្អ ដោយសារខ្ញុំឃើញមានឈ្លបតាមដានយើងនៅពេលយប់។"]។ ឯកសារ D219/829 កំណត់ហេតុស្តាប់ចម្លើយ សេក មឿន ឯ.៩៩ KH 01327976 [នៅវិហារវត្តរាំងកេសី ខែកញ្ញា ឆ្នាំ១៩៧៧ (សូមមើល ឯ.៦១-៦២)៖ "ស៖ តើពួកខ្មែរក្រហមមានតាមដានលោក និងប្តីប្រពន្ធគូផ្សេងទៀតទេ បន្ទាប់ពីថ្ងៃរៀបការនោះ? ឯ.៩៩៖ គេមានតាមដានដែរ គេមកតែពេលយប់ទេ ពេលខ្លួនយើងដឹង ពេលខ្លះយើងមិនដឹងទេ។"]។ ឯកសារ D219/831 កំណត់ហេតុស្តាប់ចម្លើយ វ៉ាញ វណ្ណា ឯ.៨២-៨៣ KH 01328008 [នៅវត្តរាំងកេសី ខែកក្កដា ឆ្នាំ១៩៧៧ នៅក្រោមការគ្រប់គ្រងពួកនិរតី (សូមមើល ឯ.៦៨, ៧១-៧២)៖ "មិនឃើញសម្លាប់ទេ តែបាត់ខ្លួន យកទៅបាត់ខ្លួន៥គូ ៥នាក់អ៊ីចឹង ពេលសួរគ្នាទៅ [...] គេថាយកទៅធ្វើការនៅទីឆ្ងាយ តែមិនដែលឃើញពួកហ្នឹងត្រឡប់មកវិញទេ។"] ឯ.៨៦-៨៧ KH 01328008។ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឯ.៩៣ KH 01032229 [ក្នុងឃុំរាំងកេសី ១៩៧៨ (សូមមើល ឯ.៨២-៨៣)៖ "អង្គការ [...] ឲ្យគូស្រករថ្មីៗផ្សំដំណេកជាមួយគ្នា។ បន្ទាប់មកគេឲ្យខាងយោធាដើរស៊ើបមើលតាមបន្ទប់។"] ឯ.១០៥-១០៦, ១០៨ KH 01032230-01032231 ["ស៖ តើ ហ្ជត ត្រូវគេបង្ខំឲ្យរៀបការ [...]? ឯ.១០៥៖ គេបង្ខំឲ្យរៀបការក្នុងពេលជាមួយខ្ញុំដែរ។ ឯ.១០៦៖ [...] ប្រហែលជា១អាទិត្យក្រោយរៀបការហើយ ហ្ជត ក៏បាត់ខ្លួនក្នុងឆ្នាំ១៩៧៨។ [...] ឯ.១០៨៖ [...] គាត់មិនពេញចិត្តប្រពន្ធគាត់។ [...] ខ្ញុំឮមេកងតូចតាចនិយាយអំពីរឿងនេះ។ ក្រោយរៀបការហើយខ្ញុំឮ ហ្ជត ថាគាត់មិនព្រមយកនារីម្នាក់នោះទេ ហើយក៏មិនបានចូលទៅផ្សំដំណេកតាមអង្គការនោះទេ។"]។ ឯកសារ D219/257 កំណត់ហេតុស្តាប់ចម្លើយ សេក ជោត ឯ.១៦-១៨ KH 01085174 [វត្តរាំងកេសី ឆ្នាំ១៩៧៨ (សូមមើល ឯ.២, ៦)៖ "ស៖ តើសកម្មភាពនៃការរៀបការត្រូវបានគេតាមដានដែរឬទេ ដូចជាការរួមដំណេកជាមួយគ្នាជាដើម? ឯ.១៦៖ បាទ នៅយប់ទី១ ឬយប់ទី២ មានពួកឈ្លបបានមកតាមដានយើង ដើម្បីឲ្យដឹងថាយើងរៀបការថ្មីៗនេះត្រូវរ៉ូវជាមួយគ្នាឬអត់។ ស៖ ពាក្យថា "ត្រូវរ៉ូវគ្នានេះ" មានន័យថាជាការរួមភេទជាមួយគ្នាឬយ៉ាងណា? ឯ.១៧៖ បាទ"។]។ ឯកសារ D219/872 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឯ.១១២-១១៣ KH 01352098-01352099 [ក្នុងឃុំរាំងកេសីស្ថិតនៅក្រោមការគ្រប់គ្រងរបស់និរតី (សូមមើល ឯ.១១៧, ១២៧)៖ "គ្រាន់តែយើងរៀបការហើយមិនត្រូវគ្នា ក៏ត្រូវគេយកទៅសម្លាប់ចោលដែរ។ [...] គ្មានអ្នកណាហ៊ានទេ សូម្បីតែការហើយ អត់ត្រូវគ្នា ខាង

ប្រុសរាយការន៍ថា ខាងស្រីអត់ឲ្យរួមដំណេកជាមួយ គេនឹងយកខាងស្រីទៅសម្លាប់ចោល តែបើខាងប្រុសគេអត់រាយការណ៍ តែគេដឹងដោយខ្លួនឯង គេនឹងយកទាំងពីរនាក់ទៅសម្លាប់។ ប៉ុន្តែខ្ញុំរត់ផុត ខ្ញុំអត់អីទេ។"] ឯ.១២៤-១២៦ KH 01352100។ ឃុំកំពង់ព្រៀង៖ ឯកសារ D219/300 កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៊ុនឈឿន ឯ.៩-១០ KH 01096522-01096523 [នៅភូមិថ្មី សហករណ៍កំពង់គោស្ថិតនៅក្រោមការគ្រប់គ្រងរបស់កម្មាភិបាលនិរតី (សូមមើល ឯ.៦-៧)៖ "សម្រាប់អ្នកដែលមិនស្គាល់គ្នា ពួកគេមិនចុះសម្រុងនឹងគ្នាទេ ដូច្នេះខ្ញែរក្រហមក៏សម្លាប់ចោល។ [...] គណៈសហករណ៍ប្រើលេសថា អង្គការឲ្យប្តីប្រពន្ធទៅធ្វើការនៅខាងក្រៅ ប៉ុន្តែពួកគេមិនដែលត្រឡប់មកវិញទេ យើងត្រូវតែធ្វើតាមគេ។"] ឯ.១០, ១៨ KH 01096522-01096525 ["ឈ្លបដែលមានអាវុធបានតាមដានយើងនៅពេលយប់។ [...]ប្រសិនបើពួកគេពួថា យើងមិនចុះសម្រុងនឹងគ្នា គេនឹងរាយការណ៍ទៅមេរបស់គេ ហើយយកយើងទៅសម្លាប់។ [...] គេណែនាំប្រាប់យើងឲ្យរស់នៅជាមួយគ្នាដូចប្តីប្រពន្ធ បើយើងមិនធ្វើតាម គេនឹងពិន័យយើង។ ហេតុនេះហើយ បានជាគេបញ្ជូនឈ្លបឲ្យតាមដានយើងនៅពេលយប់។ នៅពេលដែលយើងកំពុងគេង ដើម្បីចង់ដឹងថា យើងមានឈ្លោះគ្នា ឬមិនចុះសម្រុងនឹងគ្នា ឬអត់។"]។ ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ ស្បៀង ចាន់ថន ឯ.២៤ KH 01096535 [នៅភូមិថ្មី សហករណ៍កំពង់គោ ខែសីហា ឆ្នាំ១៩៧៨ (សូមមើល ឯ.១៣, ១៥)៖ "បើសិនជាយើងឈ្លោះគ្នា គេនឹងសម្លាប់យើងជាមិនខាន។ ប្រពន្ធរបស់គូខ្លះ បានយកកន្ត្រៃ ឬកាំបិត ចាក់ប្តីរបស់ខ្លួន ដូច្នេះប្តីប្រពន្ធទាំងនោះ ត្រូវបានគេសម្លាប់ចោល។ ខ្ញុំមិនដឹងថា អ្នកទាំងនោះ បានកន្ត្រៃ ឬកាំបិត ពីណាទេ។ នៅក្នុងរបបនោះ បើសិនជាយើងឈ្លោះគ្នា ហើយគេដឹងថា យើងមិននៅជាមួយគ្នាជាប្តីប្រពន្ធ គេនឹងសម្លាប់យើងចោល។"] ឯ.២៥ KH 01096535 ["ពួកគេក៏បានតាមដានខ្ញុំដែរ ប៉ុន្តែដោយសារតែយើងមិនដែលឈ្លោះគ្នា ក៏មិនមានបញ្ហាអ្វីទេ។ យើងធ្វើការធម្មតា។ យាយជី ដែលជាកម្មាភិបាលខ្ញែរក្រហមតាមឃ្លាំមើលខ្ញុំ ហើយគាត់ប្រាប់ខ្ញុំថា ខ្ញុំមើលទៅដូចអ្នកនៅលីវអ៊ីចឹង តែខ្ញុំប្រាប់គាត់វិញថា ខ្ញុំរស់នៅជាមួយប្តីរបស់ខ្ញុំដូចគូស្រករដទៃទៀត។ ខ្ញុំមិនច្បាស់ថា នេះជាការបញ្ឆោតរបស់គាត់ ឬយ៉ាងណានោះទេ។ ប៉ុន្តែខ្ញុំធ្លាប់ប្រាប់គាត់ថា ខ្ញុំរស់នៅដូចគូស្រករដទៃទៀតដែរជាមួយប្តីរបស់ខ្ញុំ។ ដូច្នេះជីវិតគូស្រករររបស់ខ្ញុំប្រព្រឹត្តទៅធម្មតា។"]។ ឯកសារ D219/307 កំណត់ហេតុស្តាប់ចម្លើយ ប៉ាល់ យ៉ុង ឯ.៥៩ KH 01096603 [នៅសហករណ៍កំពង់គោ ឃុំកំពង់ព្រៀង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួកនិរតី (សូមមើល ឯ.៣៧, ៤២)៖ "គេតាមដានយើង។ [...] ខ្ញុំបានឮសំឡេង ហើយពេលខ្ញុំមើលទៅ ស្រាប់តែឃើញពួកយោធា។"]។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី ស្ងើម ឯ.៨៨-៨៩ KH 01047391-01047392។ ឯកសារ D219/207 កំណត់ហេតុស្តាប់ចម្លើយ ឡុង ឈឿម ឯ.៨ KH 01074026។ ឯកសារ D219/303 កំណត់ហេតុស្តាប់ចម្លើយ ខ្ឿន ច័ម ឯ.៣-៤, ១១ KH 01096552-01096553។ សម្រាប់គោលបំណងសហឧក្រិដ្ឋកម្មរួម សូមមើលផងដែរ៖ ឯកសារ D219/12 កំណត់ហេតុស្តាប់ចម្លើយ មុយ រ្ជ ចណាង ឯ.៤០-៤១ KH 01025683 [នៅខេត្តបាត់ដំបង ឆ្នាំ១៩៧៧ (សូមមើល ឯ.៣៥)៖ "ឯ៖មានឈ្លបតាមស្តាប់នៅតាមក្រោមផ្ទះ។ ស៖ ចុះបើសិនជាគូ (ប្តី-ប្រពន្ធ) មិនព្រមចុះដំណេកគ្នា តើនីមានអ្វីកើតឡើង? ឯ៖ ទេ គឺពួកគេត្រូវតែសុខចិត្ត បើមិនព្រមគនឹងយកទៅវ៉ៃចោល។"]។ ឯកសារ D219/361 កំណត់ហេតុស្តាប់ចម្លើយ លើយ តើស ឯ.១២៨ KH 01105596 [នៅខេត្តបន្ទាយមានជ័យ៖ "គឺឈ្លបគេតាមដាន។ បើមិនព្រមរួមភេទទេ ខ្លាចឈ្លបយកទៅវាយចោល។"]។

801. អ្នកណាប្រកែកមិនព្រមផ្សំដំណេកត្រូវទទួលពិន័យ[2893]។ ជួនកាល ប្តីត្រូវបានជំរុញឲ្យបង្ខំប្រពន្ធរួមភេទ[2894]។ ជាទូទៅពីរបីថ្ងៃក្រោយ ប្តីប្រពន្ធដែលរៀបការថ្មោងថ្មីត្រូវបានបញ្ជូនទៅធ្វើការវិញ ដែល

[2893] ឯកសារ D219/798 កំណត់ហេតុស្តាប់ចម្លើយ ងិន ធីយ ឆ.៤០ KH 01306571 [នៅឃុំកំពង់ព្រៀង ក្រោយពួកនិរតីកាន់កាប់៖ "មានបងស្រីម្នាក់ [...] មិនព្រម គេក៏យកគាត់ទៅកសាង កសាងហើយគាត់មិនព្រមទៀត គេក៏ដាក់កងជើងកងដៃគាត់ ឲ្យប្តីធ្វើម៉េចធ្វើទៅ។ ពេលនោះប្តីគាត់ចាប់រំលោភគាត់។"]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.30.45-14.32.06 [ក្រោយដើមបណ្តឹងរដ្ឋប្បវេណីបានបដិសេធមិនរួមដំណេកនៃការរៀបការដោយបង្ខំ ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "ឃ្លាសម័យនោះ គឺដូច [មិត្ត អ៊ុំ] និយាយអ៊ីចឹង បើមិនស្រឡាញ់ គឺមិនដក គេសម្លាប់ក្នុងពេលហ្នឹង គេធ្វើបាបទារុណកម្ម] ម៉ោង 14.38.06-14.40.23 ["សម្តីសមមិត្តប្រធាន អ៊ុំ ក៏ខ្ញុំចងចាំថា ខ្ញុំមិនព្រម ខ្ញុំត្រូវស្តាប់។"]។ ឯកសារ D219/12 កំណត់ហេតុស្តាប់ចម្លើយ មុយ រ្ជចណង ឆ.៤១ KH 01025683 [នៅខេត្តបាត់ដំបង ឆ្នាំ១៩៧៧ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "ស៖ ចុះបើសិនជាគូ (ប្តី-ប្រពន្ធ) មិនព្រមចុះដំណេកគ្នា តើនឹមានអ្វីកើតឡើង? ឆ.៤១៖ ទេ គឺពួកគេត្រូវតែសុខចិត្ត បើមិនព្រមគេនឹងយកទៅវ៉ៃចោល។"]។ ឯកសារ D118/258 កំណត់ហេតុស្តាប់ចម្លើយ រស់ ហ៊ីម ឆ.៨៩ KH 00996482 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់៖ "ក្រោយរៀបការហើយខ្មែរក្រហមបានឲ្យគេលប [...] បើប្តីប្រពន្ធថ្មីរស់នៅចុះសម្រុងនឹងគ្នាគឺមិនអីទេ តែបើមិនចុះសម្រុងនឹងគ្នាទេ គេនឹងយកប្តីប្រពន្ធថ្មីនោះទៅសម្លាប់ចោលភ្លាម។"]។ ឯកសារ D219/64 កំណត់ហេតុស្តាប់ចម្លើយ ពៅ គឿន ឆ.៧៣, ៧៩-៨០ KH 01037181-01037182 [ក្នុងឆ្នាំ១៩៧៧៖ "ឈ្មោះ ឈិត (ប្រុស) រស់នៅមិនចុះសម្រុងជាមួយនឹងខាងស្រី ហើយក៏ត្រូវគេបញ្ជូនទៅរៀនបាត់ទៅ។ ម្នាក់ទៀតឈ្មោះ រ៉ីត (ស្រី) [...] រស់នៅមិនចុះសម្រុងនឹងខាងប្រុស ហើយក៏ត្រូវគេបញ្ជូនទៅរៀនសូត្របាត់ដែរ។"]។ ឯកសារ D119/131 កំណត់ហេតុស្តាប់ចម្លើយ ថង ធឿយ ឆ.៧៧-៨២ KH 00996501 [នៅខេត្តបន្ទាយមានជ័យ ឆ្នាំ១៩៧៧៖ ស្ត្រីពីរបីនាក់ដែលនៅក្នុងកងចល័តជាមួយដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានឈ្លបយកទៅសម្លាប់នៅក្នុងព្រៃ ព្រោះពួកគេបដិសេធមិនព្រមរួមដំណេក។]។ ឯកសារ D219/36 កំណត់ហេតុស្តាប់ចម្លើយ ឈ្លូម សារ៉ៃន ឆ.២៨ KH 01032095-01032096។ ឯកសារ D219/336 កំណត់ហេតុស្តាប់ចម្លើយ ទាំ ជ៉ះ ឆ.៧១-៧៣ KH 01102804។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១២៥ KH 01032179 [នៅរ៉ាំងកេសី ឆ្នាំ១៩៧៨ (សូមមើល ឆ.២៦, ១០០)៖ "ស៖ តើមានអ្វីកើតឡើងចំពោះអ្នកដែលមិនព្រមរួមរក្សាជាមួយគ្នា? ឆ៖ គេដាក់ទោសគឺ យកបុរសនោះទៅកសាង តែមិនដែលឃើញត្រឡប់មកវិញនោះទេ។"]។

[2894] ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.21.19-14.23.05 [នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ឆ្នាំ១៩៧៨៖ "ពេលដែលយើងចេញមកពីធ្វើការរៀង១ខ្លួន ឃើញមុខគ្នា គាត់ [ប្តីរបស់ខ្ញុំ] ស្តាប់ឈ្លប គេដឹងថាថ្ងៃរៀបការ គាត់ស្តាប់ឈ្លបឲ្យធ្វើបាបចំពោះនាងខ្ញុំ ឃើញស្លៀកខោច្រើនជាន់អ៊ីចឹង គឺឈ្លបគរាយការណ៍មកថា ឲ្យធ្វើបាបទាល់តែបាន។ ចាប់រំលោភយ៉ាងម៉េចឲ្យទាល់តែបាន។"] ម៉ោង 15.05.00-15.07.29 ["ឃប់ទី៣ គេបានហែកខោហែកអាវខ្ញុំ ឈ្លបឈរមើលគឺខ្ញុំក៏មិនហ៊ានធ្វើអ្វីចំពោះគេដែរ ព្រោះដៃនាងខ្ញុំជាប់ចំណងហើយ អ៊ីចឹងគេសម្រាតយើងបាន រំលោភយើងបានតាមចិត្ត។ [...] ហើយពួកឈ្លបមើលនោះគេថា អើ! ធ្វើអ៊ីចឹងបានល្អសម្រេចជូនអង្គការហ្នឹងឯង យកកូនជូនអង្គការ។"] ម៉ោង 15.42.50-15.44.46 ["[ពួកឈ្លប] គ្រាន់តែថាបានចាប់ដៃគ្នា គឺប្តីប្រពន្ធហើយ ត្រូវតែចាប់រំលោភឲ្យបាន។"] និង ឯកសារ D219/974.1.3 ប៉ែន សុចាន់ ប្រតិចារឹក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ម៉ោង 11.47.10-11.49.50 និង ឯកសារ D310/1.1.11R រ៉េដេអូ អាពាហ៍ពិពាហ៍ក្រហម ឆ្នាំ២០១១ ម៉ោង 09:42-10:12 [ប៉ែន សុចាន់ រំឭកថា៖ "ប្តីខ្ញុំបានធ្វើឲ្យខ្ញុំឈឺចាប់។ នៅឃប់ដំបូង គាត់ចាប់ និងហែកខោអាវខ្ញុំ។ គាត់ធ្វើឲ្យខ្ញុំឈឺចាប់ ហើយបានឲ្យគេមកតាមដានយើង។ គាត់ចងដៃខ្ញុំទៅក្រោ

រមែងឃ្លាតពីប្តី ឬប្រពន្ធរបស់ពួកគាត់ ប៉ុន្តែភាគច្រើនត្រូវបានអនុញ្ញាតឲ្យមកលេងដៃគូថ្មីរបស់ពួកគាត់ដើម្បីបង្កើនឱកាសនៃការបង្កើនចំនួនប្រជាជន[2895]។

802. នៅសំឡូត **យីម ទិញ្ញ** បានតម្រូវឲ្យមនុស្សក្រោមបង្គាប់របស់គាត់តាមដានអត្រាកំណើតប្រចាំខែ និងជូនដំណឹងទៅគាត់[2896]។ អនុលេខាស្រុកសំឡូត ណុប ងឹម បាននិយាយថា គាត់បានយល់ថា គោលបំណងនៃអាពាហ៍ពិពាហ៍ គឺដើម្បីឲ្យប្តីប្រពន្ធ "អាចមានកូន" ដើម្បី "បញ្ជូនកូនឲ្យអង្គការ"[2897]។

ង. ការប៉ះទង្គិចផ្លូវកាយនិងផ្លូវចិត្តដែលជនរងគ្រោះបានទទួលរង

803. នៅទូទាំងប្រទេស ជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការផ្សំដំណេកដោយបង្ខំ រមែងបានទទួលរងការប៉ះទង្គិចផ្លូវកាយ និងផ្លូវចិត្ត។ ចំពោះបុរសស្ត្រីភាគច្រើន ការប៉ះទង្គិចក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ មានផលប៉ះពាល់រយៈពេលយូរ ដោយបានបន្តជះឥទ្ធិពលមកលើជីវិតរបស់ពួកគាត់នាពេលបច្ចុប្បន្ន និងដែលបង្ហាញបន្ថែមទៀតអំពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មនេះ។

យ។ ខ្ញុំមិនអាចកំរើកបានទេ។ ខ្ញុំស្លៀកខោពីរជាន់ គាត់ហែកខោទាំងពីរជាន់ទៀត។ គាត់ហែកចោលទាំងអស់ [...] ចាប់ដោះខោអាវខ្ញុំចេញអស់ ហើយចាប់ផ្តើមធ្វើបាបខ្ញុំ។"]។ ឯកសារ D219/243 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ សង ឆ.៨២ KH 01080954 [នៅឃុំអូតាប៉ោង ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ៖ ចំពោះគូស្រករក្រោយមកទៀត អ្នកខ្លះទម្រាំនឹងរួមដំណេកជាមួយគ្នាបានខាងបុរសរបួសលើទ្រូង និងមុខ ដោយសារខាងនារីក្រញ្ជៅ ព្រោះនារីនោះមិនព្រមរួមដំណេក។"] ឆ.៨៣-៨៧ KH 01080954-01080955 [នៅក្នុងឆ្នាំ១៩៧៧ មិត្តភក្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ ចន បានប្រាប់ថា គាត់បានរំលោភប្រពន្ធគាត់៖ "បើមិនរំលោភធ្វើម៉ែចបានរួមដំណេក។"]។

[2895] ឯកសារ D219/301 កំណត់ហេតុស្តាប់ចម្លើយ សៀង ចាន់ថន ឆ.២២-២៣ KH 01096534-01096535។ ឯកសារ D219/317 កំណត់ហេតុស្តាប់ចម្លើយ អៀម រុយ ឆ.៦៩ KH 01097877។ ឯកសារ D6.1.142 កំណត់ហេតុស្តាប់ចម្លើយ ជា ឡេង KH 00267735 [នៅខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ៖ "ខ្ញុំរក្រហមឲ្យរស់នៅជាមួយគ្នា២ទៅ៣ថ្ងៃ ហើយបំបែកទៅតាមកងរៀងៗខ្លួន។"]។

[2896] ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.១៣៣-១៣៤, ១៤០-១៤១ KH 01329403-04។ ឯកសារ D219/298 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.១៨ KH 01095989 ["នៅក្នុងពេលប្រជុំ គាត់បានសួរពួកយើងអំពីថា តើមានកូនង៉ែតកើតប៉ុន្មានក្នុងមួយខែ។"]។

[2897] <u>ស្រុកសំឡូត</u>៖ ឯកសារ D219/974.1.2 ណុប ងឹម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.05.53-11.09.05 ម៉ោង 11.09.05-11.14.36។ សូមមើលផងដែរ ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ងឹម ឆ.១៤៥ KH 01329404 ["បើការហើយមានកូនមានចៅហើយ។"]។

804. សាក្សីមួយចំនួនបានរងទុក្ខវេទនាផ្លូវកាយ នៅបន្ទាប់ពី ឬភ្លាមៗក្រោយពេលពួកគាត់រៀបការ[2898]។ បន្ថែមពីលើទុក្ខវេទនាផ្លូវកាយ ជនរងគ្រោះជាញឹកញាប់បានយំ និងមានអារម្មណ៍តានតឹង ដូចជាអារម្មណ៍ក្រៀមក្រំ ខឹងសម្បារ និងភ័យខ្លាច[2899]។ ង៉ែត ចាន នៅស្រុកបាកាន "មានអារម្មណ៍ភ័យខ្លាច"

[2898] ឯកសារ D347/2.1.42 សយ សារឿន ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 10.38.81-10.41.11 [ការរៀបការដោយបង្ខំក្នុងភូមិភាគឧត្តរ សយ សារឿន បានផ្តល់សក្ខីកម្មថា គាត់បានដឹងនៅពេលដែលកំពុងតែរៀបការ ខ្លួនគាត់ឡើងគ្រុនញ័រ "ត្រជាក់ស្រ្ទីប" និងចង់ទៅជា "គ្រុនចាញ់"]។ ឯកសារ D347/2.1.42 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.13.19-09.17.38 [ង៉ែត ចាត ត្រូវបានបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ក្នុងខែសីហា ឆ្នាំ១៩៧៨៖ "អារម្មណ៍បេះដូងខ្ញុំចង់គាំបន្ដិច ញ័របន្ដិច។ មើលទៅឃើញគេ ខ្ញុំយំអត់ហ៊ានឲ្យគេឃើញទេ ខ្ញុំបិទភ្នែកយំធ្វើហៀរទឹកភ្នែក ខ្ញុំអត់ហ៊ានយំ ខ្ញុំចេះតែក្លាហាន គេនិយាយប្រាប់ថា ប្ដេជ្ញាចិត្ត ចេះតែស្រែកនឹងគេ នឹងឯងអ៊ីចឹង។ ប៉ុន្ដែអារម្មណ៍នោះ វាញ័រអស់ ចង់សន្ធប់បន្ដិចអ៊ីបន្ដិច។"។ ឯកសារ D219/888.1.7 ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.05.34-15.08.15 [ក្នុងស្រុកព្រៃឈរ ខេត្ដកំពង់ចាម ភូមិភាគកណ្ដាល ឆ្នាំ១៩៧៧]។ ឯកសារ D219/888.1.1 អ៊ុំ ឃឿន ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.53.54-15.57.57 [ក្នុងស្រុកចំការលើ តំបន់ ៤២ ភូមិភាគកណ្ដាល ចុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨]។ ឯកសារ D219/974.1.2 ណុប ធ៉ីម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.59.55-11.03.38 [ស្រុកសំឡូត ខេត្ដបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "អត់បាយឡើងពីរបីថ្ងៃ ការហើយអត់ គេមាននាំគ្នាហូបបាយឯណា ខឹងពេក។ គេបង្ខំគាត់ដែរហ្ម៊ីងណា បង្ខំៗមែនទែន។ បើគាត់ មិនអ្នកណាស្រឡាញ់ ត្ដានអ្នកណាស្រឡាញ់អ្នកណាទេ អត់ទេជំនាន់ហ្ម៊ីង។ បង្ខំ គេបង្ខំតែម្ដង។"]។

[2899] ឯកសារ D219/888.1.1 អ៊ុំ ឃឿន ប្រតិចារឹក ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.53.54-15.57.57 [ក្នុងស្រុកចំការលើ តំបន់ ៤២ ភូមិភាគកណ្ដាល ចុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨៖ "ស៖ ចំណុចត្រង់ណាដែលលោកស្រីអន់ចិត្ត មិនពេញចិត្ដនោះ? ឆ៖ មនុស្សដែលអត់ស្គាល់គ្នា។ មនុស្សខ្ញុំអត់ពេញចិត្ដ។"]។ ឯកសារ D219/974.1.2 ណុប ធ៉ីម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.39.58-10.43.40 [ស្រុកសំឡូត ខេត្ដបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "ចាស ខ្ញុំគាត់ការនៅសំឡូត ការ ៤០គូ។ [...] ខ្លះយំ ខ្លះស្រែក ខ្លះរត់ចោល។ រត់ចោលពីរនាក់។ [...] ខ្ញុំយំដែរហ្ម៊ីង ប៉ុនអត់ចិត្ដអត់ដឹងខ្លួនសោះ អន់ចិត្ដៗមាំណាស់ ព្រោះអ៊ីអត់ដែលឃើញ"] ម៉ោង 10.50.02-10.54.16 ["ទាំងអស់គ្នាហ្ម៊ីង ខឹងណាស់ ខឹងចាប់ការ។ និយាយតាមត្រង់ជាក់ស្ដែងតែម្ដង ខឹងចាប់ការ។ នារីទាំងអស់គ្នាហ្ម៊ីង។"]។ ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 14.25.59-14.16.14 [ក្នុងទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥៖ "នៅពេលដែលអង្គការរៀបគូស្រករនេះ ខ្ញុំគ្ដានសប្បាយចិត្ដអ៊ីម៉ាបន្ដិចណាទេ ខ្ញុំមានតែទឹកភ្នែករហូតហ្ម៊ីង។ តាំងពីមិនទាន់ចូលផ្ទឹម ផ្ទឹមរួចទៀត ខ្ញុំយំរាល់តែថ្ងៃ មិនថាយប់ មិនថាថ្ងៃទេ ព្រោះខ្ញុំ ខ្ញុំឈឺចិត្ដណាស់ ប៉ុន្ដែមិនដឹងធ្វើម៉េច។ ត្ងចចិត្ដ។"]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 13.41.45-13.49.18 [ក្នុងស្រុកបាកាន ខេត្ដពោធ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "កាលនោះ ខ្ញុំនៅវ័យក្មេង មានការភ័យខ្លាច។"] ម៉ោង 15.38.34-15.40.34 ["ខាងស្រីក៏យំ ខាងប្រុសក៏យំដូចគ្នារៀងៗខ្លួន។ គូដែលចាប់តែពីរគូទាំងនាងខ្ញុំនោះ គឺគ្ដានអ្នកណាមួយបានដឹងខ្លួនទុកជាមុនទេ។"]។ ឯកសារ D219/888.1.8 កុល ណែម ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.27.45-14.30.00 [ក្នុងខេត្ដមណ្ឌលគិរី ភូមិភាគឦសាន ឆ្នាំ១៩៧៧៖ "ពេលរៀបការខ្ញុំហ្ម៊ីងក៏ខ្លួនខ្ញុំដែរ ក៏យើងគោរពគេហើយ យើងទៅ តែក្នុងចិត្ដនៅក្ដុកក្ដួលនៅលំបាក។ បាទ ខ្ញុំសុខចិត្ដទៅទាំងទ្រាំ ទាំងមុខស្លូតទៅទាំងគ្រាំគ្រាបាទ។"]។ ឯកសារ D5/1166/3.1 ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ម៉ោង 15.12.56-15.17.12 [ក្នុងស្រុកបាទី ខេត្ដកំពង់ស្ពឺ ភូមិភាគនិរតី ឆ្នាំ១៩៧៨៖ "១០៧គូហ្ម៊ីងអត់មានអ្នកណាហ៊ានប្រកែកទេ គ្រាន់តែខ្ញុំដឹងថា រឿងចិត្ដប្រកែកហ្ម៊ីង ប្រកែកណាស់ហើយ

នៅពេលគាត់ក្រឡេកមើលមុខប្តីថ្មីរបស់គាត់ ដែលមានអាយុលើសគាត់២០ឆ្នាំ[2900]។ ម៉ៅ |សារឿន ដែលត្រូវបានបង្ខំឲ្យរៀបការនៅភូមិភាគកណ្តាល បាននិយាយថា៖ "ខ្ញុំមានអារម្មណ៍ថាដូចគេយកខ្ញុំទៅសម្លាប់"[2901]។ ប្រហែល ៤០ ឆ្នាំក្រោយមក អនុស្សាវរីយ៍ដ៏ចុកចាប់ទាំងនេះនៅតែលងបន្ទាចជនរងគ្រោះ[2902]។

សម្តែងដោយចេញទឹកភ្នែក។ នារីៗយំហើមភ្នែក។ បុរសមានអ្នកខ្លះយំ អ្នកខ្លះអត់។"]។ ឯកសារ D347/2.1.38 ម៉ុ រ៉ុន ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 15.48.15-15.51.06 ["ចាស បានជាខ្ញុំដឹងថា គេចាប់បង្ខំទាំងអស់គ្នា ព្រោះគូភាគីដែលរៀបការនឹង៦០គូនោះ សុទ្ធតែយំទាំងអស់ យំទាំងអស់។ មកឈរជុំគ្នាយំទាំងអស់ ទាល់តែពួកគេមកដល់ បាននាំគ្នាជូតទឹកភ្នែកហើយឈប់យំ។ [...] ទាំងខ្ញុំទាំងគេ យំតែទាំងអស់គ្នាហ្នឹងឯង មិនថាមេម៉ាយ មិនថាក្រមុំទេ យំតែទាំងអស់ហ្នឹង។ [...] មកជុំគ្នាទាំងអស់៦០នាក់ហ្នឹងយំមើណេមុខគ្នាបណ្តោយទៅ។"]។ ឯកសារ D219/136 កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់ ឆ.២៦-២៧ KH 01053262 [ក្នុងស្រុកកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ចុងឆ្នាំ១៩៧៨៖ "ខ្ញុំតូចចិត្តមែនទេ។ [...] ស្ត្រីដែលត្រូវរៀបការមានអាយុ ២២ ទៅ ២៣ឆ្នាំ ហើយបុរសមានអាយុប្រហែល ៣៥ឆ្នាំ។ អ្នកខ្លះមិនពេញចិត្តគូស្រកររបស់ខ្លួនបានយំនៅក្នុងអំឡុងពេលរៀបការនោះ។"]។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន យីម ឆ.៩ KH 01039251 [ក្នុងស្រុកកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៨៖ "ខ្ញុំមានអារម្មណ៍ខឹងសម្បារ ដោយសារខ្ញុំមិនចូលចិត្តពិធីរៀបការហ្នឹង ខ្ញុំមិនស្រឡាញ់ប្តីរបស់ខ្ញុំទេ។"] ឆ.៤០ KH 01039256 ["នៅពេលនោះ ខ្ញុំមានអារម្មណ៍ខឹងសម្បារ ពិបាកចិត្ត។ ប្រហែលជា ៤ ទៅ៥ឆ្នាំ ក្រោយមកខ្ញុំមានអារម្មណ៍ខឹងសម្បារម្តងម្កាល។"]។ ឯកសារ D117/60 កំណត់ហេតុស្តាប់ចម្លើយ សុ ប៉ែត ឆ.៣១ KH 01007618 [ក្នុងស្រុកកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "មានអារម្មណ៍លំបាក [...] ចំពោះប្រពន្ធរបស់ខ្ញុំក៏មានអារម្មណ៍ភ័យខ្លាច។"]។ ឯកសារ D6.1.676 កំណត់ហេតុស្តាប់ចម្លើយ ជាំង ស្រីមុំ ឆ.៨ KH 00402465 [ក្នុងខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៧៖ "ខ្ញុំមានការតក់ស្លុតយ៉ាងខ្លាំង នៅពេលដែលគេមកប្រាប់ថា ខ្ញុំត្រូវរៀបចំខ្ញុំឲ្យការនៅពេលយប់នេះ។ អ្ករ ប្រាប់ខ្ញុំថា ខ្ញុំត្រូវរៀបការជាមួយឈ្មោះ ទ្រី ទូច។ [...] ខ្ញុំស្អប់គាត់ខ្លាំងណាស់។ [...] ខ្ញុំមិនមានជម្រើសអ្វីផ្សេងទេ។ ក្នុងចិត្តរបស់ខ្ញុំ ខ្ញុំយំនិងកើតទុក្ខជាខ្លាំង។"]។ ឯកសារ D219/99 កំណត់ហេតុស្តាប់ចម្លើយ ខ ខែត សុខន ឆ.៨៤ KH 01043278 [ក្នុងខេត្តកំពត ភូមិភាគនិរតី ឆ្នាំ១៩៧៨៖ "ខ្ញុំមានអារម្មណ៍ក្តុកក្តួលនៅក្នុងចិត្ត ហើយខ្ញុំក៏ល្ងចយំផងដែរ តែមិនឲ្យអ្នកណាដឹងនោះទេ។"]។

[2900] ឯកសារ D219/888.1.8 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 16.02.04-16.06.49 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ខែសីហា ឆ្នាំ១៩៧៨៖ "ខ្ញុំងាកទៅមើល ហ៊ឹ! អ៊ីក៏ចាស់មាំម្ល៉េះ ហើយយកខ្ញុំមកអាយុទើប២០ជាងគាត់ ៤០ជាងហើយ បងខ្ញុំឡើង១៨ឆ្នាំ។ [...] វាចិត្ត វាហួសចិត្តអានេះគេហៅថាហួសចិត្ត។ វារកអ៊ីទឹកមិនឃើញ និយាយក៏មិនរួចថាក៏មិនចេញ ខ្ជាច។ និយាយទៅថា ខ្ជាចគេអ៊ីចឹងហ្ម្ល ដូចបាក់រលាក់ ដូចថាឃើញគេហ្នឹងខ្ជាចបណ្តោយ។"]។

[2901] ឯកសារ D219/687 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ សារឿន ឆ.៧៨ KH 01203965 [ក្នុងស្រុកព្រៃឈរ តំបន់ ៤១ ភូមិភាគកណ្តាល បន្ទាប់ពីការមកដល់របស់កម្មាភិបាលភូមិភាគនិរតី។]។

[2902] ឯកសារ D219/888.1.3 កាស៊ូមិ ណាកាហ្ការ៉ា ប្រតិចារឹក ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 09.23.44-09.26.37 ["នៅពេលដែលខ្ញុំសួរសំណួរជាក់លាក់មួយចំនួនអំពីពេលវេលាដែលពួកគាត់បានរៀបការនៅក្នុងសម័យខ្មែរក្រហម ពួកគាត់អត់មានការចងចាំសប្បាយរីករាយ ឬក៏នឹកឃើញចងចាំទេ។ ភាគច្រើន គឺថាពួកគាត់ខឹងសម្បារណាស់ ថាពួកគាត់ហ្នឹង ត្រូវបានខ្មែរក្រហមបង្ខំឲ្យរៀបការ។ គូស្រករខ្លះនោះ អាចមានបញ្ហាផ្លូវកាយ បញ្ហាផ្លូវចិត្ត ដែលបន្តមានរហូតដល់សព្វថ្ងៃ ហើយអ្នកខ្លះអាច

805. សាក្សីនានាដែលត្រូវបានបង្ខំឲ្យរៀបការជាមួយមនុស្សដែលខ្លួនមិនស្គាល់ ទោះបីជាមានការប្តេជ្ញាចិត្តមុនមួយជាមួយអ្នកផ្សេងរួចទៅហើយក៏ដោយ បានរៀបរាប់អំពីការមិនចុះសម្រុងរបស់ពួកគាត់ រវាងការផ្តល់កិត្តិយសដល់ដៃគូរបស់ពួកគាត់ និងការនៅរស់[2903]។ គុល ណែម ដែលត្រូវបានបង្ខំឲ្យ

មានជំងឺបាក់ស្បាត រហូតមកដល់សព្វថ្ងៃនេះទៀតផង។"]។ ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 14.16.14-14.19.58 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ខំឲ្យរៀបការក្នុងទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥៖ "ពេលណាខ្ញុំនឹកឃើញ ពេលដែលខ្ញុំមិនពេញចិត្តនឹងគ្រួសារ មិនពេញចិត្តនឹងអង្គការរៀបគ្រួសារ គឺថាក្នុងចិត្តក្តុកក្តួលឈឺចាប់ចុកណែន ប៉ុនមិនដឹងនិយាយថាម៉េច ធ្លើយថាម៉េចទៀត មានតែប៉ុណ្ណឹង។"]។ ឯកសារ D5/190/5 អែម អឿន ប្រតិចារឹក ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង 15.57.31-16.01.43 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបង្ខំឲ្យរៀបការក្នុងតំបន់ ២០ ភូមិភាគបូព៌ា ឆ្នាំ១៩៧៧ ឬ ១៩៧៨ ៖ "ដោយសារទាំងប៉ុន្ម្មាន ដោយសារនឹកឃើញរឿងអតីតកាល ថាខ្ញុំចុះជាបុរស ប៉ុន្តែគ្នាជាស្រីក៏ជួបរឿងដូចខ្ញុំដែរ រហូតដល់គ្នាបង្ខំចិត្តមនុស្សមិនស្រឡាញ់"]។ ឯកសារ D347/2.1.42 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.17.38-09.21.15 [ដើមបណ្តឹងរដ្ឋប្បវេណីរៀបការដោយបង្ខំក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ក្នុងខែ សីហា ឆ្នាំ១៩៧៨ ៖ "ស៖ [...] ដូចជាការឲ្យអ្នកស្រីបែកពីប្តី ហើយនិងការចាប់ឲ្យរៀបអាពាហ៍ពិពាហ៍ដែលមិនដឹងខ្លួនមុននេះ តើអ្នកស្រីមានការឈឺចាប់អ្វីខ្លះដល់បច្ចុប្បន្ននេះ? ឆ៖ ខ្ញុំឈឺចាប់ខ្លាំង យ៉ាក ខ្ញុំនិយាយប្រាប់កូនខ្ញុំថា កូនអើយ ខ្ញុំម៉ែវេទនាណាស់។"]។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន ឃីម ឆ.១៥-១៦ KH 01039252 [សាក្សីត្រូវបានបង្ខំឲ្យរៀបការនៅក្នុងស្រុកកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៨ (សូមមើល ឆ.៣)៖ "ស៖ តើអ្នកស្រីនៅមានអារម្មណ៍ខឹងសម្បារ ឬមិនសប្បាយចិត្ត នៅពេលដែលអ្នកស្រីគិតទៅដល់ពិធីរៀបការនោះដែរឬទេ? ឆ.១៥៖ ចាស។ ស៖ ប្រសិនបើអ្នកស្រីអាចលែងលះប្តីរបស់អ្នកស្រី តើអ្នកស្រីនឹងរៀបការជាមួយនឹងបុរសផ្សេងទៀតនៅក្រោយការលែងលះនោះដែរឬទេ? ឆ.១៦៖ អ្នកនៅក្នុងភូមិនឹងមិននិយាយអ្វី [...] ប៉ុន្តែខ្ញុំមិនចង់រៀបការម្តងទៀតទេ។ ខ្ញុំសុខចិត្តនៅតែម្នាក់ឯងជៀសជាងនៅជាមួយអ្នកដែលខ្ញុំមិនស្រឡាញ់។"]។ ឯកសារវីដេអូ D310/1.1.11R អាពាហ៍ពិពាហ៍ក្រហម ឆ្នាំ២០១១ ម៉ោង 26:15-26:38 [ប៉ែន សុចាន់ អ្នកដែលត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៨៧៖ "និយាយប្រាប់គេមួយ យើងយំមួយ ទឹកភ្នែកស្ទើនឹងសម្ពីបានៗ។ ស្តាយៗខ្លួន ប៉ុនដឹងយើងធ្វើម៉េច។ បើយើងនិយាយប្រាប់ម្នាក់ យើងយំម្នាក់ [...] ម្ល៉ោះហើយយើងចេះតែទុកក្នុងចិត្តយើងទ្រាំលំបាក អស់ចិត្តយ៉ាងណាក៏យើង។"]។

[2903] ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.១៦ KH 01096585 [ក្នុងខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ខែកុម្ភៈ ឆ្នាំ១៩៧៨៖ "គូដណ្តឹងខ្ញុំគេចាប់ឲ្យរៀបការជាមួយអ្នកផ្សេង។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនពេញចិត្តទេ ប៉ុន្តែខ្ញុំគ្មានជម្រើសទេ។ បើខ្ញុំមិនធ្វើតាមគេ ខ្ញុំខ្លាចគេយកយើងទៅសម្លាប់ចោល។"]។ ឯកសារ D219/101 កំណត់ហេតុស្តាប់ចម្លើយ កៅ សន ឆ.៤៨ KH 01043227 [ក្នុងខេត្តកំពត ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៦៖ "ពេលនោះខ្ញុំមិនស្រឡាញ់គាត់ ដោយសារខ្ញុំមានគូដណ្តឹងនៅក្នុងភូមិផ្សេង។ ដោយសារគូដណ្តឹងខ្ញុំនៅភូមិផ្សេង គេមិនអនុញ្ញាតឲ្យរៀបការជាមួយគ្នាទេ ដូច្នេះខ្ញុំត្រូវរៀបការជាមួយនឹងបុរសនៅក្នុងភូមិដូចគ្នា។"] ឆ.៥៧ KH 01043228 ["ស៖ លោកស្រីស្រឡាញ់បុរសម្នាក់ ហើយគេបង្ខំឲ្យលោកស្រីរៀបការជាមួយនឹងបុរសម្នាក់ផ្សេងទៀត។ តើលោកស្រីមានអារម្មណ៍ដូចម្តេចនៅពេលនោះ? ឆ.៥៧៖ ខ្ញុំមានអារម្មណ៍ក្រៀមក្រំនៅក្នុងចិត្ត ប៉ុន្តែដោយសារខ្ញុំខ្លាចគេ ដូច្នេះខ្ញុំមិនហ៊ានបដិសេធទេ។"]។ ឯកសារ D219/217 កំណត់ហេតុស្តាប់ចម្លើយ ឆេង ហម ឆ.១២០ KH 01075817 [ក្នុងស្រុកព្រៃឈរ តំបន់ ៤១ ភូមិភាគឧត្តរ ឆ្នាំ១៩៧៦៖ "ខ្ញុំសូមរៀបរាប់ដូចតទៅ៖ នៅវេលាម៉ោង២ គេហៅខ្ញុំទៅប្រជុំ។ រយៈពេលប្រហែល១៥នាទីក្រោយមកគេសួរថា "តើអ្នកចង់រៀបការទេ?" ខ្ញុំធ្លើយថា "ខ្ញុំនៅមិនចង់បានគ្រួសារទេ" ហើយ

រៀបការជាមួយមនុស្សដែលខ្លួនមិនស្គាល់នៅមណ្ឌលគិរី នៅតែមានអារម្មណ៍ "មិនស្រួល" អំពីការរៀបការជាមួយស្ត្រីម្នាក់ដែលមិនមែនជាអតីតគូរដណ្តឹងរបស់គាត់ "ដើម្បីរួចពីសេចក្តីស្តាប់"[2904]។ ក្នុងករណីខ្លះ ប្តីឬប្រពន្ធដើមរបស់ជនរងគ្រោះត្រូវបានបញ្ជូនទៅអប់រំ ឬត្រូវបានសម្លាប់ភ្លាមៗមុនអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគាត់[2905]។ ជនរងគ្រោះនៅភូមិភាគពាយ័ព្យ ង៉ែត ចាត បានរំឭក

បន្ទាប់មកទៀតពួកគេនិយាយថា "មិត្តឯងត្រូវតែរៀបការ" ខ្ញុំឆ្លើយថា "ខ្ញុំមានគូដណ្តឹងហើយ តើខ្ញុំអាចរៀបការជាមួយគូដណ្តឹងរបស់ខ្ញុំបានទេ?" គេឆ្លើយថា "មិនបានទេ"។ ខ្ញុំនៅតែប្រកែកថា "ខ្ញុំមិនព្រមរៀបការទេ"។ បន្ទាប់មកពួកគេបានជិះម៉ូតូទៅការិយាល័យតំបន់ ហើយប្រហែលជា៣០នាទីក្រោយមក គេត្រឡប់មកវិញ ហើយបានចាប់ដៃខ្ញុំ និងសួរខ្ញុំថា "ខ្ញុំសូមសួរមិត្ត ដោយខ្ជីថា តើបច្ចុប្បន្ននេះមិត្តរស់នៅជាមួយអ្នកណា?" ខ្ញុំឆ្លើយថា "ខ្ញុំរស់នៅជាមួយអង្គការ" ពួកគេបាននិយាយថា "ប្រសិនបើមិត្តប្រកែក តើមិត្តរស់នៅទីណា?" ខ្ញុំឆ្លើយដោយខ្ជីថា "ខ្ញុំត្រូវតែរស់នៅជាមួយអង្គការ" ពួកគេបានបោះខោអាវមួយកំណ្ត និងក្រមាមួយឲ្យខ្ញុំ ហើយធ្វើដំណើរទៅកន្លែងរៀបការនៅប្រហែលជាម៉ោង៦ល្ងាច ពេលនោះយើងទាំង២នាក់ អត់ដែលបានឃើញគ្នាពីមុនមកឡើយ ហើយគេហៅឲ្យយើងប្តេជ្ញា ប៉ុន្តែខ្ញុំមិនព្រម ដោយប្រាប់ពួកគេថា "ខ្ញុំមិនព្រម ឲ្យអ្នកដទៃប្តេជ្ញាជំនួសខ្ញុំចុះ"។"]។ សូមមើលផងដែរ ឯកសារ D219/323 កំណត់ហេតុស្តាប់ចម្លើយ មុត សុផុន ឆ.២៨ KH 01099668 [ក្នុងស្រុកកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "ប្រពន្ធបច្ចុប្បន្នរបស់ខ្ញុំជាអ្នកនៅក្នុងកងចល័ត ហើយកន្លែងដែលគាត់សម្រាកនៅក្រោយសាលារៀន។ យាយយុត គាត់ឃើញដែរ និងបានជ្រើសរើសយកគាត់តែម្តង។ យាយយុត ដឹងថាពេលនោះគាត់នឹងគូដណ្តឹងរបស់គាត់ត្រូវមករៀបការនៅថ្ងៃនោះ ដូច្នេះ យាយយុត បានប្រាប់ពួកគេថា ពួកគេមិនអាចរៀបការជាមួយគ្នាឡើយ ដោយសារតែប្រពន្ធរបស់ខ្ញុំត្រូវបានជ្រើសរើសឲ្យមករៀបការជាមួយខ្ញុំវិញ។ គាត់បានប្រាប់គូដណ្តឹងរបស់ប្រពន្ធខ្ញុំឲ្យជ្រើសរើសអ្នកផ្សេងទៀត។ ពេលនោះគាត់យំ។"]។

[2904] ឯកសារ D219/888.1.8 កុល ណែម ប្រតិចារឹក ថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.20.50-14.27.45 [ក្នុងខេត្តមណ្ឌលគិរី ភូមិភាគឦសាន ឆ្នាំ១៩៧៧៖ "ខ្ញុំមានគូដណ្តឹងទៅស្រុក បាទខ្ញុំគិតអ៊ីចឹង។ ដល់នឹកគិតយូរៗបាន៣ថ្ងៃ ខ្ញុំថាបើគិតវែងខ្លីវែងពេកមិនបាន សុខចិត្តបាន ៣ថ្ងៃក៏គេមកសួរទៀត។ ដល់គេសួរខ្ញុំក៏ឯកភាពមួយគេថា ការក៏ការទៅធ្វើម៉េចទេ។ ប៉ុន្តែក្នុងចិត្តនៅ១ដងដែលបាទ នៅក្តៅដងដែល គេបង្ខំ ព្រោះយើងមានគូដណ្តឹងនៅស្រុកបាទ។ [...] ដូច្នេះ ខ្ញុំសុខចិត្តខ្ញុំទៅស្រុកខ្ញុំទៅជួបគូដណ្តឹងគេអត់ទាន់យកប្តីដែរគេនៅចាំបាទ។ ហើយខ្ញុំក៏ឲ្យគេ សូមទោសគេ បាទធ្វើម៉េចបើខ្ញុំយកនេះហើយ ខ្ញុំលែងទៅ ក៏គ្នាខូចកិត្តិយសដែរហ្ន៏ងហើយ។ ដូច្នេះក៏គេអត់ថាអីដែរហ្ន៏ងហើយ ប៉ុន្តែក្នុងចិត្តខ្ញុំនៅតែអត់រហូត។"]។

[2905] ឯកសារ D347/2.1.38 ម៉ុំ រ៉ុន ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.13.12-11.17.05 [ក្នុងខេត្តសៀមរាប ភូមិភាគឧត្តរ ចុងឆ្នាំ១៩៧៥៖ "កាលដែលប្តីខ្ញុំគេហៅរៀនផុត កន្លងផុតប្រហែលជាពីរខែ ឬក៏បីខែ មិត្តគេបានបង្ខំឲ្យខ្ញុំរៀបការ។ បង្ខំឲ្យរៀបការហើយ ខ្ញុំប្រកែកថា ខ្ញុំអត់រៀបការទេ ខ្ញុំខ្លាចប្តីខ្ញុំមកវិញ។ អត់ការក៏ត្រូវតែការដែរ គេនិយាយបែបនេះ។"] ម៉ោង 11.15.28-11.20.29 ["ហើយខ្ញុំក៏ចេះតែភ័យហើយ ថាទៅការឯណា បើប្តីទើបតែទៅបាត់មួយថ្ងៃណោះ ហើយតែដល់វិលមកវិញអ៊ីទៅ មិនកើតរឿងរ៉ាវធំហើយ អ៊ីចឹងចេះតែដល់នេះទៅ នៅស្ងៀមទៅ។"]។ ឯកសារ D118/276 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ហ៊ីម ឆ.១៤ KH 01000017 [ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៥៖ "ប្តីទី១ របស់ខ្ញុំត្រូវគេហៅទៅរៀនសូត្រ រួចក៏បាត់ខ្លួនតែម្តង។ ប្រហែលជា១ខែក្រោយមកទៀត គេបានបង្ខំឲ្យខ្ញុំរៀបការ។"]។ ឯកសារ D310/1.1.6 កាស៊ូមិ ណា កាហ្ការ៉ា អំពើហិង្សាលើយេនឌ័រក្នុងអំឡុងរបបខ្មែរក្រហម KH 00738347 [អ្នកឆ្លើយតបម្នាក់បាននិយាយថា៖ "ប្តីរបស់ខ្ញុំគឺជាកងទ័ពបារាំង។ ពួកគេបានពន្ធ្លាកប្តីរបស់ខ្ញុំ។ ប្រាំខែបន្ទាប់មកពួកគេប្រាប់ខ្ញុំថា ខ្ញុំត្រូវរៀបអាពាហ៍ពិពាហ៍"]។ ឯកសារ

ថាប៉ុន្មានថ្ងៃក្រោយប្តីខ្មែរក្រោមរបស់គាត់ ត្រូវបានគេយកទៅ "ខ្ញុំនៅតែយំស្ពាយការបាត់បង់ប្តីរបស់ខ្ញុំ ហើយខ្ញុំត្រូវបានបញ្ជូនទៅរៀបការ"[2906]។

806. ជនរងគ្រោះរមែងសំដែងវិប្បដិសារី ដែលពួកគាត់មិនបានរៀបការតាមប្រពៃណីសាសនា និងវប្បធម៌ខ្មែរ[2907]។ ការដកគ្រួសារចេញពីដំណើរការរៀបការ ក៏ជាប្រភពនៃការឈឺចាប់របស់ជនរងគ្រោះជាច្រើនផងដែរ[2908]។ ស្ត្រីនានាក្នុងការសិក្សាមួយបានចាត់ទុកការរៀបការដោយបង្ខំថាជា

D219/115.1 Rochelle Braaf អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម KH 01045805-01045806 ["ការសិក្សាស្រាវជ្រាវកន្លងមក និងឯកសារផ្ទាល់នៃរបបខ្មែរក្រហមបង្ហាញថា របបនេះបានបង្ខំប្រជាជននៅលីវ ឬមេម៉ាយជាច្រើននាក់ឲ្យរៀបការដើម្បី "អង្គការ"។ ពេលខ្លះប្តីប្រពន្ធដែលត្រូវបានបង្ខំរៀបការនេះត្រូវបានសម្លាប់ដោយអតីតប្តីប្រពន្ធដែលជាខ្មែរក្រហម ជាពិសេសប្រសិនបើពួកគេត្រូវបានចាត់ទុកជាសត្រូវនៃបដិវត្តន៍។"] KH 01045809-01045811។

[2906] ឯកសារ D347/2.1.42 ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.55.34-09.59.13 [ស្រុកបាកាន ភូមិភាគពាយ័ព្យ ខែសីហា ឆ្នាំ១៩៧៨]។

[2907] ឯកសារ D219/974.1.2 ណុប ធ៉ីម ប្រតិចារឹក ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.26.55-11.28.00 [ការរៀបការដោយបង្ខំក្នុងស្រុកសំឡូត ខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "គឺខ្ញុំជម្រាបតាមត្រង់ ព្រោះអីកាលជំនាន់ហ្នឹង ក្នុងចិត្តនោះ វាចង់បានការមានប្រពៃណីនឹងគេហើយ ប៉ុនធ្វើម៉េចវាតាមដំណើរទៅអ៊ីចឹងហើយ។ អារឿងចិត្តនោះវាចង់បានប្រពៃណីហើយ ប្រពៃណីតាំងអ្ងួនតាម៉ាកុងយើងពីដើមមកនោះ ប៉ុន្តែដល់សម័យនេះ សម័យអ៊ីចឹងមិនដឹងធ្វើម៉េច តាមដំណើរទៅ"]។ ឯកសារ D5/1334/3 ជា ឌៀប ប្រតិចារឹក ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៦ ម៉ោង 14.14.40-14.18.02 [រៀបការដោយបង្ខំក្នុងទីក្រុងភ្នំពេញ ឆ្នាំ១៩៧៥៖ "បានថា ខ្ញុំតូចចិត្តដែរហ្នឹង ដល់ឃើញសព្វថ្ងៃ មកឃើញសម័យឥឡូវនិងសម័យពីដើម តូចចិត្តនឹងវាសនាខ្លួនឯង។"]។ ឯកសារ D117/68 កំណត់ហេតុស្តាប់ចម្លើយ វ៉ា លីមហ៊ាន់ ឆ.៤៤ KH 01025630 [ក្នុងស្រុកកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ចុងឆ្នាំ១៩៧៧។]។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន យីម ឆ.៤ KH 01039249 [ក្នុងខេត្តកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៨]។ ឯកសារ D219/99 កំណត់ហេតុស្តាប់ចម្លើយ ខែត សុខន ឆ.៨៣ KH 01043278 [ក្នុងខេត្តកំពត ភូមិភាគនិរតី ឆ្នាំ១៩៧៨]។ ឯកសារ D219/115.1 Rochelle Braaf អំពើហិង្សាផ្លូវភេទលើជនជាតិភាគតិចក្នុងរបបខ្មែរក្រហម KH 01045832-01045833 ["អ្នកផ្តល់បទសម្ភាសទាំងនេះបន្តរស់នៅដោយមានវិប្បដិសារី និងទុក្ខសោកសៅដោយសារខ្លួនមិនអាចរៀបការតាមប្រពៃណី ឬរៀបការជាមួយនឹងមនុស្សដែលខ្លួនស្រឡាញ់"]។ ឯកសារ D219/882.1.24 Peggy Levine ការសិក្សាបរិបទអំពីពិធីរៀបអាពាហ៍ពិពាហ៍ និងការចាប់កំណើតក្រោមរបបខ្មែរក្រហម៖ បដិវត្តន៍ទំនៀមទម្លាប់ EN 00482424 ["ការសិក្សានេះមិនគ្របដណ្តប់លើប្រភេទមួយនៃភាពតានតឹងអារម្មណ៍ដោយសារជំនឿអរូបិយ ដែលវាទាក់ទងទៅនឹងការបាត់បង់នូវទំនៀមទម្លាប់នានា ហើយដែលបន្តមានក្នុងអារម្មណ៍សុវត្ថិភាព និងអនាគតដែលអាចប្រមើលមើលបានរបស់អ្នកឆ្លើយមួយចំនួន។"] EN 00482475។

[2908] ឯកសារ D219/888.1.2 កាស៊ូមិ ណាកាហ្ការ៉ា ប្រតិចារឹក ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១១ ម៉ោង 15.33.50-15.35.34 ["ខ្ញុំមានរឿងរ៉ាវជាច្រើនរបស់ស្ត្រីដែលបានរៀបការពេលនោះ ពីអារម្មណ៍របស់ពួកគាត់ដែលថាឪពុកម្តាយមិនបានចូលរួមនោះ។ ពួកគេមានទុក្ខព្រួយខ្លាំង ពួកគេយល់ថា ខ្លួនគេគឺត្រូវបាត់បង់នូវតម្លៃ ឬក៏សោកស្តាយ។ ហើយវិប្បដិសារី ហើយនិងការសោកស្តាយហ្នឹងស្ថិតនៅក្នុងចិត្តរបស់គេរហូតដល់ពេលបច្ចុប្បន្ន។"]។ ឯកសារ D219/888.1.6 ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី១២ ខែតុលា

ឆ្នាំ២០១៦ ម៉ោង 13.55.20-13.58.02 [ការរៀបការដោយបង្ខំក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "ត្រង់នេះហើយបានជាតែខ្ញុំឈឺចាប់។ ការរៀបការនោះ គ្មានបង គ្មានប្អូន គ្មានសាច់ញាតិណោហិតណា ដែលដឹងថា យើងរៀបការយ៉ាងម៉េចទេ គ្មានទេ"]។ ឯកសារ D219/494.1.11 ឃី ឡៃសូរ ប្រតិចារឹក ថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៥ ម៉ោង 14.12.36-14.20.00 [អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងឃុំប៉ោយចារ ខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ចុងឆ្នាំ១៩៧៨៖ ឆ៖ បងប្អូនខ្ញុំអត់ទៅជិតទេ។ ស៖ តើលោកស្រីមានអារម្មណ៍យ៉ាងដូចម្តេចដែរ នៅពេលដែលបងប្អូនលោកស្រីមិនអាចចូលរួមនៅក្នុងពេលលោកស្រីរៀបការនុង? ឆ៖ មានអារម្មណ៍ថាតូចចិត្តខ្លួនឯង ព្រោះអីគេមិនឲ្យឪពុកម្តាយទៅជិត។"]។ ឯកសារ D219/444.1.8 ជុំ នៅ ប្រតិចារឹក ថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៩ ម៉ោង 10.27.43-10.37.07 [ក្នុងទីក្រុងភ្នំពេញ ឆ្នាំ១៩៧៦៖ "លឿនត្រង់ថា ប្រាប់ពីព្រឹក ថ្ងៃហ្នឹងយើងរៀបការហើយ ថ្ងៃរសៀលម៉ោងពីរមានកម្មវិធី។ អ៊ីចឹងក្នុងអារម្មណ៍ខ្ញុំវាក្តុកក្តួល [...] បងមានអញ្ជើញម៉ែឪ បងប្អូនខ្ញុំពីស្រុកមកទេ? គាត់ថា អ្ហ! មិនបាច់ទេ យើងកូនអង្គការហើយ។ ពេលហ្នឹងខ្ញុំការមិនសប្បាយចិត្តទេ មិនសប្បាយចិត្តទេ កាលហ្នឹងខ្ញុំយំដែរ។ ប៉ុន្តែពេលវេលា វាដល់ហើយ យើងមិនអាចទៅណារួចទេ។ [...] គេថា ក៏ន្លែងគេពន្យល់ហេតុផលមក [...] អ៊ីចឹងយើងមិនអីទេ អង្គការជាម៉ែជាឪហើយ បើយើងមិនព្រម យើងមិនស្តាប់គេ សួរថា យើងស្ទុះរួចទេ? យើងស្ទុះអត់រួចទេ។ អ៊ីចឹងយើងត្រូវតែទៅ ទៅការក្នុងពិធីហ្នឹងទាំងទឹកភ្នែក ខ្ញុំយំដែរថ្ងៃហ្នឹង ថ្ងៃការហ្នឹង ដោយវាហួសចិត្ត ត្រង់ថាអត់មានបងប្អូនញាតិពីស្រុកមក ដែលគេអត់ផ្តល់ដំណឹងឲ្យចូលរួម។"]។ ឯកសារ D219/494.1.3 ឃិន រ៉ាត ប្រតិចារឹក ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 15.36.42-15.40.35 [អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងខេត្តកំពង់ឆ្នាំង ភូមិភាគបស្ចិម ចុងឆ្នាំ១៩៧៧៖ "ទឹកក្នុងចិត្តថា ឆាចោល ឆាកជីវិតរបស់ខ្ញុំ មិនបានម៉ែឪដឹងក៏ហីចុះ ធ្វើម៉េច កើតមកទទួលកម្មអ៊ីចឹងហើយ ខ្ញុំនឹកឃើញអ៊ីចឹងក៏ខ្ញុំទ្រាអត់ធ្មត់ ចាស។"]។ ឯកសារ D347/2.1.38 ម៉ុំ រ៉ុន ប្រតិចារឹក ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 15.48.15-15.51.06 [ក្នុងខេត្តសៀមរាប ភូមិភាគឧត្តរ ចុងឆ្នាំ១៩៧៥៖ "ណាមួយមិនស្គាយខ្លួន មិនមានសួរម៉ែប្រាប់ម៉ែមួយម៉ាត់ផង វាមានច្បាប់អី សូម្បីតែចំណុចមួយអក្សរមួយអង្គអីមានច្បាប់សុំពីម៉ែឪមករៀបការឯណាក៏គ្មាន ចាប់ដាក់ ចាប់ដាក់ស្រេចតែនឹងអំពើចិត្តដែលបានធ្វើនោះ។ អាកន្ល្ងងត្រង់ណោះ ហើយដែលយំនោះ យំទាំងអស់គ្នា អត់មាននេះទេ។"]។ ឯកសារ D117/68 កំណត់ហេតុស្តាប់ចម្លើយ រ៉ា លីមហ៊ាន់ ឆ.២០ KH 01025624 [ក្នុងស្រុកកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ចុងឆ្នាំ១៩៧៧៖ "ខ្ញុំនឹងសប្បាយចិត្តជាង បើសិនជាឪពុកម្តាយជាអ្នករើសគូស្រករឲ្យ ទោះបីជាកូនកំលោះ មាន ឬក្រក៏ដោយ។"]។ ឯកសារ D219/738.1.35 ប្រតិចារឹកនៃកម្រងសំណួរ លេខ ៩២ របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ឆ.៤៤ KH 01221170 [ក្នុងខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "ខ្ញុំគឺខឹងវាដែលវាបង្ខំឲ្យរៀបការ ម៉ែឪមិនបានចូលរួម"។]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត ដូចខ្ញោចប្រៃកាយ-ការសិក្សាពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម EN 01037042-43, 01037075 ["ការខកចិត្ត គឺជាការឆ្លើយតបខាងផ្លូវអារម្មណ៍ទូទៅរបស់អ្នកផ្តល់បទសម្ភាសន៍ករណីសិក្សា ចំពោះអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេ ពោលគឺខកចិត្តដែលបានបាត់បង់ឱកាសក្នុងការដាក់ការគ្រប់គ្រងលើការសម្រេចចិត្តដ៏ធំមួយក្នុងជីវិត ដូចជាអាពាហ៍ពិពាហ៍ជាដើម និងមិនបានឲ្យក្រុមគ្រួសារ និងជីដូនជីតាផ្តល់សុពលភាព និងបំពេញឲ្យត្រឹមត្រូវតាមច្បាប់លើការសម្រេចដ៏ធំក្នុងជីវិតនោះ។"]។

"ការរៀបការមិនពេញមុខមាត់" ពីព្រោះខ្វះទាំង "ការអនុញ្ញាតពីឪពុកម្តាយ ព្រមទាំងសុពលភាពនៃទំនៀមទម្លាប់ និងភាពស្របច្បាប់ដែលផ្តល់ដោយពិធីប្រពៃណីនានា"[2909]។

807. បន្ថែមពីលើទុក្ខវេទនាដែលបណ្តាលមកពីអាពាហ៍ពិពាហ៍ បុរសស្ត្រីកម្ពុជាបានរងការប៉ះទង្គិចធ្ងន់ធ្ងរពីការផ្សំដំណេកដោយបង្ខំ។ ជនរងគ្រោះជាច្រើនបានរំឭកអំពីការភ័យខ្លាចនៅរាត្រីជាប្តីប្រពន្ធរៀបការថ្មីថ្នោង និងសម្ពាធដែលពួកគាត់ទទួលរងក្នុងការផ្សំដំណេក ឬក្នុងការលាក់បាំងការពិតដែលថា

[2909] ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដួចខ្មោចប្រែកាយ-ការសិក្សាពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម* EN 01037073។

ពួកគាត់ពុំបានផ្សំដំណេក[2910]។ ជនរងគ្រោះខ្លះបានរំពឹកដោយការភ័យខ្លាច[2911]។ វ៉ា លីមហ៊ីន ដែលជាជនរងគ្រោះមួយរូបនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀមក្នុងភូមិភាគ

[2910] ឯកសារ D219/888.1.7 ព្រាប សុឃៀន ប្រតិចារឹក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.05.34-15.08.15 [ស្រុកព្រៃឈរ តំបន់ ៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "ដល់អ៊ីចឹងគឺថាអារម្មណ៍ខ្ញុំហ្នឹង គិតតែ [...] ឃើញថាបើសិនរឿងរ៉ាវដែលខ្ញុំធ្វើនេះដឹងដល់អង្គការ គេនឹងសម្លាប់ខ្ញុំ។ ប៉ុន្តែខ្ញុំខំកែប្រែចរិត ធ្វើឲ្យល្អ មិនឲ្យមិត្តក្នុងរួមការងារជាមួយនឹង អត់ឲ្យដឹង។"]។ ឯកសារ D5/1166/3.1 អ៊ុំ ឃៀន ប្រតិចារឹក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៦ ម៉ោង 09.15.01-09.21.47 [ក្នុងស្រុកចំការលើ តំបន់ ៤២ ភូមិភាគកណ្តាល ចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨៖ "បើសិនជាយើងមិនរួចខ្លាចគេយកយើងទៅធ្វើបាប [...] ហើយដល់យប់ឡើង គេមិនឲ្យអ្នកការពារហ្នឹងការពារចំពោះនាងខ្ញុំផង ហើយមកមើល តើរួមដំណេកឬអត់ បើសិនជាអត់មានរួមដំណេកទេ គេអាចមានធ្វើវិធានការផ្សេងទៀត ហើយនាងខ្ញុំព្រមទៅ។"] ម៉ោង 13.33.12-13.36.44 ["ខ្ញុំមិនបានស្រែក ហើយខ្ញុំមិនបានតវ៉ាទៅទៀតទេ ព្រោះពេលនេះ ខ្ញុំខ្លាច។ ហើយចប់គ្នានៅត្រឹមហ្នឹងតែម្តងទៅ ឲ្យបានជួបគ្នាត្រឹមហ្នឹងតែម្តងទៅ ព្រោះឲ្យថាខ្ញុំស្រឡាញ់តែរហូតហ្នឹង ខ្ញុំនេះទេ គ្រាន់តែថា នៅគុំទុក្ខក្តៅជីវិតនៅក្នុងខ្លួនខ្ញុំ ខ្ញុំក្នាញ់ក្នុងចិត្តខ្ញុំ ខ្ញុំឈឺចាប់ណាស់"]។ ឯកសារ D347/2.1.42 សយ សារឿន ប្រតិចារឹក ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 10.44.57-10.51.06 [ស្រុកចំការលើ តំបន់ ៤២ ភូមិភាគឧត្តរ ឆ្នាំ១៩៧៥៖ "ចាស អរគុណ។ ចាស អរគុណអ្នកស្រី។ ចាស តើអ្នកស្រីមានអារម្មណ៍ក្តុកក្តួលដូចម្តេចដែរ នៅពេលអ្នកស្រីរួមដំណេកដំបូងជាមួយប្តីអ្នកស្រីដែលអ្នកស្រីមិនពេញចិត្តនោះ? ឆ៖ នាងខ្ញុំមានអារម្មណ៍ញ័រ មានអារម្មណ៍ចុកណែនក្នុងខ្លួនដើមទ្រូងរបស់ខ្ញុំ ចង់គាំងបេះដូងដុំៗ ដោយមួយជីវិតខ្ញុំ តាំងពីខ្ញុំដឹងក្តីមក ខ្ញុំពុំដែលជួបប្រទះ ខ្លួនខ្ញុំជាស្ត្រីខ្ទេរមួយរូប អ្វីៗក៏វាមិនសំខាន់ដល់ស្មើនឹងខ្លួនរបស់នាងខ្ញុំដែរ។ តែនាងខ្ញុំសុខចិត្តញ័ររញ្ជាក់ ដូចកូនសត្វយ៉ាងណាក៏ដោយ ក៏នាងខ្ញុំសុខចិត្តថានៅស្ងៀម ដើម្បីឲ្យប្តីបម្រើទៅតាមចំណង់ចំណូលចិត្តរបស់គាត់រួមភេទ ព្រោះគាត់បានប្តេជ្ញាចិត្តនៅមុខអង្គការ។ នាងខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់ សូមឲ្យលោកប្រធានពិចារណា។"]។ ឯកសារ D219/888.1.8 ង៉ែត ចាត ប្រតិចារឹក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 16.02.04-16.06.49 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ខែសីហា ឆ្នាំ១៩៧៨៖ "នាំគ្នាដេកគិតគ្នាថា បើយើងរើបម្រះទៅខ្លាចគេឮ ម្ល៉ោះហើយចេះតែនាំគ្នាដេកស្ងុកៗអ៊ីចឹងទៅ មានឈ្លបគេតូចៗ គេលបចាំស្តាប់មើល គេដើរ។ [...] គិតគ្នា អត់ហ៊ាននិយាយជាមួយគ្នា សូម្បីតែខ្សឹបគ្នា ក៏មិនហ៊ាននិយាយដែរ។ ព្រោះអ៊ីយកទៅវ៉ៃ យកទៅរាងដូចស្រស់ៗពេក ខ្លាចអត់ហ៊ាននិយាយបណ្តោយ។"]។ ឯកសារ D219/702.1.104 ជុំ សាមឿន ប្រតិចារឹក ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 14.25.09-14.27.54 [ក្នុងខេត្តកំពង់ឆ្នាំង ភូមិភាគបស្ចិម ឆ្នាំ១៩៧៨៖ "ដល់ពេលគេការហើយ គេបង្ខំឲ្យខ្ញុំទៅរៀងៗខ្លួន។ ខ្ញុំក៏ទៅបន្ទប់ហ្នឹង ក៏ខ្ញុំញ័ររដូចកូនកណ្តុរអ៊ីចឹងចាស។ ពេលដែលគេនេះហើយ ក៏ខ្ញុំអត់បានប្រាប់អ្នកដែលស្រឡាញ់ខ្ញុំថា "ពូអ៊ីយអាណិតខ្ញុំទៅ ពូឯងកុំអាលធ្វើអ៊ីខ្ញុំ ខ្ញុំខ្លាចណាស់"។ ដល់ហើយអ្នកនោះក៏គេអត់បានធ្វើអ្វីខ្ញុំដែរ។ ដល់ពេលនោះក៏មាន មិនដឹងជាឈ្លបគេ ឬគេអ្វីឮសូរស្នូរជើងគេដើរនៅខាងក្រៅហ្នឹង ខ្ញុំក៏ភ័យញ័រ ខ្ញុំខ្លាចៗគេ ចាស។"] ម៉ោង 14.29.44-14.32.44 ["ចាស មានឈ្លបគេតាមដានហ្នឹង គេៗអត់បានចង់ធ្វើអ៊ីទេ ព្រោះខ្ញុំអត់បានដឹងគេកាន់អាវុធឬអ៊ីទេ ព្រោះខ្ញុំឮតែសម្រ៊ីបជើងដើរចាស។ [...] គេចង់ដឹងថាយើងចុះសម្រុងអត់។"] ម៉ោង 14.29.44-14.32.44 ["ចាស អត់បានរួមដំណេកទេ ព្រោះខ្ញុំខ្លាច ខ្ញុំធម្មតា ស្រីយើងមិនមែនការភ្លាម រ៉ាបភ្លាមទេ។ ខ្ញុំញ័ររដៃញ័ររជើងណាស់ ខ្ញុំខ្លាច ខ្ញុំឲ្យប្តីខ្ញុំលាក់ការណ៍ថា ឲ្យលាក់ការណ៍ឲ្យជិតទៅ ហើយក៏បានលាក់ការណ៍ជិតរហូតដល់សព្វថ្ងៃចាស។"]។ ឯកសារ D117/68 កំណត់ហេតុស្តាប់ចម្លើយ វ៉ា លីមហ៊ីន, ឆ.៣៦, ៤២-៤៣ KH 01025629-30 [ក្នុងស្រុកកំពង់សៀម តំបន់ ៤១ ភូមិភាគកណ្តាល ចុងឆ្នាំ១៩៧៧៖ "ស៖ តើប្តីរបស់លោកស្រីមានអារម្មណ៍នឹងចង់រួមដំណេក ឬយ៉ាងណា? ឆ.៣៦៖ គាត់មានការអៀន ហើយនិងភ័យខ្លាចផងដែរ។ [...] ប្រធានកងខ្ញុំ ឆេន ប្រាប់ខ្ញុំត្រង់តែម្តងថា បន្ទាប់ពីចាប់ដៃរួច

កណ្ដាល បានផ្ដល់សក្ខីកម្មថាអ្វីដែលគាត់អាចគិតឃើញ "គឺនៅពេលណាគេយកគាត់ទៅសម្លាប់"[2912]។ ជនរងគ្រោះដទៃបានរៀបរាប់អំពីការពិបាកចិត្តដែលត្រូវបានបង្ខំឲ្យរៀបការជាមួយ

បើខ្ញុំមិនចុះសម្រុងជាមួយប្ដីទេ ខ្ញុំនឹងត្រូវគេយកទៅសម្លាប់។ [...] ស៖ តើលោកស្រី មានអារម្មណ៍យ៉ាងម៉េច បន្ទាប់ពីរួមដំណេកនៅយប់ដំបូង? ឆ.៤៣៖ ខ្ញុំនៅតែមានការភ័យខ្លាច ហើយគិតឃើញជានិច្ចថា មិនដឹងជាថ្ងៃណាគេនឹងយកខ្ញុំទៅសម្លាប់។"]។

[2911] ឯកសារ D347/2.1.42 ប្រតិចារឹក សយ ណារឿន ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 10.48.09-10.49.44។ D219/702.1.104 ប្រតិចារឹក ជុំ សាម៉ៀន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៥ ម៉ោង 14.25.08-14.27.34។

[2912] ឯកសារ D117/68 កំណត់ហេតុស្ដាប់ចម្លើយ រ៉ា លីមហ៊ាន់ ឆ.៤៣ KH 01025630។

មនុស្ស ដែលពួកគាត់មិនបានស្រឡាញ់[2913] ពិសេសនៅពេលដែលគ្មានការព្រមព្រៀងពីឪពុកម្តាយ[2914]។

[2913] ឯកសារ D219/888.1.7 ប្រតិចារឹក ព្រាប សុឃៀន ថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.31.22-14.35.06 [ក្នុងស្រុកព្រៃឈរ តំបន់៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "បើគេឃើញយើងចេញញ៉ីកពេក គេសួរថា មិត្តឯងទៅណា? ខ្ញុំ កាលហ្នឹង ខ្ញុំអត់មានអារម្មណ៍អីចេះស្រឡាញ់ ហើយនិងពេញចិត្តអីនឹងអ្នករៀបការជាមួយ។ ខ្ញុំប្រាប់គាត់ថា ខ្ញុំចេញមកបត់ជើងអ៊ីចឹងទៅ។ ខ្ញុំ ភ្ជួតគាត់អ៊ីចឹងទៅ។ ខ្ញុំចេញមកសំកុកខាងក្រៅទេ កុំឲ្យនៅក្បែរបុរសហ្នឹង។ [...] ខ្ញុំគ្មានអារម្មណ៍ទៅរួមរក្សាជាមួយបុរស ដែលខ្ញុំអត់ពេញចិត្ត។ ខ្ញុំ គាត់ដេកទៅ ខ្ញុំអង្គុយទៅ គាត់ក្រោក ខ្ញុំចេញមក ខ្ញុំខ្លាចគាត់ចាប់ខ្ញុំដែរ។ កាលនៅហ្នឹង សហជីពហ្នឹង ខ្ញុំចេះចេញដើរផុតៗដែរ ខ្ញុំអត់បានទៅដេកជាមួយផង"]។ ឯកសារ D219/702.1.10 ប្រតិចារឹក ជាំង ស្រីមុំ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.27.16-09.29.40 [ក្នុងឃុំញ៉ែងញ៉ង ខេត្តតាកែវ ភូមិភាគនិរតី ឆ្នាំ១៩៧៧៖ "ទោះបីតែយើងមិនពេញចិត្តយ៉ាងណាក៏ដោយ ក៏យើងត្រូវតែសម្រេចិត្ត សម្រួមចិត្តនូវការក្នុងការភ័យខ្លាចរហូត ការស្រឡាញ់គ្នា មិនស្រឡាញ់គ្នា ក៏ត្រូវតែស្រឡាញ់ដែរពេលហ្នឹង។ តែយើងដាក់ចិត្តថា រួមជាមួយក្នុងគ្រួសារមែនពិត ប៉ុន្តែចិត្តវាមានអត់ទាន់ចិត្តស៊ីសង្វាក់គ្នា ចំពោះប្តីរបស់ខ្ញុំក៏អ៊ីចឹង ចំពោះខ្ញុំក៏អ៊ីចឹងដែរ។ ប៉ុន្តែនៅក្នុងការភ័យខ្លាច ត្រូវតែដាក់ចិត្តនៅក្នុងពេលហ្នឹង បើកាលណាយើងមិនស្របទៅតាមការចាត់តាំងរបស់បក្សទេ គឺខ្ញុំដឹងប្រាកដថា ខ្ញុំមានគ្រោះថ្នាក់ដល់ជីវិត"]។ ឯកសារ D5/190/5 ប្រតិចារឹក អែម អឿន ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១២ ម៉ោង 15.55.36-15.59.41 [ក្នុងតំបន់២០ ភូមិភាគបូព៌ា ឆ្នាំ១៩៧៧ ឬ១៩៧៨៖ "ទាំង១នារីជាភរិយារបស់ខ្ញុំ ទាំងខ្ញុំដេក ពេលចូលដំណេកដេកជាមួយគ្នា បង្ហូរទឹកភ្នែកដាក់គ្នា [...] ថាខ្ញុំចុះជាបុរស ប៉ុន្តែគ្នាជាស្រីក៏ជួបរឿងដូចខ្ញុំដែរ រហូតដល់គ្នាបង្ខំចិត្តមនុស្សមិនស្រឡាញ់។ ប៉ុន្តែក្នុងឱកាសនោះ ខ្ញុំគិតឃើញ ប៉ុន្តែសួរគ្នា ដេកសួរគ្នា តើយើងធ្វើម៉េច ? បើយើងដកដៃ យើងនឹងជាប់ តើយើងធ្វើម៉េច? ហើយការនិយាយនេះ មិនបាននិយាយឲ្យគេឮទៀត។ មើល៍តើពិចារណា ហ្នឹងមានតែយើងពីរនាក់បង្ខំចិត្ត ទាំងងាប់ ទាំងរស់ដើម្បីបំពេញបំណង១ អ្នកត្រូវការដើម្បីជីវិតរបស់យើង យើងគួរធ្វើអ៊ីចឹងដែរឬអត់?"] ម៉ោង 15.59.41-16.01.45 ["បើយើងមិនស្រឡាញ់ គេតាមដានទាំងថ្ងៃ ទាំងយប់ រកតែនិយាយគ្នាអត់រួចទេ។ អ៊ីចឹង ដោយសារគាំទ្រអំពើការគាបសង្កត់នេះមិនបាន ខ្លាចងាប់ផង ក៏ខ្ញុំសម្រេចចិត្តពីរនាក់ផ្ទេចភ្នែកយក"]។ D219/494.1.3 ប្រតិចារឹក ឃិន រ៉ាត ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៥ ម៉ោង 15.38.30-15.40.38 [ក្នុងខេត្តកំពង់ឆ្នាំង ភូមិភាគបញ្ជ្ចឹម ចុងឆ្នាំ១៩៧៧៖ "ប្តីខ្ញុំគាត់និយាយថា "បើមិនស្រឡាញ់ខ្ញុំទេ ក៏ហើចុះ តែកុំប្រាប់គេអី បើមិនត្តឯងប្រាប់គេ មុខជាស្លាប់ហើយ ហើយជុំវិញផ្ទះយើងសម្រាកនេះ សុទ្ធតែគេយាម គេចាំស្តាប់យើង"។ ដល់អ៊ីចឹង ខ្ញុំក៏ខ្លាច ខ្ញុំអត់ប៉ានិយាយអីដែរ ហើយខ្ញុំក៏បង្ខិតបង្ខំដែរ ខ្ញុំទទួលយកពីគាត់ យកប្តីហ្នឹងតាមគេ ហើយក៏អាណិតគាត់ដែរ"]។ ឯកសារ D219/306 កំណត់ហេតុស្តាប់ចម្លើយ សិន បាន ឆ.ពាព KH 01096588 [ក្នុងខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ខែកុម្ភៈ ឆ្នាំ១៩៧៨៖ "វាលំបាកណាស់សម្រាប់ខ្ញុំដែលរៀបការជាមួយមនុស្ស ដែលយើងមិនស្រឡាញ់ ហើយត្រូវរៀបការដោយបង្ខំ ប៉ុន្តែយើងខ្លាចគេសម្លាប់ចោល យើងចេះតែទ្រាំទៅ"]។ ឯកសារ D310/1.1.9R *ទីដេអូ ផលិតឆ្នាំ២០១៣ ស្តីពីការស្តាប់ស្ត្រីជាមួយមនុស្សជំនាន់ក្រោយស្តីពីអំពើហិង្សាផ្លូវភេទក្នុងសម័យខ្មែរក្រហម* ផលិតថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ម៉ោង 08:36-08:47 [មុំ រ៉ុន ដែលគេបង្ខំឲ្យរៀបការនៅខេត្តសៀមរាប ភូមិភាគឧត្តរ ចុងឆ្នាំ១៩៧៥ បានរំឭកថា "នៅពេលយប់ នៅពេលចូលដេក ក្នុងនាមជាប្តីប្រពន្ធ ដែលមិនស្រឡាញ់គ្នា យើងប្រាប់គ្នាថា យើងធ្វើជារួមរស់នៅជាមួយគ្នារហូតដល់ពេលរំដោះ ហើយពេលនោះយើងនឹងរស់នៅដាច់ដោយឡែកពីគ្នា"]។ ឯកសារ D5/1169 ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះ អ៊ីង មុំ KH 01030555 [ក្នុងស្រុកទន្លេបិទ ខេត្តកំពង់ចាម ភូមិភាគបូព៌ា ឆ្នាំ១៩៧៨៖ "ក្នុងរបបខ្មែរក្រហមនេះ ខ្ញុំត្រូវគេ

808. នៅពេលប្តីប្រពន្ធត្រូវបានបង្ខំឲ្យរួមភេទ ទំនាក់ទំនងត្រូវបានប៉ះពាល់យ៉ាងធ្ងន់ធ្ងរ និងម្នាក់ឬទាំងពីរនាក់បានរងការប៉ះទង្គិចផ្លូវកាយ និង/ឬ ផ្លូវចិត្ត[2915]។ ព្រាប សុខឃឿន ដែលត្រូវបានបង្ខំឲ្យរៀបការនៅស្រុកព្រៃឈរ បានផ្តល់សក្ខីកម្មថា៖

ធ្វើបាបទាំងផ្លូវកាយ និងផ្លូវចិត្ត ដោយត្រូវបង្ខំចិត្តទទួលយល់ព្រមរៀបការជាមួយនឹងមនុស្ស ដែលខ្លួនមិនស្រឡាញ់ [...] ការបង្ខំចិត្តរស់នៅជាមួយនឹងមនុស្សដែលខ្លួនមិនស្រឡាញ់នោះ គឺមានការពិបាកណាស់"]។

[2914] ឯកសារ D219/888.1.2 ប្រតិចារឹក Kasumi Nakagawa ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង15.50.21-15.51.20 ["ដូច្នេះការបាត់បង់ ការយល់ស្របពីឪពុកម្តាយរបស់នាង គឺជាបទពិសោធន៍ដ៏រន្ធត់មួយហើយ ឥឡូវនេះមកដល់ពេលមួយ គឺគេបង្ខំឲ្យនាងមានទំនាក់ទំនងផ្លូវភេទជាមួយបុរសដោយបំផ្លាញដល់ព្រហ្មចារីរបស់នាង ដោយគ្មានការយល់ព្រមពីឪពុកម្តាយ [...] ធ្វើឲ្យស្ថិតនៅក្នុងបទពិសោធន៍ដ៏រន្ធត់មួយផ្សេងទៀត"]។ ឯកសារ D219/888.1.7 ប្រតិចារឹក ព្រាប សុឃឿន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.41.55-15.43.36 [ក្នុងស្រុកព្រៃឈរ តំបន់៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៧៖ "ខ្ញុំបើនិយាយសេចក្តីបរិសុទ្ធខ្ញុំកាលពីក្មេងហ្នឹង ខ្ញុំស្តាយៗសេចក្តីបរិសុទ្ធខ្ញុំទល់សព្វថ្ងៃ ព្រោះខ្ញុំក្មេងស្រីមួយ ដែលគោរពទោតាមប្រពៃណី គោរពឪពុកម្តាយ ពាក្យចាស់លោកថា "បើមុននឹងប្រគល់ខ្លួនឲ្យទៅបុរសណាម្នាក់ ទាល់តែឪពុកម្តាយអង្គុយក្បាលកន្ទេល"។ ដល់ពេលនោះ ខ្ញុំអត់មានឪពុកម្តាយអង្គុយក្បាលកន្ទេលផង ខ្ញុំត្រូវអស់ក្តីបរិសុទ្ធរបស់ខ្លួនខ្ញុំ។ ដល់អ៊ីចឹង ខ្ញុំសោកស្តាយបំផុតទាល់សព្វថ្ងៃហ្នឹង ខ្ញុំនៅតែនឹងសោកស្តាយថា មិនគួរណាស់អស់សេចក្តីបរិសុទ្ធមុនឪពុកម្តាយអង្គុយក្បាលកន្ទេល។ កាលសម័យនុងគាត់ចង់បានយើងអង្គុយក្បាលកន្ទេល រៀបចំតាមប្រពៃណីត្រឹមត្រូវ"]។

[2915] ឯកសារ D219/888.1.2 ប្រតិចារឹក Kasumi Nakagawa ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 15.45.55-15.48.27 ["ការបង្ខំបុរសឲ្យរំលោភអ្នកណាម្នាក់ហ្នឹង គឺជាអំពើអមនុស្សធម៌ មិនមែនបុរសទាំងអស់អាចធ្វើបានទេ ជាបឋមនោះ។ ប៉ុន្តែ គេបង្ខំអ្នកនោះធ្វើបែបនោះ។ ការភ័យខ្លាច គឺជាកត្តា ដែលមិនអាចវាស់វែងបាន។ ហើយស្ត្រីជាច្រើន គាត់ភ័យខ្លាចខ្លាំងណាស់ ឬមួយក៏ពួកគេបង្ហាញមនោសញ្ចេតនាថា ពួកគេមិនចង់ទទួលប្តីនោះទេ។ ហើយកាល:ទេសៈដ៏អាក្រក់បំផុតនោះ ដែលបុរសនោះត្រូវតែធ្វើ។ [...] អ៊ីចឹង គឺថាវាប៉ះពាល់ជីវិតអាពាហ៍ពិពាហ៍ បុរសជាប្តីនោះ អាចមានអារម្មណ៍ថា មានកំហុសចំពោះប្រពន្ធ ឬមួយក៏មានការព្រួយបារម្ភ គឺថា ក្នុងចិត្តរបស់ខ្លួនហ្នឹង គឺថា គិតថា ប្រពន្ធមិនបានស្រឡាញ់ខ្លួនទេ។ វាអាចជាជំងឺបាកស្បាតក្នុងចិត្តរបស់គាត់ក្នុងរយៈពេលវែង"] ម៉ោង 15.48.27-15.51.20 ["ចំពោះការរំលោភវិញ គឺថាវាមានកើតឡើងនៅក្នុងករណីខុសៗគ្នា ក្នុងករណីខ្លះ គឺដោយអំពើហិង្សា ដោយសារប្តីបានប្រើអំពើហិង្សា។ ប៉ុន្តែ ការរំលោភខ្លះទៀត គឺមិនមានអំពើហិង្សាទេ ខ្ញុំបានកត់ត្រាទុកទេ ប៉ុន្តែបុរសត្រូវបានគេបង្ខំឲ្យរំលោភប្រពន្ធ ហើយប្រពន្ធត្រូវតែរងអំពើការរំលោភពីប្តី។ អំពើនេះ គឺបានបន្សល់ទុកនូវបទពិសោធន៍ដ៏រន្ធត់ ចាក់ស្បាតចំពោះប្រពន្ធ គឺមិនងាយនឹងភ្លេចបានដោយងាយៗទេ"]។ ឯកសារ D219/888.1.7 ប្រតិចារឹក ព្រាប សុឃឿន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.11.22-15.15.38 [ក្នុងស្រុកព្រៃឈរ តំបន់៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៧ ៖ "ខ្ញុំយំផងអ៊ីផងទៅ ខ្ញុំថា ឪខ្ញុំមិនឲ្យគេធ្វើអ៊ីចឹងទេ ព្រោះត្បិតអី ឪខ្ញុំហាមណាស់ ខ្ញុំស្រី មិត្តឯងប្រុស មកធ្វើអ៊ីខ្ញុំអ៊ីចឹង។ គាត់ថាអត់ទេ អានេះ គឺទិសដៅរបស់អង្គការទេ អ៊ីចឹងគាត់ត្រូវធ្វើទៅតាមទិសដៅអង្គការ។ ខ្ញុំយំរហូតទល់តែភ្លឺ។ [...] ពេលហ្នឹង ខ្ញុំឈឺចាប់ ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ។ ទី១ ការរួមរស់ ដែលយើងមិនដែលធ្លាប់ធ្វើឲ្យចុកចាប់នៅលើរាងកាយរបស់ខ្លួន។ ហើយទី២ ចុកចាប់លើផ្លូវចិត្ត ដែលខ្ញុំមិនមានបំណងកសាងអនាគតប្តីសើរោះ។ ដល់អ៊ីចឹង ខ្ញុំមានតែសេចក្តីយំស្រែក ស្តាយ។ ណាមួយ គឺថាក្បត់នឹងបណ្តាំឪពុកផង អ៊ីចឹងធ្វើឲ្យអារម្មណ៍ខ្ញុំហ្នឹងណា ឈឺចាប់ក្នុងការរួមរក្សហ្នឹងផង ឈឺចាប់ផ្លូវចិត្តផង ធ្វើឲ្យខ្ញុំដេកមិនលក់

> ដំបូង ខ្ញុំឈឺចាប់ផ្លូវកាយដែលគាត់បានធ្វើមកលើខ្ញុំ និងទីពីរ ខ្ញុំឈឺផ្លូវចិត្ត។ ខ្ញុំគ្មានបំណងចង់មានទំនាក់ទំនងប្តីប្រពន្ធទាល់តែសោះ ហើយខ្ញុំគ្មានអ្វីក្រៅពីយំស្តាយអ្វីដែលបានកើតឡើង។ [...] ខ្ញុំដេកមិនលក់ ហូបមិនបាន ធ្លាក់ខ្លួនស្លេកស្លាំង[2916]។

809. ផលប៉ះពាល់ផ្លូវចិត្ត និងផ្លូវកាយនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការផ្សំដំណេកដោយបង្ខំ មានរយៈពេលវែង។ ទាក់ទងព្យសនកម្មផ្លូវកាយ ការសិក្សាមួយរបស់អង្គការធីភីអូ បានសន្និដ្ឋានថា ជនរងគ្រោះនៃ "ការបំពាន, ការវាយដំ និងការរំលោភផ្លូវភេទ" ទាក់ទងការជួបជុំសម័យកម្មុជាប្រជាធិបតេយ្យ រមែងជួបប្រទះ "ការបំពេញមុខងារផ្លូវភេទអវិជ្ជមាន" ដែលរួមបញ្ចូលបញ្ហា អោគស្ត្រី និងបាន

ហូបបាយមិនឆ្ងាញ់។ ដល់អីចឹង វាឲ្យប្រែអាកាសធាតុខ្ញុំទៅជាស្លេកស្លាំង"]។ ឯកសារ D219/888.1.6 ប្រតិចារឹក ប៉ែន សុចាន់ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.22.27-14.24.17 [ក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "គេចាប់រ៉ែធ្វើបាបនាងខ្ញុំ តាំងយប់ទី១ តែខ្ញុំបានសំពះអង្វរគេ។ ខ្ញុំបានស្នៀកខោពីរជាន់កុំឲ្យធ្វើបាបខ្ញុំ ហើយក៏គេចេះតែធ្វើបាបយើងតទៅ ក៏ថ្ងៃហ្នឹង ក៏មិនបានធ្វើអ្វីខ្ញុំដែរ។ គេគ្រាន់តែបានចាប់ទះ ចាប់តប់រូបរាងកាយរបស់នាងខ្ញុំ។ ក្នុងពេលហ្នឹង ក៏ខ្ញុំសូមអង្វរគេយំ អង្គុយយំអង្វរគេអីចឹងទៅ គេក៏ដេកលក់ទៅ។ គ្នាក៏អស់កម្លាំងដែរ"] ម៉ោង 14.39.32 ["ចួកដល់យប់ទី៣ សម្តីសមមិត្តប្រធានអ៊ុំ ក៏ខ្ញុំចងចាំថា យប់ទី៣ គឺយប់ដែលខ្ញុំត្រូវស្លាប់ ដល់ពេលនោះ ខ្ញុំក៏ចូលរួមដំណេក ដេកនឹងគេ ក៏ខ្ញុំមិនព្រមដែរ លោកប្រធាន។ ខ្ញុំគ្រាន់តែចូលទៅ ខ្ញុំស្នៀកខោពីរជាន់។ ដល់ពេលហើយ ឈ្លបមកបីនាក់។ ឈ្លបមកបីនាក់ គេឈរឲ្យចងដៃខ្ញុំទៅជាប់នឹងសសរ សសរវោងហ្នឹងទៅក្រោយទៅ ហើយក៏គេចាប់សម្រាតខោ សម្រាតអាវខ្ញុំអស់ នៅយប់ទី៣ចាស។ គេរំណេកខ្ញុំបានសម្រេច រួចហើយក៏ខ្ញុំធ្លាក់ឈាមជាប់ជាងមួយខែជាង លោកប្រធាន"] *សូមមើលផងដែរ* ភាពយន្តឯកសារផ្តោតលើបទពិសោធន៍របស់ ប៉ែន សុចាន់ ដែលក្នុងនោះ គាត់ពណ៌នាអំពីកំហឹងរបស់គាត់៖ ឯកសារ D310/1.1.11R វីដេអូស្តីពី *អាពាហ៍ពិពាហ៍ក្រហម* ផលិតឆ្នាំ ២០១១ ម៉ោង 11:00-11:34 ["ខ្ញុំអាណិតខ្លួនខ្លាំងណាស់ ព្រោះគេបង្ខំឲ្យរៀបការ! [...] ខ្ញុំអាណិតខ្លួនខ្ញុំ។ ហើយខ្ញុំស្អប់ពួកគេ។ ខ្ញុំចង់កាត់ចេញកន្លែង ដែលប្តីខ្ញុំបានប៉ះពាល់ នៅពេលនោះ។ បើគ្មានថ្នាំងងុយដេកទេ ខ្ញុំដេកមិនលក់ទេ។ ខ្ញុំលេបថ្នាំងុយដេករាល់ថ្ងៃ"] នាទី 26:15-26:38 ["បើខ្ញុំនិយាយពីរឿងហ្នឹង ខ្ញុំយំ។ ទឹកភ្នែកហូរដូចពាក្យសំដី។ ខ្ញុំមានអារម្មណ៍សោកស្តាយខ្លាំងណាស់។ [...] ដូច្នេះ ខ្ញុំព្យាយាមលាក់រឿងនេះ ហើយឈឺចាប់តែម្នាក់ឯង"]។ ឯកសារ D219/136 កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់ ឆ.៤៥, ៤៧ KH 01053266 [ក្នុងស្រុកកំពង់សៀម តំបន់៤១ ភូមិភាគកណ្តាល ចុងឆ្នាំ១៩៧៨៖ "ស៖ តើលោកស្រីមានអារម្មណ៍បែបណា នៅពេលដែលលោកស្រីព្រមរួមភេទ ដែលលោកស្រីមិនចង់? ឆ.៖ ខ្ញុំមានអារម្មណ៍ភ័យខ្លាច ខ្ញុំយំប៉ុន្តែប្តី របស់ខ្ញុំបិទមាត់របស់ខ្ញុំ ដើម្បីកុំឲ្យអ្នកដទៃស្តាប់ឮ។ ខ្ញុំបន្តមានអារម្មណ៍បែបនេះ នៅពេលក្រោយមក ប៉ុន្តែខ្ញុំមិនហ៊ានប្រាប់អ្នកដទៃទេ។ [...] ខ្ញុំមានអារម្មណ៍ភ័យខ្លាច។ ខ្ញុំបន្តមានអារម្មណ៍ភ័យខ្លាច និងយំ ក្នុងរយៈពេល៣ខែនោះ។ [...] ប៉ុន្តែនៅពេលណា ដែលខ្ញុំគិតពីរឿងនេះ ខ្ញុំស្ទើរតែស្រក់ទឹកភ្នែក"]។

[2916] ឯកសារ D219/888.1.7 ប្រតិចារឹកព្រាប សុឃៀន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.12.50-15.15.38។

បាត់បង់ ឬធ្លាក់ចុះចំណង់ផ្លូវភេទ[2917]។ ទាក់ទងព្យសនកម្មផ្លូវចិត្ត ការសិក្សារបស់ ធីភីអូ បានរកឃើញថា៖

> អ្នកឆ្លើយសំណួរចំនួនលើសពីរភាគបីក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់ (70.2%) បានរាយការណ៍អំពីបញ្ហាសុខភាពផ្លូវចិត្តដែលកំពុងកើតមាន ដោយបានចាត់ទុកបញ្ហាទាំងនេះក្នុងសំណួរបើកមួយថា "មិនពេញចិត្តជាមួយជីវិត" និងជាការអស់សង្ឃឹមធ្ងន់ធ្ងរពីអាពាហ៍ពិពាហ៍ដោយបង្ខំ ពិសេសនៅពេល "ចូលរួមពិធីអាពាហ៍ពិពាហ៍ ឬបានឮភ្លេងការ" ។ អ្នកខ្លះបានរាយការណ៍ថាឆាប់ខឹង ខ្លះស្រើត និងខ្លះទៀតទទួលការប៉ះទង្គិចផ្លូវចិត្តនៅពេលពួកគាត់ចងចាំអំពីការរៀបការដោយបង្ខំរបស់ពួកគាត់។ រោគសញ្ញាដែលបានពិពណ៌នា រួមបញ្ចូល "ញ័រខាងក្នុង" "ភាពក្រៀមក្រំ និងទុក្ខវេទនា" និង សុបិនអាក្រក់ ពិសេសសុបិនឃើញការរំលោភសេពសន្តវៈ ពីសំណាក់ដៃគូក្នុងអំឡុងពេលរៀបការដោយបង្ខំ[2918]។

[2917] ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្ញោចក្រឡាខ្លួន-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម* EN 01037059។

[2918] ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្ញោចក្រឡាខ្លួន-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម* EN 01037059។ *សូមមើលផងដែរ* D219/738.1.4 ប្រតិចារឹកកម្រងសំណួរលេខ ១៦ របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា ឆ.៤៤ KH 01220841 [អ្នកផ្តល់ចម្លើយ ដែលជាខ្មែរក្រោមត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកគីរីវង់ ខេត្តតាកែវ ភូមិភាគនិរតី៖ "ខ្ញុំមានកំហឹងឈឺចាប់ ខ្ញុំខឹងអាពត វាធ្វើបាប បង្ខំឲ្យយើងប្តេជ្ញា យើងមិនព្រម វានៅតែបង្ខំ បង្ខិតបង្ខំ មានល្ហប មានអីមកយាមយើង ខ្ញុំឈឺចាប់ណាស់"]។ ឯកសារ D267.1.78 យ៉ីម សុធារី *អតីតកាល និងបច្ចុប្បន្នភាពរបស់ជនរងគ្រោះពីការបង្ខំឲ្យរៀបការសម័យខ្មែរក្រហម* KH 01003537 [ទាក់ទងនឹងអ្នកផ្តល់ចម្លើយម្នាក់ ដែលត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ចុងឆ្នាំ១៩៧៧៖ "អ្នកស្រីធ្លាប់គិតចង់សម្លាប់ខ្លួនជាច្រើនដង"] KH 01003558 [ពាក់ព័ន្ធនឹងអ្នកផ្តល់ចម្លើយម្នាក់ផ្សេងទៀត ដែលត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "ពេលខ្លះ អ្នកស្រីគិតចង់តែសម្លាប់ខ្លួន ប៉ុន្តែនៅបារម្ភពីកូនៗ ចៅៗ គិតវែងឆ្ងាយពីអនាគតរបស់ពួកគេ"] KH 01003570 [អ្នកផ្តល់ចម្លើយម្នាក់ត្រូវបានគេបង្ខំឲ្យរៀបការក្នុងខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "ដោយមិនសម្រេចចិត្តរៀបការជាលើកទីពីរទៀតទេ ពីព្រោះ គាត់ភ័យខ្លាច បើរៀបការទៀត ប្តីក្រោយអាចធ្វើបាបកូនៗ"]។ ឯកសារ D310/1.1.11R រ៉ីដេអូស្តីពី *អាពាហ៍ពិពាហ៍ក្រហម* ផលិតឆ្នាំ២០១១ ម៉ោង 11:00-11:34 [ប៉ែន សុចាន់ ត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "ខ្ញុំចង់កាត់ចេញកន្ទែង ដែលប្តីខ្ញុំបានប៉ះពាល់ នៅពេលនោះ។ បើគ្មានថ្នាំងងុយដេកទេ ខ្ញុំដេកមិនលក់ទេ។ ខ្ញុំលេបថ្នាំងុយដេករាល់ថ្ងៃ"] ម៉ោង 20:36-21:16 ["អ្វីដែលកើតឡើងក្នុងសម័យខ្មែរក្រហមស្ថិតក្នុងចិត្តខ្ញុំជានិច្ច។ យប់ឡើង ខ្ញុំដេកមិនលក់ទេ។ ខ្ញុំសុបិនអាក្រក់ ងើបឡើងឈឺក្បាល និងវិលមុខ [...] មួយជីវិតខ្ញុំ ខ្ញុំនៅតែចងចាំការឈឺចាប់របស់ខ្ញុំពីសម័យខ្មែរក្រហម"]។ ឯកសារ D301/2.1.21 Theresa De

810. ជាក់ស្តែង ជនរងគ្រោះជាច្រើននៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការផ្សំដំណែកដោយបង្ខំ បានដក់ជាប់នូវអារម្មណ៍អាម៉ាស់ និងការស្តីបន្ទោសខ្លួនឯងយ៉ាងធ្ងន់ធ្ងរ[2919]។ ក្នុងការជម្នះនូវអារម្មណ៍ទាំងនេះ និងការដិតដាមជាប់នូវការភ័យខ្លាចអំពីការរើសអើងពីសង្គម ឬការភ័យខ្លាចអំពីការធ្វើឲ្យកូន

Langis និងអ្នកផ្សេងទៀត *ដូចខ្មោចក្រឡាខ្លួន-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម* EN 01037073 [អ្នកផ្តល់ចម្លើយពីករណីសិក្សាទី៨ ស្ត្រីខ្មែរអ៊ីស្លាមម្នាក់បានប្រាប់អ្នកស្រាវជ្រាវថា៖ "ដោយសារតែការបង្ខំឲ្យរៀបការ ខ្ញុំមិនបានប្តីល្អ។ ខ្ញុំមិនរៀបការម្តងទៀតទេ ក្រោយពីលែងលះគ្នា ដោយសារថា ខ្ញុំខ្លាចប្តីក្រោយ គេធ្វើបាបខ្ញុំម្តងទៀត ហើយគេអាចអាក្រក់នឹងកូនៗខ្ញុំ"]។

[2919] ឯកសារ D347/2.1.40 ប្រតិចារឹក ម៉ុ រ៉ុន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 09.49.26-09.51.21 [ក្នុងខេត្តសៀមរាប ភូមិភាគឧត្តរ ចុងឆ្នាំ១៩៧៥៖ "ឲ្យខ្ញុំទៅរៀបការជាមួយនឹងប្តីហ្នឹងហើយ គេបង្ខំឲ្យផ្សំដំណែក ដូចដាក់បាយជ្រូកអ៊ីចឹង។ សេចក្តីឈឺចាប់ អាម៉ាស់របស់ខ្ញុំ គឺថាគ្មានទេ"]។ ឯកសារ D347/2.1.38 ប្រតិចារឹក ម៉ុ រ៉ុន ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.39.23-14.41.16 ["ស៖ អម្បាញ់មិញ លោកស្រី និយាយថា វាហួសពីខ្ទាសទៅទៀត លោកស្រីបាននិយាយអំពីដំបូងហ្នឹងដែលថា ពួកឈ្លបហ្នឹងមកចាប់ប្រដាប់ភេទរបស់ប្តីលោកស្រីហ្នឹងបញ្ចូលមកក្នុងប្រដាប់ភេទរបស់លោកស្រី។ [...] នៅក្នុងបរិបទមួយ ដែលយើងត្រូវរួមភេទ ដោយមានឈ្លបមើល។ [...] តើវាប៉ះពាល់ដល់អារម្មណ៍លោកស្រីកម្រិតណាហើយវាប៉ះពាល់ ? ? ដល់ភាពទុកចិត្តខ្លួនឯងហ្នឹង បានកម្រិតណាដែរសម្រាប់ថ្ងៃអនាគតនោះ ធ៖ ចាស ក្នុងពេលនោះមក ខ្ញុំមានអារម្មណ៍អៀនខ្ទាសចុកចាប់ក្នុងចិត្តខ្ញុំ ចុកចាប់ខ្លាំងមែនទ័ទ ប៉ុន្តែខ្ញុំចង់តវ៉ាជុំគេដែរ ប៉ុន្តែខ្ញុំអត់ហ៊ាន ខ្លាចគេសម្លាប់ចោល។ ម្ល៉ោះហើយ ការខ្ទាសអៀនទាំងអស់នេះ ខ្ញុំអាចោលថា ក្តីអាម៉ាស់របស់ខ្ញុំនេះ ក្នុងមួយជីវិតខ្ញុំនេះ សំណាងអាក្រក់ដែលមកជួបហេតុការណ៍បែបនេះ"]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្មោចក្រឡាខ្លួន-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម* EN 01037035 ["ករណីសិក្សាផ្សេងៗបញ្ជាក់អំពីការខកចិត្ត និងភាពអាម៉ាស់ ដែលជនរងគ្រោះជាច្រើនមានក្នុងចិត្ត ដោយសារតែការផ្ទូរផ្ទងមានលក្ខណៈចាត់តាំងនេះ"] EN 01037076 ["ការបន្ទោសចំពោះខ្លួនឯង និងការផ្តាច់ខ្លួនពីគេឯង [...] ជាលទ្ធផលមួយចំនួន ដែលស្ត្រីប្រឈមមុខ ដោយសារតែការរើសអើង ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម"] EN 01037076 [កត់សម្គាល់ថា ក្នុងករណីមួយចំនួន អារម្មណ៍អាម៉ាស់ គឺផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងការពិតដែលថា ជនរងគ្រោះមិនទទួលបានអាពាហ៍ពិពាហ៍តាមប្រពៃណីខ្មែរ ហើយថា អាពាហ៍ពិពាហ៍របស់ពួកគេមិនត្រូវបានអនុញ្ញាតដោយក្រុមគ្រួសារ និងមួនតា]។ ឯកសារ D267.1.78 យ៉ឹម សុធារី *អតីតកាល និងបច្ចុប្បន្នភាពរបស់ជនរងគ្រោះពីការបង្ខំឲ្យរៀបការសម័យខ្មែរក្រហម* KH 01003537 [អ្នកផ្តល់ចម្លើយត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "[ឡាយ គឹមឈាន] ពីមុន អ្នកស្រីតែងតែយល់ថា ខ្លួនឯងមិនមានតម្លៃ តែងតែប្រៀបធៀបខ្លួនឯងទៅនឹងអ្នកដទៃ ដោយសារតែខ្លួនរស់នៅកំព្រា គ្មានឪពុកម្តាយ បងប្អូន ត្រូវគេបង្ខំឲ្យរៀបការ ទើបគេមិនឲ្យតម្លៃ ហើយអភ័ពយ៉ាងនេះ"] EN 01003557 [អ្នកផ្តល់ចម្លើយត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧ "[អ៊ុំ យ៉ាន] មានអារម្មណ៍ថា គាត់រស់នៅ ដោយមានការពិបាក ជាពិសេសសាច់ញាតិខាងប្តីរបស់គាត់មិនទទួលស្គាល់ និងមើលងាយគាត់ជាប្រចាំក៏ដោយ"] KH 01003570 [អ្នកផ្តល់ចម្លើយត្រូវបានគេបង្ខំឲ្យរៀបការក្នុង ខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "លោកស្រី សន ភាព [...] គាត់មានអារម្មណ៍ថាអាណិតកូនៗគាត់ ដោយពួកគេមានឈ្មោះថា ជាកូនឥតខាន់ស្លា"]។

របស់ពួកគាត់ឈឺចាប់ អ្នកខ្លះបានលាក់ទុកបទពិសោធទាំងនេះជាច្រើនទសវត្សរ៍[2920]។ ក្នុងករណីមួយចំនួន ការភ័យខ្លាចរបស់ជនរងគ្រោះអំពីការមិនចូលចំណោមជាមួយសង្គមខាងក្រៅ ត្រូវបានជួបប្រទះ ដោយ "ការមើលងាយ" ពីសំណាក់សហគមន៍ ទៅលើជនរងគ្រោះ និងគ្រួសាររបស់ពួកគាត់ និងមិនបានដាក់បញ្ចូលពួកគាត់ក្នុងកម្មវិធីសង្គមនានា ពិសេសពិធីមង្គលការ[2921]។ អ្នកឆ្លើយសំណួរភេទស្រីម្នាក់ក្នុងការសិក្សារបស់ធីភីអូបានកត់សម្គាល់ថា៖

[2920] ឯកសារ D347/2.1.38 ប្រតិចារឹក មុំ រ៉ុន ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 11.13.35-11.16.02 ["ខ្ញុំអត់ប៉ានិយាយ ព្រោះខ្ញុំខ្ជាសគេ។ [...] កាលដល់គេហៅមកប្រជុំនៅភ្នំពេញ កន្លែងធីភី.អូ.នោះ ហើយក្មេងនោះ គេក្មេងជាងខ្ញុំផង គេប៉ាន.និយាយលាតត្រដាងរឿងហ្នឹង ហើយដល់ខ្ញុំ គេឮសួរថា អ្នកណាដែលគេបង្ខំរៀបការខ្លះ។ ខ្ញុំក៏លើកដៃថា ខ្ញុំ គេបង្ខំចិត្តឲ្យរៀបការដែរ។ ទៅ គេកត់ឡើងមក បានចូលមកកន្លែងនេះទៀត"] *សូមមើលផងដែរ* វីដេអូក្នុងវេទិការបស់អង្គការធីភីអូ មានលោកស្រី មុំ រ៉ុន ក្នុង ឯកសារ D310/1.1.9R វីដេអូស្តីពីការស្តាប់ស្ត្រីជាមួយមនុស្សជំនាន់ក្រោយ ស្តីពីអំពើហិង្សាផ្លូវភេទ ក្នុងអំឡុងរបបខ្មែរក្រហម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ម៉ោង 09:42-10:04 [មុំ រ៉ុន "ខ្ញុំមានអារម្មណ៍អៀនខ្ជាសខ្លាំងណាស់ ហើយសោកស្តាយក្នុងជីវិតខ្ញុំ។ ខ្ញុំសំណាងអាក្រក់ណាស់ ដែលបានជួបហេតុការណ៍នេះ។ ទោះពេលខ្ញុំស្លាប់ទៅ ក៏មិនអាចបំភ្លេចបានដែរ។ ខ្ញុំមិនលាក់ទុកវាទៀតទេ។ ខ្ញុំចង់ឲ្យជនទូទៅដឹងរឿងនេះ"]។ ឯកសារ D219/83 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន យ៉ីម ឆ.៣៩ KH 01039256 [សាក្សីត្រូវបានបង្ខំឲ្យរៀបការក្នុងស្រុកកំពង់សៀម តំបន់៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៨ (សូមមើល ឆ.២)៖ "ស ៖ តើកូនរបស់អ្នកស្រីមានដឹងអំពីការរៀបការរបស់អ្នកស្រីដែរ ឬទេ? ឆ ៖ ទេ ពួកគេមិនដឹងទេ ដោយសារតែខ្ញុំមិនចង់ឲ្យពួកគេដឹងអំពីរឿងនេះ។ ខ្ញុំមិនដែលនិយាយប្រាប់ក្រុមគ្រួសារ ឬមិត្តភក្តិអំពីរឿងនេះទេ ពីព្រោះខ្ញុំយល់ថា ការនិយាយរឿងនេះប្រាប់ពួកគេ គឺជារឿងឥតប្រយោជន៍"]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដួចឡោចក្រឡាខ្លួន-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម* EN 01037035 ["ក្នុងករណីសិក្សា ជាពិសេស ឪពុកម្តាយមានការលំបាកក្នុងនិយាយការពិតអំពីអាពាហ៍ពិពាហ៍ដោយបង្ខំប្រាប់កូនៗខ្លួន ដែលកើតចេញពីអាពាហ៍ពិពាហ៍នេះ។ ចំពោះអ្នកដែលមិនបាននិយាយប្រាប់អ្នកដទៃអំពីអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ខ្លួន គឺមានច្រើនជាងពាក់កណ្តាល (៥២.៦%) បង្ហាញអំពីអារម្មណ៍អាម៉ាស់ ខណៈដែលច្រើនជាងមួយភាគបី (៣៦.៨%) បង្ហាញអំពីការភ័យខ្លាចនឹងការរើសអើង"]។ ឯកសារ D267.1.78 យ៉ីម សុធារី *អតីតកាល និងបច្ចុប្បន្នភាពរបស់ជនរងគ្រោះពីការបង្ខំឲ្យរៀបការសម័យខ្មែរក្រហម* KH 01003569 [អ្នកផ្តល់ចម្លើយត្រូវបានគេបង្ខំឲ្យរៀបការក្នុងខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "លោកស្រី សន ភាព មិនសូវចូលចិត្តរំឭក ឬនិយាយរឿងបង្ខំឲ្យរៀបការនោះទេ ជាពិសេសជាមួយអ្នកភូមិ"]។ ឯកសារ D310/1.1.12R វីដេអូស្តីពី *ស្ត្រី និងយុត្តិធម៌អន្តរកាល* ផលិតឆ្នាំ២០១២ ម៉ោង 04:00-04:09 ["ជាញឹកញាប់ អ្នកនៅរស់រានមានជីវិតពុំបាននិយាយអំពីបទពិសោធន៍របស់ពួកគេទេ ដោយសារតែមានអារម្មណ៍អាម៉ាស់ចំពោះខ្លួនឯង និងក្រុមគ្រួសារ និងខ្លាចការរើសអើង"]។ ឯកសារ D310/1.1.11R វីដេអូស្តីពី *អាពាហ៍ពិពាហ៍ក្រហម* ផលិតឆ្នាំ២០១១ នាទី 25:45-26:11 [ប៉ែន សុចាន់ត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៨៖ "បើខ្ញុំនិយាយប្រាប់កូនៗខ្ញុំ ដែលគ្នាស្រឡាញ់ខ្ញុំ ពួកគេនឹងខ្ជាសគេ។ [...] ខ្ញុំសោកស្តាយមួយជីវិត។ អញ្ចឹងហើយបានជាខ្ញុំមិននិយាយប្រាប់នរណាទេ សូម្បីតែកូនៗខ្ញុំក៏ដោយ"]។

[2921] ឯកសារ D347/2.1.40 ប្រតិចារឹក មុំ រ៉ុន ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 09.49.26-09.51.21 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេបង្ខំឲ្យរៀបការក្នុងខេត្តសៀមរាប ភូមិភាគឧត្តរ ចុងឆ្នាំ១៩៧៥៖ "អ្នកដទៃគេមើលងាយខ្ញុំ"]។ ឯកសារ D219/136

[ការរៀបការទាំងបង្ខំរបស់ខ្ញុំ] នៅធ្វើឲ្យខ្ញុំពិបាកសព្វថ្ងៃ ដូចជាខ្ញុំកំពុងស្លៀក "ខោរបែក" [សញ្ញានៃការអាម៉ាស់]។ ខ្ញុំកម្រទៅផ្ទះគេណាស់។ ខ្ញុំនៅផ្ទះម្នាក់ឯងភាគច្រើន។ [...] ខ្ញុំមានអារម្មណ៍ខ្មាសគេខ្លាំងណាស់ ហើយខ្ញុំមិនចង់ឲ្យគេដឹងរឿងរបស់ខ្ញុំទេ[2922]។

811. ដោយសារហេតុផលជាច្រើន ប្តីប្រពន្ធជាច្រើនដែលត្រូវបានបង្ខំឲ្យរៀបការក្នុងអំឡុងរបបកម្មុជាប្រជាធិបតេយ្យ បានសម្រេចចិត្តរស់នៅជាមួយក្រោយរបបនោះ៖ ខ្លះបានស្រឡាញ់មនុស្សដែលពួកគាត់ត្រូវបានផ្ទ្ការផ្គង និងបានរួចពីស្លាប់ជាមួយគ្នា ខ្លះទៀតយល់ថាជាកាតព្វកិច្ច ខ្លះទៀតចង់

កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់ ឆ.៥៧-៥៨ KH 01053268 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ខំឲ្យរៀបការក្នុងស្រុកកំពង់សៀម តំបន់៤១ ភូមិភាគកណ្តាល ចុងឆ្នាំ១៩៧៨៖ "កូនស្រីរបស់ខ្ញុំដឹងថា ខ្ញុំត្រូវបានបង្ខំឲ្យរៀបការ។ នាងមានអារម្មណ៍ឈឺចាប់អំពីរឿងនេះ។ ប្រជាជនមើលងាយទាំងកូន និងឪពុកម្តាយ ដែលត្រូវបានបង្ខំឲ្យរៀបការ [...] វាមានផលប៉ះពាល់មកលើពួកយើង។ អ្នកខ្លះនិយាយថា ខ្ញុំរៀបការពីព្រោះខ្ញុំខ្លាចរកប្តីមិនបាន។ ប៉ុន្តែខ្ញុំពន្យល់ប្រាប់ពួកគេថា ខ្ញុំត្រូវបានបង្ខំឲ្យរៀបការ"]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្ទោចក្រឡាខ្លួន-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម* EN 01037059 ["អ្នកផ្តល់ចម្លើយប្រាប់ថាប្តីប្រពន្ធ ដែលគេបង្ខំឲ្យរៀបការ ត្រូវបានគេមើលងាយ និងមិនរាប់រកក្នុងសហគមន៍ ក្នុងនោះអ្នកផ្តល់ចម្លើយម្នាក់និយាយថា 'គេរើសអើងគ្រួសារខ្ញុំខ្លាំងណាស់ ដោយសារតែក្នុងសម័យខ្មែរក្រហម គេបង្ខំឲ្យខ្ញុំរៀបការ'"] EN 01037076 ["ជាពិសេស ស្ត្រីហាក់ដូចជារក្សាទុកក្នុងចិត្តនូវភាពអាម៉ាស់ និងការរើសអើងពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលនាំដល់ការបន្ទាបតម្លៃជាទូទៅដល់ស្ត្រីក្នុងសង្គម [...] ភាពអាម៉ាស់ និងការស្តីបន្ទោសគឺសហគមន៍ទម្លាក់ទៅលើជនរងគ្រោះជាស្ត្រី ហើយបញ្ហានេះត្រូវបានលើកឡើងក្នុងបទសម្ភាសន៍ជាច្រើនជាមួយស្ត្រីក្នុងប៉ាន់សិក្សាស្រាវជ្រាវ"] EN 01037076 ["ការបាត់បង់នូវការរៀបចំតាមបែបប្រពៃណី សេចក្តីស្រឡាញ់ និងទម្លាប់នៃការស្រឡាញ់។ ការបាត់បង់ការគាំទ្រផ្នែកអារម្មណ៍ និងឱកាសផ្នែកសេដ្ឋកិច្ច គឺជាលទ្ធផលមួយចំនួន ដែលកំពុងប្រឈមដោយស្ត្រី ដោយសារតែមានការរើសអើងពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម [...] កូនៗក៏ប្រឈមនឹងការរើសអើងក្នុងសហគមន៍។ [អ្នកផ្តល់ចម្លើយម្នាក់ដំណាលប្រាប់៖] 'អ្នកភូមិខ្លះមិនឲ្យកូនគេរៀបការនឹងកូនខ្ញុំទេ។ ខ្ញុំពួនឹងត្រចៀកខ្ញុំតែម្តង" [...] [អ្នកផ្តល់ចម្លើយជាស្ត្រីម្នាក់ទៀតនិយាយថា៖] 'កូនៗខ្ញុំ គេមិនហៅទៅធ្វើកូនកំដរគេទេ ព្រោះតែពួកគេគ្មានឪពុក។ ទោះក្នុងពេលកូនស្រីខ្ញុំរៀបការក្តី ខ្ញុំមិនអាចចូលរួមក្នុងពិធី [...]។ ទាំងអស់នេះ គឺដោយសារតែអាពាហ៍ពិពាហ៍នោះវាខុស [...] នេះវាប៉ះពាល់ដល់កូនៗ និងម្តាយមួយជីវិត។ បើ ប ុ ល ពត មិនបានបង្ខំឲ្យខ្ញុំរៀបការទេ ខ្ញុំពិតជាបានរៀបការតាមប្រពៃណីត្រឹមត្រូវ ហើយកូនៗ និងខ្ញុំនឹងមានកេរ្តិ៍ឈ្មោះល្អ"]។ ឯកសារ D310/1.1.12R វីដេអូស្តីពី *ស្ត្រី និងយុត្តិធម៌អន្តរកាល* ផលិតឆ្នាំ២០១២ ម៉ោង 04:08-04:41 [ជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំឈ្មោះ ហង់ អ្ងន ពន្យល់៖ "សហគមន៍ខ្ញុំនិយាយថា ខ្ញុំមិនមែនជាស្ត្រីល្អទេ។ គេថា ខ្ញុំមិនបានរៀបការតាមប្រពៃណីត្រឹមត្រូវ។ គេមើលងាយខ្ញុំ។ ជាងនេះទៀត គេមើលងាយកូនៗខ្ញុំ។ ក្នុងពេលរៀបការ គេមិនហៅឲ្យកូនៗខ្ញុំទៅធ្វើជាកូនកំដរទេ។ គេមិនចាត់ទុកពួកយើង គឺជាមនុស្សធម្មតា ដូចគេ ដូចឯងនោះទេ"]។

[2922] ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្ទោចក្រឡាខ្លួន*-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម EN 01037076។

ជៀសផុតពីការវើសអើង ហើយខ្លះទៀតដើម្បីកូនៗរបស់ពួកគាត់[2923]។ ជនរងគ្រោះមួយចំនួនបាន នៅបន្តទំនាក់ទំនងបែបនេះ ទោះជាមានការបំពារបំពានពីសំណាក់ប្តី ឬប្រពន្ធជាបន្តបន្ទាប់ក៏

[2923] ឯកសារ D347/2.1.42 ប្រតិចារឹក សយ ណារ៉ៃន ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៦ ម៉ោង 11.15.50-11.17.20 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកចំការលើ តំបន់៤២ ភូមិភាគឧត្តរ ឆ្នាំ១៩៧៥៖ "ក្រោយពីឆ្នាំដាច់មកហ្នឹង ខ្ញុំបានជាខ្ញុំរួមរស់ជាមួយគ្រួសារជាប្តីប្រពន្ធរហូតមកដល់សព្វថ្ងៃ ដោយខ្ញុំគិតថា ខ្ញុំអាណិតកូន កើតក្នុងសម័យសង្គ្រាម កូនមិនបានពេញលេញទេ។ ហើយណាមួយ ខ្លួនខ្ញុំជាស្ត្រីខ្មែរ ខ្ញុំមិនចង់ឲ្យកូនមានឪមួយ ឪពីរ ប្តីមួយ ប្តីពីរទេ ខ្ញុំសុខចិត្តតែទ្រាំនៅរួមរស់ជាមួយគាត់ រហូតមកដល់បច្ចុប្បន្នកាលនេះ ក៏ខ្ញុំនៅតែមានភាពឈឺចាប់ដែរចំពោះគ្រួសាររបស់ខ្ញុំ តែខ្ញុំសុខចិត្តទ្រាំ ដោយសារកូន បានជាកូនហើយ ខ្ញុំមិនចង់ឲ្យកូនបែកបាក់ទៅខាងណាមកខាងណាទេ។ ខ្ញុំក៏ទ្រាំរស់ ទាំងការឈឺចាប់រហូតមកដល់សព្វថ្ងៃ"]។ ឯកសារ D219/888.1.8 ប្រតិចារឹក កុល ណែម ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 14.39.41-14.42.55 [ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ខំឲ្យរៀបការក្នុងខេត្តមណ្ឌលគិរី ភូមិភាគឥសាន ឆ្នាំ១៩៧៧៖ "ស៖ មុននេះ លោកបាននិយាយថា លោកមានគូដណ្តឹងនៅភូមិ ហើយក្រោយរបបខ្មែរក្រហម លោកបានជួបគាត់វិញ។ អ៊ីចឹង ខ្ញុំចង់សួរថា ក្រោយពីរបបខ្មែរក្រហមហើយហ្នឹង លោមានដែលធ្លាប់គិតថា ចង់បែកពីប្រពន្ធលោកទេ? ឆ.៖ ខ្ញុំចង់ៗបែកដែរ ប៉ុន្តែបែកវាមិនរួច យើងបានការហើយ ក៏យើងមិនហ៊ាន យើងខ្លាច ដូចថា ម្តាយយើង ក៏ស្រី គេក៏ស្រី។ យើងសុខចិត្តទៅសុំទោសគេខាងនោះវិញ គូដណ្តឹង។ បាទ សុំទោសគេថា ខ្ញុំសុំទៅ បើធ្វើម៉េច ខ្ញុំបានជាយកគេងនេះជ្រុលហើយ។ ខ្ញុំសុខចិត្ត ខ្ញុំសារភាព ខ្ញុំជូនពរជី ហ្នឹងហើយ បាទជំនាន់រៀតណាមរំដោះហើយហ្នឹង ខ្ញុំជូនគេ"]។ ឯកសារ D219/83 ស្ងួន ឃីម ឆ.១៤ KH 01039252 [សាក្សីត្រូវបានបង្ខំឲ្យរៀបការក្នុងស្រុកកំពង់សៀម តំបន់៤១ ភូមិភាគកណ្តាល ឆ្នាំ១៩៧៨ (*សូមមើល* ឆ.៣)៖ "[ខ្ញុំចង់លែងលះ ប៉ុន្តែប្តីខ្ញុំមិនព្រម ដូច្នេះហើយ ខ្ញុំសម្រេចចិត្តឈប់លែងលះ។ ប្រសិនបើមានតែម្ខាងចង់លែងលះ នោះគេមិនអាចលែងលះបានទេ នេះមិនមែនជាការតម្រូវផ្នែកច្បាប់ ប៉ុន្តែយើងរស់នៅក្នុងផ្ទះជាមួយគ្នា ដូច្នេះ បើខ្ញុំចង់លែងលះ ខ្ញុំត្រូវចាកចេញពីភូមិនេះ។ យើងមានកូនពីរ។ [...] ខ្ញុំមិនចង់ឲ្យកូនរបស់ខ្ញុំមានជីវិតលំបាកទេ ដូច្នេះហើយ ខ្ញុំសម្រេចចិត្តបន្តរស់នៅជាមួយគាត់"]។ ឯកសារ D267.1.78 ឃីម សុធារី *អតីតកាល និងបច្ចុប្បន្នភាពរបស់ជនរងគ្រោះពីការបង្ខំឲ្យរៀបការសម័យខ្មែរក្រហម* KH 01003547 [ហេង គុយឡាង ត្រូវបានគេបង្ខំឲ្យរៀបការក្នុងខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖ "គឺគ្រាន់តែជាការរៀបការ ដើម្បីគេចវេសពីការសម្លាប់ ហើយក្រោយមក គាត់ព្រមរស់នៅជាមួយនឹងប្តី ដោយសារតែការអាណិតអាសូរកូនៗ ពុំមានការស្រឡាញ់រវាងប្តីប្រពន្ធអ្វីទេ។ [...] ទំនាក់ទំនងរបស់គាត់នឹងប្តីស្ទើរតែធ្លាប់ឈានដល់ការលែងលះគញ្ជា ប៉ុន្តែគាត់មិនអាចធ្វើទៅបាន ដោយសារតែគិតដល់កូនៗ មិនចង់ឲ្យជនទូទៅមាក់ងាយថាជាកូនគ្មានឪពុក"]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្ទោចក្រឡាខ្លួន-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម* EN 01037043 ["ការសិក្សាស្រាវជ្រាវរបស់ Toy-Cronin ពិភាក្សាទៅលើមូលហេតុផ្សេងៗ ដែលប្តីប្រពន្ធមួយចំនួនបន្តរួមរស់នៅជាមួយគ្នា ដោយផ្តោតទៅលើភាគីខាងស្ត្រី៖ បំណងប្រាថ្នាចង់រក្សាក្រុមគ្រួសារ ពិសេសនៅពេលមានកូន ភាពចាំបាច់ផ្នែកសេដ្ឋកិច្ច តម្រូវការការការពារ និងការថែទាំគ្នាទៅវិញទៅមក ឬឥទ្ធិពលនៃប្រពៃណីទំនៀមទម្លាប់ប្រឆាំងនឹងការលែងលះ"] EN 01037071 ["កូន ត្រូវបានលើកឡើងជាកត្តាចម្បង ដោយអ្នកផ្តល់ចម្លើយទាំងអស់ក្នុងបទសម្ភាស នៅពេលដំណាល់ប្រាប់អំពីការរក្សាចំណងអាពាហ៍ពិពាហ៍របស់ពួកគេ"] EN 01037075 ["ប្តីប្រពន្ធខ្លះជ្រើសរើសបន្តរួមរស់នៅជាមួយគ្នា ដោយសារតែការស្រឡាញ់ ប្រយោជន៍កូនៗ ឬស្មារតីទទួលខុសត្រូវចំពោះកាតព្វកិច្ច"] EN 01037079 ["ច្រើនជាងពាក់កណ្តាល (៥៣.១%) នៃអ្នកផ្តល់ចម្លើយ បន្តរក្សាចំណងអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ពួកគេ ក្រោយការដួលរំលំនៃរបបខ្មែរក្រហម ជាចម្បងគឺដោយសារកត្តាកូនៗ ដូចពណ៌នា ក្នុងករណីសិក្សា។ កត្តាផ្សេងៗទៀត ដែលពួក

ដោយ[2924]។ ការពិតដែលថា អាពាហ៍ពិពាហ៍ដោយបង្ខំខ្លះដែលនៅបន្តក្រោយឆ្នាំ១៩៧៩ គ្មានប៉ះពាល់ដល់ការពិតដែលថា ឧក្រិដ្ឋកម្មនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ត្រូវបានប្រព្រឹត្តតាមបញ្ជា

គេរក្សាចំណងអាពាហ៍ពិពាហ៍របស់ពួកគេ គឺការអាណិតអាសូរ ការទទួលយកទ្រឹស្តីកម្មផល និងសារៈសំខាន់នៃឆ្លងកាត់ដូចគ្នានូវបទពិសោធន៍នៃការប៉ះទង្គិចផ្លូវចិត្តក្នុងសម័យនោះ ហើយចុងក្រោយ គឺការស្រឡាញ់"]។ ឯកសារ D219/882.1.21 អត្ថបទសិក្សាស្រាវជ្រាវដោយ Kasumi Nakagawa មានចំណងជើងថា៖ *ភាពជាម្តាយក្នុងសម័យសង្គ្រាម* EN 01322857 ["ក្នុងសង្គមស្ត្រីមិនគួរនៅលីវ មិនយកប្តីនោះទេ"] EN 01322885 ["លោកស្រី ប៊ុន ផណ្ណា ត្រូវគេបង្ខំឲ្យរៀបការ ហើយបន្ទាប់មក គាត់មានកូនស្រីម្នាក់ជាចំណងដៃនៃអាពាហ៍ពិពាហ៍បង្ខំនោះ ហើយគាត់បន្តរួមរស់នៅជាមួយប្តីគាត់ ក្រោយរបបខ្មែរក្រហម។ ទាក់ទងនឹងអាពាហ៍ពិពាហ៍នេះ លោកស្រី ប៊ុន និយាយថា៖ ប្តីខ្ញុំស្រឡាញ់ខ្ញុំ ហើយមើលថែកូនៗ។ ហេតុនេះហើយបានជាខ្ញុំបន្តរួមរស់នៅ" ជាមួយគាត់"។ ស្ត្រីជាច្រើនមានទស្សនៈដូចគ្នានឹងលោកស្រី នៅពេលត្រូវបានចោទសួរអំពីមូលហេតុ ដែលពួកគេបន្តរួមរស់នៅជាមួយបុរស ដែលពួកគេត្រូវបានបង្ខំឲ្យរៀបការជាមួយ។ គាត់មិនដែលស្រឡាញ់ប្តី ដែលគេបង្ខំគាត់ឲ្យរៀបការជាមួយនោះទេ ប៉ុន្តែ រហូតទាល់តែគាត់ស្លាប់ប៉ុន្មានឆ្នាំមុននេះ ទើបពួកគេបន្តរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ។ ស្ត្រីខ្លះក៏បាននិយាយថា ពួកគេជ្រើសរើសរក្សាលំនឹងក្នុងជីវិត ពិសេស នៅពេលពួកគេមានកូនហើយ"]។ ឯកសារ D219/882.1.24 អត្ថបទសិក្សាស្រាវជ្រាវដោយ Peggy Levine មានចំណងជើងថា៖ *បរិបទសិក្សាអំពីពិធីអាពាហ៍ពិពាហ៍ និងការចាប់កំណើតក្នុងរបបខ្មែរក្រហម៖ បដិវត្តន៍ទំនៀមទម្លាប់* EN 00482550 [ដោយកត់មស្គាល់ថា ក្តីអាណិតអាសូរដល់ដៃគូ គឺជាហេតុផលមួយក្នុងចំណោមហេតុផលនានា ដែលពួកគេបន្តរួមរស់នៅជាមួយប្តី ឬប្រពន្ធខ្លួន]។

[2924] ឯកសារ D5/1234/4.1 ប្រតិចារឹក សៀង ចាន់ថី ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ម៉ោង 10.46.05-10.47.17 [បងស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេបង្ខំឲ្យរៀបការក្នុងខេត្តស្វាយរៀង ភូមិភាគបូព៌ា ឆ្នាំ១៩៧៨៖ "គាត់នៅជុំគ្នាតើ ប៉ុន្តែប្តីហ្នឹង គាត់ធ្វើបាផ្លូវចិត្ត ផ្លូវកាយបងស្រីខ្ញុំរហូតហ្នឹង។ គាត់ស្រវឹងស្រា គាត់រករឿង ជេរ ធ្វើបាបបងស្រីខ្ញុំ។ រាល់ថ្ងៃហ្នឹង នៅគាត់ចេះតែទ្រាំរស់នៅទៅ ព្រោះគាត់មានកូន មានចៅហើយ។ គាត់នៅជុំគ្នា។ គាត់មិនបានបែកបាក់គ្នាទៅណាទេ លែងគ្នាក៏លែងមិនដាច់ ពេលគាត់មានកូន មានចៅទន្ទឹមខ្លួនអស់ហើយ។ គាត់ចេះតែស៊ូទ្រាំរស់នៅទៅ ធ្វើម៉េច តាមពាក្យចាស់គាត់ថាកម្ម តាមផលកម្មរបស់គាត់"]។ ឯកសារ D219/738.1.13 ប្រតិចារឹកកម្រងសំណួរលេខ៥៦ របស់ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា ឆ.៤៤ KH 01220950 [អ្នកផ្តល់ចម្លើយត្រូវបានគេបង្ខំឲ្យរៀបការក្នុងស្រុកបាកាន ខេត្តពោធិ៍សាត់ ភូមិភាគពាយ័ព្យ៖ "ទោះបីជាសព្វថ្ងៃ ប្តីខ្ញុំដែលបានប្តេជ្ញាបានរស់នៅជាមួយគ្នាមែន តែវាតែងតែមានបញ្ហារកាំរកុះនឹងគ្នា។ គាត់តែងតែសម្តុតកូន ហើយពេលរួមភេទម្តងៗ ទាល់តែមានការសម្តុត ទើបខ្ញុំព្រម"]។ ឯកសារ D301/2.1.21 Theresa De Langis និងអ្នកផ្សេងទៀត *ដូចខ្ជោចក្រឡាខ្លួន-ការសិក្សាអំពីផលប៉ះពាល់នៃអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យខ្មែរក្រហម* EN 01037075 ["អាពាហ៍ពិពាហ៍ ដែលនៅបន្ត ទោះបីមានតែមួយរយៈពេលក្តី គឺទំនងមានអំពើហិង្សា នេះបើយោងតាមបទសម្ភាសន៍ក្នុងករណីសិក្សា (និងបញ្ជាក់បន្ថែមដោយលទ្ធផលនៃការសិក្សាបែបបរិមាណ)។"] EN 01037071 ["អាពាហ៍ពិពាហ៍ដោយបង្ខំ ដែលមានអំពើហិង្សា អាចជាអ្វីដែលពិបាកបំផុតក្នុងការដោះស្រាយ ដោយសារតែការចងគំនុំសងសឹក ការពឹងផ្អែកផ្នែកសេដ្ឋកិច្ច ការភ័យខ្លាចបាត់បង់កូនៗ និងការប៉ះទង្គិចផ្លូវចិត្ត ដែលកើតចេញពីអំពើហិង្សា"] EN 01037079 ["អាពាហ៍ពិពាហ៍ដោយបង្ខំជាច្រើន ដែលនៅបន្ត គេមើលឃើញថា មិនដំណើរការប្រក្រតីទេ គឺមានចំនួនលើសពាក់កណ្តាល (៥២.៩%) ក្នុងប៉ាន់សិក្សាស្រាវជ្រាវ បានរៀបរាប់អំពីអំពើហិង្សាពីសំណាក់ភាគីដៃគូ"]។ ឯកសារ D267.1.78 ឃីម សុធារី *អតីតកាល និងបច្ចុប្បន្នភាពរបស់ជនរងគ្រោះពីការបង្ខំឲ្យរៀបការសម័យខ្មែរក្រហម* KH 01003547 [ហេង គុយឡាង ត្រូវបានគេបង្ខំឲ្យរៀបការក្នុងខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ ឆ្នាំ១៩៧៧៖

របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យឡើយ ហើយប្តីប្រពន្ធត្រូវបានបង្ខំឲ្យរៀបការដោយគ្មានការព្រមព្រៀងរបស់ពួកគាត់នៅពេលនោះ។

812. ជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ ប.ក.ក និងគោលនយោបាយផ្សំដំណេកដោយបង្ខំ រងផលប៉ះពាល់ខ្លាំងសម្រាប់របបនេះដើម្បីសម្រេចគោលដៅបដិវត្តន៍របស់ខ្លួន។ ជនរងគ្រោះជាច្រើនបានបន្តរងផលប៉ះពាល់ អស់ជិត ៤០ ឆ្នាំកន្លងទៅហើយ។ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ដែលត្រូវបានប្រព្រឹត្ត (តាមរយៈការផ្សំដំណេកដោយបង្ខំ) ដោយមន្ត្រីកម្ពុជាប្រជាធិបតេយ្យ ដោយរួមបញ្ចូល **យ៉ីម ទិត្យ** និងមនុស្សក្រោមបង្គាប់របស់គាត់ក្នុងភូមិភាគពាយ័ព្យ និងពិសេសនៅស្រុកសំឡូត នៅអាងចក្រស្ករសកំពង់គល់ និងវាំងកេសី និងឃុំកំពង់ព្រាង មានលក្ខណៈទូទៅ ជាប្រព័ន្ធ និងមានស្ថានទម្ងន់ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត ដែលត្រូវបានលើកឡើង។

ច. ឧក្រិដ្ឋកម្មដែលការចោទប្រកាន់ត្រូវបានស្វែងរក

813. ផ្អែកលើភ័ស្តុតាងខាងលើ ស.ព.អ ស្នើសុំការចោទប្រកាន់ **យ៉ីម ទិត្យ** អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀត (អាពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ) ទាក់ទងស្រុកសំឡូត ឃុំវាំងកេសី និងឃុំកំពង់ព្រាង និងអំពើអមនុស្សធម៌ដទៃទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ) ទាក់ទងអាងចក្រស្ករសកំពង់គល់[2925]។

"គឺគ្រាន់តែជាការរៀបការ ដើម្បីគេចវេសពីការសម្លាប់ ហើយក្រោយមក គាត់ព្រមរស់នៅជាមួយនឹងប្តី ដោយសារតែការអាណិតអាសូរកូនៗ ពុំមានការស្រឡាញ់រវាងប្តីប្រពន្ធអ្វីទេ។ អ្នកស្រីទទួលរងអំពើហិង្សាទាំងផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ"]។

[2925] សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ឃើញថា លោកចង់ចោទប្រកាន់ចំពោះឧក្រិដ្ឋកម្ម ដូចដែលបានដាក់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប៉ុន្តែមិនបានចោទប្រកាន់លើ យ៉ីម ទិត្យ នោះទេ។ ទាំងនេះ គឺជាអំពើអមនុស្សធម៌ផ្សេងៗទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ) នៅអាងចក្រស្ករកំពង់គុលក្នុងស្រុកសង្កែ និងអំពោះអមនុស្សធម៌ផ្សេងៗទៀត (ការរំលោភសេពសន្ថវៈ) ក្នុងស្រុកសំឡូត ឃុំកំពង់ព្រៀង និងឃុំវាំងកេសី។ សហចៅក្រមស៊ើបអង្កេតបានទទួលឧក្រិដ្ឋកម្មទាំងនេះ ក្នុង ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ៤-៦។ ក្រោមវិធាន៥៥)៣) សហចៅក្រមស៊ើបអង្កេតក៏ទទួលបានអង្គហេតុទាំងអស់ ដូចមានលើកឡើងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាំងអស់ ក្នុងនោះរួមមាន ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ កថាខណ្ឌ៤ ជើងទំព័រ១១ ដូចបញ្ជាក់ក្នុង ឯកសារ D191.1.29 របាយការណ៍ពីអង្គភាពជនរងគ្រោះស្តីពីដើមបណ្តឹងរដ្ឋប្បវេណី ខ្ចៀន ច័ម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១០។ របាយការណ៍នេះពិពណ៌នាអំពីភ

គ. ឧក្រិដ្ឋកម្មប្រឆាំងប្រជាជនវៀតណាម

១. សេចក្តីផ្តើម

814. យុទ្ធនាការរបស់ខ្មែរក្រហមដើម្បីបំផ្លាញប្រជាជនវៀតណាម ដែលជាក្រុមជាតិពន្ធុមួយនៅកម្ពុជា បានដាក់គោលដៅជាក់លាក់ទៅលើខ្មែរក្រោម ដែលខ្មែរក្រហមបានចាត់ទុកជាជនជាតិវៀតណាម។ ផែនការរបស់ ប.ក.ក បានរួមបញ្ចូលការដកហូតសិទ្ធិជាសារវន្តដោយចេតនា និងការសម្លាប់ជនជាតិភាគតិចវៀតណាម និងខ្មែរក្រោមក្នុងទ្រង់ទ្រាយធំ។

815. **យ៉ីម ទិត្យ** ជាសមាជិកដ៏សំខាន់មួយរូបនៃ JCE ដែលបានអនុវត្តផែនការ ប.ក.ក ដើម្បីបំផ្លាញក្រុមជាតិពន្ធុវៀតណាម ពិសេសខ្មែរក្រោម ព្រមជាមួយបុគ្គលនានាដែលរួមបញ្ចូល តា ម៉ុក និងយាយ រីម។ **យ៉ីម ទិត្យ** បានរួមចំណែកក្នុងយុទ្ធនាការ ដែលអនុវត្តដោយកម្មាភិបាលភូមិភាគនិរតីក្នុងភូមិភាគនិរតីនិងពាយ័ព្យ ដើម្បីដាក់ជាគោលដៅទៅលើជនទាំងឡាយណាដែល ប.ក.ក ចាត់ទុកជាផ្នែកមួយនៃក្រុមជាតិពន្ធុវៀតណាម នៅខណៈពេលគាត់កំពុងបម្រើការងារក្នុងគណៈកម្មាធិការស្រុកគិរីវង្ស និងគណៈតំបន់ ១៣ ក្នុងភូមិភាគនិរតី និងជាមេដឹកនាំ *តាមព្រឹត្តន័យ* និង *តាមនីតិន័យ* ក្នុងភូមិភាគពាយ័ព្យ។ **យ៉ីម ទិត្យ** បានមានសិទ្ធិអំណាចក្នុងតំបន់សំខាន់ចំនួន ២ ដែលប្រជាជនខ្មែរក្រោមត្រូវបានប្រមូលផ្តុំ និងត្រូវបានសម្លាប់ជាបន្តបន្ទាប់-ខេត្តតាកែវ និងខេត្តពោធិ៍សាត់។

ស្តីតាងដែលថា ផ្ទះគណៈត្រូវបានគេរៀបចំសម្រាប់អ្នកទើបរៀបការថ្មីថ្មោង ដែលបង្ហាញយ៉ាងច្បាស់អំពីមូលហេតុសម្រាប់អាពាហ៍ពិពាហ៍ដោយបង្ខំ ដើម្បីបង្កើនចំនួនប្រជាជន តាមរយៈការផ្សំដំណែកនៃអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនោះ។ ជាងនេះទៀត ការចូលរួមរបស់ យ៉ីម ទិត្យ ក្នុងការសម្របសម្រួលលទ្ធភាពក្នុងការរួមរស់នៅជាមួយគ្នាបន្ទាប់ពីអាពាហ៍ពិពាហ៍ដោយបង្ខំទាំងនេះ ក៏ត្រូវបានលើកឡើងផងដែរក្នុង ឯកសារ D272/1 ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី ៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់១ និងតំបន់៤ ចុះថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ជើងទំព័រ២១។ ភស្តុតាង ដូចមានបង្ហាញក្នុងជើងទំព័រ រួមបញ្ចូលទាំងភស្តុតាងដែលថា តាម៉ុកបានប្រាប់ យ៉ីម ទិត្យឲ្យដឹកគ្រែ មុង និងអង្រឹងឲ្យអ្នកទើបរៀបការថ្មីថ្មោងទាំងនោះ ហើយបីថ្ងៃក្រោយមក អ្នកទើបរៀបការថ្មីថ្មោងទាំងនោះទទួលបានសម្ភារៈទាំងនោះ ជាមួយនឹងលិខិតមានចុះហត្ថលេខា ដែលសរសេរថា "ពីគណៈតំបន់១ ទិត្យ"។ ការរួមដំណែកដោយបង្ខំ (ការរំលោភសេពសន្តវៈ) ដូច្នេះ វាមានទំនាក់ទំនងយ៉ាងច្បាស់ក្រឡែតទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយដែលហេតុការណ៍ទាំងពីរនេះកើតឡើងដំណាលគ្នាក្នុងសម័យនោះ។ ចំពោះហេតុផលទាំងអស់នេះ សហចៅក្រមស៊ើបអង្កេតក៏បានទទួលពិនិត្យមើលឧក្រិដ្ឋកម្មនៃអំពើអមនុស្សធម៌ផ្សេងៗទៀតផងដែរ អាពាហ៍ពិពាហ៍ដោយ) បង្ខំ និងការរំលោភសេពសន្តវៈ) នៅតាមទីតាំង ដូចបានបញ្ជាក់។

816. ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** អំពីឧក្រិដ្ឋកម្មខាងក្រោមទាក់ទងការប្រព្រឹត្តទៅលើជនជាតិភាគតិចវៀតណាម ដែលភ័ស្តុតាងត្រូវបានបញ្ជាក់លម្អិតខាងក្រោម និងនៅក្នុងផ្នែកស្តីពីតំបន់ទីតាំងឧក្រិដ្ឋកម្មរោងចក្រស្ករសកំពង់គល់នៃដីកាសន្និដ្ឋាននេះ៖ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយនិងពូជសាសន៍ តាមរយៈអំពើមនុស្សឃាត និងការសម្លាប់រង្គាលជាមូលដ្ឋាន[2926]។

817. ស.ច.ស.អ បានចោទប្រកាន់ **យ៉ីម ទិត្យ** អំពីឧក្រិដ្ឋកម្មខាងក្រោមទាក់ទងការប្រព្រឹត្តទៅលើខ្មែរក្រោម ដែលមានបញ្ជាក់ភ័ស្តុតាងជាលម្អិតខាងក្រោម និងក្នុងដីកាសន្និដ្ឋាននេះត្រង់ផ្នែកស្តីពីទីតាំងឧក្រិដ្ឋកម្ម៖ អំពើប្រល័យពូជសាសន៍តាមរយៈការសម្លាប់[2927] ការបង្កដោយចេតនាឲ្យមានស្ថានភាពរស់នៅដែលនាំមកនូវការបំផ្លិចបំផ្លាញ[2928] និងការបង្ករបួសនកម្មធ្ងន់ធ្ងរលើរូបរាងកាយ និងផ្លូវចិត្ត[2929] និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់នៃការធ្វើទុក្ខបុកម្នេញ ដោយហេតុផលនយោបាយ និងពូជសាសន៍[2930] តាមរយៈអំពើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស ការដាក់ជាទាសករ ការចាប់ដាក់ពន្ធនាគារ ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការជម្លៀស

[2926] <u>ភូមិភាគពាយ័ព្យ</u>៖ រោងចក្រស្ករកំពង់គុល។ *សូមមើល* ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426542។

[2927] <u>ភូមិភាគនិរតី</u>៖ មន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្ស ភូមិព្រៃល ទីតាំងសម្លាប់មនុស្ស វត្តអង្គុណ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី។ ភូមិភាគពាយ័ព្យ៖ រោងចក្រស្ករកំពង់គុល មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់មនុស្ស ទួលសេះញ៉ូ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ឃុំកំពង់ព្រៀង និងឃុំរ៉ាំងកេសី។ *សូមមើល* ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426544-47។

[2928] <u>ភូមិភាគនិរតី</u>៖ ទីតាំងសម្លាប់មនុស្សភូមិព្រៃល ទីតាំងសម្លាប់មនុស្សវត្តអង្គុណ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង។ *សូមមើល* ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426548-49។

[2929] <u>ភូមិភាគពាយ័ព្យ</u>៖ មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ។ *សូមមើល* ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426552។

[2930] <u>ភូមិភាគនិរតី</u>៖ មន្ទីរសន្តិសុខវត្តប្រធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់មនុស្ស ភូមិព្រៃល ទីតាំងសម្លាប់មនុស្ស វត្តអង្គុណ ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង ទីតាំងសម្លាប់មនុស្សព្រៃសុខុន និងវត្តអង្គសិរីមុនី។ ភូមិភាគពាយ័ព្យ៖ រោងចក្រស្ករកំពង់គុល មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់មនុស្ស ទួលសេះញ៉ូ ទីតាំងសម្លាប់មនុស្សព្រៃក្របៅ ឃុំកំពង់ព្រៀង និងឃុំរ៉ាំងកេសី។ *សូមមើល* ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ KH 01426544-47។

ដោយបង្ខំ) (អាពាហ៍ពិពាហ៍ដោយបង្ខំ) (ការបង្ខាំងក្នុងលក្ខខណ្ឌអមនុស្សធម៌) និង (ការធ្វើការងារក្នុងលក្ខខណ្ឌអមនុស្សធម៌)[2931]។

818. ផ្នែកខាងក្រោមនឹងគូសបញ្ជាក់អំពីវិធីដែលខ្មែរក្រោម និងប្រជាជនវៀតណាមបានបង្កើតជាក្រុមជាក់លាក់មួយ និងថា ប.ក.ក បានចាត់ទុកពួកគាត់ដូច្នោះ។ ចេតនារបស់ ប.ក.ក ទៅលើប្រជាជនវៀតណាម និងខ្មែរក្រោម នឹងត្រូវបានពិភាក្សាជាបន្តបន្ទាប់។ ជាចុងក្រោយ ការផ្សព្វផ្សាយរបស់ **យ៉ីម ទិត្យ** និងសមាជិក JCE របស់គាត់ទូវផែនការដើម្បីបំផ្លាញប្រជាជនវៀតណាម និងការអនុវត្តផែនការរបស់ពួកគាត់ក្នុងតំបន់១៣ នៃភូមិភាគនិរតី និងតំបន់ ១ តំបន់ ២ និងតំបន់ ៧ នៃភូមិភាគពាយ័ព្យ នឹងត្រូវបានបង្ហាញ។

២. ប្រជាជនវៀតណាម និងខ្មែរក្រោមជាក្រុមជាក់លាក់

819. ប្រជាជនវៀតណាមជាក្រុមជាតិពន្ធុដាច់ដោយឡែកមួយនៅកម្ពុជា ដែលខុសពីក្រុមដទៃតាមរយៈលក្ខណៈផ្សេងៗដូចជារូបរាងកាយ ភាសា និងទំនៀមទម្លាប់[2932]។ ខ្មែរខ្លះបានចាត់ទុកជនជាតិភាគ

[2931] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ EN 01426070-75។

[2932] *សូមមើលខ១ាបារណ៍* ឯកសារ D219/879.1.17 មជ្ឈមណ្ឌលសម្រាប់ការសិក្សាជាន់ខ្ពស់ *ជនជាតិភាគតិចនៅកម្ពុជា* EN 00489295-96, 301, 318។

តិចវៀតណាមថាមានមុខមាត់ខុសពីខ្មែរ[2933] មានសម្បុរ ស[2934]។ ប្រជាជនវៀតណាមក៏ត្រូវបានគេនិយាយថា និយាយសំឡេងខុសពីប្រជាជនខ្មែរ[2935] ឬនិយាយភាសាខ្មែរមិនច្បាស់[2936]។

820. "ខ្មែរក្រោម" ជាពាក្យប្រើសម្គាល់ជនជាតិខ្មែរភាគតិចដែលកើត ឬជាកូនចៅអ្នកដែលកើតនៅកម្ពុជាក្រោម ដែលជាតំបន់មួយក្នុងផ្នែកខាងត្បូងវៀតណាមក្នុងអំឡុងរបបខ្ជែរក្រហម។ ប.ក.ក បានចាត់ទុកខ្ជែរក្រោមថាជាប់ខ្ជែ្ជរយ: ឬជាផ្នែកមួយនៃក្រុមវៀតណាម ដោយសារទំនាក់ទំនងរបស់ពួកគាត់ជាមួយវៀតណាម។

[2933] ឯកសារ D347/2.1.22 ប្រតិចារឹក ស៊ាន ស៊ីង ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ម៉ោង 15.16.42-15.18.58។ ឯកសារ D347/2.1.23 ប្រតិចារឹក ស៊ាន ស៊ីង ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ ម៉ោង 09.10.18-09.12.27។ ឯកសារ D219/792.1.4 ប្រតិចារឹក សៀង ចាន់ថី ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 15.45.29-15.48.05។

[2934] ឯកសារ D289.7 ប្រតិចារឹក ប្រាក់ ឌឿន ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 11.24.41-11.27.26។ ឯកសារ D219/792.1.4 ប្រតិចារឹក សៀង ចាន់ថី ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 15.45.29-15.48.05។ ឯកសារ D5/1234/4.1 ប្រតិចារឹក សៀង ចាន់ថី ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ម៉ោង 09.34.42-09.36.28។

[2935] ឯកសារ D347/2.1.24 ប្រតិចារឹក អ៊ីំ ស្ងួន [ព្រុំ សារុន] ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 13.45.54-13.50.45។ ឯកសារ D347/2.1.27 ប្រតិចារឹក ឡាច ត្រី ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ ម៉ោង 15.07.25-15.09.05។ ឯកសារ D347/2.1.30 ប្រតិចារឹក មាស រឿន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 16.06.12-16.07.30។ ឯកសារ D347/2.1.24 ប្រតិចារឹក ព្រុំ សារុន ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 14.02.58-14.05.55, 15.56.14-15.58.00។ ឯកសារ D5/1234/4.1ប្រតិចារឹក ខ្ងង ម្ងយ ហៅ ខ្ងង ម្ងូល ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ម៉ោង 13.40.22-13.42.20។ សូមមើលផងដែរ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លីម ទីម អ.៧៦ KH 01196466។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម អ.១៩-២០ KH 00987227។ ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ឈួន អ.៣០ KH 00905856។ ឯកសារ D347/2.1.11 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប្រាក់ សារិន EN 00197566-67។

[2936] ឯកសារ D347/2.1.29 ប្រតិចារឹក ដ្ងង អ៊ីន ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ម៉ោង11.17.27-11.19.04។

821. ដូចប្រជាជនវៀតណាមដែរ ខ្មែរក្រោមត្រូវបាននិយាយថា និយាយភាសាខ្មែរមិនច្បាស់[2937] និងត្រូវបានគិតថាមានស្បែកភ្លឺជាងខ្មែរ[2938]។ ខ្មែរក្រោមក៏អាចសម្គាល់បានតាមសម្លៀកបំពាក់របស់ពួកគាត់[2939]។ ស្ត្រីខ្មែរក្រោម ដូចស្ត្រីវៀតណាមដែរ ស្លៀកខោ ចំណែកស្ត្រីខ្មែរស្លៀកសារ៉ុង[2940]។

[2937] <u>គិរីវង្ស</u>៖ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម អ.១៩-២២ KH 00987227 អ.២៤-២៥ KHKH 00987228 អ.២៩-៣៣ KH 00987228-29។ ឯកសារ D118/269 កំណត់ហេតុស្តាប់ចម្លើយ ថាន់ ធីម អ.៥៥ KH 01។ ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្រូ អ.១៦៨ KH 01022445។ ឯកសារ D118/203 កំណត់ហេតុស្តាប់ចម្លើយ ឌឹក ប៉ែត អ.៩២ KH 00979210។ <u>ត្រាំកក់</u>៖ ឯកសារ D118/300 កំណត់ហេតុស្តាប់ចម្លើយ គឹម ប៊ុនលី អ.២០២ KH 01024538 ។ ឯកសារ D219/918 កំណត់ហេតុស្តាប់ចម្លើយ សយ សែន អ.២៧ KH 01390475។ ឯកសារD118/133 កំណត់ហេតុស្តាប់ចម្លើយ សយ សែន អ.៩០ KH 00960638។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន គេង អ.១០ KH 010។ <u>ក្រោះអណ្តែត</u>៖ ឯកសារ D219/568 កំណត់ហេតុស្តាប់ចម្លើយ មុំ ផណ្ណា អ.១១២, ១២២ KH 01165972, 73។ <u>ភូមិភាគពាយ័ព្យ</u>៖ ឯកសារ D118/174 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ពុំ អ.១៨ KH 00973936។ ឯកសារ D118/170 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ ឃាយ រ៉ែម អ.១៦៦ KH 00969601។ ឯកសារ D118/288 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ឫនី អ.១៦, ១៨ KH 01022018-19។ ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ើ អ.៨៨ KH 01186831។ ឯកសារ D219/796 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ អ.១៣៣ KH 01304988។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ចូក អ.៤៦ KH 00973924។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ អ.១៦ KH 01058787។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន អ.៣២ KH 00955697។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត អ.៧៦ KH 00977069-00977070។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង អ.៨៣-៨៤ KH 00955736-37។ ឯកសារ D219/277 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម ឈាន អ.៤៨ KH 01088963។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម អ.១៧២ KH 01047403។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន អ.៤២ KH 00955684។ ឯកសារ D118/246 កំណត់ហេតុស្តាប់ចម្លើយ មាស រ៉ឿន អ.៩០ KH 00990658។ ឯកសារ D219/221 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង អ.២៤ KH 01075676។ ឯកសារ D219/733 កំណត់ហេតុស្តាប់ចម្លើយ គឹម ផែន អ.៧៣ KH 01218104 ។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង អេង អ.៨ KH 00996441។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្រូ អ.១៣ KH 00955708។ D219/309 កំណត់ហេតុស្តាប់ចម្លើយ សយ យ៉ែន អ.៥ KH 01097670-01097671 ។

[2938] ឯកសារ D219/758 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម លន់ អ.១៦, ២១, ២៣ KH 01240851។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម អ.៦៣ KH 01047388។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា អ.៨៩ KH 01032176។

[2939] ឯកសារ D118/269 កំណត់ហេតុស្តាប់ចម្លើយ ថាន់ ធីម អ.៥៥ KH 00998115 ["គេសម្គាល់តាមសំនៀងជាភាសាខ្មែរ និងស្លៀកសម្លៀកបំពាក់ ដូចជា ស្រីស្លៀកខោ និងពាក់អាវដូចស្រីវៀតណាម។ ខ្ញុំក៏ដឹងថា ពួកខ្មែរក្រហមយកជនជាតិយួនទៅប្តូរយកខ្មែរក្រោមដែរ"]។

[2940] ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្រូ អ.៤១, ១៧២ KH 01022425 KH 01022446។

បន្ថែមពីលើនេះ ខ្មែរក្រោមប្រើឈ្មោះខុសពីខ្មែរ[2941]។ បុរសខ្មែរក្រោមដាក់ត្រកូលដូចគ្នា ចំណែកស្ត្រីខ្មែរក្រោមប្រើឈ្មោះឪពុកឬជីតា ជាត្រកូលរបស់ពួកគាត់[2942]។

822. ដោយសារសំនៀង និងវប្បធម៌ដាច់ដោយឡែករបស់ពួកគាត់ ខ្មែរក្រោមអាចត្រូវបានចាត់ទុកជាក្រុមជាតិពន្ធុជាក់លាក់។ ប៉ុន្តែភ័ស្តុតាងបង្ហាញថា ខ្មែរក្រហមបានដាក់ខ្មែរក្រោមជាគោលដៅ ដោយសារដើមកំណើតរបស់ពួកគាត់ក្នុងទឹកដីនេះ ដែលកាលណោះស្ថិតនៅក្នុងព្រំប្រទល់វៀតណាម និងបានចាត់ទុកខ្មែរក្រោមថាជាប់ខ្សែរយៈវៀតណាម។ ហេតុនេះ ខ្មែរក្រហមបានដាក់ខ្មែរក្រោមជាគោលដៅ ដែលជាផ្នែកមួយនៃយុទ្ធនាការរបស់ខ្មែរក្រហម ដើម្បីបំផ្លាញក្រុមជាតិវៀតណាមនៅកម្ពុជា[2943]។ អាស្រ័យហេតុនេះ ស.ព.អ សន្និដ្ឋានថា សម្រាប់គោលបំណងនៃនិយមន័យនៃក្រុមដែលទទួលបានការការពារក្នុងអនុសញ្ញាប្រល័យពូជសាសន៍ និងយុត្តិសាស្ត្រដែលកំណត់និយមន័យនៃពាក្យទាំងនេះ ខ្មែរក្រោមជាផ្នែកមួយនៃក្រុមជាតិវៀតណាមនៅកម្ពុជា។ ការសម្លាប់ខ្មែរក្រោម និងជាតិពន្ធុវៀតណាម ជាផ្នែកនៃផែនការខ្មែរក្រហម ដើម្បីបំផ្លាញក្រុមជាតិវៀតណាម នៅកម្ពុជា។

៣. គោលនយោបាយ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាម

ក. ចេតនារបស់ ប.ក.ក ចំពោះប្រជាជនវៀតណាមនិងខ្មែរក្រោម

823. ការយោសនារបស់ ប.ក.ក ជាញឹកញយបានហៅជនជាតិវៀតណាម ឬប្រជាជនខ្មែរដែលស្ថិតក្នុងជាតិពន្ធុវៀតណាមថាជា "យួន"[2944]។ ឯកសារ *Black Paper* ដែលបានបោះពុម្ពផ្សាយក្នុងឆ្នាំ ១៩៧៨ បានផ្តល់និយមន័យពាក្យ "យួន" ថាមានន័យ "អាក្រក់"[2945]។ អ្នកជំនាញ Alexander Hinton បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ថាពាក្យ "យួន" បង្ហាញ "ការស្អប់ខ្ពើមទៅលើ

[2941] ឯកសារ D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.៣៣ KH 00960561 ["អាចសម្គាល់តាមរយៈសំឡេងនៃ ការនិយាយ នាមត្រកូល របៀបនៃការរស់នៅខុសគ្នា"]។

[2942] ឯកសារ D118/291 កំណត់ហេតុស្តាប់ចម្លើយ ឃិន ស្ងួរ ឆ.១៦៩ KH 01022445។

[2943] *សូមមើលឧទាហរណ៍* ឯកសារ D347/2.1.12 កំណត់ហេតុស្តាប់ចម្លើយ ចាន់ សុគាត EN 00275057-EN 00275058។

[2944] ឯកសារ D219/792.1.7 ប្រតិចារឹក សាក្ស្តាចារ្យ Alexander Hinton ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ម៉ោង 15.54.30-15.55.47។

[2945] ឯកសារ D1.3.17.2 ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ *សៀវភៅខ្មៅ* EN 00082517។

ប្រជាជនវៀតណាម"[2946] និង "ជាពាក្យមួយដែលអាចបង្កការស្អប់ខ្ពើម និងក្នុងបរិបទកម្ពុជា ប្រជាធិបតេយ្យ វាជាការញុះញង់ឲ្យមានអំពើប្រល័យពូជសាសន៍"[2947]។

824. ប.ក.ក បានប្រើពាក្យ "យួន" ដើម្បីសម្គាល់ខ្មែរក្រោម ពីព្រោះពួកគាត់បានចាត់ទុកខ្មែរក្រោមជាវៀតណាម[2948]។ ដូចដែល រ៉ែន ណាត បានពិពណ៌នា "ប្រជាជនខ្មែរក្រោមមិនត្រូវបានចាត់ទុកជា

[2946] ឯកសារ D219/792.1.7 ប្រតិចារឹក សាស្ត្រាចារ្យ Alexander Hinton ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ម៉ោង 09.15.50-09.17.13។ *សូមមើលផងដែរ* ឯកសារ D347/2.1.30 ប្រតិចារឹក មាស រ៉ែន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 16.01.44-16.03.41។

[2947] ឯកសារ D219/792.1.9 ប្រតិចារឹក សាស្ត្រាចារ្យ Alexander Hinton ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ម៉ោង 12.10.24-12.11.14។ *សូមមើលផងដែរ* ឯកសារ D347/2.1.10 សៀវភៅនិពន្ធដោយនរោត្តម សីហនុ មានចំណងជើងថា៖ កាលប្បវត្ត សង្គ្រាម និង សេចក្តីសង្ឃឹម KH 00763547 ["[ខៀវ សំផន] បានសារភាពប្រាប់ខ្ញុំតាមត្រង់ ដោយគ្មានលាក់លៀមថា '[...] គ្មានអ្វីក្រៅតែអំពីជំរុញពួកគេឲ្យស្អប់យួនកាន់តែខ្លាំងឡើងៗនោះទេ"]។

[2948] ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ្ស៊ីន ឆ.ពាព KH 00980102 ["វៀតណាមដែលកើតនៅក្នុងទឹកដីកម្ពុជាទាំងអស់ត្រូវបានគេចោទថា "យួន"]។ ឯកសារ D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.៤០ KH 00960562 ["ហើយពេលខ្លះនិយាយថា អាគិញយួន"]។ ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀល សន ឆ.១៦៤ KH 00975639 ["ជាខ្មែរក្រោមដែលពុំមានកូន ពុំមានចៅ ហើយដែលមានវ័យចំណាស់បន្តិច គឺត្រូវគេចោទថា ជាគិញយួន"]។ ឯកសារ D219/918 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឆ.២៣-២៤ KH 01390474 ["ស៖ តើក្រុមមនុស្សណា ដែលលោកហៅគេថាជាខ្មែរក្រោម? ឆ.២៣៖ កាលហ្នឹង គេមិនហៅខ្មែរក្រោមទេ គេមិនហៅខ្មែរក្រោមទេ គេហៅយួន ជំនាន់ហ្នឹង គេហៅយួន។ [...] ឆ.២៤៖ [...] ចាប់ច្រើនមកពីខាង [គីរីវង់] ហើយមានខ្មែរក្រោមនៅហ្នឹង តែគេហៅយួន។ ឲ្យតែចេះយួន គេហៅយួនហើយ [...] ហ្នឹងយកមកពីហ្នឹង [ខ្មែរក្រោមពីស្រុកគីរីវង់] គេហៅយួន តែពួកហ្នឹងមិនមែនយួនទេ គឺខ្មែរក្រោម"]។ ឯកសារ D219/918 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឆ.២៦, ៣៤ KH 01390475-01390476។ ឯកសារ D118/133 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឆ.៨៤-៨៥ KH 00960638។ ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រ៉ី ពៅ ឆ.៥២ KH 00960588។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រ៉ុធ ឆ.៩០ KH 00985424។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៨៩ KH 01032176។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៧១ KH 01047389។ ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ុច ឆ.៤៥-៤៦, ៤៨ KH 00977096-00977097។ ឯកសារ D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង EN 00387497។ ឯកសារ D219/588 កំណត់ហេតុស្តាប់ចម្លើយ គុយ ឃ្ស៊ីន ឆ.៩៧-៩៨ KH 01167585។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រ៉ុន ឆ.១០៥ KH 01034507។ ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ផ្ទួយ ឆ.១៦ KH 01058787។ ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៉ាន់ ឆ.១៣០, ១៣២ KH 01167530, 01167531។ ឯកសារ D219/311 កំណត់ហេតុស្តាប់ចម្លើយ ពែង សាន្ត ឆ.៧ KH 01097690។ ឯកសារ D118/214 កំណត់ហេតុស្តាប់ចម្លើយ ចឹង ភ៉ី ឆ.១៧, ៣៨ KH 00982148 KH 00982150។ ឯកសារ D219/277 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម ឈាន ឆ.៨១ KH 01088968។ ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.៦៦ KH 01414393។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.៦៣ KH 01198092។ ឯកសារ

ប្រជាជនខ្មែរ។ ពួកគាត់ត្រូវបានចាត់ទុកជាប្រជាជនវៀតណាម”[2949]។ ខ្មែរក្រោមត្រូវបានចោទថា ជា “ភ្នាក់ងារ យួន”[2950] “ខ្មែរយៈ យួន”[2951] “ខ្មែរប្រែដើម្បីយួន”[2952] “អាយ៉ងយួន”[2953] និងមាន “ទំនាក់ទំនងជាមួយ យួន”[2954]។ វិធីសាមញ្ញបំផុតដែល ប.ក.ក បានហៅខ្មែរក្រោម គឺ “ក្បាលយួនខ្ជនខ្មែរ”[2955]។

D219/758 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម លន់ ឆ.២៧ KH 01240852។ ឯកសារ D219/921 កំណត់ហេតុស្តាប់ចម្លើយ ចាប ពុធ ឆ.១០២ KH 01391801។ ឯកសារ D219/758 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម លន់ ឆ.២៧ KH 01240852។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៤៣-៤៤ KH 00996457។ ឯកសារ D219/276 កំណត់ហេតុស្តាប់ចម្លើយ ញ៊ីម ង៉ុយ ឆ.៦៣ KH 01088946។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៥ KH 01097670។ ឯកសារ D347/2.1.11 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ សារិន EN 00197567 EN 00197579។

[2949] ឯកសារ D219/248 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៧៨ KH 01083710។

[2950] ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.១០១ KH 00977073។

[2951] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១៣៣ KH 01068146។

[2952] ឯកសារ D219/98 កំណត់ហេតុស្តាប់ចម្លើយម៉ម ស្ង ឆ.៥១ KH 01043262។

[2953] ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ឆ.៤៦, ៥៤ KH 00960588, 00960589 [“ឆ.៤៦៖ ខ្ញុំគិតថា ជាខ្មែរក្រោម ព្រោះអ្នកដែលមកពីកម្ពុជាក្រោមត្រូវបានគេហៅថា “អាយ៉ងយួន” [...] ស៖ ពាក្យថា “ក្បាលយួនខ្ជនខ្មែរ” តើត្រូវបានគេប្រើប្រាស់ដែរ ឬទេនៅទីនោះ? ឆ.៥៤៖ បាទ គេប្រើ ជាពាក្យរើសអើងខ្មែរក្រោម”]។

[2954] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួរ ឆ.២៧ KH 00955710។ ឯកសារ D219/737 កំណត់ហេតុស្តាប់ចម្លើយ ឌឹម គឹមហ៊ាត ឆ.៩១ KH 01221313។

[2955] ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន រ៉ន ឆ.៣៦ KH 00977083 [“ស៖ តើខ្មែរក្រហមធ្លាប់ចោទប្រកាន់លោកថា “មនុស្សក្បាលយួនខ្ជនខ្មែរ” ដែរឬទេ? ឆ.៣៦៖ បាទ មាន”]។ ឯកសារ D219/729 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន សាមុត ឆ.១៣៧ KH 01214612 [“ស៖ តើលោកដឹងតើហេតុអ្វីដែលធ្វើឲ្យគេមានបំណងបោសសម្អាតខ្មែរកម្ពុជាក្រោម? ឆ.១៣៧៖ មកពីខ្មែរកម្ពុជាក្រោម មកពីតំបន់ដែលយួនកាន់កាប់ ដែលគេថា ក្បាលយួន ខ្ជនខ្មែរហ្នឹង”]។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៤៥ KH 00955684 [“គេបាននិយាយថា “ពួកហ្នឹងគឺជាពួកក្បាលយួន ខ្ជនខ្មែរទេ នៅពេលដែលយួនចូលមកដល់ ពួកហ្នឹងនឹងចូលជាមួយយួនដើម្បីវ៉ៃយើងវិញ”]។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន ឆ.១២ KH 00955694។ ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីន្ធន ឆ.៨២ KH 01067999។ ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយរ៉ីម ឆ.៣១-៣៣, ៤០ KH 01348861-01348862, 01348863។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ើន ដារ៉ា ឆ.១០០-១០១ KH 00973957។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ហៅ ខៀវ សារ៉ឿន ឆ.៦៣ KH 01198092។ ឯកសារ D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ប៊ីងង ឆ.២៨ KH 00968134។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឆ.៨៦-៨៧ KH 01024604។ ឯកសារ D118/132 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន សុវណ្ណារី ឆ.៨១ KH 00960622។ ឯកសារ D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ប៊ីងង ឆ.២៨ KH 00968134។ ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៨៤ KH 00993603។ ឯកសារ

825. ឯកសារ ប.ក.ក នានាបានចាត់ទុកវៀតណាមជា "ខ្មាំង"[2956]។ មាស រឿន ដែលជាមេបញ្ជាការរង នៃកងពលធំលេខ ១ នៃកងទ័ពបដិវត្តន៍កម្ពុជា[2957] បានគូសបញ្ជាក់ថា ប្រជាជនបានចាត់ទុកវៀតណាមជាសត្រូវលេខ ១ របស់កម្ពុជាប្រជាធិបតេយ្យ[2958] ដោយបានផ្តល់សក្តីកម្មថា "គ្រប់គ្នាបានឮអំពីវា ថាពួកវាជាសត្រូវសួរពូជ"[2959]។ **យ៉ីម ទិព្ធ** "បានជជែកអំពីខ្មាំងវៀតណាម" និង "ខ្មាំងយួន" ក្នុងអំឡុងពេលប្រជុំនានា ដោយព្រមានឲ្យមានការប្រុងប្រយ័ត្ន និងដោយបានចោទប្រកាន់ថា "វៀតណាមចង់លេបប្រទេសយើង"[2960]។

D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.៤០ KH 00960562។ D118/130 កំណត់ហេតុស្តាប់ចម្លើយ រ៉ ពៅ ឆ.៥៤ KH 00960589។ *សូមមើល* ឯកសារ D219/692 កំណត់ហេតុស្តាប់ចម្លើយ ឈួន ហ៊ ឆ.៤៧ KH 01205255។ ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា៖ *របប ប៉ុល ពត ពួជសាសន៍ អំណាច និងអំពើប្រល័យពួជសាសន៍ នៅកម្ពុជាក្រោមដៃពួកខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩*EN 00678714។

[2956] ឯកសារ D6.1.1161 កំណត់ហេតុប្រជុំកងពល៩២០នៃកម្ពុជាប្រជាធិបតេយ្យ *កំណត់ហេតុនៃការប្រជុំសមមិត្ត* ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៧៦ EN 00923160-00923161។ ឯកសារ D6.1.743 ទស្សនាវដ្តី *ទង់បដិវត្តន៍* ចុះខែកក្កដា ឆ្នាំ១៩៧៨ EN 00428289, 303-04។ ឯកសារ D347/2.1.6 របាយការណ៍នៃសន្និបាតភូមិភាគបូព៌ា នៅពាក់កណ្តាលឆ្នាំ១៩៧៧ EN 01313124-01313125។

[2957] ឯកសារ D347/2.1.30 ប្រតិចារឹក មាស រឿន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 13.54.29-13.57.50។

[2958] ឯកសារ D347/2.1.31 ប្រតិចារឹក មាស រឿន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 09.54.58-09.56.22។

[2959] ឯកសារ D347/2.1.31 ប្រតិចារឹក មាស រឿន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 09.54.58-09.56.22។ *សូមមើលផងដែរ* ឯកសារ D322/8.1.37 សេចក្តីថ្លែងការណ៍នៃរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០២ ខែមករា ឆ្នាំ១៩៧៩ EN 00419728។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.១៥ KH 01097673។

[2960] ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៩ KH 01080844។ ឯកសារ D219/943 កំណត់ហេតុស្តាប់ចម្លើយ ឡម លិន ឆ.៣៧ KH 01415377។ *សូមមើលផងដែរ* ឯកសារ D219/406 កំណត់ហេតុស្តាប់ចម្លើយ ឃ្ង ភ្ញ ឆ.១៧៥-១៧៧, ១៨៤ KH 01117238-01117239។ ឯកសារ D219/763 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៣៤-១៣៥ KH 01244135។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.១៣-១៤ KH 00960664-00960665។ ឯកសារ D118/77 កំណត់ហេតុស្តាប់ចម្លើយ ណង នី ឆ.៣០ KH 00934389។ ឯកសារ D219/515 កំណត់ហេតុស្តាប់ចម្លើយ ធ្ន ឈ្ម ឆ.៣០-៣១, ៣៣-៣៤, ៤៤, ៥៥ KH 01149403, 01149404, 01149406, 01149407។ ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ រ៉ ផាន់ ឆ.៤-៥ KH 01040094។

826. ដូចគ្នានេះ ការឃោសនារបស់ខ្មែរក្រហមបានណាបពណ៌ខ្មែរក្រោមថាជា "ខ្មាំង"[2961] "ខ្មាំងយួន"[2962] ឬបានចាត់ទុកពួកគាត់ថា "ក្បត់បក្ស"[2963]។ ង៉ែត ឡួយ ដែលប្តីខ្មែរក្រោមរបស់គាត់ត្រូវបានគេនាំយកចេញទៅ និងបានបាត់ខ្លួន ត្រូវបានហៅទៅប្រជុំនៅខ្នារទទឹង ស្រុកបាកាន ព្រមជាមួយបុរសស្ត្រីដទៃទៀត ដែលបានរៀបការជាមួយខ្មែរក្រោម ដែលត្រូវបានគេនាំយកចេញទៅ[2964]។ ក្នុងការប្រជុំនោះ កម្មាភិបាលទាំងនោះបានប្រកាសថា "ខ្មាំងវៀតណាមចំនួន៣ពាន់នាក់" ត្រូវបានសម្លាប់-ដោយសំដៅទៅលើខ្មែរក្រហម ដោយរួមបញ្ចូលប្តីរបស់ ង៉ែត ឡួយ ដែលបានបាត់ខ្លួន[2965]។ ស្រដៀងនេះ ឌុច បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០១ ថា ប.ក.ក ក៏ "បានចាត់ទុក [ខ្មែរក្រោម] ជាគិញ"[2966] ដោយបានប្រកាសថា "ប្រជាជនវៀតណាមដែលបានចូលមកកម្ពុជាក្រោយថ្ងៃទី១៧ មេសា ត្រូវបានចាត់ទុកជាគិញ ទោះបីវាជាការចោទប្រកាន់ដ៏ខុសឆ្គង ឬជាបញ្ហាមួយទៀតក៏ដោយ"[2967]។

[2961] ឯកសារ D219/7 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ឃ្យៀ ឆ.១០៣ KH 01025525 ["ខ្ញុំឮថា "ខ្មែរក្រោមជាខ្មាំង" តែខ្ញុំមិនដឹងថា គេយកខ្មែរក្រោមទាំងអស់នោះទៅណាទេ"]។ ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហើយ សាន្ត ឆ.៩១ KH 00988054 ["គេចោទខ្មែរក្រោមថា ជាខ្មាំង"]។ ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៤៤ KH 00996457។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ ទឹម លន ឆ.៨៧-៨៨ KH 01102925។ *សូមមើលផងដែរ* ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួរ ឆ.២០-២១ KH 00955709។ ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ហៅ ខៀវ សារ៉ៃន ឆ.១៩, ២៩, ៦៣ KH 01198088 KH 01198089 KH 01198092។

[2962] ឯកសារ D118/199 កំណត់ហេតុស្តាប់ចម្លើយ អ្លង សារ ឆ.៣០ KH 00978995។

[2963] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ុន ដារ៉ា ឆ.៩៩ KH 00973956។ *សូមមើលផងដែរ* ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀល សន ឆ.៩៧ KH 00975632 ["ព្រោះខ្មែរក្រោមត្រូវបានគេចោទថាជាក្រុម ក.ហ្ស.ប"]។

[2964] ឯកសារ D118/254 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ឡួយ ឆ.៣៤ KH 00996425។

[2965] ឯកសារ D118/254 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ឡួយ ឆ.៣១, ៣៥ KH 00996425-00996426។

[2966] ឯកសារ D219/702.1.117 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ហៅ ឌុច ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 10.13.30-10.18.58 ។

[2967] ឯកសារ D219/702.1.117 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ម៉ោង 13.52.28-13.56.03 ។

827. ឯកសារ ប.ក.ក ជាញឹកញាប់បានណែនាំឲ្យកម្ទាភិបាល "កម្ទាត់"[2968] "កម្ទេច"[2969] "ប្រោសសម្អាត"[2970] "ដកចេញ"[2971] "សម្លាប់"[2972] "ជម្រះបំណុល"[2973] "កាប់បំបែក"[2974] និង "បំផ្លាញ"[2975] ប្រជាជនវៀតណាម។ ឯកសារ ប.ក.ក បានប្រើប្រាស់ពាក្យប្រមាថមាក់ងាយ និងបន្ទោកទៅលើប្រជាជនវៀតណាម ដូចជា "យួនស្អុយច្រាសខ្យល់ និងថោកទាបគួរឲ្យស្អប់

[2968] ឯកសារ D322/8.1.23 ទស្សនាវដ្ដី *ទង់បដិវត្ដន៍* ចុះខែមេសា ឆ្នាំ១៩៧៧ EN 00478500។ ឯកសារ D6.1.741 ទស្សនាវដ្ដី *ទង់បដិវត្ដន៍* ចុះ*ខែកុម្ភៈ ឆ្នាំ១៩៧៨* EN 00464065។ ឯកសារ D347/2.1.32 ប្រតិចារឹក អ៊ុច ស៊ីនឡាយ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៦ ម៉ោង 09.14.44-09.18.00។

[2969] ឯកសារ D322/8.1.23 ទស្សនាវដ្ដី *ទង់បដិវត្ដន៍* ចុះខែមេសា ឆ្នាំ១៩៧៧ EN 00478502។ ឯកសារ D347/2.1.30 ប្រតិចារឹក មាស រ៉ៀន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 15.54.15- 15.58.47។

[2970] ឯកសារ D6.1.50 ទូរលេខពីសារុនផ្ញើជូនបង មផ៧០ ចុះថ្ងៃទី០១ ខែមករា ឆ្នាំ១៩៧៨ EN 00975143។ ឯកសារ D219/370.1.13 របាយការណ៍ពីមន្ទីរ៤០១ផ្ញើជូនអង្គការ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ EN 00143623។

[2971] ឯកសារ D132.1.97 បណ្ដាញផ្សព្វផ្សាយ FBIS កងទ័ពកម្ពុជាអនុម័តសេចក្ដីសម្រេចស្ដីពីជម្លោះជាមួយសាធារណរដ្ឋសង្គមនិយម វៀតណាម ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៧៨ KH 00244271-00244273។

[2972] ឯកសារ D132.1.97 បណ្ដាញផ្សព្វផ្សាយ FBIS កងទ័ពកម្ពុជាអនុម័តសេចក្ដីសម្រេចស្ដីពីជម្លោះជាមួយសាធារណរដ្ឋសង្គមនិយម វៀតណាម ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ១៩៧៨ KH 00244271-00244273។

[2973] ឯកសារ D219/370.1.15 ទស្សនាវដ្ដី *យុវជន និងយុវនារីបដិវត្ដ* ចុះខែតុលា ឆ្នាំ១៩៧៨ EN 00539998។

[2974] ឯកសារ D1.3.21.1 ស្នាដៃនិពន្ធព្រះបីតា សីហនុ ក្រោមចំណងជើងថា *ថ្ងៃអវសានៃនៃរបប ប៉ុល ពត និងខ្ញុំ* EN 00224394 ។

[2975] ឯកសារ D322/8.1.37 *សេចក្ដីផ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ* ចុះថ្ងៃទី០២ ខែមករា ឆ្នាំ១៩៧៩ EN 00419729។

ខ្ញើម"[2976] ពួកវាជា "បិសាច"[2977] "ឧក្រិដ្ឋជន"[2978] "ពិសពុល"[2979] "សាហាវ"[2980] "ពួកឈ្លានពាន"[2981] "សត្វកណ្តុរ"[2982] "ឆ្កែបម្រើ"[2983] "មេរោគ"[2984] ឬ "បញ្ជើក្អែក"[2985]។

ខ. ផែនការរបស់ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាម និងខ្មែរក្រោម

828. ប.ក.ក បានរៀបចំផែនការកម្ចាត់ប្រជាជនវៀតណាម ពីកម្ពុជាពីដើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាគោលនយោបាយទាក់ទងវិធីកម្ចាត់ប្រជាជនវៀតណាមពីទឹកដីនេះ បានប្រែប្រួលទៅតាមពេលវេលា ដោយយុទ្ធសាស្ត្រដើមដំបូងគឺនិរទេសប្រជាជនវៀតណាមទៅវៀតណាម ឬប្តូរប្រជាជនវៀតណាមយកខ្មែរក្រោម ដែលកំពុងរស់នៅក្នុងប្រទេសវៀតណាម[2986]។ ការសម្រេចបណ្តេញប្រជាជនវៀតណាមទាំងអស់ ពីកម្ពុជាត្រូវបានប្រកាសប្រាប់មេដឹកនាំខ្មែរក្រហម

[2976] ឯកសារ D6.1.743 ទស្សនាវដ្ដី *ទង់បដិវត្ដន៍* ចុះខែកក្កដា ឆ្នាំ១៩៧៨ EN 00428289។

[2977] ឯកសារ D1.3.21.1 ស្នាដៃនិពន្ធព្រះបិតា សីហនុ ក្រោមចំណងជើងថា *ថ្ងៃអវសានៃរបប ប៉ុល ពត និងខ្ញុំ* EN 00224394 ។ *សូមមើលផងដែរ* ឯកសារ D347/2.1.8 មិន្ទិញនៅក្រុងភ្នំពេញរំលឹកខួបទិវាជ័យជំនះ ១៧ មេសា ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ EN 00010412។

[2978] ឯកសារ D132.1.82 សន្ទរកថារបស់ ខៀវ សំផន ក្នុងឱកាសពិធីបុណ្យខួបលើកទី៣ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៨ EN 00280397។

[2979] ឯកសារ D1.3.22.6 ទស្សនាវដ្ដី *ទង់បដិវត្ដន៍* ចុះខែឧសភា-មិថុនា ឆ្នាំ១៩៧៨ EN 00185333។

[2980] ឯកសារ D1.3.17.2 ក្រសួងការបរទេសនៃកម្ពុជាប្រជាធិបតេយ្យ *សៀវភៅខ្មៅ* EN 00082517។ *សូមមើលផងដែរ* ឯកសារ D1.3.17.1 សៀវភៅនិពន្ធដោយ Elizabeth Becker ក្រោមចំណងជើងថា *ពេលដែលសង្គ្រាមរលត់ទៅ* EN 00237827។

[2981] ឯកសារ D132.1.16 សេចក្ដីថ្លែងការណ៍ជាសាធារណៈរបស់ ប៉ុល ពត ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៩ EN 00017564-00017565។

[2982] ឯកសារ D322/8.1.23 ទស្សនាវដ្ដី *ទង់បដិវត្ដន៍* ចុះខែមេសា ឆ្នាំ១៩៧៧ EN 00478496។

[2983] ឯកសារ D6.1.743 ទស្សនាវដ្ដី *ទង់បដិវត្ដន៍* ចុះខែកក្កដា ឆ្នាំ១៩៧៨ EN 00428291, 00428295, 00428303-00428304។

[2984] ឯកសារ D6.1.742 ទស្សនាវដ្ដី *ទង់បដិវត្ដន៍* ចុះខែមេសា ឆ្នាំ១៩៧៨ EN 00519842។

[2985] ឯកសារ D118/130 កំណត់ហេតុស្ដាប់ចម្លើយ រី ពៅ ឆ.៦០ KH 00960590 ["ស៖ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់លោក លោកនិយាយថា "លោកបានឃើញខ្មែរ៣០នាក់ត្រូវបានចាប់ខ្លួន ដោយសារគេចោទថា បញ្ជើក្អែក"។ តើត្រឹមត្រូវ? លោកបានឃើញរឿងនេះដែរឬទេ? ឆ.៦០៖ បាទ ត្រឹមត្រូវ"]។

[2986] *សូមមើលឧទាហរណ៍* ឯកសារ D347/2.1.4 សេចក្ដីរាយការណ៍ពីឈ្លោះផន ទៅស្រុកត្រាំកក់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ EN 00742890 ["ប្រជាជនកម្ពុជាក្រោម និងប្រជាជន ដែលយួនដូរមក មាន៦៤គ្រួសារ ចំនួនមនុស្សមានចំនួន២២៨នាក់"]។ ឯកសារ D347/2.1.30 ប្រតិចារឹក មាស រឿន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 13.54.29-13.57.50, 15.54.15-16.00.12។ ឯកសារ D347/2.1.31 ប្រតិចារឹក មាស រឿន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 09.24.04-09.31.35។

នៅក្នុងពេលប្រជុំមហាជននៅភ្នំពេញនាថ្ងៃទី២០ ដល់ថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៧៥[2987]។ ខ្មែរក្រហមបានបណ្តេញប្រជាជនស៊ីវិលវៀតណាមចំនួន ១៥០.០០០ នាក់នៅឆ្នាំដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ[2988] ដែលខ្លះត្រូវបានសម្លាប់ *នៅតាមផ្លូវ* ទៅវៀតណាម[2989]។ អ្នកនិពន្ធ Ben Kiernan បានកត់សម្គាល់ឃើញថា នៅចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ "អ្នកទទួលខុសត្រូវការសម្លាប់រង្គាលខ្មែរក្រោម ហាក់ដូចជាត្រូវបានកំហិតត្រឹមកម្លាំងភូមិភាគនិរតី"[2990]។ **យ៉ាម ទិត្យ** ជាឥស្សរជនជាន់ខ្ពស់មួយរូបក្នុងតំបន់ ១៣ នៃភូមិភាគនិរតី ដែលការនិរទេសភាគច្រើនបានកើតមានពីទីនោះ។

829. នៅក្នុងឆ្នាំ១៩៧៧ ដែលទំនាក់ទំនង និងជម្លោះជាមួយវៀតណាមកាន់តែអាក្រក់ឡើង គោលនយោបាយ ប.ក.ក បានប្រែប្រួល។ មេដឹកនាំបានតឿនកម្មាភិបាលឲ្យសម្លាប់មនុស្សទាំងឡាយដែលត្រូវបានចាត់ទុកជាជនជាតិវៀតណាម ដែលនៅបន្តស្ថិតនៅកម្ពុជា[2991]។ ប៉ាក សុខ សមាជិក

[2987] ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា *របប ប៉ុល ពត៖ ពួជសាសន៍ អំណាច ណិង អំពើប្រល័យពួជសាសន៍នៅកម្ពុជា ក្រោមពួកខ្មែរក្រោម ឆ្នាំ១៩៧៥-៧៩* EN 00678522 EN 00678524។ *សូមមើលផងដែរ* ឯកសារ D179/1.2.9 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ម៉ោង 11.23.28-11.25.02។ ឯកសារ D6.1.755 ទស្សនាវដ្ដី *ទង់បដិវត្តន៍* ចុះខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧ EN 00491422។ ឯកសារ D6.1.750 ទស្សនាវដ្ដី *ទង់បដិវត្តន៍* ចុះខែមេសា ឆ្នាំ១៩៧៦ EN 00517853។

[2988] ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា *របប ប៉ុល ពត៖ ពួជសាសន៍ អំណាច ណិង អំពើប្រល័យពួជសាសន៍នៅកម្ពុជា ក្រោមពួកខ្មែរក្រោម ឆ្នាំ១៩៧៥-៧៩* EN 00678650។ ឯកសារ D219/792.1.7 ប្រតិចារឹកសាស្ត្រាចារ្យ Alexander Hinton ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ម៉ោង 09.21.48-09.22.42។

[2989] ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា *របប ប៉ុល ពត៖ ពួជសាសន៍ អំណាច ណិង អំពើប្រល័យពួជសាសន៍នៅកម្ពុជា ក្រោមពួកខ្មែរក្រោម ឆ្នាំ១៩៧៥-៧៩* EN 00678650។ ឯកសារ D219/792.1.7 ប្រតិចារឹកសាស្ត្រាចារ្យ Alexander Hinton ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ម៉ោង 09.21.48-09.22.42។

[2990] ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា *របប ប៉ុល ពត៖ ពួជសាសន៍ អំណាច ណិង អំពើប្រល័យពួជសាសន៍នៅកម្ពុជា ក្រោមពួកខ្មែរក្រោម ឆ្នាំ១៩៧៥-៧៩* EN 00678652។

[2991] ឯកសារ D347/2.1.39 ប្រតិចារឹក ហេង ឡៃប៊ីង ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 14.38.59-14.41.45 ["តាមស្តាប់មើលហ៍ គោលការណ៍ទី១ គឺបញ្ជូនទៅស្រុកវិញ។ ចាស ជាលើកដំបូង គឺបញ្ជូនទោស្រុកទាំងឡានៗវិញ។ ឃើញបញ្ជូនទៅស្រុក។ តែដល់គោលការណ៍ក្រោយ ដែលវៀតណាមវ៉ៃចូលខ្លាំង អាហ្ម៉ីងបានគេមានវិធានការកម្ទេចអ្នក ដែលនៅសេសសល់"]។ ឯកសារ D347/2.1.30 ប្រតិចារឹក មាស រឿន ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 14.31.25-14.35.36, 15.58.47-16.00.12, 16.03.41-16.02.12 ["ខ្ញុំយល់ថា គេមិនឲ្យនៅទេ"]។ ឯកសារ D347/2.1.31 ប្រតិចារឹក មាស រឿន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៦ ម៉ោង 09.24.04- 09.25.26 ["ខ្ញុំដឹងថា ជាសំខាន់ គឺយួនដែលមិនឲ្យនៅទឹកដីខ្មែរនុង [...]។ ឲ្យប្រមូលយកមក ដើម្បីឲ្យបញ្ជូនមកខាងថ្នាក់លើ"]។ ឯកសារ D347/2.1.20 ប្រតិចារឹក Elizabeth Becker ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង

នៃកងទ័ពជើងទឹកកម្ពុជាប្រជាធិបតេយ្យ[2992] បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ថាមានការបណ្តុះបណ្តាលជាចាំបាច់នៅដើមឆ្នាំ ១៩៧៧[2993] ដែលនៅទីនោះ "យើងត្រូវបានណែនាំឲ្យសម្លាប់ [ប្រជាជនវៀតណាម] សូម្បីតែកូនង៉ែត ពីព្រោះពួកគាត់ជាសត្រូវសួរពូជរបស់យើង ដូច្នេះយើងត្រូវតែសម្លាប់ពួកគាត់"[2994]។

10.06.19 ["គឺវាមានការណែនាំថ្មីមួយនៅពាក់កណ្តាលឆ្នាំ១៩៧៧ គឺសម្លាប់ប្រភេទសម្រេវថ្មីមួយទៀត គឺអ្នក ដែលមានញាតិសន្តានជាវៀតណាម។ [...] ពួកគចាប់ផ្តើមសម្លាប់អ្នកណាដែលមានឈាមជ័រជាវៀតណាម និងពួកកម្ពុជាក្រោម"]។ ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា *របប ប៉ុល ពត៖ ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍នៅកម្ពុជា ក្រោមពួកខ្មែរក្រោម ឆ្នាំ១៩៧៥-៧៩*EN 00678650 ["បន្ទាប់មក នៅថ្ងៃទី១ ខែមេសា ឆ្នាំ១៩៧៧ មជ្ឈិមពិតជាបានបញ្ជូនបទបញ្ជាមួយ។ ខណៈគេទុកឲ្យគាត់នៅតែម្នាក់ឯង ពេលរង់ចាំក្នុងមន្ទីរគណៈស្រុកឧដុង (តំបន់១៥ក្នុងភូមិភាគបស្ចិម) ជាងឡានម្នាក់ឈ្មោះ រស់ សារឿន បានលួចអានបទបញ្ជានេះ។ "បទបញ្ជាពី៨៧០" នេះ (គណៈមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា) ណែនាំមន្ត្រីមូលដ្ឋានឲ្យចាប់ខ្លួនជនជាតិវៀតណាមទាំងអស់ និងខ្មែរទាំងអស់ ដែលចេះនិយាយភាសាវៀតណាម ឬមានមិត្តភក្តិជាជនជាតិវៀតណាម ហើយត្រូវប្រគល់ពួកគេឲ្យមកកម្លាំងសន្តិសុខរដ្ឋ។ ប្រពន្ធសារឿន គឺជាជនជាតិវៀតណាម ហើយគាត់ក៏បានប្រញ៉ាប់ត្រឡប់មកផ្ទះវិញ និងប្រាប់ប្រពន្ធគាត់។ ប៉ុន្តែ ដូច លោក Nayan Chandra រៀបរាប់ដែរ គឺប្រពន្ធគាត់បានដឹងរួចហើយ។ 'ស្ត្រីវៀតណាមក្នុងភូមិម្នាក់ត្រូវបានវាយនិងដំបងរហូតដល់ស្លាប់ដោយពួកខ្មែរក្រហម ហើយកប់នៅក្រៅភូមិ បន្ទាប់ពីគេបានបញ្ជូនប្តីនាងទៅកាប់ឈើក្នុងព្រៃ។ ក្រោយមក ប្តីរបស់នាងក៏បានរកឃើញសាកសពរបស់ប្រពន្ធ។ សារឿន និងប្រពន្ធបានព្យាយាមលាក់អត្តសញ្ញាណរបស់នាងដោយជោគជ័យ"]។ *សូមមើលផងដែរ* ឯកសារ D6.1.447 កំណត់ហេតុស្តាប់ចម្លើយ ថេង ហ៊ីយ EN 00233300។ ឯកសារ D347/2.1.8 មិន្ទិញនៅក្រុងភ្នំពេញរំលឹកខួបទិវាជ័យជំនះ ១៧ មេសា ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ KH S00679973។ ឯកសារ D347/2.1.29 ប្រតិចារឹក ដូង អ៊ីន ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.30.16, 09.32.18-09.35.57, 13.51.40-13.54.30។ ឯកសារ D347/2.1.22 ប្រតិចារឹក ស៊ាន ស៊ង់ [មុន មុត] ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៥ ម៉ោង 15.07.52, 15.12.10-15.16.42, 15.20.21-15.24.55, 15.33.22-15.38.41។ ឯកសារ D347/2.1.23 ប្រតិចារឹក ស៊ាន ស៊ង់ ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥ ម៉ោង 09.10.18-09.23.31, 09.25.35-09.28.35, 09.33.45-09.36.26។

[2992] ឯកសារ D366/4.1.2 ប្រតិចារឹក ប ុ៉ាក សុក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 09.50.18-09.58.05។

[2993] ឯកសារ D366/4.1.2 ប្រតិចារឹក ប ុ៉ាក សុក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 13.31.00-13.35.23។ *សូមមើលផងដែរ* ឯកសារ D366/4.1.3 ប្រតិចារឹក ប ុ៉ាក សុក ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៦ ម៉ោង 14.16.24-14.19.00។

[2994] ឯកសារ D366/4.1.2 ប្រតិចារឹក ប ុ៉ាក សុក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 13.36.35-13.38.32។ *សូមមើលផងដែរ* ឯកសារ D347/2.1.41 ប្រតិចារឹក ហ្ជួន ជ្ជឿន ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៦ ម៉ោង 10.45.48-10.48.54 ["គេថា អ្ហ្ហ!អត់បាន! ទេ! ឲ្យតែជាប់សាច់ឃ្លួន គឺអត់បាន។ គេហៅឡើងកាណូតទៅ ចងដាក់កាណូត បើកមកតាមស្ទឹងបាត់ដំបង មកទន្លេសាបនេះ យកមកបាញ់ចោលក្នុងទឹក ក្នុងព្រៃទាំងអស់។ ហើយផុតពីហ្នឹងមក ខ្ជះនៅតាមទូក តាមអ៊ីក្រោម១ហ្នឹង គេដើរប្រមូល គេចាប់អត់ឲ្យសល់ទេ។ គេចាប់យកទៅសម្លាប់ទាំងអស់នៅឆ្នាំ១៩៧៨ហ្នឹង"]។ ឯកសារ D219/370.1.13 របាយការណ៍ពីម៤០១. គោរពជូនអង្គការចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ១៩៧៨ KH 00143604-00143612។

830. បម្រែបម្រួលនៃគោលនយោបាយនេះស្របពេលជាមួយព្រឹត្តិការណ៍ចំនួន ២។ ទីមួយ ប.ក.ក បានបើកការលុកលុយផ្នែកយោធាមួយចំនួន និងបានបាញ់កាំភ្លើងធំចូលទឹកដីវៀតណាមក្នុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨[2995]។ អំឡុងការវាយប្រហារទាំងនោះ ប.ក.ក បានជម្លៀសខ្មែរក្រហមដោយបង្ខំពីកម្ពុជាក្រោមកាត់ព្រំដែន ចូលមកកម្ពុជា ពិសេសចូលក្នុងស្រុកគិរីវង្ស[2996] ដែលនៅទីនោះ **យ៉ីម ទិត្យ** ស្ថិតក្នុងជួរគណៈស្រុក។ ខ្មែរក្រោមជាច្រើនត្រូវបានសម្លាប់ដោយ ប.ក.ក នៅកម្ពុជាក្រោម ឬនៅតាមផ្លូវដំណើរទៅគិរីវង្ស[2997]។

831. ទីពីរ **យ៉ីម ទិត្យ** តា ម៉ុក និងកម្មាភិបាលភូមិភាគនិរតីដទៃទៀត បានចូលត្រួតត្រាភូមិភាគនិរតី[2998]។ ណាម អ៊ីម ប្រធានក្រុមមួយនៅស្រុកបាកាន បាននិយាយថា កម្មាភិបាលភូមិភាគនិរតីបានរៀបចំផែនការប្រមូលខ្មែរក្រោមយកទៅសម្លាប់[2999]។ នៅឆ្នាំ១៩៧៨ **យ៉ីម ទិត្យ** បាននិយាយថា មេដឹកនាំ ប.ក.ក "ចង់បោសសម្អាតខ្មាំងយួន" នៅពេលប្រជុំមួយនៅទំនប់កងហាត់ ដោយត្រូវបានរៀបចំជាពិសេសដើម្បីពិភាក្សាអំពីបញ្ហានេះ[3000]។ អ្នកចូលប្រជុំម្នាក់បាននិយាយទាក់ទងនឹងការប្រជុំនោះថា

[2995] ឯកសារ D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ហ៊ីង ឆ.៧-៨, ១០ KH 00968131។

[2996] ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ ឥប ផាន ឆ.៩១ KH 01024605 ["ស៖ តាមលោកដ៏ង តើខ្មែរក្រោមទាំងអស់នោះចូលមកកម្ពុជាដោយស្ម័គ្រចិត្ត ឬក៏ត្រូវខ្មែរក្រហមបង្ខំ? ឆ.៩១៖ ពួកគេរត់ដោយខ្លាចខ្មែរក្រហមបាញ់ ពីព្រោះខ្មែរក្រហមបានវៃចូលទៅដល់ទឹកដីកម្ពុជាក្រោម។"]។ *សូមមើលផងដែរ* ឯកសារ D118/304 កំណត់ហេតុស្តាប់ចម្លើយ ផុស ឈាន ឆ.១៨ KH 01024589 ["ស៖ តើខ្មែរក្រោមទាំងអស់នោះត្រូវគេបញ្ជូនទៅទិសដៅណា តើគេបញ្ជូនទៅវៀតណាម ?ឬក៏បញ្ជូនពីវៀតណាមចូលមកកម្ពុជា? ឆ.១៨៖ គេបញ្ជូនពីវៀតណាមចូលមកកម្ពុជា"]។

[2997] ឯកសារ D118/129 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សុខាន់ ឆ.២៩-៣៣ KH 00960572-00960573។

[2998] សូមមើលឧទាហរណ៍ ឯកសារ D219/956 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.៣៥ KH 01425222។ ឯកសារ D219/981 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១៤-១៥, ២២ KH 01425219, 20។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៩៦ KH 00985425។ ឯកសារ D219/276 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ង៉ុយ ឆ.២៤ KH 01088940។

[2999] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១២៨ KH 01000270។ *សូមមើលផងដែរ* ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.៣៨ KH 00955768។

[3000] ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈ៉ង ឈ្យ៉ាត ឆ.១៦, ៦២, ៦៤, ៧០KH 01425164-01425165, 01425174, 01425175-01425176 ["[យ៉ីម ទិត្យ] ថា បោសសម្អាតខ្មាំងយួនតែប៉ុណ្ណឹងឯង"] ឆ.៧១-៧៥ KH 01425176។ *សូមមើលផងដែរ* ឯកសារ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.៥ KH 01040094 ["គាត់មាននិយាយអំពីរឿងខ្មាំងផ្ទៃក្នុង ដែលលាក់ខ្លួនស៊ីរ្វរងផ្ទៃក្នុងរបស់ចលនាយើង ហើយក៏មានពួកសេ.អ៊ី.អា កា.ហ្ស.បេ យួន លាក់ខ្លួនជាមួយយើងផងដែរ។ តា ទិត្យបាននិយាយប្រាប់ពួកយើងថា យើងត្រូវតែឃ្លាំមើលពួកទាំងនេះ ហើយបើយើងបានព័ត៌មានទាក់ទងនឹងសកម្មភាពទាំងនេះ គឺយើងត្រូវរាយការណ៍ទៅអង្គការលើ ដើម្បីអង្គការកម្ទេចពួកនេះ មុននឹងពួកនេះកម្ទេចពួកយើង"]។

"អ្នកណាចេះភាសាវៀតណាម និងជាប់ឈាមជ័រវៀតណាម ត្រូវសម្លាប់ចោល"[3001]។ មិនយូរប៉ុន្មានមុនពេលប្រជាជនវៀតណាមមកដល់ស្រុកបាកាន នៅចុងបញ្ចប់នៃរបបខ្មែរក្រហម ហាម ស៊ីន្ធួន បានអានឯកសារអង្គលីលេខមួយច្បាប់ ដែលផ្ញើមកប្រធានអង្គភាពដែលមានខ្លឹមសារថា "យើងត្រូវសម្លាប់ខ្មែរក្រោម។ យើងត្រូវសម្លាប់ពួកគាត់ ពីព្រោះយួនកំពុងមករំដោះពួកគាត់"[3002]។

832. ទីបំផុតទៅ គ្រួសារជាតិពន្ធ និងគ្រួសារប្រជាជនវៀតណាមជាច្រើនជំនាន់ និងភូមិទាំងមូលត្រូវបានបោសសម្អាតនៅភូមិភាគនិរតី និងភាគពាយ័ព្យ ដែលមានជនរងគ្រោះចំនួនរាប់ពាន់នាក់ ដោយសារការអនុវត្តរបស់ **យ៉ីម ទិត្យ** និងសមាជិកសហឧក្រិដ្ឋកម្មរបស់គាត់នូវផែនការរបស់ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាម[3003]។

[3001] ឯកសារ D219/953 កំណត់ហេតុស្តាប់ចម្លើយ ឈ៉ីង ឈ្យីត ឆ.១៦, ៦២, ៦៤, ៧០, ៧២, ៧៥ KH 01425164-01425165, 01425174, 01425177 ["[យ៉ីម ទិត្យ] ថា បោសសម្អាតខ្លាំងយួន តែប៉ុណ្ណឹងឯង។ [...] ព្រោះគោលដៅគេមកប្រជុំពីរឿងហ្នឹងឯង។ អ្នកណាជាប់ខ្សែយួន ចេះភាសាយួនបោសសម្អាតទាំងអស់។ [...] តែយើងក្តាប់មិនបាន តែឮថា ខ្លាំងយួនៗ។"] ឆ.៧១-៧៥ KH 01425177។

[3002] ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីន្ធួន ឆ.៨២ KH 01067999 ["ពេលទៅនៅខ្នាទទ៍ង មានទ្លួលមួយដែលជាផ្ទះរបស់កុមារ ហើយ នី ក៏នៅក្នុងផ្ទះនោះដែរ។ នៅពេលដែលគេចេញពីផ្ទះអស់ ខ្ញុំបានលួចមើលឯកសារមួយដែលគេដាក់នៅក្នុងកេះនៅក្នុងផ្ទះនោះ។ គេសរសេរថា "យើងត្រូវវ៉ៃខ្មែរកម្ពុជាក្រោមចោល ត្រូវសម្លាប់ខ្មែរកម្ពុជាក្រោមចោល យួនមករំដោះវាឥឡូវហើយ"។ នៅពេលដែលខ្ញុំបានដឹងដូច្នេះហើយ ទើបខ្ញុំបានប្រាប់មនុស្សចាស់ៗ និងអ្នកដទៃថា "បើគេឲ្យដូរសមរភូមិអី កុំទៅ" ព្រោះគេនឹងយកទៅសម្លាប់ចោលជាមិនខាន។ ខ្ញុំមើលឃើញសំបុត្រនេះនៅពេលយួនជិតចូលមកដល់។"] ឆ.៩០-៩១ KH 01068000 ["ស៖ ឥឡូវត្រឡប់ទៅឯកសារនោះវិញ តើជាឯកសារសរសេរដោយដៃ ឬក៏ជាឯកសារវាយអង្គុលីលេខ? ឆ.៩០ ៖ ជាអក្សរសរសេរដោយអង្គុលីលេខពីថ្នាក់លើមក។ ស៖ តើលោកស្រីដឹងថា ឯកសារនោះមកពីថ្នាក់លើដោយរបៀបណា? ឆ.៩១៖ ខ្ញុំគ្រាន់តែឃើញអក្សរនោះជាអក្សរដែលគេវាយចេញមកស្អាតៗ ដូច្នេះខ្ញុំគិតថា ជាឯកសារចេញមកពីថ្នាក់លើ"]។ *សូមមើលផងដែរ* ឯកសារ D118/45 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ឈួន ឆ.៣១-៣២ KH 00905856 ["ស៖ តើហេតុដូចម្តេចបានជាមកយកខ្មែរក្រោមដូចនេះ? ឆ.៣១៖ តាមខ្ញុំគិត វាជានយោបាយរបស់ខ្មែរក្រហមទេ។ ស៖ តើហេតុអ្វីបានជាគេយកខ្មែរក្រោមចេញពីភូមិព្រៃរំដេងនេះ? ឆ.៣២៖ តើតាមខ្ញុំយល់ គេចង់សម្លាប់ខ្មែរក្រោមចោលទាំងអស់"]។

[3003] ឯកសារ D6.1.197 ការវាយតម្លៃស៊ីជម្រៅ ដោយបណ្ឌិត Ewa Tabeau និង លោក ចឺ ឃាម *ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា* ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ EN 00385311។ ឯកសារ D219/792.1.7 ប្រតិចារឹក សាស្ត្រាចារ្យ Alexander Hinton ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ម៉ោង 09.21.48-09.22.42។

គ. ការផ្សព្វផ្សាយគោលនយោបាយ ប.ក.ក នៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ

833. ប.ក.ក បានប្រើប្រាស់ការប្រជុំដើម្បីញុះញង់ឲ្យមានការស្អប់ខ្ពើម និងផ្សព្វផ្សាយគោលនយោបាយ របស់ពួកគេដោយដាក់គោលដៅទៅរកប្រជាជនវៀតណាម និងខ្មែរក្រោម[3004]។ នៅភូមិភាគនិរតី **យ៉ឹម ទិត្យ** និងសមាជិកគណៈស្រុកដទៃទៀត បាននិយាយអំពី "ការរំដោះ" ខ្មែរពីទឹកដីវៀតណាម[3005]។ "ការរំដោះ" នេះត្រូវបានពន្យល់ដោយ តឹម ផល ដែលជាសមាជិកគណៈឃុំកំពែង[3006] ដូចខាងក្រោម។ នៅចុងឆ្នាំ១៩៧៧ **យ៉ឹម ទិត្យ** និងគណៈស្រុកគិរីវង្ស បានបញ្ជូនខ្មែរក្រោមទៅរស់នៅឃុំគោកព្រិច ចំណែកប្រជាជនមូលដ្ឋានដែលមកពីគោកព្រិច ត្រូវបានបញ្ជូនទៅរស់នៅស្រុកកោះអណ្តែត[3007]។ **យ៉ឹម ទិត្យ** និងគណៈស្រុកគិរីវង្សបានបញ្ជូន តឹម ផល គណៈឃុំកំពែង ទៅកាន់ឃុំគោកព្រិចដើម្បី "គ្រប់គ្រង" ខ្មែរក្រោមដែលត្រូវបានជម្លៀសដោយបង្ខំទៅកាន់ទីនោះ[3008]។ តឹម ផល បានចាត់ទុកខ្មែរក្រោមចំនួនរាប់រយនាក់នៅភូមិនានានៃឃុំគោកព្រិចជា "អ្នកទោស"[3009] ដែលត្រូវបានសម្លាប់

[3004] ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រៀល សន ឆ.៣៥ KH 00975626 ឆ.៤៣ KH 00975627 ["នៅក្នុងកិច្ចប្រជុំនោះក៏បានលើកឡើងថា ត្រូវសម្លាប់ខ្មែរក្រោមទាំងអស់នោះផងដែរ។"] ឆ.៩៧ KH 00975632 ["ស៖ លោកបាននិយាយថា ខ្មែរក្រោមត្រូវបានចាត់ជាក្រុមមនុស្សដែលត្រូវបោសសម្អាត។ តើត្រឹមត្រូវដែរឬទេ ?ឆ.៩៧៖ បាទ ត្រឹមត្រូវ ព្រោះខ្មែរក្រោមត្រូវបានគេចោទថាជាក្រុម ក.ហ្ស.បេ។"] ឆ.១៦៤ KH 00975639។ ឯកសារ D347/2.1.1 កិច្ចប្រជុំផ្ទៃក្នុង ដើម្បីប្រារព្ធជ័យជម្នះនៅថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៨ KH 01340036 ["ការបំផុសកំហឹងទៅលើជនជាតិ និងកំហឹងវណ្ណៈនៅក្នុងសហគមន៍ចំពោះពួកណ្ហានពានវៀតណាម និងញុះញុងឲ្យមានកំហឹងទៅលើជនជាតិ ដើម្បីឲ្យក្លាយទៅជានិន្នាការដ៏សំខាន់មួយ"]។

[3005] ឯកសារ D219/471 តឹម ផល ឆ.១១៣-១១៤ KH 01133426។

[3006] ឯកសារ D219/471 តឹម ផល ឆ.២-៣ KH 01133412។

[3007] ឯកសារ D219/471 តឹម ផល ឆ.៣១ KH 01133415-01133416 ["ស៖ នៅពេលដែលលោកស្រីនិយាយថា គណៈឃុំកំពែង ត្រូវបានប្តូរទៅឃុំគោកព្រេច តើវារួមបញ្ចូលទាំងលោកស្រីផងឬ? ឆ.៣១៖ ចាស គឺទៅទាំងអស់។ នៅពេលនោះ ប្រជាជនទាំងអស់ដែលរស់នៅក្នុងឃុំគោកព្រេចត្រូវបានបញ្ជូនទៅរស់នៅក្នុងស្រុកកោះអណ្តែតវិញ ហើយខ្មែរក្រោមត្រូវបានគេបញ្ជូនឲ្យមករស់នៅក្នុងឃុំគោកព្រេចវិញ។ ខ្ញុំមិនដឹងថា ប្រជាជនៅក្នុងឃុំកំពែងត្រូវបានបញ្ជូនទៅស្រុកកោះអណ្តែតដែរឬអត់ទេ។"] ឆ.១០៩-១១០ KH 01133426 ឆ.១១១-១១៣ KH 01133426 ["ស៖ ខ្មែរក្រោមទាំងអស់នោះរស់នៅក្នុងទឹកដីវៀតណាម តើពួកគេធ្វើអ្វីនៅក្នុងឃុំគោកព្រេច? ឆ.១១១៖ គឺថ្នាក់ស្រុកបញ្ជូនខ្មែរក្រោមទាំងអស់នោះ មកដាក់នៅក្នុងឃុំគោកព្រេច។ ស៖ តើលោកស្រីដឹងពីមូលហេតុដែលពួកគេមកទីនោះដែរឬទេ? ឆ.១១២៖ ពួកគេត្រូវបានរំដោះ ហើយយកមកដាក់នៅទីនោះ ប៉ុន្តែខ្ញុំមិនដឹងពីមូលហេតុនោះទេ។ ស៖ កាលពេលនោះ តើនរណាជាគណៈស្រុក? ឆ.១១៣៖ គឺតាសៀង តាទិត្យ និងឃ្យៀន"]។

[3008] ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ តឹម ផល ឆ.១០៨, ១១០, ១១៥-១១៦, ១១៨ KH 01133426-01133427។

[3009] ឯកសារ D219/471 [D118/23] កំណត់ហេតុស្តាប់ចម្លើយ តឹម ផល ឆ.៤៧ KH 00891163 ["ស៖ តើលោកស្រីបានដឹងរឿងអ្វីខ្លះពីការសម្លាប់ខ្មែរក្រោម? ឆ.៤៧៖ ខ្ញុំមិនបានដឹងរឿងអ្វីទេ គ្រាន់តែដឹងថា គេហៅថាអ្នកទោសៗ"]។ [ឯកសារ D219/471 កំណត់ហេតុស្តាប់ចម្លើយ តឹម ផល] ឆ.១២៣-១២៤ KH 01133427 ["ស៖ តើមានប្រហែលជាប្លន់ដប់នាក់ ឬ

និងបានបាត់ខ្លួនពីពេលដែលពួកគាត់បានមកដល់គោកព្រិច[3010]។ **យឹម ទិត្យ** និងគណៈស្រុកបាន ទទួលរបាយការណ៍ស្ដីពី "សត្រូវ" ខ្មែរក្រោម និងបានបញ្ជាឲ្យចាប់ និងឃុំឃាំង ឬសម្លាប់ខ្មែរក្រោម[3011]។

ហាសិបនាក់? ឆ.១២៣៖ មានរាប់រយនាក់។ ខ្មែរក្រោមរស់នៅច្រើនភូមិ ប៉ុន្តែខ្ញុំមិនចាំចំនួនទេ។ ស៖ លោកស្រីនិយាយថា ខ្មែរក្រោមរស់នៅច្រើនភូមិ តើមានភូមិណាខ្លះ? ឆ.១២៤៖ ខ្មែរក្រោមទាំងអស់រស់នៅក្នុងភូមិត្រពាំងព្រីង ភូមិស្ដេង ភូមិគោកព្រេច និងភូមិចំបក់"]។

[3010] ឯកសារ D118/23 កំណត់ហេតុស្ដាប់ចម្លើយ គិម ផល ឆ.៤៥-៤៦ KH 00891163 ["ស៖ តើលោកស្រីដឹងទេថា មានពួកខ្មែរក្រោមត្រូវបានគេយកទៅសម្លាប់ដែរឬទេ? ឆ.៤៥៖ ខ្ញុំបានឮពីការសម្លាប់ហ្នឹង។ ស៖ តើលោកស្រីចាំទេថា គេយកទៅសម្លាប់នៅកន្លែងណា? ហើយនៅក្នុងឆ្នាំណា? ឆ.៤៦៖ កាលពួកកម្ពុជាក្រោមឡើងមកភូមិនេះប្រហែលជាក្នុងឆ្នាំ១៩៧៦ ឬ១៩៧៧។"] ឆ.៤៩-៥១ KH 00891163-00891164 ["ស៖ តើគេសម្លាប់ខ្មែរក្រោមប្រហែលជាប៉ុន្មាននាក់? ឆ.៤៩៖ ខ្ញុំមិនដឹងពីចំនួនទេ គ្រាន់តែដឹងថា គេសម្លាប់។ កាលនោះតាប៉ោះ ជាអ្នកទទួលខុសត្រូវលើពួកខ្មែរក្រោម ហើយម្នាក់ទៀតឈ្មោះតាសារ៉ូ។ កាលនោះ គាត់ទាំងពីរនាក់នេះ ជាអ្នកចាត់ចែងការងារខ្មែរក្រោម ដូចជា ឲ្យជីកប្រឡាយ។ ស៖ តើលោកស្រីដែលឮពីពួកកន្សែងស ដែរឬទេ? ឆ.៥០៖ ខ្ញុំមិនដែលដឹងទេ។ ស៖ តើអ្នកណាប្រាប់លោកស្រីពីការសម្លាប់ខ្មែរក្រោម? ឆ.៥១៖ ខ្ញុំនៅជាមួយខ្មែរក្រោម ដែលគេចាត់តាំងឲ្យធ្វើជី ធ្វើស្រែ ទើបខ្ញុំបានដឹងពីពួកទាំងនោះថា មានការសម្លាប់"]។ ឯកសារ D219/471 កំណត់ហេតុស្ដាប់ចម្លើយ គឹម ផល ឆ.១២៩-១៣២ KH 01133428 ["ស៖ ចន្លោះពេលដែលលោកស្រីចូលមកកាន់ និងពេលចាកចេញពីឃុំគោកព្រេច តើលោកស្រីមានសង្កេតឃើញចំនួនខ្មែរក្រោមមានការប្រែប្រួលដែរ ឬទេ? ឆ.១២៩៖ មានប្រជាជនបាត់ខ្លះ។ ប៉ុន្តែខ្ញុំមិនដឹងថា តើពួកគេត្រូវបានយកទៅទីណានោះទេ។ ស៖ ចុះអ្នកដែលបាត់ខ្លួនទាំងអស់នោះ តើលោកស្រីមានឃើញត្រឡប់មកវិញដែរ ឬទេ? ឆ.១៣០៖ អត់ដែលឃើញត្រឡប់មកវិញទេ។ ស៖ តើលោកស្រីដឹងថាមូលហេតុអ្វីបានជាពួកគេបាត់ខ្លួនដែរ ឬទេ? ឆ.១៣១៖ ខ្ញុំមិនដឹងទេ ប៉ុន្តែការបាត់ខ្លួន មានន័យថា គឺត្រូវបានគេយកទៅសម្លាប់។ ស៖ តើបាត់ខ្លួននោះ បាត់របៀបម៉េចដែរ? បាត់ម្ដងមួយ ឬបាត់ជាក្រុម? ឆ.១៣២៖ មិនមែនបាត់ជាក្រុមទេ គឺបាត់ម្ដងមួយៗ។"] ឆ.១៤១ KH 01133429។

[3011] ឯកសារ D219/471 កំណត់ហេតុស្ដាប់ចម្លើយ គឹម ផល ឆ.១៣៣-១៣៦ KH 01133428-01133429 ["ស៖ មុននេះ លោកស្រីរៀបរាប់ពីនីតិវិធីនៅក្នុងឃុំកំពែង គឺលោកស្រីត្រូវបានគេប្រាប់ឲ្យតាមដានជនខិលខូច រាយការណ៍ទៅថ្នាក់ស្រុក ហើយបន្ទាប់មក មានមនុស្សត្រូវបានគេចាប់ខ្លួន តើដូចគ្នា ឬក៏ខុសគ្នានៅក្នុងឃុំគោកព្រេច? ឆ.១៣៣៖ ចាស គឺដូចគ្នា។ ស៖ ដើម្បីបញ្ជាក់ឲ្យច្បាស់ តើនរណាដែលជាអ្នកប្រមូលព័ត៌មានពីជនខិលខូចខ្មែរក្រោម នៅក្នុងឃុំគោកព្រេច? ឆ.១៣៤៖ តាប៉ស់ និងតាសារ៉ូ។ ស៖ តើពួកគេទាំងពីរនេះ ដើរប្រមូលព័ត៌មានអ្វីខ្លះពីខ្មែរក្រោម? ឆ.១៣៥៖ ខ្ញុំមិនដឹងរឿងច្រើនទេ ប៉ុន្តែពួកគេទាំងពីរ ធ្វើការជាមួយឈ្លប ដើរស្វែងរកខ្មែរក្រោមណា ដែលប្រព្រឹត្តិសកម្មភាពណាមួយ ដែលគេចាត់ទុកថាជាខ្មាំង។ ស៖ នៅពេលដែលគេប្រមូលបានព័ត៌មានហើយ តើពួកគេបញ្ជូនព័ត៌មានទៅណាដែរ? ឆ.១៣៦៖ បញ្ជូនទៅថ្នាក់ស្រុក"] ឆ.១៣៨-១៣៩ KH 01133429 ["ស៖ នៅពេលដែលថ្នាក់ស្រុកទទួលបានរបាយការណ៍អំពីខ្មែរក្រោម ដែលគេចាត់ទុកថា ជាខ្មាំង តើមានរឿងអ្វីកើតឡើងបន្ទាប់មកទៀត? ឆ.១៣៨៖ ក្រោយពេលទទួលបញ្ជាពីថ្នាក់ស្រុក គឺមនុស្សត្រូវបានគេចាប់ខ្លួន។ ស៖ ក្រោយពេលចាប់ខ្លួនរួចហើយ តើលោកស្រីដឹងថា ពួកគេត្រូវបញ្ជូនទៅណាដែរ? ឆ.១៣៩៖ ខ្ញុំមិនដឹងថា ពួកគេត្រូវបានបញ្ជូនទៅដាក់នៅវត្តព្រះធាតុ ឬក៏ត្រូវបានគេសម្លាប់ចោលនោះទេ។"]។ ឯកសារ D105/5 កំណត់ហេតុស្ដាប់ចម្លើយ អោក ចន ឆ.៤០-៤៣ KH 00788846 ["ស៖ តើតាទិ

834. ការប្រជុំដទៃទៀតនៅស្រុកគិរីវង្ស នៅពេល **យ៉ីម ទិត្យ** មានសិទ្ធិអំណាច ជាឧទាហរណ៍។ ជាក់ស្តែង ក្នុងឆ្នាំ១៩៧៨ គង់ សំណាង បានចូលប្រជុំនៅវត្តស្ពែងកន្លែងដែលកម្មាភិបាល ប.ក.ក បាននិយាយ អំពីខ្មែរក្រោម ដោយបានប្រាប់អ្នកចូលរួមឲ្យ "សម្លាប់ពួកគាត់ទាំងអស់! កុំទុកជីវិតឲ្យពួកវា"[3012]។ សាក្សីនានាក៏បានបញ្ជាក់លម្អិតផងដែរអំពីអ្វីដែលគេហៅថា "ពិធី" ដែលរៀបចំសម្រាប់ខ្មែរក្រោម នៅភូមិស្ពែង កំពែង និងឃុំគោកព្រិច ដើម្បីប្រមូលខ្មែរក្រោមយកទៅសម្លាប់ នៅពេលបន្ទាប់ពីនោះ[3013]។

835. **យ៉ីម ទិត្យ** ស្ថិតក្នុងគណៈតំបន់ ១៣ និងហេតុដូច្នេះ មានការទទួលខុសត្រូវលើស្រុកត្រាំកក់ និងកោះអណ្តែត ដែលនៅទីនោះផែនការរបស់ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាមត្រូវបានផ្សព្វផ្សាយស្រដៀងៗគ្នា។ សន រៀល បានចូលរួមការប្រជុំនានានៅស្រុកត្រាំកក់ ដែលអ្នកចូលរួមត្រូវបានប្រាប់ថាត្រូវតែ "បោសសម្អាត" ខ្មែរក្រោម-ដែលមានន័យថា "ត្រូវតែសម្លាប់ខ្មែរក្រោមទាំងអស់"[3014]។ តា ជិម លេខាស្រុកត្រាំកក់ បានប្រាប់អ្នកចូលរួមប្រជុំអំពីប្រភេទមនុស្សដែលត្រូវ

ត្យ មានតួនាទីក្នុងការសួរចម្លើយពួកខ្មែរក្រោមដែរទេ? ឆ. ៤០៖ ខាងផ្នែកនយោបាយ ខាងខ្មែរក្រហម គឺគេមានការទាក់ទងខាងឃុំ ក្នុងការចាប់ខ្លួនខ្មែរក្រោម។ ខាងគណៈស្រុកគេទាក់ទងមកឃុំ ហើយទើបបញ្ជូនខ្មែរក្រោមមកកន្លែងឃុំឃាំងនេះ។ ស៖ តើលោកចង់និយាយថា តាទិត្យ គាត់ជាគណៈស្រុកក្នុងសម័យនោះមែនទេ? ឆ.៤១៖ បាទ។ ស៖ ហើយគាត់ទំនាក់ទំនងមកថ្នាក់ឃុំ តើត្រូវទេ? ឆ.៤២៖ បាទ។ ស៖ តើនេះជារបៀបគេទំនាក់ទំនង ដើម្បីចាប់ខ្មែរក្រោមឬទេ? ឆ.៤៣៖ បាទ"]។

[3012] ឯកសារ D118/253 កំណត់ហេតុស្តាប់ចម្លើយ គង់ សំណាង ឆ.៨៤ KH 00993603។

[3013] ឯកសារ D118/164 កំណត់ហេតុស្តាប់ចម្លើយ ប៉ែន ហ៊ាង ឆ.៤១-៤២ KH 00968135។ ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៥ KH 01097670។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.១០១, ១០៦ KH 00987238 ["ស៖ លោកស្រីនិយាយថា ពេលដែលគេឲ្យហូបចុកច្រើនដូច្នេះ គឺគេមានគម្រោងយកទៅសម្លាប់។ តើលោកស្រីមានស្គាល់អ្នកណាដែលបានចូលរួមក្នុងការហូបចុកដូច្នេះ ហើយរត់គេចខ្លួនរួចដែរឬទេ? ឆ.១០៦៖ ខ្ញុំពុំស្គាល់ទេ ខ្ញុំគ្រាន់តែឮពីអ្នកផ្សេងថា ពេលដែលគេឲ្យចូលរួមហូបចុកដូច្នេះ គឺនឹងត្រូវគេយកទៅសម្លាប់ហើយ"]។

[3014] ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រៀល សន ឆ.៣៥ KH 00975626 ["ស៖ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត លោកបានបញ្ជាក់ថា គេបានប្រកាសប្រាប់អ្នកចូលរួមប្រជុំទាំង" ?អសង់អំពីប្រភេទមនុស្ស ដែលត្រូវបោសសម្អាតមានអ្នកណាខ្លះ"។ តើនៅចាំដែរ ឬទេ ឆ.៣៥៖ បាទ ខ្ញុំចាំ។"] ឆ.៤៣ KH 00975627 ["នៅក្នុងកិច្ចប្រជុំនោះ ក៏បានលើកឡើងថា ត្រូវសម្លាប់ខ្មែរក្រោមទាំងអស់នោះផងដែរ។"] ឆ.៩៧ KH 00975632 ["ស៖ លោកបាននិយាយថា ខ្មែរក្រោមត្រូវបានចាត់ជាក្រុមមនុស្សដែលត្រូវបោសសម្អាត។ តើត្រឹមត្រូវដែរ ឬទេ? ឆ.៩៧៖ បាទ ត្រឹមត្រូវ ព្រោះខ្មែរក្រោមត្រូវបានគេចោទថាជាក្រុម កា.ហ្ស.បេ។"] ឆ.១៦៤ KH 00975639 ["ស៖ លោកបានបញ្ជាក់ថា នៅក្នុងការប្រជុំមួយចំនួន ដែលលោកបានចូលរួម គេបានប្រកាសថា ខ្មែរក្រោមត្រូវចាត់ចូលជាក្រុមមនុស្សដែលត្រូវគេបោសសម្អាត។ តើជាប្រភេទខ្មែរក្រោមយ៉ាងម៉េចដែលត្រូវគេបោសសម្អាត? ឆ.១៦៤៖ ជាខ្មែរក្រោមដែលពុំមានកូន ពុំមានចៅ ហើយដែលមានវ័យចំណាស់បន្តិច គឺត្រូវគេចោទថាជាគិញយួន"]។

បោសសម្អាត[3015]។ សាក្សី ឯក (អ៊ីល) ហ៊ីន ដែលធ្វើការនៅមន្ទីរពាណិជ្ជកម្មស្រុកត្រាំកក់[3016] ត្រូវបានគេប្រាប់ថា "ត្រូវតែបោសសម្អាតប្រជាជនវៀតណាមទាំងស្រុងពីភូមិនានា និងប្រទេស"[3017]។ ដូចគ្នានេះ យិន តេង ប្រធានក្រុមក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ បានចូលរួមប្រជុំមួយនៅឃុំគុស ស្រុកត្រាំកក់ ដែលអ្នកចូលរួម រួមបញ្ចូលទាំងគណៈភូមិ ប្រធានក្រុម និងឈ្លប[3018] ត្រូវបានគេប្រាប់ថាខ្មែរក្រហម "បានយកខ្មែរក្រោមទាំងនោះត្រឡប់មកវិញដើម្បីទប់ស្កាត់ពួកគាត់មិនឲ្យសេពគប់ជាមួយ យួន"[3019]។ យិន តេង បានកត់សម្គាល់ថា ខ្មែរក្រោមទាំងឡាយដែលត្រូវបានបង្ខំឲ្យផ្លាស់ទីលំនៅទៅកម្ពុជា "ត្រូវបានយកទៅសម្លាប់"[3020]។ នៅកោះអណ្តែត គ្រួសារខ្មែរក្រោមដែលត្រូវបានជម្លៀសដោយបង្ខំនៅទីនោះក្នុងឆ្នាំ១៩៧៥ ត្រូវបានចាត់ទុកជា "ខ្មាំង" សូម្បីតែ

[3015] ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រ៉ៀល សន ឆ.៣៤ KH 00975626 ["ខ្ញុំទៅប្រជុំបានបី ប៉ុន្តែការប្រជុំលើកដំបូង ខ្ញុំភ្លេចហើយ ខ្ញុំចាំតែពាក់កណ្តាល ហើយនិងចុងរបបខ្មែរក្រហមប៉ុណ្ណោះ។"] ឆ.៣៧ KH 00975626-00975627 ["សៈ តើគណៈស្រុកមានឈ្មោះអ្វី? ហើយតើប្រជុំនេះធ្វើឡើងនៅពេលណា? ឆ.៣៧៖ គាត់ឈ្មោះ ជឹម [លេខាគណៈស្រុក]"] ឆ.៣៩ KH 00975627 ["ស៖ តើឈ្មោះ ជឹម ដែលជាគណៈស្រុកនេះហើយដែលបាននិយាយថា ក្រុមមនុស្សប្រភេទណាខ្លះ ដែលត្រូវបោសសម្អាតនោះមែនទេ? ឆ.៣៩៖ បាទ"]។

[3016] ឯកសារ D118/208 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ីន ឆ.២០ KH 00980084 ["ស៖ ប៉ុន្តែនៅក្នុងបទសម្ភាសជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបញ្ជាក់ថា ដំបូង លោកធ្វើជាអនុប្រធានភូមិ ក្រោយមកទៀត តាជឹម បានបញ្ជូនលោកទៅធ្វើការនៅសាលាស្រុកត្រាំកក់។ តើត្រឹមត្រូវដែរឬទេ? ឆ.២០៖ តាជឹម បានបញ្ជូនខ្ញុំទៅពាណិជ្ជស្រុក ដើម្បីជួយកាយអង្ករ និងអំបិល"]។

[3017] ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ីន ឆ.៥៣ KH 00980105 ["គេនិយាយថា ត្រូវបោសសម្អាតជនជាតិវៀតណាមឲ្យអស់ពីប្រទេស និងពីក្នុងភូមិ"]។

[3018] ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.១៣៣ KH 01052705 ["ស៖ តើអ្នកណាជាអ្នករៀបចំការប្រជុំនេះ? ឆ.១៣៣៖ មេឃុំជាអ្នករៀបចំ។"] ស.១៣៨ KH 01052706 ["ស៖ តើការប្រជុំនេះប្រព្រឹត្តទៅនៅកន្លែងណា? ឆ.១៣៨៖ នៅឃុំគុស។"] ឆ.១៣៣ KH 01052705។

[3019] ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.១៣១ KH 01052705 ["ពួកគេជាមនុស្សមកពីកម្ពុជាក្រោម ព្រោះក្នុងភូមិខ្ញុំមានតែបីគ្រួសារទេ។ គេបាននិយាយអំពីមូលហេតុ ដែលគេនាំខ្មែរក្រោមចេញពីវៀតណាមថា គេអូសខ្មែរក្រោម" មកវិញ កុំឲ្យនៅជាប់យួន"។ តាមពិត គេយកទៅសម្លាប់សោះ។"] ឆ.១៣២ KH 01052705 ["ស៖ តើលោកស្រីដឹងថា ប្រជាជនទាំងអស់នោះមកពីកម្ពុជាក្រោមដោយរបៀបណា? ឆ.១៣២៖ គេប្រជុំ ព្រោះមុនទៅយកមនុស្សពីកម្ពុជាក្រោម គេបានប្រជុំនិយាយប្រាប់"]។

[3020] ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យិន តេង ឆ.១៣១-១៣២ KH 01052705។

កុមារ[3021]។ រង ណុប ត្រូវបានប្រាប់ដោយប្រធានគណៈកម្មការ ម៉ោង ថាថ្នាក់លើដែលអាចរួមបញ្ចូល **យ៉ីម ទិត្យ** បានចាត់តាំងគាត់ (ម៉ោង) ឲ្យ "បំផ្លាញ" ខ្មាំង[3022]។

836. ក្រោយពេល **យ៉ីម ទិត្យ** និង/ឬកម្លាភិបាលភូមិភាគនិរតី និងសមាជិក JCE មកដល់ភូមិភាគពាយ័ព្យ ឈ្លបនៅស្រុកបាកានត្រូវបានគេស្តាប់ឮ នៅពេលនិយាយអំពីការសម្លាប់ខ្មែរក្រោមទាំងអស់[3023]។ ដំណើររឿងនានាបង្ហាញអំពីការដឹងជាចំហ អំពីផែនការសម្លាប់ប្រជាជនខ្មែរក្រោម[3024]។ រឿន តារា បានរៀបរាប់អំពីមហិច្ឆតារបស់ ប.ក.ក ដើម្បី "កម្ចាត់ឈាមជ័រខ្មែរក្រោម"[3025] ហើយសាក្សីដទៃ បានបញ្ជាក់លម្អិតអំពីការប្រមូលជាប្រព័ន្ធ ការបាត់ខ្លួន និងការសម្លាប់ខ្មែរក្រោម[3026]។

[3021] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រង ណុប ឯ.២៥-២៦ KH 01171495 ["កាលនោះ គេហៅថាខ្មាំង អ្នកមកនៅកន្លែងនេះ គេហៅថា ខ្មាំងទាំងអស់។ គេបានមកហៅបបួលខ្ញុំទៅជួយវ៉ៃសំពង តែខ្ញុំបដិសេធ ហើយខ្ញុំប្រាប់ពួកគេថា ខ្ញុំមិនចូលរួមទេ អ្នកឯងធ្វើតែឯងចុះ។ ខ្ញុំមិនអាចធ្វើបានទេ បើប្រជាជនអត់មានកំហុសអ្វី ប៉ុន្តែពួកគេបែរជាចាប់ចង និងយកប្រជាជនទាំងនោះទៅវ៉ៃសម្លាប់។ ដូច្នេះ ខ្ញុំមិនអាចធ្វើយ៉ាងនេះបានទេ។ [...] ខ្ញុំមិនដឹងទេ សូម្បីតែកូនក្មេង ក៏គេហៅថាខ្មាំងដែរ"]។ *សូមមើលផងដែរ* ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឯ.៧៨, ១១៥-១១៦, ១១៩, ១២១-១២៣ KH 01169872, 01169876-01169877។

[3022] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រង ណុប ឯ.៣៥-៣៨ KH 01171496 ឯ.៤៤ KH 01171497 ["ស៖ តើ ម៉ោង មានធ្លាប់និយាយថា ប្រជាជនខ្មែរក្រោម ជាខ្មាំង ឬក៏គោលដៅដែលត្រូវកម្ទេចចោលរបស់អង្គការទេ? ឯ.៤៤៖ គេនិយាយថា អង្គការថ្នាក់លើចាត់តាំងគេធ្វើជាប្រធានគណៈកម្មការ ដើម្បីមកកម្ទេចតែម្តង"]។

[3023] ឯកសារ D219/341 កំណត់ហេតុស្តាប់ចម្លើយ នក់ សាង៉ាវ ឯ.២០-២១ KH 01102872។

[3024] ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន ឯ.៣០ KH 00955697 ["ស៖ [...] តើលោកនៅចាំថា ខ្មែរក្រហមមានផែនការសម្រិតសម្រាំងខ្មែរក្រោមដែរឬទេ? ឯ.៣០៖ បាទ នេះជាផែនការរបស់គេ"]។ ឯកសារ D219/921 កំណត់ហេតុស្តាប់ចម្លើយ ចាប ពុធ ឯ.១០៥-១០៦ KH 01391801 ["ឯ.១០៥៖ [...] ខ្ញុំឮតែគេនិយាយតៗគ្នាដែរថា ឲ្យតែកម្ពុជាក្រោម អត់ទុកអត់ទុកសោះ។ ស៖ តើខ្មែរក្រហមហ្នឹងនៅថ្នាក់សហការណ៍ ឬថ្នាក់លើទៀត? ឯ.១០៦៖ ថ្នាក់សហការណ៍ ដែលនិយាយពីមិនទុកខ្មែរកម្ពុជាក្រោម ហើយមេខ្ញុំ ប្រធានក្រុមដឹកជញ្ជូនខ្ញុំក៏និយាយដែរថា មិនទុកខ្មែរកម្ពុជាក្រោម"]។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ដារ៉ា ឯ.៦៩-៧០ KH 00973952-00973953 ["ស៖ បើតាមលោកដឹង តើខ្មែរក្រហមមានផែនការសម្លាប់ខ្មែរក្រោមទាំងអស់ ឬក៏យ៉ាងណា? ឯ.៦៩៖ បាទ គឺសម្លាប់ទាំងអស់ សម្លាប់បំផុតពូជ។ ស៖ ហេតុអ្វីបានជាលោកដឹងអំពីផែនការនេះ? ឯ.៧០៖ នៅពេលនោះ យើងទាំងអស់គ្នាដឹងថា ខ្មែរក្រហមចង់សម្លាប់ខ្មែរក្រោមទាំងអស់។ ម្យ៉ាងទៀត ដោយសារមានការសម្លាប់ខ្មែរក្រោមជាបន្តបន្ទាប់នេះហើយ ទើបខ្ញុំសន្ធត់ថា ខ្មែរក្រហមមានផែនការសម្លាប់ខ្មែរក្រោមទាំងអស់"]។

[3025] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ដារ៉ា ឯ.៦៩-៧០ KH 00973953។

[3026] ឯកសារ D219/9 កំណត់ហេតុស្តាប់ចម្លើយ ឃុន សាមឿន ឯ.៨៦ KH 01025565 ["ខ្ញុំមិនដឹងគេបញ្ជូនខ្មែរក្រោមមកពីណាទេ មានចំនួនច្រើនណាស់ ក្រោយមកគេយកទៅវ៉ៃចោលទាំងអស់ ថែមទាំងពួកបួ៉ាផងដែរ"]។

837. យាម រឹម កម្មាភិបាលភូមិភាគនិរតី ដែលត្រូវបានតែងតាំងជាលេខាស្រុកបាកានពីពាក់កណ្តាលឆ្នាំ ១៩៧៧[3027]។ គាត់ជាឥស្សរជនសំខាន់មួយរូបក្នុងការអនុវត្តផែនការ ប.ក.ក ដើម្បីបំផ្លាញប្រជាជនវៀតណាមនៅភូមិភាគនិរតី ដោយធានាបានថា បញ្ញានានាពីថ្នាក់លើ ដែលបានរួមបញ្ចូល **យ៉ីម ទិត្យ** ត្រូវបានអនុវត្តនៅថ្នាក់ក្រោមក្នុងស្រុកបាកាន។ យាម រឹម បាននិយាយថា តា សារុន នៃគណៈតំបន់២ បានបើកការប្រជុំនានានៅតាមសហករណ៍ដែលក្នុងនោះគាត់បានបញ្ជាថាត្រូវតែរក "ខ្សែបណ្តាញវៀតណាម"[3028]។ នៅឆ្នាំ១៩៧៨ តា សារុន បានបញ្ជាឲ្យ យាយ រឹម បញ្ជូនប្រជាជនខ្មែរក្រោមដែលស្ថិតក្នុងស្រុករបស់គាត់ ទៅខ្នារទទឹង[3029]។ យាយ រឹម បានទទួលស្គាល់ការអនុវត្តបញ្ជាទាំងនេះ និងការណែនាំឲ្យសហករណ៍ស្រាវជ្រាវរកមនុស្សដែលមាន "ខ្សែរយៈវៀតណាម"[3030]។

[3027] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឯ.១០-១១ KH 01348857-01348858 ["ស៖ នៅក្នុងវីដេអូ ដែលលោកស្រីបានមើលកាលពីថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០១៦ វីដេអូស្តីពី "សត្រូវរបស់ប្រជាជន" មានបុរសពីរនាក់បាននិយាយ។ បុរសម្នាក់ឈ្មោះ ស្ងួន និងម្នាក់ទៀតឈ្មោះ ឃន។ ស្ងួន បាននិយាយថា គាត់បានទទួលបញ្ជាពីលោកស្រីហើយ លោកស្រីបានទទួលបញ្ជាពីថ្នាក់លើ។ តើនេះត្រឹមត្រូវទេ ដែលថា សកម្មភាពបានកើតឡើងបន្ទាប់ពីមានការប្រជុំរវាងតាសារុន និងតាម៉ុក? តើលោកស្រីយល់សំណួរទេ? ឯ.១០៖ យល់។ ស៖ តើនេះជាអ្វីដែលបានកើតឡើងជាក់ស្តែងមែនទេ? ឯ.១១៖ ដូចវីដេអូ គាត់បានបញ្ជាក់។ រឿងពីមុនមកអត់មានទេ តែរឿងក្រោយមក សកម្មភាពប្រទេសច្រឫកច្របល់ ហ្ម?ងក៏មានសកម្មភាពមក"] ។ ឯកសារ D118/170 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឯ.១៥៤ KH 00969600 ["ស៖ តើពេលនោះ លោកស្រីធ្វើតាមការណែនាំ ឬក៏បញ្ជាពីថ្នាក់លើ ឬពីអង្គការដែរឬទេ? ឯ.១៥៤៖ ពេលនោះ យើងចេះតែធ្វើតាមគេទៅ"]។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឯ.៤០ KH 01075611 ["យាយ រ៉ន ជាអ្នកដែលមានឋានៈធំជាងគេ។ យាយ យ៉ាន និងយាយ រ៉ន ជាអ្នកមកពីស្រែអំបិល ពីនិរតី"]។

[3028] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឯ.១៤ KH 01348858 ["ស៖ [...] សកម្មភាព គឺសំដៅដល់សកម្មភាពក្នុងការតាមរកកំណត់អត្តសញ្ញាណ និងលុបបំបាត់ពួកគេ តើមែនទេ? ឯ.១៤៖ ហ្ម?ង គាត់ណែនាំឲ្យសហករណ៍ទាំងអស់ ឲ្យតាមដាន ហ្ម?ងខ្ជាចលោខ្សែរយៈយួនវ៉ៃលុកអ៊ីចឹងទេ"]។

[3029] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឯ.២៧-២៨ KH 01348861 ["ស៖ តើគាត់បានណែនាំលោកស្រីឲ្យបញ្ជូនមនុស្សទៅខ្នារទទឹង ឬទេ? ឯ.២៧៖ គាត់បានណែនាំនៅអង្គប្រជុំ គាត់បានណែនាំ។ ស៖ គាត់បានណែនាំ? ឯ.២៨៖ ចាស"]។

[3030] ឯកសារ D219/869 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅ យាយ រ៉ីម ឯ.១៦ KH 01348859 ["ស៖ មូលហេតុអ្វីបានជាលោកស្រីមិនឆ្លើយនឹងសំណួរនេះ? កាលពីសម្អាសថ្ងៃមុន លោកស្រីបានបញ្ជាក់ថា លោកស្រីបានទទួលបញ្ជាពីថ្នាក់លើមក ហើយលោកស្រីបានណែនាំឲ្យថ្នាក់ក្រោមរបស់លោកស្រីជាអ្នកអនុវត្ត ណែនាំដល់មេយោធា មេឈ្លប សហករណ៍ តាម ដាន និងស្រាវជ្រាវ កំណត់អត្តសញ្ញាណ និងសម្លាប់អ្នកដែលជាប់ខ្សែរយៈយួន។ ហើយភស្តុតាងនេះមាននៅក្នុងវីដេអូ និងអ្វីដែលលោកស្រីបានបញ្ជាក់ប្រាប់យើងកាលពីថ្ងៃទី៧ និងទី៨ ខែវិច្ឆិកា នោះ។ ខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ម្តងទៀត ដើម្បីជាទម្លាក់ករណ៍

838. បញ្ជាទាំងនេះត្រូវបានអនុវត្ត។ អ៊ុក សៀម ជាប្រធានសហករណ៍រំលិច នៅពេលកម្មាភិបាលភូមិភាគនិរតីចូលកាន់កាប់ភូមិភាគពាយ័ព្យ[3031]។ នៅឆ្នាំ១៩៧៨ គាត់បានទទួលបញ្ជាពីលេខាស្រុកបាកាន ឲ្យប្រមូល និងបញ្ជូនខ្មែរក្រោមទាំងអស់ក្នុងតំបន់នោះ ទៅខ្នារទទឹង ពីព្រោះពួកគាត់ត្រូវបានចោទថា "ជាប់ខ្សែរយៈវៀតណាម"[3032]។ អ៊ុក សៀម បានបញ្ជូនខ្មែរក្រោមចំនួនជាង ១០០០ នាក់ទៅគណៈសហករណ៍ខ្នារទទឹង[3033] ដោយដឹងថា មានផែនការសម្លាប់ខ្មែរក្រោម[3034]។ គាត់បានដឹងដូច្នេះពីការចូលរួមអង្គប្រជុំមួយជាមួយប្រធានសហករណ៍ទាំងអស់នៅស្រុកបាកាន ដែលក្នុងនោះ យាយ រីម ដែលជាសមាជិក JCE របស់ **យ៉ីម ទិព្ធ** "បាននិយាយអំពីផែនការសម្លាប់ខ្មែរក្រោម"[3035]។ គណៈស្រុកបាកានបានប្រាប់ប្រធានសហករណ៍ថា បទបញ្ជាឲ្យសម្លាប់ខ្មែរក្រោមគឺចេញមកពី "អង្គការ"[3036]។

ចំពោះរឿងនេះឲ្យកាន់តែច្បាស់ ហើយលោកស្រីមានសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ ដូច្នេះ សូមលោកស្រីកុំភិតភ័យអី។ ឆ.១៦៖ ខ្ញុំឆ្លើយថា យើងបានទទួលផែនការហើយ យើងអត់ប្រជុំអត់កើត។ ដូច្នេះ យើងប្រជុំប្រាប់ គ្រាន់តែប្រជុំប្រាប់ទេណា រឿងធ្វើអត់ទេ ខ្ញុំអត់មានទេ សូមទោស អត់សោះ។ គេណែនាំប៉ុនណា យើងធ្វើតាមអ្វីដែលគេណែនាំ។ ខ្ញុំមិនប្រឆាំងនឹងតុលាការទេ សំណួរខ្លះទៅ ក្រែងឆ្លើយទៅ វាប៉ះលើខ្លួនឯង ខ្លួនឯងមានទោស"]។ ឆ.១៩ KH 01348859 ឆ.៦០-៦១ KH 01348866 ["ស៖ ត្រឡប់ទៅនិយាយអំពីការស្រាវជ្រាវរកអ្នកជាប់ខ្សែរយៈវៀតណាមវិញ។ សូមប្រាប់យើងអំពីឧទាហរណ៍ជាក់លាក់នៃរបៀបដែលអ្នកនៅក្រោមបង្គាប់របស់លោកស្រី បានធ្វើការស្រាវជ្រាវ ដើម្បីកំណត់អត្តសញ្ញាណអ្នកជាប់ខ្សែរយៈវៀតណាម។ តើពួកគេបានធ្វើការងារនេះដូចម្តេច តើពួកគេបានរៀបចំការងារនេះដូចម្តេច និងតើអ្នកណាបានធ្វើការងារនេះ? ឆ.៦០៖ និយាយទៅការណែនាំហ្នឹង ចេះតែណែនាំថាទេៗអ៊ីចឹងទៅ ហើយការណែនាំមានអ្នកណាមានតែសហករណ៍អ៊ីហ្នឹងធ្វើទៅ។ តែមានទាហានយើងអត់ដឹងមុខសញ្ញាទាហានហ្នឹង វាច្រឡូកច្រឡបល់ដែរ វារញ៉ៃរញ៉ៃណាស់ យើងមិនដឹងថា អ្នកណាជាអ្នកណា។ ខ្ញុំវិសៗដែរហ្នឹង ខ្ញុំកម្មពារ។ ស៖ អ៊ីចឹងខ្ញុំមិនចង់ដឹងរឿងសកម្មភាពរញ៉ៃរញ៉ៃ ហើយលោកស្រីផ្តល់សកម្មភាពដល់សហករណ៍ ហើយសហករណ៍រៀបចំមនុស្សឲ្យស្រាវជ្រាវ។ តើលោកស្រីចង់និយាយអ៊ីចឹងឬ? ឆ.៦១៖ ចាស"]។

[3031] ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.៣-៥ KH 00872596-00872597។

[3032] ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.១៧ KH 00872599។ *សូមមើលផងដែរ* ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ឿន ដារ៉ា ឆ.៥៤ KH 00973951។

[3033] ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.១៧ KH 00872599។

[3034] ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.១៩ KH 00872599។

[3035] ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម, ឆ២០ KH 00872599។

[3036] ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.២១-២២ KH 00872599-00872600 ["ឆ.២១៖ មានប្រហែល ២០ ទៅ៣០នាក់ អ្នកចូលរួមការប្រជុំទាំងអស់ ជាប្រធានសហករណ៍។ គណៈស្រុកបាកានបានចូលរួមប្រជុំជាមួយថ្នាក់លើ ហើយបន្ទាប់មកពីប្រជុំជាមួយថ្នាក់លើ គណៈស្រុកបានផ្សព្វផ្សាយព័ត៌មានជាមួយប្រធានសហករណ៍។ ស៖ តើថ្នាក់លើ ដែល

839. បុគ្គលជាច្រើនបានរៀបរាប់អំពីការប្រជុំនានា នៅស្រុកបាកានដែលកម្មាភិបាលបានបញ្ជាក់លម្អិតអំពីផែនការបំផ្លាញខ្មែរក្រោម។ ហេង សៀង បានចូលរួមការប្រជុំទាំងនោះនៅសហករណ៍ស្រែងក្នុងឆ្នាំ ១៩៧៦ ឬ១៩៧៧ ដែលពិភាក្សាអំពីផែនការ "បោសសម្អាត" ខ្មែរក្រោម[3037]។ គាត់បានឮពីដំបូងអំពីផែនការនេះពីប្រធានសហករណ៍ស្រែង ដែលបានជូនដំណឹងបន្តទៅប្រធានតំបន់ ដើម្បីផ្សព្វផ្សាយនៅតាមអង្គប្រជុំដែលអ្នកចូលរួមត្រូវបានប្រាប់ថាបទបញ្ជានេះចេញមកពី "អង្គការ"[3038]។ សុខ ប៉ាន ដែលបានធ្វើការងារឲ្យ យាយ រីម ពីឆ្នាំ១៩៧៧ រហូតដល់ឆ្នាំ១៩៧៨[3039] បានឮ យាយ រីម ហៅខ្មែរក្រោមថា "ខ្ទាំងយួន" និងនិយាយថាថ្នាក់លើបានបញ្ជាឲ្យ "បោសសម្អាត" ខ្មែរក្រោមនៅក្នុងការប្រជុំមួយនៅចុងឆ្នាំ១៩៧៨[3040]។ ស្រដៀងនេះ ឡាម សារ៉ុន នីរសារ១របស់ យាយ រីម នៅស្រុកបាកាន[3041] បានឮថា យាយ រីម បានបញ្ជាឲ្យប្រធានសហករណ៍អនុវត្តផែនការ "សម្អាត និងកម្ទេច" ប្រជាជនខ្មែរក្រោមក្នុងឆ្នាំ១៩៧៨[3042]។

លោកនិយាយនោះ សំដៅលើអ្នកណា? ឆ.២២៖ សំដៅទៅលើថ្នាក់តំបន់ ដូចជា តា សារ៉ុន ដែលពេលនោះជាលេខតំបន់២ បានជួបប្រជុំជាមួយគណៈស្រុកនានារបស់តំបន់២"] ឆ.២៤-២៦ KH 00872600។

[3037] ឯកសារ D219/221 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.១១, ៦៤-៦៥, ៦៨, ៧៤ KH 01075673, 01075681, 01075682, 01075683។

[3038] ឯកសារ D219/221 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.៦៤, ៧០, ៧២ KH 01075682, 01075683។

[3039] ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៉ាន់ ឆ.៩, ១៤, ២០-២១ KH 01167519, 01167520។

[3040] ឯកសារ D219/587 កំណត់ហេតុស្តាប់ចម្លើយ សុខ ប៉ាន់ ឆ.១៣៣-១៣៧, ១៣៩, ១៤៣-១៤៧ KH 01167531, 01167532 ["ស៖ ម៉េចបានលោកស្រីដឹងថា គេមានផែនការ បោសសម្អាតខ្មែរក្រោមពីទឹកដីកម្ពុជាតើបងរ៉ីមមានដែលបាន ??និយាយអំពីរឿងនេះដែរ ឬទេ ឆ.១៣៣៖ ចាស។ គាត់និយាយថា ខ្ទាំងយួន គាត់មិនបានថា រ៉ៀតណាមទេ។ "ស៖ តើលោកស្រីមានបានឮបងរ៉ីមនិយាយថា "គេត្រូវបោសសម្អាតខ្មែរកម្ពុជាក្រោម" ដែរទេ? ឆ.១៣៤៖ ចាស ខ្ញុំឮ បោសសម្អាតឲ្យអស់ពីទឹកដីកម្ពុជា។ "ស៖ តើលោកស្រីឮបងរ៉ីមនិយាយបែបនេះនៅពេលណា? ឆ.១៣៥៖ ភ្លេចហើយ។ ស៖ តើបងរ៉ីមបាននិយាយអំពីរឿងនេះនៅក្នុងកិច្ចប្រជុំ ឬគាត់និយាយរឿងនេះជាមួយអ្នកដទៃ ឬគាត់ប្រាប់រឿងនេះមកលោកស្រីផ្ទាល់ ឬលោកស្រីស្តាប់ឮគាត់និយាយគ្នាដោយចៃដន្យ? ឆ.១៣៦៖ ខ្ញុំឮគាត់និយាយនៅក្នុងកិច្ចប្រជុំតែម្តង ឮថា បោសសម្អាតខ្ទាំងយួន។ "ស៖ តើកិច្ចប្រជុំនោះធ្វើឡើងនៅទីកន្លែងណា? ឆ.១៣៧៖ ប្រជុំនៅព្រៃតោ"]។

[3041] ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ុន ឆ.៤៦-៤៧ KH 01176410-01176411 ["ស៖ តើគេជ្រើសរើសលោកស្រីឲ្យនៅជាមួយយាយរ៉ីម ដោយរបៀបណា? ឆ.៤៦៖ រើសចេញពីកុមារមកឲ្យនៅធ្វើនិរសារគាត់។ ស៖ តើនរណាជាអ្នកជ្រើសរើសលោកស្រីឲ្យធ្វើនិរសារគាត់? ឆ.៤៧៖ គាត់ហ្នឹងតែម្តង ទៅជ្រើសរើសពីកន្លែងកុមារ"] ឆ.២២ KH 01176408 ។

[3042] ឯកសារ D219/611 កំណត់ហេតុស្តាប់ចម្លើយ ឡម សារ៉ុន ឆ.៨២-៨៥ KH 01176414-01176415 ["ស៖ តើលោកស្រីដែលឮនិយាយអំពីផែនការបោសសម្អាតខ្មែរកម្ពុជាក្រោមដែរទេ? ឆ.៨២៖ ឮគាត់និយាយផែនការបោសសម្អាត សម្លាប់មនុស្ស

840. ផាន ខន បានសារភាពអំពីការត្រួតពិនិត្យការសម្លាប់ខ្មែរក្រោមចំនួនជាង ១០០ នាក់ រួមបញ្ចូលស្ត្រី កុមារ និងទារក នៅសហករណ៍ស្រែងក្នុងចុងឆ្នាំ១៩៧៨។ គាត់បាននិយាយថា ការសម្លាប់រង្គាលនេះគឺតាមបញ្ជាដែលគេផ្តល់ទៅឲ្យគ្រប់សហករណ៍ដែលត្រូវបាន "បញ្ជូនបន្តពីម្នាក់ទៅម្នាក់ក្នុងឋានានុក្រម [ប.ក.ក]"[3043]។ មុនពេលមានការសម្លាប់នេះ ផាន ខម បានចូលរួមការប្រជុំមួយ ដែលធ្វើឡើងដោយ យាយ រីម ជាមួយប្រធានសហករណ៍ទាំងអស់ និងគណៈសមរភូមិនៅកោះរុន ឃុំខ្នារទទឹង ក្នុងខែឬម្ភុំខែសីហា ឆ្នាំ១៩៧៨[3044]។ ផាន ខន បានដឹងថា យាយ រីម ត្រូវបានតំបន់បញ្ជាឲ្យប្រមូលខ្មែរក្រោមនៅមួយកន្លែង និងថាហេតុដូច្នេះខ្មែរក្រោមពីគ្រប់សហករណ៍ត្រូវបានបញ្ជូនទៅខ្នារទទឹងដើម្បីអនុវត្តផែនការ "បោសសម្អាត"[3045]។ ខ្មែរក្រោមខ្លះក៏ត្រូវបានបញ្ជូនទៅសម្លាប់នៅសហករណ៍ស្រែង ហើយនៅពេលខ្មែរក្រោមត្រូវបានប្រទះឃើញ នៅតាមសហករណ៍ផ្សេងៗគ្នា "ពួកគាត់ត្រូវបានសម្លាប់នៅតាមសហករណ៍របស់ពួកគាត់រៀងៗខ្លួន"[3046]។

841. សាក្សីជាច្រើនបានផ្តល់សេចក្តីលម្អិតដ៏ស៊ីចង្វាក់អំពីផែនការសម្លាប់ប្រជាជនវៀតណាម និងខ្មែរក្រោម នៅតាមតំបន់នានានៃភូមិភាគពាយ័ព្យក្រោមការគ្រប់គ្រងរបស់ **យ៉ីម ទិព្ធ** និងសមាជិក

សម្រេចផែនការអ៊ីហ្ម៉ីង។ ស៖ តើយាយរ៉ីម និយាយអំពីរឿងនេះនៅឯកន្លែងណា នៅក្នុងកិច្ចប្រជុំណា ?ឆ.៨៣៖ នៅទីប្រជុំធំអ៊ីហ្ម៉ីង គាត់ដាក់ផែនការឲ្យប្រជាជនអ៊ីៗចឹងទៅ។ [...] ឆ.៨៤៖ ៧ មករា និយាយនៅទីកន្លែង ដូចកន្លែងណាធំដុំ បុណ្យ៧ មករាអ៊ីចឹង គាត់និយាយរ៉ាយរ៉ាប់ប្រាប់ប្រជាជនអ៊ីៗចឹងទៅ។ [...] ឆ.៨៥៖ ផែនការសម្រេច ដូចជា ផែនការដាក់សម្លាប់មនុស្សចោលហ្ម៉ីង គាត់ដាក់ហ្ម៉ីង ឲ្យសម្រេចអ៊ីៗចឹងទៅទាន់ពេលវេលា"] ឆ.៨៧-៩២ KH 01176415។ ម៉ី សារឿន ក៏បានចូលរួមប្រជុំផងដែរនៅស្រុកបាកាន នាពាក់កណ្តាលឆ្នាំ១៩៧៨ ដែលពេលនោះ យាយ រ៉ីម ផ្តែងថា "ពួកក្បត់ត្រូវតែបោសសម្អាត" និង "ត្រូវកម្ចាត់ឲ្យអស់" សូមមើល ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សារឿន ឆ.៦៨-៦៩ KH 00955755។

[3043] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១៥-១១៧, ១២១, ១២៣-១២៥, ១២៨, ១៣១ KH 01068143, 01068144-01068145។

[3044] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១១-១១២ KH 01068142 ["ស៖ ពាក់ព័ន្ធនឹងប្រជាជនកម្ពុជាក្រោម តើលោកបានដឹងអំពីផែនការក្នុងការបោសសម្អាតប្រជាជនខ្មែរក្រោមដែរឬទេ? ឆ.១១១៖ បាទ ខ្ញុំដឹង ព្រោះខ្ញុំត្រូវគេឲ្យចូលរួមប្រជុំនេះ។ ស៖ តើការប្រជុំអំពីផែនការបោសសម្អាតខ្មែរក្រោមនេះធ្វើឡើងនៅពេលណា? តើនៅកន្លែងណា? តើអ្នកណាជាប្រធានអង្គប្រជុំនៅពេលនោះ? ឆ.១១២៖ ខ្ញុំបានចូលរួមប្រជុំនៅកោះរុន ហើយគេនិយាយអំពីផែនការបោសសម្អាតខ្មែរក្រោមនេះ។ កិច្ចប្រជុំនេះធ្វើឡើងនៅឆ្នាំ១៩៧៨ ហើយមានគ្រប់មេសហករណ៍ គណៈសមរភូមិចូលរួមប្រជុំទាំងអស់។ យាយរ៉ីម ជាប្រធានអង្គប្រជុំនៅពេលនោះ"] ឆ.១១៤ KH 01068143។

[3045] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១២ KH 01068142។ *សូមមើលផងដែរ* ឯកសារ D219/793.1 ប្រតិចារ៉ឹករបស់រឿង *សត្រូវរបស់ប្រជាជន* ផលិតឆ្នាំ២០០៩ EN 01322984, 01322986។

[3046] ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.១១២ KH 01068142។

JCE ដទៃទៀតរួមមាន៖ ណាម អ៊ីនន[3047] ចាប ពុត[3048] កឹម ស្ងួ[3049] ខៀវ ផាន[3050] នឹម ឡុន[3051] យិន សោយ[3052] យ៉ាង សុខុម[3053] វ៉ន ឃឿ[3054] រ៉ឿន ដារ៉ា[3055] ว่าน ណេត[3056] និង ឯក (អ៊ីល) ហ៊ឿន[3057]។

[3047] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.៩២ KH 01000266 ឆ.៩៣ KH 01000266 ["នៅក្នុងការប្រជុំនោះ គណៈសហការណ៍និយាយអំពីបញ្ហាបង្ករបង្កើនផល ហើយក៏និយាយផងដែរថា "ពួកខ្មែរក្រោមនេះមិនគួរទុកទេ ព្រោះពួកគេជាពួកក្បាលយួន ខ្ជូនខ្មែរ"] ឆ.៩៥ KH 01000266 ឆ.៩៦ KH 01000266 ["ស៖ តើការប្រជុំនេះកើតឡើងមុន ឬក៏ក្រោយពេលដែលកម្មាភិបាលភូមិភាគនិរតីទោដល់តំបន់របស់លោក? ឆ.៩៦៖ ក្រោយកម្មាភិបាលពីភូមិភាគនិរតីមកដល់កន្លែងរបស់ខ្ញុំ"]។

[3048] ឯកសារ D219/921 កំណត់ហេតុស្តាប់ចម្លើយ ចាប ពុធ ឆ.១០២-១០៦ KH 01391801។

[3049] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួ ឆ.២៧ KH 00955710 ["ខ្ញុំក៏បានឮអំពីការសម្អាតគិញយួននេះដែរ"] ឆ.២៨-៣០ KH 00955710-00955711។ *សូមមើលផងដែរ* ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ងួ ឆ.៣៣-៣៥ KH 00955711។

[3050] ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ. ១១៤, ១១៦-១១៨ KH 01198097-01198098។

[3051] ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ នឹម លន ឆ.១៤, ៦២-៦៣, ៦៥ KH 01102917, 22, 23 ["ខ្ញុំដឹងតែថា អ្នកត្រូវគេយកទៅសម្លាប់នោះ មកពីខ្នារទទឹង។ បើតាមឃើញមនុស្សគេបណ្តើរទៅកន្លែងសម្លាប់ប្រហែលជា២០០ទៅ៣០០នាក់"] ឆ. ៧៥ KH 01102924 ["ស៖ តាមដែលលោកដឹង អ្នកណាជាអ្នករៀបចំ និងប្រតិបត្តិការសម្លាប់មនុស្សនេះ? ឆ. ៧៥៖ បើនិយាយឲ្យចំទៅ មានថ្នាក់លើ ដូចជា ថ្នាក់ស្រុក ថ្នាក់ខេត្ត ថ្នាក់តំបន់ ជាអ្នករៀបចំ ហើយគណៈសហការណ៍ដែលគេបញ្ជូនពីយោធាមក ឃ្លានដប់នាក់ជាអ្នកប្រតិបត្តិ"]។

[3052] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.១៥ KH 01097673 ["ពួកគាត់បាននិយាយភាគច្រើនទាក់ទងទៅនឹងការស្អប់យួន និងការបង្ករបង្កើនផលស្រូវ ដើម្បីទៅប្តូរយកអាវុធជាមួយនឹងប្រទេសចិន។ ពួកគាត់និយាយថា ស្អប់យួន ហើយប្រើគ្រប់មធ្យោបាយទាំងអស់ ដើម្បីដឹកឃ្ញសយួនឲ្យអស់។ កាលនោះ គេតែងនិយាយពាក្យថា នៅពេលកាប់ដើម ត្រូវដឹកឃ្ញសឲ្យអស់"]។

[3053] ឯកសារ D219/8 កំណត់ហេតុស្តាប់ចម្លើយ យង់ សុខុម ឆ.៧៩-៨១, ៨៩ KH 01025543, 01025544 ["ស៖ តើគេនិយាយអ្វីខ្លះពាក់ព័ន្ធនឹងខ្មែរកម្ពុជាក្រោម? ឆ.៨៩៖ គេនិយាយថា "មិនទុកចិត្តទៅលើខ្មែរកម្ពុជាក្រោមនោះទេ""] ឆ.៩៥ KH 01025544 ["ស៖ តើលោកស្រីធ្លាប់ឮបងរ៉ីម បងយ៉ាន បងរ៉េន និយាយថា "ពួកកម្ពុជាក្រោមភាគច្រើនជាអ្នកក្បត់ជាតិដែរ ឬទេ? ឆ.៩៥៖ ចាស បងរ៉ីម និងបងរ៉េន និយាយពាក្យទាំងអស់នេះ"] ឆ.៩៨-១០០ KH 01025545 ឆ.១០៤ KH 01025545 ["ពេលនោះ គេនិយាយថា "ពួកអ្នកកម្ពុជាក្រោមជាអ្នកក្បត់ជាតិ"] ឆ.១០៥ KH 01025545។ *សូមមើលផងដែរ* ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៧១ KH 00996460។

[3054] ឯកសារ D219/7 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ឃឿ ឆ.៥៦, ៧៥, ១០០-១០១, ១០៣-១០៥ KH 01025520, 01025522, 01025524, 01025525។

[3055] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ដារ៉ា ឆ.៥៤ KH 00973951។

៤. ការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ទៅលើប្រជាជនវៀតណាម និងខ្មែរក្រោម

ក. ការស្រាវជ្រាវរកប្រជាជនវៀតណាម និងខ្មែរក្រោម

842. ប.ក.ក បានប្រើប្រាស់វិធីសាស្ត្រជាច្រើនដើម្បីស្វែងរកប្រជាជនវៀតណាម និងខ្មែរក្រោមក្នុងចំណោមប្រជាជនទូទៅ[3058]។ នៅដើមរបបខ្មែរក្រហម នៅពេលស្រុកគិរីវង្សស្ថិតក្រោមការដឹកនាំរបស់ **យ៉ឹម ទិត្យ** កម្មាភិបាលបានកត់ប្រវត្តិរូបរបស់អ្នកភូមិទាំងអស់ មួយផ្នែក ដើម្បីកំណត់អត្តសញ្ញាណខ្មែរក្រោម[3059]។ ប.ក.ក ក៏បានស្វែងរកអ្នកណាដែលជាប្រជាជនវៀតណាម និងបានសម្គាប់ពួកគាត់ នៅពេលពួកវាបានរកឃើញ[3060]។ ក្រោយមក កម្មាភិបាលមូលដ្ឋានដូចជាប្រធានភូមិ បានធ្វើប្រវត្តិរូប និងបានប្រមូលឈ្មោះខ្មែរក្រោម ដែលត្រូវជម្លៀសដោយបង្ខំទៅស្រុកគិរីវង្ស[3061]។

843. នៅតំបន់១៣ ដែលគ្រប់គ្រងដោយ **យ៉ឹម ទិត្យ** និងសមាជិក JCE ដទៃទៀត កម្មាភិបាល "បានស្រាវជ្រាវ" និងបានចាប់ខ្លួនខ្មែរក្រោមនៅភូមិកោះអណ្តែត នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ[3062]។ ដូចគ្នានេះ នៅស្រុកត្រាំកក់ ប្រធានឃុំបានបង្កើតបញ្ជីឈ្មោះគ្រួសារខ្មែរក្រោម និងគ្រួសារវៀតណាម នៅតាមតំបន់របស់ពួកគាត់ និងបានរាយការណ៍ទៅថ្នាក់ស្រុក[3063]។ បុគ្គល

[3056] ឯកសារ D118/112 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ណាត់ ឆ.៣៨ KH 00963064។

[3057] ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ឿន ឆ.១៣៨-១៤៥ KH 00980116។

[3058] ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា៖ *របប ប៉ុល ពត ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍ នៅកម្ពុជាក្រោមដៃពួកខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩* EN 00678714។ *សូមមើលផងដែរ* ឯកសារ D347/2.1.25 ប្រតិចារឹក ព្រុំ សារុន ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 09.10.50-09.12.50។

[3059] ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ពិ ឆ.៤៣-៤៤, ៤៦-៤៨ KH 01112275-01112276។ ឯកសារ D118/305 កំណត់ហេតុស្តាប់ចម្លើយ តុប ផាន ឆ.៨០-៨៣ KH 01024604។

[3060] ឯកសារ D118/132 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន សុវណ្ណារី ឆ.៥៦-៥៧ KH 00960619។

[3061] ឯកសារ D219/98 កំណត់ហេតុស្តាប់ចម្លើយ ម៉ម ស្ង ឆ.៤៩ KH 01043262។ ឯកសារ D118/132 កំណត់ហេតុស្តាប់ចម្លើយ អ៊ុន សុវណ្ណារី ឆ.៤៩-៥១ KH 00950619។ ឯកសារ D118/233 កំណត់ហេតុស្តាប់ចម្លើយ ឡាច សែម ឆ.៨៧-៩០ KH 00987235-00987236។

[3062] ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.១៥ KH 01169864 ["ពួកគេ [ខ្មែរក្រោម] ត្រូវបានគេស្រាវជ្រាវចាប់ទុកនៅទីនោះតែម្តង"] ឆ.២០-២១ KH 01169864-01169865។

[3063] ឯកសារ D315.2.6 ប្រតិចារឹក រៀល សន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 11.13.37-11.17.12, 13.35.50-13.38។ ឯកសារ D347/2.1.4 សេចក្ដីរាយការណ៍បញ្ជាក់ពីផនធ្វើជូនអង្គការស្រុក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ EN 00742890

ទាំងឡាយត្រូវបានតម្រូវឲ្យធ្វើប្រវត្តិរូបដើម្បីបង្ហាញអតីតភាពរបស់ពួកគាត់[3064]។ ម៉ិច ញ៉ាញ់ និងសាច់ញាតិរបស់គាត់ ត្រូវបានគេពិនិត្យអតីតភាពរបស់ពួកគាត់ ចំពោះទំនាក់ទំនងជាមួយវៀតណាមនៅវត្តតាសេត ក្នុងស្រុកត្រាំកក់ ក្នុងឆ្នាំ ១៩៧៥[3065]។ រី ពៅ ក៏បាននិយាយលម្អិតអំពីវិធី ដែលកម្មាភិបាលនៅឃុំសំរោង ស្រុកត្រាំកក់ បានបញ្ជាឲ្យប្រជាជនបង្ហាញប្រវត្តិរូបក្នុងឆ្នាំ១៩៧៧ និងបន្ទាប់មកបានបែងចែកប្រជាជនជាក្រុម ដោយខ្មែរក្រោមត្រូវបានដាក់បញ្ចូលក្នុងក្រុម "យួន"[3066]។

844. ដូចនៅតំបន់១៣ ដែរ នៅពេលកម្មាភិបាលភូមិភាគនិរតីមកដល់ភូមិភាគពាយ័ព្យ ក្រោមការគ្រប់គ្រងរបស់ **យ៉ីម ទិព្យ** និងសមាជិក JCE ដទៃទៀត ពួកគេបានបង្កើតប្រវត្តិរូបដើម្បីកត់ត្រាអតីតភាពគ្រួសារ[3067]។ ជាឧទាហរណ៍ រ៉ឿន ដារា ដែលជាខ្មែរក្រោមរស់នៅស្រុកបាកានអំឡុង

["ប្រជាជនកម្ពុជាក្រោម និងប្រជាជនដែលយួនដូរមកមាន៦៤គ្រួសារ ចំនួនមនុស្សមានចំនួន២២៨នាក់"]។ ឯកសារ D6.1.1216 បញ្ជីប្រជាជនកម្ពុជាក្រោមដែលស្នាក់នៅឃុំអង្គតាសោម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ EN 00290262-00290263។ ឯកសារ D6.1.1210 បញ្ជីឈ្មោះអ្នកទោសដែលបានប្តូរក្នុងឃុំអង្គតាសោម EN 00290199-201។ ឯកសារ D65.1.52 បញ្ជីឈ្មោះប្រជាជនកម្ពុជាក្រោមក្នុងឃុំពពេល EN 00742626-00742628។ ឯកសារ D6.1.470 បញ្ជីឈ្មោះប្រជាជនកម្ពុជាក្រោមក្នុងឃុំគុស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៧ EN 00366665-00366675។ ឯកសារ D347/2.1.3 បញ្ជីឈ្មោះប្រជាជនដែលទើបមកពីស្រុកយួន [វៀតណាម] EN 00323977-00323978 [កំណត់អត្តសញ្ញាណគ្រួសារខ្មែរក្រោមក្នុងឃុំស្រែរនោង]។ ឯកសារ D6.1.262 របាយការណ៍ពីវៀតណាមនៅស្រុកត្រាំកក់ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៧៧។ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ីន ឆ.៤៧ KH 00980104។

[3064] ឯកសារ D6.1.676 កំណត់ហេតុស្តាប់ចម្លើយ ជាំង ស្រីមុំ ឆ.៤ KH 00402464 ["ប្រធានកងជាអ្នកធ្វើប្រវត្តិរូប។ គាត់មិនបានសួរសំណួរខ្ញុំ អំពីប្រវត្តិរបស់គ្រួសាររបស់យើងទេ គាត់ធ្វើប្រវត្តិរូប តាមការសង្កេតរបស់គាត់។ ខ្ញុំបានលួចមើលប្រវត្តិរូបរបស់គ្រួសារខ្ញុំ ដោយសារខ្ញុំនៅក្នុងកងកុមារ ហើយមេកងកុមារបានធ្វើប្រវត្តិរូបខ្ញុំ ដោយផ្អែកលើប្រវត្តិរូបដែលប្រធានកងបានធ្វើ"]។ ឯកសារ D6.1.703 កំណត់ហេតុស្តាប់ចម្លើយ ប៊ិន ហេង ឆ.១ KH 00418433។

[3065] ឯកសារ D219/16 កំណត់ហេតុស្តាប់ចម្លើយ ម៉ិច ញ៉ាញ់ ឆ.២៥-២៨ KH 01027382។

[3066] ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ឆ.៥០ KH 00960588 ["ខ្មែរក្រហមបានឲ្យយើងធ្វើប្រវត្តិរូប ហើយធ្វើការបែងចែកប្រជាជនជាយួន អ្នក១៧មេសា អ្នកបញ្ញើ អ្នកមូលដ្ឋាន អ្នកត្រៀម ហើយយើងត្រូវបានគេចោទជាយួន"] ឆ.៥៣ KH 00960588 ["ស៖ តើណោកត្រូវគេសួរចម្លើយ ឬក៏ឲ្យធ្វើប្រវត្តិរូបដែរ ឬទេ? ឆ.៥៣៖ គេមិនបានឲ្យយើងធ្វើប្រវត្តិរូបនោះទេ ប៉ុន្តែគេហៅថា យើងថា "អាយួន! អាគិញយួន!" ហើយគេមិនទុកចិត្តយើងទេ។ នៅកន្លែងនោះខ្ញុំខ្មែរក្រហមបានឲ្យប្រជាជនកម្ពុជាក្រោមនៅដោយឡែកពីប្រជាជន ដែលគេទុកចិត្ត"] ឆ.៣៧ KH 00960587 ["ខ្ញុំនៅឃុំសំរោងរហូតដល់ចប់របបនេះ"]។ សូមមើលផងដែរ ឯកសារ D347.4 បទសម្ភាសន៍ជាមួយបងស្រី ផាត់ សមុទ្រ ដោយ គឹម កែវកន្ទ្ធិដ្ឋា EN 01413675។

[3067] ឯកសារ D219/733 កំណត់ហេតុស្តាប់ចម្លើយ គឹម ផែន ឆ.៧១-៧៤ KH 01218103-01218104។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.៤២, ៥១ KH 00977065, 00977066។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក ឃីន ឆ.៣៤-៣៦ KH 00955698។ ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៨២, ៨៧ KH 00955736,

របបកម្ពុជាប្រជាធិបតេយ្យ បាននិយាយថា ប.ក.ក បានស្រាវជ្រាវអតីតភាពរបស់ខ្មែរក្រោមនៅស្រុកបាកាន ក្រោយពាក់កណ្តាលឆ្នាំ១៩៧៧[3068]។ នៅពេល រ៉ន ម៉ុច ត្រូវបានតម្រូវឲ្យធ្វើប្រវត្តិរូបនៅឃុំរំលេច គាត់បានប្រាប់ថា ប្រពន្ធរបស់គាត់ជាខ្មែរក្រោម[3069]។ បន្ទាប់មកប្រពន្ធ និងកូនៗរបស់គាត់ត្រូវបានយកចេញទៅ និងមិនដែលបានវិលត្រឡប់មកវិញឡើយ[3070]។ ឈួន ហៃ ក៏បាននិយាយថា ប.ក.ក បានយកគ្រួសារជាច្រើនចេញទៅនៅរំលេច និងឃុំខ្នារទទឹង ដោយផ្អែកលើប្រវត្តិរូបរបស់ពួកគាត់[3071]។

845. ប្រធានថ្នាក់ក្រោមមានតួនាទីសំខាន់ក្នុងការស្រាវជ្រាវរកខ្មែរក្រោម[3072] និងហេតុដូច្នេះបានសម្របសម្រួលផែនការសមាជិក JCE ដើម្បីបំផ្លាញប្រជាជនវៀតណាម។ ប្រធានសហករណ៍ និងប្រធានឃុំ ត្រូវបានតម្រូវឲ្យធ្វើប្រវត្តិរូប និងប្រមូលព័ត៌មានអំពីខ្មែរក្រោមក្នុងតំបន់របស់ពួកគាត់[3073]។ វិធីសាស្ត្រកំណត់អត្តសញ្ញាណបែបនេះបានអនុញ្ញាតឲ្យ ប.ក.ក ងាយស្រួលបំបែកខ្មែរក្រោម ចូលទៅតាមអង្គភាពនានាដែលផ្តាច់ចេញពីប្រជាជនទូទៅ និងជម្លៀសពួកគាត់ទៅទីតាំងនានាដូចជាខ្នារទទឹងដើម្បីសម្លាប់[3074]។

00955737។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៣៧ KH 00955711-00955712។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៣៩ KH 00955683។

3068 ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.២៥-២៧ KH 00973947-00973948។

3069 ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ រ៉ន ម៉ុច ឆ.៥៤-៥៥ KH 00977097។

3070 ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ រ៉ន ម៉ុច ឆ.៥៧-៥៩ KH 00977098។

3071 ឯកសារ D219/692 កំណត់ហេតុស្តាប់ចម្លើយ ឈួន ហៃ ឆ.៥៦ KH 01205256 ["ស៖ តើលោកស្រីដឹងទេ តើមានខ្មែរក្រោមប៉ុន្មានគ្រួសាររស់នៅសហករណ៍របស់លោកស្រី? ឆ.៥៦៖ អត់មានទេ គេស្រាវជ្រាវតាមប្រវត្តិរូបយកអស់"]។

3072 ឯកសារ D347/2.1.24 ប្រតិចារ៉ឹក ព្រ៉ុ សារុន ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 13.45.34-13.50.19។ *សូមមើលផងដែរ* ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា៖ *របប ប៉ុល ពត ពួជសាសន៍ អំណាច និងអំពើប្រល័យពួជសាសន៍ នៅកម្ពុជាក្រោមដែពួកខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩* EN 00678650។ ឯកសារ D1.3.17.1 សៀវភៅនិពន្ធដោយ Elizabeth Becker មានចំណងជើងថា៖ *នៅពេលដែលសង្គ្រាមរលត់ទៅ* EN 00237947។

3073 ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធួន ឆ.២៦ KH 00955766។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ រ៉ន ចូក ឆ.៤៩ KH 00973925។

3074 ឯកសារ D118/126 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សារ៉ឿន ឆ.៤៦ KH 00955753។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.២៥ KH 00973947។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ រ៉ន ចូក ឆ.៤៨ KH 00973925។ ឯកសារ D219/676 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុក សារិន ឆ.៦៥-៦៦, ៧៨, ៨០-៨១, ៨៥, ១០២-១០៣, ១១០ KH 01202402, 04, 05, 08, 10។

846. នៅពេលដែលគ្រោះថ្នាក់មានភាពច្បាស់លាស់ ខ្មែរក្រោមខ្លះបានលាក់អតីតភាពរបស់ពួកគាត់ដើម្បីបិទបាំងដើមកំណើតខ្មែរក្រោម[3075]។ ខ្មែរក្រោមខ្លះបានរស់រានពីស្លាប់ដោយការប្តូរឈ្មោះ[3076] ឬការបិទបាំងកេរដំណែល និងអត្តសញ្ញាណខ្មែរក្រោមរបស់ពួកគាត់នៅពេល ប.ក.ក ស្រាវជ្រាវរកមនុស្ស[3077]។ ក្នុងឆ្នាំ១៩៧៧ គីម សូ ដែលជាខ្មែរក្រោម ត្រូវបានជួយក្នុងអំឡុងពេលធ្វើប្រវត្តិរូបដោយអនុប្រធានគុកភូមិវាល ដែលបានប្រាប់ គីម សូ ឲ្យធ្វើពុតថាគាត់ជាស្ថិតក្នុងចំណោមកូនៗរបស់អនុប្រធានរូបនេះ[3078]។ ស្រដៀងនេះ ប៉ាន សាមុត ត្រូវបានព្រមានដោយមនុស្សដទៃក្នុងកងចល័តរបស់គាត់នៅស្រុកបាកានក្នុងឆ្នាំ១៩៧៨ ឲ្យ "និយាយខ្មែរលើឲ្យច្បាស់ និងមិនឲ្យនិយាយសំនៀងខ្មែរក្រោម។ បើមិនដូច្នេះ ពួកគាត់នឹងស្គាល់យើងថាជាខ្មែរក្រោម"[3079]។ យោងតាម ពៅ ស៊ីន្ធន ដែលបានរស់នៅរំលេចក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានស្តាប់យ៉ាងប្រុងប្រយ័ត្ន ទ្ធវសម្ដីរបស់ប្រជាជនដើម្បីកំណត់អតីតភាពរបស់ពួកគាត់[3080]។ ការត្រូវបានកំណត់អត្តសញ្ញាណជាខ្មែរ ជំនួសឲ្យខ្មែរក្រោម អាចជួយជីវិត។ ជាឧទាហរណ៍ វ៉ិន ឃឿ ដែលជានីរសាររបស់គណៈស្រុកបាកាន ត្រូវបានចោទថាជា "កូនកាត់ឃ្លួន" និងត្រូវបានបង្ខំឲ្យជីករណ្ដៅសាកសពទុកកប់ខ្លួន

[3075] ឯកសារ D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.២៤-២៥ KH 00960559 ["ឆ.២៤៖ នៅពេលនោះ ខ្ញុំបានលាក់ប្រវត្តិរបស់ខ្ញុំ ហេតុដូច្នេះហើយគេមិនដឹងថា ខ្ញុំជាខ្មែរក្រោមនោះទេ ដូច្នេះហើយទើបខ្ញុំត្រូវបានគេដាក់ឲ្យនៅសហករណ៍ជាមួយនឹងខ្មែរផ្សេងៗទៀត។ ខ្ញុំបានដូរឈ្មោះទៅជា ន១ នី។ ស៖ នៅពេលដែលលោកនៅស្រុកមោងឫស្សី តើមានការធ្វើទុក្ខបុកម្នេញទៅលើខ្មែរក្រោមដែរ ឬទេ? ឆ.២៥៖ ពេលនោះ ខ្ញុំបានលាក់ប្រវត្តិរូបរបស់ខ្ញុំ ដូច្នេះ គេមិនដឹងទេ។ ពួកយើង ទៅធ្វើការ និងហូបចុកដូចគ្នា"]។ ឯកសារ D118/133 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឆ.៩៧ KH 00960639 ["បាទ ខ្ញុំមិនដឹងទេ។ បើទោះបីជាដឹង ក៏គាត់លាក់ឈ្មោះដែរ ទោះបីជាគាត់កម្ពុជាក្រោម ក៏គាត់ប្រាប់ថាជាខ្មែរដែរ"]។

[3076] ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.៤៥ KH 01198090។

[3077] ឯកសារ D118/258 កំណត់ហេតុស្តាប់ចម្លើយ រស់ ហ៊ីម ឆ.៥១, ៥៤-៥៥ KH 00996477-00996478។ ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៧៨ KH 01032228។ ឯកសារ D219/729 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន សាមុត ឆ.១២៦ KH 01214611។

[3078] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គីម សូរ ឆ.៣៧ KH 00955711-00955712។

[3079] ឯកសារ D219/729 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន សាមុត ឆ.១២៤-១២៥ KH 01214611។ *សូមមើលផងដែរ* ឯកសារ D219/276 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម ង៉ុយ ឆ.៦២ KH 01088946 ["នៅរោងដែកខ្ញុំ ក៏មានខ្មែរក្រោមផងដែរ។ ខ្ញុំចេះតែជួយលាក់គាត់ទៅ បង្ហាត់គាត់និយាយភាសាខ្មែរឲ្យច្បាស់"]។

[3080] ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.២៤-២៥ KH 00955766។

ឯង[3081]។ លេខាស្រុកបាកាន ឃាយ រ៉ែម បានជួយជីវិត រ៉ែន ឃ្យៀ ដោយបាននិយាយថា "គាត់មិនមែនយួនទេ! ឪពុកម្តាយរបស់គាត់ស្បែកខ្មៅ"[3082]។

៥. ឧក្រិដ្ឋកម្មប្រឆាំងប្រជាជនវៀតណាមនៅភូមិភាគនិរតី

847. **យ៉ីម ទិត្យ** ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ខ្មែរក្រោម នៅតាមទីតាំងឧក្រិដ្ឋកម្មដូចខាងក្រោមនៅតំបន់ ១៣៖ វត្តព្រះធាតុ ក្រាំងតាចាន់ វត្តអង្គញ្ជ ១ វត្តអង្គសិរីមុន្នី និងព្រៃសុខន ភូមិស្ពែង និងភូមិព្រាល[3083]។ ស.ព.អ ព្យាយាមចោទប្រកាន់ **យ៉ីម ទិត្យ** ពីបទប្រល័យពូជសាសន៍ នៅតាមទីតាំងទាំងអស់នេះ និងបន្ថែមពីលើនេះ ស្នើសុំចោទប្រកាន់ **យ៉ីម ទិត្យ** ពីបទប្រល័យពូជសាសន៍ទៅលើប្រជាជនវៀតណាម រួមបញ្ចូលខ្មែរក្រោម នៅតាមទីតាំងផ្សេងៗនៅស្រុកគិរីវង្ស ស្រុកត្រាំកក់ និងស្រុកកោះអណ្តែត (បញ្ជាក់លម្អិតខាងក្រោម) ដែល ស.ច.ស ត្រូវបានប្តឹងឲ្យពិនិត្យ និងចាត់ការ[3084]។

ក. ការនិរទេសប្រជាជនវៀតណាម ពីកម្ពុជា ទៅវៀតណាម និងខ្មែរក្រោមពីវៀតណាមទៅកម្ពុជានៅឆ្នាំ១៩៧៥-១៩៧៧

848. នៅដើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ ប.ក.ក បានបញ្ជូនប្រជាជនវៀតណាមដែលរស់នៅកម្ពុជា ត្រឡប់ទៅវៀតណាមវិញ ដើម្បីដួរយកខ្មែរក្រោមដែលរស់នៅលើទឹកដីវៀតណាម[3085]។

[3081] ឯកសារ D219/7 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន ឃ្យៀ ឆ.១១៩ KH 01025526។

[3082] ឯកសារ D219/7 កំណត់ហេតុ ស្តាប់ចម្លើយ រ៉ែន ឃ្យៀ ឆ.១១៩ KH 01025526។

[3083] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ EN 01426068។

[3084] ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ KH 00728927-00728930 កថាខណ្ឌ១១-១៥។

[3085] ឯកសារ D118/269 កំណត់ហេតុស្តាប់ចម្លើយ ថាន់ ធីម ឆ.៥៥ KH 00998115 ["ខ្ញុំក៏ដឹងថា ពួកខ្មែរក្រហម យកជនជាតិយួន ទៅប្តូរយកខ្មែរក្រោមដែរ"]។ ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រ៉ី ពៅ ឆ.៨ KH 00960584 ["ខ្មែរក្រហមបានយកវៀតណាមពីលើទៅ ដើម្បីដួរយកកម្ពុជាក្រោមត្រឡប់មកកម្ពុជាវិញ"]។ ឯកសារ D219/111 កំណត់ហេតុ ស្តាប់ចម្លើយ ម៉ៅ ឆោម ឆ.១១២-១១៤ KH 01045279។ ឯកសារ D5/49/3 ប្រតិចារឹក តាក សាន់ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ម៉ោង 13.12.57-13.15.33 ["នាងខ្ញុំចេញពីកម្ពុជាក្រោម ដោយដួរយួនហ្ម៉ង"]។ ឯកសារ D5/49/3.1 ប្រតិចារឹក បេង ហ្ម៉ីន ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ ម៉ោង 14.40.35-14.43.53 ["ហើយក៏ពេលនោះ គេថា អង្គការនឹងបញ្ជូនបងប្អូនវៀតណាមទៅ

ចៅ នី ស្ថិតនៅព្រំដែនវៀតណាម នៅពេលគាត់បានឮវិទ្យុប្រកាសក្នុងឆ្នាំ១៩៧៥ ថាប្រជាជនវៀតណាមត្រូវត្រឡប់ទៅវៀតណាម ហើយខ្មែរក្រោមត្រូវវិលត្រឡប់មកកម្ពុជា[3086]។ ប្រជាជនវៀតណាមចំនួនប្រហែល១៥០.000 នាក់ ត្រូវបាននិរទេសទៅវៀតណាម នៅឆ្នាំដំបូងនៃរបបនេះ[3087]។

849. ហេតុការណ៍ទាំងនេះស្ថិតក្នុងតំបន់១៣ ពិសេសនៅស្រុកគិរីវង្ស និងត្រាំកក់ដែល **យ៉ីម ទិញ** បានអនុវត្តសិទ្ធិអំណាចទាំងនៅថ្នាក់ស្រុក និងថ្នាក់តំបន់។ សាន់ ឡន ដែលជាបងប្អូនសាច់ផ្ទៃរបស់គា ម៉ុក[3088] បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ ថាវាជាគោលនយោបាយរបស់ខ្មែរក្រហមក្នុងការប្រមូលផ្តុំ និងនិរទេសប្រជាជនវៀតណាមក្នុងឆ្នាំ១៩៧៥[3089] និងថា "ប្រជាជនវៀតណាមមួយចំនួនធំត្រូវបានប្រមូលផ្តុំ និងនិរទេសត្រឡប់ទៅវៀតណាម" នៅស្រុកត្រាំកក់ក្នុងដើមដំបូងនៃរបប

ស្រុកវិញ មិនឮថា ផ្លាស់ប្តូរទេ"]។ ឯកសារ D315.1.19 ប្រតិចារឹក ថាន់ ធីម ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៥ ម៉ោង 09.36.50-09.39.15 ["មានការដោះដូរជនជាតិវៀតណាមជាមួយនឹងខ្មែរមែន"]។ ឯកសារ D315.1.20 ប្រតិចារឹក ឯក (អ៊ីល) ហ្ស៊ីន ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.13.39 ["ចាប់ពី៧៦ឡើងទៅ គឺមានផែនការៗដោះដូរខ្មែរ ដែលរត់ទៅស្រុកយួន ដូរយកខ្មែរពីស្រុកយួន មកដូរយួននៅស្រុកខ្មែរ ទៅស្រុកយួន"]។ ឯកសារ D315.1.4 ប្រតិចារឹក រ៉ី ពៅ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.12.53-09.14.21 ["ខ្ញុំបានទៅរស់នៅប្រទេសវៀតណាម។ លុះដល់ខែ០២ ឆ្នាំ១៩៧៦ ត្រូវបានដូរវៀតណាម ជាផ្ទួរជាមួយវៀតណាមមករស់នៅកម្ពុជាវិញ"]។ ឯកសារ D6.1.676 កំណត់ហេតុស្តាប់ចម្លើយ ជាំង ស្រីមុំ ឆ.១៤ KH 00402468 ។ ឯកសារ D347/2.1.4 សេចក្តីរាយការណ៍ពីផនគោរពជូនស្រុកត្រាំកក់ ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ KH 00079090 ["ប្រជាជនកម្ពុជាក្រោម និងប្រជាជនដែលយួនដូរមកមាន៦៤គ្រួសារ ចំនួនមនុស្សមានចំនួន២២៨នាក់"]។

[3086] ឯកសារ D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.២៧-២៨ KH 00960559 ["ស៖ លោកបាននិយាយថា "មានការប្រកាសតាមវិទ្យុរបស់ខ្មែរក្រហម អំពីគោលនយោបាយប្រឆាំងនឹងវៀតណាម និងខ្មែរក្រោម។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានប្រកាសថា វៀតណាមត្រូវត្រឡប់ទៅវៀតណាមវិញ ចំណែកខ្មែរក្រោមត្រឡប់មកកម្ពុជាវិញ"។ តើត្រឹមត្រូវដែរឬទេ? ឆ.២៧៖ បាទ ត្រឹមត្រូវ ប៉ុន្តែជាអ្វីដែលខ្ញុំបានឮតែប៉ុណ្ណោះ។ ស៖ តើលោកបានឮការប្រកាសនេះដោយផ្ទាល់ ឬក៏យ៉ាងណា? ឆ.២៨៖ ខ្ញុំមិនបានឮដោយផ្ទាល់នោះទេ គឺឮតាមតៗគ្នាប៉ុណ្ណោះ"]។ ឯកសារ D65.1.7 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ចៅ នី EN 00596048។

[3087] ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា៖ *របប ប៉ុល ពត ពួជសាសន៍ អំណាច និងអំពើប្រល័យពួជសាសន៍ នៅកម្ពុជាក្រោមដៃពួកខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩* EN 00678522 EN 00678524 EN 00678548។ ឯកសារ D6.1.518 កំណត់ហេតុស្តាប់ចម្លើយ សៅ សារុន EN 00348375។

[3088] ឯកសារ D219/974.1.1 ប្រតិចារឹក សាន់ ឡន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.26.10-09.29.28។

[3089] ឯកសារ D219/974.1.1 ប្រតិចារឹក សាន់ ឡន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ម៉ោង 14.24.24-14.25.06 ["ស. អ៊ីចឹងគោលនយោបាយខ្មែរក្រហមឲ្យប្រមូលប្រជាជនវៀតណាម គឺនៅប្រហែលជាក្រោយឆ្នាំ៧៥ អ៊ីចឹងមែនទេ? ឆ. បាទ ហ្នឹងៗ"]។ *សូមមើលផងដែរ* ឯកសារ D118/102 កំណត់ហេតុស្តាប់ចម្លើយ ទាត់ ធ្ងៀន ឆ.១៦៥ KH 00947607។

កម្ពុជាប្រជាធិបតេយ្យ[3090]។ បន្ទាប់ពីនោះ គាត់ត្រូវបានគណៈស្រុកត្រាំកក់ឲ្យប្រមូលប្រជាជនវៀតណាមរាប់ពាន់នាក់ពីបណ្តាឃុំនានា ក្នុងស្រុកនេះដើម្បីបញ្ជូនទៅវៀតណាម[3091]។

850. ចៅ នី បានពិពណ៌នាអំពីការប្តូរចំនួន៣ នូវប្រជាជនវៀតណាម ដែលរស់នៅកម្ពុជា យកខ្មែរក្រោមពីវៀតណាម។ ទីមួយ ខ្មែរក្រោមត្រូវបានបញ្ជូនពីកម្ពុជាក្រោម ទៅស្រុកគិរីវង្សក្នុងខែមករា ឆ្នាំ១៩៧៦[3092]។ ចៅ នី បានជឿថាខ្មែរក្រោមទាំងនេះ បន្ទាប់មកត្រូវបាននាំយកទៅមន្ទីរសន្តិសុខក្រាំងតាចាន់ក្នុងស្រុកត្រាំកក់[3093]។ ការប្តូរលើកទីពីរបានកើតឡើងនៅខែកុម្ភៈ ឆ្នាំ១៩៧៦ និងលើកទីបីនៅខែមីនា ឬខែមេសា ឆ្នាំ១៩៧៦[3094]។ ចៅ នី បាននិយាយថា ខ្មែរក្រោមចំនួនប្រហែល ៨០០នាក់ ដែលត្រូវបាននាំយកចូលមកក្នុងការប្តូរលើកទីបីនេះ ត្រូវបានសម្លាប់នៅឃុំសោម ស្រុកគិរីវង្ស[3095]។

851. ក្នុងខែមិថុនា ឆ្នាំ១៩៧៦ រី ពៅ បានកំពុងរស់នៅកម្ពុជាក្រោម និងត្រូវបានបញ្ជូនជាមួយគ្រួសារខ្មែរក្រោមដទៃតាមរថយន្តយោធាពីវៀតណាម ទៅខ្ពក្ត្របែក និងឃុំសំរោងនៅស្រុកត្រាំកក់[3096]។

[3090] ឯកសារ D219/974.1.1 ប្រតិចារឹក សាន់ ឡន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ម៉ោង 09.53.41-09.56.38 ["ការបញ្ជូនប្រជាជនវៀតណាមទៅវៀតណាមវិញនេះ គឺក្នុង ក្រោយឆ្នាំ១៩៧៥ ហ្នឹងតាមខ្ញុំបានដឹង"] ម៉ោង 09.56.38-09.58.14។

[3091] ឯកសារ D219/974.1.1 ប្រតិចារឹក សាន់ ឡន ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ម៉ោង 10.44.25-10.46.57, 10.48.40-10.52.08។

[3092] ឯកសារ D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.២៩ KH 00960560 ["ការដោះដូរលើកទី១ នៅខែមករា ឆ្នាំ១៩៧៦។ ឡានខ្មែរក្រហមបានដឹកវៀតណាមដាក់នៅត្រឹមភ្នំដិន"]។

[3093] ឯកសារ D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.២៩ KH 00960560 ["ឡានខ្មែរក្រហមបានដឹកវៀតណាមដាក់នៅត្រឹមភ្នំដិន ដោយចាំទទួលខ្មែរក្រោមពីភ្នំដិនត្រឡប់ទៅវិញ។ ហើយខ្មែរក្រោមទាំងនោះត្រូវបានបញ្ជូនទៅរស់នៅក្រាំងតាចាន់ ស្រុកត្រាំកក់"]។

[3094] ឯកសារ D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.២៩ KH 00960560 ["ការដោះដូរលើកទី២ នៅខែកុម្ភៈ ឆ្នាំ១៩៧៦។ ការដោះដូរលើកទី៣ ប្រហែលជាខែមីនា ឬមេសា ឆ្នាំ១៩៧៦"]។

[3095] ឯកសារ D118/128 កំណត់ហេតុស្តាប់ចម្លើយ ចៅ នី ឆ.២៩ KH 00960560 ["គេបានយកអ្នកទាំងនោះយកទៅសម្លាប់នៅឃុំសោម ស្រុកគីរីវង់។ ខ្មែរក្រោមដែលត្រូវបានយកទៅសម្លាប់នៅពេលដោះដូរលើកទី៣ មានប្រហែល ៨០០នាក់។ ក្រោយពីដឹងថា មានការសម្លាប់ទៅលើខ្មែរក្រោមក្នុងការដោះដូរលើកទី៣ ទើបគេបញ្ឈប់លែងឲ្យមានការដោះដូរ"]។

[3096] ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ឆ.២១-២២ KH 00960585 ["ស៖ តើខ្មែរក្រោមទាំងនោះត្រូវបានគេអនុញ្ញាតឲ្យយកឥវ៉ាន់ទៅជាមួយដែរឬទេ? ហើយចំពោះផ្ទះសម្បែងវិញដូចម្តេចដែរ? ឆ.២១៖ យើងបានចាកចេញចោលផ្ទះសម្បែងរបស់យើង គឺគ្រាន់តែយករបស់របរមានតម្លៃ ដូចជា មាសខ្លះទៅជាមួយយើងប៉ុណ្ណោះ។ នៅពេលដែលយើងទៅដល់ខ្ពបត្របែក ខ្មែរក្រហមបានដកហូតរបស់របរទាំងនោះពីយើងទាំងអស់។ ក្រោមមកខ្ញុំត្រូវបំបែកចេញពីឪពុកម្តាយរបស់ខ្ញុំ ហើយគេបញ្ជូនឪពុកម្តាយខ្ញុំទៅធ្វើការកន្លែងផ្សេង ចំណែកខ្ញុំធ្វើការនៅក្នុងកងយុវជន។ ពេលនោះ ខ្មែរក្រហមបាននិយាយថា "កុំឲ្យបង

គាត់បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង០០២ ថាមនុស្សចំនួនប្រហែល១៥០០ គ្រួសារ ដែលមានចំនួនរាប់ពាន់នាក់ ត្រូវបានប្រមូលផ្តុំដើម្បីវិលត្រឡប់ទៅកម្ពុជា[3097]។ ចំនួនប្រជាជនវៀតណាមដូចគ្នានេះត្រូវបានបញ្ជូនទៅវៀតណាម ពីត្រាំកក់ និងទីកន្លែងផ្សេងទៀតក្រោមការប្តូរប្រជាជនគ្នានេះ[3098]។ ក្រុមខ្មែរក្រោមមួយទៀតត្រូវបានប្តូរជាមួយប្រជាជនវៀតណាមមួយខែក្រោយ និងត្រូវបានបញ្ជូនទៅឃុំពពិល និងឃុំតាភឹមនៅស្រុកត្រាំកក់[3099]។ ឡាច សែម ក៏បានពិពណ៌នាអំពីវិធីដែលអ្នកភូមិវៀតណាមពីភូមិសោម ត្រូវបានបញ្ជូនទៅវៀតណាម និងខ្មែរក្រោមដែលពីមុនបានភៀសខ្លួនទៅវៀតណាម ត្រូវបានបញ្ជូនត្រឡប់ទៅភូមិសោម[3100]។

ប្អូនយើងព្រួយបារម្ភអី ទ្រព្យសម្បត្តិនៅទីនេះមិនចាយទេ ហើយអង្គការនឹងចិញ្ចឹមបងប្អូន"។ ស៖ តើមានអ្វីកើតឡើងចំពោះអត្តសញ្ញាណប័ណ្ណរបស់លោក? ឆ.២២៖ ពេលនោះ ខ្ញុំមិនទាន់មានអត្តសញ្ញាណប័ណ្ណទេ។ ចំពោះឪពុកម្តាយរបស់ខ្ញុំត្រូវបានខ្មែរក្រហមដកហូតយកកាតអត្តសញ្ញាណប័ណ្ណនោះដុតចោលទាំងអស់"] ឆ.៨-១៦, ៨១ KH 00960584 KH 00960592។

[3097] ឯកសារ D315.1.4 ប្រតិចារឹក រី ពៅ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 09.27.33-09.29.12 ["ខ្ញុំដឹងចំនួនប្រជាពលរដ្ឋដែលចុះភៀសខ្លួនទៅនៅប្រទេសវៀតណាម គឺនៅក្នុងភូមិហ្នឹង មានប្រជាពលរដ្ឋចំនួន១០០០គ្រួសារ គេដាក់ប្រមូលផ្តុំមួយកន្លែងងាយស្រួល។ [...] ខ្ញុំដឹងថា នៅក្នុងបួកហ្នឹង វាមានប្រហែលជា១០០០គ្រួសារទៅ១៥០០គ្រួសារ។ ឡើងមក វាចន្លោះពេលហ្នឹង វាឡើងមក គេបែងចែកជាបីដង។ អ៊ីចឹង ពេលឡើងមកសាមុនហ្នឹង គឺច្រើន សាក្រោយៗទៀតខ្ញុំឡើងមកហួសហើយ មិនដឹងគេទៅដឹកប៉ុន្ឌានទេ ប៉ុន្តែប៉ុន្ឌានដងទៀតទេ ប៉ុន្តែពេលនោះ គេប្រាប់ថា យើងទៅមួយវគ្គអ៊ីចឹង ហើយខ្ញុំមកមុនគេ មកវគ្គទី១"]។

[3098] ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ឆ.១២, ១៤ KH 00960584។ សូមមើលផងដែរ ឯកសារកម្ពុជាប្រជាធិបតេយ្យដែលនៅសេសសល់ ពាក់ព័ន្ធនឹងប្រជាជនមកពីវៀតណាម ដែលបញ្ជូនទៅឃុំផ្សេងៗគ្នាក្នុងស្រុកត្រាំកក់ បន្ទាប់ពីការដោះដូរ ដែលអាចបំភ្លឺបន្ថែមទៅលើចំនួន ដោយសារថា គឺត្រូវមានចំនួនដូចគ្នានេះដែរ ដែលត្រូវបញ្ជូនចេញពីកម្ពុជាប្រជាធិបតេយ្យ។ ឯកសារ D347/2.1.4 សេចក្តីរាយការណ៍បញ្ជាក់ពីផន ផ្ញើជូនអង្គការស្រុក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ EN 00742890 ["ប្រជាជនកម្ពុជាក្រោម និងប្រជាជនដែលយួនដូរមកមាន៦៤គ្រួសារ ចំនួនមនុស្សមានចំនួន២២៨នាក់"]។ ឯកសារ D347/2.1.3 បញ្ជីឈ្មោះអ្នកដែលទើបយកពីស្រុកយួន [វៀតណាម] ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ EN 00323977-78 [បញ្ជីឈ្មោះខ្មែរក្រោម១៨គ្រួសារ ក្នុងឃុំជាងទង]។

[3099] ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រី ពៅ ឆ.៨១-៨២ KH 00960592។ សម្រាប់ការដោះដូរខ្មែរក្រោមជាមួយនឹងវៀតណាម *សូមមើលផងដែរ* ឯកសារ D347/2.1.4 សេចក្តីរាយការណ៍បញ្ជាក់ពីផនផ្ញើជូនអង្គការស្រុក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ EN 00742890។

[3204] ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រៀល សន ឆ.១១៧ KH 00975634 ["មានរោងវែងមួយ ហើយមានរោងតូចមួយ ដែលរោងទាំងពីរនេះបិទជិត។ ខ្ញុំមិនដឹងថា អ្នកទោសត្រូវដេករបៀបណានោះទេ ប្រហែលជាដេកនៅនឹងដី ព្រោះខ្ញុំមិនឃើញមានគ្រែនោះទេ"]។

[3205] ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រៀល សន ឆ.១០៣ KH 00975633 ["ខ្ញុំបានឃើញគេបណ្តើរមនុស្ស ប្រហែលជាង២០នាក់ពីស្រុកគិរីវង់ កាត់តាមកន្លែងរបស់ខ្ញុំ ហើយពួកគេបានឈប់នៅកន្លែងរបស់ខ្ញុំ ដើម្បីសុំផ្ទាំ។ ពេលនោះ ខ្ញុំបានសួរគេថា ស្អីគេហ្នឹង? គេបានប្រាប់ថា សុទ្ធជាពួក កា.ហ្សេ.បេ និងគិញយួន ហើយពួកគេបញ្ជាក់ថា យកទៅដាក់គុក២០៤"]។

[3206] ឯកសារ D118/181 កំណត់ហេតុស្តាប់ចម្លើយ រៀល សន ឆ.១០៩-១១០, ១១៧-១១៩ KH 00975633-00975634។

[3207] ឯកសារ D118/300 កំណត់ហេតុស្តាប់ចម្លើយ ទីម ប៊ុនលី ឆ.៥, ១៦៤ KH 01024521, 01024535 ឆ.២៣៣-២៣៤ KH 01024541 ["ឆ.២៣៣៖ គេយកទុកមួយយប់ ទើបគេយកទៅសម្លាប់។ ស៖ តើធ្វើយ៉ាងម៉េចបានលោកដឹង? ឆ.២៣៤៖ ខ្ញុំឮតាមសាច់ញាតិរបស់កងឈ្លប"] ឆ.២៣៦-២៣៨ KH 01024541 ["ឆ.២៣៦៖ ខ្ញុំឈរចម្ងាយប្រហែល ៥០០ម៉ែត្រពីវត្ត។ ស៖ តើលោកដឹងថា គេយកមនុស្សទាំងនោះមកពីខាងណា? ឆ.២៣៧៖ ខ្ញុំឃើញគេបណ្តើរតាមផ្លូវពីខាងកើតបត់ចូលមកក្នុងវត្ត។ ស៖ នៅពេលដែលលោកឃើញគេបណ្តើរមនុស្សនោះ តើវាមានចម្ងាយប៉ុន្មានពីលោក ទៅអ្នកបណ្តើរនោះ? ឆ.២៣៨៖ មានចម្ងាយប្រហែល ៥០០ម៉ែត្រ ទៅ៦០០ម៉ែត្រ"] ឆ.១៨៦-១៨៧, ១៩២-១៩៦ KH 01024537 ឆ.១៩៨-១៩៩ KH 01024538 ["ឆ.១៩៨៖ នៅពេលនោះ មានសាច់ញាតិរបស់កងឈ្លបប្រាប់ថា អ្នកទាំងនោះ ជាខ្មែរក្រោម។ ស៖ តើពេលណា ដែលសាច់ញាតិកងឈ្លបនោះ ប្រាប់ថា ជាខ្មែរក្រោម? ឆ.១៩៩៖ ក្រោយពេលដែលពួកគេត្រូវបានសម្លាប់ចោល"] ឆ.២០៥ KH 01024538 ["សាច់ញាតិកងឈ្លបបានប្រាប់ថា ពួកគេជាខ្មែរក្រោម"]។

សម្លាប់ដោយឈ្លប[3208]។ មិនយូរប៉ុន្មាន ទីម ប៊ុនលី បានទៅវត្តនោះ និងបានឃើញសាកសពហើមក្នុងរណ្តៅមួយ[3209]។

877. ឯក (អ៊ុល) ហៀន បានផ្តល់សក្ខីកម្មក្នុងសំណុំរឿង ០០២ ថាខ្មែរក្រោមចំនួន៩០ នាក់ ដែលត្រូវបានបញ្ជូនដោយតាម៉ុក ទៅធ្វើការងារពលកម្មនៅទំនប់ខ្ពកត្របែក ក្រោមលេខាត្រាំកក់ឈ្នោះ តា ជីម និងថាបន្ទាប់មកមនុស្សទាំង៩០ នាក់នោះត្រូវបានសម្លាប់ទាំងអស់[3210]។ បន្ថែមពីលើនេះ កាំ កែវ

[3208] ឯកសារ D118/300 កំណត់ហេតុស្តាប់ចម្លើយ ទីម ប៊ុនលី ឆ.២១៧-២២០ KH 01024539-01024540 ឆ.២២២-២២៣ KH 01024540 ["ស៖ តើការសម្លាប់នោះ ធ្វើនៅកន្លែងណាដែរ? ឆ.២២២៖ ការសម្លាប់នោះ នៅក្នុងបរិវេណវត្ត ប៉ុន្តែនៅកន្លែងផ្សេង។ ស៖ ហេតុការណ៍ដែលលោកបានឃើញគេយកមនុស្សចេញនោះ តើលោកឃើញផ្ទាល់ភ្នែក ឬឮតាមគេ? ឆ.២២៣៖ ខ្ញុំឮតាមសាច់ញាតិរបស់កងឈ្លប"] ឆ.២២៥, ២៣៣-២៣៤, ២៣៨ KH 01024540, 01024541។

[3209] ឯកសារ D118/300 កំណត់ហេតុស្តាប់ចម្លើយ ទីម ប៊ុនលី ឆ.៥, ១៦៨-៧០ KH 01024521, 01024535-01024536 ឆ.២២៦-២២៨ KH 01024540 ["ឆ.២២៦៖ ក្រោយមក ខ្ញុំបានទៅកន្លែងសម្លាប់នោះ ខ្ញុំបានឃើញមានសាកសពកប់ ហើយហើមផុសចេញពីដី។ ពីមុន ខ្ញុំមិនជឿថា មានគេសម្លាប់មនុស្សនៅទីនោះទេ ប៉ុន្តែពេលខ្ញុំឃើញសាកសពហើមចេញ ទើបខ្ញុំជឿ។ ស៖ នៅក្នុងទំរង់បែបបទព័ត៌មានជនរងគ្រោះ លោកបាននិយាយថា គេសម្លាប់ដោយដែកភ្លៅរទេះ។ តើលោកធ្វើម៉េចបានដឹង? ឆ.២២៧៖ ខ្ញុំដឹងដោយសារខ្ញុំបានទៅកន្លែងនោះ ហើយបានឃើញដែកភ្លៅរទេះ។ ស៖ តើដែកភ្លៅរទេះនៅក្នុងបរិវេណវត្តឬ? ឆ.២២៨៖ បាទ។ ស៖ តើលោកបានទៅឃើញនៅពេលណាដែរ។ ឆ.២២៩៖ ខ្ញុំបានទៅទីនោះ ប្រហែល១០ថ្ងៃក្រោយ ដោយសារនៅវត្តវាស្ងាត់"] ឆ.២៣២ KH 01024541 ["គេសម្លាប់នៅកន្លែងតែមួយ គឺគេជីករណ្តៅឲ្យហើយ ហើយគេកប់នៅទីនោះតែម្តង"]។

[3210] ឯកសារ D315.1.21 ប្រតិចារឹក ឯក (អ៊ុល) ហៀន ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 09.16.29-09.20.09 ["តាជីមគាត់ថា យប់ឡើងរវល់តែដើរលួចចានឆ្នាំង បោះដាក់ទឹក បោះដាក់ត្រពាំងអ៊ីចឹង ឲ្យគេយក៩០នាក់ហ្នឹងទៅសម្លាប់ចោល"]។ ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ុល) ហៀន ឆ.៦២-៦៣ KH 00980106-00980107 ["ឆ.៦២៖ ខ្ញុំរដែលធ្លាប់រស់នៅស្រុកយួន នៅពេលធ្វើការ គឺលួចរបស់របរច្រើនពេក ដូច្នេះទើបគេលើកផែនការឲ្យសម្លាប់ខ្ញុំ ដែលដូរជាមួយនឹងយួននោះ។ បន្ទាប់មក គេលែងដូរយួនជាមួយនឹងខ្ញុំរទៀតហើយ គឺសម្លាប់យួនចោលទាំងអស់នៅក្នុងស្រុកខ្ញុំរ។ ស៖ ប្រជាជនខ្ញុំរ ដែលរស់នៅប្រទេសវៀតណាម និងត្រូវគេដូរឲ្យមករស់នៅស្រុកខ្ញុំរវិញ តើនៅពេលដូរនោះត្រូវគេបង្ខំដែរ ឬទេ? ឆ.៦៣ [...]មានម្តង តាម៉ុកបានដូរខ្ញុំរឲ្យត្រឡប់មកវិញចំនួន៩០នាក់ ហើយក៏ប្រគល់ទៅឲ្យ តាជីម ដើម្បីជួយរែកប្រឡាយខ្ពបត្របែក។ តាជីមថា ខ្ញុំរទាំង៩០នាក់នោះចេះតែលួចពេក ក៏យកអ្នកទាំងអស់នោះទៅសម្លាប់ចោល។ ១ខែក្រោយមក តាម៉ុក ក៏មកមើលខ្ញុំរទាំង៩០នាក់នោះ ដោយនិយាយជាមួយនឹង តាជីមថា "ឯណាមនុស្ស?" តាជីម និយាយថា "រ៉ែចោលអស់ហើយ ព្រោះលួចពេក"]។

បានពិពណ៌នាអំពីវិធីដែលគ្រួសារខ្មែរក្រោមរបស់ប្រពន្ធរបស់គាត់ត្រូវបានយកទៅត្រាំកក់ និងបានបាត់ខ្លួនក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[3211]។

i. មន្ទីរសន្តិសុខក្រាំងតាចាន់

878. ប្រធានឃុំបានរៀបចំបញ្ជីឈ្មោះមនុស្សដែលជាខ្មែរក្រោម និងបានបញ្ជូនបញ្ជីទាំងនេះទៅគណៈស្រុកត្រាំកក់។ ខ្មែរក្រោម និងប្រជាជនវៀតណាមនៅក្នុងបញ្ជីទាំងនោះ បន្ទាប់មកត្រូវបានចាប់ខ្លួន

[3211] ឯកសារ D118/162 កំណត់ហេតុស្តាប់ចម្លើយ កែវ កន ឆ.៤១ KH 00968113 ["ស៖ តើសមាជិកក្រុមគ្រួសារណោកផ្ទាល់ដែលជាខ្មែរក្រោមហ្នឹង ធ្លាប់ខ្មែរក្រហមចាប់ធ្វើបាប និងសម្លាប់ទេ? ឆ.៤១៖ បាទ ខាងប្រពន្ធរបស់ខ្ញុំ គេចាប់យកទៅបាត់ មិនឃើញមកវិញទេ"]។

និងត្រូវបានបញ្ជូនទៅក្រាំងតាចាន់[3212]។ ខ្មែរក្រោមនៅក្រាំងតាចាន់ត្រូវបានចាត់ទុកជា "យួន" និងត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខនេះ ឬនៅតាមទីតាំងនានាក្នុងតំបន់នេះ[3213]។

ង. ការប្រព្រឹត្តទៅលើប្រជាជនវៀតណាម និងខ្មែរក្រោមនៅស្រុកកោះអណ្តែតឆ្នាំ១៩៧៥-១៩៧៩

879. **យ៉ីម ទិព្ធ** បានមានសិទ្ធិអំណាចនៅស្រុកកោះអណ្តែតពីឆ្នាំ១៩៧៥-១៩៧៩ ជាមេដឹកនាំថ្នាក់លើនៅតំបន់១៣ និងជាអ្នករួមចំណែកដ៏សំខាន់ទៅដល់សហឧក្រិដ្ឋកម្មរួម។ **យ៉ីម ទិព្ធ** ជាអ្នកទទួលខុសត្រូវទៅលើមន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងពិឃាតព្រៃសុខុន ព្រមទាំងទីតាំងដទៃនៅស្រុកកោះអណ្តែត ដែលឧក្រិដ្ឋកម្មានានាត្រូវបានប្រព្រឹត្តទៅលើប្រជាជនវៀតណាម និងខ្មែរក្រោម។

[3212] *សូមមើលឧទាហរណ៍* ឯកសារ D315.2.6 ប្រតិចារឹក រ៉ៀល សន ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៥ ម៉ោង 11.13.37-11.17.12, 13.35.50-13.38.52។ ឯកសារ D347/2.1.4 សេចក្តីរាយការណ៍បញ្ជាក់ពីផនទៅអង្គការស្រុក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ១៩៧៧ KH 00079090។ ឯកសារ D6.1.1216 ស្ថិតិប្រជាជនកម្ពុជាក្រោម ដែលស្នាក់នៅឃុំអង្គតាសោម ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ KH 00079100-01000791។ ឯកសារ D6.1.1210 ស្ថិតិអ្នកទោសដែលបានដោះដូរក្នុងឃុំតាសោម KH 00068019-20។ ឯកសារ D65.1.52 បញ្ជីប្រជាជនកម្ពុជាក្រោមនៅក្នុងឃុំពពេល KH 00068576។ ឯកសារ D6.1.470 បញ្ជីប្រជាជនកម្ពុជាក្រោមពីឃុំគុស ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៧ KH 00270811-00270814។ ឯកសារ D347/2.1.3 បញ្ជីប្រជាជនទើបមកពីស្រុកយួន [វៀតណាម] ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ KH 00068024-00068037 [កំណត់ត្រាសារខ្មែរក្រោមក្នុងឃុំស្រែរនង]។ ឯកសារ D6.1.262 សេចក្តីរាយការណ៍ពីជនជាតិវៀតណាមនៅស្រុកត្រាំកក់ ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៧៧ KH 00079112។ D118/269 កំណត់ហេតុស្តាប់ចម្លើយ ថាន់ ធីម ឆ.៥៧ KH 00998116 ["ហើយចុងឆ្នាំ១៩៧៧ ពួកខ្មែរក្រហមបានប្រមូលពួកខ្ញុំមកនៅស្រុកត្រាំកក់វិញ។ គេបានប្រមូលប្រជាជនពីភូមិផ្សេងៗមកផ្ទុំគ្នានៅវត្តកំពែង ដែលខ្ញុំបានឃើញមនុស្សស្លាប់ជាង២០នាក់ ដូចរៀបរាប់ខាងលើ។ ការសម្លាប់ គេធ្វើនៅពេលយប់ ហើយព្រឹកឡើង គេមកដឹកជញ្ជូនពួកខ្ញុំឲ្យទៅរស់នៅស្រុកត្រាំកក់។ ខ្ញុំស្ថិតនៅក្នុងព្រឹត្តិការណ៍នោះដែរ"]។ ឯកសារ D118/301 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម ស៊ន ឆ.៨៧ KH 01024557 ["ស៖ តើលោកដឹងដោយរបៀបណាថា ពួកគេជាខ្មែរក្រោម? [...] ឆ.៨៧៖ ខ្ញុំមិនដឹងថា ចំនួនប៉ុន្មាននាក់ទេ ប៉ុន្តែខ្មែរក្រោមមានបញ្ជីឈ្មោះខ្មែរក្រោមទាំងអស់នោះហើយ។ បន្ទាប់មក ខ្ញុំឮថា គេបានបញ្ជូនខ្មែរក្រោមទៅសម្លាប់នៅឃុំពេជសារ [ស្រុកត្រាំកក់]"]។ ឯកសារ D118/209 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ឿន ឆ.៤៥-៤៧, ៥៣ KH 00980104, 00980105។ ឯកសារ D315.1.4 ប្រតិចារឹក រ៉ី ពៅ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 11.32.02-11.36.00 EN 01452131-01452132 *សូមអានជាមួយនឹង* ឯកសារ D118/130 កំណត់ហេតុស្តាប់ចម្លើយ រ៉ី ពៅ ឆ.៥៦, ៦០-៦៨ KH 00960589, 00960590-00960591។ ឯកសារ D315.1.20 ប្រតិចារឹក ឯក (អ៊ីល) ហ៊ឿន ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៥ ម៉ោង 15.28.17-15.29.23។ ឯកសារ D219/135 កំណត់ហេតុស្តាប់ចម្លើយ យ៉ិន គេង ឆ.១២៩-១៣១, ១៤១-១៥៤, ១៥៦ KH 01052705 KH 01052706-01052708។ ឯកសារ D118/162 កំណត់ហេតុស្តាប់ចម្លើយ កែវ ក ន ឆ.៣២-៣៣ KH 00968112។

[3213] *សូមមើល* V.A.1.e.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់១៣ – មន្ទីរសន្តិសុខក្រាំងតាចាន់ – ឧក្រិដ្ឋកម្ម។

880. នៅខែមេសា និងខែមិថុនា ឆ្នាំ១៩៧៥ ខ្មែរក្រោមពីភ្នំពេញ និងផ្នែកនានានៃខេត្តតាកែវ ត្រូវបានបង្ខំឲ្យដើរទៅកាន់ស្រុកកោះអណ្តែត[3214]។ ក្នុងហេតុការណ៍មួយ ខ្មែរក្រោមចំនួនចន្លោះ ១២០០ ទៅ ១៤០០ នាក់ត្រូវបានជម្លៀសទៅភូមិសំភី[3215]។ ខ្មែរក្រោមដែលបានរស់នៅកម្ពុជារួចហើយ ត្រូវបានគេហៅថា "ក្រុមថ្មី" ឬ "ខ្មែរក្រោម១៧ មេសា" ចំណែកខ្មែរក្រោមដែលត្រូវបានជម្លៀសដោយបង្ខំពីកម្ពុជាក្រោម ត្រូវបានស្គាល់ថាជា "ខ្មែរប្តូរយកយួន"[3216]។ ក្រៅពីការសម្លាប់ប្រជាជនវៀតណាមនៅមន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងពិឃាតព្រៃសុខុន កម្មាភិបាលនានាបានយកខ្មែរក្រោមដែលត្រូវបានចាប់ខ្លួននៅស្រុកគិរីវង្ស យកទៅសម្លាប់នៅពេជ្រ ស ស្រុកកោះអណ្តែតក្នុងឆ្នាំ ១៩៧៨[3217]។

[3214] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.៧ KH 01171491 ["ស៖ តើមានជនជាតិខ្មែរក្រោមរស់នៅទីនេះទេ [ភូមិសំភ្លី ស្រុកកោះអណ្តែត]? ឆ.៧៖ ទេ មិនមានទេ គឺមានតែខ្មែរក្រោម ដែលគេនាំមកពីភ្នំពេញ និងតាកែវ"] ឆ.១៥ KH 01171492 ឆ.២៩ KH 01171495 ["ស៖ តើបន្ទាប់ពីប្រជាជនមកពីតាកែវបានមកដល់បានប៉ុន្មាន បានប្រជាជនពីភ្នំពេញមកដល់? ឆ.២៩៖ មកដល់បានប្រហែល១០ថ្ងៃ។ វាយូរដែរ ព្រោះពួកគេដើរមកពីភ្នំពេញ"]។ ឯកសារ D219/591 កំណត់ហេតុស្តាប់ចម្លើយ គុណ សំ ឆ.១១-១៣ KH 01169863 ["ក្រោយពីរំដោះហើយ គេបានយកប្រជាជនខ្មែរក្រោមដាក់នៅវត្តអង្គសេរីមាលីហៅ វត្តសំភ្លី។ ស៖ ក្រោយរំដោះហ្នឹងមានន័យថាម៉េច តើលោកអាចជួយបញ្ជាក់បានដែរទេ? ឆ.១២៖ ក្រោយរំដោះឆ្នាំ៧៥ [...] ឆ.១៣៖ នៅឆ្នាំ៧៥ ក្រោយពេលដែលប្រជាជនដែលបែកពីភ្នំពេញមក គេយកប្រជាជនកម្ពុជាក្រោមយកមកដាក់នៅវត្តអង្គសេរីមាលី"]។

[3215] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ វង ណុប ឆ.២១-២៤ KH 01171493-01171494 ["ស៖ តើប្រជាជនខ្មែរក្រោម ដែលមកពីភ្នំពេញមានចំនួនប៉ុន្មាននាក់ដែរ? ឆ.២១៖ ខ្ញុំមិនបានដឹងពីចំនួនទេ ព្រោះគេមិនឲ្យខ្ញុំទៅជិតទេ។ ពេលខ្លះ ពេលគេមកលែងផ្ទះខ្ញុំ ខ្ញុំសួរពួកគេ ពួកគេប្រាប់ខ្ញុំថា មានខ្មែរក្រោមច្រើននាក់។ ស៖ តាមអ្វីដែលលោកចាំ តើលោកអាចស្មាន តើខ្មែរក្រោមដែលមកពីភ្នំពេញមានចំនួនប៉ុន្មានដែរ? ឆ.២២៖ ប្រជាជនខ្មែរក្រោមប្រហែល២០០នាក់។ ស៖ យើងសូមបញ្ជាក់ឡើងវិញ ក្នុងចំណោមប្រជាជនមកពីភ្នំពេញ គឺមានខ្មែរក្រោមប្រហែល២០០នាក់។ តើត្រឹមត្រូវទេ? ឆ.២៣៖ ខ្ញុំសូមបញ្ជាក់ថា ២០០ គ្រួសារ មិនមែន២០០នាក់ទេ។ ស៖ តើក្នុងមួយគ្រួសារមានសមាជិកប៉ុន្មាននាក់? ឆ.២៤៖ មិនកំណត់ទេ គ្រួសារខ្លះមានបីនាក់ បួននាក់ ប្រាំនាក់ និងខ្លះមានដល់ប្រាំមួយនាក់ ទៅប្រាំពីរនាក់ឯណោះ"] ឆ.៣២ KH 01171495 [ស៖ ក្នុងចំណោមប្រជាជនមកពីតាកែវ៣០០គ្រួសារហ្នឹង តើមានខ្មែរក្រោមប្រហែលប៉ុន្មានគ្រួសារដែរ? ឆ.៣២៖ ខ្មែរក្រោមមានប្រហែល២០០គ្រួសារ"]។

[3216] ឯកសារ D118/162 កំណត់ហេតុស្តាប់ចម្លើយ កែវ កន ឆ.១១ KH 00968110។ ឯកសារ D219/379 កំណត់ហេតុស្តាប់ចម្លើយ ឡាច សម្ត្ត ឆ.៦៩-៧០ KH 01112280។ ឯកសារ D118/269 កំណត់ហេតុស្តាប់ចម្លើយ ថាន់ ធីម ឆ.២២ KH 00998111។

[3217] ឯកសារ D118/301 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម ស៊ីន ឆ.៧១ KH 01024555 ["ឆ្នាំ១៩៧៨ ខ្ញុំនៅមន្ទីរ២០៤ បន្ទាប់មកគេបញ្ជូនមកភូមិកំណើត[ភូមិភ្នំលន្ទុះ ឃុំអង្គប្រាសាទ] វិញ ហើយចុងក្រោយ គេបញ្ជូនទៅឃុំព្រៃខ្ជា ស្រុកកោះអណ្តែត។"] ឆ.៨៤-៨៦ KH 01024556 ["ឆ.៨៤៖ មានខ្មែរក្រោមជាច្រើនត្រូវគេហៅមក ហើយយកទៅសម្លាប់ចោល។ ស៖ តើលោកដឹងរឿងនេះ

i. មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងពិឃាតព្រៃសុខុន

881. ដូចដែលបានបង្ហាញលម្អិតក្នុងផ្នែកស្តីពីទីតាំងឧក្រិដ្ឋកម្ម[3218] ខ្មែរក្រោមចំនួនប្រមាណ ៤០០ គ្រួសារ ត្រូវបាននាំខ្លួនដោយបង្ខំទៅវត្តអង្គសិរីពីភ្នំពេញ និងតាកែវក្នុងរង្វង់ពាក់កណ្តាលឆ្នាំ ១៩៧៥[3219]។ កម្លាំងរបស់ ប.ក.ក ដែលធ្វើតាមបញ្ជារបស់ "ថ្នាក់លើ" ដែលនឹងបានរួមបញ្ចូល **យ៉ម ទិត្យ** បានសម្លាប់ខ្មែរក្រោមនៅវត្តអង្គសិរី និងបន្ទាប់មកបានរាយការណ៍អំពីការសម្រេចភារកិច្ចប្រកបដោយជោគជ័យ[3220]។

ii. ឧក្រិដ្ឋកម្មប្រឆាំងប្រជាជនវៀតណាមនៅភូមិភាគពាយ័ព្យ

882. **យ៉ម ទិត្យ** ត្រូវបានចោទប្រកាន់ពីបទប្រល័យពូជសាសន៍ទៅលើខ្មែរក្រោមនៅតាមទីតាំងឧក្រិដ្ឋកម្ម ដូចខាងក្រោម៖ រោងចក្រស្ករ ស កំពង់គល់ មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងពិឃាតទួលស្រង៉ូវ ទីតាំងពិឃាតព្រៃក្រចៅ ឃុំកំពង់ព្រាង និងឃុំវាំងកេសី[3221]។ **យ៉ម ទិត្យ** ក៏ត្រូវបានចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយទៅលើប្រជាជនវៀតណាមនៅរោងចក្រស្ករ ស កំពង់គល់[3222]។ ស.ព.អ ស្នើសុំថា **យ៉ម ទិត្យ** ត្រូវទទួលការចោទប្រកាន់ពីឧក្រិដ្ឋកម្មនីមួយៗ ក្នុងចំណោមឧក្រិដ្ឋកម្មទាំងនេះ និងបន្ថែមពីនេះ ស្នើសុំឲ្យបញ្ជូន **យ៉ម ទិត្យ** ទៅជំនុំជម្រះពីបទប្រល័យពូជសាសន៍ទៅលើប្រជាជន

ដោយរបៀបណា? តើព្រឹត្តិការណ៍នេះកើតឡើងនៅកន្លែងណា? ហើយនៅពេលណា? ឆ.៨៥៖ ខ្ញុំមិនចាំឆ្នាំណានោះទេ។ ចំពោះឃុំផ្សេង ខ្ញុំមិនដឹងទេ តែចំពោះខ្មែរក្រោមនៅឃុំអង្គប្រាសាទ ត្រូវគេយកទៅសម្លាប់នៅឃុំពេជសារក្នុងព្រៃបូស្សី។ ស៖ តើព្រឹត្តិការណ៍នេះកើតឡើងមុន ឬក្រោយពេលដែលគេបញ្ជូនលោកទៅមន្ទីរ២០៤? ឆ.៨៦៖ ព្រឹត្តិការណ៍សម្លាប់ខ្មែរក្រោមនេះកើតឡើង ក្រោយគេបញ្ជូនខ្ញុំចេញពីមន្ទីរ២០៤ គឺមិនយូរប៉ុន្មាននោះទេ"]។

[3218] *សូមមើល* V.A.1.f.iv. ឧក្រិដ្ឋកម្ម – ភូមិភាគនិរតី – តំបន់១៣ – មន្ទីរសន្តិសុខវត្តអង្គសិរី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន – ឧក្រិដ្ឋកម្ម។

[3219] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រង ណុប ឆ.២៩ ឆ.ពាង KH 01171495។ ឯកសារ D119/2 រង ណុប ឆ.៨ KH 01171491។

[3220] ឯកសារ D219/592 កំណត់ហេតុស្តាប់ចម្លើយ រង ណុប ឆ.៦៧ KH 01171502។

[3221] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ EN 01426069។

[3222] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ម ទិត្យ ដែលបានកែប្រែ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ EN 01426072។

រៀតណាម ដោយរួមបញ្ចូលខ្មែរក្រោម នៅតាមទីតាំងដទៃក្នុងស្រុកបាកាន និងតំបន់១ និងតំបន់៤ (ដូចដែលបានបង្ហាញលម្អិតខាងក្រោម) ដែល ស.ច.ស ត្រូវបានប្តឹងឲ្យពិនិត្យ និងចាត់ការ[3223]។

883. **យ៉ីម ទិត្យ** និងកម្មាភិបាលភូមិភាគនិរតីបានកាន់កាប់ភូមិភាពពាយ័ព្យ នៅដើមឆ្នាំ១៩៧៧ ហើយចាប់ពីពេលនោះរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ បានអនុវត្តផែនការបំផ្លាញប្រជាជនវៀតណាម ដោយសហការជាមួយ និង/ឬ ដោយប្រើប្រាស់កម្មាភិបាលភូមិភាគនិរតីពាព័ព្យ និងបស្ចិមថ្នាក់ក្រោមដើម្បីអនុវត្តយុទ្ធនាការប្រល័យពូជសាសន៍នេះ។

ក. ការប្រព្រឹត្តទៅលើប្រជាជនវៀតណាម និងខ្មែរក្រោមក្នុងតំបន់ ១ ក្នុងឆ្នាំ១៩៧៧-១៩៧៩

884. **យ៉ីម ទិត្យ** ជាលេខាតំបន់ ១ និងបានបម្រើការងារជាអនុលេខាភូមិភាគពាយ័ព្យ ដែលដូច្នេះមានសិទ្ធិអំណាចលើហេតុការណ៍នានាក្នុងតំបន់ និងភូមិភាគនេះ[3224]។ មិនយូរប៉ុន្មាន បន្ទាប់ពីគាត់មកដល់

[3223] <u>ស្រុកបាកាន</u>៖ ឯកសារ D65 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានា នៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ កថាខណ្ឌ១៦-១៧។<u>តំបន់ ១ និង៤</u>៖ ឯកសារ D191 ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ៨។

[3224] <u>លេខាតំបន់១</u>៖ *សូមមើលឧទាហរណ៍* ឯកសារ D219/974.1.2 ណុប ង៉ីម ប្រតិចារ៉ីក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ម៉ោង 10.39.42-10.43.35។ ឯកសារ D118/285 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៧, ៦៣ KH 01008697, 07។ ឯកសារ D219/835 កំណត់ហេតុស្តាប់ចម្លើយ ណុប ង៉ីម ឆ.៩២ KH 01008712។ ឯកសារ D219/210 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.៤ KH 01074048។ ឯកសារ D219/236 កំណត់ហេតុស្តាប់ចម្លើយ លេខ ភីរ ឆ.១៨ KH 01080844។ ឯកសារ D118/136 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៧, ២១-២៣ KH 00960663, 00960666។ ឯកសារ D219/233 កំណត់ហេតុស្តាប់ចម្លើយ ឈាន ប៊ា ឆ.៨, ២១ KH 00960663, 00960666។ ឯកសារ D34.1.9 បទសម្ភាសជាមួយ ហេង ទារ ហៅ តាប៉ែត ដោយ លោក ស្ទីវ ហេដឌ័រ EN 01181114។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈឿង ប៊ាន ឆ.១១-១៦ KH 01110175។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.២០, ៨១ KH 01205203, 01205217 ។ D219/85 កំណត់ហេតុស្តាប់ចម្លើយ វ៉ី ផាន់ ឆ.២ KH 01040093។ ឯកសារ D118/245 កំណត់ហេតុស្តាប់ចម្លើយ ជួន ថន ឆ.៤, ១៨ KH 00990642-00990643, 00990646។ D118/299 កំណត់ហេតុ ស្តាប់ចម្លើយ ជួន ថនឆ.២៤ KH 01023877។ D118/208 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ីន ឆ.៦៤ KH 00980089។ <u>អនុលេខាភូមិភាគពាយ័ព្យ</u>៖ *សូមមើលឧទាហរណ៍* ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១៦-១៨, ២៧ EN 00951928, 00951929។ ឯកសារ D118/271 ឈាន ប៊ា ឆ.៣៤ KH 00998559។ ឯកសារ D118/150 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ម៉ឿន ឆ.៥៩-៦១, ៦៥ KH 00968003-00968004។ ឯកសារ D118/222 កំណត់ហេតុស្តាប់ចម្លើយ ហ៊ែម ម៉ឿន ឆ.១៤ KH 00983235។ ឯកសារ D118/69 កំណត់ហេតុស្តាប់ចម្លើយ ន្ហួន ម្ហួន ឆ.១៤, ១៦-១៧ KH 00920212-00920213។ ឯកសារ D219/917 ដែ ទូច ឆ

ស្រុកគាស់ក្រឡ **យ៉ីម ទិត្យ** បានបញ្ជាឲ្យសម្លាប់ "ភ្នាក់ងារសេអ៊ីអា និងវៀតណាម" ចំនួនរាប់ ពាន់នាក់ក្នុងឆ្នាំ១៩៧៦ ឬ ១៩៧៧ យោងតាម សៅ ចុប[3225]។ ពីពាក់កណ្តាលឆ្នាំ១៩៧៧ មានការសម្លាប់ជាទូទៅទៅលើប្រជាជន ដែលគេចាត់ទុកថាវៀតណាមនៅភូមិភាគពាយ័ព្យ ដោយរួមបញ្ចូលមនុស្សដែលមាន "ឈាមជ័រវៀតណាម"[3226]។ អ្នកណាដែលមានប្តីឬប្រពន្ធជាជនជាតិវៀតណាមក៏ត្រូវបានសម្លាប់ផងដែរ[3227]។ ទីតាំងសំខាន់នៃការធ្វើបាប និងការសម្លាប់ខ្មែរក្រោមក្នុងតំបន់ ១ គឺរោងចក្រស្ករសកំពង់គល់ នៅស្រុកសង្កែ។

.១១, ១៣-១៥ KH 01388675, 76។ ឯកសារ D105/8 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.២៧ KH 00794129។ ឯកសារ D219/34 កំណត់ហេតុស្តាប់ចម្លើយ ឯក (អ៊ីល) ហ៊ីន ឆ.៤៣ KH 01032073។

[3225] ឯកសារ D219/982 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២៦-៣៣ KH 01477628-01477629 ["[យ៉ីម ទិត្យ] ចាត់តាំងគេតើ [សម្លាប់] [...] គាត់ឈ្មោះ អន។ [...] ខ្ញុំសួរថា មិត្តឯងធ្វើឃាតការសម្លាប់ប្រជាជនហ្នឹង អ្នកណាចាត់តាំងមក។ គាត់ថា ឈ្មោះ ទិត្យ ហ្នឹង។ [...] ចុះបើឃើញសម្លាប់ [អន] ចាប់យកទៅសម្លាប់។ [...] អាហ្នឹងនៅគាស់ក្រឡ។ [...] រាប់ពាន់នាក់ដែរ។ ខ្ញុំសួរដែរថា ចុះមនុស្សដែលចាប់យកទៅសម្លាប់ហ្នឹង ខុសអី វាថាជា សេ.អ៊ីអា ឃ្លួន។ [...] នៅក្នុងឆ្នាំ តាំងពីឆ្នាំ៧៥ ហ្នឹងក៏សម្លាប់ ហើយ៧៧ ពួកនិរតីមក។ ហើយក្នុងឆ្នាំ៧៦ ៧៧ ហ្នឹង អាទិត្យ ចាត់តាំងរកខ្មាំង សេអ៊ីអា ឃ្លួន។ អាហ្នឹង គេស្រាវជ្រាវរកចាប់រហូត។ ការចាប់ហ្នឹងទល់ពួកនិរតីចូលមក"]។ ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.១០-១១ EN 01477637 ["ឆ.១០៖ ខ្ញុំសួរត្រង់ថា ចាប់ហ្នឹងមានមូលហេតុអី ខុសអី។ គេថា ចាប់សេ.អ៊ីអា ឃ្លួន ឌីបេ ឃ្លួន។ ហើយខ្ញុំសួរទាំងអស់គ្នាហ្នឹង ទាំង អន, ប៉ក់ និង ថាច។ ស៖ តើ ឌីបេ។ ហ្នឹងជាអី? ឆ.១១៖ ឌីបេ ដូចជា សេ.អ៊ីអា ឃ្លួន ដូចតែគ្នា ពាក្យគេ"]។

[3226] ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា៖ *របប ប៉ុល ពត ពួជសាសន៍ អំណាច និងអំពើប្រល័យពួជសាសន៍ នៅកម្ពុជាក្រោមដែពួកខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩* EN 00678650 ["នៅភូមិភាគពាយ័ព្យ ស្ត្រីខ្មែរម្នាក់រំពឹកថា នៅពាក់កណ្តាលឆ្នាំ១៩៧៧ ក្រោយពីពួកកម្មាភិបាលនិរតីមកដល់ អាជ្ញាធរ "ចាប់ផ្តើមសម្លាប់អ្នកដែលជាប់សាច់ឈាមវៀតណាម"។ បុរសម្នាក់មកពីភូមិភាគពាយ័ព្យបន្ថែមថា ក្រោយពីពួកកម្មាភិបាលនិរតីមកដល់ក្នុងខែឧសភា ឆ្នាំ១៩៧៧ ជនជាតិវៀតណាមចំនួនប្រាំមួយនាក់ក្នុងភូមិគាត់ ត្រូវបានគេសម្លាប់ក្នុងខែសីហា"]។ សូមមើលផងដែរ ឯកសារ D6.1.168 កំណត់ហេតុស្តាប់ចម្លើយ ព្រ័ំ សារុន EN 00274177-00274178។ ឯកសារ D6.1.165 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម អាន់ EN 00274160 ។ ឯកសារ D119/73 កំណត់ហេតុស្តាប់ចម្លើយ ន្ធ ជួង EN 00980543។ ឯកសារ D6.1.610 បទសម្ភាសន៍របស់ SOAS ជាមួយ ហាក់ ញ៉ឹម EN 00352000។ D123/1/2.57 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ឃ ម៉ុត EN 00987554-00987556។ ឯកសារ D123/1/2.46 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡូត បណ្ណែត EN 00969799។ ឯកសារ D123/1/2.52 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ភាច រស់ EN 00969843-00969844។

[3227] ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហ្ជន ជ្ជឿម ឆ.៥៨ KH 00951910។

i. រោងចក្រស្ករសកំពង់គល់

885. ពលករខ្មែរក្រោម និងវៀតណាមត្រូវបានឃុំឃាំងនៅនឹងទីកន្លែងឯរោងចក្រស្ករស មុនពេលត្រូវបានសម្លាប់ដោយកម្មាភិបាលភូមិភាគនិរតី[3228]។ **យ៉ឹម ទិត្យ** ត្រូវបានសាក្សីរៀបរាប់ថាបានផ្តល់ឱវាទទៅបុគ្គលិករោងចក្រនោះនៅក្នុងការប្រជុំនានា និងថាបានតែងតាំងប្រធានរោងចក្រ[3229]។ ដូចដែលបានរៀបរាប់ក្នុងផ្នែកស្តីពីទីតាំងឧក្រិដ្ឋកម្ម[3230] ខ្មែរក្រោមនៅរោងចក្រនោះត្រូវបានដាក់ជាគោលដៅ ពីព្រោះពួកគាត់ត្រូវបានគេចាត់ទុកជា "ខ្សែបណ្តាញវៀតណាម"[3231]។ ប្រជាជនវៀតណាម និងខ្មែរក្រោមទាំងអស់ត្រូវបានរាយការណ៍ថាបានបាត់ខ្លួនពីរោងចក្រនេះ[3232]។

ខ. ការប្រព្រឹត្តទៅលើប្រជាជនវៀតណាម និងខ្មែរក្រោមក្នុងតំបន់២ ឆ្នាំ១៩៧៧-១៩៧៩

886. ការសម្លាប់ប្រជាជនវៀតណាមនៅភូមិភាគពាយ័ព្យត្រូវបានប្រមូលផ្តុំក្នុងស្រុកបាកាន ក្នុងតំបន់២។ **យ៉ឹម ទិត្យ** ជាមេដឹកនាំថ្នាក់ខ្ពស់មួយរូបនៅភូមិភាគពាយ័ព្យ ហើយសាក្សីនានាបាននិយាយថា **យ៉ឹម ទិត្យ** ក៏មានមុខតំណែងជាលេខាតំបន់ ២ ផងដែរ[3233]។ យាយ រីម ជាលេខាស្រុកបាកាន។ គាត់មកពីភូមិភាគនិរតីក្នុងដើមឆ្នាំ១៩៧៧ និងបានដើរតួនាទីដ៏សំខាន់មួយក្នុងការអនុវត្តផែនការបំផ្លាញប្រជាជនវៀតណាម។ មិនយូរប៉ុន្មានបន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីបានកាន់កាប់ស្រុក បាកាន ក

[3228] *សូមមើលខ១ទាហរណ៍* ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៤៧-៥១, ៥៣-៥៤ KH 00951931-00951932។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៧៦, ៨២, ៩៩-១០០, ១៣០ KH 01196466, 01196467, 01196469-01196470, 01196475។

[3229] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.១៨, ២២ KH 00951928, 00951929។ ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៣៩-៤១, ៦២, ៦៤, ៦៨-៦៩ KH 01196460, 01196463, 01196464។ ឯកសារ D219/931 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សឿន ឆ.១៩, ២១, ២៦-២៨ KH 01395016, 01395017។ ឯកសារ D118/106 កំណត់ហេតុស្តាប់ចម្លើយ ហ្ជន ជឿម ឆ.១២ KH 00951904។

[3230] *សូមមើល* V.B.2.d.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់១ – រោងចក្រស្ករកំពង់គុល – ឧក្រិដ្ឋកម្ម។

[3231] ឯកសារ D118/108 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៥៣ KH 00951932។

[3232] ឯកសារ D219/649 កំណត់ហេតុស្តាប់ចម្លើយ លឹម ទីម ឆ.៨៤ KH 01196467។

[3233] ឯកសារ D219/684 កំណត់ហេតុស្តាប់ចម្លើយ ឈឿន រ៉ុន ឆ.១៣, ២០ KH 01203936, 01203937 ["ឮគេថា [យ៉ឹម ទិត្យ] គណៈតំបន់។ មេកងជាអ្នកប្រាប់ថាជាគណៈតំបន់ [...] ខ្ញុំឮមេកងគេថា គណៈតំបន់២ ខ្ញុំក៏ថា គាត់គណៈតំបន់២ទៅ"]។ D219/294 កំណត់ហេតុស្តាប់ចម្លើយ មូល អេង ឆ.១១០ KH 01095252 ["ស៖ នៅក្នុងកិច្ចប្រជុំហ្នឹង តើគេប្រកាសថា យ៉ឹម ទិត ហ្នឹងជាគណៈតំបន់៣ ឬយ៉ាងណាដែរ? ឆ.១១០៖ បន្ទាប់ពីដេកគិតឡើងវិញទៅ ខ្ញុំមិនច្បាស់ថា តាទិត ត្រូវបានគេតែងតាំងឲ្យគ្រប់គ្រងតំបន់៣ ឬតំបន់២ទេ។ តែខ្ញុំចាំច្បាស់ថា ស្រុកបរវិលត្រូវបានកាត់ឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ យ៉ឹម ទិត"]។

ម្ចាភិបាលថ្នាក់ក្រោមនៅរំលិច ដែលជាខ្មែរក្រោមត្រូវបានបញ្ជូនទៅឃុំខ្ទារទទឹង ហើយតំណែងដែលនៅទំនេរត្រូវបានចូលជំនួសដោយកម្ចាភិបាលភូមិភាគនិរតី[3234]។ មេក្រុមរបស់ឈឹម ស្រេន ត្រូវបានយកចេញទៅក្នុងចុងឆ្នាំ១៩៧៧ ទៅកាន់ភូមិកូនកំប្រុកនៅខ្ទារទទឹង។ ឈឹម ស្រេន ត្រូវបានប្រាប់កាលពីពេលនោះថាខ្មែរក្រោមត្រូវបានប្រមូលយកទៅសម្លាប់[3235]។

i. ការប្រព្រឹត្តទៅលើប្រជាជនវៀតណាម និងខ្មែរក្រោមនៅស្រុកបាកាន

887. ខ្មែរក្រោមបានរស់នៅស្រុកបាកាន ជាច្រើនជំនាន់មកហើយ មុនពេលខ្មែរក្រហមឡើងកាន់អំណាច[3236]។ នៅដើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រោមមានចំនួនភាគច្រើននៃ

[3234] ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.៤៨-៥០, ៦៤ KH 00977066, 00977068។

[3235] ឯកសារ D118/198 កំណត់ហេតុស្តាប់ចម្លើយ ឈឹម ស្រេន ឆ.៥៧-៥៩ KH 00978984-00978985 ["ស៖ តើលោកដឹងថាប្រជាជនខ្មែរក្រោមត្រូវបានខ្មែរក្រហមកំណត់ថា ជាគោលដៅយកទៅសម្លាប់ដែរ ឬទេ? ឆ.៥៧៖ បាទ ខ្ញុំដឹង។ [...] ឆ.៥៨៖ ខ្ញុំដឹងថា មេក្រុមរបស់ខ្ញុំដែលជាខ្មែរក្រោមត្រូវគេហៅយកទៅសម្លាប់នៅភូមិកំប្រាក់កូន ក្នុងឃុំខ្ទារទទឹង។ ខ្ញុំបានឮគេនិយាយខ្សឹបខ្សៀវគ្នាថា "ឥឡូវ គេប្រមូលយកខ្មែរក្រោមទៅសម្លាប់ចោល"។ ស៖ តើលោកឮពីអ្នកណា? ហើយលោកឮរឿងនេះនៅពេលណា? ឆ.៥៩៖ ខ្ញុំមិនចាំឈ្មោះអ្នកដែលនិយាយប្រាប់ខ្ញុំនោះទេ។ ពេលនោះ ដោយសារបាត់មេកងរបស់ខ្ញុំ ខ្ញុំក៏បានសួរគេ ហើយគេប្រាប់ខ្ញុំថា "គេយកទៅសម្លាប់ចោលហើយ"។ រឿងនេះកើតឡើងប្រហែលចុងឆ្នាំ១៩៧៧"]។

[3236] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៤-៧ KH 00955727-00955728។ ឯកសារ D118/214 កំណត់ហេតុស្តាប់ចម្លើយ ចឹង ភី ឆ.៦-៧ KH 00982146។ ឯកសារ D118/227 កំណត់ហេតុស្តាប់ចម្លើយ ជា ហេង ឆ.៧ KH 00955728។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.២-៣ KH 00985414។ ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន រ៉ន ឆ.៧៣ KH 00977087។ ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ុច ឆ.៤៤ KH 00977096។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធួន ឆ.១៩ KH 00955765។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ឆ.៧៨ KH 01034504។ ឯកសារ D219/277 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម ឈាន ឆ.៤៦ KH 01088962។ ឯកសារ D219/733 កំណត់ហេតុស្តាប់ចម្លើយ គ៉ីម ផែន ឆ.២២២ KH 01218127។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង ចេង ឆ.៨ KH 00996441។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន ឆ.៣៩-៤០ KH 00955698។ ឯកសារ D118/223 កំណត់ហេតុស្តាប់ចម្លើយ គ៉ីម ហ្ជួយ ឆ.៧ KH 00985377។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.១១ KH 00955680។ ឯកសារ D118/262 កំណត់ហេតុស្តាប់ចម្លើយ ទេព ផុន ឆ.១១-១២ KH 00997941។ ឯកសារ D219/729 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន សាមុត ឆ.១០ KH 01214601។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ.៤៣ KH 01102905។

ប្រជាជនក្នុងភូមិនានាជុំវិញឃុំរំលិច និងឃុំខ្នារទទឹង[3237]។ តាមការព្យាករ ខ្មែរក្រោមនៅស្រុកបាកានក្នុងឆ្នាំ១៩៧៥ មានចំនួនពី ៧.000 ទៅដល់ជាង ១0.000 នាក់[3238]។

888. ខ្មែរក្រោមបានរស់នៅ និងបានរៀបការជាមួយខ្មែរទូទៅនៅស្រុកបាកាន[3239]។ ខ្មែរក្រោមជាច្រើនបានបម្រើក្នុងជួរកងទ័ព លន់ នល់[3240] ចំណែកខ្លះទៀតបម្រើការក្នុងកងកម្លាំងប្រយុទ្ធខ្មែរក្រហមកាលពីដំបូង[3241]។ បន្ទាប់ពីកម្ទាភិបាលភូមិភាគនិរតីបានចូលកាន់កាប់ស្រុកបាកាន[3242] ពួកគាត់បានចាប់ផ្តើមដាក់ខ្មែរក្រោមជាគោលដៅ[3243]។ ប.ក.ក បានចាប់ផ្តើមស្វែងខ្មែរក្រោម ដែលបន្ទាប់មកត្រូវបានដាក់ជាក្រុម ឬជាកងដើម្បីឲ្យធ្វើការងារពលកម្មដ៏លំបាក[3244]។ ក្នុងឆ្នាំ១៩៧៧ និងពិសេសក្នុងឆ្នាំ១៩៧៨ ប.ក.ក បានប្រមែប្រមូលខ្មែរក្រោមពីបណ្តាសហការណ៍នានានៅស្រុក បាកាន និងបានយកពួកគាត់ទៅសម្លាប់នៅខ្នារទទឹង[3245]។ នៅចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរ

[3237] ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.៧១ KH 01075616។

[3238] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ដារ៉ា ឆ.១0, ១៨, ៥២ KH 00973946 KH 00973950។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ជួន ឆ.១៩ KH 00955765។

[3239] ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយ លន ហេង ឆ.១២-១៦ KH 00973978។ ឯកសារ D118/214 កំណត់ហេតុស្តាប់ចម្លើយ ចឹង ភី ឆ.១៥ KH 00982147។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.១៧-១៨ KH 00979031។ ឯកសារ D219/733 កំណត់ហេតុស្តាប់ចម្លើយ គឹម ផែន ឆ.១១, ១៧ KH 01218094-01218095។

[3240] ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន ឆ.៤៥ KH 00955699។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៤៤ KH 00955684។

[3241] ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៤៣ KH 00955684។

[3242] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រ៉ុធ ឆ.៩៦ KH 00985425។ ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន រ៉ន ឆ.៩៧ KH 00977089។ ឯកសារ D118/198 ឈ៉ីម ស្រ៊ិន ឆ.៩-១0, ១២, ៥២ KH 00978979។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.៤៨-៥0, ៦៤ KH 00977066។ *សូមមើលផងដែរ* ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ដារ៉ា ឆ.៥១-៥២ KH 00973950។

[3243] ឯកសារ D219/729 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន សាមុត ឆ.៩0-៩១ KH 01214607-01214608។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សំ ឆ.៥៧-៥៨ KH 00982194។ ឯកសារ D118/234 កំណត់ហេតុស្តាប់ចម្លើយ ទុំ ង៉ា ឆ.៥៥-៥៦ KH 00987980។ ឯកសារ D219/224 កំណត់ហេតុស្តាប់ចម្លើយ ឈួន សុង ឆ.៤៧ KH 01075634។ ឯកសារ D118/213 កំណត់ហេតុស្តាប់ចម្លើយ យ៉ីម ឌុន ឆ.១0៦ KH 00982139។

[3244] ឯកសារ D219/733 កំណត់ហេតុស្តាប់ចម្លើយ គឹម ផែន ឆ.១៩, ២៤0-២៤១ KH 01218130។

[3245] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រ៉ុធ ឆ.៥២-៥៧ KH 00985419-00985420។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ជួន ឆ.២២ KH 00955765។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.៧៣ KH 01075617។ ឯកសារ D219/9 កំណត់ហេតុស្តាប់ចម្លើយ ឃុន សាម៉ៀន ឆ.៨៦, ១១១-១១២ KH 01025565, 01025568

ក្រោមចំនួនរាប់ពាន់នាក់ត្រូវបានសម្លាប់ ហើយប្រជាជនខ្មែរក្រោមនៅបាកានត្រូវបានបំផ្លាញទាំងអស់[3246]។

ii. ការជម្លៀសខ្មែរក្រោមដោយបង្ខំ ទៅកាន់ខ្នារទទឹង និងការសម្លាប់

889. បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីបានមកដល់[3247] ខ្មែរក្រោមត្រូវបានចាប់ខ្លួន និងត្រូវបានបញ្ជូនទៅខ្នារទទឹង ដែលនៅទីនោះពួកគាត់ត្រូវបានបង្ខំឲ្យធ្វើការងារពលកម្ម និងត្រូវបានសម្លាប់ ឬត្រូវបានបញ្ជូនទៅទីតាំងសម្លាប់ដទៃដែលស្ថិតក្នុងស្រុកបាកាន ដូចជាព្រៃក្របៅ ឬទួលស្រែញ៉ែ[3248]។ ប.ក.ក បានបើកការប្រជុំនានានៅឃុំរំលិច ដែលនៅទីនោះមានការប្រកាសថា អ្នកណាដែលមានអតីតភាពជាខ្មែរក្រោម ត្រូវទៅខ្នារទទឹង[3249]។ វ៉ាន់ ចូក ដែលបានរៀបការជាមួយស្ត្រីខ្មែរក្រោម បានចូលប្រជុំនៅរំលិចក្នុងឆ្នាំ១៩៧៧ ដែល ប.ក.ក បានប្រកាសថា ខ្មែរក្រោម និងគ្រួសាររបស់ពួកគាត់ទាំងអស់កំពុងត្រូវបានបញ្ជូនទៅកន្លែងមួយ[3250]។ កម្មាភិបាលបានប្រាប់ខ្មែរក្រោមថា "អង្គការលើ"

។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.២៤ KH 00973948។ ឯកសារ D219/345 កំណត់ហេតុស្តាប់ចម្លើយ នឹម លន ឆ.៥៥, ៦០ KH 01102921-01102922។

[3246] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.២៥ KH 00973948។ ឯកសារ D219/224 កំណត់ហេតុស្តាប់ចម្លើយ ឈួន សុង ឆ.៤៧ KH 01075634។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ចូក ឆ.៧១-៧៣ KH 00973927។ ឯកសារ D118/214 កំណត់ហេតុស្តាប់ចម្លើយ ចឹង ភី ឆ.៣៨ KH 00982150។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ន្ជួន រិន ឆ.៧៣ KH 01075617។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង អេង ឆ.៦៦-៦៧ KH 00996447។

[3247] ឯកសារ D1.3.17.5 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា៖ *របប ប៉ុល ពត ពូជសាសន៍ អំណាច និងអំពើប្រល័យពូជសាសន៍ នៅកម្ពុជាក្រោមដៃពួកខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩*EN 00678751។ *សូមមើលផងដែរ* ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ.៥១ KH 01102906។

[3248] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ែន ដារ៉ា ឆ.៥១-៥២, ៨៤-៨៥ KH 00973950, 00973955។ ឯកសារ D219/692 កំណត់ហេតុស្តាប់ចម្លើយ ឈួន ហ៊ៃ ឆ.២៧ KH 01205252។ ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រ៉ុធ ឆ.៥៩ KH 00985420។

[3249] ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.៤២-៤៣ KH 00977065។

[3250] ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ចូក ឆ.៧-១០, ៤១ KH 00973921, 00973924 ["គេបានប្រជុំប្រាប់យើងទាំងអស់គ្នា ដោយបញ្ជាក់ថា ខ្មែរក្រោមឲ្យនៅម្តុំ ហើយអ្នកដែលមានប្ដី ឬក៏ប្រពន្ធជាខ្មែរក្រោម ក៏ត្រូវទៅជាមួយដែរ"]។

បានកំពុងបញ្ជូនពួកគាត់ទៅខ្នារទទឹង[3251]។ មនុស្សយល់ថា ខ្មែរក្រោមកំពុងត្រូវបានផ្លាស់ទីលំនៅ ពីព្រោះពួកគាត់ត្រូវបានចាត់ទុកជា "យួន"[3252]។ នៅខ្នារទទឹង ខ្មែរក្រោមត្រូវបានបង្ខំឲ្យធ្វើការ[3253] ត្រូវបានផ្តល់ចំណីអាហារបន្តិចបន្តួច និងត្រូវបានវាយដំដូច "សត្វពាហនៈ"[3254]។

890. ដំណើររឿងជាច្រើនបង្ហាញអំពីវិសាលភាពនៃការជម្លៀសដោយបង្ខំទៅខ្នារទទឹង[3255]។ កែវ ម៉ៀ ដែលត្រូវបានបង្ខំឲ្យផ្លាស់ទីលំនៅពីឃុំរលិច ទៅខ្នារទទឹងក្នុងដើមឆ្នាំ១៩៧៧ បាននិយាយថា ខ្មែរក្រោមចំនួនរាប់រយគ្រួសារត្រូវបានបញ្ជូនទៅខ្នារទទឹងក្នុងដើមឆ្នាំ១៩៧៧ ពីព្រោះពួកគាត់ត្រូវបានចាត់ទុកថាមានទំនាក់ទំនងជាមួយ "យួន"[3256]។ ស្រដៀងនេះ ផេក ប៊ុនរឿន បាននិយាយថា ក្នុងឆ្នាំ១៩៧៧ ខ្មែរក្រោមត្រូវបានស្វែងរកក្នុងភូមិរំលិច ហើយប្រហែល២០០ គ្រួសារ ស្មើនឹង១.០០០ នាក់ ត្រូវបានបញ្ជូនទៅខ្នារទទឹងតាមបញ្ជារបស់ ឃាយ រីម ដែលជាសមាជិកសហឧក្រិដ្ឋកម្មរួម[3257]។

[3251] ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ចូក ឆ.៥០ KH 00973925 ["ពួកគេប្រព្រឹត្តិធម្មតា ប៉ុន្តែគេបានប្រាប់ថា អង្គការថ្នាក់លើតម្រូវឲ្យជម្លៀសចេញទៅនៅឃុំខ្នារទទឹង"] ឆ.៤០ KH 00973924 ["ស៖ តើមានគ្រួសារខ្មែរក្រោមប៉ុន្មាន ដែលត្រូវបានជម្លៀសទៅឃុំខ្នារទទឹង? ឆ.៤០៖ មានប្រហែល១០០គ្រួសារ ហើយបើគិតជាចំនួនមនុស្ស មានប្រហែល២០០០នាក់"]។

[3252] ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ចូក ឆ.៤០ KH 00973924 ["ស៖ តើមានគ្រួសារខ្មែរក្រោមប៉ុន្មាន ដែលត្រូវបានជម្លៀសទៅឃុំខ្នារទទឹង? ឆ.៤០៖ មានប្រហែល១០០គ្រួសារ ហើយបើគិតជាចំនួនមនុស្ស មានប្រហែល២០០០នាក់"] ឆ.៤២ KH 00973924 ["គេពុំបានប្រាប់អំពីមូលហេតុនៅពេលប្រជុំនោះ ប៉ុន្តែមានពាក្យនិយាយនៅខាងក្រៅថា ខ្មែរក្រោមទាំងនោះ គឺជាយួន"] ឆ.៥០ KH 00973925 ["ពួកគេប្រព្រឹត្តិធម្មតា ប៉ុន្តែគេបានប្រាប់ថា អង្គការថ្នាក់លើតម្រូវឲ្យជម្លៀសចេញទៅនៅឃុំខ្នារទទឹង"]។

[3253] ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ៀ ឆ.៩០-៩១ KH 01186831។ ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយ លន ហេង ឆ.៥០ KH 00973981។

[3254] ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ រ៉ាន់ ចូក ឆ.៦០ KH 00973927។

[3255] ឯកសារ D118/254 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ឡូយ ឆ.២២-២៣ KH 00995424 ["ឆ.២២៖ នៅដើមដំបូងនៃរបបខ្មែរក្រហមប្រព័ត្តដូចគ្នាចំពោះខ្មែរក្រោម និងប្រជាជនធម្មតា គឺគេឲ្យធ្វើមេកង ឬក៏អ្វីផ្សេងដូចគ្នា។ ប៉ុន្តែប្រហែលជាប៉ុន្មានឆ្នាំក្រោយមក គេបានប្រមូលខ្មែរក្រោម ហើយបញ្ជូនទៅដាក់នៅខ្នារទទឹង ដើម្បីសម្លាប់ចោល។ ស៖ តើលោកស្រីអាចពិពណ៌នាអំពីការចាប់ប្រមូលខ្មែរក្រោមទៅដាក់នៅខ្នារទទឹងបានដែរ ឬទេ? ឆ.២៣៖ គេបានដាក់ខ្មែរក្រោមនៅខ្នារទទឹង ហើយគេឲ្យខ្មែរក្រោមស្ទូងដកនៅទីនោះ"]។

[3256] ឯកសារ D219/639 កំណត់ហេតុស្តាប់ចម្លើយ កែវ ម៉ៀ ឆ.៨៣, ៨៥-៨៧ KH 01186831។

[3257] ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរឿន ឆ.២៦, ២៨-៣៥ KH 00955682, 00955683។

891. ឡុន ប៊ីង ដែលត្រូវបានផ្ទាស់ទីលំនៅជាមួយគ្រួសាររបស់គាត់ និងសាច់ផ្ទៃរបស់គាត់ក្នុងឆ្នាំ ១៩៧៧[3258] បាននិយាយថា ការជម្លៀសដោយបង្ខំទៅលើខ្មែរក្រោមបានបណ្តាលឲ្យខ្មែរក្រោមចំនួនរាប់ពាន់នាក់ ត្រូវបានស្ថិតក្នុងឃុំខ្ទារទទឹង[3259]។ ដូចគ្នានេះ ឆាត់ ផាន ខ្មែរក្រោមរស់នៅឃុំខ្ទារទទឹង បានបញ្ជាក់លម្អិតអំពីវិធីដែលក្នុងចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨ ក្រោមការត្រួតពិនិត្យរបស់ យាយ រីម ខ្មែរក្រោមចំនួនរាប់ពាន់នាក់ត្រូវបានប្រមូលផ្តុំ និងត្រូវបានបញ្ជូនទៅខ្ទារទទឹង[3260]។

892. ការសម្លាប់បានចាប់ផ្តើមមិនយូរប៉ុន្មានក្រោយពេលគ្រួសារខ្មែរក្រោមត្រូវបានបញ្ជូន ដោយបង្ខំទៅតំបន់នោះ។ ង៉ែត រុត ដែលត្រូវបានជម្លៀសទៅជាមួយគ្រួសាររបស់គាត់ និងខ្មែរក្រោមចំនួនរាប់រយ គ្រួសារទៀត[3261] បានរៀបរាប់លម្អិតអំពីវិធីដែលបីខែក្រោយពួកគាត់បានមកដល់ក្នុងឆ្នាំ ១៩៧៧ ប.ក.ក បានប្រមូលខ្មែរក្រោមយកទៅសម្លាប់នៅកូនកំប្រុកក្នុងឃុំខ្ទារទទឹង[3262]។ ម្តាយរបស់ ង៉ែត រុធ បានប្រាប់កម្មាភិបាលថាគាត់ និងកូនប្រុស ជាខ្មែរ ហើយពួកគាត់ត្រូវបានបញ្ជូនត្រឡប់ទៅសហករណ៍វិញ[3263]។ ល្ងាចនោះ បុរស ស្ត្រី កុមារ និងមនុស្សចាស់ខ្មែរក្រោមចំនួនរង្វង់ ២០០នាក់ ដោយរួមទាំងឪពុករបស់ ង៉ែត រុធ ផង ត្រូវបានយកទៅសម្លាប់[3264]។

893. អ្លង សារ ដែលធ្វើការនៅសហករណ៍បាកាន បាននិយាយថា ពីដើមឆ្នាំ១៩៧៧ រហូតដល់ខែមីនា ឆ្នាំ ១៩៧៨ ខ្មែរក្រោមត្រូវបានយកទៅសម្លាប់ "ថ្ងៃយប់" ពីព្រោះពួកគាត់ត្រូវបានចោទថាជា "ខ្ជាំង

[3258] ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយ លន ហេង ឆ.៣៨ KH 00973980 ["បន្ទាប់មករហូតដល់ឆ្នាំ១៩៧៧ គេបានជម្លៀសខ្ញុំទៅភូមិកំប្រាក់កូន ក្នុងឃុំខ្ទារទទឹង គឺជម្លៀសទាំងប្រពន្ធដើម ទាំងកូន ទាំងឪពុកម្តាយក្មេក គឺទាំងគ្រួសារតែម្តង។ នៅពេលនោះ គឺជម្លៀសតែគ្រួសារខ្មែរក្រោមប៉ុណ្ណោះ ចំណែកខ្មែរធម្មតា គឺពុំជម្លៀសទេ"]។

[3259] ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយ លន ហេង ឆ.៣៩ KH 00973980 ["ស៖ តើខ្មែរក្រហមជម្លៀសខ្មែរក្រោមទាំងអស់ ឬក៏យ៉ាងណា? ឆ.៣៩៖ បាទ គឺទាំងអស់ឲ្យតែជាខ្មែរក្រោម គឺមានរាប់ម៉ឺននាក់។ ខ្មែរក្រោមត្រូវបានគេដាក់នៅក្នុងភូមិពីរ គឺភូមិខ្ទារទទឹង និងភូមិកំប្រាក់កូន"]។

[3260] ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៧៥-៧៩, ៨៤ KH 00996460, 00996461។

[3261] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៥៣ KH 00985419 ["គេបានប្រមូលខ្ទេរកម្ពុជាក្រោមដាក់ម្ពុំ បន្ទាប់មក គេបញ្ជូនទៅដាក់នៅក្នុងសហករណ៍ខ្ទារទទឹង។ ខ្ទេរក្រោម ដែលនៅក្នុងសហករណ៍ណាក៏ដោយ ក្នុងស្រុកបាកាន ត្រូវគេបញ្ជូនទៅដាក់ក្នុងសហករណ៍ខ្ទារទទឹងទាំងអស់។ នៅពេលនោះ គឺពុំមានឃុំទេ គេប្រើពាក្យសហករណ៍ខ្ទារទទឹង"] ឆ.៥៤, ៥៧ KH 00985419-00985420។

[3262] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៥៩-៦០ KH 00985420។

[3263] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៦០ KH 00985420។

[3264] ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៦១-៦៣ KH 00985420។

ឃ្លួន"[3265]។ ខ្មែរក្រោមដែលត្រូវបានបញ្ជូនទៅសម្លាប់នៅខ្នារទទឹង[3266] បានរួមបញ្ចូលប្រពន្ធរបស់ អ្លង សារ (ដែលជាខ្មែរក្រោម) និងបងប្អូនជីដូនមួយរបស់គាត់ (ដែលបានរៀបការជាមួយស្ត្រីខ្មែរ ក្រោម)។ ប្រធានឈ្លបនៃសហករណ៍របស់ អ្លង សារ ត្រូវបានសម្លាប់ជាមួយប្រពន្ធ និងកូនរបស់ គាត់ពីព្រោះគាត់ជាប់ភេរវដំណែលវៀតណាម[3267]។

894. សមាជិកគ្រួសារខ្មែរក្រោមរបស់ សឿន ធឿន ចំនួន ៥០ ទៅ ៦០ នាក់ រួមបញ្ចូលឪពុកម្តាយ និងជីដូន ជីតារបស់គាត់ ត្រូវបានបញ្ជូនទៅសម្លាប់នៅខ្នារទទឹង ពីព្រោះពួកគាត់ត្រូវបានចោទថាជា វៀត ណាម[3268]។ ក្នុងឆ្នាំ១៩៧៨ ប្រពន្ធខ្មែរក្រោមរបស់ កឹម ផែន កូនៗរបស់គាត់ បងប្អូន និងឪពុក ម្តាយរបស់ប្រពន្ធរបស់គាត់ និងខ្មែរក្រោមចំនួនរាប់រយនាក់ផ្សេងទៀត ត្រូវបានបញ្ជូនពីឃុំត្រពាំង ជង ទៅភូមិកូនកំប្រុក ខ្នារទទឹង[3269]។ ប្រធានសហករណ៍របស់ កឹម ផែន បាននិយាយថា អ្នកណា ជាប់ខ្សែរយៈជាមួយខ្មែរក្រោមនឹងត្រូវសម្លាប់[3270]។

[3265] ឯកសារ D118/199 កំណត់ហេតុស្តាប់ចម្លើយ អ្លង សារ ឆ.១៦, ៣០-៣១ KH 00978993, 00978995។

[3266] ឯកសារ D118/199 កំណត់ហេតុស្តាប់ចម្លើយ អ្លង សារ ឆ.៤១ KH 00978997។

[3267] ឯកសារ D118/199 កំណត់ហេតុស្តាប់ចម្លើយ អ្លង សារ ឆ.៣០, ៤៣ KH 00978995, 00978997។

[3268] ឯកសារ D219/342 កំណត់ហេតុស្តាប់ចម្លើយ សឿន ធឿន ឆ.៩៧-៩៨ KH 01102888 ["ស៖ ក្នុងពាក្យបណ្តឹងរបស់លោក និយាយថា សាច់ញាតិពី ៥០ទៅ ៦០នាក់ រួមទាំងយាយតារបស់លោកទៀត ត្រូវបានគេយកទៅភូមិខ្នារទទឹង។ តើមានរឿងអ្វីកើត ឡើងចំពោះពួកគាត់? ឆ.៩៧៖ គេសម្លាប់ទាំងអស់ ព្រោះគេចោទថាជាឃ្លួន។ សូម្បីតែខ្ញុំ ក៏គេសម្លាប់ដែរ។ គេចាប់ចងដៃគាត់ ហើយហ្នឹង តែគាត់រើណ្ណបងាប់បានមួយ។ ប៉ុន្តែខ្ញុំអត់ឃើញនឹងភ្នែកទេ។ ខ្ញុំនៅព្រំដែន។ ខ្ញុំឮតែតាមគេប្រាប់ដែរទេ។ បើខ្ញុំដឹង នៅ ពេលនោះ ខ្ញុំប្រាកដជាមកមិនខាន ព្រោះខ្ញុំមានកាំភ្លើងនៅនឹងដៃដែរ។ ស៖ តើពួកគាត់សុទ្ធតែជាខ្មែរកម្ពុជាក្រោមទាំងអស់ឬ?"] ឆ .១០២ KH 01102888។

[3269] ឯកសារ D219/733 កំណត់ហេតុស្តាប់ចម្លើយ គឹម ផែន ឆ.៥៧ KH 01218101 ["ខ្ញុំសហករណ៍ហ្នឹង សូមជម្រាបអ៊ីចឹង ដល់ហ្នឹងសហករណ៍ត្រពាំងជងខ្ញុំចេញហើយ ខ្ញុំទៅតាមគ្រួសារខ្ញុំ ដែលគេយកទៅសម្លាប់ ដល់ ៧៨ គេយកគ្រួសារខ្ញុំទោសម្លាប់។ ប្រមូលប្រពន្ធកូនទៅភូមិកំប្រាក់កូនសហករណ៍ខ្នារទទឹង។ ដល់ពេល ៧៨ហ្នឹង គេយកគ្រួសារខ្ញុំ បងប្អូនគ្រួសារខ្ញុំ បងប្អូនខ្ញុំ ឪពុក ម្តាយក្មេក និងបងប្អូនខ្មែរក្រោមច្រើនរយនាក់ទៅភូមិខ្នារទទឹង"] ឆ.៥៩ KH 01218102 ["ដំណាក់កាលទី ១ គេប្រមូលខ្មែរក្រោម ទាំងអស់ ទាំងក្មេង ទាំងធំទៅទាំងអស់។ ដំណាក់កាលទី ១ គេប្រមូលពីសហករណ៍ត្រពាំងជងទៅដាក់ខ្នារទទឹង។ ដំណាក់កាលទី ២ គេយកខ្មែរក្រោមពីខ្នារទទឹងទៅសម្លាប់នៅកំប្រាក់កូន"]។

[3270] ឯកសារ D219/733 កំណត់ហេតុស្តាប់ចម្លើយ គឹម ផែន ឆ.៦២-៦៤ KH 01218102 ["ឆ.៦២៖ ខ្ញុំសុំគេ ២ថ្ងៃបានគេឲ្យទៅ។ ខ្ញុំសុំគណៈសហករណ៍ឈ្មោះ សន។ គេប្រាប់ខ្ញុំថា មិត្តឯងទៅធ្វើស្អី គេយកប្រពន្ធមិត្តឯងទៅសម្លាប់ហើយ មិត្តឯងទៅធ្វើស្អី។ ខ្ញុំ បានប្រាប់ថា ខ្ញុំអាណិតប្រពន្ធកូនខ្ញុំណាស់ បើសិនជាសម្លាប់ សម្លាប់ទាំងខ្ញុំចុះ។ ក្រោយពីសុំគេ គេក៏អនុញ្ញាតឲ្យខ្ញុំទៅតាមគ្រួសារ នៅខ្នារទទឹង។ ស៖ តើ សន បានប្រាប់លោកថា មូលហេតុអីបានគេយកប្រពន្ធទៅសម្លាប់នៅខ្នារទទឹង? ឆ.៦៣៖ គេបានប្រាប់

895. ការសម្លាប់ និងការបាត់ខ្លួនខ្មែរក្រោមនៅខ្នារទទឹងក្នុងឆ្នាំ១៩៧៧-១៩៧៨ ក៏បានរួមបញ្ចូល[3271]ៃ ឪពុកម្តាយ និងបងប្អូនរបស់ កឹម ហួយ ព្រមទាំងបងប្អូនស្រីជីដូនមួយរបស់គាត់ដែលត្រូវបានរំលោភមុនពេលត្រូវបានសម្លាប់[3272] ឪពុកម្តាយរបស់ គីម ស្ង[3273] ប្តីរបស់ ឈួន ហាយ និងគ្រួសាររបស់គាត់[3274] ប្រពន្ធ និងកូនៗរបស់ វន ម៉ុច[3275] គ្រួសារមីង និងពូរបស់ រឿន ដារា សរុប៤២ នាក់[3276] បងស្រី២ នាក់ និងកូនៗរបស់ពួកគាត់របស់ សម វណ្ណា[3277]។ មីងរបស់ ឆាត ផាន និងខ្ញែ

មូលហេតុអត់ច្បាស់ តែគេប្រាប់ថា ឲ្យតែជាប់ខ្ញែស្រឡាយខ្មែរក្រោម គេយកទៅសម្លាប់ទាំងអស់។ ស៖ សន ប្រាប់លោកថា អ្នកណាឲ្យតែជាប់ខ្ញែខ្មែរក្រោម គេយកទៅសម្លាប់? ឆ.៦៤៖ បាទ"] ឆ.១១៥, ២០៨, ២១០ KH 01218110, 01218125។

[3271] ឯកសារ D219/729 កំណត់ហេតុស្តាប់ចម្លើយ ប៉ាន សាមុត ឆ.១២៩ KH 01214611។

[3272] ឯកសារ D118/223 កំណត់ហេតុស្តាប់ចម្លើយ គឹម ហួយ ឆ.៣៣ KH 00985380 ឆ.៣៥ KH 00985380 ["នៅខែ៧ ឆ្នាំ១៩៧៧ ខ្ញុំដឹងថាបងប្អូន និងឪពុកម្តាយរបស់ខ្ញុំត្រូវគេសម្លាប់។ ប្តីរបស់ខ្ញុំ (គី ហេង) បានធ្វើដំណើរទៅកំពង់ឆ្នាំង ហើយពេលគាត់ត្រឡប់មកវិញបានប្រាប់ខ្ញុំថា គេបានចម្រាញ់រកខ្ញែរកម្ពុជាក្រោម។ ពេលនោះ ខ្ញុំគិតថា បើដូច្នោះ ឪពុកម្តាយ ណាងបងប្អូនរបស់ខ្ញុំច្បាស់ជាមិនរស់ទេ។ ក្រោយចប់របបខ្ញែរក្រហម ម្តាយមីងរបស់ខ្ញុំបានប្រាប់ថា បងប្អូន និងឪពុកម្តាយរបស់ខ្ញុំត្រូវគេប្រមូលឲ្យទៅរស់នៅខ្នារទទឹងនៅថ្ងៃទី១៧ ខែ៧ ឆ្នាំ១៩៧៧។ ខ្ញែរក្រោមទាំងអស់ត្រូវគេប្រមូលយកទៅដាក់នៅខ្នារទទឹង បានតែ១២ថ្ងៃប៉ុណ្ណោះ គេបានបញ្ជូនខ្ញែរក្រោមទាំងអស់នោះទៅដាក់នៅភូមិកំប្រាក់ក្ងន ហើយដាក់នៅភូមិកំប្រាក់ក្ងនបានពីរយប់ ទើបគេយកទៅសម្លាប់។ គេបានយកខ្ញែរក្រោមទៅសម្លាប់នៅទួលសេះញ៉ូ និងព្រៃក្របៅ។"] ឆ.៤៣ KH 00985381 ["ចាស។ នៅឆ្នាំ១៩៧៧ គេបានប្រមូលខ្ញែរក្រោមទៅសម្លាប់ចោលទាំងអស់ នៅពេលនោះ គេបានរើសយកនារីណាដែលស្អាតទុកសម្រាប់រំលោភ ហើយប្អូនជីដូនមួយរបស់ខ្ញុំក៏ត្រូវគេទុករំលោភផងដែរ។ រឿងគេរំលោភប្អូនជីដូនមួយរបស់ខ្ញុំកើតឡើងនៅ ដើមខែកក្កដា ឆ្នាំ១៩៧៧"] ឆ.៧, ១៩-២០ KH 00985377, 00985378។

[3273] ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម ស្ង, ឆ៣២-៣៣ KH 00955711។

[3274] ឯកសារ D219/692 កំណត់ហេតុស្តាប់ចម្លើយ ឈួន ហៃ ឆ.៦០-៦២ KH 01205257 ["ស៖ លោកស្រីថា លោកស្រីឃើញរណ្តៅសាកសពដោយរបៀបណា ហើយពេលណា? ឆ.៦០៖ មុនពេលសម្លាប់ គេហៅប្រជាជនទៅកាប់រណ្តៅ [...]បងប្អូនខាងប្តីខ្ញុំ គេយកទៅទាំងអស់ ទាំងចាស់ ទាំងក្មេង។ ស៖ តើបងប្អូនប្តីរបស់លោកស្រី ជាខ្ញែរក្រោមមែនទេ? ឆ.៦១៖ ខ្ញែរក្រោម។ ស៖ តើប្តីរបស់លោកស្រីជាខ្ញែរក្រោមដែរទេ? ឆ.៦២៖ ខ្ញែរក្រោម គេយកទៅសម្លាប់អស់ហើយ"]។

[3275] ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ុច ឆ.៥៧-៥៩ KH 00977098។

[3276] ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ដារ៉ា ឆ.៥៥, ៥៧-៥៨ KH 00973951។

[3277] ឯកសារ D219/46 កំណត់ហេតុស្តាប់ចម្លើយ សោម វណ្ណា ឆ.៧៤-៧៥ KH 01032227 ["ឆ.៧៤៖ ខ្ញុំឮពីអ្នកស្រុកនៅទីនោះប្រាប់ខ្ញុំក្រោយរបបខ្ញែរក្រហមថា បងស្រីរបស់ខ្ញុំទាំងពីរនាក់ត្រូវគេយកទៅវ៉ៃចោលបាត់ហើយ។ ស៖ លោកមានបងស្រីបង្កើតពីរនាក់ត្រូវគេសម្លាប់នៅខ្នារទទឹង តើត្រឹមត្រូវដែរ ឬទេ? ឆ.៧៥៖ បាទ ត្រឹមត្រូវ។ បើរាប់ទាំងកូយរបស់ខ្ញុំផង គឺមានទាំងអស់ប្រាំមួយនាក់"] ឆ.៧៧ KH 01032228 ["ស៖ តើលោកដឹងអំពីមូលហេតុ ដែលគេសម្លាប់បងស្រីទាំងពីរនាក់របស់លោកដែរ ឬទេ? ឆ.៧៧៖ គេប្រាប់ថា "ឲ្យតែជាខ្ញែរក្រោម គេសម្លាប់ចោលទាំងអស់"។ គេនិយាយទៀតថា "ខ្ញែរក្រោមជាយួន"]។ *សូមមើលផងដែរ* ឆ.៤, ១០-១៣ KH 01032220។

ក្រោម៥ នាក់ផ្សេងទៀត ដែលរួមមានស្ត្រីមានគភ៌ម្នាក់[3278] ឪពុកម្តាយ និងបងប្អូនរបស់ សេង អេង[3279] ឪពុកម្តាយរបស់ ចឹង ភី[3280] និងស្ត្រីមួយក្រុមចំនួន២០ នាក់[3281]។ ខ្មែរក្រោមខ្លះដែលត្រូវបានបញ្ជូនទៅខ្នារទទឹង បានអត់ឃ្លានរហូតដល់ស្លាប់[3282]។ ខ្មែរក្រោមជាច្រើនដែលដំបូងត្រូវបានបញ្ជូនទៅខ្នារទទឹង ក្រោយមកត្រូវបានបញ្ជូនទៅទីតាំងផ្សេងៗដើម្បីសម្លាប់ ពិសេសនៅទីតាំងពិឃាតទួលស្រយ៉ូវ និងព្រៃក្របៅ[3283]។

ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូវ និងព្រៃក្របៅ

896. ខ្មែរក្រោមត្រូវបានបញ្ជូនពីតំបន់ដទៃនៃស្រុកបាកាន ទៅសម្លាប់នៅទីតាំងសម្លាប់មនុស្ស ទួលសេះ ញ៉ូវ និងព្រៃក្របៅ ពីពាក់កណ្តាលទៅចុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨[3284]។ ដូចដែលបានបញ្ជាក់

[3278] ឯកសារ D118/257 កំណត់ហេតុស្តាប់ចម្លើយ ឆាត់ ផាន់ ឆ.៨៥-៨៧, ៩០-៩៦, ១០៣-១០៤ KH 00996461 KH 00996462, 00996463។

[3279] ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង អេង ឆ.៦១-៦៤, ៧៦, ៧៩-៨០ KH 00996446-00996447, 00996448, 00996449។

[3280] ឯកសារ D118/214 កំណត់ហេតុស្តាប់ចម្លើយ ចឹង ភី ឆ.៣៥ KH 00982150 ["ខ្ញុំត្រូវគេជម្លៀសនៅបាត់ដំបង ទើបខ្ញុំអាចនៅរស់រានមានជីវិតបាន។ ចំណែកឪពុកម្តាយខ្ញុំនៅភូមិរំលេចទាំងអស់ គេបានយកពួកគាត់ទៅដាក់នៅខ្នារទទឹង បន្ទាប់មក គេយកទៅសម្លាប់នៅទួលសេះញ៉ូវ"]។

[3281] ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីនួន ឆ.៦១-៦៤ KH 00955771 ["ឆ.៦១៖ គេបានចាប់ខ្ញុំនៅដីរនាត ដោយមានការី១៩ផ្សេងទៀត ហើយសុទ្ធតែជាខ្មែរក្រោម។ ស៖ តើមូលហេតុនៃការចាប់ គឺដោយសារតែអ្នកទាំងអស់នោះ ជាខ្មែរក្រោមមែនទេ? ឆ.៦២៖ ចាស ដោយសារមូលហេតុជាខ្មែរក្រោម ហើយគេបានប្រាប់ថា ឲ្យដូរសមរភូមិ។ ស៖ តើអ្នកណាជាអ្នកចាប់ណេកស្រី? ឆ.៦៣៖ ១ខែក្រោយពេល ដែលខ្ញុំទៅធ្វើការនៅដីរនាត សហករណ៍រំលេចបានដាក់សំបុត្រ ដោយប្រាប់ថា គេមានការបែងចែកខ្ទែរក្រោមរស់នៅផ្សេង ខ្ទែរធម្មតារស់នៅផ្សេង។ ដូច្នេះហើយទើបគេឲ្យយើងត្រឡប់មកវិញ។ គេបានសរសេរសំបុត្រទៅតាសយ ប៉ុន្តែ តាសយជួយខ្ញុំ ដោយសារកូយរបស់គាត់ស្រឡាញ់ខ្ញុំ។ ស៖ ចុះនារី១៩នាក់ផ្សេងទៀត តើមានអ្វីកើតឡើងចំពោះពួកគេ? ឆ.៦៤៖ គេបញ្ជូនមកនៅខ្នារទទឹង គឺស្លាប់ទាំងអស់"]។

[3282] ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីម ស៊ីនួន ឆ.៨១ KH 01067988។

[3283] ឯកសារ D219/692 កំណត់ហេតុស្តាប់ចម្លើយ ឈួន ហ៊ៃ ឆ.៥៣ KH 01205256 ["គេយកទៅច្រើនណាស់ ពេលខ្លះ យក ៥០ទៅ ៦០នាក់ ថ្ងៃក្រោយ១០ទៅ ២០នាក់ទៅ។ គេស្រាវជ្រាវរកឲ្យអស់"] ឆ.៥៨ KH 01205256 ["គេកាប់រណ្តៅ៥ទៅ៦ម៉ែត្រ ហើយគេសម្លាប់ដាក់ក្នុងនោះទាំងអស់"]។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ.៥៣ KH 01102906 ["ភាគច្រើន គេយកកម្ពុជាក្រោម ពួកព្រះត្រពាំង ពីរំលេច ទៅព្រៃក្របៅ នៅភូមិទួលថ្ម"]។

[3284] ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.៣៧-៣៨ KH 01198089-01198090។ ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភេ ឆ.៦៧, ៧៣ KH 01102907, 01102908។ ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ រ៉ើន ដារ៉ា ឆ.២៤ KH 00973947។ ឯកសារ D219/57 កំណត់ហេតុស្តាប់ចម្លើយ គង់ រុន ឆ.១៤៦ KH 01034512។ ឯកសារ

លម្អិតក្នុងផ្នែកស្តីពីទីតាំងឧក្រិដ្ឋកម្ម[3285] ជនរងគ្រោះនៅទីតាំងទាំងពីរនេះបានរួមបញ្ចូលប្តីប្រពន្ធខ្មែរនៃខ្មែរក្រោម និងកុមារដែលបានជ្រើសរើសយកឪពុកម្តាយខ្មែរក្រោមរបស់ពួកគាត់ នៅពេលកម្មាភិបាល ប.ក.ក បានបង្ខំពួកគេឲ្យជ្រើសរើសរវាងឪពុកឬម្តាយខ្មែរ ឬខ្មែរក្រោម[3286]។ ខ្មែរក្រោមចំនួនរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីតាំងពិឃាតទាំងនេះ[3287]។

<u>ការប្រព្រឹត្តទៅលើប្រជាជនវៀតណាម និងខ្មែរក្រោមនៅឃុំរំលេច</u>

897. នៅពេលចាប់ផ្តើមនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រោមជាច្រើនបានរស់នៅឃុំរំលិច[3288]។ ខ្មែរក្រោមតិចតួច ដែលបានរួចពីស្លាប់ក្នុងរបបខ្មែរក្រហម។ មានការព្យាករថា ខ្មែរក្រោមចំនួនរាប់ពាន់នាក់ត្រូវបានសម្លាប់នៅរំលិច[3289]។ ប.ក.ក បានចាប់ផ្តើមសម្លាប់ខ្មែរក្រោមនៅរំលិចក្នុងឆ្នាំ

D6.1.758 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង EN 00387496-00387497។ ឯកសារ D118/199 កំណត់ហេតុស្តាប់ចម្លើយ អ្ជង សារ ឆ.៣០ KH 00978995។

3285 *សូមមើល* V.B.5.c.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់២ – ទីតាំងសម្លាប់មនុស្សទួលសេះញ្ជ៉ូ និងព្រៃក្រហៅ – ឧក្រិដ្ឋកម្ម។

3286 ឯកសារ D118/226 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត រុធ ឆ.៥៨-៦១, ៩៣-៩៥ KH 00985420, 00985424។

3287 ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង អេង ឆ.៦៦-៦៧ KH 00996447។ ឯកសារ D118/122 កំណត់ហេតុស្តាប់ចម្លើយ ចឹក ប៊ុនរ៉ឿន ឆ.៤៨ KH 00955685។ *សូមមើលផងដែរ* ឯកសារ D118/147.1.43 របាយការណ៍សិក្សាស្រាវជ្រាវអំពីសាលាក្តីខ្មែរក្រហម ប្រវត្តិសាវតារ រ៉ែន រ៉ន EN 00527117-00527118។

3288 ឯកសារ D118/1 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក សៀម ឆ.១៧ KH 00872599 ["នៅក្នុងឃុំរំលេច មានខ្មែរក្រោមជាច្រើនមករស់នៅតាំងពីមុនរបបខ្មែរក្រហម"]។ ឯកសារ D118/193 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ម៉ុច ឆ.៥-៦ KH 00977093។ ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.៧-៩ KH 00955708។ ឯកសារ D118/127 កំណត់ហេតុស្តាប់ចម្លើយ ពៅ ស៊ីន្ធន ឆ.៤ KH 00955764។ ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.១៦ KH 00979031។ ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២៣ KH 01075700។ ឯកសារ D118/191 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត ចាត ឆ.៤១ KH 00977065។

3289 ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក ឃីន ឆ.២១-២២ KH 00955698 ["ឆ.២១៖ មិនមែនអ៊ីចឹងទេ ភូមិរំលេចភាគច្រើនជាខ្មែរក្រោម ហើយមានតែ១៥គ្រួសារ ប៉ុន្តែដែលនៅរស់រានមានជីវិត។ ស៖ តើលោកអាចប្រាប់ពីចំនួនខ្មែរក្រោម ដែលគេសម្លាប់បានដែរ ឬទេ? ហើយមានអ្នកនៅរស់រានមានជីវិតមានចំនួនប៉ុន្មាន? ឆ.២២៖ ខ្ញុំមិនដឹងទេ មិនតិចជាងពាក់នាក់ទេ ដែលត្រូវយកទៅសម្លាប់ ហើយនៅក្នុងភូមិមានតែ១៥គ្រួសារប៉ុណ្ណោះ ដែលនៅរស់រានមានជីវិត"] ឆ.៤១-៤៣ KH 00955699 ["ស៖ តាមដែលលោកដឹងនៅសម័យខ្មែរក្រហម តើខ្មែរក្រោមត្រូវបានគេរើសអើង ឬបៀតបៀនដែរ ឬទេ? ឆ.៤១៖ បាទ ពួកគេត្រូវបានគេយកទៅសម្លាប់ផុតពូជអស់ទៅហើយ នៅសល់តែប្រហែល១៥គ្រួសារប៉ុណ្ណោះ។ ខ្មែរក្រោម ដែលនៅរស់សព្វថ្ងៃនេះ ក៏ត្រូវបានគេហៅទៅសម្ភាសនៅភ្នំពេញផងដែរ។ ស៖ តើលោកដឹងអំពីការសម្លាប់ពួកខ្មែរក្រោម ជាទ្រង់ទ្រាយធំនៅ ស្រុកបាកានដែរ ឬទេ? ឆ.៤២៖ បាទ ខ្ញុំដឹង។ [...] ស៖ តើលោកដឹងអ្វីអំពីរឿងនេះ? ឆ.៤៣៖ គេសម្លាប់ច្រើនណាស់ សម្លាប់ទាល់តែអស់ពីភូមិ

១៩៧៧[3290]។ ណាម អ៊ីន ប្រធានក្រុមនៅបាក់ចិញ្ជៀន[3291] បាននិយាយថា ប.ក.ក បានស្នើសុំការបញ្ជូនខ្មែរក្រោមទៅរំលិចក្នុងឆ្នាំ១៩៧៨[3292]។ មនុស្សចំនួនប្រហែល ៥ គ្រួសារ ត្រូវបានយកចេញពីសហករណ៍របស់ ណាម អ៊ីន[3293]។ ណាម អ៊ីន បន្ទាប់មកបានដឹងថា ខ្មែរក្រោមដែលត្រូវបានបញ្ជូនចេញទៅនោះ ត្រូវបានសម្លាប់ទាំងអស់[3294]។

ហើយនៅសល់តែកូនចៅប្រហែល១៥គ្រួសារប៉ុណ្ណោះ"]។ *សូមមើលផងដែរ* ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.១១-១២ KH 00979030។ ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ KH 00267776 ["ស៖ តើក្រោយឆ្នាំ១៩៧៩ មានខ្មែរកម្ពុជាក្រោមរស់នៅក្នុងភូមិរំលេចដែរ ឬទេ? ឆ៖ គ្មានទេ។ មានតែខ្មែរកម្ពុជាក្រោម ដែលទៅរស់នៅបាត់ដំបងនៅរស់"]។

[3290] ឯកសារ D118/227 កំណត់ហេតុស្តាប់ចម្លើយ ហេង ជា ឆ.៣១ KH 00985435។

[3291] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.១៧, ៣២ KH 01000258, 01000260។

[3292] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.៨២-៨៣ KH 01000265 ["ស៖ នៅក្នុងតំបន់របស់លោក តើមានប្រជាជនខ្មែរកម្ពុជាក្រោមរស់នៅដែរ ឬទេ? ឆ.៨២៖ បាទ មាន។ ស៖ តើខ្មែរកម្ពុជាក្រោមត្រូវគេបែងចែកទៅដាក់តាមសហករណ៍ដែរ ឬទេ? ឆ.៨៣៖ នៅឆ្នាំ១៩៧៨ គេបានស្នើសុំឲ្យខ្មែរក្រោមទៅនៅរំលេច ដើម្បីរៀបសហករណ៍ថ្មីនៅទីនោះ។ បន្ទាប់មកខ្មែរក្រោមក៏ត្រូវគេយកទៅសម្លាប់"]។

[3293] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.៨៤ KH 01000265 ["ក្នុងសហករណ៍របស់ខ្ញុំមានខ្មែរក្រោមប្រហែលជា ៤ទៅ ៥គ្រួសារដែរ ដែលបានទៅសហករណ៍រំលេច។ ដំបូង គេពុំទាន់សម្លាប់ទេ"] ឆ.៨៨ KH 01000266។

[3294] ឯកសារ D118/278 កំណត់ហេតុស្តាប់ចម្លើយ ណម អ៊ីម ឆ.៨៤-៨៦ KH 01000265។

898. ការសម្លាប់ខ្មែរក្រោមនៅរំលិចក្នុងឆ្នាំ១៩៧៧-១៩៧៨ ក៏បានរួមបញ្ចូល៖ គ្រួសាររបស់បងប្អូនធម៌របស់ គួយ ប៊ុនធឿន[3295] ឪពុកធម៌របស់ ប្រាក់ សារិន[3296] បងប្អូនរបស់ ហាម ស៊ីន្ធួន[3297] និងប្រពន្ធរបស់ យាន ផាន និងគ្រួសាររបស់គាត់[3298]។ យាន ផាន បាននិយាយថា ខ្មែរក្រោមចន្លោះពី ១០ ទៅ ៣០ នាក់ ត្រូវបានយកទៅសម្លាប់ជាប្រចាំថ្ងៃ ពីព្រោះពួកគេត្រូវបានចោទថា ជាភ្នាក់ងារវៀតណាម[3299]។ សមាជិកមួយរូបនៃគណៈសហការណ៍ស្រោង បានប្រាប់ សុខ ផេ ក្នុងឆ្នាំ១៩៧៧

[3295] ឯកសារ D118/229 កំណត់ហេតុស្តាប់ចម្លើយ គួយ ប៊ុនធឿន ឆ.២៥-២៦ KH 00985458 ["ស៖ ពេលដែលខ្មែរក្រោមឈឺ តើត្រូវគេបញ្ជូនទៅមន្ទីរពេទ្យរបស់លោកដែរ ឬទេ? ឆ.២៥៖ ដំបូង ពេលអ្នកណាដែលឈឺនឹងត្រូវគេយកទៅដាក់នៅមន្ទីរពេទ្យរបស់ខ្ញុំ។ តែក្រោយមកទៀត ខ្មែរក្រោមនៅក្នុងតំបន់របស់ខ្ញុំត្រូវគេយកទៅសម្លាប់ទាំងអស់។ រឿងនេះកើតឡើងប្រហែលនៅឆ្នាំ ១៩៧៧ ឬ១៩៧៨។ ខ្ញុំមានបងធម៌ម្នាក់ជាខ្មែរកម្ពុជាក្រោម ហើយគាត់រស់នៅក្នុងភូមិរំលេច គ្រួសាររបស់គាត់ត្រូវគេយកទៅសម្លាប់ចោលទាំងអស់។ ស៖ តើគេសម្លាប់ខ្មែរក្រោមនៅចន្លោះឆ្នាំណា? ឆ.២៦៖ ប្រហែលជាឆ្នាំ១៩៧៨។ ពេលដែលគេយកខ្មែរក្រោមទៅសម្លាប់ គេពុំបាននិយាយថា យកទៅសម្លាប់នោះទេ គេនិយាយថា យកទៅរៀន"]។

[3296] ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.៣០ KH 00979031 ["ប៉ុន្តែខ្ញុំដឹងថា ខ្មែរក្រោមត្រូវគេយកទៅសម្លាប់ចោលអស់ហើយ ព្រោះអ្នកភូមិជាអ្នកនិយាយប្រាប់ខ្ញុំអំពីរឿងនេះ។ ខ្ញុំមានឪពុកធម៌ម្នាក់ជាខ្មែរក្រោម ក៏ត្រូវគេយកទៅសម្លាប់ដែរ។ នៅទីនេះ ពីដើមគេហៅថាព្រៃឈើទាល ហើយសុទ្ធតែជាខ្មែរក្រោមទាំងអស់រស់នៅតាំងពីភូមិរូងតាកុក ភូមិរំលេច ភូមិប្រឡាយ រំដឹង ជាដើម។ មានកូនរបស់ខ្មែរក្រោមខ្លះបាននៅរស់ គឺដោយសារតែពួកគេទៅរស់នៅបាត់ដំបង ដូច្នេះ ទើបរួចផុតពីការកាប់សម្លាប់នេះ"] ឆ.៨៥ KH 00979041។

[3297] ឯកសារ D219/184 កំណត់ហេតុស្តាប់ចម្លើយ ហ៊ាម ស៊ីន្ធួន ឆ.១៤-១៦ KH 01067988 ["ស៖ តើគេសម្លាប់ យ៉ាន និងស៊ីណាត នៅពេលណា? ឆ.១៤៖ គេសម្លាប់ពួកគាត់នៅឆ្នាំ១៩៧៧ គឺក្រោយគ្នាតែប៉ុន្មានខែប៉ុណ្ណោះ។ ស៖ តើមានមូលហេតុអ្វី ដែលគេសម្លាប់យ៉ាន និងស៊ីណាត? ឆ.១៥៖ គេចោទយើងថា ជាខ្មែរកម្ពុជាក្រោម។ ស៖ តើគេសម្លាប់យ៉ាន និងស៊ីណាត នៅកន្លែងណា? ឆ.១៦៖ បងយ៉ាន គេសម្លាប់នៅភូមិវាល ចំណែក បងស៊ីណាត គេសម្លាប់នៅទួលសេះញ៉ូវ។ ប្រពន្ធនិងកូនប្រាំនាក់របស់បងយ៉ាន ត្រូវគេសម្លាប់ចោល។ ប្តី និងកូនម្នាក់របស់បងស៊ីណាត ត្រូវគេសម្លាប់ចោលដែរ។ បងយ៉ានត្រូវគេធ្វើទារុណកម្ម រៃនៅភូមិវាល គាត់មិននិយាយអ្វីទាំងអស់ បន្ទាប់មក ក៏ត្រូវគេសម្លាប់ចោល"]។

[3298] ឯកសារ D118/197 កំណត់ហេតុស្តាប់ចម្លើយ យាន ផាន ឆ.៩ KH 00978967 ឆ.៤៧-៤៩ KH 00978970-00978971 ["ស៖ នៅក្នុងរបបខ្មែរក្រហម តើមានអ្វីកើតឡើងចំពោះប្រពន្ធខ្មែរក្រោមរបស់គាត់ និងក្រុមគ្រួសាររបស់គាត់? ឆ.៤៧៖ ប្រពន្ធទី២របស់ខ្ញុំដែលជាខ្មែរក្រោម និងក្រុមគ្រួសាររបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ទាំងអស់។ ស៖ តើគេយកប្រពន្ធទី២ និងក្រុមគ្រួសាររបស់គាត់ទៅសម្លាប់នៅឆ្នាំណា? ហើយនៅកន្លែងណា? ឆ.៤៨៖ គេយកទៅសម្លាប់នៅឆ្នាំ១៩៧៧ នៅវត្តរំលេច។ ស៖ តើហេតុអ្វីបានជាលោកដឹងអំពីរឿងនេះ? តើលោកបានឃើញគេសម្លាប់ប្រពន្ធរបស់លោក និងក្រុមគ្រួសាររបស់គាត់ដោយផ្ទាល់ភ្នែកដែរ ឬទេ? ឆ.៤៩៖ ខ្ញុំបានឃើញគេយកប្រពន្ធរបស់ខ្ញុំ និងក្រុមគ្រួសាររបស់គាត់ទៅសម្លាប់"]។

[3299] ឯកសារ D118/197 កំណត់ហេតុស្តាប់ចម្លើយ យាន ផាន ឆ.៥២ KH 00978971 ["ក្នុង១ថ្ងៃ គេយកមនុស្សទៅសម្លាប់បីដង ហើយក្នុងម្តងៗ គឺមានមនុស្សប្រហែល១០ទៅ៣០នាក់។ អ្នកទាំងអស់នោះ គឺជាខ្មែរក្រោម"] ឆ.៥៣ KH 00978971។

ឬ ១៩៧៨ ថាខ្មែរក្រោមនៅរំលិចត្រូវបានសម្លាប់[3300]។ ចំណុចនេះត្រូវបានបញ្ជាក់ការពិតដោយ កុល សេត ដែលជាឈ្លបនៅបាកាន និងត្រូវបានប្រាប់ដោយអតីតឈ្លបដែលជាសហសេវិករបស់គាត់ថា ពួកគាត់បានយកខ្មែរក្រោមពីរំលិចទៅសម្លាប់[3301]។

<u>ឧក្រិដ្ឋកម្មប្រឆាំងប្រជាជនវៀតណាមនៅតាមទីតាំងដទៃក្នុងស្រុកបាកាន</u>

899. សាក្សីនានាបានផ្តល់ភ័ស្តុតាងថា នៅទូទាំងស្រុកបាកាន ខ្មែរក្រោមត្រូវបានចោទថាជា "យួន" និងត្រូវបានសម្លាប់[3302]។ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ហេង សៀក បានចូលរួមក្នុងការសម្លាប់ជាទ្រង់ទ្រាយធំទៅលើមនុស្សមួយក្រុមដែលមានចំនួនជាង១០០ នាក់ ដោយរួមបញ្ចូលខ្មែរក្រោម ក្នុងសហករណ៍ស្រែង[3303]។ ការបញ្ជាសម្លាប់ បានមកពីគណៈសហករណ៍ស្រែង ដែលបានទទួលពី "អង្គការ"[3304]។

[3300] ឯកសារ D219/344 កំណត់ហេតុស្តាប់ចម្លើយ សុខ ភា ឆ.២៨, ៣២, ៦៦-៦៧, ៧០-៧១ KH 01102903, 01102904, 01102907, 01102908។

[3301] ឯកសារ D118/238 កំណត់ហេតុស្តាប់ចម្លើយ កុល សែត ឆ.៩០ KH 00988034 ["ខ្ញុំឮអំពីការសម្លាប់មនុស្សនៅព្រៃក្របៅ ហើយអ្នកដែលសម្លាប់មនុស្សនៅព្រៃក្របៅ គឺស្លាប់អស់ហើយ។ ខ្មែរកម្ពុជាក្រោម ដែលបានមករស់នៅរំលេច និងពោលាំយ៉ូរ ណាស់មកហើយ ត្រូវគេយកទៅសម្លាប់នៅព្រៃក្របៅ"]។ ឯកសារ D118/238 កំណត់ហេតុស្តាប់ចម្លើយ កុល សែត ឆ.៩២-៩៤ KH 00988034។ *សូមមើលផងដែរ* ឯកសារ D118/197 កំណត់ហេតុស្តាប់ចម្លើយ យាន ផាន ឆ.៥៤-៥៥ KH 00978972 ["ស៖ តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការចាប់ចងខ្មែរក្រោមយកទៅសម្លាប់? ឆ.៥៤៖ ជាបញ្ជាមកពីថ្នាក់លើក្នុងការសម្លាប់ខ្មែរក្រោម ហើយអ្នកដែលចុះមកចាប់ខ្មែរក្រោមទៅសម្លាប់ គឺមានឈ្មោះ ម៉ី, ស៊ុន, ប៉ុច។ ស៖ លោកនិយាយថា មានបញ្ជាពីថ្នាក់លើ តើពីថ្នាក់លើណា? ឆ.៥៥៖ គឺបញ្ជាពីថ្នាក់ស្រុក គង់ សំអ្រៀន"]។

[3302] ឯកសារ D219/664 កំណត់ហេតុស្តាប់ចម្លើយ ខៀវ ផន ឆ.១៩, ២៩ KH 01198088, 01198089។ ឯកសារ D219/921 កំណត់ហេតុស្តាប់ចម្លើយ ចាប ពុធ ឆ.១០៧, ១១១-១១២ KH 01391801។ ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថា ច់ សុខ EN 00279242។

[3303] ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២ KH 01075697 ["ខ្ញុំចង់បន្ថែមពាក់ព័ន្ធនឹងហេតុការណ៍នៃការសម្លាប់មនុស្សរហូតដល់ចាក់ក្រោល។ នៅថ្ងៃដែលគវៃមនុស្សរហូតទាល់តែចាក់ក្រោលនោះ គេបានបិទសមរភូមិទាំងអស់ ហើយគេហៅកម្លាំងពីគ្រប់កងទាំងអស់ ទាំងកងភ្ជួរ កងចល័ត កងឈ្លប គណៈសហករណ៍ គណៈសមរភូមិ កងតូច ប្រធានកងធំ ខាងពាណិជ្ជកម្ម អ៊ី គឺហៅទាំងអស់គ្នា ដោយឲ្យមកប្រមូលគ្នានៅកន្លែងក្រោលនោះ។ ក្រោលនេះ គឺនៅក្នុងភូមិកោះអណ្តែត។ ខ្ញុំក៏បានចូលរួមនៅក្នុងការវៃសម្លាប់នៅកន្លែងទីនោះផងដែរ"] ឆ.១៣-១៦, ២០-២៤ KH 01075699, 01075700-01075701។

[3304] ឯកសារ D219/225 កំណត់ហេតុស្តាប់ចម្លើយ ហេង សៀង ឆ.២៩ KH 01075701-01075702 ["ស៖ មុននេះ លោកនិយាយថា អង្គការជាអ្នកឲ្យសម្លាប់។ តើអ្នកណាជាសម្របសម្រួល និងបញ្ជាឲ្យលោក និងអ្នកផ្សេងឲ្យទៅសម្លាប់ប្រជាជន? ឆ.២៩៖ គណៈសហករណ៍ជាអ្នកបញ្ជា ហើយគណៈសហករណ៍និយាយថា ទទួលបញ្ជាពីអង្គការមកដែរ"]។

900. កម្មាភិបាលបានចោទប្រជាជនវៀតណាមចំនួន៥ គ្រួសារថាជាគិញយួន និងបានសម្លាប់ពួកគាត់នៅឃុំតាលូ ប្រហែលនៅឆ្នាំ ១៩៧៧[3305]។ ជនរងគ្រោះទាំងនេះបានរួមបញ្ចូលប្រពន្ធរបស់ រ៉ែន រ៉ាន់ និងកូន[3306]។ រ៉ែន រ៉ាន់ ក៏បានឮថាបុរសស្ត្រី និងកុមារ និងមនុស្សចាស់ខ្មែរក្រោមចំនួន៥០ ទៅ៦០ នាក់ ត្រូវបានសម្លាប់នៅភូមិទ្ចលគក្នុងឆ្នាំ១៩៧៨[3307]។ ក្នុងខែកក្កដា ឆ្នាំ១៩៧៨ ប្តីខ្មែរក្រោមរបស់ ទេព ផាន កូនប្រុស២នាក់ និងសមាជិកគ្រួសារចំនួន៤០ នាក់របស់ប្តីរបស់គាត់ត្រូវបានយកចេញទៅពីភូមិស្រះរំដេង[3308]។ ក្រោយមក គាត់បានឃើញសម្លៀកបំពាក់របស់ពួកគាត់ត្រូវបានចែកចាយទៅអ្នកភូមិ និងបានដឹងថា ពួកគាត់ត្រូវបានសម្លាប់[3309]។ ក្នុងហេតុការណ៍ដដែលនេះ ខ្មែរក្រោមខ្លះក៏ត្រូវបានសម្លាប់ ដោយរួមទាំងស្ត្រី ដែលត្រូវបានរំណោភមុនសម្លាប់[3310]។ ទេព ផាន បានឃើញសមាជិកសហឧក្រិដ្ឋកម្មរួមឈ្មោះ ឃាយ រីម និងទាហាន ប.ក.ក បណ្តើរខ្មែរក្រោមចេញពីភូមិស្រះរំដេង[3311]។

[3305] ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន រ៉ន ឆ.៥២ KH 00977084 ["ស៖ តើលោកដឹងដោយរបៀបណាថាប្រពន្ធដើមរបស់លោក និងវៀតណាមប្រាំគ្រួសារទៀតត្រូវគេយកទៅសម្លាប់នៅទ្ចលកកោះ? ឆ.៥២៖ ខ្ញុំពុំបានដឹងដោយផ្ទាល់នោះទេ គឺខ្ញុំដឹងដោយញាតិលោហិត ដែលធ្វើការនៅភូមិវាល ដោយគេនិយាយថា "ប្រពន្ធរបស់អ្នែងទៅទីនោះបានតែពីរថ្ងៃទេ គេយកទៅសម្លាប់ហើយ អ្នែងកុំមាត់ណា!"] ឆ.៤៣-៤៤ KH 00977083។

[3306] ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន រ៉ន ឆ.៤៣-៤៤, ៥២ KH 00977083។

[3307] ឯកសារ D118/192 កំណត់ហេតុស្តាប់ចម្លើយ រ៉ែន រ៉ន ឆ.៨៤-៩០ KH 00977088។

[3308] ឯកសារ D118/262 កំណត់ហេតុស្តាប់ចម្លើយ ទេព ផុន ឆ.១១, ២៦ KH 00997941 ឆ.៥៤ KH 00997942 ["គេបានមកហៅពួកគាត់នៅនឹងមុខខ្ញុំថា ឲ្យពួកគាត់ទៅធ្វើស្រែ"] ឆ.៥៨-៥៩ KH 00997946 ["ស៖ តើខ្ញែរក្រហមបាននិយាយផែនការយកតែខ្ញែរក្រោមឲ្យទៅធ្វើស្រែដែរ ឬទេ? ឆ.៥៨៖ ចាស ខ្ញែរក្រហមថាឲ្យទៅធ្វើស្រែ។ [...] ឆ.៥៩៖ គេបានហៅមនុស្សនៅកន្ទ្បែរផ្ទះរបស់ខ្ញុំ រួចហើយក៏ចូលមកហៅនៅផ្ទះរបស់ខ្ញុំទៀត។ ក្រុមគ្រួសាររបស់ប្តីខ្ញុំជាង៤០នាក់ត្រូវគេហៅចេញទៅ។ ខ្ញុំបានសួមគេទៅជាមួយប្តីខ្ញុំ តែគេប្រាប់ថា "មិនទាន់មានផែនការទេ កុំអាលទៅអី!"] ឆ.៦១ KH 00997945 ["ស៖ តើគេយកខ្ញែរក្រោមទាំងអស់នោះទៅកន្ល្ងណា? ឆ.៦១៖ គេយកទៅក្រោលគោនៅស្រះរំដេង ក្នុងឃុំតាណោ"]។

[3309] ឯកសារ D118/262 កំណត់ហេតុស្តាប់ចម្លើយ ទេព ផុន ឆ.៥៤, ៦៣ KH 00997945។

[3310] ឯកសារ D118/262 កំណត់ហេតុស្តាប់ចម្លើយ ទេព ផុន ឆ.៦៩-៧២ KH 00997946។

[3311] ឯកសារ D118/262 កំណត់ហេតុស្តាប់ចម្លើយ ទេព ផុន ឆ.៨៦-៨៨ KH 00997948។

901. សឹម ឆាន បានធ្វើការនៅសហករណ៍អន្តង់ក្រាយ ឃុំអូតាពង់[3312] ដែលជាតំបន់ដែលមានខ្មែរក្រោមរស់នៅច្រើន[3313]។ ក្នុងឆ្នាំ១៩៧៨ ប្រធាន ប.ក.ក មូលដ្ឋានបាននិយាយថា ខ្មែរក្រោមបានកំពុងសហការជាមួយវៀតណាម និងត្រូវតែ "កម្ទេច"[3314]។ សមាជិកខ្មែរក្រោមទាំងអស់នៃកងការងាររបស់ សឹម ឆាន ត្រូវបានហៅទៅបេះពោត ឬដកដំឡូង និងបានបាត់ខ្លួន[3315]។ ការសម្លាប់បានកើតឡើងពីឆ្នាំ១៩៧៨ រហូតដល់ឆ្នាំ១៩៧៩[3316]។

902. ប្រពន្ធរបស់ រ៉ែន ឆ្លួន និងបងប្អូនសាច់ផ្ទៃ ត្រូវបានសម្លាប់នៅឃុំដំណាក់កន្ទ្រែងក្នុងឆ្នាំ១៩៧៧ ពីព្រោះពួកគាត់ជាខ្មែរក្រោម[3317]។ ក្នុងឆ្នាំ១៩៧៨ ប្រពន្ធរបស់ ជា ព្រៃន ដែលជាខ្មែរក្រោម ត្រូវបានប្រមូលផ្តុំជាមួយខ្មែរក្រោមដទៃទៀត និងត្រូវបានឃុំឃាំងនៅមន្ទីរត្រាចក្រោល[3318] ដែលនៅទីនោះ ពួកគាត់បានធ្វើការរហូតដល់អស់កម្លាំង និងត្រូវបានសម្លាប់[3319]។ ខ្លះត្រូវបានសម្លាប់ដោយសារពួក

[3312] ឯកសារ D219/277 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម ឈាន ឆ.២៦ KH 01088958។

[3313] ឯកសារ D219/277 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម ឈាន ឆ.៤៦ KH 01088962 ["បាទ មានរស់នៅច្រើន។ ប្រជាជនកម្ពុជាក្រោម ពួកគាត់មករស់នៅទីនេះយូរណាស់មកហើយ មិនមែនទើបតែមករស់នៅនោះទេ ពួកគាត់មានកូន មានចៅនៅទីនេះ។ អ្នកខ្លះកើតនៅទីនេះ ក៏ត្រូវគេចោទជាខ្មែរក្រោម ហើយគេយកទៅសម្លាប់ចោលដែរ"]។

[3314] ឯកសារ D219/277 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម ឈាន ឆ.៤៧ KH 01088962 ["ស៖ តើលោកបានដឹងអ្វីខ្លះពាក់ព័ន្ធនឹងការបោសសម្អាតខ្មែរកម្ពុជាក្រោម? ឆ.៤៧៖ មេៗខ្មែរក្រហមចោទខ្មែរក្រោមថា "ខ្មែរក្រោមចូលដៃជាមួយនឹងយួន ខ្មែរក្រោមជាយួនអ៊ីចឹង ត្រូវតែកម្ទេចចោល""] ឆ.៤៨ KH 01088962។

[3315] ឯកសារ D219/277 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម ឈាន ឆ.៤៩ KH 01088963 ["ប៉ុន្តែ តាមការសង្កេត គឺឃើញមានមនុស្សបាត់ខ្លួនរហូត។ ក្នុងក្រុមរបស់ខ្ញុំ មានខ្មែរក្រោមបាត់ខ្លួនដែរ គេប្រាប់ថាឲ្យទៅកាច់ពោត ដកដំឡូងអ៊ីជាដើម ហើយអ្នកដែលឮគេនិយាយដូច្នេះក៏អរ រួចក៏ទៅ ហើយក៏បាត់ខ្លួន"] ឆ.៥២-៥៣ KH 01088963។

[3316] ឯកសារ D219/277 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម ឈាន ឆ.៥១ KH 01088963 ["កើតឡើងនៅឆ្នាំ១៩៧៨ ហើយសម្លាប់ខ្លាំងណាស់រហូតដល់ឆ្នាំ១៩៧៩។ ដំបូង គេសម្លាប់ខ្មែរក្រោម"]។

[3317] ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ឆ្លួន រ៉ែន ឆ.១៨, ៧៣ KH 01075607, 01075617 ["ក្រោយគេសម្លាប់ខ្មែរក្រោមប្រហែលជា១ខែ ឬ២ខែ ទើបខ្ញុំដឹងថា ខ្មែរក្រោមត្រូវគេយកទោសម្លាប់ចោល។ ខ្ញុំដឹងរឿងនេះដោយសារ ខ្ញុំមានបងប្អូនសាច់ផ្ទៃខ្លះជាខ្មែរក្រោម ហើយត្រូវគេយកទៅសម្លាប់ចោលផងដែរ។ អ្នកដែលប្រាប់ខ្ញុំជាបងជីដូនមួយខ្ញុំ គាត់ឈ្មោះ ឈាង។ [...] ខ្ញុំបានជួបគាត់អំឡុងខែ៦ ឬខែ៧ នៅឆ្នាំ១៩៧៨ [...] ហើយខ្ញុំបានសួរគាត់ថា "បងស្រីទៅណាហើយបង?" [...] គាត់ប្រាប់ថា គេយកគាត់ទៅសម្លាប់ហើយ"]។

[3318] ឯកសារ D118/225 កំណត់ហេតុស្តាប់ចម្លើយ ជា ព្រៃន ឆ.៥១ KH 00985407។

[3319] ឯកសារ D118/225 កំណត់ហេតុស្តាប់ចម្លើយ ជា ព្រៃន ឆ.៥០ KH 00985406-00985407។

គាត់គ្រាន់តែបានរៀបការជាមួយខ្មែរក្រោម[3320]។ ជា ព្រៃន ក៏បានពិពណ៌នាអំពីការសម្លាប់ខ្មែរក្រោម ដែលបានកើតឡើង ក្រោយពេលប្រជុំមួយនៅភូមិកំប៉ាងក្នុងខែតុលាឆ្នាំ១៩៧៨[3321]។

903. ចាប ខ្ជង ដែលត្រូវបានឃុំឃាំងនៅគុកភូមិវាល[3322] បាននិយាយថាក្នុងឆ្នាំ១៩៧៧ អ្នកទោសខ្មែរក្រោមចំនួន៥០ ទៅ៦០ នាក់ ដែលត្រូវបានឃុំឃាំងនៅទីនោះ ត្រូវបានបញ្ជូនទៅសម្លាប់នៅទួលក្របៅ[3323]។ បន្ទាប់មក យាយ រីម បានបញ្ជាឲ្យសម្លាប់ខ្មែរក្រោមចំនួន១០ គ្រួសារពីភូមិវាល ដោយរួមបញ្ចូលសាច់ញាតិខ្ពះរបស់ ចាប ខ្ជង[3324]។ ខ្មែរក្រោមក៏ត្រូវបានឃុំឃាំង និងសម្លាប់នៅឃុំបឹងខ្នារផងដែរ[3325] ដែលរួមបញ្ចូលសាច់ញាតិរបស់ រាជ សារ៉ាន់ ដែលត្រូវបានចោទថាជាវៀតណាម[3326]។ បន្ថែមពីលើនេះ ខ្មែរក្រោមត្រូវបានឃុំឃាំង និងសម្លាប់នៅឯមន្ទីរសន្តិសុខចំនួន២ នៅស្រុក បាកាន ស្វាយជ្រុំ និងភូមិវាល។

<u>មន្ទីរសន្តិសុខស្វាយជ្រុំ</u>

904. ខ្មែរក្រោមដែលជាប់ឃុំឃាំងនៅស្វាយជ្រុំ ត្រូវបានយកទៅសម្លាប់នៅពេលសំនៀងភាសារបស់ពួកគាត់ត្រូវបានកំណត់អត្តសញ្ញាណ[3327]។ ដូចដែលបានបង្ហាញលម្អិតក្នុងផ្នែកស្តីពីទីតាំងឧក្រិដ្ឋកម្ម

[3320] ឯកសារ D118/273 កំណត់ហេតុស្តាប់ចម្លើយ ង៉ែត យី ឆ.៦០, ១៦៨, ១៧២, ១៧៧, ២៧៤ KH 00998686-00998687, 00998697, 00998702។

[3321] ឯកសារ D118/225 កំណត់ហេតុស្តាប់ចម្លើយ ជា ព្រៃន ឆ.៤៦-៤៩ KH 00985406។

[3322] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.២៨ KH 00955730 ["ខ្ញុំជាប់គុកនៅឆ្នាំ១៩៧៦ ក្រោយពេលដែលគេសម្លាប់ឪពុកម្តាយ និងបងប្អូនរបស់ខ្ញុំអស់ហើយ គឺពេលដែលខ្ញុំនៅក្នុងកងចល័ត ខ្ញុំក៏រត់ ហើយក៏ ត្រូវគេចាប់បាន រួចបញ្ជូនមកដាក់គុកភូមិវាលតែម្តង"] ឆ.៥៥ KH 00955733 ["នៅពេលយប់ឡើង គេដាក់ខ្នោះជើងរបស់យើង ព្រឹកឡើង ទើបគេដោះខ្នោះជើងឲ្យទៅចាំងស្មៅចាំងអី"]។

[3323] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៧៧-៧៨ KH 00955736 ["ឆ.៧៧៖ បាទ មាន ប៉ុន្តែដល់ឆ្នាំ១៩៧៧ គឺគេបញ្ជូនមកដាក់នៅទួលព្រៃបក្របៅអស់ហើយ។ ស៖ តើគេបញ្ជូនមកទួលព្រៃក្របៅដើម្បីធ្វើអ្វី? ឆ.៧៨៖ គេបញ្ជូនមកដើម្បីវ៉ៃចោល គឺវ៉ៃសម្លាប់ចោលនៅទីនោះ ជាមួយនឹងខ្មែរក្រោមផ្សេងទៀត ដែលបញ្ជូនពីខ្នាទទឹង"]។ *សូមមើលផងដែរ* ឯកសារ D118/124 កំណត់ហេតុស្តាប់ចម្លើយ គឹម សូរ ឆ.១០៦ KH 00955720។

[3324] ឯកសារ D118/125 កំណត់ហេតុស្តាប់ចម្លើយ ចាប ខ្ជង ឆ.៩២-៩៥ KH 00955737-00955738។

[3325] ឯកសារ D219/224 កំណត់ហេតុស្តាប់ចម្លើយ ឈួន សុង ឆ.៤៧ KH 01075634។

[3326] ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.២៩-៣០ KH 01110165។

[3327] ឯកសារ D118/288 កំណត់ហេតុស្តាប់ច ម្លើយ ឡាយ ឃូនី ឆ.១៣, ១៦ KH 01022018។

អ្នករួចពីស្លាប់នៃស្វាយជ្រុំម្នាក់បាននិយាយថា ខ្មែរក្រោមគ្រប់រូបក្នុងក្រុមអ្នកទោសរបស់គាត់ត្រូវបានសម្លាប់[3328]។

<u>មន្ទីរសន្តិសុខភូមិវាល</u>

905. ដូចដែលបានពិពណ៌នាក្នុងផ្នែកស្ដីពីទីតាំងឧក្រិដ្ឋកម្ម[3329] ខ្មែរក្រោមត្រូវបានចាប់ខ្លួន ចាប់ដាក់ពន្ធនាគារ និងរមែងបានរងទារុណកម្ម និងទីបំផុតត្រូវបានសម្លាប់នៅភូមិវាល ពីព្រោះពួកគាត់ត្រូវបានចាត់ទុកថាជាប់ខ្សែរយ:វៀតណាម[3330]។ កម្មាភិបាលភូមិភាគនិរតី និង យាយ រីម ដែលជាសមាជិកសហឧក្រិដ្ឋកម្មរួមរបស់ **យឹម ទិត្យ** និង តា ម៉ុក បានចុះទៅមន្ទីរសន្តិសុខភូមិវាល និងបានផ្ដល់ការណែនាំទាក់ទងអ្នកទោស[3331]។

[3328] *សូមមើល* V.B.5.b.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់២ – មន្ទីរសន្តិសុខស្វាយជ្រុំ – ឧក្រិដ្ឋកម្ម។

[3329] *សូមមើល* V.B.5.a.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់២ – មន្ទីរសន្តិសុខភូមិវាល – ឧក្រិដ្ឋកម្ម។

[3330] *សូមមើលឧទាហរណ៍* ឯកសារ D219/861 កំណត់ហេតុស្ដាប់ចម្លើយ សេក សំអាត ហៅ យាយរីម ឆ.៨៣ KH 01347265 ។ ឯកសារ D118/1 កំណត់ហេតុស្ដាប់ចម្លើយ អ៊ុក សឿម ហៅ សន សឿម ឆ.២០ KH 00872599។ ឯកសារ D219/188 កំណត់ហេតុស្ដាប់ចម្លើយ ផាន យេន ឆ.១១២-១១៧, ១២១, ១២៣-១៣១ KH 01068142-01068143, 01068144-01068145 ។ ឯកសារ D118/125 កំណត់ហេតុស្ដាប់ចម្លើយ ចាប ខួង ឆ.៧៧-៧៩, ៨០-៨៧ KH 00955736, 00955737។ ឯកសារ D6.1.758 កំណត់ហេតុស្ដាប់ចម្លើយ ចាប ខួង EN 00387497។ ឯកសារ D6.1.759 កំណត់ហេតុស្ដាប់ចម្លើយ គីម សួរ EN 00388620។ ឯកសារ D219/57 កំណត់ហេតុស្ដាប់ចម្លើយ គង់ រុន ហៅ គង់ សារុន ឆ.១២៣ KH 01034510។ ឯកសារ D240R វីដេអូស្ដីពី "*សត្រូវរបស់ប្រជាជន*" វីដេអូបន្ថែម៖ ឃួនពណ៌នាអំពីផែនការ ចេញឆ្នាំ២០១០ ម៉ោង 1:00-3:58។ ឯកសារ D118/147.1.43 របាយការណ៍សិក្សាស្រាវជ្រាវអំពីសាលាក្ដីខ្មែរក្រហម ប្រវត្តិសាវតាររបស់ គីម សួរ EN 00527089, 00527101-00527113។ ឯកសារ D6.1.759 កំណត់ហេតុស្ដាប់ចម្លើយ គីម សួរ EN 00388620។ ឯកសារ D118/124 កំណត់ហេតុស្ដាប់ចម្លើយ គីម សួរ ឆ.៣៧ KH 00955711-00955712។ ឯកសារ D118/246 កំណត់ហេតុស្ដាប់ចម្លើយ មាស រឿន ឆ.១០៥ KH 00990659។ D219/184 កំណត់ហេតុស្ដាប់ចម្លើយ ហ៊ឹម ស៊ីនួន ឆ.១៣-១៨ KH 01067988-01067989។ ឯកសារ D118/123 កំណត់ហេតុស្ដាប់ចម្លើយ ចឹក យឹន ឆ.៦០ KH 00955700។

[3331] ឯកសារ D118/125 កំណត់ហេតុស្ដាប់ចម្លើយ ចាប ខួង ឆ.៩២-៩៦, ១០៤, ១០៦-១០៩ KH 00955737-00955738, 00955739, 00955740។ ឯកសារ D219/842 កំណត់ហេតុស្ដាប់ចម្លើយ ឡូម សាវួន ឆ.៨២-៨៣ KH 01335681។ ឯកសារ D118/123 កំណត់ហេតុស្ដាប់ចម្លើយ ចឹក យឹន ឆ.២៣-២៤, ៦៥ KH 00955697-00955698, 00955701។ ឯកសារ D118/125 កំណត់ហេតុស្ដាប់ចម្លើយ ចាប ខួង ឆ.១០៤ KH 00955739។ ឯកសារ D219/222 កំណត់ហេតុស្ដាប់ចម្លើយ ទូច សេង ហៅ យាយ យាន ឆ.៩០, ១៧០ KH 01075729, 01075743។ ឯកសារ D5/61 ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ ចឹក យឹន EN 00427010-00427011។

គ. ការប្រព្រឹត្តទៅលើប្រជាជនវៀតណាម និងខ្មែរក្រោមក្នុងតំបន់ ៤ ឆ្នាំ១៩៧៧-១៩៧៩

906. **យ៉ីម ទិត្យ** ជាមេដឹកនាំថ្នាក់ខ្ពស់មួយរូបនៅថ្នាក់ភូមិភាគ និងក៏ត្រូវបានកំណត់អត្តសញ្ញាណដោយសាក្សីនានាថាជាលេខាតំបន់ ៤[3332]។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទៅលើប្រជាជនវៀតណាម និងខ្មែរក្រោមក្នុងតំបន់ ៤ ដែលបានរៀបរាប់ខាងក្រោម ត្រូវបានប្រព្រឹត្តជាផ្នែកមួយសហឧក្រិដ្ឋកម្មរួមនៃភូមិភាគនិរតី ដែលក្នុងនោះ **យ៉ីម ទិត្យ** បានដើរតួនាទីដ៏សំខាន់មួយ។

907. ខ្មែរក្រោម បានរស់នៅក្នុងតំបន់ ៤ អស់រយៈពេលជាច្រើនឆ្នាំមុនរបបកម្ពុជាប្រជាធិបតេយ្យ[3333]។ សៅ យេន ដែលបានធ្វើការងារក្នុងស្រុកនេះ បាននិយាយថាកម្មាភិបាលភូមិភាគនិរតីបានមកដល់ក្នុងពាក់កណ្តាលឆ្នាំ១៩៧៧ និងបានចាប់ផ្តើមបង្ខំខ្មែរក្រោមពីផ្ទះរបស់ពួកគាត់ និងធ្វើឲ្យពួកគាត់អត់ឃ្លាន[3334]។ ស្រដៀងនេះ ហាម សោម បានពិពណ៌នាអំពីការបាត់ខ្លួនខ្មែរក្រោមចំនួនរាប់រយនាក់នៅឃុំកន្ទឹ រ បន្ទាប់ពីពួកគាត់ត្រូវបានចោទប្រកាន់ថាជាប់ខ្សែរយៈវៀតណាម[3335]។

908. កម្មាភិបាល ប.ក.ក បានស្វែងរកខ្មែរក្រោមតាមភូមិនានានៃស្រុកនេះ ហើយអ្នកណានិយាយភាសាខ្មែរមិនច្បាស់ ត្រូវបានចាប់ខ្លួន[3336]។ ខ្មែរក្រោមក្នុងតំបន់ ៤ ត្រូវបានចាប់ខ្លួន ពីព្រោះពួកគាត់ត្រូវបានគេចោទថាជាវៀតណាម[3337]។ ការសម្លាប់ខ្មែរក្រោមជាច្រើនគ្រួសារបានកើតឡើងនៅតាមភូមិនានានៅទូទាំងស្រុកនេះ[3338]។ ស្រី សៀម ដែលធ្វើការងារជាកសិករនៅភូមិសាលាក្រៅ បាន

[3332] ឯកសារ D105/8 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៧ KH 00794127 [“តាទិត កាលណោះគឺគាត់នៅតំបន់ ៤”]។ ឯកសារ D118/63 កំណត់ហេតុស្តាប់ចម្លើយ ហាន់ ធី ឆ.៣៤-៣៥ KH 00920171 ។ ឯកសារ D118/96 កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ឆ.២៩ KH 00947291 [“កាលនោះ តាទិត ជាប្រធានតំបន់ ក្នុងនោះមានឃុំបឹងព្រៃផង”]។ ឯកសារ D219/627 កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ឆ.៤ KH 01184312 [“បឹងប្រី នៅក្នុងស្រុកដូនទាវ”]។ ឯកសារ D219/884 កំណត់ហេតុស្តាប់ចម្លើយ ឡុច អេង ឆ.៤-៨ KH 01362501-01362502 ។

[3333] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៦៣ KH 01047388 ។

[3334] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៣-៥, ១០ KH 01097670-01097671 ។ *សូមមើលផងដែរ* ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៧០-៧១, KH 01047389 ។

[3335] ឯកសារ D118/149 ហាម សោម ឆ.៦៤-៦៦, ៦៨, ៧០ KH 00967989-00967990 ។

[3336] ឯកសារ D219/157 កំណត់ហេតុស្តាប់ចម្លើយ ខយ ឆ្ងយ ឆ.១៦ KH 01058787 ។ ឯកសារ D219/749 កំណត់ហេតុនៃកិច្ចសើបសួរ អំពីឈ្មោះ ខយ ឆ្ងយ KH 01379130 ។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៦៣-៦៤, ៦៦-៦៧ KH 01047388-01047389 ។

[3337] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.៥ KH 01097670 ។

[3338] ឯកសារ D219/367 កំណត់ហេតុស្តាប់ចម្លើយ រាជ្យ សារ៉ន ឆ.២៩-៣០ KH 01110165 ។

និយាយថាការសម្លាប់ខ្មែរក្រោមបានកើតឡើងជាប្រចាំថ្ងៃក្រោមកម្មាភិបាលភូមិភាគនិរតី[3339]។ ជាឧទាហរណ៍ ម្តាយខ្មែរក្រោមរបស់ ហ្ស៊ីយ សាន និងសាច់ញាតិត្រូវបានចាប់ខ្លួន ត្រូវបានឃុំឃាំង និងសម្លាប់នៅសាលាក្រៅ ភូមិកាច់រទេះក្នុងឆ្នាំ១៩៧៨ ពីព្រោះពួកគាត់ត្រូវបានចោទថាជាវៀតណាម[3340]។ ការដាក់ជាគោលដៅ និងការធ្វើបាបប្រជាជនវៀតណាម និងខ្មែរក្រោមបានកើតឡើង នៅឃុំចំនួន២ គឺ៖ កំពង់ព្រាង និងវ៉ាងកេសី។

i. ឃុំកំពង់ព្រាង

909. ដូចដែលបានបង្ហាញលម្អិតក្នុងផ្នែកស្តីពីទីតាំងឧក្រិដ្ឋកម្ម[3341] កម្មាភិបាលភូមិភាគនិរតីបានពិភាក្សាអំពីការសម្លាប់ខ្មែរក្រោមទាំងអស់ក្នុងការប្រជុំនានា[3342]។ ខ្មែរក្រោមត្រូវបានចាត់ទុកជា "ឃ្លួន" និង "ខ្មាំង" ហើយត្រូវបានសម្លាប់និងបានបាត់ខ្លួននៅទូទាំងឃុំកំពង់ព្រាង[3343]។ ខ្មែរក្រោមជាង១.០០០ នាក់ត្រូវបានសម្លាប់ ដែលនេះបើយោងតាមការព្យាករនានា[3344]។

[3339] ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.១០-១២, ៦៩-៧១ KH 01047382។

[3340] ឯកសារ D118/240 កំណត់ហេតុស្តាប់ចម្លើយ ហ៊ីយ សាន្ត ឆ.៥៩-៦០, ៦៧-៦៨, ៧៤ KH 00988050, 00988051-00988052, 00988053។

[3341] *សូមមើល* V.B.4.b.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់៤ – ឃុំកំពង់ព្រៀង – ឧក្រិដ្ឋកម្ម។

[3342] *សូមមើលឧទាហរណ៍* ឯកសារ D219/303 កំណត់ហេតុស្តាប់ចម្លើយ ខ្ចឿន ចឹម ឆ.២១ KH 01096555។

[3343] *សូមមើលឧទាហរណ៍* ឯកសារ D219/414 កំណត់ហេតុស្តាប់ចម្លើយ ម៉ៅ ហ្ស៊ៀង ឆ.៥, ៧ KH 01117333-01117334។ ឯកសារ D219/125 កំណត់ហេតុស្តាប់ចម្លើយ ស្រី សៀម ឆ.៧០ KH 01047389។ ឯកសារ D219/394 រ៉ៀម ឌី ឆ.៦, ៨ KH 01114690។ ឯកសារ D219/528 កំណត់ហេតុស្តាប់ចម្លើយ ឡូញ លន់ ឆ.៩៧ KH 01151010-01151011។ ឯកសារ D219/404 កំណត់ហេតុស្តាប់ចម្លើយ ហ្ស៊ៀង សំបូរ ឆ.១៨ KH 01117191។ ឯកសារ D219/304 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម ប៊ុនឈ្យ៉ាន ឆ.១៧ KH 01096565។

[3344] ឯកសារ D219/864 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.៦៧, ៦៩ KH 01347378។ ឯកសារ D219/838 កំណត់ហេតុស្តាប់ចម្លើយ ឡុង ខេន ឆ.១២០, ១២២ KH 01335608។

ii. ឃុំវាំងកេសី

910. ខ្មែរក្រោមត្រូវបានកំណត់ជាគោលដៅនៅក្នុងឃុំវាំងកេសី ដោយសារពួកគេត្រូវចាត់ទុកថាជាជនជាតិវៀតណាម[3345]។ ដូចបានរៀបរាប់នៅក្នុងផ្នែកទីតាំងឧក្រិដ្ឋកម្មរួចហើយ[3346] ខ្មែរក្រោមក្នុងឃុំនេះដែលត្រូវបានសម្លាប់ រួមទាំងស្ត្រីមានផ្ទៃពោះ កុមារ និងគ្រួសារទាំងមូល[3347]។

iii. មន្ទីរសន្តិសុខវត្តសម្ពេច

911. ខ្មែរក្រោម និងវៀតណាម ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តសម្ពេច[3348]។ ដូចបានបញ្ជាក់ក្នុងផ្នែកទីតាំងឧក្រិដ្ឋកម្មរួចមក[3349] កម្មាភិបាលភាគនិរតីបានប្រាប់ខ្មែរក្រោម និងវៀតណាមថា ពួកគេត្រូវបញ្ជូនទៅធ្វើការនៅតាមវាលស្រែនៅចុងតាកុក ប៉ុន្តែផ្ទុយវិញបញ្ជូនទៅវត្តសម្ពេច ហើយសម្លាប់។

៧. ការកម្ទេចរបស់ ប.ក.ក មកលើជនជាតិវៀតណាម

912. ក្នុងឆ្នាំ១៩៧៨ ប៉ុល ពត បានប្រកាសថា "គ្មាន[ឃ្លួន]មួយគ្រាប់" នៅកម្ពុជាទេ[3350]។ អ្នកជំនាញ អេ ឡិចសេនឌ័រ ហ៊ីនតុន បានបំភ្លឺក្នុងសំណុំរឿង ០០២ ថា សេចក្តីប្រកាសនេះ "ជាសញ្ញាបង្ហាញពីការ

[3345] ឯកសារ D219/309 កំណត់ហេតុស្តាប់ចម្លើយ សោយ យ៉ែន ឆ.១៥ KH 01097673។ ឯកសារ D219/238 កំណត់ហេតុស្តាប់ចម្លើយ ផាន់ សារ៉ង ឆ.៤២ KH 01080863។ ឯកសារ D219/137 កំណត់ហេតុស្តាប់ចម្លើយ ឃៀម សោន ឆ.៥៧ KH 01053281។ ឯកសារ D219/955 កំណត់ហេតុស្តាប់ចម្លើយ កិន មឿន ឆ.២៩ KH 01425202-01425203។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៨៩ KH 01032176។ ឯកសារ D219/939 កំណត់ហេតុស្តាប់ចម្លើយ សេក មន្ត្រា ឆ.៥២ KH 01403889។

[3346] *សូមមើល* V.B.4.a.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់៤ – ឃុំវាំងកេសី – ឧក្រិដ្ឋកម្ម។

[3347] ឯកសារ D219/314 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៧-៨ KH 01097721។ ឯកសារ D219/722 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.១-២, ៦ KH 01213301, 01213302។ ឯកសារ D219/42 កំណត់ហេតុស្តាប់ចម្លើយ ចិច សុផា ឆ.៩១, ៩៥, ៩៧ KH 01032176។ ឯកសារ D219/866 ឡើយ ម៉ុន ឆ.២៤, ២៧, ២៩ KH 01347406, 0134740607។

[3348] ឯកសារ D219/683 កំណត់ហេតុស្តាប់ចម្លើយ ហ៊ុន ណុន ឆ.៥៤-៦០ KH 01203923-01203924។ ឯកសារ D219/580 កំណត់ហេតុនៃកិច្ចស្ទើបសួរ ព័ត៌មានអំពីឈ្មោះ រុន ឡាយ KH 01485012-01485013។

[3349] *សូមមើល* V.B.4.c.iv. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់៤ – មន្ទីរសន្តិសុខវត្តសម្ពេច-ឧក្រិដ្ឋកម្ម។

[3350] ឯកសារ D6.1.742 ទស្សនាវដ្ដី *ទង់ជាតិវត្ត*ន៍ ចុះខែ មេសា ឆ្នាំ១៩៧៨ EN 00519836។ *សូមមើលផងដែរ* ឯកសារ D219/852.1.11 ប្រតិចារឹក កាំង ហ្គេកអ៊ាវ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ម៉ោង 15.32.46-15.35.50។

សម្រេចអំពើប្រល័យពូជសាសន៍បានដោយជោគជ័យ”[3351] ដែលបានគាំទ្រ២ញ្ជាក់ដោយការសិក្សាប្រជាសាស្ត្រ[3352]។ នៅក្នុងបរិបទនេះ ការកម្ទេចរបស់ ប.ក.ក មកលើខ្មែរក្រោម ដែលបានចោទថា “ឃ្លន” ហើយដែលខ្មែរក្រហមចាត់ទុកថាជាផ្នែកមួយរបស់ក្រុមជាតិវៀតណាមមានលក្ខណៈជាប្រព័ន្ធ និងកើតឡើងច្រើនលើសលុបនៅតំបន់នានានៃខេត្តតាកែវ និងខេត្តពោធិ៍សាត់ ដែល យឹម ទិត្យ មានអំណាចគ្រប់គ្រង។ នយោបាយនៃការលុបបំបាត់នេះរួមមានទាំងការនិរទេស ការធ្វើទុក្ខបុកម្នេញ ការដាក់ពន្ធនាគារ ការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម និងជាចុងក្រោយការសម្លាប់ទ្រង់ទ្រាយធំ នៃសហគមន៍ខ្មែរក្រោមទាំងមូល ដែលកម្មាភិបាលថ្នាក់ក្រោម ប.ក.ក អនុវត្តក្រោមអំណាច និងការចាត់ចែងរបស់ យឹម ទិត្យ និងសមាជិកសហឧក្រិដ្ឋកម្មរួមផ្សេងទៀត។ ខ្មែរក្រោមតិចតួចប៉ុណ្ណោះដែលបានរួចជីវិតពីគោលនយោបាយកម្ទេចនេះ[3353]។

ជ. ខ្សែក្រិដ្ឋកម្មដែលសេចក្តីសន្និដ្ឋានស្តីពីការចោទប្រកាន់

913. សំអាងភ័ស្តុតាងខាងលើ សហព្រះរាជអាជ្ញាអន្តរជាតិស្នើចោទប្រកាន់យឹម ទិត្យ ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយមានចេតនាកម្ទេចជនជាតិវៀតណាម ក្នុងនាមជាក្រុមជាតិមួយ (ជាពិសេសខ្មែរក្រោម) នៅកម្ពុជា។ អំពើប្រល័យពូជសាសន៍បានប្រព្រឹត្តតាមរយៈការសម្លាប់ ការបង្ករដោយចេតនានូវលក្ខខណ្ឌរស់នៅក្នុងបំណងកម្ទេចក្រុមនោះ ព្រមទាំងបង្ករព្យសនកម្មផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរដល់សមាជិកនានានៃក្រុមនៅស្រុកគិរីវង់ ត្រាំកក់ និងកោះអណ្តែតក្នុងភូមិភាគនិរតី រួមទាំង តែមិនកំណត់ត្រឹម មន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់វត្តអង្គុញ

[3351] ឯកសារ D219/792.1.7 ប្រតិចារឹកសាស្ត្រាចារ្យ Alexander Hinton ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ម៉ោង 11.00.45-11.02.08។

[3352] ឯកសារ D6.1.197 ការវាយតម្លៃស៊ីជម្រៅ ដោយបណ្ឌិត Ewa Tabeau និង លោក ចឹ ឃាម *ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា* ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ EN 00385311។ ឯកសារ D219/792.1.7 ប្រតិចារឹក សាស្ត្រាចារ្យ Alexander Hinton ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៦ ម៉ោង 09.21.48-09.22.42។

[3353] *សូមមើលឧទាហរណ៍* ឯកសារ D118/175 កំណត់ហេតុស្តាប់ចម្លើយ ង៉ើន ដារ៉ា ឆ.២៥ KH 00973947។ ឯកសារ D219/224 កំណត់ហេតុស្តាប់ចម្លើយ ឃ្លន សុង ឆ.៤៧ KH 01075634។ ឯកសារ D118/173 កំណត់ហេតុស្តាប់ចម្លើយ វ៉ាន់ ចូក ឆ.៧១-៧៣ KH 00973927។ ឯកសារ D118/214 កំណត់ហេតុស្តាប់ចម្លើយ ចឹង ភី ឆ.៣៨ KH 00982150។ ឯកសារ D219/223 កំណត់ហេតុស្តាប់ចម្លើយ ឆ្លន រិន ឆ.៧៣ KH 01075617។ ឯកសារ D118/256 កំណត់ហេតុស្តាប់ចម្លើយ សេង អេង ឆ.៦៦-៦៧ KH 00996447។ ឯកសារ D118/123 កំណត់ហេតុស្តាប់ចម្លើយ ចឹក យ៉ីន ឆ.២១-២២, ៤១ KH 00955696 ។ *សូមមើលផងដែរ* ឯកសារ D118/202 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ សារិន ឆ.១១-១២ KH 00979030។ ឯកសារ D6.1.140 កំណត់ហេតុស្តាប់ចម្លើយ ថាច់ សុខ EN 00279244។

មន្ទីរសន្តិសុខវត្តអង្គស្រីមុនី និងទីតាំងសម្លាប់ព្រៃសុខុន ទីតាំងសម្លាប់ព្រៃភូមិស្ពែង និងទីតាំងសម្លាប់ភូមិព្រាល ហើយនៅស្រុកបាកាន និងស្រុក៤១ និង៤២ នៃភាគពាយ័ព្យ រួមទាំងតែមិនកំណត់ត្រឹម រោងចក្រស្ករសកំពង់គល់ មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់ទួលសេះញ្ជ៉ូ ទីតាំងសម្លាប់ព្រៃក្របៅ មន្ទីរសន្តិសុខវត្តសម្ពេច ឃុំកំពង់ព្រៀង និងឃុំវ៉ាងកេសី។

914. សហព្រះរាជអាជ្ញាអន្តរជាតិស្នើចោទប្រកាន់ផងដែរពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចខាងក្រោម៖

ក. មនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយមកលើខ្មែរក្រោមនៅស្រុកគិរីវង់ ត្រាំកក់ កោះអណ្តែតក្នុងភាគនិរតី រួមទាំងតែមិនកំណត់ត្រឹម មន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្លាប់វត្តអង្គុញ ទីតាំងសម្លាប់វត្តអង្គស្រីមុនី និងទីតាំងសម្លាប់ព្រៃសុខុន ទីតាំងសម្លាប់ព្រៃភូមិស្ពែង និងទីតាំងសម្លាប់ភូមិព្រាល ហើយនៅស្រុកបាកាន និងស្រុក៤១ និង៤២ នៃភាគពាយ័ព្យរួមទាំងតែមិនកំណត់ត្រឹម រោងចក្រស្ករសកំពង់គល់ មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងសម្លាប់ទួលសេះញ្ជ៉ូ ទីតាំងសម្លាប់ព្រៃក្របៅ មន្ទីរសន្តិសុខវត្តសម្ពេច ឃុំកំពង់ព្រៀង និងឃុំវ៉ាងកេសី។

ខ. មនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយមកលើជនជាតិវៀតណាមនៅមន្ទីរសន្តិសុខក្រាំងតាចាន់នៅភូមិភាគនិរតី និងរោងចក្រស្ករសកំពង់គល់ មន្ទីរសន្តិសុខវត្តសម្ពេច ឃុំកំពង់ព្រៀង នៅភាគពាយ័ព្យ។

គ. ការនិរទេសជនជាតិវៀតណាម និងខ្មែរក្រោម ពីស្រុកត្រាំកក់ និងគិរីវង់ឆ្លងកាត់ព្រំដែនកម្ពុជាទៅ
វៀតណាម និងពីវៀតណាមឆ្លងព្រំដែនកម្ពុជាមកស្រុកត្រាំកក់ និងគិរីវង់ ក្នុងភាគនិរតី រួមទាំងតែមិនកំណត់ត្រឹម ទីតាំងសម្លាប់ភូមិព្រៀល និងទីតាំងសម្លាប់ព្រៃភូមិស្ពែង។

ឃ. ការដាក់ពន្ធនាគារនៃខ្មែរក្រោមក្នុងស្រុកគិរីវង់ និងត្រាំកក់នៅភាគនិរតី រួមទាំងតែមិនកំណត់ត្រឹមមន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខវត្តអង្គស្រីមុនី ហើយនៅក្នុងភាគពាយ័ព្យ រួមទាំងតែមិនកំណត់ត្រឹម មន្ទីរសន្តិសុខភូមិវាល មន្ទីរសន្តិសុខស្វាយជ្រុំ ទីតាំងផ្សេងៗនៅក្នុងស្រុកបាណន់ រោងចក្រស្ករសកំពង់គល់ មន្ទីរសន្តិសុខវត្តសម្ពេច និងឃុំកំពង់ព្រៀង។

ង. ការដាក់ពន្ធនាគារនៃជនជាតិវៀតណាមនៅមន្ទីរសន្តិសុខក្រាំងតាចាន់ នៅភាគនិរតី និងឃុំកំពង់ព្រៀង និងមន្ទីរសន្តិសុខវត្តសម្តេចនៅភាគពាយ័ព្យ។

ច. ការធ្វើទារុណកម្មមកលើខ្មែរក្រោមនៅមន្ទីរសន្តិសុខភូមិវាល ក្នុងភាគពាយ័ព្យ

ឆ. ការធ្វើឲ្យទៅជាទាសករនៃខ្មែរក្រោមក្នុងស្រុកបាកាន នៅភាគពាយ័ព្យ

ជ. អំពើហោរយៅផ្សេងៗទៀត (ការរំលោភសេពសន្ថវៈ) មកលើជនជាតិខ្មែរក្រោមនៅស្រុកបាកានក្នុងភាគពាយ័ព្យ

ឈ. អំពើហោរយៅផ្សេងៗទៀត (ការប្រព្រឹត្តដោយហោរយៅ) ប្រឆាំងនឹងខ្មែរក្រោមនៅស្រុកគិរីវង់ ត្រាំកក់ និងកោះអណ្តែត ក្នុងភាគនិរតី រួមទាំងតែមិនកំណត់ត្រឹម មន្ទីរសន្តិសុខវត្តព្រះធាតុ មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្គាប់ភូមិព្រាល និងមន្ទីរសន្តិសុខវត្តអង្គស្រីមុនី ហើយនៅស្រុកបាកាន និងស្រុក៤១ និង៤២ នៃភាគពាយ័ព្យ រួមទាំងតែមិនកំណត់ត្រឹម មន្ទីរសន្តិសុខភូមិវាល និងឃុំកំពង់ព្រៀង។

ញ. អំពើហោរយៅផ្សេងៗទៀត (ការប្រព្រឹត្តដោយហោរយៅ) ប្រឆាំងជនជាតិវៀតណាម នៅមន្ទីរសន្តិសុខក្រាំងតាចាន់ក្នុងភាគនិរតី និងក្នុងឃុំកំពង់ព្រៀង នៃភាគពាយ័ព្យ។

ដ. អំពើហោរយៅផ្សេងៗទៀត (ការបាត់ខ្លួនដោយបង្ខំ) មកលើខ្មែរក្រោមនៅស្រុកគិរីវង់ ត្រាំកក់ កោះអណ្តែត ក្នុងភាគនិរតី រួមទាំងតែមិនកំណត់ត្រឹមទីតាំងសម្គាប់ភូមិព្រាល ទីតាំងសម្គាប់ព្រៃភូមិស្ពែង ទីតាំងសម្គាប់វត្តអង្គុញ មន្ទីរសន្តិសុខវត្តអង្គស្រីមុនី និងនៅស្រុកបាកាន និងស្រុក៤១ និង៤២ នៃភាគពាយ័ព្យ រួមទាំងតែមិនកំណត់ត្រឹម អោងចក្រស្ករសកំពង់គល់ ទីតាំងសម្គាប់ទួលសេះញ៉ូវ ទីតាំងសម្គាប់ព្រៃក្រហៅ និងឃុំកំពង់ព្រៀង ព្រមទាំង

ឋ. អំពើហោរយៅផ្សេងៗទៀត (ការជម្លៀសដោយបង្ខំ) នៃជនជាតិវៀតណាម និងខ្មែរក្រោមក្នុងស្រុកគិរីវង់ និងកោះអណ្តែត នៃភាគនិរតី រួមទាំងតែមិនកំណត់ត្រឹម មន្ទីរសន្តិសុខក្រាំងតាចាន់ ទីតាំងសម្គាប់ឃុំព្រាល ទីតាំងសម្គាប់ព្រៃភូមិស្ពែង និងក្នុងស្រុកបាកាន នៃភាគពាយ័ព្យ។

VI. ច្បាប់

ក. គោលការណ៍ច្បាប់ពាក់ព័ន្ធ

១. ឧក្រិដ្ឋកម្ម

915. យ៉ឹម ទិត្យ ត្រូវចោទពី *រួមទាំងតែមិនកំណត់ត្រឹម*[3354] ឧក្រិដ្ឋកម្មដែលមានកំណត់ក្នុងមាត្រា ៤ និង ៥ នៃច្បាប់ អ.វ.ត.ក ដែលផ្តល់ដល់ អ.វ.ត.ក នូវយុត្តាធិការលើអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចខាងក្រោម។

ក. អំពើប្រល័យពូជសាសន៍

916. មាត្រា ៤ នៃច្បាប់ អ.វ.ត.ក ផ្តល់ដល់ អ.វ.ត.ក នូវយុត្តាធិការលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានចែងនៅក្នុងអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឆ្នាំ ១៩៤៨។ ធាតុសត្យានុម័តនៃអំពើប្រល័យពូជសាសន៍រួមមាន ការប្រព្រឹត្ត[3355] យ៉ាងហោចណាស់អំពើមួយក្នុងចំណោមអំពើទាំងឡាយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានកំណត់ (បញ្ជាក់ខាងក្រោម)[3356]។ ធាតុអត្តនោម័តិ រួមមានទាំងចេតនា ដែលជាធាតុចាំបាច់ដើម្បីប្រព្រឹត្តអំពើដែលបានកំណត់នោះ និងចេតនាជាក់លាក់នៃអំពើប្រល័យពូជសាសន៍ៈ "ចេតនាក្នុងការកម្ទេចទាំងស្រុង ឬដោយផ្នែក ក្រុមជាតិ ពន្ធុ ពូជសាសន៍ ឬសាសនា *ដូចនោះ*"[3357]។

[3354] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ឹម ទិត្យ ដែលបានកែប្រែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានចោទប្រកាន់ យ៉ឹម ទិត្យ ថាបានប្រព្រឹត្តអំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្ស៊ីណែវ ឆ្នាំ ១៩៤៩ (កថាខណ្ឌ ១០) និងការរំលោភលើក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ (កថាខណ្ឌ ១២) ប៉ុន្តែមូលហេតុដូចខាងក្រោម (សូមមើល VI.គ. ច្បាប់ – ឧក្រិដ្ឋកម្មមិនត្រូវបានដាក់ស្នើ) សហព្រះរាជអាជ្ញាអន្តរជាតិពុំបទប្រកាន់ឧក្រិដ្ឋកម្មទាំងនេះទៅលើយ៉ឹម ទិត្យ នោះទេ។

[3355] ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា ៤ "ការប៉ុនប៉ងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ការសមគំនិតប្រព្រឹត្តអំពើប្រល័យពូជសាសន៍ និងការចូលរួមប្រព្រឹត្តអំពើប្រល័យពូជសាសន៍គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសនៅអ.វ.ត.ក"។

[3356] *សូមមើល* ខាងក្រោមក្នុង VI.A.1.a.ii. ច្បាប់ – គោលការណ៍ច្បាប់ពាក់ព័ន្ធ – ឧក្រិដ្ឋកម្ម – អំពើប្រល័យពូជសាសន៍ – អំពើពិរុទ្ធ។

[3357] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ២០។ សំណុំរឿង *ប្រទេសក្រូអាស៊ី តទល់នឹង ប្រទេសសែប៊ី* កថាខណ្ឌ ១៣២។ សំណុំរឿង *Al Bashir* ដីកាសម្រេចចាប់ខ្លួនដំបូង កថាខណ្ឌ ១៣៩។ របាយការណ៍គណៈកម្មការ Darfur កថាខណ្ឌ ៤៩១។

i. ក្រុមដែលបានទទួលការការពារ

917. ស្របនឹងអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ច្បាប់ អ.វ.ត.ក ចែងអំពីក្រុមដែលបានទទួលការការពារចំនួន៤៖ ជាតិ ពន្ធ[3358] ពូជសាសន៍ និងសាសនា។ ក្រុមដែលបានទទួលការការពារនេះនឹងត្រូវកំណត់ជាវិជ្ជមានដោយយោងតាមអត្តសញ្ញាណរួមមួយ មិនមែនដោយអវិជ្ជមាន ដោយយោងទៅលើតែអវត្តមាននៃអត្តសញ្ញាណណាមួយនោះទេ[3359]។ ករណីមានក្រុមលើសពីមួយ ត្រូវបានកំណត់ជាគោលដៅ ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ នឹងត្រូវកំណត់ទៅតាមក្រុមនីមួយៗដោយឡែកពីគ្នា[3360]។

918. ការប៉ុនប៉ងណាមួយក្នុងការញែកក្រុមនីមួយៗចេញពីគ្នា ដោយផ្អែកទៅលើលក្ខណៈវិនិច្ឆ័យបែបវិទ្យាសាស្ត្រ នឹងមិនសមស្របជាមួយកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ[3361]។ នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ ៩៦ (I) មហាសន្និបាតអង្គការសហប្រជាជាតិបានកំណត់និយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ថាជា "ការដកហូតសិទ្ធិមានអត្ថិភាពនៃ*ក្រុមមនុស្ស*ទាំងមូល"[3362]។ និយមន័យនេះត្រូវបានកំណត់យកដូចគ្នាដោយលេខាធិការដ្ឋានអង្គការ

[3358] បើទោះជាអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ និងច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ប្រើពាក្យ"ជាតិពន្ធ" តែភាគច្រើននៃយុត្តិសាស្ត្រសំដៅទៅលើក្រុម "ជាតិពន្ធ" ឲ្យស្របគ្នានឹងការប្រើប្រាស់ពាក្យពេជន៍ទំនើប។

[3359] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ១៦-២៨។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ៥៤១។ សំណុំរឿង សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ៦៨៥។ សំណុំរឿង *Al Bashir* ដីកាសម្រេចចាប់ខ្លួនដំបូង កថាខណ្ឌ១៣៥។ សំណុំរឿង ប្រទេសបូស្នី តទល់នឹង ប្រទេសសេប៊ី កថាខណ្ឌ១៩៣-១៩៦។

[3360] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ២៨។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ៥៤១។ សំណុំរឿង សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ៦៨០។

[3361] សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ៥៥៦។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ៦៨២។

[3362] សេចក្តីសម្រេច លេខ ៩៦ (I) នៃមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៤៦, ឯកសារអង្គការសហប្រជាជាតិ A/RES/96(I) ទំព័រ១៨៨-១៨៩ (*បន្ថែមការគូសបញ្ជាក់*)។

សហប្រជាជាតិ (១៩៤៨)[3363] និងតុលាការយុត្តិធម៌អន្តរជាតិ (១៩៥១)[3364] ហើយក្រោយមកត្រូវបានបញ្ជាក់ឡើងវិញដោយតុលាការយុត្តិធម៌អន្តរជាតិ[3365] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី[3366] និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា[3367]។ អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវីក្នុងសំណុំរឿង Krstic យល់ឃើញថា៖

> ឯកសារការងាររៀបចំនៃអនុសញ្ញានេះបង្ហាញថា ការកំណត់បញ្ជីមួយដូច្នោះ មានបំណងពណ៌នាបាតុភូតជារួមមួយ ដែលឆ្លើយតបដោយអន្ទើទៅនឹងអ្វីដែលបានទទួលស្គាល់នៅមុនសង្គ្រាមលោកលើកទី២ ថាជា "បណ្តាជនជាតិភាគតិចនៃជាតិមួយ ច្រើនជាងសំដៅលើក្រុមមនុស្សខុសៗគ្នាជាច្រើននោះ"[3368]។

919. អាស្រ័យហេតុនេះ តុលាការ និងគណៈកម្មការទាំងឡាយដែលអនុវត្តអនុសញ្ញានេះ ភាគច្រើនបានចៀសវាងមិនផ្តល់និយមន័យជាក់លាក់ ឬកំណត់ព្រំដែនច្បាស់លាស់នៃក្រុមដែលបានទទួលការការពារនោះទេ ហើយបានគូសបញ្ជាក់នូវការកំណត់យកការបកស្រាយទូលាយចំពោះក្រុមនានា។ តុលាការអន្តរជាតិសម្រាប់យូហ្គោស្លាវី[3369] តុលាការអន្តរជាតិសម្រាប់រវ៉ាន់ដា[3370] និងគណៈ

[3363] ម្យ៉ាង គឺទំនាក់ទំនងរវាងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ហើយម្យ៉ាងទៀត គឺការបង្កើតគោលការណ៍ប្រើប្រាស់នៅតុលាការ Nurnberg និងការតាក់តែងសេចក្តីព្រាងក្រមនៃបទល្មើសប្រឆាំងនឹងសន្តិភាព និងសន្តិសុខ ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៤៨, E/AC.25/3/កំណែទី១ ទំព័រ៦ ["[អំពើប្រល័យពូជសាសន៍] មានចេតនាការសម្លាប់បំផុតពូជជាលក្ខណៈប្រព័ន្ធទៅលើក្រុមមនុស្ស។ [...] ជនរងគ្រោះនៃឧក្រិដ្ឋកម្មនៃអំពើប្រល័យពូជសាសន៍ គឺជាក្រុមមនុស្ស"]។

[3364] ICJ Genocide Advisory Opinion ទំព័រ២៣ ["លក្ខណៈដើមនៃអនុសញ្ញានេះបង្ហាញថា វាជាចេតនារបស់អង្គការសហប្រជាជាតិ ដែលថ្កោលទោស និងផ្តន្ទាទោសអំពើប្រល័យពូជសាសន៍ ជា "ឧក្រិដ្ឋកម្មមួយក្រោមច្បាប់អន្តរជាតិ" *ក្នុងនោះពាក់ព័ន្ធនឹងការបដិសេធសិទ្ធិមានអត្ថិភាពនៃក្រុមមនុស្សទាំងអស់*" (បន្ថែមការគូសបញ្ជាក់)]។

[3365] សំណុំរឿង *ប្រទេសក្រូអាស៊ី* តទល់នឹង *ប្រទេសស៊ែប៊ី* កថាខណ្ឌ ៨៧, ៥០៤។ សំណុំរឿង *ប្រទេសបូស្នី* តទល់នឹង *ប្រទេសស៊ែប៊ី* កថាខណ្ឌ ១៦១, ១៩៤, ៤២២។

[3366] *សូមមើលឧទាហរណ៍* សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៣៦ ["ចារីខ្លួនឯងជាអ្នកកំណត់អត្តសញ្ញាណក្រុមមនុស្សទាំងអស់ ដែលត្រូវបំបាត់ចោលឲ្យអស់"]។

[3367] *សូមមើលឧទាហរណ៍* សាលក្រមក្នុងរឿងក្តី Akayesu កថាខណ្ឌ ៥២២។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ៩៩។

[3368] សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៥៦។

[3369] សាលក្រមក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៦៩។

[3370] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥១១, ៥១៦, ៧០២។ សាលក្រមក្នុងរឿងក្តី *Musema* កថាខណ្ឌ ១៦២។

កម្មាធិការសម្រាប់ដាហ្ស៊ីរ[3371] ទាំងអស់សុទ្ធតែបានបញ្ជាក់ឡើងវិញថា ត្រូវកំណត់ស្ថិតក្នុងវិសាលភាពនៃអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះការដាក់ទណ្ឌកម្មថាជាអំពើប្រល័យពូជសាសន៍ ដែលមានចេតនាកម្ទេចក្រុមមនុស្សដែលរស់នៅអចិន្ត្រៃយ៍ និងស្ថិតស្ថេរ ដែលមានសមាជិកនៃក្រុមនោះស្ថិតនៅ ដោយមិនគិតពីការចង់បានផ្ទាល់ខ្លួនរបស់ពួកគេ ទោះបីជាពួកគេមិនស្របទាំងស្រុងទៅនឹងនិយមន័យនៃឈ្មោះក្រុមទាំងបួន កំណត់ក្នុងអនុសញ្ញានោះក៏ដោយ។

920. ការកំណត់នូវអ្វីដែលបង្កើតបានជាក្រុមដែលទទួលបានការការពារក្នុងករណីណាមួយក៏ដោយ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យទាំងសត្យានុម័ត្ត និងទាំងអត្តនោម័ត្ត។[3372] លក្ខណៈវិនិច្ឆ័យសត្យានុម័ត្ត រួមបញ្ចូលនូវបរិបទនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ពាក់ព័ន្ធ។[3373] លក្ខណៈវិនិច្ឆ័យអត្តនោម័ត្ត រួមមានការស្អប់ខ្ពើម ឬការកំណត់សញ្ញាណដោយជនដៃដល់ចំពោះក្រុមណាមួយ ឈរលើមូលដ្ឋានលក្ខណៈដែលជនដៃដល់ចោទចំពោះក្រុមនោះ[3374] រួមមានទាំងការប្រើពាក្យបង្អាប់។[3375] នៅក្នុងស្ថានភាពខ្លះ ជនរងគ្រោះអាចចាត់ទុកខ្លួនគាត់ថាស្ថិតនៅជារបស់ក្រុមមួយ។[3376] ដូចដែលតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដាបានលើកឡើង នៅក្នុងសំណុំរឿង Bagilishema៖

[3371] របាយការណ៍គណៈកម្មការក្រុងដាហ្ស៊ីរ កថាខណ្ឌ ៤៩៨, ៥០១។

[3372] សាលក្រមក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ២៥៤។ សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣១៧។ សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៦៦៧។ របាយការណ៍ ISIS-Yazidi កថាខណ្ឌ ១០៥។ របាយការណ៍គណៈកម្មការក្រុងដាហ្ស៊ីរ កថាខណ្ឌ ៤៩៩-៥០១។

[3373] សាលក្រមក្នុងរឿងក្តី *Kamuhanda* កថាខណ្ឌ ៦៣០។ សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣១៧។ សាលក្រមក្នុងរឿងក្តី *Rutaganda* កថាខណ្ឌ ៣៧៣។ សាលក្រមក្នុងរឿងក្តី *Musema* កថាខណ្ឌ ១៦៣។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៥៧។

[3374] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៥។ សាលក្រមក្នុងរឿងក្តី *Musema* កថាខណ្ឌ ១៦១។ សាលក្រមក្នុងរឿង ក្តី *Rutaganda* កថាខណ្ឌ ៥៦។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៨៣។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៥៧។ សាលក្រមក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៧០។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ៩៨។ របាយការណ៍ ISIS-Yazidi កថាខណ្ឌ ១០៤។ របាយការណ៍គណៈកម្មការទីក្រុងដាហ្ស៊ីរ កថាខណ្ឌ ៤៩៩។

[3375] របាយការណ៍ ISIS-Yazidi កថាខណ្ឌ ១០៤។ របាយការណ៍គណៈកម្មការទីក្រុងដាហ្ស៊ីរ កថាខណ្ឌ ៥១១។

[3376] សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៨៣។ សាលក្រមក្នុងរឿងក្តី *Musema* កថាខណ្ឌ ១៦១។ សាលក្រមក្នុង រឿងក្តី *Rutaganda* កថាខណ្ឌ ៥៦។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ៩៨។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៥៩។

> ក្រុមមួយអាចនឹងមិនមានព្រំដែនកំណត់និយមន័យជាក់លាក់ ហើយអាចមានករណីលំបាកក្នុងការផ្តល់ចម្លើយជាក់លាក់ចំពោះថាតើជនរងគ្រោះម្នាក់ជាសមាជិករបស់ក្រុមដែលទទួលបានការការពារឬយ៉ាងណា។ លើសពីនេះទៀត ជនដែដល់នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អាចកំណត់ក្រុមមុខសញ្ញាតាមរបៀបផ្សេងៗ ដែលមិនឆ្លើយតបពេញលេញទៅនឹងសញ្ញាណនៃក្រុមដែលមានជាទូទៅ ឬដោយក្រុមផ្សេងៗទៀតនៃសង្គម។ នៅក្នុងករណីនោះ អង្គជំនុំជម្រះយល់ឃើញថា ផ្អែកលើភ័ស្តុតាង ប្រសិនបើជនរងគ្រោះម្នាក់ត្រូវបានជនដែដល់ចាត់ទុកថាស្ថិតនៅក្នុងក្រុមណាមួយនោះ ជនរងគ្រោះនេះ អាចត្រូវអង្គជំនុំជម្រះកំណត់ថាជាសមាជិកនៃក្រុមនោះតែម្តង សម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។[3377]

921. តុលាការអន្តរជាតិនានាបានកំណត់យកដូចៗគ្នានូវនិយមន័យទូលាយ ក្នុងការដាក់តម្រូវជនដែលជាក្រុមគោលដៅទៅក្នុងក្រុមទាំងបួនរបស់អនុសញ្ញា។ នៅក្នុងសំណុំរឿង Akayesu អង្គជំនុំជម្រះតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា កំណត់និយមន័យក្រុម**ជាតិ**មួយ ថាជា "មនុស្សមួយក្រុម ដែលត្រូវបានចាត់ទុកថា មានទំនាក់ទំនងផ្លូវច្បាប់ដូចគ្នា ផ្អែកលើសញ្ជាតិដូចគ្នា ព្រមទាំងមានការផ្តល់សិទ្ធិ និងកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក"។[3378] ទោះជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិសន្និដ្ឋានថា និយមន័យនេះមានលក្ខណៈចង្អៀតពេក ហើយមិនពេញលេញ។ នៅពេលដែលលើកឡើងពីនិយមន័យនៃយុត្តាធិការនេះ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដាបានផ្អែកយ៉ាងច្បាស់ទៅលើអត្ថបទនៃតុលាការយុត្តិធម៌អន្តរជាតិក្នុងសាលក្រម Nottebohm ប៉ុន្តែនៅក្នុងករណីនោះ តុលាការយុត្តិធម៌អន្តរជាតិបានយកចិត្តទុកដាក់លើការកំណត់និយមន័យរបស់ "ជាតិ" នៅក្នុងបរិបទសិទ្ធិនៃរដ្ឋមួយ ក្នុងការអនុវត្តការការពារផ្អែកការទូត។ តុលាការនេះមិនចាប់អារម្មណ៍នឹងខ្លឹមសារនៃ "ក្រុមជាតិ" ក្នុងវិសាលភាពនិយមន័យអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ។ "ប្រជាជាតិនានា" មិនបានបង្កើតឡើងផ្អែកតែទៅលើសញ្ជាតិរួមនោះទេ។ "ជាតិ" មានខ្លឹមសារមិនដូច "ក្រុមជាតិ" មួយ ដែលមានសមាជិកខ្លះជាក់ស្តែងអាចនឹងកាន់សញ្ជាតិ ឬបាន:

[3377] សាលក្រមក្នុងរឿងក្តី *Bagilishema* កថាខណ្ឌ ៦៥។

[3378] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥១២។

ជា "ជាតិ" នៃរដ្ឋមួយផ្សេង ឬដែលជាជនមិនមានរដ្ឋ។[3379] ផ្ទុយមកវិញ "ក្រុមជាតិមួយ មានបុគ្គលនានា ដែលមានប្រភពជាតិតែមួយ"[3380] ដរាបណា "ប្រភពជាតិ" ដែលខុសគ្នាពី "ជាតិ" អាចមានន័យច្រើនផ្សេងៗក្នុងនោះ អាចមានន័យថា ជាតំបន់ភូមិសាស្ត្រ ឬជាតិពីមុនរបស់បុគ្គលម្នាក់[3381] ឬបុព្វបុរសរបស់គាត់។ តាមពិតអ្នកធ្វើសេចក្តីព្រាងអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទទួលស្គាល់នូវសញ្ញាណនៃក្រុមជាតិមួយដូច្នេះថា៖ "បញ្ហាដ៏ល្បីល្បាញនៃជនជាតិភាគតិចអាល្លឺម៉ង់នៅប្រទេសប៉ូឡូញ ឬបញ្ហានៃជនជាតិភាគតិចប៉ូឡូញនៅអាល្លឺម៉ង់ និងបញ្ហាអាល្លឺម៉ង់ Sudeten បង្ហាញថា សញ្ញាណនៃក្រុមជាតិនោះមានលក្ខណៈច្បាស់លាស់យ៉ាងសុក្រិត"។[3382]

922. តាមពិតនៅពេលដែលបកស្រាយសញ្ញាណ "ក្រុមជាតិ" ក្នុងសំណុំរឿង Krstic និងសំណុំរឿងបន្តបន្ទាប់មកទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី បានវាស់វែកក្នុងការវិភាគសញ្ជាតិនៃក្រុមមនុស្ស ឬក្នុងការបែងចែកឲ្យច្បាស់ជាតិនៃក្រុមគោលដៅ ចេញពីក្រុមផ្សេងៗទៀត។ ទោះជាមិនមានសញ្ជាតិមួយដោយឡែកក៏ដោយ តុលាការនេះសម្រេចថា បណ្តាជនអ៊ីស្លាមបូស្នី គឺជា "ក្រុមជាតិ" ដោយផ្អែកទៅលើការទទួលស្គាល់ពួកគេថាជា "ជាតិ" មួយ យោងរដ្ឋធម្មនុញ្ញយូហ្គោស្លាវ ឆ្នាំ១៩៦៣ ព្រមទាំងអង្គហេតុដែលថា បណ្តាអាជ្ញាធរនយោបាយ និងយោធាសែ៊ីបបូស្នីមានទស្សនៈថា ជនជាតិអ៊ីស្លាមបូស្នី គឺជាក្រុមជាតិជាក់លាក់មួយ។[3383] ការសម្រេចថា បណ្តាជនអ៊ីស្លាមបូស្នី គឺជា "ក្រុមដែលបានទទួលការការពារ" មួយ បន្ទាប់មកត្រូវបានសម្រេចយកតាមដូចគ្នា

[3379] Schabas *អំពើប្រល័យពូជសាសន៍នៅក្នុងច្បាប់អន្តរជាតិ* (ឆ្នាំ២០០០) ទំព័រ ១១៥។ Shaw "អំពើប្រល័យពូជសាសន៍ និងច្បាប់អន្តរជាតិ" នៅក្នុង Yoram Dinstein, ed, *ច្បាប់អន្តរជាតិក្នុងសម័យកាលាហាល* (*អត្ថបទតែងសេចក្តីដើម្បីឧទ្ទិសដល់ Shabtai Rosenne*) ទំព័រ ៧៩៧-៨២០ ត្រង់ទំព័រ ៨០៧។

[3380] របាយការណ៍វឌ្ឍនភាពដោយលោក Nicodème Ruhashyankiko អ្នករាយការណ៍ពិសេស *ការសិក្សាអំពីបញ្ហាទប់ស្កាត់ និងផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍* ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៧៣ ឯកសារអង្គការសហប្រជាជាតិ E/CN.4/Sub.2/L.583 ("របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើប្រល័យពូជសាសន៍ ឆ្នាំ១៩៧៣") កថាខណ្ឌ ៥៦។

[3381] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើប្រល័យពូជសាសន៍ ឆ្នាំ១៩៧៣ កថាខណ្ឌ ៥៧-៥៨។

[3382] កំណត់ត្រាផ្លូវការចំនួន០៣ នៃសេចក្តីសង្ខេបរបស់គណៈកម្មការទី៦ នៃមហាសន្និបាត (ឆ្នាំ១៩៤៨) (កិច្ចប្រជុំលើកទី៧៤) ទំព័រ ៩៩-១០០ (អេហ្ស៊ីប)។

[3383] សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៥៩-៥៦០។ ការរកឃើញថា អ្នកកាន់សាសនាមូស្លីមនៅប្រទេសបូស្ន៊ៀ គឺជាក្រុមដែលត្រូវបានការពារ មិនត្រូវបានប៉ះពាល់នៅក្នុងបណ្តឹងឧទ្ធរណ៍ទេ។ *សូមមើល* សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៦, ១៥។

ដោយមិនមានការវិភាគបន្ថែមទៀតនៅក្នុងសំណុំរឿង Blagojevic[3384] Brdanin[3385] Popovic[3386] Karadzic[3387] និង Tolimir[3388] តាមពិតនៅក្នុងភាគច្រើននៃសំណុំរឿងបន្តបន្ទាប់ទាំងនេះ មិនមានយោងដល់និយមន័យ "ក្រុមជាតិ" ដែលបានលើកឡើងក្នុងសំណុំរឿង Krstic នោះទេ ហើយសំណុំរឿងមួយចំនួនច្រើនចំណាយពេលច្រើនជាងក្នុងការពិភាក្សាអំពីបណ្តាជនអ៊ីស្លាមបូស្នី ក្រូអាតបូស្នី និងស៊ែបបូស្នី ផ្តោតទៅលើជាតិពន្ធុដោយម្ឡែកផ្សេងៗទៅវិញ។[3389] តុលាការយុត្តិធម៌អន្តរជាតិ ក៏បានទទួលស្គាល់ផងដែរថា បណ្តាជនអ៊ីស្លាមបូស្នីថាជា "ក្រុមគោលដៅ" មួយ ដោយមិនបានបញ្ជាក់ថា ត្រូវគ្នានឹងក្រុមមួយណានៃក្រុមទាំង៤ នោះទេ។[3390]

[3384] សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៦៦៧។ សាលាដំបូងមិនបានបញ្ជាក់ថា មូស្លីមបូស្នៀ បង្កើតបានជាក្រុមប្រជាជាតិមួយទេ។ ប៉ុន្តែ សាលាដំបូងបានរកឃើញថា ពួកគេគ្រាន់តែជា "ក្រុមដែលត្រូវបានការពារ" ដោយសម្អាងលើសាលក្រមក្នុងរឿងក្តី *Krstić* ជាទម្លាប់ករណ៍។

[3385] សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៧៣៤-៧៣៦។ សាលាដំបូងបានរកឃើញថាមានប្រជាជនពីរក្រុមដែលត្រូវបានការពារ៖ មូស្លីមបូស្នៀ និងក្រូអាតបូស្នៀ តែមិនបានធ្វើការសន្និដ្ឋាន ឬវិភាគថា តើក្រុមក្រូអាតបូស្នៀត្រូវចាត់ចូលក្នុងក្រុមណាមួយក្នុងចំណោមប្រជាជនទាំងបួនក្រុម។ ក្នុងជើងទំព័រលេខ ១៧៨៤ សាលាដំបូងបានបញ្ជាក់ថា ក្រុមក្រូអាតបូស្នៀ "ពុំមានមាតុភូមិទេ។ ពួកគេពុំមានសង្ឃឹមថានឹងទទួលបានការគាំទ្រពីសហគមន៍ដទៃទៀត នៅក្រៅបូស្នៀ-ហ៊ីតហ្គ្រីណា និងជនជាតិរបស់ខ្លួនផ្ទាល់ ថាជាមូស្លីមបូស្នៀឡើយ"។

[3386] សាលក្រមក្នុងរឿងក្តី *Popović* កថាខណ្ឌ ៨៤០។

[3387] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ២៥៧៤។

[3388] សាលក្រមក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ៧៥០ ត្រូវបានបញ្ជាក់ក្នុងបណ្តឹងឧទ្ធរណ៍៖ សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ១៨៥។

[3389] *សូមមើលឧទាហរណ៍*៖ សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៩៤, ១៥៥, ៦៧៤។ សាលក្រមក្នុងរឿងក្តី *Popović* កថាខណ្ឌ ៩៩១, ១១៩៣, ១១៩៤, ១៣៣១, ១៣៩៨, ១៤២៦។ សាលក្រមក្នុងរឿងក្តី *Tadić* កថាខណ្ឌ ៥៦-៥៧, ៨៣។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៥៨, ៨០, *ជើងទំព័រលេខ* ៩៣។ សាលក្រមក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ១៥៩, ៨១៣, ១១៩០។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៣២ (*ជើងទំព័រលេខ* ៦០) [អង្គជំនុំជម្រះទទួលស្គាល់ថា ពាក្យ "ជាតិពន្ធុ" មិនអាចអធិប្បាយគ្រប់ជ្រុងជ្រោយពីលក្ខណៈពិសេសដោយម្ឡែករបស់មូស្លីមបូស្នៀ ក្រូអាតបូស្នៀ និងស៊ើបបូស្នៀឡើយ ពីព្រោះកត្តាដទៃទៀត ដូចជាសាសនា និងសញ្ញាតិ មានភាពពាក់ព័ន្ធទៅនឹងនិយមន័យរបស់ក្រុម ប៉ុន្តែអង្គជំនុំជម្រះបញ្ជាក់ថា ខ្លួននឹងប្រើពាក្យ "ជាតិពន្ធុ" នេះនៅក្នុងសាលក្រមទាំងមូល "ដើម្បីសង្ខេបឲ្យខ្លី"] កថាខណ្ឌ ៦០៣, ២៥៩៨។

[3390] រឿងក្តី *ហ្ស្ទ្រ្ទ្ធ គទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៩៦។

923. ក្រុម**ពន្ធុ**មួយត្រូវបានកំណត់ថាជាក្រុមមួយ "ដែលសមាជិករបស់គេមានភាសា ឬវប្បធម៌ដូចគ្នា"។[3391] ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសំណុំរឿង Akayesu អង្គជំនុំជម្រះដដែល ដែលបានផ្អែកលើនិយមន័យនេះសម្រេចថា ជនជាតិទុតស៊ី គឺជា "ក្រុមពន្ធុ" មួយដោយឡែក ទោះបីជាទុតស៊ីនេះ និងហ្វូទូ មិនអាចបែងចែកដាច់ពីគ្នាផ្អែកទៅលើភាសា ឬក៏វប្បធម៌ក៏ដោយ។ អង្គជំនុំជម្រះនេះផ្អែកសេចក្តីសម្រេចរបស់ខ្លួនលើអត្តសញ្ញាណប័ណ្ណ បញ្ជាក់ក្រុមពន្ធុរបស់ប្រជាជនវ៉ាន់ដា ការបញ្ជាក់ផ្សេងៗនៃក្រុមពន្ធុទាំងនេះ នៅក្នុងឯកសារជាតិ និងអន្តរជាតិ ព្រមទាំងលើអង្គហេតុដែលថា សាក្សីនានាក្នុងសវនាការ "បានបំភ្លឺភ្លាមៗ និងមិនរាវរែក" ស្តីអំពីអត្តសញ្ញាណពន្ធុរបស់ពួកគេ (ការកំណត់សញ្ញាណខ្លួនឯង)។[3392] នៅក្នុងសំណុំរឿង Al Bashir តុលាការព្រហ្មទណ្ឌអន្តរជាតិបានសម្រេចថា Fur, Masalit និង Zaghawa គឺជាក្រុមពន្ធុដោយឡែកពីគ្នាសម្រាប់គោលបំណងនៃអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយសារក្រុមនីមួយៗមានភាសា ប្រពៃណីកុលសម្ព័ន្ធ និងទំនាក់ទំនងប្រពៃណីរបស់ខ្លួន ទាក់ទងទៅនឹងទឹកដីរបស់គេ។[3393]

924. ក្រុម**ពូជសាសន៍**មួយ ត្រូវបានកំណត់និយមន័យ "ផ្អែកទៅលើលក្ខណៈសម្គាល់រាងកាយតំណពូជ ដែលជាទូទៅអាចកំណត់បានតាមតំបន់ភូមិសាស្ត្រមួយ ដោយមិនគិតពីកត្តាភាសា វប្បធម៌ ជាតិ ឬសាសនានោះទេ"។[3394] ទោះជាយ៉ាងណាក៏ដោយ "ពូជសាសន៍" មានការលំបាកក្នុងការបញ្ជាក់ភ័ស្តុតាង។ តុលាការយោធាអន្តរជាតិបានកំណត់ប្រជាជន ជ្វីហ្វ ថាជា "ក្រុមពូជសាសន៍" មួយ មិនមែន

[3391] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥១៣។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ៩៨។ ដើម្បីអធិប្បាយពាក្យ "វប្បធម៌" ដែលអ្ងបីយ៍ គណៈកម្មាធិការអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ បានកំណត់ថា៖ "គណៈកម្មាធិការពិចារណាថា វប្បធម៌ [...] គ្របដណ្តប់លើរបៀបរស់នៅ ភាសា អក្សរសិល្ប៍និយាយនិងសរសេរ តន្ត្រីនិងចម្រៀង ទំនាក់ទំនងមិនមែនជាពាក្យសម្តី សាសនា ឬប្រព័ន្ធជំនឿ ពិធីសែនព្រេន និងពិធីបុណ្យទាន កីឡានិងល្បែង វិធីផលិត ឬបច្ចេកវិជ្ជា បរិស្ថានធម្មជាតិ និងបរិស្ថានដែលបង្កើតដោយមនុស្ស ចំណីអាហារ ការស្លៀកពាក់និងទីជម្រក ព្រមទាំងសិល្ប: ទំនៀមទម្លាប់ និងប្រពៃណី ក្នុងចំណោមទិដ្ឋភាពជាច្រើនទៀត ដែលតាមរយ:នេះ បុគ្គលម្នាក់ៗ ក្រុមបុគ្គល និងសហគមន៍ បង្ហាញពីភាពជាមនុស្ស និងអត្ថន័យនៃអត្ថិភាពរបស់ពួកគេ"។ *សូមមើល* គណៈកម្មាធិការស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ យោបល់សន្និដ្ឋានទូទៅទី២១ - សិទ្ធិរបស់បុគ្គលគ្រប់រូបក្នុងចូលរួមក្នុងជីវិតផ្នែកវប្បធម៌ E/C.12/GC/21 កថាខណ្ឌ ១២-១៣។ សេចក្តីផ្លែងការណ៍ជាសាកលស្តីពីពិពិធភាពវប្បធម៌ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០០១ (សេចក្តីផ្តើម) កំណត់និយមន័យវប្បធម៌ជា "សំណុំលក្ខណៈពិសេសដោយឡែកខាងជំនឿ សម្ភារ: បញ្ញា និងអារម្មណ៍របស់សង្គម ឬក្រុមសង្គមមួយ" [ដែល] គ្របដណ្តប់លើរបៀបរស់នៅជាមួយគ្នា ប្រព័ន្ធគុណតម្លៃ ប្រពៃណី និងជំនឿ បន្ថែមលើសិល្ប: និងអក្សរសិល្ប៍"។

[3392] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ១៧០-១៧១, ៧០២។

[3393] ដីកាបង្គាប់ឲ្យចាប់ខ្លួន *Al Bashir* លើកដំបូង កថាខណ្ឌ ១៣៧។

[3394] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥១៤។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ៩៨។

"ក្រុមសាសនា" មួយ ដោយមិនបានធ្វើការវិភាគប្រកបដោយខ្លឹមសារក្បោះក្បាយ។[3395] ក្នុងការគូសបញ្ជាក់ពីការលំបាកក្នុងការផ្តល់និយមន័យ និងទំនាក់ទំនងទៅវិញទៅមករវាងក្រុមដែលបានទទួលការការពារ អនុសញ្ញាអន្តរជាតិស្តីអំពីការលុបបំបាត់នូវរាល់ទម្រង់នៃការបែងចែកពូជសាសន៍បានកំណត់និយមន័យនៃពាក្យការើសអើង "ពូជសាសន៍" មួយផ្នែកទៅតាមនិយមន័យនៃក្រុមផ្សេងៗ ថាជា "លក្ខណៈដោយឡែក ភាពដាច់ដោយឡែកពីគ្នា ការរឹតត្បិត ឬការទទួលយកផ្អែកលើដើមកំណើត ពូជសាសន៍ ពណ៌សម្បុរ បុព្វបុរស ឬជាតិ ឬពន្ធុ"។[3396]

925. ក្រុម**សាសនា**មួយ គឺជា "ក្រុមដែលសមាជិករបស់គេមានសាសនា លក្ខណៈ ឬបែបបទប្រណិបត្តិដូចគ្នា"។[3397] របាយការណ៍គណៈកម្មាធិការប្រទេសស៊ីរី ឆ្នាំ២០១៦ បានកំណត់ Yazidis ថាជាក្រុមសាសនាមួយ ផ្អែកទៅលើលក្ខណៈវិនិច្ឆ័យទាំងសត្យានុម័ត្ត និងទាំងអត្តនោម័ត្ត។[3398]

ii. ធាតុសត្យានុម័ត្ត

926. មាត្រា ៤ នៃច្បាប់ អ.វ.ត.ក ស្តីអំពីអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានរាយកំណត់អំពើខាងក្រោមថាជាអំពើប្រល័យពូជសាសន៍ : (១) ការសម្លាប់សមាជិកនៃក្រុម (២) ការបង្កព្យាសនកម្មផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរទៅលើសមាជិកនៃក្រុម (៣) បង្កដោយចេតនាទៅលើក្រុមនោះនូវស្ថានភាពរស់នៅ ដែលមានបំណងកម្ទេចរូបរាងទាំងស្រុក ឬដោយផ្នែក (៤) ដាក់វិធានការ ដែលមានបំណងការពារមិនឲ្យមានទារកនៅក្នុងក្រុម (៥) ជម្លៀសដោយបង្ខំ កុមារចេញពីក្រុមមួយទៅក្រុមមួយទៀត។ ដោយសារអំពើទាំងបីដំបូងមានលក្ខណៈពាក់ព័ន្ធជាងគេ ទៅនឹងភ័ស្តុតាងដែលបានរកឃើញក្នុងសំណុំរឿងយ៉ីម ទិត្យ សហព្រះរាជអាជ្ញាអន្តរជាតិស្នើកំណត់ការវិភាគរបស់ខ្លួនទៅត្រឹមអំពើទាំងបីនេះនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

[3395] សាលក្រមរបស់តុលាការយោធាអន្តរជាតិ ទំព័រ ៣០៤។

[3396] អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការើសអើងពូជសាសន៍ (ICEAFRD) មាត្រា ១(១)។

[3397] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥១៥។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ៩៨។

[3398] របាយការណ៍ ISIS-Yazidi កថាខណ្ឌ ១០៣-១០៥។

ការសម្លាប់សមាជិកនៃក្រុម

927. ធាតុសម្ភារនៃការសម្លាប់របស់អំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គឺដូចគ្នាទៅនឹងធាតុទាំងឡាយនៃអំពើមនុស្សឃាតរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3399]។ ការវាយតម្លៃជាតួលេខនៃចំនួនមនុស្សដែលត្រូវបានសម្លាប់ មិនត្រូវការចាំបាច់ទេសម្រាប់បញ្ជាក់ពីធាតុសត្យានុម័ត្ត[3400]។ ជនរងគ្រោះត្រូវតែមានស្ថិតជាផ្នែកមួយរបស់ក្រុមដែលបានទទួលការការពារ[3401] ឬជនដែលនៃឧក្រិដ្ឋកម្មដែលបានជឿថា គាត់បានប្រព្រឹត្ត[3402]។ ការសម្លាប់នៅក្នុងបរិបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនចាំបាច់មានការគិតទុកជាមុនទេ[3403]។

ការបង្កឲ្យមានឈឺចាប់ធ្ងន់ធ្ងរកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរមកលើសមាជិកនៃក្រុម

928. អំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងផ្នែកនេះមាន ការបង្កឈឺចាប់ធ្ងន់ធ្ងរកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ដែលមិនចាំបាច់ បណ្តាលឲ្យជនរងគ្រោះស្លាប់នោះទេ[3404]។ ឬក៏មិនចាំបាច់បណ្តាលឲ្យមាន

[3399] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៤២។

[3400] សាលដីកាយោងវិធាន ៩៨ស្ងួន ក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ២៣, យោងសាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៤២។ ប៉ុន្តែ កម្រិតនៃអំពើយោរយៅ មានភាពពាក់ព័ន្ធនឹងការវាយតម្លៃពី*ទោសធ្ងន់ឧក្រិដ្ឋ*ក្នុងអំពើប្រល័យពូជសាសន៍។

[3401] សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៩៦។ សាលក្រមក្នុងរឿងក្តី *Muhimana* កថាខណ្ឌ ៥០០។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៨៩-៦៩០, ៦៩២។ *សូមមើលផងដែរ* ធាតុផ្សំនៃបទឧក្រិដ្ឋនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៦(ក)-(ង) ធាតុផ្សំទី២ ដូចដែលបានអនុវត្តលើដីកាបង្គាប់ឲ្យចាប់ខ្លួន *Al Bashir* លើកទី២ កថាខណ្ឌ ១០-១២។

[3402] សាលក្រមក្នុងរឿងក្តី *Bagilishema* កថាខណ្ឌ ៦៥។ សាលក្រមក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ២៥៥។ សាលក្រមក្នុងរឿងក្តី *Muhimana* កថាខណ្ឌ ៥០០។ សាលក្រមក្នុងរឿងក្តី *Ndindabahizi* កថាខណ្ឌ ៤៦៨-៤៦៩។ សាលក្រមក្នុងរឿងក្តី *Kajelijeli* កថាខណ្ឌ ៨១៣។ សាលក្រមក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៣១៨។ សាលក្រមក្នុងរឿងក្តី *Rutaganda* កថាខណ្ឌ ៥៦។

[3403] សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៥១។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៥១៥។ សាលក្រមក្នុងរឿងក្តី *Muvunyi I* កថាខណ្ឌ ៤៨៦។ សាលក្រមក្នុងរឿងក្តី *Kajelijeli* កថាខណ្ឌ ៨១៣។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៧២, ៧១១ (*សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ២៥៦-២៥៩)។ សាលក្រមក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៣១៧។ សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣១៩។

[3404] សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣២០។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២០៣ [សំដៅជាក់លាក់ដល់ឈឺចាប់ធ្ងន់ធ្ងរ]។

ការរបួសស្នាមជាអចិន្ត្រៃយ៍ ឬប៉ះប៉ូវបាននោះឡើយ[3405]។ សហព្រះរាជអាជ្ញាអន្តរជាតិ កត់សម្គាល់ទ្ធវយុត្តិសាស្ត្រ ដែលគាំទ្រថា ព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តដែលបានបង្កមកលើសមាជិកនៃក្រុមគោលដៅ "ត្រូវមានលក្ខណៈធ្ងន់ធ្ងរដូចជាការគំរាមបំផ្លាញ[ក្រុមមួយ]ទាំងស្រុង ឬដោយផ្នែក"[3406]។ ទោះជាយ៉ាងណាក៏ដោយ ស្របជាមួយនឹងអង្គជំនុំជម្រះការ៉ាហ្ស៊ីក[3407] សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើថា យោងតាមពាក្យពេចន៍យ៉ាងច្បាស់នៃអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនមានតម្រូវការបន្ថែមថា ព្យសនកម្មធ្ងន់ធ្ងរដែលជាក់ស្តែងបានបង្កមកលើសមាជិកនៃក្រុម ដោយឈរលើអំពើនេះដោយឡែក ត្រូវតែមានលក្ខណៈគំរាមកំហែងជាសត្យានុម័ត្តដល់ការកម្ទេចក្រុមមួយទាំងស្រុង ឬដោយផ្នែកនោះឡើយ។ តាមពិតអនុសញ្ញានេះមិនតម្រូវថាជនដៃដល់ត្រូវតែព្យាយាមកម្ទេចក្រុមនោះតាមរយៈអំពើមួយនៃអំពើទាំងនេះតែមួយមុខនោះទេ។ កម្រិតនៃការគំរាមកម្ទេចក្រុមមួយ ទោះជាយ៉ាងណាក៏ដោយអាចចាត់ទុកថាជាកម្រិតនៃភាពធ្ងន់ធ្ងរនៃព្យសនកម្ម។

929. ឧទាហរណ៍នៃព្យសនកម្មផ្លូវកាយធ្ងន់ធ្ងររួមមាន "ការធ្វើទារុណកម្ម ការរំលោភ អំពើហិង្សាលើរាងកាយ ដែលមិនធ្ងន់ធ្ងរដល់ស្លាប់ ដែលបង្កឲ្យពិការ ឬរបួសធ្ងន់ធ្ងរចំពោះអវៈយវៈខាងក្នុង ឬខាងក្រៅ"[3408]។ ព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរ គឺជាព្យសនកម្មមួយ ដែលបណ្តាលឲ្យមានរបួសស្នាមធ្ងន់ធ្ងរទៅដល់សភាពផ្លូវចិត្តរបស់ជនរងគ្រោះ ហើយរួមបញ្ចូលនូវ "ការបាត់បង់ហួសពីលក្ខណៈបណ្តោះអាសន្ន ឬតិចតួច នៃផ្លូវចិត្ត ដូចជាការបង្កនូវភាពតក់ស្លុត ឬភ័យខ្លាចខ្លាំង ការសម្ពុត ឬការគំរាម

[3405] សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២០៣ [និយាយសំដៅជាក់លាក់ដល់ព្យសនកម្មផ្លូវចិត្ត]។ សាលក្រមក្នុងរឿងក្តី *Bagosora* កថាខណ្ឌ ២១១៧។ សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣២០-៣២២។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥០២។

[3406] *សូមមើល ឧទាហរណ៍*៖ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៤៦។ សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ២០៣។ រឿងក្តី *ក្រូអាត ឥទ្ធិពល ស៊ីបរៀ* កថាខណ្ឌ ១៥៧។

[3407] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៤៤។ *សូមមើល* សាលដីកាយោងវិធាន ៩៨ស្ងួន ក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៣៣។ ដូចអង្គជំនុំជម្រះរឿងក្តី *Karadžić* បានគូសបញ្ជាក់ (*សូមមើល*ជើងទំព័រលេខ ១៧២៨-១៧៣១) អង្គជំនុំជម្រះមុនៗដែលបានដកស្រង់ឡើងវិញនូវភាសាសម្រាប់លក្ខខណ្ឌតម្រូវបន្ថែម អនុវត្តដំណើរការនីតិវិធីស្មើរតែមិនប្រែប្រួល ក្នុងការវិភាគពីភាពធ្ងន់ធ្ងរនៃព្យសនកម្មដែលបានកើតឡើង ដោយមិនបានយោងលើការបង្ហាញណាមួយដែលជាការគំរាមកំហែងដល់ការបំផ្លិចបំផ្លាញក្រុម។ *សូមមើលបន្ថែម* ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៦(ខ) ធាតុផ្សំទី១ ដែលគ្រាន់តែតម្រូវថា "ចារីបានបង្កព្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរដល់មនុស្សម្នាក់ ឬច្រើននាក់"។

[3408] សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៤៦។ សាលដីកាយោងវិធាន ៩៨ស្ងួន ក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៣៣។ សាលក្រមក្នុងរឿងក្តី *Bagosora* កថាខណ្ឌ ២១១៧។ សាលក្រមក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ២៩១។

កំហែង"[3409]។ អំពើដែលបង្កឲ្យមានព្យសនកម្មផ្លូវកាយ និង/ឬផ្លូវចិត្តធ្ងន់ធ្ងររួមមាន "ការធ្វើឲ្យទៅជាទាសករ ការបង្អត់អាហារ ការនិរទេស និងការធ្វើទុក្ខបុកម្នេញ [...] ហើយ [...] ការឃុំឃាំងក្នុងមន្ទីរសន្តិសុខ ជំរំឃុំឃាំងបណ្តោះអាសន្ន និងជំរំប្រមូលផ្តុំក្នុងស្ថានភាពទាំងឡាយ ដែលមានផែនការបណ្តាលឲ្យ[ជនរងគ្រោះ] ការបន្ទាបបន្ថោក បាត់បង់នូវសិទ្ធិសេរីភាពជាមនុស្ស ហើយនិងគាបសង្កត់ពួកគេ និងបង្កដល់ពួកគេនូវការឈឺចាប់ និងទារុណកម្មយោរយៅ"[3410]។

<u>ការបង្ករដោយចេតនាមកលើក្រុមមួយ នូវស្ថានភាពរស់នៅដែលគិតចង់នាំមកនូវការកម្ទេចរូបរាងកាយទាំងស្រុង ឬដោយផ្នែក</u>

930. អំពើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងផ្នែកនេះ រួមមានវិធីសាស្ត្រនៃការកម្ទេច ដែលក្នុងនោះជនដែលមិនសម្លាប់ភ្លាមៗនូវសមាជិកនៃក្រុម ក៏ប៉ុន្តែដែលចុងក្រោយមកបណ្តាលឲ្យមានការកម្ទេចលើរូបរាងកាយរបស់ក្រុមនោះ[3411]។ ប្រភេទជាក់លាក់នៃស្ថានភាពដែលស្ថិតនៅក្នុងឧក្រិដ្ឋកម្មផ្នែកនេះ រួមមាន (១) ការខ្វះខាតជម្រក សម្លៀកបំពាក់ អនាម័យ ហើយនិងការរក្សាសុខភាព/ការខ្វះខាតសេវាសុខាភិបាលចាំបាច់ ដែលស្ថិតនៅក្រោមតម្រូវការអប្បរិមា (២) ពលកម្មការងារ ឬប្រើរាងកាយហួសកម្រិត (៣) ការរំលោភសេពសន្ថវៈ (៤) ការបង្អត់អាហារ ឬដាក់ឲ្យមនុស្សហូបអាហារ ត្រឹមតែរស់ជីវិត ហើយ (៥) បណ្តេញជាប្រព័ន្ធនូវក្រុមមនុស្សចេញពីផ្ទះរបស់គេ[3412]។ ភ័ស្តុតាងនៃការ

[3409] សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៤៦។ សាលក្រមក្នុងរឿងក្តី *Muhimana* កថាខណ្ឌ ៥០២។

[3410] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥០៣ ដោយយោងសាលក្រមក្នុងរឿងក្តី *Eichmann* (*អ៊ីស្រាអែល ឆ្នាំ១៩៦១*) កថាខណ្ឌ ១៨៦។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២០៩, ២១២។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៤៥។ សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៦៤៦។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥១៣។ *សូមមើលបន្ថែម* ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៦(ខ) *ជើងទំព័រលេខ* ៣ ["ការប្រព្រឹត្តនេះអាចរួមមាន [...] ការធ្វើទារុណកម្ម អំពើរំលោភសេពសន្ថវៈ អំពើហិង្សាផ្លូវភេទ ឬការប្រព្រឹត្តអមនុស្សធម៌ ឬបន្ថោកបន្ទាប"] ។

[3411] សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២២៧។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥០៥។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១១៦។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៥១៧-៥១៨។

[3412] សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២២៨។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១១៥-១១៦។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥០៦។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៩១។

បញ្ជាក់ថាមានការកម្ទេចតាមផ្លូវកាយជាក់ស្តែងទៅលើក្រុមគោលដៅទាំងស្រុងឬដោយផ្នែក មិនត្រូវការចាំបាច់នោះទេ[3413]។

931. ក្នុងពេលអវត្តមាននៃភ័ស្តុតាងផ្ទាល់ ដើម្បីបញ្ជាក់នូវលក្ខខណ្ឌរស់នៅ ដែលបានដាក់មកលើក្រុមមួយ ថាតើមានចេតនាគិតទុកជាមុន និងបង្កឲ្យមានការខូចខាតផ្លូវកាយរបស់ក្រុមនោះឬយ៉ាងណា អង្គជំនុំជម្រះមួយអាចនឹងយោងទៅតាមលទ្ធភាពដែលអាចកើតឡើងជាសត្យានុម័ត្ត នៃបណ្តាលក្ខខណ្ឌទាំងនេះ ដែលអាចនាំឲ្យមានការខូចខាតផ្លូវកាយដោយផ្នែកនៃក្រុម។ លក្ខណៈជាក់ស្តែងនៃស្ថានភាពរស់នៅ កម្រិតនៃរយៈពេលដែលសមាជិកនៃក្រុមបានទទួលរងស្ថានភាពទាំងនោះ និងលក្ខណៈនៃក្រុម ដូចជាភាពងាយទទួលរងគ្រោះថ្នាក់ គឺជាកត្តាបង្ហាញដែលត្រូវធ្វើងផ្ទែង វាយតម្លៃលក្ខណៈវិនិច្ឆ័យនៃលទ្ធភាព នៃអំពើដែលអាចកើតឡើង[3414]។

iii. ធាតុអត្តនោម័ត្ត

<u>ចេតនាក្នុងការកម្ទេចក្រុម "ដូចនោះ"</u>

932. ដូចបានបញ្ជាក់ខាងលើ[3415] អនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍បានអនុម័ត្តដោយមានកម្មវត្ថុ និងគោលបំណងលើកស្ទួយការរស់នៅរបស់ក្រុមមនុស្ស និងផ្តន្ទាជនណាដែលព្យាយាមលុបបំបាត់ក្រុមមនុស្សទាំងនោះ។ វាគឺជាចេតនា "កម្ទេចទាំងស្រុង ឬដោយផ្នែកនូវ [ក្រុមដែលទទួលរងការការពារ] ដូចនោះ"[3416] ដែលសម្រេចបាននូវបំណងនេះ ដែលការពារការរស់រានមានជីវិតនៃក្រុម

[3413] សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២២៥ [ដោយឯកភាពលើសេចក្តីសង្ខេបយុត្តិសាស្ត្ររបស់សាលក្រម]។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៩១។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៤៦។

[3414] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៤៨។ សាលក្រមក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ៧៤២។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៩០៦។

[3415] *សូមមើល* VI.ក.1.ក.i. អង្គច្បាប់ - គោលការណ៍ច្បាប់ពាក់ព័ន្ធ – ឧក្រិដ្ឋកម្ម – អំពើប្រល័យពូជសាសន៍ – ក្រុមដែលត្រូវបានការពារ។

[3416] និយមន័យនៃអំពើប្រល័យពូជសាសន៍នៅក្នុងមាត្រា II នៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ និងនៅក្នុង លក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា (ICTR) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) (លក្ខន្តិកៈ ICTY មាត្រា៤។ លក្ខន្តិកៈ ICTR មាត្រា២។ លក្ខន្តិកៈ ICC មាត្រា៦) មានឃ្លា "ប៉ែបហ្ស៊ីង" ជាប់ពីក្រោយពាក្យ "ក្រុមសញ្ជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនា"។ ចំណុចនេះក៏ត្រូវបានផ្ទុះបញ្ជាំងនៅក្នុងអត្ថបទជាភាសាបារាំងនៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាញ្ញក្នុងតុលាការកម្ពុជា ["អំពើប្រល័យពូជសាសន៍

មនុស្សទាំងនេះ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនត្រូវបានបង្កើតឡើងដោយសារតែមិនដូច្នេះទេ ការប្រព្រឹត្តមិនត្រឹមត្រូវ ឬមនុស្សឃាតទៅលើសមាជិកនៃក្រុម អាចនឹងមិនទទួលទណ្ឌកម្ម ឧក្រិដ្ឋកម្មទាំងនេះត្រូវបានកំណត់ជាអំពើឧក្រិដ្ឋ និងអាចផ្តន្ទាទោសបានក្នុងរូបភាពជាប្រភេទឧក្រិដ្ឋកម្មផ្សេងៗ ដូចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំពើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញ។ ផ្ទុយទៅវិញ អនុសញ្ញានេះទទួលស្គាល់ព្យួសនកម្មជាពិសេសមួយ ដែលទទួលរងនៅពេលដែលក្រុមទាំងមូលមួយបានដាក់ជាគោលដៅ៖

> *ជនរងគ្រោះជាចុងក្រោយនៃអំពើប្រល័យពូជសាសន៍ គឺជាក្រុមតែម្តង* ទោះបីជាការកម្ទេចក្រុមនោះមិនតម្រូវជាចាំបាច់ឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងសមាជិករបស់ក្រុមនោះ ពោលគឺប្រឆាំងនឹងបុគ្គលទាំងឡាយ ដែលស្ថិតនៅក្នុងក្រុមនោះ[3417]។

933. ស្របនឹងហេតុផលចម្បងនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តម្រូវការដែលថាជនដៃដល់មានចេតនាកម្ទេចក្រុមមួយ "ដូចនោះ" មានន័យថា កម្ទេចក្រុមនោះក្នុងឋានៈជា *"អង្គមួយខុសពីគេ និងដោយឡែក"*[3418] ក្នុងលក្ខណៈថា ទោះបីជាមានសមាជិកនៃក្រុម ឬអ្នកជំនាន់ក្រោយរបស់គេរស់នៅក៏ដោយ តែក្រុមនោះមិនមានអត្ថិភាពឡើយ បុគ្គលទាំងនោះមិនត្រូវបានកំណត់អត្តសញ្ញាណ ហើយក៏មិនកំណត់អត្តសញ្ញាណខ្លួនឯងថាជារបស់ក្រុមនោះឡើយ។

934. នៅក្នុងសវនាការករណីខ្លះ ទោះជាមិនសម្រាប់ជាទម្ងន់នៃសាលក្រមក៏ដោយ បានកំណត់ថាពាក្យ "ដូចនោះ" បង្ហាញពីតម្រូវការថា អំពើដែលត្រូវហាមឃាត់ នឹងបង្កើតបានជាអំពើប្រល័យពូជសាសន៍ លុះត្រាតែវាបានប្រព្រឹត្តប្រឆាំងនឹងជនរងគ្រោះម្នាក់ "ជាពិសេសដោយសារ" គាត់ជាសមា

ដែលគ្មានអាជ្ញាយុកាល គឺជាអំពើមួយក្នុងចំណោមអំពើដូចខាងក្រោម ហើយដែលបានប្រព្រឹត្តក្នុងគោលបំណងបំផ្លិចបំផ្លាចទាំងស្រុង ឬមួយផ្នែកនៃក្រុមជាតិ ជាតិពន្ធ ពូជសាសន៍ ឬសាសនាណាមួយដូចជា៖" (*បន្ថែមការសង្កត់ន័យ*)]។

[3417] សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៩៨។ សាលក្រមឲ្យរួចទោសក្នុងរឿងក្តី *Sikirica* កថាខណ្ឌ ៨៩។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៥២១។

[3418] សាលក្រមក្នុងរឿងក្តី *Bagilishema* កថាខណ្ឌ ៦៤។ សាលក្រមក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៧៩។ សេចក្តីព្រាងក្រមរបស់គណៈកម្មការច្បាប់អន្តរជាតិ ឆ្នាំ១៩៩៦ (ដោយមានសេចក្តីអត្ថាធិប្បាយ) ទំព័រ ៤៥។ *សូមមើលបន្ថែម* សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៦៦៥។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៩៨។

ជិកនៅក្នុងក្រុមមួយដែលបានទទួលការការពារ[3419] ទៅតាម "*គោលបំណងនិងកម្មវត្ថុ* នៃការបែងចែកដាច់ច្បាស់ពីគ្នារវាងការសម្លាប់រង្គាល និងឧក្រិដ្ឋកម្មទាំងឡាយដែលក្នុងនោះជនដៃដល់ដាក់គោលដៅចំក្រុមពិសេសណាមួយផ្អែកលើសញ្ជាតិ ពូជសាសន៍ ពន្ធុ ឬសាសនា"[3420]។ ប៉ុន្តែការបកស្រាយនេះនឹងធ្វើឲ្យពាក្យ "ដូចនោះ" មានលក្ខណៈច្រំដែល[3421] ពីព្រោះចេតនាកម្ទេចក្រុមមួយទាំងស្រុង ឬដោយផ្នែកមានបញ្ចូលរួចទៅហើយនូវសញ្ញាណសមាជិកភាពនៅក្នុងក្រុមគោលដៅ ដែលបានកំណត់ជនរងគ្រោះ ហើយធាតុសត្យានុម័ត្តនៃការសម្លាប់មនុស្ស ត្រូវការឲ្យមានជាពិសេស "ការសម្លាប់ *សមាជិកនៃក្រុម*"។ នៅក្នុងពេលតែមួយការបកស្រាយន័យចង្អៀតនៃពាក្យ "ដូចនោះ" មិនបានក្តោបយកខ្លឹមសារនៃឧក្រិដ្ឋកម្មប្រឆាំងពូជសាសន៍ឡើយ។ ដូចដែលតុលាការយុត្តិធម៌អន្តរជាតិបានលើកឡើង ធាតុអត្តនោម័ត្តនៃឧក្រិដ្ឋកម្មប្រឆាំងពូជសាសន៍មានវិសាលភាពហួសពីការកំណត់គោលដៅបុគ្គលមួយចំនួន គ្រាន់តែដោយសារតែសមាជិកភាពរបស់គេនៅក្នុងក្រុមណាមួយជាក់លាក់[3422]។ ចេតនាវើសអើងដូច្នោះ មានលក្ខណៈគ្រប់គ្រាន់សម្រាប់អំពើធ្វើទុក្ខបុកម្នេញនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់អំពើប្រឆាំងពូជសាសន៍ ដែលក្នុងនោះជនដៃដល់ត្រូវតែព្យាយាមកម្ទេចសហគមន៍ដោយម្ឡៃកមួយដូចនោះ[3423]។ តម្រូវការធាតុអត្តនោម័ត្តនៃឧក្រិដ្ឋកម្មប្រឆាំងពូជសាសន៍ ដែលថា អំពើទាំងឡាយត្រូវប្រព្រឹត្តដោយមានចេតនាកម្ទេចក្រុម "ដូចនោះ" មានន័យថា វាជាចេតនារបស់ជនដៃដល់ដែលថា ទោះជាបុគ្គលទាំងឡាយដែលជាអតីតសមាជិកនៃក្រុម អាចនឹងមានជីវិតរស់នៅបន្ត ប៉ុន្តែក្រុមនោះនឹងលែងមានអត្ថិភាពក្នុងរូបភាពជាក្រុមជាតិ ពន្ធុ ពូជសាសន៍ ឬសាសនា។

[3419] *សូមមើលឧទាហរណ៍*៖ សាលដីកាក្នុងរឿងក្តី *Niyitegeka* កថាខណ្ឌ ៥០។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥២១។

[3420] សាលដីកាក្នុងរឿងក្តី *Niyitegeka* កថាខណ្ឌ ៥៣។

[3421] គោលការណ៍ជាមូលដ្ឋាននៃការបកស្រាយសន្ធិសញ្ញា គឺថា បញ្ញត្តិមួយ មិនត្រូវបកស្រាយ ដើម្បីបង្កើតពាក្យឲ្យបានច្រើន ឬលើសពីតម្រូវការឡើយ។ *សូមមើល* សាលដីកាក្នុងរឿងក្តី *Nyiramasuhuko* កថាខណ្ឌ ២១៣៧ *ជើងទំព័រលេខ* ៤៩៦៣ *ដកស្រង់* សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២៨៤។ សាលក្រមលើអញ្ជត្រកម្ម ក្នុងរឿងក្តី *ហ្សកហ្ស៊ី តទល់នឹង រុស្ស៊ី* កថាខណ្ឌ ១៣៣-១៣៤។

[3422] រឿងក្តី *ប៊ូស្ន៊ៀ តទល់នឹង ស៊ើបប៊ៀ* កថាខណ្ឌ ១៨៧។ *សូមមើលផងដែរ* សាលក្រមក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៧៩។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥២២។

[3423] សាលក្រមក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៧៩។

935. លក្ខណៈវិនិច្ឆ័យនៃចេតនាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងការកម្ទេចក្រុមទាំងស្រុង ឬដោយផ្នែកក្នុងឋានៈជាអង្គប្លែកពីគេនិងដោយឡែក តាមការវិភាគមានលក្ខណៈដាច់ដោយឡែកពីលក្ខណៈវិនិច្ឆ័យនៃអំពើដែលបានហាមឃាត់ ឬ*ធាតុសត្យានុម័ត្ត* នៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។[3424] ដូចដែលចៅក្រម Shahabuddeen បានកត់សម្គាល់នៅក្នុងសំណុំរឿង Krstic គេមិនត្រូវ "មើលរំលងការខុសគ្នារវាងលក្ខណៈនៃ 'អំពើ' ដែលបានរាយក្នុងបញ្ជី ហើយនិង 'ចេតនា' ដែលអំពើនោះបានប្រព្រឹត្ត"[3425]។ ដូច្នេះ ទោះបីជា "ចេតនាក្នុងការកម្ទេច" នៃជនដៃដល់មកលើជនដែលទទួលការការពារ ជារឿយៗនឹងត្រូវស្តែងឡើងតាមរយៈការចូលរួមរបស់គាត់នៅក្នុងអំពើមួយនៃអំពើទាំងឡាយដែលបានរាយក្នុងបញ្ជី បង្កើតបានជាធាតុសត្យានុម័ត្ត ហើយតាមពិតការចូលរួមរបស់គាត់ក្នុងអំពើមួយ នៃអំពើទាំងនោះត្រូវតែមានចាំបាច់ ដើម្បីបំពេញធាតុផ្សំសម្ភារៈនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក៏ដោយ គ្មានអ្វីនៅក្នុងអនុសញ្ញា តម្រូវថាជនដៃដល់ត្រូវធ្វើផែនការកម្ទេចក្រុមនោះទាំងស្រុង ឬដោយផ្នែក ដោយសារត្រឹមតែអំពើមួយ ឬច្រើននៃអំពើទាំងនោះនោះទេ។

936. លើសពីនេះទៀតយុត្តិសាស្ត្រអន្តរជាតិខ្លះ ទោះបីជាមិនមែនសម្រាប់ជាទម្ងន់សាលក្រមក៏ដោយ បានសម្រេចថា "ការកម្ទេច" ដោយមានចេតនាទៅលើក្រុមមួយត្រូវតែ "មានលក្ខណៈជារូបរាងកាយ ឬជីវសាស្ត្រ"[3426]។ ប៉ុន្តែអត្ថិភាពនៃក្រុមមួយ គឺជាបញ្ហាដោយឡែកខុសពីការដែលគ្រាន់តែរស់រានមានជីវិតនៃសមាជិកនានា ក្រុមគឺជាអង្គមួយ ដែលមានអត្ថិភាពទាំងរូបរាងកាយ ទាំងសង្គម។ ជាការពិតណាស់អង្គនេះរួមមានបុគ្គលនានា ប៉ុន្តែអ្វីដែលធ្វើឲ្យបុគ្គលទាំងនេះអាចកំណត់បានជាក្រុមមួយ គឺមិនមែនជាអត្ថិភាពជាបុគ្គលនោះទេ ប៉ុន្តែគឺជាអត្តសញ្ញាណរួមរបស់ពួកគេ ប្រវត្តិសាស្ត្ររបស់ពួកគេ ជំនឿ វប្បធម៌ ភាសា និងប្រពៃណី ទំនាក់ទំនងរវាងសមាជិកក្រុម ទំនាក់ទំនងជាមួយទឹកដី ដែលផ្សារភ្ជាប់សមាជិកនីមួយៗនៃក្រុម[3427]។ ការកម្ទេចក្រុមមួយ ដែលគេអាចកំណត់បានជាអង្គខុសប្លែកពីគេ និងដោយឡែក ដូច្នេះអាចមានជាទម្រង់ផ្សេងៗទៀត ដែលអាចមិនមែនជាការកម្ទេចរូបរាងកាយ (ការសម្លាប់) នៃសមាជិកនានា ឬមិនមែនជាការកម្ទេចលទ្ធភាព

[3424] សាលដីកាយោងវិធាន ៩៨ស្ទ្ធ ក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ២២។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣៣-៣៥។ រឿងក្តី *ក្រូអាត តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៣០។

[3425] សាលដីកាក្នុងរឿងក្តី *Krstić* យោបល់ជំទាស់មួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៤៨។

[3426] *សូមមើលឧទាហរណ៍៖* សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ២៥។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥៣។ រឿងក្តី *ក្រូអាត តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៣៦។

[3427] សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៦៦៦។

របស់បុគ្គលពួកគេក្នុងការបន្តពូជកូនចៅទៅជំនាន់ក្រោយទៀត។ ក្រុមមួយអាចត្រូវដកហូតចេញនូវអត្តិភាពរបស់ខ្លួនតាមរយៈការកម្ទេចលក្ខណៈសម្គាល់ពិសេស ឬបំបែកសមាជិករបស់ក្រុមដែលនាំទៅដល់ការរលាយនូវឯកភាព និង/ឬអត្តសញ្ញាណរួមរបស់ក្រុមនៅក្នុងលក្ខណៈជាមូលដ្ឋាន និងមិនអាចប៉ះប៉ូវបានឡើងវិញ។ ចៅក្រម Shahabuddeen បានលើកឡើងចំណុចនេះនៅក្នុងសំណុំរឿង Krstic៖

> ការលើកឡើងជាច្រើននៅក្នុងអត្ថបទនានាស្តីអំពីតម្រូវការឲ្យមានការកម្ទេចនូវរូបរាងកាយ ឬជីវសាស្ត្រ បង្ហាញដោយត្រឹមត្រូវថា ក្រុមមួយអាចត្រូវកម្ទេចតាមមធ្យោបាយមិនមែនរូបរាងកាយ ឬមិនមែនជីវសាស្ត្រ មានហេតុផលមិនច្បាស់លាស់ ថាតើហេតុអ្វីបានជាចេតនាក្នុងការកម្ទេចក្រុមមួយតាមមធ្យោបាយមិនមែនរូបរាងកាយ ឬមិនមែនជីវសាស្ត្រ គួរតែនៅក្រៅវិសាលភាពធម្មតានៃអនុសញ្ញានេះ [...] ក្នុងករណីដែលចេតនានោះបានផ្សារភ្ជាប់ទៅនឹងអំពើដែលបានរាយក្នុងបញ្ជីរួចទៅហើយ [...][3428]។
>
> វាគឺជាក្រុមដែលត្រូវបានការពារ។ ក្រុមមួយបង្កើតឡើងដោយបុគ្គលិកលក្ខណៈជារៀយៗមិនអាចមើលឃើញ ឬចាប់បាន ហើយមានចំណងផ្សារភ្ជាប់ទាំងអស់គ្នាជាក្រុមមនុស្ស ដែលជាអង្គសង្គមមួយ។ ករណីបុគ្គលិកលក្ខណៈទាំងនោះបានបំផ្លាញរួចអស់នៅក្នុងការអនុវត្តចេតនា ដោយសារអំពើណាមួយដែលមានរាយក្នុងបញ្ជី [...] បានប្រព្រឹត្ត វាមិនអាចជឿបានទេថា ការកម្ទេចនោះទោះបីជាបានលុបបំបាត់ក្រុមនោះដោយប្រសិទ្ធភាព តែមិនបង្កើតបានជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដោយសារសំអាងថា ការលុបបំបាត់ទាំងនោះមិនមានលក្ខណៈជារូបរាងកាយ ឬជីវសាស្ត្រទេនោះ[3429]។

[3428] សាលដីកាក្នុងរឿងក្តី *Krstić*, យោបល់ជំទាស់មួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៤៩។

[3429] សាលដីកាក្នុងរឿងក្តី *Krstić* យោបល់ជំទាស់មួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៥០។ *សូមមើលបន្ថែម* សាលក្រមក្នុងរឿងក្តី *Düsseldorf ឆ្នាំ១៩៩៩* កថាខណ្ឌ ៣៨។ ["[D]er Tatbestand [des Gesetzes] [setzt] nicht zwingend voraus, daß der Täter die körperliche Vernichtung, die physische Zerstörung der Gruppe anstrebt. Es reicht aus, daß er handelt um die Gruppe in ihrer sozialen Existenz ('als solche'), als soziale Einheit in ihrer Besonderheit und Eigenart und in ihrem Zusammengehörigkeitsgefühl zu zerstören." បកប្រែក្រៅផ្លូវការ៖ "វាមិនចាំបាច់ទាល់តែអ្នកប្រព្រឹត្តព្យាយាមបំផ្លិចបំផ្លាញរូបវន្តរបស់ក្រុមនោះទេ។ វាគ្រប់គ្រាន់ណាស់ទៅហើយ ដែលអ្នកប្រព្រឹត្តនោះធ្វើសកម្មភាពបំផ្លិចបំផ្លាញអត្ថិភាពសង្គមរបស់ក្រុម ('បែបហ្នឹង') ក្នុងនាមជាអង្គភាពសង្គមមួយដែលមានលក្ខណៈពិសេស និងអារម្មណ៍នៃភាពជា

937. តាមពិតអនុសញ្ញានេះ បានបញ្ជាក់ច្បាស់ថា ក្រុមមួយអាចត្រូវកម្ទេចដោយគ្មានសេចក្ដីស្លាប់នៃសមាជិកនៃក្រុម។ អំពើនានានៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលបានចែងនៅក្នុងអនុសញ្ញា មិនចាំបាច់ត្រូវតែមានការកម្ទេចជារូបរាងកាយ ឬជីវសាស្ត្រនោះទេ។ ឧទាហរណ៍ "ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅក្រុមមួយទៀត" បានចាត់ទុកថាជាអំពើប្រល័យពូជសាសន៍មួយ[3430]។ ករណីដែលកុមារបានបញ្ជូនដោយមិនមានព្យួសនកម្មលើរូបរាងកាយ ហើយទោះជាករណីកុមារទាំងនោះបានទទួលការរស់នៅផ្នែកសម្ភារៈក្នុងកម្រិតខ្ពស់ជាងនៅក្នុងក្រុមថ្មីក៏ដោយ[3431] ការបញ្ជូនកុមារ គឺជាមធ្យោបាយប្រសិទ្ធភាពមួយក្នុងការកម្ទេចលក្ខណៈនៃក្រុម "ដែលផ្សារភ្ជាប់ក្រុមមនុស្សជាអង្គសង្គមមួយ"[3432]។ ប្រសិនបើរដ្ឋាភិបាលមួយត្រូវបញ្ជូនកុមារទាំងអស់ពីរង្វង់ក្រុមគ្រួសារទៅកាន់ក្រុមភាគតិចដោយម្នាក់ណាមួយ ទៅកាន់ស្ថាប័នរដ្ឋនានា ឬគ្រួសារនានានៅក្រៅរង្វង់នៃក្រុមនោះ ក្នុងរយៈពេលមួយជំនាន់ ឬពីរជំនាន់ ក្រុម "ដូចនោះ" នឹងត្រូវបាត់ខ្លួន។ អ្នកធ្វើសេចក្ដីព្រាងនៃអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ខ្លួនឯង បានទទួលស្គាល់ថា ការបញ្ជូលមនោគមន៍វិជ្ជាកុមារដោយបង្ខំទៅក្នុងប្រពៃណី ភាសា សាសនា និងតម្លៃនានានៃក្រុមបរទេសមួយ គឺ "ស្មើនឹងកម្ទេចក្រុម [របស់កុមារ] ដែលអនាគតរបស់ពួកគេផ្អែកលើកុមារជំនាន់នោះ"[3433]។ នេះច្បាស់ណាស់ជាអ្វីដែលគណៈកម្មាធិការស៊ីវីក្នុងពេលព្រមានអំពីអំពើប្រល័យពូជសាសន៍ ដែលកំពុងប្រព្រឹត្តឡើងដោយអាយស៊ីស មកលើយ៉ាហ្ស៊ីឌី បានរកឃើញថាកំពុងកើតឡើងចំពោះកុមារយ៉ាហ្ស៊ីឌី : តាមរយៈការដកកុមារចេញពីគ្រួសាររបស់គេ "អាយស៊ីសព្យាយាមដោយចេតនាកម្ទេចអត្តសញ្ញាណនៃយ៉ាហ្ស៊ីឌីរបស់កុមារយ៉ាហ្ស៊ីឌីស ដោយលុបបំបាត់នូវការគោរពរបស់កុមារទាំងនោះទៅនឹងសាសនាយ៉ាហ្ស៊ីឌី។ ខណៈដែលកុមារីយ៉ាហ្ស៊ីឌីបានរារាំងមិនឲ្យប្រណិបត្តិសាសនារបស់ពួក

កម្មសិទ្ធិរួម"]។ សាលក្រមក្នុងរឿងក្តី *Jorgić* កថាខណ្ឌ ២០, ២២, ២៨, ៣៣។ ច្បាប់ (ផ្ដន្ទាទោស) ពួកណាហ្ស៊ី និងអ្នកចូលដៃជាមួយពួកណាហ្ស៊ី ឆ្នាំ១៩៥០ មាត្រា១(ខ)(៦) [ចាត់ទុក "ការបំផ្លិចបំផ្លាញ ឬការប្រមាថសម្បត្តិ និងតម្លៃសាសនា និងវប្បធម៌របស់ជនជាតិជ្វីហ្ស" ជាអំពើប្រល័យពូជសាសន៍ ប្រសិនបើត្រូវបានប្រព្រឹត្តដោយចេតនាដាច់ខាត]។

[3430] **អនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍** មាត្រា II(ង)។

[3431] កំណត់ត្រាផ្លូវការចំនួន០៣ នៃសេចក្ដីសង្ខេបរបស់គណៈកម្មការទី៦ នៃមហាសន្និបាត (ឆ្នាំ១៩៤៨) (កិច្ចប្រជុំលើកទី៨៣) ទំព័រ ១៩៥ (រ៉ូណូហ្ស៊ីយអេឡា)។

[3432] សាលដីកាក្នុងរឿងក្តី *Krstić* យោបល់ជំទាស់មួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៥០។ *សូមមើល ផងដែរ* សាលាក្រមក្នុងរឿងក្តី *Düsseldorf ឆ្នាំ១៩៤៩* កថាខណ្ឌ ៣៨។

[3433] កំណត់ត្រាផ្លូវការចំនួន០៣ នៃសេចក្ដីសង្ខេបរបស់គណៈកម្មការទី៦ នៃមហាសន្និបាត (ឆ្នាំ១៩៤៨) (កិច្ចប្រជុំលើកទី៨៣) ទំព័រ ១៩៥ (រ៉ូណូហ្ស៊ីយអេឡា)។ *សូមមើលផងដែរ* កិច្ចប្រជុំលើកទី៨២ ទំព័រ ១៨៦ (ប្រទេសក្រិច និងបារាំង) [ធ្វើចំណាត់ថ្នាក់ការផ្ទេរកុមារដោយបង្ខំជាអំពើប្រល័យពូជសាសន៍ផ្នែកវប្បធម៌]។

គេ កុមារាយ៉ាហ្ស៊ីឌីបានត្រូវបញ្ជូលមនោគមន៍វិជ្ជាទាំងស្រុងទៅក្នុងអាយស៊ីស"[3434]។ ដូច្នេះទោះជាការបញ្ជូនកុមារមិនបានធ្វើអ្វីក្នុងការកម្ទេចក្រុមមួយ "ផ្នែករូបរាងកាយ ឬផ្នែកជីវសាស្ត្រ" ក៏ដោយ ដោយសារកុមារទាំងនោះបានរស់នៅមានជីវិតជាបន្ត ប៉ុន្តែការបញ្ជូននោះពិតជាបានកម្ទេចក្រុម "ដូចនោះ" ក្នុងន័យថា កុមារដែលត្រូវបានបញ្ជូននោះនឹងលែងសម្គាល់ខ្លួនឯងថាជារបស់ក្រុមនោះទៀតហើយ បង្កើតបានជាការកម្ទេចក្រុមមួយចប់សព្វគ្រប់ដូចនោះ។

938. ដូចគ្នានេះដែរអំពើនានាដូចជាការនិរទេស/ការជម្លៀសដោយបង្ខំនៃក្រុមជាក់លាក់មួយ ដែលមិនស្ថិតនៅក្នុងអំពើដែលបានរាយក្នុងបញ្ជី[3435] បង្កើតបានជាធាតុសត្យានុម័ត្តនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទេនោះ អាចចូលរួមកម្ទេចក្រុម "ដូចនោះ" ហើយអាស្រ័យហេតុនេះបង្ហាញពីធាតុអត្តនោម័ត្តដោយបញ្ជាក់ពីចេតនារបស់ជនដៃដល់ក្នុងការកម្ទេចក្រុមនោះ។ អង្គជំនុំជម្រះក្នុងសំណុំរឿង Blagojevic បានពន្យល់ថា :

> ការកម្ទេចនូវរូបរាងកាយ ឬជីវសាស្ត្រនៃក្រុមមួយ គឺទំនងជាលទ្ធផលនៃការជម្លៀសប្រជាជនដោយបង្ខំ ករណីដែលការជម្លៀសនេះបានប្រព្រឹត្តក្នុងលក្ខណៈមួយដែលក្រុមនោះមិនអាចបង្កបង្កើតជាក្រុមខ្លួនឯងឡើងវិញ ជាពិសេសករណីដែលការជម្លៀសនោះមានការបំបែកសមាជិកនានា។ នៅក្នុងករណីនោះ [...] ការជម្លៀសបុគ្គលនានាដោយបង្ខំ អាចនាំឲ្យកើតមានទ្ធូវការកម្ទេចផ្នែកសម្ភារៈនៃក្រុម ដោយសារក្រុមនោះលែងមានអត្ថិភាពជាក្រុមទៀតហើយ ឬយ៉ាងហោចណាស់លែងជាក្រុមដូចមុនទៀតហើយ[3436]។

ក្នុងករណីនេះអង្គជំនុំជម្រះសំណុំរឿង Blagojevic បានទទួលស្គាល់ការលើកឡើងមុនៗរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវីថា ការកម្ទេច "តាមរូបរាងកាយ ឬជីវសាស្ត្រ" ជាធាតុចាំបាច់ ប៉ុន្តែបានបកស្រាយការកម្ទេចតាមផ្លូវរូបរាងកាយ ថាមានបញ្ជូលស្ថានភាពនានា

[3434] របាយការណ៍ ISIS-Yazidi កថាខណ្ឌ ១៤៨។

[3435] ដូចបានបញ្ជាក់ខាងលើ *សូមមើល* កថាខណ្ឌ ៩២៩ នៅក្នុងកាលៈទេសៈមួយចំនួន, ការចាប់បញ្ជូន/ការផ្ទេរដោយបង្ខំ អាចបង្ករឲ្យសនកម្មផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ដល់សមាជិកក្រុម ហើយដូច្នេះ ត្រូវចាត់ចូលក្នុងមាត្រា II(ខ) នៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍។

[3436] សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៦៦៦។ សាលដីកាក្នុងរឿងក្តី *Krstić,* យោបល់ជំទាស់មួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៤៥-៥៨។ សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២៥៤។ សាលាក្រមក្នុងរឿងក្តី *Düsseldorf ឆ្នាំ១៩៩៩* កថាខណ្ឌ ៣៨។

ដែលសមាជិកនៃក្រុមរស់នៅជាបន្ត ប៉ុន្តែបានបែកខ្ញែកគ្នាដោយមិនអាចមានលទ្ធភាពបន្តអត្ថិភាពជាក្រុមទៀតបានឡើយ។

939. ក្នុងលក្ខណៈដូចគ្នានេះសាលាឧទ្ធរណ៍សំណុំរឿង Krstic សម្រេចថា ការជម្លៀសស្ត្រី កុមារ និងមនុស្សចាស់ចេញពីគុហារ Srebrenica ទៅកាន់ដែនដីដែលរដ្ឋាភិបាលបូស្នីកាន់កាប់ ដោយមិនមានព្យសនកម្ម "អាចជាមធ្យោបាយបន្ថែម ដែលតាមរយៈនោះ នឹងធានាឲ្យមានការកម្ទេចតាមផ្លូវរូបរាងកាយនៃសហគមន៍អ៊ីស្លាមបូស្នីនៅ Srebrenica" ដោយសារការបញ្ជូននោះបានលុបបំបាត់ "ទ្ធរ លទ្ធភាពបន្តបន្ទាប់ ដែលសហគមន៍អ៊ីស្លាមនៅតំបន់នោះមិនអាចបង្កបង្កើតជាសហគមន៍ខ្លួនឯងបានឡើងវិញ"[3437]។ តាមពិត មុនឆ្នាំ១៩៧៥ រដ្ឋខ្លះបានចុះបញ្ជីការជម្លៀសដោយបង្ខំនៃមនុស្សចាស់ បន្ថែមទៅលើកុមារ ថាជាអំពើប្រល័យពូជសាសន៍[3438]។

940. ដូចគ្នានេះដែរការបញ្ចូលសាសន៍ដោយបង្ខំ ឬការលាលែងសាសនាដោយបង្ខំ បង្ហាញពីចេតនាកម្ទេចក្រុមសាសនា "ដូចនោះ"។ ប្រសិនបើមិនមានបុគ្គលណាប្រណិបត្តិសាសនាមួយ ក្រុមនោះលែងមានអត្ថិភាពជាក្រុមសាសនាមួយទៀតហើយ។ គណៈកម្មាធិការស៊ីរីសម្រេចថា "បុរស និងយុវជនជំទង់យ៉ាហ្ស៊ីឌី ត្រូវបានបង្ខំឲ្យចូលសាសន៍ ឬបើមិនដូច្នោះត្រូវស្លាប់ ទោះក្នុងករណីណាក៏ដោយត្រូវបង្កើតបានជាការកម្ទេចពួកគេក្នុងឋានៈជាយ៉ាហ្ស៊ីឌី"[3439]។ ជាការពិត ការបញ្ចូលទស្សនៈ វិជ្ជា សីលធម៌ ឬមនោគមន៍វិជ្ជាសេដ្ឋកិច្ច ឬសូម្បីតែតាមរយៈការរើសអើងនានាក្រៅបញ្ជីអំពើប្រល័យពូជសាសន៍ក៏ដោយ នឹងមិនបង្កើតបានជាអំពើប្រល័យពូជសាសន៍តែម្តងនោះទេ។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចកើតឡើងតែករណីការកម្ទេចក្រុមបានប្រព្រឹត្តទៅយ៉ាងហោចណាស់ ដោយផ្ទៃកតាមរយៈអំពើណាមួយក្នុងចំណោមអំពើទាំងប្រាំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលជាធាតុសត្យានុម័ត្ត ត្រូវបំពេញជាចាំបាច់។ ទោះជាយ៉ាងណាក៏ដោយ ការបញ្ចូលនានាសម្រេចបានដោយ ឧទាហរណ៍ ការសម្លាប់អ្នកដែលមិនព្រមឲ្យគេបញ្ចូលទោះជាក្នុងចំនួនតិចតួចក៏ដោយ

[3437] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៣១។

[3438] *សូមមើល* ប្ចូលីវី៖ ក្រមព្រហ្មទណ្ឌ - ត្រូវបានប្រកាសឲ្យប្រើដោយក្រឹត្យច្បាប់លេខ ១០៤២៦ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧២ មាត្រា១៣៨។ អែលសាលវ៉ាដរ៖ ក្រមព្រហ្មទណ្ឌនៃសាធារណរដ្ឋអែលសាលវ៉ាដរ (ក្រឹត្យលេខ ១០៣០) ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៤ មាត្រា៣១១។ អេចូពី៖ ក្រមព្រហ្មទណ្ឌនៃប្រទេសអេចូពីឆ្នាំ១៩៥៧ មាត្រា២៨១។ ហ្គាតេម៉ាឡា៖ ក្រមព្រហ្មទណ្ឌនៃប្រទេសហ្គាតេម៉ាឡា ក្រឹត្យលេខ ១៧-៧៣ (ឆ្នាំ១៩៧៣) ជំពូកទី IV មាត្រា៣៧៦។ នីការ៉ាហ្ក្វា៖ ក្រមព្រហ្មទណ្ឌនៃសាធារណរដ្ឋនីការ៉ាហ្ក្វា (ឆ្នាំ១៩៧៤) មាត្រា៥៤៩។

[3439] របាយការណ៍ ISIS-Yazidi កថាខណ្ឌ ១៥៩។

ដោយមានចេតនាកម្ទេចក្រុមសាសនា នេះគឺជាករណីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍យ៉ាងច្បាស់លាស់។

941. លើសពីនេះទៀត អំពើនានាដែលមិនបានរាយក្នុងបញ្ជី អាចត្រូវចាត់ទុកថា ជាភ័ស្តុតាងបញ្ជាក់អំពីចេតនាក្នុងការសម្លាប់ក្រុមនោះ[3440]។ ដូចដែលចៅក្រម Shahabuddeen បានកត់សម្គាល់រួច ហើយថា "ការកម្ទេចទ្រព្យសម្បត្តិវប្បធម៌អាចប្រើជាភ័ស្តុតាងដើម្បីបញ្ជាក់ចេតនាមួយ ដែលត្រូវប្រមូលមកពីកាលៈទេសៈផ្សេងៗក្នុងការកម្ទេចក្រុម ដូចនោះ"[3441]។ តុលាការព្រហ្មទណ្ឌអន្តរជាតិបានអនុម័ត្តយកតាមសាលក្រមអង្គជំនុំជម្រះសំណុំរឿង Krstic ថា "ករណីដែលមានការកម្ទេចតាមផ្លូវរូបរាងកាយ ឬតាមជីវសាសន៍នោះនឹងមានជារឿយៗការវាយប្រហារស្របពេលជាមួយគ្នាទៅលើទ្រព្យសម្បត្តិ សាសនា និងវប្បធម៌ និងនិមិត្តរូបរបស់ក្រុមដែលបានទទួលការការពារផងដែរ ពោលគឺជាការវាយប្រហារដែលអាចត្រូវចាត់ទុកយ៉ាងត្រឹមត្រូវថា ជាភ័ស្តុតាងនៃចេតនាក្នុងការកម្ទេចក្រុមមួយតាមផ្លូវរូបរាងកាយ"[3442]។

942. នេះមិនមែនមានន័យថា គ្រប់អំពើនៃការរើសអើង ការធ្វើទុក្ខបុកម្នេញ ឬការគាបសង្កត់ទៅលើសិទ្ធិសេរីភាពខាងសាសនា វប្បធម៌ ឬភាសា សុទ្ធតែបង្កើតបាននូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ អំពើទាំងឡាយណាដែលបានប្រព្រឹត្តដោយមានចេតនា គ្រាន់តែផ្ទាស់ប្តូរវប្បធម៌ ឬសាសនារបស់ក្រុមនោះ មិនបំពេញគ្រប់គ្រាន់ ដោយសារការរើសអើងបែបនោះកម្រនឹងគំរាមកំហែងដល់ការបន្តរស់រានមានជីវិតរបស់ក្រុមនោះណាស់។ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍អាចកើតឡើងតែក្នុងករណីដែលជនដៃដល់ប្រព្រឹត្តអំពើមួយ ក្នុងអំពើទាំងប្រាំដែលបានហាមឃាត់ ហើយតែក្នុងករណីដែលអំពើទាំងនេះបានប្រព្រឹត្តដោយចេតនាកម្ទេចក្រុម ដូចនោះ។

943. សរុបមកអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងច្បាប់ អ.វ.ត.ក គឺត្រូវអានឲ្យមានន័យថា ករណីដែលជនដៃដល់បានប្រព្រឹត្តរួចមកហើយនូវអំពើណាមួយដែលបានរាយក្នុងបញ្ជី (ធាតុសត្យានុម័ត្ត) នោះចេតនាក្នុងការកម្ទេចក្រុម "ដូចនោះ" គឺអាចត្រូវបញ្ជាក់ដោយភ័ស្តុតាងនៃចេតនាបង្ក ឲ្យ

[3440] សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២៥៤។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥៣។ សាលដីកាក្នុងរឿងក្តី ***Krstić*** កថាខណ្ឌ ៣៣, ១៣៣។ សាលក្រមក្នុងរឿងក្តី ***Krstić*** កថាខណ្ឌ ៥៨០។ សាលដីកាក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ១២៣។

[3441] សាលដីកាក្នុងរឿងក្តី *Krstić* យោបល់ជំទាស់មួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៥៣។

[3442] រឿងក្តី *ហ្ស្ការ គទល់ទីង ស្ទ្រីបហ្ស្ការ* កថាខណ្ឌ ៣៤៤ *ដកស្រង់*សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៨០។

មានការកម្ទេចក្រុមមួយតាមរយៈអំពើនានា ដែលមិនបានវាយនៅក្នុងអនុសញ្ញាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬច្បាប់ អ.វ.ត.ក។ អាស្រ័យហេតុនេះវាជាផលប្រយោជន៍ដល់តុលាការនៅក្នុងការមើលឲ្យបាននូវបរិបទគ្រប់ជ្រុងជ្រោយ នៃអំពើប្រឆាំងនឹងក្រុមដែលបានទទួលការការពារ ក្នុងការពិចារណាថ្នឹងផ្ទែងអំពីធាតុអត្តោម័ត្តនៃអំពើរបស់ជនត្រូវចោទ។ នៅក្នុងលក្ខណៈនេះ ការជម្លៀសស្ត្រី និងកុមារនៅ Srebrenica មិនអាចត្រូវមើលរំលងឡើយ ដោយសារវា "ជាផ្នែកមួយ ជាផ្នែកសំខាន់មួយនៃផែនការតែមួយក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍រួមមានទាំងការសម្លាប់មនុស្ស ការជម្លៀសដោយបង្ខំ និងការកម្ទេចគេហដ្ឋាន"[3443]។

<u>ទាំងស្រុង ឬដោយផ្នែក</u>

944. បុគ្គលម្នាក់ដែលប្រព្រឹត្តអំពើដែលបានហាមឃាត់ នឹងត្រូវមានពិរុទ្ធភាពពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ក្នុងករណីគាត់មានចេតនាកម្ទេចក្រុមដែលបានទទួលការការពារទាំងស្រុង ឬដោយផ្នែក។ មិនមានការកំណត់ជាតួលេខទេចំពោះចំនួនជនរងគ្រោះ ដែលចាំបាច់គ្រប់គ្រាន់ក្នុងការបង្កើតឲ្យមានជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[3444]។

945. ចំពោះចេតនាក្នុងការកម្ទេចក្រុមមួយដោយផ្នែក ជនត្រូវចោទត្រូវតែបានបង្ហាញថា មានចេតនាកម្ទេចផ្នែក*ដែលមានសារៈសំខាន់*មួយ នៃក្រុមមួយដែលបានទទួលការការពារនោះ[3445]។ តួលេខតែមួយមុខ "គឺមិនមែននៅក្នុងគ្រប់ករណីជាចំណុចបញ្ចប់នៃការស៊ើបសួរនោះទេ"[3446]។ ការកំណត់ថាតើផ្នែកដែលបានដាក់ជាគោលដៅនោះមានសារៈសំខាន់ឬយ៉ាងណានោះ អាស្រ័យទៅលើកត្តាវិនិច្ឆ័យតាមគុណភាព និងបរិមាណមួយចំនួន។ ទំហំគួរត្រូវបានវាយតម្លៃមិនមែនតែត្រឹមក្នុងន័យដាច់

[3443] សាលដីកាក្នុងរឿងក្តី *Krstić* យោបល់ជំទាស់មួយផ្នែករបស់ចៅក្រម Shahabuddeen កថាខណ្ឌ ៣៥។ *សូមមើលបន្ថែម* របាយការណ៍ចុងក្រោយរបស់គណៈកម្មការអ្នកជំនាញ ដែលត្រូវបានបង្កើតឡើងស្របតាមសេចក្តីសម្រេចលេខ ៧៨០ របស់ក្រុមប្រឹក្សាសន្តិសុខ (ឆ្នាំ១៩៩២) ឯកសារអង្គការសហប្រជាជាតិ S/1994/674 ឯកសារអង្គការសហប្រជាជាតិ S/1994/674) ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩៤ កថាខណ្ឌ ៩៤។

[3444] សាលក្រមក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៣១៩។ សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣១៦។ សាលក្រមក្នុងរឿងក្តី *Bagosora* កថាខណ្ឌ ២១១៥។

[3445] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥៥។ សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៨។ សាលក្រមក្នុងរឿងក្តី *Bagosora* កថាខណ្ឌ ២១១៥។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ៤៤។ រឿងក្តី *ហ្ស្ម៉ៃ តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៩៨, ២០០-២០១។ រឿងក្តី *ក្រូអាត តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៤២។

[3446] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ១២។ សាលដីកាយោងវិធាន ៩៨ស្ទ្ធ ក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៦៦។

ខាតនោះទេ ប៉ុន្តែថែមទាំងស្របទៅតាមប្រជាពលរដ្ឋសរុបនៃក្រុមទាំងមូល : ប្រសិនបើផ្នែកនោះមានទំហំធំគ្រប់គ្រាន់ក្នុងន័យប្រៀបធៀបទៅនឹងទំនាក់ទំនងមួយ មានលក្ខណៈជានិមិត្តរូប ឬមានលក្ខណៈលេចធ្លោនៅក្នុងក្រុម ឬជាផ្នែកចាំបាច់ចំពោះការបន្តរស់រានៃក្រុមនោះ វាអាចនឹងត្រូវចាត់ទុកថាជាផ្នែកដែលមានសារៈសំខាន់មួយ[3447]។ លក្ខណៈវិនិច្ឆ័យទាំងនេះមិនទាន់ចប់សព្វគ្រប់នោះទេ[3448]។ ផ្នែកនោះត្រូវតែមានលក្ខណៈសំខាន់គ្រប់គ្រាន់ បង្ហាញថាការកម្ទេចនោះនឹងមានផលប៉ះពាល់លើ ឬគំរាមកំហែងដល់ការបន្តរស់រានមានជីវិតនៃក្រុមនោះទាំងមូល[3449]។ លក្ខខណ្ឌនេះអាចនឹងត្រូវបំពេញបាន ក្នុងករណីដូចជាថ្នាក់ដឹកនាំនៃក្រុមមួយត្រូវបានកំណត់ជាគោលដៅសម្រាប់ការកម្ទេច[3450]។

946. ចេតនាក្នុងការកម្ទេចក្រុមមួយដោយផ្នែក អាចត្រូវពង្រីកតែត្រឹមទៅដល់តំបន់ភូមិសាស្ត្រមួយមានកម្រិត ដូចជា តំបន់នៃប្រទេសមួយ ឬទីក្រុងមួយតែប៉ុណ្ណោះ[3451]។ ផ្នែកនៃសកម្មភាពការគ្រប់គ្រងរបស់ជនដៃដល់ និងវិសាលភាពដែលអាចពង្រីកទៅបានរបស់ជនដៃដល់ គឺជាកត្តានីមួយៗដែលពាក់ព័ន្ធទៅនឹងការធ្វើងផ្ទែងចេតនា ក្នុងការកម្ទេចផ្នែកដែលមានសារៈសំខាន់មួយនៃក្រុមដែលបានទទួលការការពារ[3452]។ ការអនុវត្តកត្តាទាំងនេះ និងទម្ងន់សមស្របរបស់កត្តាទាំងនេះ នឹងខុសៗគ្នាអាស្រ័យទៅលើកាលៈទេសៈនៃករណីជាក់លាក់ណាមួយ[3453]។

[3447] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៨, ១២, ២៨-២៩។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥៥។ រឿងក្តី *ហ្ស្ម៉ៀ តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ២០០។ រឿងក្តី *ក្រូអាត តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៤២។

[3448] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ១៤។ រឿងក្តី *ហ្ស្ម៉ៀ តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ២០១។

[3449] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥៥។ សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៨, ១២។ សាលក្រមក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ៧៤៩។ សាលក្រមក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៨២។ រឿងក្តី *ហ្ស្ម៉ៀ តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៩៣, ១៩៨។ សាលដីកាយោងវិធាន ៩៨ស្នូន ក្នុងរឿងក្តី Karadžić កថាខណ្ឌ ៦៦។

[3450] សាលក្រមក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៨២។ សាលក្រមសម្រេចឲ្យរួចខ្លួនក្នុងរឿងក្តី *Sikirica* កថាខណ្ឌ ៧៧។ សេចក្តីសម្រេចឲ្យរួចខ្លួនក្នុងរឿងក្តី *Milošević* កថាខណ្ឌ ១៣២។

[3451] សាលក្រមក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៨០, ៨៣។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៨៩-៥៩០។ រឿងក្តី *ហ្ស្ម៉ៀ តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៩៩។

[3452] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ១៣។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥៥។ សាលក្រមក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ៧៤៩។ រឿងក្តី *ហ្ស្ម៉ៀ តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៩៩។ រឿងក្តី *ក្រូអាត តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ១៤២។

[3453] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥៥។ សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ១៤។

ការបង្កើតឲ្យមានចេតនា

947. នៅក្នុងសំណុំរឿង Krstic សាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវីបានកត់សម្គាល់ថា ចេតនាប្រល័យពូជសាសន៍ ជាធម្មតាមិនសូវមានភ័ស្តុតាងផ្ទាល់នោះទេ ប៉ុន្តែជារឿយៗអាចសន្និដ្ឋានទាញចេញមកពីអង្គហេតុនានា និងកាលៈទេសៈនានានៃសំណុំរឿងមួយ[3454]។ អង្គហេតុទាំងនោះមិនចាំបាច់ត្រូវបង្កើតបានជាផ្នែកមួយ នៃធាតុសត្យានុម័ត្តនៃឧក្រិដ្ឋកម្មនោះទេ[3455]។ កត្តាទាំងឡាយដែលពាក់ព័ន្ធនឹងការវិភាគបែបនេះអាចរួមមានបរិបទជាទូទៅ ការប្រព្រឹត្តអំពើទាំងឡាយផ្សេងទៀត ដែលអាចត្រូវផ្តន្ទាទោស ហើយដែលបានប្រព្រឹត្តជាប្រព័ន្ធប្រឆាំងនឹងក្រុមដដែល (ទោះជាបានប្រព្រឹត្តដោយជនដែលដល់តែមួយ ឬផ្សេងៗទៀតក៏ដោយ) ទំហំទ្រង់ទ្រាយនៃការវិនាសកម្មដែលបានប្រព្រឹត្ត អាវុធដែលបានប្រើ និងវិសាលភាពនៃការរបួសស្នាមផ្លូវកាយដែលបានបង្ក ការកំណត់គោលដៅជាប្រព័ន្ធចំពោះជនរងគ្រោះផ្អែកទៅលើសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមជាក់លាក់ណាមួយ ការប្រព្រឹត្តអំពើដដែលៗក្នុងការកម្ទេចនិងវើសអើង ការប្រើភាសាដែលបង្ហាញភាពអាម៉ាស់ចំពោះសមាជិកនានានៃក្រុមដែលបានកំណត់ជាគោលដៅ ការធ្វើផែនការដោយមានវិធីសាស្ត្រត្រឹមត្រូវក្នុងការសម្លាប់ជាប្រព័ន្ធ[3456]។ សុន្ទរកថានានា ឬគម្រោងផ្សេងៗដែលបានរៀបចំសម្រាប់ទប់ស្កាត់ដល់អំពើនានា ដែលមានបំណងកម្ទេចមូលដ្ឋានគ្រឹះនៃក្រុមគោលដៅ[3457] និងទ្រឹស្តីនយោបាយ ដែលបង្កឲ្យមានអំពើនានាដែលបានយោងនោះ[3458]។ ក្នុងការផ្ចឹងផ្ចែងភ័ស្តុតាងនៃចេតនាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តុលាការគួរតែពិចារណាថាតើគ្រប់ភស្តុ

[3454] សាលដីកាយោងវិធាន ៩៨ស្ទ្ធ ក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៨០ *ដោយដកស្រង់*សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ៤០។ សាលដីកាក្នុងរឿងក្តី *Rutaganda* កថាខណ្ឌ ៥២៥។ សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៥៩។

[3455] សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២៥៤។ សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៣៣។ *សូមមើលផងដែរ* រឿងក្តី *ក្រូអាត គទល់នឹង ស៊ើបបៀ*កថាខណ្ឌ ១៦២-១៦៣, ៤៧៨។ រឿងក្តី *ប្ល្យេ្ស គទល់នឹង ស៊ើបបៀ*កថាខណ្ឌ ១៩០។

[3456] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥០។ សាលដីកាយោងវិធាន ៩៨ស្ទ្ធ ក្នុងរឿងក្តី Karadžić កថាខណ្ឌ ៨០។ សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២៤៦។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ៤៦៨។ សាលដីកាក្នុងរឿងក្តី *Hategekimana* កថាខណ្ឌ ១៣៣។ សាលដីកាក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៤៧។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ១៧៦។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ៤០-៤១។ របាយការណ៍ ISIS-Yazidi កថាខណ្ឌ ១៥២។

[3457] សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ៤៣។ សាលដីកាក្នុងរឿងក្តី *Kamuhanda* កថាខណ្ឌ ៨១-៨២។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥០។ សាលក្រមក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ៧៤៥។

[3458] សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ១៧៦។

តាងទាំងអស់សរុបបញ្ចូលគ្នា បានបង្ហាញនូវសភាពផ្ទូរចិត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬយ៉ាងណា មិនគួរពិចារណាដាច់ដោយឡែកពីគ្នា ថាតើជនត្រូវចោទមានចេតនាកម្ទេចក្រុមដែលបានទទួលការការពារមួយតាមរយៈអំពើនីមួយៗ នៃអំពើពាក់ព័ន្ធទាំងឡាយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះឡើយ[3459]។

948. មិនមានលក្ខខណ្ឌតម្រូវថា ចេតនាជាក់លាក់ណាមួយត្រូវតែបង្កើតឡើងមុនពេលប្រព្រឹត្តអំពើនោះឡើយ ដរាបណាភស្តុតាងបានបង្ហាញថាចេតនានោះបានមានអត្ថិភាពនៅពេលប្រព្រឹត្តអំពើទាំងនោះ[3460]។ ដូចគ្នានេះដែរ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មិនតម្រូវឲ្យមានអត្ថិភាពនៃគោលនយោបាយឬផែនការមួយទេ[3461] ទោះជាយ៉ាងណាក៏ដោយអត្ថិភាពនៃគោលនយោបាយ ឬផែនការមួយអាចជួយបញ្ជាក់ជាភ័ស្តុតាងនៃចេតនា និងឧក្រិដ្ឋកម្មតែម្តង[3462]។ ដរាបណាអាចបង្ហាញបានថាមានចេតនាកម្ទេចក្រុមដូចនោះទាំងស្រុង ឬដោយផ្នែក ហេតុផលដែលនាំឲ្យសម្រេចប្រព្រឹត្តឧក្រិដ្ឋកម្ម (ដូចជានយោបាយ យោធា ឬផលប្រយោជន៍សេដ្ឋកិច្ច ការភ័យខ្លាច ការស្អប់ខ្ពើម ឬការសងសឹក) មិនមានលក្ខណៈពាក់ព័ន្ធឡើយ[3463]។ ការលើកលែងចំពោះបុគ្គលមួយចំនួន ឬផ្នែកណាមួយនៃពលរដ្ឋទាំងមូលណាមួយនោះ ក្នុងចំណោមក្រុមដែលបានទទួលការការពារ មិនប្រាកដថាលែង

[3459] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥០។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៥៥។ សាលដីកាយោងវិធាន ៩៨ ស្ងួន ក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៦។ សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ២៤៦-២៤៧។ សាលក្រមក្នុងរឿងក្តី *Mpambara* កថាខណ្ឌ ១២១។ *សូមមើលផងដែរ* រឿងក្តី *ក្រូអាត តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ៤១៩។ *សូមមើលបន្ថែម* VI.ក.1.ក.iii. អង្គច្បាប់ - គោលការណ៍ច្បាប់ដែលពាក់ព័ន្ធ - អំពើប្រល័យពូជសាសន៍ - ចេតនាឧក្រិដ្ឋ - ចេតនាក្នុងការកម្ទេចក្រុម "បែបហ្ម៊ីង"។

[3460] សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ២៦៦។ សាលដីកាក្នុងរឿងក្តី *Munyakazi* កថាខណ្ឌ ១៤២។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៧២។

[3461] សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ៤៣០។ សាលដីកាក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៤៨។ សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៣៨។ សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ២៦០។

[3462] សាលដីកាក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៤៨។ សាលដីកាក្នុងរឿងក្តី *Semanza* កថាខណ្ឌ ២៦០។ សាលដីកាក្នុងរឿងក្តី *Rutaganda* កថាខណ្ឌ ៥២៥។ រឿងក្តី *ប្ចស្យ៊ៀ តទល់នឹង ស៊ើបបៀ* កថាខណ្ឌ ៣៧៣។

[3463] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៥៤។ សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ៨៨, ២៦៩។ សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៦១។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៤៥។ សាលដីកាក្នុងរឿងក្តី *Jelisić* កថាខណ្ឌ ៤៩។

មានអត្ថិភាពនៃចេតនាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះឡើយ ដរាបណាក្រុមដែលបានទទួលការការពារនៅតែត្រូវកំណត់ជាគោលដៅសម្រាប់ការកម្ទេចនូវផ្នែកដែលមានសារៈសំខាន់នោះ[3464]។

949. ការកម្ទេចជាក់ស្តែងនៃក្រុមមួយ ឬសូម្បីតែចំនួនច្រើននៃមនុស្សទាំងឡាយ មិនមែនជាលក្ខខណ្ឌចាំបាច់ជាដំបូង ដែលនាំឲ្យសម្រេចថា មានចេតនាប្រល័យពូជសាសន៍នោះឡើយ។ ការសម្លាប់តែម្នាក់ឲ្យតែប្រព្រឹត្តដោយមានចេតនាចាំបាច់ក្នុងការកម្ទេចក្រុមទាំងស្រុង ឬដោយផ្នែកអាចបង្កើតបានជាអំពើប្រល័យពូជសាសន៍[3465]។ ដូចគ្នានេះដែរ ការខកខានរបស់ជនដៃដល់ក្នុងការអនុវត្តចេតនារបស់ខ្លួនឲ្យបានពេញលេញដោយទុកចោលនូវអំពើកម្ទេច មិនមានលក្ខណៈចប់សព្វគ្រប់ ក៏មិនអាចជៀសផុតពីការសម្រេចថា មានចេតនាប្រល័យពូជសាសន៍នោះផងដែរ[3466]។

<u>ទម្រង់នៃការទទួលខុសត្រូវដែលអាចយកមកអនុវត្តបាន</u>

950. មាត្រា ៤ នៃច្បាប់ អ.វ.ត.ក ចែងថា ការប៉ុនប៉ង ឬការផ្សំគំនិតនៅក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ក៏ដូចជាការចូលរួមនៅក្នុងអំពើទាំងឡាយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អាចត្រូវផ្តន្ទាទោសនៅ អ.វ.ត.ក។ ប៉ុន្តែតាមទស្សនៈសហព្រះរាជអាជ្ញាអន្តរជាតិ "ការចូលរួមក្នុងអំពើទាំងឡាយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍" តាមរយៈទម្រង់នៃការទទួលខុសត្រូវដែលបានចែងនៅក្នុងមាត្រា២៩ ថ្មីនៃច្បាប់ អ.វ.ត.ក (ការប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ ការបញ្ជា ការជួយ និងការទទួលខុសត្រូវរបស់ថ្នាក់លើ) គឺមានលក្ខណៈសមស្របបំផុតចំពោះសំណុំរឿង០០៤ ហើយនិងដាក់នូវសំអាងហេតុរបស់ខ្លួនសមស្របទៅតាមនោះដែរ។

951. ទោះបីជាមាត្រា ៤មិនបានចែងច្បាស់ក៏ដោយ ទម្រង់រួមនៃការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មបានចែងនៅក្នុងមាត្រា២៩ថ្មី ដែលមានលក្ខណៈច្បាស់លាស់អាចអនុវត្តបានដូចគ្នាចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយបានឆ្លុះបញ្ចាំងទៅតាមលក្ខណៈនោះដែរ នៅក្នុងការកែប្រែការជូនដំណឹងពីការចោទប្រកាន់ដែលបានប្រគល់ដល់យ៉ីម ទិត្យ[3467]។ "ការចូលរួម" គឺមិនមែនជាពាក្យពិសេសអ្វីនោះទេ។

[3464] សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៤៩។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ១៩២-១៩៣។ សាលដីកាក្នុងរឿងក្តី *Muhimana* កថាខណ្ឌ ៣២។ សាលដីកាក្នុងរឿងក្តី *Rutaganda* កថាខណ្ឌ ៥៣៧។ សាលដីកាក្នុងរឿងក្តី *Ntabakuze* កថាខណ្ឌ ២៤១។

[3465] សាលដីកាក្នុងរឿងក្តី *Ndindabahizi* កថាខណ្ឌ ១៣៥។ សាលក្រមក្នុងរឿងក្តី *Mpambara* កថាខណ្ឌ ៨។

[3466] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៣២។

[3467] ឯកសារ D350.1 សេចក្តីជូនដំណឹងអំពីបទចោទប្រឆាំង យ៉ីម ទិត្យ ដែលបានកែប្រែ កថាខណ្ឌ ៧។

ន័យខ្លឹមសារធម្មតារបស់វា "គឺជាអំពើនៃការចូលរួមក្នុងអ្វីមួយដូចជា [...] ឧក្រិដ្ឋកម្មមួយ"[3468]។ "ការចូលរួម" ត្រូវបានប្រើយោងជារួមទៅដល់ទម្រង់ផ្សេងៗនៃការទទួលខុសត្រូវ ការប្រព្រឹត្ត ការរៀបចំផែនការ ការបញ្ជា ការញុះញង់ និងការជួយ រួមទាំងទំនាក់ទំនងទៅនឹងអំពើទាំងឡាយនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[3469]។ ទោះជាយ៉ាងណាក៏ដោយ មាត្រា២៩ ថ្មីនៃច្បាប់ អ.វ.ត.ក បានចែងយ៉ាងច្បាស់នូវទម្រង់ទាំងនេះនៃការចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលយកមកអនុវត្តបានចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ : "ជនសង្ស័យណាដែលបានរៀបចំ ញុះញង់ បញ្ជា បានជួយ ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានយោងនៅក្នុងមាត្រា [...] ៤ [...] នៃច្បាប់នេះ នឹងទទួលខុសត្រូវជាបុគ្គលចំពោះឧក្រិដ្ឋកម្មនោះ[3470]។ យោងតាមបញ្ញត្តិដដែលនេះ ជនជាប់ចោទអាចត្រូវទទួលខុសត្រូវក្នុងឋានៈជាថ្នាក់លើចំពោះអំពើឧក្រិដ្ឋកម្ម[3471]។

952. បន្ថែមទៅលើបញ្ជីនៃអំពើទាំងឡាយដែលអាចផ្តន្ទាទោសនៅក្នុងបញ្ញត្តិនានាស្តីអំពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (ក្នុងករណីតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី មាត្រា៤(៣)) លក្ខន្តិកៈនៃតុលាការមិនអចិន្ត្រៃយ៍នានា មានចែងស្រដៀងគ្នានឹងទម្រង់នានានៃការចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចគ្នានឹងទម្រង់ទាំងឡាយនៅក្នុងមាត្រា២៩ថ្មី (លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី មាត្រា៧(១) និងមាត្រា ៧(៣)) ដែលលក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវីបានចែងយ៉ាងច្បាស់ គឺអាចយកមកអនុវត្តបានចំពោះអំពើប្រល័យពូជសាសន៍។ ក្នុងការដោះស្រាយចំពោះ "ខ្លឹមសារជាន់គ្នា" នេះ តុលាការឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវីបានសម្រេចថា "ទម្រង់នៃការទទួលខុសត្រូវ" គួរតែ "អានបញ្ចូលទៅក្នុង" បញ្ញត្តិស្តីអំពីប្រល័យពូជសាសន៍នៃលក្ខន្តិកៈរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ

[3468] វចនានុក្រមច្បាប់ឈ្មោះ Black's Law Dictionary បោះពុម្ពផ្សាយលើកទី៩ (ឆ្នាំ២០០៩)។

[3469] *សូមមើលឧទាហរណ៍ :* សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៨៥។ សាលក្រមក្នុងរឿងក្តី *Musema* កថាខណ្ឌ ១១៤។ សាលក្រមក្នុងរឿងក្តី *Kamuhanda* កថាខណ្ឌ ៥៨៨។ សាលដីកាក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ៣៥១។

[3470] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាញ្ញក្នុងតុលាការកម្ពុជា (ច្បាប់អ.វ.ត.ក) មាត្រា២៩*ថ្មី*។

[3471] មាត្រា២៩*ថ្មី*នៃច្បាប់អ.វ.ត.ក ចែងថា ["ប្រការដែលថាសកម្មភាពណាមួយក្នុងចំណោមសកម្មភាពដែលមានចែងនៅក្នុង [មាត្រា] ៤ [...] នៃច្បាប់នេះ ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់នោះ មិនអាចជួយឲ្យថ្នាក់លើរួចផុតពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនោះបានទេ"]។

សម្រាប់ឃ្លាស្ពានី "ពីព្រោះលក្ខន្តិកៈនេះត្រូវតែបកស្រាយដោយយកចិត្តទុកដាក់ខ្ពស់បំផុតចំពោះភាសាដែលបានប្រើដោយអ្នកធ្វើបញ្ញត្តិនោះ"។[3472]

953. អាស្រ័យហេតុនេះ យ៉ីម ទ៉ីត អាចត្រូវសម្រេចឲ្យទទួលខុសត្រូវពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមទម្រង់ទាំងអស់នៃការចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានចែងនៅក្នុងមាត្រា២៩ថ្មី[3473]។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមកំណត់បានទៅជា "ការប្រព្រឹត្ត" ក្រោមវិសាលភាពនៃមាត្រា២៩ថ្មីនៃច្បាប់ អ.វ.ត.ក[3474] ហើយការទទួលខុសត្រូវចំពោះការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវពាក់ព័ន្ធទៅនឹងអំពើប្រល័យពូជសាសន៍[3475] តាមពិត ចុងចោទមួយចំនួននៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ឃ្លាស្ពានី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា ត្រូវបានផ្តន្ទាទោសពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ យោងទៅតាមទម្រង់មូលដ្ឋាននេះឯង គឺទម្រង់សហឧក្រិដ្ឋកម្មរួម (I)។[3476]

ខ. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

954. មាត្រា៥ នៃច្បាប់ អ.វ.ត.ក បានប្រគល់យុត្តាធិការដល់ អ.វ.ត.ក ឲ្យមានយុត្តាធិការទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គឺជាផ្នែកមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងកំឡុងពេលនៃយុត្តាធិការរបស់ អ.វ.ត.ក ទៅលើថេរវេលា។[3477] បទល្មើសជាក់លាក់រួម

[3472] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ១៣៨-១៣៩។

[3473] ការពិភាក្សាទូទៅអំពីទម្រង់នៃការទទួលខុសត្រូវទាំងនោះត្រូវបានលើកឡើងខាងក្រោម។ *សូមមើល* VI.A. អង្គច្បាប់ - គោលការណ៍ច្បាប់ដែលពាក់ព័ន្ធ - ទម្រង់នៃការទទួលខុសត្រូវ។

[3474] សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់ចៅក្រមស៊ើបអង្កេត ចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៩។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥១១។ សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបានទ្ធូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩០។

[3475] សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ១៨៨។ សេចក្តីសម្រេចលើអំពើប្រល័យពូជសាសន៍សហឧក្រិដ្ឋកម្មរួម ក្នុងរឿងក្តី *Rwamakuba* កថាខណ្ឌ ៣១។

[3476] *សូមមើលឧទាហរណ៍៖* សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៨៣១។ សាលក្រមក្នុងរឿងក្តី *Karemera & Ngirumpatse* កថាខណ្ឌ ១៦១៦-១៦១៧, ១៦២៣, ១៦២៨, ១៦៣៤, ១៦៤៤, ១៦៤៨, ១៦៥៣, ១៦៥៧-១៦៥៨។

[3477] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខរបស់ ឌុច ក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១០១-១០៤។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ ន្ហ្ជន ជា និង អ៊ៀង ធីរិទ្ធ

មាន អំពើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ឲ្យទៅជាទាសករ ការនិរទេស ការដាក់ពន្ធនាគារ ទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ពូជសាសន៍ និងសាសនា និងអំពើ ឃោរឃៅផ្សេងៗទៀត។ ធាតុផ្សំទាំងឡាយនៃបទល្មើសនីមួយៗគឺត្រូវបានពិភាក្សាក្នុងផ្នែកខាង ក្រោមនេះ។

i. លក្ខណៈវិនិច្ឆ័យទូទៅ

955. យោងតាមមាត្រា៥ នៃច្បាប់ អ.វ.ត.ក ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានលក្ខណៈសម្គាល់ដោយ ឡែកដោយសារ មានលក្ខណៈវិនិច្ឆ័យទូទៅ ដែលតម្រូវថា ឧក្រិដ្ឋកម្មទាំងនោះ ត្រូវប្រព្រឹត្ត "ជាផ្នែក មួយនៃការវាយប្រហារដែលមានទ្រង់ទ្រាយធំ ឬមានលក្ខណៈជាប្រព័ន្ធ សំដៅប្រឆាំងនឹងជនស៊ីវិល ដោយមូលហេតុជាតិ នយោបាយ ពន្ធុ ពូជសាសន៍ ឬសាសនា"។[3478] យោងតាមច្បាប់ទំនៀមទម្លាប់ អន្តរជាតិក្នុងឆ្នាំ១៩៧៥ និយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនតម្រូវឲ្យមានការពាក់ព័ន្ធ ទៅនឹង ជម្លោះប្រដាប់អាវុធ ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពនោះទេ[3479]។ ផ្នែក នីមួយៗនៃលក្ខខណ្ឌ*រួម*នោះ នឹងបកស្រាយនៅផ្នែកខាងក្រោម។

ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៣៣។ សំណុំរឿង០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ២៨៣-២៨៦។ សំណុំរឿង០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១២៩៩, ១៣០៦, ១៣១៣។

[3478] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក មាត្រា៥។ សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខរបស់ ឌុច ក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១០៦។

[3479] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១១-៧២១។ សំណុំរឿង ០០៣ ឯកសារ D87/2/1.7/1/1/7 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់នឹងដីកាសម្រេចរបស់សហចៅក្រមអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយជម្លោះប្រដាប់អាវុធ។ សំណុំរឿងលេខ ០០២ ឯកសារ E95/8 សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ឯកសារ D306/17.1/1/6.1.14 សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ មាស មុត ជំទាស់ដីកាសម្រេចរបស់សហចៅក្រមអន្តរជាតិលើសំណើរបស់ មាស មុត សុំការបញ្ជាក់បំភ្លឺទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងចំណងទាក់ទងជាមួយជម្លោះប្រដាប់អាវុធ។ សំណុំរឿង ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៦៦។

ការវាយប្រហារ

956. "ការវាយប្រហារ" គឺជាដំណើរការនៃអំពើរួមមាន ការប្រព្រឹត្តជាច្រើនលើកនូវអំពើនានា នៃអំពើហិង្សានានា ឬការធ្វើបាបទៅលើជនស៊ីវិលរួមទាំងការប្រព្រឹត្តដែលបានមកពីបទល្មើសនានាយោងមាត្រា៥នៃច្បាប់ អ.វ.ត.ក[3480]។ អំពើទាំងឡាយដែលកំណត់បានជាការវាយប្រហារមួយមិនចាំបាច់ថា អំពើទាំងនោះខ្លួនឯងត្រូវតែផ្តន្ទាទោសជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ ហើយមិនកំណត់មកត្រឹមការប្រើកម្លាំងប្រដាប់អាវុធនោះទេ[3481]។ លើសពីនេះទៀត "ការវាយប្រហារ" ទៅលើជនស៊ីវិល គឺជាសញ្ញាណដោយឡែកចេញពីជម្លោះប្រដាប់អាវុធ។ ករណីមានជម្លោះប្រដាប់អាវុធមួយការវាយប្រហារអាចនឹងកើតមានតាំងពីមុនពេលនោះ ចប់ក្រោយពេលនោះទៀត ឬបន្ត ជាមួយគ្នា ដោយមិនចាំបាច់ជាផ្នែកមួយនៃជម្លោះប្រដាប់អាវុធនោះឡើយ[3482]។

ទ្រង់ទ្រាយធំ ឬជាប្រព័ន្ធ

957. ការវាយប្រហារត្រូវតែមានទ្រង់ទ្រាយធំ ឬមានលក្ខណៈជាប្រព័ន្ធ។ លក្ខណៈមួយណាក៏ដោយគឺគ្រប់គ្រាន់[3483]។ ពាក្យ "មានទ្រង់ទ្រាយធំ" យោងទៅដល់ "សារជាតិនៃទ្រង់ទ្រាយធំ នៃការវាយ

[3480] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ២៩៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៨។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៦៦៦។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៨៦។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩១៦-៩១៨។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥០៦។

[3481] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ២៩៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៨។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩១៦, ៩១៨។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៦៦៦។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥០៦។

[3482] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ២៩៩។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៨។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៨៦។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២៥១។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៧៧។

[3483] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣០០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៨។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៩៣។

ប្រហារ និងចំនួននៃជនរងគ្រោះ"[3484] ហើយអាចត្រូវកំណត់បានដោយ "ផលវិបាកសរុបនៃអំពើឃោរឃៅជាបន្តបន្ទាប់ ឬផលវិបាកតែមួយនៃអំពើឃោរឃៅ ដែលមានវិសាលភាពវិសាមញ្ញ"[3485] ។ ពាក្យ "មានលក្ខណៈជាប្រព័ន្ធ" មិនតម្រូវថា ការវាយប្រហារត្រូវតែមានលក្ខណៈទ្រង់ទ្រាយធំ ប៉ុន្តែទាក់ទងទៅនឹង "សារជាតិនៃការចាត់តាំងនៃអំពើហិង្សា និងអវត្តមានលទ្ធភាពថា អំពើនោះកើតឡើងដោយមិនទាក់ទងគ្នា"[3486]។ លក្ខណៈជាប្រព័ន្ធ អាចត្រូវកំណត់បានដោយផ្អែកលើភ័ស្តុតាង "នៃការប្រព្រឹត្តដដែលៗដែលមានលក្ខណៈមិនចៃដន្យ ទូវអំពើឧក្រិដ្ឋដែលមានលក្ខណៈស្រដៀងៗគ្នា"[3487]។

<u>សំដៅប្រឆាំងក្រុមជនស៊ីវិលណាមួយ</u>

958. ការវាយប្រហារត្រូវតែ "សំដៅប្រឆាំងក្រុមជនស៊ីវិលណាមួយ"។ លក្ខខណ្ឌនេះតម្រូវថា ជនស៊ីវិលត្រូវតែជាកម្មវត្ថុចម្បងមិនមែនជាជនរងគ្រោះដោយចៃដន្យនោះទេ នៅក្នុងការវាយប្រហារនោះ[3488] ។ សញ្ញាណនៃពាក្យ "ស៊ីវិល" សម្រាប់គោលបំណងនៃធាតុផ្សំនេះ យោងទៅដល់គ្រប់ជនទាំងអស់ដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធរបស់សត្រូវ ដែលកំពុងសកម្មក្នុងជម្លោះ ហើយអាស្រ័យហេតុនេះរួមមានទាំងជនទាំងឡាយដូចជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធដែលបានទម្លាក់អាវុធ ព្រមទាំងជនទាំងឡាយដែលបានសម្រាកពីភារៈកិច្ចដោយសារជំងឺ របួស ការឃុំឃាំង

[3484] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣០០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៩។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៩៤។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩២០។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥១១។

[3485] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣០០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៩។ សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៥៤៥។

[3486] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣០០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៩។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៩៤។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩២០។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៧៨។

[3487] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៧៩។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៩៤។

[3488] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣០៥, ៣០៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៨២។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៩១។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥០៧។

ឬហេតុផលណាផ្សេងទៀត[3489]។ ដូចដែលបានលើកឡើងដោយអង្គជំនុំជម្រះសំណុំរឿង Blashkic "ស្ថានភាពជាក់លាក់របស់ជនរងគ្រោះនៅពេលមួយដែលឧក្រិដ្ឋកម្មបានប្រព្រឹត្តមិនមែនស្ថានភាពរបស់គាត់នោះទេ គឺត្រូវតែយកមកផ្ទឹងផ្ទែងនៅក្នុងការកំណត់ឋានៈរបស់គាត់ថាជាជនស៊ីវិលម្នាក់នោះ"[3490]។

959. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអាចរួមមានការវាយប្រហាររបស់រដ្ឋមួយមកលើប្រជាជនរបស់ខ្លួនឯងផ្ទាល់[3491]។ នេះរួមមានទាំងកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋមួយ ឬរបស់អង្គការមួយខ្លួនឯងដែលបានចាត់ទុកថាជាជនស៊ីវិលសម្រាប់គោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3492]។ មិនចាំបាច់ត្រូវបង្ហាញថា ពលរដ្ឋទាំងមូលនៅក្នុងភូមិសាស្ត្រពាក់ព័ន្ធណាមួយ បានរងនូវការវាយប្រហារនោះទេ[3493]។ "ជនស៊ីវិល" ក៏អាចរួមមានទាំងបណ្តាជនមិនមែនស៊ីវិល ដោយមិនបានក្លែង

[3489] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥៨២។ សាលក្រមក្នុងរឿងក្តី *Bisengimana* កថាខណ្ឌ ៤៨។ សាលក្រមក្នុងរឿងក្តី *Tadić* កថាខណ្ឌ ៦៣៩។ សាលក្រមក្នុងរឿងក្តី *Limaj* កថាខណ្ឌ ១៨៦។ សាលក្រមក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ២១៤។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៤២១។

[3490] សាលក្រមក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ២១៤។ អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិមិនយល់ស្របដោយក្តីគោរព ជាមួយយុត្តិសាស្ត្រមុនៗរបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ដែលបានរកឃើញថា "ជនស៊ីវិល" គួរត្រូវបានកំណត់និយមន័យ ក្នុងបំណង ដើម្បីមិនរាប់បញ្ចូល *ទាហានដែលបាត់បង់សមត្ថភាពប្រយុទ្ធ*៖ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៣៨។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣០៤។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៨៥-១៨៦។

[3491] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៨៧។ សាលក្រមក្នុងរឿងក្តី *Mrkšić* កថាខណ្ឌ ៤៤១។ សាលក្រមក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៤២៣។

[3492] ឯកសារ D306/17.1 សេចក្តីសម្រេចរបស់ ស.ច.ស.អ លើស្ថានភាពនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ។ ស.ព.អ រក្សាគោលជំហរដែលខ្លួនបានកំណត់នៅក្នុងការដាក់សំណើរបស់ ស.ព.អ អំពីបញ្ហានេះ៖ ឯកសារ D306/2 សារណាលើស្ថានភាពនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ។ ឯកសារ D306/17.1/1/6 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យ៉ីម ទិត្យ ប្រឆាំងនឹងស្ថានភាពនៃកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់រដ្ឋ។

[3493] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣០៣។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៨២។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៩០។

បន្តនូវលក្ខណៈស៊ីវិលរបស់ខ្លួនឡើយ ដរាបណាក្រុមជនទាំងនោះភាគច្រើនជាជនស៊ីវិល[3494]។ ករណីដែលបានកំណត់រួចហើយថា ការវាយប្រហារដែលមានទ្រង់ទ្រាយធំ ឬលក្ខណៈជាប្រព័ន្ធមកលើជនស៊ីវិលបានកើតឡើងនោះមិនចាំបាច់បង្ហាញថា ជនរងគ្រោះម្នាក់ៗនៃឧក្រិដ្ឋកម្មសង្គ្រាមគឺជា "ជនស៊ីវិល" ឡើយ[3495]។

ការកម្រិតទៅលើយុត្តាធិការ

960. មាត្រា៥នៃច្បាប់ អ.វ.ត.ក តម្រូវឲ្យការវាយប្រហារមកលើជនស៊ីវិលត្រូវផ្អែកទៅលើហេតុផលជាតិ នយោបាយ ពន្ធុ ពូជសាសន៍ ឬសាសនា[3496]។ លក្ខខណ្ឌនេះមានលក្ខណៈជាយុត្តាធិការ ដែលបង្រួមវិសាលភាពនៃយុត្តាធិការរបស់ អ.វ.ត.ក ទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បើប្រៀបធៀបទៅនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលអនុវត្តក្នុងរវាងឆ្នាំ១៩៧៥ និង១៩៧៩[3497]។

[3494] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៣៨, ៧៤០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៨៣។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣០៥-៣០៦។ សាលដីកាក្នុងរឿងក្ដី *Milošević* (*Dragomir*) កថាខណ្ឌ ៥០-៥១, ៥៨។ សាលដីកាក្នុងរឿងក្ដី *Blaškić* កថាខណ្ឌ ១១៣។ សាលដីកាក្នុងរឿងក្ដី *Mrkšić & Šljivančanin* កថាខណ្ឌ ៣១។ សាលក្រមក្នុងរឿងក្ដី *Taylor* កថាខណ្ឌ ៥០៧។

[3495] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៤០។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១១។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៨៧, ១៩៤។ សាលដីកាក្នុងរឿងក្ដី *Popović* កថាខណ្ឌ ៥៦៩។ សាលដីកាក្នុងរឿងក្ដី *Martić* កថាខណ្ឌ ៣០៧-៣១៤។ សាលដីកាក្នុងរឿងក្ដី *Mrkšić & Šljivančanin* កថាខណ្ឌ ២៨-២៩, ៣២-៣៣។ សាលដីកាក្នុងរឿងក្ដី *Tolimir* កថាខណ្ឌ ១៤១-១៤៣។ សាលក្រមក្នុងរឿងក្ដី *Taylor* កថាខណ្ឌ ៥០៧។

[3496] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក មាត្រា៥។

[3497] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៤៤-៧៤៥។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៣-៣១៤។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៨៨។ ទោះបីជាមានការប្រើពាក្យខុសគ្នាក្ដី មាត្រា ៣ នៃលក្ខន្តិកៈតុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា មានបញ្ញត្តិសម្រាប់លក្ខខណ្ឌតម្រូវស្រដៀងគ្នា ដែលត្រូវកែតម្រូវដោយតុលាការនេះដើម្បីឲ្យក្លាយជាលក្ខខណ្ឌតម្រូវផ្អែកយុត្តាធិការ និងមិនមែនជាលក្ខខណ្ឌចាំបាច់ដែលត្រូវបានតម្រូវដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ៖ សាលដីកាក្នុងរឿងក្ដី *Akayesu* កថាខណ្ឌ ៤៦៤-៤៦៥។ ទោះបីជាតុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានយោងទៅលើមូលហេតុទាំងនេះថាជា "ការរើសអើង" ក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា ខ្លួនពុំត្រូវបានភ្ជាប់កាតព្វកិច្ចដោយការកំណត់ចរិតលក្ខណៈនៃលក្ខខណ្ឌតម្រូវផ្អែកយុត្តាធិការផ្ទាល់ខ្លួនរបស់តុលាការអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដាឡើយ។ *សូមមើល* សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៤៨។

អាស្រ័យហេតុនេះ ទោះបីជាការវាយប្រហារដែលមានវិសាលភាពទូលាយជាងនេះក៏ដោយ ត្រូវតែប្រព្រឹត្តដោយឈរលើមូលហេតុមួយ ក្នុងចំណោមមូលហេតុទាំងនេះ ប៉ុន្តែមិនមានលក្ខខណ្ឌតម្រូវថា ការវាយប្រហារនោះត្រូវតែមានលក្ខណៈវើសអើងនោះទេ[3498]។ តាមពិតលើកលែងតែក្នុងករណីការធ្វើទុក្ខបុកម្នេញ ចេតនាវើសអើង គឺមិនមានតម្រូវទេយោងតាមចាប់ទំនៀមទម្លាប់អន្តរជាតិ ថាជាធាតុចង់ដែលច្បាប់តម្រូវឲ្យមាននៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះ[3499]។

<u>ទំនាក់ទំនងរវាងអំពើរបស់ជនដៃដល់ និងការវាយប្រហារ</u>

961. អំពើរបស់ជនដៃដល់ ត្រូវតែជាផ្នែកមួយនៃការវាយប្រហារ។ ទំនាក់ទំនងដែលតម្រូវឲ្យមាននេះ រវាងអំពើរបស់ជនដៃដល់ និងការវាយប្រហារ មានធាតុផ្សំពីរ៖ ការប្រព្រឹត្តនៃអំពើដែលតាមរយៈសារជាតិរបស់វា ឬផលវិបាករបស់វាគឺជាសត្យានុម័ត្ត ជាផ្នែកមួយនៃការវាយប្រហារ[3500]។ ដោយរួមទាំងមានការដឹងឮពីសំណាក់ជនដៃដល់ថា មានការវាយប្រហារមួយទៅលើជនស៊ីវិល ហើយថាអំពើរបស់គាត់គឺជាផ្នែកមួយនៃការវាយប្រហារនោះ[3501]។

[3498] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៤៥, ៧៤៨។ សំណុំរឿង ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៦៣។

[3499] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៤៦។ សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៣៨។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៣-៣១៤។ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៨៨។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ៣០៥។ សាលដីកាក្នុងសំណុំរឿង *Akayesu* កថាខណ្ឌ ៤៦១, ៤៦៤-៤៦៦។ លក្ខន្តិក:តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(១) ជាពិសេស មាត្រា ៧(១)(ជ) ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញ។

[3500] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៥២-៧៥៣។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៩០។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៨៥, ៩៩។ សាលដីកាក្នុងសំណុំរឿង *Martić* កថាខណ្ឌ ៣១៦។

[3501] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៥២។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៩។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៩១។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៨៥, ៩៩។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥១៣, ៥១៥។

962. បន្ថែមទៅលើធាតុផ្សំទី១ អំពើដែលបានប្រព្រឹត្តមុន ឬក្រោយការវាយប្រហារជាចម្បងនោះ ឬនៅដាច់ឆ្ងាយពីការវាយប្រហារនោះក៏ដោយ នៅតែអាចក្នុងករណីមានទំនាក់ទំនងគ្នាគ្រប់គ្រាន់ ចាត់ទុកថាជាផ្នែកមួយនៃការវាយប្រហារនោះដែរ[3502]។ អំពើរបស់ជនជាប់ចោទ ទោះបីជាជនទាំងនោះមិនមែនជាជនដៃដល់ផ្ទាល់ក៏ដោយ ត្រូវតែជាផ្នែកមួយនៃការវាយប្រហារ[3503]។ ចំពោះធាតុផ្សំទី២ ការដឹងឮអំពីភាពពិស្តារនៃការវាយប្រហារ មិនមែនជាលក្ខខណ្ឌចាំបាច់នោះទេ[3504]។ វាមានលក្ខណៈគ្រប់គ្រាន់ហើយករណីជនជាប់ចោទដឹងឮអំពីបរិបទទូទៅ ដែលនៅក្នុងបរិបទនោះអំពើរបស់គាត់បានប្រព្រឹត្តទៅ[3505]។ ហេតុផលរបស់ជនដៃដល់នោះមិនពាក់ព័ន្ធឡើយ[3506]។ ជនដៃដល់មិនចាំបាច់ត្រូវមានគោលបំណងរួមនៅពីក្រោយការវាយប្រហារនោះឡើយ[3507]។ ហើយក៏មិនជាការពាក់ព័ន្ធដែរ ថាតើជនដៃដល់មានចេតនាចង់ឲ្យអំពើរបស់គាត់តម្រង់ទិសមកប្រឆាំងនឹងប្រជាជនដែលជាគោលដៅ ឬគ្រាន់តែជាជនរងគ្រោះរបស់គាត់ ឬយ៉ាងណានោះ[3508]។

[3502] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៩០។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១០០។ សាលដីកាក្នុងរឿងក្តី *Mrkšić & Šljivančanin* កថាខណ្ឌ ៤១។ សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣២៦។

[3503] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៥៤។

[3504] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៩។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៩១។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១០២។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥១៣។

[3505] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៩។ សាលក្រមក្នុងរឿងក្តី *Limaj* កថាខណ្ឌ ១៩០។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥១៣។

[3506] សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៩៩។ សាលដីកាក្នុងរឿងក្តី*Tadić* កថាខណ្ឌ ២៤៨, ២៥២។

[3507] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៩។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១៩១។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១០៣។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៩០។

[3508] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣១៩។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១០៣។

ii. បទល្មើសជាក់លាក់

<u>អំពើមនុស្សឃាត</u>

963. អំពើមនុស្សឃាតត្រូវបានកំណត់យ៉ាងត្រឹមត្រូវថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ យោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិគិតត្រឹមឆ្នាំ១៩៧៥[3509]។ ទោះជាយ៉ាងណាក៏ដោយយឹម ទិត្យ អាចមើលឃើញ និងអាចយល់ដឹងបានថា គាត់អាចនឹងត្រូវផ្តន្ទាទោសចំពោះទង្វើរបស់គាត់ ដែលអាចកើតជាអំពើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3510]។

964. ធាតុផ្សំសត្យានុម័ត្តនៃអំពើមនុស្សឃាតរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តម្រូវឲ្យមានភ័ស្តុតាងបញ្ជាក់នូវធាតុផ្សំពីរ៖ (១) ការស្លាប់របស់ជនរងគ្រោះ និង (២) ថាការស្លាប់នោះត្រូវបណ្តាលមកពីអំពើសកម្ម ឬអកម្មរបស់ជនដែលស់[3511]។ សពរបស់ជនរងគ្រោះមិនតម្រូវជាលក្ខខណ្ឌឲ្យមានជាភ័ស្តុតាងសម្រាប់ការបញ្ជាក់ការស្លាប់នោះទេ[3512]។ ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌនៃទំនាក់ទំនងហេតុផលនេះ លក្ខណៈជាក់លាក់ដែលថាការស្លាប់របស់ជនរងគ្រោះ "បណ្តាលមកពី" អំពើសកម្ម ឬអកម្មរបស់ជនដែលស់ មិនមានន័យថា អំពើនោះត្រូវតែជាមូលហេតុតែមួយគត់នៃការស្លាប់នោះឡើ

[3509] *សូមមើល* សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១១ និងសេចក្តីដកស្រង់នៅក្នុងសាលក្រមនោះ។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣១។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤ *ដើងទំព័រលេខ* ៥១៨៦។ ការធ្វើមនុស្សឃាតក៏ត្រូវបានចាត់ទុកជាបទឧក្រិដ្ឋផងដែរនៅក្នុងច្បាប់កម្ពុជាឆ្នាំ១៩៧៥៖ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ៥០១, ៥០៣-៥០៨។

[3510] *សូមមើល* សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១១។ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៦៥។

[3511] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១២។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣១។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៤។ សាលដីកាក្នុងរឿងក្តី *Milošević* (*Dragomir*) កថាខណ្ឌ ១០៨។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤១២។ ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(១)(ក) ធាតុផ្សំទី១។ សាលក្រមក្នុងរឿងក្តី *Bemba* កថាខណ្ឌ ៨៧។

[3512] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៣។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣២។ សាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ១៤៩, ២០៨, ២៤៩, ៣១៦។ សាលក្រមក្នុងរឿងក្តី *Bemba* កថាខណ្ឌ ៨៨។

ឃ។ វាមានលក្ខណៈគ្រប់គ្រាន់ក្នុងករណីថា ទង្វើរបស់ជនដៃដល់បានចូលរួមយ៉ាងសំខាន់ទៅនឹងសេចក្ដីស្លាប់នៃជនរងគ្រោះនោះ[3513]។ ការផ្ដន្ទាទោសអំពើមនុស្សឃាតមិនអាចលើកលែងបានដោយសារតែការមិនមានលទ្ធភាពបញ្ជាក់ឲ្យបានច្បាស់លាស់នូវតួលេខសរុបនៃចំនួនមនុស្សស្លាប់ ឬមិនអាចកំណត់ករណីដោយករណីចំពោះជនដៃផ្ដល់ផ្ទាល់ និងជនរងគ្រោះរបស់ជនដៃដល់ទាំងនោះ[3514]។ ការធ្វើអត្តឃាតរបស់ជនម្នាក់អាចក្លាយជាអំពើមនុស្សឃាត ក្នុងករណីអំពើសកម្ម ឬអកម្មរបស់ជនដៃដល់ "បានជំរុញឲ្យជនរងគ្រោះនោះធ្វើសកម្មភាពដែលបណ្ដាលឲ្យគាត់ស្លាប់"[3515]។

965. ការសម្លាប់ដោយមិនបានឆ្លងដំណើរការច្បាប់ ឬគោរពទៅតាមលក្ខខណ្ឌធានានានានៃដំណើរការនីតិវិធីផ្លូវតុលាការទេនោះ បង្កើតបានជាអំពើមនុស្សឃាត ហើយមិនមែនជាការផ្ដន្ទាទោសប្រហារជីវិតនោះទេ[3516]។ សិទ្ធិមិនអាចដកហូតជីវិតមនុស្សណាម្នាក់ដោយអត្តនោម័ត្ត មិនអាចលើកលែងបានទោះជានៅក្នុងកាលៈទេសៈណាក៏ដោយ រួមទាំងក្នុងគ្រាប្រកាសអាសន្ននៃជាតិទាំងមូលក៏

[3513] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣១។ សាលក្រមក្នុងរឿងក្ដី *Milutinović* (ភាគទី១) កថាខណ្ឌ ១៣៧។ សាលក្រមក្នុងរឿងក្ដី *Čelebići* កថាខណ្ឌ ៤២៤ ជើងទំព័រលេខ ៤៣៥។ សាលក្រមក្នុងរឿងក្ដី *Taylor* កថាខណ្ឌ ៤១៣។

[3514] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២០ *ដកស្រង់* សាលក្រមក្នុងរឿងក្ដី *Stakić* កថាខណ្ឌ ២០១។ *សូមមើលផងដែរ* សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២១។

[3515] សាលក្រមក្នុងរឿងក្ដី *Krnojelac* កថាខណ្ឌ ៣២៩។

[3516] កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៦(២)។ គណៈកម្មាធិការសិទ្ធិមនុស្ស បានបញ្ជាក់ថា ការសម្លាប់មនុស្សដែលត្រូវបានធ្វើដោយរំលោភការធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលមានចែងនៅក្នុងកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាការរំលោភកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៦(២)។ *សូមមើល* រឿងក្ដី *Mbenge* *តទល់នឹង ហ្សាអ៊ៃ* កថាខណ្ឌ 17 ["ការខកខានរបស់រដ្ឋភាគីក្នុងការគោរពលក្ខខណ្ឌតម្រូវពាក់ព័ន្ធនៃមាត្រា១៤(៣) នាំដល់ការសន្និដ្ឋានថា ទោសប្រហារជីវិតដែលត្រូវបានប្រកាសប្រឆាំងនឹង [Mbenge] ត្រូវបានធ្វើឡើងផ្ទុយពីបញ្ញត្តិរបស់កតិកាសញ្ញានេះ ហើយដូច្នេះវាជាការរំលោភបំពានមាត្រា៦(២)"]។ អនុសញ្ញាស្ដីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា២(១)។ អនុសញ្ញាស្ដីពីសិទ្ធិមនុស្សអាមេរិក មាត្រា៤(២)។ មាត្រាទូទៅទី៣ នៃអនុសញ្ញាក្រុងហ្សឺណេវ។

ដោយ[3517]។ ហើយក្នុងការបណ្តាលឲ្យកើតជាអំពើប្រល័យពូជសាសន៍ជីវិតអាចនឹងមិនត្រូវបានសម្លាប់[3518]។

966. ចំពោះធាតុអត្តនោម័ត្តមិនមានលក្ខខណ្ឌតម្រូវថា ការសម្លាប់ត្រូវតែបានគិតទុកជាមុននោះទេ។[3519] ធាតុអត្តនោម័ត្តរួមមានចេតនាដោយផ្ទាល់ក្នុងការសម្លាប់ ក៏ដូចជាចេតនាដោយប្រយោល[3520]។

[3517] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៦(១) ៤(២)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ២(១) ១៥(២)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអាមេរិក មាត្រា ៤, ២៧(២)។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា សភាពនៃគ្រាអាសន្នសាធារណៈក្នុងករណីណាក៏ដោយ ត្រូវតែប្រកាសជាផ្លូវការដោយរដ្ឋាភិបាលរបស់រដ្ឋ។ *សូមមើល* កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៤(១)។ យោបល់ទូទៅលេខ ២៩ លើមាត្រា មាត្រា ៤ កថាខណ្ឌ ២ ["មុនរដ្ឋមួយយកមាត្រា ៤ មកប្រើ រដ្ឋនោះត្រូវតែបំពេញលក្ខខណ្ឌជាមូលដ្ឋានចំនួនពីរ៖ ស្ថានភាពនោះត្រូវតែនាំឲ្យមានគ្រាអាសន្នសាធារណៈដែលគម្រាមដល់អាយុជីវិតរបស់ប្រទេសជាតិ ហើយរដ្ឋនោះត្រូវតែប្រកាសគ្រាអាសន្នជាផ្លូវការ។ លក្ខខណ្ឌតម្រូវក្រោយនេះមានលក្ខណៈសំខាន់ជាសារវន្តសម្រាប់ការរក្សាឲ្យបាននូវគោលការណ៍នីតិរដ្ឋ ក្នុងគ្រាដែលគោលការណ៍ទាំងនេះមានភាពចាំបាច់បំផុត"]។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ១៥(៣)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអាមេរិក មាត្រា ២៧(៣)។

[3518] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៦(២)-៦(៣)។ ការហាមឃាត់អំពើប្រល័យពូជសាសន៍ គឺជាបទដ្ឋាននៃ*គោលការណ៍អាជ្ញាបញ្ជា* ដែលក្នុងនោះបដិប្ញញ្ញត្តិមិនត្រូវបានអនុញ្ញាត្ត។ *សូមមើលឧទាហរណ៍* រឿងក្តី *សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គូ តទល់នឹង ង្វ៉ាន់ដា* កថាខណ្ឌ ៦៤ [ពិភាក្សាពីបទដ្ឋានមួយដែលមានលក្ខណៈជាបទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិទូទៅ (*គោលការណ៍អាជ្ញាបញ្ជា*) "ដែលត្រឹមត្រូវយ៉ាងពិតប្រាកដទាក់ទងនឹងការហាមឃាត់អំពើប្រល័យពូជសាសន៍"]។

[3519] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៣៩២-៣៩៤។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១២។ សាលដីកាក្នុងរឿងក្តី *Đorđević* កថាខណ្ឌ ៥៥១-៥៥២។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥៨៨។ សាលក្រមក្នុងរឿងក្តី *Brima* កថាខណ្ឌ ៦៩០។

[3520] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤០៩-៤១០។ *សូមមើលបន្ថែម* សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១២។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៣។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៧៩។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២៥៩, ២៦១។ សាលដីកាក្នុងរឿងក្តី *Milošević* (*Dragomir*) កថាខណ្ឌ ១០៨។ សាលដីកាក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣២០។ សាលក្រមក្នុងរឿងក្តី *Brima* កថាខណ្ឌ ៦៨៨, ៦៩០។

ការសម្លាប់រង្គាល

967. ការសម្លាប់រង្គាលត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ គិតត្រឹមឆ្នាំ១៩៧៥[3521]។ យីម ទិត្យ អាចរំពឹងមើលឃើញ និងអាចយល់ដឹងបានថា គាត់អាចនឹងត្រូវផ្តន្ទាទោសចំពោះទង្វើដែលបង្កើតបានជាការសម្លាប់រង្គាលរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3522]។

968. ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាល គឺជាអំពើនៃការសម្លាប់ក្នុងទ្រង់ទ្រាយធំ[3523]។ ធាតុសត្យានុម័ត្តនៃការសម្លាប់រង្គាលរបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានអំពើសកម្ម ឬអំពើអកម្ម ឬបូករួមទាំងអំពើសកម្មផង អកម្មផង ដែលចូលរួមធ្វើឲ្យមនុស្សស្លាប់នៅក្នុងទ្រង់ទ្រាយធំ[3524]។ តួនាទីរបស់ជនដៃដល់ អាចមានលក្ខណៈជាប្រយោល ឬដោយមិនផ្ទាល់[3525] ហើយអាចរួមមានការបង្កើតនូវលក្ខខណ្ឌទាំងឡាយនៃការរស់នៅក្នុងបំណងបំផ្លាញផ្នែកនៃក្រុមប្រជាជន ដូចជា ការបង្អត់អាហារ

[3521] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៥ និងសេចក្តីដកស្រង់នៅក្នុងសាលក្រមនោះ។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៤។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤ ជើងទំព័រលេខ ៥១៨៧។

[3522] *សូមមើល* សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៥។

[3523] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥២៥។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ១៨៩។ សាលដីកាក្នុងរឿងក្តី *Ntakirutimana* កថាខណ្ឌ ៥១៦។

[3524] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៤។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៦។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨២។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ១៨៩។ ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៧(១)(ខ) ធាតុផ្សំទី១-២។

[3525] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៥។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨២។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ១៨៩។ សាលដីកាក្នុងរឿងក្តី *Ndindabahizi* *ជើងទំព័រលេខ* ២៦៨។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៣៨៩។

ឬថ្នាំសង្កូរ[3526]។ មិនមានលក្ខខណ្ឌតម្រូវថា ជនរងគ្រោះ "ត្រូវតែបានដាក់នៅក្នុងលក្ខខណ្ឌ *ដែលថ្នៀសមិនផុត ត្រូវតែនាំទៅដល់សេចក្តីស្លាប់នោះទេ*"[3527]។

969. ការផ្តន្ទាទោសចំពោះការសម្លាប់រង្គាល តម្រូវឲ្យមានការបំពេញលក្ខខណ្ឌលើសពីវិមតិសង្ស័យនៃការកើតឡើងនូវការសម្លាប់ជាទ្រង់ទ្រាយធំ[3528]។ មិនមានលក្ខខណ្ឌតម្រូវថា រាល់ការសម្លាប់បុគ្គលម្នាក់ៗត្រូវតែបញ្ជាក់ភ័ស្តុតាងឲ្យលើសពីវិមតិសង្ស័យនោះទេ ដរាបណាភ័ស្តុតាងជារួមបានបង្កើតបានជាកម្រិតលើសពីវិមតិសង្ស័យ ដែលថា ការសម្លាប់ជាទ្រង់ទ្រាយធំពិតជាបានកើតឡើងហើយនោះ[3529]។ ការបញ្ជាក់ភ័ស្តុតាងមិនចាំបាច់តម្រូវឲ្យមានការបញ្ជាក់អត្តសញ្ញាណ ការពណ៌នា ឬការ

[3526] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហេ្គចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៥។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨២។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៣៨៩។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៤៩៨, ៥០៣។ លក្ខន្តិក:តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(២)(ខ)។ ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(១)(ខ) ធាតុផ្សំទី១។

[3527] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២១-៤២៤។

[3528] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២១។ សាលដីកាក្នុងរឿងក្តី *Ntakirutimana* កថាខណ្ឌ ៥២១។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ៨៩។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៣២។

[3529] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២១។ *សូមមើលបន្ថែម* សាលក្រម*យុត្តិធម៌* ទំព័រ ១០៤៦, ១០៥៣-១០៥៤, ១០៧៩ [ជនជាប់ចោទត្រូវបានរកឃើញថាមានទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមទាំងការសម្លាប់រង្គាល ទោះបីជាពុំមានការរកឃើញហ្លួសពីវិមតិសង្ស័យ លើការសម្លាប់ក្រៅច្បាប់នីមួយៗក៏ដោយ]។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ៨៩ [រកឃើញថា ពុំចាំបាច់មានភ័ស្តុតាងបង្ហាញពីការសម្លាប់បុគ្គលទាំងឡាយដែលមានឈ្មោះនៅក្នុងដីកាចោទប្រកាន់ ដើម្បីផ្តន្ទាទោសលើអំពើសម្លាប់រង្គាលឡើយ ប៉ុន្តែសម្រេចថា ការរកឃើញហ្លួសពីវិមតិសង្ស័យ ថា "ជនភៀសខ្លួនជាច្រើនត្រូវបានសម្លាប់" គឺគ្រប់គ្រាន់ហើយ]។ សាលក្រមក្នុងរឿងក្តី *Kajelijeli* កថាខណ្ឌ ៨៨៦។

កំណត់ច្បាស់លាស់ជាក់លាក់ទៅដល់ឈ្មោះរបស់ជនរងគ្រោះនោះទេ[3530] ហើយក៏មិនតម្រូវឲ្យមានបញ្ជាក់ចំនួនជាក់លាក់នៃជនរងគ្រោះដែលបានស្លាប់នោះដែរ[3531]។

970. មិនមានចំនួនជនរងគ្រោះអប្បរិមាដែលត្រូវមានដើម្បីបំពេញលក្ខខណ្ឌដែលថា ទ្រង់ទ្រាយនៃមនុស្សស្លាប់ត្រូវតែ "មានទ្រង់ទ្រាយធំ" នោះទេ[3532]។ ការសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំណត់មានទំនាក់ទំនងទៅនឹងការសម្លាប់មនុស្សរាប់ពាន់នាក់[3533] ប៉ុន្តែក៏មានការសម្រេចផងដែរទៅនឹងទំនាក់ទំនងនៃការសម្លាប់មនុស្សតិចជាងនេះ[3534]។ ចំនួនជនរងគ្រោះធំជាពិសេសណាមួយអាចជាស្ថានទម្ងន់ទោសពាក់ព័ន្ធទៅនឹងការកំណត់ទោសក្នុងករណីដែលទំហំនៃការសម្លាប់មានចំនួនច្រើនលើសលក្ខខណ្ឌនៃការសម្លាប់រង្គាល[3535]។ អត្ថិភាពនៃ "សហគ្រាសពិឃាតដ៏ធំមួយ" គឺមិនមែនជាធាតុផ្សំនៃការសម្លាប់រង្គាលនោះទេ[3536]។

[3530] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២១។ សាលដីកាក្នុងរឿងក្តី *Ntakirutimana* កថាខណ្ឌ ៥១៨, ៥២១ ដកស្រង់ដោយមានការយល់ព្រមនៅក្នុងសាលដីកាក្នុងរឿងក្តី *Stakić ជើងទំព័រ*លេខ ៥៥២។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៣២។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨២។

[3531] សាលដីកាក្នុងរឿងក្តី *Rukundo* កថាខណ្ឌ ១៨៧, ១៨៩។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៦៥៤-៦៥៥។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨២។

[3532] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៥១។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៦។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៨៣។ សាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៥៣៧។ សាលដីកាក្នុងរឿងក្តី *Ndindabahizi* កថាខណ្ឌ ១៣៥។

[3533] សាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៥៣៧។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៧៩, ៨៤, ៤២៦, ៥០៥។ សាលដីកាក្នុងរឿងក្តី *Ntakirutimana* កថាខណ្ឌ ៥២១។

[3534] *ឧទាហរណ៍*នៅក្នុងសាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៥៤០-៥៤៤ ការសម្លាប់ "មនុស្ស៥៩ នាក់" និង "យ៉ាងតិច៦០ នាក់" មានទ្រង់ទ្រាយធំគ្រប់គ្រាន់ ក្នុងការបង្កើតឧក្រិដ្ឋកម្មសម្លាប់រង្គាល។ ក្នុងរឿងក្តី *Brđanin* ការសម្លាប់មនុស្សចន្លោះពី៦៨ នាក់ និង៣០០ នាក់ "ដោយពិចារណាលើកាលៈទេសៈដែលបានកើតឡើង" បំពេញនូវកម្រិតដែលចាំបាច់នៃវិសាលភាពសម្រាប់គោលបំណងនៃការសម្លាប់រង្គាល" (សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤៧២)។ ស្រដៀងគ្នាដែរ តុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា បានរកឃើញថា ការសម្លាប់មនុស្សប្រមាណពី៣០-៤០ នាក់ មានទ្រង់ទ្រាយធំគ្រប់គ្រាន់ ក្នុងការបង្កើតឧក្រិដ្ឋកម្មសម្លាប់រង្គាល (សាលក្រមក្នុងរឿងក្តី *Setako* កថាខណ្ឌ ៤៨១ (សេចក្តីសម្រេចនេះត្រូវបានតម្កល់នៅក្នុងសាលដីកា សាលដីកាក្នុងរឿងក្តី *Setako* កថាខណ្ឌ ៣០១)។

[3535] សាលដីកាក្នុងរឿងក្តី *Ndindabahizi* កថាខណ្ឌ ១៣៥។

[3536] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥២៧-៥២៨។

971. លក្ខខណ្ឌនៃទ្រង់ទ្រាយត្រូវតែផ្ទឹងផ្ទែងទៅតាមករណីនីមួយៗ ដោយពិចារណាទៅលើកាល:ទេស: ដែលការសម្លាប់នោះបានកើតឡើង[3537]។ កត្តាពាក់ព័ន្ធមាន តែមិនកំណត់ត្រឹម ពេលវេលានិងទីកន្លែងនៃការសម្លាប់[3538] ការជ្រើសរើសជនរងគ្រោះ និងលក្ខណ:ដែលជនរងគ្រោះត្រូវបានដាក់ជាគោលដៅ[3539] ហើយថាតើការសម្លាប់ទាំងនោះត្រូវបានប៉ងទៅចំពោះក្រុមសម្ងួហភាព មិនមែនជាជនរងគ្រោះនៅក្នុងលក្ខណ:ជាបុគ្គលឬយ៉ាងណា[3540]។ ទោះជាយ៉ាងណាក៏ដោយមិនមានលក្ខខណ្ឌតម្រូវថា ក្រុម ឬ "ផ្នែកមួយនៃ" បណ្តុំមនុស្សដែលត្រូវបានសម្លាប់ ត្រូវតែមានបុគ្គលិកលក្ខណ: ដូចគ្នាណាមួយនោះទេ[3541] ហើយក៏មិនតម្រូវថា ជនដៃដល់ត្រូវតែមានចេតនាកម្ទេចក្រុម ឬផ្នែកនៃក្រុមដែលជនរងគ្រោះទាំងនោះស្ថិតនៅនោះដែរ[3542]។ ការរៀបចំ និងការចាត់តាំងនៃឧក្រិដ្ឋកម្មក៏អាចត្រូវយកមកពិចារណាដែរ ក្នុងការកំណត់អំពីធាតុសត្យានុម័ត្ត[3543]។

972. យុត្តិសាស្ត្រ បានកំណត់ថាធាតុទ្រង់ទ្រាយនៃឧក្រិដ្ឋកម្មការសម្លាប់រង្គាលនេះ អាចត្រូវកំណត់ទៅតាមស្ថានទម្ងន់នៃបទល្មើស ដរាបណាការសម្លាប់ទាំងនោះបានបណ្តាលចេញមកពីដំណើរការតែ

[3537] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៦។ សាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៥៣៨។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៣២។

[3538] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៥១។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៦។ សាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៥៣៨។

[3539] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៥១។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៧។ សាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៥៣៨។ សាលក្រមក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ១០៦១។

[3540] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៥១។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៧។ សាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៥៣៨។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៦៣៩, ៦៥៣។

[3541] *សូមមើល* សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥១៩-៥២០ *ដោយយោងលើ*សេចក្តីព្រាងក្រមឆ្នាំ១៩៩៦ របស់គណ:កម្មការច្បាប់អន្តរជាតិ (ដោយមានសេចក្តីអត្ថាធិប្បាយ) ទំព័រ ៤៨។

[3542] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៧។ សាលដីកាក្នុងរឿងក្តី *Musema* កថាខណ្ឌ ៣៦៦។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៦៣៩។

[3543] សាលដីកាក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៥៣៨ *ដោយយោងលើ* សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥០១។

មួយនៃទង្វើរបស់ជនជាប់ចោទនោះ[3544]។ នៅក្នុងករណីដែលការសម្លាប់ជាទ្រង់ទ្រាយធំបណ្តាលមកពីគោលនយោបាយដោយចេតនាតែមួយ ដែលបានរៀបចំ និងសម្របសម្រួលរួមគ្នាដោយបណ្តាបុគ្គលជដែល ឬកើតឡើងនៅក្នុងទីតាំងផ្សេងៗ ដែលជាផ្នែកមួយនៃប្រព័ន្ធសម្របសម្រួលតែមួយដូចជាប្រព័ន្ធមួយ ឬមន្ទីរសន្តិសុខនានា នោះវាជាការចម្លែកណាស់ ក្នុងការកំណត់ថាបុគ្គលទាំងនោះមិនបានទទួលខុសត្រូវចំពោះការសម្លាប់រង្គាល ដោយគ្រាន់តែដោយសារការសម្លាប់ទាំងនោះបានកើតឡើងនូវទីតាំងជាច្រើននោះ។

973. យោងទៅតាមតុលាការកំពូល ធាតុអត្តនោម័ត្តរួមមានចេតនាក្នុងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ ឬបង្កើតនូវលក្ខខណ្ឌនៃការរស់នៅ ដោយបានរៀបចំសំដៅនាំមកនូវការស្លាប់នៃមនុស្សក្នុងចំនួនច្រើន[3545]។ ការដឹងឮអំពីការស្លាប់ណាមួយ មិនមែនជាលក្ខខណ្ឌតម្រូវឲ្យបំពេញនោះទេ[3546]។ ទាំងចេតនាក្នុងការសម្លាប់ជនរងគ្រោះចំនួនណាមួយជាក់លាក់[3547] ទាំងការដឹងឮអំពី "សហគ្រាសពិឃាតធំណាមួយ"[3548] គឺមិនមែនជាធាតុផ្សំឡើយ។ លើសពីនេះទៀត មិនមានលក្ខខណ្ឌតម្រូវថាចេតនាក្នុងការសម្លាប់ទ្រង់ទ្រាយធំត្រូវតែបានលេចជារូបរាងឡើង "មុនព្រឹត្តិការណ៍"នោះដែរ។ ការដឹងឮដែលថា ការសម្លាប់ជាច្រើនកំពុងកើតមានឡើងមានការចូលរួមជាបន្តបន្ទាប់របស់ជនជាប់ចោទនៅក្នុងការសម្លាប់ដែលពាក់ព័ន្ធ បង្ហាញឲ្យឃើញនូវចេតនាការសម្លាប់ទ្រង់ទ្រាយធំ[3549]។

[3544] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៥២ ["ហេតុការណ៍ដែលបង្កើតបានជាមូលដ្ឋានសម្រាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទ ត្រូវតែយល់ឃើញថា "ជាបទឧក្រិដ្ឋមួយដូចគ្នា និងមានធាតុផ្សំ*សត្យានុម័ត*ដូចគ្នា"]។

[3545] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥២១-៥២២, ៥២៥ *ដោយផ្អែកលើ*សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥០៣។ សាលដីកាក្នុងរឿងក្តី *Ntakirutimana* កថាខណ្ឌ ៥២២។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ៨៦។

[3546] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥២០។ សំណុំរឿង ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៦៨(ខ)។

[3547] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៦០-២៦១។

[3548] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥២៧-៥២៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤១៩។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៣៧។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៥៩។

[3549] *សូមមើលជាទូទៅ* សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៩៨, ត្រង់ចំណុចដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា បានកត់សម្គាល់ថា "ចេតនាក្នុងការចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋអាចត្រូវបានទាញការសន្និដ្ឋានពីការចូលរួមរបស់ជនជាប់ចោទ" ហើយ "ជនជាប់ចោទត្រូវតែមានសម្បជញ្ញៈច្បាស់ថា ការចូលរួម

ការធ្វើឲ្យទៅជាទាសករ

974. មិនមានការចម្រូងចម្រាស់ទេថា ការធ្វើឲ្យទៅជាទាសករត្រូវបានទទួលស្គាល់នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគិតត្រឹមឆ្នាំ១៩៧៥[3550]។ លើសពីនេះទៀតយឺមទិត្យ អាចរំពឹងមើលឃើញ និងអាចយល់ដឹងបានថា គាត់នឹងត្រូវផ្តន្ទាទោសចំពោះទង្វើដែលបង្កើតបានជា ការធ្វើឲ្យទៅជាទាសករនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3551]។

975. ការធ្វើឲ្យទៅជាទាសករមានន័យថា គឺជាការដកហូតពីបុគ្គលណាមួយនូវអំណាចណាមួយ ឬអំណាចទាំងអស់ ដែលផ្សារភ្ជាប់ទៅនឹងសិទ្ធិនៃកម្មសិទ្ធិ[3552]។ លក្ខណៈសម្គាល់នៃការធ្វើឲ្យទៅជាទាសកររួមមាន៖ "ការត្រួតត្រាទៅលើការធ្វើដំណើររបស់បុគ្គលណាមួយ ការត្រួតត្រាទៅលើបរិយាកាសផ្លូវកាយ ការត្រួតត្រាទៅលើផ្លូវចិត្ត វិធានការការពារ ឬហាមមិនឲ្យរត់គេច ការគំរាមកំហែងប្រើកម្លាំង ឬបង្ខិតបង្ខំ ការកំណត់ពេលវេលា ការអះអាងពីភាពផ្តាច់មុខ ការដាក់ឲ្យទទួលរងនូវអំពើហោរហៅ និងការរំលោភបំពាន ការត្រួតត្រាទៅលើការសេពសន្ថវៈ និងការងារដោយ

នេះនឹងនាំដល់ការប្រព្រឹត្តបទឧក្រិដ្ឋ"។ ដូចបានកំណត់ខាងលើ *សូមមើល* កថាខណ្ឌ ៩៤៨ ស្រដៀងគ្នានេះ បទប្រល័យពូជសាសន៍ មិនតម្រូវឲ្យមានភ័ស្តុតាងបង្ហាញថា ជនជាប់ចោទមានចេតនាប្រល័យពូជសាសន៍ *មុន*ការប្រព្រឹត្តឧក្រិដ្ឋកម្មជាក់ស្តែងនោះទេ។

[3550] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៣១-១៣២, ១៣៩, ១៤៤, ១៥២, ១៦១-១៦២ និងសេចក្តីដកស្រង់នៅក្នុងសាលដីកានោះ។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤២។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤ *ជើងទំព័រលេខ* ៥១៨៨។

[3551] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៦១-១៦២។

[3552] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៥២-១៥៣។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤២។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩២។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១១៦-១១៧។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៩៧-១៩៨។ លក្ខន្តិក:តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(២)(គ)។ ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(១)(គ) ធាតុផ្សំទី១។

បង្ខំ"[3553]។ ធាតុផ្សំទាំងឡាយនៃការធ្វើឲ្យទៅជាទាសករ អាចត្រូវបំពេញបានដោយមិនចាំបាច់មានភ័ស្តុតាងអំពីការធ្វើបាបបន្ថែមទៀតនោះឡើយ[3554]។

976. នៅក្នុងការពិចារណាទៅលើការចោទប្រកាន់អំពីការធ្វើឲ្យទៅជាទាសករ គឺត្រូវតែ លើសអ្វីៗទាំងអស់ ត្រូវតែកំណត់នូវលក្ខណៈ "កម្មសិទ្ធិ"[3555] ពោលគឺបណ្តាអង្គហេតុដែលចង្អុលបង្ហាញថាជនរងគ្រោះត្រូវបានបន្ទាបបន្ថោកមកត្រឹមជាមុខទំនិញមួយមុខ ដូចជាថា បុគ្គលនោះគឺជាកម្មវត្ថុមួយនៃ "ការប្រើកម្មសិទ្ធិ" ដូចជាថា គាត់ត្រូវបានប្រើ (ឧទាហរណ៍ សម្រាប់គោលបំណងផ្លូវភេទ ឬអ្វីផ្សេងៗទៀត) ត្រូវបានកេងប្រវ័ញ្ចខាងសេដ្ឋកិច្ច និងឬជាចុងបញ្ចប់ត្រូវកម្ទេចចោល[3556]។ បង្កប់នៅក្នុងអត្ថន័យនៃអំណាចកម្មសិទ្ធិ គឺជាការប្រឹងប្រែងមួយដើម្បីទាញផលចំណេញតាមរយៈការអនុវត្តអំណាចទាំងនោះ ទោះបីជាកត្តានេះមិនមែនជាធាតុផ្សំបន្ថែមនៃឧក្រិដ្ឋកម្មនោះក៏ដោយ[3557]។ រយៈពេលនៃការកំណត់ថេរវេលានៃការដាក់ឲ្យទៅជាទាសករ មិនមែនជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មនោះទេ។ ប៉ុន្តែការកំណត់ថេរវេលាអាចពាក់ព័ន្ធនៅក្នុងការយកមកកំណត់សារជាតិនៃទំនាក់ទំនងទៅវិញទៅមក[3558]។

977. ពលកម្មដោយបង្ខំ ឬដោយស្ម័គ្រចិត្តក៏អាចបង្កើតបានជាការធ្វើឲ្យទៅជាទាសករផងដែរ[3559]។ ត្រូវតែកំណត់ឲ្យបានថា បុគ្គលពាក់ព័ន្ធនោះមិនមានជម្រើសពិតប្រាកដ ថាតើពួកគេនឹងត្រូវតែធ្វើការ ឬ

[3553] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៥៤។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤២។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១១៩។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៩៩។

[3554] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤៤។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១២៣។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ២០៣។

[3555] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៥៥-១៥៦។ ទោះបីជាសញ្ញាណនៃអំពើធ្វើឲ្យទៅជាទាសករផ្តោតលើភាពជាម្ចាស់ មិនជាប់ព្រំដែនជាមួយ "ទាសភាពក្នុងនាមជាម្ចាស់ចលនទ្រព្យ" ក៏ដោយ៖ សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៥៥។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១១៧។

[3556] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៥៦។

[3557] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៥៧-១៥៨។

[3558] សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១២១, ៣៥៦។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៤៧។

[3559] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤២, ៣៤៤។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១១៩។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ៣៥៩។ សាលក្រមក្នុងរឿងក្តី *Simić* កថាខណ្ឌ ៨៥។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៩៩, ២០២។

យ៉ាងណា ហើយនេះជាការកំណត់អង្គហេតុមួយ ដែលត្រូវតែធ្វើឡើងដើម្បីបង្ហាញអំពីលក្ខណៈសម្គាល់នៃការធ្វើឲ្យទៅជាទាសករដែលបានកំណត់[3560]។ អវត្តមាននៃប្រាក់ខែមិនមែនជាធាតុផ្សំនៃការធ្វើឲ្យទៅជាទាសករនោះទេ ប៉ុន្តែអាចនឹងបង្កើតបានជាកត្តាបង្ហាញភ័ស្តុតាងពាក់ព័ន្ធ ក្នុងការកំណត់ថាតើការធ្វើពលកម្មនោះជាការបង្ខំ ឬយ៉ាងណា[3561]។

978. ការមិនមានការយល់ព្រម ក៏មិនមែនជាធាតុផ្សំមួយនៃបទល្មើសការធ្វើឲ្យក្លាយជាទាសករនោះទេ ដោយសារការធ្វើឲ្យទៅជាទាសករត្រូវកំណត់ទៅតាមការអនុវត្តអំណាចដោយជនដៃដល់ ប៉ុន្តែវាអាចជាភ័ស្តុតាងពាក់ព័ន្ធដើម្បីបញ្ជាក់ពីការអនុវត្តអំណាចលើកម្មសិទ្ធិ[3562]។ អាចសន្និដ្ឋានថាជាអវត្តមាននៃការយល់ព្រមបាន ដរាបណាការបញ្ជេញនូវការយល់ព្រមនោះមិនអាចធ្វើទៅបាន[3563] ក្នុងលក្ខណៈដូចជា ក្នុងករណីដែលជនរងគ្រោះរស់នៅ "បរិយាកាសនៃការភ័យខ្លាច"[3564]។ នៅក្នុងកាលៈទេសៈទាំងនេះ ការមិនមានការតបត ឬការជំទាស់ នឹងមិនត្រូវបកស្រាយថាជាសញ្ញានៃការយល់ព្រមបានឡើយ[3565]។ មានសេចក្តីសម្រេចកន្លងមករួចហើយថា ស្ថានភាពរស់នៅផ្ទុំគ្នាចង្អៀត ធ្ងន់ធ្ងរពេក អនាម័យមិនល្អ ការមិនបានដេក អាហារមិនគ្រប់គ្រាន់ ការបិទទ្វារ ការវាយដំញ៉ីកញ្ជាប់ ការបំពានផ្លូវចិត្ត និងស្ថានភាពរស់នៅយ៉ាងយ៉ៅ នឹងធ្វើឲ្យអ្នកទោសមិនអាចយល់ព្រមធ្វើការ ហើយកំណត់ថា ពលកម្មរបស់ពួកគេគឺត្រូវបានបង្ខំ[3566]។

[3560] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤៤។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៩៤-១៩៥។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ២០២។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៤៨។

[3561] សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១០៨២។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១១៩។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៤។

[3562] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤៣។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១២០។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៧៣៤។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៤៧។

[3563] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤៣។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១២០។

[3564] សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៩៤។

[3565] សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១២០។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៩៤-១៩៥។

[3566] សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៩៣-១៩៥។

979. ចំពោះធាតុអត្តនោម័ត្តត្រូវតែមានការបង្ហាញឲ្យឃើញថា ជនដៃដល់បានអនុវត្តដោយចេតនានូវអំណាចណាមួយ ឬអំណាចទាំងអស់ដែលផ្សារភ្ជាប់ទៅនឹងសិទ្ធិនៃកម្មសិទ្ធិ[3567]។

ការនិរទេស

980. ការនិរទេសនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបានមានអត្ថិភាពយោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិគិតមកត្រឹមឆ្នាំ១៩៧៥[3568]។ ដោយសារការនិរទេសនេះត្រូវបានបញ្ចូលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយ៉ាងច្បាស់លាស់នៅក្នុងឧបករណ៍ច្បាប់ និងយុត្តិសាស្ត្រមួយចំនួនក្រោយសង្គ្រាមលោកលើកទីពីរ យើង ទិញ្ញ អាចរំពឹងមើលឃើញ និងអាចយល់ដឹងបានថា គាត់នឹងត្រូវបានផ្តន្ទាទោសចំពោះអំពើណាដែលជាការនិរទេសនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3569]។

[3567] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៥២-១៥៣។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤៥។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣៩៥។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១១៦, ១២២។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៤៦។

[3568] សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤ *ដើងទំព័រលេខ* ៥១៨៩។ ក្រម Lieber មាត្រា ២៣។ របាយការណ៍របស់គណៈកម្មការឆ្នាំ១៩១៩ ទំព័រ ១១៤។ ធម្មនុញ្ញតុលាការយោធាអន្តរជាតិ មាត្រា ៦(គ)។ សាលក្រមតុលាការយោធាអន្តរជាតិ ទំព័រ ២២៧, ២៤៤, ២៩៥-២៩៦ (រ៉ូសេនប៊ើក) ៣១៩-៣២០ (Von Schirach) ៣២៩។ ច្បាប់ស្តីពីក្រុមប្រឹក្សាត្រួតពិនិត្យ (CCL 10) មាត្រា II(១)(គ)។ សាលក្រមក្នុងរឿងក្តី *Milch* ៧៧៣, ៧៩០-៧៩១ យោបល់សន្និដ្ឋានរបស់ Philips ៨៦៥។ សាលក្រមក្នុងរឿងក្តី *Krupp* ១៣៧៣, ១៤២៩-១៤៣៣, ១៤៤៩ សាលក្រមក្នុងរឿងក្តី*ចំណាប់ខ្ទាំង* ១៣០១-១៣០៥។ សាលក្រមក្នុងរឿងក្តី *Flick* ១១៩០-១១៩៤, ១១៩៤, ១២០២។ សាលក្រមក្នុងរឿងក្តី*អគ្គបញ្ជាការដ្ឋាន* ៤៦៥, ៤៩៥-៤៩៦, ៥៦៩-៥៧៧, ៥៨០, ៦០៣-៦០៩, ៦១៤, ៦២៩, ៦៧៩-៦៨០។ ធម្មនុញ្ញក្រុងតូក្យូ មាត្រា៥(គ)។ *Takashi Sakai* ១-៧ (ចិន ឆ្នាំ១៩៤៦)។ ពាក់ព័ន្ធនឹង *Zimmermann* ទំព័រ ៥៥២ (ហ្ស្លង់ ឆ្នាំ១៩៤៩)។ សាលក្រមក្នុងរឿងក្តី *Eichmann* កថាខណ្ឌ ៧៣, ៧៥, ១៣៧, ១៤១, ២០៧-២១៣ (អ៊ីស្រាអែល ឆ្នាំ១៩៦១)។ គោលការណ៍ទីក្រុងណ្យូរ៉ិមប៊ើក គោលការណ៍ទី VI(គ)។ សេចក្តីព្រាងក្រមឆ្នាំ១៩៥៤ របស់គណៈកម្មការច្បាប់អន្តរជាតិ មាត្រា ២(១១)។ *សូមមើលផងដែរ*អនុសញ្ញាក្រុងហ្សឺណែវ ផ្នែកទី IV មាត្រា៤៩, ១៤៧។ ពិធីសារបន្ថែម (I) មាត្រា៨៥ (៤)(ក)។

[3569] ការហាមឃាត់ការធ្វើនិរទេសក្នុងពេលមានសន្តិភាព (និងក្នុងការការពារសិទ្ធិដែលពាក់ព័ន្ធ) ក៏មាននៅក្នុងលិខិតុបរ្ចរណ៍ថ្នាក់តំបន់ និងអន្តរជាតិមុនឆ្នាំ១៩៧៥ មួយចំនួនផងដែរ។ *សូមមើល* សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ៣, មាត្រ ៥ មាត្រា១២ មាត្រា១៣(១)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា២, ៣, ៥, ៨។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៧, ១២, ១៣។ អនុសញ្ញាស្តីពីជនភៀសខ្លួន មាត្រា៣២។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអាមេរិក មាត្រា២២ (១) ២២(៥) ២២(៩)។

981. "ការនិរទេស" និង "ការជម្លៀសដោយបង្ខំ" មានការខុសគ្នាច្បាស់លាស់ត្រង់ថា ការនិរទេសតម្រូវថាការផ្លាស់ប្តូរទីកន្លែងត្រូវតែឆ្លងព្រំដែននៃរដ្ឋមួយ (តាមអង្គច្បាប់ ឬតាមអង្គហេតុ)[3570] ប៉ុន្តែឧក្រិដ្ឋកម្មទាំងពីរ "មានធាតុទាំងឡាយដូចៗគ្នាលើកលែងតែពាក់ព័ន្ធទៅនឹងទីដៅ"[3571]។

982. ធាតុអត្តនោម័ត្តនៃការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ទោះជាការនិរទេសក្តី ឬការជម្លៀសដោយបង្ខំក្តី គឺ (១) ការផ្លាស់ប្តូរទីតាំងរបស់មនុស្សដោយបង្ខំតាមរយៈការបណ្តេញចេញ ឬអំពើបង្ហិតបង្ខំណាផ្សេងៗទៀត (២) ចេញពីទីកន្លែងដែលប្រជាជនទាំងនោះបានមានវត្តមានស្របច្បាប់ (៣) ដោយមិនមានហេតុផលណាដែលបានអនុញ្ញាតយោងតាមច្បាប់អន្តរជាតិ[3572]។ មិនមានចំនួនអប្បរិមានៃប្រជាជនដែលត្រូវទទួលរងនូវការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ ដើម្បីបង្កើតបានជាការទទួលខុសត្រូវនោះទេ[3573]។ ពាក្យថា "មានវត្តមានស្របច្បាប់" មិនគួរបកស្រាយឲ្យមានន័យស្មើនឹងសញ្ញាណនៃពាក្យការរស់នៅស្របច្បាប់នោះទេ[3574]។

983. ពាក្យថា "ដោយបង្ខំ" គឺមិនកំណត់ត្រឹមការបង្ខំលើរូបរាងកាយទេ ប៉ុន្តែវារួមទាំងការគំរាមកំហែងប្រើកម្លាំង ឬបង្ហិតបង្ខំក្នុងលក្ខណៈដែលបណ្តាលឲ្យមានការភ័យខ្លាចនិងអំពើហិង្សា ការបង្ហិតបង្ខំ ការបង្ខាំងទុក ការគាបសង្កត់ផ្លូវចិត្ត ឬការរំលោភអំណាចទៅលើមនុស្សណាម្នាក់ ឬមនុស្សជាច្រើន ឬមនុស្សណាផ្សេងទៀត ឬដោយបានទាញយកផលប្រយោជន៍ពីបរិយាកាសនៃការបង្ហិតបង្ខំមួយ[3575]។ ពាក្យនេះមានលក្ខខណ្ឌតម្រូវថា ការផ្លាស់ប្តូរទីកន្លែងត្រូវតែមានលក្ខណៈមិនស្ម័គ្រចិត្ត

[3570] សេចក្តីសម្រេចឲ្យរួចទោសក្នុងរឿងក្តី *Milošević* កថាខណ្ឌ ៦៨។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥២១។ សាលក្រមក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៧២៣។ សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៥៩៥។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៥៤០, ៥៤៤។ *សូមមើលបន្ថែម* សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣០០។

[3571] សេចក្តីសម្រេចឲ្យរួចទោសក្នុងរឿងក្តី *Milošević* កថាខណ្ឌ ៧៩។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២១៨។ *សូមមើលបន្ថែម* លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ កថាខណ្ឌ ៧(២)(ឃ)។

[3572] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៥០ និងសេចក្តីដកស្រង់ក្នុងសាលក្រមនោះ។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៧៨។ សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣០៤។

[3573] សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣០៩, ៣៣៣។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៦៨៥។

[3574] សាលក្រមក្នុងរឿងក្តី *Popović* កថាខណ្ឌ ៩០០។

[3575] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៤៩៥។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ៣៦៦។ សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣១៩, ៣៣៣។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៧៩, ២៨១-២៨២។ សាលក្រមក្នុងរឿងក្តី *Naletilić & Martinović* កថាខណ្ឌ ៥១៩។ ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(១)(ឃ) ធាតុផ្សំទី

មានន័យថា ប្រជាជនដែលពាក់ព័ន្ធមិនមានការជ្រើសរើសដោយសុទ្ធចិត្តនៅក្នុងការដែលពួកគេផ្លាស់ប្តូរទីកន្លែង[3576] ដែលត្រូវថ្នឹងផ្ទែងនៅក្នុងបរិបទនៃសំណុំរឿងជាក់លាក់ណាមួយ[3577]។ ប្រសិនបើក្រុមណាមួយរត់គេចពីអំពើហិង្សា ឬការធ្វើទុក្ខបុកម្នេញដោយចេតនា[3578] ឬអ្នកជាប់ឃុំឃាំងស្នើផ្លាស់ប្តូរទីកន្លែងដើម្បីរកសេរីភាពចេញផុតពីលក្ខខណ្ឌរស់នៅ ដែលមានលក្ខណៈឃោរឃៅ ឬពីវិន័យពន្ធនាគារដែលមានការបង្ខិតបង្ខំ[3579] ក្នុងករណីនោះពួកគេនឹងមិនអាចមានការជ្រើសរើសដោយសុទ្ធចិត្តបានឡើយ។

984. ច្បាប់អន្តរជាតិអនុញ្ញាតឲ្យមានការផ្លាស់ប្តូរទីកន្លែងដោយមិនស្ម័គ្រចិត្តនៅក្នុងកាលៈទេសៈមានកម្រិតតិចតួចនិងជាក់លាក់ ពោលគឺក្នុងករណីដែលការផ្លាស់ប្តូរទីកន្លែងទាំងនោះបានប្រព្រឹត្តទៅក្នុងបំណងរក្សាសន្តិសុខចំពោះប្រជាជនដែលពាក់ព័ន្ធ ឬដោយហេតុផលយោធាជាចាំបាច់ ពោលគឺដោយមូលហេតុ "ការចាំបាច់ផ្នែកយុទ្ធសាស្ត្រយោធា"[3580] ទោះជាយ៉ាងណាក៏ដោយ សូម្បីតែហេតុផលដែលអាចអនុញ្ញាតសម្រាប់ធ្វើការជម្លៀស គឺគ្រាន់តែអនុញ្ញាតទៅបាននៅក្នុងកាលៈទេសៈចង្អៀត និងរឹតត្បិតជាទីបំផុត៖ "ក្នុងករណីនៃការផ្លាស់ប្តូរប្រជាជនដោយបង្ខំ ដែលមានលក្ខណៈធ្ងន់ធ្ងរ ការធ្វើបែបនេះអាចមានលក្ខណៈស្របច្បាប់ទៅបានតែក្នុងស្ថានភាពធ្ងន់ធ្ងរបំផុត ហើយត្រូវតែជាវិធានការចុងក្រោយតែមួយ ដែលអាចធ្វើទៅបាន"[3581]។ ការផ្លាស់ប្តូរទីកន្លែងរបស់ប្រជាជនមិនមានហេតុផលត្រឹមត្រូវទេ ក្នុងករណីដែលវិបត្តិមនុស្សធម៌ ដែលបណ្តាលឲ្យមានការផ្លាស់ប្តូរទីកន្លែងនោះ គឺជាលទ្ធផលនៃសកម្មភាពមិនស្របច្បាប់របស់ជនជាប់ចោទខ្លួនឯង[3582]។

---

១ និង*ដើងទំព័រលេខ* ១២។ *អនុសញ្ញាក្រុងហ្សឺណែវ* មាត្រា ៣១។ *សេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការអន្តរជាតិកាកបាទក្រហមសម្រាប់អនុសញ្ញាក្រុងហ្សឺណែវ* ជំពូកទី IV ទំព័រ ២១៩-២២០។

[3576] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៤៩៥។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២២៩, ២៣៣។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៧៩។

[3577] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៤៩៥។

[3578] សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥៣០។

[3579] សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២២៩, ២៣៣។

[3580] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៨៤-២៨៥។ សាលក្រមក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៧២៥។ *អនុសញ្ញាក្រុងហ្សឺណែវ* ជំពូកទី IV ទំព័រ ៤៩។

[3581] សាលក្រមក្នុងរឿងក្តី *Simić* កថាខណ្ឌ ១២៥ *ដើងទំព័រលេខ* ២១៨។ *សេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការអន្តរជាតិកាកបាទក្រហមសម្រាប់អនុសញ្ញាក្រុងហ្សឺណែវ ជំពូកទី IV* ទំព័រ ២៨០-២៨១។

[3582] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៥២៥។ សាលដីកាក្នុងរឿងក្តី *Tolimir* កថាខណ្ឌ ១៥៨។

985. ដើម្បីមានហេតុផលទទួលយកបានចំពោះការផ្លាស់ប្តូរទីកន្លែងដោយបង្ខំផ្អែកលើហេតុផល "ការចាំបាច់ផ្នែកយុទ្ធសាស្ត្រយោធា" ការពិចារណាផ្នែកយោធាយ៉ាងសំខាន់លើសលុបត្រូវតែបានកំណត់ នូវ*ការចាំបាច់*។ ការគ្រាន់តែទាញប្រយោជន៍ផ្នែកយោធាមិនមានលក្ខណៈគ្រប់គ្រាន់ឡើយ[3583]។ ទោះជាយ៉ាងណាក៏ដោយ រាល់គោលដៅដែលមានលទ្ធភាពថាមានប្រយោជន៍ មិនប្រាកដថាជាហេតុផលសមរម្យដែលត្រូវបានអនុញ្ញាត។ ឧទាហរណ៍ការជម្លៀសប្រជាជនដើម្បីបម្រើគោលបំណង "ការចាំបាច់ផ្នែកយុទ្ធសាស្ត្រយោធា ដើម្បីរារាំងកុំឲ្យមានការឈ្លបយកការណ៍ ឬដើម្បីកុំឲ្យសត្រូវមានកម្លាំងប្រជាជន" មិនមែនជាហេតុផលសមរម្យឡើយ[3584]។

986. ការជម្លៀសស្របច្បាប់ណាមួយ ដែលបានធ្វើឡើងបម្រើផលប្រយោជន៍សន្តិសុខស៊ីវិល ឬការចាំបាច់ផ្នែកយុទ្ធសាស្ត្រយោធា ត្រូវតែធ្វើឡើងស្របទៅនឹងគោលការណ៍សមាមាត្រ៖ វាត្រូវតែមានលក្ខណៈសមស្របនៅក្នុងការសម្រេចបាននូវមុខនាទីការពាររបស់វា ទោះជាឧបករណ៍ត្រូវតែមានលក្ខណៈគ្រោះថ្នាក់តិចតួចនៅក្នុងការសម្រេចបាននូវលទ្ធផលដែលចង់បាន ហើយត្រូវសមស្របទៅនឹងផលប្រយោជន៍ដែលមានបំណងចង់ការពារ[3585]។ អាស្រ័យហេតុនេះ ទោះបីជាករណីដែលការជម្លៀសត្រូវប្រព្រឹត្តទៅឈរលើមូលហេតុដែលមានការអនុញ្ញាតក៏ដោយ ការជម្លៀសនេះនឹង*ក្លាយទៅជា*មិនស្របច្បាប់នៅពេលដែលប្រជាជនមិនបានអនុញ្ញាតឲ្យត្រឡប់មកទីតាំងរបស់ពួកគេវិញ ក្នុងពេលមួយឲ្យបានលឿនតាមដែលអាចធ្វើទៅបាន[3586]។ នៅក្នុងកំឡុងពេលនៃការជម្លៀសស្របច្បាប់ណាមួយក៏ដោយ ភាគីដែលធ្វើការជម្លៀសត្រូវតែធានាថា ជនដែលត្រូវបានគេជម្លៀស

[3583] សាលក្រមក្នុងរឿងក្តី *Blagojević* កថាខណ្ឌ ៥៩៨។ *ការអត្ថាធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិសម្រាប់អនុសញ្ញាក្រុងហ្សឺណែវ ជំពូកទី IV* ទំព័រ ២៨០។ *ពាក់ព័ន្ធនឹង von Lewinski* ទំព័រ ៥២២ ["សម្រាប់កងទ័ពដែលដកថយ ការបន្សល់ទុកភាពខ្ទេចខ្ទាំ អាចធ្វើឲ្យសត្រូវរបស់ខ្លួនខូចខាតប្រយោជន៍ច្រើនយ៉ាងប្រចក្ស និងធ្វើឲ្យទាហានដែលដកទ័ពថយទទួលបានអត្ថប្រយោជន៍ច្រើនស្មើនឹងការខូចខាតនោះ។ បើសិនជាពាក្យពេចន៍នៅក្នុងមាត្រានេះមានន័យពិតប្រាកដមែននោះ អង្គហេតុនេះតែម្យ៉ាង មិនអាចគ្រប់គ្រាន់សម្រាប់ការធ្វើយុត្តិកម្មឡើយ។ បើសិនជាវាគ្រប់គ្រាន់សម្រាប់ការធ្វើយុត្តិកម្មមែន នោះមាត្រានេះគ្មានន័យអ្វីឡើយ"]។

[3584] សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥២៦។

[3585] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៥០។

[3586] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៥០។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៥២៤។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៨៤។ សាលក្រមក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៧២៥។ សាលក្រមក្នុងរឿងក្តី *Blagojević* កថាខណ្ឌ ៥៩៧។ អនុសញ្ញាក្រុងហ្សឺណែវ ជំពូកទី IV មាត្រា ៤៩។ *សេចក្តីអត្ថាធិប្បាយរបស់គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិសម្រាប់អនុសញ្ញាក្រុងហ្សឺណែវ ជំពូកទី IV* ទំព័រ ២៨០-២៨១។

នោះបានទទួលត្រឹមត្រូវដូចជាការស្នាក់នៅ អនាម័យ សុខភាព សុវត្ថិភាព ការផ្គត់ផ្គង់អាហារ ហើយតាមលទ្ធភាពជាក់ស្តែងបំផុត មិនគួរមានការបំបែកបំបាក់គ្រួសារ[3587]។

987. ធាតុអត្តនោម័ត្តគ្រាន់តែតម្រូវថា ការផ្លាស់ប្តូរទីតាំងដោយបង្ខំធ្វើឡើងដោយចេតនា[3588]។ វាមិនតម្រូវឲ្យមានចេតនាផ្លាស់ប្តូរជាអចិន្ត្រៃយ៍ឲ្យប្រជាជនទៅនៅម្ខាងទៀតនៃព្រំដែន[3589]។

<u>ការដាក់ពន្ធនាគារ</u>

988. ការដាក់ពន្ធនាគារបានទទួលស្គាល់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិយោងតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិគិតមកត្រឹមឆ្នាំ១៩៧៥[3590] លើសពីនេះទៀត យីម ទិត្យ អាចរំពឹងមើលឃើញ និងអាចយល់ដឹងបានថា គាត់អាចនឹងត្រូវផ្តន្ទាទោសចំពោះអំពើដែលបង្កើតបានជាការដាក់ពន្ធនាគារនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3591]។

989. ធាតុសត្យានុម័ត្តនៃការដាក់ពន្ធនាគារ[3592] តម្រូវថាបុគ្គលម្នាក់ត្រូវបានដកហូតនូវសេរីភាពរបស់គាត់ដោយអត្តនោម័ត្ត ពោលគឺដោយមិនបានឈរលើផ្លូវច្បាប់ត្រឹមត្រូវ និងដោយគ្មាននីតិវិធីធានា

[3587] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៥០។ សាលក្រមក្នុងរឿងក្តី *Blagojević* កថាខណ្ឌ ៥៩៩។

[3588] សាលក្រមក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៧២៦ បានតម្កល់សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣០៤។ *សូមមើលបន្ថែម* សេចក្តីសម្រេចឲ្យរួចទោសក្នុងរឿងក្តី *Milošević* កថាខណ្ឌ ៧៨។

[3589] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៧៨, ៣០៦-៣០៧។ សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣០៤។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២០៦។ ដូចអង្គជំនុំជម្រះសាលាឧទ្ធរណ៍បានអនុវត្តក្នុងរឿងក្តី *Stakić* ដែរ (កថាខណ្ឌ ៣០៦) ការិយាល័យសហព្រះរាជ្ញាកត់សម្គាល់ថា អនុសញ្ញាក្រុងហ្សឺណែវ ផ្នែកទី IV មាត្រា ៤៩ ពុំមានអ្វី ដើម្បីបញ្ជាក់ថា ការផ្ទេរត្រូវតែធ្វើឡើងដោយចេតនាថា និរទេសជននឹងមិនត្រឡប់មកវិញឡើយ។

[3590] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤៧។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣១៧-៣២៧, ៣៣២ និងសេចក្តីដកស្រង់នៅក្នុងសាលដីកានោះ។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤ *ជើងទំព័រលេខ* ៥១៩០។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១០៩ និងសេចក្តីដកស្រង់នៅក្នុងសាលក្រមនោះ។

[3591] សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣២៨-៣៣២។

[3592] ឈ្មោះបែបពណ៌នាបន្ថែមសម្រាប់ឧក្រិដ្ឋកម្មនេះ គឺ៖ "ការដាក់ក្នុងមន្ទីរឃុំឃាំងដោយគ្មានដំណើរការសមស្រប" ឬដូចអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវីបានបញ្ជាក់នៅក្នុងឱកាសជាច្រើន គឺ៖ "ការដាក់

យុត្តិធម៌តាមផ្លូវតុលាការ[3593]។ ករណីច្បាប់ជាតិត្រូវបានយកមកសំអាង បញ្ញត្តិពាក់ព័ន្ធនានាមិនត្រូវរំលោភទៅលើច្បាប់អន្តរជាតិ[3594]។ សភាពការណ៍នៃការប្រកាសអាសន្នមិនអាចជាហេតុផលសមរម្យក្នុងការដាក់ពន្ធនាគារដោយអត្តនោម័ត្ត[3595]។ ថាតើបុគ្គលម្នាក់ត្រូវបានដកហូតសិទ្ធិសេរីភាពរបស់គាត់ ឬយ៉ាងណា នឹងអាស្រ័យទៅលើកាលៈទេសៈនៃករណីជាក់លាក់នីមួយៗ ហើយត្រូវ

ក្នុងមន្ទីរឃុំឃាំងតាមទំនើងចិត្ត"៖ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៤៧១។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១១៦ ["ការដាក់ក្នុងមន្ទីរឃុំឃាំង] គួរត្រូវបានយល់ថាជាការដាក់ក្នុងមន្ទីរឃុំឃាំងតាមទំនើងចិត្ត ពោលគឺការដកហូតសេរីភាពរបស់បុគ្គលម្នាក់ៗដោយគ្មានដំណើរការសមស្របតាមច្បាប់"]។ *សូមមើល* សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥១៩។

[3593] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤៧-៣៤៨។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៣។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១១៦។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១១៣-១១៥។

[3594] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៤៨។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១១៤។ សាលក្រមក្នុងរឿងក្តី *Ntagerura* កថាខណ្ឌ ៧០២។

[3595] យោបល់សន្និដ្ឋានទូទៅលេខ២៨ លើមាត្រា ៤ កថាខណ្ឌ ១១ របស់គណៈកម្មាធិការអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ["ទោះក្នុងកាលៈទេសៈណាក៏ដោយ រដ្ឋភាគីមិនអាចធ្វើនិរាករណ៍មាត្រា ៤ នៃកតិកាសញ្ញានេះ ជាយុត្តិកម្មសម្រាប់ការប្រព្រឹត្តបំពានច្បាប់មនុស្សធម៌ ឬបទដ្ឋានដាច់ខាតនៃច្បាប់អន្តរជាតិឡើយ ឧទាហរណ៍ [...] តាមរយៈការដកហូតសេរីភាព ឬតាមការប្រព្រឹត្តខុសពីគោលការណ៍ជាមូលដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ រួមទាំងសច្ចធារណ៍និរទោស"] ១២ ["ប្រសិនបើសកម្មភាពដែលត្រូវបានអនុវត្តក្រោមអាជ្ញាធររបស់រដ្ឋមួយ បង្កើតនូវមូលដ្ឋានសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលណាម្នាក់ចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយបុគ្គលដែលបានចូលរួមក្នុងសកម្មភាពនោះ មាត្រា ៤នៃកតិកាសញ្ញានេះមិនអាចត្រូវបានប្រើជាយុត្តិកម្មថា សភាពគ្រាអាសន្នបានអនុគ្រោះឲ្យរដ្ឋនោះរួចផុតពីការទទួលខុសត្រូវរបស់ខ្លួនទាក់ទងនឹងការប្រព្រឹត្តដែលឡើយ"]។ សាលក្រមក្នុងរឿងក្តី *Aksoy តទល់នឹង ប្រទេសទួរគី* កថាខណ្ឌ ៦៥-៨៧ [ទោះបីជាសកម្មភាពអេរវកម្មរបស់គណៈបក្សពលករឃើឌីស្តានៅភូមិភាគអាគ្នេយ៍នៃប្រទេសទួរគី ដោយរកឃើញថា គណបក្សពលករឃើឌីស្តានបានបង្កើតដោយឥតសង្ស័យនូវ "គ្រាអាសន្នជាសាធារណៈដែលគម្រាមកំហែងដល់អាយុជីវិតរបស់ប្រទេសជាតិ" នៅក្នុងតំបន់នោះ ក៏ប្រទេសទួរគីនៅតែគ្មានយុត្តិកម្មក្នុងការឃុំឃាំងជនសង្ស័យអេរវកម្មរយៈពេល ១៤ថ្ងៃ ដោយគ្មានកិច្ចអន្តរាគមន៍តាមផ្លូវតុលាការដែរ។ តុលាការសិទ្ធិមនុស្សអឺរ៉ុបបានបញ្ជាក់បំភ្លឺថា ការដាក់ក្នុងមន្ទីរឃុំឃាំងណាមួយដែលខ្វះដំណើរការសមស្រប "ដែលត្រូវបានទាមទារយ៉ាងតឹងរ៉ឹងដោយការតម្រូវរបស់ស្ថានភាព" មិនអាចធ្វើយុត្តិកម្មបានឡើយ]។ *សូមមើល* សំណុំរឿង *Nuray Şen តទល់នឹង ប្រទេសទួរគី* [ការឈានដល់សេចក្តីសន្និដ្ឋានដូចគ្នា ផ្អែកលើការឃុំខ្លួនតាមទំនើងចិត្តរយៈពេល ១១ថ្ងៃ]។

តែពិចារណាទៅលើកត្តាមួយចំនួនរួមមានទាំងប្រភេទ ផេះវេលា ផលវិបាក និងលក្ខណៈនៃការចាត់វិធានការទាំងនោះ ដែលអាចចោទបានថាជាការដកហូតសិទ្ធិសេរីភាព[3596]។

990. នៅក្នុងការកំណត់ថាតើការសំអាងហេតុ និងវិធីក្នុងការដកហូតជាដំបូងនៃសិទ្ធិសេរីភាព ត្រឹមត្រូវស្របច្បាប់ឬយ៉ាងណា តុលាការអាចពិចារណាលើកត្តានានារួមទាំងពិចារណាថាតើ៖ (i) ការចាប់ខ្លួនបានផ្អែកលើដីកាត្រឹមត្រូវឬយ៉ាងណា[3597] (ii) ជនជាប់ឃុំត្រូវបានជូនដំណឹងនៅពេលចាប់ខ្លួនអំពីមូលហេតុនៃការចាប់ខ្លួនឬយ៉ាងណា[3598] (iii) ជនជាប់ឃុំត្រូវបានជូនដំណឹងភ្លាមៗដោយពិស្តារអំពីបទចោទប្រឆាំងនឹងគាត់ និង/ឬ ដែលបានចោទជាផ្លូវការ[3599] (iv) ជនជាប់ឃុំត្រូវបានជូនដំណឹងអំពីសិទ្ធិខាងនីតិវិធីរបស់គាត់[3600] រួមមានទាំងឱកាសមានមេធាវី[3601] ហើយ (v) ជនជាប់ឃុំត្រូវបាននាំភ្លាមៗមកចំពោះមុខជនមានសមត្ថកិច្ចស្របច្បាប់ ដើម្បីចាត់ការតាមផ្លូវតុលាការ (ហើយបុគ្គលនោះជាបុគ្គលឯករាជ្យ មិនលម្អៀង និងសត្យានុម័ត្ត)[3602]។ ជនជាប់ឃុំមានសិទ្ធិទទួលបាននីតិវិធីនានាដែលក្នុងនោះភាពស្របច្បាប់នៃការឃុំឃាំងត្រូវសម្រេចយ៉ាងឆាប់រហ័សដោយតុលាការមួយ ហើយត្រូវដោះលែងប្រសិនបើតុលាការសម្រេចថាការឃុំឃាំងនោះមិនស្របច្បាប់[3603]។ គាត់ក៏មានសិទ្ធិទទួលបានផងដែរនូវសវនាការជាសាធារណៈ និងត្រឹមត្រូវយុត្តិធម៌នៅក្នុងកំឡុងពេលសមរម្ម បើមិនដូច្នោះទេនឹងត្រូវបានដោះលែង[3604] ហើយទទួលបាននូវការកំណត់

[3596] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៤៧៣ *ដកស្រង់* សាលក្រមក្នុងរឿងក្តី *Nada* កថាខណ្ឌ ២២៥។ សាលក្រមក្នុងរឿងក្តី *Guzzardi* កថាខណ្ឌ ៩២។

[3597] សាលក្រមក្នុងរឿងក្តី *Ntagerura* កថាខណ្ឌ ៧០២។

[3598] សាលក្រមក្នុងរឿងក្តី *Ntagerura* កថាខណ្ឌ ៧០២។ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩(២)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៥(២)។

[3599] សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១២១។ សាលក្រមក្នុងរឿងក្តី *Ntagerura* កថាខណ្ឌ ៧០២។ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩(២)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៥(២) មាត្រា ៦(៣)(ក)។

[3600] សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១២១។ សាលក្រមក្នុងរឿងក្តី *Ntagerura* កថាខណ្ឌ ៧០២។

[3601] អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៥(២) មាត្រា ៦(៣)(គ)។

[3602] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩(៣)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៥(៣)-(៤)។ សំណុំរឿង *Kulomin* *តទល់នឹងប្រទេសហុងហ្គារី* កថាខណ្ឌ ១១.៣។

[3603] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩(៤)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៥(៤)។

[3604] អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៥(៣) ៦(១)។ ។ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៩(៣)។

ថាគ្មានទោសរហូតដល់ពេលសវនាការតុលាការសម្រេចថាមានទោស[3605]។ ដូច្នេះការគ្រាន់តែ "សង្ស័យ" ថា ជនណាម្នាក់អាចនឹងពាក់ព័ន្ធនៅក្នុងឧក្រិដ្ឋកម្មណាមួយរួមទាំងអំពើក្បត់ជាតិ មិនបានបំពេញលក្ខខណ្ឌច្បាប់គ្រប់គ្រាន់ក្នុងការសំអាងឃុំឃាំងមនុស្សដោយមិនឆ្លងកាត់នីតិវិធីតុលាការ-ដោយគ្មានការចោទប្រកាន់ ដោយមិនមានការពិនិត្យតាមផ្លូវតុលាការទៅលើភ័ស្តុតាង គ្មានមេធាវីការពារក្តី និងដោយគ្មានសិទ្ធិចូលរួមសវនាការណាមួយ។

991. ចំពោះធាតុអត្តនោម័ត្ត ត្រូវតែបង្ហាញថា ជនដៃដល់មានចេតនាដកហូតជីវិតអត្តនោម័ត្តនូវសេរីភាពរបស់បុគ្គល ឬថា ជនដៃដល់បានប្រព្រឹត្តដោយមានការដឹងឮសមហេតុផលថា អំពើរបស់គាត់អាចនឹងបណ្តាលឲ្យមានការដកហូតជីវិតអត្តនោម័ត្តនូវសេរីភាពផ្លូវកាយ[3606]។

<u>ការធ្វើទារុណកម្ម</u>

992. ឧក្រិដ្ឋកម្មនៃការធ្វើទារុណកម្មត្រូវបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិគិតមកត្រឹមឆ្នាំ១៩៧៥[3607] ហើយក៏ជាឧក្រិដ្ឋកម្មមួយយោងតាមច្បាប់កម្ពុជានៅពេលនោះដែរ[3608]។ យើង ទិព្ធ អាចរំពឹងមើលឃើញ និងអាចយល់ដឹងបានថា គាត់អាចនឹងត្រូវផ្តន្ទាទោសចំពោះអំពើដែលបង្កើតបានជាទារុណកម្មនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3609]។

993. ទាំងអង្គបុរេជំនុំជម្រះ ទាំងតុលាការកំពូល បានកំណត់ថា និយមន័យនិងធាតុផ្សំនៃទារុណកម្ម ដែលមាននៅក្នុងសេចក្តីប្រកាសស្តីអំពីទារុណកម្មឆ្នាំ១៩៧៥ បានឆ្លុះបញ្ចាំងនៅក្នុងច្បាប់ទំនៀមទម្លាប់

[3605] អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១២(២)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា៦(២)។

[3606] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥០។ សំណុំរឿង ០០៤ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៧០(ខ)។ សាលក្រមក្នុងរឿងក្តី *Simić* កថាខណ្ឌ ៦៤។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១១៥។

[3607] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៨៨, ១៩៦, ២០៥-២០៦។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៤២-៣៥១ និងសេចក្តីដកស្រង់ក្នុងសាលដីកានោះ។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤ *ដើងទំព័រលេខ* ៥១៩១។

[3608] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ៥០០។

[3609] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២១១-២១២។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥២-៣៥៦។

អន្តរជាតិនៅឆ្នាំ១៩៧៥[3610] លើសពីនេះទៀត គិតមកត្រឹមឆ្នាំ១៩៧៥ ការហាមឃាត់អំពើទារុណកម្មគឺជាគោលការណ៍អាជ្ញាបញ្ជា[3611] ដែលការលើកលែងមិនត្រូវបានអនុញ្ញាតទោះស្ថិតនៅក្រោមកាលៈទេសៈណាក៏ដោយ រួមទាំងការប្រកាសអាសន្នជាសាធារណៈ ឬក្នុងនាមសន្តិសុខជាតិក៏ដោយ[3612]។

994. ធាតុសត្យានុម័ត្តនៃទារុណកម្មតម្រូវឲ្យមានអំពើសកម្ម ឬអកម្ម បង្កជាការឈឺចាប់ ឬការទទួលរងការលំបាកធ្ងន់ធ្ងរ ក្នុងរូបភាពផ្លូវការ ឬផ្លូវចិត្ត[3613]។ នៅក្នុងការកំណត់ថាតើអំពើសកម្ម ឬអកម្ម

[3610] សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥៥។ សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៩៦, ២០៥។

[3611] សាលក្រមក្នុងរឿងក្តី *ប៉ែលហ្សិក តទល់នឹង សេណេហ្គាល់* កថាខណ្ឌ ៩៩ ដកស្រង់ឧបករណ៍សិទ្ធិមនុស្ស និងច្បាប់មនុស្ស ធម៌អន្តរជាតិផ្តាច់មុខ ដែលត្រូវបានបញ្ចប់មុនឆ្នាំ១៩៧៥។ *សូមមើល* សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (ឆ្នាំ១៩៤៨) មាត្រា៥។ អនុសញ្ញាក្រុងហ្ស៊ីណែវ ផ្នែកទី I (ឆ្នាំ១៩៤៩) មាត្រា៣, ១២, ៥០។ អនុសញ្ញាក្រុងហ្ស៊ីណែវ ផ្នែកទី II (ឆ្នាំ១៩៤៩) មាត្រា៣, ១២, ៥១។ អនុសញ្ញាក្រុងហ្ស៊ីណែវ ផ្នែកទី III (ឆ្នាំ១៩៤៩) មាត្រា៣, ១៧, ៨៧, ១៣០។ អនុសញ្ញាក្រុងហ្ស៊ីណែវ ផ្នែកទី IV (ឆ្នាំ១៩៤៩) មាត្រា៣, ៣២, ១៤៧។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ឆ្នាំ១៩៦៦) មាត្រា៧។ សេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៧៥។ *សូមមើលបន្ថែម* អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប (ឆ្នាំ១៩៥០) មាត្រា៣។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអាមេរិក (ឆ្នាំ១៩៦៩) មាត្រា៥(២)។ សាលក្រមក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ១៤៣-១៤៦។

[3612] មាត្រា៣ នៃសេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៧៥ ហាមឃាត់ដាច់ខាតមិនឲ្យមានបដិប្ដញ្ញត្តិពីការហាមឃាត់ប្រឆាំងនឹងអំពើប្រល័យពូជសាសន៍៖ "រដ្ឋភាគីមិនអាចអនុញ្ញាត ឬអត់ឱនចំពោះការប្រព្រឹត្ត ឬទណ្ឌកម្មដទៃទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប។ កាលៈទេសៈពិសេស ដូចជាស្ថានភាពសង្គ្រាម ឬការគម្រាមកំហែងពីសង្គ្រាម អស្ថេរភាពនយោបាយផ្ទៃក្នុង ឬគ្រាអាសន្នសាធារណៈផ្សេងទៀត មិនអាចយកមកប្រើជាយុត្តិកម្មសម្រាប់អំពើទារុណកម្ម ឬការប្រព្រឹត្ត ឬទណ្ឌកម្មដទៃទៀត ដែលឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាប"។ ឧបករណ៍អន្តរជាតិដទៃទៀត ដែលមានបញ្ញត្តិហាមប្រាមដូចគ្នា រួមមានអនុសញ្ញាប្រឆាំងទារុណកម្មឆ្នាំ១៩៨៤ មាត្រា២(២)។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា៧, ៤(២)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា៧, ៤(២)។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអាមេរិក មាត្រា២៧(២)។ *សូមមើល* សាលក្រមក្នុងរឿងក្តី *ប្រទេសអៀកឡង់ តទល់នឹង ចក្រភពអង់គ្លេស* កថាខណ្ឌ ១៦៣, ["អនុសញ្ញាហាមឃាត់ *ជាដាច់ខាត*នូវអំពើទារុណកម្ម និងការប្រព្រឹត្ត ឬទណ្ឌកម្ម ដែលអមនុស្សធម៌ ឬបន្ថោកបន្ទាប" *ដោយមិនគិតពីការប្រព្រឹត្តរបស់ជនរងគ្រោះ*។ ខុសពីខកំណត់សិទ្ធិរបស់ភាគី [...] មាត្រា៣ [...] មិនបង្កើតបញ្ញត្តិសម្រាប់ការលើកលែង និងអនុលោមតាមមាត្រា១៥ កថាខណ្ឌ ២ [...] មិនអាចមានបដិបញ្ញត្តិពីមាត្រានោះឡើយ *សូម្បីតែក្នុងករណីគ្រាអាសន្នសាធារណៈដែលគម្រាមកំហែងដល់អាយុជីវិតរបស់ប្រទេសជាតិ*"។ (*បន្ថែមពាក្យសង្កត់ន័យ*)]។ សាលក្រមក្នុងរឿងក្តី *Ilaşcu និងអ្នកដទៃទៀត តទល់នឹង ប្រទេសម៉ុលដូវ៉ា និងប្រទេសរុស្ស៊ី* កថាខណ្ឌ ៤២៤។

[3613] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៩១-១៩២, ១៩៥-១៩៦, ២០១, ២០៥។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ

បង្កើតបានជាការឈឺចាប់ ឬការលំបាកធ្ងន់ធ្ងរ បានឬយ៉ាងណា ចាំបាច់ត្រូវពិចារណាកត្តាអត្តនោម័ត្ត និងសត្យានុម័ត្តទាំងអស់[3614]។ លើសពីនេះទៀត សារជាតិនិងបរិបទនៃការបង្ករឲ្យមានការឈឺចាប់ ការគិតទុកជាមុន និងការរៀបចំជាស្ថាប័នចាត់តាំងនៃការធ្វើបាប លក្ខខណ្ឌផ្លូវកាយនៃជនរងគ្រោះ លក្ខណៈនិងវិធីសាស្ត្រដែលបានប្រើ និងឋានៈទាបរបស់ជនរងគ្រោះ ទាំងអស់នេះគឺជាកត្តាពាក់ព័ន្ធ[3615]។ ក្នុងករណីដែលបុគ្គលម្នាក់ត្រូវបានធ្វើបាបក្នុងរយៈពេលយូរ ឬគាត់ត្រូវបានដាក់នៅក្នុងទម្រង់នៃការធ្វើបាបផ្សេងៗ ឬដដែលៗ នោះភាពធ្ងន់ធ្ងរនៃអំពើគួរតែត្រូវថ្លឹងថ្លែងសរុបជារួម[3616]។ ផលវិបាកនៃអំពើសកម្ម ឬអកម្មមិនចាំបាច់ត្រូវតែអាចមើលឃើញនៅលើជនរងគ្រោះនោះទេ[3617] ហើយក៏មិនចាំបាច់ត្រូវមានលក្ខខណ្ឌថា របួសស្នាមត្រូវតែមានលក្ខណៈអចិន្ត្រៃយ៍នោះដែរ[3618]។

995. អំពើទាំងឡាយដែលមានលក្ខណៈធ្ងន់ធ្ងរគ្រប់គ្រាន់ក្នុងការបង្កើតបានទ្ទូរអំពើឧក្រិដ្ឋកម្ម អាចកើតចេញមកពីបណ្តាលក្ខខណ្ឌដាក់លើអ្នកទោសហើយរួមមានការវាយដំ អំពើហិង្សាផ្លូវភេទ ការឃាត់មិនឲ្យដេកយៈពេលយូរ អាហារ អនាម័យ និងជំនួសផ្នែកវេជ្ជសាស្ត្រ ការដាក់នៅក្នុងសភាពមិនប្រាកដប្រជាជាប្រចាំ ការដាក់នៅក្នុងសភាពដូចស្លាប់ និងការគំរាមធ្វើទារុណកម្ម រំលោភ ឬបង្ករៀសនកម្ម ឬសម្លាប់សាច់ញាតិ[3619]។ ការរស់នៅក្នុងសភាពខ្វាយខ្វល់ និងមិនប្រាកដប្រជាជាប្រចាំ

៣៥៣-៣៥៤។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤០៩។ សេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៨៤ មាត្រា១។ សាលដីកាក្នុងរឿងក្តី *Kunarac* ថាខណ្ឌ ១៤២-១៤៤, ១៤៩។ សាលក្រមក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ៤៦៨។ សាលក្រមក្នុងរឿងក្តី *Ntagerura* កថាខណ្ឌ ៧០៣។ ធាតុផ្សំនៃបទឧក្រិដ្ឋនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៧(១)(ច) ធាតុផ្សំទី១។ *សូមមើលផងដែរ* អនុសញ្ញាប្រឆាំងទារុណកម្មឆ្នាំ១៩៨៤ មាត្រា១។

[3614] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៥។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១៤៣។

[3615] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៥។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៨២។

[3616] សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៨២។

[3617] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៥។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១៥០។

[3618] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៥។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១៤៨។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤៨៤។

[3619] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៥។ សាលក្រមក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ៤៦៧។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១៥១។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថា

ដែលបណ្តាលមកពីការរំលោភ និងការដាក់កំហិតផ្លូវកាយ បង្កើតបានជាការលំបាកផ្លូវចិត្ត ដែលកំណត់បានជាអំពើទារុណកម្ម[3620]។ ដូចគ្នានេះដែរ ការគំរាមកំហែងដែលអាចជឿបានថា នឹងមានការធ្វើទារុណកម្មផ្លូវកាយ ការបង្ករាងកាយ ឬការសម្លាប់ជនរងគ្រោះ បង្កើតបានជាទារុណកម្មផ្លូវចិត្ត[3621]។ លើសពីនេះទៀតបុគ្គលម្នាក់អាចទទួលរងរាងកាយកម្មផ្លូវចិត្តធ្ងន់ធ្ងរ ដោយសារបានឃើញអំពើប្រឆាំងនឹងអ្នកផ្សេង[3622]។ អំពើជាក់លាក់មួយចំនួនត្រូវពិចារណាទៅតាមសារជាតិរបស់វាក្នុងការកំណត់អំពីការឈឺចាប់ និងការលំបាកធ្ងន់ធ្ងររួមមានទាំងការរំលោភសេពសន្ថវ:[3623] អំពើហិង្សាផ្លូវភេទ[3624] និងការធ្វើឲ្យពិការអវ:យវ:[3625]។

996. ទោះជាយោងតាមយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី/តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា ជនដៃដល់មិនចាំបាច់បានប្រព្រឹត្តក្នុងតួនាទីជាផ្លូវការក៏ដោយ[3626] តុលាការកំពូលបានសម្រេចថា និយមន័យនៃអំពើទារុណកម្មដូចដែលមានក្នុងសេចក្តីប្រកាសស្តីអំពីអំពើទារុណកម្មឆ្នាំ១៩៧៥ រួមមានទាំងលក្ខខណ្ឌស្តីអំពីមន្ត្រីសាធារណៈ ថាបានឆ្ពុះបញ្ជាំងពីច្បាប់

ខណ្ឌ ២៥៥។ *សូមមើល* របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីអំពើទារុណកម្ម ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៨៦ ឯកសារលេខ E/CN.4/1986/15 របស់អង្គការសហប្រជាជាតិ កថាខណ្ឌ ១១៩។ សាលក្រមក្នុងរឿងក្តី *Akkoç តទល់នឹង ប្រទេសទួរគី* កថាខណ្ឌ ១១៦-១១៧ *ផង*។ រឿងក្តី *Maritza Urrutia តទល់នឹង ប្រទេសហ្គាតេម៉ាឡា* កថាខណ្ឌ ៥៨, ៨៥, ៩៤។ សាលក្រមក្នុងរឿងក្តី *Ilaşcu និងអ្នកដទៃទៀត តទល់នឹង ប្រទេសម៉ុលដូវ៉ា និងប្រទេសរុស្ស៊ី* កថាខណ្ឌ ៤៣៥, ៤៤០។

[3620] សាលក្រមក្នុងរឿងក្តី *Hajrulahu* កថាខណ្ឌ ១០១-១០២។

[3621] *សូមមើលឧទាហរណ៍* រឿងក្តី *Estrella តទល់នឹង ប្រទេសអ៊ីយូហ្គាយ* កថាខណ្ឌ ១.៦, ៨.៣, ១០។ រឿងក្តី *Maritza Urrutia តទល់នឹង ប្រទេសហ្គាតេម៉ាឡា* កថាខណ្ឌ ៥៨.៦, ៨៥, ៩៤។

[3622] សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៥៣។

[3623] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៥។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១៥០-១៥១។

[3624] សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១៥០។

[3625] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៥។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១៤៤។

[3626] សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១៤៨។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២៨៤។ សាលដីកាក្នុងរឿងក្តី *Semanza* កថាខណ្ឌ ២៤៨, ២៨៦។

ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥[3627]។ យោងតាមនិយមន័យនេះ អំពើសកម្ម ឬអកម្ម ត្រូវតែបានប្រព្រឹត្ត "ដោយ ឬតាមរយៈការញុះញង់របស់មន្ត្រីសាធារណៈមួយរូបណាមួយ"[3628]។

997. ស្តីអំពីធាតុសត្យានុម័ត្ត ការឈឺចាប់ និងការលំបាកដែលបង្កើតបានជាអំពើទារុណកម្មត្រូវតែបានបង្កឡើងដោយចេតនា[3629]។ អំពើសកម្ម ឬអកម្មក៏ត្រូវតែបានប្រព្រឹត្តផងដែរក្នុងបំណងទទួលបានលទ្ធផល ឬគោលបំណងជាក់លាក់។ គោលបំណងទាំងនោះរួមមានទទួលព័ត៌មាន ឬចម្លើយ សារភាព ការដាក់ទណ្ឌកម្ម ការបង្ខិតបង្ខំ ឬការគំរាមកំហែង ឬការវើសអើង ឈរលើហេតុផលណាក៏ដោយឲ្យតែប្រឆាំងនឹងជនរងគ្រោះ ឬជនទី ៣ ណាម្នាក់[3630]។ គោលបំណងទាំងនេះមិន

[3627] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៩១-១៩២, ១៩៥-១៩៧, ២០៥។ សេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៨៤ មាត្រា១។

[3628] បញ្ហានេះមិនពាក់ព័ន្ធនឹងការវិនិច្ឆ័យនៅក្នុងសំណុំរឿងបច្ចុប្បន្នទេ ដោយសារអំពើទារុណកម្មទាំងអស់ដែលត្រូវបានចោទប្រកាន់ ត្រូវបានអនុវត្តដោយមន្ត្រី ឬទាហានផ្ទើរជើងនៃរបបនោះ។ ទោះជាយ៉ាងនេះក្តី ជាចំណុចច្បាប់ ខណៈដែលការសំដៅដល់អ្នកធ្វើទារុណកម្មជាមន្ត្រីរបស់រដ្ឋ ផ្ទុះបញ្ចាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់រដ្ឋ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា តុលាការអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និងតុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា បានបដិសេធយ៉ាងត្រឹមត្រូវនូវលក្ខខណ្ឌតម្រូវសាធារណៈជាផ្លូវការនៅក្នុងច្បាប់*ព្រហ្មទណ្ឌ* ទំនៀមទម្លាប់អន្តរជាតិ។ សេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៧៥ និងក្រោយមកអនុសញ្ញាប្រឆាំងទារុណកម្មឆ្នាំ១៩៨៤ ក៏ត្រូវបានលើកឡើងចំពោះរដ្ឋទាំងឡាយ និងព្យាយាមធ្វើនិយតកម្មលើការប្រព្រឹត្តរបស់រដ្ឋទាំងនោះផងដែរ។ នៅក្នុងបរិបទនោះ វាអាចឲ្យយើងយល់បានថាឧបករណ៍ទាំងនេះលើកឡើងអំពីទង្វើរបស់បុគ្គលដែលបំពេញតួនាទីក្នុងជាមន្ត្រីផ្លូវការ ពីព្រោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំមានហេតុផលត្រូវបែងចែកបុគ្គលដែលជាមន្ត្រីសាធារណៈ ពីអ្នកដទៃទៀតដែលមិនមែនជាមន្ត្រីសាធារណៈ តែបានប្រព្រឹត្តិអំពើដូចគ្នា ដោយចេតនាដូចគ្នា និងធ្វើឲ្យមានផលវិបាកដូចគ្នា ដល់ជនរងគ្រោះ ដែលការឈឺចាប់របស់ខ្លួនពិបាកនឹងសម្រួល ដោយដឹងថា បុគ្គលដែលជាអ្នកប្រព្រឹត្តនោះ មិនមែនជាមន្ត្រីសាធារណៈ។

[3629] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៩១-១៩២, ១៩៥-១៩៦, ២០១, ២០៥។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៨។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៣។ សេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៨៤ មាត្រា១។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៧៩។ សាលក្រមក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ១៦២។

[3630] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៩២, ២០៥។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៦។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៥៥។ សេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៨៤ មាត្រា១។ អនុសញ្ញាប្រឆាំងទារុណកម្មឆ្នាំ១៩៨៤ មាត្រា១។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១៤២, ១៤៤។ សាលក្រមក្នុងរឿងក្តី *Ntagerura* កថាខណ្ឌ ៧០៣។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា និយមន័យនៃទារុណកម្ម ដែលបានកំណត់នៅក្នុងសេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៧៥ ផ្ទុះ

បង្កើតបានជាបញ្ហីមួយពេញលេញនោះទេ ហើយផ្ទុយមកវិញ គ្រាន់តែមានលក្ខណៈជាតំណាង[3631] ។ មិនមានលក្ខខណ្ឌតម្រូវថា អំពើនោះបានប្រព្រឹត្តដាច់ដោយឡែកសម្រាប់តែបម្រើគោលបំណងណាមួយពិសេសដែលបានហាមឃាត់នោះទេ៖ គោលបំណងនោះត្រូវតែជា "ផ្នែកមួយនៃគោលបំណងពីក្រោយអំពើនោះ ហើយវាមិនចាំបាច់ជាគោលបំណងធំ ឬគោលបំណងតែមួយនោះទេ"[3632] ។

ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ពួជសាសន៍ ឬសាសនា

998. ការធ្វើទុក្ខបុកម្នេញ ដែលជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិគិតមកត្រឹមឆ្នាំ១៩៧៥[3633] ។ យ៉ឹម ទិត្យ អាចរំពឹងមើលឃើញ និងអាចយល់ដឹងបានគាត់អាចនឹងត្រូវផ្តន្ទាទោសចំពោះអំពើដែលបង្កើតបានជាការធ្វើទុក្ខបុកម្នេញនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3634] ។

បញ្ជាំងពីច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥ និងបានគូសបញ្ជាក់ពីខចែងពីគោលបំណងចង្អៀត ដែលលុបចោលការយោងដ៏ច្បាស់លាស់ទៅលើហេតុផលនៃការរើសអើង ដែលមានចែងនៅក្នុងអនុសញ្ញាប្រឆាំងទារុណកម្មឆ្នាំ១៩៨៤ (សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៩២) ក៏ដោយ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ខចែងពីគោលបំណងនៅក្នុងសេចក្តីប្រកាសស្តីពីអំពើទារុណកម្មឆ្នាំ១៩៧៥ មានលក្ខណៈជានិមិត្តរូប មិនមានលក្ខណៈពេញលេញឡើយ (សាលក្រមក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ៤៧០-៤៧២) ហើយដូច្នេះ ខនេះមិនកើតមុនអំពើសកម្ម ឬអកម្ម ដែលត្រូវបានធ្វើឡើងផ្អែកលើមូលហេតុនៃការរើសអើង។

[3631] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៦។ សាលក្រមក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ៤៧០-៤៧២។

[3632] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៦។ សាលក្រមក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ៤៨៦។

[3633] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២១៦-២២៥ និងសេចក្តីដកស្រង់ក្នុងសាលដីកានោះ។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧៤។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤ *ដើងទំព័រលេខ* ៥១៩៣។

[3634] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៦១, ២៧៩-២៨០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២៦។ ការធ្វើទុក្ខបុកម្នេញខាងសាសន៍ ជាបទឧក្រិដ្ឋមួយដែលមានចែងក្នុងច្បាប់កម្ពុជាឆ្នាំ១៩៧៥។ *សូមមើល* ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា២០៩-២១០។

999. ធាតុសត្យានុម័ត្តនៃការធ្វើទុក្ខបុកម្នេញ ជាអំពើសកម្ម ឬអកម្ម ដែលមានការរើសអើងនៅក្នុងអង្គហេតុ ហើយបានបដិសេធ ឬរំលោភទៅលើសិទ្ធិជាមូលដ្ឋាន ដែលចែងនៅក្នុងច្បាប់ទំនៀមទម្លាប់ ឬសន្ធិសញ្ញាអន្តរជាតិ[3635]។

អំពើសកម្ម ឬអកម្មដែលបដិសេធ ឬរំលោភលើសិទ្ធិជាមូលដ្ឋាន

1000. "អំពើធ្វើទុក្ខបុកម្នេញ" អាចមានដូចជា បទល្មើសផ្សេងៗទៀតដែលមានចែងនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ព្រមទាំងអំពើអកម្ម ឬសកម្ម ដែលមានទម្ងន់ ឬភាពធ្ងន់ធ្ងរដូចគ្នាទោះជាលក្ខណៈដោយឡែក ឬក្នុងលក្ខណៈលាយឡំជាមួយនឹងអំពើផ្សេងៗទៀតក៏ដោយ[3636]។ អំពើសកម្ម ឬអកម្មផ្សេងៗទាំងនេះអាចជា[3637] តែមិនកំណត់ត្រឹម[3638] ឧក្រិដ្ឋកម្មអន្តរជាតិនៅក្នុង និងខ្លួនឯងផ្ទាល់។ ថាតើអំពើទាំងនេះជាក់ស្តែងបង្កើតបានជាការធ្វើទុក្ខបុកម្នេញអាស្រ័យទៅលើការស៊ើបសួរទៅតាមអង្គហេតុជាក់លាក់នីមួយៗ[3639]។

[3635] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៥៧, ២៦១-២៦២, ២៧១។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧៦។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២៧។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៥។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៤២២។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣២៧។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩៨៥។

[3636] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៤៤-២៤៥, ២៥៣-២៥៤, ២៥៧-២៥៨, ២៦១។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣២-៤៣៣។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧៨។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១០២, ៦៧១។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១៣៥, ១៣៨។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ៧៦៦។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩៨៧ [បញ្ជាក់អះអាងថា វាគឺជាផលកើនឡើងនៃអំពើធ្វើទុក្ខបុកម្នេញជាមូលដ្ឋានទាំងអស់ ដែលត្រូវតែឈានដល់កម្រិតធ្ងន់ធ្ងរសមាមាត្រនឹងផលនៃកម្រិតធ្ងន់ធ្ងរសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត]។

[3637] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៥៨, ២៦០។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២១៩។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៩៦។

[3638] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៤៤-២៤៥, ២៦១។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៣។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩៨៥។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៩៦។

[3639] សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៩៥។

1001. បរិបទដែលនៅក្នុងនោះអំពើសកម្ម និងអកម្មបានកើតឡើងមានសារៈសំខាន់បម្រើឱ្យគោលបំណងថ្លឹងថ្លែងទម្ងន់ ឬភាពធ្ងន់ធ្ងររបស់វា[3640]។ កត្តាផ្សេងៗទៀតដែលគួរយកពិចារណានៅក្នុងការថ្លឹងថ្លែងនោះ រួមមាន (i) ថាតើអំពើនោះបានប្រព្រឹត្តនៅក្នុងបរិបទនៃ ឬជាផ្នែកមួយរបស់ព្រឹត្តិការណ៍ច្រើនបន្តបន្ទាប់គ្នាជាខ្សែតែមួយ នៅក្នុងយុទ្ធនាការណ៍ធ្វើទុក្ខបុកម្នេញដែលមានទ្រង់ទ្រាយធំ ឬយ៉ាងណា គោលដៅចុងក្រោយ និងលទ្ធផលចុងក្រោយរបស់វាមានលក្ខណៈធ្ងន់ធ្ងរខ្លាំងបណ្តាលឱ្យកើតមានការរំលោភធ្ងន់ធ្ងរទៅលើសិទ្ធិជាមូលដ្ឋានឬយ៉ាងណា[3641] ហើយ (ii) ផលវិបាកនៃការរើសអើង ដែលអំពើនោះនាំមកដល់ប្រជាជនទូទៅ ដើម្បីប្រឆាំងនឹងក្រុមគោលដៅមួយ[3642]។

1002. ផ្អែកលើការពិនិត្យយ៉ាងទូលាយទៅលើយុត្តិសាស្ត្រនៃតុលាការយោធាអន្តរជាតិ និងតុលាការផ្សេងៗ ចាត់ការយោងទៅតាមក្រមព្រហ្មទណ្ឌកម្ពុជាមាត្រា១០ តុលាការកំពូលបានសម្រេចថា "អំពើផ្សេងៗ ដែលមិនមានចែងនៅក្នុងឧបករណ៍នានាបង្កើតបានជាការរំលោភយ៉ាងធំធេងទៅលើសិទ្ធិបុគ្គលរួមទាំងសិទ្ធិមានទ្រព្យសម្បត្តិ សិទ្ធិទទួលបាននូវសវនាការដោយត្រឹមត្រូវយុត្តិធម៌ ការទទួលបានការការពារស្មើភាពចំពោះមុខច្បាប់ សញ្ជាតិ ការងារ ការអប់រំ ការរៀបអាពាហ៍ពិពាហ៍ ភាពជាឯកជន និងសេរីភាពនៃការធ្វើដំណើរ"[3643]។ ដូចគ្នានេះដែរ អំពើទាំងឡាយខាងក្រោមនេះ ដែលមិនបានរាយច្បាស់នៅក្នុងមាត្រា៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានចាត់ទុកថាជាអំពើធ្វើទុក្ខបុកម្នេញនៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់យូហ្គោស្លាវី និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វ៉ាន់ដា[3644]៖ ការកម្ទេចអាគារសាសនា[3645] អំពើបៀតបៀន ធ្វើឱ្យអាម៉ាស់ ការបន្ទាបបន្ថោក និងការរំលោភផ្លូវចិត្តរួមមានទាំងការបង្ខំជនរងគ្រោះឱ្យមើលឃើញ ឬឮអំពីការធ្វើទារុណកម្ម ការសួរ

[3640] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៣។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩៨៧។

[3641] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៥៩។

[3642] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៥៩។

[3643] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៥៤ បន្ទាប់ពីការពិនិត្យឡើងវិញលើនិត្យានុកូលភាពនៅក្នុង កថាខណ្ឌ ២៤២-២៥៣។

[3644] អំពើមួយចំនួនត្រូវបានដកស្រង់ដោយមានការយល់ព្រមពីអង្គជំនុំជម្រះសាលាដំបូងនៃអ.វ.ត.ក។ *សូមមើល* សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្កេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧៨។

[3645] សាលក្រមក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២០៦។

ចម្លើយ និងអំពើឃោរឃៅដែលកើតមានជាធម្មតានៅក្នុងជំរំពន្ធនាគារ[3646]។ ការបំផ្លាញហិនហោចទៅលើទ្រព្យសម្បត្តិឯកជន និងសាធារណៈ រួមទាំងវិមានវប្បធម៌ និងទីសក្តារៈ[3647] ពលកម្មដោយបង្ខំ[3648] ការផ្ទាស់ទីដោយបង្ខំ[3649] លក្ខខណ្ឌរស់នៅដែលមានលក្ខណៈឃោរឃៅ[3650] ការបាត់ខ្លួនដោយបង្ខំ[3651] ការបំបិទសិទ្ធិធ្វើការងារ សេរីភាពក្នុងការធ្វើដំណើរ ដំណើរការតាមផ្លូវតុលាការត្រឹមត្រូវ និងការថែទាំសុខាភិបាលត្រឹមត្រូវ[3652] ព្រមទាំងសម្តីធ្វើឲ្យមានការស្អប់ខ្ពើម និងការអំពាវនាវប្រព្រឹត្តអំពើហិង្សា[3653]។

ការរើសអើងនៅក្នុងអង្គហេតុ

1003. អំពើសកម្ម និងអកម្មត្រូវតែ "មានការរើសអើងនៅក្នុងអង្គហេតុ"[3654] ពោលគឺអំពើនោះត្រូវតែមានផលវិបាកដែលជាការរើសអើងជាក់ស្តែង[3655]។ តុលាការកំពូលបានសម្រេចថា "ការរើសអើងនៅក្នុងអង្គហេតុ" កើតឡើងក្នុងករណីដែលជនរងគ្រោះបានកំណត់ជាគោលដៅដោយសារតែមានសមាជិកភាពដែលគេបានចោទ ឬគាត់មានពិតប្រាកដនៅក្នុងក្រុមមួយ*ដែលកំណត់ដោយជនដែលប់*

[3646] សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៣២៣-៣២៥។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១៩០-១៩២។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៧៥៨-៧៦០, ៨០៧-៨០៨។

[3647] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥៣០-៥៣៤។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១៤៦, ១៤៩។

[3648] `សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៩៨-២០៣។

[3649] សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២២២។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១៥៣។

[3650] សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥១៤។ សាលក្រមក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៧៥៥-៧៥៦។ សាលក្រមកាត់ទោស *Nikolić* (*Dragan*) កថាខណ្ឌ ៦៩។

[3651] សាលក្រមក្នុងរឿងក្តី *Gotovina* កថាខណ្ឌ ១៨៣៩។

[3652] សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៩៤-២៩៧។ សាលក្រមក្នុងរឿងក្តី *Stanišić & Župljanin* ភាគទី១ កថាខណ្ឌ ៩១-៩២។

[3653] សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩៨៦-៩៨៨។

[3654] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៦៧។ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៦៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២៧។

[3655] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៦៧។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧៧។

ផ្អែកលើហេតុផលជាក់លាក់ ពោលគឺហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា[3656] ហើយជនរងគ្រោះនោះស្ថិតនៅក្នុងក្រុមមួយ ដែលអាចសម្គាល់បានគ្រប់គ្រាន់ថា មានលក្ខណៈដោយឡែក[3657]។ ក្រុមនោះអាចត្រូវកំណត់ក្នុងន័យទូលាយទៅតាមជនដែលដល់។ នេះអាចមានន័យអវិជ្ជមាន និងរួមបញ្ចូលទាំងអ្នកដែលពាក់ព័ន្ធ និងអ្នកដែលមានសមានចិត្តព្រមទាំងជនសង្ស័យ[3658]។

1004. ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ មិនមានលក្ខខណ្ឌតម្រូវទេថា ក្រុមគោលដៅជាក់ស្តែងពិតជាប្រកាន់ទស្សនៈនយោបាយជាក់លាក់ណាមួយនោះទេ ពីព្រោះការវាយតម្លៃជាអត្តនោម័តដោយជនដែលដល់ទៅចំពោះទស្សនៈនយោបាយរបស់ក្រុមនោះ ឬការវាយតម្លៃទៅលើការគំរាមកំហែង ឬគ្រោះថ្នាក់នយោបាយរបស់ក្រុមទៅចំពោះជនដែលដល់មានលក្ខណៈគ្រប់គ្រាន់ហើយ[3659]។

[3656] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៧២-២៧៣។ សំណុំរឿងលេខ ០០២ ឯកសារ F36 សំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៦៧, ៦៦៩, ៦៩០។ *សូមមើលផងដែរ* សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២៨។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧៧។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤១៥។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៤៩៨។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៣៦៣, ៣៦៦, ៤៥៥។ សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៥៨៣។

[3657] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៧៤-២៧៦។ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៦៧, ៧៤៤។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២៨។

[3658] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៧២-២៧៣។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៣៦៣, ៣៦៦, ៤៥៥។ សាលក្រមក្នុងរឿងក្តី *Simić* កថាខណ្ឌ ៤៩។ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៧៣៤។

[3659] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៦៩។ សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៧២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣០ *ជើងទំព័រលេខ* ១២៩០ និងសេចក្តីដកស្រង់នៅក្នុងសាលក្រមនោះ។

ធាតុអត្តនោម័ត

1005. ចំពោះធាតុអត្តនោម័ត្ត ការធ្វើទុក្ខបុកម្នេញតម្រូវឲ្យមានការប្រព្រឹត្តអំពើសកម្មដោយចេតនា ឬអំពើអកម្មដោយមានចេតនាជាក់លាក់ក្នុងការរើសអើងដោយហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា[3660] ក្នុងករណីដែលអំពើជាចម្បងទាំងនោះកំណត់បានជាឧក្រិដ្ឋកម្មយោងតាមច្បាប់អន្តរជាតិធាតុអត្តនោម័ត្តដែលតម្រូវឲ្យមានសម្រាប់ឧក្រិដ្ឋកម្មទាំងនេះមិនចាំបាច់ត្រូវបង្កើតនោះទេ។ សម្រាប់គោលបំណងនៃការចោទជាការធ្វើទុក្ខបុកម្នេញ មានលក្ខណៈគ្រប់គ្រាន់ហើយ គ្រាន់តែបញ្ជាក់ថា អំពើនោះបានប្រព្រឹត្តដោយមានចេតនារើសអើងតាមលក្ខខណ្ឌកំណត់[3661]។ ចេតនារើសអើងតម្រូវថា ជនដៃដល់បានប្រព្រឹត្តដោយមានចេតនាជាក់លាក់បង្ករៀសនកម្មលើជនរងគ្រោះ ដោយសារតែគាត់ស្ថិតនៅក្នុងក្រុម ឬសហគមន៍ជាក់លាក់មួយ[3662]។

1006. ចេតនាត្រូវបានបង្ក់ប់ន័យ "តាមរយៈការចូលរួមដោយដឹងខ្លួនរបស់ជនដៃដល់នៅក្នុងប្រព័ន្ធ ឬសហគ្រាសមួយដែលរើសអើងដោយសារហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា"[3663] ភ័ស្តុតាងបញ្ជាក់ទំនាក់ទំនងខ្លះៗរវាងជនដៃដល់ និងក្រុមគោលដៅ មិនប្រាកដថាចៀសផុតពីការសម្រេចរបស់តុលាការទៅលើអង្គហេតុ ដោយមានហេតុផលសមរម្យ ថាមានចេតនាបានបំពេញលក្ខខណ្ឌតម្រូវក្នុងការប្រព្រឹត្តការធ្វើទុក្ខបុកម្នេញ[3664]។ ភ័ស្តុតាងបញ្ជាក់ថាមានជំនួយចំពោះបុគ្គលមួយ

[3660] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២៣៦-២៤០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤២៧។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧៩។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤២៣។ *សូមមើលឧទាហរណ៍* សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៤២២។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣២៧-៣២៨។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩៨៥។

[3661] សំណុំរឿងលេខ ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្ភារៈហេតុ) កថាខណ្ឌ ៧៣(ខ) *ដកស្រង់* សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ៧៣៨។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៩៦។

[3662] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧៩។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១១១។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១៦៥។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥០០។

[3663] សាលក្រមក្នុងរឿងក្តី *Simić* កថាខណ្ឌ ៥១។

[3664] សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២៣២-២៣៣។

ចំនួនតូចទៅតាមការជ្រើសរើសនិងការកំណត់ មិនអាចចៀសផុតពីការសម្រេចថា ចេតនាក្នុងការរើសអើងបានបំពេញលក្ខខណ្ឌពេញលេញរួចហើយ[3665]។

អំពើអមនុស្សធម៌ផ្សេងៗទៀត

1007. "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិមុនឆ្នាំ១៩៧៥[3666]។ ជាងនេះទៅទៀត **យឹម ទិត្យ** អាចប្រមើលមើលជាមុន និងយល់ដឹងថា ការប្រព្រឹត្តដែលឈានដល់កម្រិត"អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចនឹងត្រូវផ្តន្ទាទោសក្នុងនាមជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3667]។ "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាបទឧក្រិដ្ឋ តាមច្បាប់អន្តរជាតិ[3668]។ ពុំចាំបាច់មានលក្ខខណ្ឌតម្រូវដែលថា ប្រភេទវងនីមួយៗអាចត្រូវចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពិសេសដោយឡែកពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ នោះឡើយ។ ការតម្រូវឲ្យមានលក្ខខណ្ឌបែបនេះ នឹងធ្វើឲ្យប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត"ពុំមានន័យ[3669]។ ផ្ទុយទៅវិញ "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាប្រភេទនៃអំពើពុំជាក់លាក់នៅ

[3665] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៩៣៦។

[3666] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៧៦។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៧១, ៣៧៩-៣៨៥, ៣៩៥-៣៩៦, ៣៩៨ និងសេចក្តីដកស្រង់នៅក្នុងសាលដីកានោះ។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦-១៥៧, ១៦៥។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៥។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៧។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤ *ជើងទំព័រលេខ* ៥១៩៤។ *សូមមើល* សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣១៥-៣១៦ *ជើងទំព័រលេខ* ៦៤៩។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៨៣ *ជើងទំព័រលេខ* ២៧៥។

[3667] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៧៧-៥៨៦។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៦៥។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៦, ៣៩៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៥។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣១៥។

[3668] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៧៦។

[3669] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨៤។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៦។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៧១, ៣៧៨។ សំណុំរឿងលេខ ០០២ ឯក

ក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលចាត់ទុកអំពើប្រព្រឹត្តដែលបំពេញលក្ខខណ្ឌនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិជាបទឧក្រិដ្ឋ ប៉ុន្តែមិនស្ថិតនៅក្នុងប្រភេទណាមួយនៃបទឧក្រិដ្ឋជាក់លាក់ដែលបានបញ្ជាក់ដទៃទៀតនោះឡើយ។[3670] អំពើសកម្ម ឬអកម្មនោះ ត្រូវមានលក្ខណៈ និងភាពធ្ងន់ធ្ងរសមស្រប ប្រហាក់ប្រហែលនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត[3671]។

1008. ដើម្បីក្លាយជាអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវមានធាតុផ្សំដូចតទៅ៖ (i) មានអំពើសកម្ម ឬអកម្ម ដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ (ii) អំពើសកម្ម ឬអកម្ម បណ្តាលឲ្យមានការឈឺចាប់ ឬព្យាសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬជាការធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ និង (iii) អំពើសកម្ម ឬអកម្មត្រូវបានប្រព្រឹត្តឡើងដោយចេតនា[3672]។

1009. ហេតុដូច្នេះ បញ្ហាថាតើការប្រព្រឹត្ត បំពេញលក្ខខណ្ឌដើម្បីចាត់ទុកថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ឬអត់ គឺជាបញ្ហារួមទាំងអង្គហេតុ និងអង្គច្បាប់[3673]។ ភាពធ្ងន់ធ្ងរនៃអំពើប្រព្រឹត្តនោះ ត្រូវធ្វើ

សារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ ន្ហន ជា និង អ៊ៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៦។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣១៥-៣១៦។

[3670] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៧៦, ៥៧៨។។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៧។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៧។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣១៥-៣១៦។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១១៧។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៨៣, ១៩៨។

[3671] សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៥-៣៩៦។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៨, ៤៤០។ ឯកសារ D257/1/8 សេចក្តីពិចារណាលើសំណើរបស់ តា អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៥។ សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ៣៣១។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៩៨។ សាលក្រមក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៩៦០។ ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(១)(ដ) ធាតុផ្សំទី២។

[3672] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨០។

[3673] *សូមមើលខាងលើ* សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៩៧។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ ន្ហន ជា និង អ៊ៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៦៦។ *សូមមើលផងដែរ* ឯកសារ D257/1/8 សេចក្តី

ការវាយតម្លៃទៅតាមករណីនីមួយៗដោយឡែកពីគ្នា[3674] ហើយអង្គហេតុត្រូវយកមកធ្វើការវាយតម្លៃដើម្បីស្វែងរកភាពធ្ងន់ធ្ងរជារួម[3675]។ កាលៈទេសៈដោយឡែកនីមួយៗ អាចរួមបញ្ចូលនូវធម្មជាតិនៃអំពើសកម្ម ឬអកម្ម បរិបទដែលអំពើនោះកើតឡើង ស្ថានភាពផ្ទាល់ខ្លួនរបស់ជនរងគ្រោះ ដូចជាអាយុ ភេទ និងសុខភាព និងឥទ្ធិពលផ្នែកកាយ ស្មារតី និងសីលធម៌ របស់ការប្រព្រឹត្តនោះទៅលើជនរងគ្រោះ[3676]។ មិនមានលក្ខខណ្ឌតម្រូវដែលថា ជនរងគ្រោះត្រូវទទួលរងឥទ្ធិពលរយៈពេលវែងនោះឡើយ ទោះបីជាបញ្ហានេះអាចពាក់ពន្ធ័នឹងភាពធ្ងន់ធ្ងរនៃការប្រព្រឹត្តទាំងនោះក៏ដោយ[3677]។ លក្ខខណ្ឌតម្រូវស្តីពីភាពធ្ងន់ធ្ងរ អាចត្រូវបំពេញតាមរយៈការបង្ហាញសិទ្ធិ និងការហាមឃាត់ប្រហាក់ប្រហែល ដែលមាននៅក្នុងលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិជាធរមាន នៅពេលវេលាពាក់ព័ន្ធ[3678]។ ក្រោយឆ្នាំ១៩៧៥ ការលេចឡើងនូវបទដ្ឋានសិទ្ធិមនុស្សជាក់លាក់ថ្មីៗជាច្រើនបន្ថែមទៀត រួមមានបទដ្ឋានរបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អាចជាការអះអាងបន្ថែមលើអនីត្យានុកូលភាពអន្តរជាតិ ស្តីពីការប្រព្រឹត្តជាក់លាក់ពីដំបូងដែលត្រូវបានចោទប្រកាន់ថាជា "អំពើ

ពិចារណាលើសំណើរបស់ គា អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស្នើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៨។

[3674] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៩។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៨។ ឯកសារ D257/1/8 សេចក្តីពិចារណាលើសំណើរបស់ គា អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស្នើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៦។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ១១៧។ សាលក្រមក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៩៦១។

[3675] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៩០។

[3676] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៩។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៨។ សាលដីកាក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ១៦៥។ ឯកសារ D257/1/8 សេចក្តីពិចារណាលើសំណើរបស់ គា អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស្នើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ៖ ចៅក្រមអន្តរជាតិ កថាខណ្ឌ ១៦ *ដកស្រង់* សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៩។

[3677] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៩។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៣៩។ សាលដីកាក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ១៦៥។ សាលក្រមក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៩៦១ *ដើងទំព័រលេខ* ២៨៨៧។

[3678] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨៤-៥៨៥។

អមនុស្សធម៌ផ្សេងៗទៀត" និងអាចត្រូវបានប្រើប្រាស់ជាវង្វាស់សម្រាប់វាយតម្លៃលើបញ្ហា ថាតើការប្រព្រឹត្តនោះឈានដល់កម្រិតធ្ងន់ធ្ងរដែលតម្រូវដែរ ឬយ៉ាងណា[3679]។

1010. ហេតុដូច្នេះ អំពើជាក់លាក់ទាំងនេះមិនតម្រូវឲ្យមាន "អត្ថន័យ និងធាតុផ្សំជាក់លាក់*ទីពិន័យ*" នោះឡើយ[3680]។ អង្គជំនុំជម្រះតុលាការកំពូល បានពន្យល់ថា "បញ្ហាដែលត្រូវបំភ្លឺ [...] ថាតើការប្រព្រឹត្តដែលចោទជាបញ្ហានេះ ដោយផ្អែកលើកាល:ទេស:ជាក់លាក់ទាំងអស់នៅក្នុងរឿងក្តីបច្ចុប្បន្ននេះ ជាក់ស្តែងបានបំពេញតាមការកំណត់និយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដែរ ឬយ៉ាងណា"[3681]។ ហេតុដូច្នេះ មិនចាំបាច់ពិចារណាលម្អិតលម្អន់លើអង្គហេតុដោយធៀបទៅនឹងធាតុផ្សំនៃបទឧក្រិដ្ឋ នៅក្នុងអំពើអមនុស្សធម៌ផ្សេងៗទៀតនោះឡើយ ប៉ុន្តែមានភាពចាំបាច់តែមួយគត់ដែលត្រូវកំណត់ថាតើអង្គហេតុ មាន "លក្ខណៈ និងភាពធ្ងន់ធ្ងរ ប្រហាក់ប្រហែលគ្នាទៅនឹង លក្ខណៈ និងភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ឬយ៉ាងណា[3682]។ ការបកស្រាយនេះ មានភាពពាក់ព័ន្ធជាក់លាក់ ត្រង់ចំណុចដែលថា ប្រភេទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានកំណត់យ៉ាងច្បាស់លាស់ចាប់តាំងពីឆ្នាំ១៩៧៩ ដូចជា ការរំលោភផ្លូវភេទ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំ ដែល "ការកំណត់ធាតុផ្សំ [....] ថាជាប្រភេទបទឧក្រិដ្ឋដាច់ដោយឡែក នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ពុំសមស្របតាមកាលកំណត់ និងពុំត្រឹមត្រូវតាមច្បាប់ឡើយ"[3683]។

1011. បន្ថែមទៅលើអំពើដែលត្រូវបញ្ជាក់កាន់តែលម្អិតដូចខាងក្រោម "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានរួមបញ្ចូល ការធ្វើឲ្យអាម៉ាស់ និងអំពើបន្ទាបបន្ថោក[3684] អំពើពេស្យាចារដោយបង្ខំ[3685] អំពើ

[3679] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨៥។

[3680] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨៩ (*សង្កត់ន័យក្នុង*ឯកសារ*ដើម*)។

[3681] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨៩។

[3682] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៩០។

[3683] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨៩។

[3684] សាលក្រមក្នុងរឿងក្តី *Kupreškić* កថាខណ្ឌ ៥៦៦។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២០៨។

[3685] សាលក្រមក្នុងរឿងក្តី *Kupreškić* កថាខណ្ឌ ៥៦៦។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២០៨។

ហិង្សាផ្លូវភេទ[3686] ការប្រើប្រាស់អ្នកជាប់ឃុំជាខែលមនុស្ស[3687] ការឲ្យមើលអំពើឧក្រិដ្ឋកម្មប្រឆាំងគ្រួសារ ឬមិត្តភ័ក្តិ[3688] ការកាត់ស្បែកចុងអង្គជាតដោយបង្ខំ ឬការគ្រៀវដោយបង្ខំ[3689] ការសម្លាប់នៅចំពោះមុខកុមារ[3690] ការធ្វើឲ្យបាតុកម្មរងរបួស[3691] និងការស្ថិតនៅអាក្រាតកាយដោយបង្ខំ[3692]។

1012. ដូចដែលត្រូវបានបង្ហាញយ៉ាងលម្អិតនៅក្នុងសារណាចុងក្រោយនេះ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើថា **យ៉ីម ទិញ** គួរត្រូវចោទប្រកាន់ ដោយផ្អែកទៅលើការប្រព្រឹត្តដូចខាងក្រោមដែលត្រូវចាត់ទុកថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត ដូចជា៖ ការប្រព្រឹត្តអមនុស្សធម៌ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ការរំលោភផ្លូវភេទ និងការផ្លាស់ទីលំនៅដោយបង្ខំ។ របៀបដែលការប្រព្រឹត្តបែបនេះ អាចចាត់ចូលទៅក្នុងក្រុម "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងត្រូវពិភាក្សានៅខាងក្រោម។

[3686] សាលក្រមក្នុងរឿងក្តី *Muvunyi I* កថាខណ្ឌ ៥២៨។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៨៤, ១៨៦។

[3687] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨១ *ដកស្រង់* សាលក្រមក្នុងរឿងក្តី *Naletilić & Martinović* កថាខណ្ឌ ២៤៥។ សាលក្រមក្នុងរឿងក្តី *Blaškić; Kordić & Čerkez* កថាខណ្ឌ ៧៧៣។

[3688] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨១ *ដកស្រង់* សាលក្រម សាលក្រមក្នុងរឿងក្តី *Kupreškić* កថាខណ្ឌ ៨១៩។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១៥៣។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៩៩។

[3689] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨១ *ដកស្រង់*សេចក្តីសម្រេចបញ្ជាក់ពីបទចោទប្រឆាំងនឹង *Kenyatta* កថាខណ្ឌ ២៧០-២៧៣។

[3690] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨១ *ដកស្រង់*សេចក្តីសម្រេចបញ្ជាក់ពីបទចោទប្រឆាំងនឹង *Kenyatta* កថាខណ្ឌ ២៧៦-២៧៧។

[3691] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨១ *ដកស្រង់*សេចក្តីសម្រេចបញ្ជាក់ពីបទចោទប្រឆាំងនឹង *Kenyatta* កថាខណ្ឌ ២៨០។

[3692] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៦៩៧។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ១០១៣។

ការធ្វើបាបដោយអមនុស្សធម៌

1013. ការធ្វើបាបដោយអមនុស្សធម៌[3693] ត្រូវហាមឃាត់យ៉ាងជាក់លាក់ដោយលិខិតូបករណ៍សិទ្ធិមនុស្ស ជាច្រើន ដូចជា សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាអឺរ៉ុបស្តីពីសិទ្ធិមនុស្ស[3694]។

1014. ការប្រព្រឹត្តដែលត្រូវរកឃើញថា ជាធាតុផ្សំបង្កើតជាការធ្វើបាបដ៏ឃោរឃៅដែលជាឧក្រិដ្ឋកម្ម សង្គ្រាម ការធ្វើបាបដោយអមនុស្សធម៌ ដែលជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើកតិកាសញ្ញាក្រុងហ្សឺណែវឆ្នាំ១៩៤៩ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ឬជាអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ រួមមាន ការវាយដំ[3695] ការវាយក្បាល[3696] ការប្រើប្រាស់ជំហរដែលធ្វើឲ្យមានអារម្មណ៍តានតឹង និងមិនអាចសម្រាកបាន[3697] និងការឃុំឃាំងនៅក្នុងស្ថានភាពអមនុស្សធម៌ ដែល

[3693] ការប្រព្រឹត្តមកលើខ្លួនដែលអមនុស្សធម៌ ក៏ត្រូវបានហៅថា ការប្រព្រឹត្តដែលអមនុស្សធម៌ផងដែរ ដូចបានកំណត់នៅក្នុងអនុសញ្ញាក្រុងហ្សឺណែវ (I) មាត្រា ៥០, អនុសញ្ញាក្រុងហ្សឺណែវ (II) មាត្រា ៥១, អនុសញ្ញាក្រុងហ្សឺណែវ (III) មាត្រា ១៣០, អនុសញ្ញាក្រុងហ្សឺណែវ (IV) មាត្រា ១៤៧ និងឧបករណ៍សិទ្ធិមនុស្សជាបន្តបន្ទាប់ខាងក្រោម។

[3694] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា ៥។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ៧។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអាមេរិក មាត្រា ៥(២)។ ធម្មនុញ្ញស្តីពីសិទ្ធិមនុស្ស និងសិទ្ធិប្រជាជនអាហ្វ្រិក មាត្រា ៥។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៣។

[3695] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧០។ សាលក្រមក្នុងរឿងក្តី *Muvunyi I* កថាខណ្ឌ ៥២៨។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២០៨។ សាលក្រមក្នុងរឿងក្តី *Tadić* កថាខណ្ឌ ៧៣០។ *សូមមើលបន្ថែមឧទាហរណ៍* សាលក្រមក្នុងរឿងក្តី *Simić* កថាខណ្ឌ ៧៧០-៧៧១ [រកឃើញថាការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ និងអមនុស្សធម៌ ជាអំពើធ្វើទុក្ខបុកម្នេញជាមូលដ្ឋាន ដោយក្នុងនោះជនជាប់ឃុំមិនមែនជាជនជាតិសៀប៊ី ត្រូវបានវាយដំយ៉ាងធ្ងន់ធ្ងរនឹងវត្ថុផ្សេងៗ ដូចជា កាំភ្លើងវែង ដុំដែក ដំបងវាយបាល់បេស្បូបល ច្រវ៉ាក់ដែក ដំបងប៉ូលីស និងជើងកៅអី]។ សាលក្រមក្នុងរឿងក្តី *Delić* កថាខណ្ឌ ៣១៥-៣១៩ [រកឃើញថាការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅជាឧក្រិដ្ឋកម្មសង្គ្រាម ដោយក្នុងនោះស្ត្រីត្រូវបានវាយធ្វើបាបដោយដៃ និងកណ្តាប់ដៃ ដំបងដែក ស្វៃកាំភ្លើង និងការទាត់ធាក់]។ សាលក្រមក្នុងរឿងក្តី *Orić* កថាខណ្ឌ ៤១៤-៤៧៤ [រកឃើញថាការប្រព្រឹត្តមកលើខ្លួនជាឧក្រិដ្ឋកម្មសង្គ្រាម ដោយក្នុងនោះអ្នកជាប់ឃុំត្រូវបានវាយទាត់ធាក់ ធាក់តន្ត្រុំ ដាល់តប់ដោយកណ្តាប់ដៃ វាយនឹងដុំឈើ ដំបង និងបង្គោលឈើ ច្រនាប់ជើង ស្វៃកាំភ្លើង ដុំដែក សរសៃដែក និងដំបងវាយបេស្បូបល ចាក់នឹងកាំបិត]។

[3696] សាលក្រមក្នុងរឿងក្តី *Orić* កថាខណ្ឌ ៤៤៣, ៤៦៩ [រកឃើញថា ការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅជាឧក្រិដ្ឋកម្មសង្គ្រាម ដែលក្បាលរបស់ជនជាប់ឃុំ ត្រូវវាយនឹងម៉ាស៊ីនបំភាយកម្តៅ (រ៉ាឌីយ៉ាទ័រ) ដែលបានបណ្តាលឲ្យគាត់សន្ធប់បាត់ស្មារតី]។

[3697] *សូមមើលឧទាហរណ៍*៖ សាលក្រមក្នុងរឿងក្តី *Delić* កថាខណ្ឌ ២៥៥-២៥៨, ២៧០, ២៧៣ [ដែលរកឃើញថា ការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ ជាឧក្រិដ្ឋកម្មសង្គ្រាម ដោយក្នុងនោះជនជាប់ឃុំត្រូវបានចងខ្សែជាប់នឹងក.ជើង ខ្លួនដេកលើដី និងដៃត្រូវបានចងស្ពាយសេក និងត្រូវបានបង្ខាំងទុកទាំងចំណងយ៉ាងតឹងពេញមួយយប់ រហូតដល់អ្នកជាប់ឃុំម្នាក់និយាយថា គាត់មាន

រួមមានការដកហូតអាហារ ទឹក ទីជម្រក ការថែទាំវេជ្ជសាស្ត្រ សមស្រប និងស្ថានភាពអនាម័យជាអប្បរមា[3698]។ ក្នុងបរិបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ការដកហូតដូចគ្នានេះ ត្រូវបានចាត់ទុកថាជាភ័ស្តុតាងបង្ហាញស្ថានភាពជីវិត ដែលអាចនាំឲ្យមានការបំផ្លាញជារូបវន្តរ៉ូបស់ក្រុមមួយ[3699]។

អារម្មណ៍ថា ជើងរបស់គាត់បានដាច់]។ សាលក្រមក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ៣៨៣, ៣៨៥ [រកឃើញថា ការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ ជាឧក្រិដ្ឋកម្មសង្គ្រាម ដោយក្នុងនោះបុរសជនជាតិអាល់បានី ត្រូវបានចងភ្នែកចងមុខ បង្ខំឲ្យដេកលើដីឲ្យគេវាយហើយវាយទៀតៗ]។

[3698] *សូមមើលឧទាហរណ៍*៖ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨១។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៥៧។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៧០។ សាលក្រមក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ៥១៤ ["ការបង្កើត និងការបន្តលក្ខខណ្ឌរស់នៅបែបអមនុស្សធម៌ ត្រូវបានចាត់ទុកជាអនុប្រភេទនៃការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ និង/ឬអមនុស្សធម៌"]។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១៥៥ [រកឃើញថា អំពើទាំងឡាយ "ដែលគ្របដណ្តប់ការឃុំឃាំងជនស៊ីវិលឥស្លាមបូស្នី ត្រូវបានសម្លាប់ ប្រើជាខែលមនុស្ស វាយធ្វើបាប ដាក់ឲ្យទទួលរងការរំលោភបំពាន និងការបំភិតបំភ័យផ្លូវកាយ ឬផ្លូវចិត្ត ការប្រព្រឹត្តមកលើខ្លួនដែលអមនុស្សធម៌ និងបង្អត់អាហារ និងទឹក សុទ្ធតែឡើងដល់កម្រិតនៃភាពធ្ងន់ធ្ងរលើអ្នកដទៃ [ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"]។ សាលក្រមក្នុងរឿងក្តី *Simić* កថាខណ្ឌ ៧៧៣ [រកឃើញថា ការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ និងអមនុស្សធម៌ ជាអំពើធ្វើទុក្ខបុកម្នេញជាមូលដ្ឋាន ដោយជនជាប់ឃុំមិនមែនជនជាតិស៊ែប៊ី ត្រូវដាក់ឲ្យទទួលរងការរំលោភបំពាន និងការបន្ទាបបន្ថោក លក្ខខណ្ឌចង្អៀតណែន អាហារ ឬទឹកមិនគ្រប់គ្រាន់ លក្ខខណ្ឌគ្មានអនាម័យ ការទទួលបានការថែទាំសុខភាពមិនសមស្រប ព្រមទាំងការវាយធ្វើបាប និងទារុណកម្ម]។ សាលក្រមក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៣៣, ១៣៥-១៧៣, ៥៣៤ [រកឃើញថា ការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ ជាឧក្រិដ្ឋកម្មសង្គ្រាម និងជាអំពើធ្វើទុក្ខបុកម្នេញជាមូលដ្ឋានលើប្រជាជនដែលមិនមែនជនជាតិស៊ែប៊ី ផ្អែកលើលក្ខខណ្ឌរស់នៅបែបឃោរឃៅ និងព្រៃផ្សៃ ដែលរួមបញ្ចូលទាំងលក្ខខណ្ឌដែលចង្អៀតណែន និងគ្មានអនាម័យ អាហារមិនគ្រប់គ្រាន់ និងការបដិសេធនូវការការពារជាមូលដ្ឋានបំផុតសម្រាប់សីតុណ្ហភាពត្រជាក់ខ្លាំង]។ សាលក្រមក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ១១១២-១១១៩ [រកឃើញថា ការប្រព្រឹត្តមកលើខ្លួនដែលឃោរឃៅ ជាឧក្រិដ្ឋកម្មសង្គ្រាម និងជាការរំលោភបំពានធ្ងន់ធ្ងរលើអនុសញ្ញាក្រុងហ្សឺណែវ ដោយអ្នកជាប់ឃុំមិនបានទទួលទឹក អាហារ ការថែទាំសុខភាព និងមូលដ្ឋានអនាម័យមិនគ្រប់គ្រាន់ ជនជាប់ឃុំត្រូវដាក់ឲ្យទទួលរងសីតុណ្ហភាពក្តៅខ្លាំង និងការរៀបចំកន្លែងដេកមិនគ្រប់គ្រាន់នៅក្នុងលក្ខខណ្ឌចង្អៀតណែន ហើយអំពើហិង្សាតាមទំនើងចិត្តបានធ្វើឲ្យបរិយាកាសភ័យរន្ធត់កើនឡើងរាលដាលពេញគ្រប់ទីកន្លែង]។ *សូមមើលផងដែរ* សាលក្រមក្នុងរឿងក្តី *Stanišić & Župljanin* កថាខណ្ឌ ២០៣, ២២៦-២២៧, ៦៧៨-៦៧៩, ៦៨១, ៦៨៣, ៧០១។ សាលក្រមក្នុងរឿងក្តី *Prlić* ភាគទី៣ កថាខណ្ឌ ១១៥៩, ១១៦១, ១១៦៧-១១៦៨, ១១៧០-១១៧២, ១១៧៦-១១៧៨, ១១៨១-១១៨២, ១១៨៤, ១១៩២-១១៩៤, ១១៩៧-១១៩៩, ១២០១-១២០២, ១២០៤-១២០៥។ សាលក្រមក្នុងរឿងក្តី *Limaj* កថាខណ្ឌ ២៨៨-២៨៩, ៣៣៣, ៦៥២។

[3699] សាលដីកាក្នុងរឿងក្តី *Karadžić* វិធាន ៩៨ស្នូន កថាខណ្ឌ ៤៨-៤៩។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៦៩១។ សាលក្រមក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ១១៥-១១៦។

ហេតុដូច្នេះ ការប្រព្រឹត្តប្រហាក់ប្រហែលដែលផ្សំបង្កើតជាការធ្វើបាបដោយអមនុស្សធម៌ បំពេញលក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរសម្រាប់ចាត់ចំណាត់ថ្នាក់ជា "អំពើអមនុស្សធម៌ផ្សេងៗទៀត"។

ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

1015. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន និង តុលាការព្រហ្មទណ្ឌអន្តរជាតិ សុទ្ធតែបានទទួលស្គាល់ថា ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលរំលោភបំពានសិទ្ធិមូលដ្ឋានក្នុងការរៀបអាពាហ៍ពិពាហ៍ដោយស្ម័គ្រចិត្ត និងក្នុងការបង្កើតគ្រួសារ[3700] អាចនឹងមានភាពធ្ងន់ធ្ងរ ប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយហេតុដូច្នេះ ត្រូវចាត់ចូលទៅក្នុងប្រភេទ "អំពើអមនុស្សធម៌ផ្សេងៗទៀត"[3701]។ សិទ្ធិរួចផុតពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មានសារៈសំខាន់យ៉ាងខ្លាំង រហូតដល់សិទ្ធិនេះត្រូវបានទទួលស្គាល់នៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨[3702]។ លិខិតូបករណ៍ជាធរមានជាច្រើនផ្សេងទៀតនៅត្រឹមឆ្នាំ១៩៧៥ ក៏ទទួលស្គាល់សារៈសំខាន់នៃការយល់ព្រមមុនពេលឈានទៅដល់ការរៀបអាពាហ៍ពិពាហ៍[3703]។

[3700] ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩៤។

[3701] សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៩៨-២០១។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ២៣០៦-២៣០៧។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤, ១៤៤២-១៤៤៣ *ជើងទំព័រលេខ* ៥១៩៥។ ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩១-៩៥។

[3702] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស មាត្រា១៦(២) ["អាពាហ៍ពិពាហ៍នឹងអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការព្រមព្រៀងដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធ"]។

[3703] *សូមមើលឧទាហរណ៍*៖ អនុសញ្ញាឆ្នាំ១៩៦២ស្តីពីការព្រមព្រៀងរៀបអាពាហ៍ពិពាហ៍ (សេចក្តីផ្តើមនៃអនុសញ្ញានេះរំលឹកឡើងវិញពីមាត្រា១៦ នៃសេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស)។ មាត្រា១ ចែងថា "គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយស្របច្បាប់ ដោយគ្មានការយល់ព្រមដោយសេរី និងពេញលេញពីភាគីទាំងពីរឡើយ"។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា២៣(៣) ចែងថា ["គ្មានអាពាហ៍ពិពាហ៍ណាអាចធ្វើឡើងដោយស្របច្បាប់ ដោយគ្មានការយល់ព្រមដោយសេរី និងពេញលេញពីអនាគតប្តីប្រពន្ធឡើយ"]។ អនុសញ្ញាស្តីពីសិទ្ធិមនុស្សអឺរ៉ុប មាត្រា ៨ [ពន្យល់លម្អិតអំពី "សិទ្ធិក្នុងការគោរពជីវិតឯកជន និងជីវិតគ្រួសារ" ដោយចែងថា "បុគ្គលគ្រប់រូបមានសិទ្ធិ ក្នុងការគោរពជីវិតឯកជន និងជីវិតគ្រួសាររបស់ខ្លួន" និង "មិនត្រូវមានការជ្រៀតជ្រែកពីអាជ្ញាធរសាធារណៈក្នុងការអនុវត្តសិទ្ធិនេះឡើង រៀរលែងតែការជ្រៀតជ្រែកបែបនេះត្រូវធ្វើឡើងស្របតាមច្បាប់"] មាត្រា១២ [ទាក់ទងជាមួយ "សិទ្ធិក្នុងការរៀបអាពាហ៍ពិពាហ៍" ដោយចែងថា "[បុរស និងស្ត្រីដែលមានអាយុអាចរៀបការបាន មានសិទ្ធិរៀបអាពាហ៍ពិពាហ៍ និងសិទ្ធិបង្កើតគ្រួសារ"]។ *សូមមើលផងដែរ* អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៧៩ មាត្រា១៦ ["រដ្ឋភាគី [...]ដោយផ្អែកលើ

1016. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំកើតឡើង នៅពេលចារី ឬអាជ្ញាធរបង្ខំឲ្យបុគ្គល ឬគូស្រក រៀបអាពាហ៍ពិពាហ៍ ដោយប្រើប្រាស់កម្លាំង ការគំរាមប្រើកម្លាំង ឬការបង្ខំ[3704]។ "ការរៀបអាពាហ៍ពិពាហ៍" បង្កប់នូវទំនាក់ទំនងផ្តាច់មុខរវាង "ស្វាមី" និង "ភរិយា"[3705] ដោយមានឋានៈសង្គម និងតួនាទីជាអ្នកថែរក្សា[3706] និងដោយមានផលវិបាកផ្នែកវិនិយដែលអាចកើតមានដោយសារការរំលោភលើការរៀបចំផ្តាច់មុខនេះ[3707]។ អាស្រ័យទៅតាមកាលៈទេសៈ "ការរៀបអាពាហ៍ពិពាហ៍" អាចពាក់ព័ន្ធនឹងភារកិច្ចតួនាទីជាច្រើនដូចជា ការរួមភេទ ការធ្វើពលកម្មនៅក្នុងផ្ទះ ការមានផ្ទៃពោះ និងថែរក្សាកូនដែលបានមកពី "ការរៀបអាពាហ៍ពិពាហ៍"[3708] និងអាចពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មអន្តរជាតិមួយ ឬច្រើន ដូចជា ការធ្វើឲ្យមនុស្សក្លាយជាទាសករ ការរំលោភផ្លូវភេទ ការវាយប្រហារផ្លូវភេទ ការធ្វើឲ្យមនុស្សក្លាយជា ទាសករផ្លូវភេទ ឬការមានផ្ទៃពោះដោយបង្ខំ នៅក្នុងចំណោមបទឧក្រិដ្ឋផ្សេងៗទៀត[3709]។ តែទោះជាយ៉ាងណាក៏ដោយ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនមែនជាបទឧក្រិដ្ឋផ្លូវភេទធ្ងន់ធ្ងរនោះឡើយ ហើយការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងគ្រោះថ្នាក់ដែលពាក់ព័ន្ធកើតមានឡើង ទោះបីជា "ស្វាមី" និង "ភរិយា" មានទំនាក់ទំនងផ្លូវភេទជាមួយគ្នាក៏ដោយ[3710]។

1017. កម្លាំងដែលត្រូវបានប្រើប្រាស់ដើម្បីបង្ខំឲ្យមនុស្សម្នាក់រៀបអាពាហ៍ពិពាហ៍ មិនសំដៅត្រឹមតែកម្លាំងរាងកាយនោះឡើយ វាក៏រួមបញ្ចូលទាំងការគំរាមកំហែងប្រើប្រាស់កម្លាំង ឬ ការបង្ខិតបង្ខំ ដូចជាការបង្ខិតបង្ខំដែលបង្កឡើងដោយការភ័យខ្លាចអំពើហិង្សា ការគំរាមកំហែង ការឃុំខ្លួន ការគាប

មូលដ្ឋានសមភាពរវាងបុរស និងស្ត្រី ត្រូវធានា៖ [...] (b) សិទ្ធិដូចគ្នាក្នុងការជ្រើសរើសសហព័ទ្ធរបស់ខ្លួនដោយសេរី និងរៀបអាពាហ៍ពិពាហ៍ ដោយការព្រមព្រៀងដោយសេរី និងពេញលេញរបស់ពួកគេតែប៉ុណ្ណោះ"]។ សន្ធិសញ្ញានេះត្រូវបានផ្តល់សច្ចាប័នដោយ អៀង សារី ខ្លួនឯងផ្ទាល់នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៨០។ *សូមមើល* ១២៤៩ ប្រជុំសន្ធិសញ្ញាអង្គការសហប្រជាជាតិ (UNTS) ៨៩។

[3704] សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៩៦។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៧៣៥-៧៣៦។ ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩១។

[3705] សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៩៥។ ។ ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩៣។

[3706] ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩៣។

[3707] ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩៣។

[3708] សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៩០។ ។ ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩២-៩៣។

[3709] សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ២០១។ ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩២។

[3710] សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៩៥។ ការបញ្ជាក់អះអាងពីបទចោទប្រឆាំង *Ongwen* កថាខណ្ឌ ៩៣-៤។

សង្កត់ផ្លូវចិត្ត ឬការរំលោភអំណាច ឬការកេងយកប្រយោជន៍ពីបរិយាកាសដែលបង្ខិតបង្ខំ[3711]។ នៅពេលដែលមានភ័ស្តុតាងបង្ហាញថា ស្ថានភាពមានលក្ខណៈបង្ខិតបង្ខំ ដែលនៅក្នុងស្ថានភាពបែបនេះ ការជ្រើសរើសដោយសេរីមិនអាចអនុវត្តបាន គូភាគីមិនអាចនឹងយល់ព្រមរៀបអាពាហ៍ពិពាហ៍នោះឡើយ។ កាលៈទេសៈដែលកើតមានជាទូទៅនៅក្នុងករណីភាគច្រើនដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "សុទ្ធតែមានលក្ខណៈបង្ខិតបង្ខំស្ទើរតែទាំងអស់" ដែលមិនអាចធ្វើឲ្យមានការយល់ព្រមពិតប្រាកដកើតមានឡើងនោះឡើយ[3712]។ ស្រដៀងគ្នានេះដែរ បរិយាកាសភ័យខ្លាច[3713] ឬស្ថានភាពបង្ខាំងខ្លួន ឬឃុំខ្លួន[3714] ត្រូវបានចាត់ទុកថាជាការបំផ្លាញការយល់ព្រមពិតប្រាកដ។ នៅក្នុងបរិយាកាសមួយដែលមានការបង្ខិតបង្ខំ ផលប្រយោជន៍ពាក់ព័ន្ធណាក៏ដោយដែលជនរងគ្រោះនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំអាចទទួលបានពីចារី មិនតំណាងឲ្យការយល់ព្រមក្នុងការបង្កើតចំណងអាពាហ៍ពិពាហ៍ដោយបង្ខំនោះឡើយ ហើយក៏មិនធ្វើមោយភាពចំពោះលក្ខណៈនៃឧក្រិដ្ឋកម្មរបស់ចារីនោះឡើយ[3715]។

ការរំលោភផ្លូវភេទ

1018. ទោះបីជាការរំលោភផ្លូវភេទតែឯងត្រូវបានចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះតុលាការកំពូល បានយល់ឃើញថា ការរំលោភផ្លូវភេទមិនមែនជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដាច់ដោយឡែកនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះឡើយ[3716]។ ក៏ប៉ុន្តែអង្គបុរេជំនុំជម្រះ បានបញ្ជាក់ថាអង្គហេតុដែលត្រូវបានចាត់

[3711] សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៧៣៦។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ២៨១។

[3712] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៣។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ១៥១។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤១៦។ ទោះបីជាការសម្រេចនេះទាក់ទងនឹងការរំលោភសេពសន្តវៈក៏ដោយ ក៏វាអាចអនុវត្តបានដោយស្មើគ្នានៅក្នុងបរិបទនៃការរៀបការដោយបង្ខំដែរ។

[3713] សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៩៤។

[3714] សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៧៣៦។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៣៩៦។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១៣២-១៣៣។ សាលក្រមក្នុងរឿងក្តី *Muhimana* កថាខណ្ឌ ៥៤៥។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១៩៤-១៩៥, ២២៦-២៣៣។

[3715] សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៩០។

[3716] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ១៨៣, ២១៣។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំង

ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងទម្រង់ជាការរំលោភផ្លូវភេទ អាចនឹងត្រូវចាត់ទុកបន្ថែមទៀតថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ "អំពើអមនុស្សធម៌ផ្សេងៗទៀត"[3717]។ ជាងនេះទៅទៀត តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន សុទ្ធតែចាត់ទុកការរំលោភផ្លូវភេទថា ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយដាច់ដោយឡែក[3718]។ ការរំលោភផ្លូវភេទក៏អាចត្រូវចាត់ទុកជាការធ្វើទារុណកម្ម នៅពេលដែលធាតុផ្សំនៃអំពើទារុណកម្មត្រូវបានរកឃើញ[3719]។ លក្ខខណ្ឌតម្រូវនៃភាពធ្ងន់ធ្ងរសម្រាប់ចាត់ចំណាត់ថ្នាក់នៃអង្គហេតុដែលជាធាតុផ្សំនៃការរំលោភផ្លូវភេទជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានបំពេញយ៉ាងច្បាស់លាស់។

1019. ចំពោះនិយមន័យនៃពាក្យ "រំលោភផ្លូវភេទ" មានការផ្តល់និយមន័យខុសៗគ្នាមួយចំនួនដោយអង្គជំនុំជម្រះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងតុលាការអន្តរជាតិនានា។ នៅក្នុងដីកាដំណោះស្រាយសំណុំរឿង ០០២ ការិយាល័យសហចៅក្រមស៊ើបអង្កេតភាគច្រើនបានប្រើប្រាស់និយមន័យដ៏ទូលំទូលាយ ដែលត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះនៃតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន នៅក្នុងរឿងក្តី Akayesu[3720] ដោយយល់ឃើញថា "តាមរយៈការបង្ខំឱ្យរួម

និងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៦៤-៣៦៥, ៣៧១។

[3717] សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៣៧២។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៥៤។ *សូមមើលបន្ថែម* សំណុំរឿងលេខ ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៥៩។

[3718] **តុលាការអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី៖** លក្ខន្តិកៈតុលាការអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី មាត្រា៥(ឆ)។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១៧៩។ **តុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា៖** លក្ខន្តិកៈតុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា មាត្រា៣(ឆ)។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥៩៦។ **តុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន៖** លក្ខន្តិកៈតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន មាត្រា២(ឆ)។ សាលក្រមក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៤៤។ **តុលាការព្រហ្មទណ្ឌអន្តរជាតិ៖** លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៧(១)(ឆ)។

[3719] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២០៧-២០៨, ២១១។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥៥, ៣៦៦។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៦៨៧។

[3720] សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៥៩៨ [ឲ្យនិយមន័យអំពើរំលោភសេពសន្ថវៈជា "អំពើឈ្លានពានផ្លូវភេទ ដែលបានប្រព្រឹត្តលើមនុស្សម្នាក់ក្រោមកាលៈទេសៈដែលលមានលក្ខណៈបង្ខិតបង្ខំ"]។

ភេទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ"[3721] ចារីបានប្រព្រឹត្តការណ្ណានពានផ្លូវភេទតាមរយៈរាងកាយប្រឆាំងនឹងជនរងគ្រោះ នៅក្នុងកាលៈទេសៈបង្ខំ ដែលនៅក្នុងកាលៈទេសៈបែបនេះមិនមានការយល់ព្រមពីជនរងគ្រោះនោះឡើយ"[3722]។ ទាំងបុរស និងនារី សុទ្ធតែអាចក្លាយជាជនរងគ្រោះនៃ "ការណ្ណានពាន"[3723]។

1020. និយមន័យរបស់លក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ក៏មានលក្ខណៈទូលំទូលាយស្មើរតែដូចគ្នានេះដែរ ដោយតម្រូវថា "ចារីណ្ណានពានរាងកាយរបស់មនុស្សម្នាក់ តាមរយៈការប្រព្រឹត្ត ដែលបណ្តាលឲ្យមានការដាក់បញ្ចូល ទោះបីជាមិនស៊ីជម្រៅក៏ដោយ ទៅក្នុងផ្នែកណាមួយនៃរាងកាយរបស់ជនរងគ្រោះ ឬរបស់ចារី ន្ទូវអង្គជាត ឬទៅក្នុងរន្ធគូទ ឬរន្ធយោនី របស់ជនរងគ្រោះ ន្ទូវវត្ថុអ្វីក៏ដោយ ឬផ្នែកណាមួយផ្សេងទៀតនៃរាងកាយ"[3724]។ អង្គជំនុំជម្រះតុលាការឧក្រិដ្ឋកម្មអន្តរជាតិបានពន្យល់យ៉ាងត្រឹមត្រូវថា ធាតុផ្សំ "ត្រូវបានកំណត់បែបនេះ ដើម្បីប្រមើលមើលទុកជាមុន [....] ន្ទូវយថាហេតុដែលចារីត្រូវបានគេដាក់បញ្ចូល បន្ថែមទៅលើហេតុការណ៍ដែលថាចារីបណ្តាល ឬញ៉ាំងឲ្យមានការដាក់បញ្ចូល"[3725] ដោយការយោងទៅដល់ឃ្លា "បណ្តាល ឬញ៉ាំងឲ្យមានការដាក់បញ្ចូល" បង្ហាញន្ទូវការយល់ដឹងរបស់អង្គជំនុំជម្រះដែលថា ចារីមិនចាំបាច់ប្រព្រឹត្តអំពើផ្លូវភេទដោយខ្លួនឯងផ្ទាល់នោះឡើយ ឲ្យតែចារីជាប់ពាក់ព័ន្ធនឹង "ការប្រព្រឹត្តដែលបង្កឲ្យមានការដាក់បញ្ចូល"។

1021. និយមន័យជាក់លាក់ជាងនេះនៃការរំលោភផ្លូវភេទ ត្រូវបានលើកឡើងនៅក្នុងសំណុំរឿង ០០១។ នៅក្នុងសំណុំរឿងនេះ អង្គជំនុះជម្រះ បានអនុវត្តតាម តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ក្នុងការកំណត់និយមន័យធាតុផ្សំនៃរាងកាយកាន់តែមានភាពជាក់លាក់ជាងមុន ថាជាការបញ្ចូលអង្គជាត ទោះបីជាមិនស៊ីជម្រៅក៏ដោយ (ក) ទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់ជនរងគ្រោះ

[3721] យោងលើរបកគំហើញអង្គហេតុនៅក្នុងសំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ៨៥៨។

[3722] សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣១។ *សូមមើលផងដែរ* កថាខណ្ឌ ១៤២៧។

[3723] ដូចបានឆ្លុះបញ្ចាំងនៅក្នុងធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ *ជើងទំព័រលេខ* ១៥។ *សូមមើលជើងទំព័រលេខ* ៣៧៣៣។

[3724] ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៧(១)(ឆ)-១ ធាតុផ្សំទី១។ ត្រង់*ជើងទំព័រលេខ* ១៥ ត្រូវបានពន្យល់បំភ្លឺថា "ទស្សនៈនៃ 'អំពើណ្ណានពាន' មានគោលបំណងពង្រីកឲ្យទូលំទូលាយល្មម ដើម្បីឲ្យមានលក្ខណៈយេនឌ័រអព្យាក្រឹត្យ"។ *សូមមើលបន្ថែម* សាលក្រមក្នុងរឿងក្តី *Bemba* កថាខណ្ឌ ៩៩-១០០។

[3725] សាលក្រមក្នុងរឿងក្តី *Katanga* កថាខណ្ឌ ៩៦៣។

ដោយអង្គជាតរបស់ចារី ឬវត្ថុផ្សេងៗទៀតដែលប្រើប្រាស់ដោយចារី ឬ (ខ) ការបញ្ចូលតាមមាត់របស់ជនរងគ្រោះដោយអង្គជាតរបស់ចារី នៅពេលដែលការបញ្ចូលអង្គជាតនោះកើតឡើងដោយគ្មានការយល់ព្រមពីជនរងគ្រោះ[3726]។ នាពេលថ្មីៗនេះ ការិយាល័យសហចៅក្រមស៊ើបអង្កេត បានលើកឡើងសារជាថ្មីនូវនិយមន័យនេះ នៅក្នុងដីកាដំណោះស្រាយសំណុំរឿង០០៤/១[3727]។ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា និយមន័យនេះមានលក្ខណៈចង្អៀតជ្រុលខ្លាំងពេក ដោយសារតែនិយមន័យនេះត្រូវបានសរសេរឡើងដើម្បីធ្វើឲ្យស្របទៅនឹងអង្គហេតុជាក់លាក់ដែលថា ចារីដាក់បញ្ចូលទៅក្នុងផ្នែកណាមួយនៃរាងកាយរបស់ជនរងគ្រោះ ដោយគ្មានការយល់ព្រមពីជនរងគ្រោះ។

1022. ដូចដែលត្រូវបានទទួលស្គាល់ ដោយ ការិយាល័យសហចៅក្រមស៊ើបអង្កេត តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រវ៉ាន់ដា និងតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និយមន័យនៃការរំលោភផ្លូវភេទដ៏ច្បាស់ដែលមានលក្ខណៈទូលំទូលាយ និងអព្យាក្រឹត្យផ្នែកភេទ គម្រូវឲ្យមានការដាក់បញ្ចូលអង្គជាត ទោះបីជាមិនស៊ីជម្រៅក៏ដោយ ទៅក្នុងរន្ធយោនី ឬរន្ធគូទរបស់បុគ្គលម្នាក់ដោយវត្ថុអ្វីក៏ដោយ ឬដោយផ្នែកណាមួយនៃរាងកាយរបស់មនុស្សម្នាក់ទៀត ឬការប៉ះពាល់ប្រដាប់ភេទរបស់មនុស្សម្នាក់ដោយផ្នែកណាមួយនៃមាត់របស់មនុស្សម្នាក់ ដោយគ្មានការយល់ព្រមដោយភាគីម្ខាងឬភាគីទាំងពីរនៅក្នុងការប្រព្រឹត្តផ្លូវភេទនោះ។ ទោះជានៅក្នុងព្រឹត្តិការណ៍មួយណាក៏ដោយ ទោះបីជាវាមិនស្របទៅតាមនិយមន័យផ្លូវច្បាប់នៃឧក្រិដ្ឋកម្មរំលោភផ្លូវភេទពីពេលមុនក៏ដោយ ការបង្ខំឲ្យមនុស្សម្នាក់ឬគូស្រក ពាក់ព័ន្ធនឹងទំនាក់ទំនងផ្លូវភេទ ដោយគ្មានការយល់ព្រមពីពួកគេ គឺពិតជាឧក្រិដ្ឋកម្មមួយដែលមានភាពធ្ងន់ធ្ងរស្មើគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត[3728]។ ការប្រព្រឹត្តនេះ ស្របយ៉ាងច្បាស់ទៅនឹងនិយមន័យ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

[3726] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦២ (ដកស្រង់ដោយគ្មានការអនុម័តយល់ព្រមជាក់ស្តែងពីអង្គជំនុំជម្រះតុលាការកំពូល៖ សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ២០៨)។ សាលដីកាក្នុងរឿងក្តី *Kunarac* កថាខណ្ឌ ១២៧។

[3727] សំណុំរឿងលេខ ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៧២។

[3728] ការតម្រូវឲ្យអ្នកដទៃរួមភេទជាមួយគ្នា ក៏ត្រូវបានរកឃើញថាជាការរំលោភបំពានផ្លូវភេទដែលត្រូវផ្តន្ទាទោសជាអំពើធ្វើទុក្ខបុកម្នេញជាមូលដ្ឋាននៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផងដែរ។ *សូមមើល* សាលក្រមក្នុងរឿងក្តី *Brdanin* កថាខណ្ឌ ១០១២-១០១៣។

ដោយវាបង្កការឈឺចាប់ផ្នែករាងកាយ ឬផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរ ចំពោះជនរងគ្រោះ និងជាការវាយប្រហារធ្ងន់ធ្ងរទៅលើសេចក្ដីថ្លៃថ្នូជាមនុស្សរបស់ជនរងគ្រោះ។

1023. ការយល់ព្រមសម្រាប់គោលបំណងបែបនេះ ចាំបាច់ត្រូវផ្ដល់ឱ្យដោយការស្ម័គ្រចិត្ត ដោយផ្អែកលើឆន្ទៈដោយសេរីរបស់ជនរងគ្រោះ ដែលត្រូវវាយតម្លៃដោយពិនិត្យមើលកាលៈទេសៈជុំវិញ[3729]។ កម្លាំង ឬការគំរាមប្រើកម្លាំង អាចផ្ដល់នូវភ័ស្ដុតាងបង្ហាញនូវការមិនយល់ព្រម ប៉ុន្តែកម្លាំងមិនមែនជាធាតុផ្សំនៃការរំលោភផ្លូវភេទនោះឡើយ ហើយមានកត្តាផ្សេងៗទៀតក្រៅពីកម្លាំង ដែលញ៉ាំងឱ្យមានអំពើដាក់បញ្ចូលអង្គជាតដោយគ្មានការយល់ព្រម ឬដោយមិនស្ម័គ្រចិត្ត ទៅលើផ្នែកណាមួយនៃរាងកាយរបស់ជនរងគ្រោះ[3730]។ ភ័ស្ដុតាងនៃការប្រឆាំងតបត (ឬការប្រឆាំងតបតឥតឈប់) ដោយជនរងគ្រោះ ក៏មិនតម្រូវឱ្យមាន នោះឡើយ[3731]។ កាលៈទេសៈនៅក្នុងករណីភាគច្រើន ដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ "ស្ទើរតែមានលក្ខណៈបង្ខំជាទូទៅ" ដែលបណ្ដាលឱ្យការយល់ព្រមពិតប្រាកដមិនអាចធ្វើទៅបាន[3732]។ ភ័ស្ដុតាងកាលៈទេសៈ អាចត្រូវគេប្រើប្រាស់ដើម្បីបង្ហាញអំពីការរំលោភផ្លូវភេទ[3733]។

1024. ចំពោះ*ធាតុផ្សំអត្តនោម័តិ* បន្ថែមទៅលើចេតនាដែលតម្រូវឱ្យមានសម្រាប់ "អំពើអមនុស្សធម៌ ផ្សេងៗទៀត" អំពើរំលោភផ្លូវភេទត្រូវធ្វើឡើងដោយចេតនា និងដោយដឹងថាគ្មានការយល់ព្រមពីជនរងគ្រោះ ឬ ដឹងថាមានកាលៈទេសៈបង្ខំដែលការយល់ព្រមមិនអាចធ្វើទៅបាន[3734]។ ការដឹងអំពីការមិន

[3729] សាលដីកាក្នុងរឿងក្ដី *Kunarac* កថាខណ្ឌ ១២៧-១២៨។ សាលក្រមក្នុងរឿងក្ដី *Taylor* កថាខណ្ឌ ៤១៦។

[3730] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្កេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៣។ សាលដីកាក្នុងរឿងក្ដី *Kunarac* កថាខណ្ឌ ១២៩-១៣០។ សាលក្រមក្នុងរឿងក្ដី *Taylor* កថាខណ្ឌ ៤១៦។ សាលក្រមក្នុងរឿងក្ដី *Brima* កថាខណ្ឌ ៦៩៤។

[3731] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្កេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៣។ សាលដីកាក្នុងរឿងក្ដី *Kunarac* កថាខណ្ឌ ១២៨។ សាលដីកាក្នុងរឿងក្ដី *Gacumbitsi* កថាខណ្ឌ ១៥៥។ សាលក្រមក្នុងរឿងក្ដី *Taylor* កថាខណ្ឌ ៤១៦។

[3732] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្កេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៣។ សាលដីកាក្នុងរឿងក្ដី *Gacumbitsi* កថាខណ្ឌ ១៥១។ សាលក្រមក្នុងរឿងក្ដី *Taylor* កថាខណ្ឌ ៤១៦។

[3733] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្កេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៤។ សាលដីកាក្នុងរឿងក្ដី *Muhimana* កថាខណ្ឌ ៤៨-៤៩។ សាលក្រមក្នុងរឿងក្ដី *Sesay* កថាខណ្ឌ ១៤៩។

[3734] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្ដី កាំង ហ្កេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៦៤។ សាលដីកាក្នុងរឿងក្ដី *Kunarac* កថាខណ្ឌ ១២៨។

យល់ព្រម អាចត្រូវបានបង្ហាញថាជាការពិត ប្រសិនបើចារី ដឹងអំពីកាលៈទេសៈបង្ខំ ដែលបំផ្លាញលទ្ធភាពនៃការផ្តល់ការយល់ព្រមពិតប្រាកដ[3735]។

ការបាត់ខ្លួនដោយបង្ខំ

1025. ការិយាល័យសហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី និង តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន សុទ្ធតែទទួលស្គាល់ថា ការបាត់ខ្លួនដោយបង្ខំ អាចជាភាពធ្ងន់ធ្ងរដែលតម្រូវឲ្យមានដើម្បី ចាត់ទុកថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ប្រសិនបើលក្ខខណ្ឌដទៃផ្សេងទៀតត្រូវបានបំពេញ[3736]។ តុលាការព្រហ្មទណ្ឌអន្តរជាតិ ក៏ទទួលស្គាល់ថាការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ គឺជាបទឧក្រិដ្ឋមួយដាច់ដោយឡែក នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3737]។

1026. ការបាត់ខ្លួនដោយបង្ខំ ត្រូវបានរកឃើញថាកើតឡើងនៅពេលដែល (i) បុគ្គលណាម្នាក់អាចត្រូវដកហូតសេរីភាពរបស់ខ្លួន ដូចជាតាមរយៈការចាប់ខ្លួន ការឃុំខ្លួន ឬការបង្ខាំងខ្លួន (ii) ការដកហូតសេរីភាពនេះ ត្រូវបានធ្វើឡើងតាមរយៈការបដិសេធមិនបង្ហាញព័ត៌មានទាក់ទងនឹងជោគវាសនា ឬទីកន្លែងដែលបុគ្គលពាក់ព័ន្ធនោះស្ថិតនៅ ឬមិនទទួលស្គាល់ការដកហូតសេរីភាពនេះ ដោយបដិសេធចំពោះដំណោះស្រាយតាមផ្លូវច្បាប់ និងការធានាផ្នែកនីតិវិធីចំពោះបុគ្គលនោះ និង (iii)

[3735] សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ១៥៧។

[3736] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៤៤-៤៤៨ និងសេចក្តីដកស្រង់ក្នុងសាលក្រមនោះ។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៤, ១៤៧០-១៤៧១, ១៤៧៦ *ជើងទំព័រលេខ* ៥១៩៧។ សំណុំរឿងលេខ ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៧៥។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ១៨៤។ សាលក្រមក្នុងរឿងក្តី *Kupreškić* កថាខណ្ឌ ៥៦៦។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២០៦-២០៩។ សាលក្រមក្នុងរឿងក្តី *Gotovina* កថាខណ្ឌ ១៨៣៨។ នៅក្នុងសាលក្រមក្នុងរឿងក្តី *Gotovina* កថាខណ្ឌ ១៨៣៨-៨៣៩ អង្គជំនុំជម្រះសាលាដំបូងនៃតុលាការអន្តរជាតិសម្រាប់អតីតយូហ្គូស្លាវី បានរកឃើញថា ការបាត់ខ្លួនដោយបង្ខំដែលត្រូវបានធ្វើឡើងផ្អែកលើមូលហេតុនៃការរើសអើង ហើយធាតុផ្សំទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានបំពេញ បង្កើតបានជាបទឧក្រិដ្ឋនៃការធ្វើទុក្ខបុកម្នេញ។

[3737] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា ៧(១)(ឈ)។

ធាតុផ្សំទីមួយ និងទីពីរ ត្រូវបានអនុវត្ត ដោយភ្នាក់ងាររដ្ឋ ឬដោយមានការអនុញ្ញាត ការគាំទ្រ ឬការយល់ព្រមពីរដ្ឋ ឬអង្គការនយោបាយណាមួយ[3738]។

1027. ពាក់ព័ន្ធនឹងការបដិសេធរបស់រដ្ឋមិនបង្ហាញព័ត៌មាន នៅក្នុងរដ្ឋដែលគ្មានច្បាប់ដូចជារដ្ឋដែលត្រូវបានគ្រប់គ្រងដោយកម្ពុជាប្រជាធិបតេយ្យ ដែលអ្នកដែលសួរព័ត៌មានអំពីមនុស្សដែលត្រូវឃុំខ្លួន ឬបាត់ខ្លួន នឹងធ្វើឲ្យខ្លួនឯងប្រឈមនឹងហានិភ័យដ៏ធំធេង ដោយជួបប្រទះជោគវាសនាដូចគ្នា ការតម្រូវឲ្យមានភ័ស្តុតាងបង្ហាញថា សមាជិកគ្រួសារ ឬមិត្តភក្តិ បានសាកសួរអំពីជោគវាសនា ឬអំពីទីកន្លែងរបស់មនុស្សដែលបាត់ខ្លួន គឺមិនសមហេតុផលនោះឡើយ។ ច្បាប់នឹងមិនអាចការពារផលប្រយោជន៍ ដែលច្បាប់ត្រូវបានតាក់តែងឡើងសម្រាប់គោលបំណងបែបនោះ ប្រសិនបើរបបមួយអាចលាក់បំបាំងនៅខាងក្រោយភាពផ្ទួរការនៃនិតិវិធី ដើម្បីគេចវេសពីការទទួលខុសត្រូវ ពោលគឺនៅពេលដែលវិធីសាស្ត្រគ្រប់គ្រងដ៏សាហាវ និងឃោរឃៅ គឺជាហេតុផលដែលរបបនោះអាចធានានិទណ្ឌភាពរបស់ខ្លួន។

1028. នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ ដូចដែលលើកឡើងនៅខាងលើ[3739] ការពិនិត្យវាយតម្លៃ ពុំមែនវាយតម្លៃថា តើអង្គហេតុបំពេញតាមនិយមន័យទំនើបនៃបទឧក្រិដ្ឋនៃការបាត់ខ្លួនដោយបង្ខំនោះឡើយ តែវាយតម្លៃថា តើអង្គហេតុបំពេញតាមលក្ខខណ្ឌតម្រូវនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែរឬទេ[3740]។ អង្គជំនុំជម្រះតុលាការកំពូល បានលើកឡើងអំពីចំណុចជាក់លាក់នេះនៅក្នុងសំណុំរឿង ០០២/០១ ដោយសម្រេចថា ការណ៍ដែលថា ខ្មែរក្រហមបដិសេធមិនបង្ហាញព័ត៌មានអំពីទីកន្លែងរបស់ប្រជាជនដែលត្រូវជម្លៀសដោយចេតនា ឬអចេតនា ក្តី គឺមិនពាក់ព័ន្ធនឹងប្រការដែលថាតើធាតុផ្សំនៃឧក្រិដ្ឋកម្មអមនុស្សធម៌ផ្សេងៗទៀតត្រូវបានបំពេញឬអត់ នោះឡើយ[3741]។

[3738] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៤៨។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៧១។ សាលក្រមក្នុងរឿងក្តី *Gotovina* កថាខណ្ឌ ១៨៣៧។ លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៧(២)(ឈ)។ ធាតុផ្សំនៃបទឧក្រិដ្ឋរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា មាត្រា៧(១)(ឈ) ធាតុផ្សំពី១-៤។ អនុសញ្ញាអន្តរជាតិស្តីពីការការពារមនុស្សគ្រប់រូបពីការបាត់ខ្លួនដោយបង្ខំ មាត្រា២។

[3739] *សូមមើល* កថាខណ្ឌ ១០១០ ខាងលើ។

[3740] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥៨៩។

[3741] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៥៣។

ការផ្លាស់ទីលំនៅដោយបង្ខំ

1029. អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក[3742] និងតុលាការអន្តរជាតិផ្សេងៗទៀត[3743] បានយល់ឃើញថា ការផ្លាស់ទីលំនៅដោយបង្ខំ ដែលជាការផ្លាស់ទីលំនៅដោយបង្ខំ នៅក្នុងព្រំដែនជាតិរបស់បុគ្គលចេញពីតំបន់មួយដែលពួកគេកំពុងរស់នៅដោយស្របច្បាប់ ដែលពុំមែនដោយសារមូលហេតុការពារ ឬសារមន្ទីរទាក់ទងនឹងសន្តិសុខរបស់ប្រជាជនស៊ីវិល ឬភាពចាំបាច់ផ្នែកយោធា[3744] អាចមានស្ថានទម្ងន់ទោសប្រហាក់ប្រហែលទៅនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយហេតុដូច្នេះត្រូវបានចាត់ចូលទៅក្នុងក្រុម "អំពើអមនុស្សធម៌ផ្សេងៗទៀត"។ តាមការពិត ការអនុវត្តការផ្លាស់ទីលំនៅដោយបង្ខំ គឺដូចទៅនឹងការបណ្តេញចេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវបានចែងនៅក្នុងច្បាប់ អ.វ.ត.ក[3745] ហើយចំណុចខុសគ្នាពាក់ព័ន្ធនឹងទិសដៅនៃការផ្លាស់ទីលំនៅដោយបង្ខំ "មិនមានការពាក់ព័ន្ធទៅនឹងការផ្តោតលទ្ធផលនៃការអនុវត្តបែបនោះ" នោះឡើយ[3746]។ នាពេលបច្ចុប្បន្ន តុលាការឧក្រិដ្ឋកម្មអន្តរជាតិ ទទួលស្គាល់ថា ការផ្លាស់ទីលំនៅដោយបង្ខំគឺជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដាច់ដោយឡែកមួយ[3747]។ ការផ្លាស់ទីលំនៅដោយបង្ខំ ក៏ត្រូវបានរកឃើញថាកើនឡើងទៅដល់កម្រិតនៃភាពធ្ងន់ធ្ងររបស់ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងៗទៀតផងដែរ និងចាត់ទុក

[3742] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៥៤-៤៥៥ និងសេចក្តីដកស្រង់ក្នុងសាលក្រមនោះ។

[3743] សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៣១៧។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥២៣។ សាលក្រមក្នុងរឿងក្តី *Kupreškić* កថាខណ្ឌ ៥៦៦។

[3744] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៤៥០។ សាលក្រមក្នុងរឿងក្តី *Blagojević* កថាខណ្ឌ ៥៩៥។

[3745] សេចក្តីសម្រេចឲ្យរួចខ្លួនក្នុងរឿងក្តី *Milošević* កថាខណ្ឌ ៧៩។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២១៨។ *សូមមើលបន្ថែម* លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ កថាខណ្ឌ ៧(២)(ឃ)។

[3746] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ៤៩១។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២១៨។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៥២២។ ដូចអង្គជំនុំជម្រះសាលាឧទ្ធរណ៍ក្នុងរឿងក្តី *Krnojelac* បានពន្យល់ "ការហាមឃាត់ចំពោះការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ មានគោលបំណងការពារសិទ្ធិ និងសេចក្តីប្រាថ្នារបស់បុគ្គលទាំងឡាយ ក្នុងការរស់នៅក្នុងសហគមន៍ និងគេហដ្ឋានរបស់ខ្លួនដោយគ្មានការជ្រៀតជ្រែកពីខាងក្រៅ។ លក្ខណៈនៃការផ្លាស់ប្តូរទីកន្លែងដោយបង្ខំ និងការបណ្តេញអ្នកស្រុកចេញពីដែនដីមួយដោយបង្ខំ គឺជាការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ចារី មិនមែនគោលដៅដែលអ្នកស្រុកទាំងនោះត្រូវបានបញ្ជូនទៅឡើយ"។

[3747] លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា(៧)(១)(ឃ)។

ការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[3748] ព្រមទាំងចាត់ទុកបទល្មើសនៃការបណ្តេញចេញ ឬការផ្លាស់ទីលំនៅជនស៊ីវិលដោយខុសច្បាប់ គឺជាការរំលោភបំពានដ៏ធ្ងន់ធ្ងរ[3749]។ ហេតុដូច្នេះ លក្ខខណ្ឌតម្រូវស្តានទម្ងន់ទោស សម្រាប់ការចាត់ចំណាត់ថ្នាក់នៃអង្គហេតុដែលជាធាតុផ្សំនៃការផ្លាស់ទីលំនៅដោយបង្ខំ ថាជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ត្រូវបានបំពេញបានយ៉ាងជាក់ច្បាស់។

២. ទម្រង់នៃការទទួលខុសត្រូវ

1030. មាត្រា*២៩ថ្មី* នៃច្បាប់ អ.វ.ត.ក ចែងអំពីការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលរបស់ជនជាប់ចោទដែល ១) រៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ ឬប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក និង ២) ផ្ទាក់លើដែលខកខានមិនបង្ការទប់ស្កាត់ ឬដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានចែងនៅក្នុងច្បាប់ អ.វ.ត.ក ដោយអ្នកនៅក្រោមបង្គាប់របស់ពួកគេ។ ចំណុចទាំងអស់នេះត្រូវបានចែងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥[3750]។ ទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌទាំងនេះ ត្រូវបានពិពិណនាលម្អិតជាងនេះ នៅខាងក្រោម។

[3748] សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ២២២។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ១៥៣។

[3749] អនុសញ្ញាក្រុងហ្ស៊ីណែវ (IV) មាត្រា១៤៧។ សាលក្រមក្នុងរឿងក្តី *Naletilić* កថាខណ្ឌ ៥១៣-៥២៧។

[3750] សំណុំរឿងលេខ ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្ភាសហេតុ) កថាខណ្ឌ ៧៨ (*រើងទំព័រលេខ* ១១៣ និងសេចក្តីដកស្រង់នៅក្នុងដីកាដំណោះស្រាយនោះ)។

ក. ដែលបានប្រព្រឹត្ត

i. ការប្រព្រឹត្តដោយផ្ទាល់

1031. ការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ អាចកើតឡើងតាមរយៈអំពើសកម្ម ឬអកម្ម[3751] និងមិនកម្រិតត្រឹមតែការប្រព្រឹត្តអំពើសកម្មដោយផ្ទាល់នោះឡើយ[3752]។ ចារីត្រូវមានចេតនាប្រព្រឹត្តបទឧក្រិដ្ឋនោះ[3753]។ ចេតនារួមបញ្ចូល (i) ចេតនាផ្ទាល់ប្រព្រឹត្តបទឧក្រិដ្ឋ (ចេតនាផ្ទាល់ កម្រិតទី១) (ii) ការយល់ដឹងថាបទឧក្រិដ្ឋនឹងកើតឡើងនៅក្នុងកិច្ចដំណើរធម្មតានៃព្រឹត្តិការណ៍ ឬនិយាយម្យ៉ាងទៀត ការយល់ដឹងអំពីលទ្ធភាពខ្ពស់ដែលថា បទឧក្រិដ្ឋនឹងកើតឡើង (ចេតនាផ្ទាល់ កម្រិតទី២)[3754] និង (iii) ចេតនា

[3751] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៤៨០។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ១៨៨។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៧៨។

[3752] សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៤៣១។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ៦០។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ១៦១ [រំលឹកឡើងវិញថា "ការប្រព្រឹត្ត" មិនកម្រិតត្រឹមតែការប្រព្រឹត្តដោយផ្ទាល់ និងការប្រព្រឹត្តដោយរូបកាយប៉ុណ្ណោះទេ និងថា អំពើផ្សេងទៀតអាចបង្កើតនូវការចូលរួមដោយផ្ទាល់ក្នុង*អំពើពិរុទ្ធ*នៃបទឧក្រិដ្ឋ"។ នៅក្នុងករណីនៃតុលាការអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដាទាំងនេះ ការប្រព្រឹត្តរាប់បញ្ចូលទាំងសកម្មភាពដែលជា "ផ្នែករួមនៃអំពើប្រល័យពូជសាសន៍ ហើយដែលជាការសម្លាប់ដែលត្រូវសកម្មភាពនោះបង្កឲ្យកើតមានឡើង"។ នៅក្នុងរឿងក្តី *Seromba* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានធ្វើការសន្និដ្ឋានថា *Seromba* "បានសម្រេចយល់ព្រម និងប្រកាន់យកជារបស់ខ្លួនផ្ទាល់" នូវសេចក្តីសម្រេចចិត្ត ក្នុងការបំផ្លិចបំផ្លាញព្រះវិហារគ្រិស្តសាសនា ដើម្បីសម្លាប់ជនភៀសខ្លួនទុតស៊ី]។ *សូមមើលផងដែរ* លក្ខន្តិក:តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា២៥(៣)(ក) បញ្ជាក់អះអាងថា ចារីអាចប្រព្រឹត្តឧក្រិដ្ឋកម្ម "តាមរយៈមនុស្សម្នាក់ទៀត"។ ទស្សនៈ "ចារីតាមរយៈមធ្យោបាយ" ត្រូវបានទទួលស្គាល់ដោយប្រព័ន្ធច្បាប់ចម្បងៗរបស់ពិភពលោក។ *សូមមើលឧទាហរណ៍*៖ ក្រមព្រហ្មទណ្ឌគំរូ (ឆ្នាំ១៩៦២) ផ្នែក២.០៦(១)-(២)។ សៀវភៅនិពន្ធដោយ Archbold ដែលមានចំណងជើងថា ការជជែកតវ៉ាក្តីព្រហ្មទណ្ឌ៖ ភ័ស្តុតាង និងការអនុវត្ត (ឆ្នាំ២០០៧) (§18-7)។

[3753] *ពាលគឺ* គាត់ត្រូវតែបំពេញធាតុផ្សំអន្តនោម៉ាតនៃឧក្រិដ្ឋកម្មដែលពាក់ព័ន្ធ។

[3754] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៤៨១។ សំណុំរឿងលេខ ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៧៩។ សាលក្រមក្នុងរឿងក្តី *Lukić & Lukić* កថាខណ្ឌ ៩០០។ សាលក្រមក្នុងរឿងក្តី *Limaj* កថាខណ្ឌ ៥០៩។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២៥១។ *សូមមើលផងដែរ*លក្ខន្តិក:តុលាការព្រហ្មទណ្ឌអន្តរជាតិ មាត្រា៣០(២)(ខ)។ និយមន័យនៃពាក្យ ចេតនា នេះ ស៊ីសង្វាក់គ្នាជាមួយលក្ខខណ្ឌបំណងឧក្រិដ្ឋនៃទម្រង់នៃការទទួលខុសត្រូវដោយផ្ទាល់ដទៃទៀត៖ ការធ្វើផែនការ ការញុះញង់ និងការបញ្ជា។

ប្រយោល[3755] ពោលគឺ ចារី ប្រមើលមើលឃើញជាមុនទូរលទ្ធភាព[3756] នៃលទ្ធផលចេញពីការប្រព្រឹត្តរបស់គាត់ ហើយគាត់ទទួលយកលទ្ធភាពនោះ[3757]។ នេះគឺជាធាតុផ្សំចេតនានៃចេតនា

[3755] *ចេតនាដោយប្រយោល* ជាទម្រង់នៃចេតនាសម្រាប់ឧក្រិដ្ឋកម្មអន្តរជាតិ ត្រូវបានរកឃើញនៅក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ (*សូមមើលឧទាហរណ៍*៖ សាលក្រម*វេជ្ជសាស្ត្រ* ទំព័រ ១៨៩-២០៧, ២៣៥-២៤១, ២៥៣-២៦៣, ២៧១, ២៨៤, ២៩០ [ដែលក្នុងនោះតុលាការយោធាអាមេរិកបានកាត់ទោសជនជាប់ចោទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយចំនួនពីបទមនុស្សឃាតកម្មពាក់ព័ន្ធក្នុងការពិសោធន៍វេជ្ជសាស្ត្រដែលបានបង្ករគ្រោះថ្នាក់រាងកាយធ្ងន់ធ្ងរដល់ជនរងគ្រោះ។ ជនជាប់ចោទ មានចេតនាបង្ករគ្រោះថ្នាក់លើរាងកាយដោយផ្ទាល់ ប៉ុន្តែបានបន្តជាមួយការពិសោធន៍នោះទាំងបានដឹងដោយសមហេតុផលថា ការស្លាប់របស់ជនរងគ្រោះ គឺជាផលវិបាកដែលអាចកើតឡើងពីសកម្មភាពរបស់ខ្លួន]) និងត្រូវបានគាំទ្រជាក់ស្តែងដោយយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គូស្លាវី (*សូមមើលឧទាហរណ៍*៖ សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៥៨៧, ៦៤២) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ (*សូមមើល*សេចក្តីសម្រេចអះអាងក្នុងរឿងក្តី *Lubanga* កថាខណ្ឌ ៣៥២។ សហព្រះរាជអាជ្ញាអន្តរជាតិកត់សម្គាល់ថា ទោះបីជាអង្គបុរេជំនុំជម្រះ និងក្រោយមក អង្គជំនុំជម្រះសាលាដំបូងតុលាការព្រហ្មទណ្ឌអន្តរជាតិ យល់ឃើញថា មាត្រា៣០ នៃលក្ខន្តិក:តុលាការព្រហ្មទណ្ឌអន្តរជាតិគ្របដណ្តប់តែចេតនាដោយផ្ទាល់ប៉ុណ្ណោះក៏ដោយ ក៏អង្គជំនុំជម្រះនេះធ្វើដូច្នេះផ្អែកលើការបកស្រាយពាក្យពេចន៍ជាក់លាក់នៃបញ្ញត្តិនោះដែរ មិនមែនជាការផ្ទុះបញ្ចាំងលើច្បាប់ទំនៀមទម្លាប់អន្តរជាតិឡើយ (*សូមមើលឧទាហរណ៍*៖ សេចក្តីសម្រេចបញ្ជាក់អះអាងក្នុងរឿងក្តី *Bemba* កថាខណ្ឌ ៣៦២-៣៦៣។ សាលក្រមក្នុងរឿងក្តី *Lubanga* កថាខណ្ឌ ១០១១)។ នៅក្នុងយុត្តាធិការប្រព័ន្ធច្បាប់ស៊ីវិលជាច្រើន "ចេតនា" មិនត្រឹមតែរាប់បញ្ចូលចេតនាដោយផ្ទាល់ (នៃកម្រិតទី១ និងទី២) ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរាប់បញ្ចូល*ចេតនាដោយប្រយោល*ទៀតផង។ *សូមមើល ឧទាហរណ៍*៖ **ប្រទេសអាល្លឺម៉ង់**៖ Joecks in *Münchener Kommentar zum StGB*, 3rd ed (2017), Mn 31 ["Als dritte Vorsatzart ist der bedingte Vorsatz (dolus eventualis) anerkannt." បកប្រែដោយការិយាល័យសហព្រះរាជអាជ្ញា៖ "ចេតនាដោយប្រយោល ត្រូវបានទទួលស្គាល់ជាទម្រង់ទីបីនៃចេតនា"]។ Sternberg-Lieben/Schuster in Schönke/Schröder (eds.), *Strafgesetzbuch Kommentar*, §15, Mn 88-89 [„Eventualvorsatz genügt bei allen Delikten, bei denen nicht Absicht iS zielgerichteten Handelns oder ein Verhalten wider besseren Wissens verlangt wird." បកប្រែដោយការិយាល័យសហព្រះរាជអាជ្ញា៖ "*ចេតនាដោយប្រយោល* គឺគ្រប់គ្រាន់សម្រាប់បទល្មើសទាំងអស់ ដែលមិនតម្រូវឲ្យមានចេតនាក្នុងន័យនៃសកម្មភាពដែលមានគោលបំណង និងការប្រព្រឹត្តប្រឆាំងនឹងការដឹងច្បាស់របស់បុគ្គលម្នាក់"]។ Kudlich in Heintschel-Heinegg (ed.), *BeckOK*, 37th ed (2018) [„Vorsatz iSd §15 ist grds. auch bereits bei bedingtem Vorsatz gegeben. […] Bei einigen Delikten allerdings stellt der Gesetzgeber durch Formulierungen wie „absichtlich oder wissentlich" […], „wider besseres Wissen" […] oder „in der Absicht" erhöhte Anforderungen an den Vorsatzgrad zumindest hinsichtlich einzelner Tatbestandsmarkmale. In diesen Fällen setzt der subjektive Tatbestand voraus, dass gerade auch dieser Vorsatzgrad erreicht ist." បកប្រែដោយការិយាល័យសហព្រះរាជអាជ្ញា៖ "ចេតនាក្នុងន័យនៃផ្នែកទី១៥ ជាគោលការណ៍ ក៏ត្រូវបានបំពេញដោយចេតនាដោយប្រយោលផងដែរ។ […] សម្រាប់ឧក្រិដ្ឋកម្មមួយចំនួន អ្នកធ្វើច្បាប់កំណត់លក្ខខណ្ឌតម្រូវខ្ពស់ជាងនេះសម្រាប់កម្រិតនៃចេតនា តាមរយៈការប្រើប្រាស់ពាក្យពេចន៍ដូចជា "ដោយមានគោលបំណង ឬដោយការដឹង" […] "ប្រឆាំងនឹងការដឹងរបស់បុគ្គលណាម្នាក់" […] ឬ "ដោយមានគោលបំណង" យ៉ាងហោចណាស់ទាក់ទងនឹងធាតុផ្សំសម្ភារៈមួយចំនួន។ ក្នុងករណីទាំងនេះ ធាតុផ្សំអត្តនោម័តតម្រូវឲ្យឈានដល់កម្រិតនៃចេតនាជាក់លាក់នេះ"]។ *សូមមើលផងដែរ* សៀវភៅនិពន្ធដោយ Michael Bohlander *គោលការណ៍នៃច្បាប់ព្រហ្មទណ្ឌអាល្លឺម៉ង់* ទំព័រ ៦៧ ["ដោយលើកលែងបទល្មើសដែលស្ថិតក្នុងប្រភេទនៃចេតនាដោយផ្ទាល់ វិធាន គឺថា បទល្មើសប្រកបដោយចេតនាណាមួយ អាចត្រូវបានប្រព្រឹត្ត

ឡើងដោយចេតនាដោយផ្ទាល់ក្នុងកម្រិតទី២ ឬចេតនាដោយប្រយោល រៀងលែងតែលក្ខណៈធាតុផ្សំនៃបទល្មើសដែលចេតនានោះ សំដៅដល់ បដិសេធជាមុនទូវចេតនាដោយប្រយោល"]។ **ប្រទេសស្វ៊ីស**៖ ក្រមព្រហ្មទណ្ឌប្រទេសស្វ៊ីស (ឆ្នាំ២០១៨) មាត្រា១២ (១)-(២) ["(១) រៀងលែងតែមានច្បាប់ចែងច្បាស់ផ្ទុយពីនេះ មនុស្សម្នាក់ទទួលខុសត្រូវចំពោះការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈឹម លុះត្រាតែបុគ្គលនោះប្រព្រឹត្តដោយចេតនា។ (២) [...] បុគ្គលម្នាក់ធ្វើអំពើដោយចេតនា នៅពេលដែលបុគ្គលនោះចាត់ទុកការសម្រេចអំពើនោះថាអាចកើតឡើងបាន ហើយទទួលយកការសម្រេចអំពើនេះ"។ បញ្ញត្តិនេះនៅតែមិនធ្វើវិសោធនកម្មនៅឡើយទេ យ៉ាងហោចណាស់ចាប់តាំងពីឆ្នាំ១៩៧១]។ **ប្រទេសអ៊ីតាលី**៖ ក្រមព្រហ្មទណ្ឌប្រទេសអ៊ីតាលី (ឆ្នាំ១៩៣០) មាត្រា៤៣ ["Il delitto: è doloso, o secondo l'intenzione, quando l'evento dannoso o pericoloso, che è il risultato dell'azione od omissione e da cui la legge fa dipendere l'esistenza del delitto, è dall'agente preveduto e voluto come conseguenza della propria azione od omissione." បកប្រែក្រៅផ្លូវការដោយការិយាល័យសហព្រះរាជអាជ្ញា៖ "ឧក្រិដ្ឋកម្ម៖ គឺដោយចេតនា ឬមានចេតនា នៅពេលដែលហេតុការណ៍ប្រកបដោយពៃរសនកម្ម ឬគ្រោះថ្នាក់ ដែលជាលទ្ធផលនៃអំពើសកម្ម ឬអំពើអកម្ម និងដែលជាបង្អែកនៃច្បាប់ដែលបង្កើតអត្ថិភាពនៃឧក្រិដ្ឋកម្ម ត្រូវបានប្រមើលឃើញដោយចារី និងចង់បានជាផលវិបាកនៃអំពើសកម្ម ឬអំពើអកម្មរបស់គាត់"។ ស្តង់ដារនេះរាប់បញ្ចូលទាំង*ចេតនាដោយប្រយោល*។ *សូមមើល* Cass. Pen., Sez. un., 24.4.2014, n. 38343, Espenhahn កថាខណ្ឌ ៤៣.២, ៥០ ["កថាខណ្ឌ ៤៣.២៖ "Il dolo eventuale, dunque, in quanto espressione di una volontà pianificatrice, non risulta in opposizione con l'immagine del delitto doloso fornita dall'art. 43 cod. pen.. In sintesi si può dire che nel dolo eventuale, oltre all'accettazione del rischio o del pericolo vi è l'accettazione, sia pure in forma eventuale, del danno, della lesione, in quanto essa rappresenta il possibile prezzo di un risultato desiderato [...] para. 50: "ma ove concretamente superato, avendo l'agente optato per la condotta anche a costo di cagionare l'evento, volitivamente accettandolo quindi nella sua prospettata verificazione, lascia sussistere il dolo eventuale." បកប្រែដោយការិយាល័យសហព្រះរាជអាជ្ញា៖ "ដូច្នេះ ជាការបង្ហាញពីចេតនាក្នុងការធ្វើផែនការ, *ចេតនាដោយប្រយោល* មិនផ្ទុយគ្នាពីសញ្ញាណនៃបទឧក្រិដ្ឋដោយចេតនា ដែលមានចែងក្នុងមាត្រា ៤៣ នៃក្រមព្រហ្មទណ្ឌនេះឡើយ។ ដោយសង្ខេប គេអាចនិយាយបានថា ទស្សនៈនៃ*ចេតនាដោយប្រយោល* មិនត្រឹមតែរាប់បញ្ចូលនូវការទទួលយកហានិភ័យ ឬគ្រោះថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការទទួលយកនូវការខូចខាត ឬពៃរសនកម្ម សូម្បីតែតាមវិធីដែលអាចធ្វើបាន ក្នុងកម្រិតមួយដែលការទទួលយកនេះបង្កើតនូវតម្លៃនៃលទ្ធផលដែលចង់បានទៀតផង។ [...] តាមរយៈការជ្រើសរើសយកការប្រព្រឹត្តនេះ ទោះបីជាការប្រព្រឹត្តនេះនឹងធ្វើឡើងក្នុងបំណងបង្កឲ្យមានហេតុការណ៍ឧក្រិដ្ឋ ចារីនឹងទទួលយកដោយស្ម័គ្រចិត្តនូវឧប្បត្តិហេតុដែលអាចមាននៃហេតុការណ៍ឧក្រិដ្ឋ និងអំពើដែលមាន*ចេតនាដោយប្រយោល*]។ **អាហ្ស្ត្រាលីខាងត្បូង**៖ E M Burchell និង P M A Hunt *ច្បាប់ និងទ្រឹតិវិធីព្រហ្មទណ្ឌនៃប្រទេសអាហ្ស្ត្រាលីខាងត្បូង៖ គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ* (ឆ្នាំ១៩៨៣) ១៤១ [កំណត់និយមន័យចេតនាច្បាប់ទាក់ទងនឹងផលវិបាកជា "ការប្រមើលឃើញមុនរបស់ជនជាប់ចោទថា ផលវិបាកអាចកើតឡើងគួបផ្សំជាមួយការធ្វេសប្រហែសចំពោះថាតើផលវិបាកកើតឡើង ឬមិនកើតឡើង" *ដកស្រង់* (ទំព័រ ១៤៤) *R v Horn* ១៩៥៣ (៣) SA ៤៥៧ (ក)]។ Paizes *ចេតនាដោយប្រយោល ត្រូវបានពិចារណាឡើងវិញ, ទិន្នានុប្បវត្តិច្បាប់លេខ៦៣៦ នៃប្រទេសអាហ្ស្ត្រាលីខាងត្បូងឆ្នាំ*១៩៨៨ ["ពុំមានទស្សនៈជាមូលដ្ឋានថែមទៀតនៅក្នុងច្បាប់ព្រហ្មទណ្ឌរបស់យើង លើសពី*ចេតនាដោយប្រយោល ឬចេតនាផ្ទូវច្បាប់ឡើយ*"]។ សាលដីកាក្នុងរឿងក្តី*រដ្ឋ តទល់នឹង De Bruyn* (ឆ្នាំ១៩៦៨) ទំព័រ ៥០៦, ៥១០-៥១២ [សម្រេចថា វាជាការគ្រប់គ្រាន់សម្រាប់ការរកឃើញពីចេតនាផ្ទូវច្បាប់ បើសិនជាជនជាប់ចោទបានដឹងមុនពីភាពអាចកើតឡើងនៃអត្ថិភាពរបស់កាលៈទេសៈ និងមានការធ្វេសប្រហែសអំពីថាតើអត្ថិភាពនោះបានកើតឡើង ឬអត់]។ សាលដីកាក្នុងរឿងក្តី *រដ្ឋ តទល់នឹង Malinga* (ឆ្នាំ១៩៦៣) ទំព័រ ៦៩៤ [រកឃើញថា ក្នុងការពិចារណាលើបញ្ហាចេតនាក្នុងការសម្លាប់ តេស្តគឺថា តើជនជាប់ចោទបានប្រមើលដឹងមុនពីលទ្ធភាពដែលថា អំពើនោះនឹងមានផលវិបាកដល់ស្លាប់ និងធ្វេសប្រហែសថា តើការស្លាប់បានកើតឡើងដែរឬអត់]។ **ប្រទេសប៉ូឡូញ**៖ ក្រមព្រហ្មទណ្ឌប្រទេសប៉ូឡូញ (ឆ្នាំ១៩៩៧) មាត្រា៩(១) ["អំពើដែលច្បាប់បានហាម

ប្រយោល ពោលគឺ ចារីពិតជាបានប្រមើលមើលឃើញជាមុននូវលទ្ធភាពនៃការកើតឡើងនូវបទឧក្រិដ្ឋ ហើយគាត់ទទួលយកការកើតឡើងនូវបទឧក្រិដ្ឋនោះ ដែលផ្ទុយទៅនឹងការណ៍ដែលថាគ្រាន់តែអាចប្រមើលមើលឃើញមុន ដោយសត្យានុម័តនូវលទ្ធភាពនៃការកើតឡើងបទឧក្រិដ្ឋ ដែលបញ្ហានេះត្រូវគេចាត់ទុកថាជាទម្រង់មួយនៃចេតនា។ ហេតុដូច្នេះ វាក៏ខុសប្លែកពីធាតុផ្សំអត្តនោម័តិ ដែលតម្រូវឲ្យមានត្រឹមតែការយល់ដឹងថា បទឧក្រិដ្ឋមួយ នឹង ឬ អាចកើតឡើង។ បទឧក្រិដ្ឋមួយចំនួន តម្រូវថា ធាតុផ្សំអត្តនោម័តិបន្ថែម ត្រូវបង្ហាញថា ភ័ស្តុតាងជាធាតុផ្សំនៃបទល្មើស ហើយនៅក្នុងករណីនោះ ធាតុផ្សំទាំងនោះក៏ត្រូវបង្ហាញផងដែរ។

ឃាត់ត្រូវបានប្រព្រឹត្តដោយចេតនា នៅពេលដែលចារីមានបំណងក្នុងការប្រព្រឹត្តអំពើនោះ គឺថា នៅពេលដែលគាត់មានបំណងក្នុងការប្រព្រឹត្ត ឬប្រមើលដឹងមុនពីភាពអាចកើតឡើងនៃការប្រព្រឹត្តអំពើនោះ គាត់នៅតែទទួលយក"។ បញ្ញត្តិនេះត្រូវបានបញ្ជាក់ឡើងវិញនៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៦៩ និង១៩៣២ (*សូមមើល*សំណុំរឿងលេខ ០០២ ឯកសារ F36 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ ជើងទំព័រលេខ ៩៩)]។ **ប្រទេសព័រទុយហ្គាល់៖** ក្រមព្រហ្មទណ្ឌប្រទេសព័រទុយហ្គាល់ (ឆ្នាំ២០០៦) មាត្រា១៤ (៣) ["នៅពេលដែលការសម្រេចអំពើមួយដែលបង្កើតនូវប្រភេទនៃឧក្រិដ្ឋកម្មមួយ ត្រូវបានបង្ហាញថាជាផលវិបាកដែលអាចកើតឡើងនៃការប្រព្រឹត្តនោះ ដោយចេតនា ប្រសិនបើភ្នាក់ងារនោះប្រព្រឹត្តអំពើដោយទទួលការសម្រេចអំពើនោះ"]។ **ប្រទេសចិន៖** ច្បាប់ព្រហ្មទណ្ឌនៃសាធារណរដ្ឋប្រជាមានិតចិន (ឆ្នាំ១៩៩៧) មាត្រា១៤ ["ឧក្រិដ្ឋកម្មដោយចេតនាសំដៅដល់ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយបុគ្គលដែលដឹងច្បាស់ថា អំពើរបស់ខ្លួននឹងបង្កើតនូវផលវិបាកដែលមានគ្រោះថ្នាក់ដល់សង្គម ប៉ុន្តែគាត់ប្រាថ្នា ឬអនុញ្ញាតឲ្យផលវិបាកបែបនោះកើតឡើង។ ការទទួលខុសត្រូវព្រហ្មទណ្ឌត្រូវមានសម្រាប់ឧក្រិដ្ឋកម្មដោយចេតនា"]។ **ប្រទេសរុស្ស៊ី៖** ក្រមព្រហ្មទណ្ឌនៃសហព័ន្ធរុស្ស៊ី (ឆ្នាំ១៩៩៦) មាត្រា២៥(១) (៣) ["១. អំពើមួយដែលត្រូវបានធ្វើឡើងដោយចេតនាច្បាស់លាស់ ឬដោយការធ្វេសប្រហែសជ្រុល ត្រូវទទួលស្គាល់ជាឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយចេតនា [...] ៣. ឧក្រិដ្ឋកម្មត្រូវចាត់ទុកថាបានត្រូវប្រព្រឹត្តដោយចេតនាដោយប្រយោល ប្រសិនបើបុគ្គលនោះបានដឹងអំពីគ្រោះថ្នាក់ផ្នែកសង្គមនៃអំពើរបស់ខ្លួន (អសកម្ម) បានដឹងមុនអំពីភាពអាចកើតឡើងនៃការចាប់ផ្តើមបង្កើតផលវិបាកប្រកបដោយគ្រោះថ្នាក់ដល់សង្គម មិនប្រាថ្នា តែបានបណ្តែតបណ្តោយឲ្យមានផលវិបាកទាំងនេះ ឬធ្វើមិនដឹងមិនឮចំពោះផលវិបាកទាំងនេះ"]។ **ប្រទេសហុងហ្គារី៖** ច្បាប់ Act C of 2012 ស្តីពីក្រមព្រហ្មទណ្ឌ ផ្នែកទី៧ ["បទល្មើសព្រហ្មទណ្ឌត្រូវបានប្រព្រឹត្តដោយចេតនា ប្រសិនបើបុគ្គលនោះបង្កើតផែនការ ដើម្បីសម្រេចលទ្ធផលណាមួយ ឬព្រមទទួលយកផលវិបាកនៃការប្រព្រឹត្តរបស់ខ្លួន"]។

[3756] ខណៈដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គូស្លាវី បានកត់សម្គាល់ក្នុងរឿងក្តី *Karadžić* "ស្តង់ដារភាពអាចកើតឡើងបាន' មិនត្រូវបានបំពេញដោយសេណារីយ៉ូពីចម្ងាយដែលមិនគួរឲ្យទុកចិត្តឡើយ [...] ស្តង់ដារនេះ [...] តម្រូវឲ្យភាពអាចកើតឡើងនៃឧក្រិដ្ឋកម្មដែលអាចត្រូវបានប្រព្រឹត្ត មានទម្លឹកករណ៍គ្រប់គ្រាន់ដែលបង្ហាញថា ជនជាប់ចោទអាចប្រមើលដឹងមុន"។ *សូមមើល*សេចក្តីសម្រេចលើភាពអាចប្រមើលដឹងមុនអំពីសហឧក្រិដ្ឋកម្ម្ឍមកម្រិតទីពាក្នុងរឿងក្តី *Karadžić* កថាខណ្ឌ ១៨។

[3757] *សូមមើល*សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៣៩០ *ដកស្រង់* សាលក្រមក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៥៨៧។

ii. សហឧក្រិដ្ឋកម្មរួម

1032. សហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវមួយ ដែលដាក់បន្ទុកការទទួលខុសត្រូវព្រហ្ម ទណ្ឌទៅលើបុគ្គលចំពោះអំពើ ដែលត្រូវបានប្រព្រឹត្តដោយក្រុមមនុស្សមួយក្រុម ដែលជួយដល់ការ រៀបចំផែនការឧក្រិដ្ឋរួមមួយ។ ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម ស្មើនឹងការប្រព្រឹត្តនៅក្នុង វិសាលភាពនៃមាត្រា ២៩ថ្មី របស់ច្បាប់ អ.វ.ត.ក[3758]។ យុត្តិសាស្ត្រអន្តរជាតិបានចង្អុលបង្ហាញ ទម្រង់សហឧក្រិដ្ឋកម្មរួមចំនួនបីផ្សេងគ្នាតែពាក់ព័ន្ធគ្នា គឺ៖ ទម្រង់**មូលដ្ឋាន** (សហឧក្រិដ្ឋកម្មរួមទម្រង់ ទី១) (JCE I) ដែលអ្នកចូលរួមទាំងអស់ធ្វើសកម្មភាពដោយ ប្រឹងប្រែងសម្រេចគោលដៅឧក្រិដ្ឋកម្ម រួមមួយ និងចែករំលែកចេតនាសំខាន់ៗសម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋមួយនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក នៅពេលគេធ្វើដូច្នោះ[3759] ទម្រង់**ជាប្រព័ន្ធ** (JCE II) ដែលជាទម្រង់មួយបែបរបស់ទម្រង់ មូលដ្ឋាន មានលក្ខណៈដូចខាងក្រោម៖ មានអត្ថិភាពនៃប្រព័ន្ធធ្វើបាបដែលមានការចាត់តាំង ដូចជា ជំរុំបង្ខាំង ឬប្រមូលផ្តុំ[3760] និងទម្រង់**ទូលាយ** (JCE III) ដែលត្រូវបានសម្រេចថាមិនអាចអនុវត្ត បានចំពោះមុខកិច្ចដំណើការនីតិវិធី អ.វ.ត.ក នោះឡើយ។

[3758] សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើប អង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៤៩។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេ ចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥១១។ សំណុំរឿងលេខ ០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបានទូវសហឧក្រិដ្ឋ កម្មរួម កថាខណ្ឌ ២២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩០។

[3759] សំណុំរឿងលេខ ០០១ ឯកសារ D99/3/42 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី របស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ១៣២។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៧។ សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩០។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ១៩៦-២០១។ សាលដីកាក្នុង រឿងក្តី *Vasiljević* កថាខណ្ឌ ៩៧។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ១៥៨។

[3760] សំណុំរឿងលេខ ០០១ ឯកសារ D99/3/42 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី របស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ១៣២។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៧។ សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេច របស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩០។ សាលដីកាក្នុងរឿងក្តី*Tadić* កថាខណ្ឌ ២០២-២០៣។ សាលដីកាក្នុង រឿងក្តី *Vasiljević* កថាខណ្ឌ ៩៨។

1033. អង្គជំនុំជម្រះតុលាការកំពូល អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង សុទ្ធតែបានរកឃើញថា នៅត្រឹមឆ្នាំ១៩៧៥ ទាំងទម្រង់**មូលដ្ឋាន** (JCE I) និងទម្រង់**ជាប្រព័ន្ធ** (JCE II) ត្រូវបានចាត់ទុកថាជាទម្រង់នៃការទទួលខុសត្រូវ ដោយអនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ[3761] ហើយការទទួលខុសត្រូវព្រហ្មទណ្ឌពាក់ព័ន្ធនឹងទម្រង់ទាំងនេះ គឺអាចរកបាន និងអាចព្យាករជាមុនបាន[3762]។ អង្គជំនុំជម្រះដដែលបានសម្រេចថា ទម្រង់**ទូលាយ** (JCE III) មិនមានអត្ថិភាពនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅត្រឹមឆ្នាំ១៩៧៥ នោះឡើយ[3763]។

ធាតុផ្សំសត្យានុម័ត

1034. ទម្រង់**មូលដ្ឋាន** (JCE I) ត្រូវនឹងអង្គហេតុរបស់សំណុំរឿង ០០៤ ទាំងស្រុង។ ធាតុផ្សំសត្យានុម័តមានធាតុបី។ ទីមួយ ត្រូវមាន "មនុស្សច្រើននាក់"[3764]។ ក្រុមមនុស្សនោះ មិនចាំបាច់ត្រូវបានគេ

[3761] សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៥៧-៧២។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥១១-៥១២។ សំណុំរឿងលេខ ០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ២២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩១។ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៧៩-៧៨៩, ៨០៧-៨១០។

[3762] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១០៩៣។ សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧២។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥១២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩១។

[3763] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៩១-៨០៧។ សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៧, ៨៣, ៨៧-៨៨។ សំណុំរឿងលេខ ០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៨។

[3764] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩២។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៧។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤៣០។ សាលដីកាក្នុងរឿងក្តី *Munyakazi* កថាខណ្ឌ ១៦០។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ៧៥។

រៀបចំនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាល នយោបាយ ឬយោធា ណាមួយឡើយ[3765]។ ចាំបាច់ត្រូវកំណត់ថា មានមនុស្សច្រើននាក់បានចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម ប៉ុន្តែប្រហែលជាមិនចាំបាច់កំណត់អំពីប្រភេទក្រុមនៃអ្នកចូលរួម និងប្រាប់ឈ្មោះរបស់បុគ្គលនោះឡើយ[3766]។

1035. ទីពីរ ត្រូវមានគោលបំណងរួម[3767] ដែលមានន័យស្មើនឹង[3768] ឬពាក់ព័ន្ធនឹង[3769] ការប្រព្រឹត្តបទឧក្រិដ្ឋណាមួយនៅក្រោមយុត្តាធិការបស់ អ.វ.ត.ក[3770]។ នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា៖

> ពុំចាំបាច់ថា អ្នកដែលយល់ស្របជាមួយគោលបំណងរួមជាក់ស្តែងត្រូវតែ*មានចេតនា* ចង់ឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនោះទេ ដរាបណាអ្នកទាំងនោះបានទទួលស្គាល់ថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្តដើម្បីសម្រេចគោលបំណងចុងក្រោយ។ នេះអាចរួមបញ្ចូលបទឧក្រិដ្ឋដែល

[3765] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៧។ សាលដីកាក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ១០០។

[3766] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩២។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៥២២។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤៣០។ សាលដីកាក្នុងរឿងក្តី *Nizeyimana* កថាខណ្ឌ ៣១៨។

[3767] ពោលគឺ គោលបំណងនេះត្រូវរួមគ្នា។ វាមិនគ្រប់គ្រាន់ទេដែលសមាជិកដែលត្រូវបានចោទប្រកាន់នៃក្រុមភាគច្រើនដោយឡែកៗពីគ្នា មានគោលបំណងដូចគ្នា។ *សូមមើល* សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤៣០។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១០៣៤, ១១៤០។

[3768] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨០៧ ["គោលបំណងរួម 'គឺជា' ការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើការប្រព្រឹត្តបទឧក្រិដ្ឋនោះ គឺជា ឬស្ថិតក្នុងចំណោមគោលដៅចម្បងនៃគោលបំណងរួម"]។

[3769] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨០៨ ["គោលបំណងរួម មានការ 'ជាប់ពាក់ព័ន្ធ' ទៅនឹងការប្រព្រឹត្តបទឧក្រិដ្ឋ ប្រសិនបើបទឧក្រិដ្ឋនោះ គឺជា*មធ្យោបាយ* ដើម្បីសម្រេចគោលដៅចុងក្រោយមួយ (ដែលគោលដៅនេះអាចពុំមែនជាបទឈ្មើស)"] *ដកស្រង់* សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ៨០។

[3770] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៨៩, ៨១៤។ សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៨។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបានទូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩២។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៧។ សាលដីកាក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ១០០។ សាលដីកាក្នុងរឿងក្តី *Munyakazi* កថាខណ្ឌ ១៦០។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ៧៥។

ត្រូវបានគិតទុកជាមុនធ្វើជាមធ្យោបាយក្នុងការសម្រេចគោលបំណងរួមណាមួយនោះ *បើទោះបីជាការប្រព្រឹត្តពុំមានលក្ខណៈច្បាស់លាស់ក៏ដោយ*។ [...] ដូច្នេះ ប្រសិនបើគោលដៅនៃគោលបំណងរួមអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋ និងមានការព្រមព្រៀងគ្នាបន្តសម្រេចគោលដៅនេះ ដោយពុំគិតពីបញ្ហាពាក់ព័ន្ធនោះ ទើបកំណត់ថា បទឧក្រិដ្ឋទាំងនេះមានរួមបញ្ចូលនៅក្នុងគោលបំណងរួម ព្រោះបើទោះបីជាពុំមានចេតនាផ្ទាល់ក៏ដោយ ក៏បទឧក្រិដ្ឋនេះត្រូវបានគ្រោងទុកដោយគោលបំណងរួម។ បញ្ហាថាតើបទឧក្រិដ្ឋមួយមានរួមបញ្ចូលនៅក្នុងគោលបំណងរួមដែរ ឬយ៉ាងណានោះ ជាចម្បង គឺជាបញ្ហាអង្គហេតុ ដោយសារពុំមានការព្រមព្រៀងច្បាស់លាស់ ទើបតម្រូវឲ្យធ្វើការវាយតម្លៃដោយពិចារណាលើរាល់កាលៈទេសៈពាក់ព័ន្ធទាំងអស់ រួមទាំងគោលដៅទូទៅនៃគោលបំណងរួម និងភាពនីយភាពដែលថា គោលបំណងរួមអាចសម្រេចបាន លុះត្រាតែមានការប្រព្រឹត្តបទឧក្រិដ្ឋ។ អ្វីដែលត្រូវកត់សម្គាល់គឺថា គោលបំណងរួមអាចរួមបញ្ចូលបទឧក្រិដ្ឋដែលចាវីពុំមានចេតនាប្រព្រឹត្ត ឬពុំដឹងច្បាស់លាស់ [...][3771]។

អ្វីដែលស័ក្តិសមនឹងបញ្ជាក់នោះគឺថា នៅគ្រប់កាលៈទេសៈទាំងអស់ ដែលបានពិពណ៌នាខាងលើ មានការយល់ស្របគ្នាជាធ្លុងមួយ បើទោះបីជាក់ច្បាស់ក្តី ឬប្រយោលក្តី ទាក់ទងទៅនឹងបទឧក្រិដ្ឋរបស់អ្នក ដែលបានយល់ស្របជាមួយគោលបំណងរួម។ ដូច្នេះ សមាជិកនៃសហឧក្រិដ្ឋកម្មរួមត្រូវទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងជាគោលដៅ ទាំងជាផលវិបាកដែលជៀសមិនរួចនៃគោលបំណងបឋម ឬទាំងគ្មានការអើពើពីយថាហេតុ ដែលអាចកើតឡើងបាន[3772]។

1036. ហេតុដូច្នេះ ពុំចាំបាច់ទាល់តែគោលបំណងចុងក្រោយនៃផែនការរួមគឺជាបទឧក្រិដ្ឋ នោះឡើយ ដរាបណាអ្នកចូលរួមព្យាករថា ផែនការនឹងត្រូវអនុវត្តដោយមធ្យោបាយឧក្រិដ្ឋ ទាំងគោលបំណង និងមធ្យោបាយដែលត្រូវគេគិតថានឹងសម្រេចគោលបំណងនោះ គឺជាធាតុផ្សំនៃគម្រោង ឬផែនការរួម[3773]។ ហេតុដូច្នេះ គោលបំណងរួមគឺជាបទល្មើសព្រហ្មទណ្ឌ នៅពេលដែលវាមានទំនាក់ទំនង

[3771] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨០៨ (*បន្ថែមការសង្កត់ន័យ*)។

[3772] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨០៩ (*បន្ថែមពាក្យសង្កត់ន័យ*)។

[3773] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧៨៩។ សំណុំរឿងលេខ ០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៦។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៣០០។ *សូមមើលផង*

យ៉ាងជិតស្និទ្ធជាមួយនឹងគោលនយោបាយ ដែលការអនុវត្តគោលនយោបាយទាំងនោះ មានន័យស្មើនឹងការប្រព្រឹត្តបទឧក្រិដ្ឋ[3774]។ ពុំមានដែនកំណត់នៃវិសាលភាពរបស់សហឧក្រិដ្ឋកម្មរួម (JCE) នោះឡើយ ទាំងទិដ្ឋភាពភូមិសាស្ត្រ និងទិដ្ឋភាពផ្សេងៗទៀត ការទទួលខុសត្រូវរបស់ជនជាប់ចោទ "អាចមានលក្ខណៈតូចចង្អៀត ឬទូលំទូលាយ ដូចជាផែនការដែលពួកគេមានឆន្ទៈចូលរួម"[3775]។ នៅទីបញ្ចប់ គោលបំណងពុំចាំបាច់ត្រូវបានរៀបចំ ឬតាក់តែង តាំងពីមុននោះឡើយ។ វាអាចកើតមានដោយឥតព្រៀងទុក ឬអាចទាញយកអត្ថន័យបង្កប់ពីអង្គហេតុ[3776]។ សហឧក្រិដ្ឋកម្មរួម (JCE) អាចពង្រីកបន្ថែមដើម្បីរួមបញ្ចូលឧក្រិដ្ឋកម្មនានា ក្រៅពីឧក្រិដ្ឋកម្ម ដែលត្រូវបានគិតដល់តាំងពីដើមដំបូង ហើយនៅក្នុងកាលៈទេសៈនេះ ភ័ស្តុតាងនៃការព្រមព្រៀងពាក់ព័ន្ធនឹងការពង្រីករបស់វា គឺត្រូវគោរពតាមលក្ខខណ្ឌតម្រូវដូចគ្នាដែលត្រូវបានអនុវត្តចំពោះកិច្ចព្រមព្រៀងដើម។ ការណ៍នេះអាចកើតឡើង នៅពេលដែលសមាជិកសហឧក្រិដ្ឋកម្មរួម (JCE) ត្រូវបានប្រាប់អំពីការពង្រីកសកម្មភាពព្រហ្មទណ្ឌ ប៉ុន្តែពុំធ្វើអ្វីសោះដើម្បីបង្ការទប់ស្កាត់សកម្មភាពនោះ និងបន្តអនុវត្តការពង្រីក ដែលហេតុដូច្នេះប្រែក្លាយជាចេតនាប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលត្រូវបានពង្រីកទាំងនេះ[3777]។

ដែរ សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ស្តីពីសហឧក្រិដ្ឋកម្មរួមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ១៥ *ជើងទំព័រលេខ* ៦៣។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ៧៦, ៨០។

[3774] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១០៧៥។

[3775] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ *Rwamakuba* ប្រឆាំងនឹងដីកាសម្រេចលើការអនុវត្តសហឧក្រិដ្ឋកម្មរួមចំពោះបទប្រល័យពូជសាសន៍ កថាខណ្ឌ ២៥។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤២៥។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១០៦, ៣១៦។

[3776] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៧។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤១៧-៤១៩។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ៦០៩។

[3777] សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ១៦៣, ១៧០-១។ សាលក្រមក្នុងរឿងក្តី *Prlić* (ភាគទី១) កថាខណ្ឌ ២១២(២)។

1037. ទីបី ជនជាប់ចោទ ពិតជាបានចូលរួមក្នុងគោលបំណងរួម[3778]។ ជនជាប់ចោទពុំចាំបាច់ចូលរួមពាក់ព័ន្ធនឹងការបង្កើតផែនការរួមនោះឡើយ[3779] ឬចូលរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មនោះឡើយ គាត់គ្រាន់តែផ្តល់ជំនួយគាំទ្រ ឬរួមចំណែក (ដោយផ្ទាល់ ឬជាប្រយោល) ទៅដល់ការអនុវត្ត ផែនការ ឬគោលបំណងរួម[3780]។ លើសពីនេះទៅទៀត ការណ៍ដែលថា ការចូលរួមរបស់ជនជាប់ចោទ មានន័យស្មើនឹង "ភារកិច្ចជាប្រចាំ" របស់គាត់ នឹងមិនដោះបន្ទុកទ្រូវបគាត់នោះឡើយ[3781]។ អ្វីដែលគេត្រូវការ គឺការណ៍ដែលថាគាត់បានចូលរួមតាមរបៀបណាមួយ ក្នុងការសម្រេចគោលបំណងរួម[3782] ដែលនឹងមានផលប៉ះពាល់ដោយផ្ទាល់ ឬជាប្រយោល ទៅលើការប្រព្រឹត្តឧក្រិដ្ឋកម្ម[3783]។ ការរួមចំណែកនោះ អាចជាអំពើអកម្មទាំងស្រុង ឬមួយចំណែក[3784]។ នៅពេលធ្វើការសន្និដ្ឋាន អំពីការចូលរួមរបស់ជនជាប់ចោទនៅក្នុងសហឧក្រិដ្ឋកម្មរួម (JCE) តាមរយៈការខកខានរបស់គាត់ក្នុងការធ្វើសកម្មភាព អត្ថិភាពនៃកាតព្វកិច្ចផ្លូវច្បាប់ក្នុងការធ្វើសកម្មភាពដែលចេញមកពីវិធានមួយ

[3778] សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៨។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩២-៦៩៣។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៧។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៦៤។ សាលដីកាក្នុងរឿងក្តី *Munyakazi* កថាខណ្ឌ ១៦០។

[3779] សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ២៥០។

[3780] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៣។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៧, ២២៩។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ៩៨៥។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៤១០, ១៨៨០។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៦១១។

[3781] សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៦១៥។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៣៩៥, ១៨៨២។

[3782] សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៨។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៣។ សាលដីកាក្នុងរឿងក្តី*Tadić* កថាខណ្ឌ ២២៩(iii)។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤២៧។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៣៧៨។ សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ២១៨។ សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ២៥០។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៦១១, ១០៣៤។

[3783] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៩៨៣-៩៨៤។

[3784] សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១៨៧, ៤២១។ *សូមមើលផងដែរ*សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៣។

របស់ច្បាប់ព្រហ្មទណ្ឌ ពុំតម្រូវឲ្យមាននោះឡើយ[3785]។ ការខកខានបង្ការទប់ស្កាត់ការកើតឡើងវិញនៃឧក្រិដ្ឋកម្មត្រូវបានយកមកពិចារណា នៅពេលដែលជនជាប់ចោទមានអំណាច និងឥទ្ធិពលមួយចំនួន ឬសិទ្ធិអំណាចគ្រប់គ្រាន់ លើចារី ក្នុងការទប់ស្កាត់ ឬបញ្ឈប់ការរំលោភបំពាន ប៉ុន្តែជនជាប់ចោទខកខានមិនបានអនុវត្តអំណាចនោះ[3786]។

1038. ការចូលរួមចំណែករបស់ជនជាប់ចោទ ពុំចាំបាច់ត្រូវតែ *ចាំបាច់ ឬច្រើន* នោះទេ សម្រាប់ការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ[3787] និងពុំមែនជាការរួមចំណែកច្រើនសន្ធឹកនោះដែរ[3788] ប៉ុន្តែវាត្រូវតែជាការរួមចំណែកដ៏សំខាន់[3789]។ ភាពសំខាន់នៃការរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម (JCE) នឹងត្រូវកំណត់ដោយផ្អែកលើករណីនីមួយៗ ដោយពិចារណាទៅលើកត្តាជាច្រើន ដូចជា ទំហំ ភាពធ្ងន់ធ្ងរ និងវិសាលភាពនៃផែនការឧក្រិដ្ឋកម្ម និងបទឧក្រិដ្ឋដែលបានប្រព្រឹត្ត តួនាទី*ភាមនីតិន័យ ឬភាមព្រឹត្តន័យ*របស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួមរបស់ជនជាប់ចោទ មតិយោបល់ពាក់ព័ន្ធជាសាធារណៈដែលជនជាប់ចោទបានធ្វើ និងកិច្ចប្រឹងប្រែងនានាដើម្បីបង្ការទប់ស្កាត់បទ

[3785] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៣៩៤, ១៤៨៨, ២០៨០។ សាលដីកាក្នុងរឿងក្តី *Stanišić & Župljanin* កថាខណ្ឌ ១១០។

[3786] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៤៨៧, ១៥៣០។

[3787] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៩៨០។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៩៨។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤០១។

[3788] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨១០ ["វានៅតែគ្រប់គ្រាន់ ក្នុងការបង្ហាញថា ជនជាប់ចោទត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋ ដែលបានប្រព្រឹត្តនៅក្នុងពេលអនុវត្តគោលបំណងរួម ដែលខ្លួនបានរួមចំណែក ក្នុងកម្រិតមួយលើសពីការត្រឹមតែឈរមើល"] កថាខណ្ឌ ៩៨០។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩២។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤៣០។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៣៧៨។ សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ៣០៣។

[3789] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៩៨០។ សំណុំរឿងលេខ ០០២ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩២។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៨។ សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៨។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤២៧, ៤៣០, ៤៣២។ សាលដីកាក្នុងរឿងក្តី *Simba* កថាខណ្ឌ ៣០៣។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៦១១។

ឧក្រិដ្ឋ[3790]។ ការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម (JCE) ពុំចាំបាច់ស្ថិតនៅក្នុង និងមានលក្ខណៈឧក្រិដ្ឋកម្មនោះឡើយ ដរាបណាជនជាប់ចោទប្រព្រឹត្តអំពើ ដែលតាមរបៀបណាមួយរួមចំណែកដល់ការសម្រេចគោលបំណងរួមរបស់សហឧក្រិដ្ឋកម្មរួម (JCE)[3791]។

1039. ច្បាប់មិនប្រមើលមើលជាមុនទូវប្រភេទជាក់លាក់នៃអំពើប្រព្រឹត្តតែឯង ដែលនឹងត្រូវចាត់ទុកថាជាការរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម (JCE) នោះឡើយ[3792]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា[3793] ប្រភេទដូចខាងក្រោមនៃអំពើប្រព្រឹត្តត្រូវបានចាត់ទុកថាជាការរួមចំណែកដ៏សំខាន់ដល់សហឧក្រិដ្ឋកម្មរួម (JCE)ៃ

> (ក) ការបង្កើត ផ្តួចផ្តើម លើកកម្ពស់ ចូលរួមក្នុង និង/ឬ លើកទឹកចិត្តឲ្យមានការបង្កើត និងអនុវត្ត [...] គោលនយោបាយរបស់រដ្ឋាភិបាលដើម្បីជំរុញគោលដៅនៃសហឧក្រិដ្ឋកម្មរួម
>
> (ខ) ការចូលរួមនៅក្នុងការបង្កើត ការគាំទ្រ ឬបន្ត [...] ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ [ជាតិ] តំបន់ ក្រុង និងមូលដ្ឋាន [...] ដែលតាមរយៈស្ថាប័នទាំងនេះ [...] អាចអនុវត្តគោលដៅនៃសហឧក្រិដ្ឋកម្មរួម
>
> (គ) ការគាំទ្រ លើកទឹកចិត្ត ជួយសម្រួល ឬចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មាន ដើម្បី [...] ទទួលបានការគាំទ្រ និងការចូលរួមដើម្បីសម្រេចនូវគោលដៅនៃសហឧក្រិដ្ឋកម្មរួម
>
> (ឃ) ការដឹកនាំ ញុះញង់ លើកទឹកចិត្ត និងផ្តល់អំណាច [...] ដល់កងកម្លាំងឲ្យប្រព្រឹត្តអំពើនានា ដើម្បីជំរុញគោលដៅនៃសហឧក្រិដ្ឋកម្មរួម [...]

[3790] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៣។ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៩៨០។ សាលក្រមក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២៩២, ៣១១។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១០១, ១៩២។ សាលក្រមក្នុងរឿងក្តី *Krstić* កថាខណ្ឌ ៦៥២។

[3791] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៨៨២, ១៩៨២, ១៩៨៨។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៦៥៣។ សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៩៨៤។

[3792] សាលដីកាក្នុងរឿងក្តី *Stanišić & Župljanin* កថាខណ្ឌ ១១០។

[3793] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៩៨២ *ដកស្រង់* សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ២១៦-២១៧។

(ង) ការចូលរួម គាំទ្រ ឬសម្រួលដល់កិច្ចខិតខំប្រឹងប្រែងបដិសេធ ឬផ្តល់នូវព័ត៌មានដែលនាំឲ្យមានការយល់ច្រឡំចំពោះឧក្រិដ្ឋកម្ម ដល់តំណាងរបស់សហគមន៍អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល និងសាធារណៈជន។

1040. អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម (JCE) អាចនឹងទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយចារីផ្ទាល់ ដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) ដរាបណាគេរកឃើញថាយ៉ាងហោចណាស់អ្នកចូលរួមក្នុង សហឧក្រិដ្ឋកម្មរួម (JCE) ម្នាក់ត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្ម ហើយអ្នកចូលរួមរូបនោះ នៅពេលប្រើប្រាស់ចារីផ្ទាល់ បានធ្វើអំពើដើម្បីសម្រេចគោលបំណងរួម។[3794] ទំនាក់ទំនងអាចត្រូវបង្កើត ដោយផ្អែកលើការបង្ហាញភ័ស្តុតាងថា សមាជិកសហឧក្រិដ្ឋកម្មរួម (JCE) (i) បានសហការយ៉ាងជិតស្និទ្ធជាមួយចារីផ្ទាល់ ឬចារីប្រយោល ដើម្បីសម្រេចគោលបំណងរួម[3795] (ii) បានស្នើសុំដោយផ្ទាល់ ឬដោយប្រយោល ឲ្យបុគ្គលដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) ប្រព្រឹត្តឧក្រិដ្ឋកម្ម[3796] ឬ (iii) ញុះញង់ បញ្ជា លើកទឹកចិត្ត ឬប្រើប្រាស់បុគ្គលដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម[3797]។ វាក៏អាចពាក់ព័ន្ធដល់បញ្ហាថាតើ ឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តដោយកងកម្លាំង នៅក្រោមការគ្រប់គ្រងរបស់សមាជិក សហឧក្រិដ្ឋកម្មរួម (JCE) ណាម្នាក់ ដែរ ឬយ៉ាងណា[3798] ឬក៏ប្រព្រឹត្តដោយមានការសម្របសម្រួលជាមួយនឹងកងកម្លាំងក្រោមការគ្រប់គ្រងរបស់សមាជិកសហឧក្រិដ្ឋកម្មរួម (JCE) ណាម្នាក់ ដែរឬទេ[3799]។

[3794] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១០៤០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ២២៥។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៩៨៨។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤១០-៤១៤, ៤១៨, ៤៣០។ សាលដីកាក្នុងរឿងក្តី *Đorđević* កថាខណ្ឌ ១៦៥។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៣៩៨-៤០០។

[3795] សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤១០។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤១៤។

[3796] សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ២២៦។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៤១៤។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤១៤។

[3797] សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ២២៦។ សាលដីកាក្នុងរឿងក្តី *Popović* ១៤១៤។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤១៤។

[3798] សាលដីកាក្នុងរឿងក្តី *Martić* កថាខណ្ឌ ១៦៩, ១៩៥។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៧៩-៨៥។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤១៤។

[3799] សាលដីកាក្នុងរឿងក្តី *Martić* កថាខណ្ឌ ១៩៥, ២០៥។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤១៤។

1041. ក៏ប៉ុន្តែ ពុំតម្រូវថា សមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) ណាម្នាក់គ្រប់គ្រងដោយប្រសិទ្ធភាព[3800] ឬពិតជា "គ្រប់គ្រង និងមានឥទ្ធិពល"[3801] លើចារីនោះឡើយ។ ចារីប្រព្រឹត្តឧក្រិដ្ឋកម្ម និងជនជាប់ចោទ ក៏មិនចាំបាច់យល់ដឹងយ៉ាងច្បាស់ ឬព្រមព្រៀងជាមួយគ្នាយ៉ាងច្បាស់លាស់ ពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្ម នោះឡើយ[3802]។ បញ្ហាពាក់ព័ន្ធនៅក្នុងបរិបទនៃការទទួលខុសត្រូវរបស់ទម្រង់**មូលដ្ឋាន** (JCE I) គឺថាតើសមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) បានប្រើប្រាស់បុគ្គលដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) ឲ្យប្រព្រឹត្ត*អំពើសព្វាគុម័ត* នៃបទឧក្រិដ្ឋមួយដែលជាផ្នែកមួយនៃគោលបំណងរួម ដែរឬទេ។ អង្គជំនុំជម្រះតុលាការកំពូល បានចាត់ទុកចំណុចនេះថាជាទម្រង់មួយនៃការប្រគល់អំណាចដល់ចារីផ្ទាល់ ដើម្បីធ្វើការសម្រេចចិត្តពាក់ព័ន្ធនឹងការអនុវត្តចុងក្រោយនៃ*អំពើសព្វាគុម័ត* ដោយកត់សម្គាល់ថា ចំណុចនេះដូចគ្នាទៅនឹងគោលគំនិតស្តីពី*ចេតនាប្រយោល*[3803]។ មិនមានការបញ្ជាក់ច្បាស់លាស់ថាតើបុគ្គលដែលមិនមែនជាសមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) មានធាតុផ្សំអត្តនោម័តិ ដូចសមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) ឬគាត់បានដឹងអំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម (JCE) ដែរឬអត់ នោះឡើយ[3804]។ ជាឧទាហរណ៍ ចារីផ្ទាល់នៃការសម្លាប់មនុស្សមិនចាំបាច់មានចេតនាប្រល័យពូជសាសន៍ ដើម្បីធ្វើឲ្យសមាជិករបស់សហឧក្រិដ្ឋកម្មរួម (JCE) មានការជាប់ពាក់ព័ន្ធទៅនឹងការសម្លាប់ ដែលមានចេតនាបែបបននោះ ដែលនឹងត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍នោះឡើយ[3805]។

1042. ជម្លោះក្នុងចំណោមមេដឹកនាំនៅក្នុងស្ថាប័នធំមួយ មិនមានផលប៉ះពាល់ទៅលើបញ្ហានៃការទទួលខុសត្រូវព្រហ្មទណ្ឌពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម (JCE) នោះឡើយ ដរាបណាធាតុផ្សំទាំងអស់នៃ

[3800] សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៣៦៨។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១៤៤។

[3801] សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤១៤, ៩០៧។

[3802] សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤១៥, ៤១៨។

[3803] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨០៩។

[3804] សាលដីកាក្នុងរឿងក្តី *Karadžić* វិធាន ៩៨ស្ងួន កថាខណ្ឌ ៧៩។ សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ២២៦។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤១០។ *សូមមើលបន្ថែម* សៀវភៅនិពន្ធដោយ Sangkul Kim៖ *ទ្រឹស្តីរួមនៃចេតនាប្រល័យពូជសាសន៍* ទំព័រ ២២១ ["តួអង្គថ្នាក់ក្រោមមិនកាន់តួនាទី ដែលអនុញ្ញាតឲ្យពួកគេបំផ្លាញក្រុមទេ ដូច្នេះពួកគេមិនអាចបង្កើតចេតនាពិតប្រាកដនោះឡើយ។ [...] សំណួរថា តើចារីផ្ទាល់នៅថ្នាក់ក្រោមនៃសហឧក្រិដ្ឋកម្មប្រល័យពូជសាសន៍មានចេតនាប្រល័យពូជសាសន៍ដែរឬអត់ លែងពាក់ព័ន្ធនឹងការសន្ទនតនៃការទទួលខុសត្រូវចម្បងចំពោះបទប្រល័យពូជសាសន៍ទៀតឡើយ"]។

[3805] សាលដីកាយោងវិធាន ៩៨ស្ងួន ក្នុងរឿងក្តី Karadžić កថាខណ្ឌ ៧៩។

ទម្រង់នៃការទទួលខុសត្រូវនេះ ត្រូវបានរកឃើញ[3806]។ ផ្អែកតាមគោលការណ៍សញ្ញាណសហឧក្រិដ្ឋកម្មរួម ក្នុងចំណោមសមាជិកនានា ដែលបានរួមចំណែកក្នុងការអនុវត្តគោលបំណងរួម បើទោះបីជាសមាជិកខ្លះមានស្វ័យភាពមានកម្រិត ទាក់ទងទៅនឹងការអនុវត្តទិដ្ឋភាពនានានៃគោលបំណងរួមនោះក៏ដោយ ក៏ពុំធ្វើឲ្យសមាជិកដទៃទៀតរបស់សហឧក្រិដ្ឋកម្មរួម រួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ បាននោះឡើយ[3807]។

ធាតុផ្សំអត្តនោម័តិ

1043. មានការកំណត់យ៉ាងច្បាស់លាស់[3808] ថា ដើម្បីទទួលខុសត្រូវពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួមទម្រង់**មូលដ្ឋាន** (JCE I) ជនជាប់ចោទត្រូវមានដូចគ្នាជាមួយនឹងអ្នកចូលរួមដទៃទៀតក្នុងសហឧក្រិដ្ឋកម្មរួម (JCE) នូវចេតនា ពោលគឺ *ធាតុផ្សំអត្តនោម័តិ*ដែលពាក់ព័ន្ធក្នុងការប្រព្រឹត្តបទឧក្រិដ្ឋនៅក្នុងគោលបំណងរួម និងចេតនាចូលរួមក្នុងផែនការរួម ដែលមានគោលដៅប្រព្រឹត្តបទឧក្រិដ្ឋនោះ[3809]។

[3806] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១០៤២។

[3807] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១០៤២។

[3808] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ១០៥៣-៤។ សំណុំរឿងលេខ ០០២ ឯកសារ D97/15/9 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៧, ៣៩។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥០៩។ សំណុំរឿងលេខ ០០២ ឯកសារ E3131 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩០, ៦៩៤។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ១៩៦, ២២០, ២២៨។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៣៦៥។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៤៧០។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៣៦៩។ សាលដីកាក្នុងរឿងក្តី *Munyakazi* កថាខណ្ឌ ១៦០។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៤៧៤-៤៧៥។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៧៧១-១៧៧២, ២៣៧២, ២៤២២។

[3809] ចេតនាសម្រាប់សហឧក្រិដ្ឋកម្មរួមកម្រិតទី១ ដែលជាទម្រង់មួយនៃការប្រព្រឹត្ត រួមបញ្ចូល (i) ចេតនាដោយផ្ទាល់ ដែលឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្ត (*ចេតនាដោយផ្ទាល់* កម្រិតទី១)។ (ii) ការដឹងថា ឧក្រិដ្ឋកម្មនោះនឹងកើតឡើងតាមដំណើរធម្មតានៃព្រឹត្តិការណ៍ ឬសរសេរមួយឃ្លាទៀតថា ការដឹងពីភាពនិយភាពពិតដែលថា ឧក្រិដ្ឋកម្មនោះនឹងកើតឡើង (*ចេតនាដោយផ្ទាល់* កម្រិតទី២)។ និង (iii) *ចេតនាដោយប្រយោល*។ *សូមមើល* កថាខណ្ឌ ១០៣១ ខាងលើ។ នេះក៏កើតចេញដោយផ្ទាល់ពីការបញ្ជាក់អះអាងរបស់អង្គជំនុំជម្រះតុលាការកំពូលថា សម្រាប់សហឧក្រិដ្ឋកម្មរួម៖ (i) "វាមិនចាំបាច់ឲ្យជនទាំងឡាយដែលយល់ស្របតាមគោលបំណងរួម ប្រាថ្នាឲ្យគេប្រព្រឹត្តបទឧក្រិដ្ឋជាក់ស្តែងឡើយ"។ (ii) ថាឧក្រិដ្ឋកម្មអាចត្រូវបាន "គេដឹងមុនជាមធ្យោបាយដើម្បីសម្រេចគោលបំណងរួមជាក់លាក់ណាមួយ ទោះបីជាការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ មិនពិតប្រាកដក៏ដោយ" និង (iii) "សមាជិកនៃសហឧក្រិដ្ឋកម្មរួម ត្រូវទទួលយកការប្រព្រឹត្តឧក្រិដ្ឋកម្ម ទាំងជាគោលដៅ ទាំងជាផលវិបាកដែលចៀសមិនរួចនៃ

ចំពោះបទឧក្រិដ្ឋដែលមានចេតនាជាក់លាក់ដូចជា ការធ្វើទុក្ខបុកម្នេញ ឬបទឧក្រិដ្ឋប្រល័យពូជសាសន៍ ជនជាប់ចោទ ត្រូវមានចេតនាជាក់លាក់ពាក់ព័ន្ធផងដែរ[3810]។ ចេតនាឧក្រិដ្ឋរួម មិនតម្រូវថាជនជាប់ចោទត្រូវមានការពេញចិត្តជាលក្ខណៈបុគ្គល ឬសេចក្តីសាទរ ឬគំនិតផ្តួចផ្តើមផ្ទាល់ខ្លួនក្នុងការរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម (JCE) នោះឡើយ[3811]។ ជាងនេះទៅទៀត ជនជាប់ចោទមិនត្រូវបានតម្រូវឲ្យដឹងអំពីព្រឹត្តិការណ៍ឧក្រិដ្ឋកម្មជាក់លាក់ ដែលកំពុងត្រូវពិភាក្សានោះឡើយ[3812]។ ចេតនាអាចត្រូវទាញសេចក្តីសន្និដ្ឋានពីការយល់ដឹងរបស់មនុស្សម្នាក់ ដោយរួមផ្សំជាមួយការចូលរួមជាបន្តបន្ទាប់ក្នុងបទឧក្រិដ្ឋ[3813]។ ភាពសំខាន់ និងវិសាលភាពនៃការចូលរួមផ្ទាល់របស់បុគ្គលម្នាក់នៅក្នុងសហឧក្រិដ្ឋកម្មរួម ក៏អាចពាក់ព័ន្ធទៅនឹងការកំណត់ថាតើ បុគ្គលរូបនោះ មាន*ធាតុផ្សំអត្តនោម័តិ*តម្រូវ ដែរឬទេ[3814]។

ខ. ដែលត្រូវបានរៀបចំផែនការ

1044. ធាតុផ្សំសត្យានុម័ត នៃ "ការរៀបចំផែនការ" តម្រូវថា បុគ្គលម្នាក់ ឬច្រើននាក់ ចូលរួមក្នុងការរៀបចំអំពើមួយ ឬការប្រព្រឹត្តមួយ ហើយជាលទ្ធផល មានឥទ្ធិពលដ៏សំខាន់ទៅលើការប្រព្រឹត្តបទឧក្រិដ្ឋដែលពិតជាត្រូវបានប្រព្រឹត្ត[3815]។ ហេតុដូច្នេះ ជនជាប់ចោទ ពុំចាំបាច់រៀបចំអំពើប្រព្រឹត្តតែ

គោលបំណងបឋម ឬទាំងគ្មានការអើពើពីយ៉ាងហោចណាស់ដែលអាចកើតឡើង" (សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨០៨-៨០៩)។

[3810] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច ជើងទំព័រលេខ ៨៩៧។ សំណុំរឿងលេខ ០០២ ឯកសារ E100/6 សេចក្តីសម្រេចលើភាពអាចអនុវត្តបានទូវសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ១៦។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៤។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១១០។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១១១។

[3811] សាលដីកាក្នុងរឿងក្តី *Popović* ជើងទំព័រលេខ ២៩៧១។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១០០។

[3812] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៨០២។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៤៩១។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ២៧៦។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៩០៦។

[3813] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៨០០, ១៩៧០, ២០១២, ២០៧៨។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៣៦៩, ១៦៥២។ សាលដីកាក្នុងរឿងក្តី *Đorđević* កថាខណ្ឌ ៥១២។ សាលដីកាក្នុងរឿងក្តី *Krajišnik* កថាខណ្ឌ ២០២, ៦៩៧។

[3814] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៤។ សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ២៤០២។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ៩៧, ១៨៨។

[3815] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៨។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥១៨។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៣៦៨,

ឯងនោះឡើយ[3816] ហើយក៏ពុំចាំបាច់ជាមនុស្សដើមដំបូងដែលរៀបចំគម្រោង ឬផែនការ នោះឡើយ[3817] ការឯកភាពយល់ព្រមលើផែនការដែលស្នើ ដោយមនុស្សម្នាក់ផ្សេងទៀត គឺគ្រប់គ្រាន់[3818]។ ភ័ស្តុតាងកាលៈទេសៈ អាចផ្តល់ភ័ស្តុតាងអំពីអត្ថិភាពនៃផែនការនោះ[3819]។ ការសម្រេចដាក់ពិរុទ្ធភាព ចំពោះការរៀបចំផែនការ មិនតម្រូវឲ្យមានការរកឃើញអំពីមុខតំណែង នោះឡើយ[3820]។

1045. ផែនការត្រូវកើតឡើងមុន និងរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តបទឧក្រិដ្ឋ[3821]។ បញ្ហាថាតើអំពើជាក់លាក់ណាខ្លះ មានន័យស្មើនឹងការរួមចំណែកដ៏សំខាន់ នឹងត្រូវវាយតម្លៃទៅតាមករណីនីមួយៗ ដោយផ្អែកលើភ័ស្តុតាងទាំងមូល[3822]។

1046. ពាក់ព័ន្ធនឹងខ្លឹមសារនៃផែនការ ពុំចាំបាច់មានការរៀបរាប់អំពីការប្រព្រឹត្តបទឧក្រិដ្ឋជាក់លាក់ណាមួយនោះឡើយ។ ការរៀបចំផែនការអាចជាវត្ថុបំណងមួយដែលនឹងត្រូវសម្រេចបានតាមរយៈការប្រព្រឹត្តបទឧក្រិដ្ឋ។ ហេតុដូច្នេះ លក្ខណៈធម្មានុរូបនៃកិច្ចប្រតិបត្តការមួយ ពុំទាត់ចោលការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទចំពោះការរៀបចំផែនការបទឧក្រិដ្ឋ ដែលត្រូវបានប្រព្រឹត្តក្នុងអំឡុងកិច្ចដំណើរការរៀបចំផែនការនោះឡើយ ប្រសិនបើគោលដៅនឹងត្រូវសម្រេចបានតាមរយៈការប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ[3823]។

៤៩៤។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៦។ សាលដីកាក្នុងរឿងក្តី *Milošević* (*Dragomir*) កថាខណ្ឌ ២៦៨។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៧៩។

[3816] សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៤។ សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១៥៤។

[3817] សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* ជើងទំព័រលេខ ៤១៨។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៤។

[3818] សាលក្រមក្នុងរឿងក្តី *Bagilishema* កថាខណ្ឌ ៣០។ សាលក្រមក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣៨០។

[3819] សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៩៥៨-៩៥៩។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ៣០១។ សាលក្រមក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ២៧៩។

[3820] សាលដីកាក្នុងរឿងក្តី *Kanyarukiga* កថាខណ្ឌ ២៥៨។

[3821] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥១៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៨។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៦។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៧៩, ៤៩២ *ជើងទំព័រលេខ* ២១១៦។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៦៨៧, ១១៧០។

[3822] សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៧៦៩។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៤។

[3823] សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១៧២។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៣-៤៩៤។

1047. ពាក់ព័ន្ធនឹង *ធាតុផ្សំអត្តនោម័តិ* ជនជាប់ចោទត្រូវមានចេតនា ឬដឹងអំពីលទ្ធភាពដ៏ធំធេងនៃការប្រព្រឹត្តបទឧក្រិដ្ឋ ដោយផ្អែកលើការអនុវត្តផែនការ[3824]។ *ធាតុផ្សំអត្តនោម័តិ* របស់ជនជាប់ចោទអាចទាញសេចក្តីសន្និដ្ឋានចេញពីកាលៈទេសៈ[3825]។ នៅពេលមានការកំណត់ថាចារីចម្បងបានដឹងអំពីកាលៈទេសៈពិតប្រាកដ ដែលកំណត់ពីឋានៈរបស់ជនរងគ្រោះ (ដូចជា ជនស៊ីវិល យោធា អ្នកមិនពាក់ព័ន្ធនឹងការប្រយុទ្ធ ។ល។) ការរកឃើញបែបនេះពុំចាំបាច់សម្រាប់ការដាក់ពិរុទ្ធភាពចំពោះការរៀបចំផែនការនោះឡើយ[3826]។

គ. ដែលត្រូវញុះញង់

1048. ដើម្បីដាក់បន្ទុកឲ្យជនជាប់ចោទទទួលខុសត្រូវចំពោះបទញុះញង់ ជនជាប់ចោទត្រូវ តាមរយៈអំពើសកម្ម ឬអកម្ម ញ៉ាំងឲ្យមនុស្សម្នាក់ផ្សេងទៀត ប្រព្រឹត្តអំពើតាមរបៀបជាក់លាក់ណាមួយ ដែលមានឥទ្ធិពលធំធេងលើការប្រព្រឹត្តបទឧក្រិដ្ឋ[3827]។ ទម្រង់នៃការទទួលខុសត្រូវនេះ ក៏ត្រូវបានហៅថា "ការជំរុញ ឬការលើកទឹកចិត្ត"[3828]។ ពុំមានលក្ខខណ្ឌតម្រូវថាការញុះញង់ត្រូវមានលក្ខណៈ "ផ្ទាល់ និងសាធារណៈ" នោះឡើយ[3829]។ ទាំងអំពើសកម្ម និងអកម្ម សុទ្ធតែអាចផ្សំបង្កើតជាការញុះញង់[3830] ដែលអាចកើតឡើងដោយអំពើស្ងៀមស្ងាត់ ជាលាយលក្ខណ៍អក្សរ ឬដោយទម្រង់អ្វីក៏

[3824] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥១៩។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៦៩៨។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៩, ៣១, ១១២។ សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ៦៨, ១៧៤។ សាលដីកាក្នុងរឿងក្តី *Milošević* (*Dragomir*) កថាខណ្ឌ ២៦៨។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៧៩។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៤។

[3825] សាលក្រមក្នុងរឿងក្តី *Galić* កថាខណ្ឌ ១៧២។ សាលក្រមក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ៣២៨។

[3826] សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ៦៧។

[3827] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០០។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៧, ៣២។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៣៦៨, ៥៨៩។ សាលដីកាក្នុងរឿងក្តី *Nzabonimana* កថាខណ្ឌ ១៤៦។

[3828] សាលក្រមក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៣០៤។ សាលក្រមក្នុងរឿងក្តី *Mpambara* កថាខណ្ឌ ១៨។

[3829] សាលដីកាក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៤៧៨-៤៨៣។

[3830] សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៥៩៥។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩ តម្កល់សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៧២ ទុកជាបានការ។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៦៩។

ដោយរបស់ជនជាប់ចោទ ដោយមិនចាំបាច់តែការនិយាយនោះទេ[3831]។ ពុំចាំបាច់បង្ហាញនូវភាសា ឬការប្រព្រឹត្តញុះញង់ជាក់លាក់ដែលត្រូវបានប្រើប្រាស់ ដោយជនជាប់ចោទ នោះឡើយ[3832]។

1049. ដើម្បីឲ្យជនជាប់ចោទម្នាក់ទទួលខុសត្រូវផ្អែកព្រហ្មទណ្ឌ ដោយផ្អែកលើមូលហេតុញុះញង់ គេត្រូវ បង្ហាញថា បទឧក្រិដ្ឋមួយពិតជាត្រូវបានប្រព្រឹត្តពិតប្រាកដមែន[3833] ទោះបីជាការកំណត់អត្ត សញ្ញាណជាក់លាក់នៃចារីចម្បងនៃបទឧក្រិដ្ឋជាក់លាក់នោះ ពុំតម្រូវឲ្យមានក៏ដោយ[3834]។ ជាងនេះ ទៅទៀត អំពើញុះញង់ត្រូវកើតឡើងមុន និងរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តបទឧក្រិដ្ឋ[3835]។ ក៏ប៉ុន្តែ ពុំចាំបាច់បង្ហាញថា បទឧក្រិដ្ឋនោះនឹងមិនអាចកើតឡើង ដោយពុំមានការពាក់ព័ន្ធរបស់ជន ជាប់ចោទនោះឡើយ[3836]។ ជាការពិត ជនជាប់ចោទគ្រាន់តែជំរុញមនុស្សម្នាក់ផ្សេងទៀតឲ្យធ្វើអំពើ តាមរបៀបណាមួយ ដោយមិនចាំបាច់ប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ឬបទល្មើសជាក់លាក់ណាមួយ ដោយខ្លួនឯងនោះឡើយ[3837]។

1050. *ធាតុផ្សំអត្តនោម័តិ* សម្រាប់ការទទួលខុសត្រូវដោយផ្អែកលើមូលដ្ឋាននៃការញុះញង់ គឺចេតនា ញុះញង់ឲ្យប្រព្រឹត្តបទឧក្រិដ្ឋ ឬការយល់ដឹងអំពីលទ្ធភាពធំធេងដែលថា បទឧក្រិដ្ឋនឹងត្រូវប្រព្រឹត្ត ដោយសារតែការញុះញង់[3838]។

[3831] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០០។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩ តម្កល់សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៧២ ទុកជាបានការ។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៦៩។

[3832] សាលដីកាក្នុងរឿងក្តី *Semanza* កថាខណ្ឌ ២៩៦។

[3833] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២២។ សាលក្រមក្នុងរឿងក្តី *Mpambara* កថាខណ្ឌ ១៨។ សាលក្រមក្នុងរឿងក្តី *Galić* កថាខណ្ឌ ១៦៨។

[3834] សាលដីកាក្នុងរឿងក្តី *Karera* កថាខណ្ឌ ៣១៨។ សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ៧៥។

[3835] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០០។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថា ខណ្ឌ ២៧។ សាលដីកាក្នុងរឿងក្តី *Karera* កថាខណ្ឌ ៣១៧។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩។

[3836] សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៧។ សាលដីកាក្នុងរឿងក្តី *Nyiramasuhuko* កថាខណ្ឌ ៣៣២៧។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៨០, ៥០២, ៦៦០។

[3837] សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១៧២។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៣។

[3838] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២៤។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០០។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថា

ឃ. បានបញ្ជា

1051. ការបញ្ជាកើតឡើង នៅពេលបុគ្គលក្នុងតួនាទីមានសិទ្ធិអំណាចណែនាំបុគ្គលម្នាក់ទៀតឲ្យអនុវត្ត សកម្មភាព ឬចូលរួមក្នុងអំពើអកម្ម ដែលមានអានុភាពគួរឲ្យកត់សម្គាល់ទៅលើការប្រព្រឹត្តឧក្រិដ្ឋ កម្មនោះ[3839]។ គ្មានលក្ខខណ្ឌតម្រូវដែលថា អ្នកបញ្ជា និងអ្នកប្រព្រឹត្តផ្ទាល់ ត្រូវតែស្ថិតក្នុងទំនាក់ ទំនងជាមេកើយ និងមនុស្សក្រោមបង្គាប់ជាផ្លូវការឡើយ[3840] ឬថាជនជាប់ចោទត្រូវតែអនុវត្តការ គ្រប់គ្រងប្រកបដោយប្រសិទ្ធភាពទៅលើគាត់ឡើយ[3841] ប៉ុន្តែត្រូវតែមានភ័ស្តុតាងអំពីតួនាទីសិទ្ធិ អំណាចរបស់ជនជាប់ចោទតាម*នីតិន័យ* ឬតាម*ព្រឹត្តន័យ* ដែលបង្ខំឲ្យជនម្នាក់ទៀតប្រព្រឹត្តឧក្រិដ្ឋ កម្ម[3842]។ សិទ្ធិអំណាចនោះអាចមិនផ្ទូរការ ឬបណ្តោះអាសន្ន[3843]។

ខណ្ឌ ២៩, ៣២។ សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ៦៨, ១៧៤។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៨០។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩។

[3839] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២៧-៥២៨។ សំណុំរឿង លេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០២។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៨, ៣២។ សាលដីកាក្នុងរឿងក្តី *Milošević* (*Dragomir*) កថាខណ្ឌ ២៦៧។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៨១។ សាលដីកាក្នុងរឿងក្តី *Renzaho* កថាខណ្ឌ ៣១៥។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩។

[3840] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០២ និងសេចក្តីដកស្រង់ក្នុងសាលក្រមនោះ។ សាល ដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៨។ សាលដីកាក្នុងរឿងក្តី *Galić* កថាខណ្ឌ ១៧៦។ សាលដីកាក្នុងរឿងក្តី *Renzaho* កថាខណ្ឌ ៣១៥។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៦៤។

[3841] សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ២០២។ សាលដីកាក្នុងរឿងក្តី *Kamuhanda* កថាខណ្ឌ ៧៥។

[3842] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២៧។ សាលដីកាក្នុងរឿង ក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១៦៤។ សាលដីកាក្នុងរឿងក្តី *Setako* កថាខណ្ឌ ២៤០។ ថាតើអាជ្ញាធរបែបនេះកើត មានឬអត់ គឺជាបញ្ហាផ្នែកអង្គហេតុ៖ សាលដីកាក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣៦៣។ *សូមមើលផងដែរ* សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ១៨២ [ការចេញបញ្ជា "តម្រូវឲ្យអាជ្ញាធរតែប៉ុណ្ណោះជាអ្នកចេញបញ្ជា ជាលក្ខណៈវិនិច្ឆ័យបែបអត្តនោម័ តបន្ថែមអាស្រ័យលើកាលៈទេសៈ និងការយល់ឃើញរបស់អ្នកស្តាប់បញ្ជា"]។

[3843] សាលដីកាក្នុងរឿងក្តី *Semanza* កថាខណ្ឌ ៣៦៣។ សាលដីកាក្នុងរឿងក្តី *Setako* កថាខណ្ឌ ២៤០។

1052. ការបញ្ជាអាចមានភាពជាក់លាក់ ឬប្រយោល និងអាចត្រូវបានបង្ហាញទៅតាមកាលៈទេសៈ[3844]។ អត្ថិភាពនៃការបញ្ជាអាចត្រូវបានសន្និដ្ឋានពីកត្តានានា រួមបញ្ចូលចំនួននៃអំពើខុសច្បាប់ ចំនួន និងប្រភេទបុគ្គលិកពាក់ព័ន្ធ ការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងការបញ្ជាដែលដាក់ទៅលើបុគ្គលិកទាំងនេះ ពស្តុភារដែលពាក់ពន្ធ ការកើតឡើងជាទូទៅនៃអំពើខុសច្បាប់ស្រដៀងនេះ ចង្វាក់នៃប្រតិបត្តិការ *វិធីនៃប្រតិបត្តិការ* នៃអំពើស្រដៀង ទីតាំងរបស់ថ្នាក់លើនៅពេលនោះ និងការដឹងឮរបស់គាត់អំពីអំពើឧក្រិដ្ឋ ដែលបានប្រព្រឹត្តក្រោមបញ្ជារបស់គាត់[3845]។

1053. ជនជាប់ចោទមិនចាំបាច់ចេញបញ្ជាដោយផ្ទាល់ទៅចារីឡើយ។ ការទទួលខុសត្រូវចំពោះការបញ្ជាអាចមាន នៅពេលជនជាប់ចោទចេញ បញ្ជូនបន្ត ឬផ្សព្វផ្សាយបទបញ្ជា ដោយរួមបញ្ចូលតាមរយៈអន្តរការី[3846]។ ការបញ្ជាត្រូវតែរួមចំណែកច្រើនដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត នៅពេលបន្ទាប់ពីនោះ[3847]។ ប៉ុន្តែមិនចាំបាច់បង្ហាញថា ឧក្រិដ្ឋកម្ម ឬបទឈ្មើសជាមូលដ្ឋាន នឹងមិនត្រូវបានប្រព្រឹត្ត បើគ្មានបញ្ជាពីជនជាប់ចោទឡើយ[3848]។ ពុំចាំបាច់បង្ហាញថា បទបញ្ជានោះមិនស្រប

[3844] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០២។ សាលដីកាក្នុងរឿងក្តី *Galić* កថាខណ្ឌ ១៧៨។ សាលដីកាក្នុងរឿងក្តី *Kamuhanda* កថាខណ្ឌ ៧៦។ សាលដីកាក្នុងរឿងក្តី *Ndindiliyimana* កថាខណ្ឌ ២៩១។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ១៦៤។

[3845] សាលក្រមក្នុងរឿងក្តី *Galić* កថាខណ្ឌ ១៧១, ៧៤១។ សាលដីកាក្នុងរឿងក្តី *Milošević* (*Dragomir*) កថាខណ្ឌ ២៧២-២៧៣។

[3846] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០២។ សាលក្រមក្នុងរឿងក្តី *Milutinović* (ភាគទី ១) កថាខណ្ឌ ៨៧។ សាលក្រមក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ២៨២។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩ ឥម្ភល់ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៧៦ ទុកជាបានការ។

[3847] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០២។ សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១៦០។ សាលដីកាក្នុងរឿងក្តី *Hategekimana* កថាខណ្ឌ ៦៧។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៣៦៨, ៥៨៩។

[3848] សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩ ឥម្ភល់សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៧៧។ សាលក្រមក្នុងរឿងក្តី *Milutinović* (ភាគទី១) កថាខណ្ឌ ៨៨។

ច្បាប់[3849] ឬជាក់លាក់ទាក់ទងផលវិបាក ដែលវាអាចនឹងមានឡើយ[3850]។ លក្ខណៈស្របច្បាប់នៃប្រតិបត្តិការ ពុំដកចេញការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទឡើយ ប្រសិនបើត្រូវសម្រេចគោលដៅដោយការប្រព្រឹត្តឧក្រិដ្ឋកម្មនានា[3851]។

1054. ចំពោះ*ធាតុផ្សំអត្តនោម័តិ* ជនជាប់ចោទត្រូវតែមានចេតនា ឬដឹងអំពីលទ្ធភាព ដែលថាការប្រព្រឹត្ត ឬការអនុវត្តបទបញ្ជា នឹងបណ្តាលឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនោះ[3852]។

ង. បានជួយនិងជំរុញ

1055. ការជួយនិងជំរុញ[3853] មានការជួយជ្រោមជ្រែងជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រស្មារតី ដែលមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត[3854]។ "ការបង្ហាប់ជាក់លាក់" ពុំមែនជាធាតុផ្សំនៃការទទួលខុសត្រូវចំពោះការជួយនិងការជំរុញក្រោមច្បាប់ទំនៀមទម្លាប់

[3849] សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៨, ៣២។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤២។ សាលដីកាក្នុងរឿងក្តី *Milošević* (*Dragomir*) កថាខណ្ឌ ២៦៧។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៨១។ សាលដីកាក្នុងរឿងក្តី *Nyiramasuhuko* កថាខណ្ឌ ១៨៩៥ *ដើងទំព័រលេខ* ៤៤៤៨។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩។

[3850] សាលដីកាក្នុងរឿងក្តី *Milošević* (*Dragomir*) កថាខណ្ឌ ២៦៧។

[3851] សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ១៧២។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៣។

[3852] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥២៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០២។ សាលដីកាក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ២៩-៣០។ សាលដីកាក្នុងរឿងក្តី *Martić* កថាខណ្ឌ ២២១-២២២។ សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ៦៨។ សាលដីកាក្នុងរឿងក្តី *Renzaho* កថាខណ្ឌ ៣១៥។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥៨៩។

[3853] ពាក្យ "ជួយ" និងពាក្យ "ជម្រុញ" មិនមានន័យដូចគ្នាទេ។ ពាក្យ "ជួយ" ពាក់ព័ន្ធនឹងការផ្តល់ជំនួយ ចំណែកពាក្យ "ជម្រុញ" ពាក់ព័ន្ធនឹងការជួយសម្រួល ការលើកទឹកចិត្ត ការផ្តល់យោបល់ ឬការគាំទ្រខាងស្មារតីឲ្យប្រព្រឹត្តបទឧក្រិដ្ឋ (សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៣៣។ សាលក្រមក្នុងរឿងក្តី *Milutinović* (ភាគីទី១) *ដើងទំព័រលេខ* ១០៧។ សាលក្រមក្នុងរឿងក្តី *Akayesu* កថាខណ្ឌ ៤៨៤។ សាលក្រមក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ២៨៦)។

[3854] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៣៣។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤៦។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៦៤៩។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៧៣២, ១៧៨៣។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៣៦៨។

អន្តរជាតិឡើយ[3855]។ វាមិនតម្រូវឲ្យមានផែនការ ឬការព្រមព្រៀងរវាងអ្នកជួយនិងជំរុញ និងចារីសម្រាប់ការទទួលខុសត្រូវចំពោះការជួយនិងការជំរុញឡើយ[3856]។ ជាការពិត ចារីពុំចាំបាច់ដឹងអំពីការរួមចំណែករបស់អ្នកជួយនិងជំរុញឡើយ[3857]។

1056. ទោះជាការជួយនិងជំរុញត្រូវតែមានផលប៉ះពាល់ធ្ងន់ធ្ងរ ទៅលើការប្រព្រឹត្តឧក្រិដ្ឋកម្មក៏ដោយ[3858] ក៏គ្មានលក្ខខណ្ឌតម្រូវឲ្យមានទំនាក់ទំនងហេតុនិងផល ឬថាទង្វើនោះជាលក្ខខណ្ឌដែលមានមុនការប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ[3859]។ ទង្វើដែលជាការជួយនិងជំរុញអាចកើតមាន មុនពេល អំឡុងពេល ឬបន្ទាប់ពី[3860] ការប្រព្រឹត្តឧក្រិដ្ឋកម្ម និងនៅទីកន្លែងមួយខុសពីទីតាំងឧក្រិដ្ឋកម្ម[3861]។

[3855] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០៧-៧១០។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៨១។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៦៤៩, ១៦៦៣។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៧៥៨។ សាលដីកាក្នុងរឿងក្តី *Stanišić & Simatović* កថាខណ្ឌ ១០៦, ១០៨។

[3856] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៣៤។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៩(ii)។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៦៣។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៥៧។

[3857] សាលដីកាក្នុងរឿងក្តី*Tadić* កថាខណ្ឌ ២២៩(ii)។ សាលដីកាក្នុងរឿងក្តី *Kalimanzira* កថាខណ្ឌ ៨៧។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៦៣។

[3858] *សូមមើលឧទាហរណ៍*៖ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ២២៩(iii)។ សាលដីកាក្នុងរឿងក្តី *Gotovina & Markač* កថាខណ្ឌ ១២៧។ សាលដីកាក្នុងរឿងក្តី *Ntawukulilyayo* កថាខណ្ឌ ២១៤។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៨១។

[3859] សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៧៤០, ១៧៨៣។ សាលដីកាក្នុងរឿងក្តី *Ndahimana* កថាខណ្ឌ ១៤៩។ សាលដីកាក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៥២២។

[3860] ដោយពិចារណាលើលក្ខខណ្ឌតម្រូវសំខាន់បំផុត គឺថា ការជួយជ្រោមជ្រែង ការលើកទឹកចិត្ត ឬការគាំទ្រខាងស្មារតី ត្រូវតែមានអានុភាពធំធេងលើការប្រព្រឹត្តបទឧក្រិដ្ឋណាមួយ។ ទំនាក់ទំនងហេតុ និងផលចាំបាច់ មិនអាចកើតមានឡើយ ប្រសិនបើការជួយជ្រោមជ្រែងនោះ ត្រូវបានផ្តល់ឲ្យ*ផ្តាច់មុខ* ក្រោយពេលដែលបទឧក្រិដ្ឋនោះត្រូវបានប្រព្រឹត្ត។ ប៉ុន្តែ ទោះបីជាយ៉ាងនេះក្តី ល្អ៊ីកណាលក្ខខណ្ឌតម្រូវនៃអានុភាពធំធេងត្រូវបានបំពេញ ការប្រព្រឹត្ត ដូចជាការព្រមព្រៀងដែលបានធ្វើឡើង*មុន ឬក្នុងកំឡុងពេល*ប្រព្រឹត្តបទឧក្រិដ្ឋ ក្នុងការជួយជ្រោមជ្រែងត្រូវផ្តល់ឲ្យក្រោយអង្គហេតុ អាចជាការគ្រប់គ្រាន់។ *សូមមើល* សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១២-៧១៣។ សាលក្រមក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ៧៣១។ សាលក្រមក្នុងរឿងក្តី *Furundžija* កថាខណ្ឌ ២៣០។ សាលក្រមក្នុងរឿងក្តី *Aleksovski* កថាខណ្ឌ ៦២។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៧៧។

[3861] សាលដីកាក្នុងរឿងក្តី *Mrkšić & Šljivančanin* កថាខណ្ឌ ៨១។ សាលដីកាក្នុងរឿងក្តី *Ntagerura* កថាខណ្ឌ ៣៧២។ សាលដីកាក្នុងរឿងក្តី *Fofana & Kondewa* កថាខណ្ឌ ៧២។

1057. ជនណាម្នាក់អាចត្រូវបានសម្រេចឲ្យអ្នកទទួលខុសត្រូវ លើការជួយនិងជំរុញឲ្យមានឧក្រិដ្ឋកម្ម នៅពេលមានការបង្ហាញថា ទង្វើរបស់ជននោះជាការឯកភាពដែលតុណ្ហីភាព និងការលើកទឹកចិត្តឲ្យមានឧក្រិដ្ឋកម្ម និងថាទង្វើបែបនេះបានរួមចំណែកខ្លាំងក្លាដល់ឧក្រិដ្ឋកម្ម[3862]។ ទោះបីជាក្នុងករណីបែបនេះ សិទ្ធិអំណាចរបស់ជនជាប់ចោទគឺជាកត្តាមួយក៏ដោយ[3863] ក៏វាពុំចាំបាច់បង្ហាញថាជនជាប់ចោទបានមានសិទ្ធិអំណាចលើចារីផ្ទាល់ឡើយ[3864]។ ជនជាប់ចោទក៏អាចជួយនិងជំរុញតាមរយៈអំពើអកម្ម ប្រសិនបើមានការបង្ហាញថា ប្រសិនបើជនជាប់ចោទបានចាត់ការទប់ស្កាត់ ការប្រព្រឹត្តឧក្រិដ្ឋកម្មនឹងពុំទំនងជាអាចកើតឡើងឡើយ[3865]។

1058. ចំពោះ*ធាតុផ្សំអត្តនោម័តិ* ជនជាប់ចោទត្រូវតែដឹង នៅពេលគាត់ផ្តល់ការជួយជ្រោមជ្រែង[3866] ថាឧក្រិដ្ឋកម្មមួយនឹងអាចត្រូវបានប្រព្រឹត្ត និងថាទង្វើរបស់គាត់ជួយ ឬសម្របសម្រួលការប្រព្រឹត្តឧក្រិដ្ឋកម្ម[3867]។ អ្នកជួយនិងជំរុញពុំចាំបាច់ដឹងអំពីឧក្រិដ្ឋកម្មជាក់លាក់ដែលត្រូវបានប្រព្រឹត្តដោយចារីឡើយ ល្អីកណាគាត់ដឹងថា ឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មមួយចំនួន នឹងអាចត្រូវបានប្រព្រឹត្ត ហើយឧក្រិដ្ឋកម្មមួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងនោះ ពិតជាត្រូវបានប្រព្រឹត្ត[3868]។ ជនជាប់ចោទត្រូវតែដឹងផងដែរអំពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្ម រួមបញ្ចូលសភាពផ្លូវចិត្តរបស់ចារី ប៉ុន្តែពុំ

[3862] សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៦៨៧។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ២៧៣, ២៧៧ [សំដៅដល់ 'អ្នកមើលដែលស្ងៀមស្ងាត់']។ សាលដីកាក្នុងរឿងក្តី *Ndahimana* កថាខណ្ឌ ១៤៧។ សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ២០១-២០២ [សំដៅដល់ 'អ្នកមើលដែលយល់ព្រម']។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៥១៤។

[3863] ដូចខាងលើ។ *សូមមើលផងដែរឧទាហរណ៍* សាលដីកាក្នុងរឿងក្តី *Muvunyi I* កថាខណ្ឌ ៨០។

[3864] សាលដីកាក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ១៩៥។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៦៧២។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៥៤១។

[3865] សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៨១២ និង១៧៤១។ សាលដីកាក្នុងរឿងក្តី *Mrkšić & Šljivančanin* កថាខណ្ឌ ៤៩, ៩៧, ១០០, ១៤៦។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៨២, ៤១។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៦៧៩, ១៦៨២ *ដើងទំព័រលេខ* ៥៥១០។

[3866] សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ១៤០។ សាលដីកាក្នុងរឿងក្តី *Seromba* កថាខណ្ឌ ៥៧-៥៨។

[3867] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៣៥។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤៥-៤៦, ៤៩-៥០។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៧៣២។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៨២។

[3868] សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៥០។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៧៧២។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៨២។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៥៤៦។

ចាំបាច់មានចេតនាដូចចារី ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ[3869]។ឧក្រិដ្ឋកម្មដែលមានចេតនាជាក់លាក់ ដូចជាការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ តម្រូវថា អ្នកជួយនិងជំរុញត្រូវដឹងអំពីឧក្រិដ្ឋកម្ម ប៉ុន្តែមិនចាំបាច់ មានចេតនាជាក់លាក់ដូចចារីឡើយ[3870]។ ការដឹងឮនេះអាចត្រូវបានសន្និដ្ឋានពីកាលៈទេសៈទាំងនោះ[3871]។

ច. ការទទួលខុសត្រូវរបស់ថ្នាក់លើ

1059. ការទទួលខុសត្រូវរបស់ថ្នាក់លើ ដែលអាចអនុវត្តបានចំពោះថ្នាក់លើយោធា និងថ្នាក់លើស៊ីវិល ត្រូវបានទទួលស្គាល់ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅឆ្នាំ១៩៧៥[3872]។ នៅពេលនោះ ទ្រឹស្តីនេះអាច

[3869] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៧៧២។ សាលដីកាក្នុងរឿងក្តី *Ndahimana* កថាខណ្ឌ ១៥៧។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ២៤៤។ ដូចអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គូស្លាវី បានពន្យល់ក្នុងរឿងក្តី *Šainović* "[ក]ម្រិតនៃការដឹងពាក់ព័ន្ធនឹងសេចក្តីលម្អិតនៃឧក្រិដ្ឋកម្ម ដែលចាំបាច់ ដើម្បីបំពេញ *បំណងឧក្រិដ្ឋ* នៃការជួយ និងការជម្រុញ គឺអាស្រ័យលើកាលៈទេសៈនៃករណីនេះ រាប់បញ្ចូលទាំងកម្រិតនៃឧក្រិដ្ឋកម្ម និងប្រភេទនៃជំនួយដែលត្រូវបានផ្តល់ឲ្យ"៖ សាលដីកាក្នុងរឿងក្តី *Šainović* កថាខណ្ឌ ១៧៧៣។

[3870] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៣៥។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧០៤។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៨៣០។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ៥២។ សាលដីកាក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ១២៧។ សាលដីកាក្នុងរឿងក្តី *Ndahimana* កថាខណ្ឌ ១៥៧។ សាលដីកាក្នុងរឿងក្តី *Fofana & Kondewa* កថាខណ្ឌ ៣៦៧។ សាលដីកាក្នុងរឿងក្តី *Vasiljević* កថាខណ្ឌ ១៤២។ សាលដីកាក្នុងរឿងក្តី *Krstić* កថាខណ្ឌ ១៤០។ សាលដីកាក្នុងរឿងក្តី *Ntakirutimana* កថាខណ្ឌ ៥០០-៥០១។

[3871] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៣៥។ សាលក្រមក្នុងរឿងក្តី *Milutinović* (ភាគទី១) កថាខណ្ឌ ៩៤។

[3872] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៤៧៦-៤៧៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១៤, ៧១៨-៧១៩។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ ន្ជួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៩០-២៣២។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤១៣-៤៦០។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣០៧, ១៣១៨-១៣១៩, ១៥៥៨។

អនុវត្តបានទៅលើឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[3873]។ ក្រោមមាត្រា២៩*ថ្មី*នៃច្បាប់ អ.វ.ត.ក និងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ការទទួលខុសត្រូវរបស់ថ្នាក់លើគឺផ្អែកលើអត្ថិភាពនៃធាតុផ្សំចំនួន៣ ខាងក្រោម៖

(១) ទំនាក់ទំនងជាថ្នាក់លើ-មនុស្សក្រោមបង្គាប់ រវាងជនជាប់ចោទ និងជនដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម។ ថ្នាក់លើត្រូវតែមានការគ្រប់គ្រងដោយប្រសិទ្ធភាពទៅលើមនុស្សក្រោមបង្គាប់[3874]។

(២) ថ្នាក់លើបានដឹង ឬមានហេតុផលដើម្បីដឹងថា មនុស្សក្រោមបង្គាប់បានប្រព្រឹត្ត ឬបម្រុងប្រព្រឹត្តឧក្រិដ្ឋកម្ម និង

(៣) ថ្នាក់លើបានខកខានពុំបានអនុវត្តវិធានការចាំបាច់ និងសមស្រប ដើម្បីទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬផ្តន្ទាទោសចារី[3875]

[3873] សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ ន្ជួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៣១-២៣២។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨៩៨, ៩១៧, ៩៣៩។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៨។

[3874] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក) មាត្រា២៩ (ថ្មី) មានលក្ខខណ្ឌតម្រូវជាក់លាក់ថា ថ្នាក់លើត្រូវតែមាន "បញ្ជា និងមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាព ឬមានអំណាច និងការត្រួតពិនិត្យទៅលើអ្នកនៅក្រោមបង្គាប់"។ ចំណុចនេះស៊ីសង្វាក់គ្នាជាមួយច្បាប់យុត្តិសាស្ត្ររបស់សាលាជម្រះក្តីចំពោះកិច្ច ដែលយល់ឃើញថា ដើម្បីឲ្យការទទួលខុសត្រូវផ្អែកព្រហ្មទណ្ឌកើតឡើងផ្អែកលើទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ វាត្រូវតែបង្ហាញថា ថ្នាក់លើមានការគ្រប់គ្រងដ៏មានប្រសិទ្ធភាពទៅលើចារី។ ការបកស្រាយដដែលនេះត្រូវបានប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូងរបស់អ.វ.ត.ក។ *សូមមើល* សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១៥។

[3875] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក) មាត្រា២៩ (*ថ្មី*)។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ ន្ជួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ១៩១។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៣៨។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១៥-៧១៦ និងឧទាហរណ៍។ សាលដីកាក្នុងរឿងក្តី *Gotovina & Markač* កថាខណ្ឌ ១២៨។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ១៤៣។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៨៤២, ៨៧៣។

i. ទំនាក់ទំនងថ្នាក់លើ - មនុស្សក្រោមបង្គាប់

1060. ទោះជាជនជាប់ចោទជាថ្នាក់លើស៊ីវិល ឬជាថ្នាក់លើយោធាក៏ដោយ[3876] ក៏ទំនាក់ទំនងថ្នាក់លើ-មនុស្សក្រោមបង្គាប់រវាងជនជាប់ចោទ និងចារីនៃឧក្រិដ្ឋកម្ម អាចមានអត្ថិភាពជាផ្លូវការ ឬមិនផ្លូវការ នោះគឺ *តាមព្រឹត្តិន័យ* ឬ *តាមនីតិន័យ* [3877]។ គេត្រូវតែបង្ហាញថា ថ្នាក់លើបានមាន "សិទ្ធិគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព" លើមនុស្សក្រោមបង្គាប់របស់គាត់[3878] ឬនិយាយម្យ៉ាងទៀត "លទ្ធភាពជាក់ស្តែង" ក្នុងការទប់ស្កាត់ ឬផ្តន្ទាទោសការប្រព្រឹត្តឧក្រិដ្ឋកម្មដោយមនុស្សក្រោមបង្គាប់[3879]។ ការអនុវត្តការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់មេបញ្ជាមួយរូប ពុំផាត់ចេញនូវការគ្រប់គ្រងប្រកបដោយ ប្រសិទ្ធភាពដែលកំពុងត្រូវបានអនុវត្តដោយមេបញ្ជាការមួយរូបទៀតឡើយ[3880]។

[3876] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៤៧៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧២០។ សំណុំរឿងលេខ ០០២ ឯកសារ D427/2/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៣០, ២៣២។ សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ៤១៨, ៤៥៩-៤៦០។ សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣១៩, ១៥៥៨។ សាលដីកាក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ១៩៥។ សាលដីកាក្នុងរឿងក្តី *Kajelijeli* កថាខណ្ឌ ៨៥។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ២៥៧។

[3877] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៤៧៧, ៥៤០។ សាលដីកាក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ១៩៣-១៩៧, ៣០៣។ សាលដីកាក្នុងរឿងក្តី *Halilović* កថាខណ្ឌ ៥៩, ២១០។ សាលដីកាក្នុងរឿងក្តី *Nyiramasuhuko* កថាខណ្ឌ ៩៩៥។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ២៥៧, ២៨៩។

[3878] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក) មាត្រា២៩ (ថ្មី)។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧២០។ សាលដីកាក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ១៩៦-១៩៧, ៣០៣។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៦៩។ សាលដីកាក្នុងរឿងក្តី *Gacumbitsi* កថាខណ្ឌ ១៤៣-១៤៤។ សាលដីកាក្នុងរឿងក្តី *Fofana & Kondewa* កថាខណ្ឌ ១៧៥។

[3879] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤០។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១៥។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៨៥៧។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៦២៥។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ២៥៧។

[3880] សាលដីកាក្នុងរឿងក្តី *Prlić* កថាខណ្ឌ ១៨៥៩។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៨៩២ (ដោយពិចារណាថា ខ្សែសង្វាក់បញ្ជាពីរស្របគ្នាបានកើតមាន *សូមមើល*សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៨៩០-១៨៩១)។

1061. លក្ខខណ្ឌនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព គឺដូចគ្នាសម្រាប់ទាំងថ្នាក់លើជាយោធា និងថ្នាក់លើជាជនស៊ីវិល[3881]។ នៅពេលការទទួលខុសត្រូវរបស់ថ្នាក់លើត្រូវបានអនុវត្តលើជនស៊ីវិល គ្មានលក្ខខណ្ឌតម្រូវដែលថា ការគ្រប់គ្រងដែលអនុវត្តដោយគាត់ មានចរិតដូចការគ្រប់គ្រងដែលអនុវត្តដោយមេបញ្ជាការយោធាឡើយ។ ការគ្រប់គ្រងនោះគ្រាន់តែចាំបាច់មានកម្រិតដូចគ្នាប៉ុណ្ណោះ[3882]។

ii. បានដឹង ឬមានហេតុផលដើម្បីដឹង

1062. សម្រាប់លក្ខខណ្ឌតម្រូវអំពីការដឹងឮ ពាក្យ "បានដឹង" សំដៅទៅលើការដឹងឮជាក់ស្តែងដែលថា ឧក្រិដ្ឋកម្មពាក់ព័ន្ធ ត្រូវបានប្រព្រឹត្ត ឬបម្រុងត្រូវបានប្រព្រឹត្ត ដែលគេអាចបង្ហាញតាមរយៈភ័ស្តុតាងផ្ទាល់ ឬភ័ស្តុតាងបន្ទាប់បន្សំ[3883]។ ថ្នាក់លើមិនចាំបាច់ដឹងអំពីអត្តសញ្ញាណជាក់លាក់របស់មនុស្សក្រោមបង្គាប់ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មឡើយ[3884]។

1063. លក្ខខណ្ឌស្តីពី "ហេតុផលដើម្បីដឹង" តម្រូវថា ថ្នាក់លើបានមានព័ត៌មានទូទៅដែលឲ្យគាត់ដឹងអំពីអំពើខុសច្បាប់ ដែលអាចកើតមានរបស់មនុស្សក្រោមបង្គាប់របស់គាត់[3885]។ លក្ខខណ្ឌនេះត្រូវបានបំពេញ ប្រសិនបើព័ត៌មានមានភាពភ្ញាក់ផ្អើលគ្រប់គ្រាន់ដើម្បីធ្វើយុត្តិកម្មការស៊ើបសួរបន្ថែម[3886]។

[3881] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧២០។ សាលដីកាក្នុងរឿងក្តី *Aleksovski* កថាខណ្ឌ ៧៦។ សាលដីកាក្នុងរឿងក្តី *Bagilishema* កថាខណ្ឌ ៥០។ សាលដីកាក្នុងរឿងក្តី *Brima* កថាខណ្ឌ ២៥៧។

[3882] សាលដីកាក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ១៩៧-១៩៨។ សាលដីកាក្នុងរឿងក្តី *Bagilishema* កថាខណ្ឌ ៥០, ៥២, ៥៥។ សាលដីកាក្នុងរឿងក្តី *Kajelijeli* កថាខណ្ឌ ៨៧។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៦០៥, ៧៨៥។

[3883] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤៣។ សាលដីកាក្នុងរឿងក្តី *Bagilishema* កថាខណ្ឌ ៣៧។ សាលក្រមក្នុងរឿងក្តី *Kordić & Čerkez* កថាខណ្ឌ ៤២៧។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៧។

[3884] សាលដីកាក្នុងរឿងក្តី *Blagojević & Jokić* កថាខណ្ឌ ២៨៧។ សាលដីកាក្នុងរឿងក្តី *Renzaho* កថាខណ្ឌ ៦៤, ១១៦។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៨៥១។

[3885] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤៤។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៦២។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៩១០, ១៩១២។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៧៩១។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៨៥២-៨៥៣។

[3886] សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១៥។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤៤។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៩១០។ សាលដីកាក្នុងរឿងក្តី *Strugar* កថាខណ្ឌ ២៩៨។

គ្មានលក្ខខណ្ឌតម្រូវដែលថាត្រូវមាន "លទ្ធផលខ្ពស់" ឬ "ហានិភ័យជាក់ស្តែង និងខ្លាំងក្លា" នៃឧក្រិដ្ឋកម្មនោះឡើយ[3887]។ លក្ខខណ្ឌស្តីពី "ហេតុផលដើម្បីដឹង" ពុំដាក់ភារកិច្ចដើម្បីទទួលបានព័ត៌មានឡើយ។ វាមិនដូចជា "គួរបានដឹង" ឡើយ នោះគឺលក្ខខណ្ឌស្តីពីភាពព្រងើយកន្តើយ។ ផ្ទាក់លើមិនអាចដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការខកខានមិនបានស្វែងរកការដឹងឮពាក់ព័ន្ធឡើយ[3888]។ ប៉ុន្តែការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនឹងត្រូវបានដាក់ទៅលើជនជាប់ចោទ ដែលមិនព្រមស្វែងរកព័ត៌មានពាក់ព័ន្ធ *ដោយចេតនា*[3889]។

1064. ផ្ទាក់លើមិនចាំបាច់មានចេតនាដូចមនុស្សក្រោមបង្គាប់របស់គាត់ឡើយ[3890]។

iii. ការខកខានមិនបានទប់ស្កាត់ ឬផ្តន្ទាទោស

1065. ភារកិច្ចរបស់ផ្ទាក់លើត្រូវបានបំពេញ នៅពេលគាត់បានចាត់វិធានការ "ចាំបាច់និងសមស្រប" ដើម្បីទប់ស្កាត់ ឬផ្តន្ទាទោសការប្រព្រឹត្តឧក្រិដ្ឋកម្ម ដោយមនុស្សក្រោមបង្គាប់ក្នុងបរិបទនៃស្ថានភាពណាមួយ។ ហេតុនេះ ការទទួលខុសត្រូវកើតឡើង នៅពេលគាត់ខកខានមិនបានធ្វើដូច្នោះ[3891]។ ភារកិច្ចទប់ស្កាត់ និងផ្តន្ទាទោស មានភាពខុសគ្នា និងតម្រូវឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដាច់ដោយឡែកពីគ្នា។ ភារកិច្ចទប់ស្កាត់ឧក្រិដ្ឋកម្ម កើតឡើងមុនការប្រព្រឹត្តឧក្រិដ្ឋកម្ម នៅពេលដែលផ្ទាក់លើបានដឹង ឬបានមានហេតុផលដើម្បីដឹងអំពីឧក្រិដ្ឋកម្មដែលបម្រុងនឹងត្រូវបានប្រព្រឹត្ត។ ពុំចាំបាច់បង្ហាញទំនាក់ទំនងហេតុផល រវាងការខកខានរបស់ផ្ទាក់លើក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្ម

[3887] សាលដីកាក្នុងរឿងក្តី *Strugar* កថាខណ្ឌ ៣០៤។

[3888] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤៤។ សាលដីកាក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ២២៦។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៦២-៦៤។ សាលដីកាក្នុងរឿងក្តី *Bagilishema* កថាខណ្ឌ ៣៤-៣៥។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៨-៤៩៩។

[3889] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤៤។ សាលដីកាក្នុងរឿងក្តី *Čelebići* កថាខណ្ឌ ២២៦។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៤០៦។ សាលក្រមក្នុងរឿងក្តី *Taylor* កថាខណ្ឌ ៤៩៩។

[3890] សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៨៦៥។ សាលដីកាក្នុងរឿងក្តី *Bagosora & Nsengiyumva* កថាខណ្ឌ ៣៨៤, ៣៩៩។

[3891] ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក) មាត្រា២៩(ថ្មី)។ សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤៥-៥៤៧។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១៦។ សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ២៣០។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៩៤៣។ សាលដីកាក្នុងរឿងក្តី *Nahimana* កថាខណ្ឌ ៤៨៤។ សាលដីកាក្នុងរឿងក្តី *Sesay* កថាខណ្ឌ ៥០២, ៨៤២។

របស់មនុស្សក្រោមបង្គាប់របស់គាត់ និងការកើតឡើងនៃឧក្រិដ្ឋកម្មទាំងនោះឡើយ[3892]។ ការខកខានមិនបានទប់ស្កាត់ ឬផ្តន្ទាទោសឧក្រិដ្ឋកម្ម អាចត្រូវបានសន្និដ្ឋានពីកត្តានានាដូចជាការរំលោភជាបន្តបន្ទាប់ ឬការរំលោភជាទូទៅ ដែលបានប្រព្រឹត្តដោយមនុស្សក្រោមបង្គាប់[3893]។

1066. ការសម្រេចថាអ្វីទៅជាវិធានការចាំបាច់និងសមស្រប ត្រូវធ្វើអាស្រ័យទៅតាមករណីនីមួយៗ[3894]។ ការសម្រេចថាតើអ្វីទៅអាចធ្វើទៅបានក្នុងការបំពេញភារកិច្ច គួរត្រូវបានធ្វើដោយពិចារណាអំពីកម្រិតនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ថ្នាក់លើ[3895]។ អត្ថិភាពនៃស្ថានភាពវិបត្តិ ពុំសម្រាលថ្នាក់លើពីភារកិច្ចរបស់គាត់បានឡើយ[3896]។

1067. ភារកិច្ចរបស់ថ្នាក់លើក្នុងការផ្តន្ទាទោសចារីនៃឧក្រិដ្ឋកម្ម រួមបញ្ចូលយ៉ាងហោចណាស់កាតព្វកិច្ចស៊ើបអង្កេតឧក្រិដ្ឋកម្មដែលអាចមាន បង្ហាញការពិត និងដាក់ទណ្ឌកម្មចារីដោយផ្ទាល់ ឬរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច តាមការចាំបាច់[3897]។

៣. បទដ្ឋានដែលការបង្ហាញភ័ស្តុតាងត្រូវបានតម្រូវសម្រាប់ការចោទប្រកាន់

1068. វិធាន៦៧(៣)(គ) នៃវិធានផ្ទៃក្នុងចែងថា ស.ច.ស ត្រូវចេញដីកាលើកលែងការចោទប្រកាន់ *ក្នុងចំណោមដីកាផ្សេង* ប្រសិនបើ "គ្មានភ័ស្តុតាងគ្រប់គ្រាន់" ប្រឆាំងជនត្រូវចោទ"[3898]។ ស្រដៀងនេះ

[3892] សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៧៧។ សាលដីកាក្នុងរឿងក្តី *Hadžihasanović & Kubura* កថាខណ្ឌ ៣៨-៤០។

[3893] សាលដីកាក្នុងរឿងក្តី *Bizimungu* (*Augustin*) កថាខណ្ឌ ១០៤។ សាលដីកាក្នុងរឿងក្តី *Bagosora & Nsengiyumva* កថាខណ្ឌ ៦៨៥។

[3894] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៥៤៥។ សំណុំរឿងលេខ ០០២ ឯកសារ E313 សាលក្រមក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៧១៦។ សាលដីកាក្នុងរឿងក្តី *Blaškić* កថាខណ្ឌ ៧២, ៤១៧។ សាលដីកាក្នុងរឿងក្តី *Halilović* កថាខណ្ឌ ៦៣។ សាលដីកាក្នុងរឿងក្តី *Orić* កថាខណ្ឌ ១៧៧។ សាលដីកាក្នុងរឿងក្តី *Hadžihasanović & Kubura* កថាខណ្ឌ ៣៣។ សាលដីកាក្នុងរឿងក្តី *Kayishema & Ruzindana* កថាខណ្ឌ ៣០២។ សាលដីកាក្នុងរឿងក្តី *Bagosora & Nsengiyumva* កថាខណ្ឌ ៦៧២, ៦៨៣។

[3895] សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ២៣១។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៩២៨។ សាលដីកាក្នុងរឿងក្តី *Bagosora & Nsengiyumva* កថាខណ្ឌ ៦៧២។

[3896] សាលដីកាក្នុងរឿងក្តី *Bagosora & Nsengiyumva* កថាខណ្ឌ ៦៧២។

[3897] សាលដីកាក្នុងរឿងក្តី *Halilović* កថាខណ្ឌ ១៨២។ សាលដីកាក្នុងរឿងក្តី *Boškoski & Tarčulovski* កថាខណ្ឌ ២៣០, ២៣៤-២៣៥។ សាលដីកាក្នុងរឿងក្តី *Hadžihasanović & Kubura* កថាខណ្ឌ ១៥៤។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ១៩៣២។ សាលដីកាក្នុងរឿងក្តី *Bagosora & Nsengiyumva* កថាខណ្ឌ ៥១០។

[3898] វិធានផ្ទៃក្នុង៦៧(៣)(គ)។

មាត្រា ២៤៧(៣) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចែងថាចៅក្រមស៊ើបសួរនឹងចេញដីកាលើកលែងការចោទប្រកាន់ប្រសិនបើ "គ្មានភ័ស្តុតាងគ្រប់គ្រាន់សម្រាប់ផ្តន្ទាទោសជនត្រូវចោទ"[3899]។

1069. ស.ច.ស បានអនុវត្តបទដ្ឋាននៃ "ភ័ស្តុតាងគ្រប់គ្រាន់" ក្នុងសំណុំរឿង 00១[3900] និង 00២[3901] ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ពួកគាត់បានសម្រេចថាបទដ្ឋានជាធរមាននៃការបង្ហាញភ័ស្តុតាង ដែលត្រូវបានគ្របដណ្តប់ដោយពាក្យ "ភ័ស្តុតាងគ្រប់គ្រាន់" គឺជាប្រូបាបនៃពិរុទ្ធភាព ជាជាងលទ្ធភាពនៃពិរុទ្ធភាព[3902]។ ស.ច.ស បានពន្យល់ថា "សម្ភារៈភ័ស្តុតាងក្នុងសំណុំរឿងត្រូវតែមានភាពធ្ងន់ធ្ងរគ្រប់គ្រាន់ និងមានភាពត្រឹមត្រូវដើម្បីផ្តល់តម្លៃជាភ័ស្តុតាងក្នុងកម្រិតណាមួយ"[3903]។ ការសម្រេចចុងក្រោយអំពីពិរុទ្ធភាពឲ្យហួសពីវិមតិសង្ស័យ នៅតែត្រូវវាយតម្លៃដោយអង្គជំនុំជម្រះសាលាដំបូង[3904]។

៤. យុត្តាធិការលើរូបបុគ្គល

1070. ទាំងកិច្ចព្រមព្រៀង អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ចែងថា គោលបំណងនៃការបង្កើតតុលាការនេះគឺដើម្បី "កាត់សេចក្តីមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្រោមយុត្តាធិការរបស់ អ.វ.ត.ក ដែលត្រូវបានប្រព្រឹត្តពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[3905]។

1071. ពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ពុំត្រូវបានកំណត់និយមន័យបន្ថែមឡើយ ទោះក្នុងច្បាប់ អ.វ.ត.ក ក្តី ឬកិច្ចព្រមព្រៀងក្តី។ ផ្អែកលើការវិភាគល្អិតល្អន់អំពីការងារត្រៀមរៀបចំ និងប្រវត្តិនៃកិច្ចចរចានៃកិច្ចព្រមព្រៀង អ.វ.ត.ក[3906] អ.ជ.ត.ក ក្នុងសំណុំរឿង *ឌុច*

[3899] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២00៨ មាត្រា២៤៧(៣)។

[3900] សំណុំរឿងលេខ 00១ ឯកសារ D99 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣0។

[3901] សំណុំរឿងលេខ 00២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២១។

[3902] សំណុំរឿងលេខ 00២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។

[3903] សំណុំរឿងលេខ 00២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។

[3904] វិធាន៨៧(១)។

[3905] កិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា១, ២។ ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មាត្រា១, ២(*ថ្មី*)។

[3906] សំណុំរឿងលេខ 00១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ 00១ កថាខណ្ឌ ៤៦-៥៧។

បានសម្រេចថា អ.វ.ត.ក មានយុត្តាធិការលើរូបបុគ្គល ទៅលើមន្ត្រីខ្មែរក្រហម[3907] និងថាពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សំដៅទៅដល់មន្ត្រីខ្មែរក្រហមចំនួន ២ ប្រភេទដាច់ដោយឡែកពីគ្នា៖

> ប្រភេទទីមួយគឺជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះមេដឹកនាំជាន់ខ្ពស់ម្នាក់មិនមែនជាជនសង្ស័យ ដោយផ្អែកតែទៅលើតួនាទីជាអ្នកដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ។ ប្រភេទមួយផ្សេងទៀតគឺអ្នកដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ប៉ុន្តែជាអ្នកដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតផងដែរ[3908]។

អាស្រ័យហេតុនេះ ប្រសិនបើជនត្រូវចោទជាមន្ត្រីខ្មែរក្រហម គាត់មិនចាំបាច់ជាមេដឹកនាំជាន់ខ្ពស់ឡើយដើម្បីស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត។

1072. ស.ច.ស.អ បានលើកឡើងថា ការសម្រេចថាតើជនត្រូវចោទជា "មេដឹកនាំជាន់ខ្ពស់" និង/ឬ ស្ថិតក្នុងចំណោមមន្ត្រីខ្មែរក្រហមដែលជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ត្រូវធ្វើនៅពេលបញ្ចប់កិច្ចស៊ើបសួរ ដោយផ្អែកទៅលើភ័ស្តុតាងទាំងអស់ក្នុងសំណុំរឿង"[3909]។

ក. អ្នកទទួលខុសត្រូវខ្ពស់បំផុត

1073. ក្នុងការសម្រេចថា តើជនណាម្នាក់ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ក្រោមច្បាប់អន្តរជាតិ អ.វ.ត.ក និងតុលាការ និងសាលាក្តីឧក្រិដ្ឋកម្មជាតិនានា បានអនុវត្តលក្ខខណ្ឌចំនួន ២៖ (i) ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ទៅលើជននោះ និង(ii) កម្រិតនៃការទទួលខុសត្រូវរបស់ជននោះ ដែលត្រូវបានចោទថាបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនោះ។

1074. តុលាការ ICTY ត្រូវបានផ្តល់អាណត្តិជាផ្នែកមួយនៃយុទ្ធសាស្ត្របញ្ចប់ការងាររបស់ខ្លួនដើម្បីផ្តោតលើ "មេដឹកនាំជាន់ខ្ពស់បំផុត ដែលជាប់សង្ស័យថា ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋ

[3907] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ៥២, ៦១។

[3908] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ៥៧ (សេចក្តីដកស្រង់ខាងក្នុងត្រូវបានលុប)។

[3909] ឯកសារ D298.1 ដីកាសម្រេចរួមលើសំណើរបស់ មាស មុត លើយុត្តាធិការបុគ្គល កថាខណ្ឌ ២៧។

កម្ម”[3910] ហើយបញ្ជូនចារីដែលនៅសេសសល់ទៅកាត់សេចក្តីនៅតុលាការថ្នាក់ជាតិ[3911]។ ក្នុងការវាយតម្លៃថា នរណាជាអ្នកទទួលខុសត្រូវខ្ពស់បំផុត គណៈចៅក្រមនៃតុលាការ ICTY បានពិចារណាអំពី “ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទ” និង “កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ”[3912]។ គោលការណ៍ទាំងពីរនេះត្រូវបានឆ្លុះបញ្ចាំងក្នុងសេចក្តីសម្រេចរបស់ SCSL[3913] សេចក្តីថ្លែងការណ៍របស់ការិយាល័យរដ្ឋអាជ្ញានៃ ICC (“OTP”)[3914] និងត្រូវបានអនុវត្តដោយអង្គជំនុំជម្រះសាលានៃ អ.វ.ត.ក[3915] អ.ជ.ត.ក[3916] និង ស.ច.ស[3917]។ ការអនុវត្តគោលការណ៍ទាំង២ នេះពុំត្រូវការការប្រៀបធៀប និងការកំណត់កម្រិតនៃការទទួលខុសត្រូវរបស់ជនដែលអាចជាចារីទាំងអស់ឡើយ[3918] ប៉ុន្តែជំនួសវិញ គួរមានទំនាក់ទំនងជាមួយសំណុំរឿងដទៃដែលជំនុំជម្រះដោយតុលាការ និងកាលៈទេសៈ និងបរិបទជាក់ស្តែង ដែលឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត[3919]។

[3910] សេចក្តីសម្រេចលេខ ១៥៣៤ (២០០៤) ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០០៤ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឯកសារអង្គការសហប្រជាជាតិ No. S/Res/1534 កថាខណ្ឌ ៥-ខ។ សេចក្តីសម្រេចលេខ ១៥០៣ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៣ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឯកសារអង្គការសហប្រជាជាតិ No. S/Res/1503 សេចក្តីដកស្រង់បុព្វកថា ចំណុចទី៧។

[3911] វិធានទីតិវិធី និងភ័ស្តុតាងនៃតុលាការអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គូស្លាវី វិធាន១១*ស្ទ*។ វិធាន១១*ស្ទ*(គ) យោងលើសេចក្តីសម្រេចលេខ ១៥៣៤ របស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងចែងថា តុលាការអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គូស្លាវី នឹងពិចារណាលើ “ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលត្រូវបានចោទ” និង “កម្រិតនៃការទទួលខុសត្រូវរបស់ជនជាប់ចោទ” ក្នុងការសម្រេចថា តើត្រូវផ្ទេរសំណុំរឿងដែរឬអត់។ *សូមមើលផងដែរ* ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញា ក្នុងការបញ្ជូនសំណុំរឿង *Milošević* (*Dragomir*) កថាខណ្ឌ ១-៣។

[3912] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៦-២៨។

[3913] ដីកាសម្រេចលើសំណើរបស់មេធាវីការពារពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលក្នុងសំណុំរឿង *Fofana* កថាខណ្ឌ ២២។

[3914] អយ្យការអមតុលាការព្រហ្មទណ្ឌអន្តរជាតិ ឯកសារស្តីពីបញ្ហាគោលនយោបាយមួយចំនួននៅចំពោះមុខអយ្យការ តុលាការព្រហ្មទណ្ឌអន្តរជាតិ ខែកញ្ញា ឆ្នាំ២០០៣ ទំព័រ ៧។

[3915] សំណុំរឿងលេខ ០០១ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ២២-២៤។

[3916] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ៧១។

[3917] សំណុំរឿងលេខ ០០៣ ឯកសារ D48 ដីកាសម្រេចលើយុត្តាធិការបុគ្គល និងចុះធ្វើការស៊ើបអង្កេតលើ មាស មុត កថាខណ្ឌ ១៥។ សំណុំរឿងលេខ ០០៣ ឯកសារ D49 ដីកាសម្រេចលើយុត្តាធិការបុគ្គល និងចុះធ្វើការស៊ើបអង្កេតលើ ស្ងួ មេត កថាខណ្ឌ ១៥។ សំណុំរឿងលេខ ០០៤/១ ឯកសារ D308/3 ដីកាដំណោះស្រាយ (សម្អាងហេតុ) កថាខណ្ឌ ៣៧-៤១។

[3918] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ៦២។

[3919] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Ademi* កថាខណ្ឌ ២៨។

1075. សេចក្តីសម្រេចរបស់គណៈចៅក្រម ICTY បានលើកឡើងថា កត្តាពាក់ព័ន្ធនានាក្នុងការកំណត់អំពីភាពធ្ងន់ធ្ងរនៃបទល្មើស ដែលត្រូវបានប្រព្រឹត្តរួមបញ្ចូល៖ វិសាលភាពភូមិសាស្ត្រនិងវិសាលភាពពេលវេលានៃឧក្រិដ្ឋកម្ម[3920] លក្ខណៈនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម[3921] ចំនួននៃហេតុការណ៍[3922] និងចំនួនជនរងគ្រោះ[3923]។ កត្តាពាក់ព័ន្ធនានាដើម្បីកំណត់កម្រិតនៃការទទួលខុសត្រូវរបស់ជន ដែលត្រូវបានចោទថាបានប្រព្រឹត្តឧក្រិដ្ឋកម្មរួមបញ្ចូល៖ កម្រិតនៃការចូលរួមក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់[3924] ឋានានុក្រម ឬតំណែងរបស់ជនជាប់ចោទ[3925] ដោយរួមបញ្ចូលចំនួន មនុស្សក្រោម

[3920] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Janković* កថាខណ្ឌ ១៩។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Ademi* កថាខណ្ឌ ២៨។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Kovačević* កថាខណ្ឌ ២០។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៧។ ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយ *Todović* ប្រឆាំងនឹងដីកាសម្រេចលើការបញ្ជូនសំណុំរឿង កថាខណ្ឌ ១៣, ១៦។ ទោះជាយ៉ាងនេះក្តី អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គូស្លាវី បានសង្កត់ធ្ងន់ថា មិនគួរសង្កត់ធ្ងន់ខ្លាំងពេកលើតួអង្គនៃឧក្រិដ្ឋកម្មក្នុងស្រុកទេ ពីព្រោះជាការពិត អ្នកដឹកនាំក្នុងស្រុកអាចមានឥទ្ធិពលធំដុំច្រើន ដែលធានានូវការបញ្ជូនពួកគេទៅក្នុងប្រភេទនៃជនដែលទទួលខុសត្រូវបំផុត។ *សូមមើល* ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយ *Lukić* កថាខណ្ឌ ២២។

[3921] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៧។

[3922] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៧។

[3923] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Janković* កថាខណ្ឌ ១៩។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Kovačević* ថាខណ្ឌ ១២, ២០។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៧ និង២៩។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Rašević & Todović* កថាខណ្ឌ ២៣។ ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយ *Todović* ប្រឆាំងនឹងដីកាសម្រេចលើការបញ្ជូនសំណុំរឿង កថាខណ្ឌ ២៥។

[3924] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Ademi* កថាខណ្ឌ ២៩។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៨។ ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយ *Lukić* ប្រឆាំងនឹងដីកាសម្រេចលើការបញ្ជូនសំណុំរឿង កថាខណ្ឌ ២១។

[3925] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Ademi* កថាខណ្ឌ ២៩។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Kovačević* កថាខណ្ឌ ២០។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Milošević* (*Dragomir*) កថាខណ្ឌ ២៣។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៨។ ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយ *Lukić* ប្រឆាំងនឹងដីកាសម្រេចលើការបញ្ជូនសំណុំរឿង កថាខណ្ឌ ២១។

បង្ក្រាប់ និងថ្នាក់លើ[3926] សិទ្ធិអំណាចប្រកបដោយប្រសិទ្ធភាពរបស់ពួកគាត់[3927] និងលទ្ធភាពផ្តល់បញ្ជា[3928] វិសាលភាពពេលវេលានៃការគ្រប់គ្រងរបស់ពួកគាត់[3929] និងសិទ្ធិអំណាចរបស់ពួកគាត់ដើម្បីចរចា ចុះហត្ថលេខា ឬអនុវត្តកិច្ចព្រមព្រៀងនានា[3930]។

ខ. មេដឹកនាំជាន់ខ្ពស់

1076. ទាក់ទងនឹងពាក្យ "មេដឹកនាំជាន់ខ្ពស់នៃកម្ពុជាប្រជាធិបតេយ្យ" ប្រវត្តិនីតិបញ្ញត្តិនៃ អ.វ.ត.ក[3931] និងយុត្តិសាស្ត្រអន្តរជាតិ[3932] បង្ហាញថាពាក្យនេះមិនកំហិតត្រឹមសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃ ប.ក.ក ឬ "អ្នកបង្កើតគោលនយោបាយទូទៅ" ឡើយ។ ប៉ុន្តែ វាជាទស្សនៈរបស់ ស.ព.អ ដែលថា អត្ថន័យសាមញ្ញនៃពាក្យនេះបង្ហាញថា វារាប់បញ្ចូលក្រុមមនុស្សមួយចំនួនតូចនៅថ្នាក់កំពូលនៃឋានានុក្រម នយោបាយ និងយោធានៃ ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ ដោយរួមបញ្ចូលលេខាតំបន់ និងសមាជិកគណៈភូមិភាគ។

១. ១ក្រិដ្ឋកម្ម និងទម្រង់នៃការទទួលខុសត្រូវដែលមិនត្រូវបានចោទប្រកាន់ពីពេលមុន

1077. ក្រោមច្បាប់ចៅក្រមស៊ើបសួរនៃកម្ពុជា និង អ.វ.ត.ក ស.ច.ស ត្រូវបានប្តឹងឲ្យពិនិត្យ និងចាត់ការ *បណ្តឹងលើអង្គហេតុ* ជាមួយអង្គហេតុទាំងអស់ដែលមានពិពណ៌នាក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមក្នុងសំណុំរឿង និងតម្រូវឲ្យស៊ើបអង្កេតអំពី

[3926] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Milošević* (*Dragomir*) កថាខណ្ឌ ២៣។ ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍ដោយ *Lukić* ប្រឆាំងនឹងដីកាសម្រេចលើការបញ្ជូនសំណុំរឿង កថាខណ្ឌ ២១។

[3927] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៨។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Ademi* កថាខណ្ឌ ២៩។

[3928] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Ademi* កថាខណ្ឌ ២៩។

[3929] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Milošević* (*Dragomir*) កថាខណ្ឌ ២៣។

[3930] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Milošević* (*Dragomir*) កថាខណ្ឌ ២៣។

[3931] សំណុំរឿងលេខ ០០១ ឯកសារ F28 សាលដីកាសម្រេចលើបណ្តឹងសាទុក្ខក្នុងសំណុំរឿងលេខ ០០១ កថាខណ្ឌ ៧៦-៧៧ *ដកស្រង់*សម័យប្រជុំលើកដំបូងនៃរដ្ឋសភាកម្ពុជា នីតិកាលទី ៣ ថ្ងៃទី ៤-៥ ខែតុលា ឆ្នាំ២០០៤ ទំព័រ ២៣។ សំណុំរឿងលេខ ០០២ ឯកសារ E188 សាលក្រមក្នុងរឿងក្តី កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ១៩ *ដកស្រង់*បាយការណ៍ក្រុមអ្នកជំនាញ កថាខណ្ឌ ១០៩។

[3932] ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Milošević* (*Dragomir*) កថាខណ្ឌ ២២។ ដីកាសម្រេចលើសំណើរបស់រដ្ឋអាជ្ញាក្នុងការបញ្ជូនសំណុំរឿង *Lukić & Lukić* កថាខណ្ឌ ២៨។

អង្គហេតុនីមួយៗ ឲ្យបានពេញលេញ និងឲ្យបានត្រឹមត្រូវ[3933]។ ក្រោមការអនុវត្តវិធាន៦៦*ស្ទ* ដែលមិនរាប់បញ្ចូលអង្គហេតុនានាក្នុងវិសាលភាពនៃកិច្ចស្ទើបសួរ ស.ច.ស មានកាតព្វកិច្ចក្នុងដីកាដំណោះស្រាយរបស់ពួកគាត់ ក្នុងការធ្វើសេចក្តីសម្រេចទាក់ទងអង្គហេតុទាំងនោះ និងការកំណត់បទចោទពាក់ព័ន្ធ ដែលស្នើឡើងដោយសហព្រះរាជអាជ្ញា តាមរយៈការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ បន្ទាប់ពីបានចោទប្រកាន់ជនត្រូវចោទ ឬតាមរយៈការចេញដីកាលើកលែងការចោទប្រកាន់ទាក់ទងអង្គហេតុទាំងអស់ ឬផ្នែកខ្លះនៃអង្គហេតុទាំងនោះ[3934]។ ក្នុងសំណុំរឿងទាំងអស់ ស.ច.ស "ត្រូវបញ្ជាក់សំអាងហេតុនៃការសម្រេច"[3935]។ ហេតុដូច្នេះ លក្ខខណ្ឌតម្រូវសម្រាប់សេចក្តីសម្រេចដែលមានសំអាងហេតុរួមបញ្ចូលការសម្រេចថា តើត្រូវបញ្ជូនទៅជំនុំជម្រះចំពោះអង្គហេតុដែលជនណាម្នាក់ ដែលត្រូវបានចោទក្នុងដីកាសន្និដ្ឋានទាំងនោះ ថាជាអ្នកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលមិនទាន់ត្រូវបានចោទប្រកាន់។

1078. អនុលោមតាមវិធាន ៦៧(៣) ដីកាលើកលែងការចោទប្រកាន់អាចត្រូវបានចេញក្នុងករណីតែបីប៉ុណ្ណោះ ទាក់ទងការចោទប្រកាន់ណាមួយ៖ ប្រសិនបើ (i) អំពើនោះមិនស្ថិតក្រោមយុត្តាធិការនៃ អ.វ.ត.ក (ii) ចារីពុំទាន់ត្រូវបានកំណត់អត្តសញ្ញាណ ឬ (iii) មានភ័ស្តុតាងមិនគ្រប់គ្រាន់។ ការខកខានរបស់ ស.ច.ស មិនបានជូនដំណឹងពីពេលមុនទៅជនសង្ស័យអំពីការចោទប្រកាន់ ដែលអាចមានទាក់ទងអង្គហេតុ ដែលមាន "ភ័ស្តុតាងគ្រប់គ្រាន់" ពុំមែនជាមូលដ្ឋានដ៏មានសុពលភាពក្រោមច្បាប់គ្រប់គ្រងរបស់ អ.វ.ត.ក សម្រាប់ការចេញដីកាលើកលែងការចោទប្រកាន់ទេ។ ជាការពិត

[3933] វិធានផ្ទៃក្នុង ៥៥(២)។ ឯកសារ D365/3/1/5 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស្ទើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ នៅក្នុងគុកលេខ៨ និងនៅក្នុងស្រុកបាកាន កថាខណ្ឌ ៣៧, ៣៩, ៤២។ សំណុំរឿងលេខ ០០១ ឯកសារ D99/3/42 សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច កថាខណ្ឌ ៣៥។ សំណុំរឿងលេខ ០០២ ឯកសារ D198/1 ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំភ្លឺអំពីបទចោទ កថាខណ្ឌ ៦, ១០។ *សូមមើលបន្ថែម* ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មាត្រា១២៥។

[3934] វិធានផ្ទៃក្នុង ៦៧(១)-(២) (៤)។ សំណុំរឿងលេខ ០០២ ឯកសារ D198/1 ដីកាសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបំភ្លឺអំពីបទចោទ កថាខណ្ឌ ១០, ផ្នែកសម្រេចសេចក្តី។ ឯកសារ D365/3/1/5 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស្ទើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ នៅក្នុងគុកលេខ៨ និងនៅក្នុងស្រុកបាកាន កថាខណ្ឌ ៣៥-៣៦។ *សូមមើល*ផងដែរ Cass. Crim. ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៧៧ លេខ 76-91442 ["ចៅក្រមស្ទើបអង្កេតត្រូវបើកការស្ទើបសួរលើអង្គហេតុទាំងអស់ ដែលខ្លួនបានទទួលត្រឹមត្រូវតាមនីតិវិធី។"]។

[3935] វិធានផ្ទៃក្នុង ៦៧(៤)។

នៅពេលមានភ័ស្តុតាង "ធ្ងន់ធ្ងរ និងដែលអាចបញ្ជាក់ការពិតគ្រប់គ្រាន់ដើម្បីផ្តល់តម្លៃជាភ័ស្តុតាងក្នុងកម្រិតណាមួយ"[3936] ដែលធានាបានការបញ្ជូនរឿងទៅជំនុំជម្រះ គេត្រូវបំពេញលក្ខខណ្ឌទាបដែលតម្រូវឲ្យគាំទ្រការចោទប្រកាន់ណាមួយ នោះគឺ "ភ័ស្តុតាងជាក់ស្តែង និងស៊ីចង្វាក់" ដែលថាជនសង្ស័យអាចជាអ្នកទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលបានលើកឡើងក្នុងដីកាសន្និដ្ឋានទានានារបស់សហព្រះរាជអាជ្ញា[3937]។

1079. អ.ប.ជ បានលើកឡើងក្នុងសំណុំរឿងនេះថា "ការចោទនានានៅដំណាក់កាលស៊ើបសួរ ជាការចោទបណ្តោះអាសន្ន" និងថា "ស.ច.ស នៅតែពិនិត្យ និងចាត់ការអង្គហេតុទាំងអស់ និងអាចកែប្រែការចោទ រហូតដល់មានដីកាដំណោះស្រាយ"[3938]។ អាស្រ័យហេតុនេះ ក្នុងដីកាសន្និដ្ឋានស្តាពរនេះ ស.ព.អ បានពិភាក្សាអំពីភ័ស្តុតាងពីកិច្ចស៊ើបសួរទាក់ទងឧក្រិដ្ឋកម្មទាំងអស់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម[3939] និងបានផ្តល់អនុសាសន៍ឲ្យមានការបញ្ជូនរឿងទៅជំនុំជម្រះ ចំពោះឧក្រិដ្ឋកម្មនិងទម្រង់នៃការទទួលខុសត្រូវទាំងនោះ ទោះជាមិនទាន់ចោទ ឬមិនត្រូវបានចោទក្តី ដែលគាត់ជឿថាភ័ស្តុតាងក្នុងសំណុំរឿងមានភាពធ្ងន់ធ្ងរ គ្រប់គ្រាន់ និងអាចបញ្ជាក់ការពិត ដើម្បីបង្ហាញអំពីប្រូបាបនៃពិរុទ្ធភាព។

គ. ឧក្រិដ្ឋកម្មដែលមិនត្រូវបានស្នើសុំ

១. ឧក្រិដ្ឋកម្មក្រោមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦

1080. អ.ប.ជ បានលើកឡើងពីពេលមុននូវជំហររបស់សហព្រះរាជអាជ្ញា[3940] ដែលថា អនុលោមតាមមាត្រា ៣ ថ្មីនៃច្បាប់ អ.វ.ត.ក អ.វ.ត.ក អាចអនុវត្តយុត្តាធិការលើបទល្មើសមនុស្សឃាត[3941] ការ

[3936] *សូមមើល* កថាខណ្ឌ ១០៧០ ខាងលើ។ *សូមមើល* សំណុំរឿងលេខ ០០២ ឯកសារ D427 ដីកាដំណោះស្រាយ កថាខណ្ឌ ១៣២៣។

[3937] វិធានផ្ទៃក្នុង ៥៥(៤)។

[3938] ឯកសារ D365/3/1/5 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងនឹងអំពើហិង្សាផ្លូវភេទ នៅក្នុងគុកលេខ ៨ និងនៅក្នុងស្រុកបាកាន កថាខណ្ឌ ៣៨។

[3939] ដោយមានការលើកលែងចំពោះជនទាំងឡាយដែលមិនត្រូវបានរាប់បញ្ចូលក្រោមយន្តការនៃវិធាន ៦៦*ស្ទួន*។ *សូមមើល* ឯកសារ D354 សេចក្តីជូនដំណឹងយោងតាមវិធានផ្ទៃក្នុង ៦៦*ស្ទួន* (២) ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៧។

[3940] សំណុំរឿងលេខ ០០២ ឯកសារ D427/1/30 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ កថាខណ្ឌ ២៧១-២៩២, ២៩៧។

[3941] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ៥០១, ៥០៣-៥០៨។

ធ្វើទារុណកម្ម[3942] និងការធ្វើទុក្ខបុកម្នេញដោយហេតុផលសាសនា[3943] (ទាំងអស់ "បទល្មើសក្រោមច្បាប់ជាតិ") ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងមិនត្រូវបានហាមឃាត់មិនឲ្យធ្វើដូច្នោះតាមរយៈអាជ្ញាយុកាល១០ឆ្នាំ ដែលមានក្នុងមាត្រា ១០៩ នៃក្រមនោះ[3944]។ ប៉ុន្តែអង្គជំនុំជម្រះសាលាដំបូងបានខកខានមិនទទួលបានសំឡេងភាគច្រើនចាំបាច់ សម្រាប់ការសម្រេចមួយលើបញ្ហាដដែលនេះ។ ស.ព.អ ពុំស្នើសុំការបញ្ជូន **យ៉ីម ទិញ** ទៅជំនុំជម្រះចំពោះបទល្មើសក្រោមច្បាប់ជាតិឡើយ។ ស.ព.អ ជឿជាក់ថា អំពើល្មើសដដែលនេះ ត្រូវបានរៀបរាប់ប្រសើរជាងនេះ នៅពេលត្រូវបានកំណត់បទចោទថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមច្បាប់អន្តរជាតិ (ពិសេស មនុស្សឃាត ការធ្វើមនុស្សឃាត និងការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ)។ ជាងនេះទៀត តាមរយៈការចាត់ទុកទង្វើនេះជាឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ជាជាងឧក្រិដ្ឋកម្មក្រោមច្បាប់ជាតិ បណ្តឹងមិនចាំបាច់នៅដំណាក់កាលជំនុំជម្រះ អាចត្រូវបានបញ្ជៀសដើម្បីធានាបានកិច្ចដំណើរការនីតិវិធីដ៏ឆាប់រហ័ស។

២. ការរំលោភបំពានធ្ងន់ធ្ងរនៃអនុសញ្ញាក្រុងហ្ស៊ីណែវឆ្នាំ១៩៤៩

1081. ស.ព.អ ពុំបានស្នើសុំការបញ្ជូន **យ៉ីម ទិញ** ទៅជំនុំជម្រះពីបទរំលោភធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្ស៊ីណែវឆ្នាំ១៩៤៩។ ដូចដែលគាត់បានគូសបញ្ជាក់ពីពេលមុន ស.ព.អ យល់ឃើញថា "អំពើល្មើសណាមួយក្នុងកិច្ចស៊ើបសួរនេះ ដែលអាចត្រូវបានចាត់ទុកជាការបំពានធ្ងន់ធ្ងរ នឹងត្រូវបានគ្របដណ្តប់យ៉ាងគ្រប់គ្រាន់ ដោយការកំណត់បទល្មើសចំពោះទង្វើក្រោម [ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ] ដោយពិចារណាអំពីភ័ស្តុតាងដ៏សន្ធឹកសន្ធាប់ នៃបរិបទនៃការវាយប្រហារជាទូទៅនិងជាលក្ខណៈ

[3942] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ៥០០។

[3943] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ២០៩, ២១០។

[3944] ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ១០៩ នៅក្នុងផ្នែកដែលពាក់ព័ន្ធ ចែងថា "ចារីមិនត្រូវបានផ្តន្ទាទោសចំពោះបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្តលើសពី ១០ឆ្នាំមុនឡើយ" (បកប្រែក្រៅផ្លូវការដោយអង្គជំនុំជម្រះសាលាដំបូង និងអនុម័តដោយអង្គបុរេជំនុំជម្រះ)។ *សូមមើល* សំណុំរឿងលេខ ០០១ ឯកសារ E187 សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងចិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី *ជើងទំព័រលេខ* ១៣)។ *សូមមើល*ផងដែរ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ មាត្រា ១១១ (ដែលគូសបញ្ជាក់ថា ចិរវេលាដែលបានបញ្ញត្តចាប់ផ្តើមនៅពេលដែលអំពើដែលបានចោទត្រូវបានប្រព្រឹត្ត) និងមាត្រា ១១២-១១៤ (ដែលចែងថា សកម្មភាពនៃការស៊ើបអង្កេត ឬការចោទប្រកាន់ណាមួយ ផ្តាច់ការកម្រិតពេលវេលា ដែលបន្តឡើងវិញ បន្ទាប់ពីសកម្មភាពចុងក្រោយបែបនេះ (ក្នុងករណីនៃបទឧក្រិដ្ឋ) សម្រាប់រយៈពេល ១០ឆ្នាំ ថ្មីទៀត)។

ប្រព័ន្ធទៅលើប្រជាជនស៊ីវិល"[3945]។ ករណីនេះដូចគ្នាជាមួយទង្វើដែលអាចត្រូវបានចោទថាជាបទល្មើសក្រោមច្បាប់ជាតិ ដែលការចាត់ទុកអំពើនេះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នឹងបញ្ជៀសបណ្តឹងមិនចាំបាច់ និងពន្លឿនកិច្ចដំណើរការនីតិវិធី ព្រមទាំងផ្តោតចំទៅលើវិសាលភាព និងចរិតលក្ខណៈសំខាន់ៗនៃទង្វើឧក្រិដ្ឋរបស់ **យ៉ីម ទិត្យ**។

VII. ចាត់ថ្នាក់តាមបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

1082. ភ័ស្តុតាងនៅក្នុងសំណុំរឿង និងដែលត្រូវបានយោងទៅដល់ នៅក្នុងសារណានេះ បង្ហាញថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលត្រូវផ្តន្ទាទោស ដោយអនុលោមតាមវិធាន ៥ នៃច្បាប់ អ.វ.ត.ក ត្រូវបានប្រព្រឹត្តនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ អង្គហេតុដែលបង្កើតលក្ខខណ្ឌតម្រូវទូទៅនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនឹងត្រូវពិភាក្សានៅខាងក្រោម។

ក. ការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល

1083. បទល្មើសដែលត្រូវបានរៀបរាប់យ៉ាងលម្អិតនៅក្នុងសារណានេះ គឺជាផ្នែកមួយនៃការវាយប្រហារដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋជាច្រើន នៅក្នុងប្រព័ន្ធនៃការគាបសង្កត់ដែលមានការរៀបចំ។ អំពើទាំងនេះរួមមាន៖ (i) ការបណ្តេញមនុស្សចេញពីទីក្រុងដោយបង្ខំ (ii) ការដាក់មនុស្សឲ្យក្លាយជាទាសករនៅក្នុងសហករណ៍ និងការដ្ឋាននានា ដែលត្រូវបានបង្កើតឡើងដោយ ប.ក.ក. (iii) ការធ្វើពលកម្មដោយបង្ខំក្នុងទ្រង់ទ្រាយធំ (iv) ការអនុវត្តការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (v) ការធ្វើបាប និងការបដិសេធសិទ្ធិ និងសេរីភាពជាមូលដ្ឋាន និងការដកហូតទ្រព្យសម្បត្តិ និង (vi) ការអនុវត្តទម្រង់ផ្សេងៗ នៃការគាបសង្កត់ទាំងនេះ តាមរយៈការប្រព្រឹត្តអមនុស្សធម៌ ការចាប់ខ្លួនតាមទំនើងចិត្ត ការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ ការឃុំខ្លួន និងការសម្លាប់។[3946] អ្នកដែលត្រូវសន្មតថាជា

[3945] ឯកសារ D342/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសេចក្តីជូនដំណឹងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីចេតនាដាក់បន្ថែមទម្រង់នៃការទទួលខុសត្រូវតាមវិធីដីកាបង្គាប់របស់តុលាការ និងអំពីការផ្អាកជាបណ្តោះអាសន្ន ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ កថាខណ្ឌ ៤។

[3946] *សូមមើល* ផ្នែកទី VIII.**ខ**.១.ក. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីខ្ទាំង។ ផ្នែកទី VIII.**ខ**.១.ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីការធ្វើឲ្យទៅជាទាសករ។ ផ្នែកទី VIII.**ខ**.១.គ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ។ ផ្នែកទី VIII.**ខ**.១.ឃ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីការ

សមាជិកក្រុមសាសនា ជាតិសាសន៍ ឬនយោបាយ ដែលចារីយល់ឃើញថាមិនមានភក្តីភាព នឹងត្រូវកំណត់ជាគោលដៅ។ ការវាយប្រហារត្រូវបានផ្តោតជាចម្បង ទៅលើប្រជាជនស៊ីវិលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទោះបីជាជនរងគ្រោះមួយចំនួនគឺជាយោធាខ្មែរក្រហមក៏ដោយ[3947]។

ខ. យ៉ាងទូលំទូលាយ ឬជាប្រព័ន្ធ

1084. ការវាយប្រហារមានលក្ខណៈទូលំទូលាយ និងជាប្រព័ន្ធ។ វាមានលក្ខណៈទូលំទូលាយដោយសារតែវិសាលភាពនៃការវាយប្រហារ តំបន់ភូមិសាស្ត្រជាក់ស្តែង ដែលវាបានកើតឡើង ព្រមទាំងតំបន់ប្រហាក់ប្រហែលដែលវាបានកើតឡើង (ដូចជា នៅទូទាំងប្រទេស និងគ្របដណ្តប់ភូមិភាគរដ្ឋបាលជាច្រើន) និងដោយសារចំនួនដ៏ច្រើននៃជនរងគ្រោះ ដែលការវាយប្រហារផ្តោតទៅលើ។ ការវាយប្រហារផ្តោតគោលដៅទៅលើ ប្រជាជនស៊ីវិលភាគច្រើនរបស់ប្រទេស នៅពាសពេញដែនដីរបស់កម្ពុជាប្រជាធិបតេយ្យ និងកើតឡើងអស់រយៈពេលជាងបីឆ្នាំនិងប្រាំបីខែ។[3948] ប្រជាជនស៊ីវិលរាប់លាននាក់ត្រូវបានបង្ខំឲ្យចាកចាញ្ជីពីទីក្រុង និងប្រជាជនក្នុងចំនួនកាន់តែច្រើនជាងនេះត្រូវបានធ្វើឲ្យក្លាយជាទាសករនៅក្នុងសហករណ៍ និងការដ្ឋាននានា[3949]។ ប.ក.ក. បានបង្កើតមន្ទីរសន្តិសុខប្រហែល ១៩៦[3950] ដែលមនុស្សរាប់ពាន់នាក់ត្រូវបានឃុំ ធ្វើបាប ធ្វើទារុណកម្ម និងសម្លាប់ នៅក្នុង

រំលោភសេពសន្តវ: និងអំពើហិង្សាផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ។ ផ្នែកទី **V.ខ.**៧. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – អាពាហ៍ពិពាហ៍ដោយបង្ខំ និងរំលោភសេពសន្តវ:។ *សូមមើលជាទូទៅ* សម្រាប់ភ័ស្តុតាងទីតាំងឧក្រិដ្ឋកម្ម៖ **V.** ឧក្រិដ្ឋកម្ម។

[3947] *សូមមើល* ផ្នែកទី VIII.ខ.១.ក. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយ:សហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីខ្ទាំង។ *សូមមើលជាទូទៅ* សម្រាប់ភ័ស្តុតាងទីតាំងឧក្រិដ្ឋកម្មនៅក្នុងផ្នែកទី **V.** ឧក្រិដ្ឋកម្ម។

[3948] *សូមមើល* ផ្នែកទី VIII.ខ.១.ក. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយ:សហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីខ្ទាំង។ ផ្នែកទី VIII.ខ.១.ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយ:សហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីការធ្វើឲ្យទៅជាទាសករ។ ផ្នែកទី VIII.ខ.១.គ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយ:សហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្តវ:។ ផ្នែកទី VIII.ខ.១.ឃ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយ:សហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីការរំលោភសេពសន្តវ: និងអំពើហិង្សាផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ។

[3949] ផ្នែកទី VIII.ខ.១.ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយ:សហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីការធ្វើឲ្យទៅជាទាសករ។

[3950] ឯកសារ D6.1.525 បញ្ជីមន្ទីរសន្តិសុខកម្ពុជាប្រជាធិបតេយ្យធ្វើបច្ចុប្បន្នភាពថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ EN 00347406-13 ។

មន្ទីរសន្តិសុខទាំងនោះ[3951]។ ចំនួនមនុស្សស្លាប់សរុបដែលបណ្តាលមកពីការវាយប្រហារ ត្រូវបានប៉ាន់ប្រមាណថា មានចំនួនចន្លោះពី ១,៦ ទៅ ២,២ លាននាក់[3952] ហើយការវាយប្រហារបានប៉ះ

[3951] *សូមមើលខ១ទាហរណ៍* ឯកសារ D1.3.29.8 កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ EN 00198898។ ឯកសារ D118/103.3 សេចក្តីសន្និដ្ឋានដែលសរសេរចុងក្រោយរបស់ជនត្រូវចោទ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៦៩ KH 00404807 ["មន្ទីរសន្តិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិចណាស់មានចំនួន១៩៦"] កថាខណ្ឌ ៧០-៧២ KH 00404807 [រៀបរាប់អំពីការគ្រប់គ្រងអង្គការមន្ទីរសន្តិបាល និងរបៀបដែលចម្លើយសារភាពត្រូវបានគេបញ្ជូនតាមខ្សែចាត់តាំងរបស់បក្ស]។ ឯកសារ D6.1.160 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម អាឡាត់ KH 00196812 ["ស៖តើនៅក្នុងសម័យខ្មែរក្រហមលោកដែលដឹងថាមានមន្ទីរសន្តិសុខឬកន្លែងសម្លាប់មនុស្សដែរឬទេ? ឆ៖នៅសម័យនោះខ្ញុំដឹងថាមានមន្ទីរសន្តិសុខដូចខាងក្រោម:មន្ទីរសន្តិសុខព្រៃស្ពឹក ឬហៅថាក្រាំងតាសំ មានចម្ងាយពីកន្លែងខ្ញុំនៅពី៧ ទៅ ៨គីឡូម៉ែត ស្ថិតនៅក្នុងស្រុកក្រគរ។ វាគ្រាន់តែជា"គុក"ឃុំឃាំងទេ។ [...] ខ្ញុំមានមិត្តម្នាក់ត្រូវបានគេចាប់ទៅ មន្ទីរសន្តិសុខ០៧នៅបាកានឬគេហៅថាមន្ទីរសន្តិសុខត្រពាំងជង ស្រុកបាកានហើយបានបាត់រហូតមកទល់ពេលនេះ។មន្ទីរសន្តិសុខនៅទួលតាប៉េវ នៅក្នុងភូមិកំពង់ក្របី ឃុំវាល ស្រុកកណ្តៀង [...] មន្ទីរសន្តិសុខចារ៉ីក ស្ថិតនៅភូមិចារ៉ីក ឃុំកញ្ជ្រ ស្រុកកណ្តៀង។មន្ទីរសន្តិសុខអាទ៍លឡ៊ីរ៉ីហៅមន្ទីរបន្ទាយកាំភ្លើងធំ [...] [ក្នុងខេត្តពោធិសាត់]។ ខ្ញុំដឹងថា វាជាមន្ទីរសន្តិសុខព្រោះខ្ញុំឃើញមានមនុស្សជាប់នៅក្នុងបន្ទប់ហើយពួកយោធាប្រាប់ថា អ្នកទាំងនោះជាអ្នកទោស"]។ ឯកសារ D6.1.80 កំណត់ហេតុស្តាប់ចម្លើយ ចាន់ ខន EN 00195544-45 [ពាក់ព័ន្ធនឹងមន្ទីរ ១៣]។ ឯកសារ D6.1.1061 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច EN 00185475-76 [ការរៀបរាប់ពីម១៣ និងស២១] KH 00185470 ["គោលការណ៍ទូទៅ នៅគ្រប់មន្ទីរសន្តិសុខទាំងអស់ក៏ដូចជានៅស២១ គឺគ្រប់មនុស្សទាំងអស់ដែលត្រូវបានចាប់ខ្លួនត្រូវតែសម្លាប់លើកលែងតែករណីពិសេសដែលមានភាពបណ្តោះអាសន្ន"]។ ឯកសារ<u>កម្ពុជាប្រជាធិបតេយ្យ</u>៖ ឯកសារ D6.1.268 សេចក្តីរាយការណ៍ជូនបក្សស្រុកអំពីឈ្មោះ ភ្លង ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00270984-85 [រាយការណ៍អំពីការធ្វើទារុណកម្ម និងការសួរចម្លើយអ្នកទោស]។ ឯកសារ D6.1.1176 ឈ្មោះអ្នកទោសសួរប្រចាំថ្ងៃ២១ ខែមេសា ឆ្នាំ១៩៧៨ ដោយពួកត្រជាក់ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៨ [បញ្ជីឈ្មោះអ្នកទោសដែលបានសួរចម្លើយ]។ <u>របាយការណ៍វិភាគ</u>៖ ឯកសារ D1.3.32.1 បញ្ជីឈ្មោះអ្នកទោស [បញ្ជីមន្ទីរសន្តិបាលទាំង១៩៥ នៅទូទាំងប្រទេស]។ ឯកសារ D6.1.525 បញ្ជីមន្ទីរសន្តិសុខកម្ពុជាប្រជាធិបតេយ្យធ្វើបច្ចុប្បន្នភាពថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨។ ឯកសារ D6.1.524 បញ្ជីនៃរណ្តៅសាកសពធ្វើបច្ចុប្បន្នភាពថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ [បញ្ជីមន្ទីរសន្តិសុខ និងទីតាំងរណ្តៅសាកសពក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងចំនួនប៉ាន់ស្មាននៃជនរងគ្រោះនៅលើទីតាំងនីមួយៗ]។ ឯកសារ D1.3.10.5 កំពង់ចាម ៩៥-៩៦ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តកំពង់ចាម]។ ឯកសារ D1.3.10.8 មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ការបញ្ជាក់ពីទីតាំងវាលពិឃាតក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៧ ក្នុងខេត្តកំពង់ចាម [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តកំពង់ចាម]។ ឯកសារ D1.3.10.12 របាយការណ៍ DC-Cam "គម្រោងផែនទី" ចំណងជើង "ខេត្តកំពង់ចាម" ឆ្នាំ១៩៩៧ ៖ ខេត្តកំពង់ធំ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តកំពង់ធំ]។ ឯកសារ D1.3.10.13 សេចក្តីរាយការណ៍អំពីខេត្តកំពង់ធំ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៩៨។ ឯកសារ D1.3.10.16 របាយការណ៍ DC-Cam "គម្រោងផែនទី" ចំណងជើង "គម្រោងផែនទី ឆ្នាំ១៩៩៩៖ ខេត្តកំពង់ធំ" ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៩។ ឯកសារ D6.1.1232 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពី "គំនូសផែនទីអំពីវាលពិឃាតនៃប្រទេសកម្ពុជា ឆ្នាំ១៩៩៧" សរសេរជាភាសាអង់គ្លេសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅខែមេសា ឆ្នាំ១៩៩៧ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើ

ពាល់ដល់ជនរងគ្រោះបន្ថែមទៀតរាប់មិនអស់ ដោយសារតែការវាយប្រហារបែបនេះ មិនបណ្តាលឲ្យពួកគេស្លាប់។

1085. ការវាយប្រហារលើប្រជាជនស៊ីវិលក៏មានលក្ខណៈជាប្រព័ន្ធផងដែរ។ មានរចនាសម្ព័ន្ធរដ្ឋអំណាចដែលមានច្រើនថ្នាក់ ដែលត្រូវបានរៀបចំយ៉ាងល្អពេញទូទាំងកម្ពុជាប្រជាធិបតេយ្យ ដោយមានចាប់ពីថ្នាក់មជ្ឈិម ប.ក.ក. ដល់ថ្នាក់ភូមិភាគ និងរហូតដល់ថ្នាក់ភូមិ និងថ្នាក់កងចល័ត។ គណៈកម្មាធិការអចិន្ត្រៃយ៍ ប.ក.ក. បានបង្កើតគោលនយោបាយដែលពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋ និងបានចេញបទបញ្ជាឲ្យអនុវត្តគោលនយោបាយទាំងនោះ។ គណៈកម្មាធិការអចិន្ត្រៃយ៍ក៏ទទួលបានរបាយការណ៍ជាទៀងទាត់ ស្តីពីការអនុវត្តគោលនយោបាយនៅតាមមូលដ្ឋាន ពីកម្មាភិបាល ប.ក.ក. គ្រប់

ជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តតាកែវ]។ ឯកសារ D1.3.10.14 របាយការណ៍ផែនទីខេត្តតាកែវ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៨។ ឯកសារ D1.3.10.10 ការចុះកណាត់ទីតាំងវាលពិឃាដក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ១៩៩៧៖ ខេត្តកំបន្ទាយមានជ័យ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តបន្ទាយមានជ័យ]។ ឯកសារ D1.3.27.10 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីគម្រោងគំនូសផែនទីឆ្នាំ១៩៩៨-ខេត្តបន្ទាយមានជ័យ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៩៨។ ឯកសារ D1.3.10.17 DC-Cam របាយការណ៍នៃការកំណត់ផែនទី "ខេត្តបន្ទាយមានជ័យ" ឆ្នាំ១៩៩៩។ ឯកសារ D1.3.10.11 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការគូសផែនទីវាលពិឃាដកម្ពុជា ឆ្នាំ១៩៩៧ ខេត្តពោធិ៍សាត់ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តពោធិ៍សាត់]។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៃបណ្តាស្រុកក្នុងខេត្តបាត់ដំបង ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង។ ឯកសារ D1.3.27.11 Henri Locard *កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ*។ ឯកសារ D1.3.10.21 Henri Locard *ភូមិភាគនិរតី* [របាយការណ៍ស្តីពីពន្ធនាគារនៅក្នុងខេត្តកណ្តាល កំពង់ស្ពឺ និងកំពត]។ ឯកសារ D6.1.1048 Henri Locard *របាយការណ៍ស្តីពីខេត្តសៀមរាប៖ ភូមិភាគឧត្តរថ្មី (ព័ត៌មានពាក់ព័ន្ធមាននៅក្នុងបទសម្ភាសន៍របស់ ពុត ពុំ ត្រង់ទំព័រ ៣៥-៣៧* [របាយការណ៍ស្តីពីពន្ធនាគារនៅក្នុងខេត្តសៀមរាប]។ ឯកសារ D1.3.11.16 ឧបសម្ព័ន្ធ ខ ០០១០៖ Henri Locard *របាយការណ៍ កំពង់ចាម ច្រាំងទន្លេខាងលិច (តំបន់ឧត្តរចាស់) ២០០៧*) [របាយការណ៍ស្តីពីពន្ធនាគារនៅក្នុងតំបន់៤១ និង៤២ នៃខេត្តកំពង់ចាម]។ ឯកសារ D1.3.11.17 សេចក្តីរាយការណ៍របស់ Henri Locard ស្តីពី៖ *កំពង់ធំ-ភូមិភាគឧត្តរ តំបន់ ឬភូមិភាគ ៤៣* [របាយការណ៍ស្តីពីពន្ធនាគារនៅក្នុងតំបន់៤៣ នៃខេត្តកំពង់ធំ]។ ឯកសារ D1.3.27.6 ឌាង រ៉ន៖ *ប្រវត្តិសង្ខេបរបស់មជ្ឈមណ្ឌលប្រល័យពូជសាសន៍ឈ្មោះក្រាំងតាចាន់របស់ ប៉ុល ពត នៅឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ជាភាសាខ្មែរ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៩៦* [របាយការណ៍ពីការិយាល័យវប្បធម៌ និងវិចិត្រសិល្ប:អំពីមន្ទីរសន្តិសុខក្រាំងតាចាន់ ស្ថិតក្នុងឃុំគូស ស្រុកត្រាំកក់ ខេត្តតាកែវ ភូមិភាគនិរតី]។

[3952] *សូមមើលឧទាហរណ៍* ឯកសារ D6.1.197 បណ្ឌិត Ewa Tabeau និងលោក ថី ឃាម៖ *ជនរងគ្រោះនៃរបបខ្មែរក្រហមនៅកម្ពុជា ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩* KH 00499411-12។

ជាន់ថ្នាក់ទាំងអស់[3953]។ ជាងនេះទៅទៀត គោលនយោបាយ និងបទឧក្រិដ្ឋដែលកម្រកើតឡើង នៅក្នុងប្រទេសកម្ពុជា នៅមុននិងក្រោយអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (ដូចជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានរៀបចំឡើង ដោយអាជ្ញាធរនយោបាយ) ត្រូវបានអនុវត្តច្រើនដែលៗ និងក្នុងរយៈពេលមួយដ៏វែង តាមរបៀបមួយដែលស្ទើរតែដូចគ្នាទាំងស្រុង នៅពេញទូទាំងប្រទេស។ វាជារឿងមិនពិតនោះឡើយដែលថាគោលនយោបាយទាំងនេះមានលក្ខណៈចៃដន្យ ឬជាគំនិតផ្តួចផ្តើមនៅក្នុងមូលដ្ឋាន។

គ. មូលហេតុនៃការវើសអើង

1086. ការវាយប្រហារ គឺផ្អែកលើមូលហេតុនៃការវើសអើង ពោលគឺ ការផ្តោតគោលដៅដោយសារមូលហេតុនយោបាយ សាសនា និង/ឬ ជាតិសាសន៍។ ការប្រឆាំងផ្នែននយោបាយណាមួយដែលត្រូវបានសន្ធត ត្រូវបាន "កម្ទេច"។ ជាទូទៅ ប្រជាជនស៊ីវិលទាំងអស់ត្រូវបានចាត់ទុកថាជាខ្មាំងពិតប្រាកដ ឬអាចជាខ្មាំង ហើយត្រូវបានយកទៅអប់រំនយោបាយ ដាក់ឲ្យក្លាយជាទាសករ ឃុំខ្លួន និង/ឬសម្លាប់។[3954] នេះរួមបញ្ចូលទាំងសមាជិករបស់អតីតរបប លន់ នល់ កម្មាភិបាលនៅក្នុងជួរ ប.ក.ក. ដែលត្រូវបានសង្ស័យ អ្នកដែលត្រូវបានចាត់ទុកថាជា "ភ្នាក់ងារសម្ងាត់" របស់រដ្ឋាភិបាលបរទេស និង "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" ដែល ប.ក.ក. ចាត់ទុកថាជាអ្នកប្រឆាំងបដិវត្តន៍[3955]។ វាក៏រួមបញ្ចូលមនុស្សទាំងអស់ ដែលត្រូវបានសង្ស័យថា មិនមានភក្តីភាពចំពោះរបប

[3953] *សូមមើល* ផ្នែកទី VIII.ខ.១.ក. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីខ្មាំង។ ផ្នែកទី VIII.ខ.១.ខ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីការធ្វើឲ្យទៅជាទាសករ។ ផ្នែកទី VIII.ខ.១.គ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ។ ផ្នែកទី VIII.ខ.១.ឃ. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីការរំលោភសេពសន្ថវៈ និងអំពើហិង្សាផ្លូវភេទក្រៅអាពាហ៍ពិពាហ៍ដោយបង្ខំ។ ផ្នែកទី IV. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទងរបស់ ប.ក.ក។

[3954] *សូមមើល* ផ្នែកទី VIII.ខ.១.ក. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីខ្មាំង។ *សូមមើលជាទូទៅ* សម្រាប់ភ័ស្តុតាងទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យនៅក្នុងផ្នែកទី V. ឧក្រិដ្ឋកម្ម។

[3955] *សូមមើល* ផ្នែកទី VIII.ខ.១.ក. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីខ្មាំង។ ផ្នែកទី III. តំណែង សកម្មភាព និងការប្រព្រឹត្តរបស់ យ៉ីម ទិត្យ។

នោះ ឬបដិវត្តន៍ ដោយសារតែកំហុសតូចតាច ដូចជាការសម្តែងការមិនពេញចិត្តចំពោះស្ថានភាពរស់នៅ ឬស្វែងរកអាហារដោយគ្មានការអនុញ្ញាត[3956]។

1087. ការវាយប្រហារលើជនស៊ីវិល នៅក្នុងករណីខ្លះ ក៏ផ្អែកលើមូលហេតុជាតិសាសន៍ និង/ឬជាតិពិន្ទុផងដែរ។ ចំពោះភូមិភាគនិរតី និងពាយ័ព្យ វាមានពាក់ព័ន្ធនឹងការផ្តោតគោលដៅចំពោះជនជាតិវៀតណាម និងអ្នកដែលត្រូវបានសន្មតថាជាជនជាតិវៀតណាម ឬមានទំនាក់ទំនងជាមួយវៀតណាម[3957]។

ឃ. ការដឹងអំពីការវាយប្រហារ របស់ យ៉ឹម ទិត្យ

1088. **យ៉ឹម ទិត្យ** និងចារីដទៃទៀត បានដឹងអំពីការវាយប្រហារប្រឆាំងនឹងប្រជាជនស៊ីវិល និងដឹងថាអំពើប្រព្រឹត្តរបស់ពួកគេ គឺជាផ្នែកមួយនៃការវាយប្រហារ។ ចំណុចនេះ ត្រូវបានបង្ហាញតាមរយៈការរួមចំណែកដ៏ច្រើនរបស់ **យ៉ឹម ទិត្យ** និងការចូលរួម ក្នុងការវាយប្រហារ ដូចដែលត្រូវបានពិភាក្សានៅក្នុងផ្នែកផ្សេងនៅក្នុងសាវណានេះ[3958]។

VIII. ការទទួលខុសត្រូវឧក្រិដ្ឋកម្មណាជាលក្ខណៈបុគ្គល

ក. ទិដ្ឋភាពទូទៅ

1089. ភ័ស្តុតាងនៅក្នុងសំណុំរឿង និងភ័ស្តុតាងដែលត្រូវបានយោងទៅដល់ នៅក្នុងសាវណានេះ បង្ហាញថា **យ៉ឹម ទិត្យ** ទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយអនុលោមតាម វិធាន៤ និង៥ នៃច្បាប់ អ.វ.ត.ក។

ផ្នែកទី V.ក.១. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – បន្សុទ្ធកម្ម។ *សូមមើលជាទូទៅ* សម្រាប់ភ័ស្តុតាងទីតាំងឧក្រិដ្ឋកម្មនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យនៅក្នុងផ្នែកទី V. ឧក្រិដ្ឋកម្ម។

[3956] *សូមមើល* ផ្នែកទី VIII.ខ.១.ក. ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ – ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម – គោលនយោបាយស្តីពីខ្ទាំង។

[3957] *សូមមើល* ផ្នែកទី V.គ.៤. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងនឹងជនជាតិវៀតណាម – ការអនុវត្តគោលនយោបាយប្រល័យពូជសាសន៍ប្រឆាំងនឹងជនជាតិវៀតណាម និងខ្មែរកម្ពុជាក្រោម។

[3958] *សូមមើល* ផ្នែកទី III. តំណែង សកម្មភាព និងការប្រព្រឹត្តរបស់ យ៉ឹម ទិត្យ។ ផ្នែកទី VIII.ខ ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់បុគ្គល – ទម្រង់នៃការទទួលខុសត្រូវ។

1090. **យ៉ីម ទិត្យ** ទទួលខុសត្រូវចំពោះបទឧក្រិដ្ឋទាំងនេះ ដោយអនុលោមតាមវិធាន ២៩*ថ្មី* នៃច្បាប់ អ.វ.ត.ក ជាពិសេសចំពោះ (i) ការប្រព្រឹត្ត ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និង/ឬ ជួយនិងជំរុញការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ និង (ii) ការខកខានក្នុងការទប់ស្កាត់ការប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ឬដាក់ទណ្ឌកម្មចារី ក្នុងនាមជាថ្នាក់លើដែលដឹង ឬមានហេតុផលត្រូវដឹងថាអ្នកក្រោមបង្គាប់របស់ខ្លួនហៀបនឹងប្រព្រឹត្តបទឧក្រិដ្ឋទាំងនោះ។ **យ៉ីម ទិត្យ** "បានប្រព្រឹត្ត" បទឧក្រិដ្ឋទាំងនេះ ដោយពុំមែនជាចារីផ្ទាល់នោះឡើយ តែជាអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម។

ខ. ទម្រង់នៃការទទួលខុសត្រូវ

១. ការប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម

1091. **យ៉ីម ទិត្យ** បានប្រព្រឹ្ធបទឧក្រិដ្ឋនីមួយៗ ដែលត្រូវបានបង្ហាញនៅក្នុងសារណានេះ តាមរយៈការចូលរួមរបស់គាត់ក្នុងសហឧក្រិដ្ឋកម្មរួម ដែលគ្របដណ្ដប់ភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ សហឧក្រិដ្ឋកម្មរួមនេះមានការពាក់ព័ន្ធនឹងទម្រង់មូលដ្ឋាន (JCE I) នៃការទទួលខុសត្រូវចំពោះផែនការរួម។ សហឧក្រិដ្ឋកម្មរួម មានគោលដៅសម្រេចគោលនយោបាយជាច្រើនរបស់ ប.ក.ក. ដោយការអនុវត្តគោលនយោបាយទាំងនេះ មានន័យស្មើនឹង ឬមានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានពិភាក្សានៅក្នុងសារណានេះ។

ក. គោលនយោបាយចំពោះខ្មាំង

1092. សមាជិកសហឧក្រិដ្ឋកម្មរួម មានគោលបំណងឧក្រិដ្ឋរួមគ្នា ដើម្បីរក្សាអំណាចរបស់ ប.ក.ក.តាមរយៈការកំណត់អត្តសញ្ញាណ និងលុបបំបាត់ការប្រឆាំង និងខ្មាំងដែលត្រូវបានសន្មត និងអនុវត្តគោលនយោបាយសង្គម សេដ្ឋកិច្ច និងកសិកម្មជ្រុលនិយម របស់មេដឹកនាំមជ្ឈិមរបស់ ប.ក.ក. នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ តាមរយៈការប្រព្រឹត្តបទឧក្រិដ្ឋដែលត្រូវបានពិពណ៌នាន)ខាងលើ។ ផែនការនោះមានគោលបំណងផ្លាស់ប្តូរសង្គមកម្ពុជាទាំងស្រុង ដើម្បីសម្រេចបាននូវសង្គមមួយ ដែលគ្មានវណ្ណៈ និងសាសនា ដែលមានអត្តសញ្ញាណជនជាតិលើសលប់ជាងគេរបស់ជាតិតែមួយគត់។ ដើម្បីកំណត់អត្តសញ្ញាណ និងលុបបំបាត់ការប្រឆាំង និងខ្មាំងដែលត្រូវបានសន្មត និងដើម្បីរក្សាអំណាចរបស់ប.ក.ក. ផែនការនោះមានការពាក់ព័ន្ធទៅដល់ការប្រព្រឹត្តបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដូចជាការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ទារុណកម្ម ការឃុំឃាំង ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ប្រឆាំងនឹងក្រុមមនុស្សផ្សេងៗជាច្រើនដែលត្រូវបានសន្មត

ថាជាខ្មាំង ដោយរួមទាំង កម្មាភិបាល ប.ក.ក. ដែលត្រូវគេមើលឃើញថាមិនមានភក្តីភាព រួមទាំងគ្រួសាររបស់ពួកគេ និងអ្នកផ្សេងៗទៀត ដែលត្រូវបានសន្ទតថាមានការពាក់ព័ន្ធនឹងពួកគេទាំងនោះ ដូចជា អតីតយោធា និងមន្ត្រីរដ្ឋការ របស់របប លន់ នល់ ក្រុមមនុស្សដែលត្រូវបានផ្ទាស់ទីលំនៅពីទីក្រុង និងទីប្រជុំជននានា ដែលជាតំបន់ចុងក្រោយដែលត្រូវបានវាយយកមកកាន់កាប់ពីរដ្ឋាភិបាល លន់ នល់ ដែលជាទូទៅអ្នកទាំងនោះត្រូវបានគេហៅថាជា "ប្រជាជនថ្មី" ឬ "ប្រជាជន ១៧ មេសា" អ្នកដែលត្រូវគេចាត់ទុកថាជាភ្នាក់ងារសម្ងាត់របស់ សេអ៊ីអា ឬកាហ្សេបេ ខ្មែរក្រោម អ្នកតាំងទីលំនៅជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា មនុស្សដែលមកពីវណ្ណៈ "គហបតី" "សក្តិភូមិ" ឬ "នាយទុន" និងប្រជាជនសាមញ្ញទាំងអស់ដែលត្រូវបានសន្ទតថាមិនមានភក្តីភាពចំពោះរបបនោះ ឬបដិវត្តន៍ ដោយសារមូលហេតុអ្វីក៏ដោយ។ ផែនការនោះ ក៏មានការពាក់ព័ន្ធនឹងការប្រព្រឹត្តបទឧក្រិដ្ឋប្រល័យពូជសាសន៍ ដោយមានចេតនាបំផ្លាញក្រុមជនជាតិវៀតណាម នៅក្នុងប្រទេសកម្ពុជា ជាពិសេសខ្មែរក្រោម (ពោលគឺ ជនជាតិខ្មែរដែលមានដើមកំណើតនៅក្នុងទឹកដីវៀតណាមបច្ចុប្បន្ន) ។

1093. សមាជិកសហឧក្រិដ្ឋកម្មរួម ប្រព្រឹត្តអំពើដោយស្របទៅតាមគោលនយោបាយដែលត្រូវបានរៀបចំយ៉ាងល្អរបស់ ប.ក.ក. ដើម្បីរក្សាអំណាចរបស់ខ្លួន តាមរយៈការលុបបំបាត់ខ្មាំង និងអ្នកប្រឆាំងផ្នែកនយោបាយដែលត្រូវបានសន្ទត។ នៅក្នុងសន្និបាតបក្សលើកទីមួយនៅក្នុងឆ្នាំ១៩៦០ ខ្មែរក្រហមបានប្តេជ្ញាចិត្តប្រើប្រាស់អំពើហិង្សាប្រដាប់អាវុធ ដើម្បី "កម្ទេចខ្មាំង" និងក្រោយមកកាន់តែបង្កើនការអនុវត្តគោលនយោបាយនេះ មិនត្រឹមតែចំពោះគូបដិបក្ខយោធាតែប៉ុណ្ណោះទេ តែចំពោះបុគ្គលណាម្នាក់ ឬក្រុមណាមួយដែលប្រឆាំងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ឬដែលត្រូវបានយល់ឃើញថាជាគ្រោះគំរាមកំហែង[3959]។ លក្ខន្តិក: ប.ក.ក. បានព្យាយាមជំរុញលើកទឹកចិត្តសមាជិកបក្សឲ្យ

[3959] ឯកសារ D6.1.808 ឯកសារស្តីពីសកម្មភាពដំណើរទស្សនកិច្ចរបស់គណ:ប្រតិភូគុយបា៖ *សមមិត្ត ឆ្លន ជា ផ្លែងក្នុងទិវាខួបកំណើតកងទ័ពបដិវត្តកម្ពុជា* ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ KH 00679796 [នៅក្នុងពិធីប្រមូលផ្តុំមហាជននៅទីក្រុងភ្នំពេញក្នុងឱកាសបុណ្យខួបទី៩នៃកំណើតកងទ័ពបដិវត្តកម្ពុជា ឆ្លន ជា បានមានប្រសាសន៍ថា៖ "ក្រោយឆ្នាំ១៩៦០ អង្គការបដិវត្តយើង បានសម្រេចច្បាស់ថា យើងត្រូវតែប្រើសកម្មនយោបាយ និងអំពើហិង្សាប្រដាប់អាវុធ ដើម្បីផ្ទួលរំលំ និងកម្ទេចខ្មាំង"]។ ឯកសារ D6.1.755 ទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-មករា ១៩៧៧ KH 00063023 ["មាគ៌ាជាយុទ្ធសាស្ត្ររបស់បក្ស [...] ដែលបានកំណត់នៅក្នុងឆ្នាំ១៩៦០ [...] មានកំណត់ថា ត្រូវវាយរំលំសក្តិភូមិ និងនាយទុន ប្រតិកិរិយានៅកម្ពុជា"]។ ឯកសារ D6.1.753 ទង់បដិវត្ត ខែកញ្ញា-តុលា ១៩៧៦ KH 00063066 ["ពិសោធន៍ជាក់ស្តែងរបស់ចលនាបដិវត្តយើង បានបង្រៀនយើងថា ទាល់តែប្រើហិង្សានយោបាយ និងហិង្សាអាវុធ ទើបយើងវាយឈ្នះខ្មាំង"]។ ឯកសារ D6.1.739 ទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៧ KH 00063148-49

រក្សាភាពប្រុងប្រយ័ត្នចំពោះ "សកម្មភាពខ្ទាំង" និងដើម្បីការពារកម្លាំងបដិវត្តន៍ពីខ្ទាំងខាងក្នុង និងខាងក្រៅបក្ស[3960]។ មាត្រា១០ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចែងថា "សកម្មភាពប្រកបដោយគ្រោះថ្នាក់" ត្រូវបាន "ផ្តោលទោសយ៉ាងខ្លាំងក្លាបំផុត" និងចែងថា "ករណីផ្សេងៗទៀត" គួរទទួលការអប់រំរៀនសូត្រកែលម្អ[3961]។

1094. នៅដើមដំបូង ប.ក.ក. ផ្តោតគោលដៅទៅលើបុគ្គលខាងក្រៅបក្ស ដែលត្រូវបានសន្មតថាជា គ្រោះគំរាមកំហែង ឬអ្នកដែលមានទស្សនៈផ្ទុយ ដោយរួមទាំងអ្នកមកពីវណ្ណៈ "គហបតី" "សក្តិភូមិ" ឬ "នាយទុន"[3962] អតីតមន្ត្រីយោធា ឬមន្ត្រីស៊ីវិលរបស់រដ្ឋាភិបាល លន់ នល់[3963] ជនជាតិវៀតណាម

។ ឯកសារ D6.1.737 ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ KH 00063328-29។ ឯកសារ D6.1.532 ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ*, KH 00380366-68។

[3960] ឯកសារ D1.3.20.1 លក្ខន្តិកៈគណបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ EN 00053010 មាត្រា ៥(ម) KH 00053022 ។

[3961] ឯកសារ D1.3.20.2 រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៧៦ មាត្រា១០ KH 00089847។

[3962] *សូមមើលឧទាហរណ៍* ឯកសារ D6.1.749 ទង់បដិវត្ត ខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦ KH 00063192-93។ ឯកសារ D6.1.739 ទង់បដិវត្ត ខែកញ្ញា ឆ្នាំ១៩៧៧ KH 00063145 ["សត្រូវមានពីរដែលត្រូវវាយ សត្រូវទី១ គឺចក្រពត្តិនិយម ពិសេសចក្រពត្តិអាមេរិកាំង ទី២គឺវណ្ណៈសក្តិភូមិ ម្ចាស់ដី និងកំប្រាន់ៈប្រតិកិរិយា]។ ឯកសារ D6.1.755 ទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-មករា ឆ្នាំ១៩៧៧ KH 00063023។ ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៧ KH 00062969-70។ ឯកសារ D5/450/3 យ៉ីម សុវណ្ណ ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ២០១២ ម៉ោង 15.15.56-15.18.26 KH 00855237-38។ ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារឹក ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 10.25.57-10.28.10 KH 00856254-55។

[3963] *សូមមើលឧទាហរណ៍* ឯកសារ D6.1.535 កំណត់ហេតុប្រជុំសមមិត្ត ១៦៤៖ រាយការណ៍បញ្ជារៀនសូត្រនាវា ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00162490 ["សមាសភាពទាហានត្រូវប្រមូល"]។ ឯកសារ D6.1.284 លិខិតបញ្ជាក់ចំពោះសមមិត្ត អាន អំពីការបញ្ជូនមនុស្ស ខែកញ្ញា ឆ្នាំ១៩៧៦ KH 00270746 [ជម្រាប អាន ថា មនុស្សបីនាក់នោះដែលត្រូវបញ្ជូនទៅឲ្យគាត់(អាន) ត្រូវបានចាប់ខ្លួនហើយ ពីព្រោះពួកគេទាំងបីនោះមានបណ្តាស័ក្តិ តាមការសម្រេចរបស់បក្ស]។ ឯកសារ D6.1.1050 ឯកសារថតចម្លងមួយច្បាប់របស់ Amnesty International ផ្ញើជូនទៅឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ខែសីហា ឆ្នាំ១៩៧៨ KH 00338190 ["ជនភៀសខ្លួនជាច្រើនបានចោទប្រកាន់ថា ការប្រហារជីវិតពួកអតីតនាយទាហានសាធារណរដ្ឋ ដោយគ្មានការជំនុំជម្រះជាលក្ខណៈទ្រង់ទ្រាយធំ បានកើតឡើងនៅក្នុងឆ្នាំ១៩៧៥ និងដើមឆ្នាំ១៩៧៦ ការប្រហារជីវិតនេះជួនកាលពាក់ព័ន្ធនឹងអ្នកនៅក្នុងបន្ទុកគ្រួសាររបស់ពួកគេផងដែរ ហើយថា មានមន្ត្រីរដ្ឋបាលចាស់ជាច្រើនត្រូវបានគេសម្លាប់ ឬ "យកទៅ" ហើយមិនបានឮថាបានត្រឡប់មកវិញទេ"]។ ឯកសារ D1.3.29.1 បទសម្ភាសន៍ ស្ទីវ ហេដ័រ ជាមួយ អ៊ៀង សារី ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩០ KH 00062460 ["ដូច្នេះគឺថា ទាហានអ៊ីគេយកទៅសម្លាប់អ៊ីគេសម្រេច [...] គឺសម្រេចក្រោយអាណឹងតាមខ្ញុំដឹង គឺក្រោយថ្ងៃ១៧ មេសា ក្នុងរវាងថ្ងៃ២០អ៊ីនឹង ណឹងបើតាមខ្ញុំដឹង [...] គឺគេសម្រេចថា ធ្វើម៉េចកុំឲ្យពួកហ្នឹងវាងើបឡើងប្រឆាំងបដិវត្តបាន"]។ ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារឹក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 10.26.59-10.28.10

ឬអ្នកដែលត្រូវបានសន្មតថាមានទំនាក់ទំនងជាមួយវៀតណាម[3964] និងប្រជាជនសាមញ្ញដែលត្រូវបានចោទប្រកាន់ថាមិនមានភក្តីភាពចំពោះរបបនោះ ពីព្រោះពួកគេបានប្រព្រឹត្តបទល្មើសតូចតាចដូចជាធ្វើឲ្យខូចឧបករណ៍ ឬសម្ភារៈប្រើប្រាស់[3965] រអ៊ូរទាំអំពីស្ថានភាពរស់នៅ ឬស្វែងរកអាហារដោយខ្លួនឯង[3966]។ ភ្លាមៗក្រោយមក គោលនយោបាយនេះក៏ត្រូវបានអនុវត្តចំពោះខ្មាំងដែលត្រូវបានសន្មតនៅក្នុងអង្គការបដិវត្តន៍ផងដែរ ដែលជារឿយៗត្រូវបានចោទប្រកាន់ថាជាភ្នាក់ងារសម្ងាត់របស់ សេអ៊ីអា ការហ្សេបេ ឬវៀតណាម[3967]។

KH 00856255-56។ ឯកសារ D6.1.355 កំណត់ហេតុស្តាប់ចម្លើយ ខ៉ីម សំហ្ជន ហៅ តូច KH 00287536 ["នៅពេលនោះគឺនៅ ខែឧសភា ឆ្នាំ១៩៧៥ មានបញ្ជាពីកងពល ដែលខ្ញុំដឹងថាត្រូវទទួលបញ្ជាពីថ្នាក់លើ គឺពី សុន សេន ដែលជាអ្នកគ្រប់គ្រង ឲ្យទៅចាប់មនុស្សដែលជាអ្នករាជការមានឋានន្តរស័ក្តិរបស់របប លន់ នល់ [...] អ្នកជំងឺដែលជាកងទ័ពលន់ នល់ កំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យកេតុមាលា"]។ ឯកសារ D219/171 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល ឆ.៣៤ KH 01065953។ ឯកសារ D219/188 កំណត់ហេតុស្តាប់ចម្លើយ ផាន ឃន ឆ.៧៦ KH 01068135។

[3964] *សូមមើល* V.ค.๓. ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងជនជាតិវៀតណាម – គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការបំផ្លាញជនជាតិវៀតណាម។

[3965] ឯកសារ D6.1.743 ទង់បដិវត្ត ខែកក្កដា ឆ្នាំ១៩៧៨ KH 00064495។ ឯកសារ D6.1.725 កំណត់ហេតុស្តាប់ចម្លើយ ឈ្មក រ៉ីន ឆ.៤ KH 00407738។ ឯកសារ D219/489 កំណត់ហេតុស្តាប់ចម្លើយ ញ្ជ៉ែម ភ ុំ ឆ.៨៥ KH 01138499។ ឯកសារ D219/689 កំណត់ហេតុស្តាប់ចម្លើយ សុខ ជាតិ ឆ.៥៧ KH 01205211។ ឯកសារ D6.1.686 កំណត់ហេតុស្តាប់ចម្លើយ សៅ ប៊ាន ឆ.៤២ KH 00408319។ ឯកសារ D219/337 កំណត់ហេតុស្តាប់ចម្លើយ រៀម ឌី ឆ.២២ EN 01102815។ ឯកសារ D219/883.1.16 កំណត់ហេតុស្តាប់ចម្លើយ សែម ហ្ជឿន ហៅ ហ្ជឿន KH 00287557-58។

[3966] *សូមមើលឧទាហរណ៍* ឯកសារ D219/494.1.9 ឈុំ សេង ប្រតិចារ៉ឹក ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ ម៉ោង 10.52.11-10.55.38 KH 01439689-90 ម៉ោង 11.11.42-11.14.26 KH 01439693-95។ ឯកសារ D315.3.4 អ៊ុង សារ៉ៀន ប្រតិចារ៉ឹក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.33.57-09.37.30 KH 01468756-58, ម៉ោង 09.54.45 KH 01468762-63។ ឯកសារ D315.3.1 ជ្ង គ ឹមឡ្ជន ប្រតិចារ៉ឹក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.55.04-11.58.43 KH 01408906-07។ ឯកសារ D118/177 កំណត់ហេតុស្តាប់ចម្លើយ លន ហេង ឆ.៥១-៥២ KH 00973981-82។ ឯកសារ D118/194 កំណត់ហេតុស្តាប់ចម្លើយ រស់ ណារ៉ីន ឆ.៤៦-៤៧ KH 00977109។ ឯកសារ D118/176 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម រ៉ឿន ឆ.៤៥-៤៦ KH 00973965។ ឯកសារ D6.1.475 កំណត់ហេតុស្តាប់ចម្លើយ Denise Affonco EN 00346935។ ឯកសារ D219/138 កំណត់ហេតុស្តាប់ចម្លើយ ឃ្ជ ว ាន់ ឆ.១០ KH 01056041។ ឯកសារ D219/120 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ឃុត ឆ.១៩ KH 01046832។

[3967] *សូមមើលឧទាហរណ៍* ឯកសារ D6.1.473 សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាអំពីគោលនយោបាយ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨។ ឯកសារ D364/2.1.1 ន្ជួន ជា ប្រតិចារ៉ឹក ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១២ ម៉ោង 10.23.53 KH 00767105 ["ជាបុគ្គលអាចមានដែលពួកបំផ្លាញ ដែលពួកឲ្យដំនឹងទៅខ្មាំង ឲ្យខ្មាំងទម្លាក់បេ៥២អ៊ីចនេះ"]។ ឯកសារ D179/1.2.7 ក ាំង ហ្ជេចអ ារ ហៅ ឌុច ប្រតិចារ៉ឹក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ម៉ោង 14.54.17 KH 00791565-66 ["អ្នក

1095. ប.ក.ក. បំផុសឲ្យមានការស្អប់ក្រុមមនុស្សទាំងអស់នោះ ដោយចាត់ទុកពួកគេថាជា “ជនក្បត់” ឬ “ខ្មាំង” និងសង្កត់ធ្ងន់លើភាពចាំបាច់ក្នុងការរក្សា “ភាពប្រុងប្រយ័ត្នបដិវត្តន៍” ប្រឆាំងនឹងពួកគេ[3968]។ មនុស្សមួយចំនួនត្រូវបានចាប់ខ្លួន ដោយសារតែពួកគេគ្រាន់តែមានទំនាក់ទំនងជាមួយនឹងសមាជិកក្រុមមនុស្សដែលជាគោលដៅតែប៉ុណ្ណោះ[3969]។

ដែលគេចោទថាគិញ [...] ត្រូវចាត់ទុកថាជាខ្មាំង ជាគិញហើយកម្ទេច”]។ ឯកសារ D219/702.1.75 បាន សៀក ប្រតិចារិក ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៥ ម៉ោង 13.47.19 KH 01424077-78 [“អានេះដឹងតាមការនិយាយដូចថា ដូច [ប្អូនអឿន] ហ្នឹងទៅជួបថាម៉េចបានជាមានការបោសសម្អាតអី ?ថាខាងលើ មិនមែនផែនការទេ រឿងទី១ សេ.អ៊ី.អា ទី២ កា.ហ្សេ.បេ ដូច្នេះគេដាក់អីចឹង ដាក់ជាស្លាកអក្សរខ្មៅថា សេ.អ៊ី.អា និងកា.ហ្សេ.បេ ត្រូវតែកម្ទេចចោលទាំងអស់”]។

[3968] ឯកសារ D6.1.542 ទង់បដិវត្ត ខែមិថុនា ឆ្នាំ១៩៧៧ KH 00062825 [“ដូច្នេះ បក្សយើងសម្រេចដាច់ខាតថា ត្រូវបន្តលើកកម្ពស់ស្មារតីប្រុងប្រយ័ត្ន បដិវត្តឲ្យខ្ពស់ថែមទៀត ហើយប្រមូលកម្លាំងនៅក្នុងបក្សទាំងមូល រួមជាមួយកងទ័ពបដិវត្ត និងប្រជាជនសមូហភាពយើង វាវរក និងវាយកម្ទេចឲ្យអស់នូវសំណល់ខ្មាំងដែលលួចបង្កប់ក្នុងបក្សយើងនេះ ដើម្បីឲ្យបក្សយើងកាន់តែបរិសុទ្ធ ហើយបរិសុទ្ធទាំងស្រុង គ្មានខ្មាំងចាស់ក្តី ថ្មីក្តីមកលបលួចបង្កប់ខ្លួនបានដាច់ខាត”]។ *សូមមើលផងដែរ* ឯកសារ D1.3.20.1 លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ខែមករា ឆ្នាំ១៩៧៦ មាត្រា៥(៥) KH 00053010-11។ ឯកសារ D6.1.774 បទឧទ្ទេសនាមរបស់សមមិត្តលេខាក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦ KH 00072760។ ឯកសារ D6.1.1146 កំណត់ហេតុនៃអង្គប្រជុំការងារឃោសនា ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៦ KH 00000845 [“យើងត្រូវប្រុងប្រយ័ត្នបដិវត្តថែមទៀត ពិសេសខ្មាំងបង្កប់។ [...] តែវានៅមានគោលបំណងបំផ្លាញយើង។ ជាទស្សនៈ ជាគោលជំហរ យើងត្រូវប្រុងប្រយ័ត្នថែម”]។ ឯកសារ D6.1.73 DK កំណត់ហេតុអង្គប្រជុំជាមួយម្ទីរ ៧០៣ របស់អង្គការ និងស-២១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00008502-03។ ឯកសារ D6.1.939 សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ KH 00292804, 00292812-13។ ឯកសារ D6.1.740 ទង់បដិវត្ត ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧ KH 00064759 [“អ្នកអន្តរាយ ត្រូវសំរិតសំរាំង។ [...] ពួកអាក្បត់បង្កប់ផ្ទៃក្នុង ក៏វាពាក់ស្លាកអង្គការដែរ [...] យើងបោសម្អាតខ្មាំងបង្កប់ស៊ីរូងបានអាក្បាលធំៗជាង ៩៩ ភាគរយហើយ។ [...] យើងកុំឲ្យខ្មាំងវាពង្រឹងពង្រីកបាន។ ត្រូវវាយសម្រុកជាប់”]។ ឯកសារ D6.1.473 សេចក្តីណែនាំរបស់គណៈមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជាអំពីគោលនយោបាយ ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៨ KH 00079281-82។

[3969] *សូមមើលឧទាហរណ៍* ឯកសារ D219/825.1.2 បញ្ជីឈ្មោះអ្នកទោសមន្ទីរ ស-២១ លេខរៀង១, ៤, ៥ EN 01222328, លេខរៀង១៩ EN 01222329 លេខរៀង៦៩ EN 01222332 [បង្ហាញអត្តសញ្ញាណអ្នកទោសជា “ប្រពន្ធរបស់”] លេខរៀង៨៤១ EN 01222366 លេខរៀង៨៧៤, ៨៧៧, ៨៧៨ EN 01222368 លេខរៀង៨២៥ EN 01222365 លេខរៀង ៨២៧, ៨៣៣, ៨៣៤, ៨៣៥ EN 01222366 លេខរៀង១៣៧៦ EN 01222389 លេខរៀង១៤៦៤ EN 01222393 [បង្ហាញអត្តសញ្ញាណអ្នកទោសជា “កូនប្រុសរបស់” ឬ “កូនស្រីរបស់”]។ ឯកសារ D267.1.99 ឡាយ បូនី ប្រតិចារិក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ម៉ោង 09.38.57 KH 00856238-39 [“មានប្តីក៏មានបណ្តាសក្តិ ”] ម៉ោង 09.46.38 KH 00856241 [“ស៖ [...] តើអ្នកស្រីផ្ទាល់ហ្នឹងត្រូវបានគេចាប់ខ្លួនដែរ ដោយសារតែប្តីរបស់អ្នកស្រីហ្នឹង ឬក៏យ៉ាងម៉េច? [ប្តីរបស់អ្នកស្រីហ្នឹង ជាអតីតទាហាន លន់ នល់]? ឆ៖ចាស ដោយសារតែប្តីខ្ញុំហ្នឹង គេចោទ គេចោទប្តីខ្ញុំ គេត្រូវតែឲ្យប្រពន្ធទៅតាម ទៅជាមួយគ្នា”]។ ឯកសារ D6.1.456

1096. បណ្តាញមន្ទីរសន្តិសុខដ៏ទូលំទូលាយ ត្រូវបានបង្កើតឡើង ដែលអនុញ្ញាតឲ្យកម្មាភិបាលនៅទូទាំងប្រទេសអាចអនុវត្តគោលនយោបាយផ្តោតគោលដៅទៅលើមនុស្ស ដែលត្រូវបានសន្មតថាជាអ្នកប្រឆាំង តាមរយៈការឃុំខ្លួនបណ្តោះអាសន្ន[3970]។ "ខ្មាំង" ត្រូវបានឃុំខ្លួន និងទទួលរងនូវស្ថានភាព

កំណត់ហេតុស្តាប់ចម្លើយ ស៊ុំ រិទ្ធី KH 00287691 ["មានការចាប់ប្រពន្ធពួកទាហាន លន់ នល់ ដែរឲ្យតែគេ [ខ្មែរក្រហម] ដឹង"] ។

[3970] *សូមមើលខ១ទាបរណ៍* ឯកសារ D6.1.525 បញ្ជីមន្ទីរសន្តិសុខកម្ពុជាប្រជាធិបតេយ្យធ្វើបច្ចុប្បន្នភាពថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨។ ឯកសារ D6.1.524 បញ្ជីនៃរណ្តៅសាកសពធ្វើបច្ចុប្បន្នភាពថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ [បញ្ជីគុក និងទីតាំងរណ្តៅសាសពទូទាំងកម្ពុជាប្រជាប្រជាធិតេយ្យ និងចំនួនប៉ាន់ស្មាននៃជនរងគ្រោះនៅលើទីតាំងនីមួយ]។ ឯកសារ D1.3.10.5 របាយការណ៍ស្តីអំពីដំណើរទស្សនៈកិច្ចរបស់ក្រុមគូសផែនទី CGP ទៅកាន់ខេត្តកំពង់ចាម [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តកំពង់ចាម]។ ឯកសារ D1.3.10.8 មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ការបញ្ជាក់ពីទីតាំងវាលពិឃាដក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៧ ក្នុងខេត្តកំពង់ចាម [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តកំពង់ចាម។ ឯកសារ D1.3.10.9 មជ្ឈមណ្ឌលឯកសារកម្ពុជា៖ ការកំណត់ផែនទីវាលពិឃាដរបស់កម្ពុជា ឆ្នាំ១៩៩៧ ខេត្តកំពង់ធំ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តកំពង់ធំ]។ ឯកសារ D6.1.1232 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាអំពី "គំនូសផែនទីអំពីវាលពិឃាដនៃប្រទេសកម្ពុជា ឆ្នាំ១៩៩៧" សរសេរជាភាសាអង់គ្លេសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា នៅខែមេសា ឆ្នាំ១៩៩៧ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តតាកែវ]។ ឯកសារ D1.3.10.10 ការចុះកំណត់ទីតាំងវាលពិឃាដក្នុងប្រទេសកម្ពុជានៅលើផែនទី ឆ្នាំ១៩៩៧៖ ខេត្តកំបន្ទាយមានជ័យ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តបន្ទាយមានជ័យ]។ ឯកសារ D1.3.10.11 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាស្តីពីការគូសផែនទីវាលពិឃាដកម្ពុជា ឆ្នាំ១៩៩៧ ខេត្តពោធិ៍សាត់ [រៀបរាប់អំពីទីតាំងផ្សេងៗដែលត្រូវបានប្រើជាមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ជុំវិញខេត្តពោធិ៍សាត់]។ ឯកសារ D1.3.10.15 របាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៃបណ្តាស្រុកក្នុងខេត្តបាត់ដំបង ឆ្នាំ១៩៩៨៖ ខេត្តបាត់ដំបង។ ឯកសារ D1.3.29.8 កំណត់ហេតុនៃការសួរចម្លើយ ឌុច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៨ EN 00198898។ ឯកសារ D118/103.3 សេចក្តីសន្និដ្ឋានដែលសរសេរចុងក្រោយរបស់ជនត្រូវចោទ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០០៩ កថាខណ្ឌ ៦៩ KH 00404807 ["មន្ទីសន្តិបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិចណាស់មានចំនួន១៩ខ"] កថាខណ្ឌ ៧០-៧២ KH 00404807 [រៀបរាប់អំពីការគ្រប់គ្រងអង្គការមន្ទីរសន្តិបាល និងរបៀបដែលចម្លើយសារភាពត្រូវបានគេបញ្ជូនតាមខ្សែចាត់តាំងរបស់បក្ស]។ ឯកសារ D6.1.268 សេចក្តីរាយការណ៍ជូនបក្សស្រុកអំពីឈ្មោះ ភ្លង ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00270984-85 [រាយការណ៍អំពីការធ្វើទារុណកម្ម និងការសួរចម្លើយអ្នកទោស]។ ឯកសារ D6.1.1176 ឈ្មោះអ្នកទោសសួរប្រចាំថ្ងៃ២១ ខែមេសា ឆ្នាំ១៩៧៨ ដោយពួកត្រជាក់ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៧៨ [បញ្ជីឈ្មោះអ្នកទោសដែលបានសួរចម្លើយ] ។ ឯកសារ D6.1.160 កំណត់ហេតុស្តាប់ចម្លើយ ស៊ីម អាឡាត់ KH 00196812-13 [ពិភាក្សាអំពីមន្ទីរសន្តិសុខផ្សេងៗដែលគាត់បានដឹងក្នុងអំឡុងរបបខ្មែរក្រហម។ ឯកសារ D6.1.80 កំណត់ហេតុស្តាប់ចម្លើយ ចាន់ ខន KH 00186763-64 [ទាក់ទងនឹងមន្ទីរ១៣]។ ឯកសារ D6.1.1061 កំណត់ហេតុស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច EN 00185475-76 [ការរៀបរាប់ពីម១៣ និងស២១] KH 00185470 ["គោលការណ៍ទូទៅ នៅគ្រប់មន្ទីរសន្តិសុខទាំងអស់ក៏ដូចជានៅស២១ គឺគ្រប់មនុស្សទាំងអស់ដែលត្រូវបានចាប់ខ្លួនត្រូវតែសម្លាប់លើកលែងតែករណីពិសេសដែលមានភាពបណ្តោះអាសន្ន"]។ ឯកសារ D1.3.27.11 Henri Locard

អមនុស្សធម៌ ការសួរចម្លើយ ទារុណកម្ម និង/ឬ ការសម្លាប់[3971]។ ពុំមានអ្នកណាម្នាក់ដែលអាចទទួលបានទម្រង់ណាមួយនៃកិច្ចដំណើរការផ្លូវច្បាប់នោះឡើយ ដោយសារតែ ប.ក.ក. បានលុបបំបាត់រចនាសម្ព័ន្ធផ្លូវច្បាប់ និងតុលាការទាំងអស់ ពោលគឺ ពុំមានដីកាបង្គាប់ឲ្យចាប់ខ្លួន ពុំមានសវនាការស្តីពីការឃុំខ្លួន ពុំមានបទចោទប្រកាន់ ពុំមានក្រុមមេធាវីការពារក្តី និងពុំមានសិទ្ធិបង្ហាញភ័ស្តុតាងការពារខ្លួន ឬសូម្បីតែការជំនុំជម្រះ[3972]។

កំណត់ស្រាវជ្រាវអំពីបណ្តាញពន្ធនាគារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ៖ ភូមិភាគពាយ័ព្យ។ ឯកសារ D1.3.10.21 Henri Locard *ភូមិភាគនិរតី* [របាយការណ៍ស្តីពីពន្ធនាគារនៅក្នុងខេត្តកណ្តាល កំពង់ស្ពឺ និងកំពត]។ ឯកសារ D6.1.1048 Henri Locard *របាយការណ៍ស្តីពីខេត្តសៀមរាប៖ ភូមិភាគឧត្តរថ្មី (ព័ត៌មានពាក់ព័ន្ធមាននៅក្នុងបទសម្ភាសន៍របស់ ពុត ពុំ ត្រង់ទំព័រ ៣៥-៣៧* [របាយការណ៍ស្តីពីពន្ធនាគារនៅក្នុងខេត្តសៀមរាប]។ ឯកសារ D1.3.11.16 ឧបសម្ព័ន្ធ ខ ០០១០៖ Henri Locard *របាយការណ៍ កំពង់ចាម ច្រាំងទន្លេខាងលិច (តំបន់ឧត្តរចាស់) ២០០៧*) [របាយការណ៍ស្តីពីពន្ធនាគារនៅក្នុងតំបន់ ៤១ និង ៤២ នៃខេត្តកំពង់ចាម]។ ឯកសារ D1.3.11.17 សេចក្តីរាយការណ៍របស់ Henri Locard ស្តីពី៖ *កំពង់ធំ-ភូមិភាគឧត្តរ តំបន់ ឬភូមិភាគ ៤៣* [របាយការណ៍ស្តីពីពន្ធនាគារនៅក្នុងតំបន់ ៤៣ នៃខេត្តកំពង់ធំ]។ ឯកសារ D1.3.27.6 នាង រ៉ន៖ *ប្រវត្តិសង្ខេបរបស់មជ្ឈមណ្ឌលប្រល័យពូជសាសន៍ឈ្មោះក្រាំងតាចាន់របស់ ប៉ុល ពត នៅឃុំគូសស្រុកត្រាំកក់ ខេត្តតាកែវ ជាភាសាខ្មែរ ចុះថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ១៩៩០* [របាយការណ៍ពីការិយាល័យវប្បធម៌ និងវិចិត្រសិល្ប:អំពីមន្ទីរសន្តិសុខក្រាំងតាចាន់ស្ថិតក្នុងឃុំគូស ស្រុកត្រាំកក់]។

[3971] *សូមមើលខទាបរណ៍* ឯកសារ D1.3.29.2 កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146677 ["សន្តិបាលរបស់ ប.ក.ក ជាសន្តិបាលខុសគេ ខុសឯងទាំងស្រុង។ មិនប្រើច្បាប់ទាល់តែសោះ ប្រើតែមាគ៌ាបក្ស និងសេចក្តីសម្រេច ចិត្តតូចតាចរបស់បក្សដែលចេញតែពីមាត់របស់ប៉ុល ពត។ [...] ប្រើតែវិធានការឧក្រិដ្ឋ (ទារុណកម្ម យកចម្លើយ កំទេច ឲ្យតែចាប់គឺត្រូវតែកំទេច)"]។ ឯកសារ D6.1.1061 កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00185470 ["គោលការណ៍ទូទៅនៅគ្រប់មន្ទីរសន្តិសុខទាំងអស់ ក៏ដូចជានៅស ២១ គឺគ្រប់មនុស្សដែលត្រូវបានចាប់ខ្លួនត្រូវតែសម្លាប់លើកលែងតែករណីពិសេស ដែលមានភាពបណ្តោះអាសន្ន [...]។សេចក្តីសម្រេចចិត្តតែមួយគត់ដែលត្រូវធ្វើ គឺទាក់ទងតែនឹងពេលវេលានៃការសម្លាប់ប៉ុណ្ណោះ"]។ ឯកសារ D6.1.1222 សេចក្តីរាយការណ៍ជូនស.ម. អ៊ុំ គិត ស្រុកត្រាំកក់ ជាទីគោរពស្នេហាជ្រាប សម្រាប់ខែកក្កដា ឆ្នាំ ១៩៧៧ KH 00068017 [រាយការណ៍ជូនបក្សថា ក្នុងរយៈខែកក្កដា ឆ្នាំ ១៩៧៧ អ្នកទោស ៣៩ នាក់ ក្នុងចំណោមអ្នកទោសទាំងអស់ ៨១ នាក់ នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបាន "បោសម្អាត"]។ ឯកសារ D6.1.1226 សេចក្តីរាយការណ៍អំពីអ្នកទោសក្នុងបំណាច់ខែវិច្ឆិកា ឆ្នាំ ១៩៧៧ KH 00068014 [រាយការណ៍ជូនបក្សថា បំណាច់ខែ ១១ ឆ្នាំ ១៩៧៧ អ្នកទោស ៩២ នាក់ នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ត្រូវបាន "បោសម្អាត" ហើយអ្នកទោសម្នាក់ (ពាក់ស័ក្តិ ៤ កន្លះ) ត្រូវបានអង្គការ "ដកទៅតំបន់"]។ *សូមមើលផងដែរ* ឯកសារ D6.1.1050 ឯកសារថតចម្លងមួយច្បាប់របស់ Amnesty International ផ្ញើជូនទៅឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស ខែសីហា ឆ្នាំ ១៩៧៨ KH 00338190-91។

[3972] *ប្រៀបធៀប* ឯកសារ D1.3.20.2 រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ៩៧៦ EN 00184836 [មាត្រា ៩ និយាយដល់តុលាការរបស់ប្រជាជន "សិទ្ធិ និងសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន"] *ជាមួយ* D6.1.83 សៀវភៅនិពន្ធដោយ ដេវីដ ឆាណ្ឌាល្ហ័រ មានចំណងជើងថា៖ *សម្តែងពីមន្ទីរ ស-២១៖ ការភ័យរន្ធត់ និងរឿងរ៉ាវនៅក្នុងគុកសម្ងាត់របស់ ប៉ុល ពត* EN

1097. ការសួរចម្លើយដោយប្រើប្រាស់ទារុណកម្ម ជាទៀងទាត់ បាននាំឲ្យមាន "ការសារភាព" ដែលដាក់បន្ទុកលើអ្នកដទៃ ដោយបង្កើតខ្ជិបនៃការចាប់ខ្លួន និងការសម្លាប់ក្រៅប្រព័ន្ធតុលាការ[3973]។ ការសម្លាប់បែបនោះ កើតមានជាទូទៅ និងពិតជាផ្នែកមួយដ៏សំខាន់នៃគោលនយោបាយចំពោះខ្មាំង

00192813 ["ក្រោយពេលខ្មែរក្រហមបានទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រព័ន្ធយុត្តិធម៌នៅកម្ពុជាបានបាត់បង់។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពុំមានតុលាការ ចៅក្រម ច្បាប់ ឬការជំនុំជម្រះទេ។ តុលាការប្រជាជនដែលមានចែងនៅក្នុងមាត្រា ៩ នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ មិនដែលត្រូវបានបង្កើតឡើងឡើយ"]។ ឯកសារ D6.1.1231 អង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសង្គមកិច្ចប្រកាសអំពីសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៧៩ KH 00294964 ["ជំពូកទី៧នៃរដ្ឋធម្មនុញ្ញរបស់កម្ពុជាប្រជាធិបតេយ្យ មានមាត្រាសង្ខេបពីរពាក់ព័ន្ធនឹងការគ្រប់គ្រងវិស័យយុត្តិធម៌ និងការតែងតាំងចៅក្រម (មាត្រា ៩) និងកំណត់ពីទម្រង់នៃការផ្តន្ទាទោស (មាត្រា ១០)។ ទោះជាយ៉ាងនេះក្តី មានការចោទប្រកាន់ជាក់ស្តែងថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពុំមាននីតិវិធីតុលាការ ឬតុលាការទាល់តែសោះនៅក្នុងប្រទេស ហើយការផ្តន្ទាទោសលើបទល្មើសត្រូវបានធ្វើឡើងទាំងស្រុងដោយគ្មានការជំនុំជម្រះ"]។ ឯកសារ D347/2.1.24 ព្រុំ សារុន ប្រតិចារឹក ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០១៥ ម៉ោង 15.20.00-15.22.46 KH 01417625-26។ ឯកសារ D6.1.863 កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ម៉ោង 10.03.38 KH 00328658-59 ["ដែលហៅថា កម្មេចគឺមិនមែនដោះលែង។ បើកាលណាដោះលែងគឺមិនមែនកម្មេច បើកម្មេច គឺមិនមែនដោះលែង។ [...] គឺអត់ឆ្លងកាត់តុលាការទេ ព្រោះគ្មានច្បាប់គ្មានតុលាការ អចិន្ត្រៃយ៍មជ្ឈិមបក្សប្រមូលផ្តុំអំណាចទាំងបី"]។ ឯកសារ D1.3.29.2 កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00146677 ["សន្តិបាលរបស់ ប.ក.ក ជាសន្តិបាលខុសគេខុសឯងទាំងស្រុង។ មិនប្រើច្បាប់ទាល់តែសោះ ប្រើតែមាគ៌ាបក្ស និងសេចក្តីសម្រេចចិត្តតូចតាចរបស់បក្សដែលចេញពីមាត់ ប៉ុល ពត"]។ ឯកសារ D119/124 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន ឆ.៤៤ KH 00987273។ ឯកសារ D219/337 កំណត់ហេតុនៃការស្តាប់។ចម្លើយសាក្សី រៀម ឌី ឆ.១០ KH 01102812។ ឯកសារ D347/2.1.18 កំណត់ហេតុស្តាប់ចម្លើយ គុយ សម្ប្ផត្ថិ ឆ.3 KH 01096711។ ឯកសារ D219/983 កំណត់ហេតុស្តាប់ចម្លើយ សៅ ជាប់ ឆ.២២-២៣ KH 01477639។ ឯកសារ D219/954 កំណត់ហេតុស្តាប់ចម្លើយ ឈឹង ឈ្យីត ឆ.៥ KH 01425185។ ឯកសារ D123/1/1.2a ឈុំ វណ្ណី បទសម្ភាសន៍ជាមួយ ឈុំ វណ្ណី KH 00923669-70។ ឯកសារ D5/1097 ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ជា ធន្នី 13-VSS-00112 KH 01025736-37។ ឯកសារ D1.3.17.8 សៀវភៅនិពន្ធដោយ អ៊ីសា អ្ងស្ទាន់ មានចំណងជើងថា៖ *អ៊ីគ្ងបា: យុត្តិធម៌សម្រាប់ជនជាតិចាមមូស្លីម ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ* EN 00078543។

[3973] *សូមមើលឧទាហរណ៍* ឯកសារ D6.1.268 សេចក្តីរាយការណ៍ជូនបក្សស្រុកអំពីឈ្មោះ ភ្ជង ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00270984-85។ ឯកសារ D6.1.95 កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00244237 ["អ្នកទាំងអស់នេះ ត្រូវបានសួរចម្លើយដោយមានធ្វើទារុណកម្មហើយបានឆ្លើយដាក់អ្នកផ្សេងទៀតដែលជាហេតុ[នាំឲ្យ] មានការចាប់ខ្លួនជាទ្រង់ទ្រាយធំ។ការចាប់ខ្លួនទាំងនេះ មិនមានហេតុផលអ្វីផ្សេងទៀតនោះទេហើយក៏មិនមានការផ្ទៀតផ្ទាត់ជាមុនដែរ"]។ ឯកសារ D6.1.1062 កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្គេកអ៊ាវ ហៅ ឌុច KH 00185491 ["មិនមានករណីលើកលែងទេ ខ្ញុំជានិច្ចជាកាលរាយការណ៍ផ្ទាក់លើ ហើយផ្ទាក់លើនេះតែងតែបញ្ជាឲ្យចាប់ខ្លួនអ្នកដែលត្រូវបានគេឆ្លើយដាក់ទាំងនោះ"]។ ឯកសារ D219/290 កំណត់ហេតុស្តាប់ចម្លើយ ស ឈាង ឆ.២២ KH 01091453។ ឯកសារ D119/124 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន ឆ.៣២ KH 00987270។

ដែលត្រូវគេសង្ស័យ។ សេចក្តីសម្រេចរបស់គណៈកម្មការមជ្ឈិមក្នុងឆ្នាំ១៩៧៦ បានផ្តល់ដល់គណៈភូមិភាគនូវ "សិទ្ធិកម្ទេចអ្នកនៅខាងក្នុង និងខាងក្រៅ"[3974] ដោយពាក្យ "កម្ទេច" សំដៅទៅដល់ការសម្លាប់ក្រៅប្រព័ន្ធតុលាការ[3975]។ នៅក្នុងតំបន់ខ្លះ សេចក្តីសម្រេច "កម្ទេច" ត្រូវបានបញ្ជូនបន្តពីថ្នាក់ភូមិភាគ ទៅកាន់ថ្នាក់តំបន់[3976] ហើយមនុស្សដែលត្រូវបានស្នើយកទៅសម្លាប់ ជារឿយៗត្រូវបានថ្កោលទោស ដោយអាជ្ញាធរតំបន់ ហើយត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខស្រុក[3977]។

[3974] ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ KH 00003136។ *សូមមើលផងដែរ* ឯកសារ D6.1.863 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ម៉ោង 10.08.58-10.23.38 KH 00328659-60 [និយាយយោងដល់សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦៖ "តាមរយៈឯកសារនេះ បានប្រគល់សិទ្ធិ ឬក៏ថាប្រតិភូអំណាចខាងកាប់សម្លាប់ ខាងសម្រេចកម្ទេច ទាំងក្នុង និងទាំងក្រៅជូនទៅឲ្យមនុស្សបួនក្រុម [...] អំណាចដែលមជ្ឈិមប្រគល់ឲ្យពួកបួនក្រុមហ្នឹង ដែលមានសិទ្ធិពេញបរិបូរណ៍។ [...] សរុបមក ពេញមួយរយៈកាលពីថ្ងៃ ៣០ ខែមីនា ១៩៧៦ រហូតដល់ថ្ងៃ៧ មករា បក្សកុម្មុយនីស្តកម្ពុជា អនុវត្តមាគ៌ាចាត់តាំងនេះពេញលេញ និងតឹងរ៉ឹងបំផុត"]។

[3975] *សូមមើលឧទាហរណ៍* ឯកសារ D179/1.2.7 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ ម៉ោង 15.55.03 KH 00791577 ["កម្ទេច' ហ្នឹងយកទៅវ៉ៃចោល ។នៅតែដដែលគ្រាន់តែប្តូរតែមួយម៉ាត់អ៊ីចេះ មួយម៉ាត់អ៊ីចឹង នៅតែធ្វើឲ្យគ្នាស្លាប់"]។ ឯកសារ D6.1.863 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០៩ ម៉ោង 10.03.38 KH 00328658-59។ ឯកសារ D219/883.1.123 ក្រេក អេតវេសាន់ ប្រតិចារឹក ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ម៉ោង 09.09.48 KH 00337060-62។ ឯកសារ D6.1.99 កំណត់ហេតុស្តាប់ចម្លើយ ឈូក រ៉ានហៅ សុខ KH 00210214 ["កម្ទេច គឺបានន័យថាចាប់ និងសម្លាប់"]។

[3976] ឯកសារ D6.1.653 កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម KH 00373475 ["សេចក្តីសម្រេចនៅក្នុងចម្លើយសារភាពក្នុងស្រុក ១០៥ ដែលផ្ញើមកស្រុកជាចំហរ ខ្ញុំឃើញមានចម្លើយសារភាពខ្លះ[ដែល] មានសញ្ញាសម្គាល់ខ្វែង [ជា] ប៊ិចក្រហមនៅលើឈ្មោះចម្លើយសារភាពនោះ។ នេះមានន័យថាថ្នាក់តំបន់សម្រេចឲ្យបោសសំអាតឈ្មោះនោះ។ បោសសម្អាតមានន័យថាសម្លាប់"]។

[3977] *សូមមើលឧទាហរណ៍* ឯកសារ D6.1.1200 សេចក្តីរាយការណ៍របស់មន្ទីរអប់រំស្រុក ១០៥ ជូនបក្សអំពីចម្លើយអ្នកទោស ខែកក្កដា-សីហា ឆ្នាំ១៩៧៧ KH 00082724 [សរសេរដៃបញ្ជាក់ដោយ ប្រាក់ ត.១៣ (គណៈតំបន់១៣) ផ្តល់ការណែនាំដល់ អាន ប្រធានមន្ទីរសន្តិសុខក្រាំងតាចាន់៖ "សម្រេចកម្ទេចចុះ។ ថ្ងៃទី៧ ខែសីហាឆ្នាំ១៩៧៧។ ត.១៣ ប្រាក់"] KH 00082725 ["សម្រេចកម្ទេចចុះ។ ថ្ងៃទី៧ ខែសីហា ឆ្នាំ១៩៧៧ ត.១៣ ប្រាក់"] KH 00082727 [សេចក្តីណែនាំពីលេខស្រុក គិត ជូនដល់ អាន បញ្ជាក់ថា៖ "បញ្ជូនអ្នកទោសទាំងអស់ ដែលបានចាប់នៅក្នុងឃុំជាងទង [...] ស្រាវជ្រាវសួររកចម្លើយ ផុតខ្សែវាឲ្យអស់ កំទេចចុះ"]។ ឯកសារ D6.1.695 កំណត់ហេតុស្តាប់ចម្លើយ ផាន់ ឆេន ឆ.១៨-២០ KH 00414444 ["ស៖ នៅក្នុងឯកសារ [សេចក្តីរាយការណ៍ពីមន្ទីរអប់រំស្រុក ១០៥] ដែលលោកបានមើលនេះ [...] គឺជារូបភាពរបាយការណ៍ដែល អាន បានធ្វើសម្រាប់ផ្ញើទៅថ្នាក់លើ ហើយជាគំរូនៃរបាយការណ៍ដែលបានធ្វើទៅថ្នាក់លើនិងជាបញ្ជាដែលថ្នាក់លើបញ្ជូនមកអាន់វិញឬយ៉ាងណា [...]? ឆ.១៨៖ តាមមើលគឺអ៊ីចឹងឯង។ [...] ស៖តើនៅក្នុងកន្លែងអក្សរដៃដែលនិយាយអំពី សេចក្តីណែនាំនោះជាសេចក្តីណែនាំយ៉ាងដូចម្តេច? ឆ.២០ ៖ នេះជារបាយការណ៍ដែលគេធ្វើទៅឲ្យស្រុក ស្រុកទៅឲ្យតំបន់ ហើយតំបន់បញ្ជាមកវិញ"]។

1098. គោលនយោបាយចាប់ខ្លួន "សមាសធាតុមិនល្អ" និង "កម្ទេចខ្មាំង" ត្រូវបានផ្សព្វផ្សាយតាមរយៈឯកសារបោះពុម្ពផ្សាយផ្ទៃក្នុងរបស់ ប.ក.ក.[3978] សុន្ទរកថារបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ[3979] និងកិច្ចប្រជុំនៅគ្រប់ថ្នាក់ទាំងអស់[3980]។ សារទូរលេខរវាងថ្នាក់ផ្សេងៗនៃឋានានុក្រមរបស់ ប.ក.ក. ក៏

[3978] *សូមមើលឧទាហរណ៍* ឯកសារ D6.1.737ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៥ KH 00063342 ["កម្ទេចពួកចារកម្ម កម្ទេចពួកវិធ្មេទកម្ម ដែលវាចង់បំផ្លិចបំផ្លាញបដិវត្តយើង គឺយើងបន្តកម្ទេចសំណល់ខ្មាំងដែលចាញ់នោះ ហើយបន្តពង្រឹងជ័យជម្នះរបស់យើង"]។ ឯកសារ D6.1.755 ទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-មករា ឆ្នាំ១៩៧៧ KH 00063005។ ឯកសារ D6.1.542 ទង់បដិវត្ត ខែមិថុនា ឆ្នាំ១៩៧៧ KH 00446862។ ឯកសារ D1.3.22.6 ទង់បដិវត្ត ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ KH 00064577-78។ ឯកសារ D219/370.1.15 យុវជន និងយុវនារីបដិវត្ត ខែតុលា ឆ្នាំ១៩៧៨ KH 00376480-81។

[3979] *សូមមើលឧទាហរណ៍* ឯកសារ D6.1.939 *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខួប* ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ KH 00292804-05។ ឯកសារ D322/8.1.23 ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៧ KH 00062986 [សេចក្ដីដកស្រង់ពីបទឧទ្ទេសនាមរបស់ "សមមិត្តតំណាងអង្គការបក្ស" ក្នុងឱកាសមហាមីទิញទទួលអំណរខួបឆ្នាំទី២ នៃមហាជ័យជម្នះ ១៧ មេសា៖ "ឯចំពោះខ្មាំងជាភ្នាក់ងា 'សេអ៊ីអា' 'កាសេបេ' និងភ្នាក់ងារ 'ឃ្លីន' ជាអ្នកបំរើខ្មាំងយ៉ាងថោកទាប ដែលលួចបង្កប់នៅក្នុងបក្សយើង និងជួរបដិវត្តយើង ពួកអានេះវាកំពុងបិតក្នុងសភាពបាត់ម្ចាស់ការកម្រិតខ្ពស់បំផុត ដោយក្បាលម៉ាស៊ីនធំៗ និងមធ្យមរបស់វាត្រូវកម្ទេចជាមូលដ្ឋាន ហើយកម្លាំងដែលនៅសេសសល់ក៏ត្រូវខ្ចាត់ខ្ចាយ រប៉ាត់រប៉ាយជាមូលដ្ឋានដែរ ប្រៀបបីដូចកណ្ដុរត្រូវវាយបែកសម្បុកធ្លាក់ទឹក ហើយកំពុងត្រូវប្រជាជនដេញសំពងឲ្យវិនាសអន្ដរធាន។ យើងត្រូវបន្ដវាយវាតទៅទៀត ជាន់ករវាថែមទៀត ក្នុងឋានៈយើងមានប្រៀបដាច់ខាត វាយសម្រុកវាជាប់ជានិច្ច ក្នុង១ឆ្នាំ១៩៧៧ នេះ ឲ្យវាកាន់តែខ្ទេចខ្ទីតទៅទៀត ងើបក្បាលមិនរួច"]។ ឯកសារ D322/8.1.26 ទង់បដិវត្ត ខែសីហា ឆ្នាំ១៩៧៧ KH 00062963-64 [បទឧទ្ទេសនាមរបស់ "តំណាងអង្គការបក្ស" (គេជឿថា ឆ្លួន ជា) នៅក្នុងមីទิញកម្មាភិបាលភូមិភាគបស្ចិមនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧៖ "យកឧទាហរណ៍នៅក្នុងភាគនេះ នៅក្នុងភាគនេះក៏មានខ្មាំងបង្កប់។ ក្នុងតំបន់ក៏មានសមាសភាពខ្មាំងបង្កប់ ក្នុងស្រុកក៏មានសមាសភាពខ្មាំងបង្កប់ ។ល។ យើងដណ្ដើមបានជ័យជម្នះទូទាំងប្រទេសហើយ វាមករៀបចំកម្លាំងវា វាមកស៊ីរួង ដើម្បីដណ្ដើមរដ្ឋអំណាច ពីយើងវិញ រដ្ឋអំណាចភាគ រដ្ឋអំណាចតំបន់ រដ្ឋអំណាចស្រុក [...] ត្រូវរៀបចំកម្លាំងទៅវ៉ៃ រ៉ែកម្ទេចខ្មាំង និងសមាសភាពមិនល្អ បង្កប់កាន់កាប់នៅក្នុងសហករណ៍"]។ ឯកសារ D6.1.815 លោក អ៊ឿង សារី រៀបចំពិធីជប់លៀងសម្រាប់គណៈប្រតិភូភូមា ថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៧៧ KH 00658434។

[3980] *សូមមើលឧទាហរណ៍* D1.3.24.2 ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ KH 00019121។ ឯកសារ D6.1.1146 កំណត់ហេតុនៃអង្គប្រជុំការងារឃោសនាការ ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ១៩៧៦ KH 00000845។ ឯកសារ D6.1.774 បទឧទ្ទេសនាមរបស់សមមិត្តលេខាក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦ KH 00072760-61។ ឯកសារ D6.1.73 កំណត់ហេតុអង្គប្រជុំជាមួយមន្ទីរ៧០៣ និង ស២១ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ១៩៧៦ KH 00008503។ ឯកសារ D219/494.1.8 ឈុំ សេង ប្រតិចារឹក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៥ ម៉ោង 15.39.28-15.42.21 KH 01448636-38។ ឯកសារ D119/155 កំណត់ហេតុស្ដាប់ចម្លើយ ឡាច ឈានឡុង ឆ.៤១, ៤៣-៤៤ KH 01024759-60។ ឯកសារ D6.1.688 កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធឿន KH 00368610-11។ ឯកសារ D118/274 កំណត់ហេតុស្ដាប់ចម្លើយ ប៊ុន ធឿន ឆ.៣០-៣៤ KH 00999991-92។ ឯកសារ D118/242 កំណ់តហេតុនៃការស្ដាប់ចម្លើយសាក្សី ខឹម ហ៊ីន ឆ.៨៧-៩១ KH 00998734។ ឯកសារ D119/139 កំណត់ហេតុស្ដាប់ចម្លើយ មុន មុត ឆ.៤៥ KH 01003884។

បានរាយការណ៍ផងដែរអំពី "សកម្មភាពខ្មាំង" និងព័ត៌មានលម្អិតអំពីមនុស្សដែលត្រូវបានសម្លាប់[3981]។

1099. ខណៈពេល ដែលបរាជ័យរបស់គោលនយោបាយសេដ្ឋកិច្ច និងភូមិសាស្ត្រនយោបាយរបស់ ប.ក.ក .កាន់តែលេចឡើងយ៉ាងច្បាស់ សេចក្ដីសង្ស័យ និងភាពភ័យខ្លាចរបស់ ប.ក.ក. បានកើនឡើង ហើយយុទ្ធនាការកម្ចាត់គូប្រជែងនយោបាយដែលមានសក្តានុពល (ដែលត្រូវគេហៅថា "ខ្មាំងផ្ទៃក្នុង" និង "ជនក្បត់") គ្រួសាររបស់ពួកគេ និងមនុស្សក្នុងបន្ទុកគ្រួសាររបស់ពួកគេ ឬអ្នកក្រោមបង្គាប់របស់ពួកគេកើនឡើងយ៉ាងខ្លាំង[3982]។ មជ្ឈិមសម្របសម្រួលការបោសសម្អាតកម្ចាភិបាល ប.ក.ក. ក្នុង

[3981] *សូមមើលឧទាហរណ៍* ឯកសារ D6.1.794 ទូរលេខ ១០០៖ សូមជម្រាបបង ញ៉ឹម អំពីសភាពការណ៍ខ្មាំងនៅតំបន់ ៥ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ឯកសារ D1.3.30.19 របាយការណ៍របស់ ញ៉ឹម "គោរពជូនអង្គការ ៨៧០" ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ ១៩៧៨ KH 00021043-44 [រាយការណ៍អំពីសភាពការណ៍ខ្មាំងខាងក្នុង និងខាងក្រៅនៅក្នុងតំបន់១, ៣, ៤ និង៥ ធានាថា ពួកគេនឹងមានវិធានការ "ប្រុងប្រយ័ត្នឲ្យខ្ពស់ថែមទៀត វាយកម្ទេចខ្មាំងណ្ណានពាន និងបោសម្អាតពួកសមាសភាពអន្តរាយជាបន្តបន្ទាប់ទៅទៀត ទប់ទល់ការរត់លួន និងលួចនេះលួចនោះឲ្យអស់"]។ ឯកសារ D1.3.27.4 ទូរលេខពី ញ៉ឹម៖ គោរពជូនអង្គការ ៨៧០ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ១៩៧៨ KH 00021046។ ឯកសារ D219/702.1.62 ទូរលេខ ៦០៖ គោរពជូនគណៈ ៨៧០ ជាទីស្នេហា និងនឹករលឹកអំពីសភាពការណ៍ត្រប់ផ្ទៃកមួយចំនួន ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ១៩៧៧ KH 00069447-48។ ឯកសារ D132.1.165 ទូរលេខ ៣១៣៖ គោរពជូនគណៈ ៨៧០ ជាទីស្នេហាអំពីសភាពការណ៍មួយចំនួន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ១៩៧៨ KH 00001084-85 [ទាក់ទងនឹង "សភាពការណ៍ខ្មាំងបង្កប់ស៊ីរ្ជូងផ្ទៃក្នុង"]។ ឯកសារ D132.1.7 របាយការណ៍ពី មុន មុត ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ ១៩៧៨ KH 00017026 ["សរុបយួនដែលចាប់បាននិងបាញ់ងាប់ចាប់ពីថ្ងៃទី២៧ ខែមីនា ឆ្នាំ១៩៧៨ មកដល់ ថ្ងៃទី៣០ ខែមីនា ឆ្នាំ ១៩៧៨ មានចំនួន ១២០ ក្បាល "]។

[3982] *សូមមើលឧទាហរណ៍* ឯកសារ D6.1.1159 កំណត់ហេតុនៃការប្រជុំលេខា និងភស្តុភារកងពល និងវរៈសេនាធំឯករាជអំពីសកម្មភាពខ្មាំងខាងក្នុង និងខាងក្រៅ ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៦ EN 00233718។ ឯកសារ D6.1.740 ទង់បដិវត្ត ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧ KH 00064757-60 ["ខ្មាំងសត្រូវទាំងក្នុងប្រទេស ទាំងក្រៅប្រទេស [...] វាចង់បំផ្ទិចបំផ្លាញបដិវត្តយើងគ្រប់ពេល ហើយតាមគ្រប់វិធី។ [...] នៅក្នុងមជ្ឈិម នៅក្នុងសេនាធិការ នៅក្នុងភូមិភាគ នៅក្នុងមូលដ្ឋាន សុទ្ធតែមានខ្មាំងបង្កប់នៅក្នុងជួរយើង។ បើយើងមិនមានវិធានការទាន់ពេលវេលា គឺគ្រោះថ្នាក់ [...] ឥឡូវនេះ យើងពិនិត្យថា បក្សយើងខ្លាំងហើយ បានជាយើងបោសសម្អាតខ្មាំងបង្កប់ស៊ីរ្ជូងបាន អាក្បាលធំៗជាង៩៩ ភាគរយហើយ។ [...] តាមពិតយើងកុំឲ្យខ្មាំងវាពង្រីងពង្រីកបាន។ ត្រូវវាយសម្រុកជាប់"]។ ឯកសារ D219/888.1.8 ព្រាប សុឃៀន ប្រតិចារឹក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 09.45.00-09.48.50 KH 01365162-64។ ឯកសារ D119/124 កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម អេន ឆ.២៦ KH 00987269-70។ ឯកសារ D219/171 កំណត់ហេតុស្តាប់ចម្លើយ ញ៉ឹម កុល ឆ.៣៣ KH 01065952។ ឯកសារ D118/274 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន ឆ.៣០-៣៤ KH 00999991-92។

ទ្រង់ទ្រាយធំ[3983] ដែលនៅក្នុងភូមិភាគពាយ័ព្យត្រូវបានអនុវត្តដោយកម្លាភិបាលភូមិភាគបស្ចិម និងភូមិភាគនិរតី[3984]។ ទស្សនាវដ្ដី*ទង់បដិវត្ដន៍* ឆ្នាំ១៩៧៨ បានបញ្ជាសមាជិកបក្សគ្រប់ជាន់ថ្នាក់ឲ្យ "វាយប្រហារខ្លាំង [...] ទាំងអស់ បោសសម្អាតពួកគេឲ្យស្អាត បោសសម្អាតហើយបោសសម្អាតទៀត ដោយគ្មានមឿយហត់" ដើម្បីធ្វើឲ្យបក្សយើង "ល្អបរិសុទ្ធ" និង "ស្អាតគ្រប់ពេលទាំងអស់"[3985]។

ខ. គោលនយោបាយប្រែក្លាយប្រជាជនទៅជាទាសករ

1100. ការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងកសិកម្មជ្រុលនិយមរបស់មេដឹកនាំ ប.ក.ក. ដែលជាសហឧក្រិដ្ឋកម្មរួមដែល **យ៉ីម ទិត្យ** បានចូលរួម មានការពាក់ព័ន្ធដល់ការប្រព្រឹត្ដបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៃការដាក់មនុស្សឲ្យក្លាយជាទាសករ ការធ្វើមនុស្សឃាត និងអំពើអមនុស្សធម៌ផ្សេងៗទៀត (ការធ្វើបាបអមនុស្សធម៌ និងការធ្វើឲ្យបាត់ខ្លួនដោយបង្ខំ) នៅតាមសហករណ៍ និងការដ្ឋាន។

1101. **យ៉ីម ទិត្យ** និងសមាជិកសហឧក្រិដ្ឋកម្មរួមរបស់គាត់ បានអនុវត្តគោលនយោបាយរបស់ ប.ក.ក. ដែលត្រូវបានបង្កើតឡើងយ៉ាងល្អ នៅក្នុងគោលបំណងបែបនេះ។ ក្រោយពេលកាន់កាប់ទីក្រុងភ្នំពេញនៅខែមេសា ឆ្នាំ១៩៧៥ ប.ក.ក. បានបង្ខំប្រជាជនទីក្រុងឲ្យចាកចេញពីផ្ទះរបស់ពួកគេនៅក្នុងទីក្រុង ទៅធ្វើការនៅក្នុងសហករណ៍ និងការដ្ឋាននៅទីជនបទនៅទូទាំងប្រទេស ដែលបង្កឲ្យ

[3983] *សូមមើលឧទាហរណ៍* ឯកសារ D240R ខ្សែភាពយន្ដ មានចំណងជើងថា៖ *សត្រូវរបស់ប្រជាជន* ឆ្នាំ២០០៩ ត្រង់ម៉ោង 01.02.23-01.02.48 [ន្ហូន ជា៖ "យើងត្រូវដោះស្រាយបញ្ហាពួកកាត់ដោយក្ដាប់ឲ្យបានជាប់ និងកុំឲ្យធ្លងដល់ប្រជាជនស្ងួតត្រង់នៅថ្នាក់ក្រោម។ ដូច្នេះ យើងហ៊ានសន្និដ្ឋានថា ការសម្រេចរបស់យើង គឺត្រឹមត្រូវ។ បើយើងអាណិតអាសូរចំពោះពួកនេះ នោះជាតិយើងប្រាកដជាបាត់បង់មិនខាន"]។ ឯកសារ D322/8.1.23 ទង់បដិវត្ដ ខែមេសា ឆ្នាំ១៩៧៧ KH 00062992 ["ត្រូវសម្រិតសម្រាំងជម្រុះ និងបោសម្អាតសមាសភាពមិនល្អ និងសមាសភាពខ្លាំង"]។ ឯកសារ D6.1.1157 *កំណត់ហេតុនៃការប្រជុំលេខា អនុលេខា កងពលនិងវរៈសេនាធំឯករាជ* ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៦ (ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦)។ ឯកសារ D219/899.1.4 ម៉ឹង រេត ប្រតិចារ៉ីក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៦ ម៉ោង 14.33.27-14.35.11 KH 01329920-21។ ឯកសារ D118/102 កំណត់ហេតុស្ដាប់ចម្លើយ ទាត់ ធឿន ឆ.៤៦ KH 00947586។ ឯកសារ D6.1.379 កំណត់ហេតុស្ដាប់ចម្លើយ កែ ពេជ្រវណ្ណ: KH 00340564-66 [កូនប្រុសរបស់ កែ ពក បញ្ជាក់ថា ការបោសម្អាតនៅក្នុងភូមិភាគកណ្ដាល (ឧត្ដរចាស់) ត្រូវបានធ្វើឡើងដោយកម្លាភិបាលនិរតី រហូតដល់ថ្នាក់ "ភូមិ"]។ ឯកសារ D1.3.16.1 ប្រវត្ដិតស្ទ្ងរបស់លោក កែ ពក EN 00095551-52 [លើកឡើងអំពីការចាប់ខ្លួននៅភូមិភាគកណ្ដាលនៅក្នុងខែកុម្ភ: ឆ្នាំ១៩៧៧]។

[3984] *សូមមើល* V.ខ.១. បទឧក្រិដ្ឋ – ភូមិភាគពាយ័ព្យ – ការបោសម្អាត។

[3985] ឯកសារ D1.3.22.6 ទង់បដិវត្ដ ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ KH 00064579-80។

មានលំហូរមនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់[3986]។ ប្រជាជនទាំងនោះត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅតាមសហករណ៍ធ្វើស្រែ ការដ្ឋានសាងសង់បណ្តាញប្រព័ន្ធធារាសាស្ត្រ និងការដ្ឋានសាងសង់

[3986] *សូមមើលខគាហារណ៍* ឯកសារ D1.3.24.1 កំណត់ហេតុអំពីទស្សនៈកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ KH 00008489 [“ត្លុនាទីក្រោយពេលរំដោះទាំងស្រុងសហករណ៍ស្រូបប្រជាជនថ្មី ចេញពីទីក្រុងទាំងអស់ ពិសេសក្រុងភ្នំពេញ ហើយនៅពាយ័ព្យគឺបាត់ដំបង។ប្រជាជនថ្មីរាប់សែននាក់នៅបាត់ដំបង មានសមាសភាពអាក្រក់គ្រប់យ៉ាង។ តែសហករណ៍ស្រូបយកអស់ ផ្គត់ផ្គង់ស្បៀង ព្រមទាំងចាត់ចែងកម្លាំង ធ្វើការងារទៀត។ អនុសហករណ៍ខ្លាំងក្លាណាស់”]។ ឯកសារ D6.1.749 ទង់បដិវត្ត ខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦ KH 00063207-08 [“ក្រោយរំដោះទូទាំងប្រទេសភ្លាម ពេលដែលប្រជាជនរាប់ម៉ឺនរាប់សែននាក់ ទើបជម្លៀសចេញពីទីក្រុងនានា ទៅកាន់មូលដ្ឋានជនបទភ្លាម”] KH 00063220 [“ប្រជាជនទីក្រុងនានា ជិតបីលាននាក់ ត្រូវផ្លាស់ប្តូរទីកន្លែងទៅរស់នៅបង្ករបង្កើនឯជនបទ”]។ ឯកសារ D267.1.41 សុខ ឈិន ប្រតិចារឹក ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ ម៉ោង 10.01.37-11.31.15 KH 00855500-18។ ឯកសារ D179/1.2.8 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ម៉ោង 11.18.39-11.21.34 KH 00791939-40។ ឯកសារ D179/1.2.9 កាំង ហ្គេចអ៊ាវ ហៅ ឌុច ប្រតិចារឹក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១២ ម៉ោង 09.33.36-09.35.49 KH 00792467-68។ ឯកសារ D179/1.2.21 ស្ងួត ទ្យើង ប្រតិចារឹក ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១២ ម៉ោង 11.28.54-11.30.07 KH 00801720-21។ ឯកសារ D219/486.1.2 ស្ងួន កានិល ប្រតិចារឹក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ម៉ោង 10.16.38-10.19.53 KH 00871500-01។ ឯកសារ D267.1.80 ពេជ្រ ជ៉ីម ប្រតិចារឹក ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៣ ម៉ោង 10.52.56-10.54.24 KH 00934794-95, ម៉ោង 13.37.42-13.39.49 KH 00934815-16។ ឯកសារ D5/526/3.1 ចៅ នី ប្រតិចារឹក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១២ ម៉ោង 12.02.29-12.04.08 KH 00865500-01 [នៅភូមិភាគពាយ័ព្យ៖ “ពេលខ្ញុំទៅដល់ស្រុកមោងឬស្សី ពេលចុះពីលើរថភ្លើង នៅពេលនោះ [...] មានរទេះគោ គេ មកចាំៗដឹកយើងចុះទៅកន្លែងសហករណ៍ហ្នឹង [...] គេហ្នឹងជាសហករណ៍តាហ៊ីយ [...] នៅចកធំ នៅខាងស្រុកមោងឬស្សី ខេត្តបាត់ដំបង”]។ ឯកសារ D179/1.2.24 សៅ សារុន ប្រតិចារឹក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ ម៉ោង 09.19.27-09.23.00 KH 00814403-05។ ឯកសារ D6.1.532 ខៀវ សំផន ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា EN 00498281 [ខៀវ សំផនទទួលស្គាល់នូវការពង្រីកយ៉ាងលឿននៃសហករណ៍កម្រិតខ្ពស់]។

ទំនប់[3987] រាលយន្តហោះ[3988] ស្រែអំបិល និងការដ្ឋានវាយថ្ម[3989]។ កងចល័ត ត្រូវបានបង្កើតឡើង ដើម្បីធ្វើការនៅទីកន្លែងជាច្រើន ដោយអាស្រ័យទៅតាមការចាំបាច់[3990]។ សហករណ៍ និងការដ្ឋាន

[3987] ឯកសារ D322/8.1.9 កសាង និង ពង្រឹងគោលជំហរវិភាគគ្រប់បាតុភាពគ្រប់បញ្ហាតាមគោលជំហរនៃវណ្ណៈអធនរបស់បក្ស KH 00441897-99។ ឯកសារ D6.1.837 ឯកសារទី៣ របស់កម្ពុជាប្រជាធិបតេយ្យ៖ ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ចនិងរៀបចំកសាងប្រទេសគ្រប់ផ្នែក ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072371-72។ ឯកសារ D1.3.31.1 សៀវភៅនិពន្ធដោយដេវីដ ឆាណ្ឌល្ល័រ និងអ្នកដទៃទៀត មានចំណងជើងថា៖ *ប៉ុល ពត ធ្វើផែនការសម្រាប់អនាគត* "គម្រោងផែនការ ៤ ឆ្នាំកសាងសង្គមនិយមគ្រប់ផ្នែករបស់ក្ស ឆ្នាំ១៩៧៧-១៩៨០" KH 00075867។ ឯកសារ D6.1.1257 សម័យប្រជុំពេញអង្គលើកទី២៨ នៃមហាសន្និបាតរបស់អង្គការសហប្រជាជាតិជាភាសាអង់គ្លេសជជែកដេញដោលអំពីកម្ពុជាប្រជាធិបតេយ្យ នៅថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ ក្រោមអធិបតិភាពលោកប្រធាន ឡាហ្ការ៉ាម៉ូស សូរ ជាជនជាតិយូហ្គូស្លាវី KH 00291027-28 ។ ឯកសារ D6.1.941 បទសម្ភាសន៍ជាមួយ ជា ស៊ីម ដោយ Ben Kiernan ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៩១ EN 00419370។ ឯកសារ D118/217 កំណត់ហេតុស្តាប់ចម្លើយ ម៉ី សំ ឆ.៤៣ KH 00982192 ។ ឯកសារ D219/589 កំណត់ហេតុស្តាប់ចម្លើយ ចឹ ម ប៊ុនរ៉ែត ឆ.៥ KH 01167592 ឆ.២២ KH 01167594-95 ឆ.៧២ KH 01167601។ ឯកសារ D219/941 កំណត់ហេតុស្តាប់ចម្លើយ ស្ងួន សោភ័ណ្ឌ ឆ.៣ KH 01414384។ ឯកសារ D219/448 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៣ KH 01129716-17។ ឯកសារ D219/6 កំណត់ហេតុស្តាប់ចម្លើយ អ៊ុក ប៊ាង ឆ.៩៦ KH 01025503។ ឯកសារ D219/453 កំណត់ហេតុស្តាប់ចម្លើយ យ៉ាត ឃឿន ឆ.៣ KH 01129769។

[3988] *សូមមើលឧទាហរណ៍* ឯកសារ D1.3.24.2 ការប្រជុំអចិន្ត្រៃយ៍ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ EN 00183407។ ឯកសារ D6.1.354 កំណត់ហេតុស្តាប់ចម្លើយ ចាន់ ម៉ន ហៅ ជួប សុខុន KH 00287526-27 ["នៅពាក់កណ្តាលឆ្នាំ១៩៧៦ គឺរដូវដកស្ទូងស្ទៀតបានចាត់តាំងខ្ញុំឲ្យមកមើលការដ្ឋានព្រលានយន្តហោះនៅឃុំក្រាំងណាវ ខេត្តកំពង់ឆ្នាំង។ [...] ខ្ញុំបានឃើញមនុស្សជាច្រើនម៉ឺននាក់មានស្រី ប្រុស សុទ្ធតែជាយោធានៅក្នុងការដ្ឋាននោះតែម្តង"]។ ឯកសារ D219/883.1.16 កំណត់ហេតុស្តាប់ចម្លើយ សែម ហ៊ឿន KH 00287558-59។ ឯកសារ D219/487.1.1 មជ្ឈមណ្ឌលឯកសារកម្ពុជា៖ សំដីរបស់លោក សែម ហ៊ឿន ហៅគីម KH 00020590-92។

[3989] *សូមមើលឧទាហរណ៍* ឯកសារ D6.1.409 កំណត់ហេតុស្តាប់ចម្លើយ ជុំ លន KH 00241997-98។ ឯកសារ D6.1.442 កំណត់ហេតុស្តាប់ចម្លើយ កែម ញ៉ KH 00271423។ ឯកសារ D6.1.984 កំណត់ហេតុស្តាប់ចម្លើយ សេក សំអាត ហៅវ៉ីម ឆ.៧-៨ KH 00488712។ ឯកសារ D118/292 កំណត់ហេតុស្តាប់ចម្លើយ សៅ ว๊ាន់ ឆ.៤០ KH 01022459។ ឯកសារ D219/481 កំណត់ហេតុស្តាប់ចម្លើយ ជ្រ៊ីង សុភាព ឆ.១៤-១៥ KH 01136283-84 ឆ.២៤ KH 01136286 ឆ.៤៦ KH 01136291 ឆ.២០ KH 01136285 ឆ.២៣ KH 01136286។ ឯកសារ D219/551 កំណត់ហេតុស្តាប់ចម្លើយ ហេង ឃ្លី ឆ.៤៥ KH 01157596 ឆ.៨៤ KH 01157600 ឆ.៦៣-៦៤ KH 01157598។ ឯកសារ D106/4 កំណត់ហេតុស្តាប់ចម្លើយ ឡាយ ខាន់ ឆ.២១ KH 00800990។ ឯកសារ D119/22 កំណត់ហេតុស្តាប់ចម្លើយ ភោគ គុយ ឆ.១០ KH 00894513។

[3990] *សូមមើលឧទាហរណ៍* ឯកសារ D219/370.1.4 សារធ្វើតាមហិបទ្ធតស្តីពី៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៦ KH 00709589-90។ ឯកសារ D322/8.1.17 យុវជន និងយុវនារីបដិវត្ត ខែមិថុនា ឆ្នាំ១៩៧៦ KH 00064110 ["ហើយបងប្អូនមួយចំនួនទៀត ជាកងផលិតចល័ត បានចុះជួយតាមសហករណ៍នានា ពិសេស ជួយភ្ជួររាស់និងដកស្ទូង"]។ ឯកសារ D6.1.542 ទង់បដិវត្ត ខែមិថុនា ឆ្នាំ១៩៧៧ KH 00062811 ["កងចល័តយើងចាត់ចែងទៅណាក៏បាន ធ្វើអាងទឹកក៏បាន ដាំដំឡូង

ទាំងនោះ ត្រូវបានតម្រូវឲ្យប្រកាន់យកវចនាសម្ព័ន្ធ និងវិធីសាស្ត្រប្រតិបត្តិការប្រហាក់ប្រហែលគ្នានៅទូទាំងប្រទេស[3991] ហើយគោលនយោបាយពាក់ព័ន្ធត្រូវបានផ្សព្វផ្សាយតាមរយៈបទបញ្ជា[3992] កិច្ចប្រជុំនៅគ្រប់ជាន់ថ្នាក់[3993] ឯកសារបោះពុម្ពផ្សាយ[3994] និងការផ្សាយតាមវិទ្យុ[3995]។

ក៏បាន ដាំចេកក៏បាន"]។ ឯកសារ D219/405 កំណត់ហេតុស្តាប់ចម្លើយ ឈឹម ប៊ុនសេរី ឆ.៣៨ KH 01117212។ ឯកសារ D219/368 កំណត់ហេតុស្តាប់ចម្លើយ ឈៀង ប៊ាន ឆ.៨ KH 01110175។ ឯកសារ D219/20 កំណត់ហេតុស្តាប់ចម្លើយ ឈុំ រ៉ាន់នី ឆ.៨២ KH 01029500។ ឯកសារ D219/153 កំណត់ហេតុស្តាប់ចម្លើយ អ៊ីម សឿន ឆ.៧-៩ KH 01058763។ ឯកសារ D219/772 កំណត់ហេតុស្តាប់ចម្លើយ សាត ស៊ីម ឆ.១៣៥-១៣៦ KH 01247974-75។

[3991] ឯកសារ D6.1.1127 ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិ ប្រជាធិបតេយ្យ របស់បក្ស (ឯកសារទី៦) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072401-06។ ឯកសារ D6.1.746 ទង់បដិវត្ត ខែតុលា វិច្ឆិកា ឆ្នាំ១៩៧៥ KH 00063268-70។ ឯកសារ D6.1.100 ទង់បដិវត្ត ខែកក្កដា ឆ្នាំ១៩៧៦ KH 00062916-18។ ឯកសារ D6.1.740 ទង់បដិវត្ត ខែតុលា-វិច្ឆិកា ឆ្នាំ១៩៧៧។

[3992] *សូមមើលឧទាហរណ៍* ឯកសារ D6.1.837 ពិនិត្យការក្តាប់និងអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ចនិងរៀបចំកសាងប្រទេសគ្រប់ផ្នែក (ឯកសារទី៣) ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ១៩៧៥។ ឯកសារ D6.1.1127 ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយ ប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិ ប្រជាធិបតេយ្យ របស់បក្ស (ឯកសារទី៦) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072401-06។ ឯកសារ D1.3.19.1 សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ KH 00003136 [អនុវត្តរបបរាយការណ៍ប្រចាំសប្តាហ៍ជូនមន្ទីរ ៨៧០ ដើម្បី "តាមដានផែនការឲ្យជាប់ និងដោះស្រាយបញ្ហាឲ្យទាន់ពេលវេលាក្នុងទិសដៅសម្រេចពពោន មួយហ៊ិកតា"]។ ឯកសារ D6.1.773 ការកសាងជួរកម្មាភិបាល៖ សេចក្តីណែនាំរបស់បក្ស ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៨ KH 00658260-64។

[3993] *សូមមើលឧទាហរណ៍* ឯកសារ D1.3.24.1 កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ KH 00008489 KH 00008489-90។ ឯកសារ D6.1.1165 កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៦ KH 00017114។ ឯកសារ D6.1.688 កំណត់ហេតុស្តាប់ចម្លើយ ប៊ុន ធឿន KH 00368602-03។ ឯកសារ D1.3.31.1 សៀវភៅនិពន្ធដោយដេវីដ ឆាណ្ឌាល្ល័រ និងអ្នកដទៃទៀត មានចំណងជើងថា៖ *ប៉ុល ពត ផ្ទៀងផ្ទាត់ការសម្រាប់អនាគត* កំណត់ហេតុអង្គប្រជុំគណៈអចិន្ត្រៃយ៍៖ "គម្រោងផែនការ ៤ឆ្នាំ កសាងសង្គមនិយមគ្រប់ផ្នែករបស់ក្ស ឆ្នាំ១៩៧៧-១៩៨០" KH 00075867-00075917។

[3994] *សូមមើលឧទាហរណ៍* D6.1.749 ទង់បដិវត្ត ខែកុម្ភៈ-មីនា ឆ្នាំ១៩៧៦ KH 00063224។ ឯកសារ D6.1.542 ទង់បដិវត្ត ខែមិថុនា ឆ្នាំ១៩៧៧ KH 00062815-17។ ឯកសារ D322/8.1.31 ទង់បដិវត្ត ខែមីនា ឆ្នាំ១៩៧៨ KH 00064466។ ឯកសារ D6.1.743 ទង់បដិវត្ត ខែកក្កដា ឆ្នាំ១៩៧៨ KH 00064502-04។

[3995] *សូមមើលឧទាហរណ៍* ឯកសារ D6.1.800 ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរទេសការប្រមូលរបាយការណ៍សម្រាប់ខែមករា ឆ្នាំ១៩៧៦ *(សង្កត់ធ្ងន់លើតម្រូវការសម្រាប់ភាពត្រឹមត្រូវគ្រប់ជ្រុងជ្រោយ)* ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦ EN 00167833 [ពិភាក្សាពីភាបចាំបាច់នៃសន្សំសំចៃនៅតាមសហការណ៍ និងអង្គការបដិវត្តនីមួយៗ] *វិទ្យុផ្សាយសម្តែងសង្កត់ធ្ងន់ពីសារៈសំខាន់នៃការជ្រើសរើសគ្រាប់ពូជ* ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៧៦ KH 00657459-62។ ឯកសារ D6.1.809 ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន

1102. ទិដ្ឋភាពឧក្រិដ្ឋនៃគោលនយោបាយសេដ្ឋកិច្ចរបស់ ប.ក.ក. គឺស្ថិតនៅត្រង់របៀប ដែលមនុស្សត្រូវបានប្រព្រឹត្តដាក់ប្រៀបដូចជាទ្រព្យសម្បត្តិសេដ្ឋកិច្ច មិនមែនជាមនុស្ស។ ប.ក.ក. បានគ្រប់គ្រងគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរបស់ពួកគេ ដោយបដិសេធមិនផ្តល់ដល់អ្នកធ្វើការនូវសិទ្ធិមូលដ្ឋានទាំងអស់របស់ពួកគេ ដោយបង្ខំពួកគេឲ្យធ្វើការងារធ្ងន់ធ្ងរអស់រយៈពេលជាច្រើនម៉ោងដោយមិនមានប្រាក់ឈ្នួល នៅក្នុងស្ថានភាពដ៏អាក្រក់ និងបោសសម្អាតចោលអ្នកដែលគេគិតថាមិនមានប្រយោជន៍ដល់របៀបវារៈរបស់ ប.ក.ក. (“ទុកមិនចំណេញ ដកចេញមិនខាត”)[3996]។ ប.ក.ក. បានបង្ខំឲ្យប្រជាជនហូបរួមគ្នា បំបែកសមាជិកគ្រួសារ ផ្តល់អាហារមិនគ្រប់គ្រាន់ និងការថែរក្សាសុខភាពមិនសមស្រប បដិសេធសិទ្ធិសេរីភាពធ្វើដំណើរ សិទ្ធិសេរីភាពនៃគំនិត និងជំនឿសាសនា និងដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ចំពោះការប្រឆាំងនឹងការដាក់កំហិតនេះ[3997]។ អ្នកធ្វើការ មិនមានសិទ្ធិ និងមិនហ៊ានតវ៉ាឡើយ។ អ្នកណាម្នាក់ដែលតវ៉ា លួចអាហារ ទៅទីកន្លែងណាមួយ ដោយគ្មានការ

បរទេស៖ *បទអត្ថាធិប្បាយរបស់វិទ្យុផ្សាយសម្តែងអំពីកិច្ចការនយោបាយកសិកម្មឆ្នាំ១៩៧៨* ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៧ EN 00168429។ ឯកសារ D6.1.827 ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានបរទេស៖ *ផែនការបង្កើតសហករណ៍កម្រិតខ្ពស់នៅឆ្នាំ១៩៨០* ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៧៨ EN 00170069។

[3996] *សូមមើលឧទាហរណ៍* ឯកសារ D179/1.2.31 ដេវីដ ឆេនដ៍ល័រ ប្រតិចារឹក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 13.54.02 KH 00825105 [“ស៖តើលោកអាចរកឃើញអ្វីបន្ថែមទៀតទេ ដែលឃ្លាមួយនិយាយថា ‘ទុកក៏មិនចំនេញ ដកចេញក៏មិនខាត’ -- តើគេយកទៅអនុវត្តដែរឬទេ? បើសិនជាអនុវត្តក្នុងភាពជាក់ស្តែងនោះវាចេញជាផលវិបាកដូចម្តេច? ឆ៖គឺថាឃ្លានេះធ្វើឲ្យប្រជាជនមានភាពភ័យខ្លាច ឲ្យគេប្រឹងធ្វើការ គេតែងតែនិយាយជាញឹកញាប់ [...] ចង់និយាយថា៖ អ្នកឯងគ្មានតម្លៃទេ ប៉ុន្តែបើអ្នកឯងចង់នៅរស់ ធ្វើការឲ្យខ្លាំងទៅ។ហើយយើងនឹងសម្រេចថា តើអ្នកឯងត្រូវរស់ឬត្រូវស្លាប់ មួយថ្ងៃទៅមួយថ្ងៃ។ នេះហើយជាពាក្យស្ពោក [...] ទូទាំងប្រទេសដែលគេប្រើ ”]។

[3997] *សូមមើលឧទាហរណ៍* ឯកសារ D179/1.2.31 ដេវីដ ឆេនដ៍ល័រ ប្រតិចារឹក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 13.43.51-13.46.04 KH 00825102-03។ ឯកសារ D119/93 កំណត់ហេតុស្តាប់ចម្លើយ ចាន់ ផុន ឆ.៥-៦ KH 00976164 ឆ.២៦-២៧ KH 00976167-68។ ឯកសារ D193/462 កំណត់ហេតុស្តាប់ចម្លើយ ពេញ ចន្ថា ឆ.៨-៩ EN 01148860។ ឯកសារ D6.1.648 កំណត់ហេតុនៃការស្តាប់ចម្លើយ អ៊ុក ភន KH 00368659-61។ ឯកសារ D6.1.440 កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ ដី KH 00271398-00271401។ ឯកសារ D219/99 កំណត់ហេតុស្តាប់ចម្លើយខែត សុខន ឆ.៣៥ KH 01043273។ ឯកសារ D219/676 កំណត់ហេតុស្តាប់ចម្លើយ ហុក សារិន ឆ.៣៤-៣៥ KH 01202397។ ឯកសារ D219/836 កំណត់ហេតុស្តាប់ចម្លើយ ទូច ម៉ារី ឆ.២២-២៣ KH 01335557។ ឯកសារ D219/733 កំណត់ហេតុស្តាប់ចម្លើយ គឹម ផែន ឆ.៤៥ KH 01218099 ។ ឯកសារ D6.1.407 កំណត់ហេតុស្តាប់ចម្លើយ ឌី ហ្ស KH 00239910-11។ ឯកសារ D6.1.115 កំណត់ហេតុស្តាប់ចម្លើយ ជុច ពន្ធក KH 00221548-49។

អនុញ្ញាត ធ្វើឲ្យបាក់បែកឧបករណ៍ ធ្វើឲ្យបាក់ស្ពាបព្រា ឬប្រព្រឹត្ត "កំហុស" បែបណាមួយក៏ដោយ ត្រូវបានចាត់ទុកថាជាជនក្បត់បដិវត្តន៍ និងត្រូវដាក់ទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ឬត្រូវសម្លាប់[3998]។

1103. នៅឆ្នាំក្រោយៗមកទៀត មេដឹកនាំ ប.ក.ក. បានទទួលស្គាល់ថា ក្នុងអំឡុងរបបកម្ពុជាប្រជាធិប តេយ្យ ប្រជាជនកម្ពុជាត្រូវបានបង្ខំឲ្យធ្វើការ និង "ពុំមានសិទ្ធិសេរីភាព" នៅក្នុងសហករណ៍ នោះ ឡើយ[3999]។ ដោយមិនខ្វល់ពីផលវិបាកចំពោះមនុស្ស មេដឹកនាំបក្សបានកំណត់បរិមាណកូតា ផលិតកម្មខ្ពស់ដែលមិនអាចអនុវត្តបាន ដោយកំណត់គោលដៅបង្កើនផលិតផលស្រូវនៅទូទាំង ប្រទេសស្មើរតែចំនួនបីដង ដោយធៀបទៅនឹងផលិតផលស្រូវនៅក្នុងទសវត្សរ៍ ១៩៦០[4000]។

[3998] *សូមមើលឧទាហរណ៍* ឯកសារ D322/8.1.40 នួន ជា ប្រតិចារឹក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១១ ម៉ោង 10.34.28-10.36.17 KH 00760261-62 ["មានពួកសមាសភាពមិនល្អវាបំផ្លាញសហករណ៍អ៊ីវ៉ាន់ដែលដឹកយកទៅពីភ្នំពេញដូចជា [...] ចាន ស្ពាបព្រា ស្អីអស់នេះវាយកទៅចាក់ចោលទន្លេសាបឯនោះ។ ដូច្នេះ ធ្វើឲ្យប្រជាជនអត់មានចានហូបបាយអត់មានអីហូបបាយ "]។ ឯកសារ D219/888.1.8 ព្រាប សុឃៀន ប្រតិចារឹក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៦ ម៉ោង 15.23.10-15.26.50 KH 01365229-30។ ឯកសារ D219/972.2.2 សយ សែន ប្រតិចារឹក ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៥ ម៉ោង 14.00.42-14.03.26 KH 01408273-75 ។ ឯកសារ D315.3.4 អ៊ុង សារឿន ប្រតិចារឹក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ម៉ោង 09.33.57-09.37.30 KH 01468757-58។ ឯកសារ D315.3.1 ជ្ង គឹមឡន ប្រតិចារឹក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ម៉ោង 11.29.06-11.31.47 KH 01408899-00។ ឯកសារ D5/49/3.1 អ្រៀម យេន ប្រតិចារឹក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ ម៉ោង 09.18.27-09.21.26 KH 01086606-07។ ឯកសារ D6.1.721 កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ ឃុត ឆ.២៩ KH 00404645។ ឯកសារ D219/395 កំណត់ហេតុស្តាប់ចម្លើយ ចៀវ ហេង ឆ.២០ KH 01114704។

[3999] ឯកសារ D6.1.899 អ្រៀ ម៉េងទ្រី និង សូភ័ក្ត្រ លឿង កំណត់ត្រា (ខៀវ សំផន និង នួន ជា) ថ្ងៃទី៩-១១ ខែមិថុនា ឆ្នាំ២០០៦ KH 00347036-37។ ឯកសារ D6.1.1127 ឯកសារទី៦៖ ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយប្រមូលកម្លាំងរណសិរ្ស ប្រជាជាតិ ប្រជាធិបតេយ្យ របស់បក្ស ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072404 ["ពួកគេទៅជាពលករ។ [...] អ្វីៗទាំងអស់នៅលើយើង [...] យើងកសាងគេទៅបាន"]។ ឯកសារ D6.1.532 សៀវភៅនិពន្ធដោយ ខៀវ សំផន មានចំណងជើងថា៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា* KH 00498302-03 ["ដោយសារតែមានការចាត់តាំងសហករណ៍តាំងពីដើមឆ្នាំ១៩៧១ ទៅ ហើយ ទើប ប.ក.ក [...] ក្តាប់មនុស្សបាន [...] ដូច្នេះត្រូវមានការបង្ខំសិនហើយ។ គឺបង្ខំឲ្យធ្វើការនឿយហត់ក្នុងសភាពខ្វះសព្វ ខ្វះគ្រប់"]។

[4000] "គម្រោងផែនការ ៤ ឆ្នាំរបស់មក្ស" តម្រូវឲ្យបង្កបង្កើនផលស្រូវឲ្យបាន៥.៥ លានតោនក្នុងឆ្នាំ១៩៧៧, ៦.២៥ លានតោន ក្នុងឆ្នាំ១៩៧៨ និង៧ លានតោន ក្នុងឆ្នាំ១៩៧៩ ដែលកើនឡើងប្រហែលបីដងលើសពីផលស្រូវប្រចាំឆ្នាំជាមធ្យមក្នុងទសវត្សរ៍ទី ៦០។ *សូមមើល* ឯកសារ D1.3.31.1 ឯកសារបក្សកុម្មុយនីស្តកម្ពុជា៖ *គម្រោងផែនការ ៤ ឆ្នាំកសាងសង្គមនិយមគ្រប់ផ្នែករបស់ក្ស ឆ្នាំ១៩៧៧-១៩៨០* ដូចបានចុះផ្សាយក្នុងសៀវភៅនិពន្ធដោយដេវីដ ឆាណ្ឌ្លរ និងអ្នកដទៃទៀត *ប៉ុល ពតផ្ញើផែនការសម្រាប់អនាគត* KH 0075831-32។ ឯកសារ D117/36.1.11 សៀវភៅនិពន្ធដោយ Craig Etcheson មានចំណងជើងថា៖ *ការចាប់ផ្តើម និងការបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ* EN 00393208។ ទាក់ទងនឹងការជម្រុញផលិតកម្មកម្រិតខ្ពស់ *សូមមើល* ឯក

បរិមាណកូតាទាំងនេះ ត្រូវតែសម្រេចឲ្យបាន "ឲ្យខានតែបាន" និងតាមវិធីចាំបាច់ណាក៏ដោយ "ទោះបីជាជីវិតមនុស្សត្រូវបាត់បង់នៅពេលធ្វើការក៏ដោយ"[4001]។ ជាលទ្ធផល ការប្រព្រឹត្តអមនុស្ស ធម៌ ដោយរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានរាយការណ៍យ៉ាងទូលំទូលាយនៅក្នុងប្រព័ន្ធ ផ្សព្វផ្សាយអន្តរជាតិ និងក្នុងរបាយការណ៍របស់រដ្ឋាភិបាល[4002]។ មេដឹកនាំ ប.ក.ក. នៅថ្នាក់ផ្សេងៗ

សារ D6.1.747 យុវជន និងយុវនារី បដិវត្ត ខែកុម្ភៈ ឆ្នាំ១៩៧៦ KH 00063807-08 ["ធ្វើយ៉ាងណាបង្កើនផលស្រូវយើង មិនមែនឲ្យបានត្រឹមតែ ១ ហិកតា ៣ តោនប៉ុណ្ណោះទេ តែត្រូវឲ្យបាន ៤-៥-៦-៧-៨ តោនក្នុង១ហិកតាទៅទៀត។ ធ្វើការយ៉ាងនេះទើបហៅថា វាយសម្រុកដោយលឿនមហាលោតផ្លោះ"]។ ឯកសារ D1.3.19.1 *សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន* ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ KH 00003136 ["សំណូមពរ [២]៖ ដើម្បីតាមដានផែនការឲ្យជាប់ និងដោះស្រាយបញ្ហាឲ្យទាន់ពេលវេលា ក្នុងទិសដៅសម្រេច ៣តោន ១ហិកតា"]។ ឯកសារ D6.1.1148 *កំណត់ហេតុនៃការប្រជុំលេខា អនុលេខាកងពល និងវរៈសេនាធំ អំពីលទ្ធផលនៃការរៀនសូត្រ និងសេចក្តីសម្រេចចិត្តរបស់សន្និបាតកងពល* ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ១៩៧៦ KH 00052358-59 [លើកឡើងពីយុទ្ធសាស្ត្រសម្រេច ៣ តោន ១ហិកតា ឲ្យបានដាច់ខាត]។ ឯកសារ D6.1.1147 *កំណត់ហេតុប្រជុំការងារសង្គមកិច្ច សុខាភិបាល* ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ KH 0017155 [ថ្នាក់ដឹកនាំបក្សបញ្ជាក់ឡើងវិញថា លុះត្រាតែបាន៣ តោន ១ហិកតា ទើបយើងដោះស្រាយជីវភាពប្រជាជនបានគ្រប់គ្រាន់]។ ឯកសារ D6.1.750 ទង់បដិវត្ត ខែមេសា ឆ្នាំ១៩៧៦ KH 00062766-69។ ឯកសារ D6.1.1133 យុវជន និងយុវនារីបដិវត្ត ខែឧសភា ឆ្នាំ១៩៧៦ KH 00064005-09។ ឯកសារ D6.1.837 ឯកសារទី៣៖ *ពិនិត្យការក្តាប់ និងអនុវត្តមាគ៌ានយោបាយស្តារសេដ្ឋកិច្ច និងរៀបចំកសាងប្រទេសគ្រប់ផ្នែក* ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៧៥ KH 00072367, 00072374-76។

[4001] ឯកសារ D347/2.1.8 *មិទ្ធិញនៅក្រុងភ្នំពេញរំលឹកខួបទិវាជ័យជម្នះ១៧ មេសា* ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៨ KH 00679984-85 ["នៅក្នុងវិស័យស្តាបនាសង្គមនិយម [...] ព្យាយាមសម្រេចផែនការបង្កបង្កើនស្រូវឆ្នាំ១៩៧៨ ដោយការសម្រេចឲ្យបានទិន្នផលពី៣.៥ តោនក្នុងមួយហិចតា និង៧ តោន ក្នុងមួយហិចតា ទោះបីជាត្រូវចំណាយប៉ុន្មានក៏ដោយ"]។ ឯកសារ D6.1.1131 យុវជន និងយុវនារីបដិវត្ត ខែមករា-កុម្ភៈ ១៩៧៨ KH 00063511 ["យើងត្រូវតែប៉ានលះបង់ទាំងអស់ ទោះបីជាវាត្រូវការកម្លាំងកាយប៉ុណ្ណា កម្លាំងលះបង់ខាងសតិអារម្មណ៍ប៉ុណ្ណា ក៏ដោយ ឬក៏ត្រូវធ្វើពលីកម្មដល់អាយុជីវិតក៏ដោយ"]។

[4002] *សូមមើលឧទាហរណ៍* ឯកសារ D6.1.1099 ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ចអង្គការសហប្រជាតិ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៨ KH 00228732, 00228754, 00228757-58, 00228759-60, 00228761-65។ ឯកសារ D6.1.1231 អង្គការសហប្រជាជាតិ និងក្រុមប្រឹក្សាសង្គមកិច្ចប្រកាសអំពីសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៧៩ KH 00294951-53, 65-66, 69-72។ ឯកសារ D219/370.1.4 សារធ្វើតាមហិបទ្ធតស្តីពី៖ ជីវិតនៅក្នុងប្រទេសកម្ពុជា ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៦ KH 00709591។ ឯកសារ D6.1.894 អនុស្សរណៈរបស់ Brent SCOROFT ជូនចំពោះលោកប្រធានាធិបតី FORD ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧៦ KH 00826246-47, 52-53។ ឯកសារ D6.1.893 ទូរលេខស្ថានទូតអាមេរិកប្រចាំទីក្រុងបាងកកផ្ញើជូនរដ្ឋមន្ត្រីក្រសួងការបរទេស និងស្ថានទូតផ្សេងៗ៖ បណ្តាញព័ត៌មានរបស់បាងកក មានចំណងជើងថា *ជនភៀសខ្លួនខ្មែរបានដើរចេញពីទីក្រុងភ្នំពេញ* ឆ្នាំ១៩៧៥ KH 00658219-24។ ឯកសារ D6.1.947 សារព័ត៌មាន Chigago Tribune ៖ *ប្រជាជនខ្មែររត់ភៀសខ្លួនចេញពីខ្មែរក្រហមណ្ណានពាន*៖ វាចាស់ណាស់ថា "អ្នកខ្លះនឹងមិនរស់រានមានជីវិតទេ"។ ឯកសារ D6.1.953 សារព័ត៌មាន New York Times៖ *បទឧក្រិដ្ឋនៅប្រទេសកម្ពុជា*។ ឯកសារ D6.1.957 សារព័ត៌មាន Washington

គ្នាបានធ្វើទស្សនកិច្ចទៅកាន់ការដ្ឋានៈនានា[4003] ហើយកង្វះអាហារ និងជំងឺ ត្រូវបានទទួលស្គាល់នៅក្នុងកិច្ចប្រជុំនានា[4004] នៅក្នុងឯកសារបោះពុម្ពផ្សាយរបស់ ប.ក.ក.[4005] និងនៅក្នុងរបាយការណ៍បញ្ជូនទៅកាន់ថ្នាក់លើ[4006]។ ក៏ប៉ុន្តែ[4007] មជ្ឈិមបក្ស នៅតែផ្តោតទៅលើការនាំចេញស្រូវទៅកាន់

Post៖ *រឿងគួរឲ្យភ័យរន្ធត់មួយនៅកម្ពុជា*។ ឯកសារ D6.1.955 សារព័ត៌មាន New York Times៖ *ជនភៀសខ្លួនពណ៌នាពីប្រទេសកម្ពុជាដែលហ៊ុំព័ទ្ធដោយភាពអត់ឃ្លាន*។

[4003] *សូមមើលឧទាហរណ៍* ឯកសារ D1.3.24.1 កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥។ ឯកសារ D6.1.850 សរុបសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍ក្នុងអង្គប្រជុំ ថ្ងៃទី១៩-២០ ខែមេសា ឆ្នាំ១៩៧៦ KH 00019147-8។ ឯកសារ D6.1.1090 កំណត់ហេតុស្តាប់ចម្លើយសាក្សី រស់ ស៊ីយ KH 00172051-52។ ឯកសារ D6.1.1085 កំណត់ហេតុស្តាប់ចម្លើយសាក្សី ថា សុត KH 00204741-42។

[4004] *សូមមើលឧទាហរណ៍* ឯកសារ D1.3.24.1 កំណត់ហេតុអំពីទស្សនកិច្ចអចិន្ត្រៃយ៍នៅភូមិភាគពាយ័ព្យ ថ្ងៃទី២០-២៤ ខែសីហា ឆ្នាំ១៩៧៥ KH 00008485 ["កន្លែងស្រុកឆ្ងាយ នៅខ្វះខាតខ្លះដែរ។ ជំងឺថ្កាត់ក៏មានច្រើន។ ប្រជាជនថ្មីមានការខ្វះខាត ខ្វះស្បៀងផង ខ្វះថ្នាំសង្កូវផង"]។ ឯកសារ D6.1.1145 កំណត់ហេតុនៃអង្គប្រជុំគណៈរដ្ឋមន្ត្រីលើកទី២ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៧៦ KH 00000789-00000791។ ឯកសារ D6.1.1147 *កំណត់ហេតុប្រជុំការងារសង្គមកិច្ច សុខាភិបាល* ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៧៦ KH 0017155។

[4005] *សូមមើលឧទាហរណ៍* ឯកសារ D6.1.755 ទង់បដិវត្ត ខែធ្នូ ឆ្នាំ១៩៧៦-មករា ឆ្នាំ១៩៧៧ KH 00063008 ["ឆ្នាំ៧៦ នេះ យើងខ្វះស្បៀង ខ្វះថ្នាំសង្កូវ"]។ ឯកសារ D1.3.22.6 ទង់បដិវត្ត ខែឧសភា-មិថុនា ឆ្នាំ១៩៧៨ KH 00064571, 00064580-81។

[4006] *សូមមើលឧទាហរណ៍* ឯកសារ D1.3.30.2 ទូរលេខ ៩៤ ពី ពក (កែ ពក)៖ សូមគោរពជូនបង ប៉ុល ជាទីគោរព ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៧៦ KH 00000766។ ឯកសារ D6.1.1266 ទូរលេខ ១៤ ពី ភ្លង៖ ជម្រាបមន្ទីរ ៨៧០ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៧។ ឯកសារ D6.1.977 ទូរលេខពី ឡៅ ជូនបងជាទីគោរពអំពីស្ថានភាពខ្ទាំងនៅតំបន់១០១, ១០២, ១០៤ និង១០៧ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00021111 [រាយការណ៍ថា នៅក្នុងស្រុក២១ និងស្រុក២២ "ផលស្រូវមានការខ្វះខាត ទូទាត់ក្នុងតំបន់ មិនគ្រប់ហូបទេ" និងជំងឺរួមមាន៖ គ្រុនចាញ់ ឈឺពោះ នោមចេញឈាម កើតលឿង។ នៅក្នុងស្រុក៣៤ "នៅតឹង" សភាពការណ៍កង្វះខាតស្បៀងអាហារមានសភាពធ្ងន់ធ្ងរ ហើយជំងឺរួមមាន៖ គ្រុនក្តៅ រាកមួល ឈឺប្រកាច់។ នៅក្នុងស្រុក៨២ និងស្រុក ៨៣ ហូបបីនាក់មួយកំប៉ុងមួយពេល មនុស្សឃ្លង់កើនដល់ជាង១០០០ នាក់]។ ឯកសារ D6.1.1267 ទូរលេខ ២៥៤ ពី សៃ លេខាភូមិភាគឧត្តរ៖ គោរពជូនគណៈ៨៧០ ជាទីស្នេហា ចុះថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៨ KH 00001061-2 [រាយការណ៍អំពីខ្ទាំងបំផ្លាញការបង្កបង្កើនផលនៅក្នុងតំបន់១០៣ និងការអត់បាយនៅតំបន់ព្រះវិហារ បណ្តាលមកពីការបង្កបង្កើនផលបានតិច]។ ឯកសារ D6.1.770 កំណត់ហេតុកិច្ចប្រជុំយោធាកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ១៩៧៦ EN 00517911-13 [មេបញ្ជាការផ្សេងៗរាយការណ៍អំពីសភាពការណ៍នៅក្នុងអង្គភាពរបស់ពួកគេ ដូចជា សមមិត្ត អ៊ីន (កងពលលេខ១០៣) រាយការណ៍ថា មានអ្នកឈឺជាង៨០០ នាក់នៅក្នុងអង្គភាពរបស់គាត់។ អង្គការទទួលស្គាល់ថា យើងប្រើថ្នាំខ្លាំងហួសកម្រិត និងប្រើថ្នាំខុស]។ ឯកសារ D6.1.385 កំណត់ហេតុស្តាប់ចម្លើយសាក្សី ស៊ូ ស្ងឿន EN 00360113។

[4007] *សូមមើលឧទាហរណ៍* ឯកសារ D6.1.197, Ewa Tabeau និង They Kheam ជនរងគ្រោះនៃរបបខ្មែរក្រហម ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ KH 00499451 ["ទុក្ខវេទនាប្រចាំថ្ងៃ ដូចជា ជំងឺតម្កាត់ ការងារយ៉ាប់យ៉ឺន ការជម្លៀសដោយបង្ខំ កន្លែងរស់នៅមិនល្អ ការកង្វះម្ហូបអាហារ និងថ្នាំសង្កូវ [...] ។ល។ ទាំងអស់នេះបានបណ្តាលឲ្យប្រជាជនស្លាប់ច្រើនជាង

ពេលធម្មតា"]។ ឯកសារ D179/1.2.1 រម៉ាម ឃុន ប្រតិចារឹក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១២ ម៉ោង 14.47.16-14.51.40 KH 00766682 ["កូនក៏អត់មាន ស៊ីវាមិនផ្អែត ដូចយើងដែរ។ [...] អាហ្នឹងហើយអង្គការថ្នាក់លើ គណៈភូមិភាគ គណៈតំបន់ គណៈស្រុក គណៈខេត្ត គេថា អ្ហេ! មូលដ្ឋានស្រួលណាស់ ដឹកនាំស្រួលណាស់ អត់អីទេ! ស្រួលម៉េច! យើងនៅដល់ស្រុក ចុះក្រោមវាមិនស្រួលមិនម៉េច! ពេលកំពុងឡើងវាហាត់ចងងាប់ ភ្នំនោះ។ ដឹងដល់ ដឹងមិនដល់ យ៉ាងម៉េចវាមិនដល់"]។ ឯកសារ D179.1.2.31 ដេវីដ ឆាណ្ឌាល្ហ័រ ប្រតិចារឹក ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២ ម៉ោង 13.44.28-13.46.01 ["មានភ័ស្តុតាងជាច្រើនបង្ហាញថា ដើម្បីខិតចូលកាន់តែជិតគោលដៅ ពួកគេបានកាត់បន្ថយចំនួនស្រូវដែលត្រូវលៃទុកសម្រាប់ធ្វើពូជ និងសម្រាប់ការចិញ្ចឹមប្រជាជន ក្នុងបំណង ដើម្បីដឹកជញ្ជូនចំនួនឲ្យបានគ្រប់គ្រាន់ឡើងទៅលើ"]។ ឯកសារ D6.1.596 សៀវភៅនិពន្ធដោយដេវីដ ឆាណ្ឌាល្ហ័រ មានចំណងជើងថា៖ *បងធំទីមួយ* EN 00393031 ["ត្រឹមឆ្នាំ១៩៧៦ 'ប្រជាជនថ្មី' ភាគច្រើននៅក្នុងភូមិភាគពាយ័ព្យ មានកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ ស្ថានភាពនេះបានធ្លាក់ដុនដាបខ្លាំងនៅក្នុងឆ្នាំ១៩៧៧ ដែលពេលនោះប្រជាជនរាប់ពាន់នាក់បានស្លាប់ដោយការអត់អាហារ ខណៈដែលប្រជាជនរាប់ពាន់នាក់ទៀតបានបាត់បង់សមត្ថភាពធ្វើការ ដោយសារជំងឺតម្កាត់ និងការហូបចុកមិនគ្រប់គ្រាន់"]។

ប្រទេសដទៃទៀត ដើម្បីទទួលបានរូបិយប័ណ្ណបរទេស សម្រាប់ទិញគ្រឿងម៉ាស៊ីន និងអាវុធ[4008]។ នាពេលក្រោយមក ខៀវ សំផន បានសារភាពថា "ការដកហូតយកស្រូវពីប្រជាជនដើម្បីដឹកស្រូវទាំងនោះយកទៅឲ្យរដ្ឋ ដើម្បីបង្ក្រាប់តាមបរិមាណកំណត់ បាននាំឲ្យបាត់បង់ជីវិតមនុស្សជាច្រើន"[4009]។

គ. គោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ

1104. ដើម្បីសម្រួលដល់ការអនុវត្តគោលនយោបាយកសិកម្ម សេដ្ឋកិច្ច និងយោធារបស់ ប.ក.ក. តាមរយៈការបង្កើនចំនួនប្រជាជនឲ្យបានឆាប់រហ័ស សហឧក្រិដ្ឋកម្មរួមដែល **យ៉ាម ទិញ្ញ** បានចូលរួម មានពាក់ព័ន្ធនឹងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃអំពើអមនុស្សធម៌ផ្សេងៗទៀត តាមរយៈការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបង្ខំគូស្រករដែលត្រូវបានបង្ខំឲ្យរៀបការឲ្យរួមភេទដោយគ្មានការយល់ព្រមពីភាគីម្ខាង ឬភាគីទាំងពីរ (ការរំលោភផ្លូវភេទ)។

[4008] ឯកសារ D6.1.774 បទឧទ្ទេសនាមរបស់សមមិត្តលេខាក្នុងសម័យប្រជុំគណៈរដ្ឋមន្ត្រីលើកទី១ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៧៦ KH 00072757 ["យើងផ្តល់ជំនួយជាស្រូវ ៣០០០ តោន ឲ្យលាវទៀត ក្នុងលក្ខណៈដែលយើងទើបនឹងចេញពីសង្គ្រាមវិនាសកម្មផង"]។ ឯកសារ D1.3.31.1 *កំណត់ហេតុនៃអង្គប្រជុំគណៈអចិន្ត្រៃយ៍ស្តីអំពីគម្រោងផែនការ ៤ឆ្នាំ កសាងសង្គមនិយមគ្រប់ផ្នែក ឆ្នាំ១៩៧៧-១៩៨០* ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៧៦ ដូចបានបោះពុម្ពផ្សាយនៅក្នុងសៀវភៅរបស់ដេវីដ ឆាណ្ឌាល្ហ័រ និងអ្នកនិពន្ធដទៃទៀត *ប៉ុល ពត មានផែនការសម្រាប់អនាគត* EN 00104071 ["យើងត្រូវនាំចេញអង្ករចេញទៅក្រៅប្រទេសឲ្យបានច្រើន។ នៅក្នុងឆ្នាំ១៩៧៧ យើងមានផែនការនាំអង្ករចេញទៅក្រៅពី ៨០០,០០០ តោន ទៅ១,០០០,០០០ តោន"]។ ឯកសារ D6.1.754 ទង់បដិវត្ត ខែវិច្ឆិកា ឆ្នាំ១៩៧៦ KH 00064966 ["ស្រូវឆ្នាំ១៩៧៦ នេះ ចេញទៅក្រៅខ្ពង់សែនតោន។ ការដែលយើងនាំអង្ករទៅក្រៅបាន ក្រោយពេលសង្គ្រាមដូច្នេះ ជះឥទ្ធិពលសម្បើមណាស់នៅក្នុងសកលលោក"]។ ឯកសារ D6.1.772 សុន្ទរកថារបស់លោក ន្ហ ជា នៅក្នុងមេទិញខ្ជូបកងទ័ព ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៧ EN S00004076 ["ប្រជាជនយើងមានហូបគ្រប់គ្រាន់។ [...] យើងមានផលិតផលស្រូវលើសតម្រូវការ ចំនួន១៥០,០០០ តោន ដើម្បីនាំចេញ"]។ ឯកសារ D6.1.939 *សុន្ទរកថារបស់ ខៀវ សំផន នៅឯកិច្ចប្រជុំគម្រប់ខ្ជូប* ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៧ KH 00292805 ["ជាលទ្ធផល យើងបានប្រមូលផលដំណាំល្អសម្រាប់ឆ្នាំ១៩៧៧។ ឥឡូវនេះ យើងអាចចិញ្ចឹមប្រជាជនយើងតាមការបែងចែករបបអាហារបានគ្រប់គ្រាន់ពីរដ្ឋ។ យើងនៅសល់សម្រាប់នាំចេញទៀតផង"]។ ឯកសារD267.1.136 រស់ ស៊ីយ ប្រតិចារឹក ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៣ ម៉ោង 10.29.14-10.30.54 KH 00905469-70 ["កន្លងមក គឺសម្រាប់ជូនទៅប្រជាពលរដ្ឋដែលនៅតាមភូមិភាគ នៅតាមតំបន់ឥតមានទេ។ មានតែក្នុងស្រុកហ្នឹង [...] ហើយនិងនាំចេញ"]។ ឯកសារ D6.1.1105 សៀវភៅនិពន្ធដោយ Ben Kiernan មានចំណងជើងថា៖ *"របបប៉ុល ពត ពួជសាសន៍ អំណាច និងអំពើប្រល័យពួជសាសន៍* EN 00678692។ ឯកសារ D6.1.54 របាយការណ៍ដោយ Ben Kiernan មានចំណងជើងថា៖ *កម្ពុជា៖ ការសម្លាប់រង្គាលនៅភូមិភាគបូព៌ា* EN S00048799។ ឯកសារ D6.1.596 សៀវភៅនិពន្ធដោយដេវីដ ឆាណ្ឌាល្ហ័រ មានចំណងជើងថា៖ *បងធំទីមួយ* EN 00393031។

[4009] ឯកសារ D6.1.532 ខៀវ សំផន៖ *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ* EN 00498287។

1105. គោលនយោបាយរបស់ ប.ក.ក. ដើម្បីបង្កើនចំនួនប្រជាជនពីរដង ឬបីដង ដើម្បីឲ្យចំនួនប្រជាជនកើនទៅដល់ចំនួន ១៥ ទៅ ២០ លាននាក់ មានគោលដៅបង្កើតអ្នកធ្វើការ និងយោធា សម្រាប់ពេលអនាគត ដើម្បីធ្វើឲ្យប្រទេសមានចីរភាព[4010]។ ដើម្បីសម្រេចគោលដៅនេះ របបនោះបានបង្ខំមនុស្សរាប់ម៉ឺននាក់ឲ្យរៀបអាពាហ៍ពិពាហ៍ និងរួមភេទ ដែលជារឿយៗដោយគ្មានការយល់ព្រមពិតប្រាកដពីពួកគេនោះឡើយ។ ការគ្រប់គ្រងលើជម្រើសរបស់បុគ្គលថាតើរៀបការនៅពេលណា និងជាមួយអ្នកណា និងលើបូរណភាពរាងកាយ គឺជាឧទាហរណ៍បន្ថែមទៀតស្តីពីការអនុវត្តអំណាចជាម្ចាស់លើប្រជាជនដោយរបបកម្ពុជាប្រជាធិបតេយ្យ។ គោលនយោបាយនេះ និងការអនុវត្តរបស់វាត្រូវបានពិភាក្សាយ៉ាងលម្អិតនៅក្នុងផ្នែក *ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ* នៅក្នុងសារណានេះ[4011]។

ឃ. ការរំលោភផ្លូវភេទ និងអំពើហិង្សាផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ

1106. បន្ថែមពីលើការរំលោភផ្លូវភេទ នៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ភ័ស្តុតាងនៅក្នុងសំណុំរឿងនេះបង្ហាញថា ការរំលោភផ្លូវភេទ និងអំពើហិង្សាផ្លូវភេទដែលបានរាលដាល ក្រៅការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ បានកើតមានឡើងនៅក្នុងស្រុកបាកាន។ **យ៉ីម ទិត្យ** និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម ក៏ទទួលខុសត្រូវផងដែរចំពោះឧក្រិដ្ឋកម្មទាំងនេះ។ ទោះជាភ័ស្តុតាងមិនបានបញ្ជាក់ថា **យ៉ីម ទិត្យ** និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម មានចេតនាដោយផ្ទាល់ក្នុងការធ្វើឲ្យមានឧក្រិដ្ឋកម្មទាំងនេះក៏ដោយ ក៏ភ័ស្តុតាងនេះពិតជាបានបញ្ជាក់ថា ផែនការឧក្រិដ្ឋកម្មរួមមានជាប់ពាក់ព័ន្ធ និងជំរុញឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ហើយថា **យ៉ីម ទិត្យ** បានទទួលយកដោយខ្លួនគាត់នូវការពិតដែលថាឧក្រិដ្ឋកម្មទាំងនេះ ត្រូវបានប្រព្រឹត្ត និងបន្តជំរុញឲ្យមានផែនការឧក្រិដ្ឋកម្មរួម។

1107. នៅក្នុងសាលដីកាសំណុំរឿង ០០២/០១ របស់ខ្លួន អង្គជំនុំជម្រះតុលាការកំពូល (“SCC”) បានសម្រេចថា ផែនការឧក្រិដ្ឋកម្មរួម អាចពាក់ព័ន្ធ និងជំរុញឲ្យមានឧក្រិដ្ឋកម្មនានា ដែលមិនមែនជា

[4010] ឯកសារ D6.1.739 ទង់បដិវត្ត *ខែកញ្ញា ឆ្នាំ១៩៧៧* EN 00486262-63។ ឯកសារ D6.1.1257 សុន្ទរកថារបស់ អ៊ៀង សារី នៅក្នុងសម័យប្រជុំពេញអង្គលើទី២៨ នៃមហាសន្និបាតអង្គការសហប្រជាជាតិ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៧៧ កថាខណ្ឌ ៦០, ៦៣ KH 00291027, 00291028។ ឯកសារ D257/1/3.11 សុន្ទរកថារបស់ ប៉ុល ពត នៅក្នុងមីទ្ទิញពិភាក្សារបស់គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ជាមួយគណៈប្រតិភូសមាគមប៉ែលស៊ីក-កម្ពុជា ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៧៨ KH 00380472។

[4011] *សូមមើល* ផ្នែកទី **V**.ខ.៧. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – អាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្តវៈ។

គោលដៅចុងក្រោយ ឬជាបំណងយ៉ាងពិតប្រាកដរបស់សមាជិកសហឧក្រិដ្ឋកម្មរួម ប្រសិនបើ ភ័ស្តុតាងបង្ហាញថា ជនជាប់ចោទមានចេតនាចាំបាច់ក្នុងការបំពេញលក្ខខណ្ឌ*ធាតុផ្សំអត្តនោម័ត* សម្រាប់ឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់ទាំងនេះ[4012]។ ដូច្នេះ ជាឧទាហរណ៍ អង្គជំនុំជម្រះ តុលាការកំពូលយល់ឃើញថា ឧក្រិដ្ឋកម្មនៃការសម្លាប់រង្គាលត្រូវមានភ័ស្តុតាងបញ្ជាក់ថា ជនជាប់ ចោទមានចេតនាជាក់លាក់ក្នុងការសម្លាប់រង្គាលមនុស្សយ៉ាងច្រើន ហើយដូច្នេះ រាល់ការផ្តន្ទាទោស ក្រោមសហឧក្រិដ្ឋកម្មទី១ ត្រូវមានភ័ស្តុតាងបញ្ជាក់ថា ជនជាប់ចោទមានចេតនាដូច្នោះ[4013]។ ផ្ទុយ ទៅវិញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា សម្រាប់ឧក្រិដ្ឋកម្មដែល*ចេតនាប្រយោល*គឺជា ទម្រង់អាចទទួលយកបាននៃភ័ស្តុតាងបង្ហាញពីចេតនា ដូចជា ការធ្វើមនុស្សឃាត គេអាចបញ្ជាក់ បានថា ជនជាប់ចោទបានដឹងថា ឧក្រិដ្ឋកម្មនោះអាចកើតចេញពីផែនការឧក្រិដ្ឋកម្ម ប៉ុន្តែបានទទួល យកដោយខ្លួនគាត់នូវលទ្ធផលនោះ ព្រោះគាត់បានចូលរួមក្នុងផែនការនោះ[4014]។ ក្នុងការពិភាក្សាពី "ការជម្លៀសប្រជាជនចេញ" ពីទីក្រុងភ្នំពេញ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "គោលបំណងរួមនៃការផ្លាស់ទីលំនៅប្រជាជនចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទ [...] គឺជាប់ ពាក់ព័ន្ធទៅនឹងការស្លាប់របស់ជនស៊ីវិលដែលបណ្តាលមកពីលក្ខខណ្ឌនៃការជម្លៀសនោះ" ព្រោះ ជនជាប់ចោទ និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម "បានដឹងអំពីលក្ខខណ្ឌចំពោះអ្នកដែល ត្រូវជម្លៀស រួមទាំងអ្នកដែលងាយទទួលរងគ្រោះបំផុតនោះ នឹងត្រូវទទួលរងទុក្ខវេទនា និងជា

[4012]សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៣៨២-៤១០, ៨៥១-៨៦០ [យល់ ឃើញថា *ធាតុផ្សំអត្តនោម័ត* (*ចេតនាឧក្រិដ្ឋ*) នៃបទមនុស្សឃាត រួមបញ្ចូលទាំង*ចេតនាដោយប្រយោល* និងរកឃើញថា (i) ការ ស្លាប់ដោយសារលក្ខខណ្ឌផ្សេងៗ ក្នុងអំឡុងពេលការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ (ii) ការសម្លាប់ដោយចេតនានូវជន ស៊ីវិល ដែលប្រឆាំងនឹងបញ្ជាឲ្យជម្លៀសចេញ និង (iii) ការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបបលន់ នល់ ត្រូវបានស្រូប ចូលក្នុងផែនការឧក្រិដ្ឋកម្មរួម ពីព្រោះការស្លាប់ និងការសម្លាប់ទាំងនេះទំនងជាបានកើតឡើងក្នុងការអនុវត្តផែនការរួម ដើម្បី ជម្លៀសប្រជាជនចេញឲ្យអស់ពីទីក្រុង]។

[4013]សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៥០៩-៥២២។

[4014] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៣៨២-៤១០, ៨៥១-៨៦០ [យល់ ឃើញថា *ធាតុផ្សំអត្តនោម័ត* (*ចេតនាឧក្រិដ្ឋ*) នៃបទមនុស្សឃាត រួមបញ្ចូលទាំង*ចេតនាដោយប្រយោល* និងរកឃើញថា (i) ការ ស្លាប់ដោយសារលក្ខខណ្ឌផ្សេងៗ ក្នុងអំឡុងពេលការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ (ii) ការសម្លាប់ដោយចេតនានូវជន ស៊ីវិល ដែលប្រឆាំងនឹងបញ្ជាឲ្យជម្លៀសចេញ និង (iii) ការសម្លាប់អតីតទាហាន និងអ្នករដ្ឋការនៃរបប លន់ នល់ ត្រូវបានស្រូប ចូលក្នុងផែនការឧក្រិដ្ឋកម្មរួម ពីព្រោះការស្លាប់ និងការសម្លាប់ទាំងនេះទំនងជាបានកើតឡើងក្នុងការអនុវត្តផែនការរួម ដើម្បី ជម្លៀសប្រជាជនចេញឲ្យអស់ពីទីក្រុង]។

ពិសេសអ្នកដែលងាយទទួលរងគ្រោះបំផុត នឹងត្រូវស្លាប់ក្នុងអំឡុងពេលនៃការជម្លៀសនោះ"[4015]។ ដូចគ្នានេះដែរ សូម្បីតែក្នុងករណីគ្មានភ័ស្តុតាងចេញបញ្ជាឲ្យសម្លាប់អ្នករស់នៅក្នុងទីក្រុង ដែលប្រឆាំងនឹងបញ្ជាជម្លៀសចេញក្តី ក៏គោលបំណងឧក្រិដ្ឋកម្មរួម "បានបង្ហាញឲ្យឃើញដោយប្រយោលថា [...] បានរួមបញ្ចូលការរំពឹងទុកនូវការប្រើប្រាស់អំពើហិង្សាដែលបណ្តាលឲ្យស្លាប់" ព្រោះ "មានភ័ស្តុតាងបង្ហាញថា កងកម្លាំងដែលបានទទួលភារកិច្ចអនុវត្តការជម្លៀសប្រជាជនចេញពីទីក្រុង ទំនងជាប្រើអំពើហិង្សាដែលបណ្តាលឲ្យស្លាប់ ប្រសិនបើមានចេតនារឹងរូស។ នេះពុំជាប់ពាក់ព័ន្ធទៅនឹងបញ្ហាថាតើមានបទបញ្ជាជាក់លាក់ឲ្យសម្លាប់ [និង] អ្នកណាជាអ្នកដាក់បទបញ្ជាឡើយ"[4016]។ អង្គជំនុំជម្រះតុលាការកំពូល បានចេញសេចក្តីសន្និដ្ឋានស្រដៀងគ្នាមួយពាក់ព័ន្ធនឹងការសម្លាប់ទាហាននៃរបបសាធារណរដ្ឋខ្មែ*រដែលបាត់បង់សមត្ថភាពប្រយុទ្ធ*ៈ អំពើមនុស្សឃាតទាំងនោះរួមបញ្ចូលនៅក្នុងផែនការឧក្រិដ្ឋកម្មរួម ទោះបីជាគ្មានគោលនយោបាយបញ្ជាឲ្យសម្លាប់ក្តី ព្រោះការកាប់សម្លាប់ទាំងនេះទំនងជាកើតឡើង ក្នុងកាលៈទេសៈជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ [4017]។

1108. ភ័ស្តុតាងបង្ហាញថា **យ៉ីម ទិញ្ញ** និងអ្នកក្រោមបង្គាប់របស់គាត់ដែលជាសមាជិកសហឧក្រិដ្ឋកម្មរួម មានចេតនាផ្ទាល់ក្នុងការដកហូតការការពារផ្លូវច្បាប់គ្រប់បែបយ៉ាងចេញពីជនរងគ្រោះ និងដាក់ឲ្យពួកគេប្រឈមនឹងប្រព័ន្ធអំណាចតាមទំនើងចិត្ត និងដាច់ខាតលើមនុស្សរបស់ខ្លួន។ ក្រៅពីនេះ ពួកគេបានជំរុញគ្នាទៅវិញទៅមក និងអ្នកក្រោមបង្គាប់របស់ខ្លួនឲ្យចាត់ទុក "ខ្មាំង" ជាមនុស្សជាន់ទាបដែលគ្មានសិទ្ធិអ្វីទាំងអស់ និងមិនចាំបាច់ពិចារណាអ្វីឡើយ។ ការបង្កើតភាពងាយរងគ្រោះ និងផ្នត់គំនិតនេះ ជាកត្តាដ៏សំខាន់ក្នុងការសម្រេចបានគោលដៅផែនការឧក្រិដ្ឋកម្មរួម ព្រោះថាបើសិនជាគ្មានការលុបបំបាត់ទាំងស្រុងនូវការការពារផ្លូវច្បាប់ និងបើសិនជាគ្មានការចាត់តាំងអំណាចកំណត់ឲ្យរស់ និងស្លាប់តាមទំនើងចិត្ត ទៅឲ្យកម្មាភិបាលថ្នាក់ក្រោម កងទ័ព និងកងឈ្លបទេនោះ គោលដៅនៃគោលនយោបាយកម្ទេចខ្មាំង គោលនយោបាយនៃការធ្វើឲ្យទៅជាទាសករ និងគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ នឹងមិនអាចសម្រេចបានឡើយ។

1109. ក្នុងការបង្កើតភាពងាយរងគ្រោះនេះលើជនរងគ្រោះរបស់ពួកគេ **យ៉ីម ទិញ្ញ** និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម បានដឹងថា យ៉ាងហោចណាស់កម្មាភិបាលថ្នាក់ក្រោម កងទ័ព និងកងឈ្លប

[4015] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨៥៣ (បន្ថែមការសង្កត់ន័យ)។
[4016] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨៥៧ (បន្ថែមការសង្កត់ន័យ)។
[4017] សំណុំរឿងលេខ ០០២ ឯកសារ F36 សាលដីកាក្នុងសំណុំរឿងលេខ ០០២/០១ កថាខណ្ឌ ៨៦០ (បន្ថែមការសង្កត់ន័យ)។

មួយចំនួនដែលទទួលបានអំណាចតាមទំនើងចិត្តលើប្រជាជនទន់ខ្សោយ នឹងបំពានលើមុខតំណែងដែលមានអំណាចរបស់ខ្លួនដើម្បីប្រព្រឹត្តការរំលោភផ្លូវភេទ និងបទឧក្រិដ្ឋផ្លូវភេទផ្សេងទៀត។ ការបំពាននេះពិតជាមិនអាចគេចផុតបានឡើយក្នុងប្រព័ន្ធអំណាចតាមទំនើងចិត្ត ដោយគ្មានការការពារផ្លូវច្បាប់ ដូចជាប្រព័ន្ធដែលសមាជិកសហឧក្រិដ្ឋកម្មរួម បានបង្កើតឡើង ហើយប្រជាជនគ្រប់ប្រភេទត្រូវបានចាត់ទុកជា "ខ្មាំង" ដែលគួរ "ត្រូវបានកម្ទេច" ដោយគ្មានដំណើរការនីតិវិធីច្បាប់។ នៅពេលឧក្រិដ្ឋកម្ម ដូចជា ការធ្វើឲ្យទៅជាទាសករ ការធ្វើទារុណកម្ម និងការធ្វើមនុស្សឃាត ត្រូវបានដាក់ទណ្ឌកម្មក្នុងផ្នែកនៃផែនការឧក្រិដ្ឋកម្ម វានឹងបង្ហាញច្បាស់ដល់អ្នកពាក់ព័ន្ធទាំងអស់ថា ការប្រព្រឹត្តអំពើហិង្សាផ្លូវភេទ រួមទាំងការរំលោភផ្លូវភេទ នឹងត្រូវបានធ្វើឡើងលើសមាជិករបស់ក្រុមគោលដៅ ទោះបីជាគ្មានការអនុញ្ញាតច្បាស់លាស់លើឧក្រិដ្ឋកម្មទាំងនោះក្តី។ តាមពិត ភ័ស្តុតាងបង្ហាញថា កម្មាភិបាលមួយចំនួន រួមទាំងអ្នកក្រោមបង្គាប់មួយចំនួនរបស់ **យ៉ីម ទិត្យ** បានទទួលរបាយការណ៍ស្តីពីការកើតមានអំពើហិង្សាផ្លូវភេទ តាមរយៈរចនាសម្ព័ន្ធអំណាចផ្តាច់ការរបស់ ប.ក.ក[4018]។

1110. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ដើម្បីដាក់ឲ្យជនជាប់ចោទទទួលខុសត្រូវ ក្រោមសហឧក្រិដ្ឋកម្មរួមក្នុងផែនការឧក្រិដ្ឋកម្មនេះ ជនជាប់ចោទត្រូវមានទម្រង់នៃចេតនាចាំបាច់សម្រាប់ឧក្រិដ្ឋកម្មនោះ។ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការរំលោភផ្លូវភេទ ឬទម្រង់ផ្សេងៗទៀតនៃអំពើហិង្សាផ្លូវភេទ សុទ្ធតែជាចេតនាឧក្រិដ្ឋកម្មទូទៅ ហើយ*ចេតនាប្រយោល* បានបំពេញនូវ*ធាតុផ្សំអត្តនោម័ត* ដើម្បីបញ្ជាក់ថា ឧក្រិដ្ឋកម្មនេះធ្វើឡើងដោយចេតនា[4019]។ **យ៉ីម ទិត្យ** និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមបានដឹងថា ការរំលោភផ្លូវភេទ និងអំពើហិង្សាផ្លូវភេទអាចកើតចេញពីផែនការឧក្រិដ្ឋកម្មរបស់ពួកគេ[4020] (តាមពិត ហេតុការណ៍ទាំងនេះគឺជាលទ្ធផលដែលមិនអាចចៀសផុតបានពីផែនការនេះ) ប៉ុន្តែ **យ៉ីម ទិត្យ** និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម

[4018] *សូមមើល* ផ្នែកទី **V**.ខ.៥.ង. ឧក្រិដ្ឋកម្ម – ភូមិភាគពាយ័ព្យ – តំបន់២ – អំពើហិង្សាផ្លូវភេទនៅក្នុងស្រុកបាកាន។

[4019] *សូមមើល* ផ្នែកទី VI.ក.១.ខ.ii. អង្គច្បាប់ – គោលការណ៍ច្បាប់ដែលពាក់ព័ន្ធ – ឧក្រិដ្ឋកម្ម – ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ – បទល្មើសជាក់លាក់ – អំពើអមនុស្សធម៌ផ្សេងទៀត។ ផ្នែកទី VI.ក.១.ក.i. អង្គច្បាប់ - គោលការណ៍ច្បាប់ពាក់ព័ន្ធ – ទម្រង់នៃការទទួលខុសត្រូវ – បានប្រព្រឹត្ត – ការប្រព្រឹត្តដោយផ្ទាល់។ ផ្នែកទី VI.ក.២.ក.ii. អង្គច្បាប់ - គោលការណ៍ច្បាប់ពាក់ព័ន្ធ – ទម្រង់នៃការទទួលខុសត្រូវ – បានប្រព្រឹត្ត – សហឧក្រិដ្ឋកម្មរួម – បំណងឧក្រិដ្ឋ។

[4020] ទាក់ទងនឹងអំពើរំលោភសេពសន្ថវៈ: ការយល់ដឹងនេះរាប់បញ្ចូលការដឹងអំពីកាលៈទេសៈបង្ខិតបង្ខំ ដែលក្នុងនោះសកម្មភាពផ្លូវភេទ នឹងប្រព្រឹត្តទៅ និងការយល់ដឹងថា កាលៈទេសៈបង្ខិតបង្ខំទាំងនេះនឹងបំផ្លាញនូវលទ្ធភាពនៃការព្រមព្រៀងពិតប្រាកដចំពោះសកម្មភាពផ្លូវភេទនោះ។

បានទទួលយកដោយខ្លួនឯងនូវលទ្ធផលនោះ និងបន្តជំរុញឲ្យមានផែនការឧក្រិដ្ឋកម្មនោះ។ ដូច្នេះ **យ៉ីម ទិញ** ទទួលខុសត្រូវលើការរំលោភផ្លូវភេទ និងទម្រង់ផ្សេងទៀតនៃអំពើហិង្សាផ្លូវភេទដែលបានកើតឡើង ហើយអំពើទាំងនេះបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត។

ង. *ធាតុផ្សំអត្តនោម័ត* អំឡុងពេល សមាជិកភាព និងការចូលរួមចំណែក

1111. **យ៉ីម ទិញ** និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម មានចេតនាដោយផ្ទាល់ក្នុងការធ្វើឲ្យមានឧក្រិដ្ឋកម្មដែលបានពិភាក្សាក្នុងដីកាសន្និដ្ឋាននេះ លើកលែងតែការរំលោភផ្លូវភេទ និងអំពើហិង្សាផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ពាក់ព័ន្ធនឹងការរំលោភផ្លូវភេទ និងអំពើហិង្សាផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ **យ៉ីម ទិញ** និងសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម មាន*ធាតុផ្សំអត្តនោម័ត*ចាំបាច់ ព្រោះភ័ស្តុតាងបញ្ជាក់ថា ពួកគេមាន*ចេតនាប្រយោល*។ ឧក្រិដ្ឋកម្មទាំងអស់ដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ ត្រូវបានប្រព្រឹត្តឡើងទៅតាមសហឧក្រិដ្ឋកម្មរួមនេះ។

1112. **យ៉ីម ទិញ** បានក្លាយជាសមាជិកសហឧក្រិដ្ឋកម្មរួមនេះនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងនៅតែបន្តសមាជិកភាព យ៉ាងហោចណាស់រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

1113. **យ៉ីម ទិញ** បានប្រព្រឹត្តឧក្រិដ្ឋកម្មរួមគ្នាជាមួយសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម។ សមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួមរួមមាន ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន សមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិម តា ម៉ុក ដែលជាលេខាភូមិភាគនិរតី និងក្រោយមកជាលេខាភូមិភាគពាយ័ព្យ វ៉ាន អ៊ែម ហៅ សារុន ដែលជាសមាជិកគណៈភូមិភាគ ពាយ័ព្យជាមួយ **យ៉ីម ទិញ** និង តាម៉ុក និងលេខាតំបន់ ២ និងតំបន់ ៧ រស់ ញ៉ឹម ដែលជាលេខាភូមិភាគពាយ័ព្យមុន តា ម៉ុក, គង់ សុផល ហៅ តាកើ អនុលេខាភូមិភាគពាយ័ព្យរបស់ រស់ ញ៉ឹមអ្នកក្រោមបង្គាប់របស់ តា ម៉ុក ក្នុងជួរកងទ័ព និងកងកម្លាំងសន្តិសុខរបស់ភូមិភាគនិរតី និងភូមិភាគពាយ័ព្យ លេខាទាំងអស់ អនុលេខា និងសមាជិកគណៈស្រុក និងគណៈតំបន់ក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដែលបម្រើការងារនៅអំឡុងពេលផ្សេងៗ និងប្រភេទទាំងអស់នៃអ្នកក្រោមបង្គាប់ផ្ទាល់ និង

ដោយប្រយោលផ្សេងទៀតរបស់ **យ៉ីម ទិញ**[4021]។ ក្រុមប្រភេទនេះរួមមាន មេភូមិ និងមេឃុំក្នុងស្រុកគិរីវង់នៅអំឡុងពេលដែល **យ៉ីម ទិញ** មានតួនាទីជាអនុលេខា ឬលេខានៅទីនោះ មេភូមិ និងមេឃុំទាំងអស់នៅតំបន់ ១៣ នៅអំឡុងពេលដែល **យ៉ីម ទិញ** មានតួនាទីជាអនុលេខា និងលេខាតំបន់ ១៣ និងមេភូមិ និងមេឃុំទាំងអស់ក្នុងភូមិភាគនិរតីនៅអំឡុងពេលដែល **យ៉ីម ទិញ** មានតួនាទីជាមេដឹកនាំ*ភាមព្រ៊ីត្តន័យ* ឬផ្នូរការនៅភូមិភាគពាយ័ព្យ[4022]។ កម្មាភិបាលដែលទទួលខុសត្រូវលើផ្នែកសន្តិសុខ កងឈ្លប និងកងទ័ពនៅគ្រប់តំបន់ដែលស្ថិតក្រោមការគ្រប់គ្រង ឬឥទ្ធិពលរបស់ **យ៉ីម ទិញ** គឺជាសមាជិកសហឧក្រិដ្ឋកម្មរួម ឬត្រូវបានប្រើប្រាស់ដោយសមាជិកសហឧក្រិដ្ឋកម្មរួមក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្ម។ ដូចគ្នានេះដែរ សមាជិកកងទ័ព ប.ក.ក កងឈ្លបភូមិភាគ តំបន់ ស្រុក និងឃុំ ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះផ្ទាល់ គឺជាផ្នែកនៃសហឧក្រិដ្ឋកម្មរួម ឬត្រូវបានប្រើប្រាស់ដោយសមាជិកនៃផែនការឧក្រិដ្ឋកម្ម ដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះដែរ។

1114. សមាជិកភាពរបស់ **យ៉ីម ទិញ** ក្នុងសហឧក្រិដ្ឋកម្មរួមត្រូវបានបង្ហាញតាមរយៈការចូលរួមចំណែក និងចេតនារបស់គាត់ក្នុងការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនេះ មុខតំណែងដែលមានអំណាច និងឥទ្ធិពលរបស់គាត់ក្នុង ប.ក.ក និងទំនាក់ទំនងការងារដ៏ជិតស្និទ្ធរបស់គាត់ជាមួយសមាជិកដទៃទៀតនៃសហឧក្រិដ្ឋកម្មរួម។ ការពាក់ព័ន្ធរបស់គាត់បានចាប់ផ្តើមនៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងបានបន្តរហូតដល់យ៉ាងហោចណាស់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។

1115. **យ៉ីម ទិញ** បានចូលរួមចំណែកយ៉ាងច្រើនក្នុងសហឧក្រិដ្ឋកម្មរួមតាមរយៈអំពើខាងក្រោម ៖

ក. ក្នុងតួនាទីរបស់គាត់ជាលេខាស្រុកគិរីវង់ ការធ្វើជាប្រធានអង្គប្រជុំដែលគាត់បានផ្តោលទោសអតីតមន្ត្រីរដ្ឋការលន់ នល់ ម្នាក់ដែលជាប់ខ្នោះ ថាជាជនក្បត់ និងបានបញ្ជាឲ្យមន្ត្រីនោះកំណត់រកអតីតមន្ត្រីរដ្ឋការលន់ នល់ ផ្សេងទៀត[4023]។

[4021] ដោយមិនកំណត់ព្រំដែននៃភាពទូទៅរបស់ប្រភេទនេះ សមាជិកមួយចំនួននៃសហឧក្រិដ្ឋកម្មរួមនៅក្នុងប្រភេទខាងលើ អាចត្រូវបានរកឃើញនៅក្នុងផ្នែកទី IV. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទងរបស់ ប.ក.ក។

[4022] ដោយមិនកំណត់ព្រំដែននៃភាពទូទៅរបស់ប្រភេទនេះ សមាជិកមួយចំនួននៃសហឧក្រិដ្ឋកម្មរួមនៅក្នុងប្រភេទខាងលើ អាចត្រូវបានរកឃើញនៅក្នុងផ្នែកទី IV. រចនាសម្ព័ន្ធអំណាច និងការប្រាស្រ័យទាក់ទងរបស់ ប.ក.ក។

[4023] *សូមមើល* កថាខណ្ឌ ១៥។

ខ. ក្នុងកិច្ចប្រជុំកាលពីចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ ការបញ្ជាក់ថា ប្រជាជនដែលត្រូវបានជម្លៀសចេញពីក្រុងភ្នំពេញ និងអ្នកដែលសាច់ញាតិរបស់ពួកគេបានធ្វើការក្នុងរដ្ឋបាលលន់ នល់ គឺជាខ្មាំង[4024]។

គ. ក្នុងកិច្ចប្រជុំរបស់កងសិប្បកម្មស្រុកគិរីវង់ ការព្រមានកម្មករថា ពួកគេត្រូវប្រឹងប្រែងធ្វើការ ហើយនរណាក៏អាចបាត់ខ្លួនបានគ្រប់ពេលដែរ[4025]។

ឃ. ក្នុងកិច្ចប្រជុំផ្សេងៗ ការពិភាក្សាពី "ខ្មែរយួន" ដែលបង្ក្រាបខ្លួនក្នុងបណ្តាញ ប.ក.ក និងបានណែនាំ និងជំរុញឲ្យអ្នកចូលរួមត្រូវត្រួតពិនិត្យមនុស្សទាំងនេះដោយប្រុងប្រយ័ត្ន និងត្រូវរាយការណ៍ទៅពួកគេតាមរយៈរចនាសម្ព័ន្ធ ប.ក.ក[4026]។

ង. ការចូលរួមក្នុងតួនាទីដឹកនាំជាន់ខ្ពស់ក្នុងកិច្ចប្រជុំដែល តា សោម (លេខាតំបន់ ១៣) កំណត់ថា សេអ៊ីអា និង ការ៉ាហ្ស្យេ គឺជាខ្មាំង ហើយ សេអ៊ីអា ស្នើនឹងសមាសភាពអ្នករស់នៅទីក្រុង ចំណែកការ៉ាហ្ស្យេ ស្នើសមាសភាពខ្មែរក្រោម[4027]។

ច. ការចូលរួមជាប្រចាំក្នុងកិច្ចប្រជុំជាមួយតំណាងរបស់ឃុំទាំង ៩ ក្នុងស្រុកគិរីវង់ ដែលគាត់បានបញ្ជាឲ្យកម្មាភិបាលថ្នាក់ឃុំរាយការណ៍ពីខ្មាំង (រួមទាំងកម្មករដែលនិយាយថា ពួកគេមានជំងឺ) ទៅថ្នាក់ស្រុក[4028]។

ឆ. ការចុះជាប្រចាំទៅមន្ទីរសន្តិសុខវត្តព្រះធាតុ ជាទីដែល "ខ្មាំង" ដែលរងការចោទប្រកាន់រាប់រយនាក់ ត្រូវបានដាក់ក្នុងមន្ទីរឃុំឃាំង និងត្រូវបានសម្លាប់ក្រៅប្រព័ន្ធតុលាការ និងការផ្តល់ព័ត៌មានទៅប្រធានមន្ទីរសន្តិសុខដែលជាអ្នកក្រោមបង្គាប់របស់គាត់[4029]។

ជ. ការត្រួតពិនិត្យដោយផ្ទាល់លើអ្នកទោសដែលត្រូវបានឃុំខ្លួននៅវត្តព្រះធាតុ[4030]។

[4024] *សូមមើល* កថាខណ្ឌ ១៦។

[4025] *សូមមើល* កថាខណ្ឌ ១៨។

[4026] *សូមមើល* កថាខណ្ឌ ២០-២១។

[4027] *សូមមើល* កថាខណ្ឌ ២៣-២៦។

[4028] *សូមមើល* កថាខណ្ឌ ២៧។

[4029] *សូមមើល* កថាខណ្ឌ ៣២។

[4030] *សូមមើល* កថាខណ្ឌ ៣២។

ឈ. ការសួរចម្លើយដោយផ្ទាល់លើអ្នកទោសនៅវត្តព្រះធាតុ ដើម្បីជាវិធីប៉ុនប៉ងកំណត់រកខ្ទាំងដែលគួរឲ្យសង្ស័យបន្ថែមទៀត[4031]។

ញ. ការយកបញ្ជាមកអនុវត្តការសម្លាប់ក្រៅប្រព័ន្ធតុលាការលើអ្នកទោសនៅវត្តព្រះធាតុ[4032]។

ដ. ការមានវត្តមានផ្ទាល់នៅវត្តព្រះធាតុ នៅពេលអ្នកទោសត្រូវបានសម្លាប់ និងវះយកប្រមាត់ រួចយកប្រមាត់ទាំងនោះទៅតាមខ្លួន[4033]។

ឋ. ការបញ្ជាឲ្យមានការសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការលើប្រជាជនប្រហែល ២០០ នាក់ ដូចជា គ្រូបង្រៀន សិស្សនិស្សិត បញ្ញវន្ត និងអ្នកដែលសង្ស័យថា បានរៀបចំផែនការរត់គេចខ្លួនទៅប្រទេសវៀតណាម ក្នុងឃុំវាមអណ្តើក[4034]។

ឌ. នៅអំឡុងពេលដែលគាត់កាន់មុខតំណែងជាលេខាតំបន់ ១៣ ការបញ្ជាឲ្យប្រធានមន្ទីរសន្តិសុខស្រុកត្រាំកក់ធ្វើការចាប់ខ្លួនក្រៅប្រព័ន្ធតុលាការ[4035]។

ឍ. ជាញឹកញាប់ ការធ្វើសេចក្តីថ្លែងការណ៍ដល់អ្នកក្រោមការគ្រប់គ្រងរបស់គាត់នៅភូមិភាគនិរតីដោយបង្គាប់ឲ្យពួកគេរៀបការ មានកូន និងជ្រើសរើសកងទ័ពថ្មីសម្រាប់របបនេះ[4036]។

ណ. ការណែនាំដល់កម្មាភិបាលក្នុងកិច្ចប្រជុំធំៗថា ពួកគេត្រូវ "កម្ទេចរាល់សមាសភាពខ្ទាំងដែលប្រឆាំងនឹងអង្គការ"[4037]។

[4031] *សូមមើល* កថាខណ្ឌ ៣២។

[4032] *សូមមើល* កថាខណ្ឌ ៣៣។

[4033] *សូមមើល* កថាខណ្ឌ ៣៣។

[4034] *សូមមើល* កថាខណ្ឌ ៣៤។

[4035] *សូមមើល* កថាខណ្ឌ ៣៥។

[4036] *សូមមើល* កថាខណ្ឌ ៣៧។

[4037] *សូមមើល* កថាខណ្ឌ ៥២។

ត. ការណែនាំដល់កម្មាភិបាលក្នុងកិច្ចប្រជុំធំៗថា ពួកគេត្រូវ "ប្រុងប្រយ័ត្នចំពោះខ្មាំង" ដែលបង្កប់ខ្លួនក្នុងអង្គភាពរបស់ពួកគេ ហើយពួកគេត្រូវធ្វើការអប់រំឡើងវិញ និងប្រសិនបើចាំបាច់សម្លាប់ខ្មាំងទាំងនោះ[4038]។

ថ. ការប្រាប់ឲ្យអ្នកចូលរួមក្នុងកិច្ចប្រជុំធំមួយនៅទំនប់កង្គតថា ពួកគេត្រូវឃ្លាំមើលខ្មាំងផ្ទៃក្នុង "ដែលបង្កប់ខ្លួនក្នុងចលនារបស់យើង" និងរាយការណ៍ពីខ្មាំងទាំងនោះ "ទៅអង្គការថ្នាក់លើ ដើម្បីឲ្យអង្គការអាចកម្ទេចពួកគេ មុនពេលពួកគេកម្ទេចយើងវិញ"[4039]។

ទ. ក្នុងកិច្ចប្រជុំដូចគ្នា ការកត់ត្រាដោយស្ងៀមស្ងាត់នៅពេលមេឃុំម្នាក់រាយការណ៍ថា អ្នកដែលត្រូវបានចាប់ខ្លួនដោយសារការប្រព្រឹត្តខុសសីលធម៌ នឹងត្រូវបានសម្លាប់ ពោលគឺគាត់គាំទ្រដល់ការអនុវត្តដូច្នេះ[4040]។

ធ. ការប្រាប់កម្មាភិបាលក្នុងកិច្ចប្រជុំធំមួយនៅវត្តភ្នំសំពៅថា ប្រសិនបើពួកគេមើលឃើញ "សកម្មភាពរបស់ខ្មាំង" ពួកគេត្រូវ "នាំយកមនុស្សទាំងនោះទៅអប់រំឡើងវិញ មុនពេលយើងកម្ទេចពួកគេ និងរាយការណ៍ទៅថ្នាក់លើ"[4041]។

ន. ក្នុងកិច្ចប្រជុំធំមួយទៀត ការចាត់ទុកអ្នកលួចដំឡូង ល្មៅ ឬចេក ថាជា ខ្មាំងស៊ីរួងផ្ទៃក្នុង" និងការបញ្ជាឲ្យរាយការណ៍ពីពួកគេ និងការបញ្ជាក់ថា អ្នកដែលមិនបានរាយការណ៍ពីអំពើទាំងនេះនឹងត្រូវបានចាត់ទុកជាខ្មាំង[4042]។

ប. ក្នុងកិច្ចប្រជុំធំមួយនៅវត្តបាយដំរ៉ា ការណែនាំឲ្យអ្នកចូលរួមមិនត្រូវកាត់នឹងការដឹកនាំរបស់ក្រុមភូមិភាគនិរតី និងការសាកសួរពីភ្នាក់ងារ សេអ៊ីអា និង យួន និងខ្មាំងស៊ីរួងផ្ទៃក្នុងដែលជាអាយ៉ងយួន[4043]។

[4038] *សូមមើល* កថាខណ្ឌ ៥៣។

[4039] *សូមមើល* កថាខណ្ឌ ៥៦។

[4040] *សូមមើល* កថាខណ្ឌ ៥៧។

[4041] *សូមមើល* កថាខណ្ឌ ៥៩។

[4042] *សូមមើល* កថាខណ្ឌ ៦០។

[4043] *សូមមើល* កថាខណ្ឌ ៦១។

ផ. ការប្រាប់កម្មករមួយក្រុមធំនៅស្រុកមោងឫស្សីថា មានការឃ្លាំមើលការងារ និងផលិតកម្ម របស់ពួកគេ ហើយពួកគេ "គួរប្រុងប្រយ័ត្នចំពោះ" ខ្លួនឯង[4044]។

ព. ក្នុងកិច្ចប្រជុំមួយផ្សេងទៀត ការណែនាំឲ្យអ្នកចូលរួម "តាមដានសមាសភាពមិនល្អ" និង រាយការណ៍ពីអ្នកដែល "ចាត់វិធានការមិនទៀងទាត់" ទៅថ្នាក់ស្រុក[4045]។

ភ. ក្នុងកិច្ចប្រជុំតទល់មួយជាមួយ មួល អិន ដែលជាលេខាស្រុកបវេល ការណែនាំឲ្យគាត់ "រាំង ស្កាត់ខ្លាំង" ដែល មួល អិន យល់ថា អ្នកណាដែល "ប្រឆាំង ក្បត់ មិនពេញចិត្ត ឬមិនបាន បំពេញការងារទៅតាមផែនការ" គឺជាខ្លាំង ហើយថា "នរណាម្នាក់ដែលមិនបានបំពេញ ការងារទៅតាមផែនការ នឹងត្រូវបានសម្លាប់[4046]។

ម. ក្នុងកិច្ចប្រជុំមួយនៅទំនប់កង្ហត ការប្រកាសជាសាធារណៈថា តា ការ ត្រូវបានចាប់ខ្លួន និង យកទៅសម្លាប់ ចំណែក តា ប៉ែត ត្រូវបានចាប់ខ្លួន ដោយសារបុរសទាំងពីរនាក់នេះគឺជា "ជនក្បត់"[4047]។

យ. ការបញ្ជាឲ្យទាហានស្រុកគាស់ក្រឡ ឬកម្មាភិបាលសន្តិសុខឈ្មោះ អាន និង ប៉ក់ ធ្វើការ សម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការលើមនុស្សរាប់ពាន់នាក់ ដែលត្រូវបានគេចាត់ទុកថាជា ខ្លាំង នៅឆ្នាំ១៩៧៦ និង ១៩៧៧ ដូចជា ជនជាតិវៀតណាម និងអ្នកដែលត្រូវបានសង្ស័យថា ស្មោះត្រង់នឹង សេអ៊ីអា[4048]។

រ. ការបញ្ជាឲ្យកម្មាភិបាលឈ្មោះ តា សាម៉ន ចាប់ខ្លួនមនុស្សមួយចំនួនទៅដាក់ក្នុងមន្ទីរឃុំឃាំង នៅគុកខ្ទងគោ[4049]។

[4044] *សូមមើល* កថាខណ្ឌ ៦២។

[4045] *សូមមើលខាងលើ* កថាខណ្ឌ ៦៣។

[4046] *សូមមើល* កថាខណ្ឌ ៦៤។

[4047] *សូមមើល* កថាខណ្ឌ ៦៥។

[4048] *សូមមើល* កថាខណ្ឌ ៦៩-៧០។

[4049] *សូមមើល* កថាខណ្ឌ ៧១។

ល. ការបញ្ជាឲ្យមានការសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ លើអ្នកទោសទាំងអស់ដែលនៅសេសសល់ក្នុងមន្ទីរឃុំឃាំងវត្តបាយដំរាមនៅខែធ្នូ ឆ្នាំ១៩៧៨[4050]។

រ. ការបញ្ជាឲ្យមានការសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ លើក្រុមកងទ័ពមកពីភូមិភាគពាយ័ព្យដែលត្រូវបានសង្ស័យថា បះបោរប្រឆាំងនឹងអាជ្ញាធរភូមិភាគនិរតី និងការសម្លាប់ជនស៊ីវិល[4051]។

ស. ការបញ្ជាឲ្យមានការសម្លាប់មនុស្សក្រៅប្រព័ន្ធតុលាការ លើសិស្សនិស្សិត កម្មកររោងចក្រ ជនជាតិចិន និងជនជាតិវៀតណាមរាប់ពាន់នាក់ នៅជំរំតារអាន ក្នុងស្រុកព្រះនេត្រព្រះ[4052]។

ហ. ការចុះទៅមន្ទីរសន្តិសុខចកកកោះ និងមន្ទីរសន្តិសុខគាស់ក្រឡ[4053]។

ឡ. ការប្រើប្រាស់រោហារសាស្ត្រយ៉ាងសាហាវបំផុត ប្រឆាំងនឹងជនជាតិវៀតណាមក្នុងអំឡុងពេលពាក់ព័ន្ធនឹងករណីនេះ ដូចជា ការផ្ដែងពីគោលនយោបាយរបស់ ប.ក.ក ក្នុងការ "បោសសម្អាតខ្មាំងយួន" ក្នុងកិច្ចប្រជុំធំមួយនៅទំនប់កង្ហត[4054]។

អ. ការពិគ្រោះយោបល់ជាមួយ តា ម៉ុក មុនពេលរៀបចំពិធីអាពាហ៍ពិពាហ៍ដោយបង្ខំដ៏ធំមួយក្នុងភូមិភាគនិរតី និងក្រោយពិធីនេះ ការណែនាំឲ្យគូស្វាមីភរិយា "ស្រឡាញ់គ្នាទៅវិញទៅមក" និង "ធ្វើទៅតាមអ្វីដែលអង្គការបានរៀបចំឲ្យ" ដែលស្នើនឹងការណែនាំឲ្យគូស្វាមីភរិយាថ្មីត្រូវរួមដំណេកជាមួយគ្នា[4055]។

កក. ការគំរាមកំហែងយ៉ាងច្បាស់លើកម្មករក្នុងទម្រង់ជាការសម្លាប់ ឬការបាត់ខ្លួន ប្រសិនបើពួកគេមិនសម្រេចបានគោលដៅកសិកម្ម ឬគោលដៅផលិតកម្មផ្សេងទៀត ហើយវាបានបង្ក

[4050] *សូមមើល* កថាខណ្ឌ ៧១។

[4051] *សូមមើល* កថាខណ្ឌ ៧២។

[4052] *សូមមើល* កថាខណ្ឌ ៧៣។

[4053] *សូមមើល* កថាខណ្ឌ ៧៤។

[4054] *សូមមើល* កថាខណ្ឌ ៧៦-៨១។

[4055] *សូមមើល* កថាខណ្ឌ ៨២-៨៤។

បរិយាកាសភ័យខ្លាចដែលចាំបាច់សម្រាប់ការបំពេញមុខងារនៃប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ច របស់កម្ពុជាប្រជាធិបតេយ្យ[4056]។

ខខ. ការគំរាមកំហែងដោយប្រយោលចំពោះកម្មករក្នុងទម្រង់ជាព្យសនកម្ម ប្រសិនបើពួកគេមិន សម្រេចបានគោលដៅនានា ដោយពិភាក្សាពីការវាយប្រហារខ្លាំងក្នុងកិច្ចប្រជុំដូចគ្នាដែល គាត់បានកំណត់គោលដៅផលិតកម្ម និងជំរុញឲ្យកម្មករប្រឹងប្រែងធ្វើការបន្ថែម ហើយវាបាន បង្កភាពភ័យខ្លាច ដែលចាំបាច់សម្រាប់ការបំពេញមុខងារនៃប្រព័ន្ធកសិកម្ម និងសេដ្ឋកិច្ច របស់កម្ពុជាប្រជាធិបតេយ្យ[4057]។

គគ. ការព្រមានកម្មករថា ពួកគេស្ថិតក្រោមការឃ្លាំមើល ហើយកម្រិតផលិតកម្មរបស់ពួកគេត្រូវ បានពិនិត្យតាមដាន[4058]។

ឃឃ.ការណែនាំឲ្យ ណុប ង៉ីម ដែលជាអ្នកក្រោមបង្គាប់របស់គាត់ តាមដានកម្មករដែលប្រឹងប្រែង ធ្វើការ និងកម្មករដែលមិនប្រឹងប្រែងធ្វើការ[4059]។

ងង. ការកំណត់គោលដៅផលិតកម្មដែលគ្មានភាពជាក់ស្តែង និងការជំរុញឲ្យកម្មករប្រឹងប្រែងធ្វើ ការ ទោះបីជាមានលក្ខខណ្ឌអមនុស្សធម៌នៅការដ្ឋានក្តី[4060]។

ចច. ការត្រួតពិនិត្យការដ្ឋាន ដើម្បីធានាការអនុវត្តតាមផែនការផលិតកម្មរបស់គាត់[4061]។

ឆឆ. ក្នុងបរិបទឧក្រិដ្ឋកម្មទាំងនេះ និងគោលនយោបាយរបស់ ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ ការបំពេញមុខងារប្រកបដោយឆន្ទៈក្នុងនាមជាអនុលេខាស្រុកគិរីវង់ លេខាស្រុកគិរីវង់ អនុ លេខាតំបន់ ១៣ លេខាតំបន់ ១៣ លេខាតំបន់ ១ និងអនុលេខាភូមិភាគពាយ័ព្យ[4062] និង

[4056] *សូមមើល* កថាខណ្ឌ ៨៧។

[4057] *សូមមើល* កថាខណ្ឌ ៨៧។

[4058] *សូមមើល* កថាខណ្ឌ ៨៨។

[4059] *សូមមើល* កថាខណ្ឌ ៨៨។

[4060] *សូមមើល* កថាខណ្ឌ ៩៣។

[4061] *សូមមើល* កថាខណ្ឌ ៩៤។

[4062] *សូមមើល* កថាខណ្ឌ ១០, ៤៥។

ជជ. ក្នុងបរិបទឧក្រិដ្ឋកម្មទាំងនេះ និងគោលនយោបាយរបស់ ប.ក.ក និងរបបកម្ពុជាប្រជាធិបតេយ្យ ការបំពេញមុខងារប្រកបដោយឆន្ទៈ ក្នុងនាមជាមេដឹកនាំ*ភាគព្រ៊ីត្តន័យ* ដ៏សំខាន់ក្នុងភូមិភាគពាយ័ព្យ[4063]។

1116. ក្រៅពីមានការចូលរួមចំណែកយ៉ាងច្រើនក្នុងផែនការឧក្រិដ្ឋកម្មរួម អំពើ និងការប្រព្រឹត្តរបស់ **យ៉ឹម ទិត្យ** ដែលមានរៀបរាប់ខាងលើ ក៏បង្ហាញផងដែរថា គាត់ពាក់ព័ន្ធ និងមានចេតនាបន្តជំរុញផែនការឧក្រិដ្ឋកម្មរួម និងមានចេតនាដែលធ្វើឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗក្នុងផែនការឧក្រិដ្ឋកម្មរួម។

1117. អង្គហេតុខាងក្រោមបានផ្តល់ភ័ស្តុតាងបន្ថែមទៀតស្តីពីចេតនារបស់ **យ៉ឹម ទិត្យ** ក្នុងការចូលរួមចំណែកយ៉ាងសំខាន់ក្នុងផែនការឧក្រិដ្ឋកម្មរួម ចេតនារបស់គាត់ ដែលធ្វើឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មនីមួយៗដែលរងការចោទប្រកាន់ និងការដឹងឮរបស់គាត់អំពីការប្រព្រឹត្តឧក្រិដ្ឋកម្ម៖

ក. ការពិតដែលការផ្ទេរកម្មាភិបាលភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ គឺសម្រាប់គោលបំណងច្បាស់លាស់នៃការកម្ចាត់សមាសធាតុក្បត់ក្នុងភូមិភាគពាយ័ព្យ[4064]។

ខ. ការត្រួតពិនិត្យជាប្រចាំរបស់ **យ៉ឹម ទិត្យ** នៅការដ្ឋានក្នុងតំបន់ដែលគាត់ទទួលខុសត្រូវ[4065]។

គ. ការពិភាក្សាជាប្រចាំរបស់ **យ៉ឹម ទិត្យ** អំពី "ទិន្នន័យនានា ដូចជា អត្រាមរណប្រមាណ និងអត្រាកំណើត និងផលិតកម្មសន្ទូងក្នុងឃុំនីមួយៗ" ជាមួយអ្នកក្រោមបង្គាប់របស់គាត់[4066]។

ឃ. ការទទួលបានជាប្រចាំនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរប្រចាំខែដោយ **យ៉ឹម ទិត្យ** ពីអ្នកក្រោមបង្គាប់របស់គាត់ ពាក់ព័ន្ធនឹងប្រជាជន ជំងឺ ការរកបានសម្លៀកបំពាក់ និងអាហារ និងទំនាស់ក្នុងចំណោមប្រជាជន[4067]។

[4063] *សូមមើល* កថាខណ្ឌ ៤៨-៤៩។

[4064] *សូមមើល* កថាខណ្ឌ ៤២។

[4065] *សូមមើល* កថាខណ្ឌ ៩៤។

[4066] *សូមមើល* កថាខណ្ឌ ៩៤។

[4067] *សូមមើល* កថាខណ្ឌ ១០៤។

ង. ការត្រួតពិនិត្យផ្ទាល់ដោយ **យ៉ាម ទិត្យ** លើបណ្តាស្រុកដែលគាត់គ្រប់គ្រង[4068] និង

ច. ការទទួលបានព័ត៌មានដោយ **យ៉ាម ទិត្យ** ស្តីពីរចនាសម្ព័ន្ធភូមិភាគពាយ័ព្យពីតា ប៉ែត និងតា សាម៉ន[4069]។

២. ការរៀបចំផែនការ ការញុះញង់ ការបញ្ជា និងការជួយនិងជំរុញឲ្យប្រព្រឹត្ត

1118. ក្រៅពីការទទួលខុសត្រូវរបស់គាត់ចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលរងការចោទប្រកាន់ *តាមរយៈ* សហឧក្រិដ្ឋកម្មរួម **យ៉ាម ទិត្យ** ក៏ទទួលខុសត្រូវផងដែរលើការរៀបចំ ការញុះញង់ ការបញ្ជា និងការជួយនិងជំរុញឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មដែលរងការចោទប្រកាន់។ គាត់មានចេតនាក្នុងការធ្វើឲ្យមានឧក្រិដ្ឋកម្មនីមួយៗ និងបានដឹងពីភវនីយហេតុដ៏សំខាន់ថា ឧក្រិដ្ឋកម្មទាំងនោះនឹងត្រូវបានប្រព្រឹត្តក្នុងការអនុវត្តផែនការរួម ហើយចំណុចនីមួយៗសុទ្ធតែបំពេញលក្ខខណ្ឌ*ធាតុផ្សំអត្តនោម័ត*សម្រាប់ការរៀបចំផែនការ ការញុះញង់ និងការបញ្ជា។ ក្រៅពីនេះ គាត់បានធ្វើសកម្មភាពផ្សេងៗដោយចេតនាដែលធ្វើឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ ក៏ដូចជាដឹងថា សកម្មភាពទាំងនេះធ្វើឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ដូច្នេះ ចំណុចនេះបំពេញលក្ខខណ្ឌ*ធាតុផ្សំអត្តនោម័ត*នៃការ ជួយនិងជំរុញ។

1119. **យ៉ាម ទិត្យ** បានរៀបចំផែនការឧក្រិដ្ឋកម្មដែលត្រូវបានរៀបរាប់ក្នុងដីកាសន្និដ្ឋាននេះ។ ផ្អែកតាមតួនាទីរបស់គាត់នៅថ្នាក់ស្រុក តំបន់ និងភូមិភាគ **យ៉ាម ទិត្យ** មានអំណាចរៀបចំ និង/ឬចូលរួមក្នុងការរៀបចំរបៀបអនុវត្តគោលនយោបាយរបស់ ប.ក.ក ក្នុងតំបន់ទាំងនោះ។ ការពាក់ព័ន្ធរបស់គាត់ក្នុងការរៀបចំ និងបង្កើតការអនុវត្តគោលនយោបាយជាតិរបស់ ប.ក.ក នៅថ្នាក់តំបន់ បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ **យ៉ាម ទិត្យ** មានចេតនាក្នុងការធ្វើឲ្យមានឧក្រិដ្ឋកម្មទាំងនោះ ហើយតាមរយៈតួនាទី និងមុខតំណែងរបស់គាត់ **យ៉ាម ទិត្យ** បានដឹងពីភវនីយហេតុដ៏សំខាន់ថា នឹងមានការប្រព្រឹត្តឧក្រិដ្ឋកម្មតាមរយៈការអនុវត្តសកម្មភាពដែលគាត់បានចូលរួមក្នុងការរៀបចំផែនការ។

1120. **យ៉ាម ទិត្យ** បានញុះញង់ឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលបានរៀបរាប់ខាងលើ។ តាមរយៈមុខតំណែងរបស់គាត់ **យ៉ាម ទិត្យ** បានបំផុស ជំរុញ ញុះញង់ និងលើកទឹកចិត្តចារីដែលប្រព្រឹត្តឧក្រិដ្ឋ

[4068] *សូមមើល* កថាខណ្ឌ ១០៨។

[4069] *សូមមើល* កថាខណ្ឌ ១០១-១០២។

កម្មទាំងនេះ។ ការញុះញង់របស់គាត់ដែលធ្វើឲ្យមានឧក្រិដ្ឋកម្ម បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ការលើកឡើងញឹកញាប់របស់ **យ៉ីម ទិញ្ញ** ស្តីពីគោលនយោបាយរបស់ ប.ក.ក ដល់កម្មាភិបាលថ្នាក់ក្រោម បង្ហាញថា គាត់មានចេតនាញុះញង់ឲ្យចារីផ្ទាល់ប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ និងបានដឹងពីភាពនឿយហេតុដ៏សំខាន់ថា នឹងមានការប្រព្រឹត្តឧក្រិដ្ឋកម្មក្នុងការអនុវត្តសកម្មភាពដែលគាត់ញុះញង់។

1121. **យ៉ីម ទិញ្ញ** បានបញ្ជាឲ្យមានការប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានរៀបរាប់លម្អិតក្នុងដីកាសន្និដ្ឋាននេះ។ យោងតាមមុខតំណែងដែលមានអំណាច **យ៉ីម ទិញ្ញ** បានដាក់ និងចេញបញ្ជា និងការណែនាំទៅកម្មាភិបាល ប.ក.ក ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ **យ៉ីម ទិញ្ញ** មានចេតនាបំផុសអ្នកស្ថិតក្រោមអំណាច*តាមព្រឹត្តន័យ* និង/ឬ*តាមនីតិន័យ*របស់គាត់ ឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម និងបានដឹងពីភាពនឿយហេតុដ៏សំខាន់ថា នឹងមានការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះក្នុងការអនុវត្តបទបញ្ជា។ ផ្អែកតាមវចនា សម្ព័ន្ធរបស់ ប.ក.ក **យ៉ីម ទិញ្ញ** ដឹងថា គាត់មានអំណាចជំរុញឲ្យកម្មាភិបាលថ្នាក់ក្រោមធ្វើសកម្មភាព។

1122. **យ៉ីម ទិញ្ញ** បានជួយនិងជំរុញឧក្រិដ្ឋកម្មទាំងនេះ។ គាត់បានផ្តល់ការលើកទឹកចិត្ត កម្លាំងចិត្ត និងជំនួយជាក់ស្តែងដល់កម្មាភិបាល ប.ក.ក ដែលប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ ការលើកទឹកចិត្ត ការផ្តល់កម្លាំងចិត្ត និងជំនួយជាក់ស្តែងបានជះឥទ្ធិពលយ៉ាងខ្លាំងលើការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ។ **យ៉ីម ទិញ្ញ** បានដឹងតាមរយៈមុខតំណែងដែលមានអំណាចរបស់គាត់ និងវចនាសម្ព័ន្ធរបស់ ប.ក.ក ថា ការលើកទឹកចិត្ត ការផ្តល់កម្លាំងចិត្ត និងជំនួយជាក់ស្តែង បានជួយដល់ការប្រព្រឹត្តឧក្រិដ្ឋកម្មទាំងនេះ និងមានចេតនាផ្តល់ជំនួយទាំងនោះ។ **យ៉ីម ទិញ្ញ** បានដឹងពីធាតុផ្សំសំខាន់ៗនៃឧក្រិដ្ឋកម្មដែលគាត់ជួយនិងជំរុញ ព្រោះគាត់ទទួលបានព័ត៌មានជាប្រចាំស្តីពីសកម្មភាពរបស់ចារីផ្ទាល់។

៣. ការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ

1123. លើសពីនេះ **យ៉ីម ទិញ្ញ** មានការទទួលខុសត្រូវលើឧក្រិដ្ឋកម្មនីមួយៗក្នុងនាមជាថ្នាក់លើយោងតាមមាត្រ ២៩*ថ្មី* នៃច្បាប់ អ.វ.ត.ក ដោយផ្អែកតាម៖ (១) មុខតំណែងរបស់គាត់ក្នុងនាមជាថ្នាក់លើរបស់ចារីឧក្រិដ្ឋកម្ម ដែលមានរៀបរាប់លម្អិតក្នុងដីកាសន្និដ្ឋាននេះ (២) ការដឹងឮ ឬការទទួលបានព័ត៌មានដែលគាត់មានហេតុផលដឹងថា អ្នកក្រោមបង្គាប់របស់គាត់បានប្រព្រឹត្ត ឬនឹងប្រព្រឹត្តឧក្រិដ្ឋកម្ម និង (៣) ការខកខានរបស់គាត់ក្នុងការទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចារី។

1124. មានទំនាក់ទំនងថ្នាក់លើ-អ្នកក្រោមបង្គាប់រវាង **យ៉ីម ទិត្យ** និងកម្លាភិបាល ប.ក.ក ដែលពាក់ព័ន្ធផ្ទាល់ក្នុងឧក្រិដ្ឋកម្មដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានេះ។ ខណៈដែលទំនាក់ទំនងមួយចំនួនអាចមានលក្ខណៈដោយប្រយោល ឬ*តាមព្រឹត្តន័យ* **យ៉ីម ទិត្យ** គឺជាថ្នាក់លើរបស់បុគ្គលទាំងនេះ ដោយសារដែលការគ្រប់គ្រងដោយប្រសិទ្ធភាពរបស់គាត់ លើពួកគេក្នុងនាមជាមេដឹកនាំថ្នាក់ស្រុក ថ្នាក់តំបន់ ថ្នាក់ភូមិភាគ និងមេដឹកនាំ*តាមព្រឹត្តន័យ*។ **យ៉ីម ទិត្យ** មានលទ្ធភាពសំខាន់ក្នុងការរារាំងអ្នកក្រោមបង្គាប់របស់គាត់មិនឲ្យប្រព្រឹត្តឧក្រិដ្ឋកម្ម ដកពួកគេចេញពីមុខតំណែង និង/ឬដាក់ទណ្ឌកម្មពួកគេ។ **យ៉ីម ទិត្យ** បានដឹងពីឧក្រិដ្ឋកម្មដែលកំពុងត្រូវបានប្រព្រឹត្ត ដោយអ្នកក្រោមបង្គាប់របស់គាត់ តាមរយៈតួនាទីរបស់គាត់ក្នុងការបង្កើតការអនុវត្តគោលនយោបាយ ប.ក.ក នៅថ្នាក់តំបន់ ដែលធ្វើឲ្យមានឧក្រិដ្ឋកម្ម និងរបាយការណ៍ញឹកញាប់ដែលគាត់ទទួលបានពាក់ព័ន្ធនឹងព្រឹត្តិការណ៍ដែលបានកើតឡើងក្នុងតំបន់ដែលគាត់កាន់កាប់។ **យ៉ីម ទិត្យ** មិនបានចាត់វិធានការណាមួយដើម្បីទប់ស្កាត់ ឬដាក់ទណ្ឌកម្មឧក្រិដ្ឋកម្មទាំងនេះឡើយ ទោះបីជាគាត់មានលទ្ធភាពក្តី។

IX. យុត្តាធិការផ្ទៃកបុគ្គល

1125. សំណុំរឿងនេះបញ្ជាក់ថា **យ៉ីម ទិត្យ** គឺជា "មេដឹកនាំជាន់ខ្ពស់" នៃ ក.ប.ប ហើយក៏ជាមនុស្សម្នាក់ក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" លើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយរបបនេះ។ កត្តាពាក់ព័ន្ធនានាក្នុងការកំណត់ថា តើជនសង្ស័យម្នាក់ ឬជនត្រូវចោទម្នាក់ គឺជាអ្នកដែលស្ថិតក្នុងចំណោមអ្នកទាំងឡាយណាដែលស្ថិតក្នុងយុត្តាធិការផ្ទៃកបុគ្គលរបស់ អ.វ.ត.ក ឬយ៉ាងណានោះ ត្រូវបានពិភាក្សាដូចខាងក្រោម។ ភ័ស្តុតាងដែលបង្ហាញពីមុខតំណែង និងការចូលរួមចំណែករបស់ **យ៉ីម ទិត្យ** ចំពោះឧក្រិដ្ឋកម្ម មានបង្ហាញជូនលម្អិតនៅទូទាំងដីកាសន្និដ្ឋានេះ ជាពិសេសក្នុងផ្ទៃកដែលមានចំណងជើងថា *មុខតំណែង អំពើ និងការប្រព្រឹត្តរបស់* ***យ៉ីម ទិត្យ***[4070]។

[4070] *សូមមើល* ផ្នែកទី III. តំណែង អំពើ និងការប្រព្រឹត្តរបស់ យ៉ីម ទិត្យ។ ដើម្បីចៀសវាងការបង្ហាញជាថ្មីដែលមិនចាំបាច់ ភ័ស្តុតាងជាមូលដ្ឋានដែលកំណត់ពីតំណែង និងការចូលរួមចំណែករបស់ យ៉ីម ទិត្យ ចំពោះឧក្រិដ្ឋកម្ម នឹងមិនត្រូវបានបញ្ជាក់ឡើងវិញនៅទីនេះទេ។

ក. ការអនុវត្តកត្តាពាក់ព័ន្ធ

១. មេដឹកនាំជាន់ខ្ពស់

1126. **យ៉ីម ទិញ** គឺជាអ្នកដែលស្ថិតក្នុងចំណោមកម្មាភិបាលដែលមានឥទ្ធិពលបំផុតក្នុង ប.ក.ក ដោយកាន់កាប់មុខតំណែងថ្នាក់ខ្ពស់មួយចំនួននៅក្នុងភូមិភាគចំនួនពីរ។ តួនាទីខ្ពស់បំផុតរបស់ **យ៉ីម ទិញ** គឺជាអនុលេខា*ភាមទីពិនិត្យ* នៃភូមិភាគពាយ័ព្យ និងជាលេខា*ភាមព្រឹត្តន័យ* នៃភូមិភាគនេះ នៅពេលដែល តា ម៉ុក មិននៅ។ មុនពេលក្លាយជាឥស្សរជនថ្នាក់ដឹកនាំមួយរូបនៅកម្រិតភូមិភាគ **យ៉ីម ទិញ** មានអំណាចខ្លាំងរួចទៅហើយ ក្នុងតំបន់មួយចំនួននៃភូមិភាគពាយ័ព្យ។ បន្ថែមលើមុខតំណែងជាលេខាតំបន់ ១ សាក្សីបានលើកឡើងថា គាត់គឺជាលេខាភូមិភាគ ២ ភូមិភាគ ៣ និង ៤។

1127. **យ៉ីម ទិញ** ក៏បានអនុវត្តអំណាចយ៉ាងខ្លាំងក្នុងភូមិភាគនិរតី។ **យ៉ីម ទិញ** គឺជាលេខាតំបន់ ១៣ នៃភូមិភាគនិរតី និងស្រុកគីរីវង់ ដែលជាទីតាំងកើតមានឧក្រិដ្ឋកម្មដ៏គួរឲ្យខ្ពាចនានា រួមទាំងឧក្រិដ្ឋកម្មនៅវត្តព្រះធាតុ និងមន្ទីរសន្តិសុខក្រាំងតាចាន់។ **យ៉ីម ទិញ** កន្លងមកមានមុខតំណែងជាអនុលេខាតំបន់ ១៣ ព្រមទាំងជាអនុលេខា និងលេខាស្រុកគីរីវង់ផងដែរ។

1128. តាមរយៈមុខតំណែងថ្នាក់ខ្ពស់របស់គាត់នៅឋានានុក្រមរបស់ ប.ក.ក **យ៉ីម ទិញ** បានអនុវត្តផែនការឧក្រិដ្ឋកម្មរួមយ៉ាងយង់ឃ្នង។ គាត់បានបញ្ជា និងសម្របសម្រួលឲ្យមានការសម្លាប់ និងចាប់ខ្លួនក្រៅប្រព័ន្ធតុលាការ ធ្វើទារុណកម្ម អាពាហ៍ពិពាហ៍ដោយបង្ខំ និងការធ្វើឲ្យប្រជាជនក្លាយទៅជាទាសករ។ ភ័ស្តុតាងដ៏លើសលុបបង្ហាញថា **យ៉ីម ទិញ** បានចូលរួមក្នុងផែនការកំណត់អត្តសញ្ញាណ និងសម្លាប់ខ្មាំងរបស់កម្ពុជាប្រជាធិបតេយ្យជាលក្ខណៈប្រព័ន្ធ។ នៅក្នុងការលើកតម្កើងផែនការនេះ និងដើម្បីធានាថា អ្នកក្រោមបង្គាប់របស់គាត់អនុវត្តគោលនយោបាយរបស់ ប.ក.ក **យ៉ីម ទិញ** បានមើលការខុសត្រូវលើមន្ទីរសន្តិសុខនានាក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ គាត់បានធ្វើអធិការកិច្ចដោយផ្ទាល់ទៅលើលក្ខខណ្ឌអមនុស្សធម៌នៃមន្ទីរសន្តិសុខទាំងនេះ និងបានចូលរួមក្នុងការសួរចម្លើយអ្នកទោសផងដែរ។ គាត់ក៏បានធ្វើដំណើរជាទៀងទាត់ផងដែរទៅកាន់ការដ្ឋានផ្សេងៗ ជាទីដែលគាត់បានធ្វើជាអធិបតីក្នុងអង្គប្រជុំនានា បានត្រួតពិនិត្យមើលផលិតកម្ម និងអនុម័តឲ្យមានការសម្លាប់ក្រៅប្រព័ន្ធតុលាការ។ **យ៉ីម ទិញ** បានចូលរួមយ៉ាងសកម្មទៅក្នុងបញ្ហារដ្ឋបាលថ្នាក់ខ្ពស់ផ្សេងទៀត ដែលបានសម្របសម្រួលដល់ផែនការឧក្រិដ្ឋកម្មនេះ ការចូលរួមចំណែកនានាដែលមានចាប់ពីការបែងចែកសេដ្ឋកិច្ច និងអាហារ និងឃោសនាការ។

1129. **យ៉ីម ទិត្យ** ទទួលបានសិទ្ធិអំណាចភាគច្រើនតាមរយៈទំនាក់ទំនងគ្រួសារ និងទំនាក់ទំនងវិជ្ជាជីវៈ របស់គាត់ជាមួយ តា ម៉ុក ដែលជាសមាជិកម្នាក់នៃគណៈអចិន្ត្រៃយ៍របស់ ប.ក.ក ហើយក៏មានតួនាទីជាលេខាភូមិភាគពាយ័ព្យ និងភូមិភាគនិរតីនៅក្នុងពេលដែល **យ៉ីម ទិត្យ** បានធ្វើការនៅក្នុងភូមិភាគទាំងនោះ។ ទំនាក់ទំនងរបស់ **យ៉ីម ទិត្យ** ជាមួយ តា ម៉ុក ដែលជាបងថ្លៃរបស់គាត់ត្រូវបានគេនិយាយថាប្រៀបដូចទៅនឹងទំនាក់ទំនងរវាង "ឪពុក និងកូន"។

២. ជាអ្នកទទួលខុសត្រូវខ្ពស់បំផុត

1130. តាមរយៈការវាយតម្លៃប្រកបដោយហេតុផល **យ៉ីម ទិត្យ** គឺជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលទាំងឡាយ ដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តឡើងក្នុងរយៈកាលចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ **យ៉ីម ទិត្យ** គឺជាមេដឹកនាំសំខាន់មួយរូបនៅក្នុងភូមិភាគចំនួនពីរ ហើយដូច្នេះ គាត់មានអំណាចលើមនុស្សប្រុស ស្រី និងកុមារស្ពួតត្រង់រាប់ម៉ឺននាក់ ដែលត្រូវបានធ្វើឲ្យទៅជាទាសករនៅក្នុងសហករណ៍ និងការដ្ឋានការងាររបស់ខ្មែរក្រហម។ ឧក្រិដ្ឋកម្មដែល **យ៉ីម ទិត្យ** ត្រូវបានចោទប្រកាន់មានភាពធ្ងន់ធ្ងរបំផុត ហើយកម្រិតនៃការទទួលខុសត្រូវរបស់គាត់មានកម្រិតខ្ពស់ខ្លាំង។ ភ័ស្តុតាងនេះបង្ហាញឲ្យឃើញពីការចូលរួមដោយផ្ទាល់របស់ **យ៉ីម ទិត្យ** នៅក្នុងឧក្រិដ្ឋកម្មទាំងនេះ និងកិច្ចប្រឹងប្រែងឥតឈប់ឈររបស់គាត់ក្នុងនាមជាមេដឹកនាំជាន់ខ្ពស់ ក្នុងការជំរុញគោលនយោបាយឧក្រិដ្ឋកម្មរបស់ ប.ក.ក ក្នុងតំបន់ទាំងអស់ដែលគាត់បានបម្រើការងារ។

ក. កត្តាពាក់ព័ន្ធទៅនឹងការកំណត់ភាពធ្ងន់ធ្ងរនៃអំពើឧក្រិដ្ឋកម្ម

1131. *<u>វិសាលភាពភូមិសាស្ត្រ និងពេលវេលានៃឧក្រិដ្ឋកម្ម</u>*ៈ ការចូលរួមរបស់ **យ៉ីម ទិត្យ** ក្នុងផែនការឧក្រិដ្ឋកម្មរួម បានកើតមានចាប់ពីភូមិភាគនិរតីរហូតដល់ភូមិភាគពាយ័ព្យ ដែលគ្របដណ្ដប់លើតំបន់ជាច្រើន។ ក្នុងអំឡុងប្រតិបត្តិការឧក្រិដ្ឋកម្មដ៏ធំនេះ ដែលគ្របដណ្ដប់លើចំណែកដ៏ធំនៃប្រជាជនកម្ពុជា **យ៉ីម ទិត្យ** បានចូលរួមក្នុងការបង្កើត និងផ្សព្វផ្សាយគោលនយោបាយនានា រួមទាំងការកំណត់ទិសដៅ "ខ្ទាំង" ការជំរុញឲ្យមានកម្លាំងពលកម្មទាសកររបស់ខ្មែរក្រហម និងបង្ខំឲ្យមនុស្សវ័យក្មេងរៀបការ ដើម្បីបង្កើតកូនសម្រាប់ប្រជាជនេះ។ គាត់បានអនុវត្តគោលនយោបាយទាំងនេះនៅមូលដ្ឋានដោយធ្វើអធិការកិច្ចនៅតាមការដ្ឋាន និងមន្ទីរសន្តិសុខ និងធ្វើជាអធិបតីក្នុងពិធីអាពាហ៍ពិពាហ៍ដោយបង្ខំ។

1132. ការចូលរួមរបស់ **យ៉ីម ទិញ** ក្នុងផែនការឧក្រិដ្ឋកម្មរួមនេះ បានកើតមានពេញមួយរបបខ្មែរក្រហម ដោយចាប់ផ្តើមនៅឆ្នាំ១៩៧៥ ដែលគាត់បានដឹកនាំស្រុកគីរីវង់ ហើយក្រោយមកបានដឹកនាំតំបន់ ១៣ ក្នុងភូមិភាគនិរតី។ នៅប្រហែលឆ្នាំ១៩៧៧ **យ៉ីម ទិញ** ទទួលបានអំណាចបន្ថែមទៀតនៅផ្នែកដ៏ធំនៃភូមិភាគពាយ័ព្យ តាមរយៈការគ្រប់គ្រង *តាមនីតិន័យ* និង*តាមព្រឹត្តន័យ*របស់គាត់លើតំបន់ ១ តំបន់ ២ តំបន់ ៣ តំបន់ ៤ និងតំបន់ ៧ ហើយជាចុងក្រោយបានក្លាយជាអនុលេខាភូមិភាគពាយ័ព្យ និងជាលេខា*តាមព្រឹត្តន័យ* ក្នុងពេលដែល តា ម៉ុក អវត្តមាន។ អំណាចរបស់ **យ៉ីម ទិញ** ក្នុងភូមិភាគពាយ័ព្យ មានការជាប់ពាក់ព័ន្ធទៅនឹងការបោសសម្អាតភូមិភាគនេះ ដែល **យ៉ីម ទិញ** និងសមាជិករបស់សហឧក្រិដ្ឋកម្មរួមផ្សេងទៀត ទទួលបានការគ្រប់គ្រងលើតំបន់នេះ ដែលបង្កឲ្យមានមនុស្សស្លាប់រាប់ពាន់នាក់។

1133. <u>*លក្ខណៈនៃការប្រព្រឹត្ត*</u>ៈ **យ៉ីម ទិញ** បានដឹកនាំរបបនៃភាពរន្ធត់មួយនៅទូទាំងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដែលត្រូវបានពិពណ៌នាតាមរយៈភាពយោរយៅជាប្រព័ន្ធ។ គាត់បានបញ្ជាឲ្យសម្លាប់មនុស្សរាប់ពាន់នាក់ និងបានធ្វើដំណើរដោយផ្ទាល់ខ្លួនទៅកាន់មន្ទីរសន្តិសុខនានា ដើម្បីធានាថា អ្នកក្រោមបង្គាប់របស់គាត់អនុវត្តតាម តាមរយៈការអនុវត្តគោលនយោបាយសន្តិសុខរបស់ ប.ក.ក។ សូម្បីតែទារកក៏មិនត្រូវបានទុកជីវិតផងដែរ។ អ្នកទាំងឡាយណាដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ ត្រូវទទួលរងការធ្វើបាប ហាក់ដូចជាមិនមែនមនុស្ស ខណៈដែលបង្ខំឲ្យធ្វើការងារយ៉ាងធ្ងន់ធ្ងរក្នុងលក្ខខណ្ឌដ៏អាក្រក់ បង្អត់អាហារ និងអត់ទ្រាំនឹងការបន្ទាបបន្ថោកជាប្រចាំ។ មុនពេលត្រូវបានបញ្ជូនទៅរកសេចក្តីស្លាប់ ជាញឹកញាប់អ្នកទោសបានទទួលរងនូវទម្រង់នៃការធ្វើទារុណកម្មដ៏គួរឲ្យរន្ធត់ ដូចជា វះពោះទាំងរស់ដើម្បីយកប្រមាត់ជាដើម។ **យ៉ីម ទិញ** ត្រូវបានគេដឹងថាមកយកប្រមាត់ដែលត្រូវបានគេវះពោះយកចេញនោះដោយខ្លួនឯង។ នៅក្នុងតំបន់ដែល **យ៉ីម ទិញ** បានគ្រប់គ្រងមនុស្សរាប់ពាន់នាក់ត្រូវបានបង្ខំឲ្យរៀបការ ហើយត្រូវបានបង្ខំឲ្យរួមភេទដោយគ្មានការព្រមព្រៀងដោយសេរីពីពួកគេ (រំលោភ)។ **យ៉ីម ទិញ** បានធ្វើជាអធិបតីក្នុងពិធីអាពាហ៍ពិពាហ៍មួយចំនួនក្នុងចំណោមអាពាហ៍ពិពាហ៍ទាំងនេះ។ **យ៉ីម ទិញ** ក៏បានអនុម័តគោលនយោបាយយោរយៅនៅតាមការដ្ឋានផងដែរ ដែលបានធ្វើឲ្យមានលក្ខខណ្ឌនៃការធ្វើឲ្យទៅជាទាសករកាន់តែមានភាពធ្ងន់ធ្ងរខ្លាំងឡើង។ ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ សាក្សីបានរាយការណ៍ថា របបអាហារបានថយចុះ ហើយម៉ោងធ្វើការបានកើនឡើង ដែលបានរួមចំណែកដល់ការបង្អត់អាហារ និងការធ្វើឲ្យលក្ខខណ្ឌការងារដែលគួរឲ្យស្អប់ខ្ពើមស្រាប់ទៅហើយនោះ កាន់តែមានស្ថានភាពធ្ងន់ធ្ងរឡើង។ បន្ថែមពីលើនេះទៀត **យ៉ីម ទិញ** បានចូលរួមក្នុងយុទ្ធនាការបំផ្ទិចបំផ្លាញមួយប្រឆាំងនឹងជន

ជាតិវៀតណាម ដែលរួមមានការនាំយកគ្រួសារដោយការភ្ជង់កាំភ្លើងចេញពីផ្ទះរបស់ពួកគេនៅកម្ពុជាក្រោមដើម្បីយកមកធ្វើបាបយ៉ាងឃោរឃៅ បង្អត់អាហារ និងសម្លាប់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ។

1134. *<u>ចំនួនខ្ជប្ជតិហេតុ</u>*៖ តាមរយៈមុខតំណែងផ្សេងៗដ៏មានអំណាចរបស់គាត់ **យ៉ីម ទិញ** បានមើលការខុសត្រូវយ៉ាងជិតដល់លើការអនុវត្តអំពើហិង្សាដោយគ្មានមេត្តា តាមការគ្រោងទុក និងដោយចេតនាដែលត្រូវបានអនុវត្តជាលក្ខណៈប្រព័ន្ធនៅទូទាំងពហុតំបន់ ស្រុក និងឃុំនៅក្នុងភូមិភាគពីរផ្សេងគ្នា។ មនុស្សរាប់ពាន់នាក់ត្រូវបានសម្លាប់ ហើយមនុស្សជាច្រើនឥតគណនាផ្សេងទៀតបានជួបប្រទះនឹងការឈឺចាប់ដែលមិនអាចវាស់វែងបាន នៅក្នុងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ **យ៉ីម ទិញ** បានមើលការខុសត្រូវលើមន្ទីរសន្តិសុខមួយចំនួន ដែលនៅទីនោះអ្នកក្រោមបង្គាប់របស់គាត់ បានអនុវត្តបទបញ្ជា ដើម្បីធ្វើទារុណកម្ម និងសម្លាប់អ្នកជាប់ឃុំឃាំង និងបានរក្សាលក្ខខណ្ឌអមនុស្សធម៌ដែលបានចូលរួមចំណែកដល់ការឈឺចាប់របស់អ្នកទោស។ ស្របពេលជាមួយគ្នានោះដែរ **យ៉ីម ទិញ** បានគ្រប់គ្រងការដ្ឋានមួយចំនួន ជាទីដែលមនុស្សដែលត្រូវបានគេធ្វើឲ្យទៅជាទាសករជាច្រើនឥតគណនា បានទទួលរងទុក្ខស្ថិតក្រោមលក្ខខណ្ឌធ្ងន់ធ្ងរនានា ដូចជា ការបង្អត់អាហារ និងពលកម្មដោយបង្ខំ ខ្លាំងក្លា និងមានរយៈពេលច្រើនម៉ោង។ គាត់ក៏បានបង្កឲ្យមានជនរងគ្រោះពីអំពើហិង្សាផ្លូវភេទជាច្រើននាក់ផងដែរ តាមរយៈការអនុវត្តយុទ្ធនាការអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ ប.ក.ក នៅក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់។ ទាំងនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ **យ៉ីម ទិញ** បានមើលការខុសត្រូវលើគោលនយោបាយមួយដែលមានបំណងកម្ទេចជនជាតិវៀតណាមទាំងអស់នៅក្នុងតំបន់ ដែលជាលទ្ធផលបណ្តាលឲ្យមានការកើតមានជាច្រើនទ្រង់ការនិរទេស ការជម្លៀសដោយបង្ខំ និងការសម្លាប់។ លើសពីនេះទៀត ក្នុងនាមជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំសំខាន់ៗ ដែលត្រូវបានដាក់ពង្រាយពីភូមិភាគនិរតីទៅភូមិភាគពាយ័ព្យ **យ៉ីម ទិញ** បានចូលរួមក្នុងការបោសសម្អាតកម្មាភិបាលរាប់ពាន់នាក់ ដែលត្រូវបានឃុំឃាំង ធ្វើទារុណកម្ម បានបាត់ខ្លួន និងសម្លាប់ជាលក្ខណៈប្រព័ន្ធ ដោយសារលទ្ធផលនៃការឡើងគ្រប់គ្រងអំណាចដែលត្រូវបានរៀបចំនេះ។

1135. *<u>ចំនួនជនរងគ្រោះ</u>*៖ ចំនួនជនរងគ្រោះដែលបានរងទុក្ខពីយុទ្ធនាការឧក្រិដ្ឋកម្មរបស់ **យ៉ីម ទិញ** និងសមាជិកសហឧក្រិដ្ឋកម្មរួមដែលជាសហសេវិករបស់គាត់ មិនអាចត្រូវបានបញ្ជាក់ជាក់លាក់បានទេ។ បុគ្គលរាប់ម៉ឺននាក់បានជាប់ក្នុងប្រព័ន្ធសន្តិសុខរបស់ ប.ក.ក នៅទូទាំងតំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **យ៉ីម ទិញ**៖ មន្ទីរសន្តិសុខដែលត្រូវបានបង្កើតឡើងដើម្បីឃុំខ្លួនក្រៅប្រព័ន្ធ

តុលាការ ដើម្បីធ្វើបាប និងក្នុងករណីភាគច្រើន ដើម្បីសម្លាប់អ្នកជាប់ឃុំឃាំងទាំងនោះ ព្រមទាំងទីតាំងសម្លាប់មនុស្សដែលមានគោលបំណងតែមួយគត់ គឺធ្វើជាទីបញ្ចុះសព ដែលខ្វះសេចក្តីផ្តែផ្ទួរសម្រាប់ជនស្លូតត្រង់ ដែល ប.ក.ក ចាត់ទុកថា ពួកគេគ្មានតម្លៃក្នុងការរស់នៅ។ មនុស្សរាប់ពាន់នាក់បានចំណាយពេលថ្ងៃរបស់ពួកគេទៅនឹងការបង្ខំឲ្យធ្វើការ ក្នុងលក្ខខណ្ឌដ៏រន្ធត់នៅការដ្ឋាននានាដែលស្ថិតក្រោមដែនអំណាចរបស់ **យ៉ីម ទិត្យ** ជាទីដែលជនស្លូតត្រង់ជាច្រើនឥតគណនា ត្រូវបានបង្អត់អាហារមិនគ្រប់ស្ពាប់ ឬត្រូវបានសម្លាប់។

1136. មនុស្សរាប់ពាន់នាក់ផ្សេងទៀត បានជួបប្រទះនូវវាសនាដ៏វេទនាស្រដៀងគ្នាដោយគ្មានហេតុផលណាមួយក្រៅពីដោយសារតែភាពជាសញ្ជាតិ ឬជនជាតិវៀតណាមរបស់ពួកគេ។ ជនរងគ្រោះទាំងនេះ ត្រូវបានជម្លៀសដោយបង្ខំ និរទេស ឃុំខ្លួនក្នុងលក្ខខណ្ឌអមនុស្សធម៌ និងសម្លាប់ក្នុងទ្រង់ទ្រាយធំ ភាគច្រើននៅក្នុងតំបន់ ២ និងតំបន់ ៣ ខណៈពេលដែលតំបន់ទាំងនេះស្ថិតក្រោមអំណាចរបស់ **យ៉ីម ទិត្យ**។ លើសពីនេះទៀត មនុស្សជាច្រើនទៀតគឺជាជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទ ដែលត្រូវបានអនុវត្តយ៉ាងសកម្មដោយ **យ៉ីម ទិត្យ** និងអ្នកក្រោមបង្គាប់របស់គាត់ ដើម្បីបំពេញបំណងរបស់ ប.ក.ក ក្នុងការឲ្យមានប្រជាជនកាន់តែច្រើន ដើម្បីបម្រើជាការងារជាទាហាន និងពលករសម្រាប់របបនេះ។

1137. *<u>ភាពជាជនរងគ្រោះរបស់ជនរងគ្រោះ</u>*៖ **យ៉ីម ទិត្យ** បានកំណត់ទិសដៅលើជនស្លូតត្រង់ដែលគ្មានទីពឹងតាមរយៈឧក្រិដ្ឋកម្មដែលគាត់បានសម្របសម្រួល ជំរុញ ផ្សព្វផ្សាយ គាំទ្រ បញ្ជា និងប្រព្រឹត្តដោយផ្ទាល់។ បុគ្គលទាំងពីរភេទ និងគ្រប់អាយុទាំងអស់ រួមទាំងស្ត្រីមានផ្ទៃពោះ ចាស់ជរា និងទារក គឺជាជនរងគ្រោះនៃគោលនយោបាយដែល **យ៉ីម ទិត្យ** បានអនុវត្ត។ អ្នកទាំងឡាយដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ ជាញឹកញាប់ត្រូវបានចាប់ខ្លួន និងឃុំឃាំងតាមទំនើងចិត្ត និងគ្មានហេតុផល។ ប្រជាជន បានរស់នៅក្រោមការជិះជាន់ និងភាពភ័យខ្លាចជាប្រចាំចំពោះការបាត់ខ្លួន និងការសម្លាប់។ កម្មករនៅក្នុងឃុំ និងសហករណ៍ និងនៅការដ្ឋាន ត្រូវបានកំណត់ជាគោលដៅដោយសារហេតុផលតិចតួចបំផុតដូចជា ឈឺ "ក្នុងកម្រិតមធ្យម" អង្គុយចុះដើម្បីសម្រាក និងសូម្បីតែធ្វើឲ្យខូចឧបករណ៍ ឬកាំបិត។ **យ៉ីម ទិត្យ** និងអ្នកក្រោមបង្គាប់របស់គាត់ បានរក្សាបរិយាកាសភ័យខ្លាចនេះជាមួយនឹងការគំរាមកំហែងដោយផ្ទាល់ និងប្រយោល ដោយរំឭកកម្មករជានិច្ចថា ពួកគេស្ថិតក្រោមការឃ្លាំមើល និងជំរុញឲ្យពួកគេរាយការណ៍ពីគ្នាទៅវិញទៅមក។ គ្រួសារ និងសហគមន៍ទាំងមូលរបស់ខ្មែរក្រោម ត្រូវបានបង្ខំឲ្យត្រឡប់មកពីកម្ពុជាក្រោមដោយការគំរាមសម្លាប់ ហើយក្រោយមកត្រូវបានឃុំខ្លួននៅកម្ពុជាប្រជាធិបតេយ្យ និងស្ថិតក្រោមភាពភ័យខ្លាច

ចំពោះការសម្លាប់ជាបន្តបន្ទាប់។ លើសពីនេះទៀត ក្នុងកាលៈទេសៈមួយចំនួន បុរស និងស្ត្រីដែលមិនធ្លាប់បានជួបគ្នាផង ត្រូវបានតម្រូវឲ្យរៀបការ និងរួមភេទស្ថិតក្រោមសម្ពាធនៃការសម្លាប់ បើពួកគេមិនធ្វើតាម។

1138. *<u>ចេតនារើសអើងចំពោះឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត</u>*៖ **យ៉ាម ទិត្យ** បានអនុវត្តយ៉ាងសកម្មនូវគោលនយោបាយរបស់ ប.ក.ក ដែលមានជាប់មកជាមួយនូវការរើសអើង ដោយកំណត់គោលដៅចំពោះក្រុមផ្សេងៗ ដោយសារការយល់ឃើញតាមទំនើងចិត្ត ដែលជាញឹកញាប់មិនបានកើតចេញពីអ្វីក្រៅតែពីការភ័យខ្លាចមិនទុកចិត្តគ្នា។ **យ៉ាម ទិត្យ** ចិញ្ចឹមចិត្ត *ស្អប់ខ្ពើម* រើសអើងខ្លាំងបំផុតចំពោះជនជាតិវៀតណាម រួមទាំងខ្មែរក្រោមផងដែរ ដែល ប.ក.ក បានមើលឃើញថាមិនមានភាពបរិសុទ្ធដែលមិនអាចកែប្រែបាន ដោយសារតែដើមកំណើតរបស់ពួកគេមកពីដែនដី ដែលនៅពេលនោះ ស្ថិតក្នុងប្រទេសវៀតណាម។ ក្រុមជនជាតិវៀតណាមនេះ ត្រូវបានកំណត់ទិសដៅសម្រាប់ការកម្ទេចទាំងស្រុង ដោយ **យ៉ាម ទិត្យ** ខ្លួនឯងផ្ទាល់បានបញ្ជាឲ្យសម្លាប់ជនជាតិខ្មែរក្រោមរាប់ពាន់ នាក់។ ការស្អប់ខ្ពើមចំពោះជនជាតិវៀតណាម និងខ្មែរក្រោម មានភាពខ្លាំងក្លាណាស់ ដែលបុគ្គលនានាត្រូវបានប្រមូលផ្តុំដោយផ្អែកលើពណ៌សម្បុរស្បែក ឬការលើកដាក់សំឡេងនិយាយរបស់ពួកគេ។ ការប្រព្រឹត្តអំពើឧក្រិដ្ឋប្រឆាំងនឹងខ្មែរក្រោម និងជនជាតិវៀតណាម ត្រូវបានប្រមូលផ្តុំនៅក្នុងតំបន់ចំនួនពីរ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ **យ៉ាម ទិត្យ** ហើយបានបន្តកើតមានឡើងនៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ៖ តំបន់ ១៣ នៃភូមិភាគនិរតី និងតំបន់ ២ នៃភូមិភាគពាយ័ព្យ។ ខ្មែរក្រោមត្រូវបាននិរទេសដោយបង្ខំពីកម្ពុជាក្រោម មកកាន់កម្ពុជាប្រជាធិបតេយ្យ ជាទីដែលពួកគេត្រូវបានបង្អត់អាហារ បង្ខំឲ្យធ្វើពលកម្ម និងសម្លាប់ ដែលបង្ហាញឲ្យឃើញពីវិសាលភាពដែលក្រុមជនជាតិនេះ ត្រូវបាននិយាយបង្ខូច ហើយជាចុងក្រោយត្រូវបានប៉ុនប៉ង់សម្លាប់។

1139. *<u>ផលប៉ះពាល់នៃឧក្រិដ្ឋកម្មលើប្រជាជនកម្ពុជា</u>*៖ លទ្ធផលនៃឧក្រិដ្ឋកម្ម ដែលត្រូវបានដឹងឮដោយ **យ៉ាម ទិត្យ** និងអ្នកផ្សេងទៀតទៅលើប្រជាជនរបស់ភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ស្ទើរតែមិនអាចវាស់វែងបាន។ បុគ្គលពីរបីនាក់ដែលបានរស់នៅក្នុងភូមិភាគទាំងនេះនៅពេលនោះ បានជួយសង្គ្រោះជីវិតរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនមានវិធានការសំខាន់ៗក្នុងការទប់ស្កាត់ការឈឺចាប់។ ការឈឺចាប់ភាគច្រើនគឺជាការខូចខាតដែលមិនអាចផ្លាស់ប្តូរបាន។ ផលប៉ះពាល់រយៈពេលយូរនៃការលុបបំបាត់សិទ្ធិជាមូលដ្ឋានបំផុតរបស់ប្រជាជន ដែលមានលក្ខណៈរីករាលដាល ត្រូវបានធ្វើឡើងដោយចេតនា តាមវិធីសាស្ត្រ និងតាមការគ្រោងទុក ការដាក់បុគ្គលឲ្យស្ថិតនៅក្រោមបំណងរបស់អង្គការ និងការប្រមាថមើលងើយដ៏ខ្លាំងក្លាដល់ជីវិតមនុស្ស ដែលត្រូវបានបង្ហាញ

ដោយ **យ៉ាម ទិញ** ក្នុងទ្រង់ទ្រាយធំ បានកម្ទេចសង្គមកម្ពុជា និងបានពន្យារពេលការអភិវឌ្ឍមនុស្ស និងស្ថាប័នយ៉ាងយូរក្រោយការបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ។

ខ. កត្តាពាក់ព័ន្ធទៅនឹងការកំណត់កម្រិតនៃការទទួលខុសត្រូវ

1140. *<u>កម្រិតនៃការចូលរួម</u>*៖ **យ៉ាម ទិញ** គឺជាអ្នកចូលរួមដ៏សំខាន់ក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋនៃសហឧក្រិដ្ឋកម្មរួម។ ក្នុងអំឡុងពេលកាន់កាប់មុខតំណែងរបស់គាត់នៅទូទាំងតំបន់ និងភូមិភាគ **យ៉ាម ទិញ** បានចូលរួមចំណែកដោយមិនចេះរារែកចំពោះគោលដៅឧក្រិដ្ឋកម្មរបស់ ប.ក.ក។ **យ៉ាម ទិញ** បានធ្វើដូច្នេះនៅក្នុងតួនាទីពីរ។ ទីមួយ គាត់បានប្រើប្រាស់មុខតំណែងជាន់ខ្ពស់របស់គាត់នៅក្នុងឋានានុក្រមរបស់ ប.ក.ក ដើម្បីបង្កើត និងផ្សព្វផ្សាយគោលនយោបាយឧក្រិដ្ឋកម្មទាក់ទងនឹង "ខ្មាំង" ការធ្វើឲ្យទៅជាទាសករ និងអាពាហ៍ពិពាហ៍ដោយបង្ខំ។ ទីពីរ គាត់បានធានាឲ្យមានការអនុវត្តផែនការឧក្រិដ្ឋកម្មទាំងនេះតាមរយៈវត្តមានរបស់គាត់នៅអង្គប្រជុំ នៅមន្ទីរសន្តិសុខ និងការដ្ឋាននានា បន្ថែមលើការប្រព្រឹត្តឧក្រិដ្ឋកម្មដោយផ្ទាល់របស់គាត់។

1141. **យ៉ាម ទិញ** បានចេញបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ និងបានធ្វើដំណើរទៅមន្ទីរសន្តិសុខនានា ជាទីដែលមានការប្រព្រឹត្តការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងការសម្លាប់ដោយខុសច្បាប់។ គាត់ក៏បានសួរចម្លើយអ្នកជាប់ឃុំនៅមន្ទីរសន្តិសុខផងដែរ។ **យ៉ាម ទិញ** បានបញ្ជាឲ្យសម្លាប់មនុស្សរាប់ពាន់នាក់ដែលជា "ភ្នាក់ងារសេអ៊ីអា" "ជនជាតិវៀតណាម" និង "ជនជាតិចិន" ក្នុងឆ្នាំ១៩៧៦ ឬ ១៩៧៧ និងម្តងទៀតនៅឆ្នាំ១៩៧៨ ឬ ១៩៧៩។ ការណ៍នេះគឺជាការបន្ថែមទៅលើការមើលការខុសត្រូវលើការនិរទេសក្នុងទ្រង់ទ្រាយធំ ការជម្លៀសដោយបង្ខំ និងការសម្លាប់ជនជាតិវៀតណាម រួមទាំងខ្មែរក្រោមផងដែរ នៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ **យ៉ាម ទិញ** បានចូលរួមយ៉ាងសកម្មក្នុងការកំណត់ និងប្រកាសគោលដៅផលិតកម្ម ដោយតម្រូវឲ្យកម្មករដែលអស់កម្លាំង ខិតខំធ្វើការឲ្យខ្លាំងថែមទៀត គំរាមកំហែងកម្មករ និងត្រួតពិនិត្យកម្រិតផលិតកម្ម។ លក្ខខណ្ឌការងារ និងរស់នៅមិនល្អស្រាប់ទៅហើយនោះ បានប្រែក្លាយកាន់តែអាក្រក់ខ្លាំងថែមទៀត បន្ទាប់ពី **យ៉ាម ទិញ** បានចូលកាន់អំណាច។ **យ៉ាម ទិញ** ក៏បានចូលរួមដោយខ្លួនឯងផ្ទាល់ផងដែរក្នុងពិធីអាពាហ៍ពិពាហ៍ដោយបង្ខំ ព្រមទាំងជាញឹកញាប់ណែនាំឲ្យមនុស្សដែលស្ថិតក្រោមអំណាចរបស់គាត់ថា ពួកគេត្រូវតែរៀបការ បង្កើតកូន និង "បង្កើតទាហានថ្មី"។

1142. *<u>មុខតំណែងតាមឋានានុក្រម</u>*៖ **យ៉ាម ទិញ** បានកាន់កាប់មុខតំណែងសំខាន់ៗមួយចំនួនទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ ចាប់ពីដើមរបបកម្ពុជាប្រជាធិបតេយ្យ **យ៉ាម ទិញ** គឺជាមេដឹកនាំ

ម្នាក់នៅស្រុកគិរីវង់ ហើយជាបន្តបន្ទាប់បានក្លាយជាអនុលេខាតំបន់ ១៣។ គាត់បានបន្តកាន់តាប់តួនាទីទាំងនេះ ខណៈដែលគាត់បានក្លាយជាឥស្សរជនសំខាន់ម្នាក់ក្នុងភូមិភាគពាយ័ព្យ។ នៅទីនោះ **យ៉ាម ទិត្យ** គឺជាអនុលេខាភូមិភាគ ហើយទទួលបន្ទុកភូមិភាគនេះនៅពេលដែល តា ម៉ុក អវត្តមាន។ ហេតុដូច្នេះ **យ៉ាម ទិត្យ** បានឈរដោយផ្ទាល់ប្រកបដោយប្រសិទ្ធភាពនៅក្រោមមជ្ឈិមបក្ស ទាក់ទងនឹងអំណាច។ លើសពីនេះ **យ៉ាម ទិត្យ** គឺជាលេខាតំបន់ ១ ហើយសាក្សីបានកំណត់អត្តសញ្ញាណគាត់ថាជាលេខាតំបន់ ២ តំបន់ ៣ និងតំបន់ ៤។ សូម្បីតែមុនពេលចូលកាន់មុខតំណែងទាំងនេះ **យ៉ាម ទិត្យ** គឺជាមេដឹកនាំ*តាមព្រឹត្តន័យ* ដ៏មានអំណាចនៅក្នុងភូមិភាគពាយ័ព្យ ដោយត្រូវបានណែនាំជាសាធារណៈថាជាមនុស្សម្នាក់ដែលបាន "មកជួយគ្រប់គ្រង" មុនពេលមានការបោសសម្អាត។ ហេតុដូចនេះ នៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ អ្នកក្រោមបង្គាប់របស់ **យ៉ាម ទិត្យ** រួមមានអ្នកមកពីឃុំដែលជាថ្នាក់ក្រោមបំផុត និងកម្មាភិបាលថ្នាក់ខ្ពស់បំផុតដែលស្ថិតនៅថ្នាក់តំបន់។ **យ៉ាម ទិត្យ** បានប្រើប្រាស់មុខតំណែងផ្សេងៗរបស់គាត់ដើម្បីធានាថា គោលនយោបាយរបស់ ប.ក.ក ត្រូវបានផ្សព្វផ្សាយ និងបំពេញនៅថ្នាក់នីមួយៗនៃថ្នាក់ទាំងនេះ ដោយធានាឲ្យមានការបំផ្ទិចបំផ្លាញទៅលើមនុស្សយ៉ាងច្រើននៅទូទាំងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។

1143. *<u>វិសាលភាពពេលវេលានៃការគ្រប់គ្រង</u>*៖ អំណាចរបស់ **យ៉ាម ទិត្យ** នៅថ្នាក់ស្រុក និងតំបន់ក្នុងភូមិភាគនិរតី មាននៅពេញមួយរបបកម្ពុជាប្រជាធិបតេយ្យ ខណៈការគ្រប់គ្រង និងការទទួលខុសត្រូវរបស់គាត់លើប្រព្រឹត្តិការណ៍នានាក្នុងភូមិភាគពាយ័ព្យ តាមរយៈតួនាទីរបស់គាត់ជាមេដឹកនាំ*តាមព្រឹត្តន័យ* និងមុខតំណែង*តាមនីតិន័យ* និង*តាមព្រឹត្តន័យ* របស់គាត់នៅថ្នាក់តំបន់ និងភូមិភាគ បានកើតមាននៅទូទាំងអំឡុងពេលនៃការបោសសម្អាតភូមិភាគពាយ័ព្យ រហូតដល់ការដួលរលំរបបនេះនៅខែ មករា ឆ្នាំ១៩៧៩។

1144. *<u>អំណាចប្រកបដោយប្រសិទ្ធភាព និងលទ្ធភាពក្នុងការចេញបញ្ជា</u>*៖ **យ៉ាម ទិត្យ** បានអនុវត្តអំណាចដ៏ធំធេងទៅលើអ្នកក្រោមបង្គាប់នៅថ្នាក់តំបន់ ស្រុក និងឃុំនៅទូទាំងភូមិភាគពាយ័ព្យ និងភូមិភាគ និរតី។ ចាប់ពីដើមរបបកម្ពុជាប្រជាធិបតេយ្យមក **យ៉ាម ទិត្យ** បានព្រមានអ្នកចូលរួមក្នុងអង្គប្រជុំនានា "ថា អ្នកណាម្នាក់អាចបាត់ខ្លួននៅពេលណាមួយ" ហើយបានធ្វើដំណើរជាប្រចាំទៅកាន់មន្ទីរសន្តិសុខនានា និងបានទទួលរបាយការណ៍ពីប្រធានមន្ទីរសន្តិសុខ ដើម្បីធានាថា ពួកគេកំពុងអនុវត្តតាមការណែនាំរបស់គាត់។ **យ៉ាម ទិត្យ** បានបញ្ជាឲ្យមានការសម្លាប់ក្រៅប្រព័ន្ធតុលាការ និង "ការអប់រំកែប្រែ" នៅក្នុងមន្ទីរសន្តិសុខ និងតំបន់ផ្សេងទៀតនៃស្រុកគិរីវង់ ព្រមទាំងនៅក្នុងស្រុកត្រាំកក់ និងស្រុកកោះអណ្តែត តាមរយៈអំណាចថ្នាក់តំបន់របស់គាត់។ **យ៉ាម ទិត្យ** ក៏បានចេញបញ្ជាផងដែរ

ទាក់ទងនឹងការដាំដុះស្រូវ និងការកសាងប្រឡាយ ទៅកាន់មេកងថ្នាក់ទាប និងបាននិយាយនៅក្នុងអង្គប្រជុំថ្នាក់ស្រុកអំពីផែនការការងារ និងផលិតកម្មកសិកម្ម ដែលជំរុញការធ្វើឲ្យទៅជាទាសកររបស់ ប.ក.ក ចំពោះប្រជាជន។ ជាញឹកញាប់ **យ៉ឹម ទិត្យ** បានណែនាំប្រជាជនដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ថា ពួកគេត្រូវតម្រូវឲ្យរៀបការ និងបង្កើតកូន ដើម្បីសម្រេចបានគោលដៅរបស់ ប.ក.ក។ លើសពីនេះទៀត គណៈស្រុកគិរីវង់ដែលដឹកនាំដោយ **យ៉ឹម ទិត្យ** បានបញ្ជាឲ្យមានការសម្លាប់ពលរដ្ឋខ្មែរក្រោមយ៉ាងច្រើន។

1145. ស្រដៀងគ្នានេះដែរ ក្នុងភូមិភាគពាយ័ព្យ **យ៉ឹម ទិត្យ** "បានជជែកអំពីខ្មាំងផ្ទៃក្នុងស៊ីរួងចលនារបស់យើង" នៅក្នុងអង្គប្រជុំនានា ដោយណែនាំឲ្យអ្នកចូលរួមរាយការណ៍អំពី "ខ្មាំង" ដែលត្រូវបានសង្ស័យដើម្បីឲ្យ "អង្គការអាចកម្ទេចពួកគេ មុនពេលពួលគេកម្ទេចយើងវិញ"។ **យ៉ឹម ទិត្យ** ថែមទាំងបានកំណត់អ្នកដែលបានលួចអាហារថាជា "ខ្មាំងស៊ីរួងផ្ទៃក្នុង" ហើយបានប្រាប់អ្នកចូលរួមអង្គប្រជុំថា ពួកគេត្រូវរាយការណ៍រាល់កំហុសឆ្គងបែបនេះ បើមិនដូច្នេះទេពួកគេខ្លួនឯងផ្ទាល់នឹងត្រូវបានចាត់ទុកថាជាខ្មាំងផងដែរ។ នៅក្នុងអង្គប្រជុំផ្សេងទៀត **យ៉ឹម ទិត្យ** បានណែនាំឲ្យអ្នកចូលរួមពិនិត្យតាមដាន និងរាយការណ៍អំពីកម្មករជាសហសេវិករបស់ពួកគេ។ ខណៈគាត់មានសិទ្ធិអំណាចក្នុងភូមិភាគនិរតី **យ៉ឹម ទិត្យ** បានបញ្ជាឲ្យសម្លាប់មនុស្ស និងបានធ្វើដំណើរទៅពិនិត្យមើលមន្ទីរសន្តិសុខក្នុងតំបន់ដែលគាត់ទទួលខុសត្រូវ។ ឧទាហរណ៍ ក្នុងឆ្នាំ១៩៧៦ ឬ ១៩៧៧ **យ៉ឹម ទិត្យ** បានចាត់តាំងឲ្យសមាជិកនៃយោធាស្រុកគាស់ក្រឡាស្ងែងរក "ភ្នាក់ងារសេអ៊ីអា និងជនជាតិ វៀតណាម" ហើយបានណែនាំថា អ្នកទាំងឡាយណាដែលត្រូវបានចាប់ខ្លួនដោយសារត្រូវបានមើលឃើញថាជា "ខ្មាំង" នឹងត្រូវបានសម្លាប់ចោល។ គាត់បានផ្តល់រង្វាន់ដល់អ្នកទាំងឡាយណាដែលទទួលខុសត្រូវលើការប្រព្រឹត្តឧក្រិដ្ឋកម្មឃោរឃៅតាមរយៈការដំឡើងឋានៈ។ ក្នុងឆ្នាំ១៩៧៨ **យ៉ឹម ទិត្យ** បានបញ្ជាឲ្យសម្លាប់អ្នកទោសទាំងអស់ដែលស្ថិតក្នុងមន្ទីរឃុំឃាំងវត្តបាយដំរ៉ា ដែលអ្នកក្រោមបង្គាប់របស់គាត់បានអនុវត្ត។ **យ៉ឹម ទិត្យ** ក៏បានធ្វើជាអធិបតីដោយខ្លួនឯងផ្ទាល់ផងដែរក្នុងពិធីរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងភូមិភាគពាយ័ព្យ ដោយជនរងគ្រោះដឹងថា ប្រសិនបើពួកគេបដិសេធមិនរៀបការ ពួកគេ "នឹងត្រូវបានសម្លាប់"។ ភ្លាមៗ បន្ទាប់ពីពិធីរៀបអាពាហ៍ពិពាហ៍រួច **យ៉ឹម ទិត្យ** បានផ្តល់ឲ្យប្តីប្រពន្ធរៀបការថ្មីថ្មោងទាំងនេះនូវគ្រែ និងអង្រ៊ីង ហើយបានប្រាប់ពួកគេថា ពួកគេត្រូវ "ដេកជាមួយគ្នា"។

1146. *<u>ការចូលរួមចំណែកចំពោះគោលនយោបាយ និងការអនុវត្តគោលនយោបាយទាំងនោះ</u>*៖ **យ៉ឹម ទិត្យ** បានចូលរួមយ៉ាងខ្លាំងក្លាក្នុងការធានាថា សហឧក្រិដ្ឋកម្មដ៏ធំធេងរបស់ ប.ក.ក ត្រូវបានអនុវត្តក្នុង

តំបន់ដែលស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ **យ៉ីម ទិញ** បានចូលរួមចំណែកយ៉ាងពិសេសមួយក្នុងគោលនយោបាយសហឧក្រិដ្ឋកម្មរួម ដែលខុសពីការចូលរួមរបស់គាត់ក្នុងអង្គប្រជុំ ជាទីដែលគោលនយោបាយនានាត្រូវបានប្រគល់ឲ្យទៅថ្នាក់ក្រោម ចូលរួមចំណែកចំពោះការទទួលរបាយការណ៍របស់គាត់អំពីការអនុវត្តពីកម្មាភិបាលថ្នាក់ក្រោម ចូលរួមចំណែកចំពោះការចេញបញ្ជារបស់គាត់ទៅកាន់អ្នកក្រោមបង្គាប់ អំពីការអនុវត្តគោលនយោបាយរបស់ ប.ក.ក និងចូលរួមចំណែកចំពោះការប្រព្រឹត្តអំពើឧក្រិដ្ឋកម្មផ្ទាល់ខ្លួនរបស់គាត់ក្នុងការលើកតម្កើងគោលដៅរបស់ ប.ក.ក។

1147. *<u>ការដឹងពុតិត្យាកដអំពីឧក្រិដ្ឋកម្ម</u>*: ***យ៉ីម ទិញ*** បានដឹងឮទាំងស្រុងដោយឥតសង្ស័យអំពីប្រតិបត្តិការឧក្រិដ្ឋកម្មទ្រង់ទ្រាយធំរបស់ ប.ក.ក នៅទូទាំងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដោយសារកម្រិតនៃការចូលរួមរបស់គាត់ក្នុងការអនុវត្តប្រតិបត្តិការនេះ។ **យ៉ីម ទិញ** បានបង្កើត និងផ្សព្វផ្សាយគោលនយោបាយរបស់ ប.ក.ក ដែលនាំឲ្យមានវិនាសកម្ម បានធានាឲ្យមានការអនុវត្តគោលនយោបាយទាំងនោះនៅទូទាំងតំបន់ក្នុងភូមិភាគទាំងពីរ ដែលគាត់បានកាន់កាប់អំណាច និងបានចូលរួមដោយផ្ទាល់ក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋ ដែលត្រូវបានបង្កើតឡើងដើម្បីធានាថា គោលនយោបាយទាំងនេះត្រូវបានបំពេញ។ នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ **យ៉ីម ទិញ** បានធ្វើដំណើរទៅកាន់មន្ទីរសន្តិសុខ និងការដ្ឋាននានា ដូច្នេះគាត់បានឃើញលក្ខខណ្ឌអមនុស្សធម៌ និងបានដឹងពីការចាប់ខ្លួន និងការសម្លាប់ក្រៅប្រព័ន្ធតុលាការនៅទីតាំងទាំងនោះ។ គាត់ក៏បានទទួលរបាយការណ៍នានាផងដែរពីថ្នាក់ក្រោមស្តីពីវឌ្ឍនភាពនៃការស្វែងរក និងការកម្ទេច "ខ្មាំង" និងការសម្រេចបានទិសដៅផលិតកម្មតាមរយៈកម្លាំងពលកម្ម ដែល **យ៉ីម ទិញ** បានដឹងថាបានធ្វើឡើងដោយគ្មានការស្ម័គ្រចិត្ត។ លើសពីនេះទៀត **យ៉ីម ទិញ** បានដឹងថា ការគ្រប់គ្រងរបស់គាត់ និងរបស់សមាជិកនៃសហឧក្រិដ្ឋកម្មរួមដែលជាសហសេវិករបស់គាត់នៅភូមិភាគពាយ័ព្យ បានកើតមានឡើងពីការចាប់ខ្លួន ឃុំឃាំង និងសម្លាប់កម្មាភិបាលក្នុងទ្រង់ទ្រាយធំ។ ការចូលរួមដ៏សកម្មរបស់ **យ៉ីម ទិញ** ក្នុងអង្គប្រជុំដើម្បីដោះស្រាយបញ្ហានានាដែលផ្តោតលើគោលនយោបាយកម្ទេច "ខ្មាំង" របស់ ប.ក.ក ផ្លាស់ប្តូរទាំងស្រុងនូវផលិតកម្មកសិកម្ម និងសេដ្ឋកិច្ចរបស់ប្រទេស និងបង្កើនយ៉ាងលឿននូវចំនួនប្រជាជន មិនបន្សល់ទុកនូវចម្ងល់នោះទេថា គាត់បានដឹងថា ការអនុវត្តគោលនយោបាយទាំងនេះ មានការពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើឧក្រិដ្ឋ។

1148. *<u>ការកាត់ទោសអ្នកទាំងឡាយណាដែលស្ថិតក្នុងឋានៈជាន់ខ្ពស់</u>*: **យ៉ីម ទិញ** គឺជាមនុស្សម្នាក់ក្នុងចំណោមកម្មាភិបាលរបស់ ប.ក.ក ដែលនៅរស់រានមានជីវិត។ **យ៉ីម ទិញ** បានធ្វើការងារដោយ

ផ្ទាល់ជាមួយ តា ម៉ុក ដែលជាសមាជិករបស់គណៈអចិន្ត្រៃយ៍របស់ ប.ក.ក និងបានចូលកាន់មុខតំណែងជាលេខាភូមិភាគពាយ័ព្យក្នុងពេលដែល តា ម៉ុក អវត្តមាន។ ខណៈដែលសមាជិកគណៈ អចិន្ត្រៃយ៍ទាំងអស់ត្រូវបានចោទប្រកាន់នៅ អ.វ.ត.ក ឬបានស្លាប់ មិនមាននៅសេសសល់កម្មាភិបាលរបស់ ប.ក.ក ណាម្នាក់ ដែលមានកម្រិតនៃអំណាច និងការទទួលខុសត្រូវខ្ពស់ជាង **យ៉ីម ទិញ** ឡើយ។

1149. ស.ព.អ សន្និដ្ឋានថា **យ៉ីម ទិញ** មានកម្រិតនៃការទទួលខុសត្រូវលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្ត ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ខ្ពស់ជាង កាំង ហ្គេកអ៊ាវ ហៅ ឌុច ដែលតុលាការបានកំណត់ថាស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តដោយរបបកម្ពុជាប្រជាធិបតេយ្យ។ **យ៉ីម ទិញ** បានប្រតិបត្តិការក្នុងកម្រិតផ្សេងមួយ និងខ្ពស់ជាង ឌុច នៅក្នុង ប.ក.ក។ ចំនួនសរុបនៃការសម្លាប់ដែលត្រូវបានប្រព្រឹត្តដោយ **យ៉ីម ទិញ** និងអ្នកក្រោមបង្គាប់របស់គាត់ មានចំនួនលើសពីការសម្លាប់ដែលត្រូវបានប្រព្រឹត្តដោយអ្នកក្រោមបង្គាប់របស់ ឌុច។ **យ៉ីម ទិញ** បានទទួលខុសត្រូវលើតំបន់ភូមិសាស្ត្រដ៏ធំធេង និងចំណែកដ៏ច្រើននៃប្រជាជនកម្ពុជា។ **យ៉ីម ទិញ** ក៏មានការទទួលខុសត្រូវលើឧក្រិដ្ឋកម្មច្រើនជាងដោយមិនគ្រាន់តែរួមបញ្ចូលទាំងមន្ទីរសន្តិសុខប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងការដ្ឋាន និងគោលនយោបាយអាពាហ៍ពិពាហ៍ដោយបង្ខំ និងការកម្ទេចខ្ទេចក្រោម និងជនជាតិវៀតណាមក្នុងតំបន់ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់ផងដែរ។ ការទទួលខុសត្រូវរបស់ ឌុច នៅមានកម្រិតទាបជាងខ្លាំងទាក់ទងនឹងវិសាលភាពភូមិសាស្ត្រ និងឧក្រិដ្ឋកម្ម។

ខ. សេចក្តីសន្និដ្ឋានៃការអនុវត្តកត្តាពាក់ព័ន្ធ

1150. ដោយផ្អែកលើអ្វីដែលបានលើកឡើង និងភ័ស្តុតាងដែលបានពិភាក្សានៅក្នុងដីកាសន្និដ្ឋាននេះ ស.ព.អ សន្និដ្ឋានថា ភាពទាំងស្រុងនៃការស៊ើបអង្កេត បញ្ជាក់ថា **យ៉ីម ទិញ** គឺជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងជាមនុស្សម្នាក់ក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ហេតុដូច្នេះ **យ៉ីម ទិញ** ស្ថិតក្នុងយុត្តាធិការផ្នែកបុគ្គលរបស់ អ.វ.ត.ក។

គ. ការពិចារណាបន្ថែមលើការចោទប្រកាន់

1151. ស.ព.អ បានពិចារណាយ៉ាងប្រុងប្រយ័ត្នលើផលប៉ះពាល់ដែលការចោទប្រកាន់របស់ **យ៉ីម ទិត្យ** អាចបង្កឲ្យកើតមានទៅលើយុត្តិធម៌ ការផ្សះផ្សាជាតិ ស្ថិរភាព សន្តិភាព និងសន្តិសុខក្នុងប្រទេសកម្ពុជា។ ស.ព.អ បានសម្លឹងមើលលើសវនាការកន្លងមកនៅ អ.វ.ត.ក ហើយបានសន្និដ្ឋានថា ការចោទប្រកាន់ និងការកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ដែលបានសម្រេចក្នុងសំណុំរឿង ០០១ និង សំណុំរឿង ០០២/០១ មិនមានផលប៉ះពាល់អវិជ្ជមានទៅលើការផ្សះផ្សាជាតិ ស្ថិរភាព សន្តិភាព ឬសន្តិសុខឡើយ។ លើសពីនេះទៀត ស.ព.អ សន្និដ្ឋានថា មិនមានផលប៉ះពាល់អវិជ្ជមានដោយសារលទ្ធផលនៃការបង្ហាញថា **យ៉ីម ទិត្យ** និងជនសង្ស័យផ្សេងទៀត កំពុងស្ថិតក្រោមការស៊ើបអង្កេតក្នុងសំណុំរឿង ០០៣ និង ០០៤ នោះទេ ហើយក៏មិនមានប្រតិកម្មសាធារណៈបែបអវិជ្ជមានណាមួយផងដែរ នៅពេលដែលមានការប្រកាសជាសាធារណៈថា **យ៉ីម ទិត្យ** ត្រូវបានចោទប្រកាន់ ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

1152. ស.ព.អ យល់ឃើញថា មិនមានហេតុផលដែលត្រូវជឿថា ការចោទប្រកាន់ **យ៉ីម ទិត្យ** នឹងធ្វើឲ្យអន្តរាយដល់យុត្តិធម៌ ការផ្សះផ្សាជាតិ ស្ថិរភាព សន្តិភាព ឬសន្តិសុខក្នុងប្រទេសកម្ពុជានោះទេ។ ជំនួសមកវិញ ការចាប់បង្ខំឲ្យមេដឹកនាំខ្មែរក្រហមថ្នាក់ខ្ពស់ទទួលខុសត្រូវលើតួនាទីរបស់ពួកគេក្នុងការប្រព្រឹត្តអំពើឧក្រិដ្ឋទ្រង់ទ្រាយធំ នឹងពង្រឹងទំនុកចិត្តសាធារណៈ តាមរយៈការបង្ហាញថា ជនដែលមានឥទ្ធិពល ពិតណាស់មិនអាចគេចផុតពីការទទួលខុសត្រូវលើឧក្រិដ្ឋកម្មរបស់ពួកគេបានទេ និងថា យុត្តិធម៌អាចនឹងសម្រេចបាន។ ការណ៍នេះនឹងថែមទាំងជួយពង្រឹងដល់ស្ថិរភាព និងសន្តិភាពរយៈពេលវែងរបស់កម្ពុជា។

1153. ខ្មែរក្រហមលែងក្លាយជាការគំរាមកំហែងយូរមកហើយដល់សន្តិភាព និងសន្តិសុខរបស់ប្រទេសកម្ពុជា ដោយបានដួលរលំជិតពីរទសវត្សរ៍មកហើយ។ សព្វថ្ងៃនេះ របបកម្ពុជាប្រជាធិបតេយ្យស្ទើរតែត្រូវបានគេស្គាល់ខ្ពើមជាទូទៅនៅកម្ពុជា។ ជំនួសឲ្យការដែលមានភាពរំជើបរំជួលដោយពេលប្រជាជនកម្ពុជាបានបង្ហាញចំណាប់អារម្មណ៍ខ្លាំងចំពោះ និងគាំទ្រដល់ការកាត់ទោសមេដឹកនាំខ្មែរក្រហម ដោយភាគីដើមបណ្តឹងរដ្ឋប្បវេណីរាប់ពាន់នាក់បានចូលរួម ឬបានដាក់ពាក្យចូលរួមក្នុងកិច្ចដំណើរការនីតិវិធី ហើយប្រជាជនជាង ២០០.០០០ នាក់បានចូលរួមក្នុងសវនាការរហូតមកដល់សព្វថ្ងៃនេះ។ ស.ព.អ បានបង្ហាញយ៉ាងច្បាស់ក្នុងឱកាសជាច្រើនថា គាត់នឹងមិនស្នើឲ្យមានការស៊ើបអង្កេតលើបុគ្គលបន្ថែមណាមួយនៅ អ.វ.ត.ក នោះទេ បន្ទាប់ពីសំណុំរឿង ០០៣ និង ០០៤។

ដោយសារដំណាក់កាលដែលមានភាពរីកចម្រើននៃ អ.វ.ត.ក មិនមានហេតុផលណាមួយដែលត្រូវឲ្យអ្នកណាម្នាក់ភ័យខ្លាចថា ជនសង្ស័យបន្ថែមទៀតនឹងត្រូវបានកំណត់ឈ្មោះនោះទេ ប្រសិនបើ **យ៉ាម ទិញ្ញ** ត្រូវបានចោទប្រកាន់។

1154. ហេតុដូច្នេះ ស.ព.អ ជឿជាក់ថា ការចោទប្រកាន់ **យ៉ាម ទិញ្ញ** គឺជាការអនុវត្តដ៏សមស្របនូវឆន្ទានុសិទ្ធិរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត និងថា ប្រសិនបើសំណុំរឿងនេះដំណើរការទៅមុខ ឆ្ពោះទៅរកសវនាការ ការងាររបស់ អ.វ.ត.ក អាចត្រូវបានបញ្ចប់ក្នុងអំឡុងពេលមួយ ដ៏សមហេតុផល។

X. បទចោទប្រកាន់

1155. ផ្អែកលើអង្គហេតុ និងអង្គច្បាប់ ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ ស.ព.អ សូមគោរពស្នើសុំ ស.ច.អ មេត្តាចោទប្រកាន់ **យ៉ាម ទិញ្ញ** និងបញ្ជូនរូបគាត់ទៅជំនុំជម្រះលើបទចោទប្រកាន់នានាដូចខាងក្រោម។

ក. បទចោទទី ១ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

1156. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ាម ទិញ្ញ** ដោយមានចេតនាបំផ្លាញទាំងស្រុង ឬដោយផ្នែកចំពោះក្រុមជនជាតិវៀតណាមនៅក្នុងប្រទេសកម្ពុជា (រួមទាំងខ្សែក្រោម) ដែលបានប្រព្រឹត្តជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍*តាមរយៈ*សហឧក្រិដ្ឋរួមដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៤ មាត្រា ២៩*ថ្មី* និងមាត្រា ៣៩*ថ្មី*នៃច្បាប់ អ.វ.ត.ក តាមរយៈការកាប់សម្លាប់ ការដាក់លក្ខខណ្ឌលើជីវិតដោយចេតនាដែលបានគិតទុកជាមុន ដើម្បីឲ្យមានការបំផ្លាញលើក្រុមទាំងនោះ និងការបង្កឲ្យមានឈឺចាប់ធ្ងន់ធ្ងរលើរាងកាយ ឬផ្លូវចិត្តដល់សមាជិកនៃក្រុមនេះ។

1157. **យ៉ាម ទិញ្ញ** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម ៖

១. ភូមិភាគនិរតី

(១) ស្រុកគិរីវង់ ស្រុកត្រាំកក់ និងស្រុកកោះអណ្តែត រួមបញ្ចូលដោយមិនកំណត់ត្រឹម៖

ក. មន្ទីរសន្តិសុខវត្តព្រះធាតុ

ខ. មន្ទីរសន្តិសុខក្រាំងតាចាន់

គ. ទីតាំងសម្ជាប់មនុស្សភូមិព្រៃល

ឃ. ទីតាំងសម្ជាប់មនុស្សវត្តអង្គុណ

ង. ទីតាំងសម្ជាប់មនុស្សព្រៃភូមិស្លែង

ច. មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងសម្ជាប់មនុស្សព្រៃសុខុន

២. ភូមិភាគឌាយ៉ាង

(២) ស្រុកបាកាន និងស្រុកសង្កែ រួមបញ្ចូលដោយមិនកំណត់ត្រឹម៖

ក. រោងចក្រស្ករសកំពង់គុល

ខ. មន្ទីរសន្តិសុខវត្តសម្ពេច

គ. មន្ទីរសន្តិសុខភ្នំវាល

ឃ. មន្ទីរសន្តិសុខស្វាយជ្រំ

ង. ទីតាំងសម្ជាប់មនុស្សទួលសេះញ្ជ្ញ

ច. ទីតាំងសម្ជាប់មនុស្សព្រៃក្រហៅ

ឆ. ឃុំកំពង់ព្រៀង

ជ. ឃុំរាំងកេសី

ខ. បទចោទទី ២ ការធ្វើមនុស្សឃាត

1158. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ាម ទិព្ធ** ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្ត ឧក្រិដ្ឋកម្មនៃ**ការធ្វើមនុស្សឃាត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ* សហឧក្រិដ្ឋរួម ដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី*និងមាត្រា ៣៩*ថ្មី*នៃច្បាប់ អ.វ.ត.ក តាមរយៈការប្រព្រឹត្តដោយចេតនាក្នុងការសម្លាប់ ឬដោយបានដឹងឮពីភវនីយហេតុដ៏សំខាន់ ដែលថាការស្លាប់នឹងកើតមានឡើងដោយសារសកម្មភាពរបស់គាត់។ **យ៉ាម ទិព្ធ** ក៏ទទួលខុសត្រូវផងដែរចំពោះការធ្វើមនុស្សឃាត ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី*នៃច្បាប់ អ.វ.ត.ក។

1159. **យ៉ាម ទិព្ធ** ទទួលខុសត្រូវចំពោះការធ្វើមនុស្សឃាតនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគឧត្តរ

(១) *មន្ទីរសន្តិសុខវត្តព្រះធាតុ*

(២) *មន្ទីរសន្តិសុខក្រាំងតាចាន់*

(៣) *ទីតាំងសម្លាប់មនុស្សភូមិព្រាល*

(៤) *ទីតាំងសម្លាប់មនុស្សវត្តអង្គុណ*

(៥) *ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង*

(៦) *មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន*

(៧) *ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោម នៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកគិរីវង់ ស្រុកត្រាំកក់ និងស្រុកកោះអណ្តែត។*

២. ភូមិភាគពាយ័ព្យ

(៨) *មន្ទីរសន្តិសុខគាស់ក្រឡ*

(៩) *សហការណ៍ធិបតី*

(១០) *ការដ្ឋានពលកម្មដោយបង្ខំនៅទំនប់កង្គត*

(១១) *មន្ទីរសន្តិសុខបាណន់*

(១២) *មន្ទីរសន្តិសុខខ្នងគ្ងី*

(១៣) *រោងចក្រស្ករសកំពង់គុល*

(១៤) *មន្ទីរសន្តិសុខភ្នំវាល*

(១៥) *មន្ទីរសន្តិសុខស្វាយជ្រុំ*

(១៦) *ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូ*

(១៧) *ទីតាំងសម្លាប់មនុស្សព្រៃក្របៅ*

(១៨) *ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី*

(១៩) *មន្ទីរសន្តិសុខវត្តគិរីរម្យ*

(២០) *មន្ទីរសន្តិសុខវត្តសម្ពេច*

(២១) *ឃុំកំពង់ព្រៀង*

(២២) *ឃុំវាំងកេសី*

(២៣) *គុកលេខ ៨*

(២៤) *ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង*

(២៥) *ទាក់ទងនឹងជនរងគ្រោះខ្ទ្ចរក្រោមនៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកបាកាន និងស្រុក សង្កែ*

(២៦) *ទាក់ទងនឹងកម្លាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់នៅតាមទីតាំងផ្សេងៗទៀតក្នុងភូមិភាគពាយ័ព្យ រួមទាំងអ្នកដែលត្រូវបានចាប់ខ្លួននៅភូមិភាគពាយ័ព្យ ហើយត្រូវបានយកទៅសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ក្នុងទីក្រុងភ្នំពេញ។*

គ. បទចោទនី ៣ ការសម្លាប់រង្គាល

1160. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ីម ទិញ** ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ**ការសម្លាប់រង្គាល ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ* សហឧក្រិដ្ឋរួម ដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី*និងមាត្រា ៣៩*ថ្មី*នៃច្បាប់ អ.វ.ត.ក តាមរយៈការសម្លាប់ក្រៅប្រព័ន្ធតុលាការក្នុងទ្រុងទ្រាយធំ។ ករណីកាប់សម្លាប់ទាំងនេះភាគច្រើនបានកើតឡើងនៅទីតាំងជាច្រើន ដែលជាផ្នែកមួយនៃប្រព័ន្ធតែមួយ មានទំនាក់ទំនងគ្នាទៅវិញទៅមក និងត្រូវបានរៀបចំឡើងនៅតាមការដ្ឋានពលកម្ម ដោយបង្ខំ មន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស។ **យ៉ីម ទិញ**មានចេតនាសម្លាប់ មនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់។ **យ៉ីម ទិញ** ក៏ទទួលខុសត្រូវផងដែរចំពោះការសម្លាប់រង្គាល ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី*នៃច្បាប់ អ.វ.ត.ក។

1161. ការកាប់សម្លាប់ទាំងនេះបានកើតឡើងនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគនិរតី

(១) *មន្ទីរសន្តិសុខវត្តព្រះធាតុ*

(២) *មន្ទីរសន្តិសុខក្រាំងតាចាន់*

(៣) *ទីតាំងសម្លាប់មនុស្សភូមិព្រាល*

(៤) *ទីតាំងសម្លាប់មនុស្សវត្តអង្គុណ*

(៥) *ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែង*

(៦) *មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន*

(៧) ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោម នៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកគិរីវង់ ស្រុកត្រាំកក់ និងស្រុកកោះអណ្តែត។

២. ភូមិភាគពាយ័ព្យ

(៨) មន្ទីរសន្តិសុខគាស់ក្រឡ

(៩) សហករណ៍ធិបតី

(១០) ការដ្ឋានពលកម្មដោយបង្ខំនៅទំនប់កង្ហត

(១១) មន្ទីរសន្តិសុខបាណន់

(១២) មន្ទីរសន្តិសុខខ្នងគូ

(១៣) រោងចក្រស្ករសកំពង់គុល

(១៤) មន្ទីរសន្តិសុខភ្នំវាល

(១៥) ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូ

(១៦) ទីតាំងសម្លាប់មនុស្សព្រៃក្រហៅ

(១៧) មន្ទីរសន្តិសុខស្វាយជ្រុំ

(១៨) ទីតាំងសម្លាប់មនុស្សវត្តចន្ទរង្សី

(១៩) មន្ទីរសន្តិសុខវត្តគិរីរម្យ

(២០) មន្ទីរសន្តិសុខវត្តសម្ពេច

(២១) ឃុំកំពង់ព្រៀង

(២២) ឃុំវាំងកេសី

(២៣) គុកលេខ ៨

(២៤) *ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីង*

(២៥) *ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោមនៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកបាកាន និងស្រុកសង្កែ*

(២៦) *ទាក់ទងនឹងកម្លាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់នៅតាមទីតាំងផ្សេងៗទៀតក្នុងភូមិភាគពាយ័ព្យ រួមទាំងអ្នកដែលត្រូវបានចាប់ខ្លួននៅភូមិភាគពាយ័ព្យ ហើយត្រូវបានយកទៅសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ក្នុងទីក្រុងភ្នំពេញ។*

ឃ. បទចោទទី ៤ ការធ្វើឲ្យទៅជាទាសករ

1162. ចាប់ពីប្រហែលចុងឆ្នាំ១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ីម ទិញ** ដែលប្រព្រឹត្តជា លក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ**ការធ្វើឲ្យទៅជាទាសករ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ* សហឧក្រិដ្ឋរួម ដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី* និងមាត្រា ៣៩*ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការប្រើប្រាស់អំណាចដោយមានចេតនានៃភាពជាម្ចាស់កម្មសិទ្ធិទៅលើបុគ្គលផ្សេងទៀត។ **យ៉ីម ទិញ** ក៏ទទួលខុសត្រូវផងដែរចំពោះការធ្វើឲ្យទៅជាទាសករ ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី* នៃច្បាប់ អ.វ.ត.ក។

1163. **យ៉ីម ទិញ** ទទួលខុសត្រូវចំពោះការធ្វើឲ្យទៅជាទាសករនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគពាយ័ព្យ

(១) *សហករណ៍ធិបតី*

(២) *ការដ្ឋានពលកម្មដោយបង្ខំនៅទំនប់កណ្ដត*

(៣) *ឃុំកំពង់ព្រៀង*

(៤) *ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោមនៅក្នុងស្រុកបាកាន*

១. បទចោទទី ៥ ការនិរទេស

1164. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ាម ទិព្ធ** ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការញុះញង់ បញ្ជា សមគំនិតដោយការជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ**ការនិរទេសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ* សហឧក្រិដ្ឋរួម ដែលមានចែង និង ផ្តន្ទាទោសដោយមាត្រា ៥ មាត្រា២៩*ថ្មី*និងមាត្រា៣៩*ថ្មី*នៃច្បាប់ អ.វ.ត.ក តាមរយៈការប្រើកម្លាំង ការគំរាមប្រើកម្លាំង ឬការបង្ខិតបង្ខំក្នុងការផ្លាស់ទីលំនៅជនជាតិវៀតណាម និងខ្មែរក្រោម និងអ្នកដែលត្រូវបានចាត់ទុកថាជាជនជាតិវៀតណាម និងខ្មែរក្រោម និងប្រជាជន "ដែលជាប់ពាក់ព័ន្ធ" ជាមួយនឹងពួកគេ រវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាមដោយគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវ។ **យ៉ាម ទិព្ធ** ក៏ទទួលខុសត្រូវផងដែរចំពោះការនិរទេស ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី* នៃច្បាប់ អ.វ.ត.ក។

1165. **យ៉ាម ទិព្ធ** ទទួលខុសត្រូវចំពោះការនិរទេសប្រជាជន ដែលបញ្ជូនឆ្លងកាត់ព្រំដែនអន្តរជាតិទៅកាន់ឬមកពីទីតាំងដូចខាងក្រោម៖

១. ភូមិភាគឧត្តរ

(១) *ស្រុកត្រាំកក់ និងស្រុកគិរីវង់ រួមមាន៖*

ក. *ទីតាំងសម្លាប់មនុស្សភូមិព្រាល*

ខ. *ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង*

២. បទចោទទី ៦ ការដាក់ក្នុងមន្ទីរឃុំឃាំង

1166. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ាម ទិព្ធ** ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ**ការដាក់ក្នុងមន្ទីរឃុំឃាំង ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ*សហឧក្រិដ្ឋរួម ដែលមានចែង និងផ្តន្ទាទោសដោយ

មាត្រា ៥ មាត្រា ២៩ថ្នី និងមាត្រា ៣៩ថ្នី នៃច្បាប់ អ.វ.ត.ក តាមរយៈការឃុំខ្លួនមនុស្សដោយខុសច្បាប់ ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋាននេះ *ពោលគឺ* ដោយគ្មានមូលដ្ឋានច្បាប់ត្រឹមត្រូវ និងដោយគ្មាននីតិវិធីច្បាប់ត្រឹមត្រូវ។ **យ៉ីម ទិត្យ** ក៏ទទួលខុសត្រូវផងដែរចំពោះការដាក់ក្នុងមន្ទីរឃុំឃាំងក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩ថ្នី នៃច្បាប់ អ.វ.ត.ក។

1167. **យ៉ីម ទិត្យ** ទទួលខុសត្រូវចំពោះការដាក់ក្នុងមន្ទីរឃុំឃាំងនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគឧត្តរ

(១) *មន្ទីរសន្តិសុខវត្តព្រះធាតុ*

(២) *មន្ទីរសន្តិសុខក្រាំងតាចាន់*

(៣) *មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងសម្រាប់មនុស្សព្រៃសុខុន*

(៤) *ទាក់ទងនឹងជនរងគ្រោះខ្ទែរក្រោម នៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកគិរីវង់ ស្រុកត្រាំកក់ និងស្រុកកោះអណ្តែត។*

២. ភូមិភាគពាយ័ព្យ

(៥) *មន្ទីរសន្តិសុខគាស់ក្រឡ*

(៦) *សហករណ៍ធិបតី*

(៧) *ការដ្ឋានពលកម្មដោយបង្ខំនៅទំនប់កង្គត*

(៨) *មន្ទីរសន្តិសុខបាណន់*

(៩) *មន្ទីរសន្តិសុខខ្នងគ្ងី*

(១០) *រោងចក្រស្ករសកំពង់គុល*

(១១) *មន្ទីរសន្តិសុខភ្នំវ៉ាល*

(១២) *មន្ទីរសន្តិសុខស្វាយជ្រំទី*

(១៣) *មន្ទីរសន្តិសុខវត្តគិរីរម្យ*

(១៤) *មន្ទីរសន្តិសុខវត្តសម្ពេច*

(១៥) *ឃុំកំពង់ព្រៀង*

(១៦) *គុកលេខ ៨*

(១៧) *ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោមនៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកបាកាន*

(១៨) *ទាក់ទងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់នៅតាមទីតាំងផ្សេងៗទៀតក្នុងភូមិភាគពាយ័ព្យ រួមទាំងអ្នកដែលត្រូវបានចាប់ខ្លួននៅភូមិភាគពាយ័ព្យ ហើយត្រូវបានយកទៅសម្ជាប់នៅមន្ទីរសន្តិសុខ ស-២១ ក្នុងទីក្រុងភ្នំពេញ។*

ឆ. បទចោទទី ៧ ការធ្វើទារុណកម្ម

1168. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ាម ទិព្យ** ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល និងដោយសហការជាមួយមន្ត្រីសាធារណៈ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ**ការធ្វើទារុណកម្ម ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ*សហឧក្រិដ្ឋរួម ដែលមានចែង និងផ្តន្ទាទោស ដោយមាត្រា ៥ មាត្រា ២៩*ថ្មី* និងមាត្រា ៣៩*ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈចេតនាក្នុងការបង្កឲ្យមានការឈឺចាប់ ឬការទទួលរងទុក្ខដ៏ធ្ងន់ធ្ងរលើរាងកាយ ឬស្មារតីលើបុគ្គលទាំងឡាយ ដូចបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានេះ។ **យ៉ាម ទិព្យ** ក៏ទទួលខុសត្រូវផងដែរចំពោះការធ្វើទារុណកម្ម ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី* នៃច្បាប់ អ.វ.ត.ក។

1169. **យ៉ាម ទិព្យ** ទទួលខុសត្រូវចំពោះការធ្វើទារុណកម្មនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគនិរតី

(១) *មន្ទីរសន្តិសុខវត្តព្រះធាតុ*

(២) *មន្ទីរសន្តិសុខក្រាំងតាចាន់*

២. ភូមិភាគពាយ័ព្យ

(៣) *សហករណ៍ធិបតី*

(៤) *មន្ទីរសន្តិសុខបាណន់*

(៥) *មន្ទីរសន្តិសុខខ្នងគូ*

(៦) *មន្ទីរសន្តិសុខវត្តគិរីរម្យ*

(៧) *មន្ទីរសន្តិសុខភ្នំវាល*

(៨) *មន្ទីរសន្តិសុខស្វាយជ្រុំ*

(៩) *ឃុំកំពង់ព្រៀង*

(១០) *គុកលេខ ៨*

៩. បទចោទនី ៨ ការធ្វើទុក្ខបុកម្នេញ

1170. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ីម ទិញ** ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ**ការធ្វើទុក្ខបុកម្នេញ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ* សហឧក្រិដ្ឋរួម ដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩ថ្មី និងមាត្រា ៣៩ថ្មី នៃច្បាប់ អ.វ.ត.ក តាមរយៈការរើសអើងក្នុងការបដិសេធ និងបំពានសិទ្ធិជាមូលដ្ឋានរបស់បុគ្គលទាំងឡាយ ដែលត្រូវបានចាត់ទុកថាជា "ខ្មាំង" ដោយមូលហេតុនយោបាយ។ **យ៉ីម ទិញ** ក៏ទទួលខុសត្រូវផងដែរចំពោះការធ្វើទុក្ខបុកម្នេញ ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩ថ្មី នៃច្បាប់ អ.វ.ត.ក។

1171. **យ៉ីម ទិញ** ទទួលខុសត្រូវចំពោះការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយនៅក្នុង និងជុំវិញ ទីតាំងដូចខាងក្រោម៖

១. ភូមិភាគនិរតី

(១) *មន្ទីរសន្តិសុខវត្តព្រះធាតុប្រឆាំងនឹង "ប្រជាជន ១៧ មេសា" អតីតសមាជិករបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និងខ្មែរក្រោម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការរំលោភផ្លូវភេទ និងអំពើហិង្សាផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)*

(២) *មន្ទីរសន្តិសុខក្រាំងតាចាន់ប្រឆាំងនឹង "ប្រជាជន ១៧ មេសា" ខ្មែរក្រោម និងវៀតណាម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការជម្លៀសដោយបង្ខំ ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)*

(៣) *ទីតាំងសម្លាប់មនុស្សភូមិព្រាលប្រឆាំងនឹងខ្មែរក្រោមតាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស និងអំពើអមនុស្សធម៌ដទៃទៀត (ការជម្លៀសដោយបង្ខំ ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)*

(៤) *ទីតាំងសម្លាប់មនុស្សវត្តអង្គុណប្រឆាំងនឹងខ្មែរក្រោមតាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត (ការបាត់ខ្លួនដោយបង្ខំ)*

(៥) *ទីតាំងសម្លាប់មនុស្សព្រៃភូមិស្លែងប្រឆាំងនឹងខ្មែរក្រោមតាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការនិរទេស និងអំពើអមនុស្សធម៌ដទៃទៀត (ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)*

(៦) *មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន ប្រឆាំងនឹង "ប្រជាជន ១៧ មេសា" អតីតសមាជិករបបលន់ នល់ និងខ្មែរក្រោម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការបាត់ខ្លួនដោយបង្ខំ)*

(៧) ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោម នៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកគិរីវង់ ស្រុកត្រាំកក់ និងស្រុកកោះអណ្តែត តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការបាត់ខ្លួនដោយបង្ខំ)

២. ភូមិភាគពាយ័ព្យ

(៨) មន្ទីរសន្តិសុខគាស់ក្រឡប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ អតីតសមាជិករបបលន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និង "ប្រជាជនថ្មី" តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយ អមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)

(៩) សហករណ៍ធិបតីប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)

(១០) ការដ្ឋានពលកម្មដោយបង្ខំនៅទំនប់កង្ហតប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)

(១១) មន្ទីរសន្តិសុខបាណន់ប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ និងអតីតសមាជិករបបលន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយ អមនុស្សធម៌)

(១២) មន្ទីរសន្តិសុខខ្នងគ្ងប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ អតីតសមាជិករបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និង

"ប្រជាជនថ្មី" តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌)

(១៣) *រោងចក្រស្ករសកំពង់គុលប្រឆាំងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ ប្រជាជនវៀតណាម និងខ្មែរក្រោម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការបាត់ខ្លួនដោយបង្ខំ)*

(១៤) *មន្ទីរសន្តិសុខភ្នំវ៉ាលប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា និងខ្មែរក្រោមតាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌)*

(១៥) *មន្ទីរសន្តិសុខស្វាយជ្រុំប្រឆាំងនឹង "ប្រជាជន ១៧ មេសា" កម្មាភិបាលភូមិភាគពាយ័ព្យ អតីតសមាជិករបបលន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ និងខ្មែរក្រោម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)*

(១៦) *ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូ២ប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា និងខ្មែរក្រោម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត (ការបាត់ខ្លួនដោយបង្ខំ)*

(១៧) *ទីតាំងសម្លាប់មនុស្សព្រៃក្រពៅប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា និងខ្មែរក្រោមតាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត (ការបាត់ខ្លួនដោយបង្ខំ)*

(១៨) *ទីតាំងសម្លាប់មនុស្សវត្តចន្ទ្ររង្សីប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល*

(១៩) *មន្ទីរសន្តិសុខវត្តគិរីរម្យប្រឆាំងនឹងកម្ពាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌)*

(២០) *មន្ទីរសន្តិសុខវត្តសម្តេចប្រឆាំងនឹងកម្ពាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ "ប្រជាជនថ្មី" អតីតសមាជិករបបលន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ ប្រជាជនវៀតណាម និងខ្មែរក្រោម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង*

(២១) *ឃុំកំពង់ព្រៀងប្រឆាំងនឹងកម្ពាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ ប្រជាជនវៀតណាម និងខ្មែរក្រោម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)*

(២២) *ឃុំកំពង់ព្រៀងប្រឆាំងនឹងកម្ពាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់ ប្រជាជនវៀតណាម និងខ្មែរក្រោម តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)*

(២៣) *គុកលេខ ៨ ប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា "ប្រជាជន ១៧ មេសា" អតីតសមាជិករបប លន់ នល់ និងក្រុមគ្រួសាររបស់ពួកគេ "ពួកសក្តិភូមិ" និង "ពួកចក្រពត្តិ"តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌ ការលំណៃកផ្លូវភេទ និងអំពើហិង្សាផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ)*

(២៤) *ទីតាំងសម្លាប់មនុស្សវាលបាក់ជញ្ជីងប្រឆាំងនឹងប្រជាជនភូមិភាគបូព៌ា តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល*

(២៥) *ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោមនៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកបាកាន និងស្រុកសង្កែ និងស្រុក ៤១ និង ៤២ តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌ និងការបាត់ខ្លួនដោយបង្ខំ)*

(២៦) *ទាក់ទងនឹងកម្លាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់នៅតាមទីតាំងផ្សេងៗទៀតក្នុងភូមិភាគពាយ័ព្យ តាមរយៈបទល្មើសជាមូលដ្ឋាននៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ដទៃទៀត (ការបាត់ខ្លួនដោយបង្ខំ)*

ឈ. បទចោទទី ៩ អំពើអមនុស្សធម៌ដទៃទៀត (ការជម្លៀសដោយបង្ខំ)

1172. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យីម ទិត្យ** ដែលប្រព្រឹត្តជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ**អំពើអមនុស្សធម៌ដទៃទៀតនៃការជម្លៀសដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ*សហឧក្រិដ្ឋរួម ដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី* និងមាត្រា ៣៩*ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការប្រើកម្លាំង ការគំរាមប្រើកម្លាំង ឬការបង្ខិតបង្ខំក្នុងការផ្លាស់ទីលំនៅជនជាតិវៀតណាម និងខ្មែរក្រោម និងអ្នកដែលត្រូវបានចាត់ទុកថាជាជនជាតិវៀតណាម និងខ្មែរក្រោម និងប្រជាជន "ដែលជាប់ពាក់ព័ន្ធ" ជាមួយនឹងពួកគេនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។ **យីម ទិត្យ** ក៏ទទួលខុសត្រូវផងដែរចំពោះអំពើអមនុស្សធម៌ដទៃទៀតនៃការជម្លៀសដោយបង្ខំ ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី*នៃច្បាប់ អ.វ.ត.ក។

1173. **យីម ទិត្យ** ទទួលខុសត្រូវចំពោះអំពើអមនុស្សធម៌ដទៃទៀត ក្រោមទម្រង់ជាការជម្លៀសដោយបង្ខំទៅកាន់ និងចេញពីទីតាំងដូចខាងក្រោម៖

១. ភូមិភាគនិរតី

(១) *ស្រុកគិរីវង់ និងស្រុកកោះអណ្តែត រួមមាន៖*

ក. *ទីតាំងសម្គាប់មនុស្សភូមិព្រាល*

ខ. *មន្ទីរសន្តិសុខក្រាំងតាចាន់*

គ. *ទីតាំងសម្គាប់មនុស្សព្រៃភូមិស្ពែង*

២. ភូមិភាគពាយ័ព្យ

(២) *ស្រុកបាកាន*

ញ. បទចោទទី ១០ អំពើអមនុស្សធម៌ដទៃទៀត (ការធ្វើបាបដោយអមនុស្សធម៌)

1174. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ាម ទិព្យ** ដែលបានប្រព្រឹត្ត ជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើ ប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្ត**អំពើអមនុស្សធម៌ដទៃទៀតនៃការធ្វើបាប ដោយអមនុស្សធម៌** *តាមរយៈ*សហឧក្រិដ្ឋរួមដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី*និងមាត្រា ៣៩*ថ្មី*នៃច្បាប់ អ.វ.ត.ក តាមរយៈការប្រព្រឹត្តអំពើអមនុស្សធម៌ដោយចេតនាទៅ លើអ្នកទោស និងកម្មករ ដែលបង្កឲ្យមានការឈឺចាប់ ឬរងរបួសធ្ងន់ធ្ងរលើរាងកាយ ឬផ្លូវចិត្ត ឬប៉ះ ពាល់ដល់សេចក្តីថ្លៃថ្នូររបស់ពួកគេយ៉ាងធ្ងន់ធ្ងរ។ **យ៉ាម ទិព្យ** ក៏ទទួលខុសត្រូវចំពោះអំពើអមនុស្ស ធម៌ដទៃទៀតតាមរយៈការធ្វើបាបដោយអមនុស្សធម៌ ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី*នៃច្បាប់ អ.វ.ត.ក។

1175. **យ៉ាម ទិព្យ** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃ ទៀត តាមរយៈការធ្វើបាបដោយអមនុស្សធម៌ទៅលើបុគ្គលនានានៅក្នុង និងជុំវិញទីតាំងដូចខាង ក្រោម៖

១. ភូមិភាគឧត្តរ

(១) មន្ទីរសន្តិសុខវត្តព្រះធាតុ

(២) មន្ទីរសន្តិសុខក្រាំងតាចាន់

(៣) មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន

(៤) ទីតាំងសម្លាប់មនុស្សភូមិព្រាល

(៥) ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោមនៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកគិរីវង់ ស្រុកត្រាំកក់ និងស្រុកកោះអណ្តែត។

២. ភូមិភាគពាយ័ព្យ

(៦) មន្ទីរសន្តិសុខគាស់ក្រឡ

(៧) សហករណ៍ធិបតី

(៨) ការដ្ឋានពលកម្មដោយបង្ខំនៅទំនប់កង្គត

(៩) មន្ទីរសន្តិសុខបាណន់

(១០) មន្ទីរសន្តិសុខភ្នំវាល

(១១) មន្ទីរសន្តិសុខស្វាយជ្រំរោងចក្រស្ករសកំពង់គុល

(១២) មន្ទីរសន្តិសុខខ្នងគ

(១៣) មន្ទីរសន្តិសុខវត្តគិរីរម្យ

(១៤) ឃុំកំពង់ព្រៀង

(១៥) គុកលេខ ៨

(១៦) ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោមនៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកបាកាន និងស្រុកសង្កែ

ជ. បទចោទទី ១១ អំពើអមនុស្សធម៌ដទៃទៀត (អាពាហ៍ពិពាហ៍ដោយបង្ខំ)

1176. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ីម ទិញ** ដែលបានប្រព្រឹត្ត ជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើ ប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្ត**អំពើអមនុស្សធម៌ដទៃទៀតនៃអាពាហ៍ពិពាហ៍ ដោយអមនុស្សធម៌** *តាមរយៈ*សហឧក្រិដ្ឋរួមដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី*និងមាត្រា ៣៩*ថ្មី*នៃច្បាប់ អ.វ.ត.ក តាមរយៈការបង្ខំឲ្យមនុស្សរៀបការដោយប្រើកម្លាំង គ ម្រាមប្រើកម្លាំង ឬការបង្ខិតបង្ខំ។ **យ៉ីម ទិញ** ក៏ទទួលខុសត្រូវផងដែរចំពោះអំពើអមនុស្សធម៌ដទៃ ទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី*នៃច្បាប់ អ.វ .ត.ក។

1177. **យ៉ីម ទិញ** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃ ទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគពាយ័ព្យ

(១) ស្រុកសង្កែ រួមមាន៖

ក. រោងចក្រស្ករសកំពង់គុល

ខ. ស្រុកសំឡូត

គ. ឃុំកំពង់ព្រៀង

ឃ. ឃុំវាំងកេសី

ឍ. បទចោទទី ១២ អំពើអមនុស្សធម៌ដទៃទៀត (ការកំណៀសសេពសន្តវៈ តាមរយៈការរួមសន្ធាស់ដោយបង្ខំ)

1178. ចាប់ពីប្រហែលចុងឆ្នាំ១៩៧៦ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ីម ទិញ** ដែលបានប្រព្រឹត្តជាលក្ខ ណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កង កម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការ ញុះញង់

បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្ត**អំពើអមនុស្សធម៌ដទៃទៀតនៃការរំលោភផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ* សហឧក្រិដ្ឋរួមដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី* និងមាត្រា ៣៩*ថ្មី* នៃច្បាប់ អ.វ.ត.ក តាមរយៈការបង្ខំឲ្យប្តីប្រពន្ធរៀបការដោយបង្ខំ ដើម្បីរួមដំណេកដោយគ្មានការព្រមព្រៀងដោយសេរីពីដៃគូម្នាក់ ឬទាំងពីរនាក់។ **យ៉ីម ទិញ** ក៏ទទួលខុសត្រូវផងដែរចំពោះអំពើអមនុស្សធម៌ដទៃទៀតនៃការរំលោភផ្លូវភេទនៅក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី* នៃច្បាប់ អ.វ.ត.ក។

1179. **យ៉ីម ទិញ** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀតនៃការរំលោភផ្លូវភេទនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគពាយ័ព្យ

(១) ស្រុកសង្កែ រួមមាន៖

ក. ឃុំវាំងកេសី

ខ. ឃុំកំពង់ព្រៀង

(២) ស្រុកបាកាន

២. បទចោទទី ១៣ អំពើអមនុស្សធម៌ដទៃទៀត (ការរំលោភផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ)

1180. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ីម ទិញ** ដែលបានប្រព្រឹត្ត ជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បាន ប្រព្រឹត្ត**អំពើអមនុស្សធម៌ដទៃទៀតនៃការរំលោភផ្លូវភេទ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ*សហឧក្រិដ្ឋរួមដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី* និងមាត្រា ៣៩*ថ្មី* នៃច្បាប់ អ.វ.ត.ក។ **យ៉ីម ទិញ** ក៏ទទួលខុសត្រូវផងដែរចំពោះអំពើអមនុស្សធម៌ដទៃទៀតនៃការរំលោភផ្លូវភេទ និងអំពើហិង្សាផ្លូវភេទនៅក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី* នៃច្បាប់ អ.វ.ត.ក។

1181. **យ៉ាម ទិញ្ញ** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀតនៃការរំលោភផ្លូវភេទនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគនិរតី

(១) មន្ទីរសន្តិសុខវត្តព្រះធាតុ

២. ភូមិភាគពាយ័ព្យ

(២) ស្រុកបាកាន

(៣) គុកលេខ ៨

៣. បទចោទទី ១៤ អំពើអមនុស្សធម៌ដទៃទៀត (ការធាត់ខ្លួនដោយបង្ខំ)

1182. ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ **យ៉ាម ទិញ្ញ** ដែលបានប្រព្រឹត្ត ជាលក្ខណៈបុគ្គល និងដោយសហការជាមួយអាជ្ញាធរ ក.ប.ធ និង ប.ក.ក ផ្សេងៗទៀត និងប្រើប្រាស់កងកម្លាំង និងបុគ្គលិកក្រោមការគ្រប់គ្រងរបស់គាត់ និង/ឬរបស់ពួកគេ បានរៀបចំផែនការ ញុះញង់ បញ្ជា ជួយនិងជំរុញ និង/ឬបានប្រព្រឹត្តឧក្រិដ្ឋកម្មនៃ**អំពើអមនុស្សធម៌ដទៃទៀតនៃការធាត់ខ្លួនដោយបង្ខំ ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** *តាមរយៈ*សហឧក្រិដ្ឋរួមដែលមានចែង និងផ្តន្ទាទោសដោយមាត្រា ៥ មាត្រា ២៩*ថ្មី*និងមាត្រា ៣៩*ថ្មី*នៃច្បាប់ អ.វ.ត.ក តាមរយៈការលាក់បាំងនូវជោគវាសនារបស់បុគ្គលទាំងឡាយ ដែលត្រូវបានអាជ្ញាធរចាប់ខ្លួន។ **យ៉ាម ទិញ្ញ** ក៏ទទួលខុសត្រូវផងដែរ ចំពោះអំពើអមនុស្សធម៌ដទៃទៀតនៃការបាត់ខ្លួនដោយបង្ខំ ក្នុងឋានៈជាថ្នាក់លើ ដូចមានចែងក្នុងមាត្រា ២៩*ថ្មី*នៃច្បាប់ អ.វ.ត.ក។

1183. **យ៉ាម ទិញ្ញ** ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្រោមទម្រង់ជាអំពើអមនុស្សធម៌ដទៃទៀតនៃការបាត់ខ្លួនដោយបង្ខំនៅក្នុង និងជុំវិញទីតាំងដូចខាងក្រោម៖

១. ភូមិភាគនិរតី

(១) *មន្ទីរសន្តិសុខវត្តព្រះធាតុ*

(២) *មន្ទីរសន្តិសុខក្រាំងតាចាន់*

(៣) *មន្ទីរសន្តិសុខវត្តអង្គសិរីមុនី និងទីតាំងសម្លាប់មនុស្សព្រៃសុខុន*

(៤) *ទីតាំងសម្លាប់មនុស្សភូមិព្រៃល*

(៥) *ទីតាំងសម្លាប់មនុស្សវត្តអង្គុណ*

(៦) *ទីតាំងសម្លាប់មនុស្សព្រៃភូមិស្ពែង*

(៧) *ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោមនៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកគិរីវង់ ស្រុកត្រាំកក់ និងស្រុកកោះអណ្តែត។*

២. ភូមិភាគពាយ័ព្យ

(៨) *មន្ទីរសន្តិសុខគាស់ក្រឡ*

(៩) *សហករណ៍ធិបតី*

(១០) *ការដ្ឋានពលកម្មដោយបង្ខំនៅទំនប់កង្ហត*

(១១) *រោងចក្រស្ករសកំពង់គុល*

(១២) *ឃុំកំពង់ព្រៀង*

(១៣) *គុកលេខ ៨*

(១៤) *ទីតាំងសម្លាប់មនុស្សព្រៃក្រហៅ*

(១៥) *ទីតាំងសម្លាប់មនុស្សទួលសេះញ៉ូ*

(១៦) *មន្ទីរសន្តិសុខស្វាយជ្រុំ*

(១៧) *ទាក់ទងនឹងជនរងគ្រោះខ្មែរក្រោមនៅតាមទីតាំងផ្សេងៗទៀតក្នុងស្រុកបាកាន និងស្រុកសង្កែ*

(១៨) *ទាក់ទងនឹងកម្មាភិបាលភូមិភាគពាយ័ព្យ និងក្រុមគ្រួសាររបស់ពួកគេ និងអ្នកក្រោមបង្គាប់នៅតាមទីតាំងផ្សេងៗទៀតក្នុងភូមិភាគពាយ័ព្យ*

ដោយក្តីគោរព

កាលបរិច្ឆេទ	**ឈ្មោះ**	**ទីកន្លែង**	**ហត្ថលេខា**
០៤ មិថុនា ២០១៨	Nicholas KOUMJIAN សហព្រះរាជអាជ្ញាអន្តរជាតិ	ភ្នំពេញ	